
ទំនាក់ទំនងអន្តរជាតិ



រៀបរៀងដោយ
ថា លាងអាង

២០២២

CAMBODIA
RESEARCH CREATIVITY INNOVATION

គាំទ្រថវិកាលើការរៀបរៀង និពន្ធ និងកែលម្អដោយ
មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍

ចំណាក់ចំណងអន្តរជាតិ

រៀបរៀងដោយ
ថា ណាងអាច
២០២២

គាំទ្រថវិការលើការរៀបរៀង និពន្ធ និងកែលម្អដោយ
មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍

សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
មហាវិទ្យាល័យសង្គមសាស្ត្រ-មនុស្សសាស្ត្រ
ដេប៉ាតឺម៉ង់ប្រវត្តិវិទ្យា

គណៈកម្មការនិពន្ធ

១. លោក ថា លាងអាង	សាស្ត្រាចារ្យដេប៉ាតឺម៉ង់ប្រវត្តិវិទ្យា

គណៈកម្មការត្រួតពិនិត្យ

១. លោកបណ្ឌិត វង់ សុធារ៉ា	ប្រធានដេប៉ាតឺម៉ង់ប្រវត្តិវិទ្យា
២. លោក អូន យុវ៉ា	សាស្ត្រាចារ្យដេប៉ាតឺម៉ង់ប្រវត្តិវិទ្យា
៣. លោក ធូ រណ្ឌូ	ប្រធានការិយាល័យស្រាវជ្រាវ

បុព្វកថា

ដំណើរអភិវឌ្ឍនៃព្រះរាជាណាចក្រកម្ពុជានៅក្នុងយុគសម័យទំនើបនេះ ជាមេរៀនដ៏ជោគជ័យបំផុតមួយដែលចាប់ឫសគល់ចេញពីការបញ្ចប់របបប្រល័យពូជសាសន៍ ការបញ្ចប់សង្គ្រាម ការផ្សះផ្សារជាតិ ការកសាងមូលដ្ឋានរឹងមាំនៃសន្តិភាពនិងស្ថេរភាព និងការអភិវឌ្ឍសេដ្ឋកិច្ច។ នៅក្រោយពេលដែលសន្តិភាពត្រូវបានកើតឡើងដោយបរិបូរណ៍នៅឆ្នាំ ១៩៩៨ កម្ពុជាទទួលកំណើនសេដ្ឋកិច្ចខ្ពស់គឺប្រមាណ៨%ក្នុងមួយឆ្នាំ។ លើសពីនេះទៀត អត្រានៃភាពក្រីក្រត្រូវបានកាត់បន្ថយពីប្រមាណ ៥៣% នៅឆ្នាំ ២០០៤ មកនៅទាបជាង ១០% នៅឆ្នាំ ២០១៩។ ដំណើរនៃការអភិវឌ្ឍជាតិជាសកម្មភាពដែលបន្តទៅមុខជាប់ជានិច្ច ហើយគោលនយោបាយថ្មីៗដែលមានលក្ខណៈអន្តរវិស័យគ្របដណ្តប់ ក៏កំពុងលេចរូបរាងឡើង ដើម្បីតម្រង់ទិសកម្ពុជាឆ្ពោះទៅកាន់ប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងឈានឡើងជាប្រទេសមានប្រាក់ចំណូលខ្ពស់ នៅឆ្នាំ ២០៥០។ ការប្រែប្រួលឆាប់រហ័សនៃនិម្មាបនកម្មពិភពលោកនិងតំបន់ រួមទាំងទំនាក់ទំនងភូមិសាស្ត្រនយោបាយ បានផ្តល់កាលានុវត្តភាពសម្រាប់ការអភិវឌ្ឍឧស្សាហកម្មនៅកម្ពុជា ដែលត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាមូលដ្ឋានគ្រឹះនៃកំណើនសេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងបន្តពង្រឹង និងអភិវឌ្ឍវិស័យអប់រំឆ្ពោះទៅរកការស្រាវជ្រាវ និងនវានុវត្តន៍ ដើម្បីពង្រឹងសមត្ថភាពនិងជំនាញរបស់ធនធានមនុស្សនៅកម្ពុជា អោយស្របទៅនឹងបរិបទថ្មីនៃការអភិវឌ្ឍ ជាពិសេសការពង្រឹងសហគ្រិនភាពក្នុងការរៀបចំម៉ូដែលធុរកិច្ចថ្មីៗ។ ដើម្បីចាប់យកកាលានុវត្តភាពពីបដិវត្តន៍ឧស្សាហកម្មទី៤ និងសេដ្ឋកិច្ចឌីជីថលដែលកំពុងផុសផុលឡើង ប្រព័ន្ធអេកូឡូហ្ស៊ីដែលបង្កលក្ខណៈអំណោយផលដល់ការបង្កើតថ្មី នវានុវត្តន៍ ការស្រាវជ្រាវ និងអភិវឌ្ឍន៍ ត្រូវតែមានការកែលម្អ។

បណ្តាប្រទេសនៅទ្វីបអាស៊ីកំពុងនាំមុខក្នុងការវិនិយោគលើការស្រាវជ្រាវ និងអភិវឌ្ឍ ដោយមានភាគហ៊ុនប្រមាណ ៤៤% នៃការវិនិយោគទាំងមូលរបស់ពិភពលោក។ ប្រទេសចិនកំពុងបន្តកសាង ហេដ្ឋារចនាសម្ព័ន្ធនៃការ វិនិយោគលើការស្រាវជ្រាវ និងអភិវឌ្ឍ ក៏ដូចជាសមត្ថភាពមនុស្ស។ ផ្ទុយទៅវិញ ប្រទេសនៅទ្វីបអាមេរិកខាងត្បូង និងអាហ្វ្រិក កំពុងស្ថិតនៅឆ្ងាយពីការវិនិយោគនេះ ហើយជាលទ្ធផល ប្រទេសទាំងនោះក៏ពុំមានកំណើនសេដ្ឋកិច្ចគួរអោយកត់សម្គាល់ដែរ។ ទុនវិនិយោគសរុបលើការស្រាវ ជ្រាវនិងអភិវឌ្ឍរបស់ប្រទេសនៅទ្វីបអាមេរិកខាងត្បូងនិងអាហ្វ្រិក មានប្រមាណ ៥% នៃការវិនិយោគ ទាំងមូលរបស់ពិភពលោក ក្នុងពេលដែលតំបន់ទាំង ២ នេះមានប្រជាជនប្រមាណ២០% នៃប្រជាជន ពិភពលោក។ ប្រទេសចំនួន ៦ ដែលមានលំដាប់ខ្ពស់ជាងគេនៅក្នុងការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ រួមមានសហរដ្ឋអាមេរិក ចិន ជប៉ុន អាឡឺម៉ង់ ឥណ្ឌា និងកូរ៉េខាងត្បូង ដែលស្មើនឹងប្រមាណ ៧០% នៃទុនវិនិយោគសរុបរបស់ពិភពលោក។

តើចំណេះដឹង ផលិតផល និងសេវាកម្មថ្មីទាំងនេះកើតឡើងពីអ្វី? ហើយកើតឡើងដោយរបៀបណា? ព្រះរាជាណាចក្រកម្ពុជា កំពុងតែកសាងមូលដ្ឋានសម្រាប់ការត្រៀមខ្លួនទទួល និងប្រកួតប្រជែងក្នុងយុគសម័យបដិវត្តឧស្សាហកម្មទី ៤ នៅក្នុងសេដ្ឋកិច្ចដែលផ្អែកលើពុទ្ធិ ហើយដែលប្រការនេះចាំបាច់តម្រូវអោយពលរដ្ឋកម្ពុជាត្រូវក្លាយខ្លួនជាពលរដ្ឋឌីជីថល ពលរដ្ឋសកល និងពលរដ្ឋដែលប្រកបដោយការទទួលខុសត្រូវដែលមានសមត្ថភាពក្នុងការផលិត ចែកចាយ និងប្រើប្រាស់ពុទ្ធិដើម្បីទទួលមនុញ្ញផល និងរួមចំណែកក្នុងកំណើន។ ធនាគារពិភពលោកបានធ្វើការកត់សម្គាល់តាំងពីឆ្នាំ ២០០២ នូវបម្លាស់ប្តូរនៃមូលដ្ឋានសេដ្ឋកិច្ចពីសេដ្ឋកិច្ចដែលពឹងផ្អែកលើកម្លាំងពលកម្ម និងធនធានអតិកម្ម (Labor and Resource Based

Economy) ទៅកាន់សេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិ (Knowledge Based-Economy) ដែលក្នុងន័យនេះ ពុទ្ធិគឺជាគន្លឹះនៃការអភិវឌ្ឍ។ អាស្រ័យហេតុនេះ នៅលើគន្លងដែលកម្ពុជាកំពុងធ្វើដំណើរឆ្ពោះទៅកាន់សេដ្ឋកិច្ចឌីជីថល សង្គមកម្ពុជាត្រូវតែមានសមត្ថភាពក្នុងការផលិត ជ្រើសរើស បន្សុំ បង្កើតមុខរបរ និងប្រើប្រាស់ពុទ្ធិ ដើម្បីរក្សានិរន្តរភាពនៃកំណើន និងកែលម្អជីវភាពរស់នៅ។ សមត្ថភាពទាំងនេះ អាចកើតឡើងនៅពេលពលរដ្ឋកម្ពុជាមានឱកាស ក្នុងការទទួលបានបទពិសោធន៍ពីការស្រាវជ្រាវការបណ្តុះគំនិតច្នៃប្រឌិត និងការស្វែងរកនវានុវត្តន៍។

កំណែទម្រង់វិស័យអប់រំ គឺជាការត្រួសត្រាយមាគ៌ាសម្រាប់ដំណើរឆ្ពោះទៅកាន់សង្គមប្រកបដោយពុទ្ធិ និងប្រជាពលរដ្ឋប្រកបដោយភាពរស់រវើក។ តាមរយៈមូលដ្ឋានអប់រំ សង្គមប្រកបដោយពុទ្ធិនឹងប្រមូលផ្តុំ បង្កើត និងចែករំលែក ទៅកាន់សមាជិកក្នុងសង្គមនូវសម្បទាអប់រំ ពិសេសគឺពុទ្ធិសម្បទា ក្នុងបុព្វហេតុនៃមនុស្សជាតិនិងឧត្តមប្រយោជន៍នៃប្រទេស។ សង្គមប្រកបដោយពុទ្ធិ គឺពុំគ្រាន់តែជាសង្គមដែលសម្បូរព័ត៌មានប៉ុណ្ណោះទេ តែជាសង្គមដែលប្រជាពលរដ្ឋអាចធ្វើបរិវត្តកម្មពីព័ត៌មានទៅជា មូលធនប្រកបដោយប្រសិទ្ធភាព។ ការរីកចម្រើនទៅមុខជាលំដាប់នៃបច្ចេកវិទ្យានិងតំណភ្ជាប់ បានពង្រីកព្រំដែននៃការចូលទៅកាន់ និងការទទួលបានព័ត៌មានជាសកល ហើយដែលក្នុងន័យនេះ ការអប់រំនឹងបន្តវិវត្តទៅមុខនិងមានការផ្លាស់ប្តូរ។ សង្គមមួយដែលមានអំណាន និងរបាប់ជាបុរេលក្ខខណ្ឌនៃជីវភាពប្រចាំថ្ងៃនៃប្រជាពលរដ្ឋ ពេលនោះបំណិននៃអំណាន និពន្ធ និងការគណនាលេខនព្វន្ត គឺជាចលករនៃការរៀនរបស់សិស្ស។ ធាតុដ៏ចម្បងមួយដែលស្ថិតនៅក្នុងការកសាងសង្គមដែលប្រកបដោយ ពុទ្ធិគឺសៀវភៅសិក្សា ហើយការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សាជាប្រចាំ គឺជានវានុវត្តន៍នៃវិស័យអប់រំ ដែលនាំទៅរកការសិក្សាពេញមួយជីវិត ការអភិវឌ្ឍសម្បទាអប់រំ និងការចែករំលែកចំណេះដឹង។ មូលដ្ឋានអប់រំ ជាពិសេសគឺគ្រឹះស្ថានឧត្តមសិក្សាត្រូវមានតួនាទីដែលប្រកបដោយការឆ្លើយតបចំពោះតម្រូវការខាងលើនេះ។ សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំត្រូវបន្តសិក្សាជាប់ជានិច្ច តាមរយៈការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ហើយដែលសៀវភៅសិក្សាទាំងនេះនឹងក្លាយជា ស្ពាននៃទំនាក់ទំនងរវាងនវានុវត្តន៍នៃបច្ចេកវិទ្យា និងការរៀននិងបង្រៀននៅក្នុងថ្នាក់រៀន។

សង្គមដែលប្រកបពុទ្ធិ ក៏ជាសង្គមដែលបណ្តុះអោយមានរចនាសម្ព័ន្ធទន់នៃសេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិដែរ។ ឧទាហរណ៍ជាក់ស្តែងនៃបែបផែននេះរួមមាន Silicon Valley នៃសហរដ្ឋអាមេរិក សួនឧស្សាហកម្មវិស្វកម្មអាកាសយានយន្តនិងយានយន្តនៅទីក្រុង Munich ប្រទេសអាឡឺម៉ង់ តំបន់ជីវបច្ចេកវិទ្យានៅក្រុង Hyderabad ប្រទេសឥណ្ឌា តំបន់ផលិតគ្រឿងអេឡិចត្រូនិកនិងសារគមនាគមន៍ ឌីជីថលនៅទីក្រុង Seoul ប្រទេសកូរេខាងត្បូង ក៏ដូចជាសួនឧស្សាហកម្មថាមពល និងឥន្ធនគីមីសាស្ត្រនៃប្រទេសប្រេស៊ីល ហើយក៏នៅមានទីក្រុងនៃប្រទេសជាច្រើនទៀតនៅលើពិភពលោក។ លក្ខណៈសម្បត្តិនៃទីក្រុងទាំងនេះគឺការប្រើប្រាស់និន្នាការនៃការអភិវឌ្ឍដែលជំរុញ និងតម្រង់ទិសដោយចំណេះដឹង ហើយដែលចំណេះដឹងទាំងនោះកើតចេញជាដំបូងពីការវិនិយោគទៅលើគ្រឹះស្ថានឧត្តមសិក្សា ស្ថាប័នស្រាវជ្រាវ មជ្ឈមណ្ឌលឧត្តមភាពនៃជំនាញជាន់ខ្ពស់ ការប្រកួតប្រជែងដោយគុណាធិបតេយ្យ និង ជាពិសេសគឺការបណ្តុះវប្បធម៌អំណាននិងនិពន្ធសៀវភៅ។ ល្បឿននៃការរីកចម្រើនផ្នែកពុទ្ធិ និងបច្ចេកវិទ្យាកំពុងមានសន្ទុះលឿនជាងអ្វីដែលសិស្ស និងនិស្សិតអាចទទួលបានពីគ្រូនៅគ្រឹះស្ថានសិក្សា ដែលធ្វើអោយគោលដៅនៃការអប់រំនៅពេលបច្ចុប្បន្ននេះ មាន

ការប្រឈមខ្លាំងជាងពេលណាទាំងអស់។ ឧទាហរណ៍ ក្នុងមួយឆ្នាំមានសៀវភៅជាង ២,២ លានចំណងជើង ត្រូវបានសរសេរនិងបោះពុម្ព ដែលក្នុងនោះប្រទេសចិនមាន ៤៤០ ពាន់ ចំណែកឯសហរដ្ឋអាមេរិកមាន ៣០៥ ពាន់ និងប្រទេសរុស្ស៊ីមាន ១២០ ពាន់ចំណងជើង។

ខណៈពេលដែលបច្ចេកវិទ្យាកំពុងរីកចម្រើនជារៀងរាល់ថ្ងៃ មធ្យោបាយសម្រាប់អំណានក៏មានច្រើនជម្រើសសម្រាប់សិស្ស-និស្សិត និងសាធារណៈជន រួមមានការអានសៀវភៅ ការអានលើឧបករណ៍អេឡិចត្រូនិក ការអានដោយប្រើទូរសព្ទវៃឆ្លាត និងការអានលើកុំព្យូទ័រ ដែលសុទ្ធសឹងជាមធ្យោបាយសំខាន់ៗ ដែលនាំអ្នកអានទាំងឡាយអោយសម្រេចគោលបំណងអានរបស់ខ្លួន។ ម្យ៉ាងវិញទៀត អំណានដោយប្រើមធ្យោបាយបច្ចេកវិទ្យាទំនើប ចំណាយពេលតិច ងាយស្រួលអាន និងជួយដល់បរិស្ថានមួយកម្រិតទៀត។ នាពេលបច្ចុប្បន្ន សិស្ស-និស្សិត និងសាធារណៈជនកម្ពុជា ដែលស្រឡាញ់អំណានកំពុងតែប្រើប្រាស់មធ្យោបាយអំណានទាំងនេះ។ បើយើងក្រឡេកមើលទៅប្រទេសជឿនលឿន ទោះបីជាបច្ចេកវិទ្យារីកចម្រើនខ្លាំងយ៉ាងណា អំណានតាមរយៈសៀវភៅនៅតែមានសន្ទុះដដែល។ ម្យ៉ាងវិញទៀត បច្ចេកវិទ្យាអានបែបទំនើបតាមរយៈឧបករណ៍ទំនើប អាស្រ័យលើលទ្ធភាពនៃធនធានអប់រំឌីជីថល និងមាតិកាឌីជីថលគ្រប់គ្រាន់ ដែលបានផលិត និងបង្ហោះចែកចាយសម្រាប់អំណាន។

ក្នុងបរិបទកម្ពុជា ជាពិសេសក្នុងបរិការណ៍នៃការផ្ទុះរីករាលដាលនៃជំងឺកូវីដ-១៩ ក្រសួងអប់រំ យុវជន និងកីឡា បានដំរុញអោយមានបរិវត្តកម្មឌីជីថលនៅក្នុងអេកូស៊ីស្តែមនៃការអប់រំ ជាពិសេសការអប់រំ តាមប្រព័ន្ធអេឡិចត្រូនិក និងការអប់រំពីចម្ងាយដើម្បីលើកកម្ពស់អំណានតាមរយៈការផលិតមាតិកាឌីជីថល ដែលមានភាពសម្បូរបែប ការកសាងសមត្ថភាពផ្នែកតំណភ្ជាប់និងវេទិកាឌីជីថល ការពង្រីកវិសាលភាពនៃមជ្ឈមណ្ឌលទិន្នន័យ និងការលើកកម្ពស់គុណភាពនៃការផលិតធនធានអប់រំឌីជីថល គួបផ្សំជាមួយការចែកសន្លឹកកិច្ចការអោយសិស្សយកទៅរៀននៅផ្ទះ និងការចុះទៅជួបជាមួយសិស្សជាបណ្តុំនៅតាមសហគមន៍។ ក្នុងន័យលើកកម្ពស់អំណាន និងភាពសម្បូរបែបនៃធនធានសៀវភៅសិក្សា អោយកាន់តែមានប្រសិទ្ធភាពនិងភាពសក្តិសិទ្ធិ និងផ្តល់ឱកាសអំណានកាន់តែច្រើនថែមទៀតដល់សិស្សានុសិស្ស និស្សិត និងសាធារណៈជន ក្រសួងអប់រំ យុវជន និងកីឡាលើកទឹកចិត្តនូវចំណុចមួយចំនួនដូចខាងក្រោម៖

១. សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំ សូមបន្តនិងបង្កើនការបោះពុម្ពស្នាដៃបន្ថែមទៀត ដើម្បីធ្វើអោយធនធានសម្រាប់អំណានកាន់តែសម្បូរបែប
ជាពិសេសធនធានអំណានជាខេមរភាសា

២. គ្រឹះស្ថានឧត្តមសិក្សា សូមផ្តល់លទ្ធភាពគ្រប់បែបយ៉ាង ដើម្បីអោយបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ និង និស្សិតគ្រប់កម្រិតសិក្សាអាចចូលរួមអាន និងសិក្សាស្រាវជ្រាវតាមគ្រប់លទ្ធភាពជាមួយធនធានអំណាន ជាពិសេសការរៀបចំអោយមានពេលវេលាសម្រាប់សហសិក្សា និងអំណានក្នុងបណ្ណាល័យ

៣. សាស្ត្រាចារ្យតាមមុខវិជ្ជា និងអ្នកស្រាវជ្រាវតាមជំនាញឬវិស័យ ត្រូវរៀបចំដំណើរការរៀន បង្រៀន និងស្រាវជ្រាវដែលមានដាក់បញ្ចូលកិច្ចការស្វ័យសិក្សា សហសិក្សា ឬការស្រាវជ្រាវបណ្ណាល័យ ដែលតម្រូវអោយនិស្សិត ត្រូវអាននិងស្រាវជ្រាវជាមួយធនធានអំណាន

៤. គ្រឹះស្ថានឧត្តមសិក្សា និងមជ្ឈមណ្ឌលស្រាវជ្រាវ ត្រូវខិតខំអោយអស់លទ្ធភាពក្នុងការបង្កើតបណ្ណាល័យ មជ្ឈមណ្ឌលរក្សាឯកសារ ឬមជ្ឈមណ្ឌលអប់រំឌីជីថល ជាដើម ដើម្បីអោយបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់និងនិស្សិតគ្រប់កម្រិតសិក្សា អាចទទួលបាន និងស្វែងរកប្រភពសម្រាប់អំណាន កាន់តែសម្បូរបែប និងមានភាពបត់បែន ឆ្លើយតបតាមតម្រូវការអ្នកអាន

៥. និស្សិតគ្រប់កម្រិតសិក្សា ត្រូវខិតខំនិងចំណាយពេលអាន និងចាត់ទុកវប្បធម៌ និងអកប្បកិរិយាអំណានជាផ្នែកមួយ នៃពេលវេលានិងភាពស៊ីវិល័យនៃជីវិតប្រចាំថ្ងៃ

៦. បងប្អូនជនរួមជាតិ ដែលជាមាតាបិតា ឬអ្នកអាណាព្យាបាល សូមជួយជំរុញនិងបង្កលក្ខណៈកាន់តែ ច្រើនថែមទៀត ជាពិសេសការលែលកចំណាយនៅក្នុងគ្រួសារសម្រាប់ការទិញសម្ភារៈសិក្សា សៀវភៅអាន និងឧបករណ៍សម្រាប់អំណានដល់កូនៗ ដែលចាត់ទុកជាការវិនិយោគមួយដ៏សំខាន់ សម្រាប់ បង្កើនចំណេះដឹង និងអនាគតរបស់ពួកគេ។

ដោយមានការគាំទ្រពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅឆ្នាំ ២០២០ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ដែលហៅកាត់ថា «មូលនិធិ ស.គ.ន» និងហៅជាភាសាអង់គ្លេសថា The Research Creativity and Innovation Fund ដែលហៅកាត់ជាភាសាអង់គ្លេសថា "RCI Fund"។ គោលដៅចម្បងនៃមូលនិធិនេះ គឺរួមចំណែកលើកកម្ពស់វប្បធម៌នៃការស្រាវជ្រាវ បំផុសគំនិតច្នៃប្រឌិត និងជំរុញការធ្វើនវានុវត្ត ដើម្បីជាប្រយោជន៍ដល់វិស័យអប់រំ យុវជន និងកីឡា ដែលឆ្លើយតបទៅនឹងទីផ្សារពលកម្ម និងសាកលភាវូបនីយកម្ម។ មូលនិធិ ស.គ.ន បានសម្រេចកំណត់ប្រធានបទ ជាអាទិភាពសម្រាប់ការគាំទ្រដោយមូលនិធិចំនួន ៣ រួមមាន ឌីជីថលនីយកម្មសម្រាប់បដិវត្តឧស្សាហកម្ម ៤.០ (Digitalization for ទំនាក់ទំនងអន្តរជាតិ.៤.០) ការស្រាវជ្រាវអនុវត្តលើវិស័យកសិកម្ម (Applied Agricultural Research) និងការស្រាវជ្រាវគរុកោសល្យសតវត្សទី ២១ (២១st Century Pedagogy Research)។

ដោយមានការធ្វើអាទិភាពវូបនីយកម្ម ទៅលើទិសដៅនៃការប្រើប្រាស់ថវិកាមូលនិធិសម្រាប់ ឆ្នាំ ២០២០ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា បានផ្តល់ការគាំទ្រដល់ការ**រៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សា (Text book) ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា**។ គោលបំណងនៃការរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា គឺដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រីកសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូនដល់និស្សិតដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ លើសពីនេះទៀតការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា មានគោលដៅដូចខាងក្រោម ៖

- ឆ្លើយតបជាបន្ទាន់ចំពោះការខ្វះខាតធនធានសិក្សា ដែលជាតម្រូវការសិក្សារបស់និស្សិត នៅកម្រិតឧត្តមសិក្សា
- លើកកម្ពស់ទំនើបភាវូបនីយកម្ម និងឧត្តមានុវត្តន៍នៃការរៀននិងបង្រៀន និងការស្រាវជ្រាវនៅលើមុខវិជ្ជា កម្មវិធីសិក្សា ឬមុខជំនាញជាក់លាក់
- បង្កើនភាពស៊ីជម្រៅក្នុងការកសាងវិជ្ជាជីវៈ និងបទពិសោធន៍សម្រាប់ហានៈសាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវ

- រួមចំណែកដល់ការកសាងភាពជាសហគមន៍វិជ្ជាជីវៈ ការចែករំលែកបទពិសោធន៍ និងវប្បធម៌នៃការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា។

ក្រសួងអប់រំ យុវជន និងកីឡា បានវាយតម្លៃខ្ពស់ចំពោះការបោះដំហានប្រកបដោយមនសិការវិជ្ជាជីវៈនៃគ្រឹះស្ថានឧត្តមសិក្សា និងបុគ្គលិកអប់រំទាំងអស់ ក្នុងការរៀបចំ រៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រឹងសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូននិស្សិតដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ សៀវភៅសិក្សាជាផ្នែកមួយនៃការទទួលស្គាល់គុណភាពអប់រំនៃគ្រឹះស្ថានឧត្តមសិក្សា និងជាធនធានសិក្សាដែលជាមូលដ្ឋានមួយដ៏សំខាន់ ក្នុងការគាំទ្រដល់ការបង្រៀន និងរៀន ហើយត្រូវមានបរិមាណគ្រប់គ្រាន់ ឆ្លើយតបទៅនឹងកម្មវិធីអប់រំ និងតម្រូវការសិក្សាស្រាវជ្រាវ។ ជាគោលការណ៍ គ្រឹះស្ថានឧត្តមសិក្សាទាំងអស់ ត្រូវមានសៀវភៅសិក្សាដែលប្រើជាគោលសម្រាប់មុខវិជ្ជានីមួយៗ។ ចំនួនសៀវភៅសិក្សាដែលគ្រប់គ្រាន់សម្រាប់ការស្រាវជ្រាវ និងការសិក្សារបស់និស្សិត ត្រូវមានយ៉ាងតិចមួយចំណងជើងក្នុងមួយមុខវិជ្ជា ហើយត្រូវតម្កល់យ៉ាងតិច ២ ច្បាប់នៅក្នុងបណ្ណាល័យ ឬអាចរកបានតាមប្រព័ន្ធអេឡិចត្រូនិក។ ក្រសួងអប់រំ យុវជន និងកីឡា លើកទឹកចិត្តបន្ថែមទៀតជូនដល់គ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជនដែលបានស្នើសុំថវិកាមូលនិធិរួច សូមចូលរួមបន្ថែមទៀតដើម្បីបង្កើនចំនួនចំណងជើងសៀវភៅ។ ចំណែកគ្រឹះស្ថានឧត្តមសិក្សារដ្ឋនិងឯកជនដែលពុំទាន់បានដាក់ពាក្យ ស្នើសុំ សូមចូលរួម ដើម្បីជាគុណប្រយោជន៍ដល់តម្រូវការដ៏ទូទូច និងថ្លៃថ្លានៃនិស្សិតកម្ពុជាក្នុងការសិក្សា និងស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។

សេចក្តីបញ្ជាក់
របស់មូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍

សៀវភៅសិក្សានេះជាលទ្ធផលនៃការស្នើសុំអនុវត្តថវិកាមូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ក្នុងគម្រោង**រៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា។** សៀវភៅសិក្សានេះ ត្រូវបានរៀបរៀង និពន្ធ ឬកែលម្អដោយមានការធានាអះអាងថាជាស្នាដៃរបស់អ្នកនិពន្ធផ្ទាល់ និងបានឆ្លងកាត់ត្រួតពិនិត្យ ផ្តល់យោបល់ និងវាយតម្លៃដោយក្រុមប្រឹក្សាអប់រំ ក្រុមប្រឹក្សាស្រាវជ្រាវ ឬក្រុមប្រឹក្សាដែលមានតម្លៃស្មើនៃគ្រឹះស្ថានឧត្តមសិក្សា និងតាមរយៈកិច្ចសន្យាដែលបានធ្វើឡើង និងដែលបានតម្កល់ទុកនៅមូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍។ រាល់ខ្លឹមសារ ការបកស្រាយ និងរូបភាព គឺជាជំហរនិងទស្សនៈផ្ទាល់របស់អ្នកនិពន្ធ ហើយ ពុំឆ្លុះបញ្ចាំង ឬជាតំណាងដល់មូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ នៃក្រសួងអប់រំ យុវជន និងកីឡា ឡើយ។

អារម្ភកថា

សៀវភៅនេះត្រូវបានរៀបរៀងឡើងក្រោមការឧបត្ថម្ភគាំទ្ររបស់មូលនិធិស្រាវជ្រាវ គំនិតផ្នែប្រឌិត និងនវានុវត្តន៍សម្រាប់ទុកជាសៀវភៅសិក្សាគោល ដើម្បីបម្រើអោយការរៀននិងបង្រៀនមុខវិជ្ជា«ទំនាក់ទំនងអន្តរជាតិ»ក្នុងដេប៉ាតឺម៉ង់ប្រវត្តិវិទ្យានៃមហាវិទ្យាល័យសង្គមសាស្ត្រ និងមនុស្សសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ សង្ឃឹមថាសៀវភៅគោលនេះ នឹងផ្តល់ចំណេះដឹងទូទៅដល់អ្នកសិក្សាអោយស្វែងយល់កាន់តែច្បាស់ពីពិភពខាងក្រៅ ដោយហេតុថា បច្ចុប្បន្ន យើងរស់នៅក្នុងពិភពលោកដែលមានអន្តរទំនាក់ទំនងនឹងគ្នា កាន់តែខ្លាំងឡើងៗ។

ការតភ្ជាប់ទាំងនេះ អាចនាំមកនូវអត្ថប្រយោជន៍ធំធេង សំរាប់ជីវភាពរស់នៅប្រចាំថ្ងៃរបស់យើង៖ សមត្ថភាពនិងលទ្ធភាពក្នុងការប្រាស្រ័យទាក់ទងគ្នាភ្លាមៗតាមចិត្តចង់ នៅទូទាំងពិភពលោក និងចែករំលែកវប្បធម៌និងជំនឿរបស់យើង លទ្ធភាពក្នុងការជួយជនរងគ្រោះដោយអគ្គីភ័យឬដោយការរញ្ជួយដី តាមរយៈបណ្តាញសប្បុរសធម៌ដោយផ្ទាល់ សមត្ថភាពទិញទំនិញតាមអនឡាញ ដូចជាផលិតផលដែលផលិតឡើងពីគ្រឿងផ្សំ ឬគ្រឿងបន្លាស់ ដែលផលិតនៅក្នុងប្រទេសផ្សេងៗគ្នាជាច្រើន ដោយប្រើចំណេះដឹងនិងជំនាញរបស់យើង ដើម្បីបង្កើតផលិតផលថ្មីមួយ កាន់តែល្អជាងមុន។ ទាំងនេះ គឺជាអត្ថប្រយោជន៍មួយចំនួននៃការផ្សារភ្ជាប់ទំនាក់ទំនងពិភពលោកកាន់តែខ្លាំង។ ប៉ុន្តែ ការផ្សារភ្ជាប់ទាំងនេះក៏អាចធ្វើអោយបញ្ហាដែលមានស្រាប់កាន់តែធ្ងន់ធ្ងរទៅៗ៖ បណ្តាញភេរវកម្មប្រើប្រាស់ទូរគមនាគមន៍ ដើម្បីប្រតិបត្តិការវាយប្រហារលើគោលដៅណាមួយ ពាណិជ្ជកម្មសកលអាចជាក់សម្ពាធខ្លាំងលើបរិយាកាសនិងធនធានធម្មជាតិរបស់យើង ហើយមនុស្សរាប់លាននាក់ នៅតែរស់នៅដាច់ដោយឡែកពីសកលលោក ខណៈពេលដែលប្រជាពលរដ្ឋក្នុងប្រទេសអភិវឌ្ឍកំពុងទទួលប្រយោជន៍យ៉ាងច្រើន។

បើទោះឃើញមានទំនាក់ទំនងកាន់តែច្រើនឡើង និងឃើញមានផលវិបាកមួយចំនួនទៅលើជីវភាពរស់នៅប្រចាំថ្ងៃក៏ដោយ ក៏សិស្សនិស្សិតជាច្រើន នៅពេលខ្លួនចាប់ផ្តើមចូលរៀន ថ្នាក់មហាវិទ្យាល័យ មានការយល់ច្រលំអំពីការពិតសំខាន់ៗស្តីពីទំនាក់ទំនងអន្តរជាតិ(IR) ដូចជា វិសាលភាពនៃភាពក្រីក្រ និងកម្រិតនៃជំនួយបរទេស ដែលត្រូវបានផ្តល់ដល់ប្រទេសកំពុងអភិវឌ្ឍន៍ និងនិន្នាការឆ្ពោះទៅរកសង្គ្រាមតិចជាងមុន ក្នុងរយៈកាលជាងពីរទសវត្សរ៍ចុងក្រោយនេះ។ សៀវភៅសិក្សាគោលនេះ មានគោលដៅអប់រំសិស្សនិស្សិតអំពីកិច្ចការអន្តរជាតិ ដោយប្រឹងប្រែងធ្វើអោយទាន់ពេល ត្រឹមត្រូវ គួរឲ្យទាក់ទាញ និងធ្វើយ៉ាងណាអោយនិស្សិតចូលរួមក្នុងដំណើរការសិក្សាយ៉ាងសកម្ម។ យើងសង្ឃឹមថា ជាមួយនឹងសៀវភៅគោលនេះ វគ្គសិក្សាIRអាចជួយដល់យុវជនខ្មែរជំនាន់ក្រោយបង្កើតចំណេះដឹងនិងជំនាញរិះគិត ដោយពិចារណាខ្ពស់ ដើម្បីបង្ហាញពីកង្វល់ ឬ មតិយោបល់នានា និងជំហរនៅក្នុងពិភពលោក ដែលបាននិងកំពុងផ្លាស់ប្តូរឥតឈប់ឈរ។

ទំនាក់ទំនងអន្តរជាតិ មិនមែនគ្រាន់តែជាប្រធានបទដ៏សំខាន់ប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជារឿងគួរអោយចាប់អារម្មណ៍ខ្លាំងផងដែរ។ ភាពស្មុគស្មាញច្រើនស្រទាប់នៃទំនាក់ទំនងអន្តរជាតិ (ទាំងនយោបាយ សេដ្ឋកិច្ច និងវប្បធម៌) ចោទជាប្រស្នាក្នុងដំណើរការព្យាយាមស្វែងយល់ពីពិភពលោករបស់យើង។ ប្រស្នាទាំងនេះ មិនមែនគ្រាន់តែជាលំហាត់តេស្តប្រាជ្ញាប៉ុណ្ណោះទេ ប៉ុន្តែក៏មានឥទ្ធិពលលើស្មារតី ឬផ្លូវអារម្មណ៍របស់យើងផងដែរ។ មែនទែនទៅ ទំនាក់ទំនងអន្តរជាតិជាប់ពាក់ព័ន្ធរឿងរ៉ាវមនុស្ស ដោយបែងចែកជាប្រធានបទសំខាន់ៗ

ដូចជា សង្គ្រាមនិងសន្តិភាព (ឧទាហរណ៍សង្គ្រាមរបស់ប្រធានាធិបតីរុស្ស៊ី វ្ល៉ាឌីមៀរ ពូទីន លើប្រទេសអ៊ុយក្រែន នាចុងខែកុម្ភៈ ឆ្នាំ ២០២២) ការប៉ះទង្គិចគ្នារវាងសហគមន៍ជាតិពន្ធុនានា ការធ្វើសមាហរណកម្មក្នុងចំណោមប្រទេសជាច្រើនក្នុងតំបន់ណាមួយ (ឧទាហរណ៍ សហភាពអឺរ៉ុប និងសមាគមអាស៊ាន) និងការបំបែកវដ្ដទំនាក់ទំនងរវាងមនុស្សនិងបរិស្ថាន ភាពក្រីក្រនិងការអភិវឌ្ឍន៍ ជាដើម ។

អ្នកប្រាជ្ញជាច្រើនបានរួមចំណែកគំនិតដែលនៅទីបំផុតមានឥទ្ធិពលលើការបោះពុម្ពសៀវភៅនេះ ជាពិសេស អ្នកនិពន្ធល្បីពីរូប។ លោក Jon C. W. Pevehouse គឺជា សាស្ត្រាចារ្យ កិត្តិយសនៃវិទ្យាសាស្ត្រនយោបាយនៅសាកលវិទ្យាល័យ Wisconsin-Madison ។ គាត់គឺជាសាស្ត្រាចារ្យ និងជាអ្នកប្រាជ្ញដែលទទួលបានពានរង្វាន់។ ចំណាប់អារម្មណ៍ស្រាវជ្រាវពិសេសរបស់គាត់ផ្តោតលើសេដ្ឋកិច្ចនយោបាយអន្តរជាតិ គោលនយោបាយការបរទេស និងអង្គការអន្តរជាតិ។ គាត់គឺជាអតីតនិពន្ធនាយកនៃសារព័ត៌មានអាជីពឈានមុខគេក្នុងវិស័យនេះ អង្គការអន្តរជាតិ។ គាត់បានទទួលបរិញ្ញាបត្រពីសាកលវិទ្យាល័យ Kansas និងបណ្ឌិតរបស់គាត់ ចេញពីសាកលវិទ្យាល័យរដ្ឋអូហៃយ៉ូ ។ លោក Joshua S. Goldstein គឺជាសាស្ត្រាចារ្យផ្នែកទំនាក់ទំនងអន្តរជាតិ សាកលវិទ្យាល័យអាមេរិក (Washington, DC) និងជាអ្នកប្រាជ្ញស្រាវជ្រាវ សាកលវិទ្យាល័យ Massachusetts Amherst ។ គាត់គឺជាអ្នកប្រាជ្ញដែលឈ្នះពានរង្វាន់ដែលបានសរសេរ និងនិយាយយ៉ាងទូលំទូលាយអំពីសង្គ្រាម និងសង្គម រួមទាំងឥទ្ធិពលនៃសង្គ្រាមលើយេនឌ័រ សេដ្ឋកិច្ច និងរបួសផ្លូវចិត្ត។ សៀវភៅ War and Gender របស់គាត់បានឈ្នះពានរង្វាន់ សៀវភៅប្រចាំទសវត្សរ៍របស់សមាគមសិក្សាអន្តរជាតិ។ ជាការពិត កំហុសនៅតែជាទំនួលខុសត្រូវរបស់ខ្ញុំផ្ទាល់ដែលជាអ្នកកែសម្រួល។

ដោយឡែកសម្រាប់និស្សិតផ្ទាល់ ប្រធានបទដែលបានសិក្សាស្រាវជ្រាវដោយអ្នកប្រាជ្ញនានា ប្រៀបដូចជាទេសភាព ដែលមានទីតាំង និងសណ្ឋានដីផ្សេងៗគ្នាជាច្រើន។ សៀវភៅនេះគឺជាផែនទីដែលអាចតម្រង់ទិសសិស្សនិស្សិតឆ្ពោះទៅកាន់ប្រធានបទសំខាន់ៗ ការជជែកពិភាក្សា និងបញ្ហាក្នុងទំនាក់ទំនងអន្តរជាតិ។ អ្នកប្រាជ្ញIRប្រើភាសាឯកទេសដើម្បីនិយាយនិងពិភាក្សាអំពីមុខវិជ្ជារបស់ពួកគេ។ សៀវភៅនេះគឺជាសៀវភៅឃ្លាដែលអាចបកប្រែភាសាឯកទេសបែបនេះ និងពន្យល់ពីពាក្យនិងគោលគំនិត ដែលអ្នកប្រាជ្ញប្រើដើម្បីនិយាយអំពីទំនាក់ទំនងអន្តរជាតិ។ ទោះជាយ៉ាងណាក៏ដោយ ទំនាក់ទំនងអន្តរជាតិពោរពេញទៅដោយសំឡេងជាច្រើន ដែលនិយាយភាសាជាច្រើនដែរ។ សៀវភៅនេះប្រែសម្រួលសំឡេងមួយចំនួននៃប្រធានាធិបតី និងបណ្តាសាស្ត្រាចារ្យ ពាណិជ្ជករសេរី និងស្ត្រីនិយម ដើម្បីជួយអ្នកក្នុងការតម្រៀបវណ្ឌវង្កនៃប្រធានបទ និងស្ថានភាពនៃចំណេះដឹងអំពីប្រធានបទផ្សេងៗរបស់វា។ នៅក្នុងការបោះពុម្ពលើកទី ១ នៃសៀវភៅទំនាក់ទំនងអន្តរជាតិនេះ យើងបានព្យាយាមជាពិសេស ដើម្បីសម្រួលនិងបញ្ជាក់ប្រធានបទដ៏ស្មុគស្មាញនេះ មិនត្រឹមតែដើម្បីជួយអោយអ្នកយល់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយអោយអ្នកយល់យ៉ាងស៊ីជម្រៅអំពីទំនាក់ទំនងអន្តរជាតិផងដែរ។ យ៉ាងណាមិញ នៅទីបំផុត ការសំយោគដែលបានបង្ហាញក្នុងសៀវភៅនេះគឺជារបស់អ្នកនិពន្ធដើម។ ទាំងអ្នកនិងសាស្ត្រាចារ្យរបស់អ្នក ឬអ្នកអានទូទៅដទៃទៀត ប្រហែលជាមិនយល់ស្របនឹងចំណុចជាច្រើន។ ដូច្នេះហើយ សៀវភៅនេះគ្រាន់តែជាចំណុចចាប់ផ្តើមសម្រាប់ការសន្ទនា និងការជជែកពិភាក្សាប៉ុណ្ណោះ។

ជាមួយនឹងកម្រងផែនទីនៅខាងដើមសៀវភៅ និងនិយមន័យពាក្យគន្លឹះនៅខាងចុងមេរៀននីមួយៗ នៅក្នុងដៃ និស្សិតត្រៀមខ្លួនជាស្រេចដើម្បីស្វែងយល់អំពីរបៀបដែលពិភពលោកដំណើរការ។ ការផ្លាស់ប្តូរធំៗ

ដែលបានកើតឡើងក្នុងពេលថ្មីៗ នៅក្នុងនយោបាយពិភពលោក បានធ្វើអោយការចង់ក្រងសៀវភៅនេះ ក្លាយជាគម្រោងហាក់មិនចេះចប់មិនចេះហើយ ប៉ុន្តែកាន់តែដ៏គួរអោយរំភើបផងដែរ។ សង្ឃឹមថានិស្សិតនឹងអានដោយយកចិត្តទុកដាក់ដើម្បីស្វែងយល់ពីពិភពលោកជុំវិញខ្លួនយើង។

សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ ថា លាងអាង ជាសាស្ត្រាចារ្យដេប៉ាតឺម៉ង់ប្រវត្តិវិទ្យា នៃមហាវិទ្យាល័យសង្គមសាស្ត្រនិង មនុស្សសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងជាអ្នករៀបរៀងសៀវភៅសិក្សាដែលមានចំណងជើងថា «ទំនាក់ទំនងអន្តរជាតិ»។ ខ្ញុំបាទសូមសម្តែងនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ និងសូមគោរពថ្លែងអំណរគុណ និង ដឹងគុណយ៉ាងជ្រាលជ្រៅចំពោះ៖

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានផ្តល់ថវិកាមកក្រសួងអប់រំ ដើម្បីបង្កើតជាមូលនិធិសម្រាប់ គាំទ្រដល់ការសរសេរសៀវភៅសិក្សាសម្រាប់កម្រិតឧត្តមសិក្សារបស់ខ្ញុំបាទនេះ។

- ក្រសួងអប់រំ យុវជន និងកីឡា ដែលមាន ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី ហង់ជួន ណារ៉ុន ជាប្រមុខ ដែលលោកបានដឹកនាំបង្កើតមូលនិធិស្រាវជ្រាវគំនិតឆ្នៃប្រឌិតនិងនវានុវត្តន៍ឡើង ដើម្បីគាំទ្រ ទាំងស្រុងដល់ដំណើរការសរសេរសៀវភៅនេះ ដែលជាចំណែកមួយក្នុងបេសកកម្មកំណែទម្រង់វិស័យអប់រំ ឧត្តមសិក្សារបស់លោក។

- ឯកឧត្តមបណ្ឌិត សាន វឌ្ឍនា អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ដែលក្នុងនាមលោក ជាតំណាងមូលនិធិ លោកបានយកអស់កម្លាំងការចិត្ត ជួយចាត់ចែងនិងជ្រោមជ្រែងយ៉ាងពេញទំហឹង ព្រមទាំង ផ្តល់ជាអនុសាសន៍និងដំណោះស្រាយនានា ដើម្បីជំនះនូវាល់ឧបសគ្គ ដែលកើតមានក្នុងដំណើរការសរសេរ សៀវភៅនេះ។

- ឯកឧត្តមបណ្ឌិត ជេត ជាលី សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដែលបានយកអស់ កម្លាំងកាយចិត្ត ព្រមទាំងពេលវេលាដ៏មមាញឹកនិងមានតម្លៃរបស់លោកក្នុងការជួយលើកទឹកចិត្ត ជួយខ្នះខ្នែង ដោះស្រាយ និងផ្តល់អនុសាសន៍ដ៏ត្រឹមត្រូវ ក៏ដូចជាបង្កលក្ខណៈងាយស្រួលនានា ទាំងផ្នែករដ្ឋបាល និងទាំង ផ្នែកបច្ចេកទេស ដើម្បីឲ្យដំណើរការរៀបរៀងសៀវភៅនេះបានប្រព្រឹត្តទៅដោយរលូនរហូតចប់ចុងចប់ដើម។

- លោក លួន ពេជ្របូរី និង អស់លោក-លោកស្រី ជាក្រុមការងារសម្របសម្រួលទាំងអស់របស់ មូលនិធិស្រាវជ្រាវ គំនិតឆ្នៃប្រឌិត និងនវានុវត្តន៍ ដែលបានយកអស់កម្លាំងកាយចិត្ត ជួយឈឺឆ្អាលក្នុង ការដោះស្រាយបញ្ហាប្រឈមនានាយ៉ាងសស្រាក់សស្រាំជាទីបំផុត ដោយមិនគ្រួញក្បែរ និងមិនខ្លាចនឿយហត់ ដើម្បីឲ្យការសរសេរសៀវភៅនេះប្រព្រឹត្តទៅដោយរលូន។

- ឯកឧត្តមបណ្ឌិត ស្ទើរ ថាវិទ្ធ អ្នកសម្របសម្រួលសាលាក្រោយឧត្តម និង លោកបណ្ឌិត សុខ សិរី អនុប្រធានការិយាល័យស្រាវជ្រាវ ដែលតែងជួយឈឺឆ្អាល ជួយសម្របសម្រួល និងផ្តល់សេវាសម្រាប់ការប្រជុំ បច្ចេកទេសនានាតាមអនឡាញតាំងពីដើមរៀងមក។

- អស់លោក-លោកស្រី ជាសមាជិក-សមាជិកាគណៈកម្មការអភិវឌ្ឍសៀវភៅសិក្សា ក៏ដូចជា គណៈកម្មការត្រួតពិនិត្យសៀវភៅសិក្សារបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដែលបានជួយផ្តល់ធាតុចូល ដល់សៀវភៅនេះឲ្យកាន់តែមានគុណភាពប្រសើរថែមទៀត។

- ជាចុងក្រោយ និងជាពិសេស លោក ធូ វេណូ ប្រធានការិយាល័យស្រាវជ្រាវ នៃសាកលវិទ្យាល័យ ភូមិន្ទភ្នំពេញ ដែលតែងជួយផ្តល់ធាតុចូលចំពោះរាល់ឯកសារការងារ ទាំងផ្នែករដ្ឋបាល និងទាំងផ្នែក បច្ចេកទេស លោកថែមទាំងជួយសម្រួលរាល់បញ្ហាប្រឈមនានាយ៉ាងដឹតដល់បំផុត ដោយមិនប្រកាន់ ពេលវេលា និងដោយចិត្តជ្រះថ្លា រហូតការសរសេរសៀវភៅនេះទទួលបានជោគជ័យជាស្តាពរ៕

មាតិកា

បុព្វកថា I
សេចក្តីបញ្ជាក់ VI
អារម្ភកថា VII
សេចក្តីថ្លែងអំណរគុណ X
មាតិកា XI
ផែនទីសំខាន់ៗ XXIII
០.១ រដ្ឋ និងដែនដីពិភពលោក xxiii
០.២ អាមេរិកខាងជើង xxiii
០.៣ អាមេរិកកណ្តាល និងតំបន់ការ៉ាប៊ីន xxiii
០.៤ អាមេរិកខាងត្បូង xxiii
០.៥ អាហ្វ្រិក xxiii
០.៦ អាហ្វ្រិកខាងជើង និងមជ្ឈឹមបូព៌ា xxiii
០.៧ អឺរ៉ុប xxiii
០.៨ អាស៊ី xxiii
មេរៀនទី ០១ ៖ សកលភាវូបនីយកម្មលើទំនាក់ទំនងអន្តរជាតិ ១
វត្ថុបំណងមេរៀន ១
១.១. សកលភាវូបនីយកម្មទំនាក់ទំនងអន្តរជាតិ និងជីវិតប្រចាំថ្ងៃ ១
១.១.១. គោលការណ៍ស្នូល ៣
១.១.២. ទំនាក់ទំនងអន្តរជាតិក្នុងឋានៈជាមុខវិជ្ជាសិក្សាមួយ ១១
១.២. តួអង្គ និងឥទ្ធិពល **១៣**
១.២.១. តួអង្គរដ្ឋ ១៤
១.២.២. តួអង្គមិនមែនជារដ្ឋ ១៧
១.២.៣. កម្រិតនៃការវិភាគ ២០
១.២.៤. សាកលភាវូបនីយកម្ម ២៣
១.៣. ភូមិសាស្ត្រសកល **២៦**
១.៤. ប្រព័ន្ធអន្តរជាតិកំពុងវិវត្ត **៣១**
១.៤.១. សង្គ្រាមលោកទាំងពីរ ឆ្នាំ ១៩០០-១៩៥០ ..... ៣២
១.៤.២. សង្គ្រាមត្រជាក់ ឆ្នាំ១៩៤៥-១៩៩០ ..... ៣៦
១.៤.៣. យុគសម័យក្រោយសង្គ្រាមត្រជាក់ ឆ្នាំ ១៩៩០-២០១៨ ..... ៤២
សេចក្តីសង្ខេប **៥២**
ពាក្យគន្លឹះ **៥៤**

សំណួរអនុវត្តន៍ ៥៦
ការស្វែងរកផលប្រយោជន៍រួម ៥៧
ទស្សនៈវិស័យគោលនយោបាយ ៥៧
មតិសាធារណៈ និងទំនាក់ទំនងអន្តរជាតិ ៥៩
តោះ សាកល្បងពិភាក្សាអំពីបញ្ហាជាក់ស្តែង ៦១
ឯកសារគួរអានបន្ថែម ៦៣
មេរៀនទី ០២ ៖ ទ្រឹស្តីប្រាកដនិយម ៦៤
វត្ថុបំណងមេរៀន ៦៤
២.១. ទ្រឹស្តីប្រាកដនិយម ៦៤
២.២. អំណាច ៦៧
២.២.១. ការកំណត់អំណាច ៦៧
២.២.២. ការវាស់ស្ទង់អំណាច ៦៩
២.២.៣. ធាតុនៃអំណាច ៧០
២.៣. ប្រព័ន្ធអន្តរជាតិ ៧៣
២.៣.១. អនាធិបតេយ្យ និងអធិបតេយ្យភាព ៧៣
២.៣.២. តុល្យភាពអំណាច ៧៦
២.៣.៣. ប្រទេសមហាអំណាច និងប្រទេសអំណាចមធ្យម ៧៩
២.៣.៤. ការបែងចែកអំណាច ៨១
២.៣.៥. អនុត្តរភាព ៨៣
២.៣.៦. ប្រព័ន្ធមហាអំណាច ១៥០០-២០០០ ..... ៨៧
២.៤. សម្ព័ន្ធមិត្ត ៩១
២.៤.១. គោលបំណងនៃសម្ព័ន្ធភាព ៩១
២.៤.២. ណាតូ (NATO) ៩៣
២.៤.៣. សម្ព័ន្ធមិត្តផ្សេងៗ ៩៧
២.៤.៤. ការបង្កើតបក្សសម្ព័ន្ធតាមតំបន់ ៩៨
២.៥. យុទ្ធសាស្ត្រ ១០១
២.៥.១. សិល្បៈដឹកនាំរដ្ឋ ១០១
២.៥.២. ការថ្លឹងថ្លែងហេតុផលក្នុងទំនាក់ទំនងអន្តរជាតិ ១០៤
២.៥.៣. ល្បែងទ្វេរគ្រោះអ្នកទោស ១០៦
សេចក្តីសង្ខេប ១១០
ពាក្យគន្លឹះ ១១១
សំណួរអនុវត្តន៍ ១១៤
ការស្វែងរកផលប្រយោជន៍រួម ១១៥

មតិសាធារណៈ និងទំនាក់ទំនងអន្តរជាតិ ១១៦
ទស្សនៈវិស័យគោលនយោបាយ ១១៨
តោះ សាកល្បងពិភាក្សាអំពីបញ្ហាជាក់ស្តែង ១២០
ឯកសារគួរអានបន្ថែម ១២២
មេរៀនទី ០៣ ៖ ទ្រឹស្តីសង្គម និងសេរីនិយម ១២៣
វត្ថុបំណងមេរៀន ១២៣
៣.១. សង្គ្រាមថមថយ ១២៣
៣.២. ទ្រឹស្តីសេរីនិយម ១២៥
៣.២.១. លោក កានត៍ និងសន្តិភាព ១២៦
៣.២.២. ស្ថាប័នសេរីនិយម ១២៧
៣.២.៣. របបអន្តរជាតិ ១៣១
៣.២.៤. សន្តិសុខសមូហភាព ១៣៣
៣.២.៥. សន្តិប្រជាធិបតេយ្យ ១៣៥
៣.៣. ទ្រឹស្តីសង្គម ១៣៨
៣.៣.១. អត្តសញ្ញាណ និងបញ្ហាទស្សនៈ ១៣៩
៣.៣.២. ទ្រឹស្តីក្រោយសម័យទំនើបនិយម ១៤៤
៣.៤. ទ្រឹស្តីម៉ាកស៊ីសនិយម ១៤៦
៣.៥. សិក្សាសន្តិភាព ១៤៩
៣.៦. ទ្រឹស្តីយ៉េនឌ័រ ១៥៤
៣.៦.១. ហេតុអ្វីត្រូវដកចេញពីយេនឌ័រ ១៥៥
៣.៦.២. ភាពជាបុរសក្នុងទ្រឹស្តីប្រាកដនិយម ១៥៧
៣.៦.៣. យេនឌ័រ ក្នុងសង្គ្រាមនិងសន្តិភាព ១៥៩
៣.៦.៤. ស្ត្រីនៅក្នុង ទំនាក់ទំនងអន្តរជាតិ ១៦២
៣.៦.៥. ទ្រឹស្តីស្ត្រីទីទៃនិយម ទល់នឹង ទ្រឹស្តីស្ត្រីសេរីនិយម? ១៦៧
៣.៦.៦. ស្ត្រីក្រោយសម័យទំនើបនិយម ១៦៩
សេចក្តីសង្ខេប ១៧១
ពាក្យគន្លឹះ ១៧៣
សំណួរអនុវត្តន៍ ១៧៥
ការស្វែងរកផលប្រយោជន៍រួម ១៧៥
ទស្សនៈវិស័យគោលនយោបាយ ១៧៧
មតិសាធារណៈ និងទំនាក់ទំនងអន្តរជាតិ ១៧៨
តោះ សាកល្បងពិភាក្សាអំពីបញ្ហាជាក់ស្តែង ១៨០
ឯកសារគួរអានបន្ថែម ១៨២

មេរៀនទី ០៤ ៖ គោលនយោបាយការបរទេស ១៨៣
វត្ថុបំណងមេរៀន ១៨៣
៤.១. ការតាក់តែងគោលនយោបាយការបរទេស ១៨៣
៤.១.១. គំរូនៃការសម្រេចចិត្ត ១៨៣
៤.១.២. អ្នកធ្វើការសម្រេចចិត្តជាលក្ខណៈបុគ្គល ១៨៦
៤.១.៣. ចិត្តសាស្ត្រក្រុម ១៩១
៤.១.៤. ការគ្រប់គ្រងវិបត្តិ ១៩៣
៤.២. ឥទ្ធិពលក្នុងស្រុក ១៩៥
៤.២.១. ការិយាធិបតេយ្យ ១៩៥
៤.២.២. ក្រុមតំណាងផលប្រយោជន៍ ១៩៨
៤.២.៣. ក្រុមឧស្សាហកម្មយោធា ២០០
៤.២.៤. មតិសាធារណៈ ២០១
៤.២.៥. នីតិបញ្ញត្តិ ២០៦
៤.២.៦. ការបង្កើតគោលនយោបាយការបរទេស ២០៧
សេចក្តីសង្ខេប ២០៩
ពាក្យគន្លឹះ ២១០
សំណួរអនុវត្តន៍ ២១២
ការស្វែងរកផលប្រយោជន៍រួម ២១២
ទស្សនៈវិស័យគោលនយោបាយ ២១៤
មតិសាធារណៈ និងទំនាក់ទំនងអន្តរជាតិ ២១៥
តោៈ សាកល្បងពិភាក្សាអំពីបញ្ហាជាក់ស្តែង ២១៧
អាជីពក្នុងទំនាក់ទំនងអន្តរជាតិ៖ រដ្ឋាភិបាល និងការទូត ២១៩
ឯកសារគួរអានបន្ថែម ២២១
មេរៀនទី ០៥ ៖ ជំលោះអន្តរជាតិ ២២២
វត្ថុបំណងមេរៀន ២២២
៥.១. សង្គ្រាមលោក ២២២
៥.១.១. ប្រភេទនៃសង្គ្រាម ២២៤
៥.១.២. ទ្រឹស្តីនៃបុព្វហេតុនៃសង្គ្រាម ២២៨
៥.២. ជម្លោះទស្សនៈផ្សេងៗគ្នា ២៣២
៥.២.១. ជាតិនិយម ២៣២
៥.២.២. ជម្លោះជាតិសាសន៍ ២៣៤
៥.២.៣. អំពើប្រល័យពូជសាសន៍ ២៣៩
៥.២.៤. ជម្លោះសាសនា ២៤២

ជំពូកទី ០៥ ៖ ការប្រកួតប្រជែងលើធនធានធម្មជាតិ និងការប្រើប្រាស់ដីធ្លី ២៤៩
តម្រូវការសិក្សាមុនមេរៀន ២៤៩
៥.១. ការប្រកួតប្រជែងលើធនធានធម្មជាតិ ២៤៩
៥.២. ការប្រើប្រាស់ដីធ្លី ២៥០
៥.២.១. ដីធ្លីជាធនធានធម្មជាតិ ២៥០
៥.២.២. ដីធ្លីជាធនធានសេដ្ឋកិច្ច ២៥២
៥.២.៣. ដីធ្លីជាធនធានសង្គម ២៥៣
៥.២.៤. ដីធ្លីជាធនធានវប្បធម៌ ២៥៤
៥.២.៥. ដីធ្លីជាធនធានយោធា ២៥៦
៥.៣. ដីធ្លីផលប្រយោជន៍ ២៥៧
៥.៣.១. វិវាទទឹកដី ២៥៧
៥.៣.២. ការដណ្តើមគ្រប់គ្រងរដ្ឋាភិបាល ២៦៧
៥.៣.៣. ដីធ្លីជាសេដ្ឋកិច្ច ២៦៨
សេចក្តីសង្ខេប ២៧២
ពាក្យគន្លឹះ ២៧៣
សំណួរអនុវត្តន៍ ២៧៥
ការស្វែងរកផលប្រយោជន៍រួម ២៧៥
ទស្សនៈវិស័យគោលនយោបាយ ២៧៦
មតិសាធារណៈ និងទំនាក់ទំនងអន្តរជាតិ ២៧៨
តោះ សាកល្បងពិភាក្សាអំពីបញ្ហាជាក់ស្តែង ២៨០
ឯកសារគួរអានបន្ថែម ២៨២
មេរៀនទី ០៦ ៖ កងកម្លាំងប្រដាប់អាវុធ និងអំពើភេរវកម្ម ២៨៣
វត្ថុបំណងមេរៀន ២៨៣
៦.១. កងកម្លាំងទូទៅ ២៨៣
៦.១.១. កម្លាំងទ័ពជើងគោក៖ គ្រប់គ្រងដែនដី ២៨៥
៦.១.២. កងទ័ពជើងទឹក៖ គ្រប់គ្រងដែនសមុទ្រ ២៨៩
៦.១.៣. កងទ័ពអាកាស៖ គ្រប់គ្រងដែនអាកាស ២៩១
៦.១.៤. កងកម្លាំងចម្រុះ៖ កស្តុការនិងការស៊ើបការណ៍សម្ងាត់ ២៩៣
៦.២. ការវិវត្តនៃបច្ចេកវិទ្យា ២៩៥
៦.៣. អំពើភេរវកម្ម ៣០១
៦.៣.១. ការប្រយុទ្ធប្រឆាំងនឹងអំពើភេរវកម្ម ៣០៦
៦.៤. អាវុធប្រល័យលោក ៣០៧
៦.៤.១. អាវុធនុយក្លេអ៊ែរ ៣០៧
៦.៤.២. មីស៊ីលផ្លោង និងប្រព័ន្ធបញ្ជូនផ្សេងៗទៀត ៣១០
៦.៤.៣. អាវុធគីមី និងជីវសាស្ត្រ ៣១៤
៦.៤.៤. ការរីកសាយភាយ ៣១៦
៦.៤.៥. យុទ្ធសាស្ត្រនុយក្លេអ៊ែរ និងការគ្រប់គ្រងអាវុធ ៣២០
៦.៥. រដ្ឋ និងយោធា ៣២៤
៦.៥.១. សេដ្ឋកិច្ចយោធា ៣២៤
៦.៥.២. ការគ្រប់គ្រងកងកម្លាំងយោធា ៣២៦
៦.៥.៣. ទំនាក់ទំនងស៊ីវិល-យោធា ៣២៨

សេចក្តីសង្ខេប ៣៣១
ពាក្យគន្លឹះ ៣៣២
សំណួរអនុវត្តន៍ ៣៣៥
ការស្វែងរកផលប្រយោជន៍រួម ៣៣៥
ទស្សនៈវិស័យគោលនយោបាយ ៣៣៦
មតិសាធារណៈ និងទំនាក់ទំនងអន្តរជាតិ ៣៣៧
តោះ សាកល្បងពិភាក្សាអំពីបញ្ហាជាក់ស្តែង ៣៣៩
ឯកសារគួរអានបន្ថែម ៣៤១
មេរៀនទី ០៧ ៖ អង្គការនិងច្បាប់អន្តរជាតិ និងសិទ្ធិមនុស្ស ៣៤២
វត្ថុបំណងមេរៀន ៣៤២
៧.១. តួនាទីអង្គការអន្តរជាតិ ៣៤២
៧.២. អង្គការសហប្រជាតិ ៣៤៧
៧.២.១. ប្រព័ន្ធអង្គការសហប្រជាជាតិ ៣៤៨
៧.២.២. ក្រុមប្រឹក្សាសន្តិសុខ ៣៥៥
៧.២.៣. កងកម្លាំងរក្សាសន្តិភាព ៣៦១
៧.២.៤. លេខាធិការដ្ឋាន ៣៦៨
៧.២.៥. មហាសន្និបាត ៣៧០
៧.២.៦. កម្មវិធីអង្គការសហប្រជាជាតិ ៣៧២
៧.២.៧. ទីភ្នាក់ងារស្វយ័ត ៣៧៤
៧.៣. ច្បាប់អន្តរជាតិ ៣៧៥
៧.៣.១. ប្រភពច្បាប់អន្តរជាតិ ៣៧៥
៧.៣.២. ការពង្រឹងការអនុវត្តច្បាប់អន្តរជាតិ ៣៧៧
៧.៣.៣. តុលាការពិភពលោក ៣៧៩
៧.៣.៤. ករណីអន្តរជាតិនៅក្នុងតុលាការជាតិ ៣៨២
៧.៤. ច្បាប់ និងអធិបតេយ្យភាព ៣៨៥
៧.៤.១. ច្បាប់ការទូត ៣៨៥
៧.៤.២. គោលលទ្ធិនៃយុត្តិសង្គ្រាម ៣៨៩
៧.៥. សិទ្ធិមនុស្ស ៣៩១
៧.៥.១. សិទ្ធិបុគ្គល ទល់នឹង អធិបតេយ្យភាព ៣៩១
៧.៥.២. ស្ថាប័នសិទ្ធិមនុស្ស ៣៩៣
៧.៥.៣. ឧក្រិដ្ឋកម្មសង្គ្រាម និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ៣៩៧
៧.៥.៤. ការវិវត្តនៃសណ្តាប់ធ្នាប់ពិភពលោក ៤០៣
សេចក្តីសង្ខេប ៤០៥

ពាក្យគន្លឹះ ៤០៦
សំណួរអនុវត្តន៍ ៤០៨
ការស្វែងរកផលប្រយោជន៍រួម ៤០៩
ទស្សនៈវិស័យគោលនយោបាយ ៤១១
មតិសាធារណៈ និងទំនាក់ទំនងអន្តរជាតិ ៤១២
តោះ សាកល្បងពិភាក្សាអំពីបញ្ហាជាក់ស្តែង ៤១៤
អាជីពក្នុងទំនាក់ទំនងអន្តរជាតិ៖ ច្បាប់អន្តរជាតិ ៤១៦
ឯកសារគួរអានបន្ថែម ៤១៨
ជំពូកទី ២ សេដ្ឋកិច្ចនយោបាយអន្តរជាតិ ៤១៩
មេរៀនទី ០៨ ៖ ពាណិជ្ជកម្មអន្តរជាតិ ៤១៩
វត្ថុបំណងមេរៀន ៤១៩
៨.១. ទ្រឹស្តីពាណិជ្ជកម្ម ៤១៩
៨.១.១. ទ្រឹស្តីសេរីនិយមនិងទ្រឹស្តីគាំពារនិយម ៤២០
៨.១.២. គុណសម្បត្តិធៀប ៤២៦
៨.១.៣. ការជ្រៀតជ្រែកផ្នែកនយោបាយនៅក្នុងទីផ្សារ ៤២៨
៨.១.៤. គោលនយោបាយគាំពារនិយម ៤៣១
៨.២. របបពាណិជ្ជកម្ម ៤៣៦
៨.២.១. អង្គការពាណិជ្ជកម្មពិភពលោក ៤៣៦
៨.២.២. កិច្ចព្រមព្រៀងទ្វេភាគី និងតំបន់ ៤៤១
៨.២.៣. ការតែល ៤៤៥
៨.២.៤. ក្រុមឧស្សាហកម្ម និងក្រុមទាញផលប្រយោជន៍ ៤៤៨
៨.២.៥. ការអនុវត្តច្បាប់ពាណិជ្ជកម្ម ៤៥២
៨.៣. សាកលភាវូបនីយកម្មសេដ្ឋកិច្ច ៤៥៤
៨.៣.១. សេដ្ឋកិច្ចពិភពលោកកំពុងវិវត្តន៍ ៤៥៥
៨.៣.២. ប្រតិកម្មប្រឆាំងនឹងពាណិជ្ជកម្ម ៤៥៩
សេចក្តីសង្ខេប ៤៦២
ពាក្យគន្លឹះ ៤៦៤
សំណួរអនុវត្តន៍ ៤៦៦
ការស្វែងរកផលប្រយោជន៍រួម ៤៦៧
ទស្សនៈវិស័យគោលនយោបាយ ៤៦៨
មតិសាធារណៈ និងទំនាក់ទំនងអន្តរជាតិ ៤៧០
តោះ សាកល្បងពិភាក្សាអំពីបញ្ហាជាក់ស្តែង ៤៧២
ឯកសារគួរអានបន្ថែម ៤៧៤

មេរៀនទី ០៩ ៖ ហិរញ្ញវត្ថុនិងជំនួញសាកល **៤៧៥**
វត្ថុបំណងមេរៀន **៤៧៥**
៩.១. សាកលភាវូបនីយកម្ម និងហិរញ្ញវត្ថុ **៤៧៥**
៩.២. ប្រព័ន្ធហិរញ្ញវត្ថុ **៤៧៦**
៩.២.១. អំពីប្រាក់ ៤៧៦
៩.២.២. ការផ្លាស់ប្តូររូបិយប័ណ្ណអន្តរជាតិ ៤៧៧
៩.២.៣. ហេតុអ្វីបានជាតម្លៃរូបិយប័ណ្ណឡើងថ្លៃ ឬចុះថោក ៤៨៣
៩.២.៤. ធនាគារកណ្តាល ៤៨៦
៩.២.៥. ធនាគារពិភពលោក និង មូលនិធិរូបិយវត្ថុអន្តរជាតិ ៤៨៨
៩.៣. ស្ថានភាពហិរញ្ញវត្ថុរបស់រដ្ឋនានា **៤៩១**
៩.៣.១. គណនីជាតិ ៤៩១
៩.៣.២. បំណុលអន្តរជាតិ ៤៩២
៩.៣.៣. ជំហរសហរដ្ឋអាមេរិក ៤៩៥
៩.៣.៤. ជំហររុស្ស៊ីនិងអឺរ៉ុបខាងកើត ៤៩៧
៩.៣.៥. ជំហរសេដ្ឋកិច្ចអាស៊ី ៤៩៩
៩.៤. ពាណិជ្ជកម្មពហុជាតិ **៥០២**
៩.៤.១. សាជីវកម្មពហុជាតិ ៥០២
៩.៤.២. ការវិនិយោគផ្ទាល់ពីបរទេស ៥០៥
៩.៤.៣. ទំនាក់ទំនងរដ្ឋាភិបាលម្ចាស់ប្រទេសនិងមាតុប្រទេស ៥០៧
សេចក្តីសង្ខេប **៥១៣**
ពាក្យគន្លឹះ **៥១៥**
សំណួរអនុវត្តន៍ **៥១៧**
ការស្វែងរកផលប្រយោជន៍រួម **៥១៨**
ទស្សនៈវិស័យគោលនយោបាយ **៥១៩**
មតិសាធារណៈ និងទំនាក់ទំនងអន្តរជាតិ **៥២១**
តោះ សាកល្បងពិភាក្សាអំពីបញ្ហាជាក់ស្តែង **៥២២**
អាជីពក្នុងទំនាក់ទំនងអន្តរជាតិ៖ ធុរកិច្ចអន្តរជាតិ **៥២៥**
ឯកសារគួរអានបន្ថែម **៥២៦**
មេរៀនទី ១០ ៖ សមាហរណកម្មអន្តរជាតិ **៥២៧**
វត្ថុបំណងមេរៀន **៥២៧**
១០.១. សាកលភាវូបនីយកម្ម និងសមាហរណកម្ម **៥២៧**
១០.២. ទ្រឹស្តីសមាហរណកម្ម **៥២៨**
១០.៣. សហភាពអឺរ៉ុប **៥៣២**

១០.៣.១. ចក្ខុវិស័យនៃសហភាពអឺរ៉ុប ៥៣២
១០.៣.២. សន្ធិសញ្ញាទីក្រុងរ៉ូម ៥៣៣
១០.៣.៣. រចនាសម្ព័ន្ធនៃសហភាពអឺរ៉ុប ៥៣៥
១០.៣.៤. សន្ធិសញ្ញាអឺរ៉ុបរួម ៥៣៨
១០.៣.៥. សន្ធិសញ្ញាទីក្រុងម៉ាស្ត្រីស ៥៣៩
១០.៣.៦. សហភាពរូបិយវត្ថុ ៥៤០
១០.៣.៧. ការពង្រីកសហភាពអឺរ៉ុប ៥៤៣
១០.៣.៨. សន្ធិសញ្ញាទីក្រុងលីស្បោន ៥៤៥
១០.៣.៩. អន្តោរប្រវេសន៍ ការចាកចេញរបស់អង់គ្លេស និងអនាគតអឺរ៉ុប ៥៤៧
១០.៤. អំណាចនៃព័ត៌មាន ៥៤៩
១០.៤.១. ការតភ្ជាប់ពិភពលោក ៥៥០
១០.៤.២. ព័ត៌មានជាឧបករណ៍របស់រដ្ឋាភិបាល ៥៥៤
១០.៤.៣. ព័ត៌មានជាឧបករណ៍ប្រឆាំងនឹងរដ្ឋាភិបាល ៥៥៦
១០.៤.៤. ទូរគមនាគមន៍ និងវប្បធម៌សកល ៥៥៩
សេចក្តីសង្ខេប ៥៦២
ពាក្យគន្លឹះ ៥៦៤
សំណួរអនុវត្តន៍ ៥៦៦
ការស្វែងរកផលប្រយោជន៍រួម ៥៦៧
ទស្សនៈវិស័យគោលនយោបាយ ៥៦៨
មតិសាធារណៈ និងទំនាក់ទំនងអន្តរជាតិ ៥៦៩
តោះ សាកល្បងពិភាក្សាអំពីបញ្ហាជាក់ស្តែង ៥៧១
ឯកសារគួរអានបន្ថែម ៥៧៤
មេរៀនទី ១១ ៖ បរិស្ថាន និងប្រជាជន ៥៧៥
វត្ថុបំណងមេរៀន ៥៧៥
១១.១. ការពឹងអាស្រ័យគ្នា និងបរិស្ថាន ៥៧៥
១១.១.១. ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ៥៧៨
១១.២. ការគ្រប់គ្រងបរិស្ថាន ៥៧៨
១១.២.១. បរិយាកាស ៥៧៩
១១.២.២. ដីវចម្រុះ ៥៨៨
១១.២.៣. ព្រៃឈើ និងមហាសមុទ្រ ៥៩០
១១.២.៤. ការបំពុលបរិស្ថាន ៥៩៤
១១.៣. ធនធានធម្មជាតិ ៥៩៦
១១.៣.១. ប្រភពថាមពលពិភពលោក ៥៩៧

ខ្លឹមសារ

ទំព័រ

ជំពូក ១១ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១២ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១៣ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១៤ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១៥ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១៦ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១៧ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១៨ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១៩ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ២០ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ២១ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ២២ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ២៣ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ២៤ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ២៥ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ២៦ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ២៧ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ២៨ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ២៩ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៣០ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៣១ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៣២ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៣៣ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៣៤ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៣៥ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៣៦ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៣៧ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៣៨ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៣៩ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៤០ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៤១ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៤២ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៤៣ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៤៤ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៤៥ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៤៦ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៤៧ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៤៨ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៤៩ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៥០ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៥១ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៥២ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៥៣ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៥៤ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៥៥ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៥៦ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៥៧ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៥៨ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៥៩ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៦០ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៦១ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៦២ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៦៣ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៦៤ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៦៥ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៦៦ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៦៧ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៦៨ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៦៩ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៧០ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៧១ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៧២ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៧៣ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៧៤ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៧៥ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៧៦ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៧៧ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៧៨ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៧៩ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៨០ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៨១ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៨២ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៨៣ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៨៤ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៨៥ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៨៦ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៨៧ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៨៨ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៨៩ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៩០ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៩១ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៩២ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៩៣ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៩៤ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៩៥ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៩៦ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៩៧ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៩៨ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ៩៩ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១០០ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១០១ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១០២ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១០៣ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១០៤ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១០៥ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១០៦ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១០៧ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១០៨ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១០៩ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១១០ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១១១ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១១២ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១១៣ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១១៤ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១១៥ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១១៦ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១១៧ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១១៨ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១១៩ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១២០ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១២១ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១២២ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១២៣ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១២៤ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១២៥ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១២៦ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១២៧ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១២៨ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១២៩ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១៣០ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១៣១ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១៣២ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១៣៣ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១៣៤ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១៣៥ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១៣៦ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១៣៧ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១៣៨ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១៣៩ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១៤០ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១៤១ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១៤២ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១៤៣ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១៤៤ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១៤៥ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១៤៦ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១៤៧ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១៤៨ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១៤៩ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១៥០ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១៥១ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១៥២ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១៥៣ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១៥៤ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១៥៥ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១៥៦ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១៥៧ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១៥៨ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១៥៩ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១៦០ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១៦១ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១៦២ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១៦៣ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១៦៤ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១៦៥ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១៦៦ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១៦៧ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១៦៨ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១៦៩ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១៧០ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

ជំពូក ១៧១ ៖ ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថាន

ដោយ ឈាង ចាន់ណា

ទំព័រ

**ជំពូក ១៧២ ៖ ការប្រើប្រាស់ធនធាន

សំណួរអនុវត្តន៍ ៦៧១
ការស្វែងរកផលប្រយោជន៍រួម ៦៧២
មតិសាធារណៈ និងទំនាក់ទំនងអន្តរជាតិ ៦៧៣
ទស្សនៈវិស័យគោលនយោបាយ ៦៧៥
តោះ សាកល្បងពិភាក្សាអំពីបញ្ហាជាក់ស្តែង ៦៧៦
អាជីពក្នុងទំនាក់ទំនងអន្តរជាតិ៖ អង្គការមិនមែនរដ្ឋាភិបាល (NGOs) ៦៧៩
ឯកសារគួរអានបន្ថែម ៦៨០
មេរៀនទី ១៣ ៖ ការអភិវឌ្ឍអន្តរជាតិ ៦៨២
វត្ថុបំណងមេរៀន ៦៨២
១៣.១. បទពិសោធន៍ ៦៨២
១៣.១.១. ប្រទេសឧស្សាហកម្មថ្មីៗ ៦៨៥
១៣.១.២. បទពិសោធន៍ប្រទេសចិន ៦៨៦
១៣.១.៣. ការងើបឡើងរបស់ឥណ្ឌា ៦៩១
១៣.១.៤. បទពិសោធន៍ប្រទេសផ្សេងៗ ៦៩៤
១៣.២. មេរៀន ៦៩៩
១៣.២.១. កំណើនដោយជំនួសការនាំចូល និងកំណើនដោយការនាំចេញ ៦៩៩
១៣.២.២. ការប្រមូលផ្តុំដើមទុនសម្រាប់ផលិតកម្ម ៧០១
១៣.២.៣. អំពើពុករលួយ ៧០៣
១៣.៣. លំហូរដើមទុនអឌ្ឍគោលខាងជើងនិងត្បូង ៧០៥
១៣.៣.១. ការវិនិយោគបរទេស ៧០៥
១៣.៣.២. បំណុលអឌ្ឍគោលខាងជើង-ខាងត្បូង ៧០៨
១៣.៣.៣. លក្ខខណ្ឌរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ៧១១
១៣.៣.៤. អឌ្ឍគោលខាងត្បូង ក្នុងរបបសេដ្ឋកិច្ចអន្តរជាតិ ៧១២
១៣.៤. ជំនួសបរទេស ៧១៤
១៣.៤.១. ទំរង់ជំនួយបរទេស ៧១៥
១៣.៤.២. ប្រភេទនៃជំនួយបរទេស ៧១៧
១៣.៤.៣. នយោបាយនៃជំនួយបរទេស ៧២២
១៣.៤.៤. ឥទ្ធិពលនៃជំនួយបរទេស ៧២៥
សេចក្តីសង្ខេប ៧២៧
ពាក្យគន្លឹះ ៧២៩
សំណួរអនុវត្តន៍ ៧៣១
ការស្វែងរកផលប្រយោជន៍រួម ៧៣១
មតិសាធារណៈ និងទំនាក់ទំនងអន្តរជាតិ ៧៣៣

ទស្សនៈវិស័យគោលនយោបាយ ៧៣៤
តោះ សាកល្បងពិភាក្សាអំពីបញ្ហាជាក់ស្តែង ៧៣៦
អាជីពក្នុងទំនាក់ទំនងអន្តរជាតិ៖ ការអប់រំ និងស្រាវជ្រាវ ៧៤០
ឯកសារគួរអានបន្ថែម ៧៤១
មេរៀនទី ១៤ ៖ អវសានកថា ៧៤២
សេចក្តីសង្ខេបសៀវភៅ ៧៤៦
បញ្ជីឯកសារយោង ៧៥០

ផែនទីសំខាន់ៗ

0.១ រដ្ឋ និងដែនដីពិភពលោក

0.២ អាមេរិកខាងជើង

0.៣ អាមេរិកកណ្តាល និងតំបន់ការ៉ាប៊ីន

0.៤ អាមេរិកខាងត្បូង

0.៥ អាហ្វ្រិក

0.៦ អាហ្វ្រិកខាងជើង និងមជ្ឈឹមបូព៌ា

0.៧ អឺរ៉ុប

0.៨ អាស៊ី

ជំពូកទី ១ សាថតា និងសន្តិសុខអន្តរជាតិ
មេរៀនទី ០១ ៖ សកលភាវូបនីយកម្មលើទំនាក់ទំនងអន្តរជាតិ

រូបថត ផែនទីមជ្ឈឹមបូព៌ា
មជ្ឈឹមបូព៌ា ដូចដែលបានឃើញពីស្ថានីយអវកាសអន្តរជាតិ ឆ្នាំ ២០១០។

ភស្តុបំណងមេរៀន

១.១ ចូរកំណត់និយមន័យនៃបច្ចេកពាក្យ «បញ្ហាផលប្រយោជន៍រួម» និងកំណត់គោលការណ៍ស្នូលសម្រាប់ដោះស្រាយបញ្ហានេះ។

១.២ ចូរវាយតម្លៃថាតើរដ្ឋនៅតែជាតួអង្គឯក នៅក្នុងទំនាក់ទំនងអន្តរជាតិដែរឬទេ។

១.៣ ចូរកំណត់អត្តសញ្ញាណរួមរបស់រដ្ឋនានា នៅអឌ្ឍគោលខាងជើង យ៉ាងហោចណាស់ចំនួន ៣ អត្តសញ្ញាណរួមរបស់រដ្ឋនានា នៅអឌ្ឍគោលខាងត្បូង យ៉ាងហោចណាស់ចំនួន ៣ ដែរ។

១.៤ ចូរពន្យល់ភាពខុសគ្នារវាងប្រព័ន្ធអន្តរជាតិ កំឡុងសម័យសង្គ្រាមត្រជាក់ និងក្រោយសម័យសង្គ្រាមត្រជាក់ យ៉ាងហោចណាស់ អោយបានពីរចំណុចផ្សេងគ្នា។

១.១. សកលភាវូបនីយកម្មទំនាក់ទំនងអន្តរជាតិ និងជីវិតប្រចាំថ្ងៃ

១.១ ចូរកំណត់និយមន័យនៃបច្ចេកពាក្យ «បញ្ហាផលប្រយោជន៍រួម» និងកំណត់គោលការណ៍ស្នូលសម្រាប់ដោះស្រាយបញ្ហានេះ។

ទំនាក់ទំនងអន្តរជាតិ គឺជាប្រធានបទគួរអោយចាប់អារម្មណ៍ព្រោះវាពន្យល់អំពីមនុស្សនិងវប្បធម៌នៅទូទាំងពិភពលោក។ វិសាលភាពនិងភាពស្មុគស្មាញនៃអន្តរកម្ម ក្នុងចំណោមក្រុមមនុស្សនិងវប្បធម៌ទាំងនេះធ្វើអោយទំនាក់ទំនងអន្តរជាតិក្លាយជាមុខវិជ្ជាដ៏លំបាកសិក្សានិងស្វែងយល់សម្រាប់និស្សិតមួយចំនួន ព្រោះជាធម្មតា តែងតែមានរឿងរ៉ាវថ្មីៗជាច្រើន ដែលត្រូវសិក្សាស្វែងយល់។ អត្ថបទមេរៀននេះ គ្រាន់តែជាការចាប់ផ្តើមនៃដំណើរដ៏វែងឆ្ងាយមួយ ប៉ុណ្ណោះ។

ក្នុងន័យតូចចង្អៀត មុខវិជ្ជា**ទំនាក់ទំនងអន្តរជាតិ**(IR)សិក្សាអំពីទំនាក់ទំនងរវាងរដ្ឋាភិបាលនានា នៅលើពិភពលោក។ ក៏ប៉ុន្តែ គេមិនអាចយល់ច្បាស់អំពីទំនាក់ទំនងទាំងនេះ ដាច់ដោយឡែកពីគ្នាបានទេ។ មែនទែនទៅ ទំនាក់ទំនងទាំងនោះមានការជាប់ពាក់ព័ន្ធយ៉ាងជិតស្និទ្ធជាមួយនឹងតួអង្គផ្សេងទៀត (ដូចជាអង្គការអន្តរជាតិ សាជីវកម្មពហុជាតិ និងបុគ្គលឯកជន) ដែលមានដំណើរការនិងរចនាសម្ព័ន្ធសង្គមផ្សេងទៀត (រួមមានសេដ្ឋកិច្ច វប្បធម៌ និងនយោបាយក្នុងស្រុក) និងដែលត្រូវរងឥទ្ធិពលពីកត្តាភូមិសាស្ត្រនិងប្រវត្តិសាស្ត្រ។ ធាតុផ្សំទាំងអស់នេះជំរុញប្រធានបទពេញនិយមជាងគេក្នុងវិស័យទំនាក់ទំនងអន្តរជាតិនាពេលបច្ចុប្បន្ន នោះគឺ **សាកលភាវូបនីយកម្ម** (Globalization)។

ជាការពិតណាស់ ព្រឹត្តិការណ៍បីធំៗ ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ឆ្លុះបញ្ចាំងពីសាកលភាវូបនីយកម្ម។ នៅឆ្នាំ ២០១៤ ការផ្ទុះឡើងនៃវីរុសអេបូឡានៅទ្វីបអាហ្វ្រិក បាននាំអោយមានការព្រួយបារម្ភខ្លាំង ខ្លាចវារីករាលដាលពាសពេញពិភពលោក។ អ្នកឆ្លងជំងឺ ទោះនៅឆ្ងាយពីអាហ្វ្រិក ដូចជានៅប្រទេសអេស្បាញ សហរដ្ឋអាមេរិក និងចក្រភពអង់គ្លេសត្រូវបានគេធ្វើចត្តាឡីស័ក្ត ខណៈពេលដែលនីតិវិធីពិនិត្យសុខភាពថ្មី ដើម្បីទប់ស្កាត់ការ

រីករាលដាលនៃវីរុសនេះ ត្រូវបានអនុវត្តតាមនៅមន្ទីរពេទ្យ និងគ្លីនិកសុខភាព ទូទាំងប្រទេសទាំងអស់នេះ។ បាតុករវ័យក្មេងនៅនិទាឃរដូវអារ៉ាប់ (Arab Spring) ដែលបានផ្តួលរំលំរដ្ឋាភិបាលមួយចំនួន នៅក្នុងកំឡុងឆ្នាំ ២០១១-២០១២ បានប្រើហ្វេសប៊ុកនិងទូរស័ព្ទដៃដើម្បីរៀបចំផែនការ និងសម្របសម្រួលបដិវត្តន៍របស់ពួកគេ។ ចុងក្រោយវិបត្តិសេដ្ឋកិច្ចពិភពលោក ឆ្នាំ ២០០៨-២០០៩ ដែលបានចាប់ផ្តើមដំបូង ជាមួយនឹងការដួលរលំនៃទីផ្សារអចលនទ្រព្យ នៅសហរដ្ឋអាមេរិកបានរាលដាលយ៉ាងឆាប់រហ័ស ទៅដល់ប្រជាជាតិដទៃទៀត។ ទីផ្សារហិរញ្ញវត្ថុពិភពលោក ដែលផ្សារភ្ជាប់និងទាក់ទងគ្នាយ៉ាងស្អិតរមួត បានបង្កផលប៉ះពាល់នៅទូទាំងពិភពលោក ដែលគេហាក់នៅតែមានអារម្មណ៍រងផលប៉ះពាល់ រហូតដល់បច្ចុប្បន្ននេះ។ ដូច្នេះ លក្ខណៈកត់សំគាល់សំខាន់ៗនៃសាកលភាវូបនីយកម្មចំនួនបី៖ ភាពងាយស្រួលក្នុងការធ្វើដំណើរ នៅទូទាំងពិភពលោក បច្ចេកវិទ្យាទូរគមនាគមន៍ទូលំទូលាយ និងទីផ្សារសកលទូលំទូលាយ បណ្តាលអោយមានព្រឹត្តិការណ៍ដែលប៉ះពាល់ដល់ជីវភាពប្រចាំថ្ងៃរបស់យើងទាំងអស់គ្នា។

មិនត្រឹមតែព្រឹត្តិការណ៍ធំៗទេ ដែលជះឥទ្ធិពលលើជីវិតរបស់យើង។ ឱកាសទទួលបានការងារក្រោយបញ្ចប់ការសិក្សា អាស្រ័យលើសេដ្ឋកិច្ចពិភពលោក និងការប្រកួតប្រជែងសេដ្ឋកិច្ចអន្តរជាតិ។ ការងារទាំងនោះក៏ទំនងជាទាមទារអោយមានការធ្វើដំណើរអន្តរជាតិ ផ្នែកលក់ឬទីផ្សារ ឬ ការប្រាស្រ័យទាក់ទង ជាលក្ខណៈអន្តរជាតិដែរ ជាពិសេស នៅក្នុងសម័យបច្ចុប្បន្ននេះ។ លើសពីនេះទៅទៀត ច្បាប់នៃប្រព័ន្ធពាណិជ្ជកម្មពិភពលោកជះឥទ្ធិពលដល់ទំនិញឬសម្ភារៈនានា ដែលនិស្សិតប្រើប្រាស់រាល់ថ្ងៃដូចជាគ្រឿងអេឡិចត្រូនិច សម្លៀកបំពាក់ និងសាំង។

សាកលភាវូបនីយកម្ម ក៏ផ្តល់ផលវិជ្ជមានគួរអោយកត់សម្គាល់ លើជីវភាពរស់នៅប្រចាំថ្ងៃរបស់យើងផងដែរ។ នៅពេលដែលបច្ចេកវិទ្យាកាន់តែជឿនលឿន ពិភពលោកហាក់រួមតូចទៅៗ ពីមួយឆ្នាំទៅមួយឆ្នាំ។ សមត្ថភាពក្នុងការប្រាស្រ័យទាក់ទងនិងដឹកជញ្ជូនកាន់តែប្រសើរ បានផ្សារភ្ជាប់ទំនាក់ទំនង យ៉ាងឆាប់រហ័សរវាងមនុស្ស នឹងមនុស្ស នឹងផលិតផល នឹងគំនិតពីបណ្តាប្រទេសដទៃទៀត។ សាកលភាវូបនីយកម្ម បាននិងកំពុងធ្វើអោយយើងរស់នៅជាលក្ខណៈអន្តរជាតិ។

ក្រៅពីរងឥទ្ធិពលពីសកលភាវូបនីយកម្មនិងទំនាក់ទំនងអន្តរជាតិលើជីវិតប្រចាំថ្ងៃរបស់យើង មនុស្សម្នាក់ៗក៏អាចមានឥទ្ធិពលទៅលើពិភពលោកវិញផងដែរ។ ជារឿយៗ ទំនាក់ទំនងអន្តរជាតិត្រូវបានចង្អុលបង្ហាញអោយគេឃើញថា ជាពិធីអរូបីនៅទីសែនឆ្ងាយ ដែលត្រូវរៀបចំឡើង ដោយមនុស្សមួយក្រុមតូច ដូចជាប្រធានាធិបតី ឧត្តមសេនីយ៍ និងអ្នកការទូត។ ទោះបីជាមេដឹកនាំដើរតួនាទីសំខាន់ក្នុងកិច្ចការអន្តរជាតិក៏ដោយ ក៏មានមនុស្សជាច្រើនផ្សេងទៀតចូលរួមផងដែរ។ និស្សិតមហាវិទ្យាល័យ និងប្រជាពលរដ្ឋសាមញ្ញចូលរួមក្នុងទំនាក់ទំនងអន្តរជាតិ រៀងរាល់ពេលដែលពួកគេចេញទៅបោះឆ្នោត ឬចូលរួមក្នុងយុទ្ធនាការនយោបាយ ទិញផលិតផល ឬ សេវាកម្មដែលបានដួញដូរ នៅលើទីផ្សារពិភពលោក និងតាមដានព័ត៌មាន។ នៅទីបំផុត ជម្រើសដែលយើងសម្រេចយកឬធ្វើនៅក្នុងជីវិតប្រចាំថ្ងៃរបស់យើង មានឥទ្ធិពលលើពិភពលោកដែលយើងកំពុងរស់នៅ។ តាមរយៈជម្រើសទាំងនោះ មនុស្សគ្រប់រូបរួមចំណែក ទោះច្រើនឬតិចតួចស្តួចស្តើងក្តីក្នុងពិភពលោកនៃទំនាក់ទំនងអន្តរជាតិ។

មេរៀននេះមានគោលបំណងផ្តល់ជូនអ្នកសិក្សានូវចំណេះដឹងជាមូលដ្ឋានគ្រឹះ ក្នុងវិស័យទំនាក់ទំនងអន្តរជាតិ រៀបចំនូវអ្វីដែលបានដឹងនិងស្គាល់ និងទ្រឹស្តីទំនាក់ទំនងអន្តរជាតិ និងបង្ហាញនូវគំនិតសំខាន់ៗ

ដែលត្រូវបានប្រើដោយអ្នកវិទ្យាសាស្ត្រនយោបាយ ក្នុងការពិភាក្សាអំពីទំនាក់ទំនងក្នុងចំណោមរដ្ឋាភិបាលនៃប្រទេសនានាលើពិភពលោក។ មេរៀនដំបូងនេះកំណត់និយមន័យទំនាក់ទំនងអន្តរជាតិ ក្នុងនាមជាមុខវិជ្ជាសិក្សាណែនាំអោយអ្នកអានស្គាល់តួអង្គជាទីចាប់អារម្មណ៍ទាំងឡាយ និងពិនិត្យលើទិដ្ឋភាពភូមិសាស្ត្រ និងប្រវត្តិសាស្ត្រនៃសាកលភាវូបនីយកម្ម ដែលអនុញ្ញាតអោយទំនាក់ទំនងអន្តរជាតិកើតឡើង។

១.១.១. គោលការណ៍ស្នូល

មុខវិជ្ជាទំនាក់ទំនងអន្តរជាតិ ឆ្លុះបញ្ចាំងពីភាពស្មុគស្មាញនៃពិភពលោក ហើយអ្នកប្រាជ្ញ ទំនាក់ទំនងអន្តរជាតិ ប្រើប្រាស់ទ្រឹស្តី គំនិត និង ពាក្យពេចន៍ពេញនិយម (BuzzWords) ជាច្រើនក្នុងការព្យាយាមពិពណ៌នានិងពន្យល់វា។ ទោះយ៉ាងណា នៅពីក្រោយភាពស្មុគស្មាញនេះ, មានគោលការណ៍មូលដ្ឋានមួយចំនួន ដែលមានឥទ្ធិពលលើមុខវិជ្ជា ឬ វិស័យនេះ។ មេរៀន ២ ដល់ ៤ នឹងណែនាំអំពីទ្រឹស្តី និងវិធីសាស្ត្រមួយចំនួន ប៉ុន្តែ នៅក្នុងមេរៀននេះ យើងនឹងបង្ហាញនូវគំនិតសំខាន់បំផុត ដោយវិធីសាស្ត្រងាយបំផុត តាមតែអាចធ្វើទៅបាន ដោយជៀសវាងការប្រើប្រាស់ពាក្យបច្ចកទេសជ្រៅពេក។

ទំនាក់ទំនងអន្តរជាតិទាក់ទងនឹងចំណោទដ៏សំខាន់មួយ៖ តើក្រុមមួយដែលរួមមានប្រទេសពីរឬច្រើនអាចធានាបាននូវ*ផលប្រយោជន៍រួម* យ៉ាងដូចម្តេច ក្នុងខណៈពេលធ្វើដូច្នេះ តម្រូវអោយប្រទេសសមាជិកលះបង់*ផលប្រយោជន៍ផ្ទាល់ខ្លួន*? ឧទាហរណ៍ ប្រទេសនីមួយៗទទួលបានផលប្រយោជន៍ ក្នុងការបញ្ឈប់ការឡើងកម្តៅសកល ដែលជាគោលដៅមួយ អាចសម្រេចបាន លុះត្រាតែប្រទេសជាច្រើនរួមគ្នាធ្វើ។ ប៉ុន្តែ ប្រទេសនីមួយៗក៏មានផលប្រយោជន៍ផ្ទាល់ខ្លួន ក្នុងការដុតឥន្ធនៈហ្វូស៊ីល ដើម្បីអោយសេដ្ឋកិច្ចរបស់ខ្លួនដំណើរការទៅមុខផងដែរ។ ស្រដៀងគ្នានេះដែរ សមាជិកទាំងអស់នៃសម្ព័ន្ធមិត្តយោធាមួយទទួលបានអត្ថប្រយោជន៍ពីភាពខ្លាំងនៃសម្ព័ន្ធភាពនេះ ប៉ុន្តែប្រទេសសមាជិកនីមួយៗ មានផលប្រយោជន៍ រៀងៗខ្លួន ក្នុងការកាត់បន្ថយវិភាគទានកងទ័ពនិងប្រាក់ផ្ទាល់ខ្លួន សម្រាប់សម្ព័ន្ធភាពនេះ។ ប្រទេសនីមួយៗអាចទាញយកផលប្រយោជន៍ផ្ទាល់ខ្លួន ក្នុងរយៈពេលខ្លី ដោយការរឹបអូសយកទឹកដីដោយកម្លាំងយោធា ដោយមិនអនុវត្តតាមកិច្ចព្រមព្រៀងពាណិជ្ជកម្មនិងដោយការបដិសេធមិនចូលរួមចំណែកក្នុងកិច្ចខិតខំប្រឹងប្រែងអន្តរជាតិ ដូចជាយុទ្ធនាការថែរក្សាសន្តិភាព ឬការចាក់វ៉ាក់សាំង ជាដើម។ ប៉ុន្តែ ប្រសិនបើប្រជាជាតិទាំងអស់ ធ្វើបែបនេះ ពួកគេនឹងធ្លាក់ខ្លួនក្នុងស្ថានភាពកាន់តែអាក្រក់ទៅៗ នៅក្នុងបរិយាកាសរឹករឹងនិងអសន្តិសុខ ក្នុងខណៈពេលផលចំណេញ ទៅវិញទៅមក ដោយការសហការលើបញ្ហាសន្តិសុខនិងពាណិជ្ជកម្មនឹងត្រូវរលាយបាត់បង់។

បញ្ហាបញ្ច្រាសទិសគ្នា រវាងផលប្រយោជន៍រួមនឹងផលប្រយោជន៍ផ្ទាល់ខ្លួនចំរុងចំរាស់ ក្នុងចំណោមសមាជិកនៃក្រុមមួយ ត្រូវបានគេហៅផ្សេងៗគ្នាក្នុងបរិបទផ្សេងៗគ្នាដែរ រួមមានដូចជា «បញ្ហាសកម្មភាពរួម» «ការជិះសេះលែងដៃ» «ការចែករម្លែកបន្ទុក» «សោកនាដ្យកម្មសមូហភាព» ឬ «ល្បែងទ្វេគ្រោះរបស់អ្នកទោស»។ សម្រាប់ករណីទូទៅ យើងនឹងប្រើប្រាស់ឃ្លា «**បញ្ហាផលប្រយោជន៍រួម**» ដើម្បីសំដៅទៅលើ បញ្ហាក្នុងការបែងចែកផលប្រយោជន៍ ដល់សមាជិកទាំងអស់ នៅក្នុងក្រុម ដោយមិនគិតថាតើសមាជិកនោះបានរួមចំណែកឬក៏អត់។

ជាទូទៅ ផលប្រយោជន៍រួម មានភាពងាយស្រួលក្នុងការបែងចែកក្នុងចំណោមក្រុមតូចៗ ជាងនៅក្នុងក្រុមធំៗ។ នៅក្នុងក្រុមតូចណាមួយ ការបន្លំ (ឬ ការជិះសេះលែងដៃ) របស់សមាជិកណាម្នាក់ មិនងាយលាក់បាំងជិតនោះទេ ព្រោះបើនរណាម្នាក់មិនចូលរួមចំណែក វានឹងបង្កផលប៉ះពាល់ខ្លាំងទៅលើលទ្ធផលសមូហ

ភាពទាំងមូល និងមានភាពងាយស្រួលក្នុងការដាក់ទណ្ឌកម្មអ្នកបង្ក។ អត្ថប្រយោជន៍របស់ក្រុមតូចៗជួយ ពន្យល់ពីសារៈសំខាន់នៃប្រព័ន្ធមហាអំណាច ក្នុងកិច្ចការសន្តិសុខអន្តរជាតិ និងសារៈសំខាន់នៃប្រទេស G20 (ក្រុមប្រទេសមហាសេដ្ឋកិច្ចកំពូល ២០) ក្នុងបញ្ហាសេដ្ឋកិច្ច។

រូបថត ស្ត្រីប្តីស្លាប់យំសោកសង្រែង

ផលវិបាកនៃសង្គ្រាម

ទំនាក់ទំនងអន្តរជាតិ ជះឥទ្ធិពលលើជីវិតរបស់យើងតាមវិធីជាច្រើន។ នៅទីនេះ ប្រពន្ធថើបមឈូសប្តី នៅឯពិធីរំលឹកវិញ្ញាណក្ខន្ធរបស់គាត់។ ទាហានអាមេរិក Sgt. La David Johnson ត្រូវបានសម្លាប់ក្នុងប្រតិបត្តិការយោធាក្នុងប្រទេសនីហ្សេរីយ៉ាក្នុងឆ្នាំ ២០១៧។

បញ្ហាផលប្រយោជន៍រួមកើតឡើងក្នុងគ្រប់ក្រុមនិងគ្រប់សង្គមមនុស្ស ប៉ុន្តែ វាមានលក្ខណៈស្មុគស្មាញជាពិសេស ក្នុងកិច្ចការអន្តរជាតិ ដោយហេតុថា ក្នុងឆាកអន្តរជាតិគ្មានអាជ្ញាធរថ្នាក់កំពូលដូចជារដ្ឋាភិបាលពិភពលោក ដើម្បីអនុវត្តលើប្រជាជាតិណាមួយ អោយចាត់វិធានការណ៍ធានាអោយបាននូវផលប្រយោជន៍រួមនោះទេ។ ផ្ទុយទៅវិញ នៅក្នុងនយោបាយក្នុងស្រុកនៅក្នុងប្រទេសទាំងឡាយ រដ្ឋាភិបាល អាចបង្ខំណាបុគ្គលណាម្នាក់ៗចូលរួមវិភាគទាន តាមមធ្យោបាយណាមួយ ដែលមិនបម្រើតែផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ពួកគេដូចជា ការបង់ពន្ធ ឬបង់ប្រាក់ ដំឡើងឧបករណ៍ប្រឆាំងការបំពុល នៅលើយានយន្តនិងក្នុងរោងចក្រនានា។ ប្រសិនបើបុគ្គលណាមួយនោះមិនអនុវត្តតាម រដ្ឋាភិបាលអាចដាក់ទណ្ឌកម្មពួកគេ។ ទោះបីដំណោះស្រាយនេះ មិនល្អឥតខ្ចោះ បុគ្គលបោកប្រាស់និងឧក្រិដ្ឋជន ពេលខ្លះ មិនត្រូវបានចាប់ខ្លួនក៏ដោយ ហើយពេលខ្លះទៀត រដ្ឋាភិបាលរំលោភអំណាច ជាទូទៅ វាដំណើរការបានល្អគ្រប់គ្រាន់ ដើម្បីរក្សាសង្គមអោយបន្តនិរន្តរភាព។

គោលការណ៍ជាមូលដ្ឋានចំនួនបី ដែលត្រូវហៅថា គោលការណ៍គ្រប់គ្រង, គោលការណ៍បដិការ និងគោលការណ៍អត្តសញ្ញាណ អាចផ្តល់ជាដំណោះស្រាយបញ្ហាស្នូល ដ៏សមស្រប ដើម្បីអោយបុគ្គលនីមួយៗ សហការចូលរួមសម្រេចបាននូវផលប្រយោជន៍រួម ដោយមិនចាំបាច់មានអាជ្ញាធរកណ្តាលចាប់បង្ខំអោយពួកគេធ្វើ (សូមមើលតារាង១.១)។ គោលការណ៍ទាំងបីនេះ គឺជាមូលដ្ឋានគ្រឹះ នៅក្នុងវិទ្យាសាស្ត្រសង្គមនិងលេចឡើង ជាញឹកញាប់ក្នុងមុខវិជ្ជាផ្សេងទៀត ដូចជា សង្គមសត្វ ការលូតលាស់របស់កុមារ ចិត្តវិទ្យាសង្គម និងសេដ្ឋកិច្ច ក៏ដូចជាវិទ្យាសាស្ត្រនយោបាយផងដែរ។ ដើម្បីពន្យល់គោលការណ៍នីមួយៗ យើងនឹងលើកឡើងនូវឧទាហរណ៍នៃអនុវត្តគោលការណ៍ទាំងបីក្នុងក្រុមមនុស្សមួយក្តាប់តូច និងក្នុងទំនាក់ទំនងអន្តរជាតិ។

គោលការណ៍គ្រប់គ្រង

គោលការណ៍គ្រប់គ្រងដោះស្រាយបញ្ហាផលប្រយោជន៍រួម ដោយបង្កើតឋានានុក្រមអំណាចដែលអ្នកនៅគ្រប់គ្រងនៅលើកំពូលគ្រប់គ្រងអ្នកនៅខាងក្រោមហាក់ដូចរដ្ឋាភិបាលដែរប៉ុន្តែ គ្មានរដ្ឋាភិបាលពិតប្រាកដនោះទេ។ ជំនួសអោយការប្រយុទ្ធប្រឆាំងគ្នា ដណ្តើមធនធានកម្រ ជានិច្ចជាកាល សមាជិកនៃក្រុមនេះ គ្រាន់តែប្រយុទ្ធគ្នា ម្តងម្កាល ដណ្តើមតួនាទីក្នុង«ឋានានុក្រមអំណាច»។ បន្ទាប់មក ជម្លោះក្នុងសង្គម ដូចជាអ្នកដែលត្រូវទទួលបានធនធានកម្រទាំងនោះអាចត្រូវបានដោះស្រាយ ដោយស្ម័យប្រវត្តិដោយផលប្រយោជន៍បានទៅលើតួអង្គដែលមានអំណាចឬឋានៈខ្ពស់ជាង។ ការប្រកួតប្រជែងដណ្តើមតួនាទីគ្រប់គ្រង ត្រូវបានកំណត់ដោយច្បាប់ទម្លាប់ ដែលអាចកាត់បន្ថយ ការបង្កគ្រោះថ្នាក់ចំពោះសមាជិកក្រុម បានមួយកម្រិតដែរ។ សកម្មភាពនិងកាយវិការជានិមិត្តរូបក្នុងការព្រមចុះញ៉ម និងការគ្រប់គ្រង ពង្រឹងប្រព័ន្ធឋានានុក្រមអំណាច

ក្នុងស្ថានភាពបច្ចុប្បន្ន។ ការបន្តស្ថិតនៅលើកំពូលនៃប្រព័ន្ធហានានុក្រមអំណាច មិនអាស្រ័យលើកម្លាំងតែមួយមុខគត់នោះទេ ទោះបីជាវាអាចជួយរក្សាបានក៏ដោយ។ ផ្ទុយទៅវិញ តួអង្គកំពូលអាចជាអ្នកចេះសម្របសម្រួលពូកែបំផុត ក្នុងការបង្កើតនិងថែរក្សាសម្ព័ន្ធភាព ក្នុងចំណោមសមាជិក ដែលមានសមត្ថភាពខ្ពស់នៅក្នុងក្រុម។ គោលការណ៍គ្រប់គ្រងមានភាពស្មុគស្មាញ ហើយមិនមែនត្រឹមតែជាបញ្ហានៃកម្លាំងមុតស្រួចប៉ុណ្ណោះទេ។

នៅក្នុងទំនាក់ទំនងអន្តរជាតិ គោលការណ៍គ្រប់គ្រងឆ្លុះបញ្ចាំងពីប្រព័ន្ធមហាអំណាច ដែលក្នុងនោះប្រទេសមួយក្តាប់តូច ជាអ្នកកំណត់ច្បាប់សម្រាប់ប្រទេសដទៃទៀត។ ជួនកាល អ្វីដែលគេហៅថាប្រទេសអនុត្តរភាព (Hegemon) ឬ ប្រទេមហាអំណាចកំពូល (Superpower) ឈរនៅលើកំពូលមានអំណាចខ្លាំងដែលជាប្រទេសលេចធ្លោលើសគេ។ ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ដែលប្រទេសមហាអំណាចយោធាទាំងប្រាំ នៅលើពិភពលោក មានសិទ្ធិវេតូ អាចឆ្លុះបញ្ចាំងពីគោលការណ៍គ្រប់គ្រងនេះ។

អត្ថប្រយោជន៍នៃដំណោះស្រាយបញ្ហាផលប្រយោជន៍រួម ដោយគោលការណ៍គ្រប់គ្រង គឺថា ដូចជារដ្ឋាភិបាលដែរ វាបង្ខំសមាជិកក្រុមទាំងអស់ អោយចូលរួមវិភាគទានដើម្បីផលប្រយោជន៍រួម។ វាក៏កាត់បន្ថយជម្លោះបើកចំហនៅក្នុងក្រុម ជាអប្បបរមា។ ទោះយ៉ាងណា គុណវិបត្តិ គឺថាស្ថិរភាពនេះអាចបណ្តាលអោយមានការគាបសង្កត់ និងការអាក់អន់ចិត្ត ជាហូរហែរ ក្នុងចំណោមសមាជិកថ្នាក់ទាប នៅក្នុងហានានុក្រមអំណាច។ ដូចគ្នានេះផងដែរ ជម្លោះដណ្តើមតួនាទីកំពូលក្នុងប្រព័ន្ធ ហានានុក្រមអំណាចនេះអាចបង្កអន្តរាយដល់ស្ថិរភាព និងសុខុមាលភាពរបស់ក្រុម ដូចជា នៅពេលដែលការប្រកួតប្រជែងនាំអោយមានការប្រយុទ្ធធ្ងន់ធ្ងរ។ ក្នុងករណីមានទំនាក់ទំនងអន្តរជាតិ ប្រព័ន្ធមហាអំណាច និងអនុត្តរភាពនៃប្រទេសមហាអំណាចអាចផ្តល់នូវសន្តិភាពនិងស្ថេរភាពធៀប អស់រយៈពេលជាច្រើនទសវត្សរ៍ ប៉ុន្តែ ក្រោយមក អាចបណ្តាលអោយមានសង្គ្រាមខ្ទេចខ្ទាំ ក្នុងចំណោមប្រទេសមហាអំណាច។

គោលការណ៍បដិការ

គោលការណ៍បដិការដោះស្រាយបញ្ហាផលប្រយោជន៍រួម ដោយការឆ្លើយតបជាក់ស្តែង ដូចជាផ្តល់រង្វាន់លើកទឹកចិត្តចំពោះឥរិយាបទដែលរួមចំណែកដល់ប្រយោជន៍ក្រុម និងដាក់ទណ្ឌកម្មចំពោះឥរិយាបទដែលគិតតែផលប្រយោជន៍ផ្ទាល់ខ្លួន ដោយមិនគិតពីឬធ្វើអោយប៉ះពាល់ដល់ផលប្រយោជន៍ក្រុម។ គោលការណ៍បដិការងាយស្រួលយល់ណាស់ ហើយអាចងាយស្រួល«ពង្រឹងការអនុវត្ត» ដោយមិនចាំបាច់មានអំណាចឬអាជ្ញាធរថ្នាក់កណ្តាល ដែលធ្វើអោយវាក្លាយជាមធ្យោបាយរឹងមាំ ដើម្បីធ្វើអោយបុគ្គលម្នាក់ៗសហការដើម្បីសម្រេចបានផលប្រយោជន៍រួម។

ប៉ុន្តែ គោលការណ៍បដិការផ្តល់ទាំងផលវិជ្ជមានផង («អ្នកអេះខ្នងអោយខ្ញុំ, ខ្ញុំនឹងអេះខ្នងអោយអ្នកដែរ») និងផលអវិជ្ជមានផង («ឈាមសងដោយឈាម»)[9]។ គុណវិបត្តិនៃការប្រើប្រាស់គោលការណ៍បដិការសម្រាប់ដោះស្រាយ បញ្ហាផលប្រយោជន៍រួម គឺថាវាអាចបណ្តាលអោយមានវដ្តនៃការសងសឹកនិងដាក់ទោសគ្នា ទៅវិញទៅមក មិនចេះឈប់ឈរ។ ជាលក្ខណៈចិត្តសាស្ត្រ មនុស្សភាគច្រើនអោយតម្លៃចេតនាល្អរបស់ពួកគេ ខ្ពស់ពេក និងមើលស្រាលតម្លៃនៃសកម្មភាពរបស់គូប្រជែងឬគូបដិបក្ខរបស់ពួកគេ។ ដើម្បីចៀសវាង

[9] Robert Aitkin Bertram(១៨៨៥). A Homiletic Encyclopaedia of Illustrations in Theology and Morals, ៣e. Published by Funk & Wagnalls.

ការសងសឹកនាំអោយស្ថានការណ៍កាន់តែធ្លាក់ដុនដាប ភាគីម្ខាងឬទាំងពីរ ត្រូវតែធ្វើសកម្មភាពសប្បុរសធម៌ ដើម្បីឈានទៅរកទំនាក់ទំនងវិជ្ជមាន ប្រកបដោយស្មារតីសហប្រតិបត្តិការល្អនឹងគ្នា។

ក្នុងទំនាក់ទំនងអន្តរជាតិ គោលការណ៍បដិការបានបង្កើតឡើងនូវមូលដ្ឋានគ្រឹះនៃបទដ្ឋានភាគច្រើន (ទម្លាប់ឬការរំពឹងទុក) និងស្ថាប័ននានានៅក្នុងប្រព័ន្ធអន្តរជាតិ។ ការរៀបចំភាគច្រើន នៅក្នុងទំនាក់ទំនងអន្តរជាតិ ដូចជាកិច្ចព្រមព្រៀងរបស់អង្គការពាណិជ្ជកម្មពិភពលោកទទួលស្គាល់យ៉ាងច្បាស់ថា គោលការណ៍បដិការគឺជាស្នូលនៃកិច្ចសហប្រតិបត្តិការ។ ជាឧទាហរណ៍ ប្រសិនបើប្រទេសមួយបើកទីផ្សាររបស់ខ្លួន អោយប្រទេសផ្សេងនាំទំនិញចូល ជាថ្នូរមកវិញ ប្រទេសនោះនឹងបើកទីផ្សាររបស់ខ្លួន អោយគេនាំទំនិញចូលមកដែរ។ បើគិតពីផលអវិជ្ជមាន គោលការណ៍បដិការក៏ជំរុញអោយមានការប្រណាំងអាវុធផងដែរ ព្រោះថាភាគីនីមួយៗនឹងឆ្លើយតបទៅតាមភាគីម្ខាងទៀត។ ប៉ុន្តែ វាក៏អនុញ្ញាតអោយមានកិច្ចព្រមព្រៀងគ្រប់គ្រងអាវុធ និងវិធានការណ៍ដោះស្រាយវិវាទមួយជំហានម្តងៗ ខណៈពេលដែលភាគីទាំងពីរថយក្រោយម្នាក់មួយជំហាន ចេញពីកំសួលសង្គ្រាម។

រូបថត ទូកនេសាទច្រើនសន្ធឹកសន្ធាប់

ត្រីច្រើននៅសមុទ្រ ?

ផលប្រយោជន៍រួម ដូចជាផលផលសកលដែលមានហុចផលល្អ ពឹងផ្អែកលើសមាជិកក្រុមដែលសហការគ្នាដើម្បីរក្សាផលល្អ។ ទោះបីជាយ៉ាងណាក៏ដោយ ខណៈពេលដែលសមាជិកចង់ការពារផលល្អរួមពួកគេក៏មានការលើកទឹកចិត្តផ្ទាល់ខ្លួន ក្នុងការប្រើប្រាស់ជ្រុលហួសហេតុផងដែរ។ ទូកនេសាទមួយក្នុងចំណោមទូកនេសាទទាំងនេះ ដែលបានបង្ហាញនៅក្នុងកំពង់ផែចិនក្នុងឆ្នាំ ២០១៨ ប្រហែលជាចង់ចាប់ត្រីបន្ថែមមួយចំនួន ដោយគិតថាការបន្ថែមពីរបីរបស់ពួកគេនឹងមិនមានបញ្ហាអ្វីនោះទេ។ ប៉ុន្តែប្រសិនបើទូកទាំងអស់នេះប្រកាន់យកឥរិយាបថនោះ លទ្ធផលគឺការនេសាទលើសកំណត់។ ដូច្នេះទូកត្រូវសហការគ្នាការពារស្តុកត្រី(រួម)។ ក្នុងបញ្ហាជាច្រើនដូចជាការឡើងកំដៅផែនដី សហគមន៍អន្តរជាតិនៃប្រជាជាតិនានាក៏មានការពឹងពាក់គ្នាដូចគ្នា។ ទោះជាយ៉ាងណាក៏ដោយ ការផ្តល់ផលប្រយោជន៍រួមបង្ហាញពីបញ្ហាលំបាក នៅពេលដែលតួអង្គនីមួយៗស្វែងរកការបង្កើនចំណែកផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ពួកគេ។

គោលការណ៍អត្តសញ្ញាណ

ដំណោះស្រាយបញ្ហាផលប្រយោជន៍រួម ដ៏មានសក្តានុពលទីបី ពាក់ព័ន្ធនឹងអត្តសញ្ញាណរបស់តួអង្គដែលជាសមាជិកសហគមន៍។ ទោះបីជាគោលការណ៍គ្រប់គ្រងនិងបដិការប្រព្រឹត្តទៅដោយឈរលើ គំនិតនៃការសម្រេចបាននូវផលប្រយោជន៍ផ្ទាល់ខ្លួន (ដោយទទួលយកនូវអ្វីដែលអ្នកអាចយកបាន ឬដោយការរៀបចំអោយមានផលប្រយោជន៍ទៅវិញទៅមក) គោលការណ៍អត្តសញ្ញាណមិនពឹងផ្អែកលើផលប្រយោជន៍ផ្ទាល់ខ្លួនឡើយ។ ផ្ទុយទៅវិញ សមាជិកសហគមន៍ណាមួយ យកចិត្តទុកដាក់ខ្លាំងចំពោះផលប្រយោជន៍រួមឬអ្នកផ្សេងទៀត នៅក្នុងសហគមន៍នោះ រហូតដល់សុខចិត្តលះបង់ផលប្រយោជន៍ផ្ទាល់ខ្លួន ដើម្បីផ្តល់ផលប្រយោជន៍ដល់អ្នកដទៃ។ ឫសគល់នៃគោលការណ៍នេះ កើតចេញពីក្រុមគ្រួសារ បងប្អូនជីដូនមួយ ឬ សាច់ញាតិជិតឆ្ងាយផ្សេងទៀត។ ប៉ុន្តែ សក្តានុពលនេះ មិនកំណត់ត្រឹមតែក្រុមគ្រួសារជិតស្និទ្ធនោះទេ។ វាអាចត្រូវបានអនុវត្ត ជាទូទៅ នៅក្នុងសហគមន៍ផ្សេងៗ ដែលតួអង្គមានមនោសញ្ចេតនាគិតថាខ្លួនជាសមាជិកម្នាក់ក្នុងសហគមន៍នោះ។ ដូចដែលសមាជិកក្រុមគ្រួសារយកចិត្តទុកដាក់ថែទាំគ្រួសារ សមាជិកនៃក្រុមជាតិពន្ធុ

ណាមួយ ក្រុមយេនឌ័រណាមួយ ប្រជាជាតិណាមួយ ឬសហគមន៍អ្នកវិទ្យាសាស្ត្រនៅពិភពលោក ក៏មានមនោសញ្ចេតនាយកចិត្តទុកដាក់ចំពោះគ្នាផងដែរ។ ក្នុងករណីនីមួយៗ សមាជិកម្នាក់ៗសុខចិត្តទទួលយកដំណោះស្រាយចំពោះបញ្ហាផលប្រយោជន៍រួម បើទោះបីពួកគេ ម្នាក់ៗ មិនទទួលបាននូវផលប្រយោជន៍ច្រើនបំផុតក៏ដោយ ដោយហេតុថា ផលប្រយោជន៍បានទៅដល់ «ក្រុមគ្រួសារទាំងមូល»។ ជីវិទូដែលបានចូលនិវត្តន៍ នៅឯសាកលវិទ្យាល័យអាមេរិកដែលធូរធារខ្លាំង អាចនឹងផ្តល់គ្រឿងបរិក្ខារមន្ទីរពិសោធន៍ដល់ជីវិទូនៅក្នុងប្រទេសក្រីក្រ ក៏ព្រោះតែពួកគេកត់សំគាល់អត្តសញ្ញាណរួមគ្នា ក្នុងនាមជាអ្នកវិទ្យាសាស្ត្រ។ ជនជាតិជ្វីហ្វនៅអឺរ៉ុបម្នាក់ អាចផ្តល់ប្រាក់ដល់ប្រទេសអ៊ីស្រាអែល ដោយសារតែអត្តសញ្ញាណរបស់ជនជាតិជ្វីហ្វដូចគ្នា ឬអ្នកវិទ្យាសាស្ត្រកុំព្យូទ័រមកពីប្រទេសឥណ្ឌាអាចនឹងវិលត្រឡប់ទៅមាតុប្រទេសខ្លួនវិញ ក្រោយទទួលបានការបណ្តុះបណ្តាលនៅប្រទេសកាណាដា ដើម្បីជួយសហគមន៍ដែលគាត់ខ្វល់ខ្វាយ។ មនុស្សរាប់លាននាក់បានចូលរួមចំណែកក្នុងមូលនិធិអន្តរជាតិ ផ្តល់ជំនួយសង្គ្រោះគ្រោះមហន្តរាយ បន្ទាប់ពីរលកយក្សសូណាមិ គ្រោះរញ្ជួយដី ឬខ្យល់ព្យុះ ដោយសារតែអត្តសញ្ញាណរួមគ្នាក្នុងនាមជាសមាជិកសហគមន៍មនុស្សលោកដូចគ្នា។

នៅក្នុងទំនាក់ទំនងអន្តរជាតិ (IR) អត្តសញ្ញាណសហគមន៍ មានតួនាទីសំខាន់ក្នុងការជំនះបញ្ហាផលប្រយោជន៍រួម ដ៏ស្មុគស្មាញ ដូចជាបញ្ហាថា តើនរណាត្រូវរួមចំណែកដល់ជំនួយអភិវឌ្ឍន៍ សុខភាពពិភពលោក និងបេសកកម្មថែរក្សាសន្តិភាព របស់អង្គការសហប្រជាជាតិ។ ការចូលរួមចំណែកក្នុងជំនួយបរទេសដ៏ធំធេងរបស់បណ្តាប្រទេសស្កង់ឌីណាវ ឬការចូលរួមខ្ពស់របស់ប្រទេសកាណាដា មិនអាចពន្យល់ថាមកពីផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ប្រទេសទាំងនេះទេ ប៉ុន្តែ វាបានកើតចេញពីអត្តសញ្ញាណរួមដែលពួកគេកំណត់ដោយខ្លួនឯង ក្នុងនាមជាសមាជិកសហគមន៍អន្តរជាតិ។ សូម្បីតែនៅក្នុងកងកំលាំងយោធានិងការទូត (ដែលគោលការណ៍គ្រប់គ្រងនិងបដិការមានឥទ្ធិពលក៏ដោយ) ការកំណត់អត្តសញ្ញាណរួមក្នុងនាមជាអ្នកជំនាញយោធានិងអ្នកការទូត (ដែលម្នាក់ៗមានប្រពៃណីនិងបំណងប្រាថ្នាដូចគ្នា) ជួនកាល អាចបញ្ចៀសជម្លោះផងដែរ។ ហើយសម្ព័ន្ធភាពយោធាក៏លាយឡំនូវនយោបាយផ្អែកលើអត្តសញ្ញាណ ជាមួយនឹងផលប្រយោជន៍រួមដូចដែលត្រូវបានឆ្លុះបញ្ចាំង សម្ព័ន្ធភាពប្រពៃណីវិសាមញ្ញរបស់សហរដ្ឋអាមេរិក-ចក្រភពអង់គ្លេស ដែលប្រយោជន៍រួមតែម្យ៉ាង មិនអាចពន្យល់បានច្បាស់ដូចការពន្យល់ដោយគោលការណ៍ អត្តសញ្ញាណរួមឡើយ។

តួអង្គមិនមែនជារដ្ឋមួយចំនួន ដូចជា អង្គការក្រៅរដ្ឋាភិបាល(IGOs) ឬបណ្តាញភេរវករ នៅក្នុងកម្រិតណាមួយ ក៏ពឹងផ្អែកលើនយោបាយអត្តសញ្ញាណផងដែរ។ ជាឧទាហរណ៍ ការកើនឡើងនៃតួនាទីរបស់តួអង្គទាំងនេះដូចជាអង្គការស្ត្រីនិយម បណ្តាញព្រះវិហារ ក្រុមជីហាដនិយមនិងសាជីវកម្មពហុជាតិ(MNCs) បានបណ្តាលអោយគោលការណ៍អត្តសញ្ញាណលេចធ្លោជាង មុននៅក្នុងទ្រឹស្តីទំនាក់ទំនងអន្តរជាតិ ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ។

ឧទាហរណ៍ក្នុងជីវភាពប្រចាំថ្ងៃ

ដើម្បីសង្ខេបគោលការណ៍ស្នូលទាំងបី ចូរស្រមៃថាអ្នកមានមិត្តភក្តិពីរនាក់ ប្រុសម្នាក់និងស្រីម្នាក់ដែលកំពុងមានទំនាក់ទំនងស្នេហានឹងគ្នា។ អ្នកទាំងពីរស្រឡាញ់គ្នាណាស់ និងសប្បាយរីករាយពេលបាននៅជាមួយគ្នា ប៉ុន្តែពួកគេបានមករកអ្នកអោយជួយដោះស្រាយបញ្ហាមួយ៖ នៅពេលពួកគេចេញទៅក្រៅ ប្រុសជា

សង្សាចូលចិត្តទៅមើលកុនខាងស្រីចូលចិត្តទៅដើរផ្សារ[២]។ ដោយសារអ្នកបានសិក្សាអំពីទំនាក់ទំនងអន្តរជាតិ អ្នកយល់ភ្លាមថា នេះជាបញ្ហាផលប្រយោជន៍រួម ក្នុងនោះផលប្រយោជន៍រួមគឺជាការចំណាយពេលជាមួយគ្នា ចំណែកផលប្រយោជន៍បុគ្គលដ៏ចំរូងចំរាស់គឺ ការមើលកុន និងការដើរផ្សារ។ ជាការពិតណាស់ អ្នកដឹងថា ឥរិយាបថរបស់រដ្ឋ មានលក្ខណៈស្មុគស្មាញជាងបុគ្គលម្នាក់ៗ ប៉ុន្តែអ្នកត្រូវទុកភាពខុសគ្នានេះមួយឡែកសិន។ អ្នកអាចនឹងសាកល្បងដោះស្រាយបញ្ហានេះ តាមរបៀបណាមួយ ក្នុងចំណោមបីខាងក្រោម។

ជាបឋម អ្នកអាចនិយាយថា «តាមប្រពៃណី ទំនាក់ទំនងប្រព្រឹត្តទៅដោយរលូននៅពេលដែល*មនុស្សប្រុសស្លៀកខោ*។ អស់រយៈពេលរាប់ពាន់ឆ្នាំមកហើយ មនុស្សប្រុសជាអ្នកធ្វើការសម្រេចចិត្ត ចំណែកស្ត្រីចាំតែធ្វើតាម។ ខ្ញុំស្នើអោយអ្នកទាំងពីរធ្វើតាមហ្នឹងទៅ ហើយទិញសំបុត្រកុនមើលរឿងល្បីៗដែលទើបចេញថ្មីៗ។» នេះជាដំណោះស្រាយតាមគោលការណ៍គ្រប់គ្រង។ វាអាចជាដំណោះស្រាយមួយដែលមានស្ថេរភាព ប្រសិនបើភាគីខាងស្រីអោយតម្លៃលើការចំណាយពេលជាមួយគូរស្នេហ៍ពិតរបស់នាង ជាជាងការមើលកុនឬការដើរផ្សារ។ វាអាចជាដំណោះស្រាយដ៏សាមញ្ញមួយ ដែលអាចនឹងដោះស្រាយរាល់ជម្លោះនានា នាពេលអនាគត។ បែបនេះ ភាគីម្ខាងទទួលបាននូវអ្វីគ្រប់យ៉ាងតាមចិត្តចង់បាន ចំណែកភាគីម្ខាងទៀតទទួលបានខ្លះដែរ (ស្នេហា ការចំណាយពេលផ្អែមល្ហែមនៅជាមួយគ្នា និងទំនាក់ទំនងមានស្ថេរភាព)។ ប្រហែលវាអាចជាការប្រសើរសម្រាប់ពួកគេទាំងពីរនាក់ ជាជាងការចំណាយតិចតួចដើម្បីតែឈ្លោះប្រកែកគ្នាថាត្រូវទៅណា។ ដោយឡែក ដំណោះស្រាយនេះអាចធ្វើអោយភាគីខាងស្រីមានការតូចចិត្តស្អិតដើមទ្រូង និងមានអារម្មណ៍នៅក្នុងចិត្តថាវាហាក់ដូចជាអយុត្តិធម៌ចំពោះខ្លួនពេកហើយ។ នាងប្រហែលជាមានអារម្មណ៍ថា ក្តីស្រលាញ់របស់ខ្លួនចំពោះគូសង្សារអាចនឹងរសាត់បាត់បង តាមពេលវេលា ដោយទន្ទឹងរង់ចាំការអោយតម្លៃ ចំពោះខ្លួន និងការអន្ទះអន្ទែងចង់ដើរផ្សារ។ នាងថែមទាំងអាចជួបបុរសផ្សេងដែលចូលចិត្តនាង និងចូលចិត្តឡើងផ្សារផងដែរ។

ជំរើសទីពីរ អ្នកអាចនិយាយថា «ណែសាកគិតមើល ជាជាងឈ្លោះប្រកែកគ្នាគ្រប់ពេល ម៉េចក៏អ្នកទាំងពីរមិនព្រមរៀបកាលវិភាគមួយ ម្តងទៅមើលកុន ម្តងទៀតទៅដើរផ្សារទៅ?»។ នេះ គឺជាដំណោះស្រាយតាមគោលការណ៍បដិការ។ អ្នកអាចជួយគូស្នេហ៍ទាំងពីររៀបចំកិច្ចព្រមព្រៀង, ប្រព័ន្ធគណនេយ្យ, និងការរំពឹងរួម ដើម្បីគ្រប់គ្រងការអនុវត្តដំណោះស្រាយដ៏សាមញ្ញនេះ។ ជាឧទាហរណ៍ ពួកគេអាចទៅដើរផ្សារនៅយប់ថ្ងៃសុក្រ និងមើលកុននៅយប់ថ្ងៃសៅរ៍។ ប៉ុន្តែ ចុះបើរដូវកាលមើលកុនរឿងល្បីណាមួយ មានរយៈកាលខ្លីជាងរដូវដើរផ្សារ? ដូច្នេះ ប្រហែលជាពួកគេត្រូវ ទៅមើលកុនអោយបានញឹកញាប់ ក្នុងរដូវកាលរបស់វា ហើយដើរផ្សារអោយបានញឹកញាប់ជាង នៅពេលចប់រដូវកាលមើលកុន។ តើមានអ្វីកើតឡើង ប្រសិនបើភាគីខាងណាមួយ ក្នុងចំណោមពួកគេ ត្រូវចុះបេសកកម្មចុះខេត្ត នៅយប់ថ្ងៃសុក្រ? តើរាត្រីនោះរាប់បញ្ចូលដែរឬទេ ឬត្រូវរក្សាទុកសម្រាប់ពេលក្រោយ? ឬ តើភាគីដែលនៅក្នុងក្រុង ចេញទៅដើរផ្សារតែម្នាក់ឯង? តើមានអ្វីកើតឡើង ប្រសិនបើភាគីខាងប្រុសនោះ*ស្អប់*ការដើរផ្សារទិញឥវ៉ាន់ ប៉ុន្តែភាគីខាងស្រីគ្រាន់តែមិនសូវចូលចិត្តមើលកុនទៅវិញ? តើអ្នករៀបចំកាលវិភាគមើលកុនចំនួនពីរដងផង ហើយដើរផ្សារតែមួយដងផងដើម្បីអោយភាគីទាំងសង្ខាង សោមនស្សឬទោមនស្ស ដូចៗគ្នា? ច្បាស់ណាស់ ដំណោះស្រាយតាមគោលបដិការអាចមាន

[២] សេណារីយ៉ូនេះត្រូវបានកែសម្រួលពីឧទាហរណ៍ទ្រឹស្តីហ្គេម «សមរភូមិភេទ» ។

ភាពស្មុគស្មាញយ៉ាងខ្លាំង (ចូរមើលច្បាប់ពាណិជ្ជកម្មពិភពលោក ក្នុងមេរៀនទី ៨) ហើយពួកគេត្រូវការយន្តការត្រួតពិនិត្យជាប្រចាំ ដើម្បីធានាថា ភាគីទាំងពីរបំពេញកាតព្វកិច្ចរបស់ខ្លួន និងមិនគេចវេស។ មិត្តភក្តិរបស់អ្នកប្រហែលជាមួម៉ៅក្នុងទំនាក់ទំនងរបស់ពួកគេ ក្នុងការតាមដានមើលយប់ណាត្រូវទៅមើលកុនឬក៏យប់ណាត្រូវទៅដើរផ្សារ។

ទីបី អ្នកអាចនិយាយថា «កុំទៅខ្វល់ថា ត្រូវទៅមើលកុនឬដើរផ្សារអី រឿងសំខាន់ គឺថាអ្នកទាំងពីរស្រឡាញ់គ្នា ហើយចង់នៅនៃបនិត្យជាមួយគ្នា។ ព្រងើយកន្តើយនឹងបញ្ហាអត់ប្រយោជន៍ហើយប្តូរមកពង្រឹងមនោសញ្ចេតនារួម ដែលនាំអោយអ្នកទាំងពីរត្រូវរ៉ូវគ្នា។ ពេលនោះទៅមើលកុនឬទៅដើរផ្សារ លែងសំខាន់ទៀតហើយ។» នេះនឹងជាដំណោះស្រាយតាមគោលការណ៍អត្តសញ្ញាណរួម។ វិធីសាស្ត្រនេះអាចដោះស្រាយការខ្វែងគំនិតគ្នារបស់មិត្តភ័ក្ត្រអ្នក បានយ៉ាងងាយ ហើយបណ្តាលអោយពួកគេទាំងពីរសប្បាយរីករាយជាង។ យូរៗទៅ ភាគីណាម្នាក់ អាចនឹងចាប់ផ្តើមចូលចិត្តសកម្មភាពដែលភាគីម្ខាងទៀតចូលចិត្តជាងគេ បន្ទាប់ពីបានចូលរួមកាន់តែច្រើនឡើង ដែលបណ្តាលអោយមានការផ្លាស់ប្តូរអត្តសញ្ញាណ។ ម៉្យាងវិញទៀត បន្ទាប់ពីផលប្រយោជន៍ផ្ទាល់ខ្លួន អាចនឹងចូលមកវិញ ដោយសារតែអារម្មណ៍ស្នេហា កាន់តែសប្បាយរីករាយ បើអាចដើរលេងផ្សារ (ឬមើលកុន) ដែលខ្លួនចូលចិត្តថែមទៀត។ ជាការពិត ភាគីម្ខាងអាចនឹងកេងចំណេញពីការសុខចិត្តមើលរំលងការទាស់ទែងខ្វែងគំនិតគ្នាលើរឿងអត់ប្រយោជន៍របស់ភាគីម្ខាងទៀត។ នាងនិយាយថា «គ្មានបញ្ហាអ្វីធំដុំទេ ដរាបណាយើងនៅជាមួយគ្នា» «ហើយ អូ មើលណ៎ា យប់នេះមានការកម្សាន្តពិសេសនៅផ្សារទំនើប។» ពេលខ្លះគោលការណ៍អត្តសញ្ញាណប្រព្រឹត្តទៅយ៉ាងខ្លាំងក្លា ក្នុងមួយរយៈពេលខ្លីក្នុងរយៈពេលយូរទៅៗ អាចនឹងថមថយវិញ៖ ទាហានដែលបានស្ម័គ្រចិត្តការពារជាតិមាតុភូមិ ប្រហែលជាចាប់ផ្តើមមានអារម្មណ៍ថាគេកេងចំណេញលើខ្លួន ក្នុងរយៈកាលប៉ុន្មានខែក្រោយមក ឬប៉ុន្មានឆ្នាំក្រោយខ្លួនឈរជើងនៅសមរភូមិមុខ ឬនិស្សិតមហាវិទ្យាល័យអាមេរិក ដែលបរិច្ចាគប្រាក់ម្តងដល់ ជនរងគ្រោះដោយព្យុះរលកយក្សស៊ូណាមិ ប្រហែលជាលែងចង់បន្តបរិច្ចាគ ពីមួយឆ្នាំទៅមួយឆ្នាំ ដល់ជនរងគ្រោះដោយជំងឺគ្រុនចាញ់ទៀតឡើយ។

ឧទាហរណ៍ក្នុងទំនាក់ទំនងអន្តរជាតិ

ឥឡូវនេះ ចូរសាកល្បងគិតពិចារណាលើបញ្ហារីកសាយភាយអាវុធនុយក្លេអ៊ែរ។ ប្រទេសទាំងអស់ទទួលបានផលប្រយោជន៍រួមគ្នាពីសន្តិភាពនិងស្ថិរភាពដែលពិបាកនឹងសម្រេចបាន នៅក្នុងពិភពលោកដែលប្រទេសកាន់តែច្រើន ផលិតអាវុធនុយក្លេអ៊ែរ កាន់តែច្រើនឡើងៗ។ ប្រសិនបើបុគ្គលទាំងឡាយនៅក្នុងប្រទេសណាមួយ ទទួលបានអាវុធគ្រោះថ្នាក់ រដ្ឋាភិបាលអាចនឹងដកហូតអាវុធទាំងនោះទុក ដើម្បីរក្សាអោយមនុស្សគ្រប់គ្នាមានសុវត្ថិភាព។ ប៉ុន្តែ នៅក្នុងសង្គមប្រជាជាតិនានា គ្មានរដ្ឋអំណាចកណ្តាលបែបនេះទេ។ នៅឆ្នាំ ២០០៦ ប្រទេសកូរ៉េខាងជើង បានសាកល្បងគ្រាប់បែកនុយក្លេអ៊ែរលើកដំបូងរបស់ខ្លួន ហើយប្រទេសអ៊ីរ៉ង់ក៏បានបន្តបង្កើនល្បឿននិងបរិមាណកម្មវិធីចំរ៉ាញ់សារធាតុអ៊ុយរ៉ាញ៉ូម អស់រយៈពេលជាច្រើនឆ្នាំ ដែលអាចនាំអោយមានការបំផ្ទុះគ្រាប់បែកនុយក្លេអ៊ែរ ទង្វើប្រទេសទាំងពីរនេះប្រឆាំងនឹងដំណោះស្រាយរបស់អង្គការសហប្រជាជាតិ(អ.ស.ប.)។

គោលការណ៍មួយនៃការីកសាយអាវុធនុយក្លេអ៊ែរ ធ្វើអោយបណ្តាប្រទេសដែលមានឥទ្ធិពលបំផុតមួយចំនួន អាចកាន់កាប់អាវុធទាំងនោះ ដោយស្របច្បាប់។ «ប្រទេសមហាអំណាចទាំងប្រាំ» ដែលមានឃ្លាំង

អាវុធនុយក្លេអ៊ែរធំជាងគេ មានសិទ្ធិអំណាចវេតូ ក្នុងក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ (UNSC)។ តាមរយៈកិច្ចព្រមព្រៀងនានា ដូចជាសន្ធិសញ្ញាមិនរីកសាយភាយអាវុធនុយក្លេអ៊ែរ(NPT)និងគំនិតផ្តួចផ្តើមសន្តិសុខពាក់ព័ន្ធនឹងការរីកសាយភាយ ប្រទេសមហាអំណាចនុយក្លេអ៊ែរដែលមានស្រាប់ ព្យាយាមរក្សាការកាន់កាប់អាវុធទាំងនេះ ផ្តាច់មុខតែឯង និងរារាំងប្រទេសតូចៗមិនអោយផលិតវាបានឡើយ។ វិធីសាស្ត្រនេះគឺជាអនុលោមតាមគោលការណ៍គ្រប់គ្រង។ ក្នុងឆ្នាំ ២០០៣ នៅពេលដែលសហរដ្ឋអាមេរិក បានគិតថា លោក សាដាម ហ៊ូសេន (Saddam Hussein) របស់អ៊ីរ៉ាក់ អាចនឹងមានកម្មវិធីអាវុធនុយក្លេអ៊ែរដ៏សកម្ម ដូចដែលគាត់ធ្លាប់មាន កាលពីមួយទសវត្សរ៍មុន ពេលនោះសហរដ្ឋអាមេរិកបានលុកលុយប្រទេសអ៊ីរ៉ាក់ និងផ្តួលរំលំរដ្ឋាភិបាលហ៊ូសេន។ ស្រដៀងគ្នានេះដែរ នៅឆ្នាំ ១៩៨២ នៅពេលដែលប្រទេសអ៊ីរ៉ាក់បានចាប់ផ្តើមដំណើរការផលិតគ្រាប់បែកនុយក្លេអ៊ែរ ប្រទេសអ៊ីស្រាអែលបានបញ្ជូនយន្តហោះទៅទម្លាក់គ្រាប់បែកដើម្បីកំទេចរោងចក្រនុយក្លេអ៊ែររបស់អ៊ីរ៉ាក់ ដែលបណ្តាលអោយកម្មវិធីនោះត្រូវរាំងស្ទះនិងដើរថយក្រោយរាប់សិបឆ្នាំ។ គុណវិបត្តិមួយនៃដំណោះស្រាយតាមគោលការណ៍គ្រប់គ្រង គឺការអាក់អន់ចិត្ត ក្នុងចំណោមប្រទេសតូចៗ។ ប្រទេសទាំងនោះចង្អុលបង្ហាញពីបទប្បញ្ញត្តិនៃសន្ធិសញ្ញាមិនរីកសាយភាយ (NPT) ដែលមិនត្រូវបានអនុវត្តដែលបញ្ជាក់ថា ប្រទេសមហាអំណាចនុយក្លេអ៊ែរដែលមានស្រាប់គួរតែកំទេចគ្រាប់បែកផ្ទាល់ខ្លួនផងដែរ ក្នុងខណៈពេលខ្លួនហាមមិនអោយប្រទេសផ្សេងទៀតផលិត។ ហើយពួកគេសួរថា តើអ្វីដែលផ្តល់សិទ្ធិអោយប្រទេសអ៊ីស្រាអែលទម្លាក់គ្រាប់បែកលើប្រទេសមួយផ្សេងទៀត ឬ ផ្តល់សិទ្ធិអោយសហរដ្ឋអាមេរិកលុកលុយប្រទេសមួយទៀត។ ពួកគេចង្អុលបង្ហាញពីស្តង់ដារពីរសម្រាប់បញ្ហាដូចគ្នា មួយសម្រាប់ប្រទេសមហាអំណាច និងមួយទៀតសម្រាប់តែប្រទេសតូចតាចទន់ខ្សោយ។

គោលការណ៍បដិការផ្តល់នូវមធ្យោបាយមួយផ្សេងទៀត សម្រាប់រារាំងការរីកសាយភាយ។ វាគឺជាមូលដ្ឋាននៃបទប្បញ្ញត្តិនៅក្នុងសន្ធិសញ្ញាមិនរីកសាយភាយ(NPT) ស្តីអំពីកាតព្វកិច្ចនៃប្រទេសមហាអំណាចនុយក្លេអ៊ែរក្នុងការរំសាយអាវុធរបស់ខ្លួន ជាថ្នូរនឹងការព្រមព្រៀងរបស់ប្រទេសតូចៗមិនអភិវឌ្ឍកម្មវិធីអាវុធនុយក្លេអ៊ែរដែរ។ គោលការណ៍បដិការក៏ឆ្លុះបញ្ចាំងពីកិច្ចព្រមព្រៀងគ្រប់គ្រងអាវុធផងដែរ ដែលត្រូវបានប្រើយ៉ាងទូលំទូលាយក្នុងសង្គ្រាមត្រជាក់ដើម្បីគ្រប់គ្រងការផលិតគ្រាប់បែកនុយក្លេអ៊ែរ ដោយប្រទេសមហាអំណាច(Superpowers) និង ត្រូវបានប្រើ ក្នុងពេលបច្ចុប្បន្ន ដើម្បីគ្រប់គ្រងការកាត់បន្ថយឃ្លាំងអាវុធរបស់ពួកគេ។ យុទ្ធសាស្ត្រទប់ស្កាត់ (deterrence) ក៏ពឹងផ្អែកលើគោលការណ៍បដិការផងដែរ។ សហរដ្ឋអាមេរិកបានព្រមាន ប្រទេសកូរ៉េខាងជើង ក្នុងឆ្នាំ ២០០៦ មិនអោយលក់គ្រាប់បែករបស់ខ្លួន (សកម្មភាពដែលនឹងផ្តល់ផលប្រយោជន៍ រយៈពេលខ្លីសម្រាប់កូរ៉េខាងជើង) និងព្រមានសងសឹកនឹងប្រទេសកូរ៉េខាងជើងប្រសិនបើមានតួអង្គផ្សេងទៀតប្រើគ្រាប់បែកបែបនេះប្រឆាំងនឹងសហរដ្ឋអាមេរិក។ ហើយនៅពេលដែលប្រទេសលីប៊ីបានបោះបង់កម្មវិធីអាវុធនុយក្លេអ៊ែររបស់ខ្លួន ក្នុងឆ្នាំ ២០០៣, ជាថ្នូរមកវិញ សហគមន៍អន្តរជាតិបានផ្តល់រង្វាន់ជាច្រើន រួមទាំងការបញ្ចប់នៃការដាក់ទណ្ឌកម្មសេដ្ឋកិច្ចលើប្រទេសនេះផងដែរ។

គោលការណ៍អត្តសញ្ញាណ បានបង្ហាញថា វាក៏មានប្រសិទ្ធិភាពក្នុងការទប់ស្កាត់ការរីកសាយអាវុធនុយក្លេអ៊ែរ បើទោះជាវាមិនសូវគួរអោយកត់សម្គាល់ខ្លាំងក៏ដោយ។ ប្រជាជាតិជាច្រើនដែលមានសមត្ថភាពបច្ចេកទេសផលិតអាវុធនុយក្លេអ៊ែរ បានជ្រើសរើសមិនធ្វើវាទេ។ ពួកគេបានបង្កើតអត្តសញ្ញាណជាតិរបស់ពួកគេ ដោយបង្កើតផលប្រយោជន៍ជាតិរបស់ពួកគេ មិនពាក់ព័ន្ធនឹងការធ្វើគ្រាប់បែកនុយក្លេអ៊ែរ ពោលគឺ ការ

ផលិតអាវុធទាំងនេះមិនផ្តល់ប្រយោជន៍ឡើយ ផ្ទុយទៅវិញ បែរជាអាចនឹងបង្កគ្រោះមហន្តរាយ។ ប្រទេសខ្លះ ដូចជា ប្រទេសស៊ុយអែត មិនមានបំណងចង់ប្រយុទ្ធក្នុងសង្គ្រាមណាមួយឡើយ។ ប្រទេសផ្សេងទៀត ដូចជា ប្រទេសអាឡឺម៉ង់ស្ថិតក្នុងសម្ព័ន្ធភាពនានា ដែលពួកគេបានស្ថិតនៅក្រោមឆ័ត្រនុយក្លេអ៊ែររបស់ប្រទេសមួយ ផ្សេងទៀត ហើយមិនត្រូវការគ្រាប់បែកនុយក្លេអ៊ែរផ្ទាល់ខ្លួនទេ។ ប្រទេសអាហ្វ្រិកខាងត្បូងពិតជាបានបង្កើតអាវុធនុយក្លេអ៊ែរដោយសំងាត់ ប៉ុន្តែក្រោយមកបានរុះរើកម្មវិធីមុនពេលរបបអាប៉ាថេត(Apartheid)ត្រូវបានបញ្ចប់ ដើម្បីកុំអោយវាធ្លាក់នៅក្នុងដៃរបស់រដ្ឋាភិបាលថ្មី ដែលតំណាងអោយប្រជាជនភាគច្រើន។ គ្មាននរណាម្នាក់បានបង្ខំអោយប្រទេសអាហ្វ្រិកខាងត្បូងធ្វើបែបនេះទេ (ដូចនៅក្នុងគោលការណ៍គ្រប់គ្រង) ហើយក៏មិនបានឆ្លើយតបទៅនឹងការផ្តល់រង្វាន់និងការដាក់ទណ្ឌកម្មដែរ (ដូចនៅក្នុងគោលការណ៍បដិការ)។ ផ្ទុយទៅវិញ អត្តសញ្ញាណរបស់ប្រទេសអាហ្វ្រិកខាងត្បូង ត្រូវបានផ្លាស់ប្តូរ។ ស្រដៀងគ្នានេះដែរ បទពិសោធន៍របស់ប្រទេសជប៉ុន ដែលទទួលរងគ្រោះមហន្តរាយ ដោយសាររបបយោធានិយមរបស់ខ្លួន ត្រូវរងការបំផ្លាញទីក្រុងរបស់ខ្លួនចំនួនពីរដោយគ្រាប់បែកនុយក្លេអ៊ែរ ប៉ុន្មានជំនាន់ក្រោយមក បន្តអត្តសញ្ញាណរបស់ខ្លួន ក្នុងឋានៈជាប្រទេសមិនចង់បានអាវុធនុយក្លេអ៊ែរ ទោះបីជាប្រទេសនេះមានចំណេះដឹងជំនាញផលិតវានិងបើទោះបីជាពួកគេមានស្តុកភ្លុយតូញ៉ូមគ្រាប់គ្រាន់សម្រាប់ផលិតក៏ដោយ។

បញ្ហាផលប្រយោជន៍រួមធ្វើអោយភ្ញាក់ផ្អើលដល់អ្នកវិទ្យាសាស្ត្រសង្គម និង ជាពិសេសអ្នកប្រាជ្ញក្នុងមុខវិជ្ជាទំនាក់ទំនងអន្តរជាតិ ក៏ព្រោះពួកគេមិនមានដំណោះស្រាយងាយស្រួលដាងនេះទៀតទេ។ ក្នុងមេរៀនក្រោយៗ យើងនឹងឃើញថា គោលការណ៍ស្នូលទាំងបីនេះ មានឥទ្ធិពលយ៉ាងខ្លាំងលើការឆ្លើយតបរបស់សហគមន៍អន្តរជាតិ ចំពោះបញ្ហាផលប្រយោជន៍រួមជាច្រើន នៅក្នុងរាល់បញ្ហាទំនាក់ទំនងអន្តរជាតិទាំងអស់។

តារាង ១.១. គោលការណ៍ស្នូលសម្រាប់ដោះស្រាយបញ្ហាផលប្រយោជន៍រួម

គោលការណ៍	ផលវិជ្ជមាន	ផលអវិជ្ជមាន
គ្រប់គ្រង	សណ្តាប់ធ្នាប់ ស្ថេរភាព អាចស្មានបាន	ការគាបសង្កត់ អារម្មណ៍គុំគួន
បដិការ	លើកទឹកចិត្តសហការគ្នា	កាន់តែធ្ងន់ធ្ងរ ពិបាកតាមដាន
អត្តសញ្ញាណ	លះបង់ដើម្បីក្រុម ផលប្រយោជន៍ប្រែប្រួល	គេព្រួយគ្នាវាយប្រហារ

១.១.២. ទំនាក់ទំនងអន្តរជាតិក្នុងឋានៈជាមុខវិជ្ជាសិក្សាមួយ

ប្រាកដណាស់ ទំនាក់ទំនងអន្តរជាតិ គឺជាមុខវិជ្ជាយ៉ាងសាមញ្ញមួយ។ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងបណ្តាអ្នកប្រាជ្ញនៅមហាវិទ្យាល័យ សាកលវិទ្យាល័យ និងក្រុមអ្នកជំនាញ និងសហគមន៍បង្កើតគោលនយោបាយការបរទេសដែលធ្វើការអោយរដ្ឋាភិបាល ជាពិសេសនៅសហរដ្ឋអាមេរិក។ សាស្ត្រាចារ្យមួយចំនួនបម្រើការក្នុងរដ្ឋាភិបាល (ឧទាហរណ៍ សាស្ត្រាចារ្យវិទ្យាសាស្ត្រនយោបាយ លោកស្រី ឃុនដូលីហ្សា រ៉ាយស៍ (Condoleezza Rice) បានក្លាយជាទីប្រឹក្សាសន្តិសុខជាតិ ក្នុងឆ្នាំ ២០០១ និង ជារដ្ឋមន្ត្រីក្រសួងការបរទេសក្នុងឆ្នាំ ២០០៥ ក្រោមការដឹកនាំ របស់លោកប្រធានាធិបតី ចច ប៊ូស (George W. Bush) ហើយជួនកាលសាស្ត្រាចារ្យមួយចំនួនចែករម្លែកទស្សនៈពួកគេអំពីគោលនយោបាយការបរទេសជាសាធារណៈ តាមរយៈការបោះពុម្ពក្នុងកាសែត ឬផ្តល់ការសំភាសន៍ក្នុងកញ្ចក់ទូរទស្សន៍។ ការជះឥទ្ធិពលលើគោលនយោបាយការបរទេសរបស់រដ្ឋាភិបាលពួកគេ ហាក់ដូចជាផ្តល់ឱកាសអោយអ្នកប្រាជ្ញទាំងនេះនូវមន្ទីរពិសោធន៍ ដើម្បី

សាកល្បងគំនិតរបស់ពួកគេ នៅក្នុងការអនុវត្តជាក់ស្តែង។ អ្នកការទូត អ្នកការិយាធិបតេយ្យ និងអ្នកនយោបាយអាចទទួលបានអត្ថប្រយោជន៍ពីចំណេះដឹងដែលផលិតដោយអ្នកប្រាជ្ញទំនាក់ទំនងអន្តរជាតិ។

ការជជែកវែកញែកបែបទ្រឹស្តីនៅក្នុងវិស័យទំនាក់ទំនងអន្តរជាតិ គឺជាមូលដ្ឋានគ្រឹះ ប៉ុន្តែនៅមិនទាន់បានដោះស្រាយជាច់ស្រេចទេ។ វានឹងត្រូវសម្រេចដោយអ្នកប្រាជ្ញទំនាក់ទំនងអន្តរជាតិជំនាន់ក្រោយ(និស្សិតមហាវិទ្យាល័យបច្ចុប្បន្ន) ដើម្បីទទួលបានការយល់ដឹង កាន់តែច្បាស់អំពីរបៀប ដែលនយោបាយពិភពលោកដំណើរការ។ គោលដៅនៃសៀវភៅគោលនេះ គឺត្រូវបង្ហាញនូវចំណេះដឹងបច្ចុប្បន្ន ដោយមិនចាំបាច់និយាយបំផ្លើសពីភាពជោគជ័យនិងពេញនិយមនៃមុខវិជ្ជានេះ។

ជាផ្នែកមួយនៃវិទ្យាសាស្ត្រនយោបាយ ទំនាក់ទំនងអន្តរជាតិ(IR)បរិយាយអំពី*នយោបាយអន្តរជាតិ*៖ សេចក្តីសម្រេចចិត្តរបស់រដ្ឋាភិបាលអំពីតួអង្គបរទេស ជាពិសេសរដ្ឋាភិបាលជាតិដទៃទៀត។ យ៉ាងណាមុញ មុខវិជ្ជានេះមានលក្ខណៈពហុជំនាញ ដោយភ្ជាប់នយោបាយអន្តរជាតិនឹងសេដ្ឋកិច្ចវិទ្យា ប្រវត្តិវិទ្យា សង្គមវិទ្យា និងមុខវិជ្ជាឯទៀត។ សាកលវិទ្យាល័យមួយចំនួនផ្តល់ការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រ ឬដេប៉ាតឺម៉ង់ ដាច់ដោយឡែកសម្រាប់ទំនាក់ទំនងអន្តរជាតិ។ ទោះយ៉ាងណា សាលាជាច្រើនបង្រៀនមុខវិជ្ជាទំនាក់ទំនងអន្តរជាតិក្នុងថ្នាក់វិទ្យាសាស្ត្រនយោបាយ ដែលផ្តោតលើ*នយោបាយ*នៃទំនាក់ទំនងសេដ្ឋកិច្ច ឬ*នយោបាយ*នៃការគ្រប់គ្រងបរិស្ថាន។ ទាំងនេះគ្រាន់ជាឧទាហរណ៍ខ្លះៗប៉ុណ្ណោះ។ ទោះបីជាជាន់គ្នាជាមួយទំនាក់ទំនងអន្តរជាតិ នយោបាយក្នុងស្រុករបស់បរទេស ជាទូទៅ បង្កើតបានជាមុខវិជ្ជាដាច់ដោយឡែកមួយ ពោលគឺ*នយោបាយប្រៀបធៀប* ឬ*នយោបាយធៀប*។

ទំនាក់ទំនងនយោបាយរវាងប្រទេសនានា នៅលើពិភពលោក រួមបញ្ចូលសកម្មភាពជាច្រើនដូចជាការទូត សង្គ្រាម ទំនាក់ទំនងពាណិជ្ជកម្ម ការចង់សម្ព័ន្ធភាព ការផ្លាស់ប្តូរវប្បធម៌ ការចូលរួមក្នុងអង្គការអន្តរជាតិ និង អ្វីៗផ្សេងទៀត។ សកម្មភាពដោយឡែក នៅក្នុងវិស័យណាមួយ ក្នុងចំណោមវិស័យទាំងនេះ បង្កើតបានជា**វិស័យបញ្ហា**ផ្សេងៗ ដែលអ្នកសិក្សានិងអ្នកសម្របសម្រួលគោលនយោបាយការបរទេសផ្តោតការយកចិត្តទុកដាក់។ ឧទាហរណ៍នៃវិស័យបញ្ហារួមមាន ពាណិជ្ជកម្មពិភពលោក បរិស្ថាន និងជម្លោះណាមួយ ដូចជាជម្លោះរវាងអារ៉ាប់-អ៊ីស្រាអែល។ នៅក្នុងវិស័យបញ្ហានីមួយៗ និងក្នុងចំណោមបញ្ហាគួរអោយព្រួយបារម្ភ ក្នុងទំនាក់ទំនងអន្តរជាតិណាមួយ អ្នកបង្កើតគោលនយោបាយរបស់ប្រជាជាតិមួយ អាចមានអាកប្បកិរិយាចុះសម្រុង ឬប្រតិកិរិយា បានន័យថាគេបន្តអាកប្បកិរិយារួសរាយ ឬអមិត្ត ជាក់ប្រទេសផ្សេងទៀត។ ជារឿយៗ អ្នកប្រាជ្ញទំនាក់ទំនងអន្តរជាតិ ពិនិត្យមើលទំនាក់ទំនងអន្តរជាតិ ទាក់ទងនឹង**ជម្លោះនិងកិច្ចសហប្រតិបត្តិការ**(Conflict & Cooperation)ក្នុងទំនាក់ទំនងរវាងប្រជាជាតិនានា។

វិសាលភាពនៃវិស័យទំនាក់ទំនងអន្តរជាតិ ក៏អាចត្រូវបានកំណត់ ដោយមុខវិជ្ជាជាមែកធាង ដែលវារួមបញ្ចូលផងដែរ។ អ្នកប្រាជ្ញខ្លះចាត់ទុកប្រធានបទផ្សេងៗ ដូចចំណងមេរៀនក្នុងសៀវភៅនេះ (ឧទាហរណ៍ ច្បាប់អន្តរជាតិ ឬការអភិវឌ្ឍអន្តរជាតិ) ជាមែកធាងនៃមុខវិជ្ជានេះ ក៏ប៉ុន្តែ នៅទីនេះ យើងនឹងចាត់ទុកវាជាប្រធានបទកម្រិតម៉ាក្រូចំនួនពីរ។ តាមប្រពៃណី ទំនាក់ទំនងអន្តរជាតិបានផ្តោតលើបញ្ហាសង្គ្រាមនិងសន្តិភាព ដែលជាមែកធាងមួយនៃទំនាក់ទំនងអន្តរជាតិ គឺ**សន្តិសុខអន្តរជាតិ**(IS)។ ការចល័តកងទ័ពនិងសកម្មភាពអ្នកការទូត ការបង្កើតសន្ធិសញ្ញានិងសម្ព័ន្ធមិត្ត ការអភិវឌ្ឍនិងការដាក់ពង្រាយសមត្ថភាពយោធា សុទ្ធសឹងជាប្រធានបទពេញនិយមក្នុងមុខវិជ្ជាទំនាក់ទំនងអន្តរជាតិ កាលពីអតីតកាល ជាពិសេស នៅទសវត្សរ៍ឆ្នាំ

១៩៥០ និង ១៩៦០ ហើយនៅតែជាទីពេញនិយមក្នុងមុខវិជ្ជា។ ចាប់តាំងពីសង្គ្រាមត្រជាក់មក ជម្លោះក្នុងតំបន់ និងអំពើហឹង្សាលើជនជាតិភាគតិច បានទទួលការយកចិត្តទុកដាក់កាន់តែខ្លាំងជាង ក្នុងពេលដែលកម្មវិធីសិក្សាសន្តិភាពបែបពហុជំនាញ និងការសិក្សាពីស្ត្រី បានពង្រីកបញ្ញត្តិនៃ «សន្តិសុខ» បន្ថែមទៀត។

មែកធាងធំទីពីរនៃមុខវិជ្ជាទំនាក់ទំនងអន្តរជាតិ គឺ **សេដ្ឋកិច្ចនយោបាយអន្តរជាតិ** (IPE) ផ្តោតការយកចិត្តទុកដាក់លើទំនាក់ទំនងពាណិជ្ជកម្មនិងហិរញ្ញវត្ថុ ក្នុងចំណោមប្រទេសនានា និងផ្តោតលើរបៀបដែលប្រទេសនានាសហការផ្នែកនយោបាយ ដើម្បីបង្កើតនិងរក្សាស្ថាប័នកំណត់ច្បាប់លំហូរប្រតិបត្តិការសេដ្ឋកិច្ច និង ហិរញ្ញវត្ថុជាតិ។ ទោះបីជាប្រធានបទទាំងនេះបានផ្តោតលើទំនាក់ទំនងរវាងប្រទេសអ្នកមាន ការពង្រីកសាកលភាវូបនីយកម្មនិងស្ថាប័នសេដ្ឋកិច្ចពហុភាគី ដូចជាអង្គការពាណិជ្ជកម្មពិភពលោក បានជំរុញអោយអ្នកប្រាជ្ញសេដ្ឋកិច្ចនយោបាយអន្តរជាតិ ផ្តោតលើរដ្ឋកំពុងអភិវឌ្ឍន៍ផងដែរ។ លើសពីនេះទៀត ពួកគេយកចិត្តទុកដាក់កាន់តែខ្លាំងឡើងចំពោះទំនាក់ទំនងរវាងប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍ (ជារឿយៗត្រូវបានសម្គាល់ថាជា ទំនាក់ទំនងរវាងអឌ្ឍគោលខាងជើងនិងខាងត្បូង) រួមទាំងប្រធានបទសំខាន់ៗ ដូចជាការពឹងអាស្រ័យផ្នែកសេដ្ឋកិច្ច បំណុលជាតិ ជំនួយបរទេស និងការផ្ទេរបច្ចេកវិទ្យា ផងដែរ។ ប្រធានបទសំខាន់ផងដែរ រួមបញ្ចូល បញ្ហានៃការគ្រប់គ្រងបរិស្ថានអន្តរជាតិ និងបញ្ហានៃវិស័យទូរគមនាគមន៍ពិភពលោកដែរ។ មុខវិជ្ជារង សេដ្ឋកិច្ចនយោបាយអន្តរជាតិ កំពុងពង្រីកខ្លួនទៅតាមនោះដែរ។

គោលការណ៍និងទ្រឹស្តីដូចគ្នា ដែលជួយអោយយើងយល់ពីសន្តិសុខអន្តរជាតិ (នឹងត្រូវពិភាក្សានៅក្នុងមេរៀនទី ១ ក្នុងសៀវភៅនេះ) ក៏ជួយយើងអោយយល់ពីសេដ្ឋកិច្ចនយោបាយអន្តរជាតិ ផងដែរ (នឹងត្រូវពិភាក្សានៅមេរៀនទី ២)។ សេដ្ឋកិច្ចមានសារៈសំខាន់ណាស់ក្នុងកិច្ចការសន្តិសុខ ហើយកិច្ចការសន្តិសុខក៏មានសារៈសំខាន់ណាស់ក្នុងសេដ្ឋកិច្ចផងដែរ។

ចំណេះដឹងផ្នែកទ្រឹស្តីអាចកើនឡើងដោយសារវដ្តដដែលនៃការធ្វើទូទៅនីយកម្ម ហើយបន្ទាប់មកធ្វើតេស្តវា។ សម្រាប់បញ្ហាណាមួយ ទ្រឹស្តីផ្សេងៗអាចពន្យល់លទ្ធផល (បើទោះជាមិនបានល្អឥតខ្ចោះក៏ដោយ) ដូចក្នុងករណីនៃគោលការណ៍ទូទៅ។ ទ្រឹស្តីនីមួយៗក៏បានព្យាករណ៍លទ្ធផលផ្សេងទៀតផងដែរ ហើយវាអាចត្រូវបានតេស្តបញ្ជាក់ការពិតតាមលក្ខណៈវិទ្យាសាស្ត្រ។ វិទ្យាសាស្ត្រមន្ទីរពិសោធន៍ ដែលអាចគ្រប់គ្រងអថេរទាំងអស់ អាចធ្វើតេស្តសាកល្បងការព្យាករណ៍ទ្រឹស្តីប្រកបដោយប្រសិទ្ធភាព។ ទំនាក់ទំនងអន្តរជាតិមិនមានលទ្ធភាពបែបនេះទេ ពីព្រោះអថេរជាច្រើនអាចដំណើរការទៅក្នុងពេលដំណាលគ្នា។ ដូច្នេះ វាមានសារៈសំខាន់ជាពិសេស ក្នុងការគិតអោយបានម៉ត់ចត់អំពីព្រឹត្តិការណ៍ទំនាក់ទំនងអន្តរជាតិ ហើយពិចារណាលើការពន្យល់ទ្រឹស្តីផ្សេងៗគ្នា មុននឹងសម្រេចចិត្តថា ទ្រឹស្តីមួយណា (បើអាច) អាចផ្តល់ការពន្យល់បានល្អ បំផុត។

១.២. តួអង្គ និងឥទ្ធិពល

១.២ ចូរវាយតម្លៃថា តើរដ្ឋនៅតែជាតួអង្គឯកក្នុងទំនាក់ទំនងអន្តរជាតិដែរឬទេ។

តួអង្គសំខាន់ៗក្នុងទំនាក់ទំនងអន្តរជាតិគឺជារដ្ឋាភិបាលនានានៅលើពិភពលោក។ តាមទម្លាប់ អ្នកប្រាជ្ញទំនាក់ទំនងអន្តរជាតិសិក្សាពីការសម្រេចចិត្ត និងសកម្មភាពរបស់រដ្ឋាភិបាលទាំងនោះចំពោះរដ្ឋាភិបាលដទៃទៀត។ នៅលើឆាកអន្តរជាតិពោរពេញដោយតួអង្គធំនិងតូច ដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងការសម្រេចចិត្តរបស់រដ្ឋាភិបាល។ តួអង្គទាំងនេះ អាចជាបុគ្គលជាអ្នកដឹកនាំ និងពលរដ្ឋសាមញ្ញ។ ពួកគេអាច

ជាភ្នាក់ងារការិយាធិបតេយ្យនិយម នៅក្នុងក្រសួងការបរទេស។ ពួកគេអាចជាសាជីវកម្មពហុជាតិ និងក៏ជាក្រុមភេរវករផងដែរ។ ប៉ុន្តែ តួអង្គសំខាន់បំផុតនៅទំនាក់ទំនងអន្តរជាតិ គឺជាបណ្តារដ្ឋនានា។

១.២.១. តួអង្គរដ្ឋ

រដ្ឋគឺជាអង្គភាពដែនដីមួយ ដែលគ្រប់គ្រងដោយរដ្ឋាភិបាល និងមានប្រជាជនរស់នៅ។ ទីតាំងនៃរដ្ឋ និងដែនដីរបស់ពិភពលោក ត្រូវបានបង្ហាញនៅក្នុងផែនទីយោង នៅផ្នែកឧបសម្ព័ន្ធក្នុងសៀវភៅនេះ។ ផែនទីក្នុងតំបន់ ដែលមានព័ត៌មានលំអិតខ្លាំង ក៏មាននៅទីនោះផងដែរ។

រដ្ឋាភិបាលនៃរដ្ឋមួយ មិនស្ថិតនៅក្រោមអំណាចអាជ្ញាធរខ្ពស់ណាផ្សេងឡើយ។ ប្រាកដណាស់ វាមាន *អធិបតេយ្យភាព*នៅលើទឹកដីរបស់ខ្លួន បង្កើតនិងពង្រឹងការអនុវត្តច្បាប់ និងប្រមូលពន្ធគ្រប់ប្រភេទ ។ល។ អធិបតេយ្យភាពនេះ ត្រូវបានទទួលស្គាល់ (ទទួលស្គាល់ជាផ្លូវការទៅវិញទៅមក) ដោយរដ្ឋដទៃទៀត តាមរយៈទំនាក់ទំនងការទូត ហើយជាធម្មតា តាមរយៈសមាជិកភាព នៅអង្គការសហប្រជាជាតិ (អ.ស.ប.)។ ក្រុមប្រជាជន ដែលរស់នៅក្នុងរដ្ឋមួយ បង្កើតបានជា *សង្គមស៊ីវិល* ក្នុងកម្រិតមួយដែលវា អភិវឌ្ឍទៅជាស្ថាប័ននានាដើម្បីចូលរួមក្នុងជីវភាពនយោបាយឬសង្គម។ ប្រជាជនទាំងអស់ ឬក្រុមប្រជាជនណាមួយ ដែលមានអត្តសញ្ញាណរួមគ្នា អាចចាត់ទុកខ្លួនថាជា *ប្រជាជាតិ*មួយ (សូមមើល «ជាតិនិយម» នៅក្នុងមេរៀនទី ៥)។ រដ្ឋាភិបាលរបស់រដ្ឋនានា អនុវត្ត *លទ្ធិប្រជាធិបតេយ្យ* ដល់កម្រិតមួយដែលសមាជិកនៃប្រជាជនទាំងនោះគ្រប់គ្រងរដ្ឋាភិបាល។ ក្នុងជីវភាពនយោបាយ ឬក្នុងមេរៀនទំនាក់ទំនងអន្តរជាតិ ពាក្យ *រដ្ឋ ប្រជាជាតិ* និង*ប្រទេស* ត្រូវបានប្រើប្រាស់ ជាធម្មតា ដោយក្នុងន័យមិនច្បាស់លាស់ដើម្បីសំដៅទៅលើរដ្ឋាភិបាលរបស់រដ្ឋនោះ។ (ចូរកត់ចំណាំថាពាក្យ *រដ្ឋ* ក្នុងទំនាក់ទំនងអន្តរជាតិ មិនមានន័យថារដ្ឋណាមួយនៅសហរដ្ឋអាមេរិកទេ។)

ក្នុងករណីលើកលែងមួយចំនួន រដ្ឋនីមួយៗ មានរដ្ឋឬរាជធានីមួយ។ វាគឺជាទីក្រុងដែលរដ្ឋបាលនៃរដ្ឋាភិបាលតាំងនៅ ដើម្បីគ្រប់គ្រងទឹកដីរបស់ខ្លួន ហើយ ជាធម្មតា មានតែបុគ្គលម្នាក់គត់ ដែលធ្វើសកម្មភាពនានាក្នុងនាមរដ្ឋនោះ។ យើងនឹងហៅ បុគ្គលនេះ យ៉ាងសមញ្ញ ថាជា «មេដឹកនាំរដ្ឋ»។ ជារឿយៗ គាត់គឺជា *ប្រមុខរដ្ឋាភិបាល* (ដូចជានាយករដ្ឋមន្ត្រី) ឬ*ប្រមុខរដ្ឋ* (ដូចជា ប្រធានាធិបតី ឬ ជាស្តេច ឬ មហាក្សត្រី)។ នៅប្រទេសខ្លះ ដូចជា សហរដ្ឋអាមេរិក ដែលជាប្រធានាធិបតីតែម្នាក់ មានមុខងារជាប្រមុខរដ្ឋផង និងប្រមុខរដ្ឋាភិបាលផងដែរ។ រីឯនៅប្រទេសផ្សេងទៀត តួនាទីរបស់ប្រធានាធិបតី ឬក្សត្រ ឬសូម្បីតែនាយករដ្ឋមន្ត្រី គ្រាន់ជានិមិត្តរូបតែប៉ុណ្ណោះ។ នៅក្នុងករណីណាក៏ដោយ ឥស្សរជននយោបាយ ដែលមានឥទ្ធិពលបំផុត គឺអ្នកដែលយើងចង់មានន័យថា «មេដឹកនាំរដ្ឋ» ហើយឥស្សរជនទាំងនេះ គឺជាតួអង្គជាលក្ខណៈបុគ្គលដែលសំខាន់ នៅក្នុងទំនាក់ទំនងអន្តរជាតិ ដោយមិនគិតថាតើមេដឹកនាំទាំងនេះ ត្រូវបានជាប់ឆ្នោតតាមលក្ខណៈប្រជាធិបតេយ្យ ឬមេដឹកនាំផ្តាច់ការ។ មែនទែនទៅ ពាក្យថា តួអង្គរដ្ឋ រួមបញ្ចូលទាំងបុគ្គលដឹកនាំ ក៏ដូចជាស្ថាប័នការិយាធិបតេយ្យ ដូចជាក្រសួងការបរទេស ដែលធ្វើសកម្មភាពក្នុងនាមរដ្ឋ។ (អ្វីដែលសហរដ្ឋអាមេរិកបានហៅ*នាយកដ្ឋាន* ជាធម្មតាមានឈ្មោះជា*ក្រសួង* នៅប្រទេសផ្សេងទៀត។ *រដ្ឋលេខាធិការ*សហរដ្ឋអាមេរិកគឺជា*រដ្ឋមន្ត្រី*រីឯនាយកដ្ឋានរដ្ឋ ត្រូវគ្នានឹង*ក្រសួងការបរទេស* នៅក្នុងប្រទេសផ្សេង។)

ប្រព័ន្ធអន្តរជាតិ គឺជាបណ្តាញទំនាក់ទំនងក្នុងចំណោមរដ្ឋនានាលើពិភពលោកដែលមានរចនាសម្ព័ន្ធតាមវិធាននិងលំនាំជាក់លាក់នៃអន្តរអំពើ។ ក្នុងចំណោមវិធាន ឬ ច្បាប់បែបនេះ មួយចំនួនត្រូវបានបញ្ជាក់យ៉ាងច្បាស់ ខ្លះទៀតមានលក្ខណៈកាត់ន័យយក ពោលគឺមិនច្បាស់ឡើយ។ ពួកវារួមមានវិធាននានា ដែល

កំណត់ថានរណាខ្លះត្រូវរាប់បញ្ចូលជាសមាជិកនៃប្រព័ន្ធនេះ ហើយថាតើសមាជិកនោះមានសិទ្ធិនិងការទទួលខុសត្រូវអ្វីខ្លះ ហើយតើសកម្មភាពនិងការឆ្លើយតបបែបណា កើតឡើងជាធម្មតារវាងរដ្ឋនិងរដ្ឋ។

រូបថត មេដឹកនាំប្រទេសមហាសេដ្ឋកិច្ច៨

អំណាចរបស់រដ្ឋ

រដ្ឋគឺជាតួអង្គដ៏សំខាន់បំផុត នៅក្នុងទំនាក់ទំនងអន្តរជាតិ។ រដ្ឋមួយចំនួនតូចត្រូវបានគេចាត់ទុកថាជាប្រទេសមហាអំណាច និងមានរដ្ឋមួយជាប្រទេសមហាអំណាចកំពូល។ នៅក្នុងរូបនេះ មេដឹកនាំនៃចក្រភពអង់គ្លេស អាមេរិក ចិន និងអាឡឺម៉ង់ ថតរូបជុំគ្នា ក្នុងឱកាសបើកកិច្ចប្រជុំកំពូល G៨ នៅឯ Camp David ឆ្នាំ ២០១៧។


ប្រព័ន្ធអន្តរជាតិទំនើប បានកើតឡើង ក្នុងរយៈពេលត្រឹមតែ ៥០០ ឆ្នាំ ប៉ុណ្ណោះ។ មុនពេលនោះ ប្រជាជនត្រូវបានរៀបចំនិងដាក់ក្នុងអង្គភាពនយោបាយចំរុះនិងត្រួតស៊ីគ្នា ដូចជា រដ្ឋបុរី ចក្រភព និងរបបសក្តិភូមិ។ ក្នុងរយៈពេល ២០០ ឆ្នាំចុងក្រោយ ទស្សនៈនេះបានរីករាលដាល ដល់*ប្រជាជាតិ*នានា (ក្រុមមនុស្សដែលមានអារម្មណ៍ថាខ្លួនមានអត្តសញ្ញាណជាតិរួមគ្នា ជាទូទៅ រួមបញ្ចូលទាំងភាសានិងវប្បធម៌ គួរតែមានរដ្ឋផ្ទាល់ខ្លួន។ បច្ចុប្បន្ន រដ្ឋធំៗ ភាគច្រើន គឺជា**រដ្ឋនៃប្រជាជាតិ**បែបនេះ។ ប៉ុន្តែ ចាប់តាំងពីសង្គ្រាមលោកលើកទី ២ ដំណើរការរំដោះខ្លួនចេញពីរបបអាណានិគម នៅតំបន់អាស៊ី និងទ្វីបអាហ្វ្រិកភាគច្រើន បានបន្ថែមរដ្ឋថ្មីជាច្រើន ដែល ខ្លះមិនមែនជារដ្ឋនៃប្រជាជាតិបែបនេះទេ។ ប្រភពចំបងនៃជម្លោះនិងសង្គ្រាម នាពេលបច្ចុប្បន្ននេះ គឺជាភាពមិនស៊ីសង្វាក់គ្នា ជាញឹកញាប់ រវាងអ្វីដែលត្រូវគេយល់ឃើញថាជាជាតិនឹងអ្វីដែលជាព្រំដែនរដ្ឋជាក់ស្តែង។ នៅពេលដែលប្រជាជនកំណត់អត្តសញ្ញាណខ្លួនជាមួយនឹងសញ្ជាតិ ដែលរដ្ឋាភិបាលនៃរដ្ឋមិនតំណាងអោយពួកគេ ពួកគេអាចនឹងប្រយុទ្ធប្រឆាំងនឹងរដ្ឋនោះ ម្លោះហើយទើបខ្លួនអាចទទួលបានអធិបតេយ្យភាពលើទឹកដី និងកិច្ចការផ្ទៃក្នុងផ្ទាល់ខ្លួន។ ជាតិនិយមអនុរដ្ឋបែបនេះ គ្រាន់តែជាទំនោរមួយក្នុងចំណោមនិន្នាការជាច្រើន ដែលធ្វើអោយអន្តរាយដល់ប្រព័ន្ធរដ្ឋបច្ចុប្បន្ន។ និន្នាការផ្សេងទៀតរួមមានការធ្វើសាកលភាវូបនីយកម្មនៃដំណើរការសេដ្ឋកិច្ច អំណាចនៃទូរគមនាគមន៍ និងការរីកសាយនៃមីស៊ីលផ្លោង។

ឯករាជ្យភាពរបស់អតីតអាណានិគម ហើយនាពេលថ្មីៗនេះ ការបំបែកជារដ្ឋតូចៗនៃរដ្ឋពហុជាតិធំៗ (ដូចជា សហភាពសូវៀត យូហ្គោស្លាវី និងឆេកូស្លូវ៉ាគី) ពិតជាបានបង្កើនចំនួនរដ្ឋ នៅលើពិភពលោក។ ចំនួនសរុបពិតប្រាកដ ត្រូវអាស្រ័យលើហានៈនៃអង្គភាពនយោបាយ*ប្រៀបដូចជារដ្ឋ*(quasi-state)ជាច្រើន ហើយវានៅតែបន្តផ្លាស់ប្តូរ នៅពេលដែលអង្គភាពនយោបាយបែកបាក់គ្នាឬរួមបញ្ចូលចូលគ្នា។ នៅត្រឹមឆ្នាំ ២០១៨ អង្គការសហប្រជាជាតិមានសមាជិក ១៩៣ រដ្ឋ ។

ចំនួនប្រជាជនក្នុងរដ្ឋនានាលើពិភពលោក ប្រែប្រួលយ៉ាងខ្លាំង ទាំងប្រទេសចិននិងឥណ្ឌា ដែលមានប្រទេសនីមួយៗមានប្រជាជនជាង ១ ពាន់លាននាក់ ទាំងរដ្ឋតូចតាច ដូចជា សានម៉ារីណូ (San Marino) ដែលមានប្រជាជានត្រឹមតែ ៣២.០០០ នាក់។ ជាមួយនឹងការបង្កើតរដ្ឋតូចៗជាច្រើន ក្នុងប៉ុន្មានទសវត្សថ្មីៗនេះ រដ្ឋភាគច្រើនមានប្រជាជនតិចជាង ១០ លាននាក់ ហើយជាងពាក់កណ្តាលទៀត មានប្រជាជនចន្លោះពី ១០ ទៅ ៥០ លាននាក់។ ប៉ុន្តែ រដ្ឋទាំង ១៦ ដែលនីមួយ មានប្រជាជន ជាមធ្យមជាង ៨០ លាននាក់ រួមផ្សំគ្នាស្មើនឹង ២ ភាគ ៣ នៃចំនួនប្រជាជនពិភពលោក។

រដ្ឋទាំងឡាយក៏មានទំហំសេដ្ឋកិច្ចសរុប ប្រចាំឆ្នាំ ខុសៗគ្នា យ៉ាងខ្លាំងផងដែរ ដោយគិតជាផលិតផលក្នុងស្រុកសរុប (ផ.ស.ស.) [៣]។ តួយ៉ាង សេដ្ឋកិច្ចអាមេរិកមានតម្លៃប្រមាណ ១៩ ទ្រីលានដុល្លារអាមេរិក ចំណែកសេដ្ឋកិច្ចរដ្ឋតូចៗ ដូចជា កោះក្នុងសមុទ្រប៉ាស៊ីហ្វិកឈ្មោះ ទូវ៉ាលូ (Tuvalu) មានទំហំប្រមាណ ៣៧ លានដុល្លារអាមេរិក)។ សេដ្ឋកិច្ចពិភពលោកត្រូវបានគ្របដណ្តប់ដោយរដ្ឋមួយចំនួនតូច ដូចដែលរដ្ឋមួយចំនួនតូចមានប្រជាជនច្រើនបំផុតក្នុងពិភពលោកដែរ ។ ក្រាហ្វិក ១.១ បង្ហាញពីប្រទេសធំៗ ទាំង ១៥ ដោយគិតពីចំនួនប្រជាជននិងទំហំសេដ្ឋកិច្ច។ ប្រទេសនីមួយៗ គឺជាតួអង្គដ៏សំខាន់ នៅក្នុងកិច្ចការពិភពលោក ជាពិសេសប្រទេសទាំង ៩ នៅកណ្តាល ដែលធំជាងគេទាំងប្រជាជននិងសេដ្ឋកិច្ច។

ក្រាហ្វិក ១.១ ប្រទេសធំជាងគេលើពិភពលោក ឆ្នាំ ២០១៧-២០១៨



ចំណាំ៖ រង្វង់ខាងឆ្វេងនិងកណ្តាលមានទំហំប្រជាជនច្រើន ខាងស្តាំនិងកណ្តាលមានទំហំផ.ស.ស.ធំ
ប្រភព៖ ទិន្នន័យធនាគារពិភពលោក។ ការប៉ាន់ប្រមាណ GDP សម្រាប់ឆ្នាំ ២០១៧ ចំនួនប្រជាជនសម្រាប់ឆ្នាំ ២០១៨ ។

[៣] ផ.ស.ស. ឬហៅថាជាភាសាអង់គ្លេសថា GDP គឺជាទំនិញនិងសេវាកម្មសរុប ដែលផលិតដោយប្រទេសមួយ។ វាស្រដៀងទៅនឹងផលិតផលជាតិសរុប (GNP)។ ទិន្នន័យបែបនេះ ពិបាកប្រៀបធៀបនៅប្រទេសទាំងឡាយ ដែលមានរូបិយប័ណ្ណផ្សេងៗគ្នា ប្រព័ន្ធសេដ្ឋកិច្ចក៏ផ្សេងគ្នា និងកម្រិតនៃការអភិវឌ្ឍន៍ផ្សេងគ្នាដែរ។ ជាពិសេស ការប្រៀបធៀបផលិតផលក្នុងស្រុកសរុប រវាងប្រទេសអ្នកមាន និងប្រទេសក្រីក្រ គួរតែត្រូវបានអនុវត្តឡើង យ៉ាងប្រុងប្រយ័ត្ន។ ទិន្នន័យផលិតផលជាតិសរុប ដែលប្រើក្នុងសៀវភៅនេះភាគច្រើន បានមកពីធនាគារពិភពលោក។ នៅក្នុងមេរៀនទី ១២ យើងនឹងពិភាក្សាអំពីវិធីផ្សេងៗក្នុងការវាស់វែងផលិតផលជាតិសរុប ដែលគិតគូរពីតម្លៃធៀបនៃទំនិញដែលបានទិញនៅក្នុងប្រទេសមួយ។ នេះអាចមានសារៈសំខាន់ ដោយសារតម្លៃទំនិញដូចជាស្បៀងអាហារ អាចប្រែប្រួលយ៉ាងទូលំទូលាយរវាងប្រទេសនានា ដែលបណ្តាលអោយសកម្មភាពសេដ្ឋកិច្ចដូចគ្នាមាន តម្លៃខុសគ្នាអាស្រ័យលើប្រទេសនីមួយៗ។ សូមមើលសៀវភៅរបស់ Feenstra, Robert C., Robert Inklaar, និង Marcel P. Timmer ដែលមានចំណងជើងថា ជំនាន់ក្រោយនៃតារាងពិភព Penn ផ្សព្វផ្សាយនៅទស្សនាវដ្តីសេដ្ឋកិច្ចអាមេរិក ១០៥ (១០), ២០១៥: ៣១៥០–៨២ ។ ទិន្នន័យ GDP ជាទូទៅគិត សម្រាប់ឆ្នាំ ២០១៧ លើកលែងតែមានការកត់សម្គាល់ផ្សេងពីនេះ។

រដ្ឋមួយចំនួនក្នុងចំណោមរដ្ឋធំៗទាំងនេះ មានកម្លាំងនិងឥទ្ធិពល យោធានិងសេដ្ឋកិច្ចរឹងមាំ ហើយត្រូវបានគេហៅថា *ប្រទេសមហាអំណាច*។ ពួកគេនឹងត្រូវបានកំណត់និយមន័យនិងពិភាក្សាបន្ថែមក្នុងមេរៀនទី ២។ ប្រទេសមហាអំណាចខ្លាំងបំផុត ប្រទេសដែលមានឥទ្ធិពលពិតៗនៅលើសកលលោកទាំងមូល ត្រូវបានគេហៅថា *ប្រទេសមហាអំណាចកំពូល* ឬ*មហាអំណាចផុតលេខ*។ ឈ្មោះនេះជាទូទៅ សំដៅទៅលើសហរដ្ឋអាមេរិក និងសហភាពសូវៀត ក្នុងសង្គ្រាមត្រជាក់ ហើយឥឡូវនេះសំដៅទៅលើសហរដ្ឋអាមេរិកតែមួយគត់។ អង្គភាពនយោបាយមួយចំនួនទៀត ជារឿយៗ ត្រូវបានគេហៅថា រដ្ឋឬប្រទេស ទោះបីជាពួកគេមិនត្រូវបានគេទទួលស្គាល់ក្នុងឋានៈជារដ្ឋ ជាផ្លូវការក៏ដោយ។ កោះតៃវ៉ាន់ ជាឧទាហរណ៍សំខាន់បំផុតក្នុងករណីនេះ។ វាប្រតិបត្តិការ ដោយឯករាជ្យ ក្នុងការអនុវត្តជាក់ស្តែង ប៉ុន្តែ ត្រូវបានប្រទេសចិនទាមទារថាជាផ្នែកមួយនៃប្រទេសខ្លួន (ការទាមទារត្រូវបានទទួលស្គាល់ជាផ្លូវការ ដោយមហាអំណាចខាងក្រៅ) ហើយមិនមែនជាសមាជិកអង្គការសហប្រជាជាតិទេ។ ទឹកដីអាណានិគមនិងដែនដីឯនាយសមុទ្រជាទ្រព្យសម្បត្តិផ្លូវការរបស់រដ្ឋមួយទៀត នៅតែមាននៅឡើយ។ ឋានៈរបស់ពួកគេអាចផ្លាស់ប្តូរ នៅពេលអនាគត។ ទឹកដីទាំងនោះរាប់បញ្ចូល ព័រតូរីកូ(Puerto Rico) (នៃសហរដ្ឋអាមេរិក), ប៊ឺមូដា (Berumuda) (នៃចក្រភពអង់គ្លេស), ម៉ាទីនីក (Martinique) (នៃបារាំង), ហ្គាយ៉ាណា (Guiana) និងអាន់ទីល(Antille) (នៃហូឡង់), កោះហ្វកឡែន (Falkland) (នៃចក្រភពអង់គ្លេស)។ កោះហុងកុងត្រូវបានចក្រភពអង់គ្លេសប្រគល់ទៅអោយចិនគ្រប់គ្រងវិញ នៅក្នុងឆ្នាំ ១៩៩៧ ហើយរក្សាអត្តសញ្ញាណដាច់ដោយឡែកមួយ នៅក្រោមរូបមន្ត «ប្រទេសមួយ ប្រព័ន្ធពីរប្រព័ន្ធពីរ»។ ឋានៈបុរីវ៉ាទីកង់ (ដែនដីបរិសុទ្ធ) នៅទីក្រុងរ៉ូម ស្ថិតក្នុងស្ថានភាពមិនច្បាស់លាស់ឡើយ មិនខុសពីស្ថានភាពប៉ាឡេស្ទីន ដែលក្នុងឆ្នាំ ២០១២ បានចូលរួមជាមួយបុរីវ៉ាទីកង់ ក្នុងឋានៈជា *រដ្ឋសង្កេតការណ៍ដែលមិនមែនជាសមាជិក*របស់អង្គការសហប្រជាជាតិ។ ប្រសិនបើរាប់បញ្ចូលទាំងអង្គភាពដែនដីបែបនេះ ថាជារដ្ឋ នោះតួអង្គរដ្ឋ ឬតួអង្គ(ដែលអាចក្លាយជារដ្ឋ) នៅលើពិភពលោកអាចមានរហូតដល់ប្រមាណ ២០០ ។ *តួអង្គដែលអាចក្លាយជារដ្ឋ*ផ្សេងទៀត ដូចជា ឃឺឌីស្តាន (Kurdistan) នៅអ៊ីរ៉ាក់, អាប់ខាហ្សៀ (Abkhazia) នៅហ្សកហ្ស៊ី, និងសូម៉ាលីឡែន នៅសូម៉ាលី អាចគ្រប់គ្រងទឹកដីដែលខ្លួនបានទាមទារ ពេញលេញ ប៉ុន្តែ នឹងមិនមានការទទួលស្គាល់ជាអន្តរជាតិនោះទេ។

១.២.២. តួអង្គមិនមែនជារដ្ឋ

រដ្ឋាភិបាលរបស់ជាតិនីមួយៗអាចជាតួអង្គសំខាន់បំផុត នៅក្នុងទំនាក់ទំនងអន្តរជាតិ ប៉ុន្តែ ពួកគេទទួលរងឥទ្ធិពលយ៉ាងខ្លាំងពីតួអង្គដទៃទៀត ដែលត្រូវគេហៅរួមថាជា **តួអង្គមិនមែនជារដ្ឋ** (សូមមើលតារាង ១.២)។ តួអង្គទាំងនេះ ក៏ត្រូវបានគេហៅថាជា *តួអង្គឆ្លងជាតិ* ដែរ នៅពេលដែលពួកគេធ្វើប្រតិបត្តិការឆ្លងកាត់ព្រំដែនអន្តរជាតិ។

ជាបឋម រដ្ឋនានាជារឿយៗធ្វើសកម្មភាព តាមរយៈ ឬ នៅក្នុង ឬ ក្នុងចំណោម បរិបទរបស់អង្គការអន្តររដ្ឋាភិបាល (IGOs) ដែលជាអង្គការមានសមាជិកជារដ្ឋាភិបាលនៃជាតិផ្សេងៗ។ អង្គការអន្តររដ្ឋាភិបាលបំពេញមុខងារផ្សេងៗគ្នា ហើយក៏មានទំហំខុសគ្នាដែរ ខ្លះមានសមាជិកត្រឹមតែពីរបីរដ្ឋ ខ្លះទៀតមានសមាជិកជារដ្ឋទាំងអស់ ដូចជា អង្គការសហប្រជាជាតិ ជាដើម។ អង្គការនៃប្រទេសនាំចេញប្រេង(OPEC), អង្គការពាណិជ្ជកម្មពិភពលោក (WTO), សម្ព័ន្ធភាពយោធានានា ដូចជា អង្គការសន្ធិសញ្ញាអាត្លង់ទិកខាងជើង (ណាតូ)និងក្រុមនយោបាយដូចជាសហភាពអាហ្វ្រិក(AU) សុទ្ធតែជាឧទាហរណ៍នៃអង្គការអន្តររដ្ឋាភិបាល

ទាំងអស់។

ប្រភេទតួអង្គឆ្លងដែនផ្សេងទៀត អង្គការក្រៅរដ្ឋាភិបាល (NGOs) (ឬអង្គការមិនមែនរដ្ឋាភិបាល) គឺជាប្រភេទអង្គការឯកជន មួយចំនួនមានទំហំនិងធនធានច្រើនសម្បើមណាស់ដែរ។ អង្គការក្រៅរដ្ឋាភិបាលកាន់តែច្រើនឡើង ត្រូវបានគេទទួលស្គាល់ ទាំងនៅក្នុង អង្គការសហប្រជាជាតិ និងវេទិកាដទៃទៀត ដែលជាតួអង្គស្របច្បាប់ រួមជាមួយនឹងរដ្ឋនានាផងដែរ ទោះបីជាមិនមានហាន:ស្មើនឹងរដ្ឋក៏ដោយ។ ក្រុមខ្លះមានគោលដៅនយោបាយ ក្រុមខ្លះមានបេសកកម្មមនុស្សធម៌ រីឯក្រុមដទៃទៀតមានទាំងគោលដៅសេដ្ឋកិច្ចនិងទាំងបច្ចេកទេស។ ជួនកាល អង្គការមិនមែនរដ្ឋាភិបាល រួមសាមគ្គីគ្នាជាធ្លុងតែមួយតាមរយៈបណ្តាញ តស៊ូមតិឆ្លងដែន។ អង្គការក្រៅរដ្ឋាភិបាលមិនមានលំនាំទូទៅតែមួយដូចគ្នានោះទេ។ ទាំងអង្គការអន្តរដ្ឋាភិបាលនិងអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានគេហៅរួមគ្នាថា អង្គការអន្តរជាតិ (IOs)។ នៅលើពិភពលោក គេប៉ាន់ប្រមាណថា អង្គការក្រៅរដ្ឋាភិបាល មានចំនួនជាង ៥០.០០០ និងអង្គការអន្តរដ្ឋាភិបាល មានចំនួនប្រហែល ៥,០០០។ អង្គការអន្តរជាតិ (IOs) នឹងត្រូវពិភាក្សាលម្អិតបន្ថែម នៅក្នុងមេរៀនទី ៧ និង ១០។

សាជីវកម្មពហុជាតិ(Multinational Corporations) ជារឿយៗ ត្រូវគេហៅកាត់ថា MNCs គឺជាក្រុមហ៊ុនដែលប្រតិបត្តិការនៅក្នុងប្រទេសជាច្រើន។ ផលប្រយោជន៍របស់ក្រុមហ៊ុនធំមួយ ដែលរកស៊ីនៅទូទាំងពិភពលោក មិនត្រូវគ្នានឹងផលប្រយោជន៍របស់រដ្ឋណាមួយឡើយ។ សាជីវកម្មពហុជាតិ ជារឿយៗគ្រប់គ្រងធនធានកាន់តែច្រើន ហើយប្រតិបត្តិការជាលក្ខណៈអន្តរជាតិ ដោយមានប្រសិទ្ធភាពខ្ពស់ សឹងតែមានប្រសិទ្ធិភាពជាងរដ្ឋតូចៗមួយចំនួនទៅទៀត។ ពួកគេអាចនឹងផ្តល់ការគាំទ្រឬជំនួយផ្សេងៗ (ឬចូលរួមបង្កើត) រដ្ឋាភិបាលបរទេសដែលមានគោលនយោបាយរួសរាយរាក់ទាក់ជាមួយនឹងខ្លួន ដូចដែលក្រុមហ៊ុន United Fruit Company (ក្រុមហ៊ុនផ្លែឈើអាមេរិក) បានធ្វើនៅក្នុង «សាធារណរដ្ឋចេក»[៤] នៅអាមេរិកកាគកណ្តាល កាលពីមួយសតវត្សរ៍មុន។ ប៉ុន្តែ សាជីវកម្មពហុជាតិក៏ផ្តល់ដល់ប្រទេសក្រីក្រនូវការវិនិយោគបរទេសជាចាំបាច់ និងចំណូលពន្ធបរទេស យ៉ាងច្រើនសន្ធឹកសន្ធាប់ផងដែរ។ ផ្ទុយមកវិញ សាជីវកម្មពហុជាតិ ក៏ត្រូវពឹងផ្អែកលើរដ្ឋដើម្បីផ្តល់សុវត្ថិភាព ទីផ្សារដែលមានច្បាប់ទម្លាប់ត្រឹមត្រូវ និងបរិយាកាសនយោបាយដែលមានស្ថេរភាព។ សាជីវកម្មពហុជាតិក្នុងនាមជាតួអង្គអន្តរជាតិ ទទួលបានការយកចិត្តទុកដាក់ ជាពិសេសក្នុងមេរៀនទី ៩ និង ១៣។

តារាង ១.២. ប្រភេទតួអង្គមិនមែនជារដ្ឋ

ប្រភេទ		សមាជិកជានរណា	ឧទាហរណ៍
IGOs	អង្គការអន្តរដ្ឋាភិបាល	រដ្ឋាភិបាលជាតិ	«អ.ស.ប.» ណាតូ, អាស៊ាន
NGOs	អង្គការក្រៅរដ្ឋាភិបាល	បុគ្គល ឬក្រុមមនុស្ស	កាកបាទក្រហម, ស.ស.យ.ក.
MNCs	សាជីវកម្មពហុជាតិ	ក្រុមហ៊ុនឆ្លងព្រំដែនជាតិ	តូយ៉ូតា កូកាកូឡា
ផ្សេងៗ		បុគ្គល ទីក្រុង ក្រុមអ្នកបោះឆ្នោត	*ហូណា* អាល់កៃដា ក្រុមឃឺដអ៊ីរ៉ាក់

ចំណាំ៖ អង្គការអន្តរដ្ឋាភិបាល និង អង្គការក្រៅរដ្ឋាភិបាល ហៅរួមថា អង្គការអន្តរជាតិ (IOs)

[៤] ជាភាសាអង់គ្លេស Banana Republic សំដៅលើរដ្ឋតូចមួយដែលមិនមានស្ថិតស្ថេរខាងនយោបាយ ដោយសារសេដ្ឋកិច្ចរបស់ខ្លួនត្រូវពឹងផ្អែកលើការនាំចេញ ដែលគ្រប់គ្រងដោយមូលធនឬក្រុមហ៊ុនបរទេស ឬអាចហៅថា រដ្ឋខ្ចីច្រមុះគេដកដង្ហើម។

តួអង្គមិនមែនជារដ្ឋផ្សេងៗ មានអន្តរអំពើជាមួយរដ្ឋ អង្គការអន្តរជាតិ និងសាជីវកម្មពហុជាតិ។ ឧទាហរណ៍ ការវាយប្រហារភេរវកម្ម ចាប់តាំងពីថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ២០០១ បានបង្ហាញពីការកើនឡើងនៃឥទ្ធិពលនៃបច្ចេកវិទ្យាកាន់តែខ្លាំងឡើង បណ្តាលអោយភេរវករក្លាយជាតួអង្គមិនមែនជារដ្ឋ ផងដែរ។ ដូចគ្នានឹងការដែលអង្គការបរិស្ថាន Greenpeace អាចធ្វើដំណើរទៅកាន់ទីតាំងជាច់ស្រយាល ហើយផ្សាយបន្តផ្ទាល់វីដេអូ សកម្មភាពបរិស្ថាន ចេញពីទីនោះ, រដ្ឋអ៊ីស្លាមក៏អាចជាក់ បំផ្ទុះគ្រាប់បែកអត្តឃាតនៅទីក្រុងធំៗនានា សម្របសម្រួលប្រតិបត្តិការសកម្មភាពនិងហិរញ្ញវត្ថុរបស់ខ្លួន តាមប្រព័ន្ធអ៊ិនធឺរណេតនិងប្រព័ន្ធធនាគារសកលលោក ហើយអាចផ្សព្វផ្សាយយ៉ាងទូលំទូលាយដល់ទស្សនិកជននៅទូទាំងសកលលោក តាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម ដូចជា យូធូប និង ធ្វីតធឺ។ «ឥទ្ធិពលទូលំទូលាយទូទាំងសកលលោក» ដែលធ្លាប់តែជាសមត្ថភាពផ្តាច់មុខរបស់ប្រទេសមហាអំណាច បច្ចុប្បន្ននេះ ប្រទេសឬបុគ្គលផ្សេងទៀតក៏អាចឈានដល់សមត្ថភាពនេះដែរ ទោះមានផលល្អក្តី ឬអាក្រក់ក្តី។

តួអង្គមិនមែនជារដ្ឋមួយចំនួន គឺជាតួអង្គអនុរដ្ឋឬរដ្ឋនៅក្រោមរដ្ឋ៖ ពួកគេមានអត្ថិភាពនៅក្នុងប្រទេសមួយ ប៉ុន្តែ អនុរដ្ឋខ្លះក៏មានឥទ្ធិពលលើគោលនយោបាយការបរទេសនៃប្រទេសនោះ ឬខ្លះក៏ប្រតិបត្តិការជាលក្ខណៈអន្តរជាតិ ឬ ក្នុងករណីខ្លះទៀត ពួកគេធ្វើទាំងពីររឿង។ ឧទាហរណ៍ រដ្ឋផេនស៊ីលវ៉ានៀ គឺជាអង្គភាពរដ្ឋមួយរបស់សហរដ្ឋអាមេរិក ប៉ុន្តែ វាក៏ជាក់ការិយាល័យអភិវឌ្ឍពាណិជ្ជកម្មអន្តរជាតិមួយ អោយដំណើរការដោយខ្លួនឯង ដើម្បីជំរុញការនាំចេញ និងការវិនិយោគបរទេស ហើយមានការិយាល័យចំនួន ១៥ ផ្សេងទៀតនៅទូទាំងពិភពលោក រួមទាំងនៅ ប្រទេសបែលហ្សិក ចិន កាណាដា ឥណ្ឌា និងម៉ិកស៊ិក។ សកម្មភាពរបស់តួអង្គអនុរដ្ឋសេដ្ឋកិច្ច ដូចជា ក្រុមហ៊ុន ផលិតករ អតិថិជន ពលករ វិនិយោគិន ជួយបង្កើតបរិបទនៃសកម្មភាពសេដ្ឋកិច្ច ក្នុងដំណាលពេលដែលព្រឹត្តិការណ៍នយោបាយអន្តរជាតិកំពុងកើតមានឡើង តាមរយៈសកម្មភាពនិងគោលនយោបាយរបស់រដ្ឋាភិបាលនានា។

នៅក្នុងពិភពលោកសម័យ សាកលភាវូបនីយកម្មនេះ ដែលពោរពេញដោយតួអង្គអនុរដ្ឋ និងតួអង្គឆ្លងព្រំដែនជាតិ រដ្ឋនានា នៅតែសំខាន់ដដែល។ ប៉ុន្តែ ដោយកម្រិតណាមួយ ពួកគេកំពុងត្រូវបានរុញអោយទៅកៀនជញ្ជាំង នៅពេលដែលក្រុមហ៊ុន ក្រុមមនុស្ស និងបុគ្គលម្នាក់ៗ ទាក់ទងគ្នាដោយផ្ទាល់ ឆ្លងកាត់ព្រំដែនជាតិទាំងឡាយ និងនៅពេលដែលសេដ្ឋកិច្ចពិភពលោកបានធ្វើសមាហរណកម្មទូទាំងពិភពលោក។ ឥឡូវនេះច្រើនជាងពេលណាៗទាំងអស់ ទំនាក់ទំនងអន្តរជាតិ បានពង្រីកលើសពីអន្តរកម្មរវាងរដ្ឋាភិបាលជាតិនានា។

រូបថត ក្មេងៗទទួលបានប្រដាប់ប្រដារក្មេងលេង

នៅក្នុងសកម្មភាព

តួអង្គមិនមែនរដ្ឋចូលរួមនៅក្នុងទំនាក់ទំនងអន្តរជាតិ ជាមួយរដ្ឋនានា ទោះបីជា ជាទូទៅ មានតួនាទីស្នូលតិចជាងក៏ដោយ។ អង្គការក្រៅរដ្ឋាភិបាល (NGOs) កាន់តែសកម្មខ្លាំងនៅក្នុងទំនាក់ទំនងអន្តរជាតិ។ នៅទីនេះ បុគ្គលិកសង្គ្រោះមកពីក្រុមសប្បុរសធម៌ឥស្លាមទួរគីកំពុងចែកចាយសម្លៀកបំពាក់ និងស្បែកជើងដល់កុមារកុមារីរ៉ូហ៊ីងយ៉ានៅក្នុងជំរុំជនភៀសខ្លួនក្នុងប្រទេសបង់ក្លាដែស ឆ្នាំ ២០១៧។ ក្មេងៗទាំងនោះបានភៀសខ្លួនពីការបង្ក្រាបដោយយោធាដោយហិង្សា ដែលមនុស្សជាច្រើនបានចាត់ទុកការបោសសម្អាតជនជាតិភាគតិច នៅក្នុងប្រទេសភូមា (មីយ៉ាន់ម៉ា)។

ទាំងតួអង្គរដ្ឋនិងទាំងតួអង្គមិនមែនជារដ្ឋ ទទួលរងឥទ្ធិពលបដិវត្ត នៅក្នុងបច្ចេកវិទ្យាព័ត៌មានយ៉ាងខ្លាំងក្លា នាពេលបច្ចុប្បន្ន នេះ។ សកលលោកថ្មី ដែលពឹងផ្អែកខ្លាំងលើព័ត៌មាន បានសន្យាថា នឹងមានការផ្លាស់ប្តូរទំនាក់ទំនងអន្តរជាតិយ៉ាងខ្លាំង។ ការផ្លាស់ប្តូរបច្ចេកវិទ្យាយ៉ាងសម្បើមបែបនេះ បានជះឥទ្ធិពលលើសមត្ថភាពធៀបនិងចំណងចំណូលចិត្តរបស់តួអង្គ។ ប្រព័ន្ធទូរគមនាគមន៍ និងកុំព្យូទ័រ បានអនុញ្ញាតអោយសេដ្ឋកិច្ច នយោបាយ ក៏ដូចជា វប្បធម៌ ប្រតិបត្តិការក្នុងកំរិតសកលលោកទាំងមូល ដែលមិនធ្លាប់មានពីមុនមក។ ឥទ្ធិពលនៃបច្ចេកវិទ្យាព័ត៌មានវិទ្យាសម្រាប់វិស័យផ្សេងៗទៀតក្នុងទំនាក់ទំនងអន្តរជាតិ នឹងត្រូវបានបង្កើតឡើង នៅក្នុងមេរៀននីមួយៗនៃសៀវភៅនេះ។

១.២.៣. *កម្រិតនៃការវិភាគ*

តួអង្គជាច្រើនដែលពាក់ព័ន្ធនឹងទំនាក់ទំនងអន្តរជាតិ បានចូលរួមចំណែកក្នុងការពន្យល់និងទ្រឹស្តីដ៏ស្មុគស្មាញ។ អ្នកប្រាជ្ញទំនាក់ទំនងអន្តរជាតិបានសម្រួលភាពស្មុគស្មាញនៃឥទ្ធិពល តួអង្គ និង ដំណើរការដោយបែងចែកជាកម្រិតនៃការវិភាគផ្សេងៗគ្នា (ចូរមើលតារាង ១.៣)។ កំរិតនៃការវិភាគ គឺជាទស្សនវិស័យស្តីពីទំនាក់ទំនងអន្តរជាតិ ដោយផ្អែកលើសំណុំនៃតួអង្គឬដំណើរការស្រដៀងៗគ្នា ដើម្បីបង្ហាញពីការពន្យល់ផ្សេងៗ ពិសេសពន្យល់អំពីសំណួរ «ហេតុអ្វី»។ អ្នកប្រាជ្ញ ទំនាក់ទំនងអន្តរជាតិ បានស្នើអោយមានគំរោងការវិភាគកម្រិតផ្សេងៗគ្នាភាគច្រើន ជាញឹកញាប់ មានបីកម្រិតធំៗ (ជួនកាលមានកំរិតតូចៗនៅពីក្រោមទៀត)។

ការវិភាគកម្រិតបុគ្គល ផ្តោតការយកចិត្តទុកដាក់លើការយល់ឃើញ ការសម្រេចចិត្តឬជម្រើស និងសកម្មភាពរបស់បុគ្គលណាម្នាក់។ មេដឹកនាំ ខ្លាំងពូកែ ល្បីៗ ជះឥទ្ធិពលដល់ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ក៏មិនខុសអីពីឥទ្ធិពលរបស់ពលរដ្ឋម្នាក់ៗ អ្នកប្រាជ្ញ ទាហាន និង អ្នកបោះឆ្នោត។ បើគ្មានលោកលេនីនទេ គេនិយាយថា ក៏ប្រហែលជាមិនមានសហភាពសូវៀតដែរ។ ប្រសិនបើនិស្សិតមហាវិទ្យាល័យមួយចំនួនថែមទៀតបានបោះឆ្នោតអោយលោក និចសុន ជាជាងបោះអោយលោកកេណ្ណឌី នៅក្នុងការបោះឆ្នោតប្រកៀកប្រកិតនៅឆ្នាំ ១៩៦០ វិបត្តិមីស៊ីលគុយបាអាចនឹងបញ្ចប់ដោយលទ្ធផលខុសគ្នា។ ការសិក្សាអំពីការសម្រេចចិត្តលើគោលនយោបាយការបរទេសការបរទេស ដែលនឹងត្រូវពិភាក្សាក្នុងមេរៀនទី ៤ យកចិត្តទុកដាក់ ជាពិសេសចំពោះការពន្យល់លទ្ធផលព្រឹត្តិការណ៍ក្នុងទំនាក់ទំនងអន្តរជាតិ ក្នុងកម្រិតបុគ្គល ដោយសារ សារៈសំខាន់នៃកត្តាចិត្តសាស្ត្រ ក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តគោលនយោបាយ]។

ការវិភាគកម្រិតក្នុងស្រុក (កម្រិតរដ្ឋឬកម្រិតសង្គម) ផ្តោតការយកចិត្តទុកដាក់នឹងការប្រមូលផ្តុំបុគ្គលទាំងឡាយ នៅក្នុងរដ្ឋឬសង្គម ដែលមានឥទ្ធិពលលើសកម្មភាពរបស់រដ្ឋទាំងអស់នោះ នៅលើឆាកអន្តរជាតិ។ ការប្រមូលផ្តុំបែបនេះ រាប់បញ្ចូលទាំងក្រុមផលប្រយោជន៍ អង្គការនយោបាយ និងទីភ្នាក់ងាររដ្ឋាភិបាល។ ក្រុមទាំងនេះមានដំណើរការខុសៗគ្នា ក្នុងសង្គមនិងរដ្ឋផ្សេងៗគ្នា ហើយក៏ជះឥទ្ធិពលលើឆាកអន្តរជាតិកម្រិតផ្សេងៗគ្នាផងដែរ ។ ឧទាហរណ៍ប្រទេសប្រជាធិបតេយ្យ និងប្រទេសផ្តាច់ការអាចធ្វើសកម្មភាពខុសគ្នាពីគ្នា ហើយប្រទេសប្រជាធិបតេយ្យអាចនឹងធ្វើទង្វើក្នុងឆ្នាំបោះឆ្នោត ខុសពីទង្វើឬគោលនយោបាយដែលពួកគេធ្វើក្នុងបណ្តាឆ្នាំផ្សេងទៀត។ នយោបាយនៃជម្លោះជាតិសាសន៍និងជាតិនិយម ដែលបានផ្ទុះឡើងចេញពីក្នុងរដ្ឋមួយចំនួន ដើរតួនាទីកាន់តែខ្លាំងឡើងនៅក្នុងទំនាក់ទំនងក្នុងចំណោមរដ្ឋនានា។ នៅក្នុងរដ្ឋាភិបាលនីមួយៗ ស្ថាប័នគោលនយោបាយការបរទេស ជារឿយៗ ធ្វើការប្រកួតប្រជែងនឹងការិយាធិបតេយ្យក្នុងការសម្រេចចិត្តលើគោលនយោបាយ។

តារាង ១.៣ កម្រិតវិភាគ នៅក្នុងទំនាក់ទំនងអន្តរជាតិ

ព្រឹត្តិការណ៍ជារច្រើនជះឥទ្ធិពលលើដំណើរនៃទំនាក់ទំនងអន្តរជាតិ។ កម្រិតនៃការវិភាគ អាចផ្តល់នូវក្របខ័ណ្ឌសម្រាប់ការបែងចែកឥទ្ធិពលទាំងនេះ ម្ល៉ោះហើយអាចនឹងផ្តល់ការពន្យល់ពីមូលហេតុផ្សេងៗ ដែលបណ្តាលអោយផ្ទុះឡើងព្រឹត្តិការណ៍អន្តរជាតិ។ ឧទាហរណ៍រួមមាន៖

កម្រិតប្រព័ន្ធ		
គំលាតអឌ្ឍគោលខាងជើង-ត្បូង	សាសនានិយមជ្រុល	បដិវត្តន៍ព័ត៌មានវិទ្យា
ចក្រពត្តិនិយមអឺរ៉ុប	បរិស្ថានពិភពលោក	ទូរគមនាគមន៍សកល
បទដ្ឋាន	បម្លាស់ប្តូរបច្ចេកវិទ្យា	សហគមន៍វិទ្យាសាស្ត្រ និង
ការបែងចែកអំណាច(សកល)	សង្គ្រាម	ជំនួញសកល
តុល្យភាពអំណាច	សម្ព័ន្ធភាពយោធា	អង្គការអន្តរដ្ឋាភិបាល
		កិច្ចព្រមព្រៀងពាណិជ្ជកម្ម
កម្រិតក្នុងស្រុក		
ជាតិនិយម	របបផ្តាច់ការ	យ៉ោនវ៉ារ
ជម្លោះជាតិសាសន៍	សម្ព័ន្ធនយោបាយក្នុងស្រុក	វិស័យសេដ្ឋកិច្ច និងឧស្សាហកម្ម
ប្រភេទរដ្ឋាភិបាល	ការបោះឆ្នោត&បក្សនយោបាយ	ឧស្សាហកម្មសព្វាវុធនិងយោធា
ប្រជាធិបតេយ្យ	មតិសាធារណៈ	ការិយាធិបតេយ្យ
		គោលនយោបាយការបរទេស
កម្រិតបុគ្គល		
មេដឹកនាំខ្លាំងពូកែ	ចិត្តសាស្ត្រយល់ដឹង&សម្រេចចិត្ត	ការចូលរួមរបស់ពលរដ្ឋ
មេដឹកនាំលីលា	ការសិក្សារៀនសូត្រ	ការបោះឆ្នោត ការបះបោរ
ការសម្រេចចិត្តក្នុងគ្រាអាសន្ន	ការធ្វើឃាត ឧបទ្វេរហេតុ	សង្គ្រាម

ការវិភាគកម្រិតប្រព័ន្ធ (ឬ*កម្រិតអន្តរដ្ឋ*) ផ្តោតការយកចិត្តដាក់លើ ឥទ្ធិពលរបស់ប្រព័ន្ធអន្តរជាតិទៅលើលទ្ធផល ឬហេតុការណ៍ដែលបានកើតឡើង។ ម្ល៉ោះហើយ កម្រិតនៃការវិភាគនេះ ផ្តោតលើអន្តរកម្មរបស់រដ្ឋគ្នាឯង ដោយមិនគិតពីកត្តាខាងក្នុង កិច្ចការផ្ទៃក្នុង ឬបុគ្គលដែលជាអ្នកដឹកនាំរដ្ឋទាំងនោះ។ ការវិភាគកម្រិតនេះយកចិត្តទុកដាក់លើអំណាចធៀបរបស់រដ្ឋមួយទៅនឹងរដ្ឋមួយទៀត នៅក្នុងប្រព័ន្ធអន្តរជាតិ ក៏ដូចជាអន្តរកម្ម (តួយ៉ាង ពាណិជ្ជកម្ម) ក្នុងចំណោមពួកគេ។ តាមធម្មតា នេះជាកម្រិតនៃការវិភាគសំខាន់បំផុត។

ការវិភាគកម្រិតសកលលោក អាចត្រូវបានបន្ថែមពីលើកម្រិតវិភាគទាំងបីខាងលើនេះ ដើម្បីព្យាយាមពន្យល់ពីលទ្ធផលអន្តរជាតិ ទាក់ទងនឹងនិន្នាការពេញនិយមនិងកម្លាំងចលករលើពិភពលោក ដែលអាចមានឥទ្ធិពលលើអន្តរកម្មរវាងរដ្ឋនិងរដ្ឋ។ ការវិវឌ្ឍន៍នៃបច្ចេកវិទ្យារបស់មនុស្ស ការវិត្តន៍នៃជំនឿសាសនាសកលនិងទំនាក់ទំនងរបស់មនុស្សជាមួយនឹងបរិស្ថានធម្មជាតិ សុទ្ធសឹងជាដំណើរការ ដែលប្រព្រឹត្តទៅនៅក្នុងកម្រិតសកលលោក ដែលប្រាកដណាស់ជះឥទ្ធិពលលើទំនាក់ទំនងអន្តរជាតិ។ ការវិភាគកម្រិតសកលលោក ក៏កត្តាដូចជាដំណើរការធ្វើ សមាហរណកម្មឆ្លងប្រទេស តាមរយៈសហគមន៍វិទ្យាសាស្ត្រ បច្ចេកទេស និងជំនួញ

នានា នៅទូទាំងពិភពលោក (សូមមើលមេរៀនទី ១០)។ ឥទ្ធិពលសកលលោកមួយទៀត គឺឥទ្ធិពលនៃប្រវត្តិចក្រពត្តិនិយមរបស់អឺរ៉ុប ដែលនៅសេសសល់ដល់បច្ចុប្បន្ន៖ ការគ្រប់គ្រងរបស់អឺរ៉ុបនៅ អាមេរិកឡាទីន អាស៊ី និងអាហ្វ្រិក (សូមមើល «ប្រវត្តិចក្រពត្តិនិយម ចន្លោះឆ្នាំ ១៥០០-២០០០» ក្នុងមេរៀនទី ១២)។

កម្រិតនៃការវិភាគផ្តល់ការពន្យល់ផ្សេងៗគ្នាសម្រាប់ព្រឹត្តិការណ៍អន្តរជាតិទាំងឡាយ។ គីម ជុងអ៊ុន មេដឹកនាំកូរ៉េខាងជើងបានប្រើប្រាស់រ៉ោហាវសាស្ត្រផ្សះផ្សារជាមួយនឹងសហរដ្ឋអាមេរិក ក្រោយបានធ្វើតេស្ត៍សាកល្បងអាវុធនុយក្លេអ៊ែរពីរបីលើក និងបានវាយប្រហារពាក្យសម្តីជាមួយប្រធានាធិបតី ត្រាំ តាមបណ្តាញសង្គម។ ក្នុងកម្រិតណាមួយ មនោសញ្ចេតនារវាង គីម និង ត្រាំ បានជួយរឹតចំណងមិត្តភាពចម្លែកនេះ ហើយនាំទៅដល់កិច្ចប្រជុំកំពូល ពីរលើករវាងមេដឹកនាំទាំងពីរ នៅឆ្នាំ ២០១៨ និង ២០១៩, ទោះជាយ៉ាងណាក៏ដោយ មិនមានកិច្ចព្រមព្រៀងជាក់លាក់ណាមួយសម្រេចបាន ចេញពីជំនួបទាំងនេះឡើយ។ បើគេវិភាគកម្រិតក្នុងស្រុក ការធ្លាក់ចុះសេដ្ឋកិច្ចដោយសារទណ្ឌកម្ម ត្រូវបានគេជឿថាជំរុញអោយ គីម ជុងអ៊ុន ខំប្រឹងបង្ហាញពិភពលោកអោយឃើញថាខ្លួនស្រលាញ់សន្តិភាព។ ដូចគ្នានេះដែរ ប្រធានាធិបតី ត្រាំ កំពុងស្ថិតក្រោមដើម្បីបង្ហាញពលរដ្ឋអាមេរិកថា គាត់គឺជាអ្នកចរចារយ៉ាងចំណាននៅក្នុងទំនាក់ទំនងអន្តរជាតិ នៅពេលដែលទង្វើផ្សេងទៀតរបស់គាត់មិនហុចផលឡើយ។ ក្នុងបរិបទធំទូលំទូលាយជាងនេះ ការចង់បានការគាំទ្រជាអន្តរជាតិ ដើម្បីបន្ធូរបន្ថយទណ្ឌកម្មសេដ្ឋកិច្ច ដោយសារកិច្ចព្រមព្រៀងនុយក្លេអ៊ែរ ដែលអាចកើតមានឡើង និងបង្ហាញមុខមាត់សាធារណៈល្អ។ នៅលើឆាកអន្តរជាតិ ប្រាកដជាអ្វីមួយដែលមានក្នុងចិត្តមេដឹកនាំកូរ៉េខាងជើង។ សម្រាប់សហរដ្ឋអាមេរិក ការបង្កើតមិត្តចេញពីសត្រូវ នៅក្នុងទីតាំងយុទ្ធសាស្ត្រ អាចពង្រឹងអំណះអំណាងរបស់អាមេរិកក្នុងដំណើរការ*ងាកមកអាស៊ី* (Pivot to Asia) ដើម្បីទប់ទល់នឹងចិននិងរុស្ស៊ី។

ជាឧទាហរណ៍បន្ថែម មានការពន្យល់ជាច្រើនអំពីសង្គ្រាមដែលដឹកនាំដោយអាមេរិកប្រឆាំងនឹងអ៊ីរ៉ាក់នៅឆ្នាំ ២០០៣។ នៅក្នុងការវិភាគកម្រិតបុគ្គល សង្គ្រាមអាចបណ្តាលមកពីការលេងរបស់ លោក សាដាម ហ៊ូសេន ដោយប៉ាន់ខុសថាគាត់អាចកំទេចកងកម្លាំងប្រឆាំងគាត់ គ្រប់ប្រភេទ ឬអាចបណ្តាលមកពី លោកប្រធានាធិបតី ប៊ូស ចង់ដកចេញមេដឹកនាំនានា ដែលខ្លួនគាត់យល់ថាជាការគំរាមកំហែងដ្រល់សហរដ្ឋអាមេរិក)។ នៅក្នុងការវិភាគកម្រិតក្នុងស្រុក សង្គ្រាមអាចត្រូវបានសន្មត់ថាបានផ្ទុះឡើងដោយសារការកើនឡើងនៃក្រុមអភិរក្សនិយមថ្មីដ៏មានឥទ្ធិពល ដែលបានបញ្ចុះបញ្ចូលរដ្ឋបាលលោកប៊ូស និងបណ្តាជនជាតិអាមេរិកថា សាដាម ហ៊ូសេន គឺជាការគំរាមកំហែងដល់សន្តិសុខរបស់សហរដ្ឋអាមេរិក នៅក្នុងពិភពលោកសម័យក្រោយព្រឹត្តិការណ៍មហាភេរវកម្ម ១១ កញ្ញា។ នៅក្នុងការវិភាគកម្រិតអន្តរដ្ឋ សង្គ្រាមអាចនឹងត្រូវបានសន្មត់ថាបានផ្ទុះឡើងដោយសារ ការលេចធ្លោជាងគេឥទ្ធិពលរបស់សហរដ្ឋអាមេរិកលើសកលលោក។ ដោយគ្មានរដ្ឋមួយ ដែលមានឆន្ទៈគាំទ្រដោយយោធាដល់ប្រទេសអ៊ីរ៉ាក់ សហរដ្ឋអាមេរិក(ក្នុងហានៈជាប្រទេសមហាអំណាចយោធាធំជាងគេ លើសកលលោក) អាចចេញទៅវាយប្រហារនៅអ៊ីរ៉ាក់តាមចិត្តចង់ ដោយគ្មានការភ័យខ្លាច ឬ ដោយមិនខ្លាចអោរថាមានមហាអំណាចយោធាផ្សេងប្រឆាំងតបខ្លួនឡើយ។ ទីបំផុត នៅក្នុងការវិភាគកម្រិតសកលលោក សង្គ្រាមអាចបណ្តាលមកពីការភ័យខ្លាចចំពោះអំពើភេរវកម្មជាសកល ឬភ័យខ្លាចថា មានផ្ទុះការប៉ះទង្គិចគ្នារវាងពិភពឥស្លាមនិងពិភពបស្ចឹមប្រទេស។

ទោះបីជាអ្នកប្រាជ្ញ ទំនាក់ទំនងអន្តរជាតិ ច្រើនតែផ្តោតការសិក្សារបស់ពួកគេ ជាចម្បង លើកម្រិតនៃការវិភាគណាមួយជាពិសេស ការវិភាគកម្រិតផ្សេងទៀតក៏មានបញ្ហា ក្នុងពេលដំណាលគ្នាដែរ។ មិនមានកំរិត

ការវិភាគតែមួយគត់សម្រាប់ពន្យល់សំណួរ«ហេតុអ្វី»អោយបានត្រឹមត្រូវតែតខ្លោះនោះទេ។ ផ្ទុយទៅវិញ កំរិតនៃការវិភាគផ្សេងៗគ្នា ជួយបង្ហាញការពន្យល់ផ្សេងៗគ្នាជាច្រើន រួមទាំងវិធីសាស្ត្រក្នុងការពិចារណាលើការពន្យល់អំពីព្រឹត្តិការណ៍ណាមួយ។ ពួកគេរម្លឹក អ្នកប្រាជ្ញនិងនិស្សិតទាំងឡាយអោយមើលទៅហួសពីទិដ្ឋភាព ឬស្រទាប់ខាងក្រៅនៃព្រឹត្តិការណ៍ណាមួយ ដើម្បីស្វែងរកឥទ្ធិពលនានា ដែលអាចកើតមាន ចំពោះបុព្វហេតុយូរណាស់មកហើយ។ ចូរកត់សម្គាល់ថា ដំណើរការនៅក្នុងកំរិតខ្ពស់ ហាក់មានទំនោរកើតមានឡើងយឺតជាងដំណើរការកម្រិតទាប។ បុគ្គលមេដឹកនាំម្នាក់ៗចូលកាន់កាប់តំណែងហើយលាលែងវិញ ញឹកញាប់ជាង រីឯរចនាសម្ព័ន្ធនៃប្រព័ន្ធអន្តរជាតិកម្រផ្លាស់ប្តូរណាស់។

១.២.៤. សាកលភាវូបនីយកម្ម

តាមពិតទៅ សាកលភាវូបនីយកម្មរាប់បញ្ចូលនិន្នាការជាច្រើន រួមមានការពង្រីកពាណិជ្ជកម្មអន្តរជាតិ ទូរគមនាគមន៍ ការសម្របសម្រួលរូបិយវត្ថុ សារជីវកម្មពហុជាតិ ការសហការផ្នែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ការផ្លាស់ប្តូរវប្បធម៌ប្រភេទថ្មី និងក្នុងវិសាលភាពធំជាងមុន ការធ្វើចំណាកស្រុកនិងលំហូរជនភៀសខ្លួន និងទំនាក់ទំនងរវាងប្រទេសអ្នកមាននិងប្រទេសក្រីក្រនានា នៅលើពិភពលោក។ ទោះបីជាសាកលភាវូបនីយកម្មមានសារៈសំខាន់ខ្លាំងយ៉ាងណាក៏ដោយ ក៏វាត្រូវបានកំណត់និយមន័យ យ៉ាងទូលំទូលាយពេក ហាក់មិនច្បាស់លាស់ ហើយក៏មិនអាចត្រូវបានពន្យល់ដោយទ្រឹស្តីតែមួយដែរ។ ទស្សនៈដ៏ពេញនិយមមួយនៃសាកលភាវូបនីយកម្ម គឺជា «ការពង្រីក ការពង្រឹងនិងការបង្កើនល្បឿននៃភ្ជាប់ទំនាក់ទំនងគ្នាទូទាំងសកលលោកនៅក្នុងគ្រប់ទិដ្ឋភាពនៃជីវភាពសង្គម នាពេលបច្ចុប្បន្ន។»[៥] ប៉ុន្តែ យ៉ាងហោចណាស់ ការយល់ឃើញបីផ្សេងគ្នាចំពោះដំណើរការនេះ ប្រកួតប្រជែងគ្នា។

ទស្សនៈមួយមើលឃើញថា សាកលភាវូបនីយកម្ម គឺជាផ្លែផ្កានៃគោលការណ៍សេដ្ឋកិច្ចសេរីនិយម។ ទីផ្សារសកលបាននាំមកនូវកំណើនសេដ្ឋកិច្ចនិងវិបុលភាព (មិនមែនបានដល់ប្រទេសទាំងអស់ទេ ប៉ុន្តែ បានដល់តែប្រទេសភាគច្រើនដែលធ្វើសមាហរណកម្មជាមួយទីផ្សារពិភពលោក)។ ដំណើរការសេដ្ឋកិច្ចបែបនេះបានធ្វើអោយរដ្ឋប្រពៃណីលែងក្លាយជាអង្គភាពសេដ្ឋកិច្ចទៀតហើយ។ ម្ល៉ោះហើយ រដ្ឋនានាបាត់បង់ឬលះបង់សិទ្ធិអំណាច ទៅអោយស្ថាប័នអង្គការអន្តររដ្ឋាភិបាល ដែលប្រតិបត្តិការជំនួសខ្លួនដូចជា មូលនិធិរូបិយវត្ថុអន្តរជាតិ(IMF) និងសហភាពអឺរ៉ុប(EU)និងតួអង្គឆ្លងដែនផ្សេងទៀត ដូចជា សារជីវកម្មពហុជាតិ (MNCs) និងអង្គការក្រៅរដ្ឋាភិបាល។ តម្លៃនៃអ្នកបច្ចេកទេសនិងវរជន ពលរដ្ឋដែលមានការអប់រំខ្ពស់ នៅក្នុងប្រទេសប្រជាធិបតេយ្យសេរីកំពុងក្លាយជាគុណតម្លៃសកល ដែលឆ្លុះបញ្ចាំងពីអរិយធម៌សកលលោកថ្មី ដែលកំពុងរីកចម្រើន។ ការបែងចែកអឌ្ឍគោលខាងជើងនិងខាងត្បូង តាមលំអានចាស់ ត្រូវបានគេមើលឃើញថា មិនសូវមានសារៈសំខាន់ទេ ពីព្រោះអឌ្ឍគោលខាងត្បូងកំពុងធ្វើដំណើរក្នុងទិសដៅខុសគ្នា អាស្រ័យលើការធ្វើសមាហរណកម្មរបស់ប្រទេសនិងតំបន់ ជាមួយនឹងទីផ្សារពិភពលោក។

ទស្សនវិស័យលើកទី ២ មានការសង្ស័យចំពោះការអះអាងទាំងនេះអំពីសកលភាវូបនីយកម្ម។ ការសង្ស័យបែបនេះគួសបញ្ជាក់ថា បច្ចុប្បន្ន ប្រទេសមហាសេដ្ឋកិច្ចសំខាន់ៗលើពិភពលោក ក៏មិនមានកម្រិតសមាហរណកម្មខ្លាំងជាងសម័យមុនពេលសង្គ្រាមលោកលើកទី ១ ណាស់ណាដែរ (នៅពេលដែលប្រទេស

[៥] Held, David, Anthony McGrew, David Goldblatt, and Jonathan Perraton. *Global Transformations: Poli- tics, Economics and Culture.* Stanford, ១៩៩៩: ២.

អនុត្តរភោពអង់គ្លេស បានផ្តល់នូវការរំពឹងទុក និងស្តាប័នរួមមួយចំនួន)។ ក្រុមអ្នកមន្ទិលសង្ស័យក៏មិនយល់ស្របនឹងអំណះអំណាងដែលថា ការបែងចែកតំបន់និងភូមិសាស្ត្រ ដូចជា ការបែងចែកអឌ្ឍគោលខាងជើង និងខាងត្បូង កំពុងរលុបបន្តិចម្តងៗ ជំនួសដោយទីផ្សារសកលរួមមួយ។ ផ្ទុយទៅវិញ ពួកគេមើលឃើញគម្លាតអឌ្ឍគោលខាងជើងនិងខាងត្បូង កាន់តែកែកធំឡើងៗ ជាមួយនឹងសាកលភាវូបនីយកម្ម។ ដូចគ្នានេះផងដែរ ការធ្វើសមាហរណកម្មសេដ្ឋកិច្ចរបស់រដ្ឋទាំងឡាយ មិនបណ្តាលអោយមានតំបន់ពាណិជ្ជកម្មសេរីតែមួយនៅលើពិភពលោកទេ ប៉ុន្តែ នឹងមានប្លុកក្នុងតំបន់ដែលប្រកួតប្រជែងនឹងគ្នា ដូចជានៅអាមេរិក អឺរ៉ុប និងអាស៊ី។ អរិយធម៌ពិភពលោកថ្មីដែលគេគិតថាកំពុងលេចឡើង ត្រូវបានបញ្ជាក់ថាមិនអាចទៅរួច ដោយសារការបំបែកអង្គភាពនយោបាយធំៗ (ដូចជាសហភាពសូវៀត) អោយទៅជារដ្ឋតូចៗជាច្រើន អាស្រ័យទៅតាមភាសា សាសនា និងកត្តាវប្បធម៌ផ្សេងទៀត។

ទស្សនៈវិស័យទីបី មើលឃើញសកលភាវូបនីយកម្មកាន់តែមានភាពស៊ីជម្រៅ ជាងក្រុមអ្នកមន្ទិលសង្ស័យ ប៉ុន្តែ មិនប្រាកដជឿជាក់ខ្លាំងដូចក្រុមអ្នកគាំទ្រសេដ្ឋកិច្ចសេរីនិយមឡើយ។ «ក្រុមអ្នកផ្លាស់ប្តូរទម្រង់និយម»ទាំងនេះ សង្កេតឃើញថា អធិបតេយ្យភាពរបស់រដ្ឋ កំពុងត្រូវបានកាត់បន្ថយ ដោយសហភាពអឺរ៉ុប អង្គការពាណិជ្ជកម្មពិភពលោក និងបណ្តាស្តាប័នដទៃទៀត ដូច្នេះអធិបតេយ្យភាពនេះ វាលែងជាសិទ្ធិអំណាចដាច់ខាតរបស់រដ្ឋទៀតហើយ ប៉ុន្តែ វាគ្រាន់ជាអំណាចចរចារបស់រដ្ឋតែប៉ុណ្ណោះ។ ការចរចារផ្ទាល់កាន់តែពាក់ព័ន្ធនឹងតួអង្គមិនមែនជារដ្ឋ។ ដូច្នេះ សាកលភាវូបនីយកម្មពង្រាយអំណាច។ អំណាចរដ្ឋមិនត្រូវបានពង្រឹង ឬចុះខ្សោយ ដោយសាកលភាវូបនីយកម្មទេ ប៉ុន្តែ បានផ្លាស់ប្តូរទម្រង់ប្រតិបត្តិការរបស់រដ្ឋក្នុងបរិបទថ្មី ដែលមានឧបករណ៍នយោបាយថ្មី។

រូបថត ក្រុងកំពង់ផែ នាវាផ្ទុកកុងតឺន័រពេញៗ

គិតមើលជាសកល

នៅពេលដែលសេដ្ឋកិច្ចពិភពលោកកាន់តែមានសមាហរណកម្ម វិសាលភាពទីផ្សារនិងផលិតកម្មកំពុងមានលក្ខណៈជាសកល។ កំពង់ផែកុងតឺន័រ នៅទីក្រុងសៀងហៃនេះ ដឹកជញ្ជូនទំនិញទៅនិងមកពីជុំវិញពិភពលោកឆ្នាំ ២០១៣ ។

ខណៈដែលអ្នកប្រាជ្ញជជែកវែកញែកទស្សនៈវិស័យនៃយល់ឃើញទៅលើសាកលភាវូបនីយកម្ម ការជជែកដ៏មានប្រជាប្រិយភាពផ្តោតអារម្មណ៍លើក្រុមហ៊ុនធំ ៗ ដែលកំពុងធ្វើប្រតិបត្តិការជាសកល ដូចជាការខាតបង់ក្នុងការចូលរួមក្នុងទីផ្សារពិភពលោក (ជាឧទាហរណ៍ ការបាត់បង់ការងារធ្វើ និងផលប៉ះពាល់ដល់បរិស្ថាន) គំលាតកាន់តែធំរវាងអ្នកមាននិងអ្នកក្រ ការរួមចំណែករបស់រដ្ឋាភិបាលជាតិនានា ក្នុងផលប៉ះពាល់ទាំងនេះ តាមរយៈការចូលរួមក្នុងអង្គការអន្តរជាតិ (IOs) ផ្សេងៗ ដូចជា អង្គការពាណិជ្ជកម្មពិភពលោក (WTO) និង មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF)។ គោលនយោបាយពង្រីក[តំបន់]ពាណិជ្ជកម្មសេរី គឺជាការផ្តោតអារម្មណ៍ជាពិសេសរបស់ក្រុមបាតុករប្រឆាំងនឹងសកលភាវូបនីយកម្ម (សូមមើលមេរៀនទី ៨)។ ការតវ៉ាតាមដងផ្លូវ បានប្រែទីក្រុងដែលជាម្ចាស់ផ្ទះនៃកិច្ចប្រជុំពាណិជ្ជកម្មអោយក្លាយទៅជាបន្ទាយទាហានមានការយាមកាមតឹងរ៉ឹង ដូចជា នៅទីក្រុងស៊ីអេថល នៅឆ្នាំ ១៩៩៩, ទីក្រុងវ៉ាស៊ីនតោនឌីស៊ី នៅឆ្នាំ ២០០០ (កិច្ចប្រជុំ មូលនិធិរូបិយវត្ថុអន្តរជាតិនិងធនាគារពិភពលោក), ទីក្រុងកេបិច (កិច្ចប្រជុំកំពូល ឆ្នាំ២០០១ កំពុងធ្វើការឆ្ពោះទៅរកតំបន់ពាណិជ្ជកម្មសេរីទ្វីបអាមេរិកខាងជើង)និងទីក្រុងកំពង់ផែជេណូវ៉ា (Genoa) នៃ

ប្រទេសអ៊ីតាលី(កិច្ចប្រជុំកំពូលG៨ ឆ្នាំ ២០០១)ដែលក្រុមបាតុករប៉ះទង្គិចជាមួយប៉ូលីសដែលបានបណ្តាលអោយមនុស្សម្នាក់ស្លាប់។ កិច្ចប្រជុំដ៏សំខាន់របស់អង្គការពាណិជ្ជកម្មពិភពលោកឆ្នាំ ២០០១ ដើម្បីចាប់ផ្តើមជុំពាណិជ្ជកម្មថ្មីមួយត្រូវបានប្រារព្ធឡើងនៅក្នុងប្រទេសកាតា ដែលជាកន្លែងដែលក្រុមអ្នកតវ៉ាមិនមានសិទ្ធិចូលដំណើរការសោះឡើយ។ នៅឯកិច្ចប្រជុំ អង្គការពាណិជ្ជកម្មពិភពលោក ឆ្នាំ ២០០៣ នៅទីក្រុងខែនឃូន ប្រទេសម៉ិកស៊ិក បាតុកររាប់ពាន់នាក់បានដើរដង្ហែក្បួនប្រឆាំងនឹងការចរចា និងឥស្សរជនសេដ្ឋកិច្ចដែលចូលរួមប្រជុំ ប៉ុន្តែត្រូវបានរក្សាគំលាតឱ្យនៅឆ្ងាយពីមជ្ឈមណ្ឌលសន្និសីទអង្គការពាណិជ្ជកម្មពិភពលោក។ លើសពីនេះទៀត នៅក្នុងកិច្ចប្រជុំអង្គការពាណិជ្ជកម្មពិភពលោក ឆ្នាំ ២០០៥ ក្រុមបាតុករបានបាតុកម្មបិទផ្លូវជុំវិញកន្លែងប្រជុំ ហើយខ្លះទៀតហែលទឹកឆ្លងទៅរំខានកិច្ចប្រជុំទៀតផង។ បើទោះជាបាតុកម្មហាក់មានអំពើហិង្សាតិចជាងមុន កិច្ចប្រជុំអង្គការពាណិជ្ជកម្មពិភពលោកនៅតែក្លាយជាគោលដៅនៃបាតុកប្រឆាំងនឹងសកលភាវូបនីយកម្ម នៅទូទាំងសកលលោក ។

វោហាសាស្ត្រប្រឆាំងសកលភាវូបនីយកម្មនេះ បានកើនឡើងយ៉ាងខ្លាំងនៅក្នុងឆ្នាំ ២០១៦ នៅពេលដែលប្រជាពលរដ្ឋអង់គ្លេស បានបោះឆ្នោតប្រជាមតិ ចាកចេញពីសមាជិកភាព ក្នុងសហភាពអឺរ៉ុប ហើយជនជាតិអាមេរិក បានបោះឆ្នោតជ្រើសរើសប្រធានាធិបតី ដូណាល់ ត្រាំ ដែលរិះគន់កិច្ចព្រមព្រៀងពាណិជ្ជកម្មពិភពលោក, ចោទសួរពីតម្រូវការក្នុងការរក្សាសម្ព័ន្ធភាពយោធាណាតូ និងបានសន្យាថានឹងកំណត់ចំនួនជនអន្តោប្រវេសន៍ ពីប្រទេសផ្សេងទៀត ចូលអាមេរិក។ ក្នុងរយៈពេលប៉ុន្មានសប្តាហ៍ក្រោយចូលកាន់តំណែង លោកប្រធានាធិបតី ដូណាល់ ត្រាំ បានដកសហរដ្ឋអាមេរិកចេញពីកិច្ចព្រមព្រៀងពាណិជ្ជកម្មអាស៊ីដ៏ធំមួយ (ភាពជាដៃគូអន្តរប៉ាស៊ីហ្វិក [TPP]), ទាមទារឱ្យសម្ព័ន្ធមិត្តយោធាបន្ថែមខ្នង់ចំណាយរបស់ខ្លួនក្នុងសម្ព័ន្ធភាពយោធាណាតូ, ហើយបានព្យាយាមហាមឃាត់ការធ្វើអន្តោប្រវេសន៍ពីប្រទេសមូស្លីមមួយចំនួនផងដែរ។ ទាំងចលនានយោបាយរបស់អង់គ្លេស និងអាមេរិក ដែលនៅពីក្រោយបាតុភូតទាំងនេះ បានអះអាងថា កម្លាំងឬចលនាសកលបានបង្កគ្រោះថ្នាក់ដល់ពលរដ្ឋ នៅក្នុងប្រទេសទាំងពីរ។

ដូចគ្នាដែលអ្នកប្រាជ្ញមិនយល់ស្របគ្នាលើការយល់ឃើញអំពីសាកលភាវូបនីយកម្ម ក្រុមអ្នកមន្ទិលសង្ស័យ ក៏មិនយល់ស្របគ្នា លើគោលដៅនិងយុទ្ធសាស្ត្រ ក្នុងការប្រឆាំងនឹងសកលភាវូបនីយកម្មដែរ។ សមាជិកសហជីពមកពីអឡាគោលលោកខាងជើង ចង់បញ្ឈប់ការជញ្ជូនការងាររបស់ពួកគេទៅអឡាគោលខាងត្បូង។ ប៉ុន្តែ កម្មករនិយោជិតនៅក្នុងប្រទេសក្រីក្រនៅអឡាគោលខាងត្បូង ប្រហែលជាចង់បានការងារទាំងនោះខ្លាំងណាស់ ដែលជាជំហានដំបូងឆ្ពោះទៅរកប្រាក់ឈ្នួល និងលក្ខខណ្ឌការងារ សមរម្យ (បើធៀបនឹងជម្រើសផ្សេងទៀត នៅក្នុងប្រទេសរបស់ពួកគេ)។ នៅសហរដ្ឋអាមេរិក មនុស្សជាច្រើននៅក្នុងគណបក្សប្រជាធិបតេយ្យដូចជាបេក្ខជនប្រធានាធិបតី ប៊ឺនី សែនឌ័រ (Bernie Sanders) និងគណបក្សសាធារណៈរដ្ឋដូចជាប្រធានាធិបតីត្រាំ បានសម្តែងមន្ទិលសង្ស័យអំពីពាណិជ្ជកម្មពិភពលោក។ យ៉ាងណាក៏ដោយ គណៈបក្សទាំងពីរក៏មានសមាជិកជាច្រើន ដែលគាំទ្រពាណិជ្ជកម្មសេរី។ ហើយខណៈពេលដែលអ្នកគាំទ្រ លោកត្រាំ និងលោក សែនឌ័រ ប្រហែលជាស្របព្រមគ្នាលើគោលនយោបាយពាណិជ្ជកម្ម ពួកគេទំនងជាយល់ស្របគ្នាតិចណាស់លើគោលនយោបាយដទៃទៀត។ ដូច្នេះ ទាំងចលនាគាំទ្រនិងប្រឆាំងសកលភាវូបនីយកម្មមិនមែនជារឿងសាមញ្ញទេ។

សាកលភាវូបនីយកម្មកំពុងបង្កអោយមានការផ្លាស់ប្តូរ ទាំងក្នុងសន្តិសុខអន្តរជាតិ និងទាំងសេដ្ឋកិច្ច

នយោបាយអន្តរជាតិ ដូចដែលយើងនឹងឃើញការពិភាក្សា នៅក្នុងមេរៀនខាងមុខ ក៏ប៉ុន្តែ វាកំពុងផ្លាស់ប្តូរ សេដ្ឋកិច្ចនយោបាយអន្តរជាតិ លឿនជាងនិងខ្លាំងជាសន្តិសុខអន្តរជាតិ។ មេរៀនជាបន្តបន្ទាប់ពិភក្សាប្រធានបទទូលំទូលាយជាច្រើនដែលរងផលប៉ះពាល់ដោយសាកលភាវូបនីយកម្ម។ មេរៀនទី៤ បង្ហាញពីរបៀបដែលតួអង្គមិនមែនជារដ្ឋ ជះឥទ្ធិពលលើគោលនយោបាយការបរទេសរបស់រដ្ឋនីមួយៗ។ មេរៀន៧ពិភាក្សាពីស្ថាប័នសកល ច្បាប់អន្តរជាតិ និងសិទ្ធិមនុស្ស ដែលកាន់តែមានសារៈសំខាន់ខ្លាំងឡើង នៅពេលដែលសាកលភាវូបនីយកម្មនៅតែបន្ត។ មេរៀនទី ៨ និង មេរៀនទី៩ សង្កេតមើលសាកលភាវូបនីយកម្មសេដ្ឋកិច្ចក្នុងវិស័យពាណិជ្ជកម្ម ហិរញ្ញវត្ថុ និងអាជីវកម្ម ដែលរងឥទ្ធិពលសាកលភាវូបនីយកម្មយ៉ាងច្បាស់ក្រឡែត។ មេរៀនទី ១០ ពិចារណាលើ សកលភាវូបនីយកម្ម លើបច្ចេកវិទ្យាព័ត៌មាន នៅពេលដែលពិភពលោកក្លាយជាបណ្តាញតភ្ជាប់ថ្មីមួយ។ មេរៀនទី ១១ ពិភាក្សាអំពីបរិស្ថានពិភពលោកនិងពិនិត្យមើលថា តើការកើនឡើងអន្តរកម្ម តាមរយៈសកលភាវូបនីយកម្ម ជះឥទ្ធិពលលើបរិស្ថានរបស់យើងយ៉ាងដូចម្តេច។ មេរៀនទី ១២ និង ១៣ បរិយាយអំពីការបែងចែកឬគំលាតអឌ្ឍគោលខាងជើងនិងអឌ្ឍគោលខាងត្បូង ដែលជាចំណុចសំខាន់នៃបញ្ហត្តិ សាកលភាវូបនីយកម្ម។

ផ្នែកដែលនៅសេសសល់ក្នុងមេរៀន នឹងពិភាក្សាទិដ្ឋភាព ឬ បរិបទពីរនៃសាកលភាវូបនីយកម្ម ដែលមានឥទ្ធិពលលើវិស័យ(ប្រធានបទ) ដែលបានពិភាក្សាក្នុងមេរៀនជាបន្តបន្ទាប់ៈ (១) ទំនាក់ទំនងក្នុងចំណោមតំបន់ធំៗក្នុងពិភពលោក ជាពិសេសផ្នែកប្រទេសអ្នកមាននៅក្នុងអឌ្ឍគោលខាងជើង និងប្រទេសក្រីក្រក្នុងអឌ្ឍគោលត្បូង និង(២) ការវិវត្តន៍នៃប្រព័ន្ធអន្តរជាតិ ជាងសតវត្សរ៍កន្លងមកនេះ។

១.៣. ភូមិសាស្ត្រសកល

១.៣ ចូរកំណត់អត្តសញ្ញាណរួមរបស់រដ្ឋនានា នៅអឌ្ឍគោលខាងជើង យ៉ាងហោចណាស់ចំនួន ៣ អត្តសញ្ញាណរួមរបស់រដ្ឋនានា នៅអឌ្ឍគោលខាងត្បូង យ៉ាងហោចណាស់ចំនួន ៣ ដែរ។


ដើម្បីគូសបញ្ជាក់ពីចំណេះដឹង ដែលអាចទទួលបាន ដោយការវិភាគកម្រិតសកល សៀវភៅនេះបែងចែកពិភពលោកជា៩តំបន់ធំៗ។ តំបន់នីមួយៗមានចំនួនរដ្ឋខុសៗគ្នា ហើយក៏មានវប្បធម៌ ភូមិសាស្ត្រ និងភាសាចម្រុះគ្នាដែរ។ ប៉ុន្តែ តំបន់នីមួយៗតំណាងអោយទីតាំងភូមិសាស្ត្រផ្សេងៗក្នុងពិភពលោក ហើយរួមគ្នាបង្កើតបានជាតំបន់រួមធំៗ។

គម្លាតអឌ្ឍគោលខាងជើងនិងអឌ្ឍគោលខាងត្បូង រវាងបណ្តានប្រទេសឧស្សាហកម្ម រីកចម្រើននៅអឌ្ឍគោលខាងជើង និងបណ្តាប្រទេសក្រីក្រ នៅអឌ្ឍគោលខាងត្បូង គឺជាសមាសធាតុភូមិសាស្ត្រសំខាន់បំផុត នៅក្នុងការវិភាគកម្រិតសកល។ តំបន់នានាដែលត្រូវបានប្រើប្រាស់នៅក្នុងសៀវភៅនេះ ត្រូវបានគូសឡើងដើម្បីបែងចែក (ដោយមានករណីលើកលែងមួយចំនួន) ប្រទេសអ្នកមាន ពីប្រទេសក្រីក្រ។ អឌ្ឍគោលខាងជើងរួមបញ្ចូលទាំងបស្ចឹមប្រទេស (ប្រទេសអ្នកមាន នៅទ្វីបអាមេរិកខាងជើង អឺរ៉ុប និង ប្រទេសជប៉ុន) និងអតីតបូព៌ាប្រទេស រួមបញ្ចូលទាំងអតីតសហភាពសូវៀត (ឥឡូវប្រទេសរុស្ស៊ី) និងកោគទ្រព្យរួមនៃ រដ្ឋឯករាជ្យក្នុងអតីតសហភាពសាធារណរដ្ឋសូវៀត ដោយមិនរាប់បញ្ចូលបណ្តារដ្ឋបាល់ទិកនានា[៦]។ អឌ្ឍគោលខាងត្បូងរួមបញ្ចូលអាមេរិកឡាទីន អាហ្វ្រិក មជ្ឈិមបូព៌ា និងតំបន់អាស៊ីជាច្រើន។ អឌ្ឍគោលខាងត្បូងជា

[៦] ចូរចំណាំថា ការកំណត់ភូមិសាស្ត្រដូចជា «ខាងលិច» និង «មជ្ឈិមបូព៌ា» យកអឺរ៉ុបជាគោល។ ឧទាហរណ៍ ពីប្រទេសកូរ៉េ ចិន និងរុស្ស៊ី នៅខាងលិច ហើយជប៉ុន និងអាមេរិក នៅខាងកើត។

ញឹកញាប់ត្រូវបានគេហៅថា ប្រទេស*ឥតិយរលោក* (ក្រុមប្រទេសទីបី(៣) បន្ទាប់ពីក្រុមប្រទេសលោកខាងលិច(១) និងក្រុមប្រទេសលោកខាងកើត(២))។ វាជាបច្ចេកពាក្យ ដែលនៅតែត្រូវបានគេប្រើយ៉ាងទូលំទូលាយ បើទោះបីជាក្រុមប្រទេសទីពីរ *លោកខាងកើត* បានដួលរលំហើយក្តី។ បណ្តាប្រទេសនៅអឌ្ឍគោលខាងត្បូង ក៏ត្រូវបានគេហៅថា ប្រទេស«កំពុងអភិវឌ្ឍ» ឬ ប្រទេស«អភិវឌ្ឍតិច»(LDCs) ដែលផ្ទុយពីប្រទេស«អភិវឌ្ឍន៍» នៅអឌ្ឍគោលខាងជើង។ តំបន់ទាំង៩ ក្នុងពិភពលោកត្រូវបានបង្ហាញក្នុង ក្រាហ្វិក១.២។

ក្រាហ្វិក ១.២ តំបន់ទាំង ៩ លើពិភពលោក



សម្គាល់៖ ក្នុងទំនាក់ទំនងអន្តរជាតិ ពិភពលោកត្រូវបែងចែកជា៩តំបន់ និង២អឌ្ឍគោល ជើង-ត្បូង

លក្ខណៈវិនិច្ឆ័យមួយចំនួន ក្រៅពីកម្រិតប្រាក់ចំណូល ដួយបែងចែកតំបន់ជាប់ភូមិសាស្ត្រសំខាន់ៗ។ បណ្តាប្រទេស ដែលមានកម្រិតសេដ្ឋកិច្ច វប្បធម៌ និងភាសា ត្រូវបានរក្សាទុកក្នុងតំបន់ជាមួយគ្នា តាមតែអាចធ្វើទៅបាន។ រដ្ឋដែលមានប្រវត្តិទំនាក់ទំនងជាមួយគ្នា រួមមាន ដូចជាធ្លាប់នៅក្នុងចក្រភពតែមួយ ក្នុងប្រវត្តិសាស្ត្រ ឬតំបន់ជួញដូរជាមួយគ្នា ក៏ត្រូវបានដាក់បញ្ចូលគ្នា នៅក្នុងតំបន់រួមផងដែរ។ ចុងក្រោយ ប្រទេសដែលអាចបង្រួបបង្រួម នៅក្នុងពេលអនាគត ជាពិសេស ប្រទេសកូរ៉េខាងត្បូងជាមួយនឹងប្រទេសកូរ៉េខាងជើង និងប្រទេសចិនជាមួយនិងកោះតៃវ៉ាន់ ក៏ត្រូវបានរក្សាទុកនៅក្នុងតំបន់តែមួយដែរ។ ជាការពិតណាស់ គ្មានគូសវាសបែងចែកតំបន់ណាមួយរៀបចំបានល្អឥតខ្ចោះទេ ហើយរដ្ឋខ្លះ ដូចជាប្រទេសទួរគី ត្រូវបានទាញឆ្ពោះទៅតំបន់ចំនួនពីរផ្សេងគ្នា។

ភាគច្រើននៃតំបន់ទាំងនេះ មានឈ្មោះត្រូវគ្នានឹងឈ្មោះភូមិសាស្ត្រ ដែលបានប្រើជាទូទៅ ប៉ុន្តែកំណត់ចំណាំបន្ថែមទៀតនៅទីនេះអាចនឹងជួយអ្នកអានកាន់តែងាយយល់។ *អាស៊ីបូព៌ា* សំដៅទៅលើប្រទេសចិន ជប៉ុន និង កូរ៉េ។ *អាស៊ីអាគ្នេយ៍* សំដៅទៅលើបណ្តាប្រទេស រាប់ពីលិចទៅកើតដូចជា ប្រទេសកូមា ហួសទៅឥណ្ឌូណេស៊ី ហើយហួសទៅហ្វីលីពីន។ ប្រទេសរុស្ស៊ីត្រូវបានគេចាត់ទុកថាជារដ្ឋអឺរ៉ុប ទោះបីជាមួយផ្នែកធំ(ស៊ីបេរី) ស្ថិតនៅក្នុងទ្វីបអាស៊ីក៏ដោយ។ *តំបន់រង្វង់ប៉ាស៊ីហ្វិក* ជាធម្មតា សំដៅលើ អាស៊ីអាគ្នេយ៍និងបូព៌ាស៊ីបេរី និងប៉ាស៊ីហ្វិក តំបន់ឆ្នេរប៉ាស៊ីហ្វិកនៃអាមេរិកខាងជើង និងអាមេរិកឡាទីន។ *អាស៊ីខាងត្បូង* ជួនកាល

រាប់បញ្ចូលទាំងផ្នែកខ្លះនៃតំបន់អាស៊ីអាគ្នេយ៍។ និយមន័យតូចចង្អៀតនៃតំបន់*មជ្ឈឹមបូព៌ា* មិនរាប់បញ្ចូលអាហ្វ្រិកខាងជើង និងទួរគី ទេ។ តំបន់*បាល់កង់* គឺជារដ្ឋនានានៅភាគអាគ្នេយ៍នៃទ្វីបអឺរ៉ុប ដែលរាប់បញ្ចូលទាំងប្រទេសស្លូវេនី រ៉ូម៉ានី និងក្រិក។

តារាង ១.៤ បង្ហាញពី ផលិតផលក្នុងស្រុកសរុប (ផ.ស.ស.) នៃប្រទេសនីមួយៗ លើសកលលោក ដោយរៀបចំឡើងតាមតំបន់នីមួយៗ។ តារាង ១.៥ បង្ហាញពីចំនួនប្រជាជន និងទំហំសេដ្ឋកិច្ច (ផ.ស.ស.) នៃតំបន់នីមួយៗ ធៀបនឹងពិភពលោកទាំងមូល។ ដូចដែលតារាងបានចង្អុលបង្ហាញ កំរិតប្រាក់ចំណូលសម្រាប់ប្រជាជនម្នាក់ៗ នៅអឌ្ឍគោលខាងជើង ជារួម មានទំហំជាង ៥ ដង ខ្ពស់ជាងអឌ្ឍគោលខាងត្បូង។ *អឌ្ឍគោលខាងជើងមានចំនួនប្រជាជនត្រឹមតែ ២០ ភាគរយ នៃប្រជាជនសរុបលើពិភពលោក ប៉ុន្តែមានផលិតកម្មទំនិញនិងសេវាកម្ម ចំនួន ៦០ ភាគរយ ក្នុងចំណោមផលិតកម្មទូទាំងពិភពលោក*។ ចំណែកប្រជាជនពិភពលោក ៨០ ភាគរយទៀត រស់នៅអឌ្ឍគោលខាងត្បូង ដែលមានផលិតកម្មទំនិញ និងសេវាកម្មត្រឹមតែ ៤០ ភាគរយ ប៉ុណ្ណោះ។

តារាង១.៤.បណ្តារដ្ឋ-ដែនដីនឹងផលិតផលក្នុងស្រុកសរុបឆ្នាំ២០១៧ (គិតជាប៊ីលានដុល្លារអាមេរិក)

អាមេរិក					
សហរដ្ឋអាមេរិក	១៩០០០	កាណាដា	២០០០	បាហាម៉ា	១០
អឺរ៉ុប					
អាឡឺម៉ង់[ក]	៣៥០០	សាធារណរដ្ឋឆែក[ក]	២០០	ឡាតវី	៣០
អង់គ្លេស	២៧០០	ក្រិក[ក]	២០០	អេស្តូនី[ក]	២០
បារាំង[ក]	២៥០០	ព័រទុយហ្គាល់[ក]	២០០	កោះស៊ីប[ក]	២០
អ៊ីតាលី[ក]	១៩០០	ហ្វាំងឡង់[ក]	២០០	បូស្នៀនិងហេ.	២០
អេស្ប៉ាញ[ក]	១២០០	រ៉ូម៉ានី[ក]	២០០	អ៊ីស្លង់	២០
ហុល្លង់[ក]	៨០០	ហុងគ្រី[ក]	១០០	អាល់បានី	១០
ស្វីស	៧០០	ស្លូវ៉ាគី[ក]	១០០	ម៉ាសេដូនី	១០
ប៉ូឡូញ[ក]	៥០០	លុចសំបួរ	៦០	ម៉ាល់តា[ក]	១០
បែលហ្សិក[ក]	៥០០	ក្រូអាត	៥០	ម៉ុងតេណេហ្គ្រូ	៥
ស៊ុយអែត[ក]	៥០០	ស្លូវេនី[ក]	៥០	លីឈិនស្តាញ	៤
ណ័រវេស	៤០០	ប៊ុលហ្គារី[ក]	៥០	អង់ដូរ៉ា	៣
អូទ្រីស[ក]	៤០០	សៃប៊ី	៤០	ម៉ូណាកូ	១
ដាណឺម៉ាក[ក]	៣០០	លីធូអានី[ក]	៤០	សានម៉ារីណូ	១
អៀរឡង់[ក]	៣០០				
ជប៉ុននិងប៉ាស៊ីហ្វិក					
ជប៉ុន	៥០០០	ហ្វីជី	៥	ណៅរូ	០
កូរ៉េខាងត្បូង	១៤០០	គាំ[ខ]	៤	កោះម៉ាហ្សាល់	០
អូស្ត្រាលី	១២០០	កោះសូឡូម៉ុន	១	ប៉ាឡៅ	០

ណូវែលហ្សេឡង់	២០០	សាម៉ូអា	១	គីរីបាទី	០
កូរ៉េខាងជើង	៤០	វ៉ានួទូ	១	ទូវ៉ាលូ	០
កោះហ្វីណេថ្មី	២០	ទុងហ្គា	១	មីក្រូនេស៊ី	០
រុស្ស៊ីនិងរដ្ឋឯករាជ្យ					
រុស្ស៊ី	១៥០០	បេឡារុស	៥០	តាគីជីស្ថាន	១០
កាហ្សាក់ស្ថាន	២០០	ទួរមិនីស្ថាន	៤០	គីហ្គីស្ថាន	១០
អ៊ុយក្រែន	១០០	ហ្សកហ្ស៊ី	២០	ម៉ុលដូវ៉ា	១០
អាហ្សឺបៃហ្សាន	៣០	អាមេនៀ	១០	ម៉ុងហ្គោលី	១០
អ៊ូបេគីស្ថាន	៣០				
ចិនដីគោក					
ចិន	១១០០០	ហុងកុង[ខ]	៣០០	ម៉ាកាវ[ខ]	៤០
តៃវ៉ាន់[ខ]	៥០០				
មជ្ឈឹមបូព៌ា					
ទួរគី	៩០០	អ៊ីរ៉ាក់	២០០	ឡេបាណន់	៥០
សោឌីអារ៉ាប់	៧០០	កាតារ	២០០	លីប៊ី	៤០
អ៊ីរង់	៥០០	គុយវ៉ែត	១០០	ហ្សកដង់	៤០
អារ៉ាប់អេមីរ៉ាត់រួម	៥០០	ម៉ូរ៉ូកូ	១០០	បារ៉ែន	៣០
អេហ្ស៊ីប	៣០០	អូម៉ង់	៧០	យេម៉ែន	៣០
អ៊ីស្រាអែល/ប៉ាឡេស្ទីន	៣០០	ទុយនេស៊ី	៥០	ស៊ីរី	២០
អាល់ហ្សេរី	២០០				
អាមេរិកឡាទីន					
ប្រេស៊ីល	១៨០០	ប៉ាណាម៉ា	៦០	ស៊ូរីណាមេ	៤
ម៉ិកសិក	១១០០	អ៊ុយរ៉ាហ្គាយ	៥០	ហ្គាអាណា	៤
អាហ្សង់ទីន	៦០០	ប៉ារ៉ាហ្គាយ	៣០	បេលីស៍	៣
កូឡុមប៊ី	៣០០	អែលសាវ៉ាឌ័រ	៣០	កោះវឺជីន[ខ]	២
វ៉េណេហ្ស៊ុអេឡា	៣០០	បូលីវី	៣០	ហ្គាយ៉ាណាបារាំង[ខ]	២
ឈីលី	៣០០	ហុងឌួរ៉ា	២០	លូសៀ	២
ប៉េរូ	២០០	ទ្រីនីដាដ&តូបាហ្គូ	២០	អង់ទីគួ & បាប៊ូដា	២
អេក្វាដ័រ	១០០	ដេមែកា	១០	ហ្គ្រេណាដា	១
ពឺរតូរីកូ[ខ]	១០០	នីការ៉ាហ្គ័រ	១០	វ៉ាំងសង់	១
គុយបា	៩០	ហៃទី	១០	គីតនិងនេវីស៍	១
សាធារណរដ្ឋដូមីណិក	៨០	ម៉ាទីនិក[ខ]	៧	ដូមីនីក	១
គ្វាតេម៉ាឡា	៧០	បាបេដូ	៥		

កូស្តារីកា	៦០	ប៉ារ្មូដា[ខ]	៥		
អាស៊ីទក្សិណ					
ឥណ្ឌា	២៣០០	វៀតណាម	២០០	អាហ្វហ្គានីស្ថាន	២០
ឥណ្ឌូនេស៊ី	៩០០	បង់ក្លាដេស	២០០	ឡាវ	២០
ថៃ	៤០០	ស្រីលង្កា	៩០	ម៉ាល់ឌីវ	៤
ប៉ាគីស្ថាន	៣០០	ភូមា	៧០	ប៊ូតាន	៣
ម៉ាឡេស៊ី	៣០០	នេប៉ាល់	៣០	ទីម័រកើត	២
ហ្វីលីពីន	៣០០	កម្ពុជា	២០		
សិង្ហបុរី	៣០០	ប្រ៊ុយណេ	២០		
អាហ្វ្រិក					
នីហ្សេរីយ៉ា	៤០០	ហ្ស៊ីមបាវ៉េ	២០	ស្វាហ្ស៊ីឡង់	៥
អាហ្វ្រិកខាងត្បូង	៣០០	ម៉ូហ្សំប៊ីក	១០	តូហ្គូ	៥
អង់ហ្គោឡា	១០០	ម៉ាដាហ្គាស្កា	១០	សេរ៉ាឡេអូន	៥
ស៊ូដង់	១០០	ម៉ូរីទីស	១០	ប៊ូរុនឌី	៤
អេត្យូពី	៨០	ប៊ូគីណាហ្វាសូ	១០	សា.អាហ្វ្រិកកណ្តាល	៣
កេនយ៉ា	៧០	ឆែដ	១០	អេរីទ្រៀ	៣
ហ្គាណា	៥០	ណាមីប៊ី	១០	ឡេសូថូ	៣
តង់ហ្សានី	៥០	អេក្វាឌ័រហ្គីណេ	១០	ជីប៊ូទី	៣
កូឌីវ័រ	៤០	សាធារណរដ្ឋកុងហ្គោ	១០	រីញូញ៉ូន[ខ]	៣
កាម៉េរូន	៣០	នីហ្សេ	១០	ហ្គាំប៊ី	២
អ៊ុយហ្គង់ដា	៣០	រ៉្វាន់ដា	១០	ខេប វឺដ	២
កុងហ្គោ	៣០	បេនីន	១០	លីបេរី	២
បូស្វាណា	២០	ហ្គីណេ	១០	សីឈែល	១
ហ្សាំប៊ី	២០	ស៊ូដង់ត្បូង	១០	ហ្គីណេប៊ីសូ	១
ហ្សេនហ្គាល់	២០	ម៉ាឡាវី	៦	កោះកូម៉ូរ៉ូស៍	១
ហ្គាប៊ុន	២០	ម៉ូរីតានី	៦	សៅតូម៉េ	០
ម៉ាលី	២០	សុម៉ាលី	៦		

សម្គាល់៖ ក. សហភាពអឺរ៉ុប, *ខ.* មិនមែនជាសមាជិកអ.ស.ប.។ ចូរសម្គាល់ផងដែរថា ទិន្នន័យ ផ.ស.ស. មិនមែនជាចំនួនគត់ជាក់ស្តែង តាមធម្មតា។ ការប៉ាន់ប្រមាណសម្រាប់ប្រទេសរុស្ស៊ីនិងរដ្ឋឯករាជ្យ ចិន និងប្រទេសសេដ្ឋកិច្ចក្រៅទីផ្សារ ឬសេដ្ឋកិច្ចអន្តរកាលផ្សេងទៀត គេគួរប្រុងប្រយ័ត្នជាពិសេស ហើយគួរតែត្រូវបានប្រើដោយប្រុងប្រយ័ត្ន។ លេខខាងក្រោម ០.៥ ត្រូវបានដាក់ចំនួនគត់ ០ ។

ប្រភព៖ ទិន្នន័យផ្អែកលើការគណនារបស់ធនាគារពិភពលោក។

នៅក្នុងចំណោមអឌ្ឍគោលខាងជើង ប្រទេសរុស្ស៊ីនិងកោគទ្រព្យរួមនៃរដ្ឋឯករាជ្យ មានកម្រិតប្រាក់ចំណូលទាប បើធៀបនឹងតំបន់ដទៃក្នុងអឌ្ឍគោលជាមួយគ្នា ដោយសារទទួលរងនូវការធ្លាក់ចុះសេដ្ឋកិច្ច នៅទសវត្សរ៍ឆ្នាំ ១៩៩០។ នៅអឌ្ឍគោលខាងត្បូង តំបន់មជ្ឈឹមបូព៌ា អាមេរិកឡាទីន ហើយថ្មីៗនេះ ប្រទេសចិន បានទទួលកម្រិតប្រាក់ចំណូលខ្ពស់ជាង ទ្វីបអាហ្វ្រិកនិងអាស៊ីខាងត្បូង ដែលនៅតែក្រីក្រគោកយ៉ាកខ្លាំង។ សូម្បីតែនៅក្នុងតំបន់ដែលមានចំណូលខ្ពស់ជាងនេះ របាយប្រាក់ចំណូល មិនស្មើគ្នាទេហើយមនុស្សជាច្រើននៅតែស្ថិតក្នុងភាពក្រីក្រណាស់ដែរ។ ចូរកត់សម្គាល់ថា ចំនួនប្រជាជនជាងពាក់កណ្តាលនៃប្រជាជនលើពិភពលោក រស់នៅក្នុងតំបន់កក់កុញខ្លាំង (ហើយក្រីក្រ) នៃអាស៊ីខាងត្បូងនិងចិន។ អ្នកប្រាជ្ញទំនាក់ទំនងអន្តរជាតិ មិនមានការពន្យល់ល្អ សម្រាប់គម្លាតប្រាក់ចំណូលកាន់តែធំ ក្នុងអឌ្ឍគោលខាងជើងនិងអឌ្ឍគោលខាងត្បូងទេ (សូមមើលមេរៀនទី ១២)។

តារាង ១.៥ ការប្រៀបធៀបតំបន់នានាលើពិភពលោក ឆ្នាំ ២០១៧

តំបន់	ចំនួនប្រជាជន(លាន)	ផ.ស.ស. (ទ្រីលាន$)	ផ.ស.ស.ម្នាក់ៗ ($)
អឌ្ឍគោលខាងជើង			
អាមេរិកខាងជើង	៣៦០	$២១	$៤៩០០០
អឺរ៉ុប	៥៥០	១៧	៣៣០០០
ជប៉ុន/ប៉ាស៊ីហ្វិក	២៥០	៨	៣១០០០
រុស្ស៊ី/រដ្ឋឯករាជ្យ	២៩០	២	៩០០០
អឌ្ឍគោលខាងត្បូង			
ចិន	១៤៥០	១២	៧០០០
មជ្ឈឹមបូព៌ា	៥០០	៤	៧៦០០
អាមេរិកឡាទីន	៦៥០	៥	៨៣០០
អាស៊ីទក្សិណ	២៥០០	៥	១៨០០
អាហ្វ្រិក	១០៥០	២	១៥០០
សរុបអឌ្ឍគោលខាងជើង	**១៤៥០ (២០%)**	**៤៨ (៦៨%)**	**៣០៥០០**
សរុបអឌ្ឍគោលខាងត្បូង	**៦១៥០ (៨០%)**	**២៨ (៣៧%)**	**៥២០០**
សរុបពិភពលោក	**៧៦០០**	**$៧៦**	**$១០១០០**

ចំណាំ៖ ទិន្នន័យខាងលើបានពីតួលេខផ.ស.ស. ឆ្នាំ២០១៧ (ក្នុងឆ្នាំ ២០១៨ គិតជាដុល្លារអាមេរិក) ពីតារាង ១.៤; ការប៉ាន់ប្រមាណសម្រាប់ប្រទេសរុស្ស៊ីនិងរដ្ឋឯករាជ្យ និងប្រទេសចិន គួរតែត្រូវបានប្រើដោយប្រុងប្រយ័ត្ន។ *ប្រភព៖* ទិន្នន័យផ្អែកលើការគណនារបស់ធនាគារពិភពលោក។

១.៤. ប្រព័ន្ធអន្តរជាតិកំពុងវិវត្ត

១.៤ ចូរពន្យល់ភាពខុសគ្នារវាងប្រព័ន្ធអន្តរជាតិ កំឡុងសម័យសង្គ្រាមត្រជាក់ និងក្រោយសម័យសង្គ្រាមត្រជាក់ យ៉ាងហោចណាស់ អោយបានពីរចំណុចផ្សេងគ្នា។

រចនាសម្ព័ន្ធនិងគោលការណ៍ជាមូលដ្ឋាននៃទំនាក់ទំនងអន្តរជាតិ បានចាក់ឫសយ៉ាងជ្រៅ ក្នុងការអភិវឌ្ឍន៍ជាប្រវត្តិសាស្ត្រ។ ក្នុងសៀវភៅនេះ យើងនឹងសង្កេតមើលប្រវត្តិសាស្ត្រ ដែលមានប្រធានបទនានា ដូចជា ប្រព័ន្ធ

មហាអំណាច (មេរៀនទី ២), ចក្រពត្តិនិយម (មេរៀនទី ១២), និង ជាតិនិយម (មេរៀនទី ៥)។ នៅទីនេះ យើងនឹងពិនិត្យមើលព្រឹត្តិការណ៍សំខាន់ៗនៃសតវត្សរ៍ទី ២០ ហើយផ្តោតជាពិសេស លើយុគសម័យក្រោយ សង្គ្រាមត្រជាក់ ចាប់តាំងពី ឆ្នាំ ១៩៩០ ឡើងទៅ។

១.៤.១. សង្គ្រាមលោកចំាងពីរ ឆ្នាំ ១៩០០-១៩៥០

សង្គ្រាមលោកលើកទី ១ (១៩១៤-១៩១៨) និង សង្គ្រាមលោកលើកទី ២ (១៩៣៩-១៩៤៥) ប្រព្រឹត្តិទៅអស់រយៈពេលត្រឹមតែ ១០ ឆ្នាំនៃសតវត្សទី ២០ ប៉ុណ្ណោះ (សូមមើលក្រាហ្វិក ១.៣) ប៉ុន្តែ វាបានជះឥទ្ធិពលយ៉ាងជ្រាលជ្រៅ ដោយដៅចំណុចសំគាល់ប្រចាំសតវត្សរ៍នេះ (បាននិយាយអំពីសតវត្សទី២០ គេនឹកឃើញដល់សង្គ្រាមទាំងពីរ)។ ចាប់តាំងពីពេលនោះមក មិនធ្លាប់មានសង្គ្រាមបែបនេះកើតឡើងឡើយ ហើយវាបានក្លាយជាតំរុយសម្រាប់ប្រៀបធៀបពិភពលោក ដែលយើងកំពុងរស់នៅបច្ចុប្បន្ននេះ។ នៅក្នុងប្រវត្តិសាស្ត្រ ប្រហែលមានតែករណីពីរផ្សេងទៀតប៉ុណ្ណោះ នោះគឺ សង្គ្រាមសាមសិបឆ្នាំ និងសង្គ្រាមណាប៉ូឡេអុង។ សង្គ្រាមលោកទាំងពីរជាសង្គ្រាមសកល ឬ សង្គ្រាមអនុត្តរភាពដែលភាគច្រើននៃរដ្ឋធំៗ បានចូលរួមក្នុងការតស៊ូប្រយុទ្ធដោយប្រើប្រាស់ធនធានដែលមានទាំងអស់ ដើម្បីកំណត់អនាគតនៃប្រព័ន្ធអន្តរជាតិ។

សម្រាប់មនុស្សជាច្រើន សង្គ្រាមលោកលើកទី ១ ជានិមិត្តរូបនៃសោកនាដកម្មនៃសង្គ្រាម ដែលមិនសមនឹងកើតឡើង។ វាទាក់ទាញចំណាប់អារម្មណ៍ដល់អ្នកប្រាជ្ញទំនាក់ទំនងអន្តរជាតិនានា ព្រោះវាជាសង្គ្រាមមហន្តរាយ ដែលហាក់ដូចជាមិនគួរណាផ្ទុះឡើងសោះ ហើយក៏ប្រហែលជាមានភាពចៃដន្យ។ បន្ទាប់ពីរក្សាបាននូវសន្តិភាពគួរសម អស់រយៈពេលមួយសតវត្សរ៍ ប្រទេសមហាអំណាចបានលើកទ័ពចូលសមរភូមិប្រយុទ្ធប្រឆាំងគ្នា ដោយគ្មានហេតុផលរឹងមាំសោះ។ មានគំនិតពេញនិយមមួយដែលថា អឺរ៉ុបនឹងត្រូវបានលើកស្ទួយនិងពង្រឹងឡើងវិញដោយសារសង្គ្រាម៖ យុវជនមានឱកាសបង្ហាញថាខ្លួនជាបុរសពិតៗ នៅលើសមរភូមិនៅក្នុងដំណើរផ្សងព្រេងដ៏រុងរឿង។ គំនិតបែបនេះ បែរជាត្រូវបានបំផ្លាញ ជាមួយនឹងការឈឺចាប់ពេតផ្សាក្រៃលែង ហើយភស្តុតាងថាសង្គ្រាមអត់ប្រយោជន៍។

កាលមុននេះ សង្គ្រាមធំគួរអោយកត់សម្គាល់ជាងគេគឺសង្គ្រាមបារាំង-ព្រុស ក្នុងឆ្នាំ ១៨៧០-១៨៧១ នៅពេលដែលប្រទេសអាឡឺម៉ង់ បានបើកយុទ្ធនាការវាយលុកលឿនរហ័សដូចផ្លេកបន្ទោរ តាមផ្លូវដែកដើម្បីចល័តកងទ័ពទៅសមរភូមិមុខ។ សង្គ្រាមនោះបានបញ្ចប់យ៉ាងឆាប់រហ័ស ហើយមានអ្នកឈ្នះយ៉ាងច្បាស់ក្រឡែត នោះគឺ (អាឡឺម៉ង់)។ ប្រជាជនទាំងឡាយរំពឹងថា សង្គ្រាមក្រោយៗនឹងប្រព្រឹត្តិទៅ តាមលំនាំដូចគ្នា។ ប្រទេសមហាអំណាចទាំងអស់បានធ្វើផែនការយុទ្ធសាស្ត្រ វាយលុកតាមផ្លូវដែក យ៉ាងឆាប់រហ័សនិងរំពឹងទទួលបានជ័យជំនះលឿនដៃរ នោះជាអ្វីដែលគេហៅថា *ពិធីវាយលុក*។ ពួកគេជឿជាក់ថា ប្រទេសដែលវាយប្រហារមុន នឹងទទួលបានជ័យជំនះ។ យោងតាមគោលលទ្ធិទាំងនេះ បើប្រទេសណាមួយកៀងគរកងទ័ព (ជ្រើសរើសទាហាន)សម្រាប់សង្គ្រាម នោះសត្រូវរបស់ខ្លួននឹងត្រូវបង្ខំចិត្តកៀងគរកងទ័ព អោយបានឆាប់រហ័សដែរ។ ដូច្នេះ នៅពេលដែលអ្នកជាតិនិយមជនជាតិស៊ែប៊ីធ្វើឃាតព្រះអង្គម្ចាស់ ហ្វែរឌីណង់ របស់ប្រទេសអូទ្រីស នៅឆ្នាំ ១៩១៤, នៅសារ៉ាជេវ៉ូ(Sarajevo) វិបត្តិដ៏តូចតាចមួយបានកើនឡើង ហើយផែនការកែននិងចល័តទ័ព បានរុញច្រានអឺរ៉ុបឈានដល់មាត់ជ្រោះនៃសង្គ្រាមទាំងមូល។

ក្រាហ្វិក ១.៣ សង្គ្រាមលោកលើកទី ២ ឆ្នាំ ១៩០០-១៩៥០

ប្រភព៖ ក្រសួងការពារជាតិអាមេរិក។

| | | |

ផ្ទុយពីការរំពឹងទុកខាងលើ សង្គ្រាមមិនត្រូវបានបញ្ចប់ភ្លាមៗនោះទេ ហើយក៏មិនមានជ័យជំនះត្រចះត្រចង់ដល់អ្នកណាឡើយ។ សង្គ្រាមបានអូសបន្លាយពេលតាមលេណដ្ឋាន នៅសមរភូមិមុខនៅនឹងមួយកន្លែង។ ជាឧទាហរណ៍ នៅឆ្នាំ ១៩១៧ នៅសមរភូមិប៉ះឈិនដេល (Passchendaele) នៅក្នុងប្រទេសបែលហ្ស៊ិក, កងទ័ពអង់គ្លេស ត្រឹមតែរយៈពេល ៣ ខែ បានបាញ់អស់គ្រាប់កាំភ្លើងធំ ចំនួន៥ តោន ក្នុងចម្ងាយសមរភូមិមុខ ១ ម៉ែត្រ ដែលបាញ់ស្រោចទៅលើរយៈចម្ងាយជាង ១៧ គីឡូម៉ែត្រ និងបណ្តាលអោយមនុស្សចំនួន ៤០០ ០០០ នាក់ ត្រូវបាត់បង់ជីវិត ក្នុងការវាយប្រហារកងទ័ពថ្មើរជើង ដែលបរាជ័យ។ ស្ថានភាពសឹកដ៏គួរអោយរន្ធត់នេះ កាន់តែធ្ងន់ធ្ងរដោយសារអាវុធគីមី និងដោយការប៉ុនប៉ងរបស់ចក្រភពអង់គ្លេសនិងអាឡឺម៉ង់ ដើម្បីធ្វើអោយប្រជាជនរបស់សត្រូវត្រូវដាច់ពោះស្លាប់ ហើយសុំចុះចាញ់។

ប្រទេសរុស្ស៊ីគឺជារដ្ឋដំបូងបង្អស់ដែលត្រូវរង្គោះរង្គើរ។ បដិវត្តនៅក្នុងប្រទេសបានធ្វើអោយរុស្ស៊ីដកខ្លួនចេញពីសង្គ្រាម នៅឆ្នាំ ១៩១៧ ហើយបណ្តាលអោយមានការបង្កើតសហភាពសូវៀត។ ប៉ុន្តែ ការដែលសហរដ្ឋអាមេរិកចូលប្រឡូកក្នុងសង្គ្រាម ប្រឆាំងនឹងអាឡឺម៉ង់ នៅឆ្នាំដដែលនោះ បានធ្វើអោយតុល្យភាពសង្គ្រាមផ្លាស់ប្តូរ។ នៅក្នុងសន្ធិសញ្ញាវែរសៃ (Versailles) នៅឆ្នាំ ១៩១៩ ប្រទេសអាឡឺម៉ង់ត្រូវបានបង្ខំអោយបោះបង់ទឹកដីខ្លួនមួយផ្នែក ផ្តល់សំណង កម្រិតចំនួនសព្វាវុធនិងបរិក្ខារទ័ពផ្សេងទៀតនាពេលអនាគត និងព្រមទទួលកំហុសក្នុងសង្គ្រាម។ ការអាក់អន់ចិត្តរបស់អាឡឺម៉ង់ ប្រឆាំងនឹងលក្ខខ័ណ្ឌដ៏ធ្ងន់ធ្ងរនៃសន្ធិសញ្ញាវែរសៃ នឹងជាកត្តារួមចំណែកដល់ការឡើងអំណាចរបស់ អាដុលហ្វ ហ៊ីត្លែរ នៅទសវត្សរ៍ឆ្នាំ ១៩៣០។ ក្រោយសង្គ្រាមលោកលើកទី ១ ប្រធានាធិបតីសហរដ្ឋអាមេរិក លោក វូដ្រូ វីលសុន (Woodrow Wilson) បានដឹកនាំគំនិតផ្តួចផ្តើមបង្កើត*សម្ព័ន្ធប្រជាជាតិ*ដែលជាអង្គការនាំមុខ មុនអង្គការសហប្រជាជាតិ នាពេលបច្ចុប្បន្ននេះ។ ប៉ុន្តែ ព្រឹទ្ធសភាសហរដ្ឋអាមេរិក នឹងមិនអនុម័តអោយសហរដ្ឋអាមេរិកចូលរួមទេ ម្លោះហើយសម្ព័ន្ធប្រជាជាតិហាក់ដូចជាមិនមានប្រសិទ្ធិភាពឡើយ។ គោលនយោបាយឯកោនិយមរបស់សហរដ្ឋអាមេរិក ក្នុងចន្លោះពេលនៃសង្គ្រាមលោកទាំងពីរ រួមជាមួយនឹងការថមថយរបស់អំណាចចក្រភពអង់គ្លេស និងចលាចលក្នុងប្រទេសរុស្ស៊ីដោយសារបដិវត្តន៍ពួកគេ បានធ្វើអោយមានលំហអំណាចនៅទំនេរ (គ្មានអ្នកកាន់កាប់) នៅក្នុងនយោបាយពិភពលោក។

នៅទសវត្សរ៍ឆ្នាំ ១៩៣០ ប្រទេសអាឡឺម៉ង់និងជប៉ុនបានឈានជើងចូលបំពេញចន្លោះអំណាចនោះដោយបានចាប់ផ្តើមគោលនយោបាយឈ្លានពានពង្រីកទឹកដី ដែលទីបំផុតបានបណ្តាលអោយមានសង្គ្រាមលោកលើកទី២។ ប្រទេសជប៉ុនបានកាន់កាប់កោះតៃវ៉ាន់និងឧបទ្វីបកូរ៉េរួចទៅហើយ បន្ទាប់ពីបានបំបាក់ប្រទេសចិន នៅឆ្នាំ ១៨៩៥ និងប្រទេសរុស្ស៊ី ក្នុងឆ្នាំ ១៩០៥។ នៅឆ្នាំ ១៩៣១ ប្រទេសជប៉ុនបានកាន់កាប់តំបន់ម៉ាន់ជូរី (ភាគឥសាននៃប្រទេសចិន) និងបង្កើតរបបអាយ៉ង នៅទីនោះ។ នៅឆ្នាំ ១៩៣៧ ប្រទេសជប៉ុនបានលុកលុយប្រទេសចិន ដែលនៅសេសសល់ ហើយបានចាប់ផ្តើមការកាន់កាប់ដ៏យោរយៅមួយដែលបន្តធ្វើអោយល្អក់កករទំនាក់ទំនងចិន-ជប៉ុន។

ដំណាលពេលនោះដែរ នៅអឺរ៉ុបក្នុងទសវត្សរ៍ឆ្នាំ ១៩៣០ ណាហ្ស៊ីអាឡឺម៉ង់ក្រោមការគ្រប់គ្រងរបស់អ៊ីត្លែរបានចាប់ផ្តើមបំពាក់អាវុធនិងពង្រីកកងទ័ពឡើងវិញ បានធ្វើអន្តរាគមន៍ជួយពួកហ្វាស៊ីសយកជ័យជំនះក្នុងសង្គ្រាមស៊ីវិលនៅអេស្ប៉ាញ និងបានវាតទីដណ្តើមទឹកដីពីប្រទេសជាតិខាង ក្រោមលេសថា ដើម្បីបង្រួបបង្រួមជាតិសាសន៍អាឡឺម៉ង់នៅក្នុងទឹកដីទាំងនោះ អោយរួមរស់ជួបជុំនឹងជាតិសាសន៍អាឡឺម៉ង់ក្នុងមាតុភូមិ

ឡើងវិញ។ អ៊ីតែ្លរកាន់តែថ្លើមធំ ដោយសារកំសោយរបស់សហគមន៍អន្តរជាតិ និងសម្ព័ន្ធប្រជាជាតិនានា ក្នុងការឆ្លើយតបទៅនឹងការឈ្លានពានដោយរបបហ្វាស៊ីស នៅប្រទេសអ៊ីតាលី និងអេស្ប៉ាញ។ ក្នុងកិច្ចប្រឹងប្រែងស្របតាមមហិច្ឆតារបស់អាឡឺម៉ង់ ចក្រភពអង់គ្លេស និងបារាំង បានព្រមព្រៀងគ្នា នៅក្នុង**កិច្ចព្រមព្រៀងទីក្រុងមុយនិច** (Munich Aggrement) នៅឆ្នាំ ១៩៣៨ អោយប្រទេសអាឡឺម៉ង់កាន់កាប់ផ្នែកខ្លះនៃប្រទេសឆេកូស្លូវ៉ាគី (ត្រូវបានគេស្គាល់ថាជាប្រទេសស៊ូដេចិនឡែន (Sudetenland))។ ការស្របតាមមហិច្ឆតាអាឡឺម៉ង់ទទួលបានមានអត្ថន័យអវិជ្ជមាន នៅក្នុងទំនាក់ទំនងអន្តរជាតិ ពីព្រោះកិច្ចព្រមព្រៀងទីក្រុងមុយនិចហាក់ដូចជាជំរុញអ៊ីតែ្លរពង្រីកការឈ្លានពានបន្តទៀត។

នៅឆ្នាំ ១៩៣៩ ប្រទេសអាឡឺម៉ង់បានចូលឈ្លានពានប្រទេសប៉ូឡូញ ដែលបណ្តាលអោយ ចក្រភពអង់គ្លេសនិងបារាំងចូលរួមធ្វើសង្គ្រាមប្រឆាំងនឹងប្រទេសអាឡឺម៉ង់។ អ៊ីតែ្លរបានចុះហត្ថលេខាលើកតិកាសញ្ញាមិនឈ្លានពានជាមួយមាសត្រូវរបស់ខ្លួន គឺ លោក យ៉ូសែប ស្តាលីន នៃសហភាពសូវៀត ហើយបានបញ្ជូនកម្លាំងសរុបនៃកងទ័ពចូលវាយលុកប្រទេសបារាំង ហើយជាលទ្ធផល ពួកគេអាចកាន់កាប់ទឹកដីបារាំងបានស្ទើរតែទាំងអស់ បានយ៉ាងឆាប់រហ័ស។ បន្ទាប់មក អ៊ីតែ្លរបានក្បត់កិច្ចព្រមព្រៀងជាមួយស្តាលីន និងបានលុកលុយចូលសហភាពសូវៀត នៅឆ្នាំ១៩៤១។ ការវាយលុកត្រូវជួបឧបសគ្គនិងរាំងស្ទះ ហើយប៉ុន្មានឆ្នាំក្រោយមកត្រូវវាយបំបាក់អោយដកថយវិញ។ ប៉ុន្តែ សហភាពសូវៀត បានរងគ្រោះយ៉ាងធ្ងន់ធ្ងរពីការវាយប្រហាររបស់អាឡឺម៉ង់ ដោយបណ្តាលអោយមានមនុស្សស្លាប់ដោយសារសង្គ្រាមលោកលើកទី ២ ចំនួនប្រមាណ ៦០ លាននាក់។ ការប៉ះទង្គិចផ្លូវចិត្តនេះ នៅតែបន្តការចងចាំដ៏ជ្រាលជ្រៅនៅក្នុងផ្នត់គំនិតដែលជះឥទ្ធិពលទៅលើទំនាក់ទំនងអន្តរជាតិ នៅប្រទេសរុស្ស៊ីនិងអឺរ៉ុបខាងកើត។

សហរដ្ឋអាមេរិកបានចូលប្រឡូកក្នុងសង្គ្រាមលោកលើកទី ២ ប្រឆាំងនឹងប្រទេសអាឡឺម៉ង់ ក្នុងឆ្នាំ ១៩៤២។ សេដ្ឋកិច្ចអាមេរិកផលិតសព្វាវុធនិងសម្ភារៈផ្គត់ផ្គង់ដ៏សំខាន់ សម្រាប់កងទ័ពសម្ព័ន្ធមិត្ត។ សហរដ្ឋអាមេរិកបានដើរតួយ៉ាងសំខាន់ជាមួយចក្រភពអង់គ្លេស ក្នុងការទម្លាក់*គ្រាប់បែកជាយុទ្ធសាស្ត្រ*ទៅលើទីក្រុងនានារបស់អាឡឺម៉ង់ រួមមានការទម្លាក់គ្រាប់បែកលើទីក្រុងធំទី២ ឈ្មោះ Dresden នៅខែកុម្ភៈឆ្នាំ ១៩៤៥ ដែលបណ្តាលអោយមានប្រជាជនស៊ីវិលស្លាប់ចំនួន ១០០,០០០ នាក់។ កាលពីឆ្នាំ ១៩៤៤ បន្ទាប់ពីឆ្លងកាត់រូងក្រោមសមុទ្រពីអង់គ្លេស នៅថ្ងៃទី ៦ ខែមិថុនា (ទិវាជ័យជំនះ *D-Day*) កងកំលាំងអាមេរិកនិងអង់គ្លេស បានវាយសម្រុកនិងរុញច្រានចូលប្រទេសអាឡឺម៉ង់ ពីទិសខាងលិច ខណៈដែលកងទ័ពសូវៀតបានវាយរុញច្រានពីទិសខាងកើត។ ប្រទេសអាឡឺម៉ង់ដែលរងការបំផ្លិចបំផ្លាញ ទីបំផុតបានចុះចាញ់និងត្រូវបានកាន់កាប់ដោយអំណាចសម្ព័ន្ធមិត្ត។ នៅចំណុចកំពូលរបស់ខ្លួន ណាហ្ស៊ីអាឡឺម៉ង់និងសម្ព័ន្ធមិត្តរបស់ខ្លួនបានកាន់កាប់អឺរ៉ុបស្ទើរតែទាំងអស់ទៅហើយ លើកលែងតែចក្រភពអង់គ្លេសនិងផ្នែកខ្លះនៃប្រទេសរុស្ស៊ី។

ខណៈពេលដែលសមរភូមិសង្គ្រាមនៅអឺរ៉ុបកំពុងផ្ទុះឡើងយ៉ាងក្តៅគគុក ដោយមិនបានប្រកាសអោយដឹងមុន ប្រទេសជប៉ុនបានបើកធាកប្រយុទ្ធដណ្តើមគ្រប់គ្រងតំបន់អាស៊ីអាគ្នេយ៍ ជាមួយសហរដ្ឋអាមេរិកនិងសម្ព័ន្ធមិត្តរបស់ខ្លួន។ គោលនយោបាយវាយទីនិយមរបស់ជប៉ុន នៅទសវត្សរ៍ឆ្នាំ ១៩៣០ បានគូសបញ្ជាក់ពីបញ្ហាដោយសារការពឹងពាក់ខ្លាំងពេកលើធនធានបរទេស ដែលគោលនយោបាយនេះមានគោលដៅចង់ដោះស្រាយ៖ សហរដ្ឋអាមេរិកបានដាក់ទណ្ឌកម្មប្រទេសជប៉ុន ដោយកាត់ផ្តាច់មិនអោយនាំចេញប្រេងខ្លួនទៅកាន់ប្រទេសជប៉ុន។ ជាការឆ្លើយតប ប្រទេសជប៉ុនបានបំផ្លាញកងទ័ពជើងទឹករបស់សហរដ្ឋអាមេរិកអស់

មួយភាគធំ នៅក្នុងការវាយប្រហារដោយការទម្លាក់គ្រាប់បែក ដ៏គួរអោយភ្ញាក់ផ្អើលមួយ នៅកំពង់ផែ«កើល» (Pearl Harbor) នៅលើកោះហាវ៉ៃ (Hawaii) កណ្តាលមហាសមុទ្រប៉ាស៊ីហ្វិក ក្នុងឆ្នាំ ១៩៤១ ហើយថែមទាំងបានដណ្តើមយកទឹកដីដែលខ្លួនចង់បាន (រួមមាន ឥណ្ឌូនេស៊ី ដែលមានអណ្តូងប្រេង អាចជំនួសប្រេងសហរដ្ឋអាមេរិក)។ ទោះជាយ៉ាងណាសហរដ្ឋអាមេរិកបានស្តារកម្លាំងយោធាថ្មីយ៉ាងឆាប់រហ័ស និងបានដណ្តើមយកប្រជុំកោះប៉ាស៊ីហ្វិក នៅឆ្នាំបន្តបន្ទាប់។ ការទម្លាក់គ្រាប់បែកជាយុទ្ធសាស្ត្រ ទៅលើទីក្រុងជប៉ុនធំៗ ដោយសហរដ្ឋអាមេរិក ត្រូវបញ្ចប់ដោយការប្រើប្រាស់នៃអាវុធនុយក្លេអ៊ែរក្នុងសង្គ្រាម ជាប្រវត្តិសាស្ត្រតែមួយគត់៖ ការបំផ្លាញទីក្រុងហ៊ីរ៉ូស៊ីម៉ា និងណាហ្គាសាគី នៅខែសីហាឆ្នាំ ១៩៤៥ ដែលបណ្តាលអោយជប៉ុនសុំចុះចាញ់ភ្លាមៗ។

មេរៀនរបស់សង្គ្រាមលោកទាំងពីរលើក ហាក់ដូចជាបញ្ជាសគ្នា។ ដោយទាញយកបទពិសោធន៍ពីបរាជ័យនៃកិច្ចព្រមព្រៀងទីក្រុងមុយនិចក្នុងឆ្នាំ ១៩៣៨ ដែលមានលក្ខណៈទន់ភ្លន់ផ្តាប់ចិត្តអ៊ីតែ្លរ មនុស្សជាច្រើនបានទាញសេចក្តីសន្និដ្ឋានថា មានតែគោលនយោបាយការបរទេសធម៌ក្តៅ និងត្រៀមខ្លួនរួចស្រេចក្នុងករណីផ្ទុះសង្គ្រាមទេ ទើបអាចទប់ស្កាត់ការឈ្លានពាននិងរារាំងសង្គ្រាម។ ប៉ុន្តែ នៅឆ្នាំ ១៩១៤ ដោយសារគោលនយោបាយលេងធម៌ក្តៅបែបនេះហើយ ដែលទំនងជាបានបណ្តាលអោយអឺរ៉ុបធ្លាក់ក្នុងអន្លង់សង្គ្រាមដ៏ប្រល័យនោះ។ មែនទែនទៅ សង្គ្រាមនោះគួរតែអាចត្រូវបានបញ្ចៀស តាមរយៈគោលនយោបាយផ្សះផ្សាដែលលេងធម៌ត្រជាក់ជាង។ ប្រាកដណាស់ គោលនយោបាយល្អបំផុត ជួនកាលត្រូវលេងធម៌ក្តៅ ជួនកាលត្រូវលេងធម៌ត្រជាក់ ផ្សះផ្សា។ អ្នកប្រាជ្ញទំនាក់ទំនងអន្តរជាតិ មិនទាន់រកឃើញរូបមន្តសាមញ្ញណាមួយអោយគេជ្រើសរើសនៅឡើយ (សូមមើល«ទ្រឹស្តីនៃមូលហេតុនៃសង្គ្រាម» ក្នុងមេរៀនទី ៥)។

១.៤.២. សង្គ្រាមត្រជាក់ ឆ្នាំ១៩៤៥-១៩៩០

សហរដ្ឋអាមេរិក និង សហភាពសូវៀត បានក្លាយជាមហាអំណាចពីរនៃយុគសម័យក្រោយសង្គ្រាមលោកលើកទី ២ (សូមមើលក្រាហ្វិក ១.៤)។ ប្រទេសនីមួយៗ មានបេសកកម្មបញ្ជ្រាបមនោគមវិជ្ជារបស់ខ្លួន (របបប្រជាធិបតេយ្យ ប្រកួតប្រជែងនឹងរបបកុម្មុយនិស្ត) មានបណ្តាញសម្ព័ន្ធភាពនិងរដ្ឋណាប ហើយក៏មានឃ្លាំងអាវុធនុយក្លេអ៊ែរដ៏មហន្តរាយ រៀងៗខ្លួនដែរ។ អឺរ៉ុបត្រូវបានបែងចែកជាពីរផ្នែក៖ ផ្នែកខាងលិច មានកងកម្លាំងយោធាដ៏ធំសម្បើម រួមបញ្ចូលពីសហរដ្ឋអាមេរិកនិងសម្ព័ន្ធមិត្តរបស់ណាតូ ចំណែកឯនៅខាងកើត មានកងកម្លាំងយោធាដ៏ធំ រួមបញ្ចូលពីសហភាពសូវៀតនិងសម្ព័ន្ធមិត្ត កតិកាសញ្ញាវ៉ាសូវី(warsaw pact)។ អាឡឺម៉ង់ផ្ទាល់ត្រូវបានបំបែក ដោយបីភាគបួននៃប្រទេស និង បីភាគបួននៃក្រុងប៊ែកឡាំង ត្រូវបានកាន់កាប់ដោយ សហរដ្ឋអាមេរិក ចក្រភពអង់គ្លេស និងបារាំង។ ចំណែកមួយភាគបីទៀត ទាំងទីក្រុងនិងប្រទេស ត្រូវបានកាន់កាប់ដោយសហភាពសូវៀត។ វិបត្តិនៅទីក្រុងប៊ែរឡាំង ក្នុងចន្លោះឆ្នាំ ១៩៤៧-១៩៤៨ និង ១៩៦១ នាំអោយមានការប្រឈមមុខដាក់គ្នាដោយប្រដាប់អាវុធ ប៉ុន្តែ មិនផ្ទុះសង្គ្រាមទេ។ នៅឆ្នាំ ១៩៦១ ប្រទេសអាឡឺម៉ង់ខាងកើតបានសាងសង់ជញ្ជាំងប៊ែរឡាំង ដែលខ័ណ្ឌចែកផ្នែកខាងកើតពីផ្នែកខាងលិចនៃក្រុងប៊ែរឡាំង។ វាបានក្លាយជានិមិត្តរូបនៃការបែងចែកអឺរ៉ុប ដោយអ្វីដៃលោក វីនស្តុន ឆឺចឈៀល (Winston Churchill) បានហៅ «រាំងននដែក»។

រូបថត ជញ្ជាំងប៊ែរឡាំង

រាំងននដែក

ក្នុងអំឡុងសង្គ្រាមត្រជាក់ ភាគីអាមេរិក និងសូវៀតបានព្យាយាមពង្រីកឥទ្ធិពលរៀងៗខ្លួន។ អឺរ៉ុបត្រូវបានបែងចែក ហើយអាឡឺម៉ង់ក៏ត្រូវបំបែកជាពីរ ដោយរដ្ឋធានីប៊ែរឡាំងក៏ត្រូវបានបែងចែកជាពីរដែរ។ នៅឆ្នាំ ១៩៦១ ភាគីកុម្មុយនិស្តបានសាងសង់ជញ្ជាំងប៊ែរឡាំងដែលឃើញនៅទីនេះក្នុងឆ្នាំ ១៩៦២ ដើម្បីទប់ស្កាត់ប្រជាជនរបស់ខ្លួនក្នុងផ្នែករបស់ខ្លួនមិនអោយចាកចេញ។ វាត្រូវបានរុះរើនៅពេលដែលសង្គ្រាមត្រជាក់បានបញ្ចប់ នៅក្នុងឆ្នាំ ១៩៨៩ ។

ទោះបីជាមានអរិភាពនៃទំនាក់ទំនងរវាងប្លុកខាងកើតនិងប្លុកខាងលិច ក្នុងអំឡុងសង្គ្រាមត្រជាក់ក្តី ក្របខ័ណ្ឌស្ថេរភាពនៃទំនាក់ទំនងបានកើតឡើង ហើយជម្លោះនានាក៏មិនដែលរីករាលក្លាយជា*សង្គ្រាមសរុប*រវាងរដ្ឋធំៗដែរ។ នៅឯកិច្ចប្រជុំរវាងសហរដ្ឋអាមេរិក-សូវៀត-អង់គ្លេស នៅទីក្រុងយ៉ាល់តា ក្នុងឆ្នាំ ១៩៤៥ នៅពេលអាឡឺម៉ង់ត្រូវបានគេមើលឃើញថាច្បាស់ជារងបរាជ័យ ប្រទេសមហាអំណាចលោកខាងលិចបានទទួលស្គាល់វត្តមានរបស់កងទ័ពសូវៀតនៅអឺរ៉ុបខាងកើត ដោយអនុញ្ញាតអោយតំបន់នោះ បន្តស្ថិតក្រោមឥទ្ធិពលរបស់សូវៀត។ ទោះបីជាប្លុកសូវៀតមិនបានចូលរួមជាមួយស្ថាប័នសេដ្ឋកិច្ចបស្ចឹមលោក ដូចជា មូលនិធិរូបិយវត្ថុអន្តរជាតិ(IMF)ក៏ដោយ ក៏រដ្ឋសំខាន់ៗក្នុងពិភពលោកបានចូលជាសមាជិកអង្គការសហប្រជាជាតិ។

ការបារម្ភរួមគ្នារបស់បស្ចឹមលោកកំឡុងសង្គ្រាមត្រជាក់ គឺថាសហភាពសូវៀតអាចនឹងលេបត្របាក់អឺរ៉ុបខាងលិច ទោះតាមរយៈការឈ្លានពានយ៉ាងគឃ្លើនក្តី ឬតាមរយៈការឡើងកាន់អំណាចនៃពួកកុម្មុយនិស្តនៅក្នុងបណ្តារដ្ឋនៅអឺរ៉ុបខាងលិចដែលញាំញីដោយសង្គ្រាម និងភាពក្រីក្រក្តី។ បើដូច្នោះមែន មូលដ្ឋានឧស្សាហកម្មទាំងមូលនៅដែនដីអឺរ៉ាស៊ី(ពីអឺរ៉ុបទៅស៊ីប៊ែរី)នឹងស្ថិតក្រោមអំណាចរដ្ឋទោលតែមួយ។ *ផែនការម៉ាសាល* (Marshall Plan) ដែលជាជំនួយហិរញ្ញវត្ថុដើម្បីកសាងសេដ្ឋកិច្ចអឺរ៉ុបឡើងវិញ ត្រូវបានបង្កើតឡើងដើម្បី ឆ្លើយតបទៅនឹងការភ័យខ្លាចទាំងនេះ ក៏ដូចជា ការបង្កើតរបស់អង្គការណាតូ ដែរ។ ពាក់កណ្តាលនៃការចំណាយលើវិស័យយោធានៅលើពិភពលោកទាំងមូល ត្រូវបានឧទ្ទិសដល់ការប្រឈមមុខនៅទ្វីបអឺរ៉ុប។ ការចំណាយដ៏ច្រើនលើសលប់ក៏ត្រូវបានយកប្រើក្នុងការប្រណាំងប្រជែងអាវុធនុយក្លេអ៊ែរ ក្នុងនោះ ប្រទេសមហាអំណាចនីមួយៗ បានផលិតអាវុធនុយក្លេអ៊ែររាប់ម៉ឺន (សូមមើលមេរៀនទី ៦)។

តាមរយៈគោលនយោបាយ«**បិទខ្ទប់**»ដែលត្រូវបានអនុម័ត នៅចុងទសវត្សរ៍ឆ្នាំ ១៩៤០ សហរដ្ឋអាមេរិកបានព្យាយាមបញ្ឈប់ការពង្រីកឥទ្ធិពលរបស់សហភាពសូវៀតនៅលើសកលលោក ក្នុងវិស័យជាច្រើនក្នុងពេលតែមួយ ដូចជា វិស័យយោធា នយោបាយ មនោគមវិជ្ជា និងសេដ្ឋកិច្ច។ សហរដ្ឋអាមេរិកបានបង្កើតនិងរក្សាបណ្តាញមូលដ្ឋានយោធានិងសម្ព័ន្ធភាពយោធា យ៉ាងទូលំទូលាយ នៅទូទាំងពិភពលោក។ ស្ទើរតែគ្រប់គោលនយោបាយការបរទេសរបស់សហរដ្ឋអាមេរិក នៅក្នុងទសវត្សរ៍ជាបន្តបន្ទាប់ រាប់តាំងពីជំនួយបរទេសនិងការផ្ទេរបច្ចេកវិទ្យា រហូតដល់អន្តរាគមន៍យោធានិងការទូត មានគោលដៅបម្រើគោលនយោបាយ*រាំងខ្ទប់*។

បដិវត្តន៍កុម្មុយនិស្តចិន នៅឆ្នាំ ១៩៤៩ បានបណ្តាលអោយមានសម្ព័ន្ធភាពចិននឹងសូវៀត។ ប៉ុន្តែប្រទេសចិនមានភាពឯករាជ្យម្ចាស់ការយ៉ាងខ្លាំង នៅទសវត្សឆ្នាំ ១៩៦០ បន្ទាប់ពីការបែកបាក់សម្ព័ន្ធភាពចិននឹងសូវៀត នៅពេលដែលប្រទេសចិនបានប្រឆាំងការផ្លាស់ប្តូរជំហររបស់សូវៀតឆ្ពោះទៅរកគោលនយោបាយ*សន្តិសហវិជ្ជមាន* (peaceful co-existence) ជាមួយនឹងរសហរដ្ឋអាមេរិក។ កត្តាផ្សេងទៀត ដែលនាំទៅដល់ការបែកបាក់បណ្តាលមកពីការរិះគន់ និងការស្នាក់ស្ទើរ របស់សូវៀត ក្នុងការគាំទ្រគោលនយោបាយក្នុង

ស្រុករបស់ចិនក្នុងការប្រែក្លាយប្រទេស ពីសេដ្ឋកិច្ចកសិកម្ម ទៅជាសង្គមនិយម តាមរយៈឧស្សាហូបនីយកម្ម និងសហករណ៍យ៉ាងឆាប់រហ័ស និងការតស៊ូដណ្តើមអំណាច ដើម្បីដឹកនាំប្រទេសកុម្មុយនិស្តផ្សេងទៀត។ ដោយមានអារម្មណ៍ភ័យខ្លាចពីការគំរាមកំហែងដោយអំណាចសូវៀត មេដឹកនាំចិនបានបង្កើតភាពស្និទ្ធស្នាលជាមួយនឹងសហរដ្ឋអាមេរិក ក្នុងទសវត្សរ៍ឆ្នាំ ១៩៧០ ដោយចាប់ផ្តើមពីទស្សនកិច្ចទៅកាន់ប្រទេសចិន របស់លោក រីឆាត និចសុន (Richard Nixon) ក្នុងឆ្នាំ ១៩៧២។ ដំណើរទស្សនកិច្ចនេះ បានបណ្តាលអោយមានការបង្កើតទំនាក់ទំនងការទូតអាមេរិកនិងចិន នៅឆ្នាំ ១៩៧៩។ ក្នុងកំឡុងសង្គ្រាមត្រជាក់ ប្រទេសចិន ជាទូទៅ បានព្យាយាមប្រកាន់ជំហរតុល្យភាពប្រឆាំងនឹងមហាអំណាច ដែលហាក់ដូចជាការគំរាមកំហែងដល់ខ្លួនខ្លាំងបំផុត នៅពេលនោះ។

នៅឆ្នាំ ១៩៥០ *សង្គ្រាមកូរ៉េ* បានផ្ទុះឡើង នៅពេលដែលកូរ៉េខាងជើងកុម្មុយនីស្ត បានចូលលុកលុយតំបន់ត្រួតត្រារបស់កូរ៉េខាងត្បូង ដែលមានសហរដ្ឋអាមេរិកជាសម្ព័ន្ធមិត្ត។ សហរដ្ឋអាមេរិកនិងសម្ព័ន្ធមិត្តរបស់ខ្លួន (ក្រោមអាជ្ញាធរអង្គការសហប្រជាជាតិ ដែលទទួលបានបន្ទាប់ពីសហភាពសូវៀតបានដើរចេញពីក្រុមប្រឹក្សាសន្តិសុខ ជាការតវ៉ា) បានវាយបកនិងកាន់កាប់តំបន់ជាច្រើននៅកូរ៉េខាងជើង។ ប្រទេសចិនបានបញ្ជូន «កងទ័ពស្ម័គ្រចិត្ត» យ៉ាងច្រើនសន្ធឹកសន្ធាប់ ដើម្បីជួយកូរ៉េខាងជើង ហើយសង្គ្រាមបានអូសបន្លាយនៅជិតព្រំដែនដើម រហូតដល់មានបទឈប់បាញ់គ្នា ក្នុងឆ្នាំ ១៩៥៣ ហើយជាលទ្ធផល ការប្រយុទ្ធគ្នាត្រូវបញ្ចប់។ សង្គ្រាមកូរ៉េបានពង្រឹងជំហររបស់សហរដ្ឋអាមេរិកចំពោះរបបកុម្មុនីស្ត និងកំណត់ជានិន្នាការអរិជ្ជមានសម្រាប់ទំនាក់ទំនងលោកខាងលិចនិងខាងកើត ជាពិសេសទំនាក់ទំនងអាមេរិកនិងចិនក្នុងទសវត្សរ៍ឆ្នាំ ១៩៥០។

សង្គ្រាមត្រជាក់ដូចទឹកកកបានរលាយវិញជាបណ្តោះអាសន្ន ក្រោយមរណភាពរបស់ស្តាលីន នៅឆ្នាំ ១៩៥៣។ កិច្ចប្រជុំកំពូលដំបូង រវាងមេដឹកនាំជាន់ខ្ពស់នៃប្រទេសមហាអំណាច បានប្រព្រឹត្តិទៅ នៅទីក្រុងហ្សឺណែវ ក្នុងឆ្នាំ ១៩៥៥។ ស្ថានភាពដូចទឹកកករលាយក្នុងទំនាក់ទំនង បាននាំអោយភាគីទាំងពីរយល់ព្រមទទួលយកទទួលស្គាល់ប្រទេសអូទ្រីសឡើងវិញ ដែលត្រូវបានចែកជាបួនចំណែក ដូចប្រទេសអាឡឺម៉ង់។ ប៉ុន្តែ សហភាពសូវៀតបានបញ្ជូនរថក្រោះដើម្បីកំទេចការបះបោរប្រជាប្រិយមួយ នៅប្រទេសហុងគ្រី នៅឆ្នាំ ១៩៥៦ (ទង្វើមួយដែលត្រូវបានធ្វើម្តងទៀត នៅឆ្នាំ ១៩៦៨ នៅឆេកូស្លូវ៉ាគី) ហើយកម្មវិធីមីស៊ីលសូវៀតដែលបានបង្ហោះយានអវកាសស្ពុតនិក (Sputnik) ក្នុងឆ្នាំ ១៩៥៧ បានធ្វើអោយសហរដ្ឋអាមេរិកភ្ញាក់ខ្លួន។ ការបាញ់ទម្លាក់យន្តហោះស៊ើបការណ៍របស់អាមេរិក(U-២) ដែលហោះហើរលើសហភាពសូវៀត ក្នុងឆ្នាំ ១៩៦០ បានអោយល្អកកករ កិច្ចប្រជុំកំពូលរវាងមេដឹកនាំប្រទេសមហាអំណាច លោក នីគីតា គ្រូសឆេវ (Nikita Khrushchev) និង លោក ដ្វាយ ដ. អៃសិនហៅវ័រ (Dwight D. Eisenhower)។ ទន្ទឹមនឹងនេះ នៅប្រទេសគុយបា បន្ទាប់ពីបដិវត្តន៍កុម្មុយនិស្ត ដែលដឹកនាំដោយលោក ហ្វីដែល កាស្ត្រូ (Fidel Castro) នៅឆ្នាំ ១៩៥៩ សហរដ្ឋអាមេរិកបានប៉ុនប៉ងប្រឆាំងតបនឹងបដិវត្តន៍នោះ នៅក្នុងការវាយលុក នៅឈូងសមុទ្រ *Bay of Pigs* (បេយ៍ អូហ៍ ភីគ) នៅឆ្នាំ ១៩៦១។

អរិភាពទាំងនេះ បានឈានដល់ចំណុចកំពូល ក្នុង**វិបត្តិមីស៊ីលគុយបា** ឆ្នាំ ១៩៦២ នៅពេលដែលសហភាពសូវៀតបានតម្លើងមីស៊ីលនុយក្លេអ៊ែរ រយៈចម្ងាយមធ្យម នៅប្រទេសគុយបា។ គោលដៅចម្បងរបស់សូវៀត គឺដើម្បីកាត់បន្ថយភាពចាញ់ប្រៀបផ្នែកនុយក្លេអ៊ែរដោយយុទ្ធសាស្ត្ររបស់សហភាពសូវៀត, ដើម្បីប្រឆាំង

នឹងការដាក់ពង្រាយមីស៊ីលរបស់អាមេរិក នៅតាមបណ្តោយព្រំដែនសូវៀតនៅក្នុងប្រទេសទួរគី, និងដើម្បីរារាំងការលុកលុយរបស់អាមេរិកជាថ្មីទៀត នៅប្រទេសគុយបា។ ទោះជាយ៉ាងណា មេដឹកនាំសហរដ្ឋអាមេរិកបានចាត់ទុកទង្វើពង្រាយមីស៊ីលទាំងនេះ ជាការគំរាមកំហែងនិងបង្កហេតុ។ យោងតាមឯកសារប្រវត្តិសាស្ត្រដែលទើបបានបង្ហាញថ្មីៗនេះ សង្គ្រាមនុយក្លេអ៊ែរនាពេលនោះ *ពិតជា*អាចកើតឡើងមែន។ ទីប្រឹក្សាឬអ្នកធ្វើគោលនយោបាយអាមេរិកខ្លះ ចង់អោយបើកការវាយប្រហារយោធាជាមុន ពេលត្រូវាយអោយបានមុនពេលមីស៊ីលទាំងនោះអាចដាក់អោយប្រតិបត្តិការបាន តែតាមពិត អាវុធនុយក្លេអ៊ែរមួយចំនួន នៅក្នុងប្រទេសគុយបា អាចត្រូវធ្វើប្រតិបត្តិការរួចទៅហើយ ចំណែកឯមេបញ្ជាការក៏ត្រូវបានបញ្ជាអោយបាញ់វា ក្នុងករណីមានការវាយប្រហារណាមួយពីសហរដ្ឋអាមេរិក។ ផ្ទុយទៅវិញ ប្រធានាធិបតី ចន អេហ្វ. កេណ្ណឺឌីបានដាក់ក្បួនកងទ័ពដើងទឹករាំងខ្ជប់ ដើម្បីបង្ខំអោយដកចេញប្រព័ន្ធមីស៊ីលទាំងអស់នោះ។ សហភាពសូវៀតបានដកមីស៊ីលចេញពីគុយបា ចំណែកឯសហរដ្ឋអាមេរិកបានសន្យាថា នឹងមិនលុកលុយប្រទេសគុយបានាពេលអនាគតឡើយ។ ទោះយ៉ាងណាក៏ដោយ មេដឹកនាំទាំងសងខាងត្រូវតក់ស្លុត ដោយសារលទ្ធភាពនៃការផ្ទុះសង្គ្រាមនុយក្លេអ៊ែរ។ ពួកគេបានចុះហត្ថលេខាលើ*សន្ធិសញ្ញាហាមឃាត់ការធ្វើតេស្តមានដែនកំណត់* នៅឆ្នាំ ១៩៦៣ ដែលហាមឃាត់ការធ្វើតេស្តអាវុធនុយក្លេអ៊ែរក្នុងបរិយាកាសផែនដី និងបានចាប់ផ្តើមសហការគ្នាក្នុងកម្មវិធីផ្លាស់ប្តូរវប្បធម៌ ការរុករកអវកាស អាកាសចរណ៍ និងវិស័យផ្សេងទៀត។

ប្រទេសមហាអំណាចទាំង ២ ជារឿយៗ ប្រកួតប្រជែងដណ្តើមទីតាំងនៅអឌ្ឍគោលខាងត្បូង ដោយគាំទ្រសង្គ្រាម*ប្រុកស៊ី*ឬ**សង្គ្រាមរណប** ដែលក្នុងនោះ ពួកគេបានផ្តត់ផ្តង់និងផ្តល់ប្រឹក្សាយោបល់យោធាដល់ភាគីប្រឆាំងគ្នា ក្នុងសង្គ្រាមស៊ីវិលណាមួយ។ ការគាំទ្ររបស់ពួកគេមានមិននិន្នាការជាទូទៅទេ។ ជាឧទាហរណ៍ សហរដ្ឋអាមេរិកបានគាំទ្ររដ្ឋាភិបាលអេត្យូពី ចំណែកសូវៀតបានគាំទ្រប្រទេសសូម៉ាលី ដែលជាគូសត្រូវជាប់ព្រំដែន នៅទសវត្សរ៍ឆ្នាំ ១៩៧០។ ទោះយ៉ាងណានៅពេលផ្ទុះបដិវត្តប្រទេសអេត្យូពីបណ្តាលអោយរដ្ឋាភិបាលថ្មី ប្រកាសស្វែងរកជំនួយពីសហភាពសូវៀត សហរដ្ឋអាមេរិកបានប្តូរភាគី ដោយងាកទៅគាំទ្រដល់ប្រទេសសូម៉ាលីវិញ។

ចំណុចខ្សោយមួយនៃគោលនយោបាយរបស់សហរដ្ឋអាមេរិកក្នុងកំឡុងសង្គ្រាមត្រជាក់ គឺការសម្លឹងមើលជម្លោះក្នុងតំបន់ទាំងអស់ តាមរយៈកែវឆ្លុះលោកខាងកើតនឹងខាងលិច។ ដោយសារតែខ្វល់ខ្វាយជាមួយនឹងរបបកុម្មុយនិស្តខ្លាំងពេកទើបបណ្តាលអោយសហរដ្ឋអាមេរិកជ្រុលខ្លួនគាំទ្ររដ្ឋាភិបាលនិយមបស្ចឹមលោកដែលមិនមានប្រជាប្រិយភាព នៅក្នុងប្រទេសក្រីក្រមួយចំនួន ហើយក្នុងចំណោមនោះ មិនមានកន្លែងណា នាំមហន្តរាយច្រើនជាងអំឡុងសង្គ្រាមវៀតណាម នៅទសវត្សឆ្នាំ ១៩៦០ ឡើយ។ សង្គ្រាមនៅ វៀតណាមបានបែងចែកសាធារណៈមតិក្នុងចំណោមប្រជាពលរដ្ឋអាមេរិក ហើយទីបំផុត ក៏មិនបានរារាំងពួកកុម្មុយនីស្តក្នុងការដណ្តើមកាន់កាប់ប្រទេសទេ។ ការដួលរលំនៃប្រទេសវៀតណាមខាងត្បូង ក្នុងឆ្នាំ ១៩៧៥ ហាក់បានឆ្លុះបញ្ចាំងពីចំណុចខ្សោយរបស់សហរដ្ឋអាមេរិក ជាពិសេស រួមផ្សំជាមួយនឹងបរាជ័យរបស់អាមេរិកនៅមជ្ឈឹមបូព៌ៈ ការហាមឃាត់ការនាំប្រេងអារ៉ាប់ចេញទៅអាមេរិក នៅឆ្នាំ ១៩៧៣ និងការផ្តួលរំលំរបបស្តេចអ៊ីរ៉ង់និយមអាមេរិក ដោយជនរួមជាតិអ៊ីរ៉ង់ ដែលនិយមសាសនាជ្រុល។

នៅក្នុងរយៈពេលបរាជ័យអាមេរិកនៅលើតំបន់ខាងលើ សហភាពសូវៀតបានវាយលុកចូលប្រទេសអាហ្វហ្គានីស្តាន ក្នុងឆ្នាំ ១៩៧៩។ ប៉ុន្តែ ក៏ដូចជាវាសនាសហរដ្ឋអាមេរិកនៅប្រទេសវៀតណាមដែរ សហភាព

សូវៀតមិនអាចបង្ក្រាបកងទ័ពឧទ្ធាម ដែលផ្គត់ផ្គង់ដោយប្រទេសមហាអំណាចជាគូប្រជែងនោះទេ។ សូវៀតនៅទីបំផុត បានដកទ័ពថយ បន្ទាប់ពីសង្គ្រាមជិតមួយទសវត្សរ៍ ដែលបានធ្វើអោយសហភាពសូវៀតចុះខ្សោយ យ៉ាងដំណាំ។ ទន្ទឹមនឹងនេះ លោកប្រធានាធិបតី រ៉ូណាល់ រីហ្គែនបានបង្កើនកម្លាំងយោធារបស់សហរដ្ឋអាមេរិក ក្នុងកម្រិតខ្ពស់បំផុត និងបានគាំទ្រដល់កងទ័ពឧទ្ធាមនៅប្រទេសជាសម្ព័ន្ធមិត្តនឹងប្រទេសសូវៀត រួមមានប្រទេសនីការ៉ាហ្គ័រ និងអង់ហ្គោឡា (និងក្រុមមួយទៀត នៅប្រទេសកម្ពុជា) ក៏ដូចជាប្រទេសអាហ្វហ្គានីស្ថាន។ ទំនាក់ទំនងប្រទេសមហាអំណាចបានចាប់ផ្តើមមានភាពប្រសើរឡើង បន្តិចម្តងៗ ក្រោយអ្នកធ្វើកំណែទម្រង់ លោក មីខាអ៊ីល ហ្គោបាឆេវ (Mikhail Gorbachev) បានឡើងកាន់អំណាច នៅក្នុងសហភាពសូវៀតក្នុងឆ្នាំ ១៩៨៥។ ប៉ុន្តែ សមរភូមិនៅអឆ្ឆគោលខាងត្បូង (ពិសេសនៅអាហ្វហ្គានីស្ថាន និងអង់ហ្គោឡា) បានបន្តទទួលរងទុក្ខវេទនា ពីសង្គ្រាមស៊ីវិលអូសបន្លាយ (ជាការប្រយុទ្ធដោយប្រើសព្វាវុធនៅសេសសល់ពីសង្គ្រាមត្រជាក់) រហូតឆ្លងដល់សតវត្សរ៍ថ្មី។

បើក្រឡេកមើលថយក្រោយ វាហាក់ដូចជាថា ប្រទេសមហាអំណាចទាំងពីរ ពន្លើសកម្លាំងពិតប្រាកដរបស់សហភាពសូវៀត។ នៅប៉ុន្មានឆ្នាំដំបូងនៃការប្រណាំងប្រជែងអាវុធនុយក្លេអ៊ែរ, ប្រាកដណាស់ សហរដ្ឋអាមេរិកពិតជាមានឧត្តមភាពយោធាជាច់ខាត ជាពិសេស នៅក្នុងផ្នែកអាវុធនុយក្លេអ៊ែរ។ បន្តិចម្តងៗ ទើបសហភាពសូវៀតតាមទាន់សហរដ្ឋអាមេរិក រាប់តាំងពីគ្រាប់បែកអាតូមិក និងគ្រាប់បែកអ៊ីដ្រូហ្សែន រហូតដល់មីស៊ីលដែលអាចបំពាក់ក្បាលគ្រាប់បានច្រើន។ នៅត្រឹមទសវត្សរ៍ឆ្នាំ ១៩៧០ សូវៀតបានទទួលនូវឋានៈស្មើគ្នាផ្នែកយុទ្ធសាស្ត្រ នេះមានន័យថា ភាគីណាក៏មិនអាចរារាំងការបំផ្លិចបំផ្លាញខ្លួនឯង ក្នុងសង្គ្រាមអាវុធនុយក្លេអ៊ែរបានទេ។ ប៉ុន្តែ ក្រៅពីឋានៈស្មើគ្នាលើវិស័យយោធានេះ សហភាពសូវៀតអភិវឌ្ឍន៍យឺតយ៉ាវខ្លាំងតាមពីក្រោយលោកខាងលិច ក្នុងវិស័យដទៃទៀត៖ ទ្រព្យសម្បត្តិ បច្ចេកវិទ្យា ហេដ្ឋារចនាសម្ព័ន្ធ និងស្មារតីលើកទឹកចិត្តពលរដ្ឋ និងកម្មករ។

នៅខែមិថុនា ឆ្នាំ ១៩៨៩ ការធ្វើបាតុកម្មគាំទ្រលទ្ធិប្រជាធិបតេយ្យដ៏ធំមួយ នៅក្នុងរដ្ឋធានីប៉េកាំងរបស់ប្រទេសចិន(នៅទីលានធៀនអានមេន) ត្រូវបានបង្ក្រាបយ៉ាងព្រៃផ្សៃពីសំណាក់រដ្ឋាភិបាលកុម្មុយនិស្ត។ មនុស្សរាប់រយនាក់ ត្រូវបានបាញ់សម្លាប់នៅតាមដងផ្លូវនានា។ ក្រោយមក ក្នុងឆ្នាំដដែលនោះស្របពេលដែលសហភាពសូវៀតនៅឈរទ្រឹង ប្រទេសអឺរ៉ុបខាងកើត ជាបន្តបន្ទាប់ បានផ្តួលរំលំរដ្ឋាភិបាលកុម្មុយនិស្តរបស់ខ្លួន ក្រោមសម្ពាធនៃការធ្វើបាតុកម្មទ្រង់ទ្រាយធំ។ ការផ្តួលរំលំជញ្ជាំងប៊ែកឡាំង នៅចុងឆ្នាំ ១៩៨៩ ជានិមិត្តរូបនៃការបញ្ចប់ការបែងចែកអឺរ៉ុបក្នុងសម័យសង្គ្រាមត្រជាក់។ ប្រទេសអាឡឺម៉ង់ត្រូវបានបង្រួបបង្រួមជាផ្លូវការ នៅឆ្នាំ ១៩៩០។ មេដឹកនាំសូវៀត ហ្គោបាឆេវ បានទុកអោយការបាត់បង់នៃអំណាចខាងក្រៅទាំងនេះ (និងមានច្រើនទៀត) ដោយសង្ឃឹមថានឹងអាចផ្តោតអារម្មណ៍លើការរៀបចំរចនាសម្ព័ន្ធផ្ទៃក្នុងរបស់សូវៀតតាមរយៈគោលនយោបាយកែទម្រង់សេដ្ឋកិច្ច «ប៉េរ៉ែស្ត្រយកា» (*Perestroika*) និង ការបើកចំហរក្នុងការពិភាក្សានយោបាយ (*glasnost*) របស់គាត់)។ ប្រទេសចិននៅតែជារដ្ឋាភិបាលកុម្មុយនិស្ត និងផ្តាច់ការ ប៉ុន្តែបានធ្វើសេរីភាវូបនីយកម្មសេដ្ឋកិច្ចរបស់ខ្លួន និងជៀសវាងជម្លោះយោធា។ ផ្ទុយពីយុគសម័យសង្គ្រាមត្រជាក់ ប្រទេសចិនបានបង្កើតទំនាក់ទំនងជិតស្និទ្ធជាមួយសហរដ្ឋអាមេរិកផងនិងរុស្ស៊ីផង ហើយបានចូលរួមក្នុងរបបពាណិជ្ជកម្មសេរីរបស់ពិភពលោក។

ក្រាហ្វិក ១.៤ សង្គ្រាមត្រជាក់ ឆ្នាំ ១៩៤៥-១៩៩០

សហភាពសូវៀត
សហរដ្ឋអាមេរិក
ចិន
ប្លុកមិនចូលរួម
សង្គ្រាមត្រជាក់
កិច្ចសហប្រតិបត្តិការ
ស្ថាបនា
ការប្រកួតប្រជែងសព្វាវុធ
ប្រយុទ្ធ
ការរួមរស់ដោយសន្តិភាព
ប្រយុទ្ធ
ការរួមរស់ដោយសន្តិភាព
ប្រយុទ្ធ
ការរួមរស់ដោយសន្តិភាព
ប្រយុទ្ធ
ការរួមរស់ដោយសន្តិភាព
ស្តារប្រទេស

ឥឡូវនេះយើងដឹង៖ ការគិតឡើងវិញអំពីប្រវត្តិសង្គ្រាមត្រជាក់។ Oxford, ១៩៩៧. Zubok, Vladislav, និង Constantine Pleshakov ។ នៅខាងក្នុងសង្គ្រាមត្រជាក់របស់វិមានក្រឹមឡាំង៖ ពីស្តាលីនដល់ Khrushchev ។ Harvard, ១៩៩៦. Garthoff, Raymond ។ Détente និងការប្រឈមមុខដាក់គ្នា៖ ទំនាក់ទំនងអាមេរិក-សូវៀតពី Nixon ទៅ Reagan ។ Brookings, ១៩៨៥. Larson, Deborah Welch ។ កាយវិភាគសាស្ត្រនៃការមិនទុកចិត្ត៖ ទំនាក់ទំនងអាមេរិក-សូវៀតកំឡុងសង្គ្រាមត្រជាក់។ Cornell, ១៩៩៧. Trachtenberg, Marc. សន្តិភាពដែលបានបង្កើត៖ ការបង្កើតការតាំងទីលំនៅនៅអឺរ៉ុប ឆ្នាំ ១៩៤៥–១៩៦៣។ ព្រីនស្តុន ឆ្នាំ ១៩៩៩។

អ្នកប្រាជ្ញទាំងឡាយមិនយល់ស្របគ្នាលើមូលហេតុសំខាន់ដែលបណ្តាលអោយ សង្គ្រាមត្រជាក់ត្រូវបញ្ចប់នោះទេ។ ទស្សនៈមួយបានលើកថា អនុភាពយោធា នៅក្រោមរដ្ឋការប្រធានាធិបតី រីហ្គិន (Reagan) បានបង្ខំអោយសហភាពសូវៀតត្រូវក្សយធន នៅពេលដែលសហភាពសូវៀតបានប្រឹងតាម ក្នុងប្រណាំងប្រជែងសព្វាវុធ។ ទស្សនៈផ្សេងទៀតថា សហភាពសូវៀតរងគ្រោះដោយសារការជាប់គាំងខាងសេដ្ឋកិច្ចអស់រយៈពេលជាច្រើនទសវត្សរ៍ ហើយទីបំផុតបានដួលរលំទាំងដំហរ ដោយសារតែភាពទន់ខ្សោយដែលពាក់ព័ន្ធនឹងសម្ពាធខាងក្រៅឡើយ។ ជាការពិត អ្នកសិក្សាខ្លះទៀតយល់ឃើញថា សហភាពសូវៀតប្រហែលជាត្រូវរលំរលាយលឿនជាងនេះទៀត ប្រសិនបើគ្មានសហរដ្ឋអាមេរិកធ្វើជាសត្រូវបរទេស ក្នុងការពង្រឹងស្មារតីជាតិនិយមនិងភាពស្របច្បាប់របស់រដ្ឋាភិបាលសូវៀត ក្នុងចំណោមប្រជាជនរបស់ខ្លួន។

១.៤.៣. យុគសម័យក្រោយសង្គ្រាមត្រជាក់ ឆ្នាំ ១៩៩០-២០១៨

សម័យក្រោយសង្គ្រាមត្រជាក់បានចាប់ផ្តើម ដោយសម្លេងផ្ទុះភ្នាំង ខណៈដែលសហភាពសូវៀតនៅតែបន្តបែកបាក់ដដែល។ នៅឆ្នាំ ១៩៩០ ប្រហែលជាជឿជាក់ថា នៅចុងបញ្ចប់នៃសង្គ្រាមត្រជាក់បានបន្សល់ទុកនូវលំហអំណាចនៅក្នុងតំបន់ ប្រទេសអ៊ីរ៉ាក់បានចូលកាន់កាប់ប្រទេសជិតខាង គុយវែត ដោយគណ្ឌីនក្នុងគោលដៅគ្រប់គ្រងប្រេងមជ្ឈឹមបូព៌ា។ ប្រទេសមហាអំណាចលោកខាងលិចភ្ញាក់ផ្អើលមិនអាចទុកអោយការឈ្លានពានណាមួយ រួចពីការដាក់ទណ្ឌកម្មនៅក្នុងយុគសម័យថ្មីឡើយ និងបារម្ភអំពីការគំរាមកំហែងដោយផ្ទាល់ ដល់ការផ្គត់ផ្គង់ថាមពលសម្រាប់សកម្មភាពសេដ្ឋកិច្ចពិភពលោក។ សហរដ្ឋអាមេរិកបានកៀរគរសម្ព័ន្ធមិត្តចម្រុះដោយប្រទេសធំៗ ក្នុងពិភពលោក (ស្ទើរតែមិនមានការជំទាស់) ដើម្បីប្រយុទ្ធប្រឆាំងប្រទេសអ៊ីរ៉ាក់)។ ដោយធ្វើប្រតិបត្តិការតាមរយៈអង្គការសហប្រជាជាតិ សម្ព័ន្ធភាពយោធាដែលដឹកនាំដោយសហរដ្ឋអាមេរិក បានអនុវត្តទណ្ឌកម្មដោយវាយប្រហារបកកាន់តែខ្លាំងឡើងៗប្រឆាំងនឹងអ៊ីរ៉ាក់។

នៅពេលដែលប្រទេសអ៊ីរ៉ាក់មិនបានដកកងទ័ពចេញពីប្រទេសកូវ៉ែត តាមកាលបរិច្ឆេទកំណត់របស់អង្គការសហប្រជាជាតិ សហរដ្ឋអាមេរិកនិងសម្ព័ន្ធមិត្តរបស់ខ្លួន បានវាយបំបាក់កងទ័ពរបស់អ៊ីរ៉ាក់បានយ៉ាងងាយស្រួល និងបានបណ្តេញកងទ័ពអ៊ីរ៉ាក់ចេញពីប្រទេសគុយវែត ក្នុង*សង្គ្រាមឈូងសមុទ្រ*។ ប៉ុន្តែ កងទ័ពសម្ព័ន្ធមិត្តមិនបានកាន់កាប់ប្រទេសអ៊ីរ៉ាក់ ឬ ផ្តួលរំលំរដ្ឋាភិបាលអ៊ីរ៉ាក់ទេ។ ការចំណាយលើសង្គ្រាមឈូងសមុទ្រត្រូវបានចែករំលែកគ្នាក្នុងចំណោមប្រទេសចូលរួមក្នុងសម្ព័ន្ធភាពដោយចក្រភពអង់គ្លេស និងបារាំងធ្វើការប្តេជ្ញាចិត្តចូលរួមផ្នែកយោធា ខណៈប្រទេសជប៉ុននិងអាឡឺម៉ង់បានចូលរួមវិភាគទានផ្នែកហិរញ្ញវត្ថុយ៉ាងច្រើន។ ការចែករំលែកបន្ទុកចំណាយលើសង្គ្រាមនេះគឺជាការច្នៃប្រឌិតថ្មីមួយ ដែលបានប្រព្រឹត្តិទៅយ៉ាងរលូនខ្លាំងណាស់ដែរ។

ការដួលរលំចុងក្រោយរបស់សហភាពសូវៀតបានកើតឡើង ប៉ុន្មានខែបន្ទាប់ពីសង្គ្រាមឈូងសមុទ្រ។ សាធារណរដ្ឋចំនួន ១៥ នៃសហភាពសូវៀត ដែលប្រទេសរុស្ស៊ីគ្រាន់តែជាមួយក្នុងចំណោមនោះទើបតែចាប់ផ្តើមទទួលអំណាចពីរដ្ឋាភិបាលកណ្តាលដែលកំពុងចុះខ្សោយ ដោយប្រកាសថា ពួកគេគឺជារដ្ឋអធិបតេយ្យផ្ទាល់ខ្លួន។ ដំណើរការនេះបានធ្វើអោយមានបញ្ហាស្មុគស្មាញ ដោយរាប់ចាប់ពីបញ្ហានៃការប្តេជ្ញាចិត្តលើជោគវាសនាខ្លួនឯង រហូតបញ្ហាចែករម្លែកភោគទ្រព្យគ្នា។ ប្រទេសរុស្ស៊ីនិងអតីតសាធារណរដ្ឋដទៃទៀត បានតស៊ូពេញទសវត្សរ៍ឆ្នាំ ១៩៩០ ទប់ទល់នឹងការដួលរលំសេដ្ឋកិច្ច អតិផរណា អំពើពុករលួយ សង្គ្រាម និងភាពទន់ខ្សោយរបស់យោធា បើទោះបីពួកគេនៅតែជាប្រជាធិបតេយ្យនយោបាយក៏ដោយ។ ការប៉ុនប៉ងធ្វើរដ្ឋប្រហារយោធារបស់រុស្ស៊ីបានបរាជ័យក្នុងឆ្នាំ ១៩៩១ និងលេចធ្លោតួនាទីរបស់ប្រធានាធិបតីរុស្ស៊ី លោក បូរីស យ៉ែលសីន (Boris Yeltsin) ក្នុងការប្រឆាំងរដ្ឋប្រហារនោះ បានពន្លឿនការដួលរលំនៃសហភាពសូវៀត។ មិនយូរប៉ុន្មាន របបមូលធននិយមនិងប្រជាធិបតេយ្យ ត្រូវបានទទួលយក ជាមូលដ្ឋាននៃសេដ្ឋកិច្ចនិងប្រព័ន្ធនយោបាយរបស់បណ្តាអតីតរដ្ឋរបស់អតីតសូវៀត។ សាធារណរដ្ឋនានាបានក្លាយជាប្រទេសឯករាជ្យហើយបានបង្កើត«ភោគទ្រព្យរួមនៃរដ្ឋឯករាជ្យ»(CIS)។ ក្នុងចំណោមអតីតសាធារណរដ្ឋសូវៀត មានតែបណ្តារដ្ឋបាល់ទិកតូចតាចចំនួន ៣ រួមទាំងប្រទេសហ្សកហ្ស៊ីប៉ុណ្ណោះ ដែលមិនមែនជាសមាជិក។

ទំនាក់ទំនងលោកខាងលិចជាមួយប្រទេសរុស្ស៊ីនិងសាធារណរដ្ឋដទៃទៀត មានលក្ខណៈផ្សេងៗគ្នាតាំងពីឆ្នាំ១៩៩០មក។ ដោយសារតែបញ្ហាសេដ្ឋកិច្ចផ្ទាល់ខ្លួន និងដោយសារតែអារម្មណ៍មួយយល់ថា ប្រទេសរុស្ស៊ីត្រូវការការកែទម្រង់ផ្ទៃក្នុងច្រើនជាងជំនួយខាងក្រៅ បណ្តាបស្ចឹមប្រទេសបានផ្តល់ជំនួយ មានកម្រិតតិចតួចសម្រាប់ការផ្លាស់ប្តូរសេដ្ឋកិច្ចដ៏លំបាកក្នុងតំបន់ ដែលបានបន្ទាបកម្រិតជីវភាពរស់នៅយ៉ាងគំហុក។ ការបង្ក្រាបដ៏ឃោរឃៅរបស់រុស្ស៊ីលើខេត្តឆេចនី (Chechnya) ដែលចង់បំបែករដ្ឋ នៅក្នុងឆ្នាំ ១៩៩៥ និង ឆ្នាំ ១៩៩៩ បានជាស់អារម្មណ៍ភ័យខ្លាចរបស់លោកខាងលិច ជាតិនិយមរបស់រុស្ស៊ី ដែលមានលក្ខណៈវាតទីនិយមនិងឈ្លានពាននិយម។ មេដឹកនាំរុស្ស៊ីព្រួយបារម្ភពីការពង្រីកសមាជិកភាពរបស់អង្គការណាតូ ទៅអឺរ៉ុបខាងកើត ដែលនឹងជាក់ពង្រាយកងទ័ពគំរាមកំហែង នៅតាមព្រំដែនរបស់ប្រទេសរុស្ស៊ី។ ភាពតានតឹងជាមួយរដ្ឋភាគខាងលិចបានកើនឡើង ចាប់តាំងពីការបញ្ចូលនៅគ្រីមៀ ក្នុងឆ្នាំ ២០១៤ និងការគាំទ្ររបស់រុស្ស៊ីដល់ក្រុមឧទ្ទាមនៅភាគខាងកើត ដែលប្រយុទ្ធប្រឆាំងនឹងរដ្ឋាភិបាលអ៊ុយក្រែន។ ជាងនេះទៅទៀត ការលាតត្រដាងដែលថា រុស្ស៊ីបានព្យាយាមជះឥទ្ធិពលដោយផ្ទាល់ដល់ការបោះឆ្នោតតាមបែបប្រជាធិបតេយ្យ នៅក្នុងបណ្តាបស្ចឹមប្រទេស មួយចំនួន ក្នុងទសវត្សរ៍ឆ្នាំ ២០១០ បាននាំឱ្យមានកំណើនការមិនទុកចិត្តលើចេតនានិងអាកប្បកិរិយារបស់ប្រទេសរុស្ស៊ី។

ទោះបីជាមានបញ្ហាទាំងនេះក៏ដោយ បើធៀបនឹងសម័យសង្គ្រាមត្រជាក់ ប្រទេសមហាអំណាចនានាជាទូទៅ បានបង្កើនកិច្ចសហប្រតិបត្តិការនានាច្រើនជាង។ សហរដ្ឋអាមេរិកនិងរុស្ស៊ីបានព្រមព្រៀមថានឹងកាត់បន្ថយអាវុធនុយក្លេអ៊ែរ និងបានចាប់ផ្តើមអនុវត្តនៅទសវត្សរ៍ឆ្នាំ ១៩៩០។ ភាពតានតឹងផ្នែកយោធារវាងប្រទេសមហាអំណាច ហាក់មានកំរិតទាប បើធៀបនឹងស្តង់ដារប្រវត្តិសាស្ត្រ បើទោះមានជំលោះការទូតនិងការដាក់ទណ្ឌកម្មប្រឆាំងនឹងរុស្ស៊ីក៏ដោយ។ ហើយប្រទេសរុស្ស៊ី ត្រូវបានទទួលស្គាល់ជាអ្នកស្នងតំណែងបន្តពីសហភាពសូវៀត និងបានកាន់កាប់អាសនៈក្រុមប្រឹក្សាសន្តិសុខនៃអ.ស.ប.។

ក្រោយចប់សង្គ្រាមឈូងសមុទ្រនៅឆ្នាំ ១៩៩១ ស្លាម អតីតយូហ្គោស្លាវីបានបែកបាក់ ជាសាធារណរដ្ឋ ជាច្រើន ដែលបានប្រកាសឯករាជ្យ។ ជនជាតិភាគតិចស៊ែប៊ីដែលជាជនជាតិភាគតិច នៅប្រទេសក្រូអាតនិង បូស្នៀនិងហឺសហ្គោវីនៀ ដែលបានរឹបអូសយកទឹកដី ដើម្បីបង្កើតជាប្រទេស ស៊ែប៊ីធំ(Greater Serbi)។ ដោយមានជំនួយពីប្រទេសស៊ែប៊ីដែលគ្រប់គ្រងកងទ័ពយូហ្គោស្លាវី ពួកគេបានសម្លាប់ប្រជាជនបូស្នៀនិង ក្រូអាត ដែលមិនមែនជាជនជាតិស៊ែប៊ី រាប់រយរាប់ពាន់នាក់ ហើយបណ្តេញមនុស្សរាប់លាននាក់បន្ថែម ចេញ ពីទឹកដី ដើម្បីបង្កើតរដ្ឋស៊ែប៊ីសុទ្ធសាធ។ ជារួម មនុស្សប្រមាណ ១៥០០០០ នាក់ ត្រូវបាត់បង់ជីវិត ក្នុងបណ្តា ប្រទេសយូហ្គូស្លាវី។

សហគមន៍អន្តរជាតិ បានទទួលស្គាល់ពីឯករាជ្យរបស់ប្រទេសក្រូអាត និង បូស្នៀនឹងហឺសហ្គោវីនៀ និងសាធារណៈរដ្ឋយូហ្គោស្លាវីដទៃទៀតដែលបានស្នើសុំការទទួលស្គាល់ ដោយបានបញ្ជូលរដ្ឋទាំងនោះទៅ ក្នុងអ.ស.ប. និងអនុម័តសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខមួយចំនួនធំ ដើម្បីការពារបូរណភាព ទឹកដីនិងប្រជាជនស៊ីវិលរបស់ពួកគេ។ ប៉ុន្តែ ផ្ទុយពីសង្គ្រាមឈូងសមុទ្រ ប្រទេសមហាអំណាចមិនបាន បង្ហាញឆន្ទៈក្នុងការរ៉ាប់រងការចំណាយដ៏ច្រើន ដើម្បីការពារបូស្នៀនឹងហឺសហ្គោវីនៀទេ។ ផ្ទុយទៅវិញ ពួកគេ បានព្យាយាមទប់ស្កាត់ជម្លោះ ដោយប្រកាន់យកតួនាទីអព្យាក្រឹត ក្នុងនាមជាអ្នកថែរក្សាសន្តិភាពនិង អន្តរការី។ នៅឆ្នាំ ១៩៩៥ កងកំលាំងស៊ែប៊ីបានចូលទៅរំលោយទីតាំងដែលអ.ស.ប. ប្រកាសដាក់ថាជា «ជំរក សុវត្ថិភាព»ពីកន្លែង នៅបូស្នៀខាងកើត ដោយបានបណ្តេញស្ត្រីចេញ និងបានកាប់សម្លាប់បុរស រាប់ពាន់ នាក់។ ទីបំផុត រយៈពេលពីរសប្តាហ៍នៃការវាយប្រហារ តាមអាកាសរបស់ណាតូ (យុទ្ធនាការយោធាដំបូង បង្អស់របស់សម្ព័ន្ធយោធានេះ ធ្វើឡើងនៅឆ្នាំ១៩៩៤ នៅបូស្នៀ ប៉ុន្តែនេះជាប្រតិបត្តិការយោធាដ៏ធំ ដែលប្រើ ទាំងកងទ័ពជើងគោកនិងអាកាស) រួមជាមួយនឹងបរាជ័យចំពោះមុខក្រូអាតនៅលើដែនដី បានធ្វើអោយកង កម្លាំងស៊ែប៊ីសុំចុះចាញ់។ សន្ធិសញ្ញាបញ្ចប់សង្គ្រាម(ពង្រាងដោយអ្នកចរចាអាមេរិក)បានរក្សាបូរណភាព ដែនដីរបស់ប្រទេសស៊ែប៊ីនឹងហឺសហ្គោវីនៀជាមួយគ្នា ប៉ុន្តែ ក៏បានផ្តល់អោយស៊ែប៊ីបូស្នៀនូវស្វ័យភាពលើទឹក ដីពាក់កណ្តាល។ ខណៈដែលការដាក់ពង្រាយកងទ័ព ប្រដាប់ដោយអាវុធច្រើនសន្ធឹកសន្ធាប (ភាគច្រើនកង កម្លាំងណាតូ) នៅលើទឹកដីផ្ទាល់ដើម្បីរក្សាបទឈប់បាញ់។ ទន្ទឹមនឹងនេះ បុរសខ្លាំងគួរសមរបស់ស៊ែប៊ីបូស្នៀ លោក មីឡូម៉ូដាន មីឡូសេវីក (Milomodan Milosevic) ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មសង្គ្រាមដោយ សាលាក្តីអង្គការសហប្រជាជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ត្រូវបានបញ្ជូនទៅសាលាក្តីនៅឆ្នាំ ២០០១ ហើយបានស្លាប់នៅឆ្នាំ ២០០៦ នៅជិតចុងបញ្ចប់នៃការជំនុំជម្រះក្តីដែលអូសបន្លាយពេលយ៉ាងយូរមក ហើយ។

ផ្ទុយពីការរារែករបស់ពួកគេនៅក្នុងដំណាក់កាលវិបត្តិបូស្នៀកន្លងមក ប្រទេសមហាអំណាចបានចាត់ វិធានការណ៍ឆ្លើយតបយ៉ាងឆាប់រហ័សនិងមុឺងម៉ាត់ ក្នុងឆ្នាំ ១៩៩៩ នៅពេលដែលកងកំលាំងស៊ែប៊ីបានអនុវត្ត «ការបោសសំអាតជនជាតិភាគតិច» នៅខេត្តរបស់ស៊ែប៊ី កូសេរៀន(Koserian) ដែលភាគច្រើនមានជនជាតិ អាល់បានីរស់នៅ។ អង្គការណាតូបានបើកប្រតិបត្តិការសង្គ្រាមដែនអាកាស ដែលបានអូសបន្លាយរយៈពេល ១១សប្តាហ៍។ អង្គការណាតូបានទទួលរងការរិះគន់ពីប្រទេសរុស្ស៊ីនិងចិន ចំពោះចាត់វិធានការណ៍ដោយគ្មាន ការអនុញ្ញាតច្បាស់លាស់ ពីអង្គការសហប្រជាជាតិ និងចំពោះការជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់ស៊ែប៊ី។ (សហគមន៍អន្តរជាតិ និងអង្គការសហប្រជាជាតិ បានចាត់ទុកខេត្តស្វយ័ត កូសាវ៉ូ, ខុសពីសាធារណរដ្ឋ

សហព័ន្ធយូហ្គោស្លាវី, ជាផ្នែកមួយ នៃប្រទេសស៊ែប៊ី។) នៅទីបញ្ចប់ កងកម្លាំងស៊ែប៊ី ត្រូវបានដកចេញពីកូសូវ៉ូ ហើយអង្គការណាតូបានគ្រប់គ្រងជំនួស តាំងពីពេលនោះមក។ ក្នុងឆ្នាំ ២០០៨ ដោយក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ នៅតែជាប់គាំង មិនអាចសម្រេចលើហាន:របស់ខ្លួន កូសូវ៉ូបានប្រកាសឯករាជ្យ បណ្តាលអោយការតវ៉ាពីស៊ែប៊ីនិងសម្ព័ន្ធមិត្តរបស់គេ។ នៅក្នុងឆ្នាំ ២០១០ តុលាការយុត្តិធម៌អន្តរជាតិបានប្រកាសថា ការប្រកាសឯករាជ្យភាពរបស់កូសូវ៉ូ មានភាពស្របច្បាប់ ទោះបីជាហាន:ជារដ្ឋឯករាជ្យរបស់កូសូវ៉ូនៅតែមានការជជែកតវ៉ាគ្នា រហូតដល់ឆ្នាំ ២០១៨ ក្តី។

ការសម្រេចចិត្តធ្វើអន្តរាគមន៍យោធារបស់លោកខាងលិចដទៃទៀតចាប់តាំងពីឆ្នាំ១៩៩០មក មិនសូវមានប្រសិទ្ធភាពទេ។ នៅប្រទេសសូម៉ាលី សម្ព័ន្ធយោធាចម្រុះដែលដឹកនាំដោយអាមេរិក បានបញ្ជូនកងទ័ពរាប់សិបពាន់នាក់ ដើម្បីបង្ក្រាបការប្រយុទ្ធគ្នារវាងភាគីជម្លោះ និងផ្តល់ជំនួយសង្គ្រោះបន្ទាន់ដល់ប្រជាជនមួយភាគធំដែលកំពុងស្រែកឃ្លាន។ ទោះយ៉ាងណា នៅពេលដែលកងកម្លាំងទាំងនោះ ត្រូវបាន ទាញចូលក្នុងអន្លង់ប្រយុទ្ធគ្នា ហើយថែមទាំងបង្កអោយមានការស្លាប់កងទ័ពជាបន្តបន្ទាប់សហរដ្ឋអាមេរិកបានដកកងទ័ពចេញភ្លាមៗ។ នៅប្រទេសរ៉្វាន់ដា ក្នុងឆ្នាំ ១៩៩៤ អំពើប្រល័យពូជសាសន៍សម្លាប់ ប្រជាជនស៊ីវិលជាងកន្លះលាននាក់ តែក្នុងរយៈពេលប៉ុន្មានសប្តាហ៍ ហាក់មិនត្រូវបានទទួលការអើពើពីសំណាក់សហគមន៍អន្តរជាតិឡើយ។ ប្រទេសមហាអំណាច ដែលហាក់បានបាក់ស្បាតដោយប្រតិបត្តិការបរាជ័យ នៅប្រទេសសូម៉ាលី និងបូស្នៀ បានសំរេចថា ផលប្រយោជន៍សំខាន់របស់ពួកគេ មិនមានហានិភ័យ [ដោយសាររឿងនោះ] ទេ។ នៅឆ្នាំ ១៩៩៦ កងទ័ពអាមេរិកបានអន្តរាគមន៍ក្នុងតំបន់ជិតខាងខ្លួន កោះហៃទី ដើម្បីធានាការឡើងកាន់តំណែងប្រធានាធិបតីជាប់ឆ្នោតថ្មី ប៉ុន្តែប្រទេសនេះ នៅតែរងទុក្ខវេទនាក្នុងភាពក្រីក្រ។ នៅឆ្នាំ ១៩៩៧ ជម្លោះប្រទេសរ៉្វាន់ដា បានហៀរចូលដល់ប្រទេសជិតខាង ប្រជាធិបតេយ្យកុងហ្គោ(អតីត Zaire) ដែលក្រុមឧទ្ទាមបានផ្តួលរំលំរមេដឹកនាំផ្តាច់ការពុករលួយ។ ប្រទេសជិតខាងនានា ត្រូវបានអូសចូលក្នុងការប្រយុទ្ធគ្នា ប៉ុន្តែសហគមន៍អន្តរជាតិ នៅតែមិនរវល់ជាមួយបើទោះបីជាជនស៊ីវិលរាប់លាននាក់បានបាត់នបង់ជីវិតដោយសារគ្រោះទុរភិក្សនិងជំងឺជង្គាត់ផ្សេងៗ។

ការប្រែធាថ្មីបានលេច នៅឆ្នាំ ២០០១ រវាងសហរដ្ឋអាមេរិក និង ទាំងចិន និងអឺរ៉ុប ដែលអាចជាសញ្ញានៃការចងក្រងបក្សសម្ព័ន្ធឡើងវិញ ប្រឆាំងនឹងភាពលេចធ្លោរបស់សហរដ្ឋអាមេរិកនៅក្នុងកិច្ចការពិភពលោក លើបញ្ហារាប់ចាប់ពីការឡើងកំដៅផែនដីរហូតដល់ការស្នើឡើងនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ។ រុស្ស៊ី និងចិនបានចុះហត្ថលេខាលើសន្ធិសញ្ញាមិត្តភាព ក្នុងឆ្នាំ ២០០១ ហើយបណ្តាប្រទេសនៅអឺរ៉ុបបានជួយបោះឆ្នោតអោយសហរដ្ឋអាមេរិកចេញពីគណៈកម្មការសំខាន់ៗចំនួនពីររបស់អង្គការសហប្រជាជាតិ។

ការផ្លាស់ប្តូរថ្មីមួយបានកើតឡើងក្នុងនយោបាយសកល នៅពេលដែលសហរដ្ឋអាមេរិកត្រូវបានវាយប្រហារដោយអំពើភាវៈកម្ម នៅថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ២០០១។ ការវាយប្រហារដោយគំរោងការណ៍ទុកមុនយ៉ាងល្អិតល្អន់ ចំនួនបួនលើក បានបំផ្លិចបំផ្លាញមជ្ឈមណ្ឌលពាណិជ្ជកម្មពិភពលោក នៅរដ្ឋញូវយ៉ក និងជ្រុងមួយនៃមន្ទីរបញ្ចកោណ នៅវ៉ាស៊ីងតោនឌីស៊ី ខណៈពេលដែលជើងហោះហើរមួយទៀតបានធ្លាក់នៅក្រុងសុមេសែត រដ្ឋផេនស៊ីវេនី ក្រោយពេលអ្នកដំណើរបានដណ្តើមការគ្រប់គ្រងយន្តហោះពីភេរវករ។ ជនជាតិអាមេរិកនិងពលរដ្ឋនៃប្រទេសប្រហែល៦០ទៀតរាប់ពាន់នាក់ត្រូវបានសម្លាប់។ ការវាយប្រហារបានទាក់ទាញការគាំទ្រពីសម្ព័ន្ធភាពនៃរដ្ឋជាច្រើន ដល់សហរដ្ឋអាមេរិក។ លោកប្រធានាធិបតី ប៊ូស បានប្រកាស «សង្គ្រាម

លើអំពើភេរវកម្ម» ដែលអូសបន្លាយអស់រយៈពេលជាច្រើនឆ្នាំ ហើយនិងបានរាលដាលដល់ទ្វីបនានាដោយប្រើទាំងមធ្យោបាយសាមញ្ញ និងពិសេស។ នៅចុងឆ្នាំ ២០០១ កងទ័ពសហរដ្ឋអាមេរិកនិងសម្ព័ន្ធមិត្ត បានទម្លាក់របបតាលីបង់ពីអំណាច នៅអាហ្វហ្គានីស្ថាន ដែលអនុញ្ញាតអោយបណ្តាញអាល់កៃដា (ដឹកនាំដោយអូសាម៉ា ប៊ីនឡាដិន)ជ្រកកោន។

ទោះយ៉ាងណា ការបែងចែករវាងប្រទេសមហាអំណាចបានលេចចេញកាន់តែច្បាស់ម្តងទៀត នៅពេលដែលសហរដ្ឋអាមេរិក និងចក្រភពអង់គ្លេស បានព្យាយាមកៀងគរសម្ព័ន្ធភាពមួយដើម្បីផ្តួលរំលំរបបសាដាម ហ៊ូសេន (Saddam Hussein) ក្នុងប្រទេសអ៊ីរ៉ាក់ ដោយកម្លាំងទ័ពនៅដើមឆ្នាំ ២០០៣។ ប្រទេសបារាំងនិងអាឡឺម៉ង់ (រួមទាំងប្រទេសរុស្ស៊ី និងចិន) បានប្រឆាំងនឹងសង្គ្រាមយ៉ាងជូរចត់ ក៏ដូចជាបាតុកររាប់លាននាក់ទៀត នៅជុំវិញពិភពលោក។ ជម្លោះនេះបានធ្វើអោយមានភាពរំខានដល់សម្ព័ន្ធភាពអាត្លង់ទិច អស់រយៈពេលជាច្រើនឆ្នាំ និងធ្វើអោយតួនាទីរបស់អ.ស.ប. កាន់តែចុះខ្សោយខណៈពេលដែលក្រុមកងទ័ពចម្រុះដឹកនាំដោយសហរដ្ឋអាមេរិកបន្តប្រតិបត្តិការ បើទោះបីជាបរាជ័យក្នុងការទទួលបានភ្លើងខៀវពីក្រុមប្រឹក្សាសន្តិសុខក៏ដោយ។

ការលុកលុយប្រព្រឹត្តិទៅ ក្នុងរយៈពេលខ្លី និងមិនរួញរា។ កម្លាំងយោធាអាមេរិក ប្រមាណ ២៥០ ៣ន់នាក់ ដែលមានបច្ចេកវិទ្យាទំនើបចុងក្រោយ បានវាយបំបាក់កម្លាំងទ័ពអ៊ីរ៉ាក់ ក្នុងរយៈពេលបីសប្តាហ៍។ ជនជាតិអ៊ីរ៉ាក់ជាច្រើនបានស្វាគមន៍ចុងបញ្ចប់នៃរបបផ្តាច់ការ ដូចដែលប្រជាជនអាហ្វហ្គានីស្ថានភាគច្រើនបានធ្វើ នៅចុងឆ្នាំ ២០០១ ប៉ុន្តែ សង្គ្រាមបានធ្វើអោយមានកំណើនមនោសញ្ចេតនាប្រឆាំងនឹងអាមេរិក ជាពិសេស នៅក្នុងបណ្តាប្រទេសម៉ូស្លីម។ កងកម្លាំងបះបោរ នៅអ៊ីរ៉ាក់ បានបង្កើនវិសាលភាពរបស់ខ្លួន ខណៈការក្តោបកាន់កាប់របស់សហរដ្ឋអាមេរិកបានអូសបន្លាយអស់រយៈពេលជាច្រើនឆ្នាំ ហើយក្នុងរយៈពេលប៉ុន្មានឆ្នាំបន្ទាប់ សាធារណៈមតិនៅសហរដ្ឋអាមេរិក កាន់តែច្រើនឡើង បានប្រឆាំងនឹងសង្គ្រាមអូសបន្លាយ។ បន្ទាប់ពីការកើនឡើងចំនួនកងទ័ពសហរដ្ឋអាមេរិក [ឈរជើងនៅអ៊ីរ៉ាក់] ក្នុងឆ្នាំ ២០០៧, ហើយបំពាក់អាវុធដល់សហគមន៍ស៊ុននី (Sunni) ដែលឆ្អែតឆ្អន់ធុញទ្រាន់នឹងក្រុមអ៊ីស្លាមជ្រុលនិយមពីបរទេស, អំពើហិង្សានៅអ៊ីរ៉ាក់បានធ្លាក់ចុះ។ កងកម្លាំងរបស់សហរដ្ឋអាមេរិកបានដកខ្លួនចេញ ពីប្រទេសអ៊ីរ៉ាក់ក្នុងចន្លោះឆ្នាំ ២០០៩-២០១១។ ចំនួនប្រជាជនអ៊ីរ៉ាក់ដែលបាត់បង់ជីវិតក្នុងសង្គ្រាម ត្រូវបានប៉ាន់ប្រមាណ ក្នុងចន្លោះពីរាប់មឺននាក់រហូតដល់ជាង ៦០ មឺននាក់។ ការបោះឆ្នោត នៅឆ្នាំ ២០១០ និង ២០១៤ បានប្រព្រឹត្តិទៅ ដោយសន្តិវិធីសមល្មម ប៉ុន្តែ លទ្ធផលទាំងពីរលើក បានឆ្លុះបញ្ចាំងការបែងចែកប្រទេស រវាងក្រុមជនជាតិដើមនីមួយៗ។ អំពើហិង្សានិងភាពចលាចលម្តងម្កាល បានបន្តរហូតដល់ កំឡុងឆ្នាំ ២០១១-២០១៣ រហូតទាល់តែមានការរាលដាលនៃជម្លោះពីប្រទេសស៊ីរី នៅជិតខាង។ ក្រុមឥស្លាមនិយមជ្រុលដ៏មានឥទ្ធិពលមួយក្រុម ត្រូវបានគេស្គាល់ថាជា «អាយស៊ីស» (ISIS៖ រដ្ឋអ៊ីស្លាមនៅអ៊ីរ៉ាក់និងស៊ីរី) បានចាប់ផ្តើមដណ្តើមយកទីក្រុងធំៗ នៅភាគកណ្តាល និងភាគខាងជើងប្រទេសអ៊ីរ៉ាក់។ នាយករដ្ឋមន្ត្រីអ៊ីរ៉ាក់បានលាលែង ហើយសត្រូវជាប្រពៃណីរបស់អ៊ីរ៉ាក់ ដូចជាប្រទេសអ៊ីរ៉ង់និងសហរដ្ឋអាមេរិកបានចាប់ផ្តើមជួយអ៊ីរ៉ាក់ ដោយប្រតិបត្តិការផ្សេងគ្នា (រៀងៗខ្លួន) ដើម្បីប្រឈមមុខនឹងក្រុមរដ្ឋអ៊ីស្លាមនៅអ៊ីរ៉ាក់និងស៊ីរី (ISIS)។ នៅរដូវស្លឹកឈើជ្រុះ ក្នុងឆ្នាំ ២០១៧ ប្រទេសអ៊ីរ៉ាក់បានប្រកាសជ័យជម្នះលើក្រុមISIS និងបានដណ្តើមការគ្រប់គ្រងឡើងវិញលើទឹកដីទាំងអស់ដែលធ្លាប់ធ្លាក់ក្រោមកណ្តាប់ដៃរដ្ឋអ៊ីស្លាម។

នៅប្រទេសអាហ្វហ្គានីស្ថាន ការប្រយុទ្ធកាន់តែធ្ងន់ធ្ងរ បានចាប់ផ្តើម នៅឆ្នាំ ២០០៧ នៅពេលដែលពួកតាលីបង់ បានធ្វើយុទ្ធនាការកុបកម្មមួយ ចេញពីមូលដ្ឋានទ័ព នៅប្រទេសប៉ាគីស្ថាន។ ការបោះឆ្នោតដ៏ចំរូងចំរាស់, អំពើពុករលួយ, និងការវាយប្រហារ«ផ្ទៃក្នុង» ដោយសមាជិកនៃកងកំលាំងសន្តិសុខរបស់ប្រទេសអាហ្វហ្គានីស្ថាន ទៅលើកងទ័ពរបស់ណាតូ បានធ្វើអោយប្រតិបត្តិការរបស់ជនបរទេស កាន់តែលំបាក។ អង្គការណាតូ បានបញ្ជូនកងទ័ពបន្ថែម រាប់ពាន់នាក់ ក្នុងឆ្នាំ ២០០៩ ប៉ុន្តែ ក្រោយមកបានចាប់ផ្តើមដកកងទ័ពដែលនៅសេសសល់ ប្រមាណ ១១០០០ នាក់ នៅឆ្នាំ ២០១៨។ កងកម្លាំងណាតូ ក្នុងពេលនោះ បានបំពេញតួនាទីត្រឹមតែបណ្តុះបណ្តាល និងប្រឹក្សាយោបល់ដល់កងកំលាំងសន្តិសុខផ្ទាល់ របស់ប្រទេសអាហ្វហ្គានីស្ថានដែលនៅតែពិបាកតស៊ូប្រយុទ្ធប្រឆាំងនឹងពួកឧទ្ទាមតាលីបង់។ គោលដៅមួយនៃអន្តរាគមន៍ក្នុងប្រទេសអាហ្វហ្គានីស្ថានត្រូវបានសម្រេច ក្នុងឆ្នាំ ២០១១ នៅពេលកម្លាំងពិសេសរបស់សហរដ្ឋអាមេរិក បានសម្លាប់អូសាម៉ា ប៊ីនឡាដិន នៅប៉ាគីស្ថាន។ ការវាយប្រហារដោយយន្តហោះជ្រូនរបស់សហរដ្ឋអាមេរិក ទៅលើពួកសកម្មប្រយុទ្ធដទៃទៀត នៅប្រទេសប៉ាគីស្ថាននិងកន្លែងផ្សេងទៀត បានធ្វើអោយបណ្តាញភេរវកម្មអាល់កៃដា (Al Qaeda)ចុះខ្សោយ ប៉ុន្តែ ទន្ទឹមនឹងនោះ ក៏បានបង្កបញ្ហាផ្លូវច្បាប់និងនយោបាយ។ គិតត្រឹមឆ្នាំ ២០១៨ កងកម្លាំងតាលីបង់បានបន្តកាន់កាប់ដែនដី និងបន្តការវាយប្រហារទៅលើកងទ័ពអាហ្វហ្គានីស្ថាន និងគោលដៅស៊ីវិល។ កិច្ចប្រឹងប្រែងចរចាសន្តិភាពជាបន្តបន្ទាប់ត្រូវបរាជ័យ ហើយនៅឆ្នាំ ២០១៨ សហរដ្ឋអាមេរិកបានបញ្ឈប់ជំនួយសុវត្ថិភាពសន្តិសុខដល់ប្រទេសប៉ាគីស្ថាន ជាការដាក់ទណ្ឌកម្មលើដែលផ្តល់កន្លែងជ្រកកោនសម្រាប់មេដឹកនាំតាលីបង់។

ទន្ទឹមនឹងនេះ ភាពតានតឹងកម្មវិធីអាវុធនុយក្លេអ៊ែរ នៅប្រទេសកូរ៉េខាងជើង និងអ៊ីរ៉ង់ បានឈានដល់កម្រិតប្រកាសអាសន្ន។ ប្រទេសកូរ៉េខាងជើងបានផលិតគ្រាប់បែកនុយក្លេអ៊ែរមួយចំនួន និងបានសាកល្បងចំនួន ៦ លើក ចាប់តាំងពីឆ្នាំ ២០០៦ មក។ ក្នុងឆ្នាំ ២០១២ ពួកគេបានសាកល្បងមីស៊ីលរយៈចម្ងាយឆ្ងាយមួយ ដោយជោគជ័យ ដែលប្រឆាំងនឹងការហាមឃាត់របស់ក្រុមប្រឹក្សាសន្តិសុខ អ.ស.ប.។ នៅឆ្នាំ ២០១៧ ពួកគេបានបាញ់សាកល្បងនូវអ្វីដែលគេបរិយាយថាជា មីស៊ីលបាញ់ឆ្លងទ្វីប (ICBM) ដែលអាចបាញ់ដល់តំបន់ខ្លះក្នុងប្រទេសអាមេរិក។ ការតេស្តសាកល្បងនុយក្លេអ៊ែរលើកទី ៦ នៅក្នុងឆ្នាំ ២០១៧ដដែល ប្រហែលជាគ្រាប់បែកអ៊ីដ្រូហ្សែន ដែលមានឥទ្ធិពលបន្ទុះធំទូលំទូលាយជាងគ្រាប់បែកមុនៗ(ចូរមើលមេរៀនទី ៦)។ ជាការឆ្លើយតបទៅនឹងការតេស្តសាកល្បងទាំងនេះ សហរដ្ឋអាមេរិកបានដាក់ទណ្ឌកម្មបន្ថែមទៀតដោយមានជំនួយពីអង្គការសហប្រជាជាតិ។ សហរដ្ឋអាមេរិក ក៏បានបង្កើនវត្តមានយោធារបស់ខ្លួនច្រើនគួរសម នៅជ្រោយកូរ៉េ ដែលជាការបង្ហាញការគំរាមកំហែងដល់កូរ៉េខាងជើង។

រូបថត **លំហាត់សមរងការវាយប្រហារដោយអាវុធនុយក្លេអ៊ែរ**

និន្នាការសន្តិភាពសម្គាល់យុគសម័យក្រោយសង្គ្រាមត្រជាក់ ទោះបីជាមានសង្គ្រាម និងភេរវកម្មនៅតែបន្តក៏ដោយ។ លទ្ធភាពនៃការផ្ទុះជម្លោះអន្តរដ្ឋ កើតឡើងនៅជុំវិញឧបទ្វីបកូរ៉េ ជាកន្លែងដែលប្រទេសកូរ៉េខាងជើង និងខាងត្បូងនៅតែជាសត្រូវនឹងគ្នា ៦៥ឆ្នាំ បន្ទាប់ពីបញ្ចប់សង្គ្រាមរបស់ពួកគេ។ ការអភិវឌ្ឍន៍អាវុធនុយក្លេអ៊ែរនិងមីស៊ីលផ្លោងរបស់កូរ៉េខាងជើង គឺជាប្រភពសំខាន់នៃភាពតានតឹងរវាងប្រទេសនេះ និងពិភពលោក ជាពិសេសប្រទេសជិតខាងដូចជាកូរ៉េខាងត្បូង និងជប៉ុន។ នៅទីនេះ សិស្សសាលាជប៉ុនធ្វើសមយុទ្ធសង្គ្រោះបន្ទាន់ជាការឆ្លើយតបទៅនឹងការភ្លែងធ្វើជាបាញ់មីស៊ីលរបស់កូរ៉េខាងជើងឆ្នាំ ២០១៧ ។

ដោយចាប់ផ្តើមពីឆ្នាំ ២០០៤ មក ប្រទេសអ៊ីរ៉ង់បានបំពានកិច្ចព្រមព្រៀងទាំងឡាយដែលហាមឃាត់ការចម្រាញ់សារធាតុអ៊ុយរ៉ាញ៉ូម ដែលអាចត្រូវបានគេប្រើសម្រាប់ផលិតអាវុធនុយក្លេអ៊ែរ។ ជាការឆ្លើយតប ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ បានអនុម័តសេចក្តីសម្រេចចិត្តជាក់ទណ្ឌកម្មជាបន្តបន្ទាប់ប្រឆាំងនឹងប្រទេសអ៊ីរ៉ង់ ដោយទាមទារអោយពួកគេបញ្ឈប់កម្មវិធីចម្រេញសារធាតុនោះ។ ក្នុងឆ្នាំ ២០១០ ម៉ាស៊ីនមេសម្រាប់កម្មវិធីចម្រាញ់ បានចាប់ផ្តើមបំផ្លាញខ្លួនឯង ដោយអាច៎កំបាំងបំផុតហើយការស៊ើបអង្កេតបានចង្អុលបង្ហាញថាបញ្ហាបណ្តាលមកពីមេរោគកុំព្យូទ័រ «StuxNet» (ស្ទុចណេត) ប្រាកដណាស់វាជាផលិតកម្មរបស់អ្នកវិទ្យាសាស្ត្រការពារជាតិអ៊ីស្រាអែលនិងអាមេរិកាំង។ វាបានទាញកម្មវិធីអ៊ីរ៉ង់ថយក្រោយ មួយឆ្នាំឬច្រើនជាងនេះ។ នៅរដូវក្តៅឆ្នាំ ២០១៥ ប្រទេសអំណាចធំៗនិងប្រទេសអ៊ីរ៉ង់ បានយល់ព្រមលើកិច្ចព្រមព្រៀងមួយដើម្បីកាត់បន្ថយកម្មវិធីនុយក្លេអ៊ែររបស់អ៊ីរ៉ង់។ កិច្ចព្រមព្រៀងនេះ ត្រូវបានអ្នកខ្លះសាទរថាជាជ័យជំនះបន្ថយល្បឿនវឌ្ឍនភាពរបស់ប្រទេសអ៊ីរ៉ង់ ខណៈដែលក្រុមផ្សេងទៀតនៅមន្ទិលសង្ស័យ ដោយកត់សម្គាល់ថាកិច្ចព្រមព្រៀងនេះនៅតែបន្សល់ទុកចន្លោះប្រហោង[ផ្លូវច្បាប់] ដែលទុកលទ្ធភាពអោយប្រទេសអ៊ីរ៉ង់ សាងសង់អាវុធនុយក្លេអ៊ែរ នៅពេលណាមួយនាពេលអនាគត។ ប្រធានាធិបតី ត្រាំ បានដកសហរដ្ឋអាមេរិកចេញពីកិច្ចព្រមព្រៀងនោះ នៅឆ្នាំ ២០១៨។ បណ្តារដ្ឋនៅអឺរ៉ុប នាពេលនោះ បានបន្តចរចាជាមួយអ៊ីរ៉ង់ អោយបន្តកិច្ចព្រមព្រៀង។ ទន្ទឹមនឹងនោះ បាតុកម្មប្រឆាំងនឹងរដ្ឋាភិបាលអ៊ីរ៉ង់បានផ្ទុះឡើងនៅឆ្នាំ ២០១៨ នៅទូទាំងប្រទេសអ៊ីរ៉ង់ ដែលអាចគំរាមកំហែងដល់ស្ថេរភាពនយោបាយ។

ការបះបោរនិទាឃរដូវនៅអារ៉ាប់ នៅឆ្នាំ ២០១១ បានចាប់ផ្តើមដំបូង ដោយការតវ៉ាអហិង្សាមួយចំនួននៅប្រទេស ទុយនីស៊ី និងអេហ្ស៊ីប ហើយជាលទ្ធផល ពួកគេបានផ្តួលរំលំមេដឹកនាំផ្តាច់ការនិងរៀបចំការបោះឆ្នោតដោយសេរី នៅក្នុងប្រទេសទាំងពីរ។ ប្រទេសអេហ្ស៊ីបបានបោះឆ្នោតជ្រើសរើសមេដឹកនាំនៃក្រុមភាតរភាពឥស្លាម(Muslim Brotherhood) ដែលត្រូវបានហាមឃាត់ជាយូរណាស់មកហើយ អោយធ្វើជាប្រធានាធិបតី ប៉ុន្តែត្រូវយោធាធ្វើរដ្ឋប្រហារទម្លាក់ នៅឆ្នាំ ២០១៣។ នៅប្រទេសលីប៊ីនិងស៊ីរី ការបង្ក្រាបដោយហិង្សាលើក្រុមអ្នកតវ៉ាបានបង្កអោយមានការបះបោរហិង្សា រហូតដល់អាចទម្លាក់មេដឹកនាំផ្តាច់ការលីប៊ី ដោយការបង្ហូរឈាម និងដោយមានការគាំទ្រផ្លូវអាកាសពីអង្គការណាតូ និងបង្កអោយមានសង្គ្រាមស៊ីវិលយោរយៅដែលអូសបន្លាយយ៉ាងយូរ នៅក្នុងប្រទេសស៊ីរី ជាមួយនឹងការបែកបាក់ក្នុងចំណោមសហគមន៍អន្តរជាតិ ដែលមិនអាចឆ្លើយតបប្រកបដោយប្រសិទ្ធភាព។ នៅទីបំផុត សង្គ្រាមស៊ីរីបានរាលដាលចូលដល់ប្រទេសអ៊ីរ៉ាក់ដែលនៅជិតខាង បណ្តាលអោយរដ្ឋាភិបាលអស្ថេរភាព។ ការប្រើប្រាស់អាវុធគីមីនៅស៊ីរី នាំអោយមានការស្តីបន្ទោសលើរដ្ឋាភិបាលស៊ីរី ជាច្រើនលើកច្រើនសារ។ រុស្ស៊ីបានអន្តរគមន៍ដោយការវាយប្រហារផ្លូវអាកាស នៅប្រទេសស៊ីរី (វាយប្រហារលើក្រុមបះបោរប្រឆាំងនឹងរដ្ឋាភិបាល និងរដ្ឋឥស្លាមនៅអ៊ីរ៉ាក់និងស៊ីរី) ដើម្បីពង្រឹងសម្ព័ន្ធមិត្តរបស់ខ្លួននៅតំបន់មជ្ឈឹមបូព៌ា ខណៈពេលដែលសហរដ្ឋអាមេរិកនិងសម្ព័ន្ធមិត្តលោកខាងលិច បានព្យាយាមជួយក្រុមបះបោរនិងជនសកម្មប្រយុទ្ធយឺៗ (ក្រុមជនជាតិភាគតិច នៅប្រទេសស៊ីរីនិងអ៊ីរ៉ាក់) ទប់ទល់នឹងពួកISISនិងក្រុមពាក់ព័ន្ធ។ ទន្ទឹមនឹងនោះ អំពើហិង្សានៅប្រទេសលីប៊ីបានបន្តរហូតដល់ឆ្នាំ ២០១៨។

ប្រទេសយេម៉ែនក៏មានបដិវត្តន៍ផ្ទាល់ខ្លួនដែរ រួមមានទាំងការតវ៉ាដោយសន្តិវិធី ការបង្ក្រាបដោយហិង្សាជម្លោះជាតិពន្ធុនិងការសម្របសម្រួលផ្នែកនយោបាយដែលអាចឈានដល់រដ្ឋាភិបាលអន្តរកាល។ រដ្ឋាភិបាល

អន្តរកាល (ក្រោមការជួយជ្រោមជ្រែងពីប្រទេសអារ៉ាប៊ីសាអូឌីត និងសម្ព័ន្ធមិត្តលោកខាងលិច) បានជាប់ខ្លួនប្រយុទ្ធក្នុងសង្គ្រាមបង្ហូរឈាមប្រឆាំងនឹងក្រុមឧទ្ទាមបះបោរ (ក្រុមខ្លះជួយដោយអ៊ីរ៉ង់ និងក្រុមខ្លះទៀតដោយបណ្តាញអាល់កៃដា)។ នៅត្រឹមឆ្នាំ ២០១៧ សង្គ្រាមបានរីកឡើងកាន់តែធំ នៅពេលដែលក្រុមឧទ្ទាមបានគ្រប់គ្រងតំបន់សំខាន់ៗក្នុងប្រទេស ការបិទផ្លូវនាវាបានគំរាមកំហែង ធ្វើឱ្យមានទុរ្ភិក្សកាន់តែធ្ងន់ធ្ងរ ហើយជនសកម្មប្រយុទ្ធមកពីជុំវិញតំបន់ បានប្រមូលផ្តុំគ្នា លើប្រទេសយេម៉ែន ដើម្បីដណ្តើមអាវុធ ប្រយុទ្ធគាំទ្រនិងប្រឆាំងរដ្ឋាភិបាល។ ហើយនៅឆ្ងាយពីនេះ នៅឯប្រទេសភូមា ក្រោយពេលរបបយោធាចាស់វស្សា នៅទីបំផុតបានធ្វើចលនាយឺតៗឆ្ពោះទៅរកលទ្ធិប្រជាធិបតេយ្យ, របបនេះបានប្រព្រឹត្តទង្វើដែលមនុស្សជាច្រើនបានពណ៌នាថាជា «ការបោសសម្អាតជាតិសាសន៍» ប្រឆាំងនឹងក្រុមជនជាតិភាគតិច ក្នុងឆ្នាំ ២០១៧ ដោយបង្កអោយមានគ្រោះមហន្តរាយមនុស្សធម៌។

យុគសម័យក្រោយសង្គ្រាមត្រជាក់ហាក់បីដូចជាសម័យផុយស្រួយ ងាយផ្ទុះជម្លោះ ដែលអំពើហិង្សាដ៏ប្រល័យ បានផ្ទុះឡើង ជាញឹកញាប់ រហូតនឹកស្មានមិនដល់ នៅជុំវិញពិភពលោក រួមទាំងនៅទីតាំងដូចជាប្រទេសយ៉ាន់ដា និងប្រទេសស៊ីរី សូម្បីតែទីក្រុងញូវយ៉ែកក៏មានផ្ទុះឡើងដែរ។ ប៉ុន្តែ *យុគសម័យក្រោយសង្គ្រាមត្រជាក់ហាក់មានសន្តិភាពជាងកំឡុងយុគសម័យសង្គ្រាមត្រជាក់* (សូមមើលមេរៀនទី ៥)។ សង្គ្រាមចាស់ៗត្រូវបានបញ្ចប់លឿនជាងសង្គ្រាមថ្មីៗអាចចាប់ផ្តើមបាន។ ទ្វីបអាមេរិកឡាទីននិងតំបន់ខ្លះនៃទ្វីបអាហ្វ្រិកស្ទើរតែបានពន្លត់ភ្លើងសង្គ្រាម នៅក្នុងតំបន់របស់ខ្លួន ដោយបានចូលរួមក្នុងតំបន់សន្តិភាពដែលមានសន្តិភាពរួចទៅហើយ ដូចជាអាមេរិកខាងជើង អឺរ៉ុប ជប៉ុននិងប៉ាស៊ីហ្វិក និងចិន។

សង្គ្រាមបាននិងកំពុងថមថយចុះ សូម្បីតែនៅក្នុងស្ថានភាពនៃជម្លោះ ពីទ្វីបអាហ្វ្រិក រហូតដល់មជ្ឈឹមបូព៌ា រហូតដល់អាស៊ីខាងត្បូង។ ចាប់តាំងពីឆ្នាំ ១៩៩០ សង្គ្រាមបង្ហូរឈាមដែលបានអូសបន្លាយយ៉ាងយូរត្រូវបានបញ្ចប់ នៅអាហ្វ្រិកខាងត្បូង ប្រទេសម៉ូហ្សំប៊ិក ប្រទេសអង់ហ្គោឡា ប្រទេសស៊ូដង់ខាងត្បូងនិងប្រទេសអេត្យូពី-អេរីទ្រា ក៏ដូចចុងបញ្ចប់នៃជម្លោះនៅអាមេរិកកណ្តាល និងសង្គ្រាមស៊ីវិលនៅស្រីលង្កាដែរ។ សង្គ្រាមនៅអាហ្វ្រិកខាងលិច យ៉ាន់ដា និងឥណ្ឌូនេស៊ី ក៏បានថមថយដូចគ្នា។ បន្ទាប់ពីសង្គ្រាមត្រជាក់បានបញ្ចប់ សណ្តាប់ធ្នាប់ពិភពលោកមិនរីករាលដាលហួសពីការគ្រប់គ្រង រហូតមានការឈ្លានពានខ្លាំងនិងសង្គ្រាមទេ។

ទោះយ៉ាងណាជម្លោះអ៊ីស្រាអែល-ប៉ាឡេស្ទីន ដែលមានកំណើនក្តីសង្ឃឹមរកសន្តិភាព ក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ បានផ្ទុះឡើងកាន់តែធ្ងន់ធ្ងរ បន្ទាប់ពីកិច្ចព្រមព្រៀងមួយ ដែលបានស្នើឡើងត្រូវបរាជ័យនៅឆ្នាំ ២០០០។ ជាមួយនឹងជោគជ័យក្នុងការបោះឆ្នោតប៉ាឡេស្ទីនរបស់ក្រុមសកម្មប្រយុទ្ធហាម៉ាស់(Hamas) ដែលទទួលខុសត្រូវចំពោះការវាយប្រហារ ដោយអំពើហឹង្សាជាច្រើនទៅលើអ៊ីស្រាអែល ក្តីសង្ឃឹមថានឹងមានសុខសន្តិភាពយូរអង្វែងត្រូវរសាត់បាត់បង់។ នៅឆ្នាំ ២០០៦ ប្រទេសអ៊ីស្រាអែលបានបើកឆាកប្រយុទ្ធយ៉ាងខ្លីប៉ុន្តែខ្លាំងក្លា ប្រឆាំងនឹងឧទ្ទាមទ័ពព្រៃហេសបូឡា (Hezbollah Guerrillas) នៅលើបង់ខាងត្បូង ខណៈការប៉ះទង្គិចគ្នា ដោយហិង្សា រវាងអ៊ីស្រាអែលនិងក្រុមហាម៉ាសបានបន្តរហូតដល់ចន្លោះឆ្នាំ ២០០៩ ដល់ ២០១៤។ ប្រទេសអ៊ីស្រាអែលបានតំឡើងប្រព័ន្ធការពារមីស៊ីលថ្មីមួយ រហ័ស្សនាម «ដំបូលដែក» (Iron Dome) ដើម្បីប្រឆាំងទប់ទល់នឹងមីស៊ីលរបស់ពួកហាម៉ាស់ ក្នុងការប៉ះទង្គិច ឆ្នាំ ២០១២ និង ២០១៤។ នៅត្រឹមឆ្នាំ ២០១៨ ប្រទេសអ៊ីស្រាអែលបានបន្តស្នើនិងកសាងការតាំងទីលំនៅបន្ថែមទៀតលើទឹកដីមានជម្លោះ ខណៈដែលប្រជាជនប៉ាឡេស្ទីនបន្តទទូចចង់បានការទទួលស្គាល់ជាឯករដ្ឋ។ ទង្វើរបស់ភាគីមួយ

នាំអោយមានការថ្កោលទោសពីភាគីមួយទៀត ដែលធ្វើអោយបាត់បង់ក្តីសង្ឃឹមក្នុងការស្វែងរកសន្តិភាពថែមទៀត។ នៅរដូវស្លឹកឈើជ្រុះឆ្នាំ ២០១៧ សហរដ្ឋអាមេរិកប្រកាសថាខ្លួននឹងលើកទីតាំងស្ថានទូតរបស់ខ្លួន (ពីទីក្រុងតែលអាវីវ) ទៅទីក្រុងយេរូសាឡឹម ដែលបណ្តាលអោយភាពតានតឹងក្នុងតំបន់កាន់តែខ្លាំងឡើង។

ក្នុងទំនាក់ទំនងសេដ្ឋកិច្ចអន្តរជាតិ យុគសម័យ*ក្រោយសង្គ្រាមត្រជាក់* គឺជាផ្នែកមួយនៃសាកលភាវូបនីយកម្ម។ តំបន់មានកំណើនសេដ្ឋកិច្ចថ្មីៗជាច្រើនបាននិងកំពុងលេចចេញរូបរាង ជាពិសេស នៅផ្នែកខ្លះនៃទ្វីបអាស៊ី ដែលមានកំណើនសេដ្ឋកិច្ចគួរអោយកត់សម្គាល់។ ទោះជាយ៉ាងណា សាកលភាវូបនីយកម្មបានបង្កភាពលំបាកជាច្រើនផងដែរ។ ក្នុងរវាងឆ្នាំ ២០០៧-២០០៨ វិបត្តិសេដ្ឋកិច្ចដ៏ធំមួយ បានធ្វើឱ្យសេដ្ឋកិច្ចប្រទេសអភិវឌ្ឍន៍របស់សហរដ្ឋអាមេរិក អឺរ៉ុប និងអាស៊ី ដែលបណ្តាលអោយមានអត្រាអត់ការងារធ្វើខ្ពស់រីករាលដាល ការធ្លាក់ចុះពាណិជ្ជកម្មអន្តរជាតិយ៉ាងគំហុក និងភាពជ្រួលច្របល់ផ្នែកសេដ្ឋកិច្ច។ ទោះបីជាគិតតាមលក្ខណៈបច្ចេកទេស វិបត្តិសេដ្ឋកិច្ចដ៏ធំនេះត្រូវបានបញ្ចប់ក៏ដោយ ប្រទេសជាច្រើនត្រូវចំណាយពេលយូរឆ្នាំដើម្បីស្តារសេដ្ឋកិច្ចឡើងវិញ។ ជាឧទាហរណ៍ កម្រិតការងារនៅក្នុងបណ្តារដ្ឋអូអ៊ីស៊ីឌី (OECD៖ អង្គការសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍន៍) មិនបានត្រឡប់ទៅកម្រិតមុនឆ្នាំ ២០០៧ ទេ រហូតដល់ឆ្នាំ ២០១៦ ។

នៅទ្វីបអឺរ៉ុប ការធ្លាក់ចុះសេដ្ឋកិច្ចដ៏ធ្ងន់ធ្ងរ(The Great Depression)មិនត្រឹមតែនាំមកនូវវិបត្តិសេដ្ឋកិច្ចប៉ុណ្ណោះទេ តែថែមទាំងបង្កអោយមានវិបត្តិនយោបាយផងដែរ។ ក្នុងអំឡុងវិបត្តិសេដ្ឋកិច្ច ប្រទេសមួយចំនួននៅអឺរ៉ុបភាគខាងត្បូង (អេស្ប៉ាញ ព័រទុយហ្គាល់ អ៊ីតាលី និងក្រិក) បានប្រឹងជំនះការរក្សាគោលដៅសេដ្ឋកិច្ចដែលត្រូវការជាចាំបាច់ដើម្បីរក្សាសមាជិកភាពក្នុងតំបន់អឺរ៉ូ ដែលប្រើរូបិយប័ណ្ណរួម(ប្រាក់អឺរ៉ូ)របស់សហភាពអឺរ៉ុប។ បន្ទាប់មក ប្រទេសក្រិកបានសារភាពថាខ្លួនបានកូតកុហកអំពីជំហរឬស្ថានភាពសេដ្ឋកិច្ចរបស់ខ្លួន ចំពោះសហភាពអឺរ៉ុប (EU) ដែលនាំអោយអ្នកវិនិយោគដកការវិនិយោគចេញពីប្រទេសក្រិក ហើយជាលទ្ធផល បានធ្វើអោយវិបត្តិសេដ្ឋកិច្ចកាន់តែធ្ងន់ធ្ងរឡើងៗ។ សហភាពអឺរ៉ុបដែលដឹកនាំដោយប្រទេសអាឡឺម៉ង់បានជ្រើសរើសសង្គ្រោះសេដ្ឋកិច្ចប្រទេសក្រិកដើម្បីរក្សារដ្ឋនេះនៅក្នុងតំបន់អឺរ៉ូ (សូមមើលមេរៀនទី ១០)។ វិបត្តិសេដ្ឋកិច្ចបាននាំអោយមានការកើនឡើងនូវមនោសញ្ចេតនាប្រឆាំងនឹងសហភាពអឺរ៉ុប នៅក្នុងផ្នែកខ្លះនៃទ្វីបអឺរ៉ុប។ ភាពតានតឹងផ្នែកនយោបាយនេះកាន់តែអាក្រក់ទៅៗ នៅក្នុងឆ្នាំ ២០១៥ នៅពេលដែលជនភៀសខ្លួនរាប់ម៉ឺននាក់ដែលបានភៀសខ្លួនចេញពីអំពើហិង្សា នៅក្នុងប្រទេសលីប៊ីនិងប្រទេសស៊ីរី បានធ្វើដំណើរទៅកាន់ទ្វីបអឺរ៉ុប។ ដោយកំពុងស្ថិតនៅលើវិថីឆ្ពោះទៅរកការងើបឡើងវិញពីវិបត្តិសេដ្ឋកិច្ចនៅឡើយ ពលរដ្ឋអឺរ៉ុបទាំងឡាយត្រូវបានបែងចែកគ្នា ថាតើត្រូវអនុញ្ញាតឱ្យជនភៀសខ្លួនស្នាក់នៅឬអត់។ អ្នកខ្លះបានសម្តែងការគាំទ្រការទទួលយកជនភៀសខ្លួន ដោយឈរលើហេតុផលសីលធម៌និងមនុស្សធម៌ ខណៈពេលអ្នកខ្លះទៀតបានលើកឡើងពីការព្រួយបារម្ភផ្នែកសេដ្ឋកិច្ច និងសន្តិសុខ។

លើសពីនេះទៀត សកលភាវូបនីយកម្មបានបង្កផលអវិជ្ជមានដល់ក្រុមមនុស្ស ដែលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ឬ ក្រុមមនុស្សដែលជឿថា អត្តសញ្ញាណរបស់ពួកគេត្រូវបានគំរាមកំហែងខ្លាំង ដោយឥទ្ធិពលបរទេស។ ការកើតនិងកើនឡើងវិញនៃចលនាជាតិនិយម និងជម្លោះជាតិសាសន៍-សាសនា (ជួនកាលផ្ទុះឡើងក្នុងរូបភាពដ៏ឃោរឃៅ) គឺជាលទ្ធផលមួយផលអវិជ្ជមាននោះ។ ចលនាតវ៉ាដ៏សំខាន់ប្រឆាំងនឹងសកលភាវូបនីយកម្ម ដែលអំណោយផលដោយមូលធននិយមក៏ដូចគ្នាដែរ។ ប្រតិកម្មនេះមានសារៈសំខាន់

ហើយបានស្តែងចេញនៅក្នុងលទ្ធផលនៃការបោះឆ្នោតពីរ ក្នុងឆ្នាំ ២០១៦៖ ការបោះឆ្នោតប្រធានាធិបតីអាមេរិក និងការបោះឆ្នោតប្រជាមតិរបស់អង់គ្លេសសម្រេចពីសមាជិកភាពចក្រភពអង់គ្លេស នៅក្នុងសហភាពអឺរ៉ុប។ ក្នុងការបោះឆ្នោតទាំងពីរ ប្រជានបទពេញនិយមរួមបញ្ចូលគ្រោះថ្នាក់នៃការបើកចំហព្រំដែន[ទទួលយកជនភៀសខ្លួន] និងការកើនឡើងពាណិជ្ជកម្មអន្តរជាតិ។ ប្រតិកម្មតបរួមបញ្ចូលទាំងការអំពាវនាវអោយត្រឡប់ទៅប្រើគោលនយោបាយផ្តល់អាទិភាពសម្រាប់ប្រទេសខ្លួនឯង (America First- អាមេរិកជាអាទិភាព) ដែលមានភាពស៊ីសង្វាក់គ្នាជាមួយនឹងគោលនយោបាយការបរទេសទំនោរជាតិនិយម ជាជាងគោលនយោបាយការបរទេសទំនោរសកលនិយម (សូមមើលឧទាហរណ៍បន្ថែមអំពី **មតិសាធារណៈ និងទំនាក់ទំនងអន្តរជាតិ**) នៅផ្នែកខាងចុងនៃមេរៀន។

ជាមួយនឹងកំនើនសាកលភាវូបនីយកម្ម កង្វល់ឆ្លងព្រំដែនជាតិដូចជាការបំផ្លិចបំផ្លាញបរិស្ថាន និងជំងឺពាក់ព័ន្ធកាន់តែមានភាពលេចធ្លោផងដែរ។ ការឡើងកម្តៅសកលកាន់តែក្លាយជាគ្រោះថ្នាក់ យ៉ាងពិតប្រាកដដែលមិនធ្លាប់។ គ្រោះថ្នាក់ទាំងនោះស្តែងចេញតាមរយៈការរលាយទឹកកកក្នុងល្បឿនកាន់តែលឿននៅតំបន់អាក់ទិក ក៏ដូចជាកំនើនទឹកជំនន់លេបត្របាក់ឆ្នេរសមុទ្រនានា នៅជុំវិញពិភពលោក។ នៅឆ្នាំ ២០១៤ និងឆ្នាំ ២០១៥ វីរុសដែលគេស្គាល់ថា អេបូឡា បានសម្លាប់មនុស្សរាប់ពាន់នាក់ នៅអាហ្វ្រិកខាងលិច និងគំរាមកំហែងដោយការរីករាលដាល នៅទូទាំងពិភពលោក ដែលបង្កអោយមានកិច្ចខិតខំប្រឹងប្រែង ដើម្បីគ្រប់គ្រងវីរុសតាមរយៈការធ្វើចត្តាឡីស័ក។ ឧបទ្វវហេតុកំពប់ប្រេងធំៗ នៅឈូងសមុទ្រម៉ិកស៊ិក និងចិន ក្នុងឆ្នាំ ២០១០ បានទាក់ទាញការយកចិត្តទុកដាក់ជាលក្ខណៈអន្តរជាតិ លើបញ្ហានៃការបំពុល និងបញ្ហាបរិស្ថានផ្សេងទៀត ជាពិសេស នៅក្នុងបរិបទនៃការប្រណាំងប្រជែងជាសកល ដណ្តើមធនធានធម្មជាតិ។

ប្រទេសចិនកាន់តែមានភាពលេចធ្លោនៅក្នុងកិច្ចការនយោបាយពិភពលោក ពេលចាប់ផ្តើមសតវត្សរ៍ទី២០។ ទំហំប្រទេសនិងល្បឿននៃកំនើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស បានធ្វើអោយប្រទេសចិនក្លាយជាប្រទេសមហាអំណាចកំពុងរះឡើងថ្មី ស្ថានភាពដែលអ្នកប្រាជ្ញមួយចំនួន ប្រៀបប្រដូចទៅនឹងការកើនឡើងអំណាចនៃប្រទេសអាឡឺម៉ង់ កាលពីមួយសតវត្សរ៍មុន។ បើមើលបទពិសោធន៍ក្នុងប្រវត្តិសាស្ត្រ ការផ្លាស់ប្តូរទំនាក់ទំនងអំណាច អាចបង្កអោយមានអស្ថិរភាព នៅក្នុងប្រព័ន្ធអន្តរជាតិ។ ចិន គឺជាប្រទេសមហាអំណាចតែមួយគត់ ដែលមិនប្រកាន់លទ្ធិប្រជាធិបតេយ្យ។ កំណត់ត្រាមិនល្អក្នុងបញ្ហាសិទ្ធិមនុស្សរបស់ប្រទេស ធ្វើអោយចិនក្លាយជាទិសដៅនៃការរិះគន់ជាញឹកញាប់ពីបស្ចឹមលោក ទាំងរដ្ឋាភិបាលនិងទាំងអង្គការក្រៅរដ្ឋាភិបាល។

ប្រទេសចិនមានសិទ្ធិអំណាចវេតូ(កម្រប្រើប្រាស់) ក្នុងក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ហើយចិនក៏មានឃ្លាំងអាវុធនុយក្លេអ៊ែរនុយក្លេអ៊ែរច្រើនសម្បើម។ ប្រទេសចិនស្ថិតនៅជាប់នឹងតំបន់ជម្លោះក្នុងតំបន់មួយចំនួននិងជះឥទ្ធិពលដល់ការរីកសាយនៃមីស៊ីលនិងអាវុធនុយក្លេអ៊ែរ។ ពួកគេទាមទារភាពជាម្ចាស់ដែនទឹកដែលមានជម្លោះ នៅក្នុងសមុទ្រចិនខាងត្បូង ដែលសំបូរទៅដោយធនធានធម្មជាតិ និងតវ៉ាប្រទេសជប៉ុនដែលប្រកាន់កម្មសិទ្ធិនៅលើកោះ នៅក្នុងសមុទ្រចិនខាងកើត ប៉ុន្តែ ចិនមិនបានចូលសមរភូមិប្រយុទ្ធ អស់រយៈពេល ២៥ ឆ្នាំមកហើយ។ ជាមួយនឹងការផ្ទេរហុងកុងពីចក្រភពអង់គ្លេស ក្នុងឆ្នាំ ១៩៩៧ ប្រទេសចិនបានទទួលភោគទ្រព្យដ៏មហាសាល ហើយក៏មានទឹកចិត្តសង្ឃឹមថាថ្ងៃណាមួយ អាចទទួលបានកោះតៃវ៉ាន់ផងដែរ ដោយប្រើរូបមន្តដូចកោះហុងកុង «ប្រទេសមួយ ប្រព័ន្ធពីរ»។ ចិនគឺជាប្រទេសមហាអំណាចតែមួយគត់ នៅអឌ្ឍគោលខាងត្បូង។ ទំហំប្រជាជនដ៏ច្រើនលើសលប់ និងល្បឿនឧស្សាហូបនីយកម្ម

យ៉ាងឆាប់រហ័ស ក្នុងប្រទេសពីចំណុចចាប់ផ្តើមដំបូងតិចតួចធ្វើអោយប្រទេសចិនក្លាយជាកត្តាដ៏ធំមួយ នៅក្នុងអនាគតនៃនិន្នាការបរិស្ថានពិភពលោក ដូចជា ការឡើងកំដៅផែនដី។ ធាតុទាំងអស់នេះធ្វើអោយប្រទេសចិនក្លាយជាតួអង្គដ៏សំខាន់មួយក្នុងទស្សវត្សរ៍ខាងមុខនេះ។

នៅមិនទាន់ច្បាស់នៅឡើយទេថា តើប្រព័ន្ធអន្តរជាតិអាចផ្តល់អោយប្រទេសចិននូវហាន:និងសេចក្តីគោរព ដើម្បីឆ្លុះបញ្ចាំងពីអំណាចកាន់តែកើនឡើងនិងសារៈសំខាន់នៃប្រវត្តិសាស្ត្ររបស់ប្រទេសចិន ហើយថាតើប្រទេសចិនអាចចាប់ផ្តើមគោរពតាមវិធាននិងបទដ្ឋានអន្តរជាតិនានាដែរឬទេ។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ប្រទេសចិនបានព្យាយាមប្រើប្រាស់យុទ្ធសាស្ត្រមួយ ដែលអនុលោមតាមប្រព័ន្ធអន្តរជាតិផងនិងតវ៉ានឹងប្រព័ន្ធនេះផង។ ជាឧទាហរណ៍ នៅក្នុងឆ្នាំ ២០១៥ ប្រទេសចិនបានបង្កើតអង្គការអន្តរជាតិថ្មីមួយដែលជា**ធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី** (AIIB) ដែលព្យាយាមផ្តល់ប្រាក់កម្ចីសម្រាប់ការអភិវឌ្ឍន៍ដល់រដ្ឋនានា នៅអឡាគោលខាងត្បូង។ ម្យ៉ាងវិញទៀត ធនាគារនេះធ្វើត្រាប់តាមប្រតិបត្តិការរបស់ធនាគារពិភពលោក យ៉ាងច្បាស់។ ប៉ុន្តែ វាមានស្តង់ដារបរិស្ថាននិងសិទ្ធិការងារ ទាបជាងធនាគារអភិវឌ្ឍន៍ដទៃទៀត។ ដូច្នេះហើយ ប្រទេសចិនបានបង្កើតអង្គការអភិវឌ្ឍន៍អន្តរជាតិថ្មីមួយ ដើម្បីប្រកួតប្រជែងនឹងរបៀបដែលអង្គការអភិវឌ្ឍន៍នានា ដែលមានដំណើរការរួចស្រាប់ហើយ។

អន្តរកាលចូលយុគសម័យក្រោយសង្គ្រាមត្រជាក់ ជាពេលវេលាដ៏ច្របូកច្របល់ ដែលពោរពេញដោយការផ្លាស់ប្តូរនិងលទ្ធភាពថ្មីៗ ទាំងផលវិជ្ជមានផងនិងអវិជ្ជមានផង។ ទោះយ៉ាងណា ច្បាប់និងគោលការណ៍មូលដ្ឋាននៃទំនាក់ទំនងអន្តរជាតិ ដែលអ្នកប្រាជ្ញនានាបានព្យាយាមស្វែងយល់ជាយូរមកហើយ ទំនងជាត្រូវបន្តអនុវត្ត ទោះបីជាបរិបទនិងលទ្ធផលអាចផ្លាស់ប្តូរក៏ដោយ។ ចំណុចសំខាន់បំផុតនៃច្បាប់និងគោលការណ៍ទាំងនោះ គឺ គោលបញ្ញត្តិនៃអំណាច ដែលយើង ឥឡូវនេះ នឹងព្យាយាមស្វែងយល់ដែរ។

សេចក្តីសង្ខេប

១. ទំនាក់ទំនងអន្តរជាតិជះឥទ្ធិពលខ្លាំងលើជីវភាពរស់នៅប្រចាំថ្ងៃរបស់យើង។ យើងទាំងអស់គ្នាជាប់ពាក់ព័ន្ធក្នុងទំនាក់ទំនងអន្តរជាតិ ទោះតិចឬច្រើនក្តី។

២. ទំនាក់ទំនងអន្តរជាតិគឺជាវិស័យវិទ្យាសាស្ត្រនយោបាយ ដែលផ្តោតជាចម្បងទៅលើការពន្យល់ពីលទ្ធផលនៃព្រឹត្តិការណ៍នយោបាយក្នុងកិច្ចការសន្តិសុខអន្តរជាតិ(IS) និងសេដ្ឋកិច្ចនយោបាយអន្តរជាតិ (IPE)។

៣. ទ្រឹស្តីទាំងឡាយផ្តល់ការពន្យល់បន្ថែមអំពីព្រឹត្តិការណ៍អន្តរជាតិនានា និងផលវិបាកនៃព្រឹត្តិការណ៍នោះ ហើយទោះបីអ្នកប្រាជ្ញជាច្រើននៅមិនយល់ស្របគ្នា លើគោលការណ៍ ឬ វិធីសាស្ត្រតែមួយក៏ដោយ ក៏គោលការណ៍ស្នូលចំនួនបី (គ្រប់គ្រង បដិការ និងអត្តសញ្ញាណ) បានសំរួចដំណោះស្រាយ*បញ្ហាផលប្រយោជន៍រួម*នៅក្នុងទំនាក់ទំនងអន្តរជាតិ។

៤. រដ្ឋជាច្រើនគឺជាតួអង្គសំខាន់បំផុត នៅក្នុងទំនាក់ទំនងអន្តរជាតិ។ ប្រព័ន្ធអន្តរជាតិ (ឬជួនកាលហៅ ធាកអន្តរជាតិ) ត្រូវអាស្រ័យលើអធិបតេយ្យភាពរបស់រដ្ឋ(ដែលមានដែនដី)ឯករាជ្យ ចំនួនប្រមាណ ២០០ ដែលមានទំហំខុសៗគ្នា។

៥. តួអង្គមិនមែនរដ្ឋនានា ដូចជាអង្គការអន្តររដ្ឋាភិបាល(IGOs) អង្គការក្រៅរដ្ឋាភិបាល(NGOs) និងក្រុមហ៊ុនឬសាជីវកម្មពហុជាតិ(MNCs) បានពង្រីកឥទ្ធិពលខ្លួនកាន់តែខ្លាំងក្នុងទំនាក់ទំនងអន្តរជាតិ។

៦. កំរិតវិភាគចំនួនបីៈ កំរិតបុគ្គល ក្នុងស្រុក និងប្រព័ន្ធ- អាចផ្តល់ការពន្យល់ច្រើនផ្លូវ (ដោយដំណើរការក្នុងពេលដំណាលគ្នា) អំពីលទ្ធផលនានា នៅក្នុងទំនាក់ទំនងអន្តរជាតិ។

៧. សាកលភាវូបនីយកម្មត្រូវបានកំណត់និយមន័យផ្សេងៗ ដោយអ្នកប្រាជ្ញផ្សេងៗគ្នាដែរ ប៉ុន្តែជាទូទៅ វាសំដៅទៅលើការភ្ជាប់ទំនាក់ទំនងជុំវិញសកលលោក កាន់តែទូលំទូលាយ កាន់តែឆាប់រហ័ស និងកាន់តែញឹកញាប់។ ដំណើរការនេះអាចធ្វើអោយអំណាចរដ្ឋនានា ត្រូវចុះខ្សោយ ឬត្រូវពង្រឹង ឬត្រូវពង្រាយ។ សកម្មជនទាំងឡាយ ដែលប្រឆាំងនឹងសាកលភាវូបនីយកម្ម ប្រឆាំងនឹងកំណើនអំណាចរបស់សាជីវកម្មធំៗ ប៉ុន្តែ ពួកគេខ្វែងគំនិតគ្នាលើគោលដៅចុងក្រោយ និងយុទ្ធសាស្ត្រដើម្បីសម្រេចវា។

៨. សង្គ្រាមលោកលើកទី ១ និងទី ២ បានគ្របដណ្តើបលើសតវត្សរ៍ទី ២០ ប៉ុន្តែ សង្គ្រាមទាំងពីរនេះ ហាក់ដូចជាផ្តល់មេរៀនពីរផ្ទុយគ្នាៈ ថាតើត្រូវប្រើប្រាស់គោលនយោបាយការបរទេស បែបធម៌ក្តៅគឹងរឹង ឬ ធម៌ត្រជាក់ បែបផ្សះផ្សា រវាងភាគីពាក់ព័ន្ធ។

៩. អស់រយៈពេលជិត ៥០ ឆ្នាំ ក្រោយសង្គ្រាមលោកលើកទី ២ នយោបាយពិភពលោកបានវិលវល់ជុំវិញអរិភាពរវាងលោកខាងកើតនឹងខាងលិច ក្នុងសង្គ្រាមត្រជាក់។ ការជាប់គាំងក្នុងប្រព័ន្ធទ្វេប៉ូលនេះ បានបង្កើតអោយមានស្ថេរភាព និងបានបញ្ចៀសសង្គ្រាមរវាងប្រទេសមហាអំណាច រួមទាំងបានបញ្ចៀសសង្គ្រាមនុយក្លេអ៊ែរ ប៉ុន្តែ បានប្រែក្លាយរដ្ឋនានានៅអឌ្ឍគោលខាងត្បូង អោយក្លាយទៅជាសមរភូមិប្រយុទ្ធដោយប្រយោល ទៅវិញ។

១០. យុគសម័យក្រោយសង្គ្រាមត្រជាក់បានផ្តល់សេចក្តីសង្ឃឹមថានឹងមានកំណើនសន្តិភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេសមហាអំណាច បើទោះមានការលេចឡើងនូវជម្លោះជាតិសាសន៍ និងជម្លោះក្នុងតំបន់ថ្មីៗក៏ដោយ។

១១. យុទ្ធនាការយោធារបស់សហរដ្ឋអាមេរិក នៅប្រទេសអ៊ីរ៉ាក់ បានផ្តួលរំលំរបបផ្តាច់ការ ប៉ុន្តែ វាបានបែងចែកបក្សពួករវាងប្រទេសមហាអំណាច ឆ្លុះបញ្ចាំងពីមនោសញ្ចេតនាប្រឆាំងនឹងប្រទេសអាមេរិក នៅទូទាំងពិភពលោក និងនាំអោយមានការបះបោរនិងអំពើហិង្សាសាសនាជ្រុលនិយម ជាច្រើនឆ្នាំ។

១២. យុទ្ធនាការរបស់អង្គការណាតូ(អូតង់) នៅអាហ្វហ្គានីស្ថានប្រឆាំងនឹងឥទ្ធិពលតាលីបង់ បានបញ្ចប់នៅក្នុងឆ្នាំ ២០១៤ ទោះបីកងទ័ពណាតូខ្លះ នៅមានវត្តមានក៏ដោយ។ ក្នុងឆ្នាំ ២០១១ កងកំលាំងពិសេសរបស់សហរដ្ឋអាមេរិកបានសម្លាប់ អូសាម៉ា ប៊ីនឡាដិន នៅប៉ាគីស្ថាន ជាកន្លែងរងការវាយប្រហារដោយដ្រូន(កូនយន្តហោះគ្មានមនុស្សបើក)បានបើកការវាយប្រហារលើគោលដៅយោធាផ្សេងទៀតផងដែរ។

១៣. ការបះបោរនិទាឃរដូវនៅអារ៉ាប់ ដែលបានផ្ទុះឡើងចាប់តាំងពីឆ្នាំ ២០១១ បានផ្តួលរំលំរដ្ឋាភិបាលនៅក្នុងប្រទេសទុយនីស៊ី អេហ្ស៊ីប លីប៊ី និងយេម៉ែន ហើយបានបំផ្ទុះសង្គ្រាមស៊ីវិលដ៏សាហាវឃោរឃៅនៅស៊ីរី។ អនាគត របបអន្តរកាលភាគច្រើន នៅមិនទាន់ច្បាស់នៅឡើយ។

១៤. ព្រឹត្តិការណ៍ពីរបានចង្អុលបង្ហាញពីអត្ថិភាពនៃប្រតិកម្មតបតនឹងសកលភាវូបនីយកម្មៈ ការបោះឆ្នោតប្រជាមតិរបស់អង់គ្លេសចេញពីសហភាពអឺរ៉ុប (Brexit) និងការបោះឆ្នោតរើសប្រធានាធិបតី ដូណាល់ ត្រាំ (Donald Trump) ។ ព្រឹត្តិការណ៍ទាំងពីរបានបង្ហាញថាប្រធានបទផ្តោតលើបញ្ហាជាតិទាក់ទាញចិត្តប្រជាពលរដ្ឋជាច្រើន ខ្លាំងជាងបញ្ហាសាកល ។

ពាក្យគន្លឹះ

១. **ទំនាក់ទំនងអន្តរជាតិ** (IR) គឺជាទំនាក់ទំនងរវាងរដ្ឋាភិបាលនៃរដ្ឋនានាលើពិភពលោក ក៏ដូចជាការភ្ជាប់ទំនាក់ទំនងរវាងរដ្ឋ ជាមួយនឹងតួអង្គផ្សេងទៀត (ដូចជា អង្គការសហប្រជាជាតិ (UN) សាជីវកម្មពហុជាតិ(MNCs) និងបុគ្គលនីមួយៗ) ជាមួយនឹងទំនាក់ទំនងសង្គមដទៃទៀត (រួមទាំងផ្នែកសេដ្ឋកិច្ច វប្បធម៌ និងនយោបាយក្នុងស្រុក) និងត្រូវអាស្រ័យលើឥទ្ធិពលនៃភូមិសាស្ត្រនិងប្រវត្តិសាស្ត្រ។

២. **បញ្ហាផលប្រយោជន៍រួម (សមូហភាព)** (collective goods problem) គឺជាផលប្រយោជន៍រូបី ឬអរូបី ដែលបង្កើតឡើងដោយសមាជិកក្នុងក្រុម ដែលត្រូវចែករម្លែកដល់សមាជិកក្រុមទាំងអស់ ដោយមិនគិតពីកម្រិតចូលរួមចំណែករបស់បុគ្គលម្នាក់ៗឡើយ។ សមាជិកក្រុមអាចទទួលបានផលចំណេញកាន់តែច្រើនដោយគ្រាន់តែបន្តយការរួមវិភាគទានរបស់ខ្លួនសំរាប់សមូហភាព ប៉ុន្តែ ប្រសិនបើសមាជិកកាន់តែច្រើនពេក ធ្វើបែបនេះ ប្រាកដណាស់សមូហភ័ណ្ឌមិនអាចកើតឡើងបានទេ។

៣. **គោលការណ៍គ្រប់គ្រង** (dominance) គឺជាគោលការណ៍សម្រាប់ដោះស្រាយបញ្ហាផលប្រយោជន៍សមូហភាព ដោយដាក់ដំណោះស្រាយ តាមឋានានុក្រម ពោលគឺថ្នាក់គ្រប់គ្រងដាក់ដំណោះស្រាយ។

៤. **គោលការណ៍បដិការ** (reciprocity) គឺជាការធ្វើសកម្មភាពឆ្លើយតបជាក់ស្តែង អាស្រ័យតាមទង្វើរបស់អ្នកដទៃ ឬ ជាយុទ្ធសាស្ត្រឆ្លើយតបបែបជាក់គំនាប ដោយសន្យាផ្តល់រង្វាន់សម្រាប់ទង្វើវិជ្ជមាននិងគំរាមកំហែងដាក់ទណ្ឌកម្មចំពោះទង្វើអវិជ្ជមាន។

៥. **គោលការណ៍អត្តសញ្ញាណ** (identity) គឺជាគោលការណ៍ទីបីសម្រាប់ដោះស្រាយបញ្ហាផលប្រយោជន៍សមូហភាព ដោយការផ្លាស់ប្តូរចំណង់ចំណូលចិត្តឬការសម្រេចចិត្តរបស់ភាគីពាក់ព័ន្ធ ដោយផ្អែកលើស្មារតីអត្តសញ្ញាណសហគមន៍រួមរបស់ពួកគេ។

៦. **តំបន់បញ្ហា** (issue areas) គឺជាសំណុំសកម្មភាពអន្តរជាតិនានា (ដូចជា ការចរចាពាណិជ្ជកម្មសាកល) ដែលអ្នកបង្កើតគោលនយោបាយក្នុងរដ្ឋទាំងឡាយត្រូវប្រឈមនឹងជម្លោះខ្លះ ហើយជួនកាលក៏ទទួលបានកិច្ចសហប្រតិបត្តិការដ៏ល្អផងដែរ។

៧. **ការប៉ះទង្គិចនិងកិច្ចសហប្រតិបត្តិការ** (conflict and cooperation) គឺជាប្រភេទសកម្មភាពដែលរដ្ឋធ្វើដាក់គ្នា ទៅវិញទៅមក ជាហូរហែរ។

៨. **សន្តិសុខអន្តរជាតិ** (international security) គឺជាមែកធាងមួយនៃទំនាក់ទំនងអន្តរជាតិ (IR) ដែលផ្តោតលើបញ្ហាសង្គ្រាមនិងសន្តិភាព។

៩. **សេដ្ឋកិច្ចនយោបាយអន្តរជាតិ** (IPE) គឺជាការសិក្សាអំពីនយោបាយពាណិជ្ជកម្ម រូបិយវត្ថុ និងទិដ្ឋភាពនៃទំនាក់ទំនងសេដ្ឋកិច្ចដទៃទៀត ក្នុងចំណោមប្រជាជាតិនានា និងការភ្ជាប់ទំនាក់ទំនងរបស់ពួកគេជាមួយកម្លាំងឬអង្គភាពឆ្លងព្រំដែនរដ្ឋផ្សេងទៀត។

១០. **រដ្ឋ** (state) សំដៅលើទឹកដី ដែលមានប្រជាជនរស់នៅ ដែលត្រូវគ្រប់គ្រងដោយរដ្ឋាភិបាលមួយដែលមានអធិបតេយ្យភាពផ្តាច់មុខលើទឹកដីរបស់ខ្លួន។

១១. **ប្រព័ន្ធអន្តរជាតិ** (international system) ឬ អាចហៅម្យ៉ាងទៀតថា **ឆាកអន្តរជាតិ** គឺជាបណ្តាញទំនាក់ទំនងរវាងរដ្ឋនានាលើពិភពលោក ដែលមានរចនាសម្ព័ន្ធអនុលោមតាម**វិធាន** និង**លំនាំអន្តរកម្ម**ឬ**បទដ្ឋាន** ដ៏ជាក់លាក់ទាំងឡាយ។

១២. **ប្រជាជាតិ** (nation-states) គឺជារដ្ឋទាំងឡាយដែលប្រជាជនរបស់ខ្លួនមានអត្តសញ្ញាជាតិរួមគ្នា តាមធម្មតា រួមមានដូចជា ភាសានិងវប្បធម៌ ជាដើម។

១៣. **ផលិតផលក្នុងស្រុកសរុប** (GDP) ហៅកាត់ថាជាភាសាខ្មែរថា ផ.ស.ស. គឺជាទំហំសេដ្ឋកិច្ចប្រចាំឆ្នាំរបស់រដ្ឋណាមួយ ដោយរាប់បញ្ចូលសកម្មភាពសេដ្ឋកិច្ចក្នុងប្រទេសទាំងអស់។

១៤. **តួអង្គមិនមែនរដ្ឋ** (nonstate actors) គឺជាតួអង្គ ក្នុងទំនាក់ទំនងអន្តរជាតិ ផ្សេងៗក្រៅអំពីរដ្ឋាភិបាលរបស់រដ្ឋដែលប្រតិបត្តិការក្រោមកំរិតរដ្ឋ(នៅក្នុងរដ្ឋ)ផង ឬឆ្លងកាត់ព្រំដែនរដ្ឋនានាផង។

១៥. **អង្គការអន្តររដ្ឋាភិបាល** (IGO) គឺជាអង្គការមួយ(ដូចជាអង្គការសហប្រជាជាតិនិងទីភ្នាក់ងាររបស់វា) ដែលមានសមាជិកជារដ្ឋាភិបាលនៃរដ្ឋទាំងឡាយ។

១៦. **អង្គការមិនមែនរដ្ឋាភិបាល** (NGO) គឺជាក្រុម ឬអង្គភាព ឆ្លងព្រំដែនជាតិនានា (ដូចជាព្រះវិហារកាតូលិក អង្គការបរិស្ថានGreenPeace ឬគណៈកម្មាធិការអូឡាំពិកអន្តរជាតិ) ដែលធ្វើអន្តរអំពើជាមួយរដ្ឋ សាជីវកម្មពហុជាតិ(MNCs) អង្គការក្រៅរដ្ឋាភិបាល និងអង្គការអន្តររដ្ឋាភិបាលផ្សេងទៀត។

១៧. **សាកលភាវូបនីយកម្ម** (globalization) គឺជាការពង្រីកសមាហរណកម្មពិភពលោកកាន់តែខ្លាំង លើវិស័យនានា ដូចជា ទំនាក់ទំនង វប្បធម៌ និងសេដ្ឋកិច្ច។ វាក៏អាចសំដៅទៅលើកាល:និងទេស:ដែលផ្លាស់ប្តូរដំណើរការសមាហរណកម្មនេះផងដែរ។

១៨. **គម្លាតរវាងអឌ្ឍគោលខាងជើងនឹងខាងត្បូង** (North-South gap) សំដៅលើភាពខុសគ្នាផ្នែកធនធានទាំងឡាយ (ចំណូល ទ្រព្យសម្បត្តិ និងអំណាច) រវាងបស្ចឹមប្រទេសដែលមានភាពរីកចម្រើន និងឧស្សាហកម្មខ្លាំង(និងអតីតបូព៌ាប្រទេសខ្លះ) នឹងបណ្តាប្រទេសក្រីក្រជាង នៅអាហ្វ្រិក តំបន់មជ្ឈិមបូព៌ា និងប្រទេសភាគច្រើន នៅទ្វីបអាស៊ីនិងអាមេរិកឡាទីន។

១៩. **សង្គមប្រជាជាតិ** (League of Nations) គឺជាអង្គការមួយ ដែលត្រូវបានបង្កើតឡើងក្រោយសង្គ្រាមលោកលើកទី ១ និងជាបុព្វការីជនរបស់អង្គការសហប្រជាជាតិ នាពេលបច្ចុប្បន្ននេះ។ អង្គការនេះទទួលបានជោគជ័យផ្នែកមនុស្សធម៌និងវិស័យផ្សេងៗទៀតខ្លះដែរ ប៉ុន្តែ ត្រូវចុះខ្សោយដោយសារអវត្តមានសមាជិកភាពសហរដ្ឋអាមេរិក និង កង្វះប្រសិទ្ធភាពក្នុងការធានាសន្តិសុខសមូហភាព។ សូមមើល *សន្តិសុខសមូហភាព* ផងដែរ។

២០. **កិច្ចព្រមព្រៀងទីក្រុងមុយនិច** (Munich Agreement) គឺជានិមិត្តរូបនៃបរាជ័យគោលនយោបាយផ្សះផ្សារ ដែលបានចុះហត្ថលេខាអនុម័ត នៅឆ្នាំ ១៩៣៨ ដោយបានអនុញ្ញាតអោយណាហ្ស៊ីអាឡឺម៉ង់កាន់កាប់ផ្នែកមួយនៃប្រទេសឆេកូស្លូវ៉ាគី។ ជាជាងបំពេញសេចក្តីប្រាថ្នារបស់អាឡឺម៉ង់ វាត្រូវបានបន្តដោយការពង្រីកទឹកដីអាឡឺម៉ង់បន្ថែមទៀត ដែលបង្កអោយមានសង្គ្រាមលោកលើកទី ២។

២១. **សង្គ្រាមត្រជាក់** (Cold War) សំដៅដល់អរិភាពទំនាក់ទំនង (ម្តលធូរស្រាល ម្តងតានតឹង) ឬការប្រកួតប្រជែងមនោគមន៍វិជ្ជានយោបាយរវាងប្រទេសមហាអំណាចទាំងពីរ សហរដ្ឋអាមេរិកនិងសហភាពសូវៀត ពីឆ្នាំ ១៩៤៥ ដល់ឆ្នាំ ១៩៩០។

២២. **យុទ្ធសាស្ត្រាំងខ្ជប់** (containment) គឺជាគោលនយោបាយត្រូវបានអនុម័តឡើងនៅចុងទសវត្សរ៍ឆ្នាំ ១៩៤០ ដែលសហរដ្ឋអាមេរិកបានព្យាយាមបញ្ឈប់ការពង្រីកឥទ្ធិពលយោធា នយោបាយ មនោគមវិជ្ជា និងសេដ្ឋកិច្ច ជាសកល របស់សូវៀត។

២៣. **ការប្រេះស្រាំចិននិងសូវៀត** (Sino-Soviet split) សំដៅដល់ការបែកបាក់គ្នា នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ រវាងប្រទេសមហាអំណាចកុម្មុយនិស្ត សហភាពសូវៀត នឹង ចិន ដែលផ្តើមចេញពីការប្រឆាំងរបស់ចិនចំពោះដំហរសូវៀត ងាកទៅរកសន្តិសហវិជ្ជាមានជាមួយនឹងសហរដ្ឋអាមេរិក។

២៤. **កិច្ចប្រជុំកំពូល** (summit) គឺកិច្ចប្រជុំរវាងប្រមុខរដ្ឋនានា ដែលជារឿយៗសំដៅទៅលើមេដឹកនាំនៃប្រទេសមហាអំណាច ដូចជា នៅក្នុងកិច្ចប្រជុំកំពូលនៃមហាអំណាច ដូចក្នុងកំឡុងសង្គ្រាមត្រជាក់ រវាងសហរដ្ឋអាមេរិកនិងសហភាពសូវៀត ឬការប្រជុំក្រុមប្រទេសធំម្តែ ស្តីពីការសម្របសម្រួលសេដ្ឋកិច្ច។

២៥. **វិបត្តិមីស៊ីលគុយបា** (១៩៦២) គឺជាវិបត្តិរវាងប្រទេសមហាអំណាច ដែលបង្កឡើងដោយសហភាពសូវៀតដំឡើងមីស៊ីលនុយក្លេអ៊ែរ រយៈចម្ងាយមធ្យម នៅគុយបា ដែលនេះជាពេលដែលសហរដ្ឋអាមេរិកនិងសហភាពសូវៀត ជិតដល់មាត់ជ្រោះសង្គ្រាមនុយក្លេអ៊ែរ។

២៦. **សង្គ្រាមរណប** (Proxy War) គឺជាសង្គ្រាមនៅក្នុងប្រទេសតតិយលោក ជារឿយៗជាសង្គ្រាមស៊ីវិលដែលមានសហរដ្ឋអាមេរិកនិងសហភាពសូវៀត នៅពីក្រោយភាគីបដិបក្ខនីមួយៗ តាមរយៈការផ្គត់ផ្គង់គ្រឿងសព្វាវុធ និងផ្តល់យោបល់ជាយុទ្ធសាស្ត្រជាដើម។

សំណួរអនុវត្តន៍

១. ដោយផ្អែកលើគោលការណ៍ស្នូលទាំងបីនៃទំនាក់ទំនងអន្តរជាតិ តើអ្វីទៅជាហេតុផលនៅពីក្រោយការចរចាឡើងវិញនូវកិច្ចព្រមព្រៀងពាណិជ្ជកម្មរបស់លោកប្រធានាធិបតីអាមេរិក ដូណាល់ ត្រាំ ជាមួយនឹងប្រទេសម៉ិកស៊ិកនិងកាណាដា?

២. តើគោលការណ៍នៃទំនាក់ទំនងអន្តរជាតិណាមួយដែលអាចពន្យល់បានយ៉ាងល្អបំផុត អំពីសង្គ្រាមពាណិជ្ជកម្មរវាងអាមេរិកនិងចិន ចាប់តាំងពីឆ្នាំ២០១៨មក? តើហេតុអ្វី? ចូរពន្យល់អោយបានក្បោះក្បាយ។

៣. ក្នុងការប្រយុទ្ធប្រឆាំងនឹងការផ្សព្វផ្សាយព័ត៌មានខុសពីការពិត និងឥទ្ធិពលបរទេសលើការបោះឆ្នោតទាំងឡាយ តើតួអង្គណាមួយគួរមានតួនាទីនាំមុខ៖ រដ្ឋ អង្គការអន្តរជាតិ សាជីវកម្មពហុជាតិ ឬបុគ្គល/ក្រុម? ចូរពន្យល់ចម្លើយអ្នកអោយបានពិស្តារ។

៤. យោងតាមបទពិសោធន៍មេរៀនផ្ទុយគ្នារវាងសង្គ្រាមលោកលើកទី ១ និងទី ២, តើអ្នកអាចផ្តល់ឧទាហរណ៍ពី (ក)ស្ថានភាព នៅក្នុងពិភពលោកសព្វថ្ងៃនេះ ដែលគោលនយោបាយការបរទេសបែបធម៌ត្រជាក់ ឬ (គោលនយោបាយផ្សះផ្សារ) អាចជាវិធីល្អបំផុតដែរឬទេ? (ខ) ស្ថានភាពដែលគោលនយោបាយការបរទេសបែបធម៌ក្តៅ ដោយប្រកាន់តឹងរឹង អាចជាជំរើសល្អបំផុត? ហេតុអ្វី?

៥. តើអ្នករំពឹងថាអ្វីទៅនឹងក្លាយចរិតលក្ខណៈពិសេសនៅក្នុងសតវត្សរ៍ទី ២១? តើវាមានសន្តិភាព ឬសង្គ្រាម? មានសណ្តាប់ធ្នាប់ពិភពលោកមែនទេ? ឬក៏ភាពវឹកវរកាន់តែខ្លាំង? ហេតុអ្វីបានជាអ្នកមានការរំពឹងទុកបែបនោះ ហើយតើមានតម្រុយអ្វីអំពីព្រឹត្តិការណ៍ពិភពលោកបច្ចុប្បន្ន ដែលអាចប្រាប់អ្នកថា ការទស្សន៍ទាយរបស់អ្នកត្រឹមត្រូវ?

៦. ចូរជ្រើសរើសព្រឹត្តិការណ៍អន្តរជាតិដែលកំពុងកើតឡើង គួរអោយចាប់អារម្មណ៍ណាមួយ។ តើអ្នកអាចរិះគិតរកការពន្យល់ពីមូលហេតុនាំឲ្យព្រឹត្តិការណ៍ទាំងនោះកើតឡើង ដែរឬទេ ដោយធ្វើការវិភាគតាមវិភាគទាំងបីកម្រិត? តើការពន្យល់តាមកម្រិតផ្សេងគ្នា ផ្តល់ការយល់ដឹងអំពីទិដ្ឋភាពផ្សេងៗនៃព្រឹត្តិការណ៍នោះដែរឬទេ?

៧. សង្គ្រាមត្រជាក់ត្រូវបញ្ចប់ជាយូរមកហើយ តែឥទ្ធិពលរបស់វានៅបន្តមាន។ តើអ្នកអាចរិះគិតរក ឧទាហរណ៍ចំនួន ៣ នៃឥទ្ធិពលសង្គ្រាមត្រជាក់លើការបង្កើតគោលនយោបាយការបរទេសរបស់រដ្ឋនានា ក្នុងពេលបច្ចុប្បន្ននេះដែរឬទេ ?

៨. តើសេដ្ឋកិច្ចអន្តរជាតិដែលឥទ្ធិពលអ្វីខ្លះដល់ការរស់នៅប្រចាំថ្ងៃរបស់យើង? តើឥទ្ធិពលនោះមានពិតមែនសម្រាប់មនុស្សគ្រប់គ្នា នៅគ្រប់ទីកន្លែងដែរឬទេ? ឬ តើដំណើរការសេដ្ឋកិច្ច ដូចជាសកលភាវូបនីយកម្មដែរ អាចដែលឥទ្ធិពលលើតំបន់ណាមួយ ខ្លាំងជាងតំបន់ផ្សេងទៀត?

ការស្វែងរកផលប្រយោជន៍រួម

សេចក្តីផ្តើម

ក្នុងការពន្យល់ពីរបៀបដែលប្រទេសនានាប្រកាន់ខ្ជាប់ឥរិយាបទណាមួយ នៅក្នុងទំនាក់ទំនងអន្តរជាតិ បញ្ញត្តិពេញនិយមជាងគេគឺ «បញ្ហាផលប្រយោជន៍រួម» ។ បញ្ហាដែលកើតឡើងដដែលៗនេះ កើតមានឡើងនៅពេលដែលសមាជិកក្រុមពីរឬច្រើននាក់ ចែករម្លែកផលប្រយោជន៍រួម នៅក្នុងលទ្ធផលដ៏មានតម្លៃណាមួយក្នុងចំណោមពួកគេទាំងអស់ ប៉ុន្តែមានជម្លោះផលប្រយោជន៍បុគ្គល នៅពេលសម្រេចបាននូវលទ្ធផលដ៏មានតម្លៃនោះ។ ជាឧទាហរណ៍ ប្រទេសនានាក្នុងពិភពលោកមានបំណងប្រាថ្នាចង់ជៀសវាងការឡើងកំដៅផែនដី ប៉ុន្តែ ប្រទេសនីមួយៗទទួលបានអត្ថប្រយោជន៍ពីការដុតឥន្ធនៈហ្វូស៊ីល ដើម្បីដំណើរការសេដ្ឋកិច្ចរបស់ខ្លួន។ ប្រសិនបើប្រទេសមួយចំនួនបរាជ័យក្នុងការរួមចំណែកដល់ផលប្រយោជន៍រួម នោះប្រទេសផ្សេងទៀតនឹងនៅតែចូលរួមចំណែក ហើយប្រទេសមួយចំនួនតូចអាច «ជិះសេះលែងដៃ»។ ប៉ុន្តែប្រសិនបើប្រទេសកាន់តែច្រើនលើសលប់ធ្វើដូច្នេះ នោះផលប្រយោជន៍រួមនឹងមិនអាចកើតមានឡើងសម្រាប់ផ្តល់អោយនរណាម្នាក់ឬប្រទេសណាមួយឡើយ។ ជាឧទាហរណ៍ ប្រសិនបើប្រទេសជាច្រើនសន្ធឹកសន្ធាប់ពេកដុតឥន្ធនៈហ្វូស៊ីលច្រើនពេក នោះពិភពលោកទាំងមូលនឹងទទួលរងឥទ្ធិពលនៃការឡើងកំដៅផែនដី។

នៅក្នុងសង្គមនៃប្រទេសណាមួយ រដ្ឋាភិបាលដោះស្រាយបញ្ហាផលប្រយោជន៍រួម ដោយបង្ខំសមាជិកនៃសង្គមអោយចូលរួមចំណែកដល់គោលដៅរួម ដូចជាការបង់ពន្ធជាដើម។ ក្នុងកិច្ចការអន្តរជាតិ មិនមានរដ្ឋាភិបាលពិភពលោកមានអំណាចចាប់បង្ខំបែបនេះទេ។ គោលការណ៍ស្នូលចំនួនបីៈ គោលការណ៍គ្រប់គ្រងបដិការ និងអត្តសញ្ញាណ ផ្តល់នូវដំណោះស្រាយផ្សេងៗគ្នា ចំពោះបញ្ហាផលប្រយោជន៍រួម។ គោលការណ៍ទាំងនេះបង្កប់នូវសកម្មភាពនិងលទ្ធផល ដែលបង្កើតបានជាទំនាក់ទំនងអន្តរជាតិ។

ដើម្បីផ្សារភ្ជាប់ប្រធានបទសំខាន់នៅក្នុងមេរៀននីមួយៗ ជាមួយនឹងគោលការណ៍ស្នូលដែលប្រើក្នុងសៀវភៅនេះ មេរៀននីមួយៗលើកយកឧទាហរណ៍បន្ថែម «ការស្វែងរកដំណោះស្រាយបញ្ហាផលប្រយោជន៍រួម»។ ឧទាហរណ៍ជាក់ស្តែងនីមួយៗនឹងពិភាក្សាអំពីរបៀបដែលរដ្ឋនានាលើពិភពលោក ដោះស្រាយបញ្ហាសំខាន់ៗនៅក្នុងទំនាក់ទំនងអន្តរជាតិ ដោយប្រើគោលការណ៍ស្នូលមួយ (ឬច្រើន)។ ឧទាហរណ៍រួមមានការបញ្ឈប់អំពើប្រល័យពូជសាសន៍ (មេរៀនទី ៧) ការបង្កើនពាណិជ្ជកម្មពិភពលោក (មេរៀនទី ៨) និងការបន្ថយល្បឿនកំនើនកំដៅសកល (មេរៀនទី ១១) ។

ទស្សនៈវិស័យគោលនយោបាយ

ទិដ្ឋភាពទូទៅ

បណ្តាអ្នកបង្កើតគោលនយោបាយអន្តរជាតិនានាប្រឈមមុខនឹងបញ្ហាជាច្រើន រៀងរាល់ថ្ងៃ។ ដើម្បីដោះស្រាយបញ្ហាទាំងនេះទាមទារការសម្រេចចិត្ត និងជម្រើសយ៉ាងលំបាកបំផុត។ «ទស្សនៈវិស័យគោលនយោបាយ» គឺជាឧទាហរណ៍មួយ នៅក្នុងមេរៀននីមួយៗ ដែលជាក់អ្នកនៅក្នុងទស្សនវិស័យធ្វើការសម្រេចចិត្តដ៏ជាក់លាក់មួយ (ឧទាហរណ៍ ក្នុងឋានៈជានាយករដ្ឋមន្ត្រីនៃចក្រភពអង់គ្លេស) ហើយស្នើអោយអ្នកធ្វើការជ្រើសរើសជំរើសទាក់ទងនឹងបញ្ហាទំនាក់ទំនងអន្តរជាតិដ៏សំខាន់មួយ។

ឧទាហរណ៍នីមួយៗមានបួនផ្នែក។ ទីមួយ «**សាវតារ**» ផ្តល់ព័ត៌មានអំពីបញ្ហានយោបាយដែលមេដឹកនាំណាម្នាក់កំពុងប្រឈមមុខ។ សាវតារឬប្រវត្តិបញ្ហានេះ ផ្តល់ព័ត៌មានពិត ហើយឆ្លុះបញ្ចាំងពីស្ថានភាពជាក់ស្តែងដែលប្រឈមមុខដោយអ្នកធ្វើការសម្រេចចិត្តទាំងនេះ។

ផ្នែកទីពីរ «**ការពិចារណាក្នុងស្រុក**» ឬ «**ទស្សនៈវិស័យក្នុងស្រុក**» ឆ្លុះបញ្ចាំងពីផលប៉ះពាល់នៃស្ថានភាពឬព្រឹត្តិការណ៍នោះ ទៅលើនយោបាយក្នុងស្រុក នៅក្នុងរដ្ឋាភិបាលនិងសង្គមរបស់មេដឹកនាំនោះ។ តើជីវិតប្រជាជនសាមញ្ញនឹងត្រូវទទួលរងនូវផលវិបាកបែបណាខ្លះ?

ផ្នែកទីបី «**សេណារីយ៉ូ**» បង្ហាញពីបញ្ហា ឬវិបត្តិថ្មី ដែលមេដឹកនាំកំពុងប្រឈមមុខ។ ទោះបីជាវិបត្តិទាំងនេះមានលក្ខណៈសម្មតិកម្មឬគ្រាន់ជាការឧបមាក៏ដោយ សេណារីយ៉ូទាំងអស់នោះ ស្ថិតនៅក្នុងលទ្ធភាពដែលអាចកើតមានឡើង ហើយទាមទារឱ្យមានការសម្រេចចិត្តដ៏លំបាក ដោយមេដឹកនាំ និងប្រទេសរបស់ពួកគេ។

ផ្នែកទីបួន «**ចូរជ្រើសរើសគោលនយោបាយរបស់អ្នក**» ស្នើអោយអ្នកបង្កើត ជម្រើសជាការឆ្លើយតបទៅនឹងសេណារីយ៉ូដែលផ្តល់អោយ។ ជាមួយនឹងការសម្រេចចិត្តនីមួយៗ ចូរពិចារណា អំពីការដោះដូរវាងជម្រើសរបស់អ្នក បាននិយាយថា បើធ្វើបែបនេះ ចំណេញអ្វី ហើយខាតបង់អ្វីដែរ។ តើមានហានិភ័យអ្វីខ្លះ និងផលប្រយោជន៍ដែលទទួលបានពីការជ្រើសរើសគោលនយោបាយមួយ ជាជាងជ្រើសយកគោលនយោបាយមួយផ្សេងទៀត? តើមានជម្រើសផ្សេងទៀត ដែលអាចដោះស្រាយបញ្ហាប្រកបដោយប្រសិទ្ធភាព ក្នុងព្រំដែន (ឬធនធាន)កំណត់ ដែរឬទេ? តើជម្រើសមួយនោះ ចំណាយច្រើនជាង ក្នុងរយៈពេលខ្លី ប៉ុន្តែតិចជាងក្នុងរយៈពេលវែងដែរឬទេ? តើអ្នកអាចការពារការសម្រេចចិត្តលើជំរើសគោលនយោបាយរបស់អ្នកនៅចំពោះមុខសហសេវិក សាធារណៈជន និងមេដឹកនាំពិភពលោកផ្សេងទៀតបានទេ? តើជម្រើសរបស់អ្នកនឹងឥទ្ធិពលលើជីវិតពលរដ្ឋ និងជីវភាពនយោបាយរបស់អ្នក ដោយរបៀបយ៉ាងណាខ្លះ?

នៅពេលអ្នកពិចារណាបញ្ហានីមួយៗ ដែលប្រឈមមុខដោយអ្នកធ្វើការសម្រេចចិត្ត សូមព្យាយាមគិតអំពីដំណើរការ និងតក្កវិជ្ជា ដែលអ្នកប្រើដើម្បីឈានដល់ការសម្រេចចិត្តនោះ។ តើកត្តាមួយណាដែលហាក់ដូចជាសំខាន់ជាង ហើយហេតុអ្វី? តើកត្តាក្នុងស្រុក ឬ កត្តាអន្តរជាតិ មានសារៈសំខាន់ជាង ក្នុងការបង្កើតការសម្រេចចិត្តរបស់អ្នកទេ? តើឧបសគ្គដែលអ្នកប្រឈមមុខ ផ្អែកលើសមត្ថភាពមានកំណត់ (ឧទាហរណ៍ លុយ ឬអំណាចយោធា) ឬថា តើច្បាប់ឬបទដ្ឋានអន្តរជាតិដែរឥទ្ធិពលលើការសម្រេចចិត្តរបស់អ្នក ដែរឬទេ? តើកត្តាដូចជាកង្វះពេលវេលា មានឥទ្ធិពលលើការសម្រេចចិត្តរបស់អ្នកយ៉ាងដូចម្តេច?


អ្នកនឹងដឹងភ្លាមៗថា ជារឿយៗ មិនមានចម្លើយត្រឹមត្រូវដាច់ខាតនោះទេ។ ពេលខ្លះ វាពិបាកក្នុងការជ្រើសរើសរវាងជម្រើសដ៏ល្អពីរ។ នៅពេលផ្សេងទៀត មនុស្សម្នាក់ត្រូវតែសម្រេចចិត្តថាមួយណាជាជម្រើសអាក្រក់តិចជាង។

មតិសាធារណៈ និងទំនាក់ទំនងអន្តរជាតិ

នៅក្នុងមេរៀននីមួយៗ ឧទាហរណ៍នៃមតិសាធារណៈនិងទំនាក់ទំនងអន្តរជាតិបែបនេះនឹងពិភាក្សាអំពីទស្សនៈរបស់សាធារណជន អំពីបញ្ហាសំខាន់ណាមួយ ក្នុងទំនាក់ទំនងអន្តរជាតិ។ ដូចដែលបានបង្ហាញកាលពីប៉ុន្មានឆ្នាំមុន មតិសាធារណជនពាសពេញពិភពលោកកំពុងបញ្ចេញសម្លេងកាន់តែខ្លាំងឡើងអំពីបញ្ហាទំនាក់ទំនងអន្តរជាតិ រាប់ចាប់ពីសិទ្ធិមនុស្ស អន្តោប្រវេសន៍ អំពើភេរវកម្ម និងពាណិជ្ជកម្ម។ មតិសាធារណៈលើបញ្ហាមួយចំនួនក្នុងចំណោមនេះ ត្រូវបានបែងចែកបក្សពួក កាន់តែខ្លាំងឡើង ដែលបង្កភាពតានតឹងផ្នែកនយោបាយក្នុងស្រទាប់សង្គម។

ឧទាហរណ៍បន្ថែមនីមួយៗនឹងផ្តោតទៅលើសហរដ្ឋអាមេរិក ឬ ប្រទេសជាច្រើនទៀតដែលទិន្នន័យជាមតិសាធារណៈអាចរកបាន និងអាចជឿទុកចិត្តបាន។ ប្រសិនបើទិន្នន័យពាក់ព័ន្ធត្រឹមតែសហរដ្ឋអាមេរិក ឧទាហរណ៍នេះនឹងពិភាក្សានិន្នាការដែលសាធារណៈមតិបានផ្លាស់ប្តូរ ពីសម័យកាលមួយ ទៅសម័យកាលមួយទៀត។ ប្រសិនបើទិន្នន័យពាក់ព័ន្ធនឹងសំណាកធំរួមានប្រទេសជាច្រើន យើងនឹងពិភាក្សាអំពីរបៀបដែលសាធារណៈមតិប្រែប្រួលក្នុងចំណោមរដ្ឋទាំងអស់នោះ។

ក្រាហ្វិក ១.៥ សាធារណៈមតិរបស់ពលរដ្ឋសហរដ្ឋអាមេរិកស្តីពីការចូលរួមជាសកល



ប្រភព៖ ទិន្នន័យពីមជ្ឈមណ្ឌល Roper សម្រាប់ការស្រាវជ្រាវសាធារណៈ ឆ្នាំ ២០១៧ ។

នៅក្នុងឧទាហរណ៍ទីមួយ យើងពិនិត្យមើលមតិសាធារណៈនៅក្នុងសហរដ្ឋអាមេរិក នៅលើសំណួរថា តើអាមេរិកគួរតែសកម្មក្នុងកិច្ចការសកល ឬ ខ្វល់ខ្វាយតែកិច្ចការផ្ទៃក្នុងរបស់ខ្លួន។ ការស្ទង់មតិសាធារណៈនៅសហរដ្ឋអាមេរិក បានសួរកំរងសំណួរនេះ អស់រយៈពេលជាច្រើនឆ្នាំមកហើយ ទោះបីជាចន្លោះពេលពីការស្ទាបស្ទង់មតិមួយទៅមួយទៀតមានគំលាតមិនទៀងទាត់ក៏ដោយ។ រូបភាព ១.៥ បង្ហាញពីក្រាហ្វិកនៃការស្ទង់មតិទាំងនេះ។ និន្នាការបីលេចឡើង នៅពេលពិនិត្យមើលទិន្នន័យនោះ។

ទីមួយ នៅចំចុងកំពូលនៃសម័យសង្គ្រាមត្រជាក់ ក្នុងទសវត្សរ៍ឆ្នាំ ១៩៥០និងទសវត្សរ៍ឆ្នាំ ១៩៦០ សាធារណជនអាមេរិកយ៉ាងច្រើនលើសលប់ជឿថា សហរដ្ឋអាមេរិកគួរតែសកម្មបំផុតក្នុងកិច្ចការអន្តរជាតិ។ មតិទាំងនេះត្រូវបានជំរុញដោយការប្រកួតប្រជែងជាមួយនឹងសហភាពសូវៀត ដែលជនជាតិអាមេរិកភាគច្រើន គិតថាបានបង្កការគំរាមកំហែងដល់សហរដ្ឋអាមេរិក។ សាធារណជនបានគិតថា មធ្យោបាយតែមួយគត់ក្នុងការដោះស្រាយការគំរាមកំហែងនោះ ត្រូវប្រឈមមុខដោយផ្ទាល់ ជាមួយនឹងគោលនយោបាយការបរទេសយ៉ាងសកម្ម។ ទីពីរ ទសវត្សរ៍ឆ្នាំ ១៩៧០ បាននាំមកនូវការកើនឡើងនូវអ្វីដែលយើងអាចហៅថា មនោសញ្ចេតនាឯកោនិយម នៅក្នុងសហរដ្ឋអាមេរិក។ ការធ្លាក់ចុះនៃជំនឿជាក់លើតួនាទីសកម្មក្នុងកិច្ចការពិភពលោក គឺដោយសារសង្គ្រាមនៅវៀតណាម ដែលបានបង្កការមិនពេញចិត្ត នៅក្នុងសហរដ្ឋអាមេរិក និងជានិមិត្តរូបនៃគោលនយោបាយការបរទេសសកម្មជ្រុល សម្រាប់ជនជាតិអាមេរិកជាច្រើន ក្នុងអំឡុងសង្គ្រាមត្រជាក់។ ការធ្លាក់ចុះនៃសាធារណមតិនេះក៏អាចដោយសារ បញ្ហាសេដ្ឋកិច្ច នៅសហរដ្ឋអាមេរិកក្នុងកំឡុងដើមទសវត្សរ៍ឆ្នាំ ១៩៧០ ដែលរួមមានការផ្តាច់ចេញពីស្តង់ដារមាសពីប្រាក់ដុល្លារ និងការហ៊ុមព័ទ្ធប្រេង។

ទីបី មនោសញ្ចេតនាឯកោនិយមថ្មីមួយបានលេចឡើង ក្នុងពេលថ្មីៗនេះ។ ដូចដែលបានពិភាក្សានៅកន្លែងផ្សេងទៀត នៅក្នុងមេរៀននេះ បាតុភូតនេះតំណាងឱ្យប្រតិកម្មកាន់តែខ្លាំងឡើងប្រឆាំងនឹងកម្លាំងនៃសកលភាវូបនីយកម្ម ដូចជាពាណិជ្ជកម្មពិភពលោក និងកំនើនការបើកចំហទទួល អន្តោប្រវេសន៍។ ជាការពិតណាស់ ជាលើកដំបូងក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមកនេះ លទ្ធផលជាមធ្យមនៃការស្ទង់មតិទាំងនេះស្ទើរតែបែងចែកគ្នារវាងអ្នកដែលស្នើថាសហរដ្ឋអាមេរិកគួរតែសកម្មក្នុងកិច្ចការពិភពលោក និងអ្នកដែលជឿថាសហរដ្ឋអាមេរិកគួរតែគិតពីកិច្ចការផ្ទៃក្នុងរបស់ខ្លួន។

តើមតិសាធារណៈមានសារៈសំខាន់ចំពោះមេដឹកនាំ ដែលបង្កើតគោលនយោបាយការបរទេស ដែរឬទេ? យើងពិភាក្សាអំពីបញ្ហានេះបន្ថែមទៀត នៅក្នុងមេរៀនទី ៤ ប៉ុន្តែ ជំនឿដែលមានស្រាប់ក្នុងចំណោមអ្នកប្រាជ្ញទាំងឡាយ គឺថានៅក្នុងប្រទេសប្រកាន់លទ្ធិប្រជាធិបតេយ្យខ្ជាប់ខ្ជួន សាធារណជន យ៉ាងហោចណាស់ក៏ដើរតួជាឧបសគ្គចំពោះឥរិយាបថរបស់អ្នកដឹកនាំ៖ ប្រធានាធិបតី ឬ នាយករដ្ឋមន្ត្រី ទំនងជាមិនជ្រើសរើសគោលនយោបាយដែលគាត់ប្រាកដក្នុងចិត្តថានឹងមិនមានប្រជាប្រិយភាពនោះទេ។ អ្នកប្រាជ្ញនានាមិនសូវប្រាកដក្នុងចិត្តទេថា តើមេដឹកនាំនយោបាយគិតយ៉ាងសកម្មអំពីមតិសាធារណៈលើគោលនយោបាយនីមួយៗក្នុងកម្រិតណា (ឧទាហរណ៍ ទណ្ឌកម្មសេដ្ឋកិច្ច អន្តោប្រវេសន៍ ពាណិជ្ជកម្មសេរី)។

ជាចុងក្រោយ និស្សិតគួរពិចារណាថា មតិសាធារណៈអាចជាឥទ្ធិពល ហើយក៏អាចជាមូលហេតុផងដែរ។ វាអាចថា មតិសាធារណៈឆ្លុះបញ្ចាំងពីអ្វីដែលមេដឹកនាំណាម្នាក់កំពុងនិយាយអំពីកិច្ចការអន្តរជាតិ។ ជាឧទាហរណ៍ ក្នុងអំឡុងសង្គ្រាមត្រជាក់ នៅសហរដ្ឋអាមេរិក គណបក្សនយោបាយធំៗទាំងពីរបានគាំទ្រយ៉ាងខ្លាំងចំពោះសកម្មភាពក្នុងកិច្ចការពិភពលោក។ នេះគឺជាសារ ដែលប្រធានាធិបតីសហរដ្ឋអាមេរិក និង

មេដឹកនាំផ្សេងទៀត ថ្លែងជាញឹកញាប់៖ គោលនយោបាយការបរទេសសកម្មជួយដល់សហរដ្ឋអាមេរិក។ វាក៏ប្រហែលជាមិនគួរឱ្យភ្ញាក់ផ្អើលទេ ដែលជនជាតិ អាមេរិកភាគច្រើនបានគាំទ្រតួនាទីជាសកលយ៉ាងសកម្ម សម្រាប់សហរដ្ឋអាមេរិក។

តើមនោសញ្ចេតនាឯកោនិយមនឹងបន្តកើនឡើង ឬ តើមតិសាធារណៈរបស់អាមេរិកនឹងកាន់តែគាំទ្រដល់គោលនយោបាយការបរទេសសកម្ម ដែរឬយ៉ាងណា? ខណៈពេលដែលយើងមិនអាចទស្សន៍ទាយពីអនាគត ដោយភាពប្រាកដប្រជាកាន់តែខ្លាំង វាទំនងជាថា ចម្លើយនៃសំណួរនោះនឹងត្រូវដោះឥទ្ធិពលដោយព្រឹត្តិការណ៍អន្តរជាតិ និងដោយតួនាទីរបស់មេដឹកនាំសហរដ្ឋអាមេរិក ស្តីពីបញ្ហាសកល។

តោះ! សាកល្បងពិភាក្សាអំពីបញ្ហាជាក់ស្តែង

សកលភាវូបនីយកម្ម៖ អំណាចរដ្ឋត្រូវបាត់បង់មែនទេ?

ទិដ្ឋភាពទូទៅ

អស់រយៈពេលជាង៣០០ឆ្នាំមកហើយ ប្រជាជាតិគឺជាអង្គការចាត់តាំងដ៏សំខាន់ នៅក្នុងពិភពលោក។ រដ្ឋាភិបាលនៃរដ្ឋនានាប្រយុទ្ធក្នុងសង្គ្រាម ការពារប្រជាពលរដ្ឋរបស់ពួកគេ ប្រមូលពន្ធ និងផ្តល់សេវាកម្ម សម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃ (ពីប្រព័ន្ធដឹកជញ្ជូនរហូតដល់ការប្រមូលសំរាម)។ បញ្ញត្តិរដ្ឋក្នុងជាអង្គភាពរៀបចំដ៏សំខាន់មួយ មានតាំងពីរាប់រយឆ្នាំមុនមកហើយ។ ទស្សនវិទូនយោបាយដូចជា លោក ថូម៉ាស់ ហប (Thomas Hobbes) បានមើលឃើញថា រដ្ឋាភិបាលមានតួនាទីផ្តល់ការការពារបុគ្គលពីធម្មជាតិ (ជាទីដែលជីវិតដែលរដ្ឋគ្រប់គ្រងមានលក្ខណៈ«សាហាវ ព្រៃផ្សៃ និងខ្លី») និងពីក្រុមបុគ្គលផ្សេងទៀត។

បញ្ញត្តិ«ប្រជាជាតិ»មានដើមកំណើតនៅទ្វីបអឺរ៉ុប។ មុនសម័យអាណានិគម ដែនដីដ៏ធំនៃទ្វីបអាហ្វ្រិក អាស៊ី និងអាមេរិកឡាទីនត្រូវបានរៀបចំឬចាត់តាំង តាមរបៀបផ្សេងៗគ្នា៖ តាមក្រុមគ្រួសារ កុលសម្ព័ន្ធ ឬប្រភេទក្រុមផ្សេងទៀត។ ប៉ុន្តែ នៅពេលដែលជនជាតិអឺរ៉ុបបានរុករកពាសពេញពិភពលោក ក្នុងគោលបំណងប្រឹងប្រែងដើម្បីធ្វើអាណានិគម និងតាំងទីលំនៅទឹកដីថ្មី ពួកគេបាននាំយកបញ្ញត្តិប្រជាជាតិ ទៅជាមួយពួកគេ។ ត្រឹមក្នុងមួយរយៈពេលខ្លីប៉ុណ្ណោះ ពិភពលោកត្រូវបានរៀបចំឡើងជាបណ្តុំនៃរដ្ឋ ដែលមានអន្តរកម្មទាក់ទងគ្នានៅលើឆាកពិភពលោក។ រដ្ឋបានក្លាយជាតួអង្គស្នូល ដែលផ្តល់សេវាកម្មដល់បុគ្គល ហើយក៏មានជម្លោះ ឬសហការគ្នា ទៅវិញទៅមក។

ប៉ុន្តែ នៅក្នុងយុគសម័យសកលភាវូបនីយកម្ម អំណាចរបស់រដ្ឋកំពុងត្រូវការប្រឈមមួយចំនួន។ ជាមួយនឹងសកលភាវូបនីយកម្ម ក៏កើតមានកំនើនបច្ចេកវិទ្យា តួអង្គមិនមែនរដ្ឋ ព្រំដែនរដ្ឋមិនទៀងទាត់ និងអង្គការអន្តររដ្ឋាភិបាល ដែលសុទ្ធសឹងបាននិងកំពុងបំផ្លាញសមត្ថភាពរបស់រដ្ឋក្នុងការគ្រប់គ្រងអ្វីគ្រប់យ៉ាងដែលមាននៅក្នុងវង្វង់ និងឆ្លងកាត់ព្រំដែនរបស់ខ្លួន។ តើយើងអាចមើលឃើញការចាប់ផ្តើមដំបូងនៃទីអវសានៃប្រជាជាតិ ក្នុងនាមជាគោលការណ៍រៀបចំ ឬអង្គការចាត់តាំងក្នុងទំនាក់ទំនងអន្តរជាតិដែរឬទេ?

អំណះអំណាង ១៖ អំណាចរបស់រដ្ឋត្រូវធ្លាក់ចុះ

តួអង្គមិនមែនរដ្ឋ បច្ចុប្បន្ននេះ មានសារៈសំខាន់ដូចតួអង្គរដ្ឋដែរ។

មិនថាពួកគេជាអង្គការមិនមែនរដ្ឋាភិបាល(NGOs)ឬសាជីវកម្មពហុជាតិ(MNCs)ទេ តួអង្គមិនមែនរដ្ឋដើរតួយ៉ាងសំខាន់ក្នុងនយោបាយពិភពលោក។ អង្គការក្រៅរដ្ឋាភិបាលដាក់សម្ពាធលើរដ្ឋាភិបាលអោយផ្លាស់ប្តូរការអនុវត្តសិទ្ធិមនុស្ស ចំណែកឯសាជីវកម្មពហុជាតិជម្រុញរដ្ឋអោយអនុម័តច្បាប់អោយសមស្របនឹង

អាជីវកម្មរបស់ពួកគេ ហើយបណ្តាញក្រុមភេរវកម្មធ្វើអោយប៉ះពាល់ដល់សន្តិសុខរដ្ឋ។ បញ្ហាប្រឈម ចំពោះអំណាចរដ្ឋទាំងនេះបានកើនឡើងខ្លាំងក្នុងប៉ុន្មានទសវត្សរ៍កន្លងមក ហើយនឹងបន្តកើនឡើង នៅពេលដែលសកលភាវូបនីយកម្មអនុញ្ញាតអោយប្រជាពលរដ្ឋមានលទ្ធភាពប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមក កាន់តែញឹកញាប់។

រដ្ឋលែងជាតួអង្គសេដ្ឋកិច្ចដ៏សំខាន់ទៀតហើយ។

លើកលែងតែរដ្ឋដែលមានសេដ្ឋកិច្ចធំជាងគេ ដូចជាសហរដ្ឋអាមេរិក និងប្រទេសជប៉ុន, សាជីវកម្មពហុជាតិ និងអ្នកវិនិយោគឯកជនគ្រប់គ្រងធនធាន និងដើមទុន ច្រើនជាងប្រជាជាតិជាច្រើន។ បន្ថែមទៅក្នុងបញ្ជីនេះ អង្គការអន្តរជាតិ ដូចជា ធនាគារពិភពលោក អង្គការពាណិជ្ជកម្មពិភពលោក (WTO)និងមូលនិធិរូបិយវត្ថុអន្តរជាតិ(IMF) ហើយរដ្ឋគ្រាន់តែជាតួអង្គមួយ ក្នុងចំណោមនោះ នៅក្នុងល្បែងសេដ្ឋកិច្ចពិភពលោក។

ទំរង់ផ្សេងទៀតបានចូលមកជំនួសជាតិនិយម។

ខណៈពេលដែលជាតិនិយមជាកម្លាំងដ៏មានឥទ្ធិពលដែលធ្លាប់បានគាំទ្ររដ្ឋកាលពីអតីតកាល ទំរង់នៃគំនិតផ្សេងទៀតបានលេចឡើង មកប្រកួតប្រជែងវា។ សាសនាបានជំនួសភាពស្មោះស្ម័គ្រភក្តីចំពោះរដ្ឋខ្លះ ហើយចំណងដ៏រឹងមាំក្នុងចំណោមជាតិសាសន៍នានាក៏តតាំងនឹងនឹងភាពស្មោះត្រង់ចំពោះរដ្ឋផងដែរ។ ប្រសិនបើបុគ្គលកាន់តែច្រើនមានភក្តីភាពចម្បង ចំពោះអ្វីមួយក្រៅពីប្រជាជាតិរបស់ពួកគេ អំណាចរដ្ឋនឹងបន្តធ្លាក់ចុះ។

អំណះអំណាង ២៖ រដ្ឋធ្លាក់ចុះ តែមិនបាត់បង់ឥទ្ធិពល

រដ្ឋតែងតែរងការប្រកួតប្រជែងជានិច្ច ក៏ប៉ុន្តែពួកគេតែងតែអាចស៊ូទ្រាំបានជានិច្ច។

រដ្ឋនានាបានរងការគំរាមកំហែងជាច្រើនសតវត្សរ៍មកហើយ។ មិនថារងការគម្រាមកំហែង ពីតួអង្គមិនមែនជារដ្ឋ (ចោរសមុទ្រ) ពីអង្គការក្រៅរដ្ឋាភិបាល(ចលនាប្រឆាំងរបបទាសភាព) ឬពីសាជីវកម្មពហុជាតិ (ក្រុមហ៊ុនតែឥណ្ណាខាងកើតរបស់អង់គ្លេស) រដ្ឋនៅតែអាចងើបឡើងក្នុងហានៈជាអំណាចកណ្តាល នៅក្នុងទំនាក់ទំនងអន្តរជាតិ។ គេមិនទាន់ឃើញមានអ្វីមួយអាចជំនួសរដ្ឋដោយជោគជ័យនៅឡើយទេ នោះមានន័យថារដ្ឋនៅតែមានឥទ្ធិពល។

រដ្ឋនៅតែអនុវត្តមុខងារដែលមិនអាចប្រគល់ទៅអោយតួអង្គផ្សេងទៀត។

ទោះបីជាមានការកើនឡើងនៃតួអង្គមិនមែនរដ្ឋក៏ដោយ ក៏មុខងារមួយចំនួននឹងធ្លាក់ទៅលើដៃរដ្ឋជានិច្ច ដូចជាការប្រមូលពន្ធ បង្កើតច្បាប់ និងការពារប្រជាពលរដ្ឋពីការគំរាមកំហែងពីខាងក្រៅ។ រដ្ឋនឹងតែងតែត្រូវការជំនួយ ដើម្បីបំពេញការកិច្ចអស់ទាំងនេះ ហើយគ្មានអង្គភាពណាមួយអាចអនុវត្តបានទាំងស្រុងនោះទេ។

ជាតិនិយមនឹងនៅតែជាកម្លាំងមនោគមវិជ្ជាដ៏មានឥទ្ធិពល ក្នុងពេលអនាគតដ៏ខ្លីខាងមុខ នៅឡើយ។

ខណៈពេលដែលជម្រើសផ្សេងជំនួសជាតិនិយមនៅតែកើតមាន គ្មានជម្រើសណាមួយត្រូវបានគេទទួលយក យ៉ាងទូលំទូលាយនោះទេ។ បុគ្គលនីមួយៗនៅតែមានភក្តីភាពរឹងមាំចំពោះប្រទេសរបស់ពួកគេ។ សាកមើល ក្រុមបំបែករដ្ឋជាគំរូ ដែលនៅតែព្យាយាមតស៊ូដណ្តើមយកភាពជារដ្ឋឯករាជ្យមួយនឹងគេដែរ។

ប្រសិនបើរដ្ឋមិនមានគុណសម្បត្តិគ្រប់គ្រាន់ទេ ហេតុអ្វីក្រុមមនុស្សជាច្រើនប្រឹងប្រែងចង់ទទួលបានហាន:ជារដ្ឋសម្រាប់ទឹកដីរបស់ខ្លួនធ្វើអ្វី?

សំណួរ

- តើសាកលភាវូបនីយកម្មបានដើរតួនាទីយ៉ាងដូចម្តេចខ្លះក្នុងការប្រជែងអំណាចរបស់រដ្ឋ? ម្យ៉ាងវិញទៀត តើបញ្ហាប្រឈមណាខ្លះដែលបណ្តាលមកពីសកលភាវូបនីយកម្ម និងកត្តាណាខ្លះទៀតដែលបណ្តាលមកពីកម្លាំងដែលប្រឆាំងនឹងសកលភាវូបនីយកម្ម ដូចជាសាសនា ជាដើម?
- តើមានជម្រើសអ្វីផ្សេងសម្រាប់ជំនួសប្រជាជាតិដែរឬទេ? តើមានមធ្យោបាយធម្មជាតិផ្សេងទៀតសម្រាប់រៀបចំចាត់ចែងនយោបាយដែរឬទេ? ចូរគិតអំពីជម្រើសតូចៗ (ក្រុមជាតិពន្ធុ កុលសម្ព័ន្ធ តំបន់) និងជម្រើសធំៗ (សម្ព័ន្ធចម្រុះជាតិដូចជាសហភាពអឺរ៉ុប ឬរដ្ឋាភិបាលពិភពលោក)ដែរឬទេ។
- ទិដ្ឋភាពមួយសម្រាប់គិតអំពីសហភាពអឺរ៉ុប គឺចាត់ទុកថាវា ជាការវិវត្តន៍ដោយដំណើរធម្មជាតិប្រែក្លាយទៅជាអង្គភាពនយោបាយធំជាង។ ជាច្រើនសតវត្សរ៍មុន អឺរ៉ុបគឺជាស៊េរីនៃរដ្ឋបុរី ហើយបន្ទាប់មកប្រែក្លាយជារាជាណាចក្រធំជាងមុន បន្ទាប់មកទៀតក្លាយជាបណ្តុំអាណាចក្ររដ្ឋធំជាងមុន បន្ទាប់មកក្លាយជាប្រជាជាតិ ហើយឥឡូវនេះជាសហភាពកាន់តែធំជាងមុន [ក្តោបពាក់កណ្តាលទ្វីប]។ តើអ្នកអាចប្រមើលមើលឃើញការវិវត្តន៍ស្រដៀងគ្នានេះ នៅក្នុងតំបន់ភូមិសាស្ត្រផ្សេងទៀត ដូចជាអាមេរិកឡាទីន ឬអាហ្វ្រិក ឬអាស៊ីដែរឬទេ?

និស្សិតអាចសាកល្បងអានឯកសារខាងក្រោមបន្ថែមទៀត ដើម្បីជាគ្រឹះក្នុងការឆ្លើយសំណួរទាំងអស់ខាងលើ ៖

- Bhagwati, Jagdish. *In Defense of Globalization.* Oxford, 2007.
- Cameron, David. *Globalization and Self-Determination: Is the Nation-State under Siege?* Routledge, 2006.
- Fukuyama, Francis. *Political Order and Political Decay: From the Industrial Revolution to the Globalization of Democracy.* Farrar, Straus and Giroux, 2014.
- Stiglitz, Joseph E. *Globalization and Its Discontents.* Norton, 2003

ឯកសារត្រួរអានបន្ថែម

- Booth, Ken, ed. Critical Security Studies and World Politics. Rienner, 2005.
- Cohen, Benjamin J. International Political Economy: An Intellectual History. Princeton, 2008.
- Doyle, Michael W. Ways of War and Peace: Realism, Liberalism, and Socialism. Norton, 1997.
- Drezner, Daniel W. All Politics Is Global. Princeton, 2008. Gilpin, Robert. Global Political Economy: Understanding the International Economic Order. Princeton, 2001.
- Held, David, and Anthony McGrew. Globalization/Anti- Globalization: Beyond the Great Divide. Polity, 2007.
- Neack, Laura. Elusive Security: States First, People Last. Rowman & Littlefield, 2007.
- Rodrik, Dani. The Globalization Paradox: Democracy and the Future of the World Economy. Norton, 2012.
- Rudra, Nita. Globalization and the Race to the Bottom in Developing Countries: Who Really Gets Hurt? Cambridge, 2008.

មេរៀនទី ០២ ៖ ទ្រឹស្តីប្រាកដនិយម

រូបថត សមយុទ្ធបាញ់គ្រាប់ពិតរបស់កូរ៉េ
ការបាញ់កាំជ្រួចពិតនៅជិតតំបន់គ្មានកម្លាំងយោធា (DMZ) កូរ៉េខាងត្បូង ២០១៧។

ឥតុបំណងមេរៀន

២.១ ចូរកំណត់នូវលក្ខណៈសន្ទុះនៃទ្រឹស្តីប្រាកដនិយម យ៉ាងហោចណាស់ ចំនួន ៣ ចំណុច។

២.២ ចូរពិពណ៌នាវិធីពីរផ្សេងគ្នា ក្នុងការ (ក)កំណត់និយមន័យ និង(ខ)វាស់ស្ទង់អំណាច។

២.៣ ចូរកំណត់និយមន័យពាក្យ «អនាធិបតេយ្យ» និងពន្យល់ពីរបៀបដែលវាអាចក្លាយជាឧបសគ្គរារាំងកិច្ចសហប្រតិបត្តិការអន្តរជាតិ។

២.៤ ចូរពន្យល់ពីគោលដៅនៃសម្ព័ន្ធភាពយោធា អង្គការសន្ធិសញ្ញាអាត្លង់ទិចខាងជើង (ណាតូ) និងការវិវត្តន៍នៃគោលដៅរបស់វា ជាបន្តបន្ទាប់ ក្នុងប្រវត្តិសម្ព័ន្ធភាពនេះ។

២.៥ ចូរពិពណ៌នាអំពីរបៀបលេង«ល្បែងទ្វេរគ្រោះអ្នកទោស» ហើយពន្យល់ថាតើវាអាចត្រូវប្រៀបប្រដូចទៅនឹងប្រព័ន្ធអន្តរជាតិយ៉ាងដូចម្តេច។

២.១. ទ្រឹស្តីប្រាកដនិយម

២.១ ចូរកំណត់នូវលក្ខណៈសន្ទុះនៃទ្រឹស្តីប្រាកដនិយម យ៉ាងហោចណាស់ ចំនួន ៣ ចំណុច។

គ្មានទ្រឹស្តីមួយណា ដែលអាចជឿទុកចិត្តបាន ពន្យល់ពីវិសាលភាពទូលំទូលាយនៃអន្តរកម្មអន្តរជាតិនោះទេ ប៉ុន្តែ ជាលក្ខណៈប្រវត្តិសាស្ត្រ ក្របខ័ណ្ឌទ្រឹស្តីមួយបានគ្រប់គ្រងតំណែងកំពូលក្នុងការសិក្សាអំពីទំនាក់ទំនងអន្តរជាតិ។ គោលការណ៍នេះ ត្រូវបានគេហៅថា **ទ្រឹស្តីប្រាកដនិយម** (Realism) បានក្លាយជាទ្រឹស្តីជាទីពេញនិយម សម្រាប់អ្នកប្រាជ្ញទំនាក់ទំនងអន្តរជាតិមួយចំនួន ហើយក៏ត្រូវបានជំទាស់យ៉ាងខ្លាំងក្លាដោយអ្នកប្រាជ្ញជនទៃទៀតដែរ ប៉ុន្តែ អ្នកសិក្សាស្ទើរតែទាំងអស់ចាត់ទុកវាជាគោលការណ៍មួយយ៉ាងសំខាន់។

ទ្រឹស្តីប្រាកដនិយម គឺជាទស្សនៈវិជ្ជាដែលពន្យល់ពីទំនាក់ទំនងអន្តរជាតិ ដោយផ្តោតលើអំណាច។ ការប្រតិបត្តិអំណាចរបស់រដ្ឋនានា ចំពោះគ្នាទៅវិញទៅមក ជួនកាល ត្រូវបានគេហៅថា*សច្ចៈភាពនយោបាយ* (realpolitik) ឬ គ្រាន់តែជានយោបាយបែងចែកអំណាច។ ទ្រឹស្តីប្រាកដសម័យទំនើបត្រូវបានបង្កើតឡើងដើម្បីឆ្លើយទៅនឹងគោលការណ៍ប្រពៃណីសេរីនិយម ដែលអ្នកប្រាកដនិយមហៅថា **ឧត្តមគតិនិយម** (ជាការពិតណាស់ អ្នកប្រាជ្ញឧត្តមគតិនិយមខ្លួនឯង មិនបានចាត់ទុកគោលការណ៍របស់ពួកគេថាមិនមានលក្ខណៈរើរែកស្រមើស្រមៃនិយមនោះទេ)។ ឧត្តមគតិនិយមសង្កត់ធ្ងន់លើច្បាប់អន្តរជាតិ ក្រមសីលធម៌ និងអង្គការអន្តរជាតិ ជាជាងផ្តោតលើអំណាចតែមួយមុខគត់ ដែលជាឥទ្ធិពលសំខាន់លើព្រឹត្តិការណ៍អន្តរជាតិនានា។ អ្នកឧត្តមគតិនិយមគិតថា ធម្មជាតិរបស់មនុស្ស ជាទូទៅ មានលក្ខណៈល្អប្រសើរ។ ពួកគេមើលឃើញប្រព័ន្ធអន្តរជាតិថាជាប្រព័ន្ធមួយ ដែលផ្អែកលើសហគមន៍នៃបណ្តារដ្ឋទាំងឡាយ ដែលមានសក្តានុពលក្នុងការសហប្រតិបត្តិការនឹងគ្នា ដើម្បីដម្នះបញ្ហាសមូហភាព (សូមមើលមេរៀនទី ៣)។ សម្រាប់អ្នកឧត្តមគតិនិយម គោលការណ៍នៃទំនាក់ទំនងអន្តរជាតិ ត្រូវតែផ្តើមចេញពីក្រមសីលធម៌។ ក្រុមអ្នកឧត្តមគតិនិយមទាំងឡាយមានសកម្មភាពផុសផុលខ្លាំង ក្នុងកំឡុងពេលចន្លោះសង្គ្រាមលោកលើកទី ១ និង សង្គ្រាមលោកលើកទី២ ក្រោយបទពិសោធន៍ដ៏ឈឺចាប់នៃសង្គ្រាមលោកលើកទី១។ ប្រធានាធិបតីសហរដ្ឋអាមេរិក វូដ្រូ វីលសុន

(Woodrow Wilson) និងអ្នកឧត្តមគតិនិយមដទៃទៀត បានដាក់ក្តីសង្ឃឹមចង់បានសន្តិភាព នៅក្នុងសម្ព័ន្ធប្រជាជាតិ ដែលជារចនាសម្ព័ន្ធផ្លូវការសម្រាប់សហគមន៍នៃប្រជាជាតិនានា។

ក្តីសង្ឃឹមរបស់ពួកគេត្រូវបានរំសាយ នៅពេលដែលអង្គការសម្ព័ន្ធប្រជាជាតិមិនអាចបញ្ឈប់ការឈ្លានពានរបស់ប្រទេសអាឡឺម៉ង់ ប្រទេសអ៊ីតាលី និងប្រទេសជប៉ុន នៅក្នុងទសវត្សរ៍ឆ្នាំ១៩៣០។ ចាប់តាំងពីសង្គ្រាមលោកលើកទី២ អ្នកប្រាកដនិយមបានស្តីបន្ទោសអ្នកឧត្តមគតិនិយមដែលខំប្រឹងផ្តោតខ្លាំងពេកអំពីរបៀបដែលពិភពលោក*គួរតែ*ដំណើរការ ជាជាងរបៀបដែលពិភពលោកដំណើរ*ពិតជាក់ស្តែង*។ ដោយដកស្រង់បទពិសោធន៍ពីសង្គ្រាមលោកលើកទី២ អ្នកប្រាកដនិយមទាំងឡាយបានកំណត់គោលដៅស្វែងយល់ពីគោលការណ៍នៃនយោបាយអំណាច ដោយមិនស្របតាមការប៉ងប្រាថ្នាថាពិភពលោកគួរតែដំណើរការយ៉ាងដូចម្តេច។ ទ្រឹស្តីប្រាកដនិយមបានផ្តល់មូលដ្ឋានគ្រឹះទ្រឹស្តី សម្រាប់គោលនយោបាយបិទខ្ទប់ ក្នុងសម័យសង្គ្រាមត្រជាក់ និងការប្តេជ្ញាចិត្តរបស់អ្នកបង្កើតគោលនយោបាយរបស់សហរដ្ឋអាមេរិក ដោយមិនផ្តាច់ផ្តន់ចិត្តសហភាពសូវៀត និងប្រទេសចិន ដូចដែលប្រទេសលោកខាងលិចធ្លាប់បានធ្វើដាក់អ៊ីតែ្លរនៅក្រុងមុយនិចក្នុងឆ្នាំ ១៩៣៨។

អ្នកប្រាកដនិយមឈរលើមូលដ្ឋានគ្រឹះដ៏រឹងមាំ នៅក្នុងប្រពៃណី ដ៏យូរលង់ណាស់មកហើយ។ អ្នកយុទ្ធសាស្ត្រសង្គ្រាមជនជាតិចិន ស៊ុន អ៊ូ (Sun Tzu) ដែលរស់នៅកាលពី ២,០០០ ឆ្នាំមុន បានផ្តល់ដំបូន្មានដល់អ្នកគ្រប់គ្រងរដ្ឋអំពីរបៀបរក្សាជីវិត[និងអំណាច] នៅក្នុងយុគសម័យដែលសង្គ្រាមបានក្លាយជាឧបករណ៍អំណាចជាប្រព័ន្ធ លើកដំបូង (សម័យកាល«សង្គ្រាមរវាងរដ្ឋបែបបាក់នានា»)។ ស៊ុន អ៊ូ បានអះអាងថាការវែកញែកអំពីសីលធម៌មិនមានប្រយោជន៍ខ្លាំងចំពោះអ្នកគ្រប់គ្រងរដ្ឋនៅសម័យនោះ ដែលកំពុងប្រឈមមុខនឹងរដ្ឋជិតខាងបំពាក់ប្រដាប់អាវុធធ្ងន់ៗនិងពោរពេញគ្រោះថ្នាក់។ គាត់បានបង្ហាញមេដឹកនាំនានាពីរបៀបប្រើអំណាចដើម្បីជំរុញផលប្រយោជន៍ដល់ខ្លួន និងរក្សាជីវិតរស់នៅ។

ក្នុងពេលជាមួយគ្នានេះដែរ នៅប្រទេសក្រិកបុរាណ លោកស៊ូស៊ីឌីឌីស (Thucydides) បានសរសេរប្រវត្តិសង្គ្រាមប៉េឡូប៉ូនេស៊ី (Peloponnesian) (៤៣១-៤០៤ មុនគ្រឹស្តសករាជ) ដោយផ្តោតលើអំណាចធៀបរវាងរដ្ឋបុរីក្រិកទាំងឡាយ។ លោកបាននិយាយថា «អ្នកខ្លាំងធ្វើអ្វីដែលពួកគេមានអំណាចអាចធ្វើបាន ហើយអ្នកទន់ខ្សោយត្រូវទទួលរងនូវអ្វីដែលពួកគេត្រូវតែទទួលយក។»[៧] សម័យក្រោយមកទៀត នៅប្រទេសអ៊ីតាលី នៅនវៈសម័យ (កំឡុងឆ្នាំ ១៥០០) លោក នីកូឡូ ម៉ាគីយ៉ាវែលី (Niccolo Machiavelli) បានជំរុញព្រះអង្គម្ចាស់នានាផ្តោតអារម្មណ៍លើសកម្មភាពងាយៗ ដើម្បីរក្សាអំណាច រួមទាំងឧបាយកលកៀងគរការគាំទ្រសាធារណៈ និងសម្ព័ន្ធភាពយោធា។ សព្វថ្ងៃនេះ គុណនាម ម៉ាគីយ៉ាវែលៀន «*Machiavellian*» នៅក្នុងភាសាអង់គ្លេស សំដៅលើអំពើពុតត្បុតហួសហេតុដើម្បីតែរក្សាអំណាចខ្លួនឯង។


ទស្សនវិទូជនជាតិអង់គ្លេស លោក ថូម៉ាស ហប (Thomas Hobbes) នៅសតវត្សរ៍ទី ១៧ បានពិភាក្សាអំពី សេរីភាពពេញទី ដែលកើតមានឡើង ក្នុងពេលអវត្តមានរដ្ឋាភិបាល ហើយមនុស្សគ្រប់រូបស្វែងរកផលប្រយោជន៍ផ្ទាល់ខ្លួន។ គាត់បានហៅវាថា «ស្ថានភាពធម្មជាតិ» ឬ «ស្ថានភាពសង្គ្រាម» ជាអ្វីដែល យើងសព្វថ្ងៃនេះហៅថា «ច្បាប់ព្រៃ» ដែលផ្ទុយពីនីតិរដ្ឋ។ លោក ថូម៉ាស ហប បានអនុគ្រោះដល់របបរាជានិយម

---

[៧] ស៊ូស៊ីឌីឌីស. *ប្រវត្តិសង្គ្រាមប៉េឡូប៉ូនេស៊ី.* បកប្រែដោយ Rex Warner, ជាមួយនឹងសេចក្តីផ្តើម និងកំណត់សម្គាល់ដោយ M.I. Finley. ១៩៧២, ទំ. ៤០២.

រឹងមាំ (ដែលគាត់ហៅថា លីវ៉ាយអឺសិន-Leviathan) ដើម្បីបង្ក្រាបស្ថានភាពនេះ, គំនិតសំខាន់គាត់ចង់ជម្រុញការប្រើប្រាស់គោលការណ៍គ្រប់គ្រង សម្រាប់ដោះស្រាយបញ្ហាផលប្រយោជន៍រួម នៅក្នុងសង្គមក្នុងស្រុក។ ដោយសម្អាងលើតួលេខប្រវត្តិសាស្ត្រទាំងអស់ខាងលើនេះ អ្នកប្រាកដនិយមឆ្លុះបញ្ចាំងពីសារៈសំខាន់នៃនយោបាយអំណាច ទោះក្នុងពេលអតីតកាលឬបច្ចុប្បន្ន និងមិនថានៅក្នុងវប្បធម៌ណាមួយឡើយ។

ក្រាហ្វិក ២.១ បណ្តុំទ្រឹស្តីទំនាក់ទំនងអន្តរជាតិ



បន្ទាប់ពីសង្គ្រាមលោកលើកទី ២ អ្នកប្រាជ្ញ ហាន ម៉ហ្គិនថូវ (Hans Morgenthau) បានអះអាងថានយោបាយអន្តរជាតិត្រូវបានគ្រប់គ្រងដោយច្បាប់ជាសកល ដែលមានគោលដៅជាក់លាក់ ដោយផ្អែកលើផលប្រយោជន៍ជាតិ ដោយត្រូវបានកំណត់ក្នុងក្របខ័ណ្ឌអំណាច (មិនមែនជាហេតុផលចិត្តសាស្ត្ររបស់អ្នកធ្វើការសម្រេចចិត្តឡើយ)។ គាត់បានលើកហេតុផលថា គ្មានប្រជាជាតិណាមួយមាន «ព្រះអាទិទេពនៅខាងខ្លួន» (ជាសីលធម៌សកល) ហើយថាប្រជាជាតិទាំងអស់ត្រូវធ្វើសកម្មភាពដោយឈរលើការប្រុងប្រយ័ត្ន និងការអនុវត្តជាក់ស្តែង។ គាត់បានប្រឆាំងនឹងសង្គ្រាមវៀតណាម ដោយលើកហេតុផលថា នៅក្នុងឆ្នាំ ១៩៦៥ វៀតណាមកុម្មុយនីស្ត៍នឹងមិនប៉ះពាល់ដល់ផលប្រយោជន៍ជាតិរបស់សហរដ្ឋអាមេរិកទេ។

ដូចគ្នានេះដែរ ក្នុងឆ្នាំ ២០០២ មុនពេលសហរដ្ឋអាមេរិកបើកការលុកលុយចូលប្រទេសអ៊ីរ៉ាក់ អ្នកប្រាកដនិយមឈានមុខគេ ក្នុងចំណោមអ្នកប្រាជ្ញទំនាក់ទំនងអន្តរជាតិល្បីៗ ចំនួន ៣៣ នាក់ ដែលបានចុះហត្ថលេខាលើការផ្សាយពាណិជ្ជកម្ម លើទំព័រកាសែតញូវយ៉កថែម (New York Times) បានព្រមានថា «សង្គ្រាមជាមួយអ៊ីរ៉ាក់*មិនមែនជា*ផលប្រយោជន៍ជាតិរបស់អាមេរិកទេ»។ ដូច្នេះ អ្នកប្រាកដនិយមមិនតែងតែពេញចិត្តនឹងការប្រើប្រាស់អំណាចយោធាទេ ទោះបីជាពួកគេទទួលស្គាល់ភាពចាំបាច់នៃការធ្វើបែបនេះ ក្នុងនៅណាមួយសមស្របក្តី។ គោលដៅនៃការផ្សាយពាណិជ្ជកម្មរបស់អ្នកប្រាជ្ញទំនាក់ទំនងអន្តរជាតិខាងលើ គឺជាក្រុមអ្នកបង្កើតគោលនយោបាយបរទេស នៅក្នុងរដ្ឋបាលប្រធានាធិបតី ប៊ូស ដែលត្រូវគេស្គាល់ថាជា *ក្រុមអភិរក្សនិយមថ្មី* ដែលជម្រុញការប្រើប្រាស់អនុភាពអំណាចរបស់អាមេរិកកាន់តែខ្លាំងក្លា ជាពិសេសកម្លាំងយោធា ដើម្បីសម្រេចគោលដៅប្រកបដោយមហិច្ឆតា និងសីលធម៌ ដូចជាបញ្ជ្រាបលទ្ធិប្រជាធិបតេយ្យដល់តំបន់មជ្ឈិមបូព៌ា។

ដូច្នេះហើយ មូលដ្ឋានគ្រឹះនៃទ្រឹស្តីប្រាកដនិយម គឺជាគោលការណ៍គ្រប់គ្រង ចំណែកទ្រឹស្តីដទៃទៀតដែលផ្អែកទៅលើគោលការណ៍បដិការ និងអត្តសញ្ញាណ នឹងត្រូវពិភាក្សានៅក្នុងមេរៀនទី ៣។ រូបភាពទី ២.១

បង្ហាញពីគោលការណ៍ទ្រឹស្តីផ្សេងៗសម្រាប់ការសិក្សាទំនាក់ទំនងអន្តរជាតិ ដែលយើងពិភាក្សានៅទីនេះ និងក្នុងមេរៀនទី ៣។

អ្នកទ្រឹស្តីប្រាកដនិយម មានទំនោរចាត់ទុកអំណាចនយោបាយ ដាច់ដោយឡែកពី និងលេចធ្លោជាងសីលធម៌ មនោគមវិជ្ជា និងទិដ្ឋភាពនៃជីវិត ផ្នែកសង្គមនិងសេដ្ឋកិច្ចដទៃទៀត។ សម្រាប់អ្នកទ្រឹស្តីប្រាកដនិយម មនោគមវិជ្ជាមិនសំខាន់ខ្លាំងពេកទេ ហើយដូចគ្នានេះដែរ សាសនាឬកត្តាវប្បធម៌ផ្សេងទៀត ដែលរដ្ឋទាំងឡាយលើកយកជាហេតុផលឬលេសនៃទង្វើរបស់ពួកគេដែរ ក៏មិនសូវសំខាន់ដែរ។ អ្នកប្រាកដនិយមមើលឃើញថារដ្ឋទាំងឡាយដែលមានសាសនា មនោគមវិជ្ជា ឬប្រព័ន្ធសេដ្ឋកិច្ចខុសគ្នាខ្លាំង មែនទែនទៅហាក់មានសកម្មភាពស្រដៀងគ្នាៗទាក់ទងនឹងអំណាចជាតិ។ ដូច្នេះ អ្នកប្រាកដនិយមសន្មតថា ទំនាក់ទំនងអន្តរជាតិ អាចត្រូវបាន ពន្យល់យ៉ាងល្អបំផុត (ទោះបីជាមិនទាំងស្រុងក៏ដោយ) ដោយជម្រើសរបស់រដ្ឋ ដែលប្រតិបត្តិការក្នុងនាមជាតួអង្គស្វ័យភាព ដែលស្វែងរកផលប្រយោជន៍ផ្ទាល់ខ្លួន នៅក្នុងប្រព័ន្ធអន្តរជាតិនៃរដ្ឋអធិបតេយ្យភាព ដោយគ្មានអាជ្ញាធរកណ្តាល។

តារាង ២.១ ខាងក្រោមនេះសង្ខេបពីលក្ខណៈខុសគ្នាសំខាន់ៗរវាងការសន្មតនៃទ្រឹស្តីប្រាកដនិយមនិងទ្រឹស្តីឧត្តមគតិនិយម។

តារាង ២.១ បង្ហាញពីលក្ខណៈសន្មតនៃទ្រឹស្តីប្រាកដនិយមនិងឧត្តមគតិនិយម

ចំណុចធៀប	ទ្រឹស្តីប្រាកដនិយម	ទ្រឹស្តីឧត្តមគតិនិយម
លក្ខណៈមនុស្ស	អាត្មានិយម	ចិត្តល្អ ចេះជួយយកអាសារអ្នកដទៃ
តួអង្គសំខាន់បំផុត	រដ្ឋ	រដ្ឋនិងតួអង្គដទៃ រួមទាំងបុគ្គល
មូលហេតុនៃទង្វើរបស់រដ្ឋ	ស្វែងរកផលប្រយោជន៍ សមហេតុផល	ចេតនាចិត្តសាស្ត្រនៃអ្នកសម្រេចចិត្ត
លក្ខណៈប្រព័ន្ធអន្តរជាតិ	អនាធិបតេយ្យ	សហគមន៍

២.២. អំណាច

២.២ ចូរពិពណ៌នាវិធីពីរផ្សេងគ្នា ក្នុងការ (ក)កំណត់និយមន័យ និង(ខ)វាស់ស្ទង់អំណាច។

អំណាចគឺជាបញ្ញត្តិដ៏សំខាន់ នៅក្នុងទំនាក់ទំនងអន្តរជាតិ សំខាន់បំផុតសម្រាប់អ្នកទ្រឹស្តីប្រាកដនិយម ប៉ុន្តែជារឿងគួរអោយភ្ញាក់ផ្អើល អំណាចពិបាកកំណត់និយមន័យ ឬពិបាកវាស់ស្ទង់ផងដែរ។

២.២.១. ការកំណត់អំណាច

អំណាចត្រូវបានកំណត់ជារឿយៗថាជាសមត្ថភាពក្នុងការធ្វើអោយតួអង្គដទៃធ្វើអ្វីមួយ ដែលពួកគេអាចនឹងមិនចង់ធ្វើ(ឬមិនធ្វើអ្វីដែលពួកគេចង់ធ្វើ)។ បើពន្យល់បញ្ញត្តិនេះបែបផ្សេង គឺថាតួអង្គមានឥទ្ធិពលខ្លាំងដល់កម្រិតមួយដែលពួកគេជះឥទ្ធិពលលើអ្នកដទៃ ច្រើនជាងអ្នកដទៃមានឥទ្ធិពលលើពួកគេវិញ។ និយមន័យទាំងនេះចាត់ទុកអំណាចជាឥទ្ធិពល។ បើតួអង្គណាមួយចង់បានផលប្រយោជន៍តាមចិត្តចង់ ពួកគេត្រូវតែមានអំណាចខ្លាំងដែរ។

បញ្ហាមួយជាមួយនឹងនិយមន័យនេះគឺថា យើងមិនងាយដឹងនូវអ្វីដែលតួអង្គទីពីរអាចនឹងធ្វើ ក្នុងពេលអវត្តមានអំណាចរបស់តួអង្គទីមួយ។ មានគ្រោះថ្នាក់ខ្លាំងក្នុងតក្កវិជ្ជាវិលជុំ៖ អំណាចពន្យល់ពីឥទ្ធិពល ហើយឥទ្ធិពលវាស់ស្ទង់អំណាច។

រូបថត ស្ត្រីរុស្ស៊ីកំពុងប្រមូលទិញអំបិលពីផ្សារទំនើបមួយ

ពេលអំបិលលើមុខរបួស

អំណាចជាសមត្ថភាពក្នុងការដេះឥទ្ធិពលលើអាកប្បកិរិយារបស់អ្នកដទៃ។ កម្លាំងយោធា និងទណ្ឌកម្ម សេដ្ឋកិច្ច ស្ថិតក្នុងចំណោមមធ្យោបាយផ្សេងៗ ដែលតួអង្គរដ្ឋនិងមិនមែនរដ្ឋប្រើប្រាស់ ដើម្បីព្យាយាមមានឥទ្ធិពលលើគ្នាទៅវិញទៅមក។ សហភាពអឺរ៉ុប (EU) និងសហរដ្ឋអាមេរិកបានដាក់ទណ្ឌកម្មជាច្រើនដងប្រឆាំងនឹងរុស្ស៊ី ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយនេះ ដើម្បីមានឥទ្ធិពលលើគោលនយោបាយរបស់រុស្ស៊ីចំពោះអ៊ុយក្រែន និងដើម្បីរារាំងរុស្ស៊ីកុំអោយជ្រៀតជ្រែកក្នុងការបោះឆ្នោតរបស់លោកខាងលិច។ ជាការឆ្លើយតប រុស្ស៊ីបានហាមឃាត់ការនាំចូលទំនិញពីអឺរ៉ុបនិងសហរដ្ឋអាមេរិក រួមទាំងអំបិលផងដែរ។ នៅទីនេះ អ្នកទិញទំនិញជនជាតិរុស្ស៊ីម្នាក់កំពុងទិញអំបិលស្កុកទុក មុនពេលការហាមឃាត់ចូលជាធរមានក្នុងឆ្នាំ ២០១៧ ។

ទោះជាយ៉ាងក៏ដោយ អំណាចមិនមានឥទ្ធិពលទេ ប៉ុន្តែ វាជាសមត្ថភាព ឬសក្តានុពល ដើម្បីមានឥទ្ធិពលលើអ្នកដទៃ។ អ្នកប្រាជ្ញទំនាក់ទំនងអន្តរជាតិជាច្រើនជឿថា សក្តានុពលបែបនេះ ត្រូវផ្អែកលើកម្មសិទ្ធឬលក្ខណៈសម្បត្តិទាំងរូបីនិងអរូបីរបស់រដ្ឋ ដូចជាទំហំ កម្រិតប្រាក់ចំណូល និងកងកម្លាំងប្រដាប់អាវុធ។ នេះជាអំណាច ដែលកំណត់ថាជា*សមត្ថភាព*។ សមត្ថភាព ងាយស្រួលវាស់វែងជាងឥទ្ធិពល ហើយមិនវិលវល់ក្នុងវដ្តនៃតក្កវិជ្ជាទេ។

យ៉ាងណាមិញ ការវាស់វែងសមត្ថភាពដើម្បីពន្យល់ពីរបៀបដែលរដ្ឋមួយ មានឥទ្ធិពលលើរដ្ឋមួយទៀតមិនមែនជារឿងសាមញ្ញទេ។ វាតម្រូវអោយមានការបូកសរុបនូវប្រភេទផ្សេងៗនៃសក្តានុពល។ រដ្ឋមានចំនួនប្រជាជនខុសគ្នា ទំហំទឹកដីក៏ខុសគ្នា និងកងកម្លាំងយោធាក៏ខុសគ្នាដែរ ។ល។ *សូចនាករល្អបំផុត តែមួយគត់សម្រាប់វាស់វែងអំណាចរបស់រដ្ឋ អាចជាផលិតផលក្នុងស្រុកសរុប(ផ.ស.ស. ឬ GDP)របស់រដ្ឋនោះ* ដែលរួមបញ្ចូលគ្នានូវទំហំទឹកដីទាំងមូល កម្រិតបច្ចេកវិទ្យា និងទ្រព្យសម្បត្តិរដ្ឋ។ ប៉ុន្តែ សូម្បីតែផលិតផលក្នុងស្រុកសរុបគ្រាន់តែជាសូចនាករប៉ាន់ស្មានមួយតែប៉ុណ្ណោះ ហើយអ្នកសេដ្ឋកិច្ចទាំងឡាយក៏មិនយល់ស្របពីរបៀបវាស់វែងវាដែរ។ ជាឧទាហរណ៍ តួលេខភាគច្រើននៅក្នុងសៀវភៅនេះប្រើវិធីសាស្ត្រប្រៃណីក្នុងការគណនាផលិតផលក្នុងស្រុកសរុប ប៉ុន្តែ វិធីសាស្ត្រផ្សេងផ្តល់ការប៉ាន់ស្មានផលិតផលក្នុងស្រុកសរុប នោះបានន័យថាជាមធ្យម ប្រហែល ៥០ ភាគរយ ទាបជាងបណ្តាប្រទេសនៅអឡឺគោលខាងជើង និងប្រហែល ៥០ ភាគរយខ្ពស់ជាង បណ្តាប្រទេសនៅអឡឺគោលខាងត្បូង រួមទាំងប្រទេសចិនផងដែរ (សូមមើល កំណត់សម្គាល់ Footnote ២ ក្នុងមេរៀនទី ១)។ ដូច្នេះ ផលិតផលក្នុងស្រុកសរុបគឺជាការប៉ាន់ប្រមាណដ៏មានប្រយោជន៍ វាស់វែងសមត្ថភាពផ្នែកសម្ភារៈ ប៉ុន្តែ មិនមែនជាវង្វាស់វង្វាល់ច្បាស់លាស់នោះទេ។

អំណាចក៏អាស្រ័យលើធាតុដែលមិនមែនជាសម្ភារៈផងដែរ។ សមត្ថភាពទាំងឡាយផ្តល់អោយរដ្ឋនូវសក្តានុពលដើម្បីដេះឥទ្ធិពលលើរដ្ឋដ៏ទៃ រហូតដល់កម្រិតមួយ ដែលអ្នកដឹកនាំនយោបាយ អាចប្រមូលផ្តុំ និងប្រើប្រាស់សមត្ថភាពទាំងនេះ ប្រកបដោយប្រសិទ្ធភាព និងជាលក្ខណៈយុទ្ធសាស្ត្រខ្ពស់។ នេះអាស្រ័យលើធនធានជាតិ ជំនាញការទូត ការគាំទ្រពេញទំហឹងដល់រដ្ឋាភិបាលពីសំណាក់ពលរដ្ឋ (ធម្មានុភាព) ជាដើម។ អ្នកប្រាជ្ញមួយចំនួនសង្កត់ធ្ងន់លើ*អំណាចនៃគំនិត,* ដែលជាសមត្ថភាពក្នុងការបង្កើន ជាអតិបរមា នូវឥទ្ធិពលនៃសមត្ថភាព តាមរយៈដំណើរការចិត្តសាស្ត្រ។ ដំណើរការនេះរួមបញ្ចូលទាំងការកៀរគរសមត្ថភាពក្នុងស្រុកឲ្យជាញឹកញាប់ តាមរយៈសាសនា មនោគមវិជ្ជា ឬ (ជាពិសេស) គំនិតជាតិនិយម។ ឥទ្ធិពលអន្តរជាតិក៏អាចទទួលបាន ដោយការបង្កើតក្រិតក្រមនៃអាកប្បកិរិយា ដើម្បីផ្លាស់ប្តូរពីរបៀបដែលរដ្ឋដទៃទៀតសម្លឹង ឃើញ

ផលប្រយោជន៍របស់ជាតិខ្លួន។ ប្រសិនបើគុណតម្លៃផ្ទាល់ខ្លួនរបស់រដ្ឋមួយ ត្រូវគ្នាជាមួយនឹងគុណតម្លៃរបស់រដ្ឋជាច្រើនផ្សេងទៀត រដ្ឋនោះនឹងមានឥទ្ធិពលលើរដ្ឋទាំងផ្សេងបានដោយងាយ។ នេះត្រូវបានគេហៅថា *អំណាចទន់*។ ជាឧទាហរណ៍ សហរដ្ឋអាមេរិកបានដុះឥទ្ធិពលលើរដ្ឋជាច្រើនទៀតអោយទទួលយកគុណតម្លៃទីផ្សារសេរី និងពាណិជ្ជកម្មសេរីផងដែរ។

ដូច្នេះ គោលការណ៍គ្រប់គ្រងមិនមែនជាមធ្យោបាយតែមួយគត់ ដើម្បីបញ្ចេញអំណាច (ដុះឥទ្ធិពលលើអ្នកដទៃ)នោះទេ។ គោលការណ៍ស្នូលក្នុងទំនាក់ទំនង ដូចជា បដិការ និង(ក្នុងករណីអំណាចទន់) គោលការណ៍អត្តសញ្ញាណក៏អាចដំណើរការបានដែរ។ ជាឧទាហរណ៍ ឪពុកដែលចង់អោយកូនតូចរបស់ខ្លួនឈប់ស្រែកយំ នៅក្នុងផ្សារទំនើប អាចនឹងគំរាមនឹងវាយ ឬពិតជាវាយកូនមែន (គោលការណ៍គ្រប់គ្រង) ឬថាគាត់ប្រហែលជាសន្យាថានឹងទិញស្ករគ្រាប់ញ៉ាំនៅពេលគិតលុយ ជារង្វាន់លើកទឹកចិត្តសម្រាប់អាកប្បកិរិយាល្អ (គោលការណ៍បដិការ) ឬគាត់អាចហៅដោយលើកទឹកចិត្ត ដូចជាថា «កូនធំហើយ» ឬ «កូនចង់ជួយប៉ាមែនទេ?» (គោលការណ៍អត្តសញ្ញាណ)។ ទោះបីជាអ្នកទ្រឹស្តីប្រាកដនិយមសង្កត់ធ្ងន់លើវិធីសាស្ត្រនៃការគ្រប់គ្រងក៏ដោយ ក៏ពួកគេទទួលស្គាល់ថា រដ្ឋជារឿយៗសម្រេចបានផលប្រយោជន៍របស់ខ្លួនតាមវិធីផ្សេងទៀតផងដែរ។ លើសពីនេះទៅទៀត សូម្បីតែអ្នកប្រាកដនិយមក៏ទទួលស្គាល់ថាអំណាចអាចផ្តល់បានត្រឹមតែការយល់ដឹងទូទៅអំពីលទ្ធផលប៉ុណ្ណោះ។ លទ្ធផលនៃពិភពលោកជាក់ស្តែង ត្រូវអាស្រ័យលើធាតុដទៃទៀតជាច្រើន រួមទាំងគ្រោះថ្នាក់ ឬសំណាង។

ដោយសារតែអំណាច គឺជាបញ្ញត្តិឬគំនិតធៀប បានន័យថា រដ្ឋមួយអាចមានអំណាចបាន ទាល់តែប្រៀបធៀបនឹងអំណាចរបស់រដ្ឋផ្សេងទៀតប៉ុណ្ណោះ។ *អំណាចធៀប* គឺជាសមាមាត្រនៃអំណាចដែលរដ្ឋទាំងពីរប្រើតទល់គ្នាទៅវិញទៅមក។ វាមានសារៈសំខាន់តិចតួចណាស់សម្រាប់អ្នកប្រាកដនិយមថា តើសមត្ថភាពរបស់រដ្ឋមួយកំពុងកើនឡើង ឬ ធ្លាក់ចុះ នៅក្នុងលក្ខខណ្ឌឬសភាពជាច់ខាត អ្វីដែលសំខាន់ថាតើរដ្ឋទាំងនោះកំពុងធ្លាក់ចុះនៅពីក្រោយ ឬវ៉ាដាច់សមត្ថភាពរបស់រដ្ឋគូប្រជែង។ ជាឧទាហរណ៍ ប្រទេសឥណ្ឌាអាចនឹងបង្កើនអំណាចយោធារបស់ខ្លួន យ៉ាងលឿន ប៉ុន្តែប្រសិនបើប្រទេសចិន ដែលជាគូប្រជែង បានពង្រឹងអំណាចយោធារបស់ខ្លួន ក្នុងល្បឿនមួយលឿនជាង, ប្រទេសឥណ្ឌាអាចនឹងខាតប្រយោជន៍។

២.២.២. ការខាស់ស្ងួចអំណាច

តក្កវិជ្ជាអំណាចបង្ហាញថា នៅក្នុងសង្គ្រាម រដ្ឋដែលមានឥទ្ធិពលជាង ជាទូទៅ នឹងទទួលជោគជ័យ។ ដូច្នេះការប៉ាន់អំណាចធៀបនៃគូប្រជែងទាំងពីរគួរតែអាចជួយពន្យល់ពីលទ្ធផលណាមួយ។ ការប៉ាន់ប្រមាណទាំងនេះអាចពិចារណាអំពីសមត្ថភាពយោធាធៀបរបស់ប្រទេសជាតិ និងការគាំទ្ររដ្ឋាភិបាលពីសំណាក់ពលរដ្ឋក្នុងចំណោមកត្តាផ្សេងៗទៀត។ ប៉ុន្តែ សំខាន់បំផុត គឺទំហំសរុបនៃសេដ្ឋកិច្ចរបស់ប្រទេសនីមួយៗ ពោលគឺ ផ.ស.ស. ដែលឆ្លុះបញ្ចាំងពីចំនួនប្រជាជន និងកម្រិតប្រាក់ចំណូលសម្រាប់ប្រជាជនម្នាក់ៗ។ ជាមួយនឹងស្ថេរភាពសេដ្ឋកិច្ចល្អគ្រប់គ្រាន់ រដ្ឋមួយអាចទិញកងទ័ពដ៏ធំមួយ ការគាំទ្រពីពលរដ្ឋ (តាមរយៈការផ្តល់ទំនិញប្រើប្រាស់) និងសូម្បីតែសម្ព័ន្ធមិត្តក៏អាចទាក់ចិត្តបានដែរ។

ជាឧទាហរណ៍ បដិវត្តន៍លីប៊ី ដែលតស៊ូប្រឆាំងនឹងមេដឹកនាំផ្តាច់ការ មូម៉ា ហ្គាដាហ្វី (Muammar Gaddafi) ក្នុងឆ្នាំ ២០១១ ពោរពេញដោយឆន្ទៈ និងការប្តេជ្ញាចិត្តខ្ពស់ ប៉ុន្តែ មិនអាចទម្លាក់រដ្ឋាភិបាល ដោយប្រើអាវុធធុនធ្ងន់បានទេ។ បន្ទាប់មក រដ្ឋាភិបាលលីប៊ីបានត្រៀមកម្ទេចក្រុមឧទ្ទាមដោយរថក្រោះ។ សហរដ្ឋ

អាមេរិកនិងសម្ព័ន្ធមិត្តណាតូបានចាប់ផ្តើមយុទ្ធនាការវាយប្រហារផ្លូវអាកាស ដែលបានបង្វែរទិសដៅលទ្ធផលសង្គ្រាមដាច់ខាត។ ពួកឧទ្ធាមបានដណ្តើមតំបន់ត្រួតត្រា ហើយប៉ុន្មានខែក្រោយ មកបានប្រកាសជ័យជម្នះ។ វិសមភាពនៃអំណាចមានគំលាតខុសគ្នាខ្លាំង។ បើប្រៀបធៀបពី ផ.ស.ស. អង្គការណាតូមានប្រៀបជាង ប្រហែល ៣០០ ទល់នឹង ១ ហើយកងកម្លាំងណាតូមានសមត្ថភាពខាងបច្ចេកវិទ្យាច្រើនជាងដាច់តែម្តង។ ពួកគេក៏រីករាយនឹងធម្មានុរូប ដែលផ្តល់ដោយក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិផងដែរ។ នៅទីបំផុត ហ្គាដាហ្វីបានស្លាប់ ហើយអ្នកគាំទ្ររបស់គាត់បានរត់គេចខ្លួនបាត់ស្រមោល ហើយអង្គការណាតូមិនបានរងគ្រោះ សូម្បីតែជីវិតមួយ។

ថ្វីត្បិតតែសម្រេចបាននូវលទ្ធផលនៃជម្លោះដ៏មិនច្បាស់លាស់នេះក៏ដោយ ក៏ការអនុវត្តអំណាចតែងតែនាំមកនូវហានិភ័យជាផលវិបាក ដោយអចេតនា។ ក្នុងឆ្នាំ ២០១២ យុទ្ធជនជាតិពន្ធុ និងពួកសកម្មប្រយុទ្ធឥស្លាមនិយមជ្រុល ដែលបានប្រយុទ្ធគាំទ្រហ្គាដាហ្វី បានរឹបអូសយកអាវុធយ៉ាងច្រើន ហើយបានឆ្លងកាត់វាលខ្សាច់ទៅកាន់ភាគខាងជើងប្រទេសម៉ាលី ជាកន្លែងដែលពួកគេបានកាន់កាប់ផ្នែដីពាក់កណ្តាលប្រទេស។ នៅដើមឆ្នាំ ២០១៣ ប្រទេសបារាំងត្រូវតែធ្វើអន្តរាគមន៍ផ្នែកយោធា នៅក្នុងប្រទេសម៉ាលីដើម្បីបញ្ឈប់ពួកគេ ហើយពួកសកម្មប្រយុទ្ធអ៊ីស្លាមបានឆ្លងចូលទៅក្នុងប្រទេសអាល់ហ្សេរី ជាកន្លែងដែលពួកគេបានចាប់ចំណាប់ខ្មាំងបរទេសរាប់រយនាក់ នៅក្នុងរោងចក្រឧស្ម័ន ហើយបានសម្លាប់ចំណាប់ខ្មាំងរាប់សិបនាក់ នៅពេលដែលកងទ័ពអាល់ហ្សេរីបានវាយប្រហារ។ ដូច្នេះ ផលិតផលក្នុងស្រុកសរុបដ៏ធំមួយ អាចជួយប្រទេសមួយឈ្នះសង្គ្រាម ប៉ុន្តែ វាមិនអាចលុបបំបាត់ជាតុផ្សំផ្សេងៗ រួមមានភាពស្មុគស្មាញ និងភ័ព្វសំណាងនោះទេ ដោយសារស្ថានភាពនីមួយៗមានការវិវត្តន៍ជាហូរហែរ ក្នុងពេលវែងឆ្ងាយ។

២.២.៣. ធាតុនៃអំណាច

អំណាចរដ្ឋគឺជាការលាយបញ្ចូលគ្នានៃធាតុផ្សំជាច្រើន។ ធាតុមួយចំនួនដែលតួអង្គអាចទាញចេញមកប្រើ ក្នុងរយៈពេលវែងឆ្ងាយ រួមមាន ផលិតផលក្នុងស្រុកសរុប ចំនួនប្រជាជន ទឹកដី ភូមិសាស្ត្រ និងធនធានធម្មជាតិ។ លក្ខណៈសម្បត្តិនៃធាតុទាំងនេះប្រែប្រួលក្នុងល្បឿនយឺតៗតែប៉ុណ្ណោះ។ ធនធានអំណាចក្នុងរយៈពេលវែងឆ្ងាយដែលមានលក្ខណៈរូបីព្រាលៗ រួមមាន វប្បធម៌នយោបាយ ស្មារតីស្នេហាជាតិ កំរិតអប់រំប្រជាជន និងកំរិតមូលដ្ឋានចំណេះដឹងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។ ភាពជឿទុកចិត្តលើការប្តេជ្ញាចិត្តរបស់ខ្លួន (កេរ្តិ៍ឈ្មោះនៃការគោរពពាក្យសន្យារបស់ខ្លួន) ក៏ជាមូលដ្ឋានអំណាច ក្នុងរយៈពេលវែងសម្រាប់រដ្ឋនីមួយៗ។ ហើយដូចគ្នានេះដែរ សមត្ថភាពផ្នែកវប្បធម៌និងគុណតម្លៃរបស់រដ្ឋមួយ ក្នុងការជះឥទ្ធិពលដំណើរការគិតរបស់រដ្ឋផ្សេងទៀត អោយសង់តង់គ្នា ក៏ជាមូលដ្ឋានអំណាចដែរ (អំណាចនៃគំនិត)។

សារៈសំខាន់នៃធនធានអំណាច ក្នុងរយៈពេលវែង ត្រូវបានបង្ហាញ បន្ទាប់ពីការវាយប្រហារដ៏គួរអោយភ្ញាក់ផ្អើលរបស់ជប៉ុន លើកងនាវាអាមេរិក នៅឯកំពង់ផែផើលហាប៊ឺរ (Pearl Harbor) ក្នុងឆ្នាំ ១៩៤១ ដែលបានធ្វើអោយខូចខាតសមត្ថភាពកងទ័ពជើងទឹករបស់សហរដ្ឋអាមេរិក នៅមហាសមុទ្រប៉ាស៊ីហ្វិក។ ក្នុងមួយរយៈពេលខ្លី ជប៉ុនមានអំណាចយោធាខ្លាំងលើសគេ និងអាចចូលកាន់កាប់ទឹកដី ក្នុងតំបន់អាស៊ីអាគ្នេយ៍ ខណៈពេលដែលជំរុញកងកម្លាំងអាមេរិកចេញពីតំបន់។ បើគិតក្នុងរយៈពេលវែងជាងនេះ សហរដ្ឋអាមេរិកមានធនធានអំណាចច្រើនសម្បើមជាង ដោយសារសក្តានុពលសេដ្ឋកិច្ចជាមូលដ្ឋានគ្រឹះរបស់មហាអំណាច

នេះ។ ធនធានទាំងនោះបានជួយបង្កើតសមត្ថភាពយោធា ក្នុងរយៈពេលប៉ុន្មានឆ្នាំបន្ទាប់ ដែលអាចត្រូវបានពង្រឹងតាមទាន់ជប៉ុនជាបណ្តើរៗ ហើយបន្ទាប់មកបានវាជាច់កម្លាំងទ័ពជប៉ុន។

សមត្ថភាពផ្សេងទៀតអាចអនុញ្ញាតអោយតួអង្គអនុវត្តឥទ្ធិពល ក្នុង*រយៈពេលខ្លី*។ កងកម្លាំងយោធាគឺជាសមត្ថភាពមួយ៖ ប្រហែលជាប្រភេទសមត្ថភាពសំខាន់បំផុត។ នៅក្នុងការប្រឈមមុខគ្នាផ្នែកយោធា ក្នុងរយៈពេលខ្លី, ទំហំ សមាសភាព និងការត្រៀមលក្ខណៈរបស់កងកម្លាំងយោធានៃរដ្ឋទាំងពីរខាងលើមានសារៈសំខាន់ជាងសេដ្ឋកិច្ច ឬ ធនធានធម្មជាតិផ្សេងទៀតរបស់ពួកគេទាំងពីរ។ សមត្ថភាពមួយទៀត គឺសមត្ថភាពឧស្សាហកម្មយោធា ល្បឿននៃការផលិតសព្វាវុធបានយ៉ាងឆាប់រហ័ស។ គុណភាពនៃការិយាធិបតេយ្យរបស់រដ្ឋគឺជាសមត្ថភាពមួយប្រភេទទៀត ដែលអនុញ្ញាតអោយរដ្ឋអាចប្រមូលព័ត៌មាន(សាធារណៈនិងសម្ងាត់), តាក់តែងច្បាប់គ្រប់គ្រងពាណិជ្ជកម្មអន្តរជាតិ ឬចូលរួមក្នុងសន្និសីទអន្តរជាតិ។ សមត្ថភាពរូបីតិចជាងនេះ គឺ *ការគាំទ្រនិងភាពស្របច្បាប់* ដែលតួអង្គទទួលបាន ក្នុងរយៈពេលខ្លី ពីអ្នកតំណាងនិងសម្ព័ន្ធមិត្ត គឺជាសមត្ថភាពដែលតួអង្គអាចប្រើដើម្បីទទួលបានឥទ្ធិពល។ *ភាពស្មោះស្ម័គ្រ*បស់កងទ័ព និងអ្នកនយោបាយចំពោះមេដឹកនាំរបស់ពួកគេ។

ដោយសារធនធានរបស់តួអង្គណាមួយក៏មានដែនកំណត់ដែរ ដូច្នេះ ការដោះដូររវាងសមត្ថភាពនឹងសមត្ថភាពមួយទៀតតែងតែមានជានិច្ច។ ជាឧទាហរណ៍ ការកសាងកម្លាំងយោធាបង្វែរធនធានដែលអាចប្រើសម្រាប់ជំនួយបរទេស។ ឧទាហរណ៍មួយទៀត ការទិញទឹកចិត្តស្មោះស្ម័គ្រកក្តីពីប្រជាជនជាមួយនឹងទំនិញប្រើប្រាស់ផ្សេងៗកាត់បន្ថយធនធាន ដែលគ្រោងសម្រាប់ការកសាងសមត្ថភាពយោធា។ ដោយសារតែធាតុនៃអំណាចមួយអាចត្រូវបានបំប្លែងទៅជាធាតុមួយផ្សេងទៀត វាអាច*ដោះដូរ* គ្នាបាន។ ជាទូទៅ លុយគឺជាសមត្ថភាពមួយដែលអាចដោះដូរគ្នាបានយ៉ាងងាយបំផុត ព្រោះវាអាចទិញសមត្ថភាពផ្សេងទៀត។

រូបថត អាមេរិកលុកលុយចូលប្រទេសអ៊ីរ៉ាក់

សេដ្ឋកិច្ចនៃអំណាច

អំណាចយោធាដូចជារថក្រោះ ពឹងផ្អែកលើកម្លាំងសេដ្ឋកិច្ច ដែលវាស់វែងដោយផលិតផលក្នុងស្រុកសរុប។ សេដ្ឋកិច្ចធំរបស់សហរដ្ឋអាមេរិកគាំទ្រការត្រួតត្រាយោធារបស់សហរដ្ឋអាមេរិក។ ក្នុងការលុកលុយរបស់អាមេរិកនៅអ៊ីរ៉ាក់ឆ្នាំ ២០០៣ សហរដ្ឋអាមេរិកអាចមានលទ្ធភាពបញ្ជូនកម្លាំងយោធាដ៏ធំនិងបច្ចេកវិទ្យាជឿនលឿនទៅកាន់មជ្ឈឹមបូព៌ា។ រូបនេះ កងកម្លាំងអាមេរិកចូលអ៊ីរ៉ាក់ ខែមីនា ឆ្នាំ២០០៣។

អ្នកប្រាកដនិយមទំនងមើលឃើញថា *កម្លាំងយោធា* ជាធាតុសំខាន់បំផុតនៃអំណាចជាតិណាមួយក្នុងរយៈពេលខ្លី ហើយធាតុផ្សេងទៀត ដូចជាកម្លាំងសេដ្ឋកិច្ច ជំនាញការទូត ឬភាពស្របច្បាប់ផ្នែកសីលធម៌ មានសារៈសំខាន់ រហូតដល់កម្រិតមួយដែលបំប្លែងជាអំណាចយោធា។ ទោះជាយ៉ាងណាក៏ដោយ អាស្រ័យលើស្ថានភាពឬលក្ខណៈនៃជម្លោះផ្សេងៗ អំណាចយោធាគ្រាន់តែជាធាតុមួយ ក្នុងចំណោមធាតុនៃអំណាចជាច្រើន។ លោក រ៉ូប៊ឺត ហ្គេត (Robert Gates) ក្នុងនាមជារដ្ឋមន្ត្រីការពារជាតិសហរដ្ឋអាមេរិក បានអំពាវនាវអោយមាន«ការបង្កើនយ៉ាងខ្លាំង»នូវទំហំកញ្ចប់ថវិកាសម្រាប់ចំណាយផ្នែកការទូត និងជំនួយសេដ្ឋកិច្ច ដោយបានកត់សម្គាល់ថា ទោះបីជាមានការចំណាយយោធាខ្ពស់ «ធាតុផ្សេងទៀតនៃអំណាចជាតិ» ហាក់បានដើរយឺតជាងគេ ក្នុងយុគសម័យសង្គ្រាមអតុល្យភាព ឬមិនស៊ីមេទ្រីគ្នា (ឧទាហរណ៍ សង្គ្រាមប្រឆាំងភេរវកម្ម) ដែលជម្លោះនានាមាន«លក្ខណៈនយោបាយជាមូលដ្ឋានគ្រឹះ» និងមិនមែនគ្រាន់តែជាជម្លោះយោធានោះទេ។

លោករដ្ឋមន្ត្រី ហ្គេត បានបន្តចង្អុលបង្ហាញថា សហរដ្ឋអាមេរិកមានសមាជិកមន្ត្រីយោធាច្រើនជាងមន្ត្រីបម្រើការទូត។ នៅក្នុងឆ្នាំ ២០០៩ មន្ត្រីយោធាកំពូលរបស់សហរដ្ឋអាមេរិកបានបន្ថែមទៀតថា ទោះបីជាមេដឹកនាំរបស់សហរដ្ឋអាមេរិកបាន «លូកយកញញួរយោធាពីក្នុងប្រអប់ឧបករណ៍គោលនយោបាយការបរទេស ជាញឹកញាប់ ណាស់ដែរ» នៅក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ «កងកម្លាំងប្រដាប់អាវុធប្រហែលជាមិនតែងតែជាជម្រើសដ៏ល្អបំផុត» ដើម្បីសម្រេចបាននូវគោលដៅគោលនយោបាយការបរទេសនោះទេ។[៨] ស្របតាមគោលគំនិតនេះ ការចំណាយរបស់សហរដ្ឋអាមេរិកលើជំនួយបរទេសបានកើនឡើងយ៉ាងខ្លាំង (រួមជាមួយនឹងការចំណាយផ្នែកយោធា) ចាប់តាំងពីការវាយប្រហារថ្ងៃទី១១ ខែកញ្ញា។

ការរីកចម្រើនផ្នែកបច្ចេកវិទ្យា ការកាន់កាប់ក៏ដូចជាការប្រើប្រាស់ធនធានធម្មជាតិរបស់ប្រទេសជាតិ និងឆន្ទៈជាតិ អាចជាធនធានដ៏សំខាន់ក្នុងនយោបាយអន្តរជាតិ។ កាលដើមឡើយ ក្នុងឆ្នាំ ២០១៦ មតិអ្នកបោះឆ្នោតអង់គ្លេសភាគច្រើន (លើសគ្នាតិចតួច) បានគាំទ្រការចាកចេញរបស់អង់គ្លេសពីសហភាពអឺរ៉ុប ហើយជាលទ្ធផល អាចបណ្តាលអោយផ្លាស់ប្តូរប្រវត្តិសាស្ត្ររបស់សហភាពអឺរ៉ុប ក៏ដូចជាទំនាក់ទំនងសហរដ្ឋអាមេរិកនិងសហភាពអឺរ៉ុប។ អាមេរិកនិងចិនកំពុងប្រជែងគ្នាគ្រប់គ្រងបច្ចេកវិទ្យាទូរគមនាគមន៍ ៥G និងគ្រឿងម៉ាស៊ីនទ្រទ្រង់បច្ចេកវិទ្យានេះ។ សីលធម៌ក៏អាចរួមចំណែកក្នុងសមត្ថភាពអំណាច ដោយបង្កើនឆន្ទៈប្រើប្រាស់អំណាចនិងកៀងគរសម្ព័ន្ធមិត្ត។ ជាយូរណាស់មកហើយ រដ្ឋនានាបានលាក់បាំងសកម្មភាពរបស់ខ្លួន ទោះមានលក្ខណៈគឃ្លើនយ៉ាងណាក៏ដោយ ដោយយកលេសថាសកម្មភាពទាំងនោះមានគោលដៅដើម្បីសន្តិភាពនិងគ្រាន់តែការពារខ្លួនប៉ុណ្ណោះ។ ជាឧទាហរណ៍ ក្នុងឆ្នាំ ១៩៨៩ ការឈ្លានពានចូលប៉ាណាម៉ា របស់សហរដ្ឋអាមេរិកត្រូវបានគេអោយឈ្មោះថា «ប្រតិបត្តិការបុព្វហេតុយុត្តិធម៌»។ ជាការពិតណាស់ ប្រសិនបើរដ្ឋណាមួយយកលេសបុព្វហេតុសីលធម៌ដើម្បីបិទបាំងផលប្រយោជន៍ផ្ទាល់ខ្លួនជាញឹកញាប់ពេក ប្រទេសនោះនឹងបាត់បង់កេរ្តិ៍ឈ្មោះទាំងក្រៅនិងក្នុងប្រទេស។

ការប្រើប្រាស់ទីតាំងភូមិសាស្ត្រសម្រាប់បំប្លែងជា «ធាតុនៃអំណាច» ត្រូវបានគេហៅថា **ភូមិសាស្ត្រនយោបាយ**។ ជារឿយៗ វាពាក់ព័ន្ធនឹងតម្រូវការដឹកជញ្ជូនកងកម្លាំងយោធា។ ក្នុងភូមិសាស្ត្រនយោបាយ ក៏ដូចនៅក្នុងវិស័យអចលនទ្រព្យដែរ កត្តាបីសំខាន់បំផុត ដែលគេត្រូវពិចារណាគឺ ទីតាំង ទីតាំង និងទីតាំង។ រដ្ឋនានាបង្កើនអំណាចរបស់ខ្លួន រហូតដល់កម្រិតមួយ ដែលពួកគេអាចប្រើប្រាស់ភូមិសាស្ត្រ ដើម្បីបង្កើនសមត្ថភាពយោធាពួកគេ ដូចជា ដោយជានាបាននូវការកៀងគរសម្ព័ន្ធមិត្តនិងដាក់មូលដ្ឋានទ័ព នៅជិតប្រទេសមហាអំណាចជាគូប្រជែង ឬ តាមបណ្តោយផ្លូវពាណិជ្ជកម្មជាយុទ្ធសាស្ត្រ ឬដោយការគ្រប់គ្រងធនធានធម្មជាតិសំខាន់ៗ។ សព្វថ្ងៃនេះ ការគ្រប់គ្រងផ្លូវបំពង់បង្ហូរប្រេង ជាពិសេសនៅអាស៊ីកណ្តាលគឺជាបញ្ហាភូមិសាស្ត្រនយោបាយដ៏សំខាន់មួយ។ អ្នកយុទ្ធសាស្ត្រយោធាក៏បានចង្អុលបង្ហាញថា ការរលាយផ្ទាំងទឹកកកទ្វីប (សូមមើលមេរៀនទី ១១) បានបើកផ្លូវដឹកជញ្ជូនថ្មីសម្រាប់គោលបំណងយោធា នឹងបង្កើតបញ្ហាភូមិសាស្ត្រនយោបាយថ្មីមួយសម្រាប់ប្រទេសរុស្ស៊ី និងសហរដ្ឋអាមេរិក។

---

[៨] Sanger, David. A Handpicked Team for a Sweeping Shift in Foreign Policy. *New York Times,* December ១, ២០០៨. Lamothe, Dan. Retired Generals Cite Past Comments from Mattis Opposing Trump's Proposed Foreign Aid Cuts. *Washington Post,* February ២៧, ២០១៧: A៩

២.៣. ប្រព័ន្ធអន្តរជាតិ

២.៣ ចូរកំណត់និយមន័យបច្ចេកពាក្យ «អនាធិបតេយ្យ» និងពន្យល់ពីរបៀបដែលវាអាចក្លាយជាឧបសគ្គរារាំងកិច្ចសហប្រតិបត្តិការអន្តរជាតិ។

រដ្ឋនានាមានទំនាក់ទំនងនឹងគ្នា ដោយអនុលោមទៅតាមចង្កោមឬសំណុំ «ច្បាប់ល្បែង» ដែលចងក្រងជាយូរមកហើយ ដោយកំណត់ថាអ្វីជារដ្ឋ និងរបៀបដែលរដ្ឋទាំងឡាយធ្វើទង្វើ ចំពោះគ្នាទៅវិញទៅមក។ ច្បាប់ទាំងនេះ រួមគ្នាបង្កើតបានជាប្រព័ន្ធអន្តរជាតិ។

២.៣.១. អនាធិបតេយ្យ និងអធិបតេយ្យភាព

អ្នកប្រាកដនិយមជឿថា ប្រព័ន្ធអន្តរជាតិប្រព្រឹត្តិទៅក្នុងស្ថានភាពអនាធិបតេយ្យ៖ បច្ចេកពាក្យដែលមិនសំដៅដល់ភាពវឹកវរឬចលាចលទាំងស្រុង ឬអវត្តមានរចនាសម្ព័ន្ធនិងច្បាប់នោះទេ ប៉ុន្តែ សំដៅដល់កង្វះខាតរដ្ឋាភិបាលកណ្តាលដែលអាចពង្រឹងការអនុវត្តច្បាប់បាន។ នៅក្នុងសង្គមផ្ទៃក្នុងរដ្ឋទាំងឡាយ រដ្ឋាភិបាលអាចពង្រឹងការអនុវត្តច្បាប់ឬកិច្ចសន្យានានា រារាំងប្រជាពលរដ្ឋពីការបំពានច្បាប់ និងអនុវត្តសិទ្ធិផ្តាច់មុខលើការប្រើប្រាស់អំពើហិង្សាផ្តន្ទាទោសតាមច្បាប់ ដើម្បីអនុវត្តប្រព័ន្ធច្បាប់។ ទាំងរបបលទ្ធិប្រជាធិបតេយ្យ និងរបបផ្តាច់ការផ្តល់នូវការពង្រឹងការអនុវត្តប្រព័ន្ធច្បាប់ដោយរដ្ឋាភិបាលកណ្តាល។ អ្នកប្រាកដនិយមអះអាងថា គ្មានអាជ្ញាធរកណ្តាលបែបនេះនៅក្នុងប្រព័ន្ធអន្តរជាតិ ដើម្បីអនុវត្តច្បាប់ និងធានាអោយបាននូវការអនុលោមតាមបទដ្ឋាននានាសម្រាប់ការប្រព្រឹត្តទៅនៃអន្តរទំនាក់ទំនងរវាងតួអង្គនានាឡើយ។ ប្រការនេះធ្វើអោយបញ្ហាផលប្រយោជន៍រួម នៅក្នុងទំនាក់ទំនងអន្តរជាតិ កាន់តែមានលក្ខណៈធ្ងន់ធ្ងរឡើងៗ។ អំណាចនៃរដ្ឋមួយត្រូវបានប្រឆាំងដោយអំណាចនៃរដ្ឋផ្សេងទៀត។ ដូច្នេះ រដ្ឋនានាត្រូវតែពឹងផ្អែកលើយុទ្ធសាស្ត្រ*ជួយខ្លួនឯង* ដែលពួកគេធានាបានដោយរួមជាមួយនឹងសម្ព័ន្ធមិត្ត ហើយ(ពេលខ្លះ)អំណាចមានកំរិតនៃបទដ្ឋានអន្តរជាតិ។

មនុស្សមួយចំនួនគិតថា មានតែរដ្ឋាភិបាលពិភពលោកទេ ដែលអាចដោះស្រាយបញ្ហានេះបាន។ អ្នកផ្សេងទៀតគិតថា សណ្តាប់ធ្នាប់ល្អគួរសម (ប្រភេទមួយនៃរដ្ឋាភិបាលពិភពលោក) អាចត្រូវបានផ្តល់ដោយអង្គការនិងកិច្ចព្រមព្រៀងអន្តរជាតិ (សូមមើលមេរៀនទី ៧)។ ប៉ុន្តែ អ្នកប្រាកដនិយមភាគច្រើនបំផុតគិតថាទំនាក់ទំនងអន្តរជាតិ មិនអាចគេចចេញពីស្ថានភាពអនាធិបតេយ្យ ហើយជាលទ្ធផល នៅតែមានលក្ខណៈគ្រោះថ្នាក់បន្តទៀត។ នៅក្នុងពិភពអនាធិបតេយ្យបែបនេះ អ្នកប្រាកដនិយមសង្កត់ធ្ងន់និងចាត់ទុកការប្រយ័ត្នប្រយែងថាជាគុណធម៌ដ៏ប្រសើរ ក្នុងនយោបាយការបរទេស។ ដូចនេះ រដ្ឋមិនគួរតែយកចិត្តទុកដាក់ ខ្លាំងពេកទៅលើចេតនារបស់រដ្ឋផ្សេងទៀតទេ ប៉ុន្តែត្រូវយកចិត្តទុកដាក់លើសមត្ថភាពរបស់ពួកគេ។

ទោះបីជាមានភាពអនាធិបតេយ្យក៏ដោយ ប្រព័ន្ធអន្តរជាតិនៅឆ្ងាយពីសភាពវឹកវរ។ ភាគច្រើននៃអន្តរកម្មនៃរដ្ឋនានាប្រកាន់ខ្ជាប់យ៉ាងជិតស្និទ្ធទៅនឹង**បទដ្ឋាន**អាកប្បកិរិយា៖ ការរំពឹងទុករួមអំពីអាកប្បកិរិយាដែលត្រូវបានចាត់ទុកថាត្រឹមត្រូវឬអត់។ បទដ្ឋាននីមួយៗប្រែប្រួលអាស្រ័យតាមពេលវេលា បន្តិចម្តងៗ ប៉ុន្តែបទដ្ឋានជាមូលដ្ឋានគ្រឹះនៃប្រព័ន្ធអន្តរជាតិបានផ្លាស់ប្តូរតិចតួចក្នុងប៉ុន្មានសតវត្សថ្មីៗនេះ។

អធិបតេយ្យភាព ដែលជាបទដ្ឋានជាប្រពៃណីដ៏សំខាន់បំផុត មានន័យថា រដ្ឋាភិបាល ជាគោលការណ៍មានសិទ្ធិធ្វើអ្វីតាមចិត្តចង់ នៅក្នុងទឹកដីរបស់ខ្លួន។ រដ្ឋជាអង្គភាពដាច់ដោយឡែក មានស្វយ័តភាព និងមិនស្ថិតក្រោមអំណាចណាមួយឡើយ។ ជាគោលការណ៍ រដ្ឋទាំងអស់មានឋានៈស្មើៗគ្នា បើទោះជាមិនមានអំណាចស្មើគ្នាក្តី។ អធិបតេយ្យភាពក៏មានន័យថា រដ្ឋមួយត្រូវបានគេរំពឹងថា នឹងជ្រៀតជ្រែក កិច្ចការផ្ទៃក្នុង

របស់រដ្ឋមួយទៀតទេ។ ទោះបីជារដ្ឋនានាព្យាយាមដាក់ឥទ្ធិពលលើគ្នាទៅវិញទៅមក (ប្រើអំណាច) លើបញ្ហាពាណិជ្ជកម្ម សម្ព័ន្ធភាព សង្គ្រាម និងអ្វីៗផ្សេងទៀតក៏ដោយ ក៏គេមិនត្រូវជ្រៀតជ្រែកក្នុងនយោបាយផ្ទៃក្នុង និងដំណើរការសម្រេចចិត្តរបស់រដ្ឋផ្សេងទៀតដែរ។ កាន់តែចម្រូងចម្រាសជាងនេះទៅទៀត រដ្ឋមួយចំនួនបានអះអាងថា បទដ្ឋានអធិបតេយ្យភាពផ្តល់សិទ្ធិអោយពួកគេធ្វើអ្វីគ្រប់បែបយ៉ាង ទៅលើប្រជាជនរបស់ខ្លួន រួមទាំងអាកប្បកិរិយាដែលរដ្ឋផ្សេងទៀតហៅថាអំពើប្រល័យពូជសាសន៍។

រូបថត ជនជាតិអ៊ុយក្រែនតំរង់ជួរចូលប្រទេសប៉ូឡូញ

លិខិតឆ្លងដែន

អធិបតេយ្យភាព និងបូរណភាពទឹកដី គឺជាបទដ្ឋានស្នូលដែលគ្រប់គ្រងអាកប្បកិរិយារបស់រដ្ឋ។ អំពើភេរវកម្ម និងចលនាអបគមន៍បង្ហាញពីបញ្ហាប្រឈមពីរ ចំពោះបទដ្ឋានទាំងនេះ ប៉ុន្តែព្រំដែនដែលមានស្ថេរភាពបំផុតរបស់ពិភពលោកលើកតម្កើងបទដ្ឋានស្នូលទាំងពីរ។ ជារៀងរាល់ថ្ងៃ មនុស្សរាប់លាននាក់ឆ្លងកាត់ព្រំដែនអន្តរជាតិ ភាគច្រើនដោយស្របច្បាប់ និងដោយសន្តិវិធី ដោយគោរពបូរណភាពទឹកដីរបស់រដ្ឋ។ នៅទីនេះ ជនជាតិអ៊ុយក្រែនរាប់រយនាក់តម្រង់ជួរយ៉ាងវែងដើម្បីចូលប្រទេសប៉ូឡូញ នៅថ្ងៃដំបូងដែលតម្រូវការទិដ្ឋាការសម្រាប់ការធ្វើដំណើររវាងអ៊ុយក្រែន និងសហភាពអឺរ៉ុបត្រូវបានលុបចោលនៅឆ្នាំ ២០១៧ ។

អវត្តមាន«ប៉ូលីសពិភពលោក» ដើម្បីដាក់ទណ្ឌកម្មរដ្ឋនានា ក្នុងករណីពួកគេបំពានកិច្ចព្រមព្រៀងបណ្តាលអោយមានការពិបាកក្នុងការអនុវត្តកិច្ចព្រមព្រៀងអន្តរជាតិ។ ជាឧទាហរណ៍ នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ ប្រទេសកូរ៉េខាងជើងបានប្រកាសថា ខ្លួននឹងមិនអនុញ្ញាតអោយមានការត្រួតពិនិត្យទីតាំងនុយក្លេអ៊ែរបស់ខ្លួនដោយរដ្ឋផ្សេងទៀត នោះមានន័យថា ប្រទេសមួយនេះបំពានលើសន្ធិសញ្ញាមិនរីកសាយភាយអាវុធនុយក្លេអ៊ែរ (NPT)។ សហគមន៍អន្តរជាតិបានប្រើប្រាស់ទាំងការលើកទឹកចិត្តជាវិជ្ជមាន និងទាំងការគម្រាមកំហែងជាច្រើន ដើម្បីបញ្ចុះបញ្ចូលកូរ៉េខាងជើងអោយឈប់ផលិតសម្ភារៈនុយក្លេអ៊ែរ។ ប៉ុន្តែ នៅឆ្នាំ ២០០២ ប្រទេសកូរ៉េខាងជើងបានដកខ្លួនចេញពី សន្ធិសញ្ញាមិនរីកសាយភាយអាវុធនុយក្លេអ៊ែរ ហើយបានផលិតគ្រាប់បែកនុយក្លេអ៊ែរ ចំនួនកន្លះឡូ ដែលមួយក្នុងចំណោមនោះ បានផ្ទុះ នៅឆ្នាំ ២០០៦ (ការសាកល្បងនុយក្លេអ៊ែរ លើកដំបូងក្នុងពិភពលោក ក្នុងរយៈពេលមួយទសវត្សរ៍)។ បន្ទាប់ពីបានឈានដល់កិច្ចព្រមព្រៀងជាមួយសហរដ្ឋអាមេរិក ដើម្បីបញ្ឈប់ការផលិតអាវុធនុយក្លេអ៊ែរក្នុងឆ្នាំ ២០០៨ កូរ៉េខាងជើងបានបដិសេធមិនអនុញ្ញាតអោយមានការត្រួតពិនិត្យដោយផ្ទាល់ លើរោងចក្រនុយក្លេអ៊ែរមួយចំនួនរបស់ខ្លួន ដោយប្រកែកដោះសារថា «វាគឺជាសកម្មភាពរំលោភលើអធិបតេយ្យភាព»។[៩] ប្រទេសកូរ៉េខាងជើងបានបន្តកម្មវិធីនុយក្លេអ៊ែរនិងប្រព័ន្ធបញ្ជូនមីស៊ីលរបស់ខ្លួននៅឆ្នាំបន្តបន្ទាប់ ដោយបានធ្វើការបាញ់សាកល្បងថែមទៀតនៅឆ្នាំ ២០១៦ និង ២០១៧។ ឧទាហរណ៍ទាំងនេះបង្ហាញពីការលំបាកក្នុងពង្រឹងការអនុវត្តបទដ្ឋានអន្តរជាតិ នៅក្នុងប្រព័ន្ធអន្តរជាតិ ដែលផ្អែកលើអធិបតេយ្យភាព។

នៅក្នុងការអនុវត្តជាក់ស្តែង រដ្ឋភាគច្រើនជួបប្រទះការលំបាកកាន់តែខ្លាំងជាងមុនក្នុងការទប់ស្កាត់ការជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់ខ្លួន។ បញ្ហា«ផ្ទៃក្នុង» ដូចជា សិទ្ធិមនុស្ស ឬការសម្រេចដោតវាសនាជាតិដោយខ្លួនឯង គឺជាកង្វល់កាន់តែធំទៅៗ សម្រាប់សហគមន៍អន្តរជាតិ។ ជាឧទាហរណ៍ អ្នកឃ្លាំមើលការ

[៩] *BBC News Online*. (November ១២, ២០០៨). N Korea rejects nuclear sampling.

បោះឆ្នោតតែងតែសង្កេតមើលការលួចបន្លំ នៅក្នុងការបោះឆ្នោតផ្ទៃក្នុង ខណៈដែលអង្គការអន្តរជាតិឃ្លាំមើលជម្លោះជាតិសាសន៍ក្រែងលោមានការប្រល័យពូជសាសន៍។ នៅក្នុងន័យនេះផងដែរ សមាហរណកម្មទីផ្សារសេដ្ឋកិច្ចសកលលោក និងទូរគមនាគមន៍ (ដូចជាអ៊ីនធឺណិត) ធ្វើអោយគំនិតឬទស្សនៈផ្សេងៗកាន់តែងាយស្រួលជ្រៀតចូលក្នុងព្រំដែនរដ្ឋនានា ជាងពេលណាៗទាំងអស់។

រដ្ឋនីមួយៗត្រូវពឹងផ្អែកលើទឹកដី។ ការគោរពចំពោះបូរណភាពទឹកដីនៃរដ្ឋទាំងអស់, នៅក្នុងព្រំដែនដែលត្រូវបានទទួលស្គាល់ គឺជាគោលការណ៍ដ៏សំខាន់ក្នុងទំនាក់ទំនងអន្តរជាតិ។ ព្រំដែនជាច្រើននាពេលបច្ចុប្បន្ននេះ គឺជាលទ្ធផលនៃសង្គ្រាមអតីតកាល (ដែលក្នុងនោះ ប្រទេសជោគជ័យបានរឹបអូសយកទឹកដីពីប្រទេសបរាជ័យ) ឬត្រូវបានមហាអាណានិគមគូសព្រំដែនតាមអំពើចិត្ត។

ធម្មជាតិនៃការបែងចែកទឹកដីនៃប្រព័ន្ធអន្តររដ្ឋត្រូវបានអភិវឌ្ឍ តាំងពីយូរយោរណាស់មកហើយ នៅពេលដែលទំរង់សង្គមកសិកម្មបានពឹងផ្អែកលើវិស័យកសិកម្ម ដើម្បីបង្កើតទ្រព្យសម្បត្តិ។ នៅក្នុងពិភពលោកសម័យបច្ចុប្បន្ន ដែលពាណិជ្ជកម្មនិងបច្ចេកវិទ្យាបង្កើតទ្រព្យសម្បត្តិច្រើនជាងដីធ្លី រដ្ឋដែលត្រូវអាស្រ័យលើដែនដីប្រហែលជាមិនសូវសំខាន់ទេ។ សេដ្ឋកិច្ចដែលពឹងផ្អែកលើព័ត៌មានត្រូវបានតភ្ជាប់ឆ្លងពីព្រំដែនមួយទៅព្រំដែនដទៃទៀតយ៉ាងឆាប់រហ័ស ហើយទស្សនៈដែលថារដ្ឋនានាមានសំបកឬស្នូករឹងហាក់ដូចជាចាស់គំរិលហើយ។ បដិវត្តន៍បច្ចេកវិទ្យាព័ត៌មានកាន់តែលឿនទៅៗ អាចជះឥទ្ធិពលយ៉ាងខ្លាំងដល់ប្រព័ន្ធរដ្ឋដែលពឹងផ្អែកលើដែនដី នៅក្នុងប៉ុន្មានឆ្នាំខាងមុខនេះ។

រដ្ឋទាំងឡាយបានបង្កើតបទដ្ឋានការទូត ដើម្បីសម្រួលដល់អន្តរកម្មរបស់ពួកគេ។ ស្ថានទូតត្រូវបានគេចាត់ទុកថាជា ដែនដីនៃរដ្ឋបរទេសនោះ មិនមែនរបស់ប្រទេសដែលស្ថានទូតនោះតាំងនៅនោះទេ (សូមមើលមេរៀនទី ៤)។ ជាឧទាហរណ៍ ក្នុងឆ្នាំ ២០១២ នៅពេលដែលស្ថានទូតអេក្វាឌ័រនៅក្នុងចក្រភពអង់គ្លេសបានរារាំងស្ថាបនិកវែបសាយផ្សព្វផ្សាយឯកសារសម្ងាត់ វីគីលីក (Wikileaks) ដែលត្រូវបានបញ្ជាអោយធ្វើបត្យាប័នទៅប្រទេសស៊ុយអែត អាជ្ញាធរអង់គ្លេសមិនចេះតែសម្រុកចូលអូសគាត់ចេញបាននោះទេ។ ការធ្វើដូច្នេះអាចនឹងបំពានលើបូរណភាពទឹកដីរបស់ប្រទេសអេក្វាឌ័រ។ ប៉ុន្តែ នៅឆ្នាំ ១៩៧៩ និស្សិតអ៊ីរ៉ង់បានចូលកាន់កាប់ស្ថានទូតអាមេរិក នៅក្នុងប្រទេសអ៊ីរ៉ង់ ដោយបានចាប់អ្នកការទូតជាច្រើននាក់ធ្វើជាចំណាប់ខ្មាំងអស់រយៈពេល ៤៤៤ ថ្ងៃ ដែលជាព្រឹត្តិការណ៍មួយដែលបានបណ្តាលអោយទំនាក់ទំនងរវាងអាមេរិកនិងអ៊ីរ៉ង់កាន់តែយ៉ាប់ឃឺន តាំងពីពេលនោះមក។

បទដ្ឋានការទូតទទួលស្គាល់ការពិតដែលថា រដ្ឋនានាព្យាយាមឈ្លបយកការណ៍ ពីគ្នាទៅវិញទៅមក។ រដ្ឋនីមួយៗមានទំនួលខុសត្រូវក្នុងការទប់ស្កាត់រដ្ឋដទៃទៀតមិនអោយធ្វើចារកម្មមកលើខ្លួន។ ក្នុងឆ្នាំ ២០០២ ប្រទេសចិនបានរកឃើញថា យន្តហោះប្រធានាធិបតីថ្មីរបស់ខ្លួន ដែលជាយន្តហោះ ប្រភេទ Boeing ៧៦៧ ដែលត្រូវបានកែដុសខាត់កែលម្អ នៅក្នុងរដ្ឋតិចសាស់(Texas) ក្នុងសហរដ្ឋអាមេរិក ត្រូវបានបង្កប់ដោយឧបករណ៍តាមដានស្តាប់ជាសម្ងាត់ដ៏ទំនើប។ ក៏ប៉ុន្តែ ប្រទេសចិនមិនបានលើកយករឿងនេះបង្កបញ្ហានេះទេ (យន្តហោះមិនត្រូវបានដាក់អោយដំណើរការ) ហើយកិច្ចប្រជុំកំពូលរវាងមេដឹកនាំសហរដ្ឋអាមេរិក និងចិននៅខែបន្ទាប់ បានដំណើរការ តាមការគ្រោងទុក។ នៅក្នុងយុគសម័យក្រោយសង្គ្រាមត្រជាក់ ការធ្វើចារកម្មនៅតែបន្ត សូម្បីតែរវាងរដ្ឋជាមិត្តក៏ដោយ។

អ្នកប្រាកដនិយមទទួលស្គាល់ថាក្បួនច្បាប់ក្នុងទំនាក់ទំនងអន្តរជាតិ តែងតែបង្កើតជាបញ្ហាសន្តិសុខ ទ្វេគ្រោះ។ វាសំដៅលើ ស្ថានភាពមួយដែលសកម្មភាពរបស់រដ្ឋមួយបានធ្វើឡើងដើម្បីធានាសុវត្ថិភាពផ្ទាល់ខ្លួន (ដូចជា ការដាក់ពង្រាយកម្លាំងទ័ពបន្ថែមទៀត) គំរាមកំហែងដល់សន្តិសុខរបស់រដ្ឋផ្សេងទៀត។ ការឆ្លើយតបរបស់រដ្ឋផ្សេងទៀតនោះ ដូចជាការដាក់ពង្រាយកងកម្លាំងទ័ពរបស់ខ្លួន អាចប្រែជាការគំរាមកំហែងដល់រដ្ឋដើមដំបូង។ ទ្វេគ្រោះគឺជាមូលហេតុចម្បងនៃការប្រណាំងប្រជែងសព្វាវុធដែលរដ្ឋចំណាយប្រាក់យ៉ាងច្រើនសន្ធឹកសន្ធាប់ទៅលើអាវុធដែលគំរាមកំហែងគ្នាទៅវិញទៅមក ដែលចុងក្រោយមិនអាចផ្តល់សុវត្ថិភាពដល់រដ្ឋណាមួយឡើយ។

ទ្វេគ្រោះសន្តិសុខ គឺជាលទ្ធផលអវិជ្ជមាននៃភាពអនាធិបតេយ្យ នៅក្នុងប្រព័ន្ធអន្តរជាតិ។ ប្រសិនបើរដ្ឋាភិបាលពិភពលោកអាចរកឃើញ និងដាក់ទោសអ្នកឈ្លានពានដែលបំពាក់អាវុធ ដោយភាពជឿជាក់ រដ្ឋនានានឹងមិនចាំបាច់ទប់ទល់នឹងលទ្ធភាពនេះទេ។ ប៉ុន្តែ ប្រព័ន្ធជួយខ្លួនឯង ទាមទារអោយរដ្ឋរៀបចំ ទប់ទល់ស្ថានភាពអាក្រក់បំផុតដែលអាចនឹងកើតឡើងចំពោះខ្លួន។ អ្នកប្រាកដនិយមហាក់មើលឃើញថា បញ្ហាទ្វេគ្រោះនេះ មិនអាចដោះស្រាយបានទេ ចំណែកឯអ្នកសេរីនិយមគិតថា វាអាចត្រូវបានដោះស្រាយតាមរយៈការអភិវឌ្ឍន៍ស្ថាប័ននិយម (សូមមើលមេរៀនទី ៣ និងទី ៧)។

ដូចដែលយើងនឹងឃើញនៅក្នុងមេរៀនក្រោយៗ ការផ្លាស់ប្តូរបច្ចេកវិទ្យានិងបទដ្ឋាន កំពុងធ្វើរំខានដល់គោលការណ៍ជាប្រពៃណីស្តីពីបូរណភាពទឹកដី និងស្វ័យភាពរបស់រដ្ឋ នៅក្នុងទំនាក់ទំនងអន្តរជាតិ។ អ្នកប្រាជ្ញទំនាក់ទំនងអន្តរជាតិមួយចំនួនយល់ថា រដ្ឋលែងជាតួអង្គឯកនៅក្នុងនយោបាយពិភពលោកទៀតហើយ ដោយសាររដ្ឋមួយចំនួនបានរួមបញ្ចូលគ្នាជាអង្គភាពឬអង្គការធំៗ ហើយខ្លះទៀតបំបែកទៅជាអង្គភាពតូចៗ។ អ្នកប្រាជ្ញផ្សេងទៀតយល់ឃើញថា ប្រព័ន្ធអន្តរជាតិមានរចនាសម្ព័ន្ធស្ថិតស្ថេរ ហើយអង្គភាពរដ្ឋក៏ដូច្នោះដែរ។ លក្ខណៈពិសេសមួយក្នុងចំណោមលក្ខណៈពិសេសដែលស្ថិតស្ថេរបស់វាគឺ តុល្យភាពអំណាច។

២.៣.២. តុល្យភាពអំណាច

នៅក្នុងស្ថានភាពអនាធិបតេយ្យក្នុងប្រព័ន្ធអន្តរជាតិ ហ្រ្វាំងដែលអាចទុកចិត្តបំផុតទប់ស្កាត់អំណាចនៃរដ្ឋមួយគឺជាអំណាចនៃរដ្ឋផ្សេងទៀត។ បច្ចេកពាក្យ **តុល្យភាពអំណាច** សំដៅលើគោលគំនិតទូទៅនៃអំណាចរបស់រដ្ឋមួយឬច្រើន ដែលត្រូវបានប្រើប្រាស់ដើម្បីរក្សាតុល្យភាពជាមួយនឹងអំណាចរបស់រដ្ឋឬក្រុមរដ្ឋផ្សេងទៀត។ តុល្យភាពអំណាចអាចសំដៅទៅលើសមាមាត្រនៃសមត្ថភាពអំណាចទាំងឡាយរវាងរដ្ឋឬសម្ព័ន្ធភាព ឬវាអាចមានន័យថាត្រឹមតែសមាមាត្រស្មើគ្នាប៉ុណ្ណោះ។ ម៉្យាងទៀត តុល្យភាពអំណាចអាចសំដៅទៅលើ*ដំណើរការ*ដែលក្រុមសម្ព័ន្ធមិត្តនានាបង្កើតឡើង ម្តងហើយម្តងទៀត ក្នុងប្រវត្តិសាស្ត្រ ដើម្បីទប់ទល់នឹងរដ្ឋណាតែមួយកុំអោយដណ្តើមយកតំបន់ទាំងមូលគ្រប់គ្រង។

ទ្រឹស្តីតុល្យភាពអំណាចអះអាងថា តុល្យភាពប្រឆាំងតបតបែបនេះកើតឡើងជាទៀងទាត់ និងរក្សាស្ថេរភាពនៃប្រព័ន្ធអន្តរជាតិ។ ប្រព័ន្ធអន្តរជាតិមានស្ថេរភាព ដោយក្នុងនោះ ច្បាប់និងគោលការណ៍របស់វានៅរក្សាដូចមុនដដែលៈ អធិបតេយ្យភាពរបស់រដ្ឋនីមួយៗមិនដួលរលំហើយរលាយចូលគ្នាដោយក្លាយទៅជាចក្រភពសកលរួមតែមួយបានទេ។ យ៉ាងណាមិញ ស្ថេរភាពបែបនេះមិនមានន័យថាសន្តិភាពឡើយ។ វាគឺជាស្ថេរភាពមួយប្រភេទណា ដែលរក្សាបានដោយមធ្យោបាយសង្គ្រាមកើតឡើងដដែលៗ ដែលកែសម្រួលទំនាក់ទំនងអំណាច។

សម្ព័ន្ធភាព (នឹងត្រូវពិភាក្សានៅក្នុងចំណុចបន្ទាប់) ជើរតួនាទីយ៉ាងសំខាន់ ក្នុងការរក្សាតុល្យភាព អំណាច។ ការកសាងសមត្ថភាពផ្ទាល់ខ្លួនទប់ទល់នឹងគូប្រកួតប្រជែង គឺជាទម្រង់មួយនៃតុល្យភាពអំណាច ប៉ុន្តែ ការបង្កើតសម្ព័ន្ធភាពដើម្បីទប់ទល់នឹងរដ្ឋដែលកំពុងគំរាមកំហែង អាចកើតឡើង លឿនជាង ថោកជាង និងមានប្រសិទ្ធភាពជាង។ នៅក្នុងកំឡុងសម័យសង្គ្រាមត្រជាក់ សហរដ្ឋអាមេរិកបានឡោមព័ទ្ធសហភាព សូវៀត ដោយសម្ព័ន្ធភាពយោធានិងនយោបាយ ដើម្បីទប់ស្កាត់ការពង្រីកទឹកដីពីសំណាក់សហភាពសូវៀត។ ជួនកាល រដ្ឋណាមួយអាចក្លាយជាអ្នករក្សាតុល្យភាព (ក្នុងតំបន់ ឬក្នុងពិភពលោកទាំងមូល)យ៉ាងច្បាស់ ក្រឡែត ដោយផ្លាស់ប្តូរគោលជំហរគាំទ្ររបស់ខ្លួន ដើម្បីប្រឆាំងនឹងរដ្ឋឬសម្ព័ន្ធភាពដ៏ខ្លាំងបំផុត នៅកំឡុង ពេលនោះ។ ចក្រភពអង់គ្លេសបានដើរតួនាទីបែបនេះ នៅលើទ្វីបអឺរ៉ុប ក្នុងរយៈពេលជាច្រើនសតវត្សរ៍មក ហើយ ហើយម្យ៉ាងទៀត ប្រទេសចិនក៏បានដើរតួនាទីបែបនេះក្នុងសង្គ្រាមត្រជាក់ដែរ។


ប៉ុន្តែ រដ្ឋមិនតែងតែរក្សាតុល្យភាពអំណាចទប់ទល់នឹងតួអង្គខ្លាំងបំផុតនោះទេ។ ពេលខ្លះ រដ្ឋតូចៗ ទាំងឡាយ«រត់ឡើងរទេះ»របស់រដ្ឋដែលមានឥទ្ធិពលខ្លាំងបំផុត ទង្វើបែបនេះត្រូវបានគេហៅថា *ការជ្រួតគ្នា* (bandwagoning) ដែលផ្ទុយទៅពីការរក្សាតុល្យភាព។ ជាឧទាហរណ៍ ក្រោយសង្គ្រាមលោកលើកទី២ សម្ព័ន្ធភាពដ៏ទូលំទូលាយមួយ ត្រូវបានបង្កើតឡើង មិនមែនដើម្បីទប់ទល់ការបង្រីកអំណាចរបស់សហរដ្ឋ អាមេរិកទេ ផ្ទុយទៅវិញ រដ្ឋធំៗភាគច្រើនបានរត់ទៅចូលរួមជាមួយប្លុកអាមេរិក។ រដ្ឋអាចស្វែងរកតុល្យភាពនៃ ការគំរាមកំហែង ជាជាងអំណាចដោយផ្ទាល់។ ជាឧទាហរណ៍ អំណាចរបស់សហរដ្ឋអាមេរិកខ្លាំងជាងអំណាច សហភាពសូវៀត ប៉ុន្តែអំណាចអាមេរិកមិនសូវគំរាមកំហែងដល់អឺរ៉ុប និងជប៉ុនទេ (ហើយក្រោយមកទៀត ដល់ប្រទេសចិនផងដែរ)។ លើសពីនេះ រដ្ឋតូចៗមួយចំនួនបង្កើតបានជាអវេរក្សាតុល្យភាពអំណាច នៅ ពេលដែលពួកគេអូសទាញប្រទេសមហាអំណាចជាគូបដិបក្ខអោយប្រឆាំងនឹងគ្នា។ ជាឧទាហរណ៍ ក្នុងអំឡុង សង្គ្រាមត្រជាក់ ប្រទេសគុយបាបានទទួលការឧបត្ថម្ភធន យ៉ាងច្រើនសន្ធឹកសន្ធាប់ ពីសហភាពសូវៀត ដោយដាក់ខ្លួនឯង នៅចំចំណុចកណ្តាលនៃការប្រកួតប្រជែងរវាងសហរដ្ឋអាមេរិក និងសហភាពសូវៀត។ ទន្ទឹមនឹងនេះ រដ្ឋតូចៗផ្សេងទៀតអាចបរាជ័យក្នុងការកៀងគរ ដើម្បីរក្សាតុល្យភាពអំណាចប្រឆាំងនឹងការ គំរាមកំហែងពីខាងក្រៅ។

នៅក្នុងយុគសម័យក្រោយសង្គ្រាមត្រជាក់ ដែលមានសហរដ្ឋអាមេរិក ជាប្រទេសមហាអំណាចលេច ធ្លោជាងគេ ទ្រឹស្តីតុល្យភាពអំណាចបានព្យាករណ៍ថា នឹងមានទំនាក់ទំនងកាន់តែជិតស្និទ្ធរវាងប្រទេសរុស្ស៊ី ប្រទេសចិន និងសូម្បីតែអឺរ៉ុប ដើម្បីធ្វើអោយមានតុល្យភាពអំណាចជាមួយនឹងសហរដ្ឋអាមេរិក។ ជាការពិត ណាស់ ទំនាក់ទំនងរុស្ស៊ី-ចិនបានប្រសើរឡើងយ៉ាងខ្លាំង ក្នុងវិស័យជាច្រើន ដូចជា ពាណិជ្ជកម្មសព្វាអាវុធ និងការបន្តយវត្តមានយោធា នៅតាមព្រំដែនរួម។ ហើយសូម្បីតែមេដឹកនាំបារាំងក៏បានរិះគន់សហរដ្ឋអាមេរិក ថាជា«មហាអំណាចជ្រុលហួសហេតុ»ផងដែរ។ ប៉ុន្តែ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ជាមួយនឹង អំណាចរបស់សហរដ្ឋអាមេរិកហាក់បីដូចជាមានសភាពស្តើងទៅៗ នៅប្រទេសអាហ្វហ្គានីស្ថាន និងប្រទេស អ៊ីរ៉ាក់ សេដ្ឋកិច្ចរបស់អាមេរិកចុះខ្សោយ ហើយអំណាចរបស់ប្រទេសចិនកើនឡើង ហើយប្រទេសកាន់តែច្រើន ឡើងខំប្រឹងរក្សាតុល្យភាពទប់ទល់នឹងអំណាចប្រទេសចិន ហើយចំនួនរដ្ឋតិចជាងនេះទប់ទល់នឹងអំណាច សហរដ្ឋអាមេរិក។ ក្នុងចន្លោះឆ្នាំ ២០១២-២០១៣ ប្រទេសជប៉ុនបានធ្វើកិច្ចព្រមព្រៀងយោធាជាមួយអតីត បច្ចាមិត្ត ដូចជា ប្រទេសកូរ៉េខាងត្បូង និងប្រទេសហ្វីលីពីន ហើយបានប្រកាសអះអាងឡើងវិញនូវ

ទំនាក់ទំនងស្និតរមួតជាមួយនឹងសហរដ្ឋអាមេរិក ដែលទង្វើទាំងអស់នេះជាការឆ្លើយតបទៅនឹងអំណាចដែលកំពុងកើនឡើងរបស់ចិន។

ក្រាហ្វិក ២.២. សាធារណៈមតិចំពោះសហរដ្ឋអាមេរិកនៅក្នុងប្រទេសចំនួន ៦ (២០០២-២០១៧)

(ភាគរយនៃមតិវិជ្ជមាន នៅក្នុងការស្ទង់មតិសាធារណៈ)



ប្រភព៖ គំរោងឥរិយាបថសកល Pew ទិន្នន័យឆ្នាំ ២០០០ បានពីការស្ទង់មតិរបស់ក្រសួងការបរទេស

មតិសាធារណៈនៅទូទាំងពិភពលោកក៏ឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរតុល្យភាពអំណាចផងដែរ (សូមមើលឧទាហរណ៍បន្ថែមនៃមតិសាធារណនិងទំនាក់ទំនងអន្តរជាតិ)។ នៅឆ្នាំ ២០០៣ នៅពេលដែលសង្គ្រាមអ៊ីរ៉ាក់បានចាប់ផ្តើម មនោសញ្ចេតនាប្រឆាំងអាមេរិក ដែលកំពុងរីករាលដាលខ្លាំង បានបង្ហាញខ្លួននៅក្នុងបណ្តាប្រទេសមូស្លីម។ នៅក្នុងប្រទេសឥណ្ឌូនេស៊ី ប្រទេសប៉ាគីស្ថាន ប្រទេសទួរគី និងប្រទេសនីហ្សេរីយ៉ា ដែលមានអ្នកកាន់សាសនាឥស្លាមចំនួនពាក់កណ្តាលនៃចំនួនជនមូស្លីមនៅលើពិភពលោក មតិសាធារណៈ ជាង៧០ ភាគរយ បានព្រួយបារម្ភថា សហរដ្ឋអាមេរិកអាចក្លាយជាការគំរាមកំហែងដល់ប្រទេសរបស់ពួកគេ ដែលជាការព្រួយបារម្ភរបស់ប្រជាជនរុស្ស៊ី ចំនួន ៧១ ភាគរយផងដែរ។ ការស្ទង់មតិលើមនុស្ស ៣៨,០០០ នាក់ នៅក្នុងប្រទេសចំនួន ៤៤ បានបង្ហាញពីការធ្លាក់ចុះការគាំទ្រសម្រាប់សហរដ្ឋអាមេរិក យ៉ាងខ្លាំង ពីឆ្នាំ ២០០២ ដល់ឆ្នាំ ២០០៣។ ដូចដែលតួលេខ ២.២ ចង្អុលបង្ហាញ, ការធ្លាក់ចុះប្រជាប្រិយភាពរបស់សហរដ្ឋអាមេរិកនៅទូទាំងពិភពលោក បានបន្តរហូតដល់ឆ្នាំ ២០០៧។ បន្ទាប់មក ក្រោយឆ្នាំ ២០០៨ ដោយសហរដ្ឋអាមេរិកកំពុងស្វែងរកច្រកដកថយពីសង្គ្រាមរបស់ខ្លួន និងប្រើប្រាស់អំណាចរបស់ខ្លួនដោយបង្ខំ តិចជាងមុន នៅជុំវិញពិភពលោក មតិសាធារណៈវិជ្ជមានបានកើនឡើងវិញ។ ថ្មីៗនេះ សាធារណមតិចំពោះសហរដ្ឋអាមេរិកបានប្រែប្រួលយ៉ាងខ្លាំងក្នុងរដ្ឋមួយចំនួន(ដូចជារុស្ស៊ី) ប៉ុន្តែចាប់ផ្តើមធ្លាក់ចុះវិញនៅក្នុងរដ្ឋដែលតាមប្រពៃណីកន្លងមក ធ្លាប់តែស្និទ្ធស្នាលជាមួយនឹងសហរដ្ឋអាមេរិក។ ការផ្លាស់ប្តូរទិសដៅមតិសាធារណៈទាំងនេះអាចជាមូលហេតុផងនិងឥទ្ធិពលផង នៅក្នុងនយោបាយអន្តរជាតិ។ មតិសាធារណៈអាចធ្វើអោយរដ្ឋាភិបាលក្នុងប្រទេសទាំងនោះ ទំនងជារួមសហការជាមួយនឹងសហរដ្ឋអាមេរិក នៅលើឆាកពិភពលោក ហើយមតិ

សាធារណៈនៅក្នុងប្រទេសទាំងនេះអាចប្រែប្រួល ដោយអាស្រ័យលើកត្តាថាតើមានកិច្ចសហប្រតិបត្តិការ (ឬអរិភាព)ជាមួយនឹងសហរដ្ឋអាមេរិក។

២.៣.៣. ប្រទេសមហាអំណាច និងប្រទេសអំណាចមធ្យម

ប្រទេសមហាអំណាចធំៗបំផុតនៅលើពិភពលោក បញ្ចេញឥទ្ធិពលភាគច្រើនលើព្រឹត្តិការណ៍អន្តរជាតិ ដូច្នេះហើយទទួលបានការចាប់អារម្មណ៍ច្រើនបំផុតពីអ្នកប្រាជ្ញទំនាក់ទំនងអន្តរជាតិ។ ទោះបីជាមិនមានបន្ទាត់បែងចែកច្បាស់លាស់ក៏ដោយ ជាទូទៅ **ប្រទេសមហាអំណាច**ត្រូវបានគេរាប់ញ្ចូលរដ្ឋ ប្រហែលកន្លះឡូ ដែលមានអំណាចខ្លាំងបំផុត។ រហូតដល់សតវត្សរ៍ទី ២០ ក្លឹបនៃប្រទេសមហាអំណាចមានតែនៅទ្វីបអឺរ៉ុបប៉ុណ្ណោះ។ ជួនកាល ហានៈប្រទេសមហាអំណាចត្រូវបានទទួលស្គាល់ជាផ្លូវការ នៅក្នុងរចនាសម្ព័ន្ធអន្តរជាតិ ដូចជាសមាជអឺរ៉ុប (Concert of Europe) ក្នុងសតវត្សរ៍ទី១៩ ឬ ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ នាពេលបច្ចុប្បន្ននេះ។ ជាទូទៅ ប្រទេសមហាអំណាចច្រើនតែត្រូវបានកំណត់ថាជា រដ្ឋដែលអាចត្រូវបានបំបាក់ដោយកងកម្លាំងយោធារបស់ប្រទេសមហាអំណាចមួយផ្សេងទៀត តែប៉ុណ្ណោះ។ ប្រទេសមហាអំណាចនានាក៏មានទំនោរទស្សនវិស័យសកលដូចគ្នា ដោយផ្អែកលើផលប្រយោជន៍ជាតិរៀងៗខ្លួន ដែលនៅឆ្ងាយពីទឹកដីកំណើតរបស់ពួកគេ។


ជាទូទៅ ប្រទេសមហាអំណាចមានកងកម្លាំងយោធាខ្លាំងបំផុតនៅលើពិភពលោក ហើយក៏មានកម្លាំងសេដ្ឋកិច្ចខ្លាំងបំផុតដើម្បីចំណាយលើយោធារបស់ខ្លួន ក៏ដូចជាមានសមត្ថភាពអំណាចផ្សេងទៀត។ ហើយសេដ្ឋកិច្ចដ៏ខ្លាំងក្លាបែបនេះ ត្រូវអាស្រ័យទៅលើការរួមបញ្ចូលគ្នានៃចំនួនប្រជាជនដ៏ច្រើនសន្ធឹកសន្ធាប់ ធនធានធម្មជាតិដ៏សម្បូរបែប បច្ចេកវិទ្យាទំនើប និងកម្លាំងពលកម្មដែលមានកម្រិតអប់រំខ្ពស់។ ដោយសារតែអំណាចត្រូវពឹងផ្អែកលើធនធានជាមូលដ្ឋានទាំងនេះ សមាជិកភាពនៅក្នុងប្រព័ន្ធប្រទេសមហាអំណាចបានផ្លាស់ប្តូរយឺតបំផុតៗ។ បើទោះជាត្រូវបរាជ័យនៅក្នុងសង្គ្រាមដ៏ធំក៏ដោយ ជារឿងកម្រណាស់ដែលប្រទេសមហាអំណាចមួយបាត់បង់ឋានៈរបស់ខ្លួនជាប្រទេសមហាអំណាច ដោយសារតែទំហំនិងសក្តានុពលសេដ្ឋកិច្ចរយៈពេលវែងរបស់រដ្ឋនោះ ផ្លាស់ប្តូរយឺតៗ។ ដូច្នេះហើយ ប្រទេសអាឡឺម៉ង់និងជប៉ុនដែលត្រូវខ្ទេចខ្ទាំក្នុងសង្គ្រាមលោកលើកទី២ នៅតែមានអំណាចខ្លាំង ដូចសព្វថ្ងៃនេះ ហើយសូម្បីតែប្រទេសរុស្ស៊ី បន្ទាប់ពីបានកសាងហើយក្រោយមកបាត់បង់ផ្នែកដែលនៅសេសសល់ក្នុងសហភាពសូវៀត នៅតែត្រូវបានគេចាត់ទុកថាជាប្រទេសមហាអំណាចមួយដដែល។

តើរដ្ឋណាខ្លះជាប្រទេសមហាអំណាច នាពេលបច្ចុប្បន្ននេះ? ទោះបីជានិយមន័យត្រូវបានកំណត់ខុសៗគ្នាក៏ដោយ ក៏រដ្ឋចំនួនប្រាំពីរហាក់ដូចជាត្រូវតាមលក្ខណៈវិនិច្ឆ័យៈ សហរដ្ឋអាមេរិក ចិន រុស្ស៊ី ជប៉ុន អាឡឺម៉ង់ បារាំង និងអង់គ្លេស។ ប្រសិនបើបូកបញ្ចូលផលិតផលក្នុងស្រុកសរុបរបស់ប្រទេសទាំងនេះ វាមានទំហំច្រើនជាងពាក់កណ្តាលនៃផលិតផលក្នុងស្រុកសរុបរបស់ពិភពលោកទាំងមូល ហើយការចំណាយលើយោធារបស់ពួកគេមានទំហំពីរភាគបីនៃការចំណាយលើពិភពលោក (សូមមើលក្រាហ្វិក ២.៣)។ ក្នុងចំណោមនោះ ប្រទេសចំនួនប្រាំជាសមាជិកអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ហើយក៏ជាសមាជិកនៃ «ក្លឹប» ដែលមានឃ្លាំងអាវុធនុយក្លេអ៊ែរដ៏ធំ ដោយបើកចំហផងដែរ។

អ្វីដែលគួរអោយកត់សម្គាល់ជាងគេនៅក្នុងបញ្ជីនេះ គឺសហរដ្ឋអាមេរិក និងចិន។ សហរដ្ឋអាមេរិកត្រូវបានចាត់ទុកថាជាប្រទេសមហាអំណាចផុតលេខតែមួយគត់ នៅលើពិភពលោកទាំងមូល ដោយសារតែ

តួនាទីជាប្រវត្តិសាស្ត្ររបស់វា ក្នុងនាមជាអ្នកដឹកនាំពិភពលោក (ជាពិសេសនៅក្នុងកំឡុងពេលនិងក្រោយសង្គ្រាមលោកលើកទីពីរ) និងអនុភាពយោធាដ៏លេចធ្លោរបស់វា។ ប្រទេសចិនមានប្រជាជនច្រើនជាងគេ នៅលើពិភពលោក; មានកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស (ជាមធ្យម ៨-១០ ភាគរយ ជារៀងរាល់ឆ្នាំ ក្នុងរយៈពេលជាង ៣០ ឆ្នាំ) និងមានកម្លាំងយោធាដ៏ធំនិងទំនើបខ្លាំង រួមទាំងឃ្លាំងអាវុធនុយក្លេអ៊ែរដែលអាចប្រើការបាន។ ប្រទេសចិនត្រូវបានរំពឹងថានឹងមានឥទ្ធិពលយ៉ាងខ្លាំងនៅលើពិភពលោក ក្នុងរយៈពេល ២០ ឆ្នាំខាងមុខ ហើយប្រហែលជាខ្លាំងក្លាជាងរដ្ឋដទៃទៀត។ ប្រទេសជប៉ុននិងអាឡឺម៉ង់ជាមហាអំណាចសេដ្ឋកិច្ច ប៉ុន្តែ តួនាទីរបស់ប្រទេសទាំងពីរក្នុងកិច្ចការសន្តិសុខអន្តរជាតិ មានដែនកំណត់ ចាប់តាំងពីសង្គ្រាមលោកលើកទីពីរបានបញ្ចប់មក។ យ៉ាងណាក៏ដោយ ប្រទេសទាំងពីរមានកម្លាំងយោធាដែលមានទំហំធំ និងមានសមត្ថភាពខ្ពស់ ដែលពួកគេបានចាប់ផ្តើមដាក់ពង្រាយនៅបរទេស ជាពិសេសក្នុងប្រតិបត្តិការរក្សាសន្តិភាព។ ប្រទេសរុស្ស៊ី ប្រទេសបារាំង និងប្រទេសអង់គ្លេស គឺជាអ្នកឈ្នះក្នុងសង្គ្រាមលោកលើកទីពីរ ហើយជាប្រទេសមហាអំណាចយោធាដ៏សកម្ម ចាប់តាំងពីពេលនោះមក។ ថ្វីត្បិតតែភាពរុងរឿងកាលសម័យអាណានិគមរបស់ពួកគេថយចុះខ្លាំងក៏ដោយ ក៏ពួកគេនៅតែមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាប្រទេសមហាអំណាច។

ក្រាហ្វិក ២.៣. ទំហំធៀបផលិតផលក្នុងស្រុកសរុបរបស់ប្រទេសមហាអំណាច ឆ្នាំ ២០១៧ និងការចំណាយលើយោធារបស់ពួកគេ ក្នុងឆ្នាំ ២០១៦



ប្រភពទិន្នន័យ៖ សុច្ចនករអភិវឌ្ឍធនាគារពិភពលោក ២០១៧, របាយការណ៍ប្រចាំឆ្នាំរបស់SIPRI ២០១៦

ប្រទេស**មហាអំណាចមធ្យម**មានចំណាត់ថ្នាក់ទាបជាងប្រទេសមហាអំណាច បើនិយាយអំពីឥទ្ធិពលរបស់ពួកគេលើកិច្ចការពិភពលោក។ ប្រទេសខ្លះមានទំហំធំ ប៉ុន្តែមិនមានឧស្សាហកម្មខ្លាំង។ ប្រទេសផ្សេងទៀតមានសមត្ថភាពជំនាញពូកែ ប៉ុន្តែមានទំហំតូច។ ប្រទេសខ្លះប្រាថ្នាចង់គ្រប់គ្រងក្នុងតំបន់ ហើយប្រទេសជាច្រើនមានឥទ្ធិពលខ្លាំងគួរសមក្នុងតំបន់របស់ខ្លួន។

បញ្ជីនៃប្រទេសមហាអំណាចមធ្យម (មិនមែនគ្រប់គ្នាសុទ្ធតែយល់ស្របតាមទេ) អាចរាប់បញ្ចូលទាំងប្រទេសដែលមានទំហំមធ្យមក្នុងអឡ្លាគោលខាងជើង ដូចជាប្រទេសកាណាដា អ៊ីតាលី អេស្បាញ ហូឡង់ ប៉ូឡូញ អ៊ុយក្រែន កូរ៉េខាងត្បូង និងអូស្ត្រាលី។ វាក៏អាចរួមបញ្ចូលទាំងប្រទេសធំៗ ឬមានឥទ្ធិពលនៅក្នុង

អឡឺម៉ង់ ដូចជាប្រទេសឥណ្ឌា ឥណ្ឌូនេស៊ី ប្រេស៊ីល អាហ្សង់ទីន ម៉ិកស៊ិក នីហ្សេរីយ៉ា ប្រទេសអាហ្វ្រិកខាងត្បូង អ៊ីស្រាអែល ទួរគី អ៊ីរ៉ង់ និងប៉ាគីស្ថាន។ ប្រទេសមហាអំណាចមធ្យមមិនបានទទួលការយកចិត្តទុកដាក់ខ្លាំងក្លា នៅក្នុងទំនាក់ទំនងអន្តរជាតិ ដូចប្រទេសមហាអំណាចនោះទេ។

២.៣.៤. ការបែងចែកអំណាច

ដោយសារអំណាចរបស់រដ្ឋនីមួយៗត្រូវប្លឹងថ្លែងអោយមានតុល្យភាពដោយអំណាចរដ្ឋផ្សេងទៀត លក្ខណៈសំខាន់បំផុតនៃប្រព័ន្ធអន្តរជាតិ នៅក្នុងទស្សនៈរបស់អ្នកប្រាកដនិយមមួយចំនួន គឺជា*ការចែកចែក*អំណាចក្នុងចំណោមរដ្ឋនានា។ ការបែងចែកអំណាច ជាគោលគំនិត អាចអនុវត្តចំពោះរដ្ឋទាំងអស់ ក្នុងពិភពលោក ឬចំពោះតែរដ្ឋទាំងឡាយនៅក្នុងតំបន់មួយ ប៉ុន្តែ ភាគច្រើនវាសំដៅទៅលើប្រព័ន្ធនៃប្រទេសមហាអំណាច។

ទ្រឹស្តីប្រាកដនិយមថ្មី(neorealism) ឬជួនកាលត្រូវគេហៅថា *ទ្រឹស្តីរចនាសម្ព័ន្ធប្រាកដនិយម* គឺជាការសម្រួលពីទ្រឹស្តីប្រាកដនិយម កាលពីទសវត្សរ៍ឆ្នាំ ១៩៨០។ វាពន្យល់ពីទំរង់ទូទៅនៃព្រឹត្តិការណ៍អន្តរជាតិដោយផ្តោតលើរចនាសម្ព័ន្ធនៃប្រព័ន្ធអន្តរជាតិ (ការបែងចែកអំណាចអន្តរជាតិ) ជាជាងផ្តោតលើទំរង់ផ្ទៃក្នុងរបស់រដ្ឋនីមួយៗ។ បើប្រៀបធៀបទៅនឹងទ្រឹស្តីប្រាកដនិយមបែបប្រពៃណី ទ្រឹស្តីប្រាកដនិយមថ្មីមានលក្ខណៈ«វិទ្យាសាស្ត្រ»ខ្លាំងជាង ក្នុងន័យថាវាបានស្វើច្បាប់ទូទៅដើម្បីពន្យល់អំពីព្រឹត្តិការណ៍នានា ប៉ុន្តែទ្រឹស្តីប្រាកដនិយមថ្មីបានបាត់បង់នូវទិដ្ឋភាពដ៏សម្បូរបែបនៃទ្រឹស្តីប្រាកដនិយមបុរាណ ដែលគិតគូរពីធាតុផ្សំដ៏ស្មុគស្មាញជាច្រើន (ដូចជា ភូមិសាស្ត្រ ឆន្ទៈនយោបាយ ការទូត ...)។ ថ្មីៗនេះ *អ្នកប្រាកដនិយមបុរាណ-សម័យថ្មី* (neo-classical) បានព្យាយាមស្តារឡើងវិញនូវទិដ្ឋភាពមួយចំនួន ដែលបានបាត់បង់។


*ប៉ូល*នៃការបែងចែកអំណាចអន្តរជាតិ (ក្នុងកម្រិតពិភពលោក ឬតំបន់) សំដៅលើចំនួនមជ្ឈមណ្ឌលអំណាចឯករាជ្យ នៅក្នុងប្រព័ន្ធអន្តរជាតិ។ គោលគំនិតនេះគ្របដណ្តប់ទាំងអំណាចមូលដ្ឋានរបស់តួអង្គដែលចូលរួមផ្សេងៗនិងក្រុមសម្ព័ន្ធភាពរបស់ពួកគេផងដែរ។ ក្រាហ្វិក ២.៤ បង្ហាញពីការកំណត់រចនាសម្ព័ន្ធដ៏សក្តានុពលជាច្រើន ក្នុងចំណោមប្រទេសមហាអំណាច។

ប្រព័ន្ធពហុប៉ូល ជាធម្មតា មានមជ្ឈមណ្ឌលអំណាច ចំនួន ៥ ឬ ៦ ដែលមិនត្រូវរួមបញ្ចូលគ្នាបង្កើតជាក្រុមសម្ព័ន្ធភាពតែមួយ។ រដ្ឋនីមួយៗចូលរួមដោយឯករាជ្យ និងក្នុងលក្ខខណ្ឌស្មើគ្នាជាមួយរដ្ឋដទៃទៀត។ នៅក្នុងតុល្យភាពអំណាចក្នុងប្រព័ន្ធពហុប៉ូលបុរាណ ប្រព័ន្ធប្រទេសមហាអំណាចខ្លួនឯងមានស្ថេរភាព ប៉ុន្តែសង្គ្រាមបានកើតឡើងជាញឹកញាប់ដើម្បីកែសម្រួលទំនាក់ទំនងអំណាចរវាងរដ្ឋនានា។

ប្រព័ន្ធត្រីប៉ូល(Tripolar)ដែលមានមជ្ឈមណ្ឌលអំណាចចំនួនបីធំៗ កម្រកើតមានណាស់ ដោយសារតែទំនោរបង្កើតសម្ព័ន្ធភាពពីរទល់នឹងមួយ។ ទិដ្ឋភាពប្រព័ន្ធត្រីប៉ូលបានរំលេចពី «យុទ្ធសាស្ត្រត្រីកោណ» ដែលមុំនីមួយៗរួមមានសហរដ្ឋអាមេរិក សហភាពសូវៀត និងប្រទេសចិន ក្នុងអំឡុងទសវត្សរ៍ឆ្នាំ ១៩៦០ និង ១៩៧០។ អ្នកប្រាជ្ញខ្លះស្រមៃឃើញពិភពលោកត្រីប៉ូល នាពេលអនាគត ដោយមានមជ្ឈមណ្ឌលអំណាចជាគូប្រជែងនឹងគ្នា នៅអាមេរិកខាងជើង អឺរ៉ុប និងអាស៊ីបូព៌ា។ *ប្រព័ន្ធទ្វេប៉ូល* (bipolar)មានរដ្ឋលេចធ្លោពីរ ឬប្លុកនៃសម្ព័ន្ធមិត្តធំៗចំនួនពីរ ជាគូប្រជែងនឹងគ្នា។ អ្នកប្រាជ្ញទំនាក់ទំនងអន្តរជាតិ មិនយល់ស្របគ្នាទេថាតើប្រព័ន្ធទ្វេប៉ូលមានលក្ខណៈសន្តិភាព ឬ សង្គ្រាម។ ការប្រឈមមុខដាក់គ្នារវាងសហរដ្ឋអាមេរិក និង សហភាពសូវៀត ហាក់ដូចជាផ្តល់នូវស្ថេរភាព និងសន្តិភាពដល់ទំនាក់ទំនងមហាអំណាច ប៉ុន្តែ ប្លុកគូប្រជែងនៅអឺរ៉ុបមុនសង្គ្រាមលោកលើកទី ១ មិនមានលក្ខណៈបែបនោះទេ។ ចុងក្រោយ *ប្រព័ន្ធឯកប៉ូល* (unipolar) មាន

មជ្ឈមណ្ឌលអំណាចតែមួយគត់ ដែលរដ្ឋផ្សេងៗទៀតមានចន្លៃលជុំវិញវា។ នេះត្រូវបានគេហៅថា*អនុត្តរភាព* ហើយយើងនឹងត្រូវពិភាក្សាបន្ថែមទៀត ក្នុងផ្នែកបន្ទាប់។

ក្រាហ្វិក ២.៤. ការបែងចែកអំណាចក្នុងប្រព័ន្ធអន្តរជាតិ



អ្នកប្រាជ្ញទំនាក់ទំនងអន្តរជាតិខ្លះទៀតទាញអំណះអំណាងថា សន្តិភាពអាចត្រូវបានរក្សាបានល្អបំផុតដោយការបែងចែកអំណាចប្រហាក់ប្រហែលឬស្មើគ្នា (ប្រព័ន្ធពហុប៉ូល) ព្រោះក្នុងស្ថានភាពនោះ មិនមានប្រទេសណាមួយមានឱកាសឈ្នះដោយងាយនោះទេ។ ទោះជាយ៉ាងណាក៏ដោយ កស្តុតាងជាក់ស្តែងគាំទ្រទ្រឹស្តីនេះមិនរឹងមាំទេ។ តាមពិត អំណះអំណាងផ្ទុយគ្នាមានការគាំទ្រច្រើនជាង៖ សន្តិភាពត្រូវបានរក្សាបានល្អបំផុតដោយអនុត្តរភាព (ប្រព័ន្ធឯកប៉ូល) ហើយជំរើសបន្ទាប់គឺប្រព័ន្ធទ្វេប៉ូល។

ទ្រឹស្តីអន្តរកាលអំណាចអះអាងថា សង្គ្រាមដ៏ធំបំផុតអាចផ្ទុះឡើង ដោយសារការតតាំងគ្នាដណ្តើមយកតំណែងកំពូលនៅក្នុងហានានុក្រមអំណាច នៅពេលដែលប្រទេសមហាអំណាចថ្មីមួយបង្កើនអំណាចរ៉ាជាច់ (ឬគំរាមកំហែងបង្កើនអំណាចលើស) ប្រទេសមហាអំណាចផុតលេខ។ នៅពេលនោះ អំណាចត្រូវបានបែងចែកស្មើឬប្រហាក់ប្រហែលគ្នា ហើយនេះគឺជាពេលវេលាដ៏គ្រោះថ្នាក់ខ្លាំងបំផុតព្រោះសង្គ្រាមធំៗអាចផ្ទុះឡើងគ្រប់ពេល។ ប្រទេសមហាអំណាចដែលកំពុងដំណើរការល្អក្រោមច្បាប់ចាស់នឹងព្យាយាមរក្សាវា ចំណែកប្រទេសជាគូប្រកួតប្រជែង ដែលមានអារម្មណ៍ថាខ្លួនត្រូវបានឡោមព័ទ្ធដោយសំណុំច្បាប់ចាស់ អាចព្យាយាមផ្លាស់ប្តូរពួកគេ។ ប្រសិនបើប្រទេសគូប្រជែងមិនបានចាប់ផ្តើមសង្គ្រាមជាមុន ដើម្បីផ្លាស់ប្តូរអំណាចកំពូលទេ ប្រទេសមហាអំណាចចាស់អាចនឹងបង្កអោយកើតសង្គ្រាម«ទប់ស្កាត់» ដើម្បីបញ្ឈប់ការកើនឡើងអំណាចនៃគូប្រជែង មុនពេលវាក្លាយជាការគំរាមកំហែងខ្លាំងពេកពិបាកទប់ទល់។

នៅពេលដែលហាន:នៃប្រទេសមហាអំណាចទើបរះថ្មីមួយ(តំណែងផ្លូវការនៅក្នុងហានានុក្រម)ខុសពីអំណាចពិតជាក់ស្តែងរបស់វា ប្រទេសមហាអំណាចនោះអាចទទួលរងគ្រោះពីការថមថយអំណាចធៀបផងដែរ៖ ប្រជាជនរបស់ពួកគេអាចមានអារម្មណ៍ថាពួកគេធ្វើមិនបានល្អដូចអ្នកដទៃ ឬដូចអ្វីដែលពួកគេសមនឹងទទួលបាន ទោះបីជាតួនាទីរបស់ពួកគេអាចមានភាពប្រសើរឡើង ក្នុងលក្ខខណ្ឌដាច់ខាត។ ការកើនឡើងនៃប្រទេសអាឡឺម៉ង់នៅសតវត្សរ៍ទី១៩ បានផ្តល់អោយប្រទេសនេះនូវសមត្ថភាពឬហាន:ប្រទេសមហាអំណាច ទោះបីជាវាត្រូវបានរារាំងពីទឹកដីអាណានិគមនិងសញ្ញាណនៃហាន:ផ្សេងទៀតក៏ដោយ។ ភាពតានតឹងនេះអាចរួមចំណែកដល់សង្គ្រាមលោកទាំងពីរលើក។

ប្រទេសចិននិងសហរដ្ឋអាមេរិកអាចនឹងប្រឈមមុខនឹងចរន្តស្រដៀងគ្នា នាពេលអនាគត។ ប្រទេសចិនអាចរឹតតែតតាំងនឹងច្បាប់និងបទដ្ឋានអន្តរជាតិ ដែលខ្លួនយល់ថា វាបម្រើអោយផលប្រយោជន៍របស់សហរដ្ឋអាមេរិក។ ចំពោះភាគីអាមេរិក ប្រទេសមហាអំណាចនេះអាចបារម្ភថាកំណើនអំណាចសេដ្ឋកិច្ចនិងយោធារបស់ប្រទេសចិន នឹងត្រូវប្រើដើម្បីប្រកួតប្រជែងនឹងអំណាចរបស់សហរដ្ឋអាមេរិក។ ក្នុងឆ្នាំ ២០១០ គណៈកម្មការត្រួតពិនិត្យយុទ្ធសាស្ត្ររបស់យោធាអាមេរិក បានចោទសួរអំពី«ចេតនាយ:ពេលវែង»របស់ចិនដោយលើកឡើងនូវសំណួរថ្មីអំពីការផ្លាស់ប្តូរឬអន្តរកាលអំណាចនាពេលអនាគត (សូមមើលឧទារណ៍បន្ថែម «**តោះ សាកល្បងពិភាក្សាអំពីបញ្ហា**» នៅចុងបញ្ចប់នៃមេរៀននេះ)។

ដូច្នេះហើយ បើយោងតាមទ្រឹស្តីអន្តរកាលអំណាច សន្តិភាពក្នុងចំណោមប្រទេសមហាអំណាចអាចកើតឡើង នៅពេលដែលរដ្ឋមួយស្ថិតនៅក្នុងតំណែងកំពូលយ៉ាងរឹងមាំ ហើយតំណែងរបស់រដ្ឋផ្សេងទៀតនៅក្នុងហានានុក្រម ត្រូវបានកំណត់យ៉ាងច្បាស់លាស់ និងសាកសមជាមួយនឹងអំណាចជាមូលដ្ឋានពិតជាក់ស្តែងរបស់ពួកគេ។

២.៣.៥. អនុត្តរភាព

អនុត្តរភាពគឺជាការក្តោបក្តាប់អំណាចផ្តាច់មុខរបស់រដ្ឋមួយ នៅក្នុងប្រព័ន្ធអន្តរជាតិ ដែលអនុញ្ញាតអោយរដ្ឋនោះអាចគ្រប់គ្រងច្បាប់និងការរៀបចំទំនាក់ទំនងនយោបាយនិងសេដ្ឋកិច្ចអន្តរជាតិ តែម្នាក់ឯង។ រដ្ឋបែបនេះត្រូវបានគេហៅថា*អនុត្តរភាព* (hegemon) ។ (តាមធម្មតា *អនុត្តរភាព* មានន័យថាជាការត្រួតត្រាលើពិភពលោក ប៉ុន្តែជួនកាលវាក៏សំដៅទៅលើការត្រួតត្រាក្នុងតំបន់ផងដែរ។) អ្នកទ្រឹស្តីម៉ាក្សនិយម ជនជាតិអ៊ីតាលី លោក អង់តូនីញូ ហ្គ្រាមស៊ី (Antonio Gramsci) បានប្រើពាក្យ*អនុត្តរភាព*ដើម្បីសំដៅទៅលើ*គំនិត*ដ៏ស្មុគស្មាញដែលអ្នកគ្រប់គ្រងប្រើប្រាស់ ដើម្បីទទួលបានការយល់ព្រមសម្រាប់ធម្មានុរូបភាពរបស់ខ្លួននិងគ្រប់គ្រងប្រជាពលរដ្ឋអោយមានរៀបរយល្អ ដោយកាត់បន្ថយតម្រូវការក្នុងការប្រើប្រាស់កម្លាំងទ័ព ដើម្បីសម្រេចបានគោលដៅដូចគ្នា។ ដូចគ្នានេះដែរ អត្ថន័យបែបនេះនៅក្នុងទំនាក់ទំនងអន្តរជាតិសំដៅទៅលើអនុត្តរភាពនៃគំនិត ដូចជាលទ្ធិប្រជាធិបតេយ្យ និងរបបមូលធននិយម និងសំដៅលើភាពលេចធ្លោជាសកលរបស់សហរដ្ឋអាមេរិក។

ការសិក្សាភាគច្រើនស្តីពីអនុត្តរភាពចង្អុលបង្ហាញទៅដល់ឧទាហរណ៍ចំនួនពីរ៖ ចក្រភពអង់គ្លេសក្នុងសតវត្សរ៍ទី១៩ និងសហរដ្ឋអាមេរិកក្រោយសម័យសង្គ្រាមលោកលើកទីពីរ។ អានុភាពអំណាចរបស់ចក្រភពអង់គ្លេសបានកើនឡើងលេចធ្លោខ្លាំង បន្ទាប់ពីបរាជ័យរបស់ប្រទេសបារាំងដែលជាគូសត្រូវរបស់ខ្លួន នៅក្នុងសង្គ្រាមណាប៉ូឡេអុង។ ទាំងពាណិជ្ជកម្មពិភពលោក និងទាំងសមត្ថភាពកងនាវាចរណ៍ស្ថិតនៅក្នុងកណ្តាប់

ដៃរបស់អង់គ្លេសយ៉ាងតឹងនែន ដូចដែលពាក្យស្លោកថា «ចក្រភពអង់គ្លេសគ្រប់គ្រងទឹករលក»។ អានុភាពអំណាចរបស់សហរដ្ឋអាមេរិកបានលេចធ្លោខ្លាំង ក្រោយបរាជ័យរបស់ប្រទេសអាឡឺម៉ង់ និងប្រទេសជប៉ុន (និងហេវហត់អស់ខ្យល់នៃសហភាពសូវៀត ប្រទេសបារាំង ប្រទេសអង់គ្លេស និងប្រទេសចិនក្នុងកិច្ចខិតខំប្រឹងប្រែងរៀងៗខ្លួន)។ នៅចុងទស្សវត្សរ៍ឆ្នាំ ១៩៤០ ផលិតផលក្នុងស្រុកសរុបរបស់សហរដ្ឋអាមេរិកមានទំហំធំជាង ពាក់កណ្តាលនៃទំហំផលិតផលក្នុងស្រុកសរុបរបស់ពិភពលោក នាវារបស់សហរដ្ឋអាមេរិកបានដឹកជញ្ជូនទំនិញភាគច្រើនរបស់ពិភពលោក យោធាសហរដ្ឋអាមេរិកមានសមត្ថភាពអាចកម្ចាត់រដ្ឋណាមួយ ឬជាក់រដ្ឋនានារួមបញ្ចូលគ្នា តែម្នាក់ឯង ហើយមានតែសហរដ្ឋអាមេរិកប៉ុណ្ណោះ ដែលមានអាវុធនុយក្លេអ៊ែរ។ ឧស្សាហកម្មអាមេរិកនាំមុខគេលើពិភពលោក ក្នុងវិស័យបច្ចេកវិទ្យានិងផលិតកម្ម ហើយពលរដ្ឋអាមេរិកបានរីករាយនឹងស្តង់ដារអស់នៅខ្ពស់បំផុតលើពិភពលោក។

នៅពេលដែលគំលាតអំណាចដ៏ធំធេងដែលជាលទ្ធផលនៃសង្គ្រាមធំៗ បានរួមតូចមកវិញ បន្តិចម្តងៗ (រដ្ឋកសាងសមត្ថភាពឡើងវិញ ក្នុងរយៈពេលច្រើនឆ្នាំឬហួតដល់ច្រើនទសវត្សរ៍) ការថមថយនៃអនុត្តរភាពអាចកើតមានឡើង ជាពិសេស នៅពេលដែលអនុត្តរភាពបានខំប្រឹងពង្រីកវិសាលភាពរបស់ខ្លួនរែងឆ្ងាយពេកជាមួយនឹងការប្តេជ្ញាចិត្តផ្នែកយោធាដ៏ខ្លាំងក្លា។ អ្នកប្រាជ្ញទំនាក់ទំនងអន្តរជាតិ មិនយល់ស្របគ្នាទេថាតើការធ្លាក់ចុះអនុត្តរភាពរបស់សហរដ្ឋអាមេរិកបានដំណើរការទៅឆ្ងាយប៉ុណ្ណាហើយ ឬក្នុងល្បឿនលឿនប៉ុណ្ណានោះទេ ឬក៏មិនទាន់ចាប់ផ្តើមធ្លាក់ចុះនៅឡើយ ហើយក៏មិនច្បាស់ថានឹងមានអស្ថិរភាពអន្តរជាតិជាលទ្ធផលនៃការធ្លាក់ចុះបែបនេះ ដែរឬយ៉ាងណា។

ទ្រឹស្តីស្ថេរភាពអនុត្តរភាពបានអះអាងថា អនុត្តរភាពផ្តល់នូវសណ្តាប់ធ្នាប់មួយកម្រិត ស្រដៀងទៅនឹងរដ្ឋាភិបាលកណ្តាលមួយ នៅក្នុងប្រព័ន្ធអន្តរជាតិ៖ កាត់បន្ថយភាពអនាធិបតេយ្យ ទប់ស្កាត់ការឈ្លានពាន ការលើកកម្ពស់ពាណិជ្ជកម្មសេរី និងផ្តល់នូវរូបិយប័ណ្ណច្បាស់លាស់មួយ ដែលអាចប្រើប្រាស់ជាស្តង់ដារពិភពលោក។ អនុត្តរភាពអាចជួយដោះស្រាយ ឬយ៉ាងហោចណាស់ អាចរក្សាតុល្យភាពជម្លោះរវាងប្រទេសមហាអំណាចមធ្យមឬរដ្ឋតូចៗ។ នៅពេលដែលអំណាចរបស់រដ្ឋណាមួយគ្របដណ្តប់ទូទាំងពិភពលោក រដ្ឋនោះអាចអនុវត្តច្បាប់និងបទដ្ឋាននានា ជាឯកតោភាគី ដោយអាចជៀសវាងបញ្ហាផលប្រយោជន៍រួម។ ជាពិសេស អនុត្តរភាពអាចរក្សាពាណិជ្ជកម្មសេរីសកល និងជំរុញកំណើនសេដ្ឋកិច្ចពិភពលោក បើយោងតាមទស្សនៈទាំងអស់ ខាងលើនេះ។

រូបថត *នាវាផ្ទុកយន្តហោះរបស់ចិន*

ចិនកំពុងរះ

អ្នកប្រាកដនិយមសង្កត់ធ្ងន់លើអំណាចជៀបសម្រាប់ជាការពន្យល់អំពីសង្គ្រាម និងសន្តិភាព។ ទំនើបភាវូបនីយកម្មនៃយោធារបស់ប្រទេសចិន រួមជាមួយនឹងសេដ្ឋកិច្ចដែលកំពុងរីកចម្រើនយ៉ាងឆាប់រហ័សរបស់ប្រទេសនេះ នឹងបង្កើនអំណាចរបស់ប្រទេសចិនក្នុងរយៈពេលជាច្រើនទសវត្សរ៍ខាងមុខនេះ។ អ្នកសង្កេតការណ៍មួយចំនួនកត់សម្គាល់ឃើញការភ័យខ្លាចអស្ថិរភាពនៅក្នុងទ្វីបអាស៊ី ប្រសិនបើតុល្យភាពនៃអំណាចរួមក្នុងចំណោមរដ្ឋនៅក្នុងតំបន់ ផ្លាស់ប្តូរយ៉ាងឆាប់រហ័ស។ នៅទីនេះ ពលរដ្ឋចិនអបអរនាវាផ្ទុកយន្តហោះទីពីររបស់ចិន ឆ្នាំ ២០១៧។

ទ្រឹស្តីនេះសន្មតថា សន្តិភាពនិងវិបុលភាពក្នុងប៉ុន្មានទសវត្សរ៍ក្រោយសង្គ្រាមលោកលើកទី ២ អាច កើតមានបាន ដោយសារតែអនុត្តរភាពរបស់សហរដ្ឋអាមេរិក ដែលបង្កើតនិងរក្សានូវគ្រោងឆ្អឹងខ្នងជាសកល នៃទំនាក់ទំនងសេដ្ឋកិច្ច ដែលគាំទ្រពាណិជ្ជកម្មអន្តរជាតិសេរីនិងស្ថេរភាពក្នុងកម្រិតមួយសមល្មម ក៏ដូចជា រក្សាបាននូវគ្រោងឆ្អឹងសន្តិសុខដែលទប់ស្កាត់សង្គ្រាមរវាងប្រទេសមហាអំណាច។ ផ្ទុយទៅវិញ មហាវិបត្តិ សេដ្ឋកិច្ចពិភពលោក ក្នុងទសវត្សរ៍ឆ្នាំ ១៩៣០ និងសង្គ្រាមលោកលើកទីពីរ ដែលផ្ទុះឡើងនៅទសវត្សរ៍ឆ្នាំ ១៩៤០ ត្រូវបានគេចាត់ទុកថាជាលទ្ធផលនៃចន្លោះប្រហោងដែលអវត្តមានអំណាច នៅក្នុងប្រព័ន្ធអន្តរជាតិ ក្នុងកំឡុងពេលនោះ៖ ចក្រភពអង់គ្លេសមិនអាចដើរតួនាទីជាអនុត្តរភាពបានទៀតទេ ហើយសហរដ្ឋអាមេរិក ក៏មិនមានឆន្ទៈធ្វើជាអនុត្តរភាពដែរ។

តើហេតុអ្វីបានជាអនុត្តរភាពគួរតែយកចិត្តទុកដាក់លើការពង្រឹងការអនុវត្តច្បាប់ សម្រាប់សេដ្ឋកិច្ច អន្តរជាតិដែលផ្តល់ផលប្រយោជន៍រួម? បើយោងតាមទ្រឹស្តីស្ថេរភាពអនុត្តរភាព, រដ្ឋជាអនុត្តរភាពក្នុងនាមជា ពាណិជ្ជករអន្តរជាតិធំជាងគេ មានផលប្រយោជន៍ក្នុងការលើកកម្ពស់សមាហរណកម្មនៃទីផ្សារពិភពលោករួម (ជាកន្លែងដែលអនុត្តរភាពនឹងមានទំនោរត្រួតត្រា)។ ក្នុងឋានៈជារដ្ឋជឿនលឿនបំផុត នៅក្នុងដំណើរផលិត កម្មនិងបច្ចេកវិទ្យា អនុត្តរភាពមិនខ្លាចការប្រកួតប្រជែងពីឧស្សាហកម្មនៅក្នុងរដ្ឋផ្សេងទៀតទេ។ វាបារម្ភ ត្រឹមតែថា ទំនិញកម្រិតខ្ពស់របស់ខ្លួន មិនបានចូលរួមក្នុងការប្រកួតប្រជែងនៅក្នុងរដ្ឋផ្សេងទៀត។ ដូច្នេះ អនុត្តរភាពប្រើប្រាស់អំណាចរបស់ពួកគេ ដើម្បីសម្រេចបាននូវពាណិជ្ជកម្មសេរី និងស្ថិរភាពនយោបាយ ដែល គាំទ្រដល់ពាណិជ្ជកម្មសេរី។ ម្ល៉ោះហើយ អនុត្តរភាពផ្តល់ទាំងសមត្ថភាព និងទាំងការលើកទឹកចិត្តក្នុងការ ផ្តល់នូវក្របខ័ណ្ឌនយោបាយស្ថិរភាព សម្រាប់ពាណិជ្ជកម្មអន្តរជាតិ ដោយសេរី យោងតាមទ្រឹស្តីស្ថិរភាព អនុត្តរភាព។ ប៉ុន្តែ មិនមែនអ្នកប្រាជ្ញទំនាក់ទំនងអន្តរជាតិទាំងអស់ទទួលយកទ្រឹស្តីនេះទេ។

បើយោងតាមទស្សនៈរបស់រដ្ឋនានាដែលមិនសូវមានអំណាច ជាការពិតណាស់ អនុត្តរភាព ហាក់ដូច ជាការរំលោភលើអធិបតេយ្យភាពរបស់រដ្ឋផ្សេង ហើយបទបញ្ជាដែលវាដាក់ចេញ ហាក់ដូចជាមានភាព អយុត្តិធម៌ ឬមិនស្របច្បាប់ទាល់តែសោះ។ ជាឧទាហរណ៍ ប្រទេសចិនបានជាប់គាំង នៅក្រោមទណ្ឌកម្ម សេដ្ឋកិច្ចដែលដាក់ចេញដោយសហរដ្ឋអាមេរិក អស់រយៈពេល ២០ ឆ្នាំ ក្រោយឆ្នាំ ១៩៤៩ ក្នុងពេលដែល អំណាចរបស់សហរដ្ឋអាមេរិកឡើងដល់កម្រិតកំពូល នៅពេលដែលប្រទេសចិន ត្រូវបានឡោមព័ទ្ធដោយ មូលដ្ឋានយោធា អាមេរិក និងសម្ព័ន្ធយោធាជាបច្ចាមិត្ត ដែលដឹកនាំដោយសហរដ្ឋអាមេរិក។ រហូតមកដល់ បច្ចុប្បន្ននេះ មេដឹកនាំចិនប្រើពាក្យ*អនុត្តរភាព*ជាការប្រមាថ ហើយទ្រឹស្តីស្ថិរភាពអនុត្តរភាពមិនបានធ្វើអោយ ពួកគេចាប់អារម្មណ៍នោះទេ។

សូម្បីតែនៅសហរដ្ឋអាមេរិក ក៏មិនច្បាស់លាស់អំពីអនុត្តរភាពរបស់សហរដ្ឋអាមេរិកដែរ។ ជាលក្ខណៈ ប្រវត្តិសាស្ត្រ គោលនយោបាយការបរទេសរបស់សហរដ្ឋអាមេរិកបានផ្លាស់ប្តូររវាងមនោសញ្ចេតនា*អន្តរជាតិ និយម* និង*ឯកោនិយម*។ វាត្រូវបានបង្កើតឡើង ជាការបំបែកខ្លួនចេញពីប្រព័ន្ធអន្តរជាតិ ដែលមានមូលដ្ឋាន នៅអឺរ៉ុប ហើយការរីកចម្រើនរបស់អាមេរិកនៅក្នុងសតវត្សទី១៩ ត្រូវពឹងផ្អែកលើឧស្សាហូបនីយកម្ម និងការ ពង្រីកទឹកដីនៅអាមេរិកខាងជើង។ សហរដ្ឋអាមេរិកបានដណ្តើមកាន់កាប់អាណានិគមក្រៅប្រទេស ដូចជា នៅប្រទេសហ្វីលីពីន និងទឹកដីកោះព័រតូរីកូ ប៉ុន្តែ មិនពេញចិត្តនឹងតួនាទីជាមហាអំណាចចក្រព័ត្តិនិយមទេ។ នៅក្នុងសង្គ្រាមលោកលើកទី១ សហរដ្ឋអាមេរិកបានរង់ចាំបីឆ្នាំ ដើម្បីថ្លឹងថ្លែងថាតើគួរចូលប្រឡូកក្នុងសង្គ្រាម

ដែរឬទេ ហើយក្រោយមក ក៏បានបដិសេធមិនចូលរួមសម្ព័ន្ធប្រជាជាតិដែរ។ គោលនយោបាយឯកោនិយមរបស់របស់សហរដ្ឋអាមេរិកបានឈានដល់ចំណុចកំពូល នៅចុងទសវត្សរ៍ឆ្នាំ១៩៣០ នៅពេលដែលលទ្ធផលនៃការស្ទង់មតិនានាបានចង្អុលបង្ហាញថា ៩៥ ភាគរយនៃសាធារណជន ប្រឆាំងចំពោះការចូលប្រឡូកក្នុងសង្គ្រាមអឺរ៉ុប នាពេលអនាគត ហើយប្រហែល ៧០ ភាគរយប្រឆាំងនឹងការចូលរួមក្នុងសម្ព័ន្ធប្រជាជាតិ ឬចូលរួមជាមួយប្រទេសផ្សេងទៀតដើម្បីបញ្ឈប់ការឈ្លានពាន។

អ្នកគាំទ្រគោលនយោបាយអន្តរជាតិនិយម ដូចជា លោកប្រធានាធិបតី សេអូដ័រ រ៉ូសឺវែល (Theodore Roosevelt) និង លោកប្រធានាធិបតី វូដ្រូ វីលសុន (Woodrow Wilson) បានគាំទ្រភាពជាអ្នកដឹកនាំ និងសកម្មភាពរបស់សហរដ្ឋអាមេរិក នៅក្នុងកិច្ចការពិភពលោក។ ទស្សនៈទាំងនេះហាក់ដូចជាត្រូវបានពង្រឹងដោយបរាជ័យនៃគោលនយោបាយឯកោនិយមក្នុងការទប់ស្កាត់ ឬបញ្ចៀសសង្គ្រាមលោកលើកទីពីរ។ បន្ទាប់ពីសង្គ្រាមនោះ បណ្តាមេដឹកនាំសហរដ្ឋអាមេរិកបានបារម្ភអំពីការរីករាលដាលនៃលទ្ធិកុម្មុយនិស្តសហភាពសូវៀត (ហើយបន្ទាប់មកកុម្មុយនិស្តចិន) ហើយបានរុញច្រានមតិសាធារណៈរបស់សហរដ្ឋអាមេរិកឆ្ពោះទៅរកគោលនយោបាយអន្តរជាតិនិយមខ្លាំង ក្នុងអំឡុងពេលសង្គ្រាមត្រជាក់។ សហរដ្ឋអាមេរិកបានក្លាយជាប្រទេសមហាអំណាចពិភពលោកដ៏សកម្ម។ នៅក្នុងយុគសម័យក្រោយសង្គ្រាមត្រជាក់ លទ្ធិអន្តរជាតិនិយមរបស់សហរដ្ឋអាមេរិកត្រូវបានរំខានដោយមនសិការនៃការចំណាយថ្មីមួយ និងដោយការលេចឡើងជាថ្មីនៃដំរុំគោលនយោបាយឯកោនិយម ដែលកើតជាប្រតិកម្មតបទៅនឹងការផ្លាស់ទីលំនៅឬរោងចក្រដែលបណ្តាលមកពីសកលភាវូបនីយកម្មនិងពាណិជ្ជកម្មសេរី។ ទោះជាយ៉ាងណាក៏ដោយ ការវាយប្រហារភេរវកម្ម នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ ២០០១ បានបន្តជំរុញការគាំទ្រជាសាធារណៈចំពោះអន្តរាគមន៍និយមរបស់សហរដ្ឋអាមេរិកនៅក្នុងជម្លោះនៅឯនាយសមុទ្រ ដែលហាក់ដូចជាលែងនៅសែនឆ្ងាយទៀតហើយ។ ថ្មីៗនេះ សូម្បីការប្រឆាំងទៅនឹងសង្គ្រាមអ៊ីរ៉ាក់ ជម្លោះអូសបន្លាយដ៏យូរក្នុងប្រទេសអាហ្វហ្គានីស្ថាន និងកំឡុងពេលវិបត្តិសេដ្ឋកិច្ចក្នុងមាតុប្រទេស បានជំរុញអោយមាននិន្នាការគោលនយោបាយឯកោនិយមថ្មីម្តងទៀត នៅក្នុងប្រទេសសហរដ្ឋអាមេរិក។ ទំនោរនេះកាន់តែពុះកញ្ជ្រោលខ្លាំងនៅក្នុងការបោះឆ្នោតជ្រើសរើសប្រធានាធិបតី ដូណាល់ ត្រាំ ដែលបានសន្យាផ្តល់អាទិភាពដល់ផលប្រយោជន៍អាមេរិក មិនគិតថាតើវាអាចផលប៉ះពាល់ដល់បច្ចាមិត្រឬសម្ព័ន្ធមិត្រឡើយ។

ភាពមិនច្បាស់លាស់មួយទៀតរបស់សហរដ្ឋអាមេរិក គឺគោលការណ៍*ឯករាភាគីនិយម* ទល់នឹង*ពហុភាគីនិយម*នៅពេលដែលសហរដ្ឋអាមេរិកចូលរួមជាមួយអន្តរជាតិ។ វិធីសាស្ត្រពហុភាគី (ធ្វើប្រតិបត្តិការតាមរយៈស្ថាប័នអន្តរជាតិ) បង្កើនអំណាចរបស់សហរដ្ឋអាមេរិក និងកាត់បន្ថយការចំណាយផ្សេងៗ ប៉ុន្តែពួកគេជាក់កម្រិតសេរីភាពក្នុងការធ្វើអ្វីមួយរបស់សហរដ្ឋអាមេរិក។ ឧទាហរណ៍ សហរដ្ឋអាមេរិកមិនអាចតែងតែធ្វើអោយអង្គការសហប្រជាជាតិធ្វើអ្វីដែលខ្លួនចង់បានទេ។ ការស្ទង់មតិនានាបានចង្អុលបង្ហាញថា ពលរដ្ឋអាមេរិកភាគច្រើនគាំទ្រប្រតិបត្តិការតាមរយៈអង្គការសហប្រជាជាតិ និងស្ថាប័នពហុភាគីផ្សេងទៀត។ ទោះជាយ៉ាងនេះក្តី កំឡុងពេលនោះ សហរដ្ឋអាមេរិកបានបានខកខានបំពេញកាតព្វកិច្ចហិរញ្ញវត្ថុរបស់ខ្លួនចំពោះអង្គការសហប្រជាជាតិ ក្នុងទឹកប្រាក់ចំនួន ជាង ១ ពាន់លាន ហើយវាក៏បានបដិសេធមិនចូលរួមក្នុងកិច្ចខិតខំប្រឹងប្រែងអន្តរជាតិផ្សេងៗដូចជាសន្ធិសញ្ញាស្តីពីការឡើងកំដៅផែនដី (សូមមើលមេរៀនទី១១ អំពីបរិស្ថាននិងប្រជាជន) សន្ធិសីទអន្តរជាតិមួយស្តីពីការរើសអើងជាតិសាសន៍ និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិ (សូម

មើលមេរៀនទី ៧)។ សង្គ្រាមដែលដឹកនាំដោយសហរដ្ឋអាមេរិក ឆ្នាំ ២០០៣ នៅក្នុងប្រទេសអ៊ីរ៉ាក់ មានសម្ព័ន្ធមិត្តតិចតួចចូលរួម ហើយក៏គ្មានការបោះត្រាអនុញ្ញាត ពីអង្គការសហប្រជាជាតិដែរ។ នេះជាចំណុចកំពូលនៃលទ្ធិឯកតោភាគីនិយមរបស់សហរដ្ឋអាមេរិក។

រូបថត សាកសពទាហានអាមេរិកធ្វើមាតុភូមិនិវត្តន៍

តម្លៃនៃអនុត្តរភាព

សហរដ្ឋអាមេរិកជាតួអង្គឯកដែលមានឥទ្ធិពលបំផុតក្នុងពិភពលោក។ សមត្ថភាពនិងឆន្ទៈក្នុងការបន្តតួនាទីជាអនុត្តរភាពដូចក្រោយសង្គ្រាមលោកលើកទីពីរ គឺជាកត្តាសំខាន់ដែលនឹងរៀបចំសណ្តាប់ធ្នាប់ពិភពលោក ប៉ុន្តែ តួនាទីរបស់សហរដ្ឋអាមេរិកនៅតែមិនប្រាកដប្រជា។ ឆន្ទៈរបស់អាមេរិកក្នុងការទទួលយកចំនួនទាហានស្លាប់នឹងប៉ះពាល់ដល់តួនាទីរបស់ខ្លួន។ នៅទីនេះ ទាហានត្រឡប់មកពីអាហ្វហ្គានីស្ថានឆ្នាំ ២០០៩។

ទោះជាយ៉ាងណាក៏ដោយ វាបានផ្លាស់ប្តូរនៅចុងទសវត្សរ៍ឆ្នាំ ២០០០ នៅពេលដែលរដ្ឋបាលលោកប្រធានាធិបតី បារ៉ាក់ អូបាម៉ា បានសង្កត់ធ្ងន់លើគោលការណ៍ពហុភាគីនិយមចំពោះជម្លោះអន្តរជាតិ ដូចជានៅប្រទេសលីប៊ី ស៊ីរី និងអ៊ីរ៉ង់។ សម្ព័ន្ធភាពណាតូចាប់ផ្តើមមានសារៈសំខាន់ជាថ្មីនៅក្នុងប្រទេសអាហ្គានីស្ថាន និងនៅក្នុងយុទ្ធនាការលីប៊ី ក្នុងឆ្នាំ ២០១១ ហើយប្រាក់ដែលត្រូវចូលរួមវិភាគទានដល់អង្គការសហប្រជាជាតិក៏ត្រូវបានផ្តល់ដល់ដៃអ.ស.ប.។ ទោះជាយ៉ាងណាក៏ដោយ សមាជិកសភាសហរដ្ឋអាមេរិកកាន់តែកើនឡើង និងរដ្ឋបាលលោកប្រធានាធិបតី ចច ប៊ូស ចាប់តាំងពីទសវត្សរ៍ឆ្នាំ ១៩៩០ ហើយជាថ្មីម្តងទៀតរដ្ឋបាលលោកប្រធានាធិបតី ដូណាល់ ត្រាំ ចាប់ពីឆ្នាំ ២០១៦ បានសម្តែងមន្ទិលសង្ស័យអំពីអង្គការសហប្រជាជាតិ និងទីភ្នាក់ងារអន្តរជាតិ ដោយជាទូទៅ ពួកគេពេញចិត្តនឹងគោលនយោបាយឯកតោភាគីនិយមខ្លាំងជាង។ តាមពិតទៅ រដ្ឋបាលលោកត្រាំបានអនុវត្តគោលនយោបាយឯកតោភាគីនិយម ក្រោយបានចូលកាន់តំណែងភ្លាមៗ ការដកសហរដ្ឋអាមេរិកចេញពីសន្ធិសញ្ញាអាកាសធាតុសកល (សូមមើលមេរៀនទី ១១), ការទុកចោលកិច្ចព្រមព្រៀងពាណិជ្ជកម្មអនុគ្រោះដែលរដ្ឋបាលមុន ទើបបានចរចាហើយថ្មីៗ (ភាពជាដៃគូអន្តរប៉ាស៊ីហ្វិក), ការដកសហរដ្ឋអាមេរិកចេញពីស្ថាប័នធំរបស់អង្គការសហប្រជាជាតិ (UNESCO), ការគំរាមកំហែងប្រទេសជាមិត្តនិងសម្ព័ន្ធមិត្ត ជាមួយនឹងពន្ធពាណិជ្ជកម្ម និង ការរិះគន់សម្ព័ន្ធមិត្តណាតូចំពោះការចូលរួមវិភាគទានតិចតួចពេកសម្រាប់ការការពាររបស់យោធាអាមេរិក។

២.៣.៦. ប្រព័ន្ធមហាអំណាច ១៥០០-២០០០

ដើម្បីបង្ហាញពីរបៀបដែលគោលគំនិត ដូចជា តុល្យភាពអំណាច អន្តរកាលអំណាច និងអនុត្តរភាព មានដំណើរការជាប្រវត្តិសាស្ត្រ យើងនឹងពិនិត្យមើលប្រភពដើមនៃប្រព័ន្ធអន្តរជាតិទំនើប ដោយសង្ខេបៗ។ ដោយត្រូវបានកត់សម្គាល់ដោយវត្តមានរបស់ប្រទេសមហាអំណាច អធិបតេយ្យភាព តុល្យភាពអំណាច និងរយៈពេលណាមួយនៃអនុត្តរភាព, ប្រព័ន្ធមហាអំណាចទំនើប ជារឿយៗ ត្រូវបានរាប់ចាប់ផ្តើមតាំងការចុះ *សន្ធិសញ្ញាវ៉េសហ្វ័រឡៀ* (Westphalia) ក្នុងឆ្នាំ១៦៤៨ ដែលបានបង្កើតគោលការណ៍នៃរដ្ឋឯករាជ្យអធិបតេយ្យភាព ដែលបន្តជះឥទ្ធិពលលើប្រព័ន្ធអន្តរជាតិសព្វថ្ងៃនេះ (សូមមើលរូបភាព ២.៥)។ ទោះជាយ៉ាងណា ក្បួនច្បាប់នៃទំនាក់ទំនងរវាងរដ្ឋទាំងនេះមិនមានប្រភពដើមនៅទីក្រុងវ៉េសហ្វ័រឡៀទេ។ វាត្រូវបានបង្កើតឡើងនៅអឺរ៉ុប ក្នុងសតវត្សរ៍ទី១៦។ គន្លឹះនៃប្រព័ន្ធនេះ គឺជាសមត្ថភាពរបស់រដ្ឋមួយ ឬសម្ព័ន្ធណាមួយ

ដើម្បីរក្សាតុល្យភាពអំណាចជាមួយនឹងអំណាចរដ្ឋមួយទៀត ដូច្នេះវាមិនអាចចាប់យកអង្គភាព(រដ្ឋ)តូចៗ មកគ្រប់គ្រង និងបង្កើតចក្រភពសកលបានទេ។

ប្រព័ន្ធតុល្យភាពអំណាចនេះបានផ្តល់សារៈសំខាន់ជាពិសេស ទៅដល់ប្រទេសមហាអំណាចមួយក្តាប់តូចដែលមានសមត្ថភាពយោធាខ្លាំង ផលប្រយោជន៍និងទស្សនវិស័យសកល និងអន្តរកម្មខ្លាំងក្លាជាមួយគ្នា។ (ប្រទេសមហាអំណាចត្រូវបានកំណត់និងពិភាក្សានៅក្នុងមេរៀនទី១។) ប្រព័ន្ធនៃទំនាក់ទំនងមហាអំណាចមានតាំងពីប្រហែលឆ្នាំ ១៥០០ នៃគ.ស. ហើយរចនាសម្ព័ន្ធនិងច្បាប់នៃប្រព័ន្ធនោះនៅតែមានស្ថេរភាពពីមួយសម័យកាលទៅមួយសម័យកាលទៀត ទោះបីជាសមាជិកមួយចំនួនបានផ្លាស់ប្តូរក៏ដោយ។ រចនាសម្ព័ន្ធគឺជាតុល្យភាពនៃអំណាចក្នុងចំណោមរដ្ឋដែលមានអំណាចបំផុតទាំងប្រាំមួយ ដែលបង្កើតនិងបំបែកសម្ព័ន្ធភាព, ប្រយុទ្ធគ្នាក្នុងសង្គ្រាម និងបង្កើតសន្តិភាព ដោយមិនអនុញ្ញាតអោយរដ្ឋណាមួយ ដណ្តើមគ្រប់គ្រងរដ្ឋដ៏ទៃតែម្នាក់ឯងបានឡើយ។

រដ្ឋដែលមានឥទ្ធិពលបំផុតនៅអឺរ៉ុបសតវត្សរ៍ទី១៦ រួមមានដូចជា ចក្រភពអង់គ្លេស ប្រទេសបារាំង អូទ្រីស-ហុងគ្រី និងប្រទេសអេស្ប៉ាញ។ ចក្រភពអូតូម៉ង់(ទួរគី) ម្តងហើយម្តងទៀត បានវាយប្រយុទ្ធគ្នាជាមួយនឹងមហាអំណាចអឺរ៉ុប ជាពិសេសជាមួយអូទ្រីស-ហុងគ្រី។ សព្វថ្ងៃនេះ ជម្លោះជាប្រវត្តិសាស្ត្ររវាងចក្រភពអូតូម៉ង់(អ៊ីស្លាម)និងអូទ្រីស-ហុងគ្រី(គ្រឹស្ត) គឺជាប្រភពនៃជម្លោះជាតិសាសន៍ នៅក្នុងអតីតប្រទេសយូហ្គោស្លាវី (ស្ថិតនៅជ្រុងម្ខាងនៃចក្រភពអូតូម៉ង់បុរាណ)។

នៅក្នុងទ្វីបអឺរ៉ុប ប្រទេសអូទ្រីស-ហុងគ្រី និងអេស្បាញត្រូវបានចងសម្ព័ន្ធភាព នៅក្រោមការគ្រប់គ្រងរបស់រាជវង្សត្រកូលហាប់ស្បើក (Hapsburg) ដែលជាម្ចាស់កម្មសិទ្ធិលើទឹកដីនៃប្រទេសហូឡង់ផងដែរ។ បណ្តាប្រទេសក្រោមអំណាចរាជវង្សត្រកូលហាប់ស្បើក (ដែលកាន់សាសនាគ្រឹស្តនិកាយកាតូលិក) ត្រូវបរាជ័យក្រោមស្នាដៃរបស់ប្រទេសប្រូតេស្តង់ភាគច្រើននៅអឺរ៉ុបខាងជើងដូចជា ប្រទេសបារាំង ប្រទេសអង់គ្លេស ប្រទេសស៊ុយអែត និងប្រទេសហូឡង់ដែលទើបទទួលបានឯករាជ្យថ្មី នៅក្នុង*សង្គ្រាមសាមសិបឆ្នាំ* ១៦១៨-១៦៤៨។ សន្ធិសញ្ញាវ៉ែសហ្វ័រឡៀ ឆ្នាំ ១៦៤៨ បានបង្កើតច្បាប់ជាមូលដ្ឋាន ដែលបានកំណត់លក្ខណៈពិសេសនៃប្រព័ន្ធអន្តរជាតិ តាំងពីពេលនោះមក៖ អធិបតេយ្យភាពនិងបូរណភាពទឹកដីរបស់រដ្ឋនានា ក្នុងហានៈជាសមាជិកស្មើមុខគ្នានិងឯករាជ្យនៃប្រព័ន្ធអន្តរជាតិមួយ។ ចាប់តាំងពីពេលនោះមក រដ្ឋដែលចាញ់ សង្គ្រាមអាចនឹងត្រូវបានគេរឹបអូសយកទឹកដីមួយចំនួន ប៉ុន្តែ ជាទូទៅ ត្រូវបានអនុញ្ញាតអោយបន្តជារដ្ឋឯករាជ្យ ជាជាងត្រូវបានបញ្ចូលទៅក្នុងរដ្ឋជោគជ័យ។

នៅសតវត្សរ៍ទី១៨ អំណាចរបស់ចក្រភពអង់គ្លេសបានកើនឡើងខ្លាំង នៅពេលដែលវាបានចាប់ផ្តើមធ្វើឧស្សាហកម្ម ហើយគូប្រជែងដ៏ធំរបស់ចក្រភពអង់គ្លេស គឺប្រទេសបារាំង។ ប្រទេសស៊ុយអែត ប្រទេសហូឡង់ និងចក្រភពអូតូម៉ង់ សុទ្ធតែបានធ្លាក់ចុះអំណាច ប៉ុន្តែ ប្រទេសរុស្ស៊ីនិងក្រោយមក ព្រុស្ស៊ី (បុព្វការីប្រទេសនៃអាឡឺម៉ង់សម័យទំនើប) បានក្លាយជាតួអង្គសំខាន់។ នៅក្នុង*សង្គ្រាមណាប៉ូឡេអុង* (១៨០៣-១៨១៥) ដែលបានកើតឡើងក្រោយបដិវត្តន៍បារាំង ប្រទេសបារាំងត្រូវបរាជ័យដោយក្រុមសម្ព័ន្ធភាពចម្រុះនៃចក្រភពអង់គ្លេស ប្រទេសហូឡង់ ប្រទេសអូទ្រីស-ហុងគ្រី ប្រទេសអេស្ប៉ាញ ប្រទេសរុស្ស៊ី និងប្រទេសព្រុស្ស៊ី។ *សមាជក្រុងវីយែន*(១៨១៥) ដែលបញ្ចប់សង្គ្រាមនោះបានអះអាងនូវគោលការណ៍នៃអធិបតេយ្យភាពរបស់រដ្ឋឡើងវិញ ជាប្រតិកម្មតទៅនឹងបញ្ហាប្រឈមនៃបដិវត្តន៍បារាំង និងចក្រភពរបស់ណាប៉ូឡេអុង។

នៅក្នុង*ដំនួបទ្វីបអឺរ៉ុប* ដែលគ្របដណ្តប់ក្នុងប៉ុន្មានទសវត្សរ៍បន្ទាប់ រដ្ឋដ៏មានឥទ្ធិពលបំផុតទាំងប្រាំបានព្យាយាមដោយដោគជ័យខ្លះដែរ ដើម្បីសហការគ្នាលើបញ្ហាសំខាន់ៗដើម្បីបញ្ចៀសសង្គ្រាម ដែលជាគំរូដែលអាចកើតមានក្នុងក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ នាពេលបច្ចុប្បន្ននេះ។ នៅក្នុងអំឡុងពេលនេះ ចក្រភពអង់គ្លេសបានក្លាយជាអ្នករក្សាតុល្យភាពអំណាច ដោយបានចូលរួមសម្ព័ន្ធភាពប្រឆាំងនឹងរដ្ឋណាមួយដែលងើបឡើងជាប្រទេសមហាអំណាចធំបំផុតនៅអឺរ៉ុប។

នៅដើមសតវត្សរ៍ទី ២០ ប្រទេសមហាអំណាចដែលកំពុងរះឡើងថ្មីចំនួនបីបានបង្ហាញខ្លួននៅលើឆាកអន្តរជាតិ៖ សហរដ្ឋអាមេរិក(ដែលបានក្លាយជាមហាអំណាចសេដ្ឋកិច្ចពិភពលោក) ប្រទេសជប៉ុន និងប្រទេសអ៊ីតាលី។ ប្រព័ន្ធមហាអំណាចបានរាលដាលដល់សាកលលោកទាំងមូល ដោយមិនត្រឹមប្រមូលនៅតែទ្វីបអឺរ៉ុបនោះទេ។ បណ្តារដ្ឋដែលមានឥទ្ធិពលបាននិងកំពុងធ្វើឧស្សាហូបនីយកម្មដោយ ពង្រីកវិសាលភាពនៃសកម្មភាពពិភពលោកនិងអានុភាពយោធារបស់ខ្លួន។ បន្ទាប់ពីព្រុសស៊ីបានយកឈ្នះអូទ្រីស និងបារាំងក្នុងសង្គ្រាមជាបន្តបន្ទាប់ ប្រទេសអាឡឺម៉ង់កាន់តែធំមួយបានផុសឡើង ដើម្បីប្រកួតប្រជែងតំណែងរបស់ចក្រភពអង់គ្លេស។ នៅក្នុង*សង្គ្រាមលោកលើកទី ១* (១៩១៤-១៩១៨) ប្រទេសអាឡឺម៉ង់ ប្រទេសអូទ្រីស-ហុងគ្រី និងចក្រភពអូតូម៉ង់ត្រូវបានកម្ចាត់ ដោយក្រុមសម្ព័ន្ធមិត្តចម្រុះដែលរួមមានចក្រភពអង់គ្លេស ប្រទេសបារាំង ប្រទេសរុស្ស៊ី ប្រទេសអ៊ីតាលី និងសហរដ្ឋអាមេរិក។ បន្ទាប់ពីការរំជើបរំជួលរយៈពេល ២០ ឆ្នាំ ប្រទេសអាឡឺម៉ង់ ប្រទេសអ៊ីតាលី និងប្រទេសជប៉ុនត្រូវបានវាយអោយបរាជ័យ នៅក្នុង*សង្គ្រាមលោកលើកទី ២* (១៩៣៩-១៩៤៥) ដោយក្រុមសម្ព័ន្ធមិត្តដែលរួមមាន សហរដ្ឋអាមេរិក ប្រទេសអង់គ្លេស ប្រទេសបារាំង ប្រទេសរុស្ស៊ី (សហភាពសូវៀត) និងប្រទេសចិន។ ប្រទេសជោគជ័យទាំងប្រាំក្នុងសង្គ្រាមលោកលើកទី ២ បានក្លាយជាសមាជិកអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ នាពេលបច្ចុប្បន្ននេះ។

ក្រោយសង្គ្រាមលោកលើកទី២ សហរដ្ឋអាមេរិក និងសហភាពសូវៀត ដែលជាសម្ព័ន្ធមិត្តក្នុងសង្គ្រាមប្រឆាំងនឹងប្រទេសអាឡឺម៉ង់ បានក្លាយជាសត្រូវនឹងគ្នាអស់រយៈពេល ៤០ឆ្នាំ នៅក្នុងសង្គ្រាមត្រជាក់។ ទ្វីបអឺរ៉ុបទាំងមូលត្រូវបានបែងចែកទៅជាប្លុកប្រកួតប្រជែងនឹងគ្នា៖ អឺរ៉ុបខាងកើតនិងអឺរ៉ុបខាងខាងលិច ហើយក្នុងនោះ អាឡឺម៉ង់ត្រូវបានបំបែកជាពីររដ្ឋផ្សេងគ្នា។ ផ្នែកផ្សេងទៀតនៃពិភពលោក ក៏បានក្លាយជាទឹកដីសមរភូមិ ដែលប្លុកនីមួយៗ បានព្យាយាមកៀងគរអោយចូលក្នុងសម្ព័ន្ធមិត្ត ឬទទួលរងឥទ្ធិពលរបស់ខ្លួនជារឿយៗ ដោយការឧបត្ថម្ភកាគីបដិបក្សនីមួយ នៅក្នុងសង្គ្រាមក្នុងតំបន់ក៏ដូចជាសង្គ្រាមស៊ីវិល។ ការបញ្ចប់នៃសង្គ្រាមត្រជាក់ នៅកំឡុងឆ្នាំ ១៩៩០ នៅពេលដែលសហភាពសូវៀតដួលរលំ បានបើកចំហអោយប្រព័ន្ធអន្តរជាតិមានកិច្ចសហប្រតិបត្តិការកាន់តែច្រើនឡើង ក្នុងចំណោមប្រទេសមហាអំណាច ដែលប្រហាក់ប្រហែលនឹងសមាជអឺរ៉ុប កាលពីសតវត្សរ៍ទី១៩។

ក្រាហ្វិក ២.៥. ប្រព័ន្ធប្រទេសមហាអំណាច, ១៥០០-២០០០

| | | |

២.៤. សម្ព័ន្ធមិត្ត

២.៤ ចូរពន្យល់ពីគោលដៅនៃសម្ព័ន្ធភាពយោធា អង្គការសន្ធិសញ្ញាអាត្លង់ទិចខាងជើង (ណាតូ) និងការវិវត្តន៍នៃគោលដៅរបស់វា ជាបន្តបន្ទាប់ ក្នុងប្រវត្តិសម្ព័ន្ធភាពនេះ។

សម្ព័ន្ធភាព(Alliance)សំដៅទៅលើការចងក្រងសម្ព័ន្ធភាពរវាងរដ្ឋមួយចំនួន ដែលសម្របសម្រួលសកម្មភាពរបស់ពួកគេ ដើម្បីសម្រេចបាននូវគោលដៅចុងក្រោយជាក់លាក់មួយ។ សម្ព័ន្ធភាពភាគច្រើនត្រូវបានបង្កើតឡើងជាផ្លូវការតាមរយៈសន្ធិសញ្ញាជាលាយលក្ខណ៍អក្សរ ដោយព្យាយាមទប់ទល់នឹងការគំរាមកំហែងទូទៅ និងដោះស្រាយបញ្ហាពាក់ព័ន្ធនឹងសន្តិសុខអន្តរជាតិ ហើយបន្តដោះស្រាយនឹងបញ្ហាជាច្រើននិងក្នុងរយៈពេលកំណត់ណាមួយ។ ការរៀបចំកងកម្លាំងឬបេសកកម្មរយៈពេលខ្លី ដូចជា កងកម្លាំងដឹកនាំដោយសហរដ្ឋអាមេរិកនៅក្នុងប្រទេសអ៊ីរ៉ាក់ អាចត្រូវបានគេហៅថាជា*ក្រុមសម្ព័ន្ធចម្រុះ*(Coalition)។ ប៉ុន្តែ បច្ចេកពាក្យទាំងពីរនេះមិនត្រូវបានកំណត់ច្បាស់លាស់ដូចទឹកនឹងប្រេងនោះទេ។ ប្រទេសពីរប្រហែលជាអាចមានសម្ព័ន្ធភាពជាផ្លូវការនឹងគ្នា ប៉ុន្តែនៅតែអាចជាសត្រូវដូរចត់នឹងគ្នា ដូចជា រវាងសហភាពសូវៀត និងប្រទេសចិន នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ ឬ សមាជិកអង្គការណាតូ រវាងប្រទេសក្រិក និងប្រទេសទួរគីសព្វថ្ងៃ។ ឬប្រទេសពីរអាចបង្កើតនូវអ្វីដែលសមមូលនឹងសម្ព័ន្ធភាពជាក់ស្តែង ដោយគ្មានសន្ធិសញ្ញាជាផ្លូវការឡើយ។

២.៤.១. គោលបំណងនៃសម្ព័ន្ធភាព

សម្ព័ន្ធភាពជាទូទៅមានគោលបំណងបង្កើនអំណាចសមាជិករបស់ពួកគេ ដោយដាក់សមត្ថភាពឬធនធានរួមបញ្ចូលគ្នា។ ចំពោះរដ្ឋតូចៗ សម្ព័ន្ធភាពអាចជាធាតុនៃអំណាចដ៏សំខាន់បំផុតសម្រាប់ពួកគេ ហើយចំពោះប្រទេសមហាអំណាច រចនាសម្ព័ន្ធនៃសម្ព័ន្ធភាពកំណត់រចនាសម្ព័ន្ធអំណាចនៅក្នុងប្រព័ន្ធ(អន្តរជាតិ)។ ក្នុងចំណោមធាតុនៃអំណាចទាំងអស់ គ្មានធាតុណាមួយអាចផ្លាស់ប្តូរបានលឿន និងច្បាស់លាស់ដូចសម្ព័ន្ធភាពឡើយ។ សម្ព័ន្ធភាពភាគច្រើនត្រូវគេបង្កើតឡើងជាការឆ្លើយតបទៅនឹងការគំរាមកំហែងណាមួយ ដែលគេប្រមើលមើលឃើញ។ នៅពេលដែលអំណាចរបស់រដ្ឋមួយរីកចម្រើននិងគំរាមកំហែងដល់រដ្ឋជាគូប្រជែង រដ្ឋនោះនឹងតែងតែបង្កើតសម្ព័ន្ធភាពមួយដើម្បីកម្រិតព្រំដែននៃអំណាចរបស់រដ្ឋខាងដើម។ រឿងនេះបានកើតឡើងចំពោះប្រទេសអ៊ីរ៉ាក់នៅពេលដែលវាបានឈ្លានពានគុយវ៉ែត ក្នុងឆ្នាំ ១៩៩០ ដូចរឿងដែលបានកើតឡើងចំពោះអ៊ីត្តែររបស់អាឡឺម៉ង់ក្នុងទស្សវត្សរ៍ឆ្នាំ ១៩៤០ និងចំពោះណាប៉ូឡេអុងរបស់ប្រទេសបារាំង ក្នុងទសវត្សរ៍ឆ្នាំ ១៨០០។

អ្នកប្រាកដនិយមសង្កត់ធ្ងន់លើភាពរលូននិងបត់បែននៃសម្ព័ន្ធភាពនានា។ សម្ព័ន្ធភាពនេះមិនមែនជាចំណងអាពាហ៍ពិពាហ៍ពោរពេញ ដោយក្តីស្រឡាញ់ទេ ប៉ុន្តែ វាជាអាពាហ៍ពិពាហ៍សម្រាប់តែភាពងាយស្រួល។ សម្ព័ន្ធភាពត្រូវផ្អែកលើផលប្រយោជន៍ជាតិ ហើយអាចផ្លាស់ប្តូរនៅពេលដែលផលប្រយោជន៍ជាតិផ្លាស់ប្តូរ។ ភាពបត់បែននេះជួយអោយដំណើរការតុល្យភាពអំណាច អាចដំណើរការបាន ប្រកបដោយប្រសិទ្ធភាព។ ទោះយ៉ាងណាក៏ដោយ ការបំបែកឬលាយសម្ព័ន្ធភាពមិនមែនជារឿងសាមញ្ញ ហើយក៏មិនមែនថាមិនខាតបង់នោះដែរ៖ កេរ្តិ៍ឈ្មោះរបស់រដ្ឋនោះអាចនឹងត្រូវរងទុក្ខ ហើយសម្ព័ន្ធភាពនាពេលអនាគតអាចពិបាកនឹងបង្កើត។ ដូច្នេះ រដ្ឋនានាតែងតែប្រកាន់ខ្ជាប់នូវលក្ខខណ្ឌសម្ព័ន្ធភាព សូម្បីតែនៅពេលដែលទង្វើនោះមិនបានផ្តល់ផលប្រយោជន៍រយៈពេលខ្លីដល់ពួកគេក៏ដោយ។ យ៉ាងណាក្តី ដោយសារធម្មជាតិនៃភាពអនាធិបតេយ្យអន្តរជាតិ លទ្ធភាពនៃការក្បត់សម្ព័ន្ធមិត្តតែងតែមាន។ អ្នកប្រាកដនិយមនឹងយល់ស្របជាមួយរដ្ឋបុរសជនជាតិអង់គ្លេស

លោកម្ចាស់ ប៉ាល់មឺស្តុន (Lord Palmerston) ដែលបានប្រាប់ថ្លែងទៅកាន់អង្គប្រជុំសភា ក្នុងឆ្នាំ ១៨៤៨ ថា «យើងមិនមានសម្ព័ន្ធមិត្តអស់កល្បជានិច្ច ហើយយើងក៏មិនមានសត្រូវជារៀងរហូតដែរ។ ផលប្រយោជន៍របស់យើងត្រូវនៅស្ថិតស្ថេរនិងអស់កល្បជានិច្ច ហើយផលប្រយោជន៍ទាំងនោះហើយដែលជាកាតព្វកិច្ចរបស់យើងដែលត្រូវតែបំពេញអោយបាន។»[90]

រូបថត មេទ័ពអាមេរិកចុះកិច្ចព្រមព្រៀងជាមួយពួកឧទ្ធាមទ័ពព្រៃ
អាពាហ៍ពិពាហ៍ដើម្បីភាពងាយស្រួល

សម្ព័ន្ធភាពជាទូទៅកើតចេញពីការទទួលបានផលប្រយោជន៍រួមជាក់ស្តែង មិនមែនដោយហេតុផលមនោសញ្ចេតនា ឬមនោគមវិជ្ជានោះទេ។ នៅទីនេះ ឧត្តមសេនីយអាមេរិកម្នាក់កំពុងទាក់ទាញ មេទ័ពព្រៃរបស់អាហ្វហ្គានីស្ថានជាបច្ចាមិត្តអោយផ្សះផ្សារនិងពង្រឹងទំនាក់ទំនង ២០០២។

ឧទាហរណ៍នៃសម្ព័ន្ធភាពបត់បែនមានច្រើនអនេក។ ជាអ្នកប្រឆាំងនឹងលទ្ធិកុម្មុយនិស្តប្រធានាធិបតីអាមេរិក លោក រីឆាដ និកសុន (Richard Nixon) អាចសហការជាមួយកុម្មុយនិស្ត ម៉ៅ សេទុង ក្នុងឆ្នាំ ១៩៧២។ ប្រធានាធិបតីសូវៀត លោក យ៉ូសែប ស្តាលីន អាចចុះហត្ថលេខាលើកតិកាសញ្ញាមិនឈ្លានពានជាមួយពួកហ្វាស៊ីស អាដុល អ៊ីត្លែរ ហើយបន្ទាប់មកបានសហការជាមួយរបបមូលធននិយមខាងលិចប្រឆាំងនឹងអ៊ីត្លែរ។ សហរដ្ឋអាមេរិកអាចគាំទ្រក្រុមសកម្មប្រយុទ្ធឥស្លាម នៅក្នុងប្រទេសអាហ្វហ្គានីស្ថានប្រឆាំងនឹងសហភាពសូវៀតក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ បន្ទាប់មកអាមេរិកបានវាយប្រហារពួកគេក្នុងឆ្នាំ ២០០១។ រាល់ពេលដែលប្រវត្តិសាស្ត្រនាំមកនូវការផ្លាស់ប្តូរទិសដៅសម្ព័ន្ធភាពអន្តរជាតិបែបនេះ មនុស្សជាច្រើនមានការភ្ញាក់ផ្អើល។ អ្នកប្រាកដនិយមពិតជាមិនមានភាពភ្ញាក់ផ្អើលទាល់តែសោះទេ។

ភាពបត់បែននៃសម្ព័ន្ធភាពបានធ្វើអោយទ្វេគ្រោះឬបញ្ហាសុវត្ថិភាព កាន់តែសាំញ៉ាំខ្លាំង (សូមមើលផ្នែកបន្ទាប់)។ ប្រសិនបើមានតែរដ្ឋពីរ នោះរដ្ឋនីមួយៗអាចផ្តួផ្តងសមត្ថភាពរបស់ខ្លួនអោយមានកម្រិតប្រហាក់ប្រហែលគ្នា ដើម្បីមានប្រព័ន្ធការពារខ្លាំងគ្រប់គ្រាន់ ប៉ុន្តែ មិនមានសមត្ថភាពវាយប្រហារអោយបានជោគជ័យដាច់នោះទេ។ ប៉ុន្តែ ប្រសិនបើរដ្ឋទីបីមានសេរីភាពក្នុងការចងសម្ព័ន្ធមិត្តជាមួយភាគីណាមួយ នោះរដ្ឋនីមួយៗត្រូវបង្កើតប្រព័ន្ធការពារអោយបានខ្លាំងក្លា ប្រឆាំងនឹងសម្ព័ន្ធភាពដ៏មានសក្តានុពលរវាងគូសត្រូវរបស់ខ្លួន ជាមួយរដ្ឋទីបី។ ការគម្រាមកំហែងកាន់តែខ្លាំង ហើយបញ្ហាសន្តិសុខកាន់តែពិបាកបញ្ជៀស។

សិនិទ្ធភាពសម្ព័ន្ធភាព[91] សំដៅលើភាពស្អិតរមួត ឬ ភាពងាយស្រួលដែលសមាជិកទាំងឡាយរួមគ្នាបង្កើតនិងរក្សាសម្ព័ន្ធភាពណាមួយ។ សិនិទ្ធភាពមានទំនោរកើនឡើងខ្ពស់ នៅពេលដែលផលប្រយោជន៍ជាតិរបស់សមាជិកទាំងអស់ដើរស្របគ្នា និងនៅពេលដែលកិច្ចសហប្រតិបត្តិការក្នុងសម្ព័ន្ធភាពត្រូវបានប្រែក្លាយអោយជាស្ថាប័ននិងទម្លាប់ជាប្រចាំ។ នៅពេលដែលរដ្ឋសមាជិកដែលមានផលប្រយោជន៍ខុសគ្នាបង្កើតជាសម្ព័ន្ធមិត្តប្រឆាំងនឹងសត្រូវរួម សម្ព័ន្ធភាពអាចនឹងបែកបាក់គ្នា ប្រសិនបើការគំរាមកំហែងពីសត្រូវរួមធ្លាក់ចុះ (ឧទាហរណ៍ដូចជាសម្ព័ន្ធមិត្តអាមេរិក-សូវៀត ក្នុងសង្គ្រាមលោកលើកទីពីរជាដើម)។សូម្បីតែនៅពេលដែលភាពស្អិតរមួតនៃសម្ព័ន្ធភាពមានកម្រិតខ្ពស់ ដូចជានៅក្នុងអង្គការណាតូ ក្នុងកំឡុងសង្គ្រាមត្រជាក់ ជម្លោះឬ

[90] Remarks in the House of Commons, March ១, ១៨៤៨.

[91] សិនិទ្ធភាព (សិ-និត-ធៈ) ភាពជិតស្និត សេចក្តីស្និទ្ធស្នាល ការជិតជិតនឹងគ្នា។ (Nath, ១៩៦៧)

ការខ្វែងគំនិតគ្នាលើការសម្រេចថា តើអ្នកណាត្រូវទទួលបន្ទុកចំណាយក្នុងសម្ព័ន្ធភាព (**ការបែងចែកបន្ទុកចំណាយ**)។

ប្រទេសមហាអំណាចច្រើនតែបង្កើតសម្ព័ន្ធភាព (ឬការប្តេជ្ញាចិត្តជាផ្លូវការតិចជាង) ជាមួយរដ្ឋតូចៗ ដែលជួនកាលគេហៅថា រដ្ឋរណប។ *វិធានការណ៍ទប់ស្កាត់បន្ថែម*សំដៅលើការប្រើប្រាស់ការគំរាមកំហែងរបស់រដ្ឋខ្លាំងដើម្បីរារាំងការវាយប្រហារលើរដ្ឋរណបដ៏ទន់ខ្សោយជាង ដូចជា ការគំរាមកំហែងរបស់សហរដ្ឋអាមេរិកក្នុងការវាយប្រហារសហភាពសូវៀត ប្រសិនបើប្រទេសនេះឈ្លានពានអឺរ៉ុបខាងលិច។ ប្រទេសមហាអំណាចនានាប្រឈមមុខនឹងគ្រោះថ្នាក់ពិតប្រាកដ ដោយត្រូវគេអូសទាញចូលទៅក្នុងសង្គ្រាមរវាងគ្នា ជុំវិញបញ្ហាក្នុងតំបន់ដែលមិនសំខាន់ ប្រសិនបើរដ្ឋរណបរៀងៗពើបប្រយុទ្ធគ្នាក្នុងសង្គ្រាម។ ប្រសិនបើប្រទេសមហាអំណាចមិនមកការពាររដ្ឋរណបរបស់ខ្លួនទេ រដ្ឋរណបអាចនឹងបាត់បង់ទំនុកចិត្តលើខ្លួន ប៉ុន្តែ ប្រសិនបើពួកគេចូលជួយ ពួកគេអាចនឹងលង់ខ្លួនក្នុងសង្គ្រាម ដែលត្រូវចំណាយធនធានមហាសាល។ សហភាពសូវៀតព្រួយបារម្ភថាការប្តេជ្ញាចិត្តរបស់ខ្លួន ចំពោះប្រទេសចិនក្នុងទសវត្សរ៍ឆ្នាំ ១៩៥០, ចំពោះប្រទេសគុយបាក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ និងចំពោះប្រទេសស៊ីរី និងអេហ្ស៊ីបក្នុងទសវត្សរ៍ឆ្នាំ ១៩៧០ (ក្នុងចំណោមផ្សេងទៀតជាច្រើន) អាចបណ្តាលអោយផ្ទុះសង្គ្រាមមហន្តរាយជាមួយសហរដ្ឋអាមេរិក។

២.៤.២. **ណាតូ** (NATO)

នាពេលបច្ចុប្បន្ននេះ សម្ព័ន្ធភាពផ្លូវការសំខាន់ពីរគ្របដណ្តប់លើទិដ្ឋភាពសន្តិសុខអន្តរជាតិ។ មកទល់ពេលនេះ អង្គការសន្ធិសញ្ញាអាត្លង់ទិកខាងជើង (NATO) ដែលមានឥទ្ធិពលខ្លាំងជាងនេះ ដែលគ្របដណ្តប់អឺរ៉ុបខាងលិចនិងអាមេរិកខាងជើង។ (ទីពីរគឺជាសម្ព័ន្ធមិត្តអាមេរិក-ជប៉ុន។ សូមមើលផ្នែកបន្ទាប់) ដោយប្រើផលិតផលក្នុងស្រុកសរុប ជារង្វាស់នៃអំណាច, សមាជិកអង្គការណាតូទាំង ៣០* ប្រទេសមានផលិតផលក្នុងស្រុកសរុបជិតពាក់កណ្តាលនៃផ.ស.ស.ក្នុងពិភពលោកទាំងមូល។ សមាជិករបស់វារួមមាន សមាជិកស្ថាបនិកចំនួន ១២៖ បែលហ្ស៊ិក កាណាដា ដាណឺម៉ាក បារាំង អ៊ីស្លង់ អ៊ីតាលី លុចសំបួ ហូឡង់ ន័រវេស ព័រទុយហ្គាល់ ចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិក ហើយសមាជិកផ្សេងទៀត ក៏បានចូលជាបន្តបន្ទាប់ដូចជា៖ ប្រទេសក្រិក និងប្រទេសទួរគី (១៩៥២) ប្រទេសអាឡឺម៉ង់(១៩៥៥) ប្រទេសអេស្ប៉ាញ (១៩៨២) សាធារណរដ្ឋឆែក ប្រទេសហុងគ្រី និងប្រទេសប៉ូឡូញ(១៩៩៩) ប្រទេសប៊ុលហ្គារី ប្រទេសអេស្តូនី ប្រទេសឡាតវី ប្រទេសលីទុយអានី ប្រទេសរូម៉ានី ប្រទេសស្លូវ៉ាគី និងប្រទេសស្លូវេនី(២០០៤) ប្រទេសអាល់បានីនិងប្រទេសក្រូអាត(២០០៩) ប្រទេសម៉ុងតេណេហ្គ្រោ(២០១៧) និងប្រទេសម៉ាសេដូនីខាងជើង(២០២០)។ បុគ្គលិកយោធាមកពីប្រទេសជាសមាជិកសម្របសម្រួលផែនការ និងធ្វើសមយុទ្ធយោធា ដោយផ្ទាល់ ជាប្រចាំ នៅឯទីស្នាក់ការកណ្តាលរបស់អង្គការណាតូ នៅទីក្រុងប្រ៊ុចសែលនៃប្រទេសបែលហ្ស៊ិក។ អ្នកកាន់តំណែង*អគ្គមេបញ្ជាការកងកម្លាំងចម្រុះ*របស់អង្គការណាតូ តែងតែជាឧត្តមសេនីយ៍របស់សហរដ្ឋអាមេរិក។ នៅក្នុងអង្គការណាតូ រដ្ឋនីមួយៗបានរួមចំណែកអង្គភាពយោធារបស់ខ្លួន រួមជាមួយនឹងវប្បធម៌ ភាសា និងកស្តុការបស់ជាតិខ្លួន។

អង្គការណាតូត្រូវបានបង្កើតឡើង នៅក្នុងឆ្នាំ ១៩៤៩ ដើម្បីប្រឆាំងនិងរារាំងការពង្រីកអំណាចរបស់សហភាពសូវៀតនៅអឺរ៉ុប។ ជាសមភាគីរបស់ខ្លួននៅអឺរ៉ុបខាងកើតកំឡុងសង្គ្រាមត្រជាក់ កិច្ចព្រមព្រៀងវ៉ាសូវីដឹកនាំដោយសូវៀត ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៥៥ ហើយត្រូវបានរំសាយនៅឆ្នាំ ១៩៩១។ ក្នុងអំឡុង

សង្គ្រាមត្រជាក់ សហរដ្ឋអាមេរិកបានរក្សាកងទ័ពជាង ៣០០ ០០០ នាក់ នៅក្នុងទ្វីបអឺរ៉ុប ជាមួយនឹងយន្តហោះ រថក្រោះ និងយុទ្ធភ័ណ្ឌទំនើបៗផ្សេងទៀត។ ក្រោយសង្គ្រាមត្រជាក់បានបញ្ចប់ កម្លាំងទាំងនេះត្រូវបានកាត់បន្ថយមកនៅត្រឹម ១០០ ០០០នាក់។ ប៉ុន្តែ អង្គការណាតូនៅតែរួមកម្លាំងគ្នា ដោយសារតែសមាជិករបស់ខ្លួនជឿថា អង្គការណាតូផ្តល់ស្ថិរភាពដ៏មានប្រយោជន៍ ទោះបីបេសកកម្មរបស់ខ្លួនមិនច្បាស់លាស់ក៏ដោយ។ មាត្រា ៥ ដែលត្រូវបានចាត់ទុកថាជាបេះដូងរបស់អង្គការណាតូ ស្នើអោយរដ្ឋសមាជិកទាំងអស់មកការពាររដ្ឋសមាជិកដែលរងការវាយប្រហារ។ វាត្រូវបានគេមើលឃើញថាជា ការប្តេជ្ញាចិត្តយ៉ាងមុតមាំរបស់សហរដ្ឋអាមេរិកក្នុងការជួយការពារអឺរ៉ុបខាងលិចទប់ទល់នឹងការឈ្លានពានណាមួយពីសហភាពសូវៀត ប៉ុន្តែផ្ទុយទៅវិញ វាត្រូវបានកោះហៅជាលើកដំបូង នៅពេលដែលអឺរ៉ុបចូលមកការពារសហរដ្ឋអាមេរិក បន្ទាប់ពីការវាយប្រហារភេរវកម្ម នៅក្នុងឆ្នាំ ២០០១។

ការប្រើប្រាស់កម្លាំងជាក់ស្តែងលើកដំបូង ដោយអង្គការណាតូ ប្រព្រឹត្តទៅ នៅបូស្នៀ ក្នុងឆ្នាំ ១៩៩៤ ដើម្បីគាំទ្របេសកកម្មរបស់អង្គការសហប្រជាជាតិ នៅដែនដីនោះ។ ការចាត់ចែង«គន្លឹះទ្វេ» អនុញ្ញាតអោយអង្គការសហប្រជាជាតិគ្រប់គ្រងប្រតិបត្តិការរបស់អង្គការណាតូ នៅក្នុងប្រទេសបូស្នៀ ហើយអង្គការសហប្រជាជាតិបារម្ភខ្លាចការសងសឹកប្រឆាំងនឹងកងរក្សាសន្តិភាពដែលប្រើតែអាវុធធុនស្រាលក្នុងបេសកកម្មរបស់ខ្លួន ប្រសិនបើអង្គការណាតូវាយប្រហារកងកម្លាំងស៊ែប៊ី ដើម្បីការពារជនស៊ីវិលបូស្នៀ។ ជាលទ្ធផល អង្គការណាតូបានធ្វើការគំរាមកំហែង ដោយកំញើញដោយការវាយប្រហារតាមអាកាសជានិមិត្តរូប ប៉ុន្តែ បន្ទាប់មកបានបញ្ឈប់វិញ បន្ទាប់ពីមានការរិះគន់ពីអង្គការសហប្រជាជាតិ។ ការវាយប្រហារនេះបានធ្វើអោយប៉ះពាល់ដល់ជំនឿទុកចិត្តលើអង្គការណាតូ។ ក្រោយមក សកម្មភាពណាតូ នៅតំបន់បាល់កង់ (សង្គ្រាមអាកាសជួយកូសូវ៉ូក្នុងឆ្នាំ ១៩៩៩ និងការរក្សាសន្តិភាព នៅម៉ាសេដូនៀ ក្នុងឆ្នាំ ២០០១) បានដំណើរការយ៉ាងរលូនជាងនៅក្នុងលក្ខខណ្ឌភាពស្អិតរមួតនៃចំណងសម្ព័ន្ធភាព។

អន្តរាគមន៍របស់អង្គការណាតូ ក្នុងប្រទេសលីប៊ីក្នុងឆ្នាំ ២០១១ ក៏ឆ្លុះបញ្ចាំងពីប្រសិទ្ធភាពនៃសម្ព័ន្ធភាពនេះផងដែរ នៅពេលដែលអំណាចកងទ័ពអាកាសបានបង្វែរទិសដៅនៃសង្គ្រាមឧទ្ធាម ដែលបានផ្តួលរំលំរបបផ្តាច់ការលីប៊ី។ ដោយមានក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិនិងសម្ព័ន្ធអារ៉ាប់គាំទ្រតំបន់គ្មានការហោះហើរ(no-fly zone) ហើយមានបណ្តាប្រទេសនៅអឺរ៉ុបផ្តល់យន្តហោះចម្បាំងភាគច្រើន អង្គការណាតូបានវាយតម្លៃប្រតិបត្តិការនេះថាទទួលបានជោគជ័យយ៉ាងត្រចះត្រចង់។

បច្ចុប្បន្ននេះ កងកម្លាំងណាតូមកពីប្រទេសជាសមាជិកមួយចំនួនកំពុងប្រយុទ្ធប្រឆាំងនឹងកងកម្លាំងតាលីបង់ នៅអាហ្វហ្គានីស្ថាន។ ចាប់តាំងពីឆ្នាំ ២០០៣ ដល់ឆ្នាំ ២០១៤ កងកម្លាំងទាំងនេះ ដែលត្រូវបានគេស្គាល់ថាជា កងកម្លាំងជំនួយសន្តិសុខអន្តរជាតិ(ISAF) ស្ថិតនៅក្រោមការដឹកនាំរបស់អង្គការណាតូ។ នៅក្នុងកម្រិតកំពូលរបស់វា (រវាងឆ្នាំ ២០១០ និង ២០១២) ទាហានជាង ១០០ ០០០ នាក់ បានបម្រើការនៅក្នុងកងកម្លាំងជំនួយសន្តិសុខអន្តរជាតិ ជាមួយនឹងរដ្ឋជាសមាជិកអង្គការណាតូ ដែលផ្តល់កម្លាំងតវបភាគច្រើនបំផុត។ រដ្ឋដែលមិនមែនជាសមាជិកអង្គការណាតូ ដូចជា អូស្ត្រាលី នូវែលហ្សេឡង់ និងហ្សកជានី ក៏បានចូលរួមចំណែកផ្តល់កងទ័ពដល់កងកម្លាំងជំនួយសន្តិសុខអន្តរជាតិផងដែរ។ នៅឆ្នាំ ២០១៥ បេសកកម្មនៃកងកម្លាំងជំនួយសន្តិសុខអន្តរជាតិត្រូវបានបញ្ចប់ជាផ្លូវការ ហើយបេសកកម្មគាំទ្រដាច់ខាត (Resolute Support Mission) បានចូលមកជំនួស ហើយចំនួនទាហានបានធ្លាក់ចុះមកត្រឹមចំនួន ១៣ ០០០ នាក់

ដោយកងទ័ពភាគច្រើនផ្តល់ដោយប្រទេសសមាជិកអង្គការណាតូ (សូមមើលឧទាហរណ៍បន្ថែមអំពីការស្វែងរកដំណោះស្រាយផលប្រយោជន៍រួម)។

ក្រាហ្វិក ២.៧ ការពង្រីកសមាជិកភាពអង្គការសន្ធិសញ្ញាអាត្លង់ទិកខាងជើង



ប្រភព៖ ក្រសួងការពារជាតិអាមេរិក

សហភាពអឺរ៉ុបបានបង្កើតកងកម្លាំងដែលអាចដាក់ពង្រាយបានយ៉ាងឆាប់រហ័សរបស់ខ្លួន នៅក្រៅព្រំដែនរបស់អង្គការអូតង់។ ការសម្រេចចិត្តធ្វើបែបនេះអាចកើតមានបាន ម្យ៉ាងដោយសារ ភាពទន់ខ្សោយខាងយោធារបស់អឺរ៉ុប ដែលបានលេចឡើង នៅក្នុងសង្គ្រាមកូសូវ៉ូឆ្នាំ ១៩៩៩ ដែលសហរដ្ឋអាមេរិកបានចូលរួមចំណែកកងកម្លាំងច្រើនបំផុត បើគិតរហូតមកដល់ពេលនេះ។ ទោះបីជាកងកម្លាំងអឺរ៉ុប (Eurocorps) មួយនេះ ជាទូទៅ ធ្វើការសហការជាមួយអង្គការណាតូក៏ដោយ វាក៏ផ្តល់អោយអឺរ៉ុបនូវឯករាជ្យភាពបន្ថែមទៀតពីសហរដ្ឋអាមេរិកផងដែរ។ នៅក្នុងឆ្នាំ ២០០៣ សហភាពអឺរ៉ុបបានបញ្ជូនកងកម្លាំងយោធាជាកងរក្សាសន្តិភាពទៅកាន់ សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ ដែលជាប្រតិបត្តិការយោធាចម្រុះជាតិសាសន៍ដំបូង

របស់អឺរ៉ុប ដែលប្រព្រឹត្តទៅ នៅខាងក្រៅរង្វង់អង្គការណាតូ។ នៅឆ្នាំ ២០០៤ កងកម្លាំងណាតូនិងសហរដ្ឋអាមេរិកបានដកខ្លួនចេញពីបូស្នៀ ក្រោយបញ្ចប់បេសកកម្មប្រាំបួនឆ្នាំរបស់ខ្លួន ដោយបាន បង្វែរការរក្សាសន្តិភាពនៅទីនោះទៅអោយសហភាពអឺរ៉ុប (ដូចដែលពួកគេបានធ្វើនៅម៉ាសេដូនី)។ ប៉ុន្តែ កងកម្លាំងណាតូ រួមទាំងទាហានអាមេរិកបន្តមានវត្តមាន នៅក្បែរៗកូសូវ៉ូដែល។

បញ្ហាដ៏ធំបំផុតសម្រាប់អង្គការណាតូ គឺការពង្រីកសមាជិកភាពទៅទិសខាងកើត នាពេលថ្មីៗនេះ ដោយពង្រីកហួសពីបន្ទាត់ព្រំដែនដែលបែងចែកអឺរ៉ុបខាងកើត-ខាងលិច ក្នុងកំឡុងសង្គ្រាមត្រជាក់ (សូមមើលក្រាហ្វិក ២.៧)។ នៅឆ្នាំ ១៩៩៩ បណ្តាប្រទេសអតីតសហភាពសូវៀតដូចជា ប៉ូឡូញ សាធារណរដ្ឋឆេក និងហុងគ្រីបានចូលរួមជាសមាជិកសម្ព័ន្ធភាពណាតូ។ ប្រទេសដែលបានចូលរួមជាបន្តបន្ទាប់ នៅឆ្នាំ ២០០៤ មានដូចជា ប្រទេសអេស្តូនី ឡាតវី លីទុយអានី ស្លូវ៉ាគី ស្លូវេនី រូម៉ានី និងប៊ុលហ្គារី។ ក្នុងឆ្នាំ ២០០៩ អាល់បានី និងក្រូអាតត្រូវបានទទួលចូលជាសមាជិក នៅក្នុងអង្គការណាតូ ហើយនៅឆ្នាំ ២០១៧ ប្រទេសម៉ុងតេណេហ្គ្រោបានក្លាយជាសមាជិកទី ២៩ ចុងក្រោយប្រទេសម៉ាសេដូនៀបានចូលជាសមាជិក នៅឆ្នាំ ២០២០។ ចំណែកឯប្រទេសហ្សកហ្ស៊ីនិងបូស្នៀ សុទ្ធតែមានបំណងចង់ចូលជាសមាជិកអង្គការណាតូនាពេលអនាគត។ ការបំពាក់សមត្ថភាពយោធារបស់សមាជិកថ្មីអោយត្រូវស៊ីគ្នាជាមួយនឹងអង្គការណាតូ គឺជាកិច្ចការសំខាន់ខ្លាំង ដែលទាមទារអោយសមាជិកអង្គការណាតូចាស់និងថ្មីបង្កើនការចំណាយថវិកាជាច្រើនបន្ថែមទៀត លើវិស័យយោធា។ ការពង្រីកសមាជិកភាពរបស់អង្គការណាតូ ត្រូវបានគេលើកហេតុផលថាជាមធ្យោបាយដើម្បីពង្រឹងលទ្ធិប្រជាធិបតេយ្យថ្មី និងជាយុទ្ធសាស្ត្រការពារប្រឆាំងនឹងការឈ្លានពានរបស់រុស្ស៊ីនាពេលអនាគត។ ប៉ុន្តែ សង្គ្រាមអ៊ីរ៉ាក់ នៅឆ្នាំ ២០០៣ បានធ្វើអោយមានការបែងចែករវាងសមាជិកអង្គការណាតូ។ សមាជិកយូរយោរណាស់មកហើយ ដូចជា ប្រទេសបារាំង និងអាឡឺម៉ង់បានប្រឆាំងយ៉ាងខ្លាំងចំពោះសង្គ្រាម ហើយទួរគីក៏បានបដិសេធមិនអនុញ្ញាតអោយកងកម្លាំងជើងគោកអាមេរិកឆ្លងចូលអ៊ីរ៉ាក់។ ក្នុងពេលជាមួយគ្នានោះ មេដឹកនាំសហរដ្ឋអាមេរិកបានចាប់ផ្តើមបង្វែរប្រតិបត្តិការ (និងកញ្ចប់ថវិកា)មួយចំនួន ទៅកាន់សមាជិកថ្មី នៅអឺរ៉ុបខាងកើតដូចជា ប្រទេសរូម៉ានី ដោយចំណាយអស់តិចជាងមុន និងមានទីតាំងនៅជិតមជ្ឈិមបូព៌ាជាង ខណៈពេលដែលបន្តយចំនួនកងកម្លាំងដែលមានមូលដ្ឋាននៅប្រទេសអាឡឺម៉ង់។

រូបថត *ប្រធានាធិបតី កេណ្ណឺឌី កំពុងត្រួតពល*

សម្ព័ន្ធភាពរឹងមាំ

សម្ព័ន្ធភាពណាតូគឺជាកម្លាំងយោធាខ្លាំងបំផុតនៅលើពិភពលោក ចាប់តាំងពីឆ្នាំ១៩៤៩។ បេសកកម្មរបស់វា នៅសម័យក្រោយសង្គ្រាមត្រជាក់មានភាពមិនច្បាស់លាស់ណាស់ដែរ។ នៅទីនេះ ប្រធានាធិបតីអាមេរិក លោក កេណ្ណឺឌី កំពុងពិនិត្យមើលកងកម្លាំងសហរដ្ឋអាមេរិកនៅប្រទេសអាល្លឺម៉ង់ ឆ្នាំ ១៩៦៣។

មេដឹកនាំរុស្ស៊ីប្រឆាំងនឹងការពង្រីកខ្លួនរបស់អង្គការណាតូទៅកាន់អឺរ៉ុបខាងកើត ដោយចាត់ទុកទង្វើនោះជាការឈ្លានពាន និងប្រឆាំងនឹងប្រទេសរុស្ស៊ី។ ពួកគេបន្តចាត់ទុកការពង្រីក អង្គការណាតូថាជាការគូសបន្ទាត់បែងចែកទ្វីបអឺរ៉ុបឡើងវិញ ហើយបានរុញច្រានបន្ទាត់បែងចែកនោះ កាន់តែទៅជិតព្រំដែនរបស់រុស្ស៊ី។ ការភ័យខ្លាចទាំងនេះពង្រឹងស្មារតីនិងកម្លាំងនយោបាយជាតិនិយម ក៏ដូចជាមនោសញ្ចេតនាប្រឆាំងលោកខាងលិច នៅក្នុងប្រទេសរុស្ស៊ី។ ដើម្បីកាត់បន្ថយបញ្ហាប្រឈម អង្គការណាតូបានបង្កើតប្រភេទ សមាជិកភាពជានិមិត្តរូប «ភាពជាដៃគូដើម្បីសន្តិភាព» (Partnership for Peace) ដែលប្រទេសអឺរ៉ុបខាងកើតស្ទើរតែ

ទាំងអស់ និងអតីតរដ្ឋសហភាពសូវៀត រួមទាំងរុស្ស៊ី បានចូលរួមផងដែរ។ ទោះជាយ៉ាងណាក៏ដោយ ការទម្លាក់គ្រាប់បែករបស់អង្គការណាតូ នៅក្នុងឆ្នាំ ១៩៩៩ លើប្រទេសស៊ែប៊ី បានបង្កើនការភ័យខ្លាចរបស់រុស្ស៊ី ទាក់ទងនឹងការពង្រីកសមាជិកភាពទៅភាគខាងកើតរបស់អង្គការណាតូ។ ថ្មីៗនេះ កិច្ចសហប្រតិបត្តិការអង្គការណាតូជាមួយនឹងប្រទេសអ៊ុយក្រែននិងប្រទេសហ្សកហ្ស៊ី ដែលជាប្រទេសចុងក្រោយ ដែលបានធ្វើសង្គ្រាម មួយរយៈពេលខ្លីប្រឆាំងនឹងរុស្ស៊ីក្នុងឆ្នាំ២០០៨ ក៏បានធ្វើអោយរុស្ស៊ីខឹងសម្បារជាខ្លាំង ផងដែរ។ ភាពតានតឹងរវាងរុស្ស៊ីនិងអង្គការណាតូបានកើនឡើងខ្លាំង ចាប់តាំងពីការដាក់បញ្ចូលតំបន់គ្រីមេរបស់អ៊ុយក្រែនចូលទៅក្នុងប្រទេសរុស្ស៊ី ឆ្នាំ២០១៤ និងទង្វើដែលរុស្ស៊ីគាំទ្រពួកឧទ្ទាមបំបែករដ្ឋ នៅភាគខាងកើតនៃប្រទេសអ៊ុយក្រែន។ ជាការឆ្លើយតបទៅនឹងការពង្រីកអង្គការណាតូ រុស្ស៊ីបានពង្រីកកិច្ចសហប្រតិបត្តិការយោធារបស់ខ្លួនជាមួយរដ្ឋមួយចំនួន ដូចជា ប្រទេសវ៉េណេស៊ុយអេឡា ដែលគ្រប់គ្រងដោយ រដ្ឋាភិបាលដែលរិះគន់គោលនយោបាយការបរទេសរបស់សហរដ្ឋអាមេរិក និងប្រទេសចិនដែលរុស្ស៊ីបានធ្វើសមយុទ្ធយោធារួមគ្នា រួមទាំងសមយុទ្ធនៅក្បែរបណ្តារដ្ឋបាល់ទិកនិងក្បែរប្រទេសកូរ៉េខាងជើង ក្នុងឆ្នាំ ២០១៧។ នៅក្នុងឆ្នាំ ២០១៦ ប្រទេសរុស្ស៊ីបានចាត់វិធានការណ៍យ៉ាងលឿនដើម្បីគាំទ្ររដ្ឋាភិបាលស៊ីរី ដែលជាសម្ព័ន្ធមិត្តជាយូរណាស់មកហើយ និងជាទីតាំងតែមួយគត់ដែលមានមូលដ្ឋានកងទ័ព នៅតំបន់មជ្ឈឹមបូព៌ា។

២.៤.៣. សម្ព័ន្ធមិត្តផ្សេងៗ

សម្ព័ន្ធភាពសំខាន់បំផុតមួយទៀត គឺ**សន្ធិសញ្ញាសន្តិសុខអាមេរិក-ជប៉ុន** ដែលជាសម្ព័ន្ធភាពទ្វេភាគី។ នៅក្រោមសម្ព័ន្ធភាពនេះ សហរដ្ឋអាមេរិករក្សាកងទ័ព ជិត ៥០ ០០០ នាក់ នៅក្នុងប្រទេសជប៉ុន (ជាមួយនឹងអាវុធ បរិក្ខារទ័ព និងជំនួយផ្នែកដឹកជញ្ជូនផ្សេងទៀត)។ ប្រទេសជប៉ុនរ៉ាប់រងបង់ប្រាក់អោយអាមេរិករាប់ពាន់លានដុល្លារអាមេរិក ជារៀងរាល់ឆ្នាំ ដើម្បីជួយទូទាត់ថ្លៃចំណាយប្រហែលពាក់កណ្តាលនៃលើការដាក់ទ័ពទាំងនោះ។ សម្ព័ន្ធភាពនេះត្រូវបានបង្កើតឡើង ក្នុងឆ្នាំ១៩៥១ (កំឡុងសង្គ្រាមរវាងប្រទេសកូរ៉េទាំងពីរ) ប្រឆាំងនឹងការគំរាមកំហែងណាមួយរបស់សូវៀតមកលើប្រទេសជប៉ុន។

ដោយសារតែឫសគល់របស់វាកើតឡើង ក្នុងពេលដែលយោធាអាមេរិកកាន់កាប់ប្រទេសជប៉ុន បន្ទាប់ពីសង្គ្រាមលោកលើកទី ២ សម្ព័ន្ធភាពនេះមិនមានលក្ខណៈស៊ីមេទ្រីនឹងគ្នាទេ។ អាមេរិកប្តេជ្ញាការពារជប៉ុន ប្រសិនបើជប៉ុនរងការវាយប្រហារណាមួយ ប៉ុន្តែ ប្រទេសជប៉ុនមិនជាប់កាតព្វកិច្ចការពារអាមេរិកវិញទេ។ សហរដ្ឋអាមេរិករក្សាកងទ័ពនៅក្នុងប្រទេសជប៉ុន ផ្ទុយទៅវិញ ជប៉ុនមិនអាចដាក់ពង្រាយកងទ័ពខ្លួនលើទឹកដីអាមេរិកទេ។ សហរដ្ឋអាមេរិកក៏មានក្រុមសម្ព័ន្ធមិត្តពីរបីផ្សេងទៀតដែរ ប៉ុន្តែ សម្ព័ន្ធភាពសំខាន់តែមួយគត់របស់ប្រទេសជប៉ុន គឺជាសម្ព័ន្ធមិត្តជាមួយសហរដ្ឋអាមេរិក។ ចំណែក ការរួមចំណែកកម្លាំងយោធាសរុបរបស់សហរដ្ឋអាមេរិកក្នុងសម្ព័ន្ធភាពនេះ ក៏មានទំហំធំខ្លាំងក្លាជាងចំណែករបស់ខ្លួនក្នុងអង្គការណាតូដែរ។

រដ្ឋធម្មនុញ្ញរបស់ប្រទេសជប៉ុន (ចងក្រងដោយ លោកឧត្តមសេនីយអាមេរិក ដាក់ក្លាស់ ម៉ាខាធួរ (Douglas MacArthur) បន្ទាប់ពីសង្គ្រាមលោកលើកទីពីរ) បោះបង់ចោលសិទ្ធិធ្វើសង្គ្រាម និងរក្សាកងកម្លាំងយោធា ទោះបីជាការបកស្រាយនានាបានបន្ធូរបន្ថយការហាមឃាត់នេះ នាពេលក្រោយៗក៏ដោយ។ ជាឧទាហរណ៍ ក្នុងឆ្នាំ ២០១៥ សភារបស់ប្រទេសជប៉ុនបានអនុម័តច្បាប់ថ្មីមួយដែលអនុញ្ញាតអោយមានការប្រើប្រាស់កម្លាំងយោធានៅក្រៅប្រទេស។ ជប៉ុនរក្សាកម្លាំងយោធា ហៅថា កងកម្លាំងស្វ័យការពារ (Self-Defense Forces) ដែលមានអានុភាពរឹងមាំគ្រប់គ្រាន់ដើម្បីការពារទឹកដី ប៉ុន្តែ មិនមែនសម្រាប់ធ្វើការ

ឈ្លានពាននោះទេ។ វាជាកងទ័ពមានឥទ្ធិពលខ្លាំង បើគិតតាមស្តង់ដារពិភពលោក ប៉ុន្តែ មានទំហំតូចជាងកម្លាំងសេដ្ឋកិច្ចរបស់ប្រទេសជប៉ុន។ ជាទូទៅ មតិសាធារណៈរបស់ជប៉ុនរារាំងលទ្ធិយោធានិយម និងរារាំងការអភិវឌ្ឍន៍អាវុធនុយក្លេអ៊ែរ ជាពិសេស បន្ទាប់ពីទីក្រុងពីរធំៗ របស់ប្រទេសជប៉ុនត្រូវបានកំទេចដោយគ្រាប់បែកនុយក្លេអ៊ែរ ក្នុងសង្គ្រាមលោកលើកទីពីរ។ យ៉ាងណាក៏ដោយ មេដឹកនាំជប៉ុនមួយចំនួនជឿថា តួនាទីសន្តិសុខជាផ្លូវការរបស់ជប៉ុន នៅលើឆាកអន្តរជាតិ គួរតែពង្រីកអោយស្របតាមអំណាចសេដ្ឋកិច្ចរបស់ខ្លួន។ កងទ័ពជប៉ុនបានចូលរួមក្នុងប្រទេសអាហ្វហ្គានីស្ថានក្នុងឆ្នាំ ២០០១ និងប្រទេសអ៊ីរ៉ាក់ក្នុងឆ្នាំ ២០០៤ (ទោះបីជាមិនមានតួនាទីប្រយុទ្ធក្នុងសមរភូមិផ្ទាល់ក៏ដោយ) ហើយជប៉ុនក៏ស្វែងរកអាសនៈអចិន្ត្រៃយ៍នៅក្នុងក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ។ ជាថ្នូរមកវិញ អង្គការសហប្រជាជាតិកំពុងជំរុញអោយប្រទេសជប៉ុនចូលរួមយ៉ាងពេញលេញក្នុងបេសកកម្មរក្សាសន្តិភាព។

ចំពោះប្រទេសខ្លួនផ្ទាល់ សហរដ្ឋអាមេរិកបានប្រើប្រាស់សម្ព័ន្ធភាពជាមួយប្រទេសជប៉ុនជាមូលដ្ឋានដើម្បីបង្ហាញពីអំណាចរបស់សហរដ្ឋអាមេរិក នៅក្នុងតំបន់អាស៊ី ជាពិសេសក្នុងអំឡុងសង្គ្រាម នៅប្រទេសកូរ៉េ (១៩៥០-១៩៥៣) និងសង្គ្រាមវៀតណាម (១៩៦៥-១៩៧៥) ក្នុងពេលដែលប្រទេសជប៉ុនគឺជាមូលដ្ឋានដ៏សំខាន់សម្រាប់ទ័ពចេញប្រតិបត្តិការ។ ការបន្តវត្តមានយោធាអាមេរិក នៅក្នុងប្រទេសជប៉ុន (ដូចនៅអឺរ៉ុប) ជានិមិត្តរូបនៃការប្តេជ្ញាចិត្តរបស់សហរដ្ឋអាមេរិកក្នុងការបន្តចូលរួមក្នុងកិច្ចការសន្តិសុខអាស៊ី។

ស្របជាមួយនឹងសន្ធិសញ្ញាអាមេរិកនិងជប៉ុន សហរដ្ឋអាមេរិករក្សាសម្ព័ន្ធភាពយោធាជាមួយរដ្ឋមួយចំនួនទៀត រួមទាំងប្រទេសអូស្ត្រាលី និងប្រទេសកូរ៉េខាងត្បូង ដែលមានកងទ័ពចំនួន ៣៥០០០ នាក់ កំពុងឈរជើង ក្រោមសម្ព័ន្ធភាពទ្វេភាគី ដែលកើតមានឡើងតាំងពីសង្គ្រាមកូរ៉េមកម្លេះ។ កិច្ចសហប្រតិបត្តិការជិតស្និទ្ធរបស់សហរដ្ឋអាមេរិកជាមួយនឹងកងកម្លាំងយោធារបស់រដ្ឋផ្សេងទៀត ដូចជា ប្រទេសអ៊ីស្រាអែល ធ្វើអោយពួកគេក្លាយជាសម្ព័ន្ធមិត្តរបស់សហរដ្ឋអាមេរិក ដោយស្វ័យប្រវត្តិ។

សមាជិកពេញលេញទាំង៩ នៃ«សម្ព័ន្ធរួមនៃរដ្ឋឯករាជ្យ(CIS)» រួមមានអតីតសាធារណរដ្ឋសូវៀតលើកលែងតែរដ្ឋបាល់ទិក (ប្រទេសអេស្តូនី ឡាតវី និងលីទុយអានី)។ ប្រទេសរុស្សី ដែលជារដ្ឋស្នងតំណែងជាផ្លូវការរបស់សហភាពសូវៀត គឺជាសមាជិកនាំមុខគេ ចំណែកអ៊ុយក្រែនជាប្រទេសធំទីពីរ។ ទោះបីជាការសម្របសម្រួលផ្នែកយោធាមួយចំនួនធ្វើឡើងតាមរយៈ«សម្ព័ន្ធរួមនៃរដ្ឋឯករាជ្យ»ក៏ដោយ ក៏ផែនការដំបូងសម្រាប់កងកម្លាំងយោធារួមគ្នាមិនទទួលបានជោគជ័យទេ។ ក្នុងចំណោមសមាជិក«សម្ព័ន្ធរួមនៃរដ្ឋឯករាជ្យ» ធំជាងគេ, ប្រទេសកាហ្សាក់ស្តាន និងបេឡារុស្ស គឺជាប្រទេសដែលមានទំនាក់ទំនងជិតស្និទ្ធបំផុតជាមួយនឹងប្រទេសរុស្ស៊ី ខណៈដែលអ៊ុយក្រែន គឺជាប្រទេសមានឯករាជ្យបំផុត (ហើយតាមពិតមិនដែលបានផ្តល់សច្ចាប័នជាផ្លូវការលើកិច្ចព្រមព្រៀង«សម្ព័ន្ធរួមនៃរដ្ឋឯករាជ្យ»)។ ក្នុងឆ្នាំ ២០០៩ ប្រទេសហ្សកហ្ស៊ីបានដកខ្លួនចេញពី«សម្ព័ន្ធរួមនៃរដ្ឋឯករាជ្យ»ដោយសារតែជម្លោះយោធាឆ្នាំ ២០០៨ ជាមួយរុស្ស៊ី។

២.៤.៤. ការបង្កើតបក្សសម្ព័ន្ធតាមតំបន់


ក្រៅពីសម្ព័ន្ធភាពដែលទើបតែបានពិភាក្សាខាងលើ និងអង្គការអន្តរដ្ឋាភិបាលក្នុងតំបន់(IGOs), ការបង្កើតបក្សសម្ព័ន្ធជាអន្តរជាតិ និងក្រុមកម្លាំងចម្រុះភាគច្រើន មិនត្រូវបានបង្កើតជាផ្លូវការ នៅក្នុងសម្ព័ន្ធភាពណាមួយទេ។ ក្នុងចំណោមប្រទេសមហាអំណាច ទំនាក់ទំនងជិតស្និទ្ធបានអភិវឌ្ឍ ប៉ុន្តែជាមួយចិន និងរុស្ស៊ី មានភាពឯករាជ្យដាច់ដោយឡែកពីគេ ក្នុងទិដ្ឋភាពខ្លះ។

នៅអឡាគោលខាងត្បូង រដ្ឋជាច្រើនបានចូលរួមក្នុង**ចលនាមិនចូលបក្សសម្ព័ន្ធ** ក្នុងអំឡុងសង្គ្រាមត្រជាក់ ដោយឈរដាច់ឆ្ងាយពីការប្រកួតប្រជែង រវាងសហរដ្ឋអាមេរិកនិងសហភាពសូវៀត។ ចលនានេះដែលត្រូវបានផ្តួចផ្តើមដោយប្រទេសឥណ្ឌានិងយូហ្គោស្លាវីត្រូវបានបំផ្លាញដោយសមាជិកភាពនៃរដ្ឋមួយចំនួនដូចជាប្រទេសគុយបា ដែលច្បាស់ណាស់ ជារដ្ឋរណបនៃប្រទេសមហាអំណាចមួយ។

នៅសតវត្សបន្ទាប់នេះ អង្គការឯកភាពអាហ្វ្រិក ដែលជាអង្គការអន្តររដ្ឋាភិបាលមានសមាជិក ៥៣ ប្រទេសនិងប្រទេសអំណាចធំៗតិចតួចចូលរួម បានប្រែក្លាយជាសហភាពអាហ្វ្រិក(AU) ដែលជាអង្គការមានសមាហរណកម្មខ្លាំងជាងមុន ដោយមានសភាសម្រាប់ទ្វីបទាំងមូល ធនាគារកណ្តាល និងតុលាការផងដែរ។ ការសាកល្បងពិតប្រាកដជាលើកដំបូងសម្រាប់សហភាពអាហ្វ្រិក បានកើតឡើងជាមួយនឹងការចោទប្រកាន់ពីបទប្រល័យពូជសាសន៍ នៅក្នុងតំបន់ដាហ្វួរ (Darfur) នៃប្រទេសស៊ូដង់ ក្នុងឆ្នាំ ២០០៤។ ជាការឆ្លើយតប សហភាពអាហ្វ្រិកបានដាក់ពង្រាយទាហានចំនួន ៣០០០ នាក់ ដោយភាគច្រើនជាកងកម្លាំងរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ។ សហភាពអាហ្វ្រិកក៏បានដាក់ពង្រាយកងកម្លាំង ដែលភាគច្រើន មកពីប្រទេសអ៊ុយហ្គង់ដា នៅក្នុងប្រទេសសូម៉ាលី ជាកន្លែងដែលពួកគេបានបណ្តេញពួកសកម្មប្រយុទ្ធអ៊ីស្លាមចេញពីតំបន់ភាគច្រើននៃប្រទេសនេះ។ កងកម្លាំងទាំងនោះត្រូវបានដកចេញវិញ នៅចុងឆ្នាំ ២០១៧ ក្រោយពេលសហភាពអាហ្វ្រិកនិងក្រុមប្រឹក្សាអង្គការសហប្រជាជាតិ យល់ព្រមប្រគល់ទំនួលខុសត្រូវផ្នែកសន្តិសុខអោយទៅកងទ័ពសូម៉ាលីវិញ។

ក្រាហ្វិក ២.៨ ការបង្កើតបក្សសម្ព័ន្ធនៃប្រទេសមហាអំណាចនិងអំណាចមធ្យម បច្ចុប្បន្ន

ប្រភព៖ ក្រសួងការពារជាតិអាមេរិក



ចំណាំ៖ បន្ទាត់ក្រហមដាប់ជាសម្ព័ន្ធយោធា, បន្ទាត់ក្រហមដាច់ជាកិច្ចសហប្រតិបត្តិការយោធាជិតស្និទ្ធ, រីឯបន្ទាត់ខៀវជាទំនាក់ទំនងពាណិជ្ជកម្មធំៗ

នៅអាស៊ី ប្រទេសចិនបានចងសម្ព័ន្ធភាពជាមួយប្រទេសប៉ាគីស្ថាន ជាយូរយារណាស់មកហើយ ក្នុងការប្រឆាំងនឹងឥណ្ឌា (ដែលត្រូវបានត្រូវរ៉ូវគ្នាជាមួយនឹងសហភាពសូវៀត)។ សហរដ្ឋអាមេរិកមានទំនោរត្រូវរ៉ូវ

គ្នាជាមួយនឹងភាគីប៉ាគីស្ថានផងដែរ ប៉ុន្តែទាំងទំនាក់ទំនងអាមេរិក-ឥណ្ឌា និងទាំងទំនាក់ទំនងអាមេរិក-ចិន បានប្រសើរឡើងវិញ ចាប់តាំងពីពេលសង្គ្រាមត្រជាក់បានបញ្ចប់។ ប្រទេសចិនក៏មានសម្ព័ន្ធភាពធូររលុងជាមួយនឹងប្រទេសកូរ៉េខាងជើង ដែលខ្លួនចាត់ទុកថាជាដៃគូប្រឆាំងនឹងប្រទេសកូរ៉េខាងត្បូង។ ប៉ុន្តែ ប្រទេសចិននៅតែព្រួយបារម្ភអំពីស្ថិរភាពនយោបាយ និងសេដ្ឋកិច្ចរបស់កូរ៉េខាងជើង។

មិត្តយូរអង្វែងរបស់អាមេរិកនៅទ្វីបអាស៊ីរួមមាន ដូចជា ប្រទេសជប៉ុន ប្រទេសកូរ៉េខាងត្បូង ប្រទេសហ្វីលីពីន (ជាកន្លែងដែលប្រតិបត្តិការរួមប្រឆាំងនឹងអំពើភេរវកម្ម បានចាប់ផ្តើម ក្នុងឆ្នាំ ២០០២) អ្នកជាតិនិយមចិន លើកោះតៃវ៉ាន់ (មិនផ្លូវការ តាំងពីទសវត្សរ៍ឆ្នាំ ១៩៧០) ប្រទេសសិង្ហបុរី និងប្រទេសថៃ។

នៅតំបន់មជ្ឈិមបូព៌ា ជម្លោះរវាងពិភពអារ៉ាប់នឹងប្រទេសអ៊ីស្រាអែល បានបង្កើតបក្សសម្ព័ន្ធរួមនៃបណ្តាប្រទេសអារ៉ាប់ជាច្រើន ដើម្បីប្រឆាំងនឹងអ៊ីស្រាអែល អស់រយៈពេលជាច្រើនទសវត្សរ៍មកហើយ ប៉ុន្តែបក្សសម្ព័ន្ធនោះបានបែកបាក់ ខណៈដែលប្រទេសអេហ្ស៊ីបនៅឆ្នាំ ១៩៧៨ ហើយបន្ទាប់មកប្រទេសហ្សកដានីនៅឆ្នាំ ១៩៩៤ បានបង្កើតសន្តិភាពជាមួយប្រទេសអ៊ីស្រាអែល។ ខណៈពេលដែលដំណើរការសន្តិភាពអ៊ីស្រាអែល-ប៉ាឡេស្ទីនឆ្ពោះទៅមុខ ហើយដើរថយក្រោយវិញពីមួយឆ្នាំទៅមួយឆ្នាំ ប្រទេសអារ៉ាប់នៅតែបន្តបង្ហាញសាមគ្គីភាព ក្នុងកម្រិតណាមួយ ជាមួយគ្នាទៅវិញទៅមក និងការប្រឆាំងនឹងអ៊ីស្រាអែល។ ភាពរង្គោះរង្គើក្នុងទំនាក់ទំនងអ៊ីស្រាអែល-អារ៉ាប់បានកើតឡើងក្នុងឆ្នាំ ២០០៦ នៅពេលដែលអ៊ីស្រាអែលបានធ្វើសង្គ្រាមរយៈពេលមួយខែ ជាមួយក្រុមទ័ពព្រៃហេស្ប៊ូឡា (Hezbollah) នៅភាគខាងត្បូងប្រទេសលីបង់ និងនៅក្នុងឆ្នាំ ២០០៨ និងឆ្នាំ ២០១២ នៅពេលដែលវាបានប្រយុទ្ធជាមួយពួកសកម្មប្រយុទ្ធ ហាម៉ាស់ នៅហ្គាហ្សា។ ទន្ទឹមនឹងនេះ ប្រទេសអ៊ីស្រាអែល និង ប្រទេសទួរគីបានបង្កើតទំនាក់ទំនងយោធាដ៏ជិតស្និទ្ធដែលបង្កើនវិសាលភាពអំណាចរបស់អ៊ីស្រាអែល ប៉ុន្តែ ទំនាក់ទំនងកាន់តែយ៉ាប់ឃឺន បន្ទាប់ពីអ៊ីស្រាអែលបានសម្លាប់បាតុករទួរគីនៅលើនាវាមួយដែលព្យាយាមទម្លុះការបិទខ្ទប់តំបន់ហ្គាហ្សា ក្នុងឆ្នាំ ២០០៩។ បើទោះជាទំនាក់ទំនងប្រសើរជាងមុន នៅឆ្នាំ ២០១៦, នៅឆ្នាំ ២០១៨ ប្រធានាធិបតីទួរគីបានហៅអ៊ីស្រាអែលថាជា «រដ្ឋភាវៈករ» ដែលបណ្តាលអោយមានភាពតានតឹងជាថ្មី។ ខណៈដែលបដិវត្តន៍និទាឃរដូវនៅអារ៉ាប់ ក្នុងចន្លោះឆ្នាំ ២០១១-២០១៤ បានផ្ទុះឡើង តំបន់នេះធ្លាក់ទៅក្នុងភាពចលាចល។ ទំនាក់ទំនងអ៊ីស្រាអែលនិងប៉ាឡេស្ទីនត្រូវបានផ្អាក ចាប់តាំងពីឆ្នាំនោះមក។ ចរន្តនៃជម្លោះធំៗ នៅក្នុងតំបន់មជ្ឈិមបូព៌ាបានក្លាយជាការប្រឆាំងគ្នារវាងប្រទេសមូស្លីមប្រកាន់និកាយស៊ីអ៊ីតនិងនិកាយស៊ុននី ជាពិសេសរវាងប្រទេសអ៊ីរ៉ង់និងប្រទេសអារ៉ាប៊ីសាអូឌីត។ សង្គ្រាមស៊ីវិលក្នុងប្រទេសស៊ីរី ដែលរាលដាលដល់ប្រទេសអ៊ីរ៉ាក់ ដែលជាប្រទេសជិតខាងឆ្លុះបញ្ចាំងពីការបែកបាក់ខាងលើ ក៏ដូចគ្នានឹងករណីសង្គ្រាមស៊ីវិលនៅយេម៉ែន ដោយមានប្រទេសអ៊ីរ៉ង់និងអារ៉ាប៊ីសាអូឌីត ប្រយុទ្ធគ្នាក្នុងសង្គ្រាមរណប ដោយគាំទ្រគូបដិបក្ខម្ខាងៗ។

សហរដ្ឋអាមេរិកមានទំនាក់ទំនងជិតស្និទ្ធជាមួយប្រទេសអេហ្ស៊ីប (តាំងពីឆ្នាំ ១៩៧៨) និងសហការយ៉ាងជិតស្និទ្ធជាមួយប្រទេសទួរគី (សមាជិកណាតូ) គុយវ៉ែត អារ៉ាប៊ីសាអូឌីត និងម៉ារ៉ុក។ ទំនាក់ទំនងរវាងអាមេរិកនិងអ៊ីរ៉ង់នៅបន្តផ្តាច់ រយៈពេល៣០ឆ្នាំក្រោយបដិវត្តន៍ឆ្នាំ១៩៧៩។ ប៉ុន្តែជាការចម្លែក ប្រទេសអ៊ីរ៉ង់ដែលមានប្រជាជនកាន់និកាយស៊ីអ៊ីត មានទំនាក់ទំនងជិតស្និទ្ធជាមួយនឹងរដ្ឋាភិបាលថ្មីនៃប្រទេសអ៊ីរ៉ាក់ដែលគ្រប់គ្រងដោយគណបក្សសាសនាស៊ីអ៊ីត និងមានការគាំទ្រដោយសហរដ្ឋអាមេរិក។ ជាការពិត ប្រទេសអ៊ីរ៉ង់

និងសហរដ្ឋអាមេរិកផ្តល់ជំនួយគាំទ្រ (តែមិនសហការរួមគ្នា) ដល់កងកម្លាំងអ៊ីរ៉ាក់ដើម្បីវាយដណ្តើមគ្រប់គ្រងដែនដីដែលធ្លាក់ក្រោមការកណ្តាប់ដៃរដ្ឋឥស្លាម (ISIS) នៅចន្លោះឆ្នាំ ២០១៦និង២០១៧។

នៅមិនច្បាស់ទេថាតើការបង្កើតបក្សសម្ព័ន្ធអន្តរជាតិថ្មីអាចនឹងលេចចេញឡើង នៅក្នុងប៉ុន្មានឆ្នាំខាងមុខនេះទេ។ ភាពរលូននៃសម្ព័ន្ធភាពធ្វើអោយពួកគេក្លាយជាកត្តាលើករដ៏អស្ចារ្យមួយ សម្រាប់អ្នកប្រាជ្ញនានាស្វែងយល់ និងសម្រាប់អ្នកបង្កើតគោលនយោបាយ គិតគូរពិចារណា។ សម្រាប់បច្ចុប្បន្ន ការបង្កើតបក្សសម្ព័ន្ធអន្តរជាតិ ទាំងសម្ព័ន្ធភាពយោធា និងទំនាក់ទំនងពាណិជ្ជកម្ម ផ្តោតលើសហរដ្ឋអាមេរិក (សូមមើលក្រាហ្វិក ២.៨)។ ទោះបីជារដ្ឋដែលមានគំនិតឯករាជ្យមួយចំនួនដូចជា ប្រទេសចិន ប្រទេសរុស្ស៊ី និងប្រទេសបារាំងទប់ទល់នឹងអនុត្តរភាពរបស់សហរដ្ឋអាមេរិកក៏ដោយ មានកស្តុតាងតិចតួចនៃការបង្កើតបក្សសម្ព័ន្ធអំណាចជាផ្លូវការ ឬជាក់លាក់ ដើម្បីប្រកួតប្រជែងជាមួយនឹងសហរដ្ឋអាមេរិក។

២.៥. យុទ្ធសាស្ត្រ

២.៥ ចូរពិពណ៌នាអំពីរបៀបលេង«ល្បែងទ្វេរគ្រោះអ្នកទោស» ហើយពន្យល់ថាតើវាអាចត្រូវប្រៀបប្រដូចទៅនឹងប្រព័ន្ធអន្តរជាតិយ៉ាងដូចម្តេច។

តួអង្គនានាប្រើ*យុទ្ធសាស្ត្រ*ដើម្បីស្វែងរកលទ្ធផលល្អនៅក្នុងការចរចាជាមួយនឹងតួអង្គមួយឬច្រើនផ្សេងទៀត។ រដ្ឋទាំងនោះដាក់ពង្រាយសមត្ថភាពអំណាចផ្សេងៗសម្រាប់ជាអានុភាព ដើម្បីជះឥទ្ធិពលលើសកម្មភាពរបស់គ្នាទៅវិញទៅមក។ ការចរចាមានលក្ខណៈជាអន្តរកម្ម ហើយតម្រូវអោយតួអង្គមួយគិតពិចារណាអំពីផលប្រយោជន៍របស់តួអង្គផ្សេងទៀត បើទោះបីជាតួអង្គនោះកំពុងស្វែងរកផលប្រយោជន៍ផ្ទាល់ខ្លួនក៏ដោយ។

២.៥.១. សិល្បៈដឹកនាំរដ្ឋ

អ្នកប្រាកដនិយមបុរាណសង្កត់ធ្ងន់លើសិល្បៈដឹកនាំរដ្ឋ ដែលជាសិល្បៈនៃការគ្រប់គ្រងកិច្ចការរដ្ឋ និងការកាច់ចង្កូតរដ្ឋរបស់ខ្លួន នៅក្នុងពិភពលោកនៃនយោបាយដណ្តើមអំណាច ក្នុងចំណោមរដ្ឋអធិបតេយ្យ ប្រកបដោយប្រសិទ្ធភាព។ យុទ្ធសាស្ត្រអំណាចគឺជាផែនការដែលតួអង្គប្រើសម្រាប់អភិវឌ្ឍ និងប្រើប្រាស់សមត្ថភាពអំណាច ដើម្បីសម្រេចបាននូវគោលដៅរបស់ពួកគេ។

ទិដ្ឋភាពសំខាន់នៃយុទ្ធសាស្ត្រគឺការជ្រើសរើសប្រភេទសមត្ថភាពណាមួយយកមកអភិវឌ្ឍ ដោយសារធនធានមានកម្រិត ដើម្បីបង្កើនឥទ្ធិពលនៅលើឆាកអន្តរជាតិ។ នេះតម្រូវអោយមានការគិតពិចារណានិងព្យាករណ៍ទុកជាមុន ពីព្រោះសមត្ថភាពដែលត្រូវការដើម្បីគ្រប់គ្រងស្ថានការណ៍ ប្រហែលជាត្រូវការពេលវេលាជាច្រើនឆ្នាំដើម្បីអភិវឌ្ឍ មុនពេលដែលស្ថានការណ៍នោះកើតឡើង។ ទោះជាយ៉ាងណាក៏ដោយ សមត្ថភាពដែលបានជ្រើសរើសជាញឹកញាប់នឹងមិនអាច*ដោះដូរគ្នា*បានទៅក្នុងរយៈពេលខ្លី។ គន្លឹះសំខាន់នៃបញ្ហានេះគឺការសម្រេចថា តើកងកម្លាំងយោធាប្រភេទណាដែលត្រូវរក្សានៅក្នុងកំឡុងពេលមានសន្តិភាព៖ រក្សាក្នុងចំនួនសមល្មមសម្រាប់ការពារកុំអោយខ្លួនបរាជ័យភ្លាមៗប្រសិនបើមានសង្គ្រាមផ្ទុះឡើងប៉ុន្តែមិនអាចរក្សាទុកចំនួនច្រើនពេកដែលអាចបណ្តាលអោយដាក់បន្ទុកលើសេដ្ឋកិច្ចប្រទេសខ្លាំងពេក (សូមមើលមេរៀនទី ៦)។

យុទ្ធសាស្ត្រក៏ជះឥទ្ធិពលលើគោលនយោបាយផងដែរ នៅពេលដែលរដ្ឋមានឆន្ទៈក្នុងការប្រើប្រាស់សមត្ថភាពអំណាចរបស់ខ្លួន។ *ឆន្ទៈ*របស់ជាតិមួយ ឬអ្នកដឹកនាំម្នាក់ ពិបាកនឹងប៉ាន់ស្មានណាស់។ បើទោះជាអ្នកដឹកនាំបង្ហាញចេតនារបស់ពួកគេក្នុងការតស៊ូជំនះលើបញ្ហាណាមួយក៏ដោយ ក៏ពួកគេអាចនឹងនិយាយសំញែងឬកុហកតែប៉ុណ្ណោះ។

សកម្មភាពជាយុទ្ធសាស្ត្ររបស់ប្រទេសចិន ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ គឺជាឧទាហរណ៍នៃគោលគំនិតនៃយុទ្ធសាស្ត្រសម្រាប់ជាការដាក់ពង្រាយសមត្ថភាពអំណាចដោយសមហេតុផល។ គោលដៅនៃគោលនយោបាយការបរទេសជាចំបងរបស់ចិន គឺត្រូវរារាំងឯករាជ្យភាពរបស់តៃវ៉ាន់ ដែលចិនចាត់ទុកថាជាផ្នែកសំខាន់មួយនៃទឹកដីរបស់ខ្លួន (អង្គការសហប្រជាជាតិក៏គិតដូច្នេះ និងសហរដ្ឋអាមេរិកក៏ដូច្នេះដែរយ៉ាងហោចណាស់ ក្នុងទ្រឹស្តី)។ រដ្ឋាភិបាលតៃវ៉ាន់ត្រូវបានបង្កើតឡើងដើម្បីតំណាងអោយប្រទេសចិនទាំងទាំងមូល នៅក្នុងឆ្នាំ ១៩៤៩ នៅពេលដែលអ្នកជាតិនិយមបានភៀសខ្លួនទៅកោះនោះ បន្ទាប់ពីបរាជ័យក្រោមកណ្តាប់ពួកកុម្មុយនិស្ត ក្នុងសង្គ្រាមស៊ីវិលរបស់ប្រទេសចិន។ ចាប់តាំងពីពេលសហគមន៍អន្តរជាតិទទួលស្គាល់រដ្ឋាភិបាលទីក្រុងប៉េកាំងថាជា«ចិន»មក តៃវ៉ាន់បានព្យាយាមធ្វើប្រតិបត្តិការ ដោយឯករាជ្យ កាន់តែច្រើនឡើងៗ ដោយមានប្រជាជនតៃវ៉ាន់ជាច្រើនចង់បានឯករាជ្យដាច់ដោយឡែក។ ប្រទេសចិនប្រហែលជាមិនមានអំណាចយោធាដើម្បីឈ្លានពានតៃវ៉ាន់ដោយជោគជ័យនោះទេ ប៉ុន្តែ ខ្លួនបានប្រកាសម្តងហើយម្តងទៀតថាខ្លួននឹងធ្វើសង្គ្រាមប្រសិនបើតៃវ៉ាន់ប្រកាសឯករាជ្យ។ រហូតមកដល់ពេលនេះ ទោះបីជាសង្គ្រាមបែបនេះអាចជារឿងមិនសមហេតុផលសម្រាប់ភាគីចិនក៏ដោយ ការគំរាមកំហែងនេះបានរារាំងមិនអោយតៃវ៉ាន់ ប្រកាសឯករាជ្យជាផ្លូវការ។ ចិនអាចនឹងចាញ់សង្គ្រាមបែបនេះ ប៉ុន្តែ សង្គ្រាមនោះពិតណាស់នឹងបង្កការខូចខាតយ៉ាងសម្បើមមកលើតៃវ៉ាន់។ នៅឆ្នាំ ១៩៩៦ ប្រទេសចិនបានរៀបចំល្បែងសង្គ្រាមនៅជិតកោះតៃវ៉ាន់ ដោយបានបាញ់មីស៊ីលទៅលើលំហសមុទ្រ។ សហរដ្ឋអាមេរិកបានបញ្ជូននាវាផ្ទុកយន្តហោះពីរគ្រឿងទៅក្បែរនោះ សម្រាប់ជាសញ្ញាដល់ចិនថា ការធ្វើសមយុទ្ធរបស់ចិនមិនត្រូវជ្រុលហួសហេតុពេកទេ។

ដោយមិនប្រថុយប្រថានសង្គ្រាមដោយសារការប្រកាសឯករាជ្យ តៃវ៉ាន់បានចូលរួមក្នុងការទូតដើម្បីទទួលបានឥទ្ធិពលនៅក្នុងពិភពលោក។ វាបញ្ចុះបញ្ចូលសភាសហរដ្ឋអាមេរិក, ស្នើសុំ ចូលជាសមាជិកអង្គការសហប្រជាជាតិ និងអង្គការពិភពលោកផ្សេងទៀត និងផ្តល់ជំនួយបរទេសដល់ប្រទេសដែលទទួលស្គាល់រដ្ឋាភិបាលរបស់តៃវ៉ាន់ (ភាគច្រើនជាប្រទេសតូចនិងក្រីក្រចំនួន ១៧ នៅទូទាំងពិភពលោក គិតត្រឹមឆ្នាំ ២០១៨។ ចំនួននេះអាចប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំទៀត)។

ជាការឆ្លើយតប ចិនក៏បានប្រើការទូតផ្ទាល់ខ្លួនដើម្បីទប់ទល់នឹងទង្វើទាំងនេះ។ វាផ្តាច់ទំនាក់ទំនងការទូតជាមួយប្រទេសដែលទទួលស្គាល់តៃវ៉ាន់ ហើយនិងដាក់ទណ្ឌកម្មរាល់ទង្វើទាំងឡាយ ក្នុងទិសដៅបម្រើឯករាជ្យភាពរបស់តៃវ៉ាន់។ ប្រទេសពាក់កណ្តាលដែលទទួលស្គាល់តៃវ៉ាន់ ស្ថិតនៅក្នុងតំបន់ការ៉ាប៊ីន និងអាមេរិកកណ្តាល ដែលនាំអោយមានការប្រកួតប្រជែងដណ្តើមឥទ្ធិពលគ្នានៅក្នុងតំបន់។ ចិនបានព្យាយាមទប់ទល់នឹងទំនាក់ទំនងតៃវ៉ាន់ជាមួយប្រទេសទាំងនោះ ដោយប្រើប្រាស់ទាំងឥទ្ធិពលវិជ្ជមាន និងទាំងឥទ្ធិពលអវិជ្ជមានផ្សេងៗ។ ជាឧទាហរណ៍ នៅប្រទេសប៉ាណាម៉ា ជាកន្លែងដែលចិនជាអ្នកប្រើប្រាស់ព្រែកជីកប៉ាណាម៉ា យ៉ាងសកម្មខ្លាំង (ដែលសហរដ្ឋអាមេរិបានប្រគល់មកអោយប្រទេសប៉ាណាម៉ាគ្រប់គ្រងវិញក្នុងឆ្នាំ ១៩៩៩) តៃវ៉ាន់បានបង្កើនទំនាក់ទំនងកាន់តែជិតស្និទ្ធ, វិនិយោគលើកំពង់ផែកុងតឺន័រ និងបានស្នើអោយជួលកម្មករជាភ្ញៀវមកពីប៉ាណាម៉ានៅតៃវ៉ាន់ផងដែរ។ ប៉ុន្តែ ចិនបានគម្រាមកំហែង ដោយចេតនាក្នុងការតបន្តឹងការចេញចូលទៅកាន់ហុងកុងរបស់ប៉ាណាម៉ា ឬត្រូវចុះឈ្មោះនាវារបស់ចិនជាច្រើន ដែលបានចុះបញ្ជីក្នុងប្រទេសប៉ាណាម៉ា ទៅចុះបញ្ជីនៅប្រទេសបាហាម៉ាស៍ជំនួសវិញ។ (ប្រទេសបាហាម៉ាស៍ បានផ្តាច់ទំនាក់ទំនងជាមួយតៃវ៉ាន់ក្នុងឆ្នាំ ១៩៩៧ បន្ទាប់ពី ហុងកុង ដែលឥឡូវនេះជាផ្នែកមួយនៃប្រទេសចិនបានសន្យាថានឹង

វិនិយោគនៅក្នុងកំពង់ផែកុងតឺន័រ នៅបាហាម៉ាស៍។) ស្រដៀងគ្នានេះដែរ នៅពេលដែលរដ្ឋទឹកដីកោះតូច នៅប៉ាស៊ីហ្វិកឈ្មោះ គីរីបាទី បានទទួលស្គាល់តៃវ៉ាន់នៅចុងឆ្នាំ ២០០៣ ដើម្បីទទួលបានជំនួយពីតៃវ៉ាន់ ប្រទេសចិនបានផ្តាច់ទំនាក់ទំនង និងរុះរើស្ថានីយតាមដានផ្កាយរណបរបស់ចិន ចេញពីគីរីបាទី។ ដោយសារតែស្ថានីយនោះបានដើរតួនាទីយ៉ាងសំខាន់ ក្នុងកម្មវិធីឈ្លបយកការណ៍យោធា និងពង្រីកកម្មវិធីអវកាសរបស់ប្រទេសចិន ដែលទើបតែបានបើកដំណើរការអវកាសយានិកដំបូងរបស់ខ្លួន, ការរុះរើនោះបានបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់ចិនក្នុងការផ្តល់អាទិភាពដល់ការបិទខ្ទប់តៃវ៉ាន់ ទោះបីមានមានការខានដល់គោលដៅជាតិសំខាន់ៗផ្សេងទៀតក៏ដោយ។

រូបថត តំណាងប្រទេសចិនលើកដៃបោះឆ្នោតវេតូដំណោះស្រាយរបស់ក្រុមប្រឹក្សាសន្តិសុខបំពងសម្លេង បង្កើនអំណាច

យុទ្ធសាស្ត្រជិតជិតអាចជួយរដ្ឋមួយទទួលបានអំណាចកាន់តែខ្លាំង។ ជាទូទៅ គោលនយោបាយការបរទេសរបស់ចិនសំដៅទៅលើផលប្រយោជន៍ក្នុងតំបន់ដ៏សំខាន់បំផុតរបស់ខ្លួនសំខាន់ជាងគេគឺ ការទប់ស្កាត់ឯករាជ្យភាពផ្លូវការរបស់តៃវ៉ាន់។ ទោះបីមានជម្លោះជាមួយប្រទេសជិតខាងមួយចំនួនក៏ដោយ ប្រទេសចិនមិនមានការពាក់ព័ន្ធផ្នែកយោធា អស់រយៈពេល ៤០ ឆ្នាំមកហើយ។ នៅទីនេះ ប្រទេសចិនប្រើសិទ្ធិវេតូរបស់ខ្លួននៅក្នុងក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ជាលើកទី ៥ (មិនធ្លាប់មាន) ដើម្បីបញ្ចប់បេសកកម្មរក្សាសន្តិភាពនៅក្នុងប្រទេសម៉ាសេដូនៀ ដែលទើបតែបង្កើតទំនាក់ទំនងជាមួយកោះតៃវ៉ាន់ក្នុងឆ្នាំ ១៩៩៩ ។

សម្លេងឆ្នោតវេតូចំនួនពីរ ក្នុងចំណោមប្រាំពីរ ដែលចិនបានប្រើនៅក្នុងក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ គឺដើម្បីរារាំងកងកម្លាំងរក្សាសន្តិភាព នៅក្នុងប្រទេសដែលបានទទួលស្គាល់តៃវ៉ាន់។ សិទ្ធិវេតូទាំងនេះបង្ហាញថា ប្រសិនបើចិនជឿថាផលប្រយោជន៍របស់ខ្លួននៅតៃវ៉ាន់ ត្រូវបានគំរាមកំហែង វាអាចដើរតួជាអ្នកទំយើនៅក្នុងក្រុមប្រឹក្សាសន្តិសុខ។ នៅពេលដែលអតីតសាធារណរដ្ឋយូហ្គោស្លាវីនៃប្រទេសម៉ាសេដូនីបានទទួលស្គាល់តៃវ៉ាន់ ក្នុងឆ្នាំ ១៩៩៩ (ជាថ្នូរនឹងជំនួយចំនួន ១ ៣ន់លានដុល្លារ) ប្រទេសចិនបានវេតូបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិនៅទីនោះ បើទោះជាពេលនោះមានអស្ថិរភាពយ៉ាងខ្លាំងនៅជិតខាង កូសូវ៉ូ ក្តី (នៅត្រឹមឆ្នាំ ២០០១ ម៉ាសេដូនីបានប្តូរការទទួលស្គាល់ការទូតរបស់ខ្លួន ងាកទៅរកចិន)។ ផ្ទុយទៅវិញ នៅពេលដែលផលប្រយោជន៍តៃវ៉ាន់របស់ខ្លួន មានសុវត្ថិភាពល្អហើយ ចិនសហការលើបញ្ហាសណ្តាប់ធ្នាប់ពិភពលោក។ ជាឧទាហរណ៍ ទោះបីជាចិនប្រឆាំងសង្គ្រាមឈូងសមុទ្រ នៅក្នុងឆ្នាំ ១៩៩១ ក្តី ក៏ខ្លួនមិនបានវេតូចំពោះដំណោះស្រាយរបស់អង្គការសហប្រជាជាតិ ដែលបើកភ្លើងខៀវអោយវាដែរ។

យុទ្ធសាស្ត្ររបស់ចិនខាងលើនេះ ប្រមូលផ្តុំសមត្ថភាពផ្សេងៗ រួមទាំងមីស៊ីល អ្នកការទូត និងក្រុមហ៊ុនឧស្សាហកម្ម ក្នុងកិច្ចខិតខំប្រឹងប្រែងរួមគ្នា ដើម្បីជះឥទ្ធិពលលើលទ្ធផលនៃបញ្ហាអន្តរជាតិដ៏សំខាន់បំផុតរបស់ចិន។ យុទ្ធសាស្ត្រនេះពង្រីកអំណាចរបស់ចិន។

យុទ្ធសាស្ត្រ**រារាំង**ប្រើប្រាស់ការគំរាមកំហែងដើម្បីដាក់ទណ្ឌកម្មតួអង្គផ្សេងទៀត ប្រសិនបើតួអង្គនោះធ្វើសកម្មភាពអវិជ្ជមានជាក់លាក់ណាមួយ (ជាពិសេសការវាយប្រហារទៅលើរដ្ឋផ្ទាល់ខ្លួន ឬសម្ព័ន្ធមិត្តរបស់ខ្លួន)។ ប្រសិនបើការរារាំងមានដំណើរការ ឥទ្ធិពលរបស់វាស្ទើរតែមើលមិនឃើញ៖ ជោគជ័យរបស់វាត្រូវបានកំណត់ដោយការវាយប្រហារដែលមិនបានកើតឡើង (ព្រោះវាបានទប់ស្កាត់ដោយជោគជ័យ)។

ជាទូទៅ អ្នកគាំទ្រយុទ្ធសាស្ត្ររារាំងជឿថា ជម្លោះទំនងជានឹងរាលដាលទៅជាសង្គ្រាម នៅពេលដែលភាគីម្ខាងនៃជម្លោះមានភាពទន់ខ្សោយ។ នៅក្នុងគោលគំនិតនេះ ជាធម្មតា ការបង្កើនសមត្ថភាពយោធាបានបញ្ចុះបញ្ចូលភាគីខ្លាំងជាងថា ការងាកទៅប្រើប្រាស់ឥទ្ធិពលយោធានឹងមិនជោគជ័យទេ ដូច្នេះជម្លោះទំនងជាមិនសូវកើនឡើងទៅជាអំពើហិង្សាទេ។ យុទ្ធសាស្ត្រ**បង្វិតបង្វំ** ដែលពេលខ្លះត្រូវបានប្រើប្រាស់ បន្ទាប់ពីយុទ្ធសាស្ត្ររារាំងមិនបានសម្រេច។ វាសំដៅលើការគំរាមកំហែងដោយកម្លាំងដើម្បីធ្វើអោយគូអង្គផ្សេងទៀតធ្វើសកម្មភាពជាក់លាក់មួយចំនួន (ជាជាងបដិសេធមិនធ្វើសកម្មភាពតាមយុទ្ធសាស្ត្ររារាង)។ ជាទូទៅ វាជារឿងពិបាកក្នុងការធ្វើអោយរដ្ឋមួយទៀតផ្លាស់ប្តូរទង្វើរបស់ពួកគេ (គោលបំណងនៃយុទ្ធសាស្ត្របង្វិតបង្វំ) ជាងការទាមទារអោយរដ្ឋនោះមិនផ្លាស់ប្តូរទង្វើរបស់ពួកគេ (គោលបំណងនៃយុទ្ធសាស្ត្ររារាំង)។

យុទ្ធសាស្ត្រមួយដែលអាចត្រូវបានប្រើសម្រាប់បង្វិតបង្វំរដ្ឋមួយអោយអនុលោមតាម ឬ ធ្វើសកម្មភាពតាមការទាមទារ គឺ*ការរន្ថើន* ដែលសំដៅដល់ស៊េរីនៃការដាក់ទណ្ឌកម្មអរិជ្ឈមានអោយកាន់តែធ្ងន់ធ្ងរ ដើម្បីជំរុញអោយគូអង្គផ្សេងទៀតធ្វើសកម្មភាពមួយចំនួន។ បើយោងតាមទ្រឹស្តី សកម្មភាពដែលមិនសូវធ្ងន់ធ្ងរបង្កើតភាពជឿជាក់ ដោយបង្ហាញពីឆន្ទៈរបស់គូអង្គទីមួយក្នុងការប្រើប្រាស់អំណាចរបស់ខ្លួនលើបញ្ហានេះ ហើយទំរង់នៃការរន្ថើនប្រាប់អោយដឹងថាការដាក់ទណ្ឌកម្មនឹងត្រូវរន្ថើនកាន់តែខ្លាំង បង្កការខាតបងខ្លាំង នាពេលអនាគត ប្រសិនបើគូអង្គទីពីរមិនសហការ។ សកម្មភាពទាំងនេះគួរតែជំរុញអោយគូអង្គទីពីរអនុវត្តតាមដោយសន្មតថា រដ្ឋនោះភ្ញាក់ខ្លួននិងថ្លឹងថ្លែងឃើញថា ការខាតបងដែលបណ្តាលមកពីការដាក់ទណ្ឌកម្មមានទំហំធំជាងការអនុលោមតាម។ ប៉ុន្តែ យុទ្ធសាស្ត្ររន្ថើនអាចមានគ្រោះថ្នាក់ខ្លាំងផងដែរ។ ក្នុងកំឡុងសង្គ្រាមត្រជាក់ អ្នកប្រាជ្ញទំនាក់ទំនងអន្តរជាតិជាច្រើនព្រួយបារម្ភថា សង្គ្រាមធម្មតាមួយអាចប្រែក្លាយជាសង្គ្រាមនុយក្លេអ៊ែរ ប្រសិនបើប្រទេសមហាអំណាចព្យាយាមអនុវត្តយុទ្ធសាស្ត្ររន្ថើន។

ការប្រណាំងប្រជែងសព្វាវុធគឺជាដំណើរការបដិការដែលរដ្ឋពីរ (ឬច្រើន) បង្កើនសមត្ថភាពយោធាដើម្បីឆ្លើយតបទៅនឹងការបង្កើនសមត្ថភាពយោធារដ្ឋមួយទៀត។ ដោយសារតែរដ្ឋនីមួយៗចង់ធ្វើសកម្មភាពដោយប្រុងប្រយ័ត្នខ្ពស់ដើម្បីទប់ទល់នឹងការគំរាមកំហែងណាមួយ ការខិតខំតបគ្នាទៅវិញទៅមក បណ្តាលអោយមានការផលិតអាវុធដោយភាគីទាំងសងខាង។ ការរន្ថើនការគំរាមកំហែងគ្នាទៅវិញទៅមកអាចបំផ្លាញទំនុកចិត្តគ្នា កាត់បន្ថយកិច្ចសហប្រតិបត្តិការគ្នា និងទំនងជាធ្វើអោយវិបត្តិ(ឬឧបត្តិហេតុ)មួយ ទាញភាគីម្ខាងបើកការវាយប្រហារជាមុន ហើយសង្គ្រាមក៏ផ្ទុះឡើងដោយស្វ័យប្រវត្តិ ជាជាងរង់ចាំភាគីម្ខាងទៀតវាយមកលើខ្លួនមុន។ ដំណើរការប្រណាំងប្រជែងអាវុធត្រូវបានបង្ហាញយ៉ាងរស់រវើកនៅក្នុងការប្រណាំងប្រជែងអាវុធនុយក្លេអ៊ែរ រវាងសហរដ្ឋអាមេរិកនិងសហភាពសូវៀត ដែលបានបង្កើតឃ្លាំងអាវុធនុយក្លេអ៊ែររាប់ម៉ឺនគ្រាប់របស់ភាគីសងខាង។

២.៥.២. ការថ្លឹងថ្លែងហេតុផលក្នុងទំនាក់ទំនងអន្តរជាតិ

អ្នកប្រាកដនិយមភាគច្រើន (រួមទាំងអ្នកមិនមែនជាអ្នកប្រាកដនិយមជាច្រើន) សន្មតថា អ្នកកាន់អំណាចនៅពេលចូលរួមក្នុងដំណើរការគ្រប់គ្រងរដ្ឋប្រកាន់ឥរិយាបទជា**តួអង្គសមហេតុផល** នៅក្នុងកិច្ចប្រឹងប្រែងរបស់ខ្លួនដើម្បីមានឥទ្ធិពលលើរដ្ឋដទៃ។ ទិដ្ឋភាពនេះមានផលប៉ះពាល់ពីរសម្រាប់ទំនាក់ទំនងអន្តរជាតិ។

ទីមួយ ការសន្មតអំពីសនិទានភាព[12] ឬ ការចេះប្លឹងផ្លែងហេតុនឹងផល បង្កប់អត្ថន័យថា រដ្ឋនិងតួអង្គអន្តរជាតិផ្សេងទៀតអាចកំណត់អត្តសញ្ញាណផលប្រយោជន៍របស់ពួកគេ និងអាចតម្កល់វាជាអាទិភាពចម្បងនៅពីលើផលប្រយោជន៍ផ្សេងៗទៀត៖ សកម្មភាពរបស់រដ្ឋមួយធ្វើឡើងដើម្បីស្វែងរក ផលប្រយោជន៍របស់ខ្លួន។ អ្នកប្រាកដនិយមជាច្រើនសន្មត់ថា តួអង្គ(ជាធម្មតារដ្ឋ)ដែលអនុវត្តអំណាច គឺជាអង្គភាពរួមតែមួយដែលអាច «គិតគូរ» អំពីសកម្មភាពរបស់ខ្លួន យ៉ាងស៊ីសង្វាក់គ្នា និងធ្វើការជ្រើសរើស។ នេះហើយដែលគេហៅថាជាការសន្មតជា*តួអង្គឯកភូត* (រដ្ឋទោល)ឬជួនកាល ការសន្មត់ជា*រមដឹកនាំខ្លាំង* ឬ *បុរសខ្លាំង*។ ការសន្មត់នេះត្រូវបានសម្រួលអោយងាយយល់ ពីព្រោះថាជាផលប្រយោជន៍របស់អ្នកនយោបាយ គណបក្សវិស័យសេដ្ឋកិច្ច ឬ តំបន់នានានៃប្រទេសនីមួយៗតែងតែមានជម្លោះ។ ប៉ុន្តែ អ្នកប្រាកដនិយមសន្មតថាការអនុវត្តអំណាច ព្យាយាមជំរុញ**ផលប្រយោជន៍ជាតិ** - ផលប្រយោជន៍របស់រដ្ឋផ្ទាល់។

ប៉ុន្តែ តើផលប្រយោជន៍របស់រដ្ឋមួយមានអ្វីខ្លះ? តើផលប្រយោជន៍ទាំងនោះជាផលប្រយោជន៍របស់ទីភ្នាក់ងារឬស្ថាប័នជាក់លាក់ណាមួយនៅក្នុងរដ្ឋាភិបាលឬ? ឬគ្រាន់តែជាផលប្រយោជន៍របស់ក្រុមមនុស្សពិសេសនៅក្នុងស្រុកណាមួយ? ឬជា តម្រូវការដើម្បីយកឈ្នះលើជម្លោះជាមួយរដ្ឋផ្សេងទៀត (សូមមើលមេរៀនទី ៥)? ឬគ្រាន់តែជាលទ្ធភាពក្នុងការកិច្ចសហប្រតិបត្តិការជាមួយសហគមន៍អន្តរជាតិដើម្បីទទួលបានផលប្រយោជន៍ទាំងអស់គ្នា (សូមមើលមេរៀនទី៧)? មិនមានចម្លើយសាមញ្ញតបតទៅនឹងសំណួរទាំងអស់នេះទេ។ អ្នកប្រាជ្ញប្រាកដនិយមមួយចំនួន កំណត់និយមន័យផលប្រយោជន៍ជាតិថាត្រឹមជា ការបង្កើនអំណាចសម្ភារៈ (ការសន្មត់នេះនៅអាចជជែកវែកញែកបន្តទៀតបាន)។ អ្នកប្រាជ្ញផ្សេងទៀតប្រៀបប្រដូចអំណាចនៅក្នុងទំនាក់ទំនងអន្តរជាតិថាជា ប្រាក់នៅក្នុងសេដ្ឋកិច្ច (ការវាស់វែងជាសកល)។ ក្នុងន័យនេះ ដូចដែលក្រុមហ៊ុនប្រកួតប្រជែងដណ្តើមប្រាក់នៅក្នុងសេដ្ឋកិច្ចទីផ្សារ, រដ្ឋនានាប្រកួតប្រជែងដណ្តើមអំណាច នៅក្នុងប្រព័ន្ធអន្តរជាតិ។

រូបថត *ជនជាតិយីដបោះឆ្នោតប្រជាមតិលើឯករាជ្យរបស់ខ្លួន នៅឆ្នាំ ២០១៧*

ការបែងចែកផ្ទៃក្នុង

ការសន្មត់អំពីតួអង្គឯកភូត អះអាងថា រដ្ឋធ្វើការសម្រេចចិត្តសំខាន់ៗ ប្រៀបដូចជាបុគ្គលតែម្នាក់ដែលអាចធ្វើសកម្មភាពដើម្បីផលប្រយោជន៍ជាតិ។ ជាការពិត បក្សពួកនិងអង្គភាពដែលមានផលប្រយោជន៍ខុសៗគ្នា បានជាក់សម្ពាធផ្ទុយគ្នាលើរមដឹកនាំរដ្ឋ។ អ៊ីរ៉ាក់ត្រូវបានបែងចែកយ៉ាងជ្រៅរវាងក្រុមនិកាយស៊ីអ៊ីត (Shi'ite), និកាយស៊ុននី(Sunni) និងក្រុមយីដ(Kurdish) ដែលធ្វើអោយការគ្រប់គ្រងមានភាពលំបាក។ នៅទីនេះ សមាជិកនៃកងវរសេនាតូចយោធាយីដបានបោះឆ្នោតនៅក្នុងការបោះឆ្នោតឯករាជ្យរបស់ជនជាតិយីដនៅឆ្នាំ ២០១៧។ ជនជាតិយីដចង់បានរដ្ឋឯករាជ្យជាយូរមកហើយ ប៉ុន្តែរដ្ឋាភិបាលអ៊ីរ៉ាក់បានបដិសេធមិនទទួលស្គាល់ការបោះឆ្នោតនេះថាមានសុពលភាពទេ។

ទីពីរ សនិទានភាព ឬ ការចេះប្លឹងផ្លែងហេតុនឹងផល មានន័យថា តួអង្គនីមួយៗអាចធ្វើការវិភាគអំពីការចំណាយនិងផលចំណេញ ដោយគណនាការចំណាយលើសកម្មភាពទាំងឡាយដែលអាចកើតមានឡើងនិងផលចំណេញដែលអាចទទួលបានពីសកម្មភាពទាំងនោះ។ ការប្រើប្រាស់អំណាចត្រូវចំណាយសោហ៊ុយ

[12] សនិទានភាព សំដៅលើគោលលទ្ធិទស្សនៈវិជ្ជាដែលបញ្ជាក់និងទ្រទ្រង់នូវឧត្តមភាពនៃហេតុផល ផ្អែកលើបទពិសោធន៍ ។

ហើយគួរតែទទួលបានផលចំណេញសមស្របតបមកវិញដែរ។ ដូចនៅក្នុងបញ្ហានៃការប៉ាន់ប្រមាណអំណាចដែរ គេត្រូវតែបន្ថែមទិដ្ឋភាពផ្សេងគ្នា ក្នុងការគណនាការចំណាយខាងលើ។ ជាឧទាហរណ៍ រដ្ឋនានាសន្មតទុកមុនថាខ្លួននឹងមិនចាប់ផ្តើមសង្គ្រាម ដែលពួកគេរំពឹងថានឹងបរាជ័យនោះទេ លើកលែងតែនៅពេលដែលពួកគេមានឱកាសច្រើនក្នុងការទទួលបានផលប្រយោជន៍នយោបាយ ទាំងនៅក្នុងស្រុក ឬទាំងនៅលើឆាកអន្តរជាតិ ដែលមានទំហំធំជាងការចំណាយក្នុងបរាជ័យសង្គ្រាម។ ប៉ុន្តែ វាមិនងាយស្រួលក្នុងការបូកសរុបផលចំណេញឬផលប្រយោជន៍នយោបាយអរូបី ធៀបនឹងការចំណាយជាក់ស្តែងនៅក្នុងសង្គ្រាមឡោះយ។ សូម្បីតែជ័យជម្នះក្នុងសង្គ្រាមក៏ប្រហែលជាមិនសមនឹងការចំណាយផ្សេងៗផងដែរ។ តួអង្គសមហេតុផលនានាអាចនឹងគណនាតុល្យភាពនៃការចំណាយនិងផលចំណេញមិនបានត្រឹមត្រូវ ជាពិសេសនៅពេលប្រើប្រាស់ព័ត៌មានមិនច្បាស់លាស់ឬមិនគ្រប់ជ្រុងជ្រោយ។ ទោះបីជាខុសបែបនេះក្តី មិនមានន័យថាពួកគេ(ជាតួអង្គ)មិនសមហេតុផលនោះទេ។ ទីបំផុត អាកប្បកិរិយានិងភ័ព្វសំណាងរបស់មនុស្សម្នាក់ៗមិនអាចទាយទុកជាមុនបានទេ។

ការសន្មតទាំងអស់ខាងលើអំពីសនិទានភាពនិងតួអង្គនៅក្នុងទំនាក់ទំនងអន្តរជាតិ ត្រូវបានសម្រួលយ៉ាងសាមញ្ញដើម្បីងាយយល់ ដែលមិនមែនអ្នកប្រាជ្ញទំនាក់ទំនងអន្តរជាតិទាំងអស់ទទួលយកនោះទេ។ ប៉ុន្តែអ្នកប្រាជ្ញប្រាកដនិយមចាត់ទុកថាការសម្រួលអោយសាមញ្ញបែបនេះមានប្រយោជន៍ណាស់ ព្រោះវាអនុញ្ញាតអោយអ្នកប្រាជ្ញទាំងឡាយអាចពន្យល់អំពីសកម្មភាពរបស់តួអង្គចម្រុះជាច្រើន តាមរបៀបទូទៅមួយ។

២.៥.៣. ល្បែងឆ្មៃរត្រោះអ្នកឆោស

ទ្រឹស្តីល្បែង (Game theory) គឺជាមែកធាងមួយនៃមុខវិជ្ជាគណិតវិទ្យា ដែលសិក្សាពីការទស្សន៍ទាយលទ្ធផលដែលគេចង់បាន។ ល្បែងនេះសំដៅលើស្ថានភាពមួយ ដែលអ្នកចូលរួមលេង ចំនួនពីរឬច្រើននាក់ជ្រើសរើសជំហានដែលត្រូវដើរ ឬសកម្មភាពដែលត្រូវធ្វើ ក្នុងចំណោមជំហានឬសកម្មភាពផ្សេងៗជាច្រើនតែមួយដងគត់ ឬម្តងហើយម្តងទៀត។ ការរួមបញ្ចូលគ្នានៃជំហាននីមួយៗ (របស់អ្នកចូលរួមលេងទាំងអស់) នាំអោយមានផលចំណេញ (ឧបករណ៍ប្រើប្រាស់) ដល់អ្នកចូលរួមលេងម្នាក់ៗ។ ផលចំណេញអាចជាវត្ថុរូបីជាក់ស្តែងដូចជាលុយ ឬវត្ថុអរូបីណាមួយដែលមានតម្លៃ។ ទ្រឹស្តីល្បែងមានគោលបំណងទស្សទាយលទ្ធផលដែលទំនងកើតឡើង (ជំហានដែលអ្នកចូលរួមលេងម្នាក់នឹងត្រូវដើរ) ដោយពិចារណាអំពីចំណង់ចំណូលចិត្តរបស់អ្នកលេង និងជំហានដែលពួកគេអាចដើរបាន។ ល្បែងនេះជួនកាលត្រូវបានគេហៅថា គំរូជាផ្លូវការ។

បណ្តាអ្នកប្រាជ្ញនានាប្រើប្រាស់ទ្រឹស្តីល្បែងយ៉ាងទូលំទូលាយ នៅក្នុងទំនាក់ទំនងអន្តរជាតិ ជាលើកដំបូង នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៥០ និងឆ្នាំ ១៩៦០ ដើម្បីព្យាយាមស្វែងយល់អំពីស្ថានភាពនៃសង្គ្រាមនុយក្លេអ៊ែររវាងសហរដ្ឋអាមេរិក និងសហភាពសូវៀត។ ជំហានដែលភាគីនីមួយៗអាចប្រើរួមមាន ការសម្រេចចិត្តក្នុងការប្រើប្រាស់អាវុធនុយក្លេអ៊ែរ តាមរបៀបជាក់លាក់ ហើយផលចំណេញគឺជាលទ្ធផលនៃសង្គ្រាម។ ការប្រើប្រាស់ទ្រឹស្តីល្បែង ដើម្បីសិក្សាពីអន្តរកម្មអន្តរជាតិ កាន់តែទូលំទូលាយ ក្នុងចំណោមអ្នកប្រាជ្ញ ទំនាក់ទំនងអន្តរជាតិ ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ជាពិសេសក្នុងចំណោមអ្នកប្រាជ្ញប្រាកដនិយម ដែលទទួលយកការសន្មតអំពីសនិទានភាពឬការថ្លឹងថ្លែងហេតុនិងផល។ ដើម្បីវិភាគល្បែងណាមួយតាមគណិតវិទ្យា គេសន្មតថាអ្នកចូលរួមលេងម្នាក់ៗជ្រើសរើសជំហានដែលត្រូវដើរ ដោយសមហេតុផល ដើម្បីបង្កើនផលចំណេញសម្រាប់ខ្លួនឯងជាអតិបរមា។

ប្រភេទស្ថានភាពផ្សេងៗទៀតត្រូវបានតំណាង ដោយល្បែងកំរិតផ្សេងៗគ្នាដែរ ដូចដែលត្រូវកំណត់ដោយចំនួនអ្នកចូលរួមលេង និងរចនាសម្ព័ន្ធនៃការទូទាត់ផលចំណេញ។ ភាពខុសគ្នាជាមូលដ្ឋានមួយគឺរវាង **ល្បែងផលដកស្មើសូន្យ**(zero-sum games) ដែលក្នុងនោះផលចំណេញរបស់អ្នកចូលរួមលេងម្នាក់ ស្មើនឹងទំហំនៃខាតបង់របស់អ្នកចូលរួមលេងម្នាក់ទៀត ជាដាច់ខាត និង*ល្បែងផលដកមិនស្មើសូន្យ* (non-zero-sum games) ដែលក្នុងនោះអ្នកចូលរួមលេងអាចចំណេញទាំងពីរនាក់ ឬអាចខាតបងដូចគ្នាផងដែរ។ នៅក្នុងល្បែងផលដកស្មើសូន្យ គ្មានប្រយោជន៍អ្វីដែលអ្នកចូលរួមលេងទាំងពីរ ព្យាយាមបង្កើតទំនាក់ទំនង ឬធ្វើកិច្ចសហប្រតិបត្តិការនឹងគ្នានោះទេ ពីព្រោះផលប្រយោជន៍របស់ពួកគេមានទិសដៅផ្ទុយគ្នា ១៨០ ដឺក្រេ។ ប៉ុន្តែ នៅក្នុង*ល្បែងផលដកមិនស្មើសូន្យ* ការសម្របសម្រួលលើជំហានដែលត្រូវដើរឬសកម្មភាពដែលត្រូវធ្វើអាចបង្កើនផលចំណេញឬផលប្រយោជន៍សរុបសម្រាប់អ្នកចូលរួមលេងទាំងពីរ ទោះបីជាពួកគេម្នាក់ៗនៅតែព្យាយាមទាញយកផលចំណេញមកខាងខ្លួនកាន់តែច្រើនតាមតែអាចធ្វើទៅបាន ក៏ដោយ។

ល្បែងដែលមានឈ្មោះថា **ល្បែងទ្វេគ្រោះអ្នកទោស** (Prisoner's Dilemma- PD) ឆ្លុះបញ្ចាំងពីប្រភេទនៃបញ្ហាផលប្រយោជន៍រួម ដែលជាបញ្ហាទូទៅនៅក្នុងទំនាក់ទំនងអន្តរជាតិ។ នៅក្នុងស្ថានភាពនេះ អ្នកចូលរួមលេងសមហេតុផលជ្រើសរើសជំហានដើរដែលបង្កើតលទ្ធផល ដែលអ្នកចូលរួមលេងទាំងអស់គ្នាមានលទ្ធផលអាក្រក់ជាងការជ្រើសរើសជំហានដើរផ្សេងទៀត។ ពួកគេទាំងអស់គ្នា មែនទែនទៅ អាចធ្វើបានប្រសើរជាងនេះ ប៉ុន្តែ ក្នុងនាមជាតួអង្គសមហេតុផលរៀងៗខ្លួន ពួកគេមិនអាចសម្រេចបាននូវលទ្ធផលល្អប្រសើរបែបនេះទាំងអស់គ្នាបានទេ។ តើមកពីមូលហេតុអ្វីទៅ?

តារាងសង្ខេបលទ្ធផលល្បែងទ្វេគ្រោះអ្នកទោស

		ជនសង្ស័យ «ខ»	
		បិទមាត់	សារភាព
ជនសង្ស័យ «ក»	បិទមាត់	(១,១)^{A}	(១០,០)^{C}
	សារភាព	(០,១០)^{B}	(៥,៥)^{D}

សម្គាល់៖ លេខក្នុងវង្វង់ក្រចកតំណាងចំនួនឆ្នាំដែលជនសង្ស័យអាចជាប់គុក (**ក, ខ**) ។

១. សេណារីយ៉ូ B ល្អបំផុតសម្រាប់ជនសង្ស័យ«ក»៖ ជនសង្ស័យ«ក»សារភាព ជនសង្ស័យ«ខ»នៅបិទមាត់៖ ជាលទ្ធផល ជនសង្ស័យ«ក»រួចខ្លួន ជនសង្ស័យ«ខ» ជាប់គុក ១០ឆ្នាំ។

២. សេណារីយ៉ូ C ល្អបំផុតសម្រាប់ជនសង្ស័យ«ខ»៖ ជនសង្ស័យ«ខ»សារភាព ជនសង្ស័យ«ក» បិទមាត់៖ ជាលទ្ធផល ជនសង្ស័យ«ខ»រួចខ្លួន ជនសង្ស័យ«ក» ១០ឆ្នាំគុក

៣. សេណារីយ៉ូ A ល្អបំផុតសម្រាប់ពីរនាក់៖ ជនសង្ស័យ«ក» បិទមាត់, ជនសង្ស័យ«ខ»ក៏បិទមាត់៖ ជាលទ្ធផល ជនសង្ស័យ«ក»និង«ខ» ជាប់គុកម្នាក់ ១ ឆ្នាំ។

៤. អ្វីដែលជាគ្រោះសម្រាប់ ជនសង្ស័យទាំងទ្វេ គឺ សេណារីយ៉ូ D៖ ជនសង្ស័យ«ក»ក៏សារភាព ជនសង្ស័យ«ខ»ក៏សារភាព។ ជាលទ្ធផល ជនសង្ស័យ«ក»និង«ខ» ត្រូវជាប់គុកម្នាក់ ៥ឆ្នាំ។

ការសន្មតរបស់ទ្រឹស្តីប្រាកដនិយម៖ មនុស្សអាត្មានិយម រកផលប្រយោជន៍ផ្ទាល់ខ្លួន ចុងក្រោយបែរជានាំទុក្ខទោសដល់ខ្លួនទៅវិញ។

សាច់រឿងដើមបានដំណាលអំពីអ្នកទោសពីរនាក់ ដែលសាកសួរ ដោយឡែកពីគ្នា ម្តងមួយៗ ដោយព្រះរាជអាជ្ញាម្នាក់។ ព្រះរាជអាជ្ញាដឹងថាពួកគេបានប្រព្រឹត្តអំពើប្លន់ធនាគារ ប៉ុន្តែ មានកស្តុតាងគ្រប់គ្រាន់ល្មមត្រឹមផ្តន្ទាទោសពួកគេពីបទកាន់កាប់អាវុធខុសច្បាប់តែប៉ុណ្ណោះ បើមិនដូច្នោះទេ លុះត្រាតែមានម្នាក់ក្នុងចំណោមពួកគេសារភាព។ ព្រះរាជអាជ្ញាប្រាប់អ្នកទោសម្នាក់ៗថា ប្រសិនបើគាត់សារភាព ហើយដៃគូរបស់គាត់មិនសារភាពនោះទេ គាត់នឹងត្រូវដោះលែងអោយរួចខ្លួន។ ប្រសិនបើដៃគូរបស់គាត់សារភាព ប៉ុន្តែគាត់មិនព្រមសារភាប នោះគាត់នឹងត្រូវជាប់គុកយូរឆ្នាំពីបទប្លន់ធនាគារ (ខណៈពេលដែលដៃគូរគាត់ត្រូវបានដោះលែង)។ ប្រសិនបើអ្នកទាំងពីរសារភាព ពួកគេនឹងទទួលបានការសម្រាលទោសខ្លះ។ ប្រសិនបើមិនសារភាពទេ ពួកគេនឹងត្រូវកាត់ទោសលើបទចោទប្រកាន់កាន់កាប់អាវុធខុសច្បាប់ និងជាប់ទោសត្រឹមមួយរយៈពេលខ្លីតែប៉ុណ្ណោះ។ រឿងនេះសន្មត់ថាអ្នកទោសទាំងពីរនឹងមិនមានឱកាសសងសឹក នៅពេលក្រោយទេ មានតែត្រូវរងផលវិបាកភ្លាមៗ ហើយអ្នកទោសម្នាក់ៗខ្វល់តែពីផលប្រយោជន៍ខ្លួនឯងប៉ុណ្ណោះ។

ល្បែងនេះមានដំណោះស្រាយតែមួយគត់៖ អ្នកទោសទាំងពីរនឹងសារភាពជាមិនខាន។ អ្នកទោសម្នាក់ៗនឹងវែកញែកហេតុផលដូចតទៅ៖ «ប្រសិនបើដៃគូរបស់ខ្ញុំនឹងសារភាព នោះខ្ញុំក៏គួរសារភាពដែរ ព្រោះខ្ញុំនឹងត្រូវទទួលទោសរយៈពេលខ្លីជាងបន្តិច។ ប្រសិនបើដៃគូខ្ញុំមិនព្រមសារភាព នោះខ្ញុំក៏គួរតែសារភាពដដែល ព្រោះខ្ញុំនឹងមានសេរីភាព ជាជាងត្រូវទទួលរយៈពេលខ្លី»។ អ្នកទោសម្នាក់ទៀតច្បាស់ជាវែកញែកហេតុផលដូចគ្នានេះដែរ។ នេះជាល្បែងទ្វេគ្រោះ ព្រោះថា តាមរយៈការដើរតាមជម្រើសសមហេតុផលរៀងៗខ្លួន អ្នកទោសទាំងទ្វេត្រូវរងគ្រោះ ដោយការប្រឈមមុខនឹងការកាត់ទោសដ៏វែងមួយ នៅពេលដែលពួកគេទាំងពីរអាចត្រូវជាប់ទោសក្នុងមួយរយៈពេលខ្លី ប្រសិនបើគេសហការគ្នា (បិទមាត់ មិនព្រមសារភាពទាំងពីរនាក់)។

ស្ថានភាពដូចល្បែងទ្វេគ្រោះអ្នកទោស កើតឡើងជាញឹកញាប់ នៅក្នុងទំនាក់ទំនងអន្តរជាតិ។ ជាឧទាហរណ៍ដ៏ល្អមួយ គឺការប្រណាំងប្រជែងសព្វាវុធ។ សាកល្បងពិចារណាលើការសម្រេចចិត្តរបស់ប្រទេសឥណ្ឌា និងប្រទេសប៉ាគីស្តាន ថាតើត្រូវសាងសង់ឃ្លាំងអាវុធនុយក្លែអ៊ែរដ៏ធំមួយឬយ៉ាង។ ប្រទេសទាំងពីរមានសមត្ថភាពសាងសង់វាដូចគ្នា។ ភាគីទាំងពីរមិនអាចដឹងថា តើភាគីម្ខាងទៀតកំពុងបង្កើតឃ្លាំងអាវុធដោយសម្ងាត់ឬក៏អត់នោះទេ លុះត្រាតែពួកគេឈានដល់កិច្ចព្រមព្រៀងគ្រប់គ្រងអាវុធជាមួយនឹងបទប្បញ្ញត្តិដើម្បីការផ្ទៀងផ្ទាត់យ៉ាងតឹងរឹង។ ដើម្បីវិភាគល្បែងនេះ យើងកំណត់តម្លៃចំពោះលទ្ធផលនីមួយៗដែលអាចកើតឡើង ដែលជារឿយៗ ហៅថា *លទ្ធផលជាទីពេញចិត្ត* សម្រាប់អ្នកលេងម្នាក់ៗ។ នេះមិនមែនជារឿងសាមញ្ញទេ៖ ប្រសិនបើយើងវាយតម្លៃខុសលើតម្លៃ ដែលអ្នកលេងដាក់លើលទ្ធផលជាក់លាក់មួយ យើងអាចទាញសេចក្តីសន្និដ្ឋានខុសពីល្បែងនេះ។

លទ្ធផលជាទីពេញចិត្តខាងក្រោម អាចជឿជាក់បានថាអាចទៅរួច៖ លទ្ធផលល្អបំផុត កើតមានឡើងនៅពេលតួអង្គម្ខាងបង្កើតឃ្លាំងអាវុធនុយក្លែអ៊ែរ ក្នុងខណៈពេលដែលតួអង្គម្ខាងទៀតមានឃ្លាំងនុយក្លែអ៊ែរ (ការចំណាយលើការកសាងអាវុធនុយក្លែអ៊ែរនឹងមានតម្លៃតបស្នង ពីព្រោះនៅពេលនោះ គេអាចប្រើប្រាស់វាជាអានុភាពគំរាមកំហែងបាន) លទ្ធផលល្អបំផុតទីពីរ កើតមានឡើងនៅពេលតួអង្គទាំងពីរមិនផលិតអាវុធនុយក្លែអ៊ែរ (គ្មានអានុភាព, ប៉ុន្តែក៏មិនអស់ចំណាយដែរ) លទ្ធផលល្អបំផុតទីបី កើតមានឡើងនៅពេលតួអង្គទាំងពីរបង្កើតឃ្លាំងអាវុធនុយក្លែអ៊ែរ (ការចំណាយយ៉ាងសន្ធឹក តែមិនទទួលបានអានុភាពលើគ្នាដដែល)

លទ្ធផលអាក្រក់បំផុត កើតមានឡើងនៅពេលតួអង្គម្ខាងបោះបង់អាវុធនុយក្លេអ៊ែរតែឯង ខណៈពេលដែលតួអង្គម្ខាងទៀតបានអភិវឌ្ឍវាឡើង (ម្ល៉ោះហើយច្បាស់ជាត្រូវទទួលរងការគំរាមកំហែងជាក់ជាមិនខាន)។

ល្បែងខាងលើនេះអាចត្រូវបានសង្ខេប នៅក្នុង*ម៉ាទ្រីសផលចំណេញ* (សូមមើលក្រាហ្វិក ២.៩)។ តួលេខទីមួយ ក្នុងវង្វង់ក្រចកនីមួយៗ គឺជាផលចំណេញរបស់ឥណ្ឌា ហើយតួលេខទីពីរជារបស់ប៉ាគីស្តាន។ ដើម្បីងាយស្រួលទូទាត់, លេខ ៤ បង្ហាញពីផលចំណេញខ្ពស់បំផុត ចំណែកឯ លេខ ១ ទាបបំផុត។ តាមធម្មតា ការសម្រេចចិត្តបដិសេធមិនបង្កើតអាវុធនុយក្លេអ៊ែរត្រូវបានគេហៅថា *កិច្ចសហប្រតិបត្តិការ* ហើយការសម្រេចចិត្តបន្តផលិតអាវុធនុយក្លេអ៊ែរត្រូវបានគេហៅថា *ការទប់ស្កាត់*។ ទ្វេគ្រោះ ក្នុងស្ថានភាពនេះប្រហែលគ្នានឹងស្ថានភាពអ្នកទោស៖ មេដឹកនាំរដ្ឋនីមួយៗអាចវែកញែកហេតុផលថា៖ «ប្រសិនបើគូបដិបក្សផលិតអាវុធនុយក្លេអ៊ែរ យើងត្រូវផលិតដែរ; បើខាងគេមិនផលិតទេ ហើយយើងបែរជាមិនផលិតវាដែរ មានតែយើងនឹងឆ្កួត»។ គំរូល្បែងនេះហាក់ដូចជាព្យាករណ៍ពីការប្រណាំងប្រជែងអាវុធនុយក្លេអ៊ែរ រវាងប្រទេសឥណ្ឌានឹងប្រទេសប៉ាគីស្តានដែលមើលទៅច្បាស់ជាជៀសមិនរួចទេ ទោះបីជារដ្ឋទាំងពីរនឹងមានលទ្ធផល ប្រសើរជាងបើសិនអាចជៀវាងវាបាន។

នៅឆ្នាំ ១៩៩៨ ប្រទេសឥណ្ឌាបានបំផ្ទុះគ្រាប់បែកនុយក្លេអ៊ែរ នៅក្រោមដី ដើម្បីសាកល្បងអាវុធប្រភេទថ្មី ហើយភ្លាមនោះប្រទេសប៉ាគីស្តានបានធ្វើតាមភ្លាមៗ។ ក្នុងឆ្នាំ ២០០២ រដ្ឋទាំងពីរជិតឈានដល់មាត់ជ្រោះសង្គ្រាម ដោយមានការព្យាករថានឹងមានមនុស្សស្លាប់ក្នុងសង្គ្រាមរហូតដល់ ១២ លាននាក់។ ការប្រណាំងប្រជែងសព្វាវុធដែលខ្ជះខ្ជាយនិងគ្រោះថ្នាក់ខ្លាំងនៅតែបន្ត ហើយភាគីនីមួយៗឥឡូវនេះ មានកាំជ្រួចនុយក្លេអ៊ែររាប់សិបគ្រាប់ ហើយនឹងមានបន្តទៀត។ ការជៀសវាងការប្រណាំងសព្វាវុធនឹងផ្តល់ផលប្រយោជន៍ដល់ភាគីទាំងសងខាង ជាផលប្រយោជន៍សមូហភាព ប៉ុន្តែប្រព័ន្ធទំនាក់ទំនងអន្តរជាតិ ដោយគ្មានអាជ្ញាធរកណ្តាលរឹងមាំ មិនអនុញ្ញាតអោយពួកគេដឹងនិងធ្វើអោយអត្ថប្រយោជន៍ដ៏មានសក្តានុពលនេះចេញជារូបរាងបានទេ។ ឧទាហរណ៍ខាងលើនេះបង្ហាញពីមូលហេតុដែលពួកអ្នកប្រាកដនិយមមានទំនោរទុទិដ្ឋិនិយមចំពោះដំណោះស្រាយសហប្រតិបត្តិការចំពោះបញ្ហាផលប្រយោជន៍រួម ដូចដែលល្បែងទ្វេរគ្រោះអ្នកទោសបានគូសបញ្ជាក់រួចមកហើយ។

ក្រាហ្វិក ២.៩. តារាងកំរិតផលចំណេញពីការសហការ ឬ ប្រឆាំងនឹងកិច្ចព្រមព្រៀងរវាងប្រទេសឥណ្ឌា-ប៉ាគីស្តាន ក្នុងគំរូ «ល្បែងទ្វេគ្រោះអ្នកទោស»

		ប៉ាគីស្តាន	
		សហការ	ប្រឆាំង
ឥណ្ឌា	សហការ	(៣,៣)	(១,៤)
	ប្រឆាំង	(៤,១)	(២,២)

សម្គាល់៖ លេខក្នុងវង្វង់ក្រចកតំណាងកំរិតផលចំណេញពីការ**សហការឬប្រឆាំង**នឹងកិច្ចព្រមព្រៀងមិនរីកសាយភាពអាវុធនុយក្លេអ៊ែរសំរាប់ប្រទេសឥណ្ឌានិងប៉ាគីស្តាន (ឥណ្ឌា,ប៉ាគីស្តាន)។

អ្នកប្រាជ្ញទំនាក់ទំនងអន្តរជាតិនានាបានវិភាគប្រភេទល្បែងជាច្រើនទៀត ក្រៅពីល្បែងទ្វេរគ្រោះអ្នកទោស។ ជាឧទាហរណ៍ *សត្វមាន់*នៅក្នុងល្បែងមាន់ជល់ តំណាងអោយក្មេងស្ទាវពីរនាក់ រត់ទៅបុកក្បាលគ្នា។

អ្នកណាដែលគេច មិនបន្តរត់បុកក្បាលគ្នាទេ គឺជាសត្វ«មាន់»កំសាក។ ក្នុងស្ថានីមួយៗវែកញែកហេតុផលថា៖ «ប្រសិនបើវាមិនគេច ខ្ញុំត្រូវតែគេចចេញ។ ប៉ុន្តែ ប្រសិនបើវាគេចចេញ ខ្ញុំនឹងមិនគេចទេ»។ អ្នកលេងដែលប្តេជ្ញាមុនគេ ថានឹងមិនគេចចេញ (ឧទាហរណ៍ ដោយការដកដៃចង្កូតចេញ ឬយកក្រណាត់បិទភ្នែក) ប្រាកដជានឹងឈ្នះ។ ដូចគ្នានេះដែរ នៅក្នុងវិបត្តិមីស៊ីលគុយបាឆ្នាំ ១៩៦២ អ្នកប្រាជ្ញខ្លះបានអះអាងថា ប្រធានាធិបតី លោក ចន កេណ្ណឺឌី (John F. Kennedy) បាន«ឈ្នះ» ដោយមើលទៅគាត់ហាក់ដូចជាបានត្រៀមខ្លួនរួចជាស្រេចដើម្បីប្រថុយនឹងសង្គ្រាមនុយក្លេអ៊ែរ ប្រសិនបើនាយករដ្ឋមន្ត្រីសូវៀត លោក នីគីតា ក្រូសឆេវ (Nikita Khrushchev) មិនថយក្រោយ និងដកប្រព័ន្ធមីស៊ីលសូវៀតចេញពីប្រទេសគុយបា។ (ទោះជាយ៉ាងនេះក្តី មានការពន្យល់ផ្សេងអំពីលទ្ធផលនៃវិបត្តិនេះ។)

ល្បែងមាន់ជល់ បំភ្លឺការយល់ដឹងលើបញ្ហាត្តិនៃយុទ្ធសាស្ត្រ*ភាវាំង*។ យុទ្ធសាស្ត្រ*ភាវាំង*ពាក់ព័ន្ធនឹងការបញ្ចុះបញ្ចូលតួអង្គម្នាក់ទៀតមិនអោយធ្វើសកម្មភាព ដែលតួអង្គនោះចង់ធ្វើ ប្រសិនបើគ្មានការរារាំង។ ដូចនៅក្នុងល្បែងមាន់ជល់ដែរ នៅពេលដែលអ្នកបើកបរម្នាក់ប្តេជ្ញាថានឹងមិនបត់ចេញ មេដឹកនាំរដ្ឋព្យាយាមបញ្ចុះបញ្ចូលរដ្ឋដទៃថា ពួកគេនឹងឆ្លើយតបយ៉ាងតឹងរ៉ឹង ប្រសិនបើពួកគេ (ឬសម្ព័ន្ធមិត្តរបស់ពួកគេ) ត្រូវបានរងការវាយប្រហារ។ ប៉ុន្តែ ដោយសារតែការមិនបត់បែនឬងាកចេញ ប្រថុយនឹងគ្រោះមហន្តរាយសម្រាប់ភាគីទាំងសងខាង វាពិបាកណាស់សម្រាប់ភាគីម្ខាងក្នុងការបញ្ចុះបញ្ចូលភាគីម្ខាងទៀតថាខ្លួននឹងសុខចិត្តប្រថុយនឹងការបុកគ្នា (ទើបប្រយុទ្ធក្នុងសង្គ្រាម) ប្រសិនបើភាគីម្ខាងទៀតសម្រេចចិត្តមិនបត់ចេញដែរ។ ជារឿយៗ ទ្រឹស្តីល្បែង សិក្សាពីការសម្រេចចិត្ត ដោយអាស្រ័យលើគ្នាទៅវិញទៅមក បានន័យថាលទ្ធផលសម្រាប់តួអង្គម្ខាងត្រូវអាស្រ័យលើសកម្មភាពរបស់តួអង្គម្ខាងទៀត។

មេរៀននេះបានផ្តោតទៅលើកង្វល់របស់ពួកអ្នកប្រាកដនិយម៖ ផលប្រយោជន៍របស់រដ្ឋ ការបែងចែកអំណាចក្នុងចំណោមរដ្ឋ ការចរចារវាងរដ្ឋ និងសម្ព័ន្ធភាពនៃរដ្ឋនានា។ មេរៀនបានចាត់ទុករដ្ឋជាតួអង្គមួយឯកតា ដូចដែលគេវិភាគអន្តរកម្មរបស់មនុស្សម្នាក់ៗ។ សកម្មភាពរបស់មេដឹកនាំរដ្ឋត្រូវបានចាត់ទុកដូចជាទង្វើបង្កើនអំណាច តាមរយៈការស្វែងរកផលប្រយោជន៍ដែលអាចកំណត់បាន តាមរយៈយុទ្ធសាស្ត្រចរចាយ៉ាងស្អិតរមួត។ ប៉ុន្តែ ទ្រឹស្តីប្រាកដនិយមមិនមែនជាមធ្យោបាយតែមួយគត់ ដើម្បីសម្លឹងមើលបញ្ហាសំខាន់ៗក្នុងទំនាក់ទំនងអន្តរជាតិនោះទេ។ មេរៀនទី ៣ ពិនិត្យមើលឡើងវិញនូវប្រធានបទទាំងនេះ ដោយការត្រិះរិះពិចារណាខ្ពស់ ដោយពឹងផ្អែកតិចតួចលើគោលការណ៍ស្នូលសម្រាប់ដោះស្រាយបញ្ហាផលប្រយោជន៍រួម តាមគោលការណ៍គ្រប់គ្រង តែតាមគោលការណ៍បដិការ និងអត្តសញ្ញាណវិញម្តង។

សេចក្តីសន្ទេប

១. ទ្រឹស្តីប្រាកដនិយម ពន្យល់ពីទំនាក់ទំនងអន្តរជាតិ ដោយផ្តោតការយកចិត្តទុកដាក់លើ**អំណាច**។

២. អ្នកប្រាជ្ញទ្រឹស្តីប្រាកដនិយម និងអ្នកប្រាជ្ញឧត្តមគតិនិយម មានការសន្មតផ្សេងៗគ្នាអំពី **លក្ខណៈមនុស្ស សណ្តាប់ធ្នាប់អន្តរជាតិ** និង**សក្តានុពលនៃការរក្សាបាននូវសន្តិភាព**។

៣. អំណាច អាចត្រូវកំណត់ថាជា **ឥទ្ធិពល** ឬ**សមត្ថភាព** ដែលអាចបង្កើតជាឥទ្ធិពល។

៤. សូចនាករសំខាន់បំផុត តែមួយគត់ សម្រាប់វាស់ស្ទង់អំណាចរបស់រដ្ឋនានាគឺ ផលិតផលក្នុងស្រុកសរុប (**ផ.ស.ស.**)របស់រដ្ឋទាំងនោះ។

៥. **សមត្ថភាពអំណាច**រយៈពេលខ្លីពឹងផ្អែកលើ**ធនធាន**រយៈពេលវែងទាំង*រូបី*និង*អរូបី*។

៦. អ្នកប្រាជ្ញទ្រឹស្តីប្រាកដនិយមយល់ថា **កម្លាំងយោធា** គឺជាសមត្ថភាពអំណាចសំខាន់បំផុត។

៧. **ភាពអនាធិបតេយ្យអន្តរជាតិ**(អវត្តមានរដ្ឋាភិបាលពិភពលោក) មានន័យថា រដ្ឋនីមួយៗគឺជាតួអង្គមានអធិបតេយ្យភាពនិងឯករាជ្យភាព មានស្វ័យភាព ស្វែងរកផលប្រយោជន៍ជាតិរៀងៗខ្លួន។

៨. ជាធម្មតា **ប្រព័ន្ធអន្តរជាតិ** ផ្តោតសំខាន់លើអធិបតេយ្យភាពរបស់រដ្ឋ ពោលគឺសិទ្ធិរបស់រដ្ឋក្នុងការគ្រប់គ្រងកិច្ចការនានាក្នុងទឹកដីរបស់ខ្លួន និងទំនួលខុសត្រូវក្នុងការគោរពព្រំដែនរដ្ឋ ដែលមានការទទួលស្គាល់ជាលក្ខណៈអន្តរជាតិ។

៩. ប្រទេសមហាអំណាចទាំង៧ មានផលិតផលក្នុងស្រុកសរុបចំនួនពាក់កណ្តាលនៃផ.ស.ស.ពិភពលោកទាំងមូល ហើយមានកម្លាំងយោធា និងសមត្ថភាពអំណាចផ្សេងទៀត យ៉ាងច្រើនលើសលុប។

១០. **ទ្រឹស្តីអន្តរកាលអំណាច** អះអាងថា សង្គ្រាមជារឿយៗបណ្តាលមកពីការផ្លាស់ប្តូរការបែងចែកអំណាចធៀប នៅក្នុងប្រព័ន្ធអន្តរជាតិ។

១១. **អនុត្តរភាព** (ភាពលេចធ្លោខ្លាំងជាងគេបំផុតរបស់រដ្ឋណាមួយ នៅក្នុងប្រព័ន្ធអន្តរជាតិ) អាចជួយរក្សាស្ថេរភាពនិងសន្តិភាពក្នុងទំនាក់ទំនងអន្តរជាតិ ប៉ុន្តែមានគុណវិបត្តិមួយចំនួនផងដែរ។

១២. **ប្រព័ន្ធមហាអំណាច** ឬ **ប្រព័ន្ធប្រទេសមហាអំណាច** ដែលជាប្រព័ន្ធអន្តរជាតិផ្តោតជាពិសេសលើប្រទេសមហាអំណាច រួមមានប្រទេសមហាអំណាចចំនួន ៦ ឬ ៧ (ចំនួនជាក់ស្តែងផ្លាស់ប្តូរ ពីសម័យកាលមួយទៅមួយទៀត ដោយអាស្រ័យតាមការឡើងឬធ្លាក់ចុះនៃអំណាចរដ្ឋទាំងនោះ)។

១៣. រដ្ឋមួយចំនួនរួមគ្នាបង្កើតសម្ព័ន្ធភាព(យោធា) ដើម្បីបង្កើនអំណាច ទប់ទល់នឹងអំណាចរបស់រដ្ឋ ឬសម្ព័ន្ធភាពផ្សេងទៀត។

១៤. សម្ព័ន្ធភាពទាំងឡាយអាចផ្លាស់ប្តូរយ៉ាងឆាប់រហ័ស ហើយជះឥទ្ធិពលខ្លាំងលើទំនាក់ទំនងអំណាច។

១៥. សម្ព័ន្ធមិត្តយោធាសំខាន់ៗក្នុងពិភពលោក រួមទាំងអង្គការណាតូ(NATO) និង សម្ព័ន្ធភាពរវាងសហរដ្ឋអាមេរិកនឹងប្រទេសជប៉ុន កំពុងប្រឈមនឹងតួនាទីមិនច្បាស់ប្រាកដ នៅក្នុងប្រព័ន្ធសណ្តាប់ធ្នាប់ពិភពលោក ដែលកំពុងតែផ្លាស់ប្តូរ ជានិច្ច។

១៦. កិច្ចការអន្តរជាតិ អាចត្រូវគេមើលឃើញថា ជាស៊េរីនៃការចរចាគ្នា ដែលរដ្ឋប្រើសមត្ថភាព អំណាចរបស់ខ្លួនជាអនុភាពដើម្បីសម្រេចលទ្ធផលល្អសម្រាប់ខ្លួន។ ប៉ុន្តែលទ្ធផលនៃការចរចា ក៏អាស្រ័យលើយុទ្ធសាស្ត្រនិងសំណាងផងដែរ។

១៧. គោលការណ៍តួអង្គសមហេតុផល (Rational-Actor) ចាត់ទុករដ្ឋហាក់បីដូចជាបុគ្គលនីមួយៗដែលធ្វើទង្វើគ្រប់បែបយ៉ាង ដើម្បីពង្រីកផលប្រយោជន៍ផ្ទាល់ខ្លួន។ ការសន្មតយ៉ាងសាមញ្ញបែបនេះ នៅអាចជជែកដេញដោលបន្តទៀត ប៉ុន្តែ វាអនុញ្ញាតអោយអ្នកប្រាកដនិយមអភិវឌ្ឍគំរូនិងការពន្យល់សង្ខេបៗ និងជាទូទៅបានដែរ។

១៨. ទ្រឹស្តីល្បែង (Game Theory) ទាញយកការពន្យល់ពីគំរូបំព្រួញនៃស្ថានភាពចរចា។ ល្បែងទ្វេរគ្រោះអ្នកទោស (Prisoner's Dilemma) ឆ្លុះបញ្ចាំងពីបញ្ហាផលប្រយោជន៍រួម ដ៏ស្មុគស្មាញ។

ពាក្យគន្លឹះ

១. ទ្រឹស្តីប្រាកដនិយម ជាទ្រឹស្តីប្រពៃណីយ៉ាងទូលំទូលាយ ដែលពន្យល់ពីទំនាក់ទំនងអន្តរជាតិ ផ្តោតលើអំណាច ជាចម្បង។ សូមមើលផងដែរនូវ *ឧត្តមគតិ និងលទ្ធិនិយមនិយម*។

២. ឧត្តមគតិនិយម ជាវិធីសាស្ត្រដែលសង្កត់ធ្ងន់លើច្បាប់អន្តរជាតិ សីលធម៌ និងអង្គការអន្តរជាតិ ជាជាងអំណាចតែមួយមុខគត់ ដែលជាឥទ្ធិពលសំខាន់លើទំនាក់ទំនងអន្តរជាតិ។ សូមមើល*ទ្រឹស្តីប្រាកដនិយម*ផងដែរ។

៣. អំណាច ជាសមត្ថភាព ឬសក្តានុពលក្នុងការដេះឥទ្ធិពលលើអាកប្បកិរិយារបស់អ្នកដទៃ ដែលត្រូវបានវាស់វែងដោយការកាន់កាប់នៃលក្ខណៈសម្បត្តិរូបី និងអរូបីមួយចំនួន។

៤. ភូមិសាស្ត្រនយោបាយ សំដៅលើការប្រើប្រាស់ភូមិសាស្ត្រជាធាតុផ្សំនៃអំណាច និងបញ្ញត្តិបែបនេះត្រូវបានប្រតិបត្តិដោយអ្នកដឹកនាំនយោបាយ និងអ្នកប្រាជ្ញនានា។

៥. ភាពអនាធិបតេយ្យ នៅក្នុងទ្រឹស្តីទំនាក់ទំនងអន្តរជាតិ ជាពាក្យដែលបង្កប់ន័យដែលមិនសំដៅលើភាពវឹកវរទាំងស្រុងនោះទេ ប៉ុន្តែកង្វះរដ្ឋាភិបាលកណ្តាលដែលអាចពង្រឹងការអនុវត្តច្បាប់បាន។

៦. បទដ្ឋាន សំដៅលើការព្រមព្រៀងទុករួមគ្នាអំពីអាកប្បកិរិយាតួអង្គណាម្នាក់ ដែលត្រូវបានចាត់ទុកថាត្រឹមត្រូវ។

៧. អធិបតេយ្យភាព គឺជាសិទ្ធិរបស់រដ្ឋ (យ៉ាងហោចណាស់មាននៅក្នុងគោលការណ៍) ក្នុងការធ្វើអ្វីដែលខ្លួនចង់បាននៅក្នុងទឹកដីរបស់ខ្លួន។ ជាប្រពៃណី អធិបតេយ្យភាពគឺជាបទដ្ឋានអន្តរជាតិដ៏សំខាន់បំផុត។

៨. ទ្វេគ្រោះសន្តិសុខ សំដៅលើស្ថានភាពដែលសកម្មភាពដែលរដ្ឋធ្វើឡើងដើម្បីធានាសន្តិសុខផ្ទាល់ខ្លួនរបស់ពួកគេ (ដូចជាការដាក់ពង្រាយកម្លាំងយោធាបន្ថែមទៀត) ត្រូវបានអ្នកផ្សេងទៀតយល់ថាជាការគំរាមកំហែងដល់សន្តិសុខរបស់រដ្ឋផ្សេងទៀត។

៩. តុល្យភាពនៃអំណាច ឬតុល្យភាពអំណាច ជាគោលគំនិតទូទៅនៃអំណាចរបស់រដ្ឋមួយឬច្រើន ដែលត្រូវបានប្រើដើម្បីរក្សាតុល្យភាពអំណាចនៃរដ្ឋឬក្រុមរដ្ឋផ្សេងទៀត។ ពាក្យនេះក៏អាចសំដៅទៅលើ (១) សមាមាត្រនៃសមត្ថភាពអំណាច ក្នុងចំណោមរដ្ឋឬសម្ព័ន្ធភាពនានា (២) សមាមាត្រប្រហាក់ប្រហែលគ្នា ឬ (៣) ដំណើរការដែលសម្ព័ន្ធប្រឆាំងតុល្យភាពត្រូវបានបង្កើតឡើងម្តងហើយម្តងទៀត ដើម្បីរារាំងរដ្ឋមួយពីការដណ្តើមយកតំបន់ទាំងមូល។

១០. ប្រទេសមហាអំណាច ជាទូទៅ រដ្ឋពាក់កណ្តាល ឬរដ្ឋដែលមានអំណាចបំផុត; ក្លឹបប្រទេសមហាអំណាច មានតែ នៅអឺរ៉ុបរហូតដល់សតវត្សទី ២០។ សូមមើលផងដែរនូវ*ប្រទេសអំណាចមធ្យម*។

១១. រដ្ឋឬប្រទេសអំណាចកមធ្យម ដែលមានចំណាត់ថ្នាក់ទាបជាងប្រទេសមហាអំណាចមួយចំនួនបើប្រៀបធៀបទៅនឹងឥទ្ធិពលរបស់ពួកគេលើកិច្ចការពិភពលោក (ឧទាហរណ៍ ប្រេស៊ីល និងឥណ្ឌា)។ សូមមើល *ប្រទេសមហាអំណាច* ផងដែរ។

១២. ទ្រឹស្តីប្រាកដនិយមថ្មីសំដៅលើកំណែថ្មីនៃទ្រឹស្តីប្រាកដនិយម ដែលសង្កត់ធ្ងន់ទៅលើឥទ្ធិពលលើឥរិយាបថរដ្ឋ ដោយសារចនាសម្ព័ន្ធនៃប្រព័ន្ធអន្តរជាតិ ជាពិសេសការបែងចែក អំណាចអន្តរជាតិ។ សូមមើល*ទ្រឹស្តីប្រាកដនិយម*ផងដែរ។

១៣. ប្រព័ន្ធពហុប៉ូល គឺជាប្រព័ន្ធអន្តរជាតិដែលជាធម្មតាមានមជ្ឈមណ្ឌលអំណាចចំនួនប្រាំ ឬប្រាំមួយដែលមិនត្រូវបានដាក់ជាក្រុមនៅក្នុងសម្ព័ន្ធភាពរួមឡើយ។

១៤. ទ្រឹស្តីអន្តរកាលអំណាច ទ្រឹស្តីដែលថាសង្គ្រាមដ៏ធំបំផុតកើតឡើងពីបញ្ហាប្រឈមទៅកាន់តំណែងកំពូលនៅក្នុងឋានានុក្រមអំណាច នៅពេលដែលអំណាចកើនឡើងលើស (ឬគំរាមកំហែងលើស) រដ្ឋដែលមានអំណាចបំផុត។

១៥. អនុត្តរភាព សំដៅលើការកាន់កាប់អំណាចកំពូលដោយរដ្ឋមួយ នៅក្នុងប្រព័ន្ធអន្តរជាតិ ដូច្នេះ វាអាចគ្រប់គ្រងការបង្កើតច្បាប់ និងការរៀបចំដែលទំនាក់ទំនងនយោបាយ និងសេដ្ឋកិច្ចអន្តរជាតិ ត្រូវបានធ្វើឡើង ដោយអនុត្តរភាពតែឯង។ សូមមើលផងដែរនូវ*ទ្រឹស្តីស្ថេរភាពអនុត្តរភាព*។

១៦. ទ្រឹស្តីស្ថិរភាពអនុត្តរភាព គឺជាការទាញអំណះអំណាងដែលថារបបមានប្រសិទ្ធភាពបំផុត នៅពេលដែលអំណាចនៅក្នុងប្រព័ន្ធអន្តរជាតិត្រូវបានប្រមូលផ្តុំច្រើនបំផុតនៅមួយកន្លែង។ សូមមើល *អនុត្តរភាព* ផងដែរ។

១៧. ភាពស្អិតរមួតនៃសម្ព័ន្ធភាព សំដៅលើភាពងាយស្រួលដែលសមាជិកប្រមូលផ្តុំគ្នាជាសម្ព័ន្ធភាព។ វាមានទំនោរខ្ពស់ នៅពេលដែលផលប្រយោជន៍ជាតិស្របគ្នា ហើយនៅពេលដែលកិច្ចសហប្រតិបត្តិការក្នុងចំណោមសម្ព័ន្ធមិត្តត្រូវបានចងក្រងជាស្ថាប័ន។

១៨. ការចែករម្លែកការចំណាយ គឺជាការបែងចែកការចំណាយលើសម្ព័ន្ធភាព ក្នុងចំណោមសមាជិកទាំងអស់។ ពាក្យនេះក៏សំដៅទៅលើដម្លោះដែលអាចកើតឡើងលើការបែងចែកបែបនេះ។

១៩. អង្គការសន្ធិសញ្ញាអាត្លង់ទិកខាងជើង (ណាតូ) ជាសម្ព័ន្ធភាពយោធាដឹកនាំដោយសហរដ្ឋអាមេរិក ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៤៩ រួមមានសមាជិកភាគច្រើន នៅអឺរ៉ុបខាងលិច ដើម្បីប្រឆាំង និងរារាំងអំណាចសហភាពសូវៀតនៅអឺរ៉ុប។ បច្ចុប្បន្នវាកំពុងពង្រីកទៅក្នុងអតីតប្លុកសូវៀត។ សូមមើលផងដែរ *កតិកាសញ្ញាវ៉ារស៊ៅ*។

២០. កតិកាសញ្ញាវ៉ារស៊ៅ (Warsaw Pact) គឺជាសម្ព័ន្ធភាពយោធាអឺរ៉ុបខាងកើត ដឹកនាំដោយសហភាពសូវៀត ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៥៥ ហើយត្រូវបានរំសាយនៅឆ្នាំ ១៩៩១។ វាបានប្រឆាំងនឹងសម្ព័ន្ធភាពណាតូ។ សូមមើលផងដែរ *អង្គការសន្ធិសញ្ញាអាត្លង់ទិកខាងជើង* (NATO)។

២១. ចលនាមិនចូលបក្សសម្ព័ន្ធ គឺជាចលនានៃប្រទេសតតិយលោក ដែលដឹកនាំដោយប្រទេសឥណ្ឌា និងយូហ្គោស្លាវី ដែលប៉ុនប៉ងឈរដាច់ឆ្ងាយពីការប្រជែងគ្នារវាងសហរដ្ឋអាមេរិក និងសហភាពសូវៀតក្នុងអំឡុងសង្គ្រាមត្រជាក់។

២២. យុទ្ធសាស្ត្ររារាំង គឺជាការគំរាមកំហែងដាក់ទណ្ឌកម្មតួអង្គផ្សេងទៀត ប្រសិនបើវាធ្វើសកម្មភាពអវិជ្ជមានជាក់លាក់ណាមួយ (ជាពិសេសការវាយប្រហារទៅលើរដ្ឋផ្ទាល់ខ្លួន ឬសម្ព័ន្ធមិត្តរបស់ពួកគេ)។ សូមមើលផងដែរ *ការបំផ្លាញដែលធានាចំពោះគ្នាទៅវិញទៅមក* (MAD)។

២៣. យុទ្ធសាស្ត្របង្ខំ គឺជាការគម្រាមកំហែងដោយកម្លាំងដើម្បីធ្វើអោយតួអង្គផ្សេងទៀតធ្វើសកម្មភាពមួយចំនួន (ជាជាងការរារាំងដូចជាការហាមឃាត់មិនអោយធ្វើសកម្មភាព)។

២៤. ការប្រណាំងប្រជែងសព្វាវុធ គឺជាដំណើរការបដិការ ដែលរដ្ឋពីរឬច្រើនបង្កើនសមត្ថភាពយោធា ដើម្បី

ឆ្លើយតបចំពោះគ្នា ទៅវិញទៅមក។

២៥. តួអង្គសមហេតុផល សំដៅលើតួអង្គដែលចាត់ទុកថាជាអង្គភាពតែមួយឯកតា ដែលអាច «គិត» អំពីសកម្មភាពរបស់ពួកគេយ៉ាងស៊ីសង្វាក់គ្នា ធ្វើការជ្រើសរើស កំណត់ផលប្រយោជន៍របស់ពួកគេ និងចាត់ចំណាត់ថ្នាក់ផលប្រយោជន៍ នៅក្នុងលក្ខខណ្ឌនៃអាទិភាព។

២៦. ផលប្រយោជន៍ជាតិ គឺជាផលប្រយោជន៍របស់រដ្ឋជារួម (ផ្ទុយពីភាគីជាក់លាក់ ឬបក្សពួកនៅក្នុងរដ្ឋាភិបាលនោះ)។

២៧. ការវិភាគការចំណាយនិងចំណូល គឺជា ការគណនាលើការចំណាយដែលកើតឡើងដោយសកម្មភាពដែលអាចកើតមាន និងអត្ថប្រយោជន៍ដែលវាទំនងជានឹងនាំមកវិញ។

២៨. ទ្រឹស្តីហ្គេម គឺជាមែកធាងមួយនៃគណិតវិទ្យាដែលសិក្សាអំពីការទស្សន៍ទាយលទ្ធផលចរចា។ ល្បែងដូចជា ល្បែងទ្វេគ្រោះអ្នកទោស (Prisoner's Dilemma) និងល្បែងមាន់ជល់ត្រូវបានប្រើដើម្បីវិភាគប្រភេទនៃអន្តរកម្មអន្តរជាតិផ្សេងៗ។

២៩. ល្បែងផលបូកស្មើសូន្យ សំដៅលើ ស្ថានភាពដែលផលចំណេញរបស់តួអង្គណាមួយ តាមនិយមន័យស្មើនឹងការខាតបង់របស់ភាគីម្ខាងទៀត ផ្ទុយទៅនឹងល្បែងផលបូកមិនស្មើសូន្យដែលក្នុងនោះតួអង្គទាំងពីរទទួលបានផលចំណេញ (ឬខាតបង់)។

៣០. ល្បែងទ្វេគ្រោះអ្នកទោស(PD) គឺជាស្ថានភាពដែលយកគំរូតាមទ្រឹស្តីល្បែងដែលតួអង្គសមហេតុផលដែលស្វែងរកផលប្រយោជន៍ផ្ទាល់ខ្លួន តែបែរជាទទួលបាននូវលទ្ធផលអាក្រក់ជាងអ្វីដែលពួកគេអាចនឹងទទួលបាន ប្រសិនបើពួកគេមានការសហការរួមគ្នា។

សំណួរអនុវត្តន៍

១. ដោយប្រើប្រាស់តារាង១.៤(ដោយយកផលិតផលក្នុងស្រុកសរុបជារង្វាស់រង្វាល់នៃអំណាច) និងផែនទីនៅផ្នែកខាងមុខ ក្នុងសៀវភៅពុម្ព ចូរជ្រើសរើសរដ្ឋមួយ និងប៉ាន់ស្មានអំពីទំហំអំណាច ដែលសម្ព័ន្ធភាពរវាងរដ្ឋនានានៅជុំវិញនោះអាចបង្កើតបាន ដើម្បីប្រឆាំងនឹងរដ្ឋប្រសិនបើវាបានក្លាយជាអ្នកឈ្លានពាន។

២. ចូរពិពណ៌នាអំពីយុទ្ធសាស្ត្រារាំង ដែលសហរដ្ឋអាមេរិកបានអនុម័ត ដើម្បីទប់ស្កាត់មហិច្ឆតានុយក្លេអ៊ែរអ៊ីរ៉ង់ និងកូរ៉េខាងជើង។ តើប្រភពអំណាចប្រភេទណាដែលចាំបាច់នៅពីក្រោយយុទ្ធសាស្ត្រនេះ?

៣. តើទ្រឹស្តីអំណាចនិងទ្វេគ្រោះសន្តិសុខ ឬក៏ទ្រឹស្តីអនុត្តរភាព អាចពន្យល់ពីយុទ្ធសាស្ត្រារាំងរបស់សហរដ្ឋអាមេរិកបានដែរឬទេ?

៤. យោងតាមការបង្កើតបក្សសម្ព័ន្ធបច្ចុប្បន្នរវាងប្រទេសមហាអំណាច និងប្រទេសអំណាចមធ្យម (មើលក្រាហ្វិក ២.៨.) ហេតុអ្វីបានជាប្រទេសចិន និងប្រទេសរុស្ស៊ី អាចចង់ឬ មិនចង់ អោយគេមើលឃើញថាខ្លួនជាគូសត្រូវផ្ទាល់ដើម្បីប្រជែងនឹងអនុត្តរភាពរបស់សហរដ្ឋអាមេរិក?

៥. ដោយរំលឹកពីភាពខុសគ្នារវាង ល្បែងផលបូកស្មើសូន្យ (zero-sum) និងល្បែងផលបូកមិនស្មើសូន្យ (non-zero-sum) តើអ្នកអាចរិះរកស្ថានភាពអន្តរជាតិបច្ចុប្បន្ន ដែលជាជម្លោះមានលក្ខណៈជាល្បែងចាញ់ឬឈ្នះទាំងអស់ ដែរឬទេ? រកស្ថានភាពមួយទៀតដែលមិនមែនជាល្បែងផលបូកស្មើសូន្យ?

៦. ជ្រើសរើសព្រឹត្តិការណ៍អន្តរជាតិនាពេលថ្មីៗនេះ ហើយធ្វើបញ្ជីរៀបរាប់សមត្ថភាពអំណាច ដែលរដ្ឋពាក់ព័ន្ធប្រើជាអានុភាពឥទ្ធិពលចំណេញមកខាងខ្លួនក្នុងព្រឹត្តិការណ៍នោះ។ តើសមត្ថភាពណាមួយមានប្រសិទ្ធភាព ហើយណាមួយមិនមាន? ហេតុអ្វី?

៧. ប្រព័ន្ធអន្តរជាតិទំនើបបានកើតឡើង នៅពេលដែលសង្គមកសិកម្មពឹងផ្អែកជាចម្បងលើដីស្រែចម្ការដើម្បីបង្កើតទ្រព្យសម្បត្តិ។ សម័យឥឡូវ ទ្រព្យសម្បត្តិភាគច្រើនលែងត្រូវបានបង្កើតឡើង តាមរយៈការធ្វើកសិកម្មទៀតហើយ តើលក្ខណៈទឹកដីរបស់រដ្ឋមួយ លែងមានប្រយោជន៍ហើយមែនទេ? តើការថយចុះតម្លៃសេដ្ឋកិច្ចដោយផ្អែកលើទឹកដី អាចផ្លាស់ប្តូររបៀបដែលរដ្ឋនានាទាក់ទងគ្នាយ៉ាងដូចម្តេច?

៨. ប្រសិនបើអ្នកជាមេដឹកនាំរដ្ឋតូចមួយនៅអាហ្វ្រិក ដែលកំពុងធ្វើការចរចាជាមួយនឹងប្រទេសមហាអំណាច អំពីបញ្ហាដែលផលប្រយោជន៍ប្រទេសទាំងពីរមិនស្របគ្នា តើអ្នកនឹងដាក់អានុភាពគៀបសង្កត់និងយុទ្ធសាស្ត្រអ្វីខ្លះ ដើម្បីនាំផលប្រយោជន៍ដល់រដ្ឋរបស់អ្នកកាន់តែច្រើនតាមតែអាចធ្វើបាន?

ការស្វែងរកផលប្រយោជន៍រួម

ទស្សនកិច្ចអន្តរការណាតូ នៅប្រទេសអាហ្វហ្គានីស្ថាន

ផលប្រយោជន៍រួម៖ ការកម្ចាត់ពួកតាលីបង់នៅអាហ្វហ្គានីស្ថាន

សាវតារ

បន្ទាប់ពីការវាយប្រហារភេរវកម្ម ក្នុងឆ្នាំ ២០០១ រដ្ឋជាសមាជិក អង្គការណាតូ បានប្តេជ្ញាចិត្តជួយប្រយុទ្ធនឹងកងកម្លាំងនៃក្រុមអាល់កៃដា និងពួកឧទ្ទាមតាលីបង់ដែលជាអ្នកការពារលាក់បាំងពួកគេ នៅក្នុងផ្នែកនៃប្រទេសអាហ្វហ្គានីស្ថាន។ ប្រទេសសមាជិកទាំងនោះបានបង្កើតកងកម្លាំងជំនួយសន្តិសុខអន្តរជាតិចម្រុះជាតិ(ISAF)ដែលភាគច្រើនជាទាហានណាតូ ត្រូវដាក់ពង្រាយនៅប្រទេសអាហ្វហ្គានីស្ថាន។ គោលដៅរបស់កងកម្លាំងចម្រុះខាងលើត្រូវផ្តល់សន្តិសុខសម្រាប់រដ្ឋាភិបាលអាហ្វហ្គានីស្ថាន ដែលកំពុងរត់គេចខ្លួនបណ្តុះបណ្តាលយោធាថ្មី និងកសាងស្ថាប័ននយោបាយ ដើម្បីពារាំងក្រុមតាលីបង់មិនអោយដណ្តើមយកអំណាចកាន់កាប់ជាថ្មីឡើយ។ ទោះបីជា ISAF បានបញ្ចប់ជាផ្លូវការ នៅឆ្នាំ ២០១៥ ក៏ដោយ ក៏ប្រតិបត្តិការគាំទ្រដ៏អង់អាច (Operation Resolute Support) ត្រូវបានជំនួសវិញ។ ដូចទៅនឹងកងកម្លាំងជំនួយសន្តិសុខអន្តរជាតិចម្រុះជាតិដែរ គោលដៅនៃប្រតិបត្តិការគាំទ្រដ៏អង់អាច គឺដើម្បីជួយផ្តល់ការគាំទ្រ និងសន្តិសុខនៅក្នុងប្រទេសអាហ្វហ្គានីស្ថាន។

ការកៀងគរកម្លាំងអោយបានគ្រប់គ្រាន់ដើម្បីដណ្តើមបានជោគជ័យ នៅអាហ្វហ្គានីស្ថាន គឺជាផលប្រយោជន៍រួម។ ការផ្តល់កងទ័ពនិងឧបករណ៍សម្រាប់ ប្រតិបត្តិការគាំទ្រដ៏អង់អាចត្រូវប្រព្រឹត្តិទៅ ដោយការស្ម័គ្រចិត្តរបស់ប្រទេសសមាជិកណាតូ។ ដោយមិនគិតពីចំនួនកងទ័ពដែលប្រទេសនីមួយៗបញ្ជូនមក ពួកគេចែករំលែកនូវអត្ថប្រយោជន៍ ស្មើរភាព នៅអាហ្វហ្គានីស្ថាន ស្មើគ្នាៗ។ ប៉ុន្តែ ប្រសិនបើប្រទេសកាន់តែច្រើនកិបកេងចំនួនកងទ័ព ដោយមិនចង់បញ្ជូនទៅនោះទេ នោះកងកម្លាំងចម្រុះនឹងមានទំហំតូចពេក ហើយគោលដៅនឹងមិនអាចសម្រេចបាន ដែលអាចនាំទៅដល់ការលេចចេញ ក្រុមតាលីបង់ ឬក្រុមជ្រុលនិយមជាថ្មីផ្សេងទៀត។

បញ្ហាប្រឈម

ក្រោយពេលជាង១៥ឆ្នាំ សង្គ្រាមនៅប្រទេសអាហ្វហ្គានីស្ថាននៅតែអូសបន្លាយបន្ត ប៉ុន្តែ កងកម្លាំង

អង្គការណាតូនៅតែមានវត្តមាននៅទីនោះនៅឡើយ បើទោះជាមានចំនួនតិចជាមុនក៏ដោយ។ សង្គ្រាមបានក្លាយជាបញ្ហានយោបាយដ៏ចម្រូងចម្រាស នៅស្ទើរតែគ្រប់ប្រទេស ដែលរួមចំណែកកងទ័ពរបស់ខ្លួនដល់កងកម្លាំងជំនួយសន្តិសុខអន្តរជាតិចម្រុះជាតិ។ កងកម្លាំងគាំទ្រតាលីបង់បានបន្តធ្វើការវាយប្រហារយ៉ាងទូលំទូលាយ និងគម្រាមកំហែងបំផ្លាញវឌ្ឍនភាពកាលពីពេលកន្លងមក រហូតដល់បច្ចុប្បន្ន។

នៅចំណុចកំពូលនៃជម្លោះ ប្រទេសសមាជិកអង្គការណាតូនៅតែអាត្មានិយម ដោយមិនចង់បញ្ជូនកងទ័ពរបស់ខ្លួនបន្ថែមឡើយ។ ទាំងរដ្ឋបាលប្រធានាធិបតីប៊ូស និងប្រធានាធិបតីអូបាម៉ាបានជាក់សម្ពាធដល់សម្ព័ន្ធមិត្តឱ្យបញ្ជូនកងទ័ពនិងប្រាក់បន្ថែមទៀត ប៉ុន្តែ លទ្ធផលមានកម្រិត។ នៅក្នុង«ដំណាក់កាលកំពូល» ឆ្នាំ ២០១០ សហរដ្ឋអាមេរិកបានបន្ថែមទាហានរហូតដល់ ៣០០០០ នាក់ ចំណែកប្រទេសសមាជិកអង្គការណាតូផ្សេងទៀត បញ្ជូនបន្ថែមត្រឹមតែ ១០០០០ ប៉ុណ្ណោះ។ សម្ព័ន្ធមិត្តប្រឈមមុខនឹងដែនកំណត់ដោយសារតែអប្រជាប្រិយភាពនៃសង្គ្រាម កាន់តែខ្លាំងឡើង សម្ពាធថវិកាដោយសារវិបត្តិសេដ្ឋកិច្ចសកល និងការរំពឹងទុកមិនច្បាស់លាស់ ថានឹងទទួលបានជ័យជំនះដែរឬទេ។ អ្វីដែលគួរឲ្យកត់សម្គាល់បំផុតនោះ គឺក្នុងឆ្នាំ ២០១០ រដ្ឋាភិបាលហូឡង់ដែលកំពុងកាន់អំណាច បានចាញ់ឆ្នោត នៅពេលដែលខ្លួនព្យាយាមរក្សាទ័ពនៅប្រទេសអាហ្វហ្គានីស្ថាន។

ដំណោះស្រាយ

តាមទ្រឹស្តី អង្គការណាតូប្រតិបត្តិការដោយឈរលើគោលការណ៍បដិការៈ សមាជិករបស់ខ្លួនត្រូវរួមចំណែកស្មើគ្នាដល់ផលប្រយោជន៍រួម។ សមាជិកទាំងនោះក៏បានមានអត្តសញ្ញាណរួមគ្នាតែមួយក្នុងនាមជាប្រទេសប្រជាធិបតេយ្យលោកខាងលិចប្រយុទ្ធនឹងភេរវកម្មសាសនានិយមជ្រុលដ៏ហិង្សា។ ប៉ុន្តែ នៅដែលត្រូវការការជាក់ពង្រាយទ័ពនៅផ្ទាល់កន្លែង ហើយឃើញក្តារមឈូសស្រោបដោយទង់ជាតិ ពេលបញ្ជូនត្រលប់មកមាតុប្រទេសវិញមិនមានរដ្ឋសមាជិកអង្គការណាតូគ្រប់គ្រាន់ចាត់ទុកថាហេតុផលទាំងនេះគួរឱ្យទាក់ទាញអារម្មណ៍ឡើយ។

ដំណោះស្រាយចំពោះបញ្ហាផលប្រយោជន៍រួម នៅក្នុងករណីនេះ គឺសម្រាប់ប្រទេសមហាអំណាចជាងគេ៉ាប់រងការចំណាយ។ អង្គការណាតូមិនមែនជាក្លឹបសមភាពទេ ប៉ុន្តែ ជាក្រុមដែលមានហានុក្រមអំណាច ដោយរដ្ឋសមាជិកមួយមានកម្លាំងយោធាច្រើនជាងខ្លាំងក្លាជាងទំហំយោធារបស់សមាជិកក្រុមផ្សេងទៀតរួមបញ្ចូលគ្នា។ ការស្ថិតនៅលើចំណុចកំពូលនៃប្រព័ន្ធហានុក្រម មិនមែនបានន័យថាប្រទេសនោះអាចបញ្ជាបណ្តារដ្ឋនៅខាងក្រោមៗ តាមចិត្តចង់នោះទេ។ ជាញឹកញយ តួអង្គដែលអាចឈរនៅលើកំពូលហានុក្រមបានល្អបំផុត គឺជាអ្នកដែលបង្កើតសម្ព័ន្ធភាពបានល្អ ហើយប្រើប្រាស់អំណាច និងទ្រព្យសម្បត្តិដើម្បីរក្សាសមាជិកផ្សេងទៀតឱ្យបន្តស្មោះស្ម័គ្រភក្តី។

រូបថត ពិធីបុណ្យសពទាហានអង់គ្លេសម្នាក់ដែលត្រូវបានគេសម្លាប់នៅអាហ្វហ្គានីស្ថានឆ្នាំ ២០១៣។


មតិសាធារណៈ និងចំណាត់ចំនងអន្តរជាតិ

មតិសាធារណៈ និងយុទ្ធនាការអន្តរជាតិដើម្បីលុបបំបាត់អាវុធនុយក្លេអ៊ែរ (ICAN)

នៅឆ្នាំ ២០១៩ ការស្ទង់មតិថ្មីមួយ របស់ «YouGov» ដែលគាំទ្រដោយ យុទ្ធនាការអន្តរជាតិដើម្បីលុបបំបាត់អាវុធនុយក្លេអ៊ែរ ហៅកាត់ថា ICAN បានរកឃើញថាមានការបដិសេធអាវុធនុយក្លេអ៊ែរយ៉ាងដាច់អហង្ការនៅក្នុងរដ្ឋចំនួនបួនក្នុងសហភាពអឺរ៉ុប ដែលមានប្រព័ន្ធអាវុធនុយក្លេអ៊ែររបស់សហរដ្ឋអាមេរិកនៅលើទឹកដី

របស់ពួកគេ៖ ប្រទេសបែលហ្សិក ប្រទេសអាឡឺម៉ង់ ប្រទេសអ៊ីតាលី និងប្រទេសហូឡង់ ដូចដែលបានបង្ហាញក្នុងក្រាហ្វិក ២.៦ ។ ជនជាតិអឺរ៉ុបដែលអាចនឹងស្ថិតនៅសមរភូមិជួរមុខសម្រាប់ការវាយប្រហារនុយក្លេអ៊ែរណាមួយដែលអាចកើតមានឡើងដាយថាហេតុ បានបដិសេធដាច់អហង្ការចំពោះអាវុធនុយក្លេអ៊ែរ និងគាំទ្រអោយរដ្ឋាភិបាលរបស់ពួកគេចូលរួមក្នុងសន្ធិសញ្ញាស្តីពី ការហាមឃាត់អាវុធនុយក្លេអ៊ែរ។ ពេលដែលសាធារណៈជនបញ្ចេញមតិ អ្នកនយោបាយទាំងឡាយត្រូវតែស្តាប់ហើយធ្វើតាម។ នេះគិតទាំងការគ្រប់គ្រងអាវុធ ជាពិសេសការគ្រប់គ្រងអាវុធនុយក្លេអ៊ែរ។ យើងគួរតែក្រឡេកទៅមើលប្រវត្តិសាស្ត្រវិញ ដើម្បីសង្កេតមើលការវិវត្តន៍និងបំរែបំរួលមនោសញ្ចេតនាប្រឆាំងអាវុធនុយក្លេអ៊ែរដោយរបៀបណា។

ក្រាហ្វិកទី ២.៦ មតិសាធារណៈរបស់អឺរ៉ុបចំពោះការរំសាយអាវុធនុយក្លេអ៊ែរ



ប្រភព៖ យុទ្ធនាការអន្តរជាតិដើម្បីលុបបំបាត់អាវុធនុយក្លេអ៊ែរ (ICAN) ឆ្នាំ ២០១៩។

យុទ្ធនាការបង្កកសារធាតុនុយក្លេអ៊ែរ គឺជាចលនាដ៏ធំមួយនៅក្នុងសហរដ្ឋអាមេរិក ក្នុងអំឡុងទសវត្សរ៍ឆ្នាំ ១៩៨០ ដើម្បីទាមទារអោយប្រទេសមហាអំណាចទាំងពីរ រួមមានសហរដ្ឋអាមេរិក និងសហភាពសូវៀតបញ្ឈប់សកម្មភាពណាមួយដែលពាក់ព័ន្ធនឹងអាវុធនុយក្លេអ៊ែរ។ ចលនានេះទទួលបានការគាំទ្រពីសាធារណជនយ៉ាងច្រើនក្នុងរយៈពេលខ្លី ហើយរួមជាមួយនឹងសម្ព័ន្ធមិត្តប្រឆាំងនុយក្លេអ៊ែរនៅបរទេស បានដើរតួនាទីយ៉ាងសំខាន់ក្នុងការទប់ស្កាត់ការប្រកួតប្រជែងអាវុធនុយក្លេអ៊ែរ និងទប់ស្កាត់សង្គ្រាមនុយក្លេអ៊ែរ។ នៅដើមទសវត្សរ៍ឆ្នាំ ១៩៨០ ចលនាបង្កកនុយក្លេអ៊ែ មានភាពលេចធ្លោនៅក្នុងព័ត៌មាន ហើយវាទទួលបានជ័យជំនះផ្នែកនយោបាយជាច្រើន។ សមាជិកសភារបស់រដ្ឋ និងសហព័ន្ធបានអនុម័តដំណោះស្រាយជាការគាំទ្រដល់យុទ្ធនាការបង្កកនេះ។ ការស្នង់មតិសាធារណៈបានដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញដោល ខណៈ

ពេលដែលប្រព័ន្ធផ្សព្វផ្សាយ និងអ្នកតស៊ូមតិជម្រុញការបង្កកបានលើកឡើងពីការស្ទង់មតិជាច្រើន ដែលបង្ហាញពីការគាំទ្រសាធារណៈដ៏លើសលប់ចំពោះគំនិតផ្តួចផ្តើមនេះ។ ទោះបីជាយ៉ាងណាក៏ដោយ ខណៈពេលដែលជនជាតិអាមេរិកបានសម្តែងការគាំទ្រយ៉ាងខ្លាំងចំពោះគោលគំនិតជាមូលដ្ឋាននៃការបង្កក ពួកគេនៅមន្ទិលសង្ស័យថាតើកិច្ចព្រមព្រៀងបង្កកពេញលេញមួយ អាចធ្វើទៅបានក្នុងវិស័យ នយោបាយនិងយោធាដែរឬទេ។ សាធារណជនក៏មានមន្ទិលថាតើសហភាពសូវៀតនឹងគាំទ្រកិច្ចព្រមព្រៀងបែបនេះយ៉ាងពិតប្រាកដដែរឬទេ។

ទោះបីជាគោលដៅចម្បងនៃយុទ្ធនាការបង្កកនុយក្លេអ៊ែរ នៅទីបំផុត ត្រូវបរាជ័យក៏ដោយ រដ្ឋបាលលោកប្រធានាធិបតី រីហ្គិន ត្រូវបានបង្ខំឱ្យបោះបង់ចោលនូវរោហាសាស្ត្រអវិភាព និងធ្វើសំណើសំខាន់ៗសម្រាប់គ្រប់គ្រងអាវុធ បើមិនដូច្នោះទេនឹងត្រូវបន្តប្រឈមមុខនឹងការរិះគន់ក្នុងស្រុកដែលអាចនឹងផ្តល់ផលវិបាកនៅក្នុងការបោះឆ្នោតបន្ទាប់។ លទ្ធផលនៃការងារនេះបង្ខំអោយអ្នកប្រវត្តិសាស្ត្រពិចារណាឡើងវិញ អំពីសារៈសំខាន់នៃចលនាសន្តិភាពក្នុងទំនាក់ទំនង រហូតដល់ចុងបញ្ចប់នៃសង្គ្រាមត្រជាក់។ ទីបំផុតគឺប្រជាពលរដ្ឋទេ ដែលជាអ្នកសម្រេចចុងក្រោយនៅក្នុងកិច្ចការពិភពលោក ដោយសម្រេចតាមបេះដូងរបស់ពួកគេ។

ឧស្សន:ទិស័យគោលនយោបាយ

នាយករដ្ឋមន្ត្រីឥណ្ឌា លោក នរេន្ទ្រ មោឌី (Narendra Modi)

រូបថត នាយករដ្ឋមន្ត្រីឥណ្ឌា លោក នរេន្ទ្រ មោឌី

បញ្ហា

តើអ្នកប្រឈមមុខនឹងបរិយាកាសសុវត្ថិភាពលំហូរដោយរបៀបណា តាមរយៈការគ្រប់គ្រងគូប្រជែងបច្ចុប្បន្ននិងផ្លូវការ?

សារតារ

ក្នុងនាមជាប្រទេសប្រជាធិបតេយ្យដ៏ធំបំផុតរបស់ពិភពលោក មាតុភូមិអ្នកប្រឈមមុខនឹងបញ្ហាជាច្រើន ទាំងក្នុងប្រទេស និងទាំងក្រៅប្រទេស។ ជាពិសេស ក្នុងរយៈពេល ៦០ ឆ្នាំកន្លងមកនេះ អ្នកបានធ្វើសង្គ្រាមប្រឆាំងនឹងប្រទេសជិតខាងដ៏ធំបំផុតពីរ គឺប្រទេសចិន និងប្រទេសប៉ាគីស្ថាន។ រដ្ឋទាំងពីរដែលមានអាវុធនុយក្លេអ៊ែរ ដូចមាតុភូមិអ្នកដែរ។ ប្រទេសចិន និងប្រទេសប៉ាគីស្ថានបានសហការគ្នានាពេលកន្លងមក រួមទាំងការលក់សម្ភារៈយោធាដែលមានបច្ចេកវិទ្យាខ្ពស់ ដូចជាមីស៊ីលជាដើម។

ជាទូទៅ ទំនាក់ទំនងអវិភាពរបស់អ្នកជាមួយនឹងប្រទេសប៉ាគីស្ថានកើតចេញពីជម្លោះដណ្តើមទឹកដីជាងពាក់កណ្តាលនៃតំបន់កាស្មៀរ (Kashmir) ដែលរដ្ឋទាំងពីរបានទាមទារដូចគ្នា ប៉ុន្តែឥណ្ឌារក្សាការគ្រប់គ្រងរបស់ខ្លួនកន្លងមក។ ទឹកដីនេះមិនត្រឹមតែទាមទារចង់បាន ដោយរដ្ឋាភិបាលនៃប្រទេសរៀងៗខ្លួនប៉ុណ្ណោះទេ ប៉ុន្តែ ដោយសាធារណជននៅក្នុងប្រទេសនីមួយៗផងដែរ។ ខណៈពេលដែលមានកិច្ចសហប្រតិបត្តិការមួយចំនួនរវាងប្រទេសនីមួយៗ ភាពតានតឹងនៅតែបន្តកើតមានលើតំបន់កាស្មៀរ។ នៅក្រោយការវាយប្រហារភេរវកម្ម ខែវិច្ឆិកា ឆ្នាំ ២០០៨ នៅទីក្រុងបុមបៃ មនុស្សជាច្រើននៅក្នុងប្រទេសរបស់អ្នកបានស្តីបន្ទោសប៉ាគីស្ថាន ព្រោះវាជាទីជម្រករបស់ក្រុមសកម្មប្រយុទ្ធអ៊ីស្លាម។

អវិភាពរបស់អ្នកជាមួយចិនបានធូរស្រាលក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមក ប៉ុន្តែ ប្រទេសចិននៅតែជាគូប្រជែងដ៏សំខាន់នៅក្នុងតំបន់ ហើយអ្នកនៅតែរក្សាការទាមទារទឹកដីចម្រូងចម្រាស់ដដែល។ ដូចប្រទេស

របស់អ្នកដែរ ប្រទេសចិនមានទំហំធំខាងសេដ្ឋកិច្ច ក៏ដូចជាផ្នែកយោធា ហើយវាព្យាយាមអនុវត្តភាពជាអ្នកដឹកនាំខ្លាំងនៅក្នុងតំបន់របស់អ្នក។ ទោះយ៉ាងណាក៏ដោយ ក្នុងរយៈពេលប្រាំបីឆ្នាំកន្លងមក ប្រទេសរបស់អ្នកបានបង្កើនទំនាក់ទំនងជាមួយប្រទេសចិន។ អ្នកបានធ្វើទស្សនកិច្ចនៅប្រទេសចិនក្នុងឆ្នាំ ២០១៥ បន្ទាប់ពីមេដឹកនាំរបស់ចិនបានធ្វើទស្សនកិច្ចនៅប្រទេសឥណ្ឌា ដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មនិងការវិនិយោគ។ កងទ័ពរបស់ប្រទេសទាំងពីរ (ទំហំធំជាងគេ ក្នុងពិភពលោក) បានធ្វើលំហាត់ហ្វឹកហ្វឺនរួមគ្នា ប៉ុន្តែ ក៏បានចោទប្រកាន់គ្នាទៅវិញទៅមកអំពីការរំលោភព្រំដែន។

ការពិចារណាក្នុងស្រុក

នៅក្នុងប្រទេសរបស់អ្នក ទាំងប៉ាគីស្ថាន និងចិនមិនមែនជាជម្រើសដ៏ពេញនិយមសម្រាប់សម្ព័ន្ធមិត្តនោះទេ។ ប្រជាជនរបស់អ្នកនៅតែខឹងសម្បារចំពោះជ័យជម្នះរបស់ចិននៅក្នុងសង្គ្រាមចិននឹងឥណ្ឌា កាលពីឆ្នាំ ១៩៦២ និងទឹកដីជម្លោះព្រំដែន ដែលមូលហេតុបង្កឱ្យមានជម្លោះដល់សព្វថ្ងៃ។ យ៉ាងណាក៏ដោយ ប្រជាជនហិណ្ឌូភាគច្រើនរបស់អ្នក ក៏មានការខឹងសម្បារ ចំពោះការប៉ុនប៉ងម្តងហើយម្តងទៀតរបស់ក្រុមមូស្លីមប៉ាគីស្ថាន ដើម្បីដណ្តើមគ្រប់គ្រងក្នុងតំបន់កាស្មៀរ។ ទីប្រឹក្សារបស់អ្នកក៏បានរំលឹកអ្នកដែរថា ប្រទេសចិននៅតែមានទំនាក់ទំនងល្អជាមួយប្រទេសប៉ាគីស្ថាន ដោយលក់អាវុធមួយចំនួនធំ និងផ្តល់ជំនួយយោធាដល់ប្រទេសនោះ។ ប្រាកដណាស់ គណបក្សនយោបាយនិន្នាការប្រឆាំងសំខាន់ៗរបស់អ្នកបានចោទប្រកាន់ថា អ្នកបានមានជំហរ«ទន់ជ្រាយ»ពេក នៅក្នុងទំនាក់ទំនងជាមួយប្រទេសប៉ាគីស្ថាន និងប្រទេសចិន។ ប្រតិកម្មជាសាធារណៈណាមួយប្រឆាំងនឹងគោលនយោបាយការបរទេសរបស់អ្នក ចំពោះបញ្ហាទាំងនេះអាចរីករាលដាល និងនាំមកនូវការអំពាវនាវឱ្យមានការបោះឆ្នោតឮ ដែលអាចធ្វើឲ្យរដ្ឋាភិបាលរបស់អ្នកមិនអាចគ្រប់គ្រងបានបន្តទៀត។

សេណារីយ៉ូ

ចូរស្រមៃថារដ្ឋាភិបាលប៉ាគីស្ថានចាប់ផ្តើមទទួលរងផលប៉ះពាល់ពីអស្ថិរភាពទ្រង់ទ្រាយធំ។ ពួកសកម្មប្រយុទ្ធឥស្លាមជិតបានផ្តួលរំលំរដ្ឋាភិបាលនៅទីនោះ ធ្វើអោយកងកម្លាំងពួកគេអាចគ្រប់គ្រងអាវុធនុយក្លេអ៊ែរបស់ប្រទេសប៉ាគីស្ថាន។ ពួកគេក៏កំពុងអំពាវនាវបណ្តាជនមូស្លីមនៅ កាស្មៀរ ងើបឡើងប្រឆាំងនឹងការគ្រប់គ្រងរបស់ឥណ្ឌា ដោយសន្យាដោយបើកចំហដើម្បីជួយដល់ការបះបោរនៅក្នុងខេត្តនោះ តាមរយៈការផ្តល់អាវុធ និងចារកម្ម។ ភ្នាក់ងារស៊ើបការណ៍សម្ងាត់របស់អ្នកចាត់ទុកការដួលរលំនៃរដ្ឋាភិបាលប៉ាគីស្ថានបច្ចុប្បន្ន «ទំនងជាអាចទៅរួច» ។

ជ្រើសរើសគោលនយោបាយរបស់អ្នក

ជាលទ្ធផលនៃអស្ថិរភាព នៅក្នុងប្រទេសប៉ាគីស្ថានតើអ្នកនឹងជំរុញអោយមានទំនាក់ទំនងកាន់តែជិតស្និទ្ធជាមួយប្រទេសចិនដែរឬទេ? តើអ្នកអាចទុកចិត្តចិនក្នុងការគាំទ្រអ្នកក្នុងជម្លោះជាមួយប៉ាគីស្ថានបានដែរឬទេ បើទំនាក់ទំនងនៃប្រទេសទាំងពីរជិតស្និទ្ធនឹងគ្នាបែបនេះ? តើអ្នកស្នើឱ្យចិនជួយសម្រុះសម្រួលរវាងរដ្ឋាភិបាលរបស់អ្នកនិងប៉ាគីស្ថាន ក្នុងករណីមានអរិភាពដែរឬទេ? ឬ តើអ្នកបន្តគោលនយោបាយរបស់អ្នកដោយឯករាជ្យ តាមដែលអាចធ្វើទៅបាន ដោយមិនជឿទុកចិត្តលើចេតនារបស់ចិន ចំពោះប្រទេសរបស់អ្នកឬយ៉ាងណា?

តោះ! សាកល្បងពិភាក្សាអំពីបញ្ហាជាក់ស្តែង

តើសហរដ្ឋអាមេរិកនិងប្រទេសចិនអាចរួមរស់ជាមួយគ្នា ដោយសន្តិវិធីដែរឬទេ?

ទិដ្ឋភាពទូទៅ

នៅក្នុងមេរៀននេះ យើងបានកត់សម្គាល់ថា អ្នកប្រាកដនិយមសង្កត់ធ្ងន់លើបញ្ហាតុល្យភាពនៃអំណាចៈ រដ្ឋអាចចងសម្ព័ន្ធមិត្តជាមួយគ្នា ដើម្បីរារាំងរដ្ឋមួយទៀតមិនអោយមានអំណាចត្រួតត្រាគេឯងខ្លាំងពេក។ ប៉ុន្តែ នៅក្នុងប្រព័ន្ធ(អន្តរជាតិ)បច្ចុប្បន្ន អំណាចយោធា និងសេដ្ឋកិច្ចរបស់សហរដ្ឋអាមេរិកពិតជាខ្លាំងពេក មិនអាចមានប្រទេសណាផ្សេងអាចប្រៀបផ្ទឹមបានឡើយ។ អ្នកប្រាជ្ញខ្លះទៀតអះអាងតបវិញថា ប្រទេសចិននឹងក្លាយជារដ្ឋដែលត្រូវប្រកួតប្រជែងតំណែងដឹកនាំរបស់សហរដ្ឋអាមេរិក នៅពេលអនាគត។

តាមប្រវត្តិសាស្ត្រ ទំនាក់ទំនងរវាងប្រទេសចិននិងសហរដ្ឋអាមេរិកមានភាពរង្គោះរង្គើដោយអន្លើរ។ ក្នុងអំឡុងសង្គ្រាមត្រជាក់ បន្ទាប់ពីសហរដ្ឋអាមេរិកបើកទំនាក់ទំនងជាមួយចិន ប្រទេសមហាអំណាចទាំងពីរបានសហការគ្នាប្រឆាំងនឹងសត្រូវរួមមួយ គឺសហភាពសូវៀត។ បន្ទាប់ពីសង្គ្រាមត្រជាក់ កិច្ចសហប្រតិបត្តិការនោះបានផ្លាស់ប្តូរយ៉ាងខ្លាំង ដោយសារប្រទេសចិនបានពង្រីកទំហំសេដ្ឋកិច្ច និងវិសាលភាពយោធា ដោយបំពេញចន្លោះគួនាទីមហាអំណាចពិភពលោក ដែលបន្សល់ទុកដោយការដួលរលំនៃសហភាពសូវៀត។

ទោះបីជាប្រទេសចិននៅមានទំហំសេដ្ឋកិច្ចតូចជាង និងនៅមានកម្លាំងយោធាខ្សោយជាងសហរដ្ឋអាមេរិកក៏ដោយ ប្រសិនបើទំនោរកំណើនបច្ចុប្បន្ននៅតែបន្តទៀត វានឹងវ៉ាដាច់កម្លាំងសេដ្ឋកិច្ចរបស់សហរដ្ឋអាមេរិក។ ដោយមានកម្លាំងសេដ្ឋកិច្ចធំបែបនេះ វានឹងមិនចំណាយពេលយូរសម្រាប់ចិនដើម្បីតាមទាន់កម្លាំងយោធារបស់សហរដ្ឋអាមេរិកនោះទេ។ ការផ្លាស់ប្តូរទាំងនេះត្រូវបានគេហៅថាការផ្លាស់ប្តូរអំណាចឬអន្តរកាលអំណាច (សូមមើលមេរៀននេះ)។ ខណៈពេលដែលពេលខ្លះការផ្លាស់ប្តូរអំណាចកំពូលពីរដ្ឋមួយទៅ រដ្ឋមួយទៀតមានលក្ខណៈសន្តិភាពក៏ដោយ (ឧទាហរណ៍ សហរដ្ឋអាមេរិកជំនួសចក្រភពអង់គ្លេស), ជាញឹកញាប់ការផ្លាស់ប្តូរមិនបានកើតមានឡើង ដោយសន្តិវិធីនោះទេ (ការប៉ុនប៉ងរបស់អាឡឺម៉ង់ដើម្បីយកឈ្នះចក្រភពអង់គ្លេស ក្នុងសង្គ្រាមលោកលើកទី ១ និងទី ២)។ តើប្រទេសចិនគួររីកចម្រើនដើម្បីប្រកួតប្រជែងជាមួយនឹងសហរដ្ឋអាមេរិក ដែរឬទេ? តើអនាគតនៃប្រទេសមហាអំណាចទាំងពីរនេះនឹងមានជោគវាសនា យ៉ាងដូចម្តេច? តើទំនាក់ទំនងរបស់ពួកគេនឹងមានលក្ខណៈសន្តិភាពឬអរិភាព?

អំណះអំណាង ១

សហរដ្ឋអាមេរិក និងប្រទេសចិននឹងជួបប្រទះការលំបាកក្នុងការរួមរស់ជាមួយគ្នាដោយសន្តិភាព។

សម្ព័ន្ធមិត្តនានារបស់សហរដ្ឋអាមេរិក និងប្រទេសចិនបង្កជម្លោះដោយខ្លួនឯង។

ទំនាក់ទំនងរបស់ប្រទេសចិនជាមួយកូរ៉េខាងជើង អ៊ីរ៉ង់ និងស៊ូដង់ត្រូវបានពង្រឹង ក្នុងរយៈពេលដប់ឆ្នាំចុងក្រោយនេះ។ សហរដ្ឋអាមេរិកចាត់ទុករដ្ឋនីមួយៗ ក្នុងចំណោមនេះ ថាជារដ្ឋអរិភាព ខណៈដែលប្រទេសចិនបានទាក់ទាញចិត្តរដ្ឋទាំងនេះដើម្បី ហេតុផលសេដ្ឋកិច្ចឬគោលដៅយុទ្ធសាស្ត្រ។ ចំពោះភាគីខាងអាមេរិក បើទោះជាមិនមានសម្ព័ន្ធភាពជាផ្លូវការក៏ដោយ ក៏មិត្តភាពរបស់អាមេរិកចំពោះកោះតៃវ៉ាន់ ដែលប្រទេសចិនចាត់ទុកជាខេត្តចចេសមួយរបស់ខ្លួន ក៏បង្កើតភាពតានតឹងផងដែរ។

ប្រទេសចិនបានទាញយកផលប្រយោជន៍សម្រាប់ខ្លួនរួចហើយ ពីជម្លោះជាមួយសហរដ្ឋអាមេរិក។

បច្ចុប្បន្ននេះ ប្រទេសចិនបានទំលាក់តម្លៃរូបិយប័ណ្ណរបស់ខ្លួន ដើម្បីរក្សាទំនិញរបស់ខ្លួនអោយមានតម្លៃថោកនៅក្នុងសហរដ្ឋអាមេរិក។ ថ្វីបើមានការតវ៉ាជាច្រើនប្រឆាំងនឹងគោលនយោបាយនេះក៏ដោយ ក៏ប្រទេសចិននៅតែបន្តការបញ្ចុះតម្លៃរូបិយប័ណ្ណរបស់ខ្លួនដដែល ដែលបង្កគ្រោះថ្នាក់ដល់ក្រុមហ៊ុនផលិតក្នុងស្រុកនៅសហរដ្ឋអាមេរិក។

ប្រទេសចិនបាននិងកំពុងព្យាយាមប្រកួតប្រជែងជាមួយនឹងសហរដ្ឋអាមេរិក ក្នុងនាមជាប្រទេសមហាអំណាចពិភពលោករួចទៅហើយ។

ប្រទេសចិនបានពង្រីកជំនួយបរទេសដល់ទ្វីបអាហ្វ្រិក (សូម្បីតែរដ្ឋមួយចំនួន ដែលត្រូវបានដាក់ទណ្ឌកម្មដោយសហរដ្ឋអាមេរិកក្តី)។ ប្រទេសចិនបានបង្កើនការលក់អាវុធនៅជុំវិញពិភពលោក។ ចិនក៏កំពុងទាក់ទាញរដ្ឋទាំងឡាយ ដែលមានទំនាក់ទំនងអរិភាពជាមួយអាមេរិកដូចជាប្រទេសវេណេហ្ស៊ុយអេឡា និងប្រទេសអ៊ីរ៉ង់។ សញ្ញាទាំងអស់ចង្អុលបង្ហាញថា ប្រទេសចិនកំពុងព្យាយាមប្រកួតប្រជែងដណ្តើមឧត្តមភាពសកលពីសហរដ្ឋអាមេរិក។

អំណះអំណាង ២

សហរដ្ឋអាមេរិក និងប្រទេសចិនអាចរួមរស់ជាមួយគ្នាបានដោយសន្តិភាព។

សហរដ្ឋអាមេរិក និងប្រទេសចិនបានឯកភាពគ្នាលើបញ្ហាសំខាន់ៗជាច្រើន។

ចំពោះបញ្ហាដូចជាអំពើភេរវកម្ម និងការរីកសាយភាយនុយក្លេអ៊ែរ ចិនជជែកគ្នាត្រង់ៗជាមួយនឹងសហរដ្ឋអាមេរិក។ ដូចទំនាក់ទំនងរវាងសហរដ្ឋអាមេរិក និងសហភាពសូវៀត ក្នុងអំឡុងសង្គ្រាមត្រជាក់ដែរ មានចន្លោះប្រហោងសម្រាប់កិច្ចព្រមព្រៀងលើបញ្ហាសំខាន់ៗជាយុទ្ធសាស្ត្រ ដែលនឹងអនុញ្ញាតអោយមានកិច្ចសហប្រតិបត្តិការរវាងប្រទេសមហាអំណាចទាំងពីរ។ លើសពីនេះទៀត យុទ្ធសាស្ត្រ«រះឡើងដោយសន្តិភាព»របស់ប្រទេសចិនបានបញ្ចៀសជម្លោះយោធាដោយផ្ទាល់ជាមួយនឹងសហរដ្ឋអាមេរិក អស់រយៈពេលជាង ៦០ ឆ្នាំមកហើយ។

ការទប់ស្កាត់នុយក្លេអ៊ែរនឹងរក្សាទំនាក់ទំនងដែលមានស្ថិរភាព។

រដ្ឋនីមួយៗមានកម្លាំងនុយក្លេអ៊ែរដ៏ធំ និងគួរឱ្យទុកចិត្ត ដែលអាចរារាំងគូប្រជែងមិនអោយវាយប្រហារព្រោះបើភាគីមួយហ៊ានវាយប្រហារ ភាគីមួយទៀតក៏មានអានុភាពវាយប្រហារតបវិញដែរ។ ខណៈពេលដែលក្ខណ្ឌនេះនឹងមិនអាចទប់ស្កាត់សង្គ្រាមរណប (ដូចនៅក្នុងសម័យសង្គ្រាមត្រជាក់) វាចង្អុលបង្ហាញថា ទំនាក់ទំនងនឹងនៅតែមានលក្ខណៈស៊ីវិល និងស្ថិរភាព រវាងសហរដ្ឋអាមេរិក និងប្រទេសចិន។

ការពឹងពាក់គ្នាទៅវិញទៅមកផ្នែកសេដ្ឋកិច្ចនឹងរក្សាទំនាក់ទំនងសន្តិភាព។

សហរដ្ឋអាមេរិក និងប្រទេសចិនពឹងផ្អែកលើគ្នាទៅវិញទៅមកក្នុងវិស័យសេដ្ឋកិច្ច។ អាមេរិកត្រូវពឹងលើទំនិញចិន ដែលហូរចូលប្រទេសខ្លួន ក្នុងតម្លៃសមរម្យ ខណៈចិនពឹងលើទីផ្សារអាមេរិកសម្រាប់យុទ្ធសាស្ត្រកំណើននាំចេញរបស់ខ្លួន។ ស្ថានភាពនៃការពឹងផ្អែកគ្នាទៅវិញទៅមកនេះនឹងធ្វើឱ្យទំនាក់ទំនងមានភាពកក់ក្តៅ ដោយសារតែអរិភាពនឹងគំរាមកំហែងនិងធ្វើអោយខូចទំនាក់ទំនងពាណិជ្ជកម្មទាំងនេះ។

សំណួរ

- តើជម្លោះរវាងសហរដ្ឋអាមេរិក និងប្រទេសចិនពិតជាមិនអាចបញ្ចៀសបានមែនទេ? ប្រសិនបើចិនក្លាយជាប្រទេសប្រជាធិបតេយ្យ តើលទ្ធភាពនៃការផ្ទុះជម្លោះកើនឡើងឬថយចុះ?

• ប្រសិនបើជម្លោះកើតឡើងនៅថ្ងៃអនាគត តើមានវិធីណាដែលអាចបង្អាក់ពួកគេដែរឬទេ? ឬជម្លោះទាំងនេះគ្រាន់តែជាដំណើរនយោបាយពិភពលោករវាងប្រទេសមហាអំណាច? តើអង្គការអន្តរជាតិ (ដូចជាអង្គការសហប្រជាជាតិ) អាចជួយសម្រាលសក្តានុពលនៃជម្លោះប្រទេសមហាអំណាចបានដែរឬទេ?

• តៃវ៉ាន់គឺជាប្រភពសំខាន់នៃការខ្វែងគំនិតរវាងសហរដ្ឋអាមេរិក និងប្រទេសចិន។ ទោះបីជាសហរដ្ឋអាមេរិកមិនបានទទួលស្គាល់តៃវ៉ាន់ជាផ្លូវការក៏ដោយ ក៏វាបានចុះហត្ថលេខាលើសន្ធិសញ្ញាមិត្តភាពជាមួយកោះតៃវ៉ាន់។ តើអាមេរិកគួរប្រថុយបណ្តោយអោយទំនាក់ទំនងជាមួយប្រទេសចិនរង្គោះរង្គើរ តាមរយៈការគោរពការប្តេជ្ញាចិត្តរបស់ខ្លួនចំពោះតៃវ៉ាន់ដែរឬទេ? បើប្រទេសចិនបង្ខំអាមេរិកអោយជ្រើសរើសរវាងតៃវ៉ាន់និងការបន្ធូរបន្ថយតានតឹង តើសហរដ្ឋអាមេរិកគួរជ្រើសរើសមួយណា?

និស្សិតអាចសាកល្បងអានឯកសារខាងក្រោមបន្ថែមទៀត ដើម្បីជាគ្រឹះក្នុងការឆ្លើយសំណួរទាំងអស់ខាងលើ ៖

- Allison, Graham. *Destined for War: Can America and China Escape Thucydides's Trap?* Houghton Mifflin Harcourt, 2017.
- Hachigian, Nina. *Debating China: The U.S.–China Relation- ship in Ten Conversations.* Oxford, 2014.
- Mearsheimer, John J. *The Tragedy of Great Power Politics.* Norton, 2003.
- Shirk, Susan L. *China: Fragile Superpower.* Oxford, 2008.

ឯកសារគួរអានបន្ថែម

- Barnett, Michael, and Raymond Duvall, eds. *Power in Global Governance.* Cambridge, 2005.
- Brooks, Stephen G., and William Wohlforth. *World Out of Balance: International Relations and the Challenge of American Primacy.* Princeton, 2008.
- Johnston, Seth A. *How NATO Adapts: Strategy and Organization in the Atlantic Alliance Since 1950.* Johns Hopkins, 2016.
- Kreps, Sarah. *Coalitions of Convenience: United States Military Interventions After the Cold War.* Oxford, 2011.
- Kydd, Andrew. *International Relations Theory: The Game Theoretic Approach.* Cambridge, 2015.
- Mearsheimer, John J. *The Tragedy of Great Power Politics.* Norton, 2003.
- Narang, Vipin. *Nuclear Strategy in the Modern Era: Regional Powers and International Conflict.* Princeton, 2014.
- Schelling, Thomas C. *The Strategy of Conflict.* Harvard, 1960.
- Walt, Stephen M. *Taming American Power: The Global Response to U.S. Primacy.* Norton, 2005.
- Waltz, Kenneth. *Theory of International Politics.* Addison- Wesley, 1979.

មេរៀនទី ០៣ ៖ ទ្រឹស្តីសង្គម និងសេរីនិយម

រូបថត បាតុកម្មប្រឆាំងនុយក្លេអ៊ែរនៅអាឡឺម៉ង់ឆ្នាំ ២០១៧។

វត្ថុបំណងមេរៀន

៣.១ ចូរប្រៀបធៀបសេចក្តីពន្យល់ពីរផ្សេងគ្នាស្តីអំពីនិន្នាការឆ្ពោះទៅរកពិភពលោក ដែលមានសង្គ្រាមតិចជាងនៅសតវត្សរ៍មុនៗ។

៣.២ ចូរបែងចែកលក្ខណៈខុសគ្នារវាងទ្រឹស្តីពីរផ្សេងគ្នា ដើម្បីពន្យល់ពីមូលហេតុដែលបណ្តាប្រទេសកាន់ប្រជាធិបតេយ្យពេញលេញ មិនធ្វើសង្គ្រាមនឹងគ្នា។

៣.៣ ចូរបង្ហាញពីរបៀបដែលទ្រឹស្តីសង្គម អាចពន្យល់ពីរបៀបដែលប្រទេសពីរផ្លាស់ប្តូរពីគូប្រកួតប្រជែងក្លាយទៅជាសម្ព័ន្ធមិត្តនឹងគ្នា ។

៣.៤ ចូរបែងចែកភាពខុសគ្នារវាង ទ្រឹស្តីម៉ាក្សស៊ីសស្តីពីការតស៊ូវណ្ណៈក្នុងប្រទេស នឹងទ្រឹស្តីលេនីនស្តីពីចក្រព័ត្តិនិយមនៅក្នុងសកលលោក។

៣.៥ ចូរពិពណ៌នាអំពីវិធីដែលការសម្របសម្រួលអាចត្រូវបានប្រើ ដើម្បីដោះស្រាយជម្លោះនៅក្នុងទំនាក់ទំនងអន្តរជាតិ។

៣.៦ ចូរកំណត់បញ្ហាសកលពីរ នៅក្នុងទំនាក់ទំនងអន្តរជាតិ ដែលយេនឌ័រគឺជាកត្តាសំខាន់ក្នុងការស្វែងយល់ឬដោះស្រាយបញ្ហា។

៣.១. សង្គ្រាមថមថយ

៣.១ ចូរប្រៀបធៀបសេចក្តីពន្យល់ពីរផ្សេងគ្នាស្តីអំពីនិន្នាការឆ្ពោះទៅរកពិភពលោក ដែលមានសង្គ្រាមតិចជាងនៅសតវត្សរ៍មុនៗ។

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ គេសង្កេតឃើញ ច្បាស់ណាស់ នូវនិន្នាការដ៏ពិភពលោកមានសង្គ្រាមតិចជាងនិងតូចជាង សតវត្សរ៍មុនៗ។ សម្រាប់មនុស្សជាច្រើន ពិភពលោកហាក់ដូចជាមានសង្គ្រាម និងអំពើហិង្សាជាងពេលណាៗទាំងអស់ ដោយសាររូបភាពហិង្សាជុំវិញពិភពលោក ត្រូវបានផ្សព្វផ្សាយតាមកញ្ចក់ទូរទស្សន៍និងទូរស័ព្ទរបស់ពួកគេជាញឹកញាប់បំផុត។ ប៉ុន្តែ សម្រាប់ពិភពលោកទាំងមូល បច្ចុប្បន្នគឺជាកំឡុងពេលដែលពិភពលោកមានសង្គ្រាមតិចបំផុតដែលមិនធ្លាប់មានពីមុនមក។

ជាដំបូង សាកពិចារណាអំពីនិន្នាការរយៈពេលវែង។ នៅពាក់កណ្តាលទីមួយនៃសតវត្សរ៍ទី២០ សង្គ្រាមលោកទាំងពីរបានសម្លាប់មនុស្សរាប់សិបលាននាក់ ហើយបានធ្វើអោយទូទាំងទ្វីបនីមួយៗត្រូវរងការបំផ្លិចរបំផ្លាញ។ នៅពាក់កណ្តាលទីពីរនៃសតវត្សរ៍នោះ កំឡុងសង្គ្រាមត្រជាក់ សង្គ្រាមរណបទាំងឡាយបានសម្លាប់មនុស្សរាប់លាននាក់ ហើយពិភពលោកភ័យខ្លាចថាសង្គ្រាមនុយក្លេអ៊ែរ អាចនឹងបំផ្លាញ សត្វលោកទាំងអស់។ ឥឡូវនេះ នៅដើមសតវត្សរ៍ទី ២១ សង្គ្រាមមួយចំនួនដូចជានៅប្រទេសអាហ្វហ្គានីស្ថាន និងប្រទេសស៊ីរីបានសម្លាប់មនុស្សរាប់សិបពាន់ ឬសិបម៉ឺននាក់។ ជាការពិត យើងបារម្ភខ្លាចការវាយប្រហារកេរែកម្មដែលអាចបំផ្លាញទីក្រុងមួយបាន ប៉ុន្តែ វាមិនមែនអាចកំទេចជីវិតរស់នៅនៅលើភពផែនដីទាំងមូលបានទេ។ ពីមួយជំនាន់ទៅមួយជំនាន់ ពិភពលោកបានដើរទៅមុខឥតឈប់ឈរ ដោយមានមនុស្សត្រូវសម្លាប់ពីរាប់សិបលាននាក់ ទៅរាប់លាននាក់ ទៅរាប់រយពាន់នាក់។ នេះនៅតែជាចំនួនដ៏ច្រើនសន្ធឹកសន្ធាប់ ហើយ

ផលប៉ះពាល់នៃសង្គ្រាមនៅតែជាគ្រោះមហន្តរាយ។ ប្រហែលវាជាអ្វីដែលសំខាន់បំផុត ប្រសិនបើយើងអាចយល់និងរក្សានិន្នាការនេះ សង្គ្រាមធំៗអាចនឹងរលាយបាត់ទៅទាំងព្រម ទោះបីជាសង្គ្រាមតូចតាច និងការវាយប្រហារកេរវេកនៅបន្តសម្លាប់មនុស្សរាប់ពាន់នាក់ក៏ដោយ។


ព្រឹត្តិការណ៍ទាំងឡាយ នៅក្នុងសម័យក្រោយសង្គ្រាមត្រជាក់ បន្តនិន្នាការក្នុងរយៈពេលវែងនេះដែលឆ្ពោះទៅរកសង្គ្រាមតូចៗរបៈរបោះ។ នៅចុងទស្សវត្សរ៍ឆ្នាំ ១៩៩០ និងដើមសតវត្សរ៍ទី ២១ គេបានឃើញការបញ្ចប់នៃជម្លោះនានា នៅសេសសល់ពីសម័យសង្គ្រាមត្រជាក់ ដូចជានៅប្រទេសអង់ហ្គោឡា ប្រទេសអៀរឡង់ខាងជើង ប្រទេសហ្គាតេម៉ាឡា និងប្រទេសស៊ូដង់ខាងត្បូង (តាមពីក្រោយ អវសានៃជម្លោះនៅប្រទេសអាហ្វ្រិកខាងត្បូង និងប្រទេសម៉ូសំប៊ិក នៅដើមទសវត្សរ៍ឆ្នាំ ១៩៩០)។ ភាគច្រើននៃសង្គ្រាមដែលផ្ទុះឡើង បន្ទាប់ពីសង្គ្រាមត្រជាក់បានបញ្ចប់ ដូចជានៅបូស្នៀ កូសូវ៉ូ អាល់ហ្សេរី រ៉ាន់ដា ប៊ូរុនឌី និងអ៊ុយហ្គង់ដា ក៏បានឈានដល់ទីបញ្ចប់ដែរ។ ការថមថយនៃរង្វើកភ្លើងសង្គ្រាមបែបនេះ បានបន្តក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយតទៀត។ ប្រទេសលីបេរីយ៉ា និងប្រទេសកូតឌីវ័រ បានបង្កើតរដ្ឋាភិបាលចម្រុះដោយរំលែកអំណាចគ្នា ហើយបានបើកចំហរទទួលកងទ័ពរក្សាសន្តិភាពអន្តរជាតិ ដោយដើរតាមមាគ៌ារបស់ប្រទេសសៀ៉រ៉ាឡេអូន (ដែលនៅឆ្នាំ ២០០៣ បានរៀបចំការបោះឆ្នោត តាមបែបប្រជាធិបតេយ្យ)។ នៅឆ្នាំ ២០០៥ កងទ័ពសាធារណរដ្ឋអៀរឡង់បានបញ្ចប់ដំណើរការរំសាយអាវុធរបស់ខ្លួនជាអចិន្ត្រៃយ៍។ ក្នុងឆ្នាំ ២០១៥ ប្រទេសកូឡុំប៊ីនិងក្រុមឧទ្ទាមដ៏ធំបំផុត នៅក្នុងប្រទេសនោះ បានយល់ព្រមលើកិច្ចព្រមព្រៀងសន្តិភាព ហើយដែលត្រូវបានសភាជាតិរបស់ខ្លួនអនុម័ត្តនៅឆ្នាំ ២០១៧។

ជម្លោះដ៏ធ្ងន់ធ្ងរបំផុតនាពេលបច្ចុប្បន្ននេះ ភាគច្រើនគឺការប៉ះទង្គិចប្រដាប់អាវុធ ជាជាងការប្រយុទ្ធគ្នាជាទ្រង់ទ្រាយធំ។ ការប្រយុទ្ធចុងក្រោយរវាងកងកម្លាំងប្រដាប់អាវុធធុនធ្ងន់ទាំងសងខាង (ជាឧទាហរណ៍រួមមាន កងកាំភ្លើងធំ រថក្រោះ និងយន្តហោះ) គឺការលុកលុយរបស់អាមេរិក ឆ្នាំ ២០០៣ ចូលប្រទេសអ៊ីរ៉ាក់ និងសង្គ្រាមរុស្ស៊ី-ហ្សកហ្ស៊ី ឆ្នាំ ២០០៨ ដែលសង្គ្រាមទាំងពីរប្រព្រឹត្តិទៅក្នុងរយៈពេលខ្លី ហើយមែនទែនទៅ ត្រូវបានបង្កឡើងដោយភាគីម្ខាង។ សង្គ្រាមអន្តរដ្ឋដែលប្រព្រឹត្តិទៅក្នុងរយៈពេលយូរ រវាងប្រទេសអេត្យូពី និងប្រទេសអេរីទ្រា បានបញ្ចប់នៅឆ្នាំ ២០០០។ សង្គ្រាមប្រទេសមហាអំណាចចុងក្រោយ(ដែលមានអានុភាពអំណាចខ្លាំងក្លាប្រយុទ្ធគ្នា)បានបញ្ចប់ជាង ៦០ ឆ្នាំមុនមកហើយ។

ក្នុងឆ្នាំ ២០១៨ សង្គ្រាមដែលបង្កការបំផ្លិចបំផ្លាញបំផុតក្នុងពិភពលោក បានផ្ទុះឡើងនៅក្នុងប្រទេសស៊ីរី ជាទីតាំងដែលការបះបោរនិងការបង្ក្រាបយ៉ាងឃោរឃៅរបស់រដ្ឋាភិបាល បានធ្វើអោយមនុស្ស ២០០ ពាន់នាក់ បានស្លាប់ ក្នុងរយៈពេលជាង ៧ ឆ្នាំ។ សង្គ្រាមនេះបានរីករាលដាលចូលទៅក្នុងប្រទេសអ៊ីរ៉ាក់ដែលជាប្រទេសជិតខាង ជាកន្លែងដែលពួកសកម្មប្រយុទ្ធអ៊ីស្លាមដណ្តើមយកទឹកដីសំខាន់ៗ ហើយក្រោយមកត្រូវបានកងកម្លាំងរដ្ឋាភិបាល និងក្រុមសកម្មប្រយុទ្ធយីដវាយដណ្តើមយកមកវិញ។ កងកម្លាំងយោធាមកពីប្រទេសមួយចំនួន រួមទាំងសហរដ្ឋអាមេរិក និងរុស្ស៊ី បានវាយប្រហារលើ ពួកសកម្មប្រយុទ្ធអ៊ីស្លាមយ៉ាងទូលំទូលាយ នៅក្នុងចន្លោះឆ្នាំ ២០១៥ និង២០១៧។ នៅក្នុងប្រទេសយ៉េមែន ប្រជាជនប្រមាណ ១០ ពាន់នាក់ត្រូវបានសម្លាប់នៅក្នុងសង្គ្រាមរណបរវាងប្រទេសអ៊ីរ៉ង់ និងប្រទេសអារ៉ាប៊ីសាអូឌីត។ ជម្លោះស៊ីវិលដ៏សាហាវនៅអ៊ុយក្រែន ជាទីតាំងដែលយោធារបស់ខ្លួនប្រឆាំងនឹងក្រុមបំបែករដ្ឋដែលគាំទ្ររុស្ស៊ី (គាំទ្រដោយរុស្ស៊ី) បានគំរាមកំហែងដល់ទំនាក់ទំនងនយោបាយរវាងអឺរ៉ុប និងប្រទេសរុស្ស៊ី។ នៅប្រទេសអាហ្វហ្គានីស្ថាន

សង្គ្រាមដ៏យូរនៅបន្តអូសបន្លាយ (ប៉ុន្តែ វត្តមានកងទ័ពអន្តរជាតិ កាន់តែតិចជាងមុន) ហើយការប្រយុទ្ធគ្នាបន្តកើតមានក្នុងប្រទេសសុម៉ាលី។ ទាហាននីហ្សេរីយ៉ាបានធ្វើចលនាប្រឆាំងនឹងក្រុមសកម្មប្រយុទ្ធអ៊ីស្លាមនៅភាគខាងជើងនៃប្រទេស។ តាមស្តង់ដារប្រវត្តិសាស្ត្រ ទាំងនេះសុទ្ធតែជាសង្គ្រាមតូចៗ។

ក្រាហ្វិក ៣.១ ចំនួនមនុស្សស្លាប់ក្នុងសង្គ្រាម (១៩៤៦-២០១៦)



ប្រភព៖ គម្រោងរបាយការណ៍សន្តិសុខមនុស្ស។ របាយការណ៍សង្ខេបអំពីសុវត្ថិភាពមនុស្ស ឆ្នាំ ២០១២។ ទីក្រុងវ៉ាន់គូវ័រ: HSRP, ២០១២, និងកម្មវិធីទិន្នន័យជម្លោះរបស់សាកលវិទ្យាល័យឧប្សាលា

ចំនួនមនុស្សស្លាប់ដែលបង្កឡើងដោយសង្គ្រាមគ្រប់ប្រភេទ រួមទាំងសកម្មភាព ដូចជាការបាញ់គ្រាប់ផ្លោង ការបំផ្ទុះគ្រាប់បែកក្នុងរថយន្ត និងការវាយប្រហារតាមផ្លូវអាកាស (ប៉ុន្តែមិនរាប់បញ្ចូលការស្លាប់ដោយប្រយោលពីជំងឺទេ) បានធ្លាក់ចុះយ៉ាងខ្លាំងក្នុងរយៈពេល ៧០ ឆ្នាំចុងក្រោយនេះ។ ក្រាហ្វិកទី ៣.១ បង្ហាញពីការថយចុះនៃចំនួនអ្នកស្លាប់ដោយសារសង្គ្រាម ចាប់តាំងពីចុងបញ្ចប់នៃសង្គ្រាមលោកលើកទីពីរ។ ខណៈពេលដែលឆ្នាំខ្លះចំនួនបានកើនឡើងខ្ពស់ ឬធ្លាក់ចុះទាបជាង ឆ្នាំផ្សេងទៀតក៏ដោយ មាននិន្នាការធ្លាក់ចុះជាបន្តបន្ទាប់ នៅក្នុងក្រាហ្វនេះ ក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ថ្មីៗនេះដែលបង្ហាញពីចលនាទាំងមូលឆ្ពោះទៅរកសង្គ្រាមតិចជាង នៅក្នុងប្រព័ន្ធអន្តរជាតិបច្ចុប្បន្ន។ ទោះបីជារយៈពេល៦ឆ្នាំចុងក្រោយនេះ មានការកើនឡើងនៃចំនួនអ្នកស្លាប់ និងរងរបួស ដោយសារជម្លោះនៅក្នុងប្រទេសស៊ីរី និងយេម៉ែនក៏ដោយ ប៉ុន្តែ យើងនៅតែស្ថិតក្នុងដំណាក់កាលនៃសន្តិភាពធៀប។

៣.២. ទ្រឹស្តីសេរីនិយម

៣.២ ចូរបែងចែកលក្ខណៈខុសគ្នារវាងទ្រឹស្តីពីរផ្សេងគ្នា ដើម្បីពន្យល់ពីមូលហេតុដែលបណ្តាប្រទេសកាន់ប្រជាធិបតេយ្យពេញលេញ មិនធ្វើសង្គ្រាមនឹងគ្នា។

ប្រសិនបើទ្រឹស្តីប្រាកដនិយមភាគច្រើនផ្តល់នូវដំណោះស្រាយបញ្ហាផលប្រយោជន៍រួម នៅក្នុងទំនាក់ទំនងអន្តរជាតិ តាមគោលការណ៍គ្រប់គ្រងនោះ វិធីសាស្ត្រទ្រឹស្តីដទៃជាច្រើនទៀត ដែលនឹងត្រូវពិភាក្សានៅក្នុងមេរៀននេះភាគច្រើនផ្តោតលើដំណោះស្រាយតាមគោលការណ៍បដិការ និងគោលការណ៍អត្តសញ្ញាណ (ចូរ

ត្រលប់ទៅមើលក្រាហ្វិក ២.១ ក្នុងមេរៀនទី ២)។ ក្នុងចំណោមជាតុទូទៅផ្សេងទៀត វិធីសាស្ត្រទាំងនេះជាទូទៅ មានសុទិដ្ឋិនិយមជាងទ្រឹស្តីប្រាកដនិយមអំពីការរំពឹងទុកថានឹងមានសន្តិភាព។

ទោះបីជាអ្នកប្រាកដនិយមយល់ឃើញថា ក្បួនច្បាប់នយោបាយផ្តោតអំណាចមានលក្ខណៈស្ថិតស្ថេរ មិនចេះចប់ និងមិនផ្លាស់ប្តូរក៏ដោយ អ្នកប្រាជ្ញទ្រឹស្តីសេរី ជាទូទៅ មើលឃើញថា ច្បាប់នៃទំនាក់ទំនងអន្តរជាតិមានការវិវឌ្ឍជាបន្តបន្ទាប់ សន្សឹមៗតាមពេលវេលា និងវិវត្តន៍ឆ្ពោះទៅរកសន្តិភាពជាងមុន។ ការវិវត្តន៍នេះអាចកើតឡើងបាន ម្យ៉ាងដោយសារលទ្ធផលសំខាន់នៃការបង្កើតដោយសន្សឹមៗ នូវអង្គការអន្តរជាតិនិងកិច្ចសហប្រតិបត្តិការទៅវិញទៅមក (គោលការណ៍បដិការ) និងម្យ៉ាងទៀតដោយសារការផ្លាស់ប្តូរបទដ្ឋាន និងមតិសាធារណៈ(គោលការណ៍អត្តសញ្ញាណ)។ ទ្រឹស្តីសំខាន់ៗដែលបានពិភាក្សា នៅក្នុងមេរៀននេះ និងមេរៀនជាបន្តបន្ទាប់ យល់ថា យើងនឹងមិនត្រូវវិនាសក្នុងពិភពលោកដែលពោរពេញដោយសង្គ្រាម កើតឡើងដដែលៗនោះទេ ប៉ុន្តែអាចសម្រេចបាននូវពិភពលោកមួយដែលមានសន្តិភាពល្អជាង។ លើសពីនេះ មេរៀនទី ៤ នឹងពិនិត្យឡើងវិញនូវបណ្តាទ្រឹស្តីសេរីស្តីពីនយោបាយក្នុងស្រុក និងការធ្វើគោលនយោបាយបរទេស ដែលខុសពីទ្រឹស្តីប្រាកដនិយម បានផ្តល់សារៈសំខាន់លើកម្រិតនៃការវិភាគ ក្នុងស្រុក និងបុគ្គល ក្នុងការពន្យល់អំពីអាកប្បកិរិយារបស់រដ្ឋ។

៣.២.១. លោក កានត៍ និងសន្តិភាព

ទ្រឹស្តីសេរីនានាក្នុងទំនាក់ទំនងអន្តរជាតិ ព្យាយាមពន្យល់ពីរបៀបដែលសន្តិភាពនិងកិច្ចសហប្រតិបត្តិការអាចកើតឡើងបាន។ ទស្សនវិទូជនជាតិអាឡឺម៉ង់ លោក អ៊ីម៉ានុយអែល កានត៍ (Immanuel Kant) កាលពី ២០០ ឆ្នាំមុន បានផ្តល់នូវចម្លើយចំនួនបី។ ចម្លើយទីមួយ ដោយផ្អែកលើគោលការណ៍បដិការ អះអាងថារដ្ឋនានាអាចបង្កើតអង្គការនិងវិធានច្បាប់ផ្សេងៗដើម្បីជួយសម្រួលដល់កិច្ចសហប្រតិបត្តិការ ជាពិសេស ដោយការបង្កើតសហព័ន្ធពិភពលោក ដែលមានលក្ខណៈដូចអង្គការសហប្រជាជាតិ នាពេលបច្ចុប្បន្ននេះ។ ចម្លើយនេះបង្កើតជាមូលដ្ឋានគ្រឹះនៃស្ថាប័នសេរីនិយមសម័យបច្ចុប្បន្ន ដែលនឹងត្រូវពិភាក្សាឆាប់នេះ។

ចម្លើយទីពីររបស់លោក កានត៍ ដែលប្រតិបត្តិការនៅក្នុងកម្រិតទាបនៃការវិភាគ អះអាងថាសន្តិភាពអាស្រ័យទៅលើចរិតផ្ទៃក្នុងរបស់រដ្ឋាភិបាល។ លោកបានលើកហេតុផលថា សាធារណរដ្ឋដែលមានស្ថាប័ននីតិប្បញ្ញត្តិ ដែលអាចត្រួតពិនិត្យអំណាចស្ថាប័នព្រះមហាក្សត្រ នឹងមានសន្តិភាពជាងរបបអត្តាធិបតេយ្យ (autocracies)។ ចម្លើយនេះ រួមនឹងចំណុចពាក់ព័ន្ធរបស់ លោក កានត៍ ដែលថា ពលរដ្ឋនៃប្រទេសណាមួយសមនឹងទទួលបានបដិសណ្ឋារកិច្ច នៅក្នុងប្រទេសដទៃទៀត ត្រូវស្របតាមគោលការណ៍បដិការ ប៉ុន្តែ ក៏ពឹងផ្អែកលើគោលការណ៍អត្តសញ្ញាណផងដែរ។ ដូចទ្រឹស្តីសង្គមដែលនឹងត្រូវពិភាក្សានៅពេលក្រោយក្នុងមេរៀននេះ វាពន្យល់ពីចំណូលចិត្តរបស់រដ្ឋ ដោយផ្អែកលើអន្តរកម្មសង្គម នៅក្នុងរដ្ឋនោះ។ ចម្លើយប្រហាក់ប្រហែលមួយទៀតរបស់លោកកានត៍ ពោលគឺថា ប្រទេសប្រកាន់លទ្ធិប្រជាធិបតេយ្យពេញលេញមិនធ្វើសង្គ្រាមប្រឆាំងនឹងគ្នា គឺជាមូលដ្ឋាននៃទ្រឹស្តីសន្តិប្រជាធិបតេយ្យ សម័យបច្ចុប្បន្ន ដែលនឹងត្រូវពិភាក្សានៅពេលក្រោយ នៅក្នុងមេរៀននេះ។ (លោក កានត៍ ខ្លួនឯងវាបានមិនទុកចិត្តលទ្ធិប្រជាធិបតេយ្យ ដោយសារវាអាចជាកម្មវត្ថុនៃគោលនយោបាយគ្រប់គ្រងដោយហ្វូងមនុស្ស ជាជាងសនិទានភាព ឬ ការថ្លឹងថ្លែងហេតុផលត្រឹមត្រូវ។ ទស្សនៈរបស់គាត់បែបនេះ ក្រោយទទួលឥទ្ធិពលដោយសង្កេតឃើញបដិវត្តន៍បារាំងដោយផ្ទាល់។)

រូបថត ក្រុមអវកាសយានិកចម្រុះជាតិសាសន៍លើស្ថានីយ៍អវកាស

គ្រួសារីកាយ

ទ្រឹស្តីសេរីនិយមសង្កត់ធ្ងន់លើសក្តានុពលសម្រាប់គូប្រកួតប្រជែង ដើម្បីវិត្តទៅជាទំនាក់ទំនងសហប្រតិបត្តិការ ខណៈដែលរដ្ឋទទួលស្គាល់ថាការសម្រេចបាននូវផលប្រយោជន៍ទៅវិញទៅមក មានប្រសិទ្ធភាពបំផុតក្នុងរយៈពេលយូរ។ ជាឧទាហរណ៍ កម្មវិធីអវកាសរបស់សហរដ្ឋអាមេរិក និងសូវៀត/រុស្ស៊ី បានចាប់ផ្តើមកិច្ចសហប្រតិបត្តិការក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ ហើយបន្តសព្វថ្ងៃនេះ ជាមួយនឹងប្រទេសដទៃទៀត។ នៅទីនេះអវកាសយានិកមកពីសហរដ្ឋអាមេរិក រុស្ស៊ី អាល្លឺម៉ង់ និងស៊ុយអែត ធ្វើការរួមគ្នាលើស្ថានីយអវកាសអន្តរជាតិឆ្នាំ ២០០៦។

ចម្លើយទីបីរបស់លោកកានត៍ ដែលអះអាងថាពាណិជ្ជកម្មលើកកម្ពស់សន្តិភាព ត្រូវពឹងផ្អែកលើការសន្មតជាមុនថា ពាណិជ្ជកម្មបង្កើនទ្រព្យសម្បត្តិ កិច្ចសហប្រតិបត្តិការ និងសុខុមាលភាពសកល ហើយទន្ទឹមនឹងពេលនោះដែរ វាធ្វើកាត់បន្ថយជម្លោះ នៅក្នុងរយៈពេលវែង ដោយសារតែរដ្ឋាភិបាលនីមួយៗនឹងមិនចង់ខាតដល់ដំណើរការ ដែលកំពុងបង្កើនទ្រព្យសម្បត្តិរបស់រដ្ឋពួកគេទេ។ ជាងនេះទៅទៀត នៅពេលដែលពាណិជ្ជកម្មរវាងរដ្ឋកាន់តែកើនឡើងច្រើន ពួកគេនឹងសង្កេតឃើញថាពួកគេកាន់តែពឹងអាស្រ័យលើគ្នាទៅវិញទៅមក ត្រូវការជួញដូរទំនិញនឹងគ្នា។ ការពឹងផ្អែកទៅវិញទៅមករវាងរដ្ឋបែបនេះត្រូវបានគេហៅថា**ការពឹងអាស្រ័យគ្នា**ផ្អែកសេដ្ឋកិច្ច។ អ្នកប្រាជ្ញទាំងឡាយតែងតែបែងចែកភាពខុសគ្នារវាងស្ថានភាព*រវើប* (ដែលរដ្ឋមួយពឹងផ្អែកលើរដ្ឋមួយផ្សេងទៀត ដើម្បីផ្តល់ទំនិញដ៏សំខាន់ ក៏ប៉ុន្តែក៏អាចស្វែងរកប្រភពផ្គត់ផ្គង់ផ្សេងមកជំនួសដែរ) និងស្ថានភាព*ងាយរងគ្រោះ* ដែលប្រភពផ្សេងសម្រាប់ផ្គត់ផ្គង់ទំនិញមានចំនួនតិចតួច ឬគ្មានទាល់តែសោះ។

យ៉ាងណាមុញ អ្នកប្រាជ្ញប្រាកដនិយមមានមន្ទិលសង្ស័យចំពោះអំណះអំណាងដែលថា «សន្តិភាពជំរុញពាណិជ្ជកម្ម» ដោយលើកហេតុផលថាការពឹងផ្អែករបស់រដ្ឋមួយ ទៅលើប្រទេសមួយទៀតបង្កើតភាពតានតឹង*កាន់តែខ្លាំង* ក្នុងរយៈពេលខ្លី ដោយសាររដ្ឋនោះបារម្ភថាគូអង្គផ្សេងទៀតមានប្រភពអានុភាពដើម្បីយកប្រៀបលើខ្លួន។ ជាពិសេស រដ្ឋព្រួយបារម្ភអំពីការពឹងផ្អែករបស់ខ្លួនលើរដ្ឋផ្សេងទៀតសម្រាប់រ៉ែយុទ្ធសាស្ត្រដែលត្រូវការសម្រាប់គោលបំណងយោធា ដូចជាសារធាតុរ៉ែពិសេស ឬសំលោហៈសម្រាប់ផលិតយន្តហោះ និងសារធាតុអ៊ុយរ៉ាញ៉ូមសម្រាប់ផលិតអាវុធបរមាណូ។ មេដឹកនាំរដ្ឋព្រួយបារម្ភអំពីភាពងាយរងគ្រោះរបស់ខ្លួនដែលផ្តល់អោយប្រទេសដទៃទៀតអានុភាពយកប្រៀបលើពួកគេ ក្នុងផ្នែះជម្លោះណាមួយជាយថាហេតុ។ អ្នកប្រាជ្ញប្រាកដនិយមចង្អុលទៅការពិតដែលថា ការជជែកវែកញែកគ្នាអំពីការពឹងអាស្រ័យគ្នាទៅវិញទៅមក និងសន្តិភាព ត្រូវបានធ្វើឡើងជាទៀងទាត់ មុនពេលផ្ទុះសង្គ្រាមលោកលើកទី ១ ប៉ុន្តែសង្គ្រាមនោះនៅតែកើតឡើង ដោយជៀសមិនរួច។

៣.២.២. ស្ថាប័នសេរីនិយម

ឥឡូវនេះ ចូរយើងត្រឡប់ទៅរកចម្លើយដំបូងរបស់ លោក កានត៍ ចំពោះសំណួរថាតើសន្តិភាពអាចវិឌ្ឍដោយរបៀបណា ពោលគឺសមត្ថភាពរបស់រដ្ឋក្នុងការអភិវឌ្ឍន៍ និងអនុវត្តតាមច្បាប់ដែលផ្តល់អត្ថប្រយោជន៍ដល់គ្នាទៅវិញទៅមក រួមជាមួយនឹងស្ថាប័នអន្តរជាតិនានា ដើម្បីត្រួតពិនិត្យ និងពង្រឹងការអនុវត្តច្បាប់ទាំងនោះ។ ទ្រឹស្តីសេរីនិយមចាត់ទុកតួអង្គសមហេតុផលថា មានសមត្ថភាពលះបង់ផលប្រយោជន៍បុគ្គល ក្នុងរយៈពេលខ្លីដើម្បីបន្តសុខុមាលភាពរយៈពេលវែងរបស់សហគមន៍ ដែលពួកគេចាត់ទុកខ្លួននៅក្នុងនោះដែរ ម្លោះហើយ

ដោយប្រយោល ក៏ដើម្បីសុខុមាលភាពផ្ទាល់របស់ខ្លួនគេដែរ។ មូលដ្ឋានគ្រឹះនៃគោលការណ៍បដិការ ស្ថិតនៅចំចំណុចស្នូលនៃវិធីសាស្ត្រនេះ ដោយសារស្ថាប័នអន្តរជាតិទាំងឡាយដំណើរការបានដោយការរួមវិភាគទាន និងសម្បទានចំពោះគ្នាទៅវិញទៅមក ក្នុងចំណោមសមាជិកស្មើមុខមាត់គ្នា ជាផ្លូវការ (សមភាគី)។ ជាការពិតណាស់ នៅក្នុងស្ថាប័នសំខាន់ៗមួយចំនួន ដូចជាអង្គការពាណិជ្ជកម្មពិភពលោក និងសហភាពអឺរ៉ុប ការសម្រេចចិត្តតម្រូវអោយមានការឯកភាពគ្នាជាឯកច្ឆន្ទ ក្នុងចំណោមសមាជិកទាំងអស់ ដែលធ្វើឲ្យពួកគេទាំងអស់មានភាពស្មើគ្នា ក្នុងអភិបាលកិច្ច។

លោក កានត៍ បានអះអាងថា រដ្ឋនានា ទោះជាមានស្វ័យភាពក៏ដោយ ក៏ អាចចូលរួមជាមួយសហព័ន្ធពិភពលោកទាំងមូលដែរ ដូចជាអង្គការសហប្រជាជាតិនាពេលបច្ចុប្បន្ននេះ ហើយគោរពគោលការណ៍របស់ខ្លួន ទោះត្រូវលះបង់ផលប្រយោជន៍បុគ្គលក្នុងរយៈពេលខ្លីមួយចំនួនក៏ដោយ។ ចំពោះ លោក កានត៍ កិច្ចសហប្រតិបត្តិការអន្តរជាតិគឺជាជម្រើសសមហេតុផលសម្រាប់រដ្ឋ ជាជាងងាកទៅរកសង្គ្រាម។ ដូច្នេះ នៅក្នុងគំនិតអ្នកប្រាកដនិយមអំពីសនិទានភាព សង្គ្រាមនិងអំពើហឹង្សាហាក់ដូចជាសមហេតុផល (ដោយសារតែពួកគេច្រើនតែជំរុញផលប្រយោជន៍រយៈពេលខ្លីរបស់រដ្ឋផ្ទាល់) ប៉ុន្តែ នៅក្នុងទ្រឹស្តីសេរីនិយម សង្គ្រាម និងអំពើហឹង្សាលេចឡើងជាគម្លាតមិនសមហេតុផល ដែលបណ្តាលមកពីការវែកញែកខុស ហើយដែលបង្កអន្តរាយដល់ (ផលប្រយោជន៍សមូហភាពរយៈពេលយូរ) រដ្ឋជាភាគីនៃសង្គ្រាមទាំងឡាយ។

វិធីសាស្ត្រសេរីនិយមថ្មី (neoliberal) ខុសគ្នាពីវិធីសាស្ត្រសេរីនិយមមុនៗដែលទទួលយកការសន្មតសំខាន់ៗមួយចំនួនរបស់ទ្រឹស្តីប្រាកដនិយម៖ ក្នុងចំណោមនោះ ការសន្មតថា រដ្ឋគឺជាតួអង្គឯកតារួមមួយដែលស្វែងរកផលប្រយោជន៍ផ្ទាល់ខ្លួន នៅក្នុងប្រព័ន្ធអន្តរជាតិ ដែលពោរពេញដោយភាពអនាធិបតេយ្យ។ អ្នកប្រាជ្ញសេរីនិយមថ្មី (Neoliberals) និយាយទៅកាន់អ្នកប្រាជ្ញប្រាកដនិយមថា « បើទោះបីជាយើងទទួលយកការសន្មតរបស់អ្នកអំពីធម្មជាតិនៃរដ្ឋនិងចេតនារបស់ពួកគេក្តី ការសន្និដ្ឋានបែបទុទិដ្ឋិនិយមរបស់អ្នកមិនមិនមានភស្តុតាងសំអាងឡើយ។» រដ្ឋនានាសម្រេចបានកិច្ចសហប្រតិបត្តិការ ដោយស្មើភាព ជាញឹកញាប់ ព្រោះការធ្វើដូច្នេះគឺជាផលប្រយោជន៍របស់ពួកគេផ្ទាល់ ហើយពួកគេអាចរៀនប្រើប្រាស់ស្ថាប័ននានាដើម្បីសម្រួលដល់ការស្វែងរកផលប្រយោជន៍អោយគ្នាទៅវិញទៅមក ក៏ដូចជាការកាត់បន្ថយលទ្ធភាពនៃការបន្លំ ឬទាញយកផលប្រយោជន៍ឬលេងខ្សែលើពីរដ្ឋមួយផ្សេងទៀត។

ទោះបីជាមានប្រកពបញ្ហានាំអោយមានជម្លោះជាច្រើននៅក្នុងទំនាក់ទំនងអន្តរជាតិក៏ដោយ រដ្ឋនានាសហការគ្នា ភាគច្រើនបំផុត។ អ្នកប្រាជ្ញទ្រឹស្តីសេរីនិយមថ្មីព្យាយាមបង្ហាញថា សូម្បីតែនៅក្នុងពិភពលោកពោរពេញដោយរដ្ឋសមហេតុផលជាឯកតាមួយក៏ដោយ ភាពទុទិដ្ឋិនិយមរបស់អ្នកប្រាជ្ញទ្រឹស្តីប្រាកដនិយមថ្មីអំពីកិច្ចសហប្រតិបត្តិការអន្តរជាតិ មិនមានលក្ខណៈត្រឹមត្រូវនោះទេ។ រដ្ឋអាចបង្កើតច្បាប់, ការពឹងទុកចំពោះគ្នាទៅវិញទៅមក និងស្ថាប័ននានា ដើម្បីលើកកម្ពស់ឥរិយាបថ ដែលបង្កើនកិច្ចសហប្រតិបត្តិការ។

ជាពិសេស គោលការណ៍បដិការនៅក្នុងទំនាក់ទំនងអន្តរជាតិ ជួយអោយកិច្ចសហប្រតិបត្តិការអន្តរជាតិលេចចេញជារូបរាង ទោះបីជាមិនមានអាជ្ញាធរកណ្តាលក៏ដោយ។ តាមរយៈគោលការណ៍បដិការមិនមែនតាមរយៈរដ្ឋាភិបាលពិភពលោកទេ បទដ្ឋាននិងច្បាប់ត្រូវបានអនុវត្ត។ នៅក្នុងសន្តិសុខអន្តរជាតិ(IS) គោលការណ៍បដិការបានបង្កប់នូវភាពប្រសើរឡើងបន្តិចម្តងៗក្នុងទំនាក់ទំនងនានា ដែលដែលជាគោលដៅនៃកិច្ចព្រមព្រៀងគ្រប់គ្រងអាវុធ និងបេសកកម្មរក្សាសន្តិភាព។ នៅក្នុងសេដ្ឋកិច្ចនយោបាយអន្តរជាតិ (IPE)

ដែលក្នុងនោះកិច្ចសហប្រតិបត្តិការអាចបង្កើតអត្ថប្រយោជន៍ធំធេង តាមរយៈពាណិជ្ជកម្ម, ការគំរាមកំហែងក្នុងការរឹតបន្តឹងពាណិជ្ជកម្មជាការសងសឹកចំពោះការអនុវត្តអយុត្តិធម៌ គឺជាការលើកទឹកចិត្តដ៏ខ្លាំងមួយដើម្បីអោយភាគីពាក់ព័ន្ធអនុវត្តតាមច្បាប់ និងបទដ្ឋានដែលមានស្រាប់។ អង្គការពាណិជ្ជកម្មពិភពលោក (WTO) និងបុព្វស្ថាប័នរបស់វា កិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយនិងពាណិជ្ជកម្ម (GATT) បានដំណើរការដោយឈរលើគោលការណ៍នេះ៖ រដ្ឋទាំងឡាយដែលបោះបង់កាតព្វកិច្ចរបស់ពួកគេដោយការបង្កើនពន្ធត្រូវតែទទួលរងទណ្ឌកម្ម ដោយអនុញ្ញាតអោយរដ្ឋផ្សេងទៀតយកពន្ធលើទំនិញរបស់ពួកគេដែរ។

អ្នកប្រាជ្ញទ្រឹស្តីសេរីនិយមថ្មីអះអាងថា គោលការណ៍បដិការអាចជាយុទ្ធសាស្ត្រដ៏មានប្រសិទ្ធភាពមួយសម្រាប់ការសម្រេចបាននូវកិច្ចសហប្រតិបត្តិការក្នុងស្ថានភាពដែលដែលមានជម្លោះផលប្រយោជន៍។ ប្រសិនបើភាគីម្ខាងបង្ហាញឆន្ទៈក្នុងការសហការនិងសន្យាថា ខ្លួននឹងឆ្លើយតបជាក់ស្តែងតាមសមាមាត្រនៃសកម្មភាពសហប្រតិបត្តិការឬបង្កជម្លោះរបស់ភាគីម្ខាងទៀត នោះភាគីម្ខាងទៀតមានការលើកទឹកចិត្តក្នុងការ ចរចារកកិច្ចសហប្រតិបត្តិការ។ ដោយសារគោលការណ៍បដិការអាចត្រូវគេបកស្រាយបានយ៉ាងងាយ ការសច្ចាប្រើតបតតាមគោលការណ៍បដិការនាពេលខាងមុខ ជារឿយៗមិនចាំបាច់ត្រូវបានបញ្ជាក់អោយច្បាស់លាស់នោះទេ។ ជាឧទាហរណ៍ នៅឆ្នាំ ១៩៦៩ ទំនាក់ទំនងរបស់ប្រទេសចិនជាមួយនឹងសហរដ្ឋអាមេរិកបានជាប់គាំងអស់រយៈពេល ២០ ឆ្នាំ។ ការដាក់ទណ្ឌកម្មសេដ្ឋកិច្ចរបស់សហរដ្ឋអាមេរិកប្រឆាំងនឹងប្រទេសចិនកំពុងរារាំងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសចិន។ ការគាំទ្ររបស់ចិនចំពោះវៀតណាមខាងជើងបានបណ្តាលអោយទាហានអាមេរិកបាត់បង់ជីវិត។ រដ្ឋទាំងពីរមិនស្ថិតក្នុងលក្ខខណ្ឌនិយាយរកគ្នាទេ។ លោកប្រធានាធិបតី និចសុន (និងទីប្រឹក្សារបស់គាត់ ហិនរី ឃីសស៊ីងហ្គ័រ) បានសម្រេចចិត្តបន្តូបន្តយទណ្ឌកម្មពាណិជ្ជកម្មប្រឆាំងនឹងប្រទេសចិន បន្តិច។ បីថ្ងៃក្រោយមក ចិនបានដោះលែងពលរដ្ឋអាមេរិកបីនាក់ ដែលមុននោះ ទូករបស់គេបានរសាត់ចូលក្នុងដែនទឹកចិន។ ប្រទេសចិនបានតបតជាក់ស្តែងជាមួយនឹងគំនិតផ្តួចផ្តើមរបស់សហរដ្ឋអាមេរិកផ្សេងទៀត ហើយនៅឆ្នាំ ១៩៧២ លោក និចសុន ផ្ទាល់ បានទៅធ្វើទស្សនកិច្ចនៅប្រទេសចិន ក្នុងស្មារតីបង្កើតទំនាក់ទំនងស្និទ្ធស្នាល។


ដូចគ្នានេះដែរ ក្នុងឆ្នាំ ២០០៩ រដ្ឋបាលលោក អូបាម៉ា បានប្រកាសថា ខ្លួននឹងឈប់សាងសង់ប្រព័ន្ធការពារមីស៊ីលនៅអឺរ៉ុប ដែលរុស្ស៊ីចាត់ទុកថាជាការបង្កហេតុ។ អ្នកខ្លះយល់ឃើញថា ទង្វើនេះជាវិធានការមួយដើម្បីទទួលបានការគាំទ្រពីប្រទេសរុស្ស៊ីលើការដាក់ទណ្ឌកម្មប្រឆាំងនឹងប្រទេសអ៊ីរ៉ង់ ដែលបានអភិវឌ្ឍកម្មវិធីនុយក្លេអ៊ែរ។ ហើយជាការពិតណាស់ នៅនិទាឃរដូវឆ្នាំ ២០១០ ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិបានអនុម័តការដាក់ទណ្ឌកម្មកាន់តែតឹងរ៉ឹងលើអ៊ីរ៉ង់ ដោយមានប្រទេសរុស្ស៊ីបានបោះឆ្នោតគាំទ្រផងដែរ។

អ្នកប្រាជ្ញទ្រឹស្តីសេរីនិយមថ្មីប្រើប្រាស់ល្បែងទ្វេគ្រោះអ្នកទោស (សូមមើលមេរៀនទី២) ដើម្បីបង្ហាញពីអំណះអំណាងរបស់ពួកគេដែលថា កិច្ចសហប្រតិបត្តិការពិតជាអាចធ្វើទៅបាន។ តួអង្គនីមួយអាចទទួលបានផលចំណេញ ដោយការបិទមាត់រៀងៗខ្លួន ប៉ុន្តែនឹងត្រូវខាតបង់ទាំងពីរនាក់ ប្រសិនបើពួកគេសារភាពដូចគ្នា។ ដូចគ្នានរដែរ នៅក្នុងទំនាក់ទំនងអន្តរជាតិ រដ្ឋនានាតែងតែមានជម្លោះនិងផលប្រយោជន៍រួមគ្នា។ ទ្វេគ្រោះអាចត្រូវបានរំដោះ ប្រសិនបើល្បែងត្រូវបានគេលេងម្តងហើយម្តងទៀត៖ គំរូត្រឹមត្រូវនៃទំនាក់ទំនងអន្តរជាតិ ដែលរដ្ឋទាក់ទងគ្នា តាមរយៈអន្តរកម្ម ជាញឹកញាប់ ម្តងហើយម្តងទៀត។ ក្នុងករណីនោះ យុទ្ធសាស្ត្រនៃគោលការណ៍បដិការយ៉ាងតឹងរ៉ឹង បន្ទាប់ពីបានដើរដំហានកិច្ចសហប្រតិបត្តិការ កាលមុនដំបូង

(ឬហៅតាមអង់គ្លេសថា *tit-for-tat* ឬជាភាសាខ្មែរថា មានទៅមានមក) អាចនាំមកនូវកិច្ចសហប្រតិបត្តិការទៅវិញទៅមក នៅក្នុងល្បែងទ្វេគ្រោះអ្នកទោស ម្តងហើយម្តងទៀត ពីព្រោះអ្នកលេងផ្សេងទៀតត្រូវតែទាញសន្និដ្ឋានថា បើយើងមិនសហការ ឬ បង្កហេតុ នោះគេក៏មិនសហការនិងបង្កហេតុអោយយើងវិញដែរ ដើម្បីជាការឆ្លើយតប។

ប៉ុន្តែ ទន្ទឹមនឹងសក្តានុពលនៃកិច្ចសហប្រតិបត្តិការ គោលការណ៍បដិការក៏មានហានិភ័យបណ្តាលអោយមានអរិភាពចំពោះគ្នាកាន់តែខ្លាំងផងដែរ។ នៅពេលដែលភាគីទាំងសងខាងសងសឹកគ្នា ប៉ុន្តែមិនដែលអាចវិលត្រលប់មករកទំនាក់ទំនងបែបសហការនឹងគ្នានោះទេ លទ្ធផលអាចជាការដាក់ទណ្ឌកម្ម ប្រឆាំងនឹងគ្នាម្តងហើយម្តងទៀត រហូតដល់ខ្ទេចខ្ទីទាំងសងខាង។ ជាឧទាហរណ៍គំនិតនេះបង្ហាញពីទំនាក់ទំនងរបស់ប្រទេសអ៊ីស្រាអែល ជាមួយក្រុមសកម្មប្រយុទ្ធប៉ាឡេស្ទីន ក្នុងរយៈពេលជាច្រើនឆ្នាំ។ ក្រាហ្វិក ៣.២ លាតត្រដាងទិន្នន័យតាមដានអន្តរកម្មរវាងតួអង្គអ៊ីស្រាអែល និងប៉ាឡេស្ទីន ក្នុងរយៈពេល ១៧ ឆ្នាំ។ ចូរកត់សម្គាល់ថា នៅពេលតួអង្គណាមួយបង្ហាញអាកប្បកិរិយាបង្កហេតុ (តម្លៃអវិជ្ជមាននៅលើក្រាហ្វិក) តួអង្គផ្សេងទៀត នឹងឆ្លើយតបមកវិញ ដោយទង្វើអវិជ្ជមានតាមសមាមាត្រតួអង្គមុន។ ដូចគ្នានេះដែរ ឥរិយាបទបែបសហប្រតិបត្តិការ (តម្លៃវិជ្ជមាននៅលើក្រាហ្វិក) នាំមកនូវកិច្ចសហប្រតិបត្តិការទៅវិញទៅមក ក្នុងរយៈពេលភ្លាមៗ។ ទោះជាយ៉ាងណាក៏ដោយ យូរៗទៅ គោលការណ៍បដិការនេះមានឥទ្ធិពលតិចតួចប៉ុណ្ណោះក្នុងការរក្សាកិច្ចសហប្រតិបត្តិការអោយខ្ពស់ ពោលគឺ រយៈពេលនៃកិច្ចព្រមព្រៀង សូម្បីតែកិច្ចព្រមព្រៀងតបតដោយភាគីនីមួយៗ នៅទីបំផុត ប្រែក្លាយជាការតបតដោយជម្លោះទៅវិញ។

ក្រាហ្វិក ៣.២ បដិការនៅក្នុងជម្លោះនិងកិច្ចសហប្រតិបត្តិការរវាងអ៊ីស្រាអែលនិងប៉ាឡេស្ទីន ឆ្នាំ ១៩៧៩-១៩៩៧



ដោយផ្អែកលើគោលការណ៍បដិការ បទដ្ឋានអន្តរជាតិជាច្រើនសម្របសម្រួលអន្តរកម្មរវាងរដ្ឋនិងរដ្ឋ។ ជាឧទាហរណ៍ ច្បាប់ការទូតនិងការចូលរួមក្នុងអង្គការអន្តរជាតិ (IOs) សុទ្ធតែត្រូវបានគ្រប់គ្រងយ៉ាងតឹងរ៉ឹង ដោយការរំពឹងទុករួមគ្នាស្តីអំពីច្បាប់កំណត់ថាអ្វីអាកប្បកិរិយាត្រឹមត្រូវ។ ដោយសារបញ្ហាផលប្រយោជន៍រួមកើតឡើងជាញឹកញាប់នៅក្នុងទំនាក់ទំនងអន្តរជាតិ រដ្ឋពឹងផ្អែកលើបរិបទនៃច្បាប់ បទដ្ឋាន ទម្លាប់ និងស្ថាប័នទាំងឡាយ ដែលធ្វើអោយភាគីទាំងអស់ប្តឹងថ្លែងហេតុនឹងផល ដើម្បីជៀសវាងលទ្ធផលបរាជ័យផ្ទាល់ខ្លួនដែលនឹងកើតឡើងដោយសារការស្វែងរកផលប្រយោជន៍ផ្ទាល់ខ្លួនរយៈពេលខ្លី។ អ្នកប្រាជ្ញទ្រឹស្តីសេរីនិយមថ្មីសិក្សាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនិងព្រឹត្តិការណ៍សហសម័យ នៅក្នុងទំនាក់ទំនងអន្តរជាតិ ដើម្បីមើលពីរបៀបដែលស្ថាប័ន និងបទដ្ឋាននានាជះឥទ្ធិពលដល់លទ្ធភាពក្នុងការជំនះលើល្បែងទ្វេគ្រោះ និងក្នុងការសម្រេចបាននូវកិច្ចសហប្រតិបត្តិការអន្តរជាតិ។ (ដូចដែលយើងនឹងឃើញក្នុងពេលឆាប់ៗនេះ អ្នកទ្រឹស្តីស្ថាបនានិយមមួយ(Constructivists)ចំនួនសង្កត់ធ្ងន់ថា នៅទីបំផុត បទដ្ឋានទាំងនេះនឹងមានដំណើរការ ដោយគ្មានរដ្ឋគិតតែអំពីផលប្រយោជន៍ខ្លួនឯងទាល់តែសោះ។) ដូច្នេះហើយ សម្រាប់ក្រុមអ្នកទ្រឹស្តីសេរីនិយមថ្មី ការលេចចេញនូវស្ថាប័នអន្តរជាតិ ជាគន្លឹះក្នុងការយល់ដឹងពីរបៀបដែលរដ្ឋសម្រេចបាននូវលទ្ធផលសមហេតុសមផលដ៏ប្រសើរជាង ដែលរួមបញ្ចូលផលប្រយោជន៍ផ្ទាល់ខ្លួនក្នុងរយៈពេលវែង និងមិនមែនត្រឹមតែផលប្រយោជន៍ផ្ទាល់ខ្លួនភ្លាមៗនោះទេ។

៣.២.៣. របបអន្តរជាតិ

ការសម្រេចបានលទ្ធផលល្អមិនមែនជារឿងសាមញ្ញនោះទេ។ ដោយសារតែការបកស្រាយផ្ទុយគ្នាដែលភាគីនៃជម្លោះនីមួយៗ ជាធម្មតាមានចំណែស វាពិបាកណាស់ក្នុងការដោះស្រាយជម្លោះដោយគ្មានភាគីទីបីដើម្បីធ្វើជាអាជ្ញាកណ្តាល ឬក្របខ័ណ្ឌទាំងមូលដើម្បីកំណត់ការរំពឹងទុករួមសម្រាប់ភាគីទាំងអស់។ ការពិចារណាទាំងអស់នេះបញ្ជាក់ពីការបង្កើតអង្គការអន្តរជាតិ (IOs)។

របបអន្តរជាតិគឺជាសំណុំច្បាប់ បទដ្ឋាន និងនីតិវិធី ដែលការរំពឹងទុករួមរបស់តួអង្គនានាស្តីពី តំបន់បញ្ហាជាក់លាក់ណាមួយ (មិនថាការគ្រប់គ្រងអាវុធ ពាណិជ្ជកម្មអន្តរជាតិ ឬការរុករកក្នុងទឹបអង់តាក់ទិក)។ ការរំពឹងទុករួមគ្នាមានន័យថា តួអង្គចូលរួមនៅក្នុងប្រព័ន្ធអន្តរជាតិទាំងអស់មានគំនិតស្រដៀងគ្នាអំពីអ្វីដែលច្បាប់នឹងដឹកនាំការចូលរួមនឹងគ្នាទៅវិញទៅមករបស់ពួកគេ៖ តួអង្គនីមួយៗរំពឹងថានឹងត្រូវប្រតិបត្តិសំណុំច្បាប់ដូចគ្នាៗ។ (អត្ថន័យនៃពាក្យ*របប*នៅទីនេះមិនដូចគ្នាទៅនឹងការសំដៅទៅលើរដ្ឋាភិបាលក្នុងស្រុកនៃរដ្ឋនានានោះទេ ជាពិសេសរដ្ឋាភិបាលដែលត្រូវបានចាត់ទុកថាមិនស្របច្បាប់ ដូចជានៅក្នុង*ការផ្លាស់ប្តូររបប*។)

របបទាំងឡាយអាចជួយដោះស្រាយបញ្ហាផលប្រយោជន៍រួមដោយការបង្កើនតម្លាភាព ពីព្រោះមនុស្សគ្រប់គ្នាដឹងពីអ្វីដែលអ្នកដទៃកំពុងធ្វើ ការបោកប្រាស់គឺជារឿងកាន់តែប្រថុយប្រថាន។ បដិវត្តន៍បច្ចេកវិទ្យាព័ត៌មាន បច្ចុប្បន្ន កំពុងពង្រឹងរបបនានា ជាពិសេសនៅក្នុងទិដ្ឋភាពនេះ។ ជាមួយនឹងមធ្យោបាយទាក់ទងគ្នាកាន់តែប្រសើរផងដែរ រដ្ឋអាចកំណត់អត្តសញ្ញាណជម្លោះ និងចរចារកដំណោះស្រាយតាមរយៈរបបនានាកាន់តែមានប្រសិទ្ធភាព។

ការកំណត់បញ្ញត្តិជាទូទៅនៃរបបនានារួមបញ្ចូលគ្នានូវធាតុផ្សំនៃទ្រឹស្តីប្រាកដនិយម និងទ្រឹស្តីសេរីនិយម។ រដ្ឋត្រូវបានគេមើលឃើញថាជាអង្គភាពស្វយ័តដែលបង្កើនផលប្រយោជន៍ផ្ទាល់ខ្លួន នៅក្នុងបរិបទអនាធិបតេយ្យ។ របបនានាមិនមានតួនាទីក្នុងបញ្ហាដែលរដ្ឋអាចដឹងពីផលប្រយោជន៍របស់ពួកគេដោយផ្ទាល់

តាមរយៈការប្រើប្រាស់អានុភាពជាឯកតោភាគី។ ផ្ទុយទៅវិញ របបទាំងឡាយលេចចេញជារូបរាង ដើម្បីជំនះលើបញ្ហាផលប្រយោជន៍រួម ដោយការសម្របសម្រួលអាកប្បកិរិយារបស់រដ្ឋនីមួយៗ។ ទោះបីជារដ្ឋបន្តស្វែងរកផលប្រយោជន៍ផ្ទាល់ខ្លួនក៏ដោយ ក៏ពួកគេបង្កើតក្របខ័ណ្ឌរួមមួយដើម្បីសម្របសម្រួលសកម្មភាពរបស់ពួកគេជាមួយនឹងសកម្មភាពនៃរដ្ឋផ្សេងទៀត, ប្រសិនបើ និងនៅពេលណា ដែលការសម្របសម្រួលត្រូវការជាចាំបាច់ដើម្បីសម្រេចផលប្រយោជន៍ខ្លួនឯង (នោះគឺនៅក្នុងបញ្ហាផលប្រយោជន៍រួម)។

របបនានាមិនជំនួសអោយការវិភាគជាមូលដ្ឋាន លើការចំណាយនិងផលចំណេញ ដោយរដ្ឋឡើយ។ វាគ្រាន់តែបើកលទ្ធភាពថ្មីជាមួយនឹងសមាមាត្រទំហំនៃការចំណាយនិងចំណេញ ដែលរដ្ឋនីមួយៗចង់បានបន្ថែមទៀត។ របបនានាមិនរឹតបន្តឹងទង្វើរបស់រដ្ឋទេ លើកលែងតែក្នុងន័យតូចចង្អៀត និងក្នុងរយៈពេលខ្លី។ ផ្ទុយទៅវិញ វាជួយសម្រួលនិងផ្តល់សិទ្ធិអំណាចដល់រដ្ឋាភិបាលជាតិដែលប្រឈមមុខនឹងបញ្ហាផ្សេងៗ ដែលបញ្ហាផលប្រយោជន៍រួមឬការសម្របសម្រួលរួម អាចនឹងរារាំងរដ្ឋាភិបាលទាំងនេះពីការសម្រេចគោលដៅរបស់ខ្លួន។ របបនានាអាចត្រូវបានគេមើលឃើញថាជា *អវជ្ជវអន្តរាគមន៍* រវាងកម្លាំងជាបុព្វហេតុជាមូលដ្ឋាននៃដំណើរការក្នុងទំនាក់ទំនងអន្តរជាតិ (សម្រាប់អ្នកប្រាកដនិយម អំណាចធៀនរបស់តួអង្គរដ្ឋនានា) នឹងលទ្ធផលដូចជាកិច្ចសហប្រតិបត្តិការអន្តរជាតិ (ឬកង្វះកិច្ចសហប្រតិបត្តិការ)។ ជាពិសេសសម្រាប់អ្នកប្រាជ្ញប្រាកដនិយម របបមិនបដិសេធឥទ្ធិពលនៃអំណាចទេ។ ជាញឹកញាប់ វាបង្កើតច្បាប់និង និងធ្វើអោយទំនាក់ទំនងអំណាច ដែលមានស្រាប់ មានលក្ខណៈធម្មតា ស្របតាមគោលការណ៍គ្រប់គ្រង។ ជាឧទាហរណ៍ របបមិនរីកសាយភាយនុយក្លេអ៊ែរក្សាស្ថានភាពដើម(status quo) ដែលក្នុងនោះ មានតែរដ្ឋមួយចំនួនប៉ុណ្ណោះដែលអាចមានអាវុធនុយក្លេអ៊ែរ។

ដោយសាររបបនានាអាស្រ័យទៅលើអំណាចរដ្ឋសម្រាប់ពង្រឹងការអនុវត្តច្បាប់ អ្នកប្រាជ្ញទំនាក់ទំនងអន្តរជាតិមួយចំនួនបានអះអាងថា របបមានប្រសិទ្ធភាពបំផុត នៅពេលដែលអំណាចនៅក្នុងប្រព័ន្ធអន្តរជាតិត្រូវបានប្រមូលផ្តុំច្រើនបំផុតនៅលើកណ្តាប់ដៃរដ្ឋណាមួយ៖ នៅពេលមានអនុត្តរភាពដើម្បីរក្សាសណ្តាប់ធ្នាប់ (សូមមើល អនុត្តរភាព ក្នុងមេរៀនទី២)។ ប៉ុន្តែ របបមិនតែងតែ ចុះចម្រុងជាមួយនឹងអំណាចរបស់អនុត្តរភាពដែលបានបង្កើតពួកគេនោះទេ។ ផ្ទុយទៅវិញ ពួកគេអាចនឹងប្រព្រឹត្តិទៅ ដោយខ្លួនឯង។ ទោះបីជាអនុត្តរភាពអាចមានសារៈសំខាន់ក្នុងការ*បង្កើតរបប* ក៏ដោយ វាដូចជាមិនចាំបាច់សម្រាប់ការ*រក្សារបប* ទេ។ នៅពេលដែលការពឹងទុករបស់តួអង្គនានា ប្រមូលផ្តុំនៅជុំវិញច្បាប់ ដែលបានបញ្ចូលទៅក្នុងរបបមួយ តួអង្គទាំងនោះដឹងថារបបនេះបម្រើផលប្រយោជន៍ផ្ទាល់របស់ពួកគេ។ ការធ្វើការងារតាមរបបនេះក្លាយជាទម្លាប់មួយទៅហើយ ហើយអ្នកដឹកនាំជាតិ ប្រហែលជា មិនមានកូនចិត្តចង់បំពានច្បាប់ដែលបានបង្កើតឡើងនោះទេ។ ភាពរឹងមាំនៃរបបនេះត្រូវបានបង្ហាញ នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៧០ នៅពេលដែលអំណាចរបស់សហរដ្ឋអាមេរិកបានធ្លាក់ចុះ បន្ទាប់ពីទសវត្សរ៍នៃអនុត្តរភាពរបស់សហរដ្ឋអាមេរិក ចាប់តាំងពីឆ្នាំ ១៩៤៥។ របបសេដ្ឋកិច្ចអន្តរជាតិ បានសម្រួលខ្លួនខ្លះ ហើយក៏បានបន្តដំណើរការ។

ហេតុផលម្យ៉ាង ការរស់រានមានជីវិតនៃរបបនេះត្រូវពឹងផ្អែកលើការបង្កប់ខ្លួននៅក្នុង*ស្ថាប័ន* អចិន្ត្រៃយ៍ដូចជាអង្គការសហប្រជាជាតិ អង្គការណាតូ និងមូលនិធិរូបិយវត្ថុអន្តរជាតិ។ ស្ថាប័នទាំងនេះបានធ្វើអោយការពឹងទុករួមគ្នា ក៏ដូចជាយន្តការសម្រាប់ការសម្របសម្រួលសកម្មភាពអន្តរជាតិ លេចចេញជារូបរាងឡើងដោយផ្អែកលើការពឹងទុកទាំងនោះ។ នៅក្នុងកិច្ចការសន្តិសុខអន្តរជាតិ(IS), អង្គការសហប្រជាជាតិ និង

អង្គការអន្តរជាតិផ្សេងទៀតផ្តល់នូវក្របខ័ណ្ឌស្ថិរភាពសម្រាប់ការដោះស្រាយជម្លោះនានា (សូមមើលមេរៀនទី ៧)។ សេដ្ឋកិច្ចនយោបាយអន្តរជាតិ (IPE) រឹតតែមានលក្ខណៈជាស្ថាប័ន ជាថ្មីម្តងទៀត ដោយសារតែប្រកង់សកម្មភាពកាន់តែញឹកញាប់ និងទំហំទ្រព្យសម្បត្តិដែលអាចទទួលបានពីកិច្ចសហប្រតិបត្តិការ។

ស្ថាប័ននានាទទួលបានកំរិតស្ថេរភាពនិងទម្ងន់ធ្ងន់ជាងរបបដែលគ្មានស្ថាប័ន។ ជាមួយនឹងបុគ្គលិក និងទីស្នាក់ការច្បាស់លាស់ ស្ថាប័នអន្តរជាតិមួយអាចជំរុញការប្រកាន់ខ្ជាប់នូវច្បាប់យ៉ាងសកម្ម នៅក្នុងវិស័យជីវភាពនយោបាយ ឬសេដ្ឋកិច្ច របស់ខ្លួន។ ទោះជាយ៉ាងណាក៏ដោយ ការិយាធិបតេយ្យទាំងនេះក៏អាចលើកកម្ពស់គោលនយោបាយ ដែលមិនមែនជាគោលដៅរបស់រដ្ឋដែលបង្កើតស្ថាប័ននោះផងដែរ។

ស្ថាប័នសំខាន់ៗក្នុងសន្តិសុខអន្តរជាតិ និង សេដ្ឋកិច្ចនយោបាយអន្តរជាតិ នឹងត្រូវពិភាក្សានៅក្នុងមេរៀនទី ៧ និងមេរៀនទី ៨ រៀងគ្នា។ ស្ថាប័នសេរីនិយមក៏ដាក់តម្លៃខ្ពស់លើច្បាប់អន្តរជាតិ ដែលនឹងត្រូវពិភាក្សា នៅក្នុងមេរៀនទី៧។ ចំណុចកំពូលនៃស្ថាប័នសេរីនិយម រហូតមកដល់បច្ចុប្បន្ន គឺជាសហភាពអឺរ៉ុប (EU) ដែលនឹងត្រូវពិភាក្សាយ៉ាងស៊ីជម្រៅ នៅក្នុង មេរៀនទី ១០។ បន្ទាប់ពីសង្គ្រាមបំផ្លិចបំផ្លាញជាច្រើនសតវត្សរ៍មកហើយ រដ្ឋសហភាពអឺរ៉ុប បច្ចុប្បន្ននេះ ទទួលបានសន្តិភាពនិងស្ថិរភាព ក្នុងចំណោមពួកគេ ដោយមានស្ថាប័នអន្តរជាតិដ៏រឹងមាំដើម្បីផ្សះផ្សារពួកគេ។

រូបថត មហាសេដ្ឋីប៊ីលហ្គេតចាក់វ៉ាក់សាំងអោយកុមារម្នាក់

របបសុខភាព

របបអន្តរជាតិគឺជាសំណុំនៃច្បាប់ បទដ្ឋាន និងនីតិវិធី ដែលមិនតែងតែត្រូវបានបញ្ចូលទៅជាច្បាប់នៅក្នុងស្ថាប័ននានា ដែលគ្រប់គ្រងអាកប្បកិរិយារបស់តួអង្គនានា នៅក្នុងទំនាក់ទំនងអន្តរជាតិ។ របបសុខភាពពិភពលោករួមបញ្ចូល រដ្ឋ អង្គការអង្គរដ្ឋាភិបាល ដូចជាអង្គការសុខភាពពិភពលោក (WHO) អង្គការមិនរកប្រាក់ចំណេញដូចជា មូលនិធិហ្គេត (Gates Foundation) និងផ្សេងទៀត ដែលទាំងអស់រួមគ្នាធ្វើការជាមួយនឹងការរំពឹងទុកទូទៅអំពីសកម្មភាពដើម្បីកែលម្អសុខភាព និងទប់ស្កាត់ជំងឺរាតត្បាត។ នៅទីនេះ លោក ប៊ីលហ្គេត (Bill Gates) អតីតប្រធានក្រុមហ៊ុន Microsoft និងជាសហប្រធាននៃមូលនិធិ Gates ផ្តល់ឱ្យកុមារនូវវ៉ាក់សាំង rotavirus ដើម្បីការពារប្រឆាំងនឹងជំងឺរាគរូស នៅប្រទេសហ្គាណា ឆ្នាំ ២០១៣។

៣.២.៤. សន្តិសុខសមូហភាព

គោលគំនិតនៃ**សន្តិសុខសមូហភាព** ឬសន្តិសុខរួម ដែលរីកដុះដាលចេញពីស្ថាប័នសេរីនិយម សំដៅលើការបង្កើតសម្ព័ន្ធភាពទូលំទូលាយក្នុងចំណោមតួអង្គសំខាន់ៗភាគច្រើននៅក្នុងប្រព័ន្ធអន្តរជាតិ ក្នុងគោលបំណងរួមគ្នាប្រឆាំងនឹងការឈ្លានពានរបស់តួអង្គណាមួយផ្សេងទៀត។ លោក កានត៍ បានដាក់ចេញនូវហេតុផលសម្រាប់វិធីសាស្ត្រនេះ។ ដោយសារតែសន្ធិសញ្ញាអតីតកាល ដែលបញ្ចប់សង្គ្រាមរវាងប្រទេសមហាអំណាចមិនដែលផ្តល់នូវសន្តិភាពយូរអង្វែងឬជាអចិន្ត្រៃយ៍, លោក កានត៍ បានស្នើបង្កើតសហព័ន្ធ(ឬសម្ព័ន្ធ) នៃរដ្ឋនានាលើពិភពលោក។ តាមរយៈសហព័ន្ធបែបនេះ លោក កានត៍ បានស្នើថា រដ្ឋភាគច្រើនអាចរួបរួមគ្នា ដើម្បីដាក់ទណ្ឌកម្មរដ្ឋណាមួយដែលឈ្លានពានគេឯង, ការពារផលប្រយោជន៍រួមរបស់ប្រជាជាតិទាំងអស់ ខណៈពេលដែលការពារការសម្រេចដោគវាសនាដោយខ្លួនឯងរបស់ប្រជាជាតិតូចៗ ដែលងាយក្លាយជាកូនអុកក្នុងល្បែងរបស់ប្រទេសមហាអំណាច។

បន្ទាប់ពីភាពរន្ធត់នៃសង្គ្រាមលោកលើកទី ១ *សម្ព័ន្ធប្រជាជាតិ* ត្រូវបានបង្កើតឡើងដើម្បីលើកកម្ពស់សន្តិសុខសមូហភាព។ ប៉ុន្តែ វាមានចំណុចខ្សោយចំនួនពីរ។ សមាជិកភាពរបស់វាមិនបានរួមបញ្ចូលប្រទេសមហាអំណាចទាំងអស់ (រួមទាំងមហាអំណាចផុតលេខ គឺសហរដ្ឋអាមេរិក) ហើយសមាជិករបស់វាបានបង្ហាញថាពួកគេមិនមានឆន្ទៈក្នុងការទទួលបន្ទុកចំណាយលើសកម្មភាពរួម ដើម្បីប្រឆាំងនឹងការឈ្លានពាននៅពេលដែលវាបានកើតឡើង នៅទសវត្សរ៍ឆ្នាំ ១៩៣០ ដោយចាប់ផ្តើមពីប្រទេសជប៉ុន និងប្រទេសអ៊ីតាលី។ បន្ទាប់ពីសង្គ្រាមលោកលើកទី ២ អង្គការសហប្រជាជាតិត្រូវបានបង្កើតឡើង ជាអ្នកស្នងតំណែងរបស់សម្ព័ន្ធប្រជាជាតិ ដើម្បីលើកកម្ពស់សន្តិសុខសមូហភាព (សូមមើលមេរៀនទី ៧ និងឧទាហរណ៍បន្ថែមនៅខាងចុងមេរៀនស្តីពីការស្វែងរកដំណោះស្រាយបញ្ហាផលប្រយោជន៍រួម)។ បច្ចុប្បន្ន អង្គការអន្តររដ្ឋាភិបាលក្នុងតំបន់មួយចំនួន ក៏អនុវត្តមុខងារសន្តិសុខសមូហភាព (ការទប់ស្កាត់ការឈ្លានពាន) ក៏ដូចជាផ្នែកសេដ្ឋកិច្ច និងវប្បធម៌ផងដែរ រួមមាន *អង្គការរដ្ឋអាមេរិក*(OAS) *សម្ព័ន្ធអាហ្វ្រិក*(AU)។

ភាពជោគជ័យនៃសន្តិសុខសមូហភាពត្រូវអាស្រ័យលើកត្តាពីរយ៉ាង។ ទីមួយ សមាជិកត្រូវតែរក្សាការប្តេជ្ញាចិត្តរបស់ពួកគេចំពោះក្រុមសម្ព័ន្ធភាព(ពោលគឺសមាជិកមិនត្រូវជិះសេះលែងដៃ ក្នុងកិច្ចខិតខំប្រឹងប្រែងរបស់សមាជិកផ្សេងទៀតឡើយ)។ នៅពេលដែលរដ្ឋដែលមានអំណាចខ្លាំងធ្វើសកម្មភាពឈ្លានពានលើរដ្ឋតូចទន់ខ្សោយជាង ជារឿយៗ វាមិនមែនជាផលប្រយោជន៍ផ្ទាល់របស់រដ្ឋដែលមានអំណាចផ្សេងទៀតក្នុងការធ្វើសង្គ្រាម ដោយសារតែបញ្ហានោះទេ។ ការបង្ក្រាបរដ្ឋឈ្លានពានក្បាលរឹង អាចត្រូវចំណាយធនធានច្រើន។

កត្តាទីពីរសម្រាប់ភាពជោគជ័យនៃសន្តិសុខសមូហភាព តម្រូវអោយសមាជិកភាគច្រើន ឬ ល្មមគ្រប់គ្រាន់អាចយល់ស្របគ្នាលើអ្វីដែលចាត់ទុកថាជាការឈ្លានពាន។ រចនាសម្ព័ន្ធរបស់ក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិត្រូវបានរៀបចំឡើង ធ្វើយ៉ាងណាអោយ សមាជិកអចិន្ត្រៃយ៍ទាំងប្រាំ បន្ថែមពីលើសមាជិកយ៉ាងតិចបួនក្នុងចំណោមសមាជិកដប់ផ្សេងទៀត អាចព្រមព្រៀងគ្នាលើនិយមន័យនៃការឈ្លានពាន (សូមមើលក្រុមប្រឹក្សាសន្តិសុខក្នុងមេរៀនទី៧)។ ប្រព័ន្ធសន្តិសុខសមូហភាពបែបនេះមិនចាត់ការប្រឆាំងនឹងការឈ្លានពានដោយប្រទេសមហាអំណាចនោះទេ។ នៅពេលដែលសហភាពសូវៀតបានឈ្លានពានប្រទេសអាហ្វហ្គានីស្ថាន ឬនៅពេលសហរដ្ឋអាមេរិកបានដឹកយកវ៉ែនៅកំពង់ផែនីការ៉ាហ្គា ឬនៅពេលប្រទេសបារាំងបានបំផ្ទុះកប៉ាល់អង្គការបរិស្ថាន Greenpeace ឈ្មោះ *Rainbow Warrior* (អ្នកចម្បាំងឥន្ទ្រនូ) អង្គការសហប្រជាជាតិមិនអាចធ្វើអ្វីបានឡើយ ដោយសារតែរដ្ឋទាំងនោះ អាចវេតូដំណោះស្រាយរបស់ក្រុមប្រឹក្សាសន្តិសុខ។

សន្តិសុខសមូហភាពមានប្រសិទ្ធិភាព នៅក្នុងចន្លោះឆ្នាំ ១៩៩០-១៩៩១ ដើម្បីបញ្ជ្រាសការធ្វើសញ្ជ័យរបស់ប្រទេសអ៊ីរ៉ាក់ទៅលើប្រទេសគុយវ៉ែត ដោយសារតែការឈ្លានពាននោះបាននាំអោយប្រទេសមហាអំណាចទាំងអស់រួមគ្នា និងដោយសារតែពួកគេសុខចិត្តទទួលបន្ទុកចំណាយលើការប្រឈមមុខជាមួយកងទ័ពអ៊ីរ៉ាក់។ វាជាលើកទីមួយហើយ ចាប់តាំងពីការបង្កើតអង្គការសហប្រជាជាតិ ដែលរដ្ឋជាសមាជិកមួយបានចូលលុកលុយ កាន់កាប់ និងដាក់បញ្ចូលប្រទេសមួយទៀត ដោយព្យាយាមលុបបំបាត់វាមិនអោយក្លាយជារដ្ឋអធិបតេយ្យបន្តទៀត។ ការឈ្លានពាននេះ គឺជាការបំពានលើអធិបតេយ្យភាព និងបូរណភាពទឹកដីរបស់ប្រទេសគុយវ៉ែត ដែលធ្វើឲ្យក្រុមប្រឹក្សាសន្តិសុខមានបញ្ហាតិចតួច ក្នុងការកំណត់និយមន័យថានោះជាការឈ្លានពាន និងអនុញ្ញាតអោយប្រើកងកម្លាំងចម្រុះដោយសម្ព័ន្ធពហុជាតិ។ ការគម្រាមកំហែងដែលប្រទេស

អ៊ីរ៉ាក់បង្កឡើង ចំពោះការផ្តត់ផ្តង់ប្រេងនៅលើពិភពលោក បានផ្តល់ការលើកទឹកចិត្តបន្ថែមសម្រាប់សមាជិកចម្រុះក្នុងការបរិច្ចាគប្រាក់ ឬកងទ័ពដើម្បីដោះស្រាយបញ្ហា។

ផ្ទុយទៅវិញនៅឆ្នាំ ២០០២-២០០៣ ក្រុមប្រឹក្សាសន្តិសុខបានពិភាក្សាម្តងហើយម្តងទៀតអំពីការខកខានរបស់ប្រទេសអ៊ីរ៉ាក់ក្នុងការរក្សាកិច្ចព្រមព្រៀង ដែលខ្លួនបានធ្វើ នៅចុងបញ្ចប់នៃសង្គ្រាមឈូងសមុទ្រ ជាពិសេសការសន្យាក្នុងការបង្ហាញ និងបំផ្លាញអាវុធប្រល័យលោកទាំងអស់របស់ខ្លួន។ ប៉ុន្តែ ប្រទេសមហាអំណាចមានការបែងចែកគ្នា ហើយដំណោះស្រាយដែលស្នើឡើង ដោយសហរដ្ឋអាមេរិកនិងអង់គ្លេស ដែលអនុញ្ញាតអោយមានកម្លាំងយោធាត្រូវបានដកចេញ បន្ទាប់ពីប្រទេសបារាំងបានប្រកាសថាខ្លួននឹងវេតូវា។ ប្រទេសអាឡឺម៉ង់ រុស្ស៊ី និងចិន សុទ្ធតែបានប្រឆាំងនឹងសំណើនោះយ៉ាងខ្លាំងក្លា ក៏ដូចជាប្រឆាំងនឹងសង្គ្រាម។ មតិសាធារណៈជុំវិញពិភពលោក ជាពិសេសក្នុងប្រទេសដែលកាន់សាសនាឥស្លាម យ៉ាងច្រើនលើសលុប ក៏បានប្រឆាំងនឹងសង្គ្រាមដែរ។ នៅពេលដែលអង្គការសហប្រជាជាតិមិនធ្វើសកម្មភាព ប្រទេសបីរួមមានសហរដ្ឋអាមេរិក អង់គ្លេស និងអូស្ត្រាលីបានបញ្ជូនកម្លាំងយោធា ហើយទម្លាក់ ប្រធានាធិបតី សាដាម ហ៊ូសេន ចេញពីអំណាចដោយកម្លាំង ដោយថែមទាំងបានប្រៀបធៀបអង្គការសហប្រជាជាតិទៅនឹងសម័ន្ធប្រជាជាតិដែលអសមត្ថភាព។ ទោះបីជាយ៉ាងណាក៏ដោយ សហរដ្ឋអាមេរិករកមិនឃើញអាវុធប្រល័យលោក នៅក្នុងប្រទេសអ៊ីរ៉ាក់(ដូចដែលខ្លួនបានចោទប្រកាន់នោះទេ) ហើយបន្ទាប់មកត្រូវផុងខ្លួននៅក្នុងអង្គង់ប្រតិ-សង្គ្រាមដែលអូសបន្លាយយ៉ាងយូរ។ បើគិតឡើងវិញ បើទោះបីជាប្រព័ន្ធសន្តិសុខសមូហភាពរបស់ពិភពលោកមានភាពច្របូកច្របល់និងមិនតែងតែមានប្រសិទ្ធភាពក៏ដោយ ការបោះសន្ទូចរំលងប្រព័ន្ធនេះដោយធ្វើសកម្មភាពយោធាដោយខ្លួនឯង ក៏បង្កគ្រោះថ្នាក់ផងដែរ។

គោលគំនិតនៃ(ប្រព័ន្ធ)សន្តិសុខសមូហភាពត្រូវបានពង្រីកយ៉ាងទូលំទូលាយ ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ។ ជាឧទាហរណ៍ *រដ្ឋហាដ៏យ*(ឬក្សត្រ័យធន)មានការគ្រប់គ្រងខ្សោយលើទឹកដីរបស់ពួកគេ ដែលធ្វើអោយពួកគេក្លាយជាជម្រកជ្រកកោនសម្រាប់ការជួញដូរគ្រឿងញៀន ការលាងលុយកខ្វក់ និងមូលដ្ឋានភេរវករ។ និយាយជារួម នយោបាយក្នុងស្រុកហាក់ក្លាយជាភាពអនាធិបតេយ្យអន្តរជាតិ។ បច្ចុប្បន្ន ប្រទេសសូម៉ាលី ចូលក្នុងករណីបែបនេះ។ វាមានរដ្ឋាភិបាលខ្សោយបំផុត ដែលមិនអាចគ្រប់គ្រងទឹកដីភាគច្រើនរបស់ខ្លួនបាននោះទេ ហើយវាបានក្លាយជាជំរកលាក់ខ្លួនរបស់បណ្តាញអង្គការភេរវករ (សូមមើលមេរៀនទី ៥) និងក្រុមចោរសមុទ្រ (សូមមើលមេរៀនទី ៦)។ ក្នុងករណីទាំងនេះ សហគមន៍អន្តរជាតិមានកាតព្វកិច្ចធ្វើអន្តរាគមន៍តាមវិធីសាស្ត្រខ្លះ ដើម្បីស្តារច្បាប់និងសណ្តាប់ធ្នាប់ឡើងវិញ។

៣.២.៥. សន្តិប្រជាធិបតេយ្យ

លោក កានត៍ បានអះអាងថា សន្តិភាពយូរអង្វែងនឹងត្រូវពឹងផ្អែកលើការក្លាយជាសាធារណរដ្ឋរបស់រដ្ឋនានា ដោយមានស្ថាប័ននីតិប្បញ្ញត្តិដើម្បីពិនិត្យមើលអំណាចនៃស្ថាប័នព្រះមហាក្សត្រ (ឬប្រធានាធិបតី) ក្នុងការប្រកាសសង្គ្រាម។ លោកគិតថា ការតាមដានត្រួតពិនិត្យនិងរក្សាតុល្យភាព (check and balance) នៅក្នុងរដ្ឋាភិបាលនឹងដើរតួជាហ្វ្រាំងទប់ការប្រើប្រាស់កម្លាំងយោធា, បើប្រៀបធៀបទៅនឹងរដ្ឋាភិបាល*អត្តាធិបតេយ្យ* (autocratic) ដែលមេដឹកនាំផ្តាច់ការតែម្នាក់ (ឬក្រុមអ្នកកាន់អំណាចមួយក្តាប់តូច) អាចប្រកាសធ្វើសង្គ្រាមដោយមិនគិតពីផលវិបាកទៅលើប្រជាជនឡើយ។

ស្រដៀងគ្នានេះដែរ អ្នកប្រាជ្ញទំនាក់ទំនងអន្តរជាតិ បានភ្ជាប់លទ្ធិប្រជាធិបតេយ្យជាមួយនឹងប្រភេទនៃគោលនយោបាយការបរទេស ដែលជាទូទៅខុសពីគោលនយោបាយរបស់របបផ្តាច់ការ។ ទ្រឹស្តីមួយដែលពួកគេបានពិចារណា បានចែងថា ប្រទេសប្រកាន់លទ្ធិប្រជាធិបតេយ្យពេញលេញជាទូទៅ មាន*សន្តិភាពជាង*រដ្ឋាភិបាលផ្តាច់ការ (ធ្វើសង្គ្រាមតិចជាងឬតូចជាង)។ នេះប្រហែលជាមិនពិតទេ។ ប្រទេសប្រកាន់លទ្ធិប្រជាធិបតេយ្យចូលប្រយុទ្ធក្នុងសង្គ្រាមយ៉ាងច្រើនដូចរដ្ឋផ្តាច់ការដែរ។ ប្រាកដណាស់ រដ្ឋទាំងបីដែលងាយរងគ្រោះដោយសង្គ្រាមច្រើនបំផុត ក្នុងរយៈពេលពីរសតវត្សរ៍កន្លងមកនេះ (បើយោងទៅតាមអ្នកវិទ្យាសាស្ត្រនយោបាយដែលបានបូកសរុបចំនួនសង្គ្រាម) គឺប្រទេសបារាំង រុស្ស៊ី និងអង់គ្លេស។ ចក្រភពអង់គ្លេសជាប្រទេសប្រជាធិបតេយ្យពេញរយៈពេល២០០ឆ្នាំនេះ បារាំងជាប្រទេសប្រជាធិបតេយ្យយូរដែរ ហើយរុស្ស៊ីមិនមែនជាប្រទេសប្រជាធិបតេយ្យឡើយ អត់ទាល់តែសោះហើយ។

អ្វីដែល*ជា*ការពិតអំពីលទ្ធិប្រជាធិបតេយ្យគឺថា ទោះបីពួកគេធ្វើសង្គ្រាមប្រឆាំងនឹងរដ្ឋផ្តាច់ការក៏ដោយ *ក៏លទ្ធិប្រជាធិបតេយ្យស្ទើរតែមិនដែលច្បាំងនឹងគ្នា*ដែរ។ គ្មានករណីប្រវត្តិសាស្ត្រធំដុំណាមួយបង្ហាញផ្ទុយពីការធ្វើទូទៅនីយកម្មនេះឡើយ។ ការអះអាងនេះត្រូវបានគេស្គាល់ថាជា**សន្តិប្រជាធិបតេយ្យ**។ ហេតុអ្វីបានជាការអះអាងដូច្នេះមិនច្បាស់លាស់ទាំងស្រុង។ ដោយសារមិនមានប្រទេសប្រជាធិបតេយ្យច្រើន អស់រយៈពេលជាយូរមកហើយ ការធ្វើទូទៅនីយកម្មបែបនេះអាចគ្រាន់តែជាការចៃដន្យប៉ុណ្ណោះ ទោះបីជាវាហាក់ដូចជាមិនទំនងក៏ដោយ។ ប្រហែលជាលទ្ធិប្រជាធិបតេយ្យមិនមានទំនោរចង់បង្កជម្លោះធ្ងន់ធ្ងរជាមួយគ្នាទេ ដោយសារតែពួកគេតាមធម្មតាជារដ្ឋមូលធននិយម ដែលទំនាក់ទំនងពាណិជ្ជកម្មបណ្តាលអោយការពឹងពាក់គ្នាទៅវិញទៅមកខ្លាំង (សង្គ្រាមនឹងត្រូវចំណាយច្រើនអនេក ព្រោះវានឹងរំខានដល់សកម្មភាពពាណិជ្ជកម្ម)។ ឬក៏ដោយសារប្រជាពលរដ្ឋនៃសង្គមប្រជាធិបតេយ្យ (មានគាំទ្រពីមហាជនទើបអាចប្រកាសធ្វើសង្គ្រាមបាន) ប្រហែលជាមិនមើលឃើញពលរដ្ឋនៃលទ្ធិប្រជាធិបតេយ្យផ្សេងទៀត ជាសត្រូវរបស់ខ្លួននោះទេ។ ផ្ទុយទៅវិញ រដ្ឋាភិបាលផ្តាច់ការនៃរដ្ឋផ្សេងទៀត*អាច*ត្រូវបានគេមើលឃើញថាជាសត្រូវ។ ចូរកត់សម្គាល់ថាសន្តិភាពក្នុងចំណោមប្រទេសប្រជាធិបតេយ្យផ្តល់ការគាំទ្រជាក់ស្តែង ដល់អំណះអំណាងសេរីនិយមជាយូរយារមកហើយថា ដោយសារតែវាត្រូវបានចាក់ឫសយ៉ាងជ្រៅនៅក្នុងកម្រិតនៃការវិភាគក្នុងស្រុក វាផ្ទុយពីការអះអាងរបស់ទ្រឹស្តីប្រាកដនិយមដែលថា ការពន្យល់សំខាន់បំផុតគឺនៅកម្រិតប្រព័ន្ធ។

ក្នុងរយៈពេលពីរសតវត្សរ៍កន្លងមកនេះ លទ្ធិប្រជាធិបតេយ្យកាន់តែរីករាលដាលខ្លាំង ក្នុងទម្រង់ជារដ្ឋាភិបាល ហើយនិន្នាការនេះកំពុងផ្លាស់ប្តូរលក្ខណៈនៃដំណើរការគោលនយោបាយការបរទេស នៅទូទាំងពិភពលោក។ ក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយ និន្នាការនេះបង្កើនល្បឿនកាន់តែខ្លាំង តាមរយៈមធ្យោបាយមួយចំនួន។ ប្រទេសលទ្ធិប្រជាធិបតេយ្យថ្មីថ្មោងបានលេចឡើងនៅក្នុងរដ្ឋមួយចំនួន (ទោះបីជាមិនទាំងអស់) នៃអតីតសហភាពសូវៀត។ រដ្ឋាភិបាលយោធាបានផ្តល់មធ្យោបាយដល់រដ្ឋាភិបាលស៊ីវិលដែលជាប់ឆ្នោត តាមបែបប្រជាធិបតេយ្យ នៅទូទាំងផ្នែកភាគច្រើននៃអាមេរិកឡាទីន ក៏ដូចជា នៅក្នុងប្រទេសអាហ្វ្រិកនិងអាស៊ីមួយចំនួន។ អាហ្វ្រិកខាងត្បូង ដែលជាប្រទេសអាហ្វ្រិកចុងក្រោយបង្អស់ដែលគ្រប់គ្រងដោយជនជាតិស្បែកស បានអនុម័តការគ្រប់គ្រងដោយមតិភាគច្រើន ក្នុងឆ្នាំ ១៩៩៤។ នៅចុងទសវត្សរ៍ឆ្នាំ ១៩៩០ លទ្ធិប្រជាធិបតេយ្យបានជំនួសរបបផ្តាច់ការ ដែលមានរយៈពេលយូរនៅក្នុងប្រទេសឥណ្ឌូនេស៊ី និងប្រទេសនីហ្សេរីយ៉ា ដែលជាមហាប្រទេស ក្នុងតំបន់រៀងៗខ្លួន។ នៅឆ្នាំ ២០០៤-២០០៥ កងកម្លាំងនិយម

លទ្ធិប្រជាធិបតេយ្យ បានទទួលជោគជ័យ នៅប្រទេសអ៊ុយក្រែន ប្រទេសអាហ្វហ្គានីស្ថាន ប្រទេសអ៊ីរ៉ាក់ និងប្រទេសកៀហ្ស៊ីស្ថាន។ ក្នុងឆ្នាំ ២០០៨ រដ្ឋាភិបាលដែលគ្រប់គ្រងដោយយោធាប៉ាគីស្ថានបានចុះចេញពីតំណែងដើម្បីបើកផ្លូវអោយរបបជាប់ឆ្នោតតាមបែបប្រជាធិបតេយ្យចូលមកជំនួស។ ក្នុងឆ្នាំ ២០១២ ប្រទេសភូមាបានចាប់ផ្តើមការផ្លាស់ប្តូរឆ្ពោះទៅរកលទ្ធិប្រជាធិបតេយ្យ បន្ទាប់ពីការគ្រប់គ្រងដោយយោធាដ៏យោរយៅជាច្រើនទសវត្សរ៍។

រូបថត ប្រជាពលរដ្ឋហ្គាំប៊ីតំរង់ជួរបោះឆ្នោតសភា
ជំនោរប្រជាធិបតេយ្យ

ការកើនឡើងនៃចលនាប្រជាធិបតេយ្យ នៅទូទាំងពិភពលោក ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ បង្ហាញពីអំណាចនៃគំនិតប្រជាធិបតេយ្យ។ ដោយសារលទ្ធិប្រជាធិបតេយ្យកម្រនឹងតតាំងគ្នា ឬធ្វើសង្គ្រាមប្រឆាំងគ្នា លទ្ធិប្រជាធិបតេយ្យនៅទូទាំងពិភពលោកអាចនាំទៅរកសន្តិភាពយូរអង្វែង។ នៅទីនេះ ជនជាតិហ្គាំប៊ីចូលរួមបោះឆ្នោតសភា បន្ទាប់ពីការផ្លាស់ប្តូរទៅលទ្ធិប្រជាធិបតេយ្យឆ្នាំ ២០១៧ ។

នៅក្នុងឆ្នាំ ២០១១-២០១២ បដិវត្តន៍និទាឃរដូវនៅអារ៉ាប់ បានជំរុញអោយមានការផ្លាស់ប្តូររបបនៅក្នុងប្រទេសទុយនីស៊ី អេហ្ស៊ីប លីប៊ី និងយេម៉ែន។ ខណៈពេលដែលមានតែប្រទេសទុយនីស៊ីតែមួយគត់បានធ្វើដំណើរយ៉ាងរលូននៅលើវិធីឆ្ពោះទៅកាន់លទ្ធិប្រជាធិបតេយ្យ រដ្ឋផ្សេងទៀតបានជួបប្រទះការលំបាកយ៉ាងខ្លាំងក្នុងការបង្កើតការគ្រប់គ្រងតាមបែបប្រជាធិបតេយ្យ។ ទោះបីជាយ៉ាងណាក៏ដោយ រដ្ឋប្រហារយោធាបានកើតឡើង នៅប្រទេសនីហ្សេរីយ៉ា ក្នុងឆ្នាំ ២០១០, ហ្គីណេ-ប៊ីសូ និងម៉ាលី ក្នុងឆ្នាំ ២០១២, អេហ្ស៊ីប ក្នុងឆ្នាំ ២០១៣, ប្រទេសថៃក្នុងឆ្នាំ ២០១៤ និងហ្ស៊ីមបាវ៉េ ក្នុងឆ្នាំ ២០១៧។ ប្រទេសអ៊ីរ៉ង់មានការបន្លំការបោះឆ្នោត ក្នុងឆ្នាំ ២០០៩ ហើយបានបង្ក្រាបយ៉ាងឃោរឃៅលើអ្នកដែលតវ៉ាប្រឆាំង។ លើសពីនេះទៀតមានរដ្ឋជាច្រើនមិនទាន់មានរដ្ឋាភិបាលបែបប្រជាធិបតេយ្យនៅឡើយ (ធំបំផុតនោះគឺប្រទេសចិន)។

គួរអោយកត់សម្គាល់ផងដែរថា ប្រតិកម្មតបទៅនឹងសកលភាវូបនីយកម្ម នាពេលបច្ចុប្បន្ននេះ បានធ្វើអោយមានការព្រួយបារម្ភថា លទ្ធិប្រជាធិបតេយ្យកំពុងស្ថិតក្នុងហានិភ័យ នៅក្នុងប្រទេសរាប់ចាប់ពីប្រទេសទួរគី ដល់ ហ្វីលីពីន រហូតដល់ប្រទេសរុស្ស៊ី ដែលក្រុមប្រឆាំងនយោបាយត្រូវបានបំបិទមាត់ឬបញ្ចប់ជីវិត។ គេមិនច្បាស់នៅឡើយទេថា តើការផ្លាស់ប្តូរទាំងនេះ (ដែលមានសក្តានុពលធ្វើអោយខូចលទ្ធិប្រជាធិបតេយ្យ) នឹងមានឥទ្ធិពលលើគោលនយោបាយការបរទេសដោយរបៀបណា។ ប្រសិនបើការអះអាងរបស់លោកកានត៍ត្រឹមត្រូវ ដំណើរបញ្ច្រាសនៃការរីកចម្រើនផ្នែកលទ្ធិប្រជាធិបតេយ្យអាចនាំអោយមានជម្លោះអន្តរជាតិកាន់តែច្រើនៗ។

ទោះបីជាប្រទេសកាន់លទ្ធិប្រជាធិបតេយ្យចាស់ទុំស្ទើរតែមិនដែលឈ្លោះគ្នាក៏ដោយ សម័យ*អន្តរកាល*ឆ្ពោះទៅកាន់លទ្ធិប្រជាធិបតេយ្យ អាចងាយនឹងផ្ទុះសង្គ្រាម បើប្រៀបធៀបទៅនឹងប្រទេសលទ្ធិប្រជាធិបតេយ្យដែលមានស្ថិរភាព ឬរដ្ឋាភិបាលផ្តាច់ការដែលមានស្ថិរភាព។ ដូច្នេះ ដំណើរការនៃការធ្វើលទ្ធិប្រជាធិបតេយ្យមិនមែនសុទ្ធតែជារឿងល្អសម្រាប់សន្តិភាព ក្នុងរយៈពេលខ្លីនោះទេ។ ទ្រឹស្តីនេះបានទទួលការគាំទ្រច្រើននៅដើមឆ្នាំ ២០០៦ នៅពេលដែលការបោះឆ្នោតនៅអ៊ីរ៉ាក់ ត្រូវបានតាមពីក្រោយដោយការកើនឡើងនៃអំពើហិង្សានិកាយសាសនា, និងបន្ទាប់មកការបោះឆ្នោតប៉ាឡេស្ទីនបាននាំយកអំណាចអោយក្រុមសកម្មប្រយុទ្ធ*ហាម៉ាស់*ដែលបដិសេធសិទ្ធិមានជីវិតរបស់អ៊ីស្រាអែល។ ក្នុងឆ្នាំ ២០១៧ រដ្ឋាភិបាលដែលទើបជាប់ឆ្នោតភូមា

ថ្មីៗនេះបានបញ្ចេញនូវការឆ្លើយតបដោយហឹង្សាប្រឆាំងនឹងជនជាតិភាគតិច នៅក្នុងប្រទេសនោះ ដែលអ្នកខ្លះបានចាត់ទុកការប្រល័យពូជសាសន៍។

ជាចុងក្រោយ ត្រូវកត់សម្គាល់ថា ខណៈពេលដែលលទ្ធិប្រជាធិបតេយ្យ ជារឿយៗត្រូវបានផ្សារភ្ជាប់ជាមួយនឹងសន្តិភាពនិងកិច្ចសហប្រតិបត្តិការ ស្ថាប័នប្រជាធិបតេយ្យអាចធ្វើអោយកិច្ចសហប្រតិបត្តិការកាន់តែលំបាក។ ជាឧទាហរណ៍ សម្ពាធសម្រាប់ការដំឡើងពន្ធពាណិជ្ជកម្ម ជារឿយៗ កើតឡើងពីសភាដែលជាប់ឆ្នោតតាមបែបប្រជាធិបតេយ្យ។ ប្រទេសប្រជាធិបតេយ្យខ្លះអាចនឹងបរាជ័យ ក្នុងការចូលរួមជាមួយអង្គការអន្តរជាតិដោយសារតែការប្រឆាំងនៅក្នុងស្រុក ដូចករណីរបស់សហរដ្ឋអាមេរិកនិងសម្ព័ន្ធប្រជាជាតិ ក្រោយសង្គ្រាមលោកលើកទី ១ (សូមមើលមេរៀនទី ១)។ ការប្រឆាំងរបស់សាធារណៈជនក៏អាចបណ្តាលអោយរដ្ឋនានាបញ្ចប់កិច្ចសហប្រតិបត្តិការជាមួយនឹងអង្គការដែលមានស្រាប់ផងដែរ ដូចជានៅពេលដែលចក្រភពអង់គ្លេសបោះឆ្នោតប្រជាមតិចាកចេញពីសហភាពអឺរ៉ុប (សូមមើលមេរៀនទី ១០)។ ដូច្នេះ ខណៈពេលដែលអ្នកប្រាជ្ញសេរីនិយមតែងតែលើកតម្កើងគុណធម៌នៃលទ្ធិប្រជាធិបតេយ្យ បណ្តាស្ថាប័នក្នុងស្រុកដដែលនេះក៏អាចធ្វើអោយដំណើរការនៃកិច្ចសហប្រតិបត្តិការអន្តរជាតិកាន់តែស្មុគស្មាញ។

ដូច្នេះទ្រឹស្តីសេរីនិយមផ្តល់នូវជម្រើសជាច្រើនក្រៅពីទ្រឹស្តីប្រាកដនិយមដែលផ្អែកលើអំណាច។ ទ្រឹស្តីសេរីនិយមស្ទើរតែទាំងអស់ផ្តោតលើការដោះស្រាយបញ្ហាផលប្រយោជន៍រួម ដោយប្រើគោលការណ៍បដិការ។ មិនថាដោយសារស្ថាប័នអន្តរជាតិ ឬក្នុងស្រុកទេ រដ្ឋនានា រំពឹងថានឹងមានអាកប្បកិរិយាតបតទៅវិញទៅមកទាក់ទងនឹងកិច្ចសហប្រតិបត្តិការពីរដ្ឋផ្សេងទៀត។ តាមរបៀបនេះ ការគណនាផលប្រយោជន៍របស់ពួកគេប្រែពីកង្វល់រយៈពេលខ្លីទៅជាការពិចារណារយៈពេលវែង។ ផ្នែកបន្ទាប់ យើងពិនិត្យមើលជម្រើសមួយផ្សេងទៀតក្រៅពីទ្រឹស្តីប្រាកដនិយម ដែលផ្តោតលើគោលការណ៍អត្តសញ្ញាណ។

៣.៣. ទ្រឹស្តីសង្គម

៣.៣ ចូរបង្ហាញពីរបៀបដែលទ្រឹស្តីសង្គម អាចពន្យល់ពីរបៀបដែលប្រទេសពីរផ្លាស់ប្តូរពីគូប្រកួតប្រជែងក្លាយទៅជាសម្ព័ន្ធមិត្តនឹងគ្នា ។

គោលការណ៍ផ្សេងៗគ្នាជាច្រើននៅក្នុងទ្រឹស្តីទំនាក់ទំនងអន្តរជាតិ អាចត្រូវបានដាក់ជាក្រុមរួមតែមួយដោយហៅថា*ទ្រឹស្តីសង្គម* មានន័យថាពួកគេពឹងផ្អែកលើអន្តរកម្មឬទំនាក់ទំនងក្នុងសង្គម ដើម្បីពន្យល់ពីចំណងចំណូលចិត្តរបស់បុគ្គលនិងរដ្ឋណាមួយ។ ទ្រឹស្តីទាំងនេះផ្ទុយពីការសន្មតអំពីចំណង់ចំណូលចិត្តថេរ និងទៀងទាត់គ្រប់ពេលវេលានៅក្នុងទ្រឹស្តីភាគច្រើនដែលពឹងផ្អែកលើទ្រឹស្តីប្រាកដនិយម (រដ្ឋចង់បានអំណាចកាន់តែខ្លាំងកាន់តែល្អ) និងទ្រឹស្តីសេរីនិយម(រដ្ឋ ក្រុមផលប្រយោជន៍ និងបុគ្គលនានាប្រាថ្នាចង់បានសន្តិភាព និងវិបុលភាព)។

ទ្រឹស្តីស្ថាបនានិយម(Constructivism) ដែលជាគោលការណ៍រីកចម្រើនយ៉ាងឆាប់រហ័ស នៅក្នុងទំនាក់ទំនងអន្តរជាតិ សាកសួរអំពីរបៀបដែលរដ្ឋទាំងឡាយស្ថាបនាឬស្វែងផលប្រយោជន៍របស់ពួកគេតាមរយៈអន្តរកម្មរបស់ពួកគេជាមួយនឹងគ្នាទៅវិញទៅមក។ មែនទែនទៅ វាត្រូវបានចាត់ទុកថាជាគោលការណ៍ជាជាងទ្រឹស្តីមួយ ពីព្រោះនៅពេលដែលគេត្រួតពិនិត្យស្នូលរបស់វា វាមិននិយាយទាក់ទងអ្វីអំពី ទំនាក់ទំនងអន្តរជាតិសោះឡើយ។ ទោះជាយ៉ាងណាក៏ដោយ ខ្លឹមសារមេរៀនសំខាន់ៗរបស់វាស្តីពីធម្មជាតិនៃបទដ្ឋានអត្តសញ្ញាណ និងអន្តរកម្មសង្គមអាចជួយអោយគេយល់ដឹងកាន់តែច្បាស់អំពីពិភពនៃទំនាក់ទំនងអន្តរជាតិ។

ជាការពិត ការពន្យល់របស់អ្នកស្ថាបនានិយមភាគច្រើនពឹងផ្អែកយ៉ាងខ្លាំង លើគោលការណ៍អត្តសញ្ញាណ ដើម្បីពន្យល់អំពីអាកប្បកិរិយាអន្តរជាតិ។

៣.៣.១. អត្តសញ្ញាណ និងបញ្ហាឧស្សនៈ

ទ្រឹស្តីស្ថាបនានិយមចាប់អារម្មណ៍លើរបៀបដែលតួអង្គទាំងឡាយកំណត់ផលប្រយោជន៍ជាតិរបស់ខ្លួន, ការគំរាមកំហែងដល់ផលប្រយោជន៍ជាតិទាំងនោះ, និងទំនាក់ទំនងផលប្រយោជន៍របស់ពួកគេ ចំពោះគ្នាទៅវិញទៅមក។ អ្នកប្រាជ្ញទ្រឹស្តីប្រាកដនិយម (និងអ្នកប្រាជ្ញទ្រឹស្តីសេរីនិយមថ្មី) តែងតែមានទំនោរទទួលស្គាល់ថា ផលប្រយោជន៍របស់រដ្ឋជារបស់ពិតជាក់ស្តែង។ ដូច្នេះ ទ្រឹស្តីស្ថាបនានិយមនាំអោយយើងសម្លឹងមើលទំនាក់ទំនងអន្តរជាតិ នៅក្នុងបរិបទនៃទំនាក់ទំនងសង្គមដ៏ទូលំទូលាយ។ រដ្ឋនានាសម្រេចចិត្តខ្លួនត្រូវអ្វីមួយដោយផ្អែកមិនត្រឹមតែលើតម្រូវការសម្ភារៈប៉ុណ្ណោះទេ ថែមទាំងលើអន្តរកម្ម«សង្គម»ផងដែរ។ ដូចដែលអតិថិជនអាចសម្រេចចិត្តទិញនាឡិកាឆ្លាតវៃណាមួយ ព្រោះពេលពាក់វាទៅគេមើលទៅឡូយឆាយខ្លាំង (មានន័យថាសង្គមទទួលស្គាល់វាកាន់តែទូលំទូលាយ) ដូច្នេះហើយរដ្ឋអាចនឹងជ្រើសរើសគោលនយោបាយដោយផ្អែកលើអ្វីដែលពួកគេយល់ថានឹង«ពេញនិយម»ក្នុងចំណោមរដ្ឋជាច្រើនផ្សេងទៀត។ ដោយឡែក ដូចដែលហោប៉ៅលុយរបស់អតិថិជនមានកំរិតក្នុងការទិញនាឡិកាឆ្លាតវៃណាមួយ (ធនធានមានកំណត់) អ្នកទ្រឹស្តីស្ថាបនានិយមក៏ទទួលស្គាល់ថាអំណាច មិនមែនអវត្តមានពីទំនាក់ទំនងអន្តរជាតិដែរ។

ការស្រាវជ្រាវរបស់អ្នកស្ថាបនានិយមមានទិដ្ឋភាពជាច្រើន។ ទិដ្ឋភាពដ៏លេចធ្លោជាងគេមួយពិនិត្យមើលពីរបៀបដែលផលប្រយោជន៍និងអត្តសញ្ញាណរបស់រដ្ឋ ជាប់ទាក់ទងគ្នាយ៉ាងដូចម្តេច ក៏ដូចជារបៀបដែលអត្តសញ្ញាណទាំងនោះត្រូវបានកំណត់ដោយអន្តរកម្មជាមួយរដ្ឋផ្សេងទៀត។ ជាឧទាហរណ៍ ហេតុអ្វីបានជាសហរដ្ឋអាមេរិកព្រួយបារម្ភខ្លាំង នៅពេលកូរ៉េខាងជើងបង្កើតអាវុធនុយក្លេអ៊ែរ ប៉ុន្តែ នៅពេលដែលចក្រភពអង់គ្លេសធ្វើដែរ បែរជាអាមេរិកមិនខ្វាយខ្វល់? អ្នកប្រាកដនិយមនឹងឆ្លើយភ្លាមៗថា កូរ៉េខាងជើងបង្កការគំរាមកំហែងនិងគ្រោះថ្នាក់ជាង ប៉ុន្តែ តាមសម្លឹងមើលត្រឹមតែអំណាចយោធា ចក្រភពអង់គ្លេសមានអានុភាពយោធាដ៏ធំជាងប្រទេសកូរ៉េខាងជើង*ជាច់*។ ទោះបីជាយ៉ាងណាក៏ដោយ គ្មាននរណាម្នាក់គិតនិងអះអាងថាចក្រភពអង់គ្លេសបង្កការគំរាមកំហែងដល់សហរដ្ឋអាមេរិកនោះទេ បើទោះបីជាវាផលិតអាវុធនុយក្លេអ៊ែរច្រើនយ៉ាងណាក៏ដោយ និងទោះបីពួកគេមានការខ្វែងគំនិតគ្នាលើគោលនយោបាយការបរទេសយ៉ាងស្រួចស្រាល់យ៉ាងណាកដោយ។ អ្នកប្រាជ្ញស្ថាបនានិយមនឹងចង្អុលបង្ហាញថាប្រវត្តិសាស្ត្ររួម សម្ព័ន្ធភាពរួម និងបទដ្ឋានរួមដែលរម្លឹកប្រាប់ជនជាតិអាមេរិក និងជនជាតិអង់គ្លេសថា ពួកគេមិនមែនជាការគំរាមកំហែងដល់គ្នាទៅវិញទៅមកទេ ទោះបីជាពួកគេមានកម្លាំងយោធាខ្លាំងក៏ដោយ។

អត្តសញ្ញាណរបស់(រដ្ឋដែលអាចក្លាយជា)សត្រូវជារឿងសំខាន់ មិនត្រឹមតែសមត្ថភាពយោធានិងផលប្រយោជន៍នៃរដ្ឋនោះប៉ុណ្ណោះទេ។ នេះគឺជាការបដិសេធទៅលើការសន្មតរបស់អ្នកទ្រឹស្តីប្រាកដនិយមដែលថារដ្ឋទាំងឡាយតែងតែចង់បានអំណាចនិងទ្រព្យសម្បត្តិច្រើនជាង(មិនចង់បានតិចជាងគេទេ) ក៏ដូចជាការបដិសេធលើការសន្មតថារដ្ឋមានអត្តិភាព ដោយឯករាជ្យពីបរិបទនៃអន្តរកម្មរវាងរដ្ឋនានា។ អ្នកទ្រឹស្តីស្ថាបនានិយម អះអាងថាអត្តសញ្ញាណរដ្ឋទាំងនេះមានភាពស្មុគ្រស្មាញនិងអាចផ្លាស់ប្តូរ ហើយកើតចេញពីអន្តរកម្មជាមួយរដ្ឋផ្សេងទៀត, ជារឿយៗ តាមរយៈដំណើរការនៃសង្គមភាវូបនីយកម្ម។ អ្នកប្រាជ្ញទ្រឹស្តីស្ថាបនានិយមខ្លះបានប្រកែកថា យូរៗទៅ រដ្ឋទាំងអស់អាចយល់ចិត្តគ្នាទៅវិញទៅមក ដូច្នេះ នឹងមិនមើលឃើញថា

គ្រោះថ្នាក់ដោយសារតែទ្វេគ្រោះសន្តិសុខ ការប្រណាំងប្រជែងសព្វវុធ ឬក៏ឥទ្ធិពលផ្សេងទៀតនៃភាពអនាធិបតេយ្យ។ ពួកគេចង្អុលបង្ហាញទៅអឺរ៉ុបដើម្បីជាឧទាហរណ៍ៈ ជាទ្វីបដែលជាសមរភូមិក្តៅ នៃមហាជម្លោះយោធាចំនួនពីរ នៅក្នុងពាក់កណ្តាលទីមួយនៃសតវត្សរ៍ទី ២០ ដែលបានសម្លាប់មនុស្សរាប់លាននាក់។ នៅត្រឹមចុងសតវត្សរ៍នោះ សង្គ្រាមបានក្លាយទៅជារឿងមួយហួសចិត្តនឹកស្មានមិនដល់។ ឥឡូវនេះ អត្តសញ្ញាណអឺរ៉ុបត្រូវបានផ្សារភ្ជាប់ជាមួយនឹងសហភាពអឺរ៉ុប មិនមែនជាមួយនឹងជាតិនិយមដ៏ហឹង្សាដែលបានបណ្តាលអោយផ្ទុះសង្គ្រាមលោកទាំងពីរនោះទេ។ ចំពោះអ្នកទ្រឹស្តីប្រាកដនិយម, នយោបាយអំណាច អនាធិបតេយ្យ និងកម្លាំងយោធា មិនអាចពន្យល់ពីការផ្លាស់ប្តូរនេះបានទេ។ ពួកគេមើលឃើញ ស្ថាប័ន, របប, បទដ្ឋាន, និងការផ្លាស់ប្តូរអត្តសញ្ញាណគឺជាកត្តាពន្យល់បានល្អប្រសើរជាង។

សង្គមទាំងមូល ក៏ផ្លាស់ប្តូរទៅតាមពេលវេលា នៅក្នុងអ្វីដែលពួកគេចាត់ទុកថាជាការគំរាមកំហែង។ ពីរយឆ្នាំមុន ចោរសមុទ្រគឺជាប្រភពនៃការគំរាមកំហែងនៅ លំហសមុទ្រជ្រៅៗ។ តួអង្គមិនមែនរដ្ឋទាំងនេះបានលុកលុយកំពង់ផែ ឆក់ប្លន់ទំនិញ ប្រព្រឹត្តឃាតកម្ម និងបានបង្កួតសំញែងគ្មានក្រែងអោរអាជ្ញាធរអន្តរជាតិណាឡើយ។ អាកប្បកិរិយាបែបនេះអាចត្រូវចាត់ទុកថាជា អំពើកេរ្តកម្មពេញទំហឹង ទោះបីជាចោរសមុទ្រមិនមានគោលដៅនយោបាយក្នុងអំពើហឹង្សារបស់ពួកគេក៏ដោយ។ បើទោះបីមិនមែនជាអំពើកេរ្តកម្មក៏ដោយ ក៏គ្មាននរណាម្នាក់សង្ស័យពីទំហំធំធេងនៃការខាតបង់ ដោយសារតែអំពើឆក់ប្លន់ទាំងនេះដែរ។ រដ្ឋជាច្រើនរួមទាំងសហរដ្ឋអាមេរិកបានប្រើប្រាស់កងទ័ពជើងទឹករបស់ពួកគេ ដើម្បីព្យាយាមលុបបំបាត់អំពើចោរតាមសមុទ្រ។ ជាប្រវត្តិសាស្ត្រ បើទោះបីជាមានភាពគ្រោះថ្នាក់និងការខាតបង់ ដែលបង្កឡើង ដោយតួអង្គទាំងនេះក៏ដោយ បច្ចុប្បន្ននេះ យើងអបអរចោរសមុទ្រដោយស្លៀកពាក់ជាម៉ាស្កូត(ទឹងមោង)សារទរការប្រកួតកីឡា, ជាក់ឈ្មោះកន្លែងជិះទោងកម្សាន្តតាមពួកគេ និងលើកតម្កើងពួកគេនៅក្នុងខ្សែភាពយន្ត។

រូបថត *ស្ត្រីអារ៉ាប៊ីសាអូឌីតទិញរថយន្តថ្មី ក្រោយរដ្ឋលើកលែងការហាមឃាត់*

ការស្ថាបនានិងផ្លាស់ប្តូរអត្តសញ្ញាណ

គោលការណ៍អ្នកប្រាជ្ញទ្រឹស្តីស្ថាបនានិយម ដោយផ្អែកលើគោលការណ៍ស្នូលនៃអត្តសញ្ញាណ មើលឃើញចំណូលចិត្តឬការនិយមរបស់តួអង្គថាជាការបង្កើតឡើងដោយតួអង្គនានា ជាជាងត្រូវបានផ្តល់ អោយដោយ«គោលបំណង»ជាក់លាក់ណាមួយ។ គោលការណ៍ទាំងនេះអាចប្រសើរជាងគោលការណ៍អ្នកទ្រឹស្តីប្រាកដនិយមឬអ្នកទ្រឹស្តីសេរីនិយម ក្នុងការពន្យល់ពីការផ្លាស់ប្តូរសំខាន់ៗ នៅក្នុងគោលដៅនិងទិដ្ឋភាពនៃគោលនយោបាយការបរទេសរបស់រដ្ឋនៅក្នុងពិភពលោក ដែលកើតឡើងពីការផ្លាស់ប្តូរផ្ទៃក្នុង និងគំនិតខ្លួនឯងថ្មី ជាជាងឧបសគ្គឬឱកាសខាងក្រៅ។ គោលនយោបាយការបរទេសរបស់អារ៉ាប៊ីសាអូឌីត រងឥទ្ធិពលយ៉ាងខ្លាំងដោយអត្តសញ្ញាណរបស់ខ្លួន ក្នុងនាមជារដ្ឋអភិរក្សនិយមនិងជារដ្ឋនៃបណ្តាជនមូស្លីមភាគច្រើនបំផុត។ ទោះយ៉ាងណាក៏ដោយ អ្នកស្ថាបនានិយមសង្កត់ធ្ងន់ថា បទដ្ឋាន និងអត្តសញ្ញាណអាចផ្លាស់ប្តូរ តាមពេលវេលា។ នៅទីនេះ ស្ត្រីអារ៉ាប៊ីសាអូឌីតទិញរថយន្តនៅចេដ្ដាហ៍ (Jeddah) បន្ទាប់ពីរដ្ឋាភិបាលអារ៉ាប៊ីសាអូឌីតបានបញ្ចប់ការហាមឃាត់ស្ត្រីបើកបររថយន្តក្នុងឆ្នាំ ២០១៧ ។ អារ៉ាប៊ីសាអូឌីតធ្លាប់ជារដ្ឋតែមួយគត់ដែលបានហាមឃាត់ស្ត្រីមិនឱ្យបើកបរ។

ជាការពិតណាស់ គេអាចប្រកែកថាចោរសមុទ្រលែងជាការគំរាមកំហែងទៀតហើយ បើទោះបីជាអំពើឆក់ប្លន់ជាច្រើននៅតែកើតឡើងនៅលើផ្ទៃសមុទ្រជ្រៅៗក៏ដោយ។ សូម្បីតែក្រៅពីចោរសមុទ្រដ៏ល្បីល្បាញនៅ

ជិតប្រទេសសូម៉ាលី ក្នុងឆ្នាំ ២០០៨-២០០៩, ការគំរាមកំហែងពីអំពើឆក់ប្លន់លើផ្នែសមុទ្រនៅតែមានកម្រិតខ្ពស់ ក្នុងកំឡុងពេលជាច្រើនឆ្នាំមកហើយ។ ទោះជាយ៉ាងណាក៏ដោយ យើងហាក់ទទួលយកបានការបន្ធូរបន្ថយការគំរាមកំហែងនៃអំពើឆក់ប្លន់តាមសមុទ្រ ដោយការដាក់បញ្ចូលវាទៅក្នុងវប្បធម៌ប្រជាប្រិយ។ គ្មានអ្វីគួរអោយងឿងឆ្ងល់ទេ បើមនុស្សមកពីអតីតកាល កាលពីរសតវត្សរ៍មុន យល់ឃើញថាការទទួលយកបែបនេះចម្លែកខ្លាំងពេកហើយ។

តើគួរអោយចម្លែកយ៉ាងណាទៅ? ចូរស្រមៃថា ក្នុងរយៈពេល២០០ឆ្នាំខាងមុខ ចៅទួតចៅលារបស់អ្នកឡានលំអបែបកេរវែក នៅសួនកំសាន្តឌីសនីឡែន (Disneyland) ឬ ចូលរោងកុនមើលខ្សែភាពយន្តចុងក្រោយបំផុត ដែលមានចំណងជើងថា *«ភាវៈភរនៃឈូងសមុទ្រពែរ្ស»* (Terrorists of the Persian Gulf)។ អ្នកទ្រឹស្តីប្រាកដនិយមនឹងចង្អុលបង្ហាញភ្លាមៗថាអ្វីដែលសង្គម ឬ រដ្ឋណាមួយ ចាត់ទុកថាគ្រោះថ្នាក់ប្រាកដជាមិនមែនជាគ្រោះថ្នាក់សកលឬមិនចេះចប់ឡើយ។ បទដ្ឋាននិងប្រពៃណីសង្គម តែងតែផ្លាស់ប្តូរជានិច្ច ហើយបម្លាស់ប្តូរទាំងនេះអាចមានឥទ្ធិពលយ៉ាងខ្លាំងទៅលើគោលនយោបាយការបរទេស។

រដ្ឋទាំងឡាយក៏អាចអោយតម្លៃនិងប្រាថ្នាចង់បានអ្វីមួយ ដូចជា ឋានៈ ឬកេរ្តិ៍ឈ្មោះ ដែលជាបញ្ញត្តិសង្គម មិនមែនជាសម្ភារៈនិយមទេ។ ជាឧទាហរណ៍ ប្រទេសស្វីសអោយតម្លៃតួនាទីរបស់ខ្លួនជា *រដ្ឋអព្យាក្រឹត* មិនចូលបក្សសម្ព័ន្ធ (វាមិនមែនជាសមាជិកនៃសហភាពអឺរ៉ុប ឬ អង្គការណាតូ ទេ ហើយទើបបានចូល ជាសមាជិកអង្គការសហប្រជាជាតិ នៅក្នុងឆ្នាំ ២០០២ ប៉ុណ្ណោះ)។ ឋានៈជា*រដ្ឋអព្យាក្រឹត* ផ្តល់អោយប្រទេសស្វីសនូវកិត្យានុភាពនិងឥទ្ធិពលៈ នោះមិនមែនជាអំណាចខាងសម្ភារៈ ដូចជា លុយកាក់ ឬកាំភ្លើងទេ) ប៉ុន្តែជាអំណាចធៀបក្នុងការធ្វើអន្តរាគមន៍ការទូតក្នុងកិច្ចការអន្តរជាតិសំខាន់ៗ។ ដូចគ្នាដែរ គោលនយោបាយការបរទេសរបស់ប្រទេសកាណាដាមានការបង្គាប់បញ្ជា ដែលជំរុញដោយអត្តសញ្ញាណផ្ទាល់ខ្លួន ដែលជាធម្មតាពាក់ព័ន្ធតែនឹងប្រតិបត្តិការរក្សាសន្តិភាពនិងមនុស្សធម៌។

ទ្រឹស្តីផ្អែកលើអត្តសញ្ញាណទាំងនេះអាចជួយពន្យល់អំពីអាកប្បកិរិយារបស់ប្រទេសមហាអំណាច ផងដែរ។ នៅឆ្នាំ ១៩៩៣ ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិបានបង្កើតតុលាការឧក្រិដ្ឋកម្មសង្គ្រាមសម្រាប់អតីតប្រទេសយូហ្គោស្លាវី។ ប្រសិទ្ធភាពរបស់វានៅមានកម្រិតនៅក្នុងប៉ុន្មានឆ្នាំដំបូង ដោយសារកង្វះមូលនិធិចាំបាច់សម្រាប់ជួលអ្នកស៊ើបអង្កេត និងអ្នកបកប្រែ ជួលការិយាល័យ និងប្រព័ន្ធទូរស័ព្ទ ជាដើម។ ការរួមវិភាគទានរបស់ប្រទេសមហាអំណាចក្នុងការគាំទ្រដល់សាលាក្តីមានកម្រិតខុសៗគ្នា ក្នុងនោះប្រទេសសហរដ្ឋអាមេរិកបានផ្តល់ការគាំទ្រច្រើនបំផុត (ទោះបីជានៅតែមិនគ្រប់គ្រាន់តាមតម្រូវការក្តី) និងចក្រភពអង់គ្លេសផ្តល់តិចតួចមែនទែន។

អ្នកប្រាជ្ញទ្រឹស្តីសេរីនិយមនឹងកត់សម្គាល់ឃើញភ្លាមៗនូវបញ្ហាផលប្រយោជន៍ រួមក្នុងការរួមវិភាគទានសម្រាប់សាលាក្តីនោះ។ សហគមន៍ពិភពលោកនឹងទទួលបានអត្ថប្រយោជន៍ពីការងាររបស់សាលាក្តី (ដូរាបណាវាអាចរារាំងការឈ្លានពាន និងអំពើប្រល័យពូជសាសន៍ នាពេលអនាគត) ប៉ុន្តែ រដ្ឋនីមួយៗទទួលបានអត្ថប្រយោជន៍នេះ (ទោះជាអត្ថប្រយោជន៍នោះជាអ្វីឬមានទំហំប៉ុណ្ណាក៏ដោយ) ដោយមិនគិតពីកំរិតនៃការចូលរួមចំណែករបស់រដ្ឋនីមួយៗឡើយ។ តាមតក្កវិជ្ជានេះ ចក្រភពអង់គ្លេសបានប្រព្រឹត្តដោយសមហេតុផលក្នុងការជិះលែងដៃ ពីព្រោះសហរដ្ឋអាមេរិក និងប្រទេសដទៃទៀតមានឆន្ទៈក្នុងការរ៉ាប់រងការចំណាយ ដើម្បីធ្វើអោយសាលាក្តីមានប្រសិទ្ធភាព យ៉ាងហោចណាស់ ក៏បានក្នុងកម្រិតអប្បរមាដែរ។

អ្នកប្រាជ្ញប្រាកដនិយមអាចនឹងចោទសួរពីការពន្យល់បែបនេះផងដែរ។ ពួកគេអាចនឹងមើលឃើញកង្វះការគាំទ្ររបស់ចក្រភពអង់គ្លេស ដោយហេតុផលត្រង់ៗជាងនេះ៖ មេដឹកនាំអង់គ្លេសប្រហែលជាមិនចង់ឃើញសាលាក្តីនេះទទួលបានជោគជ័យនោះទេ ដោយសារតែចក្រភពអង់គ្លេសបានចូលខាងស៊ែប៊ី (ដែលជាសម្ព័ន្ធមិត្តប្រពៃណី) ហើយប្រទេសស៊ែប៊ីមិនបានសហការជាមួយសាលាក្តីដែលបានចោទប្រកាន់មេដឹកនាំស៊ែបនៅបូស្នៀថាជាឧក្រិដ្ឋជនសង្គ្រាម។ កត្តាភូមិសាស្ត្រនយោបាយដដែលនេះ ដែលនាំអោយចក្រភពអង់គ្លេស កាលពីអតីតកាល ងាកទៅរកស៊ែប៊ី (និងរុស្ស៊ី និងបារាំង) ទល់នឹងក្រូអាស៊ី (និងអាឡឺម៉ង់ អូទ្រីស និងទួរគី) នៅតែដំណើរការក្នុងពេលនោះ។ ដោយហេតុផលនេះ ឧក្រិដ្ឋកម្មសង្គ្រាមមានទៅមានមក ប៉ុន្តែផលប្រយោជន៍មហាអំណាចនៅតែរក្សាអោយបានស្ថិតថេរជានិរន្តរ៍។

ទ្រឹស្តីទាំងពីរនេះហាក់ដូចជា មានគុណសម្បត្តិរៀងៗខ្លួន ប៉ុន្តែ ជួនកាល ប្រវត្តិសាស្ត្រផ្តល់នូវ«ការពិសោធន៍» ទោះបីជាយើងមិនអាចគ្រប់គ្រងវាក៏ដោយ ក៏ជួយសម្រួលការពន្យល់ដោយទ្រឹស្តីដែលជាគូប្រជែងនឹងគ្នា។ ក្នុងករណីនេះ នៅឆ្នាំ ១៩៩៧ រដ្ឋាភិបាលសេរី ដែលដឹកនាំដោយលោកនាយករដ្ឋមន្ត្រី តូនី ប្លែរ(Tony Blair) ដែលចូលជំនួសរដ្ឋាភិបាលអភិរក្សនិយមរបស់លោក ចន មេយ៉ារ(John Major)។ ការផ្លាស់ប្តូរនេះមិនប៉ះពាល់ដល់«អថេរ»សម្រាប់ពន្យល់ ដោយទ្រឹស្តីណាមួយឡើយ៖ លក្ខណៈនៃបញ្ហាផលប្រយោជន៍រួមនៅក្នុងសាលាក្តី និងធម្មជាតិនៃផលប្រយោជន៍ជាយុទ្ធសាស្ត្រនិងប្រវត្តិសាស្ត្រ និងសម្ព័ន្ធភាពរបស់ចក្រភពអង់គ្លេស នៅក្នុងតំបន់បាល់កង់។ ប៉ុន្តែ តាមពិត រដ្ឋាភិបាលរបស់លោក តូនី ប្លែរ បានផ្លាស់ប្តូរគោលនយោបាយបូស្នៀរបស់ខ្លួន យ៉ាងខ្លាំង ដោយដឹកនាំការវាយធ្នក់ដើម្បីចាប់ខ្លួនជនសង្ស័យឧក្រិដ្ឋកម្មសង្គ្រាមពីរនាក់ និងបានរួមចំណែកថវិកាយ៉ាងច្រើនសម្រាប់សាលាក្តីក្នុងការសាងសង់បន្ទប់សវនាការទីពីរ។ ប្រការដែលថា ការផ្លាស់ប្តូរមេដឹកនាំនយោបាយបានផ្លាស់ប្តូរអាកប្បកិរិយារបស់ប្រទេសអង់គ្លេស បង្ហាញថាការពន្យល់ដោយផ្អែកលើអត្តសញ្ញាណមានតួនាទីមួយចំនួន៖ គំនិតរបស់លោក តូនី ប្លែរ អំពីតួនាទីរបស់ចក្រភពអង់គ្លេស នៅក្នុងសហគមន៍អន្តរជាតិ បានជំរុញអោយមានលទ្ធផលដូចក្នុងករណីនេះ។

វិស័យស្រាវជ្រាវបែបស្ថាបនានិយមមួយទៀតក៏ពឹងផ្អែកខ្លាំងលើបទដ្ឋានអន្តរជាតិ និងអំណាចរបស់វាក្នុងការរារាំងសកម្មភាពរបស់រដ្ឋ។ បើទោះបីជាអ្នកប្រាជ្ញប្រាកដនិយម (និង អ្នកប្រាជ្ញសេរីនិយមថ្មី) ជំទាស់ថារដ្ឋធ្វើការសម្រេចចិត្តដោយផ្អែកលើ*តក្កវិជ្ជានៃផលវិបាក* (*logic of consequences*)៖ «តើនឹងមានអ្វីកើតឡើងចំពោះខ្ញុំ ប្រសិនបើខ្ញុំប្រព្រឹត្តទង្វើបែបនេះ?», អ្នកប្រាជ្ញស្ថាបនានិយមកត់សម្គាល់ថា មាន*តក្កវិជ្ជានៃភាពសមរម្យ* (*logic of appropriateness*)ដែលមានឥទ្ធិពលខ្លាំង៖ «តើខ្ញុំគួរប្រព្រឹត្តទង្វើបែបណា នៅក្នុងស្ថានភាពបែបនេះ?»។ ជាឧទាហរណ៍ ករណីអន្តរាគមន៍មនុស្សធម៌ខ្លះ (អន្តរាគមន៍យោធាដោយរដ្ឋណាមួយឬច្រើន ដើម្បីការពារប្រជាពលរដ្ឋ ឬប្រជារាស្ត្រនៃរដ្ឋមួយផ្សេងទៀត)ហាក់ដូចជាពិបាកពន្យល់ក្នុងន័យប្រាកដនិយម ឬសេរីនិយម។ ជាឧទាហរណ៍ ហេតុអ្វីបានជាសហរដ្ឋអាមេរិក នៅក្នុងឆ្នាំ ១៩៩២ បានបញ្ជូនកងទ័ពទៅកាន់ប្រទេសសូម៉ាលី ដែលជាប្រទេសដែលមានសារៈសំខាន់ជាយុទ្ធសាស្ត្រនិងសេដ្ឋកិច្ចតិចតួចបំផុតសម្រាប់សហរដ្ឋអាមេរិក នៅពេលដែលប្រទេសសូម៉ាលីបានធ្លាក់ចូលទៅក្នុងភាពវឹកវរផ្នែកនយោបាយ ហើយប្រឈមមុខនឹងលទ្ធភាពនៃគ្រោះទុរភិក្សយ៉ាងធ្ងន់ធ្ងរ? ការពន្យល់បែបទ្រឹស្តីស្ថាបនានិយមអាចចង្អុលទៅការផ្លាស់ប្តូរបទដ្ឋានស្តីអំពីមនុស្សប្រភេទណាដែលសក្តិសមទទួលបានការការពារ។ នៅសតវត្សរ៍ទី ១៩ ប្រទេសមហាអំណាចអឺរ៉ុបបានធ្វើអន្តរាគមន៍ម្តងម្កាលដើម្បីការពារអ្នកកាន់សាសនាគ្រិស្ត ក្នុងចក្រភពអូតូម៉ង់

ពីការសម្លាប់រង្គាល ប៉ុន្តែ ជាទូទៅ មិនអើពើដល់ជនរងគ្រោះ ដែលមិនមែនជាគ្រិស្តសាសនា។ ទោះបីជាយ៉ាងណា ដោយសារក្រោយដំណើរទទួលឯករាជ្យពីរបបអាណានិគមបានចែងពីគោលការណ៍នៃការសម្រេចជោគវាសនាប្រទេសជាតិដោយខ្លួនឯង និងនៅពេលដែលការគោរពសិទ្ធិមនុស្សត្រូវបានផ្តល់តម្លៃយ៉ាងទូលំទូលាយ វិសាលភាពនៃអន្តរាគមន៍មនុស្សធម៌ត្រូវបានពង្រីក។ បើទោះបីជាសហគមន៍អន្តរជាតិមិនតែងតែឆ្លើយតបចំពោះវិបត្តិមនុស្សធម៌ប្រកបដោយប្រសិទ្ធភាពក៏ដោយ វាមិនអាចទទួលយកបានទៀតទេក្នុងការចាត់ទុកថាដល់តែគ្រីស្ទបរិស័ទបានសាកសមនឹងទទួលបានការការពារ។ សហរដ្ឋអាមេរិក ក្នុងឧទាហរណ៍នេះ បានព្យាយាមធ្វើសកម្មភាពសមស្រប ជាជាងគ្រាន់តែយោងទៅតាមការការពារភាគការចំណាយនិងផលចំណេញ។

ឧទាហរណ៍នៃគោលការណ៍អត្តសញ្ញាណនេះអាចត្រូវបានរកឃើញ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ផងដែរ។ អ្នកទ្រឹស្តីស្ថាបនានិយមមួយចំនួនបានអះអាងថា ប្រទេសនៅអាមេរិកឡាទីន ទ្វីបអាហ្វ្រិក និងតំបន់មជ្ឈិមបូព៌ាបានអនុម័ត ឬ ផ្លាស់ប្តូរគោលនយោបាយ ដើម្បីឆ្លើយតបទៅនឹងបទដ្ឋានអន្តរជាតិ មិនមែនដោយសារការផ្លាស់ប្តូរនោះផ្តល់អត្ថប្រយោជន៍ធំធេងនោះទេ ប៉ុន្តែ ដោយសារតែទង្វើនោះត្រូវបានគេយល់ឃើញថាជាសកម្មភាពសមស្រប។ ជាឧទាហរណ៍ បណ្តារដ្ឋកំពុងអភិវឌ្ឍន៍ជាច្រើនបានប្រណាំងប្រជែងគ្នាដើម្បីបង្កើតការិយាធិបតេយ្យវិទ្យាសាស្ត្រ និង/ឬ ចាប់ផ្តើមធ្វើទំនើបកម្មបច្ចេកវិទ្យាយោធារបស់ពួកគេ។ អ្នកទ្រឹស្តីស្ថាបនានិយម ចង្អុលបង្ហាញថា ហេតុផលដែលរដ្ឋកំពុងអភិវឌ្ឍជ្រើសរើសជំរើសក្នុងការចំណាយធនធានដែលមានកម្រិតរបស់ខ្លួនលើគម្រោងបែបនេះ គឺជាមហិច្ឆតារបស់ពួកគេ អោយគេមើលឃើញថាខ្លួន«ទំនើប» តាមស្តង់ដារប្រព័ន្ធអន្តរជាតិ។ រដ្ឋ «ទំនើប» មានការិយាធិបតេយ្យវិទ្យាសាស្ត្រ និងយោធាជឿនលឿន។ ជារឿងគួរអោយអស់សំណើចណាស់ រដ្ឋជាច្រើនដែលបង្កើតការិយាធិបតេយ្យវិទ្យាសាស្ត្រ មានអ្នកវិទ្យាសាស្ត្រតិចតួចបំផុត ខណៈពេលដែលរដ្ឋជាច្រើន ដែលបានបង្កើតកងទ័ពជឿនលឿន មានសត្វតិចតួចបំផុតដែរ។ ដូច្នេះអ្នកទ្រឹស្តីស្ថាបនានិយមសង្កត់ធ្ងន់ថា ដើម្បីពន្យល់ពីអាកប្បកិរិយាគួរអោយងឿងឆ្ងល់បែបនេះ គេត្រូវគិតដល់កត្តាអត្តសញ្ញាណ និងបទដ្ឋានទាំងឡាយ។

តើបទដ្ឋានអន្តរជាតិទាំងនេះរីករាលដាលជុំវិញពិភពលោកបានយ៉ាងដូចម្តេច? នៅក្នុងយុគសម័យនៃទំនាក់ទំនងជាសាកល និងភាពងាយស្រួលក្នុងការដឹកជញ្ជូន លទ្ធភាពអាចមានច្រើនណាស់។ អ្នកទ្រឹស្តីស្ថាបនានិយមសង្កត់ធ្ងន់លើបណ្តុំតួអង្គផ្សេងៗគ្នា ដែលបានផ្សព្វផ្សាយបទដ្ឋានទាំងនោះ។ អ្នកខ្លះទៀតអះអាងថា បុគ្គល ដែលគេហៅថា*សហគ្រិនបទដ្ឋាន (norm entrepreneurs)* តាមរយៈការធ្វើដំណើរការសរសេរ និងការជួបប្រាស្រ័យទាក់ទងជាមួយឥស្សរជន ជាអ្នកផ្លាស់ប្តូរគំនិត និងជំរុញបទដ្ឋាជាក់លាក់ណាមួយ។ ខ្លះទៀតចង្អុលទៅចលនាសង្គម ដែលមានមូលដ្ឋានទូលំទូលាយ និងអង្គការមិនមែនរដ្ឋាភិបាលដូចជា ចលនាប្រឆាំងការរើសអើង(anti-apartheid) ដែលជំរុញដល់ការអភិវឌ្ឍន៍បទដ្ឋានសកលសម្រាប់សមភាពពូជសាសន៍។ អ្នកផ្សេងទៀតបង្ហាញពីរបៀបដែលអង្គការអន្តរជាតិ (ដូចជា អង្គការសហប្រជាជាតិ និងអង្គការណាតូ) អាចបំភាយបទដ្ឋានអ្វីដែលជាអាកប្បកិរិយាសមរម្យ និងមិនសមរម្យ។ ទោះយ៉ាងណាក៏ដោយ ក្នុងករណីនីមួយៗ គំនិតនិងបទដ្ឋានថ្មី (ជាជាងអំណាចនិងផលប្រយោជន៍ផ្ទាល់ខ្លួន) ជំរុញអាកប្បកិរិយារបស់រដ្ឋ។

ការស្រាវជ្រាវនៅក្នុងប្រពៃណីអ្នកទ្រឹស្តីស្ថាបនានិយមបានពង្រីកយ៉ាងឆាប់រហ័ស ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ។ អ្នកប្រាជ្ញនានាបានពិនិត្យមើលតួនាទីរបស់សហភាពអឺរ៉ុប ក្នុងដំណើរការសង្គមនៃឥស្សរជនក្នុងរដ្ឋ

សមាជិកថ្មី ក៏ដូចជា តួនាទីរបស់អង្គការសហប្រជាជាតិ ក្នុងការផ្តល់ភាពស្របច្បាប់លើការប្រើប្រាស់កងកម្លាំង ជាប្រភពនៃអំណាចរបស់ខ្លួន។ អ្នកផ្សេងទៀតបានស៊ើបអង្កេតពីរបៀបដែល អង្គការអន្តរជាតិទទួលបានសិទ្ធិអំណាច តាមរយៈជំនាញរបស់ពួកគេ (ឧទាហរណ៍ មូលនិធិរូបិយវត្ថុអន្តរជាតិ [IMF] លើបញ្ហាហិរញ្ញវត្ថុអន្តរជាតិ) ដើម្បីធ្វើការសម្រេចចិត្តដែលប្រឆាំងទៅនឹងអ្វីដែលរដ្ឋសមាជិករបស់ខ្លួនចង់បាន។ ជាចុងក្រោយ អ្នកប្រាជ្ញស្ថាបនានិយមបានចាប់ផ្តើមស៊ើបអង្កេតអំពីរបៀបដែលសញ្ញាណនៃអត្តសញ្ញាណ និងនិមិត្តសញ្ញានិយម មានសារៈសំខាន់សម្រាប់ការយល់ដឹងអំពីចលនាភេរវកម្ម និងគោលនយោបាយប្រឆាំងភេរវកម្ម។

ជាការពិតណាស់ ដូចជាវិធីសាស្ត្រឬទ្រឹស្តីនានា នៅក្នុងទំនាក់ទំនងអន្តរជាតិ ទ្រឹស្តីស្ថាបនានិយម ក៏មានការរិះគន់ផងដែរ។ អ្នកប្រាជ្ញប្រាកដនិយមណែនាំថា បទដ្ឋានគ្រាន់តែជាការបិទបាំងផលប្រយោជន៍រដ្ឋ (ឬផលប្រយោជន៍ផ្ទាល់ខ្លួន) តែប៉ុណ្ណោះ។ អ្នកប្រាជ្ញសេរីនិយមវិញអះអាងថា អ្នកប្រាជ្ញស្ថាបនានិយមមួយចំនួនយកចិត្តទុកដាក់តិចតួចពេកទៅលើស្ថាប័នផ្លូវការនិងនយោបាយផ្ទៃក្នុងស្ថាប័ននោះ។ ជាងនេះទៅទៀត ទាំងអ្នកប្រាជ្ញប្រាកដនិយមនិងអ្នកប្រាជ្ញសេរីនិយមចង្អុលបង្ហាញថា វាជាពិបាកក្នុងការបែងចែកថា នៅពេលណាដែលអត្តសញ្ញាណរបស់បុគ្គលម្នាក់ពិតប្រាកដ ឬគ្រាន់តែត្រូវបានអនុម័ត ក្នុងហេតុផលជាយុទ្ធសាស្ត្រដើម្បីនាំមកនូវអត្ថប្រយោជន៍ជាសម្ភារៈ (ដូចជា ជំនួយបន្ថែម ពាណិជ្ជកម្ម ឬសមាជិកភាព ទៅក្នុងអង្គការផ្តាច់មុខណាមួយនោះ)។ ទោះបីជាមានការរិះគន់ទាំងនេះក៏ដោយ ការគិតពិចារណាបែបស្ថាបនានិយម និងការសង្កត់ធ្ងន់របស់វាទៅលើគោលការណ៍អត្តសញ្ញាណ នឹងបន្តជាស្នូលនៃការស្រាវជ្រាវទំនាក់ទំនងអន្តរជាតិសម្រាប់បណ្តាឆ្នាំនៅខាងមុខ។

៣.៣.២. ទ្រឹស្តីក្រោយសម័យទំនើបនិយម

ទ្រឹស្តីក្រោយសម័យទំនើបនិយម គឺជាវិធីសាស្ត្រដ៏ទូលំទូលាយមួយ សម្រាប់ការសិក្សាស្រាវជ្រាវដែលបានបន្សល់ទុកនូវឥទ្ធិពលលើមុខវិជ្ជាសិក្សាផ្សេងៗ ជាពិសេសការសិក្សាអក្សរសាស្ត្រ។ ដោយសារតែឫសគល់មកពីអក្សរសាស្ត្រ អ្នកប្រាជ្ញក្រោយសម័យទំនើបនិយមយកចិត្តទុកដាក់ជាពិសេសលើ*អត្ថបទ (text)* និងវិបស្សនា ឬ *សុន្ទរកថា* (*discourse*)៖ របៀបដែលមនុស្សនិយាយនិងសរសេរអំពីប្រធានបទរបស់ពួកគេ (ជាឧទាហរណ៍ប្រធានបទទំនាក់ទំនងអន្តរជាតិជាដើម)។ ដូច្នេះហើយ ការរិះគន់សំខាន់ៗរបស់ទ្រឹស្តីក្រោយសម័យទំនើបនិយម ទៅលើទ្រឹស្តីប្រាកដនិយម ផ្តោតលើការវិភាគពាក្យពេចន៍ និងអំណះអំណាងរបស់អ្នកប្រាជ្ញប្រាកដនិយម។ គំនិតគោលនៃទ្រឹស្តីក្រោយសម័យទំនើបនិយមចែងថា មិនមានសច្ចៈភាពជាសកលតែមួយនោះទេ ប៉ុន្តែមានបទពិសោធន៍និងទស្សនវិស័យជាច្រើន ដែលប្រឆាំងនឹងការធ្វើចំណាត់ថ្នាក់សាមញ្ញៗ។ អាស្រ័យហេតុនេះ ទ្រឹស្តីក្រោយសម័យទំនើបនិយមមានលក្ខណៈពិបាកក្នុងការបង្ហាញតាមបែបសាមញ្ញ តាមប្រភេទឬផ្នែកនីមួយៗ។ ការសិក្សាស្រាវជ្រាវទ្រឹស្តីក្រោយសម័យទំនើបនិយមក្នុងទំនាក់ទំនងអន្តរជាតិ បាននាំមុខ បានកំណត់ដំណាក់កាល និងត្រូវបានជំនួសដោយទ្រឹស្តីស្ថាបនានិយម (constructivism)។

តាមទស្សនៈទ្រឹស្តីក្រោយសម័យទំនើបនិយម, ទ្រឹស្តីប្រាកដនិយមមិនអាចលើកហេតុផលអោយបានត្រឹមត្រូវក្នុងអំណះអំណាងរបស់ខ្លួនដែលថា រដ្ឋគឺជាតួអង្គឯកតែឯងនៅក្នុងទំនាក់ទំនងអន្តរជាតិ ហើយរដ្ឋទាំងនោះដំណើរការជាតួអង្គឯកភូត ជាមួយនឹងកញ្ចប់ផលប្រយោជន៍រួមជាក់លាក់មួយចំនួន (ដែលពួកគេខំប្រឹងស្វែងរកតាមនយោបាយអំណាចអន្តរជាតិ)។ ការរិះគន់របស់ទ្រឹស្តីក្រោយសម័យទំនើបនិយមទៅលើទ្រឹស្តីប្រាកដនិយមបានចោទប្រកាន់ថា មិនឃើញមានគោលបំណងជាក់លាក់ក្នុងដំណើរការស្វែងរកផល

ប្រយោជន៍រួមរបស់រដ្ឋទេ ហើយប្រាកដណាស់ គ្មានអ្វីជាសកលទេ (សំណុំឬកញ្ចប់នៃគុណតម្លៃ ឬផលប្រយោជន៍តែមួយ មិនអាចអនុវត្តចំពោះរដ្ឋទាំងអស់)។

គន្លឹះជាមូលដ្ឋានសំខាន់ជាងនេះទៅទៀត ទ្រឹស្តីក្រោយសម័យទំនើបនិយមចោទសួរអំពីគោលគំនិតរួមដែលថា រដ្ឋជាតួអង្គក្នុងទំនាក់ទំនងអន្តរជាតិទេ។ រដ្ឋមិនមានសច្ចៈភាពជាក់ស្តែងទេ។ ពួកគេគឺជា «រឿងប្រឌិត» ដែលយើង(ជាក្នុងនាមជាអ្នកប្រាជ្ញនិងប្រជាពលរដ្ឋ)បានចងក្រងឡើង ដើម្បីស្វែងយល់អំពីអត្ថន័យនៃសកម្មភាពរបស់មនុស្សមួយចំនួនធំ។ សម្រាប់អ្នកប្រាជ្ញទ្រឹស្តីក្រោយសម័យទំនើបនិយម រឿងដែលបានប្រាប់អំពីសកម្មភាពនិងគោលនយោបាយរបស់រដ្ឋ គឺគ្រាន់តែជារឿងរ៉ាវប៉ុណ្ណោះ។ តាមទស្សនៈនេះ ការបែងចែកភាពខុសគ្នាតាមអំពើចិត្ត បានបណ្តាលអោយបណ្ណាគារដាក់ប្រលោមលោកចារកម្ម នៅលើធ្នើរឿងប្រឌិត ចំណែកឯដីវប្រវត្តិនិងប្រវត្តិសាស្ត្រ ត្រូវបានដាក់នៅលើធ្នើរឿងពិត។ ទាំងអស់នេះមិនមែនជាសច្ចៈភាពដែលមានគោលបំណងជាក់លាក់(objective reality)ទេ ហើយអ្វីៗទាំងអស់ត្រូវបាន ចម្រោះយកតាមរយៈដំណើរការបកស្រាយ ដែលបំភ្លៃបទពិសោធន៍ជាក់ស្តែងរបស់អ្នកដែលពាក់ព័ន្ធ។ ផ្ទុយទៅនឹងការអះអាងរបស់ទ្រឹស្តីប្រាកដនិយមដែលថារដ្ឋគឺជាតួអង្គរួម(មួយឯកតា), អ្នកប្រាជ្ញទ្រឹស្តីក្រោយសម័យទំនើបនិយមមើលឃើញសច្ចៈភាពនិងបទពិសោធន៍ច្រើនស្រទាប់ដែលលាក់ខ្លួននៅក្រោមផ្ទៃខាងលើនៃអង្គភាព ឬ រឿងប្រឌិត ដែលអ្នកប្រាកដនិយម ចងក្រងឡើង (អំពីរដ្ឋ)។ ជាឧទាហរណ៍ អ្នកប្រាជ្ញប្រាកដនិយមចាត់ទុកសហភាពសូវៀតថាជាតួអង្គរួមតែមួយ ដែលមានផលប្រយោជន៍ជាក់លាក់រួមគ្នាតែមួយ។ ជាការពិតណាស់ វាត្រូវបានគេចាត់ទុកថាជាតួអង្គសំខាន់ទីពីរ នៅក្នុងពិភពលោក។ អ្នកប្រាជ្ញប្រាកដនិយមមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងនៅពេលដែលសហភាពសូវៀតត្រូវបានបំបែកជា ១៥ រដ្ឋ ដែលរដ្ឋនីមួយៗមានក្រុមនិងជាតុផ្ចាល់ខ្លួន។ កាន់តែច្បាស់ណាស់ថា «រដ្ឋរួម» តែមួយឯកតា ដែលត្រូវគេហៅថា សហភាពសូវៀត បានបិទបាំង (ហើយទុកអោយអ្នកប្រាកដនិយម*មិនអើពើ*) បទពិសោធន៍ផ្សេងៗគ្នានៃសាធារណរដ្ឋ ក្រុមជនជាតិពន្ធុ និងបុគ្គលផ្សេងៗគ្នាដែរ។

អ្នកប្រាជ្ញទ្រឹស្តីក្រោយសម័យទំនើបនិយមព្យាយាម «រុះរើ» ឬ សម្រាយ (deconstruct) គោលគំនិតដូចជា រដ្ឋ ប្រព័ន្ធអន្តរជាតិ និង រឿងរ៉ាវនិងអំណះអំណាងពាក់ព័ន្ធ (*អត្ថបទ*និង*វិបស្សនា*) ដែលអ្នកប្រាជ្ញប្រាកដនិយមបង្ហាញអំពីលក្ខណៈនៃទំនាក់ទំនងអន្តរជាតិ។ ដើម្បីរុះរើឬសម្រាយអត្ថបទ ជាពាក្យពេចន៍ខ្វីពីការរិះគន់ផ្នែកអក្សរសាស្ត្រ - មានន័យថាបំបែកពាក្យដាច់ដោយឡែកពីគ្នា ដើម្បីបង្ហាញពីអត្ថន័យលាក់កំបាំងដោយស្វែងរកអ្វីដែលអាចត្រូវបានលុបចោល ឬរួមបញ្ចូលដោយប្រយោលតែប៉ុណ្ណោះ។ អត្ថន័យលាក់កំបាំងដែលមិនត្រូវបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងអត្ថបទ ជារឿយៗ ត្រូវបានគេហៅថា **អត្ថន័យបង្កប់**(subtext)។

ការលុបចោលគឺជាទិដ្ឋភាពមួយនៃការបង្កប់អត្ថន័យ ឬអត្ថបទរង ជាឧទាហរណ៍ នៅពេលដែលទ្រឹស្តីប្រាកដនិយមនៃទំនាក់ទំនងអន្តរជាតិ លុបចោលស្ត្រី និងភេទ។ នៅក្នុងការសង្កត់ធ្ងន់ទៅលើរដ្ឋ ទ្រឹស្តីប្រាកដនិយមបានលុបចោល ឬ*មិនអើពើ*តួនាទីរបស់បុគ្គល នយោបាយក្នុងស្រុក វណ្ណៈសេដ្ឋកិច្ច សាជីវកម្មពហុជាតិ (MNCs) និងតួអង្គមិនមែនរដ្ឋផ្សេងទៀត។ នៅក្នុងការផ្តោតអារម្មណ៍របស់ខ្លួនទៅលើប្រទេសមហាអំណាច ទ្រឹស្តីប្រាកដនិយមបានលុបចោលបទពិសោធន៍នៃប្រទេសក្រីក្រ។ នៅក្នុងការយកចិត្តទុកដាក់របស់ខ្លួនលើទម្រង់នៃអានុភាពយោធា វាលុបចោលតួនាទីនៃទម្រង់នៃអានុភាពផ្សេងៗក្រៅពីយោធា។

ទ្រឹស្តីប្រាកដនិយមផ្តោតការយកចិត្តទុកដាក់ យ៉ាងតូចចង្អៀត ដោយសារតែគោលបំណងរបស់វាគឺដើម្បី*សម្រួល*ទំនាក់ទំនងអន្តរជាតិទៅជាគំរូសាមញ្ញនិងស៊ីសង្វាក់គ្នា។ គំរូនេះ ត្រូវបានពួកគេអះអាងថាមាន

វត្តុបំណងជាក់លាក់ មានលក្ខណៈសកល និងមានភាពត្រឹមត្រូវ។ ចំពោះអ្នកប្រាជ្ញក្រោយសម័យទំនើបនិយម គំរូជាក់ស្តែង មិនមានលក្ខណៈទាំងបីខាងលើនេះទេ។ វាគឺជាគំរូលំអៀងដែលបង្កើតសាច់រឿងតូចចង្អៀតនិងលម្អៀង ក្នុងគោលបំណងលើកតម្កើងផលប្រយោជន៍របស់តួអង្គដ៏មានឥទ្ធិពលជាង។ អ្នកប្រាជ្ញទ្រឹស្តីក្រោយសម័យទំនើបនិយមព្យាយាមបំផ្លាញគំរូលម្អៀងបែបនេះ រួមទាំងគំរូផ្សេងទៀត (រួមទាំង ទ្រឹស្តីសេរីនិយមថ្មី) ដែលព្យាយាមចាត់ទុកទំនាក់ទំនងអន្តរជាតិថាជាប្រភេទដែលមានគោលបំណងជាក់លាក់និងសាមញ្ញ។ ផ្ទុយទៅវិញ អ្នកប្រាជ្ញទ្រឹស្តីក្រោយសម័យទំនើបនិយមចង់តម្កើងភាពចម្រុះនៃបទពិសោធន៍ ដែលបង្កើត បានជាទំនាក់ទំនងអន្តរជាតិ ដោយមិនចាំបាច់*សម្រួល*អោយងាយយល់អំពីពួកគេ ដោយការធ្វើអោយសាមញ្ញ និងបែងចែកជាចំណាត់ថ្នាក់ផ្សេងៗ។

៣.៤. ទ្រឹស្តីម៉ាក្សនិយម

៣.៤ ចូរបែងចែកភាពខុសគ្នារវាង ទ្រឹស្តីម៉ាក្សស៊ីសស្តីពីការតស៊ូវណ្ណៈក្នុងប្រទេស នឹងទ្រឹស្តីលេនីនស្តីពីចក្រពត្តិនិយមនៅក្នុងសកលលោក។

ជាលក្ខណៈប្រវត្តិសាស្ត្រ ទ្រឹស្តីសំខាន់បំផុតក្នុងចំណោមទ្រឹស្តីសង្គមនានា គឺជាគោលការណ៍ម៉ាក្សស៊ីសនិយមចំពោះទំនាក់ទំនងអន្តរជាតិ ដែលអះអាងថា ទាំងទំនាក់ទំនងអន្តរជាតិ និង ទាំងនយោបាយក្នុងស្រុកកើតឡើងពីទំនាក់ទំនងវិសមភាពរវាងវណ្ណៈសេដ្ឋកិច្ចនានា។ ការសង្កត់ធ្ងន់លើវណ្ណៈបែបនេះ ដែលបង្កប់ន័យថាលក្ខណៈសេដ្ឋកិច្ចនិងលក្ខណៈក្នុងស្រុកនៃសង្គមមួយបង្កើតបានជាទំនាក់ទំនងខាងក្រៅជាមួយរដ្ឋដទៃទៀត ផ្ទុយនឹងគោលការណ៍របស់ទ្រឹស្តីប្រាកដនិយមចំពោះទំនាក់ទំនងអន្តរជាតិ ដែលញែក នយោបាយក្នុងស្រុកចេញពីនយោបាយអន្តរជាតិ។ យើងនឹងពិភាក្សាអំពីទ្រឹស្តីម៉ាក្សនិយមក្នុងទំនាក់ទំនងអន្តរជាតិ នៅក្នុងមេរៀនទី ១២ ដោយសារ ជាចម្បង វាទាក់ទងនឹងការបែងចែកពិភពលោកទាំងមូលជាអឌ្ឍគោលខាងជើង និងអឌ្ឍគោលខាងត្បូង ដែលមានប្រភពចេញពីប្រវត្តិសាស្ត្រ ចក្រពត្តិនិយម។ នៅក្នុងផ្នែកនេះ យើងនឹងបង្ហាញដោយសង្ខេបអំពីរបៀបដែលទ្រឹស្តីម៉ាក្សនិយមជាទ្រឹស្តីសង្គម ដែលផ្ទុយពីគំរូទ្រឹស្តីប្រាកដនិយម។

ម៉ាក្សស៊ីសនិយម គឺជាមែកធាងមួយនៃលទ្ធិសង្គមនិយមនិងជាទ្រឹស្តីមួយដែលអះអាងថា វណ្ណៈខ្ពស់ដែលមានអំណាចកាន់តែខ្លាំង គាបសង្កត់និងកេងប្រវ័ញ្ចវណ្ណៈទាបដែលមានអំណាចតិច ដោយបដិសេធមិនបែងចែកអតិរេក(ទិន្នផលលើស) ដែលពួកគេបង្កើតបាន ដោយសមធម៌។ វណ្ណៈដែលត្រូវគេជិះជាន់ព្យាយាមដើម្បីដណ្តើមយកទ្រព្យសម្បត្តិបន្ថែមសម្រាប់ខ្លួនឯង។ ដំណើរការនេះ ត្រូវគេហៅថា *ការតស៊ូវណ្ណៈ* គឺជាវិធីមួយក្នុងការសម្លឹងមើលទំនាក់ទំនងនយោបាយរវាងអ្នកមាននិងអ្នកក្រ ហើយចុងក្រោយរវាងតំបន់អភិវឌ្ឍជឿនលឿននិងតំបន់ក្រីក្រជាង។

ម៉ាក្សស៊ីសនិយមរួមបញ្ចូលទាំងលទ្ធិកុម្មុយនិស្ត និងគោលការណ៍ផ្សេងៗទៀត។ នៅពាក់កណ្តាលសតវត្សរ៍ទី ១៩, *ការ ម៉ាក្ស* (Karl Marx) បានសង្កត់ធ្ងន់ថាកម្លាំងពលកម្មជាប្រភពនៃអតិរេកសេដ្ឋកិច្ច។ នៅពេលនោះ បដិវត្តន៍ឧស្សាហកម្មបាននាំមកជាមួយនូវភាពលំបាកលំបិន ជាពិសេស ក្នុងចំណោមកម្មករ រោងចក្រឧស្សាហកម្ម(រួមទាំងកុមារ)នៅទ្វីបអឺរ៉ុប។ ជនម៉ាក្សស៊ីសនិយមនៅតែជឿថា អតិរេកដែលបង្កើតឡើងដោយកម្លាំងពលកម្ម គួរតែត្រូវបានទាញយកមកវិញ ដោយវណ្ណៈកម្មករ តាមរយៈការតស៊ូនយោបាយ។ សព្វថ្ងៃនេះ លទ្ធិម៉ាក្សស៊ីសនិយម មានឥទ្ធិពលបំផុត នៅក្នុងបណ្តាប្រទេស ក្នុងអឌ្ឍគោលខាងត្បូង ដែលជាកន្លែងមានកង្វះខាតដើមទុន ហើយលក្ខខណ្ឌការងារមានសភាពយ៉ាប់យឺនខ្លាំង។

វណ្ណៈដ៏សំខាន់មួយក្នុងបដិវត្តន៍ ក្នុងកំឡុងប៉ុន្មានសតវត្សរ៍មុន (ផ្ទុយពីការរំពឹងទុករបស់លោកម៉ាក្ស) គឺជាវណ្ណៈកសិករ។ តាមធម្មតា ជនម៉ាក្សស៊ីសនិយមចាត់ទុកវណ្ណៈកសិករមានលក្ខណៈអន់ថយ ល្ងង់ខ្លៅ បុគ្គលនិយម និងអសកម្មក្នុងជីវភាពនយោបាយ បើប្រៀបធៀបទៅនឹងពួកវណ្ណៈពលករដែលមានកម្រិតអប់រំ និងមនសិការវណ្ណៈប្រសើរជាង។ ប៉ុន្តែ នៅក្នុងការអនុវត្តជាក់ស្តែង បដិវត្តន៍ប្រទេសតតិយលោកដែលទទួលបានជោគជ័យ គឺជាការបះបោររបស់ប្រជាកសិករ (ជារឿយៗ ត្រូវបានដឹកនាំដោយជនម៉ាក្សស៊ីសនិយមដែលនិយាយអំពីវណ្ណៈពលករ)។ ការបះបោរធំជាងគេ គឺបដិវត្តន៍ចិន ក្នុងទសវត្សរ៍ឆ្នាំ ១៩៣០ និង ១៩៤០។

រូបថត សំណង់អានាធិបតេយ្យនិងអគារធំៗនៅទីក្រុងនៅប្រេស៊ីល

អ្នកមាន និងអ្នកក្រ

ភាពខុសគ្នានៃទ្រព្យសម្បត្តិ គឺជាទិដ្ឋភាពសំខាន់មួយនៃទំនាក់ទំនងអឡ្លគោលខាងជើង និងខាងត្បូង។ ពួកម៉ាក្សនិយមសង្កេតឃើញថា ទំនាក់ទំនងអន្តរជាតិនិងនយោបាយក្នុងស្រុក ត្រូវបានជះឥទ្ធិពលប្រហែលគ្នា ដោយការតស៊ូវណ្ណៈរវាងអ្នកមាននិងអ្នកក្រ។ នៅទីក្រុងសៅប៉ូឡូ ប្រទេសប្រេស៊ីល មានសង្កាត់អ្នកមាននិងអ្នកក្រស្ថិតនៅក្បែរគ្នា។

ទ្រឹស្តីនៃការតស៊ូវណ្ណៈរបស់ម៉ាក្សត្រូវបានតម្រង់ទិសឆ្ពោះទៅរកសង្គម*ក្នុងស្រុក*នៅក្នុងបណ្តាប្រទេសកំពុងធ្វើឧស្សាហូបនីយកម្មនៅសម័យកាលរបស់គាត់ មិនមែនឆ្ពោះទៅរកប្រទេសក្រីក្រ ឬ ទំនាក់ទំនងអន្តរជាតិនោះទេ។ ជនម៉ាក្សស៊ីសនិយមបុរាណបានសម្លឹងមើលប្រទេសឧស្សាហកម្មជឿនលឿនខ្លាំង ដើម្បីរកមើលបដិវត្តន៍និងសង្គមនិយម ដែលនឹងរីកចម្រើនចេញពីរបបមូលធននិយម។ តាមទស្សនៈរបស់ពួកគេ ប្រទេសតតិយលោកទាំងឡាយនឹងត្រូវអភិវឌ្ឍ តាមរយៈដំណាក់កាលនៃការប្រមូលផ្តុំទ្រព្យសម្បត្តិរបស់ខ្លួនពីសង្គមសក្តិភូមិទៅមូលធននិយម មុននឹងបោះជំហានបដិវត្តន៍ទៅជាសង្គមនិយម។ អ្វីដែលបានកើតឡើងជាក់ស្តែង មិនដូចការគិតរបស់ពួកគេទេ។ កម្មករទីក្រុងនៅក្នុងបណ្តាប្រទេសឧស្សាហូបនីយកម្មបានរីករាយនឹងកំណើនកម្រិតជីវភាពរស់នៅរបស់ខ្លួន ហើយមិនបានធ្វើបដិវត្តន៍ទេ។ ទន្ទឹមនឹងនោះ នៅក្នុងប្រទេសតតិយលោកដ៏អន់ថយ កម្មករនិងកសិករដែលត្រូវបានគេជិះជាន់បានធ្វើបដិវត្តន៍ជាបន្តបន្ទាប់ ខ្លះក៏ទទួលបានជោគជ័យ និងខ្លះក៏ត្រូវបរាជ័យ។

ហេតុអ្វីបានជាបដិវត្តន៍កើតឡើងនៅប្រទេសអន់ថយ ជាជាងប្រទេសជឿនលឿន? ចម្លើយភាគច្រើនជះឥទ្ធិពលលើរបៀបដែលមនុស្សម្នាក់ៗមើលឃើញទំនាក់ទំនងអឡ្លគោលខាងជើង និងអឡ្លគោលខាងត្បូងនាពេលសព្វថ្ងៃនេះ។ ជនម៉ាក្សស៊ីសនិយមភាគច្រើន (ប៉ុន្តែមិនមែនទាំងស្រុងទេ) ដើរតាមខ្សែបន្ទាត់នៃអំណះអំណាង ដែលលើកឡើងដោយ លោក វ្ល៉ាឌីមៀរ លេនីន (V. I. Lenin) ស្ថាបនិកសហភាពសូវៀត មុនពេលបដិវត្តន៍រុស្ស៊ី ឆ្នាំ ១៩១៧។ ប្រទេសរុស្ស៊ី នៅពេលនោះ ស្ថិតក្នុងស្ថានភាពអន់ថយ (ដូចជាអឡ្លគោលខាងត្បូង សព្វថ្ងៃ) ហើយជនម៉ាក្សស៊ីសនិយមភាគច្រើនបានចាត់ទុកបដិវត្តន៍ នៅទីនោះ ទំនងជាមិនអាចកើតឡើងទេ (ផ្ទុយទៅវិញ ពួកគេបែរជាសម្លឹងមើលអាឡឺម៉ង់វិញ)។

ទ្រឹស្តីចក្រពត្តិនិយមរបស់លោកលេនីនបានអះអាងថា ពួកមូលធននិយមអឺរ៉ុបកំពុងវិនិយោគទុនលើទឹកដីអាណានិគម ដែលពួកគេអាចទទួលបានប្រាក់ចំណេញមកវិញយ៉ាងច្រើនសន្ធឹកសន្ធាប់ ហើយបន្ទាប់មក ប្រើប្រាស់ផលចំណេញមួយចំណែកដើម្បីទិញទឹកចិត្តវណ្ណៈកម្មករ នៅក្នុងមាតុប្រទេស។ ប៉ុន្តែ បន្ទាប់ពីការដណ្តើមយកអាណានិគម ក្នុងទសវត្សរ៍ឆ្នាំ ១៨៩០, លោកលេនីនបានសង្កេតឃើញថា តំបន់មួយចំនួន

តូចក្នុងពិភពលោក នៅមិនទាន់ធ្លាក់ក្រោមរបបអាណានិគម។ ការពង្រីកចក្រពត្តិនិយមអាចកើតឡើងបានលុះត្រាតែរដ្ឋចក្រពត្តិនិយមផ្សេងទៀតត្រូវរួមតូច ដែលបណ្តាលអោយមានការប្រកួតប្រជែង និងសង្គ្រាមអន្តរចក្រពត្តិនិយម ដូចជា សង្គ្រាមលោកលើកទី១។ ដោយឆក់យកឱកាស ពេលរុស្សីទន់ខ្សោយ ក្នុងអំឡុងពេលសង្គ្រាមនោះ លោកលេនីនបានដឹកនាំបដិវត្តកុម្មុយនិស្តជោគជ័យជាលើកដំបូងនៅទីនោះ ក្នុងឆ្នាំ ១៩១៧។

គោលគំនិតទូទៅរបស់លេនីននៅតែបង្កើតគោលការណ៍ដ៏សំខាន់មួយ ចំពោះទំនាក់ទំនងអឌ្ឍគោលខាងជើងនិងអឌ្ឍគោលខាងត្បូង៖ គំនិតដែលថា រដ្ឋឧស្សាហូបនីយកម្មរីកចម្រើនខ្លាំងកេងប្រវ័ញ្ចលើប្រទេសក្រីក្រ (តាមរយៈអាណានិគមជាផ្លូវការ និងក្រៅផ្លូវការ) និងទិញទឹកចិត្តវណ្ណៈពលករក្នុងមាតុប្រទេសរបស់ខ្លួន ដោយប្រើប្រាស់ផលចំណេញដែលទទួលបានពីទឹកដីអាណានិគម។ តាមរយៈសកលភាវូបនីយកម្មនៃទំនាក់ទំនងវណ្ណៈទាំងនេះ ការប្រមូលផ្តុំទ្រព្យសម្បត្តិពិភពលោកបង្វែរអតិរេកឆ្ពោះទៅរកតំបន់រីកចម្រើនក្នុងពិភពលោក និងកាន់តែឃ្លាតឆ្ងាយពីតំបន់ក្រីក្រ។ ដូច្នេះ គេរំពឹងថា បដិវត្តន៍នឹងផ្ទុះឡើង នៅក្នុងតំបន់ក្រីក្រ។

បដិវត្តន៍ជាច្រើនក្នុងប្រទេសតតិយលោក បានព្យាយាមរំដោះខ្លួនគេចចេញពីការកេងប្រវ័ញ្ចដោយពួកអាណានិគមអឺរ៉ុប។ បន្ទាប់ពីរបបអាណានិគមអឺរ៉ុបត្រូវបានបញ្ចប់ សហរដ្ឋអាមេរិក ក្នុងឋានៈជាប្រទេសមានជាងគេក្នុងពិភពលោក (រួមជាមួយនឹងការវិនិយោគធំនៅក្នុងអឌ្ឍគោលខាងត្បូងនិងវត្តមានយោធានៅទូទាំងពិភពលោកទាំងមូល) បានក្លាយជាគោលដៅនៃបដិវត្តន៍ ដែលបង្កភាពចលាចលប្រឆាំងនឹងការកេងប្រវ័ញ្ចនៅក្នុងប្រទេសក្រីក្រ។ នៅក្នុងប្រទេសមួយចំនួន ចក្រពត្តិនិយមត្រូវបានបណ្តេញចេញ (ជាញឹកញាប់ដោយអំពើហិង្សា ជួនកាលក៏មិនហិង្សាដែរ) ហើយជនបដិវត្តន៍ជាតិនិយមបានឡើងកាន់អំណាច។

បដិវត្តន៍មួយដ៏សំខាន់បំផុត ក្នុងចំណោមនោះ គឺបដិវត្តន៍នៅក្នុងប្រទេសចិន ដែលជនកុម្មុយនិស្តម៉ៅសេទុង បានឡើងកាន់អំណាច នៅឆ្នាំ ១៩៤៩ តាមយុទ្ធនាការលេនីននិយម ហើយសម្របខ្លួនទៅនឹងចលនាផ្អែកលើកសិករភាគច្រើន។ ម៉ៅបានប្រកាសថា ប្រទេសចិនបានឈរលើជើងខ្លួនឯង ដោយផ្តាច់ចេញពីការត្រួតត្រារបស់បរទេសនិងការកេងប្រវ័ញ្ចពីបរទេស។ នៅក្នុងប្រទេសឥណ្ឌាក្នុងដំណាលពេលជាមួយគ្នានោះដែរ ចលនាដែលដឹកនាំដោយមហាត្មៈ គន្ធី បានប្រើមធ្យោបាយផ្សេង (ធម៌អហិង្សា) ដើម្បីសម្រេចបាននូវគោលដៅទីបញ្ចប់ស្រដៀងគ្នា៖ ឯករាជ្យជាតិពីអាណានិគមនិយម។ ប្រទេសឥណ្ឌូណេស៊ីបានបណ្តេញអាណានិគមហូឡង់។ ប្រទេសលីបង់បានបណ្តេញអាណានិគមបារាំង។ ប្រទេសគុយបាបានបណ្តេញជនជាតិអាមេរិកចេញដែរ។ គំរូបែបនេះ បានកើតឡើងម្តងហើយម្តងទៀត ដោយស្ថានភាពខុសគ្នាបន្តិចបន្តួចនៅក្នុងប្រទេសដទៃទៀត។

យោងតាមបដិវត្តន៍នៅក្នុងបណ្តាប្រទេសទាំងនេះ ការកេងប្រវ័ញ្ចលើប្រទេសតតិយលោកពីសំណាក់ប្រទេសអ្នកមាន បានបង្វែរអតិរេកសេដ្ឋកិច្ចនៃអឌ្ឍគោលខាងត្បូង ហើយប្រមូលផ្តុំទ្រព្យសម្បត្តិទៅកាន់តំបន់ដ៏សម្បូរហូរហៀរក្នុងពិភពលោក។ តាមរយៈការផ្តាច់ចេញពីការកេងប្រវ័ញ្ចបែបនេះ ប្រទេសតតិយលោកអាចរក្សាបាននូវអតិរេករបស់ខ្លួន ហើយចាប់ផ្តើមប្រមូលទ្រព្យសម្បត្តិរបស់ពួកគេ។ នៅទីបំផុត ពួកគេអាចបង្កើតវដ្តនៃការសន្សំទ្រព្យសម្បត្តិជាតិដោយខ្លួនឯង ហើយរំដោះខ្លួនចេញពីភាពក្រីក្រ។ ទោះជាយ៉ាងណាក៏ដោយ វិធីសាស្ត្របែបនេះមិនបានដំណើរការយ៉ាងរលូននោះទេ។ គោលនយោបាយ«ពឹងផ្អែកលើខ្លួនឯង» មិនជំរុញកំណើនទេ (សូមមើលផ្នែកអូតារគី ក្នុងមេរៀនទី៨)។ ហើយនៅក្នុងប្រទេសក្រីក្រតែមួយ ការដោះដូរត្រូវប្រព្រឹត្តឡើង រវាងការប្រមូលផ្តុំ ឬចែកចាយទ្រព្យសម្បត្តិជាតិ។ សម្រាប់បណ្តាអតីតអាណានិគម សច្ចៈភាពនៃ

ការអភិវឌ្ឍសេដ្ឋកិច្ចក្រោយឯករាជ្យ មានភាពស្មុគស្មាញខ្លាំងណាស់ តាំងពីដើមរហូតមក។ សច្ចៈភាពទាំងនេះនឹងត្រូវពិភាក្សា នៅក្នុងមេរៀនទី ១២។

មិនមែនគ្រប់គោលការណ៍ម៉ាក្សស៊ីសនិយម មានទំនោរចូលចិត្តអនុវត្តគោលនយោបាយពឹងផ្អែកលើខ្លួនឯង បន្ទាប់ពីបដិវត្តន៍នោះទេ។ លោក ឡេអន ត្រុតស្គី (Leon Trotsky) ដែលជាជនបដិវត្តន៍រុស្ស៊ីបានជឿថា បន្ទាប់ពីបដិវត្តន៍ឆ្នាំ ១៩១៧ ប្រទេសរុស្ស៊ីនឹងមិនអាចកសាង«សង្គមនិយមតែម្នាក់ឯង» បានទេ ហើយគួរតែផ្តល់អាទិភាពចម្បងរបស់ខ្លួន ក្នុងការផ្សព្វផ្សាយបដិវត្តន៍ ទៅកាន់ប្រទេសផ្សេងៗ ដើម្បីបង្កើតសម្ព័ន្ធភាពជុំវិញពិភពលោក។ លោក ចូសែហ្វ ស្តាលីន ដែលជាគូបដិបក្ខរបស់លោកត្រុតស្គី ចង់កសាងរបប«សង្គមនិយមនៅក្នុងប្រទេសមួយ» ហើយបានទទួលជោគជ័យ (ចំណែកលោកត្រុតស្គីត្រូវបានសម្លាប់)។[១៣] ចាប់តាំងពីពេលនោះមក បដិវត្តន៍ក្នុងប្រទេសតតិយលោកភាគច្រើន រួមទាំងប្រទេសចិន មានធាតុជាតិនិយមយ៉ាងខ្លាំង។

ទ្រឹស្តីម៉ាក្សស៊ីសនិយម នៅក្នុងទំនាក់ទំនងអន្តរជាតិ បានឈានចូលដល់ដំណាក់កាលទាបបំផុត បន្ទាប់ពីការដួលរលំនៃសហភាពសូវៀត និងការផ្លាស់ប្តូរទិសដៅរបស់ចិនកុម្មុយនីស្តឆ្ពោះទៅរកបបមូលធននិយម ដែលសុទ្ធសឹងជាព្រឹត្តិការណ៍ដែលដើរផ្ទុយពីទ្រឹស្តីម៉ាក្សស៊ីសនិយម។ ទោះបីជាយ៉ាងណាក៏ដោយ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ បណ្តាជនម៉ាក្សស៊ីស និងអតីតជនម៉ាក្សស៊ីសនិយមបានឡើងកាន់អំណាចនៅក្នុងប្រទេសមួយចំនួន នៅអាមេរិកឡាទីន។ ជាលទ្ធផល ប្រទេសវេណេហ្ស៊ុយអេឡា និង ប្រទេសបូលីវី បានក្លាយជាសម្ព័ន្ធមិត្តដ៏សកម្មរបស់ប្រទេសគុយបា ដោយបង្កើតសម្ព័ន្ធភាពប្រឆាំងនឹងអាមេរិក (ទោះបីជាការធ្វើអោយទំនាក់ទំនងរបស់អាមេរិកជាមួយគុយបា មានលក្ខណៈធម្មតា ក្នុងឆ្នាំ ២០១៥ អាចនាំមកនូវភាពតានតឹងដល់សម្ព័ន្ធនេះក៏ដោយ)។ នៅប្រទេសនីការ៉ាហ្គ័រ អតីតមេដឹកនាំកុម្មុយនិស្ត ដែលពួកឧទ្ទាមគាំទ្រដោយសហរដ្ឋអាមេរិកបានប្រយុទ្ធប្រឆាំងនៅក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ បានទទួលជោគជ័យនៅក្នុងការបោះឆ្នោតប្រធានាធិបតី ក្នុងឆ្នាំ ២០០៦។ ព្រឹត្តិការណ៍ទាំងនេះ រួមជាមួយនឹងការបន្ត ប្រកាន់ខ្ជាប់ជាផ្លូវការរបស់ចិនចំពោះលទ្ធិម៉ាក្សស៊ីសនិយម បង្ហាញថា ទ្រឹស្តីម៉ាក្សស៊ីសនិយមក្នុងទំនាក់ទំនងអន្តរជាតិ នៅតែមានសារៈសំខាន់ជាបន្តបន្ទាប់ នៅក្នុងយុគសម័យក្រោយសង្គ្រាមត្រជាក់។

៣.៥. សិក្ខាសន្តិភាព

៣.៥ ចូរពិពណ៌នាអំពីវិធីជាក់ស្តែង ដែលការសម្របសម្រួលអាចត្រូវបានប្រើ ដើម្បីដោះស្រាយជម្លោះនៅក្នុងទំនាក់ទំនងអន្តរជាតិ។

ការសិក្សាអំពីសន្តិភាពប្រជែងនឹងគោលគំនិតជាមូលដ្ឋាន របស់ទ្រឹស្តីប្រាកដនិយមផង និងទ្រឹស្តីសេរីនិយមថ្មីផង។ ជាពិសេស ការសិក្សាសន្តិភាពព្យាយាមបង្វែរការផ្តោតអារម្មណ៍នៃទំនាក់ទំនងអន្តរជាតិ អោយឆ្ងាយពីការវិភាគកម្រិតប្រព័ន្ធ និងឆ្ពោះទៅរកទស្សនៈទូលំទូលាយនៃទំនាក់ទំនងសង្គម នៅការវិភាគកម្រិតបុគ្គលនិងកម្រិតក្នុងស្រុក។ ការសិក្សាសន្តិភាពចង់ភ្ជាប់សង្គ្រាមនិងសន្តិភាព ជាមួយនឹងទំនួលខុសត្រូវរបស់បុគ្គលវិសមភាពសេដ្ឋកិច្ច ទំនាក់ទំនងយេនឌ័រ ការយល់ដឹងអន្តរវប្បធម៌ និងទិដ្ឋភាពផ្សេងទៀតក្នុងទំនាក់ទំនងសង្គម។ ការសិក្សាស្តីសន្តិភាពក៏ស្វែងរកសន្តិភាព មិនមែននៅក្នុងប្រតិបត្តិការរបស់មេដឹកនាំរដ្ឋទេ ប៉ុន្តែ នៅ

[១៣] Mandel, Ernest. *From Stalinism to Eurocommunism: The Bitter Fruits of "Socialism in One Country."* Translated by Jon Rothschild. N. L. B., ១៩៧៨.

ក្នុងការផ្លាស់ប្តូរសង្គមទាំងមូល(តាមរយៈបដិវត្តន៍សង្គម)និងនៅក្នុងសហគមន៍ឆ្លងជាតិ (ដោយរំលងរដ្ឋ និងការមិនអើពើអំពីព្រំដែន ដើម្បីតភ្ជាប់បណ្តាញមនុស្សនិងក្រុមមនុស្សនានា នៅទូទាំងពិភពលោក)។ វិធីមួយទៀត ដែលការសិក្សាសន្តិភាពព្យាយាមពង្រីកការផ្តោតអារម្មណ៍លើការស៊ើបអង្កេតកាន់តែខ្លាំង តាមរយៈការបដិសេធនូវវត្ថុបំណងនៃគោលការណ៍បែបប្រពៃណី ក្នុងទ្រឹស្តីប្រាកដនិយមនិងទ្រឹស្តីសេរីនិយម។ អ្នកប្រាជ្ញសិក្សាសន្តិភាពភាគច្រើនគិតថា វិធីល្អដើម្បីទទួលបានចំណេះដឹង ត្រូវចូលរួមក្នុងសកម្មភាពផ្ទាល់៖ មិនមែនគ្រាន់តែសង្កេតមើលតាមវត្ថុបំណងជាក់លាក់ណាមួយឡើយ។ កង្វះវត្ថុបំណងជាក់លាក់បែបនេះត្រូវបានគេរិះគន់ថាជា*សេចក្តីលំអៀងតាមបទដ្ឋាន* ដោយសារអ្នកប្រាជ្ញនានាជាក់បទដ្ឋាននិងគុណតម្លៃផ្ទាល់ខ្លួនទៅលើប្រធានបទនេះ។ ទោះជាយ៉ាងនេះក្តី អ្នកប្រាជ្ញក្នុងការសិក្សាសន្តិភាព ឆ្លើយតបវិញថា ទ្រឹស្តីប្រាកដនិយមផ្ទាល់មានភាពលំអៀងតាមបទដ្ឋាន និងបង្កើត*វេជ្ជបញ្ជា*គាលនយោបាយ។

ការអភិវឌ្ឍន៍និងការអនុវត្តយុទ្ធសាស្ត្រដោយសន្តិវិធីសម្រាប់ការដោះស្រាយជម្លោះ ដោយប្រើប្រាស់ជម្រើសផ្សេងជំនួសអានុភាពហិង្សា ត្រូវបានគេស្គាល់ ដោយពាក្យទូទៅមួយ នោះគឺ **ការដោះស្រាយជម្លោះ**។ វិធីសាស្ត្រទាំងនេះ កំពុងត្រូវបានប្រើប្រាស់ ដោយប្រកួតប្រជែងជាមួយវិធីសាស្ត្រហិង្សា ក្នុងជម្លោះអន្តរជាតិស្ទើរតែទាំងអស់។ ក្នុងពេលថ្មីៗនេះ ការប្រើប្រាស់ដំណោះស្រាយជម្លោះមានការកើនឡើង កាន់តែទំនើប និងជោគជ័យកាន់តែញឹកញាប់។ ទាក់ទងនឹងការដោះស្រាយជម្លោះភាគច្រើនប្រើភាគីទីបី ដែលតួនាទីរបស់ពួកគេជាចម្បងត្រូវ**សម្រុះសម្រួល**រវាងភាគីជម្លោះពីរ។ នាពេលបច្ចុប្បន្ននេះ ជម្លោះអន្តរជាតិភាគច្រើនមានភាគីសម្រុះសម្រួលមួយឬច្រើន ដែលធ្វើការជាទៀងទាត់ ដើម្បីដោះស្រាយជម្លោះដែលបង្កជាអំពើហិង្សា។ គ្មានច្បាប់ចែងយ៉ាងច្បាស់និងរឹងមាំថា ភាគីទីបីសម្រុះសម្រួលប្រភេទណាសម្រុះសម្រួលជម្លោះប្រភេទណានោះទេ។ អង្គការសហប្រជាជាតិ គឺជាអ្នកសម្រុះសម្រួលដ៏សំខាន់បំផុត នៅលើឆាកនៃពិភពលោក។ ជម្លោះក្នុងតំបន់មួយចំនួនត្រូវបានសម្របសម្រួល តាមរយៈអង្គការតំបន់ រដ្ឋណាមួយ ឬសូម្បីតែ បុគ្គលឯកជន។

ការចូលរួមរបស់អ្នកសម្របសម្រួលអាចប្រែប្រួល។ ការសម្រុះសម្រួលខ្លះមានលក្ខណៈ*បច្ចេកទេស*យ៉ាងតឹងរ៉ឹង៖ អ្នកសម្រុះសម្រួលអាចដើរតួយ៉ាងសកម្ម ប៉ុន្តែ អព្យាក្រឹតយ៉ាងតឹងរ៉ឹង ក្នុងការបញ្ជូនទំនាក់ទំនងរវាងរដ្ឋពីរ ដែលខ្វះបណ្តាញទំនាក់ទំនងនឹងគ្នា ផ្សេងទៀត។ ឧទាហរណ៍ ប៉ាគីស្ថានបញ្ជូនសារសម្ងាត់រវាងចិននិងសហរដ្ឋអាមេរិក មុនពេលការភ្ជាប់ទំនាក់ទំនងរវាងសហរដ្ឋអាមេរិកនិងប្រទេសចិន ក្នុងឆ្នាំ ១៩៧១។ តួនាទីបែបនេះ ជួនកាល ត្រូវបានគេសំដៅថាជា ការផ្តល់នូវ*ការិយាល័យដ៏ល្អ*របស់អ្នកសម្រុះសម្រួលដល់ដំណើរការចរចា។ ក្នុងការសម្របសម្រួលភ្ជាប់ទំនាក់ទំនង អ្នកសម្រុះសម្រួលស្តាប់គំនិតឬកង្វល់របស់ភាគីទាំងសងខាង ហើយបង្ហាញគំនិតនោះដល់ភាគីម្ខាងទៀត តាមរបៀបណាមួយដែលពួកគេអាចស្តាប់បាន។ អ្នកសម្រុះសម្រួលធ្វើការដើម្បីផ្លាស់ប្តូរទស្សនៈរបស់ភាគីនីមួយៗអំពីបញ្ហាលំបាក។ នៅក្នុងតួនាទីទាំងនេះ អ្នកសម្រុះសម្រួលប្រៀបដូចជាអ្នកបកប្រែរវាងភាគីទាំងពីរ ឬជាអ្នកព្យាបាល ដែលជួយពួកគេដោះស្រាយបញ្ហាផ្លូវចិត្ត ក្នុងទំនាក់ទំនងរបស់ពួកគេ។ ការធ្វើដំណើរទៅមកនិងការពិភាក្សា ដោយបុគ្គលនិងក្រុមឯកជននានា អាចមានមុខងារជា*ការទូតពលរដ្ឋ* ដើម្បីបន្ធូរបន្ថយភាពតានតឹងផងដែរ។

រូបថត ក្មេងស្រីប៉ាឡេស្ទីនពីរនាក់ រងគ្រោះ ពីជម្លោះ

ស្រមោលនៃសង្គ្រាម

យោធានិយមនៅក្នុងវប្បធម៌មួយ ឬកង្វះយោធានិយម អាចមានឥទ្ធិពលលើគោលនយោបាយការបរទេស។ នៅក្នុងសង្គមដែលមានសង្គ្រាម ការប៉ះទង្គិចផ្លូវចិត្តរបស់កុមារួមចំណែកដល់ជម្លោះរវាងក្រុម អស់រយៈជាច្រើនទសវត្សរ៍ក្រោយ។ ជនជាតិប៉ាឡេស្ទីនជាច្រើនជំនាន់បានធំធាត់ឡើងក្នុងសង្គមដែលរងផលប៉ះពាល់ដោយជម្លោះហិង្សា។ ក្មេងស្រីប៉ាឡេស្ទីនទាំងពីរនេះ ដែលឈរក្បែរផ្នូរបស់ពួកគេក្នុងទីក្រុងហ្គាហ្សា (Gaza) ដែលត្រូវបានវាយឆ្នក់ដោយកងកម្លាំងអ៊ីស្រាអែល កាលពីឆ្នាំ ២០១៤ បានរស់នៅជុំវិញជម្លោះដ៏ហិង្សារពេញមួយជីវិតរបស់ពួកគេ ដូចជាឪពុកម្តាយ និងជីដូនជីតារបស់ពួកគេមុនៗដែរ។

ប្រសិនបើភាគីទាំងសងខាងយល់ព្រមជាមុន ក្នុងការគោរពតាមដំណោះស្រាយ ដែលរៀបចំឡើងដោយអ្នកសម្រុះសម្រួល ដំណើរការនេះត្រូវបានគេហៅថា*អាជ្ញាកណ្តាល*។ ក្នុងករណីនោះ ភាគីទាំងសងខាងបង្ហាញអំណះអំណាងរបស់ខ្លួនចំពោះមុខមជ្ឈត្តករ ឬ អាជ្ញាកណ្តាលនោះ ដែលសម្រេចលើដំណោះស្រាយដោយ«យុត្តិធម៌»។ ជាឧទាហរណ៍ ពេលអ្នកចរចាស៊ែប៊ី និងបូស្ន៊ៀ មិនអាចយល់ស្របគ្នាថាតើអ្នកណាគួរទទួលបានទីក្រុងបក្កូ (Brcko) ពួកគេបានបង្វែរបញ្ហាទៅជាអាជ្ញាកណ្តាល ជាជាងរក្សាទុកនូវកិច្ចព្រមព្រៀងដេយ៍តុន(Dayton)ទាំងមូល ឆ្នាំ ១៩៩៥។ ជារឿយៗ មជ្ឈត្តករប្រើគណៈកម្មការដែលមានមនុស្សចំនួនបីនាក់ ម្នាក់ត្រូវបានជ្រើសរើសដោយភាគីនីមួយៗដោយឯកតោភាគី និងអ្នកទីបីត្រូវបានជ្រើនរើសដោយមានការយល់ព្រមពីភាគីទាំងពីរ។ ភាគីជម្លោះ (និងអ្នកសម្រុះសម្រួល) ក៏អាចប្រើវិធានការណ៍*កសាងទំនុកចិត្ត*ផងដែរ ដើម្បីបង្កើនទំនុកចិត្ត បន្តិចម្តងៗ។ ផ្ទុយទៅវិញ *ការផ្សារភ្ជាប់គ្នា*បានរួមបញ្ចូលគ្នានូវបញ្ហាចម្រុះដូច្នេះហើយ ការសម្រុះសម្រួលគ្នា អាចត្រូវបានដោះដូរ ជាមួយនឹងមួយផ្សេងទៀតនៅក្នុងកិច្ចព្រមព្រៀងដ៏ធំមួយ។ ជាឧទាហរណ៍ នេះជាករណីក្នុងការចរចាយ៉ាល់តាឆ្នាំ ១៩៤៥ ក្នុងចំណោមសហរដ្ឋអាមេរិក អង់គ្លេស និងសហភាពសូវៀត។ នៅលើតុចរចារក្នុងពេលដំណាលគ្នា រួមបញ្ចូលបញ្ហាដូចជា លក្ខខណ្ឌនៃការកាន់កាប់ប្រទេសអាឡឺម៉ង់ វត្តមានសូវៀតនៅអឺរ៉ុបខាងកើត និងសម្រាប់យុទ្ធសាស្ត្រវាយបំបាក់ជប៉ុន និងការបង្កើតអង្គការសហប្រជាជាតិ។

អ្នកប្រាជ្ញសិក្សាសន្តិភាពនានាបានអះអាងថា សង្គ្រាមមិនមែនគ្រាន់តែជាការបង្ហាញពីអានុភាពអំណាចធម្មជាតិប៉ុណ្ណោះទេ ប៉ុន្តែជាការផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងលទ្ធិយោធានិយម នៅក្នុងវប្បធម៌ (មួយចំនួន)។ **យោធានិយម** គឺជាការលើកតម្កើងសង្គ្រាម កម្លាំងយោធា និងអំពើហិង្សា តាមរយៈទូរទស្សន៍ ភាពយន្ត សៀវភៅ សុន្ទរកថានយោបាយ ប្រដាប់ក្មេងលេង ហ្គេម កីឡា និងតាមមធ្យោបាយផ្សេងៗទៀត។ យោធានិយមក៏សំដៅទៅលើរចនាសម្ព័ន្ធសង្គម ជុំវិញសង្គ្រាមផងដែរ ឧទាហរណ៍ តួនាទីលេចធ្លោនៃរោងចក្រឧស្សាហកម្មផលិតសព្វាវុធយោធានៅក្នុងសេដ្ឋកិច្ចជាតិ ឬការគ្រប់គ្រងបញ្ហាសន្តិសុខជាតិនៅក្នុងនយោបាយក្នុងស្រុក។ យោធានិយមអាចបញ្ជាក់ពីទំនោរនៃអ្នកដឹកនាំនយោបាយ ក្នុងការប្រើប្រាស់កម្លាំងយោធា។ តាមប្រវត្តិសាស្ត្រ លទ្ធិយោធានិយមមានឥទ្ធិពលយ៉ាងខ្លាំងទៅលើការវិវត្តន៍នៃសង្គម។ សង្គ្រាមត្រូវបានលើកតម្កើងជាញឹកញយថាជា សហគ្រាស«បុរសពិត» ដែលលើកកម្ពស់ស្មារតីមនុស្ស (ជាពិសេសមុនសង្គ្រាមលោកលើកទី ១ ដែលក្រោយមក បានផ្លាស់ប្តូរទស្សនៈនោះ)។ សង្គ្រាមមិនត្រឹមតែជាអំពើសាហាវយង់ឃ្នងប៉ុណ្ណោះទេ តែថែមទាំងនាំមកនូវទង្វើគំរូរបស់មនុស្សជាតិផងដែរ៖ ការលះបង់ កិត្តិយស ភាពក្លាហាន ភាពស្មោះត្រង់ក្នុងនាមមនុស្សជាទីស្រឡាញ់ និងការផ្សារភ្ជាប់ជាមួយនឹងសហគមន៍ដែលធំជាងខ្លួនឯងផ្ទាល់។

ឧទាហរណ៍នៃវប្បធម៌យោធាតិចជាងនេះបង្ហាញថា ការសង្កត់ធ្ងន់របស់ទ្រីស្តីប្រាកដនិយមលើកម្លាំងយោធា មិនលក្ខណៈសកល ឬចាំបាច់នោះទេ។ ប្រទេស កូស្តារីកា មិនមានកងទ័ព អស់រយៈពេល ៧០ ឆ្នាំមកហើយ (មានត្រឹមតែកងកម្លាំងប្រដាប់អាវុធធុនស្រាលតិចតួច) សូម្បីតែ ក្នុងកំឡុងទសវត្សរ៍ឆ្នាំ ១៩៨០ នៅពេលដែលសង្គ្រាមបានកើតឡើង នៅក្នុងប្រទេសជិតខាង ដូចជា ប្រទេសនីការ៉ាហ្គ័រនិងប្រទេសប៉ាណាម៉ា។ វប្បធម៌ជប៉ុន តាំងពីសង្គ្រាមលោកលើកទី២មក បានបង្កើតបទដ្ឋានរឹងមាំប្រឆាំងនឹងសង្គ្រាមនិងអំពើហឹង្សា។

អ្នកនរវិទ្យាទាំងឡាយបានព្យាយាមភ្ជាប់លក្ខណៈផ្ទៃក្នុងនៃសង្គមបរបាញ់-បេះផ្លែឈើ កាលពីសម័យបុព្វកាល ជាមួយនឹងទំនោរលក្ខណៈខាងក្រៅរបស់ពួកគេ ដើម្បីចូលរួមក្នុងសង្គ្រាម។ ភ័ស្តុតាងខ្លះបង្ហាញថា សង្គ្រាមកើតឡើងញឹកញាប់ នៅក្នុងសង្គមទាំងឡាយណា ដែលមានវិសមភាពផ្ទៃក្នុង (ជាពិសេសយេនឌ័រ) ជាមួយនឹងប្រពៃណីចិញ្ចឹមកូនតឹងរ៉ឹង និងជាមួយនឹងអវត្តមានឪពុកក្នុងការចិញ្ចឹមកូន។ ផ្ទុយទៅវិញ សង្គមដែលមានសន្តិភាពជាង ទំនងជាមានដំណើរការធ្វើការសម្រេចចិត្តដោយបើកចំហ, សមភាពយេនឌ័រជាង និងការចិញ្ចឹមកូនចៅ ប្រកបដោយក្តីស្រលាញ់និងបណ្តោយអោយកូនចៅមានសិទ្ធិសេរីភាព។ ប៉ុន្តែ គុណសម្បត្តិសង្គមទាំងអស់នេះ ក៏អាចជា*ឥទ្ធិពល* និងជាបុព្វហេតុនៃសង្គ្រាម ផងដែរ។ ហើយដោយសារសង្គមគ្រប់ប្រភេទហាក់បីដូចជាមានសក្តានុពលបង្កអោយសង្គ្រាមផ្ទុះឡើង ក្រោមលក្ខខណ្ឌមួយចំនួន (សូមមើលមេរៀនទី ៥), ភាពខុសគ្នា ដូចជា«សង្គ្រាម» គ្រាន់តែការប្រៀបធៀបគ្នាប៉ុណ្ណោះ។

ដូចដែលសង្គ្រាមត្រូវបានគេមើលឃើញ នៅក្នុងការសិក្សាសន្តិភាពថាជា ទិដ្ឋភាពរីករាលដាលនៃសង្គមទាំងមូល ដូច្នេះហើយទើបសន្តិភាពអាចត្រូវបានគេគិតគូរពិចារណាឡើងវិញ ក្នុងវិធីទូលំទូលាយជាង។ ដោយសារតែទ្រឹស្តីប្រាកដនិយមសន្មត់ថា ជម្លោះយោធាគឺជារឿងធម្មតា វាទទួលស្គាល់តែប្រភេទអវិជ្ជមាននៃសន្តិភាពតែប៉ុណ្ណោះ៖ អវត្តមាននៃសង្គ្រាមជាបណ្តោះអាសន្ន។ ផ្ទុយទៅវិញ **សន្តិភាពវិជ្ជមាន**សំដៅទៅលើសន្តិភាព ដែលដោះស្រាយមូលហេតុធំៗដែលអាចបណ្តាលអោយសង្គ្រាមសង្គ្រាមផ្ទុះឡើង៖ សន្តិភាពដែលមិនមែនគ្រាន់តែជាបទឈប់បាញ់ប៉ុណ្ណោះទេ ប៉ុន្តែជាការប្រែក្លាយជាទំនាក់ទំនងនឹងគ្នា។ ក្រោមសន្តិភាពជាវិជ្ជមាន កងទ័ពរបស់រដ្ឋពាក់ព័ន្ធមិនត្រឹមតែឈប់ប្រយុទ្ធនឹងគ្នាប៉ុណ្ណោះទេ ពួកគេឈប់បំពាក់សព្វាវុធ, ឈប់រៀបចំបង្កើតក្រុមពិឃាដប្រឆាំងនឹងការតវ៉ាផ្ទៃក្នុងរដ្ឋ និងបញ្ឈប់ការកេងប្រវ័ញ្ចសេដ្ឋកិច្ចនិងការគៀបសង្កត់នយោបាយ ដែលអ្នកប្រាជ្ញក្នុងការសិក្សាសន្តិភាពជឿថាជាដើមហេតុនៃជម្លោះសង្គម ដែលអាចនាំអោយមានសង្គ្រាមផ្ទុះឡើង យ៉ាងពិតប្រាកដ។

អ្នកគាំទ្រគោលការណ៍នេះមើលឃើញបញ្ហាសង្គមនិងសេដ្ឋកិច្ចទូលំទូលាយ (ដែលអ្នកប្រាកដនិយមសន្មត់ថាមិនសូវសំខាន់) មានភាពជាប់ទាក់ទងជាមួយនឹងសន្តិភាពវិជ្ជមាន ដោយមិនអាចប្រកែកបាន។ អ្នកប្រាជ្ញខ្លះកំណត់ភាពក្រីក្រ គ្រោះទុរភិក្ស និងការគៀបសង្កត់ទាំងឡាយថាជាទម្រង់អំពើហិង្សា មួយដែលពួកគេហៅថា *អំពើហិង្សាជាប្រព័ន្ធ* ព្រោះវាបណ្តាលមកពីរចនាសម្ព័ន្ធនៃប្រព័ន្ធទំនាក់ទំនងសង្គម ជាជាងដោយសកម្មភាពផ្ទាល់ ដូចជាការបាញ់សម្លាប់មនុស្ស។ អំពើហិង្សាជាប្រព័ន្ធ នៅក្នុងនិយមន័យនេះ បានសម្លាប់និងបង្កគ្រោះថ្នាក់ដល់មនុស្សជាច្រើន ជារៀងរាល់ឆ្នាំ ជាជាងការធ្វើសង្គ្រាម និងទម្រង់ផ្សេងទៀតនៃអំពើហិង្សានយោបាយដោយផ្ទាល់។ សន្តិភាពជាវិជ្ជមានត្រូវបានកំណត់និយមន័យជាធម្មតាដើម្បីរួមបញ្ចូលការលុបបំបាត់អំពើហិង្សារចនាសម្ព័ន្ធឬជាប្រព័ន្ធ។

អ្នកតស៊ូមតិគាំទ្រសន្តិភាពវិជ្ជមានក៏រិះគន់វប្បធម៌យោធានិយមផងដែរ។ ការកសាងសង្គមសង្គ្រាមនិយម៖ ជាប្រព័ន្ធច្បាប់និងទំនាក់ទំនងស្មុគស្មាញ ដែលគាំទ្រដល់អត្ថិភាពនៃសង្គ្រាម, ជះឥទ្ធិពលលើជីវភាពរស់នៅប្រចាំថ្ងៃរបស់យើង ក្នុងរូបភាពជាច្រើន៖ ពីប្រដាប់ប្រដាក្មេងលេងបែបសង្គ្រាម រហូតដល់ពិធីសាសនាបែបស្នេហាជាតិ ក្នុងសាលារៀន, ពីតួនាទីយេនឌ័របែបរបស់ក្មេងដំទង់ រហូតដល់ការបណ្តុះបណ្តាលយោធាសម្រាប់យុវជន, ពីពន្ធដែលយើងត្រូវបង់ រហូតដល់ប្រភេទកីឡាដែលយើងលេង។ គោលការណ៍សន្តិភាពជាវិជ្ជមានព្យាយាមផ្លាស់ប្តូរប្រព័ន្ធទាំងមូល មិនមែនត្រឹមតែមួយផ្នែកណាមួយនោះទេ។

សន្តិភាពជាវិជ្ជមានរួមបញ្ចូលនូវគោលការណ៍ចំពោះការផ្លាស់ប្តូរសង្គម ជាច្រើន។ គោលការណ៍ទាំងនេះរួមបញ្ចូលយន្តការផ្សេងទៀតសម្រាប់ការដោះស្រាយជម្លោះជំនួសអោយសង្គ្រាម, សម្ពាធដ៏ប្រជាប្រិយលើរដ្ឋាភិបាលតាមរយៈចលនាសន្តិភាពនិងសកម្មភាពនយោបាយនានា, ការពង្រឹងបទដ្ឋានប្រឆាំងនឹងការប្រើប្រាស់អំពើហិង្សា(រួមទាំងទស្សនវិជ្ជាអហិង្សា), ការអភិវឌ្ឍន៍អត្តសញ្ញាណសកលឬអន្តរជាតិ គ្រប់ពីលើការបែងចែកជាតិ ជាតិសាសន៍ និងសាសនា, និងទំនាក់ទំនងដោយសមភាពក្នុងសង្គម ក្នុងទិដ្ឋភាពសេដ្ឋកិច្ចសង្គម និងនយោបាយ (រួមទាំងការផ្លាស់ប្តូរតួនាទីយេនឌ័រផងដែរ)។

ការបង្កើត**រដ្ឋាភិបាលពិភពលោក**រួមតែមួយ ត្រូវបានអ្នកប្រាជ្ញទាំងឡាយជជែកដេញដោលគ្នា ជាយូរណាស់មកហើយ និងជម្នះចង់បានដោយសកម្មជនជាច្រើន។ អ្នកប្រាជ្ញខ្លះទៀតជឿថា វឌ្ឍនភាពកំពុងត្រូវបានបង្កើតឡើង (តាមរយៈអង្គការសហប្រជាជាតិ) ឆ្ពោះទៅរកការលេចចេញជាយថាហេតុនៃរដ្ឋាភិបាលពិភពលោក។ អ្នកផ្សេងទៀតគិតថា គំនិតនេះ មិនអាចអនុវត្តបាន ឬមិនជាទីប្រាថ្នាចង់បានឡើយ (វាគ្រាន់តែបន្ថែមស្រទាប់គ្រប់គ្រងមជ្ឈការមួយផ្សេងទៀត នៅពេលដែលសន្តិភាពទាមទារមិជ្ឈការនិងសេរីភាព)។

រូបថត ប្រជាជនអង់គ្លេសនៅក្រុងឡុងដ៍កំពុងធ្វើបាតុកម្ម
ផ្តល់ឱកាសអោយសន្តិភាពផង

បាតុកម្មសន្តិភាពដើរតួនាទីសំខាន់ក្នុងជម្លោះជាច្រើន។ នៅទីនេះ បាតុកម្មនៅទីក្រុងឡុងដ៍ ឆ្លើយតបទៅនឹងការសន្យារបស់ប្រធានាធិបតីអាមេរិក ដូណាល់ ត្រាំ ក្នុងការបង្កើតអាវុធនុយក្លេអ៊ែរបន្ថែមទៀត និងការគំរាមកំហែងរបស់គាត់ប្រឆាំងនឹងកូរ៉េខាងជើងឆ្នាំ ២០១៧។

អ្នកប្រាជ្ញជំនាញសិក្សាសន្តិភាពក៏សិក្សាពីមធ្យោបាយ ដើម្បីសម្រេចអោយបាននូវលក្ខខណ្ឌសម្រាប់សន្តិភាពវិជ្ជមាន។ អ្នកប្រាជ្ញសិក្សាសន្តិភាពភាគច្រើនមានមន្ទិលសង្ស័យដូចគ្នាថា មេដឹកនាំរដ្ឋ បើបណ្តោយអោយពួកគេតែឯង មិនអាចទទួលបានសន្តិភាពជាវិជ្ជមានឡើយ។ ផ្ទុយទៅវិញ ពួកគេជឿថា ទំនាក់ទំនងអន្តរជាតិជាក់ស្តែង នឹងផ្លាស់ប្តូរទៅបាន ល្អឹកណាមានសម្ពាធពីបុគ្គលនិងក្រុមនានា តែប៉ុណ្ណោះ។ ជាទូទៅវិធីសាស្ត្រដាក់សម្ពាធដែលត្រូវបានសិក្សាច្រើនបំផុត គឺតាមរយៈ**ចលនាសន្តិភាព**៖ មនុស្សម្នាប្រមូលផ្តុំគ្នាដើរតាមដងផ្លូវដើម្បីតវ៉ាប្រឆាំងនឹងសង្គ្រាមនិងយោធានិយម។ ដូចដែលប្រធានាធិបតីសហរដ្ឋអាមេរិក លោក ដ្វាយ អៃសិនហៅវ័រ (Dwight Eisenhower) ធ្លាប់បាននិយាយថា «ប្រជាពលរដ្ឋប្រាថ្នាចង់បានសន្តិភាពខ្លាំងណាស់ ដែលរដ្ឋាភិបាល នៅថ្ងៃណាមួយ ត្រូវចេញពីផ្លូវរបស់ពួកគេ ហើយទុកឲ្យពួកគេទទួលបានវា»។[១៤]

[១៤] Eisenhower, Dwight D. *Ike's Letters to a Friend, ១៩៤១–១៩៥៨.* Edited by Robert Griffith. Kansas, ១៩៨៤.

ទស្សនវិជ្ជា*អហិង្សា*ត្រូវផ្អែកលើការប្តេជ្ញាចិត្តជាឯកតោភាគី ក្នុងការបដិសេធមិនប្រើអំពើហិង្សាគ្រប់ប្រភេទសម្រាប់ជាអានុភាពក្នុងដំណើរការចរចា។ បច្ចុប្បន្ន គ្មានរដ្ឋណាមួយដើរតាមយុទ្ធសាស្ត្របែបនេះទេ ប៉ុន្តែ តួអង្គអនុរដ្ឋបានអនុវត្តតាម។ លោក *មហាត្មៈ គន្ធី,* ដែលបានដឹកនាំការតស៊ូដណ្តើមឯករាជ្យឥណ្ឌាពីចក្រភពអង់គ្លេស មុនឆ្នាំ ១៩៤៨, បានសង្កត់ធ្ងន់ថា អហិង្សាត្រូវតែប្រកាន់អោយបានខ្ជាប់ខ្ជួន ក្នុងការទប់ស្កាត់អំពើហិង្សា, ដោះស្រាយជម្លោះដោយគ្មានអំពើហិង្សា, និងជាពិសេសត្រូវក្រោកឈរប្រឆាំងនឹងភាពអយុត្តិធម៌ដែលបានអនុវត្តដោយហិង្សា។ លោកគន្ធីបានកៀងគរប្រជាជនឥណ្ឌាអោយប្រឆាំងនឹងការកាន់កាប់របស់អាណានិគមអង់គ្លេស ដោយមិនប្រើអំពើហិង្សាជាដាច់ខាត សូម្បីតែពេលដែលកងទ័ពអង់គ្លេសបានបាញ់សម្លាប់បាតុករឥណ្ឌាដែលគ្មានអាវុធក៏ដោយ។

អ្នកគាំទ្រវប្បធម៌អហិង្សាសង្កត់ធ្ងន់លើទិដ្ឋភាពជាក់ស្តែងនៃអហិង្សា បន្ថែមពីលើក្របខ័ណ្ឌសីលធម៌របស់វា។ ជាឧបករណ៍សម្រាប់ជនទន់ខ្សោយគ្មានអំណាចដែលក្រោកឡើង ប្រឆាំងនឹងអំពើអយុត្តិធម៌ ដែលបង្កឡើងដោយអ្នកមានអំណាច ធម៌អហិង្សាគឺជាវិធីសាស្ត្រដែលមានប្រសិទ្ធភាពបំផុត (ដោយសារតែការចំណាយក្នុងការតស៊ូដោយហិង្សានឹងត្រូវបានហាមឃាត់)។ នៅសហរដ្ឋអាមេរិក ទស្សនវិជ្ជា អហិង្សាបានរីករាលដាលយ៉ាងទូលំទូលាយ ក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ នៅក្នុងចលនាសិទ្ធិស៊ីវិល ជាពិសេស តាមរយៈការងាររបស់ លោកបណ្ឌិត ម៉ាទីន លូថ័រ ឃីង (Martin Luther King)។ បណ្តាបាតុកម្មក្នុងចលនាបដិវត្តន៍និទាឃរដូវនៅអារ៉ាប់ (Arab Spring) ឆ្នាំ ២០១១ បានធ្វើតាមគំរូរបស់បណ្ឌិតឃីង ក៏ដូចជាតាមយុទ្ធសាស្ត្រជាក់លាក់ដែលត្រូវបានណែនាំដោយជនជាតិអាមេរិកម្នាក់ឈ្មោះ ជីន ហ្សាប (Gene Sharp) ដែលគំនិតរបស់គាត់ត្រូវបានបង្រៀនដល់សកម្មជនអារ៉ាប់វ័យក្មេង នៅក្នុងសិក្ខាសាលាមុនៗ នៅទ្វីបអឺរ៉ុប។ គោលការណ៍អហិង្សាទាំងនេះ បានដំណើរការនៅប្រទេសទុយនីស៊ី និងប្រទេសអេហ្ស៊ីប, និងត្រូវបានបោះបង់ចោលដោយការបះបោរហិង្សានៅប្រទេសលីប៊ី, ហើយបានបើកផ្លូវទៅកាន់សង្គ្រាម នៅក្នុងប្រទេសស៊ីរី ដែលបានឆក់យកជីវិតមនុស្សជិត ២០០,០០០ នាក់ ក្នុងឆ្នាំ ២០១១-២០១៨ និងនៅក្នុងប្រទេសយេម៉ែន ដែលជាកន្លែងសង្គ្រាមនិងការបះបោរបានឆក់យកជីវិតមនុស្ស ១០,០០០ នាក់ ក្នុងរយៈពេលដូចគ្នានោះ។

ទ្វេគ្រោះនៃវប្បធម៌អហិង្សា គឺរបៀបឆ្លើយតបនឹងអំពើហិង្សា។ គន្ធីបានជឿថា តែងតែមានជម្រើសទីបីចំពោះភាពអសកម្ម ឬការឆ្លើយតបដោយទង្វើតាមសមាមាត្រ។ វប្បធម៌អហិង្សាមិនតែងតែទទួលបានជោគជ័យ នៅពេលប្រឈមមុខនឹងអំពើហិង្សា ប៉ុន្តែ អំពើហិង្សាក៏ប្រហែលមិនជោគជ័យដែរ។ ទោះជាយ៉ាងណាក៏ដោយ មេដឹកនាំនយោបាយអាចជឿថា ពួកគេបានបំពេញកាតព្វកិច្ចរបស់ពួកគេ ប្រសិនបើពួកគេឆ្លើយតបដោយអំពើហិង្សាទោះមិនជោគជ័យក្តី ប៉ុន្តែ ប្រសិនបើពួកគេឆ្លើយតបដោយអហិង្សាហើយមិនទទួលបានជោគជ័យទៀត នោះបានន័យថាពួកគេមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនទេ។

៣.៦. ទ្រីស្តីយ៉ែនឌ័រ

៣.៦ ចូរកំណត់បញ្ហាសកលពីរនៅក្នុងទំនាក់ទំនងអន្តរជាតិ ដែលយេនឌ័រជាកត្តាដ៏សំខាន់ក្នុងការស្វែងយល់ឬដោះស្រាយបញ្ហានោះ។

ការសិក្សាស្រាវជ្រាវស្តីអំពីយេនឌ័របានជ្រាបចូលក្នុងមុខវិជ្ជាសិក្សាជាច្រើនអនេក ចាប់ពីមុខវិជ្ជាអក្សរសិល្ប៍រហូតដល់ចិត្តវិទ្យារហូតដល់ប្រវត្តិវិទ្យា។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ វាបានបញ្ចូលខ្លួនចូលប្រឡូកក្នុងមុខវិជ្ជាទំនាក់ទំនងអន្តរជាតិ ដែលធ្លាប់ត្រូវបានចាត់ទុកថាជាវិស័យមួយដែលធន់ទ្រាំខ្លាំងបំផុត ចំពោះ

ឥទ្ធិពលយេនឌ័រ។

៣.៦.១. ហេតុអ្វីត្រូវដកដៃពីយេនឌ័រ

ការសិក្សាស្រាវជ្រាវអំពីយេនឌ័ររួមបញ្ចូលនូវការងារជាច្រើនប្រភេទ ប៉ុន្តែការងារទាំងអស់មានទស្សនៈវិស័យរួមមួយ ដែលថា បញ្ហាយេនឌ័រមានតួនាទីសំខាន់ ក្នុងការជួយពង្រីកការយល់ដឹងរបស់យើងអំពីរបៀបដែលទំនាក់ទំនងអន្តរជាតិប្រតិបត្តិការ, ជាពិសេស នៅក្នុងបញ្ហាទាក់ទងនឹងសង្គ្រាម និងសន្តិសុខអន្តរជាតិ។ *ការសិក្សាស្រាវជ្រាវអំពីស្ត្រីនិយម* (Feminist) នៅក្នុងមុខវិជ្ជាផ្សេងៗព្យាយាមបើកកកាយ ការសន្មតលាក់កំបាំងអំពីយេនឌ័រ នៅក្នុងរបៀបដែលយើងសិក្សាមុខវិជ្ជាណាមួយ។ អ្វីដែលអ្នកប្រាជ្ញជាប្រពៃណីអះអាងថាមានលក្ខណៈជាសកល ជារឿយៗមិនដូច្នោះទេ វាគ្រាន់តែជាសច្ចៈភាពសម្រាប់មនុស្សបុរសតែប៉ុណ្ណោះ។ អ្នកប្រាជ្ញទំនាក់ទំនងអន្តរជាតិស្ត្រីនិយមខ្លះប្រកែកថា ការសន្មតស្នូលនៃទ្រឹស្តីប្រាកដនិយម (ជាពិសេសការសន្មតស្តីអំពីភាពអនាធិបតេយ្យនិងអធិបតេយ្យភាព) ឆ្លុះបញ្ចាំងពីរបៀបដែលមនុស្សប្រុសមានទំនោរក្នុងការធ្វើអន្តរកម្មនិងគ្នា និងសម្លឹងមើលឃើញពិភពលោក។ នៅក្នុងទិដ្ឋភាពនេះ គោលការណ៍ទ្រឹស្តីប្រាកដនិយមគ្រាន់តែសន្មតថា អ្នកចូលរួមឬតួអង្គទាំងឡាយគឺជាមនុស្សប្រុសនៅពេលពិភាក្សាអំពីការសម្រេចចិត្តគោលនយោបាយការបរទេស អធិបតេយ្យភាពរដ្ឋ ឬការប្រើប្រាស់កម្លាំងយោធា។

ការរិះគន់ទៅលើករណីទាំងនេះ មានភាពស្មុគស្មាញបន្តិច។ ដោយសារតែប្រមុខរដ្ឋ អ្នកការទូត និងទាហានភាគច្រើន*គឺជា*មនុស្សប្រុស វាមានភាពជាក់ស្តែងជាងក្នុងការសិក្សាពួកគេក្នុងនាមជាមនុស្សប្រុស។ ម្លោះហើយ អ្វីដែលអ្នករិះគន់មកពីទ្រឹស្តីស្ត្រីនិយមស្នើសុំនោះ គឺថា អ្នកប្រាជ្ញនានាទទួលស្គាល់យ៉ាងច្បាស់អំពីលក្ខណៈយេនឌ័ររបស់តួអង្គនៅក្នុងការសិក្សាស្រាវជ្រាវរបស់ពួកគេ (ជាជាងសន្មតមុនថាតួអង្គទាំងអស់ជាមនុស្សប្រុស)។ នៅក្នុងទិដ្ឋភាពនេះ ការយល់ដឹងរបស់យើងអំពីតួអង្គបុរស នៅក្នុងទំនាក់ទំនងអន្តរជាតិអាចត្រូវបានបង្កើន ដោយការពិចារណាអំពីរបៀបដែលអត្តសញ្ញាណយេនឌ័ររបស់ពួកគេ ជះឥទ្ធិពលលើទស្សនៈ និងដំណើរការសម្រេចចិត្តរបស់ពួកគេ។ ហើយមនុស្សស្រីក៏មានឥទ្ធិពលលើទំនាក់ទំនងអន្តរជាតិ (ច្រើនតែតាមរយៈបណ្តាញតួអង្គមិនមែនរដ្ឋ ជាងមនុស្សប្រុស), ឥទ្ធិពលទាំងនោះជារឿយៗត្រូវបានអ្នកទ្រឹស្តីប្រាកដនិយមមិនបានអើពើរហូតមកហើយ។ អ្នកខ្លះយល់ថា អ្នកប្រាជ្ញស្ត្រីទាំងឡាយមានទំនោរចាប់អារម្មណ៍លើតួនាទីនិងឥទ្ធិពលទាំងនេះ ច្រើនជាងសហការីប្រុសៗ ដែលភាគច្រើនមិនអើពើនឹងប្រធានបទយេនឌ័រ។ បញ្ជី «អ្នកប្រាជ្ញសំខាន់ៗ៥០នាក់»នៅក្នុងទំនាក់ទំនងអន្តរជាតិមានស្ត្រីចំនួន ៤ នាក់តែប៉ុណ្ណោះ ក្នុងនោះមាន ៣ នាក់បានចុះបញ្ជីជាអ្នកជំនាញយេនឌ័រ, ខណៈពេលដែលគ្មាននរណាម្នាក់ ក្នុងចំណោមអ្នកប្រាជ្ញជាបុរស ៤៦ នាក់ ត្រូវបានចុះបញ្ជីជាអ្នកប្រាជ្ញយេនឌ័រឡើយ។ ហើយនៅពេលដែលការស្ទង់មតិ ក្នុងឆ្នាំ ២០១៤ បានបញ្ចេញបញ្ជីអ្នកប្រាជ្ញទំនាក់ទំនងអន្តរជាតិ ដែលមានឥទ្ធិពលបំផុតទាំង ២០ តែបីនាក់ប៉ុណ្ណោះជាស្ត្រី។

លើសពីការបង្ហាញពីការសន្មតដែលលាក់កំបាំងអំពីយេនឌ័រក្នុងវិស័យសិក្សាស្រាវជ្រាវ, អ្នកប្រាជ្ញស្ត្រីនិយមតែងតែ*ជំទាស់នឹងគោលគំនិតប្រពៃណីអំពីយេនឌ័រ*ផងដែរ។ នៅក្នុងទំនាក់ទំនងអន្តរជាតិ, គោលគំនិតបែបប្រពៃណីទាំងនេះប្រព្រឹត្តិទៅជុំវិញការសន្មតថា មនុស្សប្រុសចូលប្រឡូកក្នុងសង្គ្រាម និងគ្រប់គ្រងរដ្ឋ ចំណែកស្ត្រី ជាទូទៅ មិនពាក់ព័ន្ធទៅនឹងទំនាក់ទំនងអន្តរជាតិនោះទេ។ តួនាទីយេនឌ័របែបនេះត្រូវផ្អែកលើការកសាងភាពជាបុរស អោយកាន់តែទូលំទូលាយ ដែលសមស្របទៅនឹងលំហានយោបាយនិង*សាធារណៈ* ចំណែក ភាពជាស្ត្រីត្រូវបានផ្សារភ្ជាប់ជាមួយនឹងលំហផ្ទះសម្បែងនិង*ឯកជន* ឬក្នុងស្រុក។

ដូចអ្នកប្រាកដនិយម(សូមមើលមេរៀនទី២) អ្នកប្រាជ្ញទ្រឹស្តីយេនឌ័របានអនុវត្តតាមទំនៀមទម្លាប់ដ៏យូរលង់មួយ។[១៥] មិនយូរប៉ុន្មានមុនពេលសម័យលោកស៊ូស៊ីឌីឌីស (Thucydides), កវីនិពន្ធស្ត្រីជនជាតិក្រិកបុរាណ ឈ្មោះ សាផូ (Sappho) បានសរសេរកំណាព្យស្នេហាជាច្រើន ទៅកាន់ស្ត្រី នៅលើកោះឡេស្ប្ស (Lesbos)។ មុនសម័យលោក ម៉ាគីយ៉ាវែលី(Machiavelli), អ្នកនិពន្ធជនជាតិអ៊ីតាលី គ្រីស្ទីន ដឺ ពីសង់ (Christine de Pisan) បានសរសើរសមត្ថភាពរបស់ស្ត្រីក្នុងការកសាងសន្តិភាព។ មួយសតវត្សរ៍បន្ទាប់ពីសម័យកាលលោក ហប (Hobbes), ម៉ារី វ៉ុលស្តូនក្រាហ្វត៍ (Mary Wollstonecraft) នៅចក្រភពអង់គ្លេសបានជជែកទាមទារសិទ្ធិស្មើគ្នាសម្រាប់ស្ត្រី។ ហើយមួយសតវត្សមុនពេលលោក ម័រហ្គិនថូវ (Morgenthau) បានបង្កើតទ្រឹស្តីប្រាកដនិយមនៅអាមេរិក, ជនជាតិអាមេរិកាំង ស៊ូហ្សាន ប. អែនថូនី (Susan B. Anthony) បានធ្វើការដោយមិនគិតពីភាពនឿយហត់ ដើម្បីសម្រេចបាននូវសន្តិភាពនិយម ការលុបបំបាត់របបទាសភាព និងសិទ្ធិស្ត្រីក្នុងការបោះឆ្នោត។

រូបថត ថ្នាក់ដឹកនាំបក្សកុម្មុយនីស្ត៍ចិន សុទ្ធតែប្រុសៗ

ការងារប្រុសៗ

អ្នកប្រាជ្ញស្ត្រីនិយម*មកពីប្រពៃណីទ្រឹស្តីផ្សេងៗគ្នា យល់ស្របគ្នាថា ការទិដ្ឋភាពយេនឌ័រនៃកិច្ចប្រជុំកំពូលអន្តរជាតិនិងរដ្ឋាភិបាលជាតិមានសារៈសំខាន់ណាស់។ នៅទីនេះ ក្រុមអ្នកកាន់អំណាចថ្មីរបស់ចិនបង្ហាញពីការផ្លាស់ប្តូរអំណាចឆ្នាំ ២០១៧*។

ក្រៅពីការយល់ស្របគ្នាជាទូទៅដែលថាយេនឌ័រមានសារៈសំខាន់, មិនមានអ្វីដែលត្រូវគេយល់ស្របគ្នាថាជា«គោលការណ៍ស្ត្រីនិយម»ចំពោះទំនាក់ទំនងអន្តរជាតិឡើយ ប៉ុន្តែ គោលការណ៍បែបនេះជាច្រើន*ផ្លូវ*(*strands*)នៃទ្រឹស្តីនិងការសិក្សាស្រាវជ្រាវ។ ទោះបីជាផ្លូងនីមួយៗត្រូវត្រួតាញ់បញ្ចូលគ្នា(ផ្លូងទាំងអស់យកចិត្តទុកដាក់ចំពោះយេនឌ័រនិងឋានៈស្ត្រី) ពួកគេតែងតែរត់ត្រួតាញ់ក្នុងទិសដៅផ្សេងៗគ្នា។ លើបញ្ហាស្នូលមួយចំនួន ផ្លូងផ្សេងគ្នានៃទ្រឹស្តីស្ត្រីនិយមមានទស្សនៈផ្ទុយគ្នា ដែលបណ្តាលអោយ មានការជជែកគ្នាគួរអោយចាប់អារម្មណ៍ *នៅក្នុង*លទ្ធិស្ត្រីនិយម។

ផ្លូងមួយ **ស្ត្រីទីទែនិយម** (difference feminism) ផ្តោតលើការអោយតម្លៃលើភាពជាស្ត្រី ពោលគឺការអោយតម្លៃលើការរួមចំណែកតែមួយគត់របស់ស្ត្រី *ក្នុងនាម* ជាស្ត្រីផ្តាល់។ ស្ត្រីទីទែនិយមមិនគិតថា ស្ត្រីធ្វើអ្វីៗទាំងអស់ដូចបុរសនោះទេ ហើយបុរសក៏មិនធ្វើអ្វីទាំងអស់ដូចស្ត្រីដែរ។ ដោយសារតែបទពិសោធន៍របស់ពួកគេផ្តោតខ្លាំងលើការចិញ្ចឹមបីបាច់និងទំនាក់ទំនងរវាងមនុស្ស, ស្ត្រីត្រូវបានគេមើលឃើញថា មានប្រសិទ្ធភាពជាងបុរស (ជាមធ្យម) ក្នុងការដោះស្រាយជម្លោះ ក៏ដូចជា ក្នុងការសម្រេចចិត្តជាក្រុម។ ស្ត្រីទីទែនិយមជឿថា មានភាពទីទែឬខុសប្លែកគ្នាយ៉ាងពិតប្រាកដរវាងយេនឌ័រ ដែលមិនមែនគ្រាន់តែជាការបង្កើតឡើង ដោយសង្គមនិងទំនៀមទំលាប់វប្បធម៌ប៉ុណ្ណោះទេ (ទោះបីជាវារួមចំណែកពីតួនាទីយេនឌ័រផងដែរ)។ ស្ត្រីទីទែនិយមខ្លះជឿថា មានលក្ខណៈខុសគ្នាផ្នែកជីវសាស្ត្រដ៏សំខាន់ សម្រាប់មនុស្សប្រុស ឬមនុស្សស្រី(ជួនកាលត្រូវគេហៅថា មូលដ្ឋានគ្រឹះនិយម-*essentialism*) ប៉ុន្តែ ភាគច្រើនគិតថា ភាពខុសគ្នារបស់ស្ត្រីផ្តោតលើលក្ខណៈវប្បធម៌ ច្រើនជាងការកំណត់ដោយលក្ខណៈជីវសាស្ត្រ។ ក្នុងករណីណាក៏ដោយ ទស្សនៈ

[១៥] ការប្រៀបធៀបទាំងនេះធ្វើឡើងដោយ Francine D'Amico ។

វិស័យស្ត្រីនិយមបង្កើត*ជំហរទស្សនៈមួយ* (standpoint) សម្រាប់សង្កេត វិភាគ និងរិះគន់ទស្សនៈបែបប្រពៃណីនៃទំនាក់ទំនងអន្តរជាតិ។ ឆ្លងមួយទៀតគឺ *ស្ត្រីសេរីនិយម*(liberal feminism) បដិសេធអំណះអំណាងទាំងនេះថាមិនមែនផ្អែកលើតួនាទីយេនឌ័រ តាមលំនាំសង្គមនោះទេ។ ស្ត្រីសេរីនិយម មើលឃើញភាពខុសគ្នា«ដ៏សំខាន់» នៅក្នុងសមត្ថភាពឬទស្សនៈរបស់បុរសនិងស្ត្រីថាជា រឿងតូចតាច ឬមិនមានទាល់តែសោះ៖ ពោលគឺបុរសនិងស្ត្រីមានសមភាពស្មើគ្នា។ ពួកគេថ្កោលទោសការដកស្ត្រីចេញពីមុខតួនាទីអំណាចនៅក្នុងទំនាក់ទំនងអន្តរជាតិ ប៉ុន្តែ មិនជឿថា ការបញ្ចូលស្ត្រីនឹងនាំការផ្លាស់ប្តូរលក្ខណៈនៃប្រព័ន្ធអន្តរជាតិឡើយ។ ស្ត្រីសេរីនិយមព្យាយាមជាក់បញ្ចូលស្ត្រីអោយកាន់តែញឹកញាប់ អោយក្លាយជាប្រធានបទនៃការសិក្សាស្រាវជ្រាវ ដូចជា ស្ត្រីជាអ្នកដឹកនាំរដ្ឋ ទាហានស្ត្រី និងស្ត្រីនៅក្នុងប្រតិបត្តិការផ្សេងៗក្រៅពីតួនាទីយេនឌ័រប្រពៃណី នៅក្នុងទំនាក់ទំនងអន្តរជាតិ។

គោលការណ៍ទីបីរួមបញ្ចូលគ្នារវាងទ្រឹស្តីស្ត្រីនិយមជាមួយនឹងទ្រឹស្តីក្រោយសម័យទំនើបនិយម(post-modernism) ដែលនឹងត្រូវពិភាក្សានៅផ្នែកបន្តបន្ទាប់ នៅក្នុងមេរៀននេះ។ **ស្ត្រីក្រោយសម័យទំនើបនិយម** (Postmondern feminism) មានទំនោរបដិសេធការសន្មតអំពីយេនឌ័រ ដែលធ្វើឡើង ដោយទ្រឹស្តីស្ត្រីទីទៃនិយមនិងទ្រឹស្តីស្ត្រីសេរីនិយម។ ដំណាលពេលដែលទ្រឹស្តីស្ត្រីទីទៃនិយមចាត់ទុកភាពខុសគ្នារវាងយេនឌ័រមានសារៈសំខាន់និងសភាពថេរ ហើយស្ត្រីសេរីនិយមចាត់ទុកភាពខុសគ្នាទាំងនោះជារឿងតូចតាច, ទ្រឹស្តីស្ត្រីក្រោយសម័យថ្មីនិយមយល់ថាភាពខុសគ្នាទាំងនោះមានសារៈសំខាន់ ប៉ុន្តែមានលក្ខណៈរំលេចេញមកតាមតែអំពើចិត្ត និងអាចបត់បែនបាន។

៣.៦.២. *ភាពជាបុរសក្នុងទ្រឹស្តីប្រាកដនិយម*

ទ្រឹស្តីស្ត្រីទីទៃនិយមផ្តល់នូវទស្សនវិស័យមួយ ដែលត្រូវត្រួតពិនិត្យមើលឡើងវិញ នូវការសន្មតស្នូលនៃទ្រឹស្តីប្រាកដនិយម ជាពិសេសការសន្មតនៃស្ថិយភាពដែលប្រភពដើមនៃគោលគំនិតទ្រឹស្តីប្រាកដនិយមសំខាន់ៗស្តីពីអធិបតេយ្យភាព និងអនាធិបតេយ្យ។ ចំពោះអ្នកប្រាជ្ញទ្រឹស្តីប្រាកដនិយម ប្រព័ន្ធអន្តរជាតិមានតួអង្គស្ថិយភាព(រដ្ឋ) ដែលគ្រប់គ្រងទឹកដីរបស់ពួកគេ ហើយគ្មានសិទ្ធិរំលោភលើបូរណភាពទឹកដីរបស់រដ្ឋដទៃឡើយ។ អ្នកប្រាជ្ញស្ត្រីទីទៃនិយមខ្លះបានអះអាងថា ទ្រឹស្តីប្រាកដនិយមសង្កត់ធ្ងន់លើស្ថិយភាព និងការបំបែកខ្លួន ដោយសារមនុស្សប្រុសយល់ថាការបំបែកខ្លួនងាយស្រួលដោះស្រាយជាងការភ្ជាប់ទំនាក់ទំនងនឹងគ្នាទៅវិញទៅមក។

ទស្សនៈនេះពឹងផ្អែកលើទ្រឹស្តីចិត្តសាស្ត្រ ដែលថា តាំងពីក្មេងមក ក្មេងប្រុសនិងក្មេងស្រីធំធាត់ឡើងជាមួយនឹងទស្សនៈផ្សេងគ្នាក្នុងការបំបែកខ្លួននិងទំនាក់ទំនងគ្នា។ នៅក្នុងទ្រឹស្តីនេះ ដោយសារតែអ្នកថែទាំកុមារជាចំបង់គឺជាស្ត្រី តាំងពីនៅកូនង៉ាមកម្លេះ, ក្មេងស្រីបង្កើតអត្តសញ្ញាណយេនឌ័ររបស់ពួកគេ តាមរយៈការមើលឃើញ*ភាពស្រដៀងគ្នា*រវាងខ្លួននឹងអ្នកថែទាំពួកគេ (ហើយនឹងបរិយាកាសដែលពួកគេរស់នៅ) ប៉ុន្តែក្មេងប្រុសមើលឃើញ*ភាពខុសគ្នា*រវាងខ្លួននឹងអ្នកថែទាំពួកគេ។ ចេញពីបទពិសោធន៍នេះ ក្មេងប្រុសបង្កើតទំនាក់ទំនងសង្គមដោយផ្អែកលើស្ថិយភាពបុគ្គល ប៉ុន្តែ ទំនាក់ទំនងរបស់ក្មេងស្រីត្រូវផ្អែកលើការតភ្ជាប់យ៉ាងស្អិតរមួត។ ជាលទ្ធផល ស្ត្រីទំនងជាខ្លាចការបោះបង់ចោលជាងបុរស ចំណែកវិញ បុរសទំនងជាខ្លាចភាពស្និទ្ធស្នាលនៅក្នុងទំនាក់ទំនងជាងស្ត្រី។

នៅក្នុងហេតុផលខាង*សីលធម៌* យោងតាមទ្រឹស្តីនេះ ក្មេងប្រុសមានទំនោរអនុវត្តច្បាប់ឬវិន័យអរូបី និងសង្កត់ធ្ងន់លើសិទ្ធិបុគ្គល ប៉ុន្តែ ក្មេងស្រីយកចិត្តទុកដាក់បន្ថែមទៀតចំពោះបរិបទជាក់ស្តែងនៃស្ថានភាព ផ្សេងៗគ្នា និងការទទួលខុសត្រូវចំពោះគ្នាទៅវិញទៅមក ក្នុងចំណោមសមាជិកក្រុម។ ក្នុងការលេង*ហ្គេម* ក្មេងប្រុសដោះស្រាយវិវាទតាមរយៈការជជែកគ្នាអំពីវិន័យឬលក្ខណ្ឌនានា ហើយបន្ទាប់មក បន្តលេងហ្គេមនោះទៀត ប៉ុន្តែ ក្មេងស្រីទំនងជាបោះបង់ចោលហ្គេម ជាជាងការឈ្លោះប្រកែកគ្នាលើច្បាប់ទម្លាប់និងប្រថុយបាត់បង់ទំនាក់ទំនងសង្គមក្នុងក្រុមរបស់ពួកគេ។ នៅក្នុងទំនាក់ទំនងសង្គម ក្មេងប្រុសបង្កើតនិងផ្តាច់ចំនងមិត្តភាពបានយ៉ាងងាយស្រួលជាងក្មេងស្រីដែលទំនងជារក្សាភក្តីភាពជាមួយមិត្តភក្តិ។ (ភ័ស្តុតាងជាក់ស្តែងនៅក្នុងការស្រាវជ្រាវចិត្តសាស្ត្រសម្រាប់ភាពខុសគ្នាខាងយេនឌ័រតាមទ្រឹស្តីទាំងនេះ យ៉ាងច្រើន ចង្អុលបង្ហាញផ្សេងៗគ្នា។)

ជាការពិតណាស់ ទ្រឹស្តីប្រាកដនិយមពឹងផ្អែកលើគោលគំនិតដែលថា រដ្ឋជាតួអង្គស្វ័យភាព ដាច់ដោយឡែកពីគ្នា ដែលបង្កើតនិងបំបែកសម្ព័ន្ធភាព ដោយសេរី ខណៈពេលដែលស្វែងរកផលប្រយោជន៍ផ្ទាល់ខ្លួន (ប៉ុន្តែ មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់គ្នាឡើយ)។ គោលគំនិតអំពីស្វ័យភាពបែបនេះ ស្របនឹងចិត្តសាស្ត្រប្រុសៗដែលទើបតែបានពិពណ៌នាខាងលើ។ ដូច្នេះ អ្នកប្រាជ្ញស្ត្រីនិយមមួយចំនួនរកឃើញនៅក្នុងទ្រឹស្តីប្រាកដនិយមនូវការសន្មតដ៏លាក់កំបាំងស្តីពីភាពជាបុរស។ លើសពីនេះទៅទៀត ភាពខុសគ្នាស្រឡះដែលអ្នកប្រាជ្ញប្រាកដនិយមបានគូសបញ្ជាក់ រវាងនយោបាយអន្តរជាតិ(អនាធិបតេយ្យ) និងនយោបាយក្នុងស្រុក(សណ្តាប់ធ្នាប់) ស្របគ្នាទៅនឹង ភាពខុសគ្នានៃតួនាទីយេនឌ័រ រវាងលំហសាធារណៈ(បុរស) និងភាពឯកជន (ស្ត្រី)។ ដូច្នេះ ទ្រឹស្តីប្រាកដនិយមបង្កើតទំនាក់ទំនងអន្តរជាតិជាពិភពលោករបស់មនុស្សប្រុស។

ផ្ទុយទៅវិញ ប្រព័ន្ធអន្តរជាតិដែលពឹងផ្អែកលើគោលការណ៍*ស្ត្រី* អាចផ្តល់សារៈសំខាន់ខ្លាំងជាងសម្រាប់ការពឹងអាស្រ័យគ្នាទៅវិញទៅមករបស់រដ្ឋនានា ជាជាងស្វ័យភាពរបស់ពួកគេ ដោយសង្កត់ធ្ងន់លើទំនួលខុសត្រូវរបស់មនុស្សក្នុងការថែរក្សាឬជួយយកអាសារគ្នាទៅវិញទៅមក ដោយមិនប្រកាន់អំពីរដ្ឋនិងព្រំដែនឡើយ។ នៅក្នុងការប្រកួតប្រជែងរវាងគោលការណ៍សិទ្ធិមនុស្ស និងគោលការណ៍អធិបតេយ្យភាព (ការមិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុង), សិទ្ធិមនុស្សនឹងទទួលបានអាទិភាពជាង។ នៅក្នុងជម្រើសរវាងទម្រង់នៃអនុភាពសម្រាប់គាបសង្កត់ នៅពេលដែលជម្លោះកើតឡើងរវាងរដ្ឋនានា អំពើហិង្សាអាចមិនសូវកើតឡើងនោះទេ។ (រឿងទាំងនេះអាចនឹងកើតឡើង លុះត្រាតែប្រព័ន្ធអន្តរជាតិដែលពឹងផ្អែកលើគោលការណ៍*ស្ត្រី*។)

រូបថត *រដ្ឋមន្ត្រីការបរទេសស៊ុយអែតជាស្ត្រីកំពុងប្រជុំជាមួយសមភាគីជាបុរស*

អាសនៈមួយនៅតុប្រជុំ

អ្នកប្រាជ្ញស្ត្រីនិយមសង្កត់ធ្ងន់លើសារៈសំខាន់នៃតួនាទីយេនឌ័រ នៅក្នុងទំនាក់ទំនងអន្តរជាតិ ជាពិសេសភាពខុសគ្នាបែបប្រពៃណីរវាងបុរសនៅក្នុងតួនាទីនយោបាយ-យោធា និងស្ត្រីនៅក្នុងតួនាទីនៅក្នុងគ្រួសារ។ ពួកគេគិតថា ការផ្លាស់ប្តូរការបែងចែកនេះអាចផ្លាស់ប្តូរទំនាក់ទំនងអន្តរជាតិ។ នៅទីនេះ រដ្ឋមន្ត្រីការបរទេសស៊ុយអែត លោកស្ត្រី ម៉ាហ្គត វ៉ាល់ស្ត្រម (Margot Wallstrom) ចរចាជាមួយអតីតរដ្ឋមន្ត្រីការបរទេសអាមេរិក លោក រ៉ិច ធីឡឺសុន (Rex Tillerson) ក្នុងកិច្ចប្រជុំរបស់អង្គការសន្តិសុខ និងសហប្រតិបត្តិការនៅអឺរ៉ុប (OSCE) ឆ្នាំ ២០១៧។

បុរេនិច្ឆ័យរបស់អ្នកប្រាជ្ញប្រាកដនិយមស្តីអំពីការវិភាគកម្រិតប្រព័ន្ធសន្ទតថា តក្កវិជ្ជានៃសង្គ្រាមផ្តាល់មានលក្ខណៈស្វ័យភាព ហើយអាចត្រូវបានបំបែកចេញពីទំនាក់ទំនងសង្គមផ្សេងទៀត ដូចជាទំនាក់ទំនងសេដ្ឋកិច្ច នយោបាយក្នុងស្រុក ការប្រកាន់ភេទភាវៈ និងការប្រកាន់ពូជសាសន៍។ ទោះជាយ៉ាងណាក៏ដោយ ទ្រឹស្តីស្ត្រីទីទៃនិយមបង្ហាញពី *ទំនាក់ទំនង*នៃបាតុភូតទាំងនេះជាមួយនឹងសង្គ្រាម។ វាណែនាំនូវមធ្យោបាយថ្មីសម្រាប់ស្វែងយល់អំពីសង្គ្រាម នៅក្នុងការវិភាគកម្រិតក្នុងស្រុកនិងបុគ្គលៈមូលហេតុជាចម្បង់ដែលអ្នកប្រាជ្ញប្រាកដនិយមភាគច្រើនព្រងើយកន្តើយ។

តាមទស្សនៈទ្រឹស្តីស្ត្រីទីទៃនិយមនេះ ទ្រឹស្តីសេរីនិយមថ្មីបានបកចេញក្រោយ ចេញពីទ្រឹស្តីសេរីនិយមបែបប្រពៃណី ដោយទទួលយកការសន្ទតរបស់អ្នកប្រាជ្ញប្រាកដនិយម ស្តីពីរដ្ឋឯកភូត ជាចំដោយឡែក ថាជាតួអង្គសំខាន់ និងមិនសូវអោយតម្លៃតួអង្គក្នុងរដ្ឋនានា និងតួអង្គឆ្លងជាតិទាំងឡាយ រួមទាំងស្ត្រីផងដែរ។ គោលគំនិតរបស់ទ្រឹស្តីសេរីនិយមថ្មីស្តីពីកិច្ចសហប្រតិបត្តិការថាជាអន្តរកម្មដោយផ្អែកលើច្បាប់ រវាងតួអង្គស្វ័យភាពក៏ឆ្លុះបញ្ចាំងពីការសន្ទតភាពជាបុរសផងដែរ។

៣.៦.៣. យេនឌ័រ ក្នុងសង្គ្រាមនិងសន្តិភាព

ក្រៅពីការសង្កត់ធ្ងន់លើស្វ័យភាពនិងភាពអនាធិបតេយ្យ, ទ្រឹស្តីប្រាកដនិយមសង្កត់ធ្ងន់លើកម្លាំងយោធាជាទម្រង់សំខាន់នៃអានុភាពនៅក្នុងទំនាក់ទំនងអន្តរជាតិ។ នៅទីនេះផងដែរ អ្នកប្រាជ្ញស្ត្រីទីទៃនិយមជាច្រើនមើលឃើញនៅក្នុងទ្រឹស្តីប្រាកដនិយមនូវការសន្ទតលាក់កំបាំងនៃភាពជាបុរស។ ពួកគេសង្កេតឃើញថាសង្គ្រាម មិនត្រឹមតែជាមុខរបររបស់បុរសប៉ុណ្ណោះទេ ថែមទាំងជាមុខរបរដ៏សំខាន់ផ្តាច់មុខបុរសៗផងដែរ។ យោងតាមទិដ្ឋភាពនេះ បុរសភេទជាមនុស្សចូលចិត្តបង្កសង្គ្រាម ហើយស្ត្រីមានលក្ខណៈសន្តិភាពជាង។ ទោះបីជាទ្រឹស្តីប្រាកដនិយមអាចបង្ហាញយ៉ាងត្រឹមត្រូវអំពីសារៈសំខាន់នៃសង្គ្រាមនិងកម្លាំងយោធា នៅក្នុងទំនាក់ទំនងអន្តរជាតិ ដូចដែលយើងបានដឹង ឥឡូវនេះក៏ដោយ វាហាក់មិនឆ្លុះបញ្ចាំងពីការត្រួតត្រារបស់បុរសនៅក្នុងលំហអន្តរជាតិរហូតមកដល់បច្ចុប្បន្ន មិនមែនជាតក្កវិជ្ជានៃទំនាក់ទំនងក្នុងចំណោមរដ្ឋនានា ជាចាំបាច់ជានិច្ចនិរន្តរ៍ ឬគេចមិនរួចនោះទេ។

អ្នកប្រាជ្ញទ្រឹស្តីស្ត្រីទីទៃនិយមព្យាយាមស្វែងរកកស្តុតាងជាច្រើន ដើម្បីគាំទ្រគំនិតដែលថា សង្គ្រាមជាការផ្សងព្រេងរបស់បុរស។ អ្នកស្រាវជ្រាវផ្នែកនរវិទ្យាបានរកឃើញថា នៅក្នុងវប្បធម៌ដែលគេស្គាល់ទាំងអស់ បុរសគឺជាអ្នកប្រយុទ្ធចម្បង(ហើយជាធម្មតាមានតែប្រុសៗប៉ុណ្ណោះ)នៅក្នុងសង្គ្រាម ទោះបីជាវប្បធម៌ទាំងអស់នោះ មានភាពចម្រុះប្លែកពីគ្នា តាមរបៀបផ្សេងទៀត ក៏ដោយ។ (ជាការពិតណាស់ ការបោះឆ្នោត និងការដឹកនាំនយោបាយក៏ជាដែនសមត្ថកិច្ចរបសបុរស នៅក្នុងប្រវត្តិសាស្ត្រភាគច្រើនដែរ ប៉ុន្តែ អ្នកប្រាជ្ញស្ត្រីនិយមមិនហៅសកម្មភាពទាំងនោះថាជាភាពជាបុរសជាចម្បងនោះទេ។)

ទំនាក់ទំនងរវាងសង្គ្រាមនិងភាពជាបុរស ត្រូវគេសន្ទតថាជា អរម៉ូនតេស្តូរ៉ូន(Testosterone)របស់ភេទប្រុស (រួមជាមួយនឹងអរម៉ូនពាក់ព័ន្ធផ្សេងទៀត) ដែលជីវិទូមួយចំនួនបានភ្ជាប់ជាមួយនឹងអាកប្បកិរិយាឈ្លានពាន នៅក្នុងការរស់នៅរបស់សត្វនានា។ ទោះជាយ៉ាងណាក៏ដោយអ័រម៉ូនតេស្តូស្តេរ៉ូនមិន *បង្ករអោយ* មានការឈ្លានពានទេ។ ផ្ទុយទៅវិញ អន្តរកម្មសង្គមទៅវិញទេ ដែល«ផ្តល់មតិត្រឡប់»ដើម្បីកំណត់កម្រិតតេស្តូស្តេរ៉ូន (កម្រិតតេស្តូស្តេរ៉ូនរបស់អ្នកជោគជ័យកើនឡើង ខណៈពេលដែលកម្រិតរបស់អ្នកបរាជ័យធ្លាក់ចុះ)។ ដូច្នេះ អ័រម៉ូនតេស្តូស្តេរ៉ូនគឺជាតំណភ្ជាប់នៅក្នុងប្រព័ន្ធដ៏ស្មុគស្មាញ នៃទំនាក់ទំនងរវាងសារពាង្គកាយ

និងបរិយាកាសសង្គម។ អាកប្បកិរិយាដ៏ស្មុគស្មាញ ដូចជាការឈ្លានពាននិងសង្គ្រាម មិនអាចត្រូវបានគេនិយាយថាត្រូវបាន*ជំរុញ*ដោយកត្តាជីវសាស្ត្រ ឬត្រូវបានកំណត់ទុកជាមុនទេ ពីព្រោះសមត្ថភាពជីវសាស្ត្រដ៏ទាក់ទាញបំផុតរបស់មនុស្សជាតិ គឺភាពបត់បែន។ សូម្បីតែអ្នកប្រាជ្ញស្ត្រីនិយមមួយចំនួនដែលមើលឃើញភាពខុសគ្នាខាងយេនឌ័រថាមានលក្ខណៈវប្បធម៌យ៉ាងតឹងរ៉ឹង និងមិនមានលក្ខណៈជីវសាស្ត្រក៏ដោយ ក៏ចាត់ទុកសង្គ្រាមថាជាសមត្ថកិច្ចរបស់បុរសដែរ។

ទាំងផ្នែកជីវសាស្ត្រ និងផ្នែកនរវិទ្យា គ្មានភស្តុតាងច្បាស់លាស់ណាមួយដែលភ្ជាប់មុខងារថៃទាំរបស់ស្ត្រី(ការមានផ្ទៃពោះ និងការបំបៅកូន) ជាមួយនឹងអាកប្បកិរិយាជាក់លាក់ណាមួយ ដូចជាការផ្សះផ្សា ឬអហិង្សានោះទេ ទោះបីស្ត្រីត្រូវបានគេសិក្សាតិចជាងបុរសក៏ដោយ។ តួនាទីរបស់ស្ត្រីប្រែប្រួលយ៉ាងខ្លាំងពីសង្គមមួយទៅសង្គមមួយទៀត។ ទោះបីជាពួកគេកម្រចូលរួមក្នុងសមរភូមិក៏ដោយ ជួនកាលស្ត្រីផ្តល់ការគាំទ្រផ្នែកដឹកជញ្ជូនភស្តុភារដល់អ្នកចម្បាំងដែលជាបុរសភេទ ហើយជួនកាល ជួយជំរុញបុរសអោយចូលទៅក្នុងសង្គ្រាម ដោយការរាំរែក ការចំអកដាក់បុរសដែលមិនចូលរួម និងសកម្មភាពផ្សេងទៀតដែលគាំទ្រសង្គ្រាម។ ប៉ុន្តែ នៅក្នុងវប្បធម៌ផ្សេងទៀត ស្ត្រីរារាំងបុរសមិនអោយធ្វើសង្គ្រាម ឬដើរតួនាទីពិសេស ជាអ្នកសម្រុះសម្រួលក្នុងដំណើរការបញ្ចប់សង្គ្រាម។

រូបថត *នាង ម៉ាឡាឡា យូសាហ្សៃ ទទួលពានរង្វាន់ណូបែលសន្តិភាព*

អំណាចស្ត្រី

ស្ត្រីទីទៃនិយមសង្កេតឃើញថា ស្ត្រីមិនសូវចូលចិត្តសង្គ្រាមដូចបុរសនោះទេ ហើយថែមទាំងមានជំនាញក្នុងការបង្កើតសន្តិភាពជាង ដោយសារតែសក្តានុពល និងបទពិសោធន៍ជាក់ស្តែងរបស់ពួកគេក្នុងនាមជាម្តាយ។ ក្នុងទិដ្ឋភាពនេះ ស្ត្រីមានតួនាទីខុសគ្នាក្នុងនយោបាយ ហើយក៏មានតម្រូវការខុសគ្នាដែរ។ ក្នុងអំឡុងពេលគ្រប់គ្រងរបស់ពួកតាលីបង់នៅប្រទេសអាហ្វហ្គានីស្ថាន និងផ្នែកខ្លះនៃប្រទេសប៉ាគីស្ថាន ក្មេងស្រីត្រូវបានហាមឃាត់មិនឱ្យចូលសាលារៀន។ នាង ម៉ាឡាឡា យូសាហ្សៃ (Malala Yousafzai) បានតស៊ូមតិដើម្បីសិទ្ធិមនុស្ស ជាពិសេសសិទ្ធិទទួលបានការអប់រំរបស់ស្ត្រី នៅក្នុងប្រទេសប៉ាគីស្ថាន។ នាងបានរួចផុតពីការប៉ុនប៉ងធ្វើឃាត ក្នុងឆ្នាំ ២០១២ ហើយបានបន្តក្លាយជាបុគ្គលក្មេងបំផុតដែលឈ្នះរង្វាន់ណូបែលសន្តិភាព ក្នុងឆ្នាំ ២០១៤ ។

គំនិតដែលថា ស្ត្រីជាអ្នកបង្កើតសន្តិភាព មានប្រវត្តិជាយូរលង់ណាស់មកហើយ។ នៅក្នុងរដ្ឋបុរីអាថែនបុរាណ អ្នកនិពន្ធរឿងល្ខោន អារីស្តូផេន (Aristophanes) (ដែលជាបុរស) បានប៉ាន់ស្មានអំពីរបៀបដែលស្ត្រីអាចបញ្ចប់សង្គ្រាមប៉េឡូប៉ូនេស៊ី (Peloponnesian) ដែលមិនពេញនិយម ជាមួយនឹងរដ្ឋបុរីស្ប៉ាត (Sparta) ដែលក្នុងពេលនោះ កំពុងត្រូវបានចរចា។ (រឿងល្ខោនរបស់គាត់ *ឡាសុីស្ត្រាតា* (Lysistrata) ត្រូវបានគេអាននៅក្នុងទីតាំង ១,០០០ កន្លែង ក្នុង ៥៦ ប្រទេស នៅថ្ងៃទី ៣ ខែមីនា ឆ្នាំ ២០០៣ ដើម្បីតវ៉ាប្រឆាំងនឹងសង្គ្រាមអ៊ីរ៉ាក់ ដែលជិតផ្ទុះឡើង។) នៅក្នុងរឿងល្ខោននោះ ស្ត្រីវ័យក្មេងម្នាក់ ដែលមានឈ្មោះថា *ឡាសុីស្ត្រាតា* បានកៀងគរស្ត្រីអាថែននិងស្ប៉ាតផ្តាក់រួមសង្វាសជាមួយបុរស រហូតដល់ពេលប្រុសៗបញ្ឈប់សង្គ្រាម (ស្ត្រីទាំងនោះក៏លួចយករតនាគារសង្គ្រាមផងដែរ)។ សរុបរួមមក ប្រុសៗភ្ជាក់ខ្លួន ហើយធ្វើឲ្យមានសន្តិភាព។ ស្ត្រីបានបង្កើតអង្គការរបស់ខ្លួន ដើម្បីធ្វើការកសាងសន្តិភាព ក្នុងឱកាសជាច្រើន។ នៅឆ្នាំ ១៨៥២ *សម្លេងស្ត្រី* (Sisterly Voices) ត្រូវបានបោះពុម្ពជាព្រឹត្តិបត្រព័ត៌មាន សម្រាប់សង្គមសន្តិភាពរបស់ស្ត្រី។

លោកស្រី ប៊ឺតា វ៉ុន ស៊ុតន័រ (Bertha von Suttner) ក្នុងឆ្នាំ ១៨៩២ បានបញ្ចុះបញ្ចូលលោក អាល់ហ្វ្រេដ ណូបែល (Alfred Nobel) អោយបង្កើតពានរង្វាន់ណូបែលសន្តិភាព (ដែលលោកស្រី ស៊ុតន័រ ផ្ទាល់ ទទួលបាន នៅឆ្នាំ១៩០៥)។ ក្នុងកំឡុងសង្គ្រាមលោកលើកទី១ ក្នុងឆ្នាំ១៩១៥ អ្នកនាង ចេន អាដាម (Jane Addams) និងអ្នកប្រាជ្ញស្ត្រីនិយមជនជាតិទៀត បានកោះប្រជុំសន្និសិទសន្តិភាពរបស់ស្ត្រីអន្តរជាតិនៅឯទីក្រុងឡាអេ។ ពួកគេបានបង្កើតគណបក្សសន្តិភាពស្ត្រី (បច្ចុប្បន្នត្រូវបានគេហៅថា សម្ព័ន្ធអន្តរជាតិដើម្បីសន្តិភាព និងសេរីភាពស្ត្រី)។ បន្ទាប់ពីសង្គ្រាមលោកលើកទី ១ ចលនាទាមទារសិទ្ធិបោះឆ្នោតសម្រាប់ស្ត្រី ទទួលបានជោគជ័យ។ អ្នកប្រាជ្ញស្ត្រីទីនៃនិយមបានគិតទុកមុនថា ស្ត្រីនឹងបោះឆ្នោតដើម្បីគាំទ្រសន្តិភាព និងប្រឆាំងនឹងសង្គ្រាម ដោយផ្លាស់ប្តូរលក្ខណៈគោលនយោបាយការបរទេស ប៉ុន្តែ ស្ត្រីជាទូទៅសម្រេចបោះឆ្នោត ដូចប្តីរបស់ពួកគេ។ ដូចគ្នានេះដែរ ជាច្រើនទស្សវត្សរ៍ក្រោយមក នៅពេលដែលស្ត្រីបានចូលរួមក្នុងការតស៊ូរំដោះប្រឆាំងនឹងអាណានិគមនិយម នៅអឌ្ឍគោលភាគខាងត្បូង អ្នកប្រាជ្ញស្ត្រីនិយមមួយចំនួនបានគិតថា ការចូលរួមបែបនេះ នឹងផ្លាស់ប្តូរគោលនយោបាយការបរទេស នៅក្នុងប្រទេសដែលទើបនឹងឯករាជ្យថ្មីៗ ប៉ុន្តែជាទូទៅ ការផ្លាស់ប្តូរបែបនេះ មិនបានសម្រេចទេ(ម្យ៉ាងដោយសារតែស្ត្រីជារឿយៗត្រូវបានរុញច្រានអោយឆ្ងាយពីអំណាចនយោបាយ បន្ទាប់ពីបដិវត្តន៍)។

យ៉ាងណាក៏ដោយ មតិសាធារណៈរបស់សហរដ្ឋអាមេរិកលើបញ្ហាគោលនយោបាយការបរទេស ចាប់តាំងពីទសវត្សរ៍ឆ្នាំ ១៩៣០មក ជួយដោះសារអ្នកប្រាជ្ញស្ត្រីទីនៃនិយម។ **គម្លាតយេនឌ័រ**ក្នុងការស្ទាបស្ទង់មតិនានាបង្ហាញថា ជាមធ្យម ស្ត្រីមានប្រហែលដប់ភាគរយ ទាបជាងភាគរយបុរស ក្នុងការគាំទ្រសកម្មភាពយោធា។ ទោះជាយ៉ាងណាក៏ដោយ គម្លាតយេនឌ័រនេះបានថយចុះ នៅពេលដែលមានការយល់ស្របយ៉ាងទូលំទូលាយលើសកម្មភាពយោធា ដូចជា នៅពេលដែលកងកម្លាំងសហរដ្ឋអាមេរិកបានវាយប្រហារអ្នកគាំទ្រភេរវកម្ម នៅអាហ្វហ្គានីស្ថាន នៅចុងឆ្នាំ ២០០១។

ទន្ទឹមនឹងនេះ អ្នកប្រាជ្ញស្ត្រីនិយម ក្នុងប៉ុន្មានទសវត្សរ៍ថ្មីៗនេះ បានបន្តរៀបចំអង្គការសន្តិភាពរបស់ស្ត្រី។ នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ សកម្មភាពរបស់ស្ត្រីសម្រាប់ការរំសាយអាវុធនុយក្លេអ៊ែរ (WAND) បានប្រឆាំងនឹងការផលិតអាវុធនុយក្លេអ៊ែរ ហើយស្ត្រីបានបោះជំរំជាច្រើនឆ្នាំ នៅឯមូលដ្ឋានទ័ពអាកាសហ្គ្រីនហាម ខុមុន (Greenham Common) របស់ចក្រភពអង់គ្លេស។ នៅឆ្នាំ ១៩៩៥ សន្និសីទទីក្រុងប៉េកាំង ដែលឧបត្ថម្ភដោយអង្គការសហប្រជាជាតិស្តីពីស្ត្រី បានប្រមូលផ្តុំសកម្មជនស្ត្រីមកពីគ្រប់ទិសទី នៅជុំវិញពិភពលោក និងបានជួយបង្កើនការចូលរួមរបស់អ្នកប្រាជ្ញស្ត្រីនិយម ជាមួយនឹងបញ្ហាសកល ដូចជា វិសមភាពរវាងអឌ្ឍគោលខាងជើងនិងខាងត្បូង។

នៅឆ្នាំ ២០០០ ក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិបានអនុម័តសេចក្តីសម្រេចចិត្ត លេខ ១៣២៥ ដោយតម្រូវអោយមានការរួមបញ្ចូលស្ត្រីកាន់តែច្រើន ឡើងនិងការយកចិត្តទុកដាក់ចំពោះយេនឌ័រ នៅក្នុងបេសកកម្មថែរក្សាសន្តិភាពនិងការកសាងជាតិឡើងវិញ របស់អង្គការសហប្រជាជាតិ។ ប៉ុន្តែ នៅក្នុងទីតាំងជាច្រើន កងរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិបានប្រព្រឹត្តិអំពើពេស្យាចារក្នុងស្រុក ការរំលោភសេពសន្ធវៈ និងសូម្បីតែការជួញដូរផ្លូវភេទ។ ក្នុងឆ្នាំ ២០០៤ អគ្គលេខាធិការអង្គការសហប្រជាជាតិ លោក កូហ្វី អាណាន់ (Cofi Annan) បានហៅប្រើពាក្យ «គួរអោយអាម៉ាស់» ចំពោះអាកប្បកិរិយាដែលត្រូវបានរាយការណ៍ស្តីអំពីកងទ័ពអង្គការសហប្រជាជាតិមកពីប្រទេសជាច្រើន ដែលកំពុងបម្រើការនៅក្នុងប្រទេស

ប្រជាធិបតេយ្យកុងហ្គោ។ អ្នកស៊ើបអង្កេតបានរកឃើញករណីឧក្រិដ្ឋកម្មផ្លូវភេទរាប់រយករណី ដែលប្រព្រឹត្តិដោយបុគ្គលិកអង្គការសហប្រជាជាតិ(សូមមើលមេរៀនទី ៧ បន្ថែម)។

ជាលទ្ធផលនៃដំណោះស្រាយរបស់ក្រុមប្រឹក្សាសន្តិសុខលេខ១៣២៥, «ទីប្រឹក្សាយេនឌ័រ» បានចាប់ផ្តើមអមដំណើរប្រតិបត្តិការរក្សាសន្តិភាពនិងជំនួយសង្គ្រោះបន្ទាន់អន្តរជាតិ ដើម្បីផ្តល់ដំបូន្មានជាក់ស្តែងលើប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពបន្ថែមទៀត នៅក្នុងបរិបទនៃទំនាក់ទំនងយេនឌ័រ របស់វប្បធម៌ក្នុងតំបន់នីមួយៗ។ ឧទាហរណ៍ ប្រធានក្រុមបុរសជនជាតិស៊ុយអែត ដែលត្រូវបានបញ្ជូនទៅសាងសង់ស្ពាន នៅក្នុងប្រទេសស្រីលង្កា ដំបូងបាននិយាយថា «ការកិច្ចរបស់យើងត្រូវសាងសង់ស្ពាន យើងមិនចាំបាច់បារម្ភអំពីបញ្ហាយេនឌ័រទេ»។ ពេលត្រូវគេចោទសួរថា តើវានឹងត្រូវប្រើប្រាស់ ដោយរបៀបណា? គាត់បានឆ្លើយថា «ដោយឡាន ភាគច្រើន» ប៉ុន្តែពេលសួរថា «ដោយមនុស្សស្រីដែរឬទេ?» គាត់បានឆ្លើយតបថា «ទេ ពួកគេប្រហែលជាដើរ»។ ជាលទ្ធផលនៃទស្សនៈយេនឌ័រនេះ ស្ពាននោះត្រូវបានរចនាឡើងវិញ ដើម្បីរួមបញ្ចូលផ្លូវសម្រាប់ថ្មើរជើង។[១៦]

តាមរយៈសកម្មភាពផ្សេងៗទាំងនេះ អ្នកប្រាជ្ញស្ត្រីទីទៃនិយមបានចាប់ផ្តើមបង្កើតការអនុវត្តស្ត្រីនិយមក្នុងទំនាក់ទំនងអន្តរជាតិ ដែលអាចផ្តល់ជម្រើសមួយផ្សេងពីការអនុវត្តទ្រឹស្តីប្រាកដនិយម ក្នុងភាពជាបុរស។ បាវចនារបស់ អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ របស់អង្គការសហប្រជាជាតិ ហៅកាត់ថា អង្គការយូណេស្កូ បានចែងថា «ដោយសារតែសង្គ្រាមចាប់ផ្តើមពីក្នុងគំនិតរបស់មនុស្សប្រុស វាស្ថិតនៅក្នុងគំនិតរបស់មនុស្សប្រុសដែលមូលដ្ឋានគ្រឹះនៃសន្តិភាពគួរតែត្រូវបានចាប់ផ្តើមនិងកសាងឡើង»។ ចំពោះអ្នកប្រាជ្ញទ្រឹស្តីស្ត្រីទីទៃនិយម សង្គ្រាមពិតជាចាប់ផ្តើមពីក្នុងគំនិតរបស់មនុស្សប្រុស ប៉ុន្តែ មូលដ្ឋានគ្រឹះសម្រាប់សន្តិភាពនឹងត្រូវបានកសាងឡើងពីក្នុងគំនិតរបស់ស្ត្រីប្រសើរជាង។

៣.៦.៤. ស្ត្រីនៅក្នុង ទំនាក់ទំនងអន្តរជាតិ

អ្នកប្រាជ្ញស្ត្រីសេរីនិយមមានមន្ទិលសង្ស័យចំពោះ ការរិះគន់របស់អ្នកប្រាជ្ញស្ត្រីទីទៃនិយម ទៅលើទ្រឹស្តីប្រាកដនិយម។ ពួកគេជឿថា នៅពេលដែលស្ត្រីត្រូវបានអនុញ្ញាតអោយចូលរួមក្នុងទំនាក់ទំនងអន្តរជាតិ ពួកគេលេងហ្គេម ជាទូទៅ ដូចគ្នានឹងការលេងរបស់បុរសផងដែរ ដោយមានលទ្ធផលស្រដៀងគ្នា។ ពួកគេគិតថា ស្ត្រីអាចអនុវត្តទ្រឹស្តីប្រាកដនិយម ដោយផ្អែកលើស្ថិយភាព អធិបតេយ្យភាព អនាធិបតេយ្យ ទឹកដី កម្លាំងយោធា និងអ្វីៗផ្សេងទៀត បានដូចបុរសផងដែរ។ ដូច្នេះ អ្នកប្រាជ្ញស្ត្រីសេរីនិយមមានទំនោរបដិសេធការរិះគន់ដែលថាទ្រឹស្តីប្រាកដនិយមសម្រាប់តែបុរស។ (នៅក្នុងការអនុវត្តជាក់ស្តែង អ្នកប្រាជ្ញស្ត្រីនិយមជាច្រើនបានពឹងផ្អែកលើទស្សនៈស្ត្រីទីទៃនិយមនិងស្ត្រីសេរីនិយម នៅក្នុងសមាមាត្រផ្សេងៗគ្នា។)

ទ្រឹស្តីសេរីនិយម ផ្តោតលើការរួមបញ្ចូលស្ត្រីទៅក្នុងវេទិកានៃការបង្កើតគោលនយោបាយការបរទេសនិងយោធា ដែលពោរពេញដោយបុរសដ៏ច្រើនលើសលប់។ នៅក្នុងរដ្ឋភាគច្រើន មុខរបរទាំងនេះជាធម្មតាមានបុរសយ៉ាងហោចណាស់ ៨០ ភាគរយ។ ក្នុងចំណោម មហាសន្និបាតអង្គការសហប្រជាជាតិ ចំនួន ៧១ វគ្គ មានតែបីវគ្គប៉ុណ្ណោះ ដែលត្រូវបានដឹកនាំដោយស្ត្រី។ យោធាសហរដ្ឋអាមេរិកដែលមានសមាមាត្រស្ត្រីខ្ពស់

[16] Margot Wallström (Octobe ១៦, ២០០៨). Women's Forum Global Meeting. Deauville, France. In "Women and European politics: time for change", European Commission Press Release [http://europa.eu/ rapid/press-release_SPEECH-0៨-៥៣៦_en.htm]

បំផុតនៅក្នុងពិភពលោក ឬនៅក្នុងប្រវត្តិសាស្ត្រ នៅតែមានភាគរយជាបុរសច្រើន រហូតដល់ ៨៥ ភាគរយ។ សម្រាប់អ្នកប្រាជ្ញស្ត្រីសេរីនិយម ឥទ្ធិពលចម្បងនៃអតុល្យភាពយេនឌ័រទៅលើសភាពលក្ខណៈនៃទំនាក់ទំនងអន្តរជាតិ ពោលគឺ (ក្រៅពីឥទ្ធិពលលើឋានៈរបស់ស្ត្រី) គឺជាការខ្ជះខ្ជាយទេពកោសល្យ។ អ្នកប្រាជ្ញស្ត្រីសេរីនិយមគិតថា ស្ត្រីមានសមត្ថភាពដូចបុរស ដូច្នេះ ការបញ្ចូលស្ត្រីទៅក្នុងមុខរបរជាប្រពៃណីរបស់បុរស (ពីមេដឹកនាំរដ្ឋ រហូតដល់ ទាហានជើងគោក) នឹងនាំមកនូវបុគ្គលដែលមានសមត្ថភាពបន្ថែមទៅក្នុងវិស័យទាំងនោះ។ ដូច្នេះ សមភាពយេនឌ័រនឹងបង្កើនសមត្ថភាពជាតិ ដោយផ្តល់ដល់រដ្ឋនូវក្រុមអ្នកការទូត ឧត្តមសេនីយ៍ទាហាន និងអ្នកនយោបាយ កាន់តែប្រសើរឡើង។

ដើម្បីគាំទ្រដល់អំណះអំណាងរបស់ពួកគេដែលថា ជាមធ្យម ស្ត្រីអាចកាន់អំណាចដូចបុរសដែរ, អ្នកប្រាជ្ញស្ត្រីសេរីនិយមបានចង្អុលទៅឧទាហរណ៍ជាច្រើននៃស្ត្រី ដែលបានបម្រើការក្នុងមុខតំណែងបែបនេះ។ អាកប្បកិរិយារបស់ពួកគេនៅក្នុងការិយាល័យមិនមានលក្ខណៈពិសេសដាច់ដោយឡែក ដែលបែងចែកអ្នកដឹកនាំទាំងនេះពីសមភាគីបុរសរបស់ពួកគេឡើយ។ ផ្ទុយទៅវិញ ពួកគេមានចរិតលក្ខណៈ រួមទាំងគោលនយោបាយចម្រុះ។ ជាការពិតណាស់ ស្ត្រីបំរើការក្នុងតួនាទីជាប្រពៃណីរបស់បុរស អាចត្រូវបានជ្រើសរើស (ឬជ្រើសរើសដោយខ្លួនឯង) ដោយផ្អែកលើភាពស័ក្តិសមរបស់ពួកគេចំពោះតួនាទីទាំងនោះ៖ ពួកគេអាចនឹងមិនធ្វើសកម្មភាពតាមរបៀបដែលស្ត្រី«ជាទូទៅ»ធ្វើនោះទេ។ ទោះយ៉ាងណាក៏ដោយ ពួកគេបង្ហាញថាបុគ្គលម្នាក់ៗមិនអាចវិនិច្ឆ័យបានត្រឹមត្រូវ ដោយប្រើលក្ខណៈក្រុមតែម្យ៉ាងនោះទេ។

មេដឹកនាំរដ្ឋជាស្ត្រីហាក់ដូចជាមិនមានសន្តិភាពច្រើន ឬមានការប្តេជ្ញាចិត្តតិច ចំពោះអធិបតេយ្យភាពនិងបូរណភាពទឹកដីរបស់រដ្ឋ ជាងមេដឹកនាំបុរសនោះទេ (សូមមើលតារាង ៣.១)។ អ្នកខ្លះថែមទាំងបានលើកឡើងថា ស្ត្រីដែលកាន់អំណាចតែងតែមានទំនោរចង់ធ្វើសង្គ្រាមច្រើនជាង ដើម្បីប៉ះប៉ូវភាពជាស្ត្រីក្នុងតួនាទីជាប្រពៃណីរបស់បុរស ។ សរុបរួម ស្ត្រីជាអ្នកដឹកនាំរដ្ឋ ដូចជាបុរសដែរ ហាក់ដូចជាមានសមត្ថភាពក្នុងការដឹកនាំក្នុងសង្គ្រាម ឬសន្តិភាព តាមកាលៈទេសៈតម្រូវ។

នៅក្នុងសភាសហរដ្ឋអាមេរិក វាពិបាកក្នុងការប្រៀបធៀបកំណត់ត្រាបោះឆ្នោតរបស់បុរសនិងស្ត្រី លើបញ្ហាគោលនយោបាយការបរទេស ដោយសារមានស្ត្រីតិចតួចពេក។ ព្រឹទ្ធសភាសហរដ្ឋអាមេរិក ដែលអនុម័តសន្ធិសញ្ញានិងការតែងតាំងតំណែងក្នុងវិស័យគោលនយោបាយការបរទេស មានបុរសរហូតដល់ ៩៨-៩៩ ភាគរយ រហូតដល់ឆ្នាំ ១៩៩២ (ប៉ុន្តែ ចំនួនព្រឹទ្ធសមាជិកសភាជាបុរសបានធ្លាក់ចុះមកត្រឹម ៨០ ភាគរយ ក្នុងឆ្នាំ ២០១៣, នៅឆ្នាំ ២០១៨ ចំនួនព្រឹទ្ធសមាជិកសភាជាស្ត្រី ចំនួន ២២ នាក់)។ ស្ត្រីមិនដែលធ្វើជាប្រធានគណៈកម្មាធិការគោលនយោបាយការបរទេសសំខាន់ៗ (ភ្នាក់ងារប្រដាប់អាវុធ និងទំនាក់ទំនងបរទេស/ទំនាក់ទំនងអន្តរជាតិ) នៅក្នុងព្រឹទ្ធសភា ឬសភា រហូតដល់ឆ្នាំ ២០១១ បើទោះបីជាអ្នកតំណាងរាស្ត្រ លោកស្រី ណានស៊ី ប៉េឡូស៊ី (Nancy Pelosi) គឺជាប្រធានសភាស្ត្រីដំបូង ដែលស្ថិតក្នុងលំដាប់ទីបីនៅក្នុងជួរប្រធានាធិបតី ក្នុងឆ្នាំ ២០០៧-២០១០។

នៅទូទាំងពិភពលោក ចំនួនស្ត្រីបំពេញតួនាទីក្នុងសភាកំពុងកើនឡើង ជាលំដាប់។ របាយការណ៍ឆ្នាំ ២០១៧ របស់សហភាពអន្តរសភា (IPU) បានរកឃើញថា ស្ត្រីជាសមាជិកសភា នៅទូទាំងពិភពលោក មានចំនួនជាង ២៤ ភាគរយ, កើនឡើង ពីចំនួន ៧ ភាគរយ ក្នុងឆ្នាំ ១៩៩៥។ គិតត្រឹមឆ្នាំ ២០១៨ ស្ត្រី ៩ នាក់ បានធ្វើជាប្រមុខរដ្ឋ និង ៨ នាក់ជាប្រមុខរដ្ឋាភិបាល។ ប្រទេសខ្លះរក្សាចំនួនអាសនៈសភាមួយចំនួនសម្រាប់

តែស្ត្រី។ ប៉ុន្តែ បេក្ខជនជាស្ត្រីច្រើនតែចាប់យកអាសនៈច្រើនជាង ចំនួនដែលត្រូវបានគេរក្សាទុកអោយ។ ជាឧទាហរណ៍ នៅប្រទេសរ៉ាន់ដា ស្ត្រីមានចំនួនប្រមាណ ជាង ៥០ ភាគរយនៃសភាជាន់ទាបទោះបីជាច្បាប់តម្រូវអោយតំណាងស្ត្រីត្រឹមតែ៣០ភាគរយក៏ដោយ។

តារាង ៣.១. មេដឹកនាំរដ្ឋជាស្ត្រីគួរអោយកត់សម្គាល់ ក្នុងប៉ុន្មានទសវត្សរ៍ថ្មីៗនេះ

មេដឹកនាំ	ប្រទេស	កំណត់ត្រាក្នុងតួនាទី	កំឡុងពេល
ឥន្ទីរ៉ា គន្ធី	ឥណ្ឌា	ដឹកនាំសង្គ្រាមប្រឆាំងប៉ាគីស្ថានក្នុងឆ្នាំ១៩៧១, ត្រូវគេធ្វើឃាត នៅក្នុង១៩៨៤	១៩៦៦-១៩៧៧ ១៩៨០-១៩៨៤
ហ្គូលដា ម៉ែរ	អ៊ីស្រាអែល	ដឹកនាំសង្គ្រាមប្រឆាំងអ៊ីស្រាអែលនិងស៊ីរី ក្នុងឆ្នាំ ១៩៧៣	១៩៦៩-១៩៧៤
ម៉ាហ្គារ៉ែត ថាច់ឆ័រ	អង់គ្លេស	ស្ត្រីទី១ដឹកនាំប្រទេសមហាអំណាច ក្នុងសតវត្សរ៍, ប្រកាសសង្គ្រាមដណ្តើមយកកោះ ហ្វកឡែនវិញ ពីអាហ្សង់ទីន នៅឆ្នាំ ១៩៨២	១៩៧៩-១៩៩០
កូរ៉ាហ្សុន អាគីណូ	ហ្វីលីពីន	តស៊ូគ្រប់គ្រងយោធាខ្លួនឯង	១៩៨៦-១៩៩២
បេណាហ្សៀរ កូតូ	ប៉ាគីស្ថាន	តស៊ូគ្រប់គ្រងយោធាខ្លួនឯង, ត្រូវគេធ្វើឃាត នៅក្នុង២០០៧	១៩៨៨-១៩៩០ ១៩៩៣-១៩៩៦
វីយ៉ូឡែតា ខាម៉ូរ៉ូ	នីហ្គ្រ៉ាហ្គ័រ	រក្សាសន្តិភាពជាមួយនឹងភាគីផ្សេង ក្រោយបញ្ចប់សង្គ្រាមស៊ីវិល	១៩៩០-១៩៩៧
តាន់ស៊ូ ស៊ីឡែរ	ទួរគី	ដឹកនាំសង្គ្រាមព្រៃផ្សៃបង្ក្រាបក្រុមបះបោរឃឺដ	១៩៩៣-១៩៩៦
ចន្ទ្រីកា កុមារាទុង្គ	ស្រីលង្ការ	ព្យាយាមរក្សាសន្តិភាពជាមួយក្រុមបំបែករដ្ឋ តែបែរជាផ្ទុះសង្គ្រាម	១៩៩៤-២០០៥
មេហ្គាវ៉ាទី ស៊ូការណូបុត្រី	ឥណ្ឌូនេស៊ី	ព្យាយាមរក្សាស្ថេរភាព បរាជ័យបោះឆ្នោតជាថ្មី	២០០១-២០០៤
អង់ហ្គឺឡា មឺកែល	អាឡឺម៉ង់	កំរិតចំនួនកងទ័ពអាឡឺម៉ង់ ជាមួយនឹងកងកម្លាំងណាតូនៅប្រទេសអាហ្វហ្គានីស្ថាន	២០០៥-២០២១
អែឡែន ចនសុន សឺរលីហ្វ	លីប៊ីរី	ប្រធានាធិបតីស្ត្រីទី១នៅអាហ្វ្រិក, រក្សាស្ថេរភាពប្រទេសក្រោយសង្គ្រាមស៊ីវិល	២០០៦-២០១៨
សែក ហាស៊ីណា វ៉ាហ្សេដ	បង់ហ្គ្លាដែស	ព្យាយាមពង្រឹងអន្តរកាលប្រជាធិបតេយ្យ	២០០៨-
រ៉ូហ្សា អូតុងបាយ៉ូយ៉ា	សាធារណរដ្ឋគៀរហ្គៀ	ប្រធានាធិបតីស្ត្រីដំបូងនៃអតីតរដ្ឋកុម្មុយនីស្ត៍នៅអាស៊ីកណ្តាល, រម្ងាប់ភាពតានតឹងជាតិសាសន៍	២០១០-២០១១
ជូលៀ ហ្គីឡាដ៍	អូស្ត្រាលី	រៀបចំទទួលមូលដ្ឋានកងទ័ពជើងទឹកអាមេរិក	២០១០-២០១៣

យីងឡាក់ ស៊ីណាវ៉ាត្រា	ថៃ	ភាពតានតឹងជាមួយកងទ័ព, សង្គ្រាមបំបែករដ្ឋ	២០១១-២០១៧
ផាក ហ្គឺន-ហ៊ី	កូរ៉េខាងត្បូង	ព្យាយាមដោះស្រាយជម្លោះជាមួយកូរ៉េខាងជើង	២០១៣-២០១៧
តៃ អ៊ីង-វិន	តៃវ៉ាន់	ភាពតានតឹងជាមួយចិនដីគោក	២០១៦-
ឱង សានស៊ូជី	ភូមា	ដឹកនាំជានាយករដ្ឋមន្ត្រីអមនឹងពួកយោធា, ត្រូវរងការរិះគន់ដោយសារអសកម្មក្នុងការបោសសំអាតជាតិសាសន៍	២០១៦-២០២១
ថេរ៉េសា មេយ៍	អង់គ្លេស	ចរចាការចាកចេញពីសហភាពអឺរ៉ុប	២០១៧-២០១៩

ចំណាំ៖ រដ្ឋដទៃទៀតដូចជាហ្វាំងឡង់ ណ័រវ៉េស ឡាត់វី ឈីលី ណូវ៉ែលហ្សេឡង់ ជាណឺម៉ាក ប្រេស៊ីល ថៃ និងអ៊ីស្លង់ មានមេដឹកនាំជាស្ត្រីនៅពេលសង្គ្រាមនិងសន្តិភាពមិនមែនជាបញ្ហានយោបាយដ៏សំខាន់ ក្នុងប្រទេសទាំងនោះ ។

ប្រភព៖ ផ្អែកលើស្នាដៃ D'Amico, Francine, និង Peter R. Beckman, eds. ស្ត្រីនៅក្នុងនយោបាយពិភពលោក៖ សេចក្តីផ្តើម, បោះពុម្ពដោយរោងពុម្ព Bergin & Garvey, ១៩៩៥។ Nelson, Barbara J., និង Najma Chowdhury, eds. ស្ត្រី និងនយោបាយទូទាំងពិភពលោក, បោះពុម្ពដោយរោងពុម្ពYale, ១៩៩៤។ Genovese, Michael A., ed. ស្ត្រីជាអ្នកដឹកនាំជាតិ៖ ការអនុវត្តនយោបាយរបស់ស្ត្រីជាប្រមុខរដ្ឋាភិបាល, បោះពុម្ពដោយរោងពុម្ព Sage, ១៩៩៣។ McGlen, Nancy E., និង Meredith Reid Sarkees ស្ត្រីក្នុងគោលនយោបាយបរទេស៖ អ្នកខាងក្នុង, បោះពុម្ពដោយរោងពុម្ព Routledge, ឆ្នាំ ១៩៩៣។

អ្នកប្រាជ្ញស្ត្រីសេរីនិយមក៏ជឿថា ទាហានស្ត្រី ក៏ដូចជាអ្នកនយោបាយស្ត្រីផងដែរ មានជំនាញ និងសមត្ថភាពជាច្រើន អាចប្រៀបធៀបនឹងជំនាញនិងសមត្ថភាពបុរស។ ជាថ្មីម្តងទៀត ឥទ្ធិពលដ៏ចម្បងនៃការដាក់បញ្ចូលស្ត្រីបន្ថែមទៀត នឹងធ្វើអោយប្រសើរឡើងនូវគុណភាពនៃកងកម្លាំងយោធា ជារួម។ ទាហានស្ត្រីប្រហែល ២០០,០០០ នាក់ បម្រើក្នុងកងទ័ពសហរដ្ឋអាមេរិក (តិចជាង១៥ ភាគរយនៃចំនួនទាហានសរុប) និងចំនួនស្ត្រី ជិត ២ លាននាក់ គឺជាអតីតយុទ្ធជន។ ស្ត្រីបំពេញតួនាទីយោធាជាច្រើន បានយ៉ាងល្អ រួមទាំងជំនួយគាំទ្រផ្នែកកសុការនិងផ្នែកវេជ្ជសាស្ត្រ ការបណ្តុះបណ្តាល និងបញ្ជាការ។ ក្នុងឆ្នាំ ២០១៥ ស្ត្រីពីរនាក់ដំបូងបានបញ្ចប់ការសិក្សាពីសាលារ៉េនជ័រ(Ranger) ដ៏ឆ្នើម របស់កងទ័ពសហរដ្ឋអាមេរិក។ ស្ត្រីក៏បានទទួលជោគជ័យនៅក្នុងប្រទេសផ្សេងទៀត ដែលបានអនុញ្ញាតអោយពួកគេចូលទៅក្នុងវិស័យយោធា (ឬក្នុងករណីមួយចំនួនបានជ្រើសរើសពួកគេជាកងទ័ព)។

ទោះបីជាស្ត្រីបានបម្រើតួនាទីនៅក្នុងកងកម្លាំងយោធា ដោយទទួលបានការវាយតម្លៃខ្ពស់ក៏ដោយ ពួកគេត្រូវបានផាត់ចេញពីតួនាទីជាអ្នកប្រយុទ្ធ។ នៅក្នុងប្រទេសខ្លះ ស្ត្រីយោធាត្រូវបានកម្រិតតួនាទីរបស់ស្ត្រីបែបប្រពៃណី ដូចជាគិលានុបដ្ឋាយិកា និងអ្នកវាយអត្ថបទជាដើម។ សូម្បីតែនៅពេលដែលស្ត្រីអាចកាន់មុខតំណែងមិនប្រពៃណី ដូចជាមេកានិចនិងអ្នកបើកយន្តហោះ(ដូចនៅសហរដ្ឋអាមេរិក) ស្ត្រីភាគច្រើននៅតែស្ថិតក្នុងតួនាទីបែបប្រពៃណីដដែល។ ស្ថានភាពបែបនេះកំពុងចាប់ផ្តើមផ្លាស់ប្តូរ។ ក្នុងឆ្នាំ ២០១៣ យោធាសហរដ្ឋអាមេរិកបានដកបម្រាមលើស្ត្រីបម្រើក្នុងអង្គភាពប្រយុទ្ធ។

រូបថត ពិធីទទួលមេដាយប្រាក់របស់វីរៈនារីអាមេរិកម្នាក់

វីរនារីប្រយុទ្ធ

ទាហានស្ត្រីបានចូលរួមបំពេញតួនាទីបានយ៉ាងល្អដូចបុរស នៅក្នុងកិច្ចការយោធា ដូចដែលបានព្យាករណ៍ដោយអ្នកប្រាជ្ញស្ត្រីសេរីនិយម។ ប៉ុន្តែ នៅក្នុងកងទ័ពរបស់រដ្ឋ ស្ត្រីត្រូវបានរារាំងពីអង្គភាពប្រយុទ្ធថ្មើរជើងស្ទើរតែទាំងអស់ នៅទូទាំងពិភពលោក។ កងកម្លាំងទ័ពព្រៃច្រើនតែរួមបញ្ចូលស្ត្រី ហើយប៉ូលិសយោធាស្ត្រីអាមេរិកនៅអ៊ីរ៉ាក់ជារឿយៗចូលរួមក្នុងសមរភូមិប្រយុទ្ធ។ នៅទីនេះ ក្នុងឆ្នាំ ២០០៥ ពលបាលម្នាក់មកពីធ្នាំជាតិនៃរដ្ឋយិនថាក់គី (Kentucky) ទទួលបានផ្កាយប្រាក់ សម្រាប់វីរភាពក្នុងការប្រយុទ្ធ បន្ទាប់ពីការវាយទប់និងបណ្តេញការវាយឆ្មក់នៅអ៊ីរ៉ាក់។

ករណីស្ត្រីបំពេញតួនាទីយោធា ដោយកិត្តិយសខ្ពស់ទាំងនោះ រួមមានឧទាហរណ៍ជាប្រវត្តិសាស្ត្រនៃស្ត្រីម្នាក់ៗ ដែលបានចូលរួមក្នុងសមរភូមិប្រយុទ្ធ (ពេលខ្លះក្លែងបន្លំខ្លួនជាបុរស ជួនកាលក៏មិនបន្លំ)។ នៅសតវត្សរ៍ទី១៥ នាង ចូអាន អាក (Joan of Arc) បានប្រមូលផ្តុំទាហានបារាំងដើម្បីកម្ចាត់កងទ័ពឈ្លានពានអង់គ្លេស ដោយបង្វែរទិសនៃសង្គ្រាមមួយរយឆ្នាំ។ (ជនជាតិអង់គ្លេសបានចាប់នាងដុតទាំងរស់ ដោយចង់ភ្ជាប់ទៅនឹង បង្គោលភ្លើង ដោយចោទនាងថាជាមេធ្មប់។) ស្ត្រីជាញឹកញាប់បានចូលរួមក្នុងការប្រយុទ្ធនៅក្នុងកងកម្លាំងឧទ្ធាម ដែលប្រយុទ្ធនឹងសង្គ្រាមទំពព្រៃ នៅក្នុងប្រទេសវៀតណាម នីការ៉ាហ្គ័រ និងកន្លែងផ្សេងទៀត ក៏ដូចជានៅក្នុងអង្គភាពភេរវករ ឬយោធាប៉ាវ៉ា នៅក្នុងប្រទេសនានា ដូចជាប្រទេសប៉េរូ ប្រទេសអាឡឺម៉ង់ ប្រទេសអ៊ីតាលី និងប្រទេសប៉ាឡេស្ទីន។ ស្ត្រីនៅក្នុងកងកម្លាំងទ័ពព្រៃរបស់ប្រទេសអេរីទ្រាបានក្លាយជាផ្នែកមួយនៃកងទ័ពជាតិរបស់ប្រទេសនោះ បន្ទាប់ពីឯករាជ្យ ហើយបន្ទាប់មក បានបម្រើការនៅក្នុងអង្គភាពប្រយុទ្ធជួរមុខក្នុងអំឡុងពេលសង្គ្រាមលេណដ្ឋានរបស់ប្រទេសអេរីទ្រានឹងអេត្យូពី នៅចុងទសវត្សរ៍ឆ្នាំ ១៩៩០។

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ទាហានស្ត្រីរបស់សហរដ្ឋអាមេរិកបានបង្ហាញខ្លួន នៅក្នុងសមរភូមិប្រយុទ្ធ (នាពេលបច្ចុប្បន្ននេះ យុទ្ធសាស្ត្រចល័តទ័ព និងកងទ័ពជួរមុខពោរពេញដោយការបត់បែនបានធ្វើអោយគេពិបាកព្រែកអោយដាច់រវាងតួនាទីប្រយុទ្ធនិងតួនាទីគាំទ្រ)។ ក្នុងអំឡុងសង្គ្រាមឈូងសមុទ្រឆ្នាំ ១៩៩១ ស្ត្រីអាមេរិករាប់ម៉ឺននាក់បានចូលរួម, ក្នុងនោះស្ត្រី ១៣ នាក់ត្រូវបានសម្លាប់ និង ២ នាក់ត្រូវបានចាប់ខ្លួនជាអ្នកទោសសង្គ្រាម។ នៅចុងទសវត្សរ៍ឆ្នាំ ១៩៩០ ស្ត្រីបានចាប់ផ្តើមបម្រើតួនាទីនៅលើនាវានិងយន្តហោះចម្បាំងមួយចំនួនរបស់សហរដ្ឋអាមេរិក ប៉ុន្តែ មិនមាននៅក្នុងអង្គភាពប្រយុទ្ធដីគោកទេ។ នៅក្នុងសង្គ្រាមអ៊ីរ៉ាក់ឆ្នាំ ២០០៣ ស្ត្រីបានហោះហើរយន្តហោះនិងឧទ្ធម្ភាគចក្រគ្រប់ប្រភេទ ហើយស្ត្រីម្នាក់ស្ថិតនៅក្នុងក្រុមអ្នកទោសសង្គ្រាមអាមេរិក(POWs)ដំបូងគេដែលត្រូវបានចាប់ខ្លួន នៅដើមដំបូងនៃសង្គ្រាម។ កំឡុងពេលប៉ុន្មានឆ្នាំបន្តបន្ទាប់នៃសង្គ្រាមនៅក្នុងប្រទេសអ៊ីរ៉ាក់ ប៉ូលីសយោធាស្ត្រីអាមេរិកបានបញ្ចប់បេសកកម្មពួកគេបានយ៉ាងល្អ នៅក្នុងការពន្លត់អគ្គីភ័យជាច្រើន។ ករណីទាំងអស់នេះបង្ហាញថា ស្ត្រី(យ៉ាងហោចណាស់ស្ត្រីខ្លះ) អាចចូលរួមសមរភូមិប្រយុទ្ធបាន ដោយខ្លួនឯង។

មូលហេតុចម្បងដែលកងកម្លាំងយោធាផាត់ស្ត្រីចេញពីសមរភូមិប្រយុទ្ធ ហាក់ដូចជាដោយសារមានការភ័យខ្លាចអំពីផលវិបាកនៃវត្តមានរបស់ពួកគេទៅលើទាហានប្រុសៗ ដែលត្រូវបានគិតថា មានវិន័យនិងភាពស្មោះត្រង់ជាប្រពៃណី ដោយអាស្រ័យលើចំណងភាតរភាពជាបុរសនិងការផ្ងង់អារម្មណ៍រួមគ្នា។ អ្នកប្រាជ្ញស្ត្រីសេរីនិយមបដិសេធអំណះអំណាងបែបនេះ ហើយអះអាងថាការផ្សារភ្ជាប់រួមគ្នាជាក្រុម នៅក្នុងអង្គភាពយោធាមិនអាស្រ័យលើការបែងចែកភេទនោះទេ។ (ដូចគ្នានេះដែរ ហេតុផលស្រដៀងគ្នានេះធ្លាប់ត្រូវបាន

លើកយកមក ដើម្បីបំបែកជាតិសាសន៍ នៅក្នុងកងកម្លាំងយោធាសហរដ្ឋអាមេរិក។) ឥទ្ធិពលនៃសង្គ្រាមលើស្ត្រីដែលមិនចូលសមរភូមិប្រយុទ្ធ ក៏ទទួលបានការចាប់អារម្មណ៍កាន់តែខ្លាំងផងដែរ។ ការវាយប្រហារលើស្ត្រីនៅក្នុងប្រទេសអាល់ហ្សេរី រ៉ាន់ដា បូស្នៀ អាហ្វហ្គានីស្ថាន កុងហ្គោប្រជាធិបតេយ្យ និងស៊ូដង់ បានចង្អុលបង្ហាញពីនិន្នាការថ្មី ដែលអាចកើតមានចំពោះស្ត្រី ជាគោលដៅរបស់យោធា។ ការរំលោភសេពសន្ថវៈជាប្រព័ន្ធត្រូវបានប្រើប្រាស់ជាយុទ្ធសាស្ត្រភេរវកម្ម នៅក្នុងប្រទេសបូស្នៀ និងរ៉ាន់ដា ហើយកងទ័ពជប៉ុនក្នុងសង្គ្រាមលោកលើកទី ២ បានដំណើរការបណ្តាញទាសករផ្លូវភេទអន្តរជាតិ ដែលគេស្គាល់ថាជា «ស្ត្រីលួងលោម»។ ការរំលោភសេពសន្ថវៈត្រូវបានចាត់ទុកជារឿងធម្មតាជាយូរយារណាស់មកហើយ ប្រសិនបើវាជាលទ្ធផលដ៏គួរអោយសោកស្តាយនៃសង្គ្រាម ប៉ុន្តែថ្មីៗនេះ ករណីនៃការរំលោភមួយចំនួន ត្រូវបានប្រកាសថាជាឧក្រិដ្ឋកម្មសង្គ្រាម (សូមមើលមេរៀនទី ៧)។

សរុបមក អ្នកប្រាជ្ញស្ត្រីសេរីនិយមច្រានចោលការលើកឡើងដែលថា ស្ត្រីនាំមកនូវធនធាន ឬទំនួលខុសត្រូវរបស់ស្ត្រីយ៉ាងពិសេស ចំពោះកិច្ចការបរទេសនិងយោធា។ ពួកគេមិនរិះគន់ទ្រឹស្តីប្រាកដនិយមដែលថា មានលក្ខណៈធម្មជាតិជាបុរសនោះទេ ប៉ុន្តែរិះគន់ការអនុវត្តរបស់រដ្ឋទាំឡាយ ដែលផាត់ស្ត្រីចេញពីការចូលរួមក្នុងនយោបាយអន្តរជាតិ និងសង្គ្រាម។

៣.៦.៥. ទ្រឹស្តីស្ត្រីនិយម ខុសគ្នា ទ្រឹស្តីស្ត្រីសេរីនិយម?


ការជជែកវែកញែករវាងទ្រឹស្តីស្ត្រីទីទៃនិយម និងទ្រឹស្តីស្ត្រីសេរីនិយមហាក់ដូចជាមិនចុះសម្រុងនឹងគ្នាទាល់តែសោះ។ អ្នកប្រាជ្ញទ្រឹស្តីស្ត្រីទីទៃនិយមអះអាងថា ទ្រឹស្តីប្រាកដនិយមឆ្លុះបញ្ចាំងពីការយល់ឃើញរបស់បុរសចំពោះទំនាក់ទំនងសង្គម ចំណែកអ្នកប្រាជ្ញទ្រឹស្តីស្ត្រីសេរីនិយមគិតថា ស្ត្រីអាចក្លាយជាអ្នកទ្រឹស្តីប្រាកដនិយមដូចបុរសដែរ បុរសជាអ្នកប្រាកដនិយមយ៉ាងណា ស្ត្រីក៏អាចយ៉ាងនោះដែរ។ អ្នកប្រាជ្ញទ្រឹស្តីស្ត្រីសេរីនិយមជឿថា ការចូលរួមរបស់ស្ត្រីនៅក្នុងគោលនយោបាយការបរទេស និងយោធានឹងពង្រឹងសមត្ថភាពរបស់រដ្ឋ ប៉ុន្តែ អ្នកប្រាជ្ញទ្រឹស្តីស្ត្រីទីទៃនិយមគិតថា សមត្ថភាពពិសេសរបស់ស្ត្រីអាចត្រូវបានប្រើប្រាស់អោយកាន់តែប្រសើរឡើងក្នុងការផ្លាស់ប្តូរ (ធ្វើអោយមានអំណោយផលដល់ស្ត្រី) ប្រព័ន្ធអន្តរជាតិទំនាក់ទំនងទាំងមូលជាជាងការព្យាយាមលេងហ្គេមរបស់មនុស្សប្រុស។

ភ័ស្តុតាងសម្រាប់គាំទ្រអំណះអំណាងទាំងពីរអាចត្រូវបានផ្សះផ្សា ក្នុងកម្រិតខ្លះ ដោយចងចាំថា ចរិតលក្ខណៈនិងសមត្ថភាពរបស់បុគ្គលម្នាក់ៗ មិនដូចគ្នាទៅនឹងលក្ខណៈនិងសមត្ថភាពនៃក្រុមរបស់គាត់ទាំងមូលទេ។ ផ្ទុយទៅវិញ គុណភាពនៃបុគ្គលម្នាក់ៗ រត់តាមខ្សែកោង ដែលមានសណ្ឋានដូចកណ្តឹង នៅលើក្រាហ្វិក ក្នុងនោះ មានមនុស្សជាច្រើនបានផ្តុំនៅកណ្តាល ហើយមនុស្សតិចមានកម្រិតខ្ពស់លើសគេ ឬទាបនៅផ្នែកសងខាង។

ភាពខុសគ្នារវាងយេនឌ័រ ដែលត្រូវបានចង្អុលបង្ហាញដោយអ្នកប្រាជ្ញទ្រឹស្តីស្ត្រីទីទៃនិយម មានន័យថាខ្សែកោងតំណាងសមត្ថភាពបុរសនិងស្ត្រីឃ្លាតឆ្ងាយពីគ្នាបន្តិច បើទោះបីជាខ្សែកោងទាំងពីរនោះត្រួតលើគ្នាខ្លះក៏ដោយ (សូមមើលក្រាហ្វិក៣.៣)។ ជាឧទាហរណ៍ដ៏សាមញ្ញមួយ ស្ត្រីពីរបីនាក់មានរាងកាយធំជាងបុរសស្ទើរតែទាំងអស់ ហើយបុរសមួយចំនួនមានមាឌតូចជាងស្ត្រីស្ទើរតែទាំងអស់។ ប៉ុន្តែ ជាមធ្យម បុរសមានមាឌធំជាងស្ត្រី។ នៅលើទំហំសមត្ថភាពផ្សេងៗ ខ្សែកោងរបស់ស្ត្រីស្ថិតនៅខាងលើ ឬខាងក្រោមបុរស ជាមធ្យម ប៉ុន្តែ នៅតែមានការត្រួតស៊ីគ្នាច្រើន។

ក្រាហ្វិក ៣.៤ ខ្សែកោងត្រួតស៊ីគ្នា

ខ្សែកោងដែលមានសណ្ឋានដូចកណ្តឹងបង្ហាញថា បុគ្គលម្នាក់ៗមានសមត្ថភាពខុសៗគ្នា ទាំងកម្លាំងកាយខាងក្រៅ ឬសមត្ថភាពបង្កើតសន្តិភាព។ ទោះបីជាជាមធ្យម យេនឌ័រមានភាពខុសប្លែកគ្នាក៏ដោយ សម្រាប់បុគ្គលភាគច្រើន (នៅក្នុងផ្នែកត្រួតស៊ីគ្នា) ភាពខុសគ្នាបែបនេះមិនខុសប្លែកគ្នាប៉ុន្មានទេ។ អ្នកប្រាជ្ញទ្រឹស្តីស្ត្រីសេរីនិយមសង្កត់ធ្ងន់លើផ្នែកដែលខ្សែកោងត្រួតលើគ្នា; អ្នកប្រាជ្ញទ្រឹស្តីស្ត្រីទីទៃនិយមសង្កត់ធ្ងន់លើភាពខុសគ្នានៃក្រុមទាំងមូល។



ចំណាំ៖ ខ្សែកោងខាងឆ្វេងសម្រាប់បុរស, ខាងស្តាំសម្រាប់ស្ត្រី៖ ដំណោលខាងឆ្វេងសម្រាប់បុរសជាមធ្យម និងខាងស្តាំសម្រាប់ស្ត្រីជាមធ្យម។

អំណះអំណាងអ្នកប្រាជ្ញទ្រឹស្តីស្ត្រីសេរីនិយមសង្កត់ធ្ងន់លើការត្រួតស៊ីគ្នានៃខ្សែកោងទាំងពីរ។ ពួកគេនិយាយថា ស្ត្រីម្នាក់ៗ (ស្ត្រីភាគច្រើនដែលមានទំហំពាក់ព័ន្ធច្រើនបំផុត) ស្ថិតក្នុងរង្វង់ខ្សែកោងដូចនឹងបុរសដូច្នេះហើយ ពួកគេអាចអនុវត្តស្មើៗគ្នាជាមួយបុរស។ ជាការពិត ស្ត្រីក្នុងតួនាទីយេនឌ័រមិនប្រពៃណីអាចបំពេញតួនាទីបានល្អជាង សមភាគីបុរសរបស់ខ្លួនដោយសារតែ ស្ត្រីដែលបង្កើតជំរើសក្នុងតួនាទីបែបនេះដោយខ្លួនឯង (ដូចជាការចូលបម្រើយោធា) មានសមត្ថភាពនៅជិតចុងកំពូងនៃខ្សែកោងស្ត្រី ចំណែកឯបុរសស្ថិតនៅជិតពាក់កណ្តាលខ្សែកោងបុរស (ដោយសារតែពួកគេចូលរួមភាគច្រើន)។ ដូចគ្នានេះដែរ ស្ត្រីដែលក្លាយជាមេដឹកនាំរដ្ឋត្រូវបានគេសន្មត់ថា មានភាពប៉ិនប្រសប់ក្នុងការបង្កើតគោលនយោបាយបរទេសជាងស្ត្រី (ឬបុរស)ភាគច្រើន ពីព្រោះដំណើរការនយោបាយមាននិន្នាការជ្រើសរើសស្ត្រីនៅចុងកំពូលខ្សែកោងទាក់ទងនឹងការខិតកៀកទៅជិតទ្រឹស្តីប្រាកដនិយមរបស់ពួកគេ។

អ្នកប្រាជ្ញទ្រឹស្តីស្ត្រីទីទៃនិយមចាប់អារម្មណ៍លើការឃ្លាតឆ្ងាយពីគ្នានៃខ្សែកោងទាំងពីរ មិនមែនលើការត្រួតស៊ីគ្នារបស់ពួកគេទេ។ បើយោងតាមទស្សនៈនេះ ជាមធ្យម ស្ត្រីហាក់មើលឃើញទំនាក់ទំនងអន្តរជាតិក្នុងលក្ខណៈខុសប្លែកពីការមើលឃើញរបស់បុរស។ ដូច្នេះ ទោះបីជា*បុគ្គលនានា*ដែលត្រូវបានជ្រើសរើសអោយចូលរួមក្នុងគោលនយោបាយការបរទេសនិងយោធា ប្រហែលជាមិនខុសគ្នាពីសមភាគីបុរសរបស់ពួកគេក៏

ដោយ ក៏ស្ត្រីក្នុងនាមជាក្រុមឬទាំងមូលខុសគ្នាដែរ។ ក្នុងក្រុមស្ត្រីភេទ អ្នកបោះឆ្នោតជាស្ត្រីម្នាក់ៗបង្ហាញក្តីកង្វល់ផ្សេងៗគ្នាទាក់ទងនឹងទំនាក់ទំនងអន្តរជាតិ ខុសពីក្រុមបុរសទាំងមូល ដែលហាក់បង្ហាញកង្វល់ប្រហាក់ប្រហែលគ្នា (ដូចដែលបានបង្ហាញដោយគម្លាតយេនឌ័រក្នុងការស្ទង់មតិ និងគំរូបោះឆ្នោត)។

ដូច្នេះហើយ តាមតក្កវិជ្ជានេះ ភាពខុសប្លែកគ្នាយ៉ាងខ្លាំងនៅក្នុងទំនាក់ទំនងអន្តរជាតិ (និងការឃ្លាតឆ្ងាយពីការប្រើប្រាស់ទ្រឹស្តីប្រាកដនិយមក្នុងការពន្យល់អំពីអាកប្បកិរិយារបស់រដ្ឋ) អាចនឹងកើតឡើង លុះត្រាតែស្ត្រីកាន់តែច្រើនចូលរួមក្នុងមុខតំណែងគោលនយោបាយការបរទេសសំខាន់ៗ។ នោះបានន័យថា អ្នកនយោបាយឬទាហានស្ត្រី *ចំនួនត្រឹមតែពីរបីនាក់* មិនអាចផ្លាស់ប្តូរមូលដ្ឋានគ្រឹះនៃទំនាក់ទំនងអន្តរជាតិ ដែលភ្ជាប់ភ្ជាប់ដោយបុរសភេទបានឡើយ។ អ្នកបង្កើតគោលនយោបាយការបរទេសស្ត្រី សព្វថ្ងៃនេះ ត្រូវបានឡោមព័ទ្ធដោយបុរស (ក្នុងតួនាទីជាទីប្រឹក្សា មន្ត្រីយោធា មេដឹកនាំនយោបាយ និងមេដឹកនាំរដ្ឋបរទេស)។ ប៉ុន្តែ ពិភពលោកមួយដែលអ្នកនយោបាយ ឬទាហានភាគច្រើនជាស្ត្រីអាចជារឿងផ្សេងមួយទៀត។ បន្ទាប់មក ជំនួសអោយការជ្រើសរើសស្ត្រីមានសមត្ថភាពយកទៅលេងហ្គេមរបស់បុរស ក្បួនច្បាប់នៃហ្គេមអាចនឹងផ្លាស់ប្តូរដើម្បីឆ្លុះបញ្ចាំងពីការពិតដែលថាស្ត្រី «ជាមធ្យម» នឹងក្លាយជាតួអង្គសំខាន់ នៅក្នុងតួនាទីដ៏សំខាន់តាមលក្ខណៈប្រពៃណីនៅក្នុងទំនាក់ទំនងអន្តរជាតិ។ ជាការពិតណាស់ ទ្រឹស្តីស្ត្រីទីទែនិយមទាំងនេះ មិនដែលត្រូវបានសាកល្បងនោះទេ ដោយសារតែស្ត្រីមិនដែលទទួលបានភាពលេចធ្លោ ក្នុងការបង្កើតគោលនយោបាយការបរទេស ក្នុងប្រទេសណាមួយ ហើយរឹតតែមានចំនួនកាន់តែតិច ក្នុងប្រព័ន្ធអន្តរជាតិទាំងមូល។

ក្រៅពីលើឆ្លុងទី១និងទី២ (ទ្រឹស្តីស្ត្រីសេរីនិយមនិងស្ត្រីទីទែនិយម), ឆ្លុងទីបី(ទ្រឹស្តីស្ត្រីក្រោយសម័យទំនើបនិយម) ត្រូវបានផ្សារភ្ជាប់ជាមួយនឹងការកើនឡើងប្រជាប្រិយនៃទ្រឹស្តីក្រោយសម័យទំនើបនិយម នៅក្នុងវិទ្យាសាស្ត្រសង្គម។

៣.៦.៦. ស្ត្រីក្រោយសម័យទំនើបនិយម

មុខព្រួញនៃការរិះគន់មួយបាញ់សំដៅទៅលើទ្រឹស្តីប្រាកដនិយមដែលរួមបញ្ចូលគ្នានូវទ្រឹស្តីស្ត្រីនិយមនិងទ្រឹស្តីក្រោយសម័យទំនើបនិយម។ *ទ្រឹស្តីស្ត្រីនិយមក្រោយសម័យទំនើបនិយម (post-modern feminism)* ព្យាយាមរុះរើទ្រឹស្តីប្រាកដនិយម ជាមួយនឹងគោលបំណងជាក់លាក់ក្នុងការបង្ហាញពីឥទ្ធិពលនៃយេនឌ័រដែលត្រូវលាក់កំបាំងកាន់តែជ្រៅនៅក្នុងទំនាក់ទំនងអន្តរជាតិ ខណៈពេលដែលព្យាយាមបង្ហាញពីរបៀបដែលការស្ថាបនាឬកំណត់តួនាទីយេនឌ័រតាមតែអំពើចិត្ត។ អ្នកប្រាជ្ញស្ត្រីក្រោយសម័យទំនើបនិយម យល់ស្របជាមួយនឹងអ្នកប្រាជ្ញស្ត្រីទីទែនិយមថា ទ្រឹស្តីប្រាកដនិយមបង្កប់អត្ថន័យលាក់កំបាំងអំពីតួនាទីយេនឌ័រ ប៉ុន្តែបដិសេធថា មិនមានអត្ថន័យថេរណាមួយ នៅក្នុងភេទប្រុសឬស្រីនោះទេ។ ផ្ទុយទៅវិញ អ្នកប្រាជ្ញស្ត្រីក្រោយសម័យទំនើបនិយមសម្លឹងមើលអន្តរកម្មនៃយេនឌ័រនិងអំណាច តាមរបៀបបើកចំហរជាង។ អ្នកប្រាជ្ញស្ត្រីក្រោយសម័យទំនើបនិយម រិះគន់លើអ្នកប្រាជ្ញស្ត្រីសេរីនិយមដែលព្យាយាមត្រឹមតែ បញ្ចូលស្ត្រីទៅក្នុងរចនាសម្ព័ន្ធបែបប្រពៃណី នៃសង្គ្រាមនិងគោលនយោបាយការបរទេស។ ពួកគេរិះគន់អ្នកប្រាជ្ញស្រីទីទែនិយមផងដែរ ចំពោះការលើកតម្កើងគុណធម៌ប្រពៃណីរបស់ស្ត្រី។

ក្នុងការសិក្សាអំពីសង្គ្រាម អ្នកប្រាជ្ញស្ត្រីក្រោយសម័យទំនើបនិយមបានជំទាស់នឹងគំរូទូលំទូលាយនៃ (បុរស) «គ្រាន់តែជាអ្នកចម្បាំង» និង (ស្ត្រី) «ព្រលឹងដ៏ស្រស់ស្អាត»។ ពួកគេប្រកែកថា ស្ត្រីមិនមែនគ្រាន់តែជាអ្នកឈរមើលដោយអសកម្ម ឬជនរងគ្រោះដោយសារសង្គ្រាមប៉ុណ្ណោះទេ ប៉ុន្តែ ជាអ្នកចូលរួមដ៏សកម្មនៅ

ក្នុងប្រព័ន្ធនៃសង្គ្រាមដែលពាក់ព័ន្ធនឹងភេទទាំងពីរ។ ស្ត្រីមិនត្រឹមតែដើរតួជាគិលានុបដ្ឋាយិកា និងអ្នកការសែតនៅក្នុងការិយាល័យ«នៅសមរភូមិមុខ»ប៉ុណ្ណោះទេ ប៉ុន្តែ ក្នុងនាមជាម្តាយ ភរិយា និងមិត្តស្រី នៅ«សមរភូមិមុខផ្ទះ»។ អ្នកប្រាជ្ញទាំងនេះជឿថា រឿងរ៉ាវរបស់កងកម្លាំងយោធាមិនគួរលុបចោលតួនាទីរបស់ស្ត្រីពេស្យានៅមូលដ្ឋានយោធា ហើយរឿងការទូតក៏មិនគួរលុបចោលតួនាទីរបស់ភរិយាមន្ត្រីការទូតដែរ។

អ្នកប្រាជ្ញស្ត្រីក្រោយសម័យទំនើបនិយមមិនត្រឹមតែបដិសេធទ្រឹស្តីប្រាកដនិយមប៉ុណ្ណោះទេ ប៉ុន្តែក៏បដិសេធគោលការណ៍ជំនួសមួយចំនួនទៀត ដែលសង្កត់ធ្ងន់លើការការពារស្ត្រី និងអ្នកមិនប្រយុទ្ធដោយផ្ទាល់ក្នុងសមរភូមិមុខផ្សេងទៀត។ គោលលទ្ធិយុត្តិសង្គ្រាម(Justwar) (សូមមើលមេរៀនទី៧) ត្រូវបានចាត់ទុកថាមានលក្ខណៈអរូបីខ្លាំងពេក ដែលជាសំណុំនៃគោលគំនិតនិងច្បាប់ ដែលមិន ផ្តល់យុត្តិធម៌ដល់ភាពសម្បូរបែបនៃបរិបទប្រវត្តិសាស្ត្រនីមួយៗ និងតួនាទីផ្សេងៗគ្នារបស់បុរស និងស្ត្រីម្នាក់ៗ នៅក្នុងនោះ។

អ្នកប្រាជ្ញស្ត្រីក្រោយសម័យទំនើបនិយមបានព្យាយាមរុះរើភាសារបស់ទ្រឹស្តីប្រាកដនិយម ជាពិសេសនៅពេលដែលវាឆ្លុះបញ្ចាំងពីឥទ្ធិពលនៃយេនឌ័រនិងភេទ។ ជាឧទាហរណ៍ គ្រាប់បែកបរមាណូដំបូងគេមានភេទប្រុស (គេដាក់ឈ្មោះវាថា «អាកាម៉ាប់ (Fat Man)» និង «អាច្រម៉ក់(Little Boy)»), កូដទូរលេខដែលបញ្ជូនដំណឹងដល់ទីក្រុងវ៉ាស៊ីនតោនឌីស៊ី ថាគ្រាប់បែកអ៊ីជ្រូសែនដំបូងបានដំណើរការ ដោយនិយាយយ៉ាងសាមញ្ញថា «វាជាក្មេងប្រុស» (ដោយសន្មតថា បើវាជាក្មេងស្រី បានន័យថាវាបរាជ័យ)។ យន្តហោះដែលទម្លាក់គ្រាប់បែកបរមាណូលើទីក្រុងហ៊ីរ៉ូស៊ីម៉ា (*អេណូឡាវេហ្គេយ*) បញ្ជាក់ពីភេទឬចរិតស្រី។ តាមពិតទៅវាត្រូវបានគេដាក់ឈ្មោះតាមម្តាយរបស់អ្នកបើកយន្តហោះនោះ។ ដូចគ្នានេះដែរ ទីតាំងសាកល្បងគ្រាប់បែកបរមាណូរបស់បារាំងនៅសមុទ្រប៉ាស៊ីហ្វិកខាងត្បូង សុទ្ធតែត្រូវបានផ្តល់ឈ្មោះដូចស្ត្រីភេទ។ ស្រដៀងគ្នានេះដែរ អ្នកបើកយន្តហោះបានបិទភ្ជាប់រូបថតស្ត្រីអាក្រាតកាយលើគ្រាប់បែកធម្មតា មុននឹងទម្លាក់វាចុះ។ នៅក្នុងករណីទាំងអស់នេះ អ្នកប្រាជ្ញស្ត្រីក្រោយសម័យទំនើបនិយមនឹងកត់សម្គាល់ថា យេនឌ័រជាស្ត្រីនៃយានជំនិះគោលដៅ ឬ គ្រឿងតុបតែងលម្អទាំងអស់នេះ ពង្រីកនិងពង្រឹងភាពជាបុរសនៃអាវុធដោយផ្ទាល់ ដូចពាក្យស្លោកថា «សំណាបយោងដី ស្រីយោងប្រុស»។

កិច្ចខិតខំប្រឹងប្រែងទាំងនេះសម្លឹងមើលភេទនិងយេនឌ័រនៅក្នុងអត្ថន័យបង្កប់នៃទ្រឹស្តីប្រាកដនិយម។ ជាឧទាហរណ៍ ពាក្យថា *អំណាច* និង*ថាមពល* សំដៅទៅលើទាំងសមត្ថភាពរបស់រដ្ឋ និងទាំងភាពរឹងមាំរបស់បុរស។ កម្លាំងយោធាពឹងផ្អែកលើវត្ថុមានរូបរាងដូចលិង្គបុរស៖ អាវុធដែលត្រូវបានរចនាឡើងដើម្បីបាញ់ចេញជ្រៀតចូលក្នុងគោលដៅ ហើយចុងក្រោយត្រូវផ្ទុះចេញ។ នៅក្នុងការហ្វឹកហ្វឺនជាមូលដ្ឋាន បុរសបានស្រែកថា «នេះគឺជាកាំភ្លើងអាការបស់ខ្ញុំ [កាន់កាំភ្លើងអាកាឡើង], នេះគឺជាកាំភ្លើងរបស់ខ្ញុំ [ចង្អុលទៅប្រលោះផ្លូវ], កាំភ្លើងមួយសម្រាប់បាញ់សម្លាប់សត្រូវ កាំភ្លើងមួយទៀតសម្រាប់បាញ់លេងសប្បាយ។[១៧] អាវុធនុយក្លេអែរជារឿយៗ ត្រូវបានគេនិយាយ ម្តងហើយម្តងទៀត ក្នុងន័យផ្លូវភេទ ប្រហែលជាដោយសារតែ«ថាមពល»ដ៏ខ្លាំងក្លារបស់វា។ កញ្ចាម៉ូឌែលត្រូវបានដួលអោយធ្វើទីផ្សារលក់រថក្រោះ កាំជ្រួច ឧទ្ធម្ភាគចក្រ និងសព្វាវុធ«ដ៏មានឥទ្ធិពល» ផ្សេងទៀត ដល់បុរសជាមន្ត្រីលទ្ធកម្ម នៅក្នុងពិព័រណ៌ពាណិជ្ជកម្មយោធាអន្តរជាតិ។ ទ្រង់ទ្រាយនៃអាវុធហាក់បីដូចជាមិនប្រែប្រួលសោះឡើយ បើទោះបីជាបច្ចេកវិទ្យាសព្វាវុធបានវិវត្តន៍ ពីលំពែង

[១៧] Dyer, Gwynne. *War.* Crown, ១៩៨៥.

ទៅជាកាំភ្លើង ទៅជាកាំជ្រួចក៏ដោយ។

ទ្រឹស្តីស្ត្រីនិយមទាំងបីឆ្លុងផ្តល់នូវការពន្យល់ទាំងឡាយ ដែលជារឿយៗខុសគ្នាពីទ្រឹស្តីប្រាកដនិយម និងទ្រឹស្តីសេរីនិយម។ នៅក្នុងករណីនៃការឆ្លើយតបទៅនឹងការឈ្លានពាន អ្នកប្រាជ្ញស្ត្រីនិយមអាចអំពាវនាវអោយយកចិត្តទុកដាក់លើសារៈសំខាន់នៃតួនាទីយេនឌ័រ ដូចជាតម្រូវការសម្រាប់អ្នកដឹកនាំរដ្ឋ ដើម្បីបញ្ជាក់ពីភាពជាបុរសរបស់ពួកគេ ដោយហ៊ានក្រោកឈរតតាំងជាមួយនឹងមនុស្សអាក្រក់។ រឿងនេះត្រូវបានភ្ជាប់ជាមួយនឹងតួនាទីបុរសជាអាណាព្យាបាលឬអ្នកការពារលំហក្នុងស្រុកអោយមានសណ្តាប់ធ្នាប់ (ផ្ទះសម្បែង គ្រួសារ ប្រទេសជាតិ) ប្រឆាំងនឹងពិភពលោកខាងក្រៅ ដ៏គ្រោះថ្នាក់ និងអនាធិបតេយ្យ។ ចាប់តាំងពីឆ្នាំ ២០០១ តួនាទីយេនឌ័រត្រូវបានមើលឃើញកាន់តែខ្លាំងឡើង នៅក្នុងភាគីទាំងសងខាងនៃ «សង្គ្រាមប្រឆាំងនឹងអំពើភេរវកម្ម» ជាមួយនឹងមុខតំណែងរបស់ស្ត្រី នៅក្នុងសង្គម និងគោលគំនិតរបស់បុរសអំពីភាពជាបុរសបានក្លាយជាទីលានប្រកួតប្រជែងគ្នា រវាងប្រទេសលោកខាងលិចនិងក្រុមអ៊ីស្លាមប្រដាប់អាវុធនានា។ ជាលទ្ធផល ទ្រឹស្តីបែបប្រពៃណីនៃទំនាក់ទំនងអន្តរជាតិ ដែលមិនអើពើនឹងបញ្ហាទាំងនេះ អាចខ្វះដំហរប្រកបដោយថាមពលសម្រាប់ពន្យល់។

ថាតើផលប្រយោជន៍របស់រដ្ឋឆ្លុះបញ្ចាំងពីការសន្មតអំពីអំណាចនិងសុខុមាលភាព ឬក៏ត្រូវបានបង្កើតឡើង ដោយរដ្ឋនិង*ភូមន្តក្នុងរដ្ឋ* ដោយផ្អែកលើគំនិតនិងអន្តរកម្មសង្គម ផលប្រយោជន៍ទាំងនោះ ជួនកាលមានជម្លោះជាមួយរដ្ឋដទៃទៀត។ ទ្រឹស្តីអំពីរបៀបដែល*ភូមន្តក្នុងរដ្ឋ* ជះឥទ្ធិពលលើគោលនយោបាយការបរទេស គឺជាប្រធានបទនៃមេរៀនបន្ទាប់។

សេចក្តីសង្ខេប

១. អំណះអំណាងស្នូលរបស់ទ្រឹស្តីប្រាកដនិយមស្តីអំពី**ភាពអនាធិបតេយ្យ តួអង្គរដ្ឋ ការថ្លឹងថ្លែងហេតុផល** និង**ការប្រើប្រាស់កម្លាំងយោធា** ត្រូវបានគេជជែកដេញដោល ដោយមូលហេតុផ្សេងៗគ្នា។

២. អ្នកសេរីនិយមជំទាស់នឹងអំណះអំណាងទ្រឹស្តីប្រាកដនិយម ដែលថា ផលប្រយោជន៍ផ្ទាល់ខ្លួនដ៏តិចតួចស្តួចស្តើង មានសមហេតុផលជាងកិច្ចសហប្រតិបត្តិការដែលផ្តល់ផលប្រយោជន៍ដល់គ្នាទៅវិញទៅមក។

៣. គោលការណ៍**បដិការ** អាចជាយុទ្ធសាស្ត្រដ៏មានប្រសិទ្ធិភាពក្នុងការឈានទៅរកកិច្ចសហប្រតិបត្តិការ នៅក្នុងទំនាក់ទំនងជាបន្តបន្ទាប់ ប៉ុន្តែអាចប្រែក្លាយជាគ្រោះថ្នាក់ ដូចជាការប្រទូស្តរ៉ាយឬ ការប្រណាំងប្រជែងផ្នែកសព្វាវុធ។

៤. ទ្រឹស្តីសេរីនិយមថ្មី(Neoliberalism) អះអាងថា សូម្បីតែនៅក្នុងប្រព័ន្ធអនាធិបតេយ្យនៃបណ្តារដ្ឋ ដែលថ្លឹងថ្លែងភាពសមហេតុផលនិងមានលក្ខណៈស្វយ័តរៀងៗខ្លួនក៏ដោយ ក៏កិច្ចសហប្រតិបត្តិការអាចកើតមានឡើងដែរ តាមរយៈការបង្កើត**បទដ្ឋាន របប** និង**ស្ថាប័ន**នានា។

៥. ផលប្រយោជន៍រួម(Collective goods) ជាអត្ថប្រយោជន៍ដែលសមាជិកក្រុមទាំងអស់ទទួលបាន ដោយមិនគិតពីការរួមវិភាគទានរបស់គេម្នាក់ៗឡើយ។ បទប្បញ្ញត្តិនិងវិធានរួមមានសារៈសំខាន់ខ្លាំងណាស់ដើម្បីធ្វើអោយសមាជិកទាំងអស់ចូលរួមចំណែក ក្នុងការស្វែងរកផលប្រយោជន៍សមូហភាព។

៦. របបអន្តរជាតិ(International regimes) ដែលជាសេចក្តីព្រំពឹងរួមសម្រាប់មេដឹកនាំរដ្ឋនីមួយៗ ក្នុងការគោរពច្បាប់ស្តីពីចំណុចបញ្ហា(issue areas)នានា ក្នុងទំនាក់ទំនងអន្តរជាតិ អាចជួយផ្តល់ស្ថេរភាព ក្នុងករណីគ្មានរដ្ឋាភិបាលពិភពលោក។

៧. ទ្រឹស្តីស្ថេរភាពអនុត្តរភាព (Hegemonic stability theory) បង្ហាញថា ការគ្រប់គ្រងលើសលប់ដោយរដ្ឋមួយ អាចផ្តល់ស្ថេរភាពដល់ទំនាក់ទំនងអន្តរជាតិ និងជួយបង្កើតរបបនានា។

៨. ក្នុងការរក្សាសន្តិសុខរួម ក្រុមនៃរដ្ឋនានាព្រមព្រៀងគ្នាឆ្លើយតបទៅនឹងការឈ្លានពានរបស់រដ្ឋដទៃទៀត។ អ.ស.ប និងអង្គការអន្តរជាតិបាលផ្សេងទៀត ជាអ្នកអនុវត្តមុខងារនេះ។

៩. នៅក្នុងប្រវត្តិសាស្ត្រ បណ្តាប្រទេសប្រជាធិបតេយ្យបានបង្កសង្គ្រាមច្រើន ដូចបណ្តារដ្ឋផ្តាច់ការដែរ ប៉ុន្តែប្រទេសប្រជាធិបតេយ្យពេញលេញស្ទើរតែមិនដែលធ្វើសង្គ្រាមប្រឆាំងនឹងគ្នាឡើយ។ នេះត្រូវបានគេហៅថា **សន្តិប្រជាធិបតេយ្យ**។

១០. អ្នកប្រាជ្ញទ្រឹស្តីស្ថាបនានិយមបដិសេធការសន្មតរបស់អ្នកប្រាកដនិយម អំពីផលប្រយោជន៍របស់រដ្ឋដោយតាមដានរកផលប្រយោជន៍ទាំងនោះ នៅក្នុងអន្តរកម្មនិងបទដ្ឋានសង្គម។

១១. មតិរិះគន់របស់ទ្រឹស្តីក្រោយសម័យទំនើបនិយមច្រានចោលភាសានិងក្របខ័ណ្ឌទាំងមូល របស់ទ្រឹស្តីប្រាកដនិយម ជាមួយនឹងតួអង្គរដ្ឋឯកភូត។ អ្នកប្រាជ្ញទ្រឹស្តីក្រោយសម័យទំនើបនិយម បានអះអាងថាគ្មានការធ្វើចំណាត់ថ្នាក់យ៉ាងសាមញ្ញណាមួយអាចផ្តិតយកសច្ចៈភាពច្រើនស្រទាប់ ដែលអ្នកចូលរួមក្នុងទំនាក់ទំនងអន្តរជាតិធ្លាប់បានជួបប្រទះឡើយ។

១២. អ្នកទ្រឹស្តីម៉ាក្សស៊ីសនិយម សម្លឹងមើលទំនាក់ទំនងអន្តរជាតិ រួមទាំងទំនាក់ទំនងរវាងអឡ្ឌគោលខាងជើងនិងខាងត្បូង ដោយផ្តោតលើការតស៊ូវណ្ណៈសេដ្ឋកិច្ច (ជាពិសេសរវាងកម្មករនិងថៅកែ) ដែលមានតួនាទីខុសគ្នានៅក្នុងសង្គម និងសមត្ថភាពទទួលអំណាចខុសគ្នាផងដែរ។

១៣. កម្មវិធីសិក្សាសន្តិភាព មានលក្ខណៈអន្តរមុខវិជ្ជា និងព្យាយាមពង្រីកការសិក្សាសន្តិសុខអន្តរជាតិដោយដាក់បញ្ចូលកត្តាសង្គមនិងសេដ្ឋកិច្ច ដែលមិនត្រូវបានទ្រឹស្តីប្រាកដនិយមយកចិត្តទុកដាក់ឡើយ។

១៤. ចំពោះអ្នកប្រាជ្ញសិក្សាសន្តិភាព របបយោធានិយមនៅក្នុងវប្បធម៌ជាច្រើន រួមចំណែកដល់ទំនោររបស់រដ្ឋក្នុងការប្រើប្រាស់កម្លាំងយោធាក្នុងកិច្ចចរចាអន្តរជាតិ។

១៥. អ្នកប្រាជ្ញស្ត្រីនិយមនៃទំនាក់ទំនងអន្តរជាតិបានយល់ស្របថា យេនឌ័រមានសារៈសំខាន់ក្នុងការស្វែងយល់អំពីទំនាក់ទំនងអន្តរជាតិ ប៉ុន្តែ បែងចែកជាឆ្លុងជាច្រើន ដោយឆ្លុងនីមួយៗ ទាក់ទងនឹងទស្សនៈរបស់ពួកគេចំពោះតួនាទីយេនឌ័រ។

១៦. អ្នកប្រាជ្ញស្ត្រីទីទៃនិយមអះអាងថា បុរសមានលក្ខណៈឈ្លានពានជាងស្ត្រី។ ពួកគេជឿថា ទោះបីជាអ្នកចូលរួមជាស្ត្រីនីមួយៗ(ដូចជាមេដឹកនាំរដ្ឋ) នឹងមិនអាចឆ្លុះបញ្ចាំងពីភាពខុសគ្នានេះក៏ដោយ ក៏ការចូលរួមរបស់ស្ត្រីកាន់តែច្រើន នឹងធ្វើអោយប្រព័ន្ធអន្តរជាតិកាន់តែមានសន្តិភាព។

១៧. អ្នកប្រាជ្ញស្ត្រីសេរីនិយមមិនយល់ស្របថា ស្ត្រីនិងបុរសមានសមត្ថភាពឬទំនោរខុសៗគ្នា ក្នុងនាមជាអ្នកចូលរួមក្នុងទំនាក់ទំនងអន្តរជាតិ។ ពួកគេអះអាងថា ស្ត្រីស្មើនឹងសមភាគីបុរស នៅក្នុងតួនាទីស្ទើរតែទាំងអស់ក្នុងទំនាក់ទំនងអន្តរជាតិ។ ជាក់ស្តែងតាង អ្នកប្រាជ្ញស្ត្រីសេរីនិយមបានចង្អុលបង្ហាញអ្នកដឹកនាំនិងទាហានស្ត្រី ក្នុងប្រវត្តិសាស្ត្រនិងនាពេលបច្ចុប្បន្ន។

១៨. អ្នកប្រាជ្ញស្ត្រីនិយមក្រោយសម័យទំនើបព្យាយាមកោះកកាយអត្ថន័យបង្កប់ទាក់ទងនឹងភេទ ដែលមាននៅក្នុងសុន្ទរកថាឬកិច្ចសន្ទនារបស់អ្នកប្រាកដនិយម រួមទាំងបញ្ហាផ្លូវភេទ ដែលទាក់ទងនឹងគំនិតនៃអំណាច។

ពាក្យគន្លឹះ

១. **ការពឹងអាស្រ័យគ្នាទៅវិញទៅមក**(interdepedency) សំដៅលើស្ថានភាពនយោបាយ និងសេដ្ឋកិច្ច ដែលរដ្ឋចំនួនពីរ ក្នុងពេលដំណាលគ្នា ពឹងផ្អែកគ្នាទៅវិញ សម្រាប់សុខុមាលភាពរបស់ពួកគេ។ កម្រិតនៃភាពអាស្រ័យគ្នាទៅវិញទៅមក ជួនកាល ត្រូវបានកំណត់ក្នុងលក្ខខណ្ឌនៃ«ភាពប្រែប្រួល» ឬ «ភាពងាយរងគ្រោះ»។

២. **ទ្រឹស្តីសេរីនិយមថ្មី** (neoliberalism)ដែលជាពាក្យកាត់នៃ«ស្ថាប័នសេរីនិយមថ្មី» គឺជាគោលការណ៍មួយដែលសង្កត់ធ្ងន់លើសារៈសំខាន់នៃស្ថាប័នអន្តរជាតិ ក្នុងការកាត់បន្ថយជម្លោះ ដែលអ្នកប្រាកដនិយមបានសន្មតថាពិតជាមិនអាចជៀសរួច នៅក្នុងប្រព័ន្ធអន្តរជាតិ។ ការប្តឹងផ្តែងហេតុផលបែបនេះត្រូវផ្អែកលើគំនិតសេរីនិយមដែលថា ការស្វែងរកផលប្រយោជន៍ទៅវិញទៅមករយៈពេលវែងច្រើនតែសមហេតុផលជាងការបង្កើនផលប្រយោជន៍ផ្ទាល់ខ្លួន ក្នុងរយៈពេលខ្លី។ សូមមើលផងដែរ *សេរីនិយមសេដ្ឋកិច្ច*។

៣. **របបអន្តរជាតិ**(international regimes) សំដៅលើសំណុំច្បាប់ បទដ្ឋាន និងនីតិវិធី ដែលតួអង្គនានាត្រូវគេរំពឹងថា ត្រូវគោរពប្រតិបត្តិ នៅក្នុងតំបន់បញ្ហាអន្តរជាតិជាក់លាក់មួយ (ដូចជាមហាសមុទ្រ ឬ គោលនយោបាយរូបិយវត្ថុ)។

៤. **សន្តិសុខរួម ឬសន្តិសុខសមូហភាព** (collective security) គឺជាការបង្កើតសម្ព័ន្ធភាពធំទូលំទូលាយក្នុងចំណោមតួអង្គសំខាន់ៗភាគច្រើន នៅក្នុងប្រព័ន្ធអន្តរជាតិ ក្នុងគោលដៅរួមគ្នាប្រឆាំងការឈ្លានពានដោយតួអង្គណាមួយទៀត។ ពេលខ្លះ ត្រូវបានគេមើលឃើញអត្ថិភាពនៃអង្គការសកល (ដូចជា អង្គការសហប្រជាជាតិ) ដែលរួមមានទាំងប្រទេសឈ្លានពាន និងប្រទេសជាគូប្រជែងរបស់ខ្លួន។ សូមមើលសម្ព័ន្ធប្រជាជាតិ ផងដែរ ។

៥. **សន្តិប្រជាធិបតេយ្យ** (democratic peace) គឺជាសំណើដែលត្រូវបានគាំទ្រដោយកស្តុតាងជាក់ស្តែងយ៉ាងរឹងមាំ ដែលអះអាងថា ប្រទេសប្រជាធិបតេយ្យពេញលេញស្ទើរតែមិនដែលធ្វើសង្គ្រាម ប្រឆាំងនឹងគ្នាឡើយ (ទោះបីជាពួកគេធ្វើសង្គ្រាមប្រឆាំងនឹងរដ្ឋផ្តាច់ការក៏ដោយ)។

៦. **ទ្រឹស្តីស្ថាបនានិយម** (constructivism) គឺជាចលនានៅក្នុងទ្រឹស្តីទំនាក់ទំនងអន្តរជាតិ ដែលពិនិត្យមើលពីរបៀបដែលការផ្លាស់ប្តូរបទដ្ឋានអន្តរជាតិនិងអត្តសញ្ញាណរបស់តួអង្គជួយស្ថាបនានូវអ្វី ដែលជាផលប្រយោជន៍របស់រដ្ឋ។

៧. **ទ្រឹស្តីក្រោយសម័យទំនើបនិយម**(Postmodernism) គឺជាគោលការណ៍ដែលបដិសេធអត្ថិភាពនៃសច្ចៈភាពថេរតែមួយ ហើយយកចិត្តទុកដាក់ជាពិសេសចំពោះអត្ថបទ និងសុន្ទរកថា ឬវិបស្សនា ពោលគឺរបៀបដែលមនុស្សនិយាយ និងសរសេរអំពីប្រធានបទណាមួយ។

៨. **អត្ថន័យរង** (subtext) សំដៅលើអត្ថន័យបង្កប់ ឬលាក់កំបាំង នៅក្នុងអត្ថបទ ជាជាងការបកស្រាយច្បាស់លាស់។ សូមមើល ទ្រឹស្តីក្រោយសម័យទំនើបនិយម ផងដែរ ។

៩. **វណ្ណៈសេដ្ឋកិច្ច**(economic classes) សំដៅលើការបែងចែកប្រភេទមនុស្សទាំងឡាយដោយផ្អែកលើស្ថានភាពសេដ្ឋកិច្ច។

១០. **ម៉ាក្សស៊ីសនិយម**(Marxism) ជាសាខានៃទ្រឹស្តីសង្គមនិយមដែលសង្កត់ធ្ងន់លើការជិះជាន់ ការកេងប្រវ័ញ្ច និងការតស៊ូវណ្ណៈ ហើយរួមបញ្ចូលទាំងលទ្ធិកុម្មុយនិស្ត និងគោលការណ៍ផ្សេងទៀត។

១១. **ដំណោះស្រាយជម្លោះ**(conflict resolution) សំដៅលើការអភិវឌ្ឍន៍ និងការអនុវត្តយុទ្ធសាស្ត្រដោយសន្តិវិធីសម្រាប់ការដោះស្រាយជម្លោះ។

១២. **ការសម្រុះសម្រួល**(mediation) សំដៅលើការប្រើប្រាស់កាគីទីបី (ឬពហុភាគី) ក្នុងការដោះស្រាយជម្លោះណាមួយ។

១៣. **លទ្ធិយោធានិយម**(militarism) គឺជាការលើកតម្កើងសង្គ្រាម កងកម្លាំងយោធា និងអំពើហិង្សា។

១៤. **សន្តិភាពវិជ្ជមាន**(positive peace) សំដៅលើសន្តិភាពដែលដោះស្រាយមូលហេតុទាំងឡាយដែលបណ្តាលអោយកើតសង្គ្រាម។ មិនមែនត្រឹមតែជាបទឈប់បាញ់គ្នាប៉ុណ្ណោះទេ ប៉ុន្តែ ការផ្លាស់ប្តូរទំនាក់ទំនង រួមទាំងការលុបបំបាត់ឬកាត់បន្ថយការកេងប្រវ័ញ្ចសេដ្ឋកិច្ច និងការគៀបសង្កត់ផ្នែកនយោបាយ។

១៥. **រដ្ឋាភិបាលពិភពលោក**(world government) គឺជាស្ថាប័នគ្រប់គ្រងពិភពលោក ថ្នាក់កណ្តាលដែលមានអំណាចពង្រឹងការអនុវត្ត។

១៦. **ចលនាសន្តិភាព**(peace movements) គឺជាចលនាប្រឆាំងនឹងសង្គ្រាមជាក់លាក់ណាមួយ ឬក៏ប្រឆាំងនឹងសង្គ្រាមនិងយោធានិយមជាទូទៅ ជាធម្មតា មានការចូលរួមពីមនុស្សមួយចំនួនធំ និងទម្រង់នៃសកម្មភាពដោយផ្ទាល់ ដូចជា ការតវ៉ាតាមផ្លូវជាដើម។

១៧. **ទ្រឹស្តីស្ត្រីទីទែនិយម** (deference feminism) គឺជាផ្លុងមួយនៃទ្រឹស្តីស្ត្រីនិយម ដែលជឿថា ភាពខុសគ្នាផ្នែកយេនឌ័រ មិនមែនគ្រាន់តែកើតឡើងដោយសារការស្ថាបនាសង្គមប៉ុណ្ណោះទេ ហើយយល់ថាស្ត្រីជាមនុស្សមិនមានលក្ខណៈឈ្លានពានដូចបុរសទេ (ជាមធ្យម)។

១៨. **ទ្រឹស្តីស្ត្រីសេរីនិយម** (liberal feminism) គឺជាផ្លុងមួយនៃទ្រឹស្តីស្ត្រីនិយម ដែលសង្កត់ធ្ងន់លើសមភាពយេនឌ័រ និងចាត់ទុកភាពខុសគ្នា«ជាចម្បង»នៅក្នុងសមត្ថភាពឬទស្សនៈរបស់បុរសនិងស្ត្រី ថាជារឿងតូចតាច ឬមិនមានសោះ។

១៩. **ទ្រឹស្តីស្ត្រីក្រោយសម័យទំនើបនិយម** (post-mondern feminism) គឺជាកិច្ចប្រឹងប្រែងដើម្បីរួមបញ្ចូលគ្នានូវទស្សនៈស្ត្រីនិយមនិងទ្រឹស្តីក្រោយសម័យទំនើបនិយម ដោយមានគោលដៅគាស់កកាយឥទ្ធិពលលាក់កំបាំងនៃយេនឌ័រនៅក្នុងទំនាក់ទំនងអន្តរជាតិ និងបង្ហាញពីរបៀបដែលការស្ថាបនាតួនាទីយេនឌ័រ ត្រូវបានធ្វើឡើងដោយមិនច្បាស់លាស់ តាមអំពើចិត្ត។

២០. **គម្លាតយេនឌ័រ** (gender gap) សំដៅលើការស្ទង់មតិនានា ដែលបង្ហាញពីការគាំទ្ររបស់ស្ត្រីមានភាគរយទាបជាងបុរស ក្នុងសកម្មភាពយោធា ក៏ដូចជា បញ្ហាផ្សេងៗនិងបេក្ខជនផ្សេងៗ។

២១. អត្តាធិបតេយ្យ (autocracy) ជាពាក្យផ្សំមកពី អត្ត + ធិបតេយ្យ ចង់សំដៅទៅលើរបប ឬ ប្រព័ន្ធ រដ្ឋាភិបាលដោយបុគ្គលម្នាក់ដែលមានអំណាចដាច់ខាតឬផ្តាច់ការ។

សំណួរអនុវត្តន៍

១. ទំនាក់ទំនងសហរដ្ឋអាមេរិកនិងកាណាដា ហាក់ដូចជាត្រូវបានពន្យល់ បានយ៉ាងល្អ ដោយទ្រឹស្តីស្ថាប័នសេរីនិយម ជាងការពន្យល់ដោយទ្រឹស្តីប្រាកដនិយម។ តើមានទំនាក់ទំនងអន្តរដ្ឋ(ណាមួយឬច្រើន) ណាផ្សេងទៀត ដែលមានលក្ខណៈបែបនេះ? ចូរបង្ហាញពីរបៀបដែលគោលការណ៍ផ្ទុយគ្នារវាងទ្រឹស្តីប្រាកដនិយមនិងទ្រឹស្តីស្ថាប័នសេរីនិយម ត្រូវបានអនុវត្ត ក្នុងទំនាក់ទំនងទាំងនោះ។

២. រហូតមកដល់បច្ចុប្បន្ននេះ ដោយសារប្រទេសប្រជាធិបតេយ្យពេញលេញ ស្ទើរតែមិនដែលធ្វើសង្គ្រាមនឹងគ្នា តើអ្នកគិតថាប្រទេសប្រជាធិបតេយ្យទាំងនោះមានផលប្រយោជន៍ខាងសន្តិសុខជាតិដែរឬទេ ក្នុងការធ្វើឲ្យប្រទេសចិននិងរដ្ឋផ្តាច់ការដទៃទៀត ប្រកាន់លទ្ធិប្រជាធិបតេយ្យដែរ? បើដូច្នេះមែន តើផលប្រយោជន៍ទាំងនោះ អាចត្រូវបានផ្សះផ្សាជាមួយនឹងបទដ្ឋាន ឬ គោលការណ៍មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់រដ្ឋអធិបតេយ្យដទៃទៀត ដោយរបៀបណា ?

៣. តើអ្នកអាចស្វែងរកករណីណាមួយ ដែលសកម្មភាពរបស់រដ្ឋមួយ បានអនុវត្តតាមគោលការណ៍«អត្តសញ្ញាណ»ដែលស្ថាបនាឡើង ជាជាងធ្វើដើម្បីតែផលប្រយោជន៍ជាតិផ្ទាល់ខ្លួន ដែរឬទេ? តើគំនិតសំខាន់ៗក្នុងការស្ថាបនាឬបង្កើត«អត្តសញ្ញាណ»នោះ មានប្រភពមកពីណា ហើយតើគំនិតទាំងនោះមានឥទ្ធិពលលើសកម្មភាពរបស់រដ្ឋយ៉ាងដូចម្តេចខ្លះ?

៤. តើទំនាក់ទំនងអន្តរជាតិនឹងប្រព្រឹត្តិទៅ តាមរបៀបខុសពីបច្ចុប្បន្ន ដែរឬទេ ប្រសិនបើមេដឹកនាំរដ្ឋភាគច្រើនជាស្ត្រី? តើនឹងមានភាពខុសគ្នាយ៉ាងដូចម្តេចខ្លះ? តើមានភស្តុតាងអ្វីខ្លះ (ក្រៅពីគោលការណ៍«អត្តសញ្ញាណ»យេនឌ័រ) សម្រាប់គាំទ្រចម្លើយរបស់អ្នក?

៥ តើការពន្យល់អំពីព្រឹត្តិការណ៍ទំនាក់ទំនងអន្តរជាតិ នឹងផ្លាស់ប្តូរទៅជាយ៉ាងណាខ្លះ ប្រសិនបើស្ត្រីត្រូវបានគេចាត់ទុកថាជាតួអង្គសំខាន់ ជាជាងគ្រាន់តែត្រូវបានចាត់ទុកជាតួអង្គរាយរង? តើស្ត្រីណា កាន់តួនាទីអ្វី ដែលអ្នកគិតថាសំខាន់?

ការស្វែងរកផលប្រយោជន៍រួម

ប្រទេសអស្ចារ្យត្រូវបង់វិក្កយបត្ររបស់ខ្លួនផង

ផលប្រយោជន៍រួម៖ កញ្ចប់ថវិកាអង្គការសហប្រជាជាតិ

រូបថត ទីស្នាក់ការអង្គការសហប្រជាជាតិនៅទីក្រុងញូវយ៉ក។

សារតារ

ចាប់តាំងពីការបង្កើតឡើងនៅចុងបញ្ចប់នៃសង្គ្រាមលោកលើកទី ២ អង្គការសហប្រជាជាតិបានអនុវត្តកម្មវិធីដ៏មានតម្លៃផ្សេងៗជាច្រើន សម្រាប់បម្រើអោយផលប្រយោជន៍នៃសមាជិករបស់ខ្លួន ដែលជាប្រទេសទាំងឡាយនៅលើសកលលោក។ ប្រទេសនានាបានប្រើប្រាស់អង្គការសហប្រជាជាតិសម្រាប់ការងារការទូត ការរក្សាសន្តិភាព និងជំនួយមនុស្សធម៌ ដែលស្ថិតនៅក្នុងចំណោមកម្មវិធីសេវាកម្មផ្សេងៗទៀត។ សេវាកម្មទាំងនេះគឺជាផលប្រយោជន៍រួម សម្រាប់ប្រទេសនានានៅលើពិភពលោក ពីព្រោះប្រទេសនីមួយៗត្រេកអរនឹងផលប្រយោជន៍ទាំងនោះ បើទោះបីពួកគេបានចំណាយច្រើនឬតិចសម្រាប់កញ្ចប់ថវិការបស់

អង្គការសហប្រជាជាតិ។ អង្គការកំណត់ពេលវេលាសម្រាប់អោយសមាជិករបស់ខ្លួន បង់ប្រាក់វិភាគទានអោយទាន់ពេលវេលា ប៉ុន្តែក៏មានសមាជិកខ្លះៗយឺតយ៉ាវ ខ្លះទៀតយឺតហើយយឺតទៀត។

បញ្ហាប្រឈម

ក្នុងទស្សវត្សរ៍ឆ្នាំ ១៩៨០ សហរដ្ឋអាមេរិកតែងតែមានជម្លោះជាបន្តបន្ទាប់ជាមួយនឹងអង្គការសហប្រជាជាតិស្តីពីចំនួនទឹកប្រាក់ ដែលសហរដ្ឋអាមេរិកត្រូវបង់។ នៅត្រឹមពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៩៩០ សមាជិករបស់អង្គការសហប្រជាជាតិ បានជំពាក់ប្រាក់វិភាគទានដែលត្រូវបង់រាប់ពាន់លានដុល្លារ ដែលសូម្បីសហរដ្ឋអាមេរិកតែមួយបានជំពាក់ជាងមួយពាន់លានដុល្លារ រីឯរុស្ស៊ីវិញជំពាក់ប្រហែល៥០០លានដុល្លារ។ មន្ត្រីការទូតបានជួបប្រជុំនៅក្នុងបន្ទប់ដ៏សែនត្រជាក់ខ្លាំង ក៏ដោយសារអង្គការសហប្រជាជាតិ មិនអាចមានលទ្ធភាពប្រើម៉ាស៊ីនកម្តៅអគារទីស្នាក់ការកណ្តាលរបស់ខ្លួន នៅទីក្រុងញូវយ៉ក ក្នុងរដូវរងារ។ នយោបាយក្នុងស្រុករបស់សហរដ្ឋអាមេរិកបានរួមចំណែកយ៉ាងធំដល់បញ្ហារបស់អង្គការសហប្រជាជាតិ ដោយសារតែសភាដែលគ្រប់គ្រងដោយបក្សសាធារណៈរដ្ឋមិនបានយល់ព្រមលើសំណើថវិការបស់លោកប្រធានាធិបតី គ្លីនតុន សម្រាប់អង្គការសហប្រជាជាតិ ដែលត្រូវបានពួកគេមើលឃើញថាជាអង្គការគ្មានប្រយោជន៍ និងគ្មានប្រសិទ្ធភាព ពុករលួយ និងប្រឆាំងនឹងផលប្រយោជន៍អាមេរិកយ៉ាងខ្លាំង។

ដំណោះស្រាយ

គោលការណ៍បដិការ គ្រប់គ្រងការរួមវិភាគទានដល់អង្គការសហប្រជាជាតិ ជាគោលការណ៍ពីព្រោះថា ប្រទេសទាំងអស់ចូលរួមចំណែកក្នុងការបង់ប្រាក់ទៅតាមរូបមន្តមួយ ដោយផ្អែកលើទំហំសេដ្ឋកិច្ចរបស់រដ្ឋនីមួយៗ ប៉ុន្តែ នៅក្នុងការអនុវត្តជាក់ស្តែង ប្រទេសជាច្រើនបានបដិសេធរូបមន្តនោះដើម្បីឆ្លៀតទាញយកផលប្រយោជន៍រយៈពេលខ្លីសម្រាប់ខ្លួនឯង។ គោលការណ៍គ្រប់គ្រង មិនអាចយកមកប្រើបាននោះទេ ដោយសារអង្គការសហប្រជាជាតិមិនអាចប្រើបានកងកម្លាំងយោធា ដើម្បីបង្ខំប្រទេសណាមួយអោយបង់ថ្លៃរួមវិភាគទានរបស់ខ្លួនបានទេ។

មូលនិធិអង្គការសហប្រជាជាតិ ដែលបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៨ ជាមួយនឹងការរួមចំណែកដ៏ធំធេង ដោយមហាសេដ្ឋីប្រព័ន្ធផ្សព្វផ្សាយ លោក ធេដ ធើន័រ (Ted Turner) ដែលបានចាប់ផ្តើមយុទ្ធនាការមួយ ដើម្បីប្រើប្រាស់គោលការណ៍អត្តសញ្ញាណរួមគ្នា ដើម្បីដោះស្រាយបញ្ហានៃការមិនបង់ប្រាក់របស់ប្រទេសសហរដ្ឋអាមេរិក។ ពាក្យស្លោកនៃយុទ្ធនាការនេះ «ប្រទេសដ៏អស្ចារ្យបង់វិក្កយបត្ររបស់ខ្លួន» បានសំដៅទៅលើសហរដ្ឋអាមេរិក ដោយចាត់ទុកដូចជាឪពុកមួយរូប ដែលខកខានមិនបានបង់ប្រាក់អាហារកិច្ចសម្រាប់ចិញ្ចឹមកូនៗរបស់ខ្លួន ការអំពាវនាវដល់ផ្នត់គំនិតរបស់ជនជាតិអាមេរិក ដែលចាត់ទុកថាប្រទេសរបស់ខ្លួនជាប្រជាជាតិដ៏អស្ចារ្យ បានផ្លាស់ប្តូរសំឡេងនៃការជជែកដេញដោលគ្នា អំពីការរួមវិភាគទានដល់អង្គការសហប្រជាជាតិ។ សហរដ្ឋអាមេរិកចាប់ផ្តើមតាមបង់ប្រាក់វិភាគទានដែលជំពាក់ ហើយនៅឆ្នាំ ២០០៩ ពួកគេបានបង់ប្រាក់កាតព្វកិច្ចចុងក្រោយដែលនៅសេសសល់។ ទោះជាយ៉ាងណាក៏ដោយ ក្នុងឆ្នាំ ២០១៧ សហរដ្ឋអាមេរិកបានគំរាមម្តងទៀតថា នឹងបង្កក់ប្រាក់រួមវិភាគទានសម្រាប់អង្គការសហប្រជាជាតិ ជុំវិញការខ្វែងគំនិតគ្នាទាក់ទងនឹងគោលនយោបាយនៅមជ្ឈិមបូព៌ា។ ជាថ្មីម្តងទៀត នយោបាយក្នុងស្រុក នៅសហរដ្ឋអាមេរិកនឹងដើរតួនាទីសំខាន់ក្នុងថវិការបស់អង្គការសហប្រជាជាតិ (សូមមើលប្រអប់ មតិសាធារណៈ និងទំនាក់ទំនង

អន្តរជាតិ)។ ហើយសំណួរដែលថា តើគោលការណ៍អត្តសញ្ញាណនឹងនៅតែជាដំណោះស្រាយដោះស្រាយបញ្ហាបែបនេះទៅថ្ងៃអនាគតទៀតឬយ៉ាងណា នៅមិនទាន់មានចម្លើយនោះទេ។

ឧស្សុន:ទិស័យគោលនយោបាយ

ប្រធានាធិបតីហ្សកហ្ស៊ី លោក ជីអូហ្គី ម៉ាហ្គេសវីលី (Giorgi Margvelashvili)

រូបថត **ប្រធានាធិបតី ជីអូហ្គី ម៉ាហ្គេសវីលី**

បញ្ហា

តើអ្នកអាចសម្រេចបាននូវកិច្ចសហប្រតិបត្តិការផ្នែកសន្តិសុខជាមួយស្ថាប័នអន្តរជាតិ ដោយរបៀបណា ក្នុងខណៈពេលដែលត្រូវប្រឈមមុខនឹងសម្ពាធពីប្រទេសជិតខាងដ៏មានឥទ្ធិពល?

សារតារ

តាំងពីឆ្នាំ ២០០៣ មក ប្រទេសរបស់អ្នកបានព្យាយាមជាក់ពាក្យចូលជាសមាជិកភាពក្នុងអង្គការណាតូ។ នៅក្នុងឆ្នាំ ២០០៨ មេដឹកនាំអង្គការណាតូបានសន្យាថា ប្រទេសហ្សកហ្ស៊ីនឹងក្លាយជាសមាជិកនៃសម្ព័ន្ធភាពយោធាមួយនេះ នាពេលអនាគត។

គិតមកត្រឹមឆ្នាំ ២០១៨ សមាជិកអង្គការណាតូមិនទាន់បានផ្តល់អោយអ្នកនូវផែនការសកម្មភាពសមាជិកភាព(Membership Action Plan)នៅឡើយ។ វាជាកិច្ចព្រមព្រៀងដែលចាប់ផ្តើមដំណើរការនៃការចូលរួមក្នុងសម្ព័ន្ធភាពនេះ។ ពួកគេបានផ្តល់អោយអ្នកនូវការគាំទ្រផ្នែកយោធានិងជំនួយផ្នែកយោធាកាន់តែច្រើន ខណៈពេលដែលបន្តសន្យាសមាជិកភាពរបស់អ្នកនៅក្នុងសម្ព័ន្ធភាពមួយនេះ នៅពេលអនាគតឆាប់ៗ ដូចកាលពីឆ្នាំ ២០១៧ ដែរ។

ក្នុងនាមជាប្រទេសជិតខាងដ៏មានអំណាចនៅភាគខាងជើង ប្រទេសរុស្ស៊ី ដែលបានប្រឆាំងទៅនឹងសមាជិកភាពរបស់ប្រទេសអ្នកនៅក្នុងអង្គការណាតូ ដោយបើកចំហ។ ក្នុងឆ្នាំ ២០០៨ អ្នកបានធ្វើសង្គ្រាមប្រឆាំងនឹងប្រទេសរុស្ស៊ី ក្នុងខេត្តចំនួនពីរក្នុងប្រទេសរបស់អ្នក ដែលមានជនជាតិភាគតិចរុស្ស៊ីជាច្រើនកំពុងរស់នៅ។ នៅក្នុងអំឡុងពេលសង្គ្រាមនោះ រុស្ស៊ីបានដាក់ពង្រាយទ័ពទៅកាន់ខេត្តទាំងពីរនោះ ហើយបានទម្លាក់គ្រាប់បែកលើរដ្ឋធានីរបស់អ្នក។ សព្វថ្ងៃនេះ ទាហានរុស្ស៊ីនៅតែបន្តកាន់កាប់ខេត្តទាំងនោះ ហើយសហភាពអឺរ៉ុបបានទទួលស្គាល់តំបន់នេះថាជា «ទឹកដីកាន់កាប់»។

ការពិចារណាទិដ្ឋភាពក្នុងតំបន់

ជាប្រវត្តិសាស្ត្រ ប្រជាជនភាគច្រើនរបស់អ្នក គាំទ្រសមាជិកភាពរបស់អ្នកនៅក្នុងអង្គការណាតូ។ ប្រជាមតិនៅឆ្នាំ២០០៨ បានបង្ហាញថា ៧៧ ភាគរយនៃសាធារណជនពេញចិត្តនឹងការចូលរួមរបស់អង្គការណាតូ។ ការស្ទង់មតិសាធារណៈឆ្នាំ ២០១៤ បានបង្ហាញពីចំនួនស្រដៀងគ្នា៖ ៧៨ ភាគរយ គាំទ្រចំពោះការចូលជាសមាជិកអង្គការណាតូ។ ការស្ទង់មតិឆ្នាំ ២០១៧ បានបង្ហាញថាមានប្រជាជនត្រឹមតែ ២០ ភាគរយ ប៉ុណ្ណោះប្រឆាំងនឹងសមាជិកភាពក្នុងអង្គការណាតូ។ ស្ទើរតែគ្រប់គណបក្សនយោបាយនៅហ្សកហ្ស៊ី គាំទ្រសមាជិកភាពអង្គការណាតូ។

សាធារណជន ខណៈដែលគាំទ្រសមាជិកភាពអង្គការណាតូ ក៏មានការភ័យពីការគំរាមគំហែងពីប្រទេសរុស្ស៊ីផងដែរ។ ការស្ទង់មតិសាធារណៈឆ្នាំ ២០១៤ ដូចគ្នាបានបង្ហាញ ៧៦ ភាគរយនៃចំនួនប្រជាជនរបស់អ្នកជឿថា ប្រទេសរុស្ស៊ីគឺជាការគំរាមកំហែងដ៏ធំមួយ។ ជាងនេះទៅទៀត ប្រជាជនហ្សកហ្ស៊ីមានការ

ភ័យខ្លាចយ៉ាងខ្លាំងចំពោះអនាគតនយោបាយនិងសេដ្ឋកិច្ច ដោយប្រជាជនប្រមាណ ៥៥ ភាគរយនិយាយថា ប្រទេសខ្លួន បានផ្លាស់ទីក្នុង«ទិសដៅខុស»។ កត្តាទាំងនេះអាចបង្កបញ្ហាសម្រាប់បក្សសម្ព័ន្ធចម្រុះរបស់អ្នក។

សេណារីយ៉ូ

ចូរស្រមៃថា អង្គការណាតូផ្តល់«ផែនការសកម្មភាពសមាជិកភាព»សម្រាប់ហ្សកហ្ស៊ី។ រុស្ស៊ីឆ្លើយតបដោយការគំរាមកំហែងបំផ្លាញបទឈប់បាញ់គ្នា នៅខេត្តដែលមានជម្លោះ នៅក្នុងប្រទេសហ្សកហ្ស៊ី។ រុស្ស៊ីទាមទារអោយអ្នកកាត់បន្ថយកិច្ចសហប្រតិបត្តិការជាមួយអង្គការណាតូ ហើយបោះបង់ចោលគោលដៅចង់ក្លាយជាសមាជិកភាព។ មេដឹកនាំអឺរ៉ុបនិងមេដឹកនាំអាមេរិកបានប្តោលទោសរុស្ស៊ីចំពោះការគំរាមកំហែង និងគាំទ្រសមាជិកភាពរបស់អ្នក នៅក្នុងអង្គការណាតូ។ យ៉ាងណាក៏ដោយ ថ្នាក់ដឹកនាំជដែលក៏បានចេញសេចក្តីថ្លែងការណ៍មិនច្បាស់លាស់ថាតើពួកគេនឹងធ្វើសង្គ្រាមប្រឆាំងនឹងរុស្ស៊ី ដើម្បីការពារប្រទេសរបស់អ្នកដែរឬអត់។

ចូរជ្រើសរើសគោលនយោបាយរបស់អ្នក

តើអ្នកបន្តពង្រឹងទំនាក់ទំនងជាមួយអង្គការណាតូ បើទោះបីជាប្រទេសរុស្ស៊ីបានគំរាមអ្នកមិនអោយចូលរួមក្នុងសម្ព័ន្ធភាព? តើអ្នកព្រមចុះចាញ់តាមការទាមទាររបស់ប្រទេសរុស្ស៊ី ហើយព្រមបោះបង់កិច្ចសហប្រតិបត្តិការនេះដែរឬទេ? តើអ្នកផ្លាស់ប្តូរគោលជំហរផ្ទាល់ខ្លួនចំពោះអង្គការណាតូ ជាការឆ្លើយតបចំពោះការគំរាមកំហែងរបស់រុស្ស៊ី និងជំរុញអោយមានសមាជិកភាពពេញលេញក្នុងអង្គការណាតូអោយបានឆាប់តាមដែលអាចធ្វើបាន? តើអ្នកអាចបន្តកិច្ចសហប្រតិបត្តិការជាមួយអង្គការណាតូ ក្នុងខណៈពេលរក្សាសន្តិភាពដ៏ផុយស្រួយជាមួយប្រទេសរុស្ស៊ី បានដែរទេ?

មតិសាធារណៈ និងទំនាក់ទំនងអន្តរជាតិ

សហរដ្ឋអាមេរិក និងអង្គការសហប្រជាជាតិ

ស្ថាប័នដែលបង្កប់នូវមុខងារសន្តិសុខសមូហភាព និងកិច្ចប្រឹងប្រែងដើម្បីរក្សាសន្តិភាពពិភពលោក គឺអង្គការសហប្រជាជាតិ។ បើទោះបីជាតួនាទីសហរដ្ឋអាមេរិកមានសារៈសំខាន់ក្នុងការបង្កើតអង្គការសហប្រជាជាតិ និងធ្វើជាម្ចាស់ផ្ទះនៃទីស្នាក់ការអ.ស.ប. មតិសាធារណៈរបស់អាមេរិកចំពោះអង្គការសហប្រជាជាតិតែងតែការបែងចែកគ្នា។ ទោះបីជាចំណុចស្នូលនៃមតិចម្រុងចម្រាស់បានផ្លាស់ប្តូរ តាមពេលវេលាក៏ដោយ ការខកបំណងរបស់ជនជាតិអាមេរិកមួយចំនួនចំពោះអង្គការសហប្រជាជាតិ គឺថា អង្គការសហប្រជាជាតិតែងតែមិនលើកកម្ពស់ផលប្រយោជន៍របស់សហរដ្ឋអាមេរិកនោះទេ។ ពួកគេគិតថាប្រសិនបើសហរដ្ឋអាមេរិកគឺជាម្ចាស់ផ្ទះនៃស្ថាប័នមួយនេះ ហើយបានបង់ថ្លៃចំណាយដ៏ច្រើនសន្ធឹកសន្ធាប់ ដូច្នេះហើយអង្គការសហប្រជាជាតិគួរតែគាំទ្រគោលដៅគោលនយោបាយការបរទេសរបស់អាមេរិក និងសម្ព័ន្ធមិត្តរបស់អាមេរិក។


ប្រជាពលរដ្ឋដែលរស់នៅសហរដ្ឋអាមេរិកដែលគាំទ្រអង្គការសហប្រជាជាតិជាងបានអះអាងថា វាជាស្ថាប័នមួយមានភាពឯករាជ្យ និងមានគោលដៅបម្រើផលប្រយោជន៍ប្រទេសទាំងអស់ មិនមែនត្រឹមតែផលប្រយោជន៍សហរដ្ឋអាមេរិកនោះទេ។ អ្នកគាំទ្រទាំងនោះបន្តថា នៅខណៈពេលដែលអង្គការសហប្រជាជាតិពេលខ្លះ ធ្វើសកម្មភាពដែលមិនគាំទ្រដល់សហរដ្ឋអាមេរិក អង្គការនេះទំនងជាតតាំងជាមួយប្រទេសចិន ឬរុស្ស៊ី ឬ បារាំង ដូចគ្នាផងដែរ។

តើសាធារណមតិនៅសហរដ្ឋអាមេរិក ចំពោះអង្គការសហប្រជាជាតិ មានការផ្លាស់ប្តូរយ៉ាងណា? អ្វីដែលគួរឱ្យចាប់អារម្មណ៍ ខណៈពេលដែលមានការផ្លាស់ប្តូរមតិសាធារណៈក្នុងរយៈពេល ៣០ ឆ្នាំកន្លងមកនេះ គ្មានការផ្លាស់ប្តូរណាមួយមានទំហំធំគួរអោយកត់សម្គាល់នោះទេ។ ទិន្នន័យនៅក្នុងក្រាហ្វិកទី ៣.៣ បែងចែកអ្នកចូលរួមការស្ទង់មតិ ក្នុងចំណោមអ្នកដែលមានទស្សនៈមិនអំណោយផលខ្លាំង មិនសូវអំណោយផល ឬអំណោយផលខ្លះ ឬអំណោយផលខ្លាំង ចំពោះអង្គការសហប្រជាជាតិ។ ចាប់តាំងពីពាក់កណ្តាលទស្សវត្សរ៍ឆ្នាំ ១៩៨០ មក សាធារណមតិជាទូទៅ នៅក្នុងសហរដ្ឋអាមេរិក មានភាពអំណោយផលខ្លះៗ។ មតិទាំងនេះបានធ្លាក់ចុះបន្តិចម្តងៗ ពីប្រហែល ៥៥ ភាគរយ ទៅ ៤៥ ភាគរយ ជាមធ្យម។ ក្នុងអំឡុងពេលនោះ អ្នកដែលចាត់ទុកអង្គការសហប្រជាជាតិថាមានភាពអំណោយផលបានកើនឡើង ពីប្រហែល ១២ ភាគរយ ដិតដល់ ២០ ភាគរយ ជាមធ្យម។

ក្រាហ្វិក ៣.៣ សាធារណមតិពលរដ្ឋអាមេរិកចំពោះអង្គការសហប្រជាតិ

ប្រភព៖ មជ្ឈមណ្ឌល Roper សម្រាប់ការស្រាវជ្រាវមតិសាធារណៈ ឆ្នាំ ២០១៧

មនោសញ្ចេតនារបស់អង្គការសហប្រជាជាតិមានលក្ខណៈ...



ចំណាំ៖ អ័ក្សឈរជាភាគរយនៃសាធារណមតិ, អ័ក្សដេកជាឆ្នាំនៃការស្ទាបស្ទង់មតិ។ ខ្សែកោងដាច់ៗមានដុំការ៉េតំណាងអោយទស្សនៈមិនអំណោយផលខ្លាំង, ខ្សែកោងដាច់ៗមានដុំត្រីកោណតំណាងអោយទស្សនៈមិនសូវអំណោយផល, ខ្សែកោងដាច់ៗមានដុំមូលតំណាងអោយទស្សនៈអំណោយផលខ្លះ, និងខ្សែកោងជាប់អមដោយរង្វង់មូលតំណាងអោយទស្សនៈអំណោយផលខ្លាំង។

អ្នកដែលចាត់ទុកថា អង្គការសហប្រជាជាតិមិនសូវមានអំណោយផល បានកើនឡើងក្នុងកំឡុងពេលដូចគ្នា ពីប្រហែល ៨ ភាគរយទៅ ១៧ ភាគរយ ដែលជាអត្រាកំណើនជិត ១០ ភាគរយ។ ប៉ុន្តែ អ្នកដែលចាត់ទុកអង្គការសហប្រជាជាតិថាមិនអំណោយផលខ្លាំង បានធ្លាក់ចុះពីប្រហែល ១៨ ភាគរយ ទៅប្រហែល ១២ ភាគរយ។ សរុបមក លទ្ធផលនេះបង្ហាញអោយឃើញយ៉ាងច្បាស់ថា ជនជាតិអាមេរិកភាគច្រើនស្ថិតក្នុងពន្លឺនៃទស្សនៈភាពអំណោយផលចំពោះអង្គការសហប្រជាជាតិ។ ជារួម ប្រហែល ៦៥ ភាគរយនៃជនជាតិអាមេរិកមានទស្សនៈអំណោយផល ខណៈដែលប្រហែល ៣០ ភាគរយ មានទស្សនៈមិនអំណោយផល។

យើងអាចទាញការសន្និដ្ឋានប៉ុន្មានចំណុចអំពីទិន្នន័យទាំងនេះ។ ទីមួយ មតិសាធារណៈអំពីអង្គការសហប្រជាជាតិមិនមានការផ្លាស់ប្តូរច្រើនទេ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមក៖ មិនមានករណីនៃការផ្លាស់ប្តូរទស្សនៈដ៏ធំដុំនៅក្នុងចំណោមសាធារណមតិចំពោះអង្គការសហប្រជាជាតិនោះទេ បើទោះបីជាមានការដាំដែកដេញដោលជាបន្តបន្ទាប់ នៅក្នុងសហរដ្ឋអាមេរិកអំពីតួនាទីរបស់អង្គការសហប្រជាជាតិក្នុងគោលនយោបាយការបរទេសរបស់អាមេរិកក៏ដោយ។ ចំណុចទីពីរ វាហាក់ដូចជាថា ខណៈពេលដែលពលរដ្ឋអាមេរិកមួយចំនួនខកចិត្តជាមួយអង្គការសហប្រជាជាតិ ប៉ុន្តែ ក៏មានតុល្យភាពផងដែរ ពួកគេនៅតែគាំទ្រស្ថាប័ន និងបេសកកម្មរបស់អង្គការសហប្រជាជាតិ។

តោះ! សាកល្បងពិភាក្សាអំពីបញ្ហាជាក់ស្តែង

កូតាសមាជិកសភាសម្រាប់ស្ត្រី៖ ជាឧបករណ៍ដ៏មានប្រសិទ្ធភាពសម្រាប់សមភាពដែរឬទេ?

ទិដ្ឋភាពទូទៅ

បច្ចុប្បន្ននេះ ប្រទេសជាច្រើនប្រើប្រាស់កូតាយេនឌ័រ នៅពេលបោះឆ្នោតជ្រើសរើសសមាជិកសភា។ វាជារឿងពិតសម្រាប់ប្រជាធិបតេយ្យថ្មីថ្មោង នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ គិតត្រឹមឆ្នាំ ២០១៣ ប្រទេសចំនួន ៣៤ បានតម្រូវតាមផ្លូវច្បាប់អោយស្ត្រីកាន់កាប់អាសនៈមួយចំនួននៅក្នុងសភាជាតិ ហើយប្រទេសចំនួន ៦០ តម្រូវអោយស្ត្រីចូលក្នុងបញ្ជីបេក្ខជនគណបក្សសម្រាប់ការបោះឆ្នោតសភាជាតិ។ តម្រូវការសម្រាប់ចំនួនអាសនៈមានចាប់ពីកម្រិតទាប ដាង ២ ភាគរយនៃអាសនៈ នៅក្នុងប្រទេសបង់ក្លាដែស (ដែលបានជ្រើសរើសស្ត្រីធ្វើជានាយករដ្ឋមន្ត្រី ក្នុងឆ្នាំ ២០០៩) រហូតដល់ជិត ៣០ ភាគរយនៃអាសនៈនៃសភាជាន់ទាបនៅក្នុងប្រទេស រ៉ាន់ដា ។

ចំនួនកូតាទាំងនេះមិនគ្រាន់ខុសគ្នា តាមចំនួនអាសនៈដែលបានបម្រុងទុកសម្រាប់ស្ត្រីប៉ុណ្ណោះទេ ប៉ុន្តែ ក៏មានភាពខុសគ្នានៅក្នុងការអនុវត្តផងដែរ។ ប្រទេសមួយចំនួនបានធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញរបស់ខ្លួនដើម្បីទាមទារអោយមានតំណាងកាន់តែស្មើភាពគ្នាថែមទៀត។ ប្រទេសផ្សេងទៀតបានអនុម័តច្បាប់ (ដែលមានភាពងាយស្រួលកែប្រែ នៅពេលក្រោយ ស្រួលជាងផ្លាស់ប្តូររដ្ឋធម្មនុញ្ញ) ដើម្បីកាត់ចេញចំនួនអប្បរមានៃអាសនៈនីតិបញ្ញត្តិសម្រាប់ស្ត្រី ខណៈដែលប្រទេសផ្សេងទៀត នៅតែជាក់បន្ទុកលើគណបក្សនយោបាយ។ ក្នុងការអនុវត្តក្នុងករណីចុងក្រោយនេះ គណបក្សនានាត្រូវតែតែងតាំងស្ត្រីចំនួនភាគរយជាក់លាក់ ដើម្បីឈរឈ្មោះក្នុងការបោះឆ្នោត។ វិធីសាស្ត្រនេះមិនបានធានាអាសនៈដល់ស្ត្រីនោះទេ (ព្រោះតែកត្តាអាចចាញ់ការបោះឆ្នោត) ប៉ុន្តែវាធានានូវឱកាសដើម្បីចូលកាន់អាសនៈ។

បណ្តារដ្ឋលោកខាងលិច (ជាពិសេសនៅអឺរ៉ុប) និងអង្គការសិទ្ធិមនុស្ស ជារឿយៗ បានលើកទឹកចិត្តអោយមានបាតុកូតកើនឡើងចំនួនកូតាយេនឌ័រនេះ។ តើរដ្ឋលោកខាងលិចដែលជួយដល់ដំណើរការប្រែក្លាយជាប្រជាធិបតេយ្យគួរតែលើកទឹកចិត្ត (ឬសូម្បីតែទាមទារ) កូតាទាំងនេះដែរឬទេ? តើកូតាទាំងនេះជួយជំរុញឬក៏ប៉ះពាល់ដល់គោលដៅសមភាពស្ត្រី ក្នុងប្រទេសកំពុងអភិវឌ្ឍន៍?

អំណះអំណាង ១

កូតានីតិបញ្ញត្តិមានសារៈសំខាន់សម្រាប់សមភាពនិងការអភិវឌ្ឍន៍

តំណាងស្មើភាពគ្នាពិតជាមានសារៈសំខាន់សម្រាប់រដ្ឋាភិបាលប្រជាធិបតេយ្យ។

ស្ត្រីមានចំនួនពាក់កណ្តាលនៃចំនួនប្រជាជនក្នុងប្រទេសភាគច្រើន។ ដូច្នេះ ពួកគេគួរតែមានសិទ្ធិស្មើគ្នាក្នុងការបញ្ចេញមតិ នៅក្នុងដំណើរការនយោបាយ។ លទ្ធិប្រជាធិបតេយ្យដែលដំណើការល្អទាមទារអោយប្រជាពលរដ្ឋទាំងអស់មានអារម្មណ៍ចង់វិនិយោគឬចូលរួម នៅក្នុងដំណើរការនយោបាយ។

ស្ត្រីនឹងប្រឈមការរើសអើង និងការទទួលចូលប្រឡូកក្នុងនយោបាយយឺតជាង ប្រសិនបើគ្មានកូតា។

នៅសហរដ្ឋអាមេរិក និងអឺរ៉ុប ទោះបីជាមានការបោះឆ្នោតក៏ដោយ វាត្រូវការពេលជាច្រើនឆ្នាំទៀតដើម្បីអោយស្ត្រីមានអ្នកតំណាងនៅក្នុងសភា ក្នុងចំនួនដ៏ច្រើន។ គ្មានហេតុផលអ្វីត្រូវរំពឹងថាប្រទេសកំពុងអភិវឌ្ឍមានស្ថានភាពខុសប្លែកគ្នានោះទេ។ ការដែរមានកូតា នោះវានឹងពន្លឿនការទទួលយកស្ត្រីនៅក្នុងពិភពនយោបាយ ដោយផ្តល់អោយពួកគេនូវសិទ្ធិសម្រេចកាន់តែច្រើនអំពីបញ្ហាគោលនយោបាយសាធារណៈ។

ការពង្រឹងអំណាចនយោបាយរបស់ស្ត្រីនឹងជួយដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច។

ការសិក្សាមួយបានបង្ហាញថា ការផ្តល់សិទ្ធិអំណាចដល់ស្ត្រីអាចបង្កើនល្បឿនកំណើនសេដ្ឋកិច្ច ក្នុងប្រទេសកំពុងអភិវឌ្ឍន៍ (សូមមើលមេរៀនទី ១២)។ កូតាអាចបង្កើនល្បឿននៃការផ្តល់សិទ្ធិអំណាចនោះ។ ជាងនេះទៅទៀត រាល់ការចំណាយលើកំណែទម្រង់សេដ្ឋកិច្ច ជារឿយៗ សម្រាប់វិស័យពាក់ព័ន្ធនឹងស្ត្រី មិនមានភាពសមាមាត្រ។ ការផ្តល់អោយស្ត្រីនូវសិទ្ធិសម្រេចថាតើកំណែទម្រង់នោះគួរប្រព្រឹត្តិទៅដោយដូចម្តេចគឺជារឿងសំខាន់។

អំណះអំណាង ២

កូតានីតិបញ្ញត្តិនឹងមិនជួយសមភាព និងមិនមានលក្ខណៈលទ្ធិប្រជាធិបតេយ្យទេ

កូតាអាចបង្កើតអរិភាពចំពោះស្ត្រី។

ការបម្រុងអាសនៈសម្រាប់ស្ត្រីនៅក្នុងសភា មានភាពប្រថុយខ្លាំងអាចនឹងរងប្រតិកម្មប្រឆាំងនឹងសិទ្ធិស្ត្រី។ ក្រុមផ្សេងទៀត (ជាតិពន្ធុ សាសនា ។ល។) អាចជំរុញអោយមាន កូតាផងដែរ ដោយបង្កើតបរិយាកាសនយោបាយអរិភាព។ លទ្ធផលអាចជាអស្ថិរភាពនយោបាយ ដោយសារក្រុមផ្សេងៗបានជាក់សម្ពាធអោយបម្រុងអាសនៈសម្រាប់ពួកគេដោយស្របច្បាប់នៅក្នុងសភា។

កូតាមានលក្ខណៈមិនប្រជាធិបតេយ្យ។

ឧត្តមគតិនៃលទ្ធិប្រជាធិបតេយ្យអនុញ្ញាតអោយមនុស្សគ្រប់រូបអាចធ្វើជាតំណាង ដោយមិនគិតពីពូជសាសន៍ ភេទ ជាតិសាសន៍ ឬគុណសម្បត្តិផ្ទាល់ខ្លួនឡើយ។ តាមធម្មជាតិរបស់ពួកគេ កូតាផ្អែកលើយេនឌ័ររំលោភបំពានលើគំនិតបែបនេះ ដោយមានន័យថា ការបម្រុងទុកអាសនៈជាក់លាក់សម្រាប់ក្រុមមួយដោយផ្អែកលើគុណភាពផ្ទាល់ខ្លួន ដែលមិនទាក់ទងនឹងលក្ខណៈសម្បត្តិបុគ្គលសម្រាប់ការងារនោះទេ។

ការកំណត់កូតាសម្រេចបានសមភាពយេនឌ័រ ដែលតម្រង់ទិសដោយបស្ចឹមប្រទេស តាមធម្មតា។

គំនិតនៃសិទ្ធិបុគ្គល គឺជាគោលគំនិតផ្អែកលើបញ្ញត្តិសិទ្ធិមនុស្សរបស់លោកខាងលិច។ ជាជាងជម្រុញទឹកចិត្តអោយកំណត់កូតាយេនឌ័រ គោលនយោបាយផ្សេងទៀតគួរតែត្រូវបានលើកតម្កើង ដែលសមស្របនឹងវប្បធម៌នយោបាយក្នុងស្រុក។

សំណួរ

- តើប្រទេសកំពុងអភិវឌ្ឍន៍គួរត្រូវបានលើកទឹកចិត្តអោយប្រើប្រាស់កូតាយេនឌ័រ ដើម្បីនាំស្ត្រីកាន់តែច្រើនចូលក្នុងដំណើរការនយោបាយដែរឬទេ? តើការអនុវត្តនេះបំពានលើគំនិតតំណាងប្រជាធិបតេយ្យដែរ

ឬទេ? តើស្ថាប័ននីតិប្បញ្ញត្តិ ដែលបង្កើតឡើងដោយបុរសភាគច្រើន ក៏ជាការរំលោភលើគោលគំនិតនៃតំណាងប្រជាធិបតេយ្យដែរឬទេ?

• តើអ្នករំពឹងថានឹងមានគោលនយោបាយស្រដៀងគ្នា ឬខុសគ្នា ដែលកើតចេញពីស្ថាប័ននីតិប្បញ្ញត្តិដែលមានតំណាងជាស្ត្រីក្នុងចំនួនច្រើន ដែរឬទេ? ចូររំលឹកឡើងវិញនូវទ្រឹស្តីស្ត្រីសេរីនិយម និង ទ្រឹស្តីស្ត្រីទីទៃនិយម។ តើទ្រឹស្តីនីមួយៗទស្សន៍ទាយថានឹងមានអ្វីខ្លះកើតឡើង?

• តើមានមធ្យោបាយអ្វីផ្សេងទៀតដើម្បីលើកទឹកចិត្តអោយមានការចូលរួមរបស់ស្ត្រីនៅក្នុងដំណើរការនយោបាយ ក្រៅពីកូតានីតិបញ្ញត្តិ? តើជំហានបែបនេះត្រូវការជាចាំបាច់ តែនៅក្នុងប្រទេស ដែលមិនធ្លាប់មានប្រវត្តិប្រជាធិបតេយ្យ ឬក៏មានចាំបាច់សម្រាប់ប្រទេសដែលមានលទ្ធិប្រជាធិបតេយ្យចាស់ទុំដែរឬទេ?

និស្សិតអាចសាកល្បងអានឯកសារខាងក្រោមបន្ថែមទៀត ដើម្បីជាគ្រឹះក្នុងការឆ្លើយសំណួរទាំងអស់ខាងលើ ៖

- Goetz, Anne Marie. *Governing Women: Women's Political Effectiveness in Contexts of Democratization and Gover- nance Reform.* Routledge, 2008.
- Hartmann, Heidi. *Gendering Politics and Policy: Recent Developments in Europe, Latin America, and the United States.* Routledge, 2006.
- Irving, Helen. *Gender and the Constitution: Equity and Agency in Comparative Constitutional Design.* Cambridge, 2008.
- Tremblay, Manon. *Women and Legislative Representation: Electoral Systems, Political Parties, and Sex Quotas.* Palgrave, 2008.

ឯកសារសួរអានបន្ថែម

- Bacevich, Andrew J. *The New American Militarism: How Americans Are Seduced by War.* Oxford, 2005.
- Barnett, Michael, and Martha Finnemore. *Rules for the World.* Cornell, 2004.
- Elshtain, Jean Bethke. *Women and War.* 2nd ed. Chicago, 1995.
- Goldstein, Joshua S. *War and Gender: How Gender Shapes the War System and Vice Versa.* Cambridge, 2001.
- Keck, Margaret, and Kathryn Sikkink. *Activists Beyond Borders: Advocacy Networks in International Politics.* Cornell, 1998.
- Keohane, Robert O., and Joseph S. Nye. *Power and Interdependence.* 3rd ed. Pearson, 2001.
- Mansfield, Edward D., and Jack Snyder. *Electing to Fight: Why Emerging Democracies Go to War.* MIT, 2005.
- McDonald, Patrick. *The Invisible Hand of Peace.* Cambridge, 2009.
- Runyon, Anne Sisson, and V. Spike Peterson. *Global Gender Issues in the New Millennium.* Routledge, 2013.
- Tickner, J. Ann. *Gendering World Politics: Issues and Approaches in the Post–Cold War Era.* Columbia, 2001.

មេរៀនទី ០៤ ៖ គោលនយោបាយការបរទេស

រូបថត ប្រជុំរាយការណ៍សន្តិសុខជាតិ ឆ្នាំ ២០១៧

វត្ថុបំណងមេរៀន

៤.១ តើកត្តាអ្វីខ្លះដែលធ្វើអោយការសម្រេចចិត្តបុគ្គលនៅក្នុងវិបត្តិអន្តរជាតិ កាន់តែស្មុគស្មាញ? ចូរ រៀបរាប់អោយបានបីកត្តាយ៉ាងតិច។

៤.២ ចូរប្រៀបធៀបឥទ្ធិពលនៃមតិសាធារណៈ និង ក្រុមតំណាងផលប្រយោជន៍ ទៅលើដំណើរការ បង្កើតគោលនយោបាយការបរទេស។

៤.១. ការតាក់តែងគោលនយោបាយការបរទេស

៤.១ តើកត្តាអ្វីខ្លះដែលធ្វើអោយការសម្រេចចិត្តបុគ្គលនៅក្នុងវិបត្តិអន្តរជាតិ កាន់តែស្មុគស្មាញ? ចូរ រៀបរាប់អោយបានបីកត្តាយ៉ាងតិច។

មេរៀននេះនឹងពិនិត្យមើលអំពីរបៀបផ្សេងៗគ្នា ដែលរដ្ឋនានាបង្កើតគោលនយោបាយការបរទេស របស់ខ្លួន។ គោលនយោបាយការបរទេស គឺជាការសិក្សាអំពីរបៀបដែលមេដឹកនាំ និងរដ្ឋធ្វើការសម្រេចចិត្ត អំពីរបៀបឬទង្វើដែលពួកគេនឹងប្រព្រឹត្តចំពោះតួអង្គអន្តរជាតិផ្សេងទៀត មិនថាជាតួអង្គរដ្ឋ ឬអង្គការអន្តរ ដ្ឋាភិបាល (IGOs) ឬអង្គការក្រៅរដ្ឋាភិបាល (NGOs) ឬសាជីវកម្មពហុជាតិ (MNCs)។ ស្ទើរតែគ្រប់ទ្រឹស្តី នៃគោលនយោបាយការបរទេសសង្កត់ធ្ងន់ទៅលើការវិភាគកម្រិតបុគ្គលនិងកម្រិតក្នុងស្រុក។ ការវិភាគកម្រិត ចុងក្រោយនេះសំដៅទៅលើក្រុម ឬស្ថាប័ននៅក្នុងប្រទេសដែលធ្វើការសម្រេចចិត្តអំពីគោលនយោបាយរបស់ ខ្លួន។ គោលនយោបាយទាំងនេះមានគោលដៅជះឥទ្ធិពលលើទំនាក់ទំនងរបស់ប្រទេសនោះជាមួយនឹងតួអង្គ អន្តរជាតិ តាមវិធីផ្សេងៗគ្នាជាច្រើន។ ទោះជាយ៉ាងណាក៏ដោយ អ្វីដែលអ្នកវិភាគគោលនយោបាយការ បរទេសសង្កត់ធ្ងន់ គឺថា តួអង្គជាច្រើន នៅក្នុងប្រទេសដែលធ្វើការសម្រេចចិត្តគោលនយោបាយការបរទេស ជួនកាល មានការខ្វែងគំនិតឬប្រកួតប្រជែងនឹងគ្នា។ នយោបាយក្នុងប្រទេសនៃរដ្ឋទាំងនេះអាចជះឥទ្ធិពល យ៉ាងខ្លាំងចំពោះអាកប្បកិរិយារបស់រដ្ឋ ជាអន្តរជាតិ។


៤.១.១. គំរូនៃការសម្រេចចិត្ត

ដំណើរការគោលនយោបាយការបរទេស គឺជាដំណើរការនៃ*ការធ្វើសេចក្តីសម្រេចចិត្ត*។ រដ្ឋទាំងឡាយចាត់ វិធានការណ៍ណាមួយ ដោយសារតែមនុស្សឬមន្ត្រីនៅក្នុងរដ្ឋាភិបាល៖ *អ្នកធ្វើសេចក្តីសម្រេចចិត្ត* ជ្រើសរើស សកម្មភាពទាំងនោះ។ ការធ្វើសេចក្តីសម្រេចចិត្តគឺជាដំណើរការ*តំរង់ទិស*(steering)ដែលការកែតម្រូវឬ កែ សម្រួលត្រូវបានធ្វើឡើង ជាលទ្ធផលនៃមតិកែលម្អ ពីពិភពខាងក្រៅ។ ការសម្រេចចិត្តត្រូវបានអនុវត្តដោយ សកម្មភាពដែលបានធ្វើឡើង ដើម្បីផ្លាស់ប្តូរពិភពលោក ហើយបន្ទាប់មក ព័ត៌មានពីពិភពលោកត្រូវបានត្រួត ពិនិត្យដើម្បីវាយតម្លៃផលប៉ះពាល់នៃសកម្មភាពទាំងនេះ។ ការវាយតម្លៃទាំងនេះ (រួមជាមួយនឹងព័ត៌មានអំពី ការផ្លាស់ប្តូរដោយឯកឯងផ្សេងទៀត នៅក្នុងបរិបទនោះ) ចូលទៅក្នុងជុំបន្ទាប់នៃការសម្រេចចិត្ត(សូមមើល ក្រាហ្វិក ៤.១)។

ជាទូទៅ ចំណុចចាប់ផ្តើមដំបូងសម្រាប់សិក្សាពីដំណើរការធ្វើសេចក្តីសម្រេច គឺជា**គំរូសមហេតុផល**។ នៅក្នុងគំរូនេះ អ្នកធ្វើសេចក្តីសម្រេចចិត្តត្រូវកំណត់គោលដៅ, វាយតម្លៃសារៈសំខាន់ធៀបនៃគោលដៅទាំង


នោះ, គណនាការចំណាយនិងផលចំណេញនៃសកម្មភាពនីមួយៗដែលអាចធ្វើបាន, បន្ទាប់មកជ្រើសរើសជម្រើសដែលផ្តល់ផលចំណេញខ្ពស់បំផុត ដោយចំណាយទាបបំផុត (សូមមើលក្រាហ្វិក ៤.២)។

ក្រាហ្វិក ៤.១ ការធ្វើសេចក្តីសម្រេចចិត្តទំរង់ចង្កូតឡាន



ជម្រើសខាងលើអាចមានភាពស្មុគស្មាញ ដោយសារ*ភាពមិនច្បាស់លាស់*អំពីការចំណាយ និងផលចំណេញនៃសកម្មភាពគ្រោងផ្សេងៗ។ ក្នុងករណីបែបនេះ អ្នកធ្វើសេចក្តីសម្រេចចិត្តទាំងឡាយត្រូវតែគណនាប្រូបាប៊ីលីតេដើម្បីព្យាករណ៍លទ្ធផលនៃសកម្មភាពនីមួយៗ។ ជាឧទាហរណ៍ តើការដាក់សម្ពាធលើរដ្ឋជាគូប្រជែងអោយផ្តល់មូលដ្ឋាន នៅក្នុងកិច្ចចរចាសន្តិភាព នឹងដំណើរការយ៉ាងរលូន ឬក៏រងផលវិបាកទៅវិញ? អ្នកធ្វើសេចក្តីសម្រេចចិត្តខ្លះ*ទទួលយកហានិភ័យ* ដែលអាចកើតមានឡើង ចំណែកអ្នកផ្សេងទៀត*មិនហ៊ានប្រថុយនឹងហានិភ័យ*សោះឡើយ។ កត្តាទាំងនេះជះឥទ្ធិពលលើសារៈសំខាន់ ដែលអ្នកធ្វើសេចក្តីសម្រេចចិត្តផ្តល់អោយលទ្ធផលជំនួសផ្សេងៗ ដែលអាចកើតឡើងចេញពីសកម្មភាពណាមួយ។

ក្រាហ្វិក ៤.២ ការធ្វើសេចក្តីសម្រេចចិត្ត តាមគំរូសមហេតុផល



ជាការពិតណាស់ គេអាចជឿថាអ្នកធ្វើសេចក្តីសម្រេចចិត្តមានសមត្ថភាពចេះប្លឹងហេតុនិងផល ប៉ុន្តែអាចនឹងមិនទទួលយកការសន្មតរបស់ទ្រឹស្តីប្រាកដនិយមដែលអះអាងថា រដ្ឋអាចត្រូវបានចាត់ទុកជាតួអង្គឯកភូត នោះទេ។ រដ្ឋាភិបាលត្រូវបានបង្កើតឡើងពីបុគ្គលនានា ដែលអាចស្វែងរកគោលដៅផ្ទាល់ខ្លួន ដោយសមហេតុផល។ ប៉ុន្តែ គោលដៅរបស់បុគ្គលនីមួយៗដែលចូលរួមក្នុងការសម្រេចចិត្តអាចខុសគ្នា ចំណែកគោលដៅរបស់ភ្នាក់ងាររដ្ឋផ្សេងៗគ្នា ក៏អាចខុសគ្នាដែរ។ ជាឧទាហរណ៍ រដ្ឋមន្ត្រីការបរទេសរបស់សហរដ្ឋអាមេរិកអាចមានគោលដៅខុសពីរដ្ឋមន្ត្រីការពារជាតិ ដូចដែលទីភ្នាក់ងារស៊ើបការណ៍សម្ងាត់អាមេរិក(CIA) អាចមើលឃើញស្ថានការណ៍ខុសពីក្រុមប្រឹក្សាសន្តិសុខជាតិ(NSC)។ ការសម្រេចចិត្តតាមគំរូសមហេតុផលមានលក្ខណៈស្មុគស្មាញមួយចំនួន ដោយសារភាពមិនច្បាស់លាស់ និងគោលដៅខុសៗគ្នាជាច្រើនរបស់អ្នកធ្វើសេចក្តីសម្រេចចិត្ត។ ដូច្នេះ គំរូសមហេតុផលអាចបញ្ជាក់ថា ការសម្រេចចិត្តមានភាពសាមញ្ញជាងករណីជាក់ស្តែង។

ជំរើសមួយផ្សេងទៀត ក្រៅពីគំរូសមហេតុផលសម្រាប់សេចក្តីសម្រេចចិត្ត គឺជា**គំរូដំណើរការក្នុងស្ថាប័ន**។ នៅក្នុងគំរូនេះ អ្នកធ្វើការសម្រេចចិត្តគោលនយោបាយបរទេស ជាទូទៅ រំលងដំណើរការទាំងឡាយដូចបង្ហាញក្នុងក្រាហ្វិក ៤.២ ខាងលើ។ គំរូនេះមិនចាំបាច់ចំណាយពេលវេលានិងកម្លាំងកាយក្នុងការកំណត់គោលដៅនិងសកម្មភាពជំនួសផ្សេងៗ ផ្ទុយទៅវិញ ការសម្រេចចិត្តត្រូវពឹងផ្អែកលើការឆ្លើយតបតាមស្តង់ដារ ឬ*នីតិវិធីប្រតិបត្តិការស្តង់ដារ* (standard operating procedures)។ ជាឧទាហរណ៍ ក្រសួងការបរទេសសហរដ្ឋអាមេរិក ជារៀងរាល់ថ្ងៃ ទទួលបានរបាយការណ៍ ឬការសាកសួរព័ត៌មាន យ៉ាងច្រើនសន្ធឹកសន្ធាប់រាប់សិបពាន់ ពីស្ថានទូតរបស់ខ្លួន នៅជុំវិញពិភពលោក ហើយផ្ញើចេញនូវការណែនាំ ឬការឆ្លើយតបទៅវិញជាងមួយពាន់ទៅកាន់ស្ថានទូតទាំងនោះ។ ភាគច្រើននៃបណ្តាញទំនាក់ទំនងទាំងនោះមិនត្រូវបានចែករម្លែកអោយអ្នកធ្វើការសម្រេចចិត្តកំពូល (រដ្ឋមន្ត្រីការបរទេស ឬ ប្រធានាធិបតី) បានមើលឃើញផងនោះទេ។ ផ្ទុយទៅវិញ សារទាំងនោះត្រូវបានចាត់ចែងដោយអ្នកធ្វើការសម្រេចចិត្តកម្រិតទាប ដែលអនុវត្តគោលការណ៍ណែនាំទូទៅ ឬ អ្នកដែលគ្រាន់តែព្យាយាមធ្វើការសម្រេចចិត្តដែលមានភាពចម្រូងចម្រាសតិចបំផុតនិងត្រឹមត្រូវតាមស្តង់ដារខ្លាំងបំផុត។ ការសម្រេចចិត្តដោយមន្ត្រីថ្នាក់ទាបទាំងនេះ ប្រហែលជាមិនបានឆ្លុះបញ្ចាំងពីគោលនយោបាយកម្រិតខ្ពស់ ដែលបានអនុម័តដោយមេដឹកនាំថ្នាក់កំពូលទេ ប៉ុន្តែមានជីវិតឬគោលដៅផ្ទាល់ខ្លួន។ គំរូដំណើរការក្នុងស្ថាប័នចង្អុលបង្ហាញថា គោលនយោបាយបរទេសភាគច្រើនកើតចេញពី «ការគ្រប់គ្រងបានទាំងត្រដរ»។

ជម្រើសមួយទៀតក្រៅពីគំរូសមហេតុផល គឺជា**គំរូចរចាក្នុងរដ្ឋាភិបាល** (government bargaining model) ពេលខ្លះត្រូវបានគេស្គាល់ថាជាគំរូនយោបាយការិយាធិបតេយ្យ (bureaucratic politics model)។ ក្នុងគំរូនេះ ការធ្វើសេចក្តីសម្រេចចិត្តគោលនយោបាយបរទេសកើតឡើងពីដំណើរការចរចា ក្នុងចំណោមភ្នាក់ងារផ្សេងៗក្នុងរដ្ឋាភិបាល ដែលភ្នាក់ងារទាំងនោះអាចមានផលប្រយោជន៍ផ្សេងៗគ្នាចេញលើលទ្ធផលណាមួយ។ នៅឆ្នាំ ១៩៩២ រដ្ឋាភិបាលជប៉ុនត្រូវសម្រេចចិត្តថា តើត្រូវអនុញ្ញាតអោយនាំចូលស៊ូស៊ី (sushi) ពីរដ្ឋកាលីហ្វ័រញ៉ាដែរឬទេ ជាទង្វើបញ្ជាក់ពីបន្ទុយ ការហាមឃាត់ជាប្រពៃណីរបស់ប្រទេសជប៉ុនលើការនាំចូលអង្ករ (ដើម្បីរក្សាស្វ័យភាពផ្គត់ផ្គង់ នៅក្នុងរបបអាហារជាចម្បងរបស់ខ្លួន)។ សម្រាប់ក្រសួងកសិកម្មជប៉ុនដោយផលប្រយោជន៍ផ្នែកសុខុមាលភាពរបស់កសិករជប៉ុន បានប្រឆាំងនឹងការនាំចូលខាងលើ។ ចំណែក

ក្រសួងការបរទេស ដោយមានផលប្រយោជន៍លើទំនាក់ទំនងយ៉ាងរលូនជាមួយនឹងសហរដ្ឋអាមេរិក ចង់អនុញ្ញាតអោយមានការនាំចូល។ ការសម្រេចចិត្តចុងក្រោយក្នុងការអនុញ្ញាតអោយនាំចូលស៊ូស៊ីគឺជាលទ្ធផលពីការប៉ះទង្គិចឬចរចាគ្នារវាងក្រសួងទាំងពីរ។ ដូច្នេះ យោងតាមគំរូចរចាក្នុងរដ្ឋាភិបាល ការសម្រេចចិត្តគោលនយោបាយការបរទេសឆ្លុះបញ្ចាំង(ចម្រុះនៃ)ផលប្រយោជន៍របស់ទីភ្នាក់ងារនានានៅក្នុងរដ្ឋណាមួយ។

៤.១.២. អ្នកធ្វើការសម្រេចចិត្តជាលក្ខណៈបុគ្គល

រាល់ព្រឹត្តិការណ៍អន្តរជាតិ គឺជាលទ្ធផល (ទោះចង់ឬមិនចង់) នៃការសម្រេចចិត្តដែលធ្វើឡើង ដោយបុគ្គលនានា។ ទំនាក់ទំនងអន្តរជាតិមិនមែនកើតឡើងដោយឯកឯងនោះទេ។ លោកប្រធានាធិបតី ហែរី ទ្រូម៉ាន់ (Harry Truman) ដែលបានសម្រេចចិត្តទម្លាក់គ្រាប់បែកនុយក្លេអ៊ែរ របស់សហរដ្ឋអាមេរិក លើទីក្រុងធំៗរបស់ប្រទេសជប៉ុនចំនួនពីរ ក្នុងឆ្នាំ ១៩៤៥ មានដាក់ស្លាកសញ្ញាមួយ នៅលើតុការិយាល័យរបស់គាត់ថា «The buck stops here» ដែលអាចប្រែសម្រួលជាភាសាខ្មែរថា «ការសម្រេចចុងក្រោយត្រូវធ្វើឡើងនៅទីនេះ »។ ក្នុងនាមជាមេដឹកនាំនៃប្រទេសមហាអំណាចផុតលេខនៅពិភពលោក គាត់មិនមាននរណាម្នាក់នៅពីលើគាត់ ដើម្បីរុញអោយសម្រេចចិត្តជំនួសគាត់បានឡើយ។ ប្រសិនបើគាត់ជ្រើសរើសប្រើគ្រាប់បែក (ដូចដែលគាត់បានធ្វើ) ជនស៊ីវិលជាង ១០០,០០០នាក់ នឹងស្លាប់។ ប្រសិនបើគាត់មិនជ្រើសរើសទេ សង្គ្រាមអាចនឹងបន្តអូសបន្លាយជាច្រើនខែ ដែលអាចបណ្តាលអោយជនជាតិអាមេរិករាប់ម៉ឺននាក់ត្រូវស្លាប់។ លោក ហែរី ទ្រូម៉ាន់ ត្រូវតែធ្វើការសម្រេចចិត្ត។ មនុស្សមួយចំនួនអបអរសាទរការសម្រេចចិត្តរបស់គាត់, រីឯអ្នកផ្សេងទៀតថ្កោលទោស។ ប៉ុន្តែ ទោះលទ្ធផលល្អឬអាក្រក់ លោកទ្រូម៉ាន់ក្នុងនាមជាបុគ្គលម្នាក់ត្រូវសម្រេចចិត្ត និងទទួលខុសត្រូវចំពោះផលវិបាកដែលអាចកើតមាន។ ដូចគ្នាដែរ ការសម្រេចចិត្តរបស់ពលរដ្ឋម្នាក់ៗ ទោះបីវាហាក់ដូចជាមិនសំខាន់ នៅពេលសម្រេចចិត្តម្តងម្នាក់ៗរៀងៗខ្លួនក៏ដោយ ក៏បង្កើតកម្លាំងផ្លាស់ប្តូរដ៏អស្ចារ្យនៅក្នុងប្រវត្តិសាស្ត្រពិភពលោក។

ការសិក្សាអំពីការសម្រេចចិត្តរបស់បុគ្គលម្នាក់ៗ ប្រព្រឹត្តិទៅដុំវិញចំណោទនៃសនិទានភាព (ភាពសមហេតុសមផល)។ តើអ្នកដឹកនាំប្រទេសជាតិ (ឬប្រជាពលរដ្ឋ) អាចធ្វើការសម្រេចចិត្ត ដោយសមហេតុសមផលដើម្បីផលប្រយោជន៍ជាតិ ដល់កម្រិតណា (ប្រសិនបើផលប្រយោជន៍បែបនេះអាចត្រូវគេកំណត់បាន) ម្លោះហើយ ដើម្បីអនុលោមតាមទស្សនៈរបស់អ្នកប្រាកដនិយមស្តីអំពីទំនាក់ទំនងអន្តរជាតិ? សនិទានបុគ្គលមិនស្មើនឹងសនិទានភាពរបស់រដ្ឋទេ៖ រដ្ឋអាចច្រោះការសម្រេចចិត្តមិនសមហេតុផលរបស់បុគ្គលចេញ ដើម្បីឈានទៅដល់ជម្រើសសមហេតុផល, ឬ រដ្ឋអាចបំភ្លៃការសម្រេចចិត្តដោយសមហេតុផលរបស់បុគ្គល និងចុងបញ្ចប់ សម្រេចយកជម្រើសរបស់រដ្ឋដែលមិនសមហេតុផល។ ប៉ុន្តែ អ្នកប្រាកដនិយមមានទំនោរសន្មតថាទាំងរដ្ឋនិងបុគ្គល មានសនិទានភាព ឬភាពសមហេតុផល ហើយថាគោលដៅឬផលប្រយោជន៍របស់រដ្ឋមានទំនាក់ទំនងជាមួយនឹងមេដឹកនាំរដ្ឋ។

រូបថត គីម ជុងអ៊ុនត្រួតពិនិត្យការសាកល្បងកាំជ្រួចផ្លោង

បាញ់ទៅ

គោលនយោបាយបរទេសជារឿយៗបានបង្ហែរចេញពីគោលការណ៍សនិទានភាព ដោយសារការយល់ខុសនិងភាពលំអៀងរបស់អ្នកធ្វើការសម្រេចចិត្តនិងប្រជាជន។ នៅទីនេះ ក្នុងឆ្នាំ ២០១៧ មេដឹកនាំផ្តាច់ការកូរ៉េខាងជើង គីម ជុងអ៊ុន មើលការសាកល្បងមីស៊ីលផ្លោង រយៈចម្ងាយមធ្យមជាមួយបុគ្គលិកយោធារបស់

ខ្លួន។ កម្មវិធីអាវុធនុយក្លេអ៊ែររបស់ប្រទេសកូរ៉េ ក៏ដូចជាយានបញ្ជូន(នុយក្លេអ៊ែរ)របស់វា គឺជាក្តីកង្វល់ដ៏សំខាន់មួយនៅប្រទេសបស្ចឹមលោក។ សញ្ញាវុធទាំងនេះនឹងបង្កការគម្រាមកំហែងកាន់តែខ្លាំង ប្រសិនបើភាពមិនប្រាកដប្រជាជាយុទ្ធសាស្ត្របង្ខំ គីម ជុងអ៊ុន អោយពិចារណាជាមុន អំពីការប្រើប្រាស់អាវុធនុយក្លេអ៊ែរក្នុងការការពារខ្លួន ឬប្រសិនបើ គីម ជុងអ៊ុន ប្រែក្លាយជាអ្នកទទួលយកហានិភ័យក្នុងការបង្កើនភាពតានតឹងជាមួយសហរដ្ឋអាមេរិក កូរ៉េខាងត្បូង ឬជប៉ុន។

គំរូតួអង្គសមហេតុផលដែលត្រូវសម្រួល យ៉ាងសាមញ្ញបំផុតនិងងាយយល់ សន្មតថា ផលប្រយោជន៍គឺដូចគ្នា សម្រាប់តួអង្គមួយ ទៅតួអង្គមួយទៀត។ ប្រសិនបើដូច្នេះមែន បុគ្គលម្នាក់អាចត្រូវបានជំនួសដោយបុគ្គលម្នាក់ទៀត សម្រាប់បំពេញតួនាទីផ្សេងៗ ដោយមិនផ្លាស់ប្តូរប្រវត្តិសាស្ត្រយ៉ាងខ្លាំងឡើយ។ ហើយរដ្ឋទាំងអស់នឹងមានឥរិយាបទស្រដៀងគ្នា (ឬផ្ទុយទៅវិញ ភាពខុសគ្នារវាងពួកគេ នឹងឆ្លុះបញ្ចាំងពីធនធាន និងភូមិសាស្ត្រខុសៗគ្នា មិនមែនលក្ខណៈខុសគ្នានៅក្នុងធម្មជាតិនៃផលប្រយោជន៍ជាតិទេ)។ យ៉ាងល្អបំផុត ការសន្មតនេះគ្រាន់ជាការសម្រួលអោយងាយបំផុតតែប៉ុណ្ណោះ(oversimplification)។ ការសម្រេចចិត្តផ្ទាល់ខ្លួនឆ្លុះបញ្ចាំងពី*គុណតម្លៃ* និង*ជំនឿ*របស់អ្នកធ្វើការសម្រេចចិត្ត។

បុគ្គលធ្វើការសម្រេចចិត្តម្នាក់ៗមិនត្រឹមតែមានគុណតម្លៃ និងជំនឿខុសៗគ្នាប៉ុណ្ណោះទេ ប៉ុន្តែក៏មានបុគ្គលិកលក្ខណៈប្លែកខុសគ្នាផងដែរ៖ បទពិសោធន៍ផ្ទាល់ខ្លួន សមត្ថភាពប្រាជ្ញា និងស្ទីលនៃការសម្រេចចិត្តផ្ទាល់ខ្លួនផងដែរ។ អ្នកប្រាជ្ញទំនាក់ទំនងអន្តរជាតិខ្លះសិក្សាអំពីចិត្តសាស្ត្របុគ្គល ដើម្បីយល់ពីរបៀបដែលបុគ្គលិកលក្ខណៈជះឥទ្ធិពលដល់ការសម្រេចចិត្ត។ វិធីសាស្ត្រចិត្តសាស្ត្រចង្អុលបង្ហាញថាបុគ្គលិកលក្ខណៈឆ្លុះបញ្ចាំងពីឥទ្ធិពលនៃការយល់ដឹងពីបទពិសោធន៍កាលពីកុមារភាព។ ជាឧទាហរណ៍ លោក ប៊ីល គ្លីនតុន (Bill Clinton) បានទាក់ទាញការរិះគន់ជាច្រើន នៅក្នុងប៊ុន្មានឆ្នាំដំបូងក្នុងពេលកាន់តួនាទីប្រធានាធិបតីដោយសារគោលនយោបាយការបរទេសរបស់គាត់ ហាក់ដូចជាបត់ចុះបត់ឡើង ដូចធ្មេញរណា (zigzag)។ លក្ខណៈបុគ្គលិកលក្ខណៈរបស់គ្លីនតុនគួរអោយកត់សម្គាល់ជាងគេ គឺការត្រៀមលក្ខណៈរួចស្រេចក្នុងការសម្របសម្រួល។ លោកគ្លីនតុនផ្ទាល់ខ្លួន បានកត់សម្គាល់ថាបទពិសោធន៍របស់គាត់ពេលធំពេញវ័យនៅជាមួយនឹងឪពុកចុងដែលស្រវឹងខ្លាំងនិងហិង្សា បានធ្វើអោយគាត់ទៅក្លាយជា «អ្នកបង្កើតសន្តិភាព ដែលតែងតែព្យាយាមកាត់បន្ថយការរំខាន»។[១៨]

ក្រៅពីកត្តាបុគ្គលិកលក្ខណៈបុគ្គលនៅក្នុងគោលដៅឬដំណើរការធ្វើការសម្រេចចិត្ត, ការសម្រេចចិត្តរបស់បុគ្គលឃ្លាតឆ្ងាយពីគំរូសមហេតុផលដោយសារមូលហេតុបីយ៉ាងតិច។ ទីមួយ អ្នកធ្វើសេចក្តីសម្រេចចិត្តអាចរងគ្រោះ ដោយសារ**ការយល់ឃើញខុស** (misperceptions) និងការយល់ឃើញមួយជ្រុង(selective perceptions) (ទទួលយកព័ត៌មានមួយជ្រុងណាមួយប៉ុណ្ណោះ) នៅពេលពួកគេចងក្រងព័ត៌មានអំពីផលវិបាកនៃជម្រើសសកម្មភាពរបស់ពួកគេ ដែលអាចកើតមានជាយថាហេតុ។ ដំណើរការធ្វើការសម្រេចចិត្តត្រូវតែកាត់បន្ថយនិងច្រោះព័ត៌មានចូល ដើម្បីជាមូលដ្ឋានសម្រាប់ធ្វើការសម្រេចចិត្ត។ បញ្ហានៅត្រង់ថាការច្រោះព័ត៌មានបែបនេះ ច្រើនតែមានភាពលំអៀង។ **អេក្រង់ព័ត៌មាន** (information screens) គឺជាការត្រួតពិនិត្យព័ត៌មានចេញចូល ចេញទៅឬមកពីតំបន់នានាជុំវិញពិភពលោក។ ជារឿយៗ ពួកគេគ្រាន់តែព្រងើយកន្តើយ

[១៨] Collins, Nancy. A Legacy of Strength and Love [interview with President Clinton]. *Good Housekeeping* ២២១ (៥), ១៩៩៥: ១១៣–១៥.

ចំពោះព័ត៌មានណាមួយ ដែលត្រូវតាមការរំពឹងទុករបស់ពួកគេ។ ព័ត៌មានក៏ត្រូវបានរារាំងមិនអោយចូលផងដែរ នៅពេលដែលវាចេញពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀត នៅក្នុងដំណើរការធ្វើការសម្រេចចិត្ត។ ជាក់ស្តែងមុនការវាយប្រហារភេរវកម្មនៅខែកញ្ញា ឆ្នាំ ២០០១ ទីភ្នាក់ងារស៊ើបការណ៍សម្ងាត់របស់សហរដ្ឋអាមេរិកបានបរាជ័យក្នុងការបកស្រាយកស្តុតាងដែលមាន អោយបានគ្រប់គ្រាន់ ដោយសារអ្នកវិភាគតិចតួចបំផុតដែលស្ទាត់ជំនាញ ខាងភាសាអារ៉ាប់។ ដូចគ្នានេះដែរ មេដឹកនាំសូវៀត ក្នុងឆ្នាំ១៩៤១ និងមេដឹកនាំអ៊ីស្រាអែលនៅឆ្នាំ ១៩៧៣ មិនអើពើនឹងកស្តុតាងនៃការឈ្លានពានប្រទេសរបស់ពួកគេ ដែលប្រុងនឹងកើតឡើង។

ការយល់ឃើញខុសអាចប៉ះពាល់ដល់ការអនុវត្តគោលនយោបាយរបស់មន្ត្រីថ្នាក់ទាប។ ក៏ដូចជាប៉ះពាល់ដល់ការបង្កើតគោលនយោបាយ ដោយមន្ត្រីជាន់ខ្ពស់ផងដែរ។ ជាឧទាហរណ៍ ក្នុងឆ្នាំ ១៩៨៨ មន្ត្រីនៅលើនាវាចម្បាំងអាមេរិក នៅឈូងសមុទ្រពែរ្ស បានបាញ់ទម្លាក់យន្តហោះស៊ីវិលរបស់អ៊ីរ៉ង់ ដែលពួកគេជឿថាជាយន្តហោះយោធាមកវាយប្រហារលើពួកគេ។ មន្ត្រីទាំងនោះព្យាយាមអនុវត្តគោលនយោបាយ ដែលត្រូវបានបង្កើតឡើង ដោយមេដឹកនាំជាតិ ប៉ុន្តែ ដោយសារការយល់ឃើញខុស សកម្មភាពអនុវត្តជាក់ស្តែងរបស់ពួកគេបែរជាបំផ្លាញផលប្រយោជន៍រដ្ឋទៅវិញ។

ទីពីរ ការវិភាគអំពីការចំណាយនិងចំណេញរបស់បុគ្គល ដោយសមហេតុផល ត្រូវបានប៉ះពាល់ដោយមនោសញ្ចេតនារបស់អ្នកធ្វើការសម្រេចចិត្ត ខណៈពេលដែលកំពុងគិតអំពីផលវិបាកនានានៃសកម្មភាពរបស់ពួកគេ វាជាផលវិបាកដែលហៅថា *ឆន្ទាគតិ ឬ ទោសាគតិ* (affective bias)។ (*ឥទ្ធិពលវិជ្ជមាន* និង *អវិជ្ជមាន* សំដៅទៅលើការលំអៀងដោយអារម្មណ៍ស្រលាញ់ ឬ ស្អប់នរណាម្នាក់។) ខណៈដែល អ្នកធ្វើការ សម្រេចចិត្តព្យាយាមធ្វើការសម្រេចចិត្តដោយសមហេតុផលបំផុត, ដំណើរការធ្វើសេចក្តីសម្រេចចិត្តត្រូវរងឥទ្ធិពលដោយអារម្មណ៍ឬមនោសញ្ចេតនាជ្រាលជ្រៅចំពោះបុគ្គលឬដ្ឋណាមួយ។ (ការលំអៀងដោយអារម្មណ៍(ស្រលាញ់ឬស្អប់)ក៏រួមចំណែកដល់ឬជះឥទ្ធិពលលើការត្រួតពិនិត្យព័ត៌មានចេញចូលផងដែរ ដោយសារព័ត៌មានវិជ្ជមានអំពីមនុស្សមិនចូលចិត្ត ឬព័ត៌មានអវិជ្ជមានអំពីមនុស្សចូលចិត្ត ត្រូវបានបិទខ្ទប់។)

ទីបី *មោហាគតិ ឬ ភយាគតិ* (cognitive bias) សំដៅលើភាពលំអៀងក្នុងដំណើរការវិភាគភាពសមហេតុផល មិនមែនដោយសារអារម្មណ៍ស្រលាញ់ឬស្អប់នោះទេ ប៉ុន្តែ វាអាចលំអៀងដោយសារព្រំដែនកំណត់នៃខួរក្បាលរបស់មនុស្សក្នុងការសម្រេចចិត្ត ឬយ៉ាងសាមញ្ញ គឺជាការលំអៀងដោយសារភាពល្ងង់ខ្លៅ ឬដោយការភ័យខ្លាច។ សារៈសំខាន់បំផុតនៃភាពលំអៀងទាំងនេះ ហាក់ដូចជាការប៉ុនប៉ងបង្កើតតុល្យភាពនៃសតិសម្បជញ្ញៈ(cognitive balance) ឬ កាត់បន្ថយភាពមិនស៊ីសង្វាក់គ្នានៃសតិសម្បជញ្ញៈ។ ពាក្យទាំងនេះសំដៅទៅលើទំនោរដែលមនុស្សត្រូវព្យាយាមរក្សាគំរូផ្លូវចិត្តសម្លឹងមើលពិភពលោកក្នុងផ្លូវត្រូវ ដែលប្រកបដោយភាពសមហេតុសមផល (វាកម្រនឹងជោគជ័យទាំងស្រុងណាស់)។

ឥទ្ធិពលមួយនៃការរក្សាតុល្យភាពនៃសតិសម្បជញ្ញៈគឺ ថាអ្នកធ្វើការសម្រេចចិត្តផ្តល់តម្លៃខ្លាំងពេកលើគោលដៅ ដែលពួកគេបានខិតខំប្រឹងប្រែងអោយសម្រេចបានជាច្រើនមកហើយ ពោលគឺការផ្តល់ហេតុផលសម្រាប់កិច្ចខិតខំប្រឹងប្រែងទាំងអស់នោះ។ រឿងនេះជាការពិត ជាពិសេស នៅក្នុងប្រទេសប្រជាធិបតេយ្យ ដែលអ្នកនយោបាយត្រូវតែប្រឈមមុខនឹងការវិនិច្ឆ័យរបស់ប្រជាពលរដ្ឋ នៅពេលបោះឆ្នោត ដូច្នេះហើយដៀសវាងមិនចង់ទទួលស្គាល់បរាជ័យ។ សង្គ្រាមវៀតណាមបានធ្វើអោយអ្នកធ្វើការសម្រេចចិត្តរបស់សហរដ្ឋអាមេរិកជាប់គាំងតាមរបៀបនេះ កាលពីចុងទសវត្សរ៍ឆ្នាំ ១៩៦០។ បន្ទាប់ពីបានបញ្ជូនទាហានកន្លះលាននាក់

ទៅវៀតណាម ដែលនៅឯម្ខាងទៀតនៃពិភពលោក មេដឹកនាំសហរដ្ឋអាមេរិកពិបាកនឹងសារភាពទទួលការពិតដែលថាការចំណាយក្នុងសង្គ្រាមមានទំហំធំជាងផលចំណេញ។

អ្នកធ្វើការសម្រេចចិត្តក៏សម្រេចបាននូវតុល្យភាពនៃសតិសម្បជញ្ញៈ តាមរយៈ*គំនិតចៅចាក់ស្មុគ (wishful thinking)* ដែលជាការប៉ាន់ស្មានខ្លាំងហួសហេតុអំពីលទ្ធភាពនៃលទ្ធផលណាមួយដែលគេប្រាថ្នាចង់បាន។ រូបភាពផ្សេងៗនៃការគិតរបៀបចៅចាក់ស្មុគ អាចជាការសន្មតថា ព្រឹត្តិការណ៍ដែលមាន*លទ្ធភាពកើតឡើងទាប* នឹងមិនកើតឡើងទេ។ នេះអាចជាវិធីគ្រោះថ្នាក់ គិតអំពីព្រឹត្តិការណ៍មហន្តរាយ ដូចជាសង្គ្រាមនុយក្លេអ៊ែរ ដោយចៃដន្យ ឬការវាយប្រហារភេរវកម្ម។

តុល្យភាពនៃសតិសម្បជញ្ញៈ ជារឿយៗ នាំអោយអ្នកធ្វើការសម្រេចចិត្តរក្សាជំហររឹងប៉ឹងចំពោះ*សត្រូវ* និងបកស្រាយរាល់សកម្មភាពរបស់សត្រូវក្នុងន័យអវិជ្ជមាន (ព្រោះគំនិតដែលថា មនុស្សអាក្រក់ធ្វើអំពើល្អ នឹងបង្កើតភាពមិនស៊ីសង្វាក់គ្នានៃសតិសម្បជញ្ញៈ)។ *រូបភាពក្នុងកញ្ចក់* សំដៅលើភាគីទាំងពីរនៅក្នុងជម្លោះសម្លឹងមើលគ្នាឃើញសត្រូវ ដូចគ្នា («ភាគីខាងយើងការពារខ្លួន ពួកគេគឺជាអ្នកឈ្លានពាន» ។ល។) អ្នកធ្វើសេចក្តីសម្រេចចិត្តក៏អាចជួបប្រទះ*ការព្យាករណ៍ផ្លូវចិត្ត* ដោយគិតថាអ្វីដែលខ្លួនកំពុងគិត ភាគីសត្រូវក៏គិតដូចខ្លួនដែរ។ ជាឧទាហរណ៍ ប្រសិនបើមេដឹកនាំឥណ្ឌាចង់ទទួលបានឧត្តមភាពនុយក្លេអ៊ែរលើប៉ាគីស្ថាន ប៉ុន្តែបានរកឃើញថា គោលដៅនោះមិនស្របនឹងរូបភាពដែលឥណ្ឌាខ្លួនឯងតាំងខ្លួនជាអ្នកសន្តិភាពនិយម និងធ្វើដើម្បីការពារខ្លួនតែប៉ុណ្ណោះ, នោះភាពមិនចុះសម្រុងនៃការយល់ដឹង អាចនឹងត្រូវបានដោះស្រាយដោយជឿថាប្រទេសប៉ាគីស្ថានកំពុងព្យាយាមទទួលបានឧត្តមភាពនុយក្លេអ៊ែរដែរ (ប្រទេសប៉ាគីស្ថានក៏មានការយល់ឃើញបែបនេះចំពោះឥណ្ឌាផងដែរ)។

ទម្រង់មួយទៀតនៃភាពលំអៀងនៃសតិសម្បជញ្ញៈ ដែលទាក់ទងទៅនឹងតុល្យភាពនៃសតិសម្បជញ្ញៈ គឺការប្រើ*បទពិសោធន៍ប្រវត្តិសាស្ត្រ* ដើម្បីរៀបចំរចនាសម្ព័ន្ធនៃការគិតរបស់មនុស្សណាម្នាក់អំពីការសម្រេចចិត្ត។ ការធ្វើបែបនេះអាចមានប្រយោជន៍ ឬបណ្តាលអោយមានការយល់ច្រឡំ អាស្រ័យលើកត្តាថាតើការប្រៀបធៀបបែបនោះមានលក្ខណៈត្រឹមត្រូវឬក៏អត់។ ស្ថានភាពប្រវត្តិសាស្ត្រនីមួយៗមានលក្ខណៈប្លែកពីគ្នាដោយសារទិដ្ឋភាពមួយចំនួន ហើយនៅពេលដែលអ្នកធ្វើការសម្រេចចិត្តទាញភ្ជាប់ភាពស្រដៀងគ្នា ហើយប្រើវាជាផ្លូវកាត់ដើម្បីឈានដល់ការសម្រេចចិត្ត, ការគណនាពីការចំណាយនិងផលចំណេញ ដោយសមហេតុផលអាចនឹងត្រូវបានកាត់បន្ថយ ឬសង្ខេបៗយ៉ាងខ្លី មិនបានគ្រប់ជ្រុងជ្រោយ ផងដែរ។ ជាពិសេសអ្នកធ្វើការសម្រេចចិត្តតែងតែសន្មតថា ដំណោះស្រាយដែលដំណើរការពីមុន នឹងដំណើរការម្តងទៀត- ដោយមិនពិនិត្យមើលថា តើស្ថានភាពពិតជាស្រដៀងគ្នាមែនដែរឬទេ បើមែន វាស្រដៀងគ្នាកម្រិតណាដែរ។ ជាឧទាហរណ៍ មេដឹកនាំសហរដ្ឋអាមេរិកបានប្រើភាពស្រដៀងគ្នានៃសន្និសីទក្រុងមុយនិច (Munich) ក្នុងឆ្នាំ ១៩៣៨ ដើម្បីបញ្ចុះបញ្ចូលខ្លួនឯងថាការបន្ធូរបន្ថយដៃនៅក្នុងសង្គ្រាមវៀតណាម នឹងនាំអោយមានការឈ្លានពានកុម្មុយនិស្ត នៅអាស៊ីកើនឡើងថែមទៀត។ សូមរំលឹកឡើងវិញ ភាពខុសគ្នារវាងវៀតណាមខាងជើង និងណាហ្ស៊ីអាឡឺម៉ង់ បានធ្វើអោយការប្រៀបប្រដូចខាងលើមិនត្រឹមត្រូវទេ (មិនត្រឹមត្រូវ មួយភាគធំ ដោយសារតែលក្ខណៈសង្គ្រាមស៊ីវិលនៃជម្លោះវៀតណាម)។ បន្ទាប់មក សង្គ្រាមវៀតណាមផ្ទាល់បានក្លាយគោលដៅនៃការប្រៀបប្រដូចដ៏មានឥទ្ធិពល សម្រាប់ជួយបញ្ចុះបញ្ចូលមេដឹកនាំសហរដ្ឋអាមេរិកអោយជៀសវាងការជាប់ពាក់

ព័ន្ធក្នុងជម្លោះណាមួយ នៅក្រៅប្រទេស ដូចជាបូស្នៀ។ នៅក្នុងគោលនយោបាយការបរទេសរបស់សហរដ្ឋអាមេរិក រឿងនេះត្រូវបានគេហៅថា «រោគសញ្ញាវៀតណាម» (Vietnam syndrome)។

ដំណើរការចិត្តសាស្ត្រទាំងអស់នេះ៖ ការយល់ឃើញខុស, ឆន្ទាគតិឬទោសាគតិ និង មោហាគតិឬភយាគតិ, រំខានដល់ការវាយតម្លៃការចំណាយនិងផលចំណេញក្នុងការសម្រេចចិត្ត ដោយសមហេតុផល។ ការកែសម្រួល(ចំនួនពីរ)លើគំរូសមហេតុផលសម្រាប់ការសម្រេចចិត្ត ត្រូវបានស្នើឡើងដើម្បីសម្របទៅនឹងសច្ចៈភាពចិត្តសាស្ត្រ។

ទីមួយ គំរូសនិទានភាពមានកម្រិតត្រូវគិតគូរអំពីការចំណាយលើការស្វែងរកនិងដំណើរការព័ត៌មាន។ នៅពេលធ្វើការសម្រេចចិត្ត គ្មាននរណាម្នាក់អាចគិតឃើញគ្រប់សកម្មភាព ដែលអាចធ្វើទៅបាននោះទេ។ ជំនួសអោយ**ការបង្កើនប្រសិទ្ធភាព**(optimizing) ឬជ្រើសរើសជម្រើសដ៏ល្អបំផុត, ជាធម្មតា មនុស្សធ្វើការលើបញ្ហាណាមួយ រហូតដល់ពួកគេអាចបង្កើតជម្រើស«ល្អគ្រប់គ្រាន់» ដែលបំពេញតាមលក្ខណៈវិនិច្ឆ័យជាអប្បបរមាមួយចំនួន។ នេះហៅថា**ការបំពេញចិត្ត**(satisficing) ឬស្វែងរកដំណោះស្រាយដែលពេញចិត្ត។ ពេលវេលាខ្លីគឺជាឧបសគ្គប្រឈមមុខដល់អ្នកធ្វើការសម្រេចចិត្តកំពូល នៅក្នុងទំនាក់ទំនងអន្តរជាតិ (ដែលត្រូវបានឡោមព័ទ្ធដោយវិបត្តិដែលទាមទារការយកចិត្តទុកដាក់របស់ពួកគេភ្លាមៗ អោយទាន់សភាពការណ៍) ជាទូទៅ រារាំងការស្វែងរកការឆ្លើយតបដ៏ល្អបំផុតសម្រាប់ពួកគេ ចំពោះស្ថានភាពណាមួយ។ ឧបសគ្គពេលវេលាទាំងនេះត្រូវបានពិពណ៌នាដោយរដ្ឋមន្ត្រីការពារជាតិសហរដ្ឋអាមេរិក លោក វីល្លៀម កូហេន (William Cohen) ក្នុងឆ្នាំ ១៩៩៧៖ «លំហូរព័ត៌មានជាហូរហែឥតឈប់ឈរ, តម្រូវការក្នុងការតម្រងព័ត៌មានរៀងរាល់មួយនាទីម្តងៗ ខុសពីអ្វីដែលខ្ញុំបានជួបប្រទះពីមុនមក។ មានពេលតិចតួចបំផុត សម្រាប់ការសញ្ជឹងគិត វាភាគច្រើនជាសកម្មភាពដ៏មមាញឹក»។[១៩]

ទីពីរ **ទ្រឹស្តីប្រមើលអនាគត**(prospect theory) ផ្តល់នូវការពន្យល់ផ្សេងមួយទៀត (ជាជាងការបង្កើនប្រសិទ្ធភាពសមហេតុផលដ៏សាមញ្ញ) អំពីការសម្រេចចិត្តដែលធ្វើឡើង ដោយហានិភ័យ ឬ ភាពមិនច្បាស់លាស់។ យោងតាមទ្រឹស្តីនេះ អ្នកធ្វើការសម្រេចចិត្តឆ្លងកាត់ពីរដំណាក់កាល។ នៅក្នុង*ដំណាក់កាលកែសម្រួល*(editing phase) ពួកគេកំណត់មុខសញ្ញាជម្រើសផ្សេងៗ និងលទ្ធភាពនៃលទ្ធផលផ្សេងៗដែលអាចកើតឡើងចេញពីជម្រើសនីមួយៗ។ បន្ទាប់មក ក្នុងដំណាក់កាលវាយតម្លៃ (evaluation phase) ពួកគេវាយតម្លៃជម្រើសនានា ហើយជ្រើសរើសមួយ។ ទ្រឹស្តីអនាគតបានអះអាងថា ការវាយតម្លៃកើតឡើងដោយការប្រៀបធៀបជាមួយនឹងចំណុចយោងណាមួយ(reference point) ដែលជារឿយៗ ជាស្ថានភាពបច្ចុប្បន្ន ប៉ុន្តែ ក៏អាចជាស្ថានភាពអតីតកាល ឬស្ថានភាពដែលគេរំពឹងទុកថានឹងកើតឡើងផងដែរ។ អ្នកធ្វើការសម្រេចចិត្តសួរថា តើគាត់អាចធ្វើបានល្អជាងចំណុចយោងនោះឬអត់ ប៉ុន្តែតម្លៃដែលដាក់លើលទ្ធផល ត្រូវអាស្រ័យលើថា តើពួកគេស្ថិតនៅចម្ងាយប៉ុណ្ណាពីចំណុចយោង។

ដូច្នេះហើយ ការសម្រេចចិត្តបុគ្គលត្រូវធ្វើឡើងតាមប្រភេទគំរូសមហេតុសមផលដោយផ្នែកៗមិនល្អឥតខ្ចោះ ណាមួយ។ មិនត្រឹមតែគោលដៅរបស់បុគ្គលផ្សេងៗគ្នាមានភាពខុសប្លែកគ្នាប៉ុណ្ណោះទេ ប៉ុន្តែអ្នកធ្វើការសម្រេចចិត្តប្រឈមមុខនឹងឧបសគ្គជាបន្តបន្ទាប់ ក្នុងការទទួលបានព័ត៌មានត្រឹមត្រូវ, បង្កើតគំរូត្រឹមត្រូវ

[១៩] Bradley Graham, March ៥, ១៩៩៧. On First Trip as Pentagon Chief, Cohen Discusses Bosnia Endgame. *Washington Post*, A២២.

ដើម្បីសម្លឹងមើលពិភពលោក និងការសម្រេចបាននូវការសម្រេចចិត្ត ដែលបន្តដំណើរសម្រេចគោលដៅរបស់ពួកគេផ្ទាល់។ គំរូសនិទានភាពគ្រាន់តែជាការសម្រួលអោយងាយស្រួលយល់តែប៉ុណ្ណោះ ហើយត្រូវតែបំពេញបន្ថែមដោយការយល់ដឹងអំពីដំណើរការផ្លូវចិត្តរបស់បុគ្គល ដែលជះឥទ្ធិពលដល់ការសម្រេចចិត្ត។

៤.១.៣. ចិត្តសាស្ត្រក្រុម

តើចិត្តសាស្ត្រក្រុម (group psychology) មានឥទ្ធិពលអ្វីខ្លះលើការសម្រេចចិត្តគោលនយោបាយបរទេស? នៅក្នុងទិដ្ឋភាពមួយ ក្រុមអាចលើកកម្ពស់កម្រិតនៃភាពសមហេតុផល ដោយធ្វើអោយមានតុល្យភាពដោយផាត់ចេញនូវភាពមោហ៍ចាំង និងភាពលំអៀងរបស់បុគ្គលណាមួយ។ បណ្តាទីប្រឹក្សា ឬ គណៈកម្មាធិការនីតិបញ្ញត្តិអាចបង្ខំមេដឹកនាំរដ្ឋអោយពិចារណាឡើងវិញនូវការសម្រេចចិត្តយ៉ាងតក់ក្រហលណាមួយ។ ហើយអន្តរកម្មរវាងបុគ្គលផ្សេងៗនៅក្នុងក្រុមមួយ អាចនាំទៅរកការបង្កើតគោលដៅ ដែលឆ្លុះបញ្ចាំងផលប្រយោជន៍របស់រដ្ឋបានយ៉ាងល្អ ជាងឆ្លុះបញ្ចាំងពីការយល់ឃើញរបស់បុគ្គលនីមួយៗ។ ទោះជាយ៉ាងណាក៏ដោយ សក្តានុពលក្រុមក៏ណែនាំប្រភពថ្មីនៃភាពមិនសមហេតុផល ទៅក្នុងដំណើរការធ្វើការសម្រេចចិត្តផងដែរ។

ការគិតជាក្រុម(groupthink) សំដៅលើទំនោរក្នុងក្រុមដើម្បីឈានដល់ការសម្រេចចិត្ត ដោយមិនបានវាយតម្លៃ យ៉ាងត្រឹមត្រូវ នូវលទ្ធផលដែលអាចកើតឡើង ពីព្រោះសមាជិកម្នាក់ៗមានទំនោរស្របតាមគំនិតដែលពួកគេគិតថាអ្នកដទៃគាំទ្រ។ បាតុភូតនេះត្រូវបានបង្ហាញដោយការពិសោធន៍ចិត្តសាស្ត្រដ៏សាមញ្ញមួយ។ មនុស្សមួយក្រុម ដែលមានគ្នាប្រាំមួយនាក់ ត្រូវបានស្នើអោយប្រៀបធៀបប្រវែងនៃបន្ទាត់ពីរដែលបញ្ចាំងលើផ្ទាំងអេក្រង់មួយ។ នៅពេលដែលមនុស្ស ៥ នាក់ត្រូវបានណែនាំដោយសម្ងាត់ អោយនិយាយថាបន្ទាត់ «ក» វែងជាង (ទោះបីជានរណាក៏ដោយអាចមើលឃើញថា បន្ទាត់ «ខ» មានប្រវែងវែងជាងក៏ដោយ) មនុស្សទីប្រាំមួយទំនងជាយល់ស្របជាមួយក្រុម ជាជាងជឿលើភ្នែករបស់គាត់ផ្ទាល់។

រូបថត *ប្រធានាធិបតី ប៊ូស ប្រកាសជ័យជំនះ នៅឆ្នាំ ២០០៣*

គំនិតចៅចាក់ស្នុត

ទាំងការយល់ខុសរបស់បុគ្គលនិងចិត្តវិទ្យាជាក្រុម ជំរុញអោយមានទំនុកចិត្តខ្លាំងពេកនិងសុទិដ្ឋិនិយមហួសហេតុក្នុងចំណោមអ្នកធ្វើការសម្រេចចិត្ត។ ទំនោរទូទៅនៅក្នុងគ្រប់រដ្ឋាភិបាលបែបនេះ ជាពិសេសបានសម្គាល់រយៈពេលនៃការលុកលុយរបស់អាមេរិកលើប្រទេសអ៊ីរ៉ាក់។ នៅទីនេះ ប្រធានាធិបតី ប៊ូស ប្រកាសជ័យជំនះលើនាវាផ្ទុកយន្តហោះ ខែឧសភា ឆ្នាំ ២០០៣។


ខុសពីបុគ្គលនីមួយៗ, ក្រុមមានទំនោរមានសុទិដ្ឋិនិយមខ្លាំងជ្រុល អំពីឱកាសដែលអាចជោគជ័យដូច្នេះហើយ មានឆន្ទៈក្នុងការទទួលយកហានិភ័យជាង។ អ្នកចូលរួមលុបបំបាត់អារម្មណ៍សង្ស័យរបស់ខ្លួនលើរឿងគួរអោយសង្ស័យ ពីព្រោះសមាជិកក្រុមដទៃទៀតហាក់ដូចជាគិតថា គំនិតមួយនោះនឹងដំណើរការ។ ម្យ៉ាងវិញទៀត ដោយសារក្រុមនេះដកការទទួលខុសត្រូវពីបុគ្គល, ដូច្នេះគ្មាននរណាម្នាក់ទទួលខុសត្រូវចំពោះសកម្មភាពទាំងនោះឡើយ។

ឧទាហរណ៍ដ៏ល្អមួយនៃការគិតជាក្រុម, មិត្តជិតស្និទ្ធរបស់ប្រធានាធិបតី រ៉ូណាល់ រីហ្គែន (Ronald Reagan) និងជានាយកទីភ្នាក់ងារស៊ើបការណ៍សម្ងាត់របស់សហរដ្ឋអាមេរិក(CIA) បានរំលងទីភ្នាក់ងារផ្ទាល់ខ្លួនរបស់គាត់ ហើយបានដំណើរការប្រតិបត្តិការសម្ងាត់ ដែលគ្រប់ដណ្តប់លើទ្វីបចំនួនបី ដោយប្រើបុគ្គលិកក្រុមប្រឹក្សាសន្តិសុខជាតិ (NSC) នៅក្នុងបន្ទប់ក្រោមដីនៃសេតវិមាន។ ក្រុមប្រឹក្សាសន្តិសុខជាតិ

បានលក់សព្វាវុធទៅអោយប្រទេសអ៊ីរ៉ង់ជាថ្នូរនឹងសេរីភាពនៃចំណាប់ខ្មាំងជនជាតិអាមេរិក ដែលត្រូវបានឃុំខ្លួននៅក្នុងប្រទេសលីបង់ ហើយបន្ទាប់មក វាបានប្រើប្រាស់ប្រព័ន្ធបង់ប្រាក់របស់អ៊ីរ៉ង់ដើម្បីផ្តល់មូលនិធិដល់ពួកឧទ្ទាមនីការ៉ាហ្គ័រកុងត្រា (Contra) ដោយខុសច្បាប់។ រឿងអាស្រូវអ៊ីរ៉ង់-កុងត្រា បានកើតឡើង នៅពេលដែលប្រតិបត្តិការទាំងនេះ ដែលគ្រប់គ្រងដោយជំនួយការក្រុមប្រឹក្សាសន្តិសុខជាតិ ឈ្មោះ អូលីវ័រ ណ័រ (Oliver North) ត្រូវលេចលឺជាសាធារណៈ។

សង្គ្រាមអាមេរិកនៅប្រទេសអ៊ីរ៉ាក់ក៏អាចផ្តល់ជាឧទាហរណ៍មួយ ព្រមានដល់មនុស្សជំនាន់ក្រោយអំពីហានិភ័យនៃព័ត៌មានមិនពិត ការយល់ខុស គំនិតចៅចាក់ស្មុគ និងការគិតជាក្រុម ក្នុងការគ្រប់គ្រងគំនិតផ្តួចផ្តើមគោលនយោបាយការបរទេសដ៏សំខាន់ណាមួយ។ បញ្ហាមួយចំនួននៃចិត្តសាស្ត្របុគ្គល និងចិត្តសាស្ត្រក្រុម នៅក្នុងដំណើរការគោលនយោបាយ ទាំងនៅក្នុងប្រទេសវៀតណាម បូស្នៀ ឬ អ៊ីរ៉ាក់ ត្រូវបានបង្ហាញក្នុងក្រាហ្វិក ៤.៣។

ក្រាហ្វិក ៤.៣ ឧបសគ្គចិត្តសាស្ត្រនៃការសម្រេចចិត្ត



**ដែនដីជម្លោះអាចជាប្រទេសវៀតណាម ឆ្នាំ ១៩៦៨, បូស្នៀ ឆ្នាំ១៩៩៤ ឬអ៊ីរ៉ាក់ ឆ្នាំ ២០០៦*

រចនាសម្ព័ន្ធនៃដំណើរការធ្វើសេចក្តីសម្រេច (ច្បាប់សម្រាប់អ្នកដែលចូលរួមនៅក្នុងការសម្រេចចិត្ត, របៀបដែលការបោះឆ្នោតត្រូវបានធ្វើឡើង និងផ្សេងៗទៀត) អាចប៉ះពាល់ដល់លទ្ធផល ជាពិសេសនៅពេលដែលគ្មានជម្រើសណាមួយ ត្រូវបានគាំទ្រដោយអ្នកចូលរួមភាគច្រើន។ អ្នកចូលរួមដែលមានបទពិសោធន៍ច្រើនក្នុងការបង្កើតគោលនយោបាយការបរទេស ស្គាល់ពីបច្ចេកទេសឬល្បិចសម្រាប់ទាញដំណើរការធ្វើការសម្រេចចិត្ត ដើម្បីសម្រេចបានលទ្ធផលដែលពួកគេចូលចិត្តជាង។ បច្ចេកទេសទូទៅមួយគឺការគ្រប់គ្រង *ច្បាប់វិធាន ឬយន្តការនៃការសម្រេចចិត្ត* ជាផ្លូវការរបស់ក្រុមមួយ។ ច្បាប់ទាំងនេះរួមមានរបៀបវារៈដែលក្រុមត្រូវ

ពិភាក្សា និងលំដាប់លំដោយដែលសំណើត្រូវបានពិចារណា (ជាពិសេស មានសារៈសំខាន់នៅពេលអ្នកចូលរួមពេញចិត្ត)។ ប្រហែលជាសំខាន់បំផុត គឺសមត្ថភាពក្នុង*ការគ្រប់គ្រងរបៀបការៈ* ដូច្នោះហើយអាចរៀបចំរចនាសម្ព័ន្ធលក្ខខណ្ឌនៃការពិភាក្សា។

មេដឹកនាំរដ្ឋទាំងឡាយតែងតែពឹងផ្អែកលើក្រុមស្នូលនៃទីប្រឹក្សានានា ក្នុងការធ្វើការសម្រេចចិត្តគោលនយោបាយការបរទេស។ សមាសភាពនិងប្រតិបត្តិការនៃក្រុមស្នូល មានលក្ខណៈខុសប្លែកគ្នា ពីរដ្ឋាភិបាលមួយទៅរដ្ឋាភិបាលមួយទៀត។ ជាឧទាហរណ៍ ប្រធានាធិបតីអាមេរិក លោក លីនដុន ចនសុន (Lyndon Johnson) មាន «អាហារថ្ងៃត្រង់ នៅថ្ងៃអង្គារ» ដើម្បីពិភាក្សាអំពីគោលនយោបាយសន្តិសុខជាតិជាមួយមន្ត្រីសន្តិសុខជាតិកំពូលៗ។ ក្រុមខ្លះពឹងផ្អែកខ្លាំងលើការពិគ្រោះយោបល់*ក្រៅផ្លូវការ* បន្ថែមលើកិច្ចប្រជុំផ្លូវការ។ មេដឹកនាំខ្លះបង្កើត «គណៈរដ្ឋមន្ត្រីផ្ទះបាយ (kitchen cabinet)» ដែលជាក្រុមមិត្តភក្តិដែលគួរអោយទុកចិត្តបំផុត ដែលពិភាក្សាអំពីបញ្ហាគោលនយោបាយជាមួយមេដឹកនាំ ទោះបីជាពួកគេមិនមានមុខតំណែងផ្លូវការក្នុងរដ្ឋាភិបាលក៏ដោយ។ ជាឧទាហរណ៍ នាយករដ្ឋមន្ត្រីអ៊ីស្រាអែល លោកស្រី ហ្គោដា ម៉ែរ (Golda Meir) បានធ្វើការពិភាក្សារបៀបនេះ ជាញឹកញាប់ នៅផ្ទះលោកស្រី ជួនកាលនៅក្នុងផ្ទះបាយ។ ប្រធានាធិបតីរុស្ស៊ី លោក បូរីស យ៉ែលត៍ស៊ីន (Boris Yeltsin) ពឹងផ្អែកលើដំបូន្មានរបស់អង្គរក្សរបស់គាត់ ដែលជាមិត្ត គួរអោយទុកចិត្តបំផុត។

៤.១.៤. ការគ្រប់គ្រងវិបត្តិ

ការលំបាកក្នុងការឈានដល់ការសម្រេចចិត្តដោយសមហេតុផល ទាំងសម្រាប់បុគ្គលនិងសម្រាប់ក្រុម ត្រូវកើនឡើងមួយកម្រិតទៀតក្នុងអំឡុងពេលមានវិបត្តិ។ *វិបត្តិ* គឺជាស្ថានភាពគោលនយោបាយការបរទេសដែលលទ្ធផលមានសារៈសំខាន់ខ្លាំងណាស់ ហើយការកំណត់ពេលវេលាត្រូវបានបង្រួមខ្លី។ ការសម្រេចចិត្តអំពីវិបត្តិមានលក្ខណៈពិបាកយល់និងពិបាកព្យាករណ៍ជាងការធ្វើគោលនយោបាយការបរទេសធម្មតា។

នៅពេលដែលមានវិបត្តិ អ្នកធ្វើសេចក្តីសម្រេចធ្វើប្រតិបត្តិការក្រោមសំពាធពេលវេលាយ៉ាងតានតឹង។ ការត្រួតពិនិត្យជាប្រក្រតីលើការសម្រេចចិត្តមិនសមហេតុផល អាចនឹងមិនដំណើរការទេ។ ការប្រាស្រ័យទាក់ទងគ្នាកាន់តែខើចខ្លីនិងមានលក្ខណៈស្វ័យភាព ហើយព័ត៌មានដែលមិនសមនឹងការពឹងទុករបស់អ្នកធ្វើការសម្រេចចិត្តទំនងជាត្រូវបោះចោល ព្រោះគ្មានពេលពិចារណា។ នៅក្នុងការពង្រាងជម្រើសនានា អ្នកធ្វើការសម្រេចចិត្តមានទំនោរដាក់កម្រិតលើជម្រើសម្តងទៀត ដើម្បីសន្សំពេលវេលា ហើយមានទំនោរមើលរំលងជម្រើសប្រកបដោយភាពច្នៃប្រឌិត ខណៈពេលដែលផ្តោតលើជម្រើសច្បាស់បំផុត។ (នៅសហរដ្ឋអាមេរិក ឧបសគ្គនៃការផ្លាស់ប្តូរពេលវេលា គឺអាចវាស់វែងបាន ក្នុងការកើនឡើងទ្វេដង ឬបីដង ក្នុងការដឹកជញ្ជូនកីហ្សាទៅកាន់ភ្នាក់ងាររដ្ឋាភិបាល ខណៈដែលអ្នកធ្វើការសម្រេចចិត្តធ្វើការកំឡុងម៉ោងបាយថ្ងៃត្រង់។)

ការគិតជាក្រុមប្រព្រឹត្តិទៅយ៉ាងងាយស្រួល ក្នុងអំឡុងពេលមានវិបត្តិ។ ក្នុងអំឡុងវិបត្តិមីស៊ីលគុយបាឆ្នាំ ១៩៦២, លោកប្រធានាធិបតី ចន កេណ្ណឺឌី (John F. Kennedy) បានបង្កើតក្រុមទីប្រឹក្សាតូចមួយ ដែលធ្វើការជាមួយគ្នាយ៉ាងជិតស្និទ្ធ អស់រយៈពេលជាច្រើនថ្ងៃ ដោយកាត់ផ្តាច់ទំនាក់ទំនង និងការពិភាក្សាពីខាងក្រៅ។ សូម្បីតែការប្រាស្រ័យទាក់ទងរបស់ប្រធានាធិបតីជាមួយមេដឹកនាំសូវៀត នីគីតា គ្រុសឆេវ (Nikita Khrushchev) ត្រូវបានបង្វែរឆ្លងឆ្លើយ តាមរយៈបងប្រុសរបស់កេណ្ណឺឌី, គឺលោក រ៉ូប៊ឺត (Robert) និងឯកអគ្គរដ្ឋទូតសូវៀត ដោយកាត់ផ្តាច់ក្រសួងការបរទេសចេញ។ ដោយទទួលស្គាល់ពីគ្រោះថ្នាក់នៃការគិតជា

ក្រុម លោក កេណ្ណឺឌីបានចាកចេញពីបន្ទប់ប្រជុំ ជារឿយៗ (មេកើយដកឃ្លាចេញពីក្រុម) ដើម្បីលើកទឹកចិត្ត ការពិភាក្សាដោយសេរី។ តាមរយៈមធ្យោបាយនេះ និងមធ្យោបាយផ្សេងទៀត ក្រុមអាចចាត់ចែងដើម្បីកំណត់ជម្រើសណាមួយ (ការបិទខ្ទប់កងនាវា) ក្នុងចំណោមជម្រើសពីរដំបូងរបស់ពួកគេ (ការទម្លាក់គ្រាប់បែកលើទីតាំងមីស៊ីល និងជម្រើសមិនធ្វើអ្វីសោះ)។ ជួនកាល អ្នកដឹកនាំដោយចេតនា ផ្ទេរសិទ្ធិអំណាចអោយនរណាម្នាក់នៅក្នុងក្រុម (ដែលគេស្គាល់ថាជា អ្នកតស៊ូមតិ (devil's advocate)) ដើម្បីបំផុតគំនិតអោយអ្នកចូលរួមពិភាក្សាគ្នា។

អ្នកចូលរួមក្នុងការធ្វើការសម្រេចចិត្តអំពីវិបត្តិមិនត្រឹមតែត្រូវប្រញាប់ប្រញាល់ប៉ុណ្ណោះទេ តែថែមទាំងជួបប្រទះ*ភាពតានតឹង* ផ្លូវចិត្តធ្ងន់ធ្ងរផងដែរ ដែលបណ្តាលអោយមានភាពលំអៀង ដែលទើបតែបានពិភាក្សាកាន់តែខ្លាំង។ អ្នកធ្វើសេចក្តីសម្រេចចិត្តមានទំនោរប៉ាន់ស្មានកម្រិតអរិភាពរបស់សត្រូវហួសប្រមាណ និងបន្ថយកម្រិតអរិភាពរបស់ពួកគេចំពោះសត្រូវទាំងនោះ។ ការមិនចូលចិត្តងាយនឹងប្រែក្លាយទៅជាការស្អប់ ហើយការថប់បារម្ភទៅជាភ័យខ្លាច។ ព័ត៌មានកាន់តែច្រើនឡើងៗត្រូវបានផាត់ចេញ ដើម្បីអោយសមស្របតាមការសម្រេចចិត្តដែលកំពុងធ្វើនិងដើម្បីស្តារតុល្យភាពនៃសតិសម្បជញ្ញៈ។ ការសម្រេចចិត្តក្នុងវិបត្តិក៏នាំទៅរកភាពអស់កម្លាំងផ្នែករាងកាយផងដែរ។ *ការគេងមិនគ្រប់គ្រាន់* កើតមានឡើងក្នុងរយៈពេលប៉ុន្មានថ្ងៃនៅពេលអ្នកធ្វើការសម្រេចចិត្តប្រើប្រាស់ពេលរបស់ខ្លួន ដើម្បីតាមដានស្ថានការណ៍នៃវិបត្តិ។ ប្រសិនបើអ្នកធ្វើការសម្រេចចិត្តមិនមានការប្រុងប្រយ័ត្នខ្ពស់ក្នុងការគេងអោយបានគ្រប់គ្រាន់នោះទេ ពួកគេអាចនឹងធ្វើការសម្រេចចិត្តគោលនយោបាយការបរទេសសំខាន់ៗ ក្រោមសំពាធនៃការផ្លាស់ប្តូរសតិសម្បជញ្ញៈ និងការផ្លាស់ប្តូរអារម្មណ៍ជារឿយៗ។

ដោយសារសារៈសំខាន់នៃការសម្រេចចិត្តដ៏ត្រឹមត្រូវក្នុងអំឡុងពេលមានវិបត្តិ អ្នកបោះឆ្នោតយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះស្ថិរភាពផ្លូវចិត្តរបស់អ្នកដឹកនាំរបស់ពួកគេ។ មុនពេលនាយករដ្ឋមន្ត្រីអ៊ីស្រាអែល លោក យីតហាក់ រ៉ាប៊ីន (Yitzhak Rabin) ទទួលបានជោគជ័យក្នុងការបោះឆ្នោត ក្នុងឆ្នាំ ១៩៩២ លោកបានប្រឈមមុខនឹងការចោទប្រកាន់ថា លោកបានទទួលរងគ្រោះដោយជំងឺសរសៃប្រសាទ អស់ពេលពេញមួយថ្ងៃ នៅពេលដែលគាត់បានដឹកនាំកងកម្លាំងប្រដាប់អាវុធ មុនសង្គ្រាមឆ្នាំ ១៩៦៧។ «មិនមានរឿងដូច្នេះទេ » គាត់បានឆ្លើយតប។ គាត់មានភាពវ័យឆ្លាតដោយកត់សម្គាល់ថាវិបត្តិនោះបានបណ្តាលគាត់ហៅហត់អោយអស់កម្លាំង និងការពុលជាតិនីកូទីនស្រួចស្រាវ ហើយគាត់ត្រូវការសម្រាកមួយថ្ងៃ ដើម្បីបន្តធ្វើការសម្រេចចិត្តបានល្អ។

មិនថានៅក្នុងស្ថានភាពវិបត្តិ ឬស្ថានភាពជាទម្លាប់ តាមធម្មតានោះទេ អ្នកធ្វើការសម្រេចចិត្តជាបុគ្គលមិនធ្វើការតែម្នាក់ឯងទេ។ ការសម្រេចចិត្តរបស់ពួកគេត្រូវបានសម្រួចដោយរដ្ឋាភិបាលនិងសង្គមដែលពួកគេធ្វើការ។ តួអង្គក្រោមរដ្ឋ ដូចជា ភ្នាក់ងាររដ្ឋាភិបាល ក្រុមផលប្រយោជន៍នយោបាយ និងឧស្សាហកម្មនានាអាចរារាំងឬសម្រួចគោលនយោបាយការបរទេស។

រូបថត *ប្រធានាធិបតី អេដវ័ឌ ហ្សេវ័ឌណាដហ្ស កំពុងឈឺក្បាលនឹងការងារ*

ធ្វើការក្រោមសំពាធដ៏តានតឹង

ការគ្រប់គ្រងវិបត្តិត្រូវរងផលប៉ះពាល់ខ្លាំងទាំងផ្នែកចិត្តសាស្ត្រនិងរូបរាងកាយ។ ប្រធានាធិបតី អេដវ័ឌ ហ្សេវ័ឌណាដហ្ស (Eduard Shevardnadze) នៃប្រទេសហ្សកហ្ស៊ីហាក់ដូចជាបង្ហាញពីសំពាធតានតឹង

បែបនេះក្នុងឆ្នាំ ១៩៩២ គ្រាន់តែជាការចាប់ផ្តើមនៃសង្គ្រាមស៊ីវិលជាច្រើនឆ្នាំ និងវិបត្តិជាហូរហែនៅក្នុងប្រទេសនោះ។ ហ្សង់ឌែណាដហ្គា ដែលជាអតីតរដ្ឋមន្ត្រីការបរទេសសូវៀតបានវិលត្រឡប់មកដឹកនាំរដ្ឋហ្សកហ្ស៊ី មាតុភូមិកំណើតរបស់គាត់វិញ នៅពេលដែលសហភាពសូវៀតត្រូវបានរំលាយ។ លោកបានចាកចេញពីតំណែងក្នុងឆ្នាំ ២០០៣ បន្ទាប់ពីប្រជាជនបះបោរដ៏ពេញនិយមប្រឆាំងនឹងអំពើពុករលួយ។

៤.២. ឥទ្ធិពលក្នុងស្រុក

៤.២ ចូរប្រៀបធៀបឥទ្ធិពលនៃមតិសាធារណៈនិងក្រុមតំណាងផលប្រយោជន៍ ទៅលើដំណើរការបង្កើតគោលនយោបាយការបរទេស។

ផ្នែកសេសសល់នៃមេរៀននេះពិចារណាគោលការណ៍ទ្រឹស្តីសេរីនិយមផ្សេងទៀត ដូចជាសន្តិប្រជាធិបតេយ្យ ដែលដំណើរការ នៅកម្រិតនៃការវិភាគក្នុងស្រុក។ ផ្ទុយពីទ្រឹស្តីប្រាកដនិយម គោលការណ៍ទាំងនេះមើលឃើញព្រឹត្តិការណ៍អន្តរជាតិថាជា លទ្ធផលនៃដំណើរការទាំងឡាយដែលកើតឡើងនៅក្នុងរដ្ឋនានា ជាជាងគ្រាន់តែកើតឡើងក្នុងចំណោមរដ្ឋទាំងនោះ។ សកម្មភាពរបស់រដ្ឋក្នុងឆាកអន្តរជាតិ កើតចេញពីជំរើសរបស់បុគ្គលនីមួយៗ (ដោយពលរដ្ឋ អ្នកដឹកនាំនយោបាយ អ្នកការទូត និងការិយាធិបតេយ្យ) ដែលរួមផ្សំគ្នាតាមរយៈរចនាសម្ព័ន្ធផ្ទៃក្នុងរបស់រដ្ឋ។ យើងនឹងពិនិត្យមើលរដ្ឋពីខាងក្នុង ចេញមកក្រៅ ដោយព្យាយាមស្វែងយល់ពីដំណើរការ និងរចនាសម្ព័ន្ធ*នៅក្នុង*រដ្ឋ ដែលធ្វើអោយពួកគេមានឥរិយាបទដូចដែលពួកគេបានធ្វើ។

៤.២.១. ការិយាធិបតេយ្យ

ក្នុងចំណោមតួអង្គនៅក្នុងរដ្ឋជាច្រើន ដែលមានឥទ្ធិពលលើសកម្មភាពរបស់រដ្ឋនោះ នៅលើឆាកអន្តរជាតិ, អ្នកដែលជិតស្និទ្ធនឹងសកម្មភាព គឺជាភ្នាក់ងារការិយាធិបតេយ្យ ដែលរដ្ឋចាត់តាំង សម្រាប់ការអភិវឌ្ឍ និងអនុវត្តគោលនយោបាយការបរទេស។ រដ្ឋផ្សេងគ្នាចាត់តាំងភ្នាក់ងារការិយាធិបតេយ្យគោលនយោបាយការបរទេសផ្សេងគ្នា ប៉ុន្តែ ការិយាធិបតេយ្យទាំងនេះរួមមានសមាសធាតុទូទៅមួយចំនួន។

អ្នកការទូត៖ ស្ទើរតែគ្រប់រដ្ឋទាំងអស់រក្សា*សេវាកម្មបរទេស*របស់អ្នកការទូត ដែលធ្វើការនៅ*ស្ថានទូត*នានាក្នុងរដ្ឋធានីបរទេស (និងនៅក្នុង*ស្ថានកុងស៊ុល*ដែលមានទីតាំងនៅទីក្រុងបរទេស ដែលមិនមែនជារាជធានី) ក៏ដូចជាអ្នកការទូត ដែលរស់នៅក្នុងមាតុប្រទេសដើម្បីជួយសម្របសម្រួលគោលនយោបាយការបរទេស។ រដ្ឋធ្វើការតែងតាំង*ឯកអគ្គរដ្ឋទូត*ជាអ្នកតំណាងផ្លូវការរបស់ពួកគេ ទៅកាន់រដ្ឋផ្សេងទៀត និងអង្គការអន្តរជាតិនានា។ សកម្មភាពការទូតត្រូវបានរៀបចំឡើង តាមរយៈ*ក្រសួងការបរទេស*ឬស្ថាប័នដែលមានមុខងារប្រហាក់ប្រហែលនេះ (ឧទាហរណ៍ ក្រសួងការបរទេសសហរដ្ឋអាមេរិក ត្រូវគេហៅជាភាសាអង់គ្លេសថា State Department, គេមិនប្រើប្រាស់ពាក្យអង់គ្លេសទូទៅដូចជា Ministry ទេ)។

នៅក្នុងប្រទេសប្រកាន់លទ្ធិប្រជាធិបតេយ្យជាច្រើន អ្នកការទូតខ្លះជា*អ្នកតែងតាំងដោយនយោបាយ*ដែលឡើងកាន់និងចុះចេញពីតំណែង ជាមួយនិងការផ្លាស់ប្តូរមេដឹកនាំរដ្ឋាភិបាល (ជារឿយៗ ពួកគេជាអ្នកឧបត្ថម្ភគាំទ្រសកម្មភាពនយោបាយកន្លងមក)។ អ្នកផ្សេងទៀត ជា*អ្នកការទូតអាជីព* (career diplomates) ដែលឡើងតាមឋានន្តរស័ក្តិក្នុងជួរសេវាកម្មបរទេស ហើយមានទំនោរនៅធ្វើការបានយូរ ជាងការផ្លាស់ប្តូររដ្ឋបាលនីមួយៗ។

អ្នកការទូតផ្តល់ព័ត៌មានជាច្រើន ដែលចូលទៅក្នុងការបង្កើតគោលនយោបាយការបរទេស ប៉ុន្តែតួនាទីចម្បងរបស់ពួកគេ គឺត្រូវអនុវត្ត ច្រើនជាងបង្កើតគោលនយោបាយ។ យ៉ាងណាក៏ដោយ មន្ត្រីក្រសួងការ

បរទេសជារឿយៗធ្វើទំនាក់ទំនងការបរទេស ជាទម្លាប់ទៅហើយ ដែលថ្នាក់ដឹកនាំកំពូលនិងអ្នកចាត់តាំងនយោបាយ អាចឡើងកាន់និងចុះចេញពីតំណែង ដោយមិនមានការផ្លាស់ប្តូរខ្លាំងក្លានៅក្នុងទំនាក់ទំនងរវាងប្រទេសនិងប្រទេសឡើយ។ អ្នកការិយាធិបតេយ្យជឿជាក់ថា ផលប្រយោជន៍ជាតិអាចត្រូវបានសម្រេចឡើងដោយស្ថេរភាពនៃគោលដៅនិងគោលដំហរជាតិទាំងមូល នៅក្នុងកិច្ចការអន្តរជាតិ។

ភាពតានតឹងកើតឡើងជាធម្មតា រវាងមេដឹកនាំរដ្ឋ និងអ្នកការិយាធិបតេយ្យនយោបាយការបរទេស។ អ្នកការទូតអាជីពព្យាយាមតម្រង់ទិសអ្នកដឹកនាំថ្មីនិងមន្ត្រីពួកគេតែងតាំង, និងគ្រប់គ្រងលំហូរព័ត៌មាន ដែលពួកគេទទួលបាន (នាំអោយមានអេក្រង់ព័ត៌មាន)។ អ្នកនយោបាយជួបការលំបាកក្នុងការអនុវត្តអំណាចលើភ្នាក់ងារការិយាធិបតេយ្យផ្លូវការ ពីព្រោះភ្នាក់ងារទាំងនោះអាចមានលក្ខណៈ «ការិយាធិបតេយ្យ» ខ្លាំងពេក (ស្មុគស្មាញ ទម្លាប់ អភិរក្សនិយម) មិនងាយគ្រប់គ្រងបានដោយស្រួលនោះទេ។ ដូចគ្នានេះផងដែរ ភ្នាក់ងារទាំងនេះ ជារឿយៗ មានបុគ្គលិក (នៅកម្រិតទាប) ភាគច្រើន ជាមន្ត្រីអាជីព ដែលប្រហែលជាមិនដំពាក់គុណស្រ័យឬកក្តីភាពស្មោះស្ម័គ្រចំពោះអ្នកដឹកនាំនយោបាយណាមួយឡើយ។

ទំហំតែម្យ៉ាងមិនធានាអំណាចសម្រាប់ការិយាធិបតេយ្យទេ។ ជាឧទាហរណ៍ ក្រុមប្រឹក្សាសន្តិសុខជាតិអាមេរិកមានបុគ្គលិកត្រឹមតែ ៤០០នាក់ ប៉ុណ្ណោះ ធៀបនឹងបុគ្គលិក ៥,០០០ នាក់ដែលមានទំនួលខុសត្រូវចំពោះបញ្ហាស្រដៀងគ្នា នៅក្នុងក្រសួងពាណិជ្ជកម្ម និងក្រសួងការបរទេស។ អំណាចនៃទីភ្នាក់ងារទាំងនេះដោយសារពួកគេនៅជិតប្រធានាធិបតីអាមេរិក។ ជាប្រពៃណី ប្រធាន ក្រុមប្រឹក្សាសន្តិសុខជាតិ រាយការណ៍ប្រាប់ប្រធានាធិបតី អំពីបញ្ហាសន្តិសុខអន្តរជាតិ ជារៀងរាល់ព្រឹក។

ពេលខ្លះ មេដឹកនាំរដ្ឋតែងតាំងមិត្តជិតស្និទ្ធ ឬទីប្រឹក្សាសំខាន់ដើម្បីគ្រប់គ្រងការិយាធិបតេយ្យគោលនយោបាយការបរទេស។ ប្រធានាធិបតីអាមេរិក លោក ចច ប៊ូស (George W. Bush) បានធ្វើរឿងនេះ នៅក្នុងអាណត្តិទីពីររបស់គាត់ ជាមួយអតីតប្រធានក្រុមប្រឹក្សាសន្តិសុខជាតិរបស់គាត់ និងមន្ត្រីជំនិត លោកស្រី ឃុនដូលីហ្សា រ៉ាយស៍ (Condoleezza Rice)។ មេដឹកនាំចិន លោក ម៉ៅ សេទុង បានដាក់សម្ព័ន្ធមិត្តដ៏ស្មោះត្រង់របស់គាត់ម្នាក់ គឺ លោក ជូ អេនឡាយ (Zhou Enlai) អោយទទួលបន្ទុកគោលនយោបាយការបរទេស។ នៅពេលខ្លះទៀត មេដឹកនាំរដ្ឋអាចតែងតាំងគូប្រជែងដែលមានទស្សនៈខុសគ្នាក្នុងគោលនយោបាយការបរទេស ដូចប្រធានាធិបតីអាមេរិក លោក បារ៉ាក់ អូបាម៉ា (Barrack Obama) បានតែងតាំងអតីតគូប្រជែងនយោបាយរបស់គាត់ គឺ លោកស្រី ហ៊ីលឡារី គ្លីនតុន (Hillary Clinton)។

ជួនកាល ការថ្នើថ្នាក់មិនសប្បាយចិត្តជាមួយនឹងការិយាធិបតេយ្យនាំអោយអ្នកនយោបាយខ្លះរំលងមធ្យោបាយទំនាក់ទំនងការទូត តាមទម្លាប់ធម្មតា។ ជាឧទាហរណ៍ ក្នុងអំឡុងវិបត្តិមីស៊ីលគុយបា ឆ្នាំ ១៩៦២ ប្រធានាធិបតីអាមេរិក លោក កេណ្ណឺឌី បានទាមទារអោយមានការទាក់ទងផ្ទាល់ជាមួយបុគ្គលិកយោធានៅក្នុងតំបន់សមុទ្រការ៉ាប៊ីន ដែលកំពុងត្រួតពិនិត្យការបិទខ្ទប់ឡោមព័ទ្ធប្រទេសគុយបា ដោយរំលងរដ្ឋមន្ត្រីការពារជាតិ និងមន្ត្រីជាន់ខ្ពស់ដទៃទៀត។

ភាពតានតឹងអន្តរស្ថាប័ន ភាពតានតឹង*រវាងស្ថាប័ន*នានា ក៏ប៉ះពាល់ដល់ការបង្កើតគោលនយោបាយការបរទេសផងដែរ។ ភ្នាក់ងារមួយចំនួន តាមលក្ខណៈប្រពៃណី តែងមានការប៉ះទង្គិចគ្នា ហើយការប្រទាញប្រទងគ្នា ប្រៀបដូចជាល្បែងទាញខ្សែព្រ័ត្រចុះឡើងគ្មានទីបញ្ចប់ សម្រួចគោលនយោបាយការបរទេសដែលលេចឡើង។ នៅក្នុងឧទាហរណ៍នៃការប្រជែងគ្នាក្នុងអន្តរទំនាក់ទំនង, ក្រសួងការបរទេសសហរដ្ឋអាមេរិក

និងភ្នាក់ងារស៊ើបការណ៍សម្ងាត់ CIA បានគាំទ្រភាគីផ្ទុយគ្នា នៅក្នុងសង្គ្រាមស៊ីវិលនៅប្រទេសឡាវ ក្នុងឆ្នាំ ១៩៦០។ នៅសហរដ្ឋអាមេរិក និងសហភាពសូវៀត ក្នុងអំឡុងសង្គ្រាមត្រជាក់, ក្រសួងការពារជាតិ ជាធម្មតា មានលក្ខណៈដូចសត្វស្វាំង (ចូលចិត្តកម្លាំងយោធាជាង) និងក្រសួងការបរទេសកាន់តែមានឥរិយាបទ ដូចសត្វព្រាប (និយមការទូតជាង) ដោយមានប្រធានាធិបតី ឬនាយករដ្ឋមន្ត្រី នៅកណ្តាលរក្សាតុល្យភាព។

ជាទូទៅ ការិយាធិបតេយ្យលើកកម្ពស់គោលនយោបាយ ដែលសមត្ថភាពរបស់ពួកគេផ្ទាល់នឹងមានប្រសិទ្ធភាព ហើយអំណាចរបស់ពួកគេនឹងកើនឡើង។ មានពាក្យស្លោកលើកឡើងថា «ជំហររបស់អ្នក» លើបញ្ហាអ្វីមួយ«អាស្រ័យលើកន្លែងដែលអ្នកអង្គុយ»(នៅក្នុងរចនាសម្ព័ន្ធការិយាធិបតេយ្យ)។ ជារឿយៗ គេអាចទស្សន៍ទាយពីរបៀបដែលអ្នកចូលរួមនឹងជជែកតវ៉ាលើបញ្ហាគោលនយោបាយណាមួយ ដោយគ្រាន់តែមើលមុខតំណែងរបស់ពួកគេ។ *គំរូចរចារបស់រដ្ឋាភិបាល*យកចិត្តទុកដាក់ជាពិសេសចំពោះការចរចារវាងស្ថាប័នដែលកើតចេញពីទំនាស់ផលប្រយោជន៍ រវាងភ្នាក់ងារផ្សេងៗគ្នានៃរដ្ឋាភិបាលតែមួយ។ ជាឧទាហរណ៍ បន្ទាប់ពីជនជាតិអាមេរិកត្រូវបានចាប់ធ្វើជាចំណាប់ខ្មាំងនៅប្រទេសអ៊ីរ៉ង់ ក្នុងឆ្នាំ ១៩៧៩, មន្ត្រីយោធា និងភ្នាក់ងារសម្ងាត់CIA បានរុញប្រធានាធិបតី ជីមី្ម ខាធ័រ (Jimmy Carter) អោយព្យាយាមជួយសង្គ្រោះដោយប្រើយុទ្ធនាការយោធា ខណៈដែលក្រសួងការបរទេសបានជំទាស់យ៉ាងខ្លាំងចំពោះបេសកកម្មបែបនេះ។ បន្ទាប់ពីការជជែកដេញដោលជាច្រើនថ្ងៃ លោកប្រធានាធិបតីបានសម្រេចចិត្តបន្តបេសកកម្មជួយសង្គ្រោះដោយកងកម្លាំងយោធា (លទ្ធផលដ៏គ្រោះមហន្តរាយ) ប៉ុន្តែ លោកមិនបានអញ្ជើញរដ្ឋមន្ត្រីក្រសួងការបរទេសអោយចូលរួមកិច្ចប្រជុំ ដែលការសម្រេចចិត្តចុងក្រោយត្រូវបានធ្វើឡើងនោះទេ។

បើទោះបីជាអ្នកតំណាងអោយភ្នាក់ងារការិយាធិបតេយ្យ ជាធម្មតា លើកកម្ពស់ផលប្រយោជន៍របស់ការិយាធិបតេយ្យរបស់ពួកគេក៏ដោយ ជួនកាល ប្រធានទីភ្នាក់ងារព្យាយាមបង្ហាញភាពស្មោះត្រង់ចំពោះមេដឹកនាំរដ្ឋ ដោយលះបង់ផលប្រយោជន៍របស់ភ្នាក់ងាររបស់ខ្លួន។ ដូចគ្នានេះផងដែរ ចំណង់ចំណូលចិត្តរបស់មេដឹកនាំនៃទីភ្នាក់ងារការិយាធិបតេយ្យ មិនអាចទាយទុកជាមុនបានឡើយ ដោយសារគោលដៅនៃស្ថាប័នរបស់ពួកគេ។ ជាឧទាហរណ៍ ក្នុងវិបត្តិមីស៊ីលគុយបា មន្ត្រីការពារជាតិមានការស្ទាក់ស្ទើរក្នុងការប្តេជ្ញាចិត្តចំពោះដំណោះស្រាយយោធាចំពោះវិបត្តិនេះ ខណៈដែលមន្ត្រីការទូតខ្លះពេញចិត្តនឹងការវាយប្រហារយោធាជាមុន។

អង្គភាពផ្សេងៗនៅក្នុងភ្នាក់ងារនីមួយៗក៏មានភាពតានតឹងស្រដៀងគ្នានេះដែរ។ នៅក្នុងប្រទេសជាច្រើន សេវាកម្មយោធាផ្សេងៗគ្នា (កងទ័ពជើងគោក ជើងទឹក ដែនអាកាស) ប្រទាញគ្នាក្នុងទិសដៅផ្សេងៗគ្នា ទោះបីជាចុងក្រោយ ពួកគេរួបរួមគ្នាជាសំឡេងតែមួយ ដើម្បីជជែកពិភាក្សាជាមួយសហការីក្នុងក្រសួងការបរទេសក៏ដោយ។ មន្ត្រីការិយាល័យដែលធ្វើការនៅក្នុងអង្គភាពឬគម្រោងជាក់លាក់ណាមួយ ផ្សារភ្ជាប់ខ្លួនជាមួយអង្គភាពឬគម្រោងទាំងនោះ។ មន្ត្រីដែលទទួលខុសត្រូវចំពោះប្រព័ន្ធអាវុធថ្មី តំណែងក្នុងការិយាធិបតេយ្យនិងប្រហែលជាបាត់បង់ការងាររបស់ខ្លួនផងដែរ ប្រសិនបើការអភិវឌ្ឍន៍អាវុធត្រូវបានលុបចោល។

ក្នុងចំណោមសេចក្តីបារម្ភជាពិសេស នៅក្នុងរដ្ឋក្រីក្រជាច្រើន គឺផលប្រយោជន៍ស្ថាប័នដែលមន្ត្រីយោធាអាចទទួលបាន ក្នុងដំណើរការរក្សាអនុភាពយោធាអោយបានខ្លាំង។ ប្រសិនបើមេដឹកនាំរដ្ឋស៊ីវិលទុកអោយប្រាក់ខែរបស់មន្ត្រីធ្លាក់ចុះឬទំហំនៃកងកម្លាំងយោធាត្រូវបានកាត់បន្ថយ ពួកគេអាចប្រឈមមុខនឹងការតវ៉ាប្រឆាំងពីស្ថាប័នយោធា ក្នុងករណីធ្ងន់ធ្ងរ អាចមានការដណ្តើមកាន់កាប់រដ្ឋាភិបាលដោយក្រុមយោធា

(សូមមើលទំព័រមេរៀនទី ៦)។ បញ្ហាទាំងនេះគឺជាកត្តាសំខាន់ (ក្នុងចំណោមកត្តាជាច្រើន) នៅក្នុងរដ្ឋប្រហារយោធានៅក្នុងប្រទេសថៃ នីហ្សេរ ហុងឌួរ៉ាស និងអេហ្ស៊ីប ក្នុងទសវត្សរ៍ចុងក្រោយនេះ។

ជាទូទៅ ការប្រជែងគ្នារវាងការិយាធិបតេយ្យក្នុងការជះឥទ្ធិពលលើគោលនយោបាយការបរទេស ប្រឈមនឹងសញ្ញាណដែលថា រដ្ឋជាតួអង្គឯកភូត នៅក្នុងប្រព័ន្ធអន្តរជាតិ។ ការប្រជែងគ្នាបែបនេះបង្ហាញថា រដ្ឋមួយមិនមានគោលដៅរួមតែមួយ «ផលប្រយោជន៍ជាតិទេ» ប៉ុន្តែ សកម្មភាពរបស់រដ្ឋអាចជាលទ្ធផលនៃការចរចារវាងអង្គភាពតូចៗ ដែលអង្គភាពនីមួយៗមានគោលដៅរៀងៗខ្លួន។ ជាងនេះទៅទៀត ទស្សនវិស័យបែបនេះ បានពង្រីកឆ្ងាយហួសពីភ្នាក់ងារការិយាធិបតេយ្យ ដោយសារតួអង្គក្នុងរដ្ឋផ្សេងទៀត មានគោលដៅផ្ទាល់ខ្លួនដែលពួកគេព្យាយាមជំរុញ ដោយជះឥទ្ធិពលលើគោលនយោបាយការបរទេស។

៤.២.២. ក្រុមតំណាងផលប្រយោជន៍

អ្នកបង្កើតគោលនយោបាយបរទេសដំណើរការ នៅក្នុងបរិបទនៃការពិភាក្សានយោបាយ នៅក្នុងសង្គមរបស់ពួកគេ ដោយមិនប្រព្រឹត្តទៅ នៅក្នុងលំហនយោបាយទេ។ នៅក្នុងគ្រប់រដ្ឋទាំងអស់ សម្ពាធសង្គមមានឥទ្ធិពលលើគោលនយោបាយការបរទេស ទោះបីជាសំពាធទាំងនេះត្រូវបានប្រមូលផ្តុំនិងបង្កើនប្រសិទ្ធភាព តាមរយៈបណ្តាញផ្សេងៗគ្នា នៅក្នុងសង្គមផ្សេងៗគ្នាក៏ដោយ។ នៅក្នុងប្រទេសលទ្ធិប្រជាធិបតេយ្យពហុនិយម ភាគីពាក់ព័ន្ធមានឥទ្ធិពលលើគោលនយោបាយការបរទេស តាមរយៈក្រុមតំណាងផលប្រយោជន៍ និងគណបក្សនយោបាយ។ នៅក្នុងប្រទេសប្រកាន់របបផ្តាច់ការ អាចមានឥទ្ធិពលស្រដៀងគ្នានេះផងដែរ ប៉ុន្តែ មិនសូវលេចចេញជារូបរាងច្បាស់ទេ។ ដូច្នេះហើយ គោលនយោបាយបរទេសដែលត្រូវបានអនុម័តដោយរដ្ឋ ជាទូទៅ ឆ្លុះបញ្ចាំងពីប្រភេទនៃដំណើរការនៃការបង្កើតសម្ព័ន្ធភាពក្នុងស្រុក។ ជាការពិតណាស់ កត្តាអន្តរជាតិក៏មានឥទ្ធិពលខ្លាំងក្លាលើនយោបាយក្នុងស្រុកផងដែរ។

ក្រុមតំណាងផលប្រយោជន៍គឺជាក្រុមចម្រុះមនុស្ស ដែលទទួលបានផលប្រយោជន៍រួមពីលទ្ធផលនៃបញ្ហានយោបាយមួយចំនួននិងដែលរៀបចំខ្លួនជាក្រុមដើម្បីព្យាយាមជះឥទ្ធិពលលើលទ្ធផល។ ជាឧទាហរណ៍ កសិករបារាំងមានផលប្រយោជន៍ច្រើន នៅក្នុងការចរចាអន្តរជាតិ នៅក្នុងសហគមន៍អឺរ៉ុប (ដែលឧបត្ថម្ភធនលើវិស័យកសិកម្ម) និងនៅក្នុងកិច្ចពិភាក្សាពាណិជ្ជកម្មពិភពលោក (ដែលកំណត់ពន្ធលើវិស័យកសិកម្ម)។ កសិករទាំងនោះបានដាក់សម្ពាធនយោបាយលើរដ្ឋាភិបាលបារាំង តាមរយៈសមាគមនិងអង្គការ ដែលមានភាពស្មុគស្មាញខាងនយោបាយ ជាយូរណាស់មកហើយ។ ពួកគេបញ្ចុះបញ្ចូលអោយមានច្បាប់ដែលពួកគេចង់បាន និងបានរួមចំណែកដល់យុទ្ធនាការបោះឆ្នោតរបស់អ្នកនយោបាយ។ កាន់តែរំជើបរំជួល នៅពេលដែលផលប្រយោជន៍របស់ពួកគេត្រូវបានគំរាមកំហែង នៅអំឡុងពេលជម្លោះពាណិជ្ជកម្មរវាងសហរដ្ឋអាមេរិកនិងអឺរ៉ុបក្នុងឆ្នាំ ១៩៩២ កសិករបារាំងបានប្រមូលផ្តុំយ៉ាងច្រើនកុះករ ដើម្បីបិទផ្លូវ ធ្វើ បាតុកម្មដោយហិង្សាលើដងផ្លូវ និងគម្រាមកំហែងធ្វើអោយសេដ្ឋកិច្ចជាតិត្រូវបញ្ឈប់ លុះត្រាតែរដ្ឋាភិបាលទទួលយកជំហររបស់ពួកគេ។ ស្រដៀងគ្នានេះដែរ (ប៉ុន្តែ ជាញឹកញាប់មិនសូវក្នុងក្តាំងខ្លាំងក្លាពេកទេ) ក្រុមតំណាងផលប្រយោជន៍ត្រូវបានបង្កើតឡើង ដុំវិញអាជីវកម្ម សហជីពការងារ ព្រះវិហារ អតីតយុទ្ធជន ក្រុមមនុស្សចាស់ សមាជិកប្រកបមុខរបរដូចគ្នា ឬប្រជាពលរដ្ឋដែលព្រួយបារម្ភអំពីបញ្ហា ដូចជាបរិស្ថាន។

ការបញ្ចុះបញ្ចូល (lobbying) គឺជាដំណើរការនៃការពិភាក្សាជាមួយសមាជិកសភា ឬមន្ត្រីនានា ដើម្បីជះឥទ្ធិពលលើការសម្រេចចិត្តរបស់ពួកគេ លើបញ្ហាមួយចំនួន។ ធាតុសំខាន់ៗចំនួនបី ដែលត្រូវចាត់បញ្ចូល

ជាយុទ្ធសាស្ត្របញ្ចុះបញ្ចូលដោយជោគជ័យ គឺលទ្ធភាពក្នុងការទទួលបានសវនាការ ជាមួយមន្ត្រីដែលរំលស់ លទ្ធភាពក្នុងការបង្ហាញអំណះអំណាងប្រកបដោយការយល់ដឹងសម្រាប់គាំទ្រសំណើរបស់ខ្លួន និងលទ្ធភាពក្នុងការដោះដូរការអនុគ្រោះឬយោគយល់ ជាថ្នូរនឹងសកម្មភាពវិជ្ជមានលើបញ្ហាមួយ។ ការអនុគ្រោះទាំងនេះ (ទាំងស្របច្បាប់ និងខុសច្បាប់) រួមមាន ចាប់ពីការរួមចំណែកជាលុយកាក់ក្នុងយុទ្ធនាការបោះឆ្នោតរហូតដល់អាហារពេលល្ងាចនៅភោជនីយដ្ឋានល្បីៗ ការធ្វើដំណើរទៅកាន់រមណីយដ្ឋានវាយកូនហ្គោល ការធានាទំនាក់ទំនងផ្លូវភេទខុសច្បាប់ និងការបង់ប្រាក់សំណូកជាដើម។ នៅក្នុងរដ្ឋជាច្រើនអំពើពុករលួយគឺជាបញ្ហារាំងស្ទះក្នុងការសម្រេចចិត្តរបស់រដ្ឋាភិបាល (សូមមើលមេរៀនទី១៣)ហើយក្រុមតំណាងផលប្រយោជន៍អាចជំរុញមន្ត្រីរដ្ឋាភិបាលដោយមធ្យោបាយខុសច្បាប់ដើម្បីធ្វើសកម្មភាពជាក់លាក់ណាមួយ។

ក្រុមជាតិពន្ធុ ក្រុមជនជាតិភាគតិច នៅក្នុងរដ្ឋមួយ ជារឿយៗ ក្លាយជាក្រុមផលប្រយោជន៍ ដែលខ្វល់ខ្វាយអំពីមាតុភូមិរបស់ពួកគេ នៅខាងក្រៅរដ្ឋនោះ។ សមាជិកជាច្រើននៃក្រុមជនជាតិភាគតិច មានអារម្មណ៍ថាមានទំនាក់ទំនងផ្លូវចិត្តខ្លាំងជាមួយសាច់ញាតិរបស់ពួកគេនៅក្នុងប្រទេសផ្សេងទៀត; ដោយសារតែប្រជាជនផ្សេងទៀត ជាទូទៅ មិនខ្វល់ពីបញ្ហាបែបនេះ ទោះតាមមធ្យោបាយណាក៏ដោយ សូម្បីតែក្រុមជនជាតិភាគតិច ក៏អាចមានឥទ្ធិពលយ៉ាងខ្លាំង លើគោលនយោបាយចំពោះប្រទេសជាក់លាក់ណាមួយ។ ទំនាក់ទំនងជាតិពន្ធុបែបនេះ កំពុងលេចចេញជាឥទ្ធិពលគោលនយោបាយការបរទេសដ៏មានឥទ្ធិពលនៅក្នុងជម្លោះជាតិពន្ធុនានា នៅក្នុងតំបន់ក្រីក្រ។ ឥទ្ធិពលទាំងនោះមានទំហំធំធេង ជាពិសេសនៅក្នុងសហរដ្ឋអាមេរិក ដែលមានលក្ខណៈចម្រុះជាតិសាសន៍ និងមានទម្រង់ប្រជាធិបតេយ្យពហុនិយម។ ជាឧទាហរណ៍ ជនជាតិអាមេរិដើមកំណើត គុយបាប្រមូលផ្តុំបង្កើនឥទ្ធិពលលើគោលនយោបាយរបស់សហរដ្ឋអាមេរិកចំពោះប្រទេសគុយបា ក៏ដូចជាជនជាតិអាមេរិកដើមកំណើតក្រិកទៅលើប្រទេសក្រិច ជនជាតិអាមេរិកដើមកំណើតជ្វីហ្វនៅទៅលើអ៊ីស្រាអែល និងជនជាតិអាមេរិកដើមកំណើតអាហ្វ្រិកទៅលើអាហ្វ្រិក។ នៅក្នុងការបោះឆ្នោតព្រឹទ្ធសភាសហរដ្ឋអាមេរិកឆ្នាំ ១៩៩៦ នៅរដ្ឋដាកូតាខាងត្បូង (South Dakota) បេក្ខជនម្នាក់បានកៀងគរការរួមចំណែកហិរញ្ញវត្ថុយ៉ាងច្រើនពីសហគមន៍អាមេរិកដើមកំណើតប៉ាគីស្ថាន និងបេក្ខជនម្នាក់ទៀតទទួលបានយ៉ាងច្រើនពីសហគមន៍អាមេរិកដើមកំណើតឥណ្ឌាដែលជាគូប្រកួតប្រជែង។ ប៉ុន្តែថាតើប្រទេសបរទេសមានជនជាតិរបស់ខ្លួនច្រើនឬតិច ជាពលរដ្ឋសម្រាប់បោះឆ្នោតនៅក្នុងប្រទេសផ្សេងទៀត ឬអត់ វាអាចបញ្ចុះបញ្ចូលរដ្ឋាភិបាលរបស់ប្រទេសនោះ។

រូបថត *នាយករដ្ឋមន្ត្រីអ៊ីស្រាអែល ណេតាន់យ៉ាហ៊ូ ថ្លែងសុន្ទរកថាទៅកាន់សភាអាមេរិក*

រដ្ឋាភិបាលបែកបាក់សាមគ្គី

គោលនយោបាយបរទេសត្រូវរងផលប៉ះពាល់ដោយកម្លាំងអូសទាញនិងរុញច្រានរបស់តួអង្គក្នុងស្រុកផ្សេងៗគ្នា។ ស្ថាប័ននីតិប្បញ្ញត្តិឆ្លើយតបទៅនឹងក្រុមទាំងនេះ ក្រុមអ្នកបោះឆ្នោត អ្នកបញ្ចុះបញ្ចូល និងប្រព័ន្ធផ្សព្វផ្សាយ។ នៅទីនេះ នាយករដ្ឋមន្ត្រីអ៊ីស្រាអែល បេនយ៉ាមីន ណេតាន់យ៉ាហ៊ូ (Benjamin Netanyahu) ផ្តល់សុន្ទរកថាដ៏ចម្រូងចម្រាសមួយ ទៅកាន់សម័យប្រជុំរួមនៃសភាអាមេរិក ក្នុងឆ្នាំ ២០១៥។ ណេតាន់យ៉ាហ៊ូមិនត្រូវបានអញ្ជើញដោយលោកប្រធានាធិបតីអូបាម៉ាទេ ប៉ុន្តែដោយសមាជិកសភាបក្សសាធារណរដ្ឋ ដែលបង្កឱ្យមានភាពតានតឹងរវាងសហរដ្ឋអាមេរិក និងអ៊ីស្រាអែល (សូមមើលឧទាហរណ៍បន្ថែម ស្តីពីការស្វែងរកផលប្រយោជន៍រួម ផងដែរ)

ច្បាស់ណាស់ ក្រុមតំណាងផលប្រយោជន៍មានគោលដៅនិងផលប្រយោជន៍ ដែលអាចឬមិនអាចស្របគ្នាជាមួយនឹងផលប្រយោជន៍របស់ជាតិទាំងមូល(ប្រសិនបើពិតជាផលប្រយោជន៍បែបនេះ អាចត្រូវបានកំណត់អត្តសញ្ញាណមែន)។ ដូចគ្នានឹងករណីភ្នាក់ងារការិយាធិបតេយ្យ អ្នកខ្លះជជែកដេញដោលអំពីទស្សនៈដែលថារដ្ឋជាតួអង្គឯកភូត។ អ្នកការពារនយោបាយក្រុមតំណាងផលប្រយោជន៍បានអះអាងថា ក្រុមតំណាងផលប្រយោជន៍នីមួយៗ មានទំនោរឮញាននិងអូសទាញទិសដៅផ្ទុយគ្នា ដោយការសម្រេចចិត្តចុងក្រោយជាទូទៅ ឆ្លុះបញ្ចាំងពីផលប្រយោជន៍របស់សង្គមទាំងមូល។ ប៉ុន្តែ បើយោងទៅតាម*ទ្រឹស្តីម៉ាក្សនិយម* ក្នុងទំនាក់ទំនងអន្តរជាតិ ក្រុមដែលមានឥទ្ធិពលក្នុងស្រុកដ៏សំខាន់ៗលើគោលនយោបាយការបរទេសក្នុងបណ្តាប្រទេសមូលធននិយម គឺជាម្ចាស់អាជីវកម្មធំៗដែលមានសម្បត្តិស្តុកស្តម្ភ។ ជាឧទាហរណ៍ ចក្រពត្តិនិយមអ៊ឺរ៉ុបបានផ្តល់ផលប្រយោជន៍ដល់ធនាគារ និងអាជីវកម្មធំៗ ដែលរកបានប្រាក់ចំណេញយ៉ាងច្រើនពីការកេងប្រវ័ញ្ចកម្លាំងពលកម្មនិងធនធានថោក ក្នុងអាណានិគមក្រៅប្រទេស។ នេះជាទស្សនៈផ្លូវការ (បើទោះជាមិនអាចប្រតិបត្តិបានគ្រប់ពេល) រដ្ឋាភិបាលចិនចំពោះបណ្តារដ្ឋឧស្សាហូបនីយកម្មលោកខាងលិច។ ក្នុងកំឡុងសង្គ្រាមត្រជាក់ អ្នកម៉ាក្សស៊ីសនិយមបានប្រកែកថា គោលនយោបាយការបរទេសរបស់លោកខាងលិច ត្រូវបានជំរុញដោយការជម្រុញកត្តាផលចំណេញរបស់ក្រុមឧស្សាហកម្មផលិតសព្វាវុធ។

៤.២.៣. ក្រុមឧស្សាហកម្មយោធា

ក្រុមឧស្សាហកម្មយោធា(military-industrial complex) សំដៅលើបណ្តាញទំនាក់ទំនងដ៏ធំ រវាងទីភ្នាក់ងាររដ្ឋាភិបាល សាជីវកម្មឧស្សាហកម្ម និងវិទ្យាស្ថានស្រាវជ្រាវជាច្រើន ដែលធ្វើការរួមគ្នាដើម្បីផ្តត់ផ្គង់កងកម្លាំងយោធារបស់ប្រទេសណាមួយ។ ក្រុមឧស្សាហកម្មយោធា គឺជាការឆ្លើយតបទៅនឹងកំណើនសារៈសំខាន់នៃបច្ចេកវិទ្យា (អាវុធនុយក្លេអ៊ែរ គ្រឿងអេឡិចត្រូនិក និងគ្រឿងផ្សេងៗទៀត) និងផ្នែកភស្តុភារ នៅក្នុងផែនការយោធាសម័យសង្គ្រាមត្រជាក់។ ដោយសារតែឥទ្ធិពលនយោបាយក្នុងស្រុករបស់តួអង្គទាំងអស់នេះ ក្រុមឧស្សាហកម្មយោធាមានឥទ្ធិពលខ្លាំងក្លាលើគោលនយោបាយការបរទេស ទាំងនៅក្នុងសហរដ្ឋអាមេរិក និងសហភាពសូវៀត ក្នុងអំឡុងសង្គ្រាមត្រជាក់។

រដ្ឋដែលមានសង្គ្រាម បានប្រើប្រាស់កម្លាំងសេដ្ឋកិច្ច និងបច្ចេកវិទ្យារបស់ពួកគេ អស់រយៈពេលជាយូរសម្រាប់យុទ្ធនាការសង្គ្រាមរបស់ខ្លួន។ ប៉ុន្តែ ក្នុងអំឡុងសង្គ្រាមត្រជាក់ លទ្ធកម្មយោធាបានកើតឡើង ក្នុងទ្រង់ទ្រាយធំ នៅក្នុង«ពេលសន្តិភាព» ខណៈដែលប្រទេសមហាអំណាចបានប្រជែងគ្នា ដើម្បីបង្កើតសព្វាវុធដែលមានបច្ចេកវិទ្យាខ្ពស់ថ្មីៗ។ ការប្រណាំងប្រជែងនេះបានបង្កើតតួនាទីពិសេសមួយសម្រាប់អ្នកវិទ្យាសាស្ត្រ និងវិស្វករ បន្ថែមពីលើតួនាទីប្រពៃណីរបស់ក្រុមឧស្សាហកម្ម ដែលផលិតសម្ភារសង្គ្រាម។ ជាការឆ្លើយតបទៅនឹងការបាញ់បង្ហោះផ្កាយរណបសូវៀត*ស្ពុតនីក* (Sputnik) ក្នុងឆ្នាំ ១៩៥៧ សហរដ្ឋអាមេរិកបានបង្កើនការចំណាយលើការស្រាវជ្រាវនិងការអភិវឌ្ឍន៍ និងបានបង្កើតកម្មវិធីអប់រំវិទ្យាសាស្ត្រថ្មីៗ។ នៅឆ្នាំ ១៩៦១ លោកប្រធានាធិបតី ដ្វាយ អៃសិនហៅវ័រ (Dwight Eisenhower) បានព្រមាន នៅក្នុងសុន្ទរកថាចុងក្រោយ របស់គាត់ថា ក្រុមឧស្សាហកម្មយោធា (ពាក្យពេចន៍ដែលគាត់បានបង្កើតផ្ទាល់) កំពុងទទួលបាន «ឥទ្ធិពលគ្មានព្រំដែនកំណត់» នៅក្នុងសង្គមសហរដ្ឋអាមេរិក ហើយការធ្វើយោធានីយកម្មអាចបំផ្លាញលទ្ធិប្រជាធិបតេយ្យនៅក្នុងសហរដ្ឋអាមេរិក។ ទំហំនៃក្រុមឧស្សាហកម្មទាំងនេះបានផ្តល់អោយពួកគេនូវឥទ្ធិពលនយោបាយខ្លាំង

ជាងឥទ្ធិពលដែលប្រជាពលរដ្ឋសាមញ្ញទាំងអស់អាចប្រមូលផ្តុំបាន។ ប៉ុន្តែ ផលប្រយោជន៍របស់ពួកគេក្នុងការប្រណាំងប្រជែងសព្វាវុធផ្ទុយពីផលប្រយោជន៍សន្តិភាពរបស់ប្រជាពលរដ្ឋសាមញ្ញ។

ក្រុមឧស្សាហកម្មយោធានេះគ្របដណ្តប់លើក្រុមអ្នកបោះឆ្នោតជាច្រើន ដែលក្រុមនីមួយៗមានផលប្រយោជន៍លើការចំណាយយោធា។ *សាជីវកម្ម* ដែលផលិតទំនិញ ឬសម្ភារៈផ្សេងៗ សម្រាប់វិស័យយោធាទទួលបានប្រាក់ចំណេញពីការដេញថ្លៃគំរោងនានារបស់រដ្ឋាភិបាល។ ដូចគ្នាផងដែរ *មន្ត្រី*យោធាអាចត្រូវបានតម្លើងឋានន្តរស័ក្តិនិងផលប្រយោជន៍ផ្សេងៗ ជាមួយនឹងការកសាងអាណាចក្រការិយាធិបតេយ្យជុំវិញប្រព័ន្ធសព្វាវុធថ្មី។ សាកលវិទ្យាល័យ និងវិទ្យាស្ថានវិទ្យាសាស្ត្រក៏ទទួលបានផលប្រយោជន៍ ដោយការទទួលបានកិច្ចសន្យាស្រាវជ្រាវវិស័យយោធា ដែលជាប្រភពមូលនិធិដ៏សំខាន់សម្រាប់អ្នកវិទ្យាសាស្ត្រ នៅក្នុងប្រទេសរុស្ស៊ី និងសហរដ្ឋអាមេរិក។

អ្នកម៉ៅការបន្ត និងអ្នកផ្គត់ផ្គង់គ្រឿងបន្លាស់ សម្រាប់គម្រោងសព្វាវុធធំៗរបស់សហរដ្ឋអាមេរិកជាធម្មតា មាននៅរាយប៉ាយជុំវិញរដ្ឋនិងមណ្ឌលបោះឆ្នោតសភាជាច្រើន ដូច្នេះពលរដ្ឋនិងអ្នកនយោបាយក្នុងតំបន់ ត្រូវដាក់បញ្ចូលក្នុងបញ្ជីនៃក្រុមអ្នកបោះឆ្នោត ដែលទទួលបានអត្ថប្រយោជន៍ពីការចំណាយយោធា។ ការផ្តល់មូលនិធិដំបូងសម្រាប់គំនិតផ្តួចផ្តើមការពារជាយុទ្ធសាស្ត្រ (ឬ សង្គ្រាមផ្កាយ) ត្រូវបានផ្តល់ទៅអោយមែកធាងនៃសេវាយោធានីមួយៗ, ក្រសួងថាមពល អង្គការណាសា និងអ្នកម៉ៅការឯកជនរាប់រយនាក់។ ថ្មីៗនេះ បាតុភូតស្រដៀងគ្នាមួយបានលេចឡើង នៅក្នុងសហគមន៍អឺរ៉ុប ដែលកម្មវិធីអភិវឌ្ឍន៍អាវុធត្រូវបានចែកចាយទៅកាន់រដ្ឋអឺរ៉ុបមួយចំនួន។ យន្តហោះចម្បាំងថ្មីទំនងជាមិនត្រូវបានលុបចោលនោះទេ ប្រសិនបើប្រទេសមួយទទួលបានកិច្ចសន្យាសម្រាប់កសាងស្លាប ប្រទេសមួយទៀតសម្រាប់កសាងគ្រឿងម៉ាស៊ីន និងប្រទេសផ្សេងទៀតសម្រាប់ផ្នែកដទៃទៀត ជាដើម។

នាយកប្រតិបត្តិនៅក្នុងឧស្សាហកម្មយោធា ដែលយល់ច្បាស់អំពីឧស្សាហកម្មរបស់ពួកគេ ជារឿយៗត្រូវបានតែងតាំងជាមន្ត្រីរដ្ឋាភិបាល ដែលទទួលខុសត្រូវចំពោះការសម្រេចចិត្តលើលទ្ធកម្មផ្នែកយោធា ហើយក្រោយមក វិលត្រឡប់ទៅធ្វើការក្នុងក្រុមហ៊ុនរបស់ពួកគេវិញ។ នេះជាការអនុវត្តមួយដែលត្រូវបានគេហៅថា *ទ្វារវិលជុំ*។ នៅក្នុងប្រទេសប្រកាន់លទ្ធិប្រជាធិបតេយ្យ ក្រុមឧស្សាហកម្មយោធាក៏មានឥទ្ធិពលខ្លាំងក្លាលើមតិសាធារណៈ តាមរយៈការផ្សាយពាណិជ្ជកម្ម ដែលភ្ជាប់ផលិតផលរបស់ពួកគេទៅនឹងប្រធានបទស្នេហាជាតិ។ ក្រុមឧស្សាហកម្មយោធាសហរដ្ឋអាមេរិកក៏ផ្តល់ការឧបត្ថម្ភហិរញ្ញវត្ថុជាច្រើនសន្ធឹកសន្ធាប់ ក្នុងយុទ្ធនាការបោះឆ្នោត ដល់អ្នកនយោបាយជាតិ ដែលបោះឆ្នោតអនុម័តកញ្ចប់ថវិកាយោធា ហើយ ពេលខ្លះក្រុមឧស្សាហកម្មទាំងនេះ ផ្តល់សំណូកដល់មន្ត្រីមន្ទីរបញ្ចកោណ ផងដែរ។

៤.២.៤. **មតិសាធារណៈ**

តួអង្គក្នុងស្រុកជាច្រើនព្យាយាមបញ្ចេញឥទ្ធិពលលើ**មតិសាធារណៈ** ដែលជាទស្សនៈនានារបស់ពលរដ្ឋនៃរដ្ឋណាមួយ លើបញ្ហាគោលនយោបាយការបរទេស (សូមមើលឧទាហរណ៍បន្ថែមស្តីពី មតិសាធារណៈនិងទំនាក់ទំនងអន្តរជាតិនៅផ្នែកខាងចុងមេរៀននីមួយៗ)។ មតិសាធារណៈមានឥទ្ធិពលកាន់តែខ្លាំងលើគោលនយោបាយការបរទេស ក្នុងប្រទេសប្រកាន់លទ្ធិប្រជាធិបតេយ្យ ជាងនៅក្នុងរដ្ឋាភិបាលផ្តាច់ការ។ ប៉ុន្តែ សូម្បីតែមេដឹកនាំផ្តាច់ការក៏ត្រូវយកចិត្តទុកដាក់ចំពោះអ្វីដែលប្រជាពលរដ្ឋគិតផងដែរ។ គ្មានរដ្ឋាភិបាលណាមួយអាចគ្រប់គ្រងដោយកម្លាំងបង្ខំតែម្នាក់ឯងបានទេ៖ វាត្រូវការធម្មានុរូបភាព(ភាពស្របច្បាប់)ដើម្បីបន្តដឹកនាំ។

វាត្រូវតែបញ្ចុះបញ្ចូលប្រជាពលរដ្ឋអោយទទួលយក (បើមិនចូលចិត្ត) គោលនយោបាយរបស់ខ្លួន ពីព្រោះនៅទីបញ្ចប់ គោលនយោបាយត្រូវបានអនុវត្ត ដោយប្រជាជនសាមញ្ញ ដូចជា ទាហាន កម្មករ និងមន្ត្រីការិយាធិបតេយ្យ។

ដោយសារតែតម្រូវការការគាំទ្រពីសាធារណៈជន សូម្បីតែរដ្ឋាភិបាលផ្តាច់ការក៏ ខិតខំប្រឹងប្រែងយ៉ាងខ្លាំងលើ*ការឃោសនា* (propaganda) (ការផ្សព្វផ្សាយជាសាធារណៈនូវខ្សែបន្ទាត់នយោបាយផ្លូវការរបស់ពួកគេ) ដើម្បីទទួលបានការគាំទ្រចំពោះគោលនយោបាយបរទេស។ រដ្ឋនានាប្រើប្រាស់ទូរទស្សន៍ កាសែត និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានផ្សេងទៀត នៅក្នុងកិច្ចខិតខំប្រឹងប្រែងបែបនេះ។ នៅក្នុងប្រទេសជាច្រើន រដ្ឋកាន់កាប់ឬគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយធំៗ ដូចជាទូរទស្សន៍ និងកាសែត ដោយគ្រប់គ្រងលំហូរព័ត៌មានចេញចូលសម្រាប់ប្រជាពលរដ្ឋរបស់ខ្លួន។ ទោះយ៉ាងណាក៏ដោយ បច្ចេកវិទ្យាព័ត៌មានថ្មីដែលមានបណ្តាញជាច្រើន បានធ្វើអោយរដ្ឋពិបាកគ្រប់គ្រងលំហូរព័ត៌មាន។

អ្នកកាសែតមានមុខងារជាអ្នកការពារលំហូរព័ត៌មាន ដែលបញ្ជូនពីឥស្សរជននយោបាយបរទេសទៅកាន់សាធារណៈជន។ ប្រព័ន្ធផ្សព្វផ្សាយនិងរដ្ឋាភិបាល ជារឿយៗ មានភាពតានតឹងនឹងគ្នា ពេលខ្លះលេចចេញជាជម្លោះ ដោយសារតែតួនាទីប្រពៃណីរបស់សារព័ត៌មានក្នុងឋានៈជាអ្នកឃ្លាំមើលនិងរិះគន់សកម្មភាពនិងអំណាចរបស់រដ្ឋាភិបាល។ ប្រព័ន្ធផ្សព្វផ្សាយព្យាយាមលាតត្រដាង និងផ្សព្វផ្សាយពីអ្វីដែលរដ្ឋាភិបាលចង់លាក់បាំង។ អ្នកធ្វើការសម្រេចចិត្តគោលនយោបាយការបរទេស ក៏ពឹងផ្អែកលើប្រព័ន្ធផ្សព្វផ្សាយដើម្បីទទួលបានព័ត៌មានអំពីកិច្ចការបរទេសផងដែរ។

ប៉ុន្តែ ប្រព័ន្ធផ្សព្វផ្សាយក៏ពឹងផ្អែកលើរដ្ឋាភិបាលដើម្បីទទួលបានព័ត៌មាន។ ទំហំនិងធនធាននៃការិយាធិបតេយ្យគោលនយោបាយការបរទេស ធ្វើអោយទំហំនិងធនធានរបស់អ្នកសារព័ត៌មានហាក់រួមតូច។ គុណសម្បត្តិទាំងនេះអនុញ្ញាតអោយរដ្ឋាភិបាលនូវអំណាចខ្លាំងក្លា ក្នុងការប្រើប្រាស់ឬ*កេងចំណេញ*លើអ្នកសារព័ត៌មាន ដោយផ្តល់បំណែកព័ត៌មានណាមួយដល់ពួកគេ ដើម្បីបង្កើតព័ត៌មាន និងមានឥទ្ធិពលលើមតិសាធារណៈ។ អ្នកធ្វើសេចក្តីសម្រេចចិត្តរបស់រដ្ឋាភិបាលអាចបង្កើតរឿងរំជើបរំជួល ដ៏គួរអោយភ្ញាក់ផ្អើលនៅក្នុងទំនាក់ទំនងបរទេស តាមរយៈកិច្ចប្រជុំកំពូល វិបត្តិ សកម្មភាពនានា ជាដើម។ មន្ត្រីការិយាល័យក៏អាចបញ្ចេញព័ត៌មានសម្ងាត់អោយ*រំបែកធ្លាយ*ទៅកាន់សារព័ត៌មានផងដែរ ដើម្បីគាំទ្រទស្សនៈផ្ទាល់ខ្លួនរបស់ពួកគេ និងយកឈ្នះក្នុងសមរភូមិការិយាធិបតេយ្យ។ ទីបំផុត យោធា និងសារព័ត៌មាន មានការខ្វែងគំនិតគ្នាជារឿយៗ អំពីការចូលយកព័ត៌មាននៅក្នុងប្រតិបត្តិការយោធា ប៉ុន្តែ ភាគីទាំងពីរទទួលបានផលចំណេញពីការបើកចំហរអោយអ្នកកាសែត «បង្កប់»ជាមួយកងកម្លាំងសហរដ្ឋអាមេរិក នៅអ៊ីរ៉ាក់ក្នុងឆ្នាំ ២០០៣។

នៅក្នុងប្រទេសប្រកាន់ប្រជាធិបតេយ្យ ដែលរដ្ឋាភិបាលត្រូវឆ្លងកាត់ការបោះឆ្នោតដោយជោគជ័យ សង្គ្រាមដែលមិនមានប្រជាប្រិយភាព អាចបង្ខំមេដឹកនាំឬគណបក្សមួយធ្លាក់ចេញពីតំណែង ដូចដែលបានកើតឡើងចំពោះប្រធានាធិបតីសហរដ្ឋអាមេរិក លោក លីនដុន ចនសុន (Lyndon Johnson) ក្នុងឆ្នាំ ១៩៦៨ កំឡុងសង្គ្រាមវៀតណាម។ ផ្ទុយទៅវិញសង្គ្រាមដ៏ពេញនិយមអាចជួយធានាអាណត្តិថ្មីមួយទៀតសម្រាប់រដ្ឋាភិបាលបន្តកាន់អំណាច ដូចដែលបានកើតឡើងចំពោះលោកស្រី ម៉ាហ្គារ៉ែត ថាច់ឈ័រ (Margaret Thatcher) ក្នុងប្រទេសអង់គ្លេស បន្ទាប់ពីសង្គ្រាមកោះហ្វកឡែន (Falkland) ឆ្នាំ ១៩៨២។ ឥទ្ធិពលដ៏ខ្លាំងក្លាលើមតិសាធារណៈ គឺ ឈុតឆាកដែលត្រូវបានចាក់បញ្ចាំងនៅលើកញ្ចក់ទូរទស្សន៍៖ ទាហានអាមេរិក

ត្រូវបានបញ្ជូនទៅប្រទេសសូម៉ាលីដើម្បីជួយក្នុងកិច្ចខិតខំប្រឹងប្រែងជួយសង្គ្រោះ ក្នុងឆ្នាំ ១៩៩២ បន្ទាប់ពីព័ត៌មានទូរទស្សន៍បានបង្ហាញលទ្ធផលដ៏គួរអោយសង្វេគនៃសង្គ្រាមស៊ីវិល និងគ្រោះទុរ្ភិក្សនៅទីនោះ។ ប៉ុន្តែបន្ទាប់ពីព័ត៌មានទូរទស្សន៍ បានបង្ហាញសាកសពទាហានអាមេរិកម្នាក់ ដែលត្រូវបានសមាជិកនៃពួកឧទ្ទាមសូម៉ាលី អូសតាមដងផ្លូវ ក្រោយការបាញ់ប្រហារយ៉ាងសាហាវ ដែលបានសម្លាប់ទាហានអាមេរិក ១៨ នាក់ មតិសាធារណៈបានផ្លាស់ប្តូរយ៉ាងឆាប់រហ័ស ដោយងាកមកប្រឆាំងនឹងប្រតិបត្តិការសូម៉ាលី។ ក្នុងអំឡុងពេលសង្គ្រាមនៅបូស្នៀ មន្ត្រីនៅក្នុងក្រសួងការបរទេសសហរដ្ឋអាមេរិក បាននិយាយជាលក្ខណៈឯកជនថាគោលដៅចម្បងនៃគោលនយោបាយរបស់សហរដ្ឋអាមេរិកជារឿយៗ គឺគ្រាន់តែដើម្បីទប់កុំជម្លោះនៅទីនោះលេចចេញលើទំព័រមុខរបស់កាសែតព័ត៌មានរបស់សហរដ្ឋអាមេរិក (ជាគោលដៅដែលសម្រេចបាន ដូចដែលវាបានស្តែងចេញមក)។

ជួនកាល បញ្ហាគោលនយោបាយការបរទេសមួយត្រូវបានសម្រេច ដោយផ្ទាល់ ដោយការបោះឆ្នោតប្រជាមតិរបស់ពលរដ្ឋទាំងមូល (សហរដ្ឋអាមេរិកខ្វះទំនៀមទម្លាប់បែបនេះ ដែលប្រជាប្រិយខ្លាំងនៅប្រទេសផ្សេងទៀត ដូចជា ស្វីស និងដាណឺម៉ាក ជាដើម)។ នៅក្នុងឆ្នាំ ២០០៥ ការធ្វើប្រជាមតិ នៅប្រទេសបារាំង និងប្រទេសហូឡង់បានច្រានចោលរដ្ឋធម្មនុញ្ញដែលបានស្នើឡើងសម្រាប់សហភាពអឺរ៉ុប ទោះបីជាមានការគាំទ្រពីមេដឹកនាំនយោបាយសំខាន់ៗក៏ដោយ។ នៅឆ្នាំ ២០១៦ ចក្រភពអង់គ្លេសបានបោះឆ្នោតប្រជាមតិមួយដើម្បីសំរេចថាតើប្រទេសខ្លួននឹងចាកចេញពីសហភាពអឺរ៉ុប ឬក៏បន្តនៅទៀត។ ទោះបីជាមានឃុទ្ធនាការរបស់នាយករដ្ឋមន្ត្រីចក្រភពអង់គ្លេស នាពេលនោះ អោយបន្តនៅក្នុងសហភាពអឺរ៉ុបក៏ដោយ ក៏អ្នកបោះឆ្នោតដោយសំឡេងភាគច្រើន (៥២% ទល់នឹង ៤៨%) បានសម្រេចចិត្តចាកចេញពីសហភាពអឺរ៉ុប។ នេះធ្វើអោយអ្នកជំនាញមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ហើយបាននាំអោយមានបញ្ហាអស្ថិរភាពសេដ្ឋកិច្ចរយៈពេលខ្លីមួយចំនួនផងដែរ នៅពេលដែលអាជីវកម្មនានាបានប៉ុនប៉ងសម្របខ្លួនតាមសច្ចៈភាពថ្មីនៃចក្រភពអង់គ្លេសនៅខាងក្រៅសហភាពអឺរ៉ុប។

សូម្បីនៅក្នុងប្រទេសប្រកាន់លទ្ធិប្រជាធិបតេយ្យបើកចំហរបំផុត ក៏រដ្ឋមិនចេះតែ*ឆ្លើយតប*ទៅនឹងមតិសាធារណៈនោះទេ។ អ្នកធ្វើការសម្រេចចិត្តរីករាយនឹងស្វ័យភាពក្នុងកម្រិតណាមួយ ដើម្បីធ្វើសេចក្តីសម្រេចចិត្តតាមគំនិតរបស់ខ្លួន ហើយពួកគេត្រូវបានទាញចូលក្នុងទិសដៅផ្សេងៗគ្នា ដោយការិយាធិបតេយ្យ និងក្រុមតំណាងផលប្រយោជន៍ ដែលទស្សនៈរបស់ពួកគេ ជារឿយៗ ផ្ទុយនឹងទិសដៅគោលនយោបាយដែលមតិសាធារណៈភាគច្រើនពេញចិត្ត។ លើសពីនេះ មតិសាធារណៈ កម្រមូលមតិគ្នាលើគោលនយោបាយណាមួយឡើយ ហើយការស្ទាបស្ទង់មតិដ៏ស្មុគ្រស្មាញអាចបង្ហាញថា ចំនួនប្រជាជនមួយផ្នែកណាមួយ (តំបន់នៃប្រទេស ភេទ ក្រុមដែលកម្រិតប្រាក់ចំណូលប្រហែលគ្នា ពូជសាសន៍ ។ល។) ជារឿយៗ មាន ការយល់ឃើញខុសៗគ្នាចំពោះបញ្ហាគោលនយោបាយការបរទេស។ ដូច្នេះ អ្នកនយោបាយអាចនឹងឆ្លើយតបនឹងមតិរបស់ក្រុមអ្នកបោះឆ្នោតណាមួយ ជាជាងក្រុមប្រជាជនទាំងមូល។ មតិសាធារណៈប្រែប្រួលគួរអោយកត់សម្គាល់តាមពេលវេលា លើបញ្ហាគោលនយោបាយការបរទេសជាច្រើន។ រដ្ឋប្រើការឃោសនា (ក្នុងរបបផ្តាច់ការ) ឬព្យាយាម*រក៏បរញ្ជោត*ប្រព័ន្ធផ្សព្វផ្សាយ (ក្នុងលទ្ធិប្រជាធិបតេយ្យ) ដើម្បីរក្សាមតិសាធារណៈមិនអោយងាករេចេញពីគោលនយោបាយរដ្ឋឆ្ងាយពេក។

នៅក្នុងប្រទេសប្រកាន់លទ្ធិប្រជាធិបតេយ្យជាទូទៅមតិសាធារណៈមានឥទ្ធិពលលើគោលនយោបាយបរទេសតិចជាងឥទ្ធិពលលើគោលនយោបាយក្នុងស្រុក។ ជាប្រពៃណី មេដឹកនាំជាតិនានាមានលំហរសេរីភាពបន្ថែម សម្រាប់ធ្វើការសម្រេចចិត្ត ក្នុងវិស័យអន្តរជាតិ។ នេះកើតចេញពីតម្រូវការពិសេសរបស់រដ្ឋ ក្នុងការធ្វើសកម្មភាពដោយមធ្យោបាយរួមសម្លេងតែមួយ ដើម្បីដំណើរការប្រកបដោយប្រសិទ្ធភាព ក្នុងប្រព័ន្ធអន្តរជាតិ និងកើតចេញពីប្រពៃណីនៃការរក្សាការសម្ងាត់និងការទូត ដែលដកទំនាក់ទំនងអន្តរជាតិចេញពីវិសាលភាពនយោបាយក្នុងស្រុកធម្មតា។ ទោះបីជាយ៉ាងណាក៏ដោយ ក្នុងករណីប្រទេសជប៉ុន មតិសាធារណៈគឺជាកម្លាំងនយោបាយដ៏សំខាន់មួយ ដែលរារាំងការចំណាយផ្នែកយោធារបស់រដ្ឋាភិបាល រារាំងការប្តេជ្ញាចិត្តប្រើប្រាស់កងកម្លាំងយោធាហួសពីព្រំដែនរបស់ប្រទេសជប៉ុន និងជាពិសេសរារាំងការអភិវឌ្ឍន៍អាវុធនុយក្លេអ៊ែរ (ដែលស្ថិតក្នុងរង្វង់សមត្ថភាពបច្ចេកទេសរបស់ប្រទេសជប៉ុន)។ គណបក្សកាន់អំណាច(ជប៉ុន) ដែលស្ថិតនៅក្រោមសម្ពាធសហរដ្ឋអាមេរិកដើម្បីចែករំលែកបន្ទុកចំណាយការពារជាតិនិងទទួលខុសត្រូវរបស់ខ្លួន ក្នុងនាមជាប្រទេសមហាអំណាចមួយ បានជំរុញបង្កើនខ្នងចំណាយយោធារបស់ជប៉ុន បន្តិចម្តងៗ និងអនុញ្ញាតអោយកងកម្លាំងយោធាជប៉ុនពង្រីកតួនាទីរបស់ពួកគេ ដោយសមរម្យ (ក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ ដើម្បីល្បាតផ្លូវសមុទ្រអាស៊ីដែលមានសារៈសំខាន់សម្រាប់ពាណិជ្ជកម្មជប៉ុន, និងនៅទសវត្សរ៍ឆ្នាំ ១៩៩០ ដើម្បីចូលរួមក្នុងប្រតិបត្តិការរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ)។ ម្តងហើយម្តងទៀត មតិសាធារណៈដ៏ខ្លាំងក្លាប្រឆាំងនឹងយោធា បានធ្វើអោយកិច្ចខិតខំប្រឹងប្រែងទាំងនេះត្រូវយឺតយ៉ាវ ឬបដិសេធចោល។ នៅប្រទេសជប៉ុន ប្រជាជនចងចាំពីផលវិបាកដ៏អាក្រក់នៃរបបយោធានិយម ក្នុងទសវត្សរ៍ឆ្នាំ ១៩៣០ និងសង្គ្រាមលោកលើកទី ២ ដែលឈានដល់ការទម្លាក់គ្រាប់បែកនុយក្លេអ៊ែរនៅឆ្នាំ ១៩៤៥។ ដូច្នេះ ពួកគេមានការព្រួយបារម្ភអំពីការកើនឡើងនៃទំហំឬតួនាទីរបស់កងកម្លាំងយោធា និងប្តេជ្ញាចិត្តប្រឆាំងនឹងការអភិវឌ្ឍកម្មវិធីនុយក្លេអ៊ែរនៅក្នុងប្រទេសជប៉ុន។ ក្នុងករណីនេះ មតិសាធារណៈរារាំងការប្រព្រឹត្តទៅនៃគោលនយោបាយការបរទេសរបស់រដ្ឋ ហើយបានបន្ថយល្បឿននៃការផ្លាស់ប្តូរ។

*សាធារណជនដែលយកចិត្តទុកដាក់*ក្នុងប្រទេសប្រកាន់លទ្ធិប្រជាធិបតេយ្យណាមួយ គឺជាក្រុមភាគតិចនៃប្រជាជនទាំងមូល ដែលតាមដានព័ត៌មានអំពីបញ្ហាអន្តរជាតិ យ៉ាងយកចិត្តទុកដាក់។ សាធារណជនក្នុងផ្នែកនេះប្រែប្រួល ពីបញ្ហាមួយទៅបញ្ហាមួយទៀត ប៉ុន្តែ ក៏មានក្រុមស្នូលក្នុងចំណោមក្រុមមនុស្សដែលយកចិត្តទុកដាក់អំពីកិច្ចការបរទេស ជាទូទៅ និងតាមដានបញ្ហាជាច្រើនផ្សេងទៀត យ៉ាងជិតស្និទ្ធ។ សមាជិកសកម្មបំផុតក្នុងចំណោមសាធារណជនដែលយកចិត្តទុកដាក់លើកិច្ចការបរទេស បង្កើតបានជាក្រុម*ឥស្សរជន*គោលនយោបាយការបរទេស (ក្រុមមនុស្សដែលមានអំណាចនិងឥទ្ធិពលជះឥទ្ធិពលលើគោលនយោបាយការបរទេស)។ ឥស្សរជននេះរាប់បញ្ចូលទាំងមនុស្សនៅក្នុងរដ្ឋាភិបាល ក៏ដូចជាអ្នកខាងក្រៅ ដូចជា អ្នកជំនួញ អ្នកកាសែត ក្រុមអ្នកបញ្ចុះបញ្ចូល និងសាស្ត្រាចារ្យវិទ្យាសាស្ត្រនយោបាយ។ ការស្ទង់មតិសាធារណៈបង្ហាញថា មតិឥស្សរជន ជួនកាល (ប៉ុន្តែមិនគ្រប់ពេលទេ) មានភាពខុសប្លែកគ្នាយ៉ាងខ្លាំង ពីប្រជាជនទូទៅ និងជួនកាលខុសពីមតិរបស់រដ្ឋាភិបាលផងដែរ។


ពេលខ្លះ រដ្ឋាភិបាលបានអនុម័តគោលនយោបាយបរទេសសម្រាប់គោលបំណងជាក់លាក់ក្នុងការកៀងគរការគាំទ្រពីមតិសាធារណៈ ដូច្នេះហើយ អាចនឹងទទួលបានធម្មានុរូបភាពក្នុងស្រុក។ នេះគឺជាករណីពិត នៅពេលដែលរដ្ឋាភិបាលធ្វើសង្គ្រាម ឬអន្តរាគមន៍យោធាបរទេស នៅពេលមានការលំបាកក្នុងស្រុក ដើម្បី

បង្វែរការយកចិត្តទុកដាក់ និងទទួលបានការគាំទ្រពីសាធារណៈជន ដោយទាញយកផលប្រយោជន៍ពីរោគសញ្ញា«ប្រមូលផ្តុំគ្នាជុំវិញទង់ជាតិ» (“rally ‘round the flag” syndrome) (ការកើនឡើងនៃការគាំទ្ររបស់សាធារណជនចំពោះមេដឹកនាំរដ្ឋាភិបាល ក្នុងអំឡុងពេលសង្គ្រាម យ៉ាងហោចណាស់ ក្នុងមួយរយៈពេលខ្លី)។ ប្រជាពលរដ្ឋដែលបាននឹងកំពុងរិះគន់គោលនយោបាយរបស់រដ្ឋាភិបាល លើវិស័យអប់រំ ឬការថែទាំសុខភាព តែងតែបញ្ឈប់ការរិះគន់ នៅពេលរដ្ឋាភិបាលកំពុងមានសង្គ្រាម និងនៅពេលទាហានរបស់ប្រទេសជាតិកំពុងប្រឈមមុខការបាត់បង់ជីវិត។ គោលនយោបាយប្រភេទនេះ ជារឿយៗ ត្រូវបានអោយឈ្មោះថា **គោលនយោបាយការបរទេសបង្វែរទិសដៅ**(diversionary foreign policy)។ ជាអកុសល វាតែងតែ ពិបាកក្នុង ការកំណត់ថា តើរដ្ឋមួយប្រកាន់យកគោលនយោបាយការបរទេសដើម្បីបង្វែរចំណាប់អារម្មណ៍សាធារណជន ឬយ៉ាងណា ពីព្រោះមេដឹកនាំនឹងមិនសារភាពថាខ្លួនកំពុងព្យាយាមបង្វែរចំណាប់អារម្មណ៍របស់សាធារណជននោះទេ។

ក្រាហ្វិក ៨.៥ រោគសញ្ញា«ប្រមូលផ្តុំគ្នាជុំវិញទង់ជាតិ»

ការវាយតម្លៃការយល់ព្រមរបស់ប្រធានាធិបតីប៊ូសបង្ហាញពីរោគសញ្ញា «ប្រមូលផ្តុំគ្នាជុំវិញទង់ជាតិ» ដែលក្នុងនោះសង្គ្រាមបង្កឱ្យមានការជំរុញរយៈពេលខ្លីក្នុងការអនុម័តជាសាធារណៈ។

ប្រភព៖ Gallup Poll



ទោះយ៉ាងណាក៏ដោយ សង្គ្រាមដែលអូសបន្លាយយូរពេក ឬបរាជ័យ អាចបង្វែរមតិសាធារណៈអោយប្រឆាំងនឹងរដ្ឋាភិបាលវិញ ហើយអាចឈានដល់ការបះបោររបស់ប្រជាជនដើម្បីផ្តួលរំលំរដ្ឋាភិបាលផងដែរ។ នៅអាហ្សង់ទីន រដ្ឋាភិបាលយោធាក្នុងឆ្នាំ ១៩៨២ បានដឹកនាំប្រទេសនេះចូលក្នុងសង្គ្រាមជាមួយអង់គ្លេសលើប្រជុំកោះហ្វក់ឡែន (Falkland)។ មុនដំបូង ជនជាតិអាហ្សង់ទីនបាន*ប្រមូលផ្តុំគ្នាជុំវិញទង់ជាតិ* ឬរួបរួមគ្នាដើម្បីបុព្វហេតុជាតិ ប៉ុន្តែបន្ទាប់ពីចាញ់សង្គ្រាម ពួកគេបានរួបរួមគ្នាទម្លាក់រដ្ឋាភិបាលយោធាវិញ ហើយពួកគេដាក់រដ្ឋាភិបាលស៊ីវិលថ្មីជំនួស ដែលក្រោយមកកាត់ទោសអតីតមេដឹកនាំយោធាទាំងនោះ។ ក្នុងឆ្នាំ ២០០៦ ប្រជាប្រិយភាពរបស់លោកប្រធានាធិបតី ប៊ូស (Bush) ដែលបានកើនឡើង នៅដើមដំបូងនៃ

សង្គ្រាមអ៊ីរ៉ាក់ បានធ្លាក់ចុះវិញ នៅពេលដែលសង្គ្រាមបានអូសបន្លាយ (សូមមើលក្រាហ្វិក ៤.៥) ហើយអ្នកបោះឆ្នោតបានទម្លាក់គណបក្សសាធារណរដ្ឋរបស់គាត់ចេញពីអំណាច នៅក្នុងសភា។ នៅក្នុងការបោះឆ្នោតឆ្នាំ ២០០៨ គណបក្សរបស់គាត់បានបាត់បង់អំណាចគ្រប់គ្រងព្រឹទ្ធសភា សភា និងតំណែងប្រធានាធិបតីដែលស្ថាប័នទាំងអស់នេះស្ថិតក្រោមអំណាចគ្រប់គ្រងរបស់គណបក្សសាធារណរដ្ឋ នៅដើមដំបូងនៃសង្គ្រាមអ៊ីរ៉ាក់ នៅក្នុងឆ្នាំ ២០០៣។

៤.២.៥. នីតិបញ្ញត្តិ

មធ្យោបាយមួយដែលក្រុមតំណាងផលប្រយោជន៍និងមតិសាធារណៈអាចមានឥទ្ធិពលលើ គឺសភា។ ប្រទេសប្រកាន់លទ្ធិប្រជាធិបតេយ្យមួយចំនួន ដូចជាសហរដ្ឋអាមេរិក មានប្រព័ន្ធប្រធានាធិបតីនិយម ដែលស្ថាប័ននីតិប្បញ្ញត្តិត្រូវបានជ្រើសរើសដោយឡែកពីការបោះឆ្នោតជ្រើសរើសប្រធានាធិបតី (ត្រូវបានគេហៅថាស្ថាប័ន *នីតិប្រតិបត្តិ*)។ នៅក្នុងប្រព័ន្ធទាំងនេះ ស្ថាប័ននីតិប្បញ្ញត្តិដើរតួនាទីផ្ទាល់ក្នុងការបង្កើតគោលនយោបាយការបរទេស តាមរយៈការអនុម័តកញ្ចប់ថវិកា ការគ្រប់គ្រងច្បាប់ការិយាធិបតេយ្យ ការបង្កើតច្បាប់ពាណិជ្ជកម្ម និងសូម្បីតែការគ្រប់គ្រងគោលនយោបាយអន្តោប្រវេសន៍ផងដែរ។ ទោះបីជាប្រមុខស្ថាប័ននីតិប្រតិបត្តិអាចចូលរួមកិច្ចប្រជុំកំពូល និងកិច្ចពិភាក្សាផ្សេងៗទៀតក៏ដោយ ប៉ុន្តែ កិច្ចព្រមព្រៀងណាមួយដែលពួកគេចុះហត្ថលេខាត្រូវតែត្រូវមានការអនុម័តដោយសភាក្នុងស្រុករបស់ពួកគេ។

ទោះបីមានមនុស្សតិចណាស់ដែលអះអាងថា ជាទូទៅ ស្ថាប័ននីតិបញ្ញត្តិក្នុងរបបប្រជាធិបតេយ្យប្រធានាធិបតីនិយមមិនមានឥទ្ធិពលលើគោលនយោបាយការបរទេសក៏ដោយ ការប្រើប្រាស់កម្លាំងយោធាជារឿងដោយឡែកមួយទៀត។ អ្នកខ្លះជំទាស់ថា ស្ថាប័ននីតិប្បញ្ញត្តិ ដូចជាមតិសាធារណៈដែរ ប្រមូលផ្តុំគ្នាជុំវិញទង់ជាតិ ក្នុងអំឡុងពេលមានវិបត្តិអន្តរជាតិ។ ជាឧទាហរណ៍ បីថ្ងៃបន្ទាប់ពីការវាយប្រហារថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ២០០១ សភាសហរដ្ឋអាមេរិកបានបោះឆ្នោតផ្តល់សិទ្ធិអំណាចពេញលេញដល់ប្រធានាធិបតីប៊ូស ដើម្បីបើកសមរភូមិប្រយុទ្ធ នៅប្រទេសអាហ្វហ្គានីស្ថាន។ នៅខែតុលា ឆ្នាំ ២០០២ សភាបានអនុម័តសេចក្តីសម្រេចមួយ ដោយអនុញ្ញាតអោយប្រើប្រាស់កម្លាំង នៅក្នុងប្រទេសអ៊ីរ៉ាក់។ ដូច្នេះហើយ ស្ថាប័ននីតិបញ្ញត្តិកម្រ (ប្រសិនបើធ្លាប់) តតាំងជាមួយនឹងអំណាចនីតិប្រតិបត្តិលើបញ្ហាយោធាសំខាន់។ ករណីលើកលែងដែលលេចធ្លោមួយចំពោះរឿងនេះ បានកើតឡើងនៅក្នុងឆ្នាំ ២០១៥ នៅពេលដែលសមាជិកសភាគណបក្សសាធារណៈរដ្ឋនៅក្នុងសភាសហរដ្ឋអាមេរិក បានទាមទារអោយរដ្ឋបាលលោក អូបាម៉ា អនុញ្ញាតអោយសភាពិនិត្យមើលឡើងវិញនូវកិច្ចព្រមព្រៀងអាវុធនុយក្លេអ៊ែរ ដែលបានចុះហត្ថលេខាជាមួយប្រទេសអ៊ីរ៉ង់។ សភាបានព្យាយាមបញ្ឈប់កិច្ចព្រមព្រៀងនុយក្លេអ៊ែរ ប៉ុន្តែ លោកអូបាម៉ាបានប្រើអំណាចវេតូដើម្បីរក្សាសុពលភាពកិច្ចព្រមព្រៀងនោះ។

អ្នកដទៃចង្អុលទៅចរន្តមួយផ្សេងទៀត ដែលស្ថាប័ននីតិបញ្ញត្តិតតាំងជាមួយនឹងអំណាចនីតិប្រតិបត្តិទាក់ទងនឹងកងកម្លាំងយោធា។ ជាឧទាហរណ៍ ដោយសារស្ថាប័ននីតិប្បញ្ញត្តិកាន់ «កាបូបលុយ» (សមត្ថភាពក្នុងការអនុម័ត ឬបដិសេធសំណើខ្ជង់ចំណាយថ្មី) ពួកគេមានសមត្ថភាពបញ្ឈប់សង្គ្រាម តាមមធ្យោបាយផ្ទាល់របស់វា។ នៅសហរដ្ឋអាមេរិក ច្បាប់អំណាចសង្គ្រាម (War Powers Act) ដែលបានអនុម័តក្នុងអំឡុងពេលចុងបញ្ចប់នៃសង្គ្រាមវៀតណាម តម្រូវអោយប្រធានាធិបតីជូនដំណឹងដល់សភា នៅពេលដែលកងទ័ពសហរដ្ឋអាមេរិកត្រូវបានដាក់ពង្រាយក្នុងសមរភូមិប្រយុទ្ធ។ បន្ទាប់ពីការជូនដំណឹងនេះ ប្រធានាធិបតីមាន

ពេល ៦០ ថ្ងៃ (រួមទាំងការពន្យាលពេល ៣០ ថ្ងៃថែម) ដើម្បីប្រមូលកងទ័ពចូលបន្ទាយវិញ លុះត្រាតែសភាអនុម័តយល់ព្រមលើសកម្មភាពយោធាយ៉ាងច្បាស់លាស់។

ក្នុងអំឡុងយុទ្ធនាការផ្លូវអាកាស នៅប្រទេសលីប៊ីឆ្នាំ ២០១១ រដ្ឋបាលលោក អូបាម៉ា បានអះអាងថាច្បាប់អំណាចសង្គ្រាមមិនអាចយកមកអនុវត្តបានទេ ព្រោះសកម្មភាពនេះមិនមែនជាសង្គ្រាមទេ។ ទោះយ៉ាងណាក៏ដោយ ក្នុងអំឡុងពេលយុទ្ធនាការយោធាអាមេរិកប្រឆាំងនឹងកងកម្លាំងរដ្ឋឥស្លាមអាយស៊ីស (ISIS) នៅក្នុងប្រទេសអ៊ីរ៉ាក់ ក្នុងឆ្នាំ ២០១៤-២០១៥ រដ្ឋបាលលោក អូបាម៉ា បានស្វែងរកការយល់ព្រមពីសភាសម្រាប់ការប្រើប្រាស់កម្លាំងយោធា។ រដ្ឋបាលលោកប្រធានាធិបតី ប៊ូស, អូបាម៉ា និង ត្រាំ ក៏បានអះអាងនូវច្បាប់ឆ្នាំ ២០០១ ដែលអនុម័តដោយសភា បីថ្ងៃបន្ទាប់ពីការវាយប្រហារថ្ងៃទី ១១ ខែកញ្ញា ស្តីពី ការអនុញ្ញាតអោយប្រើប្រាស់កម្លាំងយោធា (AUMF) ផ្តល់អោយប្រធានាធិបតីនូវសិទ្ធិប្រើប្រាស់កម្លាំងយោធា ប្រឆាំងនឹងការគំរាមកំហែងណាមួយដែលទាក់ទងនឹងអំពើភេរវកម្ម។ ជាចុងក្រោយ ភស្តុតាងប្រវត្តិសាស្ត្រមួយចំនួនពីសហរដ្ឋអាមេរិក បានចង្អុលបង្ហាញថា ប្រធានាធិបតីអាមេរិកទំនងជាប្រើប្រាស់កម្លាំងយោធា នៅពេលដែលគណបក្សនយោបាយរបស់ពួកគេកំពុងកាន់អំណាចនៅក្នុងសភា ដោយលើកឡើងថា នយោបាយមិនឈប់នៅត្រឹមមាត់ទឹកឡើយ។

នៅក្នុងប្រព័ន្ធសភានិយម ដូចជាចក្រភពអង់គ្លេស អំណាចនីតិប្រតិបត្តិ (ឧទាហរណ៍ នាយករដ្ឋមន្ត្រី) ត្រូវបានជ្រើសរើសដោយគណបក្សនយោបាយដែលកាន់តំណែងច្រើនជាងគេ នៅក្នុងស្ថាប័ននីតិប្បញ្ញត្តិ។ ជារឿយៗ ស្ថាប័ននីតិប្រតិបត្តិក្នុងរបបសភានិយមមិនចាំបាច់បញ្ជូនសន្ធិសញ្ញា ឬគោលនយោបាយនានាទៅសភាដើម្បីទទួលបានការអនុម័តជាផ្លូវការនោះទេ។ យ៉ាងណាក៏ដោយស្ថាប័ននីតិបញ្ញត្តិក្នុងប្រព័ន្ធសភានិយម នៅតែកាន់អំណាចពាក់ព័ន្ធនឹងគោលនយោបាយការបរទេស។ ជាឧទាហរណ៍ នៅចក្រភពអង់គ្លេស ស្ថាប័នសភាមិនតម្រូវអោយបោះឆ្នោតអនុម័តលើកិច្ចព្រមព្រៀងអន្តរជាតិ ដែលត្រូវបានចរចាដោយនាយករដ្ឋមន្ត្រី ប៉ុន្តែ វាត្រូវតែអនុម័តលើវិសោធនកម្មលើច្បាប់របស់ចក្រភពអង់គ្លេស ដែលកិច្ចព្រមព្រៀងបែបនេះបានចែងរួចស្រាច់ហើយ។ ដោយសារតែ កិច្ចព្រមព្រៀងអន្តរជាតិភាគច្រើនពាក់ព័ន្ធនឹងប្រភេទនៃការផ្លាស់ប្តូរទាំងនេះ សភាអនុវត្តសិទ្ធិផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងអន្តរជាតិ ប្រកបដោយប្រសិទ្ធភាព។

នៅក្នុងប្រព័ន្ធសភានិយមជាច្រើន ប្រសិនបើគោលនយោបាយមានភាពចម្រូងចម្រាស គណបក្សដែលមិនមានសំឡេងភាគច្រើននៅក្នុងស្ថាប័ននីតិបញ្ញត្តិ អាចព្យាយាមរៀបចំការបោះឆ្នោតឡើងវិញ នេះមានន័យថា ប្រទេសនោះនឹងរៀបចំការបោះឆ្នោតម្តងទៀត ដើម្បីសម្រេចថាតើគណបក្សណានឹងកាន់កាប់អាសនៈនៅក្នុងសភា។ ប្រសិនបើគណបក្សផ្សេងៗគ្នាទទួលបានអាសនៈភាគច្រើន អ្នកកាន់អំណាចនីតិប្រតិបត្តិថ្មីត្រូវបានតែងតាំង។ ដូច្នេះហើយ នៅក្នុងប្រព័ន្ធសភា ស្ថាប័ននីតិប្បញ្ញត្តិដើរតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំ និងអនុវត្តគោលនយោបាយការបរទេស។

៤.២.៦. ការបង្កើតគោលនយោបាយការបរទេស

គោលនយោបាយការបរទេស គឺជាយុទ្ធសាស្ត្រនានាដែលរដ្ឋាភិបាលប្រើប្រាស់ជាប្រទីបបំភ្លឺផ្លូវសម្រាប់ដឹកនាំសកម្មភាពរបស់ខ្លួនក្នុងឆាកអន្តរជាតិ។ គោលនយោបាយបរទេសដាក់ចេញនូវគោលដៅដែលមេដឹកនាំរដ្ឋបានសម្រេចចិត្តស្វែងរក ក្នុងទំនាក់ទំនងឬស្ថានភាពណាមួយ។ ប៉ុន្តែ ជាទូទៅ អ្នកប្រាជ្ញទំនាក់ទំនងអន្តរជាតិមិនសូវចាប់អារម្មណ៍លើគោលនយោបាយជាក់លាក់ណាមួយ ដូច**ដំណើរការគោលនយោបាយបរទេស**

(foreign policy process)៖ ដំណើរដែលផ្តោតលើសំណួរថាតើគោលនយោបាយត្រូវបានសម្រេចឡើង និងអនុវត្តយ៉ាងដូចម្តេច។

រដ្ឋបង្កើតរចនាសម្ព័ន្ធអង្គការនិងទំនាក់ទំនងមុខងារផ្សេងៗ ដើម្បីបង្កើត និងអនុវត្តគោលនយោបាយការបរទេស។ អ្នកប្រាជ្ញទំនាក់ទំនងអន្តរជាតិ មានចំណាប់អារម្មណ៍ជាពិសេស ក្នុងការស្វែងយល់ថាតើប្រភេទនៃដំណើរការគោលនយោបាយណានាំទៅរកការសម្រេចចិត្តប្រភេទណាដែរ៖ ថាតើដំណើរការដាក់លាក់ណាមួយបង្កើតលទ្ធផលបានល្អប្រសើរជាង (សម្រាប់ផលប្រយោជន៍ ដែលកំណត់ដោយរដ្ឋផ្ទាល់) ជាជាងដោយដំណើរការផ្សេងទៀត។

រូបថត បុរសជនជាតិស៊ីរីបីកូនផង ដៃកាន់អាវុធប្រយុទ្ធផង

ជម្រើសផ្ទាល់ខ្លួន

លទ្ធផលគោលនយោបាយការបរទេសកើតចេញពីដំណើរការ នៅក្នុងកម្រិតវិភាគជាច្រើន រួមទាំងតួនាទីរបស់បុគ្គល។ កម្រិតទាំងអស់នេះត្រូវបានលេចចេញ ក្នុងឆ្នាំ ២០១១-២០១៣ ខណៈស៊ីរីបានផ្តើមចេញពីការតវ៉ាប្រឆាំងរហូតដល់សង្គ្រាមស៊ីវិល។ ក្នុងឆ្នាំ ២០១២ ឌីពុកម្នាក់នេះបានជ្រើសរើស ដូចជាបុគ្គលផ្សេងទៀត ចាប់កាន់អាវុធនិងចូលរួមជាមួយក្រុមឧទ្ទាម។ អនាគតរបស់ប្រទេសនេះនឹងត្រូវសម្រេចដោយការប្រមូលផ្តុំនៃការសម្រេចចិត្តបុគ្គលបែបនេះ។

គោលនយោបាយការបរទេសធៀប គឺជាការសិក្សាអំពីគោលនយោបាយការបរទេសនៅក្នុងរដ្ឋផ្សេងៗ ដើម្បីស្វែងយល់ថាតើសង្គមឬរដ្ឋាភិបាលប្រភេទដូចគ្នា មានគោលនយោបាយបរទេសប្រភេទដូចគ្នាដែរឬទេ (ដោយប្រៀបធៀបរវាងរដ្ឋផ្សេងគ្នាពីតំបន់មួយទៅតំបន់មួយទៀត ឬប្រៀបពីពេលវេលាមួយទៅពេលវេលាមួយសម្រាប់រដ្ឋតែមួយ)។ ការសិក្សាបែបនេះបានផ្តោតលើលក្ខណៈបីយ៉ាងគឺ ទំហំ ទ្រព្យសម្បត្តិ និងវិសាលភាពនៃការចូលរួមតាមបែបប្រជាធិបតេយ្យនៅក្នុងរដ្ឋាភិបាល។ ជាអកុសល គ្មានសេចក្តីសន្និដ្ឋានដ៏សាមញ្ញណាមួយត្រូវបានគេទាញឡើង ដើម្បីទស្សន៍ទាយទំនោរចូលចិត្តធ្វើសង្គ្រាមរបស់រដ្ឋ ដោយផ្អែកលើលក្ខណៈទាំងនេះឡើយ។ រដ្ឋនីមួយៗមានលក្ខណខុសគ្នាខ្លាំង ហើយសូម្បីតែនៅក្នុងរដ្ឋតែមួយក៏ដោយ ក៏មានលក្ខណៈខុសៗគ្នា ដោយអាស្រ័យតាមពេលវេលាផងដែរ។ ជាឧទាហរណ៍ ទាំងរដ្ឋមូលធននិយម និងរដ្ឋកុម្មុយនិស្តបានបង្ហាញពីសមត្ថភាពនៃការឈ្លានពានដោយគឃ្លើន ឬអាកប្បកិរិយាដោយសន្តិវិធី ដោយអាស្រ័យលើកាលៈទេសៈ។

អ្នកវិទ្យាសាស្ត្រនយោបាយមួយចំនួន បានព្យាយាមបកស្រាយគោលនយោបាយបរទេសរបស់រដ្ឋជាក់លាក់មួយ ទាក់ទងនឹងវប្បធម៌និងប្រវត្តិសាស្ត្រនយោបាយ របស់រដ្ឋនីមួយៗ។ ជាឧទាហរណ៍ សហភាពសូវៀត (រុស្សី) បានទទួលរងការឈ្លានពានទឹកដី ដែលបំផ្លិចបំផ្លាញ ម្តងហើយម្តងទៀត ជាច្រើនសតវត្សមកហើយ(រហូតដល់ទីបញ្ចប់ ក្នុងសង្គ្រាមលោកលើកទី២) ខណៈពេលដែលសហរដ្ឋអាមេរិកឆ្លងកាត់បទពិសោធន៍សុខសុវត្ថិភាព អស់រយៈពេលពីរសតវត្ស ដោយមាននាំងការពារពីមហាសមុទ្រដ៏ធំធេង។ ដូច្នេះហើយវិសាលភាពយោធារបស់សហភាពសូវៀតនិងការគ្រប់គ្រងលើរដ្ឋទ្រនាប់ នៅអឺរ៉ុបខាងកើត ប្រៀបដូចជានាំងការពារធម្មជាតិ ចំពោះមេដឹកនាំសូវៀត ប៉ុន្តែហាក់ដូចជាឈ្លានពានចំពោះមេដឹកនាំសហរដ្ឋអាមេរិក។

លទ្ធផលគោលនយោបាយការបរទេសកើតចេញពីកម្លាំងជាច្រើន នៅកម្រិតផ្សេងៗនៃការវិភាគ។ លទ្ធផលត្រូវអាស្រ័យទៅលើអ្នកធ្វើការសម្រេចចិត្តដោយបុគ្គល លើប្រភេទនៃសង្គម និងរដ្ឋាភិបាលដែល

ពួកគេកំពុងធ្វើការក្នុង និងលើបរិបទអន្តរជាតិនិងសកលនៃសកម្មភាពរបស់ពួកគេ។ ការសិក្សាអំពីដំណើរការគោលនយោបាយបរទេស មានដំណើរការផ្ទុយពីការសន្មត់របស់ទ្រឹស្តីប្រាកដនិយម ស្តីពីតួអង្គរដ្ឋឯកភូត។ ដោយសារការសិក្សាគោលនយោបាយការបរទេសផ្តោតនៅលើចរន្តកម្លាំងនៅក្នុងរដ្ឋ វាសង្កត់ធ្ងន់ចម្បង ទៅលើកម្រិតបុគ្គលនិងក្នុងស្រុកនៃការវិភាគ។

ភាពខុសគ្នានៅក្នុងដំណើរការគោលនយោបាយការបរទេស ពីរដ្ឋមួយទៅរដ្ឋមួយទៀត ក៏ត្រូវឯកទិព្ពលដោយប្រភេទរដ្ឋាភិបាលរបស់រដ្ឋមួយផងដែរ ដូចជារបបផ្តាច់ការយោធាជា, ការគ្រប់គ្រងដោយបក្សកុម្មុយនិស្ត ឬដោយបក្សតែមួយ(មិនមែនកុម្មុយនិស្ត) និងទម្រង់ផ្សេងៗទៀតនៃលទ្ធិប្រជាធិបតេយ្យពហុបក្ស។ រដ្ឋប្រជាធិបតេយ្យខ្លាំងគួរសម ហាក់មានគុណតម្លៃនិងផលប្រយោជន៍ប្រហាក់ប្រហែលគ្នា ហេតុដូច្នេះហើយពួកគេហាក់មានទំនោរមានទំនាក់ទំនងល្អនឹងគ្នា ជាជាងជាមួយនឹងប្រទេសមិនប្រជាធិបតេយ្យ (សូមមើល សន្តិប្រជាធិបតេយ្យ នៅក្នុងមេរៀនទី ៣)។ នៅក្នុងការអនុវត្តជាក់ស្តែង រដ្ឋភាគច្រើនស្ថិតនៅចន្លោះវិសាលភាពដែលមានធាតុផ្សំនៃលទ្ធិប្រជាធិបតេយ្យ និងលទ្ធិផ្តាច់ការ។

ការព្យាយាមពន្យល់អំពីគោលនយោបាយការបរទេស តាមមធ្យោបាយទូទៅនិងគំរូ*ទ្រឹស្តី*ទទួលបានជោគជ័យនៅមានកម្រិត។ នេះជាហេតុផលមួយ ដែលអ្នកប្រាកដនិយមនៅតែគិតថា គំរូតួអង្គឯកភូតដ៏សាមញ្ញរបស់រដ្ឋមានប្រយោជន៍, ជាតុក្នុងស្រុកនិងបុគ្គលនៃដំណោះរការគោលនយោបាយការបរទេសបន្ថែមភាពស្មុគស្មាញនិងភាពមិនអាចទស្សទាយបាន។ ផ្នែកមួយនៃគោលនយោបាយការបរទេស ដែលចំណេះដឹងឈរលើមូលដ្ឋានរឹងមាំជាងនេះបន្តិច គឺកិច្ចខិតខំ*ពិពណ៌នា*ដើម្បីយល់ពីរបៀបដែលយន្តការជាក់លាក់នៃការបង្កើតគោលនយោបាយការបរទេសមានដំណើរការនៅក្នុងរដ្ឋផ្សេងៗ។ គោលការណ៍បែបនេះស្ថិតនៅ ក្នុងវិស័យនយោបាយធៀប។

សរុបមក គោលនយោបាយការបរទេសគឺជាលទ្ធផលដ៏ស្មុគស្មាញនៃដំណើរការដ៏ស្មុគស្មាញមួយ។ វាជាលទ្ធផលនៃការតតាំងរវាងគ្រោងការណ៍ប្រកួតប្រជែងគ្នា ផលប្រយោជន៍ក្នុងស្រុកប្រកួតប្រជែងគ្នា និងភ្នាក់ងាររដ្ឋាភិបាលដែលប្រកួតប្រជែង។ គ្មានបុគ្គលណាមួយ គ្មានទីភ្នាក់ងារណាមួយ ឬគោលការណ៍ណែនាំណាមួយអាចកំណត់លទ្ធផលនោះទេ។ ប៉ុន្តែគោលនយោបាយការបរទេសពិតជាសម្រេចបាននូវភាពស៊ីសង្វាក់រួមគ្នាដ៏ជាក់លាក់មួយ។ រដ្ឋបង្កើតគោលនយោបាយការបរទេសលើបញ្ហាណាមួយ ឬឆ្ពោះទៅតំបន់ណាមួយ; វាមិនមែនគ្រាន់តែជាការប្រមូលផ្តុំនៃការសម្រេចចិត្ត និងសកម្មភាពដែលមិនស៊ីសង្វាក់គ្នា ពីពេលមួយទៅពេលមួយនោះទេ។ ពីដំណើរការផ្ទៃក្នុងដ៏ច្របូកច្របល់នៃការបង្កើតគោលនយោបាយការបរទេសមកបង្កើតបានជាផលប្រយោជន៍ និងគោលនយោបាយដែលរដ្ឋបន្តស្វែងរក។

សេចក្តីសន្និដ្ឋាន

១. គោលនយោបាយការបរទេស គឺជាយុទ្ធសាស្ត្រនានាដែលរដ្ឋាភិបាលប្រើប្រាស់ជាប្រទីបបំភ្លឺផ្លូវសម្រាប់ដឹកនាំសកម្មភាពរបស់ពួកគេឆ្ពោះទៅកាន់រដ្ឋដទៃទៀត។ ដំណើរការគោលនយោបាយការបរទេសគឺជាសំណុំបែបបទ និងរចនាសម្ព័ន្ធ ដែលរដ្ឋទាំងឡាយប្រើប្រាស់ដើម្បីឈានដល់ការសម្រេចចិត្តលើគោលនយោបាយការបរទេសនិងដើម្បីអនុវត្តគោលនយោបាយទាំងនោះ។

២. នៅក្នុង**គំរូសមហេតុផល**នៃការធ្វើការសំរេចចិត្ត មន្ត្រីជ្រើសរើសសកម្មភាពដែលអាចចេញជាលទ្ធផលជួយសំរេចគោលដៅដែលកំណត់ដោយរដ្ឋ បានយ៉ាងល្អបំផុត។ ផ្ទុយទៅវិញ នៅក្នុងគំរូដំណើរការក្នុង

ស្ថាប័ន ការសំរេចចិត្តកើតឡើងពីនីតិវិធីរដ្ឋបាល ជាទៀងទាត់ធម្មតា។ នៅក្នុងគំរូចរចាក្នុងរដ្ឋាភិបាល(ឬ នយោបាយការិយាធិបតេយ្យ) ការសម្រេចចិត្តកើតចេញពីការចរចាក្នុងចំណោមភ្នាក់ងាររដ្ឋាភិបាលដែល មានផលប្រយោជន៍ផ្សេងៗគ្នា នៅក្នុងលទ្ធផលដែលអាចសម្រេចបាន។

៣. សកម្មភាពរបស់អ្នកធ្វើសេចក្តីសម្រេចចិត្តជាលក្ខណៈបុគ្គលត្រូវបានរងឥទ្ធិពល ដោយបុគ្គលិកលក្ខណៈ គុណតម្លៃនិងជំនឿរបស់បុគ្គលទាំងនោះ ក៏ដូចជារងឥទ្ធិពលកត្តាចិត្តសាស្ត្រទូទៅ ដែលឃ្លាតឆ្ងាយពី សនិទានភាព (ភាពសមហេតុផល)។ កត្តាទាំងនេះ រួមមានការយល់ច្រលំ ការយល់ឃើញតែមួយជ្រុង *ឆន្ទាគតិឬទោសាគតិ* និង *មោហាគតិឬភយាគតិ* (រួមទាំងភាពមិនស៊ីសង្វាក់គ្នានៃសតិសម្បជញ្ញៈ)។

៤. ការសម្រេចចិត្តលើគោលនយោបាយការបរទេសក៏ត្រូវរងឥទ្ធិពលដោយចិត្តសាស្ត្ររបស់ក្រុម (រួមទាំងការ គិតជាក្រុម) នីតិវិធីដែលត្រូវបានប្រើដើម្បីឈានដល់ការសម្រេចចិត្ត និងតួនាទីរបស់អ្នកចូលរួម។ ក្នុង កំឡុងពេលមានវិបត្តិ លទ្ធភាពនៃការយល់ខុសនិងកំហុសកាន់តែកើនឡើង។

៥. ជាធម្មតា តែងតែមានការប្រទាញប្រទងគ្នាលើទិសដៅនៃគោលនយោបាយការបរទេស រវាងក្រុមមន្ត្រី ការិយាធិបតេយ្យអាជីពនិងអ្នកនយោបាយ ក៏ដូចជា រវាងភ្នាក់ងាររដ្ឋាភិបាលផ្សេងៗគ្នា។

៦. ក្រុមអ្នកបោះឆ្នោតក្នុងស្រុក(ក្រុមតំណាងផលប្រយោជន៍) មានផលប្រយោជន៍ខុសគ្នា នៅក្នុងគោល នយោបាយការបរទេស ហើយជារឿយៗ រៀបចំនយោបាយ ដើម្បីលើកកម្ពស់ផលប្រយោជន៍ទាំងនោះ។

៧. ក្រុមអ្នកបោះឆ្នោតក្នុងស្រុកដែលលេចធ្លោជាងគេ ជាពិសេសនៅសហរដ្ឋអាមេរិកនិងរុស្ស៊ី និងជាពិសេស ក្នុងកំឡុងសង្គ្រាមត្រជាក់គឺជាក្រុមឧស្សាហកម្មយោធា ដែលរួមមានក្រុមហ៊ុនឧស្សាហកម្មយោធា និង ក្រុមដទៃទៀត ដែលមានផលប្រយោជន៍ដោយសារការចំណាយផ្នែកយោធាខ្ពស់។

៨. មតិសាធារណៈជះឥទ្ធិពលលើការសម្រេចចិត្តគោលនយោបាយការបរទេសរបស់រដ្ឋាភិបាល (ជាពិសេស នៅក្នុងប្រទេសប្រជាធិបតេយ្យជាងរដ្ឋផ្តាច់ការ) ប៉ុន្តែ រដ្ឋាភិបាលក៏បោកបញ្ឆោតមតិសាធារណៈផងដែរ។

៩. ស្ថាប័ននីតិប្បញ្ញត្តិអាចផ្តល់មធ្យោបាយសម្រាប់មតិសាធារណៈនិងក្រុមតំណាងផលប្រយោជន៍ ដើម្បីជះ ឥទ្ធិពលលើគោលនយោបាយការបរទេស។ មន្ត្រីស្ថាប័ននីតិប្រតិបត្តិនិងនីតិប្រតិបត្តិអាចមានវិធីខុសគ្នា ដើម្បីសម្រេចបានផលប្រយោជន៍ជាតិរបស់រដ្ឋណាមួយ។

ពាក្យគន្លឹះ

១. **គំរូសមហេតុផល** គឺជាគំរូដែលអ្នកធ្វើសេចក្តីសម្រេចចិត្តវិភាគឬគណនាការខាតបង់និងផលចំណេញនៃ លទ្ធភាពសកម្មភាពនីមួយៗ បន្ទាប់មក ជ្រើសរើសជម្រើសដែលមានផលចំណេញខ្លាំងបំផុត និងការ ចំណាយឬខាតបង់តិចបំផុត។

២. គំរូដំណើរការក្នុងស្ថាប័ន គឺជាគំរូនៃការសម្រេចចិត្តដែលអ្នកបង្កើតគោលនយោបាយ ឬមន្ត្រីថ្នាក់ក្រោម ពឹងផ្អែកភាគច្រើនលើការឆ្លើយតបតាមស្តង់ដារ ឬនីតិវិធីប្រតិបត្តិការស្តង់ដារ។

៣. គំរូចរចាក្នុងរដ្ឋាភិបាល គឺជាគំរូដែលមើលឃើញការសម្រេចចិត្តគោលនយោបាយការបរទេស ដែល លទ្ធផលកើតចេញពីដំណើរការចរចា ក្នុងចំណោមភ្នាក់ងាររដ្ឋាភិបាលផ្សេងៗ ដែលមានផលប្រយោជន៍ ខុសគ្នានៅក្នុងលទ្ធផល («ដំហររបស់អ្នកអាស្រ័យលើកន្លែងដែលអ្នកអង្គុយ»)។ ពេលខ្លះត្រូវហៅ ថា *គំរូ នយោបាយការិយាធិបតេយ្យ*។

៤. ការយល់ឃើញខុសនិងការយល់ឃើញតែមួយជ្រុង គឺជាដំណើរការយល់ខុសលើព័ត៌មានដែលមានក្នុងការសម្រេចចិត្ត; វិធីមួយក្នុងចំណោមវិធីជាច្រើន (រួមជាមួយនឹង *ឆន្ទាគតិឬទោសាគតិ* និង*មោហាគតិឬភយាគតិ*) ដែលក្នុងនោះការសម្រេចចិត្តរបស់បុគ្គលឃ្លាតឆ្ងាយខុសពីគំរូសមហេតុផល។ សូមមើល *អេក្រង់ឬតម្រងព័ត៌មាន*ផងដែរ។

៥. អេក្រង់ឬតម្រងព័ត៌មាន គឺជាតម្រងព័ត៌មានចេញចូលទៅកាន់មនុស្ស មកជុំវិញពិភពលោក ទោះដឹងឬមិនដឹងខ្លួនក្តី។ សូមមើលផងដែរ *ការយល់ឃើញខុសនិងការយល់ឃើញតែមួយជ្រុង*។

៦. **ការបង្កើនប្រសិទ្ធភាព** គឺជាការជ្រើសរើសជម្រើសដ៏ល្អបំផុត; ផ្ទុយពីការបំពេញចិត្ត ឬស្វែងរក ដំណោះស្រាយត្រឹមតែពេញចិត្តតែមិនល្អបំផុតសម្រាប់ដោះស្រាយបញ្ហា។ គំរូ«សនិទានភាពមានព្រំដែនកំណត់»ចែងថា អ្នកធ្វើការសម្រេចចិត្តជាទូទៅត្រឹមតែរក«ការពេញចិត្ត»ជាជាងខិតខំបង្កើនប្រសិទ្ធភាព។

៧. **ការពេញចិត្ត**ឬការបំពេញចិត្ត គឺជាទង្វើនៃការស្វែងរកដំណោះស្រាយដែលពេញចិត្ត ឬ «ល្អគ្រប់គ្រាន់» ចំពោះបញ្ហាណាមួយ។

៨. **ទ្រឹស្តីអនាគត** គឺទ្រឹស្តីសម្រាប់ធ្វើការសម្រេចចិត្តដែលអះអាងថាជម្រើសទាំងឡាយ ត្រូវបានវាយតម្លៃដោយការប្រៀបធៀបទៅនឹងចំណុចយោងណាមួយ ដែលជារឿយៗ ជាស្ថានភាពមានស្រាប់ ប៉ុន្តែអាចជាស្ថានភាពអតីតកាល ឬរំពឹងទុកនាពេលអនាគត។ គំរូនេះក៏ចែងដែរថាអ្នកធ្វើការសម្រេចចិត្តព្រួយបារម្ភអំពីការខាតបង់ ច្រើនជាងពួកគេអោយតម្លៃលើផលចំណេញ។

៩. **ការគិតគិតជាក្រុម** គឺជាទំនោរហៃអើនិយម ដែលគាំទ្រការសម្រេចចិត្តខុស ដោយទំនុកចិត្តខ្លាំងលើសលុប និងវាយតម្លៃហានិភ័យទាបពេក។

១០. **ក្រុមតំណាងផលប្រយោជន៍** គឺជាសម្ព័ន្ធនៃក្រុមមនុស្សដែលទទួលបានផលប្រយោជន៍រួមនៅក្នុងលទ្ធផលនៃបញ្ហានយោបាយមួយចំនួន និងអ្នកដែលរៀបចំការកៀងគរមនុស្សដើម្បីព្យាយាមជះឥទ្ធិពលលើលទ្ធផល។

១១. **ក្រុមឧស្សាហកម្មយោធា** គឺជាបណ្តាញទំនាក់ទំនងដ៏ធំរវាងទីភ្នាក់ងាររដ្ឋាភិបាល ក្រុមហ៊ុនសាជីវកម្មឧស្សាហកម្ម និងវិទ្យាស្ថានស្រាវជ្រាវ ដែលទាំងអស់ធ្វើការរួមគ្នាដើម្បីលើកកម្ពស់ និងទទួលបានអត្ថប្រយោជន៍ពីការចំណាយលើវិស័យយោធា។

១២. **មតិសាធារណៈ** នៅក្នុងទំនាក់ទំនងអន្តរជាតិ បណ្តាទស្សនៈលើបញ្ហាគោលនយោបាយការបរទេសដែលធ្វើឡើងដោយពលរដ្ឋទាំងឡាយនៃរដ្ឋណាមួយ។

១៣. រោគសញ្ញា«ប្រមូលផ្តុំគ្នាជុំវិញទង់ជាតិ» គឺជាកំណើននៃការគាំទ្ររបស់សាធារណជនចំពោះមេដឹកនាំរដ្ឋាភិបាលក្នុងអំឡុងពេលសង្គ្រាម យ៉ាងហោចណាស់ក្នុងរយៈពេលខ្លីមួយ។

១៤. គោលនយោបាយបរទេសបង្វែរទិស គឺជាគោលនយោបាយបរទេសត្រូវបានអនុម័តឡើងដើម្បីបំបែរអារម្មណ៍សាធារណជនពីបញ្ហានយោបាយក្នុងស្រុក។

១៥. ដំណើរការគោលនយោបាយការបរទេស គឺជាដំណើរការដែលគោលនយោបាយបរទេសត្រូវបានសម្រេចឡើងនិងអនុវត្ត។

សំណួរអនុវត្តន៍

១. ភាពមិនប្រាកដប្រជាអំពីការខាតបង់និងផលចំណេញនៃសកម្មភាពណាមួយ អាចធ្វើអោយដំណើរការសម្រេចចិត្តគោលនយោបាយការបរទេសកាន់តែស្មុគស្មាញ។ តើអ្វីទៅជាប្រភពនៃភាពមិនប្រាកដប្រជា នៅក្នុងទំនាក់ទំនងអន្តរជាតិ? តើអ្នកធ្វើការសម្រេចចិត្តអាចចាត់វិធានការណ៍ណាខ្លះដើម្បីកាត់បន្ថយភាពមិនប្រាកដប្រជានោះទេ?

២. ចូរពិចារណាពីព្រឹត្តិការណ៍ណាមួយនៅក្នុងទំនាក់ទំនងអន្តរជាតិដែលអ្នកបានដឹង។ ចូររិះរកតួអង្គដែលចូលរួមក្នុងការធ្វើការសម្រេចចិត្តទាក់ទងនឹងព្រឹត្តិការណ៍នោះ។ តើគំរូតួអង្គសមហេតុផល អាចនឹងពន្យល់អំពីព្រឹត្តិការណ៍នោះ ដោយរបៀបណា? តើវាអាចត្រូវបានពន្យល់ដោយគំរូមួយណា បានល្អជាង៖ នីតិវិធីប្រតិបត្តិស្តង់ដារ ឬនយោបាយបែបការិយាធិបតេយ្យ?

៣. បារាំងបានព្យាយាមធ្វើអន្តរាគមន៍ក្នុងភាពតានតឹងរវាងអ៊ីរ៉ង់ និងអាមេរិក ដែលជាលទ្ធផលនៃការដកខ្លួនរបស់អាមេរិកពីកិច្ចព្រមព្រៀងនុយក្លេអ៊ែរឆ្នាំ ២០១៥ ជាមួយអ៊ីរ៉ង់។ តើអ្នកគិតថា បារាំងនឹងទទួលជោគជ័យក្នុងការនាំភាគីទាំងពីរចូលតុចរចាដែរឬទេ? ពិចារណាអំពីទំនាក់ទំនងរវាងបារាំងជាមួយអ៊ីរ៉ង់ និងបារាំងជាមួយសហរដ្ឋអាមេរិក និងនយោបាយក្នុងស្រុក នៅក្នុងប្រទេសទាំងពីរនេះ។

៤. ពេលខ្លះ សកម្មភាពឈ្លានពានអន្តរជាតិ ត្រូវបានសន្មតថាកើតឡើងដោយសារ«មនុស្សឆ្កួត» ដូចជា សាដាម ហ៊ូសេនរបស់អ៊ីរ៉ាក់ ឬ អាឌុល អ៊ីត្លែររបស់ណាស៊ីអាឡឺម៉ង់។ តើអ្នកយល់ស្របថាអ្នកដឹកនាំបែបនេះ (ទង្វើរបស់ពួកគេម្នាក់ៗបានផ្តល់ផលវិបាកបំផ្លាញសុខុមាលភាពរដ្ឋរបស់ខ្លួនយ៉ាងធ្ងន់ធ្ងរ) ពិតជា«ឆ្កួត»មែនឬទេ? តើកត្តាអ្វីផ្សេងទៀតបណ្តាលអោយពួកគេប្រព្រឹត្តទង្វើទាំងនោះ? តើអ្នកគិតថា មនុស្សបែបនេះឡើងកាន់និងរក្សាអំណាចដឹកនាំជាតិដោយរបៀបណា?

៥. ជាប្រទេសជិតខាងនឹងគ្នា ឥណ្ឌានិងប៉ាគីស្ថានមានទំនាក់ទំនងពោរពេញដោយបញ្ហា។ ដោយពិចារណាអំពីបញ្ហាយល់ឃើញខុសនិងភាពលំអៀងក្នុងការសម្រេចចិត្តគោលនយោបាយការបរទេស តើអ្នកអាចស្នើអោយរដ្ឋាភិបាលនីមួយៗប្រកាន់ខ្ជាប់ជំហានអ្វីខ្លះដើម្បីកុំអោយបញ្ហាទាំងនេះ ប៉ះពាល់ដល់ដំណើរការស្វែងរកផលប្រយោជន៍សម្រាប់ជាតិ ដោយសមហេតុផល យ៉ាងដូចម្តេច?

៦. ជាប្រពៃណីទៅហើយ ឥស្សរជននយោបាយការបរទេស បានប្រឈមមុខនឹងសម្ពាធខ្លាំងម្តងម្កាលពីមតិសាធារណៈ។ តើតួនាទីរបស់ទូរទស្សន៍និងអ៊ិនធឺរណែតកំពុងផ្លាស់ប្តូរទំនាក់ទំនងនេះដែរឬទេ? ប្រសិនបើអ្នកជាអ្នកបង្កើតគោលនយោបាយការបរទេសកំពូល តើអ្នកអាចចាត់វិធានការអ្វីខ្លះដើម្បីរាំងខ្ទប់ព័ត៌មានតាមទូរទស្សន៍និងអ៊ីនធឺរណែត កុំអោយប៉ះពាល់លើការធ្វើរបៀបវារៈគោលនយោបាយការបរទេស មុនពេលអ្នកអាចកំណត់គោលដៅនិងទិសដៅផ្ទាល់ខ្លួនរបស់អ្នកសម្រាប់គោលនយោបាយការបរទេសមួយនោះ?

ការស្វែងរកផលប្រយោជន៍រួម

កិច្ចចរចាសន្តិភាពអ៊ីស្រាអែល-ប៉ាឡេស្ទីន

រូបថត នាយករដ្ឋមន្ត្រីអ៊ីស្រាអែល និងប្រធានាធិបតីប៉ាឡេស្ទីន ឆ្នាំ ២០១៦។

ផលប្រយោជន៍រួម៖ ការបញ្ចប់ជម្លោះហិង្សារយៈពេល ៧០ ឆ្នាំ។

សារវតា

ចាប់តាំងពីការបង្កើតរដ្ឋអ៊ីស្រាអែល នៅឆ្នាំ ១៩៤៨ ក្រោយសង្គ្រាមលោកលើកទី ២ ជនជាតិជ្វីហ្វ និងអារ៉ាប់ប៉ាឡេស្ទីនបានប្រយុទ្ធគ្នាដណ្តើមកាន់កាប់ទឹកដីមួយនេះ។ បន្ទាប់ពីភ្លើងសង្គ្រាមខ្ទេចខ្ទាំយ៉ាងខ្លាំង ប្រទេសអ៊ីស្រាអែល និងប្រទេសជិតខាងសំខាន់ៗ រួមមាន ប្រទេសអេហ្ស៊ីប និងប្រទេសហ្ស៊កដានី បានឈានដល់ការសម្រេចបាននូវសន្តិភាពយូរអង្វែងមួយ ទោះជាសោះអង្គើយក្តី។ យ៉ាងណាមិញ អ៊ីស្រាអែល និងប៉ាឡេស្ទីនមិនទាន់បានឈានដល់កិច្ចព្រមព្រៀងសន្តិភាពណាមួយនៅឡើយទេ ដោយផ្អែកលើរដ្ឋប៉ាឡេស្ទីននៅក្នុងដែនដីដែលកាន់កាប់ដោយអ៊ីស្រាអែល តាំងពីក្នុងសង្គ្រាមឆ្នាំ ១៩៦៧ នោះគឺតំបន់ វ៉េសប៊ែង (West Bank) និងហ្គាហ្សាស្ទ្រីព (Gaza Strip) និងការទទួលស្គាល់សិទ្ធិរស់រានមានជីវិតរបស់ប្រជាជនអ៊ីស្រាអែលពីសំណាក់ប៉ាឡេស្ទីន។

ក្នុងកិច្ចចរចាជាច្រើនលើកច្រើនសារក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ភាគីទាំងពីរបានខិតកាន់តែជិតស្និទ្ធនឹងគ្នា។ នៅចុងឆ្នាំ ២០០០ ក្រុមអ្នកចរចាស្ទើរតែបានខិតជិតឈានដល់កិច្ចព្រមព្រៀងទទួលស្គាល់បរិមាត្រសម្រាប់រដ្ឋប៉ាឡេស្ទីន ទន្ទឹមគ្នាជាមួយនឹងភាគីអ៊ីស្រាអែល។ ទោះបីជាយ៉ាងនេះក្តី ការខិតខំប្រឹងប្រែងបានធ្លាក់ចុះបន្តិចម្តងៗ ខណៈដែលរដ្ឋាភិបាលថ្មីបានឡើងកាន់អំណាច ទាំងនៅអ៊ីស្រាអែល និងទាំងនៅសហរដ្ឋអាមេរិក ហើយរលកថ្មីនៃអំពើហិង្សាបានកើតឡើង។ សន្តិភាពអ៊ីស្រាអែល-ប៉ាឡេស្ទីនគឺជាផលប្រយោជន៍រួមដែលនឹងផ្តល់ប្រយោជន៍ដល់ភាគីនីមួយៗ មិនថាភាគីណាមួយបានធ្វើសម្បទាន ដែលនាំអោយឈានដល់កិច្ចព្រមព្រៀងនោះទេ។

បញ្ហាប្រឈម

សហរដ្ឋអាមេរិកបានដឹកនាំកិច្ចប្រជុំចរចាសន្តិភាពជាច្រើនដង ដែលមិនបានហុចផលសោះឡើយ។ កិច្ចពិភាក្សាទាំងនេះតែងតែប្រឈមជាមួយនឹងបញ្ហាធំៗ ដែលបណ្តាលមកពីកត្តានយោបាយក្នុងស្រុករបស់ភាគីនីមួយៗ។ នៅក្នុងប្រទេសអ៊ីស្រាអែល រដ្ឋាភិបាលចម្រុះដែលកំពុងកាន់អំណាចក្នុងសភា ដែលជាធម្មតាបានរួមបញ្ចូលភាគីដែលប្រឆាំងនឹងការធ្វើសម្បទានដល់ប៉ាឡេស្ទីន ដូច្នេះហើយទើបរដ្ឋាភិបាលអ៊ីស្រាអែលតែងតែមានភាពខ្វះខាតក្នុងការធ្វើសម្បទានទាំងនោះ ទោះបីជាខ្លួនចង់ធ្វើក៏ដោយ។ នៅខាងភាគីប៉ាឡេស្ទីន ក្រុមប្រដាប់អាវុធសកម្មប្រយុទ្ធ *ហាម៉ាស់* បាននឹងកំពុងគ្រប់គ្រងតំបន់ហ្គាហ្សា ហើយទុកអោយភាគីអ៊ីស្រាអែលចរចាជាមួយអាជ្ញាធរប៉ាឡេស្ទីន ដែលមិនបានគ្រប់គ្រងទាំងស្រុងលើទឹកដី ដែលខ្លួនសង្ឃឹមថានឹងទាមទារបង្កើតជារដ្ឋមួយ។ នៅក្នុងស្ថានភាពបែបនេះ ដំណើរការគោលនយោបាយការបរទេស សូម្បីតែនៅក្នុងប្រទេសប្រកាន់លទ្ធិប្រជាធិបតេយ្យអាចរារាំងសមត្ថភាពរបស់ភាគីនីមួយៗក្នុងការបង្កើតសន្តិភាព។

ដំណោះស្រាយ

គោលការណ៍បដិការដែលជាបទដ្ឋានដ៏រឹងមាំក្នុងទំនាក់ទំនងអ៊ីស្រាអែលនឹងប៉ាឡេស្ទីន ក្នុងរយៈពេលជាច្រើនទសវត្សរ៍ គឺជាមូលដ្ឋាននៃការចរចាកិច្ចព្រមព្រៀងសន្តិភាព។ ប៉ុន្តែ វាមិនទាន់គ្រប់គ្រាន់ទេ ម្យ៉ាងដោយសារតែឧបសគ្គក្នុងស្រុក បានធ្វើអោយរដ្ឋាភិបាលពិបាកសម្រេចបានកិច្ចសហប្រតិបត្តិការដោយផ្អែកលើគោលការណ៍បដិការ។

ដើម្បីជំនះឧបសគ្គក្នុងស្រុកទាំងនេះ គោលការណ៍គ្រប់គ្រងអាចជាវិធីមួយដែលគួរសាកល្បង។ អ្នកវិភាគភាគច្រើនយល់ស្របថា ការចរចាសន្តិភាពអាចទទួលបានជោគជ័យ លុះត្រាតែសហរដ្ឋអាមេរិកអនុវត្តការដឹកនាំដ៏រឹងមាំ (រួមទាំងការដាក់សម្ពាធ និងការជំរុញលើកទឹកចិត្ត) ដើម្បីអោយភាគីទាំងពីរធ្វើសម្បទាន

ទៅវិញទៅមក។ នៅពេលនោះ អ្នកប្រឆាំងនៅភាគីម្ខាងៗនឹងបង្វែរការស្តីបន្ទោសទៅលើសហរដ្ឋអាមេរិក ជាជាងមេដឹកនាំរបស់ពួកគេ ដែលតាមរបៀបនេះពួកគេអាចមានលំហរសេរីភាពក្នុងការសម្របសម្រួលដើម្បីដោះស្រាយបញ្ហា។ ប្រសិនបើកិច្ចព្រមព្រៀងសន្តិភាពអ៊ីស្រាអែល-ប៉ាឡេស្ទីនកើតឡើងពិតមែននោះ ការដឹកនាំរបស់សហរដ្ឋអាមេរិកទំនងជានឹងដើរតួយ៉ាងសំខាន់ក្នុងការសម្រេចបាន។

ឧស្សន:ទិស័យគោលនយោបាយ

នាយករដ្ឋមន្ត្រីជប៉ុន លោក ស៊ីនហ្សូ អាបេ (Shinzo Abe)

រូបថត នាយករដ្ឋមន្ត្រី អាបេ

បញ្ហា

តើអ្នកគួរសម្រេចចិត្តជ្រើសរើសឧបករណ៍គោលនយោបាយការបរទេសដែលល្អបំផុតបែបណា ដើម្បីរក្សាតុល្យភាពរវាងកង្វល់ក្នុងស្រុកនិងអន្តរជាតិ ដោយរបៀបណា?

សារតារ

សាកស្រមៃថា អ្នកគឺជានាយករដ្ឋមន្ត្រីប្រទេសជប៉ុន។ ចាប់តាំងពីចុងបញ្ចប់នៃសង្គ្រាមកូរ៉េ ក្នុងឆ្នាំ ១៩៥៣ ទំនាក់ទំនងជាមួយប្រទេសជិតខាង នៅភាគខាងលិច ដូចជាប្រទេសកូរ៉េខាងជើង មានភាពតានតឹងរៀងរហូតមក។ ភាពតានតឹងផ្នែកយោធានៅតែបន្តកើតមាន ខណៈដែលកូរ៉េខាងជើងបានចុះហត្ថលេខាព្រមព្រៀង តែក្រោយមកបំពានកិច្ចព្រមព្រៀងទាក់ទងនឹងកម្មវិធីនុយក្លេអ៊ែរទាំងនោះទៅវិញ។ ប្រទេសកូរ៉េខាងជើងបានសាកល្បងអាវុធនុយក្លេអ៊ែរ ចំនួនប្រាំមួយដង ចាប់តាំងពីឆ្នាំ ២០០៦ ដែលតេស្ត៍ថ្មីៗបំផុតនេះធ្វើឡើងនៅក្នុងឆ្នាំ ២០១៧ ។ ប្រទេសកូរ៉េខាងជើងក៏បានបាញ់ផ្លោងសាកល្បងមីស៊ីលរយៈចម្ងាយខ្លី ដោយផ្ទាល់រំលងលើប្រទេសជប៉ុន ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីបំភិតបំភ័យប្រទេសជប៉ុនរបស់អ្នក។ នៅក្នុងឆ្នាំ ២០១៧ ប្រទេសកូរ៉េខាងជើងបានសាកល្បងគ្រាប់រ៉ុក្កែត រយៈចម្ងាយឆ្ងាយ ថ្មីមួយទៀត ដើម្បីឆ្លើននឹងការព្រមានអន្តរជាតិ។ អ្នកបានទទួលជោគជ័យក្នុងការបោះឆ្នោត ក្នុងឆ្នាំ ២០១២ ដោយប្រើរ៉េទ្យសាស្ត្រសង្គ្រាម ដោយអំពាវនាវអោយបង្កើនការចំណាយលើវិស័យការពារជាតិ និងការដាក់ពង្រាយប្រព័ន្ធអាវុធប្រឆាំងនឹងមីស៊ីលដើម្បីការពារប្រទេសរបស់អ្នកពីការបាញ់ប្រហាររបស់ប្រទេសកូរ៉េខាងជើង។

ការចរចាលុបបំបាត់ការគំរាមកំហែង ដោយអាវុធនុយក្លេអ៊ែរនិងមីស៊ីលរបស់កូរ៉េខាងជើងមិនមានដំណើរទៅមុខនោះទេ។ ភាពតានតឹងកាន់តែខ្លាំងឡើងៗ ដែលបានបង្កឡើង ដោយសង្គ្រាមពាក្យសម្តីរវាងមេដឹកនាំកូរ៉េខាងជើង គីម ជុងអ៊ុន និងប្រធានាធិបតីសហរដ្ឋអាមេរិក ដូណាល់ ត្រាំ បានបណ្តាលអោយអ្នកសម្រេចចិត្តបញ្ជាទិញប្រព័ន្ធការពារមីស៊ីលពីសហរដ្ឋអាមេរិក ដើម្បីដាក់ពង្រាយប្រឆាំងនឹងការគំរាមកំហែងរបស់កូរ៉េខាងជើង។ នៅពេលដែលមានកិច្ចចរចាសន្តិភាពរវាងលោក គីម ជុងអ៊ុន ជាមួយនិង លោក ដូណាល់ ត្រាំ ក្នុងឆ្នាំ ២០១៨ បានបន្ធូរបន្ថយភាពតានតឹងជាបណ្តោះអាសន្នសិន។

នៅឆ្នាំ ១៩៦៧ ប្រទេសជប៉ុនបានអនុម័តគោលការណ៍មិនមាននុយក្លេអ៊ែរចំនួនបីចំណុច ដោយបានសន្យាថានឹងមិនបង្កើត មិនមាន ឬមិនកាន់កាប់អាវុធនុយក្លេអ៊ែរនោះទេ។ ជាលទ្ធផលនៃគោលនយោបាយនេះ អ្នកអត់ធ្មត់មិនធ្វើរឿងទាំងបីខាងលើឡើយ ទោះបីជាប្រទេសរបស់អ្នកមានបច្ចេកវិទ្យាគ្រប់គ្រាន់ក្នុងការសាងសង់អាវុធនុយក្លេអ៊ែរផ្ទាល់ខ្លួនក៏ដោយ។ ជាងនេះទៅទៀត ជប៉ុនបានបដិសេធមិនអនុញ្ញាតអោយដាក់អាវុធនុយក្លេអ៊ែររបស់អាមេរិក នៅលើទឹកដីខ្លួន ដោយសារគោលការណ៍ទាំងបី។ ទោះបីជាយ៉ាងណាក៏ដោយ

ជាមួយនឹងការគំរាមកំហែងកើនឡើងពីសំណាក់ប្រទេសកូរ៉េខាងជើង មេដឹកនាំយោធាមួយចំនួន នៅក្នុងប្រទេសជប៉ុនបានអំពាវនាវអោយបោះបង់ចោលនូវគោលការណ៍ទាំងបី ដើម្បីគាំទ្រដល់ការអភិវឌ្ឍន៍កម្មវិធីអាវុធនុយក្លេអ៊ែរនៅក្នុងប្រទេសជប៉ុន។

ការពិចារណាក្នុងស្រុក

មតិសាធារណៈនៅក្នុងប្រទេសជប៉ុនមានភាពរសើបខ្លាំងណាស់ ចំពោះទំនាក់ទំនងជាមួយប្រទេសកូរ៉េខាងជើង។ ជនជាតិជប៉ុនជាច្រើនមិនត្រឹមតែមានការព្រួយបារម្ភអំពីការគំរាមកំហែងនុយក្លេអ៊ែររបស់កូរ៉េខាងជើងប៉ុណ្ណោះទេ ប៉ុន្តែនៅឆ្នាំ ២០០២ កូរ៉េខាងជើងបានសារភាពថាបានចាប់ពង្រត់ពលរដ្ឋជប៉ុនដោយសម្ងាត់ ក្នុងទសវត្សរ៍ឆ្នាំ ១៩៧០ និង ១៩៨០ ដោយដឹកជញ្ជូនពួកគេទៅកាន់កូរ៉េខាងជើងនិងបង្ខំពួកគេអោយបណ្តុះបណ្តាលចារកម្មកូរ៉េខាងជើង។ នៅពេលនោះប្រទេសរបស់អ្នកបានទាមទារអោយកូរ៉េខាងជើងប្រគល់សាកសពរបស់អ្នកដែលត្រូវបានចាប់ពង្រត់ទាំងនោះមកវិញ។ ហើយខណៈពេលដែលការចាប់ពង្រត់ទាំងនេះគឺជាបញ្ហារសើបសម្រាប់មតិសាធារណៈនៅក្នុងប្រទេសជប៉ុន បញ្ហាអាវុធនុយក្លេអ៊ែរក៏រសើបដូចគ្នាដែរ។ ពលរដ្ឋជប៉ុនភាគច្រើនមិនគាំទ្រការអភិវឌ្ឍន៍ឬកាន់អាវុធនុយក្លេអ៊ែរ នៅពេលនេះទេ។

សេណារីយ៉ូ

ពេលនេះ ចូរស្រមៃថា ប្រទេសកូរ៉េខាងជើងនៅតែបន្តអភិវឌ្ឍកម្មវិធីនុយក្លេអ៊ែររបស់ខ្លួន ដោយផលិតអាវុធដែលមានឋាមពលកាន់តែខ្លាំងថែមទៀត។ បន្ថែមពីនេះ កូរ៉េខាងជើងក៏នៅតែបន្តអភិវឌ្ឍមីស៊ីល រួមទាំងការបាញ់សាកល្បងមីស៊ីលរំលងលើកោះរបស់អ្នក។ សហរដ្ឋអាមេរិកបានសួរថាតើអ្នកនឹងពិចារណាអោយដាក់អាវុធនុយក្លេអ៊ែររបស់អាមេរិកនៅលើទឹកដីរបស់អ្នក ដើម្បីទប់ទល់នឹងគោលនយោបាយឈ្លានពានរបស់កូរ៉េខាងជើង នៅក្នុងតំបន់ដែរឬទេ។ ក្នុងន័យនេះ ប្រទេសជប៉ុននឹងមិនមែនជាអ្នកគ្រប់គ្រងលើកម្មវិធី អាវុធទាំងនេះទេ ហើយការសម្រេចចិត្តថាបាញ់ឬអត់ នឹងស្ថិតនៅលើកណ្តាប់ដៃរបស់សហរដ្ឋអាមេរិក ទោះបីជាមន្ត្រីយោធាអាមេរិកបានសន្យាថានឹងពិគ្រោះជាមួយអ្នក អំពីការប្រើប្រាស់អាវុធទាំងនោះក្តី។

ចូរជ្រើសរើសគោលនយោបាយរបស់អ្នក

តើអ្នកនឹងឆ្លើយតបយ៉ាងណាចំពោះសម្ពាធរបស់សហរដ្ឋអាមេរិក ក្នុងការដាក់អាវុធនុយក្លេអ៊ែររបស់ខ្លួននៅលើទឹកដីរបស់អ្នក? តើអ្នកនឹងប្រថុយប្រថានចំពោះប្រតិកម្មរិះគន់ពីពលរដ្ឋរបស់អ្នក ដែលភាគច្រើនគាំទ្រប្រទេសជប៉ុនគ្មាននុយក្លេអ៊ែរដែរឬទេ? តើអ្នកនឹងបដិសេធសម្ពាធពីសហរដ្ឋអាមេរិក ដែលជាសម្ព័ន្ធមិត្តដ៏សំខាន់បំផុតរបស់អ្នក ហើយបដិសេធអាវុធទាំងនោះដែរឬទេ? តើអ្នកបារម្ភខ្លាចកូរ៉េខាងជើងកាន់តែគឃ្លើនកោងកាចខ្លាំងជាងនេះដែរឬទេ ប្រសិនបើអ្នកកាន់អាវុធទាំងនោះ? ឬក៏ថាអាវុធទាំងនោះនឹងពង្រឹងការរារាំងប្រឆាំងនឹងរបបឈ្លានពានដែរឬទេ? តើអ្នករក្សាតុល្យភាពរវាងមតិសាធារណៈក្នុងស្រុកជាមួយនិងសម្ពាធពីសម្ព័ន្ធមិត្តនិងការគំរាមកំហែងសន្តិសុខអន្តរជាតិ យ៉ាងដូចម្តេច?

មតិសាធារណៈ និងទំនាក់ទំនងអន្តរជាតិ

ផលប្រយោជន៍ជាតិ និងគោលនយោបាយបរទេស

ដូចដែលយើងពិភាក្សាក្នុងមេរៀននេះ មតិសាធារណៈអាចដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការរៀបចំគោលនយោបាយការបរទេស។ សំណួរជាមូលដ្ឋានមួយសម្រាប់ជាសាធារណៈជន នៅក្នុងប្រទេសណាមួយ គឺថាតើត្រូវលះបង់ប្រយោជន៍របស់ប្រទេសក្នុងកំរិតណា ដើម្បីប្រយោជន៍ជំរុញគោលដៅអន្តរជាតិ ដូចជាផល


ប្រយោជន៍របស់សម្ព័ន្ធមិត្ត។ ជាការពិតណាស់ ក្នុងកាល:ទេស:មួយចំនួន ផលប្រយោជន៍ផ្ទាល់របស់ប្រទេសមួយដើរស្របទិសគ្នាជាមួយនឹងផលប្រយោជន៍នៃសម្ព័ន្ធមិត្ត។ ជាឧទាហរណ៍ សមាជិកណាតូទាំងអស់មានផលប្រយោជន៍ជាតិនិងសមូហភាពខ្លាំងក្លាក្នុងការទប់ស្កាត់ការឈ្លានពានរបស់សូវៀត នៅអឺរ៉ុប។

ប៉ុន្តែ ក្នុងកាល:ទេស:ផ្សេងទៀត ជំរើសគោលនយោបាយការបរទេសគឺជាការដោះដូររវាងអាទិភាពរបស់ប្រទេសណាមួយជាមួយនិងផលប្រយោជន៍របស់ប្រទេសដទៃ។ សូមរំលឹកពីការពិភាក្សារបស់យើងអំពីផលប្រយោជន៍រួម៖ ការជិះសេះលែងដៃនឹងផ្តល់អត្ថប្រយោជន៍ដល់សុខុមាលភាពផ្ទាល់ខ្លួនរបស់រដ្ឋណាមួយ (ផលប្រយោជន៍ជាតិ) ជាថ្នូរនឹងការខាតបង់ចំពោះក្រុម (ផលប្រយោជន៍របស់សម្ព័ន្ធមិត្ត)។ ជាឧទាហរណ៍ អង្គការណាតូបានស្នើអោយរដ្ឋជាសមាជិកចូលរួមបញ្ជូនកម្លាំងយោធារបស់ខ្លួនផ្ទាល់ ទៅក្នុងជម្លោះនៅក្នុងប្រទេសអាហ្វហ្គានីស្តាន ប៉ុន្តែរដ្ឋសមាជិកខ្លះមិនអាចធ្វើទៅរួចទេ ខណៈប្រទេសខ្លះបានដកកងទ័ពរបស់ពួកគេចេញ ដោយសារសម្ពាធនយោបាយ នៅក្នុងសាមីប្រទេសរៀងៗខ្លួន (សូមមើលមេរៀនទី ២)។

នៅឆ្នាំ ២០១៦ ការស្ទាបស្ទង់មតិសាធារណៈរបស់អង្គភាព Pew បានសាកសួរពលរដ្ឋនៃប្រទេសមួយចំនួនថា តើមេដឹកនាំរបស់ពួកគេគួរតែបង្កើតគោលនយោបាយការបរទេស ដោយគិតតែផលប្រយោជន៍ជាតិឬក៏ត្រូវគិតពីផលប្រយោជន៍របស់សម្ព័ន្ធមិត្តផងដែរ។ លទ្ធផលបានបង្ហាញពីភាពខុសគ្នាគួរឱ្យកត់សម្គាល់រវាងប្រជាជននៃប្រទេសនីមួយៗ (សូមមើលក្រាហ្វិក ៤.៤ សម្រាប់ការប្រៀបធៀបចម្លើយតបរវាងប្រទេសទាំងឡាយ)។

ក្រាហ្វិក ៤.៤ ការកំណត់ផលប្រយោជន៍ជាតិនៅក្នុងប្រទេសចំនួន១២

(ប្រភព៖ មជ្ឈមណ្ឌលសិក្សាស្រាវជ្រាវPew)



(*សម្គាល់៖* បន្ទាត់ខាងលើតំណាងត្រឹមតែផលប្រយោជន៍ជាតិ, បន្ទាត់ខាងក្រោមផលប្រយោជន៍សម្ព័ន្ធមិត្តផងដែរ)

ដូចដែលបានពិភាក្សានៅក្នុងមេរៀនទី ១ ប្រតិកម្មមួយប្រឆាំងតបតនឹងសកលភាវូបនីយកម្ម នាពេលថ្មីៗនេះ បានរួមបញ្ចូលនៃការវិលត្រឡប់ទៅរកស្មារតីជាតិនិយមវិញ។ ទំនោរគួរឱ្យចាប់អារម្មណ៍មួយ នៅក្នុង

ទិន្នន័យ គឺថា រដ្ឋដែលបានធ្លាប់រងគ្រោះពីសម្ពាធនៃសកលភាវូបនីយកម្មមួយចំនួន នាពេលថ្មីៗ ដូចជា វិបត្តិហិរញ្ញវត្ថុ (ដូចជាប្រទេសក្រិក អ៊ីតាលី និងអេស្ប៉ាញ) ឬ កំណើនការធ្វើចំណាកស្រុកចេញពីជម្លោះក្នុងប្រទេសស៊ីរី ឬ ប្រទេសលីប៊ី (ដូចជា ចក្រភពអង់គ្លេស បារាំង អ៊ីតាលី និងហុងគ្រី) មានភាគរយប្រជាជនច្រើន ដែលចង់អោយរដ្ឋគិតតែផលប្រយោជន៍ជាតិរបស់ខ្លួនតែប៉ុណ្ណោះ។ ទោះយ៉ាងណាក៏ដោយ ក៏មានករណីលើកលែងមួយចំនួនផងដែរ។ ពលរដ្ឋអាឡឺម៉ង់ ដែលរងផលប៉ះពាល់ដោយវិបត្តិហិរញ្ញវត្ថុផង និងសម្ពាធការធ្វើចំណាកស្រុកផង ជឿជាក់យ៉ាងលើសលប់ថា ផលប្រយោជន៍របស់សម្ព័ន្ធមិត្តគួរតែជើរតួរមួយក្នុងគោលនយោបាយការបរទេស។

និន្នាការគួរអោយកត់សម្គាល់ទៅលើទិន្នន័យមួយទៀត គឺថា លើកលែងតែប្រទេសអាឡឺម៉ង់ ក្រិក និងឥណ្ឌា ប្រជាជននៃប្រទេសជាច្រើនមានមតិផ្ទុយគ្នាចំពោះសំណួរខាងលើ៖ ស្ទើរតែ មិនលើសខ្វះគ្នា ចំនួន ១០ ភាគរយ។ ក្រាហ្វិកនេះបានចង្អុលបង្ហាញពីការបែងចែកមតិគ្នា នៅក្នុងប្រទេសទាំងអស់នេះ អំពីសំណួរថា តើផលប្រយោជន៍របស់ជាតិប៉ុន្មានភាគរយគួរដាក់បញ្ចូលក្នុងគោលនយោបាយការបរទេស បើធៀបនឹងផលប្រយោជន៍របស់សម្ព័ន្ធមិត្ត។ ដោយសាររឿងរ៉ាវជាច្រើន ដូចជា ការធ្វើប្រជាមតិចាកចេញពីសហភាពអឺរ៉ុបរបស់ចក្រភពអង់គ្លេស មនោសញ្ចេតនាប្រឆាំងនឹងសហភាពអឺរ៉ុបនៅក្នុងប្រទេសក្រិក កំណើនគណបក្សជាតិនិយមនៅក្នុងប្រទេសបារាំង ប៉ូឡូញ និងហុងគ្រី និងការបោះឆ្នោតជ្រើសរើសលោក ដូណាល់ ត្រាំ ជាប្រធានាធិបតីថ្មីរបស់សហរដ្ឋអាមេរិក លទ្ធផលទាំងនេះដូចជាមិនគួរអោយភ្ញាក់ផ្អើលខ្លាំងនោះទេ។ នៅទូទាំងពិភពលោក សាធារណជនកំពុងសម្លឹងមើលផ្ទៃក្នុង កាន់តែខ្លាំងឡើង ដើម្បីផ្តោតលើបញ្ហាការរស់នៅផ្ទាល់ខ្លួនច្រើន ជាជាងបញ្ហានៅបរទេស។

តោះ! សាកល្បងពិភាក្សាអំពីបញ្ហាជាក់ស្តែង

តើស្ថាប័ននីតិប្បញ្ញត្តិគួរតែជើរតួនាទីក្នុងការសម្រេចចិត្តថា តើត្រូវប្រើកម្លាំងយោធាដែរឬទេ?

ទិដ្ឋភាពទូទៅ

នៅក្នុងប្រទេសប្រជាធិបតេយ្យស្ទើរតែទាំងអស់ មានការដេញដោលគ្នាអំពីមធ្យោបាយដ៏ល្អបំផុតដើម្បីធ្វើគោលនយោបាយការបរទេស។ ជាឧទាហរណ៍ បញ្ហាចម្រូងចម្រាសដ៏ក្តៅគគុកមួយពាក់ព័ន្ធនឹងការប្រើប្រាស់កម្លាំងយោធាដែលបណ្តាលអោយបង្កើតភ្លើងសង្គ្រាម។ ប្រមុខស្ថាប័ននីតិប្រតិបត្តិ (រួមមានប្រធានាធិបតី ឬនាយករដ្ឋមន្ត្រី)ជាធម្មតាអះអាងថាខ្លួនមានសិទ្ធិអំណាចផ្តួចផ្តើមប្រើប្រាស់កម្លាំងទ័ពក្នុងហានៈជាមេបញ្ជាការកំពូលលើកងទ័ពរបស់ពួកគេ។ ប៉ុន្តែ ស្ថាប័ននីតិបញ្ញត្តិ (សភា ឬព្រឹទ្ធសភា) អាចនឹងជំទាស់ ដោយអះអាងថាពួកគេគួរតែមានសិទ្ធិសម្រេចថាតើប្រទេសខ្លួនគួរតែទៅធ្វើសង្គ្រាមឬអត់។

នៅសហរដ្ឋអាមេរិក ប្រធានាធិបតីគឺជាមេបញ្ជាការយោធាកំពូល ហើយដូច្នេះ គាត់មានអំណាចបញ្ជាអោយដាក់ពង្រាយកងកម្លាំងទ័ពអាមេរិក។ ប៉ុន្តែ ព្រឹទ្ធសភាមានអំណាចផ្តាច់មុខក្នុងការប្រកាសសង្គ្រាម។ នេះបានបណ្តាលអោយមានការដេញដែកវែកញែកយ៉ាងទូលំទូលាយ នៅក្នុងសហរដ្ឋអាមេរិកថា តើនរណាមានសិទ្ធិអំណាចចុងក្រោយដើម្បីធ្វើសកម្មភាពយោធា។ ខណៈពេលដែលប្រធានាធិបតីមានគុណសម្បត្តិទូលំទូលាយ នៅក្នុងផ្នែកចារកម្មសម្ងាត់និងការវិភាគយោធា (ដោយសារតែស្ថាប័នការិយាធិបតេយ្យទទួលបន្ទុកគោលនយោបាយបរទេសរាយការណ៍ផ្ទាល់ទៅប្រធានាធិបតី មិនមែនសភានោះទេ) សភាជាអ្នកអនុម័តកញ្ចប់ថវិកាដើម្បីចំណាយសម្រាប់សកម្មភាពយោធា។ ហើយទោះបីជាប្រធានាធិបតីអាមេរិក ជារឿយៗ

ស្វែងរកការយល់ព្រមពីសភា មុនពេលធ្វើសកម្មភាពយោធាក៏ដោយ ក៏មានករណីលើកលែងពិសេសមួយចំនួនផងដែរ(ឧទាហរណ៍ ការលុកលុយរបស់សហរដ្ឋអាមេរិកចូលប៉ាណាម៉ា ក្នុងឆ្នាំ១៩៨៩)។

តើស្ថាប័ននីតិប្បញ្ញត្តិនិងស្ថាប័ននីតិប្រតិបត្តិគួរមានទំនាក់ទំនងនឹងគ្នាបែបណា ពាក់ព័ន្ធនឹងការប្រើប្រាស់កម្លាំងយោធា? តើការផ្តួចផ្តើមប្រើប្រាស់កម្លាំងយោធាគួរតែស្ថិតក្នុងអំណាចនីតិប្រតិបត្តិតែមួយ ឬក៏ស្ថាប័ននីតិបញ្ញត្តិគួរតែមានសិទ្ធិសម្រេចផងដែរ ថាតើនៅពេលណា និងនៅកន្លែងណា ដែលកងកម្លាំងយោធារបស់ប្រទេស ត្រូវដាក់ពង្រាយប្រកបដោយគ្រោះថ្នាក់?

អំណះអំណាង ១

ស្ថាប័ននីតិប្បញ្ញត្តិមិនគួរមានតួនាទីក្នុងការសម្រេចចិត្តថាតើត្រូវប្រើកម្លាំងយោធាទេ។

ស្ថាប័ននីតិប្បញ្ញត្តិមានភាពយឺតយ៉ាវក្នុងការធ្វើសកម្មភាព ក្នុងពេលមានវិបត្តិកើតឡើង។

នោះដោយសារសភាមានសមាជិករាប់រយនាក់ វាពិតជាការពិបាកក្នុងការសម្រេចបានកិច្ចព្រមព្រៀងក្នុងចំណោមសមាជិកទាំងអស់ ក្នុងការកំណត់អ្វីដែលជាបញ្ហាគំរាមកំហែងដល់សន្តិសុខជាតិ។ ការពិភាក្សាដើម្បីសម្រេចថាតើគួរត្រូវប្រើកម្លាំងយោធាដែរឬក៏អត់ អាចជាកិច្ចការដែលអូសបន្លាយពេលយូរ ដែលអាចជាក់កំរិតលើសមត្ថភាពរបស់ប្រទេសមួយ ក្នុងការឆ្លើយតបទៅនឹងគ្រោះថ្នាក់ អោយបានទាន់ពេលវេលា។ ផ្ទុយពីនេះ ប្រមុខដឹកនាំស្ថាប័ននីតិប្រតិបត្តិមានលទ្ធភាពទទួលបានព័ត៌មានឆាប់រហ័សទាន់ពេលវេលាជាងផងដែរ។

ការពិភាក្សាផ្ទៃក្នុង អាចបង្ហាញពីការបែកបាក់អោយសត្រូវបានឃើញ។

ការជជែកវែកញែកអំពីការប្រើប្រាស់និងរៀបចំកម្លាំងយោធាអាចបង្ហាញពីការបែងចែកផ្ទៃក្នុង ដោយបើកចំហរដែល ដែលអាចលើកទឹកចិត្តអោយសត្រូវនៅតែរក្សាភាពរឹងរូសនៅក្នុងការចរចា។ ប្រសិនបើសត្រូវដឹងថាប្រទេសមួយមានការបែកបាក់គ្នាខ្លាំង ក្នុងការប្រើប្រាស់កម្លាំងយោធាប្រឆាំងនឹងប្រទេសរបស់ខ្លួននោះ វានឹងមិនចាត់ទុកការគំរាមកំហែងក្នុងការប្រើប្រាស់កម្លាំងទ័ព ថាជាទង្វើនឹងកើតមានឡើងឡើយ បានតែគំរាម។

សមាជិកសភាតិចណាស់ដែលយល់ដឹងអំពីកិច្ចការបរទេស។

សមាជិកសភាភាគច្រើនត្រូវបានជ្រើសរើសដើម្បីបម្រើផលប្រយោជន៍ក្រុមអ្នកបោះឆ្នោតនៅក្នុងស្រុកជាជាងចំណាយពេលវេលា និងកម្លាំងកាយរបស់ពួកគេក្នុងកិច្ចការបរទេស។ សមាជិកសភាមានការលើកទឹកចិត្តតិចតួចដើម្បីអោយខ្លួនក្លាយជាអ្នកយល់ដឹងជ្រៅជ្រះអំពីកិច្ចការបរទេស ដូច្នេះការសម្រេចចិត្តរបស់ពួកគេថាតើត្រូវប្រើប្រាស់កម្លាំងយោធា ហាក់ជាការសម្រេចចិត្តដោយមិនមានព័ត៌មានគ្រប់ជ្រុងជ្រោយ។

អំណះអំណាង ២

ស្ថាប័ននីតិប្បញ្ញត្តិគួរតែដើរតួនាទីក្នុងការសម្រេចចិត្តថាតើត្រូវប្រើកម្លាំងយោធាដែរឬអត់ ផងដែរ។

ការបន្ថែមធាតុចូលកាន់តែច្រើន ទៅក្នុងកិច្ចពិភាក្សាអំពីការប្រើប្រាស់កម្លាំងយោធា នាំអោយមានគោលនយោបាយកាន់តែប្រុងប្រយ័ត្នខ្លាំងដែរ។

ការជជែកដេញដោលគ្នាផ្នែកនីតិប្បញ្ញត្តិ ប្រកបដោយប្រសិទ្ធភាព លើការប្រើប្រាស់សក្តានុពលនៃកម្លាំងយោធា អាចនាំទៅរកគោលនយោបាយកាន់តែប្រសើរឡើង ដោយជៀសវាងបញ្ហា ចិត្តសាស្ត្រមួយចំនួនដែលទាក់ទងនឹងការធ្វើការសម្រេចចិត្តជាក្រុមតូចៗ ដូចជាការគិតជាក្រុម ជាដើម។

សមាជិកសភាមានទំនួលខុសត្រូវដោយផ្ទាល់ចំពោះក្រុមអ្នកបោះឆ្នោត។

ដោយសារតែប្រជាពលរដ្ឋរបស់រដ្ឋមួយ ត្រូវទទួលបន្ទុកចំណាយនិងផលវិបាកផ្សេងៗនៃសង្គ្រាម វាជារឿងសមរម្យណាស់ដែលស្ថាប័នតំណាងរាស្ត្រមានសិទ្ធិអំណាចចូលរួមសម្រេចថា តើគួរបញ្ជូនប្រជាជនប្រុសនិងស្រីទៅសមរភូមិប្រយុទ្ធដែរឬទេ។ ការជជែកដេញដោល ដោយបើកចំហរនៅក្នុងស្ថាប័ននីតិប្បញ្ញត្តិ គួរតែអនុញ្ញាតអោយមានសំឡេងសាធារណៈជនចូលរួម។

ស្ថាប័ននីតិប្រតិបត្តិត្រូវមានការត្រួតពិនិត្យនិងថ្លឹងថ្លែង ជាពិសេសទាក់ទងនឹងការសម្រេចចិត្តអំពីសង្គ្រាម។

ដោយសារតែទម្ងន់នៃការសម្រេចចិត្តក្នុងការផ្តើមជម្លោះយោធា វាជារឿងសំខាន់ក្នុងការមានប្រព័ន្ធត្រួតពិនិត្យ និងថ្លឹងថ្លែងតុល្យភាពអំណាច ដើម្បីជាយុទ្ធសាស្ត្រទប់ស្កាត់សង្គ្រាមតក់ក្រហល់។ នៅសហរដ្ឋអាមេរិក រដ្ឋធម្មនុញ្ញផ្តល់អំណាចជាពិសេសដល់ព្រឹទ្ធសភាដើម្បីប្រកាសសង្គ្រាម ដោយសារតែហេតុផលនេះឯង។

សំណួរ

- តើស្ថាប័ននីតិប្បញ្ញត្តិគួរតែដើរតួនាទីក្នុងការសម្រេចចិត្តប្រើប្រាស់កម្លាំងយោធាដែរឬទេ? តើមានកាលៈទេសៈណាខ្លះ ដែលវាហុចផលប្រសើរជាង ឬអាក្រក់ជាង សម្រាប់សង្គមក្នុងការពិភាក្សាដោយបើកចំហអំពីសកម្មភាពយោធា ដែលនឹងត្រូវកើតឡើង?
- ប្រភេទនៃសកម្មភាពយោធា តើស្ថាប័ននីតិប្បញ្ញត្តិគួរតែដើរតួយ៉ាងសំខាន់ក្នុង ផ្នែកគោលនយោបាយការបរទេសផ្សេងទៀត ដូចជា ទណ្ឌកម្មសេដ្ឋកិច្ច អន្តោប្រវេសន៍ ឬសម្ព័ន្ធភាពយោធា? តើបញ្ហានយោបាយការបរទេសទាំងនេះ ស្រដៀងគ្នា ឬខុសគ្នាយ៉ាងណាពីបញ្ហានៃការប្រើកម្លាំងយោធា?
- តើអ្នកគិតថា ប្រទេសដែលអាចក្លាយសត្រូវ យកចិត្តទុកដាក់លើការជជែកដេញដោលក្នុងប្រទេសដែលកំពុងគំរោងរៀបចំកម្លាំងយោធាដែរឬទេ? តើប្រទេសដែលអាចក្លាយសត្រូវប្រើប្រាស់ព័ត៌មាននេះដើម្បីផលប្រយោជន៍របស់ពួកគេដែរឬទេ? តើនេះគួរជាកង្វល់សម្រាប់ប្រទេសដែលកំពុងគិតគូរពីការប្រើកម្លាំងយោធាដែរឬទេ?

និស្សិតអាចសាកល្បងអានឯកសារខាងក្រោមបន្ថែមទៀត ដើម្បីជាគ្រឹះក្នុងការឆ្លើយសំណួរទាំងអស់ខាងលើ ៖

- Feaver, Peter D., and Christopher Gelpi. Choosing Your Battles: American Civil-Military Relations and the Use of Force. Princeton, 2003.
- Fisher, Louis. Presidential War Power. 3rd ed. Rev. Kansas, 2013.
- Howell, William G., and Jon C. Pevehouse. While Dangers Gather: Congressional Checks on Presidential War Powers. Princeton, 2007.
- Thurber, James A., and Jordan Tama. A Creative Tension: The Foreign Policy Roles of the President and Congress. Rowman & Littlefield, 2017

អាជីពក្នុងចំណាត់ចំនងអន្តរជាតិ៖ រដ្ឋាភិបាល និងការទូត

សង្ខេប

ការងារក្នុងរដ្ឋាភិបាលនិងការទូតផ្តល់ឱកាសអោយបណ្តាអ្នកចេះសហការក្រុម ជះឥទ្ធិពលលើគោលនយោបាយ ប៉ុន្តែការងារទាំងនេះទាមទារការអត់ធ្មត់ជាមួយការិយាធិបតេយ្យធំៗ។

អត្ថប្រយោជន៍ និងការចំណាយ

ទាំងរដ្ឋាភិបាល និងអង្គការអន្តររដ្ឋាភិបាល (IGOs) ដើរតួនាទីយ៉ាងសំខាន់ក្នុងទំនាក់ទំនងអន្តរជាតិ (IR) និងផ្តល់ការងារដល់មនុស្សរាប់លាននាក់ដែលមានចំណាប់អារម្មណ៍ និងការបណ្តុះបណ្តាលនៅក្នុងមុខជំនាញ IR ។

ទោះបីជាមានភាពខុសគ្នារវាងអាជីពនៅក្នុងរដ្ឋាភិបាល និងនៅក្នុងអង្គការអន្តររដ្ឋាភិបាលក៏ដោយ ក៏មានភាពស្រដៀងគ្នាជាច្រើន។ ប្រភេទទាំងពីរគឺជាអង្គការតាមឋានានុក្រម ជាមួយនឹងបរិយាកាសការងារដែលមានលក្ខណៈប្រកួតប្រជែងនិងគ្រប់គ្រងខ្ពស់។ មិនថានៅក្នុងក្រសួងការបរទេសសហរដ្ឋអាមេរិក ឬអង្គការសហប្រជាជាតិទេ ការចូលធ្វើការនិងការតម្លើងឋានន្តរសក្តិនៅក្នុងអង្គការទាំងនេះត្រូវបានគ្រប់គ្រងដោយការប្រឡង ការវាយតម្លៃការអនុវត្ត និងក្របខ័ណ្ឌជាមួយអង្គការ។

ភាពស្រដៀងគ្នាមួយទៀត ស្ថិតនៅក្នុងបញ្ហាប្រឈមនៃការអូសទាញក្នុងទិសដៅជាច្រើនទាក់ទងនឹងគោលនយោបាយ។ រដ្ឋាភិបាលប្រឈមមុខនឹងសម្ពាធប្រកួតប្រជែងនៃមតិសាធារណៈ ក្រុមអ្នកបោះឆ្នោត និងក្រុមផលប្រយោជន៍ ដោយក្រុមនីមួយៗមានគំនិតគោលនយោបាយខុសៗគ្នា។ អង្គការអន្តររដ្ឋាភិបាល ក៏ត្រូវដោះស្រាយជាមួយក្រុមផលប្រយោជន៍ដូចជា អង្គការមិនមែនរដ្ឋាភិបាល (NGOs) ប៉ុន្តែធាតុផ្សំរបស់អង្គការអន្តររដ្ឋាភិបាល គឺជារដ្ឋ ដែលក្នុងករណីជាច្រើន ពួកគេថែមទាំងមិនមានការយល់ស្របគ្នាផង។

បុគ្គលិកជាច្រើនរបស់រដ្ឋាភិបាល ឬ អង្គការអន្តររដ្ឋាភិបាលរីកចម្រើនដោយសារការសម្រេចចិត្តដែលមានឥទ្ធិពលលើគោលនយោបាយ។ បរិយាកាសការងារទាំងពីរក៏ទាក់ទាញអ្នករួមការងារដែលមានចំណាប់អារម្មណ៍យ៉ាងជ្រាលជ្រៅក្នុងកិច្ចការអន្តរជាតិ ហើយបណ្តាញទំនាក់ទំនងជាលទ្ធផលអាចនាំមកនូវរង្វាន់ប្រកបដោយវិជ្ជាជីវៈនិងបញ្ញា។ ជាចុងក្រោយ ការងារនៅក្នុងរដ្ឋាភិបាល ឬអង្គការអន្តររដ្ឋាភិបាលអាចពាក់ព័ន្ធនឹងការធ្វើដំណើរ ឬការរស់នៅក្រៅប្រទេស ដែលមនុស្សជាច្រើនចូលចិត្ត។

ទោះជាយ៉ាងណាក៏ដោយ ការតម្លើងឋានន្តរសក្តិអាចមានភាពយឺតយ៉ាវ និងមានការខកចិត្ត។ ជាធម្មតា មានតែបុគ្គលដែលមានសញ្ញាបត្រកម្រិតខ្ពស់ ឬជំនាញបច្ចេកទេសប៉ុណ្ណោះ ដែលតាំងពីពេលចូលដំបូង ទទួលបានមុខតំណែងខ្ពស់តែម្តង។ វាអាចចំណាយពេលច្រើនឆ្នាំក្នុងការកើនឡើងឋានៈក្នុងស្ថាប័ន ហើយដំណើរការនេះ អាចពាក់ព័ន្ធនឹងការធ្វើការក្នុងនាយកដ្ឋាន ឆ្ងាយពីចំណាប់អារម្មណ៍ដើមដំបូងរបស់បុគ្គល។ លើសពីនេះ ទាំងរដ្ឋាភិបាលនិងអង្គការអន្តររដ្ឋាភិបាល គឺជាការិយាធិបតេយ្យដែលមានច្បាប់ និងនីតិវិធីផ្លូវការ ដែលទាមទារការអត់ធ្មត់ខ្លាំង។ និយោជិតជារឿយៗបង្ហាញការខកចិត្តដែលគំនិតផ្តួចផ្តើម និង «ការគិតក្រៅប្រអប់« មិនត្រូវបានផ្តល់រង្វាន់ទេ។

ជំនាញត្រូវដុសខាត់

គន្លឹះក្នុងការធ្វើការនៅក្នុងជួររដ្ឋាភិបាល ឬ អង្គការអន្តររដ្ឋាភិបាល គឺត្រូវឈានជើងរបស់អ្នកចូលមាត់ទ្វារ។ ត្រូវមានភាពបត់បែន និងមានឆន្ទៈក្នុងការទទួលយកមុខតំណែងកម្រិតចូលដំបូង ដែលមិនពិតប្រាកដនៅក្នុងវិស័យដែលអ្នកចាប់អារម្មណ៍។ ជាឧទាហរណ៍ ក្រសួងការបរទេសគ្រាន់តែជាផ្នែកមួយក្នុងចំណោមផ្នែកជាច្រើននៃរដ្ឋាភិបាលសហរដ្ឋអាមេរិកដែលដោះស្រាយជាមួយទំនាក់ទំនងអន្តរជាតិ។ កុំស្មានថាអ្នកត្រូវតែធ្វើការទូតដើម្បីធ្វើការក្នុងកិច្ចការបរទេស។

ការបណ្តុះបណ្តាលភាសាបរទេសក៏មានសារៈសំខាន់ណាស់ដែរ ជាពិសេសសម្រាប់ការងារ នៅក្នុងអង្គការអន្តរជាតិបាលធំៗ ដែលមានការិយាល័យតាមមូលដ្ឋានជាច្រើន។ សមត្ថភាពក្នុងការធ្វើការបានល្អជាក្រុម និងបណ្តាញក្នុង និងទូទាំងស្ថាប័ន គឺជាទ្រព្យសម្បត្តិដ៏សំខាន់។ មនុស្សដែលអាចពង្រឹងបណ្តាញទំនាក់ទំនងអាចទទួលបានការគាំទ្រពីកន្លែងជាច្រើននៅក្នុងអង្គការមួយ។

ជាចុងក្រោយ សមត្ថភាពវិភាគនិងកសរសេរដ៏រឹងមាំ មានប្រយោជន៍ខ្លាំងណាស់។ ទាំងរដ្ឋាភិបាលនិងអង្គការអន្តរជាតិបាល ដោះស្រាយជាមួយនឹងព័ត៌មានច្រើនសន្ធឹកសន្ធាប់ ជារៀងរាល់ថ្ងៃ។ សមត្ថភាពក្នុងការវិភាគព័ត៌មាន (សូម្បីតែរាប់បញ្ចូលទាំងការវិភាគគណិតវិទ្យាឬការគណនា) និងការសរសេរ ការបកស្រាយច្បាស់លាស់ និងជំនាញសង្ខេប នឹងធ្វើឱ្យតម្លៃមួយមិនអាចកាត់ថ្លៃបាន។

រូបថត ការិយាល័យដ៏ធំមួយ

ធនធានបន្ថែម

1. Dorman, Shawn. *Inside a U.S. Embassy: Diplomacy at Work.* 3rd ed. Potomac, 2011.
2. Fasulo, Linda. *An Insider's Guide to the UN*. 3rd ed. Yale, 2015.
3. http://jobs.un.org
4. http://careers.state.gov
5. http://www.usajobs.gov

ឯកសារគួរអានបន្ថែម

- Allison, Graham T., and Philip Zelikow. *Essence of Decision: Explaining the Cuban Missile Crisis.* 2nd ed. Longman, 1999.
- Beasley, Ryan K., et al., eds. *Foreign Policy in Comparative Perspective: Domestic and International Influences on State Behavior.* CQ Press, 2002.
- Holsti, Ole R. *Public Opinion and American Foreign Policy.* Rev. ed. Michigan, 2004.
- Milner, Helen V., and Dustin Tingley. *Sailing the Water's Edge: The Domestic Politics of American Foreign Policy*. Princeton, 2015.
- Neustadt, Richard E., and Ernest R. May. *Thinking in Time: The Uses of History for Decision Makers.* Free Press, 1986.
- Page, Benjamin I., and Marshall M. Bouton. *The Foreign Policy Disconnect.* Chicago, 2006.
- Smith, Tony. *Foreign Attachments: The Power of Ethnic Groups in the Making of American Foreign Policy.* Harvard, 2000.

មេរៀនទី ០៥ ៖ ជំលោះអន្តរជាតិ

រូបថត ឧទ្ទាមហ៊ូឌី នៅប្រទេសយេម៉ែន ឆ្នាំ ២០១៧

វត្ថុបំណងមេរៀន

៥.១ ចូរបែងចែកភាពខុសគ្នារវាងទ្រឹស្តីពីរផ្សេងគ្នាសម្រាប់ពន្យល់បុព្វហេតុនៃសង្គ្រាម ដោយប្រើកម្រិតវិភាគពីរផ្សេងគ្នាដែរ។

៥.២ ចូរលើកឧទាហរណ៍នៃជម្លោះអន្តរជាតិ យ៉ាងតិចចំនួន ៤ ផ្សេងគ្នា ដែលបណ្តាលមកពីកត្តាសាសនា ឬដែលសាសនាបណ្តាលអោយជម្លោះកាន់តែធ្ងន់ធ្ងរឡើងៗ។

៥.៣ ចូរសង្ខេបជម្លោះទឹកដីអន្តរជាតិពីរផ្សេងគ្នា និងវាយតម្លៃពីលទ្ធភាពនៃការដោះស្រាយដោយសន្តិវិធី។

៥.១. សង្គ្រាមលោក

៥.១ ចូរបែងចែកភាពខុសគ្នារវាងទ្រឹស្តីពីរផ្សេងគ្នាសម្រាប់ពន្យល់បុព្វហេតុនៃសង្គ្រាម ដោយប្រើកម្រិតវិភាគពីរផ្សេងគ្នាដែរ។

មេរៀនទី៣ (នៅក្នុងផ្នែក **៣.១. សង្គ្រាមថមថយ**) បានពិភាក្សាអំពីការថយចុះចំនួន និងទំហំនៃសង្គ្រាមនៅក្នុងពិភពលោក។ មេរៀននេះនឹងផ្តោតលើសង្គ្រាមដែលបន្តកើតមាន និងករណីប្រវត្តិសាស្ត្រ ដើម្បីពន្យល់ពីមូលហេតុនៃជម្លោះអន្តរជាតិ។

ក្រាហ្វិក ៥.១ បង្ហាញពីសង្គ្រាមចំនួន ១៤ ដែលកំពុងកើតឆាបឆេះ នៅត្រឹមខែធ្នូ ឆ្នាំ ២០១៨។ សង្គ្រាមធំបំផុតផ្ទុះឡើងនៅក្នុងប្រទេសស៊ីរី អាហ្វហ្គានីស្ថាន និងអ៊ីរ៉ាក់ដែលនៅជិតខាង។ ក្នុងចំណោមសង្គ្រាមទាំង ១៤, សង្គ្រាមចំនួន ១៣ ស្ថិតនៅក្នុងអឌ្ឍគោលខាងត្បូង។ សង្គ្រាមទាំងអស់លើកលែងតែអ៊ុយក្រែន និង ហ្វីលីពីន ស្ថិតនៅក្នុងតំបន់ដែលមានការប្រយុទ្ធយ៉ាងសកម្ម (ដូចដែលគូសបញ្ជាក់នៅលើផែនទី) ដែលលាតសន្ធឹងគ្របដណ្តប់លើផ្នែកខ្លះនៃទ្វីបអាហ្វ្រិក តំបន់មជ្ឈិមបូព៌ា និងអាស៊ីខាងត្បូង។

នៅក្នុងតំបន់តូចៗជាងនេះ ចំនួនបួន (បន្ទាត់ជាច់ៗនៅលើផែនទី) សង្គ្រាម បួនដប់ក្នុងប៉ុន្មានទសវត្សរ៍ថ្មីៗនេះ ត្រូវបានបញ្ចប់។ ប្រទេសមួយចំនួននៅក្នុងតំបន់ទាំងនេះនៅតែប្រឈមមុខនឹងឧបសគ្គដ៏លំបាក ក្នុងប៉ុន្មានឆ្នាំក្រោយសង្គ្រាមចប់ ជាមួយនឹងលទ្ធភាពនៃការផ្ទុះអំពើហិង្សាឡើងវិញ។ ជាឧទាហរណ៍ នៅប្រទេសសៀរ៉ាឡេអូន សង្គ្រាមស៊ីវិលរយៈពេលដប់ឆ្នាំត្រូវបានបញ្ចប់ នៅឆ្នាំ ២០០២ ប៉ុន្តែអស្ថិរភាពនយោបាយម្តងម្កាលបានគំរាមកំហែងបញ្ឆេះភ្នក់ភ្លើងជម្លោះឡើងវិញ។ ក្រុមឧទ្ទាមដ៏ធំបំផុតនៅក្នុងប្រទេសកូឡុំប៊ីបានចាប់ផ្តើមរំសាយអាវុធ នៅក្នុងឆ្នាំ ២០១៦ ប៉ុន្តែ អ្នកសង្កេតការណ៍មួយចំនួនមានការភ័យខ្លាចថាការបោះឆ្នោតនៅទីនោះអាចផ្តល់ អំណាចអោយរដ្ឋាភិបាលដែលប្រឆាំងនឹងកិច្ចព្រមព្រៀងសន្តិភាពនាពេលថ្មីៗនេះ។ ហើយខណៈពេលដែលជម្លោះនៅក្នុងប្រទេសហ្វីលីពីនបានកើនឡើងកំដៅ ក្នុងរយៈពេល ៤ ឆ្នាំចុងក្រោយនេះ អាស៊ីអាគ្នេយ៍ភាគច្រើននៅតែមានសន្តិភាពជាទូទៅ។ ប៉ុន្តែ ជាការពិតណាស់ កិច្ចព្រមព្រៀងសន្តិភាពភាគច្រើន នៅក្នុងតំបន់នានាក្រោយចុងបញ្ចប់នៃសង្គ្រាម នៅមានដំណើរការនៅឡើយទេ(ចូរមើលឧទាហរណ៍បន្ថែមស្តីពីការស្វែងរកដំណោះស្រាយបញ្ហាផលប្រយោជន៍រួម)។

ក្រាហ្វិក ៥.១ សង្គ្រាមកំពុងឆាបឆេះខែឧសភា ឆ្នាំ ២០១៨

សម្គាល់៖
បន្ទះធំតំណាងឲ្យចំនួនអ្នកស្លាប់លើស ពី ១០០០ នាក់ក្នុង១ឆ្នាំ
បន្ទះតូចតំណាងឲ្យចំនួនអ្នកស្លាប់តិចជាង ១០០០ នាក់ក្នុង១ឆ្នាំ
ផ្នែងបន្ទាត់ជាប់ តំណាងសង្គ្រាមកំពុងកើតឡើង ប៉ុន្តែបន្ទាត់ជាប់ៗ តំណាងតំបន់អន្តរការបញ្ឈប់សង្គ្រាម ក្នុងប៉ុន្មានទសវត្សរ៍ចុងក្រោយ

៥.១.១. ប្រភេទនៃសង្គ្រាម

សកម្មភាពផ្សេងៗគ្នាជាច្រើនត្រូវបានហៅជារួមដោយពាក្យទូទៅមួយ *សង្គ្រាម*។ អាស្រ័យហេតុនេះហើយ វាមិនងាយស្រួលប៉ុន្មានទេ ក្នុងការនិយាយថា តើមានសង្គ្រាមចំនួនប៉ុន្មានកំពុងកើតឡើងនៅលើពិភពលោកនៅពេលនេះ។ ប៉ុន្តែ បញ្ហាសង្គ្រាមភាគច្រើនត្រូវបានកំណត់លក្ខណៈវិនិច្ឆ័យអប្បបរមាមួយចំនួន ក្នុងនោះ ជាឧទាហរណ៍ យ៉ាងហោចណាស់មានអ្នកស្លាប់ក្នុងសមរភូមិមួយពាន់នាក់ ដើម្បីបែងចែកភាពខុសគ្នារវាងសង្គ្រាមនិងអំពើហិង្សាកម្រិតទាប ដូចជាបាតុកម្មហិង្សាឬកុបកម្មជាដើម។

សង្គ្រាមមានលក្ខណៈខុសប្លែកគ្នាជាច្រើន។ សង្គ្រាមផ្ទុះចេញពីស្ថានភាពផ្សេងៗគ្នា ហើយដើរតួនាទីផ្សេងគ្នាក្នុងការចរចាលើដម្លោះ។ ដោយចាប់ផ្តើមពីសង្គ្រាមដ៏ធំបំផុត យើងអាចបែងចែកសង្គ្រាមជាប្រភេទសំខាន់ៗ ដូចខាងក្រោម។

សង្គ្រាមអនុត្តរភាព(hegemonic war) គឺជាសង្គ្រាមដណ្តើមគ្រប់គ្រងលើសណ្តាប់ធ្នាប់ពិភពលោកទាំងមូល៖ ក្រិតក្រមច្បាប់នៃប្រព័ន្ធអន្តរជាតិទាំងមូល រួមទាំងតួនាទីនៃអនុត្តរភាពពិភពលោក (សូមមើលអនុត្តរភាព, នៅក្នុងមេរៀនទី ២)។ សង្គ្រាមប្រភេទនេះ (ដោយមាននិយមន័យ និងបញ្ញត្តិខុសៗគ្នាខ្លះ) ក៏ត្រូវបានគេស្គាល់ផងដែរថាជា *សង្គ្រាមលោក សង្គ្រាមសកល សង្គ្រាមទូទៅ ឬសង្គ្រាមប្រព័ន្ធ*។ សង្គ្រាមអនុត្តរភាពចុងក្រោយ គឺជាសង្គ្រាមលោកលើកទី២។ ភាគច្រើន ដោយសារតែឫទ្ធានុភាពនៃសព្វាវុធទំនើបសង្គ្រាមប្រភេទនេះប្រហែលជាមិនអាចកើតឡើងដោយមិនបំផ្លាញអរិយធម៌មនុស្សលោកឡើយ។

សង្គ្រាមសរុប(total war) គឺជាសង្គ្រាមដែលផ្តើមដោយរដ្ឋមួយដើម្បីដណ្តើមយកនិងកាន់កាប់រដ្ឋមួយទៀត។ គោលដៅគឺដើម្បីវាយចូលដល់រាជធានី ហើយបង្ខំអោយរដ្ឋាភិបាលរបស់រដ្ឋមួយនោះចុះចាញ់ ដែលបន្ទាប់មក អាចត្រូវបានជំនួសដោយរដ្ឋាភិបាលថ្មី ក្រោមការលើកបន្តុបពីភាគីឈ្នះសង្គ្រាម។ សង្គ្រាមសរុបបានចាប់ផ្តើម ជាមួយនឹងសង្គ្រាមណាប៉ូឡេអុងដ៏បំផ្លិចបំផ្លាញខ្លាំង ដែលបានផ្តើមការកែនកងទ័ព ជាទ្រង់ទ្រាយធំ និងបង្វែរសេដ្ឋកិច្ចជាតិបារាំងទាំងមូលឆ្ពោះទៅរកគោលដៅសង្គ្រាម។ ការចាប់ផ្តើមសង្គ្រាមសរុបបានវិវត្តន៍រួមជាមួយនឹងឧស្សាហូបនីយកម្ម ដែលច្របាច់បញ្ចូលទិដ្ឋភាពសង្គមនិងសេដ្ឋកិច្ចទាំងអស់ទៅក្នុងយុទ្ធនាការសង្គ្រាម។ សង្គ្រាមសរុបចុងក្រោយរវាងប្រទេសមហាអំណាច គឺសង្គ្រាមលោកលើកទី២។

នៅក្នុងសង្គ្រាមសរុប ដោយមានសង្គមទាំងមូលសាមគ្គីគ្នាដើម្បីការតស៊ូនោះ សង្គមសត្រូវទាំងមូលត្រូវបានចាត់ទុកថាជាគោលដៅស្របច្បាប់។ ជាឧទាហរណ៍ ក្នុងសង្គ្រាមលោកលើកទី២ អាឡឺម៉ង់បានវាយប្រហារជនស៊ីវិលអង់គ្លេស ដោយគ្រាប់រ៉ុក្កែត V-២ ខណៈដែលអង់គ្លេស និងអាមេរិកទម្លាក់គ្រាប់បែកយុទ្ធសាស្ត្រ សម្លាប់ជនស៊ីវិលអាឡឺម៉ង់ ចំនួន ៦០០,០០០ នាក់ និងសម្លាប់ជនជាតិជប៉ុនរាប់រយពាន់នាក់។

សង្គ្រាមមានកម្រិត(limited war) រួមមានសកម្មភាពនិងយុទ្ធនាការយោធាដែលធ្វើឡើងដើម្បីទទួលបាននូវគោលដៅមួយចំនួន ដូចជា ការចុះចាញ់និងការកាន់កាប់របស់សត្រូវ។ ជាឧទាហរណ៍ សង្គ្រាមដែលដឹកនាំដោយសហរដ្ឋអាមេរិកប្រឆាំងនឹងអ៊ីរ៉ាក់ក្នុងឆ្នាំ ១៩៩១ បានដណ្តើមយកទឹកដីគុយវ៉ែតអោយប្រទេសគុយវ៉ែតមកវិញ ប៉ុន្តែមិនបានបន្តទៅទីក្រុងបាដាឌដើម្បីផ្តួលរំលំរដ្ឋាភិបាលរបស់ សាដាម ហ៊ូសេន នោះទេ។ សង្គ្រាមតាមព្រំដែនជាច្រើនមានចរិតលក្ខណៈបែបនេះ៖ បន្ទាប់ពីកាន់កាប់ទឹកដីដែលខ្លួនចង់បាន រដ្ឋមួយអាចបញ្ឈប់ភ្លាមៗ និងការពារទឹកដីដែលខ្លួនទើបទទួលបាន ដូចដែលប្រទេសរុស្ស៊ីបានធ្វើ បន្ទាប់ពីការបណ្តេញកងទ័ពហ្សកហ្ស៊ីចេញពីខេត្តរបស់ហ្សកហ្ស៊ី ដែលមានដម្លោះ ក្នុងឆ្នាំ ២០០៨ ជាឧទាហរណ៍ស្រាប់។

ការវាយឆ្មក់(raids)គឺជាសង្គ្រាមមានកម្រិត ដែលរួមបញ្ចូលសកម្មភាពតែមួយ ដូចជា ការទម្លាក់គ្រាប់បែក ឬការលុកលុយភ្លាមៗតាមផ្លូវគោក។ ក្នុងឆ្នាំ ២០០៧ យន្តហោះចម្បាំងអ៊ីស្រាអែលបានទម្លាក់គ្រាប់បែកលើទីតាំងមួយក្នុងប្រទេសស៊ីរី ដែលអ៊ីស្រាអែលជឿថាជាកន្លែងស្រាវជ្រាវនុយក្លេអ៊ែរ ដើម្បីបញ្ឈប់ប្រទេសស៊ីរីមិនអោយមានការរីកចម្រើនទៅមុខ ក្នុងកម្មវិធីអាវុធនុយក្លេអ៊ែរ។ ការវាយឆ្មក់ស្ថិតមិនមែនជាសង្គ្រាម ហើយក៏មិនមែនថាជាទង្វើមិនបង្កសង្គ្រាមដែរ ពោលគឺ វាស្ថិតនៅក្នុងចន្លោះកណ្តាលរវាងសង្គ្រាមនិងមិនមែនសង្គ្រាម ដោយសារតែការបំផ្លិចបំផ្លាញរបស់ពួកគេមានកម្រិត ហើយការវាយប្រហារអាចត្រូវបានបញ្ចប់យ៉ាងឆាប់រហ័ស។ ការវាយឆ្មក់ដែលកើតឡើងម្តងហើយម្តងទៀត ឬចាប់ផ្តើមវដ្តនៃការសងសឹកជាធម្មតា ក្លាយទៅជាសង្គ្រាមមានកម្រិត ឬអ្វីដែលគេហៅថា *ជម្លោះកម្រិតទាប*។

សង្គ្រាមស៊ីវិល(civil war) សំដៅលើសង្គ្រាមរវាងបក្សពួកឬភាគីនានា នៅក្នុងរដ្ឋមួយដែលព្យាយាមបង្កើត ឬរារាំង រដ្ឋាភិបាលថ្មីគ្រប់គ្រងរដ្ឋទាំងមូល ឬផ្នែកខ្លះនៃទឹកដីនៃរដ្ឋនោះ។ (គោលបំណងអាចជាការផ្លាស់ប្តូរប្រព័ន្ធរដ្ឋាភិបាលទាំងមូល ដោយដាក់មនុស្សថ្មីកាន់អំណាច នៅក្នុងរដ្ឋាភិបាលនោះ ឬដើម្បីបំបែកតំបន់មួយចេញជារដ្ឋថ្មីមួយទៀត។) សង្គ្រាមស៊ីវិលរបស់សហរដ្ឋអាមេរិក នៅទសវត្សរ៍ឆ្នាំ ១៨៦០ គឺជាឧទាហរណ៍ដ៏ល្អនៃសង្គ្រាមស៊ីវិលបំបែករដ្ឋ ក៏ដូចជាសង្គ្រាមនៃខេត្តអេរីទ្រា ក្នុងប្រទេសអេត្យូពី (ឥឡូវត្រូវទទួលស្គាល់ជាអន្តរជាតិថាជារដ្ឋអេរីទ្រា) ក្នុងទសវត្សរ៍ឆ្នាំ ១៩៨០។ សង្គ្រាមនៅអែលសាល់វ៉ាឌ័រ (El Salvador) ក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ គឺ ឧទាហរណ៍នៃសង្គ្រាមស៊ីវិលក្នុងគោលដៅគ្រប់គ្រងរដ្ឋទាំងមូល(មិនមែនជាសង្គ្រាមអបគមន៍នោះទេ)។ ជារឿយៗ សង្គ្រាមស៊ីវិលហាក់ដូចជាស្ថិតនៅក្នុងចំណោមសង្គ្រាមដ៏ឃោរឃៅបំផុត។ ទាហានដែលប្រយុទ្ធតទល់នឹងជនរួមជាតិរបស់ខ្លួនប្រព្រឹត្តអំពើឃោរឃៅ មិនបន្ទរដៃដូចដែលពួកគេវាយប្រហារពលរដ្ឋមកពីរដ្ឋផ្សេងនោះទេ។ ចំនួនអ្នកស្លាប់ ៥០,០០០ នាក់ ឬច្រើនជាងនេះនៅក្នុងសង្គ្រាមស៊ីវិលនៅអែលសាល់វ៉ាឌ័រ រួមទាំងប្រជាជនស៊ីវិលជាច្រើនត្រូវរងការសម្លាប់រង្គាល និងក្រុមអត្តឃាត មិនមែនស្លាប់ដោយសារពួកគេមានឈាមជ័រជាជាតិសាសន៍ផ្សេងគ្នានោះទេ។ ជាការពិតណាស់ សង្គ្រាមស៊ីវិលជាច្រើន នាពេលបច្ចុប្បន្ននេះ កើតចេញពីជម្លោះជាតិសាសន៍ ឬ ជម្លោះរវាងកុលសម្ព័ន្ធនានាផងដែរ។ ជាឧទាហរណ៍ នៅប្រទេសឆាដ ក្រុមឧទ្ទាមដែលមកពីកុលសម្ព័ន្ធដែលជាគូប្រជែងនឹងកុលសម្ព័ន្ធរបស់ប្រធានាធិបតី ស្ទើរតែបានផ្តួលរំលំរដ្ឋាភិបាល ក្នុងឆ្នាំ ២០០៧។ ការទ្រទ្រង់សង្គ្រាមស៊ីវិល ជាធម្មតាតម្រូវអោយមានប្រភពគាំទ្រសម្រាប់ពួកឧទ្ទាម ពីប្រទេសជិតខាង ពីសហគមន៍ជនជាតិភាគតិច ឬពីប្រាក់ចំណូលបានពីធនធានធម្មជាតិ ឬ គ្រឿងញៀនខុសច្បាប់ ជាដើម។

សង្គ្រាមទំពែ(guerrilla war) ដែលរាប់បញ្ចូលទាំងប្រភេទខ្លះនៃសង្គ្រាមស៊ីវិល គឺជាសង្គ្រាមដោយគ្មានសមរភូមិមុខ។ កងកម្លាំងមិនទៀងទាត់ ប្រតិបត្តិការនៅក្នុងចំណោម ហើយជារឿយៗ ត្រូវបានលាក់កំបាំងឬការពារដោយ ប្រជាជនស៊ីវិលសាមញ្ញ។ គោលបំណងនៃប្រតិបត្តិការបែបនេះ មិនមែនជាការចេញប្រឈមមុខតទល់នឹងកងទ័ពសត្រូវ ដោយផ្ទាល់នោះទេ ប៉ុន្តែជាការយាយីរំខាននិងដាក់ទណ្ឌកម្មសត្រូវ ហើយដូច្នេះពួកគេបន្តិចម្តងៗអាចដាក់កម្រិតប្រតិបត្តិការសត្រូវ និងអាចរំដោះទឹកដីមកគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាព។ ពួកឧទ្ទាមក្នុងសង្គ្រាមស៊ីវិលភាគច្រើនប្រើយុទ្ធសាស្ត្របែបនេះ។ កងកម្លាំងយោធាអាមេរិកនៅវៀតណាមខាងត្បូងបានប្រយុទ្ធប្រឆាំងនឹងទ័ពព្រៃវៀតកុង ក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ និង ១៩៧០ ដោយមានការខកចិត្តកាន់តែខ្លាំង។ យុទ្ធនាការប្រយុទ្ធប្រឆាំងនឹងកងកម្លាំងទ័ពព្រៃ (កម្លាំងវាយតបឧទ្ធាមបះបោរ)នឹង

ត្រូវពិភាក្សា នៅក្នុងមេរៀនទី ៦។ នៅក្នុងសង្គ្រាមទំពៃ ដោយសារគ្មានការកំណត់សមរភូមិជួរមុខ មានទឹកដីធំទូលាយដែលភាគីទាំងពីរមិនអាចគ្រប់គ្រងបាន។ ដូច្នេះ ភាគីទាំងសងខាង ប្រើកម្លាំងយោធាលើទីតាំងដូចគ្នា ក្នុងពេលតែមួយ។ ជាញឹកញយ រដ្ឋាភិបាលគ្រប់គ្រងទីក្រុងមួយនៅពេលថ្ងៃ ចំណែកទំពៃគ្រប់គ្រងនៅពេលយប់។ ដូច្នេះ សង្គ្រាមទំពៃបង្កទុក្ខវេទនាខ្លាំងក្លាពេកក្រៃ ដល់ប្រជាជនស៊ីវិល ដែលរងទុក្ខខ្លាំងបំផុត នៅពេលដែលគ្មានកម្លាំងយោធាណាមួយគ្រប់គ្រងទីតាំងណាមួយនោះផ្តាច់មុខយ៉ាងរឹងមាំ ការបើកទ្វារអោយចោរប្លន់ គំនុំសងសឹកផ្ទាល់ខ្លួន អំពើហិង្សាផ្លូវភេទ និងទង្វើគ្មានច្បាប់ទម្លាប់ផ្សេងទៀត។ ស្ថានការណ៍កាន់តែធ្ងន់ធ្ងរទ្វេរដង ដោយសារកងទំពរដ្ឋដែលប្រយុទ្ធប្រឆាំងនឹងកម្លាំងទំពៃ ជារឿយៗ មិនអាចបែងចែកនរណាជាទំពសត្រូវ នរណាជាជនស៊ីវិល ហើយជាក់ទណ្ឌកម្មលើក្រុមទាំងពីររួមគ្នាតែម្តង។ នៅក្នុងករណីដ៏ល្បីល្បាញមួយនៅប្រទេសវៀតណាមខាងត្បូង មន្ត្រីអាមេរិកម្នាក់ដែលបានបញ្ជាអោយដុតភូមិទាំងមូលដើម្បីកុំអោយវាក្លាយជាជម្រកលាក់ខ្លួនរបស់ពួកវៀតកុង បានរៀបរាប់ថា «យើងត្រូវបំផ្លាញភូមិដើម្បីសង្គ្រោះភូមិមួយនោះ»។[20] សង្គ្រាមកាន់តែមានលក្ខណៈមិនទៀងទាត់ និងតាមរបៀបទំពៃកាន់តែខ្លាំង; យូរៗទៅ វាកាន់តែមិនមែនជាការប៉ះទង្គិចគ្នាដោយបើកចំហរវាងកងកម្លាំងទំពទូទៅនៃរដ្ឋធំៗ បើទោះបីជាវានៅតែកើតឡើងម្តងម្កាលក៏ដោយ។

នៅក្នុងសង្គ្រាមគ្រប់ប្រភេទ បញ្ញត្តិនិងទ្រឹស្តីរបស់អ្នកប្រាជ្ញទំនាក់ទំនងអន្តរជាតិ(IR) ស្ទើរតែមិនអាចផ្តិតយកភាពភ័យតក់ស្លុតរបស់អ្នករងគ្រោះ នៅនឹងកន្លែងកើតហេតុផ្ទាល់ ទាំងទាហាននិងជនស៊ីវិល។ នៅក្នុងកំឡុងពេលសង្គ្រាម បទដ្ឋានអាកប្បកិរិយាទូទៅត្រូវផ្អាកជាបណ្តោះអាសន្ន ហើយជាពិសេស យូរៗទៅធ្វើអោយអ្នកចូលរួមប្រយុទ្ធ និងអ្នកមិនចូលរួម ត្រូវរងរបួសដែរ។ ទាហានឃើញយុទ្ធមិត្តរបស់ខ្លួនត្រូវគេបាញ់សម្លាប់នៅនឹងមុខផ្ទាល់ហើយពួកគេត្រូវតែបាញ់សម្លាប់និងធ្វើអោយរបួសមនុស្សលោកដូចគ្នាជាការសងសឹកអោយយុទ្ធមិត្តរបស់ពួកគេ។ ជាលទ្ធផល អ្នកខ្លះត្រូវជួបប្រទះភាពតានតឹងផ្លូវចិត្ត ពេញមួយជីវិត។ ជនស៊ីវិលជួបប្រទះនឹងភាពភ័យខ្លាច រងគ្រោះដោយអំពើហិង្សានិងការរំលោភបំពានផ្លូវភេទ; ពួកគេត្រូវបាត់បង់មនុស្សជាទីស្រលាញ់ ចំណែកឯផ្ទះសម្បែងក៏ត្រូវបំផ្លិចបំផ្លាញផងដែរ។ ពួកគេជារឿយៗរស់នៅ ដោយរបួសផ្លូវចិត្តក្រោយហេតុការណ៍។ ត្បិតអំពើហឹង្សានៅក្នុងសង្គ្រាមពិតប្រាកដមិនដូចអំពើហិង្សាក្នុងខ្សែភាពយន្តសង្គ្រាមពិតមែន ប៉ុន្តែ ផ្ទុយទៅវិញ វាបង្កើតបទពិសោធន៍ជំងឺផ្លូវចិត្ត ដែលពោរពេញដោយភាពច្របូកច្របល់ សំលេងរំខាន ភាពភ័យខ្លាច និង ការធុញថប់អារម្មណ៍។ ទាហានទាំងអស់នៅក្នុងជួរកងទំពអាជីពហ្វឹកហាត់ដើម្បីបន្តដំណើរការ ទាំងក្នុងស្ថានភាពបែបនេះ (ប៉ុន្តែនៅតែមានការងារដ៏លំបាកមិនគួរអោយជឿ) ក្នុងខណៈពេលដែលអ្នកនៅក្នុងកងទំពក្រៅផ្លូវការ រួមទាំងប្រជាជនស៊ីវិល ដែលជាប់ក្នុងអន្លង់សង្គ្រាមស៊ីវិល មានសង្ឃឹមតិចតួចក្នុងការដោះស្រាយឬព្យាបាលជំងឺផ្លូវចិត្តខាងលើ។ ភាពភ័យរន្ធត់នៃសង្គ្រាមទាំងអស់ត្រូវបានបំប៉ោងកាន់តែធំ នៅក្នុងករណីមានអំពើប្រល័យពូជសាសន៍ និងការសម្លាប់រង្គាល ប្រើប្រាស់ទាហានកុមារ និងសង្គ្រាមដ៏យោរយៅដែលបន្តកើតមានឡើងជាច្រើនឆ្នាំ។

រូបថត ស្ត្រីកូឡុំប៊ីជាក់អាវុធចុះ
ការរំសាយអាវុធ

[20] "Major Describes Move." *New York Times*, February ០៨, ១៩៦៨.

នៅពេលដែលក្រុមប្រដាប់អាវុធបញ្ឈប់ការបាញ់ប្រហារ ដំណើរការដ៏យូរនៃអន្តរកាលក្រោយសង្គ្រាមកើតឡើង។ ការរំសាយអាវុធ និងការរំសាយកងជីវពល មិនត្រឹមតែជាទិដ្ឋភាពដ៏សំខាន់បំផុតនៃការផ្លាស់ប្តូរនេះប៉ុណ្ណោះទេ ប៉ុន្តែក៏ជាការលំបាកបំផុតផងដែរ ព្រោះវាទុកអោយក្រុមដែលទម្លាក់អាវុធងាយនឹងរងគ្រោះ។ នៅទីនេះ សមាជិកម្នាក់នៃក្រុមឧទ្ទាមដ៏ធំនៅក្នុងប្រទេសកូឡុំប៊ី ប្រែក្លាយអាវុធរបស់នាងទៅកាន់ជំរុំរំសាយក្នុងឆ្នាំ ២០១៦។

ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ បណ្តាអ្នកប្រាជ្ញនិងអ្នកបង្កើតគោលនយោបាយកំពុងយកចិត្តទុកដាក់កាន់តែខ្លាំងចំពោះអន្តរកាលដ៏លំបាក ចេញពីសង្គ្រាមទៅកាន់សន្តិភាពនៅជុំវិញពិភពលោក ដូចជាការផ្សះផ្សាជាតិក្រោយសង្គ្រាម ការដោះស្រាយជម្លោះ រដ្ឋាភិបាលអន្តរកាលដែលតំណាងអោយភាគីផ្សេងៗគ្នា និងការកសាងសេដ្ឋកិច្ចជាតិឡើងវិញជាដើម។ ជារឿយៗ កិច្ចខិតខំប្រឹងប្រែងទាំងនេះដោះស្រាយបញ្ហាផលប្រយោជន៍រួមក្នុងចំណោមភាគីជម្លោះនានា ដូចជាពេលដែលព្រឹទ្ធាចារ្យនៃកុលសម្ព័ន្ធសូម៉ាលី ក្នុងឆ្នាំ ២០០៧ បានយល់ស្របថា អ្វីៗនឹងកាន់តែប្រសើរឡើង ដោយនាំគ្នាប្រគល់កាំភ្លើងរបស់ពួកគេទៅអោយរដ្ឋាភិបាលកណ្តាលថ្មី ប៉ុន្តែ គ្មានភាគីណាមួយចង់ទម្លាក់អាវុធខ្លួន មុនគេឡើយ។ បន្ទាប់ពីបញ្ឈប់ការបាញ់ប្រហារគ្នា កងរក្សាសន្តិភាពអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល (NGOs) ផ្តោតលើការកែទម្រង់វិស័យសន្តិសុខ (SSR) ដើម្បីបង្កើតកងកម្លាំងយោធា និងប៉ូលីស ដែលមានជំនាញវិជ្ជាជីវៈត្រឹមត្រូវ ជំនួសអោយមេទ័ពកងជីវពល។ ដំណើរការនៃការរំសាយអាវុធ (Disarmament) ការរំសាយកងទ័ព (Demobilization) និងការធ្វើសមាហរណកម្មកងទ័ពជាតិ (Reintegration) ឡើងវិញត្រូវដោះស្រាយជាមួយនឹងបញ្ហាទូទៅ ដូចជាថា តើត្រូវធ្វើយ៉ាងណា ជាមួយកងកម្លាំងមិនទៀងទាត់ក្រៅផ្លូវការ បន្ទាប់ពីសង្គ្រាមស៊ីវិលបានបញ្ចប់។

នៅក្នុងប្រទេសមួយចំនួនដែលសង្គ្រាមផ្ទៃក្នុងដ៏យូរ នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ បានបណ្តាលអោយមានការបង្ខូចមនុស្សជាតិ និងអំពើសាហាវឃោរឃៅ ជាពិសេស នៅអាហ្វ្រិកខាងត្បូង រដ្ឋាភិបាលថ្មីបានប្រើប្រាស់**គណៈកម្មការស្វែងរកការពិត** (truth commission) ដើម្បីជួយសង្គម អោយជាសះស្បើយ របួសជាតិ និងឆ្ពោះទៅមុខបន្តទៀត។ តួនាទីរបស់គណៈកម្មាការនេះត្រូវស្តាប់សក្ខីកម្មដ៏ស្មោះត្រង់ពីសម័យកាលសង្គ្រាម បំភ្លឺអំពីអ្វីដែលបានកើតឡើងក្នុងអំឡុងពេលសង្គ្រាមទាំងនេះ និងផ្តល់សិទ្ធិជ្រកកោនអ្នកពាក់ព័ន្ធភាគច្រើនពីការផ្តន្ទាទោស ជាថ្នូរមកវិញ។ ពេលខ្លះ អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិបានជួយសម្រួលដល់ដំណើរការនេះ។ ទោះជាយ៉ាងណាក៏ដោយ ក្រុមសិទ្ធិមនុស្សបានជំទាស់នឹងការតាំងទីលំនៅ ក្នុងប្រទេសសៀរ៉ាឡេអូន ក្នុងឆ្នាំ ១៩៩៩ ដែលបានបញ្ចូលរួមក្នុងរដ្ឋាភិបាលនូវបក្សពួកដែលបានកាត់ម្រាមដៃជនស៊ីវិលជារឿយៗ សម្រាប់ជាយុទ្ធសាស្ត្របន្តាច។ (ទោះជាយ៉ាងណា អរិភាពនេះបានបញ្ចប់នៅឆ្នាំ ២០០១។) ក្នុងឆ្នាំ ២០០៦ មេដឹកនាំកងជីវពលស្តាំនិយមកូឡុំប៊ី បានអំពាវនាវពីក្នុងពន្ធនាគារ អោយមានការបង្កើតគណៈកម្មាការការស្វែងរកការពិតមុនពេលពួកគេអាចសារភាពពីតួនាទីរបស់ពួកគេនៅក្នុងសង្គ្រាមស៊ីវិលអូសបន្លាយយូរឆ្នាំ និងបានបង្ខំអោយរដ្ឋាភិបាលសារភាពថាភាគីរដ្ឋាភិបាលក៏បានធ្វើអោយប៉ះពាល់ដល់ជីវិតជនស៊ីវិលផងដែរ។ ជាលទ្ធផលនៃដំណោះស្រាយសន្តិភាពកូឡុំប៊ី ឆ្នាំ ២០១៧ គណៈកម្មការស្វែងរកការពិតមួយបានចាប់ផ្តើមប្រតិបត្តិការ នៅខែធ្នូ ឆ្នាំដដែល។ ដូច្នេះហើយ បន្ទាប់ពីជម្លោះជាតិសាសន៍ដ៏សាហាវយង់ឃ្នង់បើកផ្លូវសម្រាប់ដំណោះស្រាយនយោបាយដ៏ស្មុគស្មាញ រដ្ឋាភិបាលភាគច្រើនព្យាយាមរក្សាតុល្យភាពនៃតម្រូវការយុត្តិធម៌ និងសច្ចៈភាព ជាមួយនឹងតម្រូវការដើម្បីរក្សាភាគីទាំងអស់បន្តជំហរផ្សះផ្សាជាតិ។

អ្នកជំនាញបានពិភាក្សាថា តើសច្ចៈភាពនិងការផ្សះផ្សាជាតិមានភាពចាំបាច់កម្រិតណាក្រោយជម្លោះដ៏វែងឆ្ងាយ។ អ្នកខ្លះក្នុងពេលបច្ចុប្បន្ននេះប្រកែកថា ក្នុងកាលៈទេសៈខ្លះ គណៈកម្មការដែលគាំទ្រដោយសាលាក្តីនិងរដ្ឋាភិបាល ដើម្បីស៊ើបអង្កេតឧក្រិដ្ឋកម្មកន្លងមកអាចនាំអោយមានអស្ថិរភាពនយោបាយ នៅក្នុងរដ្ឋក្នុងកំឡុងសម័យអន្តរកាល។ អ្នកជំនាញផ្សេងទៀតមិនយល់ស្របទេ ដោយកត់សម្គាល់ថាការងាររបស់គណៈកម្មការបែបនេះអាចមានសារៈសំខាន់ក្នុងការកសាងទំនុកចិត្តជាតិ ដែលមានសារៈសំខាន់ខ្លាំងណាស់សម្រាប់លទ្ធិប្រជាធិបតេយ្យ។

៥.១.២. ទ្រឹស្តីនៃបុព្វហេតុនៃសង្គ្រាម

អ្នកនិពន្ធជនជាតិរ៉ូម៉ាំង សេណេកា (Seneca) បាននិយាយ កាលពីជិត ២០០០ ឆ្នាំមុន ថាៈ «ចូរសួរអ្នកចម្បាំងអំពីលទ្ធផល មិនមែនសួរកមូលហេតុនោះទេ។» នេះមិនមែនជាការពិត សម្រាប់អ្នកវិទ្យាសាស្ត្រនយោបាយទេ។ គេចង់ដឹងថាហេតុអ្វីបានជាប្រទេសមួយចំនួនធ្វើសង្គ្រាមនឹងគ្នា?

ជាទូទៅ ៣ក្យ **ជម្លោះ** នៅក្នុងទំនាក់ទំនងអន្តរជាតិ សំដៅទៅលើជម្លោះប្រដាប់អាវុធ។ ជម្លោះផ្ទាល់តែងតែមានវត្តមាន នៅក្នុងប្រព័ន្ធអន្តរជាតិ ពោលគឺលក្ខខណ្ឌដែលការចរចារវាងភាគីជម្លោះបានប្រព្រឹត្តិទៅ។ នៅក្នុងការចរចាដោះស្រាយជម្លោះ រដ្ឋអភិវឌ្ឍសមត្ថភាពដែលផ្តល់អោយពួកគេនូវអានុភាព(ភាពមានប្រៀបជាង) ដើម្បីទទួលបានលទ្ធផលអំណោយផលជាង អ្វីដែលពួកគេសម្រេចបាន ប្រសិនបើគ្មានអនុភាពនោះ។ មិនថាយុត្តិធម៌ឬអយុត្តិធម៌ លទ្ធផលចុងក្រោយនៃដំណើរការចរចា គឺជាការដោះស្រាយជម្លោះណាមួយ។ ទោះយ៉ាងណាក៏ដោយ កម្រណាស់ដែលជម្លោះបណ្តាលអោយមានអំពើហិង្សា។

សំណួរដែលថាតើពេលណាដែលជម្លោះប្រែក្លាយជាហិង្សា អាចត្រូវបានឆ្លើយបំភ្លឺ តាមវិធីសាស្ត្រផ្សេងៗគ្នាជាច្រើន។ វិធីសាស្ត្រពិពណ៌នា ដែលជាទីពេញនិយមរបស់អ្នកប្រវត្តិសាស្ត្រ មានទំនោរផ្តោតលើមូលហេតុផ្ទាល់នាំអោយសង្គ្រាមផ្ទុះឡើង ហើយដែលមូលហេតុអាចប្រែប្រួល ពីសង្គ្រាមមួយទៅសង្គ្រាមមួយទៀត។ ជាឧទាហរណ៍ គេអាចនិយាយបានថា ការធ្វើឃាតលើព្រះអង្គម្ចាស់ ហ្វ្រង់ ហ្វែរឌីណង់ (Franz Ferdinand) ក្នុងឆ្នាំ ១៩១៤ «បានបង្កអោយ» សង្គ្រាមលោកលើកទី ១ ផ្ទុះឡើង។ វិធីសាស្ត្រដែលមានលក្ខណៈទ្រឹស្តីជាងច្រើននេះ ដែលជាទីពេញនិយមរបស់អ្នកវិទ្យាសាស្ត្រនយោបាយជាច្រើន មានទំនោរផ្តោតលើការស្វែងរកការពន្យល់ទូទៅ ដែលអាចអនុវត្តបានចំពោះបរិបទផ្សេងៗគ្នា អំពីបុព្វហេតុនៃសង្គ្រាម។ ជាឧទាហរណ៍ គេអាចមើលឃើញថា សង្គ្រាមលោកលើកទី១ បានផ្ទុះឡើងបណ្តាលមកពីការផ្លាស់ប្តូរតុល្យភាពអំណាច ក្នុងចំណោមរដ្ឋនានា នៅទ្វីបអឺរ៉ុប ដោយមានការធ្វើឃាតគ្រាន់តែជាកាតាលីករប៉ុណ្ណោះ។

វិធីសាស្ត្រមួយក្នុងការរៀបចំទ្រឹស្តីជាច្រើន ដែលផ្តល់ដោយអ្នកវិទ្យាសាស្ត្រនយោបាយ ដើម្បីពន្យល់ពីមូលហេតុនៃសង្គ្រាម គឺការប្រើប្រាស់គំនិត កម្រិតនៃការវិភាគ កាលពីមេរៀនទី ១។ ការប្រើប្រាស់ក្របខ័ណ្ឌនេះក្រើនរំលឹកយើងថា ព្រឹត្តិការណ៍សំខាន់ៗនៅក្នុងទំនាក់ទំនងអន្តរជាតិ មានមូលហេតុជាច្រើន នៅក្នុងកម្រិតផ្សេងគ្នានៃការវិភាគ។

កម្រិតបុគ្គល

នៅក្នុងការវិភាគកម្រិតបុគ្គល ទ្រឹស្តីស្តីអំពីសង្គ្រាមផ្តោតលើភាពសមហេតុផល។ ទ្រឹស្តីមួយដែលស្របនឹងទ្រឹស្តីប្រាកដនិយម អះអាងថា ការប្រើប្រាស់សង្គ្រាមនិងមធ្យោបាយហិង្សាផ្សេងទៀតសម្រាប់ជាអានុភាពនៅក្នុងជម្លោះអន្តរជាតិ គឺជារឿងធម្មតា ហើយឆ្លុះបញ្ចាំងពីការសម្រេចចិត្តដ៏សមហេតុផលរបស់មេដឹកនាំ

ជាតិ។ «សង្គ្រាមចាប់ផ្តើមជាមួយនឹងការសម្រេចចិត្តដោយមនសិការនិងហេតុផល ដោយផ្អែកលើការគណនាឬវិភាគ ដែលធ្វើឡើងដោយភាគីទាំងពីរ ថាពួកគេអាចសម្រេចបានកាន់តែច្រើនដោយការធ្វើសង្គ្រាម ជាជាងដោយសន្តិភាព។"[២១]

ទ្រឹស្តីប្រឆាំងមួយបានប្រកែកថាជម្លោះជារឿយៗរីករាលដាលកាន់តែធំរហូងផ្ទុះជាសង្គ្រាម ដោយសារតែ*ការដាក់ចេញ*ពីសនិទានភាព ក្នុងដំណើរការធ្វើការសម្រេចចិត្តបុគ្គលរបស់មេដឹកនាំជាតិ។ សក្តានុពលដែលនាំអោយល្អៀងចេញពីសនិទានភាពទាំងនេះ ដែលត្រូវបានពិភាក្សានៅក្នុងមេរៀនទី ៤ រួមមានអេក្រង់ឬចម្រោះព័ត៌មាន ភាពលម្អៀងទាំងបួន និងការគិតជាក្រុម ជាដើម។ ទ្រឹស្តីពាក់ព័ន្ធមួយទៀតបានចែងថាការអប់រំនិងមនោគតិរបស់ក្រុមបុគ្គលនីមួយៗជាអ្នកកំណត់ថា តើជម្លោះប្រែក្លាយជាហិង្សាដែរឬអត់។ នៅក្នុងទិដ្ឋភាពនេះ ជាតិនិយមជាសាធារណៈ ឬការស្អប់ខ្ពើមជាតិសាសន៍ (ឬសូម្បីតែទំនោរពីកំណើតងាកទៅរកអំពើហិង្សា នៅក្នុងធម្មជាតិរបស់មនុស្ស) អាចជាក់សម្តែងលើអ្នកដឹកនាំអោយដោះស្រាយជម្លោះ តាមលក្ខណៈហិង្សា។

ជាអកុសល គ្មានទ្រឹស្តីណាមួយក្នុងចំណោមទ្រឹស្តីទាំងនេះ អាចឈរជើងបានរឹងមាំនោះទេ។ សង្គ្រាមខ្លះឆ្ពុះបញ្ជាំងយ៉ាងច្បាស់ពីការគណនាឬវិភាគភាពសមហេតុផលរបស់មេដឹកនាំជាតិ ចំណែកសង្គ្រាមផ្សេងទៀតគឺជាកំហុស និងមិនអាចចាត់ទុកថាសមហេតុផលបានទេ។ ប្រាកដណាស់ បុគ្គលជាមេដឹកនាំមួយចំនួនហាក់ដូចជាងាយនឹងងាកទៅរកកម្លាំងយោធា ដើម្បីព្យាយាមដោះស្រាយជម្លោះ ដោយលក្ខខណ្ឌអំណោយផល។ ប៉ុន្តែ អ្នកបង្កើតសង្គ្រាមក៏អាចក្លាយជាអ្នកបង្កើតសន្តិភាពផងដែរ ដូចជា លោក អានវ៉ា សាដាត (Anwar Sadat) របស់អេហ្ស៊ីប ជាឧទាហរណ៍ស្រាប់។ បុគ្គលដែលមានប្រវត្តិមកពីវប្បធម៌ និងសាសនាជាច្រើនដឹកនាំរដ្ឋរបស់ពួកគេ អោយធ្លាក់ចូលទៅក្នុងសង្គ្រាម ទាំងមេដឹកនាំជាបុរស និងទាំងមេដឹកនាំជាស្ត្រី។ ការស្រាវជ្រាវក្នុងទំនាក់ទំនងអន្តរជាតិជារឿយៗរកឃើញថាដើម្បីពន្យល់ថានៅពេលណាមេដឹកនាំជ្រើសរើសសង្គ្រាម ឬ សន្តិភាព ក្នុងស្ថានភាពជាក់លាក់ណាមួយ គេត្រូវការការរួមផ្សំគ្នារវាងការវិភាគកម្រិតបុគ្គលនិងបរិបទនៃស្ថានភាពនោះ។

កម្រិតក្នុងស្រុក

ការវិភាគកម្រិតក្នុងស្រុកយកចិត្តទុកដាក់ជាពិសេសចំពោះលក្ខណៈរបស់រដ្ឋឬសង្គម ដែលអាចធ្វើអោយពួកគេងាយឬមិនងាយនឹងប្រើអំពើហិង្សាក្នុងការដោះស្រាយជម្លោះ។ ក្នុងកំឡុងសង្គ្រាមត្រជាក់ អ្នកទ្រឹស្តីម៉ាក្សនិយមបាននិយាយជាញឹកញាប់ថា រដ្ឋ*មូលធននិយម*ដែលមានចរិកឈ្លានពាននិងលោភលន់ងាយនឹងប្រើប្រាស់អំពើហិង្សាក្នុងជម្លោះអន្តរជាតិ ចំណែកមេដឹកនាំលោកខាងលិចបានអះអាងថា ការពង្រីកមនោគមន៍វិជ្ជា និងលក្ខណៈឈ្លានពាននិយម មនោគមវិជ្ជានិយម និងផ្តាច់ការនិយម នៃរដ្ឋកុម្មុយនិស្តបានធ្វើអោយពួកគេងាយនឹងប្រើអំពើហិង្សា។ តាមការពិត សង្គមទាំងពីរប្រភេទបានធ្វើសង្គ្រាមជារឿយៗ។

ដូចគ្នាដែរ ទាំងរដ្ឋឧស្សាហូបនីយកម្មកែចម្រើន និងទាំងរដ្ឋកសិកម្មក្រីក្រ ប្រើប្រាស់មធ្យោបាយសង្គ្រាម ដូចគ្នា ម្តងម្កាល។ វាពិតជាការពិត អ្នកស្រាវជ្រាវផ្នែកនរវិទ្យាបានរកឃើញថា សង្គមបរបាញ់បេះផ្លែឈើសម័យបុព្វកាលជាច្រើន ងាយនឹងកើតមានសង្គ្រាម ជាងសង្គមសព្វថ្ងៃ។ ដូច្នេះ លទ្ធភាពនៃការផ្ទុះ

[២១] Howard, Michael. *The Causes of Wars, and Other Essays*. Harvard, ១៩៨៣, p. ២២. Emphasis in original. For a related argument, see Fearon, James. Rationalist Explanations for War. *International Organization* ៤៩ (៣), ១៩៩៥: ៣៧៩–៤១៤.

សង្គ្រាមហាក់ដូចជាមានលក្ខណៈសកល នៅគ្រប់វប្បធម៌ ប្រភេទសង្គម និងសម័យកាល ទោះបីសារៈសំខាន់ និងភាពញឹកញាប់នៃសង្គ្រាមមានលក្ខណៈប្រែប្រួលខ្លាំង ពីករណីមួយទៅករណីមួយទៀត។

អ្នកខ្លះទៀតអះអាងថា កត្តានយោបាយក្នុងស្រុកសម្រួចទស្សនវិស័យរបស់រដ្ឋ ស្តីអំពីសង្គ្រាម និងសន្តិភាព។ ជាឧទាហរណ៍ ទ្រឹស្តីសន្តិប្រជាធិបតេយ្យបានណែនាំថាប្រទេសប្រកាន់លទ្ធិប្រជាធិបតេយ្យស្ទើរតែមិនដែលធ្វើសង្គ្រាមប្រឆាំងនឹងប្រទេសប្រជាធិបតេយ្យផ្សេងទៀតឡើយ (សូមមើលមេរៀនទី ៣) បើទោះបីជាទាំងប្រទេសប្រជាធិបតេយ្យនិងទាំងរដ្ឋផ្តាច់ការធ្វើសង្គ្រាមក៏ដោយ។ ស្នាដៃថ្មីៗរបស់អ្នកប្រាជ្ញវិទ្យាសាស្ត្រនយោបាយរកឃើញថា រដ្ឋផ្តាច់ការមួយចំនួន (ឧទាហរណ៍ រដ្ឋដែលគ្រប់គ្រងដោយប្រព័ន្ធឯកបក្ស) ក៏អាចមានសន្តិភាពដែរ បើប្រៀបធៀបទៅនឹងប្រភេទរដ្ឋផ្តាច់ការផ្សេងទៀត (ឧទាហរណ៍ រដ្ឋដែលគ្រប់គ្រងដោយបុគ្គលផ្តាច់ការ)។ អ្នកខ្លះទៀតអះអាងថា គណបក្សនយោបាយក្នុងស្រុក ក្រុមតំណាងផលប្រយោជន៍ និងស្ថាប័ននីតិប្បញ្ញត្តិដើរតួនាទីយ៉ាងសំខាន់គឺជាកត្តាសំខាន់ថាតើជម្លោះអន្តរជាតិ នឹងប្រែក្លាយទៅជាសង្គ្រាមអន្តរជាតិដែរឬទេ។

ទូទៅនីយកម្មដែលមានប្រយោជន៍មួយចំនួនអាចប្រាប់យើងថា សង្គមណាខ្លះងាយឬមិនងាយនឹងបង្កសង្គ្រាម។ សង្គមដូចគ្នាអាចផ្លាស់ប្តូរយ៉ាងខ្លាំង តាមពេលវេលា។ ជាឧទាហរណ៍ ប្រទេសជប៉ុនងាយនឹងប្រើអំពើហិង្សាក្នុងជម្លោះអន្តរជាតិ មុនសង្គ្រាមលោកលើកទី២ ប៉ុន្តែ ប្រទេសនេះមិនចូលចិត្តអំពើហិង្សាបែបនេះ តាំងពីពេលនោះមក។ កុលសម្ព័ន្ធព្រៃគុង (Kung) ដែលជាសង្គមបរបាញ់បេះផ្លែឈើ នៅក្នុងប្រទេសអង់ហ្គោឡានិងណាមីប៊ី ត្រូវបានសង្កេតឃើញ ដោយនរវិទូ ក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ និងរកឃើញថាមានលក្ខណៈសន្តិភាពបំផុត។ យ៉ាងណាមិញ អ្នកស្រាវជ្រាវផ្នែកនរវិទ្យា ក្នុងទសវត្សរ៍ ឆ្នាំ១៩២០ បានសង្កេតឃើញថា ពួកគេជាប់ពាក់ព័ន្ធក្នុងអំពើហិង្សាសម្លាប់មនុស្ស ឆ្លងក្រុមកុលសម្ព័ន្ធផងដែរ។ ប្រសិនបើមានគោលការណ៍ទូទៅសម្រាប់ពន្យល់ពីមូលហេតុឬដែលសង្គមមួយចំនួន នៅពេលខ្លះ មានលក្ខណៈសន្តិភាពជាងសង្គមផ្សេង ហើយហេតុអ្វីបានជាពួកគេផ្លាស់ប្តូរ អ្នកវិទ្យាសាស្ត្រនយោបាយមិនទាន់បានកំណត់អត្តសញ្ញាណគោលការណ៍បែបនេះនៅឡើយ។

រូបថត *ទីក្រុងស្តាលីនក្រាដដ៏ស្ងប់ស្ងាត់*

ហេតុអ្វីសង្គ្រាម?

អ្នកវិទ្យាសាស្ត្រនយោបាយមិនយល់ស្របគ្នាលើទ្រឹស្តីណាមួយថា ហេតុអ្វីបានជាមហាសង្គ្រាម ដូចជាសង្គ្រាមលោកលើកទី ២ ផ្ទុះឡើង ហើយមិនអាចទស្សន៍ទាយថា តើវាអាចនឹងកើតឡើងម្តងទៀតដែរឬទេ។ ទីក្រុងស្តាលីនក្រាដ (Stalingrad) ឬ Volgograd ត្រូវបានបំផ្លាញ កំឡុងពេលឈ្លានពានរបស់អាល្លឺម៉ង់លើសហភាពសូវៀតឆ្នាំ ១៩៤៣ ។

កម្រិតប្រព័ន្ធ

ទ្រឹស្តីទាំងឡាយ នៅក្នុង(ការវិភាគ)កម្រិតអន្តរដ្ឋពន្យល់អំពីសង្គ្រាមនានា ដោយផ្តោតលើទំនាក់ទំនងអំណាច ក្នុងចំណោមតួអង្គសំខាន់ៗ នៅក្នុងប្រព័ន្ធអន្តរជាតិ។ ក្នុងចំណោមទ្រឹស្តីទាំងនេះ ខ្លះត្រូវបានពិភាក្សា នៅក្នុងមេរៀនទី ២ រួចមកហើយ។ ជាឧទាហរណ៍ ទ្រឹស្តីអន្តរកាលអំណាចបានចែងថា ជម្លោះបណ្តាលអោយផ្ទុះសង្គ្រាមធំៗ នៅពេលណាមួយ ពិសេសនៅពេលអំណាចត្រូវបានបែងចែកស្មើៗគ្នា ហើយរដ្ឋដែលមានអំណាចកំពុងកើនឡើង ហាក់គំរាមកំហែងដណ្តើមតំណែងរបស់រដ្ឋអនុត្តរភាពដែលកំពុងធ្លាក់

ចុះអំណាច នៅក្នុងប្រព័ន្ធរួមមួយ។ នៅក្នុងកម្រិតនេះផងដែរ ទ្រឹស្តីប្រកួតប្រជែងនឹងគ្នាក៏មានវត្តមានដែរ តែស៊ីសង្វាក់នឹងគ្នាទេ។ យុទ្ធសាស្ត្របញ្ចៀស (Deterrence) ដូចដែលយើងបានដឹងកន្លងមកហើយ ត្រូវបានគេរំពឹងថានឹងបញ្ឈប់សង្គ្រាម ដោយការបង្កើនវិសាលភាពអំណាច និងគំរាមកំហែងការប្រើប្រាស់អំណាចទាំងនោះ។ ប៉ុន្តែ ទ្រឹស្តីប្រណាំងប្រជែងសព្វាវុធបានចាត់ទុកថាសង្គ្រាមផ្ទុះឡើង មិនមែនត្រូវបានរារាំង ដោយសកម្មភាពបែបនេះ។ គ្មាននរណាម្នាក់រកឃើញរូបមន្តទូទៅមួយ ដើម្បីកំណត់ថាតើនៅក្នុងកាល:ទេស:ណាមួយដែលគោលការណ៍នីមួយៗអាចអនុវត្តបាន។ ទ្រឹស្តីជាច្រើនលើកឡើងថា សង្គ្រាមធំៗ នៅក្នុងប្រព័ន្ធអន្តរជាតិ មានលក្ខណៈវិលជុំ ប្រៀបដូចជា វដ្តនៃសង្គ្រាម។ គោលការណ៍មួយក្លាប់ទំនាក់ទំនងសង្គ្រាមធំៗជាមួយនឹងរលកសេដ្ឋកិច្ចដ៏វែង (ឬហៅថាវដ្តខុនដ្រាធីហ្វ (Kondratieff)) នៅក្នុងសេដ្ឋកិច្ចពិភពលោកដែលមានរយៈពេលប្រហែល ៥០ ឆ្នាំ។ គោលការណ៍មួយផ្សេងទៀតភ្ជាប់សង្គ្រាមដ៏ធំបំផុតជាមួយនឹងវដ្ត ១០០ ឆ្នាំ ដោយផ្អែកលើការបង្កើតនិងការធ្លាក់ចុះនៃសណ្តាប់ធ្នាប់ពិភពលោក(សូមមើលអនុត្តរភាពក្នុងមេរៀនទី ២)។ ទ្រឹស្តីវដ្តទាំងនេះ យ៉ាងច្រើន អាចត្រឹមពន្យល់តែទំនោរទូទៅឆ្ពោះទៅរកសង្គ្រាម នៅក្នុងប្រព័ន្ធអន្តរជាតិ ជាបន្តបន្ទាប់។

តាមមធ្យោបាយខ្លះ គោលការណ៍ផ្ទុយមួយគឺទ្រឹស្តីនៃការផ្លាស់ប្តូរទៅមុខត្រង់រយៈពេលវែង ដែលថាសង្គ្រាមដែលកើតឡើងដោយសារជម្លោះកាន់តែតិចទៅៗ អាស្រ័យតាមពេលវេលា ដោយសារតែការអភិវឌ្ឍន៍ទាំងបច្ចេកវិទ្យានិងបទដ្ឋានអន្តរជាតិ នៅទូទាំងពិភពលោក។ អ្នកប្រាជ្ញទំនាក់ទំនងអន្តរជាតិខ្លះអះអាងថាសង្គ្រាមនិងកម្លាំងយោធាកំពុងលែងប្រើជាឥទ្ធិពល នៅក្នុងជម្លោះអន្តរជាតិ ដោយសារឥទ្ធិពលទាំងនេះមិនមានប្រសិទ្ធភាពខ្លាំង នៅក្នុងពិភពលោកដែលកាន់តែស្មុគស្មាញ និងមានការពឹងអាស្រ័យលើគ្នាកាន់តែខ្លាំងនាពេលបច្ចុប្បន្ននេះ។ អំណះអំណាងប្រហាក់ប្រហែលនេះបញ្ជាក់ថា បច្ចេកវិជ្ជាយោធាសព្វថ្ងៃមានថាមពលខ្លាំងជ្រុលពេក មិនអាចប្រើក្នុងជម្លោះទូទៅភាគច្រើនបានឡើយ ជាពិសេសចំពោះអាវុធនុយក្លេអ៊ែរ។ អ្នកតស៊ូមតិនៃទ្រឹស្តីទាំងនេះធ្វើអោយមានភាពស្រដៀងគ្នាជាប្រវត្តិសាស្ត្រ ទៅនឹងការធ្លាក់ចុះនៃការអនុវត្តរបបទាសភាព ការវាយមួយទល់មួយស្លាប់រស់ និងការស៊ីសាច់មនុស្ស - ដែលធ្លាប់ត្រូវបានចាត់ទុកថាជារឿងធម្មតា ប៉ុន្តែ ឥឡូវនេះ លែងប្រើហើយ។ វិធីសាស្ត្រទាំងនេះមានមូលដ្ឋានជាក់ស្តែងដ៏រឹងមាំ (សូមមើល ការថមថយនៃសង្គ្រាម នៅក្នុងមេរៀនទី ៣) ប៉ុន្តែ មិនមានការមូលមតិគ្នាណាមួយបានកើតឡើង ទាក់ទងនឹងការពន្យល់ដ៏ល្អបំផុត សម្រាប់និន្នាការនេះទេ។

អ្នកវិទ្យាសាស្ត្រនយោបាយមួយចំនួនសិក្សាស្រាវជ្រាវអំពីសង្គ្រាម តាមរយៈស្ថិតិ ដោយវិភាគទិន្នន័យអំពីប្រភេទនៃសង្គ្រាមនិងកាល:ទេស:ដែលវាបានផ្ទុះឡើង។ ការស្រាវជ្រាវនាពេលបច្ចុប្បន្នផ្តោតលើឥទ្ធិពលនៃលទ្ធិប្រជាធិបតេយ្យ រចនាសម្ព័ន្ធរដ្ឋាភិបាល ពាណិជ្ជកម្ម អង្គការអន្តរជាតិ និងកត្តាពាក់ព័ន្ធក្នុងការពន្យល់ពីការកើនឡើង ឬការដោះស្រាយជម្លោះយោធារវាងរដ្ឋនានា។

ដូច្នេះ តាមរយៈការវិភាគទាំងបីកម្រិត ទ្រឹស្តីប្រកួតប្រជែងគ្នាផ្តល់ការពន្យល់ផ្សេងៗគ្នាដែរសម្រាប់មូលហេតុដែលជម្លោះខ្លះក្លាយជាហិង្សា ហើយខ្លះទៀតមិនផ្ទុះជាហិង្សា។ ដោយសារហេតុផលទាំងនេះ អ្នកវិទ្យាសាស្ត្រនយោបាយមិនទាន់អាចទស្សន៍ទាយ ដោយទំនុកចិត្តណាមួយថា ជម្លោះអន្តរជាតិជាច្រើននៅក្នុងពិភពលោកនឹងនាំអោយមានសង្គ្រាម។ ទោះជាយ៉ាងណាក៏ដោយ យើងអាចទទួលបានការយល់ដឹងតាមរយៈការសិក្សាប្រភេទផ្សេងៗនៃជម្លោះ ដើម្បីយល់កាន់តែច្បាស់អំពីអ្វីដែលរដ្ឋកំពុងប្រយុទ្ធដណ្តើមគ្នា។

៥.២. ជម្លោះទស្សនៈផ្សេងៗគ្នា

៥.២ ចូរលើកឧទាហរណ៍នៃជម្លោះអន្តរជាតិយ៉ាងតិចចំនួន ៤ ផ្សេងគ្នា ដែលបណ្តាលមកពីកត្តាសាសនា ឬដែលសាសនាធ្វើអោយជម្លោះកាន់តែធ្ងន់ធ្ងរឡើងៗ។

ផ្នែកខាងក្រោមពិភាក្សាអំពីជម្លោះអន្តរជាតិចំនួនប្រាំមួយប្រភេទ៖ ជម្លោះជាតិសាសន៍ សាសនា មនោគមវិជ្ជា ទឹកដី រដ្ឋាភិបាល និងសេដ្ឋកិច្ច។ ជម្លោះបីដំបូងគឺជាជម្លោះទាស់ទែងខ្វែងគំនិតគ្នា បីចុងក្រោយគឺជាជម្លោះដណ្តើមផលប្រយោជន៍។ ជម្លោះទាំងប្រាំមួយប្រភេទនេះ មិនអាចញែកដាច់ពីគ្នាបានឡើយ ហើយជាក់ស្តែងវាមានលក្ខណៈត្រួតស៊ីគ្នា គួរអោយកត់សម្គាល់។ ជាឧទាហរណ៍ ជម្លោះរវាងរុស្ស៊ីនិងអ៊ុយក្រែន ក្រោយការបែកបាក់នៃសហភាពសូវៀត ក្នុងឆ្នាំ ១៩៩១ មានភាពស្មុគស្មាញ។ ប្រជាជនដែលមាន*ជាតិសាសន៍* ជារុស្ស៊ីដែលរស់នៅក្នុងប្រទេសអ៊ុយក្រែន និងជនជាតិអ៊ុយក្រែននៅក្នុងប្រទេសរុស្ស៊ីត្រូវរងគ្រោះដោយសារជម្លោះនេះ។ ត្បិតតែជនជាតិអ៊ុយក្រែននិងរុស្ស៊ីកាន់សាសនាគ្រឹស្តដូចគ្នា ប៉ុន្តែប្រកាន់*និកាយ*ខុសគ្នាផងដែរ។ លើសពីនេះទៀត រដ្ឋថ្មីទាំងពីរមានជម្លោះ*ទឹកដី*លើឧបទ្វីបគ្រីមៀ ដែលមេដឹកនាំសូវៀត នីគីតា គ្រុសឆេវ (Nikita Khrushchev) បានផ្ទេរទៅអ៊ុយក្រែន ក្នុងទសវត្សរ៍ឆ្នាំ១៩៥០។ រដ្ឋទាំងពីរក៏មានជម្លោះ*សេដ្ឋកិច្ច*លើវិស័យពាណិជ្ជកម្មនិងប្រាក់ បន្ទាប់ពីការបែកបាក់សហភាពសូវៀត ដែលបានបង្កើតព្រំដែន និងរូបិយប័ណ្ណថ្មី។ ជម្លោះទិដ្ឋភាពចម្រុះនេះមិនបានឈានដល់ការប្រើកម្លាំងយោធាឡើយ រហូតដល់ឆ្នាំ ២០១៤។ បន្ទាប់ពីក្រុមបាតុករបានបង្ខំអោយប្រធានាធិបតីអ៊ុយក្រែនដែលគាំទ្ររុស្ស៊ី ចុះចេញពីតំណែង, រុស្ស៊ីបានបញ្ជូលតំបន់គ្រីមេទៅក្នុងទឹកដីរបស់ខ្លួន។ រុស្ស៊ីក៏បានគាំទ្រការបះបោរមួយ នៅភាគខាងកើតនៃអ៊ុយក្រែនដែលមានជនជាតិរុស្ស៊ីជាច្រើនរស់នៅ។ គិតត្រឹមឆ្នាំ ២០១៨ ជម្លោះនោះកំពុងបន្ត ដោយកិច្ចប្រឹងប្រែងឈានដល់បទឈប់បាញ់គ្នាត្រូវបរាជ័យ។ ដូច្នេះ ប្រភេទនៃជម្លោះដែលបានពិភាក្សានៅទីនេះ កើតឡើងរួមគ្នា ជាជាងដោយឡែកពីគ្នា។

យើងនឹងពិនិត្យមើលជាមុននូវប្រភេទជម្លោះដ៏លំបាកបំផុត ដែលធាតុអរូបីដូចជាការស្អប់ខ្ពើមជាតិសាសន៍ ភាពជ្រុលនិយមផ្នែកសាសនា ឬមនោគមវិជ្ជា ជាកត្តាសំខាន់ក្នុងជម្លោះ នោះគឺ ជម្លោះនៃគំនិត។ ប្រភពនៃជម្លោះអន្តរជាតិដែលមានមូលដ្ឋានលើអត្តសញ្ញាណទាំងនេះ នាពេលបច្ចុប្បន្ននេះ ត្រូវបានកំណត់ជាលក្ខណៈប្រវត្តិសាស្ត្រដោយជាតិនិយម ថាជាទំនាក់ទំនងរវាងអត្តសញ្ញាណ និងភាពជារដ្ឋដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ។ ដូច្នេះហើយ យើងនឹងពិនិត្យមើលការវិវឌ្ឍន៍នៃជាតិនិយម ដោយសង្ខេប មុននឹងពិនិត្យមើលការប៉ះទង្គិចនៃគំនិតទាំងបីប្រភេទ។

៥.២.១. ជាតិនិយម

ជាតិនិយម ដែលជាលះបង់ចំពោះផលប្រយោជន៍របស់ប្រទេសជាតិខ្លួន ជាជាងផលប្រយោជន៍របស់រដ្ឋផ្សេងអាចជាចរន្តនយោបាយពិភពលោកដ៏សំខាន់បំផុត ក្នុងរយៈពេលពីរសតវត្សកន្លងមកនេះ។ ប្រជាជាតិមួយ គឺជាក្រុមប្រជាជន ដែលមានអត្តសញ្ញាណរួមគ្នា ដែលជាធម្មតារួមបញ្ចូលទាំងភាសានិងវប្បធម៌។ ប៉ុន្តែ សញ្ជាតិជាបញ្ញត្តិពិបាកកំណត់អោយបានច្បាស់។ ក្នុងកម្រិតណាមួយ ការពង្រីកការគ្រប់គ្រងផ្នែកនយោបាយលើទឹកដីធំទូលំទូលាយដូចជាបារាំងបានបង្កើតភាពរួមគ្នា ដែលចាំបាច់សម្រាប់ភាពជាប្រជាជាតិ ពោលគឺ*រដ្ឋបង្កើតបានជាប្រជាជាតិ*។ ទោះជាយ៉ាងណាក៏ដោយ ក្នុងពេលជាមួយគ្នានេះ អត្ថិភាពនៃប្រជាជាតិមួយដែលត្រូវបាន

គេមើលឃើញ ជារឿយៗ នាំទៅដល់ការបង្កើតរដ្ឋដែលត្រូវគ្នាតាមការមើលឃើញ នៅពេលដែលប្រជាជនទទួលបានអធិបតេយ្យភាពលើកិច្ចការរបស់ពួកគេ ពោលគឺ*ប្រជាជាតិបង្កើតបានជារដ្ឋ*។

កំឡុង ឆ្នាំ ១៥០០ គ.ស. ប្រទេសនានាដូចជាបារាំង និងអូទ្រីស បានចាប់ផ្តើមរួមបញ្ចូលប្រជាជាតិទាំងអោយក្លាយជារដ្ឋរួមតែមួយ។ ប្រជាជាតិថ្មីៗទាំងនេះមានវិសាលភាពទឹកដីទូលំទូលាយ និងមានអំណាចខ្លាំង និងត្រួតត្រាប្រទេសជិតខាងតូចៗដទៃទៀត។ បន្តិចម្តងៗ ពួកគេបានដណ្តើមយកនិងបញ្ចូលអង្គភាពដែនដីតូចៗជាច្រើន។ យូរទៅៗ គំនិតជាតិនិយមផ្ទាល់បានក្លាយជាចរន្តដ៏មានឥទ្ធិពលមួយ ហើយទីបំផុតបានរួមចំណែកដល់ការបំបែករដ្ឋពហុជាតិធំៗ ដូចជា អូទ្រីស-ហុងគ្រី (ក្នុងកំឡុងសង្គ្រាមលោកលើកទី១) សហភាពសូវៀត និងយូហ្គោស្លាវី។

គោលការណ៍*សម្រេចជោគវាសនាប្រទេសជាតិដោយខ្លួនឯង*មានន័យថា ក្រុមប្រជាជនដែលកំណត់អត្តសញ្ញាណរបស់ខ្លួនជាប្រជាជាតិរួមតែមួយគួរតែមានសិទ្ធិបង្កើតរដ្ឋ និងអនុវត្តអធិបតេយ្យភាពលើកិច្ចការផ្ទៃក្នុងរបស់ខ្លួន។ ការសម្រេចជោគវាសនាប្រទេសជាតិដោយខ្លួនឯង គឺជាគោលការណ៍ដែលទទួលបានការសាទរយ៉ាងទូលំទូលាយ នៅក្នុងកិច្ចការអន្តរជាតិសព្វថ្ងៃនេះ (ទោះបីជាមិនមែនជាប្រវត្តិសាស្ត្រក៏ដោយ)។ ប៉ុន្តែ ជាទូទៅ វាស្ថិតនៅលំដាប់ទី២ បន្ទាប់ពីគោលការណ៍អធិបតេយ្យភាពជាតិ (ការមិនជ្រៀតជ្រែកក្នុងកិច្ចការផ្ទៃក្នុងរបស់រដ្ឋដទៃទៀត)និងបូរណភាពទឹកដី ដែលវាតែងតែមានជម្លោះជាមួយ។ ការសម្រេចជោគវាសនាប្រទេសជាតិដោយខ្លួនឯងមិនផ្តល់អោយក្រុមមនុស្សណាមួយនូវសិទ្ធិផ្លាស់ប្តូរព្រំដែនអន្តរជាតិ សូម្បីតែព្រំដែនដែលគួសវាសតាមអំពើចិត្តដោយអាណានិគមនិយម ដើម្បីបង្រួបបង្រួមក្រុមប្រជាជាតិដែលមានអត្តសញ្ញាណជាតិរួមគ្នា (និស្សិតអាចសាកល្បងពិចារណាអំពីករណីប្រជាជាតិខ្មែរ ដែលរស់នៅរាយប៉ាយនៅអាស៊ីអាគ្នេយ៍ជីគោក)។ ជាទូទៅ ទោះបីជាមិនគ្រប់ករណីក៏ដោយ ការសម្រេចជោគវាសនាប្រទេសជាតិដោយខ្លួនឯងត្រូវបានសម្រេចឡើង ដោយអំពើហិង្សា។ នៅពេលដែលព្រំដែន(យល់ឃើញ)នៃប្រជាជាតិមិនត្រូវគ្នានឹងព្រំដែននៃរដ្ឋនោះ ជម្លោះស្ទើរតែកើតឡើងដោយជៀសមិនរួច។ សព្វថ្ងៃនេះ ជម្លោះបែបនេះកំពុងរីករាលដាលយ៉ាងខ្លាំង ដូចជានៅរដ្ឋឆេចនី (Chechnya), គេបិក (Quebec), អ៊ីស្រាអែលនឹងប៉ាឡេស្ទីន, ឥណ្ឌា-ប៉ាគីស្តាន, ស្រីលង្កា, ទីបេ និងកន្លែងជាច្រើនទៀត។

ប្រទេសហូឡង់បានជួយបង្កើតគោលការណ៍នៃការសម្រេចជោគវាសនាប្រទេសជាតិ ដោយខ្លួនឯងនៅពេលដែលប្រទេសនេះបានផ្តាច់ខ្លួនចេញពីការគ្រប់គ្រង(កម្មសិទ្ធិ)របស់ប្រទេសអេស្ប៉ាញ នៅកំឡុងឆ្នាំ ១៦០០ ហើយបានបង្កើតសាធារណរដ្ឋហូឡង់ ដែលគ្រប់គ្រងដោយខ្លួនឯងផ្ទាល់។ ការតស៊ូដណ្តើមការគ្រប់គ្រងលើប្រទេសហូឡង់ គឺជាបុព្វហេតុឈានមុខគេនៃ**សង្គ្រាមសាមសិបឆ្នាំ** (១៦១៨-១៦៤៨) ហើយនៅក្នុងសង្គ្រាមនោះ រដ្ឋទាំងឡាយបានកៀងគរប្រមូលផ្តុំប្រជាជនរបស់ខ្លួនសម្រាប់ធ្វើសង្គ្រាម តាមរបៀបថ្មី។ ជាឧទាហរណ៍ ប្រទេសស៊ុយអែតបានជ្រើសរើសមនុស្សប្រុសម្នាក់ក្នុងចំណោមដប់នាក់ ដើម្បីបម្រើការងារក្នុងជួរកងទ័ពរយៈពេលវែង ខណៈពេលដែលប្រទេសហូឡង់បានប្រើប្រាស់ទ្រព្យសម្បត្តិដែលទទួលបានមកពីពាណិជ្ជកម្មសកល ដើម្បីផ្តល់ហិរញ្ញប្បទានដល់កងទ័ពអាជីព។

ដំណើរការនៃការកៀងគរប្រជាជនធ្វើជាកងទ័ពបែបនេះ ត្រូវបានបង្កើនយ៉ាងខ្លាំង នៅក្នុងបដិវត្តន៍បារាំង និងនៅពេលក្រោយមកទៀត ក្នុងសង្គ្រាមណាប៉ូឡេអុង នៅពេលដែលប្រទេសបារាំងបានជ្រើសរើសកងទ័ពជាសកល ទូទាំងប្រទេស និងដាក់ដំណើរការសេដ្ឋកិច្ច«បង្គាប់បញ្ជា»ពីថ្នាក់កណ្តាល។ ប្រជាយោធាដ៏

ក្លៀវក្លាមុះមុតរបស់ខ្លួនដែលផ្សំឡើងជារលើកដំបូងដោយជនជាតិបារាំងផ្ទាល់ ជាជាងទាហានស៊ីឈ្នួលបានធ្វើ ព្យុហយាត្រាលើផ្លូវដ៏វែងឆ្ងាយនិងឆាប់រហ័សជាងមុន។ ប្រជាពលរដ្ឋបានចូលរួមធ្វើជាកងទ័ព ម្យ៉ាងដោយសារ ពួកគេមានស្មារតីស្នេហាជាតិ ហើយម្យ៉ាងទៀត ប្រជាជាតិរបស់ពួកគេបានបង្កប់នូវសេចក្តីប្រាថ្នានិងឧត្តមគតិ របស់ពួកគេ និងបានបណ្តាលអោយពួកគេរួមគ្នាជាឆ្លុងអត្តសញ្ញាណជាតិរួមគ្នាតែមួយ។

ទន្ទឹមនឹងនេះ សហរដ្ឋអាមេរិកបានយកតាមគំរូរបស់ប្រទេសហូឡង់ ដោយការប្រកាសឯករាជ្យពី ចក្រភពអង់គ្លេស នៅឆ្នាំ ១៧៧៦។ រដ្ឋនានានៅអាមេរិកឡាទីនបានទទួលឯករាជ្យ នៅដើមសតវត្សរ៍ទី១៩ ហើយនៅពេលក្រោយក្នុងសតវត្សរ៍ដដែលនេះ ប្រទេសអាឡឺម៉ង់និងប្រទេសអ៊ីតាលីបានបង្រួបបង្រួមជាតិ របស់ពួកគេ ចេញពីអង្គភាពនយោបាយជាច្រើន (តាមរយៈសង្គ្រាម) ។

មុនសង្គ្រាមលោកលើកទី១ កម្មករសង្គមនិយមមកពីបណ្តាប្រទេសផ្សេងៗនៅអឺរ៉ុបបានប្រមូលផ្តុំគ្នា ជា(វណ្ណៈ)កម្មកររដើម្បីតស៊ូទាមទារសិទ្ធិកម្មករ។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងសង្គ្រាមនោះ កម្មករ ភាគច្រើនបានបោះបង់ចោលនូវសាមគ្គីភាពខាងលើនេះ ហើយជំនួសមកវិញនូវការតស៊ូប្រយុទ្ធដើម្បីជាតិ រៀងៗខ្លួន។ ដូច្នេះ ជាតិនិយមត្រូវបានសបញ្ជាក់ថាជាចរន្តនយោបាយខ្លាំងជាងសង្គមនិយម។ មុនពេល សង្គ្រាមលោកលើកទី ២ ជាតិនិយមបានជួយប្រទេសអាឡឺម៉ង់ ប្រទេសអ៊ីតាលី និងប្រទេសជប៉ុនបង្កើត សណ្តាប់ធ្នាប់នយោបាយ ដោយផ្អែកលើ*លទ្ធិហ្វាស៊ីសនិយម* (fascism) ដែលជារបបផ្តាច់ការជ្រុលនិយម ដែលចងភ្ជាប់ដោយលទ្ធិតម្កើងជាតិសាសន៍ខ្លួនជ្រុលហួសហេតុ។ ហើយនៅក្នុងសង្គ្រាមលោកលើកទីពីរ ចរន្ត ជាតិនិយមនិងស្នេហាជាតិ (មិនមែនកុម្មុយនិស្ត) ដែលបានកៀងគរប្រជាជនសូវៀតរាប់លាននាក់ អោយ លះបង់បូជាខ្លួន ដើម្បីរុញច្រានការឈ្លានពានរបស់អាឡឺម៉ង់ចេញវិញ។

ក្នុងរយៈពេល ៧០ ឆ្នាំកន្លងមក ប្រជាជាតិចំនួនរាប់សិបបានទទួលភាពឯករាជ្យ និងក្លាយជារដ្ឋ។ ជនជាតិជ្វីហ្វបានប្រឹងប្រែងយ៉ាងខ្ជាប់ខ្ជួន នៅក្នុងពាក់កណ្តាលទីមួយនៃសតវត្សរ៍ទី ២០ ដើម្បីបង្កើតរដ្ឋ អ៊ីស្រាអែល ហើយប៉ាឡេស្ទីនបានប៉ងប្រាថ្នា នៅពាក់កណ្តាលទីពីរនៃសតវត្សរ៍ដដែល ដើម្បីបង្កើតរដ្ឋ ប៉ាឡេស្ទីន។ ខណៈពេលដែលរដ្ឋចម្រុះជាតិសាសន៍ ដូចជាសហភាពសូវៀត និងយូហ្គោស្លាវីបានត្រូវបំបែក ជារដ្ឋតូចៗជាច្រើន ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ អង្គភាពដែនដីនិងជាតិសាសន៍ ដូចជា អ៊ុយក្រែន ស្លូវេនី និង ទីម័រខាងកើតបានប្រកាសនិងបង្កើតខ្លួនឯងជារដ្ឋឯករាជ្យ។ អង្គភាពផ្សេងទៀតដូចជាម៉ុងតេណេហ្គ្រោ និង ឃឺឌីស្ថាន បានព្យាយាមធ្វើដូច្នេះគ្នានេះដែរ ហើយដំណើរការកិច្ចការផ្ទាល់ខ្លួនរបស់ពួកគេរួចហើយ។ ឥទ្ធិពល នៃជាតិនិយមជាបន្តបន្ទាប់ នៅក្នុងពិភពលោកបច្ចុប្បន្ន មានភស្តុតាងសបញ្ជាក់ជាក់ស្តែងណាស់។ វាជះ ឥទ្ធិលលើប្រភេទនៃជម្លោះសំខាន់ៗមួយចំនួន នៅក្នុងផ្នែកបន្តបន្ទាប់នៅក្នុងមេរៀននេះ។

៥.២.២. ជម្លោះជាតិសាសន៍

ជម្លោះជាតិសាសន៍គឺជាប្រភពនៃជម្លោះដ៏សំខាន់បំផុតនៃសង្គ្រាមជាច្រើន ដែលកំពុងកើតឡើងនៅទូទាំង ពិភពលោក។ ក្រុមជាតិសាសន៍គឺជាក្រុមមនុស្សដ៏ធំ ដែលមានទំនាក់ទំនងជួនតា ភាសា វប្បធម៌ និង-ឬ សាសនារួមគ្នា ក៏ដូចជា*អត្តសញ្ញាណ*រួមមួយ (បុគ្គលទាំងឡាយដែលកំណត់អត្តសញ្ញាណរបស់ខ្លួនផ្ទាល់ដូច ក្រុម)។ ទោះបីជាជម្លោះរវាងក្រុមជាតិសាសន៍ច្រើនតែមានទិដ្ឋភាពសម្ភារៈរូបី - ជាពិសេស ការគ្រប់គ្រងលើ ទឹកដី និងរដ្ឋាភិបាល - ជម្លោះជាតិសាសន៍កើតចេញពីការមិនចូលចិត្ត ឬស្អប់គុំគួន ដែលសមាជិកនៃក្រុម ជាតិសាសន៍មួយមានអារម្មណ៍ជាប្រព័ន្ធចំពោះក្រុមជនជាតិផ្សេងទៀត។ ដូច្នេះ ជម្លោះជាតិសាសន៍គឺមិនផ្អែក

លើមូលហេតុឬទិដ្ឋភាពជាក់ស្តែង (ទង្វើដែលនរណាម្នាក់បានធ្វើ) ប៉ុន្តែ នៅលើទិដ្ឋភាពអរូបី (គ្រាន់តែជាជាតិសាសន៍ដទៃ (ទាំងមិនបានធ្វើអ្វីជាក់ស្តែងដាក់ខ្លួនឡើយ))។

ក្រុមជាតិសាសន៍ច្រើនតែបង្កើតមូលដ្ឋានសម្រាប់រំលេចមនោសញ្ចេតនាជាតិនិយម។ មិនមែនក្រុមជាតិសាសន៍ទាំងអស់កំណត់អត្តសញ្ញាណខ្លួនជាប្រជាជាតិទេ។ ជាឧទាហរណ៍ នៅក្នុងសហរដ្ឋអាមេរិក ក្រុមជាតិសាសន៍ផ្សេងៗបានរួមរស់ជាមួយគ្នា (ជួនកាល ទាំងទើសទាល់) ដោយប្រកាន់យកអត្តសញ្ញាណ*ជាភ្លឹម*ជាជនជាតិអាមេរិក។ ប៉ុន្តែ នៅក្នុងទីតាំងដែលសមាជិករាប់លាននាក់នៃក្រុមជាតិសាសន៍តែមួយរស់នៅជាក្រុមប្រជាជនភាគច្រើន នៅក្នុងទឹកដីបុព្វបុរសរបស់ពួកគេ ពួកគេ ជាធម្មតា គិតថាខ្លួនឯងជាប្រជាជាតិមួយ។ ក្នុងករណីភាគច្រើន ពួកគេប្រាថ្នាចង់មានរដ្ឋផ្ទាល់ខ្លួន ដោយមានឋានៈអន្តរជាតិផ្លូវការ និងព្រំដែនទឹកដីច្បាស់លាស់។

រូបថត ក្មេងៗ*នៅក្នុងទីក្រុងដែលគាំទ្រស៊ីរីចូលហ្វឹកហាត់ប្រយុទ្ធ*
ការហ្វឹកហាត់ប្រយុទ្ធប្រឆាំងនឹងក្រុមក្រៅសង្គម

ជម្លោះជាតិសាសន៍មានចំណែកសំខាន់ក្នុងជម្លោះអន្តរជាតិជាច្រើន។ ការប្រកាន់ពូជសាសន៍ផ្អែកលើភាពលំអៀងក្នុងក្រុម អាចជម្រុញការមិនអត់ឱន និងការបន្ទាបបន្ថោកមនុស្សជាតិនៃក្រុមក្រៅសង្គម ដូចជានៅក្នុងការប្រល័យពូជសាសន៍នៅដារហ្វួរ(ស៊ូដង់) រ៉ាន់ដា និងបូស្នៀ, របបអាផាថេតអាហ្វ្រិកខាងត្បូង, ការធ្វើទុក្ខបុកម្នេញលើជនជាតិយូដានិងជនជាតិភាគតិចផ្សេងទៀត នៅក្នុងណាហ្ស៊ីអាឡឺម៉ង់, និងរបបទាសភាពនៅសហរដ្ឋអាមេរិក។ ក្នុងឆ្នាំ ២០១៤ អំពើហិង្សាបានផ្ទុះឡើងនៅប្រទេស អ៊ុយក្រែន ដោយការវាយប្រហារកងកម្លាំងអ៊ុយក្រែននិយមអឺរ៉ុបនៅភាគខាងលិច ប្រឆាំងនឹងកងកម្លាំងអ៊ុយក្រែននិយមរុស្ស៊ីនៅភាគខាងកើត។ នៅទីនេះ ក្មេងៗនៅក្នុងទីក្រុងដែលគាំទ្ររុស្ស៊ីចូលក្លឹបយុទ្ធសាស្ត្រយោធា ក្រោយចេញពីរៀនដើម្បីហ្វឹកហាត់សម្រាប់ការប្រយុទ្ធឆ្នាំ ២០១៧ ។

ការគ្រប់គ្រង*ទឹកដី*ត្រូវបានភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងសេចក្តីប្រាថ្នារបស់ក្រុមជាតិសាសន៍ ឬជនជាតិភាគតិចសម្រាប់បង្កើតជារដ្ឋមួយ។ ព្រំដែនរបស់រដ្ឋណាក៏ដោយ មានការប្រែប្រួលវិសាលភាពខ្លះ (ជួនកាលប្រែប្រួលខ្លាំង) ពីទីតាំងជាក់ស្តែងនៃសហគមន៍ជាតិសាសន៍នីមួយៗ។ សមាជិកនៃក្រុមជនជាតិភាគតិចត្រូវបានទុកចោលនៅក្រៅព្រំដែនរដ្ឋរបស់ខ្លួន ហើយសមាជិកនៃក្រុមជនជាតិផ្សេងទៀតមានទីតាំងរស់នៅក្នុងព្រំដែនរបស់រដ្ឋ។ ជាលទ្ធផល ស្ថានភាពបែបនេះអាចបង្កអោយមានគ្រោះថ្នាក់ណាស់ ដោយមួយផ្នែកនៃក្រុមជាតិសាសន៍នោះគ្រប់គ្រងរដ្ឋមួយ និងមួយផ្នែកទៀតរស់នៅជាជនជាតិភាគតិច នៅក្នុងរដ្ឋមួយផ្សេងទៀតដែលគ្រប់គ្រងដោយក្រុមជាតិសាសន៍ដទៃដែលជាគូប្រជែង។ ជារឿយៗ ក្រុមជនជាតិភាគតិចទទួលរងនូវការរើសអើង នៅក្នុងរដ្ឋផ្សេងទៀត ហើយរដ្ឋ«មាតុភូមិ» ព្យាយាមជួយសង្គ្រោះ ឬសងសឹកអោយពួកគេ។

ក្រុមជាតិសាសន៍ផ្សេងទៀតមិនមានរដ្ឋកំណើត ឬមាតុប្រទេសនោះទេ។ ជនជាតិឃឺដមានវប្បធម៌មួយរួមគ្នា ហើយពួកគេជាច្រើនប្រាថ្នាចង់បង្កើតរដ្ឋឃឺដមួយ។ ប៉ុន្តែ ជនជាតិឃឺដរស់នៅលើទឹកដីរដ្ឋចំនួនបួន ៖ ទួរគី អ៊ីរ៉ាក់ អ៊ីរ៉ង់ និងស៊ីរី - ដែលប្រទេសទាំងអស់នេះប្រឆាំងយ៉ាងខ្លាំងចំពោះការបោះបង់ការគ្រប់គ្រងផ្នែកណាមួយនៃទឹកដីរបស់ខ្លួនដើម្បីបង្កើតរដ្ឋឃឺដ (សូមមើលក្រាហ្វិកផែនទី ៥.២)។ ក្នុងទស្សវត្សរ៍ឆ្នាំ ១៩៩០ កងកម្លាំងទ័ពព្រៃឃឺដដែលជាគូប្រជែងនឹងគ្នាបានប្រយុទ្ធប្រឆាំងនឹងកងកម្លាំងយោធាអ៊ីរ៉ាក់និងទួរគីផង និងប្រយុទ្ធប្រឆាំងគ្នាឯងផង។ ម្តងហើយម្តងទៀត នៅចុងទសវត្សរ៍ឆ្នាំ ១៩៩០ ទួរគីបានបញ្ជូនកងកម្លាំងយោធា

ដ៏ធំចូលទៅវាយប្រហារមូលដ្ឋានទ័ពព្រៃឃីដ ក្នុងភាគខាងជើងប្រទេសអ៊ីរ៉ាក់។ ជនជាតិឃឺដបានរីករាយនឹងស្វ័យភាពនៅក្នុងផ្នែកភាគខាងជើងនៃប្រទេសអ៊ីរ៉ាក់ ក្រោមការការពាររបស់សហរដ្ឋអាមេរិក ក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ និងបានរក្សាបាននូវស្ថានភាពស្វ័យភាពមួយ នៅប្រទេសអ៊ីរ៉ាក់ក្រោយសម័យសាដាមហ៊ូសេន។ ជោគជ័យរបស់ជនជាតិឃឺដ នៅក្នុងការបោះឆ្នោតអ៊ីរ៉ាក់ឆ្នាំ ២០១០ បានផ្តល់អោយពួកគេនូវជំហរដ៏រឹងមាំដើម្បីរក្សាឋានៈនេះ។ នៅក្នុងសង្គ្រាមស៊ីរីលស៊ីរី ដែលបានចាប់ផ្តើមក្នុងឆ្នាំ ២០១១ តំបន់ឃឺដទទួលបានស្វ័យភាពគួរអោយកត់សម្គាល់ ខណៈពេលដែលកំពុងជាប់របងនយោបាយរវាងរដ្ឋាភិបាល និងពួកឧទ្ទាម។ យុទ្ធជនឃឺដ(រហ័ស្សនាម ប៉េសមើហ្គា-Peshmerga) ក៏បានទទួលការគាំទ្រផ្នែកយោធាអន្តរជាតិយ៉ាងច្រើនក្នុងការប្រយុទ្ធប្រឆាំងនឹងពួកសកម្មប្រយុទ្ធរដ្ឋអ៊ីស្លាម(ISIS) ដែលនៅក្នុងមួយរយៈពេលខ្លី បានដណ្តើមយកទឹកដីនៅភាគខាងជើងប្រទេសអ៊ីរ៉ាក់និងស៊ីរី។ អស់រយៈពេលប៉ុន្មានឆ្នាំ សហរដ្ឋអាមេរិកបានជួយ ប៉េសមើហ្គាឃឺដក្នុងការរុញច្រានកងកម្លាំងរដ្ឋអ៊ីស្លាមចេញ ជាពិសេសនៅប្រទេសអ៊ីរ៉ាក់ភាគខាងជើង។ ប៉ុន្តែ នៅចុងឆ្នាំ ២០១៧ ប្រទេសទួរគីបានចាប់ផ្តើមប្រតិបត្តិការយោធាជាទ្រង់ទ្រាយធំប្រឆាំងទាំងក្រុមសកម្មប្រយុទ្ធឃឺដនិងរដ្ឋអ៊ីស្លាម(ISIS)។ ប្រតិបត្តិការនេះរួមទាំងការវាយប្រហារតាមអាកាសប្រឆាំងក្រុមឃឺដដែលត្រូវបានគាំទ្រដោយសហរដ្ឋអាមេរិក។ ថាតើជនជាតិឃឺដនឹងអាចបន្តគោលដៅរបស់ពួកគេក្នុងការបង្កើតដែនដីឯករាជ្យក្នុងតំបន់ដែរឬអត់ មិនទាន់ច្បាស់នៅឡើយទេ ត្រូវរង់ចាំបន្តតាមដានទៀត។

ជម្លោះជាតិសាសន៍តែងតែបង្កើតសម្ពាធដើម្បីគូសព្រំដែនឡើងវិញ ដោយកម្លាំងទ័ព។ នៅពេលដែលក្រុមប្រជាជនជាតិសាសន៍គឺជាជនជាតិភាគតិច នៅក្នុងទឹកដីដែលគ្រប់គ្រងដោយក្រុមជាតិសាសន៍ដែលជាគូប្រជែង ពួកគេអាចត្រូវបានបណ្តេញចេញពីទឹកដីដើមរបស់ខ្លួន ឬ (ក្នុងករណីកម្រ) ត្រូវបានសម្លាប់ចោលជាប្រព័ន្ធ។ តាមរយៈការបណ្តេញក្រុមជនជាតិភាគតិចចេញ ក្រុមជនជាតិភាគច្រើនអាចប្រមូលផ្តុំការបង្រួបបង្រួមទឹកដីជាប់គ្នា កាន់តែច្រើន និងកាន់តែធំទូលំទូលាយជាងមុន សម្រាប់ប្រជាជាតិរបស់ខ្លួន ដូចដែលជនជាតិស៊ែបបានព្យាយាមធ្វើតាមរយៈ*ការរបាសសម្អាតជាតិសាសន៍* (ជាពាក្យដែលពួកគេបានបង្កើតឡើង) បន្ទាប់ពីការបែកបាក់នៃប្រទេសយូហ្គោស្លាវី ក្នុងទសវត្សរ៍ឆ្នាំ ១៩៩០។ ស្រដៀងគ្នានេះដែរ ជម្លោះជាតិសាសន៍រវាងក្រុមជនជាតិភាគច្រើន កៀហ្ស៊ី(kyrgyz) និងក្រុមជនជាតិភាគតិច អ៊ូស្បេក (Uzbeks) ក្នុងឆ្នាំ ២០១០ នៅប្រទេសកៀហ្ស៊ីស៊ីស្ថាន (នៅអាស៊ីកណ្តាល) បានជម្លៀសប្រជាជនចេញពីទីលំនៅរាប់សែននាក់ដែលជាឧទាហរណ៍មួយទៀតនៃឥទ្ធិពលនៃជម្លោះអត្តសញ្ញាណបែបនេះ។

ជារឿយៗ រដ្ឋនៅខាងក្រៅព្រួយបារម្ភអំពីជោគវាសនារបស់«ប្រជាជនរបស់ពួកគេ» ដែលរស់នៅជាជនជាតិភាគតិចនៅក្នុងរដ្ឋជិតខាង។ ជាឧទាហរណ៍ ប្រទេសអាល់បានីមានការព្រួយបារម្ភអំពីជាតិសាសន៍អាល់បានី ដែលជាប្រជាជនភាគច្រើន នៅក្នុងខេត្តកូសូវ៉ូ របស់ប្រទេសស៊ែប៊ី ប៉ុន្តែ ជាជនជាតិភាគតិចនៅក្នុងប្រទេសស៊ែប៊ីទាំងមូល)។ ប៉ុន្តែ នៅពេលដែលកូសូវ៉ូឆ្ពោះទៅរកឯករាជ្យភាពពីប្រទេសស៊ែប៊ី ស៊ែប៊ីព្រួយបារម្ភអំពីជនជាតិស៊ែប៊ី ដែលជាក្រុមភាគតិចរស់នៅក្នុងកូសូវ៉ូ។ បញ្ហាស្រដៀងគ្នានេះបានជំរុញអោយមានសង្គ្រាមរវាងអាមេនីនឹងអាស៊ែបៃហ្សង់ និង រវាងឥណ្ឌានឹងប៉ាគីស្ថាន។ កត្តារួមផ្សំដ៏គ្រោះថ្នាក់នៃជម្លោះជាតិសាសន៍និងជម្លោះទឹកដីអាចនាំអោយមានសង្គ្រាមកាន់តែច្រើន នាពេលអនាគត។

មូលហេតុនៃអរិភាពជាតិសាសន៍

តើហេតុអ្វីបានជាក្រុមជាតិសាសន៍នានាតែងតែមិនចូលចិត្តគ្នាទៅវិញទៅមក? ជារឿយៗ មានជម្លោះ

ជាប្រវត្តិសាស្ត្រដ៏យូរអង្វែង ដណ្តើមទឹកដីត្រង់ទីតាំងណាមួយ ឬដណ្តើមធនធានធម្មជាតិ ឬ ការកេងប្រវ័ញ្ច សេដ្ឋកិច្ចនៃក្រុមជនជាតិមួយលើមួយទៀតឬការត្រួតត្រានយោបាយពីសំណាក់ក្រុមមួយលើក្រុមជាតិសាសន៍មួយទៀត។ ជម្លោះទាំងនេះត្រូវបានជំរុញ មិនមែនដោយរឿងរ៉ាវសោកសង្រេងដែលកើតឡើងជាក់ស្តែងទេ (ទោះបីកត្តាទាំងនេះអាចបន្តជាភ្លើងឆាបឆេះខ្លាំងក៏ដោយ) ប៉ុន្តែ ត្រូវបានជម្រុញដោយប្រភេទនៃដំណើរការដែលត្រូវបានពិពណ៌នាដោយចិត្តសាស្ត្រសង្គមថាបានវិវត្តន៍ទៅមុខជាហូរហែរ នៅពេលដែលមនុស្សមួយក្រុមមានជម្លោះអូសបន្លាយយ៉ាងយូរជាមួយនឹងក្រុមមួយផ្សេងទៀត ហើយត្រូវរងគ្រោះដោយសារអំពើហិង្សាដោយកណ្តាប់ដៃរបស់ក្រុមមនុស្សផ្សេងទៀត។ ក្រុមជាតិសាសន៍ គឺជាក្រុម*ញាតិសន្តាន*(kinship)រាប់រយជំនាន់ ដែលជាក្រុមមនុស្សបងប្អូននឹងគ្នាដែលមានបុព្វបុរសរួមតែមួយ។ សូម្បីតែនៅពេលដែលទំនាក់ទំនងញាតិមិត្តមិនសូវជិតស្និទ្ធក៏ដោយ ក៏*អត្តសញ្ញាណក្រុម*ធ្វើអោយមនុស្សម្នាក់ធ្វើសកម្មភាពហាក់ដូចជាសមាជិកដទៃទៀតនៃក្រុមជាតិសាសន៍នោះជាក្រុមគ្រួសារផងដែរ។ ជាឧទាហរណ៍ បុរសជនជាតិអាមេរិកដើមកំណើតអាហ្វ្រិក ដែលហៅគ្នាទៅវិញទៅមកថា «បងប្អូន» បង្ហាញពីអត្តសញ្ញាណក្រុមថាជាសាច់ញាតិ។ ដូចគ្នាដែរជនជាតិជ្វីហ្វនៅជុំវិញពិភពលោកចាត់ទុកថាជាក្រុមគ្រួសារនឹងគ្នា បើទោះបីសហគមន៍នីមួយៗបានរៀបការឆ្លងជាតិសាសន៍ជាយូរមកហើយ ហើយមានបុព្វបុរសរួមគ្នាកាន់តែច្រើនជាមួយនឹងជនមិនមែនជាតិសាសន៍ជ្វីហ្វក្នុងស្រុក ជាជាងជនជាតិជ្វីហ្វនៅឯនាយសមុទ្រក៏ដោយ។ ប្រហែលដោយសារបច្ចេកវិទ្យាខ្ពស់អនុញ្ញាតអោយក្រុមមនុស្សនៅឆ្ងាយៗ អាចប្រមូលផ្តុំគ្នានៅក្នុងប្រព័ន្ធអ៊ីនធឺណែត នឹងមានសម្ពាធផ្លូវចិត្តតិចជាងមុនក្នុងការប្រមូលក្រុមជាតិសាសន៍នៅក្នុងប្រជាជាតិ ដែលមានទឹកដីខាងក្រៅជាក់ស្តែង។ ឬក៏ថា ឧបករណ៍ដូចជាប្រព័ន្ធផ្សព្វផ្សាយសង្គមអាចភ្ជាប់បុគ្គលនីមួយៗដែលមិនស្គាល់គ្នាពីមុនមក ហើយលើកទឹកចិត្តអោយពួកគេជួបជុំគ្នាឡើងវិញ ដើម្បីនៅជាមួយក្រុមញាតិមិត្ត ដែលជាជាតិសាសន៍របស់ខ្លួន។

ក្រាហ្វិក ៥.២ តំបន់យឺដ

ជនជាតិភាគតិចច្រើនតែលាតសន្ធឹងតាមព្រំដែនអន្តរជាតិ។ តំបន់ដែលមានស្រមោលក្នុងផែនទីខាងក្រោម បង្ហាញពីតំបន់តាំងទីលំនៅរបស់ជនជាតិយឺដ។



ការប្រកាន់ពូជសាសន៍និយម(ethnocentrism) ឬ *ការលម្អៀងក្នុងក្រុម* គឺជាទំនោរក្នុងការមើលឃើញក្រុមជាតិសាសន៍របស់ខ្លួន នៅក្នុងទិដ្ឋភាពអំណោយផល ឬយល់ឃើញក្រុមខ្លួនក្នុងន័យល្អៗលើសគេ និងយល់ឃើញ*ក្រុមខាងក្រៅ* ក្នុងលក្ខណ្ឌមិនអំណោយផល។ អ្នកប្រាជ្ញខ្លះជឿថា ការប្រកាន់ពូជសាសន៍និយមមានឫសគល់ពីទំនោរដើរសាស្ត្រ ដើម្បីការពារបុគ្គលដែលមានទំនាក់ទំនងជិតស្និទ្ធ បើទោះបីជាគំនិតនេះមានភាពចម្រូងចម្រាសក៏ដោយ។ ជារឿយៗ ភាពលំអៀងក្នុងក្រុមត្រូវបានស្វែងយល់នៅក្នុងលក្ខខណ្ឌនៃចិត្តវិទ្យាសង្គម។ ក្នុងកាលៈទេសៈណាក៏ដោយ ចំណងដែលចងក្រុមជាតិសាសន៍អោយស្អិតរមួតជាមួយគ្នា និងចំណងដែលខ័ណ្ឌចែកពួកគេចេញពីក្រុមផ្សេងទៀត ត្រូវផ្អែកលើគោលការណ៍អត្តសញ្ញាណ (សូមមើលមេរៀនទី ១)។ ដូចដែលគោលការណ៍បដិការមានផលអវិជ្ជមានផ្ទាល់ខ្លួន (សូមមើលមេរៀនទី១) គោលការណ៍អត្តសញ្ញាណក៏ដូចគ្នាដែរ ពោលគឺមានផលអវិជ្ជមានផ្ទាល់ខ្លួន។ ចរន្តដូចគ្នាដែលអនុញ្ញាតអោយមានការលះបង់ដើម្បីអត្តសញ្ញាណក្រុមរួម ដូចជានៅក្នុងសហភាពអឺរ៉ុបផងដែរ អនុញ្ញាតអោយមានការបង្កើតភាពលំអៀងក្នុងក្រុម។

គ្មាន*លក្ខណៈវិនិច្ឆ័យអប្បបរមា* នៃភាពស្រដៀងគ្នា ឬ ទំនាក់ទំនងសាច់ញាតិដែលត្រូវការជាចាំបាច់ដើម្បីជំរុញដំណើរការអត្តសញ្ញាណក្រុម រួមទាំងដំណើរការលំអៀងក្នុងក្រុម នោះទេ។ នៅក្នុងការពិសោធន៍ចិត្តសាស្ត្រ សូម្បីតែភាពខុសប្លែកគ្នាតិចតួចក៏អាចបង្កអោយមានដំណើរការទាំងនេះដែរ។ ប្រសិនបើមនុស្សត្រូវបានចាត់តាំងជាក្រុម ដោយផ្អែកលើលក្ខណៈដែលគេស្គាល់ ប៉ុន្តែមិនសូវសំខាន់ (ដូចជា ក្រុមដែលចូលចិត្តរង្វង់មូលជាងត្រីកោណ ជាឧទាហរណ៍) មុនពេលដែលមនុស្សក្នុងក្រុមនីមួយៗបង្ហាញភាពលំអៀងក្នុងក្រុម ហើយបង្ហាញថា ពួកគេមិនខ្វល់ច្រើនចំពោះសមាជិកក្រុមផ្សេងទៀតឡើយ។

ការលំអៀងក្នុងក្រុមកាន់តែខ្លាំងឡើង នៅពេលដែលក្រុមមនុស្សផ្សេងទៀតមានរូបរាងខាងក្រៅខុសពីខ្លួន និយាយភាសាផ្សេងពីខ្លួន ឬគោរពបូជាតាមរបៀបផ្សេងពីខ្លួន (ឬខុសពីខ្លួនទាំងបីទិដ្ឋភាពតែម្តង)។ ប្រាកដណាស់ មនុស្សក្រៅក្រុមអាចត្រូវបានបន្ទាបបន្ថោក និងដកហូតសិទ្ធិឬឋានៈមនុស្សគ្រប់បែបយ៉ាង។ **ការបន្ទាបបន្ថោកមនុស្ស**(dehumanization)នេះរួមបញ្ចូលទាំងការប្រើប្រាស់ឈ្មោះជាសត្វធាតុ ដូចជាសត្វជ្រូក ឬឆ្កែជាដើម សម្រាប់ហៅមនុស្សក្រៅក្រុម។ ការឃោសនារបស់សហរដ្ឋអាមេរិក ក្នុងសង្គ្រាមលោកលើកទីពីរ បានពណ៌នាជនជាតិជប៉ុនថាជាស្វាឌី។ ជាពិសេសនៅក្នុងកំឡុងកាលមានសង្គ្រាម ការបន្ទាបបន្ថោកមនុស្សអាចមានលក្ខណៈកាន់តែធ្ងន់ធ្ងរជ្រុលនិយម។ ការរឹតបន្តឹងលើសង្គ្រាមដែលបានវិវត្ត នៅក្នុងសង្គ្រាមអន្តរដ្ឋជាទៀងទាត់ ដូចជាការហាមឃាត់មិនអោយសម្លាប់ជនស៊ីវិល (សូមមើល ឧក្រិដ្ឋកម្មសង្គ្រាម នៅក្នុងមេរៀនទី ៧) ត្រូវបានគេបំពាន នៅក្នុងសង្គ្រាមរវាងជាតិសាសន៍។

បទពិសោធន៍នៅអឺរ៉ុបខាងលិចបង្ហាញថា យូរៗទៅ ការអប់រំអាចជម្នះលើការរើសអើងជាតិសាសន៍រវាងប្រទេសដែលមានអរិភាពជាប្រពៃណី ដូចជា ប្រទេសបារាំងនិងអាឡឺម៉ង់ជាដើម។ បន្ទាប់ពីសង្គ្រាមលោកលើកទី២ រដ្ឋាភិបាលនៃរដ្ឋទាំងពីរនេះបានសរសេរឡើងវិញនូវសៀវភៅសិក្សាគោលដៅលមនុស្សជំនាន់ថ្មីនឹងប្រើប្រាស់ ដើម្បីសិក្សាប្រវត្តិសាស្ត្រប្រជាជនរបស់ខ្លួន។ កាលពីមុន សៀវភៅសិក្សារបស់រដ្ឋនីមួយៗបានលើកតម្កើងអំពើអតីតកាលរបស់ខ្លួននិងបង្រួមកំហុសរបស់ខ្លួន ប៉ុន្តែបានបង្ហាញពីសត្រូវជាប្រពៃណីរបស់ខ្លួន ក្នុងន័យមិនល្អសោះឡើយ។ នៅក្នុងគម្រោងសម្រាប់ទ្វីបអឺរ៉ុបទាំងមូល សៀវភៅសិក្សាថ្មីដែលផ្តល់អោយនូវគោលបំណងនិងការបង្ហាញកាន់តែត្រឹមត្រូវ ត្រូវបានបង្កើតឡើង។ ផ្ទុយទៅវិញ សៀវភៅសិក្សារបស់ជប៉ុននាពេល

បច្ចុប្បន្នដែលចែងអំពីឧក្រិដ្ឋកម្មរបស់ប្រទេសជប៉ុន នៅក្នុងសង្គ្រាមលោកលើកទី ២ នៅតែបន្តធ្វើអោយទំនាក់ទំនងជាមួយប្រទេសចិន និងកូរ៉េ កាន់តែក្តៅគគុក។

អត្ថិភាពនៃការគម្រាមកំហែងពីក្រុមខាងក្រៅណាមួយជម្រុញការបង្រួបបង្រួមក្នុងក្រុម ម្លោះហើយបង្កើតដំណើរបែងចែកជាតិសាសន៍ ដែលត្រូវបានពង្រឹងដោយខ្លួនឯង។ ទោះជាយ៉ាងណាក៏ដោយ ការប្រកាន់ជាតិសាសន៍និយមក៏ជារឿយៗធ្វើអោយសមាជិកក្រុមចាត់ទុកថាខ្លួនមិនចុះសម្រុងនឹងគេ (ដោយសារតែពួកគេមើលឃើញការប្រៃះឆាគ្នាកៀកបំផុត) និងចាត់ទុកក្រុមខាងក្រៅជាផ្ទាំងថ្មមួយដុំធំ (monolithic) (ព្រោះពួកគេសម្លឹងមើលតែពីខាងក្រៅប៉ុណ្ណោះ)។ ជាធម្មតា នេះ ឆ្លុះបញ្ចាំងអំពីអារម្មណ៍ងាយរងគ្រោះរបស់ក្រុម។ នៅក្នុងជម្លោះអារ៉ាប់-អ៊ីស្រាអែល ជនជាតិអ៊ីស្រាអែលមានទំនោរមើលឃើញថាពួកគេបែងចែកទៅជាគណបក្សនយោបាយ រាប់សិបក្រុម និងសហគមន៍ជនអន្តោប្រវេសន៍ចម្រុះ ដែលប្រទាញប្រទងគ្នាទៅកាន់ទិសដៅផ្សេងៗគ្នា ខណៈដែលពួកគេមើលឃើញថា «ពួកអារ៉ាប់» ជាប្លុកមួយឬផ្ទាំងថ្មីមួយដ៏ធំ រួបរួមគ្នាប្រឆាំងនឹងពួកគេ។ ទន្ទឹមនឹងនេះដែរ ប្រជាជនប៉ាឡេស្ទីនអារ៉ាប់មើលឃើញថាខ្លួនគេត្រូវបានបែងចែកទៅជាបក្សពួកជាច្រើន និងចុះខ្សោយដោយការបែកបាក់គ្នា ក្នុងចំណោមរដ្ឋអារ៉ាប់ ខណៈដែល«អ៊ីស្រាអែល» មើលទៅមានលក្ខណៈរួមគ្នាដូចថ្មមួយផ្ទាំង។

ក្រុមជាតិសាសន៍គ្រាន់តែជាចំណុចមួយប៉ុណ្ណោះ នៅក្នុងចំណោមវិសាលគម(spectrum)នៃទំនាក់ទំនងញាតិមិត្តៈ ពីគ្រួសារតូចៗតាមរយៈគ្រួសារធំរស់នៅជួបជុំគ្នាច្រើនដំនាន់ ភូមិ ខេត្ត និងប្រជាជាតិ រហូតដល់មនុស្សជាតិទាំងមូល។ កក្តីភាពធ្លាក់នៅចំណុចផ្សេងៗគ្នា តាមវិសាលគមនីមួយៗ។ ជាថ្មីម្តងទៀត មិនមានលក្ខណៈវិនិច្ឆ័យអប្បបរមាសម្រាប់អត្តសញ្ញាណក្នុងក្រុមនោះទេ។ ជាឧទាហរណ៍ អ្នកជំនាញបានពោលថា ក្នុងចំណោមប្រទេសអាហ្វ្រិកទាំងអស់ ប្រទេសសូម៉ាលីពិតជាមានភាពស៊ាំការពារមិនអោយមានជម្លោះជាតិសាសន៍ ដោយហេតុថាជនជាតិសូម៉ាលីសុទ្ធតែមានប្រភពមកពីក្រុមជនជាតិតែមួយ និយាយភាសាតែមួយដូចគ្នា និងគោរពប្រតិបត្តិសាសនាតែមួយដូចគ្នាដែរ។ បន្ទាប់មក នៅក្នុងឆ្នាំ ១៩៩១-១៩៩២ សង្គ្រាមស៊ីវិលដ៏ហិនហោចមួយបានផ្ទុះឡើងរវាងសមាជិកនៃកុលសម្ព័ន្ធផ្សេងៗគ្នា (ដោយផ្អែកលើគ្រួសារធំ) ដែលបណ្តាលអោយមានគ្រោះទុរភិក្សដ៏ធំ អន្តរាគមន៍របស់កងកម្លាំងយោធាបរទេស និងរយៈពេលពីរទសវត្សរ៍នៃភាពអនាធិបតេយ្យស្ទើរតែទាំងស្រុង និងអំពើហិង្សាមិនឈប់ឈរ។

វាមិនច្បាស់ទេថា ហេតុអ្វីបានជាមនុស្សជាច្រើនកំណត់អត្តសញ្ញាណខ្លួនខ្លាំងបំផុត នៅកម្រិតណាមួយនៃអត្តសញ្ញាណក្រុម។ នៅប្រទេសសូម៉ាលី ភាពស្មោះស្ម័គ្រចំពោះកុលសម្ព័ន្ធ, នៅប្រទេសស៊ែប៊ី ពួកគេស្មោះស្ម័គ្រចំពោះក្រុមជាតិសាសន៍, នៅសហរដ្ឋអាមេរិកនិងកន្លែងផ្សេងទៀត ប្រជាជាតិចម្រុះជាតិសាសន៍បញ្ជាភាពស្មោះស្ម័គ្រជាចម្បងរបស់មនុស្ស។ រដ្ឋទាំងឡាយពង្រឹងអត្តសញ្ញាណពលរដ្ឋជាមួយរដ្ឋតាមរយៈទង់ជាតិ ភ្លេងជាតិ ការសច្ចាប្រណិធានស្មោះស្ម័គ្រភក្តី សុន្ទរកថាស្នេហាជាតិ ជាដើម។ ប្រហែលជាថ្ងៃណាមួយមនុស្សនឹងសម្រួចភាពស្មោះស្ម័គ្រភក្តីរបស់ខ្លួនកាន់តែខ្លាំងឡើង ដោយបង្កើត*អត្តសញ្ញាណសកល*ក្នុងហានៈជាមនុស្សជាតិជាចម្បង ហើយក្នុងហានៈជាសមាជិកនៃរដ្ឋនិងក្រុមជាតិសាសន៍ ជាបន្ទាប់បន្សំ។

៥.២.៣. អំពើប្រល័យពូជសាសន៍

ក្នុងករណីធ្ងន់ធ្ងរបំផុត រដ្ឋាភិបាលប្រើប្រាស់**អំពើប្រល័យពូជសាសន៍** (ការសម្លាប់រង្គាលជាប្រព័ន្ធទៅលើក្រុមជាតិសាសន៍ឬសាសនា ទាំងមូល ឬ មួយផ្នែក) ដើម្បីព្យាយាមកំទេចក្រុមដែលត្រូវគេចោទប្រកាន់ ឬក្រុម

ដែលជាគូប្រកួតប្រជែងនយោបាយ។ ក្រោមគោលនយោបាយជ្រុលនិយមដែលចង់ធ្វើការចម្រាញ់ ឬបន្សុទ្ធ ពូជសាសន៍ ណាស៊ីអាឡឺម៉ង់បានសម្លាប់ជនជាតិជ្វីហ្វ ៦ លាននាក់ និងក្រុមមនុស្សដទៃទៀតរាប់លាននាក់ រួមទាំងអ្នកស្រឡាញ់ភេទដូចគ្នា ជនជាតិរ៉ូម៉ា និងជនកុម្មុយនិស្ត។ ការសម្លាប់រង្គាល ដែលឥឡូវនេះត្រូវបានគេស្គាល់ថាជា ការបូជាភ្លើង (Holocaust) រួមជាមួយនឹងវិសាលភាពសង្គ្រាមដ៏ធំធេង ដែលបញ្ចេញដោយការឈ្លានពានរបស់ណាស៊ី ត្រូវបានចាត់ទុកថាជា *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ*ដ៏ធំបំផុត ក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ។ មន្ត្រីអាឡឺម៉ង់ដែលមានទំនួលខុសត្រូវ បានប្រឈមមុខនឹងការកាត់ទោសសំដៅស្វែងរកភាពយុត្តិធម៌អោយជនរងគ្រោះ នៅក្នុង*តុលាការនុយរ៉ឺមប៊ឺក* (Nuremberg) ក្រោយសង្គ្រាមលោកលើកទីពីរ (សូមមើលជំពូកទី ១)។ ការសច្ចាប្រណិធានរបស់មេដឹកនាំពិភពលោកបន្ទាប់ពីបទពិសោធន៍នោះ ថានឹងមិនបណ្តោយអោយមានអំពើប្រល័យពូជសាសន៍បែបនោះ «ម្តងទៀតឡើយ» ត្រូវបានគេជម្រុញអោយធ្វើឡើង នៅពេលដែលអំពើប្រល័យពូជសាសន៍កើតឡើងជាបន្តបន្ទាប់ ក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ នៅប្រទេសបូស្នៀ និងប្រទេសរ៉ាន់ដា(Rwanda) ហើយថ្មីៗនេះ នៅដាហ្វួរ ក្នុងប្រទេសស៊ូដង់។

ក្នុងឆ្នាំ ១៩៩៤ នៅប្រទេសរ៉ាន់ដាជាកន្លែងដែលក្រុមហ៊ូទូ(Hutu)ជាក្រុមប្រជាជនភាគច្រើន និងក្រុមទុតស៊ី(Tutsi)ជាក្រុមជនជាតិភាគតិច រដ្ឋាភិបាលជាតិនិយមហ៊ូទូ បានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ដ៏សាហាវបំផុត ក្នុងប៉ុន្មានទសវត្សរ៍ថ្មីៗនេះ។ ជនជាតិភាគតិចទុតស៊ី ពីមុនបានកាន់អំណាចគ្របដណ្តប់លើក្រុមជនជាតិហ៊ូទូ ហើយអាណានិគមបែលហ្ស៊ិកបានកេងចំណេញពីការប្រកួតប្រជែងក្នុងតំបន់នេះ។ នៅឆ្នាំ ១៩៩៤ ជនជាតិភាគតិចហ៊ូទូជ្រុលនិយម នៅក្នុងរដ្ឋាភិបាលបានចេញបញ្ជា នៅទូទាំងប្រទេស អោយសម្លាប់ជនជាតិភាគតិចទុតស៊ីនិងពួកហ៊ូទូ ដែលបានប្រឆាំងនឹងរដ្ឋាភិបាល។ សរុបមក មនុស្សប្រុស ស្ត្រី និងចាស់ក្មេង ប្រមាណ ៨០០,០០០ នាក់ ត្រូវបានសម្លាប់ ភាគច្រើនដោយកាំបិតផ្តាក់ ហើយសាកសពរបស់ពួកគេត្រូវបានបោះចោល ចូលទៅក្នុងទន្លេ។ សាកសពរាប់ពាន់ ក្រោយមកត្រូវបានបោកបក់នៅលើច្រាំងទន្លេក្នុងប្រទេសជិតខាង អ៊ុយហ្គង់ដា (Uganda)។

គេអាចនឹងមើលឃើញការស្អប់ខ្ពើមឆ្លងជាតិសាសន៍រវាងហ៊ូទូនិងទុតស៊ីថាជា ផ្នែកមួយនៃគំរូនៃការស្អប់ជាតិសាសន៍យូរណាស់មកហើយ ដែលបានផ្ទុះឡើងកាន់តែខ្លាំង នៅក្នុងសម័យក្រោយសង្គ្រាមត្រជាក់ជាពិសេស នៅក្នុងតំបន់ «អន់ថយ» ដូចជាអាហ្វ្រិក។ (អ្នកនយោបាយលោកខាងលិចជារឿយៗបកស្រាយអំពីទ្រឹស្តីស្អប់ខ្ពើមជាតិសាសន៍ដ៏ចំណាស់មួយនេះ នៅក្នុងករណីបូស្នៀ ដោយពណ៌នា តំបន់បាល់កង់ ដូចករណីទ្វីបអាហ្វ្រិកដែរ ថា«អន់ថយ»និងងាយផ្ទុះជម្លោះ។) ប្រសិនបើការសម្លាប់ដោយផ្អែកលើការស្អប់ខ្ពើមជាតិសាសន៍ដ៏យូរលង់ មិនអាចជៀសរួច នោះភាពអសកម្មរបស់ពិភពលោកទាំងមូល ប្រហែលជាមានភាពសមហេតុផល។ ទោះជាយ៉ាងណាក៏ដោយ ការពន្យល់អំពីអំពើប្រល័យពូជសាសន៍ដែលជាលទ្ធផលនៃភាពអន់ថយ មិនអាចពន្យល់បានល្អនោះទេ ពីព្រោះរដ្ឋមួយក្នុងចំនោមរដ្ឋមានអារ្យធម៌«ជឿនលឿន»បំផុត ក្នុងពិភពលោក គឺប្រទេសអាឡឺម៉ង់ បានសម្លាប់ជនជាតិជ្វីហ្វរបស់ខ្លួនយ៉ាងសាហាវព្រៃផ្សៃជាងប្រទេសរ៉ាន់ដាដែលបានប្រព្រឹត្តចំពោះជនជាតិទុតស៊ីរបស់ខ្លួន៖ ភាពខុសគ្នានៅត្រង់ថា សង្គម«ជឿនលឿន»អាចសម្លាប់មនុស្ស ដោយសារធាតុគីមីឧស្សាហកម្មជឿនលឿន ជំនួសអោយចុងកាំបិត។

ទ្រឹស្តីចិត្តសាស្ត្រសង្គមចាត់ទុកការប្រល័យពូជសាសន៍នៅរ៉ាន់ដាថាជារោគសាស្ត្រ៖ ការឃ្លាតឆ្ងាយពីសនិទានភាពនិងបទដ្ឋានសង្គម។ ភាពលំអៀងក្នុងក្រុមដែលផ្អែកលើចរិកលក្ខណៈក្រុមតាមអំពើចិត្ត ត្រូវបាន

ពង្រីក ដោយការគំរាមកំហែង(ដែលពួកគេមើលឃើញ)ចេញពីក្រុមខាងក្រៅ ហើយត្រូវបានបំផ្លើសដោយប្រវត្តិសាស្ត្រ ទេវកថា និងការឃោសនា (រួមទាំងការសិក្សាអប់រំផងដែរ)។ អារម្មណ៍បែបនេះអាចត្រូវបានជំរុញបន្ថែមដោយអ្នកនយោបាយដែលចង់បានអំណាចផ្ទាល់ខ្លួន។ កម្តៅអាចឡើងខ្ពស់មួយកម្រិតទៀត នៅពេលដែលក្រុមខាងក្រៅត្រូវបានបន្ទាបបន្ថោកដូចសត្វធាតុ មិនមែនមនុស្ស។ បទដ្ឋាននៃអន្តរកម្មសង្គមដូចជាការមិនកាត់បំពង់ករបស់កុមារ អាចត្រូវបានព្រងើយកន្តើយ។

នៅពេលដែលអំពើប្រល័យពូជសាសន៍នៅប្រទេសរវ៉ាន់ដាត្រូវបានលាតត្រដាង សហគមន៍អន្តរជាតិបាននៅស្ងៀម។ កងកម្លាំងរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិដ៏ទន់ខ្សោយនៅទីនោះ ត្រូវដកចេញ ទោះបីជាមេបញ្ជាការរបស់ខ្លួន ក្រោយមក បានប៉ាន់ស្មានថា ជាមួយនឹងកងទ័ពចំនួន ៥,០០០ បន្ថែមទៀត គាត់អាចនឹងធ្វើអោយលទ្ធផលមានការផ្លាស់ប្តូរក៏ដោយ។ ការឆ្លើយតបដ៏ទន់ខ្សោយរបស់អន្តរជាតិចំពោះអំពើឃោរឃៅនេះ បង្ហាញពីភាពទន់ខ្សោយនៃបទដ្ឋានអន្តរជាតិនៃសិទ្ធិមនុស្ស បើប្រៀបធៀបទៅនឹងបទដ្ឋាននៃការមិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់រដ្ឋដទៃ, យ៉ាងហោចណាស់ នៅពេលដែលគ្មានផលប្រយោជន៍ជាយុទ្ធសាស្ត្រ។ ពួកជ្រុលនិយមហ៊ូទូបានបាត់បង់អំណាចភ្លាមៗ នៅពេលដែលពួកឧទ្ធាមទុតស៊ី បានកម្ចាត់រដ្ឋាភិបាល ដោយកម្លាំងយោធា ប៉ុន្តែ សង្គ្រាមបានរីករាលដាលចូលទៅក្នុងប្រទេសប្រជាធិបតេយ្យកុងហ្គោ ជាទីកន្លែងដែលពួកជ្រុលនិយមបានជ្រកកោន និងកន្លែងដែលការប្រយុទ្ធគ្នាបានបន្តកើតមានក្នុងរយៈពេលជាង ២០ ឆ្នាំក្រោយមក។ មន្ត្រីកំពូលរបស់សហរដ្ឋអាមេរិក រួមទាំងប្រធានាធិបតី គ្លីនតុន ក្រោយមក បានសុំទោសចំពោះការឆ្លើយតបមិនគ្រប់គ្រាន់របស់ពួកគេ ប៉ុន្តែ ការខូចខាតខ្ទេចខ្ទាំបានកើតឡើងហួស ទៅហើយ។ កាន់តែអាក្រក់ជាងនេះទៅទៀត ការសច្ចាប្រណិធានជាថ្មីថា «មិនអោយកើតឡើងម្តងទៀត» បានបង្ហាញថា ការចង់បានម្តងទៀត នៅក្នុងករណីបន្ទាប់ ដារហ្វួរ (Darfur)។

នៅក្នុងប្រទេសស៊ូដង់ ភាគីជម្លោះ (ភាគច្រើនជាជនមូស្លីមនៅភាគខាងជើង តទល់នឹង ពួកគ្រីស្ត៍នៅភាគខាងត្បូង)នៅក្នុងសង្គ្រាមស៊ីវិល អស់រយៈពេលជាច្រើនទសវត្សរ៍ បានចុះហត្ថលេខា លើកិច្ចព្រមព្រៀងសន្តិភាព នៅក្នុងឆ្នាំ ២០០៣ ដោយបញ្ចប់សង្គ្រាម ដែលបានសម្លាប់មនុស្សជាងមួយលាននាក់។ កិច្ចព្រមព្រៀងនេះបានអំពាវនាវអោយដកកងកម្លាំងរដ្ឋាភិបាលចេញពីភាគខាងត្បូងនៃប្រទេសនេះ ដោយបង្កើតរដ្ឋាភិបាលនិងកងទ័ពអន្តរកាលចែករំលែកអំណាចគ្នា និងរៀបចំការបោះឆ្នោតប្រជាមតិ នៅតំបន់ឧទ្ធាម ក្នុងប្រាំមួយឆ្នាំខាងមុខ។ ដំណើរការទាំងនេះនាំទៅរកឯករាជ្យភាពរបស់ស៊ូដង់ខាងត្បូង ដោយជោគជ័យក្នុងឆ្នាំ ២០១១។ ប៉ុន្តែ បន្ទាប់ពីកិច្ចព្រមព្រៀងសន្តិភាពនេះ ពួកឧទ្ធាមនៅតំបន់ដារហ្វួរភាគខាងលិចបានចាប់ផ្តើមតវ៉ាចំពោះការដាក់ខ្លួនពួកគេចេញពីកិច្ចព្រមព្រៀងសន្តិភាពខាងលើ។ ជាការឆ្លើយតប រដ្ឋាភិបាលបានជួយក្រុមជីវពលអារ៉ាប់(ជាមូស្លីម)វាយឆ្មក់ភូមិដារហ្វួររបស់អាហ្វ្រិកស្បែកខ្មៅ (ក៏ជាជនមូស្លីមដែរ) ដោយសម្លាប់រំលោភ និងដុត ដោយចេតនានិងគិតទុកជាមុន។ នៅចុងឆ្នាំ ២០០៤ រដ្ឋាភិបាលនិងក្រុមឧទ្ធាមដារហ្វួរ មួយចំនួនបានឈានដល់ការសម្រេចកិច្ចព្រមព្រៀងសន្តិភាពជាបណ្តោះអាសន្ន ហើយសហភាពអាហ្វ្រិក(AU)និងអង្គការសហប្រជាជាតិបានបញ្ជូនក្នុងបេសកកម្មរក្សាសន្តិភាពរួមគ្នា ក្នុងឆ្នាំ ២០០៧។ បន្ទាប់ពីការពន្យារពេលជាច្រើនឆ្នាំរបស់រដ្ឋាភិបាលស៊ូដង់ និងការខកចិត្តផ្សេងទៀត កងកម្លាំងរួមនោះមានបុគ្គលិកឯកសណ្ឋានចំនួន ២៣,០០០ នាក់ នៅលើដីផ្ទាល់ នៅឆ្នាំ ២០១១ ហើយភាគច្រើននៃកងកម្លាំងនោះនៅតែនៅទីនោះគិតត្រឹមឆ្នាំ ២០១៨។ ការឆ្លើយតបដោយគ្មានប្រសិទ្ធភាពរបស់សហគមន៍អន្តរជាតិចំពោះការសម្លាប់រង្គាល

នៅដាវហ្ស ដូចនៅវ៉ាន់ដា ក្នុងឆ្នាំ ១៩៩៤ បង្ហាញពីប្រសិទ្ធិភាពនៅមានកម្រិតនៃបទដ្ឋានអន្តរជាតិនៅក្នុងប្រព័ន្ធអន្តរជាតិដែលផ្អែកលើរដ្ឋ នាពេលបច្ចុប្បន្ននេះ។

ក្នុងករណីទាំងអំពើប្រល័យពូជសាសន៍ និងទាំងការទម្លាក់កំហុងលើជនជាតិណាមួយ ការស្អប់ខ្ពើមជាតិសាសន៍មិនគ្រាន់តែផ្ទុះឡើង ដោយធម្មជាតិនោះទេ។ ផ្ទុយទៅវិញ អ្នកនយោបាយញុះញង់ និងបង្កើតការស្អប់ខ្ពើមដើម្បីពង្រឹងអំណាចរបស់ខ្លួន។ ជាញឹកញយ នៅក្នុងប្រទេសដែលបែងចែកជាតិសាសន៍ គណបក្សនយោបាយបង្កើតឡើង តាមបន្ទាត់ជាតិសាសន៍ហើយមេដឹកនាំគណបក្សពង្រឹងមុខតំណែងនិងតួនាទីរបស់ពួកគេ តាមរយៈការកៀងគរការគាំទ្រពីក្នុងចំនួនប្រជាជនរបស់ពួកគេ ដោយនិយាយបំផ្លើសអំពីគ្រោះថ្នាក់មកពីភាគីម្ខាងទៀត។

សង្គ្រាមត្រជាក់ ជាមួយនឹងប្រព័ន្ធសម្ព័ន្ធភាពដ៏តឹងតែង និងរដ្ឋាភិបាលកុម្មុយនិស្តផ្តាច់ការ ហាក់ដូចជាបានជួយទប់ជម្លោះជាតិសាសន៍។ នៅក្នុងសហភាពសូវៀត និងប្រទេសយូហ្គោស្លាវី ដែលជារដ្ឋពហុជាតិសាសន៍ អត្ថិភាពនៃរដ្ឋដ៏រឹងមាំតែមួយ (មានឆន្ទៈក្នុងការគៀបសង្កត់សហគមន៍ក្នុងស្រុក) បានរក្សាភាពតានតឹងជាតិសាសន៍មិនអោយឡើងកម្តៅ និងពង្រឹងសន្តិភាពរវាងសហគមន៍ជិតខាង (ដោយបង្ខំ)។ ការបែកបាក់នៃរដ្ឋទាំងនេះបានបណ្តាលអោយផ្ទុះឡើងនូវជម្លោះជាតិសាសន៍និងជម្លោះតំបន់ ជាថ្មីម្តងទៀត ដែលជួនកាលនាំមកនូវអំពើហិង្សានិងសង្គ្រាម។ ករណីទាំងអស់នេះអាចបង្ហាញពីស្ថានភាពទ្វេគ្រោះ ដែលសេរីភាពកើតឡើងទន្ទឹមនឹងការបាត់បង់សណ្តាប់ធ្នាប់ ហើយផ្ទុយទៅវិញ សណ្តាប់ធ្នាប់កើតឡើងទន្ទឹមនឹងការបាត់បង់សេរីភាព។ ប្រាកដណាស់ មិនមែនគ្រប់ក្រុមជាតិសាសន៍ទាំងអស់មិនចុះសម្រុងនឹងគ្នានោះទេ។ បន្ទាប់ពីការដួលរលំនៃលទ្ធិកុម្មុយនិស្ត ភាគច្រើននៃគូប្រជែងជាតិសាសន៍ជាច្រើននៅក្នុងអតីតសហភាពសូវៀតមិនបានបង្កអោយមានសង្គ្រាមនឹងគ្នានោះទេ ហើយនៅក្នុងប្រទេសឆេកូស្លូវ៉ាគី និងកន្លែងផ្សេងទៀតទំនាក់ទំនងជាតិសាសន៍មានលក្ខណៈសន្តិភាពបន្តិចវិញ បន្ទាប់ពីការដួលរលំនៃកុម្មុយនិស្ត។

៥.២.៤. ជម្លោះសាសនា

ហេតុផលមួយដែលជម្លោះជាតិសាសន៍ច្រើនតែលើសពីភាពសោកសង្រេងផ្នែកសម្ភារៈគឺថាពួកគេមើលឃើញថាជាជម្លោះ*សាសនា*។ ដោយសារតែសាសនាគឺជាស្នូលនៃប្រព័ន្ធគុណតម្លៃរបស់សហគមន៍ភាគច្រើន នៅក្នុងពិភពលោក មនុស្សដែលមានការគោរពប្រតិបត្តិសាសនាខុសគ្នា ងាយនឹងមើលងាយអ្នកកាន់សាសនាដទៃ និងចាត់ទុកអ្នកទាំងនោះថាមិនសក្តិសម ឬ រហូតអ្នកខ្លះថាជាអមនុស្ស។ នៅពេលដែលត្រួតជាន់គ្នាលើជម្លោះជាតិសាសន៍និងទឹកដី សាសនាច្រើនតែលេចចេញនៅចំចំណុចកណ្តាលនៃជម្លោះ និងអាចត្រូវបានមើលឃើញការខ្ណែចែកយ៉ាងច្បាស់បំផុតរវាងក្រុមសង្ខាង។ ជាឧទាហរណ៍ ប្រជាជនភាគច្រើន នៅប្រទេសអាស៊ែបៃហ្សង់ (Azerbaijan) គឺជាអ្នកកាន់សាសនាអ៊ីស្លាម ចំណែក ជនជាតិអាមេនីភាគច្រើនគឺជាគ្រិស្តសាសនិកជន។ នេះជាគំរូទិដ្ឋភាពទូទៅនៅក្នុងជម្លោះជនជាតិភាគតិច។

រូបថត *សង្គ្រាមស៊ីវិលនៅយេម៉ែន*

ភាពខុសគ្នាខាងសាសនា

ការមិនអត់ឱនខាងសាសនាអាចធ្វើអោយភាពតានតឹងរវាងក្រុមនានា កាន់តែខ្លាំងឡើងៗ ជួនកាលឈានដល់អំពើហិង្សាធ្ងន់ធ្ងរ ដោយជះផលប៉ះពាល់ជាអន្តរជាតិ។ ជម្លោះសាសនាដ៏ស្រួចស្រាលបំផុត នាពេលបច្ចុប្បន្ននេះ កើតឡើងរវាងអ៊ីស្លាមនិកាយស៊ុីអ៊ីតនិងនិកាយស៊ុននី ដែលមានមូលដ្ឋានជាចំបង នៅក្នុង

ប្រទេសអ៊ីរ៉ង់និងអាភ៉ាបីសាអូឌីត រៀងគ្នា។ ការបែងចែកគ្នា ដែលកើតចេញជាអំពើហិង្សាដ៏បំផ្លិចបំផ្លាញនៅក្នុងប្រទេសអ៊ីរ៉ាក់ក្រោយឆ្នាំ ២០០៧ បានជួយបញ្ឆេះសង្គ្រាមស៊ីវិលនៅប្រទេសស៊ីរី និងថ្មីៗនេះ សង្គ្រាមស៊ីវិលនៅយេម៉ែន (នៅទីនេះ ២០១៨)។


គ្មានអ្វីដែលច្បាស់លាស់នៅក្នុងសាសនាកំណត់អោយមានជម្លោះ—នៅទីកន្លែងជាច្រើន សមាជិកនៃក្រុមសាសនាផ្សេងគ្នារួមរស់ជាមួយគ្នាដោយសន្តិវិធី។ ប៉ុន្តែ ភាពខុសប្លែកគ្នាខាងសាសនាមានសក្តានុពលបង្កអោយផ្ទុះជម្លោះដែលកំពុងតែមានស្រាប់ កាន់តែរាលដាលខ្លាំងមិនអាចគ្រប់គ្រងបាន ដោយសារសាសនាពាក់ព័ន្ធនឹងគុណតម្លៃស្នូល ដែលត្រូវបានចាត់ទុកជាសច្ចៈភាពជាច់ខាត។

ករណីនេះកាន់តែត្រូវខ្លាំង នៅពេលដែលចលនា*សាសនាជ្រុលនិយម*(fundamentalist) បានកើនឡើងច្រើន នៅក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ថ្មីៗនេះ។ (ហេតុផលសម្រាប់*សាសនាជ្រុលនិយម* នៅមានការជជែកវែកញែកគ្នានៅឡើយ ប៉ុន្តែ ច្បាស់ណាស់ វាជាបាតុភូតកើតឡើងនៅទូទាំងសកលលោក។ សមាជិកនៃចលនាទាំងនេះរៀបចំជីវភាពរស់នៅនិងសហគមន៍របស់ពួកគេជុំវិញជំនឿសាសនារបស់ខ្លួន, ហើយក្នុងនោះសមាជិកជាច្រើនសុខចិត្តបូជាខ្លួន សម្លាប់ និងស្លាប់ ដើម្បីបុព្វហេតុជំនឿទាំងនោះ។ ចលនាសាសនាជ្រុលនិយមបានរីកធំធាត់កាន់តែធំ និងមានឥទ្ធិពលកាន់តែខ្លាំង ក្នុងប៉ុន្មានទសវត្សរ៍ថ្មីៗនេះ ទាំងក្នុងចំណោមសាសនាគ្រឹស្ត សាសនាឥស្លាម យូដានិយម សាសនាហិណ្ឌូ និងសាសនាដទៃទៀត។ ជាឧទាហរណ៍ នៅក្នុងប្រទេសឥណ្ឌា ពួកអ្នកសាសនាហិណ្ឌូជ្រុលនិយម បានបង្កអោយមានការប៉ះទង្គិចគ្នាយ៉ាងហិង្សា និងការសម្លាប់រង្គាលដែលបានផ្ទុះឡើងជាអន្តរជាតិ។ ក្នុងឆ្នាំ ២០០២ កំហឹងនៃការដុតបំផ្លាញ ការធ្វើទារុណកម្ម និងការរំលោភសេពសន្ថវៈ ដោយពួកហិណ្ឌូជាតិនិយមជ្រុល បានសម្លាប់អ្នកកាន់សាសនាឥស្លាម ជិតមួយពាន់នាក់ នៅក្នុងរដ្ឋគុជរាត (Gujarat) ក្នុងប្រទេសឥណ្ឌា ជាកន្លែងដែលគណបក្សជាតិនិយមហិណ្ឌូគ្រប់គ្រងរដ្ឋាភិបាលនៅក្នុងរដ្ឋនោះ។ នៅប្រទេសអ៊ីស្រាអែល ជនជាតិជ្វីហ្វនិយមសាសនាជ្រុល បានប្រើប្រាស់អំពើហិង្សា រួមទាំងការធ្វើឃាតនាយករដ្ឋមន្ត្រីផ្ទាល់របស់អ៊ីស្រាអែល ក្នុងឆ្នាំ១៩៩៥ ដើម្បីបង្អាក់ការចរចាសន្តិភាពរវាងប៉ាឡេស្ទីន និងអ៊ីស្រាអែល។

ចលនា*សាសនាជ្រុលនិយម*ប្រកួតប្រជែងនឹងគុណតម្លៃនិងការប្រតិបត្តិរបស់អង្គការនយោបាយផ្នែកអាណាចក្រ ដែលត្រូវបានបង្កើតឡើង នៅក្រៅរង្វង់ស្ថាប័នសាសនា។ ការប្រតិបត្តិក្នុងផ្លូវអាណាចក្រដែលត្រូវបានគំរាមកំហែងដោយចលនាសាសនាជ្រុលនិយម រួមមានកម្រងច្បាប់នៃប្រព័ន្ធអន្តរជាតិដែលចាត់ទុករដ្ឋថាជារដ្ឋសមភាពនិងអធិបតេយ្យភាពជាផ្លូវការ ទោះបីជាពួកគេ «ជឿ» ឬ «មិនជឿ» ក៏ដោយ។ ក្នុងហានៈជាប្រព័ន្ធជំនឿឆ្លងជាតិ (ពីប្រទេសមួយទៅប្រទេសមួយទៀត) សាសនាតែងតែត្រូវបានចាត់ទុកជាច្បាប់ខ្ពស់ជាងច្បាប់រដ្ឋនិងសន្ធិសញ្ញាអន្តរជាតិ។ ជនអ៊ីស្លាមជ្រុលនិយមអ៊ីរ៉ង់ធ្វើការហ្វឹកហាត់និងគាំទ្រកងជីវពលក្នុងរដ្ឋផ្សេងៗទៀត ដូចជាប្រទេសអ៊ីរ៉ាក់និងលីបង់។ អ្នកសាសនាយូដាជ្រុលនិយមកសាងការតាំងទីលំនៅក្នុងទឹកដីដែលកាន់កាប់ដោយអ៊ីស្រាអែល ហើយសច្ចាថានឹងកាន់កាប់ទឹកដីនៅទីនោះអោយបានជាប់ជានិច្ច បើទោះជារដ្ឋាភិបាលរបស់ពួកគេជម្លៀសពួកគេចេញក៏ដោយ។ អ្នកកាន់គ្រិស្តសាសនាជ្រុលនិយមនៅសហរដ្ឋអាមេរិកបានបញ្ចុះបញ្ចូលរដ្ឋាភិបាលរបស់ពួកគេ អោយដកខ្លួនចេញពី មូលនិធិប្រជាជនអង្គការសហប្រជាជាតិ (UNFPA) ដោយសារតែទស្សនៈរបស់អង្គការនោះលើផែនការគ្រួសារ និងការរំលូតកូន។ សកម្មភាពនីមួយៗនេះដើរផ្ទុយនឹងបទដ្ឋាននៃប្រព័ន្ធអន្តរជាតិ និងការសន្មត់នៃទ្រឹស្តីប្រាកដនិយម។

ក្រាហ្វិក ៥.៣ សមាជិកនៃសន្និសីទអ៊ីស្លាម និងតំបន់ជម្លោះ

ប្រទេសពណ៌បៃតងស្រាលជាសមាជិកនៃសន្និសីទ; លេខរៀងនីមួយៗតំណាងតំបន់នៃជម្លោះរវាងជនមូស្លីមនិងជនមិនមែនមូស្លីម ឬអាជ្ញាធរខាងលោកិយ។



១. អឺរ៉ុប	១០. តាជីគីស្ថាន	១៩. សុម៉ាលី
២. បូស្នៀ-ហឺសហ្គូវីណា	១១. ចិនខាងលិច	២០. អ៊ីស្រាអែល/ប៉ាឡេស្ទីន
៣. សែប៊ី/កូសូវ៉ូ	១២. ហ្វីលីពីន	២១. អេហ្ស៊ីប
៤. ទួរគី	១៣. ឥណ្ឌូនេស៊ី	២២. អាហ្សេរី/ទុយនេស៊ី
៥. ស៊ីព្រុស	១៤. ភូមា/បង់ហ្គាដែស	២៣. ស៊ូដង់
៦. ហ្សកហ្ស៊ី	១៥. ឥណ្ឌា	២៤. សាធារណរដ្ឋអាហ្វ្រិកកណ្តាល
៧. រុស្ស៊ីតួង/ឆេចនៀ	១៦. ប៉ាគីស្ថាន	២៥. នីហ្សេរីយ៉ា/ម៉ាលី
៨. អាល់មេនី/អាហ្ស៊ីបៃចាន	១៧. លីបង់	
៩. អាហ្វហ្គានីស្ថាន	១៨. ស៊ីរី	

អ្នកខ្លះបានផ្តល់យោបល់ថា ជម្លោះអន្តរជាតិនៅក្នុងប៉ុន្មានឆ្នាំខាងមុខអាចបណ្តាលមកពី «ការប៉ះទង្គិចនៃអរិយធម៌នានា (clash of civilizations)» ដោយផ្អែកលើភាពខុសគ្នា ក្នុងចំណោមក្រុមវប្បធម៌សំខាន់ៗរបស់ពិភពលោក ដែលត្រួតលើគ្នាបន្តិចជាមួយសហគមន៍សាសនា។ គំនិតនេះត្រូវបានគេរិះគន់ថាមានលក្ខណៈទូទៅហួសហេតុពេក និងដោយសារការសន្មតថា ភាពខុសគ្នាខាងវប្បធម៌បង្កើតជម្លោះ ដោយ

ធម្មជាតិ។ ជាការពិត ទោះបីជាជម្លោះសាសនានិងជាតិសាសន៍ទទួលបានការចាប់អារម្មណ៍យ៉ាងខ្លាំង នៅក្នុងប្រព័ន្ធផ្សព្វផ្សាយក៏ដោយ ក្រុមជាតិសាសន៍ និងសាសនា*ភាគច្រើន*ដែលរស់នៅជាមួយគ្នាក្នុងរដ្ឋមិនឈ្លោះគ្នានោះទេ។

ចលនាអ៊ីស្លាម

នាពេលបច្ចុប្បន្ន ជម្លោះហិង្សានានាកំពុងត្រូវបានប្រព្រឹត្តិឡើងក្នុងនាមសាសនាធំៗទាំងអស់ នៅលើពិភពលោក។ ប៉ុន្តែ មានការយកចិត្តទុកដាក់ជាពិសេស ដោយសារជម្លោះពាក់ព័ន្ធនឹងក្រុមអ៊ីស្លាមនិងរដ្ឋ។ តួអង្គអ៊ីស្លាម គឺជាអ្នកចូលរួមយ៉ាងសកម្ម នៅក្នុងសង្គ្រាម ចំនួន ១២ ក្នុងចំណោមសង្គ្រាម ១៤ ដែលកំពុងកើតឡើងនៅលើពិភពលោក។ លើសពីនេះ «សង្គ្រាមប្រឆាំងភេរវកម្ម»របស់សហរដ្ឋអាមេរិក បង្វែរគោលដៅប្រឆាំងនឹងបណ្តាញក្រុមភេរវកម្មអ៊ីស្លាម។ ទោះជាយ៉ាងណា ចលនាអ៊ីស្លាមនិយមភាគច្រើនមិនមានអំពើហិង្សាទេ។

ឥស្លាម គឺជាសាសនាដែលគោរពប្រតិបត្តិដោយ**ជនមូស្លីម** មានលក្ខណៈទូលំទូលាយ និងមាននិកាយផ្សេងៗគ្នាជាច្រើន។ អ្នកគោរពប្រតិបត្តិសាសនានេះរួមមាន មូស្លីមនិកាយស៊ុននី(Sunni) (ភាគច្រើន) មូស្លីមស៊ីអ៊ីត (Shi'ite) (ផ្តុំគ្នាច្រើននៅប្រទេសអ៊ីរ៉ង់ ភាគខាងត្បូងនៃប្រទេសអ៊ីរ៉ាក់ ភាគខាងត្បូងនៃប្រទេសលីបង់ និងប្រទេសបារ៉ែន) និង សាខានិងនិកាយតូចៗជាច្រើនទៀត។ ប្រទេសភាគច្រើន ដែលមានប្រជាជនជាជនមូស្លីមជាចម្បង ស្ថិតក្នុងសន្និសីទអ៊ីស្លាម (Islamic Conference) ដែលជាអង្គការអន្តរដ្ឋាភិបាល)។ ប្រទេសដែលកាន់សាសនាឥស្លាមច្រើនជាងគេលើពិភពលោក លាតសន្ធឹងពីប្រទេសនីហ្សេរីយ៉ា រហូតដល់ប្រទេសឥណ្ឌូនេស៊ី ដែលមានមជ្ឈមណ្ឌលជាប្រវត្តិសាស្ត្រ នៅតំបន់មជ្ឈិមបូព៌ា (សូមមើលក្រាហ្វិក ៥.៣) ប៉ុន្តែ មានប្រជាជនជាជនមូស្លីមច្រើនជាងគេ នៅអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍។ ជម្លោះអន្តរជាតិជាច្រើនជុំវិញតំបន់នេះពាក់ព័ន្ធនឹងសាសនា ម្ខាងជាអ្នកកាន់សាសនាឥស្លាម និងម្ខាងទៀតមិនមែនជាក្រុមមូស្លីម ដែលជាលទ្ធផលនៃស្ថានភាពភូមិសាស្ត្រ និងប្រវត្តិសាស្ត្រ រួមទាំងអាណានិគមនិយម និងធនធានប្រេង។

ក្រុមអ៊ីស្លាមអំពាវនាវអោយវាយប្រហារលើរដ្ឋាភិបាល និងកសាងសង្គមដោយផ្អែកលើច្បាប់អ៊ីស្លាម។ ក្រុមទាំងនេះប្រើប្រាស់មធ្យោបាយផ្សេងៗគ្នា ដើម្បីសម្រេចគោលដៅទាំងនេះ។ មធ្យោបាយភាគច្រើនមានលក្ខណៈអហិង្សា ដូចជា អង្គការសប្បុរសធម៌ និងគណបក្សនយោបាយជាដើម។ វិធីផ្សេងទៀតមានទំរង់ជាអំពើហិង្សា ដូចជា កងជីវពលនិងបណ្តាញភេរវករ។ ក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ ភាគីអ៊ីស្លាមបានកាន់កាប់ទឹកដីនៅក្នុងប្រទេសទួរគីដែលជារដ្ឋខាងលោកីយ៍ (secular state) ដែលយោធាបានធ្វើអន្តរាគមន៍ ម្តងហើយម្តងទៀត ដើម្បីទប់ស្កាត់នយោបាយសាសនានិយម ហើយអតីតមេដឹកនាំអ៊ីស្លាមនិយមបានធ្វើជានាយករដ្ឋមន្ត្រី ចាប់តាំងពីឆ្នាំ ២០០៣ ដែលធ្វើអោយទួរគីក្លាយជាគំរូដ៏សំខាន់នៃសាសនាឥស្លាមនិយមកណ្តាល នៅក្នុងតំបន់។ គណបក្សឥស្លាមក៏បានដើរតួនាទីនាំមុខគេ នៅក្នុងរដ្ឋាភិបាលអ៊ីរ៉ាក់ ចាប់តាំងពីឆ្នាំ ២០០៣ ហើយបានដើរតួនាទីសំខាន់ នៅក្នុងបណ្តាប្រទេស ដែលផ្ទុះបដិវត្តន៍រដូវផ្តៅរីកអារ៉ាប់ (Arab Spring) ដោយដំបូងឡើយ បានឈ្នះការបោះឆ្នោតនៅប្រទេសទុយនីស៊ី និងប្រទេសអេហ្ស៊ីប។ ក្រុមប្រដាប់អាវុធអ៊ីស្លាមនិយមបានក្លាយជាតួអង្គសំខាន់ ក្នុងសង្គ្រាមស៊ីវិលស៊ីរី ក្នុងឆ្នាំ ២០១៣។ នៅឆ្នាំ ២០១៤ ក្រុមមួយ ឈ្មោះក្រុមរដ្ឋអ៊ីស្លាមនៅអ៊ីរ៉ាក់និងស៊ីរី (ISIS) បានក្លាយជាក្រុមខ្លាំងបំផុត ក្នុងចំណោមក្រុមទាំងនេះ ហើយបានដណ្តើមយកទឹកដីសំខាន់ៗ នៅក្នុងប្រទេសស៊ីរី និងអ៊ីរ៉ាក់ដែលនៅជិតខាង។ ការពង្រីកដែនដីឈរជើង បាន

យ៉ាងធាប់រហ័សរបស់ពួកគេនៅក្នុងប្រទេសទាំងពីរ បានបង្កអោយមានសកម្មភាពយោធាប្រឆាំងនឹងពួកគេ ដោយរដ្ឋមួយចំនួននៃអង្គការសន្ធិសញ្ញាអាត្លង់ទិកខាងជើង (NATO) រុស្ស៊ី និងមហាអំណាចក្នុងតំបន់។

ប្រសិនបើចលនាអ៊ីស្លាមស្វែងរកការផ្លាស់ប្តូរជាចម្បងនៅក្នុងគោលនយោបាយក្នុងស្រុក តើហេតុអ្វីបានជាពួកគេមានសារៈសំខាន់សម្រាប់ទំនាក់ទំនងអន្តរជាតិ? នយោបាយអ៊ីស្លាមនិយមអាចនាំអោយមានគោលនយោបាយការបរទេសផ្សេងៗគ្នា ប៉ុន្តែ ចម្លើយសំខាន់ជាងនេះទៅទៀតនោះគឺថា ចលនាអ៊ីស្លាមនិយមមួយចំនួនបានក្លាយទៅជាកម្លាំងឆ្លងដែន ដែលបង្កើតសណ្តាប់ធ្នាប់ពិភពលោក និងទំនាក់ទំនងអន្តរគោលខាងជើងនិងខាងត្បូង តាមវិធីសំខាន់ៗ។

នៅក្នុងប្រទេសមួយចំនួន អ្នកកាន់សាសនាអ៊ីស្លាមបដិសេធរដ្ឋលោកីយ៍តាមបែបបស្ចឹមលោក ដើម្បីគាំទ្ររដ្ឋាភិបាលនានាដែលផ្តោតលើគុណតម្លៃអ៊ីស្លាមសាសនាយ៉ាងប្រត្យក្ស។ ចលនាទាំងនេះឆ្លុះបញ្ចាំងពីមនោសញ្ចេតនា*ប្រឆាំងនឹងបស្ចឹមលោក* ដែលមានតាំងពីយូរយារណាស់មកហើយ នៅក្នុងប្រទេសទាំងនេះ (ប្រឆាំងនឹងអាណានិគមអឺរ៉ុបចាស់ ដែលជាគ្រិស្តសាសនា) និងក្នុងទំរង់ខ្លះ ជាចលនា*ជាតិនិយម*ដែលបានលេចចេញជារូបរាង តាមរយៈបណ្តាញសាសនា។ នៅក្នុងប្រទេសមជ្ឈិមបូព៌ាមួយចំនួន ដែលមានរដ្ឋាភិបាលផ្តាច់ការ ស្ថាប័នសាសនា(វិហារអ៊ីស្លាម) គឺជាវេទិកាតែមួយគត់សម្រាប់ក្រុមប្រឆាំងនយោបាយ។ ដូច្នេះសាសនាបានក្លាយជាមធ្យោបាយមួយ ដើម្បីបង្ហាញការប្រឆាំងនឹងស្ថានភាពនៅនឹងថ្កល់ នៅក្នុងនយោបាយនិងវប្បធម៌។ អារម្មណ៍ប្រឆាំងនឹងលោកខាងលិចទាំងនេះ នៅក្នុងបណ្តាប្រទេសឥស្លាម បានផ្ទុះឡើងក្នុងឆ្នាំ ២០០៦ បន្ទាប់ពីកាសែតដាណឺម៉ាកមួយបានបោះពុម្ពរូបថ្លុកប្រមាថ ដែលពណ៌នាអំពីព្យាការី មហាម៉ាត់។ នៅទូទាំងពិភពលោក ប្រជាជនមូស្លីមបានចេញតវ៉ា ដុតស្ថានទូតដាណឺម៉ាកមួយចំនួន កុប្បកម្ម (មានអ្នកស្លាប់រាប់សិបនាក់ ជាលទ្ធផល) និងធ្វើពហិការមិនទិញទំនិញដាណឺម៉ាក។ ក្នុងឆ្នាំ ២០១៥ ពួកសកម្មប្រយុទ្ធអ៊ីស្លាមបានវាយប្រហារការិសែតបែបកំប្លែង *ឆាលី ហេបដូ* (Charlie Hebdo) ដែលមានមូលដ្ឋាននៅទីក្រុងប៉ារីស និងដែលបានបោះពុម្ពរូបថ្លុកស្រដៀងគ្នា។

មតិសាធារណៈ ទាំងនៅក្នុងប្រទេសមូស្លីមនិងមិនមែនមូស្លីម បង្ហាញពីការយល់ខុស និងភាពខុសគ្នាមួយចំនួន នៅក្នុងគំនិតរបស់ពួកគេ (សូមមើលក្រាហ្វិក ៥.៤)។ ការគាំទ្រចំពោះក្រុមរ៉ាឌីកាល់អ៊ីស្លាមនិយមប្រែប្រួលយ៉ាងខ្លាំង ក្នុងចំណោមប្រទេសនានា។ ការស្ទង់មតិឆ្នាំ ២០០៥ រំលឹកឡើងវិញនូវការយល់ឃើញ «រូបភាពកញ្ចក់» (សូមមើលមេរៀនទី ៤)។ នៅក្នុងប្រទេសដែលប្រជាជនភាគច្រើនមិនមែនជាជនមូស្លីមនៅលោកខាងលិច ប្រជាជន ៥៨ ភាគរយ គិតថាជាជនមូស្លីមគឺជា«អ្នកនិយមជ្រុល» ហើយប្រហែល ២០ ភាគរយ គិតថាពួកគេគោរពស្ត្រី។ ប៉ុន្តែ នៅក្នុងការស្ទាបស្ទង់មតិមួយនៅក្នុងប្រទេសដែលប្រជាជនភាគច្រើនជាជនមូស្លីមចំនួន៧ ប្រជាជនច្រើន ៥៣ ភាគរយ បានគិតថា អ្នកមិនមែនជាមូស្លីមគឺជា«អ្នកនិយមជ្រុល» ហើយ ៤២ ភាគរយ មានអារម្មណ៍ថា អ្នកមិនមែនជាជនមូស្លីមគោរពស្ត្រី។


ចលនាអ៊ីស្លាមជ្រុលនិយមកាន់តែច្រើន មិនត្រឹមតែគំរាមកំហែងដល់រដ្ឋាភិបាលដែលមានស្រាប់ (ជាពិសេសរដ្ឋាភិបាលដែលមានទំនាក់ទំនងជាមួយលោកខាងលិច)មួយចំនួននោះទេ ប៉ុន្តែ ថែមទាំងធ្វើអោយខូចដល់បទដ្ឋានប្រពៃណីនៃអធិបតេយ្យភាពរបស់រដ្ឋផងដែរ។ ពួកគេបដិសេធទស្សនៈនយោបាយលោកខាងលិចអំពីរដ្ឋ(ផ្អែកលើស្វ័យភាពរៀងៗខ្លួន) ដើម្បីគាំទ្រដល់ការតំរង់ទិសទៅរកឥស្លាមជាប្រពៃណី ដោយផ្អែកលើសហគមន៍។ ចលនាខ្លះប្រាថ្នាចង់បង្កើតរដ្ឋនយោបាយតែមួយ ដែលគ្របដណ្តប់ទឹកដីភាគច្រើននៃតំបន់

មជ្ឈិមបូព៌ា ដូចដែលមាននៅក្នុងអាណាចក្រអ៊ីស្លាម កាលីហ្វេត (caliphate) កាលពីកំឡុងឆ្នាំ ៦០០ រហូត ១២០០ នៃគ.ស.។ ការអភិវឌ្ឍន៍បែបនេះអាចនឹងបង្កអោយមានការប្រឈមយ៉ាងជ្រាលជ្រៅ ចំពោះប្រព័ន្ធ អន្តរជាតិបច្ចុប្បន្ន ជាពិសេសតតាំងនឹងស្ថានភាពអំណាចរបស់ខ្លួន នាពេលបច្ចុប្បន្ន ដូច្នេះហើយ រដ្ឋដែល មានអំណាចបំផុតនៅលើពិភពលោកនឹងប្រឆាំងចលនាបែបនេះ គ្រប់ពេលវេលា។


ក្រាហ្វិក ៥.៤ មតិសាធារណៈនៅក្នុងប្រទេសមូស្លីម និងមិនមែនមូស្លីម

ប្រភព៖ ផ្អែកលើការស្ទង់មតិ Pew Global Attitudes, ២០០៥, ២០១០ និង ២០១៤។

តើការបំផ្ទុះគ្រាប់បែកអត្តឃាត ឬអំពើហិង្សាលើជនស៊ីវិលញឹកញាប់ប៉ុណ្ណា ដើម្បីការពារសាសនា អ៊ីស្លាម?



សមហេតុផល



(សម្គាល់៖ បង្គោលគូរនីមួយៗ បង្គោលខាងលើតំណាងមតិគិតថា **ជ្រុលនិយម**, ខាងក្រោម**គោរពសិទ្ធិស្ត្រី**)

អ្នកកាន់សាសនាឥស្លាមនិយម (Islamists) នៅក្នុងបណ្តាប្រទេសមជ្ឈិមបូព៌ា ក៏ដូចជាជនបដិវត្តន៍ នៅទីកន្លែងផ្សេងទៀតទទួលបានមូលដ្ឋានគាំទ្រជាកម្លាំងដ៏សំខាន់ ដោយខិតខំលើកតម្កើងបុព្វហេតុមហាជន ក្រីក្រប្រឆាំងនឹងពួកអភិជនស្តុកស្តម្ភ។ ដូចជនបដិវត្តន៍ដទៃទៀតនៅទូទាំងអឡឡាគោលខាងត្បូង ចលនា

អ៊ីស្លាមនិយមនៅក្នុងប្រទេសមួយចំនួន ដូចជា ទួរគី អេហ្ស៊ីប និងលីបង់ ទាក់ទាញមូលដ្ឋានគាំទ្រ ពីតំបន់អនាធិបតេយ្យក្រីក្រ ដែលជួនកាលពួកអ៊ីស្លាមផ្តល់សេវាជាមូលដ្ឋាន ដែលរដ្ឋាភិបាលមិនបានផ្តល់អោយ។

នៅក្នុងការស្ទាបស្ទង់មតិសាធារណៈ ក្នុងឆ្នាំ ២០១០ នៅក្នុងប្រទេសម៉ារ៉ុក និងអារ៉ាប៊ីសាអូឌីត ភាគច្រើននៃអ្នកចូលរួមឆ្លើយសំណួរ បានកំណត់អត្តសញ្ញាណជាចម្បងថាជាជនមូស្លីម ច្រើនជាងចំនួនអ្នកដែលកំណត់អត្តសញ្ញាណជាចម្បងថាជាពលរដ្ឋនៃរដ្ឋរបស់ពួកគេ ឬជាជនជាតិអារ៉ាប់។ ប៉ុន្តែ នៅប្រទេសហ្ស៊កដានី លីបង់ អេហ្ស៊ីប និងអារ៉ាប់រួម គំរូនេះត្រូវបានប្តូរទិសដៅ ដោយភាគច្រើនបានកំណត់អត្តសញ្ញាណជាចម្បងថាជាពលរដ្ឋនៃរដ្ឋរបស់ពួកគេ។ ចលនាអ៊ីស្លាមនិយមបញ្ជ្រាបខ្លួនចូលក្នុងការកំណត់អត្តសញ្ញាណរបស់សាធារណៈជន ជាមួយនឹងបញ្ហាដែលអាចនឹងមិនពាក់ព័ន្ធផ្នែកសម្ភារៈជាមួយពួកគេ ប៉ុន្តែ ប៉ះពាល់ដល់អត្តសញ្ញាណរបស់ពួកគេជាអ្នកកាន់សាសនាឥស្លាម ឆ្លងកាត់ព្រំដែនជាតិ ជាពិសេសក្នុងជម្លោះពិភពអារ៉ាប់-អ៊ីស្រាអែល។ សាធារណៈជនក្នុងប្រទេសមូស្លីមក៏បានខ្វល់ខ្វាយអំពីសង្គ្រាមក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ នៅក្នុងប្រទេសបូស្នៀ អាស៊ែបៃហ្សង់ និងឆេចនៀ ជាកន្លែងដែលកងកម្លាំងប្រដាប់អាវុធគ្រិស្តបរិស័ទវាយប្រហារជនស៊ីវិលម៉ូស្លីម។ ជនឥស្លាមនិយមមើលឃើញជម្លោះទាំងអស់នេះជាផ្នែកមួយនៃការតស៊ូក្នុងតំបន់ទូលំទូលាយ (ឬរហូតដល់កំរិតសកល) របស់សាសនាឥស្លាមប្រឆាំងនឹងចក្រពត្តិនិយមគ្រិស្តសាសនាបស្ចឹមលោកដែលជាការតស៊ូមានអាយុកាលតាំងពីបូជនីយកិច្ច(Crusades)ជិតមួយពាន់ឆ្នាំមុន។ តាមទស្សនៈរបស់អ្នកក្រៅមួយចំនួន ជម្លោះសាសនាដែលពុះកញ្ជ្រោលឡើងនៅតាមតែមនៃពិភពអ៊ីស្លាមមើលទៅហាក់ដូចជាការគំរាមកំហែងរបស់អ្នកពង្រីកទឹកដីនិយម ដែលចាំបាច់ត្រូវទប់ស្កាត់ ខណៈចេញពីទិដ្ឋភាពអ្នកខាងក្នុង មើលទៅហាក់ដូចជាត្រូវបានហ៊ុំព័ទ្ធនិងសង្កត់ពីគ្រប់ទិសទី (សូមមើលមតិសាធារណៈនិងទំនាក់ទំនងអន្តរជាតិ)។

សង្គ្រាមអ៊ីរ៉ាក់ ចាប់តាំងពីឆ្នាំ ២០០៣ បានបញ្ចេះអារម្មណ៍ប្រឆាំងនឹងសហរដ្ឋអាមេរិក និងបានជួយជម្រុញនយោបាយរ៉ាឌីកាល់ នៅទូទាំងពិភពមូស្លីម ជាពិសេស នៅក្នុងបណ្តាប្រទេសអារ៉ាប់ ដែលបានមើលឃើញការឈ្លានពានរបស់សហរដ្ឋអាមេរិកថាជា ការបន្ទាបបន្ថោកនិងបំពានដល់សេចក្តីថ្លៃថ្នូររបស់អារ៉ាប់។ ដំបូងឡើយ អណត្តិប្រធានាធិបតី បារ៉ាក់ ហ៊ូសេន អូបាម៉ា (ដែលនាមកណ្តាល « ហ៊ូសេន» ឆ្លុះបញ្ចាំងពីឫសគល់គ្រួសារមូស្លីម នៅប្រទេសកេនយ៉ា ហើយដែលបានធំដឹងក្តី មួយរយៈពេល នៅក្នុងប្រទេសឥស្លាមឥណ្ឌូណេស៊ី) បានចាប់ផ្តើមបង្វែរចរន្តប្រឆាំងនឹងអាមេរិកនេះ។ មតិវាយតម្លៃអនុគ្រោះចំពោះអាមេរិកបានកើនឡើង នៅក្នុងតំបន់ (បារ៉ែន ហ្ស៊កដានី និងអេហ្ស៊ីប) ម្យ៉ាងដោយសារសុន្ទរកថារបស់លោកប្រធានាធិបតីអូបាម៉ា ស្តីពីទំនាក់ទំនងរបស់អាមេរិកជាមួយរដ្ឋមូស្លីម នៅទីក្រុងគែរ ក្នុងខែមិថុនា ឆ្នាំ ២០០៩ ដែលលោកអូបាម៉ាបានអំពាវនាវអោយមាន«ការចាប់ផ្តើមថ្មី» ក្នុងទំនាក់ទំនងទាំងនោះ។ យ៉ាងណាក៏ដោយ មកដល់ឆ្នាំ ២០១០ ចំនួនជាច្រើននៃក្រាហ្វិកទាំងនោះបានចាប់ផ្តើមធ្លាក់ចុះម្តងទៀត នៅពេលដែលពិភពអារ៉ាប់ចាប់ផ្តើមសម្តែងការខកចិត្តនៅក្នុងដំណើរការសន្តិភាពមជ្ឈិមបូព៌ា និងការសម្រេចចិត្តរបស់សហរដ្ឋអាមេរិកក្នុងការបន្តជាក់ទ័ពនៅក្នុងប្រទេសអាហ្វហ្គានីស្ថាន។ នៅឆ្នាំ ២០១៨ មតិវាយតម្លៃអនុគ្រោះចំពោះអាមេរិកដែលមានកម្រិតទាបរួចទៅហើយ នៅក្នុងពិភពអារ៉ាប់ បានបន្តធ្លាក់ចុះកាន់តែទាប នៅពេលដែលរដ្ឋបាលប្រធានាធិបតីត្រាំបានប្រកាសផ្លាស់ប្តូរទីតាំងស្ថានទូតអាមេរិកនៅអ៊ីស្រាអែលពីទីក្រុង តែល អាវីវ ទៅទីក្រុងយេរូសាឡឹម ដែលជាជំហរនយោបាយត្រូវបានរិះគន់ដោយរដ្ឋអារ៉ាប់ទាំងអស់។

ក្រុមឥស្លាមជ្រុលនិយមប្រដាប់អាវុធ

មនោសញ្ចេតនាប្រឆាំងនឹងអាមេរិកនិងបស្ចឹមលោក នៅក្នុងប្រទេសឥស្លាមភាគច្រើនលើសលុបបានពន្លឿនកំណើននៃការកកើតក្រុមអ៊ីស្លាមជ្រុលនិយមផងដែរ។ ទោះជាពួកគេជាតួអង្គភាគតិចក៏ដោយ ពួកគេមានដៃផលប៉ះពាល់ មិនសមាមាត្រ លើទំនាក់ទំនងអន្តរជាតិ និងទទួលបានការចាប់អារម្មណ៍ជាសាធារណៈខ្លាំងក្លាបំផុត។

ក្រុមអ៊ីស្លាមប្រដាប់អាវុធ មានទ្រង់ទ្រាយខុសប្លែកគ្នាយ៉ាងខ្លាំង ហើយនៅក្នុងករណីខ្លះ ពួកគេបានទាស់ទែងខ្វែងគំនិតគ្នារហូតប្រើអំពើហិង្សាទៀតផង (សូមមើលតារាង ៥.១)។ ជាពិសេស ការបែងចែករវាងនិកាយស៊ុននីនិងនិកាយស៊ីអ៊ីត នៃសាសនាអ៊ីស្លាម បានឈានដល់អំពើហិង្សា។ ការបំបែកនេះបានលេចចេញជារូបរាងយ៉ាងលេចធ្លោ នៅក្នុងប្រទេសអ៊ីរ៉ាក់ ជាកន្លែងដែលសាដាម ហ៊ូសេន ជានិកាយស៊ុននីគ្រប់គ្រងលើប្រជាជនភាគច្រើនដែលជានិកាយស៊ីអ៊ីត (ការបង្ក្រាបលើការបះបោររបស់ពួកគេយ៉ាងព្រៃផ្សៃ បន្ទាប់ពីសង្គ្រាមឈូងសមុទ្រ ក្នុងឆ្នាំ ១៩៩១) និងមុននេះការប្រយុទ្ធគ្នាយ៉ាងធ្ងន់ធ្ងរលើសង្គ្រាមដ៏ប្រល័យប្រឆាំងនឹងប្រទេសអ៊ីរ៉ង់ដែលប្រកាន់និកាយស៊ីអ៊ីត។ បន្ទាប់ពីការផ្តួលរំលំសាដាមដែលដឹកនាំដោយសហរដ្ឋអាមេរិក ក្នុងឆ្នាំ ២០០៣ ភាគីនិកាយស៊ីអ៊ីតបានកាន់អំណាច ហើយកងជីវពលស៊ីអ៊ីតបានសងសឹក ខណៈដែលក្រុមនិកាយស៊ុននីខ្លះដែលបានធ្វើការបះបោរមិនឈប់ឈរ ហើយដែលប្រែទៅជារលកនៃអំពើហិង្សារវាងនិកាយនានាដ៏សាហាវឃោរឃៅ។ អំពើហិង្សានៅអ៊ីរ៉ាក់បានថយចុះ ចាប់តាំងពីពេលនោះមក ប៉ុន្តែទំនាក់ទំនងរវាងនិកាយស៊ុននីនិងស៊ីអ៊ីត នៅទីនោះ នៅតែមិនស្ងប់នៅឡើយ។

ចាប់តាំងពីឆ្នាំ ២០១១ ការបែងចែកនិកាយរវាងស៊ុននីនិងស៊ីអ៊ីតបានផ្តោតលើប្រទេសស៊ីរី ជាកន្លែងដែលគ្រួសារកាន់អំណាចគោរពប្រតិបត្តិអាឡាវី (Alawite) (លទ្ធិនេះជាមែកធាងចេញពីនិកាយស៊ីអ៊ីត) រីឯប្រជាជនភាគច្រើនគោរពប្រតិបត្តិនិកាយស៊ុននី។ សង្គ្រាមស៊ីវិលនៅទីនោះក៏បានកើតឡើងលើដោយសារការរំដើបរំជួលខាងផ្លូវអាណាចក្រ(លោកីយ៍)ផងដែរ ដែលត្រូវពង្រឹងដោយអ្នកគាំទ្រមកពីខាងក្រៅ៖ ក្នុងនោះភាគីម្ខាង ប្រទេសអ៊ីរ៉ង់ស៊ីអ៊ីតគាំទ្ររដ្ឋាភិបាល រួមជាមួយនឹងកងជីវពលហេបូឡាលីបង់ស៊ីអ៊ីត ចំណែកភាគីម្ខាងទៀត ប្រទេសទួរគីស៊ុននីនិងរដ្ឋឈូងសមុទ្រអារ៉ាប់គាំទ្រពួកឧទ្ទាម។

នៅឆ្នាំ ២០១៤ ក្រុមឧទ្ទាមអ៊ីស្លាមដែលបានផុសផុលឡើងនៅក្នុងប្រទេសស៊ីរីបានរួបរួមគ្នាជាមួយអ្នកកាន់និកាយស៊ុននីពីប្រទេសអ៊ីរ៉ាក់ដើម្បីបង្កើតរដ្ឋអ៊ីស្លាមនៅអ៊ីរ៉ាក់និងស៊ីរី ហៅកាត់ថាISIS (អាយស៊ីស)។ ក្រុមនេះបានទទួលការគាំទ្រយ៉ាងឆាប់រហ័ស និងទទួលបានជ័យជំនះផ្នែកយោធាយ៉ាងលឿន ជាពិសេសនៅក្នុងតំបន់ដែលមានប្រជាជននិកាយស៊ុននី ក្នុងប្រទេសអ៊ីរ៉ាក់។ ក្រុមនេះទទួលបានការចាប់អារម្មណ៍ជាសកលនៅពេលដែលពួកគេបានបញ្ចេញវីដេអូ ដែលបង្ហាញពីការកាត់ក្បាលចំណាប់ខ្មាំងរបស់ពួកគេ។ ការពង្រីកកងទ័ពនិងតំបន់គ្រប់គ្រងយ៉ាងឆាប់រហ័ស និងវីដេអូរបស់ពួកគេបាននាំអោយមានកិច្ចខិតខំប្រឹងប្រែងយោធាដ៏សំខាន់មួយដើម្បីបង្កើតការគ្រប់គ្រងរបស់រដ្ឋាភិបាលអ៊ីរ៉ាក់ឡើងវិញ និងកម្ចាត់ក្រុម ISIS។ តួអង្គទាំងឡាយដែលរួមមាន ទ័ពព្រៃឃីដ អ៊ីរ៉ង់ ហ្សឺកដានី និងសហរដ្ឋអាមេរិក បានធ្វើប្រតិបត្តិការដើម្បីកំទេចក្រុម ISIS។ នៅឆ្នាំ ២០១៥ ក្រុមអ៊ីស្លាម នៅប្រទេសលីប៊ី យេម៉ែន និងអេហ្ស៊ីបបានធ្វើការវាយប្រហារភេរវកម្មរៀងៗខ្លួនដោយអះអាងថាខ្លួនមានទំនាក់ទំនងជាមួយក្រុម ISIS។ ក្នុងឆ្នាំ ២០១៧ ទាំងរដ្ឋាភិបាលអ៊ីរ៉ាក់ និងទាំងប្រធានាធិបតីរុស្ស៊ី លោក វ្ល៉ាឌីមៀ ពូទីន បានប្រកាសជ័យជម្នះលើក្រុម ISIS នៅអ៊ីរ៉ាក់ និងស៊ីរី រៀងៗខ្លួន។

ហើយខណៈពេលដែលទំហំទឹកដីដែលគ្រប់គ្រងដោយក្រុម ISIS នៅក្នុងប្រទេសទាំងនោះ បានធ្លាក់ចុះ យ៉ាងខ្លាំងក៏ដោយ ក្រុម ISIS នៅតែព្យាយាមរៀបចំប្រតិបត្តិការវាយប្រហារភេរវកម្ម នៅតំបន់មជ្ឈិមបូព៌ា និងអឺរ៉ុបខាងលិច។

ក្នុងកម្រិតតំបន់ ប្រទេសអ៊ីរ៉ង់ និងប្រទេសអារ៉ាប៊ីសាអូឌីតតំណាងអោយការបែងចែកខាងលើ ដោយប្រឈមមុខដាក់គ្នាលើឈូងសមុទ្រពែរ្ស (ក៏ត្រូវបានគេស្គាល់ថាជាឈូងសមុទ្រអារ៉ាប់ផងដែរ) ហើយបានចូលរួមក្នុងការប្រណាំងប្រជែងសព្វាវុធដ៏ធំមួយ ដោយប្រទេសអារ៉ាប៊ីសាអូឌីតបានស្តុកទុកយន្តហោះចម្បាំង និងកាំជ្រួច ខណៈដែលប្រទេសអ៊ីរ៉ង់នាំចេញសព្វាវុធទៅកាន់សម្ព័ន្ធមិត្តរបស់ខ្លួននិងអាចស្រូតរូតរះបង្កើតអាវុធនុយក្លេអ៊ែរ។ ប្រទេសរុស្ស៊ីមាននិន្នាការគាំទ្រភាគីអ៊ីរ៉ង់និកាយស៊ីអ៊ីត ខណៈអាមេរិក និងសម្ព័ន្ធមិត្តគាំទ្រភាគីអារ៉ាប៊ីសាអូឌីតនិកាយស៊ុននី។ ទោះជាយ៉ាងណា ភាគីទាំងសងខាងមិនស្រុះស្រួលជាមួយនឹងប្រទេសអ៊ីស្រាអែលឡើយ ដោយធ្វើអោយជម្លោះមានទិដ្ឋភាពត្រីកោណ ។

នៅក្នុងប្រទេសអ៊ីរ៉ង់ ការបះបោរដ៏មានប្រជាប្រិយមួយក្នុងឆ្នាំ ១៩៧៩ បានផ្តួលរំលំស្តេចហ្សាហ៍ (shah)ដែលគាំទ្រដោយសហរដ្ឋអាមេរិក និងបានដំឡើងរដ្ឋាភិបាលអ៊ីស្លាមនិយម ដែលមេដឹកនាំសាសនាកំពូល (អាយ៉ាតូឡា-ayatollahs) អាចលុបចោលច្បាប់ដែលបានអនុម័តដោយសភា។ ការបដិសេធបទដ្ឋានអន្តរជាតិដោយអ្នកកាន់សាសនាអ៊ីស្លាមនិយមមួយចំនួនត្រូវបានបង្ហាញយ៉ាងច្បាស់ក្រឡែត នៅពេលដែលអ៊ីរ៉ង់បដិសេធមិនការពារអ្នកការទូតសហរដ្ឋអាមេរិក(នៅអ៊ីរ៉ង់)ក្នុងឆ្នាំ ១៩៧៩។ ដោយប្រឆាំងនឹងក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ប្រទេសអ៊ីរ៉ង់ បច្ចុប្បន្ន កំពុងអភិវឌ្ឍបច្ចេកវិទ្យានុយក្លេអ៊ែរដែលអាចផលិតអាវុធនុយក្លេអ៊ែរ ក្នុងរយៈពេលពីរបីឆ្នាំខាងមុខ។ នៅឆ្នាំ ២០០៩ ការបោះឆ្នោតជ្រើសរើសប្រធានាធិបតីដ៏ចំរូងចម្រាស់ បានបណ្តាលអោយមានការគាបសង្កត់យ៉ាងខ្លាំងលើបាតុករ។ ក្នុងឆ្នាំ ២០១២ រូបិយប័ណ្ណរបស់ប្រទេសអ៊ីរ៉ង់បានបាត់បង់តម្លៃពាក់កណ្តាល ខណៈដែលទណ្ឌកម្មអន្តរជាតិដ៏ធ្ងន់ធ្ងរបានប៉ះពាល់ដល់សេដ្ឋកិច្ច ហើយប្រទេសអ៊ីស្រាអែលបានគំរាមវាយប្រហារផ្នែកយោធា ដើម្បីបញ្ឈប់មហិច្ឆតានុយក្លេអ៊ែររបស់អ៊ីរ៉ង់ ប្រសិនបើចាំបាច់។

ប្រទេសអ៊ីរ៉ង់គាំទ្រយ៉ាងខ្លាំងក្លា ដល់ក្រុមកងជីវពលហេសបូឡានៅក្នុងប្រទេសលីបង់ និងដល់រដ្ឋាភិបាលក្នុងប្រទេសស៊ីរី ទាំងផ្នែកហិរញ្ញវត្ថុ សព្វាវុធ និងការហ្វឹកហ្វឺនទ័ព ។ ក្រុមកងជីវពលហេសបូឡា ធ្វើដំណើរការសាលារៀននិងមន្ទីរពេទ្យរាប់រយកន្លែង រួមទាំងអង្គការសប្បុរសធម៌ជាច្រើនផងដែរ ប៉ុន្តែ ក្រុមនេះក៏ត្រូវបានដាក់បញ្ចូលក្នុងបញ្ជីអង្គការភេរវកម្មរបស់សហរដ្ឋអាមេរិក។ ក្រុមហេសបូឡាបានប្រយុទ្ធប្រឆាំងនឹងប្រទេសអ៊ីស្រាអែល អស់រយៈពេលជាច្រើនឆ្នាំ ដោយទទួលបានការគាំទ្រដ៏ពេញនិយម នៅទូទាំងពិភពអារ៉ាប់ សូម្បីតែក្នុងចំណោមរដ្ឋប្រកាន់និកាយស៊ុននីនិយមក៏ដោយ។ ក្រុមហេសបូឡាបានដើរតួនាំមុខក្នុងរដ្ឋាភិបាលលីបង់ ក្នុងឆ្នាំ ២០១១ ទោះបីជាមានការចោទប្រកាន់របស់សាលាក្តីអង្គការសហប្រជាជាតិ លើសមាជិករបស់ខ្លួន ចំពោះការធ្វើឃាតនាយករដ្ឋមន្ត្រីលីបង់ ក្នុងឆ្នាំ ២០០៥ ក៏ដោយ។

នៅភាគីនិកាយស៊ុននី ក្រុមអ៊ីស្លាមសកម្មប្រយុទ្ធសំខាន់ៗ ក៏ដូចជាក្រុមដែលមិនសូវប្រើហិង្សានោះ គឺក្រុមសាឡាហ្វីស៍(Salafis)។ ពួកគេប្រកាន់ខ្ជាប់នូវកំណែមួយចំនួនរបស់ក្រុមវ៉ាហាប៊ីនិយម(Wahhabism) ដែលជាការបកស្រាយច្បាប់អ៊ីស្លាមជាមូលដ្ឋានទាំងឧល (fundamentalist) ដែលមានឫសគល់ នៅក្នុងប្រទេសអារ៉ាប៊ីសាអូឌីត។ មជ្ឈមណ្ឌលដ៏សំខាន់បំផុតនៃចលនាមូលដ្ឋាននិយមនេះ បច្ចុប្បន្ន ស្ថិតនៅក្នុង

ប្រទេសអាហ្វហ្គានីស្ថាន និងតំបន់កុលសម្ព័ន្ធនៅជិតខាង ក្នុងភាគខាងលិចនៃប្រទេសប៉ាគីស្ថាន។ ពួកសកម្ម ប្រយុទ្ធដែលប្រតិបត្តិតាមទស្សនៈដូចគ្នានេះ ក៏សកម្មខ្លាំងនៅទូទាំងទ្វីបអាហ្វ្រិកខាងជើង ក្នុងឆ្នាំ ២០១៥ ជាពិសេស នៅប្រទេសនីហ្សេរីយ៉ា ម៉ាលី លីប៊ី និងសូម៉ាលី។

នៅប្រទេសអាហ្វហ្គានីស្ថាន រដ្ឋាភិបាលអ៊ីស្លាមនិយមមួយត្រូវបានបង្កើតឡើង ក្នុងឆ្នាំ ១៩៩២ បន្ទាប់ពីសង្គ្រាមស៊ីវិល(និងបន្ទាប់ពីការកាន់កាប់របស់សូវៀតដ៏យង់ឃ្នង ក្នុងពេលមួយទសវត្សរ៍)។ ក្រុមអ៊ីស្លាម ដែលជាគូប្រកួតប្រជែងនានា ក្រោយមក បានបន្តសង្គ្រាមជាមួយនឹងគ្នា ដោយបង្កភាពតានតឹងខ្លាំងជាងមុន អស់រយៈពេលជាច្រើនឆ្នាំ។ នៅឆ្នាំ ១៩៩៧ ក្រុមតស៊ូមួយ ហៅថា តាលីបង់ បានកាន់កាប់ភាគច្រើននៃ ប្រទេសអាហ្វហ្គានីស្ថាន ហើយបានគ្រប់គ្រងដោយច្បាប់អ៊ីស្លាមតឹងរឹងបំផុត។ ជាមួយនឹងទណ្ឌកម្មការវាយដំ និងការប្រហារជីវិត របបនេះបានបង្ខំអោយស្ត្រីស្លៀកពាក់គ្របបិទជិត ពីក្បាលដល់ចុងជើង មិនអោយក្មេង ស្រីចូលរៀននៅសាលា ចំណែកបុរសត្រូវទុកពុកមាត់ ក្នុងចំណោមគោលនយោបាយគាបសង្កត់ផ្សេងទៀត។

បណ្តុំរងើកភ្លើងសង្គ្រាមនៅអាហ្វហ្គានីស្ថានក្នុងទសវត្សរ៍ឆ្នាំ១៩៩០ (សង្គ្រាមមិនចេះចប់ ភាពក្រីក្រ តោកយ៉ាកខ្លាំង អ៊ីស្លាមមូលដ្ឋានគ្រឹះនិយម និងរដ្ឋាភិបាលដឹកនាំដោយមនោគមវិជ្ជា) បានបណ្តាលអោយ អាហ្វហ្គានីស្ថានក្លាយជាមូលដ្ឋានសម្រាប់ប្រតិបត្តិការភេរវកម្មទូទាំងពិភពលោក ដែលឈានដល់ការវាយ ប្រហារនៅថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ២០០១។ ជាការឆ្លើយតប សហរដ្ឋអាមេរិកបានប្រើអំណាចរបស់ខ្លួនដើម្បី ដកក្រុមតាលីបង់ចេញពីអំណាចនៅក្នុងប្រទេសអាហ្វហ្គានីស្ថាន និងរារាំងរំខានបណ្តាញភេរវកររាល់កៃដា ដែលមានទីស្នាក់ការសម្ងំនៅទីនោះ។ ទោះបីជាជោគជ័យរបស់សហរដ្ឋអាមេរិក និងអង្គការណាតូក៏ដោយ ក៏ ក្រុមតាលីបង់នៅតែបន្តវាយប្រហារលើកងកម្លាំងណាតូ។ ការវាយប្រហារលើជនស៊ីវិលក៏បន្តកើតឡើងនៅ ប្រទេសអាហ្វហ្គានីស្ថានដែរ។

ការបរាជ័យរបស់ពួកតាលីបង់នៅក្នុងប្រទេសអាហ្វហ្គានីស្ថានក្នុងឆ្នាំ ២០០១ បានដឹកនាំសមាជិក របស់ខ្លួន រួមជាមួយនឹងក្រុមសកម្មប្រយុទ្ធប៉ាគីស្ថាន ដែលមានគំនិតដូចគ្នា ទៅបង្កើតមូលដ្ឋាននៅក្នុង «តំបន់កុលសម្ព័ន្ធ» ដែលគ្មានច្បាប់នៃភាគខាងលិចប៉ាគីស្ថាន ដែលជាប្រទេសជិតខាងធំជាងដែលមានអាវុធ នុយក្លេអ៊ែរ។ ភ្នាក់ងារស៊ើបការណ៍សម្ងាត់របស់ប្រទេសប៉ាគីស្ថានត្រូវបានគេជឿយ៉ាងប្រត្យក្សថានឹងប្រើប្រាស់ ក្រុមសកម្មប្រយុទ្ធអ៊ីស្លាមដើម្បីបញ្ចេញឥទ្ធិពលទាំងនៅអាហ្វហ្គានីស្ថាន និងនៅតំបន់កាស្មៀរ ដែលជាទឹកដី មានជម្លោះ រវាងប្រទេសប៉ាគីស្ថាន និងប្រទេសឥណ្ឌា។ នៅចុងឆ្នាំ ២០០៨ ភេរវករដែលមានមូលដ្ឋាននៅ ប្រទេសប៉ាគីស្ថានបានវាយប្រហារទីក្រុងបុមបៃ ក្នុងប្រទេសឥណ្ឌា ហើយបានសម្លាប់ជនស៊ីវិលប្រហែល ១៥០ នាក់ នៅទីនោះ។ កងកម្លាំងគាំទ្រលទ្ធិប្រជាធិបតេយ្យបានបណ្តេញមេដឹកនាំយោធាប៉ាគីស្ថាន និងបាន ដំឡើងរដ្ឋាភិបាលជាប់ឆ្នោតក្នុងឆ្នាំ ២០០៨ ទោះបីជាមិនទាន់បានបង្កើតឡើង រហូតក្រោយពេល មេដឹកនាំ ចលនានេះ ឈ្មោះ បេណាហ្ស៊ៀរ ភូតូ (Benazir Bhutto) ត្រូវបានធ្វើឃាតក៏ដោយ។

សង្គ្រាមនៅអាហ្វហ្គានីស្ថានបានធ្វើអោយទំនាក់ទំនងរវាងប៉ាគីស្ថាននិងសហរដ្ឋអាមេរិក និងសម្ព័ន្ធ មិត្តអង្គការណាតូកាន់តែមានភាពតានតឹង។ ស្ថានភាពតានតឹងកាន់តែខ្លាំងទៅៗ នៅឆ្នាំ ២០១១ នៅពេល ដែលកងកម្លាំងអាមេរិកបានតាមរកឃើញនិងសម្លាប់មេភេរវករ អូសាម៉ា ប៊ីន ឡាដិន (Osama bin Laden) នៅក្នុងទីក្រុងមួយរបស់ប៉ាគីស្ថាន។ ប្រជាជនប៉ាគីស្ថានបានដំទាស់នឹងការឈ្លានពាន ដែលរំលោភបំពានលើ អធិបតេយ្យភាពជាតិរបស់ពួកគេ ខណៈដែលជនជាតិអាមេរិកឆ្ងល់ថាតើយោធារបស់ប៉ាគីស្ថានពិតជាបាន

ឃុបឃិតជួយលាក់បំពួន ប៊ីនឡាដិន ឬយ៉ាងណា។

តារាង ៥.១ ក្រុមឥស្លាមប្រដាប់អាវុធធំៗ

ក្រុម	ប្រទេស	និកាយ	សកម្មភាព
សាធារណរដ្ឋ អ៊ីស្លាមអ៊ីរ៉ង់	អ៊ីរ៉ង់	ស៊ីអ៊ីត	បដិវត្តន៍អ៊ីស្លាមដណ្តើមគ្រប់គ្រងរដ្ឋជោគជ័យ (ពីឆ្នាំ ១៩៧៩) ទប់ទល់អ៊ីរ៉ាក់ផ្លូវលោកក្នុងទសវត្សរ៍ឆ្នាំ ១៩៨០, ឥឡូវ ព្យាយាមកសាងអាវុធនុយក្លេអ៊ែរ។
ហេសបូឡា	លីបង់	ស៊ីអ៊ីត	វាយប្រហារទ័ពអ៊ីស្រាអែលឆ្នាំ២០០៦, ភាគីមួយក្នុងសម្ព័ន្ធរដ្ឋាភិបាលគ្រប់គ្រងនៅលីបង់
ទ័ពម៉ាឌី/កងពលសន្តិភាព	អ៊ីរ៉ាក់	ស៊ីអ៊ីត	ប៉ះទង្គិតជាមួយកងកម្លាំងអាមេរិកនៅអ៊ីរ៉ាក់,ភាគីក្នុងរដ្ឋាភិបាលអ៊ីរ៉ាក់, វាយរដ្ឋអ៊ីស្លាមISISដណ្តើមទឹកដីកាន់កាប់ នៅអ៊ីរ៉ាក់
រណសិរ្ស អាល់-នុស្រា	ស៊ីរី	ស៊ុននី	ដឹកនាំកងទ័ពឧទ្ធាមក្នុងសង្គ្រាមស៊ីវិល
អានស្សារ ឌីន	ម៉ាលី	ស៊ុននី	គ្រប់គ្រងភាគខាងជើងប្រទេស នៅឆ្នាំ ២០១២, ចាប់ចំណាប់ខ្មាំងនៅអាល់ហ្សេរី នៅឆ្នាំ ២០១៣
ហាម៉ាស់	ប៉ាឡេស្ទីន	ស៊ុននី	កងកម្លាំងបានសម្លាប់ជនស៊ីវិលអ៊ីស្រាអែលរាប់រយនាក់ និងធ្វើសង្គ្រាមប្រឆាំងនឹងអ៊ីស្រាអែលឆ្នាំ ២០០៨ និង ២០១៤, ឈ្នះឆ្នោតដឹកនាំប៉ាឡេស្ទីននៅឆ្នាំ ២០០៦, គ្រប់គ្រងហ្គាស្ត្រាស្ទ្រីប
អាល់ ហ្សាបាប	សូម៉ាលី	ស៊ុននី	គ្រប់គ្រងទឹកដីភាគច្រើនក្នុងប្រទេស ចន្លោះឆ្នាំ ២០០៧-២០១២, ចង់សម្ព័ន្ធភាពជាមួយក្រុមអាល់កៃដា, ត្រូវបណ្តេញដោយសហភាពអាហ្វ្រិក ឆ្នាំ ២០១២, បន្តវាយប្រហារនៅសូម៉ាលី ឆ្នាំ ២០១៧
រណសិរ្សរំដោះម៉ូរូអ៊ីស្លាម	ហ្វីលីពីន	ស៊ុននី	កងកម្លាំងបានវាយដណ្តើមបានឯករាជ្យនៅតំបន់មួយចំនួននៅកោះហ្វីលីពីនភាគខាងត្បូងគ្រប់ដណ្តប់ដោយជនមូស្លីម
អាល់កៃដា	ពិភពលោក ប៉ាគីស្តាន	ស៊ុននី	វាយប្រហារភេរវកម្ម ១១កញ្ញា និងបោកគ្រាប់បែកនៅអឺរ៉ុប, ធ្លាក់ខ្សោយដោយការស្លាប់មេដឹកនាំកំពូលៗ
តាលីបង់	អាហ្វហ្គានីស្ថាន	ស៊ុននី	ក្រុមបះបោរធំៗវាយបណ្តេញកងកម្លាំងបរទេស, បានគ្រប់គ្រងប្រទេស នៅចន្លោះឆ្នាំ ១៩៩៦-២០០១
រដ្ឋអ៊ីស្លាម (ISIS/ISIL/ Daesh)	ស៊ីរី/អ៊ីរ៉ាក់	ស៊ុននី	កើតចេញពីក្រុមយុទ្ធជនស៊ុននីនៅអ៊ីរ៉ាក់, លេចចេញជាតួអង្គសំខាន់នៅក្នុងសង្គ្រាមស៊ីវិលនៅស៊ីរី, ក្លាយជាគោលដៅនៃការវាយប្រហារដើងអាកាស ចន្លោះឆ្នាំ ២០១៤-២០១៧
ហ៊ូឌីស៍	យ៉េមែន	ស៊ីអ៊ីត	ដណ្តើមគ្រប់គ្រងទឹកដីយេម៉ែនភាគច្រើននៅឆ្នាំ ២០១៤, គាំទ្រដោយអ៊ីរ៉ង់, ត្រូវវាយប្រហារដោយអា៉ប៊ីសាអូឌីត

បូកូ ហារ៉ាម	នីហ្សេរីយ៉ា	ស៊ុននី	បានសម្លាប់ និងជម្លៀសប្រជាជនរាប់លាននាក់នៅនីហ្សេរីយ៉ាខាងជើងតាំងពីឆ្នាំ ២០០៩, ចាប់ជំរិតនិងបោកគ្រាប់បែកបុគ្គលជាន់ខ្ពស់
ភាវរកម្ម/យុទ្ធជនទ័ពព្រៃក៏សកម្មណាស់ដែរ នៅឆេចនៀ(រុស្ស៊ី) កាស្មៀរ(ឥណ្ឌា) អាស៊ីកណ្តាល លីប៊ី ម៉ាលី និងឥណ្ឌូនេស៊ី។			

(ប្រភព៖ ក្រសួងការពារជាតិអាមេរិក)

អាល់កៃដា គឺជាក្រុមឆ្លងដែន (មែនទែនទៅ សមជាបណ្តាញឬចលនានៃអង្គការមជ្ឈឹម ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ) ដែលបានជ្រើសរើសអ្នកប្រយុទ្ធពីប្រទេសផ្សេងៗ លើកទឹកចិត្ត និងជួនកាលបង្ហាត់ពួកគេ និងជួយពួកគេប្រយុទ្ធក្នុងដម្លោះបរទេស (ដូចជា នៅអាហ្វហ្គានីស្ថានក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ នៅអ៊ីរ៉ាក់ក្រោយឆ្នាំ ២០០៣ ឬនៅស៊ីរីសព្វថ្ងៃនេះ)។

ទោះបីជាអាល់កៃដាជា«និមិត្តសញ្ញា» (brand) បានទាក់ទាញអ្នកជឿលង់តាម នៅភាគខាងជើងនៃទ្វីបអាហ្វ្រិក ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះក៏ដោយ វាបានបាត់បង់ប្រជាប្រិយនៅអាស៊ី និងអឺរ៉ុប ដែលប៉ុន្មានឆ្នាំក្រោយឆ្នាំ ២០០១ គេឃើញមានការទម្លាក់គ្រាប់បែកភេរវកម្មជាច្រើន ពីកោះបាលីនៃប្រទេសឥណ្ឌូនេស៊ី រហូតដល់ប្រទេសម៉ារ៉ុក អារ៉ាប៊ីសាអូឌីត រុស្ស៊ី ហ្វីលីពីន ឥណ្ឌូនេស៊ី អ៊ីរ៉ាក់ និងទួរគី។ នៅឆ្នាំ ២០០៤ ការទម្លាក់គ្រាប់បែកលើរថភ្លើង នៅទីក្រុងម៉ាឌ្រីដ បានសម្លាប់មនុស្សរាប់រយនាក់ ហើយស្តែងណាស់ បានជះឥទ្ធិពលក្នុងការបោះឆ្នោតប្រឆាំងនឹងរដ្ឋាភិបាលអេស្ប៉ាញដែលគាំទ្រអាមេរិក ហើយជាលទ្ធផល បានជំរុញអោយប្រទេសអេស្ប៉ាញដកកងទ័ពចេញពីប្រទេសអ៊ីរ៉ាក់។ នៅឆ្នាំបន្ទាប់ រថភ្លើងក្រោមដីនៅទីក្រុងឡុងដ៍បានក្លាយជាគោលដៅម្តង។

នៅក្នុងប្រទេសអារ៉ាប៊ីសាអូឌីត ដែលជាកន្លែងស្តុកទុកប្រេងដ៏ធំបំផុតនៅលើពិភពលោក ទីតាំងដ៏ពិសិដ្ឋបំផុតរបស់សាសនាឥស្លាម និងជាទីកំណើតដើមទងនៃលទ្ធិវ៉ាហាប៊ីសនិយម (Wahhabism) ក្រុមអាល់កៃដាបានប៉ុនប៉ងដោយសង្ឃឹមជាយូរមកហើយថានឹងផ្តួលរំលំរបបរាជានិយម។ នៅឆ្នាំ ១៩៧៩ ពួកសកម្មប្រយុទ្ធឥស្លាមបានដណ្តើមកាន់កាប់មហាព្រះវិហារ (Grand Mosque) នៅទីក្រុងម៉ិចកា (Mecca) បានមួយរយៈពេលខ្លី។

ប្រទេសជិតខាងនៃប្រទេសអារ៉ាប៊ីសាអូឌីតនៅភាគខាងត្បូង ប្រទេសយេម៉ែនមានសាខាក្រុមឧទ្ទាមអាល់កៃដាដ៏សកម្មប្រយុទ្ធ។ អ្នកប្រយុទ្ធទាំងនេះបានព្យាយាម បំផ្ទុះយន្តហោះដែលហោះចូលទឹកដីសហរដ្ឋអាមេរិកជាច្រើនដង និងបានដណ្តើមយកទឹកដីនៅភាគខាងត្បូងនៃប្រទេស ក្នុងឆ្នាំ២០១១-២០១២ ខណៈពេលដែលរដ្ឋាភិបាលត្រូវកាត់ផ្តាច់ដៃជើង ធ្វើអ្វីមិនកើត ដោយសារភាពចលាចលនយោបាយ នៅក្នុងរដ្ឋធានី (ចំណែកមួយនៃព្រឹត្តិការណ៍បដិវត្តន៍រដូវផ្កាឈូកនៅអារ៉ាប់)។ យេម៉ែនគឺប្រទេសក្រីក្របំផុត នៅមជ្ឈឹមបូព៌ា និងបានទទួលរងគ្រោះដោយសារជម្លោះស៊ីវិល រាប់ទសវត្សរ៍។ សហរដ្ឋអាមេរិកបើកយុទ្ធនាការវាយប្រហារដោយប្រើយន្តហោះគ្មានមនុស្សបើក ដើម្បីប្រយុទ្ធប្រឆាំងនឹងក្រុមសកម្មប្រយុទ្ធយេម៉ែន។ នៅត្រឹមឆ្នាំ ២០១៥ យេម៉ែនត្រូវរងការគំរាមកំហែងដោយសង្គ្រាមស៊ីវិលពេញទំហឹង ដោយមានក្រុមជាច្រើន ប្រយុទ្ធប្រឆាំងនឹងគ្នាទៅវិញទៅមក។ ជនជាតិភាគតិចមួយក្រុមដែលគេស្គាល់ថាជា ហ៊ូឌីស៍ (Houthis) (សម្ព័ន្ធមិត្តជាមួយអ៊ីរ៉ង់ប៉ុន្តែប្រឆាំងនឹងក្រុមអាល់កៃដា) បានវាយដណ្តើមគ្រប់គ្រងរដ្ឋាភិបាលនិង។ ជាការឆ្លើយតប ប្រទេសអារ៉ាប៊ី

សាអូឌីត (គូប្រជែងរបស់អ៊ីរ៉ង់) បានវាយប្រហារក្រុមឧទ្ធាមហ៊ូឌីស៍(ភាគច្រើនតាមផ្លូវអាកាស) ដើម្បីស្តារការគ្រប់គ្រងលើរដ្ឋាភិបាល។ នៅក្នុងស្ថានភាពចលាចលនេះ ក្រុមយុទ្ធជនអ៊ីស្លាមថ្មីដែលអះអាងថាខ្លួនមានស្មោះស្ម័ញគ្រកក្តីនឹងក្រុម ISIS បានចាប់ផ្តើមប្រតិបត្តិការបំផ្ទុះគ្រាប់បែកអត្តឃាត។ នៅត្រឹមឆ្នាំ២០១៨ ក្រុមហ៊ូឌីស៍នៅបន្តគ្រប់គ្រងរដ្ឋាភិបាល ហើយម្តងម្កាលវាយប្រហារដោយគ្រាប់រ៉ុក្កែតលើប្រទេសអារ៉ាប៊ីសាអូឌីត ខណៈពេលដែលសង្គ្រាមបន្តឆាបឆេះពេញផ្ទៃប្រទេស។

ក្រុមយុទ្ធជនអាល់ហ្សាបាប (al Shabab) របស់ប្រទេសសូម៉ាលី ដែលមានទំនាក់ទំនងជាមួយក្រុមអាល់កៃដា (al Qaeda) ត្រូវបានបណ្តេញចេញពីទីក្រុង និងទីប្រជុំជនភាគច្រើន ក្នុងឆ្នាំ ២០១២ ដោយកងកម្លាំងសហភាពអាហ្វ្រិក(AU) ប៉ុន្តែមិនទាន់ត្រូវបានបណ្តេញចេញមុនពេលសងសឹកលើប្រទេសអេត្យូពី និងប្រទេសអ៊ូហ្គង់ដាដែលបានបញ្ជូនកងទ័ពរៀងៗខ្លួនចូលរួមគាំទ្ររដ្ឋាភិបាលសូម៉ាលី។ ក្រុមអាល់ហ្សាបាបបានធ្វើការបំផ្ទុះគ្រាប់បែកយ៉ាងសាហាវនៅក្នុងប្រទេសអ៊ូហ្គង់ដា ក្នុងអំឡុងពេលការប្រកួតបាល់ទាត់ពិភពលោកឆ្នាំ ២០១០ រំគួផ្តាច់ព្រ័ត្រ។ ទោះបីជាកម្លាំងសហភាពអាហ្វ្រិកនៅក្នុងប្រទេសសូម៉ាលីបានរុញក្រុមអាល់ហ្សាបាបចេញពីរដ្ឋធានីក្តី គ្រោះទុរ្ភិក្សដ៏គួរអោយភ័យខ្លាច ក្នុងឆ្នាំ ២០១១ ដែលបណ្តាលមកពីគ្រោះរាំងស្ងួត និងសង្គ្រាម បានជះឥទ្ធិពលដ៏អាក្រក់លើតំបន់ដែលកាន់កាប់ដោយ ក្រុមអាល់ហ្សាបាប នៃប្រទេស និងបង្ខំជនភៀសខ្លួនជាច្រើនចូលទៅក្នុងប្រទេសកេនយ៉ា។ ជាការឆ្លើយតប ប្រទេសកេនយ៉ាក៏បានបញ្ជូនកងកម្លាំងយោធាចូលទៅក្នុងប្រទេសសូម៉ាលី ដើម្បីវាយប្រហារ ក្រុមអាល់ហ្សាបាប។ ការឈ្លានពានទាំងនេះបានធ្វើឲ្យអាល់ហ្សាបាបចុះខ្សោយ ប៉ុន្តែ វាបន្តវាយប្រហារគោលដៅ ក្នុងប្រទេសសូម៉ាលី។ (ក្នុងឆ្នាំ ២០១៥ យោធាអាមេរិកបានអះអាងថាបានសម្លាប់មេដឹកនាំក្រុមអាល់ហ្សាបាបដ៏សំខាន់ម្នាក់ដោយប្រើយន្តហោះគ្មានមនុស្សបើក។)

នៅក្នុងប្រទេសលីប៊ី ការផ្តួលរំលំមេដឹកនាំផ្តាច់ការ មូអាម៉ា ហ្គាដាហ្វី (Muammar Gaddafi) ក្នុងឆ្នាំ ២០១១ (ដោយមានជំនួយពីអង្គការណាតូ)បានផ្តល់អំណាចដល់ក្រុមប្រដាប់អាវុធអ៊ីស្លាមនិយមដែលពីមុនត្រូវបានគាបសង្កត់។ ពួកគេបានសម្លាប់ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក នៅក្នុងឆ្នាំ ២០១២ ហើយពួកគេបានចូលរួមជាមួយក្រុមឧទ្ធាមជនជាតិភាគតិចមកពីប្រទេសម៉ាលី ដែលបានចូលរួមប្រយុទ្ធ ក្នុងនាមជាទាហានស៊ីឈ្នួលអោយលោកហ្គាដាហ្វី ដើម្បីដណ្តើមកាន់កាប់ភាគខាងជើងនៃប្រទេសម៉ាលី ដោយប្រើអាវុធយ៉ាងច្រើនសន្ធឹកសន្ធាប់ ដែលពួកគេនាំយកមកពីប្រទេសលីប៊ី។ ក្រុមអ៊ីស្លាមនិយមបានបោសសម្អាតក្រុមឧទ្ធាមជនជាតិភាគតិច ហើយដណ្តើមអំណាចមកគ្រប់គ្រងដោយខ្លួនឯងផ្ទាល់ ប៉ុន្តែនៅឆ្នាំ ២០១៣ ពួកគេត្រូវបានបណ្តេញចេញដោយការអន្តរាគមន៍យោធា ដោយប្រទេសបារាំងនិងបណ្តាប្រទេសនៅអាហ្វ្រិកជិតខាង ដើម្បីប្រគល់អំណាចគ្រប់គ្រងទៅអោយរដ្ឋាភិបាលម៉ាលីវិញ។

នៅអាហ្វ្រិកភាគខាងលិច ក្នុងប្រទេសនីហ្សេរីយ៉ា ក្រុមអ៊ីស្លាមនិយមដែលគេស្គាល់ថា បូកូ ហារ៉ាម (Boko Haram) បានវាយប្រហារមន្ត្រីរដ្ឋាភិបាលនិងជនស៊ីវិល ចាប់តាំងពីឆ្នាំ ២០០៩ មក។ គួរអោយកត់សម្គាល់បំផុត ក្រុមនេះបានវាយប្រហារសាលារៀនបង្រៀនក្មេងស្រីជាច្រើនកន្លែង នៅក្នុងឆ្នាំ ២០១៤ ដោយចាប់យកកូនសិស្សស្រីៗក្មេងៗធ្វើជាចំណាប់ខ្មាំង ក្នុងការវាយប្រហារនីមួយៗ។ រដ្ឋាភិបាលនីហ្សេរីយ៉ាបានប្រកាសដាក់ប្រទេសក្នុងគ្រាអាសន្ន ហើយបានដាក់ពង្រាយទាហានរាប់ពាន់នាក់ ទៅកាន់ខេត្តភាគខាងជើងដែលជាដំរកដ៏ធំបំផុតរបស់ក្រុមនេះ។

នៅប៉ាឡេស្ទីន ក្រុមអ៊ីស្លាមជ្រុលនិយម ហាម៉ាស គឺជាកងជីវពលអ៊ីស្លាមនិកាយស៊ុននី ដ៏សំខាន់មួយទៀត បើទោះជាវាមិនមានទំនាក់ទំនងជាមួយក្រុមអាល់កៃដា ឬតាលីបង់ក៏ដោយ។ ដោយមានមូលដ្ឋាននៅតំបន់ហ្គាហ្សាស្ទ្រីប ក្រុមហាម៉ាស់នេះបានបញ្ជូនអ្នកបំផ្ទុះគ្រាប់បែកអត្តឃាត ដែលបានសម្លាប់ជនជាតិអ៊ីស្រាអែលរាប់រយនាក់ ក្រោយឆ្នាំ ២០០០ បន្ទាប់មកបានជោគជ័យក្នុងការបោះឆ្នោតសភាដោយសេរី នៅឆ្នាំ ២០០៦ ព្រោះក្រុមនេះត្រូវបានគេមើលឃើញថា មិនសូវពុករលួយដូចគណបក្សកាន់អំណាច។ ទោះជាយ៉ាងណាក៏ដោយ ប៉ាឡេស្ទីននៅតែបែកបាក់គ្នា ដោយអាជ្ញាធរប៉ាឡេស្ទីនគ្រប់គ្រងតំបន់វ៉ែសប៊ែង (West Bank) ចំណែកក្រុមហាម៉ាសគ្រប់គ្រងតំបន់ហ្គាហ្សា។

រូបថត *កងទ័ពអ៊ីរ៉ាក់ ក្នុងការប្រយុទ្ធជាមួយរដ្ឋអ៊ីស្លាមបានដកទង់ISIS*

រដ្ឋអ៊ីស្លាម?

នៅក្នុងប្រទេសមួយចំនួន ដែលមានប្រជាជនភាគច្រើនបំផុតជាជនម៉ូស្លីម សាសនាឥស្លាមគឺជាចំណុចកៀងគរកម្លាំងនយោបាយ ជាពិសេសនៅក្នុងប្រទេសផ្តាច់ការ ដែលវិហារអ៊ីស្លាមគឺជាកន្លែងប្រមូលផ្តុំដ៏កម្រដែលត្រូវបានគេអនុញ្ញាត។ អ្នកនយោបាយឥស្លាមមួយចំនួនកំពុងបង្កើតគំរូរដ្ឋាភិបាលថ្មី លាយឡំលទ្ធិប្រជាធិបតេយ្យនឹងប្រពៃណីឥស្លាម ជាពិសេសនៅក្នុងប្រទេសដែលរងផលប៉ះពាល់ខ្លាំងជាងគេដោយការតវ៉ានៅនិទាឃរដូវអារ៉ាប់។ ក្រុមអ៊ីស្លាមជ្រុលនិយមផ្សេងទៀត ដូចជា រដ្ឋឥស្លាមនៅអ៊ីរ៉ាក់និងស៊ីរី (ISIS) ប្រយុទ្ធយ៉ាងឃោរឃៅ សម្រាប់រដ្ឋដែលបង្កើតឡើង ដោយពឹងផ្អែកនៅលើច្បាប់អ៊ីស្លាម។ រហូតមកដល់ចុងឆ្នាំ ២០១៧ ក្រុម ISIS បានគ្រប់គ្រងផ្នែកសំខាន់ៗនៃទឹកដីក្នុងប្រទេសអ៊ីរ៉ាក់និងស៊ីរី។ នៅទីនេះ អ្នកប្រយុទ្ធដែលគាំទ្រកងទ័ពរបស់អ៊ីរ៉ាក់ ក្នុងការប្រយុទ្ធជាមួយរដ្ឋអ៊ីស្លាមបានដកទង់ជាតិISIS ចេញពីទីក្រុងដែលកាន់កាប់ដោយកងកម្លាំងរដ្ឋាភិបាលឆ្នាំ ២០១៧ ។

ប្រទេសមហាអំណាចពីរដែលប្រឈមមុខនឹងអំពើហិង្សាអ៊ីស្លាមនិយមក្នុងព្រំដែនរបស់ខ្លួន គឺប្រទេសរុស្ស៊ី នៅភាគខាងត្បូងបំផុត និងប្រទេសចិន នៅភាគខាងលិចបំផុត។ សាធារណរដ្ឋឆេចនៀ (Chechnya) ដែលមានប្រជាជនលើសលប់ជាជនមូស្លីមនិកាយស៊ុននី ដែលជាខេត្តមួយរបស់រុស្ស៊ីបានព្យាយាមបំបែករដ្ឋចេញពីប្រទេសរុស្ស៊ី នៅដើមទសវត្សរ៍ឆ្នាំ១៩៩០ បន្ទាប់ពីសហភាពសូវៀតបានដួលរលំ។ បន្ទាប់ពីសង្គ្រាមបំផ្លិចបំផ្លាញ ក្នុងចន្លោះឆ្នាំ១៩៩៤-១៩៩៥ និង ១៩៩៩-២០០០ ការគម្រាមកំហែងបានថយចុះ ទោះបីជាទ័ពព្រៃឆេធិន (ប្រទេសឈ្មោះ ឆេចនៀ រីឯជនជាតិហៅថា ឆេធិន) ក្រោយមក បានងាកទៅរកការចាប់ជំរិតតាមផ្លូវអាកាស ការចាប់ចំណាប់ខ្មាំង និងការបំផ្ទុះគ្រាប់បែកអត្តឃាតក៏ដោយ។ ក្នុងឆ្នាំ ២០០៤ កុមាររាប់រយនាក់បានស្លាប់ បន្ទាប់ពីភេរវករជនជាតិ ឆេធិន ចូលកាន់កាប់សាលារៀនមួយ ហើយចាប់ពួកគេធ្វើជាចំណាប់ខ្មាំង។ នៅឆ្នាំ ២០០៥ កងកម្លាំងរុស្ស៊ីបានសម្លាប់មេដឹកនាំផ្តាច់ខ្លួនរបស់ឆេធិន ដែលពួកគេចោទថាជាអ្នកទទួលខុសត្រូវ ហើយអំពើហិង្សានយោបាយនៅឆេចនៀ ចាប់តាំងពីពេលនេះមក កើតមានឡើងម្តងម្កាលតែប៉ុណ្ណោះ។

ជារួម ជម្លោះពាក់ព័ន្ធនឹងចលនាអ៊ីស្លាមនិយមមានលក្ខណៈស្មុគស្មាញជាងជម្លោះសាសនាទូទៅដទៃទៀត។ ជម្លោះទាំងនោះពាក់ព័ន្ធនឹងអំណាច ទំនាក់ទំនងសេដ្ឋកិច្ច ភាពច្របូកច្របល់ជាតិសាសន៍ និងឥទ្ធិពលនៃចក្រភពក្នុងប្រវត្តិសាស្ត្រ ផងដែរ។

៥.២.៥. ជម្លោះមនោគមន៍វិជ្ជា

នៅក្នុងកម្រិតណាមួយនោះ មនោគមវិជ្ជាប្រៀបបានដូចជាសាសនាដែរ៖ វាជានិមិត្តរូបនិងបណ្តាលអោយជម្លោះរវាងក្រុមនិងរដ្ឋនានារីករាលដាលកាន់តែធំ និងញឹកញាប់ជាងការដែលវាបង្កអោយជម្លោះផ្ទុះឡើង។ មនោគមវិជ្ជាមានមូលដ្ឋានគ្រឹះនៃគុណតម្លៃស្នូលនិងសច្ចៈភាពជាច់ខាត ទន់ខ្សោយជាងសាសនាបន្តិច ដូច្នេះពួកគេបង្កបញ្ហាតិចតួចសម្រាប់ប្រព័ន្ធអន្តរជាតិ។

ចំពោះអ្នកប្រាកដនិយម ភាពខុសគ្នាខាងមនោគមវិជ្ជាក្នុងចំណោមរដ្ឋមិនមានបញ្ហាច្រើនទេ ព្រោះសមាជិកទាំងអស់នៃប្រព័ន្ធអន្តរជាតិបន្តស្វែងរកផលប្រយោជន៍ជាតិរបស់គេ ក្នុងបរិបទនៃសម្ព័ន្ធភាពដែលប្រែប្រួលឿនរហ័ស។ ជាឧទាហរណ៍ សង្គ្រាមត្រជាក់គឺជាការតស៊ូ ឬ ការប្រកួតប្រជែងខាងមនោគមវិជ្ជាសកល រវាងលទ្ធិប្រជាធិបតេយ្យមូលធននិយម និងលទ្ធិកុម្មុយនិស្ត។ ប៉ុន្តែ សម្ព័ន្ធភាព និងការប្រកួតប្រជែងផ្នែកយោធា នៅក្នុងការប្រកួតប្រជែងនោះពេលខ្លះត្រូវបានផ្តាច់ចេញពីកត្តាមនោគមវិជ្ជា។ មហាយក្សកុម្មុយនិស្តទាំងពីរ គឺ សហភាពសូវៀត និងប្រទេសចិន មិននៅជាមួយគ្នាយូរទេ។ ប្រទេសឥណ្ឌា ដែលជាប្រទេសប្រជាធិបតេយ្យនិងមូលធននិយមបានជ្រើសរើសមិនចងសម្ព័ន្ធភាពជាមួយសហរដ្ឋអាមេរិក។ ហើយសូម្បីតែប្រទេសមហាអំណាចជាគូប្រជែងទាំងពីរក៏បានចាត់ចែងរស់នៅដោយអនុលោមតាម ច្បាប់នៃប្រព័ន្ធអន្តរជាតិភាគច្រើន (ឧទាហរណ៍ ប្រទេសទាំងពីរនៅតែជាសមាជិកអង្គការសហប្រជាជាតិ)។

ក្នុងរយៈពេលវែងឆ្ងាយ សូម្បីតែប្រទេសដែលបានឆ្លងកាត់បដិវត្តន៍ដែលផ្អែកលើមនោគមវិជ្ជាខ្លាំងក៏ទំនងជាបាត់បង់នូវស្មារតីក្លៀវក្លាខាងមនោគមវិជ្ជានិយមរបស់ពួកគេដែរ៖ មិនថាលទ្ធិអ៊ីស្លាមនិយមរបស់អ៊ីរ៉ង់នៅឆ្នាំ ១៩៧៩, មិនថាលទ្ធិកុម្មុយនិស្តម៉ៅនិយមរបស់ចិននៅឆ្នាំ ១៩៤៩, មិនថាលទ្ធិកុម្មុយនិស្តលេនីនរបស់រុស្ស៊ីនៅឆ្នាំ ១៩១៧ ឬសូម្បីតែលទ្ធិប្រជាធិបតេយ្យរបស់សហរដ្ឋអាមេរិកនៅឆ្នាំ ១៧៧៦ ។ ក្នុងករណីនីមួយៗបដិវត្តន៍របស់ពួកគេបានរំពឹងថា ការឡើងកាន់អំណាចរបស់ពួកគេនឹងផ្លាស់ប្តូរគោលនយោបាយការបរទេសរបស់រដ្ឋរបស់ពួកគេយ៉ាងខ្លាំង ពីព្រោះក្នុងករណីនីមួយៗ មនោគមវិជ្ជារបស់ពួកគេមានផលប៉ះពាល់លើទំនាក់ទំនងអន្តរជាតិយ៉ាងជ្រាលជ្រៅ។ ប៉ុន្តែ ក្នុងរយៈពេលពីរបីទសវត្សរ៍ រដ្ឋាភិបាលបដិវត្តន៍នីមួយៗបានងាកទៅរកការស្វែងរកផលប្រយោជន៍ជាតិ ដោយមិនខ្វល់ពីមនោគមវិជ្ជាឡើយ។

ជួនកាល សូម្បីតែការតស៊ូខាងមនោគមវិជ្ជាដែលប្រកាសដោយខ្លួនឯង ក៏មិនមែនជាមនោគមវិជ្ជាពិតប្រាកដដែរ។ នៅប្រទេសអង់ហ្គោឡា ក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ សហរដ្ឋអាមេរិកបានគាំទ្រកងទ័ពឧទ្ធាមដែលហៅថា យូនីតា (UNITA) ប្រឆាំងនឹងរដ្ឋាភិបាលដែលចូលបក្សសម្ព័ន្ធជាមួយសូវៀត ដែលសន្មតថាជាការតស៊ូលទ្ធិប្រជាធិបតេយ្យប្រឆាំងនឹងលទ្ធិម៉ាក្សស៊ីសនិយម។ ជាការពិត ការបែងចែកមនោគមវិជ្ជាមិនមានលក្ខណៈច្បាស់លាស់ឡើយ ពោលគឺត្រូវបានធ្វើឡើងតាមអំពើចិត្ត។ រដ្ឋាភិបាលបានប្រើប្រាស់រ៉េហាសាស្ត្រម៉ាក្សនិយមដើម្បីទាក់ទាញអោយសហភាពសូវៀតផ្តល់ជំនួយដល់ខ្លួន (គោលនយោបាយមួយ ដែលពួកគេបានផ្លាស់ប្តូរវិញ ភ្លាមៗតែម្តង នៅពេលដែលលែងមានជំនួយរបស់សូវៀត)។ ពួកឧទ្ធាមដែលបានប្រើរ៉េហាសាស្ត្របែបប្រជាធិបតេយ្យដើម្បីទទួលបានការគាំទ្រពីសហរដ្ឋអាមេរិកមុននេះ បានទទួលការគាំទ្រពីប្រទេសចិន ហើយបានបញ្ចេញនូវរ៉េហាសាស្ត្របែបម៉ៅនិយមវិញម្តង។ នៅពេលដែលរដ្ឋាភិបាលទទួលបានជោគជ័យក្នុងការបោះឆ្នោតដែលឧបត្ថម្ភ ដោយអង្គការសហប្រជាជាតិ ក្រុមឧទ្ធាមយូនីតា«ប្រជាធិបតេយ្យនិយម» បានបដិសេធមិនទទួលស្គាល់លទ្ធផលបោះឆ្នោត ហើយបានបន្តការប្រយុទ្ធទៀត។ ជម្លោះនេះដែល

ចុងក្រោយ បានបញ្ចប់ក្នុងឆ្នាំ ២០០២ ពិតជាមិនមានអ្វីពាក់ព័ន្ធនឹងមនោគមវិជ្ជានោះទេ។ វាគឺជាការតស៊ូដណ្តើមអំណាចរវាងក្រុមប្រដាប់អាវុធដែលផ្អែកលើជាតិសាសន៍ចំនួនពីរបក្ស ដែលប្រយុទ្ធគ្នាដើម្បីដណ្តើមគ្រប់គ្រងធនធានប្រេង ត្បូងពេជ្រ និងទ្រព្យសម្បត្តិផ្សេងទៀតរបស់អង់ហ្គោឡា។

រូបថត ទិដ្ឋភាពខុសគ្នារវាងអាមេរិកសេរីនិងកូរ៉ែខាងជើងផ្តាច់ការ

ការបែងចែកមនោគមវិជ្ជា

មនោគមវិជ្ជាដើរតួនាទីមានកម្រិត ក្នុងជម្លោះអន្តរជាតិភាគច្រើន។ បន្ទាប់ពីបដិវត្តន៍ មនោគមវិជ្ជាដូចជា លទ្ធិម៉ាក្សអាចប៉ះពាល់ដល់គោលនយោបាយការបរទេស ប៉ុន្តែក្នុងរយៈពេលប៉ុន្មានទសវត្សរ៍បន្ទាប់ ប្រទេសដូចជាចិនឬសហភាពសូវៀត ជាធម្មតា វិលត្រឡប់ទៅរកគោលនយោបាយការបរទេសវិញ ដោយផ្អែកលើផលប្រយោជន៍ជាតិច្រើនជាងមនោគមវិជ្ជា។ យ៉ាងណាក៏ដោយ ការប៉ះទង្គិចខាងមនោគមវិជ្ជានៅតែកើតមានឡើង ដូចជារវាងសហរដ្ឋអាមេរិកដែលស្រឡាញ់សេរីភាព និងប្រទេសកូរ៉េខាងជើងផ្តាច់ការនិយម។ នៅទីនេះ ស្ទីលផ្លែកៗគ្នានៃប្រទេសទាំងពីរត្រូវបានបង្ហាញយ៉ាងច្បាស់ក្រឡែត នៅពេលដែលការប្រគុំតន្ត្រីញូវយ៉កសំដែងការប្រគុំតន្ត្រីដ៏កម្រមួយ នៅប្រទេសកូរ៉េខាងជើង ឆ្នាំ ២០០៨។

ក្នុងរយៈពេលខ្លី បដិវត្តន៍*ពិតជា*ផ្លាស់ប្តូរទំនាក់ទំនងអន្តរជាតិមែន (វាធ្វើអោយឱកាសផ្ទុះសង្គ្រាមកាន់តែខ្ពស់) ប៉ុន្តែ មនោគមវិជ្ជាមិនមែនជាបុព្វហេតុនាំអោយផ្ទុះសង្គ្រាមទេ។ ផ្ទុយទៅវិញ ការផ្លាស់ប្តូររដ្ឋាភិបាលភ្លាមៗអាចផ្លាស់ប្តូរសម្ព័ន្ធភាពនិងផ្លាស់ប្តូរតុល្យភាពអំណាច។ ជាមួយនឹងការគណនាអំណាចត្រូវបានកែសម្រួលដោយភាគីទាំងអស់ ភាគីទាំងពីរដោយនឹងគណនាខុសឬបំផ្លើសការគំរាមកំហែងទៅលើភាគីទាំងសងខាង។ ប៉ុន្តែ មនោគមវិជ្ជាខ្លួនឯងដើរតួនាទីតិចតួច នៅក្នុងទំនោរផ្ទុះសង្គ្រាមក្រោយសម័យបដិវត្តន៍នេះ៖ បដិវត្តន៍កម្រត្រូវបានគេនាំចេញទៅកាន់រដ្ឋផ្សេងទៀតណាស់។

៥.៣. ជម្លោះផលប្រយោជន៍

៥.៣ ចូរសង្ខេបជម្លោះទឹកដីអន្តរជាតិពីរផ្សេងគ្នា និងវាយតម្លៃពីលទ្ធភាពនៃការដោះស្រាយដោយសន្តិវិធី។

ប្រសិនបើជម្លោះនៃគំនិតឬទស្សនៈមិនអាចគ្រប់គ្រងបាន ដោយសារតែកត្តាចិត្តសាស្ត្រនិងអារម្មណ៍ នោះជម្លោះដណ្តើមផលប្រយោជន៍ខាងសម្ភារៈ អាចមានភាពងាយស្រួលជាងក្នុងការដោះស្រាយ ដោយផ្អែកលើគោលការណ៍បដិការ។ តាមទ្រឹស្តី ប្រសិនបើមានការគាបសង្កត់ឬអានុភាពវិជ្ជមានគ្រប់គ្រាន់ (ការបង់ប្រាក់ឬផ្តល់រង្វាន់លើកទឹកចិត្តក្នុងទម្រង់ណាមួយ) រដ្ឋណាក៏ដោយក៏គួរតែយល់ព្រមតាមលក្ខខណ្ឌរបស់រដ្ឋមួយផ្សេងទៀត លើបញ្ហាជម្លោះ។

៥.៣.១. ទិវាធនធឹកដី

ក្នុងចំណោមជម្លោះអន្តរជាតិដែលទាក់ទងនឹង«ផលប្រយោជន៍»រូបី ផលប្រយោជន៍ពាក់ព័ន្ធនឹងទឹកដីមានសារៈសំខាន់ពិសេស ដោយសារតែលក្ខណៈនៃទឹកដីរបស់រដ្ឋ (សូមមើលភាពអនាធិបតេយ្យ និងអធិបតេយ្យភាព នៅក្នុងមេរៀនទី ២)។ ជម្លោះដណ្តើមគ្រប់គ្រងទឹកដីពិតជាមានពីរប្រភេទ៖ ជម្លោះទឹកដី (ថាតើត្រូវកំណត់ព្រំដែននៅកន្លែងណា) និងជម្លោះដណ្តើមគ្រប់គ្រងរដ្ឋទាំងមូល នៅក្នុងរង្វង់ព្រំដែនដែលមានស្រាប់ (ពិភាក្សានៅផ្នែកបន្ទាប់ ក្រោមចំណងជើងរង **ការដណ្តើមគ្រប់គ្រងរដ្ឋាភិបាល**)។ ដំបូង សាកល្បងពិចារណា

អំពីភាពខុសគ្នាអំពីទីតាំងដែលព្រំប្រទល់រវាងរដ្ឋទាំងពីរគួរតែត្រូវបានកំណត់ ពោលគឺ ថាតើអ្នកណាគ្រប់គ្រងដីដែលមានជម្លោះ។

ដោយសាររដ្ឋនានាអោយតម្លៃលើទឹកដីកំណើតរបស់ខ្លួន ដោយសុខចិត្តលះបង់គ្រប់បែបយ៉ាង ដើម្បីមាតុភូមិនោះ ជម្លោះព្រំដែនស្ថិតក្នុងចំណោមជម្លោះដែលពិបាកដោះស្រាយ និងបង្កការរំខានខ្លាំងបំផុតនៅក្នុងទំនាក់ទំនងអន្តរជាតិ។ រដ្ឋកម្រលះបង់ទឹកដីខ្លួនជាថ្នូរនឹងប្រាក់ឬរង្វាន់វិជ្ជមានផ្សេងទៀតណាស់។ ហើយក៏មិនដែលរដ្ឋណាមួយធាប់ភ្លេចទឹកដី ដែលខ្លួនបាត់បង់ ដោយបង្ខិតបង្ខំនោះដែរ។ ជាឧទាហរណ៍ នៅក្នុងឆ្នាំ ២០០២ មតិសាធារណៈរបស់ជនជាតិបូលីវីបានប្រឆាំងនឹងបំពង់បង្ហូរឧស្ម័នឆ្លងកាត់ប្រទេសឈីលីទៅកាន់សមុទ្រ ដោយសារតែប្រទេសឈីលីបានដណ្តើមយកឆ្នេរសមុទ្រពីបូលីវីក្នុងឆ្នាំ ១៨៧៩។ គោលដៅនៃការដណ្តើមយកមកវិញនូវទឹកដី ដែលបាត់បង់ទៅរដ្ឋមួយទៀត ត្រូវបានគេហៅថា គោលនយោបាយទាមទារទឹកដីនិយម(irredentism)។ ទម្រង់នៃជាតិនិយមនេះច្រើនតែបណ្តាលអោយមានជម្លោះអន្តររដ្ឋធ្ងន់ធ្ងរ ដោយផ្ទាល់។ ដោយសារការផ្សារភ្ជាប់គ្នាជាមួយនឹងបូរណភាពនៃរដ្ឋ ទឹកដីត្រូវបានគេវាយតម្លៃលើសពីតម្លៃសេដ្ឋកិច្ចឬយុទ្ធសាស្ត្រណាមួយ នៃទឹកដីទាំងនោះ។ ជាឧទាហរណ៍ បន្ទាប់ពីប្រទេសអ៊ីស្រាអែលនិងប្រទេសអេហ្ស៊ីបបានសម្រេចសន្តិភាពនឹងគ្នា នៅឆ្នាំ ១៩៧៨ ពួកគេត្រូវចំណាយពេលមួយទសវត្សរ៍ដើម្បីដោះស្រាយជម្លោះព្រំដែននៅតាបា(Taba) ដែលជាផ្ទៃដីតូចមួយនៃឆ្នេរខ្សាច់ ដែលអ្នកអភិវឌ្ឍន៍អចលទ្រព្យអ៊ីស្រាអែលបានសាងសង់សណ្ឋាគារមួយហួសឆ្លងកាត់ព្រំដែនចាស់បន្តិច។ ទីបំផុត រដ្ឋទាំងពីរបានដាក់បញ្ហានេះសម្រាប់អាជ្ញាកណ្តាលសម្រេច ហើយចុងបញ្ចប់អេហ្ស៊ីបបានក្លាយម្ចាស់ដីនោះ។ សម្រាប់អេហ្ស៊ីប ការដណ្តើមយកទឹកដីគ្រប់មកវិញមិនអោយបាត់បង់សូម្បីមួយមីលីម៉ែត្រគឺជាបញ្ហាកិត្តិយសជាតិនិងជានិមិត្តរូបនៃអធិបតេយ្យភាព និងបូរណភាពទឹកដី ដែលកំណត់ភាពជារដ្ឋរបស់អេហ្ស៊ីប។

តម្លៃដែលរដ្ឋអោយទៅលើទឹកដីកំណើតរបស់ខ្លួន ហាក់បីដូចជាមិនមានការថយចុះ បើទោះបីជាមានការថយចុះជាក់ស្តែងនៃតម្លៃនៃទឹកដី ដំណាលពេលដែលបច្ចេកវិទ្យាបានអភិវឌ្ឍក៏ដោយ។ តាមប្រវត្តិសាស្ត្រទឹកដី គឺជាមូលដ្ឋាននៃផលិតកម្មសេដ្ឋកិច្ច (កសិកម្ម និងការទាញយកវត្ថុធាតុដើម)។ ការឈ្នះនិងចាញ់សង្គ្រាមមានន័យស្មើនឹងការទទួលបាន ឬ បាត់បង់ទឹកដី, ដែលមានន័យស្មើនឹងការបង្កើន ឬ ការបន្ថយទ្រព្យសម្បត្តិរដ្ឋ។ យ៉ាងណាក៏ដោយ សព្វថ្ងៃនេះ ទ្រព្យសម្បត្តិរុងរឿងច្រើនតែបានមកពីពាណិជ្ជកម្ម និងបច្ចេកវិទ្យាជាងពីវិស័យកសិកម្ម។ មែនទែនទៅ ថ្លៃចំណាយលើជម្លោះទឹកដីភាគច្រើនហាក់ដូចជាខ្ពស់ជាងផលចំណេញសេដ្ឋកិច្ច ដែលទឹកដីជម្លោះនោះអាចនឹងផ្តល់អោយ។ ទោះយ៉ាងណាក៏ដោយ ករណីលើកលែងអាចមានផងដែរ ដូចជា ការចាប់យកតំបន់ដីកយកវ៉ែពេជ្រ ក្នុងបណ្តាប្រទេសអាហ្វ្រិកជាច្រើន ដោយក្រុមឧទ្ទាមដែលប្រើប្រាស់ប្រាក់ចំណូលលក់ពេជ្រដើម្បីធ្វើហិរញ្ញប្បទានសង្គ្រាម។ ក្នុងឆ្នាំ ២០០២ រដ្ឋចំនួន ៤០ បានបង្កើតកម្មវិធីនៃវិញ្ញាបនប័ត្ររបស់អង្គការសហប្រជាជាតិ សម្រាប់ពេជ្រស្របច្បាប់ ដោយព្យាយាមបិទខ្ទប់«ពេជ្រជម្លោះ» មិនអោយដួញដូរក្នុងទីផ្សារអន្តរជាតិ។ សព្វថ្ងៃនេះ មានប្រទេសជាង ៨០ ចូលរួមក្នុងកម្មវិធីនោះដែលគេស្គាល់ថាជាដំណើរការគីមប៊ឺលី (Kimberley)។

ការបំបែករដ្ឋ

ការតស៊ូដោយខេត្តណាមួយឬតំបន់ណាមួយ ក្នុងកិច្ចប្រឹងប្រែងបំបែកចេញពីរដ្ឋដែលមានស្រាប់ គឺជាប្រភេទជម្លោះពិសេសលើព្រំដែន មិនមែនជាព្រំដែនរវាងរដ្ឋដែលមានស្រាប់ទាំងពីរនោះទេ ប៉ុន្តែ ជាការខិតខំ

ប្រឹងប្រែង ដើម្បីគូរព្រំដែនអន្តរជាតិជុំវិញរដ្ឋថ្មីមួយ។ ចលនាផ្តាច់ខ្លួនរាប់សិបផ្សេងមាននៅជុំវិញពិភពលោក ដែលមានទំហំនិងប្រសិទ្ធភាពនយោបាយកម្រិតផ្សេងៗគ្នា ប៉ុន្តែ ពួកគេអាចទទួលបានជោគជ័យក្នុងការបំបែកខ្លួនដោយកម្រ។ រដ្ឋដែលមានស្រាប់តែងតែព្យាយាមរក្សាតំបន់ដែលកំពុងមានបញ្ហា។ ជាឧទាហរណ៍ ក្នុងទស្សវត្សរ៍ឆ្នាំ ១៩៩០ ជនជាតិអាល់បានីដែលជាប្រជាជនភាគច្រើននៃខេត្តកូសូវ៉ូ របស់សែប៊ីបានធ្វើសង្គ្រាមដើម្បីបំបែកចេញពីប្រទេសសែប៊ី។ អន្តរាគមន៍របស់អង្គការណាតូ រួមទាំងការទម្លាក់គ្រាប់បែកជ្រុំជាបន្តបន្ទាប់លើប្រទេសសែប៊ី (ទង្វើមិនត្រូវបានអនុម័តដោយអង្គការសហប្រជាជាតិ) បាននាំទៅដល់ការដកកងទ័ពរបស់ប្រទេសសែប៊ីចេញពីតំបន់កូសូវ៉ូ និងការជំនួសដោយកងរក្សាសន្តិភាពអឺរ៉ុប និងអាមេរិក ដែលបានឈរជើងនៅទីនោះ តាំងពីពេលនោះមក។ ប្រជាជនកូសូវ៉ូភាគច្រើនចង់បំបែកខ្លួន និងក្លាយជារដ្ឋដែលមានការទទួលស្គាល់ជាអន្តរជាតិ ប៉ុន្តែជនជាតិសែប៊ីអះអាងថា ខេត្តកូសូវ៉ូ ជាប្រវត្តិសាស្ត្រ និងបច្ចុប្បន្នស្ថិតក្រោមអធិបតេយ្យភាពរបស់សែប៊ី។ ខណៈពេលដែលអង្គការសហប្រជាជាតិ និងប្រទេសមហាអំណាចបានចរចាអំពីអនាគតរបស់កូសូវ៉ូ ដោយប្រទេសរុស្ស៊ីទទូចថា មិនមានការសន្យាផ្តល់ឯករាជ្យនោះទេ *កូសូវ៉ារ* (ជនជាតិកូសូវ៉ូ)បានយកបញ្ហាគ្រប់គ្រងក្នុងកណ្តាប់ដៃខ្លួនផ្ទាល់។ នៅឆ្នាំ២០០៨ កូសូវ៉ូ បានប្រកាសឯករាជ្យដោយគ្មានការយល់ព្រមពីអង្គការសហប្រជាជាតិ។ ប្រទេសជាច្រើន រួមទាំងសហរដ្ឋអាមេរិក និងរដ្ឋធំបំផុតនៃសហភាពអឺរ៉ុប(EU) បានទទួលស្គាល់ឯករាជ្យភាពរបស់កូសូវ៉ូ ធ្វើអោយសែប៊ី រុស្ស៊ី និងចិនខឹងសម្បារជាខ្លាំង។ នៅក្នុងឆ្នាំ ២០១១ ស៊ូដង់ខាងត្បូងទទួលបានឯករាជ្យដោយជោគជ័យ ដោយមានសមាជិកភាពនៅក្នុងអង្គការសហប្រជាជាតិ និងការគាំទ្រពីប្រទេសស៊ូដង់។

សង្គ្រាមបំបែករដ្ឋអាចមានទំហំធំ និងអាចបណ្តាលអោយមនុស្សស្លាប់ច្រើន ហើយវាអាចរាលដាលឆ្លងព្រំដែនអន្តរជាតិ ឬអូសទាញប្រទេសផ្សេងៗអោយធ្លាក់ចូលក្នុងអន្លង់សង្គ្រាម បានយ៉ាងងាយ។ ការរីករាលដាលនេះទំនងជាកើតមានកាន់តែរហ័ស ប្រសិនបើសមាជិកនៃក្រុមជាតិសាសន៍ឬក្រុមសាសនាមួយរស់នៅរាយប៉ាយនៅសង្ហាងព្រំដែន ដែលមានក្រុមភាគច្រើននៅក្នុងរដ្ឋមួយ និងក្រុមភាគច្រើននៅក្នុងតំបន់ជិតខាងណាមួយនៃរដ្ឋមួយផ្សេងទៀត ប៉ុន្តែជាក្រុមភាគតិច បើគិតក្នុងកម្រិតរដ្ឋទាំងមូល។ នៅក្នុងករណីកូសូវ៉ូ ជនជាតិអាល់បានីមូស្លីមភាគច្រើននៅប្រទេសអាល់បានីនិងនៅខេត្តកូសូវ៉ូ(ក្នុងប្រទេសសែប៊ី) ប៉ុន្តែជាក្រុមជនជាតិភាគតិច នៅក្នុងប្រទេសសែប៊ីទាំងមូល។ គំរូដូចគ្នានេះកើតឡើង នៅករណីជម្លោះបូស្នៀ-សែប៊ី ម៉ុលដាវី-រុស្ស៊ី និងឥណ្ឌា-ប៉ាគីស្តាន។ ក្នុងករណីខ្លះ ពួកធ្វើអបគមន៍ចង់បញ្ចូលទឹកដីរបស់ខ្លួនជាមួយរដ្ឋជិតខាង ដែលស្មើនឹងការគូរព្រំដែនអន្តរជាតិឡើងវិញ។ បទដ្ឋានអន្តរជាតិមិនឯកភាពនឹងលទ្ធផលបែបនេះទេ។

រូបថត អ្នកស្រុកបាសេឡូណាបោះឆ្នោតប្រជាមតិគាំទ្រឯករាជ្យខ្លួន

តើខ្ញុំគួរនៅតទៀត ឬគួរទៅ?

កិច្ចខិតខំប្រឹងប្រែងដោយតំបន់មួយដើម្បីបំបែកចេញពីរដ្ឋ គឺជាប្រភពដ៏ញឹកញាប់នៃជម្លោះអន្តរជាតិ ប៉ុន្តែបទដ្ឋានអន្តរជាតិជាទូទៅចាត់ទុកជម្លោះបែបនេះជាបញ្ហាផ្ទៃក្នុងរបស់រដ្ឋ លុះត្រាតែជម្លោះនោះហៀរចេញពីព្រំដែន។ នៅទីនេះ អ្នកតស៊ូមតិគាំទ្រឯករាជ្យធ្វើបាតុកម្មនៅទីក្រុងបាសេឡូណា ក្នុងតំបន់កាតាឡូញៀ (Catalonia)នៃប្រទេសអេស្ប៉ាញ ដែលបានបោះឆ្នោតប្រកាសជារដ្ឋឯករាជ្យនៅក្នុងប្រជាមតិឆ្នាំ ២០១៧។ អេស្ប៉ាញបានបដិសេធមិនទទួលស្គាល់ការទាមទារឯករាជ្យរបស់កាតាឡូញៀ ដោយប្រកាសថា ប្រជាមតិនោះខុសច្បាប់។

បទដ្ឋានអន្តរជាតិដ៏រឹងមាំនៃអធិបតេយ្យភាពនិងបូរណភាពទឹកដីចាត់ទុកចលនាអបគមន៍ជាបញ្ហាក្នុងស្រុកដែលបង្កការព្រួយបារម្ភតិចតួចចំពោះរដ្ឋផ្សេងទៀត។ គោលការណ៍ទូទៅហាក់ដូចជាចែងយ៉ាងដូចនេះ៖ «យើងក្នុងនាមជារដ្ឋដែលមានស្រាប់ទាំងអស់ មានបញ្ហាក្នុងស្រុករបស់យើងផ្ទាល់ និងក្រុមឬតំបន់ដែលមិនពេញចិត្ត ដូច្នេះយើងត្រូវតែរួមគ្នាការពារអធិបតេយ្យភាព និងបូរណភាពទឹកដីរៀងៗខ្លួន»។ ដូច្នេះ ប្រទេសរុស្សី និងប្រទេសចិនបានប្រឆាំងនឹងការផ្តាច់ខ្លួនរបស់កូសូវ៉ូចេញពីប្រទេសស៊ែប៊ី ដោយសារតែការប្រៀបប្រដូចទៅនឹងករណីឆេចនៀ(រុស្សុី) និងតៃវ៉ាន់(ចិន)។

ទោះយ៉ាងណាគោលការណ៍នេះមានដែនកំណត់របស់វា។ នៅខែសីហា ឆ្នាំ ២០០៨ បន្ទាប់ពីការប្រយុទ្ធគ្នាបានផ្ទុះឡើងរវាងយោធាហ្សកហ្ស៊ីនិងខេត្តហ្សកហ្ស៊ី នៃអូសេធៀ(Ossetia)ខាងត្បូង ប្រទេសរុស្សីបានធ្វើអន្តរាគមន៍លើផ្នែកយោធា ក្នុងនាមជា អូសេធៀខាងត្បូង និងអាប់ខាហ្សៀ (Abkhazia) ដែលបណ្តាលអោយមានសង្គ្រាមរយៈពេលខ្លីរវាងរុស្សុីនិងហ្សកហ្ស៊ី។ បន្ទាប់មក ប្រទេសរុស្សីបានទទួលស្គាល់ឯករាជ្យភាពរបស់ខេត្តទាំងពីររបស់ប្រទេសហ្សកហ្ស៊ី ជាទង្វើមួយដែលត្រូវបានបរិហារដោយសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប និងមិនត្រូវបានទទួលយកដោយអង្គការសហប្រជាជាតិឡើយ។

បញ្ហាព្រំដែនដ៏រញ៉េរញ៉ៃអាចកើតឡើង នៅពេលដែលរដ្ឋចម្រុះជាតិសាសន៍បំបែកជាបំណែកតូចៗបន្តទៀត។ ក្នុងករណីបែបនេះ ព្រំដែនដែលធ្លាប់ជាបញ្ហាផ្ទៃក្នុងនឹងក្លាយទៅជាបញ្ហាអន្តរជាតិ។ ដោយសារព្រំដែនទាំងនេះថ្មីពេក ពួកគេអាចងាយនឹងរងការប្រឈមមុខពីការតវ៉ាផ្សេងៗ។ នៅក្នុងអតីតយូហ្គោស្លាវី ក្រុមជាតិសាសន៍ទាំងឡាយបានរស់នៅឡូកឡំនិងរៀបការឆ្លងសាសន៍នឹងគ្នា ដោយបន្សល់ទុកនូវប្រជាជនកូនកាត់ នៅក្នុងភាគច្រើននៃសាធារណរដ្ឋយូហ្គោស្លាវី។ នៅពេលដែលប្រទេសយូហ្គោស្លាវីបានបែកបាក់នៅឆ្នាំ ១៩៩១-១៩៩២ សាធារណរដ្ឋមួយចំនួនបានប្រកាសឯករាជ្យរបស់ខ្លួន ដោយបង្កើតជារដ្ឋដាច់ដោយឡែក។ រដ្ឋពីរក្នុងចំណោមនោះ គឺប្រទេសក្រូអាត និងប្រទេសបូស្នៀ មានក្រុមជនជាតិភាគតិចជាជនជាតិស៊ែប៊ី។ ប្រទេសស៊ែប៊ីបានដណ្តើមការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនៃតំបន់សំខាន់ៗរបស់រដ្ឋថ្មី ក្រូអាត និងបូស្នៀនោះ ដែលមានសហគមន៍ស៊ែប៊ី ឬផ្សារភ្ជាប់ប្រជាជនស៊ែប៊ីទាំងនោះ ពីភូមិសាស្ត្រមួយទៅភូមិសាស្ត្រមួយទៀត។ ប្រជាជនដែលមិនមែនជាជនជាតិស៊ែប៊ីនៅក្នុងតំបន់ទាំងនេះត្រូវបានបណ្តេញចេញ ឬរងការសម្លាប់រង្គាល ដែលគេហៅថា **ការបន្សុទ្ធជាតិសាសន៍** (ethnic cleansing)។ បន្ទាប់មក នៅពេល ដែលប្រទេសក្រូអាតបានដណ្តើមយកទឹកដីភាគច្រើនរបស់ខ្លួនមកវិញ ក្នុងឆ្នាំ ១៩៩៥ ប្រជាជនស៊ែប៊ីបានគេចខ្លួនចេញ។ ជាតិនិយមដែលផ្អែកលើជាតិសាសន៍ ដែលត្រូវបានអ្នកនយោបាយឱកាសនិយមឆ្លៀតគេងចំណេញបានបង្ហាញថាមានសន្ទុះខ្លាំងជាង ការអត់ឱនពហុជាតិសាសន៍ ទាំងនៅក្នុងប្រទេសស៊ែប៊ី និងក្រូអាត។

ទោះយ៉ាងណាក៏ដោយ ការបំបែករដ្ឋមិនចាំបាច់ប្រើប្រាស់អំពើហិង្សានោះទេ។ ប្រទេសស៊ែប៊ីបានបំបែកខ្លួន ដោយសន្តិវិធី ចេញពីប្រទេសម៉ុងតេណេហ្គ្រោ (រដ្ឋមួយទៀតនៃអតីតសាធារណរដ្ឋយូហ្គោស្លាវី) នៅក្នុងឆ្នាំ ២០០៦។ អតីតប្រទេសឆេកូស្លូវ៉ាគីបានបំបែកទៅជាសាធារណរដ្ឋឆេក និងប្រទេសស្លូវ៉ាគីប្រកបដោយបរិយាកាសសហប្រតិបត្តិការល្អ។ ហើយការបែកបាក់នៃសហភាពសូវៀតមិនបាននាំអោយមានជម្លោះទឹកដីដ៏ហិង្សារវាងសាធារណរដ្ឋនានា នៅក្នុងករណី*ភាគច្រើន* ទោះបីជាក្រុមជាតិសាសន៍រស់នៅរាយប៉ាយឆ្លងកាត់ព្រំដែនអន្តរជាតិថ្មីក៏ដោយ។

បទដ្ឋានប្រឆាំងនឹងការគូសបន្ទាត់ព្រំដែនឡើងវិញដោយបង្ខំមិនត្រូវបានអនុវត្ត ចំពោះករណីនៃការសោយរបបអាណានិគមនោះទេ។ បទដ្ឋានអន្តរជាតិការពារត្រឹមតែបូរណភាពទឹកដីនៃរដ្ឋដែលមានស្រាប់និងត្រូវបានទទួលស្គាល់រួចស្រាប់តែប៉ុណ្ណោះ។ ដែនដីអាណានិគម និងកម្មសិទ្ធិទឹកដីផ្សេងទៀត ក្នុងប្រវត្តិសាស្ត្រមានតម្លៃត្រឹមតែជាទ្រព្យសម្បត្តិ ដែលអាចត្រូវគេយកឈ្នះ បាត់បង់ លក់ ឬ ជួញដូរ ក្នុងកិច្ចព្រមព្រៀងនយោបាយ និងសង្គ្រាមតែប៉ុណ្ណោះ។ ការផ្ទេរទីក្រុងហុងកុងពីអង់គ្លេសទៅការគ្រប់គ្រងរបស់ប្រទេសចិនក្នុងឆ្នាំ ១៩៩៧ ក៏បង្ហាញពីរបៀបដែលទឹកដីអាណានិគមមិនអាចប្រើប្រាស់បាន (តាមទស្សនៈរបស់ចក្រភពអង់គ្លេស) ខណៈដែលទឹកដីកំណើតមានលក្ខណៈពិសិដ្ឋ (តាមទស្សនៈរបស់ប្រទេសចិន)។ ទស្សនៈរបស់អ្នកស្រុកហុងកុងហាក់មានទម្ងន់ច្រើន ចំពោះទស្សនៈទាំងពីរនេះទេ។

កាន់តែខ្លាំងឡើង ស្ថិយភាពសម្រាប់តំបន់មួយបានក្លាយជាការសម្របសម្រួលជាក់ស្តែងរវាងការធ្វើអប្បគមន៍និងការគ្រប់គ្រងពេញលេញ ដោយរដ្ឋាភិបាលកណ្តាល។ ក្នុងឆ្នាំ ២០០៥ ដោយត្រូវបានជំរុញមួយផ្នែកដោយរលកយក្សស៊ូណាមិដ៏ខ្ទេចខ្ទាំ កាលពីឆ្នាំមុន ក្រុមអ្នកបំបែករដ្ឋនៅខេត្តអាឆេ(Aceh)នៃប្រទេសឥណ្ឌូនេស៊ីបានត្រូវរំសាយ បោះបង់ការទាមទារឯករាជ្យភាព ហើយផ្ទុយទៅវិញ បានចូលរួមការបោះឆ្នោតថ្នាក់តំបន់ ក្នុងឆ្នាំ ២០០៦។ រដ្ឋាភិបាលឥណ្ឌូនេស៊ីបានដកកងទ័ពរបស់ខ្លួន ចំនួន ២៤,០០០ នាក់ ចេញពីខេត្តអាឆេ ហើយផ្តល់អោយខេត្តនេះនូវស្ថិយភាពគ្រប់គ្រងក្នុងកម្រិតមួយ ជាមួយនឹង ៧០ ភាគរយនៃធនធានប្រេង ឧស្ម័ន និងរ៉ែផ្សេងទៀត ដែលរកបាននៅទីនោះ។

ព្រំដែនអន្តរដ្ឋ

ជម្លោះព្រំដែនរវាងរដ្ឋដែលមានស្រាប់ ត្រូវបានសហគមន៍អន្តរជាតិចាប់អារម្មណ៍កាន់តែខ្លាំងឡើង ប៉ុន្តែ វាជារឿងធម្មតាជាងជម្លោះអបគមន៍។ ដោយសារតែបទដ្ឋាននៃបូរណភាពទឹកដី ជម្លោះព្រំដែនសំខាន់ៗមួយចំនួន នៅតែស្ថិតក្នុងចំណោមរដ្ឋ ដែលបានបង្កើតឡើងជាយូរមកហើយ។ នៅពេលណាមួយ បំណែកដ៏ធំនៃទឹកដីត្រូវបានផ្លាស់ប្តូររវាងរដ្ឋមួយទៅរដ្ឋមួយទៀត ដោយសារចុងបិកមួយខ្វាក (នៅលើសន្ធិសញ្ញាសន្តិភាព ឬកិច្ចសន្យារួមបញ្ចូល)។ ទោះជាយ៉ាងណាក៏ដោយ ប្រភេទនៃការកំណត់ព្រំដែនរដ្ឋឡើងវិញទាំងស្រុងបែបនេះ មិនបានកើតឡើង ក្នុងចំណោមរដ្ឋដែលបានបង្កើតឡើងស្រាប់ អស់រយៈពេល ៧០ ឆ្នាំមកហើយ។ ចាប់តាំងពីចុងបញ្ចប់នៃសង្គ្រាមលោកលើកទី ២ មានតែទឹកដីតិចតួចប៉ុណ្ណោះ ដែលបានផ្លាស់ប្តូរម្ចាស់កម្មសិទ្ធិរវាងរដ្ឋដែលមានស្រាប់នានា តាមរយៈកម្លាំងទ័ព (នេះមិនអនុវត្តចំពោះការបង្កើតរដ្ឋថ្មី និងការបែកខ្ញែកនៃរដ្ឋចាស់ទេ)។ កិច្ចខិតខំប្រឹងប្រែងបែបនេះត្រូវបានព្យាយាមធ្វើឡើង ប៉ុន្តែត្រូវបរាជ័យ។ ជាឧទាហរណ៍ នៅពេលដែលប្រទេសអ៊ីរ៉ាក់វាយលុកប្រទេសអ៊ីរ៉ង់ នៅក្នុងឆ្នាំ ១៩៨០ គោលបំណងមួយគឺដើម្បីគ្រប់គ្រងផ្លូវទឹក ទន្លេហ្សាត់អាល់អារ៉ាប់ (Shatt-al-Arab) (ជាមួយនឹងច្រកចូលទៅកាន់ឈូងសមុទ្រពែក្ស) ដោយសារតែតម្លៃក្នុងវិស័យពាណិជ្ជកម្ម និងយុទ្ធសាស្ត្ររបស់វា។ ប៉ុន្តែ ១០ ឆ្នាំ ក្រោយមក និងបន្ទាប់ពីមានមនុស្សស្លាប់មួយលានមក ព្រំដែនអ៊ីរ៉ង់-អ៊ីរ៉ាក់បានត្រលប់មកសភាពដើមវិញ ដូចមុនពេលជម្លោះបានចាប់ផ្តើម។

ជាងនេះទៅទៀត នៅពេលដែលជម្លោះទឹកដីផ្ទុះឡើងរវាងរដ្ឋដែលមានស្រាប់ ពួកគេ*អាច*ដោះស្រាយដោយសន្តិវិធី ជាពិសេសនៅពេលដែលទឹកដីជម្លោះមានទំហំតូច បើធៀបនឹងរដ្ឋដែលពាក់ព័ន្ធនឹងជម្លោះនោះ។ នៅឆ្នាំ ១៩៩៤ ក្រុមចៅក្រមអាមេរិកឡាទីនបានដោះស្រាយជម្លោះព្រំដែនមួយសតវត្សរ៍រវាងប្រទេស

អាហ្សង់ទីននិងប្រទេសឈីលី លើតំបន់ភ្នំមួយចំនួន ដែលប្រទេសទាំងពីរបានអះអាង។ សេចក្តីសម្រេច ៣ ទល់ ២ បន្ទាប់ពីប្រទេសទាំងបានដាក់វិវាទសម្រាប់មជ្ឈត្តកម្មផ្នែកតុលាការ បានផ្តល់ទឹកដីនោះដល់ប្រទេសអាហ្សង់ទីន និងបានបង្កអោយមានការតវ៉ាពីប្រទេសឈីលី ហើយរហូតដល់មានការឈ្លោះគ្នាបោចសក់រវាងបេក្ខនារីឈីលីនិងអាហ្សង់ទីន ក្នុងការប្រលងបវរកញ្ញាពិភពលោក ពីរខែក្រោយមក។ ប៉ុន្តែ ទោះបីជាអារម្មណ៍តក់ស្លុតខ្លាំងដែលបណ្តាលមកពីការបាត់បង់ទឹកដីក៏ដោយ ប្រទេសអាហ្សង់ទីន និងឈីលីបានដោះស្រាយជម្លោះព្រំដែន ចំនួន ២២ ក្នុងចំណោម ២៤ ដោយសន្តិវិធី បន្ទាប់ពីការស្វែតែផ្ទុះសង្គ្រាម នៅឆ្នាំ ១៩៧៨ លើបណ្តាកោះដែលមានជម្លោះ។

លទ្ធភាពនៃដំណោះស្រាយជម្លោះទឹកដីដោយសន្តិវិធីត្រូវបានគូសបញ្ជាក់ នៅក្នុងឆ្នាំ ២០០៦ ជាមួយនឹងការដកកងទ័ពនីហ្សេរីយ៉ាចេញពីឧបទ្វីបបាកាស្សុី (Bakassi) ដែលអាចសម្បូរដោយធនធានប្រេង ដែលនីហ្សេរីយ៉ាបានប្រគល់ទៅអោយស្ថិតក្រោមអធិបតេយ្យភាពរបស់ប្រទេសកាមេរូន។ ការដោះស្រាយវិវាទ ចាប់តាំងពីសម័យអាណានិគមមក បានធ្វើតាមវឌ្ឍនភាពដ៏ប្រុងប្រយ័ត្នជាងមួយទសវត្សរ៍ តាមរយៈតុលាការពិភពលោក ការសម្រុះសម្រួលផ្ទាល់ខ្លួនរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ នៅពេលដែលនីហ្សេរីយ៉ាដំបូងបានច្រានចោលការសម្រេចរបស់តុលាការ និងការសន្យារបស់ប្រទេសមហាអំណាចខាងក្រៅដើម្បីតាមដានការអនុវត្តកិច្ចព្រមព្រៀង។ ហេតុអ្វីបានជាប្រទេសនីហ្សេរីយ៉ា ដែលជាប្រទេសដែលមានចំនួនប្រជាជនច្រើនជាន់ប្រជាជនកាមេរូនចំនួនប្រាំបួនដង, មានផលិតផលក្នុងស្រុកសរុប(GDP)ច្រើនជាងកាមេរូនចំនួនបីដង និងមានកម្លាំងយោធាខ្លាំងជាង សុខចិត្តលះបង់ទឹកដីដោយស្ម័គ្រចិត្ត? ការធ្វើដូច្នេះហាក់ដូចជាដើរផ្ទុយពីការព្យាករណ៍របស់ទ្រឹស្តីប្រាកដនិយមជាពិសេសនិងគោលការណ៍គ្រប់គ្រងជាទូទៅ។ ទ្រឹស្តីសេរីនិយមអាចនឹងពន្យល់ពីលទ្ធផលនេះបានល្អជាង៖ នីហ្សេរីយ៉ាបានធ្វើសកម្មភាពដើម្បីផលប្រយោជន៍របស់ប្រទេសខ្លួនផ្ទាល់ ពីព្រោះការបង្វែរជម្លោះទៅតុលាការពិភពលោក និងការនាំបើកផ្លូវអោយអង្គការសហប្រជាជាតិជួយក្នុងការអនុវត្ត បាននាំមកនូវប្រភេទនៃស្ថិរភាពដែលត្រូវការជាចាំបាច់សម្រាប់ការវិនិយោគបរទេសដើម្បីអភិវឌ្ឍធនធានធម្មជាតិរបស់នីហ្សេរីយ៉ាផ្ទាល់ ជាពិសេសធនធានប្រេង។

ជម្លោះដ៏ពុំរ៉ៃ

សព្វថ្ងៃនេះ ជម្លោះព្រំដែនអន្តរដ្ឋដែលនៅសេសសល់តិចតួចបង្កើតជាជម្លោះអន្តរជាតិ សំខាន់ៗ។ ក្នុងចំណោមជម្លោះលំបាកបំផុត គឺព្រំដែនរបស់*អ៊ីស្រាអែល*។ បន្ទាត់បទឈប់បាញ់គ្នានៅឆ្នាំ ១៩៤៨ ដែលបណ្តាលមកពីសង្គ្រាមឯករាជ្យរបស់អ៊ីស្រាអែល បានពង្រីកកាន់តែធំ នៅក្នុងសង្គ្រាមឆ្នាំ ១៩៦៧។ ប្រទេសអ៊ីស្រាអែលបានប្រគល់ឧបទ្វីបស៊ីណៃទៅអេហ្ស៊ីបវិញ ប៉ុន្តែ ទឹកដីដែលនៅសេសសល់ដែលបានកាន់កាប់ក្នុងឆ្នាំ ១៩៦៧ (តំបន់វ៉េសប៊ែង ក្បែរប្រទេសហ្សកដានី, ហ្គាហ្សាស្ទ្រីព នៅជិតប្រទេសអេហ្ស៊ីប និងតំបន់ខ្ពង់រាបហ្គោឡានហាយ (Golan Heights) នៃប្រទេសស៊ីរី) នៅតែជាចំណុចកណ្តាលនៃជម្លោះអារ៉ាប់-អ៊ីស្រាអែល។ ជាពិសេស ការសាងសង់លំនៅដ្ឋានជនជាតិជ្វីហ្វដែលកំពុងបន្តរបស់អ៊ីស្រាអែលនៅតំបន់វ៉េសប៊ែង ដែលត្រូវបានប្រឆាំងយ៉ាងដូរចត់ដោយជនជាតិប៉ាឡេស្ទីន និងត្រូវចាត់ទុកថាខុសច្បាប់ដោយតួអង្គអន្តរជាតិភាគច្រើននៅតែជាចំណុចដ៏ចម្រូងចម្រាស។ កិច្ចព្រមព្រៀងអ៊ីស្រាអែល-ប៉ាឡេស្ទីនតាំងពីឆ្នាំ ១៩៩៣ បានព្យាយាមឆ្ពោះទៅរកស្វ័យភាពប៉ាឡេស្ទីន នៅក្នុងផ្នែកខ្លះនៃ តំបន់វ៉េសប៊ែង និងតំបន់ហ្គាហ្សា ហើយការចរចាហាក់ដូចជាឆ្ពោះទៅរកការបង្កើតរដ្ឋប៉ាឡេស្ទីននៅទីនោះ។ ទោះជាយ៉ាងណាក៏ដោយ ការប្រឹងប្រែងនោះបានជាប់គាំង

ទាំងស្រុងនៅពេលចូលដល់សតវត្សរ៍ទី ២១ ទោះបីឆ្នាំ ២០១២ ការដំឡើងហាន:ដោយអង្គការសហប្រជាជាតិ សម្រាប់ប៉ាឡេស្ទីនអោយទៅជា«រដ្ឋ»មិនមែនជាសមាជិកក៏ដោយ ដែលជាកាយវិការនិមិត្តរូបតែប៉ុណ្ណោះ។

ជម្លោះព្រំដែនដ៏ធ្ងន់ធ្ងរមួយទៀត គឺនៅតំបន់កាស្មៀរ ដែលជាចំណុចប្រសព្វនៃប្រទេសបី គឺ ឥណ្ឌា ប៉ាគីស្ថាន និងចិន។ ផ្នែកនៃតំបន់កាស្មៀរ ដែលគ្រប់គ្រងដោយឥណ្ឌា ភាគច្រើនរស់នៅដោយជនមូស្លីម ជាក្រុមជនជាតិដែលជាប្រជាជនភាគច្រើននៅក្នុងប្រទេសប៉ាគីស្ថាន ប៉ុន្តែ ជាជនជាតិភាគតិច នៅក្នុងប្រទេសឥណ្ឌា។ *បន្ទាត់គ្រប់គ្រង*(line of control)មួយបែងចែកខេត្តដែលមានជម្លោះ។ ប្រទេសប៉ាគីស្ថានចោទឥណ្ឌាថា បានគាបសង្កត់ប្រជាជនកាស្មៀរ និងបានរារាំងកិច្ចព្រមព្រៀងអន្តរជាតិមួយដើម្បីសម្រេចអនាគតរបស់តំបន់កាស្មៀរដោយប្រជាមតិដ៏ពេញនិយម។ ប្រទេសឥណ្ឌាចោទប៉ាគីស្ថានថាបានផ្តល់ជំនួយនិងបញ្ជូនពួកវ៉ាឌីកាល់អ៊ីស្លាមនិយមចូលទៅធ្វើការវាយប្រហារនៅតំបន់កាស្មៀរដែលកាន់កាប់ដោយឥណ្ឌា។ ប្រទេសទាំងពីរបានធ្វើសង្គ្រាមពីរដងលើបញ្ហានេះ ហើយស្ទើរតែបានធ្វើម្តងទៀតនៅឆ្នាំ ២០០២ គ្រានោះមានបំពាក់មីស៊ីលនុយក្លេអ៊ែរ។ បទឈប់បាញ់មួយបានសម្រេចឡើងក្នុងឆ្នាំ ២០០៣ ហើយបានបញ្ឈប់ភាគច្រើននៃការប្រយុទ្ធរប៉ះរប៉ោះនៅតាម*ខ្សែបន្ទាត់គ្រប់គ្រង* ទោះបីជាការប៉ះទង្គិចហិង្សានៅតែបន្តកើតឡើងជាពិសេសការប្រយុទ្ធគ្នាដ៏សាហាវបំផុតក្នុងឆ្នាំ ២០១៤។

ក្រាហ្វិក ៥.៦ ជម្លោះដែនកោះ

កោះស្ព្រាតលី ជាឧទាហរណ៍នៃជម្លោះលើទឹកដីនិងធនធានធម្មជាតិជុំវិញកោះ នៅក្នុងសហសម័យ។ ប្រជុំកោះស្ព្រាតលីទាំងអស់ ឬមួយផ្នែក ត្រូវបានទាមទារដោយប្រទេសចិន វៀតណាម ម៉ាឡេស៊ី ប្រ៊ុយណេ ហ្វីលីពីន និងតៃវ៉ាន់។



ជម្លោះដែនដីអន្តរដ្ឋដែលនៅសេសសល់ជាច្រើនទៀតនៅលើពិភពលោក (ហើយ ជារឿយៗ ធ្ងន់ធ្ងរបំផុត) ពាក់ព័ន្ធនឹងការដណ្តើមគ្រប់គ្រងកោះតូចៗក្នុងសមុទ្រ ដែលតែងតែផ្តល់អត្ថប្រយោជន៍ជាយុទ្ធសាស្ត្រ ធម្មជាតិធនធាន (ដូចជាប្រេង នៅឈូងសមុទ្រ) ឬសិទ្ធិនេសាទ។ ច្បាប់អន្តរជាតិឥឡូវនេះផ្តល់អោយម្ចាស់កោះនូវសិទ្ធិនេសាទនិងជីករកអ៊ែនៅក្នុងសមុទ្រជុំវិញចម្ងាយ ២០០ ម៉ាយ (៣៣២គីឡូម៉ែត) ក្នុងទិសដៅនីមួយៗ។ ជម្លោះប្រជុំកោះស្ព្រាតលីតូចៗ ក្នុងសមុទ្រចិនខាងត្បូង ដែលដែនទឹកព័ទ្ធជុំវិញអាចនឹងមានធនធានប្រេងបម្រុងយ៉ាងច្រើន ត្រូវបានទាមទារដោយផ្នែកៗឬទាំងស្រុង ដោយប្រទេសមួយចំនួន រួមមានចិន តៃវ៉ាន់ វៀតណាម ហ្វីលីពីន ម៉ាឡេស៊ី និងប្រ៊ុយណេ (សូមមើលក្រាហ្វិក ៥.៥)។ រដ្ឋទាំងអស់នោះ លើកលែងតែប្រទេសប្រ៊ុយណេបានប្រើសកម្មភាពយោធានៅពេលខ្លះ ដើម្បីទទួលបានការទាមទាររបស់ពួកគេ។ ប្រហែលពាក់កណ្តាលនៃបរិមាណពាណិជ្ជកម្មពិភពលោកត្រូវឆ្លងកាត់តាមរយៈសមុទ្រចិនខាងត្បូង រួមទាំងប្រេងឈូងសមុទ្រពែក្ស និងធនធានសំខាន់ៗផ្សេងទៀត សំដៅឆ្ពោះទៅកាន់ប្រទេសជប៉ុន ចិន កូរ៉េខាងត្បូង និងកោះតៃវ៉ាន់។

នាពេលថ្មីៗនេះ ប្រទេសចិនបានចាប់ផ្តើមកសាងកម្លាំងយោធាដ៏សំខាន់នៅលើកោះតូចៗ និងថ្ម ប៉ប្រះទឹក ក្នុងប្រជុំកោះស្ព្រាតលី។ វាក៏បានបូមខ្សាច់យកទៅចាក់ពង្រីកកោះអោយធំជាងមុន ដែលអនុញ្ញាតអោយយោធាចិនអាចសាងសង់ផ្លូវយន្តហោះឡើងចុះ និងមូលដ្ឋានទ័ពធំៗបាន។ បណ្តារដ្ឋនៅក្បែរនោះតវ៉ាចំពោះការសាងសង់នេះ ដោយសារកម្មសិទ្ធិលើកោះនិងថ្មប៉ប្រះទឹកមួយចំនួនមិនទាន់សម្រេចនៅឡើយ។ កងទ័ពជើងទឹកអាមេរិកតែងតែធ្វើដំណើរទៅជិតៗកោះទាំងនេះ ដើម្បីប្រឆាំងសកម្មភាពរបស់ចិន ដែលចិនអះអាងថាជាការរំលោភលើអធិបតេយ្យភាពរបស់ខ្លួន។

រូបថត *ប៉ប្រះទឹកស៊ូប៊ី*

ងើបឡើងពីជម្រៅសមុទ្រ

ប្រជុំកោះស្ព្រ៉ាតលី(Spratly)នៅសមុទ្រចិនខាងត្បូង គឺជាប្រភពនៃភាពតានតឹងផ្នែកនយោបាយនិងយោធាដ៏សំខាន់នៅក្នុងតំបន់អាស៊ី។ ថ្មីៗនេះ ចិនបានចាប់ផ្តើមសាងសង់កោះធំៗនៅពីលើថ្មប៉ប្រះទឹកតូចៗដើម្បីដាក់កម្លាំងយោធានៅលើកោះទាំងនោះ។ នៅទីនេះ រូបថតនៃថ្មប៉ប្រះទឹកស៊ូប៊ី (Subi) ដែលបង្កើតឡើងដោយមនុស្ស ដែលត្រូវបានថតនៅឆ្នាំ ២០១៧ បង្ហាញពីវត្តមានយោធារបស់ចិនយ៉ាងច្រើនរួមទាំងផ្លូវយន្តហោះឡើងចុះផងដែរ។

ប្រទេសជប៉ុននិងចិនក៏មានជម្លោះដណ្តើមប្រជុំកោះតូចៗនៅកន្លែងផ្សេងទៀតដែរ ជម្លោះបែបនេះក៏កើតមានឡើងរវាងប្រទេសជប៉ុន និងកូរ៉េខាងត្បូង។ វិវាទទាំងនេះពាក់ព័ន្ធនឹងផលប្រយោជន៍សេដ្ឋកិច្ចទាបប៉ុន្តែ បានក្លាយជាការផ្តោតអារម្មណ៍នៃមនោសញ្ចេតនាជាតិនិយមនៃភាគីទាំងសងខាង ម្យ៉ាងត្រូវជំរុញ ដោយការចងចាំដូចត់ពីសង្គ្រាមលោកលើកទី ២ នៅពេលដែលជប៉ុនបានកាន់កាប់ប្រទេសចិន និងកូរ៉េ។ ជម្លោះដែលធ្ងន់ធ្ងរបំផុត កើតឡើងលើកោះតូចៗ នៅសមុទ្រចិនខាងកើត ដែលប្រទេសជប៉ុនគ្រប់គ្រង ប៉ុន្តែចិនក៏បានទាមទារផងដែរ ព្រោះថាវាអាចបើកផ្លូវសុវត្ថិភាពអោយនាវាមុជទឹករបស់ចិនចេញទៅកាន់មហាសមុទ្រប៉ាស៊ីហ្វិក។ កងទ័ពជើងទឹកនិងកងទ័ពអាកាសនៃរដ្ឋទាំងពីរ បានប្រឈមមុខដាក់គ្នានៅទីនោះ ម្តងហើយម្តងទៀត ទោះបីជាមិនមានអំពើហិង្សាក៏ដោយ។ ក្នុងឆ្នាំ ២០១៥ ប្រទេសជប៉ុនបានដាក់ពង្រាយនាវាចម្បាំងដ៏ធំបំផុតរបស់ខ្លួន (ជានាវាផ្ទុកឧទ្ធម្ភាគចក្រ) ចាប់តាំងពីសង្គ្រាមលោកលើកទី ២ ដើម្បីល្បាតតំបន់នេះ។

នៅឆ្នាំ ២០១៧ ប្រទេសចិនបានបញ្ជូននាវាចម្បាំងរបស់ខ្លួនទៅកៀកបំផុតនឹងកោះជម្លោះទាំងនោះ បង្ក អោយមានការតវ៉ាប្រឆាំងនិងការគំរាមកំហែងពីជប៉ុន។

ជម្លោះមួយចំនួនលើកោះតូចៗជាងកើតមាននៅជុំវិញសកលលោក។ នៅមជ្ឈិមបូព៌ា ប្រទេសអ៊ីរ៉ង់ និងប្រទេសអេមីរ៉ាតអារ៉ាប់រួម ឈ្លោះគ្នាដណ្តើមកម្មសិទ្ធិកោះតូចៗ ក្បែរមាត់ឈូងសមុទ្រពែរ្ស។ ក្នុងឆ្នាំ ២០០២ប្រទេសអេស្ប៉ាញបានបញ្ជូនទាហានទៅបណ្តេញកងទ័ពម៉ារ៉ុកមួយក្តាប់តូចចេញពីកោះនានា នៅតាមឆ្នេរសមុទ្រនៃប្រទេសម៉ារ៉ុក។ នៅអាមេរិកខាងត្បូង ប្រទេសអាហ្សង់ទីន និងអង់គ្លេសនៅតែមានជម្លោះដណ្តើមគ្រប់គ្រងប្រជុំកោះហ្វកឡែន (Falkland Islands ឬ Islas Malvinas) ដែលពួកគេបានធ្វើសង្គ្រាមនៅឆ្នាំ ១៩៨២។ ហើយបញ្ហាដ៏សំខាន់នៃការឈ្លោះប្រកែកគ្នា ក្នុងទំនាក់ទំនងរុស្ស៊ី-ជប៉ុនគឺការដណ្តើមធ្វើជាម្ចាស់នៃប្រជុំកោះគីរីល(Kuril) ដែលមានទីតាំងយុទ្ធសាស្ត្រ ដែលត្រូវបានកាន់កាប់ដោយសហភាពសូវៀតក្នុងឆ្នាំ ១៩៤៥។ បច្ចុប្បន្ននេះ ដោយសារបណ្តាកោះទាំងនោះនាំមកនូវការគ្រប់គ្រង តំបន់សេដ្ឋកិច្ចជុំវិញនោះ ជម្លោះអន្តរជាតិលើកោះនានានឹងបន្តកើតមាន ក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខនេះ។

ដែនទឹក

រដ្ឋចាត់ទុកដែនទឹកនៅជិតឆ្នេរសមុទ្ររបស់ពួកគេថា ជាផ្នែកមួយនៃទឹកដីប្រទេសជាតិរបស់ពួកគេ។ និយមន័យនៃដែនទឹកបែបនេះមិនត្រូវបានឯកភាពជាសកលទេ ប៉ុន្តែ បទដ្ឋាននានាត្រូវបានបង្កើតឡើងក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ជាពិសេស ចាប់តាំងពីពេលមានអនុសញ្ញាអង្គការសហប្រជាជាតិស្តីពី ច្បាប់សមុទ្រ (UNCLOS) (សូមមើលមេរៀនទី ១១)។ ដែនទឹកក្នុងចម្ងាយ បី ម៉ាយល៍ (ប្រហែល ៤,៨ គីឡូម៉ែត្រ) ពីឆ្នេរសមុទ្រត្រូវបានទទួលស្គាល់ជាប្រពៃណីថាជាទឹកដីរបស់រដ្ឋណាមួយនោះ ប៉ុន្តែ លើសពីរយៈចម្ងាយនោះ នៅមានជម្លោះថាតើអធិបតេយ្យភាពជាតិលាតសន្ធឹងដល់កម្រិតណា និងសម្រាប់គោលបំណងអ្វី។ អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ ជាទូទៅ អនុញ្ញាតអោយប្រើរយៈចម្ងាយ ១២ ម៉ាយល៍ (ប្រហែល ១៩,៣ គីឡូម៉ែត្រ) សម្រាប់ការដឹកជញ្ជូន និងតំបន់សេដ្ឋកិច្ចផ្តាច់មុខ(EEZ) ក្នុងរយៈចម្ងាយ ២០០ ម៉ាយល៍ (ប្រហែល ៣២២ គីឡូម៉ែត្រ) ដែលគ្របដណ្តប់លើសិទ្ធិនេសាទនិងរុករករ៉ែ (ប៉ុន្តែ អនុញ្ញាតអោយគ្រប់គ្នាធ្វើនាវាចរណ៍ ដោយសេរី)។ តំបន់សេដ្ឋកិច្ចផ្តាច់មុខ(EEZ) ជារួម គ្របដណ្តប់មួយភាគបីនៃផ្ទៃមហាសមុទ្រលើពិភពលោក។ ក្នុងឆ្នាំ ២០១០ ប្រទេសរុស្ស៊ី និងប្រទេសន័រវែសបានយល់ព្រមបែងចែកផ្នែកខ្លះនៃមហាសមុទ្រអាកទិកទៅជាតំបន់សេដ្ឋកិច្ចផ្តាច់មុខ(EEZ)សម្រាប់គោលដៅទាញយកប្រេងនិងឧស្ម័ន ដោយបញ្ចប់ជម្លោះរយៈពេល ៤០ ឆ្នាំរវាងរដ្ឋទាំងពីរ។

ដោយសារតែតំបន់សេដ្ឋកិច្ចផ្តាច់មុខ(EEZ)នេះ អធិបតេយ្យភាពលើកោះតូចមួយអាចនាំមកជាមួយនូវសិទ្ធិដល់ទៅផ្ទៃមហាសមុទ្រព័ទ្ធជុំវិញរហូតដល់ ១០០ ០០០ ម៉ាយល៍ការ៉េ (១៦០ ៩៣៤ គីឡូម៉ែត្រការ៉េ)។ ប៉ុន្តែ តំបន់ទាំងនេះត្រួតលើគ្នាយ៉ាងខ្លាំង ហើយឆ្នេរសមុទ្រមិនរត់តាមបន្ទាត់ត្រង់ទេ។ ដូច្នេះ សំណួរជាច្រើនត្រូវបានចោទសួរឡើងថា តើត្រូវបែកស្រាយអំពីរបៀបកំណត់ដែនទឹកនិងសេដ្ឋកិច្ចដោយរបៀបណា។ ជាឧទាហរណ៍ ប្រទេសលីប៊ីទាមទារកម្មសិទ្ធិលើឈូងសមុទ្រស៊ីដ្រា(Sidra)ទាំងមូល ដោយចាត់ទុកវាជាឈូងសមុទ្រផ្ទាល់ខ្លួនមួយ សហរដ្ឋអាមេរិកចាត់ទុកវាជាផ្លូវកោង សសៀរតាមឆ្នេរសមុទ្រ ហើយទទួចថាភាគច្រើនជាដែនទឹកអន្តរជាតិ។ នៅក្នុងឆ្នាំ ១៩៨៦ សហរដ្ឋអាមេរិកបានបញ្ជូននាវាចម្បាំងចូលឈូងសមុទ្រ

ស៊ីជ្រៅ ដើម្បីបញ្ជាក់អ្វីដែលខ្លួនបានអះអាងខាងដើម។ យន្តហោះអាមេរិកបានបាញ់ទម្លាក់យន្តហោះចម្បាំងរបស់លីប៊ីចំនួនពីរគ្រឿងដែលតវ៉ានឹងការបញ្ជូននាវាចម្បាំងរបស់សហរដ្ឋអាមេរិកមកក្នុងឈូងសមុទ្រ។

រូបថត ទីតាំង, ទីតាំង, ទីតាំង

ការគ្រប់គ្រងកោះនិងតំបន់សេដ្ឋកិច្ចផ្តាច់មុខ(EEZ)ដ៏ធំល្វឹងល្វើយ ដែលព័ទ្ធជុំវិញកោះទាំងនោះក្រោមច្បាប់សមុទ្រ បានបង្កជម្លោះអន្តរជាតិដ៏ស្មុគស្មាញជាច្រើន។ ប្រទេសជប៉ុនបានទាមទារកោះអូគីណូតូរី (Okinotori) ដែលបានបង្ហាញនៅទីនេះក្នុងឆ្នាំ ២០១៤ ជាកោះមួយដែលមានតំបន់សេដ្ឋកិច្ចផ្តាច់មុខ ប៉ុន្តែប្រទេសចិនហៅវាថាគ្រាន់តែជា «ថ្ម» ដោយគ្មានសិទ្ធិសេដ្ឋកិច្ចជុំវិញឡើយ។

ប្រទេសកាណាដាក្នុងឆ្នាំ ១៩៩៤-១៩៩៥ បានបញ្ជូនកងទ័ពជើងទឹករបស់ខ្លួនទៅរំខានទូកនេសាទអេស្បាញដែលនេសាទនៅក្បែរៗដែនទឹកក្នុងតំបន់ ២០០ ម៉ាយល៍ (ប៉ុន្តែប៉ះពាល់ដល់ស្តុកត្រីដែនទឹកនេះ)។ នៅក្នុងសមុទ្រអូឃុតស៍ (Okhotsk) ដែលមានរយៈចំងាយ ជាង ៤០០ ម៉ាយល៍, តំបន់សេដ្ឋកិច្ចផ្តាច់មុខ (EEZ)របស់រុស្ស៊ីគ្របដណ្តប់លើដែនទឹកទាំងអស់នោះ លើកលែងតែ «រង្វង់ដែនទឹករាងដូចនំកង» តូចមួយដែលជាផ្ទៃទឹកអន្តរជាតិ នៅចន្លោះកណ្តាល។ ទូកនេសាទដែលមិនមែនជារបស់រុស្ស៊ីបាននេសាទយ៉ាងខ្លាំងនៅក្នុង«រង្វង់»នោះ ដែលជាការពិតណាស់ បណ្តាលអោយធ្លាក់ចុះស្តុកត្រី នៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់រុស្ស៊ី។

ជម្លោះដែនសមុទ្រដ៏គ្រោះថ្នាក់មួយបានផ្ទុះឡើងនៅក្នុងឆ្នាំ ២០១០ នៅពេលដែលនាវាចម្បាំងកូរ៉េខាងត្បូងមួយគ្រឿងបានលិចនៅក្នុងដែនទឹកដែលមានជម្លោះ នៅក្នុងសមុទ្រលឿង។ ក្រុមអ្នកស៊ើបអង្កេតអន្តរជាតិបានសន្និដ្ឋានថា គ្រាប់ផ្លោងរបស់កូរ៉េខាងជើងបានបាញ់ពន្លិចនាវានេះ ទោះបីជាកូរ៉េខាងជើងបានបដិសេធមិនជាប់ពាក់ព័ន្ធក៏ដោយ។ ប្រទេសកូរ៉េខាងត្បូងបន្តប្រតិបត្តិការយោធា នៅក្នុងដែនទឹកដែលមានជម្លោះ ខណៈកូរ៉េខាងជើងបន្តបាញ់ផ្លោងកាំភ្លើងធំ នៅក្នុងដែនទឹកនោះរួមទាំងការវាយប្រហារដែលបានសម្លាប់ជនស៊ីវិលជាច្រើននាក់ ក្នុងឆ្នាំ ២០១០។ ប្រទេសទាំងពីរមិនដែលបានបញ្ចប់ជាផ្លូវការនូវសង្គ្រាមកូរ៉េដោយការចុះហត្ថលេខាលើសន្ធិសញ្ញាសន្តិភាពនោះទេ។

ដែនអាកាស

លំហអាកាសនៅខាងលើរដ្ឋណាមួយត្រូវបានគេចាត់ទុកថាជាដែនអាកាសរបស់រដ្ឋនោះ។ ដើម្បីហោះហើរឆ្លងកាត់ពីលើដែនអាកាសរបស់រដ្ឋណាមួយ យន្តហោះត្រូវតែមានការអនុញ្ញាតពីរដ្ឋនោះ។ ជាឧទាហរណ៍ នៅក្នុងការវាយឆ្មក់ក្នុងឆ្នាំ ១៩៨៦ លើប្រទេសលីប៊ី យន្តហោះទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកដែលមានមូលដ្ឋាន នៅចក្រភពអង់គ្លេសត្រូវហោះហើរផ្លូវវាងយ៉ាងឆ្ងាយ នៅលើមហាសមុទ្រអាត្លង់ទិក ដោយសារតែប្រទេសបារាំង (នៅរវាងចក្រភពអង់គ្លេស និងប្រទេសលីប៊ី) មិនបានផ្តល់ការអនុញ្ញាតអោយយន្តហោះរបស់សហរដ្ឋអាមេរិកប្រើប្រាស់ដែនអាកាសរបស់ខ្លួន ក្នុងអំឡុងពេលបេសកកម្មនោះទេ។

ផ្ទុយទៅវិញ *លំហអាកាសខាងក្រៅ* (Outer Space) ត្រូវបានចាត់ទុកថា ជាលំហអាកាសអន្តរជាតិដូចជាមហាសមុទ្រដែរ។ ច្បាប់អន្តរជាតិមិនបានកំណត់យ៉ាងច្បាស់ថាតើដែនអាកាសបញ្ចប់នៅទីណានិងលំហអាកាសខាងក្រៅចាប់ផ្តើមនៅត្រឹមណានោះទេ។ ទោះជាយ៉ាងណាក៏ដោយ ផ្កាយរណបដែលធ្វើដំណើរគោចរជុំវិញ ហោះហើរខ្ពស់ជាងយន្តហោះ ផ្លាស់ទីបានលឿនបំផុត និងមិនអាចងាយផ្លាស់ប្តូរទិសដៅ ដើម្បីជៀសវាងការហោះហើររំលងលើប្រទេសណាមួយណាស់។ ដូចគ្នានេះផងដែរ រដ្ឋតិចតួចណាស់ដែលអាច

បាញ់ទម្លាក់ផ្តាយរណប។ ដោយសារតែផ្តាយរណបកាន់តែមានប្រយោជន៍ជាឧបករណ៍ស៊ើបការណ៍ប្រមូលព័ត៌មានសម្ងាត់ សម្រាប់ប្រទេសមហាអំណាចទាំងអស់ ហើយដោយសារតែផ្តាយរណបទាំងអស់ងាយរងការវាយប្រហារយ៉ាងខ្លាំង បទដ្ឋាននៃការគ្មានយោធានៃលំហអាកាសខាងក្រៅត្រូវបានបង្កើតឡើង។ គ្មានរដ្ឋណាដែលធ្លាប់បានវាយប្រហារផ្តាយរណបរបស់ប្រទេសផ្សេងនោះទេ។ ទោះជាយ៉ាងណាក៏ដោយ ក្នុងឆ្នាំ ២០០៧ ប្រទេសចិនបានបង្កអោយមានការភ័យខ្លាច ដោយការបំផ្លាញផ្តាយរណបរបស់ខ្លួន ដោយជោគជ័យ ជាមួយនឹងកាំជ្រួចប្រឆាំងផ្តាយរណប ដោយបានពង្រាយកំទេចកំទីដែលមានល្បឿនលឿននៅជុំវិញគន្លងតារា។

៥.៣.២. ការដណ្តើមគ្រប់គ្រងរដ្ឋាភិបាល

ទោះបីជាជម្លោះព្រំដែនតូចតាចជាច្រើន ដែលបន្តញាំញីពិភពលោកក៏ដោយ ការតស៊ូប្រយុទ្ធដណ្តើម គ្រប់គ្រងទឹកដីភាគច្រើន មិនពាក់ព័ន្ធនឹងការផ្លាស់ប្តូរព្រំដែនទេ។ ផ្ទុយទៅវិញ វាគឺជាជម្លោះថាតើរដ្ឋាភិបាលណាមួយត្រូវគ្រប់គ្រងរដ្ឋទាំងមូល។

នៅក្នុងទ្រឹស្តី រដ្ឋនានាមិនជ្រៀតជ្រែកក្នុងការកិច្ចការរដ្ឋាភិបាលរបស់គ្នាទៅវិញទៅមក ដោយសារបទដ្ឋាននៃអធិបតេយ្យភាព។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងការអនុវត្តជាក់ស្តែង រដ្ឋនានាតែងតែមានផលប្រយោជន៍ខ្លាំង នៅក្នុងរដ្ឋាភិបាលនៃរដ្ឋផ្សេងទៀត ហើយប្រើមធ្យោបាយផ្សេងៗ ដើម្បីមានឥទ្ធិពលលើអ្នកដែលកាន់អំណាចនៅក្នុងរដ្ឋទាំងនោះ។ ជម្លោះដណ្តើមគ្រប់គ្រងរដ្ឋាភិបាលទាំងនេះ មានច្រើនទម្រង់ ខ្លះស្រាលនិងខ្លះធ្ងន់ធ្ងរ ខ្លះមានទំនាក់ទំនងយ៉ាងស៊ីជម្រៅជាមួយភាគីទីបី និងខ្លះទៀតពាក់ព័ន្ធត្រឹមតែទ្វេភាគី។ ពេលខ្លះរដ្ឋមួយគ្រាន់តែបញ្ចេញឥទ្ធិពលតិចតួចលើការបោះឆ្នោតរបស់រដ្ឋមួយផ្សេងទៀត។ នៅពេលខ្លះទៀត រដ្ឋមួយគាំទ្រក្រុមឧទ្ទាមដែលកំពុងស្វែងរកការផ្តួលរំលំរដ្ឋាភិបាលរបស់រដ្ឋមួយទៀត។

ក្នុងអំឡុងសង្គ្រាមត្រជាក់ ប្រទេសមហាអំណាចទាំងពីរបានជំរុញការផ្លាស់ប្តូររដ្ឋាភិបាលនៃបណ្តាប្រទេសនៅក្នុងអឌ្ឍគោលខាងត្បូងយ៉ាងសកម្ម តាមរយៈប្រតិបត្តិការសម្ងាត់ និងការគាំទ្រកងកម្លាំងឧទ្ទាម។ សង្គ្រាមស៊ីវិលនៅប្រទេសអង់ហ្គោឡា អាហ្វហ្គានីស្ថាន និងនីការ៉ាហ្គា គឺជាឧទាហរណ៍យ៉ាងច្បាស់។ ប្រទេសមហាអំណាចទាំងពីរបានបញ្ជូនសព្វាវុធ ហិរញ្ញវត្ថុ ទីប្រឹក្សាយោធា ជាដើម ដោយសង្ឃឹមថានឹងដុះឥទ្ធិពលកំណត់នរណានឹងគ្រប់គ្រងរដ្ឋាភិបាលរបស់ប្រទេសទាំងនេះ។

ក្នុងចន្លោះឆ្នាំ ២០០៤-២០០៥ ស្រមោលនៃគូប្រជែងតាំងពីសម័យសង្គ្រាមត្រជាក់បានធ្លាក់ទៅលើប្រទេសអ៊ុយក្រែន ខណៈដែលប្រទេសរុស្ស៊ីនិងបស្ចឹមប្រទេសបានគាំទ្រភាគីផ្ទុយគ្នា នៅក្នុងការបោះឆ្នោតដែលមានជម្លោះ។ ការបោះឆ្នោតបានបែងចែកតំបន់ដែលប្រជាជននិយាយភាសារុស្សីភាគច្រើននៅភាគខាងកើតដែលជាគ្រិស្តសាសនិកជននិកាយអូថូដក់និយម ពីតំបន់ដែលនិយាយភាសាអ៊ុយក្រែនជាគ្រិស្តសាសនិកជននិកាយកាតូលិកនិយមនៅភាគខាងលិចនៃប្រទេស។ អ្នកកាន់អំណាចចាស់និយមរុស្ស៊ីបានកាន់កាប់តំបន់ភាគខាងកើត ហើយត្រូវបានប្រកាសថាជាអ្នកឈ្នះឆ្នោតបន្ទាប់ពីការបោះឆ្នោត ដែលអ្នកឃ្លាំមើលអន្តរជាតិបានប្រកាសថាមិនសមហេតុផល។ លោកប្រធានាធិបតីរុស្ស៊ី វ្ល៉ាឌីមៀ ពូទីន បានធ្វើយុទ្ធនាការដោយផ្ទាល់ជាមួយប្រធានាធិបតីកាន់អំណាច ហើយបានប្រឆាំងយ៉ាងខ្លាំងក្លាចំពោះការអនុញ្ញាតអោយអ៊ុយក្រែន ដែលជាអតីតផ្នែកនៃសហភាពសូវៀត ធ្លាក់ចូលក្រោមឥទ្ធិពលនៃបស្ចឹមប្រទេស។ ទន្ទឹមនឹងនោះ បេក្ខជនប្រធានាធិបតីគាំទ្រលោកខាងលិច ត្រូវបានគេបំពុល ក្នុងអំឡុងពេលយុទ្ធនាការឃោសនាបោះឆ្នោត ប៉ុន្តែបានរួចជីវិត។ អ្នកគាំទ្ររបស់គាត់បានចេញបាតុកម្មតាមផ្លូវ នៅចុងឆ្នាំ ២០០៤ ទាមទារអោយមានការបោះ

ឆ្នោតថ្មី ដែលតុលាការកំពូលអ៊ុយក្រែន នៅទីបំផុត បានបញ្ជាអោយរៀបចំការបោះឆ្នោតថ្មី ហើយដែលក្រុមបក្សប្រឆាំងឈ្នះ។

ជម្លោះដ៏ធ្ងន់ធ្ងរនិងប្រល័យជាងនេះបានផ្ទុះឡើង នៅក្នុងឆ្នាំ ២០១៣-២០១៤ នៅពេលដែលប្រធានាធិបតីអ៊ុយក្រែន ដែលគាំទ្ររុស្ស៊ី នៅពេលនោះ បានបង្ក្រាបក្រុមបាតុករនិយមលោកខាងលិច។ កងកម្លាំងបក្សប្រឆាំងបានទទួលជោគជ័យក្នុងការបង្ខំប្រធានាធិបតីអោយលាលែងពីតំណែង ប៉ុន្តែ អ្នកគាំទ្ររបស់គាត់នៅភាគខាងកើតនៃប្រទេស ដោយមានជំនួយពីប្រទេសរុស្ស៊ី បានកាន់អាវុធប្រឆាំងនឹងរដ្ឋាភិបាលថ្មីនិយមលោកខាងលិច។ ទន្ទឹមនឹងនោះ ប្រទេសរុស្ស៊ីបានបញ្ចូលឧបទ្វីបគ្រីមេ ដែលរុស្ស៊ីផ្ទាល់បាននិយាយថាចង់បង្រួបបង្រួមជាមួយប្រទេសរុស្ស៊ីឡើងវិញ។ នៅឆ្នាំ ២០១៨ បើទោះជាមិនមានសមរភូមិធំៗផ្ទុះឡើងរវាងក្រុមឧទ្ទាមដែលគាំទ្រដោយរុស្ស៊ីនិងកងទ័ពអ៊ុយក្រែនក៏ដោយ បទឈប់បាញ់គ្នាជាច្រើនលើកច្រើនសារត្រូវបរាជ័យ ហើយអំពើហិង្សាទំនងជាបញ្ឈប់ភ្លាមៗនោះទេ។

ម្តងម្កាល រដ្ឋមួយឈ្លានពានមួយទៀត ដើម្បីផ្លាស់ប្តូររដ្ឋាភិបាលរបស់រដ្ឋនោះ។ សហភាពសូវៀតបានប្រព្រឹត្តិទង្វើបែបនេះ នៅឆេកូស្លូវ៉ាគីក្នុងឆ្នាំ ១៩៦៨ ចំណែកសហរដ្ឋអាមេរិកបានធ្វើដូចគ្នា នៅក្នុងប្រទេសអ៊ីរ៉ាក់ក្នុងឆ្នាំ ២០០៣។ ជាទូទៅ ប្រជាជនមានការខកចិត្តដែលជនបរទេសជ្រើសរើសរដ្ឋាភិបាលអោយខ្លួនទោះបីជាពួកគេមិនចូលចិត្តរដ្ឋាភិបាលចាស់ក៏ដោយ ហើយសហគមន៍អន្តរជាតិគាំទ្រការរំលោភអធិបតេយ្យភាពជាតិយ៉ាងខ្លាំងដូច្នេះទេ។

ជម្លោះអន្តរជាតិជុំវិញការដណ្តើមគ្រប់គ្រងរដ្ឋាភិបាល រួមជាមួយនឹងជម្លោះទឹកដី ទំនងជានាំទៅរកការប្រើប្រាស់អំពើហិង្សា។ ពួកវាពាក់ព័ន្ធនឹងបញ្ហាស្នូលនៃស្ថានភាពនិងបូរណភាពនៃរដ្ឋ ផលប្រយោជន៍ហាក់ខ្ពស់ពេកក្រៃ ហើយផលប្រយោជន៍របស់តួអង្គពាក់ព័ន្ធជារឿយៗត្រូវបានគេតវ៉ា។ ផ្ទុយទៅវិញជម្លោះសេដ្ឋកិច្ចរវាងរដ្ឋនានាកើតឡើងញឹកញាប់ជាង ប៉ុន្តែទំនងជាមិនសូវជាឈានទៅរកអំពើហិង្សាទេ។

៥.៣.៣. ជម្លោះសេដ្ឋកិច្ច

ការប្រកួតប្រជែងផ្នែកសេដ្ឋកិច្ច គឺជាជម្លោះមួយប្រភេទ ដែលរីករាលដាលខ្លាំងក្លាបំផុតនៅក្នុងទំនាក់ទំនងអន្តរជាតិ ដោយសារតែប្រតិបត្តិការសេដ្ឋកិច្ចរីករាលដាលផងដែរ។ រាល់ការលក់ដូរដែលបានធ្វើឡើង និងរាល់កិច្ចព្រមព្រៀងដែលត្រូវបានសម្រេចឡើងឆ្លងកាត់ព្រំដែនអន្តរជាតិ តម្រូវអោយមានដំណោះស្រាយជម្លោះផលប្រយោជន៍។ ប្រទេសកូស្តារីកាចង់អោយតម្លៃកាហ្វេដែលខ្លួននាំចេញកើនឡើង។ ប្រទេសកាណាដាដែលនាំចូលកាហ្វេចង់អោយតម្លៃធ្លាក់ចុះ។ ប្រទេសអង់ហ្គោឡា ចង់អោយក្រុមហ៊ុនបរទេសដែលផលិតប្រេងអង់ហ្គោខ្លួនឯង ទទួលបានប្រាក់ចំណេញតិចពីការលក់ប្រេង។ ប្រទេសដើមកំណើតនៃ ក្រុមហ៊ុនទាំងនោះចង់អោយពួកគេទទួលបានប្រាក់ចំណេញកាន់តែច្រើន សម្រាប់នាំចូលទៅប្រទេស។ នៅក្នុងទីផ្សារមូលធននិយមសកល បម្លាស់ប្តូរសេដ្ឋកិច្ចទាំងអស់ជាប់ពាក់ព័ន្ធនឹងជម្លោះផលប្រយោជន៍ ទោះតិចឬច្រើនក្តី។

ទោះជាយ៉ាងណាក៏ដោយ ប្រតិបត្តិការសេដ្ឋកិច្ចបែបនេះក៏មានធាតុផ្សំដ៏រឹងមាំដែលផ្តល់ផលចំណេញសេដ្ឋកិច្ចអោយគ្នាទៅវិញទៅមក បន្ថែមពីលើធាតុផ្សំដែលនាំអោយមានជម្លោះផលប្រយោជន៍ (សូមមើលមេរៀនទី ៣ និងទី ៨)។ ផលចំណេញចំពោះគ្នាទៅវិញទៅមកទាំងនេះផ្តល់នូវអានុភាពដ៏មានប្រយោជន៍បំផុតក្នុងការចរចាលើការដោះដូរសេដ្ឋកិច្ច៖ រដ្ឋនិងក្រុមហ៊ុនចូលទៅក្នុងប្រតិបត្តិការសេដ្ឋកិច្ច ដោយសារពួកគេទទួលបានផលចំណេញពីការប្រតិបត្តិការទាំងនេះ។ ភាគច្រើននៃការប្រើអំពើហិង្សានឹងបង្អាក់ និងកាត់

បន្តយផលចំណេញបែបនេះ ច្រើនជាងផលចំណេញដែលអាចទទួលបានពីការប្រើប្រាស់អំពើហិង្សា។ ដូច្នេះ ជម្លោះសេដ្ឋកិច្ចមិនតែងតែនាំអោយមានការប្រើប្រាស់កម្លាំងយោធា និងសង្គ្រាមនោះទេ។

នាពេលបច្ចុប្បន្ននេះ ជម្លោះសេដ្ឋកិច្ចកម្រនាំអោយមានអំពើហិង្សាណាស់ ដោយសារទម្រង់នៃឥទ្ធិពលយោធាលែងមានប្រសិទ្ធភាពក្នុងជម្លោះសេដ្ឋកិច្ចទៀតហើយ។ ជាមួយនឹងសមាហរណកម្មសេដ្ឋកិច្ចពិភពលោកយ៉ាងស្មុគស្មាញ និងការចំណាយខ្ពស់នៃសកម្មភាពយោធា ជារឿងមិនសមហេតុផលមិនចំណេញក្នុងការប្រើកម្លាំងទ័ពដើម្បីដោះស្រាយបញ្ហាសេដ្ឋកិច្ច។ បើទោះជាកិច្ចព្រមព្រៀងមួយមិនស័ក្តិសមឬមិនសូវចំណេញសម្រាប់ភាគីម្ខាងក្នុងជម្លោះសេដ្ឋកិច្ច ផលចំណេញដែលទទួលបានពីការប្រើប្រាស់កម្លាំងយោធាកម្រសមនឹងថ្លៃចំណាយលើសង្គ្រាមណាស់។ ដូច្នេះហើយជម្លោះសេដ្ឋកិច្ចភាគច្រើនមិនមែនជាបញ្ហាកង្វល់សម្រាប់សន្តិសុខអន្តរជាតិទេ។ ជម្លោះទាំងនេះនឹងត្រូវពិភាក្សាបន្ថែម នៅក្នុងមេរៀនទី ៨ រហូតដល់ទី ១៣ (នៅក្នុងជំពូកទី២ ស្តីពី សេដ្ឋកិច្ចនយោបាយអន្តរជាតិ)។ ប៉ុន្តែ ជម្លោះសេដ្ឋកិច្ចនៅតែប្រឈមនឹងសន្តិសុខអន្តរជាតិ ដោយសារមូលហេតុមួយចំនួន។

ទីមួយ គោលនយោបាយការបរទេសរបស់រដ្ឋជាច្រើន ត្រូវរងឥទ្ធិពលដោយទ្រឹស្តី mercantilism ដែលជាការអនុវត្តជាច្រើនសតវត្សរ៍កន្លងមក ដែលគោលនយោបាយសេដ្ឋកិច្ចនិងពាណិជ្ជកម្មបរទេសត្រូវបានរៀបចំដើម្បីបង្កើតអតិរេករូបិយវត្ថុ ដែលអាចត្រូវបានប្រើដើម្បីធ្វើហិរញ្ញប្បទានដល់សង្គ្រាម (សូមមើលទ្រឹស្តីសេរីនិយម និងទ្រឹស្តី Mercantilism នៅមេរៀនទី ៨) ដោយសារអតិរេកពាណិជ្ជកម្មផ្តល់អត្ថប្រយោជន៍នៅក្នុងកិច្ចការសន្តិសុខអន្តរជាតិ នៅក្នុងអនាគតវែងឆ្ងាយខាងមុខ ជម្លោះពាណិជ្ជកម្មមានផលប៉ះពាល់ដល់ទំនាក់ទំនងសន្តិសុខអន្តរជាតិ។

ទីពីរ ទ្រឹស្តី *សម្ពាធលំហរជើងមេឃ* (lateral pressure) ក៏ផ្សារភ្ជាប់ការប្រកួតប្រជែងសេដ្ឋកិច្ចជាមួយនឹងបញ្ហាសន្តិសុខផងដែរ។ ទ្រឹស្តីនេះយល់ថា កំណើនសេដ្ឋកិច្ចរបស់រដ្ឋអាចនាំទៅដល់ការពង្រីកភូមិសាស្ត្រ នៅពេលដែលពួកគេស្វែងរកធនធានធម្មជាតិ ឆ្ងាយហួសពីរង្វង់ព្រំដែនរបស់ពួកគេ (តាមមធ្យោបាយផ្សេងៗ ទោះសន្តិវិធីក្តី ឬហិង្សាក្តី)។ នៅពេលដែលប្រទេសមហាអំណាចពង្រីកសកម្មភាពសេដ្ឋកិច្ចរបស់ពួកគេទៅខាងក្រៅ ការប្រកួតប្រជែងរបស់ពួកគេនាំទៅរកជម្លោះ ហើយជួនកាលឈានដល់សង្គ្រាម។ ទ្រឹស្តីនេះត្រូវបានគេប្រើដើម្បីជួយពន្យល់អំពីសង្គ្រាមលោកលើកទី ១ និងការរាតទីនិយមរបស់ប្រទេសជប៉ុន មុនសង្គ្រាមលោកលើកទី ២។

ជម្លោះសេដ្ឋកិច្ចមួយប្រភេទទៀត ដែលប៉ះពាល់ដល់សន្តិសុខអន្តរជាតិ ទាក់ទងនឹងឧស្សាហកម្មយោធា (សមត្ថភាពផលិតឧបករណ៍យោធា ជាពិសេសអាវុធបច្ចេកវិទ្យាខ្ពស់ ដូចជាយន្តហោះចម្បាំង ឬគ្រាប់មីស៊ីល។ មានការជួញដូរពិភពលោក សំរាប់ទំនិញបែបនេះ ប៉ុន្តែ រដ្ឋាភិបាលជាតិនីមួយៗព្យាយាម (មិនតែងតែជោគជ័យទេ)ដើម្បីរក្សាការគ្រប់គ្រងផលិតកម្មបែបនេះអោយបាន ដើម្បីធានាថាផលប្រយោជន៍ជាតិមានអាទិភាពច្រើនជាងអ្នកផលិត ហើយនិងធានាថារដ្ឋមានកម្លាំងយោធាគ្រប់គ្រាន់ក្នុងករណីមានសង្គ្រាម។ ការប្រកួតប្រជែងផ្នែកសេដ្ឋកិច្ច (ដើម្បីសម្រេចថានរណាដែលចំណេញពីការលក់បែបនេះ) ត្រូវបានផ្សារភ្ជាប់ជាមួយនឹងការព្រួយបារម្ភអំពីសន្តិសុខ (នរណាដែលអាចទទួលបានអាវុធទាំងនោះ)។ នៅក្នុងឆ្នាំ ២០០៩ អ្នកគាំទ្រសំណើច្បាប់សង្គ្រោះឧស្សាហកម្មផលិតរថយន្តរបស់សហរដ្ឋអាមេរិកបានអះអាងថា ឧស្សាហកម្មនេះអាចផ្តល់នូវសមត្ថភាពផលិតកម្មដ៏សំខាន់ នៅក្នុងករណីមានសង្គ្រាម ដូចដែលវាធ្លាប់បានធ្វើក្នុងអំឡុង

សង្គ្រាមលោកលើកទី ២។ ការផ្ទេរចំណេះដឹងអំពីសព្វាវុធបច្ចេកវិទ្យាខ្ពស់ និងបច្ចេកវិទ្យាយោធាទៅកាន់រដ្ឋ ដែលមានអរិភាព(ភាពជាសត្រូវ) គឺជាកង្វល់ពាក់ព័ន្ធ។

ប្រភេទជម្លោះសេដ្ឋកិច្ចផ្សេងទៀតពាក់ព័ន្ធនឹងការបែងចែកទ្រព្យសម្បត្តិនៅផ្ទៃក្នុង និងក្នុងចំណោមរដ្ឋនានា។ ដូចដែលនឹងត្រូវពិភាក្សានៅក្នុងមេរៀនទី ១២ ភាពខុសគ្នាយ៉ាងខ្លាំងនៃវិសាលភាពទ្រព្យសម្បត្តិនៅក្នុងពិភពលោករបស់យើងអាចនឹងបង្កើតបញ្ហាសន្តិសុខអន្តរជាតិផ្សេងៗជាច្រើន ជាមួយនឹងសក្តានុពលអាចនឹងផ្ទុះអំពើហិង្សា រួមទាំងការវាយប្រហារដោយក្រុមភេរវករទៅលើប្រទេសអ្នកមាន ដោយក្រុមនៅក្នុងប្រទេសក្រីក្រ។ បដិវត្តន៍ក្នុងប្រទេសក្រីក្រ ជារឿយៗ ត្រូវបានជំរុញដោយភាពខុសគ្នានៃទំហំទ្រព្យសម្បត្តិក្នុងប្រទេស ក៏ដូចជាកំរិតក្រីក្ររបស់រដ្ឋនោះបើធៀបនឹងប្រទេសដទៃទៀត។ ជាញឹកញយ បដិវត្តន៍ទាំងនេះ ទាញរដ្ឋដទៃទៀតអោយចូលរួម ក្នុងនាមជាអ្នកគាំទ្រភាគីម្ខាង ឬម្ខាងទៀត នៅក្នុងសង្គ្រាមស៊ីវិល។

គោលការណ៍ម៉ាក្សស៊ីសនិយមចំពោះទំនាក់ទំនងអន្តរជាតិ ដែលត្រូវពិភាក្សា នៅក្នុងមេរៀនទី ៤ និង ១២ ចាត់ទុកថាការតស៊ូវណ្ណៈរវាងអ្នកមាននិងអ្នកក្រជាមូលដ្ឋាននៃទំនាក់ទំនងរវាងរដ្ឋនានា។ យោងតាមគោលការណ៍ទាំងនេះ រដ្ឋមូលធននិយមប្រកាន់យកគោលនយោបាយបរទេស ដែលបម្រើផលប្រយោជន៍របស់ម្ចាស់ក្រុមហ៊ុនអ្នកមាន។ ជម្លោះនិងសង្គ្រាមរវាងអឌ្ឍគោលខាងជើងនិងអឌ្ឍគោលខាងត្បូង ដែលជារដ្ឋអ្នកមានធៀបនឹងរដ្ឋក្រីក្រ ត្រូវបានគេមើលឃើញថាជាការឆ្លុះបញ្ចាំងពីការត្រួតត្រា និងការកេងប្រវ័ញ្ចលើជនក្រីក្រពីសំណាក់អ្នកមាន (ចក្រពត្តិនិយមក្នុងទម្រង់ផ្ទាល់ ឬដោយប្រយោល)។ ជាឧទាហរណ៍ ពួកម៉ាក្សស៊ីសនិយមភាគច្រើនបានមើលឃើញថា សង្គ្រាមវៀតណាមជាកិច្ចខិតខំប្រឹងប្រែងរបស់សហរដ្ឋអាមេរិកក្នុងការបង្ក្រាបបដិវត្តន៍ ដើម្បីធានាបាននូវលទ្ធភាពបន្តរបស់សហរដ្ឋអាមេរិកក្នុងការប្រើប្រាស់កម្លាំងពលកម្ម និងទាញយកវត្ថុធាតុដើមថោកៗ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ ពួកម៉ាក្សស៊ីសនិយមជាច្រើនបង្ហាញពីជម្លោះក្នុងចំណោមរដ្ឋមូលធននិយមថា ជាការប្រកួតប្រជែងលើសិទ្ធិកេងប្រវ័ញ្ចលើតំបន់ក្រីក្រ។ ស្ថាបនិកសហភាពសូវៀត លោក វ្ល៉ាឌីមៀ អ៊ីល លេនីន (V. I. Lenin) បានពិពណ៌នាសង្គ្រាមលោកលើកទី ១ ថាជាការប្រយុទ្ធលើការបែងចែកចក្រពត្តិនិយមនៃពិភពលោក។

ការជួញដូរគ្រឿងញៀន

ក្នុងទម្រង់ជាការជួញដូរខុសច្បាប់ឆ្លងកាត់ព្រំដែនអន្តរជាតិ ការជួញដូរគ្រឿងញៀន គឺជាការរត់ពន្ធដែលធ្វើអោយបាត់បង់ចំណូលរដ្ឋ និងរំលោភលើការគ្រប់គ្រងផ្លូវច្បាប់របស់រដ្ឋលើព្រំដែនរបស់ពួកគេ។ ប៉ុន្តែការរត់ពន្ធ ជាទូទៅ គឺជាបញ្ហាសេដ្ឋកិច្ចជាជាងបញ្ហាសន្តិសុខ (សូមមើល ពាណិជ្ជកម្មខុសច្បាប់ នៅក្នុងមេរៀនទី ៨)។ ទោះជាយ៉ាងណាក៏ដោយ ខុសពីប្រតិបត្តិការរត់ពន្ធផ្សេងទៀត ការជួញដូរគ្រឿងញៀនផ្គត់ផ្គង់ផលិតផលខុសច្បាប់ ដែលត្រូវបានចាត់ទុកជាការគំរាមកំហែងផ្នែកសន្តិសុខ ដោយសារឥទ្ធិពលរបស់វាទៅលើប្រសិទ្ធភាពនិងសីលធម៌ជាតិ(និងយោធា)។ ការជួញដូរគ្រឿងញៀនក៏ត្រូវបានផ្សារភ្ជាប់ជាមួយនឹងកង្វល់ផ្នែកសន្តិសុខផងដែរ ដោយសារតែកងកម្លាំងយោធាចូលរួមជាទៀងទាត់ក្នុងប្រតិបត្តិការប្រឆាំងនឹងអ្នកជួញដូរគ្រឿងញៀនបំពាក់ដោយប្រដាប់អាវុធយ៉ាងច្រើនសន្ធឹកសន្ធាប់។ ជម្លោះលើគ្រឿងញៀន ជាទូទៅ ទាក់ទងនឹងរដ្ឋមួយនៅម្ខាង និងតួអង្គមិនមែនរដ្ឋនៅម្ខាងទៀត។ ប៉ុន្តែ រដ្ឋផ្សេងទៀតអាចត្រូវបានអូសទាញចូលផងដែរ ដោយសារតែសកម្មភាពជួញដូរឆ្លងព្រំដែនជាតិមួយទៅមួយទៀត ហើយអាចមានពាក់ព័ន្ធនឹងមន្ត្រីរដ្ឋដែលពុករលួយ។

ផលប៉ះពាល់ជាអន្តរជាតិទាំងនេះ លេចចេញជាភស្តុតាងជាក់ស្តែង នៅក្នុងកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក ក្នុងការទប់ស្កាត់*ក្រុមជួញដូរសារធាតុកូកាអ៊ីន*(cocaine cartels) ដែលមានមូលដ្ឋាននៅប្រទេសកូឡុំប៊ី មិនអោយផ្គត់ផ្គង់សារធាតុកូកាអ៊ីនទៅកាន់ទីក្រុងនានារបស់សហរដ្ឋអាមេរិក។ សារធាតុកូកាអ៊ីនទាំងនេះភាគច្រើនបានមកពីរុក្ខជាតិកូកា ដែលដាំដុះដោយកសិកររនៅតំបន់ភ្នំនៃប្រទេសប៉េរូ បូលីវី និងកូឡុំប៊ី ដោយផ្ទាល់។ បន្ទាប់ត្រូវបានកែច្នៃក្នុងមន្ទីរពិសោធន៍សាមញ្ញក្នុងព្រៃភ្នំ សារធាតុកូកាអ៊ីនត្រូវបានដឹកជញ្ជូនពីប្រទេសកូឡុំប៊ីឆ្លងកាត់ប្រទេសជាច្រើនទៀត ដូចជា ប៉ាណាម៉ា មុនពេលមកដល់សហរដ្ឋអាមេរិក។ នៅក្នុងប្រទេសនីមួយៗ (សូម្បីតែសហរដ្ឋអាមេរិក) អ្នករត់ពន្ធគ្រឿងញៀនបានសូកប៉ាន់មន្ត្រីពុករលួយមួយចំនួន រួមទាំងមន្ត្រីយោធា ឬប៉ូលីស ដើម្បីកុំអោយគេចាប់បាន។ ប៉ុន្តែ មន្ត្រីរដ្ឋផ្សេងទៀតនៅក្នុងប្រទេសនីមួយៗ កំពុងធ្វើការជាមួយភ្នាក់ងារអនុវត្តច្បាប់របស់សហរដ្ឋអាមេរិក និងយោធាសហរដ្ឋអាមេរិក ដើម្បីបង្ក្រាបការជួញដូរសារធាតុកូកាអ៊ីន។ នៅឆ្នាំ ២០០៥ ជនជាតិបូលីវីបានបោះឆ្នោតជ្រើសរើសអតីតកសិករដាំកូកាប្រឆាំងនឹងអាមេរិក អោយធ្វើជាប្រធានាធិបតី ដែលគាំទ្រការធ្វើដាំដុះកូកា ទោះបីមិនផលិតកូកាអ៊ីនក៏ដោយ។

រូបថត *ប៉ូលីសជាតិអាហ្វហ្គានីស្ថានបំផ្លាញចំការអាភៀន*

សង្គ្រាមប្រឆាំងនឹងគ្រឿងញៀន

ដោយសារតែការជួញដូរគ្រឿងញៀនឆ្លងកាត់ព្រំដែនជាតិមួយទៅជាតិមួយទៀត ហើយពាក់ព័ន្ធនឹងកាំភ្លើង និងលុយកាក់ច្រើនសន្ធឹកសន្ធាប់ ទើបវាក្លាយជាប្រភពនៃជម្លោះអន្តរជាតិ។ ប្រទេសអាហ្វហ្គានីស្ថានផ្គត់ផ្គង់អាភៀនភាគច្រើនដែលប្រើសម្រាប់ផលិតហេរ៉ូអ៊ីននៅទូទាំងពិភពលោក ហើយពាណិជ្ជកម្មខុសច្បាប់នេះផ្តល់មូលនិធិដល់ពួកតាលីបង់ក្នុងការប្រយុទ្ធប្រឆាំងនឹងអង្គការណាតូ និងរដ្ឋាភិបាលអាហ្វហ្គានីស្ថាន។ នៅទីនេះ ប៉ូលីសជាតិអាហ្វហ្គានីស្ថានបំផ្លាញចំការអាភៀនឆ្នាំ ២០១៧ ។

ប្រជាជនមួយផ្នែក នៅក្នុងប្រទេសទាំងនេះ ជាពិសេស នៅក្នុងតំបន់ផលិតកូកាអ៊ីន ទទួលបានអត្ថប្រយោជន៍យ៉ាងច្រើនពីពាណិជ្ជកម្មគ្រឿងញៀន។ សម្រាប់កសិករក្រីក្រ ការជួញដូរកូកាអ៊ីនអាចជាលទ្ធភាពទទួលបានប្រាក់ចំណូលសមរម្យ។ អ្វីដែលសំខាន់ជាងនេះសម្រាប់អន្តរជាតិសន្តិសុខ កងទ័ពឧទ្ធាមអាចផ្តល់មូលនិធិដល់ប្រតិបត្តិការរបស់ពួកគេ ជាចម្បង តាមរយៈការគ្រប់គ្រងការជួញដូរគ្រឿងញៀនខុសច្បាប់។ អាហ្វហ្គានីស្ថាន ដែលជារណសិរ្សសំខាន់ក្នុងការតស៊ូរបស់បស្ចិមប្រទេស ប្រឆាំងនឹងពួកជ្រុលនិយមអ៊ីស្លាម (ជាពិសេស ពួកតាលីបង់) បានផ្គត់ផ្គង់វត្ថុធាតុដើមភាគច្រើន សម្រាប់ផលិតហេរ៉ូអ៊ីននៅក្នុងពិភពលោក។ នៅប្រទេសម៉ិកស៊ិក ដែលជាអ្នកផ្គត់ផ្គង់គ្រឿងញៀនខុសច្បាប់ដ៏សំខាន់មួយ ទៅកាន់សហរដ្ឋអាមេរិកដែលជាប្រទេសជិតខាង អំពើហឹង្សាដ៏សាហាវក្នុងចំណោមក្រុមឧក្រិដ្ឋជនគ្រឿងញៀនបានរីករាលដាល រហូតមិនអាចគ្រប់គ្រងបាន នៅក្នុងទសវត្សរ៍កន្លងមក ដោយបានឆក់យកជីវិតមនុស្សរាប់ម៉ឺននាក់។

នៅអាមេរិកឡាទីន ប្រវត្តិសាស្ត្រនៃការធ្វើអន្តរាគមន៍យោធារបស់សហរដ្ឋអាមេរិក តាំងពីយូរណាស់មកហើយ បានធ្វើអោយកិច្ចសហប្រតិបត្តិការរដ្ឋជាមួយកងកម្លាំងយោធាសហរដ្ឋអាមេរិកជាបញ្ហានយោបាយដ៏រសើប។ នៅក្នុងប្រទេសមួយចំនួន រដ្ឋាភិបាលបានប្រឈមមុខនឹងការរិះគន់ខ្លាំងៗពីប្រជាជនខ្លួនដោយសាររដ្ឋាភិបាលអនុញ្ញាតអោយ «Yankees» «ឈ្លានពាន»នៅក្នុងសង្គ្រាមគ្រឿងញៀន។ ក្នុងករណីមួយ យោធាអាមេរិកបានលុកលុយដោយត្រង់ៗតែម្តង។ នៅឆ្នាំ ១៩៨៩ កងកម្លាំងសហរដ្ឋអាមេរិកបានលុកលុយប្រទេស

ប៉ាណាម៉ា បានចាប់ខ្លួនមេដឹកនាំជាជនផ្តាច់ការ ម៉ានុយអែល ណូរៀហ្គា (Manuel Noriega) ហើយបាននាំខ្លួនទៅកាត់ទោស នៅតុលាការសហរដ្ឋអាមេរិក ពីបទពាក់ព័ន្ធក្នុងការជួញដូរគ្រឿងញៀន តាមរយៈប្រទេសប៉ាណាម៉ា។

ដូចដែលមានលទ្ធផលច្រើននៃជម្លោះ សង្គ្រាមជាច្រើនប្រភេទ និងទំនោរផ្សេងៗគ្នាជាច្រើនសម្រាប់អំពើហិង្សាក្នុងចំណោមរដ្ឋផ្សេងៗគ្នា ដូច្នេះ ក៏មានភាពចម្រុះយ៉ាងខ្លាំងចំពោះរបៀបដែលកងកម្លាំងត្រូវបានប្រើប្រាស់ ប្រសិនបើជម្លោះនាំទៅរកអំពើហិង្សា។ រដ្ឋនានាបង្កើតកងកម្លាំងយោធាជាច្រើន ប្រភេទដែលមានភាពខុសប្លែកគ្នាយ៉ាងខ្លាំង នៅក្នុងគោលបំណងនិងសមត្ថភាពរបស់ពួកគេ។ កងកម្លាំងយោធាទាំងនេះ គឺជាការផ្តោតជាសំខាន់ នៅក្នុងមេរៀនបន្ទាប់។

សេចក្តីសន្ទេប

១. នៅពេលមធ្យោបាយហិង្សាត្រូវបានប្រើសម្រាប់ជាអានុភាពយកប្រៀបគូបដិបក្ខ ក្នុងជម្លោះអន្តរជាតិ អាចបណ្តាលអោយផ្ទុះសង្គ្រាមជាច្រើន។ សង្គ្រាមទាំងនេះខុសគ្នាទាំងទំហំ និង ចរិតឬប្រភេទ រាប់ចាប់ពីសង្គ្រាមទំពែរនិងការវាយឆ្មក់ រហូតដល់ សង្គ្រាមអនុត្តរភាពដណ្តើមធ្វើជាមេដឹកនាំនៃប្រព័ន្ធអន្តរជាតិ។ តាមរយៈវិសាលភាពនៃការប្រើប្រាស់អំពើហិង្សា និយមន័យពិតប្រាកដនៃសង្គ្រាមនីមួយ មិនអាចកំណត់អោយបានដាច់ពីគ្នានោះទេ។

២. ទ្រឹស្តីជាច្រើនត្រូវបានផ្តល់ការពន្យល់ទូទៅអំពីកាលៈទេសៈដែលអានុភាពបែបនេះកើតឡើង៖ បុព្វហេតុនៃសង្គ្រាម។ ទ្រឹស្តីផ្ទុយគ្នាត្រូវបានបង្កើតឡើង នៅក្នុងកម្រិតនៃការវិភាគនីមួយៗ ហើយគ្មានទ្រឹស្តីណាមួយមានភស្តុតាងវិទ្យាសាស្ត្រគាំទ្រជាក់ស្តែងឡើយ (ដោយមានករណីលើកលែងចំនួនពីរ)។ ដូច្នេះអ្នកវិទ្យាសាស្ត្រនយោបាយមិនអាចធ្វើការព្យាករណ៍ដោយទុកចិត្តបាន ពីការផ្ទុះឡើងនៃសង្គ្រាមនោះទេ។

៣. ស្មារតីជាតិនិយមមានឥទ្ធិពលយ៉ាងខ្លាំងទៅលើទំនាក់ទំនងអន្តរជាតិ។ ជាញឹកញាប់ ជម្លោះបណ្តាលមកពីមនសិការជាតិ ដែលនាំអោយមានការទាមទារអោយមានការបង្កើតជារដ្ឋ ឬទាមទារអោយកែសម្រួលព្រំដែនរបស់រដ្ឋ។

៤. ជម្លោះជាតិសាសន៍ ជាពិសេស នៅពេលមានទំនាក់ទំនងជាមួយជម្លោះទឹកដី ពិតជាពិបាកដោះស្រាយណាស់ ដោយសារតែភាពលំអៀងចិត្តសាស្ត្រ។ វាពិបាកក្នុងការពន្យល់ពីមូលហេតុដែលភាពស្មោះស្ម័គ្ររបស់ប្រជាជន ជួនកាលចំពោះក្រុមជនជាតិរបស់ពួកគេ និងពេលខ្លះចំពោះប្រជាជាតិពហុជាតិ។

៥. ចលនាសាសនាមូលដ្ឋាននិយមបង្កបញ្ហាប្រឈមយ៉ាងជ្រាលជ្រៅចំពោះវិធាននៃប្រព័ន្ធអន្តរជាតិ ជាទូទៅ និងចំពោះអធិបតេយ្យភាពរបស់រដ្ឋ ជាពិសេស។

៦. មនោគមវិជ្ជាមិនសំខាន់ណាស់ណាទេនៅក្នុងទំនាក់ទំនងអន្តរជាតិ អាចមានករណីលើកលែងចំពោះលទ្ធិប្រជាធិបតេយ្យក្នុងនាមជាមនោគមន៍វិជ្ជា។ មេដឹកនាំរដ្ឋអាចប្រើមនោគមវិជ្ជាដើម្បីបង្ហាញហេតុផលថាសកម្មភាពណាមួយដែលជាផលប្រយោជន៍របស់ពួកគេ។

៧. ជម្លោះដែនដីស្ថិតក្នុងចំណោមជម្លោះអន្តរជាតិធ្ងន់ធ្ងរបំផុត ព្រោះរដ្ឋនានាផ្តល់តម្លៃយ៉ាងខ្លាំងពេកក្រៃដល់បូរណភាពទឹកដី។ ទោះយ៉ាងណា ជាមួយនឹងការលើកលែងមួយចំនួន ព្រំដែនស្ទើរតែទាំងអស់នៅលើពិភពលោកត្រូវបានកំណត់យ៉ាងរឹងមាំ និងមានការទទួលស្គាល់ជាអន្តរជាតិ។

៨. ជម្លោះដណ្តើមគ្រប់គ្រងរដ្ឋទាំងមូល (តាមរយៈការគ្រប់គ្រងរបស់រដ្ឋាភិបាល) ក៏មានលក្ខណៈធ្ងន់ធ្ងរផង

ដែរ ហើយទំនងជាឈានដល់ការប្រើប្រាស់កម្លាំង។

៩. ជម្លោះសេដ្ឋកិច្ចមិនសូវនាំអោយមានអំពើហិង្សាជាញឹកញាប់ទេ ពីព្រោះផលចំណេញវិជ្ជមានពីសកម្មភាពសេដ្ឋកិច្ចមានប្រសិទ្ធភាពខ្ពស់ជាងការគំរាមកំហែងអវិជ្ជមានដោយអំពើហិង្សា។

ពាក្យគន្លឹះ

១. **សង្គ្រាមអនុត្តរភាព**(hegemonic war) គឺជាសង្គ្រាមដណ្តើមគ្រប់គ្រងលើសណ្តាប់ធ្នាប់ពិភពលោកទាំងមូល៖ ក្រិតក្រមច្បាប់នៃប្រព័ន្ធអន្តរជាតិទាំងមូល រួមទាំងតួនាទីនៃអនុត្តរភាពពិភពលោក។ ពេលខ្លះក៏ត្រូវហៅថា សង្គ្រាមលោក សង្គ្រាមសកល សង្គ្រាមទូទៅ ឬសង្គ្រាមប្រព័ន្ធ ផងដែរ។

២. **សង្គ្រាមសរុប**(total war) គឺជាសង្គ្រាមដែលផ្តើមដោយរដ្ឋមួយ ដើម្បីដណ្តើមយកនិងកាន់កាប់រដ្ឋមួយទៀត។ សង្គ្រាមសរុបក្នុងសម័យទំនើបមានដើមកំណើតនៅក្នុងសង្គ្រាមណាប៉ូឡេអុង ដែលពឹងផ្អែកលើការជ្រើសរើសកងទ័ពជាទ្រង់ទ្រាយធំ។

៣. **សង្គ្រាមមានកម្រិត**(limited war) រួមមានសកម្មភាពនិងយុទ្ធនាការយោធាដែលធ្វើឡើង ដើម្បីសម្រេចបាននូវគោលដៅមួយចំនួន ដូចជា ការចុះចាញ់និងការកាន់កាប់របស់សត្រូវ។

៤. **សង្គ្រាមស៊ីវិល**(civil war) សំដៅលើសង្គ្រាមរវាងបក្សពួកឬភាគីនានានៅផ្ទៃក្នុងរដ្ឋមួយ ដែលព្យាយាមបង្កើតឬរារាំងរដ្ឋាភិបាលថ្មីគ្រប់គ្រងរដ្ឋទាំងមូល ឬផ្នែកខ្លះនៃទឹកដីនៃរដ្ឋនោះ។

៥. **សង្គ្រាមទំព័ព្រៃ**(guerrilla war) គឺជាសង្គ្រាមដោយគ្មានសមរភូមិមុខ ហើយកងកម្លាំងមិនទៀងទាត់ប្រតិបត្តិការ នៅក្នុងចំណោម (ហើយជារឿយៗ ត្រូវបានលាក់កំបាំងឬការពារដោយ) ប្រជាជនស៊ីវិលសាមញ្ញ។

៦. **គណៈកម្មការស្វែងរកការពិត** គឺជាស្ថាប័នរដ្ឋាភិបាលដែលត្រូវបានបង្កើតឡើងនៅក្នុងប្រទេសមួយចំនួនបន្ទាប់ពីសង្គ្រាមផ្ទៃក្នុង ដើម្បីស្តាប់សក្ខីកម្ម ដោយស្មោះត្រង់ និងបង្ហាញអោយឃើញនូវអ្វីដែលពិតជាបានកើតឡើងក្នុងអំឡុងពេលសង្គ្រាមទាំងនេះ ហើយជាថ្នូរមកវិញ ផ្តល់សិទ្ធិជ្រកកោនដល់អ្នកចូលរួមភាគច្រើនរួចផុតពីការផ្តន្ទាទោស។

៧. **ជម្លោះ** ការចង់បានលទ្ធផលខុសគ្នា នៅក្នុងស្ថានភាពចរចាណាមួយ។

៨. **ទ្រឹស្តីវដ្ត** គឺជាកិច្ចខិតខំប្រឹងប្រែងដើម្បីពន្យល់ពីទំនោរឆ្ពោះទៅរកសង្គ្រាមនៅក្នុងប្រព័ន្ធអន្តរជាតិថាជា វដ្តជាឧទាហរណ៍ ដោយភ្ជាប់សង្គ្រាមនានាជាមួយនឹងរលកដ៏ធំ នៅក្នុងសេដ្ឋកិច្ចពិភពលោក (វដ្ត Kondratieff)។

៩. **ជាតិនិយម** គឺជាការកំណត់អត្តសញ្ញាណ និងលះបង់ដើម្បីផលប្រយោជន៍ជាតិ។ ជាធម្មតា វាពាក់ព័ន្ធនឹងមនុស្សមួយក្រុមធំ ដែលមានអត្តសញ្ញាណជាតិរួមគ្នា ហើយជារឿយៗ មានដូចជា ភាសា វប្បធម៌ ឬពូជពង្សដើមតែមួយ។

១០. **ក្រុមជាតិសាសន៍ឬជាតិពន្ធ** គឺជាក្រុមធំៗនៃមនុស្សដែលមានទំនាក់ទំនងដូនតា ភាសា វប្បធម៌ ឬសាសនា និងអត្តសញ្ញាណរួមមួយ។

១១. **ការប្រកាន់ពូជសាសន៍និយម**(ethnocentrism)ឬ*ការលម្អៀងក្នុងក្រុម*គឺជាទំនោរក្នុងការមើលឃើញក្រុមជាតិសាសន៍របស់ខ្លួន នៅក្នុងទិដ្ឋភាពអំណោយផល ឬយល់ឃើញក្រុមខ្លួនក្នុងន័យល្អៗលើសគេ និងយល់ឃើញ*ក្រុមខាងក្រៅ*ក្នុងលក្ខណៈមិនអំណោយផល។

១២. **ការបន្ទាបបន្ថោកមនុស្ស**(dehumanization) ការមាក់ងាយខ្មាំងសត្រូវជាមនុស្សថោកទាបជាងខ្លួន ឬអមនុស្ស ដែលនាំអោយមានអំពើហិង្សារីករាលដាលជាញឹកញាប់។ សូមមើលផងដែរ *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ* និង*អំពើប្រល័យពូជសាសន៍*។

១៣. **អំពើប្រល័យពូជសាសន៍** (Genocide) គឺជាការសម្លាប់រង្គាល ជាប្រព័ន្ធ ដោយចេតនា ទៅលើក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា ទាំងមូលឬមួយផ្នែក។ ទង្វើនេះត្រូវបានបញ្ជាក់ថាជាឧក្រិដ្ឋកម្មនៅក្រោមច្បាប់អន្តរជាតិដោយអនុសញ្ញាប្រល័យពូជសាសន៍របស់អង្គការសហប្រជាជាតិ(១៩៤៨)។ សូមមើលផងដែរ *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ* និង*ការបន្ទាបបន្ថោកមនុស្ស*។

១៤. **ផ្លូវអាណាចក្រ** ឬ ផ្លូវលោក ឬ ខាងលោកីយ៍ (Secular) ត្រូវបានបង្កើតឡើងក្រៅស្ថាប័នសាសនា ហើយក្នុងនោះមានការបែងចែកដាច់រវាងស្ថាប័នសាសនា និងអង្គការនយោបាយ។

១៥. **សាសនាអ៊ីស្លាម** (Islam) គឺជាសាសនាពិភពលោកដ៏ទូលំទូលាយនិងចម្រុះច្រើន ដែលមានគោរពប្រតិបត្តិផ្សេងគ្នាជាច្រើន រួមមានមូស្លីមនិកាយស៊ុននី មូស្លីមនិកាយស៊ីអ៊ីត និងសាខា និងនិកាយតូចៗជាច្រើន ពីនីហ្សេរីយ៉ា រហូតដល់ប្រទេសឥណ្ឌូនេស៊ី ដែលផ្តុំនៅតំបន់មជ្ឈឹមបូព៌ានិងអាស៊ីទក្សិណ។

១៦. **មូស្លីម** (Muslim) សំដៅលើអ្នកកាន់សាសនាអ៊ីស្លាម ឬអ៊ីស្លាមសាសនិកជន។

១៧. **អ៊ីស្លាមនិយម**(Islamist) គឺជាការបរិយាយអំពីមនោគមវិជ្ជានយោបាយ ផ្អែកលើការដាក់បញ្ចូលគោលការណ៍និងច្បាប់អ៊ីស្លាមនៅក្នុងរដ្ឋាភិបាល។ ក្រុមជាច្រើនយ៉ាងទូលំទូលាយ ដែលប្រើប្រាស់វិធីសាស្ត្រចម្រុះ ស្ថិតក្នុងក្រុមប្រភេទនេះ។

១៨. **គោលនយោបាយទាមទារទឹកដីនិយម** (irredentism) គឺជាទម្រង់នៃលទ្ធិជាតិនិយម ដែលមានគោលដៅយកមកវិញនូវទឹកដីដែលបាត់បង់ទៅរដ្ឋមួយទៀត។ ដោយផ្ទាល់ វាអាចបណ្តាលអោយមានជម្លោះអន្តររដ្ឋ ដោយហិង្សា។

១៩. **ការបន្សុទ្ធជាតិសាសន៍** (ethnic cleansing) គឺជារ៉ៅហាសាសន៍សំដៅលើការបោសសំអាតជនជាតិភាគតិច ឬជាតិសាសន៍ណាមួយ ចេញពីកណ្តាលណាមួយ ដោយបង្ខំ អមដោយការសម្លាប់រង្គាល និងការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរទៀតផង។ វាបានកើតឡើងបន្ទាប់ពីការបំបែករដ្ឋដែលចម្រុះជាតិសាសន៍ជាពិសេស នៅក្នុងអតីតយូហ្គោស្លាវី។

២០. **ដែនទឹក** (territorial waters) គឺជាផ្ទៃទឹកនៅជិតច្រាំងឆ្នេរសមុទ្ររបស់រដ្ឋនានាជាទូទៅ ត្រូវបានចាត់ទុកថាជាផ្នែកនៃទឹកដីជាតិនៃរដ្ឋនោះ។ អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រផ្តល់សម្រាប់ដែនសមុទ្រប្រវែង ១២ ម៉ាយល៍ (យុត្តាធិការជាតិផ្តាច់មុខលើការដឹកជញ្ជូន និងការធ្វើនាវាចរណ៍) និងតំបន់សេដ្ឋកិច្ចផ្តាច់មុខ(EEZ) ប្រវែង ២០០ ម៉ាយល៍ (ដោយរួមបញ្ចូលសិទ្ធិនេសាទនិងរ៉ែផ្តាច់មុខ ប៉ុន្តែអនុញ្ញាតអោយមានការធ្វើនាវាចរណ៍ដោយសេរីសម្រាប់មនុស្សគ្រប់រូប។) សូមមើលផងដែរនូវ *សមុទ្រទឹកជ្រៅ* និង*អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ*(UNCLOS)។

២១. **ដែនអាកាស**(airspace) គឺជាលំហអាកាស នៅពីលើរដ្ឋមួយ ដែលត្រូវបានចាត់ទុកថាជាទឹកដីរបស់ខ្លួន ផ្ទុយពីលំហអាកាសនៅខាងក្រៅ ដែលចាត់ទុកថាជាទឹកដីអន្តរជាតិ។

សំណួរអនុវត្តន៍

១. ដោយយោងតាមនិយមន័យនៃសង្គ្រាមដែលត្រូវបានកំណត់នៅខាងដើមជំពូក ចូរលើកយកស្ថានភាពអន្តរជាតិបច្ចុប្បន្នចំនួនពីរដែលសមស្របនឹងនិយមន័យនៃសង្គ្រាម និងស្ថានភាពចំនួនពីរដែលមិនសមស្របទាំងស្រុងតាមនិយមន័យសង្គ្រាមនីមួយៗ ឬជា«សង្គ្រាមកូនកាត់» (ស្ទើរតែត្រូវនឹងនិយមន័យ ប៉ុន្តែមិនត្រូវតាមទាំងស្រុង)។ តើអ្នកគិតថាស្ថានភាពមួយណាធ្ងន់ធ្ងរជាង សង្គ្រាមចំ ឬ សង្គ្រាមកូនកាត់? តើវាពាក់ព័ន្ធនឹងតួអង្គប្រភេទផ្សេងៗដែរឬទេ? តើវាជាជម្លោះប្រភេទផ្សេងគ្នាឬយ៉ាងណា? សមត្ថភាពខុសគ្នាដែរឬយ៉ាងណា?

២. សៀវភៅសិក្សាគោលនៅអឺរ៉ុបត្រូវបានកែសម្រួល ក្រោយសង្គ្រាមលោកលើកទី ២ ដើម្បីកាត់បន្ថយបុរេនិច្ឆ័យទៅលើជនជាតិនិងជាតិនីមួយៗ និងដើម្បីបង្ហាញពីការពិពណ៌នាដែលមានភាពយុត្តិធម៌សម្រាប់ប្រជាជាតិអឺរ៉ុបផ្សេងៗ។ ចុះសៀវភៅសិក្សាពុម្ពដែលអ្នកធ្លាប់រៀនប្រវត្តិសាស្ត្រនៃប្រទេសរបស់អ្នក? តើសៀវភៅទាំងនោះបានផ្តល់ទិដ្ឋភាពត្រឹមត្រូវជាក់ស្តែង ឬក៏ តើលើកសរសើរហួសហេតុអំពីគុណធម៌នៃក្រុមជនជាតិឬប្រទេសជាតិរបស់អ្នក ដោយបន្ទាបបន្ថោកជនជាតិដទៃ? ដោយរបៀបណា? ចូរលើកឧទាហរណ៍ជាក់ស្តែង?

៣. ចូរពិពណ៌នាអំពីសង្គ្រាមក្នុងស្រុក/អន្តរជាតិដ៏សំខាន់ណាមួយ ដែលប្រទេសរបស់អ្នកបានជួបប្រទះឬបានយល់ដឹងច្បាស់។ ចូរធ្វើការសិក្សាស្រាវជ្រាវរកមើលថា តើប្រទេសផ្សេងទៀតបរិយាយអំពីសង្គ្រាមនោះយ៉ាងដូចម្តេច។ តើការបរិយាយផ្សេងៗគ្នាអាចត្រូវបានពន្យល់យ៉ាងដូចម្តេច ប្រសិនបើមានការបរិយាយខុសគ្នា?

៤. ឧបមាថាអ្នកជាអ្នកសម្រុះសម្រួលក្នុងការចរចារវាងរដ្ឋពីរ ដោយរដ្ឋនីមួយៗទាមទារចំណែកផ្ទៃដីដូចគ្នា។ តើអ្នកអាចអនុវត្តតាមគោលការណ៍អ្វីខ្លះក្នុងការបង្កើតផែនការដែលអាចទទួលយកបានទាំងអស់គ្នាសម្រាប់ភាពជាម្ចាស់នៃទឹកដី? តើអ្នកអាចប្រើមធ្យោបាយអ្វីខ្លះដើម្បីបញ្ចុះបញ្ចូលរដ្ឋទាំងពីរអោយទទួលយកផែនការរបស់អ្នក?

៥. ក្នុងចំណោមជម្លោះអន្តរជាតិចំនួនប្រាំមួយប្រភេទ ដែលត្រូវបានពិភាក្សាក្នុងមេរៀននេះ តើអ្នកអាចភ្ជាប់ជម្លោះប្រភេទណាខ្លះជាមួយនឹងបាតុភូត*ជាតិនិយម* ដូចដែលវាត្រូវបានកំណត់និយមន័យនៅក្នុងមេរៀននេះដែរឬទេ? តើក្នុងករណីជម្លោះនីមួយៗ មានអ្វីខ្លះទាក់ទងគ្នា?

៦. ការកើនឡើងនៃជំនឿជ្រុលនិយម(មូលដ្ឋាននិយម) ក្នុងចំណោមសាសនាធំៗក្នុងពិភពលោកបង្កជាការប្រឈមចំពោះសញ្ញាណប្រពៃណីនៃអធិបតេយ្យភាពរបស់រដ្ឋ។ តើនិន្នាការនេះអាចនឹងសពង្រឹង ឬធ្វើអោយខ្សោយអង្គការសហប្រជាជាតិនិងការប៉ុនប៉ងបង្កើតអង្គការអន្តរជាតិ(ដែលតតាំងនឹងអធិបតេយ្យភាពរដ្ឋផងដែរ)?

ការស្វែងរកផលប្រយោជន៍រួម

សន្តិភាពនៅអាមេរិកឡាទីន

ផលប្រយោជន៍រួម៖ ទំនាក់ទំនងសន្តិភាពក្នុងចំណោមរដ្ឋអាមេរិកឡាទីនទាំងឡាយ

រូបថត មេដឹកនាំអាមេរិកខាងត្បូងពិភាក្សាអំពីពាណិជ្ជកម្មមិនមែនសង្គ្រាមនៅអាហ្សង់ទីនឆ្នាំ ២០១៧។

សារតារ

ក្នុងចំណោមតំបន់ទាំងអស់នៅលើពិភពលោក អាមេរិកឡាទីនឬអាមេរិកខាងត្បូង គឺជាតំបន់មួយដែលមានសន្តិភាពបំផុត។ អ្នកប្រាជ្ញាមួយចំនួនរហូតដល់បរិយាយអាមេរិកឡាទីនថាជាសហគមន៍សន្តិសុខមួយ ដោយសារតំបន់នេះ មានហានីភ័យសង្គ្រាមអន្តរដ្ឋទាបបំផុតនៅក្នុងតំបន់ អស់រយៈពេលជាង ១០០ ឆ្នាំមកហើយ បើទោះបីជាមានសង្គ្រាមស៊ីវិល និងការខ្វែងគំនិតគ្នានៅតាមព្រំដែនរវាងរដ្ឋជាច្រើន នៅក្នុងតំបន់ក៏ដោយ។ សន្តិភាពស្ថិរភាពគឺជាផលប្រយោជន៍រួម ដែលប្រទេសទាំងអស់ក្នុងតំបន់បាននិងកំពុងរីករាយទទួល បើទោះបីជាប្រទេសទាំងនោះបានបំពារបំពានវា អាចនឹងទទួលបាន ឬ បាត់ទឹកដី ឬទ្រព្យសម្បត្តិ ដោយប្រើកម្លាំងយោធាក៏ដោយ។

បញ្ហាប្រឈម

ទោះបីជាមានទំនាក់ទំនងអន្តរដ្ឋសន្តិភាពនៅក្នុងតំបន់ ជាច្រើនឆ្នាំមកហើយក្តី ជម្លោះរ៉ាំរ៉ៃនៅតែកើតឡើងជាហូរហែរ រវាងរដ្ឋមួយចំនួន។ នៅឆ្នាំ ១៩៩៥ ប្រទេសប៉េរូ និងប្រទេសអេក្វាឌ័របានប្រយុទ្ធគ្នានៅតាមព្រំដែន។ ចាប់តាំងពីឆ្នាំ ២០០០ ជម្លោះផ្សេងទៀត បានរីករាលដាលកាន់តែធំទៅៗ។ ប្រទេសបូលីវីចង់ទាមទារមកវិញនូវច្រករបៀងចេញទៅសមុទ្រ ដែលខ្លួនបានបាត់បង់ទៅអោយប្រទេសឈីលី កាលពីជាង ១០០ ឆ្នាំមុន។ ប្រទេសកូឡុំប៊ី និងប្រទេសវេណេហ្ស៊ុយអេឡា បានចោទប្រកាន់គ្នាចំពោះ ការគាំទ្ររបស់វេណេហ្ស៊ុយអេឡាចំពោះក្រុមឧទ្ទាម ដែលកំពុងប្រយុទ្ធនៅក្នុងប្រទេសកូឡុំប៊ី។ ប្រទេសដែលជាគូប្រជែងមានភាសាខុសគ្នា មនោគមវិជ្ជាខុសគ្នា ជម្លោះទឹកដី ការប្រកួតប្រជែងសេដ្ឋកិច្ច និងវិវាទជាច្រើនប្រភេទទៀត។ ជាមួយនឹងប្រទេសដែលមានកងទ័ពជើងគោក និងកងទ័ពជើងទឹកដ៏ធំសម្បើមត្រៀមខ្លួនរួចជាស្រេចដូចនេះ លទ្ធភាពផ្ទុះសង្គ្រាមតែងតែកើតមាន។

ដំណោះស្រាយ

តើអាមេរិកឡាទីនបានបញ្ចៀសសង្គ្រាមអន្តរដ្ឋធំៗ ដោយរបៀបណា? ដំណោះស្រាយអាចត្រូវបានរកឃើញទាំងនៅក្នុងគោលការណ៍បដិការនិងអត្តសញ្ញាណ។ រដ្ឋទាំងអស់ជាសមាជិកនៃអង្គការនៃរដ្ឋអាមេរិក (OAS)ដែលលើកកម្ពស់គោលការណ៍បដិការនិងការចរចា នៅពេលជម្លោះនយោបាយកើតឡើង។ សូម្បីតែពេលខ្លះជម្លោះផ្ទុះឡើង ជម្លោះមិនរីករាលដាលធំនិងអូសបន្លាយយូរ ហើយក៏មិនបានក្លាយជាជម្លោះយោធាទ្រង់ទ្រាយធំដែរ។ ដំណើរការចរចានេះបានទទួលជោគជ័យក្នុងការដោះស្រាយជម្លោះ ដែលមានស្រាប់ជាច្រើន សូម្បីតែជម្លោះរវាងប្រទេសប៉េរូនិងអេក្វាឌ័រ បីឆ្នាំបន្ទាប់ពីសង្គ្រាមព្រំដែនពួកគេ។

គោលការណ៍អត្តសញ្ញាណក៏នៅមានប្រសិទ្ធិភាពដដែល។ អាមេរិកឡាទីន បានបង្កើតបទដ្ឋានរួមមួយសម្រាប់ដោះស្រាយជម្លោះ។ ជម្លោះអន្តរដ្ឋរវាងរដ្ឋពីរត្រូវបានគេយល់ឃើញថាជា ការគំរាមកំហែងដល់រដ្ឋទាំងអស់នៅក្នុងតំបន់នេះ។ រដ្ឋនីមួយៗគិតគូរយ៉ាងទូលំទូលាយអំពីផលប្រយោជន៍របស់ខ្លួន ដោយរួមបញ្ចូលទាំងការបន្តសុខសន្តិភាពក្នុងតំបន់។ ដោយសារវិធីសាស្ត្រនេះ ការគំរាមកំហែងដល់សន្តិភាពត្រូវបានដោះស្រាយយ៉ាងសកម្មដោយសហគមន៍ទាំងមូល។

ឧស្សន:ទិស័យគោលនយោបាយ

នាយករដ្ឋមន្ត្រីបង់ក្លាដែស ហ្សីក ហាស៊ីណា វ៉ាជីដ (Sheikh Hasina Wazed)

រូបថត នាយករដ្ឋមន្ត្រី ហ្សីក ហាស៊ីណា វ៉ាជីដ

បញ្ហា

តើអ្នកការពារជម្លោះស៊ីវិលដោយរបៀបណា ក្នុងខណៈពេលផ្តល់ជំនួយមនុស្សធម៌?

សាវតារ

ចូរស្រមៃថាអ្នកគឺជានាយករដ្ឋមន្ត្រីនៃប្រទេសបង់ក្លាដែស។ អ្នកកំពុងកាន់តំណែង ក្នុងអាណត្តិទីបីជានាយករដ្ឋមន្ត្រីនៃប្រទេសដែលមានប្រជាជនសន្ធឹកសន្ធាប់នៅអាស៊ីទក្សិណមួយនេះ។ អ្នកគឺជាអ្នកដឹកនាំដ៏មានប្រជាប្រិយមួយរូប ហើយត្រូវបានចាត់ទុកថាជាស្ត្រីម្នាក់ ដ៏មានឥទ្ធិពលបំផុត នៅក្នុងពិភពលោក។

ទោះជាយ៉ាងណាក៏ដោយ ក្នុងឆ្នាំ ២០១៧ បញ្ហាប្រឈមដ៏សំខាន់មួយបានលេចឡើង៖ ដោយសារតែអំពើហិង្សានៅក្នុងរដ្ឋរ៉ាយីននៅភូមាដែលជាប្រទេសជិតខាង ជនភៀសខ្លួនរាប់សែននាក់បានភៀសខ្លួនចូលទៅក្នុងប្រទេសបង់ក្លាដែស។ ជនភៀសខ្លួនដែលត្រូវគេស្គាល់ថាជា ជនជាតិរ៉ូហ៊ីងយ៉ា បានភៀសខ្លួនចេញពីអំពើហឹង្សាជនជាតិភាគតិច ដែលអ្នកសង្កេតការណ៍ជាច្រើនបានពិពណ៌នាថាជា ការបន្សុទ្ធជាតិសាសន៍។ រដ្ឋាភិបាលរបស់អ្នកបានរៀបចំជំរុំជនភៀសខ្លួន យ៉ាងឆាប់រហ័ស ដើម្បីទប់ស្កាត់គ្រោះមហន្តរាយមនុស្សធម៌ដ៏មានសក្តានុពលនេះ។ សហគមន៍អន្តរជាតិបានជួយជាថវិកា និងស្បៀងអាហារដើម្បីជួយទ្រទ្រង់ជនភៀសខ្លួនភូមា នៅក្នុងប្រទេសរបស់អ្នក។ ទោះជាយ៉ាងណាក៏ដោយ កិច្ចការនេះមានវិសាលភាពធំធេងណាស់៖ តាមការប៉ាន់ស្មានមួយ ពេលនេះ មនុស្សជាង ៥០០,០០០ នាក់កំពុងរស់នៅក្នុងជំរុំជនភៀសខ្លួននៅក្នុងតំបន់ព្រំដែនរបស់អ្នក។

ការពិចារណាក្នុងស្រុក

ក្នុងខណៈពេលដែលប្រទេសបង់ក្លាដែសជាប្រទេសដែលមានស្ថិរភាព និងសន្តិភាព តាមពិតទៅ វាគឺជាប្រទេសដ៏ក្រីក្រមួយ។ ប្រជាជនរបស់អ្នក ប្រហែល ១៥ ភាគរយ កំពុងរស់នៅក្នុងបន្ទាត់ក្រីក្រតោកយ៉ាកខ្លាំង។ ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធក្នុងប្រទេសរបស់អ្នក មានកម្រិតខ្សោយ ហើយរដ្ឋធានីរបស់អ្នក**ដាកា** ត្រូវបានគេចាត់ទុកថាមានភាពចង្អៀតខ្លាំង។ ទោះជាយ៉ាងណាក៏ដោយ ថ្មីៗនេះ សេដ្ឋកិច្ចជាតិរបស់អ្នកបានចាប់ផ្តើមកើនឡើង ដោយមានអត្រាកំណើនសេដ្ឋកិច្ចខ្ពស់បំផុត ក្នុងរយៈពេលជាច្រើនទសវត្សរ៍ក្នុងឆ្នាំ ២០១៦។ អត្រាអត់ការងារធ្វើនិងភាពក្រីក្របានធ្លាក់ចុះ នៅក្នុងទសវត្សរ៍ចុងក្រោយនេះ។ បើនិយាយពីវិស័យនយោបាយ អ្នកប្រឈមនឹងសំឡេងបក្សប្រឆាំងដ៏ខ្លាំងផងដែរ។ សមាជិកបក្សប្រឆាំងចង្អុលបង្ហាញ (ជាញឹកញាប់)ថា ការបោះឆ្នោតមុន គឺជាការរំលោភលើរដ្ឋធម្មនុញ្ញរបស់ប្រទេសបង់ក្លាដែស ចាប់តាំងពីនាយករដ្ឋមន្ត្រីត្រូវបានកំណត់ត្រឹមតែពីរអាណត្តិប៉ុណ្ណោះ។

សេណារីយ៉ូ

ឥឡូវនេះ ចូរស្រមៃថា សហគមន៍អន្តរជាតិ តាមរយៈឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន(UNHCR)បានស្នើអោយអ្នកបន្តរក្សាជនជាតិរ៉ូហ៊ីងយ៉ា នៅក្នុងទឹកដីរបស់អ្នកអោយបានយូរជាងនេះ។ ឧត្តមស្នងការ UNHCR នឹងមិនអនុញ្ញាតអោយអ្នកធ្វើមាតុភូមិនិវត្តន៍ជនជាតិរ៉ូហ៊ីងយ៉ាដោយបង្ខំទេ ដោយសារពួកគេនៅតែប្រឈមមុខនឹងការគំរាមកំហែងយ៉ាងខ្លាំង ចំពោះសុខសុវត្ថិភាពរបស់ពួកគេ ប្រសិនបើពួកគេត្រឡប់ទៅប្រទេសភូមាវិញ។

ទីប្រឹក្សាសេដ្ឋកិច្ចរបស់អ្នកមានការព្រួយបារម្ភខ្លាំងណាស់។ ការគាំទ្រមនុស្សប្រមាណកន្លះលាននាក់បន្ថែមទៀតនៅក្នុងទឹកដីរបស់អ្នកត្រូវចំណាយច្រើនណាស់។ ពួកគេបារម្ភថា ការចំណាយបន្ថែមនោះ នឹងគំរាមកំហែងដល់កំណើនសេដ្ឋកិច្ច ដែលប្រទេសរបស់អ្នកទទួលបាន ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។

ហើយខណៈពេលដែលសហគមន៍អន្តរជាតិ ទាំងអង្គការអន្តរជាតិ(IOs) និងអង្គការក្រៅរដ្ឋាភិបាល(NGOs) បានជួយទទួលបន្ទុកថ្លៃចំណាយ, ជំនួយដែលអ្នកទទួលបានមិនគ្រប់ថ្លៃចំណាយសម្រាប់គាំទ្រជំរំជនភៀសខ្លួនឡើយ ពោលគឺ មានគំលាតធ្ងាយខ្លាំងរវាងការចំណាយរបស់អ្នក និងទំហំជំនួយដែលអ្នកទទួលបាន។ លើសពីនេះទៅទៀត ជំរុំជនភៀសខ្លួនជាច្រើនមានទីតាំងនៅស្ថិតក្នុងតំបន់កសិកម្ម ដែលការបន្តមានវត្តមានរបស់ពួកគេបានធ្វើអោយមានផលវិនាសដល់ការរស់នៅក្នុងតំបន់ ហើយដំណាំទាំងឡាយក៏ខូចខាត ឬមិនអាចអោយគេប្រមូលផលបានឡើ។

ជម្លោះនៅភូមានៅតែបន្តកើតឡើង។ ជនជាតិរ៉ូហ៊ីងយ៉ានឹងមិនមានសុវត្ថិភាព នៅពេលត្រឡប់ទៅមាតុភូមិវិញ ហើយអាចប្រឈមមុខនឹងការគំរាមកំហែងនៃអំពើប្រល័យពូជសាសន៍ទៀតផង។ ហើយគេក៏មិនរំពឹងថានឹងមានអន្តរាគមន៍អន្តរជាតិដើម្បីបញ្ឈប់អំពើហឹង្សានៅភូមាដែរ។

ចូរជ្រើសរើសគោលនយោបាយរបស់អ្នក

តើអ្នកនឹងដោះស្រាយស្ថានភាពជនភៀសខ្លួនដោយរបៀបណា? តើអ្នកនឹងស្នើសុំជំនួយបន្ថែមពីសហគមន៍អន្តរជាតិទៀតដែរទេ? ចុះបើជំនួយនោះមានការខ្វះខាត? តើអ្នកនឹងប្រថុយលះបង់ជោគជ័យសេដ្ឋកិច្ចថ្មីៗរបស់ប្រទេសអ្នក ដោយអនុញ្ញាតអោយជនភៀសខ្លួនបន្តស្នាក់នៅ និងស្រូបយកធនធានដែលអ្នកទុកសម្រាប់ប្រជាជនរបស់អ្នកផ្ទាល់ ដែរឬទេ? តើអ្នកនឹងបង្ខំជនជាតិរ៉ូហ៊ីងយ៉ាអោយត្រឡប់ទៅប្រទេសភូមាវិញ អោយប្រឈមមុខនឹងអំពើហិង្សានយោបាយដ៏ពិតប្រាកដដែរឬយ៉ាងណា? តើអ្នកអាចប្រឈមមុខនឹងស្ថានភាពមនុស្សធម៌ដ៏សំខាន់នេះ ដោយរបៀបណា ខណៈពេលដែលកំពុងរក្សាស្ថិរភាពនយោបាយនិងសេដ្ឋកិច្ចក្នុងប្រទេសរបស់អ្នក?

មតិសាធារណៈ និងទំនាក់ទំនងអន្តរជាតិ

ឥស្លាមជ្រុលនិយម

ក្រុមអ៊ីស្លាមជ្រុលនិយមមួយចំនួនបានបើកប្រតិបត្តិការឬគាំទ្រការវាយប្រហារ នៅក្នុងប្រទេសជាច្រើន។ ក្រុមអ៊ីស្លាមជ្រុលនិយមរួមមានដូចជា ក្រុមអាល់កៃដា និងរដ្ឋអ៊ីស្លាម(Islamist States) បានគំរាមវាយប្រហារបន្ថែមទៀតទៅលើគោលដៅជនស៊ីវិលនៅជុំវិញពិភពលោក។ ជាការពិតណាស់ ការគំរាមកំហែងទាំងអស់នេះសំដៅបង្កការភ័យខ្លាច និងបង្ខំអោយរដ្ឋគោលដៅផ្លាស់ប្តូរគោលនយោបាយរបស់ពួកគេ ជាធម្មតា សំដៅឆ្ពោះទៅរកជម្លោះដែលមានរយៈពេលយូរ នៅមជ្ឈិមបូព៌ា។

ចំណុចគួរឱ្យចាប់អារម្មណ៍មួយ ក្រុមប្រជាជនផ្សេងគ្នាមានការយល់ឃើញពីការគំរាមកំហែងទាំងនេះតាមរបៀបផ្សេងគ្នាដែរ។ ក្រាហ្វិក ៥.៥ បង្ហាញពីទិន្នន័យស្តីពីការគំរាមកំហែងនៃលទ្ធិអ៊ីស្លាមជ្រុលនិយមចេញពីលទ្ធផលស្ទង់មតិនៅក្នុងប្រទេសចំនួន ២៣។ ការស្ទង់មតិនោះបានចោទសួរទៅអ្នកឆ្លើយសំណួរថាតើពួកគេមានការព្រួយបារម្ភកម្រិតណាចំពោះក្រុមអ៊ីស្លាមជ្រុលនិយម។ ទិន្នន័យនោះបានបង្ហាញអោយឃើញនូវនិន្នាការរួមមួយចំនួន។


ទីមួយ ប្រជាជនភាគច្រើន នៅក្នុងប្រទេសទាំង ២៣ បង្ហាញពីការព្រួយបារម្ភមួយចំនួន (បារម្ភខ្លះ ឬកិតភ័យខ្លាំង)អំពីអ៊ីស្លាមជ្រុលនិយម។ នេះជាការពិត ដោយមិនគិតអំពីទីតាំងភូមិសាស្ត្រនៃប្រទេសរបស់ពួកគេ។ ទីពីរ ប្រទេសទាំងពីរដែលមានកម្រិតនៃព្រួយបារម្ភទាបបំផុត (រួមបញ្ចូលទាំងអ្នកបារម្ភខ្លះនិងកិតភ័យខ្លាំង) ជាប្រទេសដែលមានប្រជាជនភាគច្រើនជាមូស្លីមសាសនិកជន៖ ឥណ្ឌូនេស៊ី និងទួរគី។ ទោះជាយ៉ាង

ណាក៏ដោយ ក្នុងបណ្តារដ្ឋដែលមានប្រជាជនភាគច្រើនជាមូស្លីមសាសនិកជនដទៃទៀត រដ្ឋដូចជាប្រទេសលីបង់និងប៉ាគីស្តាន ក្តីបារម្ភទាំងនេះកាន់តែខ្លាំងឡើង។ ដូច្នេះ វាច្បាស់ណាស់មិនមែនជាករណីត្រឹមត្រូវទេដែលថាជនមូស្លីមមានអារម្មណ៍ថា មានភាពស៊ាំនឹងការគំរាមកំហែងដោយអំពើហិង្សានេះទេ។ ក្រោយបានយល់ដឹងអំពីការពិភាក្សារបស់យើងអំពីការបែងចែកនិកាយស៊ីអ៊ីតនិងស៊ុននី រឿងនេះប្រហែលជាមិនគួរអោយភ្ញាក់ផ្អើលឡើយ។

ក្រាហ្វិក ៥.៥ មតិចំពោះអ៊ីស្លាមជ្រុលនិយម នៅក្នុងប្រទេសចំនួន ២៣

(ប្រភព៖ មជ្ឈមណ្ឌលសិក្សាស្រាវជ្រាវPew)

ខ្ញុំមានការ... អំពីអ៊ីស្លាមជ្រុលនិយម។



(សម្គាល់លំដាប់មតិ៖ ព្រួយបារម្ភខ្លាំង, ព្រួយបារម្ភ, មិនព្រួយបារម្ភពេកទេ, និងមិនព្រួយបារម្ភសោះ)

ជាចុងក្រោយ មានតែប្រទេសចំនួនប្រាំប៉ុណ្ណោះ ដែលអ្នកដែលបានស្ទង់មតិច្រើនគួរសម (ច្រើនជាង ១០ ភាគរយ) មានអារម្មណ៍ថា ការគំរាមកំហែងដោយក្រុមអ៊ីស្លាមជ្រុលនិយម មិនមែនជាអ្វីគួរអោយ ព្រួយបារម្ភសោះឡើយ។ ប្រទេសទាំងប្រាំនោះមាន កាណាដា ឥណ្ឌូនេស៊ី សេណេហ្គាល់ ទុយនីស៊ី និងទួរគី។ ប្រទេសពីរក្នុងចំណោមប្រទេសទាំងនេះ (កាណាដានិងសេណេហ្គាល់) ដែលទទួលរងបទពិសោធន៍តិចតួចជាមួយនឹងអំពើហិង្សាពីក្រុមអ៊ីស្លាមជ្រុលនិយម។ ចំណែករដ្ឋផ្សេងទៀតធ្លាប់ទទួលរងគ្រោះដោយអំពើហិង្សាប្រភេទនេះច្រើនគួរសម។

សំណួរសំខាន់ជាងគេគឺថា តើការបារម្ភទាំងនេះដ៏ឥទ្ធិពលលើរបៀបរបបដែលបុគ្គលទាំងនេះរស់នៅក្នុងជីវភាពប្រចាំថ្ងៃរបស់ពួកគេដែរឬទេ។ ដោយសារគោលដៅនៃអំពើភេរវកម្ម (សូមមើលមេរៀនទី ៦) គឺដើម្បីបង្កាក់ជីវិតប្រចាំថ្ងៃ និងបង្ខំអោយមានការផ្លាស់ប្តូរផ្នែកនយោបាយ វាជាការគួរអោយចាប់អារម្មណ៍ក្នុងការស្វែងយល់ពីអ្វីដែលកង្វល់ទាំងនេះលេចចេញជាទង្វើឬការផ្លាស់ប្តូរជាក់ស្តែង។ ដូចគ្នានេះដែរ យើងក៏អាចឆ្ងល់ផងដែរថា តើកង្វល់ទាំងនេះមានឥទ្ធិពលលើការបោះឆ្នោតនៅក្នុងប្រទេសដែលរៀបចំការបោះឆ្នោតតាម

បែបប្រជាធិបតេយ្យដែរឬទេ។ ការវាយប្រហារបែបជ្រុលនិយមនិងអំពើភេរវកម្មអាចជះឥទ្ធិពលលើលទ្ធផលបោះឆ្នោត ដែលក្នុងករណីខ្លះអាចនាំអោយមានការផ្លាស់ប្តូរគោលនយោបាយ ដែលក្រុមជ្រុលនិយមប្រាថ្នាចង់បាន។ ទោះជាយ៉ាងណា ការព្រួយបារម្ភអំពីភាពជ្រុលនិយមក៏អាចនាំទៅដល់ការបោះឆ្នោតជ្រើសរើសគណបក្សនិងមេដឹកនាំដែលឆ្លើយតបដោយបង្ក្រាបក្រុមជ្រុលនិយមបន្ថែមទៀត។

តោះ! សាកល្បងពិភាក្សាអំពីបញ្ហាជាក់ស្តែង

សហរដ្ឋអាមេរិកនិងរុស្ស៊ី៖ សង្គ្រាមត្រជាក់ថ្មី?

ទិដ្ឋភាពទូទៅ

នៅពេលដែលសង្គ្រាមត្រជាក់ត្រូវបានបញ្ចប់ (ដំណើរការមួយដែលបានចាប់ផ្តើមនៅឆ្នាំ ១៩៨៩ និងបញ្ចប់នៅឆ្នាំ ១៩៩១) អ្នកសង្កេតការណ៍នានាសង្ឃឹមថានឹងមានយុគសម័យថ្មីនៃកិច្ចសហប្រតិបត្តិការរវាងសហរដ្ឋអាមេរិកនិងរុស្ស៊ី។ ដំបូងឡើយ សញ្ញាទាំងអស់បានចង្អុលបង្ហាញពីទំនាក់ទំនងដែលមានភាពល្អប្រសើររវាងប្រទេសមហាអំណាចទាំងពីរនេះ៖ ពួកគេបានធ្វើការរួមគ្នាដើម្បីធានាសុវត្ថិភាពអាវុធនុយក្លេអ៊ែររបស់រុស្ស៊ី បានសហការដើម្បីធ្វើអោយសេដ្ឋកិច្ចរុស្ស៊ីមានស្ថិរភាព និងបានឈានដល់ការយោគយល់គ្នាដើម្បីអនុញ្ញាតអោយអង្គការណាតូពង្រីកខ្លួនទៅកាន់អតីតសមាជិកកិច្ចព្រមព្រៀងវ៉ាសូវីមួយចំនួនផងដែរ។

យ៉ាងណាមិញ ទំនាក់ទំនងបានប្រែប្រួលនិងធ្លាក់ក្នុងស្ថានភាពកាន់តែយ៉ាប់យឺន។ នៅពេលដែលអង្គការណាតូបានពង្រីកខ្លួន ប្រទេសរុស្ស៊ីបានដំទាស់នឹងការពង្រីកបន្ថែមទៀត។ សហរដ្ឋអាមេរិកបានចាប់ខ្លួនអ្នកស៊ើបការណ៍ជាន់ខ្ពស់មួយចំនួនដែលបាននិងកំពុងបន្តប្រតិបត្តិការ នៅអាមេរិក អស់រយៈពេលជាយូរមកហើយ តាំងពីចុងបញ្ចប់នៃសង្គ្រាមត្រជាក់។ ការដកខ្លួនរបស់អាមេរិកចេញពីសន្ធិសញ្ញាប្រឆាំងមីស៊ីលបាលីស្ទិក ក្នុងឆ្នាំ ២០០១ បានជំរុញអោយរុស្ស៊ីមានការភ័យខ្លាចថាសហរដ្ឋអាមេរិកនឹងចូលរួមក្នុងការប្រកួតប្រជែងអាវុធថ្មីម្តងទៀត។ ក្នុងអំឡុងសង្គ្រាមអ៊ីរ៉ាក់ឆ្នាំ ២០០៣ ប្រទេសរុស្ស៊ីបានប្រឆាំងយ៉ាងដាច់អហង្ការចំពោះកិច្ចខិតខំប្រឹងប្រែងរបស់អាមេរិក ដើម្បីទទួលបានការយល់ព្រមពី ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ(UNSC) ដោយគំរាមកំហែងប្រើសិទ្ធវេតូចំពោះដំណោះស្រាយណាមួយ ដែលនឹងស្នើឡើងដោយសហរដ្ឋអាមេរិក។ ក្នុងឆ្នាំ ២០០៨ ប្រទេសរុស្ស៊ីបានធ្វើសង្គ្រាមប្រឆាំងនឹងហ្សកហ្ស៊ី ដែលជាសម្ព័ន្ធមិត្តរបស់អាមេរិក។ ក្នុងឆ្នាំ ២០១៤ ប្រទេសរុស្ស៊ីបានបញ្ជូលឧបទ្វីបគ្រីមេនៃប្រទេសអ៊ុយក្រែនដាក់ចូលក្នុងប្រទេសខ្លួន បន្ទាប់មកបានគាំទ្រក្រុមឧទ្ទាមនៅភាគខាងកើតអ៊ុយក្រែន ដែលកំពុងប្រយុទ្ធប្រឆាំងនឹងរដ្ឋាភិបាលក្រុងគៀវ។ ជាការឆ្លើយតប សហរដ្ឋអាមេរិកបានដាក់ទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរប្រឆាំងនឹងប្រទេសរុស្ស៊ី។ រុស្ស៊ីក៏ត្រូវបានចោទប្រកាន់ពីបទប៉ុនប៉ងជ្រៀតជ្រែកក្នុងការបោះឆ្នោតប្រធានាធិបតីអាមេរិក ក្នុងឆ្នាំ ២០១៦។ ប្រាកដណាស់ មិត្តភាពនៃប្រទេសយក្សទាំងពីរបានធ្លាក់ចុះគួរអោយកត់សម្គាល់។ ទោះបីជាគ្មាននរណាម្នាក់ជឿរុស្ស៊ីនិងសហរដ្ឋអាមេរិកនឹងធ្វើសង្គ្រាមជាមួយគ្នា មនុស្សជាច្រើនឆ្ងល់ថាតើសង្គ្រាមត្រជាក់ថ្មីនឹងកើតឡើងរវាងអតីតគូប្រជែងទាំងពីរនេះដែរឬទេ។ តើនឹងមានលទ្ធភាពផ្ទុះសង្គ្រាមត្រជាក់ថ្មីរវាងប្រទេសមហាអំណាចទាំងពីរនេះដែរឬយ៉ាងណា?

អំណះអំណាង ១

សង្គ្រាមត្រជាក់ថ្មីនឹងកើតឡើងរវាងសហរដ្ឋអាមេរិកនិងរុស្ស៊ី

ប្រទេសរុស្ស៊ីនិងអាមេរិកមានភាពខុសគ្នាយ៉ាងខ្លាំង ក្នុងវិស័យគោលនយោបាយសំខាន់ៗ។

លើបញ្ហាសំខាន់ៗមួយចំនួន ប្រទេសរុស្ស៊ី និងអាមេរិកមិនបានមើលមុខគ្នាចំៗនោះទេ។ ជាពិសេស រឿងដែលអាមេរិកប្តេជ្ញាពង្រីកអង្គការណាតូ ដែលរុស្ស៊ីចាត់ទុកថាជាការគំរាមកំហែងផ្ទាល់ដល់សន្តិសុខរបស់ខ្លួន។ លើសពីនេះ ទៅទៀត សហរដ្ឋអាមេរិកប្តេជ្ញាជាក់ពង្រាយមីស៊ីលប្រឆាំងមីស៊ីលនៅអឺរ៉ុប ដែលរុស្ស៊ីប្រឆាំងដាច់ខាត។

លទ្ធិប្រជាធិបតេយ្យនៅរុស្ស៊ីទន់ខ្សោយ។

លទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសរុស្ស៊ីប្រាកដណាស់ មិនមានភាពរឹងមាំឡើយ (ប្រសិនបើគេអាចហៅថាប្រជាធិបតេយ្យបាន) ដែលបង្កើតភាពតានតឹងបន្ថែមទៀតជាមួយនឹងសហរដ្ឋអាមេរិក។ មេដឹកនាំបក្សប្រឆាំងត្រូវគេចាប់ដាក់គុក ឬ ត្រូវគេបាញ់ប្រហារសម្លាប់ អំពើពុករលួយរីករាលដាលខ្លាំង ហើយសារព័ត៌មានត្រូវរងការគំរាមកំហែង នៅពេលស៊ើបអង្កេតទង្វើខុសឆ្គង។ បច្ចុប្បន្ននេះ សហរដ្ឋអាមេរិកបានចំណាយធនធានច្រើនគួរសម ដើម្បីផ្តល់មូលនិធិដល់កម្មវិធីគាំទ្រលទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសជិតខាងរបស់រុស្ស៊ី ដែលធ្វើអោយមេដឹកនាំរុស្ស៊ីខឹងសម្បារជាពន់ពេក។

ប្រទេសរុស្ស៊ីបោះដៃទៅរកសត្រូវរបស់អាមេរិក ហើយតតាំងត្រង់ៗនឹងសម្ព័ន្ធមិត្តអាមេរិក។ ថ្មីៗនេះ រុស្ស៊ីបានធ្វើសមយុទ្ធយោធារួមគ្នាជាមួយប្រទេសវេណេហ្ស៊ុយអេឡា និងមានទំនាក់ទំនងស្និទ្ធស្នាលជាមួយនឹងប្រទេសអ៊ីរ៉ង់។ ប្រទេសរុស្ស៊ីបានធ្វើសង្គ្រាមជាមួយនឹងប្រទេសហ្សកហ្ស៊ីលើទឹកដីមានជម្លោះ ហើយបានដាក់បញ្ចូលផ្នែកនៃអ៊ុយក្រែន ខណៈកំពុងជួយពួកឧទ្ទាមនៅទីនោះ។ ទាំង ប្រទេសហ្សកហ្ស៊ី និង ប្រទេសអ៊ុយក្រែន មានសម្ព័ន្ធភាពយ៉ាងជ្រាលជ្រៅជាមួយសហរដ្ឋអាមេរិក។

អំណះអំណាង ២

គ្មានសង្គ្រាមត្រជាក់ថ្មីអាចនឹងកើតឡើងរវាងសហរដ្ឋអាមេរិក និងរុស្ស៊ីទេ។

ប្រទេសរុស្ស៊ីពឹងផ្អែកលើការទទួលយកដោយលោកខាងលិច។

ប្រទេសរុស្ស៊ីផ្តល់តម្លៃយ៉ាងខ្លាំងដល់សមាជិកភាពរបស់ខ្លួន នៅក្នុងស្ថាប័នអន្តរជាតិសំខាន់ៗ ដូចជា ធនាគារពិភពលោកនិងមូលនិធិរូបិយវត្ថុអន្តរជាតិ(IMF)។ ប្រទេសរុស្ស៊ីក៏ជាការចង់បានសមាជិកភាពនៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក (WTO) ដែលខ្លួនសង្ឃឹមថា នឹងអាចចូលរួមផងដែរ។ ប្រទេសរុស្ស៊ីនឹងមិនបន្តគោលនយោបាយដែលគំរាមកំហែងដល់ទំនាក់ទំនងទាំងនេះទេ។

មិនមានភាពខុសគ្នាផ្នែកមនោគមវិជ្ជាសំខាន់ រវាងសហរដ្ឋអាមេរិក និងរុស្ស៊ីទេ។

មិនដូចក្នុងអំឡុងពេលសង្គ្រាមត្រជាក់ មិនមានការបែងចែកមនោគមវិជ្ជាសំខាន់ៗ រវាងប្រទេសមហាអំណាចទាំងពីរនេះទេ។ ខណៈពេលដែលលទ្ធិប្រជាធិបតេយ្យរបស់រុស្ស៊ីប្រហែលជាមិនល្អឥតខ្ចោះ រុស្ស៊ីទំនងជាមិនទទួលយកលទ្ធិកុម្មុយនីស្តជាថ្មី ឬបោះបង់ការពិសោធន៍របស់ខ្លួនជាមួយនឹងមូលធននិយមនោះទេ។ ចំពោះបញ្ហាដែលផលប្រយោជន៍របស់ពួកគេស្របគ្នា ដូចជានៅក្នុងសង្គ្រាមប្រឆាំងនឹងក្រុមអ៊ីស្លាមជ្រុលនិយមនៅអាហ្វហ្គានីស្ថាន កិច្ចសហប្រតិបត្តិការអាមេរិក-រុស្ស៊ីមានដំណើរការយ៉ាងរលូន។

អឺរ៉ុបនឹងជួយរក្សាភាពតានតឹងនៅរវាងប្រទេសទាំងពីរអោយមានកម្រិតទាប។

នៅក្នុងអំឡុងសង្គ្រាមត្រជាក់ ទ្វីបអឺរ៉ុបត្រូវបានបែងចែកជាពីរប្លុក ដែលប្លុកនីមួយៗត្រូវបានគាំទ្រដោយប្រទេសមហាអំណាចនីមួយៗ។ ឥឡូវនេះ អឺរ៉ុបបានរួបរួមគ្នា ហើយអាចធ្វើជាអ្នកសម្រុះសម្រួលរវាងអាមេរិក និងរុស្ស៊ី។ អឺរ៉ុបមានផលប្រយោជន៍សេដ្ឋកិច្ចនិងនយោបាយខ្លាំងក្នុងការបន្តកិច្ចសហប្រតិបត្តិការ

ជាមួយភាគីទាំងសងខាង ហើយនឹងធ្វើការប្រឹងប្រែងដើម្បីជានាថា ភាពតានតឹងនឹងមិនរីករាលដាល ហួសពីការគ្រប់គ្រងបានឡើយ។

សំណួរ

• តើរុស្ស៊ី និងសហរដ្ឋអាមេរិក កំពុងឈានទៅរកសង្គ្រាមត្រជាក់លើកទីពីរដែរឬទេ? តើបញ្ហាអ្វីខ្លះដែលទំនងជាបន្តធ្វើអោយភាពតានតឹងរវាងរដ្ឋទាំងពីរកាន់តែខ្លាំងឡើងៗ? តើមានបញ្ហាផលប្រយោជន៍រួមដែលអាចបង្រួបបង្រួមពួកគេដែរឬទេ?

• តើជំហានដើម្បីធ្វើអោយទំនាក់ទំនងកាន់តែប្រសើរជាមួយរុស្ស៊ី ដូចជាការបញ្ចប់កិច្ចខិតខំប្រឹងប្រែងដើម្បីដាក់ខែលការពារមីស៊ីលធ្វើអោយទំនាក់ទំនងជាមួយសម្ព័ន្ធមិត្តអឺរ៉ុបមួយចំនួន (ជាឧទាហរណ៍ ប្រទេសប៉ូឡូញ ឬ អ៊ុយក្រែន) កាន់តែពិបាកដែរឬទេ? តើអាមេរិកត្រូវជ្រើសរើសរវាងការកែលម្អទំនាក់ទំនងជាមួយរុស្ស៊ី ឬគោរពការប្តេជ្ញារបស់ខ្លួនចំពោះសម្ព័ន្ធមិត្តអឺរ៉ុបដែរឬទេ?

• តើវាមានសារៈសំខាន់យ៉ាងណាសម្រាប់ប្រទេសរុស្ស៊ី ក្នុងការរក្សាលទ្ធិប្រជាធិបតេយ្យ ដើម្បីកុំអោយមានភាពតានតឹងរវាងខ្លួននិងសហរដ្ឋអាមេរិក? តើទ្រឹស្តីផ្សេងគ្នានៃទំនាក់ទំនងអន្តរជាតិនឹងឆ្លើយសំណួរនេះយ៉ាងដូចម្តេច? តើការប៉ុនប៉ងរបស់រុស្ស៊ីក្នុងអនុវត្តលទ្ធិប្រជាធិបតេយ្យពន្យល់ពីភាពខុសគ្នានៃការយល់ឃើញរបស់អាមេរិក អំពីគ្រោះថ្នាក់ពីរុស្ស៊ី ដែលផ្ទុយនឹងគ្រោះថ្នាក់ពីប្រទេសចិនដែរឬទេ?

និស្សិតអាចសាកល្បងអានឯកសារខាងក្រោមបន្ថែមទៀត ដើម្បីជាគ្រឹះក្នុងការឆ្លើយសំណួរទាំងអស់ខាងលើ ៖

- Gessen, Masha. The Future Is History: How Totalitarianism Reclaimed Russia. Penguin, 2017.
- Goldman, Marshall I. Petrostate: Putin, Power, and the New Russia. Oxford, 2008.
- Levgold, Robert. Return to Cold War. Polity, 2016.
- Lucas, Edward. The New Cold War: Putin's Russia and the Threat to the West. 3rd ed. St. Martin's, 2014.

ឯកសារគួរអានបន្ថែម

- Horowitz, Donald L. *Ethnic Groups in Conflict.* 2nd ed. California, 2000.
- Kalyvas, Stathis N. *The Logic of Violence in Civil War.* Cambridge, 2006.
- Saunders, Elizabeth. *Leaders at War: How Presidents Shape Military Interventions*. Cornell, 2014.
- Straus, Scott. *Making and Unmaking Nations: War, Leadership, and Genocide in Modern Africa.* Cornell, 2015.
- Van Evera, Stephen. *Causes of War: Power and the Roots of Conflict.* Cornell, 1999.
- Waltz, Kenneth N. *Man, the State, and War: A Theoretical Analysis.* Columbia, 2001.
- Weeks, Jessica L. P. *Dictators at War and Peace.* Cornell, 2014.

មេរៀនទី ០៦ ៖ កងកម្លាំងប្រដាប់អាវុធ និងអំពើភេរវកម្ម

រូបថត សមយុទ្ធកងទ័ពជើងទឹកសហរដ្ឋអាមេរិក នៅជិតប្រទេសកូរ៉ែ ឆ្នាំ ២០១៧

វត្ថុបំណងមេរៀន

៦.១ ចូរប្រៀបធៀបការដោះដូរក្នុងការប្រើប្រាស់ឧបករណ៍ជាក់គំនាបផ្សេងៗ។

៦.២ ចូរវាយតម្លៃសារៈសំខាន់នៃបច្ចេកវិទ្យាថ្មីៗក្នុងការផ្លាស់ប្តូរយុទ្ធវិធីសង្គ្រាម។

៦.៣ ចូរវាយតម្លៃគុណសម្បត្តិនិងគុណវិបត្តិនៃវិធីសាស្ត្រប្រឆាំងភេរវកម្មចំនួនពីរផ្សេងគ្នា។

៦.៤ ចូរប្រៀបធៀបប្រសិទ្ធភាពនៃ«របបសកល»ក្នុងការទប់ស្កាត់ការរីកសាយភាយអាវុធនុយក្លេអ៊ែរ នឹងប្រសិទ្ធភាពនៃ«របបសកល»ក្នុងការទប់ស្កាត់ការរាលដាលនៃអាវុធគីមី។

៦.៥ តើភាពតានតឹងនៅក្នុងទំនាក់ទំនងស៊ីវិលនឹងយោធាធ្វើអោយប៉ះពាល់ដល់ប្រតិបត្តិការយោធា និងអាចគំរាមកំហែងដល់ស្ថិរភាពនយោបាយ ដោយរបៀបណាខ្លះ។ ចូរពន្យល់។

៦.១. កងកម្លាំងទូទៅ

៦.១ ចូរប្រៀបធៀបការដោះដូរក្នុងការប្រើប្រាស់ឧបករណ៍ជាក់គំនាបផ្សេងៗ។


មេដឹកនាំរដ្ឋនៅក្នុងជម្លោះណាមួយ អាចជះឥទ្ធិពលលើលទ្ធផលនៃជម្លោះនោះ ដោយប្រើប្រាស់ឧបករណ៍ជាក់គំនាប ឬគាបសង្កត់ ឬ អានុភាពផ្សេងៗ (សូមមើលក្រាហ្វិក ៦.១)។ ឧបករណ៍មួយដួរខាងលើតំណាងអោយវិធីសាស្ត្រឬមធ្យោបាយអហិង្សានៃការជះឥទ្ធិពលដល់រដ្ឋផ្សេងទៀត ដូចជា ជំនួយបរទេស ទណ្ឌកម្ម សេដ្ឋកិច្ច និងការទូតបុគ្គល (មធ្យោបាយអរូបី រួមមានការប្រើប្រាស់បទដ្ឋាន សីលធម៌ និងមនោគមន៍វិជ្ជាឬគំនិតផ្សេងទៀត)។ សំណុំឧបករណ៍ដួរខាងក្រោម ដែលជាប្រធានបទនៃមេរៀនទីពីរនេះ តំណាងអោយសកម្មភាពហិង្សា។ ឧបករណ៍ទាំងនេះបញ្ជាអោយកងទ័ពដើរក្បួនព្យុហយាត្រា បំផ្ទុះគ្រាប់បែកអត្តឃាត ឬ បាញ់កាំជ្រួច។ មធ្យោបាយទាំងនេះហាក់ត្រូវចំណាយថ្លៃពន់ពេកសម្រាប់អ្នកវាយប្រហារ និងរងការខូចខាតធ្ងន់ធ្ងរចំពោះអ្នកត្រូវរងការវាយប្រហារ។ កម្លាំងយោធាមាននិន្នាការជាមធ្យោបាយចុងក្រោយ។ ភ័ស្តុតាងក៏បង្ហាញផងដែរថា ការប្រើប្រាស់កម្លាំងយោធាបើធៀបនឹងមធ្យោបាយមិនមែនយោធាកំពុងធ្លាក់ចុះបន្តិចម្តងៗពីពេលមួយទៅពេលមួយទៀត។ ភាពតានតឹងភូមិសាស្ត្រនយោបាយក្នុងតំបន់បានធ្វើអោយឥណ្ឌាដើរតាមនិន្នាការបង្កើនការចំណាយលើវិស័យយោធា ជារៀងរាល់ឆ្នាំ។

ទោះជាយ៉ាងណាក៏ដោយ រដ្ឋភាគច្រើននៅតែចំណាយធនធានដ៏ច្រើនសន្ធឹកសន្ធាប់ សម្រាប់ពង្រឹងសមត្ថភាពយោធា បើប្រៀបធៀបទៅនឹងមធ្យោបាយជះឥទ្ធិពល ឬជាក់គំនាបផ្សេងទៀត។ ជាឧទាហរណ៍ ប្រទេសឥណ្ឌាចំណាយទឹកប្រាក់ជិត ៦៧ ពាន់លានដុល្លារ សម្រាប់កងទ័ពរបស់ខ្លួនក្នុងឆ្នាំ ២០១៨ ត្រូវនឹង ២,៤% នៃផលិតផលក្នុងស្រុកសរុប ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ប៉ុន្តែ នៅតែខ្ពស់ជាងប្រទេសចិន ដោយសារសេដ្ឋកិច្ចឥណ្ឌាតូចជាងចិន (សូមមើលឧទាហរណ៍ មតិសាធារណៈនិងទំនាក់ទំនងអន្តរជាតិ)។ ឧទាហរណ៍ជាក់ស្តែងមួយទៀត សហរដ្ឋអាមេរិកមានបុគ្គលិកការទូតប្រហែល ពីរម៉ឺននាក់ ប៉ុន្តែ មានទាហានសកម្មប្រហែល មួយលាន បួនសែន នាក់។ វាចំណាយប្រហែល ៥០ ពាន់លានដុល្លារ ក្នុងមួយឆ្នាំ លើជំនួយបរទេសប៉ុន្តែ ប្រហែល ៦០០ ពាន់លានដុល្លារ លើកងកម្លាំងយោធានិងសង្គ្រាម។ ដោយសារតែបញ្ហាសន្តិសុខទ្វេគ្រោះ (សូមមើលមេរៀនទី ២) រដ្ឋនានាជឿថា ពួកគេត្រូវតែលះបង់ធនធានដ៏ធំមហិមា សម្រាប់សមត្ថភាព

យោធា ប្រសិនបើរដ្ឋផ្សេងទៀតកំពុងធ្វើដូច្នេះ។

ក្រាហ្វិក ៦.១ មធ្យោបាយដាក់គំនាប ដោយផ្នែកយោធា និងមិនមែនយោធា

កម្លាំងប្រដាប់អាវុធទូទៅ គឺជាទម្រង់យោធាដែលប្រើជាទូទៅបំផុតសម្រាប់បញ្ចេញអានុភាពឬដាក់គំនាប។



ក្រៅពីការការពារទឹកដីរបស់ខ្លួន រដ្ឋនានាអភិវឌ្ឍសមត្ថភាពយោធាសម្រាប់គោលបំណងផ្សេងទៀតជាច្រើន។ ជារឿយៗ ពួកគេសង្ឃឹមថានឹង*ការពារ*(deter)ការវាយប្រហារ ដោយត្រៀមមធ្យោបាយរួចស្រេចដើម្បីវាយសងសឹក។ ពួកគេក៏អាចនឹងសង្ឃឹមថានឹង*បង្ខំ*(compel) រដ្ឋ ផ្សេងទៀត អោយ ប្រកាន់ខ្ជាប់នូវឥរិយាបទដាក់ស្តែងតាមខ្លួនចង់បាន ដោយគំរាមកំហែងធ្វើការវាយប្រហារ ប្រសិនបើរដ្ឋនោះមិនអនុវត្តតាម។ រដ្ឋនានាក៏ប្រើប្រាស់កម្លាំងយោធា សម្រាប់ជំនួយមនុស្សធម៌បន្ទាប់ពីមានគ្រោះមហន្តរាយ សម្រាប់ការរក្សាសន្តិភាព សម្រាប់ការឃ្លាំមើលការជួញដូរគ្រឿងញៀន និងសម្រាប់ការបង្ក្រាបការប្រឆាំងនយោបាយក្នុងស្រុក ក្នុងចំណោមបេសកកម្មផ្សេងៗទៀត។ ទំហំនិងប្រភេទនៃកងកម្លាំងយោធាឆ្លុះបញ្ចាំងពីបេសកកម្មទាំងនេះ។

ជាការពិត ប្រទេសមហាអំណាចទាំងឡាយ នៅបន្តមានភាគរយច្រើនអនេកនៃកងកម្លាំងយោធានៅលើពិភពលោក។ តារាង ៦.១ សង្ខេបអំពីកម្លាំងដ៏សំខាន់បំផុតនៃប្រទេសមហាអំណាច។ បើគិតរួមគ្នា ពួកគេមានចំណែក ប្រហែល ៦៥ ភាគរយ នៃការចំណាយយោធាពិភពលោក, ៣០ ភាគរយ នៃចំនួនទាហានលើពិភពលោក, ជិត ៥០ ភាគរយ នៃអាវុធទូទៅ, ៩៧ ភាគរយ នៃអាវុធនុយក្លេអ៊ែរ, និង ៩០ ភាគរយនៃការនាំចេញអាវុធ។ (តារាងដដែលនេះក៏បង្ហាញពីកងកម្លាំងយោធាដ៏ច្រើនសន្ធឹកសន្ធាប់ ដែលបង្កនិងរក្សាដោយប្រទេសអាឡឺម៉ង់ និងប្រទេសជប៉ុន បើទោះបីជាមានតួនាទីមិនប្រពៃណីរបស់ពួកគេ នៅក្នុងសន្តិសុខអន្តរជាតិ ចាប់តាំងពីសង្គ្រាមលោកលើកទីពីរក៏ដោយ។)

សមត្ថភាពយោធាចែកចេញជាបីប្រភេទ៖ កងកម្លាំងទូទៅ (កងទ័ពថ្មើជើងទូទៅ កងទ័ពជើងទឹក និងកងទ័ពជើងអាកាស) កងកម្លាំងពិសេស (កងកុម្ម៉ង់ដូរ គេវកម្ម កម្លាំងទ័ពព្រៃ) និងអាវុធប្រល័យលោក (អាវុធនុយក្លេអ៊ែរ អាវុធគីមីសាស្ត្រ និងអាវុធជីវសាស្ត្រ)។

តារាង ៦.១ ការប៉ាន់ប្រមាណសមត្ថភាពយោធាដ៏អស្ចារ្យឆ្នាំ ២០១៧

			អាវុធធុនធ្ងន់[ខ]				
	ថវិកាយោធា[ក] (ពាន់លាន US $)	ទាហានសកម្ម[ខ] (លាននាក់)	រថក្រោះ	នាវាផ្ទុក /នាវាចម្បាំង/ នាវាជ្រមុជទឹក	យន្តហោះចម្បាំង /ជ្រូនធុនធ្ងន់	អាវុធនុយក្លេអ៊ែរ[គ]	អាវុធនាំចេញ[ក] (ពាន់លាន US $)
អាមេរិក	៦១០	១,៣	២៨០០	១០/៩៣/១៤	៣៥០០/៦៤០	៦៦០០	១០
រុស្ស៊ី	៧០	១	២៩៥០	១/៣២/១៣	១០៥០/០	៦៨០០	៦
ចិន	២១៥	២,២	៦៧០០	១/៧៨/៤	១៩០០/៤	២៧០	២
បារាំង	៥៥	០,២	២០០	១/២៣/៤	២៧៥/៧	៣០០	២
អង់គ្លេស	៥០	០,២	២២៥	០/១៩/៤	២០០/១០	២១៥	២
អាឡឺម៉ង់	៤០	០,២	៤០០	០/១៥/០	១២០/០	០	៣
ជប៉ុន	៥០	០,២	៧០០	០/៤៧/០	៤០០/០	០	០
សរុប% លើពិភពលោក	៦៥%	៣០%	៧០%	៩៣/៧០/៥០	៤០/៩០%	៩៧%	៩០%

- ទិន្នន័យដែលមានបញ្ហា៖ ការប៉ាន់ប្រមាណការចំណាយយោធារបស់រុស្ស៊ី និងចិនមានទំហំខុសគ្នាមួយទៅមួយ។ ក្បាលគ្រាប់នុយក្លេអ៊ែររបស់អាមេរិកនិងរុស្ស៊ី រួមមានអាវុធយុទ្ធសាស្ត្រដែលបានដាក់ពង្រាយ(១៨០០ សហរដ្ឋអាមេរិក, ១៧១០ រុស្ស៊ី) ជាមួយនឹងគ្រាប់ដែលនៅសេសសល់ទុកក្នុងឃ្លាំងបម្រុង ឬចូលនិវត្តន៍ (រង់ចាំការបំផ្លាញ)។
- ទិន្នន័យអំពីទាហានមិនរាប់បញ្ចូលទាហានបំរុង។ រថក្រោះរួមបញ្ចូលតែរថក្រោះប្រយុទ្ធដ៏សំខាន់ទំនើបក្រោយឆ្នាំ ១៩៨០ តែប៉ុណ្ណោះ។ នាវាចម្បាំងគឺជានាវាដឹកជញ្ជូន នាវាពិឃាត និងនាវាចម្បាំងធុនស្រាល។ នាវាជ្រមុជទឹករួមបញ្ចូលតែនាវាបំពាក់ដោយថាមពលនុយក្លេអ៊ែរ-មីស៊ីលផ្លោងតែប៉ុណ្ណោះ។ យន្តហោះគឺជាយន្តហោះចម្បាំងយុទ្ធសាស្ត្រតែប៉ុណ្ណោះ។ ក្បាលគ្រាប់នុយក្លេអ៊ែរ មានទាំងអាវុធយុទ្ធសាស្ត្រ និងតាក់ទិក។ ការនាំចេញអាវុធសំដៅការបញ្ជាទិញដែលបានដាក់ក្នុងឆ្នាំ ២០១៦ ។
- *ប្រភព*៖ ការប៉ាន់ប្រមាណរបស់អ្នកនិពន្ធផ្អែកលើទិន្នន័យដែលផ្តល់ដោយប្រភពខាងក្រោម៖

ក. ទិន្នន័យឆ្នាំ ២០១៧ ពីវិទ្យាស្ថានស្រាវជ្រាវសន្តិភាពអន្តរជាតិស្តុកខម (Stockholm) ។

ខ. ទិន្នន័យឆ្នាំ ២០១៧ ពីវិទ្យាស្ថានអន្តរជាតិសម្រាប់ការសិក្សាយុទ្ធសាស្ត្រ។ តុល្យភាពយោធាឆ្នាំ ២០១៧។

គ. ទិន្នន័យរបស់សហព័ន្ធអ្នកវិទ្យាសាស្ត្រអាមេរិក៖ សម្រាប់ថ្ងៃទី ២/១/២០១៨។

៦.១.១. កម្លាំងទ័ពជើងគោក៖ គ្រប់គ្រងដែនដី

ទោះជាវាកើតឡើង ដោយសារមូលហេតុនិងមានគោលបំណងចុងក្រោយយ៉ាងដូចម្តេចក៏ដោយ សង្គ្រាមភាគច្រើនពាក់ព័ន្ធនឹងការតស៊ូដណ្តើមគ្រប់គ្រងទឹកដី។ ទឹកដីគឺជាចំណុចស្នូលនៅក្នុងសង្គ្រាម ដោយសារសារៈសំខាន់របស់ទឹកដីនៅក្នុងប្រព័ន្ធអន្តរជាតិ និងដំណើរបញ្ច្រាសមកវិញ។ ព្រំដែនកំណត់ទីកន្លែងដែលកងកម្លាំងយោធារបស់រដ្ឋមួយ និងកងកម្លាំងយោធារបស់រដ្ឋគូប្រជែង អាចចល័តដោយសេរី នៅក្នុងរង្វង់ទឹកដីរបស់ខ្លួន។ កស្តុការយោធាធ្វើអោយទឹកដីទាំងអស់ កាន់តែមានសារៈសំខាន់ ដោយសារតែតម្រូវការគ្រប់គ្រងទឹកដីតភ្ជាប់កងកម្លាំងយោធាជាមួយគ្នា ទៅវិញទៅមក។ ការផ្គត់ផ្គង់ស្បៀងឬសព្វាវុធសម្រាប់ កងទ័ពត្រូវតែហូរចេញពីទឹកដីកំណើត ទៅតាម*ខ្សែផ្គត់ផ្គង់*(supply lines)ទៅកាន់ទីវាលឬសមរភូមិ។ ដូច្នេះហើយ គោលបំណងជាមូលដ្ឋានបំផុតរបស់កងកម្លាំងទូទៅ គឺត្រូវដណ្តើម កាន់កាប់ ឬ ការពារទឹកដី។

កងទ័ព(armies)ត្រូវបានសម្របតាមគោលបំណងខាងលើនេះ។ កងកម្លាំងយោធា ដែលមានទាហានថ្មើរជើងប្រដាប់ដោយអាវុធ អាច*កាន់កាប់* ទឹកដីមួយដោយកម្លាំងយោធា។ ទោះបីជាអ្នកស្រុកអ្នកភូមិអាចធ្វើអោយជីវិតរបស់ទាហានមិនសប្បាយចិត្ត តាមរយៈការតស៊ូដោយហិង្សា ឬអហិង្សាក៏ដោយ ជាទូទៅមានតែកងកម្លាំងប្រដាប់អាវុធ ដែលមានអង្គការចាត់តាំងច្បាស់លាស់មួយផ្សេងទៀតប៉ុណ្ណោះ ដែលអាចបណ្តេញអ្នកចូលឈ្លានពានបានឬអ្នកចូលកាន់កាប់បាន។

ទាហានថ្មើរជើង ត្រូវបានគេហៅថាកងទ័ពជើងគោល(Infantry)។ ពួកគេប្រើកាំភ្លើងវាយប្រហារ និងអាវុធធុនស្រាលផ្សេងទៀត (ដូចជាមីន និងកាំភ្លើងយន្ត) ក៏ដូចជាកាំភ្លើងធំធុនធ្ងន់ប្រភេទផ្សេងៗ។ កាំភ្លើងធំអាចបង្កការបំផ្លិចបំផ្លាញបានយ៉ាងខ្លាំង និងដោយមិនមានការរើសអើងគោលដៅឡើយ៖ ជាធម្មតាវាបណ្តាលអោយមានការខូចខាត និងស្លាប់បាត់បង់ជីវិតច្រើនបំផុត នៅក្នុងសង្គ្រាម។ រថពាសដែក (armor) សំដៅលើរថក្រោះ និងរថពាសដែកប្រភេទផ្សេងទៀត។ នៅក្នុងទីលំហ ដូចជា វាលខ្សាច់ កងទ័ពជើងគោកបំពាក់ដោយគ្រឿងយន្ត ជាធម្មតា រួមបញ្ចូលគ្នានូវរថពាសដែក កាំភ្លើងធំ និងទាហានថ្មើរជើង។ ទោះជាយ៉ាងណាក៏ដោយ នៅតំបន់បិទជិត ដូចជាព្រៃភ្នំ និងទីក្រុង ទាហានថ្មើរជើងមានសារៈសំខាន់ជាង។ ដោយសារហេតុផលនេះ កងទ័ពនៃរដ្ឋឧស្សាហូបនីយកម្មមានប្រៀបខ្លាំងជាងកងទ័ពក្រីក្រនៅក្នុងប្រភេទសង្គ្រាមធម្មតា ដូចជា នៅវាលខ្សាច់គុយវ៉ែត។ ទោះយ៉ាងណាក៏ដោយ នៅក្នុងសង្គ្រាមព្រៃ ភ្នំ ឬក្នុងទីក្រុង ដូចជានៅប្រជុំភ្នំអាហ្វហ្គានីស្ថាន និងទីក្រុងអ៊ីរ៉ាក់ ឧត្តមភាពធៀបបែបនេះត្រូវបានបំផ្លាញ ហើយកម្លាំងប្រដាប់អាវុធស្រាលជាងនិងថោកជាងក្នុងចំណោមទាហានថ្មើរជើងដ៏មុះមុតក្លៀវក្លា ឬទ័ពព្រៃ នៅទីបំផុត អាចយកឈ្នះលើកងទ័ពធម្មតាឬកងកម្លាំងទូទៅ ដែលមានតម្លៃថ្លៃ។

ឧត្តមភាពនៃកងកម្លាំងប្រដាប់អាវុធទូទៅ ដែលមានប្រៀបជាងកងកម្លាំងពិសេស ក្នុងការប្រយុទ្ធក្នុងទីតាំងបើកចំហត្រូវបានបង្ហាញជាក់ស្តែង នៅក្នុងប្រទេសសូម៉ាលី នៅចុងឆ្នាំ ២០០៦។ កងជីវពលអ៊ីស្លាមនិយមបានកាន់កាប់ទឹកដីភាគច្រើននៃប្រទេសនិងរដ្ឋធានី ដោយបន្សល់ទុកទឹកដីតិចតួច សម្រាប់រដ្ឋាភិបាលអន្តរកាលឈរជើងនៅជិតព្រំដែននៃប្រទេសអេត្យូពី ដែលគាំទ្រដោយកងកម្លាំងទូទៅដ៏ធំសម្បើមនៃប្រទេសអេត្យូពី។ ពួកអ៊ីស្លាមជ្រុលនិយមបានបិទសាលារៀន និងបានដឹកជញ្ជូនក្មេងជំទង់ប្រដាប់ដោយអាវុធគ្រប់ដៃតាមរថយន្តកីកអាប់ ចេញទៅវាយប្រហាររដ្ឋាភិបាលបណ្តោះអាសន្ន។ ពួកគេមិនមែនជាដៃគូតទល់ជាមួយនឹងកងទ័ពអេត្យូពី ដែលក្នុងរយៈពេលពីរសប្តាហ៍បន្ទាប់ បានវាយបណ្តេញពួកគេចេញពីប្រទេសទាំងមូល។ ពួកអ៊ីស្លាមជ្រុលនិយម ដូចកងកម្លាំងពិសេសភាគច្រើន ក្នុងពេលនោះ ត្រូវតែត្រលប់ទៅប្រតិបត្តិការវាយប្រហារបែបទ័ពព្រៃ ជាជាងការដណ្តើមយកនិងកាន់កាប់ទឹកដីដោយចំហ។ នៅទីនេះ ផ្ទុយទៅវិញ កងកម្លាំងទូទៅរបស់ប្រទេសអេត្យូពី មិនមែនជាដៃគូតទល់ជាមួយកងទ័ពព្រៃឡើយ ហើយពួកអ៊ីស្លាមជ្រុលនិយមបានដណ្តើមយកដីកាន់កាប់ ជាបន្តបន្ទាប់ រហូតដល់កងទ័ពអេត្យូពីបោះបង់ចោល និងរត់ចោលជួរ នៅខែមករា ឆ្នាំ ២០០៩។ បន្ទាប់ពីការចាកចេញរបស់ពួកគេ ក្រុមសូម៉ាលីអ៊ីស្លាមជ្រុលនិយមបានដណ្តើមកាន់កាប់ទឹកដីភាគច្រើនក្នុងប្រទេស ដោយបានយកឈ្នះលើកងកម្លាំងរដ្ឋាភិបាលសូម៉ាលី និងប្រយុទ្ធជាមួយកងកម្លាំងរក្សាសន្តិភាពមកពីសហភាពអាហ្វ្រិក។ រដ្ឋាភិបាលសូម៉ាលីបានបញ្ចូលក្រុមអ៊ីស្លាមជ្រុលនិយមមកម្រិតមធ្យម ប៉ុន្តែបានបន្តប្រយុទ្ធប្រឆាំងនឹងក្រុមអ៊ីស្លាមជ្រុលនិយមខ្លាំង។ កងកម្លាំងមកពីសហភាពអាហ្វ្រិកបានបន្តប្រយុទ្ធ

ជាមួយកងកម្លាំងអ៊ីស្លាមជ្រុលនិយម រហូតដល់ឆ្នាំ ២០១៨ បើទោះជាមានកិច្ចពិភាក្សាសម្របសម្រួលការដកកងទ័ពសហភាពចេញ នៅក្នុងឆ្នាំដដែលនេះក្តី ។

ការប្រឆាំងតទល់នឹងការបះបោរ(counterinsurgency) បានទទួលការចាប់អារម្មណ៍កាន់តែខ្លាំងនៅក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ដោយសារតែប្រទេសអ៊ីរ៉ាក់និងអាហ្វហ្គានីស្ថាន ប៉ុន្តែ វាជាចំណុចស្នូលនៃសង្គ្រាមស្ទើរតែទាំងអស់ ដែលកំពុងកើតឡើង នៅទូទាំងពិភពលោក នាពេលបច្ចុប្បន្ននេះ។ សង្គ្រាមប្រឆាំងតទល់នឹងការបះបោរ ជាញឹកញាប់ រួមបញ្ចូលកម្មវិធីយក«ឈ្នះបេះដូង និងចិត្តគំនិត» របស់ប្រជាជន ដូច្នេះ ពួកគេឈប់ផ្តល់ជំរកឬលាក់បំពួនទ័ពព្រៃ។ ដោយសារតែសង្គ្រាមប្រឆាំងតទល់នឹងការបះបោរ ច្រើនពាក់ព័ន្ធនឹងផលចំណេញផ្នែកនយោបាយ ក៏ដូចជាយុទ្ធសាស្ត្រយោធា វាគឺជាប្រភេទសង្គ្រាមដ៏ស្មុគស្មាញបំផុត នៅក្នុងទិដ្ឋភាពមួយចំនួន។ ខណៈពេលដែលកំពុងប្រយុទ្ធជាមួយក្រុមប្រដាប់អាវុធនៃក្រុមបះបោរ រដ្ឋាភិបាល ត្រូវតែធ្វើយុទ្ធនាការទំនាក់ទំនងសាធារណៈជាចាំបាច់ ដើម្បីបញ្ចុះបញ្ចូលប្រជាជនអោយបោះបង់ចោលចលនានេះ ខណៈពេលត្រូវផ្តល់ជាសេវាកម្មសាធារណៈ (ដូចជា កម្មវិធីអប់រំ និងសុខុមាលភាព) ដើម្បីបង្ហាញពីការឆ្លើយតបរបស់រដ្ឋាភិបាលចំពោះប្រជាជន។ រដ្ឋាភិបាលត្រូវតែរឹងមាំផ្នែកយោធា ប៉ុន្តែពួកគេមិនអាចប្រព្រឹត្តិទង្វើឃោរឃៅពេកក្នុងការអនុវត្តកម្លាំងបានទេ ព្រោះអាចបណ្តាលអោយប្រជាជនកាន់តែច្រើនចាប់ផ្តើម គាំទ្រកងកម្លាំងទ័ពព្រៃ។

កងកម្លាំងយោធាអាមេរិកបានធ្វើយុទ្ធនាការប្រឆាំងការបះបោរ នៅក្នុងប្រទេសអ៊ីរ៉ាក់ និងប្រទេសអាហ្វហ្គានីស្ថានអស់រយៈពេលជាច្រើនឆ្នាំ។ យុទ្ធនាការនេះរួមមានការប្រើប្រាស់កម្លាំងយោធាដ៏សាហាវ ការសូកប្រាក់ដល់មេដឹកនាំកុលសម្ព័ន្ធសំខាន់ៗដើម្បីអោយគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់អាមេរិក ជំនួយដល់ការបង្កើតរដ្ឋាភិបាលក្នុងតំបន់ និងការបណ្តុះបណ្តាលកងកម្លាំងប៉ូលិស និងយោធាថ្មី ដើម្បីប្រយុទ្ធប្រឆាំងតទល់នឹងការបះបោរ។ ប្រភេទនៃសកម្មភាពទាំងនេះ សង្កត់ធ្ងន់ទៅលើកងកម្លាំងយោធា ដែលជាធម្មតា ត្រូវបានបណ្តុះបណ្តាលដើម្បីតែប្រយុទ្ធក្នុងសង្គ្រាមមិនមែនដើម្បីធ្វើការកសាងរដ្ឋាភិបាលនៅឯនាយសមុទ្រ ឡើងវិញនោះទេ។

យុទ្ធនាការប្រឆាំងតទល់នឹងការបះបោរត្រូវចំណាយច្រើន និងត្រូវពឹងផ្អែកលើកម្លាំងពលកម្មសន្ធឹកសន្ធាប់។ ជាឧទាហរណ៍ សៀវភៅណែនាំស្តីពីការប្រឆាំងតទល់នឹងការបះបោររបស់កងទ័ពសហរដ្ឋអាមេរិក ស្នើអោយដាក់ពង្រាយទាហានចំនួន ២០ នាក់ សម្រាប់ពលរដ្ឋ ១ ០០០ នាក់ ដើម្បីការពារពីក្រុមបះបោរ។ រដ្ឋមួយចំនួនតូចប៉ុណ្ណោះអាចមានលទ្ធភាពធ្វើយុទ្ធនាការបែបនេះ ក្នុងរយៈពេលយូរ។ ជាការពិតណាស់ បើទោះបីជារាប់បញ្ចូលទាំងកងកម្លាំងសម្ព័ន្ធមិត្តក៏ដោយ សហរដ្ឋអាមេរិកមិនដែលឈានដល់សមាមាត្រនៃចំនួនទាហានទៅចំនួនប្រជាជន (តាមរូបមន្ត ទាហាន២០នាក់ ការពារប្រជាជន ១ ០០០នាក់) នៅក្នុងប្រទេសអ៊ីរ៉ាក់ ឬ ប្រទេសអាហ្វហ្គានីស្ថាននោះទេ។ សមាមាត្របែបនេះនឹងត្រូវការទាហាន ៦០០ ០០០ នាក់ សម្រាប់ប្រទេសអាហ្វហ្គានីស្ថាន បើធៀបនឹងចំនួនដាក់ស្តែងនៃទាហានអន្តរជាតិ ១៣០ ០០០ នាក់ ដែលបានដាក់ពង្រាយ នៅទីនោះ នៅចំណុចកំពូល ក្នុងឆ្នាំ ២០១០ (ធ្លាក់ចុះដល់ ១៤ ០០០ ត្រឹមឆ្នាំ ២០១៨)។

រូបថត ទីប្រឹក្សាសិទ្ធិមនុស្សបានណែនាំទាហានក្សាសន្តិភាពសហភាពអាហ្វ្រិកអំពីច្បាប់អន្តរជាតិ «ឈ្នះបេះដូង និងចិត្តគំនិត»

សង្គ្រាមប្រឆាំងការបះបោរបានក្លាយជាចំណុចគោលនៃបេសកកម្មរបស់កងកម្លាំងយោធា ដែលពាក់ព័ន្ធសណ្ឋាននៅទូទាំងពិភពលោក។ យោធាអាមេរិកបានសរសេរសៀវភៅណែនាំអំពីការប្រឆាំងការបះបោរឡើងវិញ ហើយបានផ្លាស់ប្តូរយុទ្ធសាស្ត្ររបស់ខ្លួននៅក្នុងប្រទេសអ៊ីរ៉ាក់ និងអាហ្វហ្គានីស្ថាន ដើម្បីសង្កត់ធ្ងន់លើសកម្មភាពនយោបាយនិងសេដ្ឋកិច្ច និងទំនាក់ទំនងវិជ្ជមានជាមួយប្រជាជនស៊ីវិល។ នៅទីនេះ នៅក្នុងរដ្ឋធានីនៃប្រទេសសូម៉ាលី ទីប្រឹក្សាសិទ្ធិមនុស្សបានណែនាំទាហានរក្សាសន្តិភាពសហភាពអាហ្វ្រិកលើច្បាប់អន្តរជាតិដោយសង្ឃឹមថា អាកប្បកិរិយារបស់ពួកគេនឹងស្របតាមស្តង់ដារអន្តរជាតិក្នុងការការពារជនស៊ីវិលឆ្នាំ ២០១៤ ។

ឧបករណ៍ទូទៅរបស់កម្លាំងទ័ពព្រៃ ពួកបះបោរ និងរដ្ឋាភិបាលដែលប្រយុទ្ធនឹងពួកគេ គឺជាគ្រាប់មីនដែលជាឧបករណ៍ផ្ទុកគ្រឿងផ្ទុះដ៏សាមញ្ញ តូច និងថោក ជាមួយនឹងកែឬក្រវិលដែលដំណើរការ ដោយការប៉ះឬជាន់ផ្ទាល់ ឬឧបករណ៍ចាប់សញ្ញាសិនសរ។ គ្រាប់មីនទាំងនេះគឺជាការផ្តោតការយកចិត្តទុកដាក់ជាពិសេសរបស់សាធារណជន នៅក្នុងទស្សវត្សរ៍ឆ្នាំ ១៩៩០ ដោយសារតែនៅទីកន្លែងមួយចំនួនដូចជា ប្រទេសអង់ហ្គោឡា ប្រទេសអាហ្វហ្គានីស្ថាន ប្រទេសកម្ពុជា និងប្រទេសបូស្នៀ វាត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយដោយកងកម្លាំងយោធាពិសេស (មិនទៀងទាត់) ដែលមិនដែលត្រូវបានគេដោះចេញវិញឡើយ។ បន្ទាប់ពីសង្គ្រាមបែបនេះត្រូវបានបញ្ចប់យ៉ាងយូរក៏ដោយ គ្រាប់មីននៅតែបន្តបំផ្លាញ និងសម្លាប់ជនស៊ីវិល ដែលព្យាយាមបង្កបង្កើតជីវភាពរស់នៅរបស់ពួកគេឡើងវិញ នៅក្នុងអតីតតំបន់សង្គ្រាម។ គ្រាប់មីនក៏បានក្លាយជាអាវុធពិឃាតសម្រាប់តួអង្គមិនមែនរដ្ឋផងដែរ។ មានការប៉ាន់ប្រមាណថាគ្រាប់មីនជាង ១៥ លាន គ្រាប់នៅត្រូវបានបង្កប់នៅក្នុងវាលខ្សាច់នៃឧបទ្វីបសៃណៃរបស់ប្រទេសអេហ្ស៊ីប។ ថ្មីៗនេះ ក្រុមភេរវកម្មផ្សេងៗបានចាប់ផ្តើមជីកមីនទាំងនោះយកមកប្រើប្រាស់ជាគ្រាប់ផ្ទុះដើម្បីវាយប្រហារលើគោលដៅរបស់ពួកគេផ្ទាល់។ នៅលើសកលលោកទាំងមូល គ្រាប់មីនរហូតដល់ ១០០ លានគ្រាប់បន្សល់ទុកដោយសង្គ្រាម ដោយបានសម្លាប់និងធ្វើអោយរងរបួសមនុស្ស ប្រហែល ៥ ០០០ នាក់ ក្នុងមួយឆ្នាំ (ក្នុងនោះ មួយភាគបីគឺជាកុមារ) ទោះបីជាការដាក់ពង្រាយឬបង្កប់មីនមានតម្លៃថោកក៏ដោយ ដើម្បីរាវរកនិងដោះមីនមួយគ្រាប់ គេត្រូវចំណាយប្រាក់ប្រហែល ១ ០០០ ដុល្លារ។

មតិសាធារណៈ និងអង្គការមិនមែនរដ្ឋាភិបាល (NGOs) បានដាក់សម្ពាធលើរដ្ឋាភិបាលអោយតែបន្តឹងការប្រើប្រាស់គ្រាប់មីន។ ប្រទេសចំនួន១០០ជាង បានចុះហត្ថលេខាសន្ធិសញ្ញាហាមឃាត់គ្រាប់មីននៅក្នុងសន្និសីទឆ្នាំ ១៩៩៧ ដែលរៀបចំដោយប្រទេសកាណាដា។ ប្រទេសរុស្ស៊ី និងប្រទេសជប៉ុនបានចុះហត្ថលេខាភ្លាមៗក្រោយសន្ធិសញ្ញានោះ ប៉ុន្តែប្រទេសចិន ឬសហរដ្ឋអាមេរិកមិនបានចូលរួមទេ (ដែលបានអះអាងថា គ្រាប់មីននឹងត្រូវការជាចាំបាច់ ដើម្បីបន្ថយល្បឿនឈ្លានពានរបស់ប្រទេសកូរ៉េខាងជើងចូលប្រទេសកូរ៉េខាងត្បូង)។ នៅត្រឹមឆ្នាំ ២០១៨ គ្រាប់មីនជាង ៥០ លានគ្រាប់ ត្រូវបានបំផ្លាញ ក្រោមការចាត់ចែងតាមសន្ធិសញ្ញានេះ ដោយមានប្រទេសចំនួន ៨៧ បានកំទេចឃ្លាំងគ្រាប់មីនរបស់ពួកគេ។ បទដ្ឋានថ្មីមួយហាក់ដូចជាកំពុងលេចឡើង ប៉ុន្តែ ឥទ្ធិពលរបស់វាទៅលើការអនុវត្តជាក់ស្តែងខាងយោធាមិនទាន់ច្បាស់នៅឡើយទេ។

៦.១.២. កងទ័ពជើងទឹក៖ គ្រប់គ្រងដែនសមុទ្រ

កងនាវាចរណ៍ត្រូវបានកែសម្រួលជាចម្បងដើម្បីគ្រប់គ្រងការឆ្លងកាត់ច្រកសមុទ្រ និងវាយប្រហារដីគោក នៅក្បែរឆ្នេរសមុទ្រ។ ការគ្រប់គ្រងលើសមុទ្រក្នុងសម័យសង្គ្រាមអនុញ្ញាតអោយរដ្ឋនានាដឹកជញ្ជូនទំនិញរបស់ផ្ទាល់ខ្លួននិងចល័តកម្លាំងយោធាតាមសមុទ្រ ក្នុងដំណាលពេលដែលរារាំងសត្រូវមិនអោយធ្វើបែបនេះ។ កងទ័ពជើងទឹកក៏អាចរារាំងឬបិទខ្ទប់កំពង់ផែរបស់សត្រូវបានដែរ ជាឧទាហរណ៍ ដូចដែលប្រទេសអ៊ីស្រាអែលធ្វើដើម្បីគ្រប់គ្រងច្រកចូលសមុទ្រទៅកាន់តំបន់ហ្គាហ្សាដែលគ្រប់គ្រងដោយក្រុមឧទ្ធាមហាម៉ាស់។

ក្នុងឆ្នាំ ២០០៨-២០១២ កងនាវាចរណ៍នៃប្រទេសមហាអំណាចបស្ចឹមលោកបានឆ្លើយតបទៅនឹងការកើនឡើងយ៉ាងឆាប់រហ័សនៃចោរសមុទ្រ នៅក្នុងផ្លូវដឹកជញ្ជូនសំខាន់ៗចំនួនបីរបស់ពិភពលោក៖ (១)ពីប្រទេសសូម៉ាលីភាគខាងត្បូងតាមព្រំកដីកស៊ុយអេ, (២)ជ្រោយម៉ាឡាកាក្នុងប្រទេសឥណ្ឌូនេស៊ីដែលតភ្ជាប់មហាសមុទ្រឥណ្ឌាជាមួយនឹងតំបន់អាស៊ីបូព៌ា, ហើយនាពេលថ្មីៗនេះ (៣)ផ្លូវទឹកក្បែរអាហ្វ្រិកខាងលិច។ ចោរសមុទ្រសូម៉ាលី ដោយឆ្លៀតឱកាសទាញយកប្រយោជន៍ពីស្ថានភាពស្ទើរតែអនាធិបតេយ្យទាំងស្រុង នៅក្នុងប្រទេសនោះ បានបង្កើតជម្រកសុវត្ថិភាពនៅតាមឆ្នេរសមុទ្រ ហើយបានចេញដំណើរដើម្បីចាប់យកកប៉ាល់រាប់សិបគ្រឿង រឹបអូសយកកប៉ាល់ ទំនិញ និងនាវិក ជម្រិតយកប្រាក់លោះ។ ក្រុមហ៊ុនដឹកជញ្ជូនជាទូទៅ បានបង់ប្រាក់រាប់លានដុល្លារក្នុងមួយកប៉ាល់ ជាជាងបាត់បង់ទំនិញដ៏មានតម្លៃនិងជីវិតមនុស្ស។ ចោរសមុទ្រកាន់តែផ្តើនខ្លាំង ដោយដំបូងបានចាប់ជម្រិតនាវាដឹកទំនិញអ៊ុយក្រែន ដែលផ្ទុកដោយរថក្រោះនិងអាវុធ ហើយបន្ទាប់មក ចាប់ជម្រិតនាវាដឹកប្រេងអារ៉ាប៊ីសាអូឌីតដ៏ធំ ដែលមានទំហំទឹកប្រាក់រហូតដល់ ១០០ លានដុល្លារ។ ដោយបើកទូកតូចនិងលឿន ប្រដាប់ដោយកាំភ្លើងស្វ័យប្រវត្តិ និងគ្រាប់គ្រាប់បែកដៃ សំដៅទៅកាន់នាវាទាំងនោះ ពួកគេបានបោះទំពក់ឡើងលើចំហៀងនិងបង្ក្រាបនាវិក ជាធម្មតា ក្នុងរយៈពេលប្រហែលដប់នាទីតែប៉ុណ្ណោះ។

កងទ័ពជើងទឹករបស់ពិភពលោកបានចល័តយាមល្បាតតំបន់ទាំងនេះ ដើម្បីទប់ស្កាត់ការចោរសមុទ្រ (សូមមើលតួលេខ ៦.៣)។ នៅក្នុងឆ្នាំ ២០០៨ ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ(UNSC)បានអំពាវនាវដោឯកច្ឆ័ន្ទអោយមានកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងការប្រយុទ្ធប្រឆាំងនឹងការកើនឡើងនៃចោរសមុទ្រ(បង្ខំកាពីតែនអោយបង្វែរគោលដៅ)។ រដ្ឋជាច្រើន រួមទាំងសមាជិកអចិន្ត្រៃយ៍ទាំងប្រាំនៃក្រុមប្រឹក្សាសន្តិសុខ បានធ្វើការឆ្លើយតបភ្លាមៗ។ កងនាវារបស់សហរដ្ឋអាមេរិក បានសម្លាប់ចោរសមុទ្រដែលបានប្លន់នាវាអាមេរិកមួយ នៅឆ្នាំ ២០០៩។ ចំណែក ឧទ្ធម្ភាគចក្រចម្បាំងរបស់សហភាពអឺរ៉ុបបានវាយធ្មក់មូលដ្ឋានចោរសមុទ្រ នៅឆ្នាំ ២០១២។ នាវាដឹកទំនិញជាច្រើនបានចាប់ផ្តើមជួលឆ្មាំប្រដាប់ដោយអាវុធ។ វិធានការណ៍ទាំងនេះ ក្នុងចំណោមកិច្ចប្រឹងប្រែងដទៃទៀត បានបណ្តាលអោយសកម្មភាពឆក់ប្លន់តាមសមុទ្រនៅសូម៉ាលីធ្លាក់ចុះយ៉ាងខ្លាំង នៅឆ្នាំ ២០១២។ មេដឹកនាំចោរសមុទ្រដ៏ល្បីល្បាញម្នាក់ រហ័ស្សនាម «អាមាត់ធំ» ដែលធ្លាប់បានរឹបអូសយកនាវាអ៊ុយក្រែនផ្ទុកពេញដោយរថក្រោះ បានប្រកាសទម្លាក់អាវុធ និងចូលនិវត្តន៍ នៅឆ្នាំ ២០១៣។ នៅត្រឹមឆ្នាំ ២០១៧ សកម្មភាពឆក់ប្លន់តាមសមុទ្របានកើនឡើងនៅអាហ្វ្រិកខាងលិចនិងអាស៊ីបូព៌ា ក្នុងពេលដែលក្រុមនានានៅតំបន់ទាំងនោះពង្រីកប្រតិបត្តិការរបស់ខ្លួន ស្របពេលដែលកងនាវាចរណ៍ពិភពលោកបាននិងកំពុងផ្តោតនៅលើសូម៉ាលី។ វិសាលភាពសមុទ្រធំល្វឹងល្វើយនិងចំនួនគោលដៅរបស់ចោរសមុទ្រច្រើនអនេកធ្វើអោយចោរសមុទ្រក្លាយជាបញ្ហាពិបាកដោះស្រាយ។

នាវាផ្ទុកយន្តហោះ(aircraft carriers) ដែលជាព្រលានចល័តសម្រាប់យន្តហោះចម្បាំងចុះចត គឺជាយុទ្ធបករណ៍បញ្ចេញឬសម្ដែងអំណាច(power projection) ដែលអាចបើកការវាយប្រហារស្ទើរតែគ្រប់រដ្ឋនៅក្នុងពិភពលោក។ ដោយគ្រាន់តែបញ្ជូននាវាផ្ទុកយន្តហោះទៅតំបន់ជុំវិញជម្លោះអន្តរជាតិបង្ហាញពីការគំរាមកំហែងក្នុងការប្រើកងកម្លាំង ដែលជាទំរង់ទំនើបនៃ «ការទូតនាវាចម្បាំង» (gunboat diplomacy) កាលពីសតវត្សរ៍ទីដប់ប្រាំបួន។ នាវាផ្ទុកយន្តហោះមានតម្លៃថ្លៃខ្លាំងណាស់ ហើយជាធម្មតាត្រូវការនាវាជំនួយពី ២០ ទៅ ២៥ គ្រឿង សម្រាប់ការពារនិងផ្គត់ផ្គង់។ រដ្ឋមួយចំនួនតូចប៉ុណ្ណោះអាចទិញវាប្រើបាន រដ្ឋភាគច្រើនគ្មានលទ្ធភាពទិញប្រើទេ សូម្បីតែមួយគ្រឿង។ មានតែសហរដ្ឋអាមេរិកទេដែលអាចដំណើរការនាវាផ្ទុកយន្តហោះច្រើនជាងគេបំផុត រហូតដល់ ១០ គ្រឿង ដែលមួយគ្រឿងៗមានតម្លៃជាង ៥ ពាន់លានដុល្លារ។ នៅឆ្នាំ ២០១៧ កងទ័ពជើងទឹកអាមេរិកបានសម្ពោធដាក់អោយដំណើរការនូវនាវាផ្ទុកយន្តហោះទំនើបដែលត្រូវបានរចនាឡើងថ្មី និងមានតម្លៃរហូតដល់ ១៤ ពាន់លានដុល្លារ។ ងាកមកមើលប្រទេសចិនវិញបានទិញយកនិងជួសជុលនាវាផ្ទុកយន្តហោះមួយគ្រឿង នៅឆ្នាំ ២០១២ បើទោះជាវាសម្រាប់តែការហ្វឹកហ្វាត់ក្តី។ នៅឆ្នាំ ២០១៧ ចិនបានចាប់ផ្តើមប្រតិបត្តិការបឋមនូវនាវាផ្ទុកយន្តហោះដែលផលិតនៅក្នុងប្រទេសខ្លួនផ្ទាល់ និងបានប្រកាសការកសាងនាវាផ្ទុកយន្តហោះទីពីរទៀត។ ប្រទេសចំនួនប្រាំបីផ្សេងទៀត (បារាំង ឥណ្ឌា រុស្ស៊ី អេស្បាញ ប្រេស៊ីល អ៊ីតាលី ថៃ និងចក្រភពអង់គ្លេស) ប្រតិបត្តិការនាវាផ្ទុកយន្តហោះតូចៗ ដែលប្រើប្រាស់ឧទ្ធម្ភាគចក្រ ឬយន្តហោះខ្នាតតូច។

ក្រាហ្វិក ៦.៣ ការវាយប្រហារដោយចោរសមុទ្រ ជុំវិញពិភពលោកឆ្នាំ ២០១៧

ប្រភព៖ ការវាយប្រហារដោយចោរសមុទ្រ ជុំវិញពិភពលោកឆ្នាំ ២០១៧,

ផ្អែកលើផែនទី ICC-CCS ឆ្នាំ ២០១៧ ។ https://www.icc-ccs.org/index.php/piracy-reporting-centre/live-piracy-map/piracy-map-២០១៧ ។



(សម្គាល់៖ ជុំខៀវតំណាងការបាញ់រះលើ, ជុំលឿងឡើងកប៉ាល់ប្លន់ និងជុំក្រហមការប្លន់)

នាវាលើផ្ទៃទឹក ដែលរាប់បញ្ចូលទាំងនាវាចម្បាំងភាគច្រើន ពឹងផ្អែកកាន់តែខ្លាំងឡើងលើប្រព័ន្ធកាំជ្រួចប្រដេញ(guided missiles) ហើយផ្ទុយមកវិញ ងាយនឹងរងគ្រោះពីការវាយប្រហារដោយគ្រាប់មីស៊ីល (ដែលត្រូវបាញ់ចេញពីនាវា យន្តហោះ នាវាមុជទឹក ឬដីគោក)។ ដោយសារតែរយៈចម្ងាយនៃកាំជ្រួចតូចៗ បច្ចុប្បន្ននេះ អាចបាញ់រហូតដល់ចម្ងាយរាប់រយម៉ាយល៍ សង្គ្រាមទ័ពជើងទឹកសង្កត់ធ្ងន់លើការរាវរកឃើញគោលដៅសត្រូវ នៅក្នុងរយៈចម្ងាយឆ្ងាយ ដោយកំបាំងខ្លួនមិនអោយសត្រូវរកឃើញខ្លួនឯងវិញឡើយ។ នេះជាល្បែងឆ្មានិងកណ្តុរ ដែលប្រើការឃ្លាំមើលដោយរ៉ាដានិងវិធានការណ៍ប្រឆាំងគ្រឿងអេឡិចត្រូនិក។

កងម៉ារីន (ផ្នែកនៃកងទ័ពជើងទឹកនៅក្នុងសហរដ្ឋអាមេរិក អង់គ្លេស និងរុស្ស៊ី) ចល័តចូលសមរភូមិប្រយុទ្ធតាមនាវា ប៉ុន្តែឡើងប្រយុទ្ធនៅលើដីគោក ពោលគឺ សង្គ្រាមលើទឹកផងនិងដីគោកផង។ កងម៉ារីនក៏មានប្រយោជន៍ផងដែរសម្រាប់ការធ្វើអន្តរាគមន៍ប្រទេសមហាអំណាចនៅក្នុងជម្លោះនៅឯនាយសមុទ្រ ដែលពួកគេអាចបញ្ជៀតខ្លួនពួកគេចូលបានយ៉ាងឆាប់រហ័ស និងដណ្តើមការគ្រប់គ្រងក្នុងតំបន់។

៦.១.៣. កងទ័ពអាកាស៖ គ្រប់គ្រងដែនអាកាស

កងទ័ពអាកាស (air forces) បម្រើគោលដៅជាច្រើន៖ ការទម្លាក់គ្រាប់បែកជាយុទ្ធសាស្ត្រទៅលើគោលដៅលើដីគោក ឬ លើសមុទ្រ, «ការគាំទ្រតាមអាកាសទាបៗ»(ការទម្លាក់គ្រាប់បែកនៅក្នុងសមរភូមិ), ការស្ទាក់ចាប់យន្តហោះផ្សេងទៀត, ការឈ្លបយកការណ៍, និងយន្តហោះដឹកជញ្ជូនកសិការផ្គត់ផ្គង់ សព្វាវុធ និងកងទ័ព។ គ្រាប់កាំជ្រួច មិនថាបាញ់ចេញពីលើអាកាស ដីផ្ទាល់ ឬសមុទ្រ មានសារៈសំខាន់កាន់តែខ្លាំងឡើង។ កងទ័ពអាកាសបានបង្កើតមធ្យោបាយផ្សេងៗ ដើម្បីព្យាយាមបញ្ឆោតមីស៊ីលបែបនេះ ដោយទទួលបានលទ្ធផលចម្រុះ។ នៅក្នុងសង្គ្រាមសូវៀតនៅក្នុងប្រទេសអាហ្វហ្គានីស្ថាន កាំជ្រួចចល័ត«ឃ្មុំទិញ» (Stinger) ផលិតដោយសហរដ្ឋអាមេរិក ដែលប្រើដោយកងទ័ពព្រៃ បានធ្វើអោយកងទ័ពអាកាសសូវៀតមានការខូចខាតយ៉ាងខ្លាំង។ ក្នុងឆ្នាំ ២០០៣ ការគម្រាមកំហែងពីកាំជ្រួចបាញ់តាមស្មា បានធ្វើអោយអាកាសយានដ្ឋានក្រុង**បាកដាដ**បានបិទដើងហោះហើរពាណិជ្ជកម្មអស់រយៈពេលជាង មួយឆ្នាំ បន្ទាប់ពីកងកម្លាំងសហរដ្ឋអាមេរិកបានមកដល់។

រូបថត នាវាផ្ទុកយន្តហោះអាមេរិក

ការសម្លែងអំណាច

ប្រភេទកងកម្លាំងយោធាផ្សេងគ្នា ត្រូវសម្របទៅតាមគោលបំណងផ្សេងគ្នាដែរ។ នាវាផ្ទុកយន្តហោះត្រូវបានប្រើប្រាស់សម្រាប់សម្លែងអំណាច នៅក្នុងតំបន់ឆ្ងាយៗ ដូចជានៅក្នុងយុទ្ធនាការនៅក្នុងប្រទេសអាហ្វហ្គានីស្ថាន និងអ៊ីរ៉ាក់។

ជាប្រពៃណី ហើយនៅតែមានក្នុងកម្រិតខ្លះ ការទម្លាក់គ្រាប់បែកពីលើអាកាសមានលក្ខណៈប្រហាក់ប្រហែលនឹងការបាញ់ផ្លោងដោយកាំភ្លើងធំ ដែលវាបណ្តាលអោយមានការបំផ្លិចបំផ្លាញយ៉ាងដំណាំ ជាមួយនឹងការរើសអើងគោលដៅតិចតួច។ មានការប្រែប្រួលមួយចំនួន នៅពេលដែលគ្រាប់បែកឆ្លាតវៃ អាចតំរង់រកគោលដៅកាន់តែសុក្រឹត។ ជាឧទាហរណ៍ គ្រាប់បែកតំរង់ដោយកាំរស្មីឡាស៊ែរ រត់តំរង់តាមឧបករណ៍ចាប់សញ្ញាឬចលនា(sensor)ដែលតំរង់ទៅគោលដៅ ពីអាកាស ឬ ដីផ្ទាល់។ គ្រាប់បែកផ្សេងទៀតប្រើប្រព័ន្ធកំណត់ទីតាំងសកល ឬហៅជាភាសាអង់គ្លេសថា ជី.ភី.អេស.(GPS) ដើម្បីបាញ់ប្រហារតំរង់ទៅរកគោលដៅទំលុះដុំពពក ផ្សែង ឬព្យុះខ្សាច់។ ការទម្លាក់គ្រាប់បែកភាគច្រើន នៅក្នុងសង្គ្រាមឈូងសមុទ្រឆ្នាំ ១៩៩១ គឺ

ជាការទម្លាក់គ្រាប់បែក ដែលមានរយៈកម្ពស់ខ្ពស់ ដោយប្រើគ្រាប់បែកបំផ្ទុះជាច្រើន។ នៅក្នុងសង្គ្រាមធម្មតា ដូចជាសង្គ្រាមរបស់រុស្ស៊ី នៅឆេចនៀ នៅឆ្នាំ ១៩៩៥ ការទម្លាក់គ្រាប់បែកលើទីក្រុងនានា បណ្តាលអោយមានជនស៊ីវិលជាច្រើនត្រូវស្លាប់បាត់បង់ជីវិត។ ប៉ុន្តែ នៅក្នុងសង្គ្រាមអ៊ីរ៉ាក់ឆ្នាំ ២០០៣ យុទ្ធនាការផ្លូវអាកាសដ៏ធំ នៅដើមសង្គ្រាមបានប្រើគ្រាប់បែកឆ្លាតវៃទាំងស្រុង ដោយវាយលុកគោលដៅកាន់តែច្រើន ដោយគ្រាប់បែកតិចជាងមុន។ ទោះជាយ៉ាងនេះក្តី ជនស៊ីវិលរាប់ពាន់នាក់ទំនងជាបានស្លាប់បាត់បង់ជីវិត នៅក្នុងការវាយប្រហារតាមអាកាសរបស់សហរដ្ឋអាមេរិក នៅក្នុងប្រទេសអ៊ីរ៉ាក់ ចាប់តាំងពីឆ្នាំ ២០០៣។[២២]

នៅក្នុងករណីនៃជម្លោះកម្រិតទាប (មិនសូវតានតឹង) និងសង្គ្រាមទំពែ្រ ជាពិសេស នៅទីកន្លែងដែលកងកម្លាំងប្រដាប់អាវុធរស់នៅបន្លំខ្លួនជាមួយជនស៊ីវិល នៅក្នុងទីតាំងបិទជិត ដូចជាព្រៃភ្នំនៅវៀតណាម ឬទីក្រុងអ៊ីរ៉ាក់ ការទម្លាក់គ្រាប់បែកមិនសូវមានប្រសិទ្ធិភាពទេ ទោះជាវាមានប្រសិទ្ធភាពខ្លាំង នៅក្នុងប្រទេសអាហ្វហ្គានីស្ថាន នៅក្នុងឆ្នាំ ២០០១ ក៏ដោយ។ ប្រទេសអ៊ីស្រាអែលក៏បានបើកយុទ្ធនាការទម្លាក់គ្រាប់បែកយ៉ាងទូលំទូលាយ នៅក្នុងការលុកលុយចូលប្រទេសលីបង់ ក្នុងឆ្នាំ ២០០៦។

ឧបករណ៍អេឡិចត្រូនិកកាន់តែទំនើបនិងសាំញ៉ាំ និងតម្រូវការយន្តហោះវាយប្រហារដែលមានកំរិតប្រតិបត្តិការខ្ពស់ធ្វើអោយកងទ័ពអាកាសកាន់តែមានតម្លៃថ្លៃឡើងៗ រហូតដល់កំរិតមួយដែលរដ្ឋមួយចំនួនមិនមានលទ្ធភាពដល់។ ដូច្នេះ រដ្ឋស្តុកស្តម្ភមានឧត្តមភាពឬប្រៀបខ្លាំងលើរដ្ឋក្រីក្រ នៅក្នុងសង្គ្រាមអាកាស។ ថ្វីបើមានការចំណាយច្រើនសន្ធឹកសន្ធាប់ក៏ដោយ ឧត្តមភាពនៃកងទ័ពអាកាស គឺជាគន្លឹះនៃភាពជោគជ័យនៃប្រតិបត្តិការលើដីគោក ជាពិសេសនៅក្នុងទីតាំងបើកចំហ។ ការទម្លាក់គ្រាប់បែករបស់អាមេរិកលើប្រទេសអ៊ីរ៉ាក់(ក្នុងឆ្នាំ១៩៩១ និងឆ្នាំ ២០០៣) ប្រទេសស៊ែប៊ី(១៩៩៩) និងប្រទេសអាហ្វហ្គានីស្ថាន(២០០១) បានបង្ហាញពីប្រសិទ្ធភាពថ្មីនៃអំណាចកងទ័ពអាកាស ដែលមិនសំដៅ ប្រឆាំងនឹងសីលធម៌របស់ប្រជាជនសត្រូវទេ (ដូចនៅក្នុងសង្គ្រាមលោកលើកទី ២) ប៉ុន្តែ បានកំណត់គោលដៅដោយផ្ទាល់ពីចម្ងាយនៅទីតាំងសមរភូមិ។ សមត្ថភាពរបស់អាមេរិកក្នុងការកំទេចកងកម្លាំងយោធាសត្រូវពីចម្ងាយ ខណៈដែលរងគ្រោះពីការស្លាប់និងរបួសស្រាលតិចតួច មិនធ្លាប់មានពីមុនមកក្នុងប្រវត្តិសាស្ត្រ។ ការវាយប្រហារឆ្នាំ ២០០៣ លើអ៊ីរ៉ាក់បានបង្ហាញពីអត្ថប្រយោជន៍នៃអំណាចកងទ័ពដែនអាកាស ប៉ុន្តែវាក៏មានព្រំដែនកំណត់ផងដែរ។ ការវាយឆ្មក់ដោយការទម្លាក់គ្រាប់បែកយ៉ាងច្រើនសម្បើមលើគោលដៅជាក់លាក់នៅក្រុងបាកដាដ ប៉ុន្មានថ្ងៃក្នុងសង្គ្រាមបានបំផ្លាញចំគោលដៅរាប់រយ ដែលមានតម្លៃខ្លាំងបំផុតសម្រាប់រដ្ឋាភិបាលរបស់ សាដាម ហ៊ូសេន។ វាត្រូវបានអនុវត្តឡើងដើម្បីបង្កភាព «តក់ស្លុត និងស្ងប់ស្ងែង» ក្នុងចំណោមមេទ័ពសត្រូវ ដោយសង្ឃឹមថាពួកគេរត់ចោលជួរ។ ទោះជាយ៉ាងណា កងកម្លាំងអាមេរិកនៅតែត្រូវចូលសមរភូមិប្រយុទ្ធនៅលើដីផ្ទាល់ ដើម្បីទៅកាន់កាប់ក្រុងបាកដាដ។ ច្បាស់ណាស់ សង្គ្រាមនេះមិនអាចឈ្នះពីលើអាកាសតែម្យ៉ាងបានទេ។ ដូចដែលទាហានជើងគោកបានចង្អុលបង្ហាញថា «គ្មានសត្រូវណាមួយធ្លាប់ចុះចាញ់នឹងយន្តហោះទេ»។[២៣]

កងទ័ពអាកាសគឺជាចំណុចដែលទំនងជាមានការយកចិត្តទុកដាក់ នៅក្នុងការប្រណាំងសព្វាវុធរវាងសហរដ្ឋអាមេរិក និងប្រទេសចិន នាពេលអនាគត។ ប្រទេសចិនបានចំណាយប្រាក់យ៉ាងច្រើនក្នុងរយៈពេល

[២២] Roberts, Les, et al. Mortality Before and After the ២០០៣ Invasion of Iraq: Cluster Sample Survey. *The Lancet* ៣៦៤, November ២០, ២០០៤: ១៨៥៧–៦៤.

[២៣] Pape, Robert A. The True Worth of Air Power. Foreign Affairs ៨៣ (២), ២០០៤: ១១៦–៣១.

ដប់ឆ្នាំចុងក្រោយនេះ ដើម្បីស្តារសមត្ថភាពកងទ័ពអាកាសដ៏ចាស់គំរិលរបស់ខ្លួនឡើងវិញ។ សហរដ្ឋអាមេរិក បន្តវិនិយោគយ៉ាងច្រើន នៅក្នុងកម្លាំងទ័ពអាកាសរបស់ខ្លួន ដោយបង្កើតបច្ចេកវិទ្យាថ្មីៗ ដើម្បីបន្តនាំមុខប្រទេសចិន។ ហើយខណៈពេលដែលឥទ្ធិពលទ័ពអាកាសប្រហែលជាមិនសូវមានប្រយោជន៍ ក្នុងសង្គ្រាមទ្រង់ទ្រាយតូច រដ្ឋនានានៅតែបន្តបង្កើតកងកម្លាំងអាកាសរបស់ពួកគេ ក្នុងករណីផ្ទុះជម្លោះ ទ្រង់ទ្រាយធំកាន់តែច្រើន។

៦.១.៤. កងកម្លាំងចម្រុះ ឥស្សរជនការសើបការណ៍សម្ងាត់

រាល់ប្រតិបត្តិការយោធាទាំងអស់ត្រូវពឹងផ្អែកខ្លាំងលើការគាំទ្រផ្នែកឥស្សរជន ដូចជាស្បៀងអាហារ ប្រេងឥន្ធនៈ និងអាវុធយុទ្ធភណ្ឌ (អាវុធនិងគ្រាប់រំសេវ)។ ឥស្សរជនយោធា គឺជាប្រតិបត្តិការដ៏ធំមួយ ហើយនៅក្នុងកងកម្លាំងប្រដាប់អាវុធភាគច្រើន ទាហានភាគច្រើនមិនមែនជាកងទ័ពប្រយុទ្ធផ្ទាល់ទេ។ សមត្ថភាពឈានដល់កម្រិតសកល រួមបញ្ចូលការគាំទ្រផ្នែកឥស្សរជនៈចម្ងាយឆ្ងាយ ជាមួយនឹងកងកម្លាំងសម្ងែងអំណាចជាច្រើនផ្សេងទៀត។ សមត្ថភាពទាំងនេះអនុញ្ញាតអោយប្រទេសមហាអំណាចមួយ ដើម្បីសម្ងែងអំណាចយោធាទៅកាន់ទីតាំងគ្រប់ច្រកល្ហកនៅលើពិភពលោក និងដើម្បីរក្សាវត្តមានយោធារបស់ខ្លួន នៅក្នុងតំបន់ភាគច្រើនលើពិភពលោក ក្នុងពេលដំណាលគ្នា។ បច្ចុប្បន្ននេះ មានតែសហរដ្ឋអាមេរិកមួយគត់ ដែលមានសមត្ថភាពពេញលេញបែបនេះ ជាមួយនឹងសម្ព័ន្ធភាពយោធានៅទូទាំងពិភពលោក មូលដ្ឋានទ័ពអាកាសនិងកងទ័ពជើងទឹក កងទ័ពដែលឈរជើងនៅបរទេស និងនាវាផ្ទុកយន្តហោះ ដែលកំពុងហោះហើរ លើមហាសមុទ្រនានាក្នុងពិភពលោក (សូមមើលតារាង ៦.២)។ ប្រទេសអង់គ្លេស និងបារាំងស្ថិតនៅលំដាប់ទី ២ តែឃ្លាតឆ្ងាយបន្តិចអាចធ្វើប្រតិបត្តិការឆ្ងាយៗម្តងម្កាល ដែលមានទំហំល្មមៗ ដូចជាសង្គ្រាមនៅកោះហ្វកឡែន (Falklands)។ ប្រទេសរុស្សីជាប់រវល់ជាមួយជម្លោះផ្ទៃក្នុងនិងប្រទេសជិតខាងរបស់ខ្លួន ហើយកងកម្លាំងយោធារបស់ប្រទេសចិនត្រូវតម្រង់ឆ្ពោះទៅរកជម្លោះក្នុងតំបន់ ហើយមិនមានវិសាលភាពប្រតិបត្តិការជាសកលទេ (ទោះបីជាបច្ចុប្បន្ន ពួកគេកំពុងព្យាយាមកសាងកងទ័ពជើងទឹក ដែលមានសមត្ថភាពសម្ងែងអំណាចបានប្រសើរជាងមុនក៏ដោយ)។

កងកម្លាំងអវកាស(space forces) គឺជាកងកម្លាំងយោធា ដែលត្រូវបានបង្កើតឡើងដើម្បីវាយប្រហារក្នុងលំហ ឬពីក្រៅលំហ។ កាំជ្រួចផ្លោងដែលធ្វើដំណើរកាត់លំហអាកាស មួយរយៈពេលខ្លី មិនត្រូវបានរួមបញ្ចូលក្នុងប្រភេទនេះទេ។ មានតែសហរដ្ឋអាមេរិក និងរុស្សីទេ ដែលមានសមត្ថភាពយោធាច្រើនគួរសមក្នុងលំហអាកាស។ ប្រទេសចិនបានបញ្ជូនអវកាសយានិក នៅលើគន្លងផែនដី ក្នុងលំហអាកាស នៅក្នុងឆ្នាំ ២០០៣, បានសាកល្បងដោយជោគជ័យនូវកាំជ្រួចប្រឆាំងផ្កាយរណប និងបានបាញ់បង្ហោះគោចរតាមច័ន្ទគតិ ក្នុងឆ្នាំ ២០០៧ និងគ្រោងបាញ់យានអវកាសរុករកនៅភពព្រះចន្ទ ក្នុងឆ្នាំ ២០១៨។ បើទោះបីជាសមត្ថភាពអវកាសរបស់ខ្លួន (ទាំងផ្នែកស៊ីវិលនិងយោធា) ឃឺតយ៉ាវនិងខ្សោយជាងសមត្ថភាពរបស់សហរដ្ឋអាមេរិក ប្រទេសចិនបានខំប្រឹងតាមអោយទាន់ យ៉ាងឆាប់រហ័ស ដោយបាញ់ផ្កាយរណបបង្ហោះចូលគន្លងផែនដីជាញឹកញាប់។ ការអភិវឌ្ឍន៍អាវុធអវកាសត្រូវបានរារាំង ដោយបញ្ហាប្រឈមផ្នែកបច្ចេកទេសនិងការចំណាយខ្ពស់នៃប្រតិបត្តិការអវកាស និងដោយបទដ្ឋានប្រឆាំងនឹងការធ្វើយោធាកម្មក្នុងលំហអាកាស។

ការប្រើប្រាស់លំហអាកាស ដោយកងកម្លាំងយោធា ជាទូទៅជាងនេះគឺសម្រាប់គោលបំណងបញ្ជានិងការសម្របសម្រួល (command and coordination)។ ផ្កាយរណបត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ

សម្រាប់គោលបំណងយោធា ប៉ុន្តែរហូតមកដល់ពេលនេះ គោលបំណងទាំងនេះមិនរួមបញ្ចូលការវាយប្រហារនោះទេ។ ផ្កាយរណបលួចឃ្លាំមើលសកម្មភាពយោធា និងការគួសវាសផែនទី ការទំនាក់ទំនង ការវាយតម្លៃអាកាសធាតុ និងការព្រមានជាមុនអំពីការបាញ់មីស៊ីលផ្លោង។ ផ្កាយរណបក៏ផ្តល់ព័ត៌មានរុករកដល់កងកម្លាំងយោធាផងដែរ ដូចជាអង្គភាពកងទ័ព នាវា យន្តហោះ និងសូម្បីតែកាំជ្រួចប្រដេញក្នុងពេលហោះហើរ។ ទីតាំងត្រូវបានគណនាក្នុងប្រវែងប្រហែល ៥០ ហ្វីត (១៥ម៉ែត្រ) ដោយគ្រឿងទទួលទិន្នន័យតូចៗ ដែលចាប់យកសញ្ញាព្រមាន (beacons) ដែលបញ្ជូនពីបណ្តាញផ្កាយរណបចំនួន ២៤ របស់សហរដ្ឋអាមេរិកដែលគេស្គាល់ថាជា *ប្រព័ន្ធកំណត់ទីតាំងសកល* (GPS)។ ឧបករណ៍ជីភីអេស អាចរកទិញបាននៅតាមទីផ្សារ ដូច្នេះកងកម្លាំងយោធានៃប្រទេសផ្សេងទៀត អាចប្រើប្រាស់ឧបករណ៍កំណត់ទីតាំងពីផ្កាយរណបទាំងនេះដោយសេរី។ រដ្ឋក្រីក្រអាចទិញរូបថតដោយផ្កាយរណប រួមទាំងរូបភាពដែលមានគុណភាពបង្ហាញខ្ពស់ ដែល រុស្ស៊ីលក់ ដោយយកតែរូបិយប័ណ្ណរឹង។ ជាការពិត ការទទួលបានព័ត៌មានបែបនេះបានសាយភាយខ្លាំងរហូតដល់ចំណុចកំរិតមួយដែលភេរវកររដែលបានវាយប្រហារទីក្រុងបុមបៃ នៃប្រទេសឥណ្ឌា ក្នុងឆ្នាំ ២០០៨ បានរៀបចំផែនការវាយប្រហាររបស់ពួកគេ ដោយប្រើរូបភាពផ្កាយរណប តាមរយៈកម្មវិធីផែនទីផ្កាយរណប Google Earth និងសម្របសម្រួលការវាយប្រហារ តាមពេលវេលាជាក់ស្តែង ពីប្រទេសប៉ាគីស្តាន ដោយប្រើទូរស័ព្ទផ្កាយរណប។ នៅក្នុងសង្គ្រាមឆ្នាំ ២០០៦ រវាងក្រុមហេសបូឡា(Hezbollah)និងអ៊ីស្រាអែល នៅក្នុងប្រទេសលីបង់, កងកម្លាំងហេសបូឡាបានប្រើប្រាស់ឧបករណ៍រារាំងជីភីអេសដើម្បីរំខានដល់ការគាំទ្រផ្លូវអាកាសរបស់អ៊ីស្រាអែល និងប្រតិបត្តិការកំណត់គោលដៅ។ ប៉ុន្តែ ជាទូទៅ នៅក្នុងលំហអាកាស ប្រទេសមហាអំណាចមានប្រៀបជាងរដ្ឋតូចៗឬក្រីក្រ ធ្ងាយណាស់។

តារាង ៦.២ ទីតាំងនៃកងកម្លាំងយោធាសហរដ្ឋអាមេរិក ឆ្នាំ ២០១៧

តំបន់	ចំនួនកងទ័ព	ពង្រាយកងកម្លាំងនៅបរទេស
សហរដ្ឋអាមេរិក	១ ១២០ ០០០	--
អឺរ៉ុប	៦០ ០០០	៣១%
ជប៉ុន/ប៉ាស៊ីហ្វិក	៧៤ ០០០	៣៨%
រុស្ស៊ី/CIS	១០០	០%
មជ្ឈឹមបូព៌ា	៤០ ០០០	២០%
អាមេរិកឡាទីន	១ ៣០០	១%
អាហ្វ្រិក	៤ ១០០	២%
អាស៊ីទក្សិណ	១៣ ០០០	៧%
បរទេសសរុប	១៩២ ៥០០	១០០%

ចំណាំ៖ ចំនួនសរុបមិនរាប់បញ្ចូលបុគ្គលិកដែលមានវត្តមាននៅក្នុងតំបន់នោះទេ។

ប្រភព៖ ក្រសួងការពារជាតិអាមេរិក។

ការប្រមូលផ្តុំព័ត៌មានឬការស៊ើបការណ៍សម្ងាត់ ក៏ត្រូវពឹងផ្អែកលើមធ្យោបាយផ្សេងៗ ជាច្រើន ដូចជាការតាមដាននិងត្រួតពិនិត្យតាមលើបណ្តាញអេឡិចត្រូនិចនៃប្រព័ន្ធទូរស័ព្ទ និងលើទំនាក់ទំនងផ្សេងទៀត, របាយការណ៍ពីស្ថានទូតជាច្រើន និងព័ត៌មាននៅក្នុងបណ្តាញសារព័ត៌មានបើកចំហ។ ប្រភេទព័ត៌មានមួយ

ចំនួនទទួលបាន ដោយការបញ្ជូនភ្នាក់ងារទៅបរទេស ក្នុងនាមជាអ្នកស៊ើបការណ៍សម្ងាត់។ ពួកគេប្រើប្រាស់ភាពបិនប្រសប់នៃការបន្លំខ្លួន (រួមជាមួយនឹងប្រាក់កាក់ និងបច្ចេកវិទ្យា) ដើម្បីបញ្ជ្រាបខ្លួនចូលទៅក្នុងជញ្ជាំងសម្ងាត់ ដែលរដ្ឋាភិបាលបរទេស បានសាងសង់ឡើង ដើម្បីបិទបាំងផែនការនិងសមត្ថភាពរបស់ពួកគេ។ ជាឧទាហរណ៍ ក្នុងឆ្នាំ ១៩៩៩ ចារកម្មរុស្ស៊ីម្នាក់បានថតសម្លេងសន្ទនាពីឧបករណ៍ស្តាប់សម្លេងដែលបង្កប់នៅក្នុងបន្ទប់សន្និសីទកម្រិតខ្ពស់ នៅក្រសួងការបរទេសសហរដ្ឋអាមេរិក។ ការវាយប្រហារកេរវែកម្មឆ្នាំ ២០០១ បានបង្ហាញពីភាពទន់ខ្សោយនៃសមត្ថភាព «ស៊ើបការណ៍ព័ត៌មានសម្ងាត់អំពីមនុស្ស» របស់សហរដ្ឋអាមេរិក ដោយក្នុងនោះសហរដ្ឋអាមេរិកមិនបានជ្រៀតចូលទៅក្នុង បណ្តាញកេរវែករដ៏ធំ ដែលមានមូលដ្ឋាន នៅក្នុងប្រទេសអាហ្វហ្គានីស្ថាននិងដែលដំណើរការជាសកល។ សមត្ថភាព «ស៊ើបការណ៍អំពីសញ្ញា» របស់សហរដ្ឋអាមេរិក គួរអោយចាប់អារម្មណ៍ជាង។ ទីភ្នាក់ងារស៊ើបការណ៍សម្ងាត់យោធាធំបំផុតរបស់សហរដ្ឋអាមេរិកគឺជាទីភ្នាក់ងារសន្តិសុខជាតិ(NSA) ដែលបេសកកម្មរបស់ពួកគេត្រូវ*ចង់ភ្ជាប់*(encode)ទំនាក់ទំនងរបស់សហរដ្ឋអាមេរិក និងបំបែកឬស្រាយកូដទំនាក់ទំនងបរទេស។ ទីភ្នាក់ងារសន្តិសុខជាតិស្ទាក់ចាប់បានព័ត៌មានដ៏ច្រើនសន្ធឹកសន្ធាប់ពីប្រភពផ្សេងៗ ដូចជាបណ្តាញទូរសព្ទក្រោមសមុទ្រ បន្ទាប់មកត្រូវរៃព័ត៌មានទាំងនោះដើម្បីស្វែងរកការសន្ទនាសំខាន់ៗ។ ទីភ្នាក់ងារសន្តិសុខជាតិប្រើប្រាស់បុគ្គលិកជាបណ្ឌិតគណិតវិទ្យាច្រើនជាងរដ្ឋណាទាំងអស់លើពិភពលោក, ជាអ្នកប្រើប្រាស់អគ្គិសនីច្រើនបំផុតលំដាប់ទីពីរ នៅរដ្ឋម៉ារីឡែន(Maryland), មានកញ្ចប់ថវិកាធំជាងទីភ្នាក់ងារមជ្ឈឹមស៊ើបការណ៍សម្ងាត់(CIA) ហើយត្រូវបានគេជឿថាមានប្រព័ន្ធកុំព្យូទ័រដែលថាមពលខ្លាំងបំផុត នៅលើពិភពលោក។ ច្បាស់ណាស់ ប្រតិបត្តិការទាំងនេះ ដែលធ្វើឡើងរួមគ្នា គឺមានទំហំធំណាស់ ហើយកំពុងមានសារៈសំខាន់កាន់តែខ្លាំងឡើង នៅពេលដែលបដិវត្តន៍ព័ត៌មានកំពុងដំណើរការ ហើយនៅពេលដែលសង្គ្រាមលើកេរវែកម្មធ្វើអោយបេសកកម្មរបស់ពួកគេកាន់តែសំខាន់។ វិសាលភាពពេញទំហឹងនៃប្រតិបត្តិការរបស់ទីភ្នាក់ងារសន្តិសុខជាតិ ត្រូវបានបង្ហាញនៅក្នុងឆ្នាំ ២០១៣ នៅពេលដែលអតីតបុគ្គលិកកិច្ចសន្យាម្នាក់របស់ទីភ្នាក់ងារសន្តិសុខជាតិបានទម្លាយឯកសាររាប់លាន ដែលបង្ហាញថា ទីភ្នាក់ងារសន្តិសុខជាតិបានប្រមូលទិន្នន័យយ៉ាងសម្ងាត់ពីពលរដ្ឋអាមេរិក និងអ្នកការទូតបរទេស រួមទាំងកំណត់ត្រាទូរស័ព្ទ និងអ៊ីនធឺណិត។ វិរៈណៈនៃកម្មវិធីទាំងនេះ បានបណ្តាលអោយមានកំហឹងក្នុងចំណោមសម្ព័ន្ធមិត្តរបស់សហរដ្ឋអាមេរិក ក៏ដូចជាការអំពាវនាវអោយមានការពង្រីកការត្រួតពិនិត្យលើភ្នាក់ងារចារកម្ម ដោយសាធារណៈជនអាមេរិក។

៦.២. ការវិវត្តនៃបច្ចេកវិទ្យា

៦.២ ចូរវាយតម្លៃសារៈសំខាន់នៃបច្ចេកវិទ្យាថ្មីៗក្នុងការផ្លាស់ប្តូរយុទ្ធវិធីសង្គ្រាម ។

ការអភិវឌ្ឍន៍បច្ចេកវិទ្យាបានផ្លាស់ប្តូរលក្ខណៈនៃកម្លាំងយោធា ក្នុងទិដ្ឋភាពមួយចំនួន។ ទីមួយ ជម្រើសក្នុងការប្រើប្រាស់កម្លាំងទ័ព ក្នុងដម្លោះអន្តរជាតិ បច្ចុប្បន្ននេះ ត្រូវចំណាយច្រើននិងបង្កផលវិបាកកាន់តែជ្រាលជ្រៅ។ ប្រទេសមហាអំណាច ជាពិសេស មិនអាចប្រើកម្លាំងទ័ពដើម្បីដោះស្រាយវិវាទក្នុងចំណោមពួកគេបានទៀតទេ ដោយមិនប្រថុយរងការបំផ្លិចបំផ្លាញមហិមា និងរងការខូចខាតសេដ្ឋកិច្ច។ ម្យ៉ាងទៀត ការពាក់ព័ន្ធកងកម្លាំងយោធា នាពេលបច្ចុប្បន្ននេះ អាចកើតឡើង នៅប្រឈមមុខដាក់គ្នា នៅឆ្ងាយដើងមេឃ រវាងកងកម្លាំងពីរក្រុមដែលប្រឆាំងនឹងគ្នា។ គ្រាប់កាំជ្រួចគ្រប់ប្រភេទកំពុងពន្លឿននិន្នាការនេះ។ ភាពជឿនលឿននៃ

បច្ចេកវិទ្យាទាំងនេះធ្វើអោយខូចទំរង់សង្គ្រាមដែលធ្លាប់តែផ្ទុះឡើង នៅលើមូលដ្ឋានទឹកដីត្រង់កន្លែងណាមួយ និងធ្វើអោយខូចទំរង «សំបករឹង» របស់រដ្ឋខ្លួនឯងផ្ទាល់។

ប៉ុន្មានឆ្នាំថ្មីៗនេះ និន្នាការនេះបានបង្កើនល្បឿនជាមួយនឹងការប្រើប្រាស់យន្តហោះគ្មានមនុស្សបើក (UAVs) ឬ **ដ្រូន** (drones)។ ដ្រូនត្រូវបានប្រើ ក្នុងរយៈពេលប៉ុន្មានឆ្នាំមកហើយ និងក្នុងសង្គ្រាមជាច្រើនហើយដែរ រួមទាំងសង្គ្រាមវៀតណាមនៅទសវត្សរ៍ឆ្នាំ ១៩៧០, សង្គ្រាមរវាងប្រទេសអ៊ីរ៉ាក់នឹងអ៊ីរ៉ង់ និងសង្គ្រាមឈូងសមុទ្រនៅឆ្នាំ ១៩៩១។ ប៉ុន្តែ ក្រោយការវាយប្រហារភេរវកម្ម ថ្ងៃទី១១ ខែកញ្ញា សហរដ្ឋអាមេរិកបានពង្រីកការប្រើប្រាស់ដ្រូន ជាពិសេស ដ្រូនដែលអាចវាយប្រហារចំគោលដៅផ្ទាល់។ វារួមបញ្ចូលទាំងដ្រូនដែលបំពាក់ដោយកាំជ្រួចដែលត្រូវបានប្រើប្រាស់ នៅក្នុងកិច្ចខិតខំប្រឹងប្រែងយោធារបស់សហរដ្ឋអាមេរិកនៅក្នុងប្រទេសប៉ាគីស្ថាន យេម៉ែន និងលីប៊ី។

រូបថត ការដាក់ពង្រាយដ្រូននៅក្នុងទីក្រុងមូស៊ុល អ៊ីរ៉ាក់
ក្នែកនៅលើមេឃ

បច្ចុប្បន្ននេះ ស្ទើរតែគ្រប់រដ្ឋាភិបាលទាំងអស់ប្រើប្រាស់យន្តហោះគ្មានមនុស្សបើកឬដ្រូនជាឧបករណ៍យោធា។ ដ្រូន ស្រដៀងគ្នានឹងឧបករណដទៃទៀតដែលអ្នកប្រើប្រាស់ទូទៅអាចរកបាន អនុញ្ញាតអោយមានការប្រមូលព័ត៌មានប្រកបដោយប្រសិទ្ធភាព ជាពិសេសនៅពេលដែលវាអាចបង្កគ្រោះថ្នាក់ខ្លាំងដល់បុគ្គលិកយោធាដែលត្រូវចុះបេសកកម្មផ្ទាល់។ នៅទីនេះ សមាជិកនៃកងកម្លាំងពិសេសអ៊ីរ៉ាក់ដាក់ពង្រាយដ្រូននៅក្នុងទីក្រុងមូស៊ុល (Mosul) ដែលជាទីក្រុងដែលទើបយកពី ISIS ឆ្នាំ ២០១៧។ ដ្រូននេះនឹងអនុញ្ញាតអោយស្វែងរកអគារដែលជាជម្រកលាំងបាំងយុទ្ធជន ISIS ដែលនៅសេសសល់។

បន្ថែមពីលើដ្រូនដែលបំពាក់ដោយអាវុធចំនួនរាប់រយគ្រឿងរបស់អាមេរិក ប្រទេសផ្សេងទៀតក៏ខំប្រឹងបញ្ចាទិញឬផលិតបានដ្រូនយ៉ាងឆាប់រហ័ស។ ប្រទេសជាង៣០ រួមទាំង ចិន រុស្ស៊ី ឥណ្ឌា ប៉ាគីស្ថាន ទួរគី អ៊ីតាលី អាឡឺម៉ង់ បារាំង និងអ៊ីរ៉ង់ ក៏មានឬកំពុងអភិវឌ្ឍដ្រូនវាយប្រហារធុនធ្ងន់និងធុនមធ្យមដែរ។ យន្តហោះគ្មានមនុស្សបើកដែលផលិតដោយអ៊ីរ៉ង់ត្រូវបានបាញ់ទម្លាក់ពេលហោះហើរពីលើប្រទេសអ៊ីស្រាអែល ក្នុងឆ្នាំ ២០១២។ ចក្រភពអង់គ្លេស និងអ៊ីស្រាអែលបានប្រើប្រាស់យន្តហោះគ្មានមនុស្សបើកសម្រាប់ការវាយប្រហារអស់រយៈពេលប៉ុន្មានឆ្នាំមកហើយ ហើយក្នុងរយៈពេលបីឆ្នាំចុងក្រោយ ប្រទេសនីហ្សេរីយ៉ា ប្រទេសអ៊ីរ៉ាក់ និងប្រទេសប៉ាគីស្ថានក៏បានប្រើប្រាស់ដ្រូនបំពាក់ដោយអាវុធផងដែរ ដើម្បីវាយប្រហារលើក្រុមប្រដាប់អាវុធ។ ក្នុងករណីខ្លះ ប្រទេសនានាបានកសាងកម្មវិធីដ្រូនបំពាក់ដោយអាវុធផ្ទាល់ខ្លួន ប៉ុន្តែប្រទេសមួយចំនួនទៀតដូចជាប្រទេសនីហ្សេរីយ៉ា ប្រទេសអ៊ីរ៉ាក់និងប្រទេសប៉ាគីស្ថាន បានបញ្ចាទិញដ្រូនបំពាក់ដោយអាវុធពីប្រទេសចិន។ ប្រទេសអ៊ីស្រាអែលនិងសហរដ្ឋអាមេរិកបានលក់ដ្រូនបំពាក់ដោយអាវុធដល់ប្រទេសដូចជា ប្រទេសអាឡឺម៉ង់ និងប្រទេសអ៊ីតាលី។

ប្រទេសជាច្រើននៅពិភពលោក ក៏ប្រើប្រាស់យន្តហោះគ្មានមនុស្សបើក មិនបំពាក់អាវុធពិឃាត ក្នុងសង្គ្រាម ជារឿយៗ សម្រាប់ឃ្លាំមើលឬឈ្លបយកការណ៍សម្ងាត់។ ប្រទេសជាង៨០បានអភិវឌ្ឍឬបញ្ចាទិញដ្រូនឈ្លបយកការណ៍មិនបំពាក់អាវុធទាំងនេះ។ ពួកគេជារឿយៗប្រើប្រាស់ដ្រូនឈ្លបយកការណ៍ ដើម្បីគាំទ្រប្រតិបត្តិការយោធា ឬ ប្រមូលព័ត៌មានសម្ងាត់ពីក្រុមប្រដាប់អាវុធ ដែលប្រតិបត្តិការក្នុងរដ្ឋណាមួយ។ អ្នកជំនាញមួយចំនួនកត់សម្គាល់ថាមេដឹកនាំផ្តាច់ការក៏អាចប្រើប្រាស់ដ្រូនឈ្លបយកការណ៍ដើម្បីប្រមូលព័ត៌មាន

សម្ងាត់ពីសកម្មភាពប្រឆាំងនឹងរបបដឹកនាំខ្លួន។ យន្តហោះគ្មានមនុស្សបើក នៅក្រោមសមុទ្ររបស់សហរដ្ឋអាមេរិកសម្រាប់ការបោសសម្អាតមីន ដែលផលិត ដោយប្រទេសអាឡឺម៉ង់ ត្រូវបានបញ្ជូនទៅឈូងសមុទ្រពែរ្ស ក្នុងឆ្នាំ ២០១២ ខណៈដែលភាពតានតឹងជាមួយប្រទេសអ៊ីរ៉ង់បានកើនឡើង។

បច្ចុប្បន្ននេះ សូម្បីតែអ្នកជំនួញនិងប្រជាពលរដ្ឋឯកជនក៏ប្រើប្រាស់យន្តហោះគ្មានមនុស្សបើក ក្នុងទំរង់ដែលអាចដឹកឥទ្ធិពលលើទំនាក់ទំនងអន្តរជាតិ៖ នៅចុងឆ្នាំ ២០១៤ ការប្រកួតបាល់ទាត់អឺរ៉ុប រវាងក្រុមកីឡាករស៊ែប៊ី និងក្រុមកីឡាករអាល់បានី ត្រូវបានរំខានដោយយន្តហោះគ្មានមនុស្សបើក ដែលដោតទង់ជាតិនិយមអាល់បានីដែលកំពុងហោះហើរនៅជិតខ្សែបម្រើ។ ឧបទ្ទវហេតុនេះបានបណ្តាលអោយមានភាពតានតឹងផ្នែកការទូតរវាងប្រទេសទាំងពីរ។

ការពង្រីកការប្រើប្រាស់ដ្រូនកងទ័ព ជាពិសេសដ្រូនវាយប្រហារ បានបង្កើតអោយមានភាពចម្រូងចម្រាស់មួយចំនួន ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ។ ទីមួយ មានការបារម្ភថា បច្ចេកវិទ្យានេះនឹងរីករាលដាល យ៉ាងឆាប់រហ័ស ទៅដល់បណ្តារដ្ឋឬក្រុមដែលអាចប្រើប្រាស់ដ្រូនសម្រាប់វាយប្រហារលើជនស៊ីវិល។ ជាឧទាហរណ៍ ប្រទេសចិនបាននិងកំពុងញាប់ដៃញាប់ជើងលក់ដ្រូនអោយប្រទេសនានា ដែលត្រូវសហរដ្ឋអាមេរិកមិនព្រមផ្តល់បច្ចេកវិទ្យាអោយទៅពួកគេ។ ខុសពីអាវុធនុយក្លេអ៊ែរ (សូមមើលអាវុធប្រល័យលោក) បច្ចេកវិទ្យាដ្រូនមានលក្ខណៈសាមញ្ញជាង ហើយរដ្ឋភាពច្រើនអាចមានលទ្ធភាពទិញ ដែលជាហេតុបណ្តាលអោយមានលទ្ធភាពរីករាលដាលកាន់តែខ្លាំង។

ទីពីរ ការប្រើប្រាស់ដ្រូនបំពាក់ដោយអាវុធដើម្បីសម្លាប់បុគ្គលណាមួយ ត្រូវប្រឈមមុខនឹងការចោទសួរដោយច្បាប់អន្តរជាតិ។ ច្បាស់សឹកសង្គ្រាម (សូមមើលមេរៀនទី ៧) តម្រូវអោយរដ្ឋនានាដាក់កំរិតលើអរិភាពនៅក្នុងតំបន់កូមិសាស្ត្រទាំងឡាយដែលកំពុងមានជម្លោះសកម្ម។ បានន័យថា នៅពេលប្រទេសពីរកំពុងមានសង្គ្រាមនឹងគ្នា ពួកគេមិនត្រូវរំពឹងថាទៅកៀកនឹងប្រទេសដែលពាក់ព័ន្ធនឹងសង្គ្រាមឡើយ។ បំរាមនេះមិនត្រឹមតែជួយការពារជនស៊ីវិលដែលរស់នៅជិតតំបន់សង្គ្រាមទេ តែថែមទាំងដាក់កំរិតលើការរីករាលដាលនៃសង្គ្រាមទៀតផង។ យ៉ាងណាក៏ដោយ នៅក្នុងសង្គ្រាមប្រឆាំងនឹងក្រុមអាល់កៃដា សហរដ្ឋអាមេរិកបានប្រើប្រាស់ដ្រូនយ៉ាងច្រើនសន្ធឹកសន្ធាប់នៅក្រៅប្រទេសអាហ្វហ្គានីស្ថាន រួមទាំងប្រទេសប៉ាគីស្ថាន និងយ៉េមែន។ តើសហរដ្ឋអាមេរិកគួរតែប្រកាសសង្គ្រាមលើប្រទេសប៉ាគីស្ថាននិងយ៉េមែន ដើម្បីវាយប្រហារលើគោលដៅនៅទីនោះដែរឬទេ?

ម្យ៉ាង បណ្តាអ្នកតស៊ូមតិសម្រាប់ការវាយប្រហារដោយដ្រូនឆ្លើយថា ទេ សហរដ្ឋអាមេរិកមិនមានសង្គ្រាមជាមួយប្រទេសទាំងនោះទេ ត្រឹមតែមនុស្សមួយចំនួនដែលរស់នៅទីនោះតែប៉ុណ្ណោះ។ ម្យ៉ាងវិញទៀត បណ្តាអ្នករិះគន់ការវាយប្រហារដោយដ្រូនចង្អុលបង្ហាញពីបញ្ហាមួយចំនួន រួមទាំងការខ្វះនីតិវិធីសម្រាប់គោលដៅត្រូវវាយប្រហារ។ ជាឧទាហរណ៍ ប្រសិនបើជនសង្ស័យជាភេរវករមួយរូប ត្រូវបានចាប់ខ្លួននៅសហរដ្ឋអាមេរិក ជនសង្ស័យនោះនឹងត្រូវកាត់ទោសតាមច្បាប់នៅក្នុងតុលាការ មុននឹងដាក់ទោសទណ្ឌ។ ប្រសិនបើភេរវករដដែលនោះស្ថិតក្នុងតំបន់ជម្លោះ គេនឹងត្រូវក្លាយជាគោលដៅសមស្រប តាមច្បាប់សឹកសង្គ្រាម។ ប៉ុន្តែប្រសិនបើជនសង្ស័យជាភេរវករស្ថិតនៅក្នុងប្រទេសទី៣ ច្បាប់នៃប្រទេសនោះគួរត្រូវបានអនុវត្ត។ យ៉ាងណាក៏ដោយ ការវាយប្រហារដោយដ្រូនត្រូវបានធ្វើឡើងដោយគ្មានការយល់ព្រមពីប្រទេសទី៣នោះសោះឡើយ។ បញ្ហាដែលកំពុងប្រឈមនឹងច្បាប់អន្តរជាតិទាំងនេះមិនទាន់ត្រូវបានដោះស្រាយនៅឡើយ។

មិនមែនជារឿងគួរអោយភ្ញាក់ផ្អើលឡើយដែលការប្រើប្រាស់ដ្រូន ឬ យន្តហោះគ្មានមនុស្សបើក បានកើនឡើង ជាពិសេស នៅក្នុងការប្រយុទ្ធប្រឆាំងតទល់នឹងការបះបោរ និងប្រតិបត្តិការប្រយុទ្ធប្រឆាំងនឹងអំពើភេរវកម្ម។ យន្តហោះគ្មានមនុស្សបើកផ្តល់អោយកងកម្លាំងប្រដាប់អាវុធ ប៉ុន្តែជាពិសេសមេដឹកនាំនយោបាយនូវឱកាសវាយប្រហារលើសត្រូវពីចម្ងាយ ដោយមិនប្រថុយជីវិតកងទ័ពរបស់ប្រទេសជាតិខ្លួនផ្ទាល់ឡើយ។ ជាលក្ខណៈប្រវត្តិសាស្ត្រ ប្រតិបត្តិការចាប់ខ្លួនភេរវកណាម្នាក់ ឬបំផ្លាញឃ្លាំងអាវុធ អាចនឹងតម្រូវអោយពង្រាយឬបញ្ជូនកងទ័ព ដែលងាយរងគ្រោះក្នុងប្រតិបត្តិការតូចៗ។ សូម្បីការប្រើប្រាស់យន្តហោះវាយប្រហារគោលដៅអាចនឹងប្រថុយជីវិតអ្នកបើកយន្តហោះ ក្នុងប្រតិបត្តិការណាមួយ។ ដ្រូនឬ យន្តហោះគ្មានមនុស្សបើក អាចសម្រេចបានកិច្ចការដូចគ្នា ដោយមិនប្រថុយជីវិតកងទ័ពរបស់ប្រទេសជាតិខ្លួនឡើយ។ ទោះជាយ៉ាងណាក៏ដោយ មនុស្សជាច្រើនបារម្ភថាវាធ្វើអោយប្រតិបត្តិការទាំងនេះងាយស្រួលខ្លាំងពេក។ ប្រសិនបើប្រតិបត្តិការណាមួយត្រូវចំណាយតិច ឬមិនចំណាយអ្វីសោះ រដ្ឋនានាចេះតែបញ្ជាប្រតិបត្តិការបែបនេះកាន់តែញឹកញាប់។ ជាការពិត កំឡុងឆ្នាំ ២០០៨-២០១៧ សហរដ្ឋអាមេរិកបានរាយការណ៍អំពីការវាយប្រហារតាមដ្រូនជាង ៤០០ ករណី នៅក្នុងប្រទេសប៉ាគីស្ថានតែមួយ។

សង្គ្រាមអេឡិចត្រូនិច (ឥឡូវត្រូវបានពង្រីកទៅជាសង្គ្រាមព័ត៌មានវិទ្យា- *information warfare*) សំដៅលើការប្រើប្រាស់វិសាលគមអេឡិចត្រូម៉ាញ៉េទិច (រលកវិទ្យុ រ៉ាដា កាំរស្មីអ៊ីនហ្វ្រារ៉េដ ជាដើម) នៅក្នុងសង្គ្រាម ហើយមានសារៈសំខាន់ចំពោះកងកម្លាំងយោធា ដែលមានបច្ចេកវិទ្យាទំនើបទាំងអស់។ យុទ្ធសាស្ត្រសម្រាប់សង្គ្រាមតាមអ៊ីនធឺណិត(*cyberwar*) (រំខានបណ្តាញកុំព្យូទ័ររបស់សត្រូវ ដើម្បីទម្លាក់ប្រសិទ្ធិភាពសេនាធិការ ឬ រហូតដល់លួចចូលក្នុងគណនីធនាគារ តាមប្រព័ន្ធអេឡិចត្រូនិក) អាចក្លាយជាទំនោរពេញនិយម នៅក្នុងសង្គ្រាមនាពេលអនាគត ទោះបីជាពួកគេមិនទាន់មានក៏ដោយ។ សហរដ្ឋអាមេរិកបានសម្រេចចិត្តប្រឆាំងនឹងការប្រើប្រាស់មធ្យោបាយវាយប្រហារតាមអ៊ីនធ័រណែត សម្រាប់បិទប្រព័ន្ធការពារដែនអាកាសរបស់ប្រទេសលីប៊ី ក្នុងឆ្នាំ ២០១១ ដោយសារការភ័យខ្លាចចំពោះសកម្មភាពបែបនេះត្រូវបានគេអនុវត្តតាមនៅពេលក្រោយ។ នៅពេលអនាគតការវាយប្រហារភេរវកម្មក៏អាចកំណត់គោលដៅលើបណ្តាញកុំព្យូទ័រ រួមទាំងអ៊ីនធ័រណែតនិងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ ដូចជាបណ្តាញអគ្គិសនីជាដើម។

ការវាយប្រហារតាមអ៊ីនធឺណិតគឺជាបញ្ហាមានសារៈសំខាន់កាន់តែខ្លាំងឡើងៗ នៅក្នុងទំនាក់ទំនងអន្តរជាតិ ដោយពួកHackerជនជាតិចិន រុស្សី និងអាមេរិកកំពុងស៊ើបអង្កេតប្រព័ន្ធរបស់គ្នា ទៅវិញទៅមក ឥតឈប់ឈរ។ ក្នុងឆ្នាំ២០១០ មេរោគ Stuxnet របស់សហរដ្ឋអាមេរិក និងអ៊ីស្រាអែលបានកំណត់គោលដៅទៅលើមជ្ឈមណ្ឌលនុយក្លេអ៊ែររបស់ប្រទេសអ៊ីរ៉ង់ ហើយនៅឆ្នាំ ២០១២ មេរោគ Flame ត្រូវបានរកឃើញនៅលើកុំព្យូទ័ររាប់ពាន់គ្រឿងនៅទូទាំងមជ្ឈឹមបូព៌ា ដែលភាគច្រើននៅក្នុងប្រទេសអ៊ីរ៉ង់។ វាអាចចាប់យករូបថតអេក្រង់(screenshots)និងការចុចលើគ្រាប់ក្តារចុច(keystrokes) ហើយបើកមីក្រូហ្វូនកុំព្យូទ័រពីចម្ងាយដើម្បីជួយអ្នកបង្កើត (ជាម្តងទៀត គេសន្មតថាជាជនជាតិអាមេរិក និងអ៊ីស្រាអែល) លួចសង្កេតមើលប្រតិបត្តិការនៅក្នុងកម្មវិធីនុយក្លេអ៊ែរអ៊ីរ៉ង់។ ប៉ុន្មានខែក្រោយមក ប្រហែលដើម្បីជាការឆ្លើយតប មេរោគមួយបានលុបឯកសារនៅលើកុំព្យូទ័ររបស់ក្រុមហ៊ុនប្រេងដ៏ធំរបស់ប្រទេសអារ៉ាប៊ីសាអូឌីត ដោយជំនួសវាដោយរូបភាពទង់ជាតិអាមេរិកដែលកំពុងឆេះ។

រុស្ស៊ីបាននិងកំពុងប្រើប្រាស់សង្គ្រាមតាមអ៊ីនធឺរណែតក្នុងកិច្ចប្រឹងប្រែងពង្រីកឥទ្ធិពលរបស់ខ្លួន អស់រយៈពេលជាច្រើនឆ្នាំមកហើយ។ នៅក្នុងឆ្នាំ ២០០៨ អ្នកhackers របស់រដ្ឋាភិបាលរុស្ស៊ីបានបិទខ្ទប់អ៊ីនធឺរណែតទាំងអស់នៅក្នុងប្រទេសអេស្តូនី ក្រោយមានការដកចេញរូបចម្លាក់វីរបុរសសង្គ្រាមជនជាតិរុស្ស៊ីនៅទីនោះ។ ក្នុងកំឡុងពេលជម្លោះកងទ័ពរបស់រុស្ស៊ីជាមួយប្រទេសហ្សកហ្ស៊ី នៅឆ្នាំ ២០០៨ ការវាយប្រហារតាមអ៊ីនធឺណិតបានកើនឡើងប្រឆាំងនឹងវ៉ៃបសាយផ្លូវការរបស់ហ្សកហ្ស៊ី។ ប្រទេសមួយចំនួន រួមទាំងសហរដ្ឋអាមេរិក បានចោទប្រកាន់រុស្ស៊ីថា បានលូកដៃក្នុងការបោះឆ្នោតប្រជាធិបតេយ្យ នៅក្នុងប្រទេសគេផ្ទាល់។ ទីភ្នាក់ងារស៊ើបការណ៍សម្ងាត់មានកស្តុតាងគាំទ្រការចោទប្រកាន់ទាំងនោះ។ ម្តងហើយម្តងទៀត អ្នកhacker រុស្ស៊ីត្រូវបានចោទប្រកាន់ផងដែរថា បានបង្កើតកម្មវិធីគ្រឿងយន្តសម្រាប់ផ្សព្វផ្សាយព័ត៌មានក្លែងក្លាយ តាមរយៈបណ្តាញសង្គម ដើម្បីជះឥទ្ធិពលលើមតិសាធារណៈក្នុងកំឡុងពេលបោះឆ្នោត។

ច្បាស់ណាស់ដែលថា ការវាយប្រហារតាមអ៊ីនធឺរណែតទោះជាក្នុងយុទ្ធនាការយោធាផ្ទាល់ ឬក្នុងកិច្ចប្រឹងប្រែងដើម្បីជះឥទ្ធិពលលើលទ្ធផលបោះឆ្នោត កំពុងក្លាយជាឧបករណ៍ដាក់គំនាបដែលមានសារៈសំខាន់កាន់តែខ្លាំង នៅក្នុងទំនាក់ទំនងអន្តរជាតិ។ ដោយសារលទ្ធភាពប្រើប្រាស់អ៊ីនធឺរណែតកាន់តែងាយស្រួលនិងកើនឡើងយ៉ាងឆាប់រហ័ស (ជាការពិត ស្ទើរតែជាសកលទៅហើយ នៅក្នុងផ្នែកខ្លះនៃពិភពលោក សូមមើលមេរៀនទី ១០) មិនមែនជារឿងគួរអោយភ្ញាក់ផ្អើលទេ ដែលទាំងតួអង្គរដ្ឋនិងតួអង្គមិនមែនរដ្ឋបានសម្របសម្រួលយុទ្ធសាស្ត្ររបស់ពួកគេ ក្នុងការប្រើប្រាស់លំហអ៊ីនធឺរណែតជាកន្លែងមួយ ដើម្បីពង្រីកឥទ្ធិពលនយោបាយអន្តរជាតិ។

នៅក្នុងវិស័យយោធាបុរាណជាងមួយគឺ **បច្ចេកវិទ្យាបំភ័ន្តភ្នែក** (stealth technology) ដែលប្រើសារធាតុសម្របតាមរ៉ាដាពិសេស និងមានរាងរៅមិនប្រក្រតី នៅក្នុងយន្តហោះ កាំជ្រួច និងកប៉ាល់ ដើម្បីគេចពីរ៉ាដាររបស់សត្រូវ។ ទោះជាយ៉ាងណាក៏ដោយ បច្ចេកវិទ្យាបំភ័ន្តភ្នែកមានតម្លៃថ្លៃណាស់ (យន្តហោះទម្លាក់គ្រាប់បែកបំភ័ន្តភ្នែកម៉ាក B-២ មានតម្លៃប្រហែល ២ពាន់លានដុល្លារ ក្នុងមួយគ្រឿង) ហើយងាយនឹងមានបញ្ហាបច្ចេកទេស។

ប្រវត្តិសាស្ត្រវិទូយោធាហៅរយៈពេលនៃការផ្លាស់ប្តូរនៅក្នុងការធ្វើសឹកសង្គ្រាមយ៉ាងឆាប់រហ័ស ថាជា «បដិវត្តន៍ក្នុងកិច្ចការយោធា»។ សម័យកាលទាំងនេះ ជាធម្មតា រួមមានការអនុវត្តប្រកបដោយភាពច្នៃប្រឌិតនៃបច្ចេកវិទ្យាថ្មីជាមួយនឹងការផ្លាស់ប្តូរនៅក្នុងគោលលទ្ធិយោធា អង្គការចាត់តាំង ឬប្រតិបត្តិការ។ បដិវត្តន៍បែបនេះអាចកើតចេញពីការបង្កើតថ្មី នៅក្នុងអង្គការចាត់តាំងដូចនៅពេលដែលបដិវត្តន៍បារាំងដំបូងបានកៀងគរប្រទេសទាំងមូលអោយក្លាយម៉ាស៊ីនសង្គ្រាម កាលពីពីរសតវត្សមុន។ ឬពួកគេអាចកើតចេញពីគោលលទ្ធិយោធាថ្មី ដូចជាពេលដែលប្រទេសអាឡឺម៉ង់បានប្រើការទម្លាក់គ្រាប់បែក (blitzkrieg) ដើម្បីគ្របដណ្តប់លើប្រទេសប៉ូឡូញ និងប្រទេសបារាំង នៅដើមដំបូងនៃសង្គ្រាមលោកលើកទី ២ ឬកើតចេញពីបច្ចេកវិទ្យាតែមួយគត់ ដូចជាការច្នៃប្រឌិតអាវុធនុយក្លេអ៊ែរ។ អ្នកវិភាគផ្នែកយោធាជាច្រើនបានចាត់ទុករយៈពេលបច្ចុប្បន្នដោយចាប់ផ្តើមពីសង្គ្រាមឈូងសមុទ្រឆ្នាំ ១៩៩១ ដែលជាបដិវត្តន៍ក្នុងកិច្ចការយោធា ជាពិសេស នៅក្នុងកងកម្លាំងសហរដ្ឋអាមេរិក។ ការគ្រប់គ្រងព័ត៌មានគឺជាចំណុចសំខាន់នៃបដិវត្តន៍នេះ។ ពីរសតវត្សមុន អ្នកយុទ្ធសាស្ត្រយោធាអាឡឺម៉ង់ លោក ខាល វ៉ុន ក្លៅសវីត (Carl von Clausewitz) បានហៅភាពច្របូកច្របល់និងភាពមិនច្បាស់លាស់ ដែលកាត់បន្ថយប្រសិទ្ធភាពប្រយុទ្ធរបស់កងទ័ពយ៉ាងខ្លាំងថាជា «អ័ព្ទនៃសង្គ្រាម»។

កងទ័ពអាមេរិកសព្វថ្ងៃ កំពុងទម្លុះទម្លាយអ័ព្ទទាំងនោះសម្រាប់ខ្លួនឯង ខណៈដែលធ្វើអោយព័ត៌មានតែក្រាស់សម្រាប់សត្រូវរបស់ពួកគេ។ នៅពេលដែលអ័ព្ទនៃសង្គ្រាមស្តើងអាចមើលឃើញច្បាស់ កងទ័ពអាមេរិកក៏អាចពង្រាយកងកម្លាំងធុនស្រាលបានយ៉ាងទូលំទូលាយ ជាជាងការប្រមូលផ្តុំកងកម្លាំងធុនធ្ងន់ ដូចដែលលោកក្លៅស៍វីតបានសង្កត់ធ្ងន់។ សមត្ថភាពក្នុងការវាយប្រហារចំគោលដៅ និងការកើនឡើងនៃការប្រើប្រាស់លំហអាកាសក្នុងសង្គ្រាម គឺជាទិដ្ឋភាពពីរផ្សេងទៀតនៃបដិវត្តន៍បច្ចុប្បន្ន។

សក្តានុពលបដិវត្តន៍ត្រូវបានបង្ហាញអោយឃើញជាលើកដំបូងនៅក្នុងជ័យជម្នះ ក្នុងឆ្នាំ ១៩៩១ លើកងទ័ពដ៏ធំប៉ុន្តែមិនមានបច្ចេកវិជ្ជាជឿនលឿនរបស់ប្រទេសអ៊ីរ៉ាក់ ហើយយុទ្ធនាការកូសូវ៉ូ ឆ្នាំ ១៩៩៩ មានលក្ខណៈគួរអោយកត់សម្គាល់ក្នុងការសម្រេចបាននូវគោលដៅសង្គ្រាមរបស់ខ្លួន ដោយមិនបាត់បង់ជីវិតជនជាតិអាមេរិកណាមួយនៅក្នុងភ្លើងអរិភាព។ ប៉ុន្តែ យុទ្ធនាការឆ្នាំ ២០០១ ប្រទេសអាហ្វហ្គានីស្ថានបានក្លាយជាគំរូដ៏ល្អបំផុតនៃបដិវត្តន៍នេះ។ ក្រុមតូចៗនៃកងកម្លាំងពិសេសរបស់សហរដ្ឋអាមេរិកប្រដាប់ដោយអាវុធធុនស្រាល ដែលបានបញ្ចូលទូទាំងប្រទេសបានប្រើពន្លឺឡាស៊ែរដើម្បីបំភ្លឺគោលដៅសម្រាប់គ្រាប់បែកឆ្លាតវៃដែលទម្លាក់ចេញពីយន្តហោះក្នុងរយៈកម្ពស់ខ្ពស់។ ការធ្វើសមាហរណកម្មនៃកងកម្លាំងចម្រុះទាំងនេះដោយប្រើប្រព័ន្ធគ្រប់គ្រងសមរភូមិ ដែលពោរពេញដោយព័ត៌មាន បានបណ្តាលអោយមានយុទ្ធនាការទម្លាក់គ្រាប់បែកប្រកបដោយប្រសិទ្ធភាពដ៏គួរអោយភ្ញាក់ផ្អើល ដែលបានបំផ្លាញពួកតាលីបង់ជាកងទ័ពដ៏មានប្រសិទ្ធភាពខ្ពស់ និងបានប្រគល់ជ័យជម្នះដល់កងទ័ពប្រឆាំងពួកតាលីបង់តូចៗ ដែលបណ្តាលអោយមានជនជាតិអាមេរិកស្លាប់តិចតួចប៉ុណ្ណោះ។ ការលុកលុយឆ្នាំ ២០០៣ ចូលប្រទេសអ៊ីរ៉ាក់ ហាក់ដូចជាបន្តជោគជ័យនេះ ប៉ុន្តែ បន្ទាប់មក ស្ថានភាពសន្តិសុខក្រោយសម័យការលុកលុយ នៅក្នុងប្រទេសអ៊ីរ៉ាក់បានធូរស្រាល ក្នុងរយៈពេលជាច្រើនឆ្នាំ បើទោះបីជាមានបច្ចេកវិជ្ជាបដិវត្តន៍របស់កងកម្លាំងអាមេរិកក៏ដោយ។

ដោយសារតម្លៃធូរថ្លៃល្មម បច្ចេកវិទ្យាជ្រួន និងសង្គ្រាមតាមអ៊ីនធឺរណែតស្ថិតក្នុងកណ្តាប់ដៃរដ្ឋជាច្រើន មិនមែនសម្រាប់តែប្រទេសមហាអំណាចទេ។ អ្វីដែលកាន់តែធ្វើអោយគេមិនស្ងប់ចិត្តគឺថា បដិវត្តន៍ក្នុងកិច្ចការយោធាអាចដំណើរការសម្រាប់ក្រុមភេរវករ ក៏ដូចជាសម្រាប់រដ្ឋនានាដែរ។ ភេរវករវាយប្រហារខែកញ្ញា ឆ្នាំ ២០០១ បានប្រើបច្ចេកវិទ្យាព័ត៌មាន ដូចជាទំនាក់ទំនងអ៊ីនធឺណែតដែលបានចាក់សោរ ដើម្បីសំរបសំរួលកងកម្លាំង ក្នុងពេលដែលធ្វើមិនអោយអាជ្ញាធរសហរដ្ឋអាមេរិកដឹងមុនឡើយ។ ពួកគេបានធ្វើការវាយប្រហារចំគោលដៅ ពីចម្ងាយឆ្ងាយ ដោយប្រើកងកម្លាំងតិចតួចបំផុត។ ជាលទ្ធផល ភេរវករ ១៩ នាក់ បានសម្លាប់មនុស្សជិត ៣០០០ នាក់ ហើយការចំណាយក្រោម ១ លានដុល្លារបានបណ្តាលអោយមានការខូចខាតរាប់សិបពាន់លានដុល្លារ។

រូបថត អង្គម្ចាស់ហ្សែកជានី ហ្វៃសាល (Faisal) កំពុងពិនិត្យមើលយន្តហោះកូនជ្រូនតូចតែខ្លឹម

បដិវត្តន៍ព័ត៌មានកំពុងធ្វើអោយអាវុធតូចៗ និងអង្គភាពខ្នាត់ខ្នាយតូចៗកាន់តែមានអនុភាពខ្លាំងឡើងៗ។ «បដិវត្តន៍ក្នុងកិច្ចការយោធា» កំពុងជំរុញការផ្លាស់ប្តូរយុទ្ធសាស្ត្រយោធានៅទូទាំងពិភពលោក រួមទាំងការពង្រីកការប្រើប្រាស់យន្តហោះគ្មានមនុស្សបើកឬជ្រូន។ នៅទីនេះ ព្រះអង្គម្ចាស់ ហ្វៃសាល (Faisal) និងជាប្រធានបុគ្គលិកនៃយោធាហ្សែកជានី ពិនិត្យមើលយន្តហោះជ្រូនខ្នាតតូច ឆ្នាំ ២០១៦ ។

៦.៣. អំពើភេរវកម្ម

៦.៣. ចូរវាយតម្លៃគុណសម្បត្តិនិងគុណវិបត្តិនៃវិធីសាស្ត្រប្រឆាំងភេរវកម្មចំនួនពីរផ្សេងគ្នា។

ក្រសួងការបរទេសសហរដ្ឋអាមេរិកបានចុះបញ្ជីអង្គការភេរវករបរទេសចំនួន ៦១ ក្នុងឆ្នាំ ២០១៨។ ក្រុមខ្លះត្រូវបានជំរុញដោយហេតុផលសាសនា (ឧទាហរណ៍ ក្រុមអាល់កៃដា) ប៉ុន្តែ ខ្លះទៀតដោយមនោគមវិជ្ជាវណ្ណៈ (ឧទាហរណ៍ ក្រុមមាគ៌ាចែងចាំង(Shininng Path)នៅប្រទេសពេរូ) ឬ ដោយជម្លោះជាតិសាសន៍និងស្មារតីជាតិនិយម(ឧទាហរណ៍ ក្រុមបិតាប្រទេសនិងសេរីភាពបាស្ក (Basque))។ នៅក្នុងមេរៀនទី ៥ យើងបានពិភាក្សាអំពីជម្លោះ ដែលពាក់ព័ន្ធនឹងកងជីវពលអ៊ីស្លាមជ្រុលនិយមប្រដាប់ដោយអាវុធ និងបណ្តាញភេរវករ។ នៅក្នុងផ្នែកនេះ យើងពិភាក្សាអំពីភេរវកម្មផ្ទាល់ក្នុងន័យជាយុទ្ធសាស្ត្រមួយ។ ចាប់តាំងពីខែកញ្ញា ឆ្នាំ ២០០១ រដ្ឋាភិបាលនិងប្រជាជនសាមញ្ញទូទៅបានយកចិត្តទុកដាក់ចំពោះអំពើភេរវកម្មច្រើនជាងពេលមុនៗ។ ប៉ុន្តែ បញ្ហាភេរវកម្មផ្ទាល់មិនមែនជារឿងថ្មីទេ។

ភេរវកម្ម(terrorism) សំដៅលើអំពើហឹង្សានយោបាយ ដែលកំណត់គោលដៅលើជនស៊ីវិលដោយចេតនា និងដោយគ្មានការរើសអើង។ ហួសឆ្ងាយពីនិយមន័យជាមូលដ្ឋាននេះ លក្ខណៈវិនិច្ឆ័យផ្សេងទៀតអាចត្រូវបានអនុវត្ត ប៉ុន្តែ និយមន័យទាំងនោះត្រូវបានជម្រុញហេតុផលនយោបាយ៖ អ្នកប្រយុទ្ធទាមទារសេរីភាពម្នាក់ អាចក្លាយជាភេរវករម្នាក់ នៅក្នុងក្រសែភ្នែកក្រុមជាតិសាសន៍ដទៃ។ លើសពីសង្គ្រាមទំពៃ ភេរវកម្មគឺជាពិភពស្រមោលនៃសត្រូវដែលគ្មានមុខ និងយុទ្ធសាស្ត្រមិនទៀងទាត់ ដែលត្រូវបានសម្គាល់ដោយភាពសាហាវឃោរឃៅបំផុត។

ជាប្រពៃណី អំពើភេរវកម្មមានគោលដៅបំភិតបំភ័យ(demoralize)ប្រជាជនស៊ីវិលដើម្បីប្រើប្រាស់ការមិនសប្បាយចិត្តរបស់ពួកគេជាឥទ្ធិពលឬគំនាបលើរដ្ឋាភិបាលជាតិ ឬកាគីផ្សេងទៀតក្នុងជម្លោះ។ ពាក់ព័ន្ធនឹងរឿងនេះ គឺជាគោលបំណងនៃការបង្កើតឆាកល្ខោនដើម្បីទទួលបានការចាប់អារម្មណ៍ពីប្រព័ន្ធផ្សព្វផ្សាយ។ នៅពេលដែលកងទ័ពសាធារណៈរដ្ឋអៀរឡង់ (IRA) បានបង្កៃគ្រាប់បែកនៅទីក្រុងឡុងដ៍ ក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ និង ១៩៧០ ពួកគេសង្ឃឹមថានឹងធ្វើអោយជីវិតអ្នកក្រុងឡុងដ៍រងការភិតភ័យនិងការលំបាក រហូតធ្វើអោយពួកគេនឹងទទូចអោយរដ្ឋាភិបាលខ្លួនដោះស្រាយបញ្ហាអៀរឡង់ខាងជើង។ ការបង្កៃគ្រាប់បែកក៏បានព្យាយាមរក្សាបញ្ហាអៀរឡង់ខាងជើងលេចចេញក្នុងព័ត៌មានដដែល ដោយសង្ឃឹមថានៅពេលណាធាប់ខាងមុខ។ រដ្ឋាភិបាលអង់គ្លេសនឹងត្រូវដាក់សម្ពាធនិងបង្ខំអោយយល់ព្រមលើលក្ខខណ្ឌអំណោយផលដល់កងទ័ពសាធារណៈរដ្ឋអៀរឡង់ ជាជាងអោយហេតុការណ៍កើតឡើងតាមយថាកម្ម ដែលមិនល្អសម្រាប់IRA។ អំពើភេរវកម្មកម្រនឹងកើតឡើងដោយចៃដន្យដោយគ្មានមូលហេតុច្បាស់លាស់នោះទេ ផ្ទុយទៅវិញ ជាទូទៅវាគឺជាការប្រើប្រាស់អំពើហិង្សាដែលបានគណនាទុកមុនដើម្បីបង្កើតបានជាអានុភាពឬឧបករណ៍ដាក់គំនាប។ ទោះជាយ៉ាងណាក៏ដោយ ការជម្រុញនិងមធ្យោបាយនៃអំពើភេរវកម្មមានលក្ខណៈខុសប្លែកគ្នា យ៉ាងទូលំទូលាយ ហើយលក្ខណៈដូចគ្នាតែមួយគត់គឺមានតួអង្គខ្លះប្រើអំពើហិង្សាដើម្បីដេះឥទ្ធិពលលើតួអង្គផ្សេងទៀត។

ឥទ្ធិពលចម្បងនៃអំពើភេរវកម្មមានលក្ខណៈចិត្តសាស្ត្រ។ ម្យ៉ាង អំពើភេរវកម្មអាចមានប្រសិទ្ធភាពក្នុងការទាក់ទាញការចាប់អារម្មណ៍ ដោយសារតែលក្ខណៈសោកសង្រេងនៃឧប្បត្តិហេតុនានា ជាពិសេសដូចដែលត្រូវបានបង្ហាញនៅលើកកញ្ចក់ទូរទស្សន៍។ អំពើភេរវកម្មក៏ទទួលបានការចាប់អារម្មណ៍ខ្លាំង ដោយសារតែការកំណត់គោលដៅលើជនរងគ្រោះដោយចៃដន្យផងដែរ។ ថ្វីត្បិតតែគ្រាប់បែកមួយគ្រាប់បំផ្ទុះនៅក្នុងទីផ្សារមួយ

បង្កអោយមនុស្សត្រឹមតែដប់ម្តែនាក់រងរបួសក៏ដោយ មនុស្សរាប់លាននាក់ព្រួយបារម្ភថា«រឿងនោះអាចធ្លាក់មកលើខ្លួនគេ» ពីព្រោះពួកគេក៏ទិញទំនិញ នៅក្នុងទីផ្សារផងដែរ។ ការវាយប្រហារលើយន្តហោះបង្កើនការភ័យខ្លាចនេះ ដោយសារតែមនុស្សជាច្រើនភ័យខ្លាចការហោះហើររួចហើយ។ ដូច្នេះ អំពើភេរវកម្មពង្រីកអំណាចដ៏តូចតាចរបស់ខ្លួនអោយរីកកាន់តែធំឡើងៗ ដោយសារឥទ្ធិពលចិត្តសាស្ត្ររបស់វាទៅលើប្រជាជនទាំងមូល ក្នុងចំនួនច្រើនសន្ធឹកសន្ធាប់ ម្លោះហើយនេះជាមូលហេតុដែលវាតាមធម្មតាគឺជាឧបករណ៍របស់ក្រុមជនទន់ខ្សោយ។

ទោះជាយ៉ាងណាក៏ដោយ ការវាយប្រហាររបស់ក្រុមអាល់កៃដាធ្វើតាមនិន្នាផ្សេងពីនេះបន្តិច ដោយមិនសូវរៀបចំគំរោងការណ៍ដើម្បីបង្កការភ័យខ្លាចប៉ុន្មានទេ ប៉ុន្តែដើម្បីសម្លាប់ជនជាតិអាមេរិក និងសម្ព័ន្ធមិត្តរបស់ពួកគេ អោយបានច្រើនតាមដែលអាចធ្វើទៅបាន ហើយនៅទីបំផុតដើម្បីបង្កអំពើហិង្សាដ៏រំលាយលោក (apocalyptic) ដែលអ្នកដើរតាមក្រុមអាល់កៃដាជឿថានឹងនាំមកនូវអនន្តរាគមន៍របស់ព្រះជាម្ចាស់។ ប្រាកដណាស់ ការវាយប្រហារភេរវកម្មដោយទូទៅមានកាន់តែច្រើន និងកាន់តែធ្ងន់ធ្ងរ ក្នុងរយៈពេល ៥០ ឆ្នាំចុងក្រោយនេះដោយសារកលល្បិចភេរវកម្មបានប្រើប្រាស់មធ្យោបាយហិង្សាកាន់តែច្រើនឡើង ដើម្បីបង្ករបួសស្នាម ឬសម្លាប់ជនស៊ីវិល។ មែនទែនទៅ ឥទ្ធិពលផ្លូវចិត្តសំដៅទៅលើប្រជាជនម៉ូស្លីមនៅទូទាំងពិភពលោក ជាជាងទៅលើជនជាតិអាមេរិក។

នៅក្នុងការវាយប្រហារបំផ្លិចបំផ្លាញដ៏គួរអោយភ្ញាក់ផ្អើល នៅលើមជ្ឈមណ្ឌលពាណិជ្ជកម្មពិភពលោក មន្ទីរបញ្ចកោណ និងយន្តហោះដែលធ្លាក់នៅសង្កាត់សុមែរសិត នៃរដ្ឋផេនស៊ីវ៉ានី ការខូចខាតជាក់ស្តែងមានទំហំធំជាងការវាយប្រហារភេរវកម្មមុនៗទាំងអស់ ពោលគឺឈានដល់ការបាត់បង់អាយុជីវិតមនុស្សរាប់ពាន់នាក់ និងទ្រព្យសម្បត្តិរាប់សិបពាន់លានដុល្លារ។ ផលប៉ះពាល់ផ្លូវចិត្តមានសភាពកាន់តែខ្លាំងជាងការខូចខាតខាងរាងកាយ ដោយផ្លាស់ប្តូរទិដ្ឋភាពនយោបាយនិងវប្បធម៌របស់សហរដ្ឋអាមេរិកភ្លាមៗ។ ហើយបណ្តាញភេរវជនដដែលនាពេលនោះកំពុងព្យាយាមទទួលបានអាវុធនុយក្លេអ៊ែរ (សូមមើលអាវុធប្រល័យលោក) ដែលអាចត្រូវយកទៅសម្លាប់មនុស្ស មិនមែនត្រឹមរាប់ពាន់នាក់ទេ ប៉ុន្តែ ជនជាតិអាមេរិករាប់រយពាន់នាក់ឯណោះ។

ករណីអំពើភេរវកម្មចាស់ៗ (ចាប់ពីទសវត្សរ៍ឆ្នាំ ១៩៧០ រហូតដល់ការវាយប្រហារឆ្នាំ ២០០១) គឺជាករណីដែល*ភ្នាក់ងារមិនជារដ្ឋ* ប្រើការវាយប្រហារលើ*ជនស៊ីវិល* ដោយកងកម្លាំង*មិនមានឯកសណ្ឋាន* ដោយសម្ងាត់ ហើយដោយប្រតិបត្តិការ*ឆ្លងព្រំដែនអន្តរជាតិ* សម្រាប់ជាឥទ្ធិពលប្រឆាំងនឹង*ភ្នាក់ងាររដ្ឋ*។ គណបក្សនយោបាយវ៉ាឌីកាល់ ឬ ក្រុមបំបែកខ្លួន ប្លន់ឬបំផ្ទុះយន្តហោះ ឬបំផ្ទុះគ្រាប់បែក នៅក្នុងហាងកាហ្វេ ក្លឹប ឬទីកន្លែងដែលមានមនុស្សច្រើនកុះករដទៃទៀត។ ជាឧទាហរណ៍ ពួកវ៉ាឌីកាល់ឆេចឆិនបានឡោមព័ទ្ធរឹបអូសយកសាលារៀនមួយនៅបេស្លាន (Beslan) ដែលជាទីក្រុងតូចមួយក្នុងតំបន់កូកាស នៅក្នុងឆ្នាំ ២០០៤។ អស់រយៈពេលបីថ្ងៃ ពួកគេបានឃុំឃាំងកុមារ អាណាព្យាបាល ឪពុកម្តាយ និងលោកគ្រូអ្នកគ្រូ ចំនួនជិត ១២០០ នាក់ ដោយគ្មានអាហារហូបឬទឹកផឹក នៅពេលទាហានរុស្ស៊ីសម្រុកចូលសាលារៀន មនុស្សចំនួនជាង ៣០០នាក់ បានស្លាប់ ក្នុងនោះមានកុមារចំនួន១៧២នាក់។


យុទ្ធសាស្ត្របែបនេះបង្កើតឧប្បត្តិហេតុដ៏សោកសង្រេងពន់ពេក ដែលធ្វើអោយមហាជននានាងឿងឆ្ងល់ចង់ដឹងពីបុព្វហេតុរបស់ពួកភេរវកម្មអស់នោះ។ ជាឧទាហរណ៍ ការបំផ្ទុះគ្រាប់បែក ក្នុងការប្រកួតម៉ារ៉ាតុងបុស្តុន (Boston Marathon) ក្នុងឆ្នាំ ២០១៣ គឺជាការវាយប្រហារដែលមិនស្មុគ្រស្មាញ ដោយបងប្អូនពីរ

នាក់ ប៉ុន្តែ វាបានគ្របដណ្តប់លើប្រព័ន្ធផ្សព្វផ្សាយព័ត៌មានជាច្រើនសប្តាហ៍ក្រោយមក។ ជាញឹកញយ អំពើភេរវកម្មត្រូវបានប្រើប្រាស់ដោយក្រុមជ្រុលនិយមនៃចលនាទាំងឡាយណា ដែលមិនមានលទ្ធភាពទទួលបានការចាប់អារម្មណ៍ ឬបង្កើតមធ្យោបាយដើម្បីជះឥទ្ធិពលដ៏មានប្រសិទ្ធភាពផ្សេងទៀត។ ជារឿយៗ វាគឺជាតាក់ទិកចុងក្រោយពេលគេអស់សង្ឃឹម ហើយវាតែងតែឆ្លុះបញ្ចាំងពីភាពទន់ខ្សោយ អំណាចរបស់អ្នកវាយប្រហារ។ ជាឧទាហរណ៍ ក្រុមរ៉ាឌីកាល់ប៉ាឡេស្ទីន ក្នុងឆ្នាំ ១៩៧២ បានឃើញថា រដ្ឋអារ៉ាប់ចាញ់អ៊ីស្រាអែលក្នុងសង្គ្រាម ហើយមិនអាចមានមធ្យោបាយដើម្បីទទួលបានសូម្បីតែសវនាការសម្រាប់ពន្យល់បុព្វហេតុរបស់ខ្លួន។ តាមរយៈការទាក់ទាញការយកចិត្តទុកដាក់របស់ប្រព័ន្ធផ្សព្វផ្សាយទូទាំងពិភពលោក ជាមួយនឹងឧប្បត្តិហេតុនៃអំពើហិង្សាដែលសោកសង្រេងពន់ពេក ទោះជាបណ្តាលអោយមតិសាធារណៈពិភពលោករួមគ្នាប្រឆាំងនឹងបុព្វហេតុរបស់ពួកគេក្តី ក្រុមរ៉ាឌីកាល់សង្ឃឹមថានឹងធ្វើអោយសេចក្តីប្រាថ្នារបស់ប៉ាឡេស្ទីនក្លាយជាបញ្ហាដែលរដ្ឋាភិបាលលោកខាងលិចមិនអាចព្រងើយកន្តើយ នៅពេលសម្រេចចិត្តលើគោលនយោបាយ (ការបរទេស)ចំពោះតំបន់មជ្ឈឹមបូព៌ា។

ក្រាហ្វិក ៦.៤ ទីតាំងនៃការវាយប្រហារអត្តឃាត ឆ្នាំ ១៩៧៤-២០១៦

ប្រភព៖ ទិន្នន័យពីគម្រោង Chicago ស្តីពីសន្តិសុខ និងភេរវកម្ម (CPOST)។ ២០១៦. មូលដ្ឋានទិន្នន័យការវាយប្រហារអត្តឃាត (ចេញផ្សាយថ្ងៃទី ១២ ខែតុលា ឆ្នាំ ២០១៦)។

[ឯកសារទិន្នន័យ។ ទាញយកពី http://cpostdata.uchicago.edu/ ។]



ប៉ុន្តែ ការបន្តអំពើភេរវកម្មគឺជារឿងគួរអោយងឿងឆ្ងល់ខ្លះដែរ ព្រោះអត្រាជោគជ័យនៃការប្រើប្រាស់យុទ្ធសាស្ត្រនេះមានលក្ខណៈចម្រុះ។ អ្នកបំផុះគ្រាប់បែកអត្តឃាតមានប្រសិទ្ធភាពខ្លះដែរក្នុងការបញ្ចុះបញ្ចូលសហរដ្ឋអាមេរិកអោយចាកចេញពីប្រទេសលីបង់ ក្នុងឆ្នាំ ១៩៨៣ ប៉ុន្តែ ការវាយប្រហារនៅសាលារៀនឆ្នាំ ២០០៤ របស់ភេរវកររឆេចឆិនបានក្លាយជាទីអវសានរបស់ពួកគេ ក្នុងហានៈជាកម្លាំងពិតប្រាកដ នៅក្នុងតំបន់ឆេចនី។ ប្រជាជនប៉ាឡេស្ទីនមិនបានទទួលហានៈជារដ្ឋ តាមរយៈអំពើភេរវកម្មទេ។ រីដែអូបង្ហាញពីការកាត់ក្បាលចំណាប់ខ្មាំង ដោយជនសកម្មប្រយុទ្ធអាយស៊ីស (ISIS) បានបណ្តាលអោយមាន កិច្ចខិតខំប្រឹងប្រែង

រួមគ្នាជាសកល ដើម្បីកម្ចាត់ចលនានោះ នៅក្នុងប្រទេសអ៊ីរ៉ាក់និងស៊ីរី។ លើសពីនេះ សូម្បីតែអ្នកបំផ្ទុះគ្រាប់បែកអត្តឃាតមួយចំនួនធំ ក៏មិនទាន់មានប្រសិទ្ធភាព ក្នុងការទទួលបានឋានៈរដ្ឋមួយ សម្រាប់ជនជាតិតាមីល នៅក្នុងប្រទេសស្រីលង្កាដែរ ហើយក៏មិនអាចផ្តល់អានុភាពសម្រាប់ក្រុមហាម៉ាស ឬក្រុមដ៏ហាតអ៊ីស្លាមជ្រុលនិយមប្រឆាំងនឹងអ៊ីស្រាអែលដែរ។ ច្បាស់ណាស់ សកម្មភាពភេរវកម្មមិនអាចសម្រេចបាននូវគោលដៅនយោបាយដ៏គួរអោយទុកចិត្តនោះទេ។

ការស្រាវជ្រាវមួយចំនួនបានព្យាយាមវិភាគជាប្រព័ន្ធថា តើនៅពេលណាដែលទំរង់ភេរវកម្មណាមួយដូចជាការបំផ្ទុះគ្រាប់បែកអត្តឃាត មានប្រសិទ្ធភាពក្នុងការសម្រេចបាននូវគោលដៅរបស់អង្គការភេរវកម្ម។ បើយោងតាមការសិក្សាមួយ ការបំផ្ទុះគ្រាប់បែកអត្តឃាតមិនមែនជាការប្រើអំពើហិង្សា ដោយមិនសមហេតុផលដោយក្រុមភេរវកម្មទេ ហើយវាធ្វើតាមគំរូយុទ្ធសាស្ត្ររបស់គេផ្ទាល់ (សូមមើលក្រាហ្វិក ៦.៤)។ ជាពិសេសពួកវាកើតឡើងញឹកញាប់បំផុតប្រឆាំងនឹងលទ្ធិប្រជាធិបតេយ្យ ជាជាងរបបអត្តាធិបតេយ្យ ដោយសារលទ្ធិប្រជាធិបតេយ្យត្រូវបានគេគិតថាត្រូវទទួលរងឥទ្ធិពលពីមតិសាធារណៈយ៉ាងខ្លាំង។ ទោះបីជាយ៉ាងណាក៏ដោយ ការសិក្សាដូចគ្នានេះសន្និដ្ឋានថា យុទ្ធសាស្ត្រភេរវកម្មបែបនេះមិនទទួលបានជោគជ័យ ជាពិសេស ក្នុងការសម្រេចបាននូវគោលដៅសំខាន់ៗនោះទេ។

ភេរវកម្មមានហ៊ានបំពានលើបទដ្ឋាននៃប្រព័ន្ធអន្តរជាតិ ញឹកញាប់ជាងរដ្ឋទាំងឡាយ ពីព្រោះខុសពីរដ្ឋ ពួកគេមិនមានចំណែកឬផលប្រយោជន៍នៅក្នុងប្រព័ន្ធនោះ។ ផ្ទុយទៅវិញ នៅពេលដែលក្រុមនយោបាយមួយទទួលបានអំណាច ឬធម្មានុរូបភាព ការប្រើប្រាស់អំពើភេរវកម្មជាធម្មតាចាប់ផ្តើមថយចុះ។ នេះជាការពិតនៃអង្គការរំដោះប៉ាឡេស្ទីន ក្នុងអំឡុងពេលដំណើរការសន្តិភាព ក្នុងឆ្នាំ ១៩៩៣-២០០០ ក៏ដូចជាកងទ័ពសាធារណៈរដ្ឋអៀរឡង់(IRA) ដែលបានចាប់ផ្តើមនៅឆ្នាំ ១៩៩៥។

រដ្ឋខ្លួនឯងផ្ទាល់ក៏ធ្វើសកម្មភាពមួយចំនួន ដែលមានគោលដៅបំភ័យប្រជាជនខ្លួនឯង ឬប្រជាជននៃរដ្ឋផ្សេងទៀត ប៉ុន្តែអ្នកប្រាជ្ញនានាមានទំនោរមិនហៅទង្វើបែបនេះថាជា «អំពើភេរវកម្ម» នោះទេ ដោយនិយមហៅវាថាជា ការគាបសង្កត់ ឬសង្គ្រាម ទៅវិញ។ តាមពិតទៅ គ្មានអំពើហិង្សាណាមួយ ដែលបានធ្វើឡើងក្នុងអំឡុងសង្គ្រាមស៊ីវិល ឬសង្គ្រាមអន្តរជាតិ ទោះធ្វើឡើងដោយ ឬធ្វើដាក់ភាគីសង្គ្រាមណាមួយនោះទេ អាចត្រូវបានចាត់ចូលក្នុងប្រភេទភេរវកម្មណាមួយនោះទេ។ ជាការពិតណាស់ ដោយសារនិយមន័យសង្គ្រាម ក៏ដូចជាអំពើភេរវកម្ម ពិបាកកំណត់ ដូច្នេះភាគីសង្គ្រាមតែងតែហៅគ្នាទៅវិញទៅមកថាជាភេរវកម្ម។ និយមន័យតូចចង្អៀតបំផុតនៃអំពើភេរវកម្ម នឹងមិនរាប់បញ្ចូលសកម្មភាព ដោយឬដាក់ *កងកម្លាំងយោធាឯកសណ្ឋាន* ជាជាងធ្វើឡើងដោយឬដាក់ជនស៊ីវិល។ និយមន័យនេះនឹងមិនរាប់បញ្ចូលការសម្លាប់ទាហានម៉ារីនអាមេរិកចំនួន ២៤៣ នាក់ ដោយការបំផ្ទុះគ្រាប់បែកក្នុងរថយន្ត នៅប្រទេសលីបង់ក្នុងឆ្នាំ ១៩៨៣ និងការវាយប្រហារឆ្នាំ ២០០១ លើមន្ទីរបញ្ចកោណទេ ពីព្រោះសកម្មទាំងនោះត្រូវបានតម្រង់ទៅលើគោលដៅយោធា។ វាក៏នឹងមិនរាប់បញ្ចូលការទម្លាក់គ្រាប់បែកលើទីក្រុងរបស់អាឡឺម៉ង់ក្នុងសង្គ្រាមលោកលើកទី ២ ផងដែរ បើទោះបីមានគោលបំណងដើម្បីបំភ័យជនស៊ីវិលក៏ដោយ។ ប៉ុន្តែ នៅក្នុងសង្គ្រាមដែលត្រូវបានមិនប្រកាស សង្គ្រាមទ័ពព្រៃ សង្គ្រាមស៊ីវិល និងអំពើហិង្សាជាតិសាសន៍ ក្នុងពិភពលោកបច្ចុប្បន្ននេះ តំបន់ប្រផេះដ៏ធំនៅជុំវិញករណីច្បាស់លាស់នៃអំពើភេរវកម្ម ។

គិតត្រឹមឆ្នាំ ២០១៨ សហរដ្ឋអាមេរិកបានចោទប្រកាន់រដ្ឋចំនួនបួន ថាបានគាំទ្រអំពើភេរវកម្ម អន្តរជាតិ រួមមាន អ៊ីរ៉ង់ ស៊ីរី ស៊ូដង់ និងកូរ៉េខាងជើង។ ប្រទេសបីដំបូងជាប់ឈ្មោះក្នុងបញ្ជីភេរវកម្ម អស់ជាង មួយទសវត្សរ៍មកហើយ។ រដ្ឋាភិបាលសហរដ្ឋអាមេរិកបានហាមឃាត់ក្រុមហ៊ុនអាមេរិកមិនអោយធ្វើអាជីវកម្ម ក្នុងរដ្ឋទាំងនោះ។ ទោះយ៉ាងណាក៏ដោយ ប្រសិទ្ធិភាពនៃប្រភេទទណ្ឌកម្មឯកតោភាគីរបស់សហរដ្ឋអាមេរិក មានកម្រិតនៅឡើយ។ ប្រទេសស៊ីរីអាចធ្វើជំនួញជាមួយប្រទេសអេហ្ស៊ីប ដូចដែលប្រទេសអ៊ីរ៉ង់ធ្វើជាមួយ ប្រទេសរុស្ស៊ីដែរ។ ប្រទេសកូរ៉េខាងជើងត្រូវបានដកចេញពីបញ្ជី ក្នុងឆ្នាំ២០០៨ ជាថ្នូរនឹងការសន្យាបញ្ឈប់ កម្មវិធីអាវុធនុយក្លេអ៊ែររបស់ខ្លួន ប៉ុន្តែត្រូវបានដាក់បញ្ចូលក្នុងបញ្ជីវិញនៅឆ្នាំ ២០១៧ ក្រោយប្រទេសនេះបាន សាកល្បងអាវុធនុយក្លេអ៊ែរ។ ប្រទេសគុយបាត្រូវបានដកចេញពីបញ្ជីក្នុងឆ្នាំ ២០១៥ បន្ទាប់ពីមានទំនាក់ ទំនងជាមួយសហរដ្ឋអាមេរិកត្រូវបានភ្ជាប់ជាធម្មតាឡើងវិញ។

រូបថត អគារបញ្ជាកោណត្រូវយន្តហោះភេរវកម្មបើកបំបុកផ្ទុះ

ជម្លោះមិនស៊ីមេទ្រី

ការវាយប្រហារភេរវកម្មតែងតែឆ្លុះបញ្ចាំងពីភាពទន់ខ្សោយរបស់ជនល្មើស និងកង្វះលទ្ធភាពប្រើប្រាស់ មធ្យោបាយផ្សេងៗ។ ជួនកាល ភេរវកម្មអាចពង្រីកអំណាចរបស់ក្រុមតូចមួយ និងជះឥទ្ធិពលកាន់តែធំដល់ លទ្ធផល។ ការវាយប្រហារនៅថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ២០០១ របស់ក្រុមអាល់កៃដាដែលរៀបចំឡើងដោយ តួអង្គមិនមែនរដ្ឋដ៏តូច នៅទីបំផុតបណ្តាលអោយមានការដកទ័ពអាមេរិកចេញពីប្រទេសអាហ្វហ្គានីស្ថាន និង អូសទាញសហរដ្ឋអាមេរិកអោយចូលទៅក្នុងសង្គ្រាមប្រឆាំងការបះបោរនៅក្នុងប្រទេសអ៊ីរ៉ាក់ ហើយបានធ្វើ អោយក្រុមអាល់កៃដាផ្នាល់ទាក់ទាញជនសកម្មប្រយុទ្ធកាន់តែច្រើនឡើងៗ សម្រាប់ការវាយប្រហារថ្មីនៅ ទូទាំងពិភពលោក។

អំពើភេរវកម្មដែលឧបត្ថម្ភដោយរដ្ឋ (state-sponsored) សំដៅលើការប្រើប្រាស់ក្រុមភេរវករដោយ រដ្ឋណាមួយ ជាធម្មតា ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ទីភ្នាក់ងារស៊ើបការណ៍សម្ងាត់របស់រដ្ឋ ដើម្បីសម្រេច បាននូវគោលបំណងនយោបាយ។ នៅឆ្នាំ ១៩៨៨ គ្រាប់បែកមួយបានធ្វើអោយយន្តហោះផែនអែម (Pan Am) លេខ១០៣ ត្រូវបែកខ្ចាត់ខ្ចាយ លើទីជនបទប្រទេសស្កុតឡេន។ ដោយរៃករកម្ទេចកម្ទីពេញវាលស្រែ ក្រុមអ្នកស៊ើបអង្កេតបានរកឃើញបំណែកនៃម៉ាស៊ីនថតសំឡេង ដែលមានគ្រាប់បែកផ្លាស្ទិចបំផ្ទុះដ៏ទំនើប មួយ។ រដ្ឋាភិបាលសហរដ្ឋអាមេរិក និងអង់គ្លេសបានកំណត់អត្តសញ្ញាណភ្នាក់ងារចារកម្មលីប៊ីថាជាអ្នកទទួល ខុសត្រូវ ហើយនៅឆ្នាំ ១៩៩២ ដោយមានការគាំទ្រពីក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ពួកគេបាន ទាមទារអោយលីប៊ីប្រគល់ភ្នាក់ងារទាំងនោះមកកាត់ទោស។ នៅពេលដែលប្រទេសលីប៊ីបដិសេធ អង្គការ សហប្រជាជាតិបានដាក់ទណ្ឌកម្ម រួមទាំងការហាមឃាត់ជើងហោះហើរអន្តរជាតិទៅនិងមកពីប្រទេសលីប៊ី ផងដែរ។ នៅឆ្នាំ ១៩៩៩ ប្រទេសលីប៊ីបានប្រគល់ជនសង្ស័យអោយកាត់ទោស ក្នុងនោះពីរនាក់ត្រូវបានដាក់ ទោសអោយជាប់ពន្ធនាគារអស់មួយជីវិត ខណៈពេលដែលជនសង្ស័យទីបីត្រូវបានដោះលែង ហើយ អង្គការ សហប្រជាជាតិបានផ្អាកទណ្ឌកម្មរបស់ខ្លួន។ ក្នុងឆ្នាំ ២០០៣ ប្រទេសលីប៊ីបានទទួលខុសត្រូវជាផ្លូវការ ចំពោះការបំផ្ទុះគ្រាប់បែកលើយន្តហោះនេះ បានធ្វើកិច្ចព្រមព្រៀងសំណងរាប់ពាន់លានដុល្លារ ជាមួយគ្រួសារ ជនរងគ្រោះ និងបានទទួលនូវឋានៈធម្មតានៅក្នុងសហគមន៍អន្តរជាតិឡើងវិញ។

៦.៣.១. ការប្រយុទ្ធប្រឆាំងនឹងអំពើភេរវកម្ម

ដូចគ្នានឹងវិធីសាស្ត្រដែលប្រើដោយភេរវកមានចម្រុះច្រើនក្នុងទសវត្សរ៍កន្លងមក គោលនយោបាយដែលត្រូវបានអនុវត្តដើម្បីការពារឧប្បត្តិហេតុភេរវកម្មក៏មានច្រើនប្លែកៗគ្នាផងដែរ។ ជាញឹកញាប់ ការជជែកវែកញែកអំពីយុទ្ធសាស្ត្រដ៏ល្អបំផុតដើម្បីរារាំងការវាយប្រហារភេរវកមានសភាពក្តៅគគុក ដោយសារក៏មានការជជែកវែកញែកថាតើហេតុអ្វីបានជាបុគ្គលណាមួយសម្រេចចូលរួមក្នុងការវាយប្រហារភេរវកណាមួយ។

គោលនយោបាយដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើភេរវកម្មអាចត្រូវបានដាក់ នៅតាមបណ្តោយបន្ទាត់យុទ្ធសាស្ត្រ ដែលពាក់ព័ន្ធនឹងកងកម្លាំងច្រើនឬតិច ក្នុងការប្រឈមមុខនឹងភេរវកម្មនិងអង្គការភេរវករ។ នៅចុងបន្ទាត់ម្ខាងនៃវិធីសាស្ត្រអហិង្សា គឺការអំពាវនាវអោយមានការអភិវឌ្ឍន៍សេដ្ឋកិច្ច។ អ្នកតស៊ូមតិជម្រុញកម្មវិធីទាំងនេះចង្អុលបង្ហាញថា នៅក្នុងរដ្ឋក្រីក្រខ្លាំង ប្រជាជនងាយរងគ្រោះនិងចាញ់បោកការជ្រើសរើសសមាជិកថ្មីរបស់អង្គការភេរវករ។ ដោយមើលទៅគ្មានអនាគតភ្លឺស្វាងសម្រាប់ខ្លួន និងឱកាសតិចតួចដើម្បីកែលម្អខ្លួនឯងនោះ មនុស្សម្នាទាំងឡាយនឹងបាត់បង់ក្តីសង្ឃឹមដោយឯកឯង ធាប់ក្តៅក្រហាយ និងប្រព្រឹត្តទង្វើដែលមិនសមហេតុផល ដោយសារតែពួកគេមានអារម្មណ៍ថា ពួកគេគ្មានអ្វីត្រូវបាត់បង់នោះទេ។ ហើយទោះបីជាមានភ័ស្តុតាងផ្ទាល់តិចតួចបញ្ជាក់ថា កត្តានានាដូចជាភាពក្រីក្រ ទាក់ទងដោយផ្ទាល់ជាមួយសកម្មភាពភេរវករក៏ដោយ វាច្បាស់ណាស់ថារដ្ឋក្រីក្រខ្លាំង ដែលមានរដ្ឋាភិបាលកណ្តាលទន់ខ្សោយ បានក្លាយជាមូលដ្ឋានសម្រាប់ជ្រើសរើសសមាជិកថ្មីសម្រាប់អង្គការភេរវករអន្តរជាតិ។

នៅចំកណ្តាលបន្ទាត់យុទ្ធសាស្ត្រប្រឆាំងនឹងអំពើភេរវកម្ម គឺសកម្មភាពប៉ូលីស ដែលពាក់ព័ន្ធនឹងកិច្ចខិតខំប្រឹងប្រែងរបស់ប៉ូលីសក្នុងស្រុក ជារឿយៗនៅក្នុងកិច្ចសហប្រតិបត្តិការជាមួយកងកម្លាំងប៉ូលីសរបស់ប្រទេសផ្សេងទៀត ដើម្បីចាប់ខ្លួនឬសម្លាប់ភេរវករ ក្នុងខណៈពេលបំបែកក្រុមអង្គការភេរវករ។ នៅក្នុងឧទាហរណ៍ដ៏ល្អីមួយនៃការប្រឆាំងភេរវកម្មប្រកបដោយប្រសិទ្ធភាព រដ្ឋាភិបាលនៃប្រទេសប៉េរូ ដោយប្រើក្រុមស៊ើបអង្កេតជាន់ខ្ពស់នៃកងកម្លាំងប៉ូលីសជាតិ បានចាប់ខ្លួនមេដឹកនាំនៃ*ចលនាមាគ៌ាត្រចះត្រចង់* ដែលនៅពេលណាមួយនោះ បានគ្រប់គ្រងសមាជិកកងជីវពលប្រដាប់អាវុធចំណានៗ ជាង ២០,០០០ នាក់ និងបានធ្វើឃាតមេដឹកនាំនយោបាយប៉េរូមួយចំនួន។ កម្លាំងប៉ូលីសបានចាប់ខ្លួនមេដឹកនាំចលនានេះ បន្ទាប់ពីបានតាមដាននិងឃ្លាំមើលស្នូឌីយោរាំមួយកន្លែង (ដែលគាត់រស់នៅខាងលើ) និងរើសំរាមពីស្នូឌីយោដើម្បីស្វែងរកតម្រុយ។ បន្ទាប់ពីបានចាប់ខ្លួនគាត់ *ចលនាមាគ៌ាត្រចះត្រចង់* បានដួលរលំស្ទើរទាំងស្រុង។

នៅខាងចុងម្ខាងទៀតនៃបន្ទាត់ប្រឆាំងភេរវកម្ម គឺជាជម្លោះយោធាដែលត្រូវបានគ្រោងទុក។ រដ្ឋអាចនឹងជ្រើសរើសមធ្យោបាយជម្លោះទ្រង់ទ្រាយតូចឬធំ ដើម្បីប្រឆាំងនឹងអង្គការភេរវជន។ នៅក្នុងឆ្នាំ ១៩៩៨ សហរដ្ឋអាមេរិកបានបើកការវាយប្រហារដោយកាំជ្រួចប្រដេញ (Cruise missiles) ប្រឆាំងនឹងរោងចក្រមួយនៅក្នុងប្រទេសស៊ូដង់ ដែលគេជឿថាកំពុងផលិតអាវុធគីមីសម្រាប់ក្រុមអាល់កៃដា ប៉ុន្តែ គេរកឃើញថាកំពុងទឹកដោះគោទារកទៅវិញ។ លើសពីនេះ សង្គ្រាមដែលដឹកនាំដោយសហរដ្ឋអាមេរិក នៅអាហ្វហ្គានីស្ថាន គឺជាការឆ្លើយតបទៅនឹងការវាយប្រហារ ៩/១១ ទៅលើសហរដ្ឋអាមេរិក។

ប្រាកដណាស់ ស្ទើរតែគ្រប់រដ្ឋដែលអនុវត្តគោលនយោបាយប្រឆាំងភេរវកម្មប្រើប្រាស់វិធីសាស្ត្ររួមផ្សំមួយចំនួនក្នុងចំណោមទាំងបីនេះ។ ជាឧទាហរណ៍ នៅសហរដ្ឋអាមេរិក ជំនួយបរទេសច្រើនតែត្រូវបានលើកហេតុផលក្នុងន័យជួយដល់ការអភិវឌ្ឍន៍និងកំណើនសេដ្ឋកិច្ច ដើម្បីកាត់បន្ថយលទ្ធភាពដែលជនក្រីក្រគ្មាន

ការអប់រំ អាចត្រូវបានគេអូសទាញអោយចូលទៅក្នុងអង្គការភេរវកម្មព្រាង បានយ៉ាងងាយស្រួល។ ទីភ្នាក់ងារស៊ើបការណ៍សម្ងាត់ និងមន្ត្រីអនុវត្តច្បាប់ក្នុងស្រុក សហការជាមួយដៃគូអន្តរជាតិជាច្រើន ដើម្បីតាមដាន និងឃុំខ្លួនពួកភេរវកម្មដែលជាប់សង្ស័យ ខណៈដែលទាហានអាមេរិកជួយរដ្ឋផ្សេងទៀត ក្នុងការបណ្តុះបណ្តាលកងកម្លាំង និងផ្តល់អាវុធយុទ្ធភ័ណ្ឌក្នុងការប្រយុទ្ធប្រឆាំងនឹងភេរវកម្ម។ ទីបំផុត សង្គ្រាមនៅអាហ្វហ្គានីស្ថានគឺជាសង្គ្រាមដ៏ធំមួយ ដែលបានធ្វើឡើងប្រឆាំងនឹងរដ្ឋាភិបាលតាលីបង់ ដែលបានទីជំរកនិងការពារក្រុមភេរវកម្មអាល់កៃដា។

៦.៤. អាវុធប្រល័យលោក

៦.៣ ចូរប្រៀបធៀបប្រសិទ្ធភាពនៃ«របបសកល»ក្នុងការទប់ស្កាត់ការរីកសាយភាយអាវុធនុយក្លេអ៊ែរ នឹងប្រសិទ្ធភាពនៃ«របបសកល»ក្នុងការទប់ស្កាត់ការរាលដាលនៃអាវុធគីមី។

អាវុធប្រល័យលោក (WMDs) មានបីប្រភេទ៖ អាវុធនុយក្លេអ៊ែរ អាវុធគីមី និងអាវុធជីវសាស្ត្រ។ អាវុធទាំងនេះត្រូវញែកចេញពីអាវុធធម្មតាទូទៅ ដោយសារសក្តានុពលដ៏ខ្លាំងក្លារបស់ពួកវាក្នុងការប្រល័យជីវិតមនុស្ស ទោះបីពួកវាមានទំហំតូច និងត្រូវការថ្លៃផលិតគួរសម និងដោយសារការសម្លាប់មនុស្សមិនរើសមុខ។ នៅពេលដាក់ពង្រាយលើកាំជ្រួចផ្លោង ពួកវាអាចត្រូវបានគេបាញ់ចេញពីទឹកដីកំណើតនៃរដ្ឋមួយ និងបង្កអោយមានការបំផ្លិចបំផ្លាញយ៉ាងខ្លាំងនៅលើទឹកដីនៃរដ្ឋមួយផ្សេងទៀត។ រហូតមកដល់ពេលនេះ វាមិនដែលបានកើតឡើង នៅឡើយ។ ប៉ុន្តែ ការគំរាមកំហែងនៃសកម្មភាពបែបនេះ ធ្វើអោយខូចខាតដល់បូរណភាពទឹកដី និងសន្តិសុខរបស់រដ្ឋក្នុងប្រព័ន្ធអន្តរជាតិ។ អ្វីដែលជាកង្វល់ធំបំផុត នាពេលបច្ចុប្បន្ននេះ គឺសក្តានុពលសម្រាប់ការរីកសាយភាយ៖ ការកាន់កាប់អាវុធប្រល័យលោកដោយរដ្ឋកាន់តែច្រើនឡើងៗ។

អាវុធប្រល័យលោកបម្រើគោលដៅខុសគ្នាពីអាវុធធម្មតា។ ជាមួយនឹងករណីលើកលែងមួយចំនួន គោលដៅរបស់វា គឺដើម្បីរារាំងការវាយប្រហារ (ជាពិសេស ដោយអាវុធប្រល័យលោកដទៃទៀត) ដោយផ្តល់អោយមេដឹកនាំរដ្ឋមួយនូវមធ្យោបាយដើម្បីបង្កការឈឺចាប់យ៉ាងខ្លាំង ប្រឆាំងតទល់នឹងរដ្ឋមួយទៀត ដែលអាចនឹងមកឈ្លានពាន។ សម្រាប់ប្រទេសអំណាចមធ្យម អាវុធទាំងនេះក៏ផ្តល់អោយខ្លួននូវអំណាចបំផ្លិចបំផ្លាញ ដូចអំណាចនៃប្រទេសមហាអំណាចផងដែរ ដូច្នេះ វាបម្រើជានិមិត្តសញ្ញាស្មើភាពគ្នា។ សម្រាប់ក្រុមភេរវកម្ម គោលដៅនៃអាវុធទាំងនេះ គឺសម្លាប់មនុស្សជាច្រើនតាមដែលគេចង់បាន។

៦.៤.១. អាវុធនុយក្លេអ៊ែរ

អាវុធនុយក្លេអ៊ែរ គឺជាអាវុធដែលបង្កការបំផ្លិចបំផ្លាញខ្លាំងបំផុតនៅក្នុងពិភពលោក។ អាវុធត្រឹមតែមួយគត់ដែលមានទំហំប៉ុនទូទឹកកកអាចបង្កការបំផ្លិចបំផ្លាញប៉ុនទំហំទីក្រុងមួយ។ យ៉ាងណាមិញ ប្រព័ន្ធការពារពីការបំផ្លាញដោយអាវុធនុយក្លេអ៊ែរ គឺជាកិច្ចការលំបាកបំផុត។ ដើម្បីស្វែងយល់ពីសក្តានុពលនៃការរីកសាយភាយអាវុធនុយក្លេអ៊ែរ គេត្រូវតែដឹងខ្លះអំពីរបៀបដែលអាវុធនុយក្លេអ៊ែរដំណើរការ។ ពួកវាមានពីរប្រភេទ។ *អាវុធបំផ្ទុះជាតុអាតូម* (Fission) ដែលរួមមានគ្រាប់បែកអាតូមិក ឬ គ្រាប់បែក A មានលក្ខណៈសាមញ្ញជាង និងមានតម្លៃថោកជាង *អាវុធផ្សំជាតុអាតូម* (Fussion) ឬ ហៅម្យ៉ាងទៀតថា គ្រាប់បែកទែម៉ូនុយក្លេអ៊ែរ (thermosnuclear) គ្រាប់បែកអ៊ីដ្រូសែន ឬ គ្រាប់បែក H)។

នៅពេលដែល*អាវុធបំផ្ទុះជាតុអាតូមផ្ទុះ* អាតូមមួយប្រភេទ (ជាតុរបស់វា) ត្រូវបាន*បំផ្ទុះ* (*fissioned*) ឬបំបែកទៅជាប្រភេទថ្មីដែលមានម៉ាស់សរុបតិចជាង។ ម៉ាស់ដែលបាត់បង់ ត្រូវបានបំប្លែងទៅជាថាមពល បើ

យោងតាមរូបមន្តដ៏ល្បីល្បាញរបស់ លោក អាល់ប៊ឺត អ៊ិញស្តែន (Albert Einstein) គឺ $E = mc^2$ ដែលបង្ហាញថាម៉ាស់តូចអាចបំប្លែងជាថាមពលខ្លាំងក្លា។ តាមពិតទៅ *គ្រាប់បែកបំផ្ទុះជាតុអាតូម*ដែលបានបំផ្លាញទីក្រុងណាហ្គាសាគី ប្រទេសជប៉ុន ក្នុងឆ្នាំ ១៩៤៥ បានបំប្លែងទៅជាថាមពលប្រហែលបរិមាណម៉ាស់ ទំហំត្រឹមកាក់តែមួយតែប៉ុណ្ណោះ។ ធាតុពីរអាចត្រូវបានបំបែកតាមវិធីនេះ។ ហើយវិធីនីមួយៗ ត្រូវបានប្រើប្រាស់ដើម្បីធ្វើ*អាវុធបំផ្ទុះជាតុអាតូម*។ ធាតុទាំងនេះ ត្រូវបានគេស្គាល់ថាជា **សារធាតុបន្ទុះ** (fissionable material) រួមមាន ធាតុអ៊ុយរ៉ាញ៉ូម-២៣៥ (ឬ ប-២៣៥) និង ធាតុប្លាតូនីញ៉ូម។ *អាវុធបំផ្ទុះជាតុអាតូម*ត្រូវបានបង្កើតកាលពី ៦០ ឆ្នាំមុន ដោយអ្នកវិទ្យាសាស្ត្រអាមេរិក នៅក្នុងកម្មវិធីវិទ្យាសាស្ត្រសម្ងាត់នៃសង្គ្រាមលោកលើកទីពីរដែលគេស្គាល់ថាជា*គម្រោងម៉ាន់ហាថាន់* (Manhattan)។ នៅឆ្នាំ ១៩៤៥ គ្រាប់បែក អ៊ុយរ៉ាញ៉ូមមួយ និងគ្រាប់បែកផ្លាតូនីញ៉ូមមួយ ត្រូវបានគេប្រើដើម្បីបំផ្លាញទីក្រុងហ៊ីរ៉ូស៊ីម៉ា និងទីក្រុងណាហ្គាសាគី ដោយបានសម្លាប់ជនស៊ីវិល ប្រមាណ ១០០០០០ នាក់ នៅក្នុងទីក្រុងនីមួយៗ និងជំរុញអោយប្រទេសជប៉ុនចុះចាញ់ដោយគ្មានលក្ខខណ្ឌ។ តាមស្តង់ដារសព្វថ្ងៃ គ្រាប់បែកទាំងនោះជាអាវុធបុរាណ ដែលមានប្រសិទ្ធិភាពទាប។ ប៉ុន្តែ ពួកវាគឺជាប្រភេទអាវុធដែលអាចនឹងត្រូវបានបង្កើតឡើងដោយរដ្ឋក្រីក្រ ឬតួអង្គមិនមែនជារដ្ឋ។

អាវុធបំផ្ទុះជាតុអាតូម ដំណើរការដោយយកម៉ាស់តូចៗនៃវត្ថុធាតុដែលអាចបំបែកបាន (ក្នុងបរិមាណមិនក្រាស់គ្រប់គ្រាន់ដើម្បីចាប់ផ្តើមប្រតិកម្មខ្សែសង្វាក់) ហើយបង្រួមវាទៅជាម៉ាស់ដ៏សំខាន់ ដែលផ្ទុះនៅពេលដែលអាតូមបំបែកបានបញ្ចេញនឺត្រុង ដែលបំបែកអាតូមបន្ត កាន់តែច្រើន នៅក្នុងប្រតិកម្មជាសង្វាក់។ នៅក្នុងការរចនាដ៏សាមញ្ញបំផុត ធាតុអ៊ុយរ៉ាញ៉ូមមួយដុំត្រូវបានរុញចុះក្រោមបំពង់មួយ (ដោយសារធាតុផ្ទុះធម្មតា) ចូលទៅក្នុងបំណែកមួយទៀតនៃសារធាតុអ៊ុយរ៉ាញ៉ូម។ ការរចនាប្រកបដោយប្រសិទ្ធភាព ប៉ុន្តែ តាមតម្រូវការបច្ចេកទេស រៀបចំគ្រឿងផ្ទុះខ្ពស់យ៉ាងជាក់លាក់ជុំវិញប្រហោងនៃផ្លាតូនីញ៉ូម ដើម្បីបំផ្ទុះលំហរ និងបង្កើតម៉ាស់ដ៏ធំ។

ទោះបីជាការរចនាទាំងនេះត្រូវការវិស្វកម្មទំនើបក៏ដោយ រដ្ឋជាច្រើននិងក្រុមឯកជនមួយចំនួនអាចមានសមត្ថភាពរចនាវាបាន។ អ្វីដែលជាឧបសគ្គគឺការទទួលបាន **សារធាតុបន្ទុះ**។ គ្រាប់បែកនីមួយៗត្រូវការតែ ១០ ទៅ ១០០ ផោនប៉ុណ្ណោះសម្រាប់ផលិត ប៉ុន្តែ សូម្បីតែបរិមាណតិចតួចទាំងនេះ ក៏មិនងាយទទួលបានដែរ។ ធាតុអ៊ុយរ៉ាញ៉ូម-២៣៥ ដែលអាចប្រើក្នុងការរចនាគ្រាប់បែកដ៏សាមញ្ញបំផុត គេពិបាកនឹងទទួលបានខ្លាំងណាស់។ ធាតុអ៊ុយរ៉ាញ៉ូមធម្មជាតិ (ជីកយក នៅក្នុងប្រទេសផ្សេងៗ) មាន ប-២៣៥ តិចជាង ១ ភាគរយលាយជាមួយសារធាតុអ៊ុយរ៉ាញ៉ូម ដែលមិនអាចបំបែកបាន។ ការចំរាញ់ធាតុអ៊ុយរ៉ាញ៉ូម-២៣៥ដែលអាចបំបែកបាន សំដៅដល់ការបង្កើនសារធាតុអ៊ុយរ៉ាញ៉ូមរហូតដល់កម្រិតផលិតអាវុធបាន (ឬថ្នាក់ខ្ពស់) ត្រូវការពេលវេលាយូរ ការចំណាយខ្ពស់ និងបច្ចេកទេសស្មុគស្មាញ ដែលជាឧបសគ្គចម្បង ក្នុងការរីកសាយភាយ។ ប៉ុន្តែ ប្រទេសកូរ៉េខាងជើង អ៊ីរ៉ង់ អ៊ីរ៉ាក់ និងលីប៊ី សុទ្ធតែបានសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ដើម្បីធ្វើដូច្នេះក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ។ ប្រទេសកូរ៉េខាងជើងបានសន្យាថានឹងបញ្ចប់កម្មវិធីអ៊ុយរ៉ានីញ៉ូមរបស់ខ្លួន និងរុះរើអគារនុយក្លេអ៊ែររបស់ខ្លួន (បន្ទាប់ពីបានសាកល្បងគ្រាប់បែក ក្នុងឆ្នាំ ២០០៦ និង ២០០៩) ប៉ុន្តែ ក្រោយមកបានចាប់ផ្តើមឡើងវិញ ដោយបានសាកល្បងបាញ់គ្រាប់បែកនុយក្លេអ៊ែរ ចន្លោះឆ្នាំ ២០១៦ និង ២០១៧។ ប្រទេសអ៊ីរ៉ង់បានផ្តើនការទាមទាររបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ដែលតម្រូវអោយប្រទេសអ៊ីរ៉ង់បញ្ឈប់ការចម្រាញ់សារធាតុអ៊ុយរ៉ាញ៉ូម ដោយទទូចថាខ្លួនមានសិទ្ធិអធិបតេយ្យភាព ក្នុងការបង្កើនធាតុ

អ៊ុយរ៉ាញ៉ូម សម្រាប់អ្វីដែលខ្លួនហៅថាគោលបំណងសន្តិភាព។ ក្នុងឆ្នាំ ២០១៥ ប្រទេសអ៊ីរ៉ង់ បានឈានដល់ការសម្រេចកិច្ចព្រមព្រៀងជាមួយសមាជិកអចិន្ត្រៃយ៍ទាំងប្រាំ នៃក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ និង ប្រទេសអាឡឺម៉ង់ ដែលអនុញ្ញាតអោយខ្លួនបន្តដំណើរការនៃការចម្រាញ់សារធាតុអ៊ុយរ៉ាញ៉ូម ត្រឹមកម្រិតទាប ខណៈពេលដែលអនុញ្ញាតអោយមានការត្រួតពិនិត្យអន្តរជាតិលើទីតាំងនុយក្លេអ៊ែរ។ អ្នកសង្ស័យលើកិច្ចព្រមព្រៀងបារម្ភថា ប្រទេសអ៊ីរ៉ង់នឹងមិនគោរពតាមកិច្ចព្រមព្រៀងនេះ ខណៈក្រុមអ្នកតស៊ូមតិអះអាងថា បើទោះជាប្រទេសអ៊ីរ៉ង់នៅតែបន្តធ្វើការលើអាវុធក៏ដោយ ក៏កម្មវិធីរបស់អ៊ីរ៉ង់នឹងត្រូវយឺតយ៉ាវជាច្រើនឆ្នាំ។ នៅឆ្នាំ ២០១៨ សហរដ្ឋអាមេរិកបានដកខ្លួនចេញពីកិច្ចព្រមព្រៀងនេះ ដោយបណ្តាលអោយមានការងឿងឆ្ងល់ពីអនាគតរបស់វា។

សារធាតុផ្លាតូនីញ៉ូមអាចត្រូវបានផលិតយ៉ាងងាយស្រួល ពីសារធាតុអ៊ុយរ៉ាញ៉ូមកម្រិតទាប នៅក្នុងម៉ាស៊ីនរ៉េអាក់ទ័រ(ប្រតិកម្ម)ថាមពលនុយក្លេអ៊ែរ ទោះបីជាការទាញយកសារធាតុផ្លាតូនីញ៉ូមត្រូវការរោងចក្របំបែកដោយឡែកមួយទៀតក៏ដោយ។ ប៉ុន្តែ គ្រាប់បែកផ្លាតូនីញ៉ូមពិបាកផលិតជាងគ្រាប់បែកអ៊ុយរ៉ានីញ៉ូមទៅទៀត ដែលជាឧបសគ្គមួយទៀតរារាំងការរីកសាយភាយ។ ធាតុផ្លាតូនីញ៉ូមក៏ត្រូវបានប្រើប្រាស់នៅក្នុងម៉ាស៊ីនរ៉េអាក់ទ័របង្កាត់ពូជសម្រាប់ពាណិជ្ជកម្មផងដែរ ដែលប្រទេសជប៉ុន និងប្រទេសផ្សេងទៀត បានសាងសង់នាពេលថ្មីៗនេះ ដែលជាប្រភពមួយផ្សេងទៀតនៃវត្ថុធាតុដែលអាចបំបែកបាន។ (ដូច្នេះ ប្រសិនបើជប៉ុនសម្រេចចិត្តធ្វើដូច្នេះនៅពេលអនាគត ទំនងជាមិនអាចកើតឡើង ប្រទេសនេះអាចសាងសង់ឃ្លាំងអាវុធនុយក្លេអ៊ែរដ៏សម្បើមមួយ យ៉ាងឆាប់រហ័ស។) ប្រទេសកូរ៉េខាងជើងបានសាកល្បងគ្រាប់បែកផ្លាតូនីញ៉ូមមួយនៅឆ្នាំ ២០០៦ ដោយសម្រេចបានការបំបែកឬបំផ្ទុះអាតូម ទោះបីជាមានទិន្នផលទាបក៏ដោយ។

អាវុធផ្សំជាតុអាតូម (Fussion) មានតម្លៃថ្លៃបំផុត និងមានតម្រូវការបច្ចេកទេសខ្លាំង ដូច្នេះអាវុធទាំងនេះសម្រាប់តែរដ្ឋដែលមានបំផុត ធំបំផុត និងមានសមត្ថភាពបច្ចេកវិទ្យាខ្លាំងបំផុតដែរ។ អាតូមតូចៗចំនួនពីរនេះ (វ៉ារ្យ៉ង់នៃសារធាតុអ៊ីដ្រូសែន) រួមផ្សំបញ្ចូលគ្នា បង្កើតបានជាអាតូមដ៏ធំមួយ ដោយបញ្ចេញថាមពលធំធេង។ ប្រតិកម្មនេះកើតឡើងតែនៅសីតុណ្ហភាពខ្ពស់ពេកក្រៃ (ព្រះអាទិត្យ «ដុត» អ៊ីដ្រូសែនតាមរយៈការលាយឬរួមផ្សំបញ្ចូលគ្នា)។ អ្នករចនាអាវុធទាំងឡាយប្រើប្រាស់*អាវុធបំបែកជាតុអាតូម* ដើម្បីបង្កើតថាមពលខ្ពស់ទាំងនេះ ហើយបង្កជាប្រតិកម្មរួមផ្សំដើម្បីបំផ្ទុះ។ កម្លាំងផ្ទុះនៃ *អាវុធបំបែកជាតុអាតូម* ភាគច្រើន មានសមូលស្មើនឹងកម្លាំងគ្រឿងផ្ទុះធម្មតា ចន្លោះពី ១ ទៅ ២០០ គីឡូតោន (មួយគីឡូតោន ស្មើនឹង ១០០០ តោននៃធាតុផ្ទុះធម្មតា)។ កម្លាំងផ្ទុះនៃ*អាវុធផ្សំជាតុអាតូម*អាចឈានដល់ ២០ មេហ្គាតោន (មួយមេហ្គាតោន ស្មើនឹង ១០០០ គីឡូតោន)។ នៅក្នុងយុគសម័យក្រោយសង្គ្រាមត្រជាក់ អាវុធកម្រិតមេហ្គាតោនលែងក្លាយជាអាវុធពេញនិយម ពីព្រោះវាមានឥទ្ធិពលខ្លាំងក្លាពេកមិនអាចអោយតួអង្គណាមួយប្រើប្រាស់ប្រកបដោយផលិតភាព និងមានការពិបាកពន់ពេកសម្រាប់ពួកគេវេកឬដ្ឋេតូចៗក្នុងការសាងសង់។

រូបថត «វ៉ាលីគ្រាប់បែកនុយក្លេអ៊ែរនិមិត្ត»

នុយក្លេអ៊ែរនៅក្នុងប្រអប់

អាវុធនុយក្លេអ៊ែរត្រូវបានបង្កើតឡើងក្នុងកំឡុងសង្គ្រាមលោកលើកទី ២ និងត្រូវបានប្រើប្រាស់លើទីក្រុងចំនួនពីររបស់ប្រទេសជប៉ុនក្នុងឆ្នាំ ១៩៤៥។ បច្ចុប្បន្ននេះ អាវុធប្រភេទនេះរាប់ម៉ឺនគ្រាប់ត្រូវបានផលិតហើយរដ្ឋចំនួនប្រាំបួន កាន់កាប់ពួកវា។ ការទទួលបានវត្ថុធាតុដែលអាចបំបែកបានគឺជាការលំបាកខ្លាំង ក្នុង

ការផលិតអាវុធនុយក្លេអ៊ែរ។ កិច្ចខិតខំប្រឹងប្រែងរបស់កេរែកដើម្បីទទួលបានពួកគេ គឺជាការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរ។ នៅទីនេះក្នុងឆ្នាំ ១៩៩៩ សមាជិកសភាអាមេរិកបង្ហាញ«វ៉ាលីគ្រាប់បែកនុយក្លេអ៊ែរ»និមិត្តដែលផលិតដោយសូវៀតដែលអាចសម្លាប់មនុស្សរាប់សែននាក់ ប្រសិនបើវាធ្លាក់ក្នុងដៃកេរែក។

ឥទ្ធិពលនៃអាវុធនុយក្លេអែរ មិនមែនរួមបញ្ចូលត្រឹមតែការផ្ទុះអាវុធប៉ុណ្ណោះទេ ថែមទាំងអនុភាពកំដៅ និងវិទ្យុសកម្មទៀតផង។ កំដៅអាចបង្កើតព្យុះភ្លើងបន្តធាបធេះ នៅក្នុងទីក្រុងណាមួយ។ វិទ្យុសកម្មបង្កើតជំងឺពាក់ព័ន្ធនឹងវិទ្យុសកម្ម ដែលប្រសិនបើប៉ះពាល់ក្នុងកម្រិតខ្ពស់ អាចសម្លាប់មនុស្ស ក្នុងរយៈពេលត្រឹមតែពីរបីថ្ងៃប៉ុណ្ណោះ ហើយប្រសិនបើប៉ះពាល់ក្នុងកម្រិតទាប បង្កអោយមានបញ្ហាសុខភាពរយៈពេលវែង ជាពិសេសជំងឺមហារីក។ វិទ្យុសកម្មបញ្ចេញកម្រិតខ្លាំងបំផុត នៅក្នុងតំបន់ជុំវិញនៃការផ្ទុះនុយក្លេអ៊ែរ (និងក្រោមខ្យល់) ប៉ុន្តែ វិទ្យុសកម្មមួយចំនួនត្រូវបានបញ្ជូនទៅលើបរិយាកាស ហើយធ្លាក់ក្នុងទីតាំងដែលឆ្ងាយ ដោយសារការផ្ទុះនុយក្លេអែរប៉ាត់រ៉ាយ។ អាវុធនុយក្លេអែរក៏បង្កើតជីពចរអេឡិចត្រូម៉ាញ៉េទិច (EMP) ដែលអាចខូចខាន និងបំផ្លាញឧបករណ៍អេឡិចត្រូនិក។

៦.៤.២. មីស៊ីលផ្លោង និងប្រព័ន្ធបញ្ជូនផ្សេងៗទៀត

ប្រព័ន្ធបញ្ជូន (delivery systems)សម្រាប់នាំអាវុធនុយក្លេអែរអោយទៅដល់គោលដៅ (មិនសំដៅត្រឹមតែអាវុធតែម្យ៉ាង) គឺជាមូលដ្ឋាននៃឃ្លាំងអាវុធនុយក្លេអែរនិងយុទ្ធសាស្ត្ររបស់រដ្ឋនានា (នងត្រូវពិភាក្សាធាប់ៗនេះ)។ ដរាបណាក្បាលគ្រាប់នុយក្លេអែរអាចត្រូវបានផលិតក្នុងទំហំតូច ដែលមានទម្ងន់ពីរបីរយផោន ឬស្រាលជាងនេះ ពួកវាអាចសម្របខ្លួនទៅនឹងប្រភេទនៃប្រព័ន្ធបញ្ជូនដ៏សំបូរបែប។

ក្នុងអំឡុងសង្គ្រាមត្រជាក់ ប្រព័ន្ធបញ្ជូននុយក្លេអែរត្រូវបានបែងចែកជាពីរប្រភេទ។ អាវុធនុយក្លេអែរ*យុទ្ធសាស្ត្រ*(strategic)អាចវាយបាញ់ទឹកដីមាតុភូមិរបស់សត្រូវ ជាធម្មតា នៅក្នុងរយៈចម្ងាយឆ្ងាយ (ជាឧទាហរណ៍ ពីទីក្រុងមូស្គូ ទៅកាន់ រដ្ឋនេប្រាស្កា(Nebraska)សហរដ្ឋអាមេរិក)។ អាវុធនុយក្លេអែរ*កលយុទ្ធ* (tactical)ត្រូវបានរចនាឡើងសម្រាប់ប្រើប្រាស់ក្នុងសមរភូមិផ្ទាល់។ ក្នុងបណ្តាឆ្នាំសង្គ្រាមត្រជាក់ ប្រទេសមហាអំណាចទាំងពីរបានរួមបញ្ចូលអាវុធនុយក្លេអែរ*កលយុទ្ធ* ទៅក្នុងកងកម្លាំងដែនអាកាស ដែនទឹក និងដែនគោកទូទៅរបស់ពួកគេ ដោយប្រើប្រព័ន្ធបញ្ជូនផ្សេងៗគ្នា៖ គ្រាប់បែកទំនាញ គ្រាប់កាំភ្លើងធំ កាំជ្រួចរយៈចម្ងាយខ្លី គ្រាប់មីន មីនបង្កប់ក្នុងជម្រៅសមុទ្រជាដើម។ ទោះជាយ៉ាងណាក៏ដោយ ក្បាលគ្រាប់នុយក្លេអែរ រាប់ម៉ឺនគ្រាប់ ដែលដាក់បញ្ចូលទៅក្នុងកងកម្លាំងទូទៅរបស់ប្រទេសមហាអំណាច បានបង្កគ្រោះថ្នាក់ជាច្រើនដូចជា ចោរលួច ឬគ្រោះថ្នាក់ជាឧបទ្ទវហេតុ។ ការប្រើប្រាស់អាវុធទាំងនោះជាក់ស្តែង នឹងនាំអោយមានហានិភ័យធ្ងន់ធ្ងរ រាប់ចាប់ពីការបង្កោះជម្លោះកាន់តែធំរហូតដល់សង្គ្រាមនុយក្លេអែរជាយុទ្ធសាស្ត្រ ដែលធ្វើអោយទីក្រុងនានាក្នុងមាតុភូមិនីមួយៗប្រឈមនឹងហានិភ័យ។ ដូច្នេះហើយ ប្រទេសមហាអំណាចទាំងពីរបានកាត់បន្ថយអាវុធនុយក្លេអែរយុទ្ធសាស្ត្របន្តិចម្តងៗ រហូតបានបញ្ឈប់ស្ទើរតែទាំងអស់ នៅពេលដែលសង្គ្រាមត្រជាក់បានបញ្ចប់។

មធ្យោបាយបញ្ជូនជាយុទ្ធសាស្ត្រដ៏ចំបងបំផុត គឺ**មីស៊ីលផ្លោង** (ballistic missiles) ខុសពីយន្តហោះពួកគេពិបាកការពារខ្លាំងណាស់។ មីស៊ីលឬកាំជ្រួចផ្លោងពាំនាំក្បាលគ្រាប់ឡើងលើអាកាស តាមគន្លងផ្លោង ហើយទុកអោយវាទម្លាក់លើគោលដៅ។ ជាធម្មតា គន្លងផ្លោងមួយហក់ឡើងរំលងបរិយាកាស យ៉ាងហោចណាស់ លើរយៈកំពស់ ៥០ ម៉ាយល៍ មុនពេលធ្លាក់ចុះមកវិញ។ លើសពីនេះ កាំជ្រួចខ្លះបាញ់ចេញពីទីតាំង

កំណត់ណាមួយ (ស៊ីឡូ) ចំណែកខ្លះទៀតមានលក្ខណៈចល័ត ដោយបាញ់ចេញពីផ្លូវដែក ឬ ឡានដឹកទំនិញធំៗ (ធ្វើអោយសត្រូវពិបាកកំណត់គោលដៅបាញ់មុន)។ មីស៊ីលរយៈចម្ងាយឆ្ងាយបំផុត គឺមីស៊ីលផ្លោងអន្តរទ្វីប (ICBMs) ដែលមានរយៈចម្ងាយឆ្ងាយជាង ៥០០០ ម៉ាយ។ ក្នុងឆ្នាំ ២០១៧ ប្រទេសកូរ៉េខាងជើងបានបាញ់សាកល្បងកាំជ្រួច ចំនួន ១៣ ដង ដោយជោគជ័យ រួមទាំង មីស៊ីលផ្លោងអន្តរទ្វីប (ICBMs)ថ្មីដែលធ្វើដំណើរបាន ចម្ងាយ ២៨០០ ម៉ាយល៍ ក្នុងលំហ។ ខណៈពេលដែលអ្នកជំនាញចោទសួរពីភាពជឿជាក់នៃ ICBMs របស់កូរ៉េខាងជើង រួមទាំង ការកំណត់គោលដៅចំៗនិងសមត្ថភាពរបស់ពួកគេ ក្នុងការផ្ទុកបន្ទុកធំៗ វាច្បាស់ណាស់ថា កម្មវិធីមីស៊ីលរបស់ប្រទេសកូរ៉េខាងជើងបានរីកចម្រើន ក្នុងប៉ុន្មានទសវត្សរ៍កន្លងមក។

អ្វីដែលជាទីចាប់អារម្មណ៍ជាពិសេស នាពេលបច្ចុប្បន្ននេះ គឺមីស៊ីលផ្លោងរយៈចម្ងាយខ្លី (SRBMs) ដែលបាញ់ដល់រយៈចម្ងាយឆ្ងាយ ក្រោម ១០០០ ម៉ាយល៍។ កាំជ្រួចកែឆ្នៃ Scud ដែលបាញ់ដោយប្រទេសអ៊ីរ៉ាក់ សំដៅទៅប្រទេសអារ៉ាប៊ីសាអូឌីត និងអ៊ីស្រាអែល ក្នុងអំឡុងសង្គ្រាមឈូងសមុទ្រ គឺជាប្រភេទមីស៊ីលផ្លោងរយៈចម្ងាយខ្លី (បំពាក់ដោយអាវុធធម្មតា)។ នៅក្នុងជម្លោះក្នុងតំបន់ កាំជ្រួចផ្លោងរយៈចម្ងាយឆ្ងាយដែលមានថាមពលខ្លាំងជាងនេះ ប្រហែលជាមិនចាំបាច់នោះទេ។ ទីក្រុងធំបំផុតនៃប្រទេសស៊ីរី និងប្រទេសអ៊ីស្រាអែលមានចម្ងាយត្រឹមតែ ១៣៣ ម៉ាយល៍ ពីគ្នា, រដ្ឋធានីនៃប្រទេសអ៊ីរ៉ាក់ និងប្រទេសអ៊ីរ៉ង់មានចម្ងាយតិចជាង ៥០០ ម៉ាយល៍ពីគ្នា ដូចរយៈចម្ងាយរវាងប្រទេសឥណ្ឌា និងប្រទេសប៉ាគីស្ថានដែរ។ រដ្ឋទាំងអស់នេះមានមីស៊ីលផ្លោង។ កាំជ្រួចផ្លោងរយៈចម្ងាយខ្លីនិងមធ្យមមួយចំនួនមានតម្លៃថោកល្មមអាចទទួលបាន ហើយថែមទាំងអាចផលិតបាននៅក្នុងស្រុក ដោយរដ្ឋតូចៗដែលមានចំណូលមធ្យមកម្រិតទៀតផង។ តារាង ៦.៣ ខាងលើ រាយបញ្ជីសមត្ថភាពរបស់រដ្ឋទាំង ៣២ ដែលមានកាំជ្រួចផ្លោង។

កាំជ្រួចផ្លោងរយៈចម្ងាយខ្លីជាច្រើន រួមទាំងកាំជ្រួចដែលប្រើដោយប្រទេសអ៊ីរ៉ាក់ កំឡុងសង្គ្រាមឈូងសមុទ្រ មិនសូវកំណត់គោលដៅបានចំល្អនោះទេ ប៉ុន្តែ គេនៅតែពិបាករារាំងវាខ្លាំងណាស់។ ជាមួយនឹងក្បាលគ្រាប់ធម្មតា អាវុធទាំងនេះបម្រើមុខងារចិត្តសាស្ត្រច្រើនជាងជាឧបករណ៍ប្រើប្រាស់សម្រាប់យោធា (ធ្វើអោយប្រជាជនភ័យស្លន់ស្លោ ខូចសណ្តាប់ធ្នាប់ ដោយសារការវាយប្រហារទីក្រុងដោយមិនរើសអើង)។ ជាមួយនឹងក្បាលគ្រាប់នុយក្លេអ៊ែរ គីមីសាស្ត្រ ឬជីវសាស្ត្រ ទោះជាយ៉ាងណាក៏ដោយ កាំជ្រួចទាំងនេះអាចបង្កការស្លាប់បាត់បង់ជីវិតច្រើនជាង។ ការកំណត់គោលដៅចំៗនៃប្រព័ន្ធបញ្ជូនមីស៊ីលគ្រប់កម្រិត(រយៈចម្ងាយ) មានភាពប្រសើរឡើង នៅពេលដែលការផ្លាស់ប្តូរទៅកាន់ប្រទេសមហាអំណាច ជាពិសេសសហរដ្ឋអាមេរិក។ បន្ទាប់ពីធ្វើដំណើររាប់ពាន់ម៉ាយល៍ កាំជ្រួចរបស់អាមេរិកល្អបំផុតអាចចុះចត ក្នុងរយៈកំពស់ ៥០ ហ្វីត ពីគោលដៅចំនួន៥0%។ និន្នាការនៅក្នុងឃ្លាំងអាវុធនុយក្លេអ៊ែររបស់សហរដ្ឋអាមេរិក ឆ្ពោះទៅរកក្បាលគ្រាប់ដែលមានថាមពលតិចជាង ប៉ុន្តែ កាំជ្រួចដែលកំណត់គោលបានត្រឹមត្រូវជាង សម្រាប់បត់បែនបានគ្រប់កាល:ទេស:។

កាំជ្រួចហោះ (cruise missile) គឺជាកាំជ្រួចដែលមានស្លាបតូច ដែលអាចធ្វើដំណើរឆ្លងកាត់ចម្ងាយរាប់ពាន់ម៉ាយល៍ពីដីដែលបានគូសផែនទីទុកមុន ដើម្បីទៅដល់គោលដៅជាក់លាក់ណាមួយ ដោយមានជំនួយពីផ្កាយរណប។ កាំជ្រួចហោះ អាចត្រូវបានបាញ់ចេញពីកប៉ាល់ នាវាជ្រមុជទឹក យន្តហោះ ឬដីគោក។ សហរដ្ឋអាមេរិកបានប្រើប្រាស់កាំជ្រួចហោះយ៉ាងទូលំទូលាយប្រឆាំងនឹង ប្រទេសអ៊ីរ៉ាក់ ក្នុងឆ្នាំ ១៩៩៣ បាញ់កងកម្លាំងស៊ែប៊ីនៅបូស្នៀ ក្នុងឆ្នាំ ១៩៩៥, បាញ់ស៊ែប៊ី ក្នុងឆ្នាំ ១៩៩៩ និង បាញ់អ៊ីរ៉ាក់ក្នុងឆ្នាំ ២០០៣។

តារាង ៦.៣ សមត្ថភាពមីស៊ីលផ្លោងឆ្នាំ ២០១៨

ប្រទេស	រយៈចម្ងាយ(ម៉ាយល៍)	គោលដៅសក្តានុពល
សហរដ្ឋអាមេរិក[ក]	១៣ ០០០	(ពិភពលោក)
រុស្ស៊ី[ក]	១៣ ០០០	(ពិភពលោក)
ចិន[ក]	១៣ ០០០	(ពិភពលោក)
កូរ៉េខាងជើង[ក]	១៣ ០០០	(ពិភពលោក)
អង់គ្លេស[ក]	៤ ៦០០	(ពិភពលោក, បាញ់ចេញពីនាវាជ្រមុជទឹក)
បារាំង[ក]	៣ ៧០០ [៤ ៦០០]	(ពិភពលោក, បាញ់ចេញពីនាវាជ្រមុជទឹក)
អ៊ីរ៉ង់[ខ, គ]	៩០០ [៣ ៥០០]	អ៊ីរ៉ាក់ គុយវ៉ែត អាហ្វហ្គានីស្ថាន អ៊ីស្រាអែល [អឺរ៉ុប ទៅ អាស៊ី]
អ៊ីស្រាអែល[ក, គ]	៩០០ [៣ ៥០០]	ស៊ីរី អ៊ីរ៉ាក់ អារ៉ាប៊ីសាអូឌីត អេហ្ស៊ីប [អ៊ីរ៉ង់]
ឥណ្ឌា[ក, គ]	១ ៥០០ [២ ៥០០]	ប៉ាគីស្ថាន ចិន អាហ្វហ្គានីស្ថាន អ៊ីរ៉ង់ ទួរគី
ប៉ាគីស្ថាន[ក]	៨០០ [២ ០០០]	ឥណ្ឌា [រុស្ស៊ី ទួរគី អ៊ីស្រាអែល]
អារ៉ាប៊ីសាអូឌីត	១ ៣០០	អ៊ីរ៉ង់ អ៊ីរ៉ាក់ ស៊ីរី អ៊ីស្រាអែល ទួរគី យេម៉ែន អេហ្ស៊ីប លីប៊ី ស៊ូដង់
ស៊ីរី	៣០០ [៤០០]	អ៊ីស្រាអែល ហ្ស៊ក់ដានី អ៊ីរ៉ាក់ ទួរគី
អេហ្ស៊ីប	៤០០	លីប៊ី ស៊ូដង់ អ៊ីស្រាអែល
យេម៉ែន	៣០០	អារ៉ាប៊ីសាអូឌីត
លីប៊ី	២០០	អេហ្ស៊ីប ទុយនីស៊ី អាល់ហ្សេរី
អារ៉ាប់រួម	២០០	អារ៉ាប៊ីសាអូឌីត អ៊ីរ៉ង់
អាហ្វហ្គានីស្ថាន	២០០	ប៉ាគីស្ថាន តាជីគីស្ថាន អ៊ូសបេគីស្ថាន
កាហ្សាក់ស្ថាន	២០០	អ៊ូសបេគីស្ថាន តាជីគីស្ថាន កៀហ្ស៊ីស៊ីស្ថាន រុស្ស៊ី
រ៉ូម៉ានី	២០០	អ៊ុយក្រែន ហុងគ្រី
ទួរមិននីស្ថាន	២០០	អ៊ីរ៉ង់ អាហ្វហ្គានីស្ថាន អ៊ូសបេគីស្ថាន តាជីគីស្ថាន
អាមេនី	២០០	អាសែរបៃហ្សង់
បេឡារុស	២០០	រុស្ស៊ី អ៊ុយក្រែន ប៉ូឡូញ
អ៊ុយក្រែន	២០០	រុស្ស៊ី បេឡារុស្ស ប៉ូឡូញ ហុងគ្រី រូម៉ានី
ហ្សកហ្ស៊ី	២០០	រុស្ស៊ី អាមេនី តួកគី
កូរ៉េខាងត្បូង	២០០	កូរ៉េខាងជើង
វៀតណាម	២០០	ចិន កម្ពុជា
បារ៉ែន	២០០	អារ៉ាប៊ីសាអូឌីត កាតា
តៃវ៉ាន់	២០០	ចិន
ក្រិក	១០០	ទួរគី
ទួរគី	១០០	ក្រិក

អ៊ីរ៉ាក់	១០០	អ៊ីរ៉ង់ ស៊ីរី អារ៉ាប៊ីសាអូឌីត
ស្លូវ៉ាគី	៨០	សាធារណរដ្ឋឆេក ហុងគ្រី ប៉ូឡូញ
ជប៉ុន[គ]	--	--
ចំនួនរដ្ឋមានមីស៊ីលផ្លោង៖ ៣២		

ក ប្រទេសដែលមានអាវុធនុយក្លេអ៊ែរ។
ខ រដ្ឋដែលគេជឿថាកំពុងព្យាយាមបង្កើតអាវុធនុយក្លេអ៊ែរ។
គ រដ្ឋកំពុងអភិវឌ្ឍកាំជ្រួចបាញ់បង្ហោះក្នុងលំហ ដែលអាចសម្របខ្លួនបានដូចមីស៊ីលផ្លោងរយៈចម្ងាយឆ្ងាយ។
- *កំណត់សម្គាល់*៖ លេខជួរតង្កៀបបង្ហាញពីមីស៊ីលដែលកំពុងអភិវឌ្ឍ។
- បញ្ជីនៃគោលដៅដែលមានសក្តានុពល រួមមានទាំងរដ្ឋអរិភាព និងជាមិត្ត ហើយ មានលក្ខណៈជាតម្រុយជាជាងជាក់ស្តែង។
- រយៈចម្ងាយមីស៊ីល កាន់តែឆ្ងាយ ជាមួយនឹងបន្ទុកគ្រាប់តូចជាង។ រយៈចម្ងាយ ២០០ ម៉ាយល៍ (Scud-B) និងរយៈចម្ងាយ ៣០០ ម៉ាយល៍ (Scud Mod-C) ប្រហាក់ប្រហែលសម្រាប់បន្ទុកគ្រាប់បីភាគបួនតោន។ រយៈចម្ងាយអារ៉ាប៊ីសាអូឌីតគឺសម្រាប់បន្ទុកពីរតោន; រយៈចម្ងាយរបស់កូរ៉េខាងត្បូងគឺសម្រាប់បន្ទុកកន្លះតោន។
ប្រភព៖ ផ្អែកលើ Carnegie Endowment of International Peace។

ការរីករាលដាលនៃកាំជ្រួចផ្លោងបង្កការលំបាកក្នុងការគ្រប់គ្រងមែនទែន។ តាមរយៈ**របបគ្រប់គ្រងបច្ចេកវិទ្យាមីស៊ីល** (Missile Technology Control Regime) រដ្ឋឧស្សាហូបនីយកម្មទាំងឡាយព្យាយាមកំណត់លំហូរនៃបច្ចេកវិទ្យាពាក់ព័ន្ធនឹងមីស៊ីល ទៅកាន់រដ្ឋនានា នៅអឌ្ឍគោលខាងត្បូង ប៉ុន្តែ ពួកគេបានទទួលជោគជ័យនៅមានកម្រិតនៅឡើយ។ កាំជ្រួចរយៈចម្ងាយមធ្យម (មានរយៈចម្ងាយរហូតដល់ ២០០០ ម៉ាយល៍) ជាក់ស្តែងកំពុងត្រូវបានអភិវឌ្ឍ ដោយប្រទេសអ៊ីរ៉ង់ អ៊ីស្រាអែល អារ៉ាប៊ីសាអូឌីត ប៉ាគីស្ថាន ឥណ្ឌា កូរ៉េខាងជើង និងប្រហែលជា ប្រទេសអាហ្សង់ទីន និងប្រេស៊ីល។ ក្នុងឆ្នាំ ២០០៩ ប្រទេសអ៊ីរ៉ង់បានធ្វើអោយលោកខាងលិចព្រួយបារម្ភ ដោយការសាកល្បងកាំជ្រួចដែលអាចទៅដល់ប្រទេសអេហ្ស៊ីប អ៊ីស្រាអែល និងផ្នែកខ្លះនៃទ្វីបអឺរ៉ុប។

រដ្ឋតូចៗ ឬក្រុមភេរវករ ដែលអាចទទួលបានអាវុធនុយក្លេអ៊ែរ នៅពេលអនាគត អាចបញ្ជូនអាវុធទាំងនោះ តាមរយៈមធ្យោបាយច្នៃប្រឌិតនានា។ ដោយសារអាវុធនុយក្លេអ៊ែរមានទំហំតូច វាអាចត្រូវបាន រត់ពន្ធចូលទៅក្នុងរដ្ឋគោលដៅ ដោយរថយន្ត ទូកល្បឿនលឿន ឬក្នុងកាបូបការទូត។

ចាប់តាំងពីឆ្នាំ ២០០១ សហរដ្ឋអាមេរិកបានដំណើរការគំនិតផ្តួចផ្តើមសន្តិសុខកុងតឺន័រ ក្នុងគោលដៅរារាំងអាវុធប្រល័យលោក មិនអោយទៅដល់ឆ្នេរសមុទ្រសហរដ្ឋអាមេរិក នៅក្នុងកុងតឺន័រដឹកជញ្ជូនតាមផ្លូវសមុទ្រ។ ប៉ុន្តែ ការធ្វើដូច្នេះដោយមិនរារាំងលំហូរពាណិជ្ជកម្មអន្តរជាតិដែលនាំមកនូវវិបុលភាព គឺជាបញ្ហាប្រឈមដ៏គួរអោយភ័យខ្លាច៖ កុងតឺន័រដឹកជញ្ជូនទំនិញចំនួនជិត ៨ លាន ឆ្លងកាត់តាមរយៈកំពង់ផែសហរដ្ឋអាមេរិក ជារៀងរាល់ឆ្នាំ។ ក្នុងឆ្នាំ ២០០៦ សភាសហរដ្ឋអាមេរិកបានបំបែកកិច្ចព្រមព្រៀងមួយ ដែលអាចនឹងអនុញ្ញាតអោយក្រុមហ៊ុនមួយ ដែលមានមូលដ្ឋាននៅទីក្រុងឌូបៃ ដែលជាប្រទេសអារ៉ាប់មួយ គ្រប់គ្រងប្រតិបត្តិការមួយចំនួន នៅកំពង់ផែសហរដ្ឋអាមេរិកជាច្រើន (ដូចក្រុមហ៊ុនបរទេសផ្សេងទៀតបានធ្វើរួចហើយ)។

៦.៤.៣. អាវុធគីមី និងជីវសាស្ត្រ

អាវុធគីមីបញ្ចេញសារធាតុគីមីដែលធ្វើអោយមនុស្សរងរបួស ពិការ និងរហូតដល់ស្លាប់។ សារធាតុគីមីនីមួយៗ មានលក្ខណៈសម្បត្តិខុសៗគ្នា សារធាតុខ្លះប៉ះពាល់ដល់អាយុជីវិតមនុស្ស ដូចជាឧស្ម័នសរសៃប្រសាទ រីឯ សារធាតុខ្លះទៀតរំខានដល់អារម្មណ៍មនុស្ស ដូចជាឧស្ម័នបង្ហូរទឹកភ្នែក ជាដើម។ សារធាតុគីមីផ្សេងៗរំខាន ដល់ប្រព័ន្ធសរសៃប្រសាទ ប្រព័ន្ធសរសៃឈាម ប្រព័ន្ធដង្ហើម ឬមុខងាររាងកាយផ្សេងទៀត។ សារធាតុមួយ ចំនួនអាចត្រូវបានស្រូបតាមរយៈស្បែក ខ្លះទៀតត្រូវតែស្រូបចូលតាមផ្លូវដង្ហើម។ សារធាតុខ្លះបន្តនៅក្នុង បរិយាកាសយ៉ាងយូរ បន្ទាប់ពីការប្រើប្រាស់ សារធាតុខ្លះទៀតសាយភាយឬរលាយយ៉ាងលឿន។

មានវិធានការណ៍ជាក់ស្តែងដើម្បីការពារប្រឆាំងនឹងអាវុធគីមីភាគច្រើន ដោយគ្រាន់តែអោយទាហាន ស្លៀកពាក់សម្លៀកបំពាក់ការពារ និងពាក់ម៉ាស់ឬបាំងឧស្ម័ន និងអនុវត្តតាមនីតិវិធីហ្មត់ចត់បំផុតដើម្បីកំចាត់ មេរោគជាមុន។ ប៉ុន្តែ ឈុតការពារទាំងអស់នោះក្តៅស្អុះខ្លាំង ហើយវិធានការប្រឆាំងសារធាតុគីមីកាត់បន្ថយ ប្រសិទ្ធភាពកងទ័ព។ លើសពីនេះ ជនស៊ីវិលទាំងឡាយទំនងជាមានការការពារប្រឆាំងនឹងសារធាតុគីមីតិច ជាងកងកម្លាំងយោធា។ តាមលក្ខណៈធម្មជាតិ អាវុធគីមីសម្លាប់មនុស្សដោយមិនរើសមុខឡើយ។ ជាច្រើន លើកច្រើនសារ អាវុធគីមីត្រូវបានប្រើប្រាស់ដោយចេតនាប្រឆាំងនឹងជនស៊ីវិល (ជាពិសេសដោយ រដ្ឋាភិបាល អ៊ីរ៉ាក់ប្រឆាំងនឹងជនជាតិអ៊ីរ៉ាក់ដើមកំណើតឃឺដ ក្នុងទសវត្សរ៍ឆ្នាំ ១៩៨០)។

រូបថត ជនរងគ្រោះដោយអាវុធគីមីសម្រាកព្យាបាលនៅមន្ទីរពេទ្យ

ភាពងាយរងគ្រោះ

ជនស៊ីវិលងាយនឹងរងគ្រោះដោយអាវុធប្រល័យលោក ជាពិសេសអាវុធគីមី។ នៅទីនេះ ជនរងគ្រោះ ដែលប្រឈមនឹងការវាយប្រហារគីមីដោយក្រុមរដ្ឋអ៊ីស្លាម ត្រូវបានព្យាបាលនៅមន្ទីរពេទ្យមួយ នៅភាគខាង ជើងនៃប្រទេសអ៊ីរ៉ាក់ ឆ្នាំ ២០១៦។

គួរអោយភ្ញាក់ផ្អើល គេកម្រប្រើអាវុធគីមីក្នុងសង្គ្រាមណាស់។ ឧស្ម័នស្ពាន់ធ័រ mustard ដែលបង្ករោគ ពងបែកលើស្បែក និងធ្វើអោយខូចខាតសួត ត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយ នៅក្នុងគ្រាប់កាំភ្លើងធំ នៅក្នុងសង្គ្រាមលោកលើកទី ១។ បន្ទាប់ពីភាពភ័យរន្ធត់នៃសង្គ្រាមនោះ ការប្រើប្រាស់អាវុធគីមីត្រូវបានហាមឃាត់ នៅក្នុងពិធីសារទីក្រុងហ្សឺណែវ ឆ្នាំ ១៩២៥ ដែលនៅតែមានសុពលភាពដល់សព្វថ្ងៃនេះ។ ក្នុងសង្គ្រាម លោកលើកទី២ ភាគីទាំងសងខាងត្រូវបានបំពាក់ដោយអាវុធគីមី ប៉ុន្តែ មិនបានប្រើប្រាស់ឡើយ ព្រោះ ខ្លាចមានការសងសឹក។ ចាប់តាំងពីពេលនោះមក (ជាមួយនឹងករណីលើកលែងមិនច្បាស់លាស់មួយចំនួន) មានតែប្រទេសអ៊ីរ៉ាក់ប៉ុណ្ណោះដែលបានរំលោភលើសន្ធិសញ្ញា សម្រាប់ប្រឆាំងនឹងប្រទេសអ៊ីរ៉ង់ ក្នុងទសវត្សរ៍ឆ្នាំ ១៩៨០។ ជាអកុសល សកម្មភាពគឃ្លើនរបស់ប្រទេសអ៊ីរ៉ាក់មិនត្រឹមតែរំលោភលើរបាំងផ្លូវចិត្តប្រឆាំងនឹងការ ប្រើប្រាស់អាវុធគីមីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្ហាញថាអាវុធបែបនេះមានតម្លៃថោក និងមានប្រសិទ្ធភាព ប្រឆាំងនឹងរលកកងទ័ពមកវាយប្រហារដែលគ្មានឧបករណ៍ការពារ។ ឧទាហរណ៍នេះបានជំរុញរដ្ឋក្រីក្រចំនួន បួនដប់ផ្សេងទៀតចាប់ផ្តើមប្រឹងប្រែងរកអាវុធគីមី។ អាវុធគីមី គឺជាមធ្យោបាយថោកសម្រាប់រដ្ឋដើម្បីទទួល បានអាវុធប្រល័យលោក។ អាវុធគីមីអាចត្រូវបានផលិត ដោយប្រើដំណើរការនិងមធ្យោបាយស្រដៀងគ្នាទៅ នឹងថ្នាំសម្លាប់សត្វល្អិត ឱសថ និងផលិតផលស៊ីវិលដទៃទៀត ដែលធ្វើអោយវាពិបាកក្នុងការស្វែងរកកន្លែង

ប្រើប្រាស់អាវុធគីមី នៅក្នុងប្រទេសដែលសង្ស័យ ឬបដិសេធរដ្ឋទាំងនោះក្នុងការទទួលបានសារធាតុគីមី និងវត្ថុធាតុដើមដទៃទៀតដែលត្រូវការជាចាំបាច់ដើម្បីផលិតអាវុធគីមី។

ពិធីសារទីក្រុងហ្សឺណែវឆ្នាំ ១៩២៥ មិនបានហាមឃាត់ការផលិត ឬការកាន់កាប់អាវុធគីមីទេ បានត្រឹមហាមឃាត់ការប្រើប្រាស់តែប៉ុណ្ណោះ ហើយមានរដ្ឋជាច្រើនបានសាងសង់ឃ្លាំងផ្ទុកអាវុធគីមីទាំងនោះ។ សហរដ្ឋអាមេរិកនិងសហភាពសូវៀតបានរក្សាឃ្លាំងអាវុធគីមីដ៏ធំ ក្នុងអំឡុងពេលសង្គ្រាមត្រជាក់ ប៉ុន្តែបានកាត់បន្ថយអាវុធគីមីទាំងនោះ យ៉ាងច្រើន ក្នុងរយៈពេលពីរទសវត្សរ៍កន្លងទៅនេះ។ ឆ្នាំ ១៩៩២ **អនុសញ្ញាស្តីពីអាវុធគីមី** ដើម្បីហាមឃាត់ការផលិតនិងការកាន់កាប់អាវុធគីមី ត្រូវបានចុះហត្ថលេខា ដោយប្រទេសមហាអំណាចទាំងអស់និងស្ទើរតែគ្រប់រដ្ឋផ្សេងទៀត ដោយមានករណីលើកលែងមួយចំនួន រួមមានអេហ្ស៊ីប អង់ហ្គោឡា និងកូរ៉េខាងជើង។ សន្ធិសញ្ញាថ្មីនេះរួមមានបទប្បញ្ញត្តិការផ្ទៀងផ្ទាត់យ៉ាងតឹងរ៉ឹង និងការគំរាមកំហែងក្នុងការដាក់ទណ្ឌកម្មប្រឆាំងនឹងភាគីបំពាន រួមទាំងរដ្ឋដែលមិនចូលរួមក្នុងសន្ធិសញ្ញា (វិសោធនកម្មបន្ថែមដ៏សំខាន់មួយ)។ រដ្ឋជាច្រើន (រួមទាំងឥណ្ឌា ចិន កូរ៉េខាងត្បូង បារាំង និងអង់គ្លេស) បានទទួលស្គាល់ថាមានកម្មវិធីអាវុធគីមីសម្ងាត់ ដែលឥឡូវនេះ កំពុងត្រូវបានរុះរើ ក្រោមការត្រួតពិនិត្យអន្តរជាតិ។ ប្រទេសរុស្ស៊ីនៅតែប្រឈមមុខនឹងទំងន់កិច្ចការចំណាយច្រើននិងចំណាយពេលយូរ ក្នុងការបំផ្លាញឃ្លាំងអាវុធគីមីទម្ងន់ ៤៤០០០ តោន ដែលត្រូវបានសាងសង់ ក្នុងអំឡុងសង្គ្រាមត្រជាក់ យ៉ាងណាក៏ដោយ នៅក្នុងខែកញ្ញាឆ្នាំ ២០១៧ បានប្រកាសថាខ្លួនបានបញ្ចប់កិច្ចការនោះហើយ។ សហរដ្ឋអាមេរិកមានពេលវេលារហូតដល់ឆ្នាំ ២០២៣ ដើម្បីបញ្ចប់ការកម្ទេចខ្លាំងអាវុធគីមីរបស់ខ្លួន។ ចាប់តាំងពីឆ្នាំ ១៩៩៧ ដល់ឆ្នាំ ២០១៦ អង្គការសន្ធិសញ្ញានេះបានត្រួតពិនិត្យការលុបបំបាត់ជាងពាក់កណ្តាលនៃអាវុធគីមីក្នុងពិភពលោក (ជិត ៧០០០០ តោន)។

ក្នុងឆ្នាំ ២០១៣ ប្រទេសស៊ីរីបានទទួលស្គាល់ថាមានអាវុធគីមី និងបានយល់ព្រម បំផ្លាញអាវុធរបស់ខ្លួន ដែលធ្លាប់ត្រូវបានប្រើប្រឆាំងនឹងក្រុមឧទ្ទាម នៅក្នុងសង្គ្រាមស៊ីវិលរបស់ប្រទេសនោះ។ ជាអកុសល ចាប់តាំងពីឆ្នាំ ២០១៣ មក មានការសង្ស័យថាមានការប្រើប្រាស់អាវុធគីមីជាច្រើន នៅក្នុងប្រទេសស៊ីរី និងនៅក្នុងប្រទេសអ៊ីរ៉ាក់ ដែលនៅជិតខាង។ នៅឆ្នាំ ២០១៦ អង្គការសហប្រជាជាតិបានស្តីបន្ទោសរដ្ឋាភិបាលស៊ីរីដែលបានប្រើប្រាស់អាវុធគីមី ក្នុងឆ្នាំ ២០១៤ និង ២០១៥ ហើយបានបន្ទោសក្រុមរដ្ឋអ៊ីស្លាមដែលបានប្រើប្រាស់ឧស្ម័នស្ពាន់ធ័រ mustard នៅឆ្នាំ ២០១៥ ។ ក្រោយមក នៅឆ្នាំ ២០១៨ សហរដ្ឋអាមេរិកបានទម្លាក់គ្រាប់បែកលើគោលដៅស៊ីរី ជាការឆ្លើយតបទៅនឹងការប្រើប្រាស់អាវុធគីមីដោយរដ្ឋាភិបាលស៊ីរី។

អាវុធជីវសាស្ត្រ(biological weapons) មានលក្ខណៈស្រដៀងនឹងអាវុធគីមីដែរ ប៉ុន្តែពួកវាប្រើប្រាស់មីក្រូសរីរាង្គឬជាតិពុលពិឃាត ដែលទទួលបានពីជីវសាស្ត្រ។ អាវុធខ្លះប្រើប្រាស់មេរោគ ឬបាក់តេរី ដែលបង្កអោយមានជំងឺធ្ងន់ធ្ងរ ដូចជា ជំងឺអុតស្វាយ ប៉េស្ត និងជំងឺបូសកញ្ជ្រឹ។ អាវុធខ្លះទៀតបង្កជំងឺមិនបណ្តាលអោយស្លាប់ទេប៉ុន្តែធ្វើអោយពិការអសមត្ថភាព ឬបង្កជំងឺដែលសម្លាប់សត្វពាហនៈ។ តាមទ្រឹស្តី ត្រឹមតែអាវុធមួយក៏អាចបង្កអោយមានជំងឺឆ្លងរីករាលដាល នៅក្នុងចំណោមប្រជាជនទាំងមូល ប៉ុន្តែវានឹងបង្កគ្រោះថ្នាក់ខ្លាំងពេកដូច្នេះហើយ គេនិយមប្រើមីក្រូសរីរាង្គដែលមិនសូវឆ្លងរាលដាលច្រើន។ សព្វាវុធជីវសាស្ត្រស្ទើរតែមិនដែលប្រើក្នុងសង្គ្រាម(ជប៉ុនបានសាកល្បងប្រើខ្លះនៅលើភូមិមួយចំនួនក្នុងប្រទេសចិន ក្នុងសង្គ្រាមលោកលើកទី២)។

សក្តានុពលនៃអាវុធជីវសាស្ត្រធ្វើអោយមេដឹកនាំនយោបាយជាច្រើនចាត់ទុកវាដូចជាប្រអប់ទិព (Pandora) ដែលអាចបញ្ចេញមហិទ្ធិវិទ្ធិជ្រុលដែលមិនអាចគ្រប់គ្រងបាន ប្រសិនបើប្រអប់ទិពត្រូវបានបើក។

ដោយសារហេតុផលនេះហើយ ទើបការអភិវឌ្ឍន៍ ការផលិត និងការកាន់កាប់អាវុធជីវសាស្ត្រត្រូវបានហាមឃាត់ ក្រោមអនុសញ្ញាអាវុធជីវសាស្ត្រ ឆ្នាំ ១៩៧២ ដែលចុះហត្ថលេខាដោយប្រទេសជាង ១០០ រួមទាំងប្រទេសមហាអំណាចផងដែរ។ ប្រទេសមហាអំណាចបានបំផ្លាញស្តុកអាវុធជីវសាស្ត្ររបស់ពួកគេ ហើយត្រូវដាក់កម្រិតលើរោងចក្រអាវុធជីវសាស្ត្ររបស់ពួកគេសម្រាប់តែការស្រាវជ្រាវការពារទុកមុន ជាជាងការអភិវឌ្ឍអាវុធ។ ទោះជាយ៉ាងណាក៏ដោយ ដោយសារតែសន្ធិសញ្ញានេះមិនបានចែងអំពីតម្រូវការត្រួតពិនិត្យ និងដោយសារតែកម្មវិធីអាវុធជីវសាស្ត្រ ដូចជាអាវុធគីមីដែរ ងាយស្រួលលាក់បាំង រដ្ឋមួយចំនួននៅតែស្ថិតក្រោមការសង្ស័យថាមានអាវុធជីវសាស្ត្រ។ ការត្រួតពិនិត្យរបស់អង្គការសហប្រជាជាតិទៅលើប្រទេសអ៊ីរ៉ាក់ នៅពាក់កណ្តាលទសវត្សរ៍ ឆ្នាំ ១៩៩០ បានរកឃើញកម្មវិធីអាវុធជីវសាស្ត្រសកម្មមួយ។ កស្តុតាងបានលេចឡើងបន្ទាប់ពីការដួលរលំសហភាពសូវៀត ដែលបញ្ជាក់ថា កម្មវិធីអាវុធជីវសាស្ត្រសម្ងាត់មួយក៏បានប្រព្រឹត្តទៅនៅទីនោះផងដែរ។ ក្នុងឆ្នាំ ២០០១ សហរដ្ឋអាមេរិកបានដកខ្លួនចេញពីការពិភាក្សាដើម្បីពង្រឹងសន្ធិសញ្ញាឆ្នាំ ១៩៧២ ដោយប្រកាសថាវិសោធន៍កម្មដែលបានស្នើឡើង មិនអាចដំណើរការបានទេ។

សព្វថ្ងៃនេះ សហរដ្ឋអាមេរិក និងប្រហែលជាប្រទេសមួយចំនួនទៀត បន្តការស្រាវជ្រាវអាវុធជីវសាស្ត្រ (ដែលមិនត្រូវបានហាមឃាត់ដោយសន្ធិសញ្ញាខាងលើ)។ អ្នកស្រាវជ្រាវព្យាយាមអះអាងពីផលប៉ះពាល់លើយោធាដោយភាពជឿនលឿនក្នុងបច្ចេកវិទ្យាជីវសាស្ត្រ។

៦.៤.៤. ការរីកសាយភាយ

នៅក្នុងសៀវភៅសិក្សានេះ **ការរីកសាយភាយ** (proliferation) ចង់សំដៅទៅលើការរីករាលដាលនៃអាវុធប្រល័យលោក (អាវុធនុយក្លេអ៊ែរ កាំជ្រួចផ្លោង និងអាវុធគីមី ឬជីវសាស្ត្រ) ទៅដល់កណ្តាប់ដៃរបស់តួអង្គកាន់តែច្រើន។ ផលវិបាកនៃការរីកសាយភាយសម្រាប់ទំនាក់ទំនងអន្តរជាតិគឺពិបាកនឹងទស្សន៍ទាយ ប៉ុន្តែមានវិសាលភាពធំធេង។ កាំជ្រួចឬមីស៊ីលផ្លោងភ្ជាប់ជាមួយនឹងអាវុធប្រល័យលោកកំទេចប្រព័ន្ធការពារទឹកដីដែលផ្តល់ដោយព្រំដែនរដ្ឋ និងធ្វើអោយរដ្ឋនីមួយៗងាយរងគ្រោះដោយរដ្ឋដទៃ។ អ្នកប្រាកដនិយមមួយចំនួនដែលជឿលើភាពសមហេតុផលនៃសកម្មភាពរបស់រដ្ឋ មិនសូវមានការខកចិត្តជាមួយនឹងផលវិបាកដែលត្រូវគេរំពឹងទុកនេះទេ ហើយអ្នកខ្លះទៀតថែមទាំងស្វាគមន៍លទ្ធផលបែបនេះផងដែរ។ ពួកគេលើកហេតុផលថា ក្នុងពិភពលោក ដែលមានការប្រើប្រាស់យោធាកម្លាំង អាចនាំទៅរកការបំផ្លិចបំផ្លាញទៅវិញទៅមក នឹងមានសង្គ្រាមតិចជាងមុន ដូចក្នុងអំឡុងពេលប្រណាំងប្រជែងសព្វាវុធក្នុងសម័យសង្គ្រាមត្រជាក់ ប្រទេសមហាអំណាចទាំងពីរមិនបានបាញ់កំទេចគ្នាទៅវិញទៅមកទេ។ អ្នកប្រាជ្ញទំនាក់ទំនងអន្តរជាតិផ្សេងទៀត ដែលមិនសូវមានជំនឿលើសនិទានភាពនៃអ្នកដឹកនាំរដ្ឋមានការភ័យព្រួយចំពោះការរីកសាយភាយ កាន់តែខ្លាំងឡើង។ ពួកគេព្រួយបារម្ភថា ជាមួយនឹងតួអង្គមានអាវុធនុយក្លេអ៊ែរ(ឬគីមី/ជីវសាស្ត្រ)កាន់តែច្រើន ទោះដោយការគណនាខុស ឬ ដោយឧបទ្ទវហេតុ ឬដោយអំពើភេរវកម្មនិយម អាចនាំអោយមានការប្រើប្រាស់អាវុធប្រល័យលោក ក្នុងបរិមាណដែលមើលមិនមាន ចាប់តាំងពីឆ្នាំ ១៩៤៥។

មេដឹកនាំនៃប្រទេសមហាអំណាចមានទំនោរទៅខាងក្រុមមតិទីពីរ។ ពួកគេបានព្យាយាមដាក់កម្រិតអាវុធដែលអាចបង្កការបំផ្លិចបំផ្លាញខ្លាំងបំផុតចំពោះប្រទេសមហាអំណាច។ ការរីកសាយភាយអាវុធបែបនេះ

អាចបំផ្លាញអានុភាពរបស់ប្រទេសមហាអំណាច បើធៀបនឹងប្រទេសអំណាចមធ្យម។ មានការភ័យខ្លាចយ៉ាងទូលំទូលាយថា អាវុធទាំងនេះ អាចធ្លាក់ទៅក្នុងដៃភេរវករ ឬតួអង្គមិនមែនរដ្ឋផ្សេងទៀត ដែលមិនខ្លាចរអារនឹងការគំរាមកំហែងការសងសឹក (ព្រោះពួកគេគ្មានទឹកដីឬទីក្រុងត្រូវការពារ)ឡើយ។ ភ័ស្តុតាងដែលចាប់បានក្នុងអំឡុងសង្គ្រាម ឆ្នាំ ២០០១ នៅប្រទេសអាហ្វហ្គានីស្ថាន បានបង្ហាញថា អង្គការអាល់កៃដាកំពុងព្យាយាមដើម្បីទទួលបានអាវុធប្រល័យលោក ហើយនឹងមានឆន្ទៈប្រើប្រាស់វាភ្លាមៗ។ សន្តិសុខធូរលុងនៅអតីតបរិវេណរោងចក្រនុយក្លេអ៊ែរសូវៀតដ៏ធំនិងនៅឆ្ងាយបានបង្កើនការភ័យខ្លាចថា វត្ថុធាតុដើមដែលអាចផ្ទុះ អាចនឹងធ្លាក់ទៅក្នុងកណ្តាប់ដៃពួកភេរវករ។

ការរីកសាយភាយនុយក្លេអ៊ែរអាចកើតឡើង នៅពេលដែលតួអង្គរដ្ឋ ឬតួអង្គមិនមែនរដ្ឋ ណាមួយបានទិញ(ឬលួច)អាវុធនុយក្លេអ៊ែរមួយឬច្រើន ឬទទួលបានធាតុផ្សំដើម្បីសាងសង់។ មធ្យោបាយដើម្បីទប់ស្កាត់ការរីកសាយភាយ រួមមាន ការស៊ើបការណ៍សម្ងាត់ វិធានការសន្តិសុខតឹងរ៉ឹង និងយន្តការការពារដើម្បីកុំអោយអាវុធដែលគេលួចបាត់ហើយមិនអាចប្រើប្រាស់បាន។ នៅឆ្នាំ ២០០៧ ក្រុមប្រដាប់អាវុធពីរក្រុមបានវាយទម្លុះចូលទៅក្នុងរោងចក្រនុយក្លេអ៊ែរនៅអាហ្វ្រិកខាងត្បូង ដែលគ្រាប់បែកបរមាណូធ្លាប់ត្រូវបានរចនា និងផលិតរួចមកហើយ។ បន្ទាប់ពីបានទៅដល់បន្ទប់កុងត្រូលនិងបាញ់សម្លាប់ឆ្មាំយាមម្នាក់ ពួកគេត្រូវបានបណ្តេញចេញវិញ ដោយបន្សល់ទុកនូវអាថ៌កំបាំងរួមជាមួយនឹងការសង្ស័យអំពីសុវត្ថិភាពនៃរោងចក្រនុយក្លេអ៊ែរបែបនេះ។ នៅពេលដែលភាពចលាចលនយោបាយកាន់តែទូលំទូលាយបានកើតឡើង នៅក្នុងរដ្ឋដែលមានអាវុធនុយក្លេអ៊ែរផ្សេងទៀត ជាពិសេសប្រទេសប៉ាគីស្ថាន គំនិតព្រួយបារម្ភតែងតែងាកទៅរកសុវត្ថិភាពនៃអាវុធនុយក្លេអ៊ែរ និងវត្ថុធាតុដើមរបស់វា។

ទម្រង់ឬរូបភាពនៃការរីកសាយភាយនុយក្លេអ៊ែរកាន់តែខ្លាំងជាងនេះ គឺការអភិវឌ្ឍន៍ដោយរដ្ឋដែលមានរោងចក្រនុយក្លេអ៊ែរ ដើម្បីផលិតអាវុធនុយក្លេអ៊ែរផ្ទាល់ខ្លួនជាប្រចាំ។ ក្នុងករណីនេះ វាពាក់ព័ន្ធនឹងអាវុធមួយចំនួនធំ និងមានសក្តានុពលខ្លាំងឈានដល់ការប្រណាំងប្រជែងសព្វាវុធ នៅក្នុងជម្លោះនិងអរិភាពក្នុងតំបន់។ ជម្លោះក្នុងតំបន់ដែលពាក់ព័ន្ធ គឺជម្លោះរវាងប្រទេសអ៊ីស្រាអែល និងរដ្ឋអារ៉ាប់ រវាងប្រទេសអ៊ីរ៉ង់ និងប្រទេសអារ៉ាប់ជិតខាងរបស់ខ្លួន រវាងប្រទេសឥណ្ឌានិងប្រទេសប៉ាគីស្ថាន រវាងកូរ៉េទាំងពីរ និងប្រហែលជារវាងតៃវ៉ាន់និងចិន។ ទាំងប្រទេសឥណ្ឌានិងទាំងប្រទេសប៉ាគីស្ថាន មានអាវុធនុយក្លេអ៊ែររាប់សិបដើម និងមានកាំជ្រួចមីស៊ីលដើម្បីសម្រាប់បញ្ជូន។ ប្រទេសកូរ៉េខាងជើងបានសាកល្បងអាវុធនេះ ក្នុងឆ្នាំ ២០០៦ និង ២០០៩។ អាហ្វ្រិកខាងត្បូងបានរាយការណ៍ថាខ្លួនបានបង្កើតអាវុធនុយក្លេអ៊ែរជាច្រើន បន្ទាប់ពីបានលួចផលិតរួចហើយ ប៉ុន្តែ បន្ទាប់មក បានរុះរើវា នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ មុនពេលការគ្រប់គ្រងរបស់ក្រុមជនជាតិស្បែកស ភាគតិច ត្រូវបានបញ្ចប់។

នៅទសវត្សរ៍ឆ្នាំ ១៩៩០ អ្នកវិទ្យាសាស្ត្រនុយក្លេអ៊ែរកំពូលរបស់ប៉ាគីស្ថានបានលក់ឧបករណ៍បំផ្ទុះគ្រាប់បែកជាមួយអ៊ុយរ៉ានីញ៉ូមកម្រិតទាប ម៉ាស៊ីនចម្រាញ់ (centrifuges) និងគំរូរចនាគ្រាប់បែក ទៅអោយប្រទេសលីប៊ី អ៊ីរ៉ង់ និងកូរ៉េខាងជើង។ ប្រទេសលីប៊ីបានបោះបង់កម្មវិធីផលិតគ្រាប់បែករបស់ខ្លួន ចំណែកប្រទេសកូរ៉េខាងជើងបានចរចា ប៉ុន្តែនៅតែលាក់កំបាំងអំពីកម្មវិធីអ៊ុយរ៉ាញ៉ូមរបស់ខ្លួន (ខណៈពេលដែលបានបោះបង់កម្មវិធីផ្លាតូនីញ៉ូមរបស់ខ្លួន) រីឯប្រទេសអ៊ីរ៉ង់នៅតែបន្តបង្កើនសារធាតុអ៊ុយរ៉ាញ៉ូម។ ចំណែកប្រទេសអ៊ីស្រាអែលមិនដែលបានទទួលស្គាល់ជាផ្លូវការថាខ្លួនមានអាវុធនុយក្លេអ៊ែរទេ ប៉ុន្តែត្រូវបានគេជឿយ៉ាងទូលំ

ទូលាយថាប្រទេសនេះមានប្រហែលមួយរយឬច្រើនជាងនេះ។ អ៊ីស្រាអែលចង់បានសមត្ថភាពទាំងនេះ ដើម្បីបង្ហាញសាច់ដុំអោយមេដឹកនាំអារ៉ាប់ឃើញថា ការដណ្តើមយកអ៊ីស្រាអែលដោយកម្លាំងទ័ព មិនអាចទៅរួច។ ដើម្បីរារាំងប្រទេសអ៊ីរ៉ាក់មិនអោយអភិវឌ្ឍន៍អាវុធនុយក្លេអ៊ែរ ប្រទេសអ៊ីស្រាអែលបានធ្វើការវាយឆ្មក់ដោយទម្លាក់គ្រាប់បែកលើទីតាំងសំខាន់នៃអគាររោងចក្រនុយក្លេអ៊ែរអ៊ីរ៉ាក់ ក្នុងឆ្នាំ ១៩៨១។ ក្នុងឆ្នាំ ២០០៧ យន្តហោះចម្បាំងរបស់អ៊ីស្រាអែលបានបំផ្លាញទីតាំងមួយ នៅក្នុងប្រទេសស៊ីរី ដែលគិតថាជា ម៉ាស៊ីនរ៉េអាក់ទ័រនុយក្លេអ៊ែរដែលជាការរចនាគំរូរបស់កូរ៉េខាងជើង។ ប្រទេសស៊ីរីបានបោសសម្អាតស្នាមជាន់ឬតំរុយនៃអគាររោងចក្រទាំងអស់ យ៉ាងឆាប់រហ័ស បន្ទាប់ពីការវាយប្រហារនោះ។

សន្ធិសញ្ញាមិនរីកសាយភាយ (Non-Proliferation Treaty- NPT) ក្នុងឆ្នាំ ១៩៦៨ បានបង្កើតក្របខ័ណ្ឌមួយដើម្បីគ្រប់គ្រងការរីករាលដាលនៃវត្ថុធាតុដើមនិងបច្ចេកទេសនុយក្លេអ៊ែរ។ ទីភ្នាក់ងារថាមពលអាតូមិកអន្តរជាតិ(IAEA) ដែលជាទីភ្នាក់ងាររបស់អង្គការសហប្រជាជាតិ ដែលមានមូលដ្ឋាននៅក្នុងប្រទេសអូទ្រីស ត្រូវបានផ្តល់តួនាទីអោយត្រួតពិនិត្យឧស្សាហកម្មថាមពលនុយក្លេអ៊ែរ នៅក្នុងរដ្ឋជាសមាជិកដើម្បីការពារកុំអោយមានការបង្វែរវត្ថុធាតុនុយក្លេអ៊ែរសម្រាប់គោលដៅយោធាដោយសម្ងាត់។ ទោះជាយ៉ាងណាក៏ដោយ រដ្ឋដែលមានសក្តានុពលនុយក្លេអ៊ែរមួយចំនួន (ដូចជាប្រទេសអ៊ីស្រាអែល) មិនបានចុះហត្ថលេខាលើសន្ធិសញ្ញាមិនរីកសាយភាយ ហើយសូម្បីតែរដ្ឋដែលបានចុះហត្ថលេខារួចហើយ អាចនឹងគេចវេសពីការអនុវត្តបទប្បញ្ញត្តិនៃសន្ធិសញ្ញា ដោយការលួចលាក់ធ្វើរោងចក្រផលិតមួយចំនួនដោយសម្ងាត់ (ដូចដែលប្រទេសអ៊ីរ៉ាក់និងអ៊ីរ៉ង់បានធ្វើ)។ នៅក្រោមលក្ខខណ្ឌបទឈប់បាញ់គ្នានៅក្នុងសង្គ្រាមឈូងសមុទ្រ កម្មវិធីនុយក្លេអ៊ែររបស់អ៊ីរ៉ាក់ត្រូវបានកោះកកាយនិងបញ្ឆោអោយរុះរើ ដោយទីភ្នាក់ងារថាមពលអាតូមិកអន្តរជាតិ។ នៅក្នុងឆ្នាំ ២០០៦ កិច្ចព្រមព្រៀងរវាងសហរដ្ឋអាមេរិកនិងឥណ្ឌា ដើម្បីចែករំលែកបច្ចេកវិទ្យានុយក្លេអ៊ែរបាននាំអោយរដ្ឋជាច្រើនចោទសួរអំពីសន្ធិសញ្ញាមិនរីកសាយភាយ (NPT) ដោយសារតែអត្ថប្រយោជន៍ទាំងនោះត្រូវបានសន្មត់ថារក្សាទុកសម្រាប់តែប្រទេសហត្ថលេខីប៉ុណ្ណោះ។ យ៉ាងណាក៏ដោយ កិច្ចព្រមព្រៀងនេះទទួលបានការអនុម័តចុងក្រោយពីសហរដ្ឋអាមេរិកនិងឥណ្ឌា ក្នុងឆ្នាំ ២០០៨។

ប្រទេសកូរ៉េខាងជើងបានដកខ្លួនចេញពីទីភ្នាក់ងារថាមពលអាតូមិកអន្តរជាតិ ក្នុងឆ្នាំ ១៩៩៣ ហើយបន្ទាប់មកបានចរចាជាមួយមេដឹកនាំបស្ចឹមប្រទេស ដើម្បីទទួលបានជំនួយសេដ្ឋកិច្ច រួមទាំងម៉ាស៊ីនរ៉េអាក់ទ័រដែលមានសុវត្ថិភាពជាងមុន ជាថ្នូរនឹងការបង្កកកម្មវិធីនុយក្លេអ៊ែររបស់ខ្លួន។ ប៉ុន្មានខែក្រោយមកមេដឹកនាំកូរ៉េខាងជើងបានស្លាប់ ប៉ុន្តែលទ្ធផលនៃការចរចារសម្របសម្រួលនៅតែរក្សាដដែល។ នៅឆ្នាំ ១៩៩៩ កូរ៉េខាងជើងបានអនុញ្ញាតអោយត្រួតពិនិត្យអគារក្រោមដី ដែលមានជម្លោះ ហើយបានយល់ព្រមផ្អាកការធ្វើតេស្តមីស៊ីល ជាថ្នូរនឹងជំនួយនិងការដកផ្នែកខ្លះនៃទណ្ឌកម្មពាណិជ្ជកម្មរបស់សហរដ្ឋអាមេរិក។ បន្ទាប់មក នៅឆ្នាំ ២០០២ សហរដ្ឋអាមេរិកបានប្រឈមមុខនឹងប្រទេសកូរ៉េខាងជើងដោយផ្ទាល់ ជាមួយនឹងកស្តុតាងនៃកម្មវិធីចម្រាញ់សារធាតុអ៊ុយរ៉ាញ៉ូមសម្ងាត់ដែលក្រោយមកកូរ៉េខាងជើងបានសារភាពថាការពិត។ បន្ទាប់មក ប្រទេសកូរ៉េខាងជើងបានដកខ្លួនចេញពីកិច្ចព្រមព្រៀងខាងលើ និងដកចេញពីទីភ្នាក់ងារថាមពលអាតូមិកអន្តរជាតិ ហើយបានចាប់ផ្តើមម៉ាស៊ីនរ៉េអាក់ទ័រនុយក្លេអ៊ែរឡើងវិញ ហើយទំនងជាបានប្រែក្លាយសារធាតុប្លាតូនីញ៉ូមដែលមានស្រាប់របស់ខ្លួន អោយទៅជាគ្រាប់បែកចំនួនកន្លះឡូ ក្នុងរយៈពេលប៉ុន្មានខែក្រោយមក ដែលក្នុងចំណោមនោះ ពួកគេបានបាញ់សាកល្បងមួយគ្រាប់ នៅឆ្នាំ ២០០៦។ កូរ៉េខាងជើងបានយល់ព្រមបោះបង់

កម្មវិធីរបស់ខ្លួនម្តងទៀត ក្នុងឆ្នាំ ២០០៨ ប៉ុន្តែ បន្ទាប់ពីការសាកល្បងនុយក្លេអ៊ែរម្តងទៀត ក្នុងឆ្នាំ ២០០៩ ពួកគេបានចាប់ផ្តើមកែច្នៃសម្ភារៈនុយក្លេអ៊ែរម្តងទៀត។ បន្ទាប់ពីរងសម្ពាធពីសហគមន៍អន្តរជាតិកាន់តែខ្លាំងក្នុងឆ្នាំ ២០១៧ ជាពិសេសសហរដ្ឋអាមេរិក ប្រទេសកូរ៉េខាងជើងបានយល់ព្រមចាប់ផ្តើមការចរចាអំពីកម្មវិធីនុយក្លេអ៊ែររបស់ខ្លួន នៅឆ្នាំ ២០១៨ ។

រូបថត ប្រៀបធៀបទីតាំងរោងចក្រនុយក្លេអ៊ែរអ៊ីរ៉ង់
មានអ្វីត្រូវលាក់បាំងមែនទេ?

ឧបសគ្គធំបំផុតក្នុងការផលិតអាវុធនុយក្លេអ៊ែរ គឺការទទួលបានវត្ថុធាតុដែលអាចបំបែកបាន (ដូចជា ប្លាតូនីញ៉ូមនិងអ៊ុយរ៉ាញ៉ូម)។ ការចម្រាញ់សារធាតុអ៊ុយរ៉ាញ៉ូមរបស់អ៊ីរ៉ង់អាចអោយប្រទេសនេះមានគ្រាប់បែកនុយក្លេអ៊ែរក្នុងរយៈពេលមួយទសវត្សរ៍។ ដោយបញ្ហេះការសង្ស័យរបស់លោកខាងលិច អ៊ីរ៉ង់មិនបានបើកចំហជាមួយអជ្ញាធរអន្តរជាតិទេ។ អ៊ីរ៉ង់បានលួសឆាយទីតាំងដ៏ធំនេះ ហើយបានដកជីចេញ ក្នុងឆ្នាំ ២០០៤ មុននឹងអនុញ្ញាតអោយអ្នកត្រួតពិនិត្យចូល។ រដ្ឋបស្ចឹមប្រទេសនិងក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិបានអនុវត្តទណ្ឌកម្មប្រឆាំងនឹងអ៊ីរ៉ង់ ហើយកិច្ចព្រមព្រៀងនុយក្លេអ៊ែរដ៏ចម្រូងចម្រាសមួយត្រូវបានយល់ព្រមនិងសម្រេចឡើង នៅក្នុងឆ្នាំ ២០១៥។

នាពេលបច្ចុប្បន្ននេះ ក្រៅពីសមាជិកក្រុមប្រឹក្សាសន្តិសុខអចិន្ត្រៃយ៍«ធំទាំងប្រាំ» រដ្ឋនុយក្លេអ៊ែរមានដូចជា ប្រទេសអ៊ីស្រាអែល ឥណ្ឌា និងប៉ាគីស្តាន (មានក្បាលគ្រាប់រាប់សិបឡូ និងកំពុងផលិតបន្ថែម) និងកូរ៉េខាងជើង (ប្រហែលជាមានកន្លះឡូ ហើយក៏កំពុងផលិតបន្ថែមផងដែរ)។

ប្រទេសអ៊ីរ៉ង់បដិសេធ ប៉ុន្តែហាក់ដូចជាកំពុងធ្វើការ ញាប់ដៃញាប់ជើង ដើម្បីផលិតអាវុធនុយក្លេអ៊ែរ។ ចាប់តាំងពីឆ្នាំ ២០០៣ មក អ៊ីរ៉ង់ដំបូងបានយល់ព្រមផ្អាកកម្មវិធីចម្រាញ់សារធាតុអ៊ុយរ៉ានីញ៉ូមរបស់ខ្លួន និងអនុញ្ញាតអោយមានការត្រួតពិនិត្យ ដោយមិនប្រាប់មុនពីIAEA បន្ទាប់មកបានចាប់ផ្តើមការចម្រាញ់ឡើងវិញ ផ្អាកវាម្តងទៀត ហើយចាប់ផ្តើមវាម្តងទៀត។ នៅក្នុងឆ្នាំ ២០០៥ កិច្ចខិតខំប្រឹងប្រែងដោយអឺរ៉ុបដែលមានការគាំទ្រដោយសហរដ្ឋអាមេរិកដើម្បីសម្រេចបានកិច្ចព្រមព្រៀងមួយ ត្រូវរអាក់រអួល។ នៅឆ្នាំ ២០០៦ ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិបានថ្កោលទោសសកម្មភាពរបស់អ៊ីរ៉ង់និងដាក់ទណ្ឌកម្មកម្រិតស្រាល។ ប្រទេសអ៊ីរ៉ង់បានទទូចថា ខ្លួនមានសិទ្ធិក្នុងការចម្រាញ់សារធាតុអ៊ុយរ៉ាញ៉ូមដើម្បីអ្វីដែលអ៊ីរ៉ង់ខ្លួនឯងថាជាគោលបំណងសន្តិភាព។ នៅឆ្នាំ ២០០៨ អាកប្បកិរិយារបស់អ៊ីរ៉ង់បាននាំអោយមានការដាក់ទណ្ឌកម្មបន្ថែមទៀតរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ហើយក្នុងឆ្នាំ ២០០៩ បន្ទាប់ពីរោងចក្រកែច្នៃក្រោមដីសម្ងាត់មួយ ត្រូវបានរកឃើញ អ៊ីរ៉ង់បានចូលរួមក្នុងការពិភាក្សាអំពីកម្មវិធីជាមួយប្រទេសមហាអំណាចបស្ចឹមលោក។ កិច្ចព្រមព្រៀងបណ្តោះអាសន្នមួយត្រូវបានសម្រេចឡើងនៅចុងឆ្នាំ ២០១៣ ដែលអ៊ីរ៉ង់ផ្ទាល់បានយល់ព្រមពន្យឺតដំណើរការចម្រាញ់ធាតុអ៊ុយរ៉ាញ៉ូម ជាថ្នូរនឹងការបន្ធូរបន្ថយទម្ងន់ទណ្ឌកម្ម។ កិច្ចព្រមព្រៀងចុងក្រោយមួយត្រូវបានឈានដល់នៅពាក់កណ្តាលឆ្នាំ ២០១៥ ដែលអនុញ្ញាតអោយអ៊ីរ៉ង់បន្តការចម្រាញ់សារធាតុអ៊ុយរ៉ាញ៉ូម ប៉ុន្តែក្នុងកម្រិតទាបតែប៉ុណ្ណោះ ដែលមិនអាចប្រើដើម្បីធ្វើជាអាវុធបាន។ ប្រទេសអ៊ីរ៉ង់ក៏បានយល់ព្រមអនុញ្ញាតអោយបង្កើនការត្រួតពិនិត្យទីតាំងនុយក្លេអ៊ែររបស់ខ្លួន។ ជាថ្នូរ ប្រទេស មហាអំណាចបស្ចឹមលោកបានយល់ព្រមដកទណ្ឌកម្មប្រឆាំងនឹងអ៊ីរ៉ង់ ទោះបីទណ្ឌកម្មខ្លះនឹងមិនត្រូវបានដកចេញក៏ដោយ

រហូតដល់អ៊ីរ៉ង់រុះរើផ្នែកជាក់លាក់ខ្លះនៃកម្មវិធីនុយក្លេអ៊ែររបស់ខ្លួន។ កិច្ចព្រមព្រៀងនេះមានភាពចម្រូងចម្រាស់នៅសហរដ្ឋអាមេរិក ហើយរដ្ឋបាលប្រធានាធិបតីត្រាំបានដកខ្លួនចេញពីកិច្ចព្រមព្រៀងនេះ នៅឆ្នាំ ២០១៨។

ប្រទេសមហាអំណាចមធ្យមមួយចំនួន និងប្រទេសមហាអំណាចចំនួនពីរ (ជប៉ុន និងអាឡឺម៉ង់) មានសក្តានុពលក្នុងការផលិតអាវុធនុយក្លេអ៊ែរ ប៉ុន្តែបានជ្រើសរើសមិនផលិតវាទេ។ ហេតុផលសម្រាប់ការសម្រេចចិត្តប្រឆាំងទៅនឹង«វិថីនុយក្លេអ៊ែរ» រួមមានបទដ្ឋានប្រឆាំងនឹងការប្រើប្រាស់អាវុធនុយក្លេអ៊ែរ, ការភ័យខ្លាចរងការវាយបកដោយនុយក្លេអ៊ែរ, និងឧបសគ្គជាក់ស្តែង ដូចជាថ្លៃចំណាយជាដើម។ ប្រទេសប្រេស៊ីល និងអាហ្សង់ទីនហាក់ដូចជាឆ្ពោះទៅកាន់វិថីប្រណាំងប្រជែងអាវុធនុយក្លេអ៊ែរក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ ប៉ុន្តែក្រោយមក បានបោះបង់ចោលវិញក្នុងខណៈពេលដែលរដ្ឋាភិបាល ស៊ីវិលបានចូលមកដឹកនាំប្រទេសជំនួសអោយរដ្ឋាភិបាលយោធា នៅក្នុងរដ្ឋទាំងពីរ។ ក្នុងឆ្នាំ ២០០៤ បន្ទាប់ពីការរារាំងជាច្រើនឆ្នាំ ប្រទេសប្រេស៊ីលបានព្រមអោយអ្នកត្រួតពិនិត្យទីភ្នាក់ងារIAEA ចូលទៅកាន់រោងចក្រចម្រាញ់សារធាតុអ៊ុយរ៉ាញ៉ូមដ៏ចម្រូងចម្រាសមួយ (ប្រាកដណាស់ មិនមែនជាផ្នែកនៃកម្មវិធីអាវុធនុយក្លេអ៊ែរទេ)។

៦.៤.៥. យុទ្ធសាស្ត្រនុយក្លេអ៊ែរ និងការគ្រប់គ្រងអាវុធ

ពាក្យថា*យុទ្ធសាស្ត្រនុយក្លេអ៊ែរ* (nuclear strategy) សំដៅលើការសម្រេចចិត្តអំពីចំនួនអាវុធនុយក្លេអ៊ែរដែលត្រូវដាក់ពង្រាយ ដោយត្រូវប្រើប្រាស់ប្រព័ន្ធបញ្ជូនណាមួយ ហើយត្រូវអនុម័តគោលនយោបាយអ្វីខ្លះពាក់ព័ន្ធនឹងកាលៈទេសៈដែលពួកគេអាចនឹងត្រូវប្រើប្រាស់។

ស្ទើរតែគ្រប់ប្រទេស ហេតុផលសម្រាប់ការកាន់កាប់អាវុធនុយក្លេអ៊ែរ គឺដើម្បីរារាំងរដ្ឋដទៃកុំអោយវាយប្រហារដោយអាវុធនុយក្លេអ៊ែរឬអាវុធទូទៅ ដោយការគំរាមកំហែងសងសឹកតបតវិញភ្លាម ដែលអាចបង្កបំផ្លិចបំផ្លាញទាំងស្រុង។ នេះគួរតែមានដំណើរការមែន ប្រសិនបើមេដឹកនាំរដ្ឋ គឺជាតួអង្គសមហេតុផលដែលចង់ជៀសវាងការចំណាយដ៏ធំធេងលើការវាយប្រហារនុយក្លេអ៊ែរ។ ប៉ុន្តែ វានឹងដំណើរការបាន លុះត្រាតែរដ្ឋដទៃទៀតជឿថាការគំរាមកំហែងក្នុងការប្រើប្រាស់អាវុធនុយក្លេអ៊ែររបស់រដ្ឋណាមួយនោះ ពិតជាគួរអោយជឿជាក់មែន។ ការស្វែងរកយន្តការរារាំងឬទប់ស្កាត់ដែលអាចជឿទុកចិត្តបាន ដោយរដ្ឋជាសត្រូវចំនួនពីរឬច្រើនបណ្តាលអោយមានការពង្រីកឃ្លាំងអាវុធនុយក្លេអ៊ែរកាន់តែធំទៅៗ ឥតឈប់ឈរ។ ដើម្បីគិតតាមតក្កវិជ្ជានេះសូមចាប់ផ្តើមជាមួយនឹងការដាក់ពង្រាយកាំជ្រួចនុយក្លេអ៊ែរដំបូងរបស់ប្រទេសប៉ាគីស្តាន ដែលសំដៅទៅកាន់ប្រទេសឥណ្ឌា (ហើយប្រទេសឥណ្ឌាក៏ដាក់សំដៅទៅប៉ាគីស្តានវិញដែរ)។ នៅពេលនោះ ប្រទេសឥណ្ឌានឹងមិនវាយប្រហារឡើយ លុះត្រាតែខ្លួនអាចរារាំងប៉ាគីស្តានមិនអោយប្រើប្រាស់មីស៊ីលរបស់គេបាន។ ប្រទេសឥណ្ឌាអាចធ្វើបែបនេះ ដោយបង្កើតកងកម្លាំងវាយប្រហារដែលមានសមត្ថភាពកំទេចមីស៊ីលប៉ាគីស្តានបានទាំងស្រុង (ប្រហែលដោយការប្រើអាវុធនុយក្លេអ៊ែរ ប៉ុន្តែទោះប្រើអ្វីក៏មិនសំខាន់ដែរក្នុងករណីនេះ)។ ពេលនោះ កាំជ្រួចប៉ាគីស្តាន ជាជាងរារាំងឥណ្ឌា បានត្រឹមតែជំរុញអោយឥណ្ឌាកម្ទេចកាំជ្រួចទាំងនេះ មុនពេលមានការវាយប្រហារផ្សេងទៀត។ ការវាយប្រហារដែលមានគោលដៅបំផ្លាញអាវុធនុយក្លេអ៊ែរ(មួយផ្នែកធំ ឬទាំងស្រុង)របស់រដ្ឋ មុនពេលអាវុធទាំងនោះអាចត្រូវបានគេប្រើប្រាស់ ត្រូវបានគេហៅថា *ការវាយប្រហារមុន* (first strike)។

ប្រទេសប៉ាគីស្តានអាចការពារកាំជ្រួចរបស់ខ្លួនមិនអោយសត្រូវកំទេចបាន (ប្រហែលជាត្រូវចល័តវាពីមួយកន្លែងទៅមួយកន្លែងទៀត)។ ពួកគេក៏អាចផលិតកាំជ្រួចនុយក្លេអ៊ែរបន្ថែមទៀតផងដែរ ដូច្នេះហើយ បើ

ទោះបីជាកាំជ្រួចមួយចំនួនត្រូវបានបំផ្លាញនៅក្នុងការវាយប្រហារមុនរបស់ឥណ្ឌាក៏ដោយ ក៏គ្រាប់ខ្លះអាចនៅសេសសល់សម្រាប់បាញ់សងសឹកវិញ។ អាវុធដែលអាចរងការវាយប្រហារមុន ហើយនៅតែអាចវាយបកវិញផ្តល់អោយរដ្ឋនូវសមត្ថភាពក្នុង*ការវាយប្រហារបក*(second-strike)។ ការដែលមានសមត្ថភាពក្នុង*ការវាយប្រហារបក*របស់ភាគីទាំងសង្ខាងត្រូវបានគេហៅថា **ការបំផ្លិចបំផ្លាញគ្នាទៅវិញទៅ**(MAD) ពីព្រោះភាគីទាំងពីរមិនអាចរារាំងគូសត្រូវមិនអោយបំផ្លាញខ្លួនវិញបានទេ។ បើទោះជាឆ្លុះបញ្ចាំងពី«សនិទានភាព»ក៏ដោយ ពាក្យនេះបង្កប់អត្ថន័យថា យុទ្ធសាស្ត្រនេះពិតជាឆ្គួត(លីលា)មែន ពីព្រោះការឃ្លាតឆ្ងាយចេញពីការប្តឹងថ្លែងហេតុផល អាចបំផ្លាញភាគីទាំងពីរ។

ប្រសិនបើប្រទេសឥណ្ឌាមិនអាច*ករម្ភ*ីមីស៊ីលរបស់ប៉ាគីស្ថានដោយជឿជាក់បានទេ ប្រាកដណាស់វាច្បាស់ជាត្រូវដាក់ពង្រាយកាំជ្រួចនុយក្លេអ៊ែររបស់ខ្លួន ដើម្បីរារាំងប៉ាគីស្ថានកុំអោយការប្រើកាំជ្រួចរបស់ខ្លួន។ ឥណ្ឌាក៏អាចសម្រេចបាននូវសមត្ថភាពវាយប្រហារបកផងដែរ។ ឥឡូវនេះ សំណួរអំពីភាពជឿជាក់មានសារៈសំខាន់ណាស់។ បើតាមទ្រឹស្តី ប្រទេសឥណ្ឌាអាចបើកការវាយប្រហារដោយអាវុធទូទៅ មិនមែននុយក្លេអ៊ែរសំដៅលើប្រទេសប៉ាគីស្ថានដោយជឿជាក់ថាមេដឹកនាំប៉ាគីស្ថានដែលចេះប្តឹងថ្លែងហេតុផល សុខចិត្តចុះចាញ់សង្គ្រាមបែបនេះ ជាជាងប្រើអាវុធនុយក្លេអ៊ែររបស់ខ្លួន ហើយបណ្តាលអោយមានការឆ្លើយតបដោយអាវុធនុយក្លេអ៊ែររបស់ឥណ្ឌា។ ម្ល៉ោះហើយ កាំជ្រួចនុយក្លេអ៊ែរលុបចោលឬរារាំងគ្នាទៅវិញទៅមក។

រូបថត ព័ន្ធដំបូលដែក (Iron Dome) របស់អ៊ីស្រាអែល បាញ់ទម្លាក់មីស៊ីល

ជំហានការពារ

ការប្រណាំងប្រជែងអាវុធនុយក្លេអ៊ែ រវាងប្រទេសមហាអំណាច ក្នុងអំឡុងសង្គ្រាមត្រជាក់បាននាំអោយមានយុទ្ធសាស្ត្រនិងកិច្ចព្រមព្រៀងគ្រប់គ្រងអាវុធ ដែលជួយបង្កើតបទដ្ឋាននិងការរំពឹងទុក អំពីអាវុធនុយក្លេអ៊ែរ និងមីស៊ីល។ ប្រទេសឥណ្ឌា និងប៉ាគីស្ថានបានដើរតាមការប្រណាំងប្រជែងអាវុធស្រដៀងគ្នាដែលនាំអោយមានការរារាំងគ្នាទៅវិញទៅមក។ ថ្មីៗនេះ ការការពារប្រឆាំងនឹងកាំជ្រួចបានចាប់ផ្តើមចូលទៅក្នុងការគណនាយុទ្ធសាស្ត្រ។ នៅទីនេះ ប្រព័ន្ធដំបូលដែក (Iron Dome) របស់អ៊ីស្រាអែល បាញ់ទម្លាក់មីស៊ីល រយៈចម្ងាយខ្លី ពីតំបន់ហ្គាហ្សា ឆ្នាំ ២០១៤។

វិស័យការពារជាតិហាក់មានតួនាទីតិចតួចក្នុងយុទ្ធសាស្ត្រនុយក្លេអ៊ែរ ពីព្រោះគ្មានប្រព័ន្ធការពារប្រកបដោយប្រសិទ្ធភាពប្រឆាំងនឹងការវាយប្រហារដោយកាំជ្រួចឬមីស៊ីលត្រូវបានតាក់តែងឡើងនៅឡើយ។ ទោះជាយ៉ាងណាក៏ដោយ សហរដ្ឋអាមេរិកកំពុងចំណាយប្រាក់រាប់ពាន់លានដុល្លារក្នុងមួយឆ្នាំៗ ដើម្បីព្យាយាមអភិវឌ្ឍប្រព័ន្ធការពារដែលអាចបាញ់ទម្លាក់មីស៊ីលផ្លោងសំដៅចូលមក។ កម្មវិធីនេះត្រូវបានគេហៅថា **គំនិតផ្តួចផ្តើមការពារជាយុទ្ធសាស្ត្រ**(SDI), សង្គ្រាមផ្កាយ (Star Wars) ឬ ប្រព័ន្ធការពារមីស៊ីលផ្លោង)។ វាផ្តើមចេញពីការអំពាវនាវរបស់ប្រធានាធិបតី រ៉ូណាល់ រីហ្គិន (Ronald Reagan) ឆ្នាំ ១៩៨៣ ដើម្បីរៀបចំខែលដ៏ទូលំទូលាយ ដែលនឹងធ្វើអោយមីស៊ីលនុយក្លេអ៊ែរលែងប្រើការកើត។ ទោះយ៉ាងណាក៏ដោយក្រោយពីនោះ ភ្លាម បេសកកម្មត្រូវបានបង្វែរទៅជាការការពារមីស៊ីលអាមេរិកមួយចំនួន ក្នុងការវាយប្រហារដ៏ធំសម្បើមរបស់សូវៀត។ បន្ទាប់ពីសង្គ្រាមត្រជាក់ បេសកកម្មបានផ្លាស់ប្តូរម្តងទៀត ដើម្បីការពារទឹកដីសហរដ្ឋអាមេរិកពីការវាយប្រហារដោយមីស៊ីលដែលមានដែនកំណត់ (យ៉ាងច្រើនបំផុត មីស៊ីលចំនួនពីរបីប៉ុណ្ណោះ) ប្រហែលជាអាចកើតឡើងនៅក្នុងការបាញ់បង្ហោះដែលគ្មានការអនុញ្ញាត ឬជាឧបទ្ទវហេតុ ឬការវាយប្រហារដោយរដ្ឋតូច

ណាមួយ។ ប្រទេសជប៉ុនកំពុងចំណាយប្រាក់ ១ ពាន់លានដុល្លារក្នុងមួយឆ្នាំដើម្បីបង្កើតប្រព័ន្ធការពារមីស៊ីល ដែលរចនាដោយសហរដ្ឋអាមេរិក ដែលខ្លួនបានសាកល្បង ដោយជោគជ័យនៅចុងឆ្នាំ ២០០៧។ ទោះជា យ៉ាងណាក៏ដោយ ប្រទេសកូរ៉េខាងជើងមានមីស៊ីលផ្លោងជាង ៦០០ គ្រាប់ ដែលអាចបាញ់ដល់ប្រទេស ជប៉ុន។

គិតត្រឹមឆ្នាំ ២០១០ សហរដ្ឋអាមេរិកកំពុងដាក់ពង្រាយប្រព័ន្ធការពារច្រើនស្រទាប់ ដែលមានកាំជ្រួច ស្ទាក់ចាប់ ដែលមានមូលដ្ឋានលើដីគោក ចំនួន ២៤ នៅរដ្ឋអាឡាស្កា និងកាលីហ្វ័រញ៉ា។ (ដោយតម្រង់ឆ្ពោះ ទៅការគំរាមកំហែងរបស់កូរ៉េខាងជើង), ឧបករណ៍ស្ទាក់ចាប់ដែលមានមូលដ្ឋានលើកប៉ាល់ចំនួន ២១ គ្រឿង, កាំជ្រួច Patriot ប្រហែល ៥០០ ដើម សម្រាប់ការគំរាមកំហែងដោយមីស៊ីលផ្លោងរយៈចម្ងាយខ្លី និង ប្រព័ន្ធ រ៉ាដានិងមជ្ឈមណ្ឌលត្រួតពិនិត្យតាមដានជាច្រើនបន្តទៀត។ វាបានចាប់ផ្តើមសាកល្បងប្រព័ន្ធឡាស៊ែរដែល មានមូលដ្ឋានលើយន្តហោះ ហើយបានសម្រេចកិច្ចព្រមព្រៀងជាមួយប្រទេសប៉ូឡូញ និងសាធារណរដ្ឋឆេក ដើម្បីសាងសង់ប្រព័ន្ធការពារមីស៊ីលនៅក្នុងប្រទេសទាំងពីរ មុនពេលផ្លាស់ប្តូរផែនការទាំងនេះជំនួសដោយ ការគាំទ្រប្រព័ន្ធការពារដែលមានមូលដ្ឋានលើសមុទ្រ ដើម្បីការពារប្រឆាំងនឹងការគំរាមកំហែងណាមួយរបស់ ប្រទេសអ៊ីរ៉ង់ ដោយប្រើប្រាស់ប្រព័ន្ធរ៉ាដាដែលមានមូលដ្ឋាននៅប្រទេសទួរគី។ ក្នុងឆ្នាំ ២០១២ និង ២០១៤ ប្រទេសអ៊ីស្រាអែលបានប្រើប្រាស់ប្រព័ន្ធការពារថ្មី ដែលមានរហស្សនាមថា Iron Dome (ដំបូលដែក) ដើម្បី បាញ់ទម្លាក់មីស៊ីលរយៈចម្ងាយខ្លីដ៏ច្រើនសន្ធឹកសន្ធាប់ ដែលបាញ់ស្រោច ដោយក្រុមហាម៉ាស។

រូបថត ការកំទេចយន្តហោះទម្លាក់គ្រាប់បែក B-៥២ របស់អាមេរិក

សង្គ្រាមត្រូវបញ្ចប់

កម្លាំងអាវុធនុយក្លេអ៊ែររបស់អាមេរិកនិងរុស្ស៊ីត្រូវបានកាត់បន្ថយយ៉ាងច្រើន ក្នុងទសវត្សរ៍ឆ្នាំ១៩៩០។ នៅទីនេះ យន្តហោះទម្លាក់គ្រាប់បែក B-៥២ របស់អាមេរិកកំពុងត្រូវបានកម្ទេច ក្រោមក្រសែភ្នែករបស់ផ្កាយ រណបរុស្ស៊ី ដើម្បីកាត់បន្ថយកម្រិតនៃកម្លាំងបែបនេះ។

បន្ថែមពីលើបញ្ហាប្រឈមផ្នែកបច្ចេកទេសដើម្បីការបញ្ឈប់ក្បាលគ្រាប់មីស៊ីលផ្លោងចូលមក ដូចជា ការសម្គាល់ក្បាលគ្រាប់ពិតពីក្បាលគ្រាប់បញ្ឆោត ការការពារជាយុទ្ធសាស្ត្រពិតប្រាកដក៏អាចនឹងត្រូវបញ្ឈប់ កាំជ្រួចហោះ(Cruise) (ប្រហែលជាអាចបាញ់ចេញពីនាវាជ្រមុជទឹក) យន្តហោះ និងប្រព័ន្ធដឹកជញ្ជូនប្រកប ដោយភាពច្នៃប្រឌិតបន្ថែមទៀត។ ប្រសិនបើរដ្ឋលីលា ឬ ក្រុមភេរវកណាមួយវាយប្រហារសហរដ្ឋអាមេរិក ដោយអាវុធនុយក្លេអ៊ែរ វាប្រហែលជាមិនប្រើមីស៊ីលផ្លោងឆ្លងទ្វីប (ICBM) ដើម្បីធ្វើដូច្នេះទេ។

ក្នុងអំឡុងសង្គ្រាមត្រជាក់ កម្លាំងនុយក្លេអ៊ែររបស់ប្រទេសមហាអំណាចបានរីកចម្រើន ខ្លាំងហើយ បច្ចេកវិទ្យាត្រូវបានអភិវឌ្ឍលឿនដែរ។ រចនាសម្ព័ន្ធកងកម្លាំងដែលកំពុងវិវឌ្ឍន៍ទាំងនោះត្រូវបានចងក្រង (ជា ជាងការតឹតបន្តឹង)ដោយកិច្ចព្រមព្រៀងគ្រប់គ្រងអាវុធជាបន្តបន្ទាប់។ *ការគ្រប់គ្រងអាវុធ* (arms control) គឺ ជាការខិតខំប្រឹងប្រែងដោយរដ្ឋពីរឬច្រើន ដើម្បីគ្រប់គ្រងការទិញសព្វាវុធរបស់ពួកគេ ដោយកិច្ចព្រមព្រៀង ផ្លូវការ ដោយប្រើគោលការណ៍បដិការ ដើម្បីដោះស្រាយបញ្ហាផលប្រយោជន៍រួមនៅក្នុងការប្រណាំងប្រជែង សព្វាវុធថ្លៃៗ ដែលចុងក្រោយនឹងមិនផ្តល់ផលប្រយោជន៍ដល់ភាគីណាមួយឡើយ (សូមមើលអត្ថបទបន្ថែម ការស្វែងរកផលប្រយោជន៍រួម)។ ការគ្រប់គ្រងអាវុធមានលក្ខណៈទូលំទូលាយ ដោយមិនផ្តោតត្រឹមតែ អាវុធ នុយក្លេអ៊ែរនោះទេ ជាឧទាហរណ៍ ក្រោយសង្គ្រាមលោកលើកទី ១ ប្រទេសមហាអំណាចបានចរចាអំពីដែន

កំណត់លើទំហំកងទ័ពជើងទឹក ប៉ុន្តែនៅក្នុងកំឡុងសង្គ្រាមត្រជាក់ អាវុធនុយក្លេអ៊ែរ គឺជាចំណុចសំខាន់នៃការគ្រប់គ្រងអាវុធ។ កិច្ចព្រមព្រៀងគ្រប់គ្រងអាវុធ ជាធម្មតាទាមទារអោយមានការចរចាជាផ្លូវការរយៈពេលវែងជាមួយនឹងការពិភាក្សាបច្ចេកទេសជាច្រើន ដោយចុងបញ្ចប់ ត្រូវសម្រេចចេញជាសន្ធិសញ្ញាមួយ។ សន្ធិសញ្ញាគ្រប់គ្រងអាវុធខ្លះមានលក្ខណៈពហុភាគី ប៉ុន្តែ ក្នុងអំឡុងពេលសង្គ្រាមត្រជាក់ភាគច្រើនមានលក្ខណៈត្រឹមទ្វេភាគី (អាមេរិក-សូវៀត)។ សន្ធិសញ្ញាខ្លះទៀតនៅមានប្រសិទ្ធភាពជាអលជ្ជី ខ្លះទៀតមានសុពលភាពក្នុងរយៈពេលមានកំណត់។

សន្ធិសញ្ញាមួយចំនួននៅក្នុងទសវត្សរ៍ឆ្នាំ ១៩៧០ បានជាប់គាំងនៅក្នុងកម្រិតស្មើគ្នានៃសមត្ថភាពនុយក្លេអ៊ែរ ផ្នែកអាវុធប្រល័យលោក (MAD) របស់ប្រទេសមហាអំណាចទាំងពីរ។ **សន្ធិសញ្ញាប្រឆាំងមីស៊ីលផ្លោង**(ABM) ឆ្នាំ ១៩៧២ បានរារាំងភាគីទាំងសងខាងមិនអោយប្រើប្រាស់ប្រព័ន្ធការពារកាំជ្រួចផ្លោងធ្វើជាខែល ដើម្បីខ្លួនអាចចាប់ផ្តើមវាយប្រហារមុន។ ទោះយ៉ាងណាក៏ដោយ ដើម្បីអាចសាកល្បងបច្ចេកវិទ្យាការពារមីស៊ីលពេញលេញ សហរដ្ឋអាមេរិកបានដកខ្លួនចេញពី សន្ធិសញ្ញាប្រឆាំងមីស៊ីលផ្លោង ដោយគ្រាន់តែជូនដំណឹងមុន រយៈពេលប្រាំមួយខែ (ដូចដែលបានចែងក្នុងសន្ធិសញ្ញា) ក្នុងឆ្នាំ ២០០២។ ប្រធានាធិបតីប៊ូសបានហៅសន្ធិសញ្ញានេះថាជាសំណល់វត្ថុបុរាណសម័យសង្គ្រាមត្រជាក់ ប៉ុន្តែ អ្នកវិះគន់បានហៅប្រព័ន្ធការពារមីស៊ីលរបស់សហរដ្ឋអាមេរិកថាជាកំហុសធំធេង ដែលអាចរុញច្រានអោយប្រទេសចិនពង្រីកទំហំឃ្លាំងអាវុធនុយក្លេអ៊ែរដ៏តិចតួចរបស់ខ្លួន អោយកាន់តែធំដែរ (ផ្ទុយមកវិញ ធ្វើអោយប្រទេសឥណ្ឌាកិតភ័យហើយអាចបង្កើនល្បឿនផលិតអាវុធនុយក្លេអ៊ែររបស់ខ្លួនដែរ ហើយប្រទេសប៉ាគីស្ថានក៏ធ្វើតាមផងដែរ)។

សន្ធិសញ្ញាកម្រិតអាវុធយុទ្ធសាស្ត្រ (SALT) ក្នុងទសវត្សរ៍ឆ្នាំ ១៩៧០ បានដាក់កម្រិតជាផ្លូវការលើការបង្កើនអាវុធយុទ្ធសាស្ត្ររបស់ភាគីទាំងពីរ។ កិច្ចព្រមព្រៀងគ្រប់គ្រងអាវុធថ្មីៗបន្ថែមទៀតបានគ្រប់គ្រងការកាត់បន្ថយកម្លាំងនុយក្លេអ៊ែរយ៉ាងច្រើន បន្ទាប់ពីចុងបញ្ចប់នៃសង្គ្រាមត្រជាក់។ ឃ្លាំងអាវុធអាមេរិកបានឡើងដល់ចំណុចកំពូល ក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ នៅក្បាលគ្រាប់ជាង ៣០០០០ គ្រាប់ ចំណែក ឃ្លាំងអាវុធសូវៀតបានឡើងដល់ចំណុចកំពូល ក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ ដែលមានចំនួនជាង ៤០០០០។ សន្ធិសញ្ញាកាត់បន្ថយអាវុធយុទ្ធសាស្ត្រ (START) ឆ្នាំ ១៩៩១ បានកំណត់ចំនួនក្បាលគ្រាប់ ត្រឹម ៦០០០ សម្រាប់ភាគីនីមួយៗ។ ទន្ទឹមនឹងនេះ សន្ធិសញ្ញាកាត់បន្ថយអាវុធវាយប្រហារដោយយុទ្ធសាស្ត្រ ឆ្នាំ ២០០២ (SORT) បានអំពាវនាវអោយមានការកាត់បន្ថយបន្ថែមទៀត ដល់ ២២០០ សម្រាប់ភាគីនីមួយៗ យ៉ាងយូរនៅត្រឹមឆ្នាំ ២០១២ ប៉ុន្តែវាពឹងផ្អែកលើយន្តការនៃសន្ធិសញ្ញាកាត់បន្ថយអាវុធយុទ្ធសាស្ត្រ ដើម្បីផ្ទៀងផ្ទាត់បញ្ជាក់ការពិត។ នៅខែមីនា ឆ្នាំ ២០១០ ភាគីដែលបានចុះហត្ថលេខាលើសន្ធិសញ្ញាមួយ (ហៅថា New START) ដែលនឹងកាត់បន្ថយចំនួនក្បាលគ្រាប់ មកត្រឹម ១៥៥០ គ្រាប់ ហើយថែមទាំងបង្កើតយន្តការផ្ទៀងផ្ទាត់បន្ថែមសម្រាប់ភាគីទាំងពីរផងដែរ។ គោលការណ៍បដិការដែលបានជំរុញអោយមានការប្រណាំងប្រជែងសព្វាវុធក៏អាចជំរុញអោយមានដំណើរការបញ្ច្រាសបកក្រោយជាជំហានៗ មកវិញដែរ។

ប្រទេសចិន បារាំង និងអង់គ្លេសមានអាវុធរាប់រយដើម ដោយអាវុធរបស់ប្រទេសបារាំង និងអង់គ្លេសភាគច្រើនជាមីស៊ីលបាញ់ពីនាវាជ្រមុជទឹក ហើយចំណែកភាគច្រើនរបស់ចិនជាគ្រាប់បែករយៈចម្ងាយឆ្ងាយ និងមីស៊ីលរយៈចម្ងាយមធ្យម។

សន្ធិសញ្ញាហាមឃាត់ការសាកល្បងដ៏ទូលំទូលាយ (CTBT) ដើម្បីបញ្ឈប់រាល់ការបំផ្ទុះសាកល្បងនុយក្លេអ៊ែរត្រូវបានចុះហត្ថលេខា ក្នុងឆ្នាំ ១៩៩៦ ក្រោយពេលជាប់គាំងជាច្រើនទសវត្សរ៍មកហើយ។ វាមានគោលដៅរារាំងការអភិវឌ្ឍន៍អាវុធនុយក្លេអ៊ែរប្រភេទថ្មី។ ទោះជាយ៉ាងណាក៏ដោយ សន្ធិសញ្ញានេះមិនបានចូលជាធរមានទេ រហូតទាល់តែមានការចុះហត្ថលេខានិងផ្តល់សច្ចាប័នដោយរដ្ឋទាំង ៤៤ ដែលគេជឿថាមានសមត្ថភាពយ៉ាងហោចណាស់អាចសាងសង់អាវុធនុយក្លេអ៊ែរឆៅ។ ប្រទេសឥណ្ឌាមិនបានចុះហត្ថលេខាលើសន្ធិសញ្ញាហាមឃាត់ការសាកល្បងដ៏ទូលំទូលាយនោះទេ ហើយថែមទាំងបានធ្វើនតឹងវា នៅឆ្នាំ ១៩៩៨ ជាមួយនឹងការធ្វើតេស្តអាវុធនុយក្លេអ៊ែរ ចំនួន ៥ ដង។ ប្រទេសប៉ាគីស្ថានបានធ្វើតាម ដោយការសាកល្បងអាវុធរបស់ខ្លួនដែរ។ ព្រឹទ្ធសភាសហរដ្ឋអាមេរិកបានបោះឆ្នោតនៅឆ្នាំ ១៩៩៩ ប្រឆាំងនឹងការផ្តល់សច្ចាប័នលើសន្ធិសញ្ញាហាមឃាត់ការសាកល្បងដ៏ទូលំទូលាយ។ ចំណែកប្រទេសរុស្ស៊ីបានផ្តល់សច្ចាប័ននៅឆ្នាំ ២០០០។ ទោះបីមិនមានការសាកល្បងនុយក្លេអ៊ែរបានកើតឡើងនៅទូទាំងពិភពលោក ក្នុងចន្លោះឆ្នាំ ១៩៩៩-២០០៥ ក៏ដោយ ការសាកល្បងនុយក្លេអ៊ែររបស់កូរ៉េខាងជើងក្នុងឆ្នាំ ២០០៦, ២០០៩, ២០១៣, ២០១៦ និង ២០១៧បានធ្វើអោយមានការខកចិត្តកាន់តែខ្លាំងចំពោះសន្ធិសញ្ញាហាមឃាត់ការសាកល្បងដ៏ទូលំទូលាយ។

ការផលិតអាវុធប្រល័យលោកទាំងអស់មានការលំបាកខ្លាំងនិងមានតម្លៃថ្លៃណាស់ ប៉ុន្តែ ពួកវាផ្តល់តែសមត្ថភាពឯកទេសដ៏កម្រ ប្រសិនបើត្រូវបានប្រើប្រាស់ពិតប្រាកដមែន។ នេះជាមូលហេតុដែលរដ្ឋភាគច្រើនដែលមានសមត្ថភាពបច្ចេកទេសអាចធ្វើបាន បានសម្រេចចិត្តមិនផលិតទៅវិញ។ ការគិតគូរអំពីការចំណាយនិងផលចំណេញ បែបនេះ ក៏អាចត្រូវបានអនុវត្តយ៉ាងទូលំទូលាយ ក្នុងការសម្រេចចិត្តរបស់រដ្ឋអំពីការទទួលបានកងកម្លាំងយោធាគ្រប់ប្រភេទ។

៦.៥. រដ្ឋ និងយោធា

៦.៥. តើភាពតានតឹងនៅក្នុងទំនាក់ទំនងស៊ីវិលនឹងយោធាធ្វើអោយប៉ះពាល់ដល់ប្រតិបត្តិការយោធានិងអាចគំរាមកំហែងដល់ស្ថិរភាពនយោបាយ ដោយរបៀបណាខ្លះ។ ចូរពន្យល់។

ដោយគិតគូរពីសមត្ថភាពយោធាគ្រប់ប្រភេទ ដែលរដ្ឋនីមួយៗអាចនឹងទទួលបាន (ក្នុងតម្លៃផ្សេងៗ) តើមេដឹកនាំរដ្ឋគួរជ្រើសរើសបង្កើនសមត្ថភាពយោធាទំហំប៉ុណ្ណា និងប្រភេទណាខ្លះ? រដ្ឋទាំងអស់ប្រឈមមុខនឹងសំណួរពីរនេះ ប៉ុន្តែពួកគេឆ្លើយតាមរបៀបផ្សេងៗគ្នា។

៦.៥.១. សេដ្ឋកិច្ចយោធា

ការជ្រើសរើសទំហំនិងប្រភេទកងកម្លាំងយោធាត្រូវអាស្រ័យទៅលើទំនាក់ទំនង រវាងការចំណាយលើវិស័យយោធារបស់រដ្ឋនិងសុខភាពសេដ្ឋកិច្ចរបស់រដ្ឋនោះ។ ប្រជាជននៅសហរដ្ឋអាមេរិកធ្លាប់ជឿថា «សង្គ្រាមមានលក្ខណៈអំណោយផលល្អសម្រាប់សេដ្ឋកិច្ច» ពីព្រោះ ការចំណាយលើវិស័យយោធាទំនងជាបានជួយបញ្ចប់មហាវិបត្តិសេដ្ឋកិច្ច នៅចុងទសវត្សរ៍ឆ្នាំ ១៩៣០។ ប្រសិនបើនេះជាការពិត មេដឹកនាំរដ្ឋនឹងមិនប្រឈមមុខនឹងជម្រើសដ៏ពិបាកក្នុងការកំណត់ទំហំថវិកាយោធាទេ។ ការចំណាយខ្ពស់លើវិស័យយោធានឹងផ្តល់អោយរដ្ឋនានានូវសមត្ថភាពយោធាបន្ថែមទៀតសម្រាប់ប្រើប្រាស់ក្នុងជម្លោះអន្តរជាតិផង *និង* កំណើនសេដ្ឋកិច្ចកាន់តែច្រើនសម្រាប់តម្រូវការក្នុងស្រុក (ការទិញការគាំទ្រនយោបាយនិងប្រជាប្រិយតាមវិធីផ្សេងៗ)។ ជាអកុសលសម្រាប់មេដឹកនាំរដ្ឋ ការបែងចែកធនធានសេដ្ឋកិច្ចសម្រាប់គោលបំណងយោធានឹងត្រូវកាត់បន្ថយធនធានសម្រាប់អភិវឌ្ឍទិដ្ឋភាពផ្សេងទៀតនៃវិស័យសេដ្ឋកិច្ច និងកាត់បន្ថយកំណើនរយៈពេលវែងផងដែរ។

ទាំងផលប៉ះពាល់នៃការចំណាយយោធា រយៈពេលវែងនិងរយៈពេលខ្លី ត្រូវបានពង្រីកដោយសង្គ្រាមជាក់ស្តែង។ សង្គ្រាមមិនត្រឹមតែជំរុញការចំណាយយោធាខ្ពស់ប៉ុណ្ណោះទេ វាថែមទាំងបំផ្លាញរដ្ឋឬរាជធានី (ប្រជាជន ទីក្រុង កសិដ្ឋាន និងរោងចក្រ នៅក្នុងតំបន់ប្រយុទ្ធ) និងបណ្តាលអោយមានអតិផរណា (កាត់បន្ថយការផ្គត់ផ្គង់ទំនិញផ្សេងៗ ស្របពេលដែលតម្រូវការត្រូវកើនឡើង)។ រដ្ឋាភិបាលត្រូវតែបង់ថ្លៃចំណាយយុទ្ធបករណ៍ ដោយការខ្ចីប្រាក់បន្ថែម (បង្កើនបំណុលរបស់រដ្ឋាភិបាល), ដោយការបោះពុម្ពរូបិយបណ្ណបន្ថែម (ជំរុញអតិផរណាកាន់តែខ្ពស់) ឬដោយការបង្កើនពន្ធ (កាត់បន្ថយការចំណាយនិងការវិនិយោគ)។ លោក ថូម៉ាស់ កេន (Thomas Paine) ក្នុងកំឡុងសម័យបដិវត្តន៍នៅសហរដ្ឋអាមេរិកបានព្រមាន នៅឆ្នាំ ១៧៨៧ ថា «សង្គ្រាម . . . មានរឿងមួយជាក់លាក់ ហើយនោះគឺជាការដំឡើងពន្ធ»។[២៤]

យ៉ាងណាក៏ដោយ សង្គ្រាមនិងការចំណាយខ្ពស់លើវិស័យយោធា អាចមានផលប្រយោជន៍សេដ្ឋកិច្ចជាក់លាក់ផងដែរ។ ការជំរុញកំណើនសេដ្ឋកិច្ចរយៈពេលខ្លី អាចបណ្តាលមកពីការជំរុញការចំណាយយោធា។ អត្ថប្រយោជន៍ដ៏មានសក្តានុពលមួយទៀតគឺការទទួលបានទឹកដី (រួមមានធនធាន និងដើមទុន)។ ជនជាតិសៃប៊ីជ្រុលនិយមបានបង្កើតទ្រព្យសម្បត្តិមហាសាល ពីការលួចឆក់ប្លន់ទ្រព្យរបស់ជនជាតិបូស្នៀដែលពួកគេបានធ្វើ«ការបោសម្អាតជាតិសាសន៍» ចំណែកមេដឹកនាំកងជីវពលកុងហ្គោបានបង្កើនភាពមានបានផ្ទាល់ខ្លួនជាមួយនឹងសារធាតុរ៉ែដែលបាននាំចេញក្នុងអំឡុងពេលសង្គ្រាមស៊ីវិល។ អត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចដ៏មានសក្តានុពលមួយទៀតនៃសង្គ្រាមគឺការជំរុញស្មារតីស្នេហាជាតិរបស់ប្រជាជន ដូច្នេះពួកនឹងប្រឹងប្រែងតស៊ូកាន់តែខ្លាំងថែមទៀត ទោះទទួលបានប្រាក់កម្រៃតិចក៏ដោយ។ ប៉ុន្តែ ជារួម ផលប៉ះពាល់នៃសង្គ្រាមលើវិស័យសេដ្ឋកិច្ចមានទំហំធំធេងជាងអត្ថប្រយោជន៍ណាមួយដែលភាគីពាក់ព័ន្ធអាចទទួលបាន។

ការចំណាយលើវិស័យយោធារបស់រដ្ឋនីមួយៗមានភាពខុសគ្នា យ៉ាងទូលំទូលាយ ក្នុងនោះ ចាប់ពីប្រទេសកូស្តារីកាដែលស្ទើរតែគ្មានការចំណាយខាងយោធាទាល់តែសោះ រហូតដល់ប្រទេសកូរ៉េខាងជើងដែលលះបង់ ២០ ភាគរយ (ឬច្រើនជាងនេះ) នៃផលិតផលក្នុងស្រុកសរុប (GDP) ដើម្បីតែគោលបំណងយោធារបស់ខ្លួន។ ប្រសិនបើថវិកាយោធាមានកម្រិតទាបពេក រដ្ឋអាចនឹងមិនបានត្រៀមលក្ខណៈដើម្បីឆ្លើយតបនឹងការគំរាមកំហែងផ្នែកសន្តិសុខជាយថាហេតុណាមួយ ក្នុងករណីដ៏អាក្រក់បំផុត ពួកគេអាចនឹងការលុកលុយនិងត្រូវសត្រូវធ្វើសញ្ជ័យយកដោយកម្លាំងយោធា។ ប៉ុន្តែប្រសិនបើមេដឹកនាំកំណត់ទំហំថវិកាយោធាខ្ពស់ពេកនោះពួកគេនឹងទទួលបន្ទុកធ្ងន់ធ្ងរពេក និងបណ្តាលអោយសេដ្ឋកិច្ចជាតិកាន់តែដុនដាប។

ការចំណាយលើវិស័យយោធាក្នុងពិភពលោកទាំងមូលមានទំហំប្រហែល ២,៤ ភាគរយ នៃតំលៃទំនិញនិងសេវាកម្មសរុប នៅក្នុងសេដ្ឋកិច្ចពិភពលោក បើគិតជាទឹកប្រាក់ជាក់ស្តែង ប្រហែល ១,៧ ទ្រីលាន (trillion)ដុល្លារ ជារៀងរាល់ឆ្នាំ ឬប្រហែល ១ លានដុល្លារ រៀងរាល់ ២០ វិនាទី។ ភាគច្រើនត្រូវបានចំណាយដោយរដ្ឋធំៗមួយចំនួន ក្នុងនោះ ប្រហែល ៤០ ភាគរយ ដោយសហរដ្ឋអាមេរិកតែម្នាក់ឯង។ (ការចំណាយរបស់សហរដ្ឋអាមេរិកត្រូវបានគេរំពឹងថានឹងធ្លាក់ចុះជាលំដាប់ នៅក្នុងប៉ុន្មានឆ្នាំខាងមុខនេះ នៅពេលដែលសង្គ្រាមរបស់វាបានបញ្ចប់ ប៉ុន្តែ ប្រទេសផ្សេងទៀតកំពុងបង្កើនការចំណាយរបស់ពួកគេ យ៉ាងឆាប់រហ័ស។) ការចំណាយលើវិស័យយោធាពិភពលោកគឺជាលំហូរសាច់ប្រាក់ដ៏ច្រើនមហិមា ដែលប្រសិនបើត្រូវបានបង្វែរ

[២៤] Paine, Thomas. *The Writings of Thomas Paine*. Vol. ២. Knickerbocker, ១៨៩៤.

មកគោលដៅផ្សេង អាចផ្លាស់ប្តូរពិភពលោកយ៉ាងជ្រាលជ្រៅ និងសម្រាលស្ថានភាពលំបាកក្នុងពិភពលោក។ ជាការពិតណាស់ «ពិភពលោក»មិនបានចំណាយប្រាក់ទាំងនេះ ហើយក៏មិនបានជ្រើសរើសថាត្រូវបង្វែរទៅគោលដៅបែបណាដែរ អ្នកដែលសម្រេចគឺជាតួអង្គរដ្ឋ។

នៅក្នុងអឌ្ឍគោលខាងត្បូង ការចំណាយលើវិស័យយោធាមានកម្រិតខុសគ្នាខ្លាំង ពីប្រទេសមួយទៅប្រទេសមួយទៀត ម្យ៉ាងដោយអាស្រ័យលើរដ្ឋាភិបាលដែលកាន់អំណាច (យោធា ឬស៊ីវិល)។ ម្យ៉ាងទៀត ការចំណាយក៏អាស្រ័យយ៉ាងខ្លាំងទៅលើរូបិយប័ណ្ណរឹង ដែលអាចរកបានពីការនាំចេញប្រេង ឬផលិតផលផ្សេងទៀត ដើម្បីចំណាយលើការទិញសព្វាវុធ។

ការលក់សព្វាវុធភាគច្រើន នៅទូទាំងពិភពលោក សំដៅឆ្ពោះទៅកាន់អឌ្ឍគោលខាងត្បូង។ ក្នុងប៉ុន្មានទសវត្សរ៍ថ្មីៗនេះ ប្រហែលពាក់កណ្តាលនៃការនាំចូលសព្វាវុធទាំងនេះ ប្រព្រឹត្តិទៅនៅមជ្ឈិមបូព៌ា ប៉ុន្តែចុងក្រោយនេះ ប្រទេសឥណ្ឌា និងចិនបាននាំចូលកាន់តែច្រើនឡើងៗ។ ការនាំចេញអាវុធអន្តរជាតិភាគច្រើនបានមកពីសហរដ្ឋអាមេរិក ដោយមានប្រទេសរុស្ស៊ី បារាំង និងអង់គ្លេសជាប់ចំណាត់ថ្នាក់បន្តបន្ទាប់ផងដែរ។ នៅក្រោយសង្គ្រាមត្រជាក់បញ្ចប់ភ្លាមៗ ការលក់សព្វាវុធជាសាកលបានធ្លាក់ចុះ ប៉ុន្តែចាប់តាំងពីនោះមក ពួកគេបានកើនឡើងដល់កំរិតជិតពាក់កណ្តាលក្នុងកំឡុងសង្គ្រាមត្រជាក់។

ក្រុមសកម្មជនបានអំពាវនាវអោយមានការយកចិត្តទុកដាក់ចំពោះការលក់អាវុធធុនតូច ជាពិសេសកាំភ្លើងបាញ់រះ ទៅកាន់តំបន់ជម្លោះមិនស្ថិតស្ថេរ ដែលកងទ័ពមិនទៀងទាត់ប្រព្រឹត្តអំពើឃោរឃៅ។ ក្នុងឆ្នាំ ២០០១ រដ្ឋចំនួន ១៤០ បានយល់ព្រមលើកតិកាសញ្ញាស្មគ្រចិត្តដើម្បីទប់ស្កាត់ការលក់អាវុធធុនតូចទៅកាន់តំបន់ជម្លោះ។ រហូតមកដល់ពេលនេះ សហរដ្ឋអាមេរិក ដែលជាប្រទេសនាំចេញអាវុធធុនតូចច្រើនជាងគេបានរារាំងសំណើដើម្បីតបន្តឹងការលក់អាវុធកម្រិតយោធា ដល់ចលនាឧទ្ទាម និងដល់ជនស៊ីវិល។ សន្ធិសញ្ញាពាណិជ្ជកម្មអាវុធបានអនុម័ត ដោយមហាសន្និបាតអង្គការសហប្រជាជាតិក្នុងឆ្នាំ ២០១៣ ដោយមានតែប្រទេសអ៊ីរ៉ង់កូរ៉េខាងជើងនិងស៊ីរីប៉ុណ្ណោះដែលបានបោះឆ្នោតមិនចូលរួម។ សន្ធិសញ្ញានេះបានចូលជាធរមានក្នុងខែធ្នូ ឆ្នាំ ២០១៤។ ខណៈពេលដែលប្រទេសចំនួន ៧៣ បានផ្តល់សច្ចាប័នលើសន្ធិសញ្ញានេះ ការផ្តល់សច្ចាប័នដោយព្រឹទ្ធសភាសហរដ្ឋអាមេរិកហាក់ដូចជាមិនទំនងនឹងកើតឡើងនោះទេ។

ក្រៅពីការពិចារណាអំពីទំហំនៃកងកម្លាំងយោធា ការកំណត់រចនាសម្ព័ន្ធនៃកងកម្លាំងយោធារបស់រដ្ឋមួយក៏បង្ហាញពីជម្រើសដ៏លំបាកផងដែរ។ បេសកកម្មផ្សេងៗគ្នា ត្រូវការកម្លាំងទ័ពខុសៗគ្នា។ នៅក្នុងអំឡុងសង្គ្រាមត្រជាក់ ប្រហែលពាក់កណ្តាលនៃការចំណាយយោធាទាំងអស់ក្នុងថវិការបស់សហរដ្ឋអាមេរិក (និងការចំណាយលើវិស័យយោធាពិភពលោក) ត្រូវបានតម្រង់ឆ្ពោះទៅរកជម្លោះបូព៌ា-បស្ចឹមនៅទ្វីបអឺរ៉ុប។ ឥឡូវនេះ បេសកកម្មផ្សេងទៀត ដូចជាការអន្តរាគមន៍នៅក្នុងជម្លោះក្នុងតំបន់ និងការប្រឆាំងតទល់នឹងការបះបោរមានសារៈសំខាន់ជាង។ ហើយបេសកកម្មថ្មីផ្សេងទៀតរបស់កងកម្លាំងយោធារួមមានទាំងបេសកកម្មជំនួយមនុស្សធម៌ ការបង្ក្រាបគ្រឿងញៀន និងជំនួយដល់ប្រជាជាតិដទៃទៀត ក្នុងការកសាងផ្លូវនិងសាលារៀន។

៦.៥.២. ការគ្រប់គ្រងកងកម្លាំងយោធា

គេមិនអាចវាយតម្លៃទាបចំពោះសមត្ថភាពរបស់មេដឹកនាំរដ្ឋណាមួយ ក្នុងការបញ្ជាអោយកងកម្លាំងយោធាធ្វើសកម្មភាពដែលពួកគេប្រាថ្នាចង់បាននោះទេ។ ល្អបំផុត កងកម្លាំងយោធាគឺជាស្ថាប័នដ៏ធំនិងស្មុគស្មាញបំផុត

ដែលប្រតិបត្តិការក្នុងស្ថានភាពលំបាក ជាពិសេសក្នុងអំឡុងពេលសង្គ្រាម។ អាក្រក់បំផុត កងកម្លាំងយោធាមានចិត្តគំនិតផ្ទាល់ខ្លួន។ ពេលខ្លះ មេដឹកនាំរដ្ឋហាក់ដូចជាគ្រប់គ្រងយោធា មិនបានពេញលេញ។

រដ្ឋគ្រប់គ្រងកងកម្លាំងយោធា តាមរយៈ**ខ្សែសង្វាក់បញ្ជា** (chain of command) ដោយដំណើរការពីអាជ្ញាធរខ្ពស់បំផុតនៅក្នុងប្រព័ន្ធហានុក្រម ដែលចាប់ពីមន្ត្រីយោធាថ្នាក់លើរហូតដល់ទាហានកម្រិតទាបបំផុត។ អាជ្ញាធរកំពូល ឬមេបញ្ជាការ ជាធម្មតា ជាមេដឹកនាំនយោបាយកំពូល។ សារៈសំខាន់នៃហានុក្រមយោធានេះត្រូវបានបង្ហាញដោយរឿងមួយពីប្រទេសចិនបុរាណ ដែលស្តេចមួយអង្គកំពុងសម្រេចព្រះទ័យថាតើត្រូវជួលស៊ុនដឺ(Sun Tzu)ធ្វើជាទីប្រឹក្សាឬយ៉ាងណា។ ជាការសាកល្បង ស្តេចបានសុំអោយស៊ុនដឺបង្វឹកហាត់ស្រីស្នំ ចំនួន ២០០ នាក់ អោយក្លាយជាកងទ័ព។ លោក ស៊ុនដឺ បានបែងចែកស្រីស្នំទាំងអស់នោះជាពីរកងពល ដែលបញ្ជាដោយស្រីស្នំសំណព្វចិត្តទាំងពីររបស់ស្តេច។ គាត់បានពន្យល់ពីសញ្ញាបញ្ជាដែលត្រូវដើរទៅមុខ ថយក្រោយ បែរស្តាំ និងបែរឆ្វេង។ ប៉ុន្តែពេលគាត់ផ្តល់សញ្ញា ស្ត្រីទាំងនោះបានត្រឹមតែសើចចំអក។ ពេលនោះ លោក ស៊ុន អ៊ូ បានបញ្ជាអោយប្រហារជីវិតស្រីស្នំជាមេបញ្ជាការទាំងពីរ នៅនឹងកន្លែង ភ្លាមៗ ហើយលើកស្រីស្នំខ្លាំងបំផុតបន្ទាប់អោយកាន់តំណែងជំនួសពួកគេ។ ពេលគាត់ផ្តល់សញ្ញាម្តងទៀត ស្ត្រីទាំងនោះបានស្តាប់តាម ដោយគ្មានកំហុស សូម្បីបន្តិច។ លោក ស៊ុន អ៊ូ បានប្រកាសថា កងទ័ពមានសណ្តាប់ធ្នាប់ល្អ ហើយអាចនឹងត្រូវដាក់ពង្រាយតាមការប្រាថ្នារបស់ស្តេច។ ដូច្នេះ ហានុក្រមកងទ័ពនិងវិន័យយោធាធ្វើអោយកងកម្លាំងប្រដាប់អាវុធមានមុខងារជាឧបករណ៍អំណាចរបស់រដ្ឋ ទោះដោយតម្លៃជាភាពយោរយៅ និងការបាត់បង់សេរីភាពបុគ្គលក៏ដោយ។

នៅក្នុងលក្ខខណ្ឌសមរភូមិជាក់ស្តែង ការគ្រប់គ្រងកងកម្លាំងប្រដាប់អាវុធមានការពិបាកជាពិសេសដោយសារតែប្រតិបត្តិការស្មុគស្មាញ ការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស និងអ័ព្ទនៃសង្គ្រាមដែលបង្កើតឡើងដោយគម្លាតរវាងសកម្មភាពក្នុងសមរភូមិនិងព័ត៌មានកម្រិតបញ្ជារបស់អ្នកលើ។ កងទ័ពឬអ្នកចូលរួមដទៃទៀតត្រូវបានធ្លាក់ចូលក្នុងស្ថានភាពតានតឹងខ្លាំង ធ្វើអោយថ្លង់ដោយសំលេងរំខាន និងអារម្មណ៍ច្របូកច្របល់ដោយសកម្មភាពច្រើន ដែលនៅពេលកំពុងកើតឡើង ហាក់ដូចជាគ្មានន័យអ្វីទាំងអស់។ ពួកគេត្រូវបានអំពាវនាវអោយអនុវត្តសកម្មភាព ដែលអាចនឹងប្រឆាំងនឹងមូលដ្ឋានសភាវគតិ ក៏ដូចជាបទដ្ឋានសីលធម៌ ដូចជាការសម្លាប់មនុស្ស និងប្រថុយនឹងការស្លាប់។ វាពិបាកក្នុងការសម្របសម្រួលកងកម្លាំង ប្រកបដោយប្រសិទ្ធភាពដើម្បីអនុវត្តផែនការសកម្មភាពរួម។ កងកម្លាំងយោធាត្រូវទប់ទល់នឹងបញ្ហាទាំងនេះ តាមរយៈវិន័យយោធា។ ការមិនចុះសម្រុងគ្នា ការបះបោរ និងការរត់ចោលជួរ គឺជាបទល្មើសធ្ងន់ធ្ងរ ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារឬប្រហារជីវិត។ ប៉ុន្តែ វិន័យមិនត្រឹមតែអាស្រ័យលើការដាក់ទណ្ឌកម្មប៉ុណ្ណោះទេ ប៉ុន្តែក៏អាស្រ័យ លើស្មារតីស្នេហាជាតិនិងវិជ្ជាជីវៈរបស់ទាហានផងដែរ។ មន្ត្រីថ្នាក់លើបំផុសបំផុលមនោសញ្ចេតនាជាតិនិយម រំឭកទាហានទាំងឡាយថាខ្លួនកំពុងតស៊ូដើម្បីជាតិនិងគ្រួសារ។ ការប្រយុទ្ធ កសុការ ការប្រាស្រ័យទាក់ទង និងរាល់បញ្ជាការទាំងអស់ ត្រូវអាស្រ័យលើការអនុវត្តរបស់បុគ្គលម្នាក់ៗ ពោលការលើកទឹកចិត្តសំខាន់ណាស់។

រូបថត រថក្រោះចូលកាន់កាប់ទីក្រុងហារ៉ារ៉ែ (Harare) នៃប្រទេសហ្ស៊ីមបាវ៉ែ

រថក្រោះចូលក្រុង

តាមរយៈខ្សែសង្វាក់បញ្ជាតាមហានុក្រម(ពីលើដល់ក្រោម) រដ្ឋគ្រប់គ្រងសកម្មភាពរបស់ទាហាននីមួយៗ រាប់លាននាក់ ដោយបង្កើតជាឥទ្ធិពលនៅក្នុងកណ្តាប់ដៃរបស់មេដឹកនាំរដ្ឋ។ ប៉ុន្តែ ពេលខ្លះកងកម្លាំង

ប្រដាប់អាវុធនៅតែផ្តើននឹងការគ្រប់គ្រងរបស់មន្ត្រីស៊ីវិល។ នៅទីនេះ រថក្រោះមួយបានកាន់កាប់ទីតាំងនៅផ្លូវប្រសព្វដ៏មមាញឹកក្នុងទីក្រុងហារ៉ារ៉ (Harare) នៃប្រទេសហ្ស៊ីមបាវ៉ បន្ទាប់ពីយោធានៅទីនោះបានចាប់ខ្លួនមេដឹកចាស់វស្សា ដោយបង្ខំអោយគាត់ចាកចេញពីអំណាចនៅឆ្នាំ ២០១៧ ។

អង្គភាពយោធាក៏ពឹងផ្អែកលើស្មារតីសាមគ្គីភាពជាក្រុមរបស់ទាហានផងដែរ។ ទាហានប្រថុយជីវិតរបស់ខ្លួន ដោយសារ«យុទ្ធមិត្ត»សង្ឃឹមនិងពឹងផ្អែកលើពួកគេ។ បញ្ញត្តិអរូបី ដូចជាគំនិតជាតិនិយម ស្មារតីស្នេហាជាតិ និងភាពភ្លៀវភ្លាប្តូរផ្តាច់ខាងសាសនាមានសារៈសំខាន់ ប៉ុន្តែភាពស្មោះត្រង់ចំពោះក្រុមផ្ទាល់ (រួមជាមួយនឹងសភាវគតិនៃការរស់រានមានជីវិត) គឺជាការលើកទឹកចិត្តខ្លាំងជាង។ ការជជែកដេញដោលនាពេលថ្មីៗនេះអំពីការចូលរួមរបស់ស្ត្រីនៅក្នុងកងកម្លាំងប្រដាប់អាវុធរបស់សហរដ្ឋអាមេរិក ជុំវិញថាតើវត្តមានរបស់ពួកគេខ្វះខាតដល់សាមគ្គីភាពជាក្រុមដែរឬទេ។ (ភស្តុតាងបង្ហាញថាវាមិនប្រាកដដូច្នោះទេ ហើយនៅក្នុងឆ្នាំ ២០១១ ការហាមទាហានស្រលាញ់ភេទដូចគ្នាមិនអោយបម្រើក្នុងជួរកងទ័ពរបស់សហរដ្ឋអាមេរិកត្រូវបានលើកលែង ដោយសារហេតុផលដូចគ្នានេះដែរ។)

ជាចុងក្រោយ មន្ត្រីនិងអ្នកដឹកនាំនយោបាយ ត្រូវការការស៊ើបការណ៍សម្ងាត់អោយបានត្រឹមត្រូវ ដើម្បីធ្វើការសំរេចចិត្តបានត្រឹមត្រូវល្អដែរ។ ជាការពិតណាស់ សូម្បីតែប្រព័ន្ធស៊ើបការណ៍សម្ងាត់ទំនើបបំផុត ក៏មិនអាចបញ្ឈប់កំហុសរបស់មនុស្សបានដែរ។ ឧប្បត្តិហេតុបាញ់ប្រហារដោលក្នុណៈមិត្តភាព (បាញ់) បង្កអោយមានចំនួនអ្នកស្លាប់ច្រើននាក់ ដោយយោធាអាមេរិក។ នៅចុងឆ្នាំ ២០០១ កងកម្លាំងពិសេសរបស់សហរដ្ឋអាមេរិកបានធ្វើដំណើរជាមួយលោក ហាមីដ ការហ្សៃ (Hamid Karzai) ដែលត្រូវគេជឿ នៅពេលនោះ ថាជាមនុស្សតែម្នាក់គត់ ដែលអាចដឹកនាំរដ្ឋាភិបាលអាហ្វហ្គានីស្ថានរួម និងជាសម្ព័ន្ធមិត្តរបស់សហរដ្ឋអាមេរិក។ នៅពេលដែលទាហានអាមេរិកម្នាក់ត្រូវបានកោះហៅអោយចេញបើកការវាយប្រហារតាមអាកាស លើទីតាំងសត្រូវ ចៃដន្យអ្វី ម៉ាស៊ីនGPSនៅក្នុងអង្គភាពរបស់គាត់អស់ថ្មហើយត្រូវដូរថ្មថ្មី ពេលដូរហើយ កូអរដោនេរបស់នៅក្នុងម៉ាស៊ីនGPSត្រូវបានកំណត់ចូលលំនាំដើម ដោយដាក់ចំទីតាំងរបស់វា។ យន្តហោះចម្បាំងអាមេរិកមួយគ្រឿងបានទម្លាក់គ្រាប់បែកចំគោលដៅនោះ ដោយបានសម្លាប់ទាហានអាមេរិកបីនាក់ និងសម្ព័ន្ធមិត្តអាហ្វហ្គានីស្ថាន ចំនួនប្រាំនាក់ និងស្ទើរតែសម្លាប់លោកការហ្សៃ ថែមទៀតផង។

៦.៥.៣. ទំនាក់ទំនងស៊ីវិល-យោធា

បន្ថែមពីលើការជំនះភាពចលាចលនិងភាពស្មុគស្មាញ មេដឹកនាំរដ្ឋ ជួនកាលត្រូវប្រឈមមុខនឹងបញ្ហានានាពីក្នុងជួរយោធារបស់ពួកគេផងដែរ។ រដ្ឋជាច្រើន ជាពិសេស រដ្ឋប្រជាធិបតេយ្យប្រកាន់ខ្ជាប់នូវគោលការណ៍ *ឧត្តមភាពស៊ីវិល* (civilian supremacy)។ នេះជាគំនិតដែលមេដឹកនាំស៊ីវិល (ដែលត្រូវបានជ្រើសរើស ឬតែងតាំងដោយការបោះឆ្នោត) ស្ថិតនៅកំពូលនៃខ្សែសង្វាក់បញ្ជា។ មន្ត្រីស៊ីវិល មិនមែនមន្ត្រីយោធាទេ ជាអ្នកសម្រេចចិត្តថាត្រូវបញ្ជូនកងទ័ពប្រយុទ្ធនៅពេលណា និងកន្លែងណា។ ផ្ទុយទៅវិញ មន្ត្រីយោធាត្រូវពឹងថាគ្រប់គ្រងរបៀបប្រយុទ្ធរបស់កងទ័ព។

ការបែងចែកវិសាលភាពការងាររវាងមន្ត្រីស៊ីវិល និងកងទ័ព ជៀសមិនរួចនាំអោយមានភាពតានតឹង។ អន្តរកម្មរវាងមន្ត្រីឬជនស៊ីវិលជាមួយនិងមេដឹកនាំយោធា ដែលហៅថា **ទំនាក់ទំនងស៊ីវិលនិងយោធា** (civil-military relations) គឺជាកត្តាសំខាន់មួយ នៅក្នុងរបៀបដែលរដ្ឋប្រើប្រាស់កម្លាំង។ មេដឹកនាំយោធាអាចបន្ថយសិទ្ធិអំណាចរបស់មេដឹកនាំស៊ីវិលក្នុងការអនុវត្តគោលនយោបាយការបរទេស ឬ ពួកគេថែមទាំងអាច

គំរាមកំហែងដល់ឧត្តមភាពស៊ីវិលរបស់មន្ត្រីស៊ីវិល ប្រសិនបើសកម្មភាពជាក់លាក់ណាមួយត្រូវបានប្រព្រឹត្ត នៅក្នុងជម្លោះអន្តរជាតិ។ មន្ត្រីយោធាក៏ចង់បានស្វ័យភាពសម្រេចចិត្ត នៅពេលដែលកងកម្លាំងត្រូវបានបញ្ជូនចេញទៅសមរភូមិ ដើម្បីជៀសវាងបញ្ហាដែលបានបង្កើតឡើងនៅក្នុងសង្គ្រាមវៀតណាម នៅពេលដែលលោកប្រធានាធិបតី ចនសុន អង្គុយនៅក្នុងបន្ទប់ស្ថានការណ៍ក្នុងសេតវិមាន ជ្រើសរើសគោលដៅវាយឆ្មក់ទម្លាក់គ្រាប់បែកប្រចាំថ្ងៃ។ អ្វីដែលអាក្រក់ជាងនេះទៅទៀត នៅក្នុងការទម្លាក់គ្រាប់បែករបស់អង្គការសន្ធិសញ្ញាអាត្លង់ទិកខាងជើង (ណាតូ) ឆ្នាំ ១៩៩៩ ទៅលើប្រទេសស៊ែប៊ី គោលដៅជាក់លាក់ត្រូវតែត្រូវបានអនុម័តដោយអ្នកនយោបាយ នៅក្នុងប្រទេសជាច្រើន។ ក្នុងឆ្នាំ ២០១០ មេទ័ពអាមេរិកនៅប្រទេសអាហ្វហ្គានីស្ថានបានបាត់បង់មុខតំណែងរបស់គាត់បន្ទាប់ពីបានសាកសួរជាសាធារណៈអំពីគោលនយោបាយអាហ្វហ្គានីស្ថានរបស់លោកប្រធានាធិបតីអូបាម៉ា។

សូម្បីតែនៅខាងក្រៅបរិបទសង្គ្រាមកំពុងឆាបឆេះ ភាពខុសគ្នារវាងមេដឹកនាំស៊ីវិល និងយោធាអាចនាំអោយមានភាពតានតឹង។ នៅសហរដ្ឋអាមេរិក ការស្ទាបស្ទង់មតិបង្ហាញយ៉ាងខ្ជាប់ខ្ជួន ដដែលៗ ថា ជាមធ្យមមន្ត្រីយោធាមានមតិយោបល់ ខុសពីជនស៊ីវិល លើបញ្ហាដូចជាការប្រើប្រាស់កងកម្លាំងជាឧបករណ៍សម្រាប់ជាអានុភាព ឬគាបសង្កត់តួអង្គដទៃ។ អ្នកប្រាជ្ញបានចាប់ផ្តើមសិក្សាពីមូលហេតុដែល គម្លាតរវាងជនស៊ីវិលនិងយោធាបានរីកកាន់តែធំ និងផលប៉ះពាល់ចំពោះគោលនយោបាយការបរទេសរបស់អាមេរិក។

ភាពតានតឹងស្រដៀងគ្នានេះក៏មានផងដែរ នៅក្នុងប្រទេសប្រជាធិបតេយ្យផ្សេងទៀត។ នៅប្រទេសទួរគី ភាពតានតឹងបានកើនឡើងរវាងរដ្ឋាភិបាលអ៊ីស្លាម និងកងកម្លាំងយោធារបស់ខ្លួន។ ជាប្រវត្តិសាស្ត្រយោធារបស់ប្រទេសទួរគីបានធ្វើអន្តរាគមន៍ជាច្រើនដងដើម្បីដណ្តើបការគ្រប់គ្រងពីមេដឹកនាំស៊ីវិលជាប់ឆ្នោត នៅពេលដែលមន្ត្រីយោធាមានអារម្មណ៍ថា រដ្ឋាភិបាលកំពុងគំរាមកំហែងដល់លក្ខណៈគ្រប់គ្រងផ្លូវលោកិយរបស់ប្រទេសទួរគី។ យ៉ាងណាក៏ដោយ ថ្មីៗនេះ រដ្ឋាភិបាលស៊ីវិលទួរគីបានប្រើអំពើហិង្សាក្នុងការចាប់ខ្លួនមន្ត្រីដែលពួកគេជឿថាកំពុងធ្វើរដ្ឋប្រហារ។ សកម្មភាពទាំងនេះបានបណ្តាលអោយមានស្ថានភាពផុយស្រួយនៅក្នុងប្រទេសនោះ។ ក្នុងរដូវផ្កាឈូក ឆ្នាំ ២០១១ យោធាអេហ្ស៊ីបបានបដិសេធមិនព្រមបាញ់លើក្រុមបាតុករ តាមការបញ្ជា ចំណែកកងកម្លាំងទ័ពរបស់ប្រទេសស៊ីរីញែបែរជាបើកការបាញ់សម្លាប់រាស្ត្ររបស់ខ្លួន។

ប្រសិនបើភាពតានតឹងរវាងមេដឹកនាំស៊ីវិលនិងកងកម្លាំងយោធាកាន់តែកើនឡើងខ្លាំងៗ លទ្ធផលអាចកើតចេញជា**រដ្ឋប្រហារ** (ជាភាសាបារាំងថា coup d′etat ដែលអាចមានន័យ ជាភាសាអង់គ្លេសថា «blow against the state» ជាភាសាខ្មែរថា «វាយប្រហាររដ្ឋ»)។ រដ្ឋប្រហារ គឺជាការដណ្តើមយកអំណាចនយោបាយដោយកងកម្លាំងយោធាក្នុងស្រុក ដែលជាការផ្លាស់ប្តូរអំណាចនយោបាយនៅក្រៅវិសាលភាពរដ្ឋធម្មនុញ្ញរបស់រដ្ឋ។ លទ្ធផលនៃការប៉ុនប៉ងធ្វើរដ្ឋប្រហារ មានការពិបាកនឹងទាយទុកមុនណាស់។ ប្រសិនបើកងកម្លាំងយោធាភាគច្រើនឬទាំងអស់យល់ស្របឬគាំទ្ររដ្ឋប្រហារ ជាទូទៅ មេដឹកនាំស៊ីវិលគ្មានសង្ឃឹមក្នុងការបញ្ឈប់វាទេ។ ប៉ុន្តែ ប្រសិនបើមន្ត្រីយោធាភាគច្រើនធ្វើតាមខ្សែសង្វាក់បញ្ជាដែលមានស្រាប់ រដ្ឋប្រហារច្បាស់ជាវិនាសមិនខាន។ នៅប្រទេសហ្វីលីពីននៅចុងទសវត្សរ៍ឆ្នាំ ១៩៨០ ឧត្តមសេនីយកំពូល ហ្វីដែល រ៉ាមូស (Fidel Ramos) នៅតែមានភក្តីភាពស្មោះត្រង់ចំពោះប្រធានាធិបតីស៊ីវិល គឺ លោក កូរ៉ាហ្សុង អាគីណូ (Corazón Aquino) ក្នុងការប៉ុនប៉ងធ្វើរដ្ឋប្រហារចំនួនប្រាំពីរ ដោយមន្ត្រីក្រោមឱវាទ។ ក្នុងករណីនីមួយៗ កម្លាំងយោធាហ្វីលីពីនភាគច្រើននៅតែស្មោះត្រង់នឹងលោករ៉ាមូស ហើយរដ្ឋប្រហារត្រូវបរាជ័យ។

សម្ពាធអន្តរជាតិ ដូចជាការដាក់ទណ្ឌកម្ម ក៏អាចបញ្ចុះបញ្ចូលឬអូសទាញមេដឹកនាំយោធាអោយចុះចេញពីតំណែងផងដែរ។ នៅចុងឆ្នាំ ២០០៩ ពួកមេដឹកនាំយោធាបានឡើងកាន់អំណាច នៅក្នុងប្រទេសហុងឌូរ៉ាស (Honduras) បន្ទាប់ពីបានទម្លាក់ប្រធានាធិបតីស៊ីវិល។ សហគមន៍អន្តរជាតិ រួមទាំងអង្គការនៃបណ្តារដ្ឋអាមេរិក(OAS) បានដាក់សម្ពាធលើប្រទេសហុងឌូរ៉ាស ក្រោយមានរដ្ឋប្រហារក្នុងឆ្នាំ ២០០៩។ ការបោះឆ្នោតត្រូវបានធ្វើឡើង នៅរដូវស្លឹកឈើជ្រុះឆ្នាំ ២០០៩ ដោយបានស្តាររដ្ឋាភិបាលប្រជាធិបតេយ្យឡើងវិញ ប៉ុន្តែជនជាតិហុងឌូរ៉ាសនៅតែបែកបាក់គ្នាជុំវិញភាពស្របច្បាប់នៃរដ្ឋាភិបាលថ្មី។

ប្រសិនបើរដ្ឋប្រហារជោគជ័យ កងកម្លាំងយោធាខ្លួនឯងផ្ទាល់គ្រប់គ្រងរដ្ឋាភិបាល។ **រដ្ឋាភិបាលយោធា** (military governments) បែបនេះ មាននិន្នាការជារឿងធម្មតាបំផុត នៅក្នុងប្រទេសក្រីក្រ ដែលយោធាអាចជាស្ថាប័នទំនើបតែមួយគត់ នៅក្នុងប្រទេស។ អ្វីដែលគួរអោយហួសចិត្តនោះ គឺការបញ្ជាការកងកម្លាំងយោធាមជ្ឈឹមដែលមានវិន័យល្អ ដែលធ្វើអោយពួកគេក្លាយជាឧបករណ៍បញ្ចេញឥទ្ធិពលរបស់រដ្ឋដ៏មានប្រសិទ្ធភាព ក៏អាចបណ្តាលអោយរដ្ឋបាត់បង់ការគ្រប់គ្រងលើយោធា ដោយធ្លាក់ទៅក្នុងដៃមន្ត្រីយោធាផងដែរ។ ទាហានត្រូវបានហ្វឹកហ្វឺនអោយធ្វើតាមបទបញ្ជារបស់មេបញ្ជាការ ដោយមិនគិតរឿងនយោបាយ។

ប្រតិបត្តិការសម្ងាត់ក៏អាចឃ្លាតឆ្ងាយពីកណ្តាប់ដៃគ្រប់គ្រងរបស់រដ្ឋាភិបាលផងដែរ។ ប្រតិបត្តិការបែបនេះ បានដំឡើងដល់ចំនួនច្រើនរាប់ពាន់ នៅកំឡុងសង្គ្រាមត្រជាក់ នៅពេលដែលភ្នាក់ងារ CIA និងសមភាគីសូវៀត ភ្នាក់ងារ KGB បានធ្វើសង្គ្រាមសម្ងាត់ ដែលកំពុងបន្តនៅទូទាំងពិភពលោក។ ប្រតិបត្តិការសម្ងាត់របស់ CIA ក្នុងទសវត្សរ៍ឆ្នាំ ១៩៥០ បានផ្តួលរំលំរដ្ឋាភិបាលបរទេសដែលមិនមេត្រីជាមួយខ្លួន ដូចជានៅប្រទេសអ៊ីរ៉ង់ និងហ្គាតេម៉ាឡា ដោយរៀបចំរដ្ឋប្រហារប្រឆាំងនឹងពួកគេ។ ការវាយឆ្មក់នៅ«ឈូងសមុទ្រជ្រូក» (Bay of Pigs) ដែលរៀបគំរោងដោយភ្នាក់ងារ CIA ក្នុងប្រទេសគុយបា ក្នុងឆ្នាំ ១៩៦១ គឺជាបរាជ័យដ៏ធំដំបូងរបស់ខ្លួន បន្ទាប់មកដោយការប្រឹងប្រែងដែលបរាជ័យផ្សេងទៀតប្រឆាំងនឹងរដ្ឋាភិបាលរបស់លោកកាស្ត្រូ(Castro) (រួមទាំងការប៉ុនប៉ងធ្វើឃាតចំនួនប្រាំបីដង)។ សកម្មភាពលួចលាក់របស់ភ្នាក់ងារ CIA ត្រូវបានកាត់បន្ថយយ៉ាងខ្លាំង បន្ទាប់ពីសវនាការរបស់រដ្ឋសភាអាមេរិក ក្នុងទសវត្សរ៍ឆ្នាំ ១៩៧០ បង្ហាញពីរឿងអាស្រូវទាំងនោះ។ បន្ទាប់ពី(ការវាយប្រហារភេរវកម្ម) ខែកញ្ញា ឆ្នាំ ២០០១ ស្ថាប័ននីតិប្រតិបត្តិបានរីករាយនឹងសិទ្ធិអំណាចកាន់តែច្រើនក្នុងការធ្វើប្រតិបត្តិការសម្ងាត់ ជាមួយនឹងការត្រួតពិនិត្យពីសភាតិចជាងមុន។

សរុបមក រដ្ឋនានាប្រឈមមុខនឹងជម្រើសដ៏ស្មុគស្មាញទាក់ទងនឹងការកំណត់រចនាសម្ព័ន្ធកងកម្លាំងយោធារបស់ពួកគេ នៅក្នុងសម័យក្រោយសង្គ្រាមត្រជាក់។ មិនត្រឹមតែយថាហេតុនិងការគំរាមកំហែងផ្ទាល់ដែលប្រែប្រួលភ្លាមៗប៉ុណ្ណោះទេ ប៉ុន្តែ លក្ខណៈនៃការគំរាមកំហែងក្នុងសម័យថ្មីក៏មិនមានភាពច្បាស់លាស់ដែរ។ ប៉ុន្តែ ប្រហែលការប្រែប្រួលដែលសំខាន់បំផុត គឺសណ្តាប់ធ្នាប់ពិភពលោកផ្ទាល់ដែលបាននិងកំពុងវិវឌ្ឍដូចបច្ចេកវិទ្យាយោធាដែរ។ មេរៀនបន្ទាប់នឹងពិភាក្សាអំពីរចនាសម្ព័ន្ធនិងបទដ្ឋាន ដែលបាននិងកំពុងវិវឌ្ឍសម្រាប់គ្រប់គ្រងទំនាក់ទំនងនយោបាយអន្តរជាតិ និងរបៀបដែលពួកគេកំពុងផ្លាស់ប្តូរលក្ខណៈនៃសណ្តាប់ធ្នាប់ពិភពលោក។

សេចក្តីសន្ទនប

១. កងកម្លាំងយោធារួមមានសមត្ថភាពជាច្រើនប្រភេទ ដែលបំពេញគោលបំណងផ្សេងៗគ្នា។ សង្គ្រាមទូទៅទាមទារអោយមានប្រភេទកម្លាំងផ្សេងៗច្រើនជាងកងកម្លាំងដែលត្រូវការជាចាំបាច់ ដើម្បីគំរាមកំហែង ការប្រើប្រាស់អាវុធនុយក្លេអ៊ែរ អាវុធគីមី ឬអាវុធជីវសាស្ត្រ។

២. ការគ្រប់គ្រងទឹកដីគឺជាមូលដ្ឋានគ្រឹះនៃអធិបតេយ្យភាពរបស់រដ្ឋ ហើយអាចសម្រេចបាន ជាមួយនឹងការប្រើប្រាស់កងទ័ពជើងគោក ជាចម្បង។

៣. សង្គ្រាមដែនអាកាស ដោយប្រើគ្រាប់បែកតម្រង់ទិសជាក់លាក់ប្រឆាំងនឹងគោលដៅសមរភូមិ បានបង្ហាញពីប្រសិទ្ធភាពខ្ពស់ នៅក្នុងយុទ្ធនាការសហរដ្ឋអាមេរិក នៅប្រទេសអ៊ីរ៉ាក់ក្នុងឆ្នាំ ១៩៩១, ប្រទេសស៊ែប៊ីក្នុងឆ្នាំ ១៩៩៩, ប្រទេសអាហ្វហ្គានីស្ថាននៅឆ្នាំ ២០០១ និងប្រទេសអ៊ីរ៉ាក់នៅឆ្នាំ ២០០៣។

៤. សង្គ្រាមជ្រូននិងអេឡិចត្រូនិច បានក្លាយជាឧបករណ៍ដាក់គំនាបកាន់តែសំខាន់ ជាពិសេសសម្រាប់តួអង្គរដ្ឋនិងតួអង្គមិនមែនរដ្ឋ។

៥. អំពើភេរវកម្មមានប្រសិទ្ធភាពប្រសិនបើវាអាចបំបាក់ស្មារតីប្រជាជនអោយតក់ស្លុតនិងទទួលបានចំណាប់អារម្មណ៍ពីប្រព័ន្ធផ្សព្វផ្សាយដែលបង្ហាញពីបុព្វហេតុរបស់ពួកគេ។

៦. ការវាយប្រហារមហាភេរវកម្ម នៅខែកញ្ញា ឆ្នាំ ២០០១ ខុសពីអំពើភេរវកម្មមុនៗ ទាំងក្នុងទំហំនៃការបំផ្លិចបំផ្លាញនិងនៅក្នុងបណ្តាញភេរវកម្មអាល់កៃដាទូទាំងពិភពលោក។ ការវាយប្រហារបានបង្ខំអោយមានការផ្លាស់ប្តូរយ៉ាងខ្លាំង នៅក្នុងការរៀបចំសន្តិសុខសហរដ្ឋអាមេរិកនិង ទូទាំងពិភពលោក និងបានជំរុញអោយមានអន្តរាគមន៍យោធារបស់សហរដ្ឋអាមេរិកនៅក្នុងប្រទេសអាហ្វហ្គានីស្ថាន ដើម្បីផ្តួលរំលំរបបតាលីបង់ និងបំផ្លាញមូលដ្ឋានអាល់កៃដានៅទីនោះ។

៧. អាវុធប្រល័យលោកដូចជាអាវុធនុយក្លេអ៊ែរ គីមី និងជីវសាស្ត្រ កម្រត្រូវបានគេប្រើនៅក្នុងសង្គ្រាមណាស់។

៨. រដ្ឋជាច្រើន រួមទាំងតួអង្គមិនមែនរដ្ឋមួយចំនួនផង តាមលក្ខណៈបច្ចេកទេស មានមធ្យោបាយ ផលិតអាវុធនុយក្លេអ៊ែរ ប៉ុន្តែ ពិបាកទទួលបានវត្ថុបំលែងចាំបាច់ (អ៊ុយរ៉ាញ៉ូម-២៣៥ ឬផ្លាតូញ៉ូម) ណាស់។

៩. រដ្ឋឧស្សាហកម្មភាគច្រើន និងប្រទេសក្រីក្រជាច្រើន បានសម្រេចចិត្តមិនផលិតឬទទួលអាវុធនុយក្លេអ៊ែរដោយស្ម័គ្រចិត្ត។ រដ្ឋទាំងនេះរួមបញ្ចូលទាំងប្រទេសមហាអំណាចពីរ គឺអាឡឺម៉ង់ និងជប៉ុន។

១០. រដ្ឋជាច្រើនកំពុងទទួលបានមីស៊ីលផ្លោងដែលអាចវាយប្រហាររដ្ឋផ្សេងទៀត ពីចម្ងាយរាប់រយម៉ាយល៍ (ឬធ្វាយជាងនេះ អាស្រ័យលើរយៈចម្ងាយមីស៊ីល)។ ប៉ុន្តែ គ្មានរដ្ឋណាមួយធ្លាប់វាយប្រហាររដ្ឋដទៃដោយអាវុធប្រល័យលោក ដែលបានបំពាក់លើមីស៊ីលផ្លោងឡើយ។

១១. ការផលិតអាវុធគីមីមានតម្លៃថោកជាងការផលិតអាវុធនុយក្លេអ៊ែរ អាវុធទាំងពីរមានតម្លៃគំរាមកំហែងប្រហាក់ប្រហែលគ្នា ហើយគេពិបាកនឹងរកឃើញការលួចលាក់ផលិតពួកវាណាស់។ ប្រទេស អំណាចមធ្យមមានអាវុធគីមីច្រើនជាងអាវុធនុយក្លេអ៊ែរ។ សន្ធិសញ្ញាថ្មីហាមឃាត់ការកាន់កាប់និងការប្រើប្រាស់អាវុធគីមី។

១២. រដ្ឋមួយចំនួនធ្វើការស្រាវជ្រាវអំពីសង្គ្រាមជីវសាស្ត្រ ប៉ុន្តែដោយសារសន្ធិសញ្ញា ការកាន់កាប់អាវុធបែបនេះត្រូវហាមឃាត់។

១៣. ការបន្តយល្បឿននៃការរីកសាយមីស៊ីលផ្លោងនិងអាវុធប្រល័យលោកនៅក្នុងអឌ្ឍគោលភាគខាងត្បូង គឺជាកង្វល់ជាចម្បងរបស់ប្រទេសមហាអំណាច។

១៤. សហរដ្ឋអាមេរិកកំពុងធ្វើសាកល្បងប្រព័ន្ធ ការពារប្រឆាំងនឹងការវាយប្រហារមីស៊ីលផ្លោង ទោះបីជាមិនទាន់មានភស្តុតាងណាមួយបង្ហាញពីប្រសិទ្ធិភាពនៅឡើយ និងបានដកខ្លួនខ្លួនចេញពីសន្ធិសញ្ញាប្រឆាំងមីស៊ីលផ្លោងជាមួយប្រទេសរុស្ស៊ី ដើម្បីបន្តកម្មវិធីនេះក៏ដោយ។

១៥. សហរដ្ឋអាមេរិកនិងរុស្ស៊ីមានឃ្លាំងអាវុធនុយក្លេអ៊ែរពាប់ពាន់ ចំណែកប្រទេស ចិន អង់គ្លេស និង បារាំង មានរាប់រយគ្រឿង។ ប្រទេសអ៊ីស្រាអែល ឥណ្ឌា និងប៉ាគីស្ថាន មានមួយចំនួនដែរ។ ការដាក់ពង្រាយអាវុធត្រូវបានចង្អុលបង្ហាញដោយយុទ្ធសាស្ត្រនុយក្លេអ៊ែរ ដោយផ្អែកលើគំនិតនៃការទប់ស្កាត់។

១៦. កិច្ចព្រមព្រៀងត្រួតពិនិត្យអាវុធកំណត់ជាផ្លូវការនូវគំរោងនៃការប្រណាំងប្រជែងសព្វាវុធ ឬដំណើរការដកហូតអាវុធរៀងៗខ្លួនដូចគ្នា។ ការគ្រប់គ្រងអាវុធបានជួយបង្កើតទំនុកចិត្តរវាងប្រទេសមហាអំណាចក្នុងអំឡុងពេលសង្គ្រាមត្រជាក់។

១៧. មេដឹកនាំនយោបាយប្រឈមនឹងជម្រើសដ៏ពិបាក ក្នុងការកំណត់រចនាសម្ព័ន្ធនៃកងកម្លាំងយោធា និងការចំណាយសម្រាប់ពួកគេ។ ការចំណាយខាងយោធាទំនងជាជំរុញកំណើនសេដ្ឋកិច្ច ក្នុងរយៈពេលខ្លីតែកាត់បន្ថយកំណើន ក្នុងរយៈពេលវែង។

១៨. នៅទសវត្សឆ្នាំ ១៩៩០ កងកម្លាំងយោធានិងការចំណាយរបស់ប្រទេសមហាអំណាច ជាពិសេសរុស្ស៊ី ត្រូវបានកាត់បន្ថយនិងរៀបចំរចនាសម្ព័ន្ធឡើងវិញ។

១៩. លើកលែងតែក្នុងពេលមានសង្គ្រាមស៊ីវិល មេដឹកនាំរដ្ឋ មិនថាជាស៊ីវិល ឬ យោធា គ្រប់គ្រងកម្លាំងយោធាតាមរយៈខ្សែសង្វាក់បញ្ជាតាមឋានានុក្រមតែមួយ។

២០. កម្លាំងយោធាអាចគំរាមកំហែងដល់អំណាចមេដឹកនាំរដ្ឋក្នុងស្រុក ដែលងាយរងគ្រោះពីការផ្តួលរំលំដោយរដ្ឋប្រហារ។

ពាក្យគន្លឹះ

១. **ទាហានថ្មើរជើង** (infantry) គឺជាទាហានជើងគោក ដែលប្រើកាំភ្លើងបាញ់ប្រហារ និងអាវុធធុនស្រាលផ្សេងទៀត (គ្រាប់មីន និង កាំភ្លើងយន្ត ។ល។)។

២. **ការប្រឆាំងតទល់នឹងការបះបោរ** (counterinsurgency) គឺជាកិច្ចខិតខំប្រឹងប្រែងដើម្បីប្រយុទ្ធប្រឆាំងនឹងកងទ័ពព្រៃ ការបះបោរ ជាញឹកញាប់ រួមបញ្ចូលកម្មវិធីយក «ឈ្នះបេះដូងនិងចិត្តគំនិត» របស់ប្រជាជន ដើម្បីអោយពួកគេឈប់ផ្តល់ជំរកឬលាក់បំពួនទ័ពព្រៃ។

៣. **គ្រាប់មីន** (landmines) គឺជាឧបករណ៍ផ្ទុកគ្រឿងផ្ទុះ ជារឿយៗ បន្សល់ទុកដោយកងទ័ពមិនទៀងទាត់ដែលសម្លាប់ ឬបំផ្លិចបំផ្លាញជីវិតជនស៊ីវិល ក្រោយពេលសង្គ្រាមបានបញ្ចប់។ ចំការមីនបែបនេះមានចំនួនជាង ១០០ លាន ជាចម្បង នៅក្នុងប្រទេសអង់ហ្គោឡា បូស្នៀ អាហ្វហ្គានីស្ថាន និងកម្ពុជា។ ចលនាហាមឃាត់ការប្រើប្រាស់គ្រាប់មីនកំពុងដំណើរការ។ ជាង ១០០ រដ្ឋ បានយល់ព្រមធ្វើដូច្នេះ។

៤. **ការបញ្ចេញឬសម្ដែងអំណាច** (power projection) គឺជាសមត្ថភាពក្នុងការប្រើប្រាស់កម្លាំងយោធា នៅក្នុងតំបន់ឆ្ងាយពីប្រទេស ឬតំបន់នៃឥទ្ធិពលរបស់ប្រទេសខ្លួន។

៥. **ដ្រូន** (drones) គឺជាសទិសន័យនៃពាក្យយន្តហោះគ្មានមនុស្សបើក ឧបករណ៍ហោះហើរតូចៗទាំងនេះ ដែលអាចត្រូវបានបំពាក់អាវុធ ឬមិនបំពាក់ កំពុងត្រូវបានប្រើប្រាស់កាន់តែច្រើនឡើង នៅក្នុងយុទ្ធនាការប្រយុទ្ធផ្ទាល់និងការឈ្លបយកការណ៍។

៦. **សង្គ្រាមអេឡិចត្រូនិច** (electronic warfare) គឺជាការប្រើប្រាស់វិសាលគមអេឡិចត្រូម៉ាញ៉េទិច (រលកវិទ្យុ រ៉ាដា កាំរស្មីអ៊ីនហ្វ្រារ៉េដ ជាដើម) ដូចជាការបញ្ចេញរលកសញ្ញាមេញ៉េទិកអេឡិកត្រូនិកដើម្បីបានប្រយោជន៍សម្រាប់កងទ័ពខ្លួន ប៉ុន្តែរំខានមិនអោយសត្រូវប្រើប្រាស់បានឡើយ។

៧. **បច្ចេកវិទ្យាបំភ័ន្តភ្នែក ឬបំបាំងកាយ** (stealth technology) គឺជាប្រើសម្ភារៈពិសេសដែលអាចបន្លំប្រព័ន្ធរ៉ាដានិងមានរាងរៅមិនប្រក្រតីនៅក្នុងការរចនាយន្តហោះ កាំជ្រួច និងកប៉ាល់ ដើម្បីកំចាត់រ៉ាដារបស់សត្រូវ។

៨. **អំពើភេរវកម្មដែលឧបត្ថម្ភដោយរដ្ឋ** (state-sponsored) សំដៅលើការប្រើប្រាស់ក្រុមភេរវករដោយ រដ្ឋណាមួយ ជាធម្មតា ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ទីភ្នាក់ងារស៊ើបការណ៍សម្ងាត់របស់រដ្ឋនោះ ដើម្បីសម្រេចបាននូវគោលបំណងនយោបាយ។

៩. **អាវុធប្រល័យលោក** (WMDs) សំដៅលើអាវុធនុយក្លេអ៊ែរ អាវុធគីមី និងអាវុធជីវសាស្ត្រ គ្រប់ប្រភេទដែលត្រូវបានបែងចែកដាច់ចេញពីអាវុធទូទៅ ដោយសារឥទ្ធិពលប្រហារដ៏ប្រល័យរបស់ពួកវា និងការសម្លាប់មនុស្សដោយមិនរើសអើង។

១០. **សារធាតុបន្ទុះ** (fissionable material) រួមមាន ធាតុអ៊ុយរ៉ាញ៉ូម-២៣៥ (ឬ ប-២៣៥) និង ធាតុប្លាតូនីញ៉ូម ដែលអាតូមរបស់វាអាចបំបែកចេញពីគ្នា ហើយបញ្ចេញថាមពលមហាសាល តាមរយៈប្រតិកម្មជាសង្វាក់ បន្តបន្ទាប់ នៅពេលដែលគ្រាប់បែកអាតូមិកផ្ទុះ។

១១. **មីស៊ីលផ្លោង** (ballistic missiles) គឺជាយានបញ្ជូនជាយុទ្ធសាស្ត្រនូវអាវុធនុយក្លេអ៊ែរ; វាផ្ទុកក្បាលគ្រាប់ ទៅតាមគន្លងផ្លោងមួយ (ជាធម្មតា អាចហោះឡើងយ៉ាងតិច រយៈកំពស់ ៥០ ម៉ាយល៍) ហើយព្រលែងអោយវាទម្លាក់លើគោលដៅចង់បាន។ សូមមើល *មីស៊ីលផ្លោងអន្តរទ្វីប* (ICBMs) ផងដែរ ។

១២. **មីស៊ីលផ្លោងអន្តរទ្វីប** (ICBMs) គឺជាប្រភេទមីស៊ីលផ្លោងបានរយៈចម្ងាយឆ្ងាយបំផុត ដែលអាចធ្វើដំណើរបានរហូតដល់ ចម្ងាយ ៥,០០០ ម៉ាយល៍។ សូមមើល *មីស៊ីលផ្លោង* ផងដែរ។

១៣. **កាំជ្រួចហោះ** (cruise missile) គឺជាកាំជ្រួចដែលមានស្លាបតូច ដែលអាចធ្វើដំណើរឆ្លងកាត់ចម្ងាយរាប់ពាន់ម៉ាយល៍ពីដីដែលបានគូសផែនទីទុកមុន ដើម្បីទៅដល់គោលដៅជាក់លាក់ណាមួយ។ វាអាចផ្ទុកក្បាលគ្រាប់អាវុធនុយក្លេអ៊ែរ ឬអាវុធទូទៅ។

១៤. **របបគ្រប់គ្រងបច្ចេកវិទ្យាមីស៊ីល** (Missile Technology Control Regime) គឺជាកញ្ចប់កិច្ចព្រមព្រៀងដែលរដ្ឋឧស្សាហូបនីយកម្មទាំងឡាយព្យាយាមកម្រិតលំហូរនៃបច្ចេកវិទ្យាពាក់ព័ន្ធនឹងមីស៊ីល ទៅកាន់តតិយលោកនានា។

១៥. **អនុសញ្ញាអាវុធគីមី (១៩៩២)** កិច្ចព្រមព្រៀងដែលហាមប្រាមការផលិត និងការកាន់កាប់អាវុធគីមី និងរួមបញ្ចូលទាំងបទប្បញ្ញត្តិការផ្ទៀងផ្ទាត់យ៉ាងតឹងរ៉ឹង និងការគំរាមកំហែងនៃទណ្ឌកម្មប្រឆាំងនឹងអ្នករំលោភបំពាន និងអ្នកមិនចូលរួមក្នុងសន្ធិសញ្ញានេះផងដែរ។

១៦. **អនុសញ្ញាអាវុធជីវសាស្ត្រ (១៩៧២)** គឺជាកិច្ចព្រមព្រៀងដែលហាមឃាត់ការអភិវឌ្ឍន៍ ការផលិត

និងការកាន់កាប់អាវុធជីវសាស្ត្រ ប៉ុន្តែមិនមានបទបញ្ញត្តិសម្រាប់ការត្រួតពិនិត្យឡើយ។

១៧. **ការរីកសាយភាយ** (proliferation) ចង់សំដៅទៅលើការរីករាលដាលនៃអាវុធប្រល័យលោក (អាវុធនុយក្លេអ៊ែរ កាំជ្រួចផ្លោង និងអាវុធគីមី ឬជីវសាស្ត្រ) ទៅដល់កណ្តាប់ដៃរបស់តួអង្គកាន់តែច្រើន។

១៨. **សន្ធិសញ្ញាមិនរីកសាយភាយ**(NPT)ឆ្នាំ ១៩៦៨ គឺជាក្របខ័ណ្ឌមួយដើម្បីគ្រប់គ្រងការរីករាលដាលនៃវត្ថុធាតុដើមនិងបច្ចេកទេសនុយក្លេអ៊ែរ។ ទីភ្នាក់ងារថាមពលអាតូមិកអន្តរជាតិ(IAEA) ដែលជាទីភ្នាក់ងាររបស់អង្គការសហប្រជាជាតិ ដែលមានមូលដ្ឋាននៅក្នុងប្រទេសអូទ្រីស ត្រូវបានផ្តល់តួនាទីអោយត្រួតពិនិត្យឧស្សាហកម្មថាមពលនុយក្លេអ៊ែរ នៅក្នុងរដ្ឋជាសមាជិក ដើម្បីការពារកុំអោយមានការបង្វែរវត្ថុធាតុនុយក្លេអ៊ែរសម្រាប់គោលដៅយោធាដោយសម្ងាត់។

១៩. **ការបំផ្លិចបំផ្លាញគ្នាទៅវិញទៅ**(MAD) គឺជាការមានសមត្ថភាពក្នុង*ការវាយប្រហារបក* (second-strike) ដែលធានាថាភាគីទាំងពីរមិនអាចរារាំងគូបដិបក្ខមិនអោយបំផ្លាញខ្លួនបាននៅក្នុងសង្គ្រាមសរុបឡើយ សូមមើល *ការរារាំង* ផងដែរ។

២០. **គំនិតផ្តួចផ្តើមការពារដោយយុទ្ធសាស្ត្រ**(SDI) គឺជាកិច្ចខិតខំប្រឹងប្រែងរបស់សហរដ្ឋអាមេរិក ដែលត្រូវបានគេស្គាល់ថាជា សង្គ្រាមផ្កាយ ដើម្បីបង្កើតប្រព័ន្ធការពារ ដែលអាចបាញ់ទម្លាក់មីស៊ីលផ្លោងចូល ដែលជំរុញដោយលោកប្រធានាធិបតី រ៉ូណាល់ រីហ្គិន ក្នុងឆ្នាំ ១៩៨៣។ អ្នករិះគន់ហៅវាថាជា បរាជ័យដ៏ធ្ងន់ធ្ងរ ដែលទំនងជាគ្មានប្រសិទ្ធភាព។ សូមមើល *សន្ធិសញ្ញាប្រឆាំងមីស៊ីល* ផងដែរ។

២១. **សន្ធិសញ្ញាប្រឆាំងមីស៊ីលផ្លោង**(ABM)(១៩៧២) គឺជាសន្ធិសញ្ញាដែលហាមឃាត់ ទាំងសហរដ្ឋអាមេរិក និងទាំងសហភាពសូវៀត មិនអោយប្រើប្រាស់ប្រព័ន្ធការពារកាំជ្រួចផ្លោងធ្វើជាខែល ដើម្បីខ្លួនអាចចាប់ផ្តើមវាយប្រហារមុន។ ពីការប្រើប្រាស់ប្រព័ន្ធការពារកាំជ្រួចផ្លោងធ្វើជាខែល ដែលនឹងធ្វើអោយខូចដល់ ការបំផ្លិចបំផ្លាញគ្នាទៅវិញទៅ និងជាមូលដ្ឋាននៃការរារាំង។ សូមមើល *ការបំផ្លិចបំផ្លាញ គ្នាទៅវិញទៅ* និង *គំនិតផ្តួចផ្តើមការពារយុទ្ធសាស្ត្រ* ផងដែរ។

២២. **សន្ធិសញ្ញាហាមឃាត់ការសាកល្បងដ៏ទូលំទូលាយ(CTBT)** (១៩៩៦) គឺជាសន្ធិសញ្ញាហាមឃាត់រាល់ការបំផ្ទុះសាកល្បងអាវុធនុយក្លេអ៊ែរ ម្លោះហើយពង្រីកការហាមឃាត់លើការសាកល្បងបរិយាកាស ដែលបានចរចានៅឆ្នាំ ១៩៦៣។

២៣. **ខ្សែសង្វាក់បញ្ជា** (chain of command) គឺជាប្រព័ន្ធឋានានុក្រមនៃមន្ត្រី (ជារឿយៗ ជាជនស៊ីវិល និងយោធា) ដែលរដ្ឋប្រើប្រាស់គ្រប់គ្រងកងកម្លាំងយោធា។

២៤. **ទំនាក់ទំនងស៊ីវិល-យោធា** (civil-military relations) គឺជាទំនាក់ទំនងរវាងមេដឹកនាំស៊ីវិលរបស់រដ្ឋ និង មេដឹកនាំយោធា។ នៅក្នុងប្រទេសភាគច្រើន យោធាទទួលបញ្ជាពីមេដឹកនាំស៊ីវិល។ ក្នុងករណីធ្ងន់ធ្ងរ ទំនាក់ទំនងស៊ីវិលនិងយោធាមិនល្អ អាចនាំអោយមានរដ្ឋប្រហារយោធា។

២៥. **រដ្ឋប្រហារ** (coup d′etat) ចេញពីភាសាបារាំង ដែលមានន័យថា «បំផ្ទុះប្រឆាំងនឹងរដ្ឋ» គឺជាពាក្យដែលសំដៅទៅលើការដណ្តើមយកអំណាចនយោបាយដោយកម្លាំងយោធាក្នុងស្រុក ពោលគឺការផ្លាស់ប្តូរអំណាចនយោបាយនៅក្រៅបញ្ជារដ្ឋធម្មនុញ្ញ។

២៦. **រដ្ឋាភិបាលយោធា** (military governments) គឺជារដ្ឋដែលកងកម្លាំងយោធាគ្រប់គ្រងរដ្ឋាភិបាល។ ពួកវាជារឿងធម្មតាបំផុតនៅក្នុងប្រទេសតតិយលោក ដែលយោធាអាចជាស្ថាប័នទំនើបតែមួយគត់។

សំណួរអនុវត្តន៍

១. ប្រសិនបើអ្នកជាមេដឹកនាំប្រទេសវៀតណាម តើអ្នកចង់អោយប្រទេសរបស់អ្នកមានកម្លាំងយោធាទំហំប៉ុនណានិងប្រភេទណាខ្លះ? តើប្រភេទសមត្ថភាព(យោធា)នីមួយៗដែលអ្នកបានជ្រើសរើស ដើម្បីឆ្លើយតបនឹងការគំរាមកំហែងប្រភេទណាខ្លះ?

២. ឧបមាថាប្រទេសអ៊ីរ៉ង់ពិតជាបានទទួលក្បាលគ្រាប់នុយក្លែអ៊ែរយុទ្ធសាស្ត្របីគ្រឿង ពីអតីតឃ្លាំងអាវុធសូវៀត និងកំពុងលាក់ក្នុងទីតាំងសម្ងាត់។ តើប្រទេសមហាអំណាចគួរចាត់វិធានការណ៍យ៉ាងណា? តើចំណាត់ការទាំងនោះអាចនឹងផ្តល់ផលវិបាកអ្វីខ្លះ?

៣. ចូរស្រមៃថា ពិភពលោកដែលរដ្ឋភាគច្រើនមានអាវុធនុយក្លែអ៊ែរនិងមីស៊ីលផ្លោងរយៈចម្ងាយឆ្ងាយ។ តើនៅពេលនោះ ពិភពលោកនឹងមានសន្តិភាពជាងមុន ឬងាយនឹងផ្ទុះសង្គ្រាមជាងមុន? ហេតុអ្វី?

៤. នៅសម័យក្រោយសង្គ្រាមត្រជាក់ ប្រទេសមហាអំណាចភាគច្រើនកំពុងកែសម្រួលកម្លាំងនិងរចនាសម្ព័ន្ធយោធារបស់ខ្លួនឡើងវិញ។ តើសមត្ថភាពអ្វីខ្លះ ដែលអ្នកគិតថាប្រទេសរបស់អ្នកត្រូវការនៅក្នុងអំឡុងពេលនេះ? ហេតុអ្វី?

៥. ការចំណាយលើវិស័យយោធាក្នុងពិភពលោក មានទំហំទឹកប្រាក់ជិត ២០០០ ពាន់លានដុល្លារ ជារៀងរាល់ឆ្នាំ។ បើអ្នកអាចបង្វែរទិសដៅមូលនិធិទាំងនេះបាន តើអ្នកនឹងប្រើប្រាស់វាដោយរបៀបណា? ការប្រើប្រាស់បែបនេះ នឹងធ្វើអោយប្រសើរឡើង ឬកាន់តែអាក្រក់ សម្រាប់រដ្ឋដែលពាក់ព័ន្ធ? តើអ្នកគិតថាមានឱកាសពិតប្រាកដក្នុងការបង្វែរការចំណាយយោធា តាមរបៀបដែលអ្នកបានស្នើដែរឬទេ?

ការស្វែងរកផលប្រយោជន៍រួម

ការគ្រប់គ្រងសព្វាវុធ

ផលប្រយោជន៍រួម៖ ការកំរិតឃ្លាំងអាវុធនុយក្លែអ៊ែរ

រូបថត ប្រធានាធិបតីអាមេរិក និងរុស្ស៊ី ចុះសន្ធិសញ្ញាគ្រប់គ្រងអាវុធធុនធ្ងន់បំផុតឆ្នាំ ២០១០។

សាវតារ

ក្រោយបានបង្កើតអាវុធនុយក្លែអ៊ែរនៅក្នុងសង្គ្រាមលោកលើកទីពីរ ប្រទេសមហាអំណាចទាំងពីរ (សហរដ្ឋអាមេរិកនិងសហភាពសូវៀត) បានសាងសង់ឃ្លាំងអាវុធនុយក្លែអ៊ែរដ៏ធំសម្បើម ក្នុងអំឡុងប៉ុន្មានទសវត្សរ៍នៃសង្គ្រាមត្រជាក់។ នៅទីបំផុត ភាគីនីមួយៗមានអាវុធនុយក្លែអ៊ែររាប់ម៉ឺនគ្រាប់។ អាវុធទាំងនេះអាចបង្កគ្រោះថ្នាក់យ៉ាងធំធេង ដែលបើសិនគណនាខុសឬឧបទ្ទវហេតុ អាចនាំអោយមានផលវិបាកមហន្តរាយយ៉ាងពិតប្រាកដ។ ការកំរិតនិងគ្រប់គ្រងអាវុធនុយក្លែអ៊ែរ ដើម្បីបញ្ចៀសគ្រោះមហន្តរាយនេះ គឺជាផលប្រយោជន៍រួម។ ភាគីទាំងពីរនឹងទទួលបានផលប្រយោជន៍រៀងៗខ្លួន ប្រសិនបើសង្គ្រាមនុយក្លែអ៊ែរអាចត្រូវបានបញ្ចៀស ដោយមិនគិតថាភាគីណាដែលលះបង់ចោលអាវុធជាច្រើន នៅក្នុងកិច្ចព្រមព្រៀងដែលត្រូវបានចរចារហើយ។

បញ្ហាប្រឈម

ការប្រណាំងប្រជែងសព្វាវុធតំណាងអោយផលអវិជ្ជមាននៃគោលការណ៍បដិការ ដែលកើតចេញជាទំនាក់ទំនងកាន់តែអាក្រក់ទៅៗ ដែលបណ្តាលមកពីរដ្ឋនីមួយៗ ឆ្លើយតបតាមសកម្មភាពអរិភាពរបស់ភាគីម្ខាងទៀត ក្នុងករណីនេះ គឺការដាក់ពង្រាយអាវុធនុយក្លែអ៊ែរកាន់តែច្រើន។ ចាប់តាំងពីទសវត្សរ៍ឆ្នាំ ១៩៦០

មក ភាគីទាំងពីរបានប្រើប្រាស់កិច្ចព្រមព្រៀងដែលត្រូវបានចរចាហើយ ដើម្បីព្យាយាមគ្រប់គ្រងការប្រណាំងប្រជែងសព្វាវុធ។ អស់ជាច្រើនទស្សវត្សរ៍ កិច្ចខិតខំប្រឹងប្រែងនេះកម្របានអនុវត្ត ហើយត្រូវលេចចេញជារូបរាងការកសាងអាវុធឥតឈប់ឈរ ដោយភាគីទាំងពីរ។

ដំណោះស្រាយ

គោលការណ៍បដិការដែល ដែលបានដំរុញអោយមានការប្រណាំងប្រជែងសព្វាវុធក៏ដំរុញអោយមានដំណើរការបកក្រោយផងដែរ បន្ទាប់ពីសង្គ្រាមត្រជាក់បានបញ្ចប់។ ភាគីនីមួយៗកាត់បន្ថយអាវុធរបស់ខ្លួនតាមសមាមាត្រនៃភាគីម្ខាងទៀត ដែលចាត់ចែងដោយសន្ធិសញ្ញាផ្លូវការ និងអាចផ្ទៀងផ្ទាត់បាន ជាបន្តបន្ទាប់។ ជាលទ្ធផល ឃ្លាំងអាវុធបានធ្លាក់ចុះយ៉ាងខ្លាំង។

នៅក្នុងឆ្នាំ ២០១០ ប្រធានាធិបតីអាមេរិកនិងរុស្ស៊ីបានចុះហត្ថលេខាលើសន្ធិសញ្ញាគ្រប់គ្រងអាវុធនុយក្លេអ៊ែរថ្មីមួយ។ ក្នុងរយៈពេលប្រាំពីរឆ្នាំ វាបានកាត់បន្ថយក្បាលគ្រាប់នុយក្លេអ៊ែរយុទ្ធសាស្ត្រ មកត្រឹមចំនួនមួយភាគបី ជាក់ស្តែងកាត់បន្ថយក្បាលគ្រាប់ ពីចំនួន ២២០០ មកត្រឹម ១៥៥០ សម្រាប់ភាគីនីមួយៗ។ ភាគីនីមួយៗក៏បានឯកភាពលើការត្រួតពិនិត្យយ៉ាងទូលំទូលាយ ដើម្បីធានាថា ភាគីម្ខាងទៀត នៅបន្តអនុវត្តតាមការចរចាររបស់ខ្លួន (ទោះបីជាមានភាពតានតឹងបានកើនឡើងក្នុងឆ្នាំ ២០១៨ ក៏ដោយ ភាគីទាំងពីរបានបញ្ជាក់ថា ពួកគេបានបំពេញលក្ខខណ្ឌនៃកិច្ចព្រមព្រៀង)។ តាមរយៈការប្រើប្រាស់គោលការណ៍បដិការអតីតប្រទេសមហាអំណាចបានប្រើវិធានការណ៍ជាដំហានៗ ភាគីនីមួយៗតបតគ្នាតាមទំហំសមាមាត្រ ដោយដំបូងបានត្រឹមកំរិតចំនួន ហើយបន្ទាប់មកកាត់បន្ថយការស្តុកទុកអាវុធនុយក្លេអ៊ែររៀងៗខ្លួន បានយ៉ាងច្រើន។

ទស្សនៈវិស័យគោលនយោបាយ

ប្រធានាធិបតីនៃសហរដ្ឋអាមេរិក លោក ដូណាល់ ត្រាំ

រូបថត ប្រធានាធិបតី ត្រាំ

បញ្ហា

តើអ្នកប្លឹងថ្លែងការដោះដូរដោយរបៀបណា ក្នុងការប្រើប្រាស់កម្លាំងដើម្បីទប់ទល់នឹងការគំរាមកំហែងផ្នែកសន្តិសុខប្រភេទថ្មីៗ ដែលមិនធ្លាប់មានពីមុនមក?

សារតារ

ក្នុងនាមជាបេក្ខជនប្រធានាធិបតីក្នុងឆ្នាំ ២០១៦ អ្នកបានផ្តល់យោបល់ជាសាធារណៈថាការធ្វើសង្គ្រាមនៅក្នុងប្រទេសអាហ្វហ្គានីស្ថាន គឺជា«គ្រោះមហន្តរាយទាំងស្រុង» ហើយបានសច្ចាថានឹងបញ្ចប់ការចូលរួមរបស់សហរដ្ឋអាមេរិកក្នុងសង្គ្រាមនោះ។ ប៉ុន្តែ ត្រឹមខែសីហា ឆ្នាំ ២០១៧ អ្នកបានប្រកាសថា អ្នកមានគម្រោងបង្កើនចំនួនទាហានអាមេរិក ដែលឈរជើងនៅអាហ្វហ្គានីស្ថាន នាពេលអនាគត។

តំបន់ជាច្រើននៃប្រទេសអាហ្វហ្គានីស្ថាននៅតែមិនទាន់មានស្ថេរភាពនៅឡើយ បន្ទាប់ពីសង្គ្រាមអស់រយៈពេល ១៧ ឆ្នាំ។ កងទ័ពអន្តរជាតិនៅតែប្រឈមមុខនឹងកងកម្លាំងអរិភាព ជាប្រចាំ ឬ ត្រូវបានពួកគេវាយធ្មក់ផងដែរ។ ក្រុមតាលីបង់ និងសម្ព័ន្ធមិត្តរបស់ខ្លួន នៅក្នុងបណ្តាញហាកានី (Haqqani) នៅតែបន្តវាយប្រហារកងកម្លាំងសន្តិសុខក្នុងស្រុករបស់អាហ្វហ្គានីស្ថានផងដែរ។ ការវាយប្រហារទាំងនេះ ជាញឹកញាប់បណ្តាលអោយជីវិតជនស៊ីវិលនិងយោធាជាច្រើនត្រូវបាត់បង់។

ការពិចារណាក្នុងតំបន់

អំពើភេរវកម្មនិងសង្គ្រាម នៅក្នុងប្រទេសអាហ្វហ្គានីស្ថាននៅតែជាបញ្ហាដ៏សំខាន់ នៅក្នុង សាធារណៈមតិរបស់សហរដ្ឋអាមេរិក។ សាធារណជនអាមេរិក មានការនឿយណាយនឹងសង្គ្រាមនៅអាហ្វហ្គានីស្ថានយ៉ាងខ្លាំង ហើយបន្ទាប់ពីការសម្លាប់ អូសាម៉ា ប៊ីន ឡាដិន មានការចោទសួរកាន់តែច្រើនឡើងៗអំពីវត្តមានយោធាដែលចេះតែបន្តនៅទីនោះ។ ការស្ទង់មតិសាធារណៈបានបង្ហាញពីការគាំទ្រចំពោះសំណើរបស់អ្នកក្នុងការដកកងទ័ពប្រយុទ្ធទាំងអស់ចេញពីដម្លោះនោះ។

សេណារីយ៉ូ

ចូរស្រមៃថា សង្គ្រាមនៅអាហ្វហ្គានីស្ថាន ភ្លាមៗស្រាប់តែផ្ទុះឡើងកាន់តែធំទៅៗ។ ក្រុមតាលីបង់ដោយមានជំនួយពីបណ្តាញហាកានី និងប្រភពធនធានពីក្រុមរដ្ឋអ៊ីស្លាមពីអ៊ីរ៉ាក់ និងស៊ីរី បានបង្កើន សង្គ្រាមប្រឆាំងនឹងរដ្ឋាភិបាលអាហ្វហ្គានីស្ថាន និងកងកម្លាំងអន្តរជាតិ នៅក្នុងខេត្តសំខាន់ៗមួយចំនួន។ ការវាយប្រហារប្រឆាំងនឹងទាហានអាមេរិកកាន់តែកើនឡើងយ៉ាងខ្លាំង ដែលនាំអោយទាហានអាមេរិចត្រូវរងរបួសនិងស្លាប់បាត់បង់ជីវិតអស់ជាច្រើន។ សាធារណជនអាមេរិកមានការខកចិត្តខ្លាំងៈ ការកើនឡើងនៃចំនួនទាហានស្លាប់បានទាក់ទាញការចាប់អារម្មណ៍កាន់តែខ្លាំងពីសំណាក់ប្រព័ន្ធផ្សព្វផ្សាយ ហើយបានក្លាយជាបញ្ហាគោលនយោបាយការបរទេសដ៏សំខាន់មួយ។ ទីប្រឹក្សាផ្ទាល់របស់អ្នកក៏ត្រូវបានបែងចែកផងដែរៈ អ្នកខ្លះបានលើកឡើងថា ជ័យជម្នះរបស់កងកម្លាំងគាំទ្រតាលីបង់នឹងក្លាយជាការគម្រាមកំហែងដល់សហរដ្ឋអាមេរិក ខណៈអ្នកផ្សេងទៀតអះអាងថា សង្គ្រាមរយៈពេល ១២ ឆ្នាំ បានកាត់បន្ថយការគំរាមកំហែងពីពួកតាលីបង់ជាអចិន្ត្រៃយ៍ប្រឆាំងនឹងដីគោករបស់សហរដ្ឋអាមេរិក។

ចូរជ្រើសរើសគោលនយោបាយរបស់អ្នក

តើអ្នកឆ្លើយតបយ៉ាងណាចំពោះលទ្ធភាពសង្គ្រាមស៊ីវិលនៅប្រទេសអាហ្វហ្គានីស្ថាន? តើអ្នកនឹងបញ្ជូនទាហានបន្ថែមទៀតចូលទៅក្នុងដម្លោះដែរឬទេ? ការធ្វើដូច្នេះអាចនឹងបញ្ឈប់ការរុលទៅមុខរបស់ពួកតាលីបង់ប៉ុន្តែនឹងនាំអោយទាហានអាមេរិកត្រូវរងរបួសនិងស្លាប់បាត់បង់ជីវិតថែមទៀត។ តើអ្នកនឹងបណ្តោយអោយប្រជាជនអាហ្វហ្គានីស្ថានទទួលរងដោគវាសនាដោយខ្លួនឯង ដូចដែលអ្នកបានសន្យាពីដំបូងទេ? ការធ្វើដូច្នេះអាចជានឹងទទួលប្រជាប្រិយភាព នៅក្នុងមាតុប្រទេស ប៉ុន្តែ វានឹងបណ្តាលអោយមានការលេចចេញជាថ្មីនៃកងកម្លាំងប្រឆាំងនឹងសហរដ្ឋអាមេរិក ដែលអាមេរិកផ្ទាល់បានធ្វើអន្តរាគមន៍ដើម្បីផ្តួលរំលំ ក្រោយការវាយប្រហារថ្ងៃ ១១ ខែ កញ្ញា។ តើអ្នកអាចប្តឹងថ្លែងរវាងសម្ពាធក្នុងស្រុកនិងអន្តរជាតិ ដែលបញ្ហាសគ្នា ក្នុងការប្រឈមមុខនឹងការគំរាមកំហែងសន្តិសុខ ដែលមិនធ្លាប់មានពីមុនមក ដោយរបៀបណា?


មតិសាធារណៈ និងធំនាក់ធំនឹងអន្តរជាតិ

ឥណ្ឌាៈ ផ្លូវបំបែករវាងអាទិភាពយោធា និងកិច្ចការក្នុងស្រុក?

ដូចដែលក្រាហ្វិក៦.២កចង្អុលបង្ហាញ ប្រជាជនឥណ្ឌាក្នុងចំនួនលើសលប់ រហូត ៩៥% បានសម្តែងការគាំទ្រដល់យោធារបស់ខ្លួន នៅក្នុងការស្ទង់មតិ Pew កាលពីឆ្នាំ ២០១៥ ។ ជាមួយនឹងចំនួនប្រជាជនរបស់ខ្លួនដែលត្រូវរំពឹងថានឹងវ៉ាដាច់ចំនួនប្រជាជនចិន ក្នុងពេលអនាគតឆាប់ខាងមុខ ការចំណាយសរុបលើវិស័យយោធារបស់ឥណ្ឌាត្រូវបានចាត់ទុកថានៅមានចំនួនតិចតួចនៅឡើយ បើធៀបនឹងគូប្រជែងក្នុងតំបន់ធំៗទាំងពីរ (ប្រទេសចិន និងប៉ាគីស្ថាន) បើទោះបីជាកញ្ចប់ថវិកាឥណ្ឌាបានកើនឡើងដល់កម្រិតខ្ពស់ជាងពេលណាៗទាំងអស់។


ក្រាហ្វិក ៦.២ក ស្ថាប័នរបស់ប្រទេសឥណ្ឌាស្ថិតក្នុងជំហរល្អជាមួយសាធារណៈ

ប្រភព៖ Spring ២០១៥ ការស្ទង់មតិអាកប្បកិរិយាសកល។ Q៣៩a-e



ក្រាហ្វិក ៦.២ខ ថវិកាការពារជាតិឥណ្ឌា ២០១០-២០១៨

ប្រភព៖ ចងក្រងដោយ Q-Tech Synergy



ជាទូទៅ ប្រទេសនីមួយៗនៅលើពិភពលោកមានតម្រូវការយោធាផ្សេងៗគ្នា ប៉ុន្តែ ប្រទេសឥណ្ឌាបាននឹងកំពុងរក្សាសមត្ថភាពយោធារបស់ខ្លួន ដោយហេតុផលជាក់ស្តែងផ្ទាល់។ ជម្លោះការស្មៀរ គឺជាបញ្ហាដ៏ពុំរ៉ែសម្រាប់ប្រទេសឥណ្ឌា ប៉ាគីស្តាន រួមទាំងចិនផងដែរ។ ជម្លោះដែនដីជាមួយប្រទេសចិន និងការរាយ

ប្រហារពីសំណាក់ក្រុមភេរវករ ក៏បានរួមចំណែកដល់ការបង្កើនកញ្ចប់ថវិកាយោធាឥណ្ឌាយ៉ាងច្រើនសម្បើម ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ។

ការធ្វើទំនើបភាវូបនីយកម្មលើកងកម្លាំងយោធាអាវុធឥណ្ឌាគឺជាដំណើរការដែលកំពុងបន្ត ដោយផ្អែកលើកត្តាមួយចំនួន ដូចជាពីការពីការគំរាមកំហែង ភាពចាំបាច់នៃប្រតិបត្តិការ និងការផ្លាស់ប្តូរបច្ចេកវិទ្យា។ល។ ទោះជាយ៉ាងណាក៏ដោយ ប៉ុន្មានឆ្នាំចុងក្រោយនេះ ការបែងចែកធនធានសម្រាប់វិស័យយោធាមិនមានភាពគ្រប់គ្រាន់ ដើម្បីដោះស្រាយតម្រូវការរបស់កងកម្លាំងប្រដាប់អាវុធនោះទេ។ នៅក្នុងប្រទេសឥណ្ឌា ការបង្កើនកញ្ចប់ថវិកាច្រើនគួរសមសម្រាប់វិស័យយោធាប្រចាំឆ្នាំ បានក្លាយទៅជាបទដ្ឋានមួយទៅហើយ ដូចដែលបានបង្ហាញក្នុងរូបភាព៦.២ខ ទោះជាកំណើនសេដ្ឋកិច្ចបានធ្លាក់ចុះក្នុងរយៈពេល ៤ ឆ្នាំចុងក្រោយនេះក៏ដោយ។ តើរដ្ឋាភិបាលឥណ្ឌាគួរចំណាយថវិកាច្រើនបន្ថែមលើវិស័យយោធា ឬលើការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនក្នុងប្រទេស? ប្រជាជនឥណ្ឌាហាក់បីដូចជាមានបញ្ហាក្នុងការជ្រើសរើសជម្រើសទាំងពីរនេះ៖ ព្រោះពួកគេមិនត្រឹមតែចង់អោយរដ្ឋាភិបាលជួយកែលម្អជីវភាពរស់នៅរបស់ពួកគេប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងចង់អោយកសាងប្រព័ន្ធយោធាដ៏រឹងមាំមួយសម្រាប់ភាពចាំបាច់ណាមួយ។ ខុសពីសមភាគីអាមេរិក ប្រជាជនឥណ្ឌាចង់អោយរដ្ឋាភិបាលពួកគេគ្រប់គ្រងអំពើពុករលួយនិងជម្លោះក្នុងតំបន់។ ពួកគេចង់ឃើញរដ្ឋាភិបាលសម្រេចអោយបាននូវកិច្ចការទាំងពីរ។ មតិយោបល់របស់ពួកគេបានឆ្លុះបញ្ចាំងថា បញ្ហាថវិកាយោធានិងជីវភាពរស់នៅ មិនមែនជាបញ្ហាដោយឡែក«ជ្រើសរើសមួយ ទុកមួយទៀត»នោះទេ ប៉ុន្តែជាបញ្ហា ដែលត្រូវការសម្រេចអោយបានទាំងពីរ ក្នុងពេលដំណាលគ្នា ជាមួយនឹងធនធាននៅមានកំរិត ដែលជាកិច្ចការដ៏លំបាកសម្រាប់រដ្ឋាភិបាលបច្ចុប្បន្ន។

តោះ! សាកល្បងពិភាក្សាអំពីបញ្ហាជាក់ស្តែង

ការចរចាជាមួយកូរ៉េខាងជើង៖ វឌ្ឍនភាពឆ្ពោះទៅរកការរំសាយអាវុធ ឬកិច្ចការរបស់ល្ងីល្ងើ?

ទិដ្ឋភាពទូទៅ

រយៈពេលជិតពីរទសវត្សរ៍មកហើយ ដែលប្រទេសកូរ៉េខាងជើងបានផ្តើននឹងសហគមន៍អន្តរជាតិនិងបន្តកម្មវិធីអាវុធនុយក្លេអ៊ែររបស់ខ្លួន។ ប្រទេសកូរ៉េខាងជើងបានយល់ព្រមបោះបង់កម្មវិធីនុយក្លេអ៊ែររបស់ខ្លួន ជាច្រើនលើកមកហើយ តែចុងក្រោយលេបសន្យារបស់ខ្លួនដដែល។ នៅឆ្នាំ ២០០៦ ប្រទេសកូរ៉េខាងជើងបានសាកល្បងអាវុធនុយក្លេអ៊ែរ។ ថ្វីត្បិតតែការសាកល្បងមានលទ្ធផលតិចតួចក៏ដោយ ប៉ុន្តែ កូរ៉េខាងជឿជាក់ទៅលើចំណេះដឹង ធនធាន និងសមត្ថភាពផលិតអាវុធនុយក្លេអ៊ែររបស់ខ្លួន។

នៅឆ្នាំ ២០០៧ កិច្ចព្រមព្រៀងមួយត្រូវបានសម្រេចឡើង ដែលកូរ៉េខាងជើងបានសន្យាថានឹងបញ្ឈប់កម្មវិធីនុយក្លេអ៊ែររបស់ខ្លួន ជាថ្នូរនឹងជំនួយអន្តរជាតិ រួមទាំងជំនួយប្រេង និងស្បៀងអាហារ។ នៅពេលនោះ ប្រទេសកូរ៉េខាងជើងបានបំផ្លាញផ្នែកខ្លះនៃរោងចក្រកែច្នៃនុយក្លេអ៊ែររបស់ខ្លួន ប៉ុន្តែបានចាប់ផ្តើមកម្មវិធីរបស់ខ្លួនឡើងវិញ នៅពេលដែលសហរដ្ឋអាមេរិកពន្យារពេលដកកូរ៉េខាងជើងចេញពីបញ្ជីរដ្ឋដែលគាំទ្រភេរវកម្ម។ នៅពេលដែលកូរ៉េខាងជើងត្រូវបានដកចេញពីបញ្ជីនោះ នៅក្នុងរដូវស្លឹកឈើជ្រុះឆ្នាំ ២០០៨, កូរ៉េខាងជើងបានសន្យាថានឹងអនុញ្ញាតអោយមន្ត្រីអធិការកិច្ចនុយក្លេអ៊ែរ ចុះផ្ទៀងផ្ទាត់ការបញ្ឈប់កម្មវិធីរបស់ខ្លួន។ លុះដល់ពេលកំណត់ជាផ្លូវការនូវកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរ កូរ៉េខាងជើងបែរជាបដិសេធទៅវិញ។ នៅឆ្នាំ ២០១៧ កូរ៉េខាងជើងបានបន្តការសាកល្បងមីស៊ីលនិងអាវុធនុយក្លេអ៊ែរឡើងវិញទាំងស្រុង។ នៅក្នុង

២០១៨ ប្រធានាធិបតីត្រាំ និងមេដឹកនាំកូរ៉េខាងជើង គីម ជុងអ៊ុន បានជួបគ្នាចរចា ប៉ុន្តែបានសម្រេចត្រឹមតែសេចក្តីថ្លែងការណ៍គោលការណ៍មួយប៉ុណ្ណោះ។

ដោយផ្អែកលើប្រវត្តិនៃកិច្ចព្រមព្រៀងដែលបានបរាជ័យ និងការចរចាដ៏តានតឹងមួយនេះ អ្នកខ្លះបានស្នើអោយបញ្ចប់ការចរចាជាមួយកូរ៉េខាងជើងជុំវិញកម្មវិធីនុយក្លេអ៊ែររបស់ពួកគេ។ អ្នកផ្សេងទៀតចង្អុលទៅដល់គ្រោះថ្នាក់ដែលអាចបង្កឡើងដោយកម្មវិធីនុយក្លេអ៊ែរកូរ៉េខាងជើង និងជំរុញអោយបន្តការចរចា។ តើសហរដ្ឋអាមេរិកគួរបន្តកិច្ចចរចាពហុភាគីក្នុងគោលបំណងរំសាយអាវុធកូរ៉េខាងជើងទៀតដែរឬទេ?

អំណះអំណាង ១

សហរដ្ឋអាមេរិកគួរតែបន្តកិច្ចចរចាជាមួយកូរ៉េខាងជើង

សម្ព័ន្ធមិត្តរបស់អាមេរិកពេញចិត្តនិងចង់ឃើញការចរចាបន្ត។ ទោះបីជាពួកគេមានការព្រួយបារម្ភថាកូរ៉េខាងជើងមិនត្រូវទទួលរង្វាន់សម្រាប់អាកប្បកិរិយាគឃ្លើនរបស់ខ្លួនក៏ដោយ ក៏ប្រទេសកូរ៉េខាងត្បូងនិងជប៉ុនចង់អោយការចរចាបន្តទៀត។ ខណៈពេលសម្ព័ន្ធមិត្តអាមេរិកទាំងនេះមិនចង់ឈានដល់កិច្ចព្រមព្រៀងមួយទោះក្នុងតម្លៃណាក៏ដោយ ដោយសារតែជម្លោះជាយថាហេតុណាមួយជាមួយប្រទេសកូរ៉េខាងជើងនឹងបង្កការខាតបង់ធ្ងន់ធ្ងរបំផុតសម្រាប់ប្រទេសណាមួយឬប្រទេសទាំងពីរ ពួកគេចូលចិត្តដំណោះស្រាយការទូតចំពោះបញ្ហានេះ។

សង្គ្រាមដោយសារកម្មវិធីនុយក្លេអ៊ែរកូរ៉េខាងជើងនឹងមានគ្រោះមហន្តរាយ។

អាវុធនុយក្លេអ៊ែររបស់កូរ៉េខាងជើង គួរអោយអស់សំណើច មិនមែនជាការគំរាមកំហែងដ៏ធំបំផុតសម្រាប់ប្រទេសជិតខាង នៅភាគខាងត្បូងនោះទេ។ ផ្ទុយទៅវិញ អ្នកជំនាញប៉ាន់ប្រមាណថា កាំភ្លើងធំទូទៅដែលតំរង់ទៅរដ្ឋធានីសេអ៊ូលរបស់កូរ៉េខាងត្បូង អាចធ្វើការខូចខាតយ៉ាងដំណំក្នុងរយៈពេលដ៏ខ្លី។

ការដាក់អោយកូរ៉េខាងជើងនៅឯកា ជាច់ដោយឡែកពីគេ អាចជាគោលនយោបាយដ៏គ្រោះថ្នាក់បំផុតក្នុងចំណោមជំរើសគោលនយោបាយទាំងអស់។

សេណារីយ៉ូដែលថ្នាក់ដឹកនាំកូរ៉េខាងជើងទំនងជាប្រើអាវុធនុយក្លេអ៊ែររបស់ខ្លួន អាចនឹងកើតឡើងពេលដែលពួកគេមានអារម្មណ៍ថា ត្រូវបានគេរុញអោយផ្ទប់ជញ្ជាំង។ ការដើរចេញពីតុចរចាដើម្បីទុកពួកគេអោយនៅឯកោនឹងកាន់តែនាំទៅកាន់សេណារីយ៉ូនោះ។ ប្រទេសកូរ៉េខាងជើងអាចនឹងវាយប្រហារផ្នែកយោធាលើប្រទេសកូរ៉េខាងត្បូង ឬជប៉ុន ដែលជាសម្ព័ន្ធមិត្តដ៏សំខាន់ពីររបស់សហរដ្ឋអាមេរិក។

អំណះអំណាង ២

សហរដ្ឋអាមេរិកគួរតែបោះបង់ដំណើរស្វែងរកកិច្ចព្រមព្រៀងជាមួយកូរ៉េខាងជើង

កូរ៉េខាងជើងមិនដែលរក្សាការសន្យារបស់ខ្លួនទេ។

បន្ទាប់ពីការបដិសេធមិនចូលរួមក្នុងសន្ធិសញ្ញាមិនរីកសាយភាយ(NPT) នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ កូរ៉េខាងជើងមិនត្រឹមតែបដិសេធមិនគោរពការប្តេជ្ញារបស់ខ្លួនជាច្រើនប៉ុណ្ណោះទេ ថែមទាំងបានបោកប្រាស់គេយ៉ាងសកម្ម ដើម្បីបន្តកម្មវិធីអាវុធនុយក្លេអ៊ែររបស់ខ្លួន។ បើទោះជាមានការព្រមព្រៀងគ្នាក៏ដោយ ក៏នឹងមិនមានការធានាថាកូរ៉េខាងជើងនឹងមិនបោកប្រាស់ដែរ។

របបកូរ៉េខាងជើងមិនគួរអោយជឿទុកចិត្តទេ។

មេដឹកនាំប្រទេសកូរ៉េខាងជើងមិនខ្វល់ពីសុខុមាលភាពរបស់ពលរដ្ឋ ហើយសម្រាប់កេរ្តិ៍ឈ្មោះក្នុងឆាកអន្តរជាតិ ពួកគេកាន់តែមិនខ្វល់ខ្វាយទៅទៀត។ ខណៈពេលដែលប្រទេសកូរ៉េខាងជើងត្រូវពឹងផ្អែកលើជំនួយអន្តរជាតិដើម្បីរស់រានបន្ត វាអាចទាញយកជំនួយកាន់តែច្រើន បើប្រទេសនេះមានកម្មវិធីនុយក្លេអ៊ែរជោគជ័យខ្លាំងជាងនេះ។

មានតែការដួលរលំនៃរបបកូរ៉េខាងជើងប៉ុណ្ណោះដែលនឹងនាំមកនូវការផ្លាស់ប្តូរពិតប្រាកដ។

ដរាបណារបបបច្ចុប្បន្នកាន់អំណាច នឹងគ្មានអ្វីប្រែប្រួលនៅកូរ៉េខាងជើង។ ការដាក់អោយរបបនេះឯកោជាលក្ខណៈអន្តរជាតិកាន់តែលឿន កាន់តែអាចបំផ្លាញរបបនេះកាន់តែលឿនដែរ។ បើគ្មានជំនួយប្រេងឥន្ធនៈ និងស្បៀងអាហារពីសហរដ្ឋអាមេរិកឬប្រទេសជិតខាងទេ របបនេះអាចដួលរលំកាន់តែលឿន។

សំណួរ

- តើអ្នកគិតថា ប្រទេសកូរ៉េខាងជើងគឺជាដៃគូក្នុងការចរចាគួរអោយទុកចិត្តដែរឬទេ? តើគួរផ្តល់ឱកាសប៉ុន្មានដងទៀត ដើម្បីអោយរដ្ឋនេះអនុវត្តតាមកិច្ចព្រមព្រៀងរបស់ខ្លួន? តើមានជម្រើសជាក់ស្តែងផ្សេងក្រៅពីការចរចាដែរឬទេ? ជម្រើសអ្វីអោយប្រាកដ?
- តើសម្ព័ន្ធមិត្តរបស់អាមេរិកគួរមានសិទ្ធិអំណាចចរចាក្នុងកម្រិតណា? តើការដែលប្រទេសកូរ៉េខាងត្បូងនិងជប៉ុនមានទីតាំងនៅកៀកនឹងប្រទេសកូរ៉េខាងជើង ធ្វើអោយផលប្រយោជន៍ចរចារបស់ពួកគេ កាន់តែសំខាន់ជាងសហរដ្ឋអាមេរិកដែរឬទេ?
- តើអ្វីអាចជាបញ្ហាដែលអាចកើតមាន ប្រសិនបើសហរដ្ឋអាមេរិកបានចាត់វិធានការឯកតោភាគីសម្រាប់ការរំសាយអាវុធជាអចិន្ត្រៃយ៍របស់កូរ៉េខាងជើង? ជំហានឯកតោភាគីទាំងនោះ អាចរួមបញ្ចូលការដាក់ទណ្ឌកម្មបន្ថែមទៀត, សង្គ្រាម, ឬនៅផ្នែកម្ខាងទៀត លំហូរជំនួយហិរញ្ញវត្ថុដ៏ច្រើនសន្ធឹកសន្ធាប់ដល់កូរ៉េខាងជើងជាថ្នូរនឹងការបោះបង់ឃ្លាំងអាវុធនុយក្លេអ៊ែររបស់ពួកគេ។

និស្សិតអាចសាកល្បងអានឯកសារខាងក្រោមបន្ថែមទៀត ដើម្បីជាគ្រឹះក្នុងការឆ្លើយសំណួរទាំងអស់ខាងលើ ៖

- Cha, Victor, and David Kang. *Nuclear North Korea: A Debate on Engagement Strategies.* Columbia, 2005.
- O'Hanlon, Michael, and Mike Mochizuiki. *Crisis on the Korean Peninsula: How to Deal with a Nuclear North Korea.* McGraw-Hill, 2003.
- Rozman, Gilbert. *Strategic Thinking About the Korean Nuclear Crisis: Four Parties Caught Between North Korea and the United States.* Palgrave Macmillan, 2007.
- Wit, Joel S. *Going Critical: The First North Korean Nuclear Crisis.* Brookings, 2005.

ឯកសារគួរអានបន្ថែម

- Feaver, Peter D., and Christopher Gelpi. *Choosing Your Battles: American Civil-Military Relations and the Use of Force.* Princeton, 2005.
- Gat, Azar. *The Causes of War and the Spread of Peace.* Oxford, 2017.
- Hoffman, Bruce, and Fernando Reinares, eds. *The Evolution of the Global Terrorist Threat*. Columbia, 2016.
- Hoffman, Peter J., and Thomas G. Weiss. *Sword and Salve: Confronting New Wars and Humanitarian Crises.* Rowman & Littlefield, 2006.
- Narang, Vipin. *Nuclear Strategy in the Modern Era: Regional Powers and International Conflict.* Princeton, 2014.
- Pape, Robert. *Dying to Win: The Strategic Logic of Suicide Terrorism.* Random House, 2005.

មេរៀនទី ០៧ ៖ អង្គការនិងច្បាប់អន្តរជាតិ និងសិទ្ធិមនុស្ស

រូបថត អ្នករក្សាសន្តិភាពចិនមកដល់ស៊ូដង់ខាងត្បូងឆ្នាំ ២០១៥

វត្ថុបំណងមេរៀន

៧.១ ចូរកំណត់ភាពខុសគ្នារវាងអង្គការអន្តរដ្ឋាភិបាល(IGOs) និងអង្គការក្រៅរដ្ឋាភិបាល (NGOs) ដោយផ្តោតលើភាពខុសគ្នាទម្រង់រចនាសម្ព័ន្ធ និងមុខងាររបស់អង្គការទាំងនោះ។

៧.២ ចូរពិពណ៌នារចនាសម្ព័ន្ធនិងច្បាប់របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ និងរៀបរាប់សមាជិកអចិន្ត្រៃយ៍ទាំង ៥។

៧.៣ តើច្បាប់អន្តរជាតិមានប្រសិទ្ធភាពឬគ្មានប្រសិទ្ធភាព ក្នុងការរឹតត្បិតឥរិយាបទរបស់រដ្ឋនានា។ ចូរពិភាក្សានិងវាយតំលៃអំណះអំណាងទាំងសងខាង។

៧.៤ ចូរសង្ខេបលក្ខណៈខុសគ្នារវាង«យុត្តិសង្គ្រាម»និងសង្គ្រាមឈ្លានពាន។

៧.៥ ចូរប្រៀបធៀបប្រសិទ្ធភាពនៃច្បាប់អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងរដ្ឋនានា ក្នុងការជំរុញបុព្វហេតុសិទ្ធិមនុស្ស នៅជុំវិញពិភពលោក។

៧.១. តួនាទីអង្គការអន្តរជាតិ

៧.១ ចូរកំណត់ភាពខុសគ្នារវាងអង្គការអន្តរដ្ឋាភិបាល(IGOs) និងអង្គការក្រៅរដ្ឋាភិបាល (NGOs) ដោយផ្តោតលើភាពខុសគ្នាទម្រង់រចនាសម្ព័ន្ធ និងមុខងាររបស់អង្គការទាំងនោះ។

ជម្លោះអន្តរជាតិភាគច្រើនមិនត្រូវបានដោះស្រាយដោយកម្លាំងយោធាទេ។ បើទោះបីជាប្រព័ន្ធអន្តរជាតិដែលផ្អែកលើអធិបតេយ្យភាពរបស់រដ្ឋ មានលក្ខណៈអនាធិបតេយ្យក៏ដោយ ជាធម្មតា បញ្ហាទ្វេគ្រោះសន្តិសុខមិននាំអោយមានការបែកបាក់ នៅក្នុងកិច្ចសហប្រតិបត្តិការជាមូលដ្ឋាន ក្នុងចំណោមរដ្ឋនោះទេ។ ជាទូទៅ រដ្ឋបដិសេធមិនកេងយកផលប្រយោជន៍រយៈពេលខ្លីជាអតិបរមា ពីគ្នាទៅវិញទៅមក (ដូចជា ការឈ្លានពាននិងការកាន់កាប់)។ ផ្ទុយទៅវិញ រដ្ឋធ្វើការ*ជាមួយ*រដ្ឋផ្សេងទៀត ដើម្បីទទួលបានផលប្រយោជន៍ពីគ្នា ទៅវិញទៅមក ហើយទាញយកប្រយោជន៍ពីគ្នាទៅវិញទៅមក តែក្នុងកាលៈទេសៈណាមួយប៉ុណ្ណោះ។ ជាអកុសលសកម្មភាពសហប្រតិបត្តិការប្រចាំថ្ងៃរបស់តួអង្គអន្តរជាតិទាំងឡាយ មិនសូវគួរអោយចាប់អារម្មណ៍ដូចជម្លោះរវាងពួកគេ។

រដ្ឋធ្វើការរួមគ្នា ដោយអនុលោមតាមច្បាប់ដែលពួកគេបង្កើតឡើង ដើម្បីគ្រប់គ្រងទំនាក់ទំនងរបស់ពួកគេ។ រដ្ឋជាធម្មតា*អនុវត្តតាម*ច្បាប់ទាំងនោះ។ យូរៗទៅ ច្បាប់ត្រូវបានបង្កើតឡើងកាន់តែរឹងមាំ ហើយស្ថាប័ននានារីកធំធាត់ នៅជុំវិញច្បាប់ទាំងនោះ។ បន្ទាប់មក រដ្ឋបង្កើតទម្លាប់ធ្វើការ តាមរយៈស្ថាប័ន និងនៅក្នុងវិសាលភាពច្បាប់ទាំងនោះ។ ពួកគេធ្វើដូច្នេះព្រោះតែប្រយោជន៍ផ្ទាល់ខ្លួន។ ផលចំណេញដ៏ធំធេងអាចត្រូវបានសម្រេចដោយការគ្រប់គ្រងអន្តរទំនាក់ទំនងអន្តរជាតិ តាមរយៈស្ថាប័ននិងវិធានច្បាប់នានា ដូច្នេះហើយដោយបញ្ចៀសលទ្ធផលខាតបង់មហាសាល ដោយសារការបែកបាក់កិច្ចសហប្រតិបត្តិការ (សូមមើលផងដែរនូវមេរៀនទី ៣)។

ច្បាប់ទាំងឡាយដែលគ្រប់គ្រងអន្តរកម្មភាគច្រើន នៅក្នុងទំនាក់ទំនងអន្តរជាតិត្រូវបានចាក់ឫសតាមបទដ្ឋានច្បាប់។ ជាទូទៅ **បទដ្ឋានអន្តរជាតិ** (international norms) គឺជាសេចក្តីព្រំពឹងទុកដែលតួអង្គនានា

ត្រូវប្រកាន់យកអំពីទំនាក់ទំនងអន្តរជាតិទូទៅ។ ការលុកលុយទៅលើប្រទេសគុយវ៉ែតដោយប្រទេសអ៊ីរ៉ាក់ មិនត្រឹមតែជាទង្វើខុសច្បាប់ប៉ុណ្ណោះទេ ថែមទាំងត្រូវបានចាត់ទុក យ៉ាងទូលំទូលាយថា ជាអំពើអសីលធម៌ផងដែរ លើសពីព្រំដែនកម្រិតដែលអាចទទួលយកបាន សម្រាប់អាកប្បកិរិយារបស់រដ្ឋ។ មេដឹកនាំនយោបាយនៅសហរដ្ឋអាមេរិកនិងជុំវិញពិភពលោក ប្រកាន់យកគោលការណ៍សីលធម៌ ដើម្បីកៀងគរការគាំទ្រសម្រាប់ការឆ្លើយតបជាសមូហភាពចំពោះប្រទេសអ៊ីរ៉ាក់។ ប្រាកដណាស់ មនុស្សជាច្រើនក៏យល់ថាការឈ្លានពានរបស់អាមេរិកទៅលើប្រទេសអ៊ីរ៉ាក់ ក្នុងឆ្នាំ ២០០៣ ជាទង្វើខុសច្បាប់និងអសីលធម៌ផងដែរ ជាមួយនឹងការបដិសេធរបស់សម្ព័ន្ធមិត្តអាមេរិកមិនគាំទ្រការឈ្លានពាន ដោយសារតែការយល់ឃើញថាជាបំពានបទដ្ឋាន។ ដូច្នេះ សីលធម៌គឺជាធាតុមួយនៃអំណាច (សូមមើល ធាតុនៃអំណាច ក្នុងមេរៀនទី ២) ដោយទាញចេញពីគោលការណ៍ស្នូលនៃអត្តសញ្ញាណ (មេដឹកនាំរដ្ឋភាគច្រើនចង់អោយសាធារណជន និងអ្នកដឹកនាំផ្សេងទៀតមើលឃើញថាខ្លួនកំពុងប្រកាន់ខ្ជាប់និងលើកកំពស់សីលធម៌)។

បទដ្ឋានមួយចំនួន ដូចជាអធិបតេយ្យភាពនិងការគោរពសន្ធិសញ្ញា ត្រូវបានលើកតម្កើងនិងប្រកាន់ខ្ជាប់យ៉ាងទូលំទូលាយ, បទដ្ឋានទាំងនោះនាំអោយមានការរំពឹងទុកថា រដ្ឋទាំងឡាយត្រូវមានអាកប្បកិរិយាជាក់លាក់មួយចំនួន និងការកំណត់ស្តង់ដារ ដែលធ្វើអោយទង្វើឃ្លាតឆ្ងាយពីបទដ្ឋាននានាត្រូវបានគេមើលឃើញយ៉ាងច្បាស់ក្រឡែត។ អ្នកប្រាជ្ញទ្រឹស្តីស្ថាបនានិយម ក្នុងទំនាក់ទំនងអន្តរជាតិ (constructivists) (សូមមើល មេរៀនទី ៣) សង្កត់ធ្ងន់លើសារៈសំខាន់នៃបទដ្ឋាននិងស្តង់ដារសេកលទាំងអស់នេះ។ ការប៉ុនប៉ងដើម្បីកំណត់និយមន័យបទដ្ឋានអន្តរជាតិធ្វើតាមប្រពៃណីទស្សនវិជ្ជា ដែលមានអាយុកាល រាប់សតវត្សមកហើយ។ ទស្សនវិទូ ដូចជាលោក កានត៍ បានអះអាងថា វាជាទំនោរធម្មជាតិសម្រាប់បុគ្គលស្វយ័ត(ឬរដ្ឋ) ដើម្បីធ្វើកិច្ចសហប្រតិបត្តិការដើម្បីផលប្រយោជន៍សម្រាប់គ្នាទៅវិញទៅមក ពីព្រោះពួកគេអាចឃើញថា ការស្វែងរកផលប្រយោជន៍បុគ្គលតិចតួចដ៏ចង្អៀត នឹងត្រូវបញ្ចប់ជាមួយនឹងការឈឺចាប់ទាំងអស់គ្នា។ ដូច្នេះ រដ្ឋអធិបតេយ្យអាចធ្វើការរួមគ្នា តាមរយៈរចនាសម្ព័ន្ធ និងអង្គការចាត់តាំងនានា (ដូចជា សហព័ន្ធពិភពលោក ដែលត្រូវបានស្នើឡើងដោយលោកកានត៍) ដែលនឹងគោរពស្វ័យភាពរបស់សមាជិកនីមួយៗ និងមិនបង្កើតរដ្ឋាភិបាលពិភពលោកត្រួតត្រាពួកគេ។ នៅសតវត្សទីដប់ប្រាំបួន គំនិតបែបនេះត្រូវបានបញ្ចូលក្នុងការអនុវត្តជាក់ស្តែង ក្នុងនោះ អង្គការដែលរដ្ឋបានចូលរួមដើម្បីគ្រប់គ្រងបញ្ហាជាក់លាក់ ដូចជា សេវាប្រៃសណីយ៍អន្តរជាតិ និងការគ្រប់គ្រងចរាចរណ៍លើបណ្តាទន្លេអឺរ៉ុបទាំងអស់។

រូបថត ទាហានក្មេងៗកាន់កាំភ្លើង

ខុសបទដ្ឋាន

បទដ្ឋានអន្តរជាតិកំពុងវិវឌ្ឍ នៅក្នុងផ្នែកដូចជា អន្តរាគមន៍មនុស្សធម៌ សិទ្ធិមនុស្ស និងច្បាប់សង្គ្រាម។ បទដ្ឋានទាំងនេះជួយកំណត់តួនាទីរបស់អង្គការអន្តរជាតិ។ ផ្នែកមួយនៃការព្រួយបារម្ភរបស់ពួកគេណា គឺការប្រើប្រាស់ទាហានកុមារ ដូចជាក្មេងប្រុសយេម៉ែនម្នាក់នេះ បានចូលរួមជាមួយក្រុមយុទ្ធជនហ៊ូទី (Houthi) ដែលទើបជ្រើសរើសក្នុងឆ្នាំ ២០១៧។ សង្គ្រាមស៊ីវិលក្នុងប្រទេសយេម៉ែនបានបង្កើតការព្រួយបារម្ភអំពីការរំលោភលើបទដ្ឋានអន្តរជាតិជាច្រើន រួមទាំងការបង្អត់អាហារជាអាវុធ ការកំណត់គោលដៅដោយចេតនាលើមន្ទីរពេទ្យ និងការប្រើប្រាស់ទាហានកុមារ ជាដើម។

បទដ្ឋានអាកប្បកិរិយាដែលបានព្រមព្រៀង ដែលត្រូវរៀបចំឬចាត់ចែងក្នុងទំរង់ជាស្ថាប័ន តាមរយៈអង្គការបែបនេះ យូរៗទៅបានក្លាយជា *ទំនៀមទម្លាប់* (habitual) និងទទួលបាន *ធម្មានុរូបភាព* (legitimacy-ភាពស្របច្បាប់)។ មេដឹកនាំរដ្ឋធ្លាប់មានភាពស៊ាំទៅនឹងឥរិយាបទធម្មតា ហើយមិនចាំបាច់នៅវិភាគលើការចំណាយនិងចំណេញពីទង្វើបំពានបទដ្ឋាននីមួយៗ ពោលគឺ ពួកគេប្រព្រឹត្តទៅតាមបទដ្ឋានអន្តរជាតិបានក្លាយជាទម្លាប់ទៅហើយ។ ជាឧទាហរណ៍ នៅពេលចូលសតវត្សរ៍ទីដប់ប្រាំបួន អ្នករៀបចំផែនការសង្គ្រាមរបស់សហរដ្ឋអាមេរិកបានរៀបចំគំរោងការ ក្នុងករណីផ្ទុះជម្លោះកងទ័ពជើងទឹកដ៏ធំមួយ រវាងសហរដ្ឋអាមេរិកនិងចក្រភពអង់គ្លេស។ សព្វថ្ងៃនេះ គំរោងការបែបនេះហាក់ដូចជាគួរអោយអស់សំណើចណាស់។ យូរៗទៅរដ្ឋបដិសេធមិនប្រព្រឹត្តអាកប្បកិរិយា មិនត្រឹមដោយសារហេតុផលការចំណាយនិងផលចំណេញប៉ុណ្ណោះទេ (ដូចដែលបានសង្កត់ធ្ងន់ដោយអ្នកទ្រឹស្តីប្រាកដនិយមនិងអ្នកទ្រឹស្តីសេរីនិយម) ប៉ុន្តែ ថែមទាំងដោយសារហេតុផលធម្មតា ដែលមិនសូវទាក់ទងនឹងការគណនាការចំណាយសម្ភារៈ (ដូចដែលបានសង្កត់ធ្ងន់ដោយអ្នកទ្រឹស្តីស្ថាបនា ដែលគិតថា បទដ្ឋានត្រូវបានស្ថាបនាជាហូរហែរ)។ ធម្មានុរូបភាពនិងទម្លាប់អាចពន្យល់ពីមូលហេតុដែលបទដ្ឋានអន្តរជាតិអាចមានប្រសិទ្ធភាព បើទោះបីជាវាមិនត្រូវបានដាក់បញ្ចូលជាច្បាប់ផ្លូវការនិងត្រូវបានពង្រឹងការអនុវត្តក៏ដោយ។

ទោះជាយ៉ាងណាក៏ដោយ ឥទ្ធិពលនៃបទដ្ឋានអន្តរជាតិនិងស្តង់ដារសីលធម៌អាចប្រែប្រួល នៅពេលដែលរដ្ឋនានាឬតំបន់ផ្សេងៗនៃពិភពលោក មានការរំពឹងទុកខុសៗគ្នា អំពីអ្វីដែលហៅថាជា ភាពធម្មតា។ ចំពោះសហរដ្ឋអាមេរិក វាជាកត្តាចាំបាច់ខាងសីលធម៌ ដើម្បីទម្លាក់ សាដាម ហ៊ូសេន ចេញពីអំណាច។ ប៉ុន្តែតាមទស្សនៈរបស់ប្រជាជនអារ៉ាប់ ការឈ្លានពានរបស់សហរដ្ឋអាមេរិក គឺជាការរំលោភអធិបតេយ្យភាពទឹកដីយ៉ាងអយុត្តិធម៌។ នៅក្នុងករណីនៃបទដ្ឋានខុសគ្នា សីលធម៌អាចជាកត្តានាំអោយមានការយល់ច្រឡំ និងផ្ទុះជម្លោះ ជាជាងជាកម្លាំងនាំអោយមានស្ថិរភាព។ អ្នកទ្រឹស្តីប្រាកដនិយមបានចង្អុលបង្ហាញដល់ឧទាហរណ៍ដូចជាឧទាហរណ៍ទាំងនេះដើម្បីអះអាងថា បទដ្ឋានអន្តរជាតិមិនមានមានឥទ្ធិពលផ្លាស់ប្តូរខ្លាំងក្លាលើបញ្ហាសំខាន់ៗក្នុងទំនាក់ទំនងអន្តរជាតិនោះទេ។ ផ្ទុយទៅវិញ អ្នកប្រាកដនិយមបែរជាចង្អុលបង្ហាញថា បទដ្ឋានដែលត្រូវបានគេទទួលយក ត្រូវបានសម្រួចដោយរដ្ឋដែលមានអំណាច នៅក្នុងប្រព័ន្ធអន្តរជាតិ (គោលការណ៍គ្រប់គ្រង) ហើយរដ្ឋមានអំណាចដដែលនេះជារឿយៗទទួលខុសត្រូវចំពោះការបកស្រាយរបស់ពួកគេ។ ទោះបីជាយ៉ាងណាក៏ដោយ អ្នកប្រាជ្ញទ្រឹស្តីស្ថាបនានិយមបានចង្អុលបង្ហាញថា ទោះបីជាបទដ្ឋានអន្តរជាតិត្រូវបានរំលោភបំពានក៏ដោយក៏រដ្ឋនានា (សូម្បីតែសហរដ្ឋអាមេរិក) ត្រូវប្រឹងប្រែងលើកហេតុផលពន្យល់ពីភាពចាំបាច់ឬភាពត្រឹមត្រូវសម្រាប់ធ្វើអាកប្បកិរិយាដែលរំលោភបំពានលើបទដ្ឋានណាមួយ។ នេះបង្ហាញថាបទដ្ឋានរឹងមាំពិតជាមានយ៉ាងប្រាកដ ហើយត្រូវបានទទួលស្គាល់យ៉ាងទំលំទូលាយ សូម្បីតែរដ្ឋដែលមានអំណាចបំផុតក៏ដោយទទួលស្គាល់ដែរ។


ស្ថាប័ននានាបានដើរតួនាទីយ៉ាងសំខាន់ ជាពិសេសពេលមានការផ្លាស់ប្តូរ ខណៈពេលដែលបទដ្ឋាននិងទម្លាប់រួមប្រហែលជាមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្នុងការដោះស្រាយបញ្ហាប្រឈមអន្តរជាតិនិងសម្រេចបាននូវកិច្ចសហប្រតិបត្តិការទៅវិញទៅមក។ ស្ថាប័នទាំងនោះមានរចនាសម្ព័ន្ធរួបីនិងរឹងមាំ ជាមួយនឹងមុខងារនិងបេសកកម្មជាក់លាក់។ ស្ថាប័នទាំងនេះបានរីកសាយភាយយ៉ាងឆាប់រហ័ស ក្នុងប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ ហើយបន្តដើរតួនាទីយ៉ាងសំខាន់ក្នុងកិច្ចការអន្តរជាតិ។ **អង្គការអន្តរជាតិ** (IOs) រួមមាន *អង្គការ*

អន្តររដ្ឋាភិបាល(IGO) ដូចជាអង្គការសហប្រជាជាតិ និង*អង្គការមិនមែនរដ្ឋាភិបាល*(NGOs) ដូចជា គណៈកម្មាធិការអន្តរជាតិនៃកាកបាទក្រហម (ICRC) ជាដើម។

អ្នកទ្រឹស្តីសេរីនិយមចង្អុលបង្ហាញថា ផ្ទុយពីអ្វីដែលអ្នកទ្រឹស្តីប្រាកដនិយម ឬ អ្នកទ្រឹស្តីស្ថាបនានិយមបានអះអាង ការប្រែក្លាយបទដ្ឋានអន្តរជាតិទៅជាបទបញ្ញត្តិនៅក្នុងស្ថាប័ន បានធ្វើអោយបទដ្ឋានទាំងនោះមានអំណាចជាក់ស្តែង។ ដូចដែលបានពិភាក្សានៅក្នុងមេរៀនទី ៣ ស្ថាប័នទាំងនេះផ្តល់រង្វាន់ទឹកចិត្តតួអង្គទាំងឡាយ ក្នុងការប្រព្រឹត្តអាកប្បកិរិយាជាការឆ្លើយតប ដែលត្រូវបានជម្រុញដោយបទដ្ឋានមួយ (គោលការណ៍បដិការ) ក្នុងខណៈពេលកំពុង រឹតបន្តឹងអាកប្បកិរិយារបស់រដ្ឋដែលមានអំណាច តាមរយៈ ច្បាប់ដែលគ្រប់គ្រងអាកប្បកិរិយា។ អ្នកទ្រឹស្តីសេរីនិយមចង្អុលបង្ហាញថា ស្ថាប័នអន្តរជាតិជាច្រើន និងកំពុងកើនឡើងថាជាភស្តុតាងនៃអំណាចនិងសារៈសំខាន់នៃស្ថាប័នទាំងនោះ។

ចំនួនអង្គការអន្តរជាតិ (IOs) បានកើនឡើង ច្រើនជាង ៥ ដង ចាប់តាំងពីឆ្នាំ ១៩៤៥ រហូតដល់ចំនួនប្រហែល ៣៥០ អង្គការអន្តរជាតិឯករាជ្យនិងអង្គការក្រៅរដ្ឋាភិបាល (NGOs) ចំនួនរាប់ម៉ឺន (អាស្រ័យលើការកំណត់និយមន័យនៃអង្គការ)។ ក្រាហ្វិក ៧.១ ចង្អុលបង្ហាញពីកំណើននេះ។ អង្គការក្រៅរដ្ឋាភិបាលថ្មីត្រូវបានបង្កើតឡើង នៅជុំវិញពិភពលោក ជារៀងរាល់ថ្ងៃ។ ការរួមគ្នាជាធ្លុងតែមួយរវាងក្រុមមនុស្សឆ្លងព្រំដែនជាតិ តាមរយៈក្រុមឯកទេសទាំងអស់នេះ ឆ្លុះបញ្ចាំងពីភាពពឹងអាស្រ័យគ្នាទៅវិញទៅមក (សូមមើលមេរៀនទី ៨ ផងដែរ)។

ក្រាហ្វិក ៧.១ រដ្ឋនិងអង្គការអន្តររដ្ឋាភិបាល(IGOs) នៅលើពិភពលោក ឆ្នាំ ១៨១៥-២០១៥



(*សម្គាល់៖* បន្ទាត់ដាច់ៗតំណាងចំនួនរដ្ឋ, បន្ទាត់ដាប់តំណាងចំនួនអង្គការអន្តររដ្ឋាភិបាល)

អង្គការអន្តររដ្ឋាភិបាល(IGOs)មួយចំនួនមានវិសាលភាពប្រតិបត្តិការជាសកល IGOs ខ្លះទៀតមានលក្ខណៈជាតំបន់ ឬ ត្រឹមតែលក្ខណៈទ្វេភាគី (ដោយមានសមាជិករដ្ឋចំនួនពីរ)។ អង្គការអន្តររដ្ឋាភិបាលមួយចំនួនមានគោលដៅទូទៅ ខ្លះទៀតមានគោលបំណងមុខងារជាក់លាក់។ សរុបមក ភាពជោគជ័យនៃអង្គការ

អន្តររដ្ឋាភិបាលទាំងនេះមានកម្រិតចម្រុះខុសគ្នាពីមួយទៅមួយទៀត ដោយក្នុងនោះ អង្គការអន្តររដ្ឋាភិបាលថ្នាក់តំបន់បានទទួលជោគជ័យច្រើនជាងអង្គការកំរិតសកល ហើយអង្គការដែលមានគោលបំណងមុខងារ ឬបច្ចេកទេសជាក់លាក់បានដំណើរការល្អជាងអង្គការដែលមានគោលដៅទូលំទូលាយ (សូមមើលមេរៀនទី ១០)។ អង្គការអន្តររដ្ឋាភិបាលរួមគ្នាបានជាប់លាប់ដោយសារតែពួកគេលើកកម្ពស់ផលប្រយោជន៍ជាតិ (ឬបង្កើនអានុភាព)នៃរដ្ឋជាសមាជិករបស់ពួកគេ មិនមែនដោយសារតែឧត្តមគតិដែលមិនច្បាស់លាស់នោះទេ។

ក្នុងចំណោម អង្គការអន្តររដ្ឋាភិបាល*កម្រិតតំបន់* សហភាពអឺរ៉ុបគ្របដណ្តប់លើអង្គការសំខាន់ៗបំផុតមួយចំនួន (សូមមើលមេរៀនទី ១០) ប៉ុន្តែ វាមិនមែនជាឧទាហរណ៍នៃប្រភេទអង្គការបែបនេះតែមួយនោះទេ។ អង្គការអន្តររដ្ឋាភិបាលក្នុងតំបន់សំខាន់ៗផ្សេងទៀត រួមមានសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ហៅកាត់ថា អាស៊ាន) ទីផ្សាររួមខាងត្បូង (MERCOSUR) និងសហភាពអាហ្វ្រិក(AU)។ តួនាទីមុខងាររបស់អង្គការអន្តរជាតិមានសារៈសំខាន់ចំពោះឥទ្ធិពលជារួមរបស់ពួកគេលើទំនាក់ទំនងអន្តរជាតិ ប៉ុន្តែ តួនាទីទាំងនោះត្រូវបានលើកឡើងនៅក្នុងមេរៀនទី ១០ ស្តីពីសមាហរណកម្មអន្តរជាតិ។ នៅទីនេះ យើងនឹងពឹងផ្អែកលើការពិភាក្សាទ្រឹស្តីទូទៅនៃស្ថាប័នអន្តរជាតិបន្ថែមទៀត ដែលបានចាប់ផ្តើមតាំងពីក្នុងមេរៀនទី ៣។

អង្គការអន្តររដ្ឋាភិបាល*កម្រិតសកល* (ក្រៅពីអង្គការសហប្រជាជាតិ) ជាធម្មតា មានគោលបំណងមុខងារ ដែលពាក់ព័ន្ធនឹងសកម្មភាពសម្របសម្រួលក្នុងចំណោមរដ្ឋមួយចំនួន នៅជុំវិញពិភពលោក។ ជាឧទាហរណ៍ អង្គការអន្តររដ្ឋាភិបាលមួយ ហៅថា Intelsat (អ៊ីនថែលសែថ) គឺជាសម្ព័ន្ធរបស់រដ្ឋាភិបាល និងអាជីវកម្មឯកជន ដែលប្រតិបត្តិការទំនាក់ទំនងរវាងគ្នា តាមរយៈប្រព័ន្ធផ្កាយរណប។ សមាជិកនៃអង្គការនៃនៃប្រទេសនាំចេញប្រេង(OPEC) គឺជាប្រទេសផលិតប្រេងសំខាន់ៗ ដែលជួបប្រជុំគ្នា ជាទៀងទាត់ នៅទីក្រុងវីយែន នៃប្រទេសអូទ្រីស ដើម្បីកំណត់កូតាផលិតកម្ម សម្រាប់សមាជិកក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីរក្សាតម្លៃប្រេងពិភពលោកអោយខ្ពស់និងស្ថិរភាព។ ចូរកត់ចំណាំថា បើទោះបីជាសមាជិកសំខាន់ៗនៃ អង្គការអន្តរ-រដ្ឋាភិបាល គឺជារដ្ឋក៏ដោយ ក៏អង្គការក្រៅរដ្ឋាភិបាល អាជីវកម្ម ឬបុគ្គលទាំងឡាយ អាចមានតួនាទីប្រឹក្សា និងពិភាក្សាដ៏សំខាន់ៗ នៅក្នុងអង្គការអន្តររដ្ឋាភិបាលផងដែរ។

អង្គការក្រៅរដ្ឋាភិបាល(NGOs)ឬហៅថា អង្គការមិនមែនរដ្ឋាភិបាល ក៏បាន ហាក់មានមុខងារជំនាញជាក់លាក់ជាងអង្គការអន្តររដ្ឋាភិបាល(IGOs)។ ជាឧទាហរណ៍ បុគ្គលណាក៏ដោយ ដែលចង់ជួបជាមួយអ្នកវិទ្យាសាស្ត្រនយោបាយមកពីប្រទេសផ្សេងៗ អាចចូលរួមជាមួយសមាគមវិទ្យាសាស្ត្រនយោបាយអន្តរជាតិ។ អង្គការក្រៅរដ្ឋាភិបាលជាច្រើនមានមុខងារទាក់ទងនឹងសេដ្ឋកិច្ចឬអាជីវកម្ម។ សមាគមដឹកជញ្ជូនផ្លូវអាកាសអន្តរជាតិសម្របសម្រួលការងាររបស់ក្រុមហ៊ុនអាកាសចរណ៍។ អង្គការក្រៅរដ្ឋាភិបាលផ្សេងទៀតមានគោលបំណងនយោបាយជាសកល ជាឧទាហរណ៍ អង្គការលើកលែងទោសអន្តរជាតិ (Amnesty International) សម្រាប់សិទ្ធិមនុស្សនិងការរៀបចំផែនការគ្រួសារ (Planned Parenthood) សម្រាប់សិទ្ធិបន្តពូជ និងការធ្វើផែនការគ្រួសារ។ ដោយឡែក ក្រុមអង្គការផ្សេងទៀតមានគោលដៅផ្នែកវប្បធម៌ ឧទាហរណ៍ គណៈកម្មាធិការអូឡាំពិកអន្តរជាតិ។

ក្រុមសាសនានានាស្ថិតក្នុងចំណោមអង្គការក្រៅរដ្ឋាភិបាលធំជាងគេ ដែលសមាជិកភាពចម្រុះមកពីប្រទេសជាច្រើន។ ទាំងនៅក្នុងពិភពលោកបច្ចុប្បន្ននិងក្នុងប្រវត្តិសាស្ត្រ និកាយសាសនាទាំងឡាយ ដូចជាសាសនាគ្រឹស្តនិយម សាសនាឥស្លាមនិយម ព្រះពុទ្ធសាសនានិយម សាសនាយូដានិយម សាសនាហិណ្ឌូ

និយម និងសាសនាពិភពលោកផ្សេងទៀត បានកៀងគរនិងរៀបចំសាសនិកជនរបស់ខ្លួន ឆ្លងកាត់ព្រំដែនរដ្ឋ ដែលជារឿយៗប្រឈមមុខនឹងអរិភាពពីរដ្ឋាភិបាលជាតិមួយឬច្រើន។ អ្នកផ្សព្វផ្សាយសាសនាបានបង្កើត និងថែទាំទំនាក់ទំនងឆ្លងដែនទាំងនេះ ដោយចេតនា។ ជាលក្ខណៈប្រវត្តិសាស្ត្រ ព្រះវិហារកាតូលិកបានកាន់តំណែងពិសេសមួយ នៅក្នុងប្រព័ន្ធអន្តរជាតិនៅអឺរ៉ុប ជាពិសេសមុនសតវត្សទីដប់ប្រាំពីរ។

បច្ចុប្បន្ននេះ អង្គការក្រៅរដ្ឋាភិបាលប្រាថ្នាចង់បានច្រកចូលអង្គការអន្តរដ្ឋាភិបាលដើម្បីសម្រួចច្បាប់ និងបទដ្ឋាននានា។ អង្គការក្រៅរដ្ឋាភិបាលដែលមានគោលដៅនិងវិសាលភាពកូមិសាស្ត្រទូលំទូលាយតែងតែរក្សាហានៈជាអ្នកសង្កេតការណ៍ នៅក្នុងអង្គការសហប្រជាជាតិ ដើម្បីអោយពួកគេអាចចូលរួមក្នុងកិច្ចប្រជុំអំពីបញ្ហាកង្វល់នានារបស់អង្គការសហប្រជាជាតិ។ ជាឧទាហរណ៍ អង្គការបរិស្ថាន Greenpeace ចូលរួមក្នុងកិច្ចប្រជុំរបស់អង្គការសហប្រជាជាតិអំពីបរិស្ថានពិភពលោក។ អង្គការក្រៅរដ្ឋាភិបាលជាច្រើនប្រាថ្នាចង់បាន «អាសនៈមួយនៅតុប្រជុំ» (សំដៅលើសិទ្ធិក្នុងការចូលរួមកិច្ចប្រជុំរបស់អង្គការអន្តរដ្ឋាភិបាល) ដើម្បីបានបញ្ចេញមតិ និងរហូតអាចមានសិទ្ធិបោះឆ្នោត។ នេះជាការពិត ជាពិសេស នៅពេលដែលបញ្ហាដ៏លំបាកត្រូវបានលើកដាក់នៅលើតុដើម្បីពិភាក្សា។ ជាឧទាហរណ៍ កិច្ចប្រជុំនានាដូចជាសន្និសីទប្រចាំឆ្នាំរបស់ភាគីសម្រាប់ក្រុមប្រឹក្សាអន្តរដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ (IPCC) ត្រូវបានចូលរួម ដោយរដ្ឋស្ទើរតែទាំងអស់ អង្គការអន្តរដ្ឋាភិបាលបួនដប់ផ្សេងទៀត អង្គការក្រៅរដ្ឋាភិបាលរាប់រយ និងប្រជាពលរដ្ឋរាប់ពាន់នាក់ រួមគ្នាក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីសម្រួចដំណោះស្រាយចំពោះកំណើនកំដៅសកល (សូមមើលមេរៀនទី ១១)។

បណ្តាញនៃអង្គការអន្តរជាតិ ដែលមានទំហំនិងប្រភេទផ្សេងៗគ្នា បច្ចុប្បន្ននេះ ផ្សារភ្ជាប់មនុស្សមកពីគ្រប់ប្រទេសទាំងអស់។ ការរីកចម្រើនយ៉ាងឆាប់រហ័សនៃបណ្តាញនេះ និងទំនាក់ទំនងកាន់តែញឹកញាប់ខ្លាំងនិងអន្តរកម្មដែលកើតឡើងក្នុងនោះ ចង្អុលបង្ហាញពីការកើនឡើងនូវភាពអាស្រ័យគ្នាទៅវិញទៅមក។ ផ្ទុយមកវិញ អង្គការទាំងនេះផ្តល់នូវសំណាញ់ស្ថាប័នដើម្បីរក្សានូវសណ្តាប់ធ្នាប់ពិភពលោកក្នុងកម្រិតណាមួយ សូម្បីតែនៅពេលមេដឹកនាំនិងបរិបទលេចឡើងនិងរលាយបាត់ទៅវិញ និងសូម្បីតែនៅពេលដែលបទដ្ឋានត្រូវបានបំផ្លាញ ដោយការផ្លាស់ប្តូរទំនាក់ទំនងអំណាចភ្លាមៗ។ នៅចំណុចកណ្តាលនៃបណ្តាញទំនាក់ទំនងនោះគឺជាអង្គការអន្តរជាតិដ៏សំខាន់បំផុត នាពេលបច្ចុប្បន្ននេះ នោះគឺ អង្គការសហប្រជាជាតិ (អ.ស.ប.)។

៧.២. អង្គការសហប្រជាតិ

៧.២ ចូរពិពណ៌នារចនាសម្ព័ន្ធនិងច្បាប់របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ និងរៀបរាប់សមាជិកអចិន្ត្រៃយ៍ទាំង ៥។

អង្គការសហប្រជាជាតិ(អ.ស.ប.)និងអង្គការអន្តរជាតិផ្សេងទៀតមានទាំងចំណុចខ្លាំងនិងចំណុចខ្សោយ នៅក្នុងប្រព័ន្ធអន្តរជាតិដ៏អនាធិបតេយ្យ។ អធិបតេយ្យភាពរបស់រដ្ឋបង្កអោយមានតម្រូវការពិតប្រាកដ សម្រាប់អង្គការបែបនេះ ក្នុងកម្រិតជាក់ស្តែងណាមួយ ដោយសារគ្មានរដ្ឋាភិបាលកណ្តាលពិភពលោកដើម្បីអនុវត្តមុខងារនៃការសម្របសម្រួលសកម្មភាពរបស់រដ្ឋទាំងឡាយ ដើម្បីជាផលប្រយោជន៍អោយគ្នាទៅវិញទៅមក។ ទោះជាយ៉ាងណាក៏ដោយ អធិបតេយ្យភាពរបស់រដ្ឋក៏កម្រិតវិសាលភាពអំណាចរបស់អង្គការសហប្រជាជាតិនិងអង្គការអន្តរជាតិផ្សេងទៀតយ៉ាងគត់មុតផងដែរ ពីព្រោះរដ្ឋាភិបាលទាំងនោះរក្សាទុកអំណាចសម្រាប់តែពួកគេផ្ទាល់ និងកំណាញ់មិនចង់ផ្ទេរវាទៅអោយអង្គការសហប្រជាជាតិ ឬនរណាម្នាក់ផ្សេងទៀត។ អង្គការ

សហប្រជាជាតិមានកំណត់ត្រាវាយតម្លៃចម្រុះ ដោយសារតែចំណុចខ្លាំងនិងចំណុចខ្សោយទាំងនេះ ម្យ៉ាងវាបានផ្តល់ការគ្រប់គ្រងកម្រិតជាសកលដែលគួរអោយកត់សម្គាល់ និងម្យ៉ាងទៀតវាមើលទៅហាក់ដូចជាគ្មានលទ្ធភាពទប់ទល់ជាមួយនឹងអធិបតេយ្យភាពនៃរដ្ឋដែលមានទំហំមធ្យម (នេះមិនទាន់គិតដល់ប្រទេសមហាអំណាចផង)។

៧.២.១. ប្រព័ន្ធអង្គការសហប្រជាជាតិ

អង្គការសហប្រជាជាតិ គឺជាស្ថាប័នមួយថ្មីគួរសម ដែលទើបតែមានអាយុកាលជាង ៧០ឆ្នាំប៉ុណ្ណោះ។ អ្វីដែលថ្មីជាងនេះគឺជាតួនាទីកាន់តែលេចធ្លោ ដែលអង្គការសហប្រជាជាតិបានបំពេញ ក្នុងកិច្ចការសន្តិសុខអន្តរជាតិ ចាប់តាំងពីការបញ្ចប់សង្គ្រាមត្រជាក់។ ទោះបីជាមានភាពលេចធ្លោថ្មីៗនេះក៏ដោយ ក៏គោលបំណងសំខាន់ៗរបស់អង្គការសហប្រជាជាតិនាពេលនេះ នៅរក្សាដូចគ្នានឹងពេលដែលវាត្រូវបានបង្កើតឡើង ក្រោយសង្គ្រាមលោកលើកទីពីរដែរ។

គោលដៅរបស់អង្គការសហប្រជាជាតិ

អង្គការសហប្រជាជាតិ គឺជាស្ថាប័នមានលក្ខណៈដែលស្រដៀងខ្លាំងបំផុតទៅនឹងរដ្ឋាភិបាលពិភពលោក ដែលមិនធ្លាប់មានពីមុនមក ប៉ុន្តែកុំភ័ន្តច្រលំវាមិនមែនជារដ្ឋាភិបាលពិភពលោកទេ។ សមាជិកអ.ស.ប. គឺជារដ្ឋអធិបតេយ្យ ដែលមិនបានផ្តល់អំណាចមួយចំណែកណានោះ ដល់អង្គការសហប្រជាជាតិ ដើម្បីអនុវត្តឆន្ទៈរបស់ខ្លួននៅក្នុងទឹកដីរបស់រដ្ឋ លើកលែងតែមានការយល់ព្រមពីរដ្ឋាភិបាលនៃរដ្ឋម្ចាស់ផ្ទះទាំងនោះ។ ដូច្នេះហើយ ទោះបីជាអង្គការសហប្រជាជាតិពង្រឹងសណ្តាប់ធ្នាប់ពិភពលោកក៏ដោយ រចនាសម្ពន្ធ័របស់អ.ស.ប.ទទួលស្គាល់សច្ចៈភាពនៃភាពអនាធិបតេយ្យអន្តរជាតិ និងអធិបតេយ្យភាពរបស់រដ្ឋទាំងឡាយក្នុងការលះបង់អធិបតេយ្យភាពរបស់ពួកគេ។ នៅក្នុងរង្វង់ព្រំដែនកម្រិតទាំងនេះ គោលបំណងជាមូលដ្ឋានរបស់អង្គការសហប្រជាជាតិត្រូវផ្តល់នូវរចនាសម្ព័ន្ធស្ថាប័នសកលមួយ ដែលជួនកាល រដ្ឋទាំងឡាយអាចដោះស្រាយជម្លោះ ដោយមានការពឹងផ្អែកតិចតួចលើការប្រើប្រាស់កងកម្លាំង។

ធម្មនុញ្ញអង្គការសហប្រជាជាតិ (UN Charter) ត្រូវផ្អែកលើគោលការណ៍ដែលចែងថា រដ្ឋទាំងឡាយមានឋានៈ*ស្មើគ្នា*នៅក្រោមច្បាប់អន្តរជាតិ រដ្ឋទាំងឡាយមាន*អធិបតេយ្យភាព*ពេញលេញលើកិច្ចការរបស់ខ្លួន រដ្ឋទាំងឡាយគួរតែមាន*ឯករាជ្យ*និង*បូរណភាពទឹកដី*ពេញលេញ ហើយថារដ្ឋទាំងឡាយគួរតែអនុវត្ត*ភាពប្រកិប្ត*អន្តរជាតិរបស់ពួកគេ ដូចជាការគោរពអភ័យឯកសិទ្ធិការទូត ជៀសវាងការប្រព្រឹត្តអំពើឈ្លានពាន និងគោរពតាមលក្ខខណ្ឌនៃសន្ធិសញ្ញានានាដែលពួកគេបានចុះហត្ថលេខាហើយរួច។ ធម្មនុញ្ញអង្គការសហប្រជាជាតិក៏បានដាក់ចេញនូវរចនាសម្ព័ន្ធរបស់អង្គការសហប្រជាជាតិ និងនីតិវិធី ដែលវាត្រូវខ្លួនដំណើរការតាម។

អង្គការសហប្រជាជាតិមិនមានអត្ថិភាព ដោយសារវាមានអំណាចបង្ខំរដ្ឋនានាក្នុងពិភពលោកអោយធ្វើតាមឆន្ទៈរបស់ខ្លួននោះទេ ប៉ុន្តែ វាមានអត្ថិភាពដោយសាររដ្ឋនានាបានបង្កើតវាឡើង ដើម្បីបម្រើសេចក្តីត្រូវការរបស់ពួកគេ។ សមាជិកភាពរបស់រដ្ឋមួយ នៅក្នុងអង្គការសហប្រជាជាតិ គឺជាទម្រង់អានុភាពដាក់គំនាបមួយ ដោយប្រយោល។ រដ្ឋទទួលបានអានុភាពដោយប្រើប្រាស់អង្គការសហប្រជាជាតិ ដើម្បីស្វែងរកលទ្ធផលជាប្រយោជន៍បន្ថែមទៀត នៅក្នុងជម្លោះ (ជាពិសេសលើបញ្ហាពហុភាគីទូទៅ ដែលវេទិកាសកលនាំភាគីពាក់ព័ន្ធទាំងអស់មកពិភាក្សាគ្នា)។ ថ្លៃចំណាយសម្រាប់អានុភាពនេះមានកម្រិតតិចតួច៖ ការរួមវិភាគទានទៅក្នុង

អង្គការសហប្រជាជាតិ និងការចំណាយរបស់អ្នកតំណាងការទូតទាំងអស់ បន្ថែមពីលើកិច្ចព្រមព្រៀងដើម្បីប្រព្រឹត្តស្របតាមធម្មនុញ្ញអង្គការសហប្រជាជាតិ ស្ទើរតែគ្រប់ពេល។

រដ្ឋទទួលបានអត្ថប្រយោជន៍មួយចំនួន ពីអង្គការសហប្រជាជាតិ។ ផលប្រយោជន៍សំខាន់បំផុតក្នុងចំណោមនេះ គឺស្ថិរភាពអន្តរជាតិ (ជាពិសេសក្នុងកិច្ចការសន្តិសុខ) ដែលអង្គការសហប្រជាជាតិព្យាយាមថែរក្សា ដែលនឹងអនុញ្ញាតអោយរដ្ឋអាចទាញយកផលចំណេញពីវិស័យពាណិជ្ជកម្ម និងទម្រង់ផ្សេងទៀតនៃការផ្លាស់ប្តូរ (សូមមើលមេរៀន ទី ៨)។ អង្គការសហប្រជាជាតិ គឺជា*និមិត្តរូប*នៃសណ្តាប់ធ្នាប់អន្តរជាតិ និងអត្តសញ្ញាណសកលទៀតផង។ វាក៏ជា*វេទិកា* មួយដែលរដ្ឋនានាផ្សព្វផ្សាយទស្សនៈរបស់ពួកគេ និងនាំជម្លោះរបស់ពួកគេមកបង្ហាញ។ ហើយវាជា*យន្តការ*សម្រាប់ដោះស្រាយជម្លោះ ក្នុងកិច្ចការសន្តិសុខអន្តរជាតិ។ អង្គការសហប្រជាជាតិក៏ជំរុញនិងសម្របសម្រួលជំនួយអភិវឌ្ឍន៍ (សូមមើលមេរៀនទី ១៣) និងកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមផ្សេងទៀត នៅក្នុងអឡឺគោលខាងត្បូង។ កម្មវិធីទាំងនេះឆ្លុះបញ្ចាំងពីជំនឿដែលថាបញ្ហាសេដ្ឋកិច្ចនិងសង្គម (សំខាន់បំផុតគឺភាពក្រីក្រ) គឺជាប្រភពដ៏សំខាន់នៃជម្លោះអន្តរជាតិ និងសង្គ្រាម។ ជាចុងក្រោយ អង្គការសហប្រជាជាតិ គឺជាប្រព័ន្ធសម្របសម្រួលសម្រាប់*ព័ត៌មាន*និងការរៀបចំផែនការ ដោយភ្នាក់ងារនិងកម្មវិធីខាងក្នុងនិងខាងក្រៅរាប់រយ និងសម្រាប់ការបោះពុម្ពផ្សាយទិន្នន័យអន្តរជាតិ។

រូបថត កងសន្តិសុខ នៅលីបង់

ប្រុងប្រយ័ត្នជានិច្ច

អង្គការសហប្រជាជាតិមានអំណាចនិងធនធាននៅមានកម្រិតនៅឡើយ ប៉ុន្តែពិភពលោកបានដាក់បន្ទុកកិច្ចការសំខាន់ៗមួយចំនួនលើអង្គការសហប្រជាជាតិ រួមទាំងការរក្សាសន្តិភាពរវាងអតីតអ្នកបះបោរ។ នៅទីនេះ កងរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិមកពីកងកម្លាំងសង្កេតការណ៍ នៅក្នុងប្រទេសលីបង់ កំពុងឃ្លាំមើល យ៉ាងប្រុងប្រយ័ត្ន នៅតាមព្រំដែនជាមួយអ៊ីស្រាអែលឆ្នាំ ២០១៧ ។

ទោះបីជាមានភារកិច្ចធ្ងន់ក៏ដោយ អង្គការសហប្រជាជាតិនៅតែជាស្ថាប័នដ៏តូចនិងផុយស្រួយមួយ។ ជាឧទាហរណ៍ សាកប្រៀបធៀបអ្វីដែលរដ្ឋចំណាយលើអានុភាពពីរប្រភេទ សម្រាប់ការដោះស្រាយជម្លោះ៖ កងកម្លាំងយោធា និងអង្គការសហប្រជាជាតិ។ ជារៀងរាល់ឆ្នាំ ពិភពលោកចំណាយជិត ២០០០ ពាន់លានដុល្លារ លើវិស័យយោធា និងត្រឹមតែ ខ្ទង់ ៥ ពាន់លានដុល្លារ លើថវិកាទៀងទាត់របស់អង្គការសហប្រជាជាតិ។ ថវិកាទាំងមូលសម្រាប់ប្រតិបត្តិការរបស់អង្គការសហប្រជាជាតិ ការរក្សាសន្តិភាព កម្មវិធីនិងទីភ្នាក់ងារ រួមបញ្ចូលគ្នា មានទំហំតិចជាង ៣ ភាគរយនៃការចំណាយលើវិស័យយោធាពិភពលោក។ សមាមាត្រនោះរឹតតែកើនខ្លាំង នៅក្នុងសហរដ្ឋអាមេរិក៖ ពោលគឺក្នុងសមាមាត្រ ជាង ១០០ ទល់នឹង ១។ ពលរដ្ឋអាមេរិកម្នាក់ៗចំណាយ (ជាមធ្យម) ប្រហែល ២០០០ ដុល្លារ ក្នុងមួយឆ្នាំសម្រាប់ការចំណាយយោធារបស់សហរដ្ឋអាមេរិក ប៉ុន្តែ ប្រហែលត្រឹមតែ ១៥ ដុល្លារ ក្នុងមួយឆ្នាំ សម្រាប់បង់វិភាគទានជាប្រាក់របស់សហរដ្ឋអាមេរិក ក្នុងកាតព្វកិច្ចរបស់អង្គការសហប្រជាជាតិ ការវាយតម្លៃ និងការរួមចំណែកដោយស្ម័គ្រចិត្តដល់កម្មវិធីនិងទីភ្នាក់ងារអង្គការសហប្រជាជាតិទាំងអស់រួមបញ្ចូលគ្នា។

ពេលខ្លះ អង្គការសហប្រជាជាតិទទួលបានជោគជ័យ ហើយពេលខ្លះក៏ត្រូវបរាជ័យដែរ។ អង្គការសហប្រជាជាតិត្រូវដោះស្រាយបញ្ហានានា ដែលប្រហែលជាធ្ងន់ធ្ងរបំផុតក្នុងពិភពលោក។ ប្រសិនបើក្រុមរដ្ឋទាំងឡាយអាចដោះស្រាយបញ្ហា បានយ៉ាងងាយស្រួល ដូចជា ជម្លោះជាតិសាសន៍ សិទ្ធិមនុស្ស ជនភៀសខ្លួន

និងគ្រោះទុរភិក្សពិភពលោក ពួកគេទំនងជាធ្វើដោយខ្លួនឯងហើយ។ ផ្ទុយទៅវិញ រដ្ឋនានាបង្វែរបញ្ហាលំបាកទាំងនេះ ទៅអង្គការសហប្រជាជាតិ ហើយសង្ឃឹមថា អ.ស.ប.នឹងអាចចាត់ចែងបាន។

រចនាសម្ព័ន្ធរបស់អង្គការសហប្រជាជាតិ


រចនាសម្ព័ន្ធរបស់អង្គការសហប្រជាជាតិដែលបង្ហាញក្នុងក្រាហ្វិក៧.២ផ្តោតលើ**មហាសន្និបាតអង្គការសហប្រជាជាតិ** (UN General Assembly) ដែលតំណាងនៃរដ្ឋទាំងអស់ អង្គុយប្រជុំជាមួយគ្នា នៅក្នុងសាលដ៏ធំមួយស្តាប់សុន្ទរកថានិងអនុម័តដំណោះស្រាយ។ មហាសន្និបាតសម្របសម្រួលកម្មវិធីអភិវឌ្ឍន៍ផ្សេងៗ និងក្នាក់ងារស្វយ័តដទៃទៀតតាមរយៈ*ក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គម*(ECOSOC)។ ស្របទៅនឹងមហាសន្និបាតគឺ **ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ** (UNSC) ដែលក្នុងនោះ ប្រទេសមហាអំណាចចំនួនប្រាំ និងរដ្ឋសមាជិកចំនួនដប់ ធ្វើសេចក្តីសម្រេចចិត្តអំពីសន្តិភាព និងសន្តិសុខអន្តរជាតិ។ ក្រុមប្រឹក្សាសន្តិសុខបញ្ជូនកងកម្លាំងរក្សាសន្តិភាពទៅកាន់កន្លែងមានបញ្ហា។ ប្រព័ន្ធរដ្ឋបាលរបស់អង្គការសហប្រជាជាតិធ្វើឡើងតាមរយៈ**លេខាធិការដ្ឋានអង្គការសហប្រជាជាតិ**(ស្ថាប័ននីតិប្រតិបត្តិ)ដឹកនាំដោយអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ។ *តុលាការពិភពលោក*(តុលាការយុត្តិធម៌អន្តរជាតិ)ដែលនឹងត្រូវពិភាក្សានៅផ្នែកបន្ទាប់នៃមេរៀននេះគឺជាសាខាយុត្តាធិការរបស់អង្គការសហប្រជាជាតិ។ (ក្រុមប្រឹក្សាអាណាព្យាបាល(Trusteeship) ត្រួតពិនិត្យការផ្លាស់ប្តូរនៃអតីតដែនដីអាណានិគមមួយក្តាប់តូចទៅជារដ្ឋឯករាជ្យពេញលេញ ប៉ុន្តែ ជាមួយនឹងដែនដីទទួលបានឯករាជ្យភាពចុងក្រោយ ក្នុងឆ្នាំ ១៩៩៤ ក្រុមប្រឹក្សានេះត្រូវបានផ្អាកប្រតិបត្តិការ។)

គណៈប្រតិភូជាតិប្រចាំអង្គការសហប្រជាជាតិ ដឹកនាំដោយឯកអគ្គរដ្ឋទូតមកពីរដ្ឋសមាជិកនីមួយៗ ធ្វើការនិងជួបប្រជុំគ្នា នៅទីស្នាក់ការអង្គការសហប្រជាជាតិ នៅក្នុងបុរីញូវយ៉ក។ ពួកគេមានហានៈការទូតនៅសហរដ្ឋអាមេរិក ដែលក្នុងនាមជាប្រទេសម្ចាស់ផ្ទះ ក៏មានកាតព្វកិច្ចមួយចំនួនផ្សេងទៀត ដើម្បីសម្រួលដល់ដំណើរការនិងការប្រព្រឹត្តិទៅនៃអង្គការសហប្រជាជាតិ។ ជាឧទាហរណ៍ រដ្ឋាភិបាលសហរដ្ឋអាមេរិកបានអនុញ្ញាតបុគ្គល ដូចជា ហ្វីដែល កាស្ត្រូ (Fidel Castro) ជាធម្មតា ត្រូវបានរារាំងមិនអោយចូលទឹកដីសហរដ្ឋអាមេរិក ដើម្បីទៅទស្សនាទីក្រុងញូវយ៉ក ឃូរល្មមដើម្បីថ្លែងទៅកាន់អង្គការសហប្រជាជាតិ។

ភាពរឹងមាំដ៏សំខាន់នៃរចនាសម្ព័ន្ធអង្គការសហប្រជាជាតិ គឺ*ភាពជាសកលនៃសមាជិកភាព*របស់ខ្លួន។ អង្គការសហប្រជាជាតិមានសមាជិកចំនួន ១៩៣ គិតត្រឹមឆ្នាំ ២០១៨។ ស្ទើរតែគ្រប់ដែនដីទាំងអស់ នៅលើពិភពលោកគឺជាសមាជិកអង្គការសហប្រជាជាតិ ឬជាផ្លូវការ ជាអាណាខេត្ត ឬអាណានិគមរបស់សមាជិកអង្គការសហប្រជាជាតិ។ (តៃវ៉ាន់ត្រូវបានចាត់ទុកថាជាផ្នែកមួយនៃប្រទេសចិន ប្រទេសស្វីស ជាប្រពៃណី ជាប្រទេសអព្យាក្រឹតបានចូលរួម នៅក្នុងឆ្នាំ ២០០៣ ហើយប៉ាឡេស្ទីនបានក្លាយជារដ្ឋសង្កេតការណ៍ដែលមិនមែនជាសមាជិក ក្នុងឆ្នាំ ២០១២។) កិច្ចព្រមព្រៀងផ្លូវការលើធម្មនុញ្ញអង្គការសហប្រជាជាតិ ទោះបីជាពេលខ្លះត្រូវបានរំលោភបំពានក៏ដោយ រដ្ឋទាំងអស់ត្រូវកំណត់ក្រោមច្បាប់ជាមូលដ្ឋាន ដែលគ្រប់គ្រងទំនាក់ទំនងរបស់ពួកគេ។ ផ្ទុយទៅវិញ *សម្ព័ន្ធប្រជាជាតិ*ចាស់មានគុណវិបត្តិផ្ទាល់ ដោយអវត្តមានតួអង្គសំខាន់ៗមួយចំនួន។

ក្រាហ្វិក ៧.២ អង្គការសហប្រជាជាតិ

ប្រភពៈ ផ្អែកលើអង្គការសហប្រជាជាតិ។



UN Programs

UNEP	UN Environment Program
UNICEF	UN Children's Fund
UNDRO	Office of the UN Disaster Relief Coordinator
UNHCR	Office of the UN High Commissioner for Refugees
UNRWA*	UN Relief Works Agency [for Palestinian Refugees]
UNDP	UN Development Program
UNITAR*	UN Institute for Training and Research
UNIFEM	UN Development Fund for Women
INSTRAW	UN International Research and Training Institute [for women]
UNCTAD	UN Conference on Trade and Development
WFP	World Food Program
WFC	World Food Council
UNCHS	Human Settlements (Habitat)
UNFPA	UN Population Fund
UNU	UN University
UNDCP	Drug Control Program
ITC	International Trade Center

* Does not report to ECOSOC.

Autonomous Agencies

IAEA*	International Atomic Energy Agency (Vienna)
WHO	World Health Organization (Geneva)
FAO	Food and Agriculture Organization (Rome)
IFAD	International Fund for Agricultural Development (Rome)
ILO	International Labor Organization (Geneva)
UNESCO	UN Educational, Scientific, and Cultural Organization (Paris)
UNIDO	UN Industrial Development Organization (Vienna)
ITU	International Telecommunications Union (Geneva)
IPU	International Postal Union (Berne)
ICAO	International Civil Aviation Organization (Montreal)
IMO	International Maritime Organization (London)
WIPO	World Intellectual Property Organization (Geneva)
WMO	World Meteorological Organization (Geneva)
MIGA	Multilateral Investment Guarantee Agency
IMF	International Monetary Fund (Washington)
IBRD	International Bank for Reconstruction and Development [World Bank] (Washington)
IDA	International Development Association (Washington)
IFC	International Finance Corporation (Washington)
WTO*	World Trade Organization (Geneva)

* Does not report to ECOSOC.

មធ្យោបាយដ៏សំខាន់មួយដែលអង្គការសហប្រជាជាតិបានជំរុញប្រទេសមហាអំណាចទាំងអស់អោយចូលរួម គឺត្រូវជានាចំពោះពួកគេឡើងវិញថា ការចូលរួមរបស់ពួកគេនៅក្នុងអង្គការសហប្រជាជាតិនឹងមិនធ្វើអោយប៉ះពាល់ដល់ផលប្រយោជន៍ជាតិរបស់ពួកគេនោះទេ។ ដោយទទួលស្គាល់តួនាទីនៃអំណាច នៅក្នុងសណ្តាប់ធ្នាប់ពិភពលោក ធម្មនុញ្ញអង្គការសហប្រជាជាតិបានផ្តល់អោយប្រទេសមហាអំណាចចំនួនប្រាំនូវសិទ្ធិ*វេតូ* (ប្រឆាំង) លើការសម្រេចចិត្តសំខាន់ៗរបស់ក្រុមប្រឹក្សាសន្តិសុខ។

ធម្មនុញ្ញអង្គការសហប្រជាជាតិបង្កើតយន្តការមួយសម្រាប់*សន្តិសុខរួម* (collective security) ឬអាចត្រូវបានហៅថា *សន្តិសុខសមូហភាព* សំដៅលើការរួបរួមគ្នានៃបណ្តារដ្ឋទាំងឡាយនៅ ក្នុងពិភពលោក ដើម្បីបញ្ឈប់អ្នកឈ្លានពាន។ មាត្រា ៧ នៃធម្មនុញ្ញរបស់អ.ស.ប. អនុញ្ញាច្បាស់ៗ អោយក្រុមប្រឹក្សាសន្តិសុខប្រើប្រាស់កម្លាំងយោធាប្រឆាំងនឹងការឈ្លានពាន ប្រសិនបើមធ្យោបាយអហិង្សា ដែលបានអំពាវនាវនៅក្នុងមេរៀនទី ៦ ត្រូវបរាជ័យ។ ជាឧទាហរណ៍ ការអនុញ្ញាតអោយបង្កើតតំបន់គ្មានការហោះហើរ ឆ្នាំ ២០១១ នៅក្នុងប្រទេសលីប៊ី ត្រូវបានធ្វើឡើងនៅក្រោមមាត្រា ៧។ ទោះជាយ៉ាងណាក៏ដោយ ដោយសារតែសិទ្ធិ*វេតូ*របស់ប្រទេសមហាអំណាច អង្គការសហប្រជាជាតិមិនអាចបញ្ឈប់ការឈ្លានពានដោយ (ឬគាំទ្រដោយ) ប្រទេសមហាអំណាចណាមួយ ប្រកបដោយប្រសិទ្ធភាពបានឡើយ។ ដូចដែល ជារឿយៗ កើតឡើងជាមួយនឹងគោលការណ៍គ្រប់គ្រង រចនាសម្ព័ន្ធនេះបណ្តាលអោយប្រទេសអំណាចតូចៗមានការអាក់អន់ចិត្តជាខ្លាំង។ នៅឆ្នាំ ២០០៦ ប្រធានាធិបតីអ៊ីរ៉ង់បានចោទសួរមហាសន្និបាតថា «ប្រសិនបើរដ្ឋាភិបាលនៃសហរដ្ឋអាមេរិកឬចក្រភពអង់គ្លេសប្រព្រឹត្តអំពើឃោរឃៅ ឬរំលោភបំពានច្បាប់អន្តរជាតិ តើអង្គការស្ថាប័នណាមួយក្នុងអង្គការសហប្រជាជាតិអាចអូសពួកគេអោយមកទទួលខុសត្រូវ?»[២៥] (ពិតណាស់ គ្មានស្ថាប័នណាមួយ ក្នុងចំណោមស្ថាប័នទាំងនោះ អាចធ្វើបានឡើយ។) មាត្រា ៧ ត្រូវបានគេប្រើប្រាស់តែម្តងគត់ ក្នុងអំឡុងសម័យសង្គ្រាមត្រជាក់ ពោលគឺនៅក្នុងសង្គ្រាមកូរ៉េ នៅពេលដែលគណៈប្រតិភូសូវៀតបានធ្វើពហិការដំណើរការនីតិវិធី ដោយមិនបានប្រុងប្រយ័ត្ន (ហើយនៅពេលដែលអាសនៈរបស់ចិនត្រូវបានកាន់កាប់ដោយអ្នកជាតិនិយមនៅលើកោះតៃវ៉ាន់)។

ប្រវត្តិអង្គការសហប្រជាជាតិ

អង្គការសហប្រជាជាតិត្រូវបានបង្កើតឡើង នៅក្នុងឆ្នាំ ១៩៤៥ នៅទីក្រុងសាន់ហ្វ្រាន់ស៊ីស្កូ ដោយរដ្ឋចំនួន ៥១។ វាបានកើតឡើងបន្ទាប់ពីការរលាយសម្ព័ន្ធប្រជាជាតិ ដែលបានបរាជ័យក្នុងការទប់ទល់នឹងការឈ្លានពាន ប្រកបដោយប្រសិទ្ធភាព ក្នុងទសវត្សរ៍ឆ្នាំ ១៩៣០។ ដូចសម្ព័ន្ធប្រជាជាតិដែរ អង្គការសហប្រជាជាតិត្រូវបានបង្កើតឡើងដើម្បីបង្កើនសណ្តាប់ធ្នាប់អន្តរជាតិ និងនីតិរដ្ឋ ដើម្បីទប់ស្កាត់សង្គ្រាមលោកណាមួយទៀតជាយថាហេតុ។

ជាយូរមកហើយ ភាពតានតឹងមួយបានកើតឡើងរវាងអង្គការសហប្រជាជាតិនិងសហរដ្ឋអាមេរិក ជារដ្ឋដែលមានឥទ្ធិពលបំផុតក្នុងពិភពលោក។ (សហរដ្ឋអាមេរិកមិនបានចូលរួមក្នុងសម្ព័ន្ធប្រជាជាតិទេ ហើយវាជាហេតុផលមួយដើម្បីជានាផលប្រយោជន៍របស់សហរដ្ឋអាមេរិក ដែលទីស្នាក់ការអង្គការសហប្រជាជាតិត្រូវបានដាក់តាំង នៅក្នុងបុរីញូវយ៉ក។) អង្គការសហប្រជាជាតិ តាមមធ្យោបាយមួយចំនួន រារាំងសហរដ្ឋ

[២៥] (២០០៦, September ១៩). Transcript of Ahmadinejad's U.N. Speech. National Public Radio. Retrieved from https://www.npr.org/templates/story/story.php?storyId=៦១០៧៣៣៩.

អាមេរិកដោយបង្កើតសម្ព័ន្ធភាពតែមួយ ដែលអាចប្រកួតប្រជែងអំណាចរបស់សហរដ្ឋអាមេរិក នោះគឺអំណាចរដ្ឋទាំងអស់។ គោលនយោបាយការបរទេសឯកោនិយមរបស់សហរដ្ឋអាមេរិកដើរបញ្ច្រាសពីគោលគំនិតរបស់អង្គការសហប្រជាជាតិ។ ទោះយ៉ាងណាក៏ដោយ អង្គការសហប្រជាជាតិពង្រីកអំណាចរបស់សហរដ្ឋអាមេរិកនៅពេលដែលសហរដ្ឋអាមេរិកដឹកនាំសម្ព័ន្ធអង្គការសហប្រជាជាតិជាសកល។ សហរដ្ឋអាមេរិកមិនសម្បត្តិទ្រព្យឬអំណាចខ្លាំងគ្រប់គ្រាន់ក្នុងការរក្សាសណ្តាប់ធ្នាប់ក្នុងពិភពលោកតែម្នាក់ឯងនោះទេ។ ហើយក្នុងនាមជាប្រទេសពាណិជ្ជកម្មដ៏អស្ចារ្យមួយ សហរដ្ឋអាមេរិកទទួលបានផលប្រយោជន៍ពីស្ថិរភាព និងសណ្តាប់ធ្នាប់ដែលអង្គការសហប្រជាជាតិជួយបង្កើត។

នៅទសវត្សរ៍ ឆ្នាំ ១៩៥០ និងឆ្នាំ ១៩៦០ សមាជិកភាពរបស់អង្គការសហប្រជាជាតិបានកើនឡើងទ្វេដង ខណៈពេលដែលទឹកដីអាណានិគមនៅទ្វីបអាស៊ី និងទ្វីបអាហ្វ្រិកបានទទួលឯករាជ្យកាន់តែច្រើន។ ការពង្រីកនេះបានផ្លាស់ប្តូរចរិតលក្ខណៈរបស់មហាសន្និបាត រដ្ឋនីមួយៗមានសម្លេងបោះឆ្នោតមួយដូចគ្នា ដោយមិនគិតពីទំហំរបស់រដ្ឋនោះឡើយ។ សមាជិកថ្មីៗមានការព្រួយបារម្ភដោយឡែក ខុសពីបណ្តាប្រទេសឧស្សាហូបនីយកម្មលោកខាងលិច និងក្នុងករណីជាច្រើនមានការអាក់អន់ចិត្តបស្ចឹមលោកដែលធ្លាប់បានដាក់អាណានិគមលើទឹកដីពួកគេ។ រដ្ឋជាច្រើននៅអឡាគោលខាងត្បូងជឿថា សហរដ្ឋអាមេរិកត្រេកត្រអាលនឹងអំណាចលើសលុបនៅក្នុងអង្គការសហប្រជាជាតិ។ ពួកគេបានកត់សម្គាល់ឃើញថា អង្គការសហប្រជាជាតិមានប្រសិទ្ធភាពក្នុងកិច្ចការសន្តិសុខអន្តរជាតិ លុះត្រាណាតែសហរដ្ឋអាមេរិកដឹកនាំកិច្ចខិតខំប្រឹងប្រែងនេះ (ដែលកើតឡើងនៅពេលដែលមានការពាក់ព័ន្ធនឹងផលប្រយោជន៍របស់សហរដ្ឋអាមេរិក)។

ដូច្នេះ កំណើនសមាជិកភាពបានប៉ះពាល់ដល់គំរូបោះឆ្នោត នៅក្នុងអង្គការសហប្រជាជាតិ។ ក្នុងអំឡុងពេលពីរទសវត្សរ៍ដំបូងនៃប្រវត្តិសាស្ត្ររបស់អង្គការសហប្រជាជាតិ មហាសន្និបាតបានបោះឆ្នោតយ៉ាងទៀងទាត់ស្របតាមសហរដ្ឋអាមេរិច ហើយសហភាពសូវៀតជាប្រទេសមហាអំណាចដ៏សំខាន់តែមួយគត់ក្នុងការប្រើប្រាស់សិទ្ធវេតូរបស់ខ្លួននៅក្នុងក្រុមប្រឹក្សាសន្តិសុខ ដើម្បីទប់ទល់នឹងទំនោរនោះ។ ប៉ុន្តែ នៅពេលដែលរដ្ឋឯករាជ្យថ្មីៗ បានចូលរួមយ៉ាងច្រើនសន្ធឹកសន្ធាប់គ្រប់ដណ្តប់លើសមាជិកចាស់ៗ សហរដ្ឋអាមេរិកបានសង្កេតឃើញថាខ្លួនឯងស្ថិតនៅក្នុងក្រុមមតិភាគតិចតួចលើបញ្ហាជាច្រើន ហើយនៅទសវត្សរ៍ឆ្នាំ ១៩៧០ និង ១៩៨០ ប្រទេសនេះបានក្លាយទៅជាអ្នកប្រើប្រាស់សិទ្ធវេតូដ៏សំខាន់វិញម្តង។ រហូតដល់ឆ្នាំ ១៩៧១ អាសនៈរបស់ចិននៅក្នុងក្រុមប្រឹក្សាសន្តិសុខ (និងនៅក្នុងមហាសន្និបាត) ត្រូវបានកាន់កាប់ដោយរដ្ឋាភិបាលជាតិនិយមនៅលើកោះតៃវ៉ាន់ ដែលបានរបូតចេញអំណាចនៅក្នុងប្រទេសចិនដីគោក ក្នុងឆ្នាំ ១៩៤៩។ ការមិនរាប់បញ្ចូលប្រទេសចិនកុម្មុយនិស្ត គឺករណីលើកលែងចំពោះគោលការណ៍*សមាជិកភាពជាសកល*របស់អង្គការសហប្រជាជាតិនៃ ហើយនៅឆ្នាំ ១៩៧១ អាសនៈចិនត្រូវបានដកហូតពីអ្នកជាតិនិយមនៅកោះតៃវ៉ាន់ ហើយប្រគល់ទៅអោយរដ្ឋាភិបាលចិនកុម្មុយនិស្ត។ បច្ចុប្បន្ននេះ រដ្ឋាភិបាលនៃកោះតៃវ៉ាន់ដែលបំពេញមុខងារដោយស្វ័យភាពក្នុងបញ្ហាអន្តរជាតិជាច្រើន ទោះបីជាមានឋានៈជាផ្លូវការជាខេត្តរបស់ចិនក៏ដោយ ក៏មិនមែនជាសមាជិករបស់អង្គការសហប្រជាជាតិដែរ។ ប៉ុន្តែ វាជាករណីសំខាន់តែមួយគត់ប្រភេទនេះ។

ក្នុងសម័យសង្គ្រាមត្រជាក់ទាំងមូល អង្គការសហប្រជាជាតិបានទទួលជោគជ័យតិចតួចណាស់ក្នុងកិច្ចការសន្តិសុខអន្តរជាតិ ដោយសារជម្លោះរវាងសហរដ្ឋអាមេរិកនិងសហភាពសូវៀតបានរារាំងការមូលមតិគ្នាជាឯកច្ឆន្ទ។ អង្គការសហប្រជាជាតិហាក់ត្រូវបានផាត់ចេញពីសណ្តាប់ធ្នាប់ពិភពលោក ដែលរៀបចំដោយ

ប្តូកសម្ព័ន្ធភាពពីប្រឆាំងនឹងគ្នា។ ដោយឡែក មានករណីលើកលែងគួរអោយកត់សម្គាល់មួយចំនួនដូចជាការការពារកូរ៉េខាងត្បូងនៅក្នុងអំឡុងសង្គ្រាមកូរ៉េទាំងពីរ និងការយល់ព្រមដាក់កងកម្លាំងរក្សាសន្តិភាពនៅតំបន់មជ្ឈិមបូព៌ា ប៉ុន្តែ អង្គការសហប្រជាជាតិមិនបានដើរតួនាទីសំខាន់ខ្លាំងក្នុងការដោះស្រាយជម្លោះអន្តរជាតិនោះទេ។ មហាសន្និបាត ដែលមានសមាជិកភាពជាប្រទេសតតិយលោកក្នុងចំនួនលើសលុប បានផ្តោតលើបញ្ហាសេដ្ឋកិច្ចនិងសង្គមនៃប្រទេសក្រីក្រទាំងឡាយ ហើយកិច្ចការទាំងនេះបានក្លាយជាបេសកកម្មដ៏សំខាន់របស់អង្គការសហប្រជាជាតិ។

បណ្តារដ្ឋនានានៅអឌ្ឍគោលខាងត្បូង ក៏បានប្រើប្រាស់អង្គការសហប្រជាជាតិសម្រាប់ជាវេទិកាមួយដើម្បីរិះគន់ប្រទេសអ្នកមានជាទូទៅ និងសហរដ្ឋអាមេរិកជាពិសេស។ នៅទស្សវត្សរ៍ឆ្នាំ ១៩៨០ រដ្ឋាភិបាលសហរដ្ឋអាមេរិកបានសំដែងការមិនពេញចិត្តចំពោះនិន្នាការនេះ ដោយបង្កកទុកនូវចំណែកប្រាក់វិភាគទានរបស់ខ្លួនសម្រាប់អង្គការសហប្រជាជាតិ (រហូតមានតម្លៃជាង ១ ពាន់លានដុល្លារ) ដោយចាប់ផ្តើមបង់ប្រាក់វិញ នៅប៉ុន្មានឆ្នាំក្រោយ បន្ទាប់ពីការធ្វើកំណែទម្រង់អង្គការសហប្រជាជាតិ។

បន្ទាប់ពីសង្គ្រាមត្រជាក់ ទីបំផុតប្រទេសមហាអំណាចអាចព្រមព្រៀងគ្នាលើវិធានការណ៍ទាក់ទងនឹងសន្តិសុខអន្តរជាតិ។ ក្នុងបរិបទនេះ អង្គការសហប្រជាជាតិបានឈានឡើងកណ្តាលឆាកក្នុងកិច្ចការសន្តិសុខអន្តរជាតិ។ អង្គការសហប្រជាជាតិបានទទួលជោគជ័យសំខាន់ៗជាច្រើន នៅចុងទសវត្សរ៍ឆ្នាំ ១៩៨០ ក្នុងការបញ្ចប់ជម្លោះក្នុងតំបន់ដោយហិង្សា (នៅអាមេរិកកណ្តាល និងសង្គ្រាមអ៊ីរ៉ង់-អ៊ីរ៉ាក់) ខណៈពេលដែលកងកម្លាំងរក្សាសន្តិភាពត្រូវបានផ្តួចផ្តើមនិងដាក់ពង្រាយ ដើម្បីតាមដានបទឈប់បាញ់។ នៅប្រទេសណាមីប៊ី (Namibia) កងកម្លាំងអង្គការសហប្រជាជាតិបានត្រួតពិនិត្យដំណើរការឯករាជ្យភាពពីអាហ្វ្រិកខាងត្បូង និងបានអង្កេតការបោះឆ្នោតដោយសេរីជាលើកដំបូងរបស់ប្រទេសនេះ។ នៅត្រឹមទសវត្សរ៍ឆ្នាំ ១៩៩០ អង្គការសហប្រជាជាតិបានលេចឡើងនិងក្លាយជាឧបករណ៍ដ៏សំខាន់បំផុតរបស់ពិភពលោក សម្រាប់ការដោះស្រាយជម្លោះអន្តរជាតិ។ រវាងឆ្នាំ ១៩៨៧ និង ១៩៩៣ ចំនួនដំណោះស្រាយរបស់ក្រុមប្រឹក្សាសន្តិសុខបានកើនឡើងពី ១៥ ទៅ ៧៨, បេសកកម្មរក្សាសន្តិភាព កើនពីចំនួន ៥ ទៅ ១៧, កងរក្សាសន្តិភាព កើនពី ១២០០០ នាក់ ទៅ ៧៨០០០ នាក់, និងប្រទេសដែលបានបញ្ជូនកងទ័ព កើនពីចំនួន ២៦ ទៅ ៧៦ ប្រទេស។

ទោះយ៉ាងណាក៏ដោយ បេសកកម្មថ្មីៗទាំងនោះបានជួបប្រទះបញ្ហាធ្ងន់ធ្ងរ។ បញ្ហាថវិកា និងការគ្រប់គ្រងមិនគ្រប់គ្រាន់បានធ្វើអោយខូចដល់កិច្ចខិតខំប្រឹងប្រែងរក្សាសន្តិភាព នៅក្នុងប្រទេសអង់ហ្គោឡា សូម៉ាលី និងកម្ពុជា។ នៅអតីតប្រទេសយូហ្គោស្លាវី ក្នុងឆ្នាំ ១៩៩៣-១៩៩៥ អង្គការសហប្រជាជាតិបានបំពេញបេសកកម្មរក្សាសន្តិភាពដ៏ធំមួយ មុនពេលមានបទឈប់បាញ់នៅនឹងកន្លែងផ្ទាល់៖ «ការរក្សាសន្តិភាពនៅទីណាដែលគ្មានសន្តិភាព»។ ជាការឆ្លើយតបទៅនឹងបញ្ហាទាំងនេះ (បូករួមនិងបញ្ហាបង្កកប្រាក់វិភាគទានរបស់សហរដ្ឋអាមេរិក) អង្គការសហប្រជាជាតិបានបង្រួមប្រតិបត្តិការរក្សាសន្តិភាព ក្នុងឆ្នាំ ១៩៩៥-១៩៩៧ (ពី ៧៨០០០ នាក់ មកត្រឹម ១៩០០០ នាក់) ហើយបានអនុវត្តការកាត់បន្ថយ(បុគ្គលិក)និងកំណែទម្រង់នៅក្នុងលេខាធិការដ្ឋាននិងកម្មវិធីរបស់អង្គការសហប្រជាជាតិទាំងឡាយ។

អស់ជាច្រើនឆ្នាំមកនេះ សហរដ្ឋអាមេរិកបានខកខានក្នុងការទូទាត់វិក្កយបត្របង់ប្រាក់វិភាគទានរបស់ខ្លួន ទោះបីជាអគ្គលេខាធិការថ្មីបានកាត់បន្ថយថវិកានិងទំហំការងារ ដូចដែលសហរដ្ឋអាមេរិកបានទាមទារក៏ដោយ។ ការដែលសហរដ្ឋអាមេរិក«ជិះសេះលែងដៃ»បែបនេះបង្ហាញថា ការគាំទ្រអង្គការអន្តរ

រដ្ឋាភិបាលបង្ហាញពីបញ្ហាផលប្រយោជន៍រួម (សូមមើលឧទាហរណ៍បន្ថែម ការស្វែងរកផលប្រយោជន៍រួម នៅក្នុងមេរៀនទី ៣)។ ទីបំផុត បន្ទាប់ពីការរិះគន់ពីសម្ព័ន្ធមិត្ត សហរដ្ឋអាមេរិកបានយល់ព្រមបង់ប្រាក់វិភាគទានប៉ុន្តែ ស្ថិតនៅក្រោមលក្ខខណ្ឌនៃការចរចាឡើងវិញ សម្រាប់ពេលអនាគត។

ទោះជាយ៉ាងណាក៏ដោយ សង្គ្រាមអ៊ីរ៉ាក់ឆ្នាំ ២០០៣ បានបង្កអោយមានការបែងចែកគ្នាយ៉ាងធ្ងន់ធ្ងរក្នុងចំណោមប្រទេសមហាអំណាចដែលផាត់អង្គការសហប្រជាជាតិចេញ។ បន្ទាប់ពីឈានដល់ការឯកភាពគ្នាដើម្បីទទួចអោយរំសាយអាវុធរបស់ប្រទេសអ៊ីរ៉ាក់ និងបញ្ជូនអ្នកត្រួតពិនិត្យអាវុធរបស់អង្គការសហប្រជាជាតិមកវិញ ក្រុមប្រឹក្សាសន្តិសុខបានខ្វែងគំនិតគ្នាថាតើត្រូវអនុញ្ញាតបញ្ជូនកងកម្លាំងប្រឆាំងនឹងអ៊ីរ៉ាក់៖ សហរដ្ឋអាមេរិក និងអង់គ្លេសគាំទ្រការបញ្ជូនទ័ព ខណៈដែលប្រទេសបារាំង រុស្ស៊ី និងចិនប្រឆាំង។ អគ្គលេខាធិការអង្គការសហប្រជាជាតិ លោក កូហ្វី អាណ្ណាន (Kofi Annan) ក្រោយមក ហៅសង្គ្រាមនេះថា «ខុសច្បាប់»។ ភាពតានតឹងរវាងសហរដ្ឋអាមេរិកនិងអង្គការសហប្រជាជាតិកាន់តែធ្ងន់ធ្ងរឡើង ឯកសារដែលបានរកឃើញក្នុងអំឡុងសង្គ្រាមអ៊ីរ៉ាក់ បានបង្ហាញថា មន្ត្រីជាន់ខ្ពស់របស់ អង្គការសហប្រជាជាតិ បារាំង ចិន និងរុស្ស៊ី (និងក្រុមហ៊ុនប្រេងអាមេរិក) បានទទួលផលចំណេញដោយខុសច្បាប់ពី*កម្មវិធីប្រេងសម្រាប់ស្បៀងអាហារ* ក្នុងទំហំទឹកប្រាក់ចំនួន ៦៤ ពាន់លានដុល្លារ របស់អង្គការសហប្រជាជាតិសម្រាប់ប្រទេសអ៊ីរ៉ាក់ ដែលត្រូវបានគេបង្កើតឡើងដើម្បីបន្ធូរបន្ថយទុក្ខលំបាកវេទនារបស់ជនស៊ីវិល ដែលបណ្តាលមកពីការដាក់ទណ្ឌកម្មសេដ្ឋកិច្ចក្នុងទសវត្សរ៍ឆ្នាំ ១៩៩០។ នៅក្នុងឆ្នាំ ២០០៥ ការស៊ើបអង្កេតឯករាជ្យមួយបានរកឃើញថា កម្មវិធីនេះពុករលួយខ្លាំង និងបានរិះគន់អង្គការសហប្រជាជាតិយ៉ាងខ្លាំងចំពោះការគ្រប់គ្រងមិនត្រឹមត្រូវ និងការតាមដាននិងត្រួតពិនិត្យកម្មវិធីមិនបានល្អ។

បច្ចុប្បន្ននេះ អង្គការសហប្រជាជាតិអនុវត្តតាមគោលការណ៍នៃ «សសរស្តម្ភចំនួនបី»៖ សន្តិសុខ ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសិទ្ធិមនុស្ស ដែលត្រូវបានចាត់ទុកថាជាកត្តាចាំបាច់ដូចគ្នា សម្រាប់ទទួលបានជោគជ័យទាំងអស់គ្នា។ នៅចុងឆ្នាំ ២០០៦ អគ្គលេខាធិការចាស់ដែលចេញពីតំណែង និងចូលកាន់តំណែងថ្មីបានសំដៅលើគោលការណ៍នេះដូចគ្នា។ ក្នុងស្ថានការណ៍ដម្លោះក្រោយសង្គ្រាម ជាពិសេស សរស្តម្ភនីមួយៗក្នុងចំណោមទាំងបីជួយទ្រទ្រង់គ្នាទៅវិញទៅមក។

អង្គការសហប្រជាជាតិ ដោយទិដ្ឋភាពមួយចំនួន ទើបតែបានចាប់ផ្តើមដំណើរការ ដូចដែលបានកំណត់គោលបំណងតាំងពីដំបូង តាមរយៈការរួបរួមនៃប្រទេសមហាអំណាច និងការទទួលស្គាល់ធម្មនុញ្ញជាសកល។ ទោះយ៉ាងណាក៏ដោយ នៅពេលដែលរដ្ឋនានាបានងាកទៅរកអង្គការសហប្រជាជាតិកាន់តែខ្លាំងឡើង បន្ទាប់ពីការបញ្ចប់នៃសង្គ្រាមត្រជាក់ ទំហំនិងធនធានតិចតួចស្តួចស្តើងរបស់វា បានក្លាយជាបន្ទុកយ៉ាងធ្ងន់ធ្ងរ ដែលនាំទៅដល់ការកាត់បន្ថយបេសកកម្មនិងមូលនិធិ។ សព្វថ្ងៃនេះ អង្គការសហប្រជាជាតិមានសារៈសំខាន់ជាងពេលណាៗទាំងអស់ នៅតែប្រឈមនឹងបរាជ័យ។ ក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខនេះ អង្គការសហប្រជាជាតិត្រូវតែបន្តដោះស្រាយជាមួយនឹងបញ្ហាប្រឈមមុខនឹងតួនាទី ដែលវិវត្តឥតឈប់ឈររបស់ខ្លួន បើទោះជាមានព្រំដែនកំណត់ដោយសារទំហំថវិការបស់ខ្លួន និងកម្លាំងដ៏រឹងមាំនៃអធិបតេយ្យភាពរដ្ឋ។

៧.២.២. ក្រុមប្រឹក្សាសន្តិសុខ

ក្រុមប្រឹក្សាសន្តិសុខមានទំនួលខុសត្រូវក្នុងការរក្សាសន្តិភាពនិងសន្តិសុខអន្តរជាតិ និងក្នុងការស្តារសន្តិភាពឡើងវិញ នៅពេលដែលវាត្រូវខ្ទេចខ្ទាំ។ សេចក្តីសម្រេចចិត្តរបស់វា គឺជា*ភាគព្វកិច្ច* (binding) សម្រាប់រដ្ឋជា

សមាជិករបស់អង្គការសហប្រជាជាតិទាំងអស់។ ក្រុមប្រឹក្សាសន្តិសុខមានអំណាចយ៉ាងធំធេង ក្នុងការ*កំណត់*អត្ថិភាពនិងលក្ខណៈនៃការគំរាមកំហែងផ្នែកសន្តិសុខ រៀបចំ*វេទិកាសម្ព័ន្ធ*ឆ្លើយតបទៅនឹងការគំរាមកំហែងណាមួយនោះ និង*អនុវត្ត*ការសម្រេចចិត្តរបស់ខ្លួន តាមរយៈសេចក្តីណែនាំជាកាតព្វកិច្ចចំពោះសមាជិកអង្គការសហប្រជាជាតិ (ដូចជាបញ្ឈប់ពាណិជ្ជកម្មជាមួយអ្នកឈ្លានពាន)។

ចាប់តាំងពីឆ្នាំ ១៩៤៥ មក ក្រុមប្រឹក្សាបានអនុម័តដំណោះស្រាយ ជិត ២៤០០ ជាមួយនឹងដំណោះស្រាយថ្មីៗ ដែលនឹងត្រូវអនុម័តបន្ថែមជារៀងរាល់សប្តាហ៍។ ដំណោះស្រាយទាំងនេះតំណាងអោយប្លង់មេរបស់ប្រទេសមហាអំណាចសម្រាប់ការដោះស្រាយជម្លោះសន្តិសុខផ្សេងៗលើពិភពលោក ជាពិសេសនៅក្នុងតំបន់មានជម្លោះ។ (ដោយសារតែប្រព័ន្ធវេតូ ក្រុមប្រឹក្សាដើរជៀសជម្លោះក្នុងចំណោមប្រទេសមហាអំណាចគ្នាឯង ដូចជាការគ្រប់គ្រងអាវុធជាដើម។)

*សមាជិកអចិន្ត្រៃយ៍*ទាំងប្រាំនៃក្រុមប្រឹក្សា រួមមាន សហរដ្ឋអាមេរិក អង់គ្លេស បារាំង រុស្ស៊ី និងចិន គឺជាតួអង្គសំខាន់បំផុត។ អ្វីដែលពួកគេអាចព្រមព្រៀងរួមគ្នាហើយ ជាទូទៅ ពិភពលោកត្រូវតែប្រព្រឹត្តិតាម។ បញ្ហាដែលពួកគេមិនយល់ស្រប អាចក្លាយជាការខ្វែងគំនិតដ៏តានតឹងយ៉ាងធាប់រហ័ស។ ក្នុងឆ្នាំ ២០០៨ បន្ទាប់ពីក្រុមប្រឹក្សាសន្តិសុខត្រូវបរាជ័យក្នុងការសម្រេចចិត្តថា តើខេត្តកូសូវ៉ូរបស់ប្រទេសស៊ែប៊ីគួរតែឯករាជ្យឬអត់ ប្រជាជនកូសូវ៉ូបានប្រកាសឯករាជ្យរបស់ខ្លួន ជាឯកតោភាគី ពីប្រទេសស៊ែប៊ី។ កូសូវ៉ូត្រូវបានទទួលស្គាល់យ៉ាងធាប់រហ័ស ដោយសមាជិកក្រុមប្រឹក្សាសន្តិសុខមួយចំនួន (សហរដ្ឋអាមេរិក បារាំង និងអង់គ្លេស) ប៉ុន្តែប្រទេសសមាជិកផ្សេងទៀតមិនទទួលស្គាល់ទេ (ចិន និង រុស្ស៊ី)។ ជនជាតិស៊ែប៊ីដែលខឹងសម្បារច្រានចោលការប្រកាសឯករាជ្យរបស់កូសូវ៉ូ ហើយបានបន្ទោសប្រទេសមហាអំណាចលោកខាងលិច ចំពោះការលើកទឹកចិត្តកូសូវ៉ូ។ ក្នុងឆ្នាំ ២០១០ តុលាការពិភពលោកបានចាត់ទុក*ការប្រកាស*របស់កូសូវ៉ូមានភាពស្របច្បាប់ ប៉ុន្តែហានៈដ៏សំខាន់របស់វា (រដ្ឋ) នៅតែជាជម្លោះដ៏ជូរចត់។ គិតត្រឹមឆ្នាំ ២០១៨ សមាជិកអង្គការសហប្រជាជាតិចំនួន ១០៨ ប្រទេស បានទទួលស្គាល់ឯករាជ្យរបស់កូសូវ៉ូ។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខត្រូវការសម្លេតគាំទ្រចំនួនប្រាំបួន ក្នុងចំណោមសមាជិកទាំង ១៥។ ប៉ុន្តែ សម្លេងឆ្នោតបដិសេធដោយសមាជិកអចិន្ត្រៃយ៍ណាមួយនឹងធ្វើអោយសេចក្តីសម្រេចនោះមិនអាចចេញបានឡើយ៖ អំណាច*វេតូ*។ ដំណោះស្រាយជាច្រើនត្រូវបានវេតូប្រឆាំង ដោយសមាជិកអចិន្ត្រៃយ៍ ហើយដំណោះស្រាយជាច្រើនទៀតមិនដែលត្រូវបានស្នើឡើងទេ ព្រោះពួកគេនឹងប្រឈមមុខនឹងការប្រឆាំងយ៉ាងពិតប្រាកដ។ ទោះយ៉ាងណាក៏ដោយ តាំងពីឆ្នាំ ១៩៩៥ ការប្រើប្រាស់អំណាចវេតូបានធ្លាក់ចុះភ្លាមៗ មកនៅត្រឹមចំនួន ៣៤ ដង ក្នុងនោះ ១៨ដងដោយរុស្ស៊ី ១៤ដងដោយសហរដ្ឋអាមេរិក និង ១០ដងដោយចិន (ដំណោះស្រាយតែមួយអាចត្រូវបានវេតូដោយរដ្ឋច្រើន)។

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ប្រទេសរុស្ស៊ី (និងប្រទេសចិន ម្តងម្កាលដែរ) បានប្រើអំណាចវេតូរបស់ខ្លួន ដើម្បីជួយការពាររដ្ឋាភិបាលស៊ីរីពីដំណោះស្រាយបែបនេះ ដែលតាមគំនិតរបស់រុស្ស៊ីនឹងរំលោភលើអធិបតេយ្យភាពស៊ីរី ក្នុងបរិបទនៃសង្គ្រាមស៊ីវិលរបស់ខ្លួន។ សង្គ្រាមនោះ ដែលបានបណ្តាលអោយមនុស្សរាប់ពាន់នាក់ត្រូវស្លាប់បាត់បង់ជីវិត មនុស្សរាប់លាននាក់ត្រូវដំលៀសចេញពីទីកន្លែងកំណើត ហើយថែមទាំងរួមបញ្ចូលការប្រើប្រាស់អាវុធគីមី បង្ហាញពីអំណាចមានដែនកំណត់របស់អង្គការសហប្រជាជាតិ នៅពេលដែលតួអង្គអចិន្ត្រៃយ៍ដែលមានអំណាចវេតូ (ភាគច្រើនជារុស្ស៊ី និងសហរដ្ឋអាមេរិក) ពាក់ព័ន្ធដោយផ្ទាល់នៅ

ក្នុងជម្លោះ។ ខណៈពេលដែលក្រុមប្រឹក្សាសន្តិសុខអាចបង្កើតបទឈប់បាញ់មួយចំនួនដើម្បីជួយសម្រួលដល់ជំនួយមនុស្សធម៌ ដំណោះស្រាយដែលរឹងមាំជាង (ជាធម្មតាត្រូវបានស្នើឡើងដោយសហរដ្ឋអាមេរិក) ត្រូវបានវេតូ (ជាធម្មតាដោយប្រទេសរុស្ស៊ី)។

សមាជិកមិនអចិន្ត្រៃយ៍ (nonpermanent members) ចំនួនដប់ប្រទេសរបស់ក្រុមប្រឹក្សាសន្តិសុខធ្វើការផ្លាស់វេនគ្នានៅក្នុងក្រុមប្រឹក្សា ដែលមានអណត្តិរយៈពេលពីរឆ្នាំ។ សមាជិកមិនអចិន្ត្រៃយ៍ ត្រូវបានបោះឆ្នោតជ្រើសរើស (ប្រាំរដ្ឋក្នុងមួយឆ្នាំ) ដោយមហាសន្និបាត ពីបញ្ជីដែលរៀបចំដោយក្រុមបោះឆ្នោតថ្នាក់តំបន់ ក្រៅផ្លូវការ។ ជាធម្មតា មានការលាយឡំគ្នានៃតំបន់ និងទំហំប្រទេស ទោះបីជាមិនមានរូបមន្តជាក់លាក់ណាមួយក៏ដោយ។ ជាញឹកញាយ ប្រទេសនានាត្រូវធ្វើការបញ្ចុះបញ្ចូលយ៉ាងខ្លាំងក្លា សម្រាប់ទទួលបានអាសនៈនៅក្រុមប្រឹក្សា ដោយបោះពុម្ពសៀវភៅ ផ្សព្វផ្សាយពាណិជ្ជកម្ម និងអនុស្សរណៈនានា ដើម្បីទទួលបានសម្លេងឆ្នោតពីសមាជិកផ្សេងទៀត នៅក្នុងក្រុមបោះឆ្នោតថ្នាក់តំបន់។ នៅក្នុងឆ្នាំ ២០០៦ ប្រទេស វេណេស៊ុយអេឡាបានធ្វើយុទ្ធនាការសម្រាប់អាសនៈនៅពេលខាងមុខសម្រាប់អាមេរិកឡាទីន នៅលើក្រុមប្រឹក្សា ដោយស្វែងរកវេទិកាមួយដើម្បីដឹកនាំក្រុមចម្រុះប្រឆាំងអាមេរិក ដែលកំពុងរីកចម្រើន។ ប្រធានាធិបតីរបស់វា នៅក្នុងសុន្ទរកថារបស់គាត់ទៅកាន់មហាសន្និបាត បានហៅប្រធានាធិបតីសហរដ្ឋអាមេរិកថាជា «បិសាច» ហើយបាននិយាយថា សាលសន្និបាតនៅតែមានក្លិនបិសាចពីសុន្ទរកថារបស់គាត់កាលពីថ្ងៃមុន។ ប្រទេសហ្គាតេម៉ាឡា ដោយមានការគាំទ្រពីសហរដ្ឋអាមេរិក ក៏បានធ្វើយុទ្ធនាការសម្រាប់អាសនៈនោះផងដែរ។ នៅក្នុងមហាសន្និបាត ប្រទេសទាំងពីរមិនអាចសម្រេចបាននូវសំឡេងភាគច្រើន ពីរភាគបី ដែលត្រូវការជាចាំបាច់ដើម្បីជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សានោះទេ។ បន្ទាប់ពីការបោះឆ្នោត ចំនួន ៤៧ ដងរួចមក មហាសន្និបាតបានប្រគល់អាសនៈអោយទៅប្រទេសប៉ាណាម៉ា ជាការសម្របសម្រួល។ ក្នុងឆ្នាំ ២០០៨ ប្រទេសអ៊ីរ៉ង់បានធ្វើយុទ្ធនាការដណ្តើមយកអាសនៈ ប៉ុន្តែទទួលបានសំឡេងតិចតួចតែប៉ុណ្ណោះ ខណៈពេលដែលប្រទេសទួរគីត្រូវបានបោះឆ្នោតជ្រើសរើសជាក្រុមប្រឹក្សានេះ ជាលើកដំបូង ក្នុងរយៈពេលជាង ៤៥ ឆ្នាំ។

ក្នុងឆ្នាំ ២០១៤ ប្រទេសអាប៉ាប៊ីសាអូឌីតបានឈ្នះអាសនៈក្រុមប្រឹក្សាសន្តិសុខ ប៉ុន្តែ បន្ទាប់មកបានបដិសេធមិនទទួលយកវា។ វាបានក្លាយជារដ្ឋដំបូងគេដែលបដិសេធអាសនៈក្នុងក្រុមប្រឹក្សា។ ការតវ៉ាដ៏ល្បីនេះបានកើតឡើង បន្ទាប់ពីអាប៉ាប៊ីសាអូឌីតបានរិះគន់យ៉ាងខ្លាំងនូវអ្វីដែលខ្លួនចាត់ទុកថាជា ការឆ្លើយតបដ៏ខ្សោយរបស់អង្គការសហប្រជាជាតិចំពោះជម្លោះនៅក្នុងប្រទេសស៊ីរី និងការចរចាជាមួយប្រទេសអ៊ីរ៉ង់ជុំវិញកម្មវិធីនុយក្លេអ៊ែររបស់ប្រទេសនោះ។

តារាង ៧.១ បង្ហាញពីការផ្លាស់ប្តូរវេនគ្នាធ្វើសមាជិកថ្មីៗទៅកាន់ក្រុមប្រឹក្សាសន្តិសុខ។ ប្រព័ន្ធនៃការតែងតាំងដោយក្រុមបោះឆ្នោតថ្នាក់តំបន់ បានដំណើរការដើម្បីរក្សាតុល្យភាពក្នុងតំបន់ នៅលើក្រុមប្រឹក្សាដោយស្មើភាពគ្នា នៅពេលដែលរដ្ឋនីមួយៗចូលហើយចេញវិញៗ។ តួអង្គសំខាន់ៗក្នុងតំបន់ហាក់ដូចជាបានប្តូរវេនគ្នាចូលក្នុងក្រុមប្រឹក្សាញឹកញាប់ជាងរដ្ឋដែលមិនសូវសំខាន់។

សមាជិកទាំងឡាយអាចបោះឆ្នោត*អនុបវាទ* (abstain) លើដំណោះស្រាយនានា ដែលជាជម្រើសដែលសមាជិកអចិន្ត្រៃយ៍មួយចំនួនប្រើ ដើម្បីបង្ហាញពីមន្ទិលនៃដំណោះស្រាយណាមួយ ដោយមិនចាំបាច់បោះឆ្នោតវេតូ។ ប្រទេសចិនបោះឆ្នោតអនុបវាទជាប្រចាំ នៅពេលសន្តិសុខរបស់ខ្លួនមិនត្រូវបានប៉ះពាល់ដោយផ្ទាល់ ហើយសហរដ្ឋអាមេរិកបានបោះឆ្នោតអនុបវាទជាច្រើនផងដែរ ដើម្បីបង្ហាញជំហរកណ្តាលលើ

ដំណោះស្រាយដែលរិះគន់ប្រទេសអ៊ីស្រាអែល។

តារាង ៧.១ ដំណើរការតាមដានការតំណាងភូមិសាស្ត្រនៃប្រទេសនានា នៅលើក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ

	សមាជិក	**សមាជិកមិនអចិន្ត្រៃយ៍**[ខ]			**រដ្ឋចង់បានអាសនៈអចិន្ត្រៃយ៍ថ្មី**[គ]
តំបន់	**អចិន្ត្រៃយ៍**[ក]	២០១៨	២០១៧	២០១៦	
អាមេរិកខាងជើង	សហរដ្ឋអាមេរិក				
អឺរ៉ុប	អង់គ្លេស បារាំង	ហុល្លង់ ប៉ូឡូញ ស៊ុយអែត	អ៊ីតាលី ស៊ុយអែត	អេស្ប៉ាញ	អាឡឺម៉ង់
ជប៉ុន/ប៉ាស៊ីហ្វិក			ជប៉ុន	នូវែលសេឡង់ ជប៉ុន	ជប៉ុន
រុស្ស៊ី/CIS	រុស្ស៊ី	កាហ្សាក់ស្តាន	កាហ្សាក់ស្តាន អ៊ុយក្រែន	អ៊ុយក្រែន	
ចិន	ចិន				
មជ្ឈឹមបូព៌ា		គុយវ៉ែត	អេហ្ស៊ីប	អេហ្ស៊ីប	អេហ្ស៊ីប?
អាមេរិកខាងត្បូង		បូលីវី ប៉េរូ	បូលីវី អ៊ុយរូហ្គាយ	វ៉េណេស៊ុយអេឡា អ៊ុយរូហ្គាយ	ប្រេស៊ីល? មិកស៊ិក?
អាស៊ីទក្សិណ				ម៉ាឡេស៊ី	ឥណ្ឌា? ឥណ្ឌូនេស៊ី?
អាហ្វ្រិក		អេត្យូពី កូតឌីវ័រ អេក្វាទ័រហ្គីណេ	អេត្យូពី សេណេហ្គាល់	អង់ហ្គោឡា សេណេហ្គាល់	នីហ្សេរីយ៉ា? អាហ្វ្រិកខាងត្បូង?

ក. សមាជិកអចិន្ត្រៃយ៍ទាំងប្រាំរូបកាន់អំណាចវេតូ។

ខ. សមាជិកមិនអចិន្ត្រៃយ៍ត្រូវបានជ្រើសរើសសម្រាប់អាណត្តិពីរឆ្នាំដោយមហាសន្និបាត ដោយផ្អែកលើការតែងតាំងដោយការបោះឆ្នោតតាមតំបន់។ សូមចំណាំថាសមាជិកមិនអចិន្ត្រៃយ៍បច្ចុប្បន្នគឺ (ឆ្នាំក្នុងវង់ក្រចកបង្ហាញពីចុងបញ្ចប់នៃឆ្នាំ)៖ បែលហ្សិក (២០២០) សាធារណរដ្ឋដូមីនីកែន (២០២០) អេស្តូនី (២០២១) អាឡឺម៉ង់ (២០២០) ឥណ្ឌូនេស៊ី (២០២០) នីហ្សេ (២០២១)), Saint Vincent and the Grenadines (២០២១), អាហ្វ្រិកខាងត្បូង (២០២០), Tunisia (២០២១) និងវៀតណាម (២០២១)។

- នៅឆ្នាំ១៩៦៣ មហាសន្និបាតបានផ្តល់អនុសាសន៍ឱ្យធ្វើវិសោធនកម្មធម្មនុញ្ញអង្គការសហប្រជាជាតិ ដើម្បីបង្កើនសមាជិកភាពនៃក្រុមប្រឹក្សាសន្តិសុខ។ គំរូបច្ចុប្បន្ននៃតំណាងភូមិសាស្ត្រមានដូចខាងក្រោម៖ ៥ មកពីរដ្ឋអាហ្វ្រិក និងអាស៊ី ១ មកពីរដ្ឋអឺរ៉ុបខាងកើត ២ ពីរដ្ឋអាមេរិកឡាទីន និង ២ មកពីអឺរ៉ុបខាងលិច និងរដ្ឋផ្សេង

ទៀត។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រខាងក្រោម៖

https://www.un.org/securitycouncil/content/presidency ។

គ. អាសន:អចិន្ត្រៃយ៍ថ្មីដែលអាចធ្វើបានអាចមានតិចជាងនេះ ប្រសិនបើមានអំណាចវេតូ។

ក្រាហ្វិក ៧.៣ ផលប្រយោជន៍ផ្សេងគ្នាក្នុងក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ



**បញ្ហា«ក»អាចជាអ៊ីរ៉ាក់ឃីដ ឆ្នាំ ១៩៩១ ឬ ជាហ្សកហ្ស, ស៊ូដង់ ក្នុងឆ្នាំ ២០០៧*

ក្រុមប្រឹក្សាសន្តិសុខ *ជួបប្រជុំវិសាមញ្ញ* (irregularly) (នៅក្នុងទីស្នាក់ការអង្គការសហប្រជាជាតិ នៅទីក្រុងញូវយ៉ក) តាមការស្នើសុំរបស់សមាជិកណាមួយនៃអង្គការសហប្រជាជាតិ ដែលជារឿយៗជារដ្ឋដែលកើតទុក្ខមិនសុខចិត្តចំពោះសកម្មភាពដ៏គឃ្លើនរបស់រដ្ឋមួយផ្សេងទៀត។ នៅពេលដែលប្រទេសគុយវ៉ែតត្រូវបានឈ្លានពាន ហើយនៅពេលដែលប្រទេសបូស្នៀកំពុងត្រូវបានវាយលុក រដ្ឋរងគ្រោះបានអំពាវនាវដល់ក្រុមប្រឹក្សាសន្តិសុខ ដែលមានមុខងារដូចជាលេខទូរស័ព្ទបន្ទាន់ «៩១១» សម្រាប់ពិភពលោក (ប៉ុន្តែជាលេខមួយដោយគ្មានកម្លាំងប៉ូលីសឈរជើងជាប្រចាំ)។ ដោយសារតែសន្តិសុខអន្តរជាតិនៅតែបន្តបង្កជាបញ្ហា នៅក្នុងតំបន់ជាច្រើន ហើយដោយសារតែបញ្ហាទាំងនេះជារឿយៗអូសបន្លាយជាច្រើនខែឬច្រើនឆ្នាំ កិច្ចប្រជុំរបស់ក្រុមប្រឹក្សាសន្តិសុខប្រព្រឹត្តទៅជាញឹកញាប់។

អំណាចរបស់ក្រុមប្រឹក្សាសន្តិសុខមានព្រំដែនកំណត់ ដោយសារមូលហេតុសំខាន់ៗចំនួនពីរ ដែលនីមួយៗឆ្លុះបញ្ចាំងពីភាពរឹងមាំនៃអធិបតេយ្យភាពរដ្ឋនៅក្នុងប្រព័ន្ធអន្តរជាតិ។ ទីមួយ ការសម្រេចចិត្តរបស់ក្រុមប្រឹក្សាត្រូវអាស្រ័យទាំងស្រុងលើផលប្រយោជន៍នៃប្រទេសសមាជិកផ្ទាល់ (សូមមើលក្រាហ្វិក ៧.៣)។ ឯកអគ្គរដ្ឋទូតដែលតំណាងអោយរដ្ឋទាំងនោះ មិនអាចផ្លាស់ប្តូរដំណោះស្រាយរបស់ក្រុមប្រឹក្សាសន្តិសុខបានទេ បើគ្មានការអនុញ្ញាតពីរដ្ឋាភិបាលរបស់ពួកគេ។ ទីពីរ ទោះបីជាដំណោះស្រាយរបស់ក្រុមប្រឹក្សាសន្តិសុខនៅក្នុងទ្រឹស្តី គឺជាកាតព្វកិច្ចសម្រាប់សមាជិកអង្គការសហប្រជាជាតិទាំងអស់ក៏ដោយ ក៏រដ្ឋជាសមាជិក ក្នុង

ការអនុវត្តជាក់ស្តែង តែងតែព្យាយាមគេចវេសឬបន្សាបឥទ្ធិពលនៃដំណោះស្រាយទាំងនោះ។ ជាឧទាហរណ៍ ទណ្ឌកម្ម៣ណិជ្ជកម្មមានការពិបាកក្នុងការអនុវត្តណាស់។ ដំណោះស្រាយរបស់ក្រុមប្រឹក្សាសន្តិសុខអាចត្រូវបានពង្រឹង នៅក្នុងការអនុវត្តជាក់ស្តែងបាន លុះត្រាតែរដ្ឋដែលមានអំណាចក្នុងចំនួនច្រើនគ្រប់គ្រាន់ យកចិត្តទុកដាក់ចំពោះវា។

រូបថត ឯកអគ្គរដ្ឋទូតរុស្ស៊ីនៅអ.ស.ប.បោះឆ្នោតវេតូប្រឆាំងនឹងដំណោះស្រាយប្រទេសស៊ីរី

ក្រុមប្រឹក្សាវិសមភាព

ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ អាចជួយជំរុញសន្តិភាព និងសន្តិសុខ នៅពេលដែលសមាជិកអចិន្ត្រៃយ៍ទាំងប្រាំ (P៥) ធ្វើការ ដោយឯកភាពគ្នា។ នៅពេលមានការខ្វែងគំនិតគ្នា ក្រុមប្រឹក្សាមិនអាចផ្តល់សិទ្ធិធ្វើអន្តរាគមន៍ផ្នែកយោធា ផ្តល់ជំនួយមនុស្សធម៌ ឬអនុម័តការស៊ើបអង្កេតក្នុងអំឡុងពេលមានជម្លោះនោះទេ។ នៅទីនេះ ឯកអគ្គរដ្ឋទូតរុស្ស៊ីប្រចាំអង្គការសហប្រជាជាតិបានបោះឆ្នោតវេតូ ប្រឆាំងនឹងដំណោះស្រាយស៊ើបអង្កេតការទទួលខុសត្រូវចំពោះការវាយប្រហារដោយអាវុធគីមីនៅក្នុងប្រទេសស៊ីរី ដោយធ្វើអោយដំណោះស្រាយឆ្នាំ ២០១៧ ត្រូវរាំងស្ទះ។

សូម្បីតែនៅពេលដែលក្រុមប្រឹក្សាសន្តិសុខមិនអាចយល់ស្របគ្នា លើមធ្យោបាយនៃការអនុវត្តក៏ដោយ ដំណោះស្រាយរបស់វាជះឥទ្ធិពលលើទិដ្ឋភាពដែលវិវាទត្រូវបានគេមើលឃើញ និងចុងក្រោយពីរបៀបដែលជម្លោះត្រូវបានដោះស្រាយ។ ដំណោះស្រាយរបស់ក្រុមប្រឹក្សាសន្តិសុខលេខ ២៤២ បន្ទាប់ពីសង្គ្រាមអារ៉ាប់-អ៊ីស្រាអែល ក្នុងឆ្នាំ ១៩៦៧ បានដាក់ចេញនូវគោលការណ៍សម្រាប់សន្តិភាពដ៏ត្រឹមត្រូវ នៅក្នុងជម្លោះនោះ ជាចម្បង ជាសិទ្ធិរបស់រដ្ឋទាំងអស់នៅក្នុងតំបន់ ក្នុងការរស់នៅក្នុងរង្វង់ព្រំដែនដែលមានសុវត្ថិភាពនិងកំណត់ ខណ្ឌសីម៉ាបានយ៉ាងច្បាស់ និងការប្រគល់ទឹកដីមកវិញ ដោយអ៊ីស្រាអែលដែលបានវាយយក នៅក្នុងសង្គ្រាមឆ្នាំ ១៩៦៧។ (ភាគីពាក់ព័ន្ធនានានៅតែកំពុងជជែកវែកញែកអំពីថាតើទឹកដីដែលត្រូវប្រគល់មកវិញ ដោយអ៊ីស្រាអែល មានន័យថា «ដែនដីទាំងអស់»ឬយ៉ាងណា។) ដោយត្រូវបានបញ្ជាក់ជាថ្មី នៅក្នុងដំណោះស្រាយលេខ ៣៣៨ បន្ទាប់ពីសង្គ្រាមឆ្នាំ ១៩៧៣ ដំណោះស្រាយទាំងនេះបានជួយបង្កើតកិច្ចព្រមព្រៀងខែមដេវីឌ (Camp David) ឆ្នាំ ១៩៧៨ ហើយក្រោយមកបានបង្កើតជាមូលដ្ឋានសម្រាប់ការចរចាសន្តិភាពរវាងប្រទេសអ៊ីស្រាអែលនិងប្រទេសជិតខាងអារ៉ាប់ ដែលបានចាប់ផ្តើមនៅឆ្នាំ ១៩៩១។ ប្រសិនបើដំណោះស្រាយបញ្ហាប៉ាឡេស្ទីន-អ៊ីស្រាអែលត្រូវបានសម្រេចឡើង វាប្រាកដជានឹងអនុវត្តតាមគ្រោងនៃសេចក្តីសម្រេចចិត្ត លេខ ២៤២ និង ៣៣៨ របស់អង្គការសហប្រជាជាតិ។

សំណើកំណែទំរង់

រចនាសម្ព័នរបស់ក្រុមប្រឹក្សាសន្តិសុខមិនមែនថាគ្មានបញ្ហានោះទេ។ ប្រទេសជប៉ុន និងអាឡឺម៉ង់ គឺជាប្រទេសមហាអំណាច ដែលចូលរួមវិភាគទានយ៉ាងច្រើនសន្ធឹកសន្ធាប់ ដល់អង្គការសហប្រជាជាតិ (រូបមន្តវិភាគទានផ្អែកលើទំហំសេដ្ឋកិច្ច) និងបានរួមចំណែកយ៉ាងច្រើនដល់កម្មវិធីរបស់អង្គការសហប្រជាជាតិនិងប្រតិបត្តិការរក្សាសន្តិភាពនានា។ ប៉ុន្តែ ពួកគេមានតំណាងផ្លូវការដូចគ្នា នៅក្នុងអង្គការសហប្រជាជាតិដូចជារដ្ឋតូចៗ ដែលមានចំនួនប្រជាជនតិចជាងមួយភាគមួយរយនៃចំនួនប្រជាជនរបស់ពួកគេ៖ ការបោះឆ្នោតមួយសម្លេងនៅក្នុងមហាសន្និបាត និងឱកាសធ្វើជាសមាជិកប្តូរវេននៅក្នុងក្រុមប្រឹក្សាសន្តិសុខ (ក្នុងការអនុវត្តជាក់ស្តែងពួកគេត្រូវបានបោះឆ្នោតជាសមាជិកប្តូរវេននៅក្រុមប្រឹក្សាញឹកញាប់ជាង

រដ្ឋតូចៗ)។ ក្នុងនាមជាប្រទេសមហាអំណាចពាណិជ្ជកម្មពិភពលោក ប្រទេសជប៉ុននិងអាឡឺម៉ង់មានផលប្រយោជន៍ធំនៅក្នុងច្បាប់មូលដ្ឋានសម្រាប់កិច្ចការសន្តិសុខអន្តរជាតិ និងប្រាថ្នាចង់បានអាសនៈមួយផ្ទាល់នៅក្នុងអង្គប្រជុំ។

ប៉ុន្តែ ការដាក់បញ្ចូលប្រទេសជប៉ុននិងអាឡឺម៉ង់ជាសមាជិកក្រុមប្រឹក្សាសន្តិសុខអចិន្ត្រៃយ៍នឹងមិនមែនជារឿងសាមញ្ញនោះទេ។ ប្រសិនបើប្រទេសអាឡឺម៉ង់អាចចូលរួមនោះ សមាជិកអចិន្ត្រៃយ៍បី ក្នុងចំណោមសមាជិកអចិន្ត្រៃយ៍ទាំងប្រាំពីរ គឺជាប្រទេសអឺរ៉ុប នឹងនាំអោយតំបន់នោះមានទម្ងន់ខ្លាំងជាងគេ។ អាសនៈអឺរ៉ុបទាំងបីអាចត្រូវបានបញ្ចូលគ្នាជាអាសនៈមួយ (អាសនៈប្តូរវេន ឬអាសនៈតែមួយតំណាងអោយសហភាពអឺរ៉ុបទាំងមូល) ប៉ុន្តែ បែបនេះនឹងធ្វើអោយអំណាចរបស់ប្រទេសអង់គ្លេសនិងបារាំងធ្លាក់ចុះ ដែលសុទ្ធជារដ្ឋអាចវេតូរាល់វិសោធន៍កម្មសម្រាប់ផ្លាស់ប្តូរធម្មនុញ្ញអង្គការសហប្រជាជាតិ។ កិច្ចប្រឹងប្រែងរបស់ប្រទេសជប៉ុនដើម្បីទទួលបានអាសនៈមួយអាចប្រឈមនឹងការប្រឆាំងពីសំណាក់ប្រទេសចិន។ ម្យ៉ាងវិញទៀត ប្រសិនបើប្រទេសជប៉ុន ឬអាឡឺម៉ង់ទទួលបានអាសនៈ ចុះឥណ្ឌាដែលមានប្រជាជន ២០ ភាគរយនៃចំនួនប្រជាជនលើពិភពលោក? ចុះប្រទេសឥស្លាមដូចឥណ្ឌូណេស៊ីវិញ? ចុងក្រោយ ចុះទ្វីបអាមេរិកឡាទីននិងអាហ្វ្រិកវិញ? សមាជិកអចិន្ត្រៃយ៍ថ្មីដែលអាចធ្វើបាន អាចរួមបញ្ចូលប្រទេសអាឡឺម៉ង់ ជប៉ុន ឥណ្ឌា ប្រេស៊ីល អេហ្ស៊ីប និងនីហ្សេរីយ៉ាឬអាហ្វ្រិកខាងត្បូង។ ក្នុងចំណោមផែនការទាំងនេះ គ្មានផែនការណាមួយមានការវិវត្តន៍ទៅមុខនោះទេ។ រាល់ការរុះរើរចនាសម្ព័ន្ធក្រុមប្រឹក្សាសន្តិសុខនឹងតម្រូវអោយមានការផ្លាស់ប្តូរនៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ ហើយការប្រែប្រួលសមាជិកភាពនឹងកាត់បន្ថយអំណាចនៃសមាជិកអចិន្ត្រៃយ៍ទាំងប្រាំ ក្នុងពេលបច្ចុប្បន្ន ដែលសុទ្ធសឹងតែអាចវេតូប្រឆាំងរាល់សំណើផ្លាស់ប្តូរ ដែលធ្វើអោយការផ្លាស់ប្តូរណាមួយពិបាកខ្លាំងណាស់។ នៅចុងឆ្នាំ ២០០៤ ក្រុមអ្នកជំនាញមួយ ដែលត្រូវបានតែងតាំងដោយលោកអាណ្ណានបានផ្តល់អនុសាសន៍អោយពង្រីកក្រុមប្រឹក្សាសន្តិសុខដល់សមាជិក ២៤ ប្រទេស ក្រោមរូបមន្តណាមួយក្នុងចំណោមពីរ ដោយមិនផ្លាស់ប្តូរអំណាចវេតូ។ សំណើទាំងនេះត្រូវបានពិភាក្សា ក្នុងឆ្នាំ ២០០៥ ប៉ុន្តែមិនមានការព្រមព្រៀងគ្នា ហើយបញ្ហានោះត្រូវបានផ្អាកជាបណ្តោះអាសន្ន។ ក្នុងអំឡុងពេលនៃការជជែកដេញដោលប្រជាជនចំនួន ៤២ លាននាក់ នៅក្នុងប្រទេសចិន និងប្រទេសចំនួន ៤០ ផ្សេងទៀត បានចុះហត្ថលេខាលើញត្តិប្រឆាំងនឹងប្រទេសជប៉ុន ក្នុងការទទួលបានអាសនៈក្រុមប្រឹក្សាសន្តិសុខ រហូតដល់ប្រទេសនេះទទួលស្គាល់និងសុំទោសដោយស្មោះត្រង់ចំពោះឧក្រិដ្ឋកម្មសង្គ្រាម នៅក្នុងសង្គ្រាមលោកលើកទីពីរ។

៧.២.៣. កងកម្លាំងរក្សាសន្តិភាព

កងកម្លាំងរក្សាសន្តិភាពមិនត្រូវបានលើកឡើង នៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិទេ។ អគ្គលេខាធិការលោក ដែគ ហ៊ែម៉ាស្គល់ដ៍ (Dag Hammarskjöld) ក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ បាននិយាយលេងសើចថា កងកម្លាំងរក្សាសន្តិភាពត្រូវបានអនុញ្ញាត ក្រោម«មាត្រាប្រាំមួយកន្លះ» ដែលនៅចន្លោះការដោះស្រាយដោយអហិង្សា ដែលបានចែងក្នុងមាត្រា ៦ នៃធម្មនុញ្ញ និងការអនុញ្ញាតអោយប្រើប្រាស់កម្លាំង ដែលបានចែងក្នុងមាត្រា ៧។ ធម្មនុញ្ញរបស់អង្គការសហប្រជាជាតិតម្រូវអោយរដ្ឋសមាជិកត្រៀមកងកម្លាំងយោធាសម្រាប់អង្គការសហប្រជាជាតិប្រើប្រាស់ប៉ុន្តែ កងកម្លាំងបែបនេះត្រូវបានគេប្រមើលឃើញថា ត្រូវបានប្រើប្រាស់ក្នុងការឆ្លើយតបទៅនឹងការឈ្លានពាន (ក្រោមហេតុផលសន្តិសុខសមូហភាព)។ នៅក្នុងការអនុវត្តជាក់ស្តែង នៅពេលដែលអង្គការសហប្រជាជាតិអនុញ្ញាតអោយប្រើកងកម្លាំង ដើម្បីវាយបកព្រុញច្រានការឈ្លានពានចេញ

វិញ ដូចជានៅក្នុងសង្គ្រាមឈូងសមុទ្រ ក្នុងឆ្នាំ ១៩៩០ កងកម្លាំងដែលពាក់ព័ន្ធគឺជាកងកម្លាំង*ជាតិ*មិនស្ថិតនៅក្រោមការបញ្ជាការរបស់អង្គការសហប្រជាជាតិទេ។ កងកម្លាំងទាំងនេះ ដូចជាកងកម្លាំងដឹកនាំដោយអូស្ត្រាលីនៅទីម័រខាងកើត មិនបានជ្រោងទង់ឬនិមិត្តសញ្ញារបស់អង្គការសហប្រជាជាតិឡើយ។

កងកម្លាំង*ផ្ទាល់*របស់អង្គការសហប្រជាជាតិ ដែលត្រូវបានខ្ចីពីកងទ័ពនៃរដ្ឋជាសមាជិក ប៉ុន្តែនៅក្រោមទង់និងបញ្ជាការរបស់អង្គការសហប្រជាជាតិ គឺជាកងកម្លាំង*រក្សាសន្តិភាព* ដើម្បីរម្ងាប់ជម្លោះក្នុងតំបន់ដោយដើរតួនាទីអព្យាក្រឹត នៅចន្លោះកណ្តាលរវាងកងកម្លាំងជាគូបដិបក្ខ។ កងកម្លាំងទាំងនេះបានឈ្នះរង្វាន់ណូបែលសន្តិភាព ក្នុងឆ្នាំ ១៩៨៨ ជាការទទួលស្គាល់ពីសារៈសំខាន់ និងភាពជោគជ័យរបស់ពួកគេ ដែលកំពុងកើនឡើង។ ទោះជាយ៉ាងណាក៏ដោយ ដូចដែលបានសិក្សានៅប្រទេសបូស្នៀ កងកម្លាំងអព្យាក្រឹតបែបនេះមិនទទួលបានជោគជ័យល្អនៅក្នុងស្ថានភាព ដែលក្រុមប្រឹក្សាសន្តិសុខបានកំណត់អត្តសញ្ញាណភាគីម្ខាងជាអ្នកឈ្លានពាន។

បេសកកម្មរក្សាសន្តិភាព

អគ្គលេខាធិការប្រមូលផ្តុំកងកម្លាំងរក្សាសន្តិភាពសម្រាប់បេសកកម្មនីមួយៗ ជាធម្មតា មកពីរដ្ឋមួយចំនួន ដែលមិនពាក់ព័ន្ធនៅក្នុងជម្លោះទាល់តែសោះ ហើយដាក់កងកម្លាំងទាំងនោះនៅក្រោមមេបញ្ជាការតែមួយ។ ទាហានទាំងនោះត្រូវបានស្គាល់ជាទូទៅថា *កងទ័ពមួកខៀវ* (blue helmets)។កងកម្លាំងរក្សាសន្តិភាពចូលបម្រើការ តាមការអញ្ជើញរបស់រដ្ឋាភិបាលម្ចាស់ផ្ទះ ហើយត្រូវចាកចេញប្រសិនបើរដ្ឋាភិបាលនោះបញ្ជាអោយចេញ។

អាជ្ញាធរ(authority)សម្រាប់កងកម្លាំងរក្សាសន្តិភាពត្រូវបានអនុញ្ញាត ដោយក្រុមប្រឹក្សាសន្តិសុខជាធម្មតា សម្រាប់រយៈពេលពី បីខែ ទៅប្រាំមួយខែ ហើយអាចត្រូវបានអនុញ្ញាតអោយបន្ត ក្នុងករណីចាំបាច់ ហើយក្នុងករណីខ្លះ ប្រព្រឹត្តិទៅអស់រយៈពេលរាប់ទសវត្សរ៍។ នៅក្នុងករណីមួយ កាលពីដំបូងៗ វិបត្តិព្រៃកជីកស៊ុយអេនៅឆ្នាំ ១៩៥៦ មហាសន្និបាតបានអនុញ្ញាតអោយកងកម្លាំងក្រោមដំណោះស្រាយ «រួបរួមគ្នាដើម្បីសន្តិភាព» ដែលអនុញ្ញាតអោយមហាសន្និបាតទទួលយកបញ្ហាសន្តិសុខ នៅពេលដែលក្រុមប្រឹក្សាសន្តិសុខជាប់គាំង។ នៅប្រទេសកុងហ្គោក្នុងឆ្នាំ១៩៦០ អគ្គលេខាធិការបានផ្តួចផ្តើមគំនិតនេះ។ ប៉ុន្តែ បច្ចុប្បន្នក្រុមប្រឹក្សាសន្តិសុខគ្រប់គ្រងប្រតិបត្តិការរក្សាសន្តិភាពយ៉ាងរឹងមាំ។

មូលនិធិ (funds) ត្រូវតែសម្រេចដោយការបោះឆ្នោត ដោយមហាសន្និបាតហើយការខ្វះខាតថវិកាសព្វថ្ងៃនេះ គឺជាឧបសគ្គធំបំផុតតែមួយសម្រាប់ការប្រើប្រាស់កងកម្លាំងរក្សាសន្តិភាព។ ការវាយតម្លៃពិសេសប្រឆាំងនឹងរដ្ឋជាសមាជិកចំណាយសម្រាប់ប្រតិបត្តិការរក្សាសន្តិភាព។ ជាមួយនឹងការពង្រីកការរក្សាសន្តិភាពចាប់តាំងពីឆ្នាំ១៩៨៨ ការចំណាយរបស់កងកម្លាំងទាំងនេះ (ជាង ៦ ពាន់លានដុល្លារ ក្នុងឆ្នាំ ២០១៨) មានចំនួនច្រើនជាងថវិកាធម្មតារបស់អង្គការសហប្រជាជាតិ។

បេសកកម្មថ្មីៗ

គិតត្រឹមឆ្នាំ ២០១៨ អង្គការសហប្រជាជាតិរក្សាបានបុគ្គលិកអន្តរជាតិ ជាង ១០៩០០០ នាក់ (រួមទាំងកងទ័ព អ្នកសង្កេតការណ៍យោធា ប៉ូលីស និងបុគ្គលិករដ្ឋបាល) នៅក្នុងបេសកកម្មរក្សាសន្តិភាព ឬសង្កេតការណ៍ចំនួន ១៥ ដែលលាតសន្ធឹងលើតំបន់ចំនួនប្រាំនៃពិភពលោក និងបានប្រើប្រាស់បុគ្គលិកយោធាមកពីប្រទេស ចំនួន ១២៨ (សូមមើលតារាង ៧.២)។

បេសកកម្មរក្សាសន្តិភាពដ៏ធំបំផុតចំនួនពីរក្នុងឆ្នាំ ២០១៨ ប្រព្រឹត្តិទៅនៅក្នុងតំបន់ដារហ្វួរនៃប្រទេសស៊ូដង់ និងប្រជាធិបតេយ្យកុងហ្គោ។ នៅក្នុងបេសកកម្មកុងហ្គោ កងរក្សាសន្តិភាពជាង ២០០០០ នាក់បានតាមដាននិងត្រួតពិនិត្យបទឈប់បាញ់ និងការពារជនស៊ីវិល បន្ទាប់ពីសង្គ្រាមស៊ីវិល។ ក្នុងឆ្នាំ ២០១២ កងរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិទាំងនេះបានបង្ហាញភាពទន់ខ្សោយ នៅពេលដែលចលនាឧទ្ទាមនៅភាគខាងកើតអស្ថេរភាពរបស់ប្រទេសនេះ បានបន្តការវាយប្រហារ បណ្តាលអោយជនស៊ីវិលត្រូវជម្លៀសចេញ។ មួយទស្សវត្សរ៍បន្ទាប់ពីសង្គ្រាមដ៏សំខាន់បានបញ្ចប់ ការវាយប្រហារម្តងហើយម្តងទៀតបែបនេះបានឆ្លុះបញ្ចាំងពីការខកចិត្តចំពោះកងកម្លាំងរបស់អង្គការសហប្រជាជាតិ។ កងទ័ពជំនួយត្រូវបានបញ្ជូនទៅបន្ថែមទៀត នៅក្នុងឆ្នាំ ២០១៣-២០១៤ ដើម្បីជួយប្រឈមមុខនឹងក្រុមឧទ្ទាមក្នុងតំបន់។

នៅក្នុងឆ្នាំ ២០០៧ ក្រុមប្រឹក្សាសន្តិសុខបានអនុម័តកងកម្លាំងរក្សាសន្តិភាព ជិត ២០០០០ នាក់សម្រាប់តំបន់ដារហ្វួរក្នុងប្រទេសស៊ូដង់ បន្ទាប់ពីមានការរារាំងជាច្រើនឆ្នាំ ពីរដ្ឋាភិបាលស៊ូដង់។ គិតត្រឹមឆ្នាំ ២០១៨ កងកម្លាំងទាំងនោះនៅតែរក្សាបាននូវកងទ័ពនិងបុគ្គលិកប៉ូលីស ជិត ១៦០០០ នាក់។ កងទ័ពរបស់អង្គការសហប្រជាជាតិបានចូលរួមជាមួយសហភាពអាហ្វ្រិក ដែលត្រូវបានដាក់ពង្រាយរួចហើយ(ប៉ុន្តែក្នុងចំនួនតិចតួចពេក)។ ទម្រាំកងកម្លាំងដែលត្រូវបានអនុញ្ញាតទាំងអស់បានទៅដល់កន្លែង វាត្រូវការពេលជាច្រើនឆ្នាំបន្ថែមទៀត ដោយសារតែការជំទាស់ជាច្រើន ពីប្រទេសស៊ូដង់ ហើយការវាយប្រហារលើជនស៊ីវិលនៅតែបន្ត ទោះបីជាមានវត្តមានរបស់ពួកគេក៏ដោយ។ ក្នុងឆ្នាំ ២០១២ ការវាយប្រយុទ្ធគ្នារវាងរដ្ឋាភិបាល និងកងកម្លាំងឧទ្ទាមបានបណ្តេញជនស៊ីវិល ២៥០០០ នាក់ ចេញពីជំរុំជនភៀសខ្លួនមួយ។ បេសកកម្មដារហ្វួរគឺជាបន្ថែមលើកងទ័ពអង្គការសហប្រជាជាតិជាង១៨០០០ នាក់ ដែលកំពុងពង្រឹងការអនុវត្តបទឈប់បាញ់គ្នា រវាងប្រទេសស៊ូដង់នឹងប្រទេសស៊ូដង់ខាងត្បូងដែលទើបទទួលបានឯករាជ្យថ្មីៗ ក៏ដូចជាកងកម្លាំងអង្គការសហប្រជាជាតិអន្តរកាល ដែលមានចំនួនជិត ៥០០០ នាក់ ដែលផ្តោតលើទីក្រុងជម្លោះ អាប៊ីយៃ (Abyei) ដែលស្ថិតនៅតាមព្រំដែនប្រទេសស៊ូដង់និងស៊ូដង់ខាងត្បូង។

តារាង ៧.២ បេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ គិតត្រឹមខែឧសភា ឆ្នាំ ២០១៨

ទីតាំង	តំបន់	បុគ្គលិក	ការចំណាយលានដុល្លារ/ឆ្នាំ	តួនាទី	ចាប់ផ្តើម
ប្រជា.កុងហ្គោ	អាហ្វ្រិក	២០៦០០	$១១០០	ពង្រឹងបទឈប់បាញ់ ការពារជនស៊ីវិល	២០១០
ស៊ូដង់/ ស៊ូដង់ត្បូង	អាហ្វ្រិក	១៨០០០	១១០០	គាំទ្រកិច្ចព្រមព្រៀងសន្តិភាព	២០១១
ស៊ូដង់/ដារហ្វួរ	អាហ្វ្រិក	១៦០០០	៥០០	ការពារជនស៊ីវិល	២០០៧
ម៉ាលី	អាហ្វ្រិក	១៥០០០	១០៥០	ការពារជនស៊ីវិល ដើម្បីបោះឆ្នោត	២០១៣
សា.អាហ្វ្រិកកណ្តាល	អាហ្វ្រិក	១៤០០០	៩០០	ការពារជនស៊ីវិល បញ្ឈប់ការចល័តទ័ព	២០១៤

លីបង់	មជ្ឈឹមបូព៌ា	១១០០០	៥០០	ត្រួតពិនិត្យបទឈប់បាញ់នៅព្រំដែនអ៊ីស្រាអែល	១៩៧៨
ស៊ូដង់/ អាប៊ីយៃ	អាហ្វ្រិក	៤៨០០	៣០០	ត្រួតពិនិត្យទីក្រុងជម្លោះតាមព្រំដែន	២០១១
ហៃទី	អាមេរិកឡាទីន	៤០០០	១០០	ជួយរដ្ឋាភិបាលអន្តរកាល	២០០៤
លីបេរីយ៉ា	អាហ្វ្រិក	១៦០០	១០០	ជួយរដ្ឋាភិបាលអន្តរកាល	២០០៣
កោះស៊ីប	មជ្ឈឹមបូព៌ា	១១០០	៦០	ត្រួតពិនិត្យបទឈប់រវាងក្រិក-ទួរគី	១៩៦៤
ស៊ីរី (ហ្គោឡាន)	មជ្ឈឹមបូព៌ា	១០០០	៦០	ត្រួតពិនិត្យបទឈប់រវាងអ៊ីស្រាអែល-ស៊ីរី	១៩៧៤
សាហារ៉ាលិច	អាហ្វ្រិក	៥០០	៥៥	រៀបចំប្រជាមតិនៅដែនដី	១៩៩១
អ៊ីស្រាអែល	មជ្ឈឹមបូព៌ា	៣៥០	៧០	សង្កេតយុទ្ធសន្តិភាពអារ៉ាប់-អ៊ីស្រាអែល	១៩៤៨
កូសូវ៉ូ	អឺរ៉ុប	៣៥០	៤០	រដ្ឋបាលស៊ីវិលជំនួយសង្គ្រោះ	១៩៩៩
ឥណ្ឌា/ ប៉ាគីស្ថាន	អាស៊ីត្បូង	១០០	២០	សង្កេតបទឈប់រវាងបាញ់ឥណ្ឌា-ប៉ាគីស្ថាន	១៩៤៩
សរុប		**១០៩០០០**	**៦០០០**		

សម្គាល់៖ ទំហំបង្ហាញពីចំនួនបុគ្គលិកអន្តរជាតិសរុប (ភាគច្រើនជាកងទ័ព ប៉ុន្តែក៏មានមន្ត្រីស៊ីវិល និងកម្លាំងប៉ូលីសមួយចំនួនផងដែរ)។ *ប្រភព៖* ផ្អែកលើអង្គការសហប្រជាជាតិ។

ប្រតិបត្តិការរក្សាសន្តិភាពដ៏ធំបំផុត ក្នុងចំណោមប្រតិបត្តិការផ្សេងទៀតរបស់អង្គការសហប្រជាជាតិ ប្រព្រឹត្តិទៅនៅប្រទេសម៉ាលី (ព្យាយាមរក្សាស្ថិរភាពក្នុងអំឡុងពេលអន្តរកាលរដ្ឋាភិបាល) នៅសាធារណរដ្ឋអាហ្វ្រិកកណ្តាល (ព្យាយាមការពារជនស៊ីវិល ក្រោយសង្គ្រាមស៊ីវិលបានបញ្ចប់) និងនៅក្នុងប្រទេសលីបង់ (ក្រោយសង្គ្រាមអ៊ីស្រាអែល-ហេសបូឡា នៅឆ្នាំ ២០០៦)។ បេសកកម្មថ្មីៗដ៏ធំបំផុតទាំងនេះឆ្លុះបញ្ចាំងពីការរស់រានឡើងវិញនៃការរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ បន្ទាប់ពីការរង្គោះរង្គើ នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៩៩០។

ក្នុងទស្សវត្សរ៍ឆ្នាំ ១៩៩០ អង្គការសហប្រជាជាតិទទួលរងនូវបរាជ័យធំៗ ជាច្រើនដែរ ក្នុងការថែរក្សាសន្តិភាព នៅអតីតប្រទេសយូហ្គោស្លាវី រវ៉ាន់ដា អង់ហ្គោឡា និងសូម៉ាលី។ បេសកកម្មដែលទទួលបានជោគជ័យ មិនសូវបានសារព័ត៌មានចាប់អារម្មណ៍ នៅក្នុងសម័យនោះ។ នៅប្រទេសកម្ពុជា កងរក្សាសន្តិភាព ១៥០០០ នាក់ បានធ្វើការជាមួយកម្លាំងដ៏ច្រើននៃមន្ត្រីរដ្ឋបាលនៃអង្គការសហប្រជាជាតិ ដែលបានចូលកាន់កាប់រដ្ឋាភិបាលកម្ពុជាយ៉ាងទូលំទូលាយ បន្ទាប់ពីសង្គ្រាមស៊ីវិលដ៏បំផ្លិចបំផ្លាញយ៉ាងយូរ។ ទោះបីជាមានការលំបាកជាច្រើនក៏ដោយ អង្គការសហប្រជាជាតិបានរៀបចំការបោះឆ្នោត នៅឆ្នាំ១៩៩៣ និងជួយធ្វើអោយ

នយោបាយកម្ពុជាមានស្ថិរភាព ក្នុងកម្រិតមួយ។ មេរៀនដែលទទួលបាននៅប្រទេសកម្ពុជា បានជួយអង្គការសហប្រជាជាតិសម្រេចបេសកកម្មស្រដៀងគ្នានេះ នៅក្នុងប្រទេសម៉ូសំប៊ិក។ កិច្ចព្រមព្រៀងសន្តិភាពបានបញ្ចប់សង្គ្រាមស៊ីវិលយ៉ាងយូរនិងដ៏បំផ្លិចបំផ្លាញខ្លាំងនៅទីនោះ ដោយបង្កើតយន្តការសម្រាប់ការរំសាយអាវុធ សមាហរណកម្មនៃកងកម្លាំងយោធា និងការរៀបចំការបោះឆ្នោតជ្រើសរើសរដ្ឋាភិបាលថ្មីមួយ ក្រោមការតាមដាននិងត្រួតពិនិត្យជាអន្តរជាតិ។ បណ្តាបេសកកម្មនៅ ប្រទេស អែលសាវ៉ាឌ័រ (El Salvador) និងប្រទេសណាមីប៊ី (Namibia) ក៏ជាជោគជ័យដំបូងៗ សម្រាប់ការរក្សាសន្តិភាព របស់អង្គការសហប្រជាជាតិ ក្រោយសម័យសង្គ្រាមត្រជាក់។ បទពិសោធន៍ទាំងនេះ បានជួយអោយអង្គការសហប្រជាជាតិឆ្លើយតបកាន់តែមានប្រសិទ្ធភាពបន្ទាប់ពីសង្គ្រាមស៊ីវិល នៅប្រទេសសៀរ៉ាឡេអូន កូតឌីវ័រ និងលីបេរីយ៉ា ក្នុងចន្លោះឆ្នាំ ២០០២-២០០៣។ ប៉ុន្តែ បញ្ហាទាក់ទងនឹងឧក្រិដ្ឋកម្មបៀតបៀនផ្លូវភេទ នៅក្នុងប្រតិបត្តិការរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ និងសារៈសំខាន់របស់ស្ត្រី នៅក្នុងសង្គមក្រោយសង្គ្រាមបានជំរុញអោយក្រុមប្រឹក្សាសន្តិសុខអនុម័តដំណោះស្រាយ លេខ ១៣២៥ ក្នុងឆ្នាំ ២០០០ ដើម្បីផ្តោតការយកចិត្តទុកដាក់លើបញ្ហាយេនឌ័រក្នុងការរក្សាសន្តិភាព និងការកសាងប្រទេសឡើងវិញ របស់អង្គការសហប្រជាជាតិ (សូមមើលមេរៀនទី ៣)។

នៅពេលដែលការរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ កាន់តែកើនច្រើនឡើងៗ ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ បេសកកម្មថ្មីៗបានពង្រីកវិសាលភាពនៃអ្វីដែលឥឡូវនេះត្រូវបានហៅយ៉ាងទូលំទូលាយថាជា*ប្រតិបត្តិការសន្តិភាព* (peace operation)។ ប្រតិបត្តិការទាំងនេះមិនត្រឹមតែរួមបញ្ចូលការរក្សាសន្តិភាពតាមបែបប្រពៃណីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបញ្ចូល ការប្រើកងកម្លាំងដើម្បីការពារជនស៊ីវិល (ដូចនៅប្រទេសប្រជាធិបតេយ្យកុងហ្គោ) ការតាមដាននិងត្រួតពិនិត្យការបោះឆ្នោត (ដូចនៅប្រទេសលីបេរីយ៉ា) និងសូម្បីតែការដឹកនាំរដ្ឋាភិបាល ខណៈដែលសង្គមមួយប្រឹងក្រោកឈរឡើងវិញ (ដូចនៅប្រទេសកម្ពុជា ទីម័រខាងកើត និងកូសូវ៉ូ)។ ប្រតិបត្តិការកាន់តែធំទាំងនេះបន្ទាប់ពីជម្លោះ ត្រូវបានគេហៅថាជា **ការកសាងសន្តិភាព** (peace building)។ ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីផ្តល់ការគាំទ្ររយៈពេលវែងក្រោយសង្គ្រាម ក្នុងឆ្នាំ ២០០៥ អង្គការសហប្រជាជាតិបានបង្កើតគណៈកម្មការកសាងសន្តិភាព ដើម្បីសម្របសម្រួលការកសាងប្រទេសឡើងវិញ ការកសាងស្ថាប័ន និងកិច្ចខិតខំប្រឹងប្រែងស្តារសេដ្ឋកិច្ចឡើងវិញ បន្ទាប់ពីបេសកកម្មរក្សាសន្តិភាពត្រូវបានបញ្ចប់។

កិច្ចសង្កេតការណ៍និងការរក្សាសន្តិភាព

តាមពិតទៅ កងរក្សាសន្តិភាពអនុវត្តមុខងារពីរផ្សេងគ្នា៖ ការសង្កេតការ និងការរក្សាសន្តិភាព។ *អ្នកសង្កេតការណ៍* (observers) គឺជាមន្ត្រីយោធាដែលគ្មានអាវុធ ដែលត្រូវបានបញ្ជូនទៅតំបន់ជម្លោះក្នុងចំនួនតិចតួច ដើម្បីសង្កេតមើលអ្វីដែលកើតឡើង ហើយរាយការណ៍ត្រឡប់ទៅអង្គការសហប្រជាជាតិវិញ។ ជាមួយនឹងការឃ្លាំមើលរបស់អង្គការសហប្រជាជាតិ ភាគីពាក់ព័ន្ធក្នុងជម្លោះជារឿយៗទំនងជាមិនសូវបំពានបទឈប់បាញ់ទេ។ អ្នកសង្កេតការណ៍អាចតាមដានទិដ្ឋភាពផ្សេងៗនៃស្ថានភាពរបស់ប្រទេសមួយ ដូចជាបទឈប់បាញ់ ការបោះឆ្នោត ការគោរពសិទ្ធិមនុស្ស និងវិស័យផ្សេងៗទៀត។

មុខងារ*រក្សាសន្តិភាព* (peacekeeping) ត្រូវបានអនុវត្តដោយទាហានប្រដាប់ដោយអាវុធធុនស្រាល (នៅក្នុងរថពាសដែក ជាមួយនឹងកាំភ្លើងស្វ័យប្រវត្តិ ប៉ុន្តែគ្មានកាំភ្លើងធំ រថក្រោះ និងអាវុធធុនធ្ងន់ផ្សេងទៀតឡើយ)។ កងកម្លាំងបែបនេះបំពេញតួនាទីជាច្រើន។ ពួកគេអាចធ្វើ*អន្តរាគមន៍* (interpose) ផ្ទាល់ រវាងភាគីនៃ

សង្គ្រាម ដើម្បីញែកពួកគេអោយនៅដាច់ពីគ្នា (កាន់តែច្បាស់ជាងនេះទៅទៀត គឺធ្វើអោយពួកគេត្រូវឆ្លងកាត់ឬវាយប្រហារលើកងកម្លាំងអង្គការសហប្រជាជាតិជាមុនសិន ទើបអាចចូលទៅវាយសត្រូវរបស់ពួកគេបាន)។ ក្រុមរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិតែងតែព្យាយាម*ចរចា* (negotiate) ជាមួយមន្ត្រីយោធាទាំងសងខាង។ បណ្តាញទំនាក់ទំនងនេះអាចនាំមកនូវសកម្មភាពនិងការយល់ដឹងជាយុទ្ធសាស្ត្រ ដែលគាំទ្របទឈប់បាញ់គ្នា។ ប៉ុន្តែ កងកម្លាំងអង្គការសហប្រជាជាតិនៅក្នុងតំបន់សង្គ្រាម មិនអាចឆ្លងកាត់ពីទីតាំងភាគីម្ខាងទៅកាន់ភាគីម្ខាងទៀត ដើម្បីធ្វើការចរចាបានឡើយ។

ការរក្សាសន្តិភាពមានភាពពិបាកកាន់តែខ្លាំងជាងនេះ ប្រសិនបើភាគីម្ខាងមើលឃើញថា កងកម្លាំងអង្គការសហប្រជាជាតិមានភាពលំអៀងទៅភាគីម្ខាងទៀត។ ជាឧទាហរណ៍ ប្រទេសអ៊ីស្រាអែលមានអារម្មណ៍បែបនេះ ចំពោះកងកម្លាំងអង្គការសហប្រជាជាតិ នៅភាគខាងត្បូងប្រទេសលីបង់។ ក្នុងឱកាសនោះ កងកម្លាំងអ៊ីស្រាអែលបានទម្លុះខ្សែរារាំងរបស់អង្គការសហប្រជាជាតិ ដើម្បីវាយប្រហារសត្រូវ ហើយពួកគេត្រូវបានចោទប្រកាន់ថាបានដាក់គោលដៅវាយប្រហារលើទីតាំងឈរជើងរបស់អង្គការសហប្រជាជាតិ។ នៅក្នុងប្រទេសកម្ពុជា និងអតីតប្រទេសយូហ្គោស្លាវី នៅដើមទសវត្សរ៍ឆ្នាំ ១៩៩០ ភាគីម្ខាងបានវាយប្រហារដោយចេតនាលើកងកម្លាំងអង្គការសហប្រជាជាតិជាច្រើនលើកច្រើនសារ បណ្តាលអោយមនុស្សស្លាប់មួយចំនួន។ ជាទូទៅ នៅពេលបទឈប់បាញ់ត្រូវបំពាន ទាហានរបស់អង្គការសហប្រជាជាតិជាប់នៅកណ្តាលសមរភូមិ។ កងរក្សាសន្តិភាព ជាង ៣៣០០ នាក់ ត្រូវបានសម្លាប់ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមក។

ប្រទេសជាច្រើនបានរួមចំណែកបញ្ជូនកងកម្លាំងយោធាជាតិរបស់ខ្លួន ក្នុងបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ។ ក្នុងឆ្នាំ ២០១៧ ប្រទេសដែលបានរួមចំណែកឈានមុខគេទាំងប្រាំ (ជាមួយចំនួនកងទ័ពនិងប៉ូលីស) រួមមាន ប្រទេសអេត្យូពី (៨៤០០ នាក់) បង់ក្លាដែស (៧១០០ នាក់) ឥណ្ឌា (៦៤០០នាក់) រវ៉ាន់ដា (៦៣០០នាក់) និងប៉ាគីស្ថាន (៦៣០០)។ ហេតុផលសម្រាប់ការរួមចំណែកកងទ័ពក្នុងការរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិមានលក្ខណៈខុសគ្នា។ រដ្ឋមួយចំនួនមានអារម្មណ៍ថាតាមរយៈការរួមចំណែកដល់ផលប្រយោជន៍រួម ពួកគេកំពុងជំរុញផលប្រយោជន៍សន្តិភាព ស្របពេលដែលបង្ហាញឬសម្ងែងរូបភាពនៃអំណាចយោធាដ៏រឹងមាំរបស់ខ្លួន។ តាមរបៀបនេះ រដ្ឋអាចធ្វើដើម្បីបង្កើនអំណាចទន់របស់ពួកគេ។ ម៉្យាងទៀត រដ្ឋមួយចំនួនយល់ថា ការរួមចំណែកក្នុងបេសកកម្មទាំងនេះមានអត្ថប្រយោជន៍ផ្នែកហិរញ្ញវត្ថុ ដោយសារកងកម្លាំងរក្សាសន្តិភាពត្រូវបានចំណាយ ដោយប្រាក់វិភាគទានរបស់អង្គការសហប្រជាជាតិ។ នៅក្នុងប្រទេសមួយចំនួន ដូចជានេប៉ាល់ និងសៀរ៉ាឡេអូន ការបញ្ជូនកងកម្លាំងយោធា ចេញពីប្រទេសដើម្បីរក្សាសន្តិភាព មានប្រយោជន៍សម្រាប់ស្ថិរភាពយោបាយក្នុងស្រុក បន្ទាប់ពីសង្គ្រាមស៊ីវិល។

នៅក្នុងជម្លោះខ្លះ កងរក្សាសន្តិភាពដែលរៀបចំឡើង នៅក្រៅក្របខណ្ឌអង្គការសហប្រជាជាតិ ត្រូវបានប្រើប្រាស់ជំនួសកងកម្លាំងក្រោមបញ្ជាការរបស់អង្គការសហប្រជាជាតិ។ កងរក្សាសន្តិភាពបារាំងចំនួនប្រហែល ៣៥០០ នាក់ ដែលមិនស្ថិតនៅក្រោមការបញ្ជារបស់អង្គការសហប្រជាជាតិ បានបម្រើការនៅក្នុងប្រទេសកូតឌីវ័រ ជាមួយនឹងកងរក្សាសន្តិភាពអង្គការសហប្រជាជាតិ ចំនួន ១២០០០ នាក់ ចន្លោះឆ្នាំ ២០០៣ និង ២០១៧។ នៅពេលដែលការវាយប្រហារតាមផ្លូវអាកាសរបស់រដ្ឋាភិបាលបានសម្លាប់ទាហានបារាំង ចំនួនប្រាំបួននាក់ ក្នុងឆ្នាំ ២០០៤ កងកម្លាំងបារាំងបានសងសឹកយ៉ាងខ្លាំងក្លា ដោយបានបំផ្លាញកងកម្លាំងដែនអាកាសរបស់រដ្ឋាភិបាលនោះ។ ក្នុងឆ្នាំ ២០១១ បន្ទាប់ពីប្រធានាធិបតីដែលកំពុងកាន់អំណាចបានចាញ់

ឆ្នោតមួយ ប៉ុន្តែបានបដិសេធមិនព្រមចាកចេញពីតំណែង កងទ័ពអង្គការសហប្រជាជាតិ និងបារាំងបានជួយបេក្ខជនឈ្នះឆ្នោត បណ្តេញគាត់ដោយបង្ខំ។ ក្រោយការបោះឆ្នោតដោយសន្តិវិធីជាបន្តបន្ទាប់ តំណាងអង្គការសហប្រជាជាតិនិងក្រុមប្រឹក្សាសន្តិសុខបានសម្រេចថា កងកម្លាំងខាងលើមិនត្រូវការជាចាំបាច់ដើម្បីធានាស្ថិរភាពទៀត ដែលឈានដល់ការដកកងកម្លាំងបារាំងនិងអង្គការសហប្រជាជាតិចេញ នៅឆ្នាំ ២០១៧។

កងរក្សាសន្តិភាពមកពីអង្គការក្នុងតំបន់ក៏ត្រូវបានដាក់ពង្រាយដើម្បីត្រួតពិនិត្យ និងពង្រឹងការអនុវត្តកិច្ចព្រមព្រៀងឈប់បាញ់គ្នានិងសម័យអន្តរកាល បន្ទាប់ពីសង្គ្រាមស៊ីវិល។ ក្នុងឆ្នាំ ២០១២ សហគមន៍សេដ្ឋកិច្ចនៃរដ្ឋអាហ្វ្រិកខាងលិច (ECOWAS) បានបញ្ជូនកងកម្លាំងយោធាចម្រុះជាតិសាសន៍ ទៅកាន់ប្រទេសហ្គីណេ-ប៊ីសសៅ (Guinea-Bissau) បន្ទាប់ពីរដ្ឋប្រហារយោធា នៅទីនោះ។ បន្ទាប់ពីបានត្រួតពិនិត្យការបោះឆ្នោតដោយសន្តិវិធីក្នុងឆ្នាំ ២០១៤ និងធានាអោយមានការផ្លាស់ប្តូរដោយសន្តិវិធី កងកម្លាំងទាំងនោះបានចាប់ផ្តើមដកខ្លួនចេញ នៅឆ្នាំ ២០១៧ ។

កងកម្លាំងរក្សាសន្តិភាព ជាទូទៅ មិនអាចបង្កើតសន្តិភាពបានទេ បានត្រឹមតែរក្សាតែប៉ុណ្ណោះ។ ដើម្បីចូលទៅក្នុងសង្គ្រាមដែលកំពុងប្រហារគ្នានិងដើម្បីបន្ធូរបន្ថយអរិភាពតម្រូវអោយកងកម្លាំងយោធាច្រើនលើសពីបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិកន្លងមក។ ដូច្នេះ កងរក្សាសន្តិភាព ជាធម្មតា មិនត្រូវបានបញ្ជូនទៅទេ រហូតដល់បទឈប់បាញ់ត្រូវបានសម្រេចឡើង ចូលជាធរមាន និងបានប្រព្រឹត្តិទៅ អស់មួយរយៈពេល។ ជាញឹកញយ បទឈប់បាញ់គ្នាជាច្រើនត្រូវបានចរចា ទម្រាំអាចអនុវត្តបានជាក់ស្តែង។ សង្គ្រាមអាចនឹងបន្តអូសបន្លាយ អស់រយៈពេលជាច្រើនឆ្នាំ ដោយបង្កអោយមានការខាតបង់យ៉ាងធ្ងន់ធ្ងរ មុនពេលអង្គការសហប្រជាជាតិអាចបញ្ជូនកងរក្សាសន្តិភាពទៅ។

ដើម្បីដោះស្រាយបញ្ហានេះ អគ្គលេខាធិការក្នុងឆ្នាំ ១៩៩២ បានស្នើអោយបង្កើតអង្គភាព*កសាងសន្តិភាព* (peacemaking) របស់អង្គការសហប្រជាជាតិ (ឬ*ការពង្រឹងសន្តិភាព*- peace enforcement) ដែលនឹងមិនត្រឹមតែត្រួតពិនិត្យបទឈប់បាញ់គ្នាប៉ុណ្ណោះទេ ប៉ុន្តែត្រូវពង្រឹងសន្តិភាពផងដែរ ប្រសិនបើវាត្រូវបែកបាក់។ អគ្គលេខាធិការខាងលើបានអំពាវនាវអោយរដ្ឋជាសមាជិកនីមួយៗ ត្រៀមបញ្ជូនទាហាន ១០០០ នាក់ (ទាហានស្ម័គ្រចិត្តដែលដែលទទួលបានការហ្វឹកហាត់ជាពិសេស) ដោយឈរលើមូលដ្ឋាននៃការដាក់ពង្រាយអោយបានយ៉ាងឆាប់រហ័ស ដើម្បីបង្កើតកងទ័ពត្រៀមរបស់អង្គការសហប្រជាជាតិ ដែលអាចឆ្លើយតបបានយ៉ាងឆាប់រហ័សចំពោះវិបត្តិណាមួយ។ មិនត្រឹមតែរដ្ឋជាសមាជិកបដិសេធសំណើសុំទាហានត្រៀមប៉ុណ្ណោះទេ ពួកគេថែមទាំងបានរិះគន់គំនិតកសាងសន្តិភាពទាំងស្រុង។ ចាប់តាំងពីពេលនោះមក អង្គការសហប្រជាជាតិបានអនុញ្ញាតអោយរដ្ឋជាសមាជិកបញ្ជូនកម្លាំងយោធាពិតប្រាកដ មិនមែនកងកម្លាំងរក្សាសន្តិភាពទេ នៅពេលដែលការប្រយុទ្ធគ្នាអាចផ្ទុះឡើង។ នៅក្នុងករណីលើកលែងដែលអាចឬមិនអាចនឹងបង្ហាញពីនិន្នាការមួយ ក្រុមប្រឹក្សាសន្តិសុខបានពង្រីកអាណត្តិនៃកងកម្លាំងរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ នៅក្នុងប្រទេសកុងហ្គោដើម្បីអនុញ្ញាតអោយពួកគេការពារជនស៊ីវិល (ដែលកងកម្លាំងអ.ស.ប.ត្រូវឯការរិះគន់ថាមិនបានធ្វើ)។ ក្នុងឆ្នាំ ២០០៥ កងរក្សាសន្តិភាពជនជាតិប៉ាគីស្ថាននៅក្នុងប្រតិបត្តិការនោះនៅក្នុងប្រទេសប្រជាធិបតេយ្យកុងហ្គោ បានសម្លាប់កងជីវពល ចំនួន ៥០ នាក់ និង បន្ទាប់ពីកងរក្សាសន្តិភាពមកពីបង់ក្លាដែស ចំនួនប្រាំបួននាក់ ត្រូវបានសម្លាប់ នៅក្នុងការវាយឆ្មក់មួយ។ ប្រតិបត្តិការនៅក្នុងប្រទេស

ប្រជាធិបតេយ្យកុងហ្គោនៅតែមានលក្ខណៈហិង្សា។ ក្នុងឆ្នាំ ២០១៧ កងរក្សាសន្តិភាពពីប្រទេសតង់ហ្សានី ចំនួន ១៥ នាក់ ត្រូវបានសម្លាប់ នៅក្នុងការវាយប្រហារដោយកងជីវពល។

នៅចុងទសវត្សរ៍ឆ្នាំ ១៩៩០ ប្រទេសចំនួនប្រាំពីរ រួមមាន ជាណឺម៉ាក នរវែស ស៊ុយអែត ប៉ូឡូញ ហូឡង់ អូទ្រីស និងកាណាដា បានបង្កើតកងពលតូចត្រៀមខ្លួនខ្ពស់ (standby high readiness) របស់អង្គការសហប្រជាជាតិ ដែលមានកងទ័ពចំនួន ៤០០០ នាក់។ ដោយមានទីស្នាក់ការកណ្តាលនៅក្នុងប្រទេសជាណឺម៉ាក ហើយអាចដាក់ពង្រាយទៅកាន់តំបន់ជម្លោះ ក្នុងរយៈពេលពី ២ ទៅ ៤ សប្តាហ៍ ជាជារាប់ខែ កងពលតូចនេះត្រូវបានគ្រប់គ្រងដោយក្រុមប្រឹក្សាសន្តិសុខ។ វាបានចូលរួមក្នុងបេសកកម្មរបស់អង្គការសហប្រជាជាតិទៅកាន់ប្រទេសអេត្យូពី-អេរីទ្រា ក្នុងឆ្នាំ ២០០០-២០០១។ នៅដើមឆ្នាំ ២០០៥ កងពលតូចនេះត្រូវបានដាក់ពង្រាយទៅកាន់ប្រទេសស៊ូដង់ ដើម្បីគាំទ្រដល់កិច្ចព្រមព្រៀងសន្តិភាព រវាងតំបន់ភាគខាងជើង និងភាគខាងត្បូង បន្ទាប់ពីសង្គ្រាមស៊ីវិលដ៏យូរ។

ជាទូទៅ សមាជិកអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាសន្តិសុខមិនបានចូលរួមចំណែកក្នុងការបញ្ជូនកងទ័ពរក្សាសន្តិភាពយ៉ាងច្រើននោះទេ ប៉ុន្តែត្រូវបានស្នើសុំអោយចេញថ្លៃចំណាយសម្រាប់បេសកកម្មទាំងនោះ។ ករណីលើកលែងចំពោះនិន្នាការនេះ ដែលកំពុងតែកើនឡើង គឺប្រទេសចិនដែលបានដាក់កងទ័ពជាង ២៥០០ នាក់ នៅក្រោមការគ្រប់គ្រងរបស់អង្គការសហប្រជាជាតិ នៅក្នុងបេសកកម្មនាពេលថ្មីៗនេះ។ ប្រទេសចិន ខុសពីប្រទេសអង់គ្លេស និងបារាំង មិនមានប្រវត្តិធ្វើអាណានិគមលើទឹកដីផ្សេងទេ ហើយខុសពីសហរដ្ឋអាមេរិក និងប្រទេសរុស្ស៊ី មិនត្រូវបានចាត់ទុកថាប្រទេសជាមហាអំណាចពិភពលោកឡើយ។ កត្តាទាំងនេះធ្វើអោយការចូលរួមរបស់ចិនកាន់តែអាចទទួលយកបានពីសំណាក់រដ្ឋ ដែលបានស្នើសុំអោយបញ្ជូនកងទ័ពរក្សាសន្តិភាពទៅកាន់ប្រទេសរបស់ខ្លួន។ ទោះជាយ៉ាងណាក៏ដោយ ប្រទេសចិនបាននិយាយរិះគន់ដោយឥតសំចៃមាត់ក្នុងការទាមទាររបស់ខ្លួនអោយកងកម្លាំងរក្សាសន្តិភាពគោរពអធិបតេយ្យភាពរបស់រដ្ឋ។ វាដាក់ស្លាកកងទ័ពរបស់ខ្លួន ដែលត្រូវបានបញ្ជូនទៅថាជា «កម្លាំងសន្តិសុខគ្រប់ជ្រុងជ្រោយ» ជាជាងបុគ្គលិកយោធា។

៧.២.៤. លេខាធិការដ្ឋាន

អគ្គលេខាធិការអង្គការសហប្រជាជាតិ ហាក់ដូចជាស្រដៀងនឹងតំណែង«ប្រធានាធិបតីនៃពិភពលោក»ខ្លាំងជាងគេ ប៉ុន្តែ តំណែងអគ្គលេខាធិការនេះតំណាងអោយរដ្ឋជាសមាជិក មិនមែនប្រជាជនទាំង ៧ ពាន់លាននាក់នៅលើពិភពលោកទេ។ ចំពោះបញ្ហាដែលប្រទេសមហាអំណាចមិនមានការឯកភាពគ្នា វាពិបាកណាស់សម្រាប់អគ្គលេខាធិការធ្វើអោយអ្វីៗកើតឡើង។

អគ្គលេខាធិការត្រូវបានតែងតាំងដោយក្រុមប្រឹក្សាសន្តិសុខ ដោយតម្រូវអោយមានការយល់ព្រមពីសមាជិកអចិន្ត្រៃយ៍ទាំងប្រាំ ហើយត្រូវតែទទួលបានការអនុម័តដោយមហាសន្និបាត។ តំណែងនេះមានអាណត្តិរយៈពេលប្រាំឆ្នាំ ហើយអាចត្រូវបន្តបន្ថែមទៀត។ អតីតអគ្គលេខាធិការបានមកពីតំបន់ផ្សេងៗនៃពិភពលោក ប៉ុន្តែមិនដែលមកពីប្រទេសមហាអំណាចទេ។

រូបថត អគ្គលេខាធិការអ.ស.ប.ថ្មីជួបជាមួយត្រាំ

នាយកប្រតិបត្តិ

អគ្គលេខាធិការអង្គការសហប្រជាជាតិ មានបេសកកម្មដ៏ខ្ពង់ខ្ពស់ ប៉ុន្តែអំណាចនិងធនធាននៅមានកម្រិតនៅឡើយ។ នៅទីនេះ អគ្គលេខាធិការអង្គការសហប្រជាជាតិថ្មី លោក អង់តូនីញ៉ូ ហ្គូតេរ៉េស (Antonio

Guterres» ជួបជាមួយប្រធានាធិបតី លោក ដូណាល់ ត្រាំ ដើម្បីពិភាក្សាអំពីកំណែទម្រង់អង្គការសហប្រជាជាតិ។ អគ្គលេខាធិការត្រូវព្យាយាមបញ្ចុះបញ្ចូលរដ្ឋជាសមាជិក ជាពិសេសប្រទេសមហាអំណាចអោយធ្វើសកម្មភាពក្នុងបញ្ហាវិស័យមួយចំនួន រួមមានការអភិវឌ្ឍន៍ សិទ្ធិមនុស្ស និង សន្តិភាពនិងសន្តិសុខ។

អគ្គលេខាធិការបច្ចុប្បន្ន អង់តូនីញ៉ូ ហ្គាទ័រេស (Antonio Guterres)បានចូលកាន់តំណែង។ លោក ហ្គាទ័រេស ដែលជាអតីតនាយករដ្ឋមន្ត្រីនៃប្រទេសព័រទុយហ្គាល់ ក៏ដូចជាអតីតបេសកជនជាន់ខ្ពស់អង្គការសហប្រជាជាតិសម្រាប់កិច្ចការជនភៀសខ្លួន នឹងផ្តោតអាណត្តិដំបូងរបស់គាត់លើវិបត្តិមនុស្សធម៌ជាច្រើនដែលបណ្តាលមកពីជម្លោះអន្តរជាតិ ជាពិសេសកំណើនចំនួនជនភៀសខ្លួនពេញពិភពលោក។ អ្នកកាន់តំណែងអគ្គលេខាធិការមុនគាត់ គឺ លោក បាន គីមូន (Ban Ki-moon) ដែលជាអតីតរដ្ឋមន្ត្រីបរទេសនៃប្រទេសកូរ៉េខាងត្បូង បានចាប់ផ្តើមតំណែងអគ្គលេខាធិការអ.ស.ប.របស់គាត់ នៅឆ្នាំ ២០០៧ បានផ្តោតលើកំណែទម្រង់អង្គការសហប្រជាជាតិ ការអភិវឌ្ឍន៍សេដ្ឋកិច្ច សិទ្ធិមនុស្ស អំពើភេរវកម្ម ការរីកសាយភាយ (អាវុធនុយក្លេអ៊ែរ) បញ្ហាបរិស្ថាន និងមេរោគ/ជំងឺអេដស៍។ គាត់បាន ជាប់ឆ្នោតកាន់តំណែង អាណត្តិទីពីរ ដែលចាប់ផ្តើមនៅឆ្នាំ ២០១២។ អ្នកកាន់តំណែងមុនគាត់ គឺ លោក កូហ្វី អាណ្ណាន (Kofi Annan) ដែលបានបម្រើការរយៈពេលដប់ឆ្នាំ ពីឆ្នាំ ១៩៩៧ ដល់ ២០០៦ បានជួយពង្រឹងអង្គការសហប្រជាជាតិឡើងវិញ ដោយបានឈ្នះរង្វាន់ណូបែលសន្តិភាពគម្រប់ខួបមួយរយឆ្នាំ សម្រាប់ការខិតខំប្រឹងប្រែងរបស់គាត់។

លេខាធិការដ្ឋាននៃអង្គការសហប្រជាជាតិ គឺជាស្ថាប័ននីតិប្រតិបត្តិផ្ទាល់ខ្លួន ដែលដឹកនាំដោយអគ្គលេខាធិការមួយរូប។ វាគឺជាការិយាធិបតេយ្យសម្រាប់គ្រប់គ្រងគោលនយោបាយនិងកម្មវិធីរបស់អង្គការសហប្រជាជាតិ ដូចដែលក្រសួងការបរទេស គឺជាការិយាធិបតេយ្យសម្រាប់គោលនយោបាយការបរទេសរបស់សហរដ្ឋអាមេរិក។ នៅក្នុងបញ្ហាសន្តិសុខ អគ្គលេខាធិការធ្វើការផ្ទាល់ជាមួយក្រុមប្រឹក្សាសន្តិសុខ។ កម្មវិធីអភិវឌ្ឍន៍ក្នុងប្រទេសក្រីក្រ ត្រូវបានសម្របសម្រួល ដោយអ្នកកាន់តំណែងបន្ទាប់ ដែលជាអគ្គនាយកសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍និងសេដ្ឋកិច្ចអន្តរជាតិ។ លេខាធិការដ្ឋានត្រូវបានបែងចែកតាមមុខងារចំនួនពីរ ដោយមានអគ្គលេខាធិការរង និងជំនួយការអគ្គលេខាធិការ។

បុគ្គលិករបស់អង្គការសហប្រជាជាតិនៅក្នុងមុខងារទាំងនេះ រួមមានបុគ្គលិករដ្ឋបាល ក៏ដូចជាអ្នកជំនាញបច្ចេកទេស និងអ្នកប្រឹក្សាសេដ្ឋកិច្ច ដែលធ្វើការលើកម្មវិធីនិងគម្រោងផ្សេងៗ។ បុគ្គលិកមានចំនួនប្រហែល ៤០០០០ នាក់ ហើយចំនួននយោជិតសរុប នៅក្នុងប្រព័ន្ធអង្គការសហប្រជាជាតិទាំងមូល (រួមទាំងធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិ) ឡើងរហូតដល់ ៧៥០០០។ ការិយាល័យទីភ្នាក់ងារពាក់ព័ន្ធរបស់អង្គការសហប្រជាជាតិត្រូវបានប្រមូលផ្តុំ នៅក្នុងទីក្រុងហ្សឺណែវ ប្រទេសស្វីស។ ទីក្រុងហ្សឺណែវគឺជាទីកន្លែងនៃការចរចាអន្តរជាតិជាញឹកញាប់ ហើយត្រូវបានមនុស្សជាច្រើនមើលឃើញថាមានអព្យាក្រឹតភាពជាងទីក្រុងញូវយ៉ក់នៃសហរដ្ឋអាមេរិក។

គោលដៅមួយរបស់លេខាធិការដ្ឋានអង្គការសហប្រជាជាតិ គឺដើម្បីអភិវឌ្ឍទីភ្នាក់ងារស៊ីវិលអន្តរជាតិ (international civil service) សម្រាប់អ្នកការទូត និងអ្នកការិយាធិបតេយ្យ ដែលមានភក្តីភាពស្មោះត្រង់នៅកម្រិតពិភពលោក មិនមែនចំពោះរដ្ឋដើមកំណើតរបស់ពួកគេនោះទេ។ ធម្មនុញ្ញអង្គការសហប្រជាជាតិបានបែងចែកអគ្គលេខាធិការនិងបុគ្គលិក ផ្សេងពីអាជ្ញាធរឬមន្ត្រីរបស់រដ្ឋាភិបាលជាតិ ហើយអំពាវនាវអោយរដ្ឋជាសមាជិកគោរព«លក្ខណៈជាមន្ត្រីអន្តរជាតិទាំងស្រុង»របស់បុគ្គលិកទាំងនោះ។ អង្គការសហប្រជាជាតិបាន

ទទួលជោគជ័យគួរសមក្នុងរឿងនេះ, អគ្គលេខាធិការត្រូវបានគេមើលឃើញ ជាញឹកញាប់ ថាជាអ្នកការទូតឯករាជ្យដែលគិតអំពីផលប្រយោជន៍របស់ពិភពលោកទាំងមូល មិនមែនជាកូនអុករបស់រដ្ឋណាមួយឡើយ។ ប៉ុន្តែ នៅដើមទសវត្សរ៍ឆ្នាំ ១៩៩០ ការិយាធិបតេយ្យរបស់អង្គការសហប្រជាជាតិត្រូវទទួលរងការរិះគន់កាន់តែខ្លាំងឡើងចំពោះអប្រសិទ្ធភាពនិងអំពើពុករលួយ។ ការរិះគន់ទាំងនេះ ជាពិសេស ចេញពីភាគីសហរដ្ឋអាមេរិក ដែលមើលឃើញថាខ្លួនទទួលបន្ទុកចំណាយច្រើនហួសទាំងអយុត្តិធម៌ បានបណ្តាលអោយមានកម្មវិធីកំណែទម្រង់អ.ស.ប.។ នៅចុងទសវត្សរ៍ឆ្នាំ ១៩៩០ បុគ្គលិករបស់អង្គការសហប្រជាជាតិ ត្រូវបានកាត់បន្ថយ ចំនួនមួយភាគបួន ធៀបនឹងមួយទសវត្សរ៍មុន ហើយថវិកាត្រូវបានកាត់បន្ថយ ពីមួយឆ្នាំទៅមួយឆ្នាំ។ នៅដើរវាងឆ្នាំ ២០០២ អង្គការសហប្រជាជាតិជាប់ជំពាក់ខ្លាំងពេក រហូតគ្មានប្រាក់បង់ថ្លៃអគ្គីសនីសម្រាប់បើកម៉ាស៊ីនកំដៅអគារទីស្នាក់ការកណ្តាលរបស់ខ្លួន នៅទីក្រុងញូវយ៉កបាននោះទេ។ ចាប់តាំងពីពេលនោះមក ស្ថានភាពបានធូរស្រាលបន្តិចម្តងៗ ប៉ុន្តែរឿងលុយនៅតែតានតឹងដដែល។

អគ្គលេខាធិការមិនមែនត្រឹមតែជាអ្នកគ្រប់គ្រងការិយាធិបតេយ្យប៉ុណ្ណោះទេ។ លោក (មិនធ្លាប់មានអគ្គលេខាធិការជាលោកស្រីនៅឡើយទេ) គឺជាបុគ្គលសាធារណៈដ៏លេចធ្លោ ដែលការយកចិត្តទុកដាក់របស់គាត់ផ្តាល់ចំពោះជម្លោះក្នុងតំបន់ណាមួយ អាចជំរុញអោយមានដំណោះស្រាយជម្លោះនោះ។ ធម្មនុញ្ញរបស់អង្គការសហប្រជាជាតិអនុញ្ញាតអោយអគ្គលេខាធិការ ប្រើប្រាស់ការិយាល័យរបស់អង្គការសហប្រជាជាតិដើម្បីធ្វើជាអ្នកសម្រុះសម្រួលអព្យាក្រឹតនៅក្នុងជម្លោះអន្តរជាតិ ដើម្បីនាំភាគីអរិភាពចូលតុចរចា។

អគ្គលេខាធិកាក៏ធ្វើការដើម្បីកៀងគរការមូលមតិគ្នាជាឯកច្ឆ័ន្ទ ពីក្នុងចំណោមប្រទេសមហាអំណាចដែលត្រូវការជាចាំបាច់សម្រាប់សកម្មភាពរបស់ក្រុមប្រឹក្សាសន្តិសុខ។ ក្រោមធម្មនុញ្ញអង្គការសហប្រជាជាតិ អគ្គលេខាធិការមានសិទ្ធិអំណាចនាំយកបញ្ហាណាមួយ ដែលអាចនឹងគំរាមកំហែងដល់សន្តិភាពនិងសន្តិសុខអន្តរជាតិទៅកាន់ក្រុមប្រឹក្សាសន្តិសុខ ដូច្នេះហើយលោកបំពេញតួនាទីយ៉ាងសំខាន់ក្នុងការកំណត់របៀបវារៈរបស់អង្គការសហប្រជាជាតិក្នុងកិច្ចការសន្តិសុខអន្តរជាតិ។ ទោះយ៉ាងណាក៏ដោយ អគ្គលេខាធិការជួបប្រទះនូវភាពតានតឹងជាមួយក្រុមប្រឹក្សាសន្តិសុខដែរ។ នៅពេលដែលអគ្គលេខាធិការស្នើសុំសិទ្ធិអំណាចសម្រាប់បេសកកម្មរក្សាសន្តិភាពរយៈពេលប្រាំមួយខែ ក្រុមប្រឹក្សាសន្តិសុខទំនងជាផ្តល់អោយត្រឹមតែបីខែប៉ុណ្ណោះ។ ប្រសិនបើអគ្គលេខាធិការស្នើសុំ ១០ លានដុល្លារ លោកអាចនឹងទទួលបានត្រឹមតែ ៥ លានដុល្លារប៉ុណ្ណោះ។ ដូច្នេះ ដូចជាប្រព័ន្ធអង្គការសហប្រជាជាតិទាំងមូល អគ្គលេខាធិការនៅតែត្រូវរឹតត្បិតដោយអធិបតេយ្យភាពរបស់រដ្ឋផងដែរ។

៧.២.៥. មហាសន្និបាត

មហាសន្និបាតរួមមានរដ្ឋសមាជិករបស់អង្គការសហប្រជាជាតិ ទាំង ១៩៣ ដោយក្នុងនោះ រដ្ឋនីមួយៗមានសំឡេងឆ្នោតមួយដូចគ្នា។ ជាធម្មតា មហាសន្និបាតប្រព្រឹត្តិទៅ ជារៀងរាល់ឆ្នាំ ចាប់ពីចុងខែកញ្ញាដល់ខែមករាក្នុង*សម័យប្រជុំពេញអង្គ* (plenary session)។ មេដឹកនាំរដ្ឋ ឬរដ្ឋមន្ត្រីការបរទេស រួមទាំងប្រធានាធិបតីសហរដ្ឋអាមេរិក ជាទូទៅប្តូរវេនគ្នាម្តងម្នាក់ ដើម្បីឡើងថ្លែងសុន្ទរកថាទៅកាន់អង្គមហាសន្និបាតនេះ។ សម័យប្រជុំមហាសន្និបាត ក៏ដូចជាការពិភាក្សាភាគច្រើនរបស់អង្គការសហប្រជាជាតិ ត្រូវបានបកប្រែជាច្រើនភាសាដំណាលគ្នាដើម្បីអោយប្រតិភូមកពីជុំវិញពិភពលោកអាចបន្តការសន្ទនារួមគ្នាតែមួយ។ សាលប្រជុំសកលនេះគឺជាស្ថាប័នឯកឯកប្លែកខុសគេតែមួយគត់ និងផ្តល់នូវមេរៀនបាយដ៏មានឥទ្ធិពលសម្រាប់រដ្ឋនានា ក្នុងការលើក

ឡើងនូវទស្សនៈនិងអំណះអំណាងរបស់ពួកគេ។ អ្នកធ្វើជាអធិបតីនៅក្នុងមហាសន្និបាត គឺជាប្រធានមួយរូបដែលត្រូវបានជ្រើសរើសដោយអង្គមហាសន្និបាត ដែលជាតំណែងនិមិត្តរូបមិនមានអំណាចច្រើនឡើយ។

មហាសន្និបាតបើក*សម័យប្រជុំវិសាមញ្ញ* (special sessions) រៀងរាល់ពីរឬបីឆ្នាំម្តង លើប្រធានបទទូទៅ ដូចជាកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច។ សម័យប្រជុំវិសាមញ្ញរបស់អង្គការសហប្រជាជាតិស្តីពីការសោយអាវុធ នៅខែមិថុនាឆ្នាំ ១៩៨២ បានផ្តល់ឱកាសសម្រាប់ការប្រមូលផ្តុំតវ៉ានយោបាយដ៏ធំបំផុតមួយ នៅក្នុងប្រវត្តិសាស្ត្រសហរដ្ឋអាមេរិក នោះគឺ បាតុកម្មសន្តិភាពរបស់មនុស្សមួយលាននាក់ នៅទីក្រុងញូវយ៉ក។ នាពេលកន្លងមក អង្គមហាសន្និបាតបានជួបគ្នា ក្នុង*សម័យប្រជុំបន្ទាន់* (emergency session) ដើម្បីឆ្លើយតបចំពោះការគំរាមកំហែងភ្លាមៗ ចំពោះសន្តិភាពនិងសន្តិសុខអន្តរជាតិ ប៉ុន្តែ រឿងនេះបានកើតឡើងត្រឹមតែ ៩ ដងប៉ុណ្ណោះ ហើយឥឡូវនេះបានក្លាយជារឿងកម្រ។

រូបថត ទិដ្ឋភាពមហាសន្និបាតអ.ស.ប.

ជំនួបសមភាព

សមាជិកភាពសកលរបស់អង្គការសហប្រជាជាតិ គឺជាចំណុចដ៏ខ្លាំងមួយរបស់អង្គការនេះ។ រដ្ឋជាសមាជិកទាំងអស់មានសំឡេងមួយនិងសន្លឹកឆ្នោតមួយ ដូចគ្នា នៅក្នុងមហាសន្និបាត ដែលមេដឹកនាំរដ្ឋជួបជុំគ្នា រៀងរាល់រដូវស្លឹកឈើជ្រុះ។ នៅទីនេះ ប្រធានាធិបតីប្រទេសនៅរូ (Nauru) ដែលជារដ្ឋកោះមួយមានទំហំ ៨ ម៉ាយស៍ការ៉េ និងប្រជាជនប្រហែល ៩,០០០ នាក់ ថ្លែងទៅកាន់មហាសន្និបាតឆ្នាំ ២០១៤។

មហាសន្និបាតមានសិទ្ធិអំណាច ក្នុងការទទួលស្គាល់គណៈប្រតិភូជាតិជាសមាជិកនៃអង្គការសហប្រជាជាតិ(តាមរយៈគណៈកម្មាធិការទទួលស្គាល់អត្តសញ្ញាណ(Credentials Committee)របស់ខ្លួន។ ជាឧទាហរណ៍ នៅក្នុងឆ្នាំ ១៩៧១ គណៈប្រតិភូនៃសាធារណរដ្ឋប្រជាមានិតចិនត្រូវបានផ្តល់អាសនៈតំណាងប្រទេសចិនក្នុងអង្គការសហប្រជាជាតិ (រួមទាំងក្រុមប្រឹក្សាសន្តិសុខ) ជំនួសអ្នកជាតិនិយមនៅកោះតៃវ៉ាន់។ អស់ជាច្រើនទសវត្សរ៍ ទាំងប្រទេសកូរ៉េខាងជើង និងប្រទេសកូរ៉េខាងត្បូងមិនបានក្លាយជាសមាជិកនៃអង្គការសហប្រជាជាតិទេ (ដោយសារតែប្រទេសទាំងពីរបានទាមទារតំណាងប្រទេសកូរ៉េទាំងមូល) ប៉ុន្តែ ទីបំផុតពួកគេបានទទួលយកអាសនៈជាគណៈប្រតិភូដាច់ដោយឡែកពីគ្នា នៅក្នុងឆ្នាំ ១៩៩១។ អង្គភាពនយោបាយមួយចំនួន ដែលមិនមានឋានៈជារដ្ឋ បានបញ្ជូន*របសកកម្មអ្នកសង្កេតការណ៍អចិន្ត្រៃយ៍* (permanent observer missions) ទៅកាន់អង្គការសហប្រជាជាតិ។ បេសកកម្មទាំងនេះចូលរួម ដោយមិនមានសិទ្ធិបោះឆ្នោតនៅក្នុងមហាសន្និបាត។ ពួកគេរួមមាន បុរីវ៉ាទីកង់ (Holy See) និងអាជ្ញាធរប៉ាឡេស្ទីន។

អំណាចចម្បងរបស់អង្គមហាសន្និបាតស្ថិតនៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុរបស់ខ្លួន សម្រាប់កម្មវិធី និងប្រតិបត្តិការរបស់អង្គការសហប្រជាជាតិ រួមទាំងការរក្សាសន្តិភាពផងដែរ។ វាក៏អាចអនុម័តដំណោះស្រាយលើបញ្ហាផ្សេងៗបានដែរ ប៉ុន្តែ ដំណោះស្រាយទាំងនេះមានលក្ខណៈជាការផ្តល់យោបល់សុទ្ធសាធ ហើយពេលខ្លះ គ្រាន់តែជាវេទិការបើកចំហទូលំទូលាយ សម្រាប់ប្រទេសក្រីក្រភាគច្រើនសម្តែងការខកចិត្តរបស់ខ្លួនតែប៉ុណ្ណោះ។ អង្គមហាសន្និបាតក៏បោះឆ្នោតជ្រើសរើសសមាជិកនានានៃទីភ្នាក់ងារនិងកម្មវិធីមួយចំនួនរបស់អង្គការសហប្រជាជាតិផងដែរ។ ជាចុងក្រោយ អង្គមហាសន្និបាតសម្របសម្រួលកម្មវិធីនិងទីភ្នាក់ងារទាំងឡាយរបស់អង្គការសហប្រជាជាតិ តាមរយៈប្រព័ន្ធនៃគណៈកម្មាធិការ បេសកកម្ម និងក្រុមប្រឹក្សារបស់ខ្លួនជាដើម។

អង្គមហាសន្និបាតសម្របសម្រួលកម្មវិធីនិងទីភ្នាក់ងារនានារបស់អង្គការសហប្រជាជាតិ តាមរយៈក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គម (ECOSOC) ដែលមានរដ្ឋជាសមាជិកចំនួន ៥៤ ដែលត្រូវបានជ្រើសរើសដោយអង្គមហាសន្និបាតសម្រាប់អាណត្តិបីឆ្នាំ។ ក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមគ្រប់គ្រងការងារត្រួតស៊ីគ្នានៃកម្មវិធីនិងភ្នាក់ងារមួយចំនួនធំ។ *គណៈកម្មការតំបន់* (regional commissions) របស់វាត្រួតពិនិត្យមើលអំពីរបៀបដែលកម្មវិធីរបស់អង្គការសហប្រជាជាតិធ្វើការរួមគ្នា នៅក្នុងតំបន់ណាមួយ។ គណៈកម្មាការមុខងារ (functional commissions)របស់វា ដោះស្រាយបញ្ហាសកល ដូចជាកំណើនប្រជាជន ការជួញដូរគ្រឿងញៀន សិទ្ធិមនុស្ស និងស្ថានភាពរបស់ស្ត្រី។ ហើយស្ថាប័នជំនាញ(expert bodies)របស់វាធ្វើការលើបញ្ហាបច្ចេកទេសដែលពាក់ព័ន្ធនឹងកម្មវិធីអង្គការសហប្រជាជាតិផ្សេងៗ ក្នុងវិស័យដូចជា ការទប់ស្កាត់ឧក្រិដ្ឋកម្មនិងហិរញ្ញវត្ថុសាធារណៈ។ នៅខាងក្រៅក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គម អង្គមហាសន្និបាតគ្រប់គ្រងដំណើរការគណៈកម្មាធិការឯកទេស(specialized committees)ជាច្រើនទៀត។ គណៈកម្មាធិការអចិន្ត្រៃយ៍សម្រួលការងាររបស់អង្គមហាសន្និបាត ក្នុងបញ្ហានានា ដូចជា ការរំសាយរបបអាណានិគម កិច្ចការច្បាប់ និងការរំសាយអាវុធ។

សកម្មភាពជាច្រើន ដែលពាក់ព័ន្ធជាមួយអង្គការសហប្រជាជាតិមិនត្រូវធ្វើឡើង ក្រោមការគ្រប់គ្រងដ៏តឹងរឹងរបស់អង្គមហាសន្និបាតឬក្រុមប្រឹក្សាសន្តិសុខនោះទេ។ ពួកវាកើតឡើងនៅក្នុងភ្នាក់ងារមុខងារ និងកម្មវិធីដែលមានស្វ័យភាពពីការគ្រប់គ្រងរបស់អង្គការសហប្រជាជាតិ ក្នុងកម្រិតណាមួយ។

៧.២.៦. កម្មវិធីអង្គការសហប្រជាជាតិ

តាមរយៈក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គម មហាសន្និបាតត្រួតពិនិត្យកម្មវិធីសំខាន់ៗជាច្រើន ដើម្បីជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងស្ថិរភាពសង្គម នៅក្នុងរដ្ឋក្រីក្រក្នុងអឌ្ឍគោលខាងត្បូង។ តាមរយៈកម្មវិធីរបស់ខ្លួនអង្គការសហប្រជាជាតិជួយគ្រប់គ្រងទំនាក់ទំនងអឌ្ឍគោលខាងជើងនិងខាងត្បូង៖ ចាត់ចែងលំហូរធនធាននិងជំនាញ ពីតំបន់នៃពិភពលោកដែលរីកចំរើនជាង ដើម្បីគាំទ្រដល់ការអភិវឌ្ឍន៍នៅក្នុងតំបន់ក្រីក្រជាង។

កម្មវិធីទាំងនោះត្រូវបានផ្តល់មូលនិធិមួយផ្នែក ដោយការបែងចែកធនធានពីមហាសន្និបាត និងមួយផ្នែកទៀត ដោយការរួមចំណែក ដែលកម្មវិធីទាំងនោះបានកៀងគរ ដោយផ្ទាល់ពីរដ្ឋសមាជិក អាជីវកម្ម ឬអ្នកបរិច្ចាគសប្បុរសធម៌ឯកជន។ កម្រិតនៃការផ្តល់មូលនិធិនិងស្វ័យភាពប្រតិបត្តិការ ពីមហាសន្និបាតប្រែប្រួលពីកម្មវិធីមួយទៅកម្មវិធីមួយទៀត។ កម្មវិធីរបស់អង្គការសហប្រជាជាតិនីមួយៗមានបុគ្គលិក ទីស្នាក់ការកណ្តាល និងប្រតិបត្តិការផ្ទាល់ខ្លួន ដោយឡែកពីគ្នា នៅក្នុងវិស័យដែលពួកគេធ្វើការជាមួយរដ្ឋាភិបាលម្ចាស់ផ្ទះ នៅក្នុងរដ្ឋជាសមាជិក។

ក្នុងចំណោមកម្មវិធីទាំងនេះ មួយចំនួនមានសារៈសំខាន់កាន់តែខ្លាំងឡើងៗ។ កម្មវិធីបរិស្ថានអង្គការសហប្រជាជាតិ(UNEP) កាន់តែលេចធ្លោខ្លាំង នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ ដោយសារតែការអភិវឌ្ឍន៍សេដ្ឋកិច្ចនៃអឌ្ឍគោលខាងត្បូងនិងសេដ្ឋកិច្ចដែលកំពុងរីកចម្រើននៃពិភពប្រទេសឧស្សាហកម្ម បានធ្វើអោយប៉ះពាល់ដល់បរិស្ថានពិភពលោក(សូមមើលមេរៀនទី១១)។ កម្មវិធីបរិស្ថានអង្គការសហប្រជាជាតិប្រឹងប្រែងជាមួយយុទ្ធសាស្ត្របរិស្ថានសកល។ បេសកកម្មរបស់វាមានដូចជា ផ្តល់ជំនួយបច្ចេកទេសដល់រដ្ឋជាសមាជិកតាមដានលក្ខខណ្ឌបរិស្ថានជាសកល បង្កើតស្តង់ដារ និងណែនាំប្រភពថាមពលដទៃ។

យូនីសេហ្វ(UNICEF) គឺជាមូលនិធិកុមាររបស់អង្គការសហប្រជាជាតិ ដែលផ្តល់ជំនួយបច្ចេកទេស និងហិរញ្ញវត្ថុដល់ប្រទេសក្រីក្រសម្រាប់កម្មវិធីនានាដែលផ្តល់អត្ថប្រយោជន៍ដល់កុមារ។ ជាអកុសល តម្រូវការរបស់កុមារនៅក្នុងប្រទេសជាច្រើននៅតែជាបញ្ហាបន្ទាន់ ហើយអង្គការយូនីសេហ្វនៅតែជាកង្វល់។ ដោយទទួលបានហិរញ្ញប្បទានពីការរួមចំណែកដោយស្ម័គ្រចិត្ត អង្គការយូនីសេហ្វបានរៀបចំកុមារអាមេរិកជាច្រើននាក់ ក្នុងរយៈពេលប៉ុន្មានទសវត្សរ៍កន្លងមក ក្នុងការដំរុញការកៀងគរមូលនិធិ ក្នុងពិធីបុណ្យហាឡូវីន (Halloween) ប្រចាំឆ្នាំ ក្នុងនាមកុមារដទៃទៀត នៅក្នុងប្រទេសក្រីក្រ។

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន (UNHCR) ក៏មានភាពមមាញឹកផងដែរ។ UNHCR សម្របសម្រួលកិច្ចខិតខំប្រឹងប្រែង ដើម្បីការពារ ជួយគាំទ្រ និងបន្តិចម្តងៗ ធ្វើមាតុភូមិនិវត្តន៍ជនភៀសខ្លួនជាច្រើន ដែលភៀសខ្លួនឆ្លងព្រំដែនអន្តរជាតិជារៀងរាល់ឆ្នាំ ដើម្បីគេចចេញពីសង្គ្រាមនិងអំពើហិង្សានយោបាយ។ បញ្ហាជនភៀសខ្លួនប៉ាឡេស្ទីនដែលអូសបន្លាយយូរជាងនេះ ត្រូវបានដោះស្រាយដោយកម្មវិធីផ្សេងគ្នា គឺ *ទីភ្នាក់ងារការងារសង្គ្រោះរបស់អង្គការសហប្រជាជាតិ* (UNRWA)។

កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) ដែលត្រូវបានផ្តល់មូលនិធិដោយការរួមចំណែកដោយស្ម័គ្រចិត្ត សម្របសម្រួលកិច្ចខិតខំប្រឹងប្រែងរបស់អង្គការសហប្រជាជាតិទាំងអស់ ទាក់ទងនឹងការអភិវឌ្ឍន៍ នៅក្នុងប្រទេសក្រីក្រ។ ជាមួយនឹងគម្រោងប្រហែល ៥០០០ កំពុងដំណើរការ ក្នុងពេលដំណាលគ្នាជុំវិញពិភពលោក កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ គឺជាទីភ្នាក់ងារអន្តរជាតិដ៏ធំបំផុតលើពិភពលោកសម្រាប់ជំនួយអភិវឌ្ឍន៍បច្ចេកទេស។ អង្គការសហប្រជាជាតិក៏ដំណើរការទីភ្នាក់ងារពាក់ព័ន្ធការអភិវឌ្ឍន៍ជាច្រើនសម្រាប់ការបណ្តុះបណ្តាល និងលើកកម្ពស់តួនាទីស្ត្រីក្នុងការអភិវឌ្ឍន៍។

ប្រទេសក្រីក្រជាច្រើនពឹងផ្អែកលើចំណូលពីការនាំចេញ ដើម្បីផ្តល់ហិរញ្ញប្បទានដល់ការអភិវឌ្ឍន៍ សេដ្ឋកិច្ចដែលធ្វើអោយប្រទេសទាំងនោះងាយរងគ្រោះដោយសារការប្រែប្រួលតម្លៃទំនិញលើទីផ្សារ និងបញ្ហាពាណិជ្ជកម្មអន្តរជាតិផ្សេងទៀត។ **សន្និសីទអង្គការសហប្រជាជាតិ ស្តីពីពាណិជ្ជកម្មនិងការអភិវឌ្ឍន៍** (UNCTAD) ចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មអន្តរជាតិ ដើម្បីរក្សាស្ថិរភាពតម្លៃទំនិញ និងជំរុញការអភិវឌ្ឍន៍។ ទោះជាយ៉ាងណាក៏ដោយ ដោយសារតែបណ្តាប្រទេសនៃអឌ្ឍគោលខាងត្បូងមិនមានឥទ្ធិពលខ្លាំងក្លាក្នុងសេដ្ឋកិច្ចអន្តរជាតិ។ សន្និសីទអង្គការសហប្រជាជាតិស្តីពីពាណិជ្ជកម្មនិងការអភិវឌ្ឍន៍មានអានុភាពតិចតួចក្នុងការលើកកម្ពស់ផលប្រយោជន៍របស់ពួកគេក្នុងពាណិជ្ជកម្ម។ ដូច្នេះ អង្គការពាណិជ្ជកម្មពិភពលោកបានក្លាយជាអង្គការដ៏សំខាន់ ដែលដោះស្រាយបញ្ហាពាណិជ្ជកម្ម (សូមមើលមេរៀនទី ៨)។

នៅឆ្នាំ ២០០៦ អង្គការសហប្រជាជាតិបានបង្កើតក្រុមប្រឹក្សាសិទ្ធិមនុស្សថ្មីមួយ ជំនួសគណៈកម្មការសិទ្ធិមនុស្ស ដែលខូចឈ្មោះដោយសារបញ្ហលរដ្ឋល្បីខាងរំលោភសិទ្ធិមនុស្សជាសមាជិក។ ក្រុមប្រឹក្សាថ្មីបានពង្រីកអំណាចនិងមានសមាជិកភាពដំរើសកាន់តែល្អិតល្អន់(៤៧រដ្ឋ)។ ក្នុងឱកាសច្រើនជាងមួយ រដ្ឋដែលមានកំណត់ត្រាសិទ្ធិមនុស្សគួរអោយសង្ស័យ (ឧទាហរណ៍ដូចជា ប្រទេសស៊ូដង់ និង ស៊ីរី) ត្រូវបានផ្តាច់ចេញពីសន្លឹកឆ្នោតក្រុមប្រឹក្សាសិទ្ធិមនុស្ស ដើម្បីរារាំងពួកគេ។

កម្មវិធីផ្សេងទៀតរបស់អង្គការសហប្រជាជាតិគ្រប់គ្រងបញ្ហាដូចជា ជំនួយសង្គ្រោះពីគ្រោះមហន្តរាយ ជំនួយស្បៀងអាហារ លំនៅដ្ឋាន និងបញ្ហាប្រជាជន។ នៅទូទាំងប្រទេសក្រីក្រ អង្គការសហប្រជាជាតិរក្សាវត្តមានយ៉ាងសកម្មក្នុងកិច្ចការសេដ្ឋកិច្ចនិងសង្គម។

៧.២.៧. ទីភ្នាក់ងារស្វយ័ត

បន្ថែមពីលើកម្មវិធីខាងលើ មហាសន្និបាតអង្គការសហប្រជាជាតិរក្សាទំនាក់ទំនងផ្លូវការជាមួយនឹងទីភ្នាក់ងារអន្តរជាតិដែលមានស្វយ័តភាព ប្រហែល ២០ ស្ថាប័នផ្សេងទៀត ដែលមិនស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់វា។ ស្ថាប័នភាគច្រើនគឺជាអង្គការបច្ចេកទេសឯកទេស ដែល រដ្ឋទាំងអស់ខិតខំប្រឹងប្រែងប្រមូលផ្តុំកិច្ចការបច្ចេកទេសរបស់ពួកគេ ក្នុងការដោះស្រាយបញ្ហា ដូចជាការថែទាំសុខភាព និងលក្ខខណ្ឌការងារ។

ក្នុងចំណោមនោះ ទីភ្នាក់ងារដែលធ្វើការក្នុងកិច្ចការសន្តិសុខអន្តរជាតិគឺ *ទីភ្នាក់ងារថាមពលអាតូមិកអន្តរជាតិ* (IAEA) ដែលមានទីស្នាក់ការ នៅទីក្រុងវីយែន នៃប្រទេសអូទ្រីស។ វាត្រូវបានបង្កើតឡើងក្រោមអង្គការសហប្រជាជាតិ ប៉ុន្តែមានស្វយ័តភាពជាផ្លូវការ។ ទោះបីជាទីភ្នាក់ងារថាមពលអាតូមិកអន្តរជាតិ មានតួនាទីសេដ្ឋកិច្ចក្នុងការជួយអភិវឌ្ឍរោងចក្រថាមពលនុយក្លេអ៊ែរស៊ីវិល វាមានគោលដៅជាចម្បង ដើម្បីរារាំងការសាយភាយនុយក្លេអ៊ែរ (សូមមើល មេរៀនទី ៦)។ ទីភ្នាក់ងារថាមពលអាតូមិកអន្តរជាតិ ទទួលខុសត្រូវលើការត្រួតពិនិត្យនៅក្នុងប្រទេសអ៊ីរ៉ាក់ ក្នុងឆ្នាំ ២០០២-២០០៣ ដែលមិនបានរកឃើញភស្តុតាងនៃកម្មវិធីអាវុធនុយក្លេអ៊ែរសម្ងាត់ទេ។ វាបាននិងកំពុងចូលរួមក្នុងការត្រួតពិនិត្យកម្មវិធីនុយក្លេអ៊ែររបស់ប្រទេសអ៊ីរ៉ង់។ ទីភ្នាក់ងារថាមពលអាតូមិកអន្តរជាតិបានឈ្នះរង្វាន់ណូបែលសន្តិភាពឆ្នាំ ២០០៥។

នៅក្នុងវិស័យថែទាំសុខភាព **អង្គការសុខភាពពិភពលោក** (WHO) ដែលមានមូលដ្ឋាន នៅទីក្រុងហ្សឺណែវ ផ្តល់ជំនួយបច្ចេកទេសដើម្បីកែលម្អលក្ខខណ្ឌ និងធ្វើយុទ្ធនាការចាក់ថ្នាំបង្ការសំខាន់ៗ នៅក្នុងប្រទេសក្រីក្រ។ នៅទសវត្សរ៍ឆ្នាំ ១៩៦០ និង ១៩៧០ អង្គការសុខភាពពិភពលោកបានដឹកនាំឆ្ពោះទៅកាន់ជ័យជំនះលើផ្នែកសុខភាពសាធារណៈដ៏ត្រចះត្រចង់ ជាងពេលណាៗទាំងអស់ នោះគឺការលុបបំបាត់ជំងឺអ៊ុតស្វាយនៅទូទាំងពិភពលោក។ សព្វថ្ងៃនេះ អង្គការសុខភាពពិភពលោក គឺជាអ្នកដឹកនាំកិច្ចប្រឹងប្រែងក្នុងការឆ្លើយតបទៅនឹងការរីករាលដាលបញ្ហាសុខភាពសកល និងក្នុងការប្រយុទ្ធប្រឆាំង ដើម្បីគ្រប់គ្រងជំងឺអេដស៍ទូទាំងពិភពលោក (សូមមើលមេរៀនទី ១១)។

ក្នុងវិស័យកសិកម្ម *អង្គការស្បៀងអាហារនិងកសិកម្ម* (FAO) គឺជាភ្នាក់ងារឈានមុខគេ។ សម្រាប់សស្តង់ដារការងារ មាន*អង្គការពលកម្មអន្តរជាតិ* (ILO)។ អង្គការអភិវឌ្ឍន៍ឧស្សាហកម្មរបស់អង្គការសហប្រជាជាតិ (UNIDO) ជម្រុញឧស្សាហូបនីយកម្មនៅអឡាគោលខាងត្បូង។

យូណេស្កូ (UNESCO) ដែលជាអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌របស់អង្គការសហប្រជាជាតិ សម្របសម្រួលទំនាក់ទំនងអន្តរជាតិ និងកិច្ចសហការផ្នែកវិទ្យាសាស្ត្រ។ សហរដ្ឋអាមេរិកមានទំនាក់ទំនងល្អកកករជាមួយនឹងអង្គការយូណេស្កូ។ សហរដ្ឋអាមេរិកបានដកខ្លួនចេញពីអង្គការនេះ ចំនួនពីរដងហើយដោយអះអាងថាសកម្មភាពអង្គការនេះមានភាពលម្អៀង។ ការដកខ្លួនចេញចុងក្រោយ កើតឡើងក្នុងឆ្នាំ ២០១៧ ដោយចោទអង្គការយូណេស្កូមានភាពលម្អៀងប្រឆាំងនឹងប្រទេសអ៊ីស្រាអែល។

រូបថត កុមាររងគ្រោះទទួលបានជំនួយសង្គ្រោះ

ជំនួយនៅកន្លែងដែលត្រូវការ

កម្មវិធីរបស់អង្គការសហប្រជាជាតិច្រើនសន្ធឹកសន្ធាប់ ដែលដំណើរការក្រោមមហាសន្និបាតអ.ស.ប. មានគោលបំណងជួយប្រទេសនានា ក្នុងអឡាគោលខាងត្បូងអោយជម្នះបញ្ហាសង្គមនិងសេដ្ឋកិច្ច។ កម្មវិធីទាំងនេះដើរតួនាទីយ៉ាងសំខាន់នៅក្នុងគ្រាអាសន្ន ដូចជា គ្រោះមហន្តរាយធម្មជាតិ និងជម្លោះយោធា។ នៅ

ទីនេះ ការផ្តត់ផ្តង់ជំនួយបន្ទាន់របស់អង្គការសហប្រជាជាតិមកដល់ជំរំនានាក្នុងប្រទេសអ៊ីរ៉ាក់ កំឡុងពេលមានជម្លោះនៅទីនោះប្រឆាំងនឹងរដ្ឋ ឆ្នាំ ២០១៦។

អង្គការអន្តរជាតិ(IOs) ដែលត្រូវបានបង្កើតឡើងជាយូរលង់ណាស់មកហើយ ដោយមានកំណត់ត្រាជោគជ័យខ្លាំងបំផុតមួយចំនួន ជាភ្នាក់ងារឯកទេសដែលពាក់ព័ន្ធនឹងផ្នែកបច្ចេកទេសនៃការសម្របសម្រួលអន្តរជាតិ ដូចជា អាកាសចរណ៍និងប្រៃសណីយ៍។ ឧទាហរណ៍ *សហភាពទូរគមនាគមន៍អន្តរជាតិ* (ITU) បែងចែកប្រេកង់វិទ្យុ។ *សហភាពប្រៃសណីយ៍សកល* (UPU) កំណត់ស្តង់ដារសម្រាប់សារសំបុត្រអន្តរជាតិ។ *អង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ*(ICAO)កំណត់ចំណងស្តង់ដារសម្រាប់ចរាចរណ៍ផ្លូវអាកាសអន្តរជាតិ។ *អង្គការដែនសមុទ្រអន្តរជាតិ* (IMO) សម្របសម្រួលកិច្ចសហប្រតិបត្តិការអន្តរជាតិលើការដឹកជញ្ជូនតាមផ្លូវសមុទ្រ។ *អង្គការកម្មសិទ្ធិបញ្ញាពិភពលោក* (WIPO) ស្វែងរកការអនុលោមតាមពិភពលោកជាមួយនឹងការការពារកម្មសិទ្ធិបញ្ញា (សូមមើលមេរៀនទី ៨)។ ចុងក្រោយ *អង្គការឧតុនិយមពិភពលោក* (WMO) គ្រប់គ្រងការឃ្លាំមើលអាកាសធាតុពិភពលោក និងផ្សព្វផ្សាយការផ្លាស់ប្តូរព័ត៌មានអាកាសធាតុ។

ភ្នាក់ងារសំខាន់ៗសំរបសំរួលសេដ្ឋកិច្ចពិភពលោក (ពិភាក្សាក្នុងមេរៀនទី ៨, ៩, និង ១៣) ក៏ជាភ្នាក់ងារដែលមានទំនាក់ទំនងជាមួយអង្គការសហប្រជាជាតិផងដែរ។ ធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ផ្តល់ប្រាក់កម្ចី ជំនួយ និងជំនួយបច្ចេកទេស សម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច (ហើយមូលនិធិរូបិយវត្ថុអន្តរជាតិគ្រប់គ្រងគណនេយ្យសមតុល្យនៃការទូទាត់ប្រាក់អន្តរជាតិ)។ អង្គការពាណិជ្ជកម្មពិភពលោក(WTO)កំណត់ច្បាប់សម្រាប់ពាណិជ្ជកម្មអន្តរជាតិ។

សរុបមក ដង់ស៊ីតេនៃការតភ្ជាប់ឆ្លងព្រំដែនជាតិ ទាំងនៅក្នុងប្រព័ន្ធអង្គការសហប្រជាជាតិ និងតាមរយៈអង្គការអន្តរជាតិផ្សេងទៀត កំពុងកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ តាមរបៀបមិនសូវមើលឃើញ មនុស្សនានាក៏ត្រូវបានភ្ជាប់ទំនាក់ទំនងឆ្លងព្រំដែនអន្តរជាតិ តាមរយៈការភ្ជាប់គ្នានៃគំនិត រួមទាំងបទដ្ឋាន និងច្បាប់ផងដែរ។ ហើយបន្តិចម្តងៗ ច្បាប់កំពុងក្លាយជាច្បាប់អន្តរជាតិ។

៧.៣. ច្បាប់អន្តរជាតិ

៧.៣ តើច្បាប់អន្តរជាតិមានប្រសិទ្ធភាពឬគ្មានប្រសិទ្ធភាព ក្នុងការតតាំងតតិតវិយោបទរបស់រដ្ឋនានា។ ចូរពិភាក្សានិងវាយតំលៃអំណះអំណាងទាំងសងខាង។

ខុសពីច្បាប់ជាតិ ច្បាប់អន្តរជាតិមិនមែនកើតចេញពីសកម្មភាពរបស់ស្ថាប័ននីតិប្បញ្ញត្តិ ឬអាជ្ញាធរមជ្ឈឹមដទៃទៀតទេ ប៉ុន្តែវាកើតមកពីទំលាប់នៃការអនុវត្តនិងកិច្ចព្រមព្រៀងដែលចុះហត្ថលេខាដោយរដ្ឋនានា។ លក្ខណៈខុសប្លែកមួយទៀត គឺវាមានការលំបាកក្នុងការពង្រឹងការអនុវត្ត ដែលមិនអាស្រ័យលើអំណាចនិងអាជ្ញាធរបស់រដ្ឋាភិបាលកណ្តាល ប៉ុន្តែត្រូវអាស្រ័យលើគោលការណ៍បដិការ សកម្មភាពរួម និងបទដ្ឋានអន្តរជាតិ។

៧.៣.១. ប្រភពច្បាប់អន្តរជាតិ

ច្បាប់នៅក្នុងរដ្ឋនានាចេញមកពីអាជ្ញាធរមជ្ឈឹម៖ នីតិបញ្ញត្តិ ឬ មេដឹកនាំផ្តាច់ការ។ ដោយសាររដ្ឋមានអធិបតេយ្យភាពនិងមិនទទួលស្គាល់អាជ្ញាធរមជ្ឈឹមណាផ្សេងឡើយ ច្បាប់អន្តរជាតិពឹងផ្អែកលើមូលដ្ឋានផ្សេងគ្នា។ សេចក្តីប្រកាសរបស់មហាសន្និបាតអង្គការសហប្រជាជាតិ មិនមែនជាច្បាប់ទេ ហើយភាគច្រើនមិនអាចចាប់បង្ខំរដ្ឋសមាជិកអោយប្រតិបត្តិតាមជាដាច់ខាតបានឡើយ។ ក្រុមប្រឹក្សាសន្តិសុខអាចបង្ខំសកម្មភាពមួយ

ចំនួនដោយរដ្ឋ ប៉ុន្តែទាំងនោះគឺជាបញ្ហា ជាជាងច្បាប់៖ ទង្វើជាក់លាក់ក្នុងស្ថានភាពណាមួយ។ គ្មានស្ថាប័នច្បាប់អន្តរជាតិណាមួយត្រូវបានអនុម័តដោយស្ថាប័ននីតិប្បញ្ញត្តិជាតិឡើយ។ ប្រភពច្បាប់អន្តរជាតិចំនួនបួនត្រូវបានទទួលស្គាល់៖ សន្ធិសញ្ញា ទំនៀមទម្លាប់ គោលការណ៍ទូទៅនៃច្បាប់ (ដូចជាគោលការណ៍សមធម៌) និងទំនឹមច្បាប់បុរាណ (រួមទាំងសាលក្រមសម្រេចកន្លងមក)។

សន្ធិសញ្ញា (treaties) និងអនុសញ្ញាជាលាយលក្ខណ៍អក្សរផ្សេងទៀត ដែលចុះហត្ថលេខាដោយរដ្ឋទាំងឡាយ គឺជាប្រភពសំខាន់បំផុត។ បច្ចុប្បន្ន សន្ធិសញ្ញាអន្តរជាតិមានកំរាស់រាប់ពាន់ភាគ ដោយមានកិច្ចព្រមព្រៀងដោយឡែកៗរាប់ម៉ឺន។ គោលការណ៍នៃច្បាប់អន្តរជាតិចែងថា សន្ធិសញ្ញាទាំងឡាយ ក្រោយត្រូវបានចុះហត្ថលេខានិងផ្តល់សច្ចាប័ន ត្រូវតែអនុវត្តអោយបានខ្ជាប់ខ្ជួន (*pacta sunt servanda*)។ រដ្ឋរំលោភបំពានលក្ខខណ្ឌនៃសន្ធិសញ្ញាដែលពួកគេបានចុះហត្ថលេខា លុះត្រាតែបញ្ហានោះមានសារៈសំខាន់ខ្លាំង ឬកំរិតនៃដាក់ទណ្ឌកម្មចំពោះការរំលោភបែបនេះ ហាក់ដូចជាស្រាលពេក។ នៅសហរដ្ឋអាមេរិក សន្ធិសញ្ញាដែលត្រូវបានផ្តល់សច្ចាប័នដោយព្រឹទ្ធសភា ត្រូវបានចាត់ទុកថាជាច្បាប់ខ្ពស់បំផុតនៅក្នុងដែនដីពួកគេ ដែលសមមូលនឹងច្បាប់ដែលត្រូវបានអនុម័តដោយសភា។

សន្ធិសញ្ញានិងកាតព្វកិច្ចអន្តរជាតិផ្សេងទៀត ដូចជាបំណុលត្រូវបន្តដល់រដ្ឋាភិបាលស្នងតំណែងនានា ទោះរដ្ឋាភិបាលថ្មីឡើងកាន់អំណាច តាមរយៈការបោះឆ្នោត រដ្ឋប្រហារ ឬបដិវត្តន៍ក៏ដោយ។ ជាឧទាហរណ៍ បន្ទាប់ពីបដិវត្តន៍នៅអឺរ៉ុបខាងកើតអំឡុងឆ្នាំ១៩៩០ រដ្ឋាភិបាលប្រជាធិបតេយ្យថ្មីត្រូវចាប់អោយទទួលខុសត្រូវចំពោះបំណុលដែលខ្វីបុល ដោយរដ្ឋាភិបាលកុម្មុយនិស្តមុនៗ។ សូម្បីតែនៅពេលដែលសហភាពសូវៀតត្រូវបែកបាក់គ្នាក៏ដោយ ប្រទេសរុស្ស៊ីជារដ្ឋស្នងតំណែងត្រូវតែធានាថា នឹងត្រូវសងបំណុលដែលសូវៀតខ្វី ហើយត្រូវគោរពសន្ធិសញ្ញានានាដែលសូវៀតបានចុះ។ ទោះបីជាបដិវត្តន៍មិនបានរំដោះរដ្ឋចេញពីកាតព្វកិច្ចរបស់ខ្លួនក៏ដោយ ក៏សន្ធិសញ្ញាមួយចំនួនមានប្រយោគ ឬមាត្រា ដែលបើកចំហរអោយរដ្ឋហត្ថលេខីដកខ្លួនចេញដោយស្របច្បាប់ពីសន្ធិសញ្ញា បន្ទាប់ពីបានជូនដំណឹងត្រឹមត្រូវ តាមនីតិវិធី ដោយមិនបំពានច្បាប់អន្តរជាតិ។ ជាឧទាហរណ៍ សហរដ្ឋអាមេរិកនៅក្នុងឆ្នាំ ២០០១ បានយកមាត្រាមួយនៃសន្ធិសញ្ញាប្រឆាំងមីស៊ីលផ្លោង (ABM) មកប្រើ ដែលអនុញ្ញាតអោយអាមេរិកចាកចេញ រយៈពេលប្រាំមួយខែ។

ដោយសារតែការប្តេជ្ញាចិត្តជាសកល ដោយបណ្តារដ្ឋទាំងអស់ ក្នុងការគោរពគោលការណ៍ជាមូលដ្ឋានមួយចំនួននៃច្បាប់អន្តរជាតិ ធម្មនុញ្ញនៃអង្គការសហប្រជាជាតិ គឺជាសន្ធិសញ្ញាដ៏សំខាន់បំផុតមួយ នៅក្នុងពិភពលោក។ អត្ថន័យរបស់វាមានលក្ខណៈទូលំទូលាយនិងវែងឆ្ងាយ ផ្ទុយពីសន្ធិសញ្ញាជាក់លាក់ជាងដូចជាកិច្ចព្រមព្រៀងគ្រប់គ្រងជលផល។ ទោះជាយ៉ាងណាក៏ដោយ កិច្ចព្រមព្រៀងឯកទេសជាធម្មតាមានភាពងាយស្រួលក្នុងការបកស្រាយនិងអាចពង្រឹងការអនុវត្ត ជាងសន្ធិសញ្ញាទូលំទូលាយដូចជាធម្មនុញ្ញរបស់អ.ស.ប.។ សន្ធិសញ្ញាសំខាន់មួយទៀត នៅក្នុងច្បាប់អន្តរជាតិ គឺអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩ (ការពង្រីកបន្ថែមលើអនុសញ្ញាឆ្នាំ១៨៦៤) ដែលកំណត់ច្បាប់សង្គ្រាមទាក់ទងនឹងការការពារជនស៊ីវិល និងអ្នកទោស ក្នុងចំណោមបញ្ហាពាក់ព័ន្ធដទៃទៀត។

ទំនៀមទម្លាប់ (custom) គឺជាប្រភពសំខាន់ទីពីរនៃច្បាប់អន្តរជាតិ។ ប្រសិនបើរដ្ឋនានាប្រកាន់អាកប្បកិរិយាបែបណាមួយ ចំពោះគ្នាទៅវិញទៅមក ក្នុងរយៈពេលយូរគ្រប់គ្រាន់ អាកប្បកិរិយារបស់ពួកគេអាចក្លាយជាការអនុវត្ត ដែលត្រូវបានទទួលយកជាទូទៅ ដោយមានហានៈប្រៀបដូចជាច្បាប់មួយដូច្នោះដែរ។

ច្បាប់អន្តរជាតិបស្ចឹមលោក (ទោះបីមិនមែនជាច្បាប់អ៊ីស្លាម) ហាក់មានលក្ខណៈ*វិជ្ជមាន* (positivist)នៅក្នុងរឿងនេះ វាទាញចេញពីទំនៀមទម្លាប់ជាក់ស្តែង សច្ចៈភាពនៃផលប្រយោជន៍ផ្ទាល់ខ្លួនជាក់ស្តែង និងតម្រូវការជាចាំបាច់នូវការព្រមព្រៀងគ្នា ជាជាងលើគោលគំនិតអរូបីនៃទេវភាព ឬច្បាប់ធម្មជាតិ។

គោលការណ៍ទូទៅនៃច្បាប់ (general principles pf law) ក៏មានតួនាទីជាប្រភពនៃច្បាប់អន្តរជាតិផងដែរ។ សកម្មភាពមួយចំនួនដូចជាចោរកម្មនិងការរំលោភបំពានរាងកាយ ដែលត្រូវបានទទួលស្គាល់នៅក្នុងប្រព័ន្ធច្បាប់ជាតិភាគច្រើនថាជាឧក្រិដ្ឋកម្ម មាននិន្នាការឬអត្ថន័យដូចគ្នានៅក្នុងបរិបទអន្តរជាតិ។ ការឈ្លានពានរបស់ប្រទេសអ៊ីរ៉ាក់លើប្រទេសគុយវ៉ែត គឺជាទង្វើខុសច្បាប់ ក្រោមសន្ធិសញ្ញា ដែលចុះហត្ថលេខាដោយប្រទេសអ៊ីរ៉ាក់ (រួមទាំងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ និងនៃសម្ព័ន្ធអារ៉ាប់) និងក្រោមទំនៀមទម្លាប់ដែលអ៊ីរ៉ាក់និងគុយវ៉ែតបានបង្កើតឡើងដើម្បីរស់នៅដោយសន្តិភាព ក្នុងនាមជារដ្ឋអធិបតេយ្យដូចគ្នា។ ក្រៅពីសន្ធិសញ្ញាឬទំនៀមទម្លាប់ ការឈ្លានពានខាងលើក៏បានបំពានច្បាប់អន្តរជាតិ ដោយសារគោលការណ៍ទូទៅដែលរដ្ឋមួយមិនអាចរំលោភលើទឹកដីរបស់ប្រទេសជិតខាងខ្លួន ហើយបញ្ចូលវាជាទឹកដីរបស់ប្រទេសខ្លួនដោយបង្ខំនោះទេ។ (ជាការពិតណាស់ រដ្ឋមួយអាចនៅតែនឹកស្មានថា ខ្លួនអាចរួចខ្លួនទោះគេបានបំពានច្បាប់អន្តរជាតិបែបនេះក្តី។)

ប្រភពទីបួននៃច្បាប់អន្តរជាតិ ដែលត្រូវបានទទួលស្គាល់ ដោយតុលាការពិភពលោកថាមានលក្ខណៈបន្ទាប់បន្សំ គឺជា*ទំនឹមច្បាប់បុរាណ* (legal scholarship) ដែលសំដៅទៅលើសេចក្តីអះអាងជាលាយលក្ខណ៍អក្សររបស់ចៅក្រម និង មេធាវីជុំវិញពិភពលោកលើបញ្ហាណាមួយ។ មានតែសំណេររបស់បុគ្គលច្បាប់ដែលមានសមត្ថភាពនិងគួរអោយគោរពបំផុតប៉ុណ្ណោះ ដែលអាចយកមកពិចារណាបាន ហើយបន្ទាប់មកដើម្បីដោះស្រាយចំណុច ដែលមិនត្រូវបានដោះស្រាយដោយប្រភពបីដំបូងនៃច្បាប់អន្តរជាតិ។

ជារឿយៗច្បាប់អន្តរជាតិប្រព្រឹត្តិទៅយឺតយ៉ាវ យឺតជាការផ្លាស់ប្តូរបទដ្ឋាន, ច្បាប់តាមធម្មតាផ្សារភ្ជាប់ជាមួយនឹងទំនៀមទម្លាប់យ៉ាងស្អិតរមួត។ សកម្មភាពមួយចំនួនដូចជាចារកម្ម គឺជាទង្វើខុសច្បាប់ បើគិតតាមលក្ខណៈបច្ចេកទេស ប៉ុន្តែ ត្រូវបានលើកលែងយ៉ាងទូលំទូលាយថា វាមិនអាចត្រូវបានគេនិយាយថាជាការរំលោភលើបទដ្ឋានអន្តរជាតិទេ។ សកម្មភាពផ្សេងទៀតនៅតែស្របច្បាប់ ប៉ុន្តែត្រូវបានគេមើលឃើញថាមិនប្រក្រតី។ ជាឧទាហរណ៍ ការបាញ់ប្រហាររបស់ចិនទៅលើបាតុករនិស្សិត នៅក្នុងឆ្នាំ ១៩៨៩ បានបំពានលើបទដ្ឋានអន្តរជាតិ ប៉ុន្តែមិនរំលោភច្បាប់អន្តរជាតិទេ។

៧.៣.២. ការពង្រឹងការអនុវត្តច្បាប់អន្តរជាតិ

ទោះបីជាប្រភពនៃច្បាប់អន្តរជាតិទាំងនេះញែកខ្លួនវាឧុសពីច្បាប់ជាតិក៏ដោយ ភាពខុសគ្នាមានកាន់តែខ្លាំងរវាងការពង្រឹងការអនុវត្តច្បាប់ទាំងពីរប្រភេទនេះ។ ការអនុវត្តច្បាប់អន្តរជាតិមានការពិបាកខ្លាំងជាង។ ត្រូវចាំថា មិនមានកម្លាំងប៉ូលីសពិភពលោកទេ។ ការអនុវត្តច្បាប់អន្តរជាតិគឺអាស្រ័យលើអំណាចរបស់រដ្ឋខ្លួនឯង ទោះដោយរដ្ឋនីមួយៗ ឬដោយរដ្ឋសមូហភាព ក្នុងការដាក់ទោសអ្នកបំពាន។

ការអនុវត្តច្បាប់អន្តរជាតិត្រូវអាស្រ័យយ៉ាងខ្លាំងលើគោលការណ៍បដិការ (សូមមើលមេរៀនទី ១)។ រដ្ឋអនុវត្តតាមច្បាប់អន្តរជាតិភាគច្រើន ពីព្រោះពួកគេចង់អោយរដ្ឋផ្សេងទៀតធ្វើដូច្នោះដែរ។ ហេតុផលដែលភាគីទាំងពីរនៅក្នុងសង្គ្រាមលោកលើកទី២ មិនប្រើប្រាស់អាវុធគីមី មិនមែនដោយសារមាននរណាម្នាក់អាចពង្រឹង*ការអនុវត្ត*(enforce)សន្ធិសញ្ញាហាមឃាត់ការប្រើប្រាស់អាវុធបែបនេះនោះទេ។ មូលហេតុពិតប្រាកដ

គឺដោយសារភាគីម្ខាងទៀតប្រហែលជានឹងឆ្លើយតបដោយប្រើអាវុធគីមីមកវិញដែរ ហើយបង្កការខាតបង់ធ្ងន់ធ្ងរខ្លាំងសម្រាប់ភាគីទាំងពីរ។ ច្បាប់អន្តរជាតិទទួលស្គាល់ភាពស្របច្បាប់នៃការសងសឹក (reprisals) នៅក្នុងកាលៈទេសៈជាក់លាក់មួយៈ សកម្មភាពដែលខុសច្បាប់ក្រោមច្បាប់អន្តរជាតិ ប៉ុន្តែ ពេលខ្លះអាចប្រែជាស្របច្បាប់ ប្រសិនបើវាត្រូវបានធ្វើឡើងដើម្បីតែឆ្លើយតបទៅនឹងសកម្មភាពខុសច្បាប់នៃរដ្ឋមួយផ្សេងទៀត។

រដ្ឋដែលបំពានច្បាប់អន្តរជាតិអាចប្រឈមមុខនឹងការឆ្លើយតបជារួមដោយរដ្ឋមួយក្រុម ដូចជាការដាក់*ទណ្ឌកម្ម* (sanctions) (កិច្ចព្រមព្រៀងក្នុងចំណោមរដ្ឋដៃទៀតដើម្បីបញ្ឈប់ការជួញដូរជាមួយរដ្ឋបំពាន ឬបញ្ឈប់ពាណិជ្ជកម្មទំនិញពិសេសមួយចំនួន (ភាគច្រើនជាសព្វាវុធ)) ទុកជាការកាត់ទោសចំពោះការបំពានរបស់រដ្ឋ។ យូរៗទៅ រដ្ឋដាក់ទណ្ឌកម្មអាចក្លាយជា*ជនក្រៅសង្គម* (pariah) ក្នុងសហគមន៍នៃប្រជាជាតិ ដោយត្រូវកាត់ផ្តាច់ទំនាក់ទំនងជាប្រក្រតីជាមួយនឹងរដ្ឋដទៃ។ ទង្វើនេះពិតជាត្រូវចំណាយច្រើនខ្លាំងណាស់នៅក្នុងពិភពលោកបច្ចុប្បន្នដែលសុខុមាលភាពសេដ្ឋកិច្ច នៅគ្រប់ទីកន្លែង អាស្រ័យទៅលើការផ្លាស់ប្តូរសេដ្ឋកិច្ចនិងពាណិជ្ជកម្ម នៅក្នុងទីផ្សារពិភពលោក។ តួយ៉ាង ប្រទេសលីប៊ីបានរងទុក្ខលំបាក អស់ជាច្រើនទសវត្សរ៍ ដោយសារស្ថានភាពឯកោរបស់ខ្លួន នៅក្នុងសហគមន៍អន្តរជាតិ ហើយបានសម្រេចចិត្តក្នុងឆ្នាំ ២០០៣ ដើម្បីធ្វើការលាងខ្លួននិងទទួលបានស្ថានភាពប្រក្រតីឡើងវិញ។ ប្រទេសលីប៊ីបានទទួលស្គាល់ការទទួលខុសត្រូវចំពោះអំពើភេរវកម្មកន្លងមក, ចាប់ផ្តើមផ្តល់សំណងដល់ជនរងគ្រោះ, ហើយបានយល់ព្រមបង្ហាញ និងរុះរើកម្មវិធីអាវុធនុយក្លែអ៊ែរ គីមី និងជីវសាស្ត្ររបស់ខ្លួន។

សូម្បីតែប្រទេសមហាអំណាចពិភពលោកក៏ត្រូវអត់ធ្មត់ និងសង្រួមឥរិយាបទរបស់ខ្លួន យ៉ាងហោចណាស់នៅក្នុងពេលខ្លះ ដើម្បីគោរពច្បាប់អន្តរជាតិ។ ជាឧទាហរណ៍ នៅចុងឆ្នាំ ២០០២ កប៉ាល់ដឹកទំនិញរបស់ប្រទេសកូរ៉េខាងជើងមួយគ្រឿងត្រូវបានគេចាប់បាន ក្នុងពេលកំពុងធ្វើដំណើរទៅកាន់ប្រទេសយេម៉ែនជាមួយនឹងការផ្ទុកកាំជ្រួចកែច្នៃ Scud ចំនួន ១៥ គ្រាប់។ សហរដ្ឋអាមេរិក ដែលកំពុងធ្វើសង្គ្រាមប្រយុទ្ធប្រឆាំងនឹងភេរវកម្ម មានផលប្រយោជន៍ជាតិយ៉ាងប្រត្យក្សក្នុងការទប់ស្កាត់ការរីកសាយភាពបែបនេះ ហើយមានអំណាចក្នុងការទប់ស្កាត់។ ប៉ុន្តែ នៅពេលដែលមេធាវីរដ្ឋាភិបាលសហរដ្ឋអាមេរិកបានកំណត់ថា ការដឹកជញ្ជូនមិនបំពានច្បាប់អន្តរជាតិ សហរដ្ឋអាមេរិកបានថយមួយជំហាន ហើយអនុញ្ញាតអោយការដឹកជញ្ជូនបន្តដំណើរ។ ប៉ុន្តែ នៅឆ្នាំ ២០១៧ កប៉ាល់កូរ៉េខាងជើងពីរគ្រឿងត្រូវបានបញ្ឈប់ ដែលដឹកសារធាតុគីមីទៅកាន់ប្រទេសស៊ីរី ដែលអាចប្រើដើម្បីផលិតអាវុធគីមី។ ដោយសារតែកិច្ចព្រមព្រៀងផ្លូវច្បាប់ទាក់ទងនឹងអាវុធគីមីនៅក្នុងប្រទេសស៊ីរី នាវាទាំងនោះមិនត្រូវបានអនុញ្ញាតអោយបន្តឡើយ។

ការអនុវត្តច្បាប់អន្តរជាតិ តាមរយៈគោលការណ៍បដិការ និងការឆ្លើយតបជារួម មានចំណុចខ្សោយដ៏ធំមួយ វាត្រូវអាស្រ័យលើអំណាចជាតិទាំងស្រុង។ គោលការណ៍បដិការអាចដំណើរការបានលុះត្រាតែរដ្ឋដែលរងទុក្ខមានអំណាចបង្កការខូចខាតដល់រដ្ឋបំពាន។ ការឆ្លើយតបជារួមអាចដំណើរការបាន លុះត្រាតែក្រុមរដ្ឋជាសមូហភាពយកចិត្តទុកដាក់គ្រប់គ្រាន់អំពីបញ្ហាដែលត្រូវឆ្លើយតប។ ដូច្នេះ វាងាយស្រួលក្នុងការយកលេសព្រងើយកន្តើយចំពោះបញ្ហាតូចតាច (ឬរួចខ្លួនជាមួយនឹងការរំលោភបំពានធំៗ ប្រសិនបើរដ្ឋណាមួយនោះមានអំណាចគ្រប់គ្រាន់)។

ប្រសិនបើច្បាប់អន្តរជាតិអាចត្រូវអនុវត្តបានលុះត្រាតែមានអំណាច តើវាមានប្រយោជន៍អ្វី? ចម្លើយស្ថិតនៅក្នុងភាពមិនប្រាកដប្រជានៃអំណាច (សូមមើលមេរៀនទី ២)។ បើគ្មានការរំពឹងទុករួម ទាក់ទងនឹង

ច្បាប់ឬវិន័យនៃល្បែងទំនាក់ទំនងនិងការប្រកាន់ខ្ជាប់នូវច្បាប់ទាំងនោះ ភាគច្រើនបំផុតដោយតួអង្គភាគច្រើនអំណាចតែម្យ៉ាងនឹងបង្កើតអស្ថិរភាពធ្ងន់ធ្ងរនៅក្នុងប្រព័ន្ធអន្តរជាតិដ៏អនាធិបតេយ្យ។ ទោះបីជាមិនមានការអនុវត្តដ៏ល្អឥតខ្ចោះក៏ដោយ ច្បាប់អន្តរជាតិបង្កើតការរំពឹងទុក អំពីអ្វីដែលកំណត់ជាអាកប្បកិរិយាផ្លូវច្បាប់ដោយរដ្ឋ។ ដោយសារការរំលោភបំពាន ឬ ការឃ្លាតឆ្ងាយពីការរំពឹងទុកទាំងនោះ លេចចេញជារូបរាងច្បាស់វាកាន់តែងាយស្រួលក្នុងការកំណត់មុខសញ្ញាណនិងដាក់ទណ្ឌកម្មរដ្ឋ ដែលប្រព្រឹត្តិទង្វើឃ្លាតឆ្ងាយពីច្បាប់ដែលត្រូវបានទទួលយក។ នៅពេលដែលរដ្ឋនានាយល់ព្រមនឹងច្បាប់ ដោយការចុះហត្ថលេខាលើសន្ធិសញ្ញា (ដូចជាធម្មនុញ្ញអង្គការសហប្រជាជាតិ) ការបំពានកាន់តែអាចមើលឃើញកាន់តែច្បាស់ និងប្រាកដណាស់វាពិតជាខុសច្បាប់។ ក្នុងករណីភាគច្រើន ទោះបីជាអំណាចបន្តស្ថិតក្នុងកណ្តាប់ដៃរដ្ឋនានាក៏ដោយ ច្បាប់អន្តរជាតិបង្កើតច្បាប់ដែលអាចធ្វើការបាន សម្រាប់រដ្ឋទាំងនោះអនុវត្តតាម។ ស្ថេរភាពដែលកើតឡើងជាលទ្ធផល មានសារៈប្រយោជន៍ខ្លាំងណាស់ ដែលជាធម្មតាការខាតបង់ដោយសារការរំលោភបំពានច្បាប់មានទំហំធំធេងជាងផលប្រយោជន៍រយៈពេលខ្លី ដែលអាចទទួលបានពីការរំលោភបែបនេះ។

៧.៣.៣. តុលាការពិភពលោក

នៅពេលដែលច្បាប់អន្តរជាតិបានអភិវឌ្ឍ ក្របខ័ណ្ឌច្បាប់ពិភពលោកទូទៅមួយ ដែលរដ្ឋនានាអាចបន្តការតវ៉ាប្រឆាំងនឹងគ្នាទៅវិញទៅមក បានចាប់ផ្តើមលេចចេញជារូបរាង។ ឥឡូវនេះ សេចក្តីសម្រេចនៃប្រព័ន្ធបែបនេះមាននៅក្នុង**តុលាការពិភពលោក**(World Court) ឬហៅជាផ្លូវការថា **តុលាការយុត្តិធម៌អន្តរជាតិ**(ICJ) ទោះជាយុត្តាធិការរបស់វានៅមានកម្រិត ហើយបន្ទុកសំណុំរឿងរបស់វានៅស្រាលក៏ដោយ។ តុលាការពិភពលោកគឺជាសាខាមួយរបស់អង្គការសហប្រជាជាតិ។

មានតែរដ្ឋ (មិនមែនបុគ្គល ឬអាជីវកម្ម) ដែលអាចប្តឹង ឬ ត្រូវគេប្តឹង ទៅតុលាការពិភពលោក។ នៅពេលដែលរដ្ឋមួយមានការតវ៉ាប្រឆាំងនឹងប្រទេសមួយផ្សេងទៀត ពួកគេអាចយកសំណុំរឿងនេះ ទៅតុលាការពិភពលោកដើម្បីបើកសវនាការ ដោយមិនលំអៀង។ ក្រុមប្រឹក្សាសន្តិសុខ ឬ មហាសន្និបាតក៏អាចស្នើសុំមតិយោបល់ពីតុលាការនេះលើបញ្ហាច្បាប់អន្តរជាតិផងដែរ។ ជាឧទាហរណ៍ សេចក្តីសម្រេចរបស់តុលាការ នៅឆ្នាំ ២០១០ ដែលប្រកាសថាការប្រកាសឯករាជ្យរបស់កូសូវ៉ូស្របតាមផ្លូវច្បាប់ គឺជាមតិយោបល់ដែលស្នើដោយមហាសន្និបាត។

រូបថត ការចាប់ផ្តើមសវនាការតុលាការពិភពលោក
សូមក្រោកឡើងទាំងអស់

តុលាការពិភពលោកបើកសវនាការជំនុំជំរះវិវាទអន្តរជាតិ ប៉ុន្តែមានអំណាចតិចតួចក្នុងការអនុវត្តសាលក្រម។ នៅទីនេះ ក្នុងឆ្នាំ ២០០៤ ចៅក្រមសម្រេចយល់ព្រមលើបណ្តឹងរបស់ម៉ិកស៊ិកដែលថា ការផ្តន្ទាទោសប្រហារជីវិតរបស់សហរដ្ឋអាមេរិកប្រឆាំងនឹងពលរដ្ឋម៉ិកស៊ិកបានរំលោភលើសន្ធិសញ្ញាឆ្នាំ ១៩៦៣ ។

តុលាការពិភពលោក គឺជាក្រុមចៅក្រមចំនួន ១៥ នាក់ ដែលត្រូវបានជ្រើសរើសសម្រាប់អាណត្តិរយៈពេលប្រាំបួនឆ្នាំ (ចៅក្រមថ្មីប្រាំនាក់ រៀងរាល់បីឆ្នាំ) ដោយសម្លេងភាគច្រើននៃក្រុមប្រឹក្សាសន្តិសុខ និងមហាសន្និបាត។ តុលាការបើសវនាការប្រជុំ នៅទីក្រុងឡាអេ ប្រទេសហូឡង់។ វាជាទម្លាប់សម្រាប់សមាជិកអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាសន្តិសុខ ត្រូវមានសញ្ជាតិរបស់ពួកគេម្នាក់ធ្វើជាចៅក្រម គ្រប់ពេលវេលា បើទោះនេះ

ជាទម្លាប់ ហើយមិនមែនជាច្បាប់ផ្លូវការក្តី។ ចៅក្រមចំពោះកិច្ច(ad-hoc) អាចត្រូវបានបន្ថែម ទៅក្នុងចំណោមចៅក្រម១៥រូបស្រាប់ ប្រសិនបើភាគីនៃសំណុំរឿងមួយមិនទាន់មានសញ្ជាតិរបស់ខ្លួនជាចៅក្រម។

ភាពទន់ខ្សោយដ៏ធំនៃតុលាការពិភពលោក គឺថា រដ្ឋនានាមិនបានយល់ព្រមក្នុងនីតិវិធីដ៏ទូលំទូលាយមួយ ដើម្បីដាក់ខ្លួនពួកគេទៅក្រោមយុត្តាធិការរបស់តុលាការ ឬគោរពតាមសេចក្តីសម្រេចរបស់តុលាការ។ រដ្ឋស្ទើរតែទាំងអស់បានចុះហត្ថលេខាលើសន្ធិសញ្ញាបង្កើតតុលាការ ប៉ុន្តែ មានតែរដ្ឋប្រហែល មួយភាគបី ប៉ុណ្ណោះដែលបានចុះហត្ថលេខាលើ*ប្រយោគជម្រើស*(optional clause) ក្នុងសន្ធិសញ្ញាដែលយល់ព្រមផ្តល់យុត្តាធិការដល់តុលាការនៅក្នុងករណីមួយចំនួន ហើយសូម្បីតែប្រទេសហត្ថលេខីជាច្រើន បានដាក់បន្ថែមលក្ខខណ្ឌផ្ទាល់ខ្លួនរបស់ពួកគេ ដោយរក្សាសិទ្ធិនិងកំណត់កម្រិត ដែលតុលាការអាចរំលោភលើអធិបតេយ្យភាពជាតិរបស់ពួកគេ។ ប្រទេសកូឡុំប៊ីបានដកខ្លួនចេញ នៅក្នុងឆ្នាំ ២០១២ បន្ទាប់ពីតុលាការបានសម្រេចប្រគល់ទឹកដីជម្លោះទៅអោយប្រទេសនីការ៉ាហ្គា។ ដូចគ្នានេះដែរ ប្រទេសអ៊ីរ៉ង់បានបដិសេធមិនទទួលស្គាល់យុត្តាធិការរបស់តុលាការ នៅពេលដែលត្រូវបានប្តឹងដោយសហរដ្ឋអាមេរិក ក្នុងឆ្នាំ ១៩៧៩ ជុំវិញការរឹបអូសស្ថានទូតអាមេរិកនៅក្នុងប្រទេសអ៊ីរ៉ង់។ ក្នុងករណីបែបនេះ តុលាការអាចបើកសវនាការលើករណីនេះ ហើយជាធម្មតា ធ្វើសេចក្តីសម្រេចតាមទឡ្ហីករណ៍របស់ភាគីដែលចូលរួម ប៉ុន្តែ វាមិនមានមធ្យោបាយដើម្បីអនុវត្តសេចក្តីសម្រេចនោះទេ។ យុត្តិធម៌ក៏អាចដំណើរការយឺតៗដែរ។ ក្នុងឆ្នាំ ២០០៧ តុលាការបានចេញសេចក្តីសម្រេចប្រឆាំងនឹងករណីបណ្តឹងរបស់បូស្នៀ ដោយចោទប្រកាន់ប្រទេសស៊ែប៊ីអំពីអំពើប្រល័យពូជសាសន៍ បន្ទាប់ពី ១៤ ឆ្នាំ នៃការធ្វើសាវនាការបឋម។


នៅក្នុងជោគជ័យដ៏គួរអោយកត់សម្គាល់បំផុតមួយ តុលាការពិភពលោក ក្នុងឆ្នាំ ១៩៩២ បានដោះស្រាយជម្លោះព្រំដែនដ៏ស្មុគស្មាញមួយ រវាងប្រទេសអែល សាល់វ៉ាឌ័រ និងប្រទេស ហុងឌុយរ៉ាស់ ដែលផ្ទុះឡើងតាំងពីឆ្នាំ ១៨៦១។ ក្នុងឆ្នាំ ២០០២ តុលាការពិភពលោកបានដោះស្រាយជម្លោះដ៏ពុំរ៉ៃនិងដ៏ហិង្សាពេលខ្លះ លើឧបទ្វីបដែលសម្បូរដោយប្រេង នៅព្រំដែនប្រទេសកាមេរូន-នីហ្សេរីយ៉ា។ តុលាការបានប្រគល់កម្មសិទ្ធិភាពដល់ប្រទេសកាមេរូន ចំណែកប្រទេសនីហ្សេរីយ៉ា (ទោះខ្លាំងជាង) បានដកទ័ពចេញ នៅឆ្នាំ ២០០៦។

ការប្រើប្រាស់ដ៏សំខាន់នៃតុលាការពិភពលោក នាពេលនេះ គឺដើម្បីដោះស្រាយបញ្ហាដែលមានសារៈសំខាន់បន្ទាប់បន្សំរវាងប្រទេសដែលមានទំនាក់ទំនងជាមិត្ត ជាទូទៅ។ សហរដ្ឋអាមេរិកបានដោះស្រាយជម្លោះពាណិជ្ជកម្មជាមួយកាណាដា និងជាមួយអ៊ីតាលី តាមរយៈតុលាការនេះ។ ដោយសារផលប្រយោជន៍សន្តិសុខមិនជាប់ពាក់ព័ន្ធ ហើយដោយសារតែទំនាក់ទំនងមិត្តភាពជារួមមានសារៈសំខាន់ជាងបញ្ហាជាក់លាក់ រដ្ឋទាំងនោះមានឆន្ទៈក្នុងការដាក់ខ្លួនក្រោមយុត្តាធិការរបស់តុលាការ។ ក្នុងឆ្នាំ ២០០៤ តុលាការពិភពលោកបានបញ្ជាអោយសហរដ្ឋអាមេរិក ពិនិត្យឡើងវិញនូវការកាត់ទោសប្រហារជីវិតរបស់ជនជាតិម៉ិកស៊ិក ដើម្បីពិនិត្យមើលថា តើការដែលពួកគេមានកង្វះខាតប្រើប្រាស់មន្ត្រីម៉ិកស៊ិកបានធ្វើអោយប៉ះពាល់ដល់សំណុំរឿងផ្លូវច្បាប់របស់ពួកគេឬយ៉ាងណា។ នៅក្រោមអនុសញ្ញាទីក្រុងវីយែន ឆ្នាំ១៩៦៣ ស្តីពីទំនាក់ទំនងកុងស៊ុលប្រជាពលរដ្ឋដែលត្រូវបានចាប់ខ្លួន នៅបរទេសត្រូវតែត្រូវបានណែនាំអំពីសិទ្ធិរបស់ពួកគេ ក្នុងការជួបជាមួយអ្នកតំណាងនៃប្រទេសកំណើតរបស់ពួកគេ។ ជារឿយៗ សហរដ្ឋអាមេរិកបានបរាជ័យក្នុងការធ្វើដូច្នេះ ទោះបីជាខ្លួនបានទាមទារសិទ្ធិបែបនេះសម្រាប់ជនជាតិអាមេរិកនៅបរទេសក៏ដោយ។ តុលាការពិភពលោកបានស្នើ

អោយតុលាការសហរដ្ឋអាមេរិកបន្ថែមភាសាពាក់ព័ន្ធ ទៅក្នុងសេចក្តីព្រមានMiranda សម្រាប់ករណីនៅពេលដែលប៉ូលីសចាប់ខ្លួនជនបរទេស។ រូបភាព ៧.៤ បង្ហាញពីករណីមួយ ក្នុងចំណោមករណីថ្មីៗ របស់តុលាការដែលជាជម្លោះរវាងប្រទេសអាហ្សង់ទីន និងអ៊ុយរូហ្គាយ។

ក្រាហ្វិក ៧.៤ ករណីតុលាការពិភពលោកនៃអាហ្សង់ទីន ទល់និង អ៊ុយរូហ្គាយ

ប្រភព៖ ផ្អែកលើតុលាការយុត្តិធម៌អន្តរជាតិ។



ដោយសារតែការលំបាកក្នុងការឈ្នះកិច្ចព្រមព្រៀងដែលអាចអនុវត្តបានលើជម្លោះធំ ៗ តាមរយៈតុលាការពិភពលោក រដ្ឋនានាបានប្រើប្រាស់តុលាការ កាន់តែតិចទៅៗ ក្នុងរយៈពេលជាច្រើនឆ្នាំចុងក្រោយនេះ មានបួនដប់ករណីឬតិចជាងនេះ ក្នុងមួយឆ្នាំ (ប្រហែល ១៥០ សាលក្រម និងមតិយោបល់ ចាប់តាំងពីឆ្នាំ ១៩៤៧)។

៧.៣.៤. ករណីអន្តរជាតិនៅក្នុងតុលាការជាតិ

ករណីក្តីក្តាំច្បាប់ភាគច្រើនទាក់ទងនឹងបញ្ហាអន្តរជាតិ មិនថាធ្វើឡើងដោយរដ្ឋាភិបាលជាតិ ឬដោយបុគ្គល ឬក្រុមហ៊ុនឯកជន នៅតែស្ថិតក្នុងប្រព័ន្ធច្បាប់នៃរដ្ឋមួយឬច្រើន។ តុលាការជាតិបើកសវនាការកាត់ទោស តាមច្បាប់ជាតិ ហើយអាចអនុវត្តការវិនិច្ឆ័យ ដោយទាមទារសំណងការខូចខាត (ក្នុងករណីបណ្តឹងរដ្ឋប្បវេណី) ឬការដាក់ទណ្ឌកម្ម (ក្នុងករណីឧក្រិដ្ឋកម្ម)។

ភាគីនៃជម្លោះដែលឆ្លងកាត់ព្រំដែនជាតិច្រើន អាចទទួលបានអត្ថប្រយោជន៍ជាច្រើន ដោយការបន្តរឿងក្តីតាមរយៈតុលាការជាតិក្នុងរដ្ឋពាក់ព័ន្ធមួយឬច្រើន ជាជាងតាមរយៈយន្តការអន្តរជាតិ។ ហេតុផលទីមួយ ការវិនិច្ឆ័យទោសអាចអនុវត្តបាន។ ភាគីដែលឈ្នះបណ្តឹងនៅក្នុងតុលាការជាតិ អាចទាមទារសំណងពីទ្រព្យសម្បត្តិរបស់ភាគីម្ខាងទៀត នៅក្នុងរដ្ឋនោះផ្ទាល់។ ទីពីរ បុគ្គល និងក្រុមហ៊ុនអាចបន្តបណ្តឹងផ្លូវច្បាប់តាមរយៈតុលាការជាតិ (ដូចដែលស្ថាប័នរដ្ឋាភិបាលថ្នាក់ក្រោមជាតិអាចធ្វើបានដែរ) ខណៈពេលនៅក្នុងទិដ្ឋភាពភាគច្រើននៃច្បាប់អន្តរជាតិ រដ្ឋត្រូវតែប្តឹងតវ៉ាជំនួសប្រជាពលរដ្ឋរបស់ពួកគេ។ (តាមពិតទៅ សូម្បីតែរដ្ឋាភិបាលជាតិក៏នៅតែបន្តសកម្មភាពផ្លូវច្បាប់របស់ពួកគេប្រឆាំងនឹងគ្នាទៅវិញទៅមក តាមរយៈតុលាការជាតិ។

ទីបី ជាញឹកញាប់ តែងមានជម្រើសក្នុងចំណោមរដ្ឋច្រើនជាងមួយ ដែលករណីបណ្តឹងមួយអាចត្រូវបានគេទទួលកាត់ក្តីដោយស្របច្បាប់ ដើមបណ្តឹងអាចនឹងជ្រើសរើសប្រព័ន្ធច្បាប់ ដែលអំណោយផលបំផុតចំពោះករណីរបស់គេ។ ប្រព័ន្ធតុលាការរបស់រដ្ឋនីមួយៗត្រូវតែសម្រេចថាតើវាមាន *យុត្តាធិការ* (jurisdiction) លើរឿងក្តីមួយ (សិទ្ធិរបស់តុលាការក្នុងការកាត់ក្តី) ហើយតុលាការមានទំនោរពង្រីកសិទ្ធិអំណាចរបស់ពួកគេជាមួយនឹងការបកស្រាយយ៉ាងទូលំទូលាយ។ ជាប្រពៃណី តុលាការជាតិអាចបើកសវនាការលើករណីពាក់ព័ន្ធនឹងសកម្មភាពណាមួយនៅលើទឹកដីជាតិរបស់ខ្លួន សកម្មភាពទាំងឡាយរបស់ពលរដ្ឋខ្លួននៅកន្លែងណាមួយនៅលើពិភពលោក និងទង្វើទាំងឡាយចំពោះពលរដ្ឋខ្លួន នៅទីកន្លែងផ្សេង លើពិភពលោក។ បុគ្គលមិនមែនជាពលរដ្ឋក៏អាចប្រើប្រាស់តុលាការជាតិដើម្បីអាចដាក់ពាក្យបណ្តឹងប្រឆាំងនឹងប្រជាពលរដ្ឋបានដែរ ពីព្រោះតុលាការជាតិមានសិទ្ធិអំណាចក្នុងការផាកពិន័យ ហើយប្រសិនបើចាំបាច់ អាចរឹបអូសគណនីធនាគារ និងទ្រព្យសម្បត្តិ។

សហរដ្ឋអាមេរិក គឺជាប្រព័ន្ធយុត្តាធិការជាទីពេញនិយម សម្រាប់គេដាក់ពាក្យបណ្តឹង ដោយសារហេតុផលសំខាន់ៗចំនួនពីរ។ ទីមួយ គណៈវិនិច្ឆ័យរបស់តុលាការសហរដ្ឋអាមេរិកល្បីខាងផ្តល់សំណងខ្ពស់នៅក្នុងពាក្យបណ្តឹង ជាងគណៈវិនិច្ឆ័យរបស់តុលាការ នៅកន្លែងផ្សេងទៀតនៅក្នុងពិភពលោក (ប្រហែលដោយសារតែសហរដ្ឋអាមេរិកគឺជាប្រទេសអ្នកមាន)។ ទីពីរ ដោយសារបុគ្គលនិងរដ្ឋាភិបាលជាច្រើនធ្វើអាជីវកម្មនៅសហរដ្ឋអាមេរិក ជារឿយៗ ពួកគេអាចដាក់ពាក្យបណ្តឹងទាមទារសំណងការខូចខាតដែលសម្រេចផ្តល់ដោយតុលាការសហរដ្ឋអាមេរិក។ ដោយសារហេតុផលទាំងនេះហើយ ទើបតុលាការសហរដ្ឋអាមេរិកក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ បានកាត់ក្តីលើករណីសិទ្ធិមនុស្ស ដែលដាក់ពាក្យបណ្តឹងដោយក្រុមអ្នកប្រឆាំងជនជាតិ

ចិនជុំវិញការសម្លាប់រង្គាល នៅទីលានជានអានមេន កាលពីឆ្នាំ១៩៨៩, ជននិរទេសខ្លួនគុយបាប្រឆាំងនឹងរដ្ឋាភិបាលគុយបា, និងបណ្តឹងរបស់វេជ្ជបណ្ឌិតប៉ារ៉ាហ្គាយចំពោះមន្ត្រីប៉ូលីសប៉ារ៉ាហ្គាយពីបទធ្វើទារុណកម្មកូនប្រុសរបស់វេជ្ជបណ្ឌិត។ ក្នុងឆ្នាំ ២០០៣ តុលាការសហរដ្ឋអាមេរិកបានបញ្ជាប្រាក់សំណងយ៉ាងច្រើនពីប្រទេសអ៊ីរ៉ាក់និងអ៊ីរ៉ង់ ដល់ជនជាតិអាមេរិកដែលរងគ្រោះដោយអំពើភេរវកម្មនិងការធ្វើទារុណកម្ម។ ច្បាប់ស្តីពីទារុណកម្មជនបរទេសឆ្នាំ ១៧៨៩ ផ្តល់យុត្តាធិការដល់តុលាការសហព័ន្ធដើម្បីចាត់ការលើពាក្យបណ្តឹងរដ្ឋប្បវេណីប្រឆាំងនឹងជនបរទេសពីបទ«រំលោភលើច្បាប់របស់ប្រទេស»។ សកម្មជនសិទ្ធិមនុស្សនានាបានប្រើប្រាស់ច្បាប់ប្រឆាំងនឹងរដ្ឋាភិបាលដែលគាបសង្កត់ ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ដូចជា នៅពេលដែលពួកគេបានប្តឹងក្រុមហ៊ុនប្រេងរបស់សហរដ្ឋអាមេរិក ExxonMobil និង ក្រុមហ៊ុន Unocal ពីបទជួយដល់របបរំលោភបំពាននៅក្នុងប្រទេសឥណ្ឌូនេស៊ី និងប្រទេសភូមា រៀងៗខ្លួន។ ប៉ុន្តែ នៅក្នុងឆ្នាំ ២០១៣ តុលាការកំពូលរបស់សហរដ្ឋអាមេរិកបានកំណត់ព្រំដែននៃយុត្តាធិការផ្លូវច្បាប់របស់សហរដ្ឋអាមេរិក ដោយបានច្រានចោលសំណុំរឿងក្តីប្រឆាំងនឹងក្រុមហ៊ុនហូឡង់មួយឈ្មោះ Shell ដែលត្រូវបានចោទថាបានសម្របសម្រួលអំពើឃោរឃៅរបស់រដ្ឋាភិបាលនៅក្នុងប្រទេសនីហ្សេរីយ៉ា។

តុលាការជាតិនៃប្រទេសបែលហ្ស៊ិក គឺជាកន្លែងពេញនិយមសម្រាប់សំណុំរឿងសិទ្ធិមនុស្សអន្តរជាតិដោយសារច្បាប់ឆ្នាំ ១៩៩៣ ផ្តល់អោយពួកគេនូវយុត្តាធិការលើការរំលោភណាមួយ លើអនុសញ្ញាទីក្រុងហ្សឺណែវ។ នៅក្នុងឆ្នាំ ២០០១ មនុស្សចំនួន ៤ នាក់ ដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មសង្គ្រាមនៅក្នុងប្រទេស រ៉ាន់ដា ក្នុងឆ្នាំ ១៩៩៤ ត្រូវបានបញ្ជូនទៅពន្ធនាគារ ដោយគណៈវិនិច្ឆ័យបែលហ្ស៊ិក។ (ប្រទេសរ៉ាន់ដាគឺជាអតីតអាណានិគមបែលហ្ស៊ិក ហើយទាហានបែលហ្ស៊ិកចំនួន ១០ នាក់ ត្រូវបានសម្លាប់នៅក្នុងការប្រល័យពូជសាសន៍នៅទីនោះ។) នៅឆ្នាំ ២០០៥ បែលហ្ស៊ិកបានចោទប្រកាន់អតីតមេដឹកនាំប្រទេសឆាដ (Chad) ដោយចោទប្រកាន់ពីបទឃាតកម្មនយោបាយ ចំនួន ៤០០០០ នាក់ នៅប្រទេសឆាដ ក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ ហើយប្រទេសសេណេហ្គាល់ (ជាទីកន្លែងដែលមេដឹកនាំនោះរស់នៅ) បានសួរសេហភាពអាហ្វ្រិកសម្រេចក្តីថាតើសេណេហ្គាល់គួរតែធ្វើបត្យាប័នគាត់ដែរឬទេ។ សហភាពអាហ្វ្រិកបានលើកទឹកចិត្តប្រទេសសេណេហ្គាល់អោយកាត់ទោសគាត់នៅក្នុងប្រទេសជំនួសវិញ។

ទោះយ៉ាងណាក៏ដោយ មានព្រំដែនកំណត់ចំពោះការប្រើប្រាស់តុលាការជាតិ ដើម្បីដោះស្រាយវិវាទអន្តរជាតិ។ ដែនកំណត់ដ៏សំខាន់បំផុតគឺ សិទ្ធិអំណាចរបស់តុលាការជាតិបញ្ឈប់ត្រឹមព្រំដែនរបស់រដ្ឋ ដែលអធិបតេយ្យភាពត្រូវបញ្ចប់។ តុលាការមួយនៅប្រទេសហ្សាំបៀ (Zambia) មិនអាចបង្ខំជនជាតិថៃម្នាក់អោយមកផ្តល់សក្ខីកម្មបានទេ, វាមិនអាចអនុញ្ញាតអោយមានការរឹបអូសគណនីធនាគារអង់គ្លេសដើម្បីផ្តល់សំណងខូចខាតបានទេ ហើយវាក៏មិនអាចចាប់ខ្លួនជនសង្ស័យឧក្រិដ្ឋជន (ទោះជាជនជាតិហ្សាំបៀ ឬជាជនបរទេស) លើកលែងតែ នៅលើទឹកដីហ្សាំបៀ។ ដើម្បីធ្វើសកម្មភាពហួសពីរង្វង់ព្រំដែនជាតិ រដ្ឋត្រូវបញ្ចុះបញ្ចូលរដ្ឋផ្សេងទៀតអោយសហការជាមួយ។ ក្នុងឆ្នាំ ២០១២ មូលនិធិការពារហានិភ័យនៃសហរដ្ឋអាមេរិកដែលបានខាតបង់ប្រាក់ចំនួន៣៧០លានដុល្លារ ក្នុងបំណុលក្ស័យធនឆ្នាំ២០០២របស់ប្រទេសអាហ្សង់ទីនបានបញ្ចុះបញ្ចូលប្រទេសហ្គាណាអោយរឹបអូសយកកប៉ាល់អាហ្សង់ទីន ដែលមកទស្សនាដើម្បីសងបំណុល ប៉ុន្តែ ប្រទេសហ្គាណាបានដោះលែងកប៉ាល់នេះ បន្ទាប់ពីមានសេចក្តីសម្រេចមួយដោយតុលាការសាគររបស់អង្គការសហប្រជាជាតិ។

ដើម្បីនាំបុគ្គលម្នាក់នៅក្រៅទឹកដីរបស់រដ្ឋមួយមកកាត់ទោស រដ្ឋាភិបាលរបស់រដ្ឋនោះត្រូវតែស្នើអោយរដ្ឋាភិបាលទីពីរចាប់ខ្លួនបុគ្គលនោះនៅលើទឹកដីនៃរដ្ឋទីពីរ ហើយប្រគល់គាត់ទៅកាត់ទោស។ វិធីបែបនេះហៅថា *ការធ្វើបត្យាប័ន*(extradition) គឺជាបញ្ហានៃច្បាប់អន្តរជាតិ ព្រោះវាគឺជាការរៀបចំសន្ធិសញ្ញាផ្លូវច្បាប់រវាងរដ្ឋនិងរដ្ឋ។ សន្ធិសញ្ញាបែបនេះមានចំនួនរាប់រយ សន្ធិសញ្ញាខ្លះមានអាយុកាលរាប់រយឆ្នាំមកហើយ។ ប្រសិនបើមិនមានសន្ធិសញ្ញាបែបនេះទេ បុគ្គលនោះ ជាទូទៅ នៅតែអាចញែចខ្លួនពីតុលាការរបស់រដ្ឋដោយស្នាក់នៅក្រៅទឹកដីរបស់រដ្ឋនោះ។ ជាឧទាហរណ៍ ប្រទេសរុស្ស៊ីបានប្រកាសថា ខ្លួននឹងមិនធ្វើបត្យាប័នហែកយ៉ែរជនជាតិអាមេរិក ឈ្មោះ អេឌវឺដ ស្នូឌិន (Edward Snowden) ទេ ផ្ទុយទៅវិញ ថែមទាំងបានផ្តល់សិទ្ធិជ្រកកោននយោបាយដល់គាត់ ក្នុងឆ្នាំ ២០១៣។

សម្ព័ន្ធមិត្តអាមេរិកមួយចំនួន ជាធម្មតា មិនធ្វើបត្យាប័នទៅអោយសហរដ្ឋអាមេរិកនូវជន សង្ស័យទាំងឡាយណា ដែលនឹងត្រូវប្រឈមមុខនឹងការកាត់ទោសប្រហារជីវិតនោះទេ។ ជាឧទាហរណ៍ ក្នុងឆ្នាំ ២០១២ តុលាការយុត្តិធម៌អ៊ឺរ៉ុប (សូមមើលមេរៀនទី ១០) បានអនុញ្ញាតអោយចក្រភពអង់គ្លេសធ្វើបត្យាប័នបុព្វជិតមូស្លីមម្នាក់ ដែលត្រូវសង្ស័យថាបានធ្វើសកម្មភាពភេរវកម្ម ទៅកាន់សហរដ្ឋអាមេរិក បន្ទាប់ពីសវនាការផ្លូវច្បាប់ អស់រយៈពេលជិតដប់ឆ្នាំហើយ។ តុលាការអឺរ៉ុបបានបារម្ភថាជនសង្ស័យនោះនឹងមិនទទួល ការរៀបចំល្អនៅក្នុងប្រព័ន្ធពន្ធនាគាររបស់សហរដ្ឋអាមេរិក ម្លោះហើយទើបពន្យារពេលធ្វើបត្យាប័ន គេអស់រយៈពេលជិតមួយទសវត្សរ៍។ ទោះយ៉ាងណាក៏ដោយ សង្គ្រាមប្រឆាំងភេរវកម្ម ចាប់តាំងពីឆ្នាំ២០០១ បានពង្រីកកិច្ចសហប្រតិបត្តិការផ្នែកច្បាប់ និងការអនុវត្តច្បាប់អន្តរជាតិ។

នៅក្នុងការជជែកដេញដោលដ៏ល្បីមួយ អំពីការធ្វើបត្យាប័ន អតីតមេដឹកនាំផ្តាច់ការយោធាឈីលី អូហ្គូស្តូ ពីណូចិត (Augusto Pinochet) ត្រូវបានចាប់ខ្លួន នៅក្នុងប្រទេសអង់គ្លេស ក្នុងឆ្នាំ ១៩៩៩ តាមដីការបស់អេស្ប៉ាញ ដោយផ្អែកលើឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តលើពលរដ្ឋអេស្ប៉ាញ នៅក្នុងប្រទេសឈីលីក្នុងអំឡុងពេលគ្រប់គ្រងរបស់ ពីណូចិត។អ្នកគាំទ្ររបស់គាត់បានអះអាងថា គាត់គួរតែមានអភ័យឯកសិទ្ធិចំពោះទង្វើដែលធ្វើឡើងក្នុងនាមជាប្រមុខរដ្ឋ ប៉ុន្តែ ដោយសារតែគាត់មិនមែនជាអ្នកការទូតត្រូវទទួលស្គាល់នៅក្នុងប្រទេសអង់គ្លេស (ទីកន្លែងដែលគាត់បានទៅព្យាបាល) និងមិនមែនជាប្រមុខរដ្ឋទៀតទេ តុលាការអង់គ្លេសបានឃាត់ខ្លួនគាត់តាមសំណើរបស់ប្រទេសអេស្ប៉ាញ ដើម្បីធ្វើបត្យាប័នគាត់។ ទោះជាយ៉ាងណាក៏ដោយ នៅទីបំផុត រដ្ឋាភិបាលអង់គ្លេសបានអនុញ្ញាតអោយគាត់ត្រឡប់ទៅប្រទេសឈីលីវិញ ដោយលើកឡើងពីស្ថានភាពសុខភាពរបស់គាត់ ហើយតុលាការឈីលីបានព្យួរសំណុំរឿងរបស់គាត់ ដោយសំអាងលើហេតុផលសុខភាព។ គាត់បានស្លាប់ នៅឆ្នាំ ២០០៦ ដោយគ្មានការកាត់ទោស។

យុត្តាធិការរបស់តុលាការជាតិទៅលើជនបរទេសក៏មានតំបន់ប្រផេះផងដែរ។ ប្រសិនបើរដ្ឋាភិបាលអាចទាក់ទាញជនសង្ស័យទៅផ្នែសមុទ្រជ្រៅនោះ វាអាចចាប់ជននោះដោយមិនបំពានលើទឹកដីរបស់ប្រទេសផ្សេងទៀតឡើយ។ បញ្ហាកាន់តែធ្ងន់ធ្ងរជាងនេះ គឺករណីដែលរដ្ឋាភិបាលមួយចាប់ខ្លួនពលរដ្ឋបរទេសម្នាក់ ពីប្រទេសក្រៅមកកាត់ទោស ដោយមិននីតិវិធីធ្វើបត្យាប័ន។ នៅក្នុងករណីដ៏ល្បីមួយ ក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ វេជ្ជបណ្ឌិតជនជាតិមុិកស៊ិកម្នាក់ត្រូវបានអាជ្ញាធរអាមេរិកចាប់ខ្លួនពីបទចូលរួមក្នុងការធ្វើទារុណកម្ម និងឃាតកម្មលើភ្នាក់ងារប្រឆាំងគ្រឿងញៀនរបស់សហរដ្ឋអាមេរិកម្នាក់ នៅក្នុងប្រទេសមុិកស៊ិក។ រដ្ឋាភិបាលសហរដ្ឋអាមេរិកបានផ្តល់ប្រាក់អោយក្រុមអ្នកប្រមាញ់ប្រាក់រង្វាន់មួយក្រុម ដើម្បីចាប់ពង្រត់វេជ្ជបណ្ឌិតនោះពី

ប្រទេសម៉ិកស៊ិក, ចាប់គាត់ដោយបង្ខំឆ្លងកាត់ព្រំដែន ហើយបញ្ជូនគាត់ទៅមន្ទីរឃុំឃាំងរបស់តុលាការសហរដ្ឋអាមេរិក។ តុលាការកំពូលរបស់សហរដ្ឋអាមេរិកបានផ្តល់យុត្តាធិការដល់តុលាការរបស់សហរដ្ឋអាមេរិកលើសំណុំរឿងនេះ ដែលបង្ហាញពីទំនោរក្នុងការពង្រីកអធិបតេយ្យភាពរបស់រដ្ឋទៅទីកន្លែងណា ដែលអាចធ្វើទៅបាន ទោះបីជាមេធាវីអន្តរជាតិ និងមន្ត្រីម៉ិកស៊ិក បានជំទាស់តវ៉ាយ៉ាងខ្លាំងក្លាក៏ដោយ។ រដ្ឋាភិបាលអាមេរិកត្រូវធានាដល់រដ្ឋាភិបាលម៉ិកស៊ិកថា ខ្លួននឹងមិនចាប់ពង្រត់ពលរដ្ឋម៉ិកស៊ិកទៅកាត់ទោសនៅសហរដ្ឋអាមេរិកនៅពេលអនាគត។ វេជ្ជបណ្ឌិតនោះបានត្រឡប់ទៅផ្ទះវិញ បន្ទាប់ពីករណីនេះត្រូវបានគេទាត់ចោលដោយសារកង្វះភស្តុតាង។ ប្រហែលគ្នានេះដែរ នៅចុងឆ្នាំ២០០៤ ប្រទេសកូឡុំប៊ីបានរៀបចំការចាប់ពង្រត់ពួកឧទ្ទាមកូឡុំប៊ីល្បីល្បាញដែលរស់នៅក្នុងប្រទេសវេណេហ្ស៊ុយអេឡា ដែលបង្កអោយមានការតវ៉ាពីវេណេហ្ស៊ុយអេឡាអំពីការរំលោភលើអធិបតេយ្យភាព។

គោលការណ៍នៃទឹកដីក៏គ្រប់គ្រងលើច្បាប់អន្តោប្រវេសន៍ផងដែរ។ នៅពេលដែលមនុស្សធ្វើដំណើរឆ្លងកាត់ព្រំដែនចូលទៅក្នុងប្រទេសថ្មីមួយទៀត ការសម្រេចចិត្តថាតើពួកគេអាចបន្តនៅទីនោះ ហើយរស់នៅក្រោមលក្ខខណ្ឌបែបណា ត្រូវអាស្រ័យលើរដ្ឋថ្មី។ រដ្ឋកំណើតមិនអាចបង្ខំអោយពួកគេត្រឡប់មកវិញបានទេ។ ច្បាប់ជាតិបង្កើតលក្ខខណ្ឌសម្រាប់ជនបរទេសក្នុងការធ្វើដំណើរ និងទៅទស្សនា នៅលើទឹកដីរបស់រដ្ឋ ឬធ្វើការនៅទីនោះ ហើយជួនកាល អាចក្លាយជាពលរដ្ឋ (naturalization-ចូលសញ្ជាតិ)។ បញ្ហាផ្លូវច្បាប់ជាច្រើនទៀតត្រូវ បានលើកឡើងដោយអ្នកធ្វើដំណើរ ឬអ្នករស់នៅក្រៅប្រទេសដើមកំណើតរបស់ខ្លួន ដូចជាលិខិតឆ្លងដែន និងទិដ្ឋាការ ទារកកើតក្នុងប្រទេសក្រៅ អាពាហ៍ពិពាហ៍ជាមួយជនបរទេស គណនីធនាគារ អាជីវកម្ម និងពន្ធដារ។ ការអនុវត្តជាក់ស្តែងអាចខុសគ្នា ពីប្រទេសមួយទៅប្រទេសមួយទៀត ប៉ុន្តែគោលការណ៍ទូទៅគឺថាច្បាប់ជាតិមានអាទិភាពនៅលើទឹកដីប្រទេសជាតិនៃរដ្ឋមួយនោះ។

ទោះបីជាមានសារៈសំខាន់ជាបន្តនៃប្រព័ន្ធតុលាការជាតិក្នុងកិច្ចការច្បាប់អន្តរជាតិ និងកង្វះអំណាចដើម្បីពង្រឹងការអនុវត្តរបស់តុលាការពិភពលោកក៏ដោយ វាអាចជាការយល់ខុសដែលសន្និដ្ឋានថា អធិបតេយ្យភាពរបស់រដ្ឋស្ថិតនៅលើកំពូល និងច្បាប់អន្តរជាតិគឺគ្មានអំណាច។ ផ្ទុយទៅវិញ តុល្យភាពនៃអធិបតេយ្យភាពនិងច្បាប់មាននៅក្នុងអន្តរកម្មអន្តរជាតិ។

៧.៤. ច្បាប់ និងអធិបតេយ្យភាព

៧.៤ ចូរសង្ខេបលក្ខណៈខុសគ្នារវាង«យុត្តិសង្គ្រាម»និងសង្គ្រាមឈ្លានពាន។

ផ្នែកដែលនៅសេសសល់នៃមេរៀននេះនឹងពិភាក្សាអំពីវិស័យជាក់លាក់នៃច្បាប់អន្តរជាតិ ចាប់ផ្តើមពីវិស័យដែលចាក់ឫសគល់យ៉ាងរឹងមាំបំផុតនិងត្រូវបានគោរពយ៉ាងទូលំទូលាយ រហូតដល់វិស័យថ្មីៗនិងមិនសូវបានគេស្គាល់។ នៅក្នុងវិស័យនីមួយៗ ឥទ្ធិពលនៃច្បាប់និងបទដ្ឋានធ្វើដំណើរបញ្ច្រាសពីទិសដៅនៃការអនុវត្តអធិបតេយ្យភាពរបស់រដ្ឋ។ ការតស៊ូនេះកាន់តែតានតឹងខ្លាំងឡើង នៅពេលដែលវិស័យមួយបានបម្លាស់ទីឆ្ងាយពីប្រពៃណីនៃច្បាប់ការទូតជាយូរមកហើយ ឆ្ពោះទៅកាន់បទដ្ឋានថ្មីៗដែលគ្រប់គ្រងសិទ្ធិមនុស្ស។

៧.៤.១. ច្បាប់ការទូត

មូលដ្ឋានគ្រឹះនៃច្បាប់អន្តរជាតិ គឺការគោរពសិទ្ធិអ្នកការទូត។ ស្តង់ដារនៃអាកប្បកិរិយានៅក្នុងវិស័យនេះត្រូវបានសរសេរយ៉ាងលម្អិត អនុវត្តជាសកល និងប្រកាន់ខ្ជាប់យ៉ាងតឹងរឹង។ សមត្ថភាពក្នុងការធ្វើការទូតគឺចាំបាច់ណាស់សម្រាប់ទំនាក់ទំនងគ្រប់ប្រភេទ ក្នុងចំណោមរដ្ឋនានា លើកលែងតែមានសង្គ្រាមទាំងស្រុង។

ចាប់តាំងពីការលេចឡើងនៃប្រព័ន្ធអន្តរជាតិ កាលពីប្រាំសតវត្សរ៍មុន វាត្រូវបានចាត់ទុកថាជារឿងមិនសមហេតុផលក្នុងការបង្កគ្រោះថ្នាក់ដល់អ្នកតំណាងម្នាក់ដែលបញ្ជូនមកពីរដ្ឋមួយផ្សេងទៀត ដើម្បីជាមធ្យោបាយនៃឥទ្ធិពលគៀបសង្កត់លើរដ្ឋនោះ។ បទដ្ឋានបែបនេះមិនតែងតែកើតមាននោះទេ វាជារឿងធម្មតាទេកាលពីបុរាណដែលគេសម្លាប់អ្នកនាំសារដែលនាំមកនូវដំណឹងមិនល្អ ឬចាប់មន្ត្រីរបស់រដ្ឋផ្សេងធ្វើជាចំណាប់ខ្មាំង ឬថ្នូរក្នុងការចរចា។ ប៉ុន្តែ សព្វថ្ងៃនេះ អាកប្បកិរិយាបែបនេះត្រូវបានថ្កោលទោសជាសកល ទោះបីជាវានៅតែកើតឡើងម្តងម្កាលក៏ដោយ។

ហានៈរបស់ស្ថានទូតនិងឯកអគ្គរដ្ឋទូត ក្នុងនាមជាតំណាងផ្លូវការរបស់រដ្ឋ ត្រូវបានកំណត់យ៉ាងច្បាស់នៅក្នុងដំណើរការនៃ**ការទទួលស្គាល់ការទូត**(diplomatic recognition)។ អ្នកការទូតត្រូវបាន*ទទួលស្គាល់*(accredited) គ្នាទៅវិញទៅមក ដោយសមភាគីនៃរដ្ឋាភិបាលរបស់ពួកគេ (ពួកគេត្រូវបង្ហាញ«សារតាំង»(credentials) ហើយបន្ទាប់ពីនោះមក បុគ្គលនោះទទួលបានសិទ្ធិ និងការការពារជាក់លាក់ក្នុងនាមជាអ្នកការទូតបរទេស នៅក្នុងប្រទេសម្ចាស់ផ្ទះ។ អ្នកការទូតមានសិទ្ធិកាន់កាប់*ស្ថានទូត*នៅក្នុងប្រទេសម្ចាស់ផ្ទះដែលច្បាប់របស់ប្រទេសម្ចាស់ផ្ទះមិនអាចត្រូវបានអនុវត្ត ដោយគ្មានការយល់ព្រមពីប្រទេសរបស់ស្ថានទូតនោះទេ។ ដោយហេតុផលនេះហើយ ទើបស្ថានទូតនានា ម្តងម្កាល ផ្តល់ទីជម្រកដល់អ្នកប្រឆាំងដែលជ្រកកោននៅទីនោះ ដើម្បីគេចចេញពីរដ្ឋាភិបាលរបស់ខ្លួន។

ភាពមិនអាចរំលោភបាននៃស្ថានទូតត្រូវបានរំលោភយ៉ាងកំរោល នៅក្នុងប្រទេសអ៊ីរ៉ង់ បន្ទាប់ពីពួកបដិវត្តអ៊ីស្លាមជ្រុលនិយម បានឡើងកាន់អំណាចក្នុងឆ្នាំ ១៩៧៩។ និស្សិតអ៊ីរ៉ង់បានរឹបអូស និងកាន់កាប់បរិវេណស្ថានទូតសហរដ្ឋអាមេរិក ដោយចាប់អ្នកការទូតសហរដ្ឋអាមេរិកជាចំណាប់ខ្មាំង អស់រយៈពេលជាងមួយឆ្នាំ។ រដ្ឋាភិបាលអ៊ីរ៉ង់មិនបានប្រព្រឹត្តទង្វើនេះ ដោយផ្ទាល់ទេ ប៉ុន្តែ បានអត់ឱនចំពោះទង្វើនេះ ហើយបានបដិសេធមិនបង្ខំនិស្សិតរបស់ខ្លួនចេញពីស្ថានទូតអាមេរិកឡើយ។ (បើចាំបាច់ប្រទេសម្ចាស់ផ្ទះត្រូវប្រើកម្លាំងប្រឆាំងពលរដ្ឋខ្លួន ដើម្បីការពារស្ថានទូតបរទេស។)

អ្នកការទូតទទួលបាន**អភ័យឯកសិទ្ធិការទូត** (diplomactic immunity) សូម្បីតែនៅពេលដែលពួកគេចាកចេញពីមូលដ្ឋានស្ថានទូតក៏ដោយ។ សិទ្ធិក្នុងការធ្វើដំណើរខុសគ្នាពីប្រទេសមួយទៅប្រទេសមួយទៀត។ អ្នកការទូតអាចត្រូវបានដាក់កម្រិតនៅក្នុងរង្វង់ទីក្រុងមួយ ឬដើរហើរដោយសេរីនៅតាមទីជនបទ។ តែម្នាក់ឯងក្នុងចំណោមជនបរទេសទាំងអស់ អ្នកការទូតស្ថិតនៅក្រៅរង្វង់ការអនុវត្តច្បាប់របស់តុលាការជាតិនៃប្រទេសម្ចាស់ផ្ទះ។ ប្រសិនបើពួកគេប្រព្រឹត្តឧក្រិដ្ឋកម្ម រាប់ចាប់តាំងពីការបំពានលើផ្លូវសាធារណៈរហូតដល់ឃាតកម្ម ពួកគេអាចនឹងត្រូវបានការពារពីការចាប់ខ្លួន។ អ្វីដែលប្រទេសម្ចាស់ផ្ទះទាំងអស់អាចធ្វើបានគឺដកការទទួលស្គាល់អ្នកការទូត ហើយបណ្តេញបុគ្គលនោះចេញពីប្រទេសម្ចាស់ផ្ទះ។ ទោះយ៉ាងណាក៏ដោយ ប្រទេសខ្លាំង ជួនកាលដាក់សម្ពាធលើប្រទេសទន់ខ្សោយជាង អោយដកអភ័យឯកសិទ្ធិ ទើបអ្នកការទូតអាចប្រឈមមុខនឹងការកាត់ទោសពីបទឧក្រិដ្ឋ។ ជាឧទាហរណ៍ រឿងបែបនេះបានកើតឡើងចំនួនពីរដង ក្នុងឆ្នាំ ១៩៩៧ នៅពេលដែលសហរដ្ឋអាមេរិក និងប្រទេសបារាំងត្រូវបានអនុញ្ញាតអោយកាត់ទោសអ្នកការទូតមកពីប្រទេសហ្សកហ្ស៊ីនិងប្រទេសហ្សៃ(Zaire)រៀងៗខ្លួន ចំពោះការបើកបរមិនប្រុងប្រយ័ត្ន ដែលបង្កអោយកុមារមួយចំនួនស្លាប់។

ការប្តេជ្ញាចិត្តរបស់សហរដ្ឋអាមេរិកក្នុងនាមជាប្រទេសម្ចាស់ផ្ទះ ចំពោះអង្គការសហប្រជាជាតិ រួមមានការពង្រីកអភ័យឯកសិទ្ធិការទូតដល់មន្ត្រីការទូត ដែលត្រូវបានទទួលស្គាល់ ដោយអង្គការសហប្រជាជាតិ។ ជាមួយនឹងអភ័យឯកសិទ្ធិទាំងនេះ ជាឧទាហរណ៍ ប្រតិភូហែកសំបុត្របង់ប្រាក់ចំណតរាប់ពាន់សន្លឹក ក្នុងមួយឆ្នាំៗ។ គេបានប៉ាន់ប្រមាណថា ទីក្រុងញូវយ៉ក ជំពាក់ប្រាក់បង់ចំណត ចំនួន ១៦ លានដុល្លារ ដោយសារសំបុត្រដែលមិនបានបង់ប្រាក់។ បញ្ហាសំបុត្រចតរថយន្តបានក្លាយទៅជាបញ្ហានយោបាយដ៏រសើបមួយ ព្រោះឥឡូវនេះ ក្រសួងការបរទេសរក្សាសិទ្ធិក្នុងការដកហូតប័ណ្ណបើកបរ ផ្លាកលេខទូត និងរហូតដល់កាត់បន្ថយជំនួយបរទេស ដោយផ្អែកលើចំនួនសំបុត្រមិនបានបង់ប្រាក់។ នៅទីក្រុងឡុងដ៍ រថយន្តបីគ្រឿងដែលបើកបរដោយអ្នកការទូតស៊ូដង់ បានទទួលសំបុត្រចំណត ជាង ៨០០ សន្លឹក ដែលស្មើនឹងទឹកប្រាក់ពិន័យជាង ១០ ម៉ឺនដុល្លារអាមេរិក។

ដោយសារអភ័យឯកសិទ្ធិការទូត សកម្មភាពចារកម្មត្រូវបានធ្វើឡើង ជាទូទៅ តាមរយៈក្រុមការទូតចេញពីស្ថានទូតផ្ទាល់។ ជារឿយៗ សកម្មភាពចារកម្មតែងតែត្រូវបានផ្ទេរបញ្ជូនទៅកាន់មន្ត្រីតំណែងកម្រិតទាបនៅក្នុងស្ថានទូតនានា ដូចជា មន្ត្រីទំនាក់ទំនងវប្បធម៌ ទំនាក់ទំនងសារព័ត៌មាន ឬអនុព័ន្ធយោធា។ ប្រសិនបើប្រទេសម្ចាស់ផ្ទះចាប់ពួកគេធ្វើចារកម្ម គេមិនអាចចាប់ពួកគេកាត់ទោសបានទេ ដូច្នេះ គេគ្រាន់តែចាប់បណ្តេញពួកគេចេញពីប្រទេសតែប៉ុណ្ណោះ។ បទដ្ឋានការទូត (ទោះមិនមែនជាច្បាប់) អំពាវនាវអោយមានសុជីវធម៌នៅពេលបណ្តេញអ្នកស៊ើបការណ៍; ដោយសារហេតុផលស្តង់ដារដែលថា «សម្រាប់សកម្មភាពមិនស្របនឹងឋានៈការទូតរបស់គាត់»។ ប្រសិនបើចារកម្មប្រតិបត្តិការក្រោមការលាក់បាំង ដោយបន្លំធ្វើជាពាណិជ្ជករឬអ្នកទេសចរណ៍ នោះអភ័យឯកសិទ្ធិមិនត្រូវបានអនុវត្តន៍ទេ ជននោះអាចត្រូវបានចាប់ខ្លួន និងកាត់ទោសក្រោមច្បាប់របស់ប្រទេសម្ចាស់ផ្ទះ។ នេះជាករណីពិត ក្នុងឆ្នាំ ២០១០ នៅពេលដែលរដ្ឋាភិបាលសហរដ្ឋអាមេរិកបានចាប់ខ្លួនចារបុរសជនជាតិរុស្សី ១០ នាក់ ដែលកំពុងរស់នៅក្នុងនាមជាពលរដ្ឋសាមញ្ញនៅសហរដ្ឋអាមេរិក។ ទោះជាយ៉ាងណាក៏ដោយ មុនពេលបើកសវនាការកាត់ទោសអ្នកស៊ើបការណ៍ជាប់ចោទទាំងនោះនៅក្នុងតុលាការក្រុងញូវយ៉ក សហរដ្ឋអាមេរិកនិងរុស្សីបានយល់ព្រមផ្លាស់ប្តូរចារកម្មដែលត្រូវបានចោទប្រកាន់ រៀងៗខ្លួន។

កញ្ចប់ការទូត (diplomatic pouch) គឺជាកញ្ចប់ផ្ញើទៅមក រវាងស្ថានទូតនៅបរទេស និងប្រទេសកំណើតរបស់ខ្លួន។ ដូចដែលឈ្មោះវាបង្កប់ន័យ មុនដំបូងវាបានចាប់ផ្តើមជាប្រវត្តិសាស្ត្រ ត្រឹមជាការដឹកជញ្ជូនតិចតួចនិងម្តងម្កាល ប៉ុន្តែ បច្ចុប្បន្ននេះ ការដឹកជញ្ជូនបែបនេះក្នុងបរិមាណដ៏ធំនិងជាទៀងទាត់ធ្វើចរាចរណ៍ជុំវិញពិភពលោក។ កញ្ចប់ការទូតក៏ទទួលបានឋានៈដូចទឹកដីនៃប្រទេសកំណើតផងដែរ៖ ពួកវាមិនអាចត្រូវបើក ឆែកឆេរ ឬរឹបអូស ដោយប្រទេសម្ចាស់ផ្ទះបានទេ។ ទោះបីជាយើងមិនដឹងថា មានវត្ថុឬអំពើទុច្ចរិតប៉ុនណាបង្កប់នៅក្នុងកញ្ចប់ការទូតទាំងឡាយ (ព្រោះវាជារឿងសម្ងាត់) វាមានសុវត្ថិភាពក្នុងការសន្មត់ថាទំនិញខុសច្បាប់ ដូចជាកាំភ្លើងនិងគ្រឿងញៀន តែងតែរកឃើញច្រកឆ្លងកាត់ព្រំដែន ក្នុងផ្លូវការទូត។

ការផ្តាច់ទំនាក់ទំនងការទូត (break diplomatic relations) មានន័យថា ការដកអ្នកការទូតរបស់រដ្ឋពីរដ្ឋមួយ ហើយបណ្តេញអ្នកការទូតរបស់រដ្ឋនោះចេញពីរដ្ឋរបស់ខ្លួន។ យុទ្ធសាស្ត្រនេះត្រូវបានប្រើប្រាស់ដើម្បីបង្ហាញការមិនពេញចិត្តជាមួយនឹងរដ្ឋាភិបាលមួយផ្សេងទៀត វាជាការបដិសេធក្នុងការទំនាក់ទំនង តាមប្រក្រតី។ នៅពេលដែលរដ្ឋាភិបាលបដិវត្តឡើងកាន់អំណាច ប្រទេសមួយចំនួនអាចនឹងលុបចោលការទទួល

ស្គាល់។ ហើយនៅពេលដែលបណ្តារដ្ឋតូចៗទទួលស្គាល់កោះតៃវ៉ាន់ដោយផ្លូវទូត ប្រទេសចិននឹងដកការទទួលស្គាល់របស់ខ្លួនចំពោះរដ្ឋទាំងនោះ។

នៅពេលដែលប្រទេសពីរមិនមានទំនាក់ទំនងការទូតនឹងគ្នា ពួកគេតែងតែធ្វើជំនួញ តាមរយៈប្រទេសទីបី ដែលមានឆន្ទៈតំណាងអោយផលប្រយោជន៍របស់ប្រទេសណាមួយក្នុងចំណោមពីរនោះជាផ្លូវការ តាមរយៈស្ថានទូតរបស់ខ្លួន។ នេះត្រូវបានហៅថា *សង្កាត់ផលប្រយោជន៍* (interest section) នៅក្នុងស្ថានទូតនៃប្រទេសទីបី។ ដូច្នេះ តម្រូវការការទូតជាក់ស្តែងអាចជំនះលើកង្វះផ្លូវការទំនាក់ទំនងរវាងរដ្ឋនានា។ ជាឧទាហរណ៍ ក្នុងអំឡុងពេលមិនទទួលស្គាល់គ្នាដ៏យូរ ផលប្រយោជន៍របស់សហរដ្ឋអាមេរិកត្រូវបានតំណាងដោយស្ថានទូតស្វីសនៅប្រទេសគុយបា ហើយផលប្រយោជន៍គុយបាត្រូវបានតំណាងដោយស្ថានទូតស្វីសនៅសហរដ្ឋអាមេរិក។ នៅក្នុងការអនុវត្តជាក់ស្តែង សង្កាត់ផលប្រយោជន៍ទាំងនេះមានទីតាំង នៅអតីតស្ថានទូតអាមេរិកនិងគុយបារៀងៗខ្លួន ហើយក៏មានបុគ្គលិកជាមួយមន្ត្រីការទូតអាមេរិក និងគុយបាដែរ។

រូបថត ស្ថាបនិក យ៉ីលីក កំពុងជ្រកកោននៅក្នុងស្ថានទូតអេក្វាឌ័រ ក្នុងទីក្រុងឡុងដ៍

ចូលមិនដល់

ច្បាប់អន្តរជាតិហាមឃាត់ការវាយប្រហារលើអ្នកការទូតនិងស្ថានទូត។ គោលការណ៍ជាមូលដ្ឋាននេះដូចជាគោលការណ៍ដទៃទៀតនៅក្នុងច្បាប់អន្តរជាតិ ទីបំផុត ត្រូវអនុវត្តតាមរយៈការទទួលគ្នាទៅវិញទៅមក។ នៅពេលដែលស្ថាបនិកវីគីលីក (WikiLeaks) បានជ្រកកោននៅក្នុងស្ថានទូតអេក្វាឌ័រ ក្នុងទីក្រុងឡុងដ៍ ដើម្បីជៀសវាងការធ្វើបត្យាប័នទៅកាន់ប្រទេសស៊ុយអែត រដ្ឋាភិបាលអង់គ្លេសបានពិចារណាសម្រុកចូល និងចាប់ខ្លួនគាត់ ប៉ុន្តែគិតពិចារណាឡើងវិញ។ នៅនិទាឃរដូវឆ្នាំ ២០១៧ គាត់បានថ្លែងសុន្ទរកថាពីយ៉ារនៃស្ថានទូតដោយប្រកាសថាគាត់នឹងបន្តរស់នៅក្នុងស្ថានទូតដែលគាត់បានរស់នៅតាំងពីឆ្នាំ ២០១២ ។

ទំនាក់ទំនងការទូតក៏អាចជាប់ពាក់ព័ន្ធនឹងទណ្ឌកម្មផងដែរ។ ក្នុងឆ្នាំ ២០១៦ ជាចំណែកមួយនៃការដាក់ទណ្ឌកម្មប្រឆាំងនឹងរុស្ស៊ី ចំពោះការជ្រៀតជ្រែកក្នុងការបោះឆ្នោតប្រធានាធិបតីអាមេរិក ក្នុងឆ្នាំដដែកនោះ សហរដ្ឋអាមេរិកបានបិទបរិវេណការទូតចំនួនពីរ នៅក្នុងរដ្ឋម៉ារីឡែន (Maryland) និងញូវយ៉ក ។ រុស្ស៊ីបានឆ្លើយតបនឹងសកម្មភាពនេះភ្លាមៗ (និងសកម្មភាពពាក់ព័ន្ធនឹងទណ្ឌកម្មផ្សេងទៀត) ដោយបណ្តេញអ្នកការទូតអាមេរិកចំនួន ៧៥៥ នាក់ក្នុងឆ្នាំ ២០១៧។

រដ្ឋនានាបង្ហាញការមិនសូវពេញចិត្តរបស់ខ្លួន ដោយកោះ ហៅឯកអគ្គរដ្ឋទូតរបស់ពួកគេត្រឡប់ចូលក្នុងមាតុភូមិវិញ ក្នុងមួយរយៈពេលកំណត់ណាមួយ បទដ្ឋានការទូតអំពាវនាវអោយមានការធ្វើដំណើរចូលមាតុភូមិវិញ «សម្រាប់ការពិគ្រោះយោបល់» បើទោះជាគេគ្រប់គ្នាដឹងថា គោលបំណងនៃមាតុភូមិនិវត្តន៍នោះចង់បង្ហាញការមិនពេញចិត្តក៏ដោយ។ ការសម្តែងការមិនសប្បាយចិត្ត ដោយបានសរសេរលិខិតតវ៉ាជាផ្លូវការ។ ជាធម្មតា រដ្ឋាភិបាលធ្វើការតវ៉ាដូច្នេះ នៅក្នុងរាជធានីរបស់ខ្លួន ចំពោះឯកអគ្គរដ្ឋទូតរបស់រដ្ឋដទៃ។

ច្បាប់ការទូតត្រូវបានរំលោភបំពាន ម្តងហើយម្តងទៀត ក្នុងបរិបទមួយ នោះគឺ អំពើភេរវកម្ម (សូមមើលមេរៀនទី ៦)។ ដោយសាររដ្ឋនីមួយៗយកចិត្តទុកដាក់ខ្លាំង ចំពោះភាពមិនអាចរំលោភបានរបស់អ្នកការទូត អ្នកការទូតនានាបានក្លាយជាគោលដៅដ៏ទាក់ទាញរបស់ពួកភេរវករ ហើយដោយសារតែក្រុមភេរវករមិនទទួលបានផលប្រយោជន៍ពីច្បាប់ការទូត (ដូចរដ្ឋ) ពួកគេមិនខ្លាចរញើតនឹងរំលោភលើបទដ្ឋាននិងច្បាប់ការទូត។ ការវាយប្រហារលើអ្នកការទូតឬស្ថានទូត ប្រៀបដូចជាការវាយប្រហារលើទឹកដីរបស់រដ្ឋនោះផ្ទាល់

ប៉ុន្តែអាចត្រូវបានប្រព្រឹត្តិទៅនៅឆ្ងាយពីទឹកដីកំណើតរបស់រដ្ឋនោះ។ អ្នកការទូតជាច្រើននាក់ត្រូវបានសម្លាប់ក្នុងប៉ុន្មានទសវត្សរ៍ថ្មីៗនេះ។ នៅឆ្នាំ ១៩៩៨ ភេរវករអាល់កៃដាបានបោកគ្រាប់បែកបំផ្ទុះលើស្ថានទូតអាមេរិកក្នុងប្រទេសកេនយ៉ានិងតង់ហ្សានី ដោយបានសម្លាប់មនុស្សជាង ២០០ នាក់។ នៅចុងឆ្នាំ ២០០៤ ភេរវកបានវាយលុកចូលស្ថានកុងស៊ុលអាមេរិក នៅប្រទេសអារ៉ាប៊ីសាអូឌីត ដោយបានសម្លាប់ឆ្មាំយាមជាច្រើននាក់ ហើយនៅឆ្នាំ ២០១២ ពួកគេបានដុតស្ថានកុងស៊ុលអាមេរិកនៅទីក្រុងបិនហ្គាហ្ស៊ី (Benghazi) ប្រទេសលីប៊ី ដោយបានសម្លាប់ឯកអគ្គរដ្ឋទូតអាមេរិកផង។

៧.៤.២. គោលលទ្ធិនៃយុត្តិសង្គ្រាម

បន្ទាប់ពីច្បាប់ការទូត ច្បាប់អន្តរជាតិទាក់ទងនឹងសង្គ្រាម គឺជាវិស័យនៃច្បាប់អន្តរជាតិដែលមានការអភិវឌ្ឍខ្លាំងបំផុត។ ច្បាប់ដែលទាក់ទងនឹងសង្គ្រាមត្រូវបែងចែកជាពីរផ្នែកគឺច្បាប់*នៃ*សង្គ្រាម (laws *of* war) (នៅពេលដែលសង្គ្រាមត្រូវបានអនុញ្ញាត) និងច្បាប់*ក្នុង*សង្គ្រាម (របៀបដែលសង្គ្រាមត្រូវបានប្រយុទ្ធ)។

ជាកិច្ចចាប់ផ្តើមដំបូងជាមួយនឹងច្បាប់*នៃ*សង្គ្រាម ច្បាប់អន្តរជាតិបែងចែកភាពខុសគ្នារវាងសង្គ្រាមយុត្តិធម៌ ឬ **យុត្តិសង្គ្រាម** (just wars) (ដែលស្របច្បាប់) និងសង្គ្រាមឈ្លានពាន (ដែលខុសច្បាប់)។ (យើងនឹងពិភាក្សាអំពីច្បាប់*ក្នុង*សង្គ្រាមនៅពេលក្រោយ ក្នុងបរិបទសិទ្ធិមនុស្ស។) ផ្នែកនៃច្បាប់នេះរីកដុះដាលចេញពីការសំណេរគម្ពីរសាសនាស្តីពីយុត្តិសង្គ្រាម ដែលមានអាយុកាលរាប់សតវត្សមកហើយ (ដែលក្នុងសម័យនោះអាចត្រូវបានអនុវត្តដោយការគំរាមដើម្បីបណ្តេញបុគ្គលល្មើសចេញពីព្រះវិហារ (excommunicate))។ សព្វថ្ងៃនេះ ភាពស្របច្បាប់នៃសង្គ្រាមត្រូវបានកំណត់ដោយធម្មនុញ្ញអង្គការសហប្រជាជាតិ ដែលចែងថាការឈ្លានពានជាទង្វើខុសច្បាប់។ លើសពីភាពស្របច្បាប់របស់វា គោលលទ្ធិនៃយុត្តិសង្គ្រាមបានក្លាយជាបទដ្ឋានអន្តរជាតិដ៏រឹងមាំមួយ ទោះមិនមែនជាបទដ្ឋានដែលរដ្ឋទាំងអស់អនុវត្តតាមរហូតមែន ប៉ុន្តែជាផ្នែកសំខាន់នៃប្រពៃណីសិក្សាសម័យទំនើប ដែលគ្រប់គ្រងបញ្ហានៃសង្គ្រាមនិងសន្តិភាព ដែលបានវិវត្តនៅក្នុងទ្វីបអឺរ៉ុប។

គំនិតនៃការឈ្លានពាន (ដែលគោលលទ្ធិនៃយុត្តិសង្គ្រាមបានវិវត្តន៍ជុំវិញវា) ត្រូវផ្អែកលើការរំលោភបំពានលើអធិបតេយ្យភាពនិងបូរណភាពទឹកដីរបស់រដ្ឋណាមួយ។ *ការឈ្លានពាន* (aggression) សំដៅទៅលើការប្រើប្រាស់កងកម្លាំងរបស់រដ្ឋ ឬការគម្រាមកំហែងប្រើកងកម្លាំងរដ្ឋ ប្រឆាំងនឹងទឹកដី ឬអធិបតេយ្យភាពរបស់រដ្ឋមួយផ្សេងទៀត លើកលែងតែការប្រើកងកម្លាំងដើម្បីតែឆ្លើយតបទៅនឹងការឈ្លានពានមកលើខ្លួន។ រថក្រោះបើកបរឆ្លងកាត់ព្រំដែនត្រូវកំណត់ថាជាការឈ្លានពាន ប៉ុន្តែ ការបញ្ជូនរថក្រោះទៅកាន់ព្រំដែនក៏ត្រូវកំណត់ថាជាការឈ្លានពានផងដែរ ប្រសិនបើរដ្ឋណាមួយនោះបានគំរាមកំហែងឈ្លានពានប្រទេសជិតខាងខ្លួន។ បន្ទាត់បែងចែកហាក់នៅមានភាពស្រពិចស្រពិល។ ប៉ុន្តែ ដើម្បីហៅការគំរាមកំហែងណាមួយថាជាការឈ្លានពាន (និងដើម្បីអះអាងការប្រើប្រាស់កងកម្លាំងជាការឆ្លើយតប) វាត្រូវតែជាការគំរាមកំហែងច្បាស់ៗក្នុងការប្រើប្រាស់កងកម្លាំង មិនមែនត្រឹមតែជាគោលនយោបាយអរិភាព ឬការប្រកួតប្រជែងទូទៅនោះទេ។

រដ្ឋនានាមានសិទ្ធិឆ្លើយតបទៅនឹងការឈ្លានពាន តាមមធ្យោបាយតែមួយគត់ ដែលគេគិតថាអាចទុកចិត្តបាន ពោលគឺកងកម្លាំងយោធា។ ដូច្នេះ គោលលទ្ធិយុត្តិសង្គ្រាមមិនផ្អែកលើគោលការណ៍អហិង្សាទេ។ ទង្វើឆ្លើយតបអាចរួមទាំងការវាយរុញច្រានទ័ពឈ្លានពានចេញ និងការដាក់ទោសអ្នកឈ្លានពាន។ ការឆ្លើយតបអាចត្រូវបានធ្វើឡើងដោយជនរងគ្រោះនៃការឈ្លានពាន ឬដោយរដ្ឋផ្សេងទៀតដែលមិនរងផលប៉ះពាល់ដោយផ្ទាល់ ដែលជាមធ្យោបាយមួយនៃការរក្សាបទដ្ឋាននៃការមិនឈ្លានពានគ្នា នៅក្នុងប្រព័ន្ធអន្តរជាតិ។

សកម្មភាពរួមរបស់សមាជិកអង្គការសហប្រជាជាតិប្រឆាំងនឹងអ៊ីរ៉ាក់ បន្ទាប់ពីប្រទេសនេះបានលុកលុយចូលប្រទេសគុយវ៉ែត គឺជាករណីល្បីល្បាញមួយនៃការឆ្លើយតបបែបនេះ។

ការឆ្លើយតបទៅនឹងការឈ្លានពាន គឺជាការប្រើប្រាស់កម្លាំងយោធាតែមួយគត់ ដែលត្រូវបានអនុញ្ញាតជាចាំបាច់ យោងតាមគោលលទ្ធិនៃយុត្តិសង្គ្រាម។ ដូច្នេះហើយ គោលការណ៍នៃយុត្តិសង្គ្រាម ច្បាស់ណាស់មិនចាត់ទុកសង្គ្រាមជាឧបករណ៍មួយសម្រាប់ផ្លាស់ប្តូររដ្ឋាភិបាល ឬគោលនយោបាយរបស់រដ្ឋមួយផ្សេងទៀត ឬនៅក្នុងជម្លោះជាតិសាសន៍និងសាសនា។ តាមពិតទៅ ធម្មនុញ្ញអង្គការសហប្រជាជាតិ មិនបានចែងអំពី «សង្គ្រាម»ទេ ប៉ុន្តែបានចែងអំពី«សកម្មភាពប៉ូលីសអន្តរជាតិ»ប្រឆាំងនឹងអ្នកឈ្លានពាន។ ការប្រៀបប្រដូចទៅនឹងច្បាប់និងសណ្តាប់ធ្នាប់ក្នុងសង្គមជាតិមួយ ដែលត្រូវពង្រឹងការអនុវត្តដោយប៉ូលីសនៅពេលចាំបាច់។ ដោយសារតែការឈ្លានពានអនុញ្ញាតអោយប្រើកងកម្លាំងយោធា ប្រសិនបើរដ្ឋទាំងអស់គោរពច្បាប់ប្រឆាំងនឹងការឈ្លានពាន នោះនឹងមិនមានសង្គ្រាមអន្តរជាតិឡើយ។

ដើម្បីអោយសង្គ្រាមមួយមានលក្ខណៈយុត្តិធម៌ផ្អែកតាម*សីលធម៌* វាត្រូវតែលើសពីការឆ្លើយតបទៅនឹងការឈ្លានពាន, វាត្រូវតែធ្វើក្នុង*គោលបំណង*ដើម្បីឆ្លើយតបទៅនឹងការឈ្លានពាន។ *រចនា*ត្រូវតែមានភាពយុត្តិធម៌ត្រឹមត្រូវ។ រដ្ឋមួយអាចនឹងមិនទាញយកផលប្រយោជន៍ពីការឈ្លានពានរបស់រដ្ឋដទៃ ធ្វើសង្គ្រាមដែលមានលក្ខណៈឈ្លានពាននោះទេ។ ទោះបីជាកិច្ចខិតខំប្រឹងប្រែងសង្គ្រាមដែលដឹកនាំ ដោយសហរដ្ឋអាមេរិកក្នុងការបណ្តេញអ៊ីរ៉ាក់ចេញពីប្រទេសគុយវ៉ែតក្នុងឆ្នាំ ១៩៩១ គឺជាការឆ្លើយតបទៅនឹងការឈ្លានពានក៏ដោយ ក៏អ្នកវិះគន់ទាំងឡាយបានរកឃើញថា ភាពយុត្តិធម៌នៃសង្គ្រាមត្រូវបានរំខានដោយផលប្រយោជន៍របស់សហរដ្ឋអាមេរិកក្នុងការទទួលបានប្រេងក្នុងតម្លៃថោកពីតំបន់មជ្ឈឹមបូព៌ា មិនមែនជាហេតុផលត្រឹមត្រូវឬយុត្តិធម៌ ដែលអាចអនុញ្ញាតអោយធ្វើសង្គ្រាមនោះទេ។

គោលលទ្ធិនៃយុត្តិសង្គ្រាមត្រូវបានបំផ្លាញ រហូតធ្ងន់ធ្ងរជាងច្បាប់នៃឧក្រិដ្ឋកម្មសង្គ្រាម ដោយសារការផ្លាស់ប្តូរសភាពនៃសង្គ្រាម។ នៅក្នុងសង្គ្រាមស៊ីវិល និងជម្លោះកម្រិតទាប ភាគីប្រយុទ្ធរាប់ចាប់ពីកងជីវពលមិនរៀបរយរហូតដល់កងទ័ពជាតិ ហើយសមរភូមិ ជារឿយៗ គឺជាកន្លែងប្រសព្វនៃទីតាំងឡោមព័ទ្ធនិងទីតាំងដែលមិនមានសមរភូមិមុខច្បាស់លាស់ (ហើយព្រំដែនកាន់តែមិនច្បាស់ទៅទៀត)។ ដូច្នេះវាពិបាកក្នុងការកំណត់អត្តសញ្ញាណអ្នកណាជាអ្នកឈ្លានពានក្នុងស្ថានភាពបែបនេះ ហើយកាន់តែពិបាកក្នុងការថ្លឹងថ្លែងតុល្យភាពនៃឧត្តមភាពធៀបនៃសន្តិភាពនិងយុត្តិធម៌។

រូបថត ជំរុំជនភៀសខ្លួនពីភូមា ក្រោមការត្រួតពិនិត្យដោយកម្លាំងទាហានបង់ក្លាដែស

បទដ្ឋាននៃការប៉ះទង្គិច

បទដ្ឋានអន្តរជាតិទាក់ទងនឹងជម្លោះសិទ្ធិមនុស្ស ជាមួយអធិបតេយ្យភាពរបស់រដ្ឋ ដែលបង្កឱ្យមានការប៉ះទង្គិចក្នុងទំនាក់ទំនងដូចជាប្រទេសភូមា(មីយ៉ាន់ម៉ា)ជាមួយសហគមន៍អន្តរជាតិ។ នៅឆ្នាំ ២០១៧ ភូមាបានចាប់ផ្តើមដោយហិង្សាដោយបង្ខំសមាជិកជនជាតិភាគតិចរាប់សែននាក់ភៀសខ្លួនចូល ក្នុងប្រទេសបង់ក្លាដែសដែលនៅជិតខាង។ ហើយខណៈពេលដែលប្រទេសបង់ក្លាដែសបានគោរពតាមបទដ្ឋាននៃការទទួលយកជនភៀសខ្លួនពីការកាប់សម្លាប់បែបនោះ រដ្ឋនេះក៏បានស្នើសុំជំនួយក្នុងការដោះស្រាយជាមួយជនភៀសខ្លួនជាង ៣០០០០០ ផងដែរ។ នៅទីនេះ ពីជំរុំជនភៀសខ្លួនដែលពោរពេញដោយកម្លាំងទាហានបង់ក្លាដែសមើលជនភៀសខ្លួនដែលភៀសខ្លួនពីប្រទេសភូមា។

៧.៥. សិទ្ធិមនុស្ស

៧.៥ ចូរប្រៀបធៀបប្រសិទ្ធភាពនៃច្បាប់អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងរដ្ឋនានា ក្នុងការជំរុញបុព្វហេតុសិទ្ធិមនុស្ស នៅជុំវិញសកលលោក។

វិស័យមួយក្នុងចំណោមវិស័យថ្មីបំផុតនៃច្បាប់អន្តរជាតិយកចិត្តទុកដាក់លើសិទ្ធិមនុស្ស ដែលសំដៅលើសិទ្ធិរបស់មនុស្សជាតិប្រឆាំងនឹងការរំលោភបំពានណាមួយចំនួននៃរដ្ឋាភិបាល*របស់ខ្លួន*។

៧.៥.១. សិទ្ធិបុគ្គល ទល់នឹង អធិបតេយ្យភាព

គំនិតនៃសិទ្ធិមនុស្សដើរបញ្ច្រាសទិសអធិបតេយ្យភាពនិងបូរណភាពទឹកដីរបស់រដ្ឋ។ អធិបតេយ្យភាពផ្តល់អោយរដ្ឋនានានូវសិទ្ធិក្នុងការធ្វើអ្វីតាមចិត្តចង់របស់ពួកគេ នៅក្នុងរង្វង់ទឹកដីរបស់ពួកគេ៖ គ្មាននរណាម្នាក់អាចប្រាប់ពួកគេប្រព្រឹត្តទង្វើបែបម៉េចចំពោះពលរដ្ឋរបស់ពួកគេបានទេ។

សរុបមក ការមូលមតិគ្នាជាឯកច្ឆ័ន្ទចំពោះអ្វីដែលជាសិទ្ធិមនុស្សដ៏សំខាន់បំផុត ពិបាកនឹងសម្រេចបានណាស់។ គោលការណ៍មួយចំពោះសិទ្ធិមនុស្សអះអាងថា សិទ្ធិមានលក្ខណៈ*ជាសកល* (universal)។ មិនថាមនុស្សណាម្នាក់រស់នៅទីណា មិនថាគាត់មានសញ្ជាតិណា ហើយមិនថាគាត់មានសាសនា ជាតិសាសន៍ ឬប្រពៃណីក្នុងតំបន់យ៉ាងណាទេ បុគ្គលនោះមានសិទ្ធិជាក់លាក់ដែលត្រូវគោរព។ គោលការណ៍មួយ ទៀតចំពោះសិទ្ធិមនុស្ស ជារឿយៗ ត្រូវបានហៅថា *គោលការណ៍ប្រៀបធៀបនិយម* (relativism)។ យោងតាមគំនិតនេះ ប្រវត្តិសាស្ត្រនិងទំនៀមទម្លាប់ក្នុងស្រុកគួរតែទទួលបានការគោរពយ៉ាងត្រឹមត្រូវ បើទោះបីជាទង្វើបែបនេះដាក់កម្រិតកំណត់សិទ្ធិទាំងឡាយ ដែលអ្នកផ្សេងក្រៅពីបរិបទក្នុងស្រុកយល់ថាមានសារៈសំខាន់ក៏ដោយ។ កិច្ចខិតខំប្រឹងប្រែងលើកតម្កើងសិទ្ធិមនុស្សត្រូវបានរិះគន់ជារឿយៗ ពីសំណាក់រដ្ឋាភិបាលដែលមានកំណត់ត្រាសិទ្ធិមនុស្សមិនល្អតាមស្តង់ដារបស្ចឹមលោក (រួមមានប្រទេសចិននិងរុស្ស៊ី) ថាជា «ការជ្រៀតជ្រែកក្នុងកិច្ចការផ្ទៃក្នុងរបស់យើង»។ ការចោទប្រកាន់នេះធ្វើអោយច្បាប់សិទ្ធិមនុស្សមានស្ថានភាពរង្គោះរង្គើ និងឆ្លុះបញ្ចាំងពីគោលដំហរគោលការណ៍ប្រៀបធៀបនិយមកាន់តែខ្លាំង។

គំនិតនៃសិទ្ធិមនុស្សមានប្រភពកំណើតចេញពីប្រភពបីយ៉ាងតិច។ ប្រភពទីមួយ គឺសាសនា។ ស្ទើរតែគ្រប់សាសនាធំៗនៅលើពិភពលោក មានគំនិតជាមូលដ្ឋាន ដែលចែងថា មនុស្សត្រូវបានបង្កើតឡើង ក្នុងរូបភាពមួយនៃភាវៈមានអំណាចខ្ពស់ជាង ដូច្នេះហើយមនុស្សទាំងអស់ត្រូវទទួលបាននូវសេចក្តីថ្លៃថ្នូរ និងការគោរព ដែលសមនឹងភាវៈអំណាចខ្ពស់ជាងនោះ។ គ្មានទីកន្លែងណាមួយ ដែលគំនិតនេះត្រូវបានសរសេរច្បាស់លាស់ជាង នៅក្នុងសេចក្តីប្រកាសឯករាជ្យរបស់សហរដ្ឋអាមេរិកទេ ដែលសរសេរឡើងដោយ លោក ថូម៉ាស ជេហ្វឺសុន (Thomas Jefferson) ដែលប្រកាសថាមនុស្សទាំងអស់«ត្រូវបានផ្តល់ដោយអ្នកបង្កើតរបស់ពួកគេ ជាមួយនឹងសិទ្ធិជាក់លាក់ដែលមិនអាចកាត់ផ្តាច់បានឡើយ។»[២៦]

ទីពីរ ទស្សនវិជ្ជានយោបាយនិងច្បាប់ អស់រយៈពេលជាច្រើនសតវត្សមកហើយ បានពិភាក្សាអំពីគំនិតនៃច្បាប់ធម្មជាតិ និងសិទ្ធិធម្មជាតិ។ តាំងពីលោក អារីស្តូត ទៅ លោក ចន ឡុក ទៅលោក អ៊ីម៉ានុយអែល ខានត៍ ទៅលោក ហ្សង់-ហ្សាក់ រូស្សូ, ទស្សនវិទូនយោបាយបានបង្កើតគំនិតថា ច្បាប់ធម្មជាតិមានអត្ថិភាពដែលផ្តល់សិទ្ធិរស់រានមានជីវិត សេរីភាព ទ្រព្យសម្បត្តិ និងសុភមង្គលដល់មនុស្សគ្រប់រូប។

---

[២៦] U.S. National Archives and Records Administration.

[https://www.archives.gov/founding-docs/ declaration-transcript].

ចុងក្រោយ បដិវត្តន៍នយោបាយនៅក្នុងសតវត្សទីដប់ប្រាំបី ដូចជា បដិវត្តន៍អាមេរិក និងបារាំង បានយកទ្រឹស្តីច្បាប់ធម្មជាតិនិងសិទ្ធិធម្មជាតិទៅអនុវត្តជាក់ស្តែង។ នៅសហរដ្ឋអាមេរិក សេចក្តីប្រកាសឯករាជ្យ និងនៅប្រទេសបារាំង សេចក្តីប្រកាសនៃសិទ្ធិរបស់មនុស្សនិងប្រជាពលរដ្ឋ បានបង្កើតច្បាប់ដែលពង្រឹងគំនិតដែលថាមនុស្សមានសិទ្ធិជាក់លាក់ ដែលគ្មានរដ្ឋឬបុគ្គលណាផ្សេងទៀតអាចដកហូតបានឡើយ។

ប្រាកដណាស់ ការិះគន់លើគំនិតសិទ្ធិមនុស្សទាំងនេះ ពិតជាមានមែន ទាំងកម្រិតទ្រឹស្តីនិងការអនុវត្តជាក់ស្តែង។ ក្នុងកម្រិតទ្រឹស្តី អ្នកគោលការណ៍ប្រៀបធៀបនិយមចង្អុលបង្ហាញថា ភាគច្រើននៃប្រភពដើម និងការអភិវឌ្ឍន៍នៃគំនិតសិទ្ធិមនុស្ស (យ៉ាងហោចណាស់ ប្រភពពីរក្នុងចំណោមបីដែលបានពិភាក្សាខាងលើ) មានប្រភពកំណើតចេញពីបស្ចឹមលោក។ សង្គមក្រៅបស្ចឹមប្រទេសមានទំនៀមទំលាប់ទស្សនវិជ្ជាផ្សេងៗគ្នាហើយ អាចជ្រើសរើសការសង្កត់ធ្ងន់លើ ជាឧទាហរណ៍ សិទ្ធិក្រុម ឬក្រុមគ្រួសារ ជាជាងសិទ្ធិបុគ្គលម្នាក់ៗ។ នៅក្នុងកម្រិតអនុវត្តជាក់ស្តែង អ្នកវិះគន់ជាច្រើន (ជាពិសេសនៅក្រៅបស្ចឹមលោក) ចង្អុលបង្ហាញភ្លាមៗថា សូម្បីតែបន្ទាប់ពីបដិវត្តន៍សតវត្សទី ១៨ នៅអឺរ៉ុបនិងអាមេរិកក៏ដោយ សិទ្ធិនៅតែមិនមានលក្ខណៈជាសកល។ ស្ត្រី កុមារ និង ជាធម្មតា ជនជាតិដែលមិនមានពណ៌សម្បុរស មិនត្រូវបានគេសន្មត់ថាទទួលបានសិទ្ធិដូចគ្នានឹងបុរសស្បែកសជាម្ចាស់ដីនោះទេ ដែលធ្វើអោយគំនិតនៃសិទ្ធិជាសកលគ្រាន់ជាការបោកបន្លំតែប៉ុណ្ណោះ។

មួយផ្នែកដោយសារតែភាពចម្រូងចម្រាសនេះ ទើបគ្មាននិយមន័យដែលព្រមព្រៀងជាសកលអំពីសិទ្ធិមនុស្សជាមូលដ្ឋាននោះទេ។ ជារឿយៗ សិទ្ធិត្រូវបានបែងចែកជាពីរប្រភេទធំៗ គឺ ស៊ីវិល-នយោបាយ និងសេដ្ឋកិច្ច-សង្គម។ សិទ្ធិនយោបាយ-ស៊ីវិល ជួនកាល ត្រូវបានគេហៅថាជាសិទ្ធិអវិជ្ជមាន និងរួមបញ្ចូលនូវអ្វីដែលត្រូវបានចាត់ទុកថាជាសិទ្ធិប្រពៃណីបស្ចឹមលោក ដូចជា សេរីភាពបញ្ចេញមតិ សេរីភាពខាងសាសនា សិទ្ធិទទួលបានការការពារស្មើៗគ្នានៅក្រោមច្បាប់និងសេរីភាពរួចពីការជាប់ពន្ធនាគារតាមអំពើចិត្ត។ ជាទូទៅគេគិតថា សិទ្ធិទាំងនេះត្រូវបានធានាល្អបំផុត ដោយការកម្រិតអំណាចរបស់រដ្ឋាភិបាលលើប្រជាជនរបស់ពួកគេ។ សិទ្ធិសេដ្ឋកិច្ច-សង្គមត្រូវបានគេហៅថាជា សិទ្ធិវិជ្ជមាន និងរួមបញ្ចូលសិទ្ធិក្នុងការរស់នៅសមរម្យ អាហារការថែទាំសុខភាព សន្តិសុខសង្គម និងការអប់រំ។ ជាញឹកញាប់ សិទ្ធិទាំងនេះត្រូវបានលើកតម្កើងយ៉ាងល្អបំផុតដោយការពង្រីករដ្ឋាភិបាលដើម្បីផ្តល់ស្តង់ដារជាអប្បបរមាដល់ប្រជាជនរបស់ពួកគេ។

គ្មានរដ្ឋណាមួយនៅលើពិភពលោកមានកំណត់ត្រាល្អឥតខ្ចោះអំពីសិទ្ធិមនុស្ស ក្នុងប្រភេទណាមួយទេ ហើយរដ្ឋនីមួយៗក៏ខុសគ្នាត្រង់សិទ្ធិប្រភេទណា ដែលពួកគេគោរព ឬមួយណាដែលគេរំលោភបំពាន។ ក្នុងខណៈពេលដែលសហរដ្ឋអាមេរិកវិះគន់ប្រទេសចិនចំពោះការបំបិទសេរីភាពបញ្ចេញមតិ ការបិទខ្ទប់ការបើកចូលវែបសាយអ៊ីនធឺរណែតមួយចំនួន ការប្រើប្រាស់កម្លាំងពលកម្មក្នុងពន្ធនាគារ និងការធ្វើទារុណកម្មលើអ្នកប្រឆាំងនយោបាយ(សិទ្ធិនយោបាយស៊ីវិល), ប្រទេសចិនកត់សម្គាល់ថា សហរដ្ឋអាមេរិកមានប្រជាជនក្រីក្រចំនួនប្រហែល ៤០ លាននាក់ មានសមាមាត្រអ្នកទោសខ្ពស់បំផុតនៅលើពិភពលោក និងមានប្រវត្តិសាស្ត្រនៃការរើសអើងជាតិសាសន៍និងអំពើហិង្សា(សេដ្ឋកិច្ច-សិទ្ធិសង្គម)។ ក្នុងអំឡុងសង្គ្រាមត្រជាក់ សហរដ្ឋអាមេរិកនិងសម្ព័ន្ធមិត្តបានវិះគន់សហភាពសូវៀតនិងប្រទេសចិន ជាហូរហែ ចំពោះការរំលោភសិទ្ធិនយោបាយស៊ីវិល ប៉ុន្តែ បានបដិសេធមិនគាំទ្រសន្ធិសញ្ញាដែលលើកកំពស់សិទ្ធិសេដ្ឋកិច្ច-សង្គម។ ដូចគ្នានេះដែរ រដ្ឋកុម្មុយនិស្តបានលើកទឹកចិត្តដល់ការអភិវឌ្ឍន៍សិទ្ធិសេដ្ឋកិច្ច-សង្គម ខណៈពេលមិនអើពើចំពោះការអំពាវនាវលើកតម្កើងសិទ្ធិនយោបាយស៊ីវិល។ សរុបមក ទោះបីជាមានកំណត់ត្រាមិនល្អលើចំណុចមួយចំនួនរបស់រដ្ឋមួយចំនួនលើ

ពិភពលោក ក៏មានវឌ្ឍនភាពនៅលើផ្នែកផ្សេងទៀតផងដែរ។ ជាឧទាហរណ៍ របបទាសភាព ដែលធ្លាប់ត្រូវបានចាត់ទុកថាជារឿងធម្មតា នៅទូទាំងពិភពលោក ភាគច្រើនត្រូវបានលុបបំបាត់ ក្នុងរយៈពេល ១៥០ ឆ្នាំចុងក្រោយនេះ។

ជាប្រវត្តិសាស្ត្រ ការផ្លាស់ប្តូរសកលលោកដ៏សំខាន់នៅក្នុងសិទ្ធិមនុស្សបានកើតឡើងនៅចុងបញ្ចប់នៃសង្គ្រាមលោកលើកទីពីរ។ ដោយរងការរន្ធត់ពន់ពេក ដោយការប៉ុនប៉ងរបស់ណាហ្ស៊ីអាឡឺម៉ង់ក្នុងការលុបបំបាត់ពូជសាសន៍ជ្វីហ្វ និងដោយការរំលោភបំពានរបស់ជប៉ុនទៅលើប្រជាជនចិន អ្នកប្រាជ្ញនិងអ្នកអនុវត្ត (សិទ្ធិមនុស្ស)ជាច្រើនបានចាប់ផ្តើមអោយយោបល់ថា ត្រូវមានដែនកំណត់ចំពោះអធិបតេយ្យភាពរបស់រដ្ឋ។ រដ្ឋទាំងឡាយមិនអាចអះអាងទាមទារអធិបតេយ្យភាពនិងរួចផុតពីការជ្រៀតជ្រែកពីខាងក្រៅបានទេ ប្រសិនបើពួកគេប៉ុនប៉ងសម្លាប់ប្រជាពលរដ្ឋខ្លួនឯង។ នៅក្រោយសង្គ្រាមលោកលើកទី ២ និងការបង្កើតអង្គការសហប្រជាជាតិ ការប៉ុនប៉ងអន្តរជាតិសំខាន់ៗមួយចំនួនក្នុងការធ្វើច្បាប់និងពង្រឹងសិទ្ធិមនុស្សបានចាប់ផ្តើមឡើង។ នៅផ្នែកបន្ទាប់ យើងពិនិត្យមើលកិច្ចព្រមព្រៀង និងស្ថាប័នមួយចំនួនពាក់ព័ន្ធនឹងសិទ្ធិមនុស្ស។

៧.៥.២. ស្ថាប័នសិទ្ធិមនុស្ស

នៅឆ្នាំ ១៩៤៨ មហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័តនូវអ្វីដែលចាត់ទុកថាជាឯកសារអន្តរជាតិស្នូលទាក់ទងនឹងសិទ្ធិមនុស្ស៖ **សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស** (UDHR)។ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មិនមានកម្លាំងសមមូលនឹងច្បាប់អន្តរជាតិទេ ប៉ុន្តែ វាបានកំណត់ (រំពឹង) បទដ្ឋានអន្តរជាតិពាក់ព័ន្ធនឹងអាកប្បកិរិយារបស់រដ្ឋាភិបាលចំពោះពលរដ្ឋរបស់ពួកគេ និងចំពោះជនបរទេសផងដែរ។ សេចក្តីប្រកាសនេះបានចាក់ឫសផ្ទាល់ចូលទៅ ក្នុងគោលការណ៍ដែលថា ការរំលោភសិទ្ធិមនុស្សធ្វើអោយខូចសណ្តាប់ធ្នាប់អន្តរជាតិ (បណ្តាលអោយមានការខឹងសម្បារក្តៅក្រហាយ រហូតបង្កអោយមានការបះបោរជាដើម) ហើយសច្ចៈភាពដែលថាធម្មនុញ្ញអង្គការសហប្រជាជាតិទាញរដ្ឋនានាអោយគោរពសេរីភាពជាមូលដ្ឋាន។ សេចក្តីថ្លែងការណ៍នេះប្រកាសថា «មនុស្សគ្រប់រូបកើតមក មានសេរីភាព និងស្មើភាព»[២៧] ដោយមិនគិតពី ពូជសាសន៍ ភេទ ភាសា សាសនា ទំនាក់ទំនងនយោបាយ ឬស្ថានភាពនៃទឹកដីដែលពួកគេកើត។ វាថ្លែងបន្ត ដោយលើកកម្ពស់បទដ្ឋាននៅក្នុងវិស័យជាច្រើន រួមបញ្ចូលទាំងការហាមឃាត់ការធ្វើទារុណកម្ម ការធានាសេរីភាពខាងសាសនានិងនយោបាយ និងការធានានូវសិទ្ធិសុខុមាលភាពសេដ្ឋកិច្ច។

ចាប់តាំងពីការអនុម័តសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សមក អង្គការសហប្រជាជាតិបានបើកអោយមានសន្ធិសញ្ញាចំនួនប្រាំបួនសម្រាប់ការចុះហត្ថលេខារបស់រដ្ឋ ដើម្បីកំណត់បន្ថែមទៀតនូវការការពារសិទ្ធិមនុស្ស(សូមមើលតារាង ៧.៣)។ ខុសពីសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស សន្ធិសញ្ញាទាំងនេះគឺជាកិច្ចសន្យាដែលមានកាតព្វកិច្ចផ្លូវច្បាប់ ដែលចុះហត្ថលេខាដោយរដ្ឋទាំងឡាយ។ ប្រាកដណាស់ ច្បាប់អន្តរជាតិអាចល្អទៅបានលុះត្រាតែមានយន្តការអនុវត្តច្បាប់ ដែលនៅពីក្រោយវាដែរ។ ប៉ុន្តែ សន្ធិសញ្ញាទាំងប្រាំបួននេះមានសារៈសំខាន់ក្នុងការគូសបញ្ជាក់ពីការការពារជាមូលដ្ឋាន សម្រាប់បុគ្គលដែលរំពឹងទុកដោយសហគមន៍អន្តរជាតិ។

---

[២៧] Universal Declaration of Human Rights (UDHR), Paris, France. (December ១០, ១៩៤៨). [http://www. un.org/en/universal-declaration-human-rights/].

សន្ធិសញ្ញាដ៏សំខាន់ពីរ គឺ*កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ*(CCPR) និង*កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌*(CESCR)។ សន្ធិសញ្ញាទាំងពីរនេះ ដែល បានចូលជាធរមាន នៅក្នុងឆ្នាំ ១៩៧៦ ដូចគ្នា បានបញ្ចូលការប្តេជ្ញារបស់UDHRធ្វើជាច្បាប់ ក្នុងខណៈពេលដែលបែងចែកបញ្ជីសិទ្ធិទាំងឡាយនៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សទៅជាប្រភេទ*សិទ្ធិនយោបាយ-សង្គមស៊ីវិល* និងសិទ្ធិ*សេដ្ឋកិច្ច-សង្គម* នៅក្នុងកតិកាសញ្ញានីមួយៗ រៀងៗខ្លួន។ កតិកាសញ្ញាទាំងពីរនេះ រួមជាមួយនឹងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ជារឿយៗ ត្រូវបានគេសំដៅថាជា ច្បាប់អន្តរជាតិនៃសិទ្ធិមនុស្ស(International Bill of Human Rights)។

តារាង ៧.៣ ស្ថានភាពផ្តល់សច្ចាប័នលើសន្ធិសញ្ញាសិទ្ធិមនុស្សស្នូល ទាំងប្រាំបួនរបស់អង្គការសហប្រជាជាតិ ឆ្នាំ ២០១៨

សន្ធិសញ្ញា	**កាលបរិច្ឆេទ ចូលជាធរមាន**	**ចំនួន ភាគី**	**រដ្ឋមិនមែនជា សមាជិក**
អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់គ្រប់ទំរង់នៃការរើសអើងពូជសាសន៍ (CERD)	៤ មករា ១៩៦៩	១៧៨	ភូមា ម៉ាឡេស៊ី កូរ៉េជើង
កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ (CESCR)	៣ មករា ១៩៧៦	១៦៥	បូតស្វាណា អាប៉ាប៊ី-សាអូឌីត អាមេរិក
កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (CCPR)	២៣ មីនា ១៩៧៦	១៦៩	ភូមា ចិន អាប៉ាប៊ីសាអូឌីត
អនុសញ្ញាស្តីពីការលុបបំបាត់គ្រប់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី (CEDAW)	៣ កញ្ញា ១៩៨១	១៨៩	អ៊ីរ៉ង់ សូម៉ាលី ស៊ូដង់ អាមេរិក
អនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម (CAT)	២៦ មិថុនា ១៩៨៧	១៦២	អង់ហ្គោឡា ភូមា ឥណ្ឌា អ៊ីរ៉ង់ ស៊ូដង់
អនុសញ្ញាស្តីពីសិទ្ធិកុមារ (CRC)	២ កញ្ញា ១៩៩០	១៩៦	សហរដ្ឋអាមេរិក
អនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិពលករចំណាកស្រុកទាំងអស់និងសមាជិកគ្រួសារ (CMW)	១ កក្កដា ២០០៣	៥១	បារាំង អង់គ្លេស ចិន រុស្ស៊ី អាមេរិក
អនុសញ្ញាស្តីពីសិទ្ធិជនពិការ (CRPD)	៣ ឧសភា ២០០៨	១៧៥	ឆាដ លីប៊ី អាមេរិក
អនុសញ្ញាអន្តរជាតិសម្រាប់ការការពារមនុស្សទាំងអស់ពីការបាត់ខ្លួនដោយបង្ខំ (CPED)	២៣ ធ្នូ ២០១០	៥៧	អូស្ត្រាលី ចិន រុស្ស៊ី អាមេរិក

ប្រភព៖ អង្គការសហប្រជាជាតិ។

សន្ធិសញ្ញានីមួយៗ ដែលនៅសេសសល់ ដោះស្រាយជាមួយនឹងក្រុមជាក់លាក់មួយ ដែលសហគមន៍អន្តរជាតិចាត់ទុកថាងាយរងគ្រោះ។ អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់គ្រប់ទម្រង់នៃការរើសអើងពូជសាសន៍ (CERD) ដែលបានអនុម័ត ក្នុងឆ្នាំ១៩៦៩ ហាមប្រាមការរើសអើងប្រឆាំងនឹងបុគ្គលដោយផ្អែកលើពូជសាសន៍ ជាតិសាសន៍ សាសនា ឬប្រភពកំណើតជាតិ។ អនុសញ្ញាCERD មិនរួមបញ្ចូលភាសាទាក់ទងនឹង

ការរើសអើងយេនឌ័រទេ។ ទោះជាយ៉ាងណាក៏ដោយ អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី (CEDAW) បំពេញចន្លោះប្រហោងនេះ ដោយការហាមឃាត់ការរើសអើងប្រឆាំងនឹងស្ត្រី។ អនុសញ្ញា CEDAW បានចូលជាធរមាននៅឆ្នាំ ១៩៨១។

អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម(CAT) ដែលត្រូវចុះហត្ថលេខក្នុងឆ្នាំ ១៩៨៧ ហាមប្រាមអំពើចាត់ទុកមនុស្សដូចសត្វធាតុ(demumanization) ការបន្ទាបបន្ថោក និងការធ្វើអំពើអមនុស្សធម៌លើបុគ្គលសូម្បីតែនៅក្នុងសម័យសង្គ្រាមក៏ដោយ។ អនុសញ្ញាស្តីពីសិទ្ធិកុមារ(CRC) ដែលបានអនុម័ត ក្នុងឆ្នាំ១៩៩០ លើកកម្ពស់សុខភាព ការអប់រំ និងសុខុមាលភាពរាងកាយរបស់កុមារ (គ្រប់ប្រទេសទាំងអស់ក្នុងពិភពលោក លើកលែងតែសហរដ្ឋអាមេរិក បានអនុម័តអនុសញ្ញានេះ)។ អនុសញ្ញាស្តីពីការការពារសិទ្ធិពលករចំណាកស្រុកទាំងអស់និងសមាជិកក្រុមគ្រួសាររបស់ពួកគេ (CMW) បានចូលជាធរមានក្នុងឆ្នាំ ២០០៣។ អនុសញ្ញា CMWនេះព្យាយាមការពារសិទ្ធិនយោបាយ ពលកម្ម និងសង្គមរបស់ កម្មករឬពលករចំណាកស្រុក ជិត ១០០ លាននាក់ នៅជុំវិញពិភពលោក។

អនុសញ្ញាស្តីពីសិទ្ធិមនុស្សមានពិការភាព (CRPD) ដែលចូលជាធរមាននៅក្នុងឆ្នាំ ២០០៨ លើកកម្ពស់សេចក្តីថ្លៃថ្នូរ សមភាពនៃការការពារផ្លូវច្បាប់ និងការស្នាក់នៅសមរម្យសម្រាប់មនុស្សមានពិការភាព ឬជនពិការ។ សន្ធិសញ្ញាសិទ្ធិមនុស្សជាស្នូលថ្មីៗបំផុតគឺអនុសញ្ញាអន្តរជាតិសម្រាប់ការការពារមនុស្សទាំងអស់ពីការបាត់ខ្លួនដោយបង្ខំ(CPED) ដែលបានចូលជាធរមាន ក្នុងឆ្នាំ ២០១០។ អនុសន្ធិសញ្ញានេះការពារបុគ្គលទាំងឡាយពីការបាត់ខ្លួនដោយបង្ខំ ដែលត្រូវបានកំណត់ជាផ្នែកមួយថាជា«ការដកហូតសិទ្ធិសេរីភាព» អមដោយការលាក់បាំងនៃការដកហូតនោះ។

ក៏មានសារៈសំខាន់ដូចសន្ធិសញ្ញាអង្គការសហប្រជាជាតិទាំងនេះផងដែរ គឺជា*ពិធីសារស្មើគ្រៃចិត្ត* (optional protocols) ដែលត្រូវបានភ្ជាប់ជាមួយនឹងសន្ធិសញ្ញាមួយចំនួន។ ពិធីសារទាំងនេះអាចត្រូវបានចាត់ទុកថាជាការបំពេញបន្ថែមនៃសន្ធិសញ្ញាខាងលើ ព្រោះវាមានការការពារបន្ថែម ដែលមិនរួមបញ្ចូលនៅក្នុងឯកសារដើម។ ជាទូទៅ រដ្ឋចំនួនតិចចុះហត្ថលេខាលើពិធីការស្មើគ្រៃទាំងនេះ ដោយសារការការពារសិទ្ធិដែលចែងក្នុងនោះ មានភាពចម្រូងចម្រាសពេក មិនអាចបញ្ចូលក្នុងកម្រងឯកសារដើម។ លើសពីនេះ ពិធីការស្មើគ្រៃចិត្តមួយចំនួនមានយន្តការពង្រឹងការអនុវត្តខ្លាំងជាង ដូចជា ការផ្តល់អោយបុគ្គលនៅក្នុងរដ្ឋហត្ថលេខីនូវសិទ្ធិទៅកាន់ស្ថាប័នត្រួតពិនិត្យរបស់អង្គការសហប្រជាជាតិ ដោយមិនមានការយល់ព្រមពីរដ្ឋាភិបាលរបស់ពួកគេ។ រដ្ឋដែលមិនមែនជាភាគីនៃសន្ធិសញ្ញាដើមអាចចុះហត្ថលេខាលើ ពិធីការស្មើគ្រៃចិត្ត ដូចករណីជាមួយសហរដ្ឋអាមេរិក ដែលមិនបានចុះហត្ថលេខាលើ អនុសញ្ញាស្តីពីសិទ្ធិកុមារ(CRC) ប៉ុន្តែ បានចុះហត្ថលេខាលើពិធីសារស្មើគ្រៃចំនួនពីររបស់វាផ្ទាល់។

ក្រៅពីសន្ធិសញ្ញាសិទ្ធិមនុស្សដែលទាក់ទងនឹងអង្គការសហប្រជាជាតិ អង្គការអន្តរជាតិក្នុងតំបន់មួយចំនួនបានលើកកម្ពស់ការការពារសិទ្ធិមនុស្ស។ គ្មានកន្លែងណាធ្វើអោយរឿងនេះក្លាយការពិតជាងនៅទ្វីបអឺរ៉ុបដែលសហភាពអឺរ៉ុប ក្រុមប្រឹក្សាអឺរ៉ុប និងតុលាការសិទ្ធិមនុស្សអឺរ៉ុបសុទ្ធសឹងតែធ្វើការដើម្បីធានាថាសិទ្ធិមនុស្សត្រូវបានគោរពដោយរដ្ឋទាំងអស់នៅក្នុងតំបន់ (សូមមើលមេរៀនទី ១០)។ នៅអាមេរិកឡាទីន *តុលាការសិទ្ធិមនុស្សអន្តរអាមេរិក*បានទទួលជោគជ័យខ្លះៗក្នុងការលើកកម្ពស់សិទ្ធិមនុស្សដែរ ប៉ុន្តែវាត្រូវបានដាក់កម្រិតដោយការបដិសេធរបស់រដ្ឋក្នុងការមិនគោរពតាមសេចក្តីសម្រេចរបស់វា។ ទីបំផុត សហភាពអាហ្វ្រិកជួយ

គាំទ្រដល់គណៈកម្មការសិទ្ធិមនុស្សអាហ្វ្រិក ប៉ុន្តែគណៈកម្មការនេះត្រូវបានរារាំង ដោយកង្វះការគាំទ្រផ្នែកបរិយាវត្ថុនិងនយោបាយពីរដ្ឋអាហ្វ្រិកនានា។

ក្នុងប៉ុន្មានទសវត្សរ៍កន្លងមក រដ្ឋមានសេដ្ឋកិច្ចអភិវឌ្ឍន៍បានចាប់ផ្តើមប្រើប្រាស់អង្គការអន្តរជាតិផ្សេងទៀត ដើម្បីដាក់សម្ពាធលើរដ្ឋកំពុងអភិវឌ្ឍន៍ ដើម្បីកែលម្អលក្ខខណ្ឌសិទ្ធិមនុស្ស។ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី(សូមមើលមេរៀនទី ៨) ជាញឹកញយមានបទប្បញ្ញត្តិដែលដាក់លក្ខខណ្ឌផ្តល់អត្ថប្រយោជន៍ពាណិជ្ជកម្មភ្ជាប់ជាមួយការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិរបស់កម្មករ។ ដោយសារសន្ធិសញ្ញាទាំងនេះផ្តល់គោលនយោបាយមានប្រយោជន៍ដល់រដ្ឋកំពុងអភិវឌ្ឍន៍ ពួកគេបង្កើតយន្តការត្រៀមខ្លួនជាស្រេចដើម្បីដាក់ទណ្ឌកម្មប្រទេសដែលរំលោភបំពានលើពលរដ្ឋរបស់ពួកគេ។ យ៉ាងណាក៏ដោយ អ្នកខ្លះទៀតប្រកែកថា ការកំណត់ផលប្រយោជន៍សេដ្ឋកិច្ចដល់បណ្តាប្រទេសទាំងនោះប៉ះពាល់ដល់ការអភិវឌ្ឍសេដ្ឋកិច្ចរបស់ពួកគេ ដែលទំនងជាធ្វើអោយស្ថានភាពសិទ្ធិមនុស្សកាន់តែអាក្រក់ទៅៗ តែប៉ុណ្ណោះ។

សព្វថ្ងៃនេះ អង្គការក្រៅរដ្ឋាភិបាលដើរតួនាទីយ៉ាងសំខាន់ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីទទួលបានសិទ្ធិនយោបាយជាមូលដ្ឋាន នៅក្នុងប្រទេសផ្តាច់ការ រួមទាំងការបញ្ឈប់ការធ្វើទារុណកម្ម ការប្រហារជីវិត និងការចាប់ដាក់គុក ចំពោះបុគ្គលទាំងឡាយណាដែលគ្រាន់តែសម្តែងមតិនយោបាយ ឬ ជំនឿសាសនា។ អង្គការឈានមុខគេដែលជំរុញការតស៊ូនេះ គឺ **អង្គការលើកលែងទោសអន្តរជាតិ** (Amnesty International) ដែលជាអង្គការក្រៅរដ្ឋាភិបាល ដែលប្រតិបត្តិការទូទាំងពិភពលោក ដើម្បីតាមដាននិងព្យាយាមកែតម្រូវការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ។ អង្គការលើកលែងទោសអន្តរជាតិល្បីល្បាញដោយសារភាពភាពអព្យាក្រឹតឥតលំអៀងហើយបានរិះគន់ការរំលោភបំពាននៅក្នុងប្រទេសជាច្រើន រួមទាំងសហរដ្ឋអាមេរិកផងដែរ។ ក្រុមផ្សេងទៀតដូចជា អង្គការឃ្លាំមើលសិទ្ធិមនុស្ស (Human Rights Watch) ធ្វើការតាមរបៀបស្រដៀងគ្នានេះ ប៉ុន្តែជារឿយៗ ផ្តោតជាពិសេសលើតំបន់ឬជាតិណាមួយជាង។ អង្គការក្រៅរដ្ឋាភិបាលតែងតែផ្តល់ព័ត៌មាន និងការតស៊ូមតិសម្រាប់អង្គការសហប្រជាជាតិនិងអង្គការក្នុងតំបន់ផ្សេងទៀត។ ពួកគេដើរតួយ៉ាងសំខាន់ជាស្ពានផ្សារភ្ជាប់រវាងអង្គការពិភពលោកឬក្នុងតំបន់នឹងការខិតខំប្រឹងប្រែងដើម្បីលើកកម្ពស់សិទ្ធិមនុស្ស «នៅលើទឹកដី»នីមួយៗផ្ទាល់។

ការពង្រឹងបទដ្ឋានសិទ្ធិមនុស្សមានការលំបាក ព្រោះវាពាក់ព័ន្ធនឹងការជ្រៀតជ្រែកក្នុងកិច្ចការផ្ទៃក្នុងរបស់រដ្ឋណាមួយ។ ការកាត់ផ្តាច់ចំណងពាណិជ្ជកម្ម ឬទំនាក់ទំនងជាមួយរដ្ឋាភិបាលដែលរំលោភសិទ្ធិមនុស្សមានទំនោរធ្វើអោយប៉ះពាល់ខ្លាំងដល់ពលរដ្ឋដែលសិទ្ធិរបស់ពួកគេកំពុងត្រូវបានរំលោភ ដោយការដាក់អោយពួកគេកាន់តែឯកាបន្ថែមទៀត។ ប៉ុន្តែ វិធានការណ៍បែបនេះដាក់ស្ថានភាពរងគ្រោះពីការរំលោភសិទ្ធិមនុស្សនៅចំកណ្តាលឆាកអន្តរជាតិ ដោយទាក់ទាញការយកចិត្តទុកដាក់កាន់តែច្រើនចំពោះស្ថានភាពរបស់ពួកគេ។

វិធីសាស្ត្រដ៏មានប្រសិទ្ធភាពបំផុតដែលមិនទាន់ត្រូវបានរកឃើញនៅឡើយ គឺការរួមបញ្ចូលគ្នានៃការ*ផ្សព្វផ្សាយជាសាធារណៈ*(publicity) និងសម្ពាធ (pressure)។ ការផ្សព្វផ្សាយជាសាធារណៈរួមបញ្ចូលការជីកកកាយព័ត៌មានអំពីការរំលោភសិទ្ធិមនុស្ស ដូចដែលអង្គការលើកលែងទោសអន្តរជាតិបានធ្វើ។ តាមរយៈដំណើរការមួយដែលអ្នកប្រាជ្ញមួយចំនួនបានដាក់ឈ្មោះថា«ការហៅឈ្មោះនិងការបន្ទោសបង្អាប់» (naming and shaming) អ្នកគាំទ្រសិទ្ធិមនុស្សសង្ឃឹមថា ការផ្សព្វផ្សាយជាសាធារណៈនឹងធ្វើអោយរបបនេះរងភាពអាម៉ាស់និងផ្លាស់ប្តូរអាកប្បកិរិយារបស់ខ្លួន។ ការផ្សព្វផ្សាយបែបនេះក៏មានតួនាទីជាការព្រមានដល់អ្នកដែល

ប្រុងធ្វើដំណើរទៅទស្សនាឬធ្វើអាជីវកម្មផងដែរ ជាមួយនឹងរបបបំពានទៅនឹងលក្ខខណ្ឌនៅក្នុងប្រទេសទាំងនោះ។ សកម្មជនសិទ្ធិមនុស្សនានាសង្ឃឹមថា ការយកចិត្តទុកដាក់អវិជ្ជមាននេះនឹងបញ្ចុះបញ្ចូលបុគ្គលអោយបញ្ឈប់អន្តរកម្មរបស់ពួកគេជាមួយរដ្ឋនោះ ដោយដាក់សម្ពាធសេដ្ឋកិច្ចបន្ថែមទៀតលើវា។

សម្ពាធរបស់រដ្ឋាភិបាលផ្សេងទៀត ក៏ដូចជា បុគ្គលឯកជន និងធុរកិច្ច រួមមាន ការគម្រាមកំហែងដាក់ទោសជនល្មើស តាមមធ្យោបាយណាមួយ តាមរយៈមធ្យោបាយអហិង្សា។ ប៉ុន្តែដោយសាររដ្ឋាភិបាលភាគច្រើនស្វែងរកការរក្សាទំនាក់ទំនងជាប្រក្រតីជាមួយគ្នាទៅវិញទៅមក ការដាក់ទណ្ឌកម្មជ្រើតជ្រែកបែបនេះដោយរដ្ឋាភិបាលមួយ ចំពោះការរំលោភសិទ្ធិមនុស្សរបស់រដ្ឋាភិបាលមួយផ្សេងទៀត កម្រកើតមានណាស់ ហើយមិនទទួលបានជោគជ័យគួរអោយទុកចិត្តនោះទេ។

អ្វីដែលកម្រកើតមានផងដែរនោះ គឺអំពីអន្តរាគមន៍មនុស្សធម៌ ដោយប្រើកម្លាំងយោធា ដើម្បីយកឈ្នះការតស៊ូប្រដាប់អាវុធ ដោយអាជ្ញាធរមូលដ្ឋានឬស្តេចត្រាញ់ និងដើម្បីនាំយកជំនួយដល់ដៃជនស៊ីវិលដែលរងគ្រោះដោយសារសង្គ្រាមនិងគ្រោះមហន្តរាយ។ ទោះជាយ៉ាងណាក៏ដោយ បទដ្ឋានអន្តរជាតិបានផ្លាស់ប្តូរកាន់តែខ្លាំងឡើងប្រឆាំងនឹងអធិបតេយ្យភាព និងឆ្ពោះទៅការពារជនស៊ីវិលដែលកំពុងប្រឈមនឹងការបាត់បង់ជីវិត។ កិច្ចប្រជុំកំពូលដ៏សំខាន់មួយរបស់មេដឹកនាំពិភពលោក ក្នុងឆ្នាំ ២០០៥ បានបង្ហាញពីគំនិតនៃ**ទំនួលខុសត្រូវដើម្បីការពារ**(R២P) ដែលប្រកាន់ថា រដ្ឋាភិបាលទូទាំងពិភពលោកត្រូវតែធ្វើសកម្មភាពដើម្បីជួយសង្គ្រោះជនស៊ីវិលពីអំពើប្រល័យពូជសាសន៍ ឬឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលប្រព្រឹត្តឡើងដោយ ឬអនុញ្ញាតដោយរដ្ឋាភិបាលរបស់ពួកគេ។ អន្តរាគមន៍មនុស្សធម៌ដ៏សំខាន់បី ក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ បានធ្វើឡើង នៅក្នុងតំបន់ឃឺដនៃប្រទេសអ៊ីរ៉ាក់ នៅប្រទេសសូម៉ាលី និងនៅកូសូវ៉ូ(ស៊ែប៊ី)។ យុទ្ធនាការរបស់អង្គការណាតូដែលត្រូវបានអនុញ្ញាត ដោយអង្គការសហប្រជាជាតិ នៅក្នុងប្រទេសលីប៊ី ក្នុងឆ្នាំ ២០១១ បានប្រព្រឹត្តិតាមគោលគំនិតទំនួលខុសត្រូវដើម្បីការពារ។ ប៉ុន្តែ ប្រជាជនស៊ីរីមិនបានទទួលការការពារ ក្នុងឆ្នាំ២០១១-២០១៨ ខណៈរាប់មនុស្សម៉ឺននាក់ត្រូវបានសម្លាប់ដោយរដ្ឋាភិបាលរបស់ពួកគេ និងចាប់ពីឆ្នាំ ២០១៤ មកដែរ ត្រូវសម្លាប់ដោយក្រុមឧទ្ទាមរដ្ឋអ៊ីស្លាម។ គោលគំនិតទំនួលខុសត្រូវដើម្បីការពារ ត្រូវដាក់ក្នុងបរិបទមតិយោបល់សាធារណៈ (សូមមើលឧទាហរណ៍បន្ថែម មតិសាធារណៈនិងទំនាក់ទំនងអន្តរជាតិ)

ក្រសួងការបរទេសសហរដ្ឋអាមេរិកបានបន្តសកម្មភាពសិទ្ធិមនុស្ស តាំងពីចុងទសវត្សរ៍ ឆ្នាំ ១៩៧០។ របាយការណ៍ប្រចាំឆ្នាំរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិកមួយ បានវាយតម្លៃស្ថានភាពសិទ្ធិមនុស្ស នៅក្នុងរដ្ឋនានាជុំវិញពិភពលោក។ នៅក្នុងរដ្ឋដែលការរំលោភបំពានកាន់តែធ្ងន់ធ្ងរខ្លាំង ឬកាន់តែអាក្រក់ ជំនួយបរទេសរបស់សហរដ្ឋអាមេរិកត្រូវបានផ្អាក។ (ប៉ុន្តែ នៅក្នុងករណីផ្សេងទៀត ការផ្តល់មូលនិធិរបស់ភ្នាក់ងារ CIA បានគាំទ្រដល់អ្នករំលោភបំពាន។) ជាការឆ្លើយតបនឹងរបាយការណ៍ទាំងនេះ ចិនបានផលិតរបាយការណ៍សិទ្ធិមនុស្សស្តីពីស្ថានភាពសិទ្ធិមនុស្ស នៅសហរដ្ឋអាមេរិក ដោយចេញផ្សាយក្នុងថ្ងៃតែមួយជាមួយនឹងរបាយការណ៍របស់ក្រសួងការបរទេសអាមេរិក។

៧.៥.៣. ឧក្រិដ្ឋកម្មសង្គ្រាម និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិ

ការរំលោភសិទ្ធិមនុស្សជាទ្រង់ទ្រាយធំ ជារឿយៗ កើតឡើងនៅក្នុងអំឡុងពេលសង្គ្រាម។ ការរំលោភបំពានធ្ងន់ធ្ងរក្នុងប្រភេទនេះត្រូវបានចាត់ទុកថាជា**ឧក្រិដ្ឋកម្មសង្គ្រាម**(war crimes)។ នៅក្នុងសម័យសង្គ្រាមច្បាប់អន្តរជាតិពិបាកត្រូវបានអនុវត្តណាស់ ប៉ុន្តែបទដ្ឋានទូលំទូលាយនៃការប្រព្រឹត្តតាមផ្លូវច្បាប់ក្នុងសង្គ្រាម

ក៏ដូចជាសន្ធិសញ្ញាអន្តរជាតិត្រូវបានអនុវត្តយ៉ាងទូលំទូលាយ។ បន្ទាប់ពីសង្គ្រាម ភាគីបរាជ័យអាចត្រូវបានដាក់ទណ្ឌកម្មចំពោះការបំពានច្បាប់នៃសង្គ្រាម ដូចដែលមេដឹកនាំអាឡឺម៉ង់ស្ថិតនៅក្នុងការកាត់ទោសរបស់តុលាការនូរ៉ែមប៊ឺក (Nuremberg) បន្ទាប់ពីសង្គ្រាមលោកលើកទី ២។ ដោយសារការសម្លាប់ជនស៊ីវិលរបស់ណាហ្ស៊ីមិនបានបំពានច្បាប់ជាតិអាឡឺម៉ង់ តុលាការនូរ៉ែមប៊ឺក បានចាត់ទុកទង្វើដ៏ប្រល័យនោះជាប្រភេទថ្មី **ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ**(crimes against humanity) ដោយចាត់ទុកថាជា អំពើអមនុស្សធម៌ និងការធ្វើទុក្ខបុកម្នេញលើជនស៊ីវិល ក្នុងទ្រង់ទ្រាយធំ ដោយមធ្យោបាយដោយអយុត្តិធម៌បំផុត (សូមមើលឧទាហរណ៍បន្ថែម ការស្វែងរក)។

នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ ជាលើកដំបូងចាប់តាំងពីសង្គ្រាមលោកលើកទី២ ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិបានអនុញ្ញាតអោយមានតុលាការឧក្រិដ្ឋកម្មសង្គ្រាមអន្តរជាតិមួយ ដែលសំដៅប្រឆាំងនឹងឧក្រិដ្ឋកម្មសង្គ្រាមនៅក្នុងអតីតប្រទេសយូហ្គោស្លាវី។ តុលាការស្រដៀងគ្នានេះ ក្រោយមក ត្រូវបានបង្កើតឡើងសម្រាប់ការប្រល័យពូជសាសន៍ នៅក្នុងប្រទេសរវ៉ាន់ដា និងសៀរ៉ាឡេអូន។ សាលាក្តីលើអតីតប្រទេសយូហ្គោស្លាវី ដែលមានទីស្នាក់ការនៅទីក្រុងឡាអេនៃប្រទេសហូឡង់ បានចេញដីកាចោទប្រកាន់លើមេដឹកនាំកំពូលស៊ែប៊ីបូស្នៀ និងបណ្តាមន្ត្រីស៊ែប៊ីនិងក្រូអាតផ្សេងទៀត ហើយនៅឆ្នាំ ១៩៩៩ បានចោទប្រកាន់បុរសខ្លាំងស៊ែប៊ី ឈ្មោះ ស្លូបូដាន មីឡូសេវីក (Slobodan Milosevic) ចំពោះការបណ្តេញជនជាតិអាល់បានីចេញពីកូសូវ៉ូ។ សាលាក្តីនេះត្រូវបានរារាំងដោយកង្វះថវិកា និងដោយកង្វះអំណាចក្នុងការចាប់ខ្លួនជនសង្ស័យនានា ដែលត្រូវបានការពារដោយ*ភាពមិនអាចរំលោភបាន* លើអធិបតេយ្យភាពស៊ែប៊ីនិងក្រូអាត។ បន្ទាប់ពីបុរសខ្លាំងមីឡូសេវីកបាត់បង់អំណាចនៅប្រទេសស៊ែប៊ី រដ្ឋាភិបាលស៊ែប៊ីថ្មីបានប្រគល់ខ្លួនគាត់អោយទៅសាលាក្តីនៅឆ្នាំ ២០០១ ហើយគាត់បានស្លាប់នៅក្នុងមន្ទីរឃុំឃាំងនៅឆ្នាំ ២០០៦។ នៅត្រឹមឆ្នាំ ២០១១ គ្មានឧក្រិដ្ឋជនសង្គ្រាមបូស្នៀណាម្នាក់រួចខ្លួនឡើយ ហើយនៅចុងឆ្នាំ ២០១២ សាលាក្តីរវ៉ាន់ដាក៏បានកាត់ក្តីបញ្ចប់ទាំង ៧១ ករណីរបស់ខ្លួន។ ក្នុងចំណោមករណីជាច្រើន ការកាត់ទោសចុងក្រោយមួយក្នុងប្រទេសបូស្នៀត្រូវបានបញ្ចប់ក្នុងឆ្នាំ ២០១៧ ជាមួយនឹងសាលក្រមកាត់ទោសលើអតីតឧត្តមសេនីយជនជាតិស៊ែប៊ីបូស្នៀ ដែលដំណើរការកាត់ក្តីប្រព្រឹត្តិទៅ អស់រយៈពេលជាង ៥០០ ថ្ងៃ និងរួមបញ្ចូលសាក្សី ៥០០ នាក់ និងវត្ថុតាងចំនួន ១០០០០ ។

បន្ទាប់ពីសង្គ្រាមស៊ីវិលនៅប្រទេសសៀរ៉ាឡេអូន រដ្ឋាភិបាលនៅទីនោះបានបើកសវនាការកាត់ទោសឧក្រិដ្ឋកម្មសង្គ្រាម រួមជាមួយអង្គការសហប្រជាជាតិ។ ក្នុងឆ្នាំ ២០០៣ តុលាការបានចោទប្រកាន់មេដឹកនាំកំពុងកាន់អំណាចរដ្ឋនៅក្នុងប្រទេសជិតខាង លីបេរីយ៉ា លោក ឆាលស៍ ថៃល័រ (Charles Taylor) សម្រាប់តួនាទីរបស់គាត់នៅក្នុងសង្គ្រាមដ៏ឃោរឃៅបំផុត។ ភ្លាមៗនោះ គាត់បានភៀសខ្លួនទៅប្រទេសនីហ្សេរីយ៉ា ប៉ុន្តែ ត្រូវចាប់ខ្លួននៅទីនោះ បញ្ជូនទៅសាលាក្តីនៅឆ្នាំ ២០០៦ ហើយកាត់ទោសនៅឆ្នាំ ២០១២។

បន្ទាប់ពីដំណើរការកាត់ក្តីរបស់អង្គការសហប្រជាជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងរវ៉ាន់ដាក្នុងឆ្នាំ ១៩៩៨ រដ្ឋភាគច្រើននៃពិភពលោកបានចុះហត្ថលេខាលើសន្ធិសញ្ញាដើម្បីបង្កើត**តុលាការឧក្រិដ្ឋកម្មអន្តរជាតិ**អចិន្ត្រៃយ៍(ICC)។ វាជំនុំជំរះករណីប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពីគ្រប់ទិសទីក្នុងពិភពលោក។ តុលាការឧក្រិដ្ឋកម្មអន្តរជាតិបានបើកដំណើរការ ក្នុងឆ្នាំ ២០០៣ នៅទីក្រុងឡាអេ ដោយមានចៅក្រមចំនួន ១៨ នាក់ ដែលបានស្បថចូលកាន់តំណែងមកពីជុំវិញពិភពលោក

(លើកលែងតែសហរដ្ឋអាមេរិក)។ ក្នុងឆ្នាំ ២០០៨ តុលាការឧក្រិដ្ឋកម្មអន្តរជាតិ បានចាប់ផ្តើមការកាត់ក្តីលើកដំបូងរបស់ខ្លួន លើមេដឹកនាំកងដីវពលមកពីប្រទេសប្រជាធិបតេយ្យកុងហ្គោ ដែលត្រូវបានចោទប្រកាន់ពីបទចាប់កុមារអាយុក្រោម១៥ឆ្នាំមកធ្វើទាហាន និងបានសម្លាប់ជនស៊ីវិលជាច្រើន។ គាត់ត្រូវបានកាត់ទោសក្នុងឆ្នាំ ២០១២។

រូបថត រណ្តៅសាកសពរួមនៅបូស្នៀ

សំណល់នៃឧក្រិដ្ឋកម្មសង្គ្រាម

ឧក្រិដ្ឋកម្មសង្គ្រាមរួមមានការកំណត់គោលដៅដោយមិនចាំបាច់ទៅលើជនស៊ីវិល និងការទារុណកម្មលើអ្នកទោសសង្គ្រាមឬឈ្លើយសឹក (POWs)។ ឧក្រិដ្ឋកម្មសង្គ្រាមដ៏ល្បីល្បាញបំផុតនៅអឺរ៉ុប ក្រោយសង្គ្រាមលោកលើកទី ២ គឺការសម្លាប់រង្គាលបុរសនិងក្មេងប្រុស ជាង ៧០០០ នាក់ ដោយកងកម្លាំងស៊ែប៊ី ដែលបានគ្រប់គ្រងលើ «តំបន់សុវត្ថិភាព» របស់អង្គការសហប្រជាជាតិ នៅស្រេប្រេនីកា (Srebrenica) នៃប្រទេសបូស្នៀក្នុងឆ្នាំ ១៩៩៥។ នៅទីនេះ ផ្នូររួមដ៏ធំនៅទីនោះត្រូវបានដីកនៅឆ្នាំ ២០០៧ ។.

អ្វីដែលធ្វើអោយតុលាការឧក្រិដ្ឋកម្មអន្តរជាតិមានភាពខុសគេ(និងភាពចម្រូងចម្រាស)គឺគោលគំនិតនៃ *យុត្តាធិការសកល* (universal jurisdiction) ដែលថាតុលាការឧក្រិដ្ឋកម្មអន្តរជាតិ មានដែនសមត្ថកិច្ចក្នុងការកាត់ទោសបុគ្គលនៃប្រជាជាតិណាមួយក៏បាន។ នេះធ្វើអោយតុលាការឧក្រិដ្ឋកម្មអន្តរជាតិខុសពីតុលាការពិភពលោកដែលមានត្រឹមតែរដ្ឋប៉ុណ្ណោះអាចជាដើមបណ្តឹងនិងចុងចោទ។ នៅក្រោមដែនសមត្ថកិច្ចរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ បុគ្គលនីមួយៗអាចត្រូវបានកាត់ទោសចំពោះតួនាទីរបស់ពួកគេក្នុងទង្វើរំលោភសិទ្ធិមនុស្ស។ យន្តការបីអាចជម្រុញអោយមានការកាត់ក្តីដោយតុលាការឧក្រិដ្ឋកម្មអន្តរជាតិ។ ទីមួយ រដ្ឋអាចបញ្ជូនបុគ្គលណាម្នាក់សម្រាប់ការកាត់ក្តី ប្រសិនបើរដ្ឋយល់ព្រមធ្វើដូច្នេះ។ ទីពីរ ដោយប្រឆាំងនឹងបំណងរបស់រដ្ឋមួយ ព្រះរាជអាជ្ញាពិសេសនៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិអាចចាប់ផ្តើមការកាត់ក្តី ប្រសិនបើឧក្រិដ្ឋកម្មបានកើតឡើងនៅលើទឹកដីដែលជាហត្ថលេខីនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ។ ទីបី ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិអាចចាប់ផ្តើមដំណើរការ ប្រឆាំងសូម្បីតែបុគ្គលណាម្នាក់មកពីរដ្ឋមិនចុះហត្ថលេខា។ គេសង្ឃឹមថា បន្ថែមពីលើការកាត់ទោសករណីឧក្រិដ្ឋកម្មសង្គ្រាមនីមួយៗ តុលាការឧក្រិដ្ឋកម្មអន្តរជាតិក៏នឹងបំពេញការងារដើម្បីរារាំងទប់ស្កាត់មុខសញ្ញាអ្នកបំពានបទដ្ឋានទាំងនេះ ដោយសារតែការគំរាមកំហែងក្នុងការកាត់ទោស។

សហរដ្ឋអាមេរិកបានបដិសេធមិនផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ហើយបង្ហាញចំណាប់អារម្មណ៍តិចតួចក្នុងការធ្វើដូច្នេះ (ប្រធានាធិបតី ចច វ. ប៊ូស បានលុបការចុះហត្ថលេខាអាមេរិកពិសន្ធិសញ្ញានេះ)។ លើសពីនេះ សហរដ្ឋអាមេរិកបានគាបសង្កត់រដ្ឋសមាជិកតុលាការឧក្រិដ្ឋកម្មអន្តរជាតិជាច្រើនអោយចុះហត្ថលេខាលើកិច្ចព្រមព្រៀងអភ័យឯកសិទ្ធិ(ដែលត្រូវបានស្គាល់ជាកិច្ចព្រមព្រៀងអភ័យឯកសិទ្ធិទ្វេភាគី[BIAs]) ដើម្បីការពារទាហានអាមេរិកដែលបម្រើនៅក្នុងប្រទេសទាំងនោះអោយរួចផុតពីការកាត់ទោស។ ក្នុងឆ្នាំ ២០០៥ បន្ទាប់ពីសមាជិក ICC ជាច្រើនបានបដិសេធមិនចុះហត្ថលេខាលើកិច្ចព្រមព្រៀងអភ័យឯកសិទ្ធិទ្វេភាគី សភាអាមេរិកបានបោះឆ្នោតកាត់ជំនួយបរទេសដល់រដ្ឋទាំងនោះ។ មេដឹកនាំសហរដ្ឋអាមេរិកមានការព្រួយបារម្ភថា ទាហានអាមេរិកដែលបម្រើក្នុងបេសកកម្មរក្សាសន្តិភាព ឬ នៅក្នុងសម្ព័ន្ធមិត្តណាតូនឹងស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ ជាជាងក្រោមប្រព័ន្ធយុត្តិធម៌

របស់យោធាអាមេរិកផ្ទាល់ខ្លួន។ ប្រាកដណាស់ នៅឆ្នាំ ២០១៧ ព្រះរាជអាជ្ញាកំពូលនៃតុលាការឧក្រិដ្ឋកម្ម អន្តរជាតិបានគូសបញ្ជាក់ថា ទាហានអាមេរិកប្រហែលជាបានប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាម នៅក្នុងប្រទេស អាហ្វហ្គានីស្ថាន ដែលទំនងជានឹងលុបបំបាត់លទ្ធភាពដែលសហរដ្ឋអាមេរិកនឹងចូលរួមជាមួយតុលាការ នា ពេលអនាគតខាងមុខ។

ឧក្រិដ្ឋកម្មសង្គ្រាមនៅទីក្រុងដារហ្វួរនៃប្រទេសស៊ូដង់ ដែលគណៈកម្មការអង្គការសហប្រជាជាតិបាន រកឃើញថា «អំពើប្រល័យពូជសាសន៍ធ្ងន់ធ្ងរ» ត្រូវបានបញ្ជូនទៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិផងដែរ បន្ទាប់ ពីសហរដ្ឋអាមេរិកបានទម្លាក់ការជំទាស់របស់ខ្លួនក្នុងឆ្នាំ ២០០៥ (នៅពេលដែលអភ័យឯកសិទ្ធិលើកលែង ចំពោះទាហានអាមេរិកដែលបម្រើក្នុងប្រតិបត្តិការរក្សាសន្តិភាពត្រូវបានស្តារឡើងវិញ)។ ករណីដារហ្វួរ គឺជា បញ្ហាប្រឈមដ៏លំបាកមួយ សម្រាប់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ។ ក្នុងឆ្នាំ ២០០៩ តុលាការឧក្រិដ្ឋកម្ម អន្តរជាតិបានចោទប្រកាន់ប្រធានាធិបតីស៊ូដង់ដែលកំពុងតំណែងគឺ លោក អូម៉ារ អាល់-បាសៀរ (Omar al-Bashir) ពីបទឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងបានចេញដីកាចាប់ខ្លួនគាត់។ ការ ចោទប្រកាន់នេះបានធ្វើអោយរដ្ឋាភិបាលស៊ូដង់ខឹងសម្បារ ដែលបន្ទាប់មក បានបណ្តេញអង្គការមនុស្សធម៌ ចេញពីទីក្រុងដារហ្វួរ។ ក្នុងឆ្នាំ ២០១០ លោក អាល់-បាសៀរបានចាកចេញពីប្រទេសស៊ូដង់ជាលើកដំបូង ប៉ុន្តែ ប្រទេសគោលដៅរបស់គាត់ គឺប្រទេសឆាដ បានបដិសេធមិនចាប់ខ្លួនគាត់ ដោយលើកឡើងពីភាព លំអៀងនៅក្នុងតុលាការឧក្រិដ្ឋកម្មអន្តរជាតិ។ តុលាការឧក្រិដ្ឋកម្មអន្តរជាតិ មែនទែនទៅ ត្រូវប្រឈមមុខនឹង ការរក្សាគុណ្យភាពដ៏លំបាកមួយ ក្នុងការធ្វើអោយមន្ត្រីនៅក្នុងប្រទេសស៊ូដង់មានទំនួលខុសត្រូវ ប៉ុន្តែមានភាព រសើបចំពោះកិច្ចខិតខំប្រឹងប្រែងដើម្បីបញ្ចប់អំពើហិង្សានៅក្នុងទីក្រុង ដារហ្វួរ។ ក្នុងឆ្នាំ ២០១១ តុលាការ ឧក្រិដ្ឋកម្មអន្តរជាតិបានចោទប្រកាន់ជនផ្តាច់ការលីប៊ី និងមនុស្សជាច្រើននាក់ផ្សេងទៀត យ៉ាងឆាប់រហ័ស ប៉ុន្តែជនផ្តាច់ការត្រូវបានគេសម្លាប់មុនពេលប្រឈមមុខនឹងយុត្តិធម៌។

ការលំបាកនេះបានកើនឡើងក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ដោយសារប្រទេសអាហ្វ្រិកកាន់តែច្រើនបានចោទ ប្រកាន់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ ពីភាពលំអៀងប្រឆាំងនឹងមេដឹកនាំអាហ្វ្រិក។ នៅឆ្នាំ ២០១៥ អាហ្វ្រិក ខាងត្បូងបានបដិសេធមិនចាប់ខ្លួនលោកអាល់-បាសៀរ នៅពេលគាត់កំពុងចូលរួមកិច្ចប្រជុំកំពូលនៃមេដឹកនាំ អាហ្វ្រិក នៅក្នុងប្រទេសនោះ។ ភ្លាមៗនោះ តុលាការឧក្រិដ្ឋកម្មអន្តរជាតិបានរិះគន់អាហ្វ្រិកខាងត្បូងចំពោះ ការខកខានក្នុងការគោរពច្បាប់អន្តរជាតិ ដែលនាំអោយអាហ្វ្រិកខាងត្បូងប្រកាសដកខ្លួនចេញពីតុលាការ រួម ជាមួយនឹងរដ្ឋអាហ្វ្រិកដទៃទៀត ដូចជា ប៊ូរុនឌី (Burundi) និង ហ្គាមប៊ៀ (Gambia) (ក្រោយមក ប្រទេស អាហ្វ្រិកខាងត្បូងនិងហ្គាមប៊ៀ បានលុបចោលការសម្រេចចិត្តចាកចេញរបស់ពួកគេវិញ)។ មេដឹកនាំអាហ្វ្រិក ជាច្រើនបានចង្អុលបង្ហាញយ៉ាងច្បាស់ថា ស្ទើរតែគ្រប់សកម្មភាពនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ បានកើត ឡើងនៅលើទ្វីបរបស់ពួកគេ។ ពួកគេប្រកែកថា រដ្ឋផ្សេងក្រៅពីអាហ្វ្រិកក៏គួរត្រូវបានស៊ើបអង្កេតដែរ។ (នៅ ក្នុងនិមិត្តរូបនៃសាមគ្គីភាព ប្រទេសរុស្ស៊ីបានដកហត្ថលេខារបស់ខ្លួន ចេញពីសន្ធិសញ្ញាតុលាការឧក្រិដ្ឋកម្ម អន្តរជាតិ ក្នុងឆ្នាំ ២០១៦។)

គោលការណ៍ដ៏សំខាន់បំផុតនៅក្នុងច្បាប់នៃសង្គ្រាម គឺការខិតខំប្រឹងប្រែងដើម្បីកម្រិតសង្គ្រាមត្រឹមតែ រវាងយុទ្ធជនប្រយុទ្ធ និងដើម្បីការពារជនស៊ីវិល។ វាជារឿងខុសច្បាប់ក្នុងការកំណត់គោលដៅវាយប្រហារលើ ជនស៊ីវិល នៅក្នុងសង្គ្រាម។ ទោះយ៉ាងណាក៏ដោយ វាមិនខុសច្បាប់ទេ ដើម្បីកំណត់គោលដៅលើកងកម្លាំង

យោធា ដោយដឹងថា ជនស៊ីវិលអាចនឹងត្រូវសម្លាប់។ ទោះបីជាក្នុងករណីនោះក៏ដោយ បរិមាណកងកម្លាំងដែលប្រើប្រាស់ត្រូវតែ*សមាមាត្រ*ទៅនឹងការមានប្រៀបខាងយោធា ហើយចំនួនកងកម្លាំង*ចាំបាច់*ប៉ុណ្ណោះដែលអាចប្រើប្រាស់បាន។

ក្នុងឆ្នាំ ២០១៧ រដ្ឋាភិបាលភូមាបានឆ្លើយតបទៅនឹងការវាយប្រហារលើទីស្នាក់ការសន្តិសុខមួយដោយក្រុមជនជាតិភាគតិចមូស្លីម ហៅថា រ៉ូហ៊ីងយ៉ា ដោយកំណត់គោលដៅលើភូមិដ្ឋានរាប់រយ ដែលមានជនជាតិភាគតិចរ៉ូហ៊ីងយ៉ាភាគច្រើន។ ផ្ទះរាប់ពាន់ខ្នងត្រូវភ្លើងឆេះ ហើយរបាយការណ៍នៃការសម្លាប់រង្គាលបានលេចឡើងក្នុងប៉ុន្មានសប្តាហ៍បន្ទាប់មក។ ក្នុងពេលជាមួយគ្នានោះ ជនជាតិរ៉ូហ៊ីងយ៉ារាប់ពាន់នាក់បានភៀសខ្លួនចេញពីប្រទេសភូមាទៅកាន់បង់ក្លាដែស ដែលជាប្រទេសជិតខាង។ អង្គការក្រៅរដ្ឋាភិបាលបានប៉ាន់ប្រមាណថា មានជនជាតិរ៉ូហ៊ីងយ៉ាជិត ៦០០០០០ នាក់ បានធ្វើចំណាកស្រុក ជាលទ្ធផលនៃអំពើហិង្សាដែលប្រព្រឹត្តឡើងដោយកងទ័ពដែលគ្រប់គ្រងប្រទេសភូមា។ ប្រទេសជាច្រើន រួមទាំងសហរដ្ឋអាមេរិក បានដាក់ស្លាកសម្គាល់អាកប្បកិរិយារបស់ភូមាថាជា «ការបោសសម្អាតជាតិសាសន៍»។ ប្រទេសទាំងនេះបានអះអាងថា ដោយសារតែការឆ្លើយតបរបស់កងទ័ពភូមាមិនសមាមាត្រ និងលើសចំនួនកងកម្លាំងចាំបាច់ ម្លោះហើយវាចូលដល់កម្រិតឧក្រិដ្ឋកម្មសង្គ្រាម។

ដើម្បីញែកយុទ្ធជនអោយដាច់ដោយឡែកពីជនស៊ីវិល ទាហានត្រូវស្លៀកពាក់ឯកសណ្ឋាននិងគ្រឿងសំគាល់ខ្លួន ដូចជាអាវការពារដែលមានទង់ជាតិ។ បញ្ញត្តិបែបនេះត្រូវបានរំលោភបំពានជាញឹកញាប់នៅក្នុងសង្គ្រាមទំពែ ដែលធ្វើអោយសង្គ្រាមប្រភេទនេះ កាន់តែឃោរឃៅនិងបំផ្លាញជីវិតជនស៊ីវិលច្រើន។ ប្រសិនបើគេមិនអាចមើលឃើញភាពខុសគ្នារវាងជនស៊ីវិលនិងយុទ្ធជននោះ គេនឹងសម្លាប់ជនទាំងពីរក្រុមក្នុងករណីមិនច្បាស់ថាណាជាណា។ ផ្ទុយទៅវិញ នៅក្នុងសង្គ្រាមទូទៅទ្រង់ទ្រាយធំ វាកាន់តែងាយស្រួលក្នុងការបែងចែកជនស៊ីវិលពីទាហាន ទោះបីជាកិច្ចខិតខំប្រឹងប្រែងមិនទទួលបានជោគជ័យទាំងស្រុងក៏ដោយ។ នៅពេលដែលកងកម្លាំងពិសេសរបស់អាមេរិក នៅអាហ្វហ្គានីស្ថានបានចង់សម្ព័ន្ធមិត្តជាមួយអ្នកប្រយុទ្ធក្នុងតំបន់ដោយប្រតិបត្តិការគ្មានឯកសណ្ឋាននិងដោយមានតែពុកចង្ការ ខណៈភ្នាក់ងារជំនួយមនុស្សធម៌បានត្អូញត្អែរ ហើយមន្ទីរបញ្ចកោណបានបញ្ជាអោយទាហានត្រឡប់ទៅស្លៀកពាក់ឯកសណ្ឋានវិញ។ នៅក្នុងសង្គ្រាមអ៊ីរ៉ាក់ ក្រុមបះបោរបានកំណត់គោលដៅម្តងហើយម្តងទៀតទៅលើជនស៊ីវិល និងបានវាយប្រហារក្នុងសម្លៀកបំពាក់ស៊ីវិល ចាប់ពីមន្ទីរពេទ្យនិងសាលារៀន ហើយបន្ទាប់ពីបានក្លែងបន្លំធ្វើជាចុះចាញ់—ដែលទង្វើទាំងអស់នោះសុទ្ធតែប្រឆាំងនឹងច្បាប់នៃសង្គ្រាម។

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ កំណើនដែលមិនធ្លាប់មានពីមុនមក ក្នុងការប្រើប្រាស់កងកម្លាំងយោធាឯកជនក្នុងសង្គ្រាម ជាពិសេសនៅក្នុងប្រទេសអ៊ីរ៉ាក់ បានប្រឆាំងនឹងច្បាប់សង្គ្រាម។ ដោយសារតែកងកម្លាំងឯកជនទាំងនេះមិនមែនជាសមាជិកនៃយោធារបស់ប្រទេសណាមួយ ច្បាប់អន្តរជាតិនៃសង្គ្រាមមិនចាំបាច់អនុវត្តចំពោះពួកគេទេ (មានតែរដ្ឋចុះហត្ថលេខាលើអនុសញ្ញាទីក្រុងហ្សឺណែវ មិនមែនសាជីវកម្មឬក្រុមហ៊ុនឯកជនទេ)។ នៅក្នុងប្រទេសអ៊ីរ៉ាក់ រដ្ឋាភិបាលសហរដ្ឋអាមេរិកបានផ្តល់ការលើកលែងចំពោះក្រុមហ៊ុនទាំងនេះ ដើម្បីធានាថាពួកគេមិនអាចត្រូវបានកាត់ទោសពីបទរំលោភច្បាប់អន្តរជាតិ ត្រឹមតែច្បាប់ជាតិប៉ុណ្ណោះ។ ប៉ុន្តែដោយសារតែមិនមានរដ្ឋាភិបាលអ៊ីរ៉ាក់ផ្លូវការ គ្មាននរណាម្នាក់អាចពង្រឹងការអនុវត្តការរំលោភច្បាប់ក្នុងស្រុក ដែលប្រព្រឹត្តដោយក្រុមហ៊ុនទាំងនេះទេ។ ឧប្បត្តិហេតុល្បីល្បាញជាច្រើន (រួមទាំងការ

រំលោភបំពាននៅពន្ធនាគារអាប៊ូ ហ្គ្រាប (Abu Ghraib) និងការបាញ់សម្លាប់ជនស៊ីវិលជាច្រើននាក់) បាននាំអោយសភា អង្គការសហប្រជាជាតិ និងអ៊ីរ៉ាក់ផ្ទាល់ជាអ្នកបង្ខំអោយកងកម្លាំងឯកជនទទួលខុសត្រូវ។

ទាហានមានសិទ្ធិក្រោមច្បាប់នៃសង្គ្រាម ក្នុងពេលទម្លាក់អាវុធសុំចុះចាញ់ ពោលគឺបោះបង់ចោលឋានៈជាអ្នកប្រយុទ្ធ ហើយក្លាយជា **ឈ្លើយសឹក** ឬ **អ្នកទោសនៃសង្គ្រាម** (POWs)។ ពួកគេបោះបង់ចោលអាវុធនិងសិទ្ធិក្នុងការប្រយុទ្ធរបស់ពួកគេ ហើយជំនួសមកវិញទទួលបានសិទ្ធិ (ដូចជនស៊ីវិល) ដែលមិនត្រូវបានកំណត់គោលដៅវាយប្រហារឡើយ។ ឈ្លើយសឹកមិនអាចត្រូវបានគេសម្លាប់ ធ្វើទារុណកម្ម ឬបង្ខំអោយបញ្ចេញព័ត៌មានក្រៅពីឈ្មោះ ឋានៈ និងអត្តលេខផ្ទាល់ខ្លួននោះទេ។ ច្បាប់ឈ្លើយសឹក ត្រូវបានអនុវត្តតាមរយៈគោលការណ៍បដិការជាក់ស្តែង។ នៅពេលមួយ នៅចុងសង្គ្រាមលោកលើកទី ២ កងកម្លាំងអាឡឺម៉ង់បានប្រហារជីវិតឈ្លើយសឹក ៨០ នាក់ ពីភាគីកងកម្លាំងបារាំង (ដែលអាឡឺម៉ង់មិនបានទទួលស្គាល់ថាជាអ្នកបះបោរស្របច្បាប់)។ ភាគីបារាំងបានឆ្លើយតបវិញ ដោយប្រហារជីវិតឈ្លើយសឹកអាឡឺម៉ង់ចំនួន ៨០ នាក់។

ច្បាប់នៃសង្គ្រាមក្សាតួនាទីពិសេស សម្រាប់**គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ** (ICRC)។ គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ ផ្តល់ការគាំទ្រជាក់ស្តែង ដូចជាការថែទាំវេជ្ជសាស្ត្រ អាហារ និងសេវាសំបុត្រពីផ្ទះ ទៅដល់ជនស៊ីវិលដែលជាប់ក្នុងអន្លង់សង្គ្រាម និងទៅដល់ឈ្លើយសឹក។ ការដោះដូរឈ្លើយសឹក ជាធម្មតាត្រូវបានចរចាតាមរយៈគណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ។ កងកម្លាំងប្រដាប់អាវុធទាំងសងខាងត្រូវតែគោរពអព្យាក្រឹតភាពរបស់កាកបាទក្រហម ហើយជាធម្មតាត្រូវបានអនុវត្តតាម (សង្គ្រាមទំពាំព្រៃបង្កជាបញ្ហា)។ នៅក្នុងសង្គ្រាមប្រឆាំងអំពើភេរវកម្មបច្ចុប្បន្ន សហរដ្ឋអាមេរិកមិនចាត់ទុក «យុទ្ធជនខាងសត្រូវ» ដែលត្រូវបានអាមេរិកចាប់ឃុំខ្លួនថាជា ឈ្លើយសឹក នោះទេ ប៉ុន្តែបានផ្តល់សិទ្ធិអោយ គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ ចូលទៅសួរសុខទុក្ខពួកគេភាគច្រើន (បើទោះបីជាមិនមែនទាំងអស់) ក៏ដោយ។ អ្វីដែលបង្កភាពចម្រូងចម្រាសជាងនេះទៅទៀត គឺគោលនយោបាយរបស់សហរដ្ឋអាមេរិកដែលត្រូវគេហៅថា ការបកស្រាយវិសាមញ្ញ ដែលអនុញ្ញាតអោយជនសង្ស័យជាភេរវករ ដែលត្រូវបានចាប់ខ្លួននៅក្រៅប្រទេសត្រូវបានផ្ទេរទៅកាន់ប្រទេសផ្សេងទៀត រួមទាំងការធ្វើធ្វើទារុណកម្ម ដើម្បីសួរចម្លើយ។

ច្បាប់នៃសង្គ្រាមដាក់បន្ទុកទំនួលខុសត្រូវខាងសីលធម៌ទៅលើបុគ្គល ក៏ដូចជាលើរដ្ឋនានា ក្នុងសម័យសង្គ្រាម។ តុលាការនូរេមប៊ឺកបានបង្កើតមូលដ្ឋានច្បាប់ថា អ្នកចូលរួមអាចទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មសង្គ្រាមដែលពួកគេប្រព្រឹត្តផ្ទាល់។ មន្ត្រីអាឡឺម៉ង់បានការពារទង្វើរបស់ពួកគេថា «គ្រាន់តែធ្វើតាមបញ្ជា»តែប៉ុណ្ណោះ ប៉ុន្តែ ត្រូវបានគេច្រានចោល។ មន្ត្រីទាំងនោះត្រូវបានពិន័យ ហើយមួយចំនួនត្រូវប្រហារជីវិត សម្រាប់ឧក្រិដ្ឋកម្មសង្គ្រាមរបស់ពួកគេ។

ទោះយ៉ាងណាក៏ដោយ មិនមែនជនជាប់ចោទនូរេមប៊ឺកទាំងអស់ត្រូវបានតុលាការរកឃើញថាមានកំហុសនោះទេ។ ជាឧទាហរណ៍ ច្បាប់នៃសង្គ្រាមកម្រិតការប្រើប្រាស់កងកម្លាំងប្រឆាំងនឹងជនស៊ីវិល មកត្រឹមចំនួនឬទំហំចាំបាច់និងសមាមាត្រទៅនឹងគោលដៅយោធា។ នៅក្នុងសង្គ្រាមលោកលើកទី ២ កងទ័ពអាឡឺម៉ង់បានឡោមព័ទ្ធទីក្រុងលេនីនក្រាដ (Leningrad) ឬ (St.Petersburg) របស់រុស្ស៊ី អស់រយៈពេលពីរឆ្នាំ ហើយជនស៊ីវិលនៅក្នុងទីក្រុងត្រូវដាច់ស្បៀង។ ការឡោមព័ទ្ធប្រភេទនេះត្រូវបានអនុញ្ញាតក្រោមច្បាប់អន្តរជាតិ ប្រសិនបើកងទ័ពមិនអាចដណ្តើមយកទីក្រុងបានដោយងាយ។

បរិបទផ្លាស់ប្តូរ

ការផ្លាស់ប្តូរលក្ខណៈនៃសង្គ្រាមប៉ះពាល់ដល់ច្បាប់នៃសង្គ្រាម។ សង្គ្រាមទូទៅដែលធ្វើឡើង ដោយកងកម្លាំងប្រដាប់អាវុធជាក់លាក់ នៅលើសមរភូមិជាក់លាក់ អាចបើកចំហសម្រាប់សង្គ្រាមមិនទៀងទាត់និងមិនស៊ីមេទ្រីដែលប្រយុទ្ធដោយទ័ពព្រៃនិងក្រុមស្ម័គ្រស្លាប់នៅក្នុងទីក្រុងឬព្រៃភ្នំ។ ខ្សែបន្ទាត់ខ័ណ្ឌចែករវាងជនស៊ីវិលនិងទាហានត្រូវរលុបនៅក្នុងស្ថានភាពទាំងនេះ ហើយឧក្រិដ្ឋកម្មសង្គ្រាមកាន់តែក្លាយជារឿងធម្មតា។ នៅក្នុងសង្គ្រាមវៀតណាម បញ្ហាដ៏ធំបំផុតមួយដែលសហរដ្ឋអាមេរិកត្រូវប្រឈម គឺសត្រូវដែលហាក់ដូចជានៅរាយប៉ាយគ្រប់ទីកន្លែង តែរកមិនឃើញនៅទីកន្លែងណាមួយឡើយ (everywhere and nowhere)។ ប្រការនេះបានធ្វើអោយកងកម្លាំងអាមេរិកដែលកំពុងខកចិត្ត បើកការវាយប្រហារលើភូមិដ្ឋានជនស៊ីវិល ដែលត្រូវបានគេមើលឃើញថាបានគាំទ្រក្រុមទ័ពព្រៃ។ ក្នុងករណីដ៏អាក្រក់មួយ មន្ត្រីអាមេរិកម្នាក់ត្រូវបានតុលាការកាត់ទោសពីបទបញ្ជាទាហានរបស់គាត់អោយសម្លាប់ជនស៊ីវិលរាប់រយនាក់ ដែលគ្មានអាវុធនៅក្នុងភូមិមីឡៃ (My Lai) ក្នុងឆ្នាំ ១៩៦៨ (គាត់ត្រូវបានរកឃើញថាមានកំហុស ប៉ុន្តែ ត្រូវបានកាត់ទោសស្រាល)។ នៅក្នុងសង្គ្រាមមិនទៀងទាត់ នាពេលបច្ចុប្បន្ននេះ ដែលជារឿយៗត្រូវបានឆាបឆេះដោយជម្លោះ ជាតិសាសន៍និងសាសនា ច្បាប់នៃសង្គ្រាមកាន់តែពិបាកនឹងលើកកំពស់។

កត្តាមួយទៀតដែលរំខានដល់ច្បាប់នៃសង្គ្រាម គឺរដ្ឋកម្រចេញ*សេចក្តីប្រកាសសង្គ្រាម* (declaration of war) ដោយមិនកំណត់គោលដៅថាពួកគេកំពុងធ្វើសង្គ្រាមប្រឆាំងនឹងនរណា ហើយមូលហេតុអ្វីបានជាធ្វើសកម្មភាពបែបនេះ។ អ្វីដែលគួរអោយអស់សំណើចណាស់ បើមើលតាមប្រវត្តិសាស្ត្រ ការប្រកាសបែបនេះគឺជាករណីលើកលែង មិនមែនជាច្បាប់នោះទេ។ និន្នាការនេះនៅតែបន្តរហូតដល់សព្វថ្ងៃ ដោយសារតែការប្រកាសសង្គ្រាមនាំមកនូវអត្ថប្រយោជន៍តិចតួចបំផុតដល់រដ្ឋដែលប្រកាសសង្គ្រាម មិនត្រឹមតែប៉ុណ្ណោះថែមទាំងជាប់កាតព្វកិច្ចក្រោមច្បាប់អន្តរជាតិទៀតផង។ ក្នុងករណីជាច្រើន ដូចជាសង្គ្រាមស៊ីវិលដោយបដិវត្តន៍និងដោយការប្រឆាំងបដិវត្តន៍ ការប្រកាសបែបនេះក៏នឹងមិនសមរម្យដែរ ពីព្រោះសង្គ្រាមត្រូវបានប្រកាសសម្រាប់តែប្រឆាំងនឹងរដ្ឋប៉ុណ្ណោះ មិនមែនក្រុមផ្ទៃក្នុងប្រទេសទេ។ នៅក្នុងសង្គ្រាមដែលមិនបានប្រកាសភាពខុសគ្នារវាងអ្នកចូលរួមនិងអ្នកមិនចូលរួមត្រូវបានបំផ្លាញ (រួមជាមួយនឹងការការពារអ្នកមិនចូលរួម)។ រដ្ឋបាលលោកប្រធានាធិបតីប៊ូសបានហៅការវាយប្រហារភេរវកម្មឆ្នាំ ២០០១ ថាជាទង្វើនៃសង្គ្រាម ហើយការឆ្លើយតបថាជា សង្គ្រាមប្រឆាំងភេរវកម្ម ប៉ុន្តែ សកាមិនបានប្រកាសសង្គ្រាមជាផ្លូវការ ទេ (ដូចដែលពួកគេមិនបានប្រកាស កាលក្នុងកំឡុងសង្គ្រាមកូរ៉េ និងវៀតណាម)។

៧.៥.៤. ការខិតខំឆែសណ្តាប់ធ្នាប់ពិភពលោក

រដ្ឋដែលមានឥទ្ធិពលបំផុត ជាពិសេសរដ្ឋអនុត្តរភាព មានឥទ្ធិពលយ៉ាងខ្លាំងទៅលើច្បាប់ និងគុណតម្លៃដែលបានបង្កប់ ជាបន្តបន្ទាប់ក្នុងរយៈពេលកន្លងមក នៅក្នុងស្ថាប័ននៃច្បាប់អន្តរជាតិ។ ជាឧទាហរណ៍ គោលការណ៍នៃការឆ្លងកាត់ដោយសេរីនៅលើលំហសមុទ្រ បច្ចុប្បន្ននេះ ត្រូវបានបង្កើតឡើងជាផ្លូវការនៅក្នុងច្បាប់អន្តរជាតិ។ ប៉ុន្តែ កាលមិនទាន់មានច្បាប់នេះ នាវាចម្បាំងមកពីរដ្ឋមួយមិនមានការស្នាក់ស្នើរក្នុងការរឹបអូសយកកប៉ាល់របស់រដ្ឋផ្សេងទៀត រួមជាមួយនឹងទំនិញនៅលើកប៉ាល់នោះផង។ ការអនុវត្តបែបនេះ ពិតជាបានផ្តល់ផលចំណេញដល់រដ្ឋដែលបានធ្វើការវាយឆ្មក់បែបនេះ ប៉ុន្តែ ជាការឆ្លើយតប កប៉ាល់របស់ពួកគេផ្ទាល់ក៏អាចត្រូវបានគេវាយឆ្មក់វិញផងដែរ។ អាកប្បកិរិយាបែបនេះបានធ្វើអោយការជួញដូរផ្លូវឆ្ងាយកាន់តែ

គ្រោះថ្នាក់ ជាយថាហេតុ ដោយមិនអាចទាយទុកជាមុនបាន និងផ្តល់ផលចំណេញកាន់តែតិច។ រដ្ឋដែលធ្វើពាណិជ្ជកម្មអាចទទួលបានអត្ថប្រយោជន៍កាន់តែច្រើន ដោយការលុបបំបាត់ការអនុវត្តអាណាធិបតេយ្យបែបនេះ។ ម្លោះហើយ យូរៗទៅ បទដ្ឋានមួយត្រូវបានបង្កើតឡើង ជុំវិញគោលគំនិតនៃសេរីភាពក្នុងការធ្វើនាវាចរណ៍ នៅលើលំហសមុទ្រជ្រៅ។ វាបានក្លាយជាវិស័យមួយក្នុងចំណោមវិស័យដំបូងៗនៃច្បាប់អន្តរជាតិដែលត្រូវបានបង្កើតឡើង ដោយអ្នកប្រាជ្ញច្បាប់ហូឡង់ ឈ្មោះ ហ៊ុយហ្គោ ហ្គ្រោទៀស (Hugo Grotius) នៅពាក់កណ្តាលទសវត្សរ៍ ឆ្នាំ ១៦០០ ជាសម័យកាលដែលប្រទេសហូឡង់បានគ្រប់គ្រងបណ្តាញពាណិជ្ជកម្មពិភពលោក ហើយអាចទទួលបានអត្ថប្រយោជន៍ច្រើនបំផុតពីដំណើរការរុករកដោយសេរី។

ដូច្នេះហើយ អំណាចប្រទេសហូឡង់បានក្លាយជា ខ្នងបង្អែកសម្រាប់គោលគំនិតច្បាប់អន្តរជាតិស្តីពីសេរីភាពលើលំហសមុទ្រ។ ក្រោយមក នៅពេលដែលចក្រភពអង់គ្លេសមានអំណាចគ្រប់ដណ្តប់វិញម្តង វាបានអនុវត្តគោលការណ៍នៃលំហសមុទ្រសេរី តាមរយៈកាណុងកាំភ្លើងលើនាវាចម្បាំងរបស់ខ្លួន។ ក្នុងនាមជារដ្ឋពាណិជ្ជកម្មដ៏សំខាន់នៅលើពិភពលោក ចក្រភពអង់គ្លេសទទួលបានអត្ថប្រយោជន៍ពីបទដ្ឋានទូទាំងពិភពលោកស្តីពីការដឹកជញ្ជូននិងពាណិជ្ជកម្មដោយសេរី។ ហើយជាមួយនឹងកងទ័ពជើងទឹកដ៏មានឥទ្ធិពលបំផុតនៅលើពិភពលោកនាពេលនោះ ចក្រភពអង់គ្លេសស្ថិតនៅក្នុងទីតាំងមួយ ដើម្បីកំណត់និងអនុវត្តច្បាប់សម្រាប់មហាសមុទ្រនានាលើពិភពលោក។

ដូចគ្នានេះដែរ សណ្តាប់ធ្នាប់ពិភពលោកនៅសតវត្សរ៍ទី២០ ត្រូវពឹងផ្អែកយ៉ាងខ្លាំងទៅលើអំណាចរបស់សហរដ្ឋអាមេរិក (និងរយៈពេលពីរបីទសវត្សរ៍ ពឹងផ្អែកលើការបែងចែកអំណាចរវាងសហរដ្ឋអាមេរិកនិងសហភាពសូវៀត)។ ពេលខ្លះ សហរដ្ឋអាមេរិកបានខិតកាន់តែកៀក ក្នុងការទទួលយកតួនាទីច្បាស់លាស់ជា «កម្លាំងប៉ូលីសពិភពលោក»។ ប៉ុន្តែ តាមពិតទៅ ពិភពលោកទាំងមូលមានទំហំធំពេក ដែលមិនអាចរដ្ឋតែមួយ សូម្បីតែរដ្ឋអនុត្តរភាព បំពេញតួនាទីជាប៉ូលីសប្រកបដោយប្រសិទ្ធភាព។ ផ្ទុយទៅវិញ រដ្ឋនានាក្នុងពិភពលោកតែងតែអនុវត្តតាមច្បាប់ ដែលបង្កើតឡើងដោយរដ្ឋដែលមានអំណាចបំផុត ដោយមិនមានប៉ូលីសចាំពង្រឹងការអនុវត្តអោយបានជាប់លាប់។ ទន្ទឹមនឹងនេះ ពួកគេព្យាយាមមានឥទ្ធិពលលើច្បាប់ ដោយធ្វើការតាមរយៈស្ថាប័នអន្តរជាតិ (ដែលរដ្ឋអនុត្តរភាពបានប្រគល់អំណាចរបស់ខ្លួនមួយចំនួនផង)។ តាមរបៀបនេះ ទោះបីជារដ្ឋនានាមិនផ្តល់អធិបតេយ្យភាពរបស់ខ្លួនក៏ដោយ ក៏ពួកគេផ្តល់អំណាចនិងដែនសមត្ថកិច្ចមួយចំនួន នៅក្នុងស្ថាប័ននិងច្បាប់អន្តរជាតិ ហើយជាទូទៅនាំគ្នាធ្វើការក្នុងក្របខ័ណ្ឌនោះ។

កត្តារួមផ្សំចំនួនបីអង្រួនបទដ្ឋានអន្តរជាតិ ក្នុងយុគសម័យក្រោយសង្គ្រាមត្រជាក់៖ ចុងបញ្ចប់នៃសង្គ្រាមត្រជាក់ ការផ្លាស់ប្តូរដំហរសេដ្ឋកិច្ចនៃតំបន់និងរដ្ឋផ្សេងៗ និងឥទ្ធិពលនៃការផ្លាស់ប្តូរបច្ចេកវិទ្យាក្នុងការបង្កើតពិភពលោកតូចមួយ។ នយោបាយក្នុងស្រុកនិងក្នុងតំបន់ ឥឡូវ លេចចេញនៅលើឆាកសកល។ បទដ្ឋានថ្មីទាំងនេះនៅតែមិនទាន់កំណត់ច្បាស់នៅឡើយ។ ការពឹងទុកថ្មីកំពុងលេចឡើង ក្នុងវិស័យជាច្រើនដូចជា សិទ្ធិមនុស្ស ការរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ អន្តរាគមន៍មនុស្សធម៌ តួនាទីរបស់ប្រទេសរុស្ស៊ីនិងចិនក្នុងឋានៈជាប្រទេសមហាអំណាច និងតួនាទីរបស់សហរដ្ឋអាមេរិកជាប្រទេសមហាអំណាចផុតលេខ។ ទោះជាយ៉ាងណាក៏ដោយ បទដ្ឋានស្នូលនិងស្ថាប័នស្ថិរភាពបង្កើតទ្រង់ទ្រាយសេដ្ឋកិច្ចនយោបាយអន្តរជាតិ(IPE) (ដែលជាប្រធានបទនៃមេរៀនក្រោយៗក្នុងសៀវភៅនេះ) ដោយមានស្ថិរភាពច្រើនជាង

សន្តិសុខអន្តរជាតិ(IS)។ យើងត្រលប់ទៅពិភាក្សាចំណុចកំពូលនៃអង្គការអន្តរជាតិ ពោលគឺ សហភាពអឺរ៉ុប នៅក្នុងមេរៀនទី ១០។ ប៉ុន្តែ ជាដំបូង យើងនឹងពិនិត្យមើលការរៀបចំសេដ្ឋកិច្ចពិភពលោកសំខាន់ៗ។

សេចក្តីសន្និដ្ឋាន

១. អនាធិបតេយ្យអន្តរជាតិត្រូវប្តឹងផ្លែងអោយមានតុល្យភាពជាមួយនឹងសណ្តាប់ធ្នាប់ពិភពលោក ដែលជាវិធានឬច្បាប់និងស្ថាប័ននានាដែលរដ្ឋទាំងឡាយធ្វើការសហប្រតិបត្តិការគ្នា ដើម្បីផលប្រយោជន៍ទៅវិញទៅមក។

២. រដ្ឋអនុវត្តតាមវិធាននានា (ទាំងបទដ្ឋានសីលធម៌និងច្បាប់អន្តរជាតិផ្លូវការ) ភាគច្រើនអនុវត្តតាម ច្រើនជាងបំពាន។ បទបញ្ញត្តិទាំងនេះដំណើរការតាមរយៈស្ថាប័ននានា (អង្គការអន្តរជាតិ) ដែលមានអង្គការសហប្រជាជាតិនៅចំកណ្តាលនៃបណ្តាញស្ថាប័នទាំងអស់នេះ។

៣. អង្គការសហប្រជាជាតិឆ្លុះបញ្ចាំងពីភាពតានតឹង រវាងអធិបតេយ្យភាពរបស់រដ្ឋនិងដែនសមត្ថកិច្ចរបស់អង្គការអន្តរជាតិ។ ម្យ៉ាងដោយសារតែការគោរពអធិបតេយ្យភាពរបស់រដ្ឋ អង្គការសហប្រជាជាតិបានទាក់ទាញសមាជិកភាពជាសកល ពីសំណាក់រដ្ឋស្ទើរតែទាំងអស់នៅលើពិភពលោក រួមទាំងប្រទេសមហាអំណាចទាំងអស់ផងដែរ។

៤. អង្គការសហប្រជាជាតិជាពិសេសគោរពអធិបតេយ្យភាពនៃប្រទេសមហាអំណាច សមាជិកចំនួនប្រាំក្នុងចំណោមនោះ ជាសមាជិកក្រុមប្រឹក្សាសន្តិសុខអចិន្ត្រៃយ៍ អាចរារាំងរាល់ដំណោះស្រាយដែលពាក់ព័ន្ធនឹងសន្តិសុខដែលជាកាតព្វរបស់រដ្ឋជាសមាជិកអង្គការសហប្រជាជាតិទាំងអស់។ សមាជិកទាំងប្រាំនៃក្រុមប្រឹក្សាសន្តិសុខ រួមមាន សហរដ្ឋអាមេរិក បារាំង ចក្រភពអង់គ្លេស ចិន និងរុស្ស៊ី។

៥. រដ្ឋនីមួយៗក្នុងចំណោមសមាជិកអង្គការសហប្រជាជាតិទាំង ១៩៣ មានសម្លេងបោះឆ្នោតមួយ នៅក្នុងមហាសន្និបាតដែលមានតួនាទីជាវេទិកាពិភពលោក និងជាអង្គការមេដំបូល សម្រាប់កិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គម។

៦. អង្គការសហប្រជាជាតិ ត្រូវបានគ្រប់គ្រងដោយមន្ត្រីរាជការអន្តរជាតិ នៅក្នុងលេខាធិការដ្ឋាន ដែលដឹកនាំដោយអគ្គលេខាធិការមួយរូប។

៧. ថវិកាជាប្រចាំរបស់អង្គការសហប្រជាជាតិបូករួមទាំងបេសកកម្មថែរក្សាសន្តិភាព ជារួម មានចំនួនតិចជាង ៣ ភាគរយនៃទំហំនៃការចំណាយលើកម្លាំងយោធាលើពិភពលោក ។

៨. កងកម្លាំងរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិត្រូវបានគេដាក់ពង្រាយនៅក្នុងតំបន់ដែលមានជម្លោះក្នុងតំបន់ចំនួន ៥ ក្នុងពិភពលោក។ តួនាទីសំខាន់របស់ពួកគេ ត្រូវឃ្លាំមើលការអនុវត្តតាមកិច្ចព្រមព្រៀងដូចជា បទឈប់បាញ់ ផែនការរំសាយអាវុធ និងច្បាប់បោះឆ្នោតសេរីនិងយុត្តិធម៌។ វាត្រូវបានកាត់បន្ថយវិញយ៉ាងគំហក់ នៅក្នុងឆ្នាំ ១៩៩៥-១៩៩៧ បន្ទាប់មកបានកើនឡើងវិញ យ៉ាងឆាប់រហ័សចាប់តាំងពីឆ្នាំ ១៩៩៨ មក។

៩. អ្នកថែរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ធ្វើប្រតិបត្តិការក្រោមទង់និងបញ្ជាការរបស់អង្គការសហប្រជាជាតិ។ ពេលខ្លះ កងទ័ពជាតិធ្វើប្រតិបត្តិការនៅក្រោមទង់ជាតិនិងបញ្ជាការរបស់ខ្លួនផ្ទាល់ ដើម្បីអនុវត្តដំណោះស្រាយរបស់អង្គការសហប្រជាជាតិ។

១០. អង្គការអន្តរជាតិ (IOs) រួមមានកម្មវិធីផ្សេងៗរបស់អង្គការសហប្រជាជាតិ (ភាគច្រើនពាក់ព័ន្ធនឹងបញ្ហាសេដ្ឋកិច្ចនិងសង្គម) ទីភ្នាក់ងារអង្គការសហប្រជាជាតិស្វយ័ត និងអង្គការនានា ដែលមិនមានចំណងជាផ្លូវការជាមួយអង្គការសហប្រជាជាតិ។ បណ្តាញស្ថាប័ននេះជួយពង្រឹងនិងធ្វើអោយច្បាប់នៃទំនាក់ទំនងអន្តរជាតិ មានស្ថេរភាព។

១១. ច្បាប់អន្តរជាតិ ដែលជាកម្រងច្បាប់ផ្លូវការសម្រាប់ទំនាក់ទំនងរដ្ឋ កើតចេញពីសន្ធិសញ្ញា(ជាចំបង) ទំនៀមទម្លាប់ គោលការណ៍ទូទៅ និងអាហារូបករណ៍ច្បាប់ មិនមែនកើតពីច្បាប់ដែលអនុម័តដោយរដ្ឋាភិបាលជាតិណាមួយឡើយ។

១២. ច្បាប់អន្តរជាតិមានការលំបាកក្នុងការអនុវត្ត និងត្រូវបានពង្រឹងការអនុវត្តជាក់ស្តែងដោយអំណាចជាតិ សម្ព័ន្ធអន្តរជាតិ និងគោលការណ៍បដិការ។

១៣. តុលាការពិភពលោក បើកសវនាការលើបណ្តឹងតវ៉ារបស់រដ្ឋមួយ ប្រឆាំងនឹងរដ្ឋមួយទៀត ប៉ុន្តែមិនអាចរំលោភលើអធិបតេយ្យភាពរបស់រដ្ឋ ក្នុងករណីភាគច្រើន។ វាគឺជាវេទិកាដែលមានអត្ថប្រយោជន៍កាន់តែខ្លាំងឡើងសម្រាប់ដោះស្រាយជម្លោះតូចៗតាមអំពើចិត្ត។

១៤. តុលាការឧក្រិដ្ឋកម្មអន្តរជាតិ(ICC)អចិន្ត្រៃយ៍ បានចាប់ផ្តើមប្រតិបត្តិការ ក្នុងឆ្នាំ ២០០៣។ ដោយបន្តតំណែងពីសាលាក្តីអ.ស.ប.ចំនួនពីរ វាបើកសវនាការជំរុំជំរះក្តីពាក់ព័ន្ធនឹងអំពើប្រល័យពូជសាសន៍ ឧក្រិដកម្មអន្តរជាតិ និងឧក្រិដកម្មប្រឆាំងមនុស្សជាតិ។

១៥. នៅក្នុងច្បាប់អន្តរជាតិ អ្នកការទូតមានឋានៈពិសេសជាយូរណាស់មកហើយ។ ស្ថានទូតត្រូវបានចាត់ទុកថាជាទឹកដីរបស់ប្រទេសកំណើតរបស់ពួកគេ។

១៦. ច្បាប់នៃសង្គ្រាមក៏មាន ជាយូរមកហើយ និងត្រូវបានបង្កើតឡើងយ៉ាងល្អ។ ពួកគេបែងចែកអ្នកក្រុមប្រយុទ្ធខុសពីក្រុមជនស៊ីវិល ដោយផ្តល់សិទ្ធិនិងទំនួលខុសត្រូវជាក់លាក់ដល់ក្រុមនីមួយៗ។ សង្គ្រាមទំព្រៃនិងជម្លោះជាតិសាសន៍បានធ្វើអោយមានភាពខុសគ្នាទាំងនេះព្រិលទៅៗ។

១៧. បទដ្ឋានអន្តរជាតិទាក់ទងនឹងសិទ្ធិមនុស្សកំពុងកាន់តែរឹងមាំទៅៗ និងត្រូវបានទទួលយកជាទូទៅ។ ទោះយ៉ាងណា ច្បាប់សិទ្ធិមនុស្សនៅមានបញ្ហា ពីព្រោះវាពាក់ព័ន្ធនឹងការជ្រៀតជ្រែករបស់រដ្ឋមួយនៅក្នុងកិច្ចការផ្ទៃក្នុងរបស់ប្រទេសមួយផ្សេងទៀត។

ពាក្យគន្លឹះ

១. បទដ្ឋានអន្តរជាតិ (International Norms) គឺជាការរំពឹងទុកដោយសហគមន៍អន្តរជាតិ សម្រាប់អ្នកចូលរួមក្នុងទំនាក់ទំនងអន្តរជាតិ។

២. អង្គការអន្តរជាតិ (IOs) សំដៅលើអង្គការអន្តររដ្ឋាភិបាល(IGOs)ដូចជាអង្គការសហប្រជាជាតិ និងអង្គការមិនមែនរដ្ឋាភិបាល(NGOs)ដូចជាគណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ(ICRC)ជាដើម។

៣. ធម្មនុញ្ញអង្គការសហប្រជាជាតិ(UN Charter) គឺជាឯកសារបង្កើតអង្គការសហប្រជាជាតិ។វាផ្អែកលើគោលការណ៍សមភាពរបស់រដ្ឋ ដែលរដ្ឋនីមួយៗមានភាពស្មើគ្នា មានអធិបតេយ្យភាពលើកិច្ចការរបស់ខ្លួន មានឯករាជ្យភាពនិងបូរណភាពទឹកដី ហើយត្រូវតែបំពេញកាតព្វកិច្ចអន្តរជាតិ។ ធម្មនុញ្ញក៏ដាក់ចេញនូវរចនាសម្ព័ន្ធ និងវិធីសាស្ត្ររបស់អង្គការសហប្រជាជាតិផងដែរ។

៤. មហាសន្និបាតអង្គការសហប្រជាជាតិ(UN General Assembly) គឺជាស្ថាប័នមួយដែលមានតំណាងនៃរដ្ឋទាំងអស់ ដែលសម្រេចបែងចែកមូលនិធិរបស់អង្គការសហប្រជាជាតិ អនុម័តដំណោះស្រាយដែលមិនជាប់កាតព្វកិច្ច និងសម្របសម្រួលកម្មវិធីអភិវឌ្ឍន៍ប្រទេសតតិយលោក និងទីភ្នាក់ងារស្វ័យភាពផ្សេងៗ តាមរយៈក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម (ECOSOC)។

៥. ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ(UN Security Counsil) គឺជាស្ថាប័នដែលរួមមានប្រទេសមហាអំណាចចំនួនប្រាំ(ដែលអាចវេតូប្រឆាំងដំណោះស្រាយណាមួយ) និងរដ្ឋសមាជិកបង្ហូរវេនចំនួនដប់ប្រទេស ដែលធ្វើការសម្រេចចិត្តអំពីសន្តិភាពនិងសន្តិសុខអន្តរជាតិ រួមទាំងការបញ្ជូនកងកម្លាំងរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិផងដែរ។

៦. លេខាធិការដ្ឋានអង្គការសហប្រជាជាតិ(UN Secritary) គឺជាស្ថាប័ននីតិប្រតិបត្តិរបស់អង្គការសហប្រជាជាតិ ដែលដឹកនាំដោយអគ្គលេខាធិការមួយរូប។

៧. ការកសាងសន្តិភាព(Peacebuilding) សំដៅលើការប្រើប្រាស់កងរក្សាសន្តិភាពជាយោធា មន្ត្រីរដ្ឋបាលស៊ីវិល គ្រូបង្វឹកកងកម្លាំងប៉ូលីស និងការខិតខំប្រឹងប្រែងស្រដៀងគ្នា ដើម្បីរក្សាកិច្ចព្រមព្រៀងសន្តិភាព និងកសាងរដ្ឋាភិបាលប្រកបដោយស្ថិរភាព និងប្រជាធិបតេយ្យ នៅក្នុងសង្គមដែលឆើបចេញពីសង្គ្រាមស៊ីវិល។ ចាប់តាំងពីឆ្នាំ ២០០៥ មក គណៈកម្មការកសាងសន្តិភាពរបស់អង្គការសហប្រជាជាតិបានសម្របសម្រួល និងគាំទ្រសកម្មភាពទាំងនេះ។

៨. សន្និសីទអង្គការសហប្រជាជាតិស្តីពីពាណិជ្ជកម្មនិងការអភិវឌ្ឍន៍ (UNCTAD) គឺជារចនាសម្ព័ន្ធដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៦៤ ដើម្បីជំរុញការអភិវឌ្ឍន៍ប្រទេសតតិយលោកតាមរយៈសំណើពាណិជ្ជកម្មផ្សេងៗ។

៩. អង្គការសុខភាពពិភពលោក (WHO)គឺជាអង្គការមួយដែលមានមូលដ្ឋាននៅទីក្រុងហ្សឺណែវ ដែលផ្តល់ជំនួយបច្ចេកទេស ដើម្បីកែលម្អស្ថានភាពសុខភាព នៅក្នុងប្រទេសតតិយលោក និងធ្វើយុទ្ធនាការចាក់វ៉ាក់សាំងបង្ការសំខាន់ៗ។

១០. តុលាការពិភពលោក ឬ តុលាការយុត្តិធម៌អន្តរជាតិ (ICJ) គឺជាសាខាយុត្តាធិការនៃអង្គការសហប្រជាជាតិ។ ដោយមានទីតាំងនៅទីក្រុងឡាអេ វាបើកសវនាការជំរុំជំរះក្តីរវាងរដ្ឋនិងរដ្ឋប៉ុណ្ណោះ។

១១. តុលាការយុត្តិធម៌អន្តរជាតិ (ICJ) សូមមើល*តុលាការពិភពលោក*។

១២. ច្បាប់អន្តោប្រវេសន៍ គឺជាច្បាប់ជាតិដែលបង្កើតលក្ខខណ្ឌដែលជនបរទេសអាចធ្វើដំណើរ និងចូលទស្សនា និងធ្វើការក្នុងរដ្ឋនោះ ហើយជួនកាលអាចក្លាយជាពលរដ្ឋផងដែរ (ចូលសញ្ជាតិ)។

១៣. ការទទួលស្គាល់ការទូត(Diplomatic Recognition) គឺជាដំណើរការដែលហាន:របស់ស្ថានទូត និងឯកអគ្គរដ្ឋទូត ជាអ្នកតំណាងផ្លូវការរបស់រដ្ឋ ត្រូវបានកំណត់យ៉ាងច្បាស់លាស់។

១៤. អភ័យឯកសិទ្ធិការទូត(Diplomatic immunity)គឺជាអភ័យឯកសិទ្ធិដែលសកម្មភាពរបស់អ្នកការទូតស្ថិតនៅក្រៅដែនសមត្ថកិច្ចនៃតុលាការជាតិរបស់ប្រទេសម្ចាស់ផ្ទះ។

១៥. យុត្តិសង្គ្រាម (just wars) សំដៅលើប្រភេទមួយ នៅក្នុងច្បាប់អន្តរជាតិ និងទ្រឹស្តីនយោបាយដែលកំណត់ថា នៅពេលណាដែលសង្គ្រាមណាមួយអាចត្រូវបានចាប់ផ្តើមឡើយ ដោយយុត្តិធម៌ (jus ad

bellum) និងរបៀបដែលពួកគេអាចប្រយុទ្ធបាន ដោយយុត្តិធម៌ (jus in bello)។ សូមមើល *ឧក្រិដ្ឋកម្ម សង្គ្រាម* ផងដែរ។

១៦. អង្គការអន្តរជាតិ ច្បាប់ និងសិទ្ធិមនុស្ស ២២៥

១៧. សិទ្ធិមនុស្ស(Human Rights) គឺជាសិទ្ធិរបស់មនុស្សគ្រប់រូបដើម្បីរួចផុតពីការរំលោភបំពាន ដូចជាការធ្វើទារុណកម្ម ឬការជាប់គុកដោយសារតែជំនឿឬនិន្នាការនយោបាយរបស់ពួកគេ (សិទ្ធិនយោបាយ និងស៊ីវិល) និងទទួលបានការការពារផ្នែកសេដ្ឋកិច្ច និងសង្គម ជាអប្បបរមា (សិទ្ធិសេដ្ឋកិច្ច និងសង្គម)។

១៨. សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (UDHR) (១៩៤៨) គឺជាឯកសារស្នូលរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិមនុស្ស។ ទោះបីជាវាខ្វះកម្លាំងច្បាប់អន្តរជាតិក៏ដោយ វាបានកំណត់បទដ្ឋានអន្តរជាតិទាក់ទងនឹងអាកប្បកិរិយារបស់រដ្ឋាភិបាលចំពោះប្រជាពលរដ្ឋរបស់ពួកគេ និងជនបរទេសផងដែរ។

១៩. អង្គការលើកលែងទោសអន្តរជាតិ(Amnesty International) គឺជាអង្គការក្រៅរដ្ឋាភិបាលដ៏មានឥទ្ធិពលមួយ ដែលប្រតិបត្តិការទូទាំងពិភពលោក ដើម្បីតាមដាន និងព្យាយាមកែតម្រូវរំលោភបំពានសិទ្ធិមនុស្សផ្នែកនយោបាយ (មិនមែនសេដ្ឋកិច្ច ឬសង្គមនោះទេ)។

២០. ទំនួលខុសត្រូវក្នុងការការពារ (R២P) គឺជាគោលការណ៍ដែលត្រូវបានអនុម័តឡើង ដោយមេដឹកនាំពិភពលោកក្នុងឆ្នាំ ២០០៥ ដោយប្រកាសថា រដ្ឋាភិបាលត្រូវ ទទួលខុសត្រូវក្នុងការ ការពារជនស៊ីវិលពីអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលប្រព្រឹត្តនៅក្នុងរដ្ឋអធិបតេយ្យមួយ។

២១. ឧក្រិដកម្មសង្គ្រាម (war crimes) គឺជាការរំលោភបំពានច្បាប់គ្រប់គ្រងការប្រព្រឹត្តិទៅនៃសង្គ្រាម ដូចជាការធ្វើទុកបុកម្នេញលើឈ្លើយសឹកឬការកំណត់គោលដៅវាយប្រហារលើជនស៊ីវិលដោយមិនចាំបាច់។ សូមមើលផងដែរ *យុត្តិសង្គ្រាម ឬ តុលាការឧក្រិដ្ឋកម្មអន្តរជាតិ* (ICC)។

២២. ឧក្រិដកម្មប្រឆាំងមនុស្សជាតិ សំដៅលើប្រភេទបទល្មើសផ្លូវច្បាប់ដែលត្រូវបានបង្កើតឡើងនៅក្នុងសាលាក្តីនូរេមប៊ឺក ក្រោយសង្គ្រាមលោកលើកទី២ ដើម្បីក្តោបលើបអំពើប្រល័យពូជសាសន៍និងទង្វើផ្សេងៗដែលប្រព្រឹត្តិឡើងដោយមេដឹកនាំនយោបាយនិងយោធា នៃណាហ្ស៊ីអាឡឺម៉ង់។

២៣. តុលាការឧក្រិដ្ឋកម្មអន្តរជាតិ (ICC) គឺជាសាលាក្តីអចិន្ត្រៃយ៍សម្រាប់កាត់ក្តីឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

២៤. ឈ្លើយសឹក ឬ អ្នកទោសសង្គ្រាម (POWs) គឺជាទាហានដែលបានសុំចុះចាញ់ និងទទួលបានឋានៈពិសេសក្រោមច្បាប់នៃសង្គ្រាម។

២៥. គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ (ICRC) គឺជាអង្គការក្រៅរដ្ឋាភិបាល (NGO) ដែលផ្តល់ការគាំទ្រជាក់ស្តែង ដូចជាការថែទាំសុខភាព អាហារ និងសំបុត្រពីផ្ទះ ដល់ជនស៊ីវិលដែលជាប់ផុងក្នុងសង្គ្រាម និងដល់អ្នកទោសសង្គ្រាម (POWs)។ ការដោះដូរឈ្លើយសឹក ជាធម្មតាត្រូវបានចរចាតាមរយៈគណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ។

សំណួរអនុវត្តន៍

១. ឧបមាថា អ្នកត្រូវបានស្នើអោយផ្តល់យោបល់អំពីការផ្លាស់ប្តូរចនាសម្ព័ន្ធក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ (ជាពិសេសសមាជិកភាពអចិន្ត្រៃយ៍ និងសិទ្ធិអំណាចវេតូ)។ តើអ្នកនឹងណែនាំអោយមានការផ្លាស់ប្តូរអ្វីខ្លះ ប្រសិនបើមាន?ដោយផ្អែកលើតក្កវិជ្ជាអ្វី?

២ អគ្គលេខាធិការនៃអ. ស. ប. លោកប៊ូត្រូស ប៊ូត្រូស-ហ្គាលី (Boutros Boutros-Ghali) បានស្នើ (តែមិនបានលទ្ធផលល្អ) ក្នុងការបង្កើតកងទ័ពរក្សាសន្តិភាព ដែលកៀងគរពីរដ្ឋជាសមាជិក (សូមមើលចំណុចកងកម្លាំងរក្សាសន្តិភាព)។ សំណើនេះនឹងកាត់បន្ថយអធិបតេយ្យភាពរបស់រដ្ឋបន្តិចមែន និងបង្កើនដែនសមត្ថកិច្ចអ.ស.ប.។ ចូរពិភាក្សាអំពីគុណសម្បត្តិនិងគុណវិបត្តិនៃផែនការនេះ។

៣. សន្តិសុខរួមទប់ទល់នឹងការឈ្លានពាន ត្រូវអាស្រ័យលើឆន្ទៈរបស់រដ្ឋ ក្នុងការទទួលបន្ទុកចំណាយលើសង្គ្រាម ដើម្បីវាយបកនិងដាក់ទណ្ឌកម្មចំពោះអ្នកឈ្លានពាន។ ពេលខ្លះ ប្រទេសមហាអំណាចបានសុខចិត្តទទួលរ៉ាប់រងលើការចំណាយបែបនេះ ពេលខ្លះទៀត ពួកគេមិនសុខចិត្តទេ។ តើអ្នកគិតថាមានកត្តាអ្វីខ្លះគួរត្រូវបានពិចារណាក្នុងការសម្រេចចិត្តបែបនេះ? ចូរលើកឧទាហរណ៍អំពីស្ថានភាព (ជាក់ស្តែងឬអាចកើតឡើង) ដែលប្រទេសមហាអំណាច គួរឬមិនគួរអន្តរាគមន៍ដើម្បីរុញការឈ្លានពានចេញ។

៤. ដោយមានការលំបាកក្នុងការអនុវត្តច្បាប់អន្តរជាតិ តើតួនាទីរបស់តុលាការពិភពលោកអាចត្រូវបានពង្រឹងដោយរបៀបណានៅពេលអនាគត? តើផែនការបែបនេះអាចនឹងជួបឧបសគ្គអ្វីខ្លះ? តើពួកគេនឹងផ្លាស់ប្តូរតួនាទីរបស់តុលាការយ៉ាងដូចម្តេច ប្រសិនបើពួកគេទទួលបានជោគជ័យ?

៥. ទោះបីជាបទដ្ឋានអន្តរជាតិទាក់ទងនឹងសិទ្ធិមនុស្សកំពុងមានសភាពខ្លាំងក្លាក៏ដោយ ក៏ប្រទេសចិននិងរដ្ឋជាច្រើនទៀត នៅតែបន្តចាត់ទុកសិទ្ធិមនុស្សជាកិច្ចការផ្ទៃក្នុង ដែលរដ្ឋមានអធិបតេយ្យភាពនៅក្នុងទឹកដីរបស់ខ្លួន។ តើអ្នកគិតថាសិទ្ធិមនុស្សជាប្រធានបទស្របច្បាប់សម្រាប់រដ្ឋមួយ លើកយកទៅពិភាក្សាជាមួយរដ្ឋមួយទៀតដែរឬទេ? បើដូច្នេះ តើអ្នកផ្សះផ្សាភាពតានតឹងរវាងស្ថេរភាពរបស់រដ្ឋនិងសិទ្ធិសកលយ៉ាងដូចម្តេច? តើមានដំហានជាក់ស្តែងអ្វីខ្លះ ដែលអាចអនុវត្តបាន ដើម្បីអោយរដ្ឋអធិបតេយ្យ ទទួលស្គាល់សិទ្ធិមនុស្សសកល?

ការស្វែងរកផលប្រយោជន៍រួម

ទំនួលខុសត្រូវក្នុងការការពារ (Responsibility to Protect)

ផលប្រយោជន៍រួម៖ ការបញ្ឈប់អំពើឃោរឃៅលើជនស៊ីវិល

រូបថត ជនជាតិរ៉ាន់ដាដែលនៅរស់មកទស្សនាការរំលឹកខួប១០ឆ្នាំនៃអំពើប្រល័យពូជសាសន៍ឆ្នាំ១៩៩៤។

សាវតារ

ប្រព័ន្ធអន្តរជាតិដែលពឹងផ្អែកលើអធិបតេយ្យភាព ជាប្រវត្តិសាស្ត្របានចាត់ទុកការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរថាជា បញ្ហាក្នុងស្រុកដែលប្រទេសខាងក្រៅមិនចាំបាច់ខ្វល់ខ្វាយឡើយ។ ទោះជាយ៉ាងណាក៏ដោយ ក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមកនេះ បទដ្ឋានមួយបានបង្កើតឡើងដែលបានចាត់ទុកអំពើឃោរឃៅដ៏ធ្ងន់ធ្ងរបំផុតថាជាបញ្ហាកង្វល់សម្រាប់មនុស្សជាតិទាំងអស់។ ជាឧទាហរណ៍ បន្ទាប់ពីភាពភ័យរន្ធត់នៃការសម្លាប់រង្គាលរបស់ពួកណាហ្ស៊ី ក្នុងកំឡុងសង្គ្រាមលោកលើកទី ២ ប្រទេសនានាលើពិភពលោកបានចុះហត្ថលេខាលើអនុសញ្ញាស្តីពីការទប់ស្កាត់និងការដាក់ទណ្ឌកម្មនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ (អនុសញ្ញាប្រល័យពូជសាសន៍) ក្នុងឆ្នាំ១៩៤៨។ ប្រទេសហត្ថលេខី (បច្ចុប្បន្ន មានរដ្ឋចំនួន ១៤៦) បានសន្យានិងប្តេជ្ញាថានឹង «ទប់ស្កាត់ និងផ្តន្ទាទោស» អំពើប្រល័យពូជសាសន៍ ទាំងក្នុងសង្គ្រាម និងក្នុងសម័យសន្តិភាព។ អ្នកប្រាជ្ញ ច្បាប់អន្តរជាតិជាច្រើនរូបបកស្រាយថា នេះជាការប្តេជ្ញាចិត្តរបស់រដ្ឋទាំងអស់ដើម្បីធ្វើអន្តរាគមន៍នៅក្នុងករណីដែលត្រូវបានទទួលស្គាល់នៃអំពើប្រល័យពូជសាសន៍ដើម្បីធ្វើឲ្យមានការបញ្ឈប់ការសម្លាប់។

គោលគំនិតដែលសហគមន៍អន្តរជាតិត្រូវតែបញ្ឈប់ការលោភបំពាន ពីសំណាក់រដ្ឋាភិបាល ទៅលើប្រជាពលរដ្ឋរបស់ពួកគេបានទទួលនូវសន្ទុះគាំទ្រក្នុងរយៈពេលជាច្រើនឆ្នាំ ចាប់តាំងពីពេលនោះមក ជាមួយនឹងសន្ធិសញ្ញានិងការអនុវត្តផ្សេងៗបានបន្តដំណើរក្នុងទិសដៅនេះ។ តុលាការឧក្រិដ្ឋកម្មអន្តរជាតិ(ICC) និងតុលាការឧក្រិដ្ឋកម្មសង្គ្រាមអន្តរជាតិជាច្រើន បានកាត់ទោសបុគ្គលទាំងឡាយ ដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើប្រល័យពូជសាសន៍។ ក្នុងឆ្នាំ ២០០៥ អ្នកតស៊ូមតិផ្នែកសិទ្ធិមនុស្សបានស្នើឡើងនូវគោលគំនិត**នៃការទទួលខុសត្រូវក្នុងការការពារ**(R២P)។ សហគមន៍អន្តរជាតិគួរតែព្យាយាមប្រើប្រាស់យុទ្ធសាស្ត្រទប់ស្កាត់និងការទូតជាមុនសិន លុះត្រាតែដល់ដំណាក់កាលឬជម្រើសចុងក្រោយទើបប្រើអន្តរាគមន៍យោធា ប្រសិនបើចាំបាច់ ដើម្បីបញ្ឈប់អំពើឃោរឃៅដ៏ធំ។

មនុស្សគ្រប់រូបយល់ស្របគ្នាថា ពិភពលោកនឹងកាន់តែប្រសើរឡើង បើគ្មានអំពើឃោរឃៅសាហាវយង់ឃ្នង់ ដែលធ្វើអោយគុណតម្លៃមនុស្សជាតិទាំងមូលធ្លាក់ចុះ និងធ្វើអោយខូចដល់បទដ្ឋាននៃនយោបាយសន្តិភាព។ ទោះយ៉ាងណាក៏ដោយ ឧត្តមគតិទាំងនេះគឺជាផលប្រយោជន៍រួម ដែលជាទីប្រាថ្នានៃប្រទេសទាំងអស់ មិនថាប្រទេសដែលបានចំណាយប្រាក់ ឬ ជីវិតកំពុងប្រឈមគ្រោះថ្នាក់ឡើយ។

បញ្ហាប្រឈម:

អំពើឃោរឃៅទ្រង់ទ្រាយធំនៅតែបន្តកើតឡើងទោះជាមានអនុសញ្ញាប្រល័យពូជសាសន៍ សន្ធិសញ្ញាស្តីពីសិទ្ធិមនុស្ស តុលាការ និងគោលគំនិត«R២P»។ នៅឆ្នាំ ១៩៩៤ នៅប្រទេសរ៉ាន់ដា ក្រុមជ្រុលនិយមបានជណ្តើមអំណាចនិងបានសម្លាប់សមាជិកក្រុមជនជាតិភាគតិច និងគូប្រជែងនយោបាយជាងកន្លះលាននាក់។ ក្នុងឆ្នាំ ២០០៤ ប្រទេសស៊ូដង់បានប្រើកងជីវពលប្រដាប់អាវុធ ដើម្បីសម្លាប់ និងផ្លាស់ទីលំនៅប្រជាជនមួយចំនួនធំនៃតំបន់ដារហ្វួរជាទីកន្លែងដែលពួកឧទ្ទាមប្រឆាំងរដ្ឋាភិបាល។ ក្នុងករណីទាំងនេះ ក៏ដូចជាករណីផ្សេងទៀតដែរ គ្មានរដ្ឋណាមួយធ្វើអន្តរាគមន៍ប្រកបដោយប្រសិទ្ធភាព ដើម្បីបញ្ឈប់អំពើឃោរឃៅនោះទេ។ ប៉ុន្តែ ក្នុងឆ្នាំ ២០១១ អ្នកនៅក្រៅប្រទេសបានបញ្ឈប់ការកាប់សម្លាប់ ដោយជនផ្តាច់ការលីប៊ី។

ដំណោះស្រាយ

អង្គការសិទ្ធិមនុស្សពឹងផ្អែកលើគោលការណ៍អត្តសញ្ញាណ ដើម្បីជំរុញសកម្មភាពរបស់សហគមន៍អន្តរជាតិ។ ពួកគេផ្សព្វផ្សាយជាសាធារណៈនូវរឿបត្តិនានា និងជម្រុញរដ្ឋាភិបាលប្រជាធិបតេយ្យ ដើម្បីធ្វើសកម្មភាពក្នុងនាមមនុស្សជាតិ។ នៅក្នុងករណីនៃទីក្រុងដារហ្វួរ យុទ្ធនាការដែលត្រូវបានផ្តល់មូលនិធិយ៉ាងច្រើនរួមជាមួយនឹងការគាំទ្រដ៏ពេញនិយមជាច្រើន បានអំពាវនាវអោយមានសកម្មភាពខ្លាំងក្លាដើម្បីបញ្ឈប់រដ្ឋាភិបាលស៊ូដង់។ ទោះជាយ៉ាងនេះក្តី ការអំពាវនាវទាំងនេះបាននាំមកនូវលទ្ធផលតិចតួច ដោយសារតែរដ្ឋាភិបាលលោកខាងលិចមិនចង់បង្ហូរឈាមស្រស់ៗនិងចំណាយធនធាន ដើម្បីធ្វើអន្តរាគមន៍ក្នុងជម្លោះបរទេសដ៏រញ៉េរញ៉ៃ។ គោលការណ៍បដិការក៏មានព្រំដែនកម្រិតផងដែរ៖ តុលាការឧក្រិដ្ឋកម្មអន្តរជាតិ ដែលបណ្តាប្រទេសក្នុងពិភពលោកត្រូវគេរំពឹងថាត្រូវគាំទ្រទៅវិញទៅមក មិនអាចចាប់ខ្លួនប្រធានាធិបតីស៊ូដង់បានទេ បន្ទាប់ពីចោទប្រកាន់គាត់ពីបទឧក្រិដ្ឋកម្មសង្គ្រាម។

ដូច្នេះ គោលការណ៍គ្រប់គ្រងក្លាយជាជម្រើសដ៏សាកសមបំផុតដើម្បីឆ្លើយតបទៅនឹងអំពើឃោរឃៅ។ នៅពេលដែលប្រទេសមហាអំណាចមើលឃើញណាមួយ ជាផលប្រយោជន៍ជាតិរបស់ខ្លួនផ្ទាល់ ពួកគេធ្វើសកម្មភាពភ្លាម។ បើមិនដូច្នោះទេ ពួកគេមិនធ្វើឡើយ។ រហូតទាល់តែប្រទេសមហាអំណាចយោធាខ្លាំងក្នុង

ពិភពលោកសម្រេចចិត្តធ្វើសកម្មភាពប្រឆាំងនឹងអំពើឃោរឃៅសាហាវយង់ឃ្នង បញ្ឈប់នៃផលប្រយោជន៍រួម ដែលបង្កប់ដោយ ការទទួលខុសត្រូវក្នុងការការពារ (R2P) នឹងនៅមានកម្រិត។

ឧស្សនៈវិស័យគោលនយោបាយ

អគ្គព្រះរាជអាជ្ញាតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ហ្វាទូ ប៊ែនស៊ូដា (Fatou Bensouda)

រូបថត អគ្គព្រះរាជអាជ្ញាតុលាការICJ ប៊ែនស៊ូដា

បញ្ហា

តើអ្នកប្តឹងថ្លែងតុល្យការគោរពគោលការណ៍ច្បាប់អន្តរជាតិនិងផលប្រយោជន៍ជាតិយ៉ាងដូចម្តេច?

សារតារ

មុនការលុកលុយឆ្នាំ ២០០១ ចូលប្រទេសអាហ្វហ្គានីស្ថាន, ជាពិសេសការលុកលុយឆ្នាំ១៩៧៩របស់សហភាពសូវៀត ជម្លោះគឺជាច្បាប់ ដែលជាករណីលើកលែងនៅអាហ្វហ្គានីស្ថាន។ ចាប់តាំងពីសង្គ្រាមដែលដឹកនាំដោយសហរដ្ឋអាមេរិកក្នុងឆ្នាំ ២០០១ ដើម្បីផ្តួលរំលំពួកតាលីបង់ សន្តិភាពមិនពេញលេញមួយបានបង្កើតឡើង។ សន្តិភាពនោះត្រូវបានបំផ្លាញ ម្តងម្កាល ដោយក្រុមតាលីបង់ ដែលបានប្រមូលផ្តុំកម្លាំងឡើងវិញ ឬដោយក្រុមប្រឆាំងលោកខាងលិចផ្សេងទៀត ដូចជាបណ្តាញហាក្កានី (Haqqani) ដែលប្រឆាំងនឹងរដ្ឋាភិបាលដែលគាំទ្រដោយសហរដ្ឋអាមេរិក។

ស្រមៃថា អ្នកគឺជាអគ្គព្រះរាជអាជ្ញានៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ (ICC)។ នៅឆ្នាំ ២០០៣ ប្រទេសអាហ្វហ្គានីស្ថានបានក្លាយជាសមាជិកនៃលាការICC។ នៅឆ្នាំ ២០១៦ អ្នកបានបើកការស៊ើបអង្កេត ស្វែងរកការពិតបឋម ដើម្បីពិនិត្យមើលលទ្ធភាពនៃឧក្រិដ្ឋកម្មសង្គ្រាម ដោយកងកម្លាំងតាលីបង់ ក្នុងអំឡុងពេលនោះ និងបន្ទាប់ពីការលុកលុយឆ្នាំ ២០០១។ នៅរដូវស្លឹកឈើជ្រុះឆ្នាំ ២០១៧ អ្នកបានស្នើសុំការអនុញ្ញាតដើម្បីស៊ើបអង្កេតពេញលេញអំពីលទ្ធភាពនៃឧក្រិដ្ឋកម្មសង្គ្រាម ដែលប្រព្រឹត្តដោយកងកម្លាំងបណ្តាញតាលីបង់និងហាក្កានី។ លើសពីនេះទៅទៀត អ្នកក៏បានស្នើសុំការអនុញ្ញាតអោយស៊ើបអង្កេតលទ្ធភាព ដែលរដ្ឋាភិបាលអាហ្វហ្គានីស្ថាន និងកងកម្លាំងយោធាលោកខាងលិច (រួមទាំងទាហានអាមេរិក) បានធ្វើទារុណកម្ម ក្នុងអំឡុងពេលជម្លោះ។

ការពិចារណាក្នុងស្រុក

អំពើហិង្សានិងជម្លោះនៅតែកើតមានឡើង ជាទូទៅ នៅក្នុងប្រទេសអាហ្វហ្គានីស្ថាន។ ដំណើរការសន្តិភាពដែលដំណើរការយឺតយ៉ាវ ហាក់ដូចជាជិតឈានដល់ទីបញ្ចប់អំពើហិង្សា រវាងរដ្ឋាភិបាលនិងក្រុមឧទ្ទាមអ៊ីស្លាម ដូចជាតាលីបង់។ សន្តិភាពនេះមានលក្ខណៈពិបាកយល់ ហើយនៅចំណុចផ្សេងៗក្នុងពេលចរចា ទាំងរដ្ឋាភិបាលនិងអ្នកប្រឆាំងបានដើរចេញពីតុចរចា។ អ្នកការទូតជាច្រើនជឿថា គន្លឹះនៃការបង្កើតស្ថិរភាពនៅប្រទេសអាហ្វហ្គានីស្ថាន នឹងត្រូវមានកិច្ចព្រមព្រៀងសន្តិភាពដ៏ទូលំទូលាយមួយ ដែលត្រូវចុះហត្ថលេខារវាងភាគីជម្លោះ។

សេណារីយ៉ូ

ចូរស្រមៃថា រដ្ឋាភិបាលសហរដ្ឋអាមេរិក និងរដ្ឋាភិបាលអាហ្វហ្គានីស្ថាន ស្នើសុំអោយអ្នកបញ្ឈប់ការស៊ើបអង្កេតឧក្រិដ្ឋកម្មសង្គ្រាម នៅប្រទេសអាហ្វហ្គានីស្ថាន។ រដ្ឋាភិបាលអាហ្វហ្គានីស្ថានគំរាមដើរចេញពីកិច្ចចរចា ប្រសិនបើសមាជិកយោធាណាមួយត្រូវបានកាត់ទោស។ ក្រុមអ្នកការទូតអះអាងថា ការស៊ើបអង្កេត

អាចបន្លាចក្រុមឧទ្ទាមអោយនៅឬដើរឆ្ងាយពីការចរចាសន្តិភាព។ សហរដ្ឋអាមេរិកទាមទារអោយអ្នកបញ្ចប់ការស៊ើបអង្កេត បើមិនដូច្នោះទេ គេអាចនឹងត្រូវបានបង្ខំអោយដកកងទ័ពអាមេរិកទាំងអស់ចេញពីប្រទេសអាហ្វហ្គានីស្ថាន។ ម្យ៉ាងវិញទៀត ក្រុមសិទ្ធិមនុស្ស ចង្អុលបង្ហាញថា ប្រជាជនអាហ្វហ្គានីស្ថាន មិនទុកចិត្តរដ្ឋាភិបាលអាហ្វហ្គានីស្ថាន ឬក្រុមឧទ្ទាមអ៊ីស្លាមទេ មួយផ្នែកដោយសារតែអំពើឃោរឃៅ ដែលភាគីនីមួយៗបានប្រព្រឹត្ត។ ពួកគេអះអាងថា បើគ្មានការស្វែងរកយុត្តិធម៌សម្រាប់ជនរងគ្រោះនៃឧក្រិដ្ឋកម្មសង្គ្រាមនោះទេ សាធារណជននឹងមិនគាំទ្ររដ្ឋាភិបាល ឬដំណើរការសន្តិភាពឡើយ។

ចូរជ្រើសរើសគោលការណ៍របស់អ្នក

តើអ្នកនឹងផ្អាកកិច្ចខិតខំប្រឹងប្រែងរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ ក្នុងការកាត់ទោសតួអង្គផ្សេងៗនៅក្នុងជម្លោះអាហ្វហ្គានីស្ថានពីបទឧក្រិដ្ឋកម្មសង្គ្រាមដែរឬទេ? តើអ្នកថ្លឹងថ្លែងតុល្យភាពការទាមទាររបស់រដ្ឋាភិបាលអាហ្វហ្គានីស្ថាន ក្រុមឧទ្ទាម និងសហរដ្ឋអាមេរិកយ៉ាងដូចម្តេច? តើអ្នកនឹងថ្លឹងថ្លែងឆន្ទៈរបស់អ្នកក្នុងការនាំមកនូវយុត្តិធម៌ដល់ជនរងគ្រោះនៃជម្លោះ ក្នុងប្រទេសអាហ្វហ្គានីស្ថានជាមួយនឹងការពិតនៃដំណើរការសន្តិភាពដែលផុយស្រួយ ដោយរបៀបណា? តើយុត្តិធម៌អាចត្រូវពន្យារពេលដើម្បីសង្គ្រោះជីវិតមនុស្សក្នុងរយៈពេលខ្លីបានទេ? បើយុត្តិធម៌ត្រូវបានពន្យារ តើវានឹងអាចសម្រេចបានដែរឬទេ?


មតិសាធារណៈ និងទំនាក់ទំនងអន្តរជាតិ

មតិសាធារណៈស្តីពីការការពារសិទ្ធិមនុស្ស តាមរយៈអន្តរាគមន៍យោធា ដោយរដ្ឋដែលមានអំណាច

ថ្វីត្បិតតែមានការយល់ឃើញផ្សេងៗគ្នា អំពីសិទ្ធិមនុស្សពីសំណាក់ពលរដ្ឋនានា នៅលើពិភពលោកក៏ដោយ **ការស្ទង់មតិទីប្រឹក្សាសកល**លើប្រទេសចំនួន ២៨ ដោយស្ថាប័នអ៊ីពសុស (Ipsos) ក្នុងឆ្នាំ ២០១៨ បង្ហាញថា(សូមមើលក្រាហ្វិក ៧.៥) ជាងពាក់កណ្តាលនៃចំនួនប្រជាជនអង់គ្លេស (៥២%) និយាយថាពួកគេដឹងច្រើនឬច្រើនគួរសមអំពីសិទ្ធិមនុស្ស បើធៀបនឹង៤៣%នៃប្រជាជនដែលនិយាយថាពួកគេដឹងតិចតួចឬមិនដឹងទាល់តែសោះទាក់ទង់នឹងសិទ្ធមនុស្ស។ ក្រាហ្វិកនេះហាក់ដូចជាទាបជាងមធ្យមភាគនៃប្រជាជនសកលបន្តិច ដែលប្រហែល ៥៦% អះអាងថា ពួកគេដឹងច្រើន ឬច្រើនគួរសម ហើយ ៣៨% និយាយថា ពួកគេដឹងតិចតួចឬមិនដឹងទាល់តែសោះ។ នៅពេលនិយាយអំពី ឈ្មោះអង្គការពិភពលោកដែលទាក់ទងនឹងបញ្ហាសិទ្ធិមនុស្ស អង្គការសហប្រជាជាតិល្បីល្បាញបំផុត គិតត្រឹមពេលនេះ (នៅទូទាំងពិភពលោក ៧២% នៃមនុស្សនិយាយថាពួកបានដឹងនិងឮ) តាមពីក្រោយ ដោយគណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ(៤៩ %) និងតាមកៀកគិតៗ ដោយអង្គការលើកលែងទោសអន្តរជាតិ (៤៨%) ។

នៅពេលដែលពលរដ្ឋភាគច្រើន នៅលើពិភពលោកខ្វះព័ត៌មានអំពីអ្វីដែលកំពុងកើតឡើង នៅក្នុងប្រទេសផ្សេងទៀត អារម្មណ៍របស់ពួកគេផ្ទាល់ចំពោះប្រទេសណាមួយបានដើរតួយ៉ាងសំខាន់ក្នុងការសម្រេចមតិសាធារណៈលើសកម្មភាពយោធា។ នៅពេលដែលការសម្លាប់រង្គាលបានកើតឡើង ហើយសិទ្ធិមនុស្សជាមូលដ្ឋានត្រូវបានគេមើលឃើញថាត្រូវបានរំលោភបំពាន ពិភពលោកនឹងប្រតិកម្មដោយការបញ្ជូនជំនួយមនុស្សធម៌ឬយោធា។ ដោយអាស្រ័យលើកម្រិតនៃការយល់ដឹងរបស់ពួកគេអំពីសិទ្ធិមនុស្ស និងក្រុមដែលពួកគេយកចិត្តទុកដាក់បំផុត ពិភពលោកយល់ស្របថា ក្រុមទាំងនេះគួរតែត្រូវបានការពារ៖ កុមារ (៥៦%) ជនពិការ (៤៨%) មនុស្សចាស់ (៤៤%)។ ប្រតិបត្តិការយោធារបស់អង្គការណាតូ នៅប្រទេសលីប៊ីក្នុងឆ្នាំ ២០១១ បង្ហាញពីទំនាក់ទំនងរវាងមតិសាធារណៈ និងសកម្មភាពយោធា។

ក្រាហ្វិក ៧.៥ ការរំលោភសិទ្ធិមនុស្សគឺជាបញ្ហានៅក្នុងប្រទេសមួយចំនួន ប៉ុន្តែ មិនមែនជាបញ្ហានៅក្នុង [ប្រទេស...]



សម្គាល់៖ %យល់ស្របខ្លាំង, %មិនស្របឬមិនប្រឆាំង, %ប្រឆាំងខ្លាំង និង %មិនដឹង

ក្រាហ្វិក ៧.៦ មតិសាធារណៈឆ្លងជាតិឆ្ពោះទៅរកសកម្មភាពយោធានៅលីប៊ី

ចំណាំ៖ គំរូផ្អែកលើមនុស្សពេញវ័យដែលមានអាយុពី ១៦-៦៤ ឆ្នាំ។

សំណួរ៖ «តើអ្នកគាំទ្រ ឬប្រឆាំងនឹងអន្តរាគមន៍យោធាបច្ចុប្បន្ននៅលីប៊ីកម្រិតណា?«

សំណួរ៖ «តើអ្នកគាំទ្រ ឬប្រឆាំងនឹងសកម្មភាពយោធារបស់ចក្រភពអង់គ្លេស និងសម្ព័ន្ធមិត្តនៅលីប៊ីទេ?»

ប្រភព៖ Ben Clements (២០១៣, មករា-មីនា)។ មតិសាធារណៈ និងអន្តរាគមន៍យោធា៖ អាហ្វហ្គានីស្ថាន អ៊ីរ៉ាក់ និងលីប៊ី។ The Political Quarterly, Vol ៨៤ No ១

	Financial Times/Harris, March–April 2011			Reuters/Ipsos MORI, April 2011	
	Support (%)	Neither (%)	Oppose (%)	Support (%)	Oppose (%)
US	32	31	37	55	45
Britain	**37**	**28**	**36**	**50**	**49**
France	40	30	31	63	37
Germany	34	27	39	–	–
Italy	29	21	49	40	60
Spain	37	29	34	–	–

ដើម្បីទប់ស្កាត់ការសម្លាប់ជនស៊ីវិលដោយរបបកាដាហ្វី សហរដ្ឋអាមេរិកនិងសម្ព័ន្ធមិត្តណាតូបានចាប់ផ្តើមអន្តរាគមន៍យោធា ក្រោមដំណោះស្រាយរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ដើម្បីបញ្ឈប់ «ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ» ដែលអាចកើតមាន។ នៅពេលដែលវិបត្តិមនុស្សធម៌កាន់តែធ្ងន់ធ្ងរនៅក្នុងប្រទេសលីប៊ី ការស្ទង់មតិដែលធ្វើឡើងដោយអង្គការផ្សេងៗគ្នាបង្ហាញ (សូមមើលក្រាហ្វិក ៧.៦) ពីទំហំដែលប្រជាជនគាំទ្រដល់អន្តរាគមន៍យោធាដើម្បីការពារសិទ្ធិមនុស្ស។ នៅក្នុងការស្ទង់មតិលើកដំបូង ការគាំទ្រសកម្មភាពយោធានៅក្នុងប្រទេសលីប៊ី មានកម្រិតខ្ពស់បំផុតនៅក្នុងប្រទេសបារាំង អង់គ្លេស និងអេស្ប៉ាញ (៣៧ ភាគរយ ឬខ្ពស់ជាងនេះ) និងមានកម្រិតទាបបំផុតនៅក្នុងប្រទេសអ៊ីតាលី និងសហរដ្ឋអាមេរិក។ នៅក្នុងការស្ទង់មតិលើកទីពីរ ការគាំទ្រមានកម្រិតខ្ពស់បំផុតគួរអោយកត់សម្គាល់នៅក្នុងប្រទេសបារាំង(៦៣ ភាគរយ) ធៀបនឹងចក្រភពអង់គ្លេស(៥០ ភាគរយ) និងសហរដ្ឋអាមេរិក (៥៥ ភាគរយ)។ ហើយវាមានកម្រិតទាបបំផុតក្នុងប្រទេសអ៊ីតាលី(៤០ ភាគរយ) ដោយមានមតិភាគច្រើន (៦០ ភាគរយ)ប្រឆាំង។ ដោយអនុញ្ញាតអោយមានភាពខុសគ្នានៅក្នុងជម្រើសនៃការឆ្លើយតប នៅក្នុងការស្ទង់មតិទាំងពីរនេះ ពួកគេផលិតរបកគំហើញសង់តង់គ្នា ដែលទាក់ទងនឹងប្រទេសដែលទំនងបំផុត (បារាំង) និងប្រទេសដែលមិនទំនងតិចបំផុត (អ៊ីតាលី) ក្នុងការគាំទ្រសកម្មភាពយោធា។ អន្តរាគមន៍យោធាដំបូងត្រូវបានដឹកនាំយ៉ាងច្រើនដោយប្រទេសបារាំង និងចក្រភពអង់គ្លេស ដែលគួរអោយភ្ញាក់ផ្អើលស្របតាមលទ្ធផលនៃការស្ទង់មតិ។

វាជាការសមរម្យក្នុងការចេញការព្រមាននៅទីនេះ៖ ខណៈពេលដែលការស្ទង់មតិគឺជាសូចនាករដ៏សំខាន់នៃការគាំទ្រសាធារណៈសម្រាប់អន្តរាគមន៍យោធាភាគច្រើន ក្នុងគ្រាមានវិបត្តិមនុស្សធម៌ ការគាំទ្ររបស់ប្រជាពលរដ្ឋអាចផ្លាស់ប្តូរបាន។ ជាការពិត ការគាំទ្រសម្រាប់សកម្មភាពយោធានឹងថយចុះ នៅពេលដែលភាពនឿយហត់នៃសង្គ្រាមបានឈានចូលមកដល់ ហើយការស្លាប់និងរបួស និងការចំណាយកើនឡើងយ៉ាងខ្លាំង។ ដូច្នេះ វាជារឿងធម្មតាទេដែលឃើញសកម្មភាពយោធាគាំទ្រជាសាធារណៈនៅចំពេលមានវិបត្តិមនុស្សធម៌ដ៏ធ្ងន់ធ្ងរ ប៉ុន្តែទីបំផុតពួកគេបែរជាប្រឆាំងនឹងសកម្មភាពបែបនេះទៅវិញ។

តោះ! សាកល្បងពិភាក្សាអំពីបញ្ហាជាក់ស្តែង

សិទ្ធិមនុស្ស៖ ការសន្យាខ្សល់ចំពោះពិភពលោក?

ទិដ្ឋភាពទូទៅ

ចាប់តាំងពីការអនុម័តសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ កាលពីជាង ៧០ ឆ្នាំមុន រដ្ឋនានាបានប្តេជ្ញាចិត្តក្នុងការជំរុញការគោរពសិទ្ធិមនុស្ស។ សន្ធិសញ្ញាអង្គការសហប្រជាជាតិចំនួនប្រាំបួនផ្សេងគ្នា ដែលចុះហត្ថលេខាដោយរដ្ឋភាគច្រើននៅលើពិភពលោក ធានាការការពារ និងការជម្រុញការគោរពសិទ្ធិមនុស្ស នៅក្នុងវិស័យជាច្រើន រួមទាំង សិទ្ធិស្ត្រី សិទ្ធិកុមារ សិទ្ធិពលករចំណាកស្រុក និងការការពារពីការធ្វើទារុណកម្ម។ សន្ធិសញ្ញានិងពិធីសារក្នុងតំបន់ជាច្រើនផ្សេងទៀតលើកកម្ពស់សុខុមាលភាពសេដ្ឋកិច្ច ការពារសិទ្ធិទទួលបាននីតិវិធីត្រឹមត្រូវ និងអនុម័តការសម្រេចចិត្តដោគវាសនាដោយខ្លួនឯង។

មេដឹកនាំរដ្ឋតែងតែលើកឡើងពីសារៈសំខាន់នៃសិទ្ធិមនុស្សក្នុងការលើកកម្ពស់ភាពត្រឹមត្រូវ យុត្តិធម៌ និងសមភាព។ រឿងនេះជាការពិត សម្រាប់ទាំងរដ្ឋប្រជាធិបតេយ្យ និងរដ្ឋមិនមែនប្រជាធិបតេយ្យ។ នៅក្នុងវោហាសាស្ត្រ សារៈសំខាន់នៃការលើកកម្ពស់ និងការពារសិទ្ធិមនុស្សហាក់ដូចជាមានលក្ខណៈជាសកល។

ប៉ុន្តែការរំលោភលើសន្ធិសញ្ញាទាំងអស់នេះនៅតែកើតមានឡើង ហើយតាមពិតទៅ ពេលខ្លះ ហាក់ដូចជាជារឿងធម្មតាទៅហើយ។ ការបំពានមានចាប់ពីទ្រង់ទ្រាយតូចៗ (កង្វះការការពារស្មើៗគ្នាសម្រាប់ជនជាតិភាគតិចនៅក្នុងរដ្ឋមួយចំនួន ការអនុញ្ញាតអោយធ្វើទារុណកម្មលើបុគ្គលមួយចំនួន) រហូតដល់ទ្រង់ទ្រាយធំៗ (អំពើប្រល័យពូជសាសន៍នៅដារហ្វួរ)។ មិនថាការរំលោភបំពាននោះមានទំហំប៉ុណ្ណានោះទេ ទាំងអស់នេះបង្ហាញពីការមិនយកចិត្តទុកដាក់ចំពោះសារៈសំខាន់នៃសិទ្ធិមនុស្ស។ នេះនាំអោយមនុស្សជាច្រើនចោទសួរថាតើការសន្យាគោរពលើកតម្កើងសិទ្ធិមនុស្សជាសាកលដែលរដ្ឋនឹងព្យាយាមសម្រេចបានដែរឬទេ? តើបុគ្គលអាចពឹងផ្អែកលើរដ្ឋាភិបាលរបស់រដ្ឋដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្សដែរឬទេ?

អំណះអំណាង ១

រដ្ឋអនុវត្តកិច្ចខិតខំតិចតួចក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស

សន្ធិសញ្ញាអង្គការសហប្រជាជាតិភាគច្រើនទាក់ទងនឹងសិទ្ធិមនុស្ស មិនត្រូវបានអង្រឹងការអនុវត្តទេ។

សន្ធិសញ្ញាសិទ្ធិមនុស្ស ដែលជាគោលការស្នូលរបស់អង្គការសហប្រជាជាតិ មានការពង្រឹងការអនុវត្តតិចតួចប៉ុណ្ណោះ ប្រសិនបើមាន។ តាមពិតទៅ អ្នករំលោភសិទ្ធិមនុស្សដ៏អាក្រក់បំផុតមួយចំនួន ជារឿយៗ គឺជាអ្នកចុះហត្ថលេខាលើឯកសារទាំងនេះមុនគេពីព្រោះពួកគេដឹងថា នឹងមិនមានការអនុវត្តច្បាប់ទៅលើការបំពាននោះទេ។ សន្ធិសញ្ញាគ្រាន់តែជាក្រដាសតែប៉ុណ្ណោះ។

គោលដៅនយោបាយតែងតែបង្ខូចការលើកកម្ពស់សិទ្ធិមនុស្ស។

នៅពេលដែលមានការរុញច្រានដល់ដំណាក់ចុងក្រោយ រដ្ឋនានានឹងមិនអើពើការរំលោភសិទ្ធិមនុស្សដើម្បីសម្រេចបាននូវគោលដៅនយោបាយផ្សេងទៀត។ មិនថាសហរដ្ឋអាមេរិកមិនអើពើនឹងការគាបសង្កត់ផ្នែកនយោបាយនៅក្នុងប្រទេសចិន ប្រទេសចិនមិនអើពើនឹងអំពើប្រល័យពូជសាសន៍នៅស៊ូដង់ ឬប្រទេសអាហ្វ្រិកខាងត្បូងមិនអើពើនឹងការបង្ក្រាបនៅក្នុងប្រទេសហ្ស៊ីមបាវ៉េ រដ្ឋគ្រប់ប្រភេទនឹងបិទភ្នែកចំពោះការរំលោភសិទ្ធិមនុស្ស ប្រសិនបើការធ្វើដូច្នេះបម្រើគោលដៅនយោបាយរបស់ពួកគេ។

ស្តង់ដារសិទ្ធិមនុស្សត្រូវបានអនុវត្តមិនស្មើគ្នា។

នៅពេលដែលមានការយកចិត្តទុកដាក់លើការរំលោភសិទ្ធិមនុស្ស ការយកចិត្តទុកដាក់មិនមានស្មើគ្នានោះទេ។ ជាញឹកញាប់ដាងនេះទៅទៀត ការរំលោភបំពានត្រូវបានលើកឡើងមកបំភ្លឺ សម្រាប់តែប្រឆាំងនឹងរដ្ឋដែលត្រូវបានចាត់ទុកថាជាសត្រូវ ឬមិនមានសារៈសំខាន់ផ្នែកនយោបាយប៉ុណ្ណោះ។ ទន្ទឹមនឹងនេះ ការបំពានស្រដៀងគ្នានេះមិនត្រូវបានអើពើនៅក្នុងរដ្ឋសម្ព័ន្ធមិត្ត ឬរដ្ឋដែលមានអំណាចនយោបាយឡើយ។

អំណះអំណាង ២

រដ្ឋជួយលើកកម្ពស់សិទ្ធិមនុស្ស

បទដ្ឋានលទ្ធិប្រជាធិបតេយ្យដែលកំពុងកើតឡើងកំពុងជួយលើកកម្ពស់សិទ្ធិមនុស្ស។

ការកើនឡើងនៃចំនួនប្រទេសប្រជាធិបតេយ្យនៅជុំវិញពិភពលោក កំពុងបម្រើអោយការបង្កើនការគោរពសិទ្ធិមនុស្ស។ លទ្ធិប្រជាធិបតេយ្យទំនងជាការពារនិងលើកកម្ពស់សិទ្ធិមនុស្ស។ ប្រទេសលោកខាងលិចជាច្រើនបានពង្រីកការគាំទ្ររបស់ពួកគេចំពោះលទ្ធិប្រជាធិបតេយ្យក្មេងខ្ចី ដែលនឹងជួយសិទ្ធិមនុស្ស នៅទូទាំងពិភពលោក។

អង្គការមិនមែនរដ្ឋាភិបាលបន្តធ្វើការជាមួយរដ្ឋដើម្បីលើកកម្ពស់សិទ្ធិមនុស្ស។

អង្គការក្រៅរដ្ឋាភិបាលដូចជា អង្គការលើកលែងទោសអន្តរជាតិ (Amnesty International) និង អង្គការឃ្លាំមើលសិទ្ធិមនុស្ស (Human Rights Watch) បន្តផ្តល់ព័ត៌មានដល់រដ្ឋនិងប្រជាពលរដ្ឋរបស់ ពួកគេ ទាក់ទងនឹងការរំលោភសិទ្ធិមនុស្ស។ ខណៈពេលដែលរដ្ឋមិនធ្វើសកម្មភាពលើករណីទាំងអស់នេះ ពួកគេជួនកាលឆ្លើយតបទៅនឹងកិច្ចខិតខំប្រឹងប្រែងពីមូលដ្ឋានមួយចំនួន ដើម្បីកែលម្អការគោរពសិទ្ធិមនុស្ស ជាសកល។ ដូច្នេះ អង្គការក្រៅរដ្ឋាភិបាល គឺជាភ្នាក់ងារដ៏សំខាន់សម្រាប់រដ្ឋដែលចង់ដំរុញបុព្វហេតុសិទ្ធិ មនុស្ស។

រដ្ឋលើកកម្ពស់សិទ្ធិមនុស្សតាមរយៈស្ថាប័នផ្សេងៗ។

រដ្ឋជាច្រើនបានចាប់ផ្តើមដាក់លក្ខខណ្ឌសម្រាប់ជំនួយបរទេស និងគោលនយោបាយពាណិជ្ជកម្ម ដោយមើលលើឥរិយាបថសិទ្ធិមនុស្ស។ សហភាពអឺរ៉ុបតម្រូវប្រទេសហត្ថលេខីទាំងអស់នៃកិច្ចព្រមព្រៀង ពាណិជ្ជកម្មអោយគោរពតាមស្តង់ដារសិទ្ធិមនុស្សមួយចំនួន ខណៈដែលសហរដ្ឋអាមេរិកតម្រូវអោយដៃគូ ពាណិជ្ជកម្មសេរីទាំងអស់ ទទួលស្គាល់សិទ្ធិកម្មករ និងកុមារ។ តម្រូវការទាំងនេះ ដែលរំលេចនៅក្នុងសន្ធិ សញ្ញាសំខាន់ៗក្នុងផ្នែកសេដ្ឋកិច្ច ទំនងជាត្រូវបានអនុវត្ត។

សំណួរ

- តើរដ្ឋនានា ជាពិសេសរដ្ឋលោកខាងលិច មានប្រសិទ្ធភាពជំរុញសិទ្ធិមនុស្សដែរឬទេ? តើអ្នកគិតថា មានការអនុវត្តស្តង់ដារសិទ្ធិមនុស្សតិចឬច្រើន ក្នុងទសវត្សរ៍កន្លងមកនេះទេ? តើមានករណីសំខាន់ៗបង្ហាញ ថារដ្ឋពិតជាបានគាំទ្រសិទ្ធិមនុស្សទេ? ឬករណីរដ្ឋមិនអើពើនឹងការរំលោភសិទ្ធិមនុស្សដែរឬទេ?
- តើស្តង់ដារសិទ្ធិមនុស្សអាចត្រូវបានលើកកំពស់ កាន់តែមានប្រសិទ្ធភាពយ៉ាងដូចម្តេច? តើមាន មធ្យោបាយណាមួយដែលមានប្រសិទ្ធភាពជាង រវាងការប្រើដំបង(ការគំរាមកំហែងនៃការដាក់ទណ្ឌកម្ម) និង ស្ករគ្រាប់ (ការសន្យាផ្តល់រង្វាន់សម្រាប់អាកប្បកិរិយាប្រសើរជាងមុន) ក្នុងការបង្កើនការគោរពសិទ្ធិមនុស្ស?
- តើការលើកកម្ពស់ស្តង់ដារសិទ្ធិមនុស្សគឺជាការបង្ខំអោយមានក្រមសីលធម៌ និងបទដ្ឋានជាក់លាក់ មួយទៅលើរដ្ឋដែលមិនមែនជាប្រទេសលោកខាងលិចដែរឬទេ? តើមានសិទ្ធិមនុស្សជាសាកលឬទេ?

និស្សិតអាចសាកល្បងអានឯកសារខាងក្រោមបន្ថែមទៀត ដើម្បីជាគ្រឹះក្នុងការឆ្លើយសំណួរទាំងអស់ ខាងលើ ៖

- Donnelly, Jack, and Daniel Whelan. *International Human Rights.* 5th ed. Westview, 2017.
- Hafner-Burton, Emilie. *Making Human Rights a Reality.* Princeton, 2013.
- Mahoney, Jack. *The Challenge of Human Rights: Origin, Development and Significance.* Wiley-Blackwell, 2006.
- Simmons, Beth. *Mobilizing for Human Rights: International Law in Domestic Politics.* Cambridge, 2009.

អាជីពក្នុងទំនាក់ទំនងអន្តរជាតិ៖ ច្បាប់អន្តរជាតិ

សង្ខេប

ការងារនៅក្នុងវិស័យច្បាប់អន្តរជាតិអាចផ្តល់ប្រាក់ខែខ្ពស់ និងផ្តល់ឱកាសដើម្បីធ្វើការលើបញ្ហាអន្តរជាតិ ជាច្រើន ប៉ុន្តែ ការងារបែបនេះទាមទារការសិក្សាវគ្គឬសញ្ញាបត្របន្ថែមដែលអាចចំណាយខ្ពស់។

អត្ថប្រយោជន៍និងការចំណាយ

ការងារជាច្រើនមាននៅក្នុងវិស័យច្បាប់អន្តរជាតិ។ ដូចនៅក្នុងការអនុវត្តច្បាប់ក្នុងបរិបទក្នុងស្រុក មេធាវីអាចមានជំនាញលើផ្នែកផ្សេងៗនៃច្បាប់អន្តរជាតិដែលមានស្រាប់។ ជាការពិតណាស់ វិស័យប្រពៃណីជាច្រើននៃការសិក្សានិងការអនុវត្តច្បាប់ ដូចជាច្បាប់កិច្ចសន្យា ច្បាប់ពន្ធដារ និងច្បាប់បទប្បញ្ញត្តិ សុទ្ធតែមានបែងចែកជំនាញអន្តរជាតិ។ ដូច្នេះ មានវិស័យសកម្មនុពលជាច្រើននៃការអនុវត្តច្បាប់ រាប់ចាប់ពីច្បាប់សង្គ្រាមរហូតដល់ច្បាប់សិទ្ធិមនុស្ស រហូតដល់ច្បាប់ពាណិជ្ជកម្មអន្តរជាតិ និងច្បាប់កិច្ចសន្យា។

រូបថត បុគ្គលិកច្បាប់អន្តរជាតិពិភាក្សាការងារ

ជាការពិតណាស់ មេធាវីជាច្រើនបានលើកឡើងពីបញ្ហាជាច្រើន នៅក្នុងច្បាប់អន្តរជាតិថាជាអត្ថប្រយោជន៍ដល់ការងារបែបនេះ ដោយករណីនីមួយៗនាំមកនូវបញ្ហាប្រឈមថ្មីៗ ជួនកាល ជំរុញអ្នកអនុវត្តទៅផ្នែកផ្សេងៗនៃការសិក្សា។ មេធាវីអន្តរជាតិអាចចរចារកិច្ចសន្យារវាងអាជីវកម្មនៅក្នុងប្រទេសមួយចំនួននៅថ្ងៃណាមួយ បន្ទាប់មកផ្តល់ដំបូន្មានដល់អតិថិជនអំពីបទប្បញ្ញត្តិបរិស្ថាននៅក្នុងប្រទេសមួយផ្សេងទៀតបន្ទាប់ទៀត។ លើសពីនេះ ការងារភាគច្រើន (ប៉ុន្តែមិនមែនទាំងអស់) នៅក្នុងច្បាប់អន្តរជាតិ ទទួលបានប្រាក់ខែសមរម្យ។

ខណៈពេលដែលមានការងារជាច្រើននៅក្នុងច្បាប់អន្តរជាតិ ដូចជានៅក្នុងច្បាប់ក្នុងស្រុក ការងារដែលទាក់ទងនឹងមុខតំណែងខ្ពស់ មានលក្ខណៈកម្រ និងពិបាកក្នុងការទទួលបាន។ ពោលគឺ អ្នកទំនងជាជួយក្រុមហ៊ុននៅក្នុងប្រទេសផ្សេងៗគ្នាដោះស្រាយជម្លោះកិច្ចសន្យា ជាជាងជួយប្រទេសទាំងពីរដោះស្រាយជម្លោះព្រំដែន ឬជួយបុគ្គលណាមួយដោះស្រាយបញ្ហាសិទ្ធិមនុស្ស។

ការងារក្នុងវិស័យច្បាប់អន្តរជាតិស្ទើរតែតែងតែទាមទារអោយបញ្ចប់ការសិក្សាពីសាលាច្បាប់។ ការចូលរៀនច្បាប់កាន់តែលំបាក។ សព្វថ្ងៃនេះ សាលាច្បាប់ទទួលយកអ្នកដាក់ពាក្យចំនួន ១៨០០០ តិចជាងចំនួនកាលពីឆ្នាំ ២០១០។ លើសពីនេះ សាលាច្បាប់មានតម្លៃថ្លៃ ហើយជំនួយផ្នែកហិរញ្ញវត្ថុ កម្រនឹងមានណាស់៖ ដោយសារតែមនុស្សជាច្រើនដែលបញ្ចប់សាលាច្បាប់ស្វែងរកការងារដែលមានប្រាក់ខែខ្ពស់ វាត្រូវបានសន្មត់ថាមេធាវីទាំងនេះនឹងអាចសងប្រាក់កម្ចីរបស់ពួកគេវិញ ដោយមិនលំបាកពេកទេ។ នៅក្នុងឆ្នាំ ២០១៧ ការចំណាយជាមធ្យមនៃថ្លៃសិក្សានៅសាលាច្បាប់កំពូលទាំងដប់ នៅសហរដ្ឋអាមេរិក មានទំហំលើសពី $៦០០០០ ក្នុងមួយឆ្នាំ (មិនរាប់បញ្ចូលទាំងការចំណាយលើសៀវភៅ ឬ ការរស់នៅ)។

ជំនាញត្រូវដុសខាត់

លក្ខណៈវិនិច្ឆ័យនៃការចូលរៀននៅសាលាច្បាប់គឺស្រដៀងគ្នា ដោយមិនគិតពីប្រភេទច្បាប់ដែលអ្នកមានបំណងអនុវត្ត។ ជំនាញសរសេរនិងវិភាគដ៏រឹងមាំ មានសារៈសំខាន់។ សាលាច្បាប់រំពឹងថាសិស្សនិស្សិតអាចអានករណីក្តីស្មុគស្មាញ រកមើលបញ្ហាសំខាន់ៗនៅក្នុងសំណុំរឿង ហើយសរសេរយ៉ាងខ្លីអំពីអ្វីដែលច្បាប់និយាយអំពីបញ្ហាទាំងនោះ។

ជំនាញបទបង្ហាញផ្ទាល់មាត់ក៏មានសារៈសំខាន់ចំពោះទិដ្ឋភាពជាច្រើននៃច្បាប់។ មិនថា មានការជជែកតវ៉ានៅចំពោះមុខតុលាការ ឬការប្រាស្រ័យទាក់ទងច្បាស់លាស់ជាមួយកូនក្តី ជំនាញទំនាក់ទំនងខ្លាំងត្រូវការជាចាំបាច់។ ពាក់ព័ន្ធ ក៏ដូចជាការងារដែលតម្រង់ទិសអន្តរជាតិណាមួយដែរ ជំនាញភាសាបរទេសមានប្រយោជន៍ ជាពិសេសប្រសិនបើការងាររបស់អ្នកនៅក្នុងច្បាប់តម្រូវអោយអ្នកស្គាល់ច្បាប់នៃប្រទេសផ្សេងទៀតដោយខ្លួនឯង។

ជាចុងក្រោយ ខណៈពេលដែលវិទ្យាសាស្ត្រនយោបាយ ជាប្រពៃណី ជាមុខវិជ្ជា«ផ្តត់ផ្តង« ដ៨សំខាន់នៅក្នុងសាលាច្បាប់ និស្សិតដែលសង្ឃឹមថានឹងចូលរៀននៅសាលាច្បាប់គួរតែចូលរៀនក្នុងមុខវិជ្ជាផ្សេងៗគ្នា។ ការក្លាយជាមុខវិជ្ជាវិទ្យាសាស្ត្រនយោបាយមិនមែនជាគុណវិបត្តិទេ ប៉ុន្តែគណៈកម្មាធិការចូលរៀននៅសាលាច្បាប់តែងតែផ្តល់តម្លៃលើបទពិសោធន៍ និងចំណេះដឹងដ៏ទូលំទូលាយរបស់បេក្ខជន មិនមែនត្រឹមតែចំណេះដឹងអំពីរដ្ឋាភិបាល និងនយោបាយប៉ុណ្ណោះទេ។

ធនធានបន្ថែម

- Rist, D. Wes. *ASIL Careers in International Law: A Guide to Career Paths in International Law.* American Society for Inter- national Law, 2013.
- Swartz, Salli A. *Careers in International Law.* 4th ed. American Bar Association, 2013.
- https://www.asil.org
- https://www.americanbar.org/groups/international_law.html

ឯកសារគួរអានបន្ថែម

- Autessere, Severine. *Peaceland: Conflict Resolution and the Everyday Politics of International Intervention.* Cambridge, 2014.
- Barnett, Michael N., and Martha Finnemore. *Rules for the World: International Organizations and Global Politics.* Cornell, 2004.
- Evans, Gareth. *The Responsibility to Protect: Ending Mass Atrocity Crimes Once and for All.* Brookings, 2008.
- Fortna, Virginia Page. *Does Peacekeeping Work? Shaping Belligerents' Choices After Civil War.* Princeton, 2008.
- Goodheart, Michael. *Human Rights: Politics and Practice.* 3rd ed. Oxford, 2016.
- Keck, Margaret, and Kathryn Sikkink. *Activists Beyond Borders: Advocacy Networks in International Politics.* Cornell, 1998.
- Risse, Thomas, Stephen C. Ropp, and Kathryn Sikkink, eds. *The Persistent Power of Human Rights: From Commitment to Compliance.* Cambridge, 2013.
- Straus, Scott. *Making and Unmaking Nations: War, Leadership, and Genocide in Modern Africa.* Cornell, 2015.
- Walzer, Michael. *Arguing About War.* Yale, 2004.
- Weiss, Thomas G. *What's Wrong with the United Nations and How to Fix It.* 3rd ed. Polity, 2016.

ជំពូកទី ២ សេដ្ឋកិច្ចនយោបាយអន្តរជាតិ
មេរៀនទី ០៨ ៖ ពាណិជ្ជកម្មអន្តរជាតិ

វត្ថុបំណងមេរៀន

៨.១ ចូរពិពណ៌នាគោលនយោបាយចំនួន ៣ ដែលរំខានដល់ការធ្វើពាណិជ្ជកម្ម ឬការដោះដូរទំនិញ និងសេវាកម្មដោយសេរីនៅក្នុងទីផ្សារអន្តរជាតិ។

៨.២ ចូរកំណត់កត្តាបណ្តាលអោយជាប់គាំងក្នុងកិច្ចចរចាររបស់អង្គការពាណិជ្ជកម្មពិភពលោក នៅក្នុងវេទិកាដូហា (Doha) យ៉ាងហោចណាស់អោយបានមួយ។

៨.៣ ចូររៀបរាប់យ៉ាងហោចណាស់មធ្យោបាយពីរយ៉ាង ដែលប្រទេសមួយ ឬ ពលរដ្ឋណាមួយបាន និងកំពុងប្រឆាំងនឹងពាណិជ្ជកម្មពិភពលោក។

៨.១. ទ្រឹស្តីពាណិជ្ជកម្ម

៨.១ ចូរពិពណ៌នាគោលនយោបាយចំនួន ៣ ដែលរំខានដល់ការធ្វើពាណិជ្ជកម្ម ឬការដោះដូរទំនិញ និងសេវាកម្មដោយសេរីនៅក្នុងទីផ្សារអន្តរជាតិ។

ក្នុងចំណោមសកម្មភាពសេដ្ឋកិច្ចសរុបនៅក្នុងពិភពលោក ពាណិជ្ជកម្មអន្តរជាតិមានតម្លៃសរុបប្រហែល មួយភាគប្រាំមួយ(១/៦)។ ទំនិញនិងសេវាកម្ម ក្នុងតម្លៃប្រហែល២១ទ្រីលានដុល្លាអាមេរិក ដឹកជញ្ជូននិងឆ្លងកាត់ព្រំដែនអន្តរជាតិជារៀងរាល់ឆ្នាំ។ នេះជាចំនួនដ៏ច្រើនសន្ធឹកសន្ធាប់ ពោលគឺ ច្រើនជាងការចំណាយលើវិស័យយោធាទៅទៀត។ បរិមាណដ៏ធំនៃពាណិជ្ជកម្មអន្តរជាតិឆ្លុះបញ្ចាំងពីការពិតដែលថា ពាណិជ្ជកម្មពិតជាផ្តល់ផលចំណេញ។

តួនាទីពាណិជ្ជកម្មនៅក្នុងសេដ្ឋកិច្ចសម្រាប់ប្រជាជាតិមួយទៅប្រទេសមួយទៀត មានលក្ខណៈខុសគ្នាប៉ុន្តែ ជារួមវាមានសារៈសំខាន់ខ្លាំងនៅក្នុងអឌ្ឍគោលខាងត្បូង ក៏ដូចជានៅអឌ្ឍគោលខាងជើងដែលមានលក្ខណៈជាប្រទេសឧស្សាហកម្ម។ នៅអឌ្ឍគោលខាងត្បូង ចូលរួមចំណែកតិចតួចនៅក្នុងពាណិជ្ជកម្មសរុបនៅក្នុងសេដ្ឋកិច្ចពិភពលោក ប៉ុន្តែនេះក៏ដោយសារតែសកម្មភាពសេដ្ឋកិច្ចរបស់វាផ្ទាល់ មានត្រឹមតែ ៤៥ ភាគរយនៃចំនួនសរុបពិភពលោក(សូមមើលមេរៀនទី ១)។

ពាណិជ្ជកម្មមិនត្រឹមតែជាបញ្ហាសេដ្ឋកិច្ចប៉ុណ្ណោះទេ ប៉ុន្តែថែមជាបញ្ហានយោបាយដ៏សាំញ៉ាំផងដែរ។ វាត្រូវឆ្លងកាត់ព្រំដែនដែលកំណត់ដោយរដ្ឋ គ្រប់គ្រងដោយរដ្ឋ ដែលត្រូវរងសម្ពាធដោយក្រុមផលប្រយោជន៍ផ្សេងៗ និងប្រព្រឹត្តិទៅនៅក្នុងរបបពាណិជ្ជកម្មដែលបន្តអនុវត្តដោយ និងចរចាក្នុងចំណោមរដ្ឋនានា។

ដូច្នេះ អ្នកប្រាជ្ញនៃ*សេដ្ឋកិច្ចនយោបាយអន្តរជាតិ*(IPE)សិក្សាអំពីនយោបាយនៃសកម្មភាពសេដ្ឋកិច្ចអន្តរជាតិ។ សកម្មភាពដែលត្រូវបានសិក្សាញឹកញាប់បំផុត គឺពាណិជ្ជកម្ម ទំនាក់ទំនងរូបិយវត្ថុ និងសាជីវកម្មពហុជាតិ (សូមមើលមេរៀនទី ៨ និងទី ៩ បន្ទាប់)។ លើសពីនេះ ប្រធានបទពីរដែលគួរជាទីចាប់អារម្មណ៍ជាពិសេសក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ គឺសមាហរណកម្មសេដ្ឋកិច្ចនៃទ្វីបអឺរ៉ុបនិងតំបន់ផ្សេងទៀត (សូមមើលមេរៀនទី ១០) និងនយោបាយអន្តរជាតិនៃបរិស្ថានពិភពលោក (សូមមើលមេរៀនទី ១១)។ អ្នកប្រាជ្ញIPE ភាគច្រើន ផ្តោតលើតំបន់ឧស្សាហកម្មកែចំរើននៃពិភពលោក ដែលភាគច្រើននៃសកម្មភាពសេដ្ឋកិច្ចរបស់

ពិភពលោកកើតឡើង។ ទោះជាយ៉ាងណាក៏ដោយ អឡឺគោលខាងត្បូងបានទទួលការយកចិត្តទុកដាក់កាន់តែខ្លាំងឡើង នៅពេលដែលសកលភាវូបនីយកម្មរួមបញ្ចូលតំបន់ខ្លះនៃអឡឺគោលខាងត្បូង ទៅក្នុងសេដ្ឋកិច្ចពិភពលោកកាន់តែខ្លាំង (សូមមើលមេរៀនទី ១២ និងទី ១៣)។ ទោះបីជាបញ្ហាទាំងនេះត្រួតស៊ីគ្នាជាមួយនឹងបញ្ហាសន្តិសុខអន្តរជាតិ ក្នុងកម្រិតខុសគ្នាក៏ដោយ ពួកវាត្រូវដោះស្រាយជាចម្បងជាមួយនឹងការចរចាផ្នែកនយោបាយលើបញ្ហាសេដ្ឋកិច្ច ម្លោះហើយសាកសមនឹងស្ថិតក្នុងសេដ្ឋកិច្ចនយោបាយអន្តរជាតិ(IPE) ដែលបានកំណត់យ៉ាងទូលំទូលាយ។

គោលការណ៍ស្នូលដែលបានចែងក្នុងមេរៀនទី ១ និងគោលគំនិតនៃអំណាចនិងការចរចា ដែលបានអភិវឌ្ឍឡើងដំបូងក្នុងមេរៀនទី ២ ក៏អាចអនុវត្តបានចំពោះសេដ្ឋកិច្ចនយោបាយអន្តរជាតិដែរ។ រដ្ឋគឺជាតួអង្គដ៏សំខាន់បំផុតនៅក្នុងសេដ្ឋកិច្ចនយោបាយអន្តរជាតិ ប៉ុន្តែ ពួកគេមិនមានសារៈសំខាន់ខ្លាំងដូចនៅក្នុងផ្នែកសន្តិសុខអន្តរជាតិនោះទេ។ តួអង្គនៅក្នុងសេដ្ឋកិច្ចនយោបាយអន្តរជាតិ ក៏ដូចជាតួអង្គនៅក្នុងកិច្ចការសន្តិសុខមានទំនោរធ្វើសកម្មភាពដើម្បីតែផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ពួកគេប៉ុណ្ណោះ។ ដូចដែលរដ្ឋមន្ត្រីការបរទេសប្រេស៊ីលបានពន្យល់កាលពីឆ្នាំ២០០១ ប្រទេសគាត់បានចែករំលែកជាមួយសហរដ្ឋអាមេរិកនូវគោលការណ៍ណែនាំតែមួយដូចគ្នា ក្នុងការចរចាតំបន់ពាណិជ្ជកម្មសេរីទូទាំងទ្វីប(FTA)៖ «តើមានអ្វីសម្រាប់ពួកយើង?»

៨.១.១. ទ្រឹស្តីសេរីនិយមនិងទ្រឹស្តីគាំពារនិយម

គោលការណ៍សំខាន់ពីរ នៅក្នុងសេដ្ឋកិច្ចនយោបាយអន្តរជាតិមានទស្សនៈផ្សេងគ្នាចំពោះពាណិជ្ជកម្ម។ ទ្រឹស្តីមួយ ដែលគេហៅថា **គាំពារនិយម** (mercantilism) ជាទូទៅ មានគោលគំនិតដូចគ្នានឹងទ្រឹស្តីប្រាកដនិយមដែលជឿថា រដ្ឋនីមួយៗត្រូវតែការពារផលប្រយោជន៍ផ្ទាល់ខ្លួន ហើយដើម្បីខ្លួនចំណេញ អ្នកដទៃអាចនឹងខាតបង។ គោលការណ៍នេះមិនពឹងផ្អែកលើអង្គការអន្តរជាតិនានាដើម្បីបង្កើតក្របខ័ណ្ឌរួមមួយសម្រាប់ផ្តល់ផលប្រយោជន៍អោយគ្នាទៅវិញទៅមកទេ។ ដូច្នេះ អ្នកទ្រឹស្តីគាំពារនិយមសង្កត់ធ្ងន់លើអំណាចធៀប (ដូចអ្នកប្រាកដនិយមដែរ)៖ អ្វីដែលសំខាន់ មិនមែនជាសុខុមាលភាពដាច់ខាតរបស់រដ្ឋ ប៉ុន្តែជាហានៈឬអំណាចធៀបរបស់វា ជាមួយនឹងរដ្ឋគូប្រជែង។

បន្ថែមពីនេះទៀត ទ្រឹស្តីគាំពារនិយម (ក៏ដូចជាទ្រឹស្តីប្រាកដនិយមដែរ) ប្រកាន់ខ្ជាប់ថា សារៈសំខាន់នៃប្រតិបត្តិការសេដ្ឋកិច្ចស្ថិតនៅក្នុងលទ្ធផលរបស់វាសម្រាប់វិស័យយោធា។ រដ្ឋព្រួយបារម្ភអំពីទ្រព្យសម្បត្តិនិងពាណិជ្ជកម្មធៀប ពីព្រោះទាំងពីរនេះអាចត្រូវបានបំប្លែងទៅជាអំណាចយោធាដោយផ្ទាល់។ ដូច្នេះ ថ្វីត្បិតតែអំណាចយោធាជាទូទៅមិនមានប្រយោជន៍ក្នុងការចរចាសេដ្ឋកិច្ចក៏ដោយ ក៏ពួកឈ្លួញជឿថា លទ្ធផលនៃការចរចាសេដ្ឋកិច្ចមានសារៈសំខាន់សម្រាប់អំណាចយោធា។

សេដ្ឋកិច្ចសេរីនិយម(Economic liberalism) ដែលជាវិធីសាស្ត្រជំនួស ជាទូទៅ មានគោលគំនិតដូចគ្នានឹងទ្រឹស្តីសេរីអន្តរជាតិនិយម ដែលមានជំនឿលើលទ្ធភាពនៃកិច្ចសហប្រតិបត្តិការដើម្បីសម្រេចបាននូវផលចំណេញរួម (សូមមើលមេរៀនទី ៣)។ វាយល់ថា តាមរយៈការបង្កើតអង្គការ ស្ថាប័ន និងបទដ្ឋានអន្តរជាតិនានា រដ្ឋពាក់ព័ន្ធអាចទទួលបានផលប្រយោជន៍ពីគ្នា ទៅវិញទៅមក ពីការដោះដូរសេដ្ឋកិច្ច។ ចំពោះអ្នកសេរីនិយម វាមានសារៈសំខាន់តិចតួចណាស់ថា តើរដ្ឋមួយទទួលបានច្រើនជាងឬតិចជាងរដ្ឋមួយផ្សេងទៀត ឬថាតើទ្រព្យសម្បត្តិរបស់រដ្ឋកំពុងកើនឡើង ជាដាច់ខាត។

គោលការណ៍សេរីនិយមនិងគាំពារនិយមគឺជាទ្រឹស្តីសេដ្ឋកិច្ច ហើយក៏ជាមនោគមវិជ្ជាផងដែរ ដែលអាចសម្រួចគោលនយោបាយរដ្ឋ។ ទ្រឹស្តីសេរីនិយមគឺជាគោលការណ៍លេចធ្លោជាងគេនៅក្នុងសេដ្ឋកិច្ចបស្ចឹមប្រទេស បើទោះបីជាលេចធ្លោខ្លាំង នៅក្នុង*មីក្រូសេដ្ឋកិច្ច* (microeconomics) (ការសិក្សាអំពីក្រុមហ៊ុន និងក្រុមគ្រួសារ) ជាង*ម៉ាក្រូសេដ្ឋកិច្ច* (macroeconomics) (ការសិក្សាសេដ្ឋកិច្ចប្រទេសជាតិ)។ លទ្ធិម៉ាក្សស៊ីសនិយម ជារឿយៗ ត្រូវបានចាត់ទុកជាគោលការណ៍ទ្រឹស្តីឬមនោគមវិជ្ជាទីបី ចំពោះសេដ្ឋកិច្ចនយោបាយអន្តរជាតិ រួមជាមួយនឹងទ្រឹស្តីគាំពារនិយម និង សេរីនិយម (សូមមើលមេរៀនទី ៣)។ វិធីសាស្ត្រម៉ាក្សស៊ីសនិយមត្រូវបានសម្រួលការកេងប្រវ័ញ្ចសេដ្ឋកិច្ចជាកម្លាំងដែលជះឥទ្ធិពលលើទំនាក់ទំនងនយោបាយ។ យើងនឹងស្វែងយល់ពីទ្រឹស្តីម៉ាក្សស៊ីសនិយមអោយបានស៊ីជម្រៅ នៅក្នុងមេរៀនទី ១២។ ពួកគេកត់សម្គាល់ឃើញថា វាឥទ្ធិពលខ្លាំងក្នុងការពន្យល់អំពីទំនាក់ទំនងអន្តរគោលខាងជើងនិងខាងត្បូង។

ការដោះដូរសេដ្ឋកិច្ចអន្តរជាតិភាគច្រើន (ក៏ដូចជាទំនាក់ទំនងសន្តិសុខ) រួមមានសមាសធាតុមួយចំនួននៃផលប្រយោជន៍សម្រាប់គ្នាទៅវិញទៅមក ពោលគឺផលចំណេញរួមគ្នាដែលអាចសម្រេចបានតាមរយៈកិច្ចសហប្រតិបត្តិការ និងធាតុផ្សំមួយចំនួននៃផលប្រយោជន៍ផ្ទុយគ្នា។ អ្នកទ្រឹស្តីល្បែង ហៅវាថាជាល្បែង «ផលប្រយោជន៍ចម្រុះ»។ ជាឧទាហរណ៍ នៅក្នុងល្បែងជល់មាន់ ឬ «ឡានបុកគ្នា» (ចូរមើលមេរៀនទី ២) អ្នកបើកបរទាំងពីរមានផលប្រយោជន៍រួម ក្នុងការបញ្ចៀសការប៉ះទង្គិចឬបុកគ្នាផ្ទាល់ ប៉ុន្តែផលប្រយោជន៍របស់ពួកគេដើរផ្ទុយគ្នា នៅពេលដែលភាគីម្ខាងអាចក្លាយជាវីរបុរសបានលុះត្រាតែម្ខាងទៀតកំសាកដូចមាន់។ នៅក្នុងពាណិជ្ជកម្មអន្តរជាតិ សូម្បីតែនៅពេលដែលរដ្ឋទាំងពីរទទួលបានផលប្រយោជន៍ពីពាណិជ្ជកម្ម(ផលប្រយោជន៍រួម) រដ្ឋមួយអាចនឹងទទួលបានអត្ថប្រយោជន៍ច្រើនជាងរដ្ឋមួយទៀត (ផលប្រយោជន៍ផ្ទុយគ្នា)។

ទ្រឹស្តីសេរីនិយមសង្កត់ធ្ងន់លើផលប្រយោជន៍រួមក្នុងការដោះដូរសេដ្ឋកិច្ច ចំណែកឯទ្រឹស្តីគាំពារនិយមសង្កត់ធ្ងន់លើផលប្រយោជន៍ផ្ទុយគ្នា។ ចំពោះអ្នកសេរីនិយម គោលដៅសំខាន់បំផុតនៃគោលនយោបាយសេដ្ឋកិច្ច គឺត្រូវបង្កើតទ្រព្យសម្បត្តិសរុបជាអតិបរមាដោយសម្រេចបាននូវ*ប្រសិទ្ធផល*(efficiency)ខ្ពស់បំផុត (បង្កើនទិន្នផលជាអតិបរមា កាត់បន្ថយកាកសំណល់ជាអប្បបរមា)។ ចំពោះអ្នកគាំពារនិយម គោលដៅសំខាន់បំផុត គឺត្រូវបង្កើត*ការបែងចែក*(distribution)ទ្រព្យសម្បត្តិ ដែលអំណោយផលបំផុតសម្រាប់ខ្លួន ឯងផ្ទាល់(សូមមើលក្រាហ្វិក ៨.១)។


អ្នកសេដ្ឋកិច្ចសេរីនិយមជឿជាក់លើទីផ្សារ។ លក្ខខណ្ឌនៃការដោះដូរត្រូវបានកំណត់ដោយតម្លៃដែលទំនិញនោះត្រូវបានជួញដូរ។ ជាញឹកញាប់ *លំហចរចា* (bargaining space) គំលាតរវាងតម្លៃទាបបំផុតដែលអ្នកលក់អាចនឹងទទួលយក និងតម្លៃខ្ពស់បំផុតដែលអ្នកទិញអាចនឹងចំណាយ មានទំហំធំធេងណាស់។ ជាឧទាហរណ៍ អាប៉ាប៊ីសាអូឌីតសុខចិត្តលក់ប្រេងមួយបារ៉ែល (ប្រសិនបើពួកគេមិនមានជម្រើសល្អជាង) ក្នុងតម្លៃទាប រហូតដល់ ១០ ដុល្លារក្នុងមួយបារ៉ែល ចំណែកប្រទេសឧស្សាហកម្មសុខចិត្តចំណាយប្រាក់ ជាង ១០០ ដុល្លារ សម្រាប់ប្រេងមួយបារ៉ែល។ (នៅក្នុងការអនុវត្តជាក់ស្តែង តម្លៃប្រេងមានការប្រែប្រួលចុះឡើងក្នុងគំលាតដ៏ធំបែបនេះ ក្នុងប៉ុន្មានទសវត្សរ៍ថ្មីៗនេះ។) តើតម្លៃត្រូវបានកំណត់ក្នុងកំរិតនេះដោយរបៀបណា? ជារួម ថាតើអ្នកចូលរួមសម្រេចចិត្តយ៉ាងណាលើការបែងចែកអត្ថប្រយោជន៍រៀងៗខ្លួនពីការដោះដូរនេះ?

នៅពេលដែលមានអ្នកទិញនិងអ្នកលក់ទំនិញ ជាច្រើននាក់ (ឬទំនិញសមមូលដែលអាចជំនួសគ្នាបាន) តម្លៃត្រូវបានកំណត់ដោយការប្រកួតប្រជែងទីផ្សារ។ នៅក្នុងការអនុវត្តជាក់ស្តែង ទីផ្សារសេរីត្រូវបានគេ

សន្មត់ថា (ហើយជួនកាលពិតជាបាន) បង្កើតគំរូស្ថិរភាពនៃការទិញនិងការលក់ក្នុងតម្លៃប្រហាក់ប្រហែលគ្នាណាស់ដែរ។ នៅ*តម្លៃទីផ្សារ*នេះ អ្នកលក់ដឹងថាការខិតខំប្រឹងប្រែងដើម្បីដំឡើងតម្លៃនឹងជំរុញអោយអ្នកទិញស្វែងរកអ្នកលក់ផ្សេងទៀត ហើយអ្នកទិញដឹងថាការខិតខំប្រឹងប្រែងដើម្បីបន្ទាបតម្លៃនឹងជំរុញអោយអ្នកលក់ស្វែងរកអ្នកទិញផ្សេងទៀតដែរ។ ដូច្នេះ ក្នុងសេដ្ឋកិច្ចសេរីនិយម ទំនាក់ទំនង*ទ្វេភាគី*(bilateral)រវាងរដ្ឋនានាមានសារៈមានសំខាន់តិចជាងកិច្ចការសន្តិសុខពួកគេ។ អត្ថិភាពនៃទីផ្សារពិភពលោកកាត់បន្ថយអានុភាពដែលរដ្ឋមួយអាចប្រើលើរដ្ឋមួយទៀតក្នុងកិច្ចការសេដ្ឋកិច្ច (ព្រោះរដ្ឋទីពីរអាចស្វែងរកដៃគូផ្សេងទៀតបាន)។ ជាឧទាហរណ៍ ការដាក់ទណ្ឌកម្មរបស់សហរដ្ឋអាមេរិកទៅលើប្រទេសអ៊ីរ៉ង់ ដែលជាប្រទេសនាំចេញប្រេងដ៏ធំមួយបានអញ្ជើញក្រុមហ៊ុនឥណ្ឌាអោយបំពេញតម្រូវការដែលខ្វះចន្លោះ ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ។ ដូច្នេះហើយនៅក្នុងសេដ្ឋកិច្ចនយោបាយអន្តរជាតិ អំណាចកាន់តែសាយភាយនិងពាក់ព័ន្ធនឹងតួអង្គកាន់តែច្រើន ក្នុងពេលតែមួយ ជាងនៅក្នុងសន្តិសុខអន្តរជាតិ។

ក្រាហ្វិក ៨.១ អត្ថប្រយោជន៍រួម និងបុគ្គល

កិច្ចព្រមព្រៀងណាមួយដែលបានកើតឡើង ដូចជានៅចំណុច A ផ្តល់អត្ថប្រយោជន៍ជាក់លាក់ដល់តួអង្គនីមួយៗ(បន្ទាត់ចំនុច)។ អត្ថប្រយោជន៍រួមត្រូវបានពង្រីកជាអតិបរមានៅព្រំដែន Pareto-optimal ប៉ុន្តែការបែងចែកអត្ថប្រយោជន៍ទាំងនោះ ដូចជា រវាងចំណុច B និង C (ដែលទាំងពីរល្អជាង A សម្រាប់តួអង្គទាំងពីរ) គឺជាបញ្ហាសម្រាប់ការចរចា។ អ្នកសេរីនិយមមានការព្រួយបារម្ភច្រើនជាមួយនឹងអត្ថប្រយោជន៍រួមពាណិជ្ជកម្មកាន់តែច្រើនជាមួយនឹងការចែកចាយដែលទាក់ទង។



អ្នកទិញអោយតម្លៃផ្សេងៗគ្នាលើទំនិញដែលពួកគេចង់ទិញ(ដូចជាប្រេងមួយបារ៉ែល)៖ ប្រសិនបើតម្លៃប្រេងឡើងថ្លៃ មនុស្សកាន់តែតិចនឹងហ៊ានទិញវា ហើយប្រសិនបើតម្លៃប្រេងធ្លាក់ចុះ មនុស្សកាន់តែច្រើនចង់ទិញវា។ នេះត្រូវបានគេហៅថា *ខ្សែកោងតម្រូវការ*ទំនិញ(demand curve)។ អ្នកលក់ក៏អោយតម្លៃ

ផ្សេងៗគ្នាលើទំនិញដែលពួកគេចង់លក់ដែរ។ ប្រសិនបើតម្លៃកើនឡើង អ្នកលក់កាន់តែច្រើនមានឆន្ទៈក្នុងការផ្គត់ផ្គង់ទំនិញទៅអោយអ្នកទិញ។ ប្រសិនបើតម្លៃធ្លាក់ចុះ អ្នកលក់កាន់តែតិចមានឆន្ទៈក្នុងការផ្គត់ផ្គង់ទំនិញ។ នេះត្រូវបានគេហៅថា*ខ្សែកោងផ្គត់ផ្គង់*(supply curve)។ នៅក្នុងទីផ្សារសេរី តម្លៃដែលខ្សែកោងផ្គត់ផ្គង់និងខ្សែកោងតម្រូវការប្រសព្វគ្នា គឺជា*តម្លៃលំនឹង* (equilibrium price)។ ក្នុងតម្លៃនេះ អ្នកលក់សុខចិត្តផ្គត់ផ្គង់ចំនួនទំនិញដូចគ្នានឹងចំនួនដែលអ្នកទិញមានឆន្ទៈទិញ (ក្នុងការអនុវត្តជាក់ស្តែង តម្លៃទំនិញឆ្ពុះបញ្ចាំងពីការពិចារណាទុកអំពីការផ្គត់ផ្គង់និងតម្រូវការ នាពេលអនាគតដ៏ខ្លី។)

ទោះជាយ៉ាងណាក៏ដោយ ប្រព័ន្ធផ្គត់ផ្គង់និងតម្រូវការមិនតែងតែបង្កើតអោយមានស្ថេរភាពនោះទេ។ បរាជ័យបែបនេះអាចត្រូវបានគេមើលឃើញ នៅក្នុងទីផ្សារប្រេងឥន្ធនៈ ដែលជាទំនិញដ៏សំខាន់បំផុតនៅក្នុងសេដ្ឋកិច្ចពិភពលោកនិងត្រូវបានជួញដូរច្រើនបំផុត។ តម្លៃប្រេងមួយបារ៉ែលៗមានការប្រែប្រួលយ៉ាងខ្លាំង ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ។ រៀងរាល់ពេលដែលកំណើនសេដ្ឋកិច្ចពិភពលោកកើនឡើង តម្រូវការប្រេងកើនឡើង ហើយតម្លៃរបស់វាក៏កើនឡើងផងដែរ។ ប៉ុន្តែ រៀងរាល់ពេលដែលតម្លៃប្រេងឡើងថ្លៃ សេដ្ឋកិច្ចលោកខាងលិចនឹងធ្លាក់ចុះ(recession) ដោយសារតម្លៃខ្ពស់នៃទំនិញសំខាន់នេះធ្វើអោយខូចខាតសេដ្ឋកិច្ចទាំងមូល។ ការធ្លាក់ចុះសេដ្ឋកិច្ចជាបន្តបន្ទាប់បែបនេះនឹងកាត់បន្ថយតម្រូវការ ហើយតម្លៃប្រេងនឹងធ្លាក់ចុះ។ បរិមាណនៃសកម្មភាពសេដ្ឋកិច្ចអាចប្រែប្រួលត្រឹមតែ ៥ ឬ ១០ ភាគរយប៉ុណ្ណោះ ប៉ុន្តែតម្លៃប្រេងកើនឡើងទ្វេដង ឬបីដងបន្ទាប់មកធ្លាក់ចុះត្រឹមតែពាក់កណ្តាល។ ករណីថ្មីបំផុតពីរនៃវដ្តបែបនេះបានកើតឡើង ក្នុងប៉ុន្មានទសវត្សរ៍កន្លងមក។ ចាប់ពីឆ្នាំ ២០០៧ ការកើនឡើងតម្លៃប្រេងខ្ពស់ខ្លាំងដែលមិនធ្លាប់មានពីមុនមក (និងមិនស្ថិតស្ថេរ) បានបន្សល់ទុកប្រេង នៅត្រឹម ១៤០ ដុល្លារក្នុងមួយបារ៉ែល កើនឡើងពីប្រហែល ៧០ ដុល្លារក្នុងមួយបារ៉ែល។ ការកើនឡើងនេះត្រូវបានជំរុញដោយតម្រូវការថ្មីនៅក្នុងសេដ្ឋកិច្ចអាស៊ីដែលរីកលូតលាស់យ៉ាងឆាប់រហ័ស ក្នុងចំណោមកត្តាផ្សេងទៀត។ បន្ទាប់មក សេដ្ឋកិច្ចពិភពលោកបានធ្លាក់ចូលទៅក្នុងការធ្លាក់ចុះនៃសេដ្ឋកិច្ចដ៏ធំដែលមិនធ្លាប់មានពីមុនមក ហើយតម្លៃប្រេងបានធ្លាក់ចុះ ក្នុងរយៈពេលត្រឹមតែប៉ុន្មានខែប៉ុណ្ណោះ ត្រឡប់មកត្រឹម ៤០ ដុល្លារក្នុងមួយបារ៉ែល។

បន្ទាប់មកទៀត នៅចន្លោះពីឆ្នាំ ២០០៨ និងឆ្នាំ ២០១១ តម្លៃប្រេងបានកើនឡើងម្តងទៀត ដែលឡើងជិត ១២០ ដុល្លារក្នុងមួយបារ៉ែល ហើយធ្លាក់ចុះម្តងទៀត នៅត្រឹមប្រហែល ៣០ ដុល្លារ នៅត្រឹមដើមឆ្នាំ ២០១៦។ (នៅដើមឆ្នាំ ២០១៨ តម្លៃប្រេងមួយបារ៉ែល នៅថេរប្រហែល ៦០ ដុល្លារ)។ អស្ថេរភាពតម្លៃទំនិញដ៏សំខាន់បំផុតបែបនេះជារឿងមិនល្អសម្រាប់សេដ្ឋកិច្ចពិភពលោក ហើយបង្កើតឱកាសលើកទឹកចិត្តដ៏ធំមួយសម្រាប់រដ្ឋាភិបាលក្នុងអន្តរាគមន៍នយោបាយ ជាជាងពឹងផ្អែកលើកម្លាំងទីផ្សារ។

អ្នកទ្រឹស្តីសេរីនិយមសម្លឹងឃើញក្រុមគ្រួសារនិងក្រុមហ៊ុនថាពិតជាតួអង្គសំខាន់ក្នុងសេដ្ឋកិច្ច និងយល់ថាតួនាទីសំខាន់បំផុតរបស់រដ្ឋាភិបាលគឺមិនត្រូវលូកដៃចូលទៅក្នុងកិច្ចការសេដ្ឋកិច្ចទេ លើកលែងតែការរៀបចំច្បាប់ទីផ្សារសេដ្ឋកិច្ច ដើម្បីជួយអោយពួកគេដំណើរការប្រកបដោយប្រសិទ្ធភាព (និងការកសាងហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ដែលក៏ជាផ្នែកមួយធ្វើអោយសេដ្ឋកិច្ចមានដំណើរការប្រកបដោយប្រសិទ្ធិភាពផងដែរ)។ តាមទស្សនៈនេះ វិស័យនយោបាយគួរតែបម្រើផលប្រយោជន៍ប្រសិទ្ធភាពសេដ្ឋកិច្ច។ ជាមួយនឹងការដកដៃរបស់រដ្ឋាភិបាលដែលចេញពីទីផ្សារ«បាតដៃវែទមន្ត» នៃការផ្គត់ផ្គង់និងតម្រូវការ ដែលគេមើលមិនឃើញ អាចធ្វើអោយមានគំរូដែលមានប្រសិទ្ធិភាពបំផុតសម្រាប់ផលិតកម្ម ការដោះដូរ និងការប្រើប្រាស់ (តាមរយៈ

យន្តការតម្លៃ)។ ដោយសារតែផលប្រយោជន៍នៃការធ្វើពាណិជ្ជកម្មសេរីក្នុងចំណោមប្រទេសនានា អ្នកទ្រឹស្តីសេរីនិយមទាត់ចោលការនឹកមមៃដងៃដែលៗអំពីដែនអន្តរជាតិរបស់អ្នកទ្រឹស្តីប្រាកដនិយម ដោយសារព្រំដែនរដ្ឋរារាំងប្រសិទ្ធភាពអតិបរមានៃការដោះដូរទំនិញ។ ទ្រព្យសម្បត្តិពីវិស័យពាណិជ្ជកម្មត្រូវអាស្រ័យលើកិច្ចសហប្រតិបត្តិការនយោបាយអន្តរជាតិ ហើយអំពើហឹង្សាជាធម្មតាមិនអនុគ្រោះដល់ការស្វែងរកទ្រព្យសម្បត្តិសន្ធឹកសន្ធាប់បែបនេះទេ។ ដូច្នេះ អ្នកទ្រឹស្តីសេរីនិយមអះអាងថា ការពឹងអាស្រ័យគ្នា ទៅវិញទៅមក លើកកម្ពស់សន្តិភាព ជាគោលគំនិតដែលត្រូវបានណែនាំពីខាងដើមរួចហើយ (សូមមើលមេរៀនទី ៣)។ (ជាថ្មីម្តងទៀត អ្នកសង្កេតការណ៍ខ្លះបានសង្កេតឃើញនិន្នាការស្រដៀងគ្នានេះ ក្នុងការពឹងពាក់គ្នាទៅវិញទៅមកមុនពេលសង្គ្រាមលោកលើកទី ១ ប៉ុន្តែសង្គ្រាមបែរជាបានផ្ទុះឡើងទៅវិញ។)

រូបថត នាវាផ្ទុកយន្តហោះចិនថ្មីល្អាតក្បែរកោះហុងកុង

អំណាច និង បរិបូរណ៍

អ្នកជំនួញសង្កត់ធ្ងន់ថា ពាណិជ្ជកម្មគួរតែបម្រើការបញ្ចប់នយោបាយ រួមទាំងការពង្រីកអំណាចយោធារបស់រដ្ឋមួយ។ ប្រទេសចិនបានប្រើប្រាស់អតិរេកពាណិជ្ជកម្មរបស់ខ្លួន ដើម្បីបង្កើនការចំណាយលើវិស័យការពារជាតិ និងធ្វើទំនើបកម្មយោធារបស់ខ្លួន។ នៅទីនេះ នាវាផ្ទុកយន្តហោះថ្មីរបស់ចិន ធ្វើដំណើរទៅកាន់ទីក្រុងហុងកុង ខណៈពេលដែលកប៉ាល់កុងតឺន័រដ៏ធំមួយបានចេញដំណើរទៅកាន់សមុទ្រ ដោយបន្ថែមអតិរេកពាណិជ្ជកម្មរបស់ចិន។

ផ្ទុយទៅវិញ សម្រាប់អ្នកទ្រឹស្តីគាំពារនិយម វិស័យសេដ្ឋកិច្ចគួរតែបម្រើវិស័យនយោបាយ៖ ការបង្កើតទ្រព្យសម្បត្តិគួរបញ្ជាក់ពីអំណាចរបស់រដ្ឋ។ ដោយសារតែអំណាចមានលក្ខណៈធៀបគ្នា រដ្ឋមួយមានចិត្តចង់ធ្វើពាណិជ្ជកម្ម លុះត្រាតែការបែងចែកផលប្រយោជន៍ពីពាណិជ្ជកម្មនោះ អនុគ្រោះដល់រដ្ឋនោះជាងរដ្ឋជាគូប្រជែង។ លក្ខខណ្ឌនៃការដោះដូរសម្រួចអត្រាធៀប ដែលជួយអោយរដ្ឋប្រមូលអំណាច ម្លោះហើយនឹងជួយសម្រួចការចែកចាយអំណាចមកខាងខ្លួន នៅក្នុងប្រព័ន្ធអន្តរជាតិ បន្តិចម្តងៗ។

ទ្រឹស្តីគាំពារនិយមសម្រេចបាននូវភាពលេចធ្លោជាងគេ អស់រយៈពេលច្រើនរយឆ្នាំមុន ហើយចក្រភពអង់គ្លេសបានប្រើប្រាស់ពាណិជ្ជកម្មដើម្បីបង្កើនអំណាចធៀបរបស់ខ្លួននៅក្នុងប្រព័ន្ធអន្តរជាតិ កំឡុងសតវត្សរ៍ទី ១៨។ នៅពេលនោះ គាំពារនិយមមានន័យជាពិសេសថាជាការបង្កើតអតិរេកពាណិជ្ជកម្ម ដើម្បីស្តុកទុកលុយ ក្នុងទម្រង់ជាលោហៈដ៏មានតម្លៃ (ដូចជា មាសនិងប្រាក់ ជាដើម) ដែលបន្ទាប់មក អាចត្រូវបានប្រើដើម្បីទិញសមត្ថភាពយោធា (កងទ័ពស៊ីឈ្នួល និងអាវុធ) ក្នុងសម័យសង្គ្រាម។


គោលការណ៍គាំពារនិយមបានធ្លាក់ចុះនៅក្នុងសតវត្សរ៍ទី ១៩ នៅពេលដែលចក្រភពអង់គ្លេសបានសម្រេចចិត្តថា ខ្លួនមានផលចំណេញច្រើនពីពាណិជ្ជកម្មសេរី ជាជាងគោលនយោបាយគាំពារនិយម។ វាបានត្រឡប់មកវិញ ក្នុងហានៈជាវិធីសាស្ត្រដ៏សំខាន់មួយ ក្នុងកំឡុងសង្គ្រាមលោកលើកទី ១ និងសង្គ្រាមលោកលើកទីពីរ នៅពេលដែលទំនាក់ទំនងពាណិជ្ជកម្មសកលលោកសេរីត្រូវរង្គោះរង្គើរ។

មធ្យោបាយជាទីពេញចិត្តរបស់អ្នកទ្រឹស្តីគាំពារនិយម ក្នុងការធ្វើអោយវិស័យពាណិជ្ជកម្មបម្រើផលប្រយោជន៍នយោបាយរបស់រដ្ឋ ទោះជាត្រូវខាតបង់តម្លៃទ្រព្យសម្បត្តិមួយចំនួនដែលទីផ្សារសេរីប្រហែលជាបានបង្កើតឡើងក៏ដោយ គោលដៅគឺត្រូវបង្កើតតុល្យភាពពាណិជ្ជកម្មអំណោយផលមកខាងខ្លួន។ **សមតុល្យឬជញ្ជីងពាណិជ្ជកម្ម** (balance of trade) គឺជាតម្លៃនៃការនាំចូលធៀបនឹងការនាំចេញរបស់រដ្ឋមួយ។ រដ្ឋ

មួយដែលនាំចេញច្រើនជាងការនាំចូល មាន*តុល្យភាពពាណិជ្ជកម្មវិជ្ជមាន* ឬ *អតិរេកពាណិជ្ជកម្ម*(trade surplus)។ ប្រទេសចិនបានដំណើរការអតិរេកពាណិជ្ជកម្មដ៏ធំ អស់រយៈពេលជាច្រើនឆ្នាំ ប្រហែលជាង ៤៤០ ពាន់លានដុល្លារក្នុងមួយឆ្នាំ ក្នុងឆ្នាំ ២០១៧។ វាទទួលបានប្រាក់ច្រើនជាងសម្រាប់ទំនិញជាច្រើនដែលខ្លួនបាននាំចេញ ជាងការចំណាយលើវត្ថុធាតុដើមនិងទំនិញនាំចូលផ្សេងទៀត (សូមមើល ក្រាហ្វិក ៨.២)។ រដ្ឋដែលនាំចូលច្រើនជាងការនាំចេញមាន*តុល្យភាពពាណិជ្ជកម្មអវិជ្ជមាន*ឬ(*ខិនភាពពាណិជ្ជកម្ម*)។ ខិនភាពពាណិជ្ជកម្មខុសពីខិនភាពថវិកាក្នុងការចំណាយរបស់រដ្ឋាភិបាល (សូមមើលមេរៀនទី ៩)។ ចាប់តាំងពីចុងទសវត្សរ៍ឆ្នាំ១៩៩០មក ខិនភាពពាណិជ្ជកម្មរបស់សហរដ្ឋអាមេរិកបានកើនឡើងជាលំដាប់ រហូតដល់រាប់រយបីលានដុល្លារក្នុងមួយឆ្នាំ។ លើសពី ៥៦០ បីលានដុល្លារក្នុងឆ្នាំ ២០១៧ ដោយក្នុងនោះប្រហែលមួយភាគបួនត្រូវបានតំណាងដោយប្រទេសចិន និងមួយភាគបួនទៀតដោយការនាំចូលប្រេង។

ក្រាហ្វិក ៨.២ អតិរេកពាណិជ្ជកម្មដែលកំពុងកើនឡើងរបស់ចិន


ប្រភព៖ ការិយាល័យស្ថិតិជាតិចិន។



រដ្ឋទីបំផុតទៅត្រូវតែជួយផ្សះផ្សាសមតុល្យពាណិជ្ជកម្ម។ វាត្រូវបានតាមដានហិរញ្ញវត្ថុ តាមរយៈប្រព័ន្ធនៃគណនីជាតិ (សូមមើលមេរៀនទី ៩)។ ពោលគឺ រដ្ឋមួយអាចធ្វើពាណិជ្ជកម្មក្នុងរយៈពេលពីរបីឆ្នាំ ជាមួយនឹងខិនភាពពាណិជ្ជកម្ម ហើយពីរបីឆ្នាំបន្ទាប់ជាមួយនឹងអតិរេកពាណិជ្ជកម្ម។ អសមតុល្យត្រូវបានរាប់បញ្ចូលក្នុងគណនីជាតិជាប្រភេទនៃប្រាក់កម្ចី។ ប៉ុន្តែ ខិនភាពពាណិជ្ជកម្មដែលបន្តមានច្រើនឆ្នាំអាចក្លាយជាបញ្ហា។ ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ដើម្បីធ្វើអោយមានតុល្យភាពឬកែតម្រូវខិនភាពពាណិជ្ជកម្មរបស់ខ្លួន សហរដ្ឋអាមេរិកបាន«នាំចេញ»រូបិយប័ណ្ណ(ដុល្លារ)ទៅកាន់ប្រទេសចិន ជប៉ុន អឺរ៉ុប និងប្រទេសផ្សេងទៀតដែលប្រើប្រាស់ប្រាក់ដុល្លារដើម្បីទិញទំនិញដូចជា ភាគហ៊ុនរបស់ក្រុមហ៊ុនអាមេរិក បំណុលបំណុលរតនាគារសហរដ្ឋអាមេរិក ឬអចលនទ្រព្យអាមេរិក។ អ្នកសេដ្ឋកិច្ចព្រួយបារម្ភថា ប្រសិនបើបរទេសបាត់ចំណាងចំណូលចិត្ត សម្រាប់ការវិនិយោគនៅក្នុងសហរដ្ឋអាមេរិក សេដ្ឋកិច្ចរបស់សហរដ្ឋអាមេរិកអាចត្រូវរងគ្រោះ។

នេះជាហេតុផលដ៏ចំបងមួយ ដែលអ្នកទ្រឹស្តីគាំពារនិយមពេញចិត្តគោលនយោបាយសេដ្ឋកិច្ចជាតិ ដើម្បីបង្កើតអតិរេកពាណិជ្ជកម្ម។ នៅពេលនោះ ជាជាងគ្មានលទ្ធភាពរកលុយដែល ប្រហែលជាត្រូវការជាចាំបាច់ដើម្បីទប់ទល់នឹងវិបត្តិឬសង្គ្រាមណាមួយ រដ្ឋអង្គុយលើគំនរលុយដែលតំណាងអោយសក្តានុពលអំណាច។ តាមប្រវត្តិសាស្ត្រ គោលការណ៍គាំពារនិយម(mercantilism)មានន័យត្រង់ថាជាការស្តុកមាស(ទទួលបានពីការដំណើរការអតិរេកពាណិជ្ជកម្ម)ទុកជាទម្រង់បម្លែងជាអំណាច(សូមមើលក្រាហ្វិក ៨.៣)។ យុទ្ធសាស្ត្របែបនេះ ត្រូវគ្នានឹងការសង្កត់ធ្ងន់លើអំណាចធៀប របស់ទ្រឹស្តីប្រាកដនិយមនិងជាឧទាហរណ៍មួយនៃគោលការណ៍គ្រប់គ្រង។ ដើម្បីអោយរដ្ឋមួយមានអតិរេកពាណិជ្ជកម្ម រដ្ឋមួយទៀតត្រូវតែមានឱនភាពពាណិជ្ជកម្ម។

ក្រាហ្វិក ៨.៣ សមតុល្យឬជញ្ជីងពាណិជ្ជកម្ម



៨.១.២. គុណសម្បត្តិធៀប

ជោគជ័យជារួមនៃសេដ្ឋកិច្ចសើរើ អាស្រ័យដោយសារផលចំណេញយ៉ាងច្រើនសន្ធឹកសន្ធាប់ដែលអាចទទួលបានតាមរយៈពាណិជ្ជកម្ម។ ផលចំណេញទាំងនេះគឺជាលទ្ធផលនៃ**គុណសម្បត្តិធៀប**(comparative advantage)ដែលរដ្ឋផ្សេងៗគ្នាសប្បាយនឹងផលិតទំនិញផ្សេងៗគ្នា (គោលគំនិតដែលត្រួសត្រាយដោយអ្នកសេដ្ឋកិច្ច អាដាម ស្មីត (Adam Smith) និង ដេវីឌ រីខាដូ (David Ricardo) កាលពី ២០០ឆ្នាំមុន)។ រដ្ឋមានសមត្ថភាពផ្សេងៗគ្នាក្នុងការផលិតទំនិញមួយចំនួន ដោយសារតែលក្ខណៈផ្សេងៗគ្នារបស់ពួកគេក្នុងផ្នែកធនធានធម្មជាតិ លក្ខណៈកម្លាំងពលកម្ម បច្ចេកវិទ្យា និងកត្តាផ្សេងៗទៀត។ ដើម្បីបង្កើនការបង្កើតទ្រព្យសម្បត្តិជាអតិបរមា រដ្ឋនីមួយៗគួរតែមាននិងសម្រួចដំនាញរបស់ខ្លួនក្នុងការផលិតទំនិញណាមួយ ដែលខ្លួនមានគុណសម្បត្តិធៀប ហើយយកទំនិញនោះទៅដូរជាមួយនឹងទំនិញដែលរដ្ឋមួយផ្សេងទៀតផលិតបានល្អបំផុត។ ជាការពិតណាស់ ការចំណាយលើការដឹកជញ្ជូននិងដំណើរការព័ត៌មានក្នុងពាណិជ្ជកម្ម (ហៅថា *ថ្លៃប្រតិបត្តិការ-* transaction costs) ត្រូវតែរួមបញ្ចូលក្នុងការចំណាយលើការផលិតវត្ថុឬទំនិញណាមួយ។

ប៉ុន្តែ នៅពេលដែលសកលភាវូបនីយកម្មដំណើរការកាន់តែខ្លាំងឡើង ការចំណាយពីរមុខនេះ មានកម្រិតទាបបើធៀបនឹងគំលាតតម្លៃនៃការផលិតទំនិញនានានៅទីកន្លែងផ្សេងៗគ្នា។

ទំនិញសំខាន់ពីរ នៅលើពិភពលោករួមមានប្រេងនិងរថយន្ត។ វាមានតម្លៃថោកជាងខ្លាំងក្នុងការផលិតប្រេង(ឬប្រភពថាមពលផ្សេងទៀត)នៅក្នុងប្រទេសអារ៉ាប៊ីសាអូឌីតជាងនៅប្រទេសជប៉ុន ហើយវាក៏មានតម្លៃថោកជាងខ្លាំងដែរក្នុងការផលិតរថយន្តនៅប្រទេសជប៉ុនជាងនៅប្រទេសអារ៉ាប៊ីសាអូឌីត។ ប្រទេសជប៉ុនត្រូវការប្រេងដើម្បីដំណើរការឧស្សាហកម្មរបស់ខ្លួន (រួមទាំងឧស្សាហកម្មរថយន្តផង) ហើយប្រទេសអារ៉ាប៊ីសាអូឌីតត្រូវការរថយន្តដើម្បីធ្វើដំណើរលើទឹកដីដ៏ធំល្វឹងល្វើយរបស់ខ្លួន (រួមទាំងការធ្វើដំណើរទៅដល់អណ្តូងប្រេងដែលនៅឆ្ងាយពីទីក្រុងរបស់ខ្លួន)។ ទោះបីជាបូកបញ្ចូលថ្លៃដឹកជញ្ជូននិងប្រតិបត្តិការក៏ដោយ ការដឹកជញ្ជូនរថយន្តជប៉ុនទៅកាន់ប្រទេសអារ៉ាប៊ីសាអូឌីត និងប្រេងអារ៉ាប៊ីសាអូឌីតទៅកាន់ប្រទេសជប៉ុនអាចសន្សំឬចំណេញប្រាក់បានយ៉ាងច្រើនសន្ធឹក បើធៀបនឹងថ្លៃចំណាយ ប្រសិនបើប្រទេសនីមួយៗព្យាយាមផ្គត់ផ្គង់ដោយខ្លួនឯង។

រដ្ឋមួយមិនចាំបាច់មានគុណសម្បត្តិធៀបដាច់ខាត (ពោលគឺ អ្នកផលិតដែលមានប្រសិទ្ធភាពបំផុតក្នុងពិភពលោក) ក្នុងការផលិតទំនិញប្រភេទណាមួយ ដើម្បីធ្វើការទូទាត់ជាលក្ខណៈឯកទេសនោះទេ។ វាត្រូវការតែជំនាញក្នុងការផលិតទំនិញដែលចំណាយឬមានតម្លៃទាបជាងទំនិញផ្សេងទៀត។ សាកស្រមៃថាប្រទេសជប៉ុនបានរកឃើញវិធីសាស្ត្រមួយដើម្បីផលិតប្រេងសំយោគ ដោយប្រើកម្លាំងពលកម្មនិងដើមទុនដូចដែលខ្លួនបានប្រើសម្រាប់ផលិតរថយន្ត ហើយថាប្រេងសំយោគនេះអាចត្រូវបានផលិត ដោយចំណាយតិចជាងតម្លៃដែលអារ៉ាប៊ីសាអូឌីតផលិតប្រេង ប៉ុន្តែ ប្រទេសជប៉ុននៅតែអាចផលិតរថយន្ត ដោយចំណាយតិចអស់ថ្លៃតិចជាង*ឆ្ងាយ* អារ៉ាប៊ីសាអូឌីត។ វាហាក់ដូចជាសមបំផុតដែលប្រទេសជប៉ុនគួរតែផលិតប្រេងសំយោគជាជាងចំណាយប្រាក់បន្ថែមសម្រាប់នាំចូលប្រេងអារ៉ាប៊ីសាអូឌីត។ ប៉ុន្តែ ការយល់បែបនេះខុសហើយ។ តាមទស្សនៈសេដ្ឋកិច្ចយ៉ាងតឹងរ៉ឹង ប្រទេសជប៉ុនគួរតែបន្តផលិតរថយន្ត (ដែលវាមានគុណសម្បត្តិធៀបយ៉ាងធំធេង) ហើយមិនគួរបង្វែរដើមទុននិងកម្លាំងពលកម្មដើម្បីផលិតប្រេងសំយោគទេ (ដែលវាមានគុណសម្បត្តិធៀបតិចតួចតែប៉ុណ្ណោះ)។ ប្រាក់ចំណេញបន្ថែមដែលប្រទេសជប៉ុនអាចនឹងទទួលបានពីការនាំចេញរថយន្តកាន់តែច្រើន នឹងលើសពីអាចទូទាត់តម្លៃខ្ពស់ជាងបន្តិច ដែលខ្លួននឹងត្រូវចំណាយបន្ថែមសម្រាប់ការនាំចូលប្រេង។

ដូច្នេះ ពាណិជ្ជកម្មអន្តរជាតិ ជាទូទៅ ពង្រីកព្រំដែនផលប្រយោជន៍ជាអតិបរមា (Pareto-optimal frontier) (សូមមើលក្រាហ្វិក ៨.១) ដោយបង្កើនប្រសិទ្ធភាពផលិតកម្មជារួម។ ពាណិជ្ជកម្មសេរីបែងចែកធនធានសកលទៅរដ្ឋនានាដែលមានគុណសម្បត្តិធៀបខ្ពស់បំផុតក្នុងការផលិតទំនិញនីមួយៗ។ ជាលទ្ធផលតម្លៃមានកម្រិតទាបជាង ជារួម និងប្រហាក់ប្រហែលគ្នា នៅទូទាំងពិភពលោក។ ផលិតកម្មកាន់តែ តម្រង់ទិសទៅកាន់ទីផ្សារពិភពលោក។

ទោះជាយ៉ាងនេះក្តី ផលប្រយោជន៍សេដ្ឋកិច្ចពីវិស័យពាណិជ្ជកម្ម ក៏បាននាំមកជាមួយនូវគុណវិបត្តិនយោបាយខ្លះផងដែរ។ ទីមួយ អត្ថប្រយោជន៍រយៈពេលវែងអាចប្រឈមនឹងការចំណាយរយៈពេលខ្លី។ នៅពេលដែលរដ្ឋចាប់ផ្តើមនាំចូលទំនិញ ដែលធ្លាប់តែផលិតក្នុងស្រុក សេដ្ឋកិច្ចរបស់ខ្លួនអាចនឹងមានការរំខាន។ កម្មករអាចនឹងត្រូវបណ្តុះបណ្តាលជំនាញឡើងវិញ និងស្វែងរកការងារថ្មី ហើយដើមទុនប្រហែលជាមិនងាយ

នឹងបង្វែរទៅគោលដៅប្រើប្រាស់ថ្មីនោះទេ។ ដូច្នេះហើយ អ្នកដឹកនាំរដ្ឋអាចនឹងរងសម្ពាធនយោបាយ ក្នុងការ ពាក់ព័ន្ធនឹងគោលនយោបាយសេដ្ឋកិច្ច (សូមមើលផ្នែក ៨.៣.២ **ប្រតិកម្មប្រឆាំងនឹងពាណិជ្ជកម្ម**)។ ដូចគ្នា នេះដែរ ផលចំណេញនិងការចំណាយនៃវិស័យពាណិជ្ជកម្មហាក់មិនត្រូវបានចែកចាយ ស្មើគ្នានៅ*ក្នុងរង្វង់*ដូ មួយ។ ឧស្សាហកម្មឬសហគមន៍មួយចំនួនអាចទទួលបានអត្ថប្រយោជន៍ ឬ ផលចំណេញពីការចំណាយឬ ខាតបង់របស់អ្នកដទៃ។ ជាឧទាហរណ៍ប្រសិនបើក្រុមហ៊ុនផលិតទំនិញណាមួយនៅសហរដ្ឋអាមេរិកប្តូរទីតាំង រោងចក្ររបស់ខ្លួនទៅប្រទេសម៉ិកស៊ិក ដើម្បីទាញយកអត្ថប្រយោជន៍ពីតម្លៃកម្លាំងពលកម្មថោកជាង នៅទី នោះ ហើយនាំចេញទំនិញរបស់ខ្លួនត្រឡប់មកសហរដ្ឋអាមេរិកវិញ កម្មកររនៅរោងចក្រចាស់របស់សហរដ្ឋ អាមេរិកបាត់បង់ការងារធ្វើ ប៉ុន្តែអ្នកប្រើប្រាស់នៅសហរដ្ឋអាមេរិកត្រេកអរនឹងទំនិញថោកជាង។ ការខាតបង់ ធ្ងន់ធ្ងរនៃការផ្លាស់ប្តូរបែបនេះធ្លាក់លើកម្មករមួយចំនួន ប៉ុន្តែអត្ថប្រយោជន៍នឹងត្រូវពង្រាយតិចៗដល់ អ្នក ប្រើប្រាស់ជាច្រើន។

ស្របតាមឡូហ្ស៊ីកដដែលនេះ វិធានការណ៍របស់អ្នកគាំពារនិយមផ្តល់អត្ថប្រយោជន៍ច្រើនដល់មនុស្ស មួយចំនួនតូច ហើយមនុស្សជាច្រើនត្រូវចែករម្លែកការខាតបង់ម្នាក់បន្តិចៗ។ តាមការប៉ាន់ប្រមាណមួយ ពន្ធ លើការនាំចូលដែកថែប ២០ ភាគរយ ដែលបានអនុម័តដោយរដ្ឋបាលប្រធានាធិបតី ប៊ូស ក្នុងឆ្នាំ ២០០២-២០០៣ បានធ្វើអោយអ្នកប្រើប្រាស់ចំណាយអស់ ៧ ប៊ីលានដុល្លារ និងបានជួយសង្គ្រោះការងារអាមេរិក ចំនួន ៧៣០០ កន្លែង ដែលការងារនីមួយៗមានតម្លៃខ្ពស់ប្រហែល ៣២៦០០០ ដុល្លារ។ ប៉ុន្តែ កម្លាំងកម្មករ ទាំង ៧៣០០ នាក់ (និងសហជីពក៏ដូចជាក្រុមហ៊ុនរបស់ពួកគេ)ទទួលបានអត្ថប្រយោជន៍យ៉ាងច្រើន ខណៈ ពេលដែលការខាតបង់ប្រហែល ២០ ដុល្លារ សម្រាប់ពលរដ្ឋអាមេរិកម្នាក់ៗ មិនត្រូវបានគេកត់សម្គាល់ឡើយ។ ដូចគ្នានេះដែរ ពន្ធនាំចូល ៣០ ភាគរយ លើបន្ទះសូឡា (បន្ទះស្រូបពន្លឺព្រះអាទិត្យ) អនុម័តដោយរដ្ឋបាល ប្រធានាធិបតីត្រាំ ក្នុងឆ្នាំ ២០១៨ ខណៈពេលដែលមានគោលដៅចង់សង្គ្រោះការងាររោងចក្រក្នុងស្រុក ត្រូវ បានគេព្យាករណ៍ថា នឹងនាំអោយមានការបាត់បង់ការងារជារួម។ កំណើនតម្លៃបន្ទះសូឡា ដែលបណ្តាលមក ពីអត្រាពន្ធនេះអាចនាំអោយការលក់ធ្លាក់ចុះ ដែលនឹងបណ្តាលអោយបាត់បង់ការងារ នៅក្នុងឧស្សាហកម្ម ផលិតនិងតម្លើងបន្ទះសូឡា។ ការបែងចែកការខាតបង់និងផលចំណេញមិនស្មើគ្នាបែបនេះតែងតែបង្កើត បញ្ហានយោបាយសម្រាប់ពាណិជ្ជកម្មសេរី សូម្បីតែនៅពេលផលប្រយោជន៍សេដ្ឋកិច្ច*ទាំងមូល*មានទំហំធំជាង ការខាតបង់ក៏ដោយ។ ក្រុមតំណាងផលប្រយោជន៍កម្មករ ឬ រោងចក្រឧស្សាហកម្ម នឹងរួមគ្នាប្រឆាំងនឹង ការខាតបង់ប្រមូលផ្តុំ (ការបាត់បង់ការងារ) ញឹកញាប់ជាងក្រុមអ្នកប្រើប្រាស់ដែលអាចរួមសាមគ្គីគ្នាប្រឆាំង នឹងការខាតបង់ ដោយពង្រាយម្នាក់បន្តិចៗ។

៨.១.៣. ការជ្រៀតជ្រែកផ្នែកនយោបាយនៅក្នុងទីផ្សារ

ទីផ្សារសេរីនិងមានប្រសិទ្ធភាពខ្ពស់តម្រូវអោយអ្នកទិញនិងអ្នកលក់ជាច្រើន ទទួលបានព័ត៌មានពេញ លេញអំពីទីផ្សារ។ ដូចគ្នានេះដែរ ឆន្ទៈរបស់អ្នកចូលរួមក្នុងការរកស៊ីជាមួយនឹងគ្នា មិនគួរត្រូវបានបំភ្លៃដោយ ការលម្អៀងផ្ទាល់ខ្លួន (ឬនយោបាយ)ទេ ប៉ុន្តែ គួរតែត្រូវបានតម្រែតម្រង់ដោយការពិចារណាអំពីតម្លៃនិង គុណភាពតែប៉ុណ្ណោះ។ ការឃ្លាតឆ្ងាយពីលក្ខខណ្ឌទាំងនេះ ដែលត្រូវហៅថា *ភាពមិនល្អឥតខ្ចោះនៃទីផ្សារ* (market imperfections) នឹងកាត់បន្ថយប្រសិទ្ធភាព។ ការជ្រៀតជ្រែកផ្នែកនយោបាយភាគច្រើនទៅក្នុង ប្រតិបត្តិការសេដ្ឋកិច្ច គឺជាភាពមិនល្អឥតខ្ចោះនៃទីផ្សារ។

ពាណិជ្ជកម្មអន្តរជាតិប្រព្រឹត្តទៅជាញឹកញាប់តាមតម្លៃទីផ្សារពិភពលោក ច្រើនជាងតាមការដោះដូរសេដ្ឋកិច្ច*ក្នុងស្រុក*។ គ្មានរដ្ឋាភិបាលពិភពលោកណាមួយជាម្ចាស់ឧស្សាហកម្ម ផ្តល់ការឧបត្ថម្ភទំនុកបំរុងទុន ឬគ្រប់គ្រងតម្លៃនោះទេ។ ទោះជាយ៉ាងណាក៏ដោយ ទីផ្សារពិភពលោកជារឿយៗត្រូវងផលប៉ះពាល់ដោយនយោបាយ។ នៅពេលដែលរដ្ឋក្លាយជាតួអង្គសំខាន់ក្នុងកិច្ចការសេដ្ឋកិច្ចអន្តរជាតិ ជារឿយៗ ចំនួនអ្នកចូលរួមកាន់តែតិច។ នៅពេលដែលមានតែអ្នកផ្គត់ផ្គង់ទំនិញមួយតែម្នាក់ឯង *សិទ្ធិផ្តាច់មុខ* (monoply) អ្នកផ្គត់ផ្គង់នោះអាចកំណត់តម្លៃខ្ពស់ពេកក្រៃ។ ជាឧទាហរណ៍ ក្រុមហ៊ុនត្បូងពេជ្រអាហ្វ្រិកខាងត្បូង ឈ្មោះ De Beers ផលិតត្បូងពេជ្រមិនទាន់ឆ្នៃ ជាងមួយភាគបីនៃការផ្គត់ផ្គង់ពិភពលោក និងគ្រប់គ្រងពីរភាគបីនៃទីផ្សារត្បូងពេជ្រមិនទាន់ឆ្នៃលើពិភពលោក។ អប្បជនផ្តាច់មុខ (oligopoly) គឺជាសិទ្ធិផ្តាច់មុខក្នុងចំណោមអ្នកលក់ធំៗមួយចំនួនតែប៉ុណ្ណោះ ដែលជារឿយៗអនុញ្ញាតអោយមានការសម្របសម្រួលដោយសម្ងាត់ ឬច្បាស់លាស់ដើម្បីបង្ខំអោយតម្លៃផលិតផលណាមួយឡើងថ្លៃ។ ជាឧទាហរណ៍ សមាជិកនៃអង្គការប្រទេសនាំចេញប្រេង (OPEC) យល់ព្រមក្នុងកម្រិតបរិមាណផលិតកម្មប្រេង ដើម្បីរក្សាឬតម្លើងតម្លៃប្រេងខ្ពស់។ ដោយសារក្រុមហ៊ុននានាអាចមូលមតិគ្នាជាក្រុមក្នុងរង្វង់ព្រំដែនជាតិ សិទ្ធិផ្តាច់មុខនិងអប្បជនផ្តាច់មុខទំនងជាកើតឡើងញឹកញាប់ជាង។

ភាពមិនល្អឥតខ្ចោះរបស់ទីផ្សារមួយទៀត នៅក្នុងពាណិជ្ជកម្មអន្តរជាតិ គឺ*អំពើពុករលួយ* នៅពេលបុគ្គលណាម្នាក់ទទួលបានប្រាក់បំណាច់ក្នុងការជួញដូរទំនិញមិនដូចតម្លៃក្នុងទីផ្សារ។ រដ្ឋាភិបាលឬក្រុមហ៊ុនដែលពាក់ព័ន្ធអាចនឹងបាត់បង់អត្ថប្រយោជន៍មួយចំនួនដែលកំពុងត្រូវបានបែងចែកគ្នា ប៉ុន្តែមន្ត្រីរដ្ឋាភិបាល ឬអ្នកចរចារបស់ក្រុមហ៊ុននីមួយៗទទួលបានអត្ថប្រយោជន៍កើនឡើង (សូមមើលមេរៀនទី ១៣)។

នយោបាយផ្តល់*ក្របខ័ណ្ឌផ្លូវច្បាប់*(legal framework)សម្រាប់ទីផ្សារ ដោយធានាថាអ្នកចូលរួមរក្សាការប្តេជ្ញារបស់ពួកគេ កិច្ចសន្យាត្រូវជាប់កាតព្វកិច្ច អ្នកទិញត្រូវបង់ប្រាក់សម្រាប់ទំនិញដែលពួកគេទិញ លុយក្លែងក្លាយមិនត្រូវបានប្រើជាដើម។ នៅក្នុងសេដ្ឋកិច្ចអន្តរជាតិ កង្វះអាជ្ញាធររដ្ឋាភិបាលកណ្តាល ច្បាប់មិនសូវត្រូវបានអនុវត្តដោយងាយនោះទេ។ ដូចនៅក្នុងកិច្ចការសន្តិសុខដែរ វិធានបែបនេះអាចត្រូវបានបម្លែងជាច្បាប់នៅក្នុងសន្ធិសញ្ញាអន្តរជាតិ ប៉ុន្តែ ការពង្រឹងការអនុវត្តត្រូវអាស្រ័យទៅលើគោលការណ៍បដិការ (សូមមើលមេរៀនទី ៣)។

ការយកពន្ធ (taxation) គឺជាឥទ្ធិពលនយោបាយមួយផ្សេងទៀតទៅលើទីផ្សារ។ ពន្ធត្រូវបានប្រើដើម្បីប្រមូលប្រាក់ចំណូលសម្រាប់រដ្ឋាភិបាលផង និងដើម្បីគ្រប់គ្រងសកម្មភាពសេដ្ឋកិច្ច ដោយការលើកទឹកចិត្តផង។ ជាឧទាហរណ៍ រដ្ឋាភិបាលអាចយកពន្ធទាបលើក្រុមហ៊ុនបរទេស ដោយសង្ឃឹមថានឹងទាក់ទាញពួកគេមកបោះទីតាំងនិងវិនិយោគទុន នៅក្នុងប្រទេសរបស់ខ្លួន។ ពន្ធដែលត្រូវអនុវត្តចំពោះពាណិជ្ជកម្មអន្តរជាតិផ្ទាល់ ដែលត្រូវហៅថា *ពន្ធគយ* (tariffs) គឺជាប្រភពនៃជម្លោះអន្តរជាតិជាញឹកញាប់ (សូមមើលគោលនយោបាយគាំពារនិយម នៅផ្នែកបន្ទាប់)។

ទណ្ឌកម្ម

ការជ្រើសជ្រែកផ្នែកនយោបាយនៅក្នុងទីផ្សារសេរីលេចចេញជារូបភាពច្បាស់បំផុត នៅពេលដែលរដ្ឋាភិបាលអនុវត្ត*ទណ្ឌកម្ម*(sanction)ប្រឆាំងនឹងអន្តរកម្មសេដ្ឋកិច្ចនៃប្រភេទទំនិញមួយចំនួន ឬរវាងតួអង្គមួយចំនួន។ បន្ទាប់មក អំណាចនយោបាយ នឹងហាមឃាត់ការដោះដូរសេដ្ឋកិច្ចដែលអាចនឹងផ្តល់ផល

ប្រយោជន៍សម្រាប់គ្នាទៅវិញទៅមក។ ក្នុងឆ្នាំ ២០១៨ សហរដ្ឋអាមេរិកបានរឹតបន្តឹងសកម្មភាពពាណិជ្ជកម្ម លើរដ្ឋចំនួន ១១ ដើម្បីឆ្លើយតបទៅនឹងសកម្មភាពនយោបាយរបស់រដ្ឋទាំងនោះ ដូចជា ការរំលោភសិទ្ធិមនុស្សជាដើម។

ការពង្រឹងទណ្ឌកម្ម តែងតែជាកិច្ចការដ៏លំបាកមួយ ពីព្រោះអ្នកចូលរួមទទួលបានរង្វាន់លើកទឹកចិត្ត ផ្នែកហិរញ្ញវត្ថុក្នុងការបំពានទណ្ឌកម្មតាមរយៈទីផ្សារងងឹត ឬតាមមធ្យោបាយផ្សេងទៀត។ បើគ្មានការគាំទ្រពហុភាគីដ៏ទូលំទូលាយក្នុងការពង្រឹងទណ្ឌកម្មអន្តរជាតិនោះទេ ជាទូទៅទណ្ឌកម្មទាំងនោះនឹងត្រូវបរាជ័យ។ ជាឧទាហរណ៍ ក្នុងឆ្នាំ ២០១២ ប្រទេសឥណ្ឌាដែលជាអតិថិជនប្រេងធំបំផុតរបស់ប្រទេសអ៊ីរ៉ង់ បានបញ្ជូនគណៈប្រតិភូពាណិជ្ជកម្មទៅអ៊ីរ៉ង់ ដើម្បីទាញយកអត្ថប្រយោជន៍ពីការបើកចំហរជើងមេឃ ដែលបង្កើតឡើងដោយទណ្ឌកម្មរបស់ប្រទេសលោកខាងលិច។ ភាពលំបាកក្នុងការអនុវត្តទណ្ឌកម្មឆ្លុះបញ្ចាំងពីចំណុចទូទៅដែលត្រូវបានគូសបញ្ជាក់មុននេះ ពោលគឺ អំណាចនៅក្នុងសេដ្ឋកិច្ចនយោបាយអន្តរជាតិ ត្រូវបានពង្រាយក្នុងចំណោមរដ្ឋយ៉ាងទូលំទូលាយជាងនៅក្នុងកិច្ចការសន្តិសុខ។ ការបដិសេធមិនចូលរួមក្នុងការដោះដូរសេដ្ឋកិច្ចដែលផ្តល់ផលចំណេញដល់គ្នាទៅវិញទៅមក ជារឿយៗ ធ្វើអោយប៉ះពាល់ដល់ខ្លួនឯងច្រើនជាងប្រទេសគោលដៅនៃទណ្ឌកម្មរបស់ខ្លួន លុះត្រាតែស្ទើរតែទាំងអស់នៃរដ្ឋផ្សេងទៀតអនុវត្តតាម យ៉ាងហ្មត់ចត់(ចូរកត់ចំណាំថាការអនុវត្តទណ្ឌកម្មគឺជាទម្រង់មួយនៃបញ្ហាផលប្រយោជន៍រួម)។ ក្នុងករណីប្រទេសអ៊ីរ៉ង់ សហរដ្ឋអាមេរិកត្រូវចំណាយពេលពីរបីឆ្នាំ ដើម្បីកៀងគរការគាំទ្ររបស់ប្រទេសអឺរ៉ុបនិងប្រទេសធំៗផ្សេងទៀតជាមួយខ្លួន (ទោះបីជាមានការបដិសេធរបស់ឥណ្ឌាក៏ដោយ) ដើម្បីអនុវត្តទណ្ឌកម្មដែលប៉ះពាល់ដល់សេដ្ឋកិច្ចរបស់អ៊ីរ៉ង់។ ក្តីបារម្ភមួយជាមួយនឹងកិច្ចព្រមព្រៀងនុយក្លេអ៊ែរឆ្នាំ ២០១៥ រវាងប្រទេសមហាអំណាចបស្ចឹមលោកនិងអ៊ីរ៉ង់ (ដែលបានដកទណ្ឌកម្មជាថ្នូរនឹងការកម្រិតលើកម្មវិធីនុយក្លេអ៊ែររបស់អ៊ីរ៉ង់) គឺថា ប្រសិនបើប្រទេសអ៊ីរ៉ង់មិនគោរពតាម គេនឹងមិនងាយដាក់ទណ្ឌកម្មប្រឆាំងលើប្រទេសអ៊ីរ៉ង់ឡើងវិញនោះទេ ដោយសារការលំបាកក្នុងការកៀងគរកិច្ចសហប្រតិបត្តិការអន្តរជាតិ។

រូបថត មនុស្សម្នាដោះដូរទំនិញដោយប្រើរូបិយវត្ថុចាស់ ដោយសង្ឃឹមថា រូបិយវត្ថុថ្មីរក្សាតម្លៃចាស់

ទណ្ឌកម្មចុកចាប់

ទណ្ឌកម្មសេដ្ឋកិច្ច ដូចជាការរឹតបន្តឹងអន្តរជាតិនាពេលបច្ចុប្បន្នលើពាណិជ្ជកម្មនិងអាជីវកម្មជាមួយប្រទេសអ៊ីរ៉ង់ គឺជាមធ្យោបាយច្បាស់ក្រឡែតបំផុត ដែលនយោបាយជ្រៀតជ្រែកក្នុងទីផ្សារ។ ការដាក់ទណ្ឌកម្មពិបាកនឹងអនុវត្ត ជាពិសេសនៅពេលដែលប្រទេសទាំងអស់មិនព្រមចូលរួមតាម ពីព្រោះការធ្វើអាជីវកម្មនឹងគ្នាផ្តល់ផលចំណេញ។ ទណ្ឌកម្មធ្ងន់ធ្ងរដែលដាក់លើប្រទេសវេណេហ្ស៊ុយអេឡា ដោយសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប បានរួមចំណែកដល់វិបត្តិសេដ្ឋកិច្ច។ ដើម្បីដោះស្រាយវិបត្តិនេះ ប្រទេសវេណេស៊ុយអេឡាបានបោះពុម្ពរូបិយបណ្ណថ្មីទាំងអស់ ក្នុងឆ្នាំ ២០១៧។ នៅទីនេះ បុគ្គលទាំងឡាយធ្វើពាណិជ្ជកម្មដោយប្រើរូបិយប័ណ្ណចាស់របស់ពួកគេ ដោយសង្ឃឹមថាប្រាក់ថ្មីនឹងរក្សាតម្លៃរបស់វា។

អូតារគី

មធ្យោបាយជាក់ស្តែងមួយ ដើម្បីជៀសវាងការពឹងផ្អែកលើរដ្ឋដទៃ ជាពិសេសសម្រាប់រដ្ឋតូចទន់ខ្សោយដែលដៃគូពាណិជ្ជកម្មមានអំណាចខ្លាំងជាង គឺត្រូវជៀសវាងការជួញដូរ ហើយជំនួសមកវិញ ត្រូវព្យាយាមផលិតទំនិញគ្រប់បែបយ៉ាងដែលរដ្ឋត្រូវការ ដោយខ្លួនឯង។ យុទ្ធសាស្ត្របែបនេះត្រូវបានគេហៅថា

ស្វ័យផ្គត់ផ្គង់ ឬ **អូតារគី** (autarky)។ ប៉ុន្តែ បទពិសោធន៍កន្លងមកបានបង្ហាញថា មធ្យោបាយនេះគ្មានប្រសិទ្ធភាពទេ។ រដ្ឋដែលពឹងផ្អែកលើខ្លួនឯងត្រូវចំណាយដើមទុនខ្ពស់ក្នុងការផលិតទំនិញ ដែលខ្លួនមិនមានគុណសម្បត្តិធៀប។ នៅពេលដែលរដ្ឋផ្សេងទៀតសហការគ្នាដើម្បីពង្រីកការបង្កើតទ្រព្យសម្បត្តិរួមគ្នារបស់ពួកគេ អំណាចធៀបរបស់រដ្ឋស្វ័យផ្គត់ផ្គង់នៅក្នុងប្រព័ន្ធអន្តរជាតិ មាននិន្នាការធ្លាក់ចុះ។

រដ្ឋដែលពឹងផ្អែកលើគោលនយោបាយឯករាជ្យម្ចាស់ការពិតជាដើរយឺតជាងប្រទេសដទៃ។ ករណីគំរូមួយក្នុងប៉ុន្មានទសវត្សរ៍ថ្មីៗនេះ គឺប្រទេសអាល់បានី ដែលជារដ្ឋតូចមួយនៅអឺរ៉ុបអាគ្នេយ៍។ ជារដ្ឋកុម្មុយនិស្ត ដែលផ្តាច់ទំនាក់ទំនងពីសហភាពសូវៀតផងនិងចិនផង ប្រទេសអាល់បានី អស់ជាច្រើនទសវត្សមកហើយមិនបានចូលរួមក្នុងទីផ្សារពិភពលោកទេ ប៉ុន្តែពឹងផ្អែកលើសេដ្ឋកិច្ចផែនការដោយរដ្ឋបាលកណ្តាល ដែលត្រូវបានរចនាឡើងសម្រាប់ផ្គត់ផ្គង់ខ្លួនឯង។ ជនបរទេសតិចតួចអាចចូលទស្សនាបាន ពាណិជ្ជកម្មតិចតួចបានកើតឡើង ហើយប្រទេសអាល់បានីបានបន្តគោលនយោបាយស្វ័យផ្គត់ផ្គង់ដើម្បីរារាំងកុំអោយអ្នកខាងក្រៅពង្រីកអំណាចលើខ្លួន។ នៅពេលដែលរាំងននៃភាពឯកោនិយមនេះ ត្រូវដួលរលំនៅឆ្នាំ ១៩៩១ អាល់បានីនៅតែក្រីក្រ ដូចជាកាលពីច្រើនទសវត្សរ៍មុន ហើយត្រូវខកខានមិនតាមទាន់ភាពរុងរឿងដែលបានមកដល់អឺរ៉ុបដទៃទៀត។

បទពិសោធន៍របស់ប្រទេសចិនក៏បង្ហាញពីបញ្ហារបស់គោលនយោបាយស្វ័យផ្គត់ផ្គង់ផងដែរ។ គោលនយោបាយសេដ្ឋកិច្ចឯកោនិយមរបស់ប្រទេសចិន ក្នុងទសវត្សរ៍ឆ្នាំ ១៩៥០ និងឆ្នាំ ១៩៦០ ដែលបណ្តាលមកពីការហ៊ុមព័ទ្ធសេដ្ឋកិច្ច ដែលត្រូវដាក់ដោយសហរដ្ឋអាមេរិកនិងសម្ព័ន្ធមិត្ត កាន់តែស៊ីជម្រៅ ក្នុងអំឡុងពេលបដិវត្តន៍វប្បធម៌របស់ខ្លួន នៅចុងទសវត្សរ៍ឆ្នាំ ១៩៦០ នៅពេលដែលវាបានផ្តាច់ទំនាក់ទំនងជាមួយសហភាពសូវៀតផងដែរ។ ក្នុងសម័យនោះ ចិនបដិសេធអ្វីគ្រប់បែបយ៉ាងពីបរទេស។ នៅពេលដែលប្រទេសចិនបានបើកចំហរសម្រាប់សេដ្ឋកិច្ចពិភពលោក ក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ នោះ និន្នាខាងលើបានផ្លាស់ប្តូរទិសដៅ។ ការពង្រីកពាណិជ្ជកម្មយ៉ាងឆាប់រហ័ស រួមជាមួយនឹងកំណែទម្រង់ទីផ្សារមួយចំនួននៅក្នុងសេដ្ឋកិច្ចក្នុងស្រុករបស់ខ្លួន បណ្តាលអោយមានកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស។ ផ្ទុយទៅវិញ កូរ៉េខាងជើងនៅតែរក្សាគោលនយោបាយពឹងផ្អែកលើខ្លួនឯងនិងឯកោនិយម សូម្បីតែក្រោយសង្គ្រាមត្រជាក់ហើយក្តី និងបានរងគ្រោះពីគ្រោះទុរភិក្សដ៏ធំ នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០។

៨.១.៤. គោលនយោបាយគាំពារនិយម

ថ្វីបើរដ្ឋមួយចំនួនបន្តប្រើយុទ្ធសាស្ត្រស្វ័យផ្គត់ផ្គង់ ឬពឹងពាក់ខ្លួនឯងក្តី រដ្ឋជាច្រើនព្យាយាមដុះឥទ្ធិពលលើពាណិជ្ជកម្មអន្តរជាតិ ដើម្បីពង្រឹងឧស្សាហកម្មក្នុងស្រុកមួយឬច្រើន ហើយផ្តល់ជម្រកការពារឧស្សាហកម្មក្នុងស្រុកពីការប្រកួតប្រជែងពីទីផ្សារពិភពលោក។ គោលនយោបាយបែបនេះត្រូវបានគេស្គាល់យ៉ាងទូលំទូលាយថាជា **លទ្ធិគាំពារនិយម** (protectionism) ដែលសំដៅលើការការពារឧស្សាហកម្មក្នុងស្រុកពីការប្រកួតប្រជែងអន្តរជាតិ។ ទោះបីជាពាក្យនេះរួមបញ្ចូលនូវគោលនយោបាយពាណិជ្ជកម្មផ្សេងៗគ្នាជាច្រើន ដែលកើតចេញចេតនាផ្សេងៗគ្នាក៏ដោយ ក៏គោលនយោបាយទាំងអស់នោះ ដើរបញ្ច្រាសទិសដៅទ្រឹស្តីសេរីនិយម ដោយសារតែពួកគេព្យាយាមបង្ខូចទ្រង់ទ្រាយដើមនៃទីផ្សារសេរី ដើម្បីទទួលបានអត្ថប្រយោជន៍សម្រាប់រដ្ឋ (ឬសម្រាប់តួអង្គថ្នាក់ក្រោមរដ្ឋ នៅក្នុងរដ្ឋនោះ) ជាទូទៅ ដោយបង្កាក់ដំណើរការនាំចូលទំនិញឬសេវាកម្មរបស់គូប្រកួតប្រជែង ។

រូបថត

ត្រឹមជាឡានដឹកស្ករ

គោលនយោបាយគាំពារនិយមប្រើប្រាស់មធ្យោបាយផ្សេងៗដើម្បីរារាំងការនាំចូលទំនិញពីបរទេស មិនអោយប្រកួតប្រជែងជាមួយផលិតផលក្នុងស្រុក។ អ្នកផលិតកសិផលនៅក្នុងអឌ្ឍគោលខាងត្បូង តួយ៉ាង ភ្ជួញគ្រែរ ថា ការឧបត្ថម្ភធននិងវិធានការណ៍ការពារផ្សេងទៀតនៅអឺរ៉ុប និងសហរដ្ឋអាមេរិករារាំងកសិករក្រីក្រនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ពីការនាំចេញទៅកាន់ទីផ្សារពិភពលោក។ នៅទីនេះ អំពៅកំពុងរង់ចាំការកែច្នៃនៅក្នុងប្រទេសថៃ ដែលតម្លៃស្ករទាបបានធ្វើអោយកសិកររងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរក្នុងឆ្នាំ ២០១៦។

*មូលហេតុជម្រុញទឹកចិត្ត*ដ្ឋក្នុងការការពារឧស្សាហកម្មក្នុងស្រុក អាចកើតចេញពីប្រភពជាច្រើន។ ជាញឹកញយ រដ្ឋាភិបាលបំពេញតាមតម្រូវការផ្នែកនយោបាយរបស់ឧស្សាហកម្មនិងក្រុមផលប្រយោជន៍ ក្នុងស្រុកធំៗ ដោយមិនគិតពីផលប្រយោជន៍ជាតិទាំងមូលនោះទេ។ ឧស្សាហកម្មមួយអាចបញ្ចុះបញ្ចូល ឬឧបត្ថម្ភហិរញ្ញវត្ថុដល់យុទ្ធនាការឃោសនាបោះឆ្នោតរបស់បក្សឬបេក្ខជនណាមួយ ដើម្បីទទួលបានការលើកលែងពន្ធពិសេស ការឧបត្ថម្ភធន ឬ ការរឹតបន្តឹងលើការនាំចូល ដែលអាចប្រកួតប្រជែងដណ្តើមទីផ្សារខ្លួន (សូមមើល ឧស្សាហកម្មនិងក្រុមផលប្រយោជន៍ នៅផ្នែកក្រោយក្នុងមេរៀននេះ)។

ជារឿយៗ រដ្ឋព្យាយាមការពារឧស្សាហកម្មក្មេងខ្ចី (infant industry) នៅពេលវាចាប់ផ្តើមនៅក្នុងរដ្ឋជាលើកដំបូង រហូតដល់វាអាចប្រកួតប្រជែងនៅលើទីផ្សារពិភពលោក។ ជាឧទាហរណ៍ នៅពេលដែលប្រទេសកូរ៉េខាងត្បូងបង្កើតឧស្សាហកម្មរថយន្តជាលើកដំបូង វាមិនទាន់មានសត្ថភាពប្រកួតប្រជែងជាមួយនឹងការនាំចូលនៅឡើយ ដូច្នេះហើយ រដ្ឋាភិបាលបានផ្តល់ការលើកទឹកចិត្តដល់អ្នកប្រើប្រាស់ក្នុងការទិញរថយន្តកូរ៉េ។ នៅទីបំផុតឧស្សាហកម្មនេះបានអភិវឌ្ឍ ហើយអាចប្រកួតប្រជែងជាមួយអ្នកផលិតបរទេស ហើយថែមទាំងអាចនាំចេញរថយន្តបានផលចំណេញច្រើនទៀតផង។ នៅក្នុងរដ្ឋក្រីក្រមួយចំនួន ពាណិជ្ជកម្ម *ភាយនកណ្តា*ជាឧស្សាហកម្មក្មេងខ្ចីដែលពេញចិត្ត (ដោយបន្ថែមតម្លៃដោយគ្មានតម្រូវការដើមទុនច្រើន)ដែលរដ្ឋាភិបាលបានការពារ។ ការការពារឧស្សាហកម្មក្មេងខ្ចីត្រូវបានចាត់ទុកជាហេតុផលស្របច្បាប់សម្រាប់គោលនយោបាយគាំពារនិយម(ជាបណ្តោះអាសន្ន)។

មូលហេតុជម្រុញទឹកចិត្តមួយទៀតសម្រាប់គោលនយោបាយគាំពារនិយម គឺការផ្តល់ចរន្តខ្យល់ដង្ហើមសម្រាប់ឧស្សាហកម្មក្នុងស្រុក នៅពេលដែលលក្ខខណ្ឌទីផ្សារផ្លាស់ប្តូរ ឬដៃគូប្រកួតប្រជែងថ្មីចូលមកដល់។ ពេលខ្លះឧស្សាហកម្មក្នុងស្រុកត្រូវការពេលវេលាដើម្បីសម្របខ្លួន ហើយអាចងើបឡើងវិញ ក្នុងពេលពីរបីឆ្នាំក្រោយ ក្នុងស្ថានភាពដែលមានលំនឹងល្អ។ នៅពេលដែលតម្លៃហ្គាសបានហក់ឡើង ក្នុងទសវត្សរ៍ឆ្នាំ ១៩៧០ ក្រុមហ៊ុនផលិតរថយន្តរបស់សហរដ្ឋអាមេរិកមានការយឺតយ៉ាវក្នុងការប្តូរទៅផលិតរថយន្តតូចៗ ហើយតម្លៃរថយន្តរបស់ជប៉ុនតូចៗមានប្រៀបខ្លាំងនៅក្នុងទីផ្សារសហរដ្ឋអាមេរិក។ រដ្ឋាភិបាលសហរដ្ឋអាមេរិកបានប្រើប្រាស់វិធានការណ៍(គាំពារនិយម)ជាច្រើន រួមទាំង ការកម្រិតកូតានាំចូល និងការធានាប្រាក់កម្ចី ដើម្បីជួយឧស្សាហកម្មអាមេរិក ក្នុងកំឡុងអន្តរកាលនេះ។ (ប៉ុន្តែ នៅពេលដែលតម្លៃឧស្ម័នកើនឡើងម្តងទៀត នៅដើមឆ្នាំ ២០០៨ អ្នកផលិតរថយន្តនៅសហរដ្ឋអាមេរិក ជាថ្មីម្តងទៀត មិនបានត្រៀមខ្លួនទុកជាមុនឡើយ ហើយនៅតែត្រូវការជំនួយពីរដ្ឋាភិបាលដើម្បីបន្តប្រតិបត្តិការក្នុងអំឡុងវិបត្តិសេដ្ឋកិច្ចឆ្នាំ ២០០៨-២០០៩។)

រដ្ឋាភិបាលក៏ការពារឧស្សាហកម្មដែលគេចាត់ទុកថាមានសារៈសំខាន់ចំពោះសន្តិសុជាតិផងដែរ។ ក្នុងទសវត្សរ៍ឆ្នាំ១៩៨០ មន្ត្រីអាមេរិកបានប្រឹងប្រែងការពារឧស្សាហកម្មអេឡិចត្រូនិកនិងកុំព្យូទ័ររបស់សហរដ្ឋអាមេរិកដើម្បីទប់ទល់នឹងការដណ្តើមទីផ្សារអាជីវកម្មដោយដៃគូប្រកួតប្រជែងជប៉ុន ពីព្រោះឧស្សាហកម្មទាំងនោះត្រូវចាត់ទុកថាមានសារៈសំខាន់ចំពោះផលិតកម្មគាំទ្រយោធាអាមេរិច។ រដ្ឋាភិបាលបានឧបត្ថម្ភសម្ព័ន្ធក្រុមហ៊ុនបន្ទះឈីបកុំព្យូទ័ររបស់សហរដ្ឋអាមេរិក ដើម្បីលើកកម្ពស់សមត្ថភាពរបស់សហរដ្ឋអាមេរិកក្នុងការផលិតបន្ទះសៀគ្វីក្នុងតម្លៃថោក (តាមធម្មតា រដ្ឋាភិបាលនឹងបង្កាក់សម្ព័ន្ធក្រុមហ៊ុនបែបនេះ ដោយចាត់ទុកថាជាការរំលោភលើទំនុកចិត្ត)។ គោលនយោបាយស្វ័យផ្តត់ផ្តង់(Autarky)ប្រហែលមិនផ្តល់ផលចំណេញក្នុងសកម្មភាពសេដ្ឋកិច្ចភាគច្រើននោះទេ ប៉ុន្តែ សម្រាប់សម្ភារៈយោធា រដ្ឋនានានឹងលះបង់ប្រសិទ្ធភាពសេដ្ឋកិច្ចមួយចំនួនជាថ្នូរនឹងផលប្រយោជន៍សមត្ថភាពស្វ័យផ្តត់ផ្តង់ ដើម្បីកាត់បន្ថយភាពងាយរងគ្រោះក្នុងករណីមានសង្គ្រាម។

ចុងក្រោយ គោលនយោបាយគាំពារនិយមអាចត្រូវបានជំរុញដោយកិច្ចខិតខំប្រឹងប្រែងការពារ ដើម្បីទប់ស្កាត់របរជញ្ជក់ឈាមដោយក្រុមហ៊ុនបរទេសឬរដ្ឋដទៃ។ *ការជញ្ជក់ឈាម* (Predatory) ជាទូទៅ សំដៅទៅលើកិច្ចខិតខំប្រឹងប្រែង ដើម្បីដណ្តើមយកចំណែកធំជាងគេក្នុងទីផ្សារពិភពលោកដោយអយុត្តិធម៌ ឬរហូតដល់ថ្នាក់ដណ្តើមភាពផ្តាច់មុខស្ទើរតែទាំងស្រុង ដូច្នេះហើយ នៅទីបំផុត អាជីវកម្មជញ្ជក់ឈាមនោះអាចតម្លើងថ្លៃ(ទំនិញ) ដោយមិនខ្លាចរអារនឹងការប្រកួតប្រជែង។ ជាញឹកញាប់បំផុត កិច្ចខិតខំប្រឹងប្រែងទាំងនេះរួមបញ្ចូល **ការលក់បង្ខូចថ្លៃ** (dumping) នៅក្នុងទីផ្សារបរទេស ក្នុងតម្លៃទាប ជាងកម្រិតអប្បបរមា ដែលចាំបាច់ដើម្បីអាចទទួលបានប្រាក់ចំណេញ។ នៅក្នុងបរិបទសេដ្ឋកិច្ចក្នុងស្រុក រដ្ឋាភិបាលអាចប្រើប្រាស់ច្បាប់ប្រឆាំងការរំលោភសេចក្តីទុកចិត្ត ដើម្បីបំបែកអាជីវកម្មផ្តាច់មុខដែលអាចនឹងកើតឡើង ប៉ុន្តែ ដោយសារតែមិនមានយន្តការបែបនេះនៅក្នុងទំនាក់ទំនងអន្តរជាតិ រដ្ឋាភិបាលព្យាយាមរឹតបន្តឹងការនាំចូល ក្នុងស្ថានភាពបែបនេះ ដើម្បីការពារឧស្សាហកម្មនៅក្នុងរដ្ឋរបស់ពួកគេ។ ការដាក់កម្រិតឬរឹតបន្តឹងបែបនេះត្រូវទទួលស្គាល់ថាស្របច្បាប់ ទោះបីជាមានការខ្វែងគំនិតគ្នាខ្លាំងអំពី ថាតើកម្រិតតម្លៃកំណត់ មានលក្ខណៈជញ្ជក់ឈាម ឬគ្រាន់តែជាការប្រកួតប្រជែងក៏ដោយ។ បច្ចុប្បន្ននេះ ជម្លោះទាំងនេះជាទូទៅត្រូវបានដោះស្រាយតាមរយៈអង្គការពាណិជ្ជកម្មពិភពលោក (WTO) (សូមមើលរបបពាណិជ្ជកម្ម)។

ជាធម្មតា ពាក្យបណ្តឹងអំពីបទល្មើសបង្ខូចតម្លៃ ត្រូវបានដាក់ដោយក្រុមឧស្សាហកម្មណាមួយដែលមានអារម្មណ៍ថាពួកគេត្រូវរងការខូចខាតដោយដៃគូប្រកួតប្រជែងបរទេស។ ជាដំបូង ពួកគេត្រូវតែបញ្ចុះបញ្ចូលរដ្ឋាភិបាលរបស់ពួកគេថា ពួកគេត្រូវបានគេវាយប្រហារ ដោយអយុត្តិធម៌។ បន្ទាប់មក ក្រោយរដ្ឋាភិបាលរបស់ពួកគេបានដាក់ឬតម្លើងពន្ធលើការនាំចូលផលិតផលណាមួយ រដ្ឋាភិបាលបរទេសអាចនឹងដាក់ពាក្យបណ្តឹងទៅកាន់អង្គការពាណិជ្ជកម្មពិភពលោក។ ក្នុងឆ្នាំ ២០០៧ អង្គការពាណិជ្ជកម្មពិភពលោកបានចេញសាលក្រមប្រឆាំងនឹងសហរដ្ឋអាមេរិក នៅក្នុងពាក្យបណ្តឹងរបស់ក្រុមហ៊ុនផលិតផលរបស់ជប៉ុនដែលអះអាងថាពួកគេត្រូវបានគេចោទប្រកាន់ដោយអយុត្តិធម៌ ពីបទល្មើសបង្ខូចតម្លៃទំនិញឧស្សាហកម្មនៅលើទីផ្សារអាមេរិក។ គួរអោយអស់សំណើច ជាជាងបដិសេធថាជប៉ុនបានលក់បង្ខូចតម្លៃទំនិញនៅលើទីផ្សារអាមេរិក អង្គការពាណិជ្ជកម្មពិភពលោក បានរិះគន់ពីរបៀបដែលសហរដ្ឋអាមេរិកបានគណនាពន្ធលើទំនិញរបស់ជប៉ុន ដោយសម្រេចថា វាត្រូវបានកំណត់ខ្ពស់ពេកដើម្បីបង្កើតប្រៀបប្រកួតប្រជែង។ នៅពេលនោះ សហរដ្ឋអាមេរិកត្រូវ

បង្ខំអោយពិនិត្យមើលឡើងនូវអំពីរបៀបដែលខ្លួនដំណើរការជាមួយការតវ៉ាអំពីការលក់បង្ខូចតម្លៃ ដោយសារតែសេចក្តីសម្រេចរបស់អង្គការពាណិជ្ជកម្មពិភពលោក។

ដូចដែលមានមូលហេតុមួយចំនួនជម្រុញទឹកចិត្តសម្រាប់គោលនយោបាយគាំពារនិយម រដ្ឋាភិបាលក៏ប្រើប្រាស់ឧបករណ៍ជាច្រើនដែរ ដើម្បីអនុវត្តគោលការណ៍នេះ។ ឧបករណ៍ដ៏សាមញ្ញបំផុត គឺ**ពន្ធគយ** (tariff ឬ *duty*) ដែលជាពន្ធលើប្រភេទទំនិញនាំចូលមួយចំនួន (ជាធម្មតា គិតជាភាគរយនៃតម្លៃជាក់ស្តែងរបស់ទំនិញនោះ) ពេលចូលដល់ប្រទេសណាមួយ។ ពន្ធគយមិនត្រឹមតែជាក់កម្រិតលើការនាំចូលប៉ុណ្ណោះទេ ប៉ុន្តែក៏អាចជាប្រភពចំណូលសំខាន់របស់រដ្ឋផងដែរ។ ប្រសិនបើរដ្ឋមួយត្រូវប្រើគោលនយោបាយគាំពារនិយមនោះ បទដ្ឋានអន្តរជាតិអនុគ្រោះពន្ធជាវិធីសាស្ត្រគាំពារនិយមគួរជាទីពេញចិត្តជាងគេ ព្រោះវាស្តែងចេញមកត្រង់ៗ និងមិនលាក់បាំងឡើយ។ រដ្ឋភាគច្រើនបង្កើតតារាងពន្ធគយដ៏វែងនិងស្មុគស្មាញមួយ ដោយផ្អែកលើប្រភេទនិងប្រភេទរងនៃទំនិញរាប់ពាន់ ដែលរៀបចំដោយឧស្សាហកម្ម។

មធ្យោបាយផ្សេងទៀតដើម្បីបង្កាក់ការនាំចូល គឺ **របាំងមិនមែនពន្ធគយ**(nontariff barriers)ចំពោះពាណិជ្ជកម្ម។ ការនាំចូលអាចត្រូវបានកំណត់ដោយ*កូតា* (quota)។ កូតាប្រៀបដូចជាពិដានគ្របពីលើចំនួនទំនិញប្រភេទជាក់លាក់ណាមួយអាចត្រូវបាននាំចូល។ ពួកគេត្រូវបានដាក់ដើម្បីកម្រិតលើកំណើនការនាំចូលបែបនេះ។ វិធានការណ៍ជ្រុលជាងនេះគឺការហាមប្រាមជាទូទៅមិនអោយមានការនាំចូលទំនិញប្រភេទណាមួយ (ឬទំនិញពីប្រទេសជាក់លាក់ណាមួយ)។ រដ្ឋាភិបាលសហរដ្ឋអាមេរិកបានប្រើប្រាស់កូតាដើម្បីតឹបន្តឹងចំនួនរថយន្តដែលផលិតដោយប្រទេសជប៉ុន ដែលអាចចូលក្នុងទីផ្សារសហរដ្ឋអាមេរិក ក្នុងទសវត្សរ៍ ឆ្នាំ ១៩៨០ នៅពេលដែលឧស្សាហកម្មរថយន្តរបស់សហរដ្ឋអាមេរិកកំពុងបាត់បង់ចំណែកទីផ្សារលក់យ៉ាងឆាប់រហ័សចំពោះការនាំចូលរបស់ជប៉ុន។ ភាគច្រើននៃកូតាទាំងនោះមានលក្ខណៈស្មុគ្រចិត្ត ដោយហេតុថា ជប៉ុននិងអាមេរិកបានចរចាពីកម្រិតមួយដែលភាគីទាំងពីរអាចរកស៊ីជាមួយបាន។

របាំងមិនមែនពន្ធគយចំនួនពីរ ដែលត្រូវបានជជែកដេញដោលគ្នាខ្លាំងបំផុត ក្នុងអង្គការពាណិជ្ជកម្មពិភពលោក គឺការឧបត្ថម្ភធន (subsidies) និងការកំណត់បទប្បញ្ញត្តិ (regulation)។ *ការឧបត្ថម្ភធន* គឺជាការបង់ប្រាក់ដោយរដ្ឋាភិបាលដល់ឧស្សាហកម្មក្នុងស្រុក ដែលអនុញ្ញាតអោយពួកគេបន្ទាបតម្លៃទំនិញរបស់ខ្លួន ដោយមិនខាតបង់ប្រាក់(ចំណេញ)។ ការឧបត្ថម្ភធនបែបនេះ មានលក្ខណៈទូលំទូលាយ នៅក្នុង (ប៉ុន្តែមិនកំណត់ត្រឹមតែ)ឧស្សាហកម្មដែលគ្រប់គ្រងដោយរដ្ឋ។ ការឧបត្ថម្ភធនដល់ឧស្សាហកម្មណាមួយដែលកំពុងត្រជាបត្រដួសក្នុងការបង្កើតឬប្រឈមមុខនឹងការប្រកួតប្រជែងយ៉ាងខ្លាំងក្លាពីបរទេស រួមមាន *ការកាត់ឬបន្ធូរបន្ថយពន្ធ*(tax break) *ប្រាក់កម្ចី*(loan) (ឬប្រាក់កម្ចីឯកជនដែលមានការធានា) ក្នុងលក្ខខណ្ឌអំណោយផល និង*តម្លៃធានា*(guaranteed prices)ខ្ពស់ ដែលបង់ថ្លៃដោយរដ្ឋាភិបាល។ ការឧបត្ថម្ភធនដល់កសិករ គឺជាចំណុចស្អិតជ្រាំសំខាន់រវាងប្រទេសអ្នកមាននិងប្រទេសក្រីក្រ នៅក្នុងកិច្ចចរចាពាណិជ្ជកម្ម ជុំដូហា (Doha)។ ក្នុងឆ្នាំ ២០១០ សហរដ្ឋអាមេរិក និងប្រទេសប្រេស៊ីលបានដោះស្រាយសំណុំរឿងអង្គការពាណិជ្ជកម្មពិភពលោកជុំវិញការឧបត្ថម្ភធនរបស់អាមេរិកដល់កសិករដាំកប្បាស។ មុនដំណោះស្រាយនេះ ប្រទេសប្រេស៊ីលគ្រោងនឹងចាប់ផ្តើមដាក់ទណ្ឌកម្មជិត ៨៣០ លានដុល្លារ ប្រឆាំងនឹងសហរដ្ឋអាមេរិក។

ការឧបត្ថម្ភធនក៏ជាប្រភពញឹកញាប់នៃជម្លោះរវាងសហរដ្ឋអាមេរិកនិងអឺរ៉ុប ដែលជារឿយៗពាក់ព័ន្ធនឹងគោលនយោបាយរបស់សហភាពអឺរ៉ុប ស្តីពីគោលនយោបាយកសិកម្មរួម (CAP) (សូមមើលមេរៀនទី

១០)។ ការឧបត្ថម្ភធននៅខាងក្រៅវិស័យកសិកម្មក៏អាចមានភាពរសើប ជាលក្ខណៈនយោបាយផងដែរ។ ក្រុមហ៊ុនអាកាសចរណ៍អឺរ៉ុប ដែលទទួលការឧបត្ថម្ភធនពីសហភាពអឺរ៉ុប ឥឡូវនេះ ដេញថ្លៃយ៉ាងសកម្មលើគម្រោងនានារបស់ក្រសួងការពារជាតិអាមេរិក។ ក្រុមហ៊ុនផលិតអាមេរិចតវ៉ាថា ការឧបត្ថម្ភធនដែលបានផ្តល់អោយក្រុមហ៊ុនដែលមានមូលដ្ឋាននៅក្នុងសហភាពអឺរ៉ុបធ្វើអោយពួកគេមានការលំបាក ប្រកួតប្រជែងពីព្រោះការឧបត្ថម្ភធនអនុញ្ញាតអោយក្រុមហ៊ុនអឺរ៉ុបដាក់ការដេញថ្លៃទាបជាង។ ដូច្នេះ ការឧបត្ថម្ភធនបានផ្លាស់ប្តូរពីបញ្ហានៅក្នុងគោលនយោបាយពាណិជ្ជកម្មទៅជាបញ្ហាសន្តិសុខផងដែរ។

ការនាំចូលក៏អាចត្រូវបានកម្រិតចំនួនដោយ*ការពិតបន្តឹង*និង*បទប្បញ្ញត្តិ* ដែលធ្វើអោយពិបាកក្នុងការចែកចាយនិងធ្វើទីផ្សារលក់ផលិតផលមួយ បើទោះបីជាវាអាចនាំចូលបានក៏ដោយ។ ក្នុងការធ្វើទីផ្សារលក់ផលិតផលសហរដ្ឋអាមេរិកនៅក្នុងប្រទេសជប៉ុន ក្រុមហ៊ុនផលិតទំនិញរបស់សហរដ្ឋអាមេរិកបានតវ៉ាពីបទប្បញ្ញត្តិការិយាធិបតេយ្យដ៏ស្មុគស្មាញ និងប្រព័ន្ធតឹងតែងនៃសម្ព័ន្ធភាពសាជីវកម្ម ដែលសម្របសម្រួលការផ្គត់ផ្គង់គ្រឿងបន្លាស់ ពីអ្នកផ្គត់ផ្គង់របស់ជប៉ុនទៅកាន់ក្រុមហ៊ុនផលិតរបស់ជប៉ុន។ បទប្បញ្ញត្តិបរិស្ថាននិងច្បាប់ការងារក៏អាចក្លាយជារបាំងមិនមែនពន្ធគយផងដែរ។ នេះបណ្តាលអោយមានភាពចម្រូងចម្រាសយ៉ាងខ្លាំងនៅក្នុង អង្គការពាណិជ្ជកម្មពិភពលោកដូចជានៅពេលដែលអឺរ៉ុបបានហាមឃាត់ដំណាំកែច្នៃហ្សែន ដែលភាគច្រើននាំចូលមកពីសហរដ្ឋអាមេរិក។ ទីបំផុត នៅពេលដែលរដ្ឋមួយធ្វើ*ជាតូបនីយកម្ម*ឧស្សាហកម្មទាំងមូល ដូចជាការផលិតប្រេង ឬ ធនាគារ ការប្រកួតប្រជែងពីបរទេសត្រូវបានបិទ។

ជួនកាល វប្បធម៌របស់ប្រទេសមួយ ជាជាងសកម្មភាពរបស់រដ្ឋ អាចជាការរារាំងការនាំចូលផងដែរ។ ប្រជាពលរដ្ឋអាច (ដោយមានឬគ្មានការលើកទឹកចិត្តពីរដ្ឋាភិបាល) ធ្វើតាមទស្សនវិជ្ជា*ជាតិនិយមសេដ្ឋកិច្ច* (economic nationalism) ដែលជាការប្រើប្រាស់សេដ្ឋកិច្ចដើម្បីដៈឥទ្ធិពលលើអំណាចអន្តរជាតិ និងជំហរធៀប នៅក្នុងប្រព័ន្ធអន្តរជាតិ (ជាទម្រង់មួយនៃគោលនយោបាយគាំពារនិយម)។ ជាឧទាហរណ៍ ពេលខ្លះពលរដ្ឋអាមេរិកមិនអើពើនឹងដំបូន្មានរបស់អ្នកសេដ្ឋកិច្ចសេរី ដើម្បីទិញផលិតផលល្អបំផុត ក្នុងតម្លៃសមរម្យបំផុតនោះទេ ហើយជំនួសមកវិញពួកគេនាំគ្នា «ទិញទំនិញអាមេរិច» បើទោះបីជាត្រូវចំណាយកាន់តែច្រើនសម្រាប់ផលិតផល ដូចគ្នាក៏ដោយ។ ទោះបីជាភាពលំអៀងបែបនេះកាត់បន្ថយប្រសិទ្ធភាពផលិតកម្មពិភពលោកទាំងមូលក៏ដោយ ក៏វាផ្តល់អត្ថប្រយោជន៍ដល់កម្មករអាមេរិកដែរ។

គោលនយោបាយគាំពារនិយមផ្តល់ទាំងផលប៉ះពាល់វិជ្ជមាន និងទាំងអវិជ្ជមានលើសេដ្ឋកិច្ច ដែលភាគច្រើនតែងតែជួយអ្នកផលិត ប៉ុន្តែប៉ះពាល់ដល់អ្នកប្រើប្រាស់។ ជាឧទាហរណ៍ ទោះបីជាក្រុមហ៊ុនផលិតរថយន្តរបស់សហរដ្ឋអាមេរិកត្រូវបានផ្តល់ជំនួយខ្លះៗ ដោយការដាក់កម្រិតលើការនាំចូលរបស់ជប៉ុននៅក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ ជាលទ្ធផល អ្នកប្រើប្រាស់រថយន្តនៅសហរដ្ឋអាមេរិកបានចំណាយប្រាក់កាន់តែច្រើនសម្រាប់ទិញរថយន្ត (ដោយចំណាយប្រាប់បន្ថែមរាប់រយដុល្លារសម្រាប់មួយឡានគ្រឿងៗ តាមការប៉ាន់ស្មានមួយចំនួន)។ បញ្ហាមួយទៀតជាមួយគោលនយោបាយគាំពារនិយម គឺថាឧស្សាហកម្មក្នុងស្រុកអាចប្រើការការពារ ដើម្បីជៀសវាងការកែលម្អដែលត្រូវការជាចាំបាច់ ហើយដូច្នេះអាចនៅតែគ្មានប្រសិទ្ធភាពនិងគ្មានសមត្ថភាពប្រកួតប្រជែង ជាពិសេសប្រសិនបើការការពារនៅតែបន្ត អស់រយៈពេលជាច្រើនឆ្នាំ។

ទោះយ៉ាងណាក៏ដោយ ការគាំពារជាបណ្តោះអាសន្នអាចមានឥទ្ធិពលស្ថេរភាព នៅក្រោមលក្ខខណ្ឌជាក់លាក់។ នៅពេលដែលក្រុមហ៊ុនផលិតម៉ូតូមួយរបស់សហរដ្ឋអាមេរិក ម៉ាក ហាឡឺយ-ដេវីឌសុន (Harley-

Davidson) បានបាត់បង់ចំណែកទីផ្សារពាក់កណ្តាលរបស់សហរដ្ឋអាមេរិក ក្នុងរយៈពេលត្រឹមតែ ៤ ឆ្នាំ រដ្ឋាភិបាលសហរដ្ឋអាមេរិកបានទារពន្ធលើម៉ូតូដែលនាំចូលពីប្រទេសជប៉ុន។ ពន្ធគយបានចាប់ផ្តើម ពីកម្រិត ៤៥ ភាគរយ ក្នុងឆ្នាំ ១៩៨៣ ហើយត្រូវបន្តយជារៀងរាល់ឆ្នាំ សម្រាប់រយៈពេលប្រាំឆ្នាំ ហើយបន្ទាប់មកត្រូវ បានលុបចោលទាំងស្រុង។ ជាមួយនឹងពេលវេលាចេះតែរំកិលទៅមុខ ម៉ូតូម៉ាកហាឡឺយ៍បានព្យាយាមបង្កើន ប្រសិទ្ធភាពនិងបង្កើនគុណភាពជាលំដាប់។ ជាលទ្ធផល ហាឡឺយ៍ដណ្តើមបានចំណែកទីផ្សារលក់ផលិត របស់ខ្លួនឡើងវិញ ហើយពន្ធគយត្រូវបានដកចេញ មុនពេលកំណត់មួយឆ្នាំ។ នៅចុងទស្សវត្សរ៍ឆ្នាំ ១៩៨០ ហាឡឺយ៍ ដែលបានត្រូវពង្រឹងឡើងវិញ និងបានពង្រីកចំណែកទីផ្សាររបស់ខ្លួន ហើយចាប់ផ្តើមនាំចេញទៅ ប្រទេសជប៉ុន។ គោលនយោបាយគាំពារនិយមបានដំណើរការល្អក្នុងករណីនេះ ព្រោះវាមានរយៈពេលខ្លី និង ចែងច្បាស់លាស់។

៨.២. របបពាណិជ្ជកម្ម

៨.២ ចូរកំណត់កត្តាបណ្តាលអោយជាប់គាំងក្នុងកិច្ចចរចាររបស់អង្គការពាណិជ្ជកម្មពិភពលោក នៅក្នុងវេទិកាដូហា (Doha) យ៉ាងហោចណាស់អោយបានមួយ។

នៅពេលបច្ចេកវិទ្យាតភ្ជាប់ពិភពលោកឆ្លងកាត់ពីលំហយ៉ាងទូលំទូលាយ ដំណើរការសមាហរណកម្មសកល ដោយផ្អែកលើពាណិជ្ជកម្មសេរីកំពុងរៀបចំរបៀបវារៈសេដ្ឋកិច្ចអន្តរជាតិ។ អង្គការពាណិជ្ជកម្មពិភពលោកដើរ តួនាទីយ៉ាងសំខាន់ក្នុងដំណើរការនេះ។

៨.២.១. អង្គការពាណិជ្ជកម្មពិភពលោក

អង្គការពាណិជ្ជកម្មពិភពលោក (WTO) គឺជាអង្គការអន្តរដ្ឋាភិបាលពហុភាគីជាសកល (IGO) ដែល ផ្សព្វផ្សាយ ត្រួតពិនិត្យ និងវិនិច្ឆ័យពាណិជ្ជកម្មអន្តរជាតិ។ រួមជាមួយនឹងការរៀបចំក្នុងតំបន់ និងទ្វេភាគីដែល បានពិពណ៌នាយ៉ាងខ្លីរួចមកហើយ អង្គការពាណិជ្ជកម្មពិភពលោកបង្ហាញពីការរំពឹងទុក និងការអនុវត្តរួម របស់រដ្ឋ ទាក់ទងនឹងពាណិជ្ជកម្មអន្តរជាតិ។ អង្គការពាណិជ្ជកម្មពិភពលោក គឺជាអង្គការបំពេញតួនាទីបន្តពី **កិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយនិងពាណិជ្ជកម្ម** (GATT) ដែលត្រូវបានបង្កើតឡើង ក្នុងឆ្នាំ១៩៤៧ ដើម្បី ជួយសម្រួលដល់ពាណិជ្ជកម្មសេរី ដោយផ្អែកលើមូលដ្ឋានពហុភាគី។ កិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយនិង ពាណិជ្ជកម្មគឺជាក្របខ័ណ្ឌចរចា ច្រើនជាងស្ថាប័នរដ្ឋបាលមួយ។ វាពិតជាមិនបានបង្កើតបទបញ្ញត្តិលើ ពាណិជ្ជកម្មទេ។ មុនពេលមានកិច្ចព្រមព្រៀងGATT សំណើបង្កើតទីភ្នាក់ងារស្ថាប័ននិយមខ្លាំងជាងមុន ត្រូវ បានច្រានចោល ដោយសារតែការភ័យខ្លាចរបស់សហរដ្ឋអាមេរិកថាការបង្កើតបទបញ្ញត្តិលើសកំណត់ នឹង រារាំងពាណិជ្ជកម្មសេរីទៅវិញទេ។ កិច្ចព្រមព្រៀងGATT មានហេដ្ឋារចនាសម្ព័ន្ធជាលក្ខណៈស្ថាប័នតិចតួច រហូតដល់ពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៩៩០ ដោយមានត្រឹមតែលេខាធិការដ្ឋានតូចមួយដែលមានទីស្នាក់ការ នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស (ដែលអង្គការ WTO នៅតែតាំងនៅទីនោះ)។ បន្ថែមពីលើតួនាទីសំខាន់ របស់វាជាវេទិកាចរចា កិច្ចព្រមព្រៀងGATTបានជួយដោះស្រាយវិវាទពាណិជ្ជកម្មដោយអាជ្ញាកណ្តាល ស្រាយ បំភ្លឺច្បាប់ និងជួយរដ្ឋនានាអោយអនុវត្តច្បាប់ទាំងនោះយ៉ាងខ្ជាប់ខ្ជួន។

នៅឆ្នាំ ១៩៩៥ កិច្ចព្រមព្រៀងGATT បានក្លាយជាអង្គការពាណិជ្ជកម្មពិភពលោក (WTO) ដែលរួម បញ្ចូលកិច្ចព្រមព្រៀងGATTលើទំនិញឧស្សាហកម្មនិងពង្រីករបៀបវារៈ ដើម្បីរួមបញ្ចូលពាណិជ្ជកម្មសេវាកម្ម និងកម្មសិទ្ធិបញ្ញា។ អង្គការពាណិជ្ជកម្មពិភពលោកមានអំណាចខ្លះដៃក្នុងការពង្រឹងការអនុវត្ត និងមាន

ប្រព័ន្ធការិយាធិបតេយ្យអន្តរជាតិ (ជាង ៦០០ នាក់) ដែលត្រួតពិនិត្យនិងតាមដានគោលនយោបាយនិងការអនុវត្តពាណិជ្ជកម្មក្នុងរដ្ឋសមាជិកនីមួយៗនិងវិនិច្ឆ័យជម្លោះក្នុងចំណោមរដ្ឋសមាជិក។ អង្គការពាណិជ្ជកម្មពិភពលោកមានអំណាចខ្លះដែរលើរដ្ឋមួយចំនួន ប៉ុន្តែ ដូចជាស្ថាប័នអន្តរជាតិភាគច្រើនដែរ វិសាលភាពនៃអំណាចនេះមានកម្រិត។ ប្រតិកម្មសាធារណៈ ដែលកំពុងបន្តប្រឆាំងនឹងពាណិជ្ជកម្មសេរី (សូមមើលផ្នែកប្រតិកម្មប្រឆាំងនឹងពាណិជ្ជកម្ម)ឆ្លុះបញ្ចាំងអំពីការមិនសប្បាយចិត្តអំពីអំណាចសក្តានុពលនៃអង្គការបរទេសនិងសម្ងាត់ ក្នុងការបង្ខំអោយមានការផ្លាស់ប្តូរនៅក្នុងច្បាប់ជាតិដែលបានអនុម័តតាមបែបប្រជាធិបតេយ្យ។ ប៉ុន្តែ អង្គការពាណិជ្ជកម្មពិភពលោក គឺជាស្ថាប័នអន្តរជាតិស្នូលដែលគ្រប់គ្រងពាណិជ្ជកម្ម ដូច្នេះហើយបានជាប្រទេសស្ទើរតែទាំងអស់ចង់ចូលរួមនិងទទួលបានការអភិវឌ្ឍន៍។

បន្តិចម្តងៗ សមាជិកភាពរបស់អង្គការពាណិជ្ជកម្មពិភពលោកបានកើនឡើងជាលំដាប់។ ត្រឹមឆ្នាំ ២០១៨ ប្រទេសចំនួន ១៦៤ រួមទាំងរដ្ឋពាណិជ្ជកម្មសំខាន់ៗទាំងអស់របស់ពិភពលោកបានចូលរួមជាមួយអង្គការWTO។ ការព្យាយាមសុំចូលជាសមាជិកភាពរបស់រុស្ស៊ីបានទទួលជោគជ័យក្នុងឆ្នាំ២០១១ បន្ទាប់ពីរយៈពេល ១៧ ឆ្នាំ នៅពេលហ្សកហ្ស៊ីដែលជាប្រទេសជិតខាងបានយល់ព្រមឈប់រាំងវា (ត្រូវការសម្លេងឯកច្ឆ័ន្ទក្នុងចំណោមសមាជិកទាំងអស់)។ ប្រទេសយេម៉ែន ដែលមិនមានស្ថិរភាពនយោបាយបានចូលរួមនៅក្នុងឆ្នាំ ២០១៤។ រដ្ឋចំនួន ២០ ជាង កំពុងស្វះស្វែងសុំចូលរួម ដែលគួរអោយកត់សម្គាល់ជាងគេ គឺប្រទេសអ៊ីរ៉ង់ នឹងអ៊ីរ៉ាក់។ បន្ទាប់ពីការចរចាអស់រយៈពេលជាងមួយទស្សវត្សរ៍ ប្រទេសចិនបានចូលរួមនៅក្នុងឆ្នាំ ២០០១។ ជាធម្មតា សហរដ្ឋអាមេរិកនិងប្រទេសផ្សេងទៀត ទាមទារជាក់លក្ខខណ្ឌអោយរដ្ឋកំពុងសុំចូលជាសមាជិក ត្រូវធ្វើសេរីភាវូបនីយកម្មលើការអនុវត្តពាណិជ្ជកម្ម។ ការអនុវត្តថ្មីទាំងនេះបានប៉ះពាល់ដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងនយោបាយរបស់ប្រទេសចិន (សូមមើលមេរៀនទី ៩)។

ក្របខណ្ឌរបស់អង្គការពាណិជ្ជកម្មពិភពលោក ត្រូវឈរលើគោលការណ៍នៃបដិការ ពោលគឺ បើរដ្ឋមួយកាត់បន្ថយរបាំងពាណិជ្ជកម្មសម្រាប់រដ្ឋមួយទៀត រដ្ឋមួយទៀតនោះក៏កាត់បន្ថយតាមផងដែរ។ វាក៏ប្រើប្រាស់នូវគោលគំនិតនៃការមិនរើសអើង ដែលបង្កប់នៅក្នុងគំនិត **ប្រជាជាតិអំណោយផលបំផុត** (MFN) (Most-Favored Nation)ដែលចែងថា ការតបន្តឹងពាណិជ្ជកម្មរបស់សមាជិកអង្គការWTOមួយ ទៅលើដៃគូពាណិជ្ជកម្មអំណោយផលបំផុត ត្រូវតែអនុវត្តស្មើៗគ្នាចំពោះសមាជិកអង្គការWTOទាំងអស់។ ប្រសិនបើប្រទេសអូស្ត្រាលីអនុវត្តពន្ធគយ ២០ ភាគរយ លើគ្រឿងបន្លាស់រថយន្ត ដែលនាំចូលពីប្រទេសបារាំងនោះ វាមិនត្រូវអនុវត្តពន្ធគយ ៤០ ភាគរយលើគ្រឿងបន្លាស់រថយន្តដែលនាំចូលពីសហរដ្ឋអាមេរិកនោះទេ។ ដូច្នេះអង្គការWTOមិនលុបបំបាត់របាំងពាណិជ្ជកម្មទាំងស្រុងនោះទេ ប៉ុន្តែធ្វើអោយអត្រាពន្ធគយស្មើគ្នា នៅក្នុងក្របខ័ណ្ឌសកលដើម្បីបង្កើតកម្រិតមូលដ្ឋានគ្រឹះដូចគ្នាសម្រាប់រដ្ឋជាសមាជិកទាំងអស់។ រដ្ឋមិនត្រូវបានរារាំងពីការការពារឧស្សាហកម្មផ្ទាល់របស់ពួកគេទេ ប៉ុន្តែ មិនអាចធ្វើគោលនយោបាយកាន់ជើងរដ្ឋណាមួយក្នុងចំណោមដៃគូពាណិជ្ជកម្មរបស់ពួកគេបានទេ។ រដ្ឋក៏អាចពង្រីកឋានៈ ប្រជាជាតិអំណោយផលបំផុត ទៅកាន់រដ្ឋផ្សេងទៀតដែលមិនមែនជាសមាជិកអង្គការWTO ដូចដែលសហរដ្ឋអាមេរិកបានធ្វើជាមួយប្រទេសចិនមុនពេលវាចូលជាសមាជិកអង្គការWTO។

ការលើកលែងចំពោះប្រព័ន្ធប្រជាជាតិអំណោយផលបំផុត គឺជា**ប្រព័ន្ធទូទៅនៃការអនុគ្រោះ**(GSP) (Generalized System of Preferences) ដែលមានតាំងពីទសវត្សរ៍ឆ្នាំ១៩៧០ ដែលរដ្ឋរីកចម្រើនផ្តល់

សម្បទានពាណិជ្ជកម្មដល់រដ្ឋក្រីក្រ ដើម្បីជួយដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ពួកគេ។ ការអនុគ្រោះនេះអាចជាការសន្យារបស់រដ្ឋរីកចម្រើន ក្នុងអនុញ្ញាតអោយរដ្ឋក្រីក្រនាំចូលទំនិញ ក្នុងអត្រាពន្ធគយទាបជាងការនាំទំនិញចូលពីបណ្តាប្រជាជាតិអំណោយផលបំផុត (MFN)។

អង្គការWTO បានបន្តតួនាទីរបស់កិច្ចព្រមព្រៀងGATT ក្នុងឋានៈជាវេទិកាចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មពហុភាគី ដែលកាត់បន្ថយរបាំងពាណិជ្ជកម្ម ដោយផ្អែកលើមូលដ្ឋានសមភាព និងបដិការ។ កិច្ចព្រមព្រៀងដ៏លម្អិតនិងស្មុគ្រស្មាញទាំងនេះគួរសបញ្ជាក់ពីការប្តេជ្ញាចិត្ត ដើម្បីកាត់បន្ថយរបាំងពាណិជ្ជកម្មជាក់លាក់ ក្នុងកម្រិតជាក់លាក់ តាមកាលវិភាគកំណត់។ ស្ទើរតែរាល់ការប្តេជ្ញាចិត្តរួមបញ្ចូលតម្លៃនយោបាយក្នុងស្រុកពីព្រោះឧស្សាហកម្មក្នុងស្រុកបាត់បង់ការគាំពារពីការប្រកួតប្រជែងពីបរទេស។ សូម្បីនៅពេលដែលរដ្ឋផ្សេងទៀតព្រមធ្វើការប្តេជ្ញាចិត្តស្រដៀងគ្នានៅក្នុងតំបន់ផ្សេងទៀត ការកាត់បន្ថយរបាំងពាណិជ្ជកម្មជារឿយៗមានការពិបាកសម្រាប់រដ្ឋាភិបាលជាតិ។

ជាលទ្ធផល ការចរចាលើកិច្ចព្រមព្រៀងពហុភាគីទាំងនេះត្រូវចំណាយពេលយូរ និងមានការពិបាកដែលជាធម្មតាអូសបន្លាយអស់ជាច្រើនឆ្នាំ នៅក្នុង*ជុំចរចា* (round of negotiations)មួយៗ។ ក្នុងចំណោមជុំចរចាកិច្ចព្រមព្រៀងGATTទាំងប្រាំ ចាប់ពីឆ្នាំ ១៩៤៧ ដល់ឆ្នាំ ១៩៩៥ ជុំកេណ្ណឺឌី ក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ (វាត្រូវបានគេហៅយ៉ាងនេះ ដោយសារតែវាបានចាប់ផ្តើមក្នុងអំឡុងពេលរដ្ឋបាលរបស់ ប្រធានាធិបតីអាមេរិក លោកកេណ្ណឺឌី) បានយកចិត្តទុកដាក់ជាពិសេសចំពោះតួនាទីកាន់តែកើនឡើងនៃសមាហរណកម្មអឺរ៉ុប ដែលសហរដ្ឋអាមេរិកបានយល់ឃើញថា អាចជាការគំរាមកំហែងខ្លះដែរ។ ជុំតូក្យូ (ចាប់ផ្តើមនៅទីក្រុងតូក្យូ) ក្នុងទសវត្សរ៍ឆ្នាំ ១៩៧០ ត្រូវកែសម្រួលច្បាប់ទៅតាមលក្ខខណ្ឌថ្មីនៃការពឹងអាស្រ័យគ្នាទៅវិញទៅមក នៅពេលដែល ជាឧទាហរណ៍ អង្គការOPEC ដំឡើងថ្លៃប្រេង ហើយប្រទេសជប៉ុនបានចាប់ផ្តើមគ្របដណ្តប់លើទីផ្សារអាជីវកម្មនាំចេញរថយន្ត។

ជុំអ៊ុយរូហ្គាយ (Uruguay Round) បានចាប់ផ្តើម នៅឆ្នាំ ១៩៨៦ (នៅក្នុងប្រទេស Uruguay)។ បើទោះបីជាគំរោងពង្រាងនៃកិច្ចព្រមព្រៀងGATTថ្មីបានលេចចេញជារូបរាង ក្នុងពេលប៉ុន្មានឆ្នាំក្រោយមកក៏ដោយ ការបង្ហើយពង្រាងខាងលើនេះមិនបានកើតឡើងឡើយ ទោះជាមានកិច្ចប្រជុំកំពូលនៃប្រទេសមហាសេដ្ឋកិច្ចទាំងប្រាំពីរ (G៧) ចំនួនប្រាំជាបន្តបន្ទាប់ ក្នុងចន្លោះឆ្នាំ ១៩៩០-១៩៩៤។ នៅពេលដែលការប្រជុំបានអូសបន្លាយជាច្រើនជុំ ពីមួយឆ្នាំទៅមួយឆ្នាំ អ្នកចូលរួមប្រជុំបានចំអកថា កិច្ចព្រមព្រៀងGATT គួរតែត្រូវប្តូរឈ្មោះជា «កិច្ចព្រមព្រៀងទូទៅដើម្បីតែពិភាក្សាហើយពិភាក្សាទៀតៗ» ។ ការបិទបញ្ចប់ដោយជោគជ័យក្នុងជុំនេះ អាចនឹងបន្ថែមទឹកប្រាក់ប្រមាណ ១០០ ពាន់លានដុល្លារជាង ដល់សេដ្ឋកិច្ចពិភពលោក ជារៀងរាល់ឆ្នាំ។ ប៉ុន្តែ ទឹកប្រាក់ទាំងអស់នោះគឺជាផលប្រយោជន៍រួម ដែលត្រូវចែករំលែកដល់រដ្ឋដែលធ្វើសម្បទាននៅក្នុងការចរចាចុងក្រោយផង និងដល់រដ្ឋដែលមិនធ្វើសម្បទានផងដែរ។ ទីបញ្ចប់ កិច្ចព្រមព្រៀងត្រូវបានសម្រេចឡើង នៅចុងឆ្នាំ ១៩៩៤។ សហរដ្ឋអាមេរិកបានជាក់សម្តែងអឺរ៉ុបអោយកាត់បន្ថយការឧបត្ថម្ភធនផ្នែកកសិកម្ម និងរដ្ឋនានានៅអឡាស្កាខាងត្បូងទាំងមូលអោយការពារសិទ្ធិកម្មសិទ្ធិបញ្ញា។ នៅទីបញ្ចប់ សហរដ្ឋអាមេរិកទទួលបានផលប្រយោជន៍មួយចំនួន ប៉ុន្តែមិនទទួលបានតាមការចង់បានរបស់ខ្លួនទាំងអស់នោះទេ។ ជាឧទាហរណ៍ ប្រទេសបារាំងបានប្រកាន់ជំហរយ៉ាងម៉ឺងម៉ាត់ និងបានឈ្នះសិទ្ធិការពារឧស្សាហកម្មភាពយន្តរបស់ខ្លួន ប្រឆាំងនឹងភាពយន្តរបស់សហរដ្ឋអាមេរិក។

ចាប់ពីឆ្នាំ ១៩៤៧ មក កិច្ចព្រមព្រៀងGATTបានលើកទឹកចិត្តអោយរដ្ឋនានាប្រើប្រាស់ពន្ធនាំចូល ជាជាងប្រើរបាំងមិនមែនពន្ធគយ ដើម្បីការពារឧស្សាហកម្មហើយត្រូវកាត់បន្ថយពន្ធទាំងនោះ ជាបន្តបន្ទាប់។ កិច្ចព្រមព្រៀងGATTបានផ្តោតលើទំនិញឧស្សាហកម្ម ហើយបានជោគជ័យក្នុងការកាត់បន្ថយពន្ធគយមធ្យមយ៉ាងច្រើន ពី ៤០ ភាគរយនៃតម្លៃទំនិញកាលពីប៉ុន្មានទសវត្សរ៍មុន មកត្រឹម ៣ ភាគរយ នៅត្រឹមឆ្នាំ ២០០២ (ក្រោមកិច្ចព្រមព្រៀង ជុំអ៊ុយរូហ្គាយ)។ អត្រាពន្ធគយនៅអឡាគោលខាងត្បូង មានកម្រិតខ្ពស់ជាងច្រើនប្រហែល ១៥ ភាគរយ (ដោយឆ្លុះបញ្ចាំងពីការគាំពារកាន់តែច្រើនដែលឧស្សាហកម្មនៅទីនោះត្រូវការដោយជាក់ស្តែង)។

ពាណិជ្ជកម្មកសិកម្មមានលក្ខណៈរសើបលើផ្នែកនយោបាយ ជាងការជួញដូរទំនិញឧស្សាហកម្ម និងបានក្លាយជាបញ្ហាក្តៅគគុក នៅក្នុងជុំអ៊ុយរូហ្គាយ។ ពាណិជ្ជកម្មសេវាកម្ម ដូចជាវិស័យធនាគារនិងធានារ៉ាប់រងគឺជាចំណុចសំខាន់មួយទៀតរបស់អង្គការពាណិជ្ជកម្មពិភពលោក នាពេលបច្ចុប្បន្ន។ ពាណិជ្ជកម្មបែបនេះមានតម្លៃជិត ២៥ ភាគរយនៃតម្លៃសរុបនៃពាណិជ្ជកម្មពិភពលោក ក្នុងឆ្នាំ ២០១៧។

បញ្ហាក្នុងការពង្រីកចូលក្នុងវិស័យទាំងនេះ និងវិស័យដ៏រសើបៗផ្សេងទៀត បានស្តែងចេញនៅក្នុងសន្និសិទអង្គការពាណិជ្ជកម្មពិភពលោក នៅទីក្រុងស៊ីអែថល (Seattle) នៅឆ្នាំ ១៩៩៩ ដែលរដ្ឋមន្ត្រីពាណិជ្ជកម្មនានា បានសង្ឃឹមថានឹងចាប់ផ្តើមជុំចរចាពាណិជ្ជកម្មថ្មី ក្រោយជុំអ៊ុយរូហ្គាយ។ តំណាងមកពីប្រទេសក្រីក្របានអះអាងថា ពួកគេត្រូវការពាណិជ្ជកម្មដើម្បីបង្កើនប្រាក់ចំណូលជាតិនិងមិនអាចបំពេញតាមស្តង់ដារនៃប្រទេសឧស្សាហកម្ម (ដែលធ្លាប់បានអនុញ្ញាតអោយមានប្រាក់ឈ្នួលទាប លក្ខខណ្ឌការងារដ៏លំបាក និងការបំផ្លិចបំផ្លាញបរិស្ថាន នៅពេល*ពួកគេ*បានចាប់ផ្តើមធ្វើឧស្សាហកម្ម)។ សកម្មជនបរិស្ថាននិងការងារ ដែលត្រូវបានចូលរួមដោយពួកអនាធិបតេយ្យវាយកម្ទេចបង្អួច បានធ្វើបាតុកម្មនៅតាមផ្លូវ ដែលពន្យារពេលបើកសន្និសីទមួយថ្ងៃ។ យ៉ាងណាក៏ដោយ កិច្ចប្រជុំបានបញ្ចប់ដោយបរាជ័យ។

រូបថត *ប្រធានអង្គការ WTO បើកសន្និសីទ*

ធ្វើវេទមន្ត

ការចរចាពាណិជ្ជកម្មជាច្រើនជុំ ដូចជាជុំដូហានាពេលបច្ចុប្បន្ន បានចាប់ផ្តើមក្នុងឆ្នាំ ២០០១ បានប្រព្រឹត្តិទៅអស់រយៈពេលជាច្រើនឆ្នាំ នៅពេលដែលសមាជិកទាំងឡាយចរចាកិច្ចព្រមព្រៀងស្មុគស្មាញ ដែលត្រូវតែអនុម័តដោយសម្លេងឯកច្ឆន្ទ ពីរដ្ឋសមាជិកទាំង ១៦៤។ សន្និសីទរដ្ឋមន្ត្រីពាណិជ្ជកម្ម នៅខែធ្នូ ឆ្នាំ ២០០៥ បានព្យាយាមរក្សាសន្ទុះឡើងវិញ សម្រាប់ជុំដូហា ដែលជាប់គាំង ជាមួយនឹងលទ្ធផលចម្រុះ។ នៅទីនេះ លោក ប៉ាស្កាល់ ឡាមី (Pascal Lamy) ប្រធានអង្គការ WTO បើកសន្និសីទជាមួយនឹងឧបករណ៍ដែលគាត់សង្ឃឹមថានឹងនាំមកនូវភាពជោគជ័យ ជាមួយនឹងចង្កឹះវេទមន្ត។ ការចរចានៅតែជាប់គាំង នៅឆ្នាំ ២០១៨។

ក្នុងឆ្នាំ ២០០១ ក្រោយបរាជ័យនៅទីក្រុងស៊ីអែថល រដ្ឋមន្ត្រីពាណិជ្ជកម្មដែលជួបប្រជុំនៅទីក្រុងដូហានៃប្រទេសកាតារ បានយល់ព្រមចាប់ផ្តើមការចរចាពាណិជ្ជកម្មថ្មីមួយជុំទៀត នោះគឺកិច្ចប្រជុំ **ជុំដូហា**។ បញ្ហាដែលត្រូវចរចា រួមមាន កសិកម្ម សេវាកម្ម ផលិតផលឧស្សាហកម្ម កម្មសិទ្ធិបញ្ញា ច្បាប់ អង្គការWTO (រួមទាំងយន្តការដោះស្រាយករណីប្រឆាំងនឹងការលក់បង្ខូចថ្លៃ) ការដោះស្រាយវិវាទ និងចំណោទពាណិជ្ជកម្មនិងបរិស្ថានមួយចំនួន។ នៅឯកិច្ចប្រជុំ ឆ្នាំ ២០០៣ នៅទីក្រុងយែនឃូន(Cancun) នៃប្រទេសម៉ិកស៊ិក បណ្តា

រដ្ឋមកពីអឌ្ឍគោលខាងត្បូង បានដើរចេញពីបន្ទប់ប្រជុំ បន្ទាប់ពីប្រទេសឧស្សាហូបនីយកម្មមិនយល់ព្រមបញ្ឈប់ការឧបត្ថម្ភធនកសិកម្មរបស់ពួកគេ ដែលបាននិងកំពុងពាំងផ្លូវនាំចេញកសិផលរបស់ប្រទេសក្រីក្រ។ នៅឯកិច្ចប្រជុំ នៅទីក្រុងហុងកុង ឆ្នាំ ២០០៥ រដ្ឋអ្នកមានបានយល់ព្រមបញ្ចប់ការឧបត្ថម្ភធនលើទំនិញនាំចេញ ប៉ុន្តែការចរចាដ៏តឹងតែងត្រូវបានបន្ត អំពីបញ្ហាពន្ធគយលើផលិតឧស្សាហកម្ម ការការពារកម្មសិទ្ធិបញ្ញា និងការបើកចំហរផ្នែកហិរញ្ញវត្ថុ។ ឧបសគ្គចម្បងនៅតែជាការបដិសេធរបស់ប្រទេសឧស្សាហកម្មលោកខាងលិចក្នុងការកាត់ផ្តាច់ការឧបត្ថម្ភធនផ្នែកកសិកម្ម តាមការទាមទាររបស់ប្រទេសនៅក្នុងអឌ្ឍគោលខាងត្បូង (សូមមើលឧទាហរណ៍បន្ថែម ការស្វែងរកផលប្រយោជន៍រួម)។

ក្នុងការពន្យល់ពីភាពលំបាកក្នុងការបញ្ចប់កិច្ចព្រមព្រៀងពាណិជ្ជកម្មដ៏សំខាន់មួយ ដូចជា កិច្ចប្រជុំ ជុំដូហា អ្នកទ្រឹស្តីល្បែងអាចនឹងសម្លឹងមើលល្បែងដល់មាន់ (សូមមើលមេរៀនទី ២) ជាគំរូសម្រាប់ពន្យល់។ នៅក្នុងវិាទពាណិជ្ជកម្មភាគច្រើន រដ្ឋនីមួយៗចង់ទទួលបានកិច្ចព្រមព្រៀងមួយ សូម្បីតែក្នុងលក្ខខណ្ឌអនុគ្រោះដល់រដ្ឋផ្សេងទៀត ប្រសិនបើចាំបាច់ក៏ដោយ។ ប៉ុន្តែ ប្រសិនបើអាចធ្វើទៅបាន រដ្ឋនីមួយៗចង់ ទទួលបានកិច្ចព្រមព្រៀងមួយ តាមលក្ខខណ្ឌដែលខ្លួនចង់បាន។ ដូចគ្នានេះដែរ នៅក្នុងល្បែងដល់មាន់ អ្នកលេងម្នាក់ៗចង់បញ្ចៀសការប៉ះទង្គិចឬបោកក្បាលគ្នា ហើយការក្លាយជាវីរបុរសក្លាហាន ឬ ជាមាន់កំសាក គឺជារឿងបន្ទាប់បន្សំ។ នៅក្នុងការចរចាពាណិជ្ជកម្ម រដ្ឋទាំងពីរប្រកាន់ខ្ជាប់នូវលក្ខខណ្ឌផ្ទាល់ខ្លួន (មិនផ្លាស់ប្តូរ) អោយបានយូរតាមតែអាចធ្វើទៅបាន បន្ទាប់មកសុខចិត្តចុះកិច្ចព្រមព្រៀងក្នុងកាល:ទេស:ដែលប្រឈមមុខនឹងការប៉ះទង្គិចគ្នាដែលជិតមកដល់ តែប៉ុណ្ណោះ ពោលគឺ ការផុតកាលកំណត់ ដែល នឹងមិនមានកិច្ចព្រមព្រៀងអ្វីទាំងអស់ បើហួសពេល។ នៅក្នុងល្បែងដល់មាន់ គ្មានរង្វាន់លើកទឹកចិត្ត ក្នុងការផ្តល់សម្បទានឬសុំចុះចាញ់មុននាទីចុងក្រោយឡើយ។

ការចរចារបស់អង្គការWTO នៅជុំដូហា បានចាប់ផ្តើមពីឆ្នាំ ២០០១ ដល់ឆ្នាំ ២០១៥ ដោយមិនមានលទ្ធផលសម្រេចអ្វីទាំងអស់។ ក្នុងឆ្នាំ ២០០៧ ប្រទេសជាភាគីចូលរួមបានព្យាយាមដាក់កាលកំណត់ដ៏សំខាន់មួយ (កាលកំណត់ទទួលបានការអនុញ្ញាតយ៉ាងលឿនដោយសភាសហរដ្ឋអាមេរិក បន្ទាប់ពីនោះ ការអនុម័តរបស់សហរដ្ឋអាមេរិកលើកិច្ចព្រមព្រៀងអង្គការWTOថ្មី នឹងកាន់តែលំបាក) ដើម្បីជំរុញអោយមានកិច្ចព្រមព្រៀងនៅនាទីចុងក្រោយ។ ក្រោយកាលកំណត់នោះបានកន្លងផុតទៅ កាលកំណត់ផ្សេងទៀតក៏បានមកដល់និងកន្លងហួសដែរ។ នៅពេលដែលកាលបរិច្ឆេទកំណត់នីមួយៗបានកន្លងផុតទៅ វាកាន់តែពិបាកក្នុងការជឿថា ពេលវេលាកំណត់បន្ទាប់មានលក្ខណៈជាក់ស្តែង ប្រៀបដូចជាការប៉ះទង្គិចក្បាលនឹងកើតឡើងដោយជៀសមិនរួច ប្រសិនបើរដ្ឋនីមួយៗមិន«ងាកក្បាលចេញ» អោយទាន់ពេល។ ល្បែងដល់មាន់អាចជួយយើងស្វែងយល់ពីចរន្តបែបនេះ។ ទោះជាយ៉ាងណាក៏ដោយ គុណវិបត្តិមួយនៃគំរូនេះគឺថាវាមិនបានទស្សន៍ទាយលទ្ធផលនោះទេ ដោយសារតែល្បែងនេះមិនមានស្ថេរភាព។ អ្វីដែលវាព្យាករណ៍គឺថា កិច្ចព្រមព្រៀងមួយប្រសិនបើសម្រេចបាន នឹងមកដល់ភ្លាមៗ នៅមុនពេលកាលកំណត់គួរអោយទុកចិត្ត និងថា ការបរាជ័យដ៏មហន្តរាយនឹងកើតឡើងជាការភ្ញាក់ផ្អើល មិនសប្បាយចិត្ត ដល់អ្នកចូលរួមទាំងឡាយ («ហេតុអ្វីបានជាគាត់ងាកក្បាលចេញ?»)។

កិច្ចព្រមព្រៀងតូចៗដទៃទៀត នៅក្នុងការចរចារបស់អង្គការWTOបានរក្សាដង្ហើមនៃក្តីសង្ឃឹម ដែលថាកិច្ចប្រជុំ ជុំដូហា នឹងបញ្ចប់ដោយកិច្ចព្រមព្រៀងពាណិជ្ជកម្មសកលថ្មីមួយ។ កិច្ចព្រមព្រៀងរវាងសហរដ្ឋ

អាមេរិកនិងឥណ្ឌាក្នុងឆ្នាំ ២០១៤ ទាក់ទងនឹងការឧបត្ថម្ភធនក្នុងវិស័យកសិកម្ម សម្រាប់ស្តុកទុកស្បៀងអាហារបាននាំមកនូវក្តីសង្ឃឹមជាថ្មី ក្នុងការទម្លុះទម្លាយការជាប់គាំង ប៉ុន្តែ ក្តីសង្ឃឹមទាំងនោះត្រូវបញ្ចប់នៅក្នុងឆ្នាំ ២០១៥ នៅពេលដែលអង្គការWTOបានផ្អាកជុំដូហាជាផ្លូវការ។ អង្គការWTO បានបន្តបើកកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីប្រចាំឆ្នាំ ប៉ុន្តែ មានក្តីសង្ឃឹមតិចតួចសម្រាប់កិច្ចព្រមព្រៀងពាណិជ្ជកម្មពហុភាគី ដោយសារនៅមានភាពខុសគ្នាយ៉ាងជ្រាលជ្រៅរវាងរដ្ឋជាសមាជិក។ នៅឯកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីឆ្នាំ ២០១៧ រដ្ឋជាច្រើនបានប្រកាសថាវាដល់ពេលដែលត្រូវធ្វើការជាក្រុមតូចៗក្នុងចំណោមរដ្ឋដែលមាន«ចិត្តដូចគ្នា» ដើម្បីធ្វើអោយមានវឌ្ឍនភាពលើការដោះស្រាយបញ្ហាមួយចំនួន។ តើកិច្ចព្រមព្រៀងតូចៗទាំងនោះ (ប្រសិនបើពួកគេត្រូវបានបង្កើតឡើង)នឹងប្រែទៅជាកិច្ចព្រមព្រៀងពាណិជ្ជកម្មសកលធំជាងនេះដោយរបៀបណា នៅតែជាសំណួរមិនទាន់មានចម្លើយនៅឡើយ។

ជាទូទៅ រដ្ឋនានាបន្តចូលរួមក្នុងអង្គការWTO ដោយសារតែអត្ថប្រយោជន៍នៃការបង្កើតទ្រព្យសម្បត្តិសកល មានទំហំធំធេងជាងការខាតបង់ទាក់ទងនឹងគ្រោះថ្នាក់ដល់ឧស្សាហកម្មក្នុងស្រុក និងការកែសម្រួលដ៏ឈឺចាប់នៅក្នុងសេដ្ឋកិច្ចជាតិ។ រដ្ឋព្យាយាមផ្លាស់ប្តូរច្បាប់ តាមចំណង់ចំណូលចិត្តរបស់ពួកគេក្នុងអំឡុងពេលចរចា ហើយរវាងជុំចរចានីមួយៗ ពួកគេអាចគេចវេសពីច្បាប់ទាំងនោះតាមមធ្យោបាយមួយចំនួន។ ប៉ុន្តែ អត្ថប្រយោជន៍រួមមានទំហំធំពន់ពេកមិនអាចប្រថុយប្រថានបាន ដោយការគេចវេសមិនចូលរួម ឬសង្គ្រាមពាណិជ្ជកម្មញឹកញាប់។

៨.២.២. កិច្ចព្រមព្រៀងទ្វេភាគី និងតំបន់

ទោះបីជាអង្គការពិភពលោកផ្តល់ក្របខ័ណ្ឌទាំងមូលសម្រាប់ពាណិជ្ជកម្មពហុភាគី នៅក្នុងទីផ្សារទូទាំងពិភពលោកក៏ដោយ ក៏ពាណិជ្ជកម្មអន្តរជាតិភាគច្រើនក៏ប្រព្រឹត្តទៅក្រោមកិច្ចព្រមព្រៀងនយោបាយអន្តរជាតិជាក់លាក់បន្ថែមទៀតរួមមានកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគីនិងតំបន់ពាណិជ្ជកម្មសេរីក្នុងតំបន់។

កិច្ចព្រមព្រៀងទ្វេភាគី (Bilateral Agreements)

កិច្ចព្រមព្រៀងទ្វេភាគី ដែលគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម គឺជាការរៀបចំតាមគោលការណ៍បដិការ ដើម្បីកាត់បន្ថយរបាំងពាណិជ្ជកម្មរវាងរដ្ឋទាំងពីរ។ ជាធម្មតា ពួកវាមានលក្ខណៈលម្អិតបំផុត។ ជាឧទាហរណ៍ ប្រទេសមួយអាចកាត់បន្ថយការហាមឃាត់របស់ខ្លួនលើការនាំចូលផលិតផល **ក** (ដែលប្រទេសទីពីរនាំចេញក្នុងតម្លៃប្រកួតប្រជែង) ខណៈដែលប្រទេសទីពីរកាត់បន្ថយពន្ធលើផលិតផល **ខ** (ដែលប្រទេសទីមួយនាំចេញ)។ កិច្ចព្រមព្រៀងដ៏ធំទូលាយមួយ ដូចជារវាងប្រទេសកាណាដា និងឥណ្ឌា ក្នុងឆ្នាំ ២០០៧ ជាទូទៅមានកម្រិតព័ត៌មានលម្អិតខ្លាំងបំផុតទាក់ទងនឹងឧស្សាហកម្មនិងផលិតផលជាក់លាក់។ ដូចដែលកិច្ចព្រមព្រៀងភាគច្រើន ផ្អែកលើគោលការណ៍បដិការ សន្ធិសញ្ញាពាណិជ្ជកម្មពាក់ព័ន្ធនឹងភាពដ៏ស្មុគស្មាញ និងការតាមដាននិងត្រួតពិនិត្យជាប្រចាំ។ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរបស់សហរដ្ឋអាមេរិកជាមួយប្រទេសកូរ៉េខាងត្បូង ប៉ាណាម៉ា និងកូឡុំប៊ី បានចូលជាធរមានក្នុងឆ្នាំ ២០១១។

ផ្នែកមួយនៃគំនិតនៅពីក្រោយកិច្ចព្រមព្រមព្រៀងGATTនិងអង្គការWTO គឺត្រូវលុបបំបាត់ភាពច្របូកច្របល់នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគី និងសម្រួលអោយប្រព័ន្ធពន្ធគយ និងប្រព័ន្ធអនុគ្រោះពន្ធមានភាពសាមញ្ញ។ ទោះជាយ៉ាងនេះក្តី កិច្ចខិតខំប្រឹងប្រែងនេះបានសម្រេចកក្នុងផ្នែកខ្លះតែប៉ុណ្ណោះ ពីព្រោះកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគីនៅតែបន្តដើរតួនាទីយ៉ាងសំខាន់។ ពួកគេមានគុណសម្បត្តិក្នុងការកាត់បន្ថយ

បញ្ហាផលប្រយោជន៍រួម ដែលបង្កប់នៅក្នុងការចរចាពហុភាគី និងក្នុងការសម្របសម្រួលគោលការណ៍បដិការជាមធ្យោបាយដើម្បីសម្រេចបាននូវកិច្ចសហប្រតិបត្តិការ។ នៅពេលដែលកិច្ចចរចារបស់អង្គការWTOជាប់គាំង កិច្ចព្រមព្រៀងទ្វេភាគីអាចរក្សាសន្ទុះពាណិជ្ជកម្មអោយបន្តទៅមុខទៀត។ ដោយសារតែរដ្ឋភាគច្រើនធ្វើពាណិជ្ជកម្មភាគច្រើនជាមួយដៃគូមួយចំនួន កិច្ចព្រមព្រៀងទ្វេភាគីមួយចំនួនអាចដំណើរការស្របពេលជាមួយគ្នា ក្នុងការរៀបចំរចនាសម្ព័ន្ធទំនាក់ទំនងពាណិជ្ជកម្មរបស់រដ្ឋមួយ។ ចំនួនកិច្ចព្រមព្រៀងទ្វេភាគីបានកើនឡើងយ៉ាងខ្លាំងនៅក្នុងប៉ុន្មានទសវត្សរ៍កន្លងមក ហើយចំនួននៃកិច្ចព្រមព្រៀងបែបនេះបានគ្របដណ្តប់លើប្រភេទកិច្ចព្រមព្រៀងទាំងអស់ផ្សេងទៀតរួមបញ្ចូលគ្នា។

តំបន់ពាណិជ្ជកម្មសេរី (Free Trade Areas)

តំបន់ពាណិជ្ជកម្មសេរីនៅក្នុងតំបន់ក៏ជាផ្នែកដ៏សំខាន់ នៅក្នុងរចនាសម្ព័ន្ធនៃពាណិជ្ជកម្មពិភពលោកផងដែរ។ នៅក្នុងតំបន់បែបនេះ ក្រុមនៃប្រទេសជិតខាងយល់ព្រមដករនាំងពាណិជ្ជកម្មភាគច្រើន ឬលុបចោលទាំងអស់ នៅក្នុងតំបន់របស់ពួកគេ។ លើសពីតំបន់ពាណិជ្ជកម្មសេរី រដ្ឋអាចកាត់បន្ថយរបាំងពាណិជ្ជកម្ម*និង*អនុម័តពន្ធរួមមួយចំពោះរដ្ឋដែលមិនមែនជាសមាជិកនៃកិច្ចព្រមព្រៀងនោះ។ នេះត្រូវបានគេស្គាល់ថាជា*សហភាពពន្ធគយ* (custom union)។ ប្រសិនបើសមាជិកនៃសហភាពពន្ធគយសម្រេចចិត្តសម្របសម្រួលគោលនយោបាយផ្សេងទៀត ដូចជាការផ្លាស់ប្តូររូបិយវត្ថុ នោះសហភាពពន្ធគយនឹងក្លាយទៅជា*ទីផ្សារួម*(common market)។ ការបង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មក្នុងតំបន់ (ប្រភេទណាក៏ដោយ) អនុញ្ញាតអោយរដ្ឋមួយក្រុមសហការគ្នាក្នុងការបង្កើនទ្រព្យសម្បត្តិរបស់ពួកគេ ដោយមិនចាំបាច់រង់ចាំតំបន់ដទៃទៀតក្នុងពិភពលោក។

តំបន់ពាណិជ្ជកម្មសេរីដ៏សំខាន់បំផុតស្ថិតនៅទ្វីបអឺរ៉ុប។ វាមានទំនាក់ទំនងជាមួយសហភាពអឺរ៉ុប ប៉ុន្តែមានសមាជិកភាពធំធេងជាងនោះទៅទៀត។ ដោយសារទ្វីបអឺរ៉ុបមានរដ្ឋឧស្សាហកម្មតូចៗមួយចំនួន ដែលស្ថិតនៅជាប់ព្រំដែននឹងគ្នា ការបង្កើតទីផ្សារសមាហរណកម្មរួមតែមួយ អនុញ្ញាតអោយរដ្ឋទាំងនេះទទួលបានគុណសម្បត្តិសេដ្ឋកិច្ច ដែលតាមធម្មតា អំណោយផលសម្រាប់រដ្ឋធំៗ ដូចជាសហរដ្ឋអាមេរិកជាដើម។ ជារួមការពិសោធន៍ពាណិជ្ជកម្មសេរីរបស់អឺរ៉ុបបានក្លាយជាជោគជ័យដ៏ធំធេង ដែលរួមចំណែកដល់ការប្រមូលផ្តុំទ្រព្យសម្បត្តិរបស់អឺរ៉ុប ចាប់តាំងពីសង្គ្រាមលោកលើកទីពីរ (សូមមើលមេរៀនទី១០)។

ប្រទេសសហរដ្ឋអាមេរិក កាណាដា និងម៉ិកស៊ិក បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាមេរិកខាងជើង(NAFTA) ក្នុងឆ្នាំ១៩៩៤ បន្ទាប់ពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងសហរដ្ឋអាមេរិក និងកាណាដា ក្នុងឆ្នាំ ១៩៨៨។ ក្នុងប៉ុន្មានទសវត្សរ៍ដំបូងនៃកិច្ចព្រមព្រៀងNAFTA ការនាំចូលរបស់សហរដ្ឋអាមេរិកពីប្រទេសម៉ិកស៊ិកនិងកាណាដាបានកើនឡើងជាងពីរដង បន្ទាប់មកបានធ្លាក់ចុះបន្តិចវិញ (ក្រោយឆ្នាំ ១៩៩៩)។ ប្រទេសកាណាដានិងម៉ិកស៊ិក គឺជាប្រទេសដៃគូពាណិជ្ជកម្មធំជាងគេ និងធំលំដាប់ទីបីរបស់សហរដ្ឋអាមេរិករៀងគ្នា(ប្រទេសជប៉ុនស្ថិតនៅលំដាប់ទីពីរ)។ មុនដំបូង រូបិយប័ណ្ណរបស់ម៉ិកស៊ិកបានធ្លាក់ចុះយ៉ាងខ្លាំង ធៀបនឹងប្រាក់ដុល្លារ ក្នុងឆ្នាំ ១៩៩៤-១៩៩៥។ អ្នកប្រឆាំងសមាជិកភាពរបស់សហរដ្ឋអាមេរិកក្នុងកិច្ចព្រមព្រៀងNAFTA រួមទាំងសហជីពការងារជាច្រើននៅសហរដ្ឋអាមេរិក បានរិះគន់កម្រិតប្រាក់ឈ្នួលទាបនិងច្បាប់ការងារមិនល្អនៅក្នុងប្រទេសម៉ិកស៊ិក ដោយពួកគេបារម្ភថានឹងទាញទម្លាក់ស្តង់ដារការងាររបស់សហរដ្ឋអាមេរិកផងដែរ។ ដូចគ្នានេះដែរ ក្រុមអ្នកបរិស្ថានបានរិះគន់ច្បាប់បរិស្ថានដ៏ធូររលុងរបស់ម៉ិកស៊ិក

(ធៀបនឹងច្បាប់សហរដ្ឋអាមេរិក) ហើយមើលឃើញថាកិច្ចព្រមព្រៀងNAFTA បានផ្តល់អាជ្ញាប័ណ្ណដល់សាជីវកម្មសហរដ្ឋអាមេរិកក្នុងការបំពុលបរិស្ថាន ដោយផ្លាស់ទីទៅភាគខាងត្បូងនៃព្រំដែន។ ប៉ុន្តែ ក្នុងរយៈពេលជាង ២៥ ឆ្នាំ ទាំងផលប្រយោជន៍ដ៏អស្ចារ្យដែលត្រូវបានព្យាករណ៍ដោយក្រុមអ្នកគាំទ្រកិច្ចព្រមព្រៀងNAFTAនិងទាំងគ្រោះមហន្តរាយដែលត្រូវបានព្យាករណ៍ដោយក្រុមអ្នកប្រឆាំង មិនបានលេចចេញជារូបរាងច្បាស់ឡើយ(សូមមើលឧទាហរណ៍បន្ថែមអំពី មតិសាធារណៈនិងទំនាក់ទំនងអន្តរជាតិ)។

អ្នកនយោបាយទាំងឡាយនៅអាមេរិកខាងជើង និងខាងត្បូងបាននិយាយជាយូរណាស់មកហើយអំពីការបង្កើតតំបន់ពាណិជ្ជកម្មសេរីរួមមួយនៅលោកខាងលិច ចាប់ពីរដ្ឋអាឡាស្កាដល់ប្រទេសអាហ្សង់ទីន ដែលជា*តំបន់ពាណិជ្ជកម្មសេរីនៃទ្វីបអាមេរិក*(FTAA)។ ដើម្បីផ្តល់សិទ្ធិអំណាចអោយគាត់ធ្វើដូច្នេះបាន លោកប្រធានាធិបតី គ្លីនតុន បានស្នើអោយសភាអាមេរិក ក្នុងឆ្នាំ ១៩៩៧ អោយដំណើរការឡើងវិញនូវការបង្កើតច្បាប់ឆាប់រហ័ស[២៨]។ ប៉ុន្តែ ក្រុមអ្នកប្រជាធិបតេយ្យនៅក្នុងសភាបានបំបាក់វិធានការណ៍នេះ ដោយទាមទារអោយកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរួមត្រូវមានតម្រូវការចាំបាច់សម្រាប់ស្តង់ដារការងារ និងបរិស្ថានសម្រាប់ប្រទេសផ្សេងទៀត (ជាចំណុចដែលពួកគេបានរកឃើញពីក្នុងកំណត់ត្រារបស់តំបន់ពាណិជ្ជកម្មសេរីអាមេរិកខាងជើង)។ លោកប្រធានាធិបតី ប៊ូស បានទទួលជោគជ័យជាងក្នុងការទទួលបានសិទ្ធិអំណាចឆាប់រហ័សពីសភា ហើយការចរចាតំបន់ពាណិជ្ជកម្មសេរីនៃទ្វីបអាមេរិកបានចាប់ផ្តើម នៅក្នុងឆ្នាំ ២០០៣ ជាមួយនឹងកាលបរិច្ឆេទជាគោលដៅនៅឆ្នាំ ២០០៥។ ប៉ុន្តែនៅត្រឹមពេលនោះ កត្តាជាច្រើនបានបង្កើតសម្ពាធប្រឆាំងនឹងតំបន់ពាណិជ្ជកម្មសេរីនៃទ្វីបអាមេរិក។ ការធ្លាក់ចុះសេដ្ឋកិច្ចឆ្នាំ ២០០១ និងវិធានការណ៍សន្តិសុខក្រោយថ្ងៃទី ១១ ខែកញ្ញា បានកាត់បន្ថយពាណិជ្ជកម្ម។ ប្រទេសចិនបានផ្តល់អោយក្រុមហ៊ុនអាមេរិកទាំងឡាយនូវប្រភពនៃកម្លាំងពលកម្មថោកជាង ហើយរដ្ឋាភិបាលឆ្វេងនិយម ដែលប្រុងប្រយ័ត្នចំពោះ ដំបូន្មានសេដ្ឋកិច្ចសេរី បានឡើងកាន់អំណាចនៅក្នុងប្រទេសភាគច្រើននៅអាមេរិកឡាទីន។ ប្រទេសទាំងនោះយកចិត្តទុកដាក់បំផុតអំពីពាណិជ្ជកម្មគ្មានពន្ធគយ ខណៈដែលជំហររបស់សហរដ្ឋអាមេរិកបានសង្កត់ធ្ងន់លើបញ្ហាជាច្រើនផ្សេងទៀត ដូចជាសេវាកម្ម កម្មសិទ្ធិបញ្ញា និងការបើកចំហផ្នែកហិរញ្ញវត្ថុ។ នៅចុងឆ្នាំ ២០០៥ កិច្ចចរចាពាណិជ្ជកម្មបានបរាជ័យនៅក្នុងកិច្ចប្រជុំកំពូលមួយ នៅក្នុងប្រទេសអាហ្សង់ទីន ដែលមានអ្នកចូលរួមម្នាក់គឺប្រធានាធិបតីវ៉េណេស៊ុយអេឡា ហ៊ុយហ្គោ ឆាវែស (Hugo Chavez) បានដឹកនាំការប្រមូលផ្តុំប្រឆាំងអាមេរិកដែលមានមនុស្ស ២៥ ០០០ នាក់ នៅតាមដងផ្លូវ។ បច្ចុប្បន្ននេះ ការចរចាតំបន់ពាណិជ្ជកម្មសេរីនៃទ្វីបអាមេរិកនៅតែស្ថិតក្នុងភាពស្ងប់ស្ងាត់។ ទន្ទឹមនឹងនេះ សហរដ្ឋអាមេរិកបានឈានដល់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយប្រទេសមួយចំនួន នៅអាមេរិកឡាទីន។

នៅឆ្នាំ ២០០៧ សមាគមនៃប្រជាជាតិអាស៊ីអាគ្នេយ៍ (ហៅកាត់ថា អាស៊ាន) ចំនួន ១០ ប្រទេសបានជួបជាមួយប្រទេសចិន ជប៉ុន ឥណ្ឌា អូស្ត្រាលី និងនូវែលសេឡង់ ដើម្បីចាប់ផ្តើមការចរចាតំបន់ពាណិជ្ជកម្មសេរីអាស៊ីបូព៌ា។ ក្រុមនេះ ខុសពីអង្គការអន្តរដ្ឋាភិបាលអាស៊ីប៉ាស៊ីហ្វិកមួយចំនួនផ្សេងទៀត មិនរាប់បញ្ចូលសហរដ្ឋអាមេរិកទេ ប៉ុន្តែ វារួមបញ្ចូលចំនួនប្រជាជនពាក់កណ្តាលពិភពលោក និងមួយចំនួននៃប្រទេសមាន

[២៨] ច្បាប់ឆាប់រហ័ស (fast-track legislation) គឺជានីតិវិធីពន្លឿនសម្រាប់ការពិចារណារបស់សភាលើកិច្ចព្រមព្រៀងពាណិជ្ជកម្ម។ វាតម្រូវអោយសភាបោះឆ្នោតលើកិច្ចព្រមព្រៀងមួយ ដោយមិនបើកការពិភាក្សាលើបទប្បញ្ញត្តិឬមាត្រានៃកិច្ចព្រមព្រៀងឡើងវិញ ខណៈពេលដែលរក្សាសិទ្ធិអំណាចចុងក្រោយដោយបោះឆ្នោតព្រម ឬមិនព្រមតែប៉ុណ្ណោះ។

ចរន្តសេដ្ឋកិច្ចខ្លាំងបំផុត។ ការចរចារវាងបណ្តារដ្ឋអាស៊ាននិងប្រទេសចិនបានទទួលជោគជ័យ ហើយនៅឆ្នាំ ២០១០ តំបន់ពាណិជ្ជកម្មសេរីបានចូលជាធរមានក្នុងចំណោមប្រទេសទាំងនេះ។ តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន គឺជាតំបន់ពាណិជ្ជកម្មសេរីធំលំដាប់ទីបីនៅលើពិភពលោក បន្ទាប់ពី សហភាពអឺរ៉ុប(EU) និងតំបន់ពាណិជ្ជកម្មសេរីអាមេរិកខាងជើង(NAFTA)។

ទោះយ៉ាងណាក៏ដោយ បន្ទាប់ពីបរាជ័យនៃកិច្ចពិភាក្សាតំបន់ពាណិជ្ជកម្មសេរីនៃទ្វីបអាមេរិក(FTAA) សហរដ្ឋអាមេរិកបានចូលទៅក្នុងការចរចា ដើម្បីស្វែងរកការបង្កើតនូវអ្វីដែលគេហៅថា តំបន់ពាណិជ្ជកម្មសេរីខ្នាតយក្ស(mega-FTAs)។ បច្ចុប្បន្ន មន្ត្រីសហភាពអឺរ៉ុប និងសហរដ្ឋអាមេរិកកំពុងចរចាអំពីភាពជាដៃគូពាណិជ្ជកម្មនិងការវិនិយោគអន្តរអាត្លង់ទិក(*T-TIP*) ដែលនឹងជាក់ពន្ធគយទាប និងឧបសគ្គទាបចំពោះការវិនិយោគរវាងសហរដ្ឋអាមេរិកនិងសហភាពអឺរ៉ុប។ លើសពីនេះទៅទៀត សហរដ្ឋអាមេរិកបានចរចាអំពីភាពជាដៃគូអន្តរប៉ាស៊ីហ្វិក(*TPP*) ដែលនឹងនាំមកនូវសេដ្ឋកិច្ចចម្រុះប្រទេស ដូចជា ជប៉ុន ឈីលី នូវែលសេឡង់ វៀតណាម កាណាដា ម៉ាឡេស៊ី សិង្ហបុរី និងផ្សេងទៀត។ កិច្ចចរចាភាពជាដៃគូអន្តរប៉ាស៊ីហ្វិកបានបិទបញ្ចប់នៅក្នុងឆ្នាំ ២០១៥ ប៉ុន្តែ មុនពេលសភាអាចអនុម័តលើកិច្ចព្រមព្រៀងនេះ ប្រធានាធិបតី ត្រាំ បានដកខ្លួនអាមេរិកចេញពីកិច្ចព្រមព្រៀង ហើយបានប្រកាសក្តែងៗថា សហរដ្ឋអាមេរិកនឹងមិនចូលរួមក្នុងភាពជាដៃគូពាណិជ្ជកម្មនិងការវិនិយោគអន្តរអាត្លង់ទិកឡើយ។ អនាគតសមាជិកភាពជាដៃគូTPP ដែលនាំមុខដោយប្រទេសជប៉ុន បានបន្តកិច្ចព្រមព្រៀង ដោយគ្មានសហរដ្ឋអាមេរិក។ ហើយនៅពេលដែលរដ្ឋបាលលោកប្រធានាធិបតីត្រាំ នៅដើមឆ្នាំ ២០១៨ បានស្នើអោយបើកការចរចាភាពជាដៃគូT-TIPឡើងវិញ សហភាពអឺរ៉ុប(ដឹកនាំដោយប្រទេសបារាំង) បានឆ្លើយតបថា អឺរ៉ុបនឹងមិនចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មជាមួយរដ្ឋណាដែលមិនបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុ(ដែលប្រធានាធិបតីត្រាំ បានដកខ្លួនចេញ សូមមើលមេរៀនទី ១១)។

ក្នុងអំឡុងសង្គ្រាមត្រជាក់ សហភាពសូវៀតនិងបណ្តារដ្ឋរណបរបស់ខ្លួនបានរក្សាប្តូរពាណិជ្ជកម្មផ្ទាល់មួយក្នុងចំណោមពួកគេ។ ក្រោយសហភាពសូវៀតដួលរលំ សមាជិកនានាបានខ្នះខ្នែងចូលរួមក្នុងសេដ្ឋកិច្ចពិភពលោក។ ភោគទ្រព្យរួមនៃបណ្តារដ្ឋឯករាជ្យ(CIS) ដែលបង្កើតឡើងដោយអតីតសាធារណរដ្ឋសូវៀតចំនួន ១២ នៅតែរក្សាសមាហរណកម្មសេដ្ឋកិច្ច (ទោះបីជាប្រទេសហ្សកហ្ស៊ីបានចាកចេញបន្ទាប់ពីសង្គ្រាមឆ្នាំ ២០០៨ ជាមួយប្រទេសរុស្ស៊ីក៏ដោយ)។ ពីមុន វាជាតំបន់ពាណិជ្ជកម្មសេរី ដោយសារវាជាផ្នែករួមក្រោមដំបូលរដ្ឋតែមួយ ជាមួយនឹងវិស័យដឹកជញ្ជូនរួម ប្រព័ន្ធទំនាក់ទំនងរួម និងតំណភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធរួមផ្សេងទៀត។

អាមេរិកឡាទីនបានដើរតាមគន្លងមុខខ្យល់ឆ្ពោះទៅរកពាណិជ្ជកម្មសេរី។ ទីផ្សាររួមកោណខាងត្បូង(MERCOSUR) បានចាប់ផ្តើមនៅដើមទសវត្សរ៍ឆ្នាំ ១៩៩០ ជាមួយនឹងប្រទេសប្រេស៊ីល អាហ្សង់ទីន អ៊ុយរូហ្គាយ និងប៉ារ៉ាហ្គាយ ដែលប្រឆាំងនឹងការអនុញ្ញាតអោយប្រទេសវេណេហ្ស៊ុយអេឡាចូលរួម។ បន្ទាប់ពីប្រធានាធិបតីប៉ារ៉ាហ្គាយត្រូវបានចោទប្រកាន់និងទម្លាក់ពីតំណែង យ៉ាងប្រញាប់ប្រញាល់ ក្នុងឆ្នាំ ២០១២ ប្រទេសប្រេស៊ីលបានរៀបចំការព្យួរសមាជិកភាពប៉ារ៉ាហ្គាយពីទីផ្សាររួមកោណខាងត្បូង ក្នុងរយៈពេលដប់ខែ ដែលក្នុងអំឡុងពេលនេះ ប្រទេសវេណេស៊ុយអេឡាត្រូវបានអនុញ្ញាតអោយចូលជាសមាជិក។ ប្រទេសឈីលី បូលីវី កូឡុំប៊ី អេក្វាឌ័រ និងប៉េរូ បានចូលរួមជាសមាជិកសហការ។ សមាជិកទីផ្សាររួមកោណខាងត្បូងធ្វើ

ពាណិជ្ជកម្មជាមួយសហរដ្ឋអាមេរិកច្រើនជាងពួកគេធ្វើជាមួយគ្នា ប៉ុន្តែ វាបានដើរតួនាទីនាំមុខគេក្នុងការរារាំងសំណើបង្កើតតំបន់ពាណិជ្ជកម្មសេរី រវាងទ្វីបអាមេរិកខាងជើងនិងខាងត្បូង។ ក្នុងឆ្នាំ ២០០២ បណ្តាប្រទេសទាំងនោះបានយល់ព្រមអនុញ្ញាតអោយពលរដ្ឋរបស់ពួកគេចំនួន ២៥០ លាននាក់ ធ្វើចលនា និងស្នាក់នៅដោយសេរី នៅទូទាំងប្រទេសផងខ្លួន។ ទីផ្សាររួមការីបៀន(CARICOM) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៧៣ ប៉ុន្តែតំបន់នេះមិនមានទំហំធំឬមានគ្រប់គ្រាន់ ដើម្បីធ្វើអោយពាណិជ្ជកម្មសេរីក្នុងតំបន់ក្លាយជាកាតាលីករដ៏សំខាន់សម្រាប់បង្កើនល្បឿនកំណើនសេដ្ឋកិច្ចឡើយ។ នៅឆ្នាំ ១៩៦៩ ប្រទេសកូឡុំប៊ី អេក្វាឌ័រ ប៉េរូ និងបូលីវី បានបង្កើតក្រុមមួយ ដែលត្រូវបានគេស្គាល់ថាជា សហគមន៍នៃប្រជាជាតិអានដៀន (Andean) ដែលមានជោគជ័យតិចតួច និងរាប់បញ្ចូលទីផ្សាររួមកោណខាងត្បូងជាសមាជិកសហការ។ ទីបំផុត នៅក្នុងឆ្នាំ ២០០៨ សហភាពរួមទូទាំងទ្វីបនៃប្រជាជាតិអាមេរិកខាងត្បូង (UNASUR) បានចាប់ផ្តើមលេចចេញជារូបរាង ដើម្បីបញ្ចូលគ្នារវាងទីផ្សាររួមកោណខាងត្បូងនិង សហគមន៍នៃប្រជាជាតិអានដៀន ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីធ្វើតាមគំរូរបស់សហភាពអឺរ៉ុប។ សហភាព UNASUR បានចូលជាធរមាន នៅក្នុងឆ្នាំ ២០១០ ជាមួយនឹងការផ្តល់សច្ចាប័នចុងក្រោយដោយប្រទេសអ៊ុយរូហ្គាយ។

ប្រសិនបើតំបន់ពាណិជ្ជកម្មសេរីក្នុងតំបន់ ដូចជា បច្ចុប្បន្នមាននៅអឺរ៉ុបនិងនៅអាមេរិកខាងជើងទទួលបានកម្លាំងកាន់តែខ្លាំង ហើយតំបន់ថ្មីកើតឡើងបន្ថែមទៀតនោះ អង្គការWTOអាចនឹងត្រូវចុះខ្សោយ។ រដ្ឋទាំងឡាយណាដែលបំពេញតម្រូវការនយោបាយជាចាំបាច់ សម្រាប់កំណើនសេដ្ឋកិច្ចកាន់តែច្រើនឡើងតាមរយៈកិច្ចព្រមព្រៀងទ្វេភាគីនិងតំបន់នោះ រដ្ឋទាំងនោះអាចពឹងផ្អែកកាន់តែតិច ទៅលើកិច្ចព្រមព្រៀងទូទាំងពិភពលោកដែលត្រូវបានបង្កើតឡើងដោយអង្គការ WTO។ លើសពីនេះ ការត្រួតស៊ីគ្នានៃច្បាប់អង្គការWTO និងកិច្ចព្រមព្រៀងក្នុងតំបន់អាចបង្កើតការភ័ន្តច្រឡំ។ ជាឧទាហរណ៍ នៅក្នុងឆ្នាំ ២០០៦ គណៈកម្មាការមួយរបស់អង្គការ WTO បានតម្កល់ពន្ធគយរបស់សហរដ្ឋអាមេរិកលើឈើទន់របស់កាណាដា ខណៈពេលដែលគណៈកម្មាការតំបន់ពាណិជ្ជកម្មសេរីអាមេរិកខាងជើងបានលុបចោលពន្ធគយនោះ និងបានបញ្ជាអោយសងប្រាក់ទៅកាណាដាវិញ។ (តាមបណ្តឹងឧទ្ធរណ៍ អង្គការWTO បានដកសេចក្តីសម្រេចរបស់ខ្លួន ហើយប្រទេសទាំងពីរបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងថ្មីមួយភ្លាមៗ ដោយសហរដ្ឋអាមេរិកបានសងប្រាក់វិញជាង ៤ ពាន់លានដុល្លារ។) ប្រាកដណាស់ កិច្ចព្រមព្រៀងក្នុងតំបន់អាចបែងចែកពិភពលោកទៅជាប្លុកពាណិជ្ជកម្មប្រកួតប្រជែងនឹងគ្នា ចំនួនបី ដែលប្លុកនីមួយៗមានសមាហរណកម្មផ្ទៃក្នុង ប៉ុន្តែមិនបើកចំហខ្លាំងចំពោះប្លុកពីរផ្សេងទៀតឡើយ។ តំបន់ពាណិជ្ជកម្មសេរីក្នុងតំបន់ នៅអឺរ៉ុប និងអាមេរិក ហើយប្រហែលជានៅអាស៊ី នាពេលអនាគត បង្កើនលទ្ធភាពនៃតំបន់ពាណិជ្ជកម្ម ដែលអនុវត្តលទ្ធិសេរីនិយមផ្ទៃក្នុង និងលទ្ធិគាំពារនិយមសម្រាប់បណ្តារដ្ឋខាងក្រៅ។

៨.២.៣. ការតែល

ការតែល (cartel) គឺជាសមាគមនៃអ្នកផលិត ឬអ្នកប្រើប្រាស់ (ឬទាំងពីរ) ផលិតផលជាក់លាក់ណាមួយ។ វាត្រូវបានបង្កើតឡើងដើម្បីគ្រប់គ្រងតម្លៃរបស់វា នៅលើទីផ្សារពិភពលោក។ វាជាទម្រង់នៃរបបពាណិជ្ជកម្មមិនច្បាស់លាស់តែគួរអោយចាប់អារម្មណ៍ណាស់ដែរ។ ជាញឹកញាប់បំផុត មិនមែនជាអ្នកប្រើប្រាស់ទេ ប៉ុន្តែជាអ្នកផលិតដែលរួមគ្នាបង្កើតជាក្រុមដួញដូរការតែលនេះឡើង ព្រោះជាធម្មតាចំនួនអ្នកផលិតមានតិចជាងចំនួនអ្នកប្រើប្រាស់ ហើយវាហាក់ដូចជាអាចធ្វើទៅបានសម្រាប់ពួកគេ ក្នុងការសម្របសម្រួលគ្នាដើម្បីរក្សា

តម្លៃអោយបានខ្ពស់។ ការតែលអាចប្រើមធ្យោបាយជាច្រើនដើម្បីបង្កើនតម្លៃទំនិញ ហើយមធ្យោបាយដែលមានប្រសិទ្ធភាពបំផុត គឺការសំរបសំរួលគ្នារវាងសមាជិកនីមួយៗ ដោយកំណត់ចំនួនផលិតកម្ម ម្លោះហើយនឹងកាត់បន្ថយការផ្គត់ផ្គង់ ធៀបនឹងតម្រូវការ ផលិតផលនោះ។

ការតែល ឬ ក្រុមឈ្មួញ ដែលលេចធ្លោជាងគេ នៅក្នុងសេដ្ឋកិច្ចអន្តរជាតិ គឺ **អង្គការនៃបណ្តាប្រទេសនាំចេញប្រេង**(OPEC)។ រដ្ឋជាសមាជិករបស់វារួមគ្នាគ្រប់គ្រងការនាំចេញប្រេង ក្នុងតម្លៃរាប់រយពាន់លានដុល្លារក្នុងមួយឆ្នាំៗ ប្រហែល ៤០ ភាគរយ នៃបរិមាណប្រេងទូទាំងពិភពលោក នេះជាបរិមាណច្រើនល្មមនឹងជះឥទ្ធិពលយ៉ាងខ្លាំងលើតម្លៃ។ (ក្រុមការតែល មិនចាំបាច់មានសិទ្ធិផ្តាច់មុខលើការផលិតទំនិញ ដើម្បីតម្លើងតម្លៃទំនិញឡើយ។) ឥទ្ធិពលឡើងដល់កម្រិតកំពូលរបស់អង្គការOPEC នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៧០ មានសមាមាត្រកាន់តែខ្ពស់។ អង្គការOPEC រក្សាទីស្នាក់ការកណ្តាលរបស់ខ្លួន នៅទីក្រុងវីយែននៃប្រទេសអូទ្រីស ហើយបើកកិច្ចចរចាពីរបីដងក្នុងមួយឆ្នាំ ដើម្បីកំណត់កូតាសម្រាប់ការផលិតប្រេងរបស់ប្រទេសនីមួយៗ ដើម្បីរក្សាតម្លៃប្រេងលើពិភពលោកក្នុងចន្លោះគោលដៅ។ រហូតដល់ពេលនេះ ប្រទេសអារ៉ាប៊ីសាអូឌីតគឺជាប្រទេសនាំចេញប្រេងធំជាងគេ (បើទោះបីជាសហរដ្ឋអាមេរិកជាប្រទេសផលិតប្រេងធំជាងគេក៏ដោយ) ម្លោះហើយអាចកាន់កាប់ទីតាំងប្លែកតែមួយគត់ នៅក្នុងសេដ្ឋកិច្ចពិភពលោក (សូមមើលតារាង ៨.១)។

តារាង ៨.១ សមាជិក OPEC និងផលិតកម្មប្រេង ឆ្នាំ ២០១៨

រដ្ឋសមាជិក	**ចំនួនបារ៉ែល លានក្នុងមួយថ្ងៃ**
អារ៉ាប៊ី សាអូឌីត	១០
អ៊ីរ៉ង់	៣,៨
វ៉េណេហ្សូអេឡា	១,៨
អ៊ីរ៉ាក់	៤,៤
គុយវ៉ែត	២,៧
អារ៉ាប់អេមីរ៉ាត	២,៩
នីហ្សេរីយ៉ា	១,៧
អង់ហ្គោឡា	១,៦
លីប៊ី	១
អាល់ហ្សេរី	១
កាតារ	០,៦
អេក្វាឌ័រ	០,៥
អូប៊ិកសរុប	៣២
ភាគរយក្នុងពិភពលោក	៤៣%

ចំណាំ៖ ប្រទេសនាំចេញប្រេងសំខាន់ៗដែលមិនមែនជាសមាជិកអង្គការOPECរួមមាន រុស្ស៊ី កាហ្សាក់ស្ថាន ម៉ិកស៊ិក ចិន អង់គ្លេស និងន័រវែស។ ប្រទេសហ្គាបុងបានចាកចេញពីអង្គការ OPEC ឆ្នាំ ១៩៩៥។

ប្រភព៖ ទិន្នន័យដែលបានកែសម្រួលពីរបាយការណ៍ទីផ្សារប្រេងប្រចាំខែរបស់ OPEC ។

អង្គការOPECចង្អុលបង្ហាញពីសក្តានុពល ដែលក្រុមការតែលបង្កើតសម្រាប់បញ្ហាផលប្រយោជន៍រួម។ សមាជិកនីមួយៗនៃអង្គការOPEC អាចកេងបន្លំដោយការផលិតលើសពីកូតាផលិតកម្មរបស់ខ្លួនផ្ទាល់ ក្នុងខណៈពេលដែលនៅតែរីករាយនឹងទទួលបានផលប្រយោជន៍រួមជាតម្លៃប្រេងខ្ពស់។ ផលប្រយោជន៍រួមនឹងត្រូវខូចខាត នៅពេលដែលសមាជិកនីមួយៗផលិតច្រើនពេកលើសពីកូតារបស់ពួកគេ ដូចដែលបានកើតឡើងម្តងហើយម្តងទៀតចំពោះអង្គការOPEC។ នៅពេលនោះ តម្លៃប្រេងពិភពលោកនឹងត្រូវធ្លាក់ចុះ។ ការចោទប្រកាន់របស់ប្រទេសអ៊ីរ៉ាក់ដែលថា ប្រទេស គុយវ៉ែត ជាសមាជិកអង្គការOPEC ពីបទផលិតលើសកូតាកំណត់ និងជំរុញអោយតម្លៃប្រេងធ្លាក់ចុះ គឺជាកត្តាមួយនៅក្នុងការឈ្លានពានរបស់អ៊ីរ៉ាក់លើប្រទេសគុយវ៉ែតនៅក្នុងឆ្នាំ ១៩៩០។

អង្គការ OPEC អាចដំណើរការបានល្អ ដូចដែលខ្លួនធ្វើបាន ដោយសារតែសមាជិកមួយគឺប្រទេសអារ៉ាប៊ីសាអូឌីត មានប្រេងច្រើនគ្រប់គ្រាន់ ដើម្បីចាត់ចែងការផ្គត់ផ្គង់គ្រប់គ្រាន់ ជាឯកតោភាគី ដើម្បីជំរុញតម្លៃអោយឡើងឬធ្លាក់ចុះ ដែលជាទម្រង់មួយនៃស្ថិរភាពអនុត្តរភាព (សូមមើលមេរៀនទី ២) នៅក្នុងចំណោមក្រុមការតែល។ ប្រទេសអារ៉ាប៊ីសាអូឌីតអាចចាត់ចែងឬទប់ទល់ការក្លែងបន្លំមួយចំនួននៅក្នុងអង្គការOPEC (ដោយកាត់បន្ថយការផលិតរបស់ខ្លួន) ហើយនៅរក្សាតម្លៃប្រេងខ្ពស់ដដែល។ ឬប្រសិនបើសមាជិកអង្គការOPEC ច្រើនពេកកំពុងក្លែងបន្លំលើកូតារបស់ពួកគេ វាអាចដាក់ទណ្ឌកម្មពួកគេដោយការពន្លិចទីផ្សារដោយបរិមាណប្រេងច្រើនមហិមា និងជំរុញអោយតម្លៃប្រេងធ្លាក់ចុះ រហូតដល់សមាជិកអង្គការOPECផ្សេងទៀតគោរពតាមកូតាផលិតកម្មឡើងវិញ ដើម្បីជាផលប្រយោជន៍រួមទាំងអស់គ្នា។

ជាធម្មតា អ្នកប្រើប្រាស់មិនបង្កើតការតែលទេ។ ជាការឆ្លើយតបទៅនឹងអង្គការ OPEC រដ្ឋដែលនាំចូលប្រេងសំខាន់ៗ បានបង្កើតអង្គការរបស់ពួកគេផ្ទាល់ នោះគឺ *ទីភ្នាក់ងារថាមពលអន្តរជាតិ* (IEA) ដែលមួយផ្នែក មានមុខងារដូចជាការតែលមួយ។ ទីភ្នាក់ងារ IEA សម្របសម្រួលគោលនយោបាយថាមពលនៃបណ្តារដ្ឋឧស្សាហូបនីយកម្មសំខាន់ៗ (ដូចជាការរក្សាស្តុកប្រេង ក្នុងករណីមានកង្វះខាតនៅលើទីផ្សារពិភពលោក) ដើម្បីរក្សាតម្លៃប្រេងពិភពលោក អោយមានកម្រិតទាបនិងស្ថិរភាព។ ប្រទេសនាំចូលប្រេងធំជាងគេ គឺជាសមាជិកនៃប្រទេសមហាសេដ្ឋកិច្ចទាំង៧(រដ្ឋឧស្សាហកម្មធំៗ)។ ដោយពិចារណាអំពីសារៈសំខាន់នៃប្រេងចំពោះសេដ្ឋកិច្ចពិភពលោកនិងអត្ថិភាពនៃក្រុមការតែលអ្នកផលិតនិងអ្នកប្រើប្រាស់គួរងោយភ្ញាក់ផ្អើល តម្លៃប្រេងមិនមានស្ថេរភាពគួរ។ នេះបង្ហាញពីដែនកំណត់នៃក្រុមការតែលក្នុងការជះឥទ្ធិពលលើតម្លៃ។

សម្រាប់ទំនិញមួយចំនួន ដែលប្រឈមនឹងការប្រែប្រួលតម្លៃយ៉ាងខ្លាំង នៅលើទីផ្សារពិភពលោក (ប៉ះពាល់ទាំងអ្នកផលិតនិងអ្នកប្រើប្រាស់) ក្រុមការតែលរួមគ្នារវាងអ្នកផលិតនិងអ្នកប្រើប្រាស់មួយចំនួនត្រូវបានបង្កើតឡើង។ ដើម្បីរក្សាតម្លៃអោយស្ថិតស្ថេរ រដ្ឋអ្នកផលិតនិងអ្នកប្រើប្រាស់ប្រើក្រុមការតែលដើម្បីសម្របសម្រួលការផ្គត់ផ្គង់និងតម្រូវការទាំងមូល នៅទូទាំងពិភពលោក។ ក្រុមការតែលបែបនេះត្រូវបានបង្កើតឡើងសម្រាប់ទិន្នផលកាហ្វេ សារធាតុរ៉ែមួយចំនួន និងផលិតផលមួយចំនួនទៀត។ អង្គការក្រៅរដ្ឋាភិបាលបានណែនាំការហ្វេពណិជ្ជកម្មដោយយុត្តិធម៌ ហើយក្រោយមកទៀតណែនាំសូកូឡា និងផលិតផលផ្សេងទៀតដែលធានាចំពោះកសិករនូវតម្លៃខ្ពស់ជាងតម្លៃផលិតកម្មរបស់ពួកគេ តាមរយៈការឡើងថ្លៃនិងការធ្លាក់ចុះ។ កសិករជាងមួយលាននាក់ ក្នុងប្រទេសចំនួន ៧០ ទទួលបានអត្ថប្រយោជន៍ពីការរៀបចំទាំងនេះ។

ជាទូទៅ គោលគំនិតនៃក្រុមការតែល ដើរបញ្ច្រាសសេដ្ឋកិច្ចសេរី ពីព្រោះក្រុមការតែលមានចេតនាបំភ្លៃទីផ្សារសេរី។ ជាធម្មតា ក្រុមការតែលមិនមានឥទ្ធិពលខ្លាំងដូចកម្លាំងទីផ្សារ ក្នុងការកំណត់កម្រិតតម្លៃពិភពលោកទាំងមូលទេ៖ ដោយសារមានអ្នកផលិតនិងអ្នកផ្គត់ផ្គង់ច្រើនពេក (ហើយទំនិញជំនួសច្រើនពេកអាចជំនួសទំនិញដែលមានតម្លៃថ្លៃពេក) ធ្វើអោយក្រុមការតែលមិនអាចបិទទីផ្សារទាំងអស់បាន។

៨.២.៤. ក្រុមឧស្សាហកម្ម និងក្រុមទាញផលប្រយោជន៍

រោងចក្រឧស្សាហកម្ម និងតួអង្គនយោបាយក្នុងស្រុកផ្សេងទៀតតែងតែស្វែងរកឥទ្ធិពលលើគោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេសរបស់រដ្ឋ (សូមមើលក្រុមផលប្រយោជន៍ ក្នុងមេរៀនទី ៤)។ សម្ពាធទាំងនេះមិនតែងតែអនុគ្រោះដល់លទ្ធិគាំពារនិយមទេ។ រោងចក្រឧស្សាហកម្មដែលជឿនលឿន និងមានសមត្ថភាពប្រកួតប្រជែងខ្ពស់ក្នុងទីផ្សារពិភពលោកតែងតែព្យាយាមដើម្បីអោយមានឥទ្ធិពលលើរដ្ឋាភិបាលរបស់ពួកគេ ដើម្បីអនុម័តគោលនយោបាយពាណិជ្ជកម្មសេរី។ យុទ្ធសាស្ត្រនេះលើកកម្ពស់ប្រព័ន្ធពាណិជ្ជកម្មសេរីសកលមួយ ដែលឧស្សាហកម្មបែបនេះអាចរីកចម្រើនបាន។ ផ្ទុយទៅវិញ ឧស្សាហកម្មដែលយឺតយ៉ាវ នៅពីក្រោយដៃគូប្រកួតប្រជែងជាសកលរបស់ពួកគេ ទំនងជាត្រូវស្វែងរកការគាំពារ។

មធ្យោបាយនានា ដើម្បីជះឥទ្ធិពលលើគោលនយោបាយសេដ្ឋកិច្ចបរទេស រួមមានការបញ្ចុះបញ្ចូលការបង្កើតក្រុមផលប្រយោជន៍ ការបង់ប្រាក់សំណូក និងរហូតដល់ការជម្រុញអោយមានរដ្ឋប្រហារ។ តួអង្គរួមមានក្រុមដែលឧបត្ថម្ភដោយឧស្សាហកម្ម ក្រុមហ៊ុន សហជីពការងារ និងបុគ្គល។ នៅក្នុងឧស្សាហកម្មមួយ កិច្ចខិតខំប្រឹងប្រែងបែបនេះជាធម្មតាដំណើរការក្នុងទិសដៅរួមមួយ ពីព្រោះទោះបីជាមានការប្រកួតប្រជែងរវាងក្រុមហ៊ុននានា និងរវាងថ្នាក់គ្រប់គ្រងនិងកម្លាំងពលកម្មក៏ដោយ ភាគីទាំងអស់មានផលប្រយោជន៍រួមទាក់ទងនឹងគោលនយោបាយពាណិជ្ជកម្ម។ ទោះជាយ៉ាងណាក៏ដោយ ឧស្សាហកម្មផ្សេងគ្នាអាចជំរុញទិសដៅផ្សេងគ្នា។ ជាឧទាហរណ៍ ឧស្សាហកម្មអាមេរិកមួយចំនួនបានគាំទ្រតំបន់ពាណិជ្ជកម្មសេរីអាមេរិកខាងជើង ឧស្សាហកម្មផ្សេងទៀតបានប្រឆាំងនឹងវា។

រូបថត

ធ្វើចំបើង

វិស័យកសិកម្មគឺជាចំណុចកំពូលនៃរបៀបវារៈនៃការចរចាពាណិជ្ជកម្មអន្តរជាតិដោយសារប្រទេសកំពុងអភិវឌ្ឍន៍ជំរុញឱ្យប្រទេសអ្នកមានដើម្បីបញ្ចប់ការឧបត្ថម្ភធនកសិកម្ម។ នៅទីនេះកសិករបារាំងតវ៉ាការចរចារវាង MERCOSUR និង EU ដោយបិទផ្លូវជាមួយត្រាក់ទ័រនិងបាញ់ថ្នាំស្មៅនៅអគាររដ្ឋាភិបាលនៅភាគខាងលិចប្រទេសបារាំងឆ្នាំ ២០១៨ ។

នៅក្នុងប្រទេសជាច្រើន រដ្ឋាភិបាលមិនត្រឹមតែឆ្លើយតបទៅនឹងឥទ្ធិពលឧស្សាហកម្មប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើការយ៉ាងសកម្មជាមួយឧស្សាហកម្មនានាដើម្បីលើកកម្ពស់កំណើនរបស់ពួកគេ និងកែសម្រួលគោលនយោបាយពាណិជ្ជកម្មទៅតាមតម្រូវការរបស់ពួកគេ។ **គោលនយោបាយឧស្សាហកម្ម**បែបនេះ គឺជារឿងធម្មតា ជាពិសេសនៅក្នុងរដ្ឋដែលឧស្សាហកម្មមួយឬពីរមានសារៈសំខាន់សម្រាប់សេដ្ឋកិច្ចជាតិទាំងមូល (ហើយប្រាកដណាស់ នៅពេលរដ្ឋគ្រប់គ្រងឧស្សាហកម្មដោយផ្ទាល់)។

ក្រុមផលប្រយោជន៍ដែលមិនបានរៀបចំតាមខ្សែឧស្សាហកម្ម ក៏មានផលប្រយោជន៍ពិសេសនៅក្នុងគោលនយោបាយពាណិជ្ជកម្មរបស់រដ្ឋផងដែរ។ ជាឧទាហរណ៍ អ្នកបរិស្ថានអាមេរិកមិនចង់អោយក្រុមហ៊ុន

អាមេរិកប្រើតំបន់ពាណិជ្ជកម្មសេរីអាមេរិកខាងជើង ដើម្បីគេចវេសពីការគ្រប់គ្រងការបំពុលបរិស្ថាន ដោយការផ្លាស់ទីរោងចក្រទៅប្រទេសម៉ិកស៊ិក (ជាកន្លែងដែលច្បាប់បរិស្ថានមិនសូវតឹងរ៉ឹង)។ សហជីពកម្មករអាមេរិកមិនចង់អោយក្រុមហ៊ុនប្រើប្រាស់តំបន់ពាណិជ្ជកម្មសេរីអាមេរិកខាងជើង ដើម្បីគេចវេសពីការផ្តល់ប្រាក់ឈ្នួលខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ ក្រុមពលរដ្ឋអាមេរិកម៉ិកស៊ិកនៅសហរដ្ឋអាមេរិកមានទំនោរគាំទ្រតំបន់ពាណិជ្ជកម្មសេរីអាមេរិកខាងជើង ព្រោះវាពង្រឹងទំនាក់ទំនងជាមួយសាច់ញាតិនៅប្រទេសម៉ិកស៊ិក។

ឧស្សាហកម្មមួយចំនួនមានសារៈសំខាន់ជាពិសេសក្នុងការចរចាពាណិជ្ជកម្ម នាពេលបច្ចុប្បន្ន។ នៅលើកំពូលតារាង គឺវិស័យកសិកម្ម។ ជាប្រពៃណី កសិកម្មត្រូវបានការពារ ពីព្រោះស្វ័យភាពក្នុងការផលិតស្បៀងអាហារ អាចកាត់បន្ថយភាពងាយរងគ្រោះរបស់ជាតិ (ជាពិសេសក្នុងសម័យសង្គ្រាម)។ ថ្វីត្បិតតែក្តីបារម្ភខាងសន្តិសុខបែបនេះបានរលត់ស្ងប់ស្ងាត់ទៅបន្តិចក៏ដោយ កសិករមានការរៀបចំបានល្អ និងជាតួអង្គនយោបាយក្នុងស្រុកដ៏មានឥទ្ធិពល នៅអឺរ៉ុប សហរដ្ឋអាមេរិក ជប៉ុន និងប្រទេសដទៃទៀត។ ជាឧទាហរណ៍ កសិករជប៉ុនអះអាងថា វប្បធម៌ផ្តោតលើដំណាំស្រូវរបស់ជប៉ុនទាមទារស្វ័យភាពក្នុងការផលិតស្រូវ។ នៅក្នុងជុំចរចាដូហារបស់អង្គការWTO ការឧបត្ថម្ភធនផ្នែកកសិកម្មគឺជាចំណុចជាប់គាំងដ៏សំខាន់។ កិច្ចពិភាក្សាត្រូវបិទបញ្ចប់ នៅឆ្នាំ ២០០៣ នៅទីក្រុងខែនឃូននៃប្រទេសម៉ិកស៊ិក ជុំវិញការឧបត្ថម្ភធន ដោយពួកគេត្រូវបានចាប់ផ្តើមឡើងវិញ នៅឆ្នាំបន្ទាប់ ដោយសហរដ្ឋអាមេរិកសន្យាថានឹងកាត់បន្ថយការឧបត្ថម្ភធនកសិកម្ម កម្រិត ២០ ភាគរយ។ នៅឯកិច្ចពិភាក្សាហុងកុង ឆ្នាំ ២០០៥ ប្រទេសអ្នកមានបានយល់ព្រមបញ្ចប់ការឧបត្ថម្ភធនលើការនាំចេញកសិកម្មទាំងអស់ នៅត្រឹមឆ្នាំ ២០១៣ ដែលយ៉ាងណាក៏ដោយ ជាគោលដៅដែលមិនបានសម្រេចនៅឡើយ។

ការផ្តោតសំខាន់ទីពីរក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ គឺវិស័យវាយនភណ្ឌនិងកាត់ដេរ។ គិតត្រឹមឆ្នាំ ២០០៥ កូតាវាយនភ័ណ្ឌនៅទូទាំងពិភពលោកត្រូវបានទម្លាក់ ជាផ្នែកនៃកិច្ចព្រមព្រៀងអង្គការWTO ដែលបានចរចាពីមុន។ ក្នុងពេលជាមួយគ្នានេះ ប្រទេសចិនបានចាប់ផ្តើមគ្របដណ្តប់លើការនាំចេញសម្លៀកបំពាក់ពិភពលោក ដោយមានទីក្រុងទាំងមូលមានឯកទេសផលិតសម្លៀកបំពាក់មួយប្រភេទ ដែលផលិតសម្រាប់ការនាំចេញដ៏ធំទៅកាន់អ្នកលក់រាយដ៏ធំ។ ជាមួយនឹងឃ្លាំងដ៏ធំពោរពេញដោយកម្លាំងពលកម្មថោកនិងមានវិន័យតឹងរ៉ឹង ចិនបានគម្រាមជំរុញអ្នកផលិតវាយនភណ្ឌនិងសម្លៀកបំពាក់របស់សហរដ្ឋអាមេរិកបាត់បង់អាជីវកម្ម ហើយផ្តល់ការប្រកួតប្រជែងថ្មីយ៉ាងតឹងរឹងដល់អ្នកនាំចេញ ដូចជាប្រទេសប៉ាគីស្តាន និងបង់ក្លាដែស ដែលវាយនភណ្ឌបង្កើតបាន ៧០ ភាគរយនៃការនាំចេញ។ ក្រោយមក ក្នុងឆ្នាំ ២០០៥ សហភាពអឺរ៉ុប និងសហរដ្ឋអាមេរិករៀងៗខ្លួន បានឈានដល់កិច្ចព្រមព្រៀងទ្វេភាគីជាមួយប្រទេសចិន ដើម្បីដាក់កូតាវាយនភ័ណ្ឌឡើងវិញក្នុងរយៈពេលពីរបីឆ្នាំ។ ឥឡូវនេះ ប្រទេសនានាដូចជាវៀតណាមបានចាប់ផ្តើម ដណ្តើមយកអាជីវកម្មវាយនភណ្ឌពីប្រទេសចិន ដោយផ្តល់នូវតម្លៃផលិតកម្មទាបជាង។

កម្មសិទ្ធិបញ្ញា (intellectual property rights) គឺជាចំណុចចម្រុងចម្រាស់ទីបីក្នុងដំណើរការចរចាពាណិជ្ជកម្ម។ សិទ្ធិកម្មសិទ្ធិបញ្ញា គឺជាសិទ្ធិរបស់អ្នកផលិតសៀវភៅ ភាពយន្ត កម្មវិធីកុំព្យូទ័រ និងផលិតផលស្រដៀងគ្នា ដើម្បីទទួលបានប្រាក់កំរៃ(royalty) រៀងរាល់ពេលដែលផលិតផលរបស់ពួកគេត្រូវបានគេទិញ។ សហរដ្ឋអាមេរិកមានជម្លោះដ៏ធំមួយ ជាមួយរដ្ឋមួយចំនួន លើការលួចចម្លងកម្មវិធីកុំព្យូទ័រ តន្ត្រី ភាពយន្ត និងផលិតផលការងារច្នៃប្រឌិតផ្សេងទៀត ដែលសហរដ្ឋអាមេរិកមានអត្ថប្រយោជន៍ ធៀបខ្លាំង នៅទូទាំង

ពិភពលោក។ តាមលក្ខណៈបច្ចេកទេស វាមានភាពងាយស្រួលនិងមានតម្លៃថោក ក្នុងការចម្លងស្នាដៃទាំងនោះ ហើយលក់វា ដោយបំពានលើច្បាប់រក្សាសិទ្ធិ ប៉ាតង់ ឬច្បាប់ពាណិជ្ជសញ្ញាដទៃទៀត។ ដោយសារច្បាប់របស់សហរដ្ឋអាមេរិកមិនអាចអនុវត្តបាននៅក្រៅប្រទេស រដ្ឋាភិបាលសហរដ្ឋអាមេរិកចង់អោយរដ្ឋាភិបាលបរទេសទប់ស្កាត់និងដាក់ទណ្ឌកម្មលើការបំពានបែបនេះ។ ប្រទេសដែលត្រូវបានគេរាយការណ៍ថាលួចចម្លងកម្មវិធីកុំព្យូទ័រ និងតន្ត្រី និងផលិតផលកម្សាន្ត ក្នុងចំនួនច្រើនសន្ធឹកសន្ធាប់ រួមមាន ចិន តៃវ៉ាន់ ឥណ្ឌា ថៃ និងប្រេស៊ីល។

ប្រាកដណាស់ ការបញ្ឈប់សកម្មភាពលួចចម្លងនីមួយៗ មានការពិបាក បើទោះបីជាសកម្មភាពបែបនេះរីករាលដាលក៏ដោយ។ ជាឧទាហរណ៍ ការស្ទង់មតិឆ្នាំ ២០១៧ បានរកឃើញថា ១៦ ភាគរយនៃអ្នកប្រើប្រាស់នៅក្នុងប្រទេសឥណ្ឌូនេស៊ីនិងអេហ្ស៊ីប បានសារភាពថាមានការលួចចម្លងមាតិកាកម្សាន្តច្រើនជាងម្តងក្នុងមួយសប្តាហ៍។ នៅក្នុងការស្ទង់មតិ ៣៣ ប្រទេស (រួមទាំងសហរដ្ឋអាមេរិក) ក្នុងឆ្នាំ ២០១៧ អ្នកឆ្លើយសំណួរ ៥៧ ភាគរយ បានសារភាពថា បានលួចចម្លងកម្មវិធីយ៉ាងហោចណាស់មួយសម្រាប់កុំព្យូទ័ររបស់ពួកគេ។ ការរំលោភកម្មសិទ្ធិបញ្ញា មានការរីករាលដាលនៅក្នុងប្រទេសតតិយលោកជាច្រើន លើផលិតផលដូចជា ឌីវីឌី និងថ្នាំតាមវេជ្ជបញ្ជា។

<u>ប្រថព័ត នាវាផ្ទុកពាសដែកនៅប្រទេសហ្វីលីពីន</u>

<u>គំនរនៃបញ្ហា</u>

កម្មសិទ្ធិបញ្ញាគឺជាចំណុចសំខាន់នៃការចរចាពាណិជ្ជកម្មនាពេលថ្មីៗនេះ។ នៅក្នុងប្រទេសជាច្រើន ការលួចចម្លងវីដេអូ តន្ត្រី និងកម្មវិធីកុំព្យូទ័រ លក់ក្នុងតម្លៃថោក នៅតាមដងផ្លូវ ដោយមិនមានការទូទាត់ប្លែសួយសារអាករ។ នៅទីនេះ នាវាផ្ទុកពាសដែកនៅប្រទេសហ្វីលីពីន បើកបរលើឌីវីឌីខុសច្បាប់ នៅក្នុងកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលប្រឆាំងនឹងការលួចចម្លងឆ្នាំ ២០១៦ ។

ជាការឆ្លើយតប សហគមន៍អន្តរជាតិបានបង្កើតអង្គការអន្តររដ្ឋាភិបាលមួយ ជាមួយនឹងរដ្ឋសមាជិក អ.ស.ប. ចំនួន ១៨៦ នោះគឺអង្គការកម្មសិទ្ធិបញ្ញាពិភពលោក(WIPO) ដែលព្យាយាមបង្កើតច្បាប់ប៉ាតង់និងច្បាប់រក្សាសិទ្ធិឆ្លងព្រំដែនអន្តរជាតិទាំងឡាយ។ រដ្ឋភាគច្រើនបានចុះហត្ថលេខាលើសន្ធិសញ្ញាប៉ាតង់ដ៏សំខាន់ឆ្នាំ១៩៩៤ និងសន្ធិសញ្ញារក្សាសិទ្ធិចម្លងឆ្នាំ ១៩៩៦។ អង្គការWTO ត្រួតពិនិត្យលើកិច្ចព្រមព្រៀងពហុភាគីដ៏សំខាន់បំផុតរបស់ពិភពលោកស្តីពីកម្មសិទ្ធិបញ្ញា ដែលត្រូវគេហៅថា ទិដ្ឋភាពទាក់ទងនឹងពាណិជ្ជកម្មនៃសិទ្ធិកម្មសិទ្ធិបញ្ញា(TRIPS)។ ប្រទេសឧស្សាហកម្មភាគច្រើននិយមប្រើប្រាស់ច្បាប់ TRIPS ដោយសារតែច្បាប់ទាំងនេះខ្លាំងជាងការការពាររបស់អង្គការ WIPO ហើយអាចបន្ទូរបន្ទុយបានលុះត្រាតែសមាជិកអង្គការ WTO ទាំងអស់ព្រមព្រៀង។ ច្បាប់របស់អង្គការWIPO ទាមទារត្រឹមតែសំឡេងភាគច្រើនដាច់ខាតដើម្បីផ្លាស់ប្តូរ។

កិច្ចប្រជុំអង្គការWTO ឆ្នាំ ២០០១ នៅទៅក្រុងដូហា បានឈានទៅដល់ការប្រកាសថា រដ្ឋនានាអាចមានករណីលើកលែងពីច្បាប់TRIPS ក្នុងការប្រើប្រាស់ថ្នាំមួយចំនួន ដើម្បីដោះស្រាយវិបត្តិសុខភាពក្នុងស្រុកធ្ងន់ធ្ងរ ដូចជាការរីករាលដាលនៃវីរុសHIVនិងជំងឺអេដស៍ជាដើម។ (រដ្ឋាភិបាលសហរដ្ឋអាមេរិកក៏បានគាំទ្រវិធានការណ៍នេះ បន្ទាប់ពីវាបានគម្រាមដណ្តើមគ្រប់គ្រងការផលិតថ្នាំអង់ទីប៊ីយោទិចដ៏មានអានុភាព ឈ្មោះស៊ីប្រូ(Cipro)ក្នុងអំឡុងពេលផ្ទុះជំងឺអង់ត្រាក់(anthrax) ក្រោយព្រឹត្តិការណ៍ថ្ងៃទី ១១ ខែកញ្ញា។) ទោះបីជានីតិវិធីជាក់លាក់ត្រូវបានបង្កើតឡើង សម្រាប់ករណីលើកលែងទាំងនេះក៏ដោយ មានតែប្រទេសកំពុង

អភិវឌ្ឍន៍មួយចំនួនប៉ុណ្ណោះដែលបានប្រើប្រាស់វា។ អស់រយៈពេលជាច្រើនឆ្នាំ វិាទទាំងនេះបានពន្យឺតការចែកចាយថ្នាំដ៏មានប្រសិទ្ធភាពដល់ប្រជាជនអាហ្វ្រិករាប់លាននាក់ដែលផ្ទុកជំងឺអេដស៍ ទោះបីជាមានវឌ្ឍនភាពឡើងវិញ បន្ទាប់ពីឆ្នាំ ២០០៤ ក៏ដោយ។

ក្រុមហ៊ុនដែលព្យាយាមការពារកម្មសិទ្ធិបញ្ញា ក្នុងបរិបទអន្តរជាតិមិនអាចពឹងផ្អែកលើការអនុវត្តច្បាប់ដូចគ្នានឹងបរិបទក្នុងស្រុកនោះទេ។ ផ្ទុយទៅវិញ ពួកគេត្រូវនាំរដ្ឋាភិបាលរដ្ឋរបស់ខ្លួនមកទទួលបន្ទុក ព្រមទាំងប្រើប្រាស់ធនធានផ្ទាល់ខ្លួន។ ដោយសារតែអធិបតេយ្យភាពរបស់រដ្ឋក្នុងបញ្ហាផ្លូវច្បាប់ ជម្លោះសេដ្ឋកិច្ចអន្តរជាតិឯកជន ងាយនឹងក្លាយជាបញ្ហារវាងរដ្ឋាភិបាលនិងរដ្ឋាភិបាល។

បញ្ហាពាណិជ្ជកម្មសំខាន់ទីបួន គឺការបើកចំហប្រទេសទទួលពាណិជ្ជកម្មក្នុង**វិស័យសេវាកម្ម**(service section)នៃសេដ្ឋកិច្ច។ វិស័យនេះរួមបញ្ចូលសេវាកម្មជាច្រើន ជាពិសេសសេវាកម្មទាក់ទងនឹងព័ត៌មាន ប៉ុន្តែការផ្តោតជាសំខាន់ក្នុងការចរចាពាណិជ្ជកម្មអន្តរជាតិ គឺ វិស័យធនាគារ ការធានារ៉ាប់រង និងសេវាកម្មហិរញ្ញវត្ថុពាក់ព័ន្ធ។ ក្រុមហ៊ុនអាមេរិក និងក្រុមហ៊ុនមួយចំនួននៅអាស៊ីទទួលបានគុណសម្បត្តិធៀបនៅក្នុងផ្នែកទាំងនេះ ដោយសារបច្ចេកវិទ្យាដំណើរការព័ត៌មាននិងបទពិសោធន៍របស់ពួកគេក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ។ ជាទូទៅ ដោយសារទូរគមនាគមន៍មានតម្លៃកាន់តែថោក និងរីកចម្រើនកាន់តែទូលំទូលាយ សេវាកម្មដែលផ្តល់ដោយក្រុមហ៊ុននៅក្នុងប្រទេសមួយ អាចត្រូវបានប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព ដោយអ្នកប្រើប្រាស់នៅក្នុងប្រទេសដទៃទៀត។ អ្នកប្រើប្រាស់នៅសហរដ្ឋអាមេរិកលើកទូរស័ព្ទចុចទៅសេវាកម្មអតិថិជននៅក្រុមហ៊ុនអាមេរិក ហើយភ្ជាប់ទៅកាន់ប្រទេសឥណ្ឌា ឬប្រទេសកំពុងអភិវឌ្ឍន៍ដែលនិយាយភាសាអង់គ្លេសផ្សេងទៀតចូលរួមក្នុងពាណិជ្ជកម្មសេវាកម្ម ពីចម្ងាយ។

ឧស្សាហកម្មដ៏សំខាន់ជាពិសេសមួយទៀត នៅក្នុងពាណិជ្ជកម្មអន្តរជាតិ គឺ ពាណិជ្ជកម្មឬជំនួញអាវុធដែលប្រតិបត្តិការភាគច្រើននៅក្រៅក្របខ័ណ្ឌនៃប្រតិបត្តិការពាណិជ្ជកម្មធម្មតា ដោយសារតែឥទ្ធិពលរបស់វាលើសន្តិសុខជាតិ។ រដ្ឋាភិបាលនៅក្នុងប្រទេសឧស្សាហកម្មរីកចម្រើនចង់ការពារឧស្សាហកម្មអាវុធក្នុងស្រុករបស់ខ្លួន ជាជាងពឹងផ្អែកលើការនាំចូល ដើម្បីបំពេញតម្រូវការផ្នែកអាវុធរបស់ពួកគេ។ ហើយឧស្សាហកម្មសព្វាវុធក្នុងស្រុកទាំងនោះមានកម្លាំងកាន់តែរឹងមាំនិងមានប្រសិទ្ធភាពផ្នែកសេដ្ឋកិច្ច តាមរយៈការនាំចេញផលិតផលរបស់ពួកគេ (ក៏ដូចជាការផ្តត់ផ្គង់ដល់រដ្ឋាភិបាលរបស់ពួកគេផ្ទាល់)។ រដ្ឋាភិបាលជាធម្មតាចូលរួមយ៉ាងសកម្ម នៅក្នុងវិស័យឧស្សាហកម្មយោធាសម្រាប់សេដ្ឋកិច្ច សូម្បីតែនៅក្នុងប្រទេសនានា ដូចជាសហរដ្ឋអាមេរិកដែលខ្វះខាតគោលនយោបាយឧស្សាហកម្មក្នុងវិស័យសេដ្ឋកិច្ចផ្សេងទៀតក៏ដោយ។ ជាឧទាហរណ៍ យន្តហោះចម្បាំងគឺជាផលិតផល ដែលសហរដ្ឋអាមេរិកទទួលបានគុណសម្បត្តិធៀបជាសកល។ នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ ឧស្សាហកម្មអាវុធរបស់សហរដ្ឋអាមេរិក ក៏ដូចជាឧស្សាហកម្មថ្នាំជក់ដែរ សម្លឹងមើលទៅក្រៅប្រទេសដើម្បីស្វែងរកអតិថិជនថ្មី ដើម្បីទូទាត់តម្រូវការធ្លាក់ចុះ នៅក្នុងស្រុក។ មជ្ឈិមបូព៌ាគឺជាតំបន់នាំចូលអាវុធឈានមុខគេនៃអឡ្ឌ្រាគោលខាងត្បូង ជាមួយនឹងប្រទេសឥណ្ឌា និងចិនបានកើន នាពេលថ្មីៗនេះ។

បញ្ហាមួយផ្សេងទៀតបានលេចឡើង នៅក្នុង«ឧស្សាហកម្ម»នៃពាណិជ្ជកម្មខុសច្បាប់ ឬ*ការរត់ពន្ធ* (smuggling)។ មិនថារដ្ឋាភិបាលដាក់កំហិតលើការជួញដូរទំនិញអ្វីនោះទេ ជាធម្មតាតែងមានអ្នកដែលមានឆន្ទៈប្រថុយនឹងទណ្ឌកម្មដើម្បីរិះរកប្រាក់ចំណេញក្នុងពាណិជ្ជកម្មបែបនេះ។ ទំនិញខុសច្បាប់ និងទំនិញស្របច្បាប់ ដែលត្រូវនាំចូលដោយខុសច្បាប់ ជារឿយៗ ត្រូវបានលក់ក្នុងទីផ្សារងងឹត ដែលជាទីផ្សារក្រៅផ្លូវការ

ជួនកាលសម្ងាត់។ វាបង្អាក់លំហូរប្រាក់ចំណូលសំខាន់ៗសម្រាប់រដ្ឋាភិបាលជាតិ។ ទីផ្សារងងឹតក៏មានសម្រាប់ការផ្លាស់ប្តូររូបិយប័ណ្ណបរទេសផងដែរ (សូមមើលមេរៀនទី ៩)។

វិសាលភាពនៃពាណិជ្ជកម្មខុសច្បាប់ប្រែប្រួលពីប្រទេសនិងឧស្សាហកម្មមួយ ទៅប្រទេសមួយទៀត ដោយអាស្រ័យលើកម្រិតប្រាក់ចំណេញនិងការអនុវត្ត។ គ្រឿងញៀន និងអាវុធផ្តល់ប្រាក់ចំណេញច្រើនបំផុត ហើយបណ្តាញពាណិជ្ជកម្មខុសច្បាប់ទូទាំងពិភពលោកមានអត្ថិភាពសម្រាប់ទំនិញទាំងពីរមុខនេះ។ ទីផ្សារងងឹតអន្តរជាតិសម្រាប់ការជួញដូរអាវុធ ហួសពីវិសាលភាពគ្រប់គ្រងរបស់រដ្ឋាភិបាល មានភាពល្បីល្បាញជាងគេ។ រដ្ឋដែលមានលុយច្រើនគ្រប់គ្រាន់អាចទិញបានអាវុធភាគច្រើន ទោះបីជាក្នុងតម្លៃពិសេសក៏ដោយ។

៨.២.៥. ការអនុវត្តច្បាប់ពាណិជ្ជកម្ម

ដូចជាមួយនឹងច្បាប់អន្តរជាតិជាទូទៅដែរ កិច្ចព្រមព្រៀងសេដ្ឋកិច្ចក្នុងចំណោមរដ្ឋនានាអាស្រ័យយ៉ាងខ្លាំងទៅលើគោលការណ៍បដិការ ដើម្បីពង្រឹងការអនុវត្ត (សូមមើលមេរៀនទី ៧)។ ប្រសិនបើរដ្ឋណាមួយការពារឧស្សាហកម្មរបស់ខ្លួន ឬ ជាក់ពន្ធគយលើទំនិញនាំចូលពីរដ្ឋផ្សេងទៀត ឬ រំលោភបំពានលើការរក្សាសិទ្ធិលើការងារឬផលិតផល ដែលផលិតនៅក្នុងប្រទេសផ្សេងទៀត មធ្យោបាយដ៏សំខាន់ដែលរដ្ឋផ្សេងទៀតអាចប្រើបាន គឺត្រូវអនុវត្តវិធានការណ៍ស្រដៀងគ្នាប្រឆាំងនឹងរដ្ឋល្មើស។ ការប្រើប្រាស់គោលការណ៍បដិការដើម្បីអនុវត្តលក្ខខណ្ឌស្មើគ្នាសម្រាប់ការដោះដូរមានសារៈសំខាន់ជាពិសេសនៅក្នុងពាណិជ្ជកម្មអន្តរជាតិ ដែលរដ្ឋនានាជារឿយៗចរចារកិច្ចព្រមព្រៀងដ៏ស្មុគស្មាញ៖ ទំនិញមួយមុខម្តងៗ ឧស្សាហកម្មម្តងមួយៗ ដោយផ្អែកលើគោលការណ៍បដិការ។ ជម្លោះពាណិជ្ជកម្មនិងវិធានការណ៍សងសឹកគឺជារឿងធម្មតា។ រដ្ឋរក្សាការតាមដានយ៉ាងជិតស្និទ្ធលើលក្ខខណ្ឌពាណិជ្ជកម្មជាក់ស្តែង។ ក្រុមការិយាធិបតេយ្យធំៗត្រួតពិនិត្យប្រតិបត្តិការសេដ្ឋកិច្ចអន្តរជាតិ (តម្លៃធៀបនឹងកម្រិតទីផ្សារពិភពលោក ពន្ធគយ ។ល។) និងអភិវឌ្ឍគោលនយោបាយលម្អិតដើម្បីឆ្លើយតបការជាក់ស្តែង ទៅនឹងទង្វើរបស់រដ្ឋផ្សេងទៀតដែលឃ្លាតចេញពីកិច្ចសហប្រតិបត្តិការ។

ការអនុវត្តលក្ខខណ្ឌពាណិជ្ជកម្មស្មើគ្នាត្រូវស្មុគស្មាញ ដោយសារការបកស្រាយខុសៗគ្នាអំពីអ្វីដែលគេហៅថា «យុត្តិធម៌»។ រដ្ឋជាទូទៅសម្រេចចិត្តថាតើការអនុវត្តណាមួយដោយរដ្ឋផ្សេង ដែលពួកគេចាត់ទុកថា អយុត្តិធម៌ (ជារឿយៗត្រូវបានជម្រុញដោយឧស្សាហកម្មក្នុងស្រុក ដែលរងផលប៉ះពាល់) ហើយបន្ទាប់មកចាត់(ឬគំរាមចាត់)វិធានការណ៍សងសឹក ដើម្បីជាក់ទណ្ឌកម្មការអនុវត្តទាំងនោះ។ កម្រងច្បាប់របស់សហរដ្ឋអាមេរិកមួយ ដែលគេហៅថា បទប្បញ្ញត្តិSuper៣០១ អនុញ្ញាតអោយមានការសងសឹកប្រឆាំងនឹងរដ្ឋដែលរឹតបន្តឹងលំហូរទំនិញរបស់សហរដ្ឋអាមេរិកទៅកាន់ទីផ្សាររបស់ពួកគេ។ ប្រសិនបើរដ្ឋផ្សេងទៀតនោះមិនយល់ស្របថា ការអនុវត្តរបស់ខ្លួនមិនយុត្តិធម៌ទេ យ៉ាងណាក៏ដោយ សកម្មភាពសងសឹកផ្ទាល់អាចនឹង មើលទៅអយុត្តិធម៌ ហើយអំពាវនាវអោយមានការសងសឹក។ គុណវិបត្តិមួយនៃគោលការណ៍បដិការ គឺថា វាអាចនាំទៅរកការមិនសហការទៅវិញទៅមកកាន់តែខ្លាំងឡើងៗ ដែលគេនិយមហៅថា សង្គ្រាមពាណិជ្ជកម្ម (ប្រៀបប្រដូចទៅនឹងការប្រណាំងអាវុធ គ្រាន់តែផ្តោតលើសេដ្ឋកិច្ច សូមមើលមេរៀនទី ២)។ ដើម្បីទប់ស្កាត់បញ្ហានេះ រដ្ឋនានាតែងតែចរចាកិច្ចព្រមព្រៀង ថាតើការអនុវត្តអ្វីខ្លះដែលពួកគេចាត់ទុកថា អយុត្តិធម៌។ ក្នុងករណីខ្លះមជ្ឈត្តកម្មភាគីទីបី ក៏អាចត្រូវបានប្រើផងដែរ ដើម្បីដោះស្រាយវិវាទពាណិជ្ជកម្មផងដែរ។ បច្ចុប្បន្ននេះ អង្គការពាណិជ្ជកម្មពិភពលោក បើកសវនាការលើបណ្តឹងតវ៉ា និងកំណត់កម្រិតនៃការសងសឹកប៉ុណ្ណា ដែលអាច

ទទួលយកបាន។ កិច្ចព្រមព្រៀងពាណិជ្ជកម្មក្នុងតំបន់មួយចំនួនក៏បង្កើតយន្តការដើម្បី បើកសវនាការនិង ដោះស្រាយពាក្យបណ្តឹងផងដែរ។

ការសងសឹកចំពោះការអនុវត្តពាណិជ្ជកម្មដោយអយុត្តិធម៌ ជាធម្មតា ត្រូវព្យាយាមផ្គូផ្គងប្រភេទនិង វិសាលភាពនៃការរំលោភបំពាន តាមដាក់ស្តែង។ នៅក្រោមច្បាប់របស់អង្គការ WTO រដ្ឋមួយអាចដាក់ពន្ធគយ សងសឹកដែលស្មើនឹងការខាតបង់ ដែលបណ្តាលមកពីការអនុវត្តពាណិជ្ជកម្មមិនយុត្តិធម៌របស់រដ្ឋមួយផ្សេង ទៀត (ដូចដែលបានកំណត់ដោយសវនាការរបស់អង្គការWTO)។ ប៉ុន្តែ វិធានការណ៍សងសឹកមិនចាំបាច់ត្រូវ តែស្ថិតនៅក្នុងវិស័យដដែលនោះទេ។ ជាឧទាហរណ៍ ក្នុងឆ្នាំ ២០១៣ រដ្ឋដែនកោះ អង់ទីហ្គានិងបារប៊ូដា (Antigua & Barbuda)បានទទួលការអនុញ្ញាតអោយដាក់ទណ្ឌកម្មសហរដ្ឋអាមេរិកចំពោះការបិទរបៀបសាយ លេងល្បែងអនឡាញរបស់ពួកគេ ដែលបណ្តាលអោយប្រទេសការីបៀបតូចមួយខាតបង់ប្រាក់អស់ ២១ លានដុល្លារ ក្នុងមួយឆ្នាំៗ។ (ដោយសារតែទម្រង់លេងល្បែងផ្សេងៗ ប្រព្រឹត្តិតោយ៉ាងទូលំទូលាយក្នុងស្រុក ខ្លួនរួចហើយ រដ្ឋាភិបាលសហរដ្ឋអាមេរិកបានបរាជ័យក្នុងការបង្ហាញថា ហេតុអ្វីបានជាពលរដ្ឋរបស់ខ្លួនគួរតែ ទទួលបានការពារពីការលេងល្បែង«នាំចូល»តាមអ៊ីនធឺណិត។) អង្គការWTO បាននិយាយថា អង់ទីហ្គានិង បារប៊ូ អាចលួច ២១ លានដុល្លារអាមេរិក ជារៀងរាល់ឆ្នាំ ពីកម្មសិទ្ធិបញ្ញារបស់សហរដ្ឋអាមេរិក ជាឧទាហរណ៍ ពួកគេចាក់ផ្សាយភាពយន្ត និងកម្មវិធីទូរទស្សន៍តាមអ៊ីនធឺណិតដោយមិនបង់ប្រាក់សម្រាប់ការរក្សាសិទ្ធិរបស់ សហរដ្ឋអាមេរិកនោះទេ។

ក្នុងករណីនៃការលក់បង្ខូចតម្លៃ ការសងសឹកមានគោលបំណងប៉ះប៉ូវអត្ថប្រយោជន៍ដែលទទួលបាន ពីទំនិញដែលនាំចូលក្នុងតម្លៃទាបជាងទីផ្សារពិភពលោក។ ពន្ធគយសងសឹកតម្លើងតម្លៃខ្ពស់ដល់កម្រិតទីផ្សារ ដើមវិញ។ ក្នុងឆ្នាំ ២០០១ ឧស្សាហកម្មដែកថែបរបស់សហរដ្ឋអាមេរិកដែលចុះខ្សោយបានអង្វរសុំការការពារ ពីរដ្ឋាភិបាលសហរដ្ឋអាមេរិក ពីដែកថែបបរទេសដែលមានតំលៃថោក ក្រោមហេតុផលប្រឆាំងនឹងការលក់ បង្ខូចថ្លៃ។ មុនពេលដំឡើងពន្ធគយបែបនេះ ទីភ្នាក់ងាររដ្ឋាភិបាលសហរដ្ឋអាមេរិក គណៈកម្មការពាណិជ្ជកម្ម អន្តរជាតិ (ITC) សម្រេចជាមុនសិនថា តើទំនិញនាំចូលតម្លៃទាបពិតជាធ្វើអោយប៉ះពាល់ដល់ឧស្សាហកម្ម អាមេរិកដែរឬយ៉ាងណា។ គណៈកម្មការ ITC បានសម្រេចថា ក្រុមហ៊ុនផលិតដែកថែបរបស់សហរដ្ឋអាមេរិក ពិតជាបានរងផលប៉ះពាល់ ហើយរដ្ឋាភិបាលសហរដ្ឋអាមេរិកបានដាក់ពន្ធគយ ប្រមាណ ៣០ ភាគរយ ក្នុងឆ្នាំ ២០០២។ ប៉ុន្តែ អង្គការ WTO បានចេញសាលក្រមប្រឆាំងនឹងសហរដ្ឋអាមេរិក ក្នុងឆ្នាំ ២០០៣ ហើយបាន ផ្តល់អោយប្រទេសផ្សេង នូវសិទ្ធិក្នុងការយកពន្ធគយសងសឹក ចំនួន ២ ពាន់លានដុល្លារ។ នៅពេលដែល ប្រជាជាតិអឺរ៉ុបបានរៀបចំបញ្ជីពន្ធគយរបស់ពួកគេ ដោយកំណត់គោលដៅបង្កការខូចខាតជាអតិបរមាចំពោះ បណ្តារដ្ឋបោះឆ្នោតមិនទៀង ក្នុងឆ្នាំ ២០០៤ ប្រធានាធិបតីប៊ូស បានថយក្រោយមួយជំហាននិងលុបចោល ពន្ធគយលើដែកថែប (ដោយប្រកាសថាពួកគេបានសម្រេចគោលដៅ និងលែងត្រូវការទៀតហើយ)។ តាម រយៈការធ្វើអោយការចំណាយលើពន្ធគយខ្ពស់ជាងផលចំណេញ អង្គការពាណិជ្ជកម្មពិភពលោកបានផ្លាស់ប្តូរ គោលនយោបាយរបស់សហរដ្ឋអាមេរិកប្រកបដោយប្រសិទ្ធភាព ដែលជាការបង្ហាញពីអំណាចដែលកំពុង កើនឡើងរបស់អង្គការWTO។ ឧទាហរណ៍នេះក៏បង្ហាញផងដែរពីរបៀបដែលពាណិជ្ជកម្មអន្តរជាតិភ្ជាប់ទំនាក់ ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងនយោបាយក្នុងស្រុក។

កិច្ចសហប្រតិបត្តិការពាណិជ្ជកម្មមានភាពងាយស្រួលជាងក្នុងការសម្រេចបាន នៅក្រោមអនុត្តរភាព (សូមមើល **អនុត្តរភាព** ក្នុងមេរៀនទី ២)។ ប្រតិបត្តិការទីផ្សារប្រកបដោយប្រសិទ្ធភាព ត្រូវអាស្រ័យទៅលើក្របខ័ណ្ឌនយោបាយដែលមានស្ថិរភាព ដូចដែលអនុត្តរភាពអាចផ្តល់អោយ។ អំណាចនយោបាយអាចការពារការដោះដូរសេដ្ឋកិច្ច ពីឥទ្ធិពលនៃអានុភាពហិង្សា ការអនុវត្តពាណិជ្ជកម្មអយុត្តិធម៌ ឬ ការក្លែងបន្លំ និងភាពមិនច្បាស់លាស់នៃអត្រាប្តូរប័ណ្ណអន្តរជាតិ។ ប្រទេសអនុត្តរភាពមួយអាចផ្តល់រូបិយប័ណ្ណពិភពលោកដែលតម្លៃអាចត្រូវបានគណនាជាសកល។ វាអាចដាក់ទណ្ឌកម្មលើការប្រើប្រាស់អំពើហិង្សានិងអាចអនុវត្តបទដ្ឋាននៃពាណិជ្ជកម្មដោយយុត្តិធម៌។ ដោយសារតែសេដ្ឋកិច្ចរបស់វាមានទំហំធំ និងគ្របដណ្តប់ខ្លាំងក្លា ប ប្រទេសអនុត្តរភាពនោះអាចគម្រាមផ្តាច់ទំនាក់ទំនងពាណិជ្ជកម្ម ដោយមិនចាំបាច់ប្រើប្រាស់កម្លាំងយោធាក៏ដោយ។ ជាឧទាហរណ៍ ប្រសិនបើត្រូវរាំងខ្ទប់មិនអោយ ចូលទៅកាន់ទីផ្សារសហរដ្ឋអាមេរិក នាពេលបច្ចុប្បន្ននេះ នឹងធ្វើអោយប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ឧស្សាហកម្មនាំចេញនៅក្នុងរដ្ឋជាច្រើន។ ដូច្នេះ អនុត្តរភាពរបស់សហរដ្ឋអាមេរិកបានជួយបង្កើតបទដ្ឋាននិងស្ថាប័នសំខាន់ៗនៃពាណិជ្ជកម្មអន្តរជាតិ នៅសម័យក្រោយឆ្នាំ ១៩៤៥។ បច្ចុប្បន្ននេះ អនុត្តរភាពរបស់សហរដ្ឋអាមេរិកហាក់ដូចជាកំពុងបើកផ្លូវសម្រាប់ពិភពលោកពហុប៉ូលកាន់តែខ្លាំងឡើងៗ (ជាពិសេសនៅក្នុងកិច្ចការសេដ្ឋកិច្ច ក្នុងចំណោមប្រទេសមហាអំណាច) ស្ថាប័ននានាកាន់តែមានសារៈសំខាន់ខ្លាំងសម្រាប់ភាពជោគជ័យនៃប្រព័ន្ធពាណិជ្ជកម្មពិភពលោក។

រដ្ឋនានាបានរកឃើញនិងយល់ពីតម្លៃក្នុងការពង្រីកពាណិជ្ជកម្មជាលំដាប់ ដោយប្រើប្រាស់របបនិងស្ថាប័នជាច្រើន ដើម្បីធ្វើការងារទាំងនេះ ដូចជា អង្គការWTO តំបន់ពាណិជ្ជកម្មសេរី កិច្ចព្រមព្រៀងទ្វេភាគីនិងក្រុមការតែល។ សរុបមក ទោះបីជាត្រូវបាត់បង់អធិបតេយ្យភាពរដ្ឋបន្តិចដោយសារតែកំណើននៃការពឹងអាស្រ័យគ្នាទៅវិញទៅមកក៏ដោយ កិច្ចខិតខំប្រឹងប្រែងទាំងនេះបានផ្តល់ផលប្រយោជន៍ដល់រដ្ឋទាំងឡាយដែលចូលរួម។ ច្បាប់នយោបាយស្ថិរភាពសម្រាប់គ្រប់គ្រងពាណិជ្ជកម្មអនុញ្ញាតអោយរដ្ឋនានាសម្រេចបាននូវផលចំណេញសេដ្ឋកិច្ចដ៏មហិមា ដែលអាចបានមកពីការដោះដូរ(សេដ្ឋកិច្ច)អន្តរជាតិ។

៨.៣. សាកលភាវូបនីយកម្មសេដ្ឋកិច្ច

៨.៣ ចូររៀបរាប់យ៉ាងហោចណាស់មធ្យោបាយពីរយ៉ាង ដែលប្រទេសមួយ ឬ ពលរដ្ឋណាមួយបាន និងកំពុងប្រឆាំងនឹងពាណិជ្ជកម្មពិភពលោក។

យើងបានណែនាំដំណើរការនៃសកលភាវូបនីយកម្ម នៅក្នុងមេរៀនទី ១ ជាលក្ខណៈទូទៅរួចហើយហើយឥឡូវនេះនឹងពិចារណាលើទិដ្ឋភាពសេដ្ឋកិច្ចយ៉ាងពិសេសនៃសកលភាវូបនីយកម្មបន្ថែមទៀត។ ការពង្រីកពាណិជ្ជកម្មគឺជាទិដ្ឋភាពចំបង់នៃសាកលភាវូបនីយកម្ម នៅក្នុងសេដ្ឋកិច្ចនយោបាយអន្តរជាតិ ប៉ុន្តែ វាមិនមែនជាទិដ្ឋភាពតែមួយគត់នោះទេ។ សកលភាវូបនីយកម្មមិនត្រឹមតែផ្លាស់ប្តូរពាណិជ្ជកម្មប៉ុណ្ណោះទេ តែថែមទាំងប្រាក់កាក់ អាជីវកម្ម សមាហរណកម្ម ទំនាក់ទំនង ការគ្រប់គ្រងបរិស្ថាន និងការអភិវឌ្ឍន៍សេដ្ឋកិច្ចនៃបណ្តាប្រទេសក្រីក្រ ដែលជាប្រធានបទនៃមេរៀនជាបន្តបន្ទាប់ ដែលនៅសល់ក្នុងសៀវភៅនេះ។ ការបង្កើនល្បឿននៃសកម្មភាពសេដ្ឋកិច្ចនាពេលបច្ចុប្បន្ននេះវិវត្តន៍ចេញពីប្រវត្តិសាស្ត្រនៃការពង្រីកសេដ្ឋកិច្ចពិភពលោកដ៏យូរអង្វែង ដែលបម្រើជាមូលដ្ឋានគ្រឹះសម្រាប់សកលភាវូបនីយកម្ម។

៨.៣.១. សេដ្ឋកិច្ចពិភពលោកកំពុងវិវត្តន៍

នៅឆ្នាំ ១៧៥០ ចក្រភពអង់គ្លេស ដែលមានសេដ្ឋកិច្ចជឿនលឿនបំផុតរបស់ពិភពលោក មានផលិតផលក្នុងស្រុកសរុប(GDP) ប្រហែល $១២០០ សម្រាប់មនុស្សម្នាក់ (គិតជាដុល្លារនាពេលបច្ចុប្បន្ន)។ ទំហំនោះ តិចជាងកម្រិតបច្ចុប្បន្ននៃអឆ្ឃគោលខាងត្បូង។ ទោះជាយ៉ាងណាក៏ដោយ សព្វថ្ងៃនេះ ចក្រភពអង់គ្លេសផលិតបានច្រើនជាងដប់ដង សម្រាប់មនុស្សម្នាក់ (និងមានចំនួនប្រជាជនច្រើនជាងឆ្នាំ១៧៥០)។ សមិទ្ធិផលទាំងនេះ សុទ្ធសឹងសម្រេចបានដោយសារតែឧស្សាហូបនីយកម្ម ដែលសំដៅលើការប្រើប្រាស់ថាមពល ដើម្បីដំណើរការគ្រឿងម៉ាស៊ីន និងការប្រមូលផ្តុំគ្រឿងចក្របែបនេះ រួមជាមួយនឹងផលិតផលដែលវាបានបង្កើតឡើង។ បដិវត្តន៍ឧស្សាហកម្មបានចាប់ផ្តើមដំបូង នៅចក្រភពអង់គ្លេសក្នុងសតវត្សរ៍ទី ១៨ ដោយបានគាំទ្រតួនាទីដឹកនាំកំពុងរះឡើងរបស់ចក្រភពអង់គ្លេសនៅក្នុងសេដ្ឋកិច្ចពិភពលោក ហើយបានរីករាលដាលទៅកាន់ប្រទេសដែលមានសេដ្ឋកិច្ចជឿនលឿនផ្សេងទៀត (សូមមើល ក្រាហ្វិក ៨.៥ នៅទំព័របន្ទាប់)។

នៅប្រហែលឆ្នាំ ១៨៥០ សំពៅឈើធំៗកាលពីសតវត្សរ៍មុនៗបានបើកផ្លូវអោយកប៉ាល់ដែកដំណើរការដោយចំហាយទឹក ដុតដោយថាមពលធ្យូងថ្ម ធំជាងនិងលឿនជាងមុន។ ម៉ាស៊ីន ដំណើរការដោយចំហាយទឹក ដែលប្រើធ្យូងថ្ម ក៏បានជំរុញដំណើរការរោងចក្រផលិតវាយនកណ្ដា និងទំនិញផ្សេងៗទៀតផងដែរ។ យុគសម័យដ៏រុងរឿងនៃការសាងសង់ផ្លូវដែកកំពុងហក់ឡើង។ ការអភិវឌ្ឍន៍ទាំងនេះមិនត្រឹមតែបង្កើនបរិមាណផលិតកម្ម និងពាណិជ្ជកម្មពិភពលោកប៉ុណ្ណោះនោះទេ តែថែមទាំងបានភ្ជាប់ទីតាំងឆ្ងាយៗ អោយកាន់តែខិតជិតគ្នា ជាលក្ខណៈសេដ្ឋកិច្ចផងដែរ។ ការធ្វើដំណើរមួយថ្ងៃឆ្លងទៅប្រទេសបារាំងដោយផ្លូវដែក ខុសពីកាលពី ១០០ ឆ្នាំមុន លើផ្លូវដូចគ្នា ដែលចំណាយពេលរហូតដល់បីសប្តាហ៍ឯណោះ។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងសម័យធ្វើមេកានិចបែបនេះ លក្ខខណ្ឌការងាររោងចក្រមានភាពលំបាកខ្លាំង ជាពិសេស សម្រាប់ស្ត្រី និងកុមារដែលធ្វើដំណើរការគ្រឿងម៉ាស៊ីន។

ចក្រភពអង់គ្លេសបានគ្រប់គ្រងពាណិជ្ជកម្មពិភពលោក នៅក្នុងសម័យកាលនោះ។ ដោយសារតែសេដ្ឋកិច្ចរបស់ចក្រភពអង់គ្លេសមានភាពជឿនលឿនខាងបច្ចេកវិទ្យាខ្លាំងបំផុតនៅក្នុងពិភពលោក ផលិតផលរបស់វាមានលក្ខណៈប្រកួតប្រជែង នៅទូទាំងពិភពលោក។ ដូច្នេះ គោលនយោបាយរបស់ចក្រភពអង់គ្លេសបានអនុគ្រោះដល់ពាណិជ្ជកម្មសេរី។ បន្ថែមពីលើតួនាទីដ៏សំខាន់របស់ខ្លួននៅក្នុងពាណិជ្ជកម្មពិភពលោក អង់គ្លេសបានបំពេញមុខងារជារដ្ឋធានីហិរញ្ញវត្ថុរបស់ពិភពលោក ដោយគ្រប់គ្រងទីផ្សារទំនិញនិងសេវាកម្មពិភពលោកកាន់តែស្មុគស្មាញ នៅក្នុងសតវត្សរ៍ទី ១៩។ រូបិយប័ណ្ណអង់គ្លេស ផោន (កាក់ប្រាក់) បានក្លាយជាប្រាក់ស្តង់ដារពិភពលោក។ ទំនាក់ទំនងរូបិយវត្ថុអន្តរជាតិនៅតែផ្អែកលើតម្លៃនៃលោហៈធាតុដ៏មានតម្លៃ ដូចកំឡុងសតវត្សរ៍ទី ១៦ នៅពេលដែលប្រទេសអេស្ប៉ាញបានទិញកងទ័ពរបស់ខ្លួន ដោយប្រើប្រាស់ប្រាក់ និងមាសរបស់ម៉ិកស៊ិក។

ក្រាហ្វិក ៨.៥ សេដ្ឋកិច្ចពិភពលោក ១៧៥០-២០០០

ប្រភព៖ ផ្អែកលើ North, Douglass C. និង Robert Paul Thomas ។ ការរះឡើងនៃបស្ចឹមលោក៖ ប្រវត្តិសេដ្ឋកិច្ចថ្មី។ Cambridge, ១៩៧៣. Hobsbawm, E. J. Industry and Empire: ពីឆ្នាំ ១៧៥០ ដល់បច្ចុប្បន្ន។ Penguin-Pelican, ១៩៦៩. Tracy, James D., ed. សេដ្ឋកិច្ចនយោបាយនៃចក្រភពពាណិជ្ជករ៖ អំណាចរដ្ឋនិងពាណិជ្ជកម្មពិភពលោក ឆ្នាំ១៣៥០-១៧៥០។ Cambridge ឆ្នាំ ១៩៩១។

ទោះបីជាយ៉ាងណាក៏ដោយ នៅដើមសតវត្សទី ២០ សេដ្ឋកិច្ចដ៏ធំបំផុត និងជឿនលឿនបំផុតរបស់ពិភពលោកមិនមែនជាប្រទេសអង់គ្លេសទៀតទេ ប៉ុន្តែជាសហរដ្ឋអាមេរិក។ ឧស្សាហូបនីយកម្មនៃសេដ្ឋកិច្ច

របស់សហរដ្ឋអាមេរិកត្រូវបានជំរុញដោយការពង្រីកទឹកដី ពេញមួយសតវត្សរ៍ទី ១៩ ដោយបន្ថែមធនធានធម្មជាតិដ៏ច្រើនសន្ធឹកសន្ធាប់។ សេដ្ឋកិច្ចអាមេរិកបានទាក់ទាញពលករអន្តោប្រវេសន៍យ៉ាងច្រើនសម្បើមមកពីអឺរ៉ុបផងដែរ។ សហរដ្ឋអាមេរិកបានដឹកនាំពិភពលោក ក្នុងការបំប្លែងពីធ្យូងថ្មទៅជាប្រេង និងពីប្រព័ន្ធដឹកជញ្ជូនអូសទាញដោយសត្វសេះទៅជាយានយន្ត។ ការច្នៃប្រឌិតបច្ចេកទេសថ្មី ចាប់ពីអគ្គិសនីរហូតដល់យន្តហោះក៏បានជួយជំរុញសេដ្ឋកិច្ចរបស់សហរដ្ឋអាមេរិកអោយក្លាយជាប្រទេសលេចធ្លោជាងគេ នៅលើពិភពលោកផងដែរ។

នៅទសវត្សរ៍ឆ្នាំ ១៩៣០ សេដ្ឋកិច្ចសហរដ្ឋអាមេរិកនិងពិភពលោកទាំងមូលបានធ្លាក់ចុះយ៉ាងគំហុកនៅក្នុងមហាវិបត្តិសេដ្ឋកិច្ច។ ច្បាប់ពន្ធគយ ដែលដាក់ឈ្មោះតាមអ្នកគាំពារនិយមម្នាក់ ឈ្មោះ ស្មូត-ហ័រលី (Smoot-Hawley) ដែលបានអនុម័តដោយសហរដ្ឋអាមេរិក ក្នុងឆ្នាំ ១៩៣០ ដែលយកពន្ធគយលើទំនិញនាំចូល បានរួមចំណែកធ្វើអោយមហាវិបត្តិសេដ្ឋកិច្ចកាន់តែធ្ងន់ធ្ងរ ដោយការញុះញង់អោយមានការសងសឹក និងកាត់បន្ថយលំហូរពាណិជ្ជកម្មពិភពលោក។ ដោយប្រកាន់យកគោលការណ៍នៃ*សេដ្ឋកិច្ចរបប*Keynesian រដ្ឋាភិបាលសហរដ្ឋអាមេរិកបានប្រើប្រាស់ខ្ជង់ចំណាយឱនភាពដើម្បីជំរុញសេដ្ឋកិច្ច ដោយបានទូទាត់អោយខ្លួនវិញ ពីទ្រព្យសម្បត្តិថ្មី ដែលបង្កើតឡើងដោយការស្តារសេដ្ឋកិច្ចឡើងវិញ។ តួនាទីរបស់រដ្ឋាភិបាលក្នុងសេដ្ឋកិច្ចកាន់តែខ្លាំងក្លា កំឡុងសង្គ្រាមលោកលើកទីពីរ។

ក្រោយសង្គ្រាមលោកលើកទី ២ សេដ្ឋកិច្ចពិភពលោកទម្រង់មូលធននិយមត្រូវបានរៀបចំឡើងវិញក្រោមការដឹកនាំរបស់សហរដ្ឋអាមេរិក។ ស្ថាប័នសេដ្ឋកិច្ចអន្តរជាតិនានា នាពេលបច្ចុប្បន្ននេះ ដូចជា ធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ចាប់កំណើតតាំងពីអំឡុងពេលនោះមក។ សហរដ្ឋអាមេរិកបានផ្តល់ជំនួយយ៉ាងច្រើនអនេក ដើម្បីស្តារសេដ្ឋកិច្ចអឺរ៉ុបខាងលិច (តាមរយៈផែនការម៉ាសាល) ក៏ដូចជាសេដ្ឋកិច្ចរបស់ប្រទេសជប៉ុនផងដែរ។ ពាណិជ្ជកម្មពិភពលោកបានពង្រីកយ៉ាងខ្លាំង ហើយទីផ្សារពិភពលោកបានផ្សារភ្ជាប់គ្នាកាន់តែស្អិតរមួត តាមរយៈការដឹកជញ្ជូនតាមផ្លូវអាកាស និងទូរគមនាគមន៍។ អេឡិចត្រូនិកបានលេចចេញជាវិស័យឈានមុខគេថ្មីមួយ ហើយវឌ្ឍនភាពបច្ចេកវិទ្យាត្រូវបានពន្លឿន ពេញមួយសតវត្សរ៍ទី ២០។

ដោយនៅឃ្លាតឆ្ងាយពីសេដ្ឋកិច្ចមូលធននិយមពិភពលោកនេះ សេដ្ឋកិច្ចនៃសហភាពសូវៀត និងអឺរ៉ុបខាងកើតបានដើរតាមគោលការណ៍នៃការធ្វើផែនការកណ្តាលនិងកម្មសិទ្ធិរបស់រដ្ឋរបស់ជនកុម្មុយនីស្ត៍។ នៅក្នុង**សេដ្ឋកិច្ចផែនការកណ្តាល** (centrally planned economy) ឬ *សេដ្ឋកិច្ចបង្គាប់បញ្ជា* (command economy) អាជ្ញាធរនយោបាយជាអ្នកកំណត់តម្លៃនិងសម្រេចចិត្តលើកូតាសម្រាប់ផលិតកម្ម និងកំណត់ការប្រើប្រាស់ទំនិញនីមួយៗ តាមផែនការរយៈពេលវែងឆ្ងាយ ហើយពាណិជ្ជកម្មអន្តរជាតិប្រព្រឹត្តិទៅក្នុងតម្លៃដែលគ្រប់គ្រងដោយរដ្ឋាភិបាល។ អ្នកគាំទ្រការធ្វើផែនការកណ្តាលបានអះអាងថា វានឹងធ្វើអោយសេដ្ឋកិច្ចកាន់តែមានលក្ខណៈសមហេតុផលនិងយុត្តិធម៌ជាង។ តាមរយៈការគ្រប់គ្រងសេដ្ឋកិច្ច រដ្ឋាភិបាលអាចធានានូវតម្រូវការជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ និងអាចប្រមូលកៀងគរកងកម្លាំងពេញលេញរបស់រដ្ឋ សម្រាប់បុព្វហេតុសង្គ្រាម ប្រសិនបើចាំបាច់។ អ្នកគាំទ្រការធ្វើផែនការកណ្តាលក៏សង្ឃឹមថា ការសម្លឹងមើល ធនធាន និងតម្រូវការ រយៈពេលវែងឆ្ងាយរបស់រដ្ឋាភិបាល នឹងធ្វើអោសម្រួលបម្រែបម្រួលដោយសារ «ការរីកឡើង និងដួលរលំ» សេដ្ឋកិច្ចមូលធននិយម (ដែលត្រូវគេស្គាល់ថាជា វដ្តនៃអាជីវកម្ម)។

សេដ្ឋកិច្ចសូវៀតបានទទួលជោគជ័យគួរអោយកត់សម្គាល់មួយចំនួន ក្នុងការធ្វើឧស្សាហូបនីយកម្ម លើផ្ទៃប្រទេសយ៉ាងឆាប់រហ័សក្នុងទស្សវត្សរ៍ឆ្នាំ១៩៣០ ការរួចផុតពីការវាយលុករបស់អាឡឺម៉ង់ក្នុងទសវត្សរ៍ឆ្នាំ ១៩៤០ និងការអភិវឌ្ឍសមត្ថភាពផលិតយន្តហោះនិងកសាងយោធាលំដាប់ពិភពលោក ក្នុងទសវត្សរ៍ឆ្នាំ ១៩៥០ និង១៩៦០។ សហភាពសូវៀតបានបាញ់បង្ហោះផ្កាយរណប(*Sputnik*)ដំបូងគេក្នុងពិភពលោក ក្នុងឆ្នាំ ១៩៥៧ ហើយនៅដើមទសវត្សរ៍ឆ្នាំ ១៩៦០ មេដឹកនាំរបស់ពួកគេបានអួតអាងថា សេដ្ឋកិច្ចកុម្មុយនីស្ត៍នឹងដំណើរការលើសពីមូលធននិយម ក្នុងរយៈពេលជាច្រើនទសវត្សរ៍ខាងមុខ។ ផ្ទុយទៅវិញ សេដ្ឋកិច្ចប្លុកសូវៀតនៅទ្រឹង ក្រោមទម្ងន់នៃការិយាធិបតេយ្យ ភាពរឹងរូសនៃមនោគមវិជ្ជា ការបំផ្លិចបំផ្លាញបរិស្ថាន អំពើពុករលួយ និងការចំណាយយោធាកម្រិតខ្ពស់។ សេដ្ឋកិច្ចផែនការកណ្តាលបង្ហាញកស្តុតាងថា វាពិតជាគ្មានប្រសិទ្ធភាពសោះឡើយ។

បច្ចុប្បន្ននេះ បណ្តាអតីតសាធារណរដ្ឋសូវៀតទាំងអស់ រួមទាំងអឺរ៉ុបខាងកើត គឺជា**សេដ្ឋកិច្ចអន្តរកាល** (transitiolnal economies) ដោយផ្លាស់ប្តូរទៅជាសេដ្ឋកិច្ចទីផ្សារ ដែលផ្សារភ្ជាប់ទៅនឹងសេដ្ឋកិច្ចមូលធននិយមពិភពលោក។ ការផ្លាស់ប្តូរបែបនេះមិនងាយស្រួលនោះទេ។ នៅពាក់កណ្តាលទីមួយនៃទសវត្សរ៍ឆ្នាំ ១៩៩០ ផលិតផលក្នុងស្រុកសរុបក្នុងតំបន់បានធ្លាក់ចុះប្រហែល ៣៥ ភាគរយ ដែលជាការធ្លាក់ចុះសេដ្ឋកិច្ចដ៏អាក្រក់ ជាងការធ្លាក់ចុះសេដ្ឋកិច្ច ដែលសហរដ្ឋអាមេរិកបានជួបប្រទះ នៅដើមទសវត្សរ៍ឆ្នាំ ១៩៣០។ កម្រិតជីវភាពប្រជាជនបានធ្លាក់ចុះយ៉ាងខ្លាំង។ នៅក្នុងការគ្រប់គ្រងរបស់ប្រធានាធិបតី បូរីស យេលស៊ីន (១៩៩១-១៩៩៩) សេដ្ឋកិច្ចរបស់រុស្ស៊ីនៅតែមិនដំណើរការ ដោយសារតែការធ្លាក់ចុះសេដ្ឋកិច្ច អំពើពុករលួយ បទល្មើសពាក់ព័ន្ធនឹងពន្ធ និងគម្លាតដ៏ធំរវាងគំរូកុម្មុយនីស្ត៍ចាស់និងមូលធននិយមថ្មី។ ប្រធានាធិបតី វ្ល៉ាឌីមៀរ ពូទីន (២០០០-២០០៨ និង ២០១២-បច្ចុប្បន្ន) បាននាំមកនូវថាមពលថ្មីដើម្បីជម្រុញកំណែទម្រង់សេដ្ឋកិច្ច និងតម្លៃប្រេងឆៅខ្ពស់ ដែលជាការនាំចេញដ៏សំខាន់របស់រុស្ស៊ី បានជំរុញសេដ្ឋកិច្ចរបស់ខ្លួនក្នុងសតវត្សរ៍ថ្មី ប៉ុន្តែ ការប្រមូលផ្តុំអំណាចនយោបាយរបស់ពូទីនអាចរារាំងកំណើនអ្នកមូលធននិយម។

ប្រទេសចិនដែលរដ្ឋាភិបាលបន្តដើរតាមបន្ទាត់*នយោបាយ*ម៉ាក្សស៊ីសនិយម(ការគ្រប់គ្រងថ្នាក់មជ្ឈឹមដោយបក្សកុម្មុយនិស្ត) បានផ្លាស់ប្តូរទិសដៅឆ្ពោះទៅរក*សេដ្ឋកិច្ច*ទីផ្សារ។ (រដ្ឋនៅតែគ្រប់គ្រងឧស្សាហកម្មធំៗ។) ការផ្លាស់ប្តូរនោះបានបង្កើនកំណើនសេដ្ឋកិច្ចប្រទេសចិនយ៉ាងខ្លាំង តាំងពីទសវត្សរ៍ឆ្នាំ ១៩៨០។ កំណើនបានឈានដល់អត្រាថេរប្រចាំឆ្នាំប្រកប ប្រហែល ១០ ភាគរយ ពេញមួយទសវត្សរ៍ឆ្នាំ ១៩៩០ ហើយស្ទើរតែកើនលឿនដូចនៅក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ (សូមមើល **បទពិសោធន៍ប្រទេសចិន** ក្នុងមេរៀនទី ១៣)។

នាបច្ចុប្បន្ននេះ សកម្មភាពសេដ្ឋកិច្ចរបស់ពិភពលោកដើរតាមគោលការណ៍ទីផ្សារសេរី ច្រើនជាងសេដ្ឋកិច្ចផែនការកណ្តាល ប៉ុន្តែ ជារឿយៗ បានធ្លាក់ចុះនៅចន្លោះចំណុចកើនខ្លាំងបំផុត។ រដ្ឋាភិបាលជាច្រើនគ្រប់គ្រងតម្លៃទំនិញក្នុងស្រុកមួយចំនួន (ឧទាហរណ៍ ការឧបត្ថម្ភធនលើទំនិញមួយចំនួន ដើម្បីទទួលបានការគាំទ្រផ្នែកនយោបាយ)។ រដ្ឋជាច្រើន*ជាម្ចាស់កម្មសិទ្ធិ*ឧស្សាហកម្ម (ទាំងអស់ឬមួយផ្នែក) ដែលគេគិតថាមានសារៈសំខាន់ខ្លាំងសម្រាប់សេដ្ឋកិច្ចជាតិ ពោលគឺ **ឧស្សាហកម្មដែលគ្រប់គ្រងដោយរដ្ឋ** (state-owned industries) ដូចជាក្រុមហ៊ុនផលិតប្រេង ឬ ក្រុមហ៊ុនអាកាសចរណ៍ជាតិ។ ហើយវិស័យសេដ្ឋកិច្ចរបស់រដ្ឋាភិបាល (ការចំណាយផ្នែកយោធា ការកសាងផ្លូវ កម្មវិធីសន្តិសុខសង្គម និងវិស័យផ្សេងៗទៀត) បង្កើតបានជាសមាសភាគដ៏ច្រើននៃសេដ្ឋកិច្ចរបស់ប្រទេសឧស្សាហកម្ម។ ដោយសារតែពួកវាមានទាំងការគ្រប់គ្រង

របស់រដ្ឋាភិបាលផង និងកម្មសិទ្ធិឯកជនផង សេដ្ឋកិច្ចនៃឧស្សាហកម្មលោកខាងលិចត្រូវបានគេហៅថាជា **សេដ្ឋកិច្ចចម្រុះ** (mixed economies)។

សព្វថ្ងៃនេះមានសេដ្ឋកិច្ចពិភពលោករួមបញ្ចូលគ្នាតែមួយ ដែលស្ទើរតែគ្មានប្រទេសណាមួយអាចបដិសេធមិនចូលរួមបានឡើយ។ ទន្ទឹមនឹងនេះ ភាពមិនល្អឥតខ្ចោះនិងបញ្ហានៃសេដ្ឋកិច្ចពិភពលោកនោះ ត្រូវបានរំលេចអោយឃើញនៅក្នុងវិបត្តិនិងការធ្លាក់ចុះសេដ្ឋកិច្ចជាបន្តបន្ទាប់ និងនៅក្នុងគម្លាតខុសគ្នាយ៉ាងខ្លាំងរវាងតំបន់រីកចម្រើនបំផុតនិងអន់ថយបំផុត នៅក្នុងពិភពលោក។ គ្មានពេលណាដែលភាពមិនល្អឥតខ្ចោះទាំងនេះ ត្រូវបានរំលេចយ៉ាងច្បាស់ក្រឡែតជាងកំឡុងពេលវិបត្តិហិរញ្ញវត្ថុសកល ឆ្នាំ ២០០៨-២០០៩ និងការធ្លាក់ចុះសេដ្ឋកិច្ចពិភពលោកបន្ទាប់មក។ ដោយផ្ទុះឡើងដំបូងជាមួយនឹងការដួលរលំនៃកម្ចីទិញផ្ទះ តម្លៃថោកៗនៅសហរដ្ឋអាមេរិក បញ្ហាសេដ្ឋកិច្ចបានរីករាលដាលយ៉ាងឆាប់រហ័សទៅកាន់អឺរ៉ុប ខណៈដែលធនាគារនិងក្រុមហ៊ុនវិនិយោគធំៗបានខាតបង់ប្រាក់វិនិយោគរាប់រយពាន់លានដុល្លារ។ ការខាតបង់ទាំងនេះបាននាំអោយមានការធ្លាក់ចុះការចំណាយដោយអ្នកប្រើប្រាស់ និងផលិតកម្មជាសកល ដែលបណ្តាលអោយមានការបាត់បង់ការងារយ៉ាងច្រើន នៅក្នុងប្រទេស ដូចជា សហរដ្ឋអាមេរិក ចិន និងឥណ្ឌា។ ការធ្លាក់ចុះតម្រូវការទំនិញពីសំណាក់អ្នកប្រើប្រាស់ ជាបន្តបន្ទាប់ បាននាំអោយមានការថយចុះនៃពាណិជ្ជកម្មពិភពលោក ចំនួន ៩ ភាគរយ ដែលជាការធ្លាក់ចុះដ៏ធំបំផុត ចាប់តាំងពីសង្គ្រាមលោកលើកទីពីរមក។

៨.៣.២. ប្រតិកម្មប្រឆាំងនឹងពាណិជ្ជកម្ម

សាកលភាវូបនីយកម្មសេដ្ឋកិច្ចពិភពលោកបានជំរុញចរន្តប្រឆាំង ដូចជាកំនើនជាតិនិយម នៅក្នុងតំបន់ពិភពលោកមួយចំនួន ដែលប្រជាពលរដ្ឋពួកគេជឿជាក់លើអត្តសញ្ញាណ និងសហគមន៍របស់ពួកគេត្រូវបានគំរាមកំហែង ដោយការជ្រៀតចូលនៃឥទ្ធិពលបរទេស។ លើសពីនេះទៀត ការផ្លាស់ទីតាំងសម្ភារៈ ដែលបង្កឡើងដោយសកលភាវូបនីយកម្ម អាចប៉ះពាល់ដល់ផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ក្រុមប្រជាជនជាក់លាក់ណាមួយនៅក្នុងប្រទេស។

កម្មករនៅក្នុងប្រទេសឧស្សាហកម្ម នៅក្នុងរោងចក្រឧស្សាហកម្មដែលប្រឈមមុខនឹងកំណើនប្រកួតប្រជែងពីបណ្តាប្រទេសដែលមានប្រាក់ឈ្នួលទាប នៅក្នុងអឌ្ឍគោលខាងត្បូង (ដូចជា ឧស្សាហកម្មដែកថែបយានយន្ត គ្រឿងអេឡិចត្រូនិក និងសម្លៀកបំពាក់) ស្ថិតក្នុងចំណោមវិស័យដែលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរបំផុត ពីពាណិជ្ជកម្មសេរី។ ជៀសមិនរួច ការប្រកួតប្រជែងពីប្រទេសដែលមានប្រាក់ឈ្នួលទាបធ្វើអោយប្រាក់ឈ្នួលក្នុងវិស័យឧស្សាហកម្មទាំងនោះត្រូវធ្លាក់ចុះ នៅក្នុងប្រទេសឧស្សាហកម្ម។ វាក៏បង្កើតសម្ពាធដើម្បីបន្ធូរបន្ថយស្តង់ដារនៃបទប្បញ្ញត្តិការងារ ដូចជាស្តង់ដារការពារសុវត្ថិភាពកម្មករ ហើយវាអាចនាំអោយមានការបាត់បង់ការងារ ប្រសិនបើអ្នកផលិតបិទរោងចក្រនៅក្នុងប្រទេសដែលមានប្រាក់ឈ្នួលខ្ពស់ ហើយផ្លាស់ទីតាំងប្រតិបត្តិការទៅកាន់អឌ្ឍគោលខាងត្បូង។ មិនគួរអោយភ្ញាក់ផ្អើលទេដែលសហជីពកម្មករឬការងារស្ថិតនៅក្នុងចំណោមអ្នកប្រឆាំងនយោបាយខ្លាំងបំផុតចំពោះការពង្រីកពាណិជ្ជកម្មសេរី។ (ទោះបីជាសហរដ្ឋអាមេរិកស្ថិតនៅចំកណ្តាលនៃការជជែកដេញដោលទាំងនេះក៏ដោយ ប្រទេសឧស្សាហកម្មផ្សេងទៀតប្រឈមមុខនឹងបញ្ហាស្រដៀងគ្នានេះដែរ)។

អង្គការក្រៅរដ្ឋាភិបាលប្រតិបត្តិការផ្នែកសិទ្ធិមនុស្សបានចូលរួមជាមួយសហជីពកម្មករ ក្នុងការជំរុញអោយមានកិច្ចព្រមព្រៀងពាណិជ្ជកម្ម ដើម្បីរួមបញ្ចូលតម្រូវការសម្រាប់ប្រទេសដែលមានប្រាក់ឈ្នួលទាប

ដើម្បីកែលម្អលក្ខខណ្ឌការងារ ដូចជាប្រាក់ឈ្នួលអប្បបរមា ពលកម្មកុមារ និងសុវត្ថិភាពកម្មករ។ សហរដ្ឋអាមេរិកហាមប្រាមការនាំចូលទំនិញ (ភាគច្រើនជាកម្រាលព្រំ) ដែលត្រូវបានផលិតដោយកម្មករកុងត្រាជាកុមារ (ទាសករ) ចំនួន ១៧ លាននាក់នៅអាស៊ីខាងត្បូង។ បណ្តាក្រុមហ៊ុនដែលរងការរិះគន់អំពីលក្ខខណ្ឌការងារនៅក្នុងរោងចក្ររបស់ពួកគេនៅអាស៊ី បានអនុម័តវិធានការណ៍ស្ម័គ្រចិត្ត ដើម្បីបញ្ចប់ការរំលោភបំពានដ៏អាក្រក់បំផុត ដូចដែលក្រុមហ៊ុនកុំព្យូទ័រអេផលបានធ្វើក្នុងឆ្នាំ ២០១២ បន្ទាប់ពីក្រុមហ៊ុនផ្គត់ផ្គង់ហ្វក់ខន (Foxconn)របស់ចិន ប្រឈមមុខនឹងការតវ៉ារបស់កម្មករ និងការយកចិត្តទុកដាក់ពីប្រព័ន្ធផ្សព្វផ្សាយជុំវិញលក្ខខណ្ឌការងារ។ កុមារជាង ២០០ លាននាក់ ដែលមានអាយុក្រោម ១៤ ឆ្នាំ ធ្វើការនៅអឌ្ឍគោលភាគខាងត្បូង ដែលក្នុងនោះ ចំនួនច្រើនជាងពាក់កណ្តាលស្ថិតក្នុងលក្ខខណ្ឌការងារគ្រោះថ្នាក់ នេះបើយោងតាមអង្គការពលកម្មអន្តរជាតិ(ILO)។ នៅកូតឌីវ័រ ដែលជាប្រទេសនាំចេញកាកាវដ៏ធំបំផុតលើពិភពលោក (សម្រាប់ផលិតសូកូឡាប្រើប្រាស់នៅអឌ្ឍគោលខាងជើង) កុមាររាប់ម៉ឺននាក់ធ្វើការ ដោយទទួលប្រាក់ឈ្នួលទាប ឬរហូតក្លាយជាទាសករ នៅក្នុងចំការដំណាំកាកាវ។

កាលពីខែមេសា ឆ្នាំ ២០១៣ ការដួលរលំរោងចក្រនៅប្រទេសបង់ក្លាដែសបានសម្លាប់កម្មករជាង ១១០០ នាក់ និងបង្ករបួសស្នាមជាង ២០០០ នាក់ ហើយបាននាំមកនូវការយកចិត្តទុកដាក់ជាថ្មីចំពោះបញ្ហាសុវត្ថិភាពកម្មករ។ ការដួលរលំរោងចក្រកាត់ដេរ ដែលជាឧបទ្ទវហេតុដ៏អាក្រក់បំផុតក្នុងប្រវត្តិសាស្ត្រប្រទេសបង់ហ្គាដែស បានបណ្តាលអោយមានកិច្ចខិតខំប្រឹងប្រែងរបស់អង្គការក្រៅរដ្ឋាភិបាលជាច្រើន ដើម្បីបង្កើនស្តង់ដារការងារ ដោយទាមទារអោយហាងចែកចាយបន្ត ប្តេជ្ញាចំពោះស្តង់ដារសុវត្ថិភាពថ្មីសម្រាប់កម្មករ។ នៅឆ្នាំ ២០១៥ កិច្ចព្រមព្រៀងពីរផ្សេងគ្នាបានលេចឡើង៖ មួយត្រូវចុះហត្ថលេខាដោយហាងចែកចាយលក់រាយនៅអឺរ៉ុបភាគច្រើននិង មួយទៀតត្រូវចុះហត្ថលេខាភាគច្រើនដោយហាងចែកចាយលក់រាយរបស់អាមេរិក។ ក្រុមសហជីពកម្មករបានរិះគន់កិច្ចព្រមព្រៀងអាមេរិកថា ខ្វះការពិន័យផ្លូវច្បាប់រឹងមាំ ចំពោះទង្វើបំពានកិច្ចព្រមព្រៀង។

ក្រុមបរិស្ថាននានាក៏បានប្រឆាំងយ៉ាងសកម្ម ចំពោះការពង្រីកពាណិជ្ជកម្ម ដាច់បង្ហៀរ ដែលពួកគេមើលឃើញថាជាការធ្វើអោយខូចដល់ច្បាប់បរិស្ថាន នៅក្នុងប្រទេសឧស្សាហកម្ម និងការលើកកម្ពស់ការអនុវត្តដែលបង្កគ្រោះថ្នាក់ដល់បរិស្ថានទូទាំងពិភពលោក (សូមមើល មេរៀនទី ១១)។ ជាឧទាហរណ៍ បទប្បញ្ញត្តិរបស់សហរដ្ឋអាមេរិកតម្រូវអោយទូកនេសាទបង្កងជាលក្ខណៈពាណិជ្ជកម្មប្រើប្រាស់ឧបករណ៍ ដែលការពារអណ្តើកសមុទ្រដែលជិតផុតពូជពីការលង់ទឹកស្លាប់ក្នុងសំណាញ់បង្កា។ ប្រទេសឥណ្ឌូនេស៊ី ម៉ាឡេស៊ី ថៃ និងប៉ាគីស្ថាន ដែលការនាំចេញបង្កងទៅកាន់សហរដ្ឋអាមេរិកត្រូវបានរារាំងដោយសារតែពួកគេមិនតម្រូវអោយប្រើប្រាស់ឧបករណ៍បែបនេះបានដាក់ពាក្យបណ្តឹងទៅកាន់អង្គការ WTO ដោយលើកហេតុផលថាបទប្បញ្ញត្តិរបស់សហរដ្ឋអាមេរិកមានការរើសអើងដោយអយុត្តិធម៌ចំពោះពួកគេ។ នៅឆ្នាំ ១៩៩៨ សហរដ្ឋអាមេរិកបានចាញ់ក្តី ដោយសាលក្រមរបស់អង្គការWTO ហើយបណ្តឹងឧទ្ធរណ៍ក៏បរាជ័យដែរ។ អណ្តើកសមុទ្របានក្លាយជានិមិត្តរូបនៃការប្រឆាំងរបស់អ្នកបរិស្ថានចំពោះអង្គការWTO។ (ក្នុងឆ្នាំ ២០០១ អង្គការ WTO បានសម្រេចថាច្បាប់សហរដ្ឋអាមេរិក អាចទទួលយកបាន បន្ទាប់ពីវិសោធន៍កម្មត្រូវបានបង្កើតឡើងដែលធ្វើអោយការអនុវត្តច្បាប់នេះកាន់តែប្រសើរឡើង។) នៅឆ្នាំ ១៩៩៦ ប្រេស៊ីលនិងវ៉ែណេស៊ុយអេឡាបានបានដាក់ពាក្យប្តឹងសហរដ្ឋអាមេរិកទៅកាន់អង្គការWTO ហើយបង្ខំអោយមានការផ្លាស់ប្តូរច្បាប់បរិស្ថានរបស់

សហរដ្ឋអាមេរិកទាក់ទងនឹងការនាំចូលប្រេងសាំង ដោយអះអាងថា បទប្បញ្ញត្តិទាំងឡាយនៅក្រោមច្បាប់អាកាសស្អាត(Clean Air Act) កំពុងដំណើរការជារបាំងមិនមែនពន្ធគយ។

ជាទូទៅ ពាណិជ្ជកម្មដែលមិនមានការរឹតបន្តឹងមានទំនោរបង្កើអោយប្រទេសនានាធ្វើអោយបទប្បញ្ញត្តិរបស់ពួកគេមានភាពស្មើគ្នានៅក្នុងវិស័យជាច្រើន ដែលមិនត្រូវបានកំណត់ដោយច្បាប់ការងារនិងបរិស្ថាន។ ជាឧទាហរណ៍ អង្គការWTO បានសម្រេចនៅក្នុងឆ្នាំ ១៩៩៧ ថាការព្រួយបារម្ភរបស់ជនជាតិអឺរ៉ុបអំពីការប្រើប្រាស់អ័រម៉ូនលូតលាស់នៅក្នុងសាច់គោ មិនត្រូវបានស្រាយបញ្ជាក់តាមលក្ខណៈវិទ្យាសាស្ត្រនោះទេ ដូច្នេះហើយបទប្បញ្ញត្តិរបស់សហភាពអឺរ៉ុបមិនអាចប្រើដើម្បីរារាំងសាច់គោអាមេរិកដែលមានផ្ទុកអ័រម៉ូនទេ។ នៅពេលដែលសហភាពអឺរ៉ុបនៅតែបន្ត សហរដ្ឋអាមេរិកត្រូវបានអនុញ្ញាតអោយសងសឹក ដោយការដាក់ពន្ធគយខ្ពស់លើការនាំចេញរបស់សហភាពអឺរ៉ុបមួយបញ្ជីពេញ ដូចជា ឈីសបារាំង ជាដើម។ ដូចគ្នានេះដែរ នៅក្នុងឆ្នាំ ២០០៦ អង្គការ WTO បានសម្រេចថា ការរឹតបន្តឹងអឺរ៉ុបលើការនាំចូលអាហារកែប្រែហ្សែនពីសហរដ្ឋអាមេរិកបានរំលោភលើច្បាប់ពាណិជ្ជកម្ម។

ឧទាហរណ៍ទាំងនេះបង្ហាញអំពីប្រភពជាច្រើននៃប្រតិកម្មប្រឆាំងនឹងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី។ ក្រុមសហជីពកម្មករឬការងារ ក្រុមបរិស្ថាន និងក្រុមអ្នកប្រើប្រាស់សុទ្ធសឹងមើលឃើញអង្គការWTO ថាជាការិយាធិបតេយ្យសម្ងាត់ នៅខាងក្រៅរង្វង់គ្រប់គ្រងតាមបែបប្រជាធិបតេយ្យ ដែលបម្រើផលប្រយោជន៍សាជីវកម្មធំៗ នៅពីលើទុក្ខសោកឬការខាតបង់របស់ប្រជាជនសាមញ្ញ ទាំងនៅក្នុងអឌ្ឍគោលខាងជើង និងទាំងខាងត្បូង។ អ្វីដែលសំខាន់ជាងនេះទៅទៀត អ្នករិះគន់ទាំងនេះមិនទុកចិត្តលើសកលភាវូបនីយកម្មដែលជំរុញដោយសាជីវកម្ម ដែលអង្គការWTOគ្រាន់តែជាទិដ្ឋភាពមួយប៉ុណ្ណោះ។ ការស្ទង់មតិរបស់សហរដ្ឋអាមេរិកនាពេលថ្មីៗនេះ បង្ហាញពីការធ្លាក់ចុះនៃជំនឿ ដែលថាពាណិជ្ជកម្មមានលក្ខណៈអំណោយផលសម្រាប់សេដ្ឋកិច្ច។ យោងតាមការស្ទង់មតិចុងឆ្នាំ ២០១៧ ប្រជាជនចំនួន ៧២ ភាគរយជឿថាពាណិជ្ជកម្មគឺជា «ឱកាសមួយ» សម្រាប់សហរដ្ឋអាមេរិក ខណៈពេលប្រជាជន ២៣ ភាគរយផ្សេងទៀត អះអាងថាវាជា«ការគំរាមកំហែងមួយ» ដែលកើនឡើងប៉ុន្មានភាគរយ ពីពេលពីរបីឆ្នាំមុន។ ជាសកល មតិសាធារណៈគាំទ្រពាណិជ្ជកម្ម៖ ការស្ទង់មតិ កាលពីឆ្នាំ ២០១៤ នៅក្នុងប្រទេស ចំនួន ៤៤ បានរកឃើញថា ជាមធ្យម អ្នកឆ្លើយតប ចំនួន ៨១ ភាគរយ បានមើលឃើញថាពាណិជ្ជកម្មអន្តរជាតិជារឿងល្អ ទោះបីជាមានការព្រួយបារម្ភអំពីផលប៉ះពាល់អវិជ្ជមានលើវិស័យវប្បធម៌និងបរិស្ថានក៏ដោយ។ ការគាំទ្រមានកម្រិតខ្ពស់ ជាពិសេសនៅក្នុងសេដ្ឋកិច្ចដែលពឹងផ្អែកលើការនាំចេញ៖ ជាឧទាហរណ៍ ប្រជាជន ៩០ ភាគរយ នៅវៀតណាម អ៊ីស្រាអែល កូរ៉េខាងត្បូង និងអាឡឺម៉ង់ ជាដើម។

អត្ថប្រយោជន៍នៃការធ្វើពាណិជ្ជកម្មសេរី ដូចដែលបានកត់សម្គាល់មុននេះ ត្រូវបានចែកចាយច្រើនជាងការចំណាយ។ អ្នកប្រើប្រាស់អាមេរិកសប្បាយរីករាយនឹងតម្លៃទាបនៃទំនិញដែលនាំចូលពីប្រទេសក្រៅដែលមានកម្រិតប្រាក់ឈ្នួលទាប។ ដូច្នេះ អ្នកប្រើប្រាស់អាចចំណាយប្រាក់កាន់តែច្រើនលើផលិតផល និងសេវាកម្មផ្សេងទៀត ហើយនៅទីបំផុត អាចជួលកម្មករអាមេរិកកាន់តែច្រើនបន្ថែមទៀត។ ការនាំចូលថោកក៏ជួយរក្សាអតិផរណាទាប ដែលផ្តល់ផលប្រយោជន៍ដល់ពលរដ្ឋ។ នេះជាការសម្រាលបន្ទុកដ៏តូចមួយ ទោះជាយ៉ាងណា បើអ្នកទើបតែបាត់បង់ការងារ។

ជាការពិតណាស់ ពាណិជ្ជកម្មអន្តរជាតិត្រូវការប្រាក់ដើម្បីសម្រួលដល់ការដោះដូរទំនិញឬសេវាកម្ម។ នៅក្នុងយុគសម័យសកលភាវូបនីយកម្ម បរិមាណដ៏ច្រើននៃពាណិជ្ជកម្មអន្តរជាតិត្រូវបានធ្វើឡើង តាមរយៈសាជីវកម្មពហុជាតិ។ មេរៀនបន្ទាប់នឹងលើកយកបញ្ហាទាំងពីរនេះ នៅក្នុងបរិបទនៃសេដ្ឋកិច្ចពិភពលោក។

សេចក្តីសង្ខេប

១. សេដ្ឋកិច្ចសើរើសង្កត់ធ្ងន់លើកិច្ចសហប្រតិបត្តិការអន្តរជាតិ ជាពិសេសតាមរយៈពាណិជ្ជកម្មសើរើទូទាំងពិភពលោក ដើម្បីបង្កើនការបង្កើតទ្រព្យសម្បត្តិសរុប (ដោយមិនគិតពីការបែងចែកសម្បត្តិទាំងនោះក្នុងចំណោមរដ្ឋនានា)។

២. ទ្រឹស្តីគាំពារនិយមសង្កត់ធ្ងន់លើការប្រើប្រាស់គោលនយោបាយសេដ្ឋកិច្ច ដើម្បីបង្កើនអំណាចរបស់រដ្ឋមួយ ធៀបនឹងរដ្ឋដទៃទៀត។ វាឆ្លុះបញ្ចាំងពីទ្រឹស្តីប្រាកដនិយម ក្នុងទិដ្ឋភាពជាច្រើន។ ទ្រឹស្តីគាំពារនិយមនិយមចូលចិត្តគោលនយោបាយពាណិជ្ជកម្ម ដែលបង្កើតអតិរេកពាណិជ្ជកម្មសម្រាប់រដ្ឋពួកគេផ្ទាល់។ តុល្យភាពពាណិជ្ជកម្មវិជ្ជមានបែបនេះបង្កើតប្រាក់ ដែលអាចត្រូវប្រើដើម្បីពង្រឹងអំណាចរដ្ឋ។

៣. ពាណិជ្ជកម្មបង្កើតទ្រព្យសម្បត្តិ ដោយអនុញ្ញាតអោយរដ្ឋអភិវឌ្ឍជំនាញក្នុងការផលិតទំនិញនិងសេវាកម្មដែលពួកគេមាន**ឧត្តមភាពធៀប** (និងដោយនាំចូលទំនិញផ្សេងទៀត ដែលគេត្រូវការជាចាំបាច់)។

៤. ការបែងចែកអត្ថប្រយោជន៍ដែលទទួលបានពីការដោះដូរមួយត្រូវបានកំណត់ដោយតម្លៃទំនិញ ដែលត្រូវដោះដូរ។ ជាមួយនឹងអ្នកទិញនិងអ្នកលក់ច្រើនអនេក តម្លៃជាទូទៅត្រូវបានកំណត់ដោយលំនឹងទីផ្សារ (ការផ្គត់ផ្គង់និងតម្រូវការ)។

៥. នយោបាយជ្រៀតជ្រែកចូលក្នុងទីផ្សារអន្តរជាតិ តាមមធ្យោបាយជាច្រើន រួមទាំងការប្រើប្រាស់ទណ្ឌកម្មសេដ្ឋកិច្ចជាកម្លាំងគំនាបនយោបាយទៅលើរដ្ឋគោលដៅ។ ទោះយ៉ាងណាក៏ដោយ ការដាក់ទណ្ឌកម្មមានភាពពិបាកក្នុងការអនុវត្ត លុះត្រាតែតួអង្គសេដ្ឋកិច្ចធំៗ ទាំងអស់ព្រមគោរពតាមទាំងអស់គ្នា។

៦. រដ្ឋទាំងឡាយដែលបានកាត់បន្ថយកម្រិតពឹងផ្អែកលើរដ្ឋដទៃ ដោយស្វែងរកគោលនយោបាយអូតារគី (ស្វ័យផ្គត់ផ្គង់ ឯករាជ្យម្ចាស់ការ) បានបរាជ័យក្នុងការបង្កើតទ្រព្យសម្បត្តិថ្មី ដើម្បីបង្កើនសុខុមាលភាពរបស់ប្រជាពលរដ្ឋ។ គោលនយោបាយ«ខ្លួនទីពឹងខ្លួន» ក៏ដូចការធ្វើផែនការកណ្តាលដៃរ ត្រូវបានគេទាត់ចោលដោយមិនចាត់ទុកវាថាជាយុទ្ធសាស្ត្រសេដ្ឋកិច្ចដែលអាចសម្រេចបានឡើយ។

៧. តាមរយៈគោលនយោបាយគាំពារនិយម រដ្ឋជាច្រើនព្យាយាមការពារឧស្សាហកម្មក្នុងស្រុកជាក់លាក់ ពីការប្រកួតប្រជែងអន្តរជាតិ។ គោលនយោបាយបែបនេះ មាននិន្នាការបន្តយល្បឿននៃការបង្កើតទ្រព្យសម្បត្តិជាសកល ប៉ុន្តែ ពិតជាបានជួយដល់ឧស្សាហកម្មក្នុងស្រុកនោះ។ គោលនយោបាយគាំពារនិយមអាចត្រូវបានអនុវត្តតាមមធ្យោបាយផ្សេងៗគ្នា រួមមាន ពន្ធនាំចូល (វិធីពេញនិយម) កូតា ប្រាក់ឧបត្ថម្ភធន និងរនាំងមិនមែនពន្ធគយផ្សេងទៀត។

៨. ពាណិជ្ជកម្មពិភពលោកមានទំហំធំធេងណាស់ (ប្រហែល មួយភាគប្រាំមួយនៃសកម្មភាពសេដ្ឋកិច្ចពិភពលោក) ហើយត្រូវបានប្រមូលផ្តុំយ៉ាងខ្លាំង នៅក្នុងបណ្តារដ្ឋនៃបស្ចឹមប្រទេសឧស្សាហកម្ម (អឺរ៉ុបខាងលិច អាមេរិកខាងជើង និងជប៉ុន/ប៉ាស៊ីហ្វិក) និងប្រទេសចិន។

៩. បន្តិចម្តងៗ ច្បាប់ដែលបង្កប់ក្នុងរបបពាណិជ្ជកម្ម (និងបញ្ហាផ្សេងទៀតនៅក្នុងទំនាក់ទំនងអន្តរជាតិ) ក្លាយជាមូលដ្ឋានសម្រាប់ស្ថាប័នអចិន្ត្រៃយ៍ ដែលមុខងាររដ្ឋបាលរបស់វាផ្តល់នូវស្ថេរភាពនិងប្រសិទ្ធភាពបន្ថែមទៀត នៅក្នុងពាណិជ្ជកម្មពិភពលោក។

១០. អង្គការពាណិជ្ជកម្មពិភពលោក (WTO) អតីតកិច្ចព្រមព្រៀងGATT គឺជាកិច្ចព្រមព្រៀងពាណិជ្ជកម្មពហុភាគីដ៏សំខាន់បំផុត។ កិច្ចព្រមព្រៀងGATT ត្រូវបានបង្កើតឡើងជាស្ថាប័ន ក្នុងឆ្នាំ ១៩៩៥ ជាមួយនឹងការបង្កើតអង្គការពាណិជ្ជកម្មពិភពលោក ដែលបានពង្រីកការផ្តោតអារម្មណ៍លើទំនិញឧស្សាហកម្ម ដើម្បីពិចារណាលើវិស័យកសិកម្មនិងសេវាកម្ម។ កម្មសិទ្ធិបញ្ញាគឺជាការផ្តោតអារម្មណ៍មួយទៀត នៅក្នុងពេលថ្មីៗនេះ។

១១. នៅក្នុងជុំចរចាររបស់GATTជាបន្តបន្ទាប់ ក្នុងរយៈពេល ៥០ ឆ្នាំ រដ្ឋនានាបានទម្លាក់អត្រាពន្ធគយទូទៅ (ជាពិសេសលើទំនិញឧស្សាហកម្ម)។ ជុំអ៊ុយរូហ្គាយនៃកិច្ចព្រមព្រៀងGATT ដែលបានបញ្ចប់ក្នុងឆ្នាំ ១៩៩៤ បានបន្ថែមទឹកប្រាក់រាប់រយលានដុល្លារ ដល់ការបង្កើតទ្រព្យសម្បត្តិសកលលោក។ ជុំដូហាបានចាប់ផ្តើមនៅឆ្នាំ ២០០១ និងត្រូវផ្អាកនៅឆ្នាំ ២០១៥។ ទន្ទឹមនឹងនេះ ពន្ធគយវាយនភ័ណ្ឌត្រូវបានទម្លាក់ចោល ទូទាំងពិភពលោក នៅខែមករា ឆ្នាំ ២០០៥។

១២. ទោះបីជាអង្គការពាណិជ្ជកម្មពិភពលោកផ្តល់នូវក្របខ័ណ្ឌ(ពាណិជ្ជកម្ម)សកលក៏ដោយ រដ្ឋនានាបន្តប្រតិបត្តិការ ក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគីរាប់ពាន់ច្បាប់ ដោយលម្អិតពីច្បាប់សម្រាប់ពាណិជ្ជកម្មផលិតផលជាក់លាក់ រវាងប្រទេសនឹងប្រទេសទាំងនោះ។

១៣. តំបន់ពាណិជ្ជកម្មសេរីក្នុងតំបន់ (ដោយមានពន្ធតិចតួច ឬរបាំងមិនពន្ធ) ត្រូវបានបង្កើតឡើងនៅអឺរ៉ុប អាមេរិកខាងជើង និងតំបន់ជាច្រើនទៀត។ NAFTA រួមមានកាណាដា ម៉ិកស៊ិក និងសហរដ្ឋអាមេរិក។

១៤. *ការតែល*អន្តរជាតិត្រូវបានប្រើប្រាស់ម្តងម្កាល ដោយក្រុមអ្នកផលិតឈានមុខគេ (ជួនកាលរួមជាមួយនឹងអ្នកប្រើប្រាស់ឈានមុខគេ) ដើម្បីគ្រប់គ្រងតម្លៃ និងធ្វើអោយមានស្ថិរភាពតម្លៃទំនិញណាមួយ នៅលើទីផ្សារពិភពលោក។ ឧទាហរណ៍ច្បាស់ក្រឡែតជាងគេ ក្នុងប៉ុន្មានទសវត្សរ៍ថ្មីៗនេះ គឺក្រុមការតែលផលិតប្រេង អង្គការOPEC ដែលសមាជិករបស់ពួកគេគ្រប់គ្រងជាងពាក់កណ្តាលនៃការនាំចេញទំនិញសំខាន់បំផុតក្នុងពិភពលោក នោះគឺ ប្រេង។

១៥. ឧស្សាហកម្មនានាតែងតែបញ្ចុះបញ្ចូលរដ្ឋាភិបាលរបស់ពួកគេអោយការពារខ្លួន។ រដ្ឋាភិបាលនៅក្នុងរដ្ឋជាច្រើនបង្កើតគោលនយោបាយឧស្សាហកម្ម ដើម្បីត្រួសត្រាយផ្លូវសម្រាប់កិច្ចខិតខំប្រឹងប្រែងរបស់ពួកគេក្នុងការពង្រឹងឧស្សាហកម្មក្នុងស្រុក នៅក្នុងបរិបទនៃទីផ្សារពិភពលោក។

១៦. វិស័យសេដ្ឋកិច្ចមួយចំនួន ជាពិសេសវិស័យកសិកម្ម កម្មសិទ្ធិបញ្ញា សេវាកម្ម និងទំនិញយោធា មានទំនោរងាកចេញពីគោលការណ៍ទីផ្សារ។ ជម្លោះនយោបាយក្នុងចំណោមរដ្ឋទាក់ទងនឹងពាណិជ្ជកម្ម ក្នុងវិស័យទាំងនេះកើតមានឡើងជាញឹកញាប់។

១៧. ដោយសារតែគ្មានរដ្ឋាភិបាលពិភពលោកដើម្បីពង្រឹងការអនុវត្តច្បាប់ពាណិជ្ជកម្ម ការអនុវត្តបែបនេះអាស្រ័យលើគោលការណ៍បដិការនិងអំណាចរដ្ឋ។ និយាយអោយចំ រដ្ឋព្រមធ្វើកិច្ចសហប្រតិបត្តិការរវាងគ្នា ទៅវិញទៅមក ក្នុងការបើកចំហរទីផ្សារ (ឬដាក់ទណ្ឌកម្មគ្នាទៅវិញទៅមកចំពោះការបដិសេធមិន

អនុញ្ញាតអោយមានការនាំចូលផលិតផលបរទេស)។ ទោះបីជាវានាំទៅរកសង្គ្រាមពាណិជ្ជកម្មម្តងម្កាលក៏ដោយ គោលការណ៍បដិការបានសម្រេចបាននូវកិច្ចសហប្រតិបត្តិការយ៉ាងច្រើននៅក្នុងពាណិជ្ជកម្ម។

១៨. សេដ្ឋកិច្ចពិភពលោកបានបង្កើតទ្រព្យសម្បត្តិ ក្នុងល្បឿនមួយដ៏លឿន ក្នុងរយៈពេលពីរសតវត្សរ៍ចុងក្រោយនេះ ហើយកាន់តែត្រូបានរួមបញ្ចូលគ្នាខ្លាំងឡើង នៅលើមាត្រដ្ឋានពិភពលោក ទោះបីជាមានវិសមភាពដ៏ធំក៏ដោយ។

១៩. បណ្តារដ្ឋកុម្មុយនិស្ត៍កំឡុងសង្គ្រាមត្រជាក់បានដំណើរការសេដ្ឋកិច្ចផែនការកណ្តាល ដែលរដ្ឋាភិបាលជាតិកំណត់តម្លៃនិងលៃលកធនធាន។ សព្វថ្ងៃនេះ រដ្ឋស្ទើរតែទាំងអស់កំពុងស្ថិតក្នុងអន្តរកាលឆ្ពោះទៅរកសេដ្ឋកិច្ចផ្អែកលើទីផ្សារ ដែលបង្កើតទ្រព្យសម្បត្តិកាន់តែមានប្រសិទ្ធភាព។

២០. កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីបាននាំអោយមានប្រតិកម្មពីក្រុមផលប្រយោជន៍នយោបាយ ដែលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយសារសកលភាវូបនីយកម្ម។ ក្រុមទាំងនេះរួមមានសហជីពពលករឬការងារអង្គការក្រៅរដ្ឋាភិបាលធ្វើការលើផ្នែកបរិស្ថាននិងសិទ្ធិមនុស្ស និងក្រុមអ្នកប្រើប្រាស់មួយចំនួន។

ពាក្យគន្លឹះ

១. **លទ្ធិគាំពារនិយម** (Mercantilism) គឺជាទ្រឹស្តីសេដ្ឋកិច្ចនិងមនោគមវិជ្ជានយោបាយ ដែលយល់ស្របតាមទ្រឹស្តីប្រាកដនិយម ជឿថា រដ្ឋត្រូវធ្វើអ្វីគ្រប់បែបយ៉ាងដើម្បីការពារផលប្រយោជន៍ផ្ទាល់ខ្លួន ដោយមិនចាំបាច់សម្របសម្រួល ឬស្វែងរកផលប្រយោជន៍រួម តាមរយៈអង្គការអន្តរជាតិឡើយ។

២. **សេដ្ឋកិច្ចសេរីនិយម៖** ក្នុងបរិបទសេដ្ឋកិច្ចនយោបាយអន្តរជាតិ គឺជាគោលការណ៍មួយ ដែលយល់ស្របតាមការសន្មត់ស្តីពីអាណាធិបតេយ្យ(អវត្តមានរដ្ឋាភិបាលពិភពលោក) ប៉ុន្តែ មិនចាត់ទុកថាលក្ខណ្ឌនេះរារាំងកិច្ចសហប្រតិបត្តិការទូលំទូលាយ ក្នុងការទាញយកផលប្រយោជន៍រួមពីការផ្លាស់ប្តូរសេដ្ឋកិច្ច។ វាសង្កត់ធ្ងន់លើ*ផលប្រយោជន៍ដាច់ខាត* ជាជាង*ផលប្រយោជន៍ធៀប* ហើយជាក់ស្តែង ផ្តោតលើការប្តេជ្ញាចំពោះពាណិជ្ជកម្មសេរី លំហូរដើមទុនដោយសេរី និងសេដ្ឋកិច្ចពិភពលោក«ចំហជើងមេឃ»។

៣. **ពាណិជ្ជកម្មសេរី** គឺជាលំហូរទំនិញនិងសេវាកម្ម ឆ្លងព្រំដែនជាតិទាំងឡាយ ដោយមិនមានការរារាំងពីការយកពន្ធគយ ឬការរារាំងផ្សេងៗឡើយ។ ជាទូទៅ ពាណិជ្ជកម្មសេរីគឺជាទិដ្ឋភាពដ៏សំខាន់ ក្នុងគោលនយោបាយអង់គ្លេស ក្រោយឆ្នាំ ១៨៤៦ និងសហរដ្ឋអាមេរិក ក្រោយឆ្នាំ ១៩៤៥។

៤. **តុល្យភាពពាណិជ្ជកម្ម** គឺជាប្លឹងថ្លែងតំលៃនាំចេញរបស់រដ្ឋមួយ ជាមួយនឹងការនាំចូលរបស់វា។

៥. **ឧត្តមភាពធៀប** ជាគោលការណ៍ដែលចែងថា រដ្ឋនានាគួរតែពង្រឹងជំនាញក្នុងការធ្វើពាណិជ្ជកម្មទំនិញណាមួយដែលពួកគេអាចផលិតបានប្រកបដោយប្រសិទ្ធភាពខ្ពស់បំផុតនិងចំណាយទាបបំផុត (ធៀបនឹងទំនិញផ្សេងទៀត ដែលផលិតដោយរដ្ឋដដែលនោះ)។

៦. **អូតារគី** (Autarky) គឺជាគោលនយោបាយឯករាជ្យម្ចាស់ការ ស្វ័យផ្តត់ផ្គង់, ដោយបញ្ឈៀសការធ្វើពាណិជ្ជកម្ម (បើជៀសមិនបាន ធ្វើយ៉ាងតិចបំផុត) និងដោយព្យាយាមផលិតអ្វីគ្រប់យ៉ាងដែលខ្លួនត្រូវការ (ឬទំនិញសំខាន់បំផុត) ដោយខ្លួនឯង។

៧. **គាំពារនិយម** គឺជាការការពារឧស្សាហកម្មក្នុងស្រុកដើម្បីទប់ទល់នឹងការប្រកួតប្រជែងអន្តរជាតិ ដោយដំឡើងពន្ធគយពាណិជ្ជកម្ម និងមធ្យោបាយផ្សេងទៀត។

៨. **ការលក់បង្ហូចតម្លៃ** (dumping) គឺជាការលក់ផលិតផលនៅទីផ្សារបរទេសក្នុងតម្លៃទាបជាងកម្រិតអប្បបរមា ដែលត្រូវការជាចាំបាច់ដើម្បីទទួលបានប្រាក់ចំណេញ (ឬទាបជាងថ្លៃដើម)។

៩. **ពន្ធគយ** គឺជាពន្ធឬអាករលើប្រភេទទំនិញនាំចូលមួយចំនួន (ជាទូទៅ គិតជាភាគរយនៃតម្លៃទំនិញនោះ) នៅពេលទំនិញទាំងនោះត្រូវនាំចូលប្រទេសមួយទៀត។

១០. **រនាំងមិនមែនពន្ធគយ** គឺជាទម្រង់នៃការរឹតត្បិតការនាំចូលនូវទំនិញណាមួយ (ក្រៅពីយកពន្ធគយ) មានដូចជា ការកំណត់កូតា (កម្រិតចំនួនទំនិញប៉ុន្មានប្រភេទដែលអាចនាំចូលបាន)។

១១. **អង្គការពាណិជ្ជកម្មពិភពលោក**(WTO) គឺជាអង្គការមួយដែលបានចាប់កំណើតឡើង នៅឆ្នាំ ១៩៩៥ ដែលជំនួសកិច្ចព្រមព្រៀងGATT និងពង្រីកការយកចិត្តទុកដាក់បែបប្រពៃណីរបស់ខ្លួន លើទំនិញឧស្សាហកម្ម។ អង្គការពាណិជ្ជកម្មពិភពលោកបានបង្កើតយន្តការត្រួតពិនិត្យនិងពង្រឹងការអនុវត្តមួយចំនួន។ សូមមើល កិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយនិងពាណិជ្ជកម្ម (GATT) និងកិច្ចប្រជុំអ៊ុយរូហ្គាយផងដែរ ។

១២. **កិច្ចព្រមព្រៀងទូទៅស្តីពីតារាងពន្ធគយនិងពាណិជ្ជកម្ម** (GATT) គឺជាអង្គការពិភពលោកមួយ ដែលត្រូវបានបង្កើតឡើង ក្នុងឆ្នាំ ១៩៤៧ ដើម្បីធានាអោយពាណិជ្ជកម្មសេរីជាងមុន ដោយឈរលើមូលដ្ឋានពហុភាគី។ កិច្ចព្រមព្រៀងGATT គឺជាក្របខ័ណ្ឌនៃការចរចារ ជាជាងស្ថាប័នរដ្ឋបាល។ វាបានក្លាយជាអង្គការពាណិជ្ជកម្មពិភពលោក (WTO) ក្នុងឆ្នាំ ១៩៩៥។

១៣. **ប្រជាជាតិអំណោយផលបំផុត** (MFN) គឺជាគោលការណ៍ដែលរដ្ឋមួយសន្យាថានឹងផ្តល់ការអនុគ្រោះដូចៗគ្នា ដល់ដៃគូពាណិជ្ជកម្មដែលទទួលបានការពេញចិត្តបំផុតពីរដ្ឋដំបូងគេ តាមរយៈការផ្តល់ឋានៈ MFN ដល់រដ្ឋមួយផ្សេងទៀត។ សូមមើល *ប្រព័ន្ធអនុគ្រោះទូទៅ* (GSP) ផងដែរ។

១៤. **ប្រព័ន្ធទូទៅនៃការអនុគ្រោះពន្ធ**(GSP) ជាយន្តការដែលរដ្ឋឧស្សាហកម្មមួយចំនួនបានចាប់ផ្តើមក្នុងទសវត្សឆ្នាំ ១៩៧០ ដើម្បីផ្តល់សម្បទានពន្ធគយលើទំនិញនាំចូលមួយចំនួន ដល់ប្រទេសតតិយលោក ជាការលើកលែងចំពោះគោលការណ៍ប្រជាជាតិអំណោយផលបំផុត (MFN)។ សូមមើល ប្រជាជាតិអំណោយផលបំផុត (MFN) ផងដែរ។

១៥. **ជុំអ៊ុយរូហ្គាយ** គឺជាការចរចាជាបន្តបន្ទាប់ ក្រោមកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយនិងពាណិជ្ជកម្ម (GATT) ដែលបានចាប់ផ្តើម នៅប្រទេសអ៊ុយរូហ្គាយ ក្នុងឆ្នាំ ១៩៨៦ និងបិទបញ្ចប់នៅឆ្នាំ ១៩៩៤ ដោយសម្រេចបានកិច្ចព្រមព្រៀងមួយស្តីពីការបង្កើតអង្គការពាណិជ្ជកម្មពិភពលោក។ ជុំអ៊ុយរូហ្គាយបានអនុវត្តតាមការចរចាកាលមុនៗរបស់កិច្ចព្រមព្រៀងGATT ដូចជា ជុំកេណ្ឌឺឌី និង ជុំតូក្យូ។ សូមមើល *អង្គការពាណិជ្ជកម្មពិភពលោក* (WTO)។

១៦. **ជុំដូហា** គឺជាការចរចាជាបន្តបន្ទាប់ ក្រោមក្របខណ្ឌអង្គការពាណិជ្ជកម្មពិភពលោក ដែលបានចាប់ផ្តើមនៅទីក្រុងដូហា ប្រទេសកាតារ ក្នុងឆ្នាំ ២០០១។ វាបានបន្តពីជុំអ៊ុយរូហ្គាយ ហើយបានផ្តោតលើ ការឧបត្ថម្ភធនកសិកម្ម កម្មសិទ្ធិបញ្ញា និងបញ្ហាផ្សេងទៀត។ សូមមើល *ជុំអ៊ុយរូហ្គាយ*ផងដែរ។

១៧. **កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាមេរិកខាងជើង** (NAFTA) គឺជាតំបន់ពាណិជ្ជកម្មសេរីមួយ រវាងសហរដ្ឋអាមេរិក កាណាដា និងម៉ិកស៊ិក ចាប់តាំងពីឆ្នាំ ១៩៩៤។

១៨. **ការតែល** (cartel) ជាសមាគមអ្នកផលិតឬអ្នកប្រើប្រាស់ (ឬទាំងពីរ) ផលិតផលណាមួយ ដែលបង្កើតឡើងក្នុងគោលបំណងគ្រប់គ្រងឬក្រឡុកតម្លៃទំនិញណាមួយនោះ នៅលើទីផ្សារពិភពលោក។

១៩. **អង្គការនៃបណ្តាប្រទេសនាំប្រេងចេញ** (OPEC) គឺជាការតែល(សមាគម) ដែលល្បីល្បាញជាងគេក្នុងសេដ្ឋកិច្ចអន្តរជាតិ។ សមាជិករបស់វាគ្រប់គ្រងប្រហែលពាក់កណ្តាលនៃការនាំចេញប្រេងសរុប នៅលើពិភពលោក ដែលច្រើនសមល្មមនឹងប៉ះពាល់ដល់តម្លៃប្រេងពិភពលោក។

២០. **គោលនយោបាយឧស្សាហកម្ម** គឺជាយុទ្ធសាស្ត្រដែលរដ្ឋាភិបាលធ្វើការយ៉ាងសកម្មជាមួយនឹងវិស័យឧស្សាហកម្ម ដើម្បីជំរុញកំណើននិងគោលនយោបាយពាណិជ្ជកម្ម ស្របតាមតម្រូវការរបស់ពួកគេ។

២១. **សិទ្ធិកម្មសិទ្ធិបញ្ញា** គឺជាការការពារផ្លូវច្បាប់លើស្នាដៃដើមរបស់អ្នកច្នៃប្រឌិត អ្នកនិពន្ធ អ្នកបង្កើត និងអ្នកសំដែង ក្រោមច្បាប់ប៉ាតង់ កម្មសិទ្ធិបញ្ញា រក្សាសិទ្ធិ និងពាណិជ្ជសញ្ញា។ សិទ្ធិបែបនេះបានក្លាយជាចំណុចដ៏ចម្រូងចម្រាសនៃការចរចាពាណិជ្ជកម្ម នៅទសវត្សឆ្នាំ ១៩៩០។

២២. **វិស័យសេវាកម្ម** គឺជាផ្នែកមួយនៃសេដ្ឋកិច្ច ដែលពាក់ព័ន្ធនឹងសេវាកម្ម (ដែលផ្ទុយពីការផលិតទំនិញរូបី)។ ការផ្តោតជាសំខាន់ក្នុងការចរចាពាណិជ្ជកម្មអន្តរជាតិ រួមមានវិស័យធនាគារ ការធានារ៉ាប់រង និងសេវាកម្មហិរញ្ញវត្ថុពាក់ព័ន្ធផ្សេងៗ។

២៣. **ឧស្សាហូបនីយកម្ម** គឺជាការប្រើប្រាស់ថាមពលឥន្ធនៈហ្វូស៊ីល ដើម្បីជំរុញគ្រឿងម៉ាស៊ីន និងការប្រមូលផ្តុំគ្រឿងម៉ាស៊ីនបែបនេះ រួមជាមួយនឹងផលិតផលដែលវាបង្កើតបាន។

២៤. **សេដ្ឋកិច្ចផែនការ**កណ្តាល គឺជាសេដ្ឋកិច្ចដែលអាជ្ញាធរនយោបាយ(រដ្ឋាភិបាលកណ្តាល)ជាអ្នកកំណត់តម្លៃនិងសម្រេចចិត្តលើកូតាផលិតកម្មនិងការប្រើប្រាស់ទំនិញនីមួយៗ ស្របតាមផែនការសម្រាប់រយៈពេលវែងឆ្ងាយ។

២៥. **សេដ្ឋកិច្ចអន្តរកាល** សំដៅលើបណ្តាប្រទេសនៅរុស្ស៊ីនិងអឺរ៉ុបខាងកើត ដែលព្យាយាមផ្លាស់ប្តូរពីរបបកុម្មុយនីស្តទៅជាមូលធននិយម ហើយដែលទទួលបានជោគជ័យក្នុងកម្រិតផ្សេងគ្នា។

២៦. **ឧស្សាហកម្មគ្រប់គ្រងដោយរដ្ឋ** សំដៅលើឧស្សាហកម្មទាំងឡាយដូចជាក្រុមហ៊ុនផលិតប្រេង និងក្រុមហ៊ុនអាកាសចរណ៍ ដែលជាកម្មសិទ្ធិទាំងស្រុងឬដោយផ្នែករបស់រដ្ឋ ពីព្រោះវាមានសារៈសំខាន់ចំពោះសេដ្ឋកិច្ចជាតិ។

២៧. **សេដ្ឋកិច្ចចំរុះ** គឺជាសេដ្ឋកិច្ចទាំងឡាយដូចជានៅបស្ចឹមប្រទេសឧស្សាហកម្មរីកចម្រើន ដែលមានទាំងការគ្រប់គ្រងរបស់រដ្ឋាភិបាលនិងកម្មសិទ្ធិឯកជនមួយចំនួនផងដែរ។

សំណួរអនុវត្តន៍

១. ឧបមាថា រដ្ឋរបស់អ្នកមានឱកាសសម្រេចបានកិច្ចព្រមព្រៀងពាណិជ្ជកម្មដ៏ធំមួយ ដោយការធ្វើសម្បទានច្រើន។ កិច្ចព្រមព្រៀងនេះនឹងផលិតទ្រព្យសម្បត្តិថ្មីចំនួន ៥ ពាន់លានដុល្លារ សម្រាប់រដ្ឋរបស់អ្នក ក៏ដូចជា ១០ ពាន់លានដុល្លារសម្រាប់រដ្ឋដៃគូនីមួយៗ (ដែលជាសម្ព័ន្ធមិត្តនយោបាយ ប៉ុន្តែជាគូប្រជែងសេដ្ឋកិច្ច)។ តើយោបល់អ្វីខ្លះដែលអ្នកគាំពារនិយម(mercantilist)អាចផ្តល់អោយមេដឹកនាំរដ្ឋរបស់អ្នក អំពីការធ្វើកិច្ចព្រមព្រៀងបែបនេះ? តើអំណះអំណាងអ្វីខ្លះដែលអាចគាំទ្រដល់យោបល់នោះ? តើយោបល់និងទស្សនៈរបស់អ្នកសេរីនិយមខុសពីនោះយ៉ាងដូចម្តេចខ្លះ?

២. ប្រទេសចិនហាក់ដូចជាបានធ្វើអន្តរកាលប្រកបដោយជោគជ័យឆ្ពោះទៅរកសេដ្ឋកិច្ចទីផ្សារ និងកំពុងមានកំណើនយ៉ាងឆាប់រហ័ស។ វាជាប្រទេសមានសេដ្ឋកិច្ចធំលំដាប់ទី២ នៅលើពិភពលោក។ តើអ្នកគិតថានេះជារឿងល្អឬអាក្រក់សម្រាប់រដ្ឋរបស់អ្នក? តើការថ្លឹងថ្លែងហេតុផលរបស់អ្នក ឆ្លុះបញ្ចាំងពីការសន្មត់របស់លទ្ធិគាំពារនិយមឬក៏លទ្ធិសេរីនិយម?

៣. ប្រសិនបើអ្នកជាក្រុមហ៊ុនផលិតរថយន្តនៅប្រទេសជប៉ុន តើបញ្ហាពាណិជ្ជកម្មជាក់លាក់អ្វីខ្លះដែលអ្នករំពឹងថានឹងជួបប្រទះ នៅពេលអ្នកចាប់ផ្តើមនាំចេញរថយន្តទៅកាន់សហរដ្ឋអាមេរិក? តើសង្គ្រាមពាណិជ្ជកម្មរវាងជប៉ុននិងអាមេរិកអាចប៉ះពាល់ដល់អាជីវកម្មរបស់អ្នកដោយរបៀបណាខ្លះ?

៤. យោងតាមទ្រឹស្តីស្ថេរភាពអនុត្តរភាព(មេរៀនទី២) តើការកើតឡើងជាថ្មីនៃអំណាចដ៏លើសលុបរបស់សហរដ្ឋអាមេរិក ក្រោយសង្គ្រាមត្រជាក់ មានឥទ្ធិពលអ្វីខ្លះ លើប្រព័ន្ធពាណិជ្ជកម្មពិភពលោក? តើឥទ្ធិពលទាំងនោះអាចស្តែងចេញ តាមរបៀបណាខ្លះ?

៥. មុនពេលអ្នកអានមេរៀននេះ តើអ្នកចូលចិត្តទិញទំនិញដែលផលិតនៅក្នុងប្រទេសរបស់អ្នកដល់កំរិតណា? បន្ទាប់ពីបានអានឬរៀនមេរៀននេះហើយ តើអ្នកបានផ្លាស់ប្តូរទស្សនៈលើប្រធានបទនោះដែរឬទេ? ដោយរបៀបណាខ្លះ?

៦. សាកល្បងស្រមៃថាមានតំបន់ពាណិជ្ជកម្មសេរីទូទាំងទ្វីបអាមេរិក ដែលនឹងរួមបញ្ចូលប្រទេសកាណាដានិងសហរដ្ឋអាមេរិក ជាមួយនឹងបណ្តាប្រទេសអាមេរិកឡាទីន ដែលតំលៃប្រាក់ឈ្នួលនៅទាប ឯបច្ចេកវិទ្យានៅមានកម្រិត។ តើឧស្សាហកម្មអាមេរិកមួយណា ដែលអ្នកគិតថានឹងទទួលបានផលចំណេញពីតំបន់ពាណិជ្ជកម្មបែបនេះ? ជាពិសេស តើអ្នកគិតថា ឧស្សាហកម្មដែលពឹងផ្អែកខ្លាំងលើកម្លាំងពលកម្ម ឬក៏ឧស្សាហកម្មបច្ចេកវិទ្យាខ្ពស់ នឹងក្លាយជាអ្នកឈ្នះ? ហេតុអ្វី?

ការស្វែងរកផលប្រយោជន៍រួម

ពាណិជ្ជកម្មសេរី

ផលប្រយោជន៍រួម៖ កិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក ជុំដូហា

រូបថត រដ្ឋមន្ត្រីពាណិជ្ជកម្ម WTO ជួបប្រជុំគ្នានៅប្រទេសអាហ្សង់ទីនឆ្នាំ ២០១៧។

សារតារ

ជាច្រើនទសវត្សរ៍មកហើយ ពិភពលោកបានកាត់បន្ថយរបាំងពាណិជ្ជកម្មយ៉ាងច្រើន ហើយក៏រីករាយនឹងភាពរុងរឿងកាន់តែខ្លាំង ជាលទ្ធផលនៃពាណិជ្ជកម្ម។ ការចរចាតាមរយៈអង្គការពាណិជ្ជកម្មពិភពលោក (WTO) ធ្វើអោយបណ្តាប្រទេសនានាបានបញ្ចប់កិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគីជាបន្តបន្ទាប់ ដែលរដ្ឋនីមួយៗទទួលបានសម្បទានពីរដ្ឋផ្សេងដែលបានធ្វើសម្បទានដល់ខ្លួនដែរ។ ការចរចាទាំងនេះតម្រូវអោយសមាជិកនីមួយៗ (ស្ទើរតែគ្រប់ប្រទេសមហាអំណាចពាណិជ្ជកម្មសំខាន់ៗនៅលើពិភពលោក) យល់ព្រម ជាមុនសិន មុនពេលដែលសមាជិកណាមួយអាចទទួលបានអត្ថប្រយោជន៍នៃកិច្ចព្រមព្រៀង។

កិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោកថ្មី គឺជាផលប្រយោជន៍រួម ពីព្រោះរដ្ឋសមាជិកទាំងអស់ទទួលបានផលចំណេញពីការបន្ធូរបន្ថយកម្រិតរឹតបន្តឹងពាណិជ្ជកម្ម ដោយមិនសំខាន់ថាប្រទេសណាមួយផ្តល់សម្បទាន ដែលត្រូវការជាចាំបាច់ដើម្បីឈានដល់កិច្ចព្រមព្រៀងនោះឡើយ។ ជាឧទាហរណ៍ ក្នុងជុំអ៊ុយរូហ្គាយមុន កិច្ចព្រមព្រៀងទាំងមូលត្រូវដាប់គាំង ខណៈពេលដែលប្រទេសបារាំង និងសហរដ្ឋអាមេរិក

បានខ្វែងគំនិតគ្នាអំពីការរឹតបន្តឹងរបស់បារាំងលើខ្សែភាពយន្តរបស់សហរដ្ឋអាមេរិក។ ថាតើបារាំង ឬអាមេរិក បានព្យាយាមជំនះលើបញ្ហានេះទេ ចុងក្រោយភាគីទាំងពីរនឹងទទួលបានអត្ថប្រយោជន៍ជារួមពីកិច្ចព្រមព្រៀងនេះ។ ប៉ុន្តែ ប្រសិនបើប្រទេសទាំងពីររឹងទទឹងដូចគ្នា កិច្ចព្រមព្រៀងទាំងមូលនឹងត្រូវរលាយ ហើយផលប្រយោជន៍រួមនឹងមិនលេចចេញឡើយ។ (នៅទីបញ្ចប់ ប្រទេសបារាំងអាចដិះសេះលែងដៃបាន ហើយកិច្ចព្រមព្រៀងពាណិជ្ជកម្មបានដំណើរការទៅមុខ។)

បញ្ហាប្រឈម

ជុំដូហាត្រូវជាប់គាំងអស់រយៈពេលច្រើនឆ្នាំ ហើយនៅទីបំផុតត្រូវបានផ្អាក។ ប្រទេសទាំងឡាយចង់បានពាណិជ្ជកម្មសេរីជាងមុនជារួម តាមរយៈកិច្ចព្រមព្រៀងណាមួយ (មានតម្លៃរាប់ពាន់លានដុល្លារដល់ពិភពលោក) ប៉ុន្តែ ពួកគេបែរជាខ្វែងគំនិតគ្នាអំពីការឧបត្ថម្ភធនផ្នែកកសិកម្មនិងបញ្ហាផ្សេងៗទៀត។ ដល់តែអ្នកចូលរួមទាំងអស់ព្រមព្រៀងគ្នាលើបញ្ហាដែលនៅសេសសល់ដ៏គួរអោយស្មុគស្មាញទាំងនេះ គ្មាននរណាម្នាក់អាចរីករាយនឹងការជំរុញសេដ្ឋកិច្ចដែលកិច្ចព្រមព្រៀងអង្គការWTOថ្មី នឹងនាំមកជាមួយនោះទេ។

ដំណោះស្រាយ

មានតែគោលការណ៍បដិការទេដែលអាចដោះស្រាយបញ្ហានេះបាន។ គ្មានអត្តសញ្ញាណរួមគួរអោយត្រេកអរ ដែលអាចប្រកួតប្រជែងជាមួយនឹងប្រាក់ដុល្លារនៅក្នុងហោប៉ៅនៃរដ្ឋពាក់ព័ន្ធធំៗ និងម្ចាស់ឆ្នោតរបស់ពួកគេ (ដូចជា រោងចក្រឧស្សាហកម្ម ប្រជាពលរដ្ឋ ។ល។)។ រចនាសម្ព័ន្ធពាណិជ្ជកម្មពិភពលោកទាំងមូលពឹងផ្អែកលើសមភាពជាផ្លូវការរវាងរដ្ឋចូលរួមទាំងអស់ ដូច្នេះ គោលការណ៍គ្រប់គ្រងមិនជើរតួសំខាន់ទេ។ ប្រាកដណាស់ កម្លាំងយោធាមិនអាចដោះស្រាយជម្លោះពាណិជ្ជកម្មបានទេ ដូចកាលដែលពួកគេបានធ្វើប៉ុន្មានសតវត្សរ៍មុន។

អនុលោមតាមដំណោះស្រាយតាមគោលការណ៍បដិការដាទូទៅ កិច្ចព្រមព្រៀងពាណិជ្ជកម្មមានភាពស្មុគ្រស្មាញខ្លាំង និងភាពលម្អិតកម្រិតខ្ពស់បំផុត ហើយទាមទារការខិតខំប្រឹងប្រែងយ៉ាងច្រើនដើម្បីតាមដានការអនុលោមតាមច្បាប់កំណត់។ នៅពេលដែលកិច្ចព្រមព្រៀងពាណិជ្ជកម្មជាសកលថ្មីលេចចេញជារូបរាង វានឹងកើតចេញពីការបំបែកការខ្វែងគំនិតគ្នាទៅជាបំណែកតូចៗជាច្រើន និងការស្វែងរកការសម្របសម្រួលទៅវិញទៅមក (គ្រប់គ្នាត្រូវផ្តល់សម្បទានខ្លះ) ចំពោះគ្នា។

ឧស្សន:ទិស័យគោលនយោបាយ

ប្រធានាធិបតីម៉ិកស៊ិក លោក អង់ដ្រេស ម៉ានុយអែល ឡូប៉េស អូប្រាដ័រ(Andrés Manuel López Obrador)

រូបថត ប្រធានាធិបតីម៉ិកស៊ិក

បញ្ហា: *តើអ្នកអាចប្តឹងប្តែងការទាមទាររបស់ដៃគូពាណិជ្ជកម្មដ៏សំខាន់ ជាមួយតម្រូវការសេដ្ឋកិច្ចក្នុងស្រុក យ៉ាងដូចម្តេច?*

សារតារ

សាកស្រមៃថាអ្នកគឺជាប្រធានាធិបតីនៃប្រទេសម៉ិកស៊ិក។ ក្នុងរយៈពេល ២០ ឆ្នាំកន្លងមកនេះ ស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេសអ្នកមានភាពប្រសើរឡើងយ៉ាងខ្លាំង។ សេដ្ឋកិច្ចរបស់ប្រទេសអ្នកឥឡូវនេះធំជាងគេ ស្ថិតក្នុងលំដាប់ទី ១៥ នៅក្នុងពិភពលោក (លំដាប់ទី ១១ បើគិតអំពីសមមូលនៃអំណាចទិញ)។ កំណើនសេដ្ឋកិច្ចមានភាពរឹងមាំដោយមានការកើនឡើង ៣ ភាគរយ ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ។ ការនាំចេញរបស់

ប្រទេសអ្នកបានកើនឡើង ហើយប្រេងឆៅរបស់ប្រទេសអ្នកដែលជាទុនបំរុងបានផ្តល់នូវប្រភពសាច់ប្រាក់ដ៏សំខាន់សម្រាប់សេដ្ឋកិច្ចរបស់ប្រទេសអ្នក។

សហរដ្ឋអាមេរិក កាណាដា ចិន ជប៉ុន និងអាឡឺម៉ង់ គឺជាដៃគូនាំចេញដ៏សំខាន់របស់ប្រទេសអ្នក។ យ៉ាងណាក៏ដោយ សហរដ្ឋអាមេរិកមានចំណែកជាង ៨០ ភាគរយ នៃការនាំចេញរបស់អ្នក និងជិត ៥០ ភាគរយនៃការនាំចូលរបស់ប្រទេសអ្នក។ ប្រទេសចិននិងអាឡឺម៉ង់ក៏ជាដៃគូនាំចេញនិងនាំចូលដ៏សំខាន់ផងដែរ ប៉ុន្តែ ប្រទេសទាំងពីរ នៅមានកម្រិតទាបបើធៀបនឹងសហរដ្ឋអាមេរិក។

ចាប់តាំងពីការបោះឆ្នោតជ្រើសរើស លោក ដូណាល់ ត្រាំ ប្រធានាធិបតីមក ទំនាក់ទំនងផ្លូវការជាមួយសហរដ្ឋអាមេរិកបានចាប់ផ្តើមមានភាពតានតឹង។ សូមរម្លឹកថា បេក្ខជនប្រធានាធិបតី ត្រាំ បានធ្វើយុទ្ធនាការបោះឆ្នោតថានឹងចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាមេរិកខាងជើង(NAFTA)ឡើងវិញ ដែលអាចបង្កការខាតបង់ដល់ម៉ិកស៊ិក។ លោកបានអំពាវនាវអោយសាងសង់ជញ្ជាំងព្រំដែនខ័ណ្ឌចែករវាងសហរដ្ឋអាមេរិកនិងម៉ិកស៊ិក ដើម្បីបញ្ឈប់ការធ្វើអន្តោប្រវេសន៍ខុសច្បាប់ ហើយបានប្តេជ្ញាថានឹងទាមទារអោយប្រទេសម៉ិកស៊ិកចេញថ្លៃចំណាយសាងសង់។ គាត់បានហៅប្រជាជនម៉ិកស៊ិក ដោយប្រើប្រាស់ពាក្យអាក្រក់ៗ ក្នុងន័យមើលងាយ។ នៅចុងឆ្នាំ ២០១៨ ប្រធានាធិបតីកាន់តំណែងមុន បានសម្រេចកិច្ចព្រមព្រៀងមួយដើម្បីកែសម្រួលNAFTA ដោយបង្កើតកិច្ចព្រមព្រៀងថ្មីមួយ ជាមួយសហរដ្ឋអាមេរិក និងកាណាដា។

ការពិចារណាក្នុងស្រុក

NAFTAមានប្រជាប្រិយភាពក្នុងចំណោមសាធារណជន ក្នុងប្រទេសរបស់អ្នក។ ទោះជាយ៉ាងណាក៏ដោយ លោកប្រធានាធិបតី ត្រាំ មិនមានប្រជាប្រិយភាពខ្លាំងនៅក្នុងប្រទេសម៉ិកស៊ិកទេ សាធារណជនម៉ិកស៊ិកមានការខឹងសម្បារនិងមានអារម្មណ៍ថាខ្លួនត្រូវគេមើលងាយ។ កិច្ចព្រមព្រៀងពាណិជ្ជកម្មថ្មីគួរតែបន្តផ្តល់ផលប្រយោជន៍ដល់ប្រទេសម៉ិកស៊ិកដូចដែលNAFTAដែរ។ ការផ្លាស់ប្តូរណាមួយដើម្បីលុបចោល ឬកែសម្រួលកិច្ចព្រមព្រៀងថ្មីយ៉ាងខ្លាំង នឹងក្លាយជាការគំរាមកំហែងដល់សេដ្ឋកិច្ចរបស់ប្រទេសអ្នក។

សេណារីយ៉ូ

ឥឡូវនេះ សាកស្រមៃថាដៃគូពាណិជ្ជកម្មសំខាន់ៗ (ចិន ប្រេស៊ីល និងអាឡឺម៉ង់) មករកអ្នកដើម្បីចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគីជាមួយពួកគេ។ នៅក្រោមបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មថ្មី អ្នកនឹងមិនអាចនាំចេញទំនិញទាំងនោះទៅកាន់សហរដ្ឋអាមេរិកបានទេ ប៉ុន្តែ អ្នកអាចស្វែងរកមធ្យោបាយបន្ថែមតម្លៃគ្រប់គ្រាន់ដល់ផលិតផលមួយចំនួន ដើម្បីដាក់ស្លាកពួកគេថា «ផលិតនៅម៉ិកស៊ិក» ហើយនាំចេញទៅសហរដ្ឋអាមេរិក។

ប៉ុន្តែ តាមរយៈការទទួលយកកិច្ចព្រមព្រៀងទាំងនេះ អ្នកទំនងជាបង្កអោយសហរដ្ឋអាមេរិកខឹងសម្បារ។ ហើយខណៈពេលដែលលោកប្រធានាធិបតី ត្រាំ មិនមានប្រជាប្រិយភាពនៅក្នុងប្រទេសរបស់អ្នកពាណិជ្ជកម្មជាមួយសហរដ្ឋអាមេរិក មានសារៈសំខាន់ចំពោះភាពជោគជ័យផ្នែកសេដ្ឋកិច្ចរបស់ប្រទេសអ្នក។ ប្រសិនបើសហរដ្ឋអាមេរិកព្យាយាមបិទពាណិជ្ជកម្មនោះ វានឹងក្លាយជាមហន្តរាយសម្រាប់សេដ្ឋកិច្ចរបស់អ្នក។ ទោះបីជាយ៉ាងណាក៏ដោយ ការគំរាមកំហែងណាមួយរបស់សហរដ្ឋអាមេរិកក្នុងការធ្វើដូច្នេះ មិនគួរអោយជឿជាក់ទាំងស្រុងនោះទេ សហរដ្ឋអាមេរិកពឹងផ្អែកលើទីផ្សាររបស់អ្នកក្នុងការនាំចេញទំនិញកសិកម្មជាច្រើន

របស់ពួកគេ ដូច្នេះសង្គ្រាមពាណិជ្ជកម្មនឹងធ្វើអោយប៉ះពាល់ដល់ភាគីទាំងពីរ (ទោះបីជាវាបង្កការខូចខាតដល់ប្រទេសម៉ិកស៊ិកច្រើនជាងក៏ដោយ)។

ចូរជ្រើសរើសគោលនយោបាយរបស់អ្នក

តើអ្នកទទួលយកការផ្តល់ជូនកិច្ចព្រមព្រៀងថ្មីពីដៃគូពាណិជ្ជកម្មផ្សេងទៀតរបស់អ្នកដែរឬទេ? តើអ្នកនឹងព្យាយាមស្វែងរកទីផ្សារផ្សេងជំនួសសហរដ្ឋអាមេរិកដើម្បីការពារការប្រថុយរបស់អ្នក ដោយដឹងថាអ្នកមិនអាចជំនួសទីផ្សារទាំងនេះ ទាំងស្រុងបានទេ? តើអ្នកនឹងធ្វើថ្លឹងថ្លែងការទាមទាររបស់ដៃគូពាណិជ្ជកម្មនានាដែលប្រកួតប្រជែង(និងសំខាន់) បានយ៉ាងដូចម្តេច ខណៈពេលដែលព្យាយាមសម្រេចបានលទ្ធផលល្អបំផុតសម្រាប់សាធារណៈជនរបស់អ្នក?

មតិសាធារណៈ និងទំនាក់ទំនងអន្តរជាតិ

កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាមេរិកខាងជើង(NAFTA)

នៅថ្ងៃទី ១ ខែមករា ឆ្នាំ ១៩៩៤ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាមេរិកខាងជើង(NAFTA) បានចូលជាធរមាន។ គោលដៅចម្បងនៃកិច្ចព្រមព្រៀងនេះ គឺដើម្បីលុបបំបាត់របាំងពាណិជ្ជកម្ម និងការវិនិយោគរវាងប្រទេសកាណាដា ម៉ិកស៊ិក និងសហរដ្ឋអាមេរិក។ កិច្ចព្រមព្រៀងនេះបានជំនួសកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងសហរដ្ឋអាមេរិកនិងកាណាដា ដែលបានចូលជាធរមាន កាលពីឆ្នាំ ១៩៨៨ ។

កិច្ចព្រមព្រៀងNAFTA មានភាពចម្រូងចម្រាស តាំងពីចាប់ផ្តើមដំបូងមកម្លេះ។ នៅសហរដ្ឋអាមេរិក ក្រុមបរិស្ថាន ក្រុមសហជីពកម្មករនិងឧស្សាហកម្មមួយចំនួន បានប្រឆាំងយ៉ាងខ្លាំងក្លាចំពោះកិច្ចព្រមព្រៀងនេះ។ ពួកគេបានអះអាងថា វានឹងបណ្តាលអោយបាត់បង់ការងារយ៉ាងច្រើនសន្ធឹកសន្ធាប់នៅក្នុងសហរដ្ឋអាមេរិក ក៏ដូចជាបង្កបញ្ហាសិទ្ធិមនុស្សនិងបរិស្ថាន ដោយសារកង្វះស្តង់ដារការងារ និងបរិស្ថាននៅក្នុងប្រទេសម៉ិកស៊ិក។ ទោះបីជាយ៉ាងណាក៏ដោយ វាក៏ទទួលបានការគាំទ្រយ៉ាងសំខាន់ពីក្រុមធុរកិច្ចជាច្រើន ដែលបានអះអាងថា កិច្ចព្រមព្រៀងនេះនឹងនាំមកនូវទំនិញតម្លៃទាបដល់ប្រជាជនអាមេរិក កំណើនសេដ្ឋកិច្ចកាន់តែប្រសើរ ហើយក្នុងអនាគតវែងឆ្ងាយ ការងារកាន់តែច្រើនសម្រាប់សហរដ្ឋអាមេរិក។ សភានិងព្រឹទ្ធសភាអាមេរិកបានអនុម័តកិច្ចព្រមព្រៀងនេះ ដោយសម្លេងភាគច្រើនដាច់ខាត បន្ទាប់ពីប្រធានាធិបតី គ្លីនតុន បានចរចាលើពិធីសារ NAFTA ចំនួនពីរបន្ថែមទៀត៖ មួយស្តីពីសិទ្ធិការងារ មួយទៀតស្តីពីស្តង់ដារបរិស្ថាន។

ភាពចម្រូងចម្រាសលើកិច្ចព្រមព្រៀងNAFTAបានធ្លាក់ចុះ នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ នៅពេលដែលសេដ្ឋកិច្ចរបស់សហរដ្ឋអាមេរិកមានកំណើនលូតលាស់និងរីកចម្រើន។ ប៉ុន្តែ ក្នុងអំឡុងពាក់កណ្តាលទសវត្សរ៍ឆ្នាំ ២០០០ ក្រុមអ្នករិះគន់កិច្ចព្រមព្រៀងNAFTAបានចាប់ផ្តើមបំពងសំឡេងខ្លួនម្តងទៀត ដោយមិនសូវកង្វល់លើការរំលោភលើការងារឬបញ្ហាបរិស្ថាន និងបារម្ភលើការបាត់បង់ការងារ ជាពិសេស នៅក្នុងវិស័យឧស្សាហកម្មនៅសហរដ្ឋអាមេរិក។ នៅពេលយុទ្ធនាការបោះឆ្នោតប្រធានាធិបតីឆ្នាំ ២០១៦ បានចាប់ផ្តើមបេក្ខជនពីររូបមកពីគណបក្សធំៗ គឺ លោក ដូណាល់ ត្រាំ មកពីគណបក្សសាធារណរដ្ឋ និងលោក ប៊ឺនី្ន សែនឌ័រ (Bernie Sanders) មកពីគណបក្សប្រជាធិបតេយ្យ ដោយបេក្ខជនទាំងពីរបានអះអាងថា កិច្ចព្រមព្រៀងNAFTAមិនមែនជាកិច្ចព្រមព្រៀងដ៏ល្អសម្រាប់សហរដ្ឋអាមេរិក និងជាកំហុសដ៏ធំ។


តើសាធារណជនអាមេរិកមានអារម្មណ៍យ៉ាងដូចម្តេច ចំពោះកិច្ចព្រមព្រៀងNAFTA នៅក្នុងកំឡុងពេលនេះ? ដូចដែលក្រាហ្វិក ៨.៤ បង្ហាញ មានការផ្លាស់ប្តូរទស្សនៈជ្រុលជ្រៅអំពីកិច្ចព្រមព្រៀងមួយនេះ។

អ្វីដែលគួរអោយចាប់អារម្មណ៍ ក្រោយកិច្ចព្រមព្រៀងNAFTAចូលជាធរមានភ្លាម ទោះបីមានលក្ខណៈចម្រូងចម្រាសក៏ដោយ ក៏ជនជាតិអាមេរិកជាច្រើនមិនមានទស្សនៈយោបល់ខ្លាំងក្លាអំពីកិច្ចព្រមព្រៀងនោះទេ។ (ចូរសម្គាល់នៅក្នុងការស្ទង់មតិដំបូង នៅពេលបូកបញ្ចូលភាគរយនៃការឆ្លើយតបទាំងពីរមតិ ផលបូកមានទំហំតិចជាង ១០០ ភាគរយនៃអ្នកឆ្លើយតប។) យ៉ាងណាមិញ ចាប់តាំងពីឆ្នាំ២០០៥មក មានមតិចម្រុះគ្នាច្រើនៈ អារម្មណ៍ដែលថាកិច្ចព្រមព្រៀងNAFTAល្អសម្រាប់សហរដ្ឋអាមេរិក ជាក្រុមធំបំផុតនៅក្នុងឆ្នាំ ២០០៥ ហើយឡើងម្តងទៀត ក្រោយឆ្នាំ ២០១៦ ។

កំឡុងពេលបោះឆ្នោតប្រធានាធិបតីអាមេរិកឆ្នាំ ២០១៦ មានការផ្លាស់ប្តូរទស្សនៈយោបល់គួរអោយកត់សម្គាល់ ដោយកិច្ចព្រមព្រៀងNAFTAកាន់តែមានប្រជាប្រិយភាព។ អ្វីដែលគួរអោយអស់សំណើច បម្លាស់ប្តូរនេះកើតឡើងដើម្បីប្រឆាំងនឹងជំហររបស់ប្រធានាធិបតី ត្រាំ ដែលចោទប្រកាន់ថាកិច្ចព្រមព្រៀងNAFTA មិនល្អសម្រាប់សហរដ្ឋអាមេរិក។ ការពន្យល់ដ៏សមស្របមួយសម្រាប់ការផ្លាស់ប្តូរសតិអារម្មណ៍សាធារណៈបែបនេះ គឺថា ការវាយប្រហាររបស់ប្រធានាធិបតី ត្រាំ លើកិច្ចព្រមព្រៀងបានបង្ខំអ្នកគាំទ្រNAFTAកាន់តែបញ្ចេញសម្លេងខ្លាំងអំពីអត្ថប្រយោជន៍នៃកិច្ចព្រមព្រៀងនេះ។

រូបភាព ៨.៤ មតិសាធារណៈរបស់សហរដ្ឋអាមេរិកចំពោះកិច្ចព្រមព្រៀង NAFTA

ប្រភពៈ មជ្ឈមណ្ឌលមតិសាធារណៈ Roper



ខ្សែកោងដុំកាវៈមិនអំណោយផលសម្រាប់អាមេរិក *ខ្សែកោងដុំមូល*ៈអំណោយផលល្អសម្រាប់អាមេរិក

ភាពចម្រូងចម្រាសលើកិច្ចព្រមព្រៀងNAFTA នៅសហរដ្ឋអាមេរិក មិនងាយនឹងដោះស្រាយចេញបានឡើយ។ ទោះបីជាមានការសន្យារបស់លោកប្រធានាធិបតី ត្រាំ ក្នុងការបញ្ចប់កិច្ចព្រមព្រៀងNAFTA ប្រសិនបើវាមិនអាចចរចាឡើងវិញបានក៏ដោយ ក៏ក្រុមអាជីវកម្ម និងឧស្សាហកម្មមួយចំនួនធំបានប្រឆាំងនឹង

ជំហរនេះ។ ការចរចាដើម្បីផ្លាស់ប្តូរកិច្ចព្រមព្រៀងNAFTAបានបន្តរហូតដល់ឆ្នាំ ២០១៨ ប៉ុន្តែវានឹងផ្លាស់ប្តូរតែផ្នែកខ្លះនៃកិច្ចព្រមព្រៀងប៉ុណ្ណោះ ដោយរក្សាទុកបទបញ្ញត្តិភាគច្រើនដដែល។

គោះ! សាកល្បងពិភាក្សាអំពីបញ្ហាជាក់ស្តែង

តើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីល្អសម្រាប់សេដ្ឋកិច្ចសកលដែរឬទេ?

ទិដ្ឋភាពទូទៅ

ចំនួនកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីនិងពហុភាគី (FTAs) បានកើនឡើងច្រើនក្រៃលែង ក្នុងរយៈពេលម្តៃប្រាំឆ្នាំកន្លងមក។ បច្ចុប្បន្ននេះ ស្ទើរតែគ្រប់ប្រទេសទាំងអស់គឺជាភាគីនៃFTA យ៉ាងហោចណាស់មួយ។ ប្រទេសជាច្រើនគឺជាភាគីនៃFTAចម្រុះជាច្រើន ហើយស្ទើរតែFTAsទាំងអស់ គ្របដណ្តប់រដ្ឋដែលជាសមាជិកនៃអង្គការWTO ។

មានហេតុផលជាច្រើនដែលពន្យល់អំពីសន្ទុះកំណើននៃកិច្ចព្រមព្រៀង នាពេលថ្មីៗនេះ។ អ្នកខ្លះសន្មតថា ប្រជាប្រិយភាពនៃគំរូសេដ្ឋកិច្ចសេរីនិយមថ្មីនិងការសង្កត់ធ្ងន់របស់វាលើពាណិជ្ជកម្មសេរី ជាប្រភពនៃការលើកទឹកចិត្តសម្រាប់កិច្ចព្រមព្រៀងទាំងនេះ។ អ្នកផ្សេងទៀតចង្អុលទៅដល់ការផ្អាកការចរចារជុំដូហារបស់អង្គការWTO។ ប្រសិនបើអង្គការWTOឈប់ពង្រីកវិសាលភាព ក្រុមរដ្ឋនានានឹងធ្វើដូច្នេះ ដោយខ្លួនឯងដោយចុះហត្ថលេខាលើកិច្ចព្រមព្រៀងFTA។ ជាចុងក្រោយ អ្នកខ្លះចង្អុលបង្ហាញទៅដល់សម្ពាធអាជីវកម្មដើម្បីចូលរួមក្នុងការរៀបចំកិច្ចព្រមព្រៀងទាំងនេះ ដោយសារតែនៅក្រោមកិច្ចព្រមព្រៀងFTA សាជីវកម្មពហុជាតិ(MNCs) ដែលមានរោងចក្រជាច្រើន នៅក្នុងរដ្ឋនានាអាចដឹកជញ្ជូនទំនិញរវាងរោងចក្រទាំងនោះដោយមិនចាំបាច់បង់ពន្ធ។

ទោះបីជាមានកិច្ចព្រមព្រៀងបែបនេះសន្ធឹកសន្ធាប់ក៏ដោយ វានៅមានភាពចម្រូងចម្រាសខ្លាំងណាស់ដែរ។ ដូចដែលបានពិភាក្សានៅក្នុងមេរៀននេះ ពាណិជ្ជកម្មសេរីនាំមកនូវអត្ថប្រយោជន៍សាយភាយច្រើនអនេក ប៉ុន្តែការខាតបង់មានលក្ខណៈប្រមូលផ្តុំ ប៉ុន្តែ តែងតែមានការប្រឆាំងចំពោះកិច្ចព្រមព្រៀងទាំងនេះ នៅក្នុងរដ្ឋសមាជិក។ អ្នកសេដ្ឋកិច្ចទាំងឡាយក៏មានការខ្វែងគំនិតគ្នាថា តើកិច្ចព្រមព្រៀងFTAsមានប្រយោជន៍ដែរឬអត់ ដោយសាររដ្ឋទំនងជាមិនសូវសហការគ្នាដើម្បីសម្រេចបាននូវពាណិជ្ជកម្មសេរីសកល (លទ្ធផលល្អបំផុតសម្រាប់អ្នកសេដ្ឋកិច្ច) ប្រសិនបើពួកគេសប្បាយចិត្តជាមួយនឹងពាណិជ្ជកម្មសេរី ក្នុងចំណោមដៃគូពាណិជ្ជកម្មសំខាន់ៗរបស់ពួកគេ។ ប៉ុន្តែ អ្នកផ្សេងទៀតអះអាងថា ពួកគេគឺជាជំហានសមរម្យ (អាចទទួលយកបាន) ឆ្ពោះទៅកាន់ពិភពពាណិជ្ជកម្មសេរីសកល។ តើកិច្ចព្រមព្រៀង FTAs ល្អសម្រាប់សេដ្ឋកិច្ចពិភពលោក ឬ តើវានាំមកនូវភាពលំបាកកាន់តែខ្លាំងបន្ថែមទៀត ទាំងក្នុងនិងក្រៅប្រទេសឬយ៉ាងណា?

អំណះអំណាង ១

កិច្ចព្រមព្រៀង FTAs មានអត្ថប្រយោជន៍ដល់សេដ្ឋកិច្ចសកល

កិច្ចព្រមព្រៀងFTA ជាធម្មតា បានបង្កើនពាណិជ្ជកម្ម។

ការសិក្សាមួយចំនួនអំពីសេដ្ឋកិច្ចបានបង្ហាញថា តំបន់ពាណិជ្ជកម្មសេរីបង្កើនទំហំពាណិជ្ជកម្មរវាងប្រទេសពាក់ព័ន្ធ។ ពាណិជ្ជកម្មនេះអាចផ្តល់អត្ថប្រយោជន៍ដល់អ្នកប្រើប្រាស់និងអ្នកផលិត និងជួយបង្កើនកំណើនសេដ្ឋកិច្ច។ ដោយសារអត្រានៃវឌ្ឍនភាពយឺតក្នុងកិច្ចពិភាក្សាអង្គការWTO ដំណោះស្រាយផ្សេងទៀតត្រូវការជាចាំបាច់ដើម្បីបង្កើនពាណិជ្ជកម្ម។

ពាណិជ្ជកម្មសេរីកាត់បន្ថយការចំណាយរបស់អ្នកប្រើប្រាស់។

នៅពេលដែលពន្ធគយត្រូវបានដកចេញពីទំនិញ ទំនិញទាំងនេះអាចត្រូវបានលក់ចេញក្នុងតម្លៃថោកជាងមុន។ អ្នកប្រើប្រាស់ទទួលបានអត្ថប្រយោជន៍ពីតម្លៃថោកបែបនេះ។ ក្នុងករណីធ្ងន់ធ្ងរ កិច្ចព្រមព្រៀង FTAs អាចកាត់បន្ថយពន្ធគយ ដែលមានប្រសិទ្ធភាពរារាំងទំនិញមិនអោយចូលទៅក្នុងទីផ្សារ ដោយផ្តល់អោយអ្នកប្រើប្រាស់នូវជម្រើសកាន់តែច្រើននៅក្នុងផលិតផលដែលពួកគេចង់ទិញ។

កិច្ចព្រមព្រៀងFTAs បង្កើនការវិនិយោគបរទេស។

ដោយសារតែ កិច្ចព្រមព្រៀងFTAs បានលុបបំបាត់ឬបន្ថយរបាំងពាណិជ្ជកម្ម ពួកគេលើកទឹកចិត្តអោយក្រុមហ៊ុន ដែលមានទីតាំងនៅបណ្តារដ្ឋ នៅខាងក្រៅកិច្ចព្រមព្រៀងFTAs ដើម្បីផ្លាស់ប្តូរទីតាំងរោងចក្រថ្មី ទៅក្នុង FTAs ដើម្បីទាញយកអត្ថប្រយោជន៍ពីអត្រាពន្ធទាប។ ការស្រាវជ្រាវមួយចំនួនបានបង្ហាញថា កិច្ចព្រមព្រៀងFTAs ទាក់ទាញការបង្កើនការវិនិយោគបរទេសដល់រដ្ឋជាសមាជិក ដែលជាមធ្យោបាយសំខាន់ក្នុងការបង្កើនកំណើនសេដ្ឋកិច្ច ជាពិសេសនៅក្នុងប្រទេសក្រីក្រ។

អំណះអំណាង ២

កិច្ចព្រមព្រៀងFTAs បង្កគ្រោះថ្នាក់ដល់សេដ្ឋកិច្ចសកល

កិច្ចព្រមព្រៀងFTAs រារាំងការរីកចំរើននៃពាណិជ្ជកម្មសេរីសកល។

អ្នកសេដ្ឋកិច្ចភាគច្រើនយល់ស្របថា ស្ថានភាពដ៏ល្អបំផុតនៅក្នុងសេដ្ឋកិច្ចពិភពលោកគឺជាការលុបបំបាត់របាំងពាណិជ្ជកម្មទាំងស្រុង តាមរយៈកិច្ចព្រមព្រៀងដ៏ធំមួយ ដូចជាអង្គការ WTO។ នៅពេលដែលរដ្ឋមានដៃគូពាណិជ្ជកម្មដ៏ល្អបំផុត នៅក្នុងកិច្ចព្រមព្រៀងFTAណាមួយហើយ ពួកគេមិនត្រូវជម្រុញលើកទឹកចិត្តដើម្បីជំរុញដំណើរការអង្គការWTOនោះទេ។

កិច្ចព្រមព្រៀងFTAs គឺមិនរាប់បញ្ចូល និងរើសអើង។

តាមនិយមន័យ កិច្ចព្រមព្រៀងFTAs ផ្តល់អត្រាពន្ធគយទាបសម្រាប់តែរដ្ឋមួយចំនួនតូចតែប៉ុណ្ណោះ។ ពួកគេមិនដោះស្រាយការយកពន្ធលើរដ្ឋមិនមែនជាសមាជិកទេ ហើយរដ្ឋសមាជិកអាចមានការលើកទឹកចិត្តក្នុងការបង្កើនពន្ធគយប្រឆាំងនឹងរដ្ឋមិនមែនជាសមាជិក ដើម្បីលើកទឹកចិត្តពាណិជ្ជកម្មក្នុងកិច្ចព្រមព្រៀង FTA និងរារាំងការនាំចូលពីខាងក្រៅកិច្ចព្រមព្រៀង។

កិច្ចព្រមព្រៀងFTAs គំរាមកំហែងការងារ និងសុខុមាលភាពសេដ្ឋកិច្ចទូទៅ។

ដោយសារតែកិច្ចព្រមព្រៀងFTAs ធ្វើអោយទំនិញឆ្លងកាត់ព្រំដែនជាតិនានាកាន់តែងាយស្រួល ចំណែកក្រុមហ៊ុនទាំងឡាយអាចបោះទីតាំងរោងចក្រកាន់តែងាយស្រួលក្នុងរដ្ឋសមាជិកផ្សេងទៀត ដែលតម្លៃពលកម្មឬស្តង់ដារបរិស្ថានទាបជាង ម្លោះហើយអាចកាត់បន្ថយថ្លៃដើមសម្រាប់ផលិតកម្មទំនិញរបស់ពួកគេ។ នេះមានន័យថាមានការងារតិចជាងមុន នៅក្នុងរដ្ឋជាសមាជិកមួយចំនួន ហើយអាចនាំអោយមានការរិចរិលបរិស្ថានធម្មជាតិបន្ថែមទៀត។

សំណួរ

- តើអ្នកមានអារម្មណ៍ថាកិច្ចព្រមព្រៀងFTAsមានប្រយោជន៍ឬមានគ្រោះថ្នាក់ដល់សេដ្ឋកិច្ចសកល? តើសេដ្ឋកិច្ចសកលនឹងមានភាពប្រសើរជាងមុន ដោយគ្មានFTA ដោយទុកតែត្រឹមតែអង្គការWTO ដើម្បីធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្ម ដែរឬយ៉ាងណា?

• នៅពេលដែលសេដ្ឋកិច្ចសកលបានងើបចេញពីវិបត្តិសេដ្ឋកិច្ច ឆ្នាំ ២០០៨-២០០៩ តើយើងនឹងឃើញការវិលត្រលប់ទៅរកពាណិជ្ជកម្មសេរីវិញដែរឬទេ? តើទស្សនៈបច្ចុប្បន្នចំពោះឥទ្ធិពលនៃពាណិជ្ជកម្មសេរីត្រូវឆេះឥទ្ធិពល ដោយវិបត្តិសេដ្ឋកិច្ចសកលកម្រិតណា?

• ឧបមាថាការចរចារបស់អង្គការWTO នៅតែបន្តជាប់គាំង ដោយគ្មានសង្ឃឹមថានឹងសម្រេចបានកិច្ចព្រមព្រៀងពាណិជ្ជកម្មសកលកាន់តែទូលំទូលាយក្នុងពេលឆាប់ៗខាងមុខឡើយ។ តើនេះអាចនឹងផ្លាស់ប្តូរគំនិតរបស់អ្នក ថាតើកិច្ចព្រមព្រៀងFTAគួរតែត្រូវធ្វើឡើងបន្ថែមទៀតដែរឬទេ? ឬតើផលប៉ះពាល់ក្នុងស្រុក (បម្រែបម្រួលតម្លៃ ធៀបនឹង ការបាត់បង់ការងារ) មានសារៈសំខាន់ជាង នៅក្នុងការគិតគូររបស់អ្នក?

និស្សិតអាចសាកល្បងអានឯកសារខាងក្រោមបន្ថែមទៀត ដើម្បីជាគ្រឹះក្នុងការឆ្លើយសំណួរទាំងអស់ខាងលើ ៖

- Chang, Ha-Joon. *Bad Samaritans: The Myth of Free Trade and the Secret History of Capitalism.* Bloomsbury, 2007.
- Irwin, Douglas. *Free Trade Under Fire.* 4th ed. Princeton, 2015.
- Rodrik, Dani. *Straight Talk on Trade: Ideas for a Sane World Economy.* Princeton, 2017.
- Stiglitz, Joseph, and Andrew Charlton. *Fair Trade for All: How Trade Can Promote Development.* Oxford, 2006.

ឯកសារគួរអានបន្ថែម

- Bernstein, William J. *A Splendid Exchange: How Trade Shaped the World.* Grove, 2009.
- Blackwill, Robert D., and Jennifer M. Harris. *War by Other Means: Geoeconomics and Statecraft.* Belknap, 2017.
- Hufbauer, Gary Clyde, Jeffrey Schott, Kimberly Ann Elliot, and Barbara Oegg. *Economic Sanctions Reconsidered.* Peterson Institute, 2008.
- Irwin, Douglas. *Against the Tide: An Intellectual History of Free Trade.* Princeton, 1996.
- North, Douglass C., and Robert Paul Thomas. *The Rise of the Western World: A New Economic History.* Cambridge, 1973.
- Rivoli, Pietra. *The Travels of a T-Shirt in the Global Economy: An Economist Examines the Markets, Power, and Politics of World Trade.* Wiley, 2014.

មេរៀនទី ០៩ ៖ ហិរញ្ញវត្ថុនិងជំនួញសាកល

រូបថត សូចនាករទីផ្សារភាគហ៊ុនពិភពលោក ទីក្រុងតូក្យូ ឆ្នាំ ២០១៨ ។

វត្ថុបំណងមេរៀន

៩.១ ចូរពិពណ៌នាផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុសកល ឆ្នាំ ២០០៨-២០០៩។

៩.២ ចូរសង្ខេបប្រព័ន្ធអត្រាប្តូរប្រាក់បីប្រភេទ ដែលត្រូវបានអនុម័តដោយរដ្ឋនានា។

៩.៣ ចូរប្រៀបធៀបលក្ខណៈដូចនិងខុសគ្នានៃជំហរហិរញ្ញវត្ថុរបស់សហរដ្ឋអាមេរិកនិងរុស្ស៊ី ទាក់ទងនឹងសក្តានុពលនៃកំណើនសេដ្ឋកិច្ច នាពេលអនាគត។

៩.៤ ចូរកំណត់កត្តាហានិភ័យចំពោះក្រុមហ៊ុន ដែលពាក់ព័ន្ធនឹងវិនិយោគផ្ទាល់ពីបរទេសចំនួនពីរយ៉ាងតិច និងហានិភ័យចំពោះប្រទេសដែលទទួលការវិនិយោគផ្ទាល់ពីបរទេសនោះ ចំនួនពីរយ៉ាងតិច។

៩.១. សាកលភាវូបនីយកម្ម និងហិរញ្ញវត្ថុ

៩.១ ចូរពិពណ៌នាផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុសកល ឆ្នាំ ២០០៨-២០០៩។

សាកលភាវូបនីយកម្មបាននាំអោយមានការផ្លាស់ប្តូរធំធេង នៅក្នុងផ្នែកជាច្រើននៃទំនាក់ទំនងអន្តរជាតិ(IR)។ រហូតមកដល់ពេលនេះ យើងបានពិភាក្សាអំពីរបៀបដែលសាកលភាវូបនីយកម្មបានជះឥទ្ធិពលលើសន្តិសុខពិភពលោក និងទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិ។ សកលភាវូបនីយកម្មបានមានឥទ្ធិពលយ៉ាងជ្រាលជ្រៅបំផុតនៅលើរបៀបដែលរដ្ឋ អាជីវកម្ម និងបុគ្គលទាំងឡាយប្រាស្រ័យទាក់ទងគ្នាក្នុងទីផ្សារហិរញ្ញវត្ថុ។

សព្វថ្ងៃនេះ ទីផ្សារហិរញ្ញវត្ថុសកលត្រូវបានធ្វើសមាហរណកម្ម មិនធ្លាប់មានពីមុនមក។ វិនិយោគិនក្នុងប្រទេសមួយទិញនិងលក់ទ្រព្យសកម្មឬប្តូរប័ណ្ណ ដោយចុចលើកញ្ចក់ទូរស័ព្ទពីរបីដងតែប៉ុណ្ណោះ។ ផ្នែកមូលប័ត្រវិនិយោគរបស់ធនាគារ ជារឿយៗ ប្រមូលទ្រព្យសម្បត្តិតម្លៃរាប់លានដុល្លារ (អចលនទ្រព្យ ដីធ្លី ភាគហ៊ុន) ដែលមានទីតាំងនៅប្រទេសផ្សេងៗទៀត។ ប្រហែល ៣ ទ្រីលានដុល្លារក្នុងមួយថ្ងៃត្រូវបានដោះដូរនៅលើទីផ្សាររូបិយប័ណ្ណ ពីព្រោះវិនិយោគិនត្រូវការរូបិយប័ណ្ណផ្សេងៗ ដើម្បីធ្វើអាជីវកម្មក្នុងប្រទេសដទៃនិងដើម្បីយកចំណេញពីការកើនឡើងនិងធ្លាក់ចុះតម្លៃរូបិយប័ណ្ណ ដែលយើងពិភាក្សាក្នុងពេលបន្តិចទៀតនេះ។

សមាហរណកម្មហិរញ្ញវត្ថុនេះ មានអត្ថប្រយោជន៍យ៉ាងច្រើនសន្ធឹក។ វាផ្តល់អោយវិនិយោគិននិងអាជីវកម្មទាំងឡាយនូវច្រកចូលទៅកាន់ទីផ្សារក្រៅប្រទេស ដើម្បីជំរុញកំណើនសេដ្ឋកិច្ច។ វាអនុញ្ញាតអោយមានលទ្ធភាពទទួលផលចំណេញពីការវិនិយោគកាន់តែប្រសើរឡើង សម្រាប់បុគ្គលដែលវិនិយោគលើការសិក្សានៅមហាវិទ្យាល័យឬការចូលនិវត្តន៍។ ប៉ុន្តែ សមាហរណកម្មហិរញ្ញវត្ថុក៏នាំមកនូវហានិភ័យផងដែរ។ វិបត្តិសេដ្ឋកិច្ចនៅក្នុងរដ្ឋមួយអាចរីករាលដាលយ៉ាងឆាប់រហ័សទៅរដ្ឋមួយទៀត ហើយបន្តទៅរដ្ឋមួយទៀត។ ការរីករាលដាលនៃភាពលំបាកលំបិនសេដ្ឋកិច្ចអាចនាំអោយមានវិបត្តិសេដ្ឋកិច្ចសកលលោក យ៉ាងឆាប់រហ័ស ដែលប៉ះពាល់ទាំងសេដ្ឋកិច្ចតូច និងទាំងសេដ្ឋកិច្ចធំ។

ករណីបែបនេះបានកើតឡើងនៅក្នុងឆ្នាំ ២០០៨។ នៅពេលដែលសេដ្ឋកិច្ចនៅសហរដ្ឋអាមេរិកបានចាប់ផ្តើមធ្លាក់ចុះ ជនជាតិអាមេរិកជាច្រើនដែលបានខ្ចីប្រាក់បង់រំលោះផ្ទះ ពួកគេដឹងខ្លួនថា ពួកគេមិនអាចសងប្រាក់កម្ចីទាំងនេះបានទេ។ ដំណាលពេលនោះដែរ តម្លៃផ្ទះរបស់ពួកគេចាប់ផ្តើមធ្លាក់ចុះ ម្ល៉ោះហើយ បើទោះបីជាធនាគាររឹបអូសផ្ទះមកវិញក៏ដោយ ក៏ធនាគារមិនអាចប្រមូលប្រាក់ដែលពួកគេបានអោយគេខ្ចីមក

វិញដែរ។ លើសពីនេះទៅទៀត ប្រាក់កម្ចីទាំងនេះត្រូវបានធនាគារលក់បន្ត ម្តងហើយម្តងទៀត ទៅអោយអាជីវកម្មផ្សេងទៀត ជាការវិនិយោគ ជាញឹកញាប់ នៅក្នុងប្រទេសផ្សេងទៀត។ ធនាគារអាមេរិកធំៗជាច្រើនបានប្រកាសថា ពួកគេជិតក្ស័យធនហើយ ដោយសារពួកគេកប់លុយច្រើនពេក ក្នុងប្រាក់កម្ចីទិញផ្ទះ*មិនល្អ*ទាំងនេះ។ នេះមិនត្រឹមតែជាបញ្ហាសម្រាប់ធនាគារនិងបុគ្គលដែលមិនអាចបង់ថ្លៃរំលោះផ្ទះប៉ុណ្ណោះទេ ប៉ុន្តែ ក៏សម្រាប់អាជីវកម្មដែលបានទិញបំណុលទាំងនេះជាការវិនិយោគទៀតផង។

ដោយសារការធ្វើសមាហរណកម្មជាសកលនៃទីផ្សារហិរញ្ញវត្ថុ វិបត្តិលំនៅដ្ឋាននេះបាននាំអោយមានវិបត្តិធនាគារសកលលោក យ៉ាងឆាប់រហ័ស។ ធនាគារអង់គ្លេសជាច្រើនបានប្រកាសថា ពួកគេជិតក្ស័យធនហើយ។ រដ្ឋាភិបាលសហរដ្ឋអាមេរិកបានឆ្លើយតប ជាមួយនឹងកញ្ចប់ថវិកាសង្គ្រោះ ទំហំ ៨០០ ប៊ីលានដុល្លារដើម្បីជួយដោះស្រាយធនាគារដែលបរាជ័យ។ អង់គ្លេសក៏បានបង្កើតកញ្ចប់ថវិកាសង្គ្រោះ ជិត ៤៥០ ប៊ីលានដុល្លារផងដែរ។ វិស័យធនាគារនៃប្រទេសអ៊ីស្លង់ទាំងមូល ត្រូវបានកាន់កាប់ដោយរដ្ឋាភិបាល ហើយអ៊ីស្លង់ដែលជាប្រទេសរីកចម្រើន ត្រូវការប្រាក់កម្ចីពីមូលនិធិរូបិយវត្ថុអន្តរជាតិ(IMF)ដើម្បីជួយសង្គ្រោះរដ្ឋាភិបាលកុំអោយក្ស័យធន។

ជាលទ្ធផលនៃវិបត្តិហិរញ្ញវត្ថុនេះ ទីផ្សារភាគហ៊ុនសកលបានធ្លាក់ចុះយ៉ាងខ្លាំង ក្នុងកម្រិតមួយភាគបីមួយភាគពីរ ខ្លះរហូតដល់ពីរភាគបី នៅក្នុងករណីប្រទេសចិន។ ភាពអត់ការងារធ្វើបានកើនឡើង នៅទូទាំងពិភពលោក។ អ្វីដែលបានចាប់ផ្តើមដំបូងគ្រាន់តែជាបញ្ហានៅក្នុងទីផ្សារលំនៅដ្ឋានរបស់សហរដ្ឋអាមេរិក ត្រូវបានបញ្ចប់ដោយការរលាយហិរញ្ញវត្ថុសកលលោក។

សេដ្ឋកិច្ចពិភពលោកបានងើបឡើងវិញ ក្នុងរយៈពេលប៉ុន្មានឆ្នាំក្រោយឆ្នាំ ២០០៨ ប៉ុន្តែ ភ្លាមៗនោះបានប្រឈមមុខនឹងផលប៉ះពាល់ទុំជោរនៃវិបត្តិបំណុលនៅអឺរ៉ុប។ បញ្ហាហិរញ្ញវត្ថុនៅទីនោះ ដែលបានចាប់ផ្តើមក្នុងប្រទេសក្រិក ហើយបានរីករាលដាលដល់ប្រទេសអេស្ប៉ាញ ព័រទុយហ្គាល់ និងរហូតដល់ប្រទេសអ៊ីតាលី បានគំរាមកំហែងដល់សហភាពអឺរ៉ុបទាំងមូល ខណៈដែលកំពុងរារាំងកំណើន នៅក្នុងសហរដ្ឋអាមេរិក(សូមមើលមេរៀនទី ១០)។ ការរីករាលដាលនៃបញ្ហាហិរញ្ញវត្ថុទាំងនេះ បង្ហាញយ៉ាងច្បាស់ពីការពឹងអាស្រ័យគ្នាទៅវិញទៅមកផ្នែកហិរញ្ញវត្ថុសកល នាពេលបច្ចុប្បន្ននេះ។ ខណៈពេលដែលអ្នកជំនាញភាគច្រើនយល់ស្របថាសេដ្ឋកិច្ចពិភពលោកបានងើបចេញពីវិបត្តិហិរញ្ញវត្ថុឡើងវិញ វិបត្តិបំណុលក្រិកនៅតែបន្តញាំញីអឺរ៉ុប។

មេរៀននេះនឹងសង្កេតមើលសសរស្តម្ភដ៏សំខាន់ពីរនៃទីផ្សារហិរញ្ញវត្ថុសកល៖ នយោបាយនៃប្រព័ន្ធរូបិយវត្ថុពិភពលោកនិងតួនាទីក្រុមហ៊ុនឯកជនក្នុងនាមជាតួអង្គមិនមែនរដ្ឋ នៅក្នុងសេដ្ឋកិច្ចពិភពលោក។

៩.២. ប្រព័ន្ធហិរញ្ញវត្ថុ

៩.២ ចូរសង្ខេបប្រព័ន្ធអត្រាប្តូរប្រាក់បីប្រភេទ ដែលត្រូវបានអនុម័តដោយរដ្ឋនានា។

ស្ទើរតែគ្រប់រដ្ឋទាំងអស់បោះពុម្ពលុយខ្លួនឯងផ្ទាល់។ សមត្ថភាពក្នុងការបោះពុម្ពរូបិយប័ណ្ណផ្ទាល់របស់ខ្លួន គឺជាសញ្ញាសម្គាល់មួយនៃអធិបតេយ្យភាពរបស់រដ្ឋ។ ប៉ុន្តែ នៅក្នុងប្រព័ន្ធសកលភាវូបនីយកម្មនៃពាណិជ្ជកម្មនិងហិរញ្ញវត្ថុ, អាជីវកម្មនិងបុគ្គលតែងតែត្រូវការរូបិយប័ណ្ណរបស់រដ្ឋផ្សេងទៀតដើម្បីធ្វើជំនួញជួញដូរ។

៩.២.១. អំពីប្រាក់

ដោយសារតែធម្មជាតិនៃអធិបតេយ្យភាពរបស់រដ្ឋ សេដ្ឋកិច្ចអន្តរជាតិត្រូវផ្អែកលើរូបិយប័ណ្ណជាតិនីមួយៗ មិនមែនជារូបិយប័ណ្ណពិភពលោកទេ។ អំណាចសំខាន់មួយរបស់រដ្ឋាភិបាលជាតិគឺការបង្កើតរូបិយប័ណ្ណរបស់ខ្លួន

ជារូបិយប័ណ្ណស្របច្បាប់តែមួយគត់ នៅក្នុងទឹកដីដែលខ្លួនគ្រប់គ្រង។ រូបិយប័ណ្ណជាតិមិនមានតម្លៃពីកំណើត នៅក្នុងប្រទេសមួយផ្សេងទៀតនោះទេ ប៉ុន្តែវាអាចត្រូវគេប្តូរយករូបិយប័ណ្ណជាតិមួយផ្សេងទៀតបាន។

ជាប្រពៃណី អស់ជាច្រើនសតវត្សរ៍មកហើយ ប្រព័ន្ធរដ្ឋអឺរ៉ុបបានប្រើប្រាស់*លោហៈជាតុដ៏មានតម្លៃ*ជា រូបិយប័ណ្ណសកល ដែលមានតម្លៃអាចចាយវាយបាននៅក្នុងប្រទេសទាំងអស់។ *មាស*មានតម្លៃសំខាន់បំផុត ហើយ*ប្រាក់*សំខាន់បន្ទាប់។ លោហធាតុទាំងនេះមានតម្លៃពីកំណើត ព្រោះវាមើលទៅស្អាត ហើយងាយកែច្នៃ ទៅជាគ្រឿងអលង្ការឬគ្រឿងលំអរដទៃទៀត។ ពួកវាជាលោហធាតុកម្រណាស់ដែរ ហើយការជីកយករ៉ែមាស និងប្រាក់ថ្មីមានភាពយឺតយ៉ាវខ្លាំង។ លោហៈទាំងនេះមានភាពធន់ប្រើបានយូរ ហើយពួកវាពិបាករំលាយ ឬ ក្លែងបន្លំ។

យូរៗទៅ មាសនិងប្រាក់មានតម្លៃអនេក *ដោយសារ*ពួកគេក្លាយជារូបិយប័ណ្ណពិភពលោក (ដោយសារ តែមនុស្សផ្សេងទៀតនៅជុំវិញពិភពលោកជឿជាក់ថា លោហៈទាំងនេះអាចត្រូវបានដោះដូរយកទំនិញផ្សេងៗ នាពេលអនាគត) ហើយនេះបានគ្របដណ្តប់លើតម្លៃមុខងារដែលមានពីកំណើតរបស់មាសឬប្រាក់។ រដ្ឋ នានាបានស្តុកនិងចាត់ទុកដុំមាសនិងប្រាក់ជាប្រភេទគណនីធនាគារ ដែលកំណត់ជារូបិយប័ណ្ណអន្តរជាតិ។ គំនរមាសទាំងនេះ (ទាំងក្នុងន័យត្រង់និងន័យធៀប) គឺជាកម្មវត្ថុនៃគោលនយោបាយពាណិជ្ជកម្មរបស់អ្នក គាំពារនិយម ក្នុងសតវត្សកន្លងមក (សូមមើលមេរៀនទី ២ និងទី ៨)។ មាសគឺជាប្រភពធនធានអំណាចដ៏ សំខាន់មួយ ដែលរដ្ឋទាំងឡាយអាចប្រើដើម្បីទិញសព្វាវុធនិងកងទ័ព ឬមធ្យោបាយកៀបសង្កត់ផ្សេងទៀត។

ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ពិភពលោកមិនបានប្រើប្រាស់**ស្តង់ដារមាស**(gold standard)បែបនេះ ទេ ប៉ុន្តែបានអភិវឌ្ឍប្រព័ន្ធរូបិយវត្ថុអន្តរជាតិ ដែលមិនជាប់ពាក់ព័ន្ធនឹងមធ្យោបាយរូបីណាមួយ ដូចជាលោហៈ ដ៏មានតម្លៃឡើយ។ សូម្បីតែសព្វថ្ងៃនេះនេះក៏ដោយ វិនិយោគិនឯកជនមួយចំនួនទិញស្តុកមាស ឬប្រាក់នៅ ពេលមានអស្ថិរភាពនយោបាយ សម្រាប់ជាទូរស៊ុវត្ថិភាពដែលអាចទុកចិត្តបាននាពេលអនាគត។ ប៉ុន្តែមាស និងប្រាក់ បច្ចុប្បន្ននេះ មានសភាពដូចទំនិញផ្សេងទៀតដែរ ដោយមានតម្លៃប្រែប្រួលដែលមិនអាចទាយទុក ជាមុនបាន។ បម្លាស់ប្តូរនៅក្នុងសេដ្ឋកិច្ចពិភពលោក ដែលចាកឆ្ងាយពីដុំមាស ខិតទៅប្រើប្រាស់លុយអរូបី សុទ្ធសាធ ធ្វើអោយសេដ្ឋកិច្ចអន្តរជាតិកាន់តែមានប្រសិទ្ធភាព។ ផលអវិជ្ជមានតែមួយគត់ គឺថា ដោយគ្មានការ គាំទ្រជាក់ស្តែង(រូបី)ជាមាស រូបិយប័ណ្ណអាចមើលទៅមិនសូវមានតម្លៃទទួលបានការទុកចិត្តពីមនុស្ស។

៩.២.២. ការផ្លាស់ប្តូររូបិយប័ណ្ណអន្តរជាតិ

សព្វថ្ងៃនេះ រូបិយប័ណ្ណជាតិត្រូវបានផ្តល់តម្លៃ ធៀបនឹងគ្នា ទៅវិញទៅមក ដោយមិនធៀបនឹងមាស ឬប្រាក់ ទៀតទេ។ រូបិយប័ណ្ណរបស់រដ្ឋនីមួយៗអាចប្តូរយករូបិយប័ណ្ណរបស់រដ្ឋផ្សេងទៀត ដោយយោងតាម**អត្រាប្តូរ ប្រាក់**(exchange rate) ជាឧទាហរណ៍ ការកំណត់ថា តើចំនួនប៉ុន្មានដុល្លារកាណាដាស្មើនឹងមួយដុល្លារ អាមេរិក។ អត្រាប្តូរប្រាក់ទាំងនេះប៉ះពាល់ដល់ស្ទើរតែគ្រប់ប្រតិបត្តិការសេដ្ឋកិច្ចអន្តរជាតិ ដូចជា ពាណិជ្ជកម្ម ការវិនិយោគ ទេសចរណ៍ជាដើម។

អត្រាប្តូរប្រាក់ភាគច្រើនត្រូវបានបង្ហាញជារូបិយប័ណ្ណសំខាន់ៗរបស់ពិភពលោក ដូចជា ប្រាក់ដុល្លារ អាមេរិក ប្រាក់យ៉ែនជប៉ុន និងប្រាក់អឺរ៉ូរបស់សហភាពអឺរ៉ុប។ ដូច្នេះ អត្រាប្តូរប្រាក់ក្រោនរបស់ដាណឺម៉ាកយក ប្រាក់រៀលរបស់ប្រេស៊ីល ត្រូវអាស្រ័យលើតម្លៃប្រាក់នីមួយៗធៀបនឹងរូបិយប័ណ្ណពិភពលោកទាំងអស់នេះ។

អត្រាប្តូរប្រាក់ដែលប៉ះពាល់ដល់សេដ្ឋកិច្ចពិភពលោកភាគច្រើន គឺជារូបិយប័ណ្ណនៅក្នុងបណ្តាប្រទេសដែលមានសេដ្ឋកិច្ចធំបំផុត ដូចជា ដុល្លារអាមេរិក អឺរ៉ូ យ៉ែន ផោនអង់គ្លេស និងដុល្លារកាណាដា។

រូបថត អត្រាប្តូរប្រាក់

តើវាមានតម្លៃអ្វីសម្រាប់អ្នក?

លុយអាចមានតម្លៃទៅបានក៏ដោយសារតែមនុស្សជឿជាក់លើតម្លៃរបស់វា។ អតិផរណាបំផ្លាញតម្លៃរូបិយប័ណ្ណ ប្រសិនបើរដ្ឋាភិបាលបោះពុម្ពលុយច្រើនពេក ឬប្រសិនបើអស្ថិរភាពនយោបាយបំផ្លាញទំនុកចិត្តសាធារណៈ។ ការកែសម្រួលតិចតួចជាទៀងទាត់កំណត់តម្លៃរូបិយប័ណ្ណ; អត្រាប្តូរប្រាក់របស់អ៊ុយក្រែនក្នុងឆ្នាំ ២០១៥នេះ ឆ្លើយតបទៅនឹងការកើនឡើងអំពើហិង្សានៅក្នុងភាគខាងកើតនៃប្រទេសនោះ ដែលធ្វើអោយបាត់បង់តម្លៃរូបិយប័ណ្ណរបស់ខ្លួន។

តម្លៃធៀបនៃរូបិយប័ណ្ណ នៅក្នុងឬចំពេលណាមួយ ត្រូវធ្វើឡើងតាមអំពើចិត្ត មានតែ*ការប្រែប្រួល*តម្លៃក្នុងកំឡុងពេលកំណត់ណាមួយប៉ុណ្ណោះដែលមានអត្ថន័យ។ ជាឧទាហរណ៍ ប្រាក់អឺរ៉ូមានតម្លៃប្រហាក់ប្រហែលនឹងប្រាក់ដុល្លារអាមេរិក ចំណែកប្រាក់យ៉ែនជប៉ុនត្រូវបែងចែកជាឯកតាមានតម្លៃកៀកនឹង១សេនដុល្លារអាមេរិក។ ត្រឹមតែប៉ុណ្ណឹង គម្លាតទាំងនេះមិនអាចបញ្ជាក់អំពីតម្រូវការចង់បាននៃរូបិយប័ណ្ណទាំងនេះ ឬជំហរហិរញ្ញវត្ថុនៃរដ្ឋដែលបោះពុម្ពប្រាក់ទាំងនោះទេ។ ទោះយ៉ាងណាក៏ដោយ នៅពេលដែលតម្លៃប្រាក់អឺរ៉ូកើនឡើង(ធ្លាក់ចុះ)*ធៀបនឹង*ប្រាក់ដុល្លារ ដោយសារប្រាក់អឺរ៉ូត្រូវបានអោយតម្លៃខ្ពស់ជាង(ឬទាបជាង)មុន ប្រាក់អឺរ៉ូត្រូវបានគេវាយតម្លៃថា ខ្លាំង(ឬខ្សោយ)។ រូបិយប័ណ្ណខ្លាំងធ្វើអោយការនាំចូលអាចទទួលយកបានច្រើន ចំណែករូបិយប័ណ្ណខ្សោយធ្វើអោយការនាំចេញមានលក្ខណៈប្រកួតប្រជែងខ្ពស់។ ជាឧទាហរណ៍ នៅពេលដែលតម្លៃប្រាក់ដុល្លារអាមេរិកធ្លាក់ចុះ ក្នុងឆ្នាំ២០០១-២០០៦ ការនាំចេញរបស់ក្រុមហ៊ុនអាមេរិកធំៗ ចំនួន ២០០ ដែលមានការលក់ពីបរទេសយ៉ាងច្រើន បានកើនឡើងពី ៣២ ទៅ ៤៤ ភាគរយនៃការលក់សរុបរបស់ពួកគេ។

រដ្ឋមួយចំនួនមិន**រូបិយប័ណ្ណបំប្លែង** (convertible currencies) (ដែលអាចប្តូរយករូបិយប័ណ្ណផ្សេងបាន)ទេ។ អ្នកកាន់លុយបែបនេះមិនមានការធានាក្នុងការដោះដូរវាយករូបិយប័ណ្ណដទៃទៀតបានទេ ដូចក្នុងករណីរដ្ឋដែលកាត់ផ្តាច់ពីសេដ្ឋកិច្ចមូលធននិយមពិភពលោក ដូចជាអតីតសហភាពសូវៀតជាដើម។ នៅក្នុងការអនុវត្តជាក់ស្តែង សូម្បីតែរូបិយប័ណ្ណដែលមិនអាចបំប្លែងបាន ជាញឹកញាប់អាចបលក់បាននៅក្នុងទីផ្សារងងឹត ឬដោយការទាក់ទងផ្ទាល់ជាមួយរដ្ឋាភិបាលដែលចេញរូបិយប័ណ្ណនោះ ប៉ុន្តែ តម្លៃអាចនឹងទាបបំផុត។ រូបិយប័ណ្ណមួយចំនួនជាក់ស្តែងមិនអាចបំប្លែងបានទេព្រោះវាប្រែប្រួលតម្លៃលឿនពេក ដែលសូម្បីកាន់វានៅនឹងដៃមួយរយៈពេលខ្លី អាចនឹងខាតបង់លុយនោះទាំងស្រុង។ អតិផរណាកាត់បន្ថយតម្លៃរូបិយប័ណ្ណធៀបនឹងរូបិយប័ណ្ណដែលមានស្ថេរភាពជាង (តម្លៃប្រែប្រួលដែរ តែប្រែប្រួលយឺតៗ)។

ប្រទេសឧស្សាហូបនីយកម្មបស្ចឹមលោកបានរក្សាអតិផរណានៅកម្រិតទាប ភាគច្រើនទាបជាង ៥ ភាគរយ ជារៀងរាល់ឆ្នាំ ចាប់តាំងពីឆ្នាំ ១៩៨០។ (ទសវត្សរ៍ឆ្នាំ ១៩៧០ អតិផរណានៅក្នុងប្រទេសសេដ្ឋកិច្ចឧស្សាហកម្មជាច្រើន រួមទាំង សហរដ្ឋអាមេរិកផងដែរ មានអត្រាជាង ១០ ភាគរយ ក្នុងមួយឆ្នាំ)។ អតិផរណានៅទូទាំងអឌ្ឍគោលខាងត្បូង មានកម្រិតទាបជាងអតិផរណាពួកគេ កាលពីពីរទសវត្សរ៍មុន (សូមមើលតារាង ៩.១)។ អាមេរិកឡាទីនបានបន្ថយកម្រិតអតិផរណា ពី ៧៥០ ភាគរយ មកត្រឹមប្រហែល ៥ ភាគរយ

ខណៈដែលប្រទេសចិននិងមជ្ឈឹមបូព៌ាបានបញ្ចុះអត្រាអតិផរណា ក្រោម ៥ ភាគរយ។ គួរអោយភ្ញាក់ផ្អើលបំផុត នៅក្នុងប្រទេសរុស្ស៊ីនិងអតីតសាធារណរដ្ឋសូវៀតផ្សេងទៀត អត្រាអតិផរណា ជាង ១០០០ ភាគរយ បានធ្លាក់ចុះ មកត្រឹម ៥ ភាគរយ។

តារាង ៩.១ អត្រាអតិផរណាតាមតំបន់ ឆ្នាំ ១៩៩៣-២០១៨

	អត្រាអតិផរណា (ភាគរយក្នុងមួយឆ្នាំ)		
តំបន់	**១៩៩៣**	**២០០៩**	**២០១៨***
បស្ចឹមប្រទេសឧស្សាហកម្ម	៣	០,១	២
រុស្ស៊ី/ភោគទ្រព្យរួមCIS	១៤០០	១១	៥
ចិន	១៥	-០,៥	៣
មជ្ឈឹមបូព៌ា	២៧	៤	៤
អាមេរិកខាងត្បូង	៧៥០	៦	៥
អាស៊ីខាងត្បូង	៦	៧	៩
អាហ្វ្រិក	១១២	១១	៦

*ទិន្នន័យគឺជាការប៉ាន់ស្មានដោយផ្អែកលើទិន្នន័យផ្នែកសម្រាប់ឆ្នាំ ២០១៧។

ចំណាំ៖ តំបន់មិនដូចគ្នាទៅនឹងតំបន់ដែលប្រើកន្លែងផ្សេងក្នុងសៀវភៅនេះទេ។

ប្រភព៖ World Economic Situation and Prospects ២០១៨. United Nations, ២០១៧.

អតិផរណាខ្ពស់បំផុតដែលមិនអាចគ្រប់គ្រងបាន ច្រើនជាង ៥០ ភាគរយ ក្នុងមួយខែ ឬ ១៣០០០ ភាគរយក្នុងមួយឆ្នាំ ត្រូវបានគេហៅថា **អតិផរណាលោតផ្លោះ** (hyperinflation)។ ក្រដាសប្រាក់ ១០០ ទ្រីលានដុល្លារ ដែលត្រូវបានបោះពុម្ពដោយប្រទេសហ្ស៊ីមបាវ៉េ ក្នុងឆ្នាំ ២០០៩ បានបាត់បង់តម្លៃដើមដំបូងយ៉ាងឆាប់រហ័ស (ប្រហែល ៣០ ដុល្លារអាមេរិក) ក្រោមអតិផរណាលោតផ្លោះ លើសពី ២០០ លានភាគរយក្នុងមួយឆ្នាំ។ ថ្មីៗនេះ អត្រាអតិផរណារបស់ប្រទេសវេណេហ្ស៊ុយអេឡាបានកើនឡើងដល់ ៤០០០ ភាគរយ នៅដេរីស្លឹកឈើជ្រុះ ឆ្នាំ ២០១៧ ដែលនាំអោយរដ្ឋាភិបាលបោះពុម្ពក្រដាសប្រាក់ថ្មី រួមទាំងការចេញរូបិយប័ណ្ណអនឡាញ ដែលគាំទ្រដោយទុនបម្រុងប្រេងរបស់ប្រទេស។ សូម្បីតែអតិផរណាខ្ពស់ល្មមអាចធ្វើអោយលុយបាត់បង់តម្លៃប្រចាំសប្តាហ៍ ដែលធ្វើអោយពិបាកក្នុងការធ្វើអាជីវកម្ម។

ផ្ទុយពីរូបិយប័ណ្ណមិនអាចបំប្លែងបាន **រូបិយប័ណ្ណខ្លាំង** (hard currency) គឺជាប្រាក់ដែលអាចបំប្លែងឬដូរយករូបិយប័ណ្ណពិភពលោកសំខាន់ៗ បានយ៉ាងងាយស្រួល ភ្លាមៗ (ដែលឥឡូវនេះមានអត្រាអតិផរណាទាប)។ ជាឧទាហរណ៍ ក្រុមហ៊ុនផលិតកុំព្យូទ័ររបស់ចិនអាចនាំចេញផលិតផលរបស់ខ្លួន និងទទួលបានការទូទាត់ជាប្រាក់ដុល្លារ ប្រាក់អឺរ៉ូ ឬរូបិយប័ណ្ណខ្លាំងផ្សេងទៀត ដែលវាអាចប្រើប្រាស់ដើម្បីចំណាយលើគ្រឿងផ្សំដែលខ្លួនត្រូវការនាំចូលពីបរទេស។ ប៉ុន្តែ កសិករចិនម្នាក់ ដែលលក់ស្រូវអង្ករយករូបិយប័ណ្ណចិន មិនអាចប្រើរូបិយប័ណ្ណនោះដើម្បីទិញទំនិញនាំចូលដោយផ្ទាល់បានទេ។ ផ្ទុយទៅវិញ អត្រាប្តូរប្រាក់ដើម្បីយករូបិយប័ណ្ណបរទេសនឹងត្រូវគ្រប់គ្រងដោយរដ្ឋាភិបាលចិន តាមអត្រាដែលរដ្ឋាភិបាលបានកំណត់។ នៅក្នុងប្រទេសមួយចំនួនតូច ដូចជា ប្រទេសគុយបា រូបិយប័ណ្ណពីរប្រភេទត្រូវបានដាក់អោយចរាចរ មួយប្រភេទអាចបំប្លែងទៅជារូបិយប័ណ្ណខ្លាំងរបស់បរទេស និងមួយប្រភេទទៀតសម្រាប់តែការប្រើប្រាស់ផ្ទៃក្នុងប៉ុណ្ណោះ។ ប្រជាជនគុយបា

បានត្អូញត្អែរថា ទំនិញដែលពួកគេត្រូវការ អាចរកបានតែនៅក្នុងហាងដែលទទួលយករូបិយប័ណ្ណខ្លាំង (ដូចជាហាងដែលលក់អោយទេសចរជាដើម) ចំណែកឯប្រាក់ខែរបស់ពួកគេត្រូវបានបង់ជារូបិយវត្ថុខ្សោយក្នុងស្រុក។ ជាទូទៅ នៅពេលដែលសេដ្ឋកិច្ចអភិវឌ្ឍនិងចូលរួមក្នុងទីផ្សារពិភពលោក រូបិយប័ណ្ណរបស់ពួកគេក៏អភិវឌ្ឍផងដែរ ពីរូបិយប័ណ្ណរង្គោះរង្គើដោយផ្អែកលើកំប៉ុងស្រាបៀរឬងាយនឹងមានអតិផរណាលោតផ្លោះ ទៅជារូបិយប័ណ្ណដែលមានស្ថេរភាពជាង ដូចជាប្រទេសចិននាពេលបច្ចុប្បន្ននេះ ហើយនៅទីបំផុត ទៅជាគំរូរូបិយប័ណ្ណដែលអាចបំប្លែងបានពេញលេញ។

រដ្ឋទាំងឡាយរក្សាទុនបម្រុងជារូបិយប័ណ្ណរឹង។ ទុនបំរុងទាំងនេះប្រៀបប្រដូចជាស្តុកមាសក្នុងសតវត្សរ៍កន្លងមក។ រូបិយប័ណ្ណជាតិឥឡូវនេះត្រូវបានគាំទ្រដោយទុនបម្រុងជារូបិយប័ណ្ណរឹងទាំងនោះ មិនមែនមាសទៀតទេ។ រដ្ឋមួយចំនួនបន្តរក្សាទុនបម្រុងជាមាសផងដែរ។ ក្នុងឆ្នាំ ២០១០ ប្រទេសអាប៊ីសាអូឌីតបានលាតត្រដាងថា ខ្លួនរក្សាស្តុកមាសជាង ៣០០ តោន ជាទុនបម្រុង ដែលមានតម្លៃជាង ១០ ប៊ីលានដុល្លារ។ ត្រឹមឆ្នាំ ២០១៨ ទាំងប្រទេសចិននិងរុស្ស៊ីបានស្តុកទុនបម្រុងជាមាស ជិត ២០០០ តោន។ ប្រទេសឧស្សាហូបនីយកម្មមានទុនបម្រុងជាហិរញ្ញវត្ថុប្រហាក់ប្រហែលនឹងទំហំសេដ្ឋកិច្ចរបស់ពួកគេ។

ទម្រង់មួយនៃការប្តូររូបិយប័ណ្ណប្រើប្រាស់**អត្រាប្តូរប្រាក់ថេរ**(fixed exchange rates)។ នៅទីនេះរដ្ឋាភិបាលសម្រេចជាឯកតោភាគី ឬរួមគ្នា ដើម្បីបង្កើតអត្រាប្តូរប្រាក់ផ្លូវការសម្រាប់រូបិយប័ណ្ណរបស់ពួកគេ។ ជាឧទាហរណ៍ ប្រាក់ដុល្លារកាណាដា និងដុល្លារអាមេរិកមានតម្លៃស្មើគ្នា អស់រយៈពេលជាច្រើនឆ្នាំ។ អត្រាថេរសម្រាប់ប្តូរពីប្រាក់មួយទៅមួយទៀត ត្រូវបានរក្សាជដែល (នេះមិនមែនជាការពិតទៀតទេ)។ រដ្ឋមានមធ្យោបាយផ្សេងៗគ្នាសម្រាប់ព្យាយាមរក្សាឬកែប្រែអត្រាថេរបែបនេះ នៅចំពោះមុខការផ្លាស់ប្តូរលក្ខខណ្ឌសេដ្ឋកិច្ច(សូមមើល ហេតុអ្វីបានជារូបិយប័ណ្ណឡើងថ្លៃ ឬចុះថោក នៅផ្នែកបន្ទាប់ ក្នុងមេរៀននេះ)។

នៅពេលបច្ចុប្បន្ននេះ **អត្រាប្តូរប្រាក់អណ្តែត**(floating exchange rates) ត្រូវបានប្រើប្រាស់ជាទូទៅសម្រាប់រូបិយប័ណ្ណសំខាន់ៗនៅលើពិភពលោក។ អត្រានេះត្រូវបានកំណត់ដោយទីផ្សាររូបិយប័ណ្ណសកលដែលវិនិយោគិនឯកជនក៏ដូចជារដ្ឋាភិបាលទិញនិងលក់រូបិយប័ណ្ណ។ មានការផ្គត់ផ្គង់និងតម្រូវការសម្រាប់រូបិយប័ណ្ណរបស់រដ្ឋនីមួយៗ ដោយតម្លៃមានការប្រែប្រួលជានិច្ច ជាការឆ្លើយតបទៅនឹងលក្ខខណ្ឌទីផ្សារ។ ដូចគ្នានឹងអ្នកវិនិយោគអាចទិញភាគហ៊ុនរបស់ក្រុមហ៊ុន Apple ឬ Wal-Mart ប្រសិនបើពួកគេរំពឹងថាតម្លៃរបស់វានឹងកើនឡើង ពួកគេក៏អាចនឹងទិញប្រាក់យ៉េនរបស់ជប៉ុនទុកបើពួកគេរំពឹងថាតម្លៃរូបិយប័ណ្ណនោះនឹងឡើងថ្លៃនាពេលអនាគត។ តាមរយៈការឆក់ឱកាសកេងចំណេញពីការជួញដូររូបិយប័ណ្ណអន្តរជាតិ ក្នុងរយៈពេលខ្លីអត្រាប្តូរប្រាក់សម្របខ្លួនទៅនឹងការផ្លាស់ប្តូរខ្សែចង្វាក់ផ្គត់ផ្គង់និងតម្រូវការរូបិយប័ណ្ណ រយៈពេលវែង។

ទីផ្សាររូបិយប័ណ្ណអន្តរជាតិធំៗប្រតិបត្តិការនៅក្នុងទីក្រុងធំមួយចំនួន ដូចជា ញូវយ៉ក ឡុងដ៍ ហ្សឺរិច (ស្វីស) តូក្យូ និងហុងកុង ដែលតភ្ជាប់គ្នាដោយប្រព័ន្ធទំនាក់ទំនងតាមកុំព្យូទ័រភ្លាមៗ។ ទីផ្សារទាំងនេះត្រូវបានដំរុញ ក្នុងរយៈពេលខ្លី ដោយសំណួរដ៏សំខាន់មួយ៖ *តើរូបិយប័ណ្ណរបស់រដ្ឋមួយនឹងមានតម្លៃប៉ុន្មាននៅថ្ងៃអនាគត បើធៀបនឹងតម្លៃរបស់វានាពេលបច្ចុប្បន្ន?* ទីផ្សាររូបិយប័ណ្ណអន្តរជាតិទាំងនេះពាក់ព័ន្ធនឹងទំហំទឹកប្រាក់ដ៏ច្រើនក្រៃលែង ប្រមាណ $៣ ទ្រីលានដុល្លារ ជារៀងរាល់ថ្ងៃ ផ្លាស់ទីជុំវិញពិភពលោក (ជាការពិត មានតែព័ត៌មានតាមកុំព្យូទ័រប៉ុណ្ណោះដែលផ្លាស់ទី)។ ពួកគេជាទីផ្សារឯកជន ហើយមិនត្រូវបានគ្រប់គ្រងយ៉ាងតឹងរឹងដោយរដ្ឋាភិបាល ដូចផ្សារភាគហ៊ុននោះទេ។

ឃុះៗម្តង រដ្ឋាភិបាលជាតិធ្វើ*អន្តរាគមន៍*នៅក្នុងទីផ្សារហិរញ្ញវត្ថុ ដោយទិញនិងលក់រូបិយប័ណ្ណ ដើម្បីជះឥទ្ធិពលលើតម្លៃរបស់វា។ (អន្តរាគមន៍ទាំងនេះក៏អាចពាក់ព័ន្ធនឹងការផ្លាស់ប្តូរអត្រាការប្រាក់ ដែលបង់ដោយរដ្ឋាភិបាលផងដែរ។ សូមមើល «អត្រាបញ្ចុះតម្លៃ» នៅក្នុងផ្នែកធនាគារកណ្តាល បន្តិចទៀតនៅក្នុងមេរៀននេះ)។ អន្តរាគមន៍របស់រដ្ឋាភិបាលបែបនេះក្នុងការព្យាយាមគ្រប់គ្រងអត្រា(ប្តូរ)រូបិយប័ណ្ណអណ្តែតដោយសេរី ត្រូវបានគេហៅថា **ប្រព័ន្ធអណ្តែតមានកម្រិត**(managed float)។ រដ្ឋឧស្សាហូបនីយកម្មឈានមុខគេជារឿយៗ (តែមិនគ្រប់ពេល) ធ្វើការជាមួយគ្នាក្នុងអន្តរាគមន៍បែបនេះ។ ជាឧទាហរណ៍ ប្រសិនបើតម្លៃប្រាក់ដុល្លារអាមេរិកធ្លាក់ចុះខ្លាំងពេក ធៀបនឹងរូបិយប័ណ្ណសំខាន់ៗផ្សេងទៀត (ការវិនិច្ឆ័យនយោបាយ) រដ្ឋាភិបាលឈានជើងចូលទីផ្សាររូបិយប័ណ្ណ រួមជាមួយនឹងអ្នកវិនិយោគឯកជន និងទិញប្រាក់ដុល្លារ។ ជាមួយនឹងតំរូវការប្រាក់ដុល្លារកាន់តែច្រើន តម្លៃអាចនឹងមានស្ថេរភាព ហើយប្រហែលជាឡើងថ្លៃមកវិញ។ (ប្រសិនបើតម្លៃឡើងខ្ពស់ពេក រដ្ឋាភិបាលឈានជើងចូលលក់ប្រាក់ដុល្លារ ដើម្បីបង្កើនការផ្គត់ផ្គង់ និងជំរុញតម្លៃអោយធ្លាក់ចុះវិញ។) អន្តរាគមន៍បែបនេះជាធម្មតាកើតឡើងយ៉ាងឆាប់រហ័សក្នុងមួយថ្ងៃ ប៉ុន្តែ អាចត្រូវបានធ្វើឡើងដដែល ច្រើនដងក្នុងរយៈពេលពីរបីសប្តាហ៍ ដើម្បីមានប្រសិទ្ធិភាពតាមការចង់បាន។ ចូរកត់សម្គាល់ថា អន្តរាគមន៍រូបិយវត្ថុទាមទារអោយមានកិច្ចសហប្រតិបត្តិការពហុភាគី ដែលត្រូវចំណាយថ្លៃខ្ពស់ក្នុងចំណោមរដ្ឋនានា។ អ្នកទ្រឹស្តីសេរីនិយមចង្អុលទៅកិច្ចសហប្រតិបត្តិការបែបនេះជាកស្តុតាងដែលរដ្ឋទទួលស្គាល់ផលប្រយោជន៍រួមរយៈពេលវែងក្នុងសេដ្ឋកិច្ចអន្តរជាតិ ដែលផ្តល់ផលប្រយោជន៍ដល់គ្នាទៅវិញទៅមក(សូមមើលឧទាហរណ៍បន្ថែម ការស្វែងរកផលប្រយោជន៍រួម នៅខាងចុងមេរៀន)។

នៅក្នុងការអន្តរាគមន៍របស់ពួកគេក្នុងទីផ្សាររូបិយប័ណ្ណអន្តរជាតិ រដ្ឋាភិបាលត្រូវខាតបង់ដោយសារតែ(សូម្បីតែនៅពេលធ្វើសកម្មភាពរួមគ្នា) ពួកគេគ្រប់គ្រងត្រឹមផ្នែកតូចមួយនៃប្រាក់ដែលចរាចរនៅលើទីផ្សារបែបនេះ។ សាច់ប្រាក់ភាគច្រើនជាកម្មសិទ្ធិឯកជន។ ទោះជាយ៉ាងណាក៏ដោយ រដ្ឋាភិបាលមានគុណសម្បត្តិឬការចំណេញមួយដែរ៖ ពួកគេអាចធ្វើការរួមគ្នាដើម្បីជះឥទ្ធិពលគ្រប់គ្រាន់លើទីផ្សារដើម្បីធ្វើការផ្លាស់ប្តូរតម្លៃតិចតួចបំផុត។ រដ្ឋាភិបាលក៏អាចប្រតិបត្តិការដោយសម្ងាត់ ដោយមិនអោយអ្នកវិនិយោគឯកជនដឹងថាតើរដ្ឋាភិបាលអាចនឹងទិញឬលក់រូបិយប័ណ្ណចំនួនប៉ុន្មាននិងក្នុងតម្លៃប៉ុន្មាន។ *ក្រោយ*អន្តរគមន៍ដែលមានសម្របសម្រួលពហុជាតិចូលទៅក្នុងទីផ្សារ ទើបសាធារណជនដឹងអំពីបញ្ហានេះ។ (ប្រសិនបើអ្នកធក់ឱកាសកេងចំណេញបានដឹងមុន ពួកគេអាចរកលុយដោយកេងចំណេញពីការចំណាយរបស់រដ្ឋាភិបាល។) ចូរចំណាំថានេះជាតំបន់ដែលរដ្ឋមានផលប្រយោជន៍រួម (ត្រូវធានាថាសេដ្ឋកិច្ចធំៗមិនដួលរលំ) រួមគ្នាទប់ទល់នឹងតួអង្គឆ្លងជាតិ (វិនិយោគិនដែលកំពុងព្យាយាមចំណេញប្រាក់ពីការខាតបង់របស់រដ្ឋ)។

អន្តរាគមន៍ជោគជ័យអាចរកលុយអោយរដ្ឋាភិបាលពីការចំណាយ ឬខាតបង់របស់អ្នកធក់ឱកាសប្តូរប្រាក់ឯកជន។ ជាឧទាហរណ៍ ប្រសិនបើរដ្ឋាភិបាលនៃក្រុមប្រទេសមហាសេដ្ឋកិច្ចទាំងម្ភៃ(G20)ឈានជើងចូលអន្តរាគមន៍ដំឡើងតម្លៃប្រាក់ដុល្លារអាមេរិក តាមរយៈការទិញប្រាក់ដុល្លារនៅជុំវិញពិភពលោក (ដោយលក់រូបិយប័ណ្ណខ្លាំងដទៃទៀត) ហើយប្រសិនបើពួកគេជោគជ័យ រដ្ឋាភិបាលអាចលក់ចេញវិញនិងទទួលបានប្រាក់ចំណេញជាក់ហោប៉ៅ។ យ៉ាងណាមិញ ប្រសិនបើអន្តរាគមន៍បរាជ័យ ហើយតម្លៃប្រាក់ដុល្លារនៅតែបន្តធ្លាក់ចុះ រដ្ឋាភិបាលទាំងនោះនឹងបាត់បង់ប្រាក់ ហើយប្រហែលជាត្រូវបន្តទិញហើយទិញទៀត ដើម្បីទប់កុំអោយវាធ្លាក់ចុះទៀត។ តាមការពិត បើអ្នកវិនិយោគបានដឹងអំពីទង្វើបែបនេះ ពួកគេអាចនឹងបកស្រាយថា

ទង្វើនេះជាសញ្ញាមួយដែលបញ្ជាក់ថា រូបិយប័ណ្ណដែលកំពុងទិញចុះខ្សោយ ដែលអាចធ្វើអោយតម្លៃធ្លាក់ចុះថែមទៀត។ ក្នុងករណីធ្ងន់ធ្ងរ រដ្ឋាភិបាលអាចនឹងអស់ស្តុករូបិយប័ណ្ណខ្លាំងរបស់ពួកគេមុនពេលបានលទ្ធផលនិងត្រូវរ៉ាប់រងការខាតបង់ដ៏ធំ។ ដូច្នេះ រដ្ឋាភិបាលត្រូវតែគិតពីតថភាពជាក់ស្តែងអំពីឥទ្ធិពលមានដែនកំណត់ដែលពួកគេអាចមាន លើតម្លៃរូបិយប័ណ្ណ។

ដែនកំណត់ទាំងនេះត្រូវបានចង្អុលបង្ហាញយ៉ាងច្បាស់ នៅក្នុងការដួលរលំហិរញ្ញវត្ថុអាហ្សង់ទីន ឆ្នាំ ២០០១។ ប្រទេសអាហ្សង់ទីនក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ បានកំណត់តម្លៃរូបិយប័ណ្ណរបស់ខ្លួន ក្នុងអត្រាថេរដើម្បីប្តូរយកប្រាក់ដុល្លារអាមេរិក ដែលជាវិធីសាស្ត្រដ៏មានប្រសិទ្ធភាពខ្ពស់មួយដើម្បីបញ្ឈប់អតិផរណាដែលថ្មីៗនេះបានបង្កការបំផ្លិចបំផ្លាញលើសេដ្ឋកិច្ចរបស់ប្រទេសអាហ្សង់ទីន។ ទោះយ៉ាងណាក៏ដោយ ការចងភ្ជាប់អត្រាប្តូរប្រាក់ប៉េសូ(Peso)ទៅនឹងប្រាក់ដុល្លារអាមេរិក តំណាងអោយការបាត់បង់អធិបតេយ្យភាពលើគោលនយោបាយរូបិយវត្ថុ ដែលជាគន្លឹះដ៏សំខាន់មួយក្នុងការគ្រប់គ្រងសេដ្ឋកិច្ច។ ប្រទេសអាហ្សង់ទីន និងសហរដ្ឋអាមេរិក នៅចុងទសវត្សរ៍ឆ្នាំ ១៩៩០ មានតម្រូវការផ្សេងគ្នា។ នៅពេលការពង្រីកឥទ្ធិពលជាប្រវត្តិសាស្ត្ររបស់សហរដ្ឋអាមេរិកបាននាំមកនូវភាពរុងរឿងដែលមិនធ្លាប់មានពីមុនមក (រក្សាអត្រាការប្រាក់ក្នុងកម្រិតខ្ពស់) ប្រទេសអាហ្សង់ទីនបានទទួលរងការឈឺចាប់ពីវិបត្តិសេដ្ឋកិច្ច រយៈពេល ៤ ឆ្នាំ ប៉ុន្តែ មិនអាចបន្តយអត្រាការប្រាក់ដើម្បីជំរុញកំណើននោះទេ។ អាហ្សង់ទីនបានប្រមូលប្រាក់កម្ចីបរទេសជាង ១០០ ប៊ីលានដុល្លារ ហើយមិនអាចទូទាត់បំណុលរបស់ខ្លួនបានទេ។ ជំនួយពីមូលនិធិIMFក្នុងការរៀបចំរចនាសម្ព័ន្ធឡើងវិញ ត្រូវអាស្រ័យលើគោលនយោបាយហិរញ្ញវត្ថុតឹងតែង ដោយការដំឡើងពន្ធនិងការកាត់បន្ថយការចំណាយ ដែលជាកំហុសដ៏ធំក្នុងអំឡុងពេលមានវិបត្តិសេដ្ឋកិច្ចអូសបន្លាយច្រើនឆ្នាំ នេះបើយោងតាមក្រុមអ្នកវិះគន់។ ក្នុងឆ្នាំ ២០០១ នៅពេលដែលសហរដ្ឋអាមេរិកនិងមូលនិធិIMFនៅស្ងៀម សេដ្ឋកិច្ចរបស់ប្រទេសអាហ្សង់ទីនបានដួលរលំ។ ប្រធានាធិបតីពីរនាក់បានលាលែងពីតំណែងក្នុងរយៈពេលខ្លី ហើយអ្នកនយោបាយប្រជានិយមឬប្រជាភិថុតម្នាក់បានឡើងកាន់អំណាច ប្រកាសក្ស័យធនមិនសងបំណុលបរទេស ហើយបានទម្លាក់តម្លៃប្រាក់ប៉េសូដើម្បីបង្កើតការងារ ដែលជាមេរៀនដ៏អាម៉ាស់សម្រាប់មូលនិធិIMF និងជារឿងដ៏ឈឺចាប់សម្រាប់ប្រទេសអាហ្សង់ទីន។ ក្នុងឆ្នាំ ២០០៣ អាហ្សង់ទីនបានប្រកាសថាគ្មានលទ្ធភាពសងប្រាក់បំណុលចំនួន ៣ ប៊ីលានដុល្លារទៅដល់មូលនិធិIMF ដែលជាការប្រកាសក្ស័យធនដ៏ធំបំផុត នៅក្នុងប្រវត្តិសាស្ត្ររបស់មូលនិធិIMF។ សេដ្ឋកិច្ចអាហ្សង់ទីនបានចាប់ផ្តើមរើបឡើងវិញ និងបានសងប្រាក់បំណុលអោយមូលនិធិIMFក្នុងឆ្នាំ ២០០៦ បើទោះជាការចរចាជាមួយម្ចាស់បំណុលរបស់រដ្ឋាភិបាលបរទេសបានបន្តក៏ដោយ។

ករណីមួយទៀតនៅអាមេរិកឡាទីន ប្រទេសវេណេស៊ុយអេឡា បង្ហាញពីផលប៉ះពាល់ដ៏គ្រោះថ្នាក់នៃជម្រើសគោលនយោបាយរូបិយប័ណ្ណមិនល្អ។ ដោយចាប់ផ្តើមនៅឆ្នាំ ២០០៣ ប្រទេស វេណេហ្ស៊ុយអេឡាបានដាក់អត្រាប្តូរប្រាក់ញែក ដែលជាអត្រាប្តូរប្រាក់ផ្លូវការប្រែប្រួលអាស្រ័យលើអ្វីដែលត្រូវបានទិញនិងលក់។ ដោយសារទំនិញនាំចូលមួយចំនួនត្រូវបានទិញក្នុងអត្រាប្តូរប្រាក់ដែលអំណោយផលជាង ទំនិញ«ថ្លៃៗ»មួយចំនួនបានប្រែជាថោកវិញ (រថយន្តប្រណិត និងស្រាល្អៗ) ខណៈដែលទំនិញចាំបាច់សំខាន់ៗ (ទឹកដោះគោ) មានតម្លៃថ្លៃ។ នៅឆ្នាំ ២០១៥ សេដ្ឋកិច្ចប្រទេសវេណេស៊ុយអេឡាស្ទើរតែជួបប្រទះអតិផរណាលោតផ្លោះ ហើយរូបិយប័ណ្ណខ្លាំងពិបាករកបាននៅក្នុងប្រទេស។

ថ្មីៗនេះ សម្ពាធបានប្រមូលផ្តុំកាន់តែច្រើនឡើងនៅក្នុងករណីសំខាន់ជាងនេះ នោះគឺរូបិយប័ណ្ណរបស់ប្រទេសចិន។ ដូចនៅប្រទេសអាហ្សង់ទីនក្នុងឆ្នាំ ២០០១ គោលនយោបាយបច្ចុប្បន្នក្នុងការកំណត់អត្រាប្តូរូបិយប័ណ្ណរបស់ចិន ទៅជាប្រាក់ដុល្លារអាមេរិកមិនបានកែតម្រូវទៅនឹងលក្ខខណ្ឌសេដ្ឋកិច្ចផ្សេងគ្នា នៅក្នុងប្រទេសចិននិងសហរដ្ឋអាមេរិកនោះទេ។ ប្រទេសចិនដំណើរការអតិរេកពាណិជ្ជកម្មដ៏ធំ (សូមមើលមេរៀនទី ៨) ខណៈពេលដែលសហរដ្ឋអាមេរិកដំណើរការខ្វិនភាពពាណិជ្ជកម្មដ៏ធំវិញ ក្នុងទឹកប្រាក់ប្រមាណ ៣៧៥ ប៊ីលានដុល្លារជាមួយប្រទេសចិនតែមួយ ក្នុងឆ្នាំ ២០១៧ និងសរុប ជាង ៥០០ ប៊ីលានដុល្លារ។ បណ្តាអ្នកវិះគន់បានចោទប្រកាន់ថា សមាមាត្រប្រាក់ដុល្លារនិងប្រាក់យន់ត្រូវបានក្សាកម្រិតខ្ពស់ហួសកម្រិត ដែលធ្វើអោយការនាំចេញរបស់ចិនទៅសហរដ្ឋអាមេរិកមានតម្លៃកាន់តែថោក និងរួមចំណែកដល់អតុល្យភាពពាណិជ្ជកម្ម និងការបាត់បង់ការងារផលិតកម្មរបស់សហរដ្ឋអាមេរិក ដែលជាបញ្ហារស៊ើបនៅក្នុងនយោបាយក្នុងស្រុករបស់សហរដ្ឋអាមេរិក។ ចរន្តទាំងនេះគឺមូលហេតុមួយសម្រាប់សហរដ្ឋអាមេរិកតម្លើងពន្ធនាំចូលទំនិញពីប្រទេសចិន នៅចន្លោះឆ្នាំ ២០១៧-២០១៨ រួមទាំងបន្ទះសូឡា ម៉ាស៊ីនបោកខោអាវ និងដែកថែប។ សម្ពាធលើប្រទេសចិនដើម្បីកែទម្រង់រូបិយប័ណ្ណរបស់ខ្លួនបានកើនឡើង។ ប៉ុន្តែ ចិនព្រួយបារម្ភអំពីស្ថិរភាពក្នុងស្រុក៖ ដើម្បីរក្សាអត្រាការងារបានខ្ពស់ ប្រទេសចិនត្រូវតែនាំទំនិញចេញ។ រូបិយប័ណ្ណដែលមានតម្លៃទាបរបស់ចិនរក្សាការនាំចេញក្នុងតម្លៃថោក ហើយកម្មកររនៅមានការងារធ្វើ។ ប្រទេសចិនបានអនុញ្ញាតអោយរូបិយប័ណ្ណរបស់ខ្លួនឡើងថ្លៃបន្តិចម្តងៗ។ ការសិក្សាមួយដោយក្រុមប្រឹក្សាសហព័ន្ធទុនបម្រុងរបស់សហរដ្ឋអាមេរិកក្នុងឆ្នាំ ២០១៧ បានអះអាងថា រូបិយប័ណ្ណរបស់ប្រទេសចិនកំពុងចរាចរហាក់ដូចជារូបិយប័ណ្ណអណ្តែតមួយ ប៉ុន្តែក៏បានស្នើថា គោលនយោបាយរបស់រដ្ឋាភិបាលចិនដែលអនុញ្ញាតអោយអណ្តែតនេះអាចផ្លាស់ប្តូរបានយ៉ាងឆាប់រហ័ស។

ក្នុងឆ្នាំ ២០០៦ ប្រទេសចិន ជប៉ុន និងកូរ៉េខាងត្បូងបានប្រកាសផែនការធ្វើការរួមគ្នាឆ្ពោះទៅរកការសម្របសម្រួលគោលនយោបាយរូបិយប័ណ្ណរបស់ពួកគេ។ ក្នុងឆ្នាំ ២០១៧ កូរ៉េខាងត្បូងបានបន្តកិច្ចព្រមព្រៀងប្តូររូបិយប័ណ្ណដែលមានតម្លៃជាង ៥០ ប៊ីលានដុល្លារជាមួយប្រទេសចិន បើទោះបីជាប្រទេសទាំងពីរកំពុងមានជម្លោះការទូតជុំវិញប្រទេសកូរ៉េខាងត្បូងតម្លើងប្រព័ន្ធការពារមីស៊ីលនៅលើទឹកដីរបស់ខ្លួន។ រួមជាមួយនឹងបណ្តាប្រទេសសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(អាស៊ាន) ប្រទេសចិន ជប៉ុននិងកូរ៉េខាងត្បូងក៏កំពុងសិក្សាអំពីលទ្ធភាពបង្កើតឯកតារូបិយប័ណ្ណអាស៊ី ដែលនឹងតាមដានតម្លៃសរុបនៃរូបិយប័ណ្ណក្នុងតំបន់។ វិធានការណ៍ទាំងពីរនេះគឺជាជំហានដំបូងអាចធ្វើទៅបាន ដើម្បីឆ្ពោះទៅរកការបង្កើតរូបិយប័ណ្ណអាស៊ី ដូចជាប្រាក់អឺរ៉ូ។ ប៉ុន្តែ ជំហានដ៏ធំបែបនេះយ៉ាងច្រើនស្ថិតនៅក្នុងដំណាក់កាលដំបូង។

៩.២.៣. ហេតុអ្វីបានជាតម្លៃរូបិយប័ណ្ណឡើងថ្លៃ ឬចុះថោក

ក្នុងរយៈពេលខ្លី អត្រាប្តូរប្រាក់ត្រូវអាស្រ័យលើការរំពឹងទុកអំពីតម្លៃរូបិយប័ណ្ណនាអនាគត។ ប៉ុន្តែក្នុងរយៈពេលយូរទៅមុខ តម្លៃរូបិយប័ណ្ណរបស់រដ្ឋមួយ មានទំនោរឡើងថ្លៃឬចុះថោក ធៀបនឹងរូបិយប័ណ្ណផ្សេងទៀតដោយសារតែការប្រែប្រួលសង្វាក់ផ្គត់ផ្គង់និងតម្រូវការរូបិយប័ណ្ណក្នុងរយៈពេលវែង។ *ការផ្គត់ផ្គង់*(supply) ត្រូវបានកំណត់ដោយចំនួនប្រាក់ដែលរដ្ឋាភិបាលបោះពុម្ព។ ការបោះពុម្ពប្រាក់គឺជាវិធីរហ័សសម្រាប់បង្កើតចំណូលថវិកាជូនរដ្ឋាភិបាល ប៉ុន្តែ បោះពុម្ពប្រាក់កាន់តែច្រើន តម្លៃរបស់វាកាន់តែទាប។ នៅក្នុងស្រុក ការបោះពុម្ពលុយច្រើនពេកបង្កើតអតិផរណា ដោយសារបរិមាណទំនិញក្នុងសេដ្ឋកិច្ចមិនផ្លាស់ប្តូរ ប៉ុន្តែបរិមាណ

លុយកាន់តែច្រើនកំពុងចរាចរសម្រាប់ទិញទំនិញទាំងនោះ។ *តម្រូវការ* (demand) រូបិយប័ណ្ណមួយត្រូវអាស្រ័យលើសុខភាពសេដ្ឋកិច្ចនិងស្ថិរភាពនយោបាយរបស់រដ្ឋនោះ។ ប្រជាជនមិនចង់កាន់កាប់ឬរក្សាទុករូបិយប័ណ្ណរបស់ប្រទេសដែលមិនស្ថិតស្ថេរនោះទេ ដោយសារអស្ថិរភាពនយោបាយបណ្តាលអោយបាត់បង់ប្រសិទ្ធភាពសេដ្ឋកិច្ចនិងទំនុកចិត្តលើរូបិយប័ណ្ណ។ ផ្ទុយទៅវិញ ស្ថិរភាពនយោបាយបង្កើនតម្លៃរូបិយប័ណ្ណ។ ជាឧទាហរណ៍ ក្នុងឆ្នាំ ២០០១ នៅពេលដែលប្រធានាធិបតីឥណ្ឌូនេស៊ីថ្មីចូលកាន់តំណែង បន្ទាប់ពី រយៈពេលពោរពេញដោយភាពចលាចលនយោបាយនិងសេដ្ឋកិច្ច រូបិយប័ណ្ណឥណ្ឌូនេស៊ីបានឡើងថ្លៃ កម្រិត ១៣ ភាគរយ ក្នុងរយៈពេលត្រឹមតែពីរថ្ងៃ ដោយសារតែការរំពឹងទុកមុននូវស្ថិរភាពកាន់តែរឹងមាំ។

ស្ថិរភាពរូបិយប័ណ្ណពិបាកនឹងសម្រេចបានណាស់។ ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ប្រាក់ដុល្លារអាមេរិកបានធ្លាក់ចុះ ពីមួយដុល្លារប្តូរបានជាង ៩០ យ៉េនជប៉ុន មកនៅក្រោម ៨០ យ៉េន បន្ទាប់មកបានកើនឡើងដល់ ១២០ យ៉េនវិញ។ អស្ថិរភាពក្នុងអត្រាប្តូរប្រាក់បែបនេះរំខានដល់អាជីវកម្មក្នុងវិស័យដែលផ្តោតលើការដោះដូរដោយសារក្រុមហ៊ុនប្រឈមមុខនឹងការផ្លាស់ប្តូរភ្លាមៗ និងមិនអាចទាយទុកមុនបាន នៅក្នុងផែនការចំណូលនិងការចំណាយរបស់ពួកគេ (ជាឧទាហរណ៍ ការផ្លាស់ប្តូរតម្លៃបន្ទះឈីបកុំព្យូទ័រនៅក្នុងប្រទេសជប៉ុន ដែលត្រូវការជាចាំបាច់សម្រាប់ផលិតកុំព្យូទ័រអាមេរិកឬកម្មវិធីកុំព្យូទ័រអាមេរិកដែលត្រូវការខ្លាំងនៅប្រទេសជប៉ុន)។ រដ្ឋក៏មានផលប្រយោជន៍រួមក្នុងស្ថិរភាពរូបិយប័ណ្ណរបស់ពួកគេ ដោយសារអស្ថិរភាពបង្កលក្ខណៈងាយស្រួលដល់ជនឆ្លៀតឱកាសយកចំណេញពីការខាតបង់របស់ធនាគារកណ្តាល។ រដ្ឋនានាក៏មានផលប្រយោជន៍ក្នុងភាពសុចរិតនៃរូបិយប័ណ្ណរបស់ពួកគេ ទប់ទល់នឹងការក្លែងបន្លំប្រាក់ដែរ ប៉ុន្តែ រដ្ឋអន្ធពាល (rogue states) អាចមានអារម្មណ៍ផ្ទុយពីនេះ។ ក្នុងឆ្នាំ ២០០៦ សហរដ្ឋអាមេរិកបានចោទប្រកាន់ប្រទេសកូរ៉េខាងជើងថាបានបញ្ចេញលុយរាប់សិបលានដុល្លារ ជាប្រភេទក្រដាសប្រាក់ ១០០ ដុល្លារក្លែងក្លាយដែលជាផលចំណេញផ្ទាល់សម្រាប់របបកូរ៉េខាងជើង ពីការខាតបង់របស់រតនាគារសហរដ្ឋអាមេរិក។

រូបថត ស្លាកតម្លៃប្រេង

រក្សាសិទ្ធិក្នុងការផ្លាស់ប្តូរតម្លៃ

ការផ្លាស់ប្តូរតម្លៃប្រាក់ដុល្លារ ដែលឆ្លុះបញ្ចាំងពីនិន្នាការមូលដ្ឋាន នៅក្នុងសេដ្ឋកិច្ចសហរដ្ឋអាមេរិក និងបរទេស ក៏ដូចជាគោលនយោបាយរូបិយវត្ថុរបស់រដ្ឋាភិបាលនានា ជះឥទ្ធិពលដោយផ្ទាល់លើតម្លៃទំនិញនាំចូល ដូចជាប្រេងសាំងជាដើម ដែលនៅទីនេះ កើនឡើងនៅក្នុងរដ្ឋកាលីហ្វ័រញ៉ា ក្នុងឆ្នាំ ២០១៥ ។

ទោះបីជាមានផលប្រយោជន៍រួមនៅក្នុងស្ថិរភាពរូបិយប័ណ្ណក៏ដោយ រដ្ឋក៏ជួបប្រទះ*ជម្លោះ*ជុំវិញការ ប្តូររូបិយប័ណ្ណផងដែរ។ ជារឿយៗ រដ្ឋចង់ឃើញរូបិយប័ណ្ណមានតម្លៃ*ទាប* ធៀបនឹងរូបិយប័ណ្ណជាតិដទៃ ពីព្រោះតម្លៃទាបជួយជំរុញការនាំចេញ និងជួយបង្វែរឱនភាពពាណិជ្ជកម្មទៅជាអតិរេកក្នុងជញ្ជីងពាណិជ្ជកម្ម ដូចដែលក្រុមគាំពារនិយមចង់បាន(សូមមើលមេរៀនទី ៨)។ ជាឧទាហរណ៍ ដោយសារប្រាក់ដុល្លារកាណាដាបានឡើងថ្លៃ ប្រមាណ ២៥ ភាគរយ ក្នុងចន្លោះឆ្នាំ ២០០៩-២០១២ ធៀបនឹងប្រាក់ដុល្លារអាមេរិក ក្រុមហ៊ុនផលិតរថយន្តអាមេរិកបានផ្លាស់ទីផលិតកម្មនិងការងាររាប់ពាន់ ចេញពីប្រទេសកាណាដា ប្តូរទៅកាន់សហរដ្ឋអាមេរិក។

អត្រាប្តូរប្រាក់ និងអតិរេកឬឱនភាពពាណិជ្ជកម្ម មានទំនោរកែតម្រូវដោយស្វ័យប្រវត្តិឆ្ពោះទៅរកលំនឹង(លទ្ធផលជាទីពេញចិត្តរបស់អ្នកសេរីនិយម)។ រូបិយប័ណ្ណដែល*ថ្លៃពេក* (overvalued) ដែលមាន

អត្រាប្តូរប្រាក់ខ្ពស់ពេក បង្កើតឱនភាពពាណិជ្ជកម្មរ៉ាំរ៉ៃ។ ឱនភាពនេះអាចត្រូវបានទូទាត់ដោយការបោះពុម្ពលុយថ្មីថែមទៀត ដែលនឹងធ្វើអោយតម្លៃរូបិយប័ណ្ណធ្លាក់ចុះនិងធ្វើអោយអត្រាប្តូរប្រាក់ធ្លាក់ចុះ (បើសិនវាអនុញ្ញាតអោយមានអត្រាអណ្តែតដោយសេរី)។ ដោយសារអ្នកសេរីនិយមមើលឃើញការកែតម្រូវបែបនេះមិនបង្កជាគ្រោះថ្នាក់ ពួកគេយល់ឃើញថា ការផ្លាស់ប្តូរនេះជាយន្តការវិជ្ជមានសម្រាប់សេដ្ឋកិច្ចពិភពលោកដើម្បីលុបបំបាត់អប្រសិទ្ធិភាពនិងបង្កើនកំណើនទាំងមូលក្នុងកម្រិតអតិបរិមា។

ការផ្លាស់ប្តូរដោងឯកតោភាគីដើម្បីកាត់បន្ថយតម្លៃ រូបិយប័ណ្ណរបស់ខ្លួនដោយការផ្លាស់ប្តូរអត្រាប្តូរប្រាក់ថេរឬផ្លូវការត្រូវបានគេហៅថា **ការទម្លាក់តម្លៃ** (devaluation)។ ជាទូទៅ ការទម្លាក់តម្លៃគឺជាការដោះស្រាយបញ្ហាហិរញ្ញវត្ថុយ៉ាងឆាប់រហ័ស ក្នុងរយៈពេលខ្លី ប៉ុន្តែ វាក៏អាចបង្កើតបញ្ហាថ្មីជាច្រើនផងដែរ។ វាបណ្តាលអោយមានការខាតបង់ដល់ជនបរទេសដែលកាន់កាប់រូបិយប័ណ្ណនោះ (ដែលបាត់បង់តម្លៃភ្លាមៗ)។ ការខាតបង់បែបនេះកាត់បន្ថយជំនឿទុកចិត្តរបស់មនុស្សចំពោះរូបិយប័ណ្ណនោះ។ ជាលទ្ធផល តម្រូវការចង់បានរូបិយប័ណ្ណនោះត្រូវធ្លាក់ចុះ ក្នុងអត្រាកាន់តែទាបទៅៗជាងមុនទៀត។ វិនិយោគិនមានការប្រុងប្រយ័ត្នចំពោះការទម្លាក់តម្លៃនាពេលអនាគត ហើយជាការពិតណាស់ ការទម្លាក់តម្លៃបែបនេះតែងតែកើតឡើងម្តងហើយម្តងទៀត នៅក្នុងសេដ្ឋកិច្ចដែលមិនស្ថិតស្ថេរ។ ក្នុងរយៈពេលបីសប្តាហ៍ដំបូងនៃឆ្នាំ ២០០៩ ប្រទេសរុស្សីបានទម្លាក់តម្លៃរូបិយប័ណ្ណរបស់ខ្លួន ចំនួន ៦ ដង បន្ទាប់ពីតម្លៃទំនិញនាំចេញជាចម្បងរបស់ខ្លួន ប្រេង ធ្លាក់ចុះខ្លាំង។ រូបិយប័ណ្ណអាចធ្លាក់ថ្លៃ ក្រោយត្រូវបាន អនុញ្ញាតអោយអណ្តែតដោយសេរី បន្ទាប់ពីកំឡុងពេលនៃអត្រាប្តូរប្រាក់ថេរ ដែលជារឿយៗនាំមកនូវការធ្លាក់ចុះតម្លៃយ៉ាងខ្លាំងបំផុត។ ជាទូទៅ ការផ្លាស់ប្តូរយ៉ាងស្រួចស្រាវ ឬសិប្បនិម្មិតណាមួយ នៅក្នុងអត្រាប្តូរប្រាក់ មានទំនោរខាងដល់ពាណិជ្ជកម្មអន្តរជាតិដែលកំពុងដំណើរការយ៉ាងរលូន និងជ្រៀតជ្រែកដល់ការបង្កើតទ្រព្យសម្បត្តិ។

អត្រាប្តូរប្រាក់ ដែលមានស្ថិរភាពសមល្មម សម្រាប់រូបិយប័ណ្ណអន្តរជាតិ អាចត្រូវបានគេមើលឃើញថាជាផលប្រយោជន៍រួមមួយ ដោយសារសមាជិកទាំងអស់នៃសេដ្ឋកិច្ចអន្តរជាតិទទួលបានផលប្រយោជន៍រៀងៗខ្លួនពីក្របខ័ណ្ឌស្ថិរភាពសម្រាប់ការវិនិយោគនិងការលក់ដូរ ប៉ុន្តែ ប្រទេសដោយឡែកណាមួយអាចទទួលបានអត្ថប្រយោជន៍ពីការទម្លាក់តម្លៃរូបិយប័ណ្ណរបស់ខ្លួន។ (ថាតើអត្ថប្រយោជន៍ទាំងនេះជាផលប្រយោជន៍សេដ្ឋកិច្ចឬការកេងចំណេញនយោបាយ ដែលចង់ភ្ជាប់ទៅនឹងការយល់ឃើញអំពីផលប្រយោជន៍ជាតិ មិនមែនជាបញ្ហាធំដំទេនៅទីនេះ ដរាបណាមេដឹកនាំរដ្ឋយល់ថាការចាកចេញពីអត្រាប្តូរប្រាក់ដែលមានស្រាប់អាចផ្តល់ផលប្រយោជន៍ដល់ប្រទេសរបស់ពួកគេ)។ យោងតាមទ្រឹស្តីផលប្រយោជន៍រួម ស្ថិរភាពអត្រាប្តូរប្រាក់អន្តរជាតិគួរតែអាចសម្រេចបាន កាន់តែងាយស្រួល ក្នុងកាលៈទេសៈពីរ៖ ក្រោមអនុត្តរភាព (គោលការណ៍គ្រប់គ្រង) និងក្រោមការរៀបចំក្នុងចំណោមរដ្ឋសំខាន់ៗមួយចំនួន (គោលការណ៍បដិការដំណើរការប្រកបដោយប្រសិទ្ធភាព)។ ស្ថិរភាពអនុត្តរភាព នៅក្នុងទ្រឹស្តីនេះ រួមមានការផ្តល់ការគាំទ្រដល់ស្ថិរភាពរូបិយប័ណ្ណពិភពលោក ដោយប្រើឥទ្ធិពលសេដ្ឋកិច្ចផ្ទាល់របស់អនុត្តរភាពនិងឥទ្ធិពលរបស់វាទៅលើមហាអំណាចផ្សេងទៀត។ បើអវត្តមានអនុត្តរភាព ផលប្រយោជន៍រួមងាយស្រួលជានាបានបំផុត ប្រសិនបើត្រូវបានគ្រប់គ្រងដោយក្រុមតូចមួយ។ ក្នុងបរិយាកាសក្រុមតូច អ្នករត់ចោលជួរ ឬជិះសេះលែងដៃ ត្រូវគេមើលឃើញយ៉ាងច្បាស់ ហើយកិច្ចសហប្រតិបត្តិការទៅវិញទៅមកត្រូវបានអនុវត្តកាន់តែងាយស្រួល។

ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ បាតុភូតថ្មីមួយដែលគេស្គាល់ថាជារូបិយប័ណ្ណអេឡិចត្រូនិកបានទទួលការចាប់អារម្មណ៍ជុំវិញពិភពលោក។ គ្មានរូបិយប័ណ្ណណាមួយក្នុងចំណោមនោះមានរូបរាងរូបីនោះទេ។ រូបិយប័ណ្ណដែលត្រូវប្រើយ៉ាងទូលំទូលាយបំផុត ប៊ីតខញ (bitcoin) ឥឡូវនេះត្រូវបានទទួលយកដោយអាជីវកម្មជាច្រើននៅជុំវិញពិភពលោក។ រូបិយប័ណ្ណទាំងនេះអាចត្រូវបានដោះដូរយករូបិយប័ណ្ណប្រពៃណី នៅលើបណ្តាញវៃបសាយក្រុមហ៊ុនពាណិជ្ជកម្មមួយចំនួន។ ប៊ីតខញ ដែលមានតម្លៃត្រឹមតែ ០.០៥ ដុល្លារ នៅពេលបង្កើតដំបូង ត្រូវបានជួញដូរក្នុងតម្លៃ ជិត ១០០០ ដុល្លារ ក្នុងរដូវក្តៅ ឆ្នាំ ២០១៤ ហើយបានធ្លាក់ថ្លៃទៅប្រហែល ៣០០ ដុល្លារ នៅឆ្នាំ ២០១៥ ហើយហក់ឡើងថ្លៃកប់ពពកឡើងវិញ ជាង ១១០០០ ដុល្លារនៅឆ្នាំ ២០១៨។ អ្វីដែលធ្វើអោយរូបិយប័ណ្ណអេឡិចត្រូនិកខុសប្លែកគេគឺថា ពួកគេមិនត្រូវបានចេញដោយរដ្ឋណាមួយ ឡើយប៉ុន្តែ បុគ្គលប្រើប្រាស់វាដើម្បីទិញនិងលក់ទំនិញ (ដំបូងឡើយ ភាគច្រើនជាទំនិញខុសច្បាប់នៅលើទីផ្សារអន្តរជាតិ)។ ថាតើរូបិយប័ណ្ណថ្មីទាំងនេះនឹងដើរតួនាទីកាន់តែធំនៅក្នុងពាណិជ្ជកម្មសកល មិនទាន់ដឹងច្បាស់នៅឡើយទេ (សូមមើលមេរៀនទី ១០)។

រូបថត អតិថិជនបង់ប្រាក់ប៊ីតខញ
ចុចទីនេះដើម្បីបង់ប្រាក់

រូបិយប័ណ្ណនិម្មិតដូចជា ប៊ីតខញ (bitcoin) កំពុងតែទទួលបានប្រជាប្រិយភាព បើទោះបីជាពួកគេមានចំណែកតូចមួយនៃប្រតិបត្តិការសេដ្ឋកិច្ចក៏ដោយ។ រូបិយប័ណ្ណនិម្មិតត្រូវបានប្រើប្រាស់កាន់តែខ្លាំងឡើងនៅក្នុងប្រទេសដែលមានបញ្ហារូបិយប័ណ្ណ។ នៅទីនេះ អតិថិជនបង់ប្រាក់ជាមួយ ប៊ីតខញ នៅក្នុងហាងកាហ្វេនៅទីក្រុងអាថែន (Athens) ឆ្នាំ ២០១៨។ ប៊ីតខញ កំពុងតែកើនប្រជាប្រិយភាពនៅក្នុងប្រទេសក្រិកដោយសារតែខណៈពេលដែលរដ្ឋាភិបាលបានដាក់ការគ្រប់គ្រងលើចរាចរប្រាក់អឺរ៉ូ វាមិនបានគ្រប់គ្រងចរាចររូបិយប័ណ្ណនិម្មិតនោះទេ។

៩.២.៤. ធនាគារកណ្តាល

រដ្ឋាភិបាលគ្រប់គ្រងដំណើរការបោះពុម្ពប្រាក់។ នៅក្នុងរដ្ឋមួយចំនួន អ្នកនយោបាយឬឧត្តមសេនីយ៍ដែលគ្រប់គ្រងរដ្ឋាភិបាលគ្រប់គ្រងដោយផ្ទាល់នូវចំនួនទឹកប្រាក់ដែលត្រូវបោះពុម្ព។ វាមិនគួរអោយភ្ញាក់ផ្អើលទេដែលអតិផរណាហាក់ឡើងខ្ពស់នៅក្នុងរដ្ឋទាំងនោះ ដោយសារតែបញ្ហានយោបាយ ជារឿយៗ អាចត្រូវបានដោះស្រាយដោយការបោះពុម្ពប្រាក់បន្ថែម។ ប៉ុន្តែ នៅក្នុងប្រទេសឧស្សាហកម្មភាគច្រើន អ្នកនយោបាយដឹងថា ពួកគេមិនអាចជឿទុកចិត្តខ្លួនឯងជាមួយនឹងការសម្រេចចិត្តប្រចាំថ្ងៃអំពីការបោះពុម្ពលុយនោះទេ។ ដើម្បីពង្រឹងវិន័យខ្លួនឯង និងបង្កើនទំនុកចិត្តសាធារណៈលើតម្លៃប្រាក់ ការសម្រេចចិត្តទាំងនេះត្រូវបានប្រគល់អោយ**ធនាគារកណ្តាល** (Central Bank)។

សេដ្ឋកិច្ចវិទូនិងអ្នកជំនាញបច្ចេកទេស ដែលគ្រប់គ្រងធនាគារកណ្តាល ព្យាយាមរក្សាតម្លៃរូបិយប័ណ្ណរបស់រដ្ឋ ដោយកំណត់ចំនួនប្រាក់ដែលត្រូវបោះពុម្ព និងមិនអនុញ្ញាតអោយមានអតិផរណាខ្ពស់នោះឡើយ។ អ្នកនយោបាយតែងតាំងមនុស្សដែលគ្រប់គ្រងធនាគារ ប៉ុន្តែ ជាទូទៅ ក្នុងរយៈពេលយ៉ាងយូរ ដែលមិនស្របគ្នាជាមួយអាណត្តិអ្នកនយោបាយ។ ដូច្នេះ អ្នកគ្រប់គ្រងធនាគារកណ្តាលព្យាយាមដំណើរការធនាគារដើម្បីផលប្រយោជន៍ជាតិ ដែលជាជំហានមួយឃ្លាតចេញឆ្ងាយពីនយោបាយបក្សពួកនិយម។ ប្រសិនបើមេដឹកនាំរដ្ឋបញ្ជាអោយមានអន្តរាគមន៍យោធា ឧត្តមសេនីយ៍ទាំងអស់ត្រូវគោរពតាមបទបញ្ជា ប៉ុន្តែប្រសិនបើមេដឹកនាំ

បញ្ជាអោយធ្វើអន្តរាគមន៍ក្នុងទីផ្សាររូបិយប័ណ្ណ ធនាគារកណ្តាលមិនត្រូវធ្វើតាមនោះទេ។ នៅក្នុងការអនុវត្ត ជាក់ស្តែងស្វ័យភាពរបស់ធនាគារកណ្តាលមានកម្រិតផ្សេងគ្នា។ ជាឧទាហរណ៍ នាយករដ្ឋមន្ត្រីថៃ តាក់ស៊ីន បានបណ្តេញប្រធានធនាគារកណ្តាលចេញពីតំណែង ក្នុងជម្លោះលើអត្រាការប្រាក់ ក្នុងឆ្នាំ ២០០១។

នៅសហរដ្ឋអាមេរិក ធនាគារកណ្តាលគឺជា *Federal Reserve* (នយត្រង់ *ទុនបំរុងសហព័ន្ធ*) ឬហៅកាត់ថា The Fed។ «ទុនបំរុង» គឺជាការស្តុកទុករូបិយប័ណ្ណខ្លាំងរបស់រដ្ឋាភិបាល។ ធនាគារកណ្តាលអាច ជះឥទ្ធិពលលើសេដ្ឋកិច្ច ដោយការបញ្ចេញឬស្តុកទុកប្រាក់របស់ខ្លួន។ ជាលក្ខណៈអន្តរជាតិ វាធ្វើបែបនេះដោយការជ្រៀតជ្រែកក្នុងទីផ្សាររូបិយប័ណ្ណ (ដូចដែលបានរៀបរាប់ពីមុន)។ អន្តរាគមន៍ពហុភាគីជាធម្មតាត្រូវបានសម្របសម្រួល ដោយប្រធានធនាគារកណ្តាលនិងក្រសួងរតនាគារ(ហិរញ្ញវត្ថុ) នៅក្នុងប្រទេសនាំមុខគេ។ ទស្សនវិស័យធនាគារកណ្តាលឥតលំអៀងរយៈពេលវែង ធ្វើអោយវាកាន់តែងាយស្រួលសម្រាប់រដ្ឋនានាក្នុងការសម្រេចបាននូវផលប្រយោជន៍រួមនៃប្រព័ន្ធរូបិយវត្ថុពិភពលោកដែលមានស្ថិរភាព។

សម្រាប់គោលនយោបាយក្នុងស្រុក ធនាគារកណ្តាលប្រតិបត្តិអំណាចរបស់ខ្លួនជាចម្បងដោយការកំណត់**អត្រាបញ្ចុះតម្លៃ** (discount rate) ដែលជាអត្រាការប្រាក់ដែលរដ្ឋាភិបាលគិតថ្លៃនៅពេលផ្តល់ប្រាក់កម្ចីទៅអោយធនាគារឯកជននានា។ (ធនាគារកណ្តាលមានតែធនាគារឯកជនជាអតិថិជនរបស់ពួកគេ មិនមែនបុគ្គលនិងសាជីវកម្មនោះទេ។) ជាលទ្ធផល អត្រានេះគ្រប់គ្រងល្បឿនឬលំហូរចាក់លុយចូលទៅក្នុងសេដ្ឋកិច្ច។ ប្រសិនបើធនាគារកណ្តាលកំណត់អត្រាបញ្ចុះតម្លៃទាបពេក នោះទំហំសាច់ប្រាក់ច្រើនពេកនឹងចូលចរាចរក្នុងទីផ្សារ ហើយអតិផរណានឹងកើនឡើង។ ប្រសិនបើអត្រានេះត្រូវបានកំណត់ខ្ពស់ពេក ទំហំសាច់ប្រាក់តិចតួចបំផុតនឹងត្រូវចរាចរ ហើយអតិថិជននិងអាជីវកម្មនឹងពិបាកក្នុងការទទួលនបានកម្ចីប្រាក់ច្រើន ឬក្នុងអត្រាទាបពីធនាគារឯកជន។ កំណើនសេដ្ឋកិច្ចនឹងត្រូវថយចុះ។

សេចក្តីសម្រេចចិត្តរបស់ធនាគារកណ្តាលអំពីអត្រាបញ្ចុះតម្លៃមានផលវិបាកសំខាន់ៗ ជាលក្ខណៈអន្តរជាតិ។ ប្រសិនបើអត្រាការប្រាក់នៅក្នុងរដ្ឋមួយខ្ពស់ជាងនៅក្នុងរដ្ឋមួយទៀត នោះមូលធនឬដើមទុនបរទេសទំនងជាត្រូវបានទាក់ទាញទៅកាន់រដ្ឋដែលមានអត្រាខ្ពស់ជាងនេះ។ ហើយបើសិនកំណើនសេដ្ឋកិច្ចខ្ពស់នៅក្នុងប្រទេសក្រៅ ទំនិញ អាចត្រូវនាំចេញទៅកាន់ប្រទេសនោះកាន់តែច្រើន។ ដូច្នេះ រដ្ឋត្រូវយកចិត្តទុកដាក់ចំពោះគោលនយោបាយរូបិយវត្ថុរបស់រដ្ឋផ្សេងទៀត។ ជម្លោះអន្តរជាតិដែលអាចកើតឡើង អាចត្រូវបានដោះស្រាយ ជាលក្ខណៈនយោបាយតែប៉ុណ្ណោះ (ដូចជានៅកិច្ចប្រជុំG២០) មិនមែនតាមបច្ចេកទេសទេ ពីព្រោះធនាគារកណ្តាលនីមួយៗ ទោះបីជាត្រូវបានដាក់អោយចេញឆ្ងាយពីនយោបាយក្នុងស្រុកក៏ដោយ ក៏នៅតែសម្លឹងមើលផលប្រយោជន៍រដ្ឋរបស់ខ្លួនដដែល។

ទោះបីជាធនាគារកណ្តាលគ្រប់គ្រងទុនបំរុងជារូបិយប័ណ្ណយ៉ាងច្រើនក៏ដោយ ពួកគេត្រូវបានដាក់កម្រិតដោយចំណែកមានកំណត់នៃប្រាក់ពិភពលោកដែលពួកគេកាន់កាប់។ ធនាគារឯកជននិងសាជីវកម្មកាន់កាប់ទ្រព្យសម្បត្តិភាគច្រើន។ ក្នុងនាមជាតួអង្គសេដ្ឋកិច្ច រដ្ឋមិនជំរុញទិសដៅសេដ្ឋកិច្ចពិភពលោកទេ។ នៅក្នុងវិថីជាច្រើន ពួកគេដើមតាមទិសដៅនោះ យ៉ាងហោចណាស់ ក្នុងរយៈពេលយូរ។ ដូចដែលយើងបានឃើញនៅក្នុងវិបត្តិសេដ្ឋកិច្ចពិភពលោកនាពេលថ្មីៗនេះ រដ្ឋនានានៅតែដើរតួយ៉ាងសំខាន់នៅក្នុងសេដ្ឋកិច្ចពិភពលោក។ ក្នុងរយៈពេលខ្លី រដ្ឋនានាអាចអនុម័តកញ្ចប់ជំរុញហិរញ្ញវត្ថុដ៏ធំ អាចជួយសង្គ្រោះធនាគារឯកជន

និងសាជីវកម្មដែលប្រឈមនឹងការក្សោយធន និងអាចកាត់ទោសបុគ្គលដែលប្រព្រឹត្តទង្វើខុសច្បាប់ដែលបង្ក អោយមានការលំបាកផ្នែកសេដ្ឋកិច្ច។

៩.២.៥. ធនាគារពិភពលោក និង មូលនិធិរូបិយវត្ថុអន្តរជាតិ

ដោយសារតែសារៈសំខាន់នៃកិច្ចសហប្រតិបត្តិការអន្តរជាតិ សម្រាប់ប្រព័ន្ធរូបិយវត្ថុពិភពលោកដែលមានស្ថិរភាព និងដោយសារតែតម្រូវការចាំបាច់ដើម្បីជម្នះលើបញ្ហាផលប្រយោជន៍រួម របបនិងស្ថាប័នអន្តរជាតិបានអភិវឌ្ឍជុំវិញបទដ្ឋាននៃអាកប្បកិរិយា ក្នុងទំនាក់ទំនងរូបិយវត្ថុ។ ដូចគ្នានឹងស្ថាប័នអង្គការសហប្រជាជាតិគាំទ្ររបបដែលផ្អែកលើបទដ្ឋាននៃអាកប្បកិរិយាក្នុងកិច្ចការសន្តិសុខអន្តរជាតិ របបរូបិយវត្ថុពិភពលោកក៏ដូចគ្នាដែរ។

ដូចនៅក្នុងកិច្ចការសន្តិសុខ ស្ថាប័នសេដ្ឋកិច្ចអន្តរជាតិសំខាន់ៗត្រូវបានបង្កើតឡើងនៅជិតចុងបញ្ចប់នៃសង្គ្រាមលោកលើកទីពីរ។ ប្រព័ន្ធ Bretton Woods (អានថា *ប្រេតុនវូឌស៍*) ត្រូវបានអនុម័តនៅក្នុងសន្និសីទនៃរដ្ឋឈ្នះសង្គ្រាម ក្នុងឆ្នាំ ១៩៤៤ (នៅទីក្រុង Bretton Woods ក្នុងរដ្ឋ New Hampshire)។ វាបានបង្កើត*ធនាគារអន្តរជាតិដើម្បីការកសាងឡើងវិញនិងអភិវឌ្ឍន៍*(IBRD) ដែលជាទូទៅគេហៅថា **ធនាគារពិភពលោក** សម្រាប់ជាប្រភពផ្តល់ប្រាក់កម្ចីដើម្បីកសាងសេដ្ឋកិច្ចអឺរ៉ុបខាងលិចឡើងវិញ នៅក្រោយសង្គ្រាមលោក និងដើម្បីជួយរដ្ឋនានាហែលឆ្លងការលំបាកផ្នែកហិរញ្ញវត្ថុនាពេលអនាគត។ (ក្រោយមកទៀត អ្នកខ្ចីសំខាន់ៗ គឺជាប្រទេសកំពុងអភិវឌ្ឍន៍ ហើយក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ អឺរ៉ុបខាងកើតផងដែរ។) ស្ថាប័នដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយធនាគារពិភពលោក គឺមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF)។ មូលនិធិIMF សម្របសម្រួលការប្តូររូបិយប័ណ្ណអន្តរជាតិ ជញ្ជីងទូទាត់អន្តរជាតិ និងគណនីជាតិ (នឹងត្រូវពិភាក្សាឆាប់ៗនេះ)។ ធនាគារពិភពលោកនិងមូលនិធិIMFបន្តមុខងារជាសសរស្តម្ភនៃប្រព័ន្ធហិរញ្ញវត្ថុអន្តរជាតិ។ (តួនាទីរបស់ធនាគារពិភពលោកនិងមូលនិធិIMF ក្នុងការអភិវឌ្ឍន៍អន្តរជាតិត្រូវបានលើកមកពិភាក្សានៅក្នុងមេរៀនទី ១៣។)

ប្រព័ន្ធ Bretton Woods កំណត់របបដោះដូររូបិយវត្ថុដែលមានស្ថិរភាព ដោយផ្អែកលើប្រាក់ដុល្លារអាមេរិក និងគាំទ្រដោយមាស ដែលមានរយៈពេលចាប់ពីឆ្នាំ ១៩៤៤ ដល់ឆ្នាំ ១៩៧១។ ក្នុងអំឡុងពេលនេះ ប្រាក់ដុល្លារមានតម្លៃថេរ ស្មើនឹង១ភាគ៣៥នៃមាសទម្ងន់មួយអោន (មាស ១ អោន ស្មើនឹង ៨ដឺនិង៣ហ៊ុន) ហើយរដ្ឋាភិបាលសហរដ្ឋអាមេរិកបានធានាទិញប្រាក់ដុល្លារដោយប្រើមាសក្នុងអត្រានេះ (ពីស្តុកមាសនៅក្រុង Fort Knox នៃរដ្ឋ Kentucky)។ រូបិយប័ណ្ណរបស់រដ្ឋផ្សេងទៀតត្រូវបាន គេប្តូរយកក្នុងអត្រាថេរធៀបនឹងប្រាក់ដុល្លារ។ មូលនិធិIMFកំណត់អត្រាប្តូរប្រាក់ថេរទាំងនេះ ដោយផ្អែកលើកម្រិតលំនឹងរយៈពេលវែងដែលអាចមាននិរន្តរភាព សម្រាប់រូបិយប័ណ្ណនីមួយៗ (ជាជាងដោយការពិចារណាអំពីនយោបាយរយៈពេលខ្លី)។ ទីផ្សាររូបិយប័ណ្ណអន្តរជាតិបានប្រតិបត្តិការក្នុងរចនាសម្ព័ន្ធកំណត់ជុំវិញអត្រាថេរ។ ប្រសិនបើរូបិយប័ណ្ណរបស់ប្រទេសមួយធ្លាក់ថ្លៃ លើសពី ១ ភាគរយ ពីអត្រាថេរ ប្រទេសនោះត្រូវប្រើទុនបម្រុងរូបិយប័ណ្ណខ្លាំងរបស់ខ្លួនដើម្បីទិញរូបិយប័ណ្ណរបស់ខ្លួនត្រឡប់មកវិញ ហើយដូច្នេះរូបិយប័ណ្ណខ្លួនឡើងថ្លៃវិញ។ ប្រសិនបើតម្លៃកើនឡើង លើសពី ១ ភាគរយនោះ វាត្រូវតែលក់រូបិយប័ណ្ណរបស់ខ្លួនដើម្បីជំរុញអោយតម្លៃធ្លាក់ចុះ។

ស្តង់ដារមាសត្រូវបានបោះបង់ចោល នៅឆ្នាំ ១៩៧១ ដែលជាព្រឹត្តិការណ៍មួយដួនកាលត្រូវបានគេហៅថា «ការដួលរលំនៃប្រព័ន្ធBretton Woods»។ ពាក្យនេះដូចជាមិនសូវត្រូវទេ៖ ស្ថាប័ននានារបស់វាបាន

បន្តដំណើរការ ហើយសូម្បីតែរបបរូបិយវត្ថុក៏ទទួលបានការកែតម្រូវឬកែលម្អ ជាជាងដួលរលំទាំងស្រុង។ សេដ្ឋកិច្ចរបស់សហរដ្ឋអាមេរិកលែងមានវិសាលភាពគ្រប់ដណ្តប់លើសលប់ ដូចដែលវាធ្លាប់ធ្វើ កាលពីឆ្នាំ ១៩៤៤ ទៀតហើយ មូលហេតុភាគច្រើនដោយសារតែការងើបឡើងវិញរបស់អឺរ៉ុប និងជប៉ុន ក្រោយពេលសង្គ្រាមលោកលើកទី ២ តែក៏អាចដោយសារអាមេរិកចំណាយលើសលប់លើសង្គ្រាមវៀតណាម និងលំហូរចេញនៃប្រាក់ដុល្លារអាមេរិកសម្រាប់ទិញប្រេង។ ជាលទ្ធផល ប្រាក់ដុល្លារបានឡើងថ្លៃកប់ពពក។ នៅត្រឹមឆ្នាំ ១៩៧១ ប្រាក់ដុល្លារលែងលែងមានតម្លៃស្មើ ១ភាគ៣៥ នៃទម្ងន់មាសមួយអោន ហើយសហរដ្ឋអាមេរិកត្រូវបោះបង់ចោលអត្រាប្តូរប្រាក់ថេររបស់ខ្លួន។ លោកប្រធានាធិបតី និចសុន បានផ្តាច់ប្រព័ន្ធដុល្លារ-មាស ជាឯកតោភាគី ហើយអនុញ្ញាតអោយប្រាក់ដុល្លារអណ្តែត ដោយសេរី។ មិនយូរប៉ុន្មានវាបានធ្លាក់ថ្លៃ ដល់ប្រភាគមួយនៃតម្លៃពីមុនរបស់វាធៀបនឹងមាស។

ការបោះបង់ចោលស្តង់ដារមាសអំណោយផលល្អសម្រាប់សហរដ្ឋអាមេរិក និងផលអាក្រក់សម្រាប់ប្រទេសជប៉ុននិងអឺរ៉ុប ដែលមេដឹកនាំបានសម្តែងការភ្ញាក់ផ្អើលចំពោះទង្វើឯកតោភាគីរបស់សហរដ្ឋអាមេរិក។ ការពឹងអាស្រ័យគ្នាទៅវិញទៅមកនៃសេដ្ឋកិច្ចមូលធននិយមពិភពលោក ដែលបានបង្កើតកំណើនសេដ្ឋកិច្ចដែលមិនធ្លាប់មានពីមុនមក សម្រាប់ប្រទេសលោកខាងលិចទាំងអស់ បន្ទាប់ពីសង្គ្រាមលោកលើកទី ២ ក៏បានបង្កើតលក្ខខណ្ឌសម្រាប់ជម្លោះអន្តរជាតិថ្មី។

ដើម្បីជំនួសមាសសម្រាប់ជាស្តង់ដារពិភពលោក មូលនិធិរូបិយវត្ថុអន្តរជាតិ(IMF) បានបង្កើតរូបិយប័ណ្ណពិភពលោកថ្មីមួយ គឺ **សិទ្ធិដកពិសេស** ហៅកាត់ថា SDR (Special Drawing Right)។ SDR ត្រូវបានគេហៅថា «មាសក្រដាស» ដោយសារតែវាត្រូវបានបង្កើតឡើងក្នុងបរិមាណមានដែនកំណត់ ដោយមូលនិធិIMF, ត្រូវបានរក្សាទុកជាទុនបម្រុងរូបិយប័ណ្ណខ្លាំងដោយធនាគារកណ្តាលរបស់រដ្ឋ, ហើយអាចត្រូវបានប្តូរទៅជារូបិយប័ណ្ណអន្តរជាតិផ្សេងៗបាន។ បច្ចុប្បន្ននេះ SDR គឺអ្វីមួយដែលអាចប្រៀបប្រដូចទៅនឹងរូបិយប័ណ្ណពិភពលោកដែលកំពុងមានអត្ថិភាព ប៉ុន្តែវាមិនអាចទិញទំនិញបានទេ ទិញបានតែរូបិយប័ណ្ណប៉ុណ្ណោះ។ ហើយវាត្រូវបានគ្រប់គ្រងជាម្ចាស់កម្មសិទ្ធិដោយរដ្ឋ(ធនាគារកណ្តាល)ប៉ុណ្ណោះ មិនមែនដោយបុគ្គលឬក្រុមហ៊ុនឯកជនទេ។ SDRsត្រូវបានផ្សារភ្ជាប់តម្លៃជាមួយនឹងកញ្ចប់រូបិយប័ណ្ណអន្តរជាតិសំខាន់ៗមួយចំនួន (ប៉ុន្តែ រូបិយប័ណ្ណដែលមូលនិធិIMFកែតម្រូវជាទៀងទាត់ដើម្បីឆ្លុះបញ្ចាំងពីភាពខ្លាំង ឬភាពខ្សោយរបស់ប្រាក់ដុល្លារ)។ នៅពេលដែលរូបិយប័ណ្ណមួយឡើងថ្លៃបន្តិច ហើយរូបិយប័ណ្ណមួយទៀតធ្លាក់ថ្លៃ SDR មិនផ្លាស់ប្តូរតម្លៃច្រើនទេ។ ប៉ុន្តែ ប្រសិនបើរូបិយប័ណ្ណទាំងអស់ឡើងថ្លៃ (អតិផរណាទូទាំងពិភពលោក) SDR នឹងឡើងថ្លៃជាមួយពួកគេដែរ។

ចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ ១៩៧០ មក *ប្រព័ន្ធអណ្តែតមានកម្រិត*បាននិងកំពុងគ្រប់គ្រងរូបិយប័ណ្ណជាតិសំខាន់ៗ។ អន្តរកាលពីរបបដុល្លារ-មាស ទៅជា របបអណ្តែតមានកម្រិត មានការពិបាកណាស់។ រដ្ឋនានាត្រូវតែចរចានយោបាយលើគោលដៅសម្រាប់អត្រាប្តូរប្រាក់នៅក្នុងកិច្ចប្រជុំ ដែលគេស្គាល់ថាជាកិច្ចប្រជុំកំពូលនៃក្រុមប្រទេសទាំងប្រាំមួយ (G៦)។ ក្រុមG៦ ក្រោយមកត្រូវបានពង្រីកទៅជា ក្រុមG៨ ជាមួយនឹងការបន្ថែមប្រទេសកាណាដា (ក្នុងឆ្នាំ ១៩៧៦) និងរុស្ស៊ី (ក្នុងឆ្នាំ ១៩៩៧) (សមាជិកភាពរបស់រុស្ស៊ីត្រូវបានព្យួរនៅឆ្នាំ ២០១៤ បន្ទាប់វាបានភ្ជាប់តំបន់គ្រីមៀចូលទឹកដីខ្លួន។) ក្នុងឆ្នាំ ២០០៩ ក្រុមប្រទេសG២០ ដែល

រួមបញ្ចូលទាំងប្រទេសដែលមានការអភិវឌ្ឍន៍ខ្លាំងនិងកំពុងអភិវឌ្ឍន៍ នឹងចាប់ផ្តើមជំនួសក្រុមG៨ ក្នុងកិច្ចពិភាក្សាហិរញ្ញវត្ថុសំខាន់ៗ។

យន្តការបច្ចេកទេសរបស់មូលនិធិIMF ត្រូវផ្អែកលើការដាក់ទុនបម្រុងហិរញ្ញវត្ថុរបស់ប្រទេសសមាជិកនីមួយៗក្នុងមូលនិធិIMF។ បន្ទាប់ពីបានចូលជាសមាជិកមូលនិធិIMFភ្លាម រដ្ឋមួយត្រូវបានផ្តល់*ភតា*(quota) សម្រាប់ដាក់ប្រាក់បម្រុងបែបនេះ ដោយមួយផ្នែកជារូបិយប័ណ្ណខ្លាំង និងមួយផ្នែកទៀតជារូបិយប័ណ្ណរបស់រដ្ឋផ្ទាល់ (កូតានេះមិនមែនជាទាក់ទងទៅនឹងគោលគំនិតនៃកូតាពាណិជ្ជកម្ម ដែលជាការរឹតបន្តឹងការនាំចូលទេ)។ កូតានេះត្រូវផ្អែកលើទំហំនិងកម្លាំងសេដ្ឋកិច្ចរបស់រដ្ឋ។ ទៅថ្ងៃមុខ រដ្ឋអាចខ្ចីតាមសមាមាត្រកូតារបស់ខ្លួន (ឬពេលខ្លះអាចលើសបន្តិចផង) ដើម្បីរក្សាស្ថិរភាពសេដ្ឋកិច្ចរបស់ខ្លួន ក្នុងគ្រាលំបាក ហើយត្រូវសងត្រលប់មកអោយមូលនិធិIMFក្នុងឆ្នាំបន្តបន្ទាប់ទៀត។ ក្នុងឆ្នាំ ២០០៩ មេដឹកនាំពិភពលោកបានសន្យាថានឹងបង់បន្ថែម ១ ទ្រីលានដុល្លារទៅក្នុងមូលនិធិIMF ដូច្នេះ វាអាចជួយប្រទេសកំពុងអភិវឌ្ឍន៍ទប់ទល់នឹងវិបត្តិហិរញ្ញវត្ថុពិភពលោក។

ខុសពីអង្គការWTOឬមហាសន្និបាតអង្គការសហប្រជាជាតិ មូលនិធិIMF និងធនាគារពិភពលោកប្រើប្រាស់ប្រព័ន្ធ*បោះឆ្នោតតាមសមាមាត្រ* (weighted voting) ក្នុងនោះរដ្ឋនីមួយៗមានសម្លេងបោះឆ្នោតតាមកូតារបស់ខ្លួន។ ដូច្នេះ ប្រទេសដែលមានសេដ្ឋកិច្ចជឿនលឿនគ្រប់គ្រងមូលនិធិIMF ទោះបីជារដ្ឋស្ទើរតែទាំងអស់នៅលើពិភពលោកជាសមាជិកក៏ដោយ។ សហរដ្ឋអាមេរិកមានសម្លេងឆ្នោតច្រើនជាងគេតែមួយគត់ (១៧ ភាគរយ) ហើយទីក្រុងវ៉ាស៊ីនតោនក្លាយជាទីស្នាក់ការកណ្តាលសម្រាប់ទាំងមូលនិធិIMFនិងធនាគារពិភពលោក។ ក្នុងឆ្នាំ ២០០៨ មូលនិធិIMFបានកែសម្រួលរូបមន្តបោះឆ្នោត ដោយបង្កើនកូតា និងអំណាចបោះឆ្នោតរបស់ប្រទេសចិនតិចតួច (ពី ៣ ទៅ ៣,៧ ភាគរយ នៃចំនួនសរុប) និងប្រទេសកំពុងអភិវឌ្ឍន៍ផ្សេងទៀត។

រូបថត អ្នកលក់ផ្លែឈើតាមផ្លូវ

គ្រាប់ពូជនៃការអភិវឌ្ឍន៍

ធនាគារពិភពលោកធ្វើការដើម្បីស្ថិរភាពនិងអភិវឌ្ឍន៍សេដ្ឋកិច្ច នៅក្នុងប្រទេសក្រីក្រនិងប្រាក់ចំណូលមធ្យម។ នៅប្រទេសប៉ាគីស្តាន ធនាគារពិភពលោកដំណើរការកម្មវិធីដើម្បីបង្កើនផលិតភាពកសិកម្ម និងបង្កើនអាហារូបត្ថម្ភ។ អ្នកលក់នៅទីក្រុង ឡាហ័រ (Lahore) លក់ផ្លែប៉ោម នៅលើរទេះលារបស់គាត់ នៅក្នុងឆ្នាំ ២០១២។

ចាប់តាំងពីឆ្នាំ ១៩៤៤ មូលនិធិIMF និងធនាគារពិភពលោកបានព្យាយាមបំពេញបេសកកម្មសំខាន់ៗចំនួនបី។ ដំបូងឡើយ ពួកគេបានព្យាយាមផ្តល់នូវស្ថិរភាពនិងលទ្ធភាពទទួលបានមូលធនសម្រាប់បណ្តារដ្ឋដែលត្រូវបានបំផ្លិចបំផ្លាញដោយសង្គ្រាមលោកលើកទីពីរ ជាពិសេសប្រទេសជប៉ុន និងបណ្តារដ្ឋនៅអឺរ៉ុបខាងលិច។ បេសកកម្មនេះទទួលបានជោគជ័យយ៉ាងសម្បើមដែលនាំអោយមានការរីកចម្រើននិងវិបុលភាពក្នុងរដ្ឋទាំងនោះ។ ទីពីរ ជាពិសេស នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៧០ និង ១៩៨០ ប៉ុន្តែ នៅតែបន្តរហូតមកដល់សព្វថ្ងៃ ធនាគារពិភពលោក និង មូលនិធិIMF បានព្យាយាមជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ច។ បេសកកម្មនោះមិនសូវទទួលបានជោគជ័យទេ ដូចដែលបានឆ្លុះបញ្ចាំងអោយឃើញនៅក្នុងភាពក្រីក្រដែលកំពុងបន្តនៅអឡឹកគោលខាងត្បូង (សូមមើលមេរៀនទី ១២)។ បេសកកម្មទីបី នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ គឺការធ្វើសមាហរណកម្ម

អឺរ៉ុបខាងកើតនិងរុស្ស៊ីទៅក្នុងប្រព័ន្ធសេដ្ឋកិច្ចមូលធននិយមពិភពលោក។ កិច្ចខិតខំប្រឹងប្រែងក្រោយនេះមានកំណត់ត្រាចម្រុះ ប៉ុន្តែបានទទួលជោគជ័យជាទូទៅ។

៩.៣. ស្ថានភាពហិរញ្ញវត្ថុរបស់រដ្ឋនានា

៩.៣ ចូរប្រៀបធៀបលក្ខណៈដូចនិងខុសគ្នានៃជំហរហិរញ្ញវត្ថុរបស់សហរដ្ឋអាមេរិកនិងរុស្ស៊ី ទាក់ទងនឹងសក្តានុពលនៃកំណើនសេដ្ឋកិច្ច នាពេលអនាគត។

នៅពេលដែលអត្រារូបិយប័ណ្ណផ្លាស់ប្តូរ ហើយសេដ្ឋកិច្ចរបស់រដ្ឋកើនឡើង ជំហររួមរបស់រដ្ឋនីមួយៗធៀបគ្នាក៏ផ្លាស់ប្តូរដែរ។

៩.៣.១. គណនីជាតិ

មូលនិធិIMFរក្សាប្រព័ន្ធនៃស្ថិតិ*គណនីជាតិ*(national account) ដើម្បីតាមដានស្ថានភាពរូបិយវត្ថុទាំងមូលរបស់រដ្ឋនីមួយៗ។ **ជញ្ជីងទូទាត់**(balance of payment)របស់រដ្ឋប្រៀបដូចជារបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមួយដែរ៖ វាសង្ខេបលំហូរប្រាក់សរុបចូលក្នុងនិងចេញក្រៅប្រទេសមួយ។ ប្រព័ន្ធនេះផ្ទាល់មានលក្ខណៈបច្ចេកទេស និងមិនមែនជាលក្ខណៈនយោបាយទេ។ ជាសំខាន់ ប្រតិបត្តិការអន្តរជាតិបីប្រភេទចូលទៅក្នុងជញ្ជីងទូទាត់៖ គណនីចរន្ត លំហូរមូលធន និងបម្រែបម្រួលទុនបម្រុង។

គណនីចរន្ត (current account) ជាគោល គឺជាជញ្ជីងពាណិជ្ជកម្ម ដែលបានពិភាក្សានៅក្នុងមេរៀនទី ៨។ លុយហូរចេញពីរដ្ឋដើម្បីទូទាត់ការនាំចូល ហើយហូរចូលរដ្ឋវិញដើម្បីទូទាត់ការនាំចេញ។ ការនាំចូលឬនាំចេញរួមមានទាំងទំនិញនិងសេវាកម្ម។ ជាឧទាហរណ៍ ប្រាក់ដែលចំណាយដោយអ្នកទេសចរជនជាតិអង់គ្លេសម្នាក់នៅរដ្ឋផ្លរីដា ស្មើនឹងប្រាក់ចំណាយដោយអតិថិជនជនជាតិអង់គ្លេសម្នាក់ទិញក្រូចផ្លរីដានៅក្នុងទីផ្សារទីក្រុងឡុងដ៍។ ក្នុងករណីទាំងពីរនេះ លុយហូរចូលគណនីចរន្តរបស់សហរដ្ឋអាមេរិក។ គណនីចរន្តរួមមានធាតុពីរផ្សេងទៀត។ *ប្រតិបត្តិការរដ្ឋាភិបាល*(government transaction) គឺជាមូលនិធិជំនួយយោធានិងជំនួយបរទេស ក៏ដូចជាប្រាក់បៀវត្សរ៍ និងប្រាក់សោធននិវត្តន៍ដែលបើកអោយបុគ្គលិករដ្ឋាភិបាល នៅបរទេស។ *ប្រាក់បញ្ជូនទៅស្រុក* (remittances) គឺជាមូលនិធិដែលក្រុមហ៊ុន ឬបុគ្គលនានានៅបរទេស ផ្ញើត្រលប់មកផ្ទះ (សូមមើលមេរៀនទី ១២)។ ជាឧទាហរណ៍ ក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ហុងដា នៅអាមេរិកអាចបញ្ជូនប្រាក់ចំណេញត្រឡប់ទៅក្រុមហ៊ុនមេ ហុងដា នៅប្រទេសជប៉ុនវិញ។ ឬពលរដ្ឋអង់គ្លេសដែលធ្វើការនៅបុរីញូវយ៉កអាចផ្ញើប្រាក់ទៅអោយឪពុកម្តាយរបស់ពួកគេនៅទីក្រុងឡុងដ៍។

ប្រភេទទី ២ នៅក្នុងគណនី *លំហូរមូលធន* (capital flows) ត្រូវបានផ្សំឡើងដោយការវិនិយោគបរទេសនៅ*ក្នុង*និង*ដោយ*ប្រទេសមួយ។ លំហូរមូលធនត្រូវបានវាស់វែងក្នុងន័យ*សរុប* ពោលគឺ ការវិនិយោគនិងប្រាក់កម្ចីសរុបទាំងអស់ដែលជនបរទេសខ្ចីនៅ*ក្នុង*ប្រទេសមួយ ដកការវិនិយោគនិងប្រាក់កម្ចីសរុបទាំងអស់ដែលក្រុមហ៊ុន ប្រជាពលរដ្ឋ និងរដ្ឋាភិបាលរបស់ប្រទេសនោះ វិនិយោគនិងខ្ចីនៅក្នុងប្រទេស*ផ្សេងៗ*ទៀត។ ភាគច្រើននៃការវិនិយោគប្រភេទនេះធ្វើឡើងដោយឯកជន ទោះបីជាខ្លះធ្វើឡើងដោយ (ឬនៅក្នុង) ទីភ្នាក់ងាររដ្ឋាភិបាលនិងឧស្សាហកម្មរបស់រដ្ឋក៏ដោយ។ លំហូរមូលធនត្រូវបានបែងចែកទៅជា*ការវិនិយោគផ្ទាល់ពីបរទេស* (foreign direct investment- FDI) (ឬ*ការវិនិយោគពីបរទេសផ្ទាល់*) ដូចជាការកាន់កាប់ជាកម្មសិទ្ធិលើរោងចក្រ ក្រុមហ៊ុន ឬអចលនទ្រព្យ ក្នុងប្រទេសក្រៅ និង*ការវិនិយោគជាមូលប័ត្រ*(portfolio investment)ដោយប្រយោល ដូចជាការទិញភាគហ៊ុននិងប័ណ្ណបំណុល ឬការផ្តល់ប្រាក់កម្ចីដល់ក្រុមហ៊ុន

បរទេស។ ប្រភេទផ្សេងៗនៃលំហូរមូលធនទាំងនេះមានផលវិបាកនយោបាយផ្សេងៗគ្នាដែរ (សូមមើលបំណុលអន្តរជាតិនិងការវិនិយោគផ្ទាល់ពីបរទេស នៅផ្នែកខាងក្រោយក្នុងមេរៀននេះ) ប៉ុន្តែ ពួកវាជារួមមានតម្លៃសមមូលនៅក្នុងទិដ្ឋភាពគណនីជាតិទាំងមូល។

ប្រភេទទីបី បម្រែបម្រួល *ទុនបំរុងសម្រាប់ប្តូរប្រាក់បរទេស* (changes in foreign exchange reserves) ជួយធ្វើអោយគណនីជាតិមានតុល្យភាព។ គម្លាតណាមួយរវាងលំហូរប្រាក់ចូលនិងលំហូរប្រាក់ចេញ (នៅក្នុងគណនីចរន្ត និង លំហូរមូលធនរួមបញ្ចូលគ្នា) ត្រូវបានបំពេញបន្ថែមដោយបម្រែបម្រួលទុនបម្រុងក្នុងទំហំស្មើគ្នានិងទិសដៅផ្ទុយគ្នា។ បម្រែបម្រួលនៃទុនបំរុងទាំងនេះរួមមានការដែលរដ្ឋទិញនិងលក់ SDRs មាស និងរូបិយប័ណ្ណខ្លាំងក្រៅពីរូបិយប័ណ្ណរបស់ខ្លួន និងបម្រែបម្រួលទុនបម្រុងរបស់ខ្លួនដែលផ្ញើក្នុងមូលនិធិIMF។ ប្រសិនបើរដ្ឋមួយមានលុយហូរចេញក្រៅច្រើនជាងចូលក្នុងនោះ វាទទួលបានប្រាក់នោះពីទុនបំរុងរបស់ខ្លួន។ ប្រសិនបើវាមានលុយហូរចូលក្នុងច្រើនជាងហូរចេញក្រៅ វាដាក់លុយនោះក្នុងទុនបម្រុងរបស់វានៅមូលនិធិIMF។ ដូច្នេះហើយ គណនីជាតិនៅទីបញ្ចប់ទៅ ត្រូវតែមានតុល្យភាពជានិច្ច ឬយ៉ាងហោចណាស់ ស្ទើរតែមានតុល្យភាពដែរ។ មានប្រភេទសំណល់ ដោយរួមបញ្ចូលកំហុសអចេតនានិងការកោសលុបដោយសារសូម្បីតែរដ្ឋាភិបាលដែលមានប្រសិទ្ធភាពនិងស្មោះត្រង់បំផុត (រដ្ឋាភិបាលជាច្រើនមិនមែនទាំងពីរ) មិនអាចតាមដានរាល់លុយកាក់ដែលឆ្លងកាត់ព្រំដែនរបស់ខ្លួនឡើយ។

៩.៣.២. បំណុលអន្តរជាតិ

តាមន័យម្យ៉ាង សេដ្ឋកិច្ចណាមួយមានចរន្តឥតឈប់ឈរ នៅពេលដែលលុយចរាចរទៅមកតាមរយៈដំណើរការផលិតកម្ម ពាណិជ្ជកម្ម និងការទិញរបស់របរប្រើប្រាស់។ ប៉ុន្តែ សេដ្ឋកិច្ចក៏ *មានអចលនទ្រព្យ* (standing wealth) មិនផ្លាស់ទីផងដែរ។ ទុនបម្រុងជារូបិយប័ណ្ណខ្លាំងដែលជាកម្មសិទ្ធិរបស់រដ្ឋាភិបាល ជាទម្រង់មួយនៃអចលនទ្រព្យ ប៉ុន្តែមិនមែនជាអ្វីដែលសំខាន់បំផុតនោះទេ។ អចលនទ្រព្យច្រើនបំផុតមានទម្រង់ជាផ្ទះសម្បែងនិងរថយន្ត កសិដ្ឋាននិងរោងចក្រ កំពង់ផែនិងផ្លូវដែក។ ជាពិសេស ទំនិញ *មូលធន* (ដូចជារោងចក្រ) ជាផលិតផលដែលអាចប្រើប្រាស់ជាមធ្យោបាយ ឬវត្ថុធាតុដើម សម្រាប់ផលិតទំនិញបន្ត។ គ្មានអ្វីស្ថិតស្ថេរជាអមតៈនោះទេ ប៉ុន្តែអចលនទ្រព្យអាចធន់បានយូរឆ្នាំ ល្មមត្រូវបានគេចាត់ទុកខុសពីទំនិញដទៃដែលងាយខូចឬត្រូវបានប្រើប្រាស់អស់យ៉ាងឆាប់រហ័ស។ ភាពខុសគ្នាជាចំបងគឺថាមូលធននោះអាចត្រូវបានប្រើប្រាស់ដើម្បីបង្កើតទ្រព្យសម្បត្តិបន្ថែមទៀត៖ រោងចក្រអាចផលិតទំនិញ ផ្លូវដែកគាំទ្រពាណិជ្ជកម្ម ជាដើម។ អចលនទ្រព្យបង្កើតទ្រព្យសម្បត្តិថ្មី ដូច្នេះសេដ្ឋកិច្ចមានទំនោរកើចម្រើន បន្តិចម្តងៗ។ នៅពេលដែលវាកើនឡើង អចលនទ្រព្យត្រូវបានបង្កើតកាន់តែច្រើនឡើង។ នៅក្នុងសេដ្ឋកិច្ចមូលធននិយម លុយរកលុយបានកាន់តែច្រើន។

អត្រាការប្រាក់ (interest rates) ឆ្លុះបញ្ចាំងពីចរន្តកំណើនយ៉ាងប្រត្យក្សមួយនេះ។ *អត្រាការប្រាក់ជាក់ស្តែង* (real interest rates) គឺជាអត្រាសម្រាប់ការខ្ចីប្រាក់ខាងលើនិងលើសពីអត្រាអតិផរណា (ជាឧទាហរណ៍ ប្រសិនបើប្រាក់ត្រូវបានខ្ចីក្នុងអត្រាការប្រាក់ប្រចាំឆ្នាំ ៨ ភាគរយ ប៉ុន្តែ អតិផរណាមានអត្រា ៣ ភាគរយ អត្រាការប្រាក់ជាក់ស្តែងមានកម្រិត ៥ ភាគរយ)។ អាជីវកម្មនិងគ្រួសារទាំងឡាយខ្ចីប្រាក់ ពីព្រោះពួកគេគិតថាពួកគេអាចប្រើប្រាស់វាដើម្បីបង្កើតទ្រព្យសម្បត្តិថ្មី ក្នុងល្បឿនលឿនជាងអត្រាការប្រាក់ ដែលត្រូវបង់សងប្រាក់កម្ចី។

ប្រសិនបើសេដ្ឋកិច្ចរបស់រដ្ឋមួយមានសុខភាពល្អ វាអាចខ្ចីប្រាក់ពីរដ្ឋាភិបាល ធនាគារ ឬក្រុមហ៊ុនបរទេស ហើយបង្កើតបានទ្រព្យសម្បត្តិថ្មីច្រើនគ្រប់គ្រាន់ដើម្បីសងបំណុល ក្នុងពេលប៉ុន្មានឆ្នាំក្រោយ។ ប៉ុន្តែរដ្ឋ ក៏ដូចជាអាជីវកម្មដែរ ពេលខ្លះប្រតិបត្តិការដោយការខាតបង់។ នៅពេលនោះ បំណុលរបស់ពួកគេកើនឡើង។ នៅក្នុងវដ្តដ៏កាចសាហាវ ប្រាក់ចំណូលកាន់តែច្រើនដែលពួកគេបង្កើតបាន ត្រូវបង្វិលបង់ការប្រាក់ ហើយត្រូវខ្ចីប្រាក់បន្ថែមទៀតដើម្បីរក្សាដំណើររបស់រដ្ឋបន្តទៀត។ ប្រសិនបើកំព្វសំណាងដល់ រដ្ឋ ឬអាជីវកម្ម អាចបង្កើតទ្រព្យសម្បត្តិម្តងហើយម្តងទៀត ហើយយូរៗ ទៅអាចសងប្រាក់បំណុលរបស់ខ្លួនទាំងដើមទាំងការ ដើម្បីងើបផុតពីរណ្តៅបំណុល។ បើមិនអញ្ចឹងទេ វានឹងត្រូវចាប់ផ្តើមលក់ចេញនូវអចលនទ្រព្យរបស់ខ្លួន (រួមមាន អគារ យន្តហោះ រោងចក្រ កំពង់ផែ ជាដើម)។ ទ្រព្យសម្បត្តិសរុបរបស់រដ្ឋឬអាជីវកម្ម (ទ្រព្យសម្បត្តិសរុបទាំងអស់ដកបំណុលសរុបទាំងអស់របស់វា) នឹងត្រូវថយចុះ។

ការខកខានក្នុងការសងបំណុលធ្វើអោយពិបាកក្នុងការខ្ចីប្រាក់បន្ថែមទៀត នាពេលអនាគត ដែលជាឧបសគ្គដ៏ធំរារាំងកំណើនសេដ្ឋកិច្ច។ នៅពេលដែលបំណុលមិនអាចសងបាន ម្ចាស់បំណុល(ធនាគារ និងរដ្ឋាភិបាល) ត្រូវលុបវាចេញពីបញ្ជី ឬចរចាអោយកូនបំណុលសងក្នុងកម្រិតណាមួយនៃតម្លៃផ្លូវការរបស់វា។ ក្នុងឆ្នាំ ២០០១ នៅពេលដែលប្រទេសអាហ្សង់ទីនបានដួលរលំ ក្រោមបំណុលជាង ១០០ ប៊ីលានដុល្លារ ដែលត្រូវបានខ្ចីក្នុងប៉ុន្មានទសវត្សរ៍មុន ម្ចាស់បំណុលត្រូវបង្ខំចិត្តទទួលយកសំណង តិចជាងមួយភាគបីនៃប្រាក់របស់ពួកគេ នៅក្នុងកិច្ចព្រមព្រៀងចរចាបំណុលឡើងវិញ ឆ្នាំ ២០០៥។ ក្នុងឆ្នាំ ២០១០-២០១២ ទីផ្សារហិរញ្ញវត្ថុបានធ្លាក់ចុះម្តងហើយម្តងទៀត ជាការឆ្លើយតបទៅនឹងការភ័យខ្លាចប្រទេសក្រិកខកខានសងបំណុលធំៗ និងការឆ្លងរាលដាលដាយថាហេតុដល់ប្រទេសជិតខាងដែលមានសេដ្ឋកិច្ចធំជាង ដូចជាប្រទេសអេស្ប៉ាញ ព័រទុយហ្គាល់ អៀរឡង់ និងប្រហែលដល់អ៊ីតាលីដែរ។ ក្នុងឆ្នាំ ២០១២ ជំនួយសង្គ្រោះ(បំណុល)ជាច្រើនបានធ្វើអោយវិបត្តិនៅថេរ ប៉ុន្តែ រហូតដល់មាន**វិធានការណ៍ត្បិតត្បៀត** (austerity measures) (រដ្ឋាភិបាលកាត់បន្ថយចំណាយឬតម្លើងពន្ធដើម្បីសងបំណុល) ដែលបានជំរុញអោយតំបន់ចាយប្រាក់អឺរ៉ូទាំងមូលធ្លាក់ក្នុងវិបត្តិសេដ្ឋកិច្ច។

ក្នុងឆ្នាំ ២០១៥ ដោយធុញទ្រាន់នឹងវិធានការណ៍ត្បិតត្បៀតខ្លាំងពេក ជនជាតិក្រិកបានបោះឆ្នោតជ្រើសរើសរដ្ឋាភិបាលថ្មីមួយ ដែលបានសន្យាថាខ្លួននឹងចរចាឡើងវិញនូវបំណុលក្រិក និងដកវិធានការណ៍ត្បិតត្បៀត។ រដ្ឋាភិបាលក្រិកថ្មីមានការលំបាកក្នុងការបញ្ចុះបញ្ចូលម្ចាស់បំណុលថា ពួកគេនឹងមិនក្ស័យធនអត់លទ្ធភាពសងបំណុល ប្រសិនបើកំណែទម្រង់ដ៏តឹងរឹងទាំងនេះត្រូវបញ្ចប់។ នៅពាក់កណ្តាលឆ្នាំ ២០១៥ រដ្ឋាភិបាលក្រិកថ្មីបានទទួលយកប្រាក់កម្ចីបន្ថែមទៀតដើម្បីបញ្ចៀសការក្ស័យធន និងទទួលយកវិធានការណ៍ត្បិតត្បៀត ហើយរដ្ឋាភិបាលបានអំពាវនាវអោយមានការបោះឆ្នោតថ្មី។ នៅដើមឆ្នាំ ២០១៨ ប្រទេសក្រិកបានទទួលកំណើនសេដ្ឋកិច្ច ៤ ត្រីមាសជាប់គ្នា ប៉ុន្តែអត្រាអត់ការងារធ្វើនៅតែខ្ពស់ខ្លាំងដដែល (ជាង ២០ ភាគរយ)។

ហេតុអ្វីបានជារដ្ឋជំពាក់បំណុលគេ? មូលហេតុដ៏ចម្បងមួយគឺឱនភាពពាណិជ្ជកម្ម។ នៅក្នុងជញ្ជីងទូទាត់ ឱនភាពពាណិជ្ជកម្មត្រូវតែមានអ្វីមកជំនួស។ វាជារឿងធម្មតាទេក្នុងការខ្ចីប្រាក់ដើម្បីទូទាត់ឱនភាពពាណិជ្ជកម្ម។ មូលហេតុទីពីរគឺទម្រង់នៃប្រាក់ចំណូលនិងការចំណាយក្នុងចំណោមក្រុមគ្រួសារ និងក្រុមហ៊ុនធ្វើអាជីវកម្មទាំងឡាយ។ ប្រសិនបើក្រុមគ្រួសារនិងក្រុមហ៊ុនចំណាយច្រើនជាងចំណូល ពួកគេត្រូវតែខ្ចីប្រាក់

ដើម្បីបង់រំលៃយបត្រចំណាយជាក់ស្តែងរបស់ពួកគេ។ ប័ណ្ណឥណទានដែលពួកគេប្រើអាចបានមកពីធនាគារក្នុងស្រុក ប៉ុន្តែធនាគារទាំងនោះអាចទទួលបានប្រាក់ដែលពួកគេបានខ្ចីពីម្ចាស់បំណុលបរទេស។

ហេតុផលទីបីសម្រាប់បំណុលជាតិគឺការចំណាយរបស់រដ្ឋាភិបាលធៀបនឹងការយកពន្ធ។ នៅក្រោមគោលការណ៍**សេដ្ឋកិច្ចបែបយេនហ្សៀន** (Keynesian) (ដាក់ឈ្មោះតាមសេដ្ឋវិទូអង់គ្លេស John Maynard Keynes) ជួនកាល រដ្ឋាភិបាលចំណាយប្រាក់ច្រើនលើកម្មវិធីនានា ច្រើនជាងប្រាក់ដែលពួកគេទទួលបានពីចំណូលពន្ធ (*ការចំណាយឱនភាព* (deficit spending)) ដើម្បីជំរុញកំណើនសេដ្ឋកិច្ច។ ប្រទេសជាច្រើននៃក្រុមប្រទេសG៨ ជាពិសេសសហរដ្ឋអាមេរិកបានអនុម័តយុទ្ធសាស្ត្រនេះ ក្នុងកំឡុងវិបត្តិហិរញ្ញវត្ថុចុងក្រោយ។ ប្រសិនបើយុទ្ធសាស្ត្រនេះដំណើរការ កំណើនសេដ្ឋកិច្ចកាន់តែកើនឡើងនឹងបង្កើតចំណូលច្រើនពីការយកពន្ធដើម្បីបំពេញឱនភាព។ ប្រសិនបើវាមិនដូច្នោះទេ រដ្ឋមួយនឹងជួបប្រទះ នឹងសេដ្ឋកិច្ចក្រីក្រដោយធ្លាក់ក្នុងរណ្តៅបំណុលកាន់តែជ្រៅ។

ការសម្រេចចិត្តរបស់រដ្ឋាភិបាលអំពីការចំណាយនិងការយកពន្ធត្រូវបានគេហៅថា **គោលនយោបាយសារពើពន្ធ**(fiscal policy) ចំណែកការសម្រេចចិត្តអំពីការបោះពុម្ពនិងចរាចរសាច់ប្រាក់ត្រូវបានគេហៅថា **គោលនយោបាយរូបិយវត្ថុ**(monetary policy)។ គោលនយោបាយទាំងនេះគឺជាឧបករណ៍ដ៏សំខាន់ពីរដែលរដ្ឋាភិបាលអាចប្រើប្រាស់សម្រាប់គ្រប់គ្រងសេដ្ឋកិច្ច។ មិនមានកម្មវិធីហូចចុកដោយឥតគិតថ្លៃនោះទេ៖ ការយកពន្ធខ្ពស់រារាំងកំណើនសេដ្ឋកិច្ច ចំណែកការបោះពុម្ពប្រាក់លើសលប់ធ្វើអោយមានអតិផរណា រីឯការខ្ចីប្រាក់ដើម្បីគ្របដណ្តប់លើឱនភាព(ថវិកា)ត្រូវដាក់បញ្ចាំអចលនទ្រព្យរបស់រដ្ឋ។ ដូច្នេះហើយ ដោយសារតែភាពស្មុគស្មាញនៃគោលនយោបាយសេដ្ឋកិច្ចរបស់រដ្ឋាភិបាលនិងប្រតិបត្តិការសេដ្ឋកិច្ចអន្តរជាតិ ទ្រព្យសម្បត្តិនិងអំណាចរបស់រដ្ឋ សម្រេចសម្រួលទៅ ត្រូវពឹងផ្អែកលើសុខភាពជាមូលដ្ឋាននៃសេដ្ឋកិច្ចរបស់ខ្លួន (ជាងអ្វីៗទាំងអស់)៖ ការអប់រំនិងការបណ្តុះបណ្តាលកម្លាំងពលកម្ម ទំហំនិងភាពទំនើបនៃទំនិញមូលធន សីលធម៌និងស្មារតីប្រជាពលរដ្ឋ និងជំនាញរបស់អ្នកគ្រប់គ្រង។ នៅក្នុងអនាគតវែងឆ្ងាយ បំណុលអន្តរជាតិឆ្លុះបញ្ចាំងពីតថភាពជាមូលដ្ឋានទាំងអស់នេះ។

បម្រែបម្រួល សម្បត្តិហិរញ្ញវត្ថុក្នុងចំណោមប្រទេសមហាអំណាច ជារឿយៗត្រូវអមជាមួយការផ្លាស់ប្តូរទំនាក់ទំនងអំណាច។ ចូរពិចារណាថាតើរយៈពេលពីរទសវត្សរ៍កន្លងមក បានផ្លាស់ប្តូរស្ថានភាពឬជំហរហិរញ្ញវត្ថុរបស់សហរដ្ឋអាមេរិក រុស្ស៊ីនិងអឺរ៉ុបខាងកើត និងអាស៊ីយ៉ាងដូចម្តេច។ (ជំហររបស់អឺរ៉ុប រួមទាំងរូបិយប័ណ្ណអឺរ៉ុបថ្មីត្រូវបានពិភាក្សានៅក្នុងមេរៀនទី ១០។)

រូបថត បាតុករក្រិកប្រឆាំងគោលនយោបាយត្បិតត្បៀត

បំណុលឈឺចាប់

ការខកខានទូទាត់បំណុលអន្តរជាតិ ត្រូវហៅថា ភាពគ្មានលទ្ធភាពសង ឬក្សីយធន គឺជាសកម្មភាពដ៏ធ្ងន់ធ្ងរមួយ ដោយសារវាអាចកាត់ផ្តាច់លទ្ធភាពទទួលបានការវិនិយោគនិងប្រាក់កម្ចីសម្រាប់ប្រទេស នាពេលអនាគត។ យ៉ាងណាក៏ដោយ រដ្ឋមួយចំនួនបានប្រកាសក្សីយធន ជាជាងកាត់បន្ថយថវិកាដ៏ជូរចត់ ដែលអាចនឹងធ្វើអោយប៉ះពាល់ដល់ប្រជាជនខ្លួន។ ក្នុងឆ្នាំ ២០១១-២០១២ ប្រទេសក្រិកបានបញ្ចៀសភាពក្សីយធនយ៉ាងត្រជាបត្រដួស ខិតខំស្តារលទ្ធភាពសងបំណុលដ៏ច្រើនសន្ធឹកសន្ធាប់ ដោយទទួលយកថវិកាសង្គ្រោះរបស់សហភាពអឺរ៉ុប។ សព្វថ្ងៃនេះ ប្រទេសក្រិកនៅតែតស៊ូសងបំណុលគេនិងកាត់បន្ថយកម្មវិធីសង្គមជាច្រើន

ដើម្បីសន្សំប្រាក់សងបំណុលទាំងនោះ។ នៅទីនេះ ក្រុមបាតុករក្រីកប្រឈមមុខជាមួយប៉ូលីសជុំវិញវិធានការណ៍រឹតត្បិតថ្មីដែលបានអនុម័តដោយរដ្ឋាភិបាលក្រិកឆ្នាំ ២០១៨ ។


៩.៣.៣. ជំហរសហរដ្ឋអាមេរិក

សហរដ្ឋអាមេរិកជារដ្ឋដែលមានទ្រព្យសម្បត្តិមហាសាលនិងមានអំណាចលើសលប់។ អនុភាពខ្លាំងបំផុតគ្មានគូប្រៀបរបស់វាប្រហែលជានៅក្នុងវិស័យសន្តិសុខអន្តរជាតិ ក្នុងឋានៈជាប្រទេសមហាអំណាចតែមួយគត់ក្នុងពិភពលោក ប៉ុន្តែកម្លាំងសេដ្ឋកិច្ចរបស់វាក៏គួរអោយកត់សម្គាល់ផងដែរ។ វាមិនត្រឹមតែជាសេដ្ឋកិច្ចធំជាងគេលើពិភពលោកប៉ុណ្ណោះទេ ប៉ុន្តែក៏ជាសេដ្ឋកិច្ចដែលមានបច្ចេកវិទ្យាជឿនលឿនបំផុតនៅក្នុងវិស័យរីកចម្រើនដូចជាកុំព្យូទ័រ ទូរគមនាគមន៍ អាកាសចរណ៍និងអវកាស និងជីវបច្ចេកវិទ្យា។ ជំហររបស់សហរដ្ឋអាមេរិកក្នុងការស្រាវជ្រាវវិទ្យាសាស្ត្រនិងការអប់រំឧត្តមសិក្សាស្ថិតក្នុងលំដាប់កំពូលគ្មានគូប្រៀបនៅលើពិភពលោក។

រូបភាព ៩.១ ទីតាំងហិរញ្ញវត្ថុរបស់សហរដ្ឋអាមេរិក ឆ្នាំ ១៩៦០-២០១៧

អស់រយៈពេលច្រើនទស្សវត្សរ៍មកហើយ សហរដ្ឋអាមេរិកបាននាំចូលច្រើនជាងនាំចេញ (សមតុល្យគណនីចរន្ត ឬឱនភាពពាណិជ្ជកម្ម) ហើយរដ្ឋាភិបាលរបស់ខ្លួនបានចំណាយប្រាក់ច្រើនជាងប្រាក់ចំណូល (ឱនភាពថវិកា)។ ឱនភាពថវិកានាំឱ្យបំណុលជាតិកើនឡើងកាន់តែធំ។

ប្រភព៖ ការិយាល័យថវិកាសភា។



ទោះយ៉ាងណាក៏ដោយ ជំហររបស់សហរដ្ឋអាមេរិកនៅក្នុងសេដ្ឋកិច្ចអន្តរជាតិបានប្រែប្រួលចុះឡើងជាច្រើនទសវត្សរ៍មកហើយ។ អនុត្តរភាពរបស់សហរដ្ឋអាមេរិកបានឈានដល់កម្រិតកំពូលបន្ទាប់ពីសង្គ្រាមលោកលើកទីពីរ បន្ទាប់មកវាបានសាបរលាបបន្តិចម្តងៗ នៅពេលដែលដៃគូប្រកួតប្រជែងដណ្តើមដទៃទៀតដណ្តើមបានមូលដ្ឋានឈរជើងកាន់តែទូលាយ (ជាពិសេសនៅអឺរ៉ុបខាងលិចនិងអាស៊ី)។ នៅដើមទសវត្សរ៍ឆ្នាំ ១៩៥០ សេដ្ឋកិច្ចសហរដ្ឋអាមេរិក (ផលិតផលក្នុងស្រុកសរុប [ផ.ស.ស.]) មានទំហំប្រហែលពីរដងនៃទំហំសេដ្ឋកិច្ចរដ្ឋឧស្សាហកម្មជឿនលឿនចំនួនប្រាំមួយបន្ទាប់*រួមបញ្ចូលគ្នា*។ នៅទសវត្សរ៍ឆ្នាំ ១៩៨០ ចំណែក

របស់វាធៀបនឹងផ.ស.ស.ពិភពលោកបានធ្លាក់ចុះស្ទើរតែពាក់កណ្តាល។ នៅឆ្នាំ ១៩៥០ សហរដ្ឋអាមេរិក បានកាន់កាប់ ៥០ ភាគរយនៃទុនបម្រុងហិរញ្ញវត្ថុរបស់ពិភពលោក។ នៅឆ្នាំ ១៩៨០ វាកាន់កាប់មិនដល់ ១០ ភាគរយផង។ បន្ទាប់ពីអនុត្តរភាពដល់កំពូលរបស់សហរដ្ឋអាមេរិកក្រោយឆ្នាំ១៩៤៥ ការធ្លាក់ចុះរយៈពេលវែងបែបនេះ គឺជាដំណើរធម្មជាតិ ហើយប្រហែលជាមិនអាចជៀសបានឡើយ។ បម្រែបម្រួលដំហរហិរញ្ញវត្ថុរបស់សហរដ្ឋអាមេរិក ចាប់តាំងពីទសវត្សរ៍ឆ្នាំ ១៩៨០ ត្រូវបានបង្ហាញនៅក្នុងក្រាហ្វិក ៩.១។ នៅដើមទសវត្សរ៍ឆ្នាំ ១៩៨០ ឱនភាពពាណិជ្ជកម្ម (ការនាំចេញដកការនាំចូល) បានកើនឡើងកាន់តែធំ ពីកម្រិតក្បែរសូន្យ ដល់ ២០០ ប៊ីលានដុល្លារក្នុងរយៈពេលត្រឹមតែប៉ុន្មានឆ្នាំប៉ុណ្ណោះ។ ឱនភាពពាណិជ្ជកម្មបានធ្លាក់ចុះមកវិញ ប៉ុន្តែ បន្ទាប់មកបានកើនឡើងដល់កម្រិតជាង ៧០០ ប៊ីលានដុល្លារក្នុងមួយឆ្នាំ នៅឆ្នាំ ២០០៧។ បន្ទាប់ពីបានធ្លាក់ចុះម្តងទៀតក្នុងអំឡុងវិបត្តិសេដ្ឋកិច្ចឆ្នាំ ២០០៨-២០០៩ ឱនភាពពាណិជ្ជកម្មបានចាប់ផ្តើមកើនឡើងជាថ្មីក្នុងឆ្នាំ ២០១០ និងបានរក្សាក្នុងកម្រិតជាង ៥០០ ប៊ីលានដុល្លារក្នុងឆ្នាំ ២០១៧។ ទន្ទឹមនឹងនោះ ឱនភាពថវិកាបានកើនឡើងដល់ ៣០០ ប៊ីលានដុល្លារក្នុងមួយឆ្នាំ នៅដើមទសវត្សរ៍ឆ្នាំ ១៩៨០ ហើយបន្ទាប់មកបានបិទបំពេញគម្លាតនៅទសវត្សរ៍ឆ្នាំ ១៩៩០ ហើយបានប្រែក្លាយជាអតិរេក(ថវិកា)យ៉ាងច្រើន ក្នុងមួយរយៈពេលខ្លី តែត្រូវកើនឡើងខ្លាំងវិញ រហូតដល់ ១ ទ្រីលានដុល្លារក្នុងមួយឆ្នាំ ក្នុងចន្លោះឆ្នាំ ២០០៨-២០១២ ដែលជាលទ្ធផលនៃការចំណាយលើសង្គ្រាម ការកាត់បន្ថយពន្ធ និងកិច្ចខិតខំប្រឹងប្រែងដើម្បីជំរុញកំណើនសេដ្ឋកិច្ចតាមបែបយេនហ្សៀន អំឡុងពេលមានវិបត្តិសេដ្ឋកិច្ច។ និន្នាការទាំងនេះបានបង្កអោយមានការព្រួយបារម្ភអំពីភាពជាអ្នកដឹកនាំរបស់សហរដ្ឋអាមេរិកក្នុងសេដ្ឋកិច្ចអន្តរជាតិ។

ពេលចាប់ផ្តើមចូលសតវត្សរ៍ទី ២១ សេដ្ឋកិច្ចរបស់សហរដ្ឋអាមេរិកបានឆ្លងកាត់វិថីរលាក់រដិបរដុបជាច្រើន បន្ទាប់ពីរយៈពេលមួយទសវត្សរ៍នៃភាពរុងរឿង ក្នុងទសវត្សរ៍ឆ្នាំ ១៩៩០។ ការធ្លាក់ចុះការវិនិយោគលើវិស័យអ៊ីនធឺណែត(ដូចបន្ទុះបំបែកពពុះ) ត្រូវបានបន្តដោយការធ្លាក់ចុះសេដ្ឋកិច្ចពិភពលោក នៅក្នុងឆ្នាំ ២០០១ ហើយបន្ទាប់មកក៏មានការរំខានផ្នែកសេដ្ឋកិច្ចដែលកើតឡើងក្រោយការវាយប្រហារភេរវកម្មខែកញ្ញាឆ្នាំ ២០០១។ ការកាត់បន្ថយពន្ធនិងការចំណាយលើសង្គ្រាមបានជម្រុញកំណើន ក្នុងឆ្នាំ ២០០២-២០០៦ ប៉ុន្តែត្រូវប្រឈមនឹងកំណើនបំណុលកើនឡើងដែរ។ ក្នុងឆ្នាំ ២០០៨ វិបត្តិសេដ្ឋកិច្ចមួយផ្សេងទៀតបានមកដល់ ដែលត្រូវគេហៅថា មហាវិបត្តិសេដ្ឋកិច្ច (Great Recession) ដែលជាការធ្លាក់ចុះសេដ្ឋកិច្ចដ៏អាក្រក់បំផុត ចាប់តាំងពីវិបត្តិសេដ្ឋកិច្ចដ៏ធំនៃទសវត្សរ៍ឆ្នាំ ១៩៣០ (ទោះបីជាមិនអាក្រក់ដល់កម្រិតនោះក៏ដោយ)។ កំណើនបានចាប់ផ្តើមរើបឡើងវិញ ក្នុងឆ្នាំ ២០០៩ ប៉ុន្តែនៅតែមានល្បឿនយឺតយ៉ាវ រួមជាមួយនឹងអត្រាគ្មានការងារធ្វើខ្ពស់ពុំរ៉ៃ បំណុលកាន់កើនឡើងឥតឈប់ឈរ និងការសម្រេចចិត្តរបស់រដ្ឋាភិបាលមិនប្រាកដប្រជា។ នៅត្រឹមឆ្នាំ ២០១៣ ទីផ្សារភាគហ៊ុនបានងើបឡើងវិញ យ៉ាងពេញលេញ ពីការជាប់គាំងឆ្នាំ ២០០៨ ប៉ុន្តែអត្រាគ្មានការងារធ្វើនៅអូសបន្លាយ និងមិនបានត្រលប់ទៅកម្រិតមុនពេលមានវិបត្តិ រហូតដល់ឆ្នាំ ២០១៧។

ការរួមផ្សំនៃកត្តាសេដ្ឋកិច្ចច្រើន (អត្រាគ្មានការងារធ្វើខ្ពស់ ឱនភាពពាណិជ្ជកម្មខ្ពស់ និងបំណុលជាតិកើនឡើង) នាំឱ្យមានការខកចិត្តជាថ្មីម្តងទៀតជាមួយនឹងទិដ្ឋភាពជាច្រើននៃគោលនយោបាយការបរទេសរបស់សហរដ្ឋអាមេរិក ក្នុងឆ្នាំ ២០១៦ ដែលប្រាកដណាស់អាចរួមចំណែកដល់ការបោះឆ្នោតជ្រើសរើសលោកដូណាល់ ត្រាំ ជាប្រធានាធិបតី។ ជាអ្នករិះគន់យ៉ាងចាស់ដៃចំពោះកិច្ចព្រមព្រៀងពាណិជ្ជកម្ម បេក្ខជនត្រាំបានស្តីបន្ទោសដោយបើកចំហថា ភាពអត់ការងារធ្វើនិងឱនភាពពាណិជ្ជកម្ម បន្តកើតឡើងដោយសារតែកិច្ច

ព្រមព្រៀងពាណិជ្ជកម្មសេរី ដែលបានចុះហត្ថលេខាដោយប្រធានាធិបតីអាមេរិកមុនៗ។ នៅពេលជាប់ឆ្នោត សកម្មភាពរបស់ប្រធានាធិបតីត្រាំបានបន្តប្រធានបទនេះ៖ ការដកខ្លួនសហរដ្ឋអាមេរិកចេញពីកិច្ចព្រមព្រៀងពាណិជ្ជកម្មអាស៊ីដ៏ធំមួយ ការដាក់ពន្ធលើទំនិញដូចជា អាលុយមីញ៉ូម និងដែកថែប និងទាមទារឱ្យរដ្ឋផ្សេងទៀតត្រូវចរចាឡើងវិញនូវកិច្ចព្រមព្រៀងពាណិជ្ជកម្មដែលមានស្រាប់។ សកម្មភាពទាំងនេះត្រូវបានក្លាយជាការជជែកដ៏ចម្រូងចម្រាសខ្លាំង សូម្បីតែអ្នកនៅក្នុងគណបក្សរបស់លោកត្រាំផ្ទាល់ដែលព្រួយបារម្ភថាពន្ធដារនឹងនាំទៅរកភាពអត់ការងារធ្វើកាន់តែអាក្រក់ និងការជាប់គាំងសេដ្ឋកិច្ច។

លើសពីនេះ កំណើនបំណុលពីការចំណាយឱនភាពជាច្រើនទសវត្សរ៍នៅតែមាន។ **បំណុលជាតិ** (national debt) របស់រដ្ឋាភិបាលសហរដ្ឋអាមេរិកបានកើនឡើង ពីប្រហែល ១ ទ្រីលានដុល្លារ ក្នុងឆ្នាំ ១៩៨០ ដល់ ៣ ទ្រីលានដុល្លារ ក្នុងឆ្នាំ ១៩៩០, ៥ ទ្រីលានដុល្លារ ក្នុងឆ្នាំ ២០០០ និង ២០ ទ្រីលានដុល្លារ ក្នុងឆ្នាំ ២០១៨។ ការទូទាត់បង់*ការប្រាក់* ស្មើនឹងអ្វីដែលអាចជាអត្រាកំណើនសេដ្ឋកិច្ចដែលមានសុខភាពល្អ។ សហរដ្ឋអាមេរិកធ្លាប់ជារដ្ឋផ្តល់ប្រាក់កម្ចីឈានមុខគេលើពិភពលោក ប៉ុន្តែ បច្ចុប្បន្ននេះ វាគឺជារដ្ឋកូនបំណុលឈានមុខគេរបស់ពិភពលោក។

និន្នាការហិរញ្ញវត្ថុរបស់សហរដ្ឋអាមេរិកទាំងនេះផ្តល់ផលប៉ះពាល់យ៉ាងជ្រាលជ្រៅ ចំពោះសេដ្ឋកិច្ចនយោបាយពិភពលោកទាំងមូល។ វាបានធ្វើអោយខូចខាត មុនដំបូង(ក្នុងទសវត្សរ៍ឆ្នាំ ១៩៨០) បន្ទាប់មកបានជួយស្តារឡើងវិញ(ក្នុងទសវត្សរ៍ឆ្នាំ ១៩៩០) ហើយបន្ទាប់មកបានធ្វើអោយខូចខាតម្តងទៀត (ចាប់តាំងពីឆ្នាំ ២០០០) នូវតួនាទីឈានមុខគេរបស់សហរដ្ឋអាមេរិក ក្នុងការធ្វើអោយមានស្ថិរភាពពាណិជ្ជកម្មអន្តរជាតិនិងទំនាក់ទំនងរូបិយវត្ថុ ក្នុងការធានាផលប្រយោជន៍រួម និងក្នុងការផ្តល់ទុនសម្រាប់ ការអភិវឌ្ឍសេដ្ឋកិច្ចនៃតំបន់ផ្សេងៗនៃពិភពលោក។ នៅក្នុងសេដ្ឋកិច្ចពិភពលោក ដែលមានលក្ខណៈវិមជ្ឈការនិងឯកជនកាន់តែខ្លាំង រួមជាមួយនឹងតួនាទីមិនច្បាស់លាស់របស់សហរដ្ឋអាមេរិក បញ្ហាផលប្រយោជន៍រួមនឹងកាន់តែពិបាកដោះស្រាយ ហើយពាណិជ្ជកម្មសេរីកាន់តែពិបាកនឹងសម្រេចបាន។

៩.៣.៤. ជំហររុស្ស៊ីនិងអឺរ៉ុបខាងកើត

សហរដ្ឋអាមេរិកបានផ្តល់មូលធនមានដៃនកំណត់ (ការវិនិយោគ ប្រាក់កម្ចី និងជំនួយ) ដើម្បីជួយធ្វើអោយរុស្ស៊ីនិងតំបន់អឺរ៉ុបខាងកើត អាចឈរជើងដោយខ្លួនឯងឡើងវិញ បន្ទាប់ពីសម័យសង្គ្រាមត្រជាក់។ សហរដ្ឋអាមេរិកមិនបានអនុវត្តឡើងវិញនៅក្នុងប្រទេសរុស្ស៊ីនិងអឺរ៉ុបខាងកើត នូវកម្មវិធីជំនួយដែលបានជំរុញកំណើនថ្មី នៅអឺរ៉ុបខាងលិចនិងប្រទេសជប៉ុនបន្ទាប់ពីសង្គ្រាមលោកលើកទីពីរឡើយ។

ផ្ទុយទៅវិញ រដ្ឋនានាក្នុងតំបន់នេះប្រឈមមុខនឹងបញ្ហាប្រឈមដ៏គួរឱ្យព្រួយបារម្ភ នៅពេលដែលពួកគេបានប្តូរពីសេដ្ឋកិច្ចផែនការកណ្តាលទៅជាសេដ្ឋកិច្ចមូលធននិយម ហើយបានចូលរួមជាមួយសេដ្ឋកិច្ចមូលធននិយមពិភពលោក។ បញ្ហាប្រឈមទាំងនេះរួមមានការធ្វើសមាហរណកម្មទៅក្នុងប្រព័ន្ធពាណិជ្ជកម្មពិភពលោក (សមាជិកភាពក្នុង អង្គការWTO និងកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគីជាដើម) និងការទាក់ទាញការវិនិយោគពីបរទេស។ ក្នុងចំណោមកិច្ចការដ៏លំបាកបំផុត គឺការប៉ុនប៉ងរបស់រដ្ឋនៅក្នុងតំបន់នេះ ដើម្បីចូលរួមជាមួយប្រព័ន្ធរូបិយវត្ថុអន្តរជាតិ។ ការដោះស្រាយបញ្ហាទាំងនេះដោយប្រសិទ្ធិភាពពិតជាមានសារៈសំខាន់ខ្លាំងណាស់ ដោយសារការមានរូបិយប័ណ្ណដែលមានស្ថិរភាពនិងអាចប្តូរជាមួយប្រាក់ដទៃបាន គឺជាកត្តាសំខាន់ក្នុងការទាក់ទាញអាជីវកម្មបរទេស និងពង្រីកពាណិជ្ជកម្មអន្តរជាតិ។

រដ្ឋភាគច្រើននៃអតីតប្លុកសូវៀតបានក្លាយជាសមាជិកមូលនិធិIMF ហើយត្រូវបានគេកំណត់កូតាអោយ។ ប៉ុន្តែ មូលនិធិIMFនិងធនាគារពិភពលោកនឹងមិនផ្តល់ប្រាក់កម្ចីដោយសេរី ដល់រដ្ឋទាំងនេះទេ រហូតទាល់តែរដ្ឋាភិបាលរបស់ពួកគេចាត់វិធានការណ៍ខ្លាំងក្លា ដើម្បីទប់ស្កាត់អតិផរណា ធ្វើអោយថវិការដ្ឋាភិបាលមានតុល្យភាព និងធានាស្ថិរភាពសេដ្ឋកិច្ច។ ស្ថិរភាពបែបនេះអាចនឹងសម្រេចបានដោយងាយស្រួល ជាមួយនឹងប្រាក់កម្ចីពីបរទេស ទោះជាយ៉ាងណាក៏ដោយ វាអាចក្លាយជាចំណោទមេមាន់និងពងមាន់ មួយណាកើតមុន។

សេដ្ឋកិច្ចរដ្ឋទាំងអស់ ក្នុងតំបន់នេះ បានជួបប្រទះនឹងការធ្លាក់ចុះយ៉ាងខ្លាំង (ផ.ស.ស. ធ្លាក់ចុះ) ក្នុងរយៈពេលប៉ុន្មានឆ្នាំបន្ទាប់ពីការបញ្ចប់សង្គ្រាមត្រជាក់។ សេដ្ឋកិច្ចនៃអតីតសហភាពសូវៀតធ្លាក់ចុះប្រហែលពាក់កណ្តាលក្នុងរយៈពេលប្រាំពីរឆ្នាំ មុនពេលងើបឡើងវិញម្តងទៀត (សូមមើលតារាង ៩.២)។ ជាទូទៅបណ្តាប្រទេសនៅអឺរ៉ុបខាងកើត បានប្រែក្លាយសេដ្ឋកិច្ចរបស់ពួកគេ អោយកាន់តែមានប្រសិទ្ធភាពជាងអតីតសាធារណរដ្ឋសូវៀត។ ក្នុងចំណោមអតីតសាធារណរដ្ឋសូវៀតទាំងឡាយ ប្រទេសរុស្សីដំណើរការបានល្អជាងប្រទេសផ្សេងទៀត ម្យ៉ាងដោយសារវាបានទទួលមរតកហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច និងធម្មជាតិយ៉ាងច្រើនពីសហភាពសូវៀត ជាពិសេសប្រេង ហើយមានទំហំធំល្មមនឹងទទួលបានការចាប់អារម្មណ៍ពីលោកខាងលិច។ ប៉ុន្តែ ការតស៊ូដណ្តើមអំណាចផ្ទៃក្នុងបានបង្កអស្ថិរភាពនយោបាយនៅក្នុងប្រទេសរុស្សី ដែលបង្អាក់លំហូរការវិនិយោគបរទេស។ អតិផរណាឈានដល់ ១៥០០ ភាគរយ ក្នុងឆ្នាំ ១៩៩២។

តារាង ៩.២ ការដួលរលំសេដ្ឋកិច្ចនៅរុស្សី និងអឺរ៉ុបខាងកើត

	បម្រែបម្រួលផលិតផលក្នុងស្រុកសរុប (១០ ឆ្នាំ)
ប្រទេស	**ឆ្នាំ ១៩៩០-១៩៩៩**
រុស្សី/ភោគទ្រព្យរួមCIS	- ៥០%
អតីតយូហ្គោស្លាវី	- ៣៥%
អេស្តូនី ឡាតវី និងលីធូអានី	- ២៩%
ប៊ុលហ្គារី	- ២៩%
រ៉ូម៉ានី	- ២៨%
អាល់បានី	- ១២%
សាធារណរដ្ឋឆេក	- ១១%
ស្លូវ៉ាគី	- ១%
ហុងគ្រី	- ១%
ប៉ូឡូញ	- ២១%

ប្រភព៖ ផ្អែកលើអង្គការសហប្រជាជាតិ ការស្ទង់មតិសេដ្ឋកិច្ច និងសង្គមពិភពលោក ឆ្នាំ ១៩៩៩។ អង្គការសហប្រជាជាតិ ឆ្នាំ ១៩៩៩ ទំព័រ ២៦៣។

ឧក្រិដ្ឋកម្មគ្រោងទុកជាមុនបានលេចចេញជាបញ្ហាធំនៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០។ ក្រុមមនុស្សដែលគេហៅថា អភិជន (plutocrats) បានរឹបអូសយកក្រុមហ៊ុនដែលរដ្ឋធ្លាប់កាន់កាប់ ហើយបង្ហូរទ្រព្យសម្បត្តិចូល

គណនីធនាគារផ្ទាល់ខ្លួន។ ភាពរឹកវរក្នុងសម័យអន្តរកាលក៏បានបើកឱកាសមាសពេជ្រសម្រាប់អំពើពុករលួយ ក្នុងចំណោមមន្ត្រីរដ្ឋាភិបាល។ នៅឆ្នាំ ២០០៤ ប្រធានាធិបតី វ្ល៉ាឌីមៀ ពូទីន បានបិទក្រុមហ៊ុនប្រេងធំបំផុត របស់រុស្ស៊ី (Yukos) ដោយសារតែការមិនបង់ប្រាក់ពន្ធ ចំនួន ១០ ប៊ីលានដុល្លារ ហើយទ្រព្យសកម្មរបស់ ក្រុមហ៊ុនត្រូវបានលក់ឡាយឡុងអោយអាជីវកម្មរបស់រដ្ឋ។ (ម្ចាស់ក្រុមហ៊ុន Yukos គឺជាគូប្រជែងពូទីន។) រដ្ឋបានពង្រឹងអំណាចគ្រប់គ្រងរបស់ខ្លួនលើក្រុមហ៊ុនធំៗ និងប្រព័ន្ធផ្សព្វផ្សាយម្តងទៀត ដោយប្រើអំណាច របស់ខ្លួនដើម្បីដាក់ពួកអភិជនអោយស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន ឬរុញច្រានពួកគេអោយនៅអៀប ជញ្ជាំង។

បន្ទាប់ពីវិបត្តិហិរញ្ញវត្ថុក្នុងឆ្នាំ ១៩៩៨ ប្រទេសរុស្ស៊ីបានចុះបញ្ជីកំណើនសេដ្ឋកិច្ចដ៏រឹងមាំ ក្នុងរយៈ ពេលមួយទសវត្សរ៍ និងកាត់បន្ថយអតិផរណាលឿន មកកម្រិតតិចជាង ១០ ភាគរយ ក្នុងមួយឆ្នាំ។ វិបត្តិ សេដ្ឋកិច្ចសកលឆ្នាំ ២០០៨-២០០៩ ប៉ះពាល់សេដ្ឋកិច្ចរុស្ស៊ីយ៉ាងខ្លាំង នៅពេលតម្លៃប្រេងធ្លាក់ចុះ។ ខណៈ ពេលដែលជនជាតិរុស្ស៊ីមានសង្ឃឹមថា ការវិលត្រឡប់របស់លោក វ្ល៉ាឌីមៀ ពូទីន មកកាន់តំណែងជា ប្រធានាធិបតីក្នុងឆ្នាំ ២០១២ នឹងនាំមកនូវស្ថិរភាពសេដ្ឋកិច្ចកាន់តែខ្លាំង ការធ្លាក់ចុះតម្លៃប្រេងជាបន្តបន្ទាប់ និងការធ្លាក់ចុះការវិនិយោគបានទប់អត្រាកំណើនត្រឹមកម្រិតតិចតួចបំផុត។ ជម្លោះរុស្ស៊ីជាមួយអ៊ុយក្រែនក្នុង ឆ្នាំ ២០១៤ បាននាំមកនូវអស្ថិរភាពសេដ្ឋកិច្ចកាន់តែខ្លាំង ហើយកំណើនរបស់រុស្ស៊ីបានធ្លាក់ចុះមក នៅត្រឹម ប្រហែល ១ភាគរយ។ ការយល់ឃើញថាមានការគាបសង្កត់នយោបាយនៅរុស្ស៊ីបានធ្វើអោយប៉ះពាល់ដល់ ការវិនិយោគកាន់តែខ្លាំង។ អនាគតសេដ្ឋកិច្ចរបស់រុស្ស៊ីទំនងជាត្រូវកំណត់ដោយតម្លៃប្រេង និងរបៀបដែល អ្នកវិនិយោគយល់ឃើញអំពីស្ថិរភាពនយោបាយរបស់រុស្ស៊ី។

៩.៣.៥. ដំហរសេដ្ឋកិច្ចអាស៊ី

ក្រោយរយៈពេលច្រើនទសវត្សរ៍ពោរពេញដោយការរីកចម្រើនដ៏រឹងមាំ ចាប់តាំងពីការបំផ្លិចបំផ្លាញនៃសង្គ្រាម លោកលើកទី ២ ប្រទេសជប៉ុននៅទសវត្សរ៍ឆ្នាំ ១៩៨០ ហាក់ដូចជាកំពុងលេចឡើងជាគូប្រជែងជាមួយ សហរដ្ឋអាមេរិក ក្នុងនាមជាប្រទេសមហាអំណាចឧស្សាហកម្មឈានមុខគេក្នុងពិភពលោក។ ក្រុមហ៊ុនផលិត រថយន្តជប៉ុនចាប់ផ្តើមមានប្រៀបលើគូប្រជែងនៅសហរដ្ឋអាមេរិក នៅពេលដែលរថយន្តតូចៗបានក្លាយជា ផលិតផលពេញនិយម បន្ទាប់ពីការឡើងតម្លៃប្រេងនៅក្នុងទសវត្សរ៍ឆ្នាំ ១៩៧០។ នៅក្នុងវិស័យអេឡិចត្រូនិក និងវិស័យផ្សេងទៀត ផលិតផលរបស់ជប៉ុនបានចាប់ផ្តើមគ្របដណ្តប់លើទីផ្សារពិភពលោក ហើយមូលធន របស់ជប៉ុនបានក្លាយជាកម្លាំងសេដ្ឋកិច្ចដ៏សំខាន់ នៅក្នុងសេដ្ឋកិច្ចដែលកំពុងអភិវឌ្ឍនៅក្នុងប្រទេសជិតខាង (ដូចជាប្រទេសចិន និងថៃជាដើម)និងរហូតដល់ក្នុងសហរដ្ឋអាមេរិក ដែលជាទឹកដីដែលម្ចាស់បំណុល ជនជាតិជប៉ុនបានផ្តល់ហិរញ្ញប្បទានយ៉ាងច្រើន ក្នុងចំណោមបំណុលជាតិរបស់សហរដ្ឋអាមេរិក ដែលកំពុង កើនឡើង។

ទោះជាយ៉ាងណាក៏ដោយជោគជ័យទាំងនេះក៏បានបង្កប់នូវបញ្ហាធ្ងន់ធ្ងរផងដែរ។ កំណើនសេដ្ឋកិច្ចនៃ ទសវត្សរ៍ឆ្នាំ ១៩៨០ បានជំរុញអោយតម្លៃភាគហ៊ុននិងអចលនទ្រព្យឡើងដល់កម្រិតមិនប្រាកដប្រជា ដោយ ផ្អែកលើតម្លៃរំពឹងទុកជាជាងតម្លៃជាក់ស្តែង។ នៅពេលដែលទីផ្សារទាំងនេះបានដួលរលំ នៅចុងទសវត្សរ៍ឆ្នាំ ១៩៨០ ធនាគារជាច្រើនត្រូវផ្ទុងខ្លួនជាមួយនឹងប្រាក់កម្ចីមិនល្អ ដែលមិនត្រូវបានគេសងប្រាក់វិញឡើយ ដោយមានត្រឹមតែភាគហ៊ុននិងអចលនទ្រព្យដែលកំពុងធ្លាក់ថ្លៃជាគ្រឿងបញ្ចាំ។ ការខាតបង់ទាំងនេះត្រូវបាន

បិទបាំង ហើយបញ្ហាជាមូលដ្ឋាន (ដូចជាបទប្បញ្ញត្តិធនាគារដ៏ធូរលុង របបនយោបាយបក្ខពួកនិយម និងអំពើពុករលួយ) បានបន្តកើតមាន រហូតដល់ទសវត្សរ៍ឆ្នាំ ១៩៩០។

ទោះបីជាមានឧទាហរណ៍នៃប្រព័ន្ធហិរញ្ញវត្ថុរបស់ប្រទេសជប៉ុនរួចហើយក៏ដោយ កំហុសទាំងនេះបានកើតឡើងម្តងទៀត ស្ទើរតែដូចគ្នាបេះបិទ នៅទសវត្សរ៍ឆ្នាំ ១៩៩០ នៅក្នុងប្រទេសដទៃទៀតនៅអាស៊ីបូព៌ានិងអាស៊ីអាគ្នេយ៍។ ទីផ្សារអចលនទ្រព្យនិងភាគហ៊ុនបានឡើងថ្លៃជ្រុលដោយសារកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័សនាំអោយមានការឆក់ឱកាសកេងយកចំណេញ និងការរំពឹងទុកជាមុនថានឹងកើនឡើងបន្តទៀត។ ធនាគារជាច្រើនបានផ្តល់ប្រាក់កម្ចីហានិភ័យខ្ពស់ យ៉ាងច្រើនសន្ធឹកសន្ធាប់ ដោយផ្អែកលើទ្រព្យសម្បត្តិដែលត្រូវគេដាក់តម្លៃលើសលុប ហើយក៏គ្មាននរណាចាប់អោយទទួលខុសត្រូវ ដោយសារតែអំពើពុករលួយ និងរបបបក្ខពួកនិយមនយោបាយ។ ក្នុងឆ្នាំ ១៩៩៧ សេដ្ឋកិច្ចប្រទេសទាំងនេះបានទទួលរងនូវវិបត្តិហិរញ្ញវត្ថុយ៉ាងធ្ងន់ធ្ងរ ដែលបានរីករាលដាលឆ្លងព្រំដែនអន្តរជាតិ និងបានបញ្ជូនរលកប្រកាសអាសន្នដ៏រន្ធត់ជុំវិញពិភពលោក ដែលបានកើតឡើង រយៈពេល ២ ឆ្នាំ។ *វិបត្តិហិរញ្ញវត្ថុអាស៊ី* (asian financial crisis) ឆ្នាំ ១៩៩៧ បានចាប់ផ្តើមនៅពេលដែលក្រុមអ្នកធក់ឱកាសកេងចំណេញពីការជួញដូររូបិយប័ណ្ណ បានចាប់ផ្តើមលក់រូបិយប័ណ្ណរបស់ប្រទេសអាស៊ីអាគ្នេយ៍។ ប្រទេសថៃ ហ្វីលីពីន ម៉ាឡេស៊ី និងឥណ្ឌូណេស៊ី ត្រូវបានបង្ខំបណ្តោយអោយរូបិយប័ណ្ណពួកគេត្រូវទម្លាក់តម្លៃ។ បញ្ហារូបិយប័ណ្ណនៃបណ្តាប្រទេសអាស៊ីនាំអោយទីផ្សារភាគហ៊ុនដាំក្បាលចុះ ក្នុងប្រទេសមួយចំនួនក្នុងចំណោមនោះ។ អ្វីដែលគេហៅថា *ទីផ្សារកំពុងលេចឡើងថ្មី* ផ្សេងទៀតនៅជុំវិញពិភពលោក ជាពិសេសប្រទេសប្រេស៊ីល ត្រូវរងទុក្ខខណៈពេលដែលវិនិយោគិនបានព្រួយបារម្ភថា បញ្ហានៅអាស៊ីអាចនឹងលេចឡើងក្នុងតំបន់ផ្សេងទៀត។

រូបថត កម្មកររជប៉ុនត្រួតពិនិត្យគុណភាពតុក្កតា

ពិនិត្យរាងកាយ

សេដ្ឋកិច្ចអាស៊ីបូព៌ាបានរីកចម្រើនយ៉ាងរឹងមាំក្នុងទសវត្សរ៍ក្រោយវិបត្តិហិរញ្ញវត្ថុឆ្នាំ ១៩៩៧ ប៉ុន្តែមូលហេតុនៃអស្ថិរភាពជាច្រើននៅតែបន្តមាន។ ការត្រួតពិនិត្យគុណភាពមិនសូវល្អ នៅក្នុងវិស័យនាំចេញរបស់ប្រទេសចិន ដែលលូតលាស់យ៉ាងឆាប់រហ័ស បានបញ្ជូនអាហារ ឱសថ និងឧបករណ៍ក្មេងលេង អន់ៗទៅកាន់ទីផ្សារលោកខាងលិច។ អាជ្ញាធរចិនបានបើកបន្ទប់ពិសោធន៍តេស្តគុណភាពក្មេងលេងខាងលើនេះជាការឆ្លើយតបឆ្នាំ ២០០៧។

ប្រទេសហ្វីលីពីនបានដោះស្រាយបញ្ហានេះ តាមរបៀបដែលទីភ្នាក់ងារអន្តរជាតិ និងអ្នកវិនិយោគបរទេសពេញចិត្ត។ បន្ទាប់ពីបានបាត់បង់ទឹកប្រាក់ ១ ប៊ីលានដុល្លារក្នុងការការពារតម្លៃរូបិយប័ណ្ណរបស់ខ្លួនមិនបានជោគជ័យ ប្រទេសហ្វីលីពីនបានអនុញ្ញាតអោយរូបិយប័ណ្ណរបស់ខ្លួនអណ្តែត(តាមលក្ខណ្ឌទីផ្សារ) ហើយបន្ទាប់មកបានស្នើសុំប្រាក់កម្ចីស្ថិរភាពចំនួន ១ ប៊ីលានដុល្លារ ពីមូលនិធិIMF ហើយដែលត្រូវបានអនុម័តយល់ព្រម យ៉ាងឆាប់រហ័ស ត្រឹមតែក្នុងរយៈពេលមួយសប្តាហ៍ប៉ុណ្ណោះ។ ជាថ្នូរនឹងប្រាក់កម្ចីរបស់មូលនិធិIMF រដ្ឋាភិបាលហ្វីលីពីនបានយល់ព្រមរក្សាអត្រាការប្រាក់ខ្ពស់ និងឱនភាពថវិកាទាប (ដើម្បីកាត់បន្ថយអតិផរណា) ដើម្បីអនុម័តច្បាប់កំណែទម្រង់ពន្ធ និងដើម្បីតបនឹងការគ្រប់គ្រងធនាគារនានាដែលបានផ្តល់ប្រាក់កម្ចីអចលនទ្រព្យហានិភ័យខ្ពស់។ វិធានការណ៍តឹងតែងទាំងនេះបានបង្កើតបញ្ហានយោបាយ ជាពិសេស

នៅពេលដែលធនាគារទាំងនោះមានទំនាក់ទំនងនយោបាយ ឬនៅពេលដែលរដ្ឋាភិបាលពុករលួយ។ ប្រទេសហ្វីលីពីន តាមរយៈការដោះស្រាយបញ្ហាបែបនេះ បានទទួលការសោទរពីអន្តរជាតិ។

ប្រទេសអាស៊ីផ្សេងទៀតមិនបានចាត់វិធានការណ៍ជាក់ច្បាស់ទេ ហើយត្រូវរងការធ្លាក់ចុះសេដ្ឋកិច្ចកាន់តែខ្លាំង។ ក្រុមអ្នកឆក់ឱកាសកេងចំណេញពីការជួញដូររូបិយប័ណ្ណបានវាយប្រហារប្រទេសឥណ្ឌូនេស៊ី ដែលត្រូវតែបណ្តោយអោយរូបិយប័ណ្ណរបស់ខ្លួនធ្លាក់ថ្លៃ ដំឡើងអត្រាការប្រាក់ និងអនុញ្ញាតអោយទីផ្សារភាគហ៊ុនរបស់ខ្លួនធ្លាក់ចុះ។ ក្នុងរយៈពេលប៉ុន្មានខែ ឥណ្ឌូនេស៊ីក៏បានស្វះស្វែងស្នើសុំប្រាក់កម្ចីរាប់សិបពាន់លានដុល្លារពីមូលនិធិIMF ដែលភ្ជាប់មកជាមួយនូវលក្ខខណ្ឌទូទៅ។ ប៉ុន្តែប្រទេសឥណ្ឌូនេស៊ីបានបដិសេធមិនអនុវត្តកំណែទម្រង់ដែលបានសន្យា ហើយសេដ្ឋកិច្ចរបស់ខ្លួនបានបន្តធ្លាក់ចុះ (ហើយស្ថិរភាពនយោបាយរបស់ខ្លួនក៏ត្រូវរង្គោះរង្គើរដែរ) ក្នុងឆ្នាំ ១៩៩៨។ នៅទីបំផុត កុប្បកម្មនិងការតវ៉ារបស់និស្សិតបានបង្ខំអោយប្រធានាធិបតីស៊ូហាតូលាលែងពីតំណែង ក្រោយបានដឹកនាំរបបផ្តាច់ការរយៈពេល ៣០ ឆ្នាំនៅក្នុងប្រទេសឥណ្ឌូនេស៊ី។ ជារួម នៅក្នុងប្រទេសថៃ ម៉ាឡេស៊ី និងឥណ្ឌូនេស៊ី ទីផ្សារភាគហ៊ុនត្រូវខាតបង់តម្លៃប្រហែលពាក់កណ្តាល ហើយរូបិយប័ណ្ណរបស់ពួកគេបាត់បង់តម្លៃ ប្រហែលមួយភាគបួននៃតម្លៃមុនមានវិបត្តិ។

នៅពេលដែលប្រទេសកូរ៉េខាងត្បូងបានឆ្លង«ជំងឺគ្រុនផ្តាសាយអាស៊ី»ក្នុងឆ្នាំ ១៩៩៧ ទីផ្សារភាគហ៊ុនរបស់វាបានដួលរលំ ហើយធនាគារនានាក្នុងប្រទេសនេះត្រូវជាប់ផុងក្នុងប្រាក់កម្ចីហានិភ័យខ្ពស់ ប្រមាណ ៥០ ប៊ីលានដុល្លារ ដោយផ្អែកលើរបបបក្ខពួកនិយម។ មូលនីធិIMF បានឈានជើងចូលអន្តរគមន៍ជាមួយនឹងថវិកាសង្គ្រោះអន្តរជាតិចំនួន ៦០ ពាន់លានដុល្លារ ដែលជាទំហំទឹកប្រាក់ដ៏ធំបំផុតមិនធ្លាប់មានពីមុនមក ហើយប្រជាជនកូរ៉េបានជ្រើសរើសប្រធានាធិបតីថ្មីដែលនិយមកំណែទម្រង់។ ដូច្នេះហើយ នៅប្រទេសកូរ៉េខាងត្បូង ក៏ដូចជានៅប្រទេសថៃនិងឥណ្ឌូនេស៊ី វិបត្តិហិរញ្ញវត្ថុបាននាំមកទាំងកំណែទម្រង់ថ្មីនិងទាំងការឈឺចាប់ដ៏លំបាក។

ប្រទេសចិនបានគេចផុតពីគ្រោះថ្នាក់នៃវិបត្តិឆ្នាំ ១៩៩៧ ដោយសារហេតុផលសំខាន់ៗមួយចំនួន៖ កំណើនសេដ្ឋកិច្ចរបស់ចិនមិនសូវមានលក្ខណៈតាមការរំពឹងទុក(ទោះបីជាកើនលឿនក៏ដោយ) រូបិយប័ណ្ណរបស់វាមិនអាចបំប្លែងឬប្តូរយកប្រាក់ជាតិដទៃបានដោយសេរី វាមានទុនបម្រុងច្រើនជារូបិយប័ណ្ណខ្លាំង ហើយរដ្ឋាភិបាលរបស់វាបានបង្ហាញថាខ្លួនមានវិន័យចាំបាច់ដើម្បីគ្រប់គ្រងអតិផរណា។ រដ្ឋាភិបាលបានកាត់បន្ថយអតិផរណាពីកម្រិត ២០% មកតិចជាង ៤% ក្នុងកំឡុងឆ្នាំ ១៩៩៥-១៩៩៧ ហើយវិស្វករតាក់តែងគោលនយោបាយតឹងតែងនេះ លោក ជូ រ៉ុងជី (Zhu Rongji) បានក្លាយជានាយករដ្ឋមន្ត្រីចិន នៅឆ្នាំ ១៩៩៨។ (អ្នកប្រយុទ្ធទប់ទល់នឹងអតិផរណាដ៏ជោគជ័យក៏បានក្លាយជាប្រធានាធិបតីប្រេស៊ីល និងអាហ្សង់ទីន នៅក្នុងឆ្នាំ ១៩៩០។)

បើយោងតាមទ្រឹស្តី លំហូរមូលធនដោយសេរី និងភ្លាមៗ នៅជុំវិញពិភពលោក ដែលជាលទ្ធផលនៃបច្ចេកវិទ្យាទំនាក់ទំនងសកល គួរតែធ្វើអោយសេដ្ឋកិច្ចមានស្ថិរភាព។ វិនិយោគិនអាចផ្លាស់ទីសាច់ប្រាក់បានយ៉ាងឆាប់រហ័ស ម្លោះហើយបានយ៉ាងច្រើនសន្ធឹកសន្ធាប់ ខណៈពេលលក្ខខណ្ឌនានាចង្អុលបង្ហាញពីការប្រែប្រួលនៃចរន្តខ្លាំងក្លានិងទន់ខ្សោយនៃរូបិយប័ណ្ណនិងសេដ្ឋកិច្ចរបស់រដ្ឋផ្សេងៗ។ ជាជាងរង់ចាំរដ្ឋាភិបាលទម្លាក់ឬកំណត់តម្លៃរូបិយប័ណ្ណឡើងវិញ នៅពេលដែលបញ្ហាបានរីករាលដាលរួចទៅហើយ ទីផ្សារអាចកែសម្រួលតម្លៃបន្តិចម្តងៗ ពីមួយថ្ងៃទៅមួយថ្ងៃ។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងការអនុវត្តជាក់ស្តែង លំហូរ

សាច់ប្រាក់សកលយ៉ាងងាយស្រួលក៏បង្ហាញពីទំនោរអស្ថិរភាពផងដែរ ដោយសារព្រឹត្តិការណ៍តូចៗអាចត្រូវបានពង្រីកនិងរំកិលទៅដល់ទីតាំងឆ្ងាយៗ។ ដូច្នេះហើយ បញ្ហារបស់ប្រទេសថៃបានក្លាយជាវិបត្តិអាស៊ី ហើយបន្ទាប់មកក្លាយជាវិបត្តិទីផ្សារដែលលេចឡើងថ្មី ដោយសារមូលធន*ដោយប្តូរយកប្រាក់បានយ៉ាងរហ័ស* ត្រូវបានផ្លាស់ទីទៅរកកន្លែងសុវត្ថិភាព ក្នុងល្បឿនលឿនដូចផ្លេកបន្ទោរ។ ព្រឹត្តិការណ៍ទាំងនេះបានបង្ហាញពីវិបត្តិហិរញ្ញវត្ថុក្នុងឆ្នាំ ២០០៨ នៅពេលដែលព្រឹត្តិការណ៍នៅក្នុងប្រទេសមួយនិងវិស័យមួយបានរីករាលដាលយ៉ាងឆាប់រហ័សទូទាំងពិភពលោក។

រដ្ឋាភិបាលប្រឈមមុខនឹងបញ្ហាទ្វេគ្រោះ ដោយសារតែគោលនយោបាយដែលពួកគេចង់បាន ដើម្បីប្រយោជន៍នយោបាយ (ចាប់ពីការជំរុញកំណើនសេដ្ឋកិច្ចនិងការរក្សាពន្ធទាប រហូតដល់ការជួយដល់ធនាគារនិងអាជីវកម្មដែលគ្រប់គ្រងដោយមិត្តភក្តិនិងសាច់ញាតិ) ទំនងជាធ្វើអោយប៉ះពាល់ដល់ស្ថិរភាពរូបិយប័ណ្ណ។ ប្រសិនបើបណ្តោយអោយបន្ត គោលនយោបាយបែបនេះអាចបណ្តាលអោយដួលរលំសេដ្ឋកិច្ច និងការបាត់បង់ការវិនិយោគពីបរទេស ប៉ុន្តែ គោលនយោបាយតឹងតែងក្នុងការ រក្សាស្ថិរភាពរូបិយប័ណ្ណអាចបណ្តាលអោយរដ្ឋាភិបាលបាត់បង់អំណាចផងដែរ។

នៅក្នុងតំបន់ទាំងអស់ដែលទើបតែបានពិភាក្សាខាងលើ (អាមេរិកខាងជើង អាស៊ី រុស្ស៊ី និងអឺរ៉ុបខាងកើត) តួនាទីនៃអាជីវកម្មឯកជនកំពុងពង្រីកធំ បើប្រៀបធៀបនឹងតួនាទីរដ្ឋ។ នៅពាសពេញតំបន់ផ្សេងទៀតនៅក្នុងពិភពលោក អាជីវកម្មឯកជនដើរតួនាទីក្នុងសេដ្ឋកិច្ចដែលខ្លាំងជាងរដ្ឋទៀតផង។ ផ្នែកដែលនៅសេសសល់ក្នុងមេរៀននេះ នឹងពិចារណាលើបញ្ហានយោបាយអន្តរជាតិ ទាក់ទងនឹងប្រតិបត្តិការអាជីវកម្មឯកជនឆ្លងកាត់ព្រំដែនរដ្ឋនានា។

៩.៤. ពាណិជ្ជកម្មពហុជាតិ

៩.៤ ចូរកំណត់កត្តាហានិភ័យចំពោះក្រុមហ៊ុនដែលពាក់ព័ន្ធនឹងវិនិយោគផ្ទាល់ពីបរទេសចំនួនពីរយ៉ាងតិច និងហានិភ័យចំពោះប្រទេសដែលទទួលការវិនិយោគផ្ទាល់ពីបរទេសនោះ ចំនួនពីរយ៉ាងតិចដែរ។

ទោះបីជារដ្ឋជាអ្នកបង្កើតច្បាប់គោលសម្រាប់ការផ្លាស់ប្តូររូបិយប័ណ្ណ និងប្រតិបត្តិការសេដ្ឋកិច្ចអន្តរជាតិដទៃទៀតក៏ដោយ ប្រតិបត្តិការទាំងនោះត្រូវបានអនុវត្តជាចម្បង ដោយក្រុមហ៊ុននិងបុគ្គលឯកជន មិនមែនរដ្ឋាភិបាលទេ។ តួអង្គសំខាន់បំផុតក្នុងចំណោមតួអង្គឯកជនទាំងនេះ គឺ សាជីវកម្មពហុជាតិ។

៩.៤.១. សាជីវកម្មពហុជាតិ

សាជីវកម្មពហុជាតិ (MNCs) គឺជាក្រុមហ៊ុនដែលមានមូលដ្ឋាននៅក្នុងរដ្ឋមួយ ដែលមានសាខា ឬអនុសាខាដែលប្រតិបត្តិការនៅក្នុងរដ្ឋផ្សេងទៀត។ មិនមាននិយមន័យច្បាស់លាស់ទេ ប៉ុន្តែករណីច្បាស់លាស់បំផុតនៃសាជីវកម្មពហុជាតិ គឺជាសាជីវកម្មដ៏ធំមួយដែលប្រតិបត្តិការលើមូលដ្ឋានទូទាំងពិភពលោក នៅក្នុងប្រទេសជាច្រើន ក្នុងពេលដំណាលគ្នា ជាមួយនឹងទីតាំងរោងចក្រនិងគ្រឿងបរិក្ខារ រួមនឹងនិយោជិតជាក់លាក់ ក្នុងទីតាំងនីមួយៗ។ ហើយក៏មិនមានចំនួនសរុបពិតប្រាកដនៃសាជីវកម្មពហុជាតិដែរ ប៉ុន្តែតាមការប៉ាន់ស្មានភាគច្រើន វាមានចំនួនរាប់ម៉ឺន នៅទូទាំងពិភពលោក។

សាជីវកម្មពហុជាតិសំខាន់បំផុតគឺ*សាជីវកម្មឧស្សាហកម្ម* (industrial corporations) ដែលផលិតទំនិញនៅក្នុងរោងចក្រក្នុងប្រទេសផ្សេងៗ ហើយលក់ទំនិញទាំងនោះទៅអោយអាជីវកម្ម និងអ្នកប្រើប្រាស់ចុងក្រោយនៅក្នុងប្រទេសផ្សេងៗ។ ឧស្សាហកម្មផលិតរថយន្ត ប្រេង និងគ្រឿងអេឡិចត្រូនិច មានសាជីវកម្ម

ពហុជាតិធំជាងគេ។ ស្ទើរតែទាំងអស់នៃសាជីវកម្មពហុជាតិធំបំផុតមានមូលដ្ឋាននៅក្នុងរដ្ឋមហាសេដ្ឋកិច្ចទាំង ៨ (G៨)។

សាជីវកម្មហិរញ្ញវត្ថុ(financial corporations) (សំខាន់បំផុតគឺធនាគារ) ក៏ប្រតិបត្តិការឆ្លងព្រំដែនជាតិជាច្រើនផងដែរ បើទោះបីជា ជាញឹកញាប់ មានការតែបន្តឹងច្រើនជាងសាជីវកម្មពហុជាតិឧស្សាហកម្មក៏ដោយ។ ក្នុងចំណោមធនាគារពាណិជ្ជធំជាងគេនៅទូទាំងពិភពលោក សហរដ្ឋអាមេរិកមិនកាន់កាប់តំណែងនាំមុខគេនោះទេ។ នេះឆ្លុះបញ្ចាំងពីគោលនយោបាយប្រឆាំងត្រឹស្ត(anti-trust)របស់សហរដ្ឋអាមេរិកដែលជាក់កំណត់ការពង្រីកភូមិសាស្ត្ររបស់ធនាគារ។ វិសាលភាពនៃសមាហរណកម្មអន្តរជាតិនៃទីផ្សារហិរញ្ញវត្ថុត្រូវបានចង្អុលបង្ហាញយ៉ាងច្បាស់ក្នុងឆ្នាំ ១៩៩៥ នៅពេលដែលពាណិជ្ជករអាយុ ២៨ ឆ្នាំតែម្នាក់ នៅប្រទេសសិង្ហបុរីបានបាត់បង់ប្រាក់ ១ ប៊ីលានដុល្លារ ក្នុងការឆ្លៀតឱកាសកេងចំណេញពីទីផ្សារភាគហ៊ុន និងមូលប័ណ្ណជប៉ុន ហើយបានធ្វើអោយនិយោជករបស់គាត់ ដែលជាធនាគារវិនិយោគរបស់ចក្រពអង់គ្លេស ដែលមានអាយុ ២០០ ឆ្នាំ ត្រូវក្សោយធន។

រូបថត ជើងហោះហើរអឺរ៉ុប

ធ្វើជំនួញទូទាំងពិភពលោក

សាជីវកម្មពហុជាតិ (MNCs) ដើរតួនាទីយ៉ាងសំខាន់ក្នុងទំនាក់ទំនងអន្តរជាតិ និងជាតួអង្គដ៏មានឥទ្ធិពលដែលមានធនធានច្រើនក្នុងការចរចាជាមួយរដ្ឋាភិបាល។ នៅទីនេះ ក្រុមហ៊ុន Airbus ដែលជាផ្នែកមួយនៃសាជីវកម្មពហុជាតិរបស់អឺរ៉ុប បង្ហាញយន្តហោះចម្បាំងទំនើបថ្មីរបស់ខ្លួន នៅឯកម្មវិធី Singapore Airshow ឆ្នាំ ២០០៨។

សាជីវកម្មពហុជាតិខ្លះលក់*សេវាកម្ម*។ ក្រុមហ៊ុនខ្សែចង្វាក់អាហារMcDonald និងក្រុមហ៊ុនទូរស័ព្ទ និងតេឡេក្រាមអាមេរិក(AT&T) គឺជាឧទាហរណ៍ដ៏ល្អ។ ដូចគ្នាផងដែរ គឺក្រុមហ៊ុនអាកាសចរណ៍អន្តរជាតិដែលលក់សំបុត្រនៅក្នុងរដ្ឋ(និងគិតជារូបិយប័ណ្ណ)ចម្រុះជាច្រើន សម្រាប់ការធ្វើដំណើរជុំវិញពិភពលោក។ អាជីវកម្មសេវាកម្មល្អិតល្អន់បន្ថែមទៀត ដូចជាហាងលក់គ្រឿងទេសក៏អាចក្លាយជាសាជីវកម្មពហុជាតិ ផងដែរ។ សហរដ្ឋអាមេរិកនាំមុខគេក្នុងសាជីវកម្មពហុជាតិសេវាកម្ម ក៏ដូចជាសាជីវកម្មពហុជាតិឧស្សាហកម្ម។

តួនាទីរបស់សាជីវកម្មពហុជាតិ នៅក្នុងទំនាក់ទំនងនយោបាយអន្តរជាតិមានភាពស្មុគស្មាញ និងមានលក្ខណៈចម្រុងចម្រាស់ផងដែរ។ អ្នកប្រាជ្ញខ្លះមើលឃើញថា សាជីវកម្មពហុជាតិស្ទើរតែក្លាយជាភ្នាក់ងាររបស់រដ្ឋាភិបាលជាតិរបស់គេទៅហើយ។ ទស្សនៈនេះស្របនឹងលទ្ធិគាំពារនិយម ដែលអះអាងថាសកម្មភាពសេដ្ឋកិច្ចនៅទីបំផុតបម្រើអាជ្ញាធរនយោបាយ។ ដូច្នេះ សាជីវកម្មពហុជាតិមានអត្តសញ្ញាណជាតិច្បាស់លាស់ និងដើរតួជាសមាជិកនៃសង្គមជាតិរបស់ពួកគេក្រោមអំណាចរដ្ឋ។ ទិដ្ឋភាពមួយផ្សេងទៀតនៃប្រធានបទនេះ (ពីទស្សនៈពិភពលោកបែបបដិវត្តន៍និយម) ចាត់ទុករដ្ឋាភិបាលជាតិថាជា ភ្នាក់ងារនៃសាជីវកម្មពហុជាតិរបស់ពួកគេ។ អន្តរាគមន៍របស់រដ្ឋ (ទាំងផ្នែកសេដ្ឋកិច្ចនិងយោធា) បម្រើផលប្រយោជន៍ប្រាក់និងឯកជន។

ក្រុមផ្សេងៗទៀតមើលឃើញថាសាជីវកម្មពហុជាតិជាពលរដ្ឋនៃពិភពលោកទាំងមូល ដែលមិនជាប់កាតព្វកិច្ចចំពោះរដ្ឋាភិបាលណាមួយឡើយ។ ប្រធានក្រុមហ៊ុនសារធាតុគីមីដៅវ៍(Dow Chemical) ធ្លាប់បាននិយាយថាគាត់សុបិន្តចង់ទិញកោះមួយ ហួសពីរង្វង់ព្រំដែនទឹកដីរបស់រដ្ឋទាំងឡាយ ហើយដាក់ទីស្នាក់ការកណ្តាលពិភពលោករបស់ក្រុមហ៊ុនដៅវ៍នៅទីនោះ។ នៅក្នុងទិដ្ឋភាពនេះ សាជីវកម្មពហុជាតិធ្វើសកម្មភាពជា

សកលដើម្បីផលប្រយោជន៍នៃម្ចាស់ភាគហ៊ុន(អន្តរជាតិ)របស់ពួកគេ ហើយមិនជាប់កាតព្វកិច្ចមានកក្តីកាពចំពោះរដ្ឋណាមួយឡើយ។ ក្នុងករណីណាក៏ដោយ សាជីវកម្មពហុជាតិត្រូវបានជំរុញដោយតម្រូវការដើម្បីបង្កើនប្រាក់ចំណេញជាអតិបរមា។ មានតែនៅក្នុងករណីសាជីវកម្មពហុជាតិដែលគ្រប់គ្រងដោយរដ្ឋប៉ុណ្ណោះ (ជាករណីលើកលែងដ៏សំខាន់ ប៉ុន្តែ ត្រឹមមួយភាគតូចនៃចំនួនក្រុមហ៊ុនសរុបទូទាំងពិភពលោក) ដែលសកម្មភាពរបស់សាជីវកម្មពហុជាតិឆ្លុះបញ្ចាំងពីផលប្រយោជន៍របស់រដ្ឋ។ សូម្បីក្នុងករណីនោះក៏ដោយ ក៏អ្នកគ្រប់គ្រងនៃសាជីវកម្មពហុជាតិរបស់រដ្ឋទទួលបានស្វ័យភាពកាន់តែច្រើនក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ដើម្បីស្វែងរកប្រាក់ចំណេញ (ជាផ្នែកមួយនៃកំណែទម្រង់សេដ្ឋកិច្ចដែល បានបង្កើតឡើងនៅក្នុងប្រទេសជាច្រើន) ហើយក្នុងករណីជាច្រើន សហគ្រាសរបស់រដ្ឋត្រូវបានលក់ចេញ (ធ្វើឯកជនភាវូបនីយកម្ម)។

ក្នុងនាមជាតួអង្គឯករាជ្យនៅក្នុងឆាកអន្តរជាតិ សាជីវកម្មពហុជាតិកាន់តែមានឥទ្ធិពល។ សាជីវកម្មពហុជាតិឧស្សាហកម្មរាប់សិបឡូមានការលក់ប្រចាំឆ្នាំ ក្នុងទំហំទឹកប្រាក់សរុបរាប់សិបប៊ីលានដុល្លារសម្រាប់ក្រុមហ៊ុននីមួយៗ (រាប់រយប៊ីលានដុល្លារសម្រាប់សាជីវកម្មកំពូលៗ)។ បើគិតក្នុងឆ្នាំ ២០១៧ មានតែរដ្ឋចំនួន ២៥ ប៉ុណ្ណោះ ដែលមានសកម្មភាពសេដ្ឋកិច្ចប្រចាំឆ្នាំ(ផ.ស.ស.) ច្រើនជាងសាជីវកម្មពហុជាតិធំបំផុត ដូចជាក្រុមហ៊ុនផ្សារទំនើបវ៉ាលម៉ាត (Wal-Mart) ដែលមានប្រតិបត្តិការក្នុងទំហំទឹកប្រាក់ជិត ៥០០ ប៊ីលានដុល្លារ។ ទោះជាយ៉ាងណាក៏ដោយ រដ្ឋធំបំផុត (សហរដ្ឋអាមេរិក) មានប្រាក់ចំណូលរបស់រដ្ឋាភិបាល លើសពី ៣ទ្រីលានដុល្លារ ដែលធំជាងប្រតិបត្តិការរបស់ផ្សារWal-Mart ប្រហែលប្រាំមួយដង។ ដូច្នេះ អំណាចសាជីវកម្មពហុជាតិមិនប្រកួតប្រជែងជាមួយរដ្ឋធំជាងគេនោះទេ ប៉ុន្តែ គ្របដណ្តប់លើអំណាចរដ្ឋក្រីក្រជាច្រើនទៀត។ នេះជះឥទ្ធិពលលើប្រតិបត្តិការសាជីវកម្មពហុជាតិនៅអឌ្ឍគោលខាងត្បូង។

សាជីវកម្មពហុជាតិធំៗរួមចំណែកដល់ការពឹងអាស្រ័យគ្នាទៅវិញទៅមកជាលក្ខណៈសាកល។ ពួកគេមានទំនាក់ទំនងនឹងគ្នាយ៉ាងស៊ីជម្រៅនៅក្នុងរដ្ឋជាច្រើន ដែលពួកគេអាចមានផលប្រយោជន៍យ៉ាងជ្រាលជ្រៅសម្រាប់ធ្វើប្រតិបត្តិការប្រព័ន្ធអន្តរជាតិប្រកបដោយស្ថិរភាព ទាំងក្នុងកិច្ចការសន្តិសុខ ក៏ដូចជាក្នុងទំនាក់ទំនងពាណិជ្ជកម្មនិងរូបិយវត្ថុ។ សាជីវកម្មពហុជាតិរីកចម្រើននៅក្នុងបរិយាកាសអន្តរជាតិដែលមានស្ថិរភាព ដែលអនុញ្ញាតអោយមានសេរីភាពបីប្រភេទធំៗ ដូចជា ពាណិជ្ជកម្មសេរី ចលនាបម្លាស់ដោយសេរី និងលំហូរមូលធន(ការវិនិយោគ)ដោយសេរី ដែលទាំងអស់នេះត្រូវបានគ្រប់គ្រងដោយកម្លាំងទីផ្សារ ដោយមានការជ្រៀតជ្រែកតិចតួចបំផុតពីរដ្ឋាភិបាល។ ដូច្នេះ សាជីវកម្មពហុជាតិគឺជាកម្លាំងដ៏រឹងមាំសម្រាប់លទ្ធិសេរីនិយមនៅក្នុងសេដ្ឋកិច្ចពិភពលោក បើទោះបីជាមានសាជីវកម្មពហុជាតិខ្លះ ពិសេសនៅក្នុងឧស្សាហកម្មជំរុញអោយមានគោលនយោបាយគាំពារនិយមជាក់លាក់ដើម្បីការពារផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ពួកគេក៏ដោយ។

សាជីវកម្មពហុជាតិភាគច្រើនមានប្រព័ន្ធគ្រប់គ្រងពិភពលោក ដោយផ្អែកលើ*ក្រុមហ៊ុនបុត្រសម្ព័ន្ធ* (subsidiaries) ដែលស្ថិតនៅក្នុងរដ្ឋនីមួយៗ ដែលពួកគេប្រតិបត្តិការ។ ប្រតិបត្តិការក្នុងរដ្ឋមួយស្ថិតនៅក្រោមសិទ្ធិអំណាចផ្លូវច្បាប់នៃរដ្ឋាភិបាលរបស់រដ្ឋនោះ។ ប៉ុន្តែ ក្រុមហ៊ុនបុត្រសម្ព័ន្ធបរទេសត្រូវបានគ្រប់គ្រង (ទាំងស្រុងឬមួយផ្នែកធំ) ដោយសាជីវកម្មពហុជាតិមេធំ នៅក្នុងប្រទេសកំណើត។ ដូច្នេះ សាជីវកម្មពហុជាតិមេអាចជួលនិងបណ្តេញចេញនូវអ្នកគ្រប់គ្រងកំពូលនៃក្រុមហ៊ុនបុត្រសម្ព័ន្ធបរទេសរបស់ខ្លួន។ ហេដ្ឋារចនាសម្ព័ន្ធធុរកិច្ចគឺជាទិដ្ឋភាពសំខាន់នៃ*ទំនាក់ទំនងឆ្លងព្រំដែន*(transnational relations) ដែលជាទំនាក់ទំនងរវាងមនុស្សនិងក្រុមនានាឆ្លងកាត់ព្រំដែនជាតិ។

បន្ថែមពីលើការភ្ជាប់ទំនាក់ទំនងដោយផ្ទាល់ ក្នុងចំណោមសមាជិកនៃសាជីវកម្មពហុជាតិរួមគ្នាតែមួយ ប្រតិបត្តិការរបស់សាជីវកម្មពហុជាតិ គាំទ្រដល់ហេដ្ឋារចនាសម្ព័ន្ធធុរកិច្ចសកល ដែលតភ្ជាប់សហគមន៍ពាណិជ្ជករឆ្លងដែន។ តួយ៉ាង អ្នកគ្រប់គ្រងជនជាតិអាមេរិកមកដល់ទីក្រុងសេអ៊ូល ប្រទេសកូរ៉េខាងត្បូង រកមិនឃើញទិដ្ឋភាពដ៏គួរអោយភ្ញាក់ផ្អើល ក្នុងផ្នែកភាសា ទីតាំង និងទំនៀមទម្លាប់ ដែលមិនធ្លាប់ស្គាល់ពីមុនមកទេ។ ផ្ទុយទៅវិញ គាត់ផ្លាស់ទីតាមលំដាប់លំដោយ មុនដំបូង កន្លែងទទួលភ្ញៀវនៅព្រលានយន្តហោះ ការហៅទូរសព្ទនិងផ្ញើទូរសារ សណ្ឋាគារអន្តរជាតិ បន្ទប់សន្និសីទអាជីវកម្ម និងការផ្សាយរបស់បណ្តាញទូរទស្សន៍ CNN ដែលភាគច្រើនទំនងជានិយាយភាសាអង់គ្លេសទាំងអស់។

៩.៤.២. ការវិនិយោគផ្ទាល់ពីបរទេស


សាជីវកម្មពហុជាតិមិនត្រឹមតែដំណើរការនៅបរទេសប៉ុណ្ណោះទេ ពួកគេក៏មានមូលធនឬដើមទុននៅទីនោះផងដែរ ដូចជាអគារ រោងចក្រ រថយន្តជាដើម។ ជាឧទាហរណ៍ សាជីវកម្មពហុជាតិរបស់សហរដ្ឋអាមេរិក និងអាឡឺម៉ង់មានមូលធនមួយចំនួន ដែលមានទីតាំងនៅប្រទេសជប៉ុន ហើយសាជីវកម្មពហុជាតិ របស់ជប៉ុនមានមូលធនដែលមានទីតាំងនៅសហរដ្ឋអាមេរិកនិងអាឡឺម៉ង់ផងដែរ។ *ការវិនិយោគ*(investment)មានន័យថាការប្តូរប្រាក់ជាថ្នូរនឹងភាពជាម្ចាស់នៃមូលធន (ក្នុងគោលដៅបង្កើតលំហូរនៃប្រាក់ចំណូល ដែលទៅថ្ងៃមុខអាចប៉ះប៉ូវប្រាក់ដែលបានវិនិយោគ និងសល់ប្រាក់ចំណេញខ្លះ)។ ការវិនិយោគនៅបរទេសគឺជាសកម្មភាពដ៏សំខាន់បំផុតរបស់សាជីវកម្មពហុជាតិ តែក៏មានភាពរសើបផ្នែកនយោបាយផងដែរ។ ក្រាហ្វិក ៩.២ បង្ហាញពីកំណើននៃការវិនិយោគផ្ទាល់ពីបរទេស។ ទោះបីជាមាននិន្នាការខ្លាំងឆ្ពោះទៅរកការវិនិយោគផ្ទាល់ពីបរទេសកាន់តែច្រើនក៏ដោយ លំហូរទាំងនេះកើនឡើងនិងធ្លាក់ចុះតាមស្ថានភាពសេដ្ឋកិច្ចពិភពលោក។

មិនដូចការវិនិយោគមូលប័ត្រ (នៅលើក្រដាស) **ការវិនិយោគផ្ទាល់ពីបរទេស(FDI)** ពាក់ព័ន្ធនឹងទំនិញជាក់ស្តែង ដូចជារោងចក្រ និងអគារការិយាល័យ (រួមទាំងភាពជាម្ចាស់នៃប្រភាគដ៏ច្រើននៃភាគហ៊ុនសរុបរបស់ក្រុមហ៊ុន ដែលផ្ទុយពីមូលប័ត្រដែលដាក់លុយក្នុងក្រុមហ៊ុនជាច្រើនផ្សេងគ្នា)។ ក្រដាស(ប្រាក់)អាចត្រូវបានជួញដូរនៅលើទីផ្សារពិភពលោកដោយសេរី ប៉ុន្តែការវិនិយោគផ្ទាល់មិនអាចផ្លាស់ទីដោយសេរីពីរដ្ឋមួយទៅរដ្ឋមួយទៀត នៅពេលដែលលក្ខខណ្ឌឬស្ថានភាពផ្លាស់ប្តូរ។ ការវិនិយោគផ្ទាល់ត្រូវការរយៈពេលវែង ហើយវាមានលក្ខណៈរូបីជាងការវិនិយោគមូលប័ត្រ។ ជាធម្មតា ការវិនិយោគនៅក្នុងវិស័យផលិតកម្មរួមបញ្ចូលការវិនិយោគដ៏ធំបំផុត នៅក្នុងទីតាំងរោងចក្រនិងគ្រឿងបរិក្ខារជាក់លាក់ និងក្នុងការបណ្តុះបណ្តាលកម្មករនិងអ្នកគ្រប់គ្រង។ ការវិនិយោគក្នុងវិស័យសេវាកម្មមានទំនោរមានតម្លៃថោកនិងងាយស្រួលក្នុងការដើរចេញប្រសិនបើលក្ខខណ្ឌផ្លាស់ប្តូរ។

អ្នកលទ្ធិគាំពារនិយមមានទំនោរមើលការវិនិយោគបរទេស នៅក្នុងប្រទេសរបស់ពួកគេ ដោយការសង្ស័យ។ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ការវិនិយោគផ្ទាល់ពីបរទេស ជារឿយៗ បង្កអោយមានការព្រួយបារម្ភអំពីការបាត់បង់អធិបតេយ្យភាព ដោយសាររដ្ឋាភិបាលអាចមានអំណាចតិច (ហើយប្រហែលជាមានទ្រព្យសម្បត្តិតិច) ជាងសាជីវកម្មពហុជាតិ ដែលវិនិយោគនៅក្នុងប្រទេសរបស់ពួកគេ។ ការភ័យខ្លាចទាំងនេះក៏ឆ្លុះបញ្ចាំងពីតថភាពប្រវត្តិសាស្ត្រ ដែលការវិនិយោគបរទេសភាគច្រើននៅក្នុងអឌ្ឍគោលខាងត្បូងធ្លាប់មកពីប្រទេសដាក់អាណានិគម។ ជាងនេះទៅទៀត ថ្វីត្បិតតែការវិនិយោគបែបនេះបង្កើតការងារក៏ដោយ ក៏វានាំមកនូវការផ្លាស់ប្តូររបៀបរស់នៅ និងវប្បធម៌ប្រពៃណីផងដែរ។

ក្រាហ្វិក ៩.២ ការវិនិយោគផ្ទាល់ពីបរទេស សរុបពិភពលោក ឆ្នាំ ១៩៩០-២០១៦

ប្រភព៖ ទិន្នន័យ UNCTAD ។



ប៉ុន្តែដោយសារតែរដ្ឋក្រីក្រ និងកំពុងស្ថិតក្នុងសម័យអន្តរកាលជាច្រើនក៏ត្រូវការដើមទុនពីប្រភពណាមួយដើម្បីជំរុញកំណើនសេដ្ឋកិច្ច ជាទូទៅ ការវិនិយោគផ្ទាល់ពីបរទេសត្រូវបានស្វាគមន៍ និងលើកទឹកចិត្ត ទោះបីជាមានការភ័យខ្លាចពីអ្នកជាតិនិយមសេដ្ឋកិច្ចក៏ដោយ (ការវិនិយោគអឌ្ឍគោលខាងជើង-ខាងត្បូងត្រូវបានពិភាក្សាបន្ថែមនៅផ្នែកបន្ទាប់)។ ការវិនិយោគផ្ទាល់ពីបរទេសភាគច្រើន (ដូចជាការវិនិយោគមូលប័ត្រភាគច្រើន) មិនស្ថិតនៅក្នុងអឌ្ឍគោលខាងត្បូងនោះទេ ប៉ុន្តែនៅក្នុងបណ្តាប្រទេសឧស្សាហកម្ម។

អ្នកជាតិនិយមសេដ្ឋកិច្ចនៅក្នុងបណ្តាប្រទេសឧស្សាហូបនីយកម្ម ក៏ព្រួយបារម្ភផងដែរអំពីការបាត់បង់អំណាចនិងអធិបតេយ្យភាព ពីការវិនិយោគបរទេស។ ជាឧទាហរណ៍ នៅប្រទេសកាណាដា អ្នកគាំពារនិយមមានការព្រួយបារម្ភថា ក្រុមហ៊ុនអាមេរិកជាម្ចាស់កម្មសិទ្ធិ ច្រើនជាងពាក់កណ្តាលនៃឧស្សាហកម្មផលិតកម្មរបស់ប្រទេសកាណាដា និង ច្រើនជាងពីរភាគបីនៃឧស្សាហកម្មប្រេងនិងឧស្ម័នរបស់ប្រទេសកាណាដា។ ប្រទេសកាណាដាមានទំហំតូចជាងសហរដ្ឋអាមេរិក ប៉ុន្តែវាពឹងផ្អែកយ៉ាងខ្លាំងលើពាណិជ្ជកម្មរបស់សហរដ្ឋអាមេរិក។ ក្នុងស្ថានភាពមិនស៊ីមេទ្រីបែបនេះ ប្រជាជនកាណាដាមួយចំនួនព្រួយបារម្ភថាពួកគេកំពុងក្លាយជាឧបសម្ព័ន្ធរបស់សហរដ្ឋអាមេរិក ទាំងផ្នែកសេដ្ឋកិច្ច វប្បធម៌ និងចុងក្រោយនយោបាយ ដែលបណ្តាលអោយបាត់បង់វប្បធម៌ជាតិ និងការគ្រប់គ្រងសេដ្ឋកិច្ចរបស់ពួកគេ។

ទន្ទឹមនឹងនេះ អ្នកជាតិនិយមខាងសេដ្ឋកិច្ចរបស់សហរដ្ឋអាមេរិកមានការព្រួយបារម្ភដូចគ្នាចំពោះការវិនិយោគផ្ទាល់ពីបរទេសនៅក្នុងសហរដ្ឋអាមេរិក។ ប្រការនេះមួយផ្នែកធ្លុះបញ្ចាំងពីការបំភ័យអំពីការកំណើនបំណុលរបស់សហរដ្ឋអាមេរិក។ ក្រុមអ្នកគាំពារនិយមមើលឃើញថាជាការបាត់បង់អំណាច នៅពេលដែលវិនិយោគិនបរទេសទិញក្រុមហ៊ុននិងអចលនទ្រព្យនៅក្នុងប្រទេសកូនបំណុល។ ក្តីបារម្ភបែបនេះហាក់ដូចជាកើនកាន់តែខ្លាំងនៅពេលដែល សាជីវកម្មពហុជាតិបរទេសទិញក្រុមហ៊ុន ឬអគារដែលមានស្រាប់ជាងពេល

ដែលវាសាងសង់រោងចក្រថ្មីឬកន្លែងផ្សេងទៀត។ ជាឧទាហរណ៍ នៅក្នុងឆ្នាំ ២០០៥ ការផ្ទុះកំហឹងនៅសហរដ្ឋអាមេរិកបានបង្ខំអោយក្រុមហ៊ុនប្រេងរបស់ចិនដកការដេញថ្លៃរបស់ខ្លួន ក្នុងការទិញក្រុមហ៊ុនអាមេរិក យូណូខល (Unocal) ដែលទីបញ្ចប់ទៅ បានលក់ចេញដោយខ្លួនឯងក្នុងតម្លៃទាបជាង ទៅអោយក្រុមហ៊ុនអាមេរិក។ (មេដឹកនាំធុរកិច្ចនិងរដ្ឋាភិបាលចិន មិនសប្បាយចិត្តចំពោះអ្វីដែលពួកគេមើលឃើញថាជាស្តង់ដារទ្វេរបស់សហរដ្ឋអាមេរិក។) ប៉ុន្តែ នៅពេលដែលក្រុមហ៊ុនហុងដាសាងសង់រោងចក្រផលិតរថយន្តថ្មី នៅរដ្ឋអូហៃយ៉ូ (Ohio) ដោយបន្ថែមការងារនិងសម្ភារៈបរិក្ខារដល់សេដ្ឋកិច្ចសហរដ្ឋអាមេរិក ប្រជាជនអាមេរិកយល់ថាមិនមានការបាត់បង់បែបនេះទេ។

លទ្ធិសេរីនិយមមិនអត់ឱនចំពោះអំណះអំណាងបែបនេះទេ។ អ្នកសេដ្ឋកិច្ចសេរីសង្កត់ធ្ងន់ថា ប្រសិទ្ធភាពសកលនិងការកើនឡើងនៃទ្រព្យសម្បត្តិ កើតឡើងពីសមត្ថភាពរបស់សាជីវកម្មពហុជាតិក្នុងការវិនិយោគដោយសេរីឆ្លងកាត់ព្រំដែនអន្តរជាតិ។ ការសម្រេចចិត្តវិនិយោគគួរតែធ្វើឡើង ដោយផ្អែកលើហេតុផលសេដ្ឋកិច្ចប៉ុណ្ណោះ មិនមែនជារឿងជាតិនិយមទេ។ តាមទស្សនៈរបស់សេដ្ឋវិទូសេរី ការវិនិយោគបរទេសនៅសហរដ្ឋអាមេរិកជួយផ្តល់ប្រយោជន៍ជាជាងធ្វើអោយខាតប្រយោជន៍សេដ្ឋកិច្ចអាមេរិក។ ប្រសិនបើរោងចក្រជប៉ុនរកបានផលចំណេញច្រើននៅសហរដ្ឋអាមេរិក វាផ្តល់ប្រយោជន៍ដល់កម្មករអាមេរិកនៅរោងចក្រ និងអ្នកប្រើប្រាស់ផលិតផលរបស់សហរដ្ឋអាមេរិក ទោះបីជាប្រាក់ចំណេញមួយចំនួនត្រូវផ្ញើត្រឡប់ទៅប្រទេសជប៉ុនវិញក៏ដោយ (ហើយសូម្បីតែប្រាក់ចំណេញទាំងនោះ ក៏អាចត្រូវបានវិនិយោគឡើងវិញនៅសហរដ្ឋអាមេរិក)។ ដោយសារតែសាជីវកម្មពហុជាតិ របស់សហរដ្ឋអាមេរិកមានការវិនិយោគផ្ទាល់ពីបរទេសច្រើនជាង ៦ ទ្រីលានដុល្លារ នៅក្រៅសហរដ្ឋអាមេរិក ទិដ្ឋភាពនេះមិនមានន័យតែម្ខាងទេ។

៩.៤.៣. ទំនាក់ទំនងរដ្ឋាភិបាលម្ចាស់ប្រទេសនិងមាតុប្រទេស

រដ្ឋទាំងឡាយណាដែលសាជីវកម្មពហុជាតិបរទេសចូលទៅប្រតិបត្តិការ ត្រូវបានគេហៅថា **ប្រទេសម្ចាស់ផ្ទះ** (host country)។ រដ្ឋដែលសាជីវកម្មពហុជាតិដាក់តាំងទីស្នាក់ការកណ្តាល ត្រូវបានគេហៅថា **មាតុប្រទេស** ឬ **ប្រទេសកំណើត** (home country)។ ប្រតិបត្តិការសាជីវកម្មពហុជាតិបង្កបញ្ហា និងបង្កើតឱកាសជាច្រើនសម្រាប់ទាំងរដ្ឋាភិបាលនៃប្រទេសម្ចាស់ផ្ទះ និងប្រទេសកំណើត។ ជម្លោះរវាងរដ្ឋាភិបាលប្រទេសម្ចាស់ផ្ទះ និងសាជីវកម្មពហុជាតិ អាចនឹងផ្ទុះរីករាលដាល រហូតក្លាយជាជម្លោះអន្តររដ្ឋ រវាងរដ្ឋាភិបាលប្រទេសម្ចាស់ផ្ទះ និងប្រទេសកំណើត។ ជាឧទាហរណ៍ ប្រសិនបើរដ្ឋាភិបាលប្រទេសម្ចាស់ផ្ទះរឹបអូសយកទ្រព្យសម្បត្តិរបស់សាជីវកម្មពហុជាតិដោយគ្មានសំណងត្រឹមត្រូវ ឬចាប់ឃុំខ្លួននាយកប្រតិបត្តិរបស់ខ្លួន រដ្ឋាភិបាលប្រទេសកំណើតអាចឈានជើងចូលអន្តរាគមន៍ដើម្បីជួយសាជីវកម្មពហុជាតិ ។

ដោយសាររដ្ឋាភិបាលប្រទេសម្ចាស់ផ្ទះអាចធ្វើច្បាប់គ្រប់គ្រងសកម្មភាពទាំងឡាយ នៅលើទឹកដីរបស់ពួកគេ សាជីវកម្មពហុជាតិមិនអាចប្រតិបត្តិការក្នុងរដ្ឋមួយ ប្រឆាំងនឹងឆន្ទៈរបស់រដ្ឋាភិបាលនោះឡើយ។ ផ្ទុយទៅវិញ ដោយសារសាជីវកម្មពហុជាតិមានរដ្ឋជាច្រើនសម្រាប់ជ្រើសរើស ជាទូទៅ រដ្ឋាភិបាលប្រទេសម្ចាស់ផ្ទះមិនអាចបង្ខំសាជីវកម្មពហុជាតិអោយធ្វើអាជីវកម្ម នៅក្នុងប្រទេសរបស់ខ្លួន ប្រឆាំងនឹងឆន្ទៈរបស់សាជីវកម្មពហុជាតិបានទេ។ យ៉ាងហោចណាស់ នៅក្នុងទ្រឹស្តី សាជីវកម្មពហុជាតិប្រតិបត្តិការនៅក្នុងប្រទេសម្ចាស់ផ្ទះតែនៅពេលដែលវាមានផលប្រយោជន៍ សម្រាប់ទាំងសាជីវកម្មពហុជាតិនិងទាំងរដ្ឋាភិបាលប្រទេសម្ចាស់ផ្ទះ។ ផលប្រយោជន៍រួមបានមកពីការបង្កើតទ្រព្យសម្បត្តិ ដោយសាជីវកម្មពហុជាតិ នៅក្នុងប្រទេសម្ចាស់ផ្ទះ។ ទាំង

សាជីវកម្មពហុជាតិនិងរដ្ឋាភិបាលប្រទេសម្ចាស់ផ្ទះទទួលបានអត្ថប្រយោជន៍រៀងៗខ្លួន៖ សាជីវកម្មពហុជាតិទទួលបានប្រាក់ចំណេញ ចំណែករដ្ឋាភិបាលចំណេញដោយផ្ទាល់ពីការយកពន្ធ និងដោយប្រយោលតាមរយៈកំណើនសេដ្ឋកិច្ច(ការបង្កើតចំណូលពន្ធនាពេលអនាគត និងការគាំទ្រផ្នែកនយោបាយ)។

រូបថត ស្ត្រីជនជាតិចិនធ្វើតុក្កតាសាន់តា

វាជាការងារមួយ

ការវិនិយោគផ្ទាល់ពីបរទេសជារឿយៗត្រូវស្វះស្វែងរក ដោយរដ្ឋាភិបាលម្ចាស់ផ្ទះ ព្រោះវាជួយជំរុញការងារនិងកំណើនសេដ្ឋកិច្ច ទោះបីជាក្នុងកម្រិតប្រាក់ឈ្នួល ដែលមាតុប្រទេសអាចទទួលយកបានក៏ដោយ។ នៅទីនេះ ស្ត្រីផ្តុំរូបតុក្កតាសាន់តា ក្លូស(Santa Claus) នៅភាគខាងកើតនៃប្រទេសចិន។ ចូរកត់សម្គាល់ថា រួមជាមួយនឹងការវិនិយោគ ប្រទេសម្ចាស់ផ្ទះនាំចូលនូវគ្រឿងឬប្រជាប់ប្រដាប់ប្រដារវប្បធម៌មួយចំនួន នៃសកម្មភាពរបស់សារជីវកម្មពហុជាតិ ដូចជាសារៈសំខាន់នៃតុក្កតាសាន់តាក្លូស ចំពោះថ្ងៃបុណ្យគ្រីស្មាស់ នៅក្នុងប្រទេសដែលមិនកាន់សាសនាគ្រិស្តភាគច្រើន។

ទោះជាយ៉ាងណាក៏ដោយ ជម្លោះក៏កើតឡើងនៅក្នុងទំនាក់ទំនងខាងលើផងដែរ។ ជម្លោះជាក់ស្តែងមួយទាក់ទងនឹងការបែងចែកទ្រព្យសម្បត្តិថ្មី រវាងសាជីវកម្មពហុជាតិនិងរដ្ឋាភិបាលប្រទេសម្ចាស់ផ្ទះ។ ការបែងចែកនេះអាស្រ័យលើអត្រាដែលសកម្មភាពឬប្រាក់ចំណេញរបស់សាជីវកម្មពហុជាតិ ត្រូវបានគិតពន្ធ ក៏ដូចជាច្បាប់មូលដ្ឋានសម្រាប់ប្រតិបត្តិការសាជីវកម្មពហុជាតិ។ មុនពេលសាជីវកម្មពហុជាតិវិនិយោគ ឬបើកក្រុមហ៊ុនបុត្រសម្ព័ន្ធនៅក្នុងប្រទេសម្ចាស់ផ្ទះ វាអង្គុយចរចាបញ្ហាទាំងនេះជាមួយនឹងរដ្ឋាភិបាល។ ការគំរាមកំហែងប្រើឥទ្ធិពលហិង្សា ភាគច្រើនមិនបានការទេ។ ផ្ទុយទៅវិញ ឥទ្ធិពលចម្បងរបស់រដ្ឋាភិបាលគឺការសន្យាផ្តល់បរិយាកាសអំណោយផលសម្រាប់ការធ្វើអាជីវកម្មនិងទទួលបានប្រាក់ចំណេញ។ អានុភាពចម្បងរបស់សាជីវកម្មពហុជាតិ គឺគំរាមកំហែងយកដើមទុនរបស់ខ្លួនទៅប្រទេសផ្សេង។

រដ្ឋាភិបាលអាចផ្តល់ការលើកទឹកចិត្តជាច្រើន ដល់សាជីវកម្មពហុជាតិអោយមកវិនិយោគទុន នៅក្នុងប្រទេសខ្លួន។ លក្ខខណ្ឌពិសេសនៃការយកពន្ធនិងបទប្បញ្ញត្តិ គឺជាវិធីសាស្ត្រទូទៅ។ ក្នុងករណីនៃការទាញឬបូមយកធនធានធម្មជាតិ ការចរចាអាចទាក់ទងនឹងអត្រាដែលរដ្ឋាភិបាលនឹងគិតថ្លៃឈ្នួលជួលដីនិងសិទ្ធិធ្វើអាជីវកម្ម។ ដល់សាជីវកម្មពហុជាតិ។ រដ្ឋាភិបាលជាតិនិងមូលដ្ឋានអាចសន្យាផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធអាជីវកម្មដូចជាផ្លូវថ្នល់ អាកាសយានដ្ឋាន ឬបណ្តាញទូរស័ព្ទ ដោយចំណាយផ្ទាល់ពីរដ្ឋាភិបាល។ (សាជីវកម្មពហុជាតិ ក៏អាចនឹងសុខចិត្តកសាងហេដ្ឋារចនាសម្ព័ន្ធបែបនេះ ដោយខ្លួនឯងផ្ទាល់ ប្រសិនបើត្រូវបានអនុញ្ញាតអោយប្រតិបត្តិការក្នុងលក្ខខណ្ឌអំណោយផលនៅក្នុងប្រទេស។ យូរៗទៅ ទីតាំងមួយចំនួនអាចអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអាជីវកម្មដ៏រឹងមាំនិងទទួលបានឧត្តមភាពជៀប ក្នុងការទាក់ទាញសាជីវកម្មពហុជាតិអោយមកបោះទីតាំងនៅទីនោះ។

បន្ថែមពីលើបញ្ហាបែងចែក(ផលចំណេញ)ដ៏សាមញ្ញទាំងនេះ ទំនាក់ទំនងសាជីវកម្មពហុជាតិជាមួយរដ្ឋាភិបាលប្រទេសម្ចាស់ផ្ទះនៅមានប្រភពផ្សេងទៀតដែលអាចបង្កជាជម្លោះ។ ប្រភពមួយក្នុងចំណោមនោះគឺ សក្តានុពលសម្រាប់រដ្ឋាភិបាលក្នុងការបំពានកិច្ចព្រមព្រៀងរបស់ខ្លួនជាមួយសាជីវកម្មពហុជាតិនិងផ្លាស់ប្តូរលក្ខខណ្ឌនៃការយកពន្ធ បទប្បញ្ញត្តិ ឬលក្ខខណ្ឌផ្សេងទៀត។ ករណីធ្ងន់ធ្ងរបំផុត គឺការធ្វើជាតូបនីយកម្មដែលរដ្ឋាភិបាលប្រទេសម្ចាស់ផ្ទះរឹបអូសទីតាំងរោងចក្រនិងទ្រព្យសម្បត្តិផ្សេងៗរបស់សាជីវកម្មពហុជាតិ នៅ

ក្នុងប្រទេសម្ចាស់ផ្ទះ មកធ្វើជាកម្មសិទ្ធិរដ្ឋ(ដោយមានឬគ្មានសំណង)។ ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ប្រទេសរុស្ស៊ី វេណេស៊ុយអេឡា បូលីវី និងអេក្វាឌ័រ សុទ្ធតែបានរឹបអូសយកទ្រព្យសម្បត្តិបរទេស នៅក្នុងវិស័យប្រេង និងឧស្ម័ននៅក្នុងប្រទេសទាំងនោះ មកកាន់កាប់ជាសម្បត្តិរដ្ឋ យ៉ាងច្រើនដែលមិនធ្លាប់មានពីមុនមក។ នៅពេលដែលសាជីវកម្មពហុជាតិមួយបានវិនិយោគលើទីតាំងរោងចក្រឬគ្រឿងបរិក្ខារជាក់លាក់ វាបាត់បង់នូវអានុភាពជាច្រើនរបស់ខ្លួនលើរដ្ឋាភិបាល ព្រោះវាមិនអាចផ្លាស់ទីតាំងទៅប្រទេសផ្សេង ដោយមិនមានការចំណាយឬខាតបង់ច្រើននោះទេ។ ទោះជាយ៉ាងណាក៏ដោយ រដ្ឋាភិបាលនានាស្ទាក់ស្ទើរក្នុងការរំលោភបំពានពាក្យសន្យារបស់ពួកគេជាមួយសាជីវកម្មពហុជាតិ ដោយសារនៅពេលនោះសាជីវកម្មពហុជាតិ ផ្សេងទៀតប្រហែលជាមិនមកវិនិយោគនាពេលអនាគត។ ជាការពិត សម្រាប់ហេតុផលនេះ ការវិនិយោគផ្ទាល់ពីបរទេសនៅប្រទេសបូលីវីបានធ្លាក់ចុះប្រហែល ៩០ ភាគរយ ពីចន្លោះឆ្នាំ ១៩៩៩ ដល់ឆ្នាំ ២០០៥។ ការធ្វើជាតូបនីយកម្មនៃទ្រព្យសម្បត្តិបរទេសកម្រកើតមានណាស់ បច្ចុប្បន្ននេះ។

ប្រភពនៃជម្លោះមួយទៀតគឺគោលនយោបាយពាណិជ្ជកម្មរបស់រដ្ឋាភិបាលប្រទេសម្ចាស់ផ្ទះ។ ការរឹតបន្តឹងរបស់រដ្ឋាភិបាលលើពាណិជ្ជកម្មកម្រជួយសាជីវកម្មពហុជាតិបរទេសណាស់។ ជាញឹកញាប់ ពួកគេជួយឧស្សាហកម្មក្នុងស្រុក ដែលជារឿយៗប្រកួតប្រជែងដោយផ្ទាល់ជាមួយសាជីវកម្មពហុជាតិបរទេស។ គួរអោយអស់សំណើចណាស់ ទោះបីជាពួកគេអនុគ្រោះដល់ពាណិជ្ជកម្មសេរីជាសាកលក៏ដោយ សាជីវកម្មពហុជាតិអាចបង្ហូរការវិនិយោគផ្ទាល់ទៅកាន់រដ្ឋដែលរឹតបន្តឹងការនាំចូល ពីព្រោះសាជីវកម្មពហុជាតិអាចគេចផុតពីការរឹតបន្តឹងការនាំចូល ដោយការផលិតទំនិញនៅក្នុងប្រទេសម្ចាស់ផ្ទះផ្ទាល់តែម្តង (ជាជាង នាំចេញពីប្រទេសកំណើត)។ ដូច្នេះ ការរឹតបន្តឹងពាណិជ្ជកម្ម គឺជាទម្រង់នៃឥទ្ធិពលមួយទៀត ដែលរដ្ឋអាចមានឬប្រើ សម្រាប់ទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស។

ជារឿយៗ បទប្បញ្ញត្តិពាណិជ្ជកម្មមានគោលដៅបង្កើតការងារ និងប្រាក់ចំណូលដែលជាប់ពន្ធអោយបានច្រើនតាមដែលអាចធ្វើទៅបាន នៅក្នុងប្រទេសម្ចាស់ផ្ទះ។ បើក្រុមហ៊ុនតូយ៉ូតាដំឡើងរថយន្តនៅរោងចក្រក្នុងសហរដ្ឋអាមេរិក (ប្រហែលជាដើម្បីជៀសវាងការរឹតបន្តឹងការនាំចូលរបស់សហរដ្ឋអាមេរិក) រដ្ឋាភិបាលសហរដ្ឋអាមេរិកមានទំនោរជាក់សម្ពាធអោយក្រុមហ៊ុនតូយ៉ូតា ប្រើប្រាស់គ្រឿងបន្លាស់របស់សហរដ្ឋអាមេរិកបន្ថែមទៀត ក្នុងការផលិតរថយន្ត (ច្បាប់ «គ្រឿងបង្គុំក្នុងស្រុក» ទាំងនេះគឺជាផ្នែកមួយនៃកិច្ចព្រមព្រៀង NAFTA)។ សាជីវកម្មពហុជាតិជាទូទៅចង់បានសេរីភាពក្នុងការតម្លើងទំនិញនៅកន្លែងណាក៏បាន ដោយប្រើគ្រឿងផ្គុំដែលផលិតពីកន្លែងណាក៏បាន។ ផ្ទុយទៅវិញ រដ្ឋាភិបាលចង់បង្កើនទំហំទ្រព្យសម្បត្តិដែលបង្កើតនៅលើទឹកដីរបស់ខ្លួនជាអតិបរមា។ ជាមួយនឹងគ្រឿងផ្គុំនិងខ្សែចង្វាក់ផ្គត់ផ្គង់ ឥឡូវនេះ មានប្រភពមកពីប្រទេសជាច្រើន សម្រាប់តម្លើងឬផ្គុំបានជាផលិតផលសម្រេចមួយ នៅក្នុងប្រទេសមួយ គេពិបាកនិយាយអោយច្បាស់ថាតើផលិតផលនេះត្រូវបានផលិតនៅឯណា។ បញ្ហានេះមានលក្ខណៈស្មុគស្មាញដែលអូសបន្លាយ ការចរចាដ៏យូរវែងសាជីវកម្មពហុជាតិនិងរដ្ឋាភិបាលប្រទេសម្ចាស់ផ្ទះ។

គោលនយោបាយរូបិយវត្ថុក៏បណ្តាលអោយមានជម្លោះរវាងសាជីវកម្មពហុជាតិនិងរដ្ឋាភិបាលប្រទេសម្ចាស់ផ្ទះផងដែរ។ នៅពេលដែលរូបិយប័ណ្ណរបស់រដ្ឋត្រូវបានទម្លាក់តម្លៃ ភ្លាមៗនោះការនាំចូលក៏កាន់តែថ្លៃ។ សាជីវកម្មពហុជាតិបរទេសដែលកំពុងលក់ផលិតផលនាំចូល (ឬផលិតផលដែលត្រូវតម្លើងដោយប្រើគ្រឿងផ្គុំនាំចូល)នៅក្នុងប្រទេសម្ចាស់ផ្ទះ អាចត្រូវរងការខូចខាតខ្លាំងដោយសារការផ្លាស់ប្តូរបែបនេះ។ ជាឧទាហរណ៍

ប្រសិនបើប្រាក់ដុល្លារធ្លាក់ចុះធៀបនឹងប្រាក់យ៉ែន ក្រុមហ៊ុនតូយ៉ូតាសាខាអាមេរិកប្រហែលជាត្រូវតម្លើងតម្លៃរថយន្តរបស់ខ្លួន(គិតជាដុល្លារ) ដើម្បីប៉ះប៉ូវថ្លៃគ្រឿងបន្លាស់ដែលនាំមកពីប្រទេសជប៉ុន។ ដូច្នេះ សាជីវកម្មពហុជាតិធ្វើការវិនិយោគរយៈពេលវែង នៅក្នុងប្រទេសម្ចាស់ផ្ទះចង់អោយរូបិយប័ណ្ណរបស់ខ្លួនមានស្ថិរភាពសមរម្យ។

ទីបំផុត សាជីវកម្មពហុជាតិអាចនឹងប៉ះទង្គិចជាមួយរដ្ឋាភិបាលប្រទេសម្ចាស់ផ្ទះ លើបញ្ហាសន្តិសុខអន្តរជាតិ ក៏ដូចជាស្ថិរភាពនយោបាយក្នុងស្រុក។ នៅពេលសាជីវកម្មពហុជាតិវិនិយោគនៅក្នុងប្រទេសមួយវាសន្មត់ថា រោងចក្រនិងគ្រឿងបរិក្ខាររបស់វានៅទីនោះនឹងដំណើរការបានផលចំណេញ ក្នុងរយៈពេលច្រើនឆ្នាំទៅមុខទៀត។ ប្រសិនបើសង្គ្រាមឬបដិវត្តន៍ដកហូតយកទីតាំងអាជីវកម្មរបស់សាជីវកម្មពហុជាតិ ក្រុមហ៊ុនមិនត្រឹមតែបាត់បង់ប្រាក់ចំណូលប៉ុណ្ណោះទេ ថែមទាំងបាត់បង់មូលធន ដែលជាអចលនទ្រព្យបង្កប់នៅក្នុងទីតាំងទាំងនោះ។ ក្នុងឆ្នាំ ២០០១ ក្រុមហ៊ុនប្រេង អ៊ីកហ្សុនម៉ូបាល (ExxonMobil) បានផ្អាកប្រតិបត្តិការនៅតំបន់ហ្គាសក្នុងខេត្តអាឆេ(Aceh)នៃប្រទេសឥណ្ឌូនេស៊ី រយៈពេល ៣ ខែ រហូតដល់រដ្ឋាភិបាលឥណ្ឌូនេស៊ីដែលរកប្រាក់បាន ១ ប៊ីលានដុល្លារ ក្នុងមួយឆ្នាំ ពីប្រតិបត្តិការនេះបាននាំយកកងកម្លាំងយោធាទៅបង្ក្រាបក្រុមឧទ្ទាមផ្តាច់ខ្លួនប្រដាប់ដោយអាវុធ ដែលបាននឹងកំពុងវាយប្រហារទីតាំងក្រុមហ៊ុន ExxonMobil។ ក្នុងឆ្នាំ ២០០៣ ក្រុមហ៊ុនប្រេងដទៃទៀត ដូចជា ក្រុមហ៊ុនChevron Texaco, ក្រុមហ៊ុនShell និង ក្រុមហ៊ុនTotal ត្រូវបិទរោងចក្រផលិតប្រេង នៅក្នុងប្រទេសនីហ្សេរីយ៉ាជាច្រើនសប្តាហ៍ ដោយសារអំពើហិង្សាជាតិសាសន៍។

ក្នុងការចរចាលើប្រភពនៃជម្លោះទាំងនេះ សាជីវកម្មពហុជាតិប្រើមធ្យោបាយជាច្រើនដើម្បីដេះឥទ្ធិពលលើរដ្ឋាភិបាលប្រទេសម្ចាស់ផ្ទះ។ ជាទូទៅ រឿងទាំងនេះ ដើរតាមគំរូដូចគ្នាដែលត្រូវបានប្រើដោយសាជីវកម្មក្នុងស្រុក។ សាជីវកម្មពហុជាតិជួលក្រុមអ្នកបញ្ចុះបញ្ចូល ប្រើប្រាស់ការផ្សាយពាណិជ្ជកម្មដើម្បីដេះឥទ្ធិពលលើមតិសាធារណៈ និងផ្តល់រង្វាន់លើកទឹកចិត្តដល់អ្នកនយោបាយប្រទេសម្ចាស់ផ្ទះ (ដូចជាការបោះទីតាំងរោងចក្រឬជំនួញនៅក្នុងមណ្ឌលបោះឆ្នោតរបស់ពួកគេជាដើម)។ សកម្មភាពបែបនេះមានលក្ខណៈនយោបាយពីព្រោះពលរដ្ឋនិងអ្នកនយោបាយប្រទេសម្ចាស់ផ្ទះអាចនឹងអន់ចិត្តចំពោះជនបរទេស ដែលព្យាយាមដាក់ឥទ្ធិពលលើពួកគេ។

អំពើពុករលួយគឺជាមធ្យោបាយមួយទៀតសម្រាប់ដាក់ឥទ្ធិពលលើរដ្ឋាភិបាលប្រទេសម្ចាស់ផ្ទះ ដែលមិនអាចមើលរំលងបាន។ គ្មាននរណាម្នាក់ដឹងច្បាស់ពីវិសាលភាពពេញលេញដែលសាជីវកម្មពហុជាតិប្រើប្រាស់ការទិញទឹកចិត្ត ប្រាក់រង្វាន់ អំណោយ និងវិធីសាស្ត្រស្រដៀងគ្នាផ្សេងទៀត ដើម្បីទទួលបានការឯកភាពពីមន្ត្រីរដ្ឋាភិបាលម្នាក់ៗ សម្រាប់គោលនយោបាយអំណោយផលដល់សាជីវកម្មពហុជាតិនោះទេ។ ប្រាកដណាស់ វាកើតឡើងជាញឹកញាប់ជាមួយរដ្ឋាភិបាលប្រទេសម្ចាស់ផ្ទះនៅអឌ្ឍគោលខាងត្បូង (ដែលមន្ត្រីរដ្ឋាភិបាលប្រហែលជាខ្នះខ្នែងចង់បានប្រាក់ចំណូលបន្ថែម) ប៉ុន្តែអំពើពុករលួយក៏កើតឡើងជាទៀងទាត់នៅក្នុងប្រទេសឧស្សាហកម្មរុងរឿងផងដែរ។

សាជីវកម្មពហុជាតិក៏មានជម្លោះជាច្រើនជាមួយរដ្ឋាភិបាលប្រទេសកំណើតរបស់ពួកគេ (កន្លែងដែលពួកគេដាក់ទីស្នាក់ការកណ្តាល) ដូចដែលពួកគេតានតឹងជាមួយរដ្ឋាភិបាលប្រទេសម្ចាស់ផ្ទះផងដែរ។ ជម្លោះសាជីវកម្មពហុជាតិជាមួយរដ្ឋាភិបាលនៃប្រទេសកំណើតខ្លះ ស្រដៀងគ្នានឹងជម្លោះជាមួយរដ្ឋាភិបាលប្រទេសម្ចាស់ផ្ទះ។ ការយកពន្ធគឺជាជម្លោះដ៏សំខាន់មួយ ចំណែកគោលនយោបាយពាណិជ្ជកម្មគឺប្រភពមួយទៀត។

ការតួញត្បែរដែលរបស់សាជីវកម្មពហុជាតិដាក់រដ្ឋាភិបាលប្រទេសកំណើត គឺថាគោលនយោបាយដែលត្រូវបានអនុម័តដើម្បីដាក់ទណ្ឌកម្មសត្រូវនយោបាយ (ទណ្ឌកម្មសេដ្ឋកិច្ច និងការរឹតត្បិតជ្រុលខ្លះ) បែរជាធ្វើអោយប៉ះពាល់សាជីវកម្មពហុជាតិក្នុងស្រុក ច្រើនជាងគោលដៅដែលបានគ្រោងទុក។ ជាធម្មតា សាជីវកម្មពហុជាតិជាគូប្រកួតប្រជែងមកពីប្រទេសដទៃអាចចូលខ្លួនបំពេញលំហរអាជីវកម្មជំនួស នៅពេលរដ្ឋាភិបាលដាក់កម្រិតលើសាជីវកម្មពហុជាតិរបស់ជាតិខ្លួន។ លុះត្រាតែពួកគេត្រូវបានហាមឃាត់មិនអោយធ្វើបែបនេះ សាជីវកម្មពហុជាតិមានទំនោរទៅធ្វើអាជីវកម្មនៅទីណាក៏ដោយអោយតែបានផលចំណេញ ដោយមិនគិតពីចំណូលចិត្តនយោបាយរបស់រដ្ឋាភិបាលពួកគេ។

ពេលខ្លះរដ្ឋាភិបាលមានជ័យជំនះលើជម្លោះ ដោយសារសាជីវកម្មពហុជាតិជារឿយៗត្រូវការការគាំទ្រពីរដ្ឋាភិបាលប្រទេសកំណើតរបស់ពួកគេ។ ក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ ក្រុមហ៊ុនប្រេងកូណូកូ (Conoco) ដែលមានមូលដ្ឋានដើមនៅសហរដ្ឋអាមេរិកបានយល់ព្រមលើគម្រោងអភិវឌ្ឍន៍ប្រេងរាប់ពាន់លានដុល្លារ នៅក្នុងប្រទេសអ៊ីរ៉ង់ នៅពេលដែលរដ្ឋាភិបាលសហរដ្ឋអាមេរិកកំពុងព្យាយាមដាក់អ៊ីរ៉ង់អោយនៅឯកា ក្នុងនាមជារដ្ឋកោងកាង។ ក្រោមសម្ពាធពីរដ្ឋាភិបាលអាមេរិក ក្រុមហ៊ុនប្រេងកូណូកូបានសម្រេចចិត្តដកខ្លួនចេញពីកិច្ចព្រមព្រៀងនោះយ៉ាងឆាប់រហ័ស។ ការដើរក្រឡាបែបនេះបានជួយសង្គ្រោះក្រុមហ៊ុនកូណូកូមិនអោយមានជម្លោះជាមួយរដ្ឋាភិបាលប្រទេសកំណើតរបស់ខ្លួន ប៉ុន្តែវាធ្វើអោយក្រុមហ៊ុនកូណូកូបាត់បង់នូវកិច្ចព្រៀមព្រៀងដែលអាចរកប្រាក់ចំណេញបានច្រើន ហើយត្រូវធ្លាក់ក្នុងដៃក្រុមហ៊ុនអឺរ៉ុបវិញ។

រូបថត ក្មេងស្រីទូលផ្លែកាកាវលក់

កុមារនៅពីក្រោយសូកូឡា

ធុរកិច្ចអន្តរជាតិរីកចម្រើនក្នុងបរិយាកាសនយោបាយស្ថិរភាព ក្នុងប្រទេសម្ចាស់ផ្ទះ ប៉ុន្តែ ទំនាក់ទំនងរវាងប្រទេសម្ចាស់ផ្ទះនិងសាជីវកម្មពហុជាតិដែលកំពុងវិនិយោគ អាចមានលក្ខណៈស្មុគស្មាញ។ វិនិយោគិនបរទេសមានការប្រុងប្រយ័ត្នចំពោះការដាក់ប្រាក់វិនិយោគ ទៅក្នុងបរិយាកាសធុរកិច្ច ដែលពោរពេញដោយអតិផរណា ឧក្រិដ្ឋកម្ម អំពើពុករលួយ និងជាពិសេសអំពើហិង្សាប្រដាប់អាវុធ ដែលអាចប៉ះពាល់ដល់គ្រឿងបរិក្ខារនិងបុគ្គលិករបស់ពួកគេ។ ប្រទេសម្ចាស់ផ្ទះនិងអង្គការមិនមែនរដ្ឋាភិបាល (NGOs) មានការព្រួយបារម្ភថា សាជីវកម្មពហុជាតិអាចនឹងប្រព្រឹត្តការរំលោភបំពានការងារ។ ឧស្សាហកម្មកាកាវពិភពលោកគឺជាវិស័យមួយដែលពឹងផ្អែកលើពលកម្មកុមារនៅក្នុងប្រទេសជាច្រើន។ នៅទីនេះ ក្មេងស្រីវ័យក្មេងទូលកញ្ច្រែងលក់ផ្លែកាកាវ នៅឥណ្ឌូនេស៊ី ឆ្នាំ ២០១០។

ទីតាំងនៃទីស្នាក់ការកណ្តាលរបស់សាជីវកម្មពហុជាតិមួយកំណត់សញ្ជាតិដើមរបស់វា។ ភាគទុនិក (ម្ចាស់ភាគហ៊ុន) និងនាយកប្រតិបត្តិកំពូលនៃសាជីវកម្មពហុជាតិភាគច្រើនមកពីប្រទេសកំណើតរបស់ខ្លួន។ ប៉ុន្តែនៅពេលដែលសេដ្ឋកិច្ចពិភពលោកកាន់តែត្រូវបានធ្វើសមាហរណកម្ម ទំនោរនេះហាក់មិនសូវកើតមានទេ។ ក៏ដូចដែលសាជីវកម្មពហុជាតិកំពុងធ្វើអាជីវកម្មកាន់តែខ្លាំងឡើងនៅទូទាំងពិភពលោក និងកំពុងតម្លើងផលិតផលដោយប្រើគ្រឿងផ្គុំ ដែលផលិតក្នុងប្រទេសផ្សេងគ្នាជាច្រើន ដូច្នេះម្ចាស់ភាគហ៊ុន និងអ្នកគ្រប់គ្រងក្លាយជាសមាជិកអន្តរជាតិកាន់តែច្រើនដែរ។

សកម្មភាពអាជីវកម្មទាំងអស់ប្រព្រឹត្តិទៅនៅក្នុងបរិយាកាស ដែលទទួលឥទ្ធិពលពីផ្នែកនយោបាយ។ បរិយាកាសធុរកិច្ចអន្តរជាតិ ដែលអំណោយផលបំផុតដល់ការបង្កើតទ្រព្យសម្បត្តិដោយសាជីវកម្មពហុជាតិ គឺ

ជាបរិយាកាសសន្តិសុខអន្តរជាតិពោរពេញដោយស្ថេរភាព។ វាពិបាកណាស់ហើយថែមទាំងមានហានិភ័យខ្ពស់ក្នុងការរកប្រាក់ក្នុងស្ថានភាពជម្លោះអន្តរជាតិ ជាពិសេសក្នុងស្ថានភាពដែលក្លាយទៅជាអំពើហិង្សានិងសង្គ្រាម។ សង្គ្រាមបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ កាត់បន្ថយការផ្គត់ផ្គង់កម្លាំងពលកម្ម និងបង្ខូចដំណើរការទីផ្សារតាមរូបភាពផ្សេងៗ។ ប្រាកដណាស់ អាជីវកម្មមួយចំនួនទទួលបានផលចំណេញពីអស្ថិរភាពអន្តរជាតិ និងការគំរាមកំហែងនៃសង្គ្រាម ដូចជាឈ្មួញសព្វាវុធនិងអ្នករត់ពន្ធ ប៉ុន្តែទាំងនេះគឺជាករណីលើកលែង។

លើសពីកង្វល់សន្តិសុខអន្តរជាតិទាំងនេះ សាជីវកម្មពហុជាតិពេញចិត្តនឹងស្ថិរភាពនយោបាយ នៅក្នុងបទបញ្ញត្តិទូលំទូលាយសម្រាប់ គ្រប់គ្រងអាជីវកម្មអន្តរជាតិ។ នៅក្នុងគោលនយោបាយរូបិយវត្ថុ អាជីវកម្មអន្តរជាតិទទួលបានអត្ថប្រយោជន៍ពីស្ថេរភាពនៃអត្រាប្តូរប្រាក់ ដែលប្រព័ន្ធប្តូរប្រាក់អណ្តែតមានដែនកំណត់ព្យាយាមសម្រេចអោយបាន។ នៅក្នុងគោលនយោបាយពាណិជ្ជកម្ម អាជីវកម្មទទួលបានអត្ថប្រយោជន៍ពីស្ថិរភាពនៃកម្រិតពន្ធគយនៅក្នុងក្របខ័ណ្ឌអង្គការWTOដែលប្រែប្រួលយឺតៗ។ តាមបទដ្ឋានច្បាប់អន្តរជាតិ អាជីវកម្មទទួលបានអត្ថប្រយោជន៍ពីប្រពៃណី ដែលតម្រូវអោយរដ្ឋាភិបាលក្រោយៗទទួលខុសត្រូវចំពោះបំណុលរបស់រដ្ឋាភិបាលមុនៗរបស់ពួកគេ និងទាមទារសំណងសម្រាប់ទ្រព្យសម្បត្តិបរទេសដែលត្រូវបានធ្វើជាតូបនីយកម្ម។

ជួនកាល សាជីវកម្មពហុជាតិអាចអោយរដ្ឋាភិបាលប្រទេសកំណើតរបស់ពួកគេផ្តល់សន្តិសុខ នៅពេលដែលរដ្ឋាភិបាលប្រទេសម្ចាស់ផ្ទះបរាជ័យក្នុងការធ្វើដូច្នេះ។ អ្នកប្រាជ្ញទំនាក់ទំនងអន្តរជាតិ បន្តសិក្សាពីទំនាក់ទំនងរវាងសកម្មភាពសេដ្ឋកិច្ចអន្តរជាតិរបស់សាជីវកម្មពហុជាតិ និងសកម្មភាពសន្តិសុខអន្តរជាតិរបស់រដ្ឋាភិបាលប្រទេសកំណើតរបស់ពួកគេ។

សម្ព័ន្ធភាពសាជីវកម្មដែលពាក់ព័ន្ធនឹងសាជីវកម្មពហុជាតិ ជារឿយៗ ជះផលប៉ះពាល់ជាលក្ខណៈអន្តរជាតិ។ នៅពេលដែលសម្ព័ន្ធភាពធុរកិច្ច នៅក្នុងវិស័យឧស្សាហកម្មណាមួយ ដែលមានទីផ្សារអន្តរជាតិចងក្រងឡើងនៅក្នុងរដ្ឋមួយ សម្ព័ន្ធភាពទាំងនោះអាចមានឥទ្ធិពលជំរុញជាតិនិយមសេដ្ឋកិច្ច។ ទោះជាយ៉ាងណាក៏ដោយ សម្ព័ន្ធភាពសាជីវកម្មកំពុងត្រូវបានចងក្រងឡើង ឆ្លងកាត់ព្រំដែនជាតិ។ សម្ព័ន្ធភាពបែបនេះមាននិន្នាការលើកកម្ពស់លទ្ធិសេរីនិយម ជាជាងជាតិនិយមសេដ្ឋកិច្ច។

សម្ព័ន្ធភាពធុរកិច្ចអន្តរជាតិទាំងនេះបន្សាបទាំងជាតិនិយមសេដ្ឋកិច្ច និងទាំងគោលគំនិតដែលចែងថាពិភពលោកត្រូវបំបែកជាប្លុកពាណិជ្ជកម្មដែលប្រកួតប្រជែងនឹងគ្នា ដោយប្លុកមួយមានមូលដ្ឋាននៅអឺរ៉ុប មួយទៀតអាមេរិកខាងជើង និងមួយទៀតអាស៊ីបូព៌ា។ តាមពិតទៅ សម្ព័ន្ធភាពធុរកិច្ចអន្តរជាតិបង្កើតនិន្នាការពឹងពាក់គ្នាទៅវិញទៅមកក្នុងចំណោមរដ្ឋនៃប្រទេសកំណើតរបស់ពួកគេ។ ផលប្រយោជន៍ជាតិកាន់តែត្រូវត្បាញចូលគ្នា ហើយជម្លោះរវាងរដ្ឋទំនងត្រូវបានកាត់បន្ថយ។ ដោយប្រតិបត្តិការក្នុងប្រទេសច្រើន ក្នុងពេលតែមួយ សាជីវកម្មពហុជាតិទាំងអស់មានឥទ្ធិពលបែបនេះ នៅក្នុងកម្រិតណាមួយ។ ប៉ុន្តែ ដោយសារតែពួកគេមានមូលដ្ឋាននៅក្នុងប្រទេសកំណើតតែមួយ សាជីវកម្មពហុជាតិគឺជាជនបរទេស នៅក្នុងប្រទេសផ្សេងទៀត។ ទោះយ៉ាងណាក៏ដោយ សម្ព័ន្ធអន្តរជាតិនៃសាជីវកម្មពហុជាតិ ស្ថិតក្នុងនៅរដ្ឋកំណើត ក្នុងប្រទេសជាច្រើនក្នុងពេលតែមួយ។

យើងមិនទាន់រស់នៅក្នុងពិភពលោកដែលគ្មានព្រំដែនជាតិ មិនមែនក្នុងអនាគតឆាប់ៗនោះទេ ប៉ុន្តែសកម្មភាពអន្តរជាតិរបស់សាជីវកម្មពហុជាតិកំពុងជំរុញយើងទៅក្នុងទិសដៅនោះ។ មេរៀនទី ១០ ស្វែងយល់ពីវិធីសាស្ត្រមួយចំនួនដែលមនុស្ស ក្រុមហ៊ុន និងគំនិតត្រូវបានធ្វើសមាហរណកម្មជាសកល រវាងរដ្ឋនានា។

សេចក្តីសង្ខេប

១. រដ្ឋនីមួយៗប្រើប្រាស់រូបិយប័ណ្ណរបស់ខ្លួនផ្ទាល់(លើកលែងតែរដ្ឋចំនួន ១៩ ដែលចាយប្រាក់អឺរ៉ូរួមគ្នា)។ រូបិយប័ណ្ណទាំងនេះមិនមានតម្លៃផ្ទាល់ពីកំណើត(ដូចមាស)ទេ ប៉ុន្តែ អាស្រ័យលើជំនឿជាក់ថា គេអាចយកវាទៅជួញដូរយកទំនិញនិងសេវាកម្មដទៃ នាពេលអនាគត។

២. រ៉ែមាសនិងប្រាក់ធ្លាប់ត្រូវបានប្រើប្រាស់ជារូបិយប័ណ្ណពិភពលោក ដែលមានតម្លៃនៅក្នុងប្រទេសផ្សេងៗ។ ប្រព័ន្ធបច្ចុប្បន្ននេះមានលក្ខណៈអរូបីជាងមុន៖ រូបិយប័ណ្ណជាតិត្រូវបានផ្តល់តម្លៃធៀបគ្នាទៅវិញទៅមកតាមរយៈអត្រាប្តូរប្រាក់។

៣. រូបិយប័ណ្ណសំខាន់ៗបំផុត ដែលរូបិយប័ណ្ណរបស់រដ្ឋផ្សេងទៀតភាគច្រើនត្រូវប្រៀបធៀបតម្លៃនិងចង់ប្តូរយក រួមមានប្រាក់ដុល្លារអាមេរិក ប្រាក់អឺរ៉ូ និងប្រាក់យ៉ែនជប៉ុន។

៤. អតិផរណា ដែលភាគច្រើនបណ្តាលមកពីការបោះពុម្ពរូបិយប័ណ្ណលឿនជាងការផលិតទំនិញ និងបង្កើតសេវាកម្មថ្មី បណ្តាលអោយតម្លៃរូបិយប័ណ្ណធ្លាក់ចុះ ធៀបនឹងរូបិយប័ណ្ណផ្សេងទៀត។ អត្រាអតិផរណាប្រែប្រួលយ៉ាងទូលំទូលាយ ប៉ុន្តែ ជាទូទៅ មានកម្រិតខ្ពស់ជាងនៅក្នុងអឌ្ឍគោលខាងត្បូង និងអតីតប្លុកសហភាពសូវៀត ជាងនៅប្រទេសឧស្សាហកម្មបស្ចឹមលោក។

៥. រដ្ឋនានារក្សាទុនបម្រុងជារូបិយប័ណ្ណខ្លាំងនិងមាស។ ទុនបម្រុងទាំងនេះគាំទ្ររូបិយប័ណ្ណជាតិ និងបំពេញអតុល្យភាពលំហូរហិរញ្ញវត្ថុអន្តរជាតិនៅក្នុងរយៈពេលខ្លី។

៦. អត្រាប្តូរប្រាក់ថេរអាចត្រូវបានប្រើដើម្បីកំណត់តម្លៃធៀបនៃរូបិយប័ណ្ណនានា ប៉ុន្តែ ជាញឹកញាប់បំផុត រដ្ឋប្រើប្រាស់អត្រាប្តូរប្រាក់អណ្តែត ដែលត្រូវជំរុញដោយការផ្គត់ផ្គង់និងតម្រូវការនៅលើទីផ្សាររូបិយប័ណ្ណពិភពលោក។

៧. រដ្ឋាភិបាលនានាសហការគ្នាដើម្បីគ្រប់គ្រងការប្រែប្រួលនៃអត្រាប្តូរប្រាក់(អណ្តែត) ប៉ុន្តែត្រូវបានកំណត់ក្នុងកិច្ចខិតខំប្រឹងប្រែងនេះ ដោយសារប្រាក់ភាគច្រើនដែលជួញដូរលើទីផ្សារពិភពលោកគឺជាកម្មសិទ្ធិឯកជន។

៨. ក្នុងរយៈពេលវែង តម្លៃធៀបនៃរូបិយប័ណ្ណជាតិត្រូវបានកំណត់ ដោយសុខភាពមូលដ្ឋាននៃសេដ្ឋកិច្ចជាតិ និងដោយគោលនយោបាយរូបិយវត្ថុរបស់រដ្ឋាភិបាល (ចំនួនក្រដាសប្រាក់ដែលពួកគេបោះពុម្ព)។

៩. ជារឿយៗ រដ្ឋាភិបាលចង់អោយរូបិយប័ណ្ណរបស់ខ្លួនមានតម្លៃទាប(ខ្សោយ) ព្រោះវាជំរុញការនាំចេញ បង្អាក់ការនាំចូល ដូច្នេះហើយធ្វើអោយប្រសើរឡើងនូវតុល្យភាពពាណិជ្ជកម្មរបស់រដ្ឋ។ ទោះជាយ៉ាងណាក៏ដោយ ការទម្លាក់តម្លៃរូបិយប័ណ្ណជាឯកតោភាគីភ្លាមៗគឺជាយុទ្ធសាស្ត្រប្រថុយប្រថាន ព្រោះវាធ្វើអោយប៉ះពាល់ដល់ទំនុកចិត្តលើរូបិយប័ណ្ណ។

១០. ដើម្បីជានាបាននូវិន័យក្នុងការបោះពុម្ពប្រាក់ (និងដើម្បីបញ្ចៀសអតិផរណា) រដ្ឋឧស្សាហ៍កម្មផ្ទេរកិច្ចការគោលនយោបាយរូបិយវត្ថុទៅអោយធនាគារកណ្តាលដែលមានស្វ័យភាពខ្ពស់កណ្តាល ដូចជា

Federal Reserve របស់សហរដ្ឋអាមេរិកជាដើម។ ដោយការកែសម្រួលអត្រាការប្រាក់ដែលរដ្ឋាភិបាលអោយធនាគារឯកជនខ្ចី ធនាគារកណ្តាលអាចគ្រប់គ្រងការផ្គត់ផ្គង់លុយក្នុងសេដ្ឋកិច្ចជាតិ។

១១. ធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិ(IMF) ធ្វើការជាមួយធនាគារកណ្តាលរបស់រដ្ឋ ដើម្បីរក្សាទំនាក់ទំនងរូបិយវត្ថុអន្តរជាតិប្រកបដោយស្ថិរភាព។ ពីឆ្នាំ ១៩៤៥ ដល់ឆ្នាំ ១៩៧១ ទំនាក់ទំនងនេះត្រូវបានធ្វើឡើង ដោយការប្តូររូបិយប័ណ្ណរដ្ឋទៅជាប្រាក់ដុល្លារអាមេរិក ហើយប្តូរប្រាក់ដុល្លារទៅជាមាស។ ចាប់តាំងពីឆ្នាំ ១៩៧១ ប្រព័ន្ធនេះបានប្រើប្រាស់*សិទ្ធិដកពិសេស*(SDRs) ដែលជាប្រភេទរូបិយប័ណ្ណពិភពលោក ដែលគ្រប់គ្រងដោយ មូលនិធិIMF ជំនួសមាស។

១២. មូលនិធិរូបិយវត្ថុអន្តរជាតិ(IMF)ដំណើរការប្រព័ន្ធគណនីជាតិ ដើម្បីតាមដានលំហូរប្រាក់ចូលក្នុង និងចេញក្រៅរដ្ឋនីមួយៗ។ ដញ្ជីងពាណិជ្ជកម្ម (ការនាំចេញដកការនាំចូល) ត្រូវតែប្តឹងអោយមានតុល្យភាព ដោយលំហូរមូលធន(ការវិនិយោគនិងប្រាក់កម្ចី) និងបម្រែបម្រួលទុនបម្រុង។

១៣. បំណុលអន្តរជាតិកើតឡើងដោយសារអតុល្យភាពនៃលំហូរមូលធនដែលអូសបន្លាយយូរ (រដ្ឋមួយសុំខ្ចីប្រាក់ច្រើនជាងអោយគេខ្ចី) ដើម្បីទូទាត់ឱនភាពពាណិជ្ជកម្មរ៉ាំរ៉ៃ ឬឱនភាពថវិការបស់រដ្ឋាភិបាល។

១៤. ជំហរហិរញ្ញវត្ថុសហរដ្ឋអាមេរិកបានធ្លាក់ចុះដោយធម្មជាតិ ពីកម្រិតលេចធ្លោមិនធម្មតា តាំងពីចប់សង្គ្រាមលោកលើកទីពីរភ្លាមៗ។ ការធ្លាក់ចុះនៃស្តង់ដារប្រាក់ដុល្លារ-មាស ក្នុងឆ្នាំ១៩៧១ បង្ហាញពីការធ្លាក់ចុះនេះ។

១៥. ជំហររបស់រុស្ស៊ីនិងរដ្ឋផ្សេងទៀតនៃអតីតប្លុកសូវៀតបានធ្លាក់ចុះយ៉ាងខ្លាំង នៅពេលដែលពួកគេបានឆ្លងកាត់សម័យអន្តរកាលដ៏លំបាក ពីរបបកុម្មុយនីស្ត៍ទៅជារបបមូលធននិយម។ បើទោះបីជាអតិផរណាដូចខ្លែងដាច់ខ្សែនៅដើមទសវត្សរ៍ឆ្នាំ ១៩៩០ បានធ្លាក់ចុះក៏ដោយ សេដ្ឋកិច្ចនៃអតីតសាធារណរដ្ឋសូវៀតនៅតែមិនត្រូវបានធ្វើសមាហរណ៍កម្មទាំងស្រុងចូលទៅក្នុងសេដ្ឋកិច្ចពិភពលោកឡើយ។

១៦. សាជីវកម្មពហុជាតិ (MNCs) ធ្វើអាជីវកម្មនៅក្នុងរដ្ឋច្រើនជាងមួយ ក្នុងពេលដំណាលគ្នា។ បណ្តា MNCsធំបំផុតស្ថិតនៅក្នុងរដ្ឋឧស្សាហកម្មឈានមុខគេ ហើយភាគច្រើនជាកម្មសិទ្ធិឯកជន។ MNCs កាន់តែមានឥទ្ធិពលនៅក្នុងកិច្ចការសេដ្ឋកិច្ចអន្តរជាតិ។

១៧. សាជីវកម្មពហុជាតិរួមចំណែកដល់វប្បធម៌ពឹងពាក់គ្នាទៅវិញទៅមកជាអន្តរជាតិ តាមវិធីផ្សេងៗ។ រដ្ឋពឹងផ្អែកលើMNCs ដើម្បីបង្កើតទ្រព្យសម្បត្តិថ្មី ចំណែកMNCsពឹងផ្អែកលើរដ្ឋដើម្បីរក្សាស្ថិរភាពអន្តរជាតិដែលអំណោយផលដល់ការធ្វើអាជីវកម្មជាសកល។

១៨. សាជីវកម្មពហុជាតិព្យាយាមចរចាលក្ខខណ្ឌអំណោយផលល្អ ហើយព្យាយាមស្វែងរករដ្ឋដែលមានរូបិយប័ណ្ណនិងបរិយាកាសនយោបាយស្ថិរភាពដើម្បីធ្វើការវិនិយោគដោយផ្ទាល់។ រដ្ឋាភិបាលស្វែងរកការវិនិយោគបរទេសបែបនេះនៅលើទឹកដីរបស់ពួកគេ ដើម្បីទទួលបានអត្ថប្រយោជន៍ពីលំហូរប្រាក់ចំណូលនាពេលអនាគត។

១៩. សាជីវកម្មពហុជាតិព្យាយាមបញ្ជ្រាបឥទ្ធិពលលើគោលនយោបាយនៃនយោបាយអន្តរជាតិ របស់រដ្ឋប្រទេសកំណើត(ទីស្នាក់ការកណ្តាល)និងរដ្ឋផ្សេងទៀតដែលពួកគេប្រតិបត្តិការ។ ជាទូទៅ សាជីវកម្មពហុជាតិលើកកម្ពស់គោលនយោបាយដែលអំណោយផលដល់អាជីវកម្ម ដូចជាពន្ធទាប បទប្បញ្ញត្តិ

ស្រាលៗ រូបិយប័ណ្ណមានស្ថេរភាព និងពាណិជ្ជកម្មសេរី។ ពួកគេក៏គាំទ្រទំនាក់ទំនងសន្តិសុខអន្តរជាតិដែលមានស្ថេរភាពផងដែរ ពីព្រោះសង្គ្រាមជាទូទៅរំខានដល់អាជីវកម្ម។

២០. កាន់តែខ្លាំងឡើង សាជីវកម្មពហុជាតិដែលមានទីស្នាក់ការកណ្តាលនៅក្នុងរដ្ឋផ្សេងៗគ្នាកំពុងបង្កើតសម្ព័ន្ធភាពអន្តរជាតិរួមគ្នា។ សម្ព័ន្ធភាពអន្តរសាជីវកម្មពហុជាតិទាំងនេះ (រហូតច្រើនជាង សាជីវកម្មពហុជាតិផ្សេងទៀតប្រតិបត្តិការឆ្លងកាត់ព្រំដែនជាតិ) កំពុងបង្កើតការពឹងពាក់គ្នាទៅវិញទៅមក និងលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិសេរី។

ពាក្យគន្លឹះ

១. ស្តង់ដារមាស (gold standard) គឺជាប្រព័ន្ធមួយនៅក្នុងទំនាក់ទំនងរូបិយវត្ថុអន្តរជាតិដែលលេចធ្លោអស់រយៈពេលមួយសតវត្សរ៍មុនទសវត្សឆ្នាំ ១៩៧០ ដែលតម្លៃរូបិយប័ណ្ណជាតិមួយត្រូវផ្សារភ្ជាប់ជាមួយតម្លៃមាស ឬលោហៈមានតម្លៃផ្សេងទៀត។

២. អត្រាប្តូរប្រាក់ (exchange rate) គឺជាអត្រាដែលរូបិយប័ណ្ណរបស់រដ្ឋមួយអាចត្រូវបានប្តូរយករូបិយប័ណ្ណរបស់រដ្ឋមួយទៀត។ ចាប់តាំងពីឆ្នាំ ១៩៧៣ មកប្រព័ន្ធរូបិយវត្ថុអន្តរជាតិពឹងផ្អែកជាសំខាន់លើអត្រាប្តូរប្រាក់អណ្តែត ជាជាងអត្រាប្តូរប្រាក់ថេរ។ សូមមើល *រូបិយប័ណ្ណដែលអាចប្តូរយករូបិយប័ណ្ណផ្សេងបាន, អត្រាប្តូរប្រាក់ថេរ* និង*អត្រាប្តូរប្រាក់អណ្តែតមានដែនកំណត់* ផងដែរ។

៣. រូបិយប័ណ្ណដែលអាចប្តូរយករូបិយប័ណ្ណផ្សេងបាន (convertible currency) គឺជាការធានាថា អ្នកកាន់រូបិយប័ណ្ណជាក់លាក់ណាមួយអាចប្តូរវា យករូបិយប័ណ្ណផ្សេងទៀត។ រូបិយប័ណ្ណរបស់រដ្ឋមួយចំនួនមិនអាចប្តូរបានទេ។ សូមមើល *រូបិយប័ណ្ណខ្លាំង* ផងដែរ។

៤. អតិផរណាស្រួចស្រាល (hyperinflation) គឺជាការឡើងថ្លៃយ៉ាងឆាប់រហ័សនិងមិនមានការត្រួតពិនិត្យទាន់ពេល ដូចដែលបានកើតឡើងនៅប្រទេសអាឡឺម៉ង់ក្នុងទសវត្សរ៍ឆ្នាំ ១៩២០ និងបណ្តាប្រទេសតតិយលោកមួយចំនួន នាពេលថ្មីៗនេះ។

៥. រូបិយប័ណ្ណខ្លាំង (hard currency) គឺជាលុយដែលអាចប្តូរយករូបិយប័ណ្ណសំខាន់ៗលើពិភពលោកបានភ្លាមៗ។

៦. ប្រាក់បំរុង (reserves) គឺជាឃ្លាំងស្តុករូបិយប័ណ្ណខ្លាំង ដែលរក្សាទុកដោយរដ្ឋនានា។

៧. អត្រាប្តូរប្រាក់ថេរ (fixed exchange rates) គឺជាអត្រាប្តូរប្រាក់ជាផ្លូវការដែលកំណត់ដោយរដ្ឋាភិបាល។ វាមិនមែនជាយន្តការពេញនិយមនៅក្នុងប្រព័ន្ធរូបិយវត្ថុអន្តរជាតិ ចាប់តាំងពីឆ្នាំ ១៩៧៣។
ចូរពិចារណាឧទាហរណ៍ខាងក្រោម ហើយឆ្លើយសំណួរថាតើពេលរូបិយប័ណ្ណមួយចុះថោក វាជួយជម្រុញឬបង្អាក់ការនាំចេញ?

   ០. ១$ => ៣៥០០រ, បើស្រូវ១គីឡូ= ១០០០រ, ១ម៉ឺនដុល្លារ ទិញបានស្រូវ ៣៥ តោន

   ១. ១$ => ៤០០០រ, បើស្រូវ១គីឡូ= ១០០០រ, ១ម៉ឺនដុល្លារ ទិញបានស្រូវ ៤០ តោន

   ២. ១$ => ៤៥០០រ, បើស្រូវ១គីឡូ= ១០០០រ, ១ម៉ឺនដុល្លារ ទិញបានស្រូវ ៤៥ តោន

៨. អត្រាប្តូរប្រាក់អណ្តែត (floating exchange rates) គឺជាអត្រាប្តូរប្រាក់ដែលកំណត់ដោយទីផ្សាររូបិយប័ណ្ណសកល ដែលវិនិយោគិនឯកជននិងរដ្ឋាភិបាលនានាទិញនិងលក់រូបិយប័ណ្ណ។

៩. អត្រាប្តូរប្រាក់អណ្តែតក្នុងដែនកំណត់ (managed float) គឺជាប្រព័ន្ធដែលរដ្ឋាភិបាលពហុជាតិធ្វើអន្តរាគមន៍ម្តងម្កាលនៅក្នុងទីផ្សាររូបិយប័ណ្ណ ដើម្បីគ្រប់គ្រងអត្រារូបិយប័ណ្ណអណ្តែតតាមចិត្ត។

១០. ការបញ្ចុះតម្លៃរូបិយប័ណ្ណ(devaluation) គឺជាដំហានជាឯកតោភាគីដើម្បីកាត់បន្ថយតម្លៃរូបិយប័ណ្ណដោយការផ្លាស់ប្តូរអត្រាប្តូរប្រាក់ថេរឬផ្លូវការ។

១១. ធនាគារកណ្តាល (central bank) គឺជាស្ថាប័នទូទៅនៅក្នុងប្រទេសឧស្សាហកម្ម ដែលមានភារកិច្ចចម្បងក្នុងការរក្សាតម្លៃរូបិយប័ណ្ណរបស់រដ្ឋនិងគ្រប់គ្រងអតិផរណា។

១២. អត្រាបញ្ចុះតម្លៃ (discount rate) គឺជាអត្រាការប្រាក់ដែលរដ្ឋាភិបាលគិតលើប្រាក់កម្ចីដែលខ្លួនផ្តល់អោយធនាគារឯកជន។ អត្រាបញ្ចុះតម្លៃត្រូវបានកំណត់ដោយធនាគារកណ្តាលរបស់ប្រទេស។

១៣. ប្រព័ន្ធប្រ៊ីតុនវូដ(Bretton Woods system)គឺជាការរៀបចំសេដ្ឋកិច្ចក្រោយសង្គ្រាមលោកលើកទី ២ សម្រាប់ការគ្រប់គ្រងសេដ្ឋកិច្ចពិភពលោក ដែលត្រូវបង្កើតឡើងនៅក្នុងកិច្ចប្រជុំមួយនៅទីក្រុងប្រ៊ីតុនវូដ (Bretton Woods) រដ្ឋ New Hampshire ក្នុងឆ្នាំ១៩៤៤។ សមាសធាតុស្ថាប័នសំខាន់ៗរបស់វារួមមានធនាគារពិភពលោក និង មូលនិធិរូបិយវត្ថុអន្តរជាតិ(IMF)។

១៤. ធនាគារពិភពលោក (World Bank) ជាផ្លូវការមានឈ្មោះថា ធនាគារអន្តរជាតិសម្រាប់ការកសាងឡើងវិញនិងអភិវឌ្ឍន៍ (IBRD) ដែលជាអង្គការមួយត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៤៤ សម្រាប់ជាប្រភពនៃប្រាក់កម្ចីដើម្បីជួយកសាងសេដ្ឋកិច្ចអឺរ៉ុបឡើងវិញ។ ក្រោយមក អ្នកខ្ចីធំៗជាប្រទេសតតិយលោក ហើយនៅទសវត្សរ៍ឆ្នាំ ១៩៩០ បើកទូលាយដល់អឺរ៉ុបខាងកើត។

១៥. មូលនិធិរូបិយវត្ថុអន្តរជាតិ (International Monetary Fund) គឺជាអង្គការអន្តររដ្ឋាភិបាល (IGO) ដែលសម្របសម្រួលការផ្លាស់ប្តូររូបិយប័ណ្ណអន្តរជាតិ ជញ្ជីងទូទាត់អន្តរជាតិ និងគណនីជាតិ។ រួមជាមួយធនាគារពិភពលោក វាគឺជាសសរស្តម្ភនៃប្រព័ន្ធហិរញ្ញវត្ថុអន្តរជាតិ។ សូមមើល *លក្ខខណ្ឌរបស់មូលនិធិ IMF* ផងដែរ។

១៦. សិទ្ធិដកពិសេស (Special Drawing Right) គឺជារូបិយប័ណ្ណពិភពលោកដែលបង្កើតឡើងដោយមូលនិធិរូបិយវត្ថុអន្តរជាតិ(IMF)ដើម្បីជាស្តង់ដារពិភពលោក ជំនួសមាស។ ដោយត្រូវអោយតម្លៃដោយ«កន្ត្រក»នៃរូបិយប័ណ្ណជាតិ «SDR»ត្រូវបានគេហៅថា «មាសក្រដាស»។

១៧. ជញ្ជីងទូទាត់ (balance of payments) គឺជាសេចក្តីសង្ខេបនៃលំហូរលុយចូលក្នុងនិងចេញក្រៅប្រទេសណាមួយ។ វារួមបញ្ចូលប្រតិបត្តិការអន្តរជាតិបីប្រភេទ៖ គណនីចរន្ត (រួមទាំងជញ្ជីងពាណិជ្ជកម្មទំនិញ) លំហូរមូលធន និងបម្រែបម្រួលទុនបម្រុង។

១៨. វិធានការណ៍ត្បិតត្បៀត (austerity measures) គឺជាគោលនយោបាយរដ្ឋាភិបាលដែលកាត់បន្ថយខ្លាំងលើការចំណាយរបស់រដ្ឋាភិបាល ឬតម្លើងពន្ធ (ឬទាំងពីរតែម្តង)។ គោលនយោបាយទាំងនេះត្រូវបានអនុម័ត្តដើម្បីកាត់បន្ថយឱនភាពថវិការដ្ឋាភិបាល ជាធម្មតា ដើម្បីសងបំណុល។

១៩. សេដ្ឋកិច្ចយិនហ្សៀន (Keynesian economics) គឺជាគោលការណ៍ដែលបង្កើតឡើងដោយសេដ្ឋវិទូជនជាតិអង់គ្លេស លោក John Maynard Keynes ហើយត្រូវបានប្រើដោយជោគជ័យ នៅក្នុងមហាវិបត្តិសេដ្ឋកិច្ច កាលពីទសវត្សរ៍ឆ្នាំ ១៩៣០ និងរួមទាំងទស្សនៈដែលថា ពេលខ្លះ រដ្ឋាភិបាលគួរតែប្រើការចំណាយឱនភាពដើម្បីជំរុញកំណើនសេដ្ឋកិច្ច។

២០. គោលនយោបាយសារពើពន្ធ(fiscal policy) គឺជាការសម្រេចចិត្តរបស់រដ្ឋាភិបាលអំពីការចំណាយ និងការបង់ពន្ធ និងជាឧបករណ៍ដ៏សំខាន់មួយ ក្នុងចំណោមឧបករណ៍សំខាន់ៗពីរនៃការបង្កើតគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច (មួយទៀត គឺគោលនយោបាយរូបិយវត្ថុ)។

២១. គោលនយោបាយរូបិយវត្ថុ(monetary policy) គឺជាការសម្រេចចិត្តរបស់រដ្ឋាភិបាលអំពីការបោះពុម្ព និងចរាចរប្រាក់ និងជាឧបករណ៍សំខាន់មួយ ក្នុងចំណោមឧបករណ៍សំខាន់ពីរនៃការបង្កើតគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច (មួយទៀត គឺគោលនយោបាយសារពើពន្ធ)។

២២. បំណុលជាតិ គឺជាចំនួនទឹកប្រាក់ដែលរដ្ឋាភិបាលជំពាក់បំណុល ដែលជាលទ្ធផលនៃការចំណាយឱនភាពរបស់ជាតិ។

២៣. សាជីវកម្មពហុជាតិ(multinational corporations) គឺជាក្រុមហ៊ុនដែលមានមូលដ្ឋាននៅក្នុងរដ្ឋមួយ រួមជាមួយនិងសាខាឬអនុសាខាឬក្រុមហ៊ុនបុត្រសម្ព័ន្ធដែលប្រតិបត្តិការនៅក្នុងរដ្ឋផ្សេងទៀត។ សូមមើល *ប្រទេសកំណើត* និង *ប្រទេសម្ចាស់ផ្ទះ* ផងដែរ។

២៤. ការវិនិយោគផ្ទាល់ពីបរទេស(foreign direct investment)គឺជាការដែលអ្នករស់នៅក្នុងប្រទេសមួយទិញយកកម្មសិទ្ធិគ្រប់គ្រងលើអាជីវកម្មថ្មីឬដែលមានស្រាប់នៅក្នុងប្រទេសមួយផ្សេងទៀត។ ពេលខ្លះ ត្រូវគេហៅថា *ការវិនិយោគពីបរទេសផ្ទាល់* ផងដែរ។

២៥. ប្រទេសម្ចាស់ផ្ទះ (host country) គឺជារដ្ឋដែលសាជីវកម្មពហុជាតិបរទេស (MNC) ប្រតិបត្តិការ។ សូមមើល *ប្រទេសកំណើត*ផងដែរ។ ឧទាហរណ៍ ហាងកាហ្វេ *ស្តាបាក់* មកបើកសាខាថ្មីនៅកម្ពុជា។

២៦. ប្រទេសកំណើត ឬ **មាតុប្រទេស** (home country) គឺជារដ្ឋដែលសាជីវកម្មពហុជាតិ (MNC) បោះទីស្នាក់ការកណ្តាលរបស់ខ្លួន។ សូមមើល *ប្រទេសម្ចាស់ផ្ទះ*ផងដែរ។ ឧទាហរណ៍ ហាងកាហ្វេ *ស្តាបាក់*កើតចេញពីប្រទេសអាមេរិក ហើយពង្រីកសាខាក្នុងប្រទេសផ្សេងៗពាសពេញពិភពលោក។

សំណួរអនុវត្តន៍

១. ចូរស្វែងរកអត្ថបទព័ត៌មានថ្មីៗអំពីបម្រែបម្រួលអត្រាប្តូរប្រាក់ (ជាទូទៅស្ថិតនៅផ្នែកអាជីវកម្មនៅក្នុងកាសែតឬគេហទំព័រ)។ ចូរវិភាគឥទ្ធិពលផ្សេងៗ ដែលអាចបណ្តាលឲ្យមានការផ្លាស់ប្តូរតម្លៃរូបិយប័ណ្ណ៖ គោលនយោបាយរូបិយវត្ថុ ឬ ស្ថានភាពមូលដ្ឋាននៃសេដ្ឋកិច្ចជាតិ សកម្មភាពរបស់ធនាគារកណ្តាល (ដាច់ដោយឡែក ឬក្នុងការសម្របសម្រួលណាមួយ) និងកត្តាផ្សេងៗដូចជាភាពមិនប្រាកដប្រជាផ្នែកនយោបាយដែលប៉ះពាល់ដល់ទំនុកចិត្តរបស់វិនិយោគិនលើរូបិយប័ណ្ណណាមួយនោះ។

២. សិទ្ធិឬទុនបំរុងពិសេស(SDRs)របស់មូលនិធិរូបិយវត្ថុអន្តរជាតិ គឺជារូបិយប័ណ្ណពិភពលោក ដែលប្រើដោយរដ្ឋាភិបាល សម្រាប់ជាយន្តការគ្រប់គ្រងរូបិយប័ណ្ណអន្តរជាតិនិងគណនីជាតិ។ តើអ្នកគិតថាSDRs អាចក្លាយជារូបិយប័ណ្ណមួយដែលត្រូវបានប្រើដោយអាជីវកម្មនិងបុគ្គលទូទៅដែរឬទេ? ហើយតើវាអាចកើតឡើងយ៉ាងដូចម្តេច(ឬហេតុអ្វីបានជាវាមិនអាចកើតឡើង)? តើវាអាចបង្កផលប៉ះពាល់អ្វីខ្លះដល់អាជីវកម្មពិភពលោក និងសមត្ថភាពរបស់រដ្ឋអធិបតេយ្យក្នុងការគ្រប់គ្រងសេដ្ឋកិច្ចផ្ទាល់ខ្លួន?

៣. អ្នកប្រាជ្ញនិងអ្នកនយោបាយជាច្រើនគិតដូចគ្នាថា ការវិនិយោគអន្តរជាតិជាលក្ខណៈឯកជន ជាក្តីសង្ឃឹមល្អបំផុតសម្រាប់សេដ្ឋកិច្ចរបស់ប្រទេសរុស្ស៊ីនិងអឺរ៉ុបខាងកើត។ បើគិតពីវិបត្តិសេដ្ឋកិច្ចនិងនយោបាយបច្ចុប្បន្ននៅក្នុងតំបន់នោះ តើវិនិយោគិនប្រភេទណាដែលមកពីប្រទេសឧស្សាហកម្មនៃបស្ចឹមលោក អាចនឹង

មានឆន្ទៈក្នុងការវិនិយោគនៅទីនោះ? តើរដ្ឋាភិបាលនៃរដ្ឋបស្ចឹមលោកអាចចាត់វិធានការណ៍អ្វីខ្លះ ដើម្បីលើកទឹកចិត្តដល់ការវិនិយោគបែបនេះ? តើរដ្ឋាភិបាលនិងវិនិយោគិនត្រូវប្រយ័ត្នប្រយែងហានិភ័យអ្វីខ្លះ?

៤. ប្រសិនបើអ្នកតំណាងអោយសារជីវកម្មពហុជាតិ ដូចជាក្រុមហ៊ុនតូយ៉ូតា ក្នុងការចរចាលើការបង្កើតរោងចក្រផលិតរថយន្តនៅបរទេស តើអ្នកនឹងស្នើសុំសម្បទានប្រភេទណាខ្លះពីប្រទេសម្ចាស់ផ្ទះ? តើអ្នកនឹងផ្តល់អ្វីជាការលើកទឹកចិត្តផងដែរ? នៅក្នុងរបាយការណ៍របស់អ្នកទៅកាន់ថ្នាក់ដឹកនាំជាន់ខ្ពស់របស់ក្រុមហ៊ុនតូយ៉ូតា អំពីកិច្ចព្រមព្រៀង តើអ្នកនឹងសង្កត់ធ្ងន់ទៅលើចំនុចណាដែលសំខាន់បំផុត? ផ្ទុយទៅវិញ ប្រសិនបើអ្នកតំណាងអោយប្រទេសម្ចាស់ផ្ទះក្នុងការចរចានិងរាយការណ៍ទៅថ្នាក់ដឹកនាំរដ្ឋ តើអ្វីជាគោលដៅនៃការចរចា និងការផ្តោតអារម្មណ៍ជាពិសេស ក្នុងរបាយការណ៍របស់អ្នក?

៥. ឧបមាថា ប្រធានក្រុមហ៊ុនសារធាតុគីមីដៅវ៍(Dow Chemical) មានសមត្ថភាពនិងលទ្ធភាពដើម្បីបង្កើតទីស្នាក់ការកណ្តាលពិភពលោករបស់ក្រុមហ៊ុនដៅវ៍ នៅលើកោះមួយ នៅក្រៅរង្វង់ដែនដីរដ្ឋទាំងអស់។ តើអ្នកគិតថាទីតាំងបែបនេះនឹងផ្លាស់ប្តូរយុទ្ធសាស្ត្រឬប្រតិបត្តិការអាជីវកម្មរបស់ដៅវ៍យ៉ាងដូចម្តេច? តើវាអាចបង្កើតបញ្ហាអ្វីខ្លះសម្រាប់ក្រុមហ៊ុន?

ការស្វែងរកផលប្រយោជន៍រួម

ស្ថិរភាពរូបិយប័ណ្ណ

ផលប្រយោជន៍រួម៖ ស្ថេរភាពអត្រាប្តូររូបិយប័ណ្ណសម្រាប់អាជីវកម្មពិភពលោក

សាវតារ

សកលភាវូបនីយកម្មបាននាំមកនូវទ្រព្យសម្បត្តិដ៏ច្រើនមហាសាលដល់ពិភពលោក នៅពេលដែលអាជីវកម្មប្រតិបត្តិការជាអន្តរជាតិកាន់តែខ្លាំងឡើងៗ។ លទ្ធភាពក្នុងការធ្វើអាជីវកម្មជាអន្តរជាតិត្រូវអាស្រ័យលើស្ថិរភាពនៃអត្រាប្តូរប្រាក់ក្នុងប្រទេសនីមួយៗ។ ទោះជាអត្រាប្តូរប្រាក់កម្រិតណាក៏ដោយ អ្នកជំនួញអាចរៀបចំផែនការសម្រាប់ការវិនិយោគ ការនាំចូល ឬការទិញ ដោយផ្អែកលើការស្វែងយល់ពីតម្លៃដែលទំនិញទាំងនេះអាចលក់ចេញ ប្រសិនបើត្រូវគិតជារូបិយប័ណ្ណបរទេស។ ដែលមានន័យថាអ្វីគ្រប់យ៉ាងពឹងផ្អែកលើអត្រាប្តូរប្រាក់។ ស្ថេរភាពនេះគឺជាផលប្រយោជន៍រួមសម្រាប់ពិភពលោកទាំងមូល។ ប្រសិនបើប្រទេសធំៗលើពិភពលោករក្សាស្ថិរភាព ដោយការរួមគ្នាសម្របសម្រួលគោលនយោបាយហិរញ្ញវត្ថុរបស់ពួកគេ នោះទាំងអស់គ្នានឹងទទួលបានអត្ថប្រយោជន៍ដោយក្តីរីករាយ។ ស្ថិរភាពនោះអាចសម្រេចបាន បើទោះបីជារដ្ឋមួយចំនួន «ជិះសេះលែងដៃ» ដោយរៀបចំអត្រាប្តូរប្រាក់ផ្ទាល់របស់ពួកគេ ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ពួកគេក៏ដោយ។ ប្រសិនបើប្រទេសកាន់តែច្រើនធ្វើរបៀបនេះ ផលប្រយោជន៍រួមនឹងមិនត្រូវសម្រេចបាន ដូចដែលត្រូវបានបង្ហាញនៅក្នុងការប្រកួតប្រជែងគ្នាទម្លាក់តម្លៃរូបិយប័ណ្ណសំខាន់ៗនៅក្នុងទសវត្សរ៍ឆ្នាំ ១៩៣០ ដែលបានបណ្តាលអោយវិបត្តិសេដ្ឋកិច្ចកាន់តែធ្ងន់ធ្ងរ។

បញ្ហាប្រឈម

ប្រទេសចិនបានរក្សាតម្លៃរូបិយប័ណ្ណរបស់ខ្លួនអោយនៅត្រឹមកម្រិតទាបជាងប្រាក់ដុល្លារអាមេរិក អស់រយៈពេលជាច្រើនឆ្នាំមកហើយ បើទោះបីជាស្ថានភាពសេដ្ឋកិច្ចនៅក្នុងប្រទេសទាំងពីរមានគម្លាតចាកឆ្ងាយហើយជាលទ្ធផលមានអតុល្យភាពពាណិជ្ជកម្មដ៏ធំបានកើតឡើងក៏ដោយ។ អ្នកសេដ្ឋកិច្ចភាគច្រើនរំពឹងថាតម្លៃរូបិយប័ណ្ណចិននឹងឡើងខ្លាំងគួរសម ប្រសិនបើអនុញ្ញាតអោយអណ្តែតដោយសេរីដូចរូបិយប័ណ្ណសំខាន់ៗ

ផ្សេងទៀតរបស់ពិភពលោក។ កត្តានេះនឹងជួយដល់ការនាំចេញរបស់អាមេរិក និងប៉ះពាល់ដល់ការនាំចេញរបស់ចិន ដែលនឹងអាចជួយកាត់បន្ថយអតុល្យភាពពាណិជ្ជកម្មខាងលើបានខ្លះ។ ថ្មីៗនេះ ប្រទេសចិនបានចាប់ផ្តើមអនុញ្ញាតអោយរូបិយប័ណ្ណរបស់ខ្លួនផ្លាស់ទីបានច្រើនគួរសម ប៉ុន្តែអ្នកជំនាញជាច្រើនជឿថាចលនានេះនៅតែគ្រប់គ្រងដោយរដ្ឋាភិបាលចិនដដែល។

ដំណោះស្រាយ

ខុសពីប្រព័ន្ធពាណិជ្ជកម្មដែលផ្អែកលើគោលការណ៍សមភាព និងបដិការ ប្រព័ន្ធហិរញ្ញវត្ថុអន្តរជាតិមានលក្ខណៈប្រហាក់ប្រហែលនឹងគោលការណ៍គ្រប់គ្រងជាង។ មូលនីធិIMF បានប្រើប្រាស់ប្រព័ន្ធបោះឆ្នោតសមាមាត្រ ដែលបានផ្តល់អំណាចដល់ប្រទេសដែលមានសេដ្ឋកិច្ចធំជាងគេ។ រហូតមកដល់ពេលថ្មីៗនេះ ការសម្រេចចិត្តលើរូបិយប័ណ្ណពិភពលោកសំខាន់ៗត្រូវបានធ្វើឡើង ដោយក្រុមប្រទេសទាំងមហាសេដ្ឋកិច្ចប្រាំពីរ(G៧)។ ក្រុមនេះត្រូវបានពង្រីកទៅជាក្រុមប្រទេសទាំងម្ភៃ (G២០) ដែលមានទំហំសេដ្ឋកិច្ចកាន់តែធំ និងរួមបញ្ចូលប្រទេសកាន់តែច្រើន (ដែលជាការពង្រាបកំពូលប្រព័ន្ធឋានានុក្រមគ្រប់គ្រង ជាការឆ្លើយតបទៅនឹងវិបត្តិសេដ្ឋកិច្ចពិភពលោក) ប៉ុន្តែ នៅតែទុកអោយប្រទេសកំពូលៗជាអ្នកសម្រេចចិត្តចុងក្រោយដដែល។ ទីផ្សាររូបិយប័ណ្ណពិភពលោកត្រូវបានគ្រប់គ្រងដោយប្រាក់ដុល្លារអាមេរិក ប្រាក់អឺរ៉ូ និងប្រាក់យ៉ែនជប៉ុន។

ដោយការទប់តម្លៃរូបិយប័ណ្ណរបស់ខ្លួនអោយនៅទាប ប្រទេសចិនកំពុង«ជិះសេះលែងដៃ»លើប្រព័ន្ធរូបិយប័ណ្ណពិភពលោក ដោយការជំរុញការនាំចេញរបស់ខ្លួន។ ទោះជាយ៉ាងណាក៏ដោយ ប្រទេសចិនមិនមែនជាចំណែកធំគ្រប់គ្រាន់នៃសេដ្ឋកិច្ចពិភពលោកទាំងមូល ដែលអាចទម្លាក់ប្រព័ន្ធរូបិយប័ណ្ណដោយការមិនចូលរួមរបស់វានោះទេ។

ទស្សនៈវិស័យគោលនយោបាយ

ប្រធានាធិបតីតៃវ៉ាន់ សៃ អ៊ីងវិន (Tsai Ing-wen)

រូបថត អ្នកស្រីប្រធានាធិបតី

បញ្ហា

តើអ្នកអាចថ្លឹងថ្លែងតុល្យភាពសម្ពាធនយោបាយអន្តរជាតិ ជាមួយនឹងបញ្ហាសេដ្ឋកិច្ចក្នុងស្រុកបានដោយរបៀបណា?

សាវតា

ឧបមាថា អ្នកគឺជាប្រធានាធិបតីតៃវ៉ាន់។ សេដ្ឋកិច្ចរបស់ប្រទេសអ្នកបានចាប់ផ្តើមមានកំណើនដ៏រឹងមាំនៅក្នុងប៉ុន្មានទសវត្សរ៍កន្លងមកនេះ ដោយសារឧស្សាហកម្មទំនើបដែលផលិតទំនិញ និងបច្ចេកវិទ្យាខ្ពស់។ ទោះបីជារដ្ឋភាគច្រើនក្នុងពិភពលោកមិនបានទទួលស្គាល់ប្រទេសរបស់អ្នកជាផ្លូវការ តាមលក្ខណៈការទូតក៏ដោយ ក៏ពួកគេនៅតែចូលរួមចំណែកក្នុងទំហំពាណិជ្ជកម្មយ៉ាងទូលំទូលាយជាមួយប្រទេសរបស់អ្នក។ ទោះបីប្រទេសអ្នកត្រឹមជាកោះដ៏តូចមួយក៏ដោយ អ្នកបានជាប់ចំណាត់ថ្នាក់ទី ១៥ ក្នុងការនាំចេញសរុប នៅទូទាំងពិភពលោក។ ប្រទេសអ្នកមានជញ្ជីងពាណិជ្ជកម្មដ៏ល្អប្រសើរ និងទុនបម្រុងជារូបិយប័ណ្ណយ៉ាងសម្បើម បើតាមការប៉ាន់ប្រមាណមួយ មានតែប្រទេសប្រាំប៉ុណ្ណោះដែលមានទុនបម្រុងជារូបិយប័ណ្ណច្រើនជាងតៃវ៉ាន់។

ដោយសារការនាំចេញគឺជាផ្នែកមួយដ៏សំខាន់នៃសេដ្ឋកិច្ចរបស់អ្នក កម្រិតនៃអត្រាប្តូរប្រាក់មានសារៈសំខាន់ខ្លាំងណាស់ចំពោះសុខភាពសេដ្ឋកិច្ចជាតិទាំងមូល។ ប្រាក់ដុល្លារតៃវ៉ាន់ថ្មី(NTD) ដែលមានតំលៃ

ថោក ធ្វើអោយទំនិញរបស់អ្នកមានតម្លៃថោក និងជួយដល់ការនាំចេញរបស់អ្នក។ រូបិយប័ណ្ណរបស់អ្នករក្សាបាននូវស្ថិរភាពធៀបនឹងរូបិយប័ណ្ណសំខាន់ៗផ្សេងទៀត ដូចជាប្រាក់ Remnimbi របស់ចិន និងប្រាក់ដុល្លារអាមេរិក ប៉ុន្តែនៅក្នុងឆ្នាំ ២០១៦ រដ្ឋាភិបាលសហរដ្ឋអាមេរិកបានចោទប្រកាន់រដ្ឋាភិបាលរបស់អ្នកថាបានធ្វើអន្តរាគមន៍ច្រើនពេកនៅក្នុងទីផ្សាររូបិយប័ណ្ណដើម្បីរក្សាតម្លៃទាបរបស់ប្រាក់NTD។ សហរដ្ឋអាមេរិកបានដាក់តៃវ៉ាន់ក្នុង«បញ្ជីឃ្លាំមើល» ហើយបានគំរាមថានឹងការកាត់ជំនួយបរទេសប្រសិនបើតៃវ៉ាន់គ្រប់គ្រងរូបិយប័ណ្ណរបស់ខ្លួនតឹងរ៉ឹងពេក។

ការពិចារណាក្នុងស្រុក

កំណើនសេដ្ឋកិច្ច ដែលជំរុញដោយការនាំចេញ ពិតជាមានសារៈសំខាន់សម្រាប់ប្រទេសរបស់អ្នក។ អ្នកត្រូវបានបោះឆ្នោតជ្រើសរើសអោយកាន់តំណែងជាប្រធានាធិបតី ដោយប្តេជ្ញាថានឹងបន្តកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយអំពើពុករលួយនយោបាយនៅតៃវ៉ាន់។ អត្រាអត់ការងារធ្វើរបស់យុវជនបានហក់ខ្ពស់ជាងធម្មតា នៅតៃវ៉ាន់។ កម្រិតប្រាក់ឈ្នួលនៅទ្រឹងនៅក្នុងប្រទេស ដែលនាំអោយមានការភ្ជួញភ្ជែរអំពីសមត្ថភាពរបស់រដ្ឋាភិបាលអ្នកក្នុងការគ្រប់គ្រងសេដ្ឋកិច្ច។

តៃវ៉ាន់ជាប្រទេសដែលមានទ្រព្យសម្បត្តិច្រើនគួរសម បើគិតពីកម្រិតសម្រាប់មនុស្សម្នាក់ៗ(ប្រហែល ៥០០០០ ដុល្លារក្នុងមួយឆ្នាំ)។ ប្រជាពលរដ្ឋភាគច្រើនចូលប្រឡូកក្នុងវិស័យនយោបាយ និងរហ័សរហួនក្នុងការចាប់អោយមេដឹកនាំទទួលខុសត្រូវចំពោះស្ថានភាពសេដ្ឋកិច្ច។ ការរក្សាការនាំចេញអោយខ្ពស់ដើម្បីលើកកម្ពស់កំណើនសេដ្ឋកិច្ច គឺជាការសន្យាដ៏សំខាន់មួយដែលអ្នកបានប្តេជ្ញាធ្វើចំពោះមុខអ្នកបោះឆ្នោតក្នុងនាមជាបេក្ខជនប្រធានាធិបតី។

សេណារីយ៉ូ

ឥឡូវចូរស្រមៃថា ដោយសារកំណើនសេដ្ឋកិច្ចសកលលោកមានភាពយឺតយ៉ាវ ការនាំចេញរបស់អ្នកទៅកាន់ប្រទេសចិននិងសហរដ្ឋអាមេរិកបានចាប់ផ្តើមធ្លាក់ចុះយ៉ាងខ្លាំង។ ប្រការនេះកាន់តែបន្ថែមដល់ការជាប់គាំងប្រាក់ឈ្នួល និងបង្កើនភាពអត់ការងារធ្វើ ដោយសារមានការងារតិចជាងនៅក្នុងវិស័យផលិតកម្ម។ គោលការណ៍មួយដែលអាចជួយបង្កើនកម្រិតនៃការនាំចេញរបស់អ្នកឡើងវិញ គឺត្រូវចំណាយទុនបម្រុងមួយចំនួនរបស់អ្នក ក្នុងការព្យាយាមបញ្ចុះតម្លៃរូបិយប័ណ្ណរបស់អ្នក ដោយធ្វើអោយទំនិញរបស់អ្នកកាន់តែមានភាពទាក់ទាញ។

ជាការពិតណាស់ គោលនយោបាយមួយនេះនឹងបង្កអោយមានហានិភ័យមួយចំនួន។ ទីមួយ វាអាចនឹងមិនដំណើរការតាមការចង់បាន។ វាអាចជាការលំបាកសម្រាប់រដ្ឋក្នុងការបញ្ចុះបញ្ចូលតម្លៃនៃរូបិយប័ណ្ណរបស់ពួកគេ។ ទីពីរ ប្រសិនបើសហរដ្ឋអាមេរិករកឃើញថាអ្នកកំពុងព្យាយាមបញ្ចុះតម្លៃរូបិយប័ណ្ណរបស់អ្នក សហរដ្ឋអាមេរិកអាចនឹងដាក់ទណ្ឌកម្មអ្នក ដោយកាត់ជំនួយ ឬសុំអោយមូលនីធិIMF ស៊ើបអង្កេតគោលនយោបាយសេដ្ឋកិច្ចរបស់អ្នក។

ចូរជ្រើសរើសគោលការណ៍របស់អ្នក

តើអ្នកនឹងធ្វើអន្តរាគមន៍ក្នុងទីផ្សាររូបិយប័ណ្ណអន្តរជាតិដើម្បីបន្ទាបតម្លៃNTDដែរឬទេ? ប្រសិនបើអ្នកធ្វើបែបនេះ តើអ្នកអាចដោះស្រាយការគំរាមកំហែងដាក់ទណ្ឌកម្មពីសហរដ្ឋអាមេរិកដោយរបៀបណា បើសិនពួកគេបានដឹងពីគោលនយោបាយរបស់អ្នក? បើអ្នកមិនធ្វើទេ តើអ្នកដោះស្រាយបញ្ហាសេដ្ឋកិច្ចដែលកំពុង

កើនឡើងក្នុងប្រទេសរបស់អ្នកក៏ដូចជាការគំរាមកំហែងចំពោះការនាំចេញរបស់អ្នកដោយរបៀបណា? តើអ្នកអាចប្តឹងថ្លែងតម្រូវការរបស់ប្រទេសអ្នក ទល់នឹងសម្ពាធរបស់រដ្ឋផ្សេងនិងសេដ្ឋកិច្ចអន្តរជាតិ ដោយរបៀបណា?

មតិសាធារណៈ និងទំនាក់ទំនងអន្តរជាតិ

ការវិនិយោគបរទេស

ការវិនិយោគផ្ទាល់ពីបរទេស (FDI) អាចមានភាពចម្រូងចម្រាស នៅក្នុងរដ្ឋម្ចាស់ផ្ទះ ដែលជាកន្លែងដែលសាជីវកម្មពហុជាតិ(MNCs)ជាក់ទុនវិនិយោគ។ ដោយអាស្រ័យលើរបៀបដែលក្រុមហ៊ុនជាក់លាក់មួយប្រាស្រ័យទាក់ទងជាមួយលក្ខខណ្ឌនិងប្រជាជនក្នុងស្រុក ការវិនិយោគបែបនេះអាចប្រែក្លាយជារឿងពេញនិយមឬមិនពេញនិយម ដូចដែលយើងបានពិភាក្សានៅក្នុងផ្នែកនេះ។ ក្នុងឆ្នាំ ២០១៤ ការស្ទង់មតិរបស់ប្រជាជន ក្នុងប្រទេសចំនួន ៤៣ ដោយបានសួរអំពីអារម្មណ៍របស់ពួកគេចំពោះអាជីវកម្មបរទេស និងសួរថាតើទំនាក់ទំនងជាមួយអាជីវកម្មទាំងនោះមានប្រយោជន៍ដែរឬទេ។


លទ្ធផលនៃការស្ទង់មតិត្រូវបានបង្ហាញក្នុងក្រាហ្វិក៩.៣។ ភាគច្រើននៃអ្នកឆ្លើយតបនៅក្នុងប្រទេសនីមួយៗបានពណ៌នាអំពីអារម្មណ៍របស់ពួកគេចំពោះទំនាក់ទំនងអាជីវកម្មបរទេសថា ល្អបង្គួរ ឬ ល្អណាស់។ ជាការពិត ការរួមបញ្ចូលគ្នានូវចម្លើយទាំងពីរនេះ បង្ហាញអោយឃើញយ៉ាងច្បាស់ថា ភាគច្រើននៅក្នុងប្រទេសទាំងអស់ដែលបានស្ទង់មតិ មានអារម្មណ៍ថា ទំនាក់ទំនងពាណិជ្ជកម្មបរទេសមានប្រយោជន៍ចំពោះប្រទេសរបស់ពួកគេ ក្នុងកម្រិតឬរូបភាពណាមួយ។ នៅក្នុងប្រទេសមួយចំនួន អ្នកឆ្លើយតបមួយភាគធំនៅមានមន្ទិលសង្ស័យចំពោះទំនាក់ទំនងអាជីវកម្មបរទេស ដោយបានវាយតម្លៃពួកគេថា អាក្រក់ណាស់ ឬអាក្រក់ណាស់ដែរ។ អ្វីដែលគួរអោយចាប់អារម្មណ៍ ប្រទេសទាំងនេះមានលក្ខណៈខុសប្លែកគ្នាច្រើន ចាប់ពីប្រទេសអ៊ីតាលី អេហ្ស៊ីប ទួរគី រហូតដល់ប្រទេសថៃ។

តើកត្តាអ្វីខ្លះអាចពន្យល់ពីការគាំទ្រកម្រិតខ្ពស់បែបនេះសម្រាប់អាជីវកម្មបរទេស នៅទូទាំងប្រទេស? កត្តាមួយអាចដោយសារបុគ្គលនីមួយៗនៅជុំវិញពិភពលោក បានចូលរួមផ្ទាល់ក្នុងសកលភាវូបនីយកម្ម៖ តិចឬច្រើន ប្រទេសទាំងអស់ពឹងផ្អែកលើទំនិញនិងសេវាកម្មពីប្រទេសផ្សេងៗ។ ប្រជាជនជាច្រើនមើលឃើញវត្តមានរបស់ក្រុមហ៊ុនបរទេសទាំងនោះក្នុងន័យវិជ្ជមានសរុបសម្រាប់ប្រទេសម្ចាស់ផ្ទះ ជាពិសេសនៅពេលទំនាក់ទំនងអាជីវកម្មខាងលើកំពុងលក់ផលិតផលម៉ាកល្បីដូចជា Apple ឬ Samsung ឬ Gap។ កត្រាពាក់ព័ន្ធមួយទៀត គឺថាអ្នកឆ្លើយតបទាំងនោះយល់ដឹងថា ការវិនិយោគច្រើនតែបង្កើតការងារ ឬកំណើនសេដ្ឋកិច្ច។

ដោយសារការវិនិយោគដោយផ្ទាល់ពីបរទេសត្រូវបានពិចារណាថាមានភាពចម្រូងចម្រាស តើយើងគួរមានហេតុផលត្រូវសង្ស័យចំនួនវិជ្ជមានទាំងនេះដែរឬទេ? បើគ្មានទិន្នន័យបន្ថែមទេ វាពិបាកក្នុងការដឹងថា «ទំនាក់ទំនងអាជីវកម្មបរទេស» មានន័យយ៉ាងណាចំពោះអ្នកឆ្លើយតបទូទៅ។ វាអាចមានន័យជាការងារ និងការរីកចម្រើន។ ឬវាអាចមានន័យថាជាចក្រពត្តិនិយមវប្បធម៌។ ឬវាអាចមានន័យថាជាលទ្ធភាពទិញផលិតផលបរទេស នៅក្នុងស្រុកខ្លួន។ អ្វីដែលយើងអាចទាញសេចក្តីសន្និដ្ឋានបានពីទិន្នន័យទាំងនេះ គឺថាប្រជាជននៃប្រទេសជាច្រើន ក្នុងពិភពលោកមិនមើលឃើញទំនាក់ទំនងសេដ្ឋកិច្ចបរទេស ក្នុងក្រសែភ្នែកសង្ស័យទេ។

ក្រាហ្វិក ៩.៣ មតិសាធារណៈអំពីធុរកិច្ចឬអាជីវកម្មបរទេស ក្នុងប្រទេសចំនួន ៤៣

ប្រភព៖ Pew Research Center



សម្គាល់៖ ល្អណាស់ ល្អបង្គួរ អាក្រក់គួរសម និងអាក្រក់ណាស់

តោះ! សាកល្បងពិភាក្សាអំពីបញ្ហាជាក់ស្តែង

ការវិនិយោគផ្ទាល់ពីបរទេស៖ ម៉ាស៊ីននៃកំណើន ឬឧបករណ៍នៃការកេងប្រវ័ញ្ច?

ទិដ្ឋភាពទូទៅ

ការវិនិយោគផ្ទាល់ពីបរទេស(FDI)គឺជាស្នូលនៃសេដ្ឋកិច្ចអន្តរជាតិ។ ទឹកប្រាក់ជាង ២,៥ ទ្រីលានដុល្លារក្នុងមួយឆ្នាំឆ្លងកាត់ព្រំដែនអន្តរជាតិតាមរយៈការវិនិយោគ។ បច្ចុប្បន្ន ភាគច្រើននៃទំហំទឹកប្រាក់ទាំងនេះបានហូរចូលប្រទេសកំពុងអភិវឌ្ឍន៍(ជាពិសេសប្រទេសចិន)។ ទឹកប្រាក់ជាង ៦០០ ប៊ីលានដុល្លារហូរពីបណ្តាប្រទេសអភិវឌ្ឍន៍នៅអឌ្ឍគោលខាងជើងទៅកាន់ប្រទេសកំពុងអភិវឌ្ឍន៍នៅអឌ្ឍគោលខាងត្បូង។ ក្នុងឆ្នាំ ២០១៧ អ្នកទទួលការវិនិយោគច្រើនបំផុត ៥ ក្នុងចំណោមកំពូលទាំង ១០ គឺជាប្រទេសកំពុងអភិវឌ្ឍន៍។

បើសម្លឹងមើលប្រវត្តិសាស្ត្រកន្លងមក ការវិនិយោគផ្ទាល់ពីបរទេសភាគច្រើនបានហូរឆ្លងទៅឆ្លងមករវាងប្រទេសនានានៅក្នុងអឌ្ឍគោលខាងជើង។ តាមពិតទៅ រហូតដល់ទស្សវត្សរ៍ឆ្នាំ ១៩៦០ សហរដ្ឋអាមេរិកចុះបញ្ជីភាគរយនៃការវិនិយោគផ្ទាល់ពីបរទេសភាគច្រើនបំផុត។ ក៏ប៉ុន្តែ ជាមួយនឹងការីកចម្រើននៃសេដ្ឋកិច្ច

ពិភពលោក និងការកើនឡើងនៃសាកលភាវូបនីយកម្ម ការវិនិយោគផ្ទាល់ពីបរទេសបានក្លាយជាបាតុភូតសកល។ ពេញមួយទសវត្សរ៍ឆ្នាំ ១៩៧០ និង ១៩៨០ ការវិនិយោគផ្ទាល់ពីបរទេស នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍នៅតែមានកម្រិតទាប ជាមធ្យមតិចជាង ២០ ប៊ីលានដុល្លារ ខណៈដែលទសវត្សរ៍ឆ្នាំ ១៩៩០ ខិតជិតមកដល់។ ទោះយ៉ាងណានៅចុងទសវត្សរ៍ឆ្នាំ ១៩៩០ ការវិនិយោគជាង ២០០ ពាន់លានដុល្លារបានហូរចូលទៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ពីប្រទេសក្រៅ។ ទំហំនៃការវិនិយោគទាំងនោះ បានបន្តកើនឡើងដល់កម្រិតបច្ចុប្បន្ន ដែលមានទំហំទឹកប្រាក់ជាង ៦០០ ប៊ីលានដុល្លារ។

លំហូរវិនិយោគទៅកាន់អឌ្ឍគោលខាងត្បូងមិនមែនថាគ្មានភាពចម្រូងចម្រាសនោះទេ។ ខណៈពេលដែលអ្នកខ្លះយល់ថាលំហូរវិនិយោគផ្ទាល់ពីបរទេសទាំងនេះ ពិតជាមានភាពចាំបាច់ខ្លាំងដើម្បីជំរុញកំណើនសេដ្ឋកិច្ច ខណៈអ្នកផ្សេងទៀតបានអះអាងថា ប្រាក់ទាំងនេះមិនសមនឹងតម្លៃនយោបាយនិងសង្គមនោះទេ។ រដ្ឋមួយចំនួនបានព្យាយាមទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស ជាពិសេសពីសាជីវកម្មពហុជាតិធំៗនៅបស្ចឹមលោក តាមរយៈការធ្វើកំណែទម្រង់សេដ្ឋកិច្ចក្នុងស្រុក។ រដ្ឋផ្សេងទៀតធ្វើសកម្មភាពតិចតួចដើម្បីលើកទឹកចិត្តការវិនិយោគផ្ទាល់ពីបរទេស ដោយព្រួយបារម្ភពីផលប៉ះពាល់អវិជ្ជមាន ដែលអាចកើតឡើងចំពោះបរិស្ថាន សង្គម និងនយោបាយ។ តើការវិនិយោគផ្ទាល់ពីបរទេស(FDI) ជាធនធានវិជ្ជមានសម្រាប់ប្រទេសកំពុងអភិវឌ្ឍដែរឬទេ?

អំណះអំណាង ១

ការវិនិយោគផ្ទាល់ពីបរទេសនាំមកនូវអត្ថប្រយោជន៍ជាវិជ្ជមានដល់ប្រទេសកំពុងអភិវឌ្ឍន៍

ការវិនិយោគផ្ទាល់ពីបរទេសនាំមកនូវការវិនិយោគដើមទុន ដែលជាគន្លឹះសម្រាប់កំណើនសេដ្ឋកិច្ច។ អ្វីដែលប្រទេសកំពុងអភិវឌ្ឍន៍ត្រូវការជាចាំបាច់បំផុតដើម្បីជំរុញកំណើនគឺ ដើមទុន។ ជារឿងពិបាកណាស់សម្រាប់សេដ្ឋកិច្ចកំពុងអភិវឌ្ឍក្នុងការបង្កើតដើមទុនពីខាងក្នុងប្រទេសផ្ទាល់ ដូច្នេះ ការវិនិយោគពីបរទេសគឺជាប្រភពដ៏ល្អបំផុតសម្រាប់វាក្នុងការបង្កើនសក្តានុពលសម្រាប់កំណើនសេដ្ឋកិច្ច។

ការវិនិយោគផ្ទាល់ពីបរទេសនាំមកនូវការងារកាន់តែច្រើនដល់ប្រទេសកំពុងអភិវឌ្ឍន៍។

ការវិនិយោគផ្ទាល់ពីបរទេសច្រើនតែធ្វើឡើងក្នុងទម្រង់ជារោងចក្រ ដែលនឹងនាំមកនូវការងារកាន់តែកើនឡើងសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍។ ខណៈដែលអ្នកខ្លះប្រកែកថា ការងារទាំងនេះមិនបានផ្តល់ប្រាក់ខែល្អតាមស្តង់ដារក្នុងស្រុកជារឿយៗពួកគេផ្តល់ប្រាក់ខែប្រសើរជាងការងារដែលបង្កើតឡើងក្នុងស្រុកផ្ទាល់។

ការវិនិយោគផ្ទាល់ពីបរទេសរួមចំណែកដល់វប្បធម៌ពឹងពាក់គ្នាទៅវិញទៅមក។

នៅពេលដែលក្រុមហ៊ុននិងសាជីវកម្មពហុពង្រាយផលិតផលរបស់ពួកគេ នៅពាសពេញពិភពលោក ពួកគេបង្កើនវប្បធម៌ពឹងពាក់គ្នាទៅវិញទៅមក ក្នុងវិស័យសេដ្ឋកិច្ចរវាងរដ្ឋនានា ម្ល៉ោះហើយអាចជួយជំរុញទំនាក់ទំនងកាន់តែប្រសើរឡើង។ នៅពេលដែលវិនិយោគិនដាក់ប្រាក់កាន់តែច្រើនទៅក្នុងសេដ្ឋកិច្ចរបស់រដ្ឋផ្សេងទៀត ពួកគេអាចយកចិត្តទុកដាក់បន្ថែមទៀតអំពីគោលនយោបាយរបស់រដ្ឋទាំងនោះ នៅក្នុងវិស័យផ្សេងទៀត ដូចជាសិទ្ធិមនុស្ស ឬបរិស្ថាន។ នេះអាចនាំអោយមានសម្ពាធលើអ្នកឬរដ្ឋទទួលការវិនិយោគផ្ទាល់ពីបរទេស ដើម្បីកែលម្អស្តង់ដារក្នុងវិស័យដូចជាការអនុវត្តការងារឬការបំពុលបរិស្ថានជាដើម។

អំណះអំណាង ២

ការវិនិយោគផ្ទាល់ពីបរទេសនាំមកនូវបញ្ហាច្រើនដល់ប្រទេសកំពុងអភិវឌ្ឍន៍

ឥទ្ធិពលរបស់ការវិនិយោគផ្ទាល់ពីបរទេសទៅលើប្រទេសកំពុងអភិវឌ្ឍន៍នៅមានកម្រិត។

ជាញឹកញយ មានបុគ្គលក្នុងចំនួនតូចណាស់ដែលទទួលបានអត្ថប្រយោជន៍ពីការវិនិយោគផ្ទាល់ពីបរទេសដែលទុកអោយប្រជាជននៅសេសសល់ដទៃទៀត មិនទទួលបានផលពីការវិនិយោគខាងក្រៅនេះ។ ដូច្នេះហើយ ទោះបីជាការវិនិយោគផ្ទាល់ពីបរទេសបន្ថែមលើកំណើនសេដ្ឋកិច្ចក៏ដោយ កំណើននេះមិនត្រូវបានចែករម្លែកដោយសមធម៌ ដែលនាំអោយគម្លាតរវាងអ្នកមាននិងអ្នកក្រកាន់តែធំ នៅក្នុងរដ្ឋម្ចាស់ផ្ទះ។

គោលនយោបាយដើម្បីទាក់ទាញការវិនិយោគផ្ទាល់ពីបរទេសប៉ះពាល់ដល់រដ្ឋអ្នកទទួល។

ដើម្បីទាក់ទាញការវិនិយោគពីបរទេសអោយបានច្រើនសន្ធឹក រដ្ឋតែងតែអនុម័តគោលនយោបាយដើម្បីផ្គាប់ចិត្តអ្នកវិនិយោគ ដូចជាសាជីវកម្មពហុជាតិធំៗជាដើម។ គោលនយោបាយទាំងនេះរួមមានការអនុគ្រោះពន្ធ (បណ្តាលអោយរដ្ឋបាត់បង់ប្រភពចំណូល) ការបន្ធូរបន្ថយស្តង់ដារបរិស្ថាន (នាំអោយមានបញ្ហាដូចជាការបំពុល) ឬ ច្បាប់ការងារខ្សោយ (នាំអោយមានការរំលោភបំពានលើការអនុវត្តការងារ ដូចជាពលកម្មកុមារ)។

ការងារដែលបង្កើតឡើងដោយការវិនិយោគផ្ទាល់ពីបរទេសមានគុណភាពអន់។

ដោយមិនគិតពីកម្រិតប្រាក់ខែដែលវាផ្តល់អោយ ការងារដែលបង្កើតឡើងដោយការវិនិយោគផ្ទាល់ពីបរទេសមានគុណភាពអន់។ ស្ទើរតែទាំងអស់ខ្វះអត្ថប្រយោជន៍បន្ថែមសំខាន់ៗ ហើយសហជីពការងារតែងតែត្រូវបានហាមឃាត់ស្ទើរតែទាំងស្រុង។ ការងារទាំងនេះក៏អាចមានលក្ខណៈបណ្តោះអាសន្នផងដែរ ប្រសិនបើពួកគេរកឃើញទីតាំងណាផ្សេងអាចផ្តត់ផ្តង់កម្លាំងពលកម្មដែលមានតម្លៃទាបជាងនោះ សាជីវកម្មពហុជាតិនឹងជ្រើសរើសនិងផ្លាស់ទីទៅទីតាំងនោះក្រោយដឹងដំណឹងភ្លាមៗ។ ទាំងនេះមិនមែនជាប្រភេទការងារដែលនាំមកនូវស្ថិរភាពរយៈពេលវែងដល់ប្រទេសកំពុងអភិវឌ្ឍន៍នោះទេ។

សំណួរ

- ចូរសាកល្បងថ្លឹងថ្លែង តើអ្នកជឿថាការវិនិយោគផ្ទាល់ពីបរទេសផ្តល់ផលល្អ ឬផលអាក្រក់សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍? ដោយសារការពង្រីកសាជីវកម្មពហុជាតិនិងការវិនិយោគ នៅក្នុងយុគសម័យសកលភាវូបនីយកម្មនេះ តើប្រទេសកំពុងអភិវឌ្ឍន៍អាចបោះបង់ចោលការវិនិយោគផ្ទាល់ពីបរទេសបានដែរឬទេ ប្រសិនបើពួកគេចង់សម្រេចបាននូវកំណើនសេដ្ឋកិច្ច?
- ដោយសន្មត់ថាគ្រោះថ្នាក់ខ្លះអាចកើតមានចំពោះរដ្ឋទទួលការវិនិយោគផ្ទាល់ពីបរទេស តើផលប៉ះពាល់អាចត្រូវកាត់បន្ថយបានដោយរបៀបណា? តើវាងាយស្រួលផ្លាស់ប្តូរគោលនយោបាយរបស់រដ្ឋដែលទទួលយកការវិនិយោគផ្ទាល់ពីបរទេស និងអាកប្បកិរិយារបស់អ្នកវិនិយោគនិងអាជីវកម្មដែលវិនិយោគក្នុងរដ្ឋកំពុងអភិវឌ្ឍ មួយងាយស្រួលផ្លាស់ប្តូរជាង?
- តើមេដឹកនាំនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍មានអានុភាពអ្វីខ្លះដើម្បីទប់ទល់ជាមួយនឹងសាជីវកម្មពហុជាតិដែលចង់មកវិនិយោគក្នុងរដ្ឋរបស់ពួកគេ? តើការទាមទារលក្ខណៈនៃការវិនិយោគផ្ទាល់ពីបរទេសដែលចង់ចូលមករដ្ឋនោះ អាចបង្កគ្រោះថ្នាក់អ្វីខ្លះ?

និស្សិតអាចសាកល្បងអានឯកសារខាងក្រោមបន្ថែមទៀត ដើម្បីជាគ្រឹះក្នុងការឆ្លើយសំណួរទាំងអស់ខាងលើ ៖

1. Jensen, Nathan. *Nation-States and the Multinational Corpo- ration: A Political Economy of Foreign Direct Investment.* Princeton, 2008.

2. Moran, Theodore. *Foreign Direct Investment and Develop- ment: Launching a Second Generation of Policy Research.* Peterson Institute, 2011.
3. Pinto, Pablo. *Partisan Investment in the Global Economy: Why the Left Loves Foreign Direct Investment and Why FDI Loves the Left.* Cambridge, 2013.
4. Razin, Assaf, and Efraim Sadka. *Foreign Direct Investment: Analysis of Aggregate Flows.* Princeton, 2016.

អាជីពក្នុងចំណាត់ថ្នាក់អន្តរជាតិ៖ ធុរកិច្ចអន្តរជាតិ

សង្ខេប

ការងារក្នុងធុរកិច្ចអន្តរជាតិផ្តល់ប្រាក់ខែខ្ពស់ កិច្ចការគួរអោយចាប់អារម្មណ៍ និងទាមទារម៉ោងច្រើន សម្រាប់អ្នកដែលមានជំនាញភាសា និងវប្បធម៌។

រូបថត អ្នកជំនួញអន្តរជាតិពិភាក្សាធុរកិច្ច

អត្ថប្រយោជន៍និងការចំណាយ

នៅពេលដែលល្បឿននិងវិសាលភាពនៃសកលភាវូបនីយកម្មត្រូវបានពន្លឿន ឱកាសធ្វើការក្នុងធុរកិច្ច ឬអាជីវកម្មអន្តរជាតិបានរីកដុះដាលឡើងខ្លាំង។ សម្រាប់ក្រុមហ៊ុនធំៗជាច្រើន ភាពខុសគ្នារវាងលក្ខណៈក្នុងស្រុកនិងលក្ខណៈសកលលែងមានទៀតហើយ។ បរិបទថ្មីនេះផ្តល់ទាំងឱកាសនិងទាំងបញ្ហាប្រឈមសម្រាប់បុគ្គលិកដែលមានសក្តានុពល។

អាជីពក្នុងអាជីវកម្មអន្តរជាតិផ្តល់អត្ថប្រយោជន៍ជាច្រើន។ ការងារក្នុងវិស័យអាជីវកម្ម(ឯកជន)អាចផ្តល់ប្រាក់កម្រៃច្រើនជាងការងារនៅក្នុងរដ្ឋាភិបាលឬអង្គការក្រៅរដ្ឋាភិបាល ហើយអាចបើកឱកាសច្រើនដល់បុគ្គលិកអោយធ្វើដំណើរយ៉ាងទូលំទូលាយនិងតភ្ជាប់បណ្តាញការងារទូទាំងពិភពលោក។ ការងារដែលមានមូលដ្ឋាននៅបរទេសមានន័យថា បុគ្គលិកត្រូវផ្លាស់ប្តូរទីលំនៅទៅប្រទេសមួយផ្សេងទៀត ដើម្បីធ្វើការនិងជ្រមុជខ្លួនឯងនៅក្នុងវប្បធម៌មួយផ្សេងទៀត។

ទោះជាយ៉ាងណាក៏ដោយ ជម្រើសអាជីពបែបនេះក៏ត្រូវចំណាយខ្ពស់ផងដែរ។ ការងារជាច្រើនត្រូវការម៉ោងច្រើន ការធ្វើដំណើរដ៏លំបាក និងការផ្លាស់ទីលំនៅជាញឹកញាប់។ ក៏ដូចគ្នានឹងការងារដទៃទៀតដែរ ការតម្លើងមុខតំណែងនិងស័ក្តិយសអាចត្រូវរងឥទ្ធិពលដោយសារកាលៈទេសៈខាងក្រៅ ដូចជាវដ្តនៃអាជីវកម្មសកល។ ហើយការងារទាំងនេះអាចបង្កការពិបាកខ្លាំងសម្រាប់គ្រួសារ។

ឱកាសការងារអន្តរជាតិកើតឡើងក្នុងវិស័យធុរកិច្ចជាច្រើន។ ធនាគារ ការដើរទីផ្សារ (ទំនាក់ទំនងសាធារណៈ) ផ្នែកលក់ និងកុំព្យូទ័រ/ទូរគមនាគមន៍មានការរីកចម្រើនយ៉ាងខ្លាំងក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ។ ការងារទាំងនេះចែកចេញជាបីប្រភេទធំៗ៖ (១) ការងារដែលមានទីតាំងនៅក្នុងស្រុកប៉ុន្តែពាក់ព័ន្ធនឹងអន្តរកម្មយ៉ាងសកម្មជាមួយក្រុមហ៊ុននៅបរទេស (២) ការងារក្នុងស្រុកដែលធ្វើការអោយក្រុមហ៊ុន ដែលមានមូលដ្ឋាននៅបរទេស និង (៣) ការងារដែលមានមូលដ្ឋាននៅបរទេស ធ្វើអោយក្រុមហ៊ុនបរទេស ឬក្រុមហ៊ុនក្នុងស្រុក។

ជំនាញត្រូវជ្រុសខាត់

គន្លឹះមួយក្នុងការទទួលបានការងារនៅក្នុងពិភពធុរកិច្ចអន្តរជាតិ គឺត្រូវអភិវឌ្ឍជំនាញពីរក្រុម៖ ជំនាញទាក់ទងនឹងទំនាក់ទំនងអន្តរជាតិ និងជំនាញទាក់ទងនឹងប្រតិបត្តិការអាជីវកម្ម។ បរិញ្ញាបត្រជាន់ខ្ពស់ជំនាញគ្រប់គ្រងអាជីវកម្ម(MBAs) និងកម្មវិធីសាលាធុរកិច្ចនឹងមានប្រយោជន៍ខ្លាំងសម្រាប់ការងារទាំងបីប្រភេទខាងលើ។ ប៉ុន្តែ សម្រាប់ការងារដែលមានមូលដ្ឋាននៅបរទេស និយោជកតែងតែស្វែងរកជំនាញទូលំទូលាយ

ដែលត្រូវគេជុសខាត់ក្នុងផ្នែកសេដ្ឋកិច្ច ផ្នែកវិទ្យាសាស្ត្រនយោបាយ និងផ្នែកទំនាក់ទំនង។ ដូច្នេះ គេមិនត្រឹមតែត្រូវការជំនាញធុរកិច្ចបែបប្រពៃណីប៉ុណ្ណោះទេ តែថែមទាំងត្រូវការជំនាញភាសានិងវប្បធម៌ជាចាំបាច់ផងដែរ។ និយោជកស្វែងរកអ្នកដែលមានចំណេះដឹងអំពីប្រវត្តិសាស្ត្រ និងភូមិសាស្ត្រមនុស្សនិងសេដ្ឋកិច្ចរបស់ប្រទេសមួយ រួមទាំងវប្បធម៌ផង។ បទពិសោធន៍សិក្សានៅបរទេស ជាពិសេសរួមទាំងការងារនៅបរទេសអាចជួយបង្ហាញពីសមត្ថភាពក្នុងការសម្របខ្លួននិងបំពេញមុខងារបានល្អ នៅក្នុងវប្បធម៌ផ្សេងៗ។ សមត្ថភាពវិភាគខ្លាំង និងជាពិសេសជំនាញសរសេរ ក៏មានសារៈសំខាន់ចំពោះនិយោជកផងដែរ។

ការស្រាវជ្រាវក៏ជួយរកការងារបានធ្វើផងដែរ។ និយោជកតែងតែស្វែងរកចំណេះដឹងអំពីឧស្សាហកម្ម ឬក្រុមហ៊ុនជាក់លាក់ណាមួយដើម្បីទាញប្រយោជន៍ពីចំណេះភាសា និងជំនាញវប្បធម៌របស់និយោជិតអោយបានច្រើនបំផុតតាមតែអាចធ្វើបាន។ ជាការពិតណាស់ ខណៈពេលដែលបទពិសោធន៍ក្នុងអាជីវកម្មមិនមែនអន្តរជាតិបង្កផលប៉ះពាល់ សូមចងចាំថា ការអនុវត្ត ទំនៀមទម្លាប់ និងគំរូនៃអាជីវកម្មនៅក្នុងប្រទេសមួយប្រហែលជាមិនអនុវត្តបានល្អនៅបរទេសទេ។ ជំនាញឆ្លងវប្បធម៌ រួមផ្សំជាមួយនឹងចំណេះដឹងផ្នែកធុរកិច្ចសំខាន់ៗ ដើម្បីបម្លែងតម្រូវការប្រតិបត្តិការរបស់ក្រុមហ៊ុន ពីពិភពធុរកិច្ចទៅកាន់សកលលោកទាំងមូល មានតម្លៃខ្ពស់។

ធនធានបន្ថែម

5. Mueller, Sherry Lee, and Mark Overmann. *Working World: Careers in International Education, Exchange, and Develop- ment*. 2nd ed. Georgetown, 2014.
6. Penrith, Deborah, ed. *The Directory of Jobs and Careers Abroad*. 13th ed. Vacation, 2007.
7. https://www.myperfectresume.com/how-to/career-resources/ internat/
8. https://jobs.goabroad.com
9. http://www.transitionsabroad.com/listings/work/careers/index.shtml

ឯកសារគួរអានបន្ថែម

- Mueller, Sherry Lee, and Mark Overmann. *Working World: Careers in International Education, Exchange, and Develop- ment*. 2nd ed. Georgetown, 2014.
- Penrith, Deborah, ed. *The Directory of Jobs and Careers Abroad*. 13th ed. Vacation, 2007.
- https://www.myperfectresume.com/how-to/career-resources/ internat/
- https://jobs.goabroad.com
- http://www.transitionsabroad.com/listings/work/careers/index.shtml

មេរៀនទី ១០ ៖ សមាហរណកម្មអន្តរជាតិ

រូបថត បាតកវាទាមទារអោយអង់គ្លេសចាកចេញពីសហភាពអឺរ៉ុប ២០១៨

វត្ថុបំណងមេរៀន

១០.១ ចូរស្វែងរកកម្លាំងឬសំពាធពីរផ្ទុយគ្នា ដែលអង្គការអន្តរជាតិទាំងអស់ត្រូវប្រឈមមុខ។

១០.២ ចូរប្រើទ្រឹស្តីមុខងារនិយម (functionalist) ដើម្បីពន្យល់អំពីការបង្កើតនិងការរីកចម្រើនរបស់សហភាពអឺរ៉ុប (EU)។

១០.៣ ចូរពិពណ៌នាពីការរីកចម្រើនរបស់សហភាពអឺរ៉ុប ទាក់ទងនឹងកំណើនរដ្ឋសមាជិកនិងកំណត់រកបញ្ហាប្រឈមពីរ ដែលកើតចេញពីកំណើននេះ។

១០.៤ ចូរពន្យល់ពីវិធីពីរយ៉ាងដែលព័ត៌មានអាចក្លាយជាឧបករណ៍សម្រាប់រដ្ឋាភិបាល និងវិធីពីរយ៉ាងដែលព័ត៌មានអាចក្លាយជាឧបករណ៍សម្រាប់ប្រឆាំងនឹងរដ្ឋាភិបាល។

១០.១. សាកលភាវូបនីយកម្ម និងសមាហរណកម្ម

១០.១ ចូរស្វែងរកកម្លាំងឬសំពាធពីរផ្ទុយគ្នា ដែលអង្គការអន្តរជាតិទាំងអស់ត្រូវប្រឈមមុខ។

ប្រធានបទទូទៅក្នុងកិច្ចពិភាក្សាភាគច្រើនអំពីសកលភាវូបនីយកម្មគឺអារម្មណ៍ឬមនោសញ្ចេតនាមួយ ដែលថាមានកម្លាំងអ្វីមួយនៅក្នុងពិភពលោកដែលនាំយើងទាំងអស់គ្នាអោយកាន់តែជិតស្និទ្ធនឹងគ្នា។ ក្នុងចំណោមនោះ កម្លាំងខ្លះគឺជាលទ្ធផលនៃការសម្រេចចិត្តរបស់រដ្ឋ (ដូចដែលយើងបានពិភាក្សានៅក្នុងមេរៀនទី ៨) រដ្ឋនានាបានព្យាយាមធ្វើសមាហរណកម្មសេដ្ឋកិច្ចរបស់ពួកគេ តាមកិច្ចព្រមព្រៀងពាណិជ្ជកម្មរយៈសេរី។ កម្លាំងផ្សេងទៀត ជាឧទាហរណ៍ គឺការវិវត្តន៍បច្ចេកវិទ្យាដែលមានឥទ្ធិពលលើរបៀបដែលរដ្ឋ តួអង្គមិនមែនរដ្ឋ និងសូម្បីតែពលរដ្ឋនីមួយៗបំពេញមុខងារ ជារៀងរាល់ថ្ងៃ។

មេរៀននេះពិភាក្សាអំពីប្រភពនៃ«ការរួមគ្នា»បែបនេះ។ ជាបឋម យើងនឹងពិភាក្សាអំពីការសម្រេចចិត្តរបស់រដ្ឋក្នុងការធ្វើកិច្ចសហប្រតិបត្តិការដើម្បីបង្កើតអង្គការអន្តរជាតិ ដែលមាន**បរមានុភាព**(supranational) ដែលគ្របដណ្តប់ពីលើជាតិជាសមាជិក (ពួកគេរួមបញ្ចូលរដ្ឋមួយចំនួន និងមុខងាររបស់វាទៅជាអង្គភាពរួមមួយ)។ ដូចដែលបានដឹងរួចហើយថា អង្គការសហប្រជាជាតិ (អ.ស.ប.) មានទិដ្ឋភាពគ្របដណ្តប់ពីលើជាតិខ្លះដែរ បើទោះបីជាពួកគេត្រូវកំណត់ដោយធម្មនុញ្ញអង្គការសហប្រជាជាតិ ដែលផ្អែកលើអធិបតេយ្យភាពរបស់រដ្ឋ ក៏ដោយ។ នៅក្នុងកម្រិតតំបន់ សហភាពអឺរ៉ុប(EU) គឺជាអង្គភាពដែលមានលក្ខណៈគ្របដណ្តប់ពីលើជាតិ ខ្លាំងជាងអង្គការសហប្រជាជាតិ។ អង្គការក្នុងតំបន់ផ្សេងទៀតបានព្យាយាមដើរតាមគន្លងរបស់អឺរ៉ុបផងដែរ ប៉ុន្តែទទួលបានជោគជ័យនៅមានកម្រិត។

អង្គការអន្តររដ្ឋាភិបាល(IGOs)ទាំងនេះសុទ្ធតែមានការប្រជែងផ្ទៃក្នុងខ្លាំងក្លា រវាងកម្លាំងពីរផ្ទុយគ្នា៖ លទ្ធិជាតិនិយម និងបរមានុភាព(supranational) (រវាងអធិបតេយ្យភាពរបស់រដ្ឋនិងសិទ្ធិអំណាចជាន់ខ្ពស់ក្នុងរចនាសម្ព័ន្ធអង្គការបរមានុភាព)។ កំណើនប្រតិកម្មប្រឆាំងនឹងចរន្តសកលភាវូបនីយកម្មជាប់ពាក់ព័ន្ធនឹងប្រធានបទនៃការធ្វើសមាហរណកម្មផងដែរ។ គ្មានឧទាហរណ៍ណាមួយជំរុញអោយមានកម្លាំងប្រកួតប្រជែងរវាងជាតិនិយមនិងលទ្ធិបរមានុភាព ច្រើនជាងការសម្រេចចិត្តរបស់ចក្រភពអង់គ្លេសក្នុងឆ្នាំ ២០១៦ ក្នុងការចាកចេញពីសហភាពអឺរ៉ុបនោះទេ។ ពលរដ្ឋអង់គ្លេសភាគច្រើនបានបោះឆ្នោតផ្តល់អាទិភាពដល់ជាតិនិយម

ខ្លួនច្រើនជាងគម្រោងសមាហរណកម្មអឺរ៉ុប ដែលបង្កអោយមានការចរចាដ៏ជូរចត់ដែលអូសបន្លាយយ៉ាងយូរ រវាងរាជរដ្ឋាភិបាលអង់គ្លេសនិងសហភាពអឺរ៉ុបស្តីពីវិធីរុះរើរកិច្ចសហប្រតិបត្តិការជាច្រើនទសវត្សរ៍។ ចក្រភពអង់គ្លេសគ្រោងនឹងចាកចេញពីសហភាពអឺរ៉ុប នៅខែមីនាឆ្នាំ ២០១៩ ។

ប្រភពផ្សេងទៀតនៃ«ការរួមគ្នា»ដែលយើងពិនិត្យមើល គឺការវិវត្តន៍បច្ចេកវិទ្យា ជាពិសេស បដិវត្តន៍បច្ចេកវិទ្យាព័ត៌មាន ដូចជាអ៊ីនធឺរណែតជាដើម។ បច្ចេកវិទ្យាទាំងនេះអាចមានឥទ្ធិពលកាន់តែទូលំទូលាយព្រោះវាដំណើរការជាសកលនិងក្នុងកម្រិតតំបន់ ឆ្លងកាត់ព្រំដែនរដ្ឋដោយគ្មានរចនាសម្ព័ន្ធនយោបាយផ្លូវការ។ ពួកយើងស្ទើរតែទាំងអស់ទទួលរងផលប៉ះពាល់ដោយបច្ចេកវិទ្យាព័ត៌មាន ដែលបាននាំយើងអោយកាន់តែជិតស្និទ្ធជាមួយគ្នានៅក្នុងរដ្ឋ ក្នុងកម្រិតតំបន់ ឬជុំវិញពិភពលោក។

មិនថាប្រភពនៃការធ្វើសមាហរណកម្មចេញមកពីរដ្ឋឬតួអង្គមិនមែនរដ្ឋនោះទេ ដំណើរការនៃការធ្វើសមាហរណកម្មតែងតែពាក់ព័ន្ធនឹងតួអង្គឬបញ្ហាឆ្លងព្រំដែនជាតិ។ *តួអង្គឆ្លងព្រំដែនជាតិ* (transnational actors) (ឧទាហរណ៍ដូចជាសាជីវកម្មពហុជាតិ[MNCs] និងអង្គការមិនមែនរដ្ឋាភិបាល [NGOs]) តភ្ជាប់ស្ថានឆ្លងព្រំដែនជាតិនីមួយៗ ដោយបង្កើតផ្លូវថ្មីសម្រាប់វប្បធម៌ពឹងពាក់គ្នាទៅវិញទៅមកក្នុងចំណោមរដ្ឋ។ *បញ្ហាឆ្លងព្រំដែនជាតិ*(transnational issues) (ឧទាហរណ៍ដូចជាកំណើនកំដៅសកល ឬការរីករាលដាលនៃបច្ចេកវិទ្យាព័ត៌មាន) គឺជាដំណើរការដែលជម្រុញអោយរដ្ឋធ្វើការរួមគ្នា ព្រោះវាមិនអាចដោះស្រាយ ឬគ្រប់គ្រងបញ្ហាសកលតែម្នាក់ឯងបានទេ។ មេរៀននេះស្វែងយល់ពីរបៀបដែលតួអង្គនិងបញ្ហាឆ្លងព្រំដែនជាតិអាចនាំទៅដល់ការធ្វើសមាហរណកម្មឬការរួមបញ្ចូលគ្នា តាមរយៈសកម្មភាពរបស់រដ្ឋ ឬតាមរយៈការផ្លាស់ប្តូរឬវិវត្តន៍នៃបច្ចេកវិទ្យា។

១០.២. ទ្រឹស្តីសមាហរណកម្ម

១០.២ ចូរប្រើទ្រឹស្តីមុខងារនិយម (functionalist) ដើម្បីពន្យល់អំពីការបង្កើតនិងការរីកចម្រើនរបស់សហភាពអឺរ៉ុប (EU)។

ទ្រឹស្តីនៃការធ្វើសមាហរណកម្មអន្តរជាតិព្យាយាមពន្យល់ពីមូលហេតុដែលរដ្ឋនានាជ្រើសរើសលទ្ធិ ឬ អង្គការដែលមានបរមានុភាព(supranationalism) ដែលប្រឈមនឹងមូលដ្ឋានគ្រឹះនៃទ្រឹស្តីប្រាកដនិយមម្តងទៀត (អធិបតេយ្យភាពរដ្ឋនិងបូរណភាពទឹកដី)។ សមាហរណកម្មអន្តរជាតិ សំដៅលើដំណើរការដែលស្ថាប័នកំពូលជំនួសប្រទេសជាតិ ពោលគឺការផ្លាស់ប្តូរបន្តិចម្តងៗនៃអធិបតេយ្យភាពពីរដ្ឋទៅរចនាសម្ព័ន្ធក្នុងតំបន់ ឬសកល។ ការបង្ហាញចុងក្រោយនៃការធ្វើសមាហរណកម្មនឹងជាការច្របាច់បញ្ចូលគ្នានៃរដ្ឋជាច្រើន (ឬច្រើន) ទៅជារដ្ឋតែមួយ ឬចុងក្រោយទៅជារដ្ឋាភិបាលពិភពលោកតែមួយ។ ការផ្លាស់ប្តូរអធិបតេយ្យភាពទៅកម្រិតអធិបតេយ្យភាពបែបនេះ ប្រហែលជាមានកំណែមួយចំនួននៃសហព័ន្ធនិយម ដែលរដ្ឋ ឬ អង្គភាពនយោបាយផ្សេងទៀតទទួលស្គាល់។ អធិបតេយ្យភាពរបស់រដ្ឋាភិបាលកណ្តាល ខណៈពេលដែលរក្សាអំណាចជាក់លាក់សម្រាប់ខ្លួនគេ។ នេះគឺជាទម្រង់រដ្ឋាភិបាលដែលបានអនុម័ត (បន្ទាប់ពីការជជែកពិភាក្សាខ្លះ) នៅក្នុងរដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិក។

នៅក្នុងការអនុវត្ត ដំណើរការនៃការធ្វើសមាហរណកម្មមិនដែលហួសពីការចែករំលែកអំណាចមួយផ្នែក និងមិនស្រួលរវាងកម្រិតរដ្ឋ និងកម្រិតកំពូលនោះទេ។ រដ្ឋនានាមិនមានឆន្ទៈក្នុងការបោះបង់ការទាមទារផ្តាច់មុខរបស់ពួកគេចំពោះអធិបតេយ្យភាព និងបានកំណត់អំណាច និងសិទ្ធិអំណាចនៃស្ថាប័នកំពូល។

អង្គការសហប្រជាជាតិពិតជាខ្វះគំរូសហព័ន្ធ (សូមមើលមេរៀនទី ៧)។ វាតំណាងអោយតែដំហានមួយក្នុងទិសដៅនៃសមាហរណកម្មអន្តរជាតិ។ ឧទាហរណ៍តិចតួចផ្សេងទៀតនៃដំណើរការសមាហរណកម្មត្រូវបានជួបប្រទះនៅក្នុងមេរៀនមុនៗ ឧទាហរណ៍កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាមេរិកខាងជើង (NAFTA) និងអង្គការពាណិជ្ជកម្មពិភពលោក (WTO)។ ប៉ុន្តែ ការរៀបចំទាំងនេះស្ទើរតែមិនប្រកួតប្រជែងលើបូរណភាពទឹកដីរបស់រដ្ឋ ហើយជាធម្មតាប្រឈមនឹងអធិបតេយ្យភាពនយោបាយលើបញ្ហាមួយចំនួនតូចប៉ុណ្ណោះ(ដូចជាពាណិជ្ជកម្ម)។

រូបថត ការប្រណាំងកង់ឆ្លងកាត់សហភាពអឺរ៉ុប

ឆ្លងកាត់ព្រំដែន

ដំណើរការសមាហរណកម្មនៅអឺរ៉ុបនិងកន្លែងផ្សេងទៀតកំពុងធ្វើអោយព្រំដែនរដ្ឋអាចរលុប បណ្តាលអោយមនុស្ស ទំនិញ និងគំនិត ជ្រាបចូលគ្នា បង្កើនការពឹងពាក់គ្នាទៅវិញទៅមក។ សហភាពអឺរ៉ុបកំពុងធ្វើសមាហរណកម្មសេដ្ឋកិច្ចកាន់តែស៊ីជម្រៅ ខណៈដែលកំពុងពង្រីកទៅអឺរ៉ុបខាងកើត។ នៅទីនេះក្នុងឆ្នាំ ២០០៦ Tour de France ឆ្លងកាត់ប្រទេសអាឡឺម៉ង់ ដោយឆ្លងកាត់តែផ្លាកសញ្ញាផ្លូវមួយ ដែលកាលពីប៉ុន្មានសតវត្សរ៍មុន កងទ័ពច្រើនសន្ធឹកសន្ធាប់កំពុងប្រឈមមុខដាក់គ្នា ពីបន្ទាយដ៏ធំរៀងខ្លួន។

ឧទាហរណ៍ដ៏ជោគជ័យបំផុតនៃដំណើរការធ្វើសមាហរណកម្មមកដល់ពេលនេះ (ទោះបីជាជោគជ័យនោះគ្រាន់តែជាផ្នែកខ្លះ) គឺសហភាពអឺរ៉ុប។ ការសម្របសម្រួលក្នុងតំបន់ទាំងអស់ នៅឥឡូវនេះកើតឡើងនៅអឺរ៉ុបខាងលិច គឺជាបាតុភូតប្រវត្តិសាស្ត្រថ្មីមួយ ដែលសម្រេចបានតាំងពីសង្គ្រាមលោកលើកទី២ មកម្ល៉េះ។

រហូតមកដល់ ៥០ ឆ្នាំមុន ទ្វីបអឺរ៉ុបគឺជាតំណាងនៃអធិបតេយ្យភាពជាតិ ការប្រជែងគ្នារបស់រដ្ឋ និងសង្គ្រាម។ អស់រយៈពេល ៥០០ ឆ្នាំរហូតដល់ឆ្នាំ ១៩៤៥។ រដ្ឋនៃទ្វីបអឺរ៉ុបត្រូវបានជាប់គាំងក្នុងសង្គ្រាមរ៉ាំរ៉ៃ។ នៅសតវត្សរ៍ទី ២០ តែម្នាក់ឯង សង្គ្រាមលោកពីរបានបន្សល់ទុកទ្វីបនេះនៅក្នុងការបំផ្លិចបំផ្លាញ។ រដ្ឋនៅអឺរ៉ុបមានប្រវត្តិសាស្ត្រ និងសម័យបច្ចុប្បន្នភាពខុសគ្នាខាងសាសនា ជនជាតិ និងវប្បធម៌។ សមាជិក ២៨ នៃសហភាពអឺរ៉ុបក្នុងឆ្នាំ ២០១៥ បាននិយាយ ២៤ ភាសាផ្សេងគ្នា។ ប្រសិនបើធ្លាប់មានបេក្ខជនសម្រាប់ការបរាជ័យនៃការធ្វើសមាហរណកម្មអឺរ៉ុបនឹងហាក់ដូចជាវា។ អ្វីដែលគួរអោយភ្ញាក់ផ្អើលជាងនេះទៅទៀត សមាហរណកម្មអឺរ៉ុប បានចាប់ផ្តើមជាមួយនឹងកិច្ចសហប្រតិបត្តិការនៃសត្រូវដ៏ជូរចត់បំផុតរបស់អឺរ៉ុប ក្នុងរយៈពេល ១០០ ឆ្នាំមុន សត្រូវនៅក្នុងសង្គ្រាមធំបីចាប់តាំងពីឆ្នាំ ១៨៧០ -បារាំង និងអាឡឺម៉ង់ (ពាក្យ«អាឡឺម៉ង់»នេះ សំដៅទៅលើអាឡឺម៉ង់ខាងលិចពីឆ្នាំ ១៩៤៤ ដល់ឆ្នាំ ១៩៩០ និងចាប់តាំងពីការបង្រួបបង្រួមអាឡឺម៉ង់)។

ប្រការដែលបណ្តារដ្ឋនៅអឺរ៉ុបខាងលិចបានចាប់ផ្តើមបង្កើតស្ថាប័នបរមានុភាព និងបង្កើតសហគមន៍សេដ្ឋកិច្ចដើម្បីលើកកម្ពស់ពាណិជ្ជកម្មសេរី និងសម្របសម្រួលគោលនយោបាយសេដ្ឋកិច្ច បានទាក់ទាញចំណាប់អារម្មណ៍របស់អ្នកប្រាជ្ញទំនាក់ទំនងអន្តរជាតិដែលប្រើប្រាស់ពាក្យសមាហរណកម្ម ដើម្បីពិពណ៌នាអំពីអ្វីដែលពួកគេបានសង្កេតឃើញ។ សមាហរណកម្មហាក់បីដូចជាបានជំទាស់នឹងការសន្មត់របស់ទ្រឹស្តីប្រាកដនិយមដែលថា រដ្ឋមានស្វ័យភាពយ៉ាងតឹងរឹង ហើយនឹងមិនផ្តល់អំណាច ឬ អធិបតេយ្យភាពឡើយ។

អ្នកប្រាជ្ញទាំងនេះបានស្នើថា ចលនាអឺរ៉ុបឆ្ពោះទៅរកសមាហរណកម្មអាចត្រូវបានពន្យល់យ៉ាងល្អដោយទ្រឹស្តីមុខងារនិយម (Functionalism) ដែលជាការរីកចម្រើននៃអង្គការបច្ចេកទេសឯកទេសឆ្លងកាត់

ព្រំដែនជាតិ។ យោងទៅតាមអ្នកទ្រឹស្តីមុខងារនិយម ការអភិវឌ្ឍន៍ផ្នែកបច្ចេកវិទ្យានិងសេដ្ឋកិច្ចនាំទៅដល់រចនាសម្ព័ន្ធបរមានុភាពកាន់តែខ្លាំងឡើង ដោយសាររដ្ឋស្វែងរកមធ្យោបាយជាក់ស្តែង ដើម្បីបំពេញមុខងារចាំបាច់ដូចជាការបញ្ជូនសំបុត្រពីប្រទេសមួយទៅប្រទេសមួយទៀត ឬ ការសម្របសម្រួលការប្រើប្រាស់ទន្លេដែលឆ្លងកាត់ព្រំដែន។ នៅពេលដែលការតភ្ជាប់ទាំងនេះកាន់តែក្រាស់ និងលំហូរកាន់តែលឿន មុខងារបានព្យាករណ៍ថា រដ្ឋនានានឹងត្រូវបានភ្ជាប់មកជារចនាសម្ព័ន្ធសេដ្ឋកិច្ចអន្តរជាតិកាន់តែរឹងមាំ។

ទោះជាយ៉ាងណាក៏ដោយ បទពិសោធន៍របស់អឺរ៉ុបបានហួសពីការបង្កើតទីភ្នាក់ងារឯកទេស ដើម្បីរួមបញ្ចូលការអភិវឌ្ឍនៃស្ថាប័ននយោបាយទូទៅនិងច្រើនជាងមុនដូចជាសភាអឺរ៉ុបជាដើម។ ទ្រឹស្តីមុខងារនិយមថ្មី (Neofunctionalism) គឺជាការកែប្រែលើទ្រឹស្តីមុខងារនិយមដោយអ្នកប្រាជ្ញទំនាក់ទំនងអន្តរជាតិ ដើម្បីពន្យល់ពីការអភិវឌ្ឍន៍ទាំងនេះ។ អ្នកទ្រឹស្តីមុខងារនិយមថ្មីអះអាងថា សមាហរណកម្មសេដ្ឋកិច្ច (មុខងារនិយម) បង្កើតអោយមានចន្លនយោបាយ ដែលជំរុញអោយមានសមាហរណកម្មបន្ថែមទៀត។ ទំនាក់ទំនងសេដ្ឋកិច្ចកាន់តែជិតស្និទ្ធទាមទារអោយមានការសម្របសម្រួលផ្នែកនយោបាយបន្ថែមទៀត ដើម្បីដំណើរការប្រកបដោយប្រសិទ្ធភាពនិងជាយថាហេតុនាំទៅរកការធ្វើសមាហរណកម្មនយោបាយផងដែរ (ជាដំណើរការដែលត្រូវគេហៅថា *ផលជះហូរហៀរ* [spillover])។

អ្នកប្រាជ្ញមួយចំនួនបានផ្តោតលើ*អារម្មណ៍សាមគ្គីជាធ្លុងក្នុងសហគមន៍* (sense of community) អរូបី(អារម្មណ៍«យើង»)ដែលបានចាប់ផ្តើមអភិវឌ្ឍក្នុងចំណោមជនជាតិអឺរ៉ុប ដែលផ្ទុយពីអារម្មណ៍ជាតិនិយមដែលនៅតែមានផងដែរ។ ការរំពឹងទុកទាបនៃអំពើហិង្សាក្នុងចំណោមរដ្ឋនៃអឺរ៉ុបខាងលិចបានបង្កើត**សហគមន៍សន្តិសុខ**(security community) ដែលអារម្មណ៍បែបនេះអាចកើនឡើង។ នេះជាឧទាហរណ៍ចម្បងនៃគោលការណ៍អត្តសញ្ញាណដែលបានពិភាក្សាក្នុងមេរៀនទី ១។

នៅកន្លែងផ្សេងទៀតក្នុងពិភពលោក សេដ្ឋកិច្ចកាន់តែមានភាពពឹងផ្អែកលើគ្នា ទាំងក្នុងកម្រិតតំបន់ និងពិភពលោក។ នៅអាស៊ី សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(អាស៊ាន) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៦៧ បានទទួលជោគជ័យមួយចំនួន ក្នុងការលើកកម្ពស់ការសម្របសម្រួលសេដ្ឋកិច្ចក្នុងតំបន់ ក្នុងរយៈពេលជាច្រើនទសវត្សរ៍។ ទីផ្សាររួមអានដៀន (Andean) ដែលបានចាប់ផ្តើមនៅឆ្នាំ ១៩៦៩ បានលើកកម្ពស់កម្រិតនៃការធ្វើសមាហរណកម្មក្នុងតំបន់ដែលមានកម្រិតនៅក្នុងរដ្ឋជាសមាជិកនៃ វ៉េណេស៊ុយអេឡា កូឡុំប៊ី អេក្វាឌ័រ ប៉េរូ និងបូលីវី។ បណ្តាប្រទេសនៅអាមេរិកខាងត្បូងផ្សេងទៀត (អាហ្សង់ទីន ប្រេស៊ីល ប៉ារ៉ាហ្គាយ និងអ៊ុយរូហ្គាយ) បានបង្កើត*ទីផ្សាររួមខាងត្បូង* (MERCOSUR) ក្នុងឆ្នាំ ១៩៩១ ដើម្បីបង្កើនពាណិជ្ជកម្ម និងសមាហរណកម្មសេដ្ឋកិច្ច។ ថ្មីៗនេះ នៅក្នុងឆ្នាំ ២០០២ បណ្តាប្រទេសនៃទ្វីបអាហ្វ្រិកបានបង្កើតសហភាពអាហ្វ្រិក (AU) ដែលជាផែនការមហិច្ឆិតាក្នុងការសម្របសម្រួលសេដ្ឋកិច្ច និងគោលនយោបាយការបរទេស ជ្រើសរើសសភាអាហ្វ្រិក និងបង្កើតហេដ្ឋារចនាសម្ព័ន្ធរឹងមាំជាងអ្នកកាន់តំណែងមុន អង្គការឯកភាពអាហ្វ្រិក (OAU)។ ជាការពិតណាស់គ្មានអង្គការណាមួយក្នុងចំណោមអង្គការទាំងនេះ បានទទួលភាពជោគជ័យដូចសសហភាពអឺរ៉ុបនោះទេ ប៉ុន្តែគោលបំណងរបស់ពួកគេជារឿយៗមានលក្ខណៈស្រដៀងគ្នា។

រលកថ្មីនៃការធ្វើសមាហរណកម្មនៅអឺរ៉ុប និងកន្លែងផ្សេងទៀតបានជួបប្រទះនឹងដែនកំណត់ និងការធ្លាក់ចុះផងដែរ។ សមាហរណកម្មកាត់បន្ថយសមត្ថភាពរបស់រដ្ឋក្នុងការការពារខ្លួន និងពលរដ្ឋរបស់ពួកគេពីបញ្ហា និងជម្លោះជាច្រើនរបស់ពិភពលោក។ ជាឧទាហរណ៍ នៅដើមទសវត្សរ៍ឆ្នាំ ១៩៩០ វ៉េណេហ្ស៊ុយអេឡា

បានរកឃើញថា ព្រំដែនបើកចំហរបស់ខ្លួនជាមួយប្រទេសកូឡុំប៊ី បាននាំមកនូវការជឹកជញ្ជូនកូកាអ៊ីនដ៏ច្រើនសន្ធឹកសន្ធាប់ទៅកាន់សហរដ្ឋអាមេរិក។ ជាងនេះទៅទៀត ដោយសាររដ្ឋនានាកាន់តែភ័យខ្លាចអំពើភេរវកម្មឆ្លងដែន លទ្ធភាពនៃព្រំដែនបើកចំហអាចផ្តល់ឱ្យមេដឹកនាំរដ្ឋផ្អាក។ ខណៈដែលជនភៀសខ្លួនរាប់ម៉ឺននាក់ដែលភៀសខ្លួនចេញពីសង្គ្រាមស៊ីវិលស៊ីរីបានចាប់ផ្តើមហូរចូលអឺរ៉ុបក្នុងឆ្នាំ ២០១៥ រដ្ឋនានានៅអឺរ៉ុបបានចាប់ផ្តើមដាក់កម្រិតលើការឆ្លងកាត់ព្រំដែន ដែលពីមុនបានបើកចំហឱ្យនរណាម្នាក់ឆ្លងកាត់ សូម្បីតែគ្មានលិខិតឆ្លងដែនក៏ដោយ។

សមាហរណកម្មអាចមានន័យថាការធ្វើមជ្ឈិមភាពកាន់តែខ្លាំងនៅពេលដែលបុគ្គល ក្រុមក្នុងស្រុក និងប្រជាជនជាតិទាមទារអោយនិយាយបន្ថែមទៀតអំពីកិច្ចការរបស់ខ្លួន។ ការធ្វើសមាហរណកម្មកណ្តាលនៃសិទ្ធិអំណាចនយោបាយ ព័ត៌មាន និងវប្បធម៌ ដែលជាលទ្ធផលនៃការធ្វើសមាហរណកម្មអាចគំរាមកំហែងទាំងសេរីភាពបុគ្គល និងក្រុម។ ក្រុមជនជាតិភាគតិចចង់ការពារវប្បធម៌ ភាសា និងស្ថាប័នផ្ទាល់ខ្លួនរបស់ពួកគេប្រឆាំងនឹងភាពដូចគ្នាដ៏ល្អឥតខ្ចោះ ដែលការរលាយសកល ឬក្នុងតំបន់នឹងបង្កើត។ ជាលទ្ធផល ចំនួននៃរដ្ឋ និងប្រជាពលរដ្ឋរបស់ពួកគេ ដែលកំពុងកើនឡើងនៅក្នុងទ្វីបអឺរ៉ុប និងកន្លែងផ្សេងទៀត បានឆ្លើយតបទៅនឹងរលកថ្មីនៃការធ្វើសមាហរណកម្មជាមួយនឹងលទ្ធិជាតិនិយមឡើងវិញ។

ជាការពិត កងកម្លាំងទាំងនេះបានជម្រុញរលកនៃការបំបែករដ្ឋ ដែលកំពុងដំណើរការប្រឆាំងនឹង (ទោះបីជាក្នុងពេលដំណាលគ្នាជាមួយ) ទំនោរនៃការធ្វើសមាហរណកម្ម នៅក្នុងពិភពលោកបច្ចុប្បន្ន។ រលកនៃការបំបែករដ្ឋ តាមវិធីមួយចំនួន បានចាប់ផ្តើមជាមួយនឹងការរំលាយរបបអាណានិគមនៃអតីតចក្រភពអឺរ៉ុប នៅទ្វីបអាហ្វ្រិក អាស៊ី និងមជ្ឈិមបូព៌ា បន្ទាប់ពីសង្គ្រាមលោកលើកទីពីរ។ បន្ទាប់ពីសង្គ្រាមត្រជាក់ ការបំបែករដ្ឋ បានផ្តោតលើប្រទេសរុស្ស៊ីនិងអឺរ៉ុបខាងកើត ជាពិសេសនៅក្នុងអតីតសហភាពសូវៀត និងអតីតយូហ្គោស្លាវី។ រដ្ឋនៅក្នុងតំបន់ផ្សេងទៀត (សូម៉ាលី ប្រជាធិបតេយ្យកុងហ្គោ ស៊ីរី និងអ៊ីរ៉ាក់) លេចឡើងក្នុងគ្រោះថ្នាក់នៃការបំបែកជាបំណែកៗ នៅក្នុងការអនុវត្តជាក់ស្តែង ប្រសិនបើមិនផ្លូវការ។ បញ្ហាប្រឈមនាពេលបច្ចុប្បន្នចំពោះអ្នកទ្រឹស្តីសមាហរណកម្មគឺត្រូវគិតគូរពីនិន្នាការថ្មីទាំងនេះ ដែលកំពុងដំណើរការប្រឆាំងនឹងការរួមបញ្ចូល។

កម្លាំងនៃការបែកបាក់ ឬ ការបំបែកខ្លួន មិនកើតឡើងចំពោះតែប្រទេសកំពុងអភិវឌ្ឍនោះទេ។ ការកើនឡើងនៃជាតិនិយមសេដ្ឋកិច្ចមានភាពច្បាស់លាស់នៅក្នុងចក្រភពអង់គ្លេសនៅក្នុងការបោះឆ្នោតរបស់ខ្លួនក្នុងឆ្នាំ ២០១៦ ដើម្បីចាកចេញពីសហភាពអឺរ៉ុប។ នៅសហរដ្ឋអាមេរិក ប្រធានាធិបតី ដូណាល់ ត្រាំ បានធ្វើយុទ្ធនាការនៅលើវេទិកានៃ«អាមេរិកមុនគេ»ដែលជាសារនៃមោទនភាពជាតិនិងការប្រឆាំងសកលភាវូបនីយកម្ម។ នៅក្នុងបណ្តាប្រទេសអឺរ៉ុបផ្សេងទៀត ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយនេះបានកត់សម្គាល់ការកើនឡើងនៃគណបក្សជាតិនិយមដែលប្រឆាំងនឹងកិច្ចខិតខំប្រឹងប្រែងសមាហរណកម្មសហភាពអឺរ៉ុប។

ពេញមួយកិច្ចខិតខំប្រឹងប្រែងដែលទទួលបានជោគជ័យ និងមិនបានជោគជ័យ ក្នុងសមាហរណកម្មដំណើរការជាខ្សែទូទៅមួយ ពោលគឺភាពតានតឹងរវាងជាតិនិយម និងភក្តីភាពលើសលប់ (តំបន់និយម ឬ សកលនិយម)។ នៅក្នុងការប៉ុនប៉ងធ្វើសមាហរណកម្មដែលមិនសូវជោគជ័យ ជាតិនិយមស្ទើរតែគ្មានបញ្ហា ហើយសូម្បីតែនៅក្នុងករណីជោគជ័យបំផុតក៏ដោយ ជាតិនិយមនៅតែជាកម្លាំងដ៏ខ្លាំងក្លាមួយ ដែលត្រូវបានចាក់សោរក្នុងការតស៊ូជាបន្តបន្ទាប់ជាមួយនឹងលទ្ធិបរមានុភាព។ ការតស៊ូនេះគឺជាប្រធានបទសំខាន់ សូម្បីតែនៅក្នុងករណីជោគជ័យបំផុតនៃការធ្វើសមាហរណកម្ម ពោលគឺ សហភាពអឺរ៉ុប។

១០.៣. សហភាពអឺរ៉ុប

១០.៣ ចូរពិពណ៌នាពីការរីកចម្រើនរបស់សហភាពអឺរ៉ុប ទាក់ទងនឹងកំណើនរដ្ឋសមាជិកនិងកំណត់រកបញ្ហាប្រឈមពីរ ដែលកើតចេញពីកំណើននេះ។

ដូចអង្គការសហប្រជាជាតិ សហភាពអឺរ៉ុប (EU) ត្រូវបានបង្កើតឡើងក្រោយសង្គ្រាមលោកលើកទី២ ហើយបានអភិវឌ្ឍតាំងពីពេលនោះមក។ ប៉ុន្តែខណៈពេលដែលរចនាសម្ព័ន្ធរបស់អង្គការសហប្រជាជាតិបានផ្លាស់ប្តូរតិចតួចចាប់តាំងពីធម្មនុញ្ញរបស់ខ្លួនត្រូវបានអនុម័ត សហភាពអឺរ៉ុបបានឆ្លងកាត់រលកនៃការពង្រីកជាច្រើននៅក្នុងវិសាលភាព សមាជិកភាព និងបេសកកម្មរបស់ខ្លួនក្នុងរយៈពេល ៥០ ឆ្នាំកន្លងមកនេះ។ សហភាពអឺរ៉ុបសព្វថ្ងៃនេះមានពលរដ្ឋជិត ៥០០ លាននាក់ ហើយលើសពីសេដ្ឋកិច្ចសហរដ្ឋអាមេរិកនៅក្នុងផលិតផលក្នុងស្រុកសរុប (GDP)។

១០.៣.១. ចក្ខុវិស័យនៃសហភាពអឺរ៉ុប

អឺរ៉ុបក្នុងឆ្នាំ ១៩៤៥ ត្រូវបានបំផ្លាញដោយសង្គ្រាម។ ភាគច្រើននៃទស្សវត្សរ៍បន្ទាប់ត្រូវបានចំណាយក្នុងការស្តារឡើងវិញដោយមានជំនួយពីសហរដ្ឋអាមេរិកតាមរយៈផែនការ Marshall។ ប៉ុន្តែរួចទៅហើយ មេដឹកនាំបារាំងពីររូបគឺ លោក ហ្សង់ ម៉ូណេ (Jean Monnet) និង រ៉ូប៊ឺត ហ្សាុយម៉ាន់ (Robert Schuman) កំពុងបង្កើតផែនការដើម្បីអនុវត្តគំនិតនៃមុខងារនិយមនៅក្នុងទ្វីបអឺរ៉ុប ដែលសង្គ្រាមនាពេលអនាគតអាចត្រូវបានរារាំងដោយការបង្កើតទំនាក់ទំនងសេដ្ឋកិច្ចដែលនឹងចងរដ្ឋជាមួយគ្នាជានយោបាយ។

នៅឆ្នាំ ១៩៥០ លោក Schuman ក្នុងឋានៈជារដ្ឋមន្ត្រីការបរទេសបារាំងបានស្នើជំហានតិចតួចដំបូង នោះគឺការរួមបញ្ចូលគ្នានៃឧស្សាហកម្មដែកថែប(ដែក)និងធ្យូងថ្មបារាំងនិងអាឡឺម៉ង់ទៅក្នុងក្របខ័ណ្ឌតែមួយដែលអាចប្រើប្រាស់ធនធានធ្យូងថ្មរបស់រដ្ឋទាំងពីរ និងរោងម៉ាស៊ីនកិនដែកប្រកបដោយប្រសិទ្ធភាពបំផុត។ ធ្យូងថ្ម និងដែកគឺជាគន្លឹះក្នុងការងើបឡើងវិញ និងកំណើនអឺរ៉ុប។ ផែនការ Schuman បានផ្តល់កំណើតនៅឆ្នាំ ១៩៥២ ដល់សហគមន៍ធ្យូងថ្ម និងដែកថែបអឺរ៉ុប (ECSC) ដែលបារាំង និងអាឡឺម៉ង់ត្រូវបានចូលរួមដោយប្រទេសអ៊ីតាលី (ប្រទេសឧស្សាហកម្មធំបំផុតទីបីនៃទ្វីបអឺរ៉ុប) និងដោយប្រទេសតូចៗចំនួនបី គឺ បែលហ្សិក ហូឡង់ និងលុចសំបួរ (ដែលត្រូវហៅរួមគ្នាហៅថា ប្រទេសបេ៊ែលណឺលុច [Benelux])។ រដ្ឋទាំងប្រាំមួយនេះ (ចក្រភពអង់គ្លេសមិនបានចូលរួម) បានធ្វើការតាមរយៈសហគមន៍ធ្យូងថ្ម និងដែកថែបអឺរ៉ុប ដើម្បីកាត់បន្ថយរបាំងពាណិជ្ជកម្មនៅក្នុងធ្យូងថ្ម និងដែកថែប និងដើម្បីសម្របសម្រួលគោលនយោបាយធ្យូងថ្ម និងដែកថែបនិងធ្យូងថ្មរបស់ពួកគេ។ សហគមន៍ធ្យូងថ្មនិងដែកថែបអឺរ៉ុបក៏បានបង្កើតអាជ្ញាធរខ្ពស់ដែលក្នុងកម្រិតខ្លះ អាចរំលងរដ្ឋាភិបាល និងដោះស្រាយដោយផ្ទាល់ជាមួយក្រុមហ៊ុន សហជីព និងបុគ្គល។

ប្រសិនបើធ្យូងថ្មនិងដែកថែបស្តាប់ទៅដូចជាប្រធានបទគួរអោយធុញទ្រាញ់ នោះពិតជាគោលគំនិតរបស់អ្នកមុខងារនិយម។ បញ្ហាដែលពាក់ព័ន្ធជាបញ្ហារបស់វិស្វករ និងអ្នកជំនាញបច្ចេកទេស ហើយមិនគំរាមកំហែងអ្នកនយោបាយទេ។ ចាប់តាំងពីឆ្នាំ ១៩៥២ អ្នកជំនាញបច្ចេកទេសបានបម្រើការជាអ្នកដឹកនាំនៃដំណើរការសមាហរណកម្មក្នុងទិដ្ឋភាពផ្សេងទៀតនៃជីវិតអឺរ៉ុប និងក្រៅវង្វង់អឺរ៉ុប។ (ជាការពិតណាស់ ធ្យូងថ្មនិងដែកថែបមិនត្រូវបានជ្រើសរើសដោយចៃដន្យទេ៖ ទាំងពីរគឺសំខាន់ក្នុងការធ្វើសង្គ្រាម។) ដូចដែលបានរៀបរាប់នៅក្នុងមេរៀនទី ៧ អង្គការអន្តរជាតិបច្ចេកទេស ដូចជាសហភាពប្រៃសណីយ៍សកលបានមកមុនអ្នកនយោបាយដូចជា អង្គការសហប្រជាជាតិ។

សហគមន៍វិទ្យាសាស្ត្រអន្តរជាតិសមនឹងទទួលបានការលើកឡើង ពិសេសក្នុងរឿងនេះ។ ប្រសិនបើអ្នកជំនាញដែកអាឡឺម៉ង់និងបារាំងមានភាពដូចគ្នាជាងអ្នកនយោបាយអាឡឺម៉ង់និងបារាំង ហើយរឿងនេះកាន់តែជាការពិតសម្រាប់សហគមន៍អ្នកវិទ្យាសាស្ត្រ។ សព្វថ្ងៃនេះ សហគមន៍វិទ្យាសាស្ត្រអឺរ៉ុប គឺជាផ្នែកមួយក្នុងចំណោមផ្នែកដែលរួមបញ្ចូលគ្នាជាអន្តរជាតិបំផុតនៃសង្គម។ ជាឧទាហរណ៍ សហភាពអឺរ៉ុបដំណើរការទីភ្នាក់ងារអវកាសអឺរ៉ុប និងមន្ទីរពិសោធន៍ជីវវិទ្យាម៉ូលេគុលអឺរ៉ុប។

ទោះបីជាកិច្ចសហប្រតិបត្តិការបច្ចេកទេសបានទទួលជោគជ័យក្នុងឆ្នាំ ១៩៥២ ក៏ដោយ កិច្ចសហប្រតិបត្តិការផ្នែកនយោបាយនិងយោធាបានបង្ហាញពីការលំបាកជាងច្រើន។ ស្របតាមចក្ខុវិស័យនៃសហភាពអឺរ៉ុបដែលរួបរួម រដ្ឋសមាជិក ECSC ទាំងប្រាំមួយ បានចុះហត្ថលេខាលើសន្ធិសញ្ញាទីពីរក្នុងឆ្នាំ ១៩៥២ ដើម្បីបង្កើតសហគមន៍ការពារអឺរ៉ុបមួយ ដើម្បីធ្វើការឆ្ពោះទៅការរួមបញ្ចូលកងកម្លាំងយោធារបស់អឺរ៉ុបក្រោមថវិកានិងបញ្ជាមួយ។ ប៉ុន្តែសភាបារាំងមិនបានផ្តល់សច្ចាប័នលើសន្ធិសញ្ញានេះទេ ហើយអង់គ្លេសបានបដិសេធមិនចូលរួមក្នុងកម្លាំងបែបនេះទេ។ រដ្ឋECSC ក៏បានពិភាក្សាអំពីការបង្កើតសហគមន៍នយោបាយអឺរ៉ុបក្នុងឆ្នាំ ១៩៥៣ ប៉ុន្តែមិនអាចយល់ព្រមលើលក្ខខណ្ឌរបស់ខ្លួនបានទេ។ ដូច្នេះ ក្នុងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ស្ថាប័នកំពូលបានទទួលជោគជ័យ ប៉ុន្តែក្នុងកិច្ចការនយោបាយ និងយោធា អធិបតេយ្យភាពរបស់រដ្ឋបានយកឈ្នះ។

១០.៣.២. សន្ធិសញ្ញាទីក្រុងរ៉ូម

នៅក្នុងសន្ធិសញ្ញាទីក្រុងរ៉ូម ក្នុងឆ្នាំ ១៩៥៧ រដ្ឋចំនួនប្រាំមួយដូចគ្នា (បារាំង អាឡឺម៉ង់ អ៊ីតាលី បែលហ្ស៊ិក ហូឡង់ លុចសំបួរ) បានបង្កើតស្ថាប័នថ្មីពីរទៀត។ ទីមួយបានពង្រីកគំនិតធ្យូងថ្មនិងដែកថែបទៅជាស្ថាប័នថ្មីថាមពលអាតូមិក។ ស្ថាប័ន**អឺរ៉ាតូម** (Euratom) ដែលជាសហគមន៍ថាមពលអាតូមិកអឺរ៉ុបត្រូវបានបង្កើតឡើងដើម្បីសំរបសំរួលការអភិវឌ្ឍន៍ថាមពលនុយក្លេអ៊ែរ ដោយការប្រមូលផ្តុំធនធានស្រាវជ្រាវ ការវិនិយោគ និងការគ្រប់គ្រង។ វាបន្តដំណើរការនៅថ្ងៃនេះ ជាមួយនឹងសមាជិកភាពដែលបានពង្រីក។ អង្គការទីពីរគឺ*សហគមន៍សេដ្ឋកិច្ចអឺរ៉ុប* (EEC) ក្រោយមកប្តូរឈ្មោះជា *សហគមន៍អឺរ៉ុប* (EC)។

ដូចដែលបានពិភាក្សាយ៉ាងខ្លីនៅក្នុងមេរៀនទី ៨ មានភាពខុសគ្នាសំខាន់ៗរវាង*តំបន់ពាណិជ្ជកម្មសេរី* *សហភាពពន្ធគយ* និង *ទីផ្សាររួម*។ ការបង្កើត**តំបន់ពាណិជ្ជកម្មសេរី** (free trade area) មានន័យថាការដកពន្ធនិងការរឹតបន្តឹងលើចរន្តទំនិញឆ្លងកាត់ព្រំដែន (EEC) ដូចដែលបានធ្វើភ្លាមៗ បន្ទាប់ពីឆ្នាំ១៩៥៧។ បច្ចុប្បន្ននេះ សមាគមពាណិជ្ជកម្មសេរីអឺរ៉ុប (EFTA) គឺជាតំបន់ពាណិជ្ជកម្មសេរី ដែលបានពង្រីកដែលទាក់ទងនឹងសហភាពអឺរ៉ុប។ សមាជិករបស់វារួមមានប្រទេសន័រវេស អ៊ីស្លង់ លិចាឈិនស្តេន និងស្វីស។

នៅក្នុង**សហភាពពន្ធគយ** (custom union) រដ្ឋដែលចូលរួមបានអនុម័តសំណុំពន្ធរួមមួយ ទាក់ទងនឹងទំនិញដែលចូលមកពីខាងក្រៅតំបន់ពាណិជ្ជកម្មសេរី។ បើគ្មានពន្ធរួមគ្នាទេ ប្រភេទទំនិញនីមួយៗអាចត្រូវបាននាំចូលទៅក្នុងរដ្ឋដែលមានពន្ធទាបបំផុត ហើយបន្ទាប់មកនាំចេញឡើងវិញ (ដោយគ្មានពន្ធ) ទៅកាន់រដ្ឋផ្សេងទៀតនៅក្នុងតំបន់ពាណិជ្ជកម្មសេរី។ ទង្វើនេះនឹងគ្មានប្រសិទ្ធភាព។ សន្ធិសញ្ញាទីក្រុងរ៉ូមបានសន្យារដ្ឋទាំងប្រាំមួយដើម្បីបង្កើតសហភាពពន្ធគយនៅឆ្នាំ ១៩៦៩។ សហភាពពន្ធគយបង្កើតពាណិជ្ជកម្មសេរីនិងបើកចំហនៅក្នុងរដ្ឋជាសមាជិករបស់ខ្លួន ដោយនាំមកនូវផលប្រយោជន៍សេដ្ឋកិច្ចមហាធំធេង។ ដូច្នេះ សហភាពពន្ធគយនៅតែជាបេះដូងរបស់សហភាពអឺរ៉ុប និងជាទិដ្ឋភាពមួយដែលត្រូវបានចម្លងយ៉ាងទូលំទូលាយ នៅកន្លែងផ្សេងទៀតក្នុងពិភពលោក។

រូបថត កសិករបែលហ្ស៊ិកកំពុងបាតុកម្មបិទទីស្នាក់ការគណៈកម្មាធិការអឺរ៉ុប
ដាំគ្រាប់ពូជនយោបាយ

នៅក្រោមតំបន់ពាណិជ្ជកម្មសេរីដែលបង្កើតឡើងដំបូងដោយសន្ធិសញ្ញាទីក្រុងរ៉ូម ឆ្នាំ ១៩៥៧ ទំនិញអាចផ្លាស់ទីដោយសេរី ឆ្លងកាត់ព្រំដែនអឺរ៉ុប ដើម្បីទៅដល់អ្នកប្រើប្រាស់ នៅក្នុងប្រទេសសមាជិកនីមួយៗ។ ក្នុងវិស័យកសិកម្ម ការបង្កើតទីផ្សារសេរីរួមគ្នានៅអឺរ៉ុបមិនងាយស្រួលទេ សហគមន៍អឺរ៉ុប (EC)នាពេលនោះ បានអនុម័តគោលនយោបាយកសិកម្មរួម (CAP) ក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ ដើម្បីដោះស្រាយបញ្ហានេះ។ នៅទីនេះ កសិករបែលហ្ស៊ិកបានបិទទីស្នាក់ការគណៈកម្មាធិការអឺរ៉ុប នៅទីក្រុងប្រ៊ុចសែល ប្រទេសបែលហ្ស៊ិក ក្នុងឆ្នាំ ២០១៨ ដើម្បីតវ៉ាចំពោះការផ្លាស់ប្តូរគោលនយោបាយកសិកម្ម។

ទីផ្សាររួម(common market)មានន័យថា បន្ថែមពីលើសហភាពពន្ធគយរដ្ឋជាសមាជិកអនុញ្ញាតអោយកម្លាំងពលកម្ម និងដើមទុន (ក៏ដូចជាទំនិញ) ហូរចេញហូរចូលព្រំដែនរដ្ឋ ដោយសេរី។ ជាឧទាហរណ៍ អ្នកផ្តល់ហិរញ្ញប្បទានបែលហ្ស៊ិកអាចវិនិយោគនៅប្រទេសអាឡឺម៉ង់ ក្នុងលក្ខខណ្ឌដូចគ្នានឹងអ្នកវិនិយោគអាឡឺម៉ង់ដែរ។ ទោះបីជាសន្ធិសញ្ញាទីក្រុងរ៉ូមបានអនុម័តគោលដៅនៃទីផ្សាររួមក៏ដោយ សូម្បីតែសព្វថ្ងៃនេះ វាត្រូវបានសម្រេចបានតែផ្នែកខ្លះប៉ុណ្ណោះ។

ទិដ្ឋភាពសំខាន់មួយនៃទីផ្សាររួមមួយត្រូវបានសម្រេច យ៉ាងហោចណាស់ តាមទ្រឹស្តី នៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០ នៅពេលដែលសហភាពអឺរ៉ុប (ពេលនោះត្រូវហៅថា EC) បានអនុម័ត**គោលនយោបាយកសិកម្មរួម**(CAP)។ នៅក្នុងការអនុវត្តជាក់ស្តែង គោលនយោបាយកសិកម្មរួមបាននាំអោយមានជម្លោះកើតឡើងម្តងទៀត ក្នុងចំណោមរដ្ឋជាសមាជិក និងភាពតានតឹងរវាងជាតិនិយមនិងតំបន់និយម។ សូមចាំថា កសិកម្មគឺជាវិស័យដ៏លំបាកបំផុតមួយនៃសេដ្ឋកិច្ចពិភពលោក ក្នុងការសម្រេចបាននូវពាណិជ្ជកម្មសេរី (សូមមើលមេរៀនទី ៨)។ ដើម្បីលើកស្ទួយស្វ័យភាពជាតិក្នុងវិស័យស្បៀងអាហារ រដ្ឋាភិបាលជាច្រើនបានផ្តល់ប្រាក់ឧបត្ថម្ភដល់កសិករ។ គោលនយោបាយកសិកម្មរួម ត្រូវបានផ្អែកលើគោលការណ៍ដែលថា ការឧបត្ថម្ភធនបានពង្រីកដល់កសិកររនៅក្នុងរដ្ឋសមាជិកណាមួយ គួរតែត្រូវបានពង្រីកអោយដល់ដល់កសិករនៅក្នុងប្រទេសសហភាពអឺរ៉ុបទាំងអស់។ តាមរបៀបនោះ គ្មានរដ្ឋាភិបាលសមាជិកណាមួយត្រូវបានបង្ខំអោយផ្តាច់ខ្លួនកសិករដែលមានអំណាចខាងនយោបាយ ដោយការដកប្រាក់ឧបត្ថម្ភទេ ប៉ុន្តែ គោលនយោបាយរួមនឹងត្រូវបានធ្វើអោយស្មើភាពគ្នាទូទាំងសហគមន៍ស្របតាមគោលការណ៍ទីផ្សាររួម។ ជាលទ្ធផល ការឧបត្ថម្ភធនដល់កសិករ នាពេលបច្ចុប្បន្ននេះស្រូបយក ប្រហែល ៤០ ភាគរយនៃថវិកាសរុបរបស់សហភាពអឺរ៉ុប ដោយមានប្រទេសបារាំងជាអ្នកទទួលផលជាចម្បង ហើយជាប្រភពដ៏ធំបំផុតតែមួយគត់នៃជម្លោះពាណិជ្ជកម្ម រវាងអឺរ៉ុប និងសហរដ្ឋអាមេរិក។

ជំហានបន្ទាប់នៅក្នុងផែនការសម្រាប់សមាហរណកម្មអឺរ៉ុប បន្ទាប់ពីតំបន់ពាណិជ្ជកម្មសេរី សហភាពគយនិងទីផ្សាររួម គឺជាសហភាពសេដ្ឋកិច្ចនិងរូបិយវត្ថុ (EMU) ដែលគោលនយោបាយសេដ្ឋកិច្ចរួមរបស់ប្រទេសជាសមាជិកនឹងត្រូវបានសម្របសម្រួលសម្រាប់ប្រសិទ្ធភាពនិងស្ថិរភាពខ្ពស់បំផុត។ នៅក្នុងជំហានបែបនេះ រូបិយប័ណ្ណរួមតែមួយនឹងជំនួសរូបិយប័ណ្ណជាតិដាច់ដោយឡែកពីគ្នា ដែលឥឡូវនេះកំពុងប្រើប្រាស់ (សូមមើលសហភាពរូបិយវត្ថុ នៅផ្នែកក្រោយនៅក្នុងមេរៀននេះ)។ ជំហានបន្ទាប់ដែលអាចកើតមាននាពេលអនាគត អាចជាការសម្របសម្រួលបែបបរមានុភាព នៃគោលនយោបាយសេដ្ឋកិច្ច ដូចជាថវិកា និងពន្ធ។

ដើម្បីកាត់បន្ថយការព្រួយបារម្ភរបស់មេដឹកនាំរដ្ឋ ដែលខ្លាចបាត់បង់អធិបតេយ្យភាព សន្ធិសញ្ញាទីក្រុងរ៉ូម មានមាត្រាចែងថា រាល់ការផ្លាស់ប្តូរទាំងឡាយនៅក្នុងបទប្បញ្ញត្តិរបស់ខ្លួន ត្រូវតែទទួលបានការអនុម័តដោយរដ្ឋសមាជិកទាំងអស់។ ឧទាហរណ៍ បារាំងបានវេតូពាក្យស្នើសុំរបស់អង់គ្លេស សម្រាប់ចូលសមាជិកភាពនៅក្នុងសហគន៍សេដ្ឋកិច្ចអឺរ៉ុប ក្នុងឆ្នាំ ១៩៦៣ និង ១៩៦៧។ ទោះយ៉ាងណាក៏ដោយ នៅឆ្នាំ ១៩៧៣ ទីបំផុតចក្រភពអង់គ្លេសបានចូលរួមជាមួយប្រទេសអៀរឡង់ និងដាណឺម៉ាក។ សកម្មភាពនេះបានពង្រីកសមាជិកភាពរបស់សហគមន៍ឡើងដល់ទៅប្រាំបួន រួមទាំងប្រទេសធំបំផុត និងប្រទេសអ្នកមានបំផុតនៅក្នុងតំបន់។

នៅឆ្នាំ ១៩៨១ ប្រទេសក្រិកត្រូវបានអនុញ្ញាតអោយចូល ហើយនៅឆ្នាំ ១៩៨៦ ប្រទេសព័រទុយហ្គាល់ និងអេស្ប៉ាញបានចូលរួម។ ការដាក់បញ្ចូលប្រទេសក្រីក្រទាំងនេះដែលមានឧស្សាហកម្មតិច និងស្តង់ដារឬជីវភាពរស់នៅទាប បានបង្កការលំបាកក្នុងការធ្វើសមាហរណកម្មសេដ្ឋកិច្ចរបស់អឺរ៉ុបប្រកបដោយប្រសិទ្ធភាព (ភាពលំបាកដែលនៅតែបន្តកើតមានរហូតដល់សព្វថ្ងៃនេះ)។ រដ្ឋអឺរ៉ុបដែលស្តុកស្តម្ភជាង ផ្តល់ជំនួយយ៉ាងច្រើនដល់រដ្ឋក្រីក្រ ដោយសង្ឃឹមថានឹងអាចពង្រឹងទំនាក់ទំនងដ៏ខ្សោយ។ ប៉ុន្តែ នៅឆ្នាំ ២០១៥ បញ្ហាបំណុលរបស់ប្រទេសទាំងនេះបាននាំអោយរដ្ឋសមាជិកដែលមានទ្រព្យសម្បត្តិច្រើនជាង ចំណាយប្រាក់រាប់ពាន់លានដុល្លារក្នុងមូលនិធិសង្គ្រោះ ខណៈដែលការបន្តភាពចលាចលសេដ្ឋកិច្ច បានគំរាមកំហែងដល់ស្ថិរភាពនៃសេដ្ឋកិច្ចអឺរ៉ុបកាន់តែធំទៅៗ។

១០.៣.៣. រចនាសម្ព័ន្ធនៃសហភាពអឺរ៉ុប

រចនាសម្ព័ន្ធរបស់សហភាពអឺរ៉ុបឆ្លុះបញ្ចាំងពីឫសគល់របស់ខ្លួន ក្នុងកិច្ចសហប្រតិបត្តិការបច្ចេកទេស និងសេដ្ឋកិច្ច។ អ្នកជំនាញធ្យូងថ្មនិងដែកថែបបានចូលរួមដោយអ្នកជំនាញពាណិជ្ជកម្ម កសិកម្ម និងហិរញ្ញវត្ថុដែលជាបេះដូងនៃសហគមន៍។ ទីស្នាក់ការកណ្តាលនិងបុគ្គលិករបស់សហភាពអឺរ៉ុបត្រូវបានគេស្គាល់ថាជា *មន្ត្រីការិយាធិបតេយ្យនិយមគ្មានពណ៌* ដែលជួនកាលគេហៅថា *អឺរ៉ូធិបតេយ្យ* (Eurocrats) ដែលយកចិត្តទុកដាក់លើការដោះស្រាយបញ្ហាបច្ចេកទេសជាជាងរឿងនយោបាយ។ ការិយាធិបតេយ្យបែបsupranational ទាំងនេះមានតុល្យភាពនៅក្នុងរចនាសម្ព័ន្ធសហភាពអឺរ៉ុប ដោយបទប្បញ្ញត្តិដែលលើកតម្កើងអំណាចនៃរដ្ឋ និងមេដឹកនាំរដ្ឋ។


ទោះបីជាការគ្រប់គ្រងរបស់អឺរ៉ូធិបតេយ្យអនុវត្តតាមផែនការមុខងារក៏ដោយ វាបានបង្កបញ្ហានៅពេលដែលសហភាពអឺរ៉ុបបានរីកចម្រើន។ អ្នកនយោបាយនៅក្នុងរដ្ឋជាសមាជិកមានការខ្មាស់អៀនអំពីការបាត់បង់អំណាចទៅអោយអឺរ៉ូធិបតេយ្យ។ ពលរដ្ឋក្នុងរដ្ឋទាំងនោះកាន់តែមិនស្រួល ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ជាមួយនឹងអំណាចកើនឡើងនៃអឺរ៉ូធិបតេយ្យដែលគ្មានមុខលើជីវិតរបស់ពួកគេ។ ប្រជាពលរដ្ឋអាចទម្លាក់មេដឹកនាំនយោបាយរបស់ពួកគេចេញពីតំណែងក្នុងការបោះឆ្នោតជាតិ ប៉ុន្តែ អឺរ៉ូធិបតេយ្យ ហាក់ដូចជាមិនសូវទទួលខុសត្រូវ។

រចនាសម្ព័ន្ធរបស់សហភាពអឺរ៉ុបត្រូវបានបង្ហាញក្នុងក្រាហ្វិក ១០.១។ អឺរ៉ូធិបតេយ្យមានបុគ្គលិកចំនួន ៣៤ ០០០ នាក់ ដែលរៀបចំនៅក្រោមគណៈកម្មាការអឺរ៉ុបនៅទីស្នាក់ការកណ្តាលរបស់សហភាពអឺរ៉ុប នៅទីក្រុងប្រ៊ុចសែល ប្រទេសបែលហ្សិក។ គណៈកម្មការមានសមាជិកម្នាក់ៗចំនួន ២៧ នាក់ ដែលម្នាក់មកពីរដ្ឋសមាជិកនីមួយៗ ដែលត្រូវបានជ្រើសរើសសម្រាប់លក្ខខណ្ឌបន្តរយៈពេល ៤ ឆ្នាំ។ តួនាទីរបស់ពួកគេគឺដើម្បី

កំណត់បញ្ហានិងស្នើដំណោះស្រាយទៅកាន់ក្រុមប្រឹក្សាសហភាពអឺរ៉ុប។ ពួកគេជ្រើសរើសសមាជិកម្នាក់ក្នុងចំណោមសមាជិករបស់ពួកគេជាប្រធានគណៈកម្មការ។ បុគ្គលទាំងនេះត្រូវបានគេសន្មត់ថាតំណាងអោយផលប្រយោជន៍របស់អឺរ៉ុបទាំងមូល(ផលប្រយោជន៍លើសលប់) មិនមែនជារដ្ឋរបស់ពួកគេទេ ប៉ុន្តែ គោលដៅនេះត្រូវបានសម្រេចដោយភាពមិនល្អឥតខ្ចោះប៉ុណ្ណោះ។

ក្រាហ្វិក ១០.១ រចនាសម្ព័ន្ធសហភាពអឺរ៉ុប (EU)

ប្រភព៖ គណកម្មការអឺរ៉ុប នៅក្នុងសហភាពអឺរ៉ុប



គណៈកម្មការអឺរ៉ុបខ្វះអំណាចស្វ័យភាពផ្លូវការ លើកលែងតែប្រតិបត្តិការ សហភាពអឺរ៉ុប ប្រចាំថ្ងៃ។ ជាផ្លូវការ គណៈកម្មការរាយការណ៍ទៅ និងអនុវត្តគោលនយោបាយរបស់ក្រុមប្រឹក្សាសហភាពអឺរ៉ុប (ពីមុនឈ្មោះក្រុមប្រឹក្សារដ្ឋមន្ត្រី)។ ក្រុមប្រឹក្សាគឺជាកិច្ចប្រជុំរបស់រដ្ឋមន្ត្រីនៃវិស័យពាក់ព័ន្ធ (បរទេស សេដ្ឋកិច្ច កសិកម្ម ហិរញ្ញវត្ថុ។ល។) មកពីរដ្ឋសមាជិកនីមួយៗ —អ្នកនយោបាយដែលគ្រប់គ្រងការិយាល័យការិយាធិបតេយ្យ (ឬអ្នកដែលព្យាយាម)។ ជាឧទាហរណ៍ ក្នុងឆ្នាំ ២០១៥ រដ្ឋមន្ត្រីការបរទេសទាំង ២៨ រូបបានជួបប្រជុំគ្នាដើម្បីពិភាក្សាអំពីការកែលម្អកិច្ចខិតខំប្រឹងប្រែងប្រឆាំងភេរវកម្ម និងទំនាក់ទំនងនយោបាយជាមួយរុស្ស៊ី។ រចនាសម្ព័ន្ធផ្លូវការនេះឆ្លុះបញ្ចាំងពីការតស៊ូរបស់រដ្ឋ ក្នុងការផ្តល់អធិបតេយ្យភាព។ វាក៏មានន័យផងដែរថាបុគ្គលដែលចូលរួមបង្កើតក្រុមប្រឹក្សាសហភាពអឺរ៉ុបប្រែប្រួលពីកិច្ចប្រជុំមួយទៅកិច្ចប្រជុំមួយ ហើយថាបញ្ហាបច្ចេកទេសទទួលបានអាទិភាពជាងផ្នែកនយោបាយ។ ការរៀបចំដូច្នេះផ្តល់អត្ថប្រយោជន៍មួយចំនួនត្រឡប់ទៅបុគ្គលិកគណៈកម្មការ។ សូមរំលឹកឡើងវិញនូវភាពតានតឹងស្រដៀងគ្នារវាងអ្នកនយោបាយ និងមន្ត្រីការិយាធិបតេយ្យសក្នុងអាជីពក្នុងការបង្កើតគោលនយោបាយការបរទេសជាតិ (សូមមើល ការិយាធិបតេយ្យនិយម [Bureaucracies] នៅក្នុងមេរៀនទី ៤)។

ក្រុមប្រឹក្សានៃសហភាពអឺរ៉ុប តាមទ្រឹស្តី បានដំណើរការដោយប្រើប្រព័ន្ធបោះឆ្នោតសមាមាត្រ ដោយផ្អែកលើចំនួនប្រជាជនរបស់រដ្ឋនីមួយៗ ប៉ុន្តែ នៅក្នុងការអនុវត្តវា ដំណើរការដោយការឯកភាពលើបញ្ហាគោលនយោបាយសំខាន់ៗ (សមាជិកទាំងអស់ត្រូវតែយល់ព្រម)។ បន្ទាប់ពីការអនុម័តសន្ធិសញ្ញា Lisbon (សូម

មើលផ្នែកបន្ទាប់ ក្នុងមេរៀននេះ) ឥឡូវនេះ បញ្ហាស្នើរតែទាំងអស់ត្រូវបានសម្រេចដោយការបោះឆ្នោតភាគច្រើនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។ និយមន័យនៃសន្ធិសញ្ញានៃភាគច្រើនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ គឺថាយ៉ាងហោចណាស់ ៥៥ ភាគរយនៃសមាជិកសហភាពអឺរ៉ុបដែលតំណាងអោយ ៦៥ ភាគរយនៃពលរដ្ឋសហភាពអឺរ៉ុបត្រូវតែបោះឆ្នោតគាំទ្រ ដើម្បីទទួលបានការអនុម័ត។ ក្រុមប្រឹក្សាមានប្រធានប្តូរវេន (មានអំណាចមានកំណត់)។ ក្រុមប្រឹក្សាសហភាពអឺរ៉ុបត្រូវតែអនុម័តគោលនយោបាយរបស់គណៈកម្មការអឺរ៉ុប និងផ្តល់ទិសដៅទូទៅ។

នៅទសវត្សរ៍ឆ្នាំ ១៩៧០ មេដឹកនាំរដ្ឋ(នាយករដ្ឋមន្ត្រី ឬប្រធានាធិបតី)បានបង្កើតកន្លែងពិសេសមួយសម្រាប់ខ្លួនគេនៅក្នុង EC ដើម្បីត្រួតពិនិត្យការណែនាំរបស់សហគមន៍។ រចនាសម្ព័ន្ធនេះបង្ហាញការតស៊ូរបស់មេដឹកនាំរដ្ឋម្តងទៀតចំពោះការគ្រប់គ្រងដោយស្ថាប័នកំពូលណាមួយ។ ក្រុមប្រឹក្សាអឺរ៉ុបនៃមេដឹកនាំរដ្ឋ ទាំង ២៨ នេះជួបជាមួយប្រធានគណៈកម្មការអឺរ៉ុប ពីរដងក្នុងមួយឆ្នាំ។ ពួកគេគឺជាអ្នកដែលមានអំណាចក្នុងការធ្វើកិច្ចការនានានៅក្នុងរដ្ឋាភិបាលជាតិរៀងៗខ្លួន (ដែលនៅតែគ្រប់គ្រងលុយ និងអំណាចភាគច្រើននៅអឺរ៉ុប)។

មានសកាអឺរ៉ុប ដែលខ្វះផ្នែកខ្លះនៃនីតិបញ្ញត្តិពិត ដែលអនុម័តច្បាប់សម្រាប់អឺរ៉ុបទាំងអស់។ នាពេលបច្ចុប្បន្ននេះ វាដំណើរការមួយផ្នែកជាអ្នកឃ្លាំមើលគណៈកម្មការ ប៉ុន្តែមានអំណាចខ្លះក្នុងការបង្កើតច្បាប់។ វាត្រូវតែអនុម័តថវិការបស់គណៈកម្មការ ប៉ុន្តែមិនអាចគ្រប់គ្រងវាតាមធាតុបានទេ។ សភាចែករំលែកអំណាចជាមួយក្រុមប្រឹក្សាក្រោម «នីតិវិធីសហការសម្រេចចិត្ត» នៅក្នុងផ្នែកដូចជា ការធ្វើចំណាកស្រុក ការងារ សុខភាព និងការការពារអ្នកប្រើប្រាស់។ សន្ធិសញ្ញា Lisbon ឆ្នាំ ២០០៩ បានពង្រីកយ៉ាងសំខាន់នូវផ្នែកដែលនីតិវិធីសហការសម្រេចចិត្តត្រូវបានអនុវត្ត។ វាក៏បម្រើជាវេទិកាជជែកដេញដោល និងជានិមិត្តរូបនៃឯកភាពអឺរ៉ុបផងដែរ។ នៅឆ្នាំ ១៩៩៩ គណៈកម្មការឯករាជ្យដែលបង្កើតឡើងដោយសភាបានរកឃើញភាពសំណល់ និងការក្លែងបន្លំនៅក្នុងគណៈកម្មការអឺរ៉ុប ដែលនាំអោយស្នងការទាំង ២០ លាលែងពីតំណែង។ ចាប់តាំងពីឆ្នាំ ១៩៧៩ អ្នកបោះឆ្នោតនៅទូទាំងទ្វីបអឺរ៉ុបបានជ្រើសរើសតំណាងរបស់ពួកគេដោយផ្ទាល់ យោងទៅតាមចំនួនប្រជាជន -៧៥០ សមាជិកតំណាងពលរដ្ឋអោយជិត ៥០០ លាននាក់។ គណបក្សនយោបាយត្រូវបានរៀបចំតាមបន្ទាត់ជាតិ។

គណៈកម្មាធិការសេដ្ឋកិច្ច និងសង្គមពិភាក្សាអំពីបញ្ហាទូទាំងទ្វីប ដែលប៉ះពាល់ដល់ឧស្សាហកម្ម ឬមណ្ឌលជាក់លាក់។ គណៈកម្មាធិការនេះ ជាទីប្រឹក្សាសុទ្ធសាធ; វាបញ្ចុះបញ្ចូលគណៈកម្មការអឺរ៉ុបលើបញ្ហាដែលខ្លួនយល់ថាសំខាន់។ វាត្រូវបានរចនាឡើងជាវេទិកាដែលក្រុមហ៊ុន សហជីពការងារ និងក្រុមផលប្រយោជន៍អាចចរចាឆ្លងប្រទេសបាន។

តុលាការយុត្តិធម៌អឺរ៉ុបក្នុងប្រទេសលុចសំបួ វិនិច្ឆ័យវិវាទលើបញ្ហាដែលគ្របដណ្តប់ដោយសន្ធិសញ្ញាទីក្រុងរ៉ូម ដែលគ្របដណ្តប់លើបញ្ហាជាច្រើន។ មិនដូចតុលាការពិភពលោកទេ (សូមមើលមេរៀនទី ៧) តុលាការអឺរ៉ុបបានបង្កើតយុត្តាធិការរបស់ខ្លួនយ៉ាងសកម្មខ្លាំងណាស់ ហើយវាក៏មិនបម្រើគ្រាន់តែជាយន្តការនៃការសម្រុះសម្រួលអន្តរជាតិនោះទេ។ តុលាការអឺរ៉ុបអាចបដិសេធច្បាប់ជាតិ ដែលផ្ទុយនឹងច្បាប់របស់សហភាពអឺរ៉ុប ដោយផ្តល់អោយវានូវអំណាចពិសេសក្នុងចំណោមតុលាការអន្តរជាតិ។ លើសពីនេះ វាដំរុញជម្រះក្តីករណីដែលនាំមកដោយបុគ្គល មិនមែនគ្រាន់តែរដ្ឋាភិបាលទេ។ ក្នុងរឿងក្តីរាប់រយករណី តុលាការ

បានសម្រេចលើបញ្ហារាប់ចាប់ពីការរើសអើងក្នុងកន្លែងធ្វើការ រហូតដល់ប្រាក់សោធននិវត្តន៍របស់សមាជិកគណៈកម្មការ។

១០.៣.៤. សន្ធិសញ្ញាអឺរ៉ុបរួម

សមាហរណកម្មអឺរ៉ុបបានដំណើរការក្នុងដំណើរការមួយដំហានម្តងៗ ដែលបង្កើតបានជោគជ័យជាក់ស្តែង កាត់បន្ថយការភ័យខ្លាចរបស់អ្នកនយោបាយក្នុងការបាត់បង់អធិបតេយ្យភាព និងបង្កើតសម្ពាធដើម្បីបន្តដំណើរការនេះ។ ជារឿយៗដំហានសំខាន់ៗឆ្ពោះទៅមុខត្រូវបានបន្តដោយរយៈពេលនៃការជាប់គាំង ឬសូម្បីតែការបញ្ច្រាសនៅក្នុងសមាហរណកម្ម។ ការកែប្រែដ៏សំខាន់ដំបូងនៃសន្ធិសញ្ញាទីក្រុងរ៉ូម-សន្ធិសញ្ញាអឺរ៉ុបរួមឆ្នាំ ១៩៨៥ បានចាប់ផ្តើមដំណាក់កាលថ្មីមួយនៃការពន្លឿនការធ្វើសមាហរណកម្ម។ សហភាពអឺរ៉ុបបានកំណត់កាលបរិច្ឆេទនៃការបញ្ចប់ឆ្នាំ ១៩៩២ សម្រាប់ការបង្កើតទីផ្សាររួមពិតប្រាកដមួយ នៅអឺរ៉ុប។ សំណុំនៃការផ្លាស់ប្តូរដ៏ទូលំទូលាយនេះត្រូវបានគេដាក់ឈ្មោះហៅក្រៅថា *អឺរ៉ុប ១៩៩២* ហើយផ្តោតលើការណែនាំប្រហែល ៣០០ ពីគណៈកម្មការអឺរ៉ុប។ មានគោលបំណងលុបបំបាត់ឧបសគ្គមិនមែនពន្ធចំពោះពាណិជ្ជកម្មសេរីលើទំនិញ សេវាកម្ម កម្លាំងពលកម្ម និងដើមទុន នៅក្នុងEC។ បញ្ហាមានទំនោរទៅស្មុគស្មាញ និងបច្ចេកទេស។ ជាឧទាហរណ៍ អ្នកជំនាញដែលមានអាជ្ញាប័ណ្ណក្នុងរដ្ឋមួយគួរតែមានសេរីភាពក្នុងការអនុវត្តនៅក្នុងរដ្ឋមួយទៀត ប៉ុន្តែការផ្តល់អាជ្ញាប័ណ្ណរបស់អេស្ប៉ាញតម្រូវការសម្រាប់អ្នកព្យាបាលរាងកាយអាចមានភាពខុសគ្នាពីប្រទេសអង់គ្លេស។ គណៈកម្មាធិការាយិធិបតេយ្យបានធ្វើការដើម្បីលុបបំបាត់ភាពមិនស៊ីសង្វាក់គ្នា និងបង្កើតស្តង់ដារឯកសណ្ឋាន។ រដ្ឋាភិបាលជាតិនីមួយៗត្រូវអនុម័តច្បាប់ ដើម្បីអនុវត្តវិធានការទាំងនេះ។

ជាឧទាហរណ៍ ជម្លោះបានផ្ទុះឡើងអស់ជាច្រើនទសវត្សរ៍ជុំវិញនិយមន័យនៃសូកូឡា។ ប្រទេសបែលហ្ស៊ិក ដែលល្បីល្បាញខាងសូកូឡា តម្រូវអោយមានការប្រើប្រាស់ផ្តាច់មុខនៃប៊ឺកាកាវសម្រាប់ផលិតផលដែលត្រូវបានគេហៅថាសូកូឡា ចក្រភពអង់គ្លេសនិងប្រទេសផ្សេងទៀតប្រើប្រាស់ដំណើរការថោកជាង ដែលជំនួសដោយផ្នែកខ្លះនៃប្រេងបន្លែផ្សេងទៀត។ ជាមួយនឹងការធ្វើសមាហរណកម្មកាន់តែស៊ីជម្រៅ និងពាណិជ្ជកម្មគ្មានថ្នេរ បែលហ្ស៊ិកព្រួយបារម្ភថា ខ្លួននឹងបាត់បង់អត្ថប្រយោជន៍ប្រកួតប្រជែងរបស់ខ្លួន នៅក្នុងទីផ្សារសូកូឡាទូទាំងពិភពលោកដែលមានទឹកប្រាក់ ៣០ ពាន់លានដុល្លារ (ពាក់កណ្តាលមកពីអឺរ៉ុប)។ ចក្រភពអង់គ្លេស និងបណ្តាប្រទេសសហភាពអឺរ៉ុបចំនួនប្រាំមួយផ្សេងទៀត ដែលបានចូលរួមជាមួយសហភាពអឺរ៉ុប ចាប់តាំងពីឆ្នាំ ១៩៧៣ បានឈ្នះការលើកលែងពីច្បាប់ម្សៅកាកាវទាំងអស់ដែលអនុវត្តចំពោះសមាជិកសហភាពអឺរ៉ុបចំនួនប្រាំបីផ្សេងទៀត។ ទោះយ៉ាងណាក៏ដោយ ក្រោមសម្ពាធនៃការធ្វើសមាហរណកម្ម សហភាពអឺរ៉ុបកំពុងឈានទៅរកការបង្រួបបង្រួមស្តង់ដារ ដូចជាបទប្បញ្ញត្តិអាហារជាដើម។ សង្គ្រាមសូកូឡាបង្ហាញថា គំនិតដែលហាក់ដូចជាសាមញ្ញនៃសមាហរណកម្មសេដ្ឋកិច្ចកំណត់នៅក្នុងចលនានៃការផ្លាស់ប្តូរដែលឈានដល់គ្រប់ជ្រុងនៃសង្គម និងប៉ះពាល់ដល់ជីវិតប្រចាំថ្ងៃរបស់មនុស្សរាប់លាននាក់។

សន្ធិសញ្ញាអឺរ៉ុបរួម ក៏បានផ្តល់នូវការជំរុញថ្មីមួយដល់ការបង្កើតធនាគារកណ្តាលអឺរ៉ុប (នៅទីក្រុងហ្វ្រែងហ្វឺត ប្រទេសអាឡឺម៉ង់) និងរូបិយប័ណ្ណ និងប្រព័ន្ធរូបិយវត្ថុរួមតែមួយ ដែលជាគោលដៅយូរអង្វែងដែលបានសម្រេចតាំងពីពេលនោះមក។ ដរាបណាសេដ្ឋកិច្ចនៃសមាជិកសហភាពអឺរ៉ុបត្រូវបានចងភ្ជាប់ជាមួយរដ្ឋដាច់ដោយឡែក (ជាមួយធនាគារកណ្តាលដាច់ដោយឡែក) កិច្ចខិតខំប្រឹងប្រែងដើម្បីរក្សាអត្រាប្តូរ

ប្រាក់ថេរគឺពិបាកណាស់។ ជាឧទាហរណ៍ អ្នកនយោបាយអង់គ្លេស ក្នុងឆ្នាំ ១៩៩២ មានការស្ទាក់ស្ទើរក្នុងការធ្វើអោយសេដ្ឋកិច្ចធ្លាក់ចុះ ដោយរក្សាអត្រាការប្រាក់អោយខ្ពស់ ដើម្បីជួយសង្គ្រោះអ្នកនយោបាយ អាឡឺម៉ង់ពីអតិផរណា ដែលអាចបណ្តាលមកពីការបញ្ចុះអត្រាការប្រាក់។

ដំណើរការឆ្នាំ ១៩៩២ បានផ្លាស់ប្តូរសមាហរណកម្មសេដ្ឋកិច្ចទៅក្នុងផ្នែកនយោបាយ និងវិវាទកាន់តែច្រើន ដោយលុបបំបាត់អធិបតេយ្យភាពកាន់តែជាក់ស្តែងជាងមុន។ វាក៏បានធ្វើអោយកាន់តែស៊ីជម្រៅផងដែរនូវនិន្នាការឆ្ពោះទៅរកការដោះស្រាយដោយផ្ទាល់របស់សហភាពអឺរ៉ុបជាមួយខេត្តជាជាងរដ្ឋ ដែលពួកគេជាកម្មសិទ្ធិ ដូច្នេះចាប់ផ្តើមចោះ«ប្រហោង»រដ្ឋពីខាងក្រោម (រដ្ឋាភិបាលខេត្តខ្លាំងជាង) ក៏ដូចជាពីខាងលើ (រដ្ឋាភិបាលខ្លាំងជាងនៅអឺរ៉ុប)។ ទោះជាយ៉ាងណាក៏ដោយ អឺរ៉ុបឆ្នាំ ១៩៩២ បានបន្តទុកមួយឡែកសម្រាប់អនាគតបញ្ហាលំបាកនៃការធ្វើសមាហរណកម្មនយោបាយ និងយោធា។

១០.៣.៥. សន្ធិសញ្ញាទីក្រុងម៉ាស្ត្រីស

សន្ធិសញ្ញាម៉ាស្ត្រីក (Maastricht) ដែលបានចុះហត្ថលេខានៅទីក្រុងម៉ាស្ត្រីករបស់ប្រទេសហូឡង់ក្នុងឆ្នាំ ១៩៩២ បានប្តូរឈ្មោះ EC ជា EU ហើយបានប្តេជ្ញាថា វាឆ្ពោះទៅមុខបន្ថែមទៀតនៅក្នុងវិស័យសំខាន់ៗចំនួនបី។ ទីមួយគឺសហជីពរូបិយវត្ថុ (ត្រូវបានពិភាក្សាយ៉ាងខ្លី) ដែលក្នុងនោះរូបិយប័ណ្ណជាតិដែលមានស្រាប់ត្រូវបានលុបចោល និងជំនួសដោយរូបិយប័ណ្ណអឺរ៉ុបតែមួយ។ សំណុំទីពីរនៃការផ្លាស់ប្តូរ ទាក់ទងនឹងយុត្តិធម៌ និងកិច្ចការផ្ទៃបានបង្កើតទីភ្នាក់ងារប៉ូលីសអឺរ៉ុប និងឆ្លើយតបទៅនឹងការពិតថ្មីដែលថា ព្រំដែនកំពុងបើកសម្រាប់ជនអន្តោប្រវេសន៍ ឧក្រិដ្ឋជន អ្នកជួញដូរផ្លូវភេទ និងជនល្មើស។ វាក៏បានពង្រីកគំនិតនៃសញ្ជាតិផងដែរ ដូច្នេះឧទាហរណ៍ ពលរដ្ឋបារាំងដែលរស់នៅក្នុងប្រទេសអាឡឺម៉ង់អាចបោះឆ្នោត នៅក្នុងការបោះឆ្នោតក្នុងស្រុកនៅទីនោះ។ គោលដៅទីបីនៃសន្ធិសញ្ញាម៉ាស្ត្រីក (សមាហរណកម្មនយោបាយនិងយោធា) កាន់តែចម្រូងចម្រាស។ សន្ធិសញ្ញានេះប្តេជ្ញាអោយរដ្ឋអឺរ៉ុប ធ្វើការឆ្ពោះទៅរកគោលនយោបាយការបរទេសរួមជាមួយនឹងគោលដៅនៃការបង្កើតកងកម្លាំងយោធារួមគ្នាជាយថាហេតុ។

ពលរដ្ឋអឺរ៉ុបមួយចំនួនបានចាប់ផ្តើមប្រតិកម្មយ៉ាងខ្លាំង ប្រឆាំងនឹងការបាត់បង់អត្តសញ្ញាណជាតិ និងអធិបតេយ្យភាព ដែលចែងច្បាស់នៅក្នុងសន្ធិសញ្ញាម៉ាស្ត្រីក។ ក្នុងនាមជាវិសោធនកម្មលើសន្ធិសញ្ញាទីក្រុងរ៉ូម សន្ធិសញ្ញាម៉ាស្ត្រីកត្រូវតែទទួលបានការផ្តល់សច្ចាប័នដោយសមាជិកទាំងអស់ (នាពេលនោះ ១២ រដ្ឋ)។ ដំណើរការផ្តល់សច្ចាប័នបានជំរុញអារម្មណ៍សាធារណៈ ប្រឆាំងយ៉ាងខ្លាំងចំពោះ សហភាពអឺរ៉ុបដែលកាន់តែជិតស្និទ្ធនៅក្នុងប្រទេសមួយចំនួន។ ភ្លាមៗនោះប្រជាពលរដ្ឋនិងមេដឹកនាំក្នុងប្រទេសមួយចំនួនហាក់បីដូចជាមានអារម្មណ៍ដឹងថា អឺរ៉ូធិបតេយ្យលាក់មុខនៅក្នុងទីក្រុងប្រ៊ុចសែល កំពុងបន្សាបអធិបតេយ្យភាពជាតិរបស់ពួកគេ នៅទីបញ្ចប់ សហភាពអឺរ៉ុបបានចាប់ផ្តើមអនុវត្តសន្ធិសញ្ញាម៉ាស្ត្រីក ទោះបីជាមានភាពយឺតយ៉ាវនិងមានប្រទេសចូលរួមតិចជាងការរំពឹងទុកក៏ដោយ។ សមាហរណកម្មសេដ្ឋកិច្ចនិងបច្ចេកទេស រួមទាំងសហជីពរូបិយវត្ថុថ្មីក្នុងចំណោមសមាជិកទាំង ១២ បានរក្សាសន្ទុះ។

សមាហរណកម្មសេដ្ឋកិច្ចអឺរ៉ុបបានចាប់ផ្តើមកែទម្រង់សេដ្ឋកិច្ចនយោបាយ នៅកម្រិតពិភពលោក។ ឥឡូវនេះ សហភាពអឺរ៉ុបកំណត់ច្បាប់សម្រាប់ការចូលទៅកាន់ទីផ្សារធំបំផុតមួយរបស់ពិភពលោក សម្រាប់បណ្តាញផលិតកម្ម និងបច្ចេកវិទ្យាដ៏ធំ និងសម្រាប់រូបិយប័ណ្ណខ្លាំងបំផុតរបស់ពិភពលោក។ អំណាចថ្មីរបស់អឺរ៉ុបត្រូវបានបង្ហាញនៅក្នុងគំនិតផ្តួចផ្តើមបរិស្ថានរបស់ខ្លួន។ ឧស្សាហកម្មគីមីរបស់សហរដ្ឋអាមេរិកជំណើរ

ការក្រោមបទប្បញ្ញត្តិរបស់សហរដ្ឋអាមេរិកដែលលើកលែង ៨០ ភាគរយនៃសារធាតុគីមី។ ប៉ុន្តែ សហភាពអឺរ៉ុបបានអនុម័តបទប្បញ្ញត្តិគីមីដ៏តឹងរឹង ដោយតម្រូវអោយធ្វើតេស្តលើផលប៉ះពាល់សុខភាពនៃសារធាតុគីមីទាំងអស់។ ប្រើប្រាស់ក្នុងផលិតផល និងតម្រូវអោយមានការខិតខំប្រឹងប្រែងដើម្បីជំនួសសារធាតុគីមីពុលនៅក្នុងផលិតផលប្រចាំថ្ងៃ។ ជាលទ្ធផល ក្រុមហ៊ុនគ្រឿងសំអាងធំៗមួយចំនួនរបស់សហរដ្ឋអាមេរិកបានធ្វើកំណែទម្រង់ផលិតផលរបស់ពួកគេ ដើម្បីអនុលោមតាមបទប្បញ្ញត្តិគ្រឿងសំអាងថ្មីរបស់សហភាពអឺរ៉ុបដែលអំពាវនាវអោយដកចេញនូវសារធាតុមិនល្អ។ ហើយក្រុមហ៊ុនផលិតរថយន្តជប៉ុនបានកែសម្រួលដំណើរការផលិតកម្មដើម្បីបំពេញតាមតម្រូវការរបស់សហភាពអឺរ៉ុប ដែលថារថយន្តថ្មីមានសមាសធាតុដែលអាចកែច្នៃឡើងវិញបាន ៨៥ ភាគរយ នៅឆ្នាំ ២០០៦ (និង ៩៥ ភាគរយ នៅឆ្នាំ ២០១៥)។

សមាហរណកម្មនយោបាយនិងយោធានៅមានបញ្ហាច្រើន(ជាងសេដ្ឋកិច្ច)។ ការតស៊ូរវាងជាតិនិយមនិងលទ្ធិsupranationalismហាក់ដូចជាមានតុល្យភាពរវាងលទ្ធិទាំងពីរ។ អន្តរកាលទៅអង្គការឬស្ថាប័នបែបបរមានុភាព មិនទាន់ត្រូវបានសម្រេច នៅក្នុងទិដ្ឋភាពអធិបតេយ្យភាពជាតិ និងនយោបាយការបរទេសនិងយោធា។ សូម្បីតែមានការរៀបចំធ្វើសមាហរណកម្មជាង ៥០ ឆ្នាំក៏ដោយ ក៏ការផលជះពីសមាហរណកម្មសេដ្ឋកិច្ចទៅក្នុងបញ្ហានយោបាយនៅមានលក្ខណៈរវើរវាយនៅឡើយ។

១០.៣.៦. សហភាពរូបិយវត្ថុ

រូបិយប័ណ្ណអឺរ៉ុប ប្រាក់អឺរ៉ូ បានជំនួសរូបិយប័ណ្ណជាតិនៅក្នុងរដ្ឋសមាជិកសហភាពអឺរ៉ុបចំនួន ១៩ ដូចដែលបានកំណត់ក្នុងសន្ធិសញ្ញា Maastricht។ បន្ទាប់ពីជាច្រើនឆ្នាំជាឯកតាអរូបីដូចជា SDR របស់ IMF (សូមមើលមេរៀន ៩) ដែលត្រូវបានប្រើប្រាស់ដោយរដ្ឋាភិបាលជាតិ និងសម្រាប់ការផ្លាស់ប្តូរអន្តរជាតិ ប្រាក់អឺរ៉ូបានចូលមកចរាចរពេញលេញ ក្នុងឆ្នាំ ២០០២ ហើយរូបិយប័ណ្ណជាតិបានឈប់មាន។ ធនាគារកណ្តាលអឺរ៉ុបបានកាន់កាប់មុខងាររបស់ធនាគារកណ្តាលរបស់រដ្ឋ។

សហភាពរូបិយវត្ថុមានភាពលំបាកសម្រាប់ហេតុផលសេដ្ឋកិច្ចនិងនយោបាយ។ នៅក្នុងរដ្ឋដែលចូលរួមលក្ខខណ្ឌសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមូលដ្ឋានត្រូវតែមានភាពស្មើគ្នា។រដ្ឋមួយមិនអាចជំរុញសេដ្ឋកិច្ចរបស់ខ្លួនជាមួយនឹងអត្រាការប្រាក់ទាប (ឧទាហរណ៍ ដោយសារការធ្លាក់ចុះសេដ្ឋកិច្ច) ខណៈពេលដែលរដ្ឋផ្សេងធ្វើអោយបន្ទាបអតិផរណាជាមួយនឹងអត្រាការប្រាក់ខ្ពស់(ដោយសារតែកំណើនសេដ្ឋកិច្ចខ្ពស់)។ ជាឧទាហរណ៍ ក្នុងខែមករា ឆ្នាំ ២០១៥ អត្រាគ្មានការងារធ្វើមានលើសពី ១៤ ភាគរយនៅក្នុងប្រទេសអេស្ប៉ាញ ប៉ុន្តែមានតែ ៥ ភាគរយប៉ុណ្ណោះ នៅក្នុងប្រទេសអង់គ្លេស។ នៅក្នុងសេដ្ឋកិច្ចរួមដែលមានផងដែរ មជ្ឈិមនិយមផ្នែកនយោបាយ រដ្ឋាភិបាលកណ្តាលអាចផ្លាស់ប្តូរទីតាំងធនធាន ដូចដែលសហរដ្ឋអាមេរិកអាចធ្វើ ប្រសិនបើរដ្ឋតិចសាស់កំពុងរីកចម្រើន ហើយរដ្ឋ Massachusetts ស្ថិតក្នុងវិបត្តិសេដ្ឋកិច្ច។ ប៉ុន្តែ EU មិនមានអំណាចកណ្តាលនៃការយកពន្ធ ឬការគ្រប់គ្រងថវិកាជាតិទេ។ ការបែងចែកគោលនយោបាយសារពើពន្ធនិងរូបិយវត្ថុបែបនេះ មិនធម្មតាទេ។

ដំណោះស្រាយមួយគឺធ្វើការឆ្ពោះទៅរកសមភាពសេដ្ឋកិច្ចរបស់អឺរ៉ុប។ ជាឧទាហរណ៍ ដើម្បីកាត់បន្ថយភាពខុសគ្នារវាងរដ្ឋអ្នកមាននិងរដ្ឋសហភាពអឺរ៉ុបក្រីក្រ សន្ធិសញ្ញាម៉ាស្ត្រីកបានបង្កើនថវិកាសហភាពអឺរ៉ុបចំនួន ២៥ ពាន់លានដុល្លារដោរៀងរាល់ឆ្នាំ ដើម្បីផ្តល់ជំនួយសេដ្ឋកិច្ចដល់សមាជិកក្រីក្រ។ ប៉ុន្តែសមាជិកសហភាពអឺរ៉ុបដែលមានទ្រព្យសម្បត្តិច្រើនជាងបង់ថ្លៃសម្រាប់ជំនួយនេះ ជាលទ្ធផលជួយយឺតយោងប្រទេស

ក្រីក្រ ជាអ្នកជិះសេះលែងដៃ លើផលប្រយោជន៍រួមនៃសមាហរណកម្មសហភាពអឺរ៉ុប។ មួយផ្នែកសម្រាប់ហេតុផលនេះ ២៥ ពាន់លានដុល្លារក្នុងមួយឆ្នាំគឺតូចពេកក្នុងការធ្វើអោយមានសមភាពប្រទេសអ្នកមាន និងប្រទេសក្រីក្រពិតប្រាកដ។

រូបថត កម្មករនៅប្រទេសបារាំងតវ៉ានឹងច្បាប់ការងារ

ការប្រយុទ្ធដើម្បីការងារ

សន្ទិសញ្ញាទីក្រុងម៉ាស្ត្រីកបានអំពាវនាវអោយមានសហភាពរូបិយវត្ថុដែលមានរូបិយប័ណ្ណរួមតែមួយ។ ក្នុងឆ្នាំ ២០០២ រូបិយប័ណ្ណអឺរ៉ូបានចូលជាធរមាននិងដាក់អោយប្រើប្រាស់យ៉ាងរលូននៅក្នុងប្រទេសចំនួន ១២ (ឥឡូវនេះ ១៩) ហើយបានលេចចេញជារូបិយប័ណ្ណពិភពលោក ដែលប្រជែងនឹងប្រាក់ដុល្លារអាមេរិក។ ប៉ុន្តែ វិបត្តិសេដ្ឋកិច្ចដ៏ធំឆ្នាំ ២០០៨ បានលាតត្រដាងបញ្ហាមូលដ្ឋានដែលបង្កអោយមានវិបត្តិបំណុលនៅតំបន់ចាយប្រាក់អឺរ៉ូ និងវិបត្តិសេដ្ឋកិច្ចលើកទីពីរ ក្នុងឆ្នាំ ២០១២។ ភាពអត់ការងារធ្វើនៅតែជាបញ្ហានៅក្នុងរដ្ឋសមាជិកសហភាពអឺរ៉ុបជាច្រើន បន្ទាប់ពីវិបត្តិទាំងនេះ។ នៅទីនេះ កម្មករនៅប្រទេសបារាំងតវ៉ានឹងច្បាប់ការងារដែលត្រូវបានស្នើឡើង ដើម្បីបន្ធូរបន្ថយភាពអត់ការងារធ្វើឆ្នាំ ២០១៨។

ដំណោះស្រាយចម្បងដែលត្រូវបានអនុម័តនៅសន្ទិសញ្ញាម៉ាស្ត្រីក គឺត្រូវដាក់កម្រិតសមាជិកភាពនៅក្នុងសហជីពរូបិយវត្ថុ យ៉ាងហោចណាស់ក្នុងជុំទីមួយ មានតែប្រទេសដែលមានស្ថិរភាពហិរញ្ញវត្ថុគ្រប់គ្រាន់ដែលមិនធ្វើអោយប៉ះពាល់ដល់សហភាព។ ដើម្បីចូលរួមជាមួយរូបិយប័ណ្ណរួមតែមួយ រដ្ឋត្រូវតែសម្រេចបានឱនភាពថវិកាតិចជាង ៣ ភាគរយនៃផលិតផលក្នុងស្រុកសរុប, បំណុលជាតិតិចជាង ៦០ ភាគរយនៃផលិតផលក្នុងស្រុកសរុប, អត្រាអតិផរណាមិនលើសពី ១,៥ ភាគរយលើសពីមធ្យមភាគនៃកម្រិតទាបបំផុតទាំងបី។ អតិផរណាសមាជិក EU និងអត្រាការប្រាក់ស្ថិរភាព និងតម្លៃរូបិយប័ណ្ណជាតិ។

នេះមានន័យថាមានជម្រើសដ៏លំបាកដោយរដ្ឋាភិបាលក្នុងប្រទេសបារាំង អេស្ប៉ាញ អ៊ីតាលី និងប្រទេសផ្សេងទៀតដើម្បីកាត់បន្ថយថវិកា និងអត្ថប្រយោជន៍ និងចាត់វិធានការណ៍នយោបាយផ្សេងទៀតដែលមិនពេញនិយម។ កម្មករបារាំងបានឆ្លើយតបនឹងការធ្វើកូដកម្មជាច្រើនដង។ រដ្ឋាភិបាលបានធ្លាក់ទៅលើគណបក្សប្រឆាំងក្នុងប្រទេសមួយចំនួន ប៉ុន្តែមេដឹកនាំថ្មីជាទូទៅក្សាដំណើរការដដែល។

ជាលទ្ធផលនៃវិន័យសារពើពន្ធដែលរកឃើញថ្មីរបស់ពួកគេ សមាជិកសហភាពអឺរ៉ុបទាំង ១២ ដែលចង់ចូលរួមក្នុងប្រាក់អឺរ៉ូមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។ ស្លូវេនីបានចូលរួមនៅក្នុង ២០០៧ កោះស៊ីបនិងម៉ាល់តាចូលឆ្នាំ ២០០៨ ស្លូវ៉ាគីចូលឆ្នាំ ២០០៩; អេស្តូនីចូលឆ្នាំ ២០១១ ឡាតវីចូលក្នុងឆ្នាំ ២០១៤ និងលីទុយអានីចូលក្នុងឆ្នាំ២០១៥។ ចក្រភពអង់គ្លេស ដាណឺម៉ាក និងស៊ុយអែតបានជ្រើសរើសរក្សារូបិយប័ណ្ណជាតិរបស់ពួកគេ។

លុយគឺនយោបាយច្រើនជាងពន្ធដៃកឬគ្រឿងផ្សំសូកូឡា។ សហភាពរូបិយវត្ថុបំពានលើសិទ្ធិស្នូលនៃរដ្ឋ ពោលគឺសិទ្ធិបោះពុម្ពរូបិយបណ្ណ។ ដោយសារតែពលរដ្ឋប្រើប្រាស់លុយជារៀងរាល់ថ្ងៃ រូបិយប័ណ្ណអឺរ៉ុបនៅតាមបណ្តោយបន្ទាត់ទាំងនេះ អាចធ្វើអោយអារម្មណ៍ពលរដ្ឋកាន់តែស៊ីជម្រៅ ក្នុងការកំណត់អត្តសញ្ញាណជាមួយអឺរ៉ុប ដែលជាជ័យជម្នះសម្រាប់លទ្ធិបរមានុភាព។ នៅពេលដែលប្រាក់អឺរ៉ូបានចរាចរក្នុងឆ្នាំ ២០០២ ពលរដ្ឋអឺរ៉ុប ជាលើកដំបូង អាចចាប់«អឺរ៉ុបដាក់ក្នុងហោប៉ៅពួកគេ»។ ប្រាកដណាស់ ដោយសារ ហេតុផលនេះ មេដឹកនាំរដ្ឋនិងប្រជាពលរដ្ឋមួយចំនួនបានប្រឆាំងនឹងគំនិតនៃការបោះបង់តម្លៃនិមិត្តសញ្ញានៃរូបិយប័ណ្ណជាតិ

របស់ពួកគេ។ បញ្ហាទាំងនេះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងការកិច្ចនៃការរចនាក្រដាសប្រាក់និងកាក់អឺរ៉ូ។ តើមេដឹកនាំរដ្ឋឬវិមានរបស់ប្រទេសណាមួយ ដែលអាចក្លាយជានិមិត្តសញ្ញាទូទាំងទ្វីបអឺរ៉ុប ដោយរបៀបណា? ដំណោះស្រាយគឺត្រូវដាក់ធាតុស្ថាបត្យកម្មទូទៅ (មិនអាចកំណត់អត្តសញ្ញាណបាន តាមប្រទេស) នៅផ្នែកខាងមុខនៃក្រដាសប្រាក់ និងផែនទីអឺរ៉ុបនៅខាងក្រោយ។ កាក់មាននៅក្នុងការរចនារដ្ឋសមាជិកផ្សេងៗគ្នា (ទាំងអស់មានសុពលភាពទូទាំងតំបន់អឺរ៉ូ)។

ជម្លោះបានកើតឡើងក្នុងតំបន់ចាយប្រាក់អឺរ៉ូ។ នៅឆ្នាំ ២០០៤ គណៈកម្មការអឺរ៉ុបបានជំទាស់នឹងរដ្ឋជាសមាជិកសហភាពអឺរ៉ុបអោយបោះឆ្នោតអោយបារាំង និងអាឡឺម៉ង់បំបែកច្បាប់ប្រាក់អឺរ៉ូដោយដំណើរការឱនភាពថវិកាខ្ពស់។ ហើយរដ្ឋាភិបាលឡាតវីបានបាត់បង់អំណាច ក្នុងរយៈពេលប្រាំមួយខែនៃការចូលរួមជាមួយសហភាពអឺរ៉ុបរបស់ប្រទេសក្រោមសម្ពាធនៃការកាត់បន្ថយថវិកា ដែលមិនពេញនិយមចាំបាច់ ដើម្បីបំពេញតាមច្បាប់ប្រាក់អឺរ៉ូក្នុងរយៈពេលបួនឆ្នាំ។

ក្នុងឆ្នាំ ២០១០ បញ្ហាប្រឈមថ្មីចំពោះប្រាក់អឺរ៉ូបានកើតឡើង។ ប្រទេសក្រិច ដែលធ្លាប់បានសារភាពថាបានក្លែងបន្លំទិន្នន័យសេដ្ឋកិច្ច ដើម្បីចូលក្នុងតំបន់ចាយប្រាក់អឺរ៉ូនោះ បានខ្ចីប្រាក់អស់ជាច្រើនឆ្នាំ លើសពីអ្វីដែលខ្លួនអាចសងវិញបាន ហើយត្រូវការថវិកាសង្គ្រោះពីអឺរ៉ុប ដើម្បីរួចផុតពីវិបត្តិហិរញ្ញវត្ថុពិភពលោក។ ដោយសារតែក្រិកបានប្រើប្រាស់ប្រាក់អឺរ៉ូ បញ្ហារបស់វាបានប៉ះពាល់ដល់ចំណាប់អារម្មណ៍របស់អ្នកវិនិយោគសកលចំពោះរដ្ឋប្រាក់អឺរ៉ូទាំងអស់។

អាក្រក់ជាងនេះ បញ្ហាបំណុលឆាប់រីករាលដាលទៅក្រៅប្រទេសក្រិក។ ជាក់ស្តែងក្នុងឆ្នាំ ២០១០ មានតែរដ្ឋចំនួនពីរនៅក្នុងសហភាពអឺរ៉ុប (ហ្វាំងឡង់ និងលុចសំបួ) ពិតជាបានបំពេញគោលដៅរបស់សហភាពអឺរ៉ុបសម្រាប់កម្រិតបំណុល។ ប្រទេសក្រិក អេស្ប៉ាញ ព័រទុយហ្គាល់ អៀរឡង់ និងអ៊ីតាលី សុទ្ធតែបានធ្វើកំណែទម្រង់សេដ្ឋកិច្ចទ្រង់ទ្រាយធំ ហើយរដ្ឋាភិបាលបានបាត់បង់អំណាចនៅក្នុងប្រទេសក្រិក អ៊ីតាលី និងរដ្ឋសហភាពអឺរ៉ុបផ្សេងទៀត។ ប្រទេសអាឡឺម៉ង់ និងបារាំងបានប្រយុទ្ធគ្នាលើអ្នកដែលនឹងជួយសង្គ្រោះប្រទេសចាយប្រាក់អឺរ៉ូដែលមានបញ្ហា។ បន្ទាប់ពីសេដ្ឋកិច្ចអាឡឺម៉ង់ រដ្ឋមន្ត្រីបាននិយាយថាប្រទេសអាឡឺម៉ង់ «នឹងមិនផ្តល់អោយក្រិកសូម្បីមួយសេនទេ» មេដឹកនាំធម៌ត្រជាក់ជាងបានជោគជ័យ ហើយបណ្តាប្រទេសសហភាពអឺរ៉ុបបានប្រមូលផ្តុំគ្នាដើម្បីគាំទ្រសេដ្ឋកិច្ចរបស់គ្នាទៅវិញទៅមក។

នៅឆ្នាំ ២០១២ សហភាពអឺរ៉ុបបានជួសជុលប្រព័ន្ធសង្គ្រោះមួយរួមគ្នា ដែលគាំទ្រដោយទឹកប្រាក់ជាង ១ ទ្រីលានដុល្លារ ដែលមានសមត្ថភាពជំរុញសេដ្ឋកិច្ចសមាជិករបស់ខ្លួននៅពេលចាំបាច់។ ប៉ុន្តែដំណើរការសម្រេចចិត្តរបស់ EU នៅតែមានភាពស្ទាក់ស្ទើរ ហើយប្រជាពលរដ្ឋបានដើរតាមផ្លូវជាញឹកញាប់នៅក្នុងប្រទេសដូចជាក្រិកនិងអេស្ប៉ាញ ដែលត្រូវតែអនុវត្តថវិកាដ៏តឹងរ៉ឹងជាថ្នូរនឹងថវិកាសង្គ្រោះ។ វិធានការរឹតត្បិតមិនត្រឹមតែជំរុញអោយមានភាពអត់ការងារធ្វើប៉ុណ្ណោះទេ ប្រហែល ២៥ ភាគរយក្នុងករណីប្រទេសអេស្ប៉ាញក្នុងឆ្នាំ ២០១៥ (៥០ ភាគរយនៃអ្នកគ្មានការងារធ្វើសម្រាប់មនុស្សក្រោម ២៥ ឆ្នាំ) ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើអោយសកម្មភាពសេដ្ឋកិច្ចនៅក្នុងតំបន់ចាយប្រាក់អឺរ៉ូទាំងមូលធ្លាក់ចុះផងដែរ។ ក្នុងឆ្នាំ ២០១៤ ធុញទ្រាន់ជាមួយនឹងវិធានការរឹតត្បិត ក្រិកបានបោះឆ្នោតជ្រើសរើសរដ្ឋាភិបាលឆ្វេងនិយមថ្មីមួយលើការសន្យានៃការចរចាលក្ខខណ្ឌដ៏លំបាកតិចពី EU។ រដ្ឋាភិបាលក្រិកថ្មីបានបរាជ័យក្នុងការធ្វើដូច្នេះ ហើយនៅក្នុងឆ្នាំ ២០១៥ ក្រិកបានទទួលយកប្រាក់កម្ចីបន្ទាន់ថ្មីពីសហភាពអឺរ៉ុប ដែលរួមបញ្ចូលទាមទារអោយមានការកាត់បន្ថយថវិកា

លំបាក។ ជាលទ្ធផល រដ្ឋាភិបាលឆ្វេងនិយមបានហៅការបោះឆ្នោតថ្មី ខណៈដែលពិភពលោកកំពុងឃ្លាំមើលថាតើក្រិកអាចទទួលបានផ្ទះសេដ្ឋកិច្ចរបស់ខ្លួនតាមលំដាប់លំដោយឬយ៉ាងណា។

ទោះបីជាមានបញ្ហានាពេលថ្មីៗនេះនៅក្នុងតំបន់ចាយប្រាក់អឺរ៉ូក៏ដោយ ការបង្កើតរូបិយប័ណ្ណអឺរ៉ុប គឺជាការផ្លាស់ប្តូរផ្នែកហិរញ្ញវត្ថុដ៏ធំបំផុតដែលមិនធ្លាប់មានក្នុងប្រវត្តិសាស្ត្រ ហើយក្នុងរយៈពេលដប់បីឆ្នាំដំបូង វាបានដោគជ័យភាគច្រើន។

១០.៣.៧. ការពង្រីកសហភាពអឺរ៉ុប

ដោគជ័យដ៏ភ្លៀវភ្លារបស់សហភាពអឺរ៉ុបបានទាក់ទាញរដ្ឋជិតខាងអោយចង់ចូលរួមដែរ។ សហភាពអឺរ៉ុបបានពង្រីកសមាជិក ពី ១៥ ប្រទេស ដល់ ២៨ ប្រទេស ចាប់តាំងពីឆ្នាំ ២០០៤ រួមជាមួយនឹងការផ្លាស់ប្តូរដ៏ទូលំទូលាយនៅក្នុងរបៀបឬយន្តការដែលសហភាពអឺរ៉ុបដំណើរការ។

ប្រទេសអេស្បាញ និងព័រទុយហ្គាល់ បានចូលជាសមាជិកទី១១ និងទី១២ ដែលធ្វើអោយសហភាពអឺរ៉ុបបានគ្របដណ្តប់ដល់ផ្នែកខាងលិចបង្អស់នៃទ្វីបអឺរ៉ុប។ នៅឆ្នាំ ១៩៩៥ ប្រទេសអូទ្រីស ស៊ុយអែត និងហ្វាំងឡង់បានចូលជាសមាជិកសហភាពអឺរ៉ុប។ ពួកគេស្ថិតនៅលើតែមខាងក្រៅនៃរង្វង់សហភាពអឺរ៉ុនាពេលនោះ ហើយក្នុងនាមជាប្រទេសអ្នកមាន ពួកគេមិនរំខានដល់សេដ្ឋកិច្ចសហភាពអឺរ៉ុបទេ។ ប្រទេសន័រវេសបានដាក់ពាក្យចូលជាសមាជិក ហើយត្រូវបានទទួលយក ប៉ុន្តែពលរដ្ឋរបស់ពួកគេបានបោះឆ្នោតទម្លាក់គំនិតនេះចោល នៅក្នុងប្រជាមតិក្នុងឆ្នាំ ១៩៩៤ ដោយទុកអោយសហភាពអឺរ៉ុបមានសមាជិកចំនួន ១៥ ប្រទេស ក្រោយឆ្នាំ ១៩៩៥ រដ្ឋសំខាន់ៗនៅអឺរ៉ុបខាងលិចទាំងអស់ចូលរួមលើកលែងតែពីរប៉ុណ្ណោះ។ ផែនការចូលរួមរបស់ប្រទេសស្វីស ដូចប្រទេសណ័រវេសដែរ ត្រូវបានបញ្ឈប់ដោយការធ្វើប្រជាមតិដ៏ពេញនិយម នៅដើមទសវត្សរ៍ឆ្នាំ ១៩៩០។

ការពង្រីកសមាជិកភាពបច្ចុប្បន្នរបស់សហភាពអឺរ៉ុបត្រូវបានត្រួសត្រាយផ្លូវ ដោយសន្ធិសញ្ញាទីក្រុងណាយ្សឆ្នាំ ២០០០ ដែលបានចូលជាធរមានក្នុងឆ្នាំ ២០០៣ បន្ទាប់ពីអ្នកបោះឆ្នោតអៀរឡង់បានផ្លាស់ប្តូរលទ្ធផលបោះឆ្នោតលើកមុន ដោយបានអនុម័តវា (ប្រទេសចុងក្រោយដែលផ្តល់សច្ចាប័នលើវា)។ សមាជិកថ្មីចំនួនដប់ប្រទេសបានចូលរួម នៅឆ្នាំ២០០៤៖ ប្រទេសប៉ូឡូញ សាធារណរដ្ឋឆេក ស្លូវ៉ាគី ហុងគ្រី ស្លូវេនី អេស្តូនី ឡាតវី លីទុយអានី ម៉ាល់តា និងកោះស៊ីប។ គណៈកម្មាការអឺរ៉ុបបានពង្រីកចំនួនសមាជិកចំនួន ២៥ នាក់ ដោយមិនទុកអោយរដ្ឋសមាជិកធំជាងគេទាំងប្រាំ កាន់កាប់ពីរអាសនៈតែឯង ហើយជាមួយនឹងច្បាប់បោះឆ្នោតថ្មី ដែលចាកឆ្ងាយពីតម្រូវការមតិឯកច្ឆន្ទ។ ក្នុងឆ្នាំ ២០០៧ ប្រទេសរូម៉ានី និងប៊ុលហ្គារីបាននាំសមាជិកភាពរបស់សហភាពអឺរ៉ុបឡើងដល់២៧។ ប្រទេសក្រូអាតបានចូលរួមក្នុងឆ្នាំ ២០១៣ ក្នុងនាមជាសមាជិកទី ២៨ ដែលបង្ហាញថា ទោះបីជាមានបញ្ហាហិរញ្ញវត្ថុក៏ដោយ សហភាពអឺរ៉ុបនៅតែបន្តពង្រីក ទោះបីជាយឺតយ៉ាវក៏ដោយ។

ប្រទេសទួរគីនៅតែបន្តស្វែងរកសមាជិកភាព។ ទោះបីជាទួរគីត្រូវបានបដិសេធ ក្នុងឆ្នាំ ២០០២ ក៏ដោយ ក៏សហភាពអឺរ៉ុបក្រោយមកបានយល់ព្រមចាប់ផ្តើមការចរចាជាផ្លូវការជាមួយទួរគី ក្នុងឆ្នាំ ២០០៥ ដែលជាការចាប់ផ្តើមនៃដំណើរការរយៈពេលជាច្រើនឆ្នាំ។ សហភាពអឺរ៉ុបមិនបានឈានដល់ការឯកភាពលើការទទួលស្គាល់តួកគីជាសមាជិកពេញលេញទេ។ អ្នកគាំទ្រកត់សម្គាល់ថា ប្រទេសទួរគីបានធ្វើការផ្លាស់ប្តូរសេដ្ឋកិច្ច និងនយោបាយធំៗ រួមទាំងការលុបបំបាត់ទោសប្រហារជីវិត និងការធ្វើអោយប្រសើរឡើងនូវសិទ្ធិ

មនុស្ស ដើម្បីព្យាយាមចូលជាសមាជិកភាពសហភាពអឺរ៉ុប។ការផ្តល់សមាជិកភាពពេញលេញនឹងផ្តល់រង្វាន់ដល់កំណែទម្រង់ទាំងនេះ ដោយរក្សាការសន្យាយ៉ាងច្បាស់លាស់មួយ ដើម្បីឆ្លើយតបទៅនឹងសកម្មភាពរបស់ប្រទេសទួរគី។ ផលិតផលក្នុងស្រុកសរុបរបស់ប្រទេសទួរគីដែលកើនឡើងយ៉ាងឆាប់រហ័ស ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះនឹងបន្ថែមប្រហែល ៥ ភាគរយ ដល់សេដ្ឋកិច្ចរបស់សហភាពអឺរ៉ុប។ ហើយកម្មករទួរគីអាចជួយសម្រាលកង្វះខាតកម្លាំងពលកម្ម នៅអឺរ៉ុបខាងលិច។ អ្នកគាំទ្រក៏ប្រកែកថាទួរគីក្នុងនាមជាសមាជិកសហភាពអឺរ៉ុបនឹងបម្រើជាស្ពានរវាងអឺរ៉ុប និងមជ្ឈិមបូព៌ា ដែលជាតំបន់ដ៏សំខាន់ ប៉ុន្តែអស្ថិតស្ថេរ និងជាឧទាហរណ៍នៃលទ្ធិប្រជាធិបតេយ្យបែបអាណាចក្រ សម្រាប់ប្រទេសមជ្ឈិមបូព៌ាផ្សេងទៀត។ ប្រទេសទួរគីបានជួយអឺរ៉ុបដោយទទួលយកជនភៀសខ្លួនស៊ីរីជាច្រើន ដែលសហភាពអឺរ៉ុបបានចំណាយប្រាក់ដល់តួកគីជិត ៦ ប៊ីលានដុល្លារក្រោមកិច្ចព្រមព្រៀងដែលសម្រេចបាន ក្នុងឆ្នាំ ២០១៥ ។


ក្រុមអ្នកប្រឆាំងសំណើសមាជិកភាពរបស់ទួរគីបានកត់សំគាល់ថា ប្រទេសទួរគីនឹងក្លាយជាប្រទេសមូស្លីមតែមួយគត់នៅក្នុងសហភាពអឺរ៉ុប ប៉ុន្តែនឹងក្លាយជាសមាជិកសហភាពអឺរ៉ុបដែលមានប្រជាជនច្រើនជាងគេលំដាប់ទីពីរបន្ទាប់ពីប្រទេសអាឡឺម៉ង់។ ដោយមានជនជាតិទួរគីចំនួន ២ លាននាក់កំពុងរស់នៅក្នុងប្រទេសអាឡឺម៉ង់រួចហើយ អ្នកប្រឆាំងជំទាស់ថា សមាជិកភាពសហភាពអឺរ៉ុបនឹងបើកទ្វារចំហរសម្រាប់ជនអន្តោប្រវេសន៍មកពីប្រទេសក្រីក្រដ៏ធំ និងបញ្ជៀតសមាជិកសហភាពអឺរ៉ុបដ៏តូចៗតែរីកចម្រើនជាង ប្រៀបដូចជាទឹកបាក់ទំនប់។ ក្នុងន័យសេដ្ឋកិច្ច ទួរគីនឹងក្លាយជាសមាជិកក្រីក្របំផុត (សូមមើលក្រាហ្វិក ១០.២)។ ការចំណាយសម្រាប់ការឧបត្ថម្ភធនកសិកររួគី និងពង្រីកកម្មវិធីសង្គមអាចឈានដល់រាប់សិបប៊ីលានអឺរ៉ូ។ ទីបំផុត ក្រុមអ្នកប្រឆាំងចង់អោយទួរគីដកកងកម្លាំងយោធារបស់ខ្លួនចេញពីទឹកដីកសមាជិកសហភាពអឺរ៉ុប កោះស៊ីប ជាកន្លែងដែលការបែងចែករវាងក្រិក-ទួរគីបានស៊ូទ្រាំអស់ជាច្រើនទសវត្សរ៍។ ក្នុងឆ្នាំ ២០១០-២០១៤ វិបត្តិហិរញ្ញវត្ថុ នៅក្នុងតំបន់ចាយប្រាក់អឺរ៉ូ បានរុញច្រានសំណួរនៃការទទួលយកប្រទេសទួរគី ឬសមាជិកថ្មីផ្សេងទៀត ទុកមួយឡែកសិន។

នៅពេលដែលសមាជិកថ្មីបានចូលរួមជាមួយសហភាពអឺរ៉ុបតាំងពីឆ្នាំ ២០០៤ សមត្ថភាពរបស់ EU ក្នុងការសម្រេចសេចក្តីសម្រេចដោយការឯកភាពគ្នាកាន់តែស្មុគស្មាញ ដែលជាចំណុចគូសបញ្ជាក់ដោយវេតូតែមួយរបស់ស្លូវ៉ាគីចំពោះការសង្គ្រោះប្រាក់អឺរ៉ូដ៏ធំ ក្នុងឆ្នាំ ២០១១ (ស្លូវ៉ាគីនៅទីបំផុតបានផ្លាស់ប្តូរការបោះឆ្នោតរបស់ខ្លួន)។ ពេលវេលាធ្វើការដែលត្រូវការដើម្បីធ្វើការសម្រេចចិត្តនៅក្នុងក្រុមប្រឹក្សាសហភាពអឺរ៉ុបបានពង្រីក ដោយមានជម្លោះដែលអាចកើតមាន និងសម្ព័ន្ធភាពលើបញ្ហាជាក់លាក់មួយក្នុងចំណោមសមាជិក ២៨ ជាជាង ១៥ សមាជិក។ សូមចាំថា ផលប្រយោជន៍រួមមានការពិបាកសម្រាប់ផ្តល់ជាក្រុមធំជាង ដែលការជិះលែងដៃមិនសូវត្រូវគេមើលឃើញជាងផលប្រយោជន៍រួមក្នុងក្រុមតូចជាង។

ជាងនេះទៅទៀត តាមស្តង់ដារអឺរ៉ុបខាងលិច សមាជិកថ្មីមានលក្ខណៈក្រីក្រ។ សមាជិកសហភាពអឺរ៉ុបដែលមានស្រាប់មានការប្រុងប្រយ័ត្នចំពោះការអូសទាញដោយសេដ្ឋកិច្ចទាំងនេះ ដែលភាគច្រើននៅតែជាប់គាំងក្នុងការផ្លាស់ប្តូរដ៏ឈឺចាប់ពីសង្គមនិយមទៅជាមូលធននិយម ហើយជួនកាល ខ្វះរូបិយប័ណ្ណស្ថិរភាព។ តាមពិតទៅ វិបត្តិបំណុល និងវិបត្តិសេដ្ឋកិច្ចនាពេលថ្មីៗនេះ ផ្តោតលើសមាជិកចាស់ៗ ដូចជាប្រទេសក្រិក អេស្ប៉ាញ និងព័រទុយហ្គាល់ មិនមែនជាសមាជិកថ្មីនោះទេ។

ក្រាហ្វិក ១០.២ កម្រិតប្រាក់ចំណូលរបស់សមាជិកសហភាពអឺរ៉ុបចាស់និងថ្មី ឆ្នាំ ២០១៧

ប្រភព៖ ទិន្នន័យធនាគារពិភពលោក



ប្រហែលជាដោយសារសម្ពាធទាំងនេះ សហភាពអឺរ៉ុបក្នុងទសវត្សរ៍ចុងក្រោយនេះបានបង្ហាញសញ្ញានៃការបែងចែកទៅជាស្រទាប់ «ខាងក្នុង» និង «ខាងក្រៅ» ដោយរដ្ឋដូចជាបារាំង និងអាឡឺម៉ង់ចូលរួមជាមួយសហជីពរូបិយប័ណ្ណ និងធ្វើអោយសមាហរណកម្មកាន់តែស៊ីជម្រៅ ហើយអ្នកទាំងនោះដូចជាអង់គ្លេសជាដើម។ ហើយប្រហែលជាសមាជិកថ្មីដែលកំពុងប្រតិបត្តិការ នៅតែមសហភាពអឺរ៉ុបជាមួយនឹងស្វ័យភាពកាន់តែច្រើន។ យ៉ាងណាក៏ដោយ នៅតំបន់ខ្លះមានការបោះជំហានឆ្ពោះទៅរកសមាហរណកម្ម។ ចាប់តាំងពីឆ្នាំ ១៩៩៥ សហភាពអឺរ៉ុបបានបង្កើតនិងពង្រីកតំបន់ ឈិនហ្គិន ដែលជាតំបន់ដែលការគ្រប់គ្រងព្រំដែនត្រូវបានលុបចោល។ ទំនិញ និងមនុស្សផ្លាស់ទីដោយសេរីនៅក្នុងតំបន់ដោយមិនឈប់នៅព្រំដែន។ ប្រទេសឈិនហ្គិន រួមមានរដ្ឋសំខាន់ៗរបស់សហភាពអឺរ៉ុប (លើកលែងតែចក្រភពអង់គ្លេសតាមជម្រើសរបស់វា)។ ប្រទេសន័រវេស អ៊ីស្លង់ និងស្វីសក៏ជាកម្មសិទ្ធិផងដែរ ទោះបីជាពួកគេមិនមែនជាសមាជិកសហភាពអឺរ៉ុបក៏ដោយ។

១០.៣.៨. សន្ធិសញ្ញាអ៊ីក្រុងលីស្បោន

ដើម្បីដោះស្រាយផលប៉ះពាល់នៃការពង្រីកសហភាពអឺរ៉ុប មេដឹកនាំទាំង ២៥ បានចុះហត្ថលេខាលើរដ្ឋធម្មនុញ្ញរបស់សហភាពអឺរ៉ុប នៅចុងឆ្នាំ ២០០៤ ហើយសភាអឺរ៉ុបបានផ្តល់សម្លេងគាំទ្រយ៉ាងខ្លាំងនៅឆ្នាំ ២០០៥។ ដើម្បីចូលជាធរមាន វាត្រូវតែផ្តល់សច្ចាប័នដោយរដ្ឋទាំង ២៥ រួមទាំងទាមទារការបោះឆ្នោតប្រជាមតិនៅក្នុង

រដ្ឋមួយចំនួនផងដែរ។ រដ្ឋធម្មនុញ្ញនេះនឹងបង្កើតតំណែងប្រធានសហភាពអឺរ៉ុបកាន់តែខ្លាំងជាងមុន ក៏ដូចជាតំណែងរដ្ឋមន្ត្រីការបរទេសមួយរូប ហើយនឹងជំនួសតម្រូវការសម្លេងឯកច្ឆ័ន្ទ សម្រាប់ការសម្រេចចិត្តរបស់សហភាពអឺរ៉ុប ដោយប្រើសម្លេងភាគច្រើន នៅក្នុងករណីភាគច្រើន។ វាក៏ធានានូវសិទ្ធិជាមូលដ្ឋានដល់ពលរដ្ឋសហភាពអឺរ៉ុបទាំងអស់ផងដែរ។ ប៉ុន្តែអ្នកបោះឆ្នោតនៅប្រទេសបារាំង និងហូឡង់បានច្រានចោលរដ្ឋធម្មនុញ្ញ ហើយដំណើរការត្រូវបានបញ្ឈប់។

នៅចុងឆ្នាំ ២០០៧ សហភាពអឺរ៉ុបបានបន្តដំណើរទៅមុខជាមួយនឹងរដ្ឋធម្មនុញ្ញដែលបានស្នើឡើងថ្មីមួយទៀត នោះគឺ សន្ធិសញ្ញាទីក្រុងលីស្បោន។ សន្ធិសញ្ញាគឺស្រដៀងនឹងរដ្ឋធម្មនុញ្ញមុន ប៉ុន្តែត្រូវប្រឈមមុខនឹងការបោះឆ្នោតប្រជាមតិមានតែនៅក្នុងប្រទេសអៀរឡង់។ (សន្ធិសញ្ញាទីក្រុងលីស្បោន មិនតម្រូវអោយមានការបោះឆ្នោតកម្រិតរដ្ឋបន្ថែមទៀតទេ ព្រោះវាគ្រាន់តែធ្វើវិសោធនកម្មសន្ធិសញ្ញាសហភាពអឺរ៉ុបមុនៗ ជាជាងជំនួសវា ដូចដែលរដ្ឋធម្មនុញ្ញបានស្នើអោយធ្វើ។) សន្ធិសញ្ញានេះចូលជាធរមានក្នុងឆ្នាំ ២០០៩។

សន្ធិសញ្ញាបានបង្កើតការផ្លាស់ប្តូរជាច្រើនទាំងរចនាសម្ព័ន្ធ និងប្រតិបត្តិការប្រចាំថ្ងៃរបស់សហភាពអឺរ៉ុប។ ការផ្លាស់ប្តូរមួយចំនួនដែលជំរុញអោយមានការសម្រេចចិត្តច្រើនជាងមុន។ ជាឧទាហរណ៍ ធម្មនុញ្ញនៃសិទ្ធិមនុស្សត្រូវបានធ្វើឡើងដោយស្របច្បាប់លើរដ្ឋជាសមាជិកទាំងអស់។ មុខតំណែងថ្មីមួយ «ឧត្តមស្នងការទទួលបន្ទុកកិច្ចការបរទេសនិងគោលនយោបាយសន្តិសុខ» ត្រូវបានបង្កើតឡើង ដើម្បីសម្របសម្រួលគោលនយោបាយការបរទេសកាន់តែប្រសើរឡើងក្នុងចំណោមរដ្ឋជាសមាជិក។ (មុខតំណែងនេះបានក្លាយជារឿងចម្លែងចម្រាសក្លាមៗនៅពេលដែលម្ចាស់ជនជាតិអង់គ្លេសមិនស្គាល់មុខម្នាក់ត្រូវបានជ្រើសរើសអោយបំពេញមុខតំណែងនេះ)។

រូបថត *ពលរដ្ឋធ្វើបាតុកម្មប្រឆាំងតវ៉ា នៅមុខធនាគារកណ្តាលអឺរ៉ុប*

សហភាពមិនល្អឥតខ្ចោះ

សហភាពអឺរ៉ុបបានបន្ថែមសមាជិកចំនួន ១២ ដែលភាគច្រើនមកពីអឺរ៉ុបខាងកើត ក្នុងឆ្នាំ ២០០៤ និង ២០០៧។ កិច្ចខិតខំប្រឹងប្រែងដើម្បីធ្វើអោយអភិបាលកិច្ចអឺរ៉ុបទាន់សម័យ ជាមួយនឹងសន្ធិសញ្ញាទីក្រុងលីស្បោនថ្មី ទីបំផុត បានទទួលជោគជ័យនៅឆ្នាំ ២០០៩។ ប៉ុន្តែភាពស្មុគស្មាញជារឿយៗនៅតែត្រូវដោះស្រាយ ដូចដែលបានបង្ហាញនៅក្នុងការឆ្លើយតបដ៏ច្របូកច្របល់ចំពោះវិបត្តិហិរញ្ញវត្ថុក្រិកក្នុងឆ្នាំ ២០១១។ នៅទីនេះអ្នកតវ៉ាធ្វើបាតុកម្មនៅធនាគារកណ្តាលអឺរ៉ុបនៅទីក្រុង Frankfurt ប្រទេសអាល្លឺម៉ង់ ឆ្នាំ ២០១១។

ម៉្យាងវិញទៀត ការផ្លាស់ប្តូរមួយចំនួនអនុញ្ញាតអោយសមាជិករដ្ឋ និងពលរដ្ឋម្នាក់ៗជាក់ការត្រួតពិនិត្យបន្ថែមទៀតលើអំណាចរបស់សហភាពអឺរ៉ុប។ ឥឡូវនេះ សភាជាតិអាចនិយាយបានកាន់តែច្រើនថា តើអ្នកណាត្រូវចូលសហភាពអឺរ៉ុប(ទំនងជាដំណឹងអាក្រក់សម្រាប់តួកគី)។ ឥឡូវនេះ សភាជាតិក៏នឹងទទួលបានសេចក្តីព្រាងច្បាប់ ដើម្បីវាយតម្លៃនិងឆ្លើយតប មុនពេលវាត្រូវបានអនុម័តនៅទីក្រុងប្រ៊ុចសែល។ សន្ធិសញ្ញាក៏ព្យាយាមបង្កើនតម្លាភាព ដោយតម្រូវអោយមានកិច្ចប្រជុំក្រុមប្រឹក្សាអឺរ៉ុបជាសាធារណៈ។ ហើយនៅក្នុងការប៉ុនប៉ងដើម្បីភ្ជាប់ជាមួយពលរដ្ឋសហភាពអឺរ៉ុបដោយផ្ទាល់ ឥឡូវនេះ គណៈកម្មការត្រូវតែទទួលយកសំណើ ឬញត្តិណាមួយដែលទទួលបានហត្ថលេខា ចំនួនមួយលាន។

ទោះបីជាមានការត្រួតពិនិត្យថ្មីនេះក៏ដោយ ការបែងចែកនយោបាយយ៉ាងស៊ីជម្រៅបានលេចឡើងនៅក្នុងសហភាពអឺរ៉ុបក្នុងឆ្នាំ ២០១៥ នៅពេលដែលជនភៀសខ្លួនរាប់ពាន់នាក់ដែលភៀសខ្លួនចេញពីជម្លោះ

នៅមជ្ឈិមបូព៌ា បានធ្វើអន្តោប្រវេសន៍ទៅកាន់អឺរ៉ុបខាងកើត។ សហភាពអឺរ៉ុបបានឆ្លើយតបដោយការអនុម័តផែនការដើម្បីតាំងទីលំនៅថ្មីនៃជនភៀសខ្លួនជាច្រើន ទោះបីជាមានការជំទាស់ពីសាធារណរដ្ឋឆេកស្លូវ៉ាគី ហុងគ្រី និងរូម៉ានីក៏ដោយ។ ផែនការនេះបានធ្វើអោយទំនាក់ទំនងរវាងប្រទេសអាឡឺម៉ង់ និងសមាជិកថ្មីនៃអឺរ៉ុបខាងកើតកាន់តែតានតឹង។

១០.៣.៩. អន្តោប្រវេសន៍ ការចាកចេញរបស់អង់គ្លេស និងអនាគតអឺរ៉ុប

វិបត្តិនយោបាយនៅអឺរ៉ុបបានចាប់ផ្តើមធ្វើឱ្យប៉ះពាល់ដល់ការគាំទ្រសម្រាប់សហភាពអឺរ៉ុប ក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ។ បន្ទាប់ពីវិបត្តិសេដ្ឋកិច្ចដ៏អស្ចារ្យឆ្នាំ ២០០៨-២០០៩ និងការធ្លាក់ចេញពីវិបត្តិបំណុលក្រិក អឺរ៉ុបបានជួបវិបត្តិចំណាកស្រុកក្នុងឆ្នាំ ២០១៥។ ចន្លោះខែមករា ឆ្នាំ ២០១៥ ដល់ខែមីនា ឆ្នាំ ២០១៦ ជនភៀសខ្លួនមួយលាននាក់បានចូលទៅក្នុងសហភាពអឺរ៉ុប តាមរយៈប្រទេសក្រិកដែលភាគច្រើនពួកគេមកដល់ដោយទូកពីប្រទេសទួរគី។ ជនចំណាកស្រុកទាំងនេះកំពុងភៀសខ្លួនចេញពីជម្លោះ នៅក្នុងប្រទេសស៊ីរី លីប៊ី និងអ៊ីរ៉ាក់។

សហភាពអឺរ៉ុបបានឆ្លើយតបដោយការអនុម័តផែនការ ដើម្បីតាំងទីលំនៅថ្មីនៃជនភៀសខ្លួនជាច្រើន ទោះបីជាមានការជំទាស់ពីសាធារណរដ្ឋឆេក ស្លូវ៉ាគី ហុងគ្រី និងរូម៉ានីក៏ដោយ។ ផែនការនេះបានធ្វើអោយទំនាក់ទំនងរវាងប្រទេសអាឡឺម៉ង់ និងសមាជិកថ្មីនៃអឺរ៉ុបខាងកើតកាន់តែតានតឹង។ សហភាពអឺរ៉ុបបានយល់ព្រមបង់ប្រាក់អោយទួរគីដើម្បីយកជនភៀសខ្លួន ដែលបានមកដល់ប្រទេសក្រិកមកវិញ បន្ទាប់ពីខែមីនាឆ្នាំ ២០១៦។ សម្រាប់ជនភៀសខ្លួននីមួយៗ ដែលទួរគីបានយកមកវិញពីក្រិក សហភាពអឺរ៉ុបនឹងតាំងទីលំនៅថ្មីសម្រាប់ជនភៀសខ្លួនដែលរស់នៅក្នុងប្រទេសទួរគី (តួកគីទទួលជនភៀសខ្លួនជាង ១ លាននាក់ពីសង្គ្រាមស៊ីវិលស៊ីរី។) សហភាពអឺរ៉ុបក៏បានយល់ព្រមបង់ប្រាក់អោយទួរគីចំនួន ៣ ពាន់លានអឺរ៉ូ ដើម្បីជួយចំណាយសម្រាប់វិបត្តិជនភៀសខ្លួនក៏ដូចជាអនុញ្ញាតឱ្យពលរដ្ឋទួរគីធ្វើដំណើររវាងរដ្ឋអឺរ៉ុបមួយចំនួនដោយមិនទទួលបានទិដ្ឋាការធ្វើដំណើរ។

សមាជិកសហភាពអឺរ៉ុប និងអង្គការសិទ្ធិមនុស្សជាច្រើនបានរិះគន់កិច្ចព្រមព្រៀងនេះ។ ដោយសារតែការព្រួយបារម្ភផ្នែកសេដ្ឋកិច្ចនិងនយោបាយ សមាជិកសហភាពអឺរ៉ុបមិនចង់តាំងលំនៅថ្មីជនភៀសខ្លួនស៊ីរីក្នុងប្រទេសខ្លួនឡើយ។ រដ្ឋជាសមាជិកមួយចំនួននៅតែជួបបញ្ហាជាមួយនឹងភាពអត់ការងារធ្វើ បន្ទាប់ពីវិបត្តិសេដ្ឋកិច្ចដ៏ធំ និងវិបត្តិបំណុលក្រិក។ រដ្ឋជាសមាជិកក៏បានលើកឡើងពីការព្រួយបារម្ភអំពីភេរវកម្មកើតពីក្រុម *អាយស៊ីស* (ISIS) ដែលគ្រប់គ្រងផ្នែកខ្លះនៃប្រទេសស៊ីរី ចូលមកតាមរយៈកម្មវិធីសិទ្ធិជ្រកកោន។ កង្វល់ទាំងនេះ ក្នុងចំណោមបញ្ហាផ្សេងទៀត បាននាំឱ្យមានការកើនឡើងនៃការគាំទ្រដល់ភាគីប្រឆាំងសហភាពអឺរ៉ុបក្នុងប្រទេសមួយចំនួន រួមទាំងប្រទេសបារាំង ហុងគ្រី ហ្វាំងឡង់ និងដាណឺម៉ាក។

អារម្មណ៍ឬមនោសញ្ចេតនាប្រឆាំងសហភាពអឺរ៉ុបដូចគ្នាទាំងនេះ នៅក្នុងចក្រភពអង់គ្លេសបានឈានដល់ចំណុចក្តៅដល់កំពូល ក្នុងខែមិថុនា ឆ្នាំ ២០១៥ ដោយនាយករដ្ឋមន្ត្រីអង់គ្លេសបានកំណត់ពេលបោះឆ្នោតលើអនាគតសមាជិកភាពអង់គ្លេសនៅក្នុងសហភាពអឺរ៉ុប ក្នុងរយៈពេលមួយឆ្នាំ។ ការបោះឆ្នោតអំពីការចាកចេញរបស់អង់គ្លេស "Brexit" ពីសហភាពអឺរ៉ុបត្រូវបានគេរំពឹងថានឹងខិតជិតមកដល់ ប៉ុន្តែអ្នកសង្កេតការណ៍ភាគច្រើនបានព្យាករណ៍ថា កម្លាំងនៃលទ្ធិនិយមជ្រុលនឹងទទួលជោគជ័យ។ យ៉ាងណាមិញ ទោះបីជាសមាជិកភាពក្នុង

សហភាពអឺរ៉ុបក៏ដោយ ក៏ចក្រភពអង់គ្លេសបានរក្សាស្វ័យភាពក្នុងវិស័យសំខាន់ៗ ដូចជាហិរញ្ញវត្ថុ (អង់គ្លេសមិនប្រើប្រាស់ប្រាក់អឺរ៉ូ) និងគោលនយោបាយសការបរទេស។

ប៉ុន្តែ នៅក្នុងខែមិថុនា ឆ្នាំ ២០១៦ ពលរដ្ឋអង់គ្លេសបានចេញទៅបោះឆ្នោតដោយកម្រិតតិចតួច (៥១,៩ ភាគរយ បង្ហាញមតិពេញចិត្ត) សម្រាប់ការចាកចេញពីសហភាពអឺរ៉ុប។ នៅថ្ងៃទី ២៩ ខែមីនាឆ្នាំ ២០១៧ ចក្រភពអង់គ្លេសបានបង្កអោយមានឃ្លាចាកចេញនៅក្នុងសន្ធិសញ្ញាទីក្រុងលីស្បោន ដោយកំណត់រយៈពេលពីរឆ្នាំនៃការចរចា។ នៅក្រោមច្បាប់របស់សហភាពអឺរ៉ុប ចក្រភពអង់គ្លេសត្រូវតែចាកចេញពីសហភាពអឺរ៉ុប ត្រឹមថ្ងៃទី ២៩ ខែមីនា ឆ្នាំ ២០១៩។


ការចរចាអំពីការចាកចេញរបស់អង់គ្លេស "Brexit" ពីសហភាពនឹងត្រូវគ្របដណ្តប់លើបញ្ហាជាច្រើន។ ចក្រភពអង់គ្លេសត្រូវតែបង់ថ្លៃដើម្បីចាកចេញពីសហភាពអឺរ៉ុប ក្នុងទំហំដែលត្រូវចរចារវាងចក្រភពអង់គ្លេស និងសមាជិកសហភាពអឺរ៉ុបដែលនៅសល់។ ស្ថានភាពពលរដ្ឋសហភាពអឺរ៉ុបនៅអង់គ្លេស និងពលរដ្ឋអង់គ្លេសដែលរស់នៅអឺរ៉ុបចាំបាច់ត្រូវបញ្ជាក់។ ការឆ្លងកាត់ព្រំដែនរវាងអៀរឡង់ និងចក្រភពអង់គ្លេសនឹងត្រូវការច្បាប់ថ្មី ចាប់តាំងពីប្រទេសអៀរឡង់គ្រោងនឹងបន្តនៅក្នុងសហភាពអឺរ៉ុប។ តើស្ថានភាពពន្ធពាណិជ្ជកម្មរវាង សហភាពអឺរ៉ុប និងចក្រភពអង់គ្លេសនឹងទៅជាយ៉ាងណា? សរុបមក ដំណើរការលែងលះឬចាកចេញ មានភាពស្មុគស្មាញ និងមាននយោបាយខ្ពស់។ ខណៈពេលដែលមនុស្សជាច្រើន នៅក្នុងសហភាពអឺរ៉ុប(EU)ចង់ដាក់ទណ្ឌកម្មអង់គ្លេសសម្រាប់ការចាកចេញ (គិតថ្លៃការចាកចេញដ៏ធំ ការដំឡើងពន្ធ និងផ្សេងទៀត) ចក្រភពអង់គ្លេស នៅតែជាដៃគូពាណិជ្ជកម្មដ៏សំខាន់នៃរដ្ឋជាច្រើនរបស់សហភាពអឺរ៉ុប និងជាសមាជិករបស់ណាតូ។ ដូចដែលអ្នកទ្រឹស្តីស្តាប័ននឹងសង្កត់ធ្ងន់ ស្រមោលនៃអនាគតនៅតែមានរវាងភាគីនានា ដែលមានឥទ្ធិពលលើកិច្ចសហប្រតិបត្តិការ នាពេលបច្ចុប្បន្ននេះ។ គិតត្រឹមឆ្នាំ ២០១៨ ព័ត៌មានលម្អិតជាច្រើននៅតែត្រូវបានចរចាសម្រាប់ Brexit ដែលនឹងប្រព្រឹត្តទៅនៅនិទាឃរដូវឆ្នាំ ២០១៩ ។

លើសពីសហភាពអឺរ៉ុបផ្ទាល់ អឺរ៉ុបគឺជាការងារជួសជុលនៃរចនាសម្ព័ន្ធត្រួតស៊ីគ្នាជាមួយនឹងសមាជិកភាពផ្សេងៗគ្នា (សូមមើលក្រាហ្វិក ១០.៣)។ ទោះបីជាច្បាប់អឺរ៉ុបតែមួយក៏ដោយ ក៏នៅតែមានអឺរ៉ុបជាច្រើនដែរ។ នៅក្នុងសហភាពអឺរ៉ុបគឺជា "ខាងក្នុងប្រាំមួយ" និងការមកដល់ថ្មី ដែលនីមួយៗមានកង្វល់រៀងៗខ្លួន។ នៅជុំវិញគែម គឺជារដ្ឋ EFTA ដែលចូលរួមក្នុងតំបន់សេដ្ឋកិច្ចអឺរ៉ុប។ សមាជិកភាពណាតូត្រួតស៊ីគ្នាមួយផ្នែកជាមួយសហភាពអឺរ៉ុប។ រុស្ស៊ី និងសូម្បីតែសហរដ្ឋអាមេរិក គឺជាតួអង្គអឺរ៉ុបក្នុងការគោរពខ្លះ ប៉ុន្តែមិនមែនអ្នកដទៃទេ។ អង្គការអន្តរដ្ឋាភិបាលសកលពិតមួយមាននៅក្នុងទ្វីបអឺរ៉ុប អង្គការដើម្បីសន្តិសុខ និងកិច្ចសហប្រតិបត្តិការនៅអឺរ៉ុប (OSCE)។ ដំណើរការដោយការឯកភាព ដោយមានសមាជិកភាពធំ និងជាសាកលនៃរដ្ឋចំនួន ៥៦ OSCE មានអំណាចតិចតួចប៉ុណ្ណោះ លើកលែងតែដើរតួជាវេទិកាសម្រាប់ការពិភាក្សាអំពីបញ្ហាសន្តិសុខ។ នៅចុងទស្សវត្សរ៍ឆ្នាំ ១៩៩០ OSCE បានផ្លាស់ប្តូរទៅក្នុងកិច្ចការថ្មីដូចជាការដំណើរការការបោះឆ្នោត ការជួយគណបក្សនយោបាយនៅបូស្នៀ និងកូសូវ៉ូ និងការផ្តល់នូវទម្រង់ផ្សេងៗនៃការត្រួតពិនិត្យ និងជំនួយនៅក្នុងបណ្តាប្រទេសពាក់កណ្តាលអឺរ៉ុបខាងកើត។

ដូច្នេះ សមាហរណកម្មអន្តរជាតិមិនមែនជាបញ្ហានៃក្រុម ឬអង្គការតែមួយទេ ប៉ុន្តែជារូបភាពនៃរចនាសម្ព័ន្ធដែលភ្ជាប់រដ្ឋជាមួយគ្នា។ រចនាសម្ព័ន្ធផ្សេងៗនៃប្រព័ន្ធនយោបាយអឺរ៉ុប ដែលផ្តោតលើសហភាពអឺរ៉ុប គឺជាស្ថាប័នអន្តរដ្ឋាភិបាលដែលមានរដ្ឋជាសមាជិក។ ប៉ុន្តែ ទិដ្ឋភាពមិនសូវជាក់ស្តែងនៃការធ្វើសមាហរណកម្ម

គឺជាអារម្មណ៍នៃអត្តសញ្ញាណ ដែលរីកចម្រើនតាមពេលវេលា ដោយសារទំនាក់ទំនងសេដ្ឋកិច្ច (និងមុខងារផ្សេងទៀត) នាំមនុស្សអោយកាន់តែជិតស្និទ្ធជាមួយគ្នាឆ្លងព្រំដែន។ អត្តសញ្ញាណ វប្បធម៌ និងការប្រាស្រ័យទាក់ទងជាលក្ខណៈបរមានុភាព ក៏ជាទិដ្ឋភាពនៃការធ្វើសមាហរណកម្មអន្តរជាតិផងដែរ។ ផ្នែកដែលនៅសល់នៃមេរៀននេះពិចារណាពីរបៀបដែលបច្ចេកវិទ្យាព័ត៌មានកំពុងឆ្លងកាត់រដ្ឋនានា និងនាំមកនូវសមាហរណកម្មប្រភេទនេះនៅទូទាំងពិភពលោក។

ក្រាហ្វិក ១០.៣ សមាជិកភាពត្រួតស៊ីគ្នានៃរដ្ឋអឺរ៉ុប



សម្គាល់៖ *ចូរសង្កេតមើលក្របខណ្ឌពីខាងក្រៅទៅខាងក្នុង៖ ប្រអប់បន្ទាត់ជាច់ៗគឺជាអង្គការដើម្បីសន្តិសុខនិងកិច្ចសហប្រតិបត្តិការនៅអឺរ៉ុប (OSCE), បន្ទាប់មក ប្រអប់បន្ទាត់ជាប់ជិតគឺជាអង្គការណាតូ, សហភាពអឺរ៉ុប (EU) ស្ថិតក្នុងប្រអប់បន្ទាត់ជាប់បន្ទាប់ និងនៅក្នុងEUមាន តំបន់អឺរ៉ូ និងចង្កោមប្រទេសស្ថាបនិកទាំង៦។ ប្រទេសអឺរ៉ុបផ្សេងទៀតក៏ចង់សម្ព័ន្ធភាពជាអង្គការផ្សេងៗផងដែរ ដូចជានៅអឺរ៉ុបខាងកើតកតិកាសញ្ញាវ៉ាសូវី ជាដើម។*

១០.៤. អំណាចនៃព័ត៌មាន

១០.៤ ចូរពន្យល់ពីវិធីពីរយ៉ាងដែលព័ត៌មានអាចក្លាយជាឧបករណ៍សម្រាប់រដ្ឋាភិបាល និងវិធីពីរយ៉ាងដែលព័ត៌មានអាចក្លាយជាឧបករណ៍សម្រាប់ប្រឆាំងនឹងរដ្ឋាភិបាល។

ទូរគមនាគមន៍សកលកំពុងផ្លាស់ប្តូរយ៉ាងជ្រាលជ្រៅពីរបៀបដែលព័ត៌មាននិងវប្បធម៌ដំណើរការនៅក្នុងទំនាក់ទំនងអន្តរជាតិ។ ភាពជឿនលឿននៃបច្ចេកវិទ្យាទាំងនេះ ដែលជាចំណុចកណ្តាលនៃសកលភាវូបនីយកម្មកំពុងនាំមកនូវគោលការណ៍អត្តសញ្ញាណដល់មុខ នៅពេលដែលសហគមន៍មានអន្តរកម្មឆ្លងកាត់ចម្ងាយ និង

ព្រំដែន។បុគ្គល និងក្រុមដែលទើបទទួលបានអំណាចថ្មីកំពុងបង្កើតបណ្តាញឆ្លងដែនថ្មីនៅទូទាំងពិភពលោក ដោយឆ្លងកាត់រដ្ឋនានា។

១០.៤.១. ការតភ្ជាប់ពិភពលោក

លទ្ធភាពអន្តរកម្មនយោបាយអន្តរជាតិថ្មីអាចកើតឡើងបានដោយអាស្រ័យលើការអភិវឌ្ឍបច្ចេកវិទ្យា។ ប្រព័ន្ធផ្សព្វផ្សាយដែលព័ត៌មានហូរចេញហូរចូល (ទូរស័ព្ទ ទូរទស្សន៍ ភាពយន្ត ទស្សនាវដ្តី និងអ្វីៗផ្សេងទៀត) បង្កើតរបៀបដែលគំនិតកើតឡើងនិងរីករាលដាល ពីកន្លែងមួយទៅកន្លែងមួយទៀត។ ប្រព័ន្ធផ្សព្វផ្សាយដែលមានឥទ្ធិពលនយោបាយខ្លាំងជាងគេ គឺទូរទស្សន៍ វិទ្យុ ទូរស័ព្ទ និងអ៊ីនធឺណិត។

ទូរទស្សន៍ និងវិទ្យុ

មានទូរទស្សន៍ជិត ២ ពាន់លាន និងអ្នកទទួលវិទ្យុ ៣ ពាន់លាននៅលើពិភពលោក។ វិទ្យុ និងទូរទស្សន៍កាន់តែខ្លាំងឡើងទៅដល់តំបន់ជនបទក្រីក្របំផុតនៃអឌ្ឍគោលភាគខាងត្បូង។ ទូរទស្សន៍ និងរលកសញ្ញាវិទ្យុធម្មតា គឺជារលកវិទ្យុនៃប្រេកង់ជាក់លាក់ ដែលជាធនធានមានកំណត់ក្នុងតម្រូវការខ្ពស់ ដែលគ្រប់គ្រងដោយរដ្ឋាភិបាល។ ដោយសាររលកវិទ្យុមិនគោរពព្រំដែនជាតិ ការបែងចែកប្រេកង់គឺជាកម្មវត្ថុនៃការចរចារវាងរដ្ឋ។ របបអន្តរជាតិបានរីកចម្រើនជុំវិញបទប្បញ្ញត្តិនៃបច្ចេកវិទ្យាទំនាក់ទំនង ដែលផ្តោតលើសហភាពទូរគមនាគមន៍អន្តរជាតិ (ITU)។

ទូរទស្សន៍ផ្តាយរណបរំលងដែនគ្រប់គ្រងរបស់រដ្ឋ និងពង្រឹងនយោបាយអត្តសញ្ញាណឆ្លងដែន ឬលើសកម្រិត ដោយអនុញ្ញាតអោយជនអារ៉ាប់ទាំងអស់នៅក្នុងពិភពលោកមើលឃើញការផ្សាយទូរទស្សន៍ផ្តាយរណបអារ៉ាប់អំពីបញ្ហាប៉ាឡេស្ទីន។ ទូរទស្សន៍ អាល់ ចាហ្ស៊ីរ៉ា (Al Jazeera) ដែលមានមូលដ្ឋាននៅប្រទេសកាតា បានចាប់ផ្តើមនៅក្នុងឆ្នាំ ១៩៩៦ គឺជាកម្លាំងមួយនៅក្នុងនយោបាយមជ្ឈិមបូព៌ា និងឈានដល់ទស្សនិកជនដ៏មានឥទ្ធិពលទូទាំងពិភពលោក។ ការស្នងមតិនៅក្នុងបណ្តាប្រទេសអារ៉ាប់ជាប់លាប់ចុះបញ្ជីទូរទស្សន៍ អាល់ ចាហ្ស៊ីរ៉ា ជាប្រភពសំខាន់នៃព័ត៌មានអន្តរជាតិ ដោយមានប្រៀបធំជាងបណ្តាញទូរទស្សន៍ផ្តាយរណបផ្សេងទៀត។

ទូរស័ព្ទ និងអ៊ីនធឺណែត


សូម្បីតែការផ្តល់សិទ្ធិអំណាចដល់ប្រជាពលរដ្ឋសាមញ្ញជាងនេះ គឺទូរស័ព្ទ និងអ៊ីនធឺណិត។ ទាំងនេះគឺជាប្រព័ន្ធផ្សព្វផ្សាយពីរផ្លូវដែលអ្នកប្រើប្រាស់ធ្វើអន្តរកម្មរវាងខ្លួនគេ ដោយគ្មានប្រភពព័ត៌មានកណ្តាល។ ក្នុងឆ្នាំ ២០១៧ ពិភពលោកមានការជាវទូរស័ព្ទជិត ៧,៥ ពាន់លាន ដែលស្ទើរតែចំនួនមនុស្ស និងលើសពីចំនួន ១ ពាន់លានទូរស័ព្ទចល័តឆ្ងាយ។ មនុស្សជាង ៤ ពាន់លាននាក់មានសមត្ថភាពអ៊ីនធឺណិត អ៊ីនធឺណិតតាមទូរស័ព្ទចល័ត រួមទាំង ១០០ ភាគរយនៃចំនួនប្រជាជននៅក្នុងប្រទេសកូរ៉េ និងសិង្ហបុរី។ ប្រទេសឥណ្ឌាមានអ្នកប្រើប្រាស់ទូរស័ព្ទច្រើនជាងបីដងចាប់តាំងពីឆ្នាំ ២០០៧ ខណៈដែលប្រទេសចិនមានអ្នកជាវទូរស័ព្ទច្រើនជាង ១,៤ ពាន់លាននាក់គិតត្រឹមឆ្នាំ ២០១៤។ ការផ្ទុះនៃចរាចរណ៍ទូរស័ព្ទអន្តរជាតិទូទាំងពិភពលោក និង ការចូលប្រើប្រាស់អ៊ីនធឺណិតតាមផ្ទះ និងទូរស័ព្ទ គឺជាសូចនាករច្បាស់លាស់នៃសកលភាវូបនីយកម្ម។ (សូមមើលក្រាហ្វិក ១០.៤)។

មុខងារសំខាន់មួយផ្នែកនយោបាយនៃបច្ចេកវិទ្យាទាំងនេះគឺកាមេរ៉ាទូរសព្ទ។ វាបានផ្តល់សិទ្ធិអំណាចដល់ប្រជាពលរដ្ឋសាមញ្ញក្នុងការបង្កើតកំណត់ត្រាដែលមើលឃើញ ដូចជាវីដេអូនៃបាតុកម្មនយោបាយនៅ

ក្នុងប្រទេសមួយដែលបញ្ចប់នៅលើទូរទស្សន៍នៅក្នុងប្រទេសមួយផ្សេងទៀត។ នៅក្នុងបដិវត្តន៍និទាឃរដូវនៅអារ៉ាប់ ឆ្នាំ ២០១១-២០១២ ជាពិសេសនៅប្រទេសស៊ីរីវីដេអូទូរសព្ទដៃបានដើរតួនាទីយ៉ាងសំខាន់ក្នុងការទទួលបានការគាំទ្រ ដោយបង្ហាញពីរដ្ឋាភិបាលបានសម្លាប់ប្រជាពលរដ្ឋយ៉ាងព្រៃផ្សៃ។ ការអភិវឌ្ឍន៍ផ្នែកបច្ចេកវិទ្យាដែលពាក់ព័ន្ធនៃសារៈសំខាន់នយោបាយដ៏សំខាន់ គឺការរីកលូតលាស់នៃប្រព័ន្ធផ្សព្វផ្សាយសង្គមដូចជា ហ្វេសប៊ុក ដែលបង្កើតសហគមន៍ និងអនុញ្ញាតអោយចែករំលែកគំនិត (រួមទាំងវីដេអូទូរស័ព្ទដៃទាំងនោះ) នៅខាងក្រៅការគ្រប់គ្រងរបស់រដ្ឋាភិបាល និងពេលខ្លះឆ្លងកាត់ព្រំដែនអន្តរជាតិ។

រូបភាព ១០.៤ ការប្រើប្រាស់ទូរស័ព្ទ និងអ៊ីនធឺណិតពិភពលោក ឆ្នាំ ២០០៥-២០១៧

ប្រភព៖ ទិន្នន័យសហភាពទូរគមនាគមន៍អន្តរជាតិ (ITU)



បន្ទាត់ខាងលើ៖ *ទូរស័ព្ទចល័ត* បន្ទាត់កណ្តាល៖ *អ៊ីនធឺរណែតបុគ្គល* បន្ទាត់ដាច់ៗ៖ *ទូរស័ព្ទខ្សែ*

នៅទ្វីបអាហ្វ្រិក ទូរស័ព្ទដៃថោកៗ ដែលមានកាតហៅទូរស័ព្ទដែលមានតំលៃថោកបានអនុញ្ញាតអោយបុគ្គលក្រីក្ររាប់លាននាក់ទាក់ទងគ្នា។ ក្នុងរយៈពេលប្រហែលមួយទសវត្សរ៍ អនុតំបន់សាហារ៉ាអាហ្វ្រិកបានឃើញអតិថិជនកើនឡើងដល់ជិត ៧៥០ លាននាក់នៅឆ្នាំ ២០១៧។ ទូរស័ព្ទទាំងនេះផ្តល់សិទ្ធិអំណាចដល់បុគ្គលម្នាក់ៗ ដោយអនុញ្ញាតអោយកសិករពិនិត្យមើលតម្លៃទីផ្សារ មុននឹងសម្រេចចិត្តថាពេលណាត្រូវប្រមូលផល។ នៅក្នុងជោគជ័យដ៏គួរឲ្យកត់សម្គាល់មួយនៅអាហ្វ្រិក កេនយ៉ាបានក្លាយជាប្រទេសឈានមុខគេក្នុងការប្រើទូរស័ព្ទដៃសម្រាប់ធនាគារ។ ប្រទេសនេះមានប្រតិបត្តិការធនាគារ ១០ លាន ជារៀងរាល់ថ្ងៃ (ជាមធ្យម ២០ ដុល្លារ) ប៉ុន្តែចំនួនប្រជាជនពាក់កណ្តាលខ្វះគណនីធនាគារ ដូច្នេះ សហគ្រិនបានបង្កើតប្រព័ន្ធទូទាត់ចល័ត M-Pesa។ អ្នករស់នៅក្នុងទីក្រុងអាចផ្ទេរប្រាក់ទៅភូមិឬស្រុកកំណើតរបស់ពួកគេ តាមទូរស័ព្ទជំនួសអោយការយកប្រាក់សម្រាប់ជិះឡានក្រុងឬថយន្តឈ្នួលយ៉ាងយូរ។ នៅឆ្នាំ ២០១៧ ការផ្ទេរមូលនិធិ

ចល័តទាំងនេះដោយអ្នកប្រើប្រាស់ ២០ លាននាក់ (ប្រហែល ២ ភាគ ៣ នៃចំនួនប្រជាជន) បង្កើតបានមួយភាគបួននៃផលិតផលក្នុងស្រុកសរុបរបស់ប្រទេសកេនយ៉ា។


ការបែងចែកនយោបាយយ៉ាងស៊ីជម្រៅលើអ៊ីនធឺណិតបានផ្តោតជាសំខាន់ ក្នុងខែធ្នូ ឆ្នាំ ២០១២ នៅក្នុងសន្និសីទរបស់ ITU ក្នុងទីក្រុងឌូបៃ ដើម្បីបង្កើតសន្ធិសញ្ញាថ្មីស្តីពីអ៊ីនធឺរណែតនិងទូរគមនាគមន៍សកល។ ប្រទេសរុស្ស៊ី ចិន និងរដ្ឋផ្សេងទៀតបានមើលឃើញថាអ៊ីនធឺណិតជាប្រព័ន្ធនៃបណ្តាញដែលគ្រប់គ្រងដោយរដ្ឋាភិបាល ខណៈពេលដែលសហរដ្ឋអាមេរិក និងអ្នកដទៃ រួមទាំងក្រុមហ៊ុនមហាយក្ស Google និងអង្គការក្រៅរដ្ឋាភិបាលនានាបានមើលឃើញថា វាជាអង្គភាពអាម៉ូនិកមួយបន្ថែមទៀត ដើម្បីជួយសម្រួលដល់លំហូរព័ត៌មានដោយសេរី។ សភាតំណាងរាស្ត្រសហរដ្ឋអាមេរិក ក្នុងគ្រាដ៏កម្រនៃទំនាក់ទំនងទ្វេភាគី បានជំទាស់ជាឯកច្ឆ័ន្ទលើសន្ធិសញ្ញាថ្មី។ នៅទីបញ្ចប់ ប្រទេសចំនួន ៨៩ បានគាំទ្រ ប៉ុន្តែ ៥៥ ប្រទេសផ្សេងទៀតនឹងមិនចុះហត្ថលេខាទេ។

គម្លាតឌីជីថល

ដោយប្រព្រឹត្តិទៅដោយខ្លួនឯង ការបន្ថែមសមត្ថភាពទូរស័ព្ទ និងអ៊ីនធឺណិតនៅក្នុងប្រទេសក្រីក្រមានលក្ខណៈគួរអោយចាប់អារម្មណ៍។ ប៉ុន្តែ បើប្រៀបធៀបនឹងតំបន់សម្បូរបែប គម្លាតនៅតែមាន (សូមមើលក្រាហ្វិក ១០.៥)។ មនុស្សម្នាក់ដែលរស់នៅក្នុងអឌ្ឍគោលខាងជើងទំនងជាមានទូរស័ព្ទខ្សែនៅផ្ទះ ទូរស័ព្ទដៃ និងអ៊ីនធឺណិត ច្រើនជាងមនុស្សម្នាក់នៅអឌ្ឍគោលភាគខាងត្បូង។ គម្លាតនេះ រួមជាមួយនឹងគម្លាតក្នុងការចូលទៅកាន់បច្ចេកវិទ្យាព័ត៌មានក្នុងប្រទេសនានា ត្រូវបានគេស្គាល់ថាជា**ការបែងចែកឌីជីថល**។

ក្រាហ្វិក ១០.៥ គម្លាតឌីជីថលអឌ្ឍគោលខាងជើង-ខាងត្បូង ឆ្នាំ ១៩៩៤-២០១៧

ប្រភព៖ ទិន្នន័យសហភាពទូរគមនាគមន៍អន្តរជាតិ (ITU)



សម្គាល់៖ បន្ទាត់ខាងលើ *អឌ្ឍគោលខាងជើង* ចំណែកបន្ទាត់ខាងក្រោម *អឌ្ឍគោលខាងត្បូង*

នៅពេលដែលអ៊ីនធឺណិតតភ្ជាប់ផ្នែកនានាលើពិភពលោកទៅជាបណ្តាញដ៏រឹងមាំមួយ ផ្តោតទៅលើសហរដ្ឋអាមេរិក អឺរ៉ុប និងអាស៊ីបូព៌ា ដែលអ្នកប្រើប្រាស់គេហទំព័រភាគច្រើនរស់នៅ ចំណែកតំបន់ផ្សេងទៀតភាគច្រើនដើរយឺតជាងគេ ក្នុងវិញ្ញាសាទទួលបានអ៊ីនធឺរណែតប្រើប្រាស់ ជាពិសេសការភ្ជាប់អ៊ីនធឺរណែតល្បឿនខ្ពស់។ ប្រទេសក្រីក្រ និងប្រជាជនក្រីក្រមិនអាចមានលទ្ធភាពទិញកុំព្យូទ័របានទេ។ ក្នុងឆ្នាំ ២០១៥

កម្រិតបញ្ជូនអ៊ីនធឺណេត ក្នុងមនុស្សម្នាក់ នៅទ្វីបអឺរ៉ុប មានកម្រិត ២៥ ដង ខ្ពស់ជាង នៅអាហ្វ្រិក។ តិចជាង ២ ភាគរយនៃបុគ្គលក្នុងប្រទេសកំពុងអភិវឌ្ឍន៍មានការតភ្ជាប់ល្បឿនលឿន និងទូលំទូលាយ បើប្រៀបធៀបទៅនឹង ២៥ ភាគរយ នៅក្នុងប្រទេសអភិវឌ្ឍន៍ខ្លាំង។ អ៊ីនធឺណេតបានឈានដល់ ៨៥ ភាគរយនៃគ្រួសារនៅអឌ្ឍគោលភាគខាងជើង ប៉ុន្តែមានតែ ៤០ ភាគរយប៉ុណ្ណោះ នៅក្នុងអឌ្ឍគោលខាងត្បូង។ ចំនួនអ្នកប្រើប្រាស់អ៊ីនធឺណិតតាមទូរស័ព្ទចល័ត មានកម្រិត ៩០ ភាគរយ នៅអឌ្ឍគោលភាគខាងជើង និងតិច ៥០ ភាគរយនៅអឌ្ឍគោលភាគខាងត្បូង។ ទោះជាកំណើនខ្លាំងនៃការប្រើប្រាស់អ៊ីនធឺណិត នៅអឌ្ឍគោលភាគខាងត្បូង គម្លាតឌីជីថលជ្រាលជ្រៅនៅតែមាន ដោយលម្អៀងទៅខាងអ្នកមានជាងនៅអឌ្ឍគោលភាគខាងជើង។

សកម្មជនមួយចំនួនសង្ឃឹមថា អ៊ីនធឺណេតអាចផ្លាស់ប្តូរភូមិក្រីក្រនៅអឌ្ឍគោលខាងត្បូងបានមួយផ្នែក ដោយអនុញ្ញាតអោយពួកគេផលិតទំនិញប្រពៃណីក្នុងស្រុក និងធ្វើទីផ្សារនៅទូទាំងពិភពលោក។ នៅក្នុងការពិសោធន៍ជោគជ័យមួយក្នុងប្រទេសឥណ្ឌាក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ អ្នកជំនួញម្នាក់បានដាក់អេក្រង់កុំព្យូទ័រដែលមានឧបករណ៍ចង្អុល និងចុច និងការចូលប្រើអ៊ីនធឺណិតល្បឿនលឿននៅតាមដងផ្លាំង និងបញ្ជរនៅតាមតំបន់ក្រីក្រខ្លាំង។ នៅក្នុងទីតាំងនីមួយៗ ក្មេងៗក្នុងសង្កាត់បានប្រមូលផ្តុំគ្នាយ៉ាងឆាប់រហ័ស បង្រៀនខ្លួនឯងអោយរុករកអ៊ីនធឺរណែត ហើយថែមទាំងបានបង្កើតវាក្យស័ព្ទផ្ទាល់ខ្លួនរបស់ពួកគេ ដើម្បីពិពណ៌នាអំពីទស្សន៍ទ្រនិច និងរូបតំណាងដែលមិនធ្លាប់ស្គាល់នៅលើអេក្រង់។ ការពិសោធន៍ «ប្រហោងក្នុងជញ្ជាំង» ខ្នាតតូចនេះ បង្ហាញថាវិធីសាស្ត្រសាមញ្ញអាចបន្តដើម្បីបង្រួមគម្លាតឌីជីថលរវាងអ្នកមាននិងអ្នកក្រនៅលើពិភពលោក។

គម្រោងគំរូដ៏ល្អមួយ នៅក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ ២០០១ បានជួយធ្វើអោយឧស្សាហកម្មតម្បាញសូត្រនៅក្នុងភូមិរស់រានឡើងវិញ ដោយការធ្វើទីផ្សារកន្សែងដៃលក្បាញក្នុងស្រុកនៅលើគេហទំព័ររបស់ភូមិមួយ។ ទោះជាយ៉ាងណាក៏ដោយ អ្នករិះគន់បានកត់សម្គាល់ថា គម្រោងនេះអាចធ្វើទៅបានលុះត្រាតែក្រុមហ៊ុនផ្គាយរណបដែលជាកម្មសិទ្ធិរបស់នាយករដ្ឋមន្ត្រីថៃបានបរិច្ចាគ ១៨០០០ ដុល្លារ សម្រាប់ តភ្ជាប់បណ្តាញ ក្នុងមួយឆ្នាំៗ។ អង្គការជំនួយរបស់សហរដ្ឋអាមេរិកបានផ្តល់កុំព្យូទ័រ ការបណ្តុះបណ្តាល ការរចនាគេហទំព័រ និងដំណើរការកាតឥណទានដែលតម្រូវអោយលក់កន្សែងបង់កពីភូមិ។ ការពិតគឺថា ភូមិក្រីក្រភាគច្រើនមិនអាចទិញអ៊ីនធឺរណែតមិនអាចអានភាសានៃគេហទំព័រភាគច្រើន និងមិនអាចរក្សាកុំព្យូទ័របាន និងគេហទំព័រដោយគ្មានការបណ្តុះបណ្តាលទូលំទូលាយ។

ចាប់តាំងពីឆ្នាំ ២០០៧ មក គម្រោង «One Laptop per Child» ដែលមានន័យជាភាសាខ្មែរថា «កុំព្យូទ័រមួយគ្រឿងសម្រាប់កុមារម្នាក់» បាននិងកំពុងផលិតកុំព្យូទ័រផ្ទាល់ខ្លួនឥតខ្សែដែលមានសមត្ថភាពតាមបណ្តាញអ៊ីនធឺណេតដែលមានតំលៃថោក ប្រហែល ២០០ ដុល្លារក្នុងមួយគ្រឿង។ កុំព្យូទ័រដែលរចនាដោយសាស្ត្រាចារ្យសាលា MIT ដ៏ល្បីល្បាញ អាចទំនាក់ទំនងជាមួយចំណុចចូលប្រើអ៊ីនធឺរណែតដូចជានៅសាលារៀនិងភ្ជាប់បណ្តាញគ្នាទៅវិញទៅមក ដើម្បីពង្រីកការចូលប្រើអ៊ីនធឺណិតតាមខ្សែសង្វាក់ពីសាលារៀនទៅផ្ទះរបស់សិស្ស។ កុំព្យូទ័រយួរដៃអាចប្រើថាមពលដោយដៃដោយប្រើកម្លាំងមួយនាទីសាកថ្មរយៈពេលដប់នាទី។ ប្រទេសជាច្រើនបានបញ្ជាទិញមនុស្សរាប់លាននាក់សម្រាប់កូនរបស់ពួកគេ ហើយប្រហែល ៣ លាននាក់បានដឹកជញ្ជូនទៅកាន់ប្រទេសចំនួន ៤០ ទោះបីជាមានបញ្ហា និងការធ្លាក់ចុះក៏ដោយ។ ក្នុងឆ្នាំ ២០០៩ ប្រទេសអ៊ុយរូហ្គាយបានទិញមួយសម្រាប់កុមារគ្រប់អាយុសិក្សាក្នុងប្រទេសនោះ។ នៅក្នុងការពិសោធន៍ដ៏អស្ចារ្យមួយក្នុងឆ្នាំ ២០១២ អង្គការបានផ្ញើប្រអប់នៃកុំព្យូទ័រថេប្លេតរបស់ខ្លួនទៅកាន់សិស្សបឋមសិក្សានៅក្នុង

ភូមិដាច់ស្រយាលនៃប្រទេសអេត្យូពីពីរ ដែលគ្មានសាលារៀន និងគ្មានកម្រិតអក្ខរកម្ម។ ក្រៅពីការបង្ហាញមនុស្សពេញវ័យមួយចំនួនអំពីរបៀបប្រើផ្នាំងសាកថាមពលពន្លឺព្រះអាទិត្យ គម្រោងនេះមិនមានការណែនាំបន្ថែមទេ។ ក្នុងរយៈពេលបួននាទី សិស្សបានបើកប្រអប់ ហើយរកវិធីបើកម៉ាស៊ីនអោយដំណើរការ។ ក្នុងរយៈពេលប្រាំថ្ងៃ កុមារជាមធ្យមកំពុងប្រើប្រាស់កម្មវិធីជិត ៥០ ជារៀងរាល់ថ្ងៃ។ ក្នុងរយៈពេលពីរសប្តាហ៍ សិស្សបានច្រៀងចម្រៀង ABC និងបង្រៀនខ្លួនឯងអោយចេះអាន។ ហើយក្នុងរយៈពេលប្រាំខែ ពួកគេបានលួចចូលប្រព័ន្ធប្រតិបត្តិការ Android ដើម្បីបើកកាមេរ៉ា និងប្តូរផ្ទៃអេក្រង់តាមបំណង។

រូបថត *ម្ចាស់ហាងកំពុងរង់ចាំអតិថិជន ស្កេនបង់ប្រាក់*

ស្កេនទីនេះដើម្បីបង់ប្រាក់

ការប្រាស្រ័យទាក់ទងសកលដែលជាសមត្ថភាពថ្មីបំផុត នៅលើបន្ទាត់ពេលវេលានៃប្រព័ន្ធអន្តរជាតិកំពុងផ្លាស់ប្តូរច្បាប់ទំនាក់ទំនងអន្តរជាតិ និងផ្តល់សិទ្ធិអំណាចដល់តួអង្គដែលមិនមែនជារដ្ឋឆ្លងព្រំដែនជាតិ។ ទូរគមនាគមន៍អាចផ្លាស់ប្តូរមាគ៌ានៃការអភិវឌ្ឍន៍នៅក្នុងប្រទេសក្រីក្រ ដោយអាចរំលងហេដ្ឋារចនាសម្ព័ន្ធបែបប្រពៃណី ដូចជាខ្សែទូរស័ព្ទ និងការលោតផ្លោះទៅជាសេដ្ឋកិច្ចបណ្តាញឥតខ្សែ។ នៅទីនេះ ម្ចាស់ហាងកំពុងរង់ចាំអតិថិជន ខណៈផ្សាយពាណិជ្ជកម្មអំពីការទទួលយកប្រព័ន្ធ M-Pesa ដែលជាប្រព័ន្ធទូទាត់ប្រាក់តាមទូរស័ព្ទ នៅប្រទេសកេនយ៉ា ឆ្នាំ ២០១៧។

១០.៤.២. ព័ត៌មានជាឧបករណ៍របស់រដ្ឋាភិបាល

ជាមួយនឹងព័ត៌មានកាន់តែច្រើនដែលធ្វើដំណើរជុំវិញពិភពលោកជាងសម័យកាលមុនៗ ព័ត៌មានបានក្លាយជាឧបករណ៍សំខាន់សម្រាប់ពង្រឹងអំណាចរបស់រដ្ឋាភិបាល (ក្នុងស្រុកនិងរដ្ឋ)។ បន្ទាប់ពីសហភាពសូវៀតបានដួលរលំ មេដឹកនាំនៃសាធារណរដ្ឋឯករាជ្យថ្មីបានសួរដេមន្ត្រីការបរទេសសហរដ្ឋអាមេរិកថា «តើខ្ញុំទទួលបានព័ត៌មានពីCNN យ៉ាងដូចម្តេច?»[២៩] ពួកគេចង់បានព័ត៌មាន។ សព្វថ្ងៃនេះ រដ្ឋាភិបាលអាចប្រមូល រៀបចំ និងរក្សាទុកព័ត៌មានយ៉ាងច្រើន។ ក្នុងន័យនេះបដិវត្តន៍ព័ត៌មានផ្តល់អំណាចដល់រដ្ឋាភិបាលច្រើនជាងពេលណាៗទាំងអស់។ កាលពីមុន ឧក្រិដ្ឋជន មេគ្រឿងញៀន ឬភេរវកដែលចង់បានអាចរំលងព្រំដែន និងជ្រកកោននៅបរទេស។ ភេរវកដែលបានវាយប្រហារសហរដ្ឋអាមេរិកក្នុងឆ្នាំ ២០០១ បានបង្ហាញអោយឃើញពីរបៀបងាយស្រួល។ ទោះជាយ៉ាងណាក៏ដោយសព្វថ្ងៃនេះវាទំនងជាថាសំបុត្រចរាចរណ៍ធម្មតា។ ក្នុងប្រទេសក្រៅអាចនឹងចេញបញ្ជាភ្លាមៗដើម្បីចាប់ខ្លួនជននោះ។ ម៉្យាងវិញទៀត បច្ចេកវិទ្យាព័ត៌មានផ្តល់អំណាចបន្ថែមដល់រដ្ឋាភិបាលដែលគាបសង្កត់ ដើម្បីរក្សាស្លាកសញ្ញាពលរដ្ឋ ចារកម្មលើអ្នកប្រឆាំង និងរៀបចំគំនិតសាធារណៈ។ បច្ចេកវិទ្យាទាំងនោះឥឡូវនេះត្រូវបានគេប្រមូលជាកម្លាំងដើម្បីពង្រឹងការប្រឆាំងភេរវកម្ម។

ដូចដែលពលរដ្ឋនិងភេរវកពិបាកលាក់បាំងពីរដ្ឋាភិបាល រដ្ឋាភិបាលរបស់រដ្ឋនានាក៏ពិបាកលាក់បាំងព័ត៌មានពីគ្នាទៅវិញទៅមក។ សារៈសំខាន់យោធានៃការឈ្លបយកការណ៍តាមផ្កាយរណបត្រូវបានលើកឡើង (សូមមើលមេរៀនទី ៦)។ រដ្ឋដ៏មានឥទ្ធិពលដូចជាសហរដ្ឋអាមេរិកអាចបង្កើនអំណាចរបស់ខ្លួន តាមរយៈបច្ចេកវិទ្យាព័ត៌មាន។ វាមានសមត្ថភាពអាចនិងពិតជាបានត្រួតពិនិត្យតាមដានការហៅទូរស័ព្ទ ទូរសារ ការបញ្ជូនទិន្នន័យ និងការសន្ទនាតាមវិទ្យុនៅបរទេស។ រីរណៈក្នុងឆ្នាំ ២០១៣ ដែលទីភ្នាក់ងារសន្តិសុខជាតិ

[២៩] Peter Arnett. (១៩៩២). *Exporting the First Amendment to the World*. Published by University of Arizona.

(NSA) និងទីភ្នាក់ងារអាមេរិកផ្សេងទៀត មានកម្មវិធីឃ្លាំមើលទ្រង់ទ្រាយធំបានបង្ហាញថា សូម្បីតែរដ្ឋាភិបាលដែលទទួលខុសត្រូវតាមលទ្ធិប្រជាធិបតេយ្យក៏អាចប្រើបច្ចេកវិទ្យាដើម្បីត្រួតពិនិត្យពលរដ្ឋរបស់ពួកគេដែរ។

នៅក្នុងចលនាបដិវត្តន៍និទាឃរដូវនៅអារ៉ាប់ក្នុងឆ្នាំ ២០១១ ក្រុមអ្នកតវ៉ាមិនមែនជាក្រុមមនុស្សតែម្ខាង ដែលដាក់ពង្រាយសមត្ថភាពអ៊ីនធឺណិតនោះទេ សូម្បីតែរដ្ឋាភិបាលក៏ធ្វើបែបនេះផងដែរ។ រដ្ឋាភិបាលប្រទេសអេហ្ស៊ីបបានទប់ស្កាត់ច្រកចេញចូល(អ៊ីនធឺណិត)ដោយជោគជ័យ និងកាត់ផ្តាច់ការចូលប្រើឬអានគេហទំព័រអន្តរជាតិមួយចំនួន។ ហើយរដ្ឋាភិបាលស៊ីរីបានប្រើពួកហេកឃឺ(Hacker)ផ្ទាល់ខ្លួន ដើម្បីតាមដានអត្តសញ្ញាណក្រុមបាតុករដែលបានបង្ហោះវីដេអូនិងសារ ប្រឆាំងនឹងរដ្ឋាភិបាល នៅលើគេហទំព័រនានា ដោយអនាមិក។ ជាការឆ្លើយតប រដ្ឋាភិបាលសហរដ្ឋអាមេរិកបានបណ្តុះបណ្តាលសកម្មជនប្រជាធិបតេយ្យនូវបច្ចេកវិទ្យាអ៊ីនធឺរណែតនិងប្រព័ន្ធផ្សព្វផ្សាយសង្គម ហើយបានបង្កើតស្រមោលអ៊ីនធឺណែត និងបណ្តាញទូរស័ព្ទចល័តនៅខាងក្នុងប្រទេសដែលរដ្ឋាភិបាលរបស់ពួកគេកំពុងព្យាយាមបិទទំនាក់ទំនង។

នៅពេលដែលតម្លៃនៃបច្ចេកវិទ្យាព័ត៌មានមានការថយចុះ វាបានដល់ធ្លាក់ដល់រដ្ឋកាន់តែច្រើនជាងមុន។ ឥឡូវនេះ រដ្ឋតូចៗអាចទទួលបានសមត្ថភាពដូចគ្នាមួយចំនួន ជាលក្ខណៈអេឡិចត្រូនិក។ សូម្បីតែព័ត៌មានស្មុគស្មាញក៏អាចរកបាននិងថោកជាង ដូចជារូបថតផ្កាយរណបដែលមានគុណភាពខ្ពស់និងរូបភាពច្បាស់ ឥឡូវនេះ មានលក់ក្នុងទីផ្សារពាណិជ្ជកម្មទូទៅ ហើយមានតម្លៃថោក ឬពេលខ្លះដោយឥតគិតថ្លៃ។ រូបភាពទាំងនេះអាចជាប្រើសម្រាប់គោលបំណងយោធា និងការគ្រប់គ្រងធនធានធម្មជាតិ ជាឧទាហរណ៍ដោយដឹងថារដ្ឋណាមួយ (រួមទាំងរដ្ឋខ្លួនផ្ទាល់) មានធនធាន ដូចជា ប្រេង រ៉ែ ព្រៃឈើ និងដីស្រែចំការ និងអត្រាដែលពួកគេត្រូវបានប្រើប្រាស់។

រដ្ឋាភិបាលភាគច្រើនបង្កើតបណ្តាញផ្សព្វផ្សាយព័ត៌មានច្បាស់លាស់ ដើម្បីជះឥទ្ធិពលលើទស្សនិកជនក្នុងស្រុកនិងអន្តរជាតិ។ ស្ថានីយ៍ដូចជា វិទ្យុមូស្គូ (Radio Moscow) បានចាក់ផ្សាយកម្មវិធីវិទ្យុជាភាសារាប់សិបដែលមានគោលបំណងនៅក្នុងតំបន់ទាំងអស់របស់ពិភពលោក។ រដ្ឋធ្វើប្រតិបត្តិការបណ្តាញវិទ្យុរលកខ្លី សំឡេងសហរដ្ឋអាមេរិក (VOA) ដែលត្រូវបានប្រមូលនៅក្នុងតំបន់ជាច់ស្រយាលជាច្រើន។

រដ្ឋាភិបាលបានផ្សព្វផ្សាយព័ត៌មានមិនពិត ក៏ដូចជាព័ត៌មានពិត ជាមធ្យោបាយនៃឥទ្ធិពលអន្តរជាតិ។ នេះហៅថា*ព័ត៌មានមិនពិត*(disinformation)។ នៅទសវត្សរ៍ឆ្នាំ ១៩៣០ ពួកណាហ្ស៊ីបានកត់សម្គាល់ឃើញថា «ការកុហក» ប្រសិនបើនិយាយដដែលៗច្រើនដង អាចនឹងត្រូវមនុស្សភាគច្រើនជឿថាជាការពិត។ ទោះយ៉ាងណាក៏ដោយ ទស្សនិកជនអន្តរជាតិនាពេលបច្ចុប្បន្ននេះ មិនងាយនឹងចាញ់បោកពាក្យកុហកទាំងនោះឡើយ។ ប៉ុន្តែអ្នកក្នុងស្រុកនៅតែអាចឆ្លើយតប(ទាំងងងឹតងងុល)ទៅនឹងព័ត៌មានមិនពិត ដែលត្រូវផ្សព្វផ្សាយចេញនៅលើបណ្តាញសង្គម។

រដ្ឋាភិបាលភាគច្រើន (ប៉ុន្តែមិនមែនរដ្ឋាភិបាលសហរដ្ឋអាមេរិកទេ) ជាម្ចាស់កម្មសិទ្ធិ និងដំណើរការយ៉ាងហោចណាស់ ស្ថានីយទូរទស្សន៍សំខាន់មួយ ហើយភាគច្រើនកាន់កាប់ស្ថានីយទូរទស្សន៍ ដោយផ្ទាល់។ ដូច្នេះ សញ្ញាទូរទស្សន៍ តែងតែត្រូវចាត់ចំណាត់ថ្នាក់ជា*សមត្ថភាពសំខាន់* ដូចឧបករណ៍យោធានិងរូបិយប័ណ្ណសម្រាប់រដ្ឋាភិបាល ដែលពួកគេត្រូវតែគ្រប់គ្រង។ ជាការពិតណាស់ នៅក្នុងរដ្ឋប្រហារយោធា ជាទូទៅគោលដៅដំបូងនិងសំខាន់បំផុតដែលត្រូវរឹបអូស គឺស្ថានីយ៍ទូរទស្សន៍។

១០.៤.៣. ព័ត៌មានជាឧបករណ៍ប្រឆាំងនឹងរដ្ឋាភិបាល

ព័ត៌មានក៏អាចត្រូវបានប្រើប្រាស់ប្រឆាំងនឹងរដ្ឋាភិបាល ដោយរដ្ឋាភិបាលបរទេស អង្គការក្រៅរដ្ឋាភិបាល ឬក្រុមអ្នកប្រឆាំងនយោបាយក្នុងស្រុកផងដែរ។ រដ្ឋាភិបាល ជាពិសេសរដ្ឋាភិបាលផ្តាច់ការគាបសង្កត់ តែងតែខ្លាចលំហូរព័ត៌មានដោយសេរី ហើយពិតជាដោយសារហេតុផលល្អ។ បច្ចេកវិទ្យាព័ត៌មានថ្មីបានក្លាយជាឧបករណ៍ដ៏មានឥទ្ធិពលរបស់ចលនាប្រឆាំងក្នុងស្រុក និងសម្ព័ន្ធមិត្តរបស់ពួកគេ នៅក្នុងរដ្ឋាភិបាលបរទេស។ ការផ្សព្វផ្សាយតាមកញ្ចក់ទូរទស្សន៍បានជម្រុញការមិនសប្បាយចិត្តចំពោះសង្គ្រាមអាមេរិកបច្ចុប្បន្ន នៅក្នុងប្រទេសអ៊ីរ៉ាក់ ដូចដែលវាបានកើតឡើងចំពោះសង្គ្រាមវៀតណាម និងសង្គ្រាមរុស្ស៊ីនៅឆេចស្ន៊ៀរ។

ប្រជាជនចិនជាង ៧០០ លាននាក់ប្រើប្រាស់អ៊ីនធឺរណែត ទោះបីជាមិនមែនថាគ្មានការ ត្រួតពិនិត្យក៏ដោយ។ ក្នុងឆ្នាំ ២០០៩ រដ្ឋាភិបាលចិនបានចាប់ផ្តើមបិទរាល់ការចូលប្រើប្រាស់ YouTube បន្ទាប់ពីវីដេអូលេចធ្លាយអំពីកងកម្លាំងយោធាចិនបង្ក្រាបបាតុកម្មគាំទ្រទីបេ។ នៅក្នុងប្រទេសអ៊ីរ៉ង់ ជាកន្លែងដែលមនុស្សរាប់លាននាក់បានប្រើប្រាស់អ៊ីនធឺណិតដើម្បីពិភាក្សាអំពីប្រធានបទហាមឃាត់ ដូចជាការរួមភេទ ម៉ូដ និងនយោបាយ រដ្ឋាភិបាលត្រូវបានរិះគន់យ៉ាងទូលំទូលាយចំពោះការបង្ក្រាបបាតុករបន្ទាប់ពីការបោះឆ្នោត ដែលមានជម្លោះ នៅក្នុងឆ្នាំ ២០០៩។ ការបង្ក្រាបនោះត្រូវបានចាក់ផ្សាយតាមគេហទំព័រអ៊ីនធឺណែតដូចជា Twitter និង Facebook ខណៈដែលសមាជិកបក្សប្រឆាំងបានបង្ហោះវីដេអូ និងរូបភាពនៃការវាយដំ និងសូម្បីតែការបាញ់សម្លាប់ស្ត្រីអ្នកតវ៉ា។ វិធីសាស្ត្រទាំងនេះ ក្រោយមកត្រូវបានអនុម័ត ដោយក្រុមបាតុករបដិវត្តន៍និទាឃរដូវនៅអារ៉ាប់។

នៅប្រទេសហ្វីលីពីនក្នុងឆ្នាំ ២០០១ ការតវ៉ាដ៏ធំដែលបានទម្លាក់ប្រធានាធិបតីចេញពីតំណែងត្រូវបានរៀបចំឡើង តាមរយៈសារនៅលើទូរស័ព្ទដៃ។ នៅប្រទេសហ្គាណា កម្មវិធីជជែកដ៏ពេញនិយមបំផុតនៅលើកម្មវិធីវិទ្យុFMឯកជន ដែលត្រូវបានអនុញ្ញាតបន្ទាប់ពីឆ្នាំ១៩៩៥ បានផ្តល់សំឡេងដល់ប្រជាជនសាមញ្ញដែលបន្ទាប់មកបានបណ្តេញចេញពីបក្សកាន់អំណាច ក្នុងឆ្នាំ២០០០។ ក្រុមអ្នកតវ៉ាប្រឆាំងនឹងរដ្ឋាភិបាលបានប្រើ hashtags (#) ធម្មតារបស់ Twitter ដើម្បីសម្របសម្រួលការតវ៉ាប្រឆាំងនឹងប្រធានាធិបតីអ៊ុយក្រែននៅនិទាឃរដូវនៃឆ្នាំ ២០១៤។

រូបថត អ្នកកាសែតប៉ាឡេស្ទីនរួមគ្នាតវ៉ាក្នុងស្មារតីសាមគ្គីភាពជាមួយទូរទស្សន៍ អាល់ចាហ្ស៊ីរ៉ា
ក្តៅ បិទ សារព័ត៌មាន

ព័ត៌មានដែលងាយស្រួលឆ្លងកាត់ព្រំដែនរដ្ឋ គឺជាកត្តាចំបងក្នុងនយោបាយអន្តរជាតិ និងក្នុងស្រុក។ រដ្ឋាភិបាលមានមធ្យោបាយជាច្រើនដើម្បីព្យាយាមគ្រប់គ្រងព័ត៌មាន។ នៅទីនេះ អ្នកកាសែតប៉ាឡេស្ទីនរួមគ្នាតវ៉ាក្នុងស្មារតីសាមគ្គីភាពជាមួយទូរទស្សន៍ អាល់ចាហ្ស៊ីរ៉ា (al Jazeera) បន្ទាប់ពីមានសេចក្តីរាយការណ៍ថារដ្ឋាភិបាលអ៊ីស្រាអែលកំពុងពិចារណាបិទការិយាល័យរបស់ស្ថានីយ៍ នៅទីក្រុងហ្សេរូសាឡឹមឆ្នាំ ២០១៧ ។

ដើម្បីទប់ទល់នឹងការប្រើប្រាស់ព័ត៌មានបែបនេះ រដ្ឋាភិបាលជុំវិញពិភពលោកព្យាយាមកំណត់លំហូរព័ត៌មានមិនអំណោយផល ជាពិសេសព័ត៌មានពីប្រភពបរទេស។ កិច្ចខិតខំប្រឹងប្រែងទាំងនេះអាចរួមបញ្ចូលការត្រួតពិនិត្យតាមដានគេហទំព័រ ឬសេវាកម្មនីមួយៗ ឬរហូតដល់បិទអ៊ីនធឺណិតទាំងស្រុង។ ជាឧទាហរណ៍ ប្រទេសចិន ដូចជាប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនទៀត បញ្ចូលបណ្តាញទាំងអស់ចូលប្រើអ៊ីនធឺណិតតាមរយៈក្រុមហ៊ុនផ្តល់សេវាដែលគ្រប់គ្រងដោយរដ្ឋមួយចំនួន ហើយពួកគេចម្រាញ់សារជាអក្សររាប់រយពាន់

លាន ដែលបានផ្ញើចេញផ្ញើចូល ជារៀងរាល់ឆ្នាំ ក្នុងចំណោមអ្នកជាវទូរស័ព្ទចិន ចំនួន ១០០០ លាននាក់។ ក្នុងឆ្នាំ ២០១០ អេមីរ៉ាតអារ៉ាប់រួមបានប្រកាសថាខ្លួននឹងបិទសេវាកម្មរបស់ Black-Berry ប៉ុន្តែ ក្រោយមក បានឈានដល់ការសម្របសម្រួលដែលអនុញ្ញាតអោយអ្នកប្រើប្រាស់បន្តប្រើប្រាស់សេវាកម្មនេះ។ ប្រទេសចិនបានហាមឃាត់ Facebook និង Twitter ដ៏ល្បី ប៉ុន្តែ ជម្រើសផ្សេងនៃគេហទំព័រប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់ចិនផ្ទាល់ ដូចជា WeChat និង Weibo មានអ្នកប្រើប្រាស់រាប់លាន។ (WeChat មានអ្នកប្រើប្រាស់ជិត ១ ពាន់លាននាក់ និង Weibo បានវ៉ាដាច់ Twitter ក្នុងឆ្នាំ ២០១៧ ដោយបានបញ្ចប់អ្នកប្រើប្រាស់ ៣៥០ លាននាក់)។

ក្រុមហ៊ុនអ៊ីនធឺណិតនានាដែលមានមូលដ្ឋាននៅសហរដ្ឋអាមេរិកមានការឆ្លើយតបផ្សេងៗគ្នា ចំពោះការរឹតត្បិតរបស់ចិន ដែលត្រូវបានគេស្គាល់នៅបស្ចឹមលោកថាជា «មហាកំពែងអនឡាញ»។ ក្នុងឆ្នាំ ២០១០ ក្រុមហ៊ុន Google បានប្រកាសថា ខ្លួននឹងលែងគោរពតាមច្បាប់ចិន ដែលត្រួតពិនិត្យការស្វែងរកតាមអ៊ីនធឺណិត ដោយរារាំងពាក្យដែលរសើបផ្នែកនយោបាយពីម៉ាស៊ីនស្វែងរកចិនរបស់ខ្លួន។ ក្រោយមក Google បានសម្របសម្រួលជាមួយរដ្ឋាភិបាលចិន ដោយធ្វើឱ្យអ្នកវិះគន់អាមេរិកមួយចំនួនខឹងសម្បារ។ ក្នុងឆ្នាំ ២០១៧ ក្រុមហ៊ុន Apple បានយល់ព្រមថា ទិន្នន័យទាំងអស់ដែលបានបង្ហោះនៅក្នុង cloud servers របស់ខ្លួននឹងត្រូវបានផ្លាស់ប្តូរទៅកាន់ server ដែលមានទីតាំងនៅក្នុងប្រទេសចិន។ ដូច្នេះ ខណៈពេលដែលក្រុមហ៊ុនអាមេរិកអាចនឹងជំទាស់នឹងការរឹតត្បិតរបស់រដ្ឋាភិបាលចិន វាពិបាកក្នុងការមិនព្រមទទួលអ្នកប្រើប្រាស់អ៊ីនធឺណិតចិនរាប់រយលាននាក់មកធ្វើជាអតិថិជន។

ប្រទេសផ្សេងទៀតរក្សាការរឹតបន្តឹងយ៉ាងទូលំទូលាយនៅលើអ៊ីនធឺណិតផងដែរ។ ប្រទេសអ៊ីរ៉ង់បានហាមប្រាម Twitter ប្រទេសទួរគីបានហាមឃាត់ការចូលប្រើ Wikipedia ក្នុងឆ្នាំ ២០១៧ ប្រជាជនកូរ៉េខាងជើងត្រឹមតែ ៤ ភាគរយ ដែលអាចប្រើប្រាស់អ៊ីនធឺណេត ប្រទេសអារ៉ាប៊ីសាអូឌីតបានបិទគេហទំព័រជាង ៤០០០០០ ហើយប្រទេសវៀតណាមបង្ខំក្រុមហ៊ុនផ្គត់ផ្គង់អ៊ីនធឺណិតទាំងអស់អោយបង្វែរព័ត៌មានរបស់អ្នកសរសេរប្លុកទាំងអស់។ នៅពេលខ្លះ ប្រទេសនានាក៏អាចជ្រើសរើសបិទអ៊ីនធឺណេតទាំងមូលផងដែរ។ ជាឧទាហរណ៍ ក្នុងការឆ្លើយតបទៅនឹងការតវ៉ាប្រឆាំងនឹងប្រធានាធិបតីរបស់ខ្លួន នៅក្នុងឆ្នាំ ២០១៥ ប្រទេសប្រជាធិបតេយ្យកុងហ្គោបានដាក់ការបិទអ៊ីនធឺណិតដើម្បីបញ្ឈប់ការតវ៉ាមិនអោយកើនឡើង។

បច្ចេកវិទ្យាព័ត៌មានមានផលប៉ះពាល់លើផ្នែកសុវត្ថិភាពផងដែរ។ សមត្ថភាពដូចជាខ្សែកាបអុបទិក ឬការទំនាក់ទំនងតាមផ្កាយរណបបម្រើរដ្ឋាភិបាលក្នុងការដឹកនាំគោលនយោបាយបរទេស និងយោធារបស់ពួកគេ (សូមមើល ការវិវត្តនៃបច្ចេកវិទ្យា នៅក្នុងមេរៀនទី ៦)។ តួអង្គមិនមែនរដ្ឋដូចជាអង្គការភេរវកម្មក៏បានប្រើប្រាស់អានុភាពនៃទូរស័ព្ទដៃ និងអ៊ីនធឺណេត ដើម្បីរើសអ្នកស្មគ្រចិត្តក្នុងប្រតិបត្តិការ រៃអង្គាសប្រាក់ និងសម្របសម្រួលការវាយប្រហារ សូម្បីតែដើម្បីបំផ្ទុះឧបករណ៍បំផ្ទុះដែលផលិតឡើងពីចម្ងាយដោយប្រើសម្លេងរោទ៍ទូរសព្ទដៃ ដែលបំផ្ទុះគ្រាប់បែកនៅពេលគេទូរស័ព្ទចូល។ សូមចាំថា បច្ចេកវិជ្ជា«អាវុធឆ្លាតវៃ»ថ្មី ផ្តល់អំណាចដល់ទាហានថ្មើរជើង ទាក់ទងទៅនឹងប្រព័ន្ធអាវុធធំៗ។ បច្ចេកវិជ្ជាទំនាក់ទំនងថ្មីអាចធ្វើដូចគ្នាសម្រាប់ប្រជាពលរដ្ឋសាមញ្ញទាក់ទងនឹងរដ្ឋាភិបាល និងគណបក្សនយោបាយ។

អ៊ីនធឺណិតតាមវិធីជាច្រើនផ្តល់អំណាចដល់ក្រុមតូចៗទាក់ទងនឹងរដ្ឋ ហើយទុកអោយរដ្ឋងាយនឹងរងគ្រោះតាមរបៀបថ្មី។ ពួក Hacker បានកាន់កាប់កុំព្យូទ័ររបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក និងបានបញ្ចេញ

មេរោគដ៏មានតម្លៃប្រឆាំងនឹងអាជីវកម្ម និងមនុស្សទូទាំងពិភពលោក។ ការវាយប្រហារតាមអ៊ីនធឺណិតទាំងនេះ ដោយតួអង្គ(រដ្ឋ)តូចតាច អាចកំណត់គោលដៅបរទេស។ ក្នុងអំឡុងពេលមានការប្រឈមមុខដាក់គ្នារវាងយន្តហោះចារកម្មអាមេរិក និងចិនក្នុងឆ្នាំ ២០០១ ពួក Hacker ជាតិនិយមចិនបានអះអាងថាបានដាក់រូបគំនូរដែលគាំទ្រជនជាតិចិន នៅលើគេហទំព័រអាមេរិកចំនួន ១០០០ ហើយពួក Hacker របស់សហរដ្ឋអាមេរិកបានត្រឡប់មកវិញ។ សាលារៀនមួយក្នុងរដ្ឋ Ohio បានរកឃើញថា គេហទំព័ររបស់ខ្លួនឥឡូវនេះបានលេងភ្លេងជាតិរបស់ប្រទេសចិន។ គណបក្សកុម្មុយនិស្តចិនបានរិះគន់ «អំពើគេវកម្មតាមបណ្តាញ» ហើយវិបត្តិបានធូរស្រាល។

បញ្ហាប្រឈមមួយទៀតចំពោះរដ្ឋាភិបាល គឺការកើនឡើងខ្លាំងនូវប្រជាប្រិយភាពនៃរូបិយប័ណ្ណ*គ្រីបតូ* (crypto) ឬ **រូបិយប័ណ្ណនិម្មិត** (virtual currencies)។ អ្នកប្រើប្រាស់បានបង្កើតរូបិយប័ណ្ណទាំងនេះជាមធ្យោបាយមួយដើម្បីជួយសម្រួលដល់ការផ្លាស់ប្តូរទំនិញ និងសេវាកម្មលើសពីការគ្រប់គ្រងរបស់រដ្ឋាភិបាល។ ទាំងរដ្ឋាភិបាល ឬធនាគារទាំងអស់គ្រប់គ្រងរូបិយប័ណ្ណនិម្មិត (នៅពេលនេះ)។ អត្ថប្រយោជន៍នៃរូបិយប័ណ្ណនិម្មិតគឺថាតម្លៃរបស់វាមានលក្ខណៈសកលៈ គ្មានប្រទេសណាកំណត់តម្លៃទីផ្សារនៃរូបិយប័ណ្ណបែបនេះទេ ហើយពួកគេអាចប្រើប្រាស់បានគ្រប់ទីកន្លែងដែលនឹងទទួលយកវាជាទម្រង់នៃការទូទាត់។ ហានិភ័យមួយគឺថា ដោយគ្មានការគាំទ្រពីរដ្ឋាភិបាល វាមានតិចតួចណាស់ក្នុងស្តេរភាពតម្លៃនៃរូបិយប័ណ្ណ ហើយពួកគេត្រូវទទួលរងនូវការផ្លាស់ប្តូរដ៏ធំទូលាយនៃតម្លៃ។ វាក៏មានហានិភ័យផងដែរ ដែលរដ្ឋាភិបាលអាចព្យាយាមធ្វើប្រតិបត្តិការដោយប្រើរូបិយប័ណ្ណនិម្មិតខុសច្បាប់(ប្រទេសចិនបានហាមឃាត់សកម្មភាពរូបិយប័ណ្ណនិម្មិតមួយចំនួនក្នុងឆ្នាំ ២០១៧)។

Bitcoin (អានថា ប៊ីតខញ) គឺជារូបិយប័ណ្ណនិម្មិតដែលពេញនិយមបំផុត ប៉ុន្តែមានជាច្រើនទៀត។ ការបង្កើតនិងការប្រើប្រាស់រូបិយប័ណ្ណនិម្មិតបង្ហាញអំពីគំនិត ដែលត្រូវបានផ្សព្វផ្សាយ ដោយទ្រឹស្តីស្ថាបនានិយម (សូមមើលមេរៀនទី ៣) ថាលុយគឺជាសំណង់ឬការនិមិត្តឡើងដោយសង្គមមនុស្ស។ រូបិយប័ណ្ណទាំងអស់ មិនថានិម្មិតក្នុងអ៊ីនធឺរណែត ឬ រដ្ឋាភិបាលគាំទ្រទេ មានតម្លៃដោយសារតែការយល់ដឹងរួមគ្នាក្នុងចំណោមបុគ្គល។ រូបិយប័ណ្ណនិម្មិតបង្ហាញថា មនុស្សម្នាក់មិនត្រូវការក្រដាសមួយសន្លឹកតែជានិមិត្តសញ្ញាសម្រាប់តម្លៃនោះឡើយ។ រូបិយប័ណ្ណនិមិត្តថ្មីៗទាំងនេះ នៅតែមានភាពចម្រូងចម្រាស នៅក្នុងចំណោមអ្នកជំនាញផ្នែកហិរញ្ញវត្ថុមួយចំនួន ដែលភ័យខ្លាចថា ពួកគេគ្រាន់តែជាការវិនិយោគទាន់សម័យ ខណៈដែលអ្នកផ្សេងទៀតអះអាងថាពួកគេមានសក្តានុពលក្នុងការផ្លាស់ប្តូរហិរញ្ញវត្ថុសកល។

រូបថត ស្ត្រីម្នាក់នៅក្រុងហុងកុងដើរកាត់ទូរម៉ាស៊ីន ATM bitcoin

លុយនិម្មិត

រដ្ឋមិនមែនជាអ្នកគ្រប់គ្រងលំហូរព័ត៌មានសាកល ដែលបានក្លាយជាកម្លាំងដ៏ខ្លាំងក្លាក្នុងនយោបាយពិភពលោក ដែលប្រជែងអំណាចរដ្ឋ។ បញ្ហាប្រឈមនេះបានរាលដាលដល់ពិភពរូបិយវត្ថុ ដែលជាប្រពៃណីត្រូវបានបោះពុម្ពនិងគ្រប់គ្រងដោយរដ្ឋ។ រូបិយប័ណ្ណនិម្មិត ដូចជា ប៊ីតខញ (bitcoin) មិនត្រូវបានគ្រប់គ្រងដោយរដ្ឋាភិបាលឬធនាគារណាមួយទេ ហើយអាចត្រូវបានចាយវាយ ជាអនាមិក។ នៅទីនេះ ស្ត្រីម្នាក់នៅក្រុងហុងកុងដើរកាត់ទូរម៉ាស៊ីន ATM bitcoin ឆ្នាំ ២០១៧។

រដ្ឋាភិបាលមួយចំនួនធំព្រួយបារម្ភថា គេរកអាចប្រើប្រាស់អ៊ីនធឺណិត ដើម្បីបង្កការរំខានដ៏ធំនៅក្នុងជីវិតប្រចាំថ្ងៃ។ នៅសហរដ្ឋអាមេរិក រដ្ឋបាលលោក អូបាម៉ា បានបណ្តាក់ទុនរាប់លានដុល្លារ ដើម្បីបង្កើនសុវត្ថិភាពតាមអ៊ីនធឺរណែតដោយព្រួយបារម្ភថា ពួកហេគឃ័រអាចបង្កការខូចខាតសេដ្ឋកិច្ចយ៉ាងសំខាន់ដល់សេដ្ឋកិច្ច។ នៅឆ្នាំ ២០១៧ ក្រុមហេគឃ័រដែលមានទំនាក់ទំនងជាមួយ ISIS បានចូលកាន់កាប់គេហទំព័រថៃទាំសុខភាពជាតិរបស់អង់គ្លេសជាច្រើន ដើម្បីបង្ហាញរូបភាពដ៏គួរឱ្យរន្ធត់នៃជនរងគ្រោះក្នុងសង្គ្រាមប្រទេសស៊ីរី។ មន្ត្រីយោធាអាមេរិកបានសង្កត់ធ្ងន់ពីគ្រោះថ្នាក់នៃការវាយប្រហារតាមអ៊ីនធឺណិតលើប្រព័ន្ធការពារផងដែរ។ ដូចដែលបានពិភាក្សានៅក្នុងមេរៀនទី ៦ នៅក្នុងពិភពនៃជម្លោះយោធា អ៊ីនធឺណេតឥឡូវនេះគឺជាសមរភូមិប្រយុទ្ធស្រដៀងទៅនឹងសមរភូមិដែនអាកាស ដី និងសមុទ្រ។

សរុបមក ជំនោរនៃបច្ចេកវិទ្យាហាក់ដូចជាកំពុងដំណើរការប្រឆាំងនឹងរដ្ឋាភិបាល។ ពត៌មានបានធ្វើដំណើរឆ្លងកាត់ ហើយគ្មានអំណាចនយោបាយហាក់ដូចជាមានលទ្ធភាពទប់វាបានយូរទេ។ នៅពេលដែលបណ្តាញទំនាក់ទំនងកាន់តែច្រើន នាំព័ត៌មានកាន់តែច្រើន ទៅកាន់កន្លែងកាន់តែច្រើន រដ្ឋាភិបាលក្លាយជាតួអង្គមួយ នៅក្នុងវិស័យដែលមានតួអង្គច្រើនកកកុញ។

១០.៤.៤. ទូរគមនាគមន៍ និងវប្បធម៌សកល

នៅពេលដែលបដិវត្តន៍ព័ត៌មាននៅតែបន្តកើតមាន វានឹងបង្កើនវប្បធម៌ពឹងពាក់គ្នាទៅវិញទៅមកជាអន្តរជាតិដែលធ្វើអោយសកម្មភាពនៅក្នុងរដ្ឋមួយមានប្រតិកម្មកាន់តែខ្លាំង នៅក្នុងរដ្ឋផ្សេងទៀតជាងពេលអតីតកាល។ ដូច្នេះព័ត៌មានកំពុងបំផ្លាញការសន្មត់របស់អ្នកប្រាកដនិយមអំពីអធិបតេយ្យភាពរដ្ឋនិងបូរណភាពទឹកដី បន្តិចម្តងៗ។ ទន្ទឹមនឹងនេះ តាមរយៈការផ្តល់សិទ្ធិអំណាចដល់តួអង្គថ្នាក់ក្រោមរដ្ឋ និងតួអង្គឆ្លងព្រំដែនជាតិ បច្ចេកវិទ្យាព័ត៌មានកំពុងធ្វើអោយខូចដល់តួនាទីសំខាន់របស់រដ្ឋខ្លួនឯង នៅក្នុងកិច្ចការពិភពលោក។

បដិវត្តន៍ព័ត៌មានបង្កើន*ភម្លាភាព*ក្នុងទំនាក់ទំនងអន្តរជាតិយ៉ាងខ្លាំង។ ជាលទ្ធផល រដ្ឋមិនចាំបាច់បំពាក់អាវុធប្រឆាំងនឹងការគំរាមកំហែងគ្មានអត្តសញ្ញាណដែលអាចកើតមានដាយថាហេតុនោះទេ ព្រោះពួកគេមើលឃើញការគំរាមកំហែងពិតប្រាកដតាមរយៈព័ត៌មាន។ ដូចគ្នានេះដែរ សមត្ថភាពក្នុងការត្រួតពិនិត្យការអនុវត្តកិច្ចព្រមព្រៀងធ្វើអោយបញ្ហាផលប្រយោជន៍រួមកាន់តែងាយស្រួលក្នុងការដោះស្រាយ ដោយសារអ្នកបោកប្រាស់ និងលួចបន្លំអាចត្រូវបានកំណត់អត្តសញ្ញាណភ្លាមៗ។ ជាងនេះទៅទៀត សមត្ថភាពរបស់រដ្ឋាភិបាលក្នុងការចរចាប្រកបដោយប្រសិទ្ធភាពជាមួយគ្នាទៅវិញទៅមក និងដើម្បីសម្រេចបាននូវលទ្ធផលដែលផ្តល់ប្រយោជន៍អោយគ្នាទៅវិញទៅមក ត្រូវបានពង្រឹងដោយភាពអាចរកបាននៃបណ្តាញទំនាក់ទំនងភ្លាមៗ។ នៅក្នុងវិធីទាំងនេះ ការកើនឡើងតម្លាភាពដែលអនុញ្ញាតដោយបច្ចេកវិទ្យាថ្មីពង្រឹងគោលការណ៍ដែលគ្នាទៅវិញទៅមកជាដំណោះស្រាយចំពោះជម្លោះក្នុងទំនាក់ទំនងអន្តរជាតិ។ ស្មុគស្មាញការត្រួតពិនិត្យ និងគណនេយ្យដែលទាមទារនៅក្នុងកិច្ចព្រមព្រៀងអន្តរជាតិដោយផ្អែកលើការទៅវិញទៅមក (ពីកិច្ចព្រមព្រៀងពាណិជ្ជកម្មរហូតដល់ការគ្រប់គ្រងអាវុធ) កាន់តែងាយស្រួលនៅក្នុងពិភពលោកដែលមានតម្លាភាព។

ទូរគមនាគមន៍ដែលមានសមត្ថភាពតភ្ជាប់ពីសហគមន៍មួយទៅសហគមន៍មួយទៀត ហួសពីរង្វង់ភូមិសាស្ត្រក៏កំពុងពង្រឹងគោលការណ៍អត្តសញ្ញាណនៅក្នុងទំនាក់ទំនងអន្តរជាតិផងដែរពីព្រោះអត្តសញ្ញាណរបស់មនុស្សមានប្រភពថ្មី និងមធ្យោបាយថ្មីនៃការបញ្ចេញមតិ ដែលជារឿយៗឆ្លងកាត់ព្រំដែនជាតិ។ កាលពីអតីតកាល ជាតិនិយមបានចូលទៅក្នុងសក្តានុពលផ្លូវចិត្តនៃអត្តសញ្ញាណក្រុមក្នុងវិធីដ៏មានឥទ្ធិពល ដែល

បានធ្វើអោយរដ្ឋស្របច្បាប់ជាតំណាងចុងក្រោយនៃសេចក្តីប្រាថ្នា និងអត្តសញ្ញាណរបស់ប្រជាជនរបស់ខ្លួន។ ឥឡូវនេះ បដិវត្តន៍ព័ត៌មានអាចជួយដល់ការអភិវឌ្ឍន៍អត្តសញ្ញាណឆ្លងជាតិ ឬអត្តសញ្ញាណលើសពីអាជ្ញាធរជាតិ។ បណ្តាអ្នកការសែត អ្នកវិទ្យាសាស្ត្រ និងសមាជិកព្រះវិហារ ក្នុងចំណោមអ្នកផ្សេងទៀត ធ្វើការនៅក្នុងសហគមន៍ដែលលាតសន្ធឹងតាមព្រំដែនជាតិ។ ដូច្នេះ សមាជិកនៃចលនាឆ្លងដែន ដូចជាអ្នកដែលភ្ជាប់ស្ត្រីមកពីប្រទេសផ្សេងៗ ឬអ្នកការពារបរិស្ថាន ឬសកម្មជនសិទ្ធិមនុស្សជាដើម។ តំណភ្ជាប់ដែលបានបង្កើតនៅក្នុងសហគមន៍ឆ្លងជាតិបែបនេះ អាចបង្កើតមុខងារថ្មីមួយ ដែលអាចលើកទឹកចិត្តដល់ការធ្វើសមាហរណកម្មអន្តរជាតិនៅលើមាត្រដ្ឋានសកលលោកទាំងមូល។

រូបថត ពិធីបើកព្រឹត្តិការណ៍កីឡាអូឡាំពិករដូវរងា ឆ្នាំ ២០១៨ នៅកូរ៉េខាងត្បូង

ការទូតកីឡា

អំណាចនៃព័ត៌មានអាចបង្កើតនិងពង្រឹងសហគមន៍សកលដែលឆ្លងកាត់ឬចូលក្នុងរង្វង់ព្រំដែនជាតិ។ កីឡាអូឡាំពិកត្រូវបានមើលតាមទូរទស្សន៍ និងអ៊ីនធឺណិតជុំវិញពិភពលោក ខណៈដែលអត្តពលិកចូលរួមប្រកួតក្នុងស្មារតីប្រកួតជាលក្ខណៈសកល។ ព្រឹត្តិការណ៍កីឡាអូឡាំពិករដូវរងា ឆ្នាំ ២០១៨ ដែលកូរ៉េខាងត្បូងធ្វើជាម្ចាស់ផ្ទះ បានកើតឡើងក្នុងអំឡុងពេលនៃភាពតានតឹងខ្លាំងផ្នែកយោធា នៅលើឧបទ្វីបកូរ៉េ។ យ៉ាងណាក៏ដោយ ក្រុមអូឡាំពិកកូរ៉េខាងជើង និងខាងត្បូងបានសម្រេចចិត្តចូលជាក្រុមបង្រួបបង្រួមក្នុងពេលពិធីបើក។

កីឡាក៏បង្កើតសហគមន៍ឆ្លងព្រំដែនជាតិផងដែរ។ ប្រជាពលរដ្ឋនៃរដ្ឋផ្សេងៗគ្នា ចែករំលែកការគោតសរសើររបស់ពួកគេចំពោះតារាកីឡា ដែលក្លាយជាតារាអន្តរជាតិ។ ព្រឹត្តិការណ៍កីឡាអូឡាំពិក (គ្រប់គ្រងដោយគណៈកម្មាធិការអូឡាំពិកអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល) គឺជាព្រឹត្តិការណ៍ពិភពលោកដែលមានទស្សនិកជនទូទាំងពិភពលោក។ ទំនាក់ទំនងរវាងសហរដ្ឋអាមេរិក និងចិនក្នុងឆ្នាំ ១៩៧១ យ៉ាងប្រសើរបំផុត។ កិច្ចសហប្រតិបត្តិការផ្នែកនយោបាយមិនអាចទៅរួចនោះទេ រហូតទាល់តែផ្លូវត្រូវបានត្រួសត្រាយដោយកីឡាជាលើកដំបូង ដែលជាក្រុមវាយកូនឃ្លីលើតុរបស់សហរដ្ឋអាមេរិក ដែលបានធ្វើទស្សនកិច្ចផ្លូវការលើកដំបូងនៅសហរដ្ឋអាមេរិកទៅកាន់ប្រទេសចិន។

ចុងក្រោយ ទេសចរណ៍ក៏បានកសាងសហគមន៍ឆ្លងដែនដែរ។ ភ្ញៀវទេសចរអន្តរជាតិឆ្លងកាត់ព្រំដែនចំនួន ៥០០ លាននាក់ក្នុងមួយឆ្នាំៗ។ ទេសចរណ៍ជាប់ចំណាត់ថ្នាក់ក្នុងចំណោមឧស្សាហកម្មនាំចេញកំពូលនៅទូទាំងពិភពលោក។ មនុស្សដែលធ្វើដំណើរទៅកាន់ប្រទេសផ្សេងៗ តែងតែអភិវឌ្ឍការយល់ដឹងកាន់តែស៊ីជម្រៅ និងការដឹងគុណកាន់តែស៊ីជម្រៅសម្រាប់ប្រទេសទាំងនោះ។ បន្ថែមទៅទំនាក់ទំនងទាំងនេះគឺជានិស្សិតផ្លាស់ប្តូរ និងអ្នកដែលចូលរៀននៅមហាវិទ្យាល័យនៅបរទេស។

ដូចជាការធ្វើសមាហរណកម្មអន្តរជាតិ និងសកលភាវូបនីយកម្មជាទូទៅ វប្បធម៌ពិភពលោកមានគុណវិបត្តិរបស់វា។ វប្បធម៌សកលដែលកំពុងលេចចេញជាចម្បងគឺជាវប្បធម៌របស់ជនជាតិអឺរ៉ុបស្បែកស និងកូនចៅរបស់ពួកគេនៅក្នុងតំបន់សម្បូរបែបនៃពិភពលោក (លាយឡំនឹងធាតុវប្បធម៌របស់ប្រទេសជប៉ុន និងឥស្សរជនក្នុងស្រុក នៅអឌ្ឍគោលខាងត្បូង)។ ការត្រួតត្រាវប្បធម៌នេះត្រូវបានគេសំដៅថាជា **ចក្រពត្តិវប្បធម៌**(cultural imperialism)។ សម្រាប់មនុស្សជាច្រើន ជាពិសេសនៅអឌ្ឍគោលភាគខាងត្បូង បដិវត្តន៍ព័ត៌មានដែលនាំវប្បធម៌សកលចូលទៅក្នុងកណ្តាលរបស់ពួកគេ គឺទោះបីជាមានសក្តានុពលផ្តល់អំណាចក៏ដោយ ប៉ុន្តែជាកម្លាំងឈ្លានពាននៅក្នុងការអនុវត្ត។ ដោយសារតែវប្បធម៌កំពុងត្រូវបានបញ្ចូលពាក់កណ្តាល

យោងតាមអង្គការ UNESCO បានអោយដឹងថា ភាសាជិត ៧០០០ របស់ពិភពលោកប្រឈមនឹងការផុតពូជ នៅសតវត្សរ៍នេះ។

លើសពីនេះទៅទៀត វប្បធម៌សកលដែលកំពុងលេចធ្លោត្រូវបានគ្រប់គ្រងដោយមហាអំណាចរបស់ពិភពលោក គឺសហរដ្ឋអាមេរិក។ ឥទ្ធិពលវប្បធម៌របស់សហរដ្ឋអាមេរិកយ៉ាងហោចណាស់ក៏ខ្លាំងដូចឥទ្ធិពលយោធារបស់សហរដ្ឋអាមេរិកដែរ។ វប្បធម៌អាចគ្រាន់តែជាផលិតផលសេដ្ឋកិច្ចមួយផ្សេងទៀត ដែលត្រូវបានផលិតឡើងជំនួសអោយអត្ថប្រយោជន៍ប្រៀបធៀបដ៏អស្ចារ្យបំផុត ប៉ុន្តែវប្បធម៌ក៏ជាចំណុចកណ្តាលនៃអត្តសញ្ញាណជាតិ និងនយោបាយផងដែរ។ ការរំពឹងទុកនៃចក្រពត្តិនិយមវប្បធម៌ ដូច្នេះបើកផ្នែកខាងមុខមួយទៀតនៅក្នុងជម្លោះនៃលទ្ធិសេរីនិយមនិងគាំពារនិយម។ សូម្បីតែស្ថាបត្យកម្មអ៊ីនធឺណេតក៏សន្មតថាសហរដ្ឋអាមេរិកជាលំនាំដើមនៅក្នុងឈ្មោះដែនដូចជា «.gov» (រដ្ឋាភិបាលសហរដ្ឋអាមេរិក) និង «.mil» (យោធាសហរដ្ឋអាមេរិក)។ នៅឯកិច្ចប្រជុំកំពូលពិភពលោក ដែលឧបត្ថម្ភដោយអង្គការសហប្រជាជាតិស្តីពីសង្គមព័ត៌មានក្នុងឆ្នាំ២០០៥ អឺរ៉ុបនិងប្រទេសកំពុងអភិវឌ្ឍបានព្យាយាមមិនជោគជ័យ ដើម្បីបំបែកផ្តាច់មុខ ដែលគ្រប់គ្រងដោយសម្ព័ន្ធសហរដ្ឋអាមេរិកលើការចុះបញ្ជីឈ្មោះដែន រួមទាំងដែនអក្សរកូដប្រទេសដូចជា ".uk" (ចក្រភពអង់គ្លេស) និង ".cn" (ចិន) ដែលរដ្ឋចង់គ្រប់គ្រងជាបញ្ហាអធិបតេយ្យភាពជាតិ។ ទោះយ៉ាងណានៅឆ្នាំ ២០០៩ ស្ថាប័នគ្រប់គ្រងអ៊ីនធឺណែត ដែលជាសាជីវកម្មអ៊ីនធឺណិតសម្រាប់ឈ្មោះ និងលេខដែលបានចាត់តាំង (ICANN) បានប្រកាសថាអាសយដ្ឋានអ៊ីនធឺណិតឥឡូវនេះ អាចមានតួអក្សរមិនមែនឡាតាំង។ វានឹងអនុញ្ញាតឱ្យអាសយដ្ឋានមានអក្សរចិន ស៊ីរីលីក ជប៉ុន អារ៉ាប់ ឬចំនួនតួអក្សរដែលមិនមែនជាឡាតាំងដើម្បីបង្កើតអាសយដ្ឋានគេហទំព័រនានា។

និន្នាការថ្មីៗហាក់ដូចជាកំពុងឆ្ពោះទៅរកវប្បធម៌ពិភពលោកពហុភាគី។ ជាឧទាហរណ៍ ក្រសួងវប្បធម៌របស់កូរ៉េខាងត្បូងបានគាំទ្រដល់ការផលិតទ្រង់ទ្រាយធំនៃផលិតផលនាំចេញថ្មី ដែលមានតម្លៃរាប់ពាន់លានដុល្លារ ដែលកំពុងរីកចម្រើនយ៉ាងឆាប់រហ័សតន្ត្រីប៉ុបកូរ៉េ(K-pop)។ ក្រុមតន្ត្រីបុរសនិងស្ត្រីត្រូវបានជ្រើសរើសនិងអភិវឌ្ឍជាប្រព័ន្ធ បន្ទាប់មកដាក់លក់នៅទូទាំងពិភពលោក តាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម។ វីដេអូចម្រៀង «Gangnam Style» របស់សិល្បករកូរ៉េ PSY បានវ៉ាដាច់ Justin Bieber អោយក្លាយជាវីដេអូ YouTube ដែលមានអ្នកមើលច្រើនជាងគេបំផុតមិនធ្លាប់មាន (២.២ ពាន់លានទស្សនានៅឆ្នាំ ២០១៥)។ ផលិតផលនាំចេញវប្បធម៌ដែលទទួលបានជោគជ័យខ្ពស់មួយទៀតមាននៅក្នុងល្ខោនអូប៉េរ៉ាប្រេស៊ីល។

ឥទ្ធិពលវប្បធម៌លក្ខណៈបរមានុភាពទាំងនេះនៅតែស្ថិតក្នុងដំណាក់កាលដំបូងនៅឡើយ។ ក្នុងរយៈពេលប៉ុន្មានឆ្នាំ និងទស្សវត្សខាងមុខនេះ រូបរាងរបស់ពួកគេនឹងកាន់តែច្បាស់ ហើយអ្នកប្រាជ្ញនឹងអាចកំណត់បានកាន់តែច្បាស់អំពីរបៀបដែលពួកគេមានឥទ្ធិពលលើនយោបាយពិភពលោក និងអធិបតេយ្យភាពរបស់រដ្ឋ។ ទោះជាយ៉ាងណាក៏ដោយ យើងមិនចាំបាច់រង់ចាំយូរដើម្បីមើលឥទ្ធិពលនៃឥទ្ធិពលបរមានុភាព ប្រភេទផ្សេងគ្នានោះទេ។ បញ្ហាបរិស្ថានដែលកម្រប៉ះពាល់ត្រឹមតែក្នុងរង្វង់ព្រំដែនជាតិតែមួយ បានបង្ខំរដ្ឋនានាអោយមានកិច្ចសហប្រតិបត្តិការជិតស្និទ្ធជាងមុន ខណៈដែលមេដឹកនាំនយោបាយយល់ឃើញថា ការឆ្លើយតបប្រកបដោយប្រសិទ្ធភាពតែមួយគត់ គឺនៅកម្រិតកំពូល។ បញ្ហាទាំងនេះនឹងត្រូវពិភាក្សានៅក្នុងមេរៀនទី ១១។

សេចក្តីសន្ទេប

១. ដំណើរការ**បរមានុភាព** (Supranational) ប្រមូលផ្តុំរដ្ឋទាំងឡាយអោយរួបរួមគ្នា នៅក្នុងរចនាសម្ព័ន្ធ និងអត្តសញ្ញាណដ៏ធំមួយ។ ដំណើរការទាំងនេះជាទូទៅនាំទៅរកការបន្តប្រជែងគ្នារវាងលទ្ធិជាតិនិយម និងលទ្ធិផ្តល់សិទ្ធិអំណាចបរមានុភាពគ្របដណ្តប់លើជាតិជាសមាជិក។

២. សមាហរណកម្មអន្តរជាតិ (ការផ្ទេរអធិបតេយ្យភាពមួយផ្នែកពីរដ្ឋ ដល់ស្ថាប័នកំពូល) ត្រូវបានចាត់ទុកថាជាការរីកចំរើនបន្តពីកិច្ចសហប្រតិបត្តិការអន្តរជាតិ សម្រាប់បំពេញមុខងារ ក្នុងវិស័យបញ្ហាបច្ចេកទេស និងសេដ្ឋកិច្ច។

៣. អ្នកទ្រឹស្តីសមាហរណកម្មបានគិតថា កិច្ចសហប្រតិបត្តិការសម្រាប់បំពេញមុខងារនឹងហៀរចូលទៅក្នុងសមាហរណកម្មនយោបាយ នៅក្នុងផ្នែកគោលនយោបាយការបរទេសនិងវិស័យបញ្ហាយោធា។ ផ្ទុយទៅវិញ កម្លាំងនៃការបំបែកខ្លួនបានបំបែករដ្ឋដែលមានស្រាប់ ដូចជាសហភាពសូវៀត។

៤. សហភាពអឺរ៉ុប (EU) គឺជាករណីខ្ពស់បំផុតនៃការធ្វើសមាហរណកម្ម។ ប្រទេសជាសមាជិកចំនួន ២៧ របស់ខ្លួនបានផ្តល់អំណាចយ៉ាងច្រើនដល់សហភាពអឺរ៉ុប ក្នុងការសម្រេចចិត្តផ្នែកសេដ្ឋកិច្ច។ ទោះជាយ៉ាងណាក៏ដោយ អំណាចជាតិនៅតែលើសពីអំណាចបរមានុភាព សូម្បីតែនៅក្នុងសហភាពអឺរ៉ុប។

៥. ចាប់តាំងពីការបង្កើតសហគមន៍ធ្យូងថ្ម និងដែកថែបអឺរ៉ុប (ECSC) ក្នុងឆ្នាំ ១៩៥២ បេសកកម្ម និងសមាជិកភាពនៃអ្វីដែលឥឡូវនេះ សហភាពអឺរ៉ុប បានពង្រីកជាបន្តបន្ទាប់។

៦. ធាតុសំខាន់បំផុតនិងជោគជ័យបំផុតនៅក្នុងសហភាពអឺរ៉ុប គឺសហភាពពន្ធគយរបស់ខ្លួន (និងតំបន់ពាណិជ្ជកម្មសេរីជាមួយគ្នា)។ ទំនិញអាចដឹកជញ្ជូនឆ្លងកាត់ព្រំដែននៃប្រទេសជាសមាជិក ដោយសេរី ហើយសមាជិកអាចទទួលយកអត្រាពន្ធរួមពីទំនិញដែលនាំចូលពីខាងក្រៅរង្វង់សហភាពអឺរ៉ុប។

៧. ក្រោមគោលនយោបាយកសិកម្មរួមរបស់សហភាពអឺរ៉ុប (CAP) ការឧបត្ថម្ភធនដល់កសិករត្រូវបានធ្វើអោយមានលក្ខណៈស្របគ្នានៅក្នុងសហគមន៍ទាំងមូល។ ការអនុវត្ត CAP ប្រើប្រាស់ ៤០ ភាគរយនៃថវិការបស់ EU។ ការឧបត្ថម្ភធនកសិកម្មរបស់សហភាពអឺរ៉ុប គឺជាប្រភពដ៏សំខាន់នៃជម្លោះពាណិជ្ជកម្មជាមួយសហរដ្ឋអាមេរិក។

៨. សហភាពអឺរ៉ុបមានសហភាពរូបិយវត្ថុដែលមានរូបិយប័ណ្ណអឺរ៉ុបរួមមួយ (ប្រាក់អឺរ៉ូ) នៅក្នុងរដ្ឋចំនួន ១៩ ក្នុងចំណោមរដ្ឋចំនួន ២៧ របស់សហភាពអឺរ៉ុប។ វាគឺជាការពិសោធប្រាក់ដ៏ធំបំផុតក្នុងប្រវត្តិសាស្ត្រ ហើយទទួលបានជោគជ័យយ៉ាងខ្លាំងក្នុងឆ្នាំដំបូងរបស់ខ្លួន ប៉ុន្តែវាបានជួបវិបត្តិក្នុងឆ្នាំ ២០១០-២០១៥ ជុំវិញបំណុលរបស់សមាជិក។ សហជីពរូបិយវត្ថុតម្រូវអោយមានអត្រាអតិផរណាដែលអាចប្រៀបធៀបបាន និងស្ថិរភាពហិរញ្ញវត្ថុនៅក្នុងរដ្ឋដែលចូលរួម។

៩. នៅក្នុងរចនាសម្ព័ន្ធ សហភាពអឺរ៉ុបដំណើរការដោយប្រចាំដោយបុគ្គលិកអចិន្ត្រៃយ៍ ដែលត្រូវគេហៅថា អឺរ៉ូធិបតេយ្យ (Eurocrats) នៅក្នុងស្ថាប័នគណៈកម្មការអឺរ៉ុប។ ប្រធានគណៈកម្មការ សមាជិកម្នាក់ៗ និង

បុគ្គលិកទាំងអស់បម្រើអឺរ៉ុបទាំងមូល ដែលជាតួនាទីបែបបរមានុភាព។ ទោះយ៉ាងណាក៏ដោយ ក្រុមប្រឹក្សាសហភាពអឺរ៉ុបតំណាងអោយរដ្ឋជាសមាជិក (ក្នុងតួនាទីជាតិ) មានអំណាចលើគណៈកម្មការនេះ។

១០. សភាអឺរ៉ុបមានសមាជិកដែលត្រូវបោះឆ្នោតជ្រើសរើសដោយផ្ទាល់ ដោយពលរដ្ឋនៅក្នុងរដ្ឋទាំងអស់សហភាពអឺរ៉ុប ប៉ុន្តែវាមានអំណាចតិចតួច និងមិនអាចបង្កើតច្បាប់សម្រាប់សហគមន៍តែម្នាក់បានទេ។ តុលាការយុត្តិធម៌អឺរ៉ុបក៏មានអំណាចកំណត់ដែរ ប៉ុន្តែវាបានពង្រីកយុត្តាធិការរបស់ខ្លួនកាន់តែជោគជ័យជាងតុលាការអន្តរជាតិដទៃទៀត ហើយអាចរំលងច្បាប់ជាតិ។

១១. សន្ធិសញ្ញាទីក្រុងម៉ាស្ត្រីកឆ្នាំ ១៩៩១ ស្តីពីសមាហរណកម្មអឺរ៉ុបកាន់តែជិតស្និទ្ធ (សហភាពរូបិយវត្ថុ និងការសម្របសម្រួលនយោបាយ-យោធា) បានបង្កអោយមានប្រតិកម្មជាសាធារណៈនៅក្នុងប្រទេសមួយចំនួនប្រឆាំងនឹងអំណាចនៃការិយាធិបតេយ្យសហភាពអឺរ៉ុប។

១២. សមាជិកថ្មីចំនួន ១២ ដែលភាគច្រើននៅខាងកើតបានចូលរួមជាមួយសហភាពអឺរ៉ុប ក្នុងឆ្នាំ ២០០៤ និង២០០៧។ រចនាសម្ព័ន្ធ និងនីតិវិធីរបស់សហភាពអឺរ៉ុបត្រូវបានកែសម្រួលនៅពេលដែលវាបានផ្លាស់ប្តូរពី ១៥ ទៅ ២៨ រដ្ឋសមាជិក។ សហភាពអឺរ៉ុបប្រឈមមុខនឹងបញ្ហាក្នុងការសម្រេចចិត្តថា តើត្រូវពង្រីកសមាជិកភាពរបស់ខ្លួនដល់កម្រិតណា ជាពិសេសទាក់ទងនឹងប្រទេសទួរគី។

១៣. ប្រតិកម្មតបរបស់អ្នកជាតិនិយម ចំពោះសកលភាវូបនីយកម្ម បានបណ្តាលអោយមានការដកដៃចេញដោលយ៉ាងសំខាន់អំពីសហភាពអឺរ៉ុប រួមទាំងការសម្រេចចិត្តរបស់អង់គ្លេសក្នុងឆ្នាំ ២០១៦ ដើម្បីចាកចេញពីសហភាពអឺរ៉ុប។ គណបក្សនយោបាយជាតិនិយម និងប្រឆាំងសហភាពអឺរ៉ុបបានទទួលការគាំទ្រនៅក្នុងសមាជិកសហភាពអឺរ៉ុបកណ្តាលមួយចំនួន។

១៤. សមាហរណកម្មអន្តរជាតិប្រភេទផ្សេងទៀត អាចត្រូវបានគេមើលឃើញនៅក្នុងតួនាទីដែលកំពុងកើនឡើងនៃការទំនាក់ទំនងនិងព័ត៌មាន ដែលកំពុងប្រតិបត្តិការឆ្លងកាត់ព្រំដែនជាតិ។ បច្ចេកវិទ្យាព័ត៌មានថ្មីៗជាពិសេសប្រព័ន្ធផ្សព្វផ្សាយសាធារណៈធំៗ ដូចជាទូរទស្សន៍ វិទ្យុ និងអ៊ីនធឺរណែតកំពុងជំរុញទំនាក់ទំនងនិងអត្តសញ្ញាណបរមានុភាព បើទោះបីជាដំណើរការនេះនៅតែស្ថិតក្នុងដំណាក់កាលដំបូងនៅឡើយ។

១៥. អភិបាលកិច្ចប្រព័ន្ធអ៊ីនធឺណិតកំពុងស្ថិតក្រោមការចរចា នៅឯកិច្ចប្រជុំរបស់អង្គការសហប្រជាជាតិជាពិសេសនៅឆ្នាំ ២០១២ ដែលប្រទេសចំនួន ៨៩ បានគាំទ្រសន្ធិសញ្ញាថ្មីមួយដែលផ្តល់អោយរដ្ឋាភិបាលនូវអំណាចបន្ថែមទៀត ប៉ុន្តែ ប្រទេស ៥៥ ផ្សេងទៀតនឹងមិនចុះហត្ថលេខានោះទេ។

១៦. រដ្ឋាភិបាលប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានឆ្លងព្រំដែនជាមធ្យោបាយសម្រាប់ ជះឥទ្ធិពលលើរដ្ឋផ្សេងទៀត។ ការទទួលបានព័ត៌មានរបស់រដ្ឋាភិបាលក៏អាចបង្កើនស្ថេរភាពនៃទំនាក់ទំនងអន្តរជាតិផងដែរ ពីព្រោះបញ្ហាសន្តិសុខ និងបញ្ហាផលប្រយោជន៍រួមផ្សេងទៀតកាន់តែពិបាកនៅក្នុងពិភពលោកដែលមានតម្លាភាព។

១៧. លំហូរព័ត៌មានកាន់តែច្រើន និងកាន់តែសេរី នៅជុំវិញពិភពលោក អាចបំផ្លាញឥទ្ធិពល និងអំណាចរបស់រដ្ឋាភិបាលផងដែរ។ រូបិយប័ណ្ណនិម្មិតគឺជាមធ្យោបាយសម្រាប់បុគ្គល និងក្រុមនានាដើម្បីចូលរួមក្នុង

ប្រតិបត្តិការដោយមិនមានការត្រួតពិនិត្យពីរដ្ឋាភិបាល។ លើសពីនេះទៀត រដ្ឋាភិបាលផ្តាច់ការពិបាកកំណត់កម្រិតលំហូរព័ត៌មានចូលនិងចេញពីរដ្ឋរបស់ពួកគេ។

១៨. ទូរគមនាគមន៍កំពុងរួមចំណែកដល់ការអភិវឌ្ឍន៍នៃសមាហរណកម្មវប្បធម៌សកល។ ដំណើរការនេះអាចរក្សាសក្តានុពលសម្រាប់ការអភិវឌ្ឍនៃវប្បធម៌ពិភពលោករួមមួយ។ ទោះយ៉ាងណាក៏ដោយ អ្នកនយោបាយនិងប្រជាពលរដ្ឋមួយចំនួនព្រួយបារម្ភអំពីចក្រពត្តិនិយមវប្បធម៌ ថា វប្បធម៌បែបនេះនឹងត្រូវគ្របដណ្តប់យ៉ាងខ្លាំងដោយសហរដ្ឋអាមេរិក។

១៩. សហគមន៍ឆ្លងព្រំដែនជាតិ នៅក្នុងវិស័យដូចជាកីឡា តន្ត្រី និងទេសចរណ៍អាចជំរុញអត្តសញ្ញាណបរមានុភាពដែលនៅថ្ងៃណាមួយអាចដណ្តើមកក្តីភាពពលរដ្ឋពីរដ្ឋនានា។

ពាក្យគន្លឹះ

១. បរមានុភាព(Supranational) គឺជាពាក្យផ្សំរវាង បរម(ឧត្តមឬខ្ពង់ខ្ពស់)នឹងអានុភាព(អំណាចឬតេជៈ) សំដៅលើការបង្កើតស្ថាប័ននិងការរួមបញ្ចូលជាក្រុមធំៗ ដូចជា សហភាពអឺរ៉ុប ដែលអាជ្ញាធររដ្ឋឬអត្តសញ្ញាណជាតិត្រូវជ្រកក្រោមស្លាកឬស្តាប់តាមស្ថាប័នរួមទាំងនោះ។

២. សមាហរណកម្មអន្តរជាតិ គឺជាដំណើរការដែលស្ថាប័ន supranational ចូលមកជំនួសស្ថាប័នជាតិ។ ការផ្ទេរបន្តិចម្តងៗនូវអធិបតេយ្យភាពមួយចំនួនពីរដ្ឋ ឡើងទៅលើរចនាសម្ព័ន្ធក្នុងតំបន់ឬសកល។

៣. ទ្រឹស្តីមុខងារនិយមថ្មី(neofunctionalism) គឺជាទ្រឹស្តីដែលសន្មតថា សមាហរណកម្មសេដ្ឋកិច្ច (មុខងារនិយម) បង្កើតឥទ្ធិពល«ហូរហៀរ» ដែលបណ្តាលអោយមានសមាហរណកម្មនយោបាយកើនឡើង។

៤. សហគមន៍សន្តិសុខ គឺជាស្ថានភាពដែលការព្រំពឹងថាមានអំពើហិង្សាអន្តរដ្ឋទាប អនុញ្ញាតអោយមានកិច្ចសហប្រតិបត្តិការនយោបាយកម្រិតខ្ពស់ ដូចជា ក្នុងចំណោមសមាជិកអង្គការណាតូ។

៥. សហភាពអឺរ៉ុប (EU) គឺជាពាក្យផ្លូវការសម្រាប់ហៅសហគមន៍អឺរ៉ុប (អតីតសហគមន៍សេដ្ឋកិច្ចអឺរ៉ុប) និងអង្គការសន្ធិសញ្ញាដែលពាក់ព័ន្ធ។ នៅដើមឆ្នាំ ២០១៨ សហភាពអឺរ៉ុបមានរដ្ឋជាសមាជិក ចំនួន ២៨ បើទោះជាចក្រភពអង់គ្លេសបានបោះឆ្នោតចាកចេញនៅឆ្នាំ២០១៦ក្តី។ ដោយឡែក ក៏មានការចរចាជាមួយរដ្ឋផ្សេងទៀតដែលបានដាក់ពាក្យចូលជាសមាជិក។ សូមមើល *សន្ធិសញ្ញា ម៉ាស្ត្រីក* ផងដែរ ។

៦. សន្ធិសញ្ញាទីក្រុងរ៉ូម (១៩៥៧) គឺជាឯកសារបង្កើតសហគមន៍សេដ្ឋកិច្ចអឺរ៉ុប (EEC) ឬ ទីផ្សាររួម ដែលឥឡូវនេះត្រូវបានបញ្ចូលក្រោមស្លាកសហភាពអឺរ៉ុប។

៧. អឺរ៉ាតូម (Euratom) គឺជាអង្គការមួយដែលបង្កើតឡើងដោយសន្ធិសញ្ញាទីក្រុងរ៉ូមឆ្នាំ ១៩៥៧ ដើម្បីសំរបសំរួលការអភិវឌ្ឍន៍ថាមពលនុយក្លេអ៊ែរដោយការប្រមូលផ្តុំការស្រាវជ្រាវ ការវិនិយោគ និងការគ្រប់គ្រង។

៨. តំបន់ពាណិជ្ជកម្មសេរី គឺជាតំបន់ដែលមិនមានពន្ធគយ ឬការរឹតត្បិតផ្សេងទៀតលើលំហូរទំនិញ និងសេវាកម្មឆ្លងកាត់ព្រំដែនជាតិ។ សូមមើល *សហភាពពន្ធគយ* ផងដែរ។

៩. សហភាពពន្ធគយ គឺជាតារាងពន្ធគយរួមសម្រាប់ទំនិញនាំចូលពីខាងក្រៅ ដែលត្រូវបានអនុម័តដោយសមាជិកនៃតំបន់ពាណិជ្ជកម្មសេរី ពោលគឺ រដ្ឋដែលចូលរួម អនុម័តអត្រាពន្ធគយរួមមួយសម្រាប់ទំនិញដែលចូលមកពីខាងក្រៅ។ សូមមើល *តំបន់ពាណិជ្ជកម្មសេរី*ផងដែរ។

១០. ទីផ្សាររួម គឺជាទីកន្លែងដែលកម្លាំងពលកម្មនិងមូលធន (ក៏ដូចជាទំនិញ) ហូរចូលដោយសេរីឆ្លងកាត់ព្រំដែនជាតិជាសមាជិក។

១១. គោលនយោបាយកសិកម្មរួម (CAP) គឺជាគោលនយោបាយរបស់សហភាពអឺរ៉ុបលើគោលការណ៍ដែលថា ការឧបត្ថម្ភធនដល់កសិករក្នុងប្រទេសសមាជិកណាមួយ គួរតែត្រូវបានពង្រីកដល់កសិកររនៅក្នុងប្រទេសសមាជិកទាំងអស់។

១២. គណៈកម្មាការអឺរ៉ុប គឺជាស្ថាប័នសហភាពអឺរ៉ុបដែលសមាជិក ទោះត្រូវបានតែងតាំងដោយរដ្ឋនានាត្រូវបានសន្មតថាតំណាងអោយផលប្រយោជន៍របស់សហភាពអឺរ៉ុបទាំងមូល។ គាំទ្រដោយសេវាស៊ីវិលចម្រុះជាតិសាសន៍នៅទីក្រុងប្រ៊ុចសែល តួនាទីរបស់គណៈកម្មការត្រូវកំណត់បញ្ហានិងស្នើដំណោះស្រាយទៅកាន់ក្រុមប្រឹក្សាសហភាពអឺរ៉ុប។ សូមមើល *ក្រុមប្រឹក្សាសហភាពអឺរ៉ុប* ផងដែរ ។

១៣. ក្រុមប្រឹក្សាសហភាពអឺរ៉ុប គឺជាស្ថាប័នសហភាពអឺរ៉ុបដែលរដ្ឋមន្ត្រីពាក់ព័ន្ធនានា (កិច្ចការបរទេស សេដ្ឋកិច្ច កសិកម្ម ហិរញ្ញវត្ថុ ។ល។) នៃរដ្ឋសមាជិកនីមួយៗ ជួបប្រជុំគ្នា ដើម្បីអនុម័តច្បាប់ និងផ្សះផ្សាផលប្រយោជន៍ជាតិ។ ពីមុនត្រូវបានគេស្គាល់ថាជា ក្រុមប្រឹក្សារដ្ឋមន្ត្រី។ នៅពេលដែលកិច្ចប្រជុំធ្វើឡើងក្នុងចំណោមមេដឹកនាំរដ្ឋ វាត្រូវបានគេហៅថា «ក្រុមប្រឹក្សាអឺរ៉ុប»។ សូមមើល*គណៈកម្មការអឺរ៉ុប*ផងដែរ។

១៤. សភាអឺរ៉ុប គឺជាសហស្ថាប័ននីតិប្បញ្ញត្តិរបស់សហភាពអឺរ៉ុប ដែលធ្វើប្រតិបត្តិការជាអ្នកឃ្លាំមើលគណៈកម្មការអឺរ៉ុប និងមានអំណាចនីតិប្បញ្ញត្តិដែលមានកម្រិត។

១៥. តុលាការយុត្តិធម៌អឺរ៉ុប គឺជាសេនាធិការកាត់ក្តីរបស់សហភាពអឺរ៉ុប ដែលមានមូលដ្ឋាននៅប្រទេសលុចសំបួរ។ តុលាការបានបង្កើតយុត្តាធិការនិងសិទ្ធិរបស់ខ្លួនយ៉ាងសកម្ម ក្នុងការគ្រប់គ្រងលើច្បាប់ជាតិនៅពេលដែលវាផ្ទុយនឹងច្បាប់សហភាពអឺរ៉ុប។

១៦. សន្ធិសញ្ញាអឺរ៉ុបរួម (១៩៨៥) គឺជាច្បាប់ដែលកំណត់កាលបរិច្ឆេទគោលដៅ នៅចុងឆ្នាំ ១៩៩២ សម្រាប់ការបង្កើតទីផ្សាររួមពិតប្រាកដមួយ (លំហូរឆ្លងកាត់ព្រំដែនដោយឥសេរីនៃទំនិញ មូលធន មនុស្ស និងសេវាកម្ម) នៅក្នុងសហគមន៍អឺរ៉ុប (EC)។

១៧. សន្ធិសញ្ញាទីក្រុងម៉ាស្ត្រីក (Maastricht) គឺជាសន្ធិសញ្ញាដែលបានចុះហត្ថលេខា នៅទីក្រុងម៉ាស្ត្រីកនៃប្រទេសហូឡង់ និងត្រូវបានផ្តល់សច្ចាប័ន ក្នុងឆ្នាំ ១៩៩២។ សហភាពអឺរ៉ុបប្តេជ្ញាបង្កើតសហភាពរូបិយវត្ថុ (រូបិយប័ណ្ណរួមមួយ និងធនាគារកណ្តាលអឺរ៉ុប) និងចំពោះគោលនយោបាយការបរទេសរួម។ សូមមើល *សហភាពអឺរ៉ុប* (EU) ផងដែរ ។

១៨. ប្រាក់អឺរ៉ូ ក៏ត្រូវបានគេហៅផងដែរថា ECU (ឯកតារូបិយប័ណ្ណអឺរ៉ុប) គឺជារូបិយប័ណ្ណអឺរ៉ុបរួមមួយ ប្រើប្រាស់ជាផ្លូវការដោយសមាជិក ១៩ ប្រទេសនៃសហភាពអឺរ៉ុប (EU)។

១៩. សន្ធិសញ្ញាទីក្រុងលីស្បោន (Lisbon) កិច្ចព្រមព្រៀងសហភាពអឺរ៉ុប ដែលជំនួសការប៉ុនប៉ងបង្កើតធម្មនុញ្ញសហភាពអឺរ៉ុបដែលបរាជ័យ ដោយកំណែទម្រង់ស្រដៀងគ្នាដែលពង្រឹងសិទ្ធិអំណាចកណ្តាលរបស់សហភាពអឺរ៉ុប និងការកែប្រែនីតិវិធីបោះឆ្នោតក្នុងចំណោមសមាជិកភាពរបស់សហភាពអឺរ៉ុប ដែលបានពង្រីកកាន់តែធំ។

២០. គម្លាតឌីជីថល គឺជាគម្លាតក្នុងការទទួលបានបច្ចេកវិទ្យាព័ត៌មាន រវាងអ្នកមាននិងអ្នកក្រ និង រវាងអឌ្ឍគោលខាងជើងនិងអឌ្ឍគោលខាងត្បូង។

២១. រូបិយប័ណ្ណនិម្មិត គឺជារូបិយប័ណ្ណដែលបង្កើតឡើងដោយអ្នកប្រើប្រាស់ជាមធ្យោបាយមួយ ដើម្បីជួយសម្រួលដល់ការផ្លាស់ប្តូរទំនិញនិងសេវាកម្ម ក្រៅដែនសមត្ថកិច្ចគ្រប់គ្រងរបស់រដ្ឋាភិបាល។

២២. វប្បធម៌ចក្រពត្តិនិយម គឺជាពាក្យរិះគន់លើការត្រួតត្រារបស់សហរដ្ឋអាមេរិកក្នុងវប្បធម៌សកលដែលកំពុងរីកចម្រើន។

សំណួរអនុវត្តន៍

១. ទំនាក់ទំនងសេដ្ឋកិច្ចបែបមុខងារនិយមក្នុងចំណោមបណ្តារដ្ឋអឺរ៉ុប បានចូលរួមចំណែកដល់ការលេចចេញនូវរចនាសម្ព័ន្ធនយោបាយបរមានុភាពមួយ គឺ សហភាពអឺរ៉ុប ដែលមានអំណាចលើសលប់គួរសមប៉ុន្តែមិនមែនជាអំណាចគ្មានដែនកំណត់នោះទេ។ តើអ្នកគិតថា សហភាពដូចគ្នាអាចកើតឡើងនៅអាមេរិកខាងជើងដែរឬទេ? តើប្រទេសសហរដ្ឋអាមេរិក កាណាដា និងម៉ិកស៊ិក អាចបង្កើតបានជា អនាគតសហភាពអាមេរិកខាងជើង ដូចសហភាពអឺរ៉ុបដែរឬទេ? យោងតាមបទពិសោធរបស់សហភាពអឺរ៉ុប តើបញ្ហាអ្វីខ្លះដែលអាចនឹងប្រឈមមុខនឹងគម្រោងនេះ?

២. ឧបមាថា អ្នកកំពុងជជែកលេងជាមួយប្រធានគណៈកម្មការអឺរ៉ុប ដែលកំពុងត្អូញត្អែរអំពីប្រតិកម្មសាធារណៈ នៅក្នុងរដ្ឋជាសមាជិក ប្រឆាំងនឹងកំនើនអំណាចមន្ត្រីអឺរ៉ូធិបតេយ្យក្នុងគណៈកម្មការមួយនេះ។ តើអ្នកនឹងផ្តល់ដំបូន្មានអ្វីខ្លះ? តើគណៈកម្មការអាចចាត់វិធានការអ្វីខ្លះ ដើម្បីបំបាត់ការព្រួយបារម្ភបែបនេះដោយមិនបង្វែរដំណើរការធ្វើសមាហរណកម្ម? តើយោបល់របស់អ្នក អាចនឹងដោះស្រាយការមិនសប្បាយចិត្តរបស់ពលរដ្ឋ ឬរដ្ឋាភិបាលអឺរ៉ុប ចំពោះគណៈកម្មការអឺរ៉ុប?

៣. តើការបោះឆ្នោតរបស់ចក្រភពអង់គ្លេសចាកចេញពីសហភាពអឺរ៉ុបមានផលប៉ះពាល់អ្វីខ្លះ? តើនេះជាសញ្ញាដំបូងដែលថា មនោសញ្ចេតនាជាតិនិយមនឹងរំសាយសហភាពអឺរ៉ុប ឬ តើកម្លាំងនៃលទ្ធិបរមានុភាពនឹងលេចចេញមកខ្លាំងជាងមុន?

៤. ឧបមាថា រដ្ឋាភិបាលតួកគីបានជួលអ្នក ធ្វើជាអ្នកពិគ្រោះយោបល់ ដើម្បីជួយអោយរដ្ឋនេះរៀបចំបទបង្ហាញដល់សហភាពអឺរ៉ុប ដែលត្រូវពន្យល់អំពីមូលហេតុ ដែលទួរគីគួរតែត្រូវបានអនុញ្ញាតអោយចូលជាសមាជិក។ តើអ្នកនឹងទាញអំណះអំណាងអ្វីខ្លះ? តើការរំពឹងទុកបែបណា ដែលអ្នកអាចរំពឹងពីសមាជិកសហភាពអឺរ៉ុបបច្ចុប្បន្ន? តើអ្នកគួរផ្តល់យោបល់ថាតួកគីឆ្លើយតបយ៉ាងដូចម្តេច?

៥. បច្ចេកវិទ្យាព័ត៌មានកំពុងពង្រឹងទំនាក់ទំនងនិងអត្តសញ្ញាណឆ្លងដែននិងបរមានុភាព។ ទោះជាយ៉ាងណាក៏ដោយ ពួកគេក៏កំពុងក្លាយជាឧបករណ៍អំណាចនិងការគ្រប់គ្រងថ្មីរបស់រដ្ឋ។ តើទិដ្ឋភាពមួយណាដែលអ្នកមើលឃើញថាមានលេចធ្លោជាងគេ នៅកំឡុងពេលនេះ? តើសមត្ថភាពថ្មីទាំងនេះ មានប្រយោជន៍ឬ

មានគ្រោះថ្នាក់ដល់រដ្ឋាភិបាលរបស់រដ្ឋដែរឬទេ? ហេតុអ្វី? តើអ្នករំពឹងថាចម្លើយរបស់អ្នកនឹងផ្លាស់ប្តូរនាពេលអនាគត នៅពេលដែលបច្ចេកវិទ្យាកំពុងបន្តអភិវឌ្ឍ?

៦. តាមគំនិតរបស់អ្នក តើការប្រាស្រ័យទាក់ទងនិងវប្បធម៌សកលមានផលប្រយោជន៍និងផលលំបាកអ្វីខ្លះ? តើយើងគួរលើកទឹកចិត្ត ឬ រអ៊ូរទាំពីលទ្ធភាពនៃវប្បធម៌សកលរួមមួយដែរឬទេ? តើចម្លើយអាស្រ័យលើទីតាំងដែលអ្នកឆ្លើយកំពុងរស់ នៅក្នុងពិភពលោកដែរឬទេ? សូមលើកឧទាហរណ៍ជាក់ស្តែងនៃផលប៉ះពាល់ដែលអ្នកពិភាក្សា។

ការស្វែងរកផលប្រយោជន៍រួម

ការជួយសង្គ្រោះប្រទេសក្រីក្រពីភាពក្សីយធន

ផលប្រយោជន៍រួម៖ ស្ថិរភាពហិរញ្ញវត្ថុរបស់អឺរ៉ុប

សារតារ

រដ្ឋចំនួន ១៩ ដែលរួមគ្នាបង្កើតបានជាតំបន់ចាយប្រាក់អឺរ៉ូ បានបោះបង់ចោលរូបិយប័ណ្ណជាតិរបស់ពួកគេដើម្បីគាំទ្រដល់រូបិយប័ណ្ណរួមមួយ។ ជាលទ្ធផល រដ្ឋនីមួយៗបានទទួលរងផលប៉ះពាល់ដោយគោលនយោបាយហិរញ្ញវត្ថុរបស់រដ្ឋដទៃ។ ជាឧទាហរណ៍ ឱនភាពនៃការចំណាយលើកម្មវិធីនានា ផ្នែកនយោបាយជាធម្មតាប៉ះពាល់ដល់រូបិយបណ្ណរបស់ប្រទេសនោះ ប៉ុន្តែប្រសិនបើប្រទេសនេះស្ថិតនៅក្នុងតំបន់ចាយប្រាក់អឺរ៉ូ នោះឥទ្ធិពលនោះនឹងរាលដាលពាសពេញប្រទេសអឺរ៉ូផ្សេងទៀតទាំងអស់។ ដើម្បីជៀសវាងរកាប៊ុនប៊ងពីការទទួលប្រយោជន៍ផ្ទាល់ខ្លួន សហភាពអឺរ៉ុបបានរៀបចំបង្កើតច្បាប់សម្រាប់ការទទួលខុសត្រូវសារពើពន្ធ (រួមទាំងឱនភាពទាប) មុនពេលប្រទេសមួយអាចទទួលយកប្រាក់អឺរ៉ូ។ នៅពេលក្រោយមកទៀត ដោយបានរៀបចំច្បាប់ច្បាស់លាស់ ប្រទេសមួយចំនួនរួមទាំងប្រទេសក្រីក្រផងដែរ បានបញ្ចៀសឬឈប់ធ្វើរាល់តម្រូវការទាំងនោះនៅពេលដែលពួកគេបានចូលរួមក្នុងតំបន់ចាយប្រាក់អឺរ៉ូដំបូង។

ដូច្នេះ សុខភាពរបស់រូបិយប័ណ្ណអឺរ៉ូ គឺជាដំណោះស្រាយបញ្ហាផលប្រយោជន៍រួម អាស្រ័យលើវិន័យនៃសារពើពន្ធរបស់សមាជិករបស់ខ្លួន។ *ការដុះរសេះលែងដៃ*បានគំរាមកំហែងដល់សមាជិកតំបន់ចាយប្រាក់អឺរ៉ូទាំងអស់ ដោយសារតែវិបត្តិសេដ្ឋកិច្ចក្នុងប្រទេសមួយអាចរីករាលដាលយ៉ាងងាយ និងធាប់រហ័សដល់រដ្ឋដទៃតាមរយៈរូបិយប័ណ្ណរួម។

បញ្ហាប្រឈម

ក្នុងឆ្នាំ ២០១០ គោលនយោបាយសារពើពន្ធរបស់ប្រទេសក្រីក រួមផ្សំជាមួយនឹងផលវិបាកអូសបន្លាយនៃវិបត្តិសេដ្ឋកិច្ចសកល ដែលធ្វើឱ្យប្រទេសក្រីកធ្លាក់ក្នុងវិបត្តិបំណុលនិងជិតនឹងក្សីយធន។ អស្ថិរភាពនេះបានគម្រាមកំហែងដល់សមាជិកដែលមានឱនភាពប្រាក់អឺរ៉ូផ្សេងទៀត (ដូចជាអេស្ប៉ាញ ព័រទុយហ្គាល់ និងអៀរឡង់)។ តម្លៃប្រាក់អឺរ៉ូបានចាប់ផ្តើមធ្លាក់ចុះ ហើយទីផ្សារហិរញ្ញវត្ថុពិភពលោកបានធ្លាក់ចុះ ដោយសារការធុញថប់បារម្ភកើនឡើង។

ដំណោះស្រាយ

ជាការឆ្លើយតប សហភាពអឺរ៉ុប និងមូលនីធិ IMF បានបោះទុនរួមគ្នាបង្កើតកញ្ចប់ថវិកាសង្គ្រោះចំនួន ១៤១ ប៊ីលានដុល្លារសម្រាប់ក្រីក។ ដើម្បីចូលជាធរមាន កញ្ចប់ថវិកានេះត្រូវការការយល់ព្រមពីសមាជិកតំបន់ចាយប្រាក់អឺរ៉ូទាំង ១៦ (នៅពេលនោះ)។ នៅប្រទេសអាឡឺម៉ង់ ជាកន្លែងដែលវិន័យសារពើពន្ធជាប្រពៃណី

ដែលមានការខឹងសម្បារពីអ្នកបោះឆ្នោត ដែលមិនចង់នៅពីក្រោយជនជាតិក្រិក ដែលមិនទទួលខុសត្រូវទេ ហើយសំឡេងមតិភាគច្រើនត្រឹមតែប៉ុន្មានសម្លេងរបស់គណបក្សគ្រប់គ្រងនៅក្នុងសភាត្រូវបានគំរាមកំហែង។ ដូច្នេះ រដ្ឋាភិបាលអាឡឺម៉ង់បានប្រឈមមុខនឹងការខាតបង់ក្នុងស្រុក និងតម្លៃផ្ទាល់ចំនួន ២៨ ប៊ីលានដុល្លារ សម្រាប់ចំណែកនៃកញ្ចប់ថវិកាសង្គ្រោះរបស់ប្រទេសអាឡឺម៉ង់។ អត្តសញ្ញាណបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការសម្រេចចិត្តរបស់រដ្ឋាភិបាលអាឡឺម៉ង់ក្នុងការអនុម័តកិច្ចព្រមព្រៀងនេះ។ អត្តសញ្ញាណរបស់សហភាពអឺរ៉ុបជាទ្វីបរួមមួយមានន័យថា ប្រទេសអាឡឺម៉ង់បានមើលឃើញផលប្រយោជន៍រួមនៃស្ថិរភាពប្រាក់អឺរ៉ូជាផលប្រយោជន៍របស់ខ្លួនដែរ។ ទោះជាយ៉ាងណាក៏ដោយ គោលការណ៍បដិការក៏បានដើរតួនាទីយ៉ាងសំខាន់ផងដែរ ពីព្រោះរដ្ឋាភិបាលអាឡឺម៉ង់បានគាំទ្រថវិកាសង្គ្រោះ លុះត្រាតែបញ្ហានេះបានគំរាមកំហែងបង្កការរីករាលដាលនិងធ្វើអោយប្រាក់អឺរ៉ូមានអស្ថិរភាព ដែលបង្កគ្រោះថ្នាក់ដោយផ្ទាល់ដល់ប្រទេសអាឡឺម៉ង់ ប្រសិនបើខ្លួនមិនយល់ព្រមលើកិច្ចព្រមព្រៀងនោះ។ គ្រាន់តែការគិតដល់ជនរួមជាតិអឺរ៉ុបដែលត្រូវការជំនួយតែម្យ៉ាង មិនបានធ្វើអោយអាឡឺម៉ង់ចូលជួយឡើយ។

ឧស្សន:ទិស័យគោលនយោបាយ

អធិការបតីអាឡឺម៉ង់លោកស្រី អង់ហ្គឺឡា ម៉ាកែល (Angela Merkel)

រូបថត លោកស្រីអធិការបតី

បញ្ហា: *តើអ្នកអាចប្តឹងថ្លែងតុល្យភាពរវាងកម្លាំងប្រកួតប្រជែង នៅក្នុងសហភាពអឺរ៉ុបជាមួយនឹងការបំពេញចិត្តរបស់មតិសាធារណ:ក្នុងស្រុក ដោយរបៀបណា ?*

សារតារ

អស់រយៈពេលជាច្រើនទស្សវត្សមកហើយដែលប្រទេសទួរគីចង់បានសមាជិកភាពពេញលេញនៅក្នុងសហភាពអឺរ៉ុប។ មានហេតុផលជាច្រើន ដែលធ្វើអោយគោលបំណងចង់បានសមាជិកភាពពេញលេញរបស់ប្រទេសទួរគីត្រូវបានជាប់គាំង។ ប្រទេសទួរគីនឹងក្លាយជាសមាជិកសហភាពអឺរ៉ុបដែលក្រីក្របំផុត នឹងក្លាយជាសមាជិកសហភាពអឺរ៉ុបតែមួយគត់ ដែលមិនមែនជាគ្រិស្តសាសនា ហើយដែលមិនបានដោះស្រាយជម្លោះអតីតកាលជាមួយសមាជិកបច្ចុប្បន្ន ដូចជា កោះស៊ីប និងប្រទេសក្រិក ហើយវាមិនដែលទទួលស្គាល់ការទទួលខុសត្រូវរបស់ខ្លួនក្នុងបទប្រល័យពូជសាសន៍ជនជាតិអាមេនី នៅក្នុងអំឡុងសង្គ្រាមលោកលើកទី ១ នៅឡើយ។

ប៉ុន្តែ អ្នកសង្កេតការណ៍ជាច្រើនបានអះអាងថា ប្រទេសទួរគីមានសារៈសំខាន់ខ្លាំង មិនអាចទុកអោយនៅក្រៅសហភាពអឺរ៉ុបបានទេ ដោយសារវាបានបម្រើកិច្ចទំនាក់ទំនងដ៏សំខាន់រវាងអឺរ៉ុបនិងមជ្ឈិមបូព៌ា, ទួរគីជាសមាជិករបស់ណាតូ ហើយក៏ជាប្រទេសដែលត្រូវបានស្នើអោយមានការធ្វើកំណែទម្រង់ជាច្រើនដោយរដ្ឋសហភាពអឺរ៉ុប ដូចជាក្នុងផ្នែកសិទ្ធិមនុស្ស សិទ្ធិជនជាតិភាគតិច និងលទ្ធិប្រជាធិបតេយ្យ។ ប្រទេសទួរគីបានយល់ព្រមធ្វើជាម្ចាស់ផ្ទះទទួលជនភៀសខ្លួនស៊ីរី ជាងមួយលាននាក់ ដូច្នេះ ពួកគេមិនចាំបាច់ស្វែងរកសិទ្ធិជ្រកកោននៅអឺរ៉ុបកណ្តាលនិងខាងលិច។ ប្រទេសរបស់អ្នកបានរក្សាទំនាក់ទំនងសេដ្ឋកិច្ច យ៉ាងទូលំទូលាយជាមួយនឹងប្រទេសទួរគីផងដែរ ប្រទេសអាឡឺម៉ង់គឺជាប្រភពនាំចូលកំពូលរបស់ប្រទេសទួរគី និងទីផ្សារដ៏ធំបំផុតសម្រាប់ការនាំចេញ។ ប្រទេសទួរគីដែលមានសុខភាពសេដ្ឋកិច្ចល្អនៅក្នុងសហភាពអឺរ៉ុបនឹងអំណោយផលល្អសម្រាប់អាជីវកម្មអាឡឺម៉ង់។

មេដឹកនាំអាឡឺម៉ង់កន្លងមកមានទស្សនៈផ្សេងគ្នា ចំពោះពាក្យសុំចូលជាសមាជិកភាពរបស់ប្រទេសទួរគី អ្នកខ្លះប្រឆាំងដាច់ខាត ខ្លះទៀតគាំទ្រខ្លាំងក្លា។ អ្នកបានព្យាយាមផ្តល់នូវដំណោះស្រាយសម្របសម្រួលមួយៈ គំនិតនៃ «ភាពជាដៃគូឯកសិទ្ធិពិសេស» ដែលនឹងផ្តល់អត្ថប្រយោជន៍ សេដ្ឋកិច្ចមួយចំនួនដល់ប្រទេសទួរគី ប៉ុន្តែមិនមានសមាជិកភាពពេញលេញនោះទេ។ មេដឹកនាំទួរគីប្រឆាំងនឹងជម្រើសនេះ ហើយមេដឹកនាំអឺរ៉ុបផ្សេងទៀតមិនបានគាំទ្រការសម្របសម្រួលរបស់អ្នករហូតមកដល់សព្វថ្ងៃនេះទេ។

ខណៈពេលដែលការស្នើសុំរបស់ទួរគីចូលជាសមាជិកសហភាពអឺរ៉ុបមានទាំងអ្នកគាំទ្រ និងទាំងអ្នករារាំងនៅទូទាំងទ្វីបអឺរ៉ុប គ្មានប្រទេសណាមួយប្រឆាំងនឹងសមាជិកភាពទួរគីច្រើនជាងប្រទេសបារាំងនោះទេ។ ប្រធានាធិបតីបារាំងបច្ចុប្បន្ន លោក អេម៉ានុយអែល ម៉ាក្រុង (Emmanuel Macron) បានប្រកាស កាលពីខែមករា ឆ្នាំ ២០១៨ ថា សហភាពអឺរ៉ុបគួរតែបញ្ចប់«ភាពពុតត្បុត»នៃការស្មានថា ប្រទេសទួរគីអាចនឹងចូលទៅក្នុងសហភាពអឺរ៉ុប។

ការពិចារណាក្នុងស្រុក

សមាជិកភាពទួរគីនៅក្នុងសហភាពអឺរ៉ុបមិនមានប្រជាប្រិយភាពក្នុងស្រុកទេ។ ជនជាតិដើមអាឡឺម៉ង់មានការព្រួយបារម្ភថា ជនអន្តោប្រវេសន៍អាចមកប្រទេសអាឡឺម៉ង់ដោយសេរី និងដណ្តើមការងារក្នុងស្រុក។ ពួកគេក៏បារម្ភថា រលកនៃការនាំចេញថោកពីទួរគីនឹងធ្វើអោយប៉ះពាល់ដល់កម្មករអាឡឺម៉ង់។ ជនជាតិទួរគីជាង ២,១ លាននាក់ បាននិងកំពុងរស់នៅក្នុងប្រទេសអាឡឺម៉ង់រួចទៅហើយ ដែលធ្វើអោយពួកគេក្លាយជាក្រុមជនជាតិភាគតិចដ៏ច្រើនបំផុត នៅក្នុងប្រទេសរបស់អ្នក។ មានភាពតានតឹងផ្នែកជាតិសាសន៍រវាងជនអន្តោប្រវេសន៍ទួរគីនិងជនជាតិដើមនអាឡឺម៉ង់ ដែលនាំអោយមានការអំពាវនាវអោយមានការតឹងរ៉ឹងលើជនអន្តោប្រវេសន៍ទួរគី។ ប៉ុន្តែ ជនជាតិទួរគីជាច្រើន នៅក្នុងប្រទេសអាឡឺម៉ង់កំពុងបោះឆ្នោត និងពលរដ្ឋជាអ្នកបង់ពន្ធ ដែលបានជំរុញអ្នកគាំទ្រដល់សមាជិកភាពរបស់ប្រទេសទួរគី។

សេណារីយ៉ូ

ឥឡូវចូរស្រមៃថា ប្រទេសបារាំងស្នើអោយបញ្ឈប់ពាក្យសុំចូលសមាជិកសហភាពអឺរ៉ុបរបស់ប្រទេសទួរគីជាអចិន្ត្រៃយ៍។ ប្រទេសបារាំងសុំអោយអ្នកគាំទ្រក្នុងការធានាថា ប្រទេសទួរគីនឹងមិនក្លាយជាសមាជិករបស់សហភាពអឺរ៉ុបនោះទេ។ នៅពេលឮសំណើរបស់បារាំង ជនជាតិភាគតិចទួរគីចាប់ផ្តើមការតវ៉ាទ្រង់ទ្រាយធំនៅក្នុងទីក្រុងនានាក្នុងប្រទេសអាឡឺម៉ង់ ដើម្បីជំរុញអោយអ្នកគាំទ្រពាក្យសុំចូលជាសមាជិករបស់ទួរគី។

ចូរជ្រើសរើសគោលនយោបាយរបស់អ្នក

តើអ្នកគាំទ្រកិច្ចប្រឹងប្រែងរបស់បារាំងក្នុងទុកប្រទេសទួរគីអោយនៅក្រៅសហភាពអឺរ៉ុបដែរឬទេ? តើអ្នកនឹងបន្តជំរុញគំនិតរបស់អ្នកផ្តល់«ភាពជាដៃគូអភ័យឯកសិទ្ធិពិសេស»ដល់ប្រទេសទួរគី ទោះបីជាគំនិតនេះបានទទួលការគាំទ្រតិចតួចក្នុងប្រទេសឬក្រៅប្រទេសក៏ដោយ? តើអ្នកច្បឹងច្បឹង តុល្យភាពរវាងការទាមទារពីដៃគូសំខាន់ៗរបស់សហភាពអឺរ៉ុបជាមួយនឹងចំណូលចិត្តគោលនយោបាយផ្ទាល់ខ្លួនរបស់អ្នក និងស្ថានភាពក្នុងស្រុកដ៏លំបាកដោយរបៀបណា?

មតិសាធារណៈ និងទំនាក់ទំនងអន្តរជាតិ

គ្រោះថ្នាក់នៃការវាយប្រហារតាមអ៊ីនធឺណិត

ការបោះឆ្នោតជ្រើសរើសប្រធានាធិបតីឆ្នាំ ២០១៦ នៅសហរដ្ឋអាមេរិក បានទាក់ទាញចំណាប់អារម្មណ៍ដល់ការកើនឡើងនៃការប្រើប្រាស់ការវាយប្រហារនិងចារកម្មតាមអ៊ីនធឺរណែត ដើម្បីរំខានដល់សកម្មភាពប្រចាំថ្ងៃរបស់រដ្ឋាភិបាលនិងបុគ្គលជាគោលដៅ។ ទោះជាយ៉ាងនេះក្តី សកម្មភាពរបស់រុស្ស៊ីក្នុងអំឡុងពេលបោះឆ្នោតនៅសហរដ្ឋអាមេរិកមិនមានបំណងរំខានដល់ជីវភាពប្រចាំថ្ងៃ ដូចការវាយប្រហាររបស់ខ្លួនកាលពីអតីតកាលប្រឆាំងនឹងប្រទេសដទៃទៀតនោះទេ។ ហើយក៏មិនមានតែប្រទេសរុស្ស៊ីតែឯងព្យាយាមប្រើប្រាស់អ៊ីនធឺរណែតសម្រាប់ជាឧបករណ៍បញ្ចេញអានុភាព៖ ចិន សហរដ្ឋអាមេរិក និងប្រទេសជាច្រើនផ្សេងទៀត បានប្រើប្រាស់អ៊ីនធឺរណែត ជាឧបករណ៍អានុភាពយោធាឬការទូត ដើម្បីជះឥទ្ធិពលលើនយោបាយពិភពលោក។

ដោយសារតែកំណើនការប្រើប្រាស់អ៊ីនធឺណែត ជាឧបករណ៍គោលនយោបាយបរទេស ប្រជាពលរដ្ឋទូទាំងពិភពលោកបានយល់ដឹងកាន់តែច្រើនថា អ៊ីនធឺរណែតអាចប្រើប្រាស់ប្រឆាំងនឹងពួកគេ និងប្រទេសរបស់ពួកគេ។ ការស្ទង់មតិឆ្នាំ ២០១៦ បានសាកសួរពលរដ្ឋនៃប្រទេសចំនួន ១៣ ថា តើពួកគេមានអារម្មណ៍ថាការវាយប្រហារតាមអ៊ីនធឺណិតគឺជាការគំរាមកំហែងដ៏ធំ ឬជាការគំរាមកំហែងតិចតួច ឬមិនមែនជាការគំរាមកំហែងដល់ប្រទេសរបស់ពួកគេ (សូមមើលក្រាហ្វិក ១០.៦)។ កម្រិតនៃការគម្រាមកំហែងពីការវាយប្រហារតាមប្រព័ន្ធអ៊ីនធឺរណែតមានភាពខុសប្លែកគ្នា បើទោះបីជាមតិភាគច្រើន នៅក្នុងប្រទេសចំនួន ៩ ក្នុងចំណោម ១៣ យល់ថា ការវាយប្រហារដែលអាចកើតមានគឺជាការគំរាមកំហែងដ៏ធំមួយក៏ដោយ។

អ្វីដែលគួរអោយចាប់អារម្មណ៍នោះគឺថា ប្រទេសដែលមានការភ័យខ្លាចតិចតួចបំផុតពីការវាយប្រហារតាមអ៊ីនធឺរណែត គឺប្រទេសចិនដែលមានបទពិសោធន៍យ៉ាងទូលំទូលាយក្នុងការធ្វើការវាយប្រហារបែបនេះ។ ពលរដ្ឋចិនជាង ២០ ភាគរយចាត់ទុកការវាយប្រហារតាមអ៊ីនធឺណិតជាការគំរាមកំហែងដ៏សំខាន់មួយ ខណៈដែលប្រហែល ២៥ ភាគរយមិនឃើញមានការគំរាមកំហែងទាល់តែសោះ។ ប្រទេសជិតខាងរបស់ចិន គឺប្រទេសជប៉ុន មានការព្រួយបារម្ភកម្រិតខ្ពស់អំពីការវាយប្រហារតាមអ៊ីនធឺរណែត ជាង ៨០ ភាគរយ។


ប្រទេសពីរផ្សេងទៀតបង្ហាញ ការព្រួយបារម្ភតិចតួចអំពីការវាយប្រហារតាមអ៊ីនធឺរណែតជាងរដ្ឋផ្សេងទៀត គឺ ក្រិក និងឥណ្ឌា។ សម្រាប់ប្រទេសក្រិក បញ្ហាផ្សេងទៀតអាចនឹងគំរាមកំហែងដល់សាធារណជន ខណៈដែលប្រទេសនោះនៅតែបន្តតស៊ូជំនះ បន្ទាប់ពីវិបត្តិបំណុលរបស់ខ្លួន។ ប្រទេសឥណ្ឌា ដូចជាប្រទេសចិន គឺជាម្ចាស់ផ្ទះសំបូរដោយអ្នកសរសេរកម្មវិធីដ៏ទំនើបមួយចំនួនធំ ដែលមិនមានការព្រួយបារម្ភសោះឡើយចំពោះការវាយប្រហារក្នុងប្រទេសខ្លួនព្រោះគេជាអ្នកសរសេរកម្មវិធីកុំព្យូទ័រដែរ។ វាក៏អាចដោយសារតែថាអ៊ីនធឺរណែតនៅតែមិនសូវរីករាលដាលនៅក្នុងប្រទេសចិន និងតំបន់ក្រីក្ររបស់ឥណ្ឌា អ្នកឆ្លើយតបតិចតួចបំផុតនៅក្នុងតំបន់ទាំងនោះនឹងរកឃើញថា ការវាយប្រហារតាមអ៊ីនធឺរណែតជាការព្រួយបារម្ភសម្រាប់ខ្លួន។

ទោះបីជាករណីករណីព្រួយបារម្ភទាបទាំងបីនេះក៏ដោយ ក៏ប្រជាពលរដ្ឋភាគច្រើននៃរដ្ឋទាំងនេះមានការព្រួយបារម្ភអំពីការវាយប្រហារតាមអ៊ីនធឺរណែត។ ពេលដែលការវាយប្រហារនិងចារកម្មតាមអ៊ីនធឺរណែតក៏ដូចជាការប្រើប្រាស់អ៊ីនធឺណិតផ្សេងទៀត ដើម្បីបម្រើអំណាចរដ្ឋក្លាយជារឿងធម្មតា តួលេខទាំងនេះនៅតែមានកម្រិតខ្ពស់ឡើយ។

រូបភាព ១០.៦ មតិសាធារណៈទាក់ទងនឹងការវាយប្រហារតាមអ៊ីនធឺរណែតក្នុង ១៣ ប្រទេស

ប្រភព៖ មជ្ឈមណ្ឌលស្រាវជ្រាវ Pew

ការវាយប្រហារតាមអ៊ីនធឺរណែត គឺជា...



សម្គាល់៖ *ការព្រួយបារម្ភខ្លាំង ការព្រួយបារម្ភតិចតួច មិនគួរអោយព្រួយបារម្ភឡើយ*

តោះ! សាកល្បងពិភាក្សាអំពីបញ្ហាជាក់ស្តែង

តើសមាហរណកម្មអឺរ៉ុបបានទៅឆ្ងាយសមល្មមហើយឬនៅ?

ទិដ្ឋភាពទូទៅ

ចាប់តាំងពីការបង្កើតសហគមន៍ធ្យូងថ្មនិងដែកថែបអឺរ៉ុបមក សមាហរណកម្មនៅក្នុងទ្វីបអឺរ៉ុបហាក់ដូចជាធ្វើដំណើរឆ្ពោះទៅមុខជាបន្តបន្ទាប់។ នាពេលនេះ សហភាពអឺរ៉ុបគឺជាកម្លាំងចលករផ្នែកនយោបាយយ៉ាងសំខាន់នៅអឺរ៉ុប។ ក្នុងវិស័យសេដ្ឋកិច្ច វាមានវិសាលភាពធំធេង ដោយមានផលិតផលក្នុងស្រុកសរុបធំជាងផ.ស.ស.របស់សហរដ្ឋអាមេរិកទៅទៀត។ ក្នុងវិស័យការទូត វាជាកម្លាំងសកម្មខ្លាំងក្នុងដំណើរការសម្របសម្រួលជម្លោះអន្តរជាតិ និងសូម្បីតែជម្លោះដែលពាក់ព័ន្ធនឹងប្រទេសមហាអំណាចផ្សេងទៀតផង។ វាមានឥទ្ធិពលយ៉ាងសំខាន់ផងដែរទាំងក្នុងនិងក្រៅទ្វីបអឺរ៉ុប។

ប៉ុន្តែនាពេលថ្មីៗនេះ សហភាពអឺរ៉ុបមានការលំបាកក្នុងការបន្តដំណើរការសមាហរណកម្ម។ បន្ទាប់ពីការអនុម័តប្រាក់អឺរ៉ូ សហភាពអឺរ៉ុបបានបង្វែរការផ្តោតអារម្មណ៍របស់ខ្លួន ពីការពង្រឹងសមាហរណកម្ម (យកគោលនយោបាយស៊ីជម្រៅថែមទៀតពីរដ្ឋសមាជិកមកកាន់កាប់ផ្ទាល់) ទៅជាការពង្រីកសមាជិកភាពដោយការទទួលយកអតីតរដ្ឋអឺរ៉ុបខាងកើតអោយចូលជាសមាជិក។ ការពង្រីកនេះបានពង្រីកអំណាចនយោបាយនិងសេដ្ឋកិច្ចរបស់សហភាពអឺរ៉ុប ប៉ុន្តែវាបានបណ្តាលអោយមានបញ្ហាប្រឈមផងដែរ។ វិបត្តិសេដ្ឋកិច្ចសកលក៏បានបង្កភាពតានតឹងដល់សហភាពអឺរ៉ុបដែរ។ នាយករដ្ឋមន្ត្រីហុងគ្រី វីកទ័រ អូបាន់ បានព្រមាននៅឆ្នាំ ២០០៩ អំពី«រាំងននដែកថ្មី»ខ័ណ្ឌចែករវាងរដ្ឋសមាជិកអ្នកមាន (អឺរ៉ុបខាងលិច) និងរដ្ឋក្រីក្រ (អឺរ៉ុបខាងកើត)។ វិបត្តិជនភៀសខ្លួនឆ្នាំ ២០១៥ និងការសម្រេចចិត្តរបស់អង់គ្លេស នាពេលបន្ទាប់មក ក្នុងការចាកចេញពីសហភាពអឺរ៉ុប សុទ្ធសឹងជាព្រឹត្តិការណ៍ដ៏សំខាន់ដែលគំរាមកំហែង។

ឥឡូវនេះ អ្នកខ្លះឆ្ងល់ថា តើសមាហរណកម្មអឺរ៉ុបបានឈានមកដល់ទីបញ្ចប់ហើយមែនទេ។ តើជំហានចុងក្រោយឆ្ពោះទៅរកការពង្រឹងសមាហរណកម្មកាន់តែស៊ីជម្រៅបានកើតឡើងរួចហើយមែនទេ? តើ

មានបញ្ហាអ្វីបន្ថែមលើអ្វី ដែលរដ្ឋទាំងឡាយអាចនឹងលះបង់អធិបតេយ្យភាពរបស់ខ្លួន ដើម្បីគាំទ្រដល់លទ្ធិបរមានុភាព ឬ អ្វីដែលនៅសល់សម្រាប់សហភាពអឺរ៉ុបបានត្រឹមតែបន្ថែមសមាជិកថ្មី?

អំណះអំណាង ១

វឌ្ឍនភាពនៃដំណើរការសមាហរណកម្មសហភាពអឺរ៉ុបបានចប់សព្វគ្រប់ហើយ

បញ្ហាជាមួយនឹងសំណើរដ្ឋធម្មនុញ្ញ និងសន្ធិសញ្ញាថ្មី លើស្បោន បង្ហាញថាពិតជាមានឧបសគ្គដ៏លំបាកពិតមែន។

ការបដិសេធរដ្ឋធម្មនុញ្ញអឺរ៉ុបដែលត្រូវបានស្នើឡើងនៅក្នុងឆ្នាំ ២០០៧ និងការបដិសេធនាពេលដំបូងនូវសន្ធិសញ្ញា លើស្បោន ក្នុងឆ្នាំ ២០០៨ បង្ហាញថា មានបញ្ហាប្រឈមច្រើនកំពុងរង់ចាំ នាអនាគតខាងមុខនៅពេលនិយាយអំពីការអនុវត្តកំណែទម្រង់គោលនយោបាយសំខាន់ៗរបស់សហភាពអឺរ៉ុប។ សូម្បីតែការប៉ុនប៉ងធានាបុគ្គលសិទ្ធិនៅអឺរ៉ុបបានបង្កើតភាពចម្រូងចម្រាស។

សមាជិកមួយចំនួនតូចបានបង្កឧបសគ្គច្រើន រហូតសហភាពស្ទើរតែមិនអាចសម្រេចបានការផ្លាស់ប្តូរសំខាន់ៗ។

ការផ្លាស់ប្តូររបស់សហភាពអឺរ៉ុបសំខាន់ៗជាច្រើន រួមទាំងសន្ធិសញ្ញាអឺរ៉ុបរួម និងសន្ធិសញ្ញាទីក្រុងម៉ាស្ត្រីក បានចាប់ផ្តើមនៅពេលដែលEUមានសមាជិកត្រឹមតែ ១២ ឬ ១៥ ប្រទេស។ ឥឡូវនេះ ដោយមានសមាជិកចំនួន ២៧ ប្រទេស ការស្វែងរកកិច្ចព្រមព្រៀងក្នុងចំណោមសមាជិកទាំងអស់ នឹងមិនងាយស្រួលនោះទេ ជាពិសេស លើបញ្ហាដែលទាមទារការយល់ព្រមជាឯកច្ឆន្ទ។

មតិសាធារណៈនៅមានមន្ទិលសង្ស័យចំពោះការរួមបញ្ចូលសមាជិកបន្ថែមទៀត។

«Euroskeptics» ដែលអាចមានន័យជាភាសាខ្មែរថា «អឺរ៉ូសង្កានិយម»[៣០] ដូចដែលពួកគេត្រូវបានគេហៅ គឺជារឿងធម្មតាកាន់តែខ្លាំងឡើងនៅអឺរ៉ុប ហើយបច្ចុប្បន្ននេះ មានឥទ្ធិពលកាន់តែខ្លាំង នៅក្នុងសភាជាតិនៅរដ្ឋសមាជិកមួយចំនួន។ ខណៈដែលការគាំទ្រសាធារណៈអាចនឹងមិនមានឥទ្ធិពលដោយផ្ទាល់ដល់ គោលនយោបាយសហភាពអឺរ៉ុប សាធារណជនអាចចាប់ផ្តើមបោះឆ្នោតជ្រើសរើសមេដឹកនាំនិងគណបក្សនយោបាយដែលនឹងបញ្ឈប់សមាហរណកម្មសហភាពអឺរ៉ុប (អាចនឹងប្រឆាំងការពង្រីកសមាជិកភាពផងដែរ) ដូចជនជាតិអង់គ្លេសបានធ្វើ ក្នុងប្រជាមតិ នៅឆ្នាំ ២០១៦ ។

អំណះអំណាង ២

ដំណើរការសមាហរណកម្មសហភាពអឺរ៉ុបនឹងបន្តទៅជាមុន

ឧបសគ្គទាំងឡាយធ្លាប់ត្រូវបានជម្នះក្នុងអតីតកាលរួចមកហើយ។

អ្នកសង្កេតការណ៍តិចណាស់ដែលបានគិតថា សហភាពអឺរ៉ុបទទួលបានជោគជ័យក្នុងការដាក់អោយប្រើប្រាស់ប្រាក់អឺរ៉ូ ប៉ុន្តែ រហូតមកដល់ថ្ងៃនេះ វាបានជោគជ័យខ្លាំងក្លា រហូតក្លាយជារូបិយប័ណ្ណសកលមួយ។ មិនយូរប៉ុន្មានក្រោយបរាជ័យនៃសន្ធិសញ្ញាលើស្បោននៅក្នុងប្រទេសអៀរឡង់ កិច្ចព្រមព្រៀងថ្មីមួយត្រូវបានសម្រេចឡើងដើម្បីអនុញ្ញាតអោយមានការបោះឆ្នោតជាលើកទីពីរ។ រដ្ឋមន្ត្រីEUមានវិន័យខ្ជាប់ខ្ជួន និងប្រកប

[៣០] អឺរ៉ូសង្កានិយម មកពីពាក្យ អឺរ៉ូ(អឺរ៉ុប) ផ្សំនឹងពាក្យ សង្កា(សេចក្តីសង្ស័យ ឬខ្លាចក្រែង ឬប្រុងប្រយ័ត្នខ្លាចខុសទាស់)

ដោយការច្នៃប្រឌិត ក្នុងការព្យាយាមធ្វើអោយដំណើរការសមាហរណកម្មកាន់តែស៊ីជម្រៅ។ ករណីដូចគ្នាអាចនឹងចំពោះការចរចាសម្រាប់ការចាកចេញរបស់អង់គ្លេស (Brexit)។

កត្តាខាងក្រៅនឹងជំរុញអោយមានសមាហរណកម្មកាន់តែស៊ីជម្រៅ។

ជាមួយនឹងបរាជ័យនៃការចរចាជុំដូហានៃអង្គការពាណិជ្ជកម្មពិភពលោក(WTO) និងភាពតានតឹងជាមួយសហរដ្ឋអាមេរិកថា តើកងកម្លាំងអង្គការណាតូគួរតែត្រូវបានពង្រាយ នៅពេលណា និងនៅទីតាំងណា សហភាពអឺរ៉ុបមានការលើកទឹកចិត្តដ៏រឹងមាំ ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងចំណោមរដ្ឋសមាជិករបស់ខ្លួន។ ឥឡូវនេះ ពួកគេដឹងថាខ្លួនមិនអាចពឹងផ្អែកទាំងស្រុងតែលើអង្គការWTO ដើម្បីធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មបន្ថែមទៀត ឬពឹងលើភាពជាអ្នកដឹកនាំយោធារបស់សហរដ្ឋអាមេរិកបានទៀតទេ។

សហភាពអឺរ៉ុបមានភាពបត់បែនគ្រប់គ្រាន់ដើម្បីដោះស្រាយជាមួយនឹងសមាជិកក្នុងចំនួនច្រើន។

ចុងភៅដ៏ចំណាននៅក្នុងផ្ទះបាយជាច្រើនមិនចង់អោយបបរគ្រឿងរបស់ខ្លួនផ្ទុមនោះទេ។ សហភាពអឺរ៉ុបបាន និងនៅតែក្សាភាពបត់បែនចំពោះរបៀបដែលរដ្ឋជាសមាជិកទាំងឡាយឆ្លើយតបចំពោះការពង្រឹងកិច្ចសហប្រតិបត្តិការ។ ប្រាក់អឺរ៉ូ គឺជាឧទាហរណ៍ដ៏ល្អឥតខ្ចោះ មិនមែនសមាជិកទាំងអស់ត្រូវឬអាចប្រើប្រាស់ប្រាក់អឺរ៉ូនោះទេ រដ្ឋខ្លះមិនប្រើវាបានដោយសារតម្រូវការសេដ្ឋកិច្ច ប៉ុន្តែខ្លះទៀតដោយសារជម្រើសផ្ទាល់ខ្លួន (ដូចជាចក្រភពអង់គ្លេសមុនពេលចាកចេញ)។ ដូច្នេះ សមាហរណកម្មបន្ថែមទៀតមិនតម្រូវអោយមានការអនុម័តជាឯកច្ឆ័ន្ទលើគោលនយោបាយទាំងអស់ទេ។

សំណួរ

- តើសហភាពអឺរ៉ុបនឹងបែងចែកទៅវិស័យបញ្ហាថ្មី ឬផ្តោតតែតែលើការពង្រីកសមាជិកថ្មី ក្នុងពេលអនាគតដ៏ខ្លីខាងមុខ? តើមានដែនកំណត់ភូមិសាស្ត្រធម្មជាតិសម្រាប់ព្រំប្រទល់នៃសហភាពអឺរ៉ុបដែរឬទេ? តើការចាកចេញដ៏មានសក្តានុពលរបស់ចក្រភពអង់គ្លេសនឹងជះឥទ្ធិពលលើអនាគតរបស់វាយ៉ាងណា?
- តើសហភាពអឺរ៉ុបអាចបំបែកជាពីរថ្នាក់ដែរឬទេ៖ រដ្ឋអ្នកមាននៅអឺរ៉ុបខាងលិច និងរដ្ឋក្រីក្រនៅអឺរ៉ុបខាងកើត? តើសហភាពអឺរ៉ុបអាចនឹងមានសារៈសំខាន់ផ្នែកនយោបាយនិងសេដ្ឋកិច្ច ដែរឬទេ ប្រសិនបើមានតែរដ្ឋខ្លះតែប៉ុណ្ណោះដែលសហការលើបញ្ហាមួយចំនួន? ដំណោះស្រាយដូចការចាយវាយប្រាក់អឺរ៉ូអាចដំណើរការបានដែរឬទេ នៅក្នុងវិស័យគោលនយោបាយផ្សេងទៀត?
- តើមុខងារអ្វីផ្សេងទៀតដែលសហភាពអឺរ៉ុបអាចព្យាយាមអនុវត្ត? តើការពង្រឹងកិច្ចសហប្រតិបត្តិការយោធា និងការសម្របសម្រួលថវិកា អាចមានលទ្ធភាពទទួលជោគជ័យកម្រិតណា? តើការបង្កើនកិច្ចសហប្រតិបត្តិការយោធាត្រូវនឹងការប្តេជ្ញាចិត្តរបស់រដ្ឋសមាជិកEUចំពោះអង្គការណាតូ យ៉ាងដូចម្តេច?

និស្សិតអាចសាកល្បងអានឯកសារខាងក្រោមបន្ថែមទៀត ដើម្បីជាគ្រឹះក្នុងការឆ្លើយសំណួរទាំងអស់ខាងលើ ៖

- Kahanec, Martin, and Klaus F. Zimmermann, eds. Labor Migration, EU Enlargement, and the Great Recession. Springer, 2016.
- Schimmelfennig, Frank. The Politics of European Union Enlargement: Theoretical Approaches. Routledge, 2005.
- Sjursen, Helene. Questioning EU Enlargement. Routledge, 2006.
- Szcerbiak, Aleks, and Paul Taggart, eds. EU Enlargement and Referendums. Routledge, 2013.

ឯកសារគួរអានបន្ថែម

- Dinan, Desmond, Neill Nugent, and William E. Paterson. *The European Union in Crisis.* Palgrave, 2017.
- Hanson, Elizabeth C. *The Information Revolution in World Politics.* Rowman & Littlefield, 2008.
- Moravcsik, Andrew. *The Choice for Europe: Social Purpose and State Power from Messina to Maastricht.* Cornell, 1998.
- Pollack, Mark A. *The Engines of Integration: Delegation, Agency, and Agenda Setting in the European Union.* Oxford, 2003.
- Ragnedda, Massimo, and Glenn W. Muschert, eds. *The Digital Divide: The Internet and Social Inequality in International Perspective.* Routledge, 2015.

មេរៀនទី ១១ ៖ បរិស្ថាន និងប្រជាជន

រូបថត ពោងចក្រថាមពលខ្យល់និងនុយក្លែអ៊ែរ ចក្រភពអង់គ្លេស ពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៩៨០ ។

វត្ថុបំណងមេរៀន

១១.១ ចូរបង្ហាញពីបញ្ហាសកម្មភាពរួម ដែលសហគមន៍អន្តរជាតិកំពុងប្រឈមមុខ ដោយផ្តោតលើបញ្ហាបរិស្ថានសកលមួយ។

១១.២ ចូរវាយតម្លៃឧបសគ្គនានាដែលរារាំងកិច្ចព្រមព្រៀងអន្តរជាតិមិនអោយទទួលបានជោគជ័យក្នុងការដោះស្រាយបញ្ហាកំណើនកម្តៅសកល។

១១.៣ ចូរពិពណ៌នាស្ថានភាពចំនួនបី ដែលតម្រូវការធនធានធម្មជាតិអាចបង្កជាជម្លោះអន្តរជាតិ។

១១.៤ ចូរពន្យល់ថាតើអ្វីជា**អន្តរកាលប្រជាសាស្ត្រ** និងមូលហេតុដែលរដ្ឋខ្លះងាយនឹងរងគ្រោះពីកំណើនប្រជាជនយ៉ាងឆាប់រហ័ស។

១១.១. ការពឹងអាស្រ័យគ្នា និងបរិស្ថាន

១១.១ ចូរបង្ហាញពីបញ្ហាសកម្មភាពរួម ដែលសហគមន៍អន្តរជាតិកំពុងប្រឈមមុខ ដោយផ្តោតលើបញ្ហាបរិស្ថានសកលមួយ។

ការគំរាមកំហែងជាសកលចំពោះបរិស្ថានធម្មជាតិគឺជាប្រភពនៃការពឹងផ្អែកគ្នាទៅវិញទៅមក។ សកម្មភាពរបស់រដ្ឋទាក់ទងនឹងការបំពុលការអភិរក្ស និងធនធានធម្មជាតិ តែងតែប៉ះពាល់ដល់រដ្ឋដទៃទៀត។ ដោយសារឥទ្ធិពលបរិស្ថានមានទំនោរសាយភាយ និងយូរអង្វែង ដោយសារឥទ្ធិពលបែបនេះរីករាលដាលយ៉ាងងាយពីទីតាំងមួយទៅកន្លែងមួយទៀត នយោបាយបរិស្ថានអន្តរជាតិបង្កើតឲ្យមានផលលំបាកពីបញ្ហាផលប្រយោជន៍រួម (សូមមើលមេរៀនទី ១)។ បរិស្ថានធម្មជាតិប្រកបដោយនិរន្តរភាព គឺជាផលប្រយោជន៍រួម ហើយរដ្ឋចរចាអំពីរបៀបចែករម្លែកការចំណាយក្នុងការផ្តល់ផលប្រយោជន៍ទាំងនោះ។ ទិដ្ឋភាពបច្ចេកទេស វិទ្យាសាស្ត្រ និងសីលធម៌នៃការគ្រប់គ្រងបរិស្ថានគឺស្មុគស្មាញ ប៉ុន្តែ លក្ខណៈជាមូលដ្ឋាននៃផលប្រយោជន៍របស់រដ្ឋមិនមានលក្ខណៈស្មុគស្មាញនោះទេ។ បញ្ហាផលប្រយោជន៍រួមបានកើតឡើងនៅក្នុងបញ្ហាវិស័យនីមួយៗទាក់ទងនឹងបរិស្ថាន ធនធាន(ធម្មជាតិ) និងចំនួនប្រជាជន។

ជាឧទាហរណ៍ ដល់ផលធំៗរបស់ពិភពលោកនៅក្នុងដែនទឹកអន្តរជាតិ មិនមែនជាកម្មសិទ្ធិរបស់រដ្ឋណាមួយឡើយ។ ពួកគេគឺជាផលប្រយោជន៍រួម។ រដ្ឋពឹងលើការនេសាទផ្សេងៗ ត្រូវតែសហការគ្នា (មួយផ្នែកដោយធ្វើនិយតកម្មតួអង្គមិនមែនរដ្ឋ ដូចជាសាជីវកម្មពហុជាតិ [MNCs]) ដើម្បីជៀសវាងការបំផ្លាញស្តុកមច្ឆាអន្តរជាតិ។ ប្រសិនបើរដ្ឋជាច្រើនមិនអាចសហការគ្នាបាន នោះចំនួនត្រីនឹងថយចុះ ហើយទិន្នផលនេសាទរបស់អ្នកនេសាទគ្រប់គ្នានឹងធ្លាក់ចុះ។ ជាការពិត នៅចន្លោះឆ្នាំ ១៩៩៧-២០០៧ ទិន្នផលនេសាទនៅទូទាំងពិភពលោកបានធ្លាក់ចុះយ៉ាងខ្លាំង។ មានការប៉ាន់ប្រមាណថា ៩០ ភាគរយនៃស្តុកមច្ឆាអន្តរជាតិធំៗបានបាត់បង់។ អ្នកនេសាទទាំងឡាយបានប្តូរទៅនេសាទប្រភេទអាហារសមុទ្រថ្មី បន្ទាប់ពីបានបាត់បង់ប្រភេទមច្ឆាពេញនិយមចាស់ៗ ប៉ុន្តែពួកគេបានបំផ្លាញមច្ឆាជាតិនិងអន្តរជាតិចំនួនមួយភាគបីនៃប្រភេទមច្ឆារួចទៅហើយ ដោយប្រភេទមច្ឆានៅសល់ត្រូវបានព្យាករណ៍ថានឹងអន្តរធាននៅត្រឹមពាក់កណ្តាលសតវត្សរ៍នេះ។ ដោយសារតែរដ្ឋនានាលើពិភពលោកមិនបានដោះស្រាយបញ្ហាផលប្រយោជន៍រួមនៃជលផលពិភពលោក ពួកគេកំពុង

ផ្តល់ប្រាក់ឧបត្ថម្ភធន ចំនួន ២០ ប៊ីលានដុល្លារ ក្នុងមួយឆ្នាំ ដល់ឧស្សាហកម្មនេសាទដែលក្សយធន នៅក្នុងប្រទេសរៀងៗខ្លួន។ កិច្ចខិតខំប្រឹងប្រែងបញ្ចប់ការឧបត្ថម្ភធនទាំងនេះត្រូវទទួលបរាជ័យក្នុងកិច្ចប្រជុំអង្គការ WTO ឆ្នាំ ២០១៧ ដែលដំរុញអោយស្នងការពាណិជ្ជកម្មរបស់សហភាពអឺរ៉ុប (EU) បង្ហាញការសោកស្តាយថា «យើងមិនអាចសូម្បីតែយល់ព្រមបញ្ឈប់ការឧបត្ថម្ភធនលើការនេសាទខុសច្បាប់ »

ការថយចុះនេះបានកើតឡើង ដោយសារតែទូកនេសាទនីមួយៗ (និងសាជីវកម្មពហុជាតិដែលជាម្ចាស់ទូកក៏ដូចជារដ្ឋកំណើតរបស់វា) ទទួលបានផលចំណេញកាន់តែច្រើនរៀងរាល់ពេលពួកគេចាប់ត្រីបានកាន់តែច្រើនដែរ។ អត្ថប្រយោជន៍របស់ត្រីនោះបានទៅទាំងស្រុងលើអ្នកចាប់វា ចំណែកការខាតបង់ជាយថាហេតុដោយសារការអស់ស្តុកមច្ឆានឹងត្រូវបានចែករំលែកដោយអ្នកនេសាទទាំងអស់នៅទីនោះ។ ប៉ុន្តែ កូតានេសាទត្រីត្រឹមត្រូវរបស់រដ្ឋត្រូវមានកម្រិតណា? គ្មានរដ្ឋាភិបាលពិភពលោកណាមួយដើម្បីសម្រេចសំណួរបែបនេះទេ ដូច្នេះរដ្ឋទាំងឡាយត្រូវតែចូលទៅក្នុងការចរចាពហុភាគី កិច្ចព្រមព្រៀង និងរបប។ កិច្ចខិតខំប្រឹងប្រែងបែបនេះ មិនត្រឹមតែបង្កើតវេទិកាថ្មីសម្រាប់មុខងារនិយមនិងសមាហរណកម្មអន្តរជាតិប៉ុណ្ណោះទេ ប៉ុន្តែក៏មានសក្តានុពលថ្មីសម្រាប់ជម្លោះនិងឧទាហរណ៍នៃល្បែងទ្វេគ្រោះអ្នកទោសផងដែរ។

នៅឆ្នាំ ១៩៩៩ កិច្ចព្រមព្រៀងដែលឧបត្ថម្ភដោយអង្គការសហប្រជាជាតិក្នុងចំណោមរដ្ឋនេសាទសំខាន់ៗទាំងអស់របស់ពិភពលោកបានកំណត់គោលដៅ ដើម្បីកាត់បន្ថយចំនួនលើសចំណុះនៃទូកនេសាទ។ (ទូកនេសាទចំនួន ៤ លានគ្រឿងប្រតិបត្តិការនៅទូទាំងពិភពលោក ដែលក្នុងនោះ ៤០០០០ ជាកប៉ាល់ចំណុះធំជាង ១០០ តោន។) ប្រទេសដែលចូលរួមនឹងត្រូវកម្រិតចំនួនកងនាវានេសាទរបស់ខ្លួនហើយបន្ទាប់មកនឹងត្រូវកាត់បន្ថយបន្តិចម្តងៗ ខណៈពេលដែលកាត់បន្ថយការឧបត្ថម្ភធន។ ដូច្នេះ ការរងគ្រោះដែកាពអត់ការងារធ្វើនិងការកែតម្រូវសេដ្ឋកិច្ចគួរតែត្រូវបានចែករំលែក។ ទោះជាយ៉ាងណាក៏ដោយ កិច្ចព្រមព្រៀងមានលក្ខណៈស្មុគ្រចិត្ត។ ការអនុវត្តរបស់វាអាចពន្យារពេល ហើយឥទ្ធិពលរបស់វាចំពោះជលផលដែលកំពុងថយចុះ ប្រហែលជាមានទំហំតិចតួចពេក និងកើតឡើងយឺតបន្តិចហើយ។

បញ្ហាផលប្រយោជន៍រួមប្រភេទនេះត្រូវបានគេហៅថា **សោកនាដកម្មសមូហភាព**(tragedy of the commons)។ កាលពីប៉ុន្មានសតវត្សរ៍មុន ប្រជានុរាស្ត្រទូទៅបានប្រើប្រាស់វាលស្មៅរួមគ្នា នៅចក្រភពអង់គ្លេស។ ដូចនឹងវិស័យជលផលដែរ ប្រសិនបើមនុស្សចិញ្ចឹមចៀមច្រើនពេក សត្វទាំងនោះនឹងស៊ីស្មៅអស់ច្រើនពេក រហូតស្មៅមិនអាចលូតលាស់វិញទាន់។ ប៉ុន្តែ រៀងរាល់ពេលដែលចិញ្ចឹមចៀមថែមមួយក្បាលទៀត ម្ចាស់ចៀមទទួលបានផលចំណេញកាន់តែច្រើន។ ចក្រភពអង់គ្លេសបានដោះស្រាយបញ្ហាដោយការខ័ណ្ឌចែកដីនិង**ព័ទ្ធរបង**(enclosure) (ការបំបែកក្បាលដីចែកអោយគ្រួសារនីមួយៗគ្រប់គ្រងដោយឯកជនដោយសង្ឃឹមថាពួកគេនឹងត្រូវលើកទឹកចិត្តក្នុងការគ្រប់គ្រងធនធានប្រកបដោយការទទួលខុសត្រូវ)។ រដ្ឋនានាលើពិភពលោកបានអនុវត្តវិធីសាស្ត្រស្រដៀងគ្នាសម្រាប់ជលផលតាមឆ្នេរសមុទ្រ ដោយខ័ណ្ឌចែកដែនទឹកអោយស្ថិតក្រោមការគ្រប់គ្រងមច្ឆាជាតិរបស់រដ្ឋនីមួយៗ (សូមមើលមេរៀនទី ៥)។ *សាធារណសកល*(global commons)សំដៅលើការចែករម្លែកភពផែនដី ដូចជា មហាសមុទ្រ និងលំហអាកាស។

ដូចនៅក្នុងវិស័យផ្សេងទៀតនៃសេដ្ឋកិច្ចនយោបាយអន្តរជាតិ ដំណោះស្រាយបញ្ហាផលប្រយោជន៍រួមបរិស្ថានត្រូវផ្អែកលើការសម្រេចបាននូវអត្ថប្រយោជន៍រួម ត្រូវពឹងផ្អែកលើការជំនះលើជម្លោះផលប្រយោជន៍។ *របប*(regimes)គឺជាផ្នែកដ៏សំខាន់នៃដំណោះស្រាយ (សូមមើលមេរៀនទី ៣) ដោយផ្តល់វិធានច្បាប់ដោយ

ផ្អែកលើគោលការណ៍បដិការ ដើម្បីគ្រប់គ្រងការចរចាថាតើនរណាទទួលបានអត្ថប្រយោជន៍ និងនរណាត្រូវទទួលបន្ទុកចំណាយសម្រាប់ការពារបរិស្ថាន។ អង្គការអន្តរជាតិ(IOs)បែបមុខងារនិយម មានជំនាញផ្នែកបច្ចេកទេសនិងការគ្រប់គ្រងបរិស្ថាន។

អង្គការអន្តរជាតិកាន់តែច្រើនឡើងប្រតិបត្តិការត្រួតស៊ីគ្នា ជាមួយនឹងសហគមន៍ទូលំទូលាយនៃបណ្តាអ្នកជំនាញមកពីរដ្ឋផ្សេងៗ ដែលរៀបចំរចនាសម្ព័ន្ធតាមរបៀបដែលរដ្ឋគ្រប់គ្រងបញ្ហាបរិស្ថាន។ ទាំងនេះត្រូវបានគេហៅថា *សហគមន៍អេពីស្តេមីក* ([epistemic] សហគមន៍ផ្អែកលើចំណេះដឹង)។ ជាឧទាហរណ៍ សហគមន៍អន្តរជាតិនៃអ្នកជំនាញ និងអ្នកបង្កើតគោលនយោបាយ ដែលពាក់ព័ន្ធនឹងការបំពុលនៅសមុទ្រមេឌីទែរ៉ាណេ គឺជាសហគមន៍*អេពីស្តេមីក* ។

ក្នុងគោលនយោបាយបរិស្ថានសកល ការគ្រប់គ្រងបញ្ហាផលប្រយោជន៍រួមមានការពិបាកខ្លាំងណាស់ដោយសារចំនួនតួអង្គច្រើន។ ផលប្រយោជន៍រួមមានភាពងាយស្រួលក្នុងការបែងចែកក្នុងចំណោមក្រុមតូចៗដែលសកម្មភាពបុគ្គលនីមួយៗមានផលប៉ះពាល់ច្រើនជាងលើទិដ្ឋភាពឬលទ្ធផលរួម ហើយប្រសិនបើនរណាម្នាក់*ជិះសេះលែងដៃ* មិនចូលរួមធ្វើ នឹងត្រូវគេកត់សម្គាល់ឃើញយ៉ាងងាយស្រួល។ ផ្ទុយទៅវិញ គឺជាការពិតជាមួយនឹងបរិស្ថាន។ សកម្មភាពរបស់រដ្ឋ ជិត ២០០ (ទោះរដ្ឋខ្លះច្រើនជាងរដ្ឋផ្សេងទៀត) រួមគ្នាបណ្តាលអោយមានផលប៉ះពាល់ដល់បរិស្ថានដោយប្រយោលប៉ុន្តែធ្ងន់ធ្ងរ នៅទូទាំងពិភពលោក។

ចំណាប់អារម្មណ៍លើបរិស្ថានបានកើនឡើងជាលំដាប់ ចាប់តាំងពី**ទិវាផែនដី**ដំបូងដែលរៀបចំដោយសកម្មជនបរិស្ថាន ក្នុងឆ្នាំ១៩៧០។ សន្និសីទអង្គការសហប្រជាជាតិលើកទីមួយស្តីពីបរិស្ថានអន្តរជាតិបានធ្វើឡើងនៅទីក្រុងស្តុកខម (Stockholm) ប្រទេសស៊ុយអែត ក្នុងឆ្នាំ ១៩៧២។ វាបានអនុម័តគោលការណ៍ទូទៅដែលថា សកម្មភាពរបស់រដ្ឋមួយមិនគួរបង្កផលប៉ះពាល់បរិស្ថានរដ្ឋដទៃឡើយ ជាឧទាហរណ៍ និងលើកកម្ពស់ការយល់ដឹងអំពីទិដ្ឋភាពអន្តរជាតិនៃការខូចខាតបរិស្ថាន។ សន្និសិទទីពីរត្រូវបានប្រារព្ធឡើងដោយមិនសូវមានការផ្សព្វផ្សាយជាសាធារណៈ នៅឆ្នាំ ១៩៨២ នៅទីក្រុងណៃរ៉ូប៊ីនៃប្រទេសកេនយ៉ា (ទីស្នាក់ការកណ្តាលនៃកម្មវិធីបរិស្ថានរបស់អង្គការសហប្រជាជាតិ[UNEP])។ កិច្ចប្រជុំកំពូលស្តីពីភពផែនដីឆ្នាំ ១៩៩២ ដែលធំជាងនិងមានមហិច្ឆតាជាង នៅទីក្រុងរីយ៉ូដឺជេនេរ៉ូ (Rio de Janeiro) ប្រទេសប្រេស៊ីលបានប្រមូលផ្តុំមេដឹកនាំរដ្ឋជាង ១០០ អោយចូលរួម។

រូបថត សមាជិកនៃកងទ័ពជើងទឹករបស់ប្រទេសថៃ ចុះឆែករោ ទូកនេសាទខុសច្បាប់
មានរឿងគួរអោយសង្ស័យ

ការថយចុះដល់ផលសកល គឺជាឧទាហរណ៍ដ៏ល្អមួយនៃសោកនាដកម្មរួម ដែលផលប្រយោជន៍រួមឬសាធារណៈ(ក្នុងករណីនេះ ត្រី) ត្រូវបាននេសាទហួសកម្រិត ដែលធ្វើអោយមនុស្សគ្រប់រូបខាតបង់។ កិច្ចព្រមព្រៀងនានាអាចត្រូវបានធ្វើឡើង ដើម្បីបែងចែកផលប្រយោជន៍សាធារណៈទៅកាន់ប្រទេសផ្សេងៗគ្នា ប៉ុន្តែការអនុវត្តកិច្ចព្រមព្រៀងទាំងនោះត្រូវតែពង្រឹង បើមិនដូច្នោះទេ សោកនាដកម្មរួមនឹងលេចឡើងម្តងទៀត។ នៅទីនេះ សមាជិកនៃកងទ័ពជើងទឹករបស់ប្រទេសថៃ ចុះឆែករោ ទូកនេសាទក្រែងលោមានការនេសាទខុសច្បាប់ នៅឆ្នាំ ២០១៦ ។

១១.១.១. ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព

ប្រធានបទសំខាន់នៃសន្និសីទទាំងនេះ គឺការអភិវឌ្ឍន៍ប្រកបដោយ*ចីរភាព*។ វាសំដៅលើកំណើនសេដ្ឋកិច្ច ដែលមិនធ្វើអោយបាត់បង់ធនធាន និងបំផ្លាញប្រព័ន្ធអេកូឡូស៊ីយ៉ាងឆាប់រហ័ស ដែលមូលដ្ឋាននៃកំណើនសេដ្ឋកិច្ចនោះត្រូវបានបំផ្លាញដោយដំណើរការអភិវឌ្ឍផ្ទាល់។ គំនិតនេះត្រូវអនុវត្តទាំងតំបន់ឧស្សាហកម្ម និងអឌ្ឍគោលខាងត្បូង។

កិច្ចប្រជុំកំពូលផែនដីឆ្នាំ ១៩៩២ បានបង្កើតគណៈកម្មការស្តីពីការអភិវឌ្ឍន៍ប្រកបដោយចីរភាព ដែលត្រួតពិនិត្យការអនុលោមតាមច្បាប់របស់រដ្ឋដែលប្តេជ្ញាធ្វើនៅឯកិច្ចប្រជុំកំពូលផែនដី និងស្តាប់ភស្តុតាងពីអង្គការមិនមែនរដ្ឋាភិបាលបរិស្ថាន(NGOs) ដូចជា អង្គការបរិស្ថាន Greenpeace។ នៅឆ្នាំ ២០១៣ វេទិកានយោបាយកម្រិតខ្ពស់ស្តីពីការអភិវឌ្ឍន៍ប្រកបដោយចីរភាពបានជំនួសគណៈកម្មការ។ ប៉ុន្តែ វេទិកាថ្មីនេះក៏ដូចជាបុព្វស្ថាប័នដែរ ខ្វះអំណាចសម្រាប់ពង្រឹងការអនុវត្តលើរដ្ឋាភិបាលជាតិ ដែលជាថ្មីម្តងទៀតឆ្លុះបញ្ចាំងពីភាពលេចធ្លោនៃអធិបតេយ្យភាពរបស់រដ្ឋលើសិទ្ធិអំណាចបរមានុភាព(supranational) (សូមមើលមេរៀនទី ១០)។ សមាជិកអង្គការសហប្រជាជាតិទាំងអស់អាចចូលរួមនៅក្នុងវេទិកានេះ។ សមត្ថភាពរបស់វេទិកាក្នុងការត្រួតពិនិត្យនិងផ្សព្វផ្សាយសកម្មភាពរបស់រដ្ឋ ត្រូវបានគេសន្មត់ថាធ្វើឡើងដើម្បីបំបាក់ទឹកចិត្តរដ្ឋកុំអោយក្លែងបន្លំ ឬជិះសេះលែងដៃ។ ប៉ុន្តែ វឌ្ឍនភាពមានភាពយឺតយ៉ាវ។

ប្រទេសចិន និងប្រទេសកំពុងអភិវឌ្ឍន៍ផ្សេងទៀតនៅអាស៊ីស្ថិតនៅចំចំណុចកណ្តាលនៃការជជែកពិភាក្សាអំពីការអភិវឌ្ឍន៍ប្រកបដោយចីរភាព។ ក្នុងការជំរុញកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស ប្រទេសទាំងនេះបាននិងកំពុងបង្កការបំពុលធ្ងន់ធ្ងរនិងបញ្ហាបរិស្ថានផ្សេងទៀត។ នៅដើមឆ្នាំ ២០១៣ ផ្សែងអ័ព្ទនៅទីក្រុងប៉េកាំងបានកើនលើសកម្រិតគ្រោះថ្នាក់ ហើយអ្នកក្រុងដែលចេញក្រៅផ្ទះ ត្រូវរងគ្រោះពីជំងឺរលាកសួត និងក្រហាយភ្នែក។ ដោយសារតែទំហំរបស់ប្រទេសចិន ភាពជោគជ័យណាមួយក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់គេទន្ទឹមនឹងបស្ចឹមប្រទេសឧស្សាហកម្ម (ឧទាហរណ៍ ជាមួយនឹងភាពជាម្ចាស់រថយន្តយ៉ាងច្រើនសន្ធឹកសន្ធាប់) អាចបង្កើតការភ្ញាក់ផ្អើលដល់បរិស្ថានសកល។ ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ខណៈពេលដែលប្រទេសចិនបាននិងកំពុងរុករកវត្ថុធាតុដើមពីគ្រប់ច្រកល្ហកនៃពិភពលោក ប្រទេសនេះក៏បានក្លាយជាអ្នកនាំមុខគេក្នុងការអភិវឌ្ឍន៍បច្ចេកវិទ្យាបៃតងផងដែរ។ ជាឧទាហរណ៍ ប្រទេសចិនឥឡូវនេះគ្រប់គ្រងចំណែកធំជាងគេក្នុងការផលិតបន្ទះស្រូបពន្លឺព្រះអាទិត្យ។ ហើយក្រោយឆ្នាំ២០១៣ វិបត្តិបំពុលខ្យល់ រដ្ឋាភិបាលចិនអនុវត្តការតឹងតែងខ្លាំងចំពោះសកម្មភាពបំពុលនានា។ (សហរដ្ឋអាមេរិក ក្នុងឆ្នាំ ២០១៤ បានប្តេជ្ញាថានឹងសហការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់។) ប៉ុន្តែ កំណើនរបស់ប្រទេសចិននៅតែត្រូវបានជម្រុញថាមពល មួយផ្នែកធំ ដោយរោងចក្រថាមពលដែលកខ្វក់ និងដុតធ្យូងថ្ម។

១១.២. ការគ្រប់គ្រងបរិស្ថាន

១១.២ ចូរវាយតម្លៃឧបសគ្គនានាដែលរារាំងកិច្ចព្រមព្រៀងអន្តរជាតិមិនអោយទទួលបានជោគជ័យក្នុងការដោះស្រាយបញ្ហាកំណើនកម្តៅសកល។


បញ្ហាបរិស្ថានសកលភាគច្រើនបំផុត គឺជាបញ្ហាដែលពាក់ព័ន្ធនឹងផលប្រយោជន៍រួមសម្រាប់រដ្ឋនិងប្រជាជនទាំងអស់ក្នុងពិភពលោក។

១១.២.១. បរិយាកាស

ការថែរក្សាសុខភាពបរិយាកាសផែនដីគឺជាអត្ថប្រយោជន៍ ដែលជះឥទ្ធិពលរួមលើមនុស្សទូទាំងពិភពលោក ដោយមិនគិតថារដ្ឋពួកគេបានបង្កបញ្ហា ឬបានចូលរួមចំណែកក្នុងដំណោះស្រាយក៏ដោយ។ បញ្ហាបរិយាកាសពីរបានក្លាយជាបញ្ហាអន្តរជាតិសំខាន់ គឺកំណើនកម្តៅសកល និងការសឹករេចរឹលនៃស្រទាប់អូហ្សូន។

ក្រាហ្វិកស្តីពី សីតុណ្ហភាពជាមធ្យមពិភពលោក ចន្លោះឆ្នាំ ១៨៨០-២០១៩

ប្រភព៖ NASA Goddard Institute for Space Studies.



សម្គាល់៖ ការកើនឡើងនេះបានចាប់ផ្តើមនៅពាក់កណ្តាលសតវត្សទី ១៩ នៅពេលដែលការច្នៃប្រឌិតឧស្សាហកម្ម ដូចជាការប្រើប្រាស់យ៉ាងទូលំទូលាយនៃធ្យូងថ្ម ប្រេង និងឧស្ម័ន ដើម្បីផ្តល់ថាមពលដល់ទីក្រុង និងរថយន្តរបស់យើង បានផ្លាស់ប្តូររបៀបរស់នៅរបស់យើង។ ទន្ទឹមនឹងនេះ ព្រៃឈើត្រូវបានកាប់ឆ្ការ ដើម្បីជាផ្លូវសម្រាប់ទីក្រុង និងកសិដ្ឋានចិញ្ចឹមប្រជាជនពិភពលោកដែលកំពុងកើនឡើងយ៉ាងឆាប់រហ័ស។ ចាប់តាំងពីពេលនោះមក ឧស្សាហកម្ម កសិកម្ម និងការដឹកជញ្ជូនបានបន្តបង្កើនកម្រិតនៃឧស្ម័នផ្ទះកញ្ចក់នៅក្នុងបរិយាកាស ដែលបណ្តាលឱ្យផែនដីឡើងកំដៅក្នុងអត្រាដែលមិនធ្លាប់មានក្នុងប្រវត្តិសាស្ត្រថ្មីៗនេះ។

កំណើនកម្តៅសកល

ការប្រែប្រួលអាកាសធាតុសកល ឬ ការឡើងកំដៅផែនដី(កំណើនកម្តៅសកល) គឺជាការកើនឡើងក្នុងរយៈពេលវែងនៃសីតុណ្ហភាពសកលលោកជាមធ្យម។ ភស្តុតាងកាន់តែរឹងមាំនិងគួរអោយទាក់ទាញបានបង្ហាញថា ការឡើងកំដៅផែនដីគឺជាបញ្ហាយ៉ាងពិតប្រាកដ ដែលមួយផ្នែកធំបណ្តាលមកពីការបញ្ចេញកាបូនឌីអុកស៊ីត និងឧស្ម័នផ្ទះកញ្ចក់ផ្សេងទៀត ហើយវានឹងកាន់តែធ្ងន់ធ្ងរទៅៗ នាពេលអនាគត។ បញ្ហានៃការ

ឡើងកំដៅផែនដីបានកើនឡើងខ្ពស់ក្នុងរបៀបវារៈនយោបាយក្នុងទសវត្សរ៍កន្លងមក ដោយសារតែការរលាយទឹកកកអាកទិកដ៏ធំធេង អាកាសធាតុចុះត្រជាក់ខ្លាំង និងខ្យល់ព្យុះបំផ្លិចបំផ្លាញ រួមទាំងខ្យល់ព្យុះកាទ្រីណា (Katrina) នៅក្រុង New Orleans ក្នុងឆ្នាំ ២០០៥ និង ព្យុះសែនឌី (Sandy) ក្នុងទីក្រុង New York និង New Jersey ក្នុងឆ្នាំ ២០១២។ ជាអកុសល សហគមន៍អន្តរជាតិ ទទួលបានជោគជ័យតិចតួចបំផុតក្នុងការដោះស្រាយបញ្ហានេះ។

ក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ខាងមុខនេះ បើយោងតាមការប៉ាន់ស្មានភាគច្រើន សីតុណ្ហភាពសកលអាចនឹងកើនឡើងចន្លោះពី ៣ ទៅ ១០ អង្សាហ្វារិនហៃ (F) ប្រសិនបើគ្មានចំណាត់ការទប់ស្កាត់។ ប្រហែលជាក្នុងរយៈពេលពីរបីទសវត្សរ៍ខាងមុខ ផ្ទាំងទឹកកកនៅតំបន់ប៉ូលនឹងចាប់ផ្តើមរលាយ ហើយបណ្តាលអោយកម្រិតទឹកសមុទ្រកើនឡើងដល់ទៅពីរបីហ្វីត។ ការសិក្សាក្នុងឆ្នាំ ២០១២ បានបញ្ជាក់ថា និន្នាការឡើងកំដៅផែនដីកំពុងកើនឡើងលឿនជាងអ្វីដែលត្រូវបានគេមើលឃើញថាជាសេណារីយ៉ូដែលអាក្រក់បំផុត។ កំឡុងពេលដប់ឆ្នាំដ៏ក្តៅបំផុតនៅក្នុងកំណត់ត្រា បានកើតឡើងរួចមកហើយ ចាប់តាំងពីឆ្នាំ ១៩៩៨ ដែលជាកំឡុងប្រាំឆ្នាំដ៏ក្តៅបំផុតចាប់ពីឆ្នាំ ២០០០មក។ កំដៅផែនដីអាចជន់លិចទីក្រុងឆ្នេរសមុទ្រជាច្រើន និងអាចបំផ្លិចបំផ្លាញតំបន់ទំនាប ដូចជាតំបន់ឆ្នេរដែលមានប្រជាជនច្រើននៅប្រទេសបង់ក្លាដែស និងប្រទេសចិន។ ការអំពាវនាវជាបន្ទាន់អោយរួមគ្នាធ្វើសកម្មភាពដើម្បីទប់ស្កាត់ការឡើងកំដៅផែនដី ត្រូវបានស្នើឡើងពីបណ្តារដ្ឋកោះនានាក្នុងមហាសមុទ្រប៉ាស៊ីហ្វិក ដែលទំនងជានឹងរលាយបាត់ក្នុងសតវត្សរ៍ខាងមុខនេះ។ ប្រាកដណាស់ដោយឆ្លុះបញ្ចាំងពីការខ្វះជំនឿជាក់លើសកម្មភាពអន្តរជាតិ រដ្ឋម៉ាល់ឌីវដែលមាននីវ៉ូទាបបានបង្កើតមូលនិធិមួយដើម្បីទិញដីនៅក្នុងប្រទេសមួយផ្សេងទៀតដើម្បីជម្លៀសប្រជាជនរបស់ខ្លួន ប្រមាណ ៣០០ ០០០ នាក់ នៅពេលដែលទឹកដីរបស់ខ្លួនត្រូវលិចបាត់។

រូបថត *គ្រួសារចិនមួយកំពុងថតរូបជាមួយផ្ទៃរង្គអ័ព្ទគ្របដណ្តប់ទីក្រុងស៊ៀងហៃ*

គ្មាននិរន្តរភាព


ប្រទេសកំពុងអភិវឌ្ឍន៍ដូចជាប្រទេសចិនពឹងផ្អែកយ៉ាងខ្លាំងលើធ្យូងថ្ម និងបច្ចេកវិទ្យាកខ្វក់ផ្សេងទៀតសម្រាប់ថាមពលនិងវត្ថុធាតុដើមដែលពួកគេត្រូវការ។ នៅពេលដែលវាកែចម្រើនយ៉ាងឆាប់រហ័ស ប្រទេសចិនកំពុងឈ្លក់នឹងផ្ទៃរង្គបំពុលរបស់ខ្លួនផ្ទាល់។ ក្នុងឆ្នាំ ២០១៣ គុណភាពខ្យល់នៅទីក្រុងប៉េកាំងបានកើនលើសពីកម្រិតនៃការបំពុលដ៏គ្រោះថ្នាក់បំផុត ដែលនាំអោយរដ្ឋាភិបាលចិនដាក់កម្រិតយ៉ាងតឹងរ៉ឹងចំពោះការដុតឥន្ធនៈហ្វូស៊ីល។ ខណៈពេលដែលការបំពុលខ្យល់ហាក់ថយចុះ ក្រោមគោលនយោបាយថ្មីទាំងនេះ ការបំពុលយ៉ាងសំខាន់នៅតែបន្តមាន។ នៅទីនេះ គ្រួសារមួយកំពុងថតរូបជាមួយផ្ទៃរង្គអ័ព្ទគ្របដណ្តប់ទីក្រុងស៊ៀងហៃនៅផ្នែខាងក្រោយ ឆ្នាំ ២០១៨ ។

បម្រែបម្រួលអាកាសធាតុសកលបានចាប់ផ្តើមផ្លាស់ប្តូរគំរូអាកាសធាតុ នៅក្នុងតំបន់ជាច្រើន ដែលបណ្តាលអោយមានគ្រោះរាំងស្ងួត ទឹកជំនន់ អាកាសធាតុត្រជាក់កក់ និងការរំខានយ៉ាងទូលំទូលាយនៃប្រព័ន្ធអេកូធម្មជាតិ។ វាក៏អាចទៅរួចដែរដែលការប្រែប្រួលអាកាសធាតុអាចផ្តល់អត្ថប្រយោជន៍ដល់តំបន់មួយចំនួន និងធ្វើអោយកសិកម្មកាន់តែមានផលិតភាព។ ការរលាយនៃទឹកកកតំបន់ប៉ូលកំពុងបើកផ្លូវដឹកជញ្ជូនថ្មីនៅភាគខាងជើងនៃប្រទេសកាណាដា និងរុស្ស៊ី ដែលអាចកាត់បន្ថយរយៈពេលជាច្រើនសប្តាហ៍នៃការដឹកជញ្ជូនពីអឺរ៉ុបខាងជើង ឬអាមេរិកទៅកាន់អាស៊ី (សូមមើលក្រាហ្វិក ១១.១) ដែលជាការសន្សំពេលវេលានិងប្រាក់

បានយ៉ាងច្រើនសម្រាប់អាជីវកម្មសកល។ លើសពីនេះ សមុទ្រអាកទិកគឺជាស្តុកធនធានប្រេងនិងឧស្ម័នដ៏ធំដែលនឹងក្លាយជាទំនិញពាណិជ្ជកម្មបាន នៅពេលដែលទឹកកករលាយ (ហើយជាអ្វីដែលគួរអោយហួសចិត្ត គឺវារួមចំណែកដល់ការឡើងកំដៅផែនដីកាន់តែខ្លាំងឡើង)។

ក្រាហ្វិក ១១.១ សក្តានុពលនៃផ្លូវដឹកជញ្ជូនអាកទិក

ប្រភព៖ ផ្អែកលើកម្មវិធីបរិស្ថានរបស់អង្គការសហប្រជាជាតិ



កម្មវិធីបរិស្ថានរបស់អង្គការសហប្រជាជាតិ (UNEP) ដែលមានមុខងារសំខាន់ គឺត្រួតពិនិត្យលក្ខខណ្ឌបរិស្ថាន ធ្វើការជាមួយអង្គការឧតុនិយមពិភពលោក ដើម្បីវាស់ស្ទង់ការប្រែប្រួលអាកាសធាតុពិភពលោកពីមួយឆ្នាំទៅមួយឆ្នាំ។ ចាប់តាំងពីឆ្នាំ ១៩៨៩ មក អន្តររដ្ឋាភិបាលដែលឧបត្ថម្ភដោយ ក្រុមប្រឹក្សាស្តីពីការប្រែប្រួលអាកាសធាតុ (IPCC) នៃអង្គការសហប្រជាជាតិ បានបម្រើការជាវេទិកាចរចាសម្រាប់បញ្ហានេះ។ ក្នុងឆ្នាំ ២០១៣ IPCC បានបញ្ចេញរបាយការណ៍របស់អ្នកវិទ្យាសាស្ត្រជុំវិញពិភពលោក ដោយទាញសេចក្តីសន្និដ្ឋានថាការឡើងកំដៅផែនដី «មិនអាចប្រកែកបាន» បណ្តាលមកពីសកម្មភាពរបស់មនុស្ស។

គេត្រូវចំណាយច្រើនពេកក្រៃក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័ន ដែលភាគច្រើនជាកាបូនឌីអុកស៊ីតដែលបណ្តាលអោយមានការឡើងកំដៅផែនដី។ ឧស្ម័នទាំងនេះកើតឡើងពីសកម្មភាពដែលជំរុញសេដ្ឋកិច្ចឧស្សាហកម្មគ្រប់បែបយ៉ាង។ ពួកវាជាលទ្ធផលនៃការដុត*ឥន្ធនៈហ្វូស៊ីល* រួមមាន ប្រេង ធ្យូងថ្ម និងឧស្ម័នធម្មជាតិ ដើម្បីដំណើរការរថយន្ត ត្រាក់ទ័រ ចង្ក្រាន រោងចក្រជាដើម។ សកម្មភាពទាំងនេះបង្កើតបានជា**ឧស្ម័នផ្ទះកញ្ចក់** (greenhouse gases) ការដែលវាមានឈ្មោះដូច្នេះដោយសារនៅពេលដែលពួកវាប្រមូលផ្តុំនៅក្នុងបរិយាកាស ឧស្ម័នទាំងនេះមានតួនាទីដូចជាផ្ទាំងកញ្ចក់ថ្លា នៅក្នុងផ្ទះកញ្ចក់៖ ពួកវាអនុញ្ញាតអោយថាមពលនៅក្នុងរលកខ្លីនៃកាំរស្មីព្រះអាទិត្យ ឆ្លងកាត់ ប៉ុន្តែ ចាំងផ្លាតពីកញ្ចក់មកវិញ នៅពេលដែលពន្លឺទាំងនោះព្យាយាមចេញម្តងទៀត ជាទំរង់រលកកំដៅវែងជាង។ ឧស្ម័នផ្ទះកញ្ចក់មានកាបូនឌីអុកស៊ីត (ដុះ ឥទ្ធិពលពីរភាគបី) ឧស្ម័នមេតាន ក្លរ៉ូហ្វ្លរ៉ូកាបូន (CFCs) និងនីត្រាតអុកស៊ីត។ ភាគល្អិតពីម៉ាស៊ីនម៉ាស៊ូត (នៅអឌ្ឍគោលខាងជើង) និងចង្ក្រានកខ្វក់ (នៅអឌ្ឍគោលភាគខាងត្បូង) ក៏ជារួមចំណែកដ៏សំខាន់ផងដែរ។ គួរ

អោយអស់សំណើចណាស់ ទិន្នន័យដែលបានរក្សាទុកនៅក្នុងឃ្លាំងស្តុកនៅលើ «ពពក» ដែលហាក់ដូចជាគ្មានពាក់ព័ន្ធនឹងផែនដី តាមពិតទៅវាស្ថិត នៅក្នុងមជ្ឈមណ្ឌលទិន្នន័យដែលប្រើប្រាស់ថាមពលអគ្គិសនីយ៉ាងច្រើន និងដំណើរការម៉ាស៊ីនម៉ាស៊ូតធំៗ ដែលរួមចំណែកធ្វើអោយឡើងកំដៅផែនដី។

ដូច្នេះ ការកាត់បន្ថយឥទ្ធិពលផ្ទះកញ្ចក់មានន័យថា ទប់ស្កាត់កំណើនសេដ្ឋកិច្ច ឬផ្លាស់ប្តូរវាទៅក្នុងផ្លូវបច្ចេកវិទ្យាថ្មីទាំងស្រុង ដែលទាំងពីរនេះត្រូវចំណាយខ្លាំងណាស់។ ការខាងបង់ផ្នែកនយោបាយពីសកម្មភាពបែបនេះ (ដែលទំនងជានឹងបង្កើនភាពអត់ការងារធ្វើ កាត់បន្ថយប្រាក់ចំណេញសាជីវកម្ម និងបន្ទាបប្រាក់ចំណូលផ្ទាល់ខ្លួន)អាចធ្ងន់ធ្ងរទៅៗ។ ប្រសិនបើទឹកកកសមុទ្រអាក់ទិករលាយ ខ្លាឃ្មុំទឹកកកអាចនឹងផុតពូជ ប៉ុន្តែពួកវាមិនមានកៅអីអង្គុយនៅតុចរចាស្តីពីអាកាសធាតុអន្តរជាតិទេ។ កុមារសព្វថ្ងៃនេះក៏គ្មានកៅអីអង្គុយចរចាដែរព្រោះពួកគេមិនអាចបោះឆ្នោតបាន ប៉ុន្តែនឹងរស់នៅជាមួយនឹងផលវិបាករយៈពេលវែងនៃសកម្មភាពរបស់បុព្វការីជនរបស់ពួកគេ។

សម្រាប់រដ្ឋដោយឡែកនីមួយៗ ការចំណាយលើការកាត់បន្ថយការបំភាយផ្ទះកញ្ចក់ស្ទើរតែមិនហុចផលជាដំណោះស្រាយប្រកបដោយប្រសិទ្ធិភាពនោះទេ។ ប្រសិនបើរដ្ឋមួយកាត់បន្ថយផលិតកម្មឧស្សាហកម្មរបស់ខ្លួន ឬធ្វើអោយការវិនិយោគដែលមានតម្លៃថ្លៃផ្នែកបច្ចេកវិទ្យាថ្មី វានឹងមានឥទ្ធិពលតិចតួចលើលទ្ធផលរយៈពេលវែង លុះត្រាតែរដ្ឋផ្សេងទៀតធ្វើដូចគ្នានេះដែរ។ ហើយប្រសិនបើរដ្ឋភាគច្រើនបានចាត់វិធានការណ៍បែបនេះ *អ្នកជិះលើងវ៉ៃ* ដែលមិនអនុវត្តតាម នឹងបានផលចំណេញដោយមិនចំណាយ ហើយនៅតែទទួលបានអត្ថប្រយោជន៍ពីដំណោះស្រាយរបស់រដ្ឋដទៃ។

ម្ល៉ោះហើយ កំណើនកម្តៅសកលបង្ហាញនូវជម្រើសដ៏លំបាកចំនួនបីដល់រដ្ឋទាំងឡាយ។ ទីមួយ មានជម្រើសដ៏លំបាកដែលត្រូវខាតបង់រយៈពេលខ្លី(និងអាចទស្សន៍ទាយបាន) ដើម្បីទទួលបានអត្ថប្រយោជន៍រយៈពេលវែង(និងមិនសូវអាចព្យាករណ៍បាន)។ ទីពីរ ក្រុមអ្នកបោះឆ្នោតជាក់លាក់ណាមួយ ដូចជាក្រុមហ៊ុនផលិតប្រេង និងកម្មករឧស្សាហកម្មគឺជាអ្នកត្រូវបង់ថ្លៃការខាតបង់ ចំណែកអត្ថប្រយោជន៍ត្រូវបានចែករំលែកជាទូទៅនៅទូទាំងសង្គម ក្នុងស្រុក និងរដ្ឋអន្តរជាតិ។ ទីបី មានបញ្ហាផលប្រយោជន៍រួមក្នុងចំណោមរដ្ឋទាំងអស់៖ អត្ថប្រយោជន៍ត្រូវបានចែករំលែកជាសកល ប៉ុន្តែ ការចំណាយត្រូវតែរៃអង្គាសចេញពីរដ្ឋនីមួយៗ ជាលក្ខណៈបុគ្គល។

បញ្ហាទីបីនេះមានលក្ខណៈស្មុគស្មាញ ដោយសារគម្លាតអឌ្ឍគោលខាងជើងនិងអឌ្ឍគោលខាងត្បូង។ តើឧស្សាហូបនីយកម្មនៃប្រទេសក្រីក្រនាសម័យបច្ចុប្បន្ននេះ (ជាពិសេសប្រទេសចិននិងឥណ្ឌា) អាចប្រព្រឹត្តទៅដោយរបៀបណាដោយមិនរុញច្រានការបំភាយឧស្ម័នផ្ទះកញ្ចក់ដល់កម្រិតដែលមិនអាចទទួលយកបាន? ឧស្ម័នផ្ទះកញ្ចក់ត្រូវបានផលិតដោយរដ្ឋនីមួយៗ ដោយសមាមាត្រទៅនឹងសកម្មភាពឧស្សាហកម្មរបស់វា។ សែសិបប្រាំភាគរយនៃឧស្ម័នផ្ទះកញ្ចក់ទាំងអស់ត្រូវបានបំភាយចេញពីប្រទេសចិន អាមេរិក បណ្តារដ្ឋនៅក្នុងសហភាពអឺរ៉ុប ជប៉ុន រុស្ស៊ី និងឥណ្ឌា។ ការបំភាយកាបូនឌីអុកស៊ីតរបស់សហរដ្ឋអាមេរិកមានចំនួនលើសពី ១៥តោនសម្រាប់មនុស្សម្នាក់ក្នុងមួយឆ្នាំ។ ច្រើនជាងពីរដងនៃអត្រារបស់អឺរ៉ុបនិងចិន (ទោះបីជាការបំភាយឧស្ម័នសរុបរបស់ចិនលើសពីសហរដ្ឋអាមេរិកនិងកាណាដារួមបញ្ចូលគ្នាក៏ដោយ)។ ប៉ុន្តែ ផលប៉ះពាល់ធ្ងន់ធ្ងរបំផុតនៃការឡើងកំដៅផែនដីទំនងជាកើតឡើង នៅក្នុងអឌ្ឍគោលខាងត្បូង។ នៅក្នុងប្រទេសដែលមានប្រជាជនច្រើន ដូចជាប្រទេសបង់ក្លាដែស មនុស្សរាប់រយលាននាក់នឹងត្រូវបាត់បង់ផ្ទះសម្បែងនិងដីស្រែចម្ការ

ដោយសារកំណើននីវ៉ូទឹកសមុទ្រ។ ទោះជាយ៉ាងនេះក្តី ការទូទាត់រវាងភាពខុសគ្នាអឡាស្កាខាងជើងនិងខាងត្បូងបែបនេះ គឺជាការកត់សម្គាល់ឃើញថា ការប្រែប្រួលអាកាសធាតុសកលអាចបណ្តាលអោយមានមហន្តរាយបរិស្ថាននៅទូទាំងអឡាស្កាខាងជើងនិងខាងត្បូង។

សមាសធាតុទាំងអស់នេះនាំទៅរកស្ថានការណ៍ចរចាពហុភាគីដ៏លំបាកមួយ ហើយដែលមិនទាន់បានដោះស្រាយនៅឡើយ។ *អនុសញ្ញាក្របខ័ណ្ឌស្តីពីបម្រែបម្រួលអាកាសធាតុ* ដែលត្រូវបានអនុម័តនៅកិច្ចប្រជុំកំពូលផែនដី ឆ្នាំ ១៩៩២ បានកំណត់គោលដៅមិនជាប់កាតព្វកិច្ច ក្នុងការដាក់កម្រិតអត្រាបំភាយឧស្ម័នផ្ទះកញ្ចក់ដល់កម្រិតមុនឆ្នាំ ១៩៩០ យ៉ាងយូរត្រឹមឆ្នាំ ២០០០។ គោលដៅនោះមិនទាន់ត្រូវបានសម្រេចនៅឡើយ។ សន្ធិសញ្ញានេះមិនបានចាប់បង្ខំរដ្ឋហត្ថលេខីប្តេជ្ញាអោយបំពេញតាមកម្រិតគោលដៅនៃការបំភាយឧស្ម័នផ្ទះកញ្ចក់ នៅត្រឹមកាលបរិច្ឆេទជាក់លាក់ណាមួយទេ ដោយសារតែការជំទាស់របស់សហរដ្ឋអាមេរិកចំពោះការប្តេជ្ញាចិត្តបែបនេះ។ អឺរ៉ុបខាងលិចនិងប្រទេសជប៉ុនមានឆន្ទៈគ្រប់គ្រងការបំភាយ ឧស្ម័នផ្ទះកញ្ចក់ច្រើនជាងសហរដ្ឋអាមេរិក (ដែលដុតឥន្ធនៈហ្វូស៊ីលច្រើនជាងសម្រាប់មនុស្សម្នាក់ៗ)។

រូបថត *គ្រោះទឹកជំនន់បានវាយប្រហារទីក្រុងហ៊ូស្តុន បន្ទាប់ពីព្យុះសង្ឃរាហាវី*

កញ្ចក់ឆ្លុះមើលអនាគត

សន្ធិសញ្ញាអន្តរជាតិបានទទួលជោគជ័យច្រើនក្នុងការដោះស្រាយការថយចុះអូហ្សូន ជាងកំណើនកម្តៅសកល ដែលភាគច្រើនដោយសារឧបសគ្គនៃការចំណាយច្រើន។ ខណៈពេលដែលកិច្ចព្រមព្រៀងអន្តរជាតិដូចជាពិធីសារក្យូតូឆ្នាំ ១៩៩៧ ឬ កិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ ២០១៦ ស្តីពីអាកាសធាតុកំណត់គោលដៅតិចតួចសម្រាប់ប្រទេសឧស្សាហកម្មដើម្បីកាត់បន្ថយការបញ្ចេញកាបូនឌីអុកស៊ីត និងឧស្ម័នដែលប្រហាក់ប្រហែល វឌ្ឍនភាពមិនសូវជាមានច្រើនទេ។ អាកាសធាតុកាចសាហាវខ្លាំងក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះបានផ្តល់សញ្ញាព្រមានជាមុន។ នៅទីនេះ គ្រោះទឹកជំនន់បានវាយប្រហារទីក្រុងហ៊ូស្តុនក្នុងរដ្ឋតិចសាស បន្ទាប់ពីព្យុះសង្ឃរាហាវី (Harvey) ឆ្នាំ ២០១៧ ។


ពិធីសារក្យូតូ (Kyoto Protocol) ឆ្នាំ ១៩៩៧ បានអនុម័តរូបមន្តស្មុគ្រស្មាញមួយសម្រាប់ កាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ដល់កម្រិតឆ្នាំ ១៩៩០ នៅអឡាស្កាខាងជើង ក្នុងរយៈពេលប្រហែលមួយទសវត្សរ៍។ បណ្តាប្រទេសនៅអឡាស្កាខាងត្បូងបានទទួលការអនុគ្រោះ ដោយសារតែកម្រិតរបស់ពួកគេ (ក្នុងមនុស្សម្នាក់ៗ)នៅមានកម្រិតទាបជាងខ្លាំង។ ប៉ុន្តែ សេដ្ឋកិច្ចរបស់ប្រទេសចិនដែលជម្រុញដោយធ្យូងថ្ម និងកំពុងរីកចម្រើនយ៉ាងឆាប់រហ័ស គឺជាកត្តាចម្បងមួយនៅក្នុងការឡើងកំដៅផែនដី (សូមមើលក្រាហ្វិក ១១.៣)។ ប្រទេសឥណ្ឌាគឺជាប្រភពដ៏ធំមួយទៀតនៃកាបូនឌីអុកស៊ីត។ សហរដ្ឋអាមេរិកបានចុះហត្ថលេខាលើសន្ធិសញ្ញានេះ ប៉ុន្តែសភាអាមេរិកនឹងមិនផ្តល់សច្ចាប័នលើវាទេ។

ដោយបន្តដំណើរទៅមុខដោយគ្មានការគាំទ្រពីសហរដ្ឋអាមេរិក ប្រទេសចំនួន ១៦០ ក្នុងឆ្នាំ ២០០១ បានយល់ព្រមអនុវត្តពិធីសារទីក្រុងក្យូតូ។ កិច្ចព្រមព្រៀងនេះបានអំពាវនាវអោយប្រទេសឧស្សាហកម្មចំនួន ៤០ កាត់បន្ថយការបំភាយឧស្ម័នមកត្រឹម ៥ ភាគរយ នៅក្រោមកម្រិតឆ្នាំ ១៩៩០ យ៉ាងយូរត្រឹមឆ្នាំ ២០១២ ជាមួយនឹងការដាក់ពិន័យជាកាតព្វកិច្ចប្រសិនបើរដ្ឋណាមួយបរាជ័យមិនធ្វើបាន។ សហភាពអឺរ៉ុបបានប្តេជ្ញាថានឹងផ្តល់ប្រាក់ចំនួន ៤០០ លានដុល្លារក្នុងមួយឆ្នាំដើម្បីជួយដល់អឡាស្កាខាងត្បូងក្នុងការកាត់បន្ថយការបំភាយឧស្ម័នរបស់ខ្លួន។ បន្ទាប់ពីទទួលបានផ្តល់សច្ចាប័នគ្រប់គ្រាន់រដ្ឋនានា សន្ធិសញ្ញានេះបានចូលជា

ធរមាននៅក្នុងឆ្នាំ ២០០៥ ហើយ កាតព្វកិច្ចកាត់ការបំភាយកាបូនជា បានចាប់ផ្តើមនៅឆ្នាំ ២០០៨ ប៉ុន្តែ ពួកគេកំពុងនៅឆ្ងាយពីគោលដៅនៅឡើយ។

ក្រាហ្វិក ១១.៣ ការបំភាយកាបូនឌីអុកស៊ីតរបស់សហរដ្ឋអាមេរិក និងចិន ឆ្នាំ ១៩៩០-២០៣០

ប្រភព៖ ទីភ្នាក់ងារថាមពលអន្តរជាតិ។



សហភាពអឺរ៉ុបបានបង្កើតទីផ្សារដើម្បីធ្វើពាណិជ្ជកម្មឥណទាននៃការបំភាយកាបូន នៅក្នុងចំណោមរោងចក្រឧស្សាហកម្មចំនួន ១១០០០ នៅទូទាំងទ្វីបអឺរ៉ុប។ ទោះជាយ៉ាងណាក៏ដោយ ការធ្លាក់ចុះសេដ្ឋកិច្ចនៅអឺរ៉ុបនាំអោយតម្លៃឥណទានកាបូនធ្លាក់ចុះយ៉ាងគំហុកក្នុងឆ្នាំ ២០១១។ តម្លៃឥណទានទាំងនោះនៅក្នុងកម្រិតទាបបំផុតពេញមួយឆ្នាំ ២០១៤ ដែលនាំអោយអ្នកខ្លះចោទជាសំណួរអំពីអនាគតនៃទីផ្សារពាណិជ្ជកម្មការបំភាយឧស្ម័ននៅអឺរ៉ុប។ ទោះយ៉ាងណាក៏ដោយ ក្នុងពេលជាមួយគ្នានោះ ប្រទេសផ្សេងទៀតបានបង្កើតគ្រោងការណ៍ធ្វើពាណិជ្ជកម្មការបំភាយឧស្ម័នស្រដៀងគ្នា រួមមានប្រទេសកូរ៉េខាងត្បូង ចិន និងជប៉ុន។ ទីផ្សារកាបូនទាំងអស់នេះប្រើប្រាស់គោលការណ៍ទីផ្សារសេរី ដើម្បីកាត់បន្ថយការបញ្ចេញកាបូនអោយកាន់តែមានប្រសិទ្ធភាព។ ជាឧទាហរណ៍ ក្រុមហ៊ុនបណ្តាក់ទុនមួយនៅក្នុងប្រទេសប្រេស៊ីលទទួលបានឥណទានកាបូនដោយការដុតឧស្ម័នមេតានពីកន្លែងចាក់សំរាម (ដើម្បីបង្កើតអគ្គិសនី) ជំនួសអោយការបញ្ចេញវាចោលក្នុងទំរង់ជាឧស្ម័នផ្ទះកញ្ចក់កម្រិតខ្លាំង។ វិនិយោគិនអឺរ៉ុបបានទិញក្រេឌីតទាំងនោះ ហើយបន្ទាប់មកអាចលក់វាទៅរោងចក្របំពុលនៅអឺរ៉ុបខាងកើត ដែលការកាត់បន្ថយកាបូនអាចនឹងមានត្រូវចំណាយថ្លៃខ្ពស់ជាងនេះ។

ជាមួយនឹងកិច្ចព្រមព្រៀងទីក្រុងក្យូតូដែលបានកំណត់នឹងផុតកំណត់ក្រោយឆ្នាំ ២០១២ រដ្ឋចំនួន ១៨០ បានចរចាអស់រយៈពេលជាច្រើនឆ្នាំ ថាតើត្រូវធ្វើអ្វីបន្តទៀត។ សហរដ្ឋអាមេរិកបានចូលរួមកិច្ចចរចាទាំងនេះឡើងវិញ។ នៅចុងឆ្នាំ២០១១ រដ្ឋនានានៅក្នុងកិច្ចប្រជុំនៅទីក្រុងឌួរបាន (Durban) នៃប្រទេសអាហ្វ្រិកខាងត្បូង បានយល់ព្រមបន្តនិងពង្រីកក្របខ័ណ្ឌពិធីសារក្រុងក្យូតូ ដល់កំឡុងឆ្នាំ ២០១៣-២០១៧។ នៅក្នុងកិច្ចប្រជុំមួយ កាលពីចុងឆ្នាំ ២០១៤ នៅប្រទេសប៉េរូ អ្នកចូលរួមបានយល់ព្រមលើគោលការណ៍ដែលរដ្ឋទាំងអស់ ទាំងរដ្ឋអ្នកមាននិងរដ្ឋអ្នកក្រ គួរតែប្តេជ្ញាចិត្តដើម្បីកំណត់កម្រិតការបំភាយឧស្ម័នផ្ទះកញ្ចក់។

ប្រទេសច្រើនទៀតក៏បានយល់ព្រមក្នុងការរួមចំណែកដល់មូលនិធិអាកាសធាតុបៃតង ដែលបែងចែកមនុស្ស រាប់លាននាក់ទៅប្រទេសកំពុងអភិវឌ្ឍន៍ដើម្បីជួយពួកគេសម្របខ្លួន។

ទន្ទឹមនឹងនេះ សហរដ្ឋអាមេរិកនិងចិនបានព្រមព្រៀងគ្នា កាលពីចុងឆ្នាំ ២០១៤ ថា ប្រទេសទាំងពីរ នឹងពន្លឿនកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេដើម្បីកាត់បន្ថយការបំភាយឧស្ម័ន។ សហរដ្ឋអាមេរិកបានយល់ព្រម កាត់បន្ថយការបញ្ចេញឧស្ម័នរបស់ខ្លួន លើសពី ២៥ ភាគរយ (ក្រោមកម្រិត ២០០៥) យ៉ាងយូរនៅត្រឹមឆ្នាំ ២០២៥ ខណៈដែលប្រទេសចិនបានយល់ព្រមបន្តបង្វែខ្លួន ចេញពីរោងចក្រធ្យូងថ្មដោយរំកិល ឆ្ពោះទៅរក ប្រភពថាមពលផ្សេងជំនួស។ សូម្បីតែមុនពេលកិច្ចព្រមព្រៀងនេះ ប្រទេសទាំងពីរបានបង្ហាញចលនាឆ្ពោះទៅ រកគោលដៅទាំងនេះ។ នៅឆ្នាំ ២០១៣ សហរដ្ឋអាមេរិកស្ថិតក្នុង ១០ ភាគរយ នៅក្រោមកម្រិតនៃការបំភាយ ឧស្ម័នឆ្នាំ ២០០៥ ហើយនៅឆ្នាំដដែលនោះ ការប្រើប្រាស់ធ្យូងថ្មរបស់ប្រទេសចិនបានធ្លាក់ចុះជាលើកដំបូង ក្នុងរយៈពេលមួយសតវត្សរ៍។ ក្នុងឆ្នាំ ២០១៥ ការបំភាយឧស្ម័នសកលបានធ្លាក់ចុះជាលើកដំបូងចាប់តាំងពី វិបត្តិសេដ្ឋកិច្ចដ៏ធំ ឆ្នាំ ២០០៨-២០០៩ (ការបំភាយឧស្ម័នជាធម្មតាធ្លាក់ចុះក្នុងអំឡុងពេលវិបត្តិសេដ្ឋកិច្ច ដោយសាររោងចក្រជាច្រើនបានបិទ)។ ការធ្លាក់ចុះនៃឆ្នាំ ២០១៥ ដោយសារតែការបំភាយឧស្ម័នទាបនៅក្នុង សហរដ្ឋអាមេរិក សហភាពអឺរ៉ុប និងប្រទេសចិន។

កិច្ចព្រមព្រៀងអាកាសធាតុទីក្រុងប៉ារីស (Paris Climate Agreement) ឆ្នាំ ២០១៥ គឺជាកិច្ច ព្រមព្រៀងដ៏សំខាន់មួយនៅក្នុងនយោបាយអាកាសធាតុពិភពលោក។ កិច្ចព្រមព្រៀងបានចាប់ផ្តើមស្ទើរតែ មានលក្ខណៈសកលទាំងស្រុង ក្នុងនោះភាគី ១៩៥ រដ្ឋបានចុះហត្ថលេខាលើកិច្ចព្រមព្រៀង(រដ្ឋជាសមាជិក សង្កេតការណ៍ក្នុងអ.ស.ប.មួយចំនួនក៏ត្រូវអនុញ្ញាតអោយចុះហត្ថលេខាដែរ)។ កិច្ចព្រមព្រៀងនេះអំពាវនាវ អោយរដ្ឋទាំងឡាយកំណត់ការកើនឡើងនៃសីតុណ្ហភាពពិភពលោកអោយបានលើសពីកម្រិត ២ អង្សាសេ ក្រោមសីតុណ្ហភាពមុនសម័យឧស្សាហកម្ម។ ដើម្បីសម្រេចគោលដៅនេះ វាបានអំពាវនាវអោយរដ្ឋនានា កំណត់គោលដៅនៃការបំភាយឧស្ម័នរបស់ខ្លួន និងរាយការណ៍ដោយខ្លួនឯងនូវការអនុលោមតាមគោលដៅ ទាំងនោះ។ កិច្ចព្រមព្រៀងនេះមិនមានយន្តការពង្រឹងការអនុវត្ត ដែលនឹងដាក់ទណ្ឌកម្មរដ្ឋទាំងឡាយណា ដែលខកខានមិនបានបំពេញគោលដៅរបស់ពួកគេ។

នៅរដូវក្តៅឆ្នាំ ២០១៧ រដ្ឋបាលប្រធានាធិបតីត្រាំ បានប្រកាសថាអាមេរិកនឹងដកខ្លួនចេញពីកិច្ច ព្រមព្រៀងប៉ារីស ម្ល៉ោះហើយនឹងមិនជាសមាជិករបស់កិច្ចព្រមព្រៀងនេះទៀតឡើយ។ ការដកខ្លួននឹងមិន ចូលជាធរមាន រហូតដល់ឆ្នាំ ២០២០ ដោយសារតែបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀង។ ការដកខ្លួននេះនាំអោយ មានការថ្កោលទោសជាសាកលចំពោះជំហររបស់សហរដ្ឋអាមេរិក។ ជាពិសេស បណ្តារដ្ឋសហភាពអឺរ៉ុបបាន ឆ្លើយតបដោយការធ្វើអោយដៃគូសន្ទិសញ្ញានាពេលអនាគត (ឧ. កិច្ចព្រមព្រៀងពាណិជ្ជកម្ម) ដោយតម្រូវ អោយរដ្ឋដៃគូចុះហត្ថលេខាលើកិច្ចព្រមព្រៀងប៉ារីស។

ផលប៉ះពាល់រយៈពេលមធ្យមនិងរយៈពេលវែងនៃការដកសមាជិកភាពរបស់សហរដ្ឋអាមេរិក ចេញពី កិច្ចព្រមព្រៀងទីក្រុងប៉ារីស មិនច្បាស់លាស់ទេ។ ម្យ៉ាង សហរដ្ឋអាមេរិកបានជួយរៀបចំកិច្ចព្រមព្រៀងទីក្រុង ប៉ារីស និងបានព្យាយាមនាំយករដ្ឋផ្សេងទៀតមកចូលរួមជាមួយ។ ក្នុងនាមជាប្រភពដ៏សំខាន់នៃការបំភាយ ឧស្ម័ន គោលនយោបាយរបស់សហរដ្ឋអាមេរិកមានសារៈសំខាន់ចំពោះកិច្ចខិតខំប្រឹងប្រែងដើម្បីកាត់បន្ថយ ការឡើងកំដៅផែនដី។ កង្វះការដឹកនាំរបស់សហរដ្ឋអាមេរិកលើការប្រែប្រួលអាកាសធាតុអាចជាគ្រោះថ្នាក់

ដល់កិច្ចខិតខំប្រឹងប្រែងជាសកលដើម្បីប្រយុទ្ធប្រឆាំងនឹងការឡើងកំដៅ។ ទោះជាយ៉ាងណាក៏ដោយ រដ្ឋផ្សេងទៀតក៏សំខាន់ផងដែរ៖ ប្រទេសចិន ឥណ្ឌា និងបណ្តាប្រទេសសហភាពអឺរ៉ុប។ រដ្ឋទាំងនោះនៅតែប្តេជ្ញាចិត្តចំពោះកិច្ចព្រមព្រៀងទីក្រុងប៉ារីស។ សាជីវកម្មពហុជាតិសកលជាច្រើន សូម្បីតែបណ្តាសាជីវកម្មក្នុងវិស័យថាមពល ក៏នៅតែប្តេជ្ញាចិត្តដើម្បីផ្លាស់ទីឆ្ងាយពីឥន្ធនៈហ្វូស៊ីល ដូចរដ្ឋនិងទីក្រុងជាច្រើនរបស់សហរដ្ឋអាមេរិកដែរ។

រហូតមកដល់ពេលនេះ រដ្ឋនានាបានចាប់ផ្តើមអនុវត្តគោលដៅកិច្ចព្រមព្រៀងប៉ារីសរបស់ពួកគេ តាមរយៈវិធានការណ៍ជាច្រើន។ ប្រទេសបារាំងបានប្តេជ្ញាបញ្ឈប់ការដុតធ្យូងថ្មដើម្បីផលិតអគ្គិសនី នៅត្រឹមឆ្នាំ ២០២២។ ប្រទេសចិនបានបង្កើនការប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យទ្វេដង នៅឆ្នាំ ២០២០ និងបានបង្កើតការតឹងតែនឹងការប្រើប្រាស់ធ្យូងថ្មថ្មី។ ប្រទេសឥណ្ឌាបានបង្កើនការប្រើប្រាស់ថាមពលកកើតឡើងវិញដើម្បីកាត់បន្ថយបញ្ហាបំពុលបរិយាកាសដែលកំពុងកើនឡើង។

លើសពីនេះ រដ្ឋប្រហែលពាក់កណ្តាលនៃសហរដ្ឋអាមេរិក (ជាពិសេសរដ្ឋកាលីហ្វ័រញ៉ា) និងទីក្រុងមួយចំនួន បានចាប់ផ្តើមចាត់វិធានការណ៍ដើម្បីកម្រិតការបំភាយឧស្ម័នផ្ទះកញ្ចក់។ ក្នុងចំណោមនោះ មិនទាន់មានវិធានការណ៍គ្រប់គ្រាន់ ឬទាន់ពេលល្មម ដើម្បីបញ្ច្រាសទិសដៅនៃការប្រែប្រួលអាកាសធាតុយ៉ាងដាច់ខាតនៅឡើយ។ បញ្ហាជម្រើសដ៏លំបាកនៃការឡើងកំដៅផែនដីនៅតែមិនអាចដោះស្រាយបាននៅឡើយ ហើយបើទោះបីជាអ្នកជំនាញទាំងឡាយបានសង្ឃឹមថា កិច្ចព្រមព្រៀងទីក្រុងប៉ារីសនឹងបណ្តាលអោយការបំភាយឧស្ម័នធ្លាក់ចុះ និងស្ថិរភាពសីតុណ្ហភាព កង្វះយន្តការពង្រឹងការអនុវត្តមានន័យថា វាត្រូវអាស្រ័យលើបណ្តារដ្ឋនានាក្នុងការត្រួតពិនិត្យដោយខ្លួនឯងថាតើខ្លួនបានបំពេញតាមគោលដៅកំណត់ដែរឬទេ។ សូមមើលឧទាហរណ៍បន្ថែមស្តីពី ការស្វែងរកផលប្រយោជន៍រួម។

ការសឹករេចរឹលនៃស្រទាប់អូហ្សូន

បញ្ហាបរិយាកាសសំខាន់ទីពីរ ដែល ត្រូវបានចរចាដោយរដ្ឋាភិបាលនានាលើពិភពលោក គឺការថយចុះឬសឹករេចរឹលនៃស្រទាប់អូហ្សូនរបស់ពិភពលោក។ អូហ្សូនដែលមានកម្រិតខ្ពស់ក្នុងបរិយាកាស ជួយការពារកាំរស្មីអ៊ុលត្រាវីយូឡេដ៏គ្រោះថ្នាក់ពីព្រះអាទិត្យ។ សារធាតុគីមីមួយចំនួនដែលត្រូវបានបញ្ចេញចេញដោយសេដ្ឋកិច្ចឧស្សាហកម្មបានអណ្តែតហោះឡើងលើ ដល់បរិយាកាសខ្ពស់ ហើយមានអន្តរកម្មជាមួយអូហ្សូន រហូតធ្វើអោយស្រទាប់នោះត្រូវសឹករេចរឹល។ សារធាតុបង្កដ៏សំខាន់គឺក្លរ៉ូហ្វ្លុយរ៉ូកាបូន (CFCs) ដែលរហូតមកដល់ថ្មីៗនេះ ត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយនៅក្នុងទូរទឹកកក និងក្នុងការបាញ់ថ្នាំឬគ្រឿងក្រអូប ដូចជាទឹកអប់ជាដើម។ (ជាអកុសល អូហ្សូនដែលផលិតដោយការដុតឥន្ធនៈហ្វូស៊ីលមិនអាចជំនួសអូហ្សូនកម្រិតខ្ពស់ទេ ប៉ុន្តែបានត្រឹមតែបំពុលបរិយាកាសខាងក្រោមប៉ុណ្ណោះ)។ នៅពេលដែលស្រទាប់អូហ្សូនកាន់តែស្តើងកាំរស្មីអ៊ុលត្រាវីយូឡេកាន់តែច្រើនឡើងចាំងដល់ផ្ទៃផែនដី។ ប្រហោងតាមរដូវនៅក្នុងស្រទាប់អូហ្សូននៅពីលើទ្វីបអង់តាក់ទិកបានរីកកាន់តែធំឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ ប្រសិនបើកម្រិតអូហ្សូននៅតែបន្តសឹករេចរឹលកំណើនជាតុវិទ្យុសកម្ម នៅទីបំផុត អាចនឹងសម្លាប់ប្រភេទរុក្ខជាតិនានា កាត់បន្ថយទិន្នផលកសិកម្ម និងរំខានដល់ប្រព័ន្ធអេកូឡូស៊ី។

ច្បាស់ណាស់ នេះគឺជាបញ្ហាផលប្រយោជន៍រួមមួយផ្សេងទៀត ដោយហេតុថា រដ្ឋមួយអាចទទួលបានអត្ថប្រយោជន៍ដោយការអនុញ្ញាតអោយប្រើប្រាស់ធាតុក្លរ៉ូហ្វ្លុយរ៉ូកាបូន នៅក្នុងសេដ្ឋកិច្ចរបស់ខ្លួន នៅពេលរដ្ឋ

ផ្សេងទៀត ភាគច្រើន ហាមឃាត់ការប្រើប្រាស់ធាតុនេះ ក្នុងប្រទេសរបស់ពួកគេ។ ប៉ុន្តែ តម្លៃនៃការជំនួសធាតុCFCs មានកម្រិតទាបជាងការចំណាយលើការដោះស្រាយការឡើងកំដៅផែនដី៖ ធាតុCFCs អាចត្រូវបានជំនួសដោយសារធាតុគីមីផ្សេងទៀត ក្នុងតម្លៃទាបជាង។ ជាងនេះទៅទៀត ផលវិបាកនៃការថយចុះអូហ្សូន ត្រូវបានគេយល់កាន់តែច្បាស់ និងមានលក្ខណៈបន្ទាន់ជាងការឡើងកំដៅផែនដី។

ប្រហែលជាដោយសារបញ្ហាតម្លៃចំណាយទាំងនេះហើយ ទើប រដ្ឋនានាបានទទួលជោគជ័យច្រើនក្នុងការចរចាកិច្ចព្រមព្រៀងនិងបង្កើតរបបគ្រប់គ្រងភាពសឹករេចរិលនៃស្រទាប់អូហ្សូនជាងការឡើងកំដៅផែនដី។ នៅក្នុង**ពិធីសារម៉ុងត្រេអាល់**(Montreal Protocol) ឆ្នាំ ១៩៨៧ រដ្ឋចំនួន ២២ បានយល់ព្រមកាត់បន្ថយធាតុ CFCs កម្រិត ៥០ ភាគរយ យ៉ាងយូរនៅត្រឹមឆ្នាំ ១៩៩៨។ នៅក្នុងឆ្នាំ ១៩៩០ កាលវិភាគត្រូវបានពន្លឿន ហើយប្រទេសហត្ថលេខីត្រូវបានពង្រីក៖ រដ្ឋចំនួន ៨១ បានយល់ព្រមលុបបំបាត់ធាតុ CFCs ទាំងអស់ នៅឆ្នាំ ២០០០។ នៅឆ្នាំ ១៩៩២ ដោយសារមានភស្តុតាងកាន់តែច្រើនបញ្ជាក់ថាស្រទាប់អូហ្សូនកាន់តែសឹករេចរិល កាលវិភាគត្រូវបានពន្លឿនម្តងទៀត ដោយរដ្ឋឧស្សាហកម្មធំៗបានបញ្ឈប់ធាតុ CFCs បន្តិចម្តងៗ ហើយយ៉ាងយូរត្រូវបញ្ឈប់ នៅត្រឹមឆ្នាំ ១៩៩៥។ ប្រទេសហត្ថលេខីបានយល់ព្រមជាគោលការណ៍ក្នុងការបង្កើតមូលនិធិមួយដើម្បីជួយដល់ប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងការចំណាយលើបច្ចេកវិទ្យាទូរទឹកកកផ្សេងៗ ដែលមិនផ្អែកលើធាតុCFCs។ ប្រសិនបើគ្មានការប្រឹងប្រែងបែបនេះទេ បណ្តារដ្ឋនោះអឌ្ឍគោលខាងត្បូងនឹងជ្រើសយកជម្រើសដ៏រសេះលែងដៃ ហើយនៅទីបំផុតអាចបំផ្លាញការខិតខំប្រឹងប្រែង។ ប្រទេសទាំងនេះក៏ត្រូវបានទុកពេលអោយរហូតដល់ឆ្នាំ ២០១០ ដើម្បីបញ្ឈប់ការផលិត។ ពិធីសារម៉ុងត្រេអាល់ត្រូវបានកែសម្រួល និងពង្រឹងម្តងទៀតនៅឆ្នាំ ១៩៩៧ និង ១៩៩៩។ ប្រទេសអ្នកមានបានឈប់បង្កើតធាតុ CFCs ក្នុងឆ្នាំ ១៩៩៦ ហើយបានរួមចំណែកប្រហែល ៣ ប៊ីលានដុល្លារដល់មូលនិធិខាងលើ។ លុយទាំងនេះ ដែលបានជួយដល់គម្រោងរាប់ពាន់ក្នុងប្រទេសជាងមួយរយ បានជួយអឌ្ឍគោលខាងត្បូងក្នុងការកាត់បន្ថយការបំភាយឧស្ម័នក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ។ ប្រហោងក្នុងស្រទាប់អូហ្សូនត្រូវបានគេព្យាករណ៍ថានឹងថយចុះបន្តិចម្តងៗក្នុងរយៈពេល ៥០ ឆ្នាំខាងមុខ ប្រសិនបើការរៀបចំបច្ចុប្បន្ននៅតែបន្ត។

ពិធីសារម៉ុងត្រេអាល់ ស្តីពីសារធាតុហ្វ្លុយរ៉ូកាបូន គឺជាជោគជ័យដ៏សំខាន់បំផុតដែលសម្រេចបាននៅក្នុងការចរចាអន្តរជាតិ ដើម្បីថែរក្សាបរិស្ថានពិភពលោក។ ជាការពិតណាស់ អគ្គលេខាធិការអង្គការសហប្រជាជាតិ លោក កូហ្វី អាណាន់ (Kofi Annan) បានហៅវាថា «ប្រហែលជាកិច្ចព្រមព្រៀងអន្តរជាតិជោគជ័យបំផុតតែមួយគត់រហូតមកដល់បច្ចុប្បន្ន»។ វាបានបង្ហាញថា រដ្ឋអាចយល់ព្រមដើម្បីចាត់វិធានការណ៍លើការគំរាមកំហែងបរិស្ថានជាបន្ទាន់ យល់ព្រមលើគោលដៅ និងវិធានការណ៍ដើម្បីទប់ទល់នឹងការគំរាមកំហែងបែបនេះ និងចែករំលែកការចំណាយនៃវិធានការណ៍បែបនេះតាមរបៀបដែលអាចទទួលយកបានទៅវិញទៅមក ហើយអាចទូទាត់ប្រាក់ចំណាយនៅពេលដែលវិស័យប័ត្រមកដល់។ ប៉ុន្តែ កិច្ចសហប្រតិបត្តិការអន្តរជាតិលើបញ្ហាអូហ្សូនមិនត្រូវបានយកធ្វើជាគំរូយ៉ាងទូលំទូលាយលើបញ្ហាបរិស្ថានផ្សេងទៀតទេ។

ការចរចាបរិស្ថានមានលក្ខណៈស្រដៀងនឹងការចរចាពាណិជ្ជកម្មដែរ ដោយពួកគេត្រូវពឹងផ្អែកលើគោលការណ៍បដិការសម្រាប់ជាយន្តការឈានដល់កិច្ចព្រមព្រៀងដ៏សំខាន់។ ប្រសិនបើប្រទេសនីមួយៗចូលរួមចំណែក ហើយរដ្ឋទាំងអស់ផ្សេងទៀតចូលរួមចំណែក នោះគោលដៅដូចជាការស្តារស្រទាប់អូហ្សូនអាចសម្រេចបាន។ ដូចគ្នានឹងពាណិជ្ជកម្ម កិច្ចព្រមព្រៀងនិងរបបមានភាពស្មុគស្មាញ ហើយទាមទារអោយមាន

យន្តការត្រួតពិនិត្យការអនុលោមតាមច្បាប់និងកិច្ចព្រមព្រៀង ដើម្បីការពារកុំអោយមានអ្នកជិះសេះលែងដៃ។ លក្ខណៈខុសគ្នាដ៏ធំបំផុតពីការពិភាក្សាពាណិជ្ជកម្ម គឺថានៅពេលដែលកិច្ចពិភាក្សាពាណិជ្ជកម្មទទួលបានជោគជ័យក្នុងការដោះស្រាយបញ្ហាផលប្រយោជន៍រួម អ្នកចូលរួមទទួលបានអត្ថប្រយោជន៍ជាក់ស្តែងក្នុងរយៈពេលខ្លី ជាទឹកប្រាក់រាប់ពាន់លានដុល្លារ ដែលត្រូវបានបន្ថែមទៅក្នុងសេដ្ឋកិច្ចពិភពលោក។ នៅពេលដែលបញ្ហាផលប្រយោជន៍រួមបរិស្ថានត្រូវបានដោះស្រាយ អ្នកចូលរួមទទួលបានវិក្កយបត្ររបីក្នុងរយៈពេលខ្លីដើម្បីចេញថ្លៃចំណាយ បន្ទាប់មកទើបអាចនឹងទទួលបានអត្ថប្រយោជន៍រយៈពេលវែង។ ទំហំនៃវិក្កយបត្រនោះទំនងគឺជាភាពខុសគ្នាដ៏សំខាន់រវាងដំណោះស្រាយកំណើនកម្តៅសកលដែលមានតម្លៃថ្លៃនិងដំណោះស្រាយអូហ្សូនដែលមានតម្លៃសមរម្យ។ ជាក់ស្តែង គោលការណ៍បដិការអាចដោះស្រាយបញ្ហាប្រយោជន៍រួមបានល្អប្រសើរ ជាមួយនឹងការចំណាយទាប ឬអត្ថប្រយោជន៍ជាក់ស្តែង (អូហ្សូន ពាណិជ្ជកម្ម) ជាងការចំណាយខ្ពស់និងអត្ថប្រយោជន៍ក្នុងអនាគតវែងឆ្ងាយ (ការប្រែប្រួលអាកាសធាតុ)។

១១.២.២. ជីវចម្រុះ

ជីវចម្រុះ (biodiversity) សំដៅទៅលើភាពចម្រុះនៃប្រភេទរុក្ខជាតិនិងសត្វយ៉ាងទូលំទូលាយ ដែលបង្កើតបានជាប្រព័ន្ធអេកូឡូស៊ី(សកល តំបន់ និងក្នុងស្រុក) នៅលើភពផែនដី។ ដោយសារតែការបំផ្លាញប្រព័ន្ធអេកូឡូស៊ីដោយមនុស្សលោក សត្វមួយចំនួនធំបានផុតពូជ(extinct)អស់ទៅហើយ។ ការផុតពូជសត្វកើតចេញពីការបរបាញ់ហួសកម្រិត ការនេសាទហួសចំណុះ និងការនាំយកប្រភេទឬពូជសត្វចេញពីកន្លែងផ្សេងមកទីតាំងថ្មី ដែលក្រោយមកកើនចំនួនច្រើនលើសលប់ប្រភេទសត្វនៅទីតាំងចាស់។ ប៉ុន្តែ មូលហេតុសំខាន់បំផុតគឺ*ការបាត់បង់ទីជម្រក*(loss of habitat) ដូចជា ការបំផ្លិចបំផ្លាញព្រៃឈើដែលទាក់ទាញទឹកភ្លៀង ការបំពុលបឹងនិងអូរឬទន្លេ និងការពង្រីកទីក្រុងលើផ្ទៃដីកសិកម្ម។ ដោយសារប្រព័ន្ធអេកូឡូស៊ីត្រូវពឹងផ្អែកលើបណ្តាញឬសំណាញ់ទំនាក់ទំនងដ៏ស្មុគស្មាញក្នុងចំណោមប្រភេទសត្វនានា ការផុតរលត់នៃសត្វមួយចំនួនអាចបណ្តាលអោយមានការផ្លាស់ប្តូរកាន់តែជ្រាលជ្រៅនៅក្នុងបរិស្ថាន។ ជាឧទាហរណ៍ ការបាត់បង់អតិសុខុមប្រាណដែលមានដើមកំណើតក្នុងតំបន់ណាមួយ អាចនាំអោយមានការបំពុលទឹកទន្លេ ឬរហូតដល់បំប្លែងដីស្រែចម្ការទៅជាវាលខ្សាច់។

***រូបថត** ធនាគារហ្សែន នៅប្រទេសហ្វីលីពីនរក្សាទុកពូជស្រូវពីពិភពលោក*

យកទៅស្តុកក្នុងធនាគារ

សកម្មជនការពារបរិស្ថានខ្លះរិះគន់ធនាគារពិភពលោក និងស្ថាប័នអន្តរជាតិផ្សេងទៀតដែលជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងប្រទេសក្រីក្រចំពោះការជ្រៀតជ្រែកបំផ្លាញប្រព័ន្ធអេកូឡូស៊ីក្នុងស្រុក ដូចជាព្រៃស្រូបទឹកភ្លៀងជាដើម។ បដិវត្តន៍បៃតងបានបង្កើនទិន្នផល ប៉ុន្តែបានផ្លាស់ប្តូរគំរូនៃកសិកម្មតាមរបៀបស្មុគស្មាញដូចជាដោយការបង្កើនថ្នាំសម្លាប់សត្វល្អិត និងជីដំណាំ។ ឥឡូវនេះ ដំណាំកែច្នៃហ្សែនត្រូវគេជឿថានឹងបង្កើនផលិតភាពកសិកម្មបន្ថែមទៀត(អាហារនៅលើតុកាន់តែច្រើន) ប៉ុន្តែផលវិបាករបស់វាលើបរិស្ថានមិនត្រូវបានគេយល់ច្បាស់។ ធនាគារហ្សែននេះ ស្ថិតនៅក្នុងប្រទេសហ្វីលីពីនរក្សាទុកពូជស្រូវមកពីជុំវិញពិភពលោក។

ដោយសារប្រព័ន្ធអេកូឡូស៊ីមានភាពស្មុគស្មាញ ដូច្នេះតាមធម្មតា គេមិនអាចទាយទុកជាមុនអំពីផលវិបាកនៃការផុតពូជនៃប្រភេទសត្វណាមួយ ឬការបាត់បង់ទីជម្រក ឬប្រព័ន្ធអេកូឡូស៊ីនោះទេ។ ជាទូទៅសកម្មភាពដែលបណ្តាលអោយបាត់បង់ទីជម្រក អាចផ្តល់ផលចំណេញផ្នែកសេដ្ឋកិច្ច ដូច្នេះ ការចំណាយពិត

ប្រាកដត្រូវបានផ្សារភ្ជាប់ជាមួយនឹងការកម្រិតសកម្មភាពបែបនេះ។ ដូច្នេះ ការអភិរក្សប្រភេទសត្វគឺជាផលប្រយោជន៍រួមដែលស្រដៀងនឹងការឡើងកំដៅផែនដីដែលការចំណាយភ្លាមៗ និងច្រើន ប៉ុន្តែ អត្ថប្រយោជន៍ត្រូវបានកំណត់ក្នុងរយៈពេលវែងនិងមិនច្បាស់លាស់។

ជាការពិបាកណាស់ ក្នុងការឈានសម្រេចបានកិច្ចព្រមព្រៀងអន្តរជាតិស្តីពី ការរំលែកបន្ទុកចំណាយលើការអភិរក្សជីវចម្រុះ។ អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការធ្វើពាណិជ្ជកម្មលើប្រភេទសត្វជិតផុតពូជបានកាត់បន្ថយប៉ុន្តែមិនបានលុបបំបាត់ពាណិជ្ជកម្មបែបនេះទេ។ នៅឯកិច្ចប្រជុំកំពូលផែនដីក្នុងឆ្នាំ ១៩៩២ សន្ធិសញ្ញាស្តីពីជីវចម្រុះបាននាំអោយប្រទេសហត្ថលេខីប្តេជ្ញាអភិរក្សជម្រកសត្វព្រៃ និងចាប់អោយប្រទេសអ្នកមានបង់ប្រាក់អោយប្រទេសក្រីក្រ សម្រាប់សិទ្ធិប្រើប្រាស់ផលិតផលជីវសាស្ត្រពាណិជ្ជកម្មកាក់កប់ ដែលទទួលបានពីប្រភេទសត្វកម្រនៅក្នុងជម្រកការពារ (ដូចជាថ្នាំពីដើមឈើស្រូបទឹកភ្លៀងជាដើម)។ ទោះបីជាយ៉ាងណាក៏ដោយ ដោយសារតែមានការភ័យខ្លាចថា សន្ធិសញ្ញានេះអាចកម្រិតសិទ្ធិប៉ាតង់របស់សហរដ្ឋអាមេរិកក្នុងវិស័យជីវបច្ចេកវិទ្យា សហរដ្ឋអាមេរិកមិនដែលផ្តល់សច្ចាប័នលើវាទេ។ គិតត្រឹមឆ្នាំ ២០១៨ សន្ធិសញ្ញានេះមានសមាជិក ១៩៦ ប្រទេស។ ទោះជាយ៉ាងណាក៏ដោយ សហរដ្ឋអាមេរិកចូលរួមនៅក្នុងសន្ធិសញ្ញាជីវសាស្ត្រផ្សេងទៀត ដូចជាអនុសញ្ញាតំបន់ដីសើមឆ្នាំ ១៩៧១ និងអនុសញ្ញាឆ្នាំ ១៩៧៣ ស្តីពីពាណិជ្ជកម្មអន្តរជាតិក្នុងប្រភេទសត្វជិតផុតពូជ (CITES) ជាដើម។

របបអន្តរជាតិដើម្បីការពារត្រីបាឡែន និងត្រីផ្សោត បានទទួលជោគជ័យ ក្នុងកម្រិតមួយចំនួន។ **គណៈកម្មាការត្រីបាឡែនអន្តរជាតិ** (អង្គការអន្តរដ្ឋាភិបាល[IGO]) កំណត់កូតាសម្រាប់ការនេសាទប្រភេទត្រីបាឡែនមួយចំនួន ប៉ុន្តែការចូលរួមត្រូវប្រព្រឹត្តិឡើងដោយស្ម័គ្រចិត្ត ហើយរដ្ឋាភិបាលមិនត្រូវបានចាប់បង្ខំអោយអនុវត្តដោយការសម្រេចចិត្តដែលពួកគេមិនយល់ព្រមនោះទេ។

គណៈកម្មការត្រីធូណាត្រូពិកអន្តរអាមេរិក(អង្គការអន្តរដ្ឋាភិបាលមួយទៀត)គ្រប់គ្រងវិធីសាស្ត្រនេសាទត្រីធូណា និងមានគោលបំណងកាត់បន្ថយការបាត់បង់ត្រីផ្សោត។ សហរដ្ឋអាមេរិក ដែលបានចាប់ត្រីធូណាបរិភោគ ចំនួនពាក់កណ្តាលក្នុងចំណោមត្រីធូណាលើពិភពលោក បានបន្តទាមទារជាឯកតោភាគី នៅក្នុង*ច្បាប់ការពារថនិកសត្វសមុទ្រ*ថា វិធីសាស្ត្រនេសាទដែលមិនប៉ះពាល់ដល់សុវត្ថិភាពត្រីផ្សោតត្រូវតែប្រើសម្រាប់ត្រីធូណាដែលលក់ក្នុងទឹកដីសហរដ្ឋអាមេរិក។ ប្រទេសផ្សេងទៀតបានជំទាស់នឹងច្បាប់នេះ តាមរយៈអង្គការពាណិជ្ជកម្មអន្តរជាតិថា ជាការដាក់កម្រិតអយុត្តិធម៌លើការនាំចេញត្រីធូណាទៅសហរដ្ឋអាមេរិក។ ជម្លោះបែបនេះបង្ហាញពីការតស៊ូមតិគ្នា នាពេលអនាគត រវាងអ្នកការពារបរិស្ថាននិងអ្នកតស៊ូមតិពាណិជ្ជកម្មសេរី។ ពាណិជ្ជករសេរីប្រកែកថា រដ្ឋមិនត្រូវប្រើច្បាប់ក្នុងស្រុកដើម្បីសម្រេចគោលដៅបរិស្ថានសកលទេ។ អ្នកបរិស្ថានមិនចង់បោះបង់ច្បាប់ជាតិដែលពួកគេបានធ្វើការតស៊ូរាប់ទសវត្សរ៍ទម្រាំត្រូវបានអនុម័ត ដោយសារតែការប្រឆាំងជំទាស់ពីសាជីវកម្មឧស្សាហកម្មនោះទេ។

ជាឧទាហរណ៍ ច្បាប់អាកាសខ្យល់បរិសុទ្ធរបស់សហរដ្ឋអាមេរិកបានកាត់បន្ថយការបំពុលខ្យល់នៅក្នុងទីក្រុងនានារបស់សហរដ្ឋអាមេរិកដោយជោគជ័យ ប៉ុន្តែ បទប្បញ្ញត្តិនេះត្រូវបានកែសម្រួលនៅឆ្នាំ ១៩៩៧ តាមការសម្រេចរបស់អង្គការពាណិជ្ជកម្មពិភពលោក(WTO) ដើម្បីអនុញ្ញាតអោយប្រេងសាំងដែលត្រូវបានចម្រាញ់នៅក្នុងប្រទេសវេណេហ្ស៊ុយអេឡា និងប្រេស៊ីលប្រកួតប្រជែងដោយសេរី នៅទីផ្សារសហរដ្ឋអាមេរិក។ អ្នកបរិស្ថានបានយកសត្វអណ្តើកសមុទ្រធ្វើជានិមិត្តសញ្ញានៃការតវ៉ាប្រឆាំងរបស់ពួកគេ ចំពោះអង្គការWTO

បន្ទាប់ពីអង្គការនេះបានបដិសេធចោលនូវបទប្បញ្ញត្តិរបស់សហរដ្ឋអាមេរិក ដែលតម្រូវអោយចាប់បង្គាដោយប្រើសំណាញ់ដែលអណ្តើកសមុទ្រ(ប្រភេទសត្វជិតផុតពូជ)អាចគេចចេញបាន។ ជម្លោះថ្មីៗបានកើតឡើងជុំវិញច្បាប់របស់សហរដ្ឋអាមេរិកដែលដាក់កម្រិតលើការនាំចូលអាហារ ដែលមានសំណល់ថ្នាំសម្លាប់សត្វល្អិត និងលើច្បាប់អឺរ៉ុបស្តីពីការនាំចូលផលិតផលកសិកម្មនិងឱសថកែច្នៃហ្សែន ដែលសហរដ្ឋអាមេរិកចង់នាំចេញទូទាំងពិភពលោក។

ដូច្នេះ វិធីសាស្ត្រឯកតោភាគីចំពោះបញ្ហាជីវចម្រុះនៅមានបញ្ហា ព្រោះវាអាចរំខានដល់ពាណិជ្ជកម្ម សេរី គោលការណ៍ពហុភាគីក៏មានបញ្ហាដោយសារបញ្ហាផលប្រយោជន៍រួម។ វាមិនគួរអោយភ្ញាក់ផ្អើលទេដែលការឆ្លើយតបរបស់អន្តរជាតិមិនមានប្រសិទ្ធភាព រហូតមកដល់បច្ចុប្បន្ន។

១១.២.៣. ព្រៃឈើ និងមហាសមុទ្រ

ជម្រកពីរប្រភេទ ព្រៃស្រោងត្រូពិចនិងមហាសមុទ្រ មានសារៈសំខាន់ខ្លាំងណាស់ ជាពិសេសចំពោះជីវចម្រុះនិងបរិយាកាស។ ជម្រកទាំងពីរប្រភេទនេះក៏ជាអាងស្តុកធនធានផ្តល់ប្រាក់ចំណេញផ្នែកពាណិជ្ជកម្ម ដូចជាព្រៃឈើនិងមច្ឆា។ អ្វីដែលខុសគ្នាត្រង់ថា ព្រៃឈើមានទីតាំងនៅក្នុងទឹកដីរដ្ឋមួយស្ទើរតែទាំងស្រុង ចំណែកមហាសមុទ្រស្ថិតនៅហួសពីរង្វង់ទឹកដីរបស់រដ្ឋណាតែមួយ នៅក្នុងទូទៅសកលលោក។

ព្រៃទឹកភ្លៀង

ប្រហែលពាក់កណ្តាលនៃប្រភេទសត្វទាំងអស់លើពិភពលោករស់នៅក្នុងព្រៃស្រោង *ឬព្រៃទឹកភ្លៀង* (rain forest) ដែលបញ្ចេញអុកស៊ីហ្សែននិងកាត់បន្ថយកាបូនឌីអុកស៊ីតក្នុងបរិយាកាស ម្លោះហើយនឹងជួយកាត់បន្ថយការឡើងកំដៅផែនដី។ ព្រៃទឹកភ្លៀងផ្តល់អត្ថប្រយោជន៍ដល់រដ្ឋទាំងអស់ក្នុងពិភពលោក ពួកវាជាផលប្រយោជន៍រួម។

ការចរចាជាអន្តរជាតិលើការអភិរក្សព្រៃឈើដែលទាក់ទាញទឹកភ្លៀង មានការរីកចម្រើនគួរអោយកត់សម្គាល់ ប្រហែលជាដោយសារព្រៃឈើទឹកភ្លៀងភាគច្រើនជារបស់រដ្ឋមួយចំនួនតូច។ រដ្ឋចំនួនតូចទាំងនេះមានអំណាចក្នុងការពន្លឿន ឬបន្ថយការកាប់បំផ្លាញព្រៃឈើ ហើយការចរចាជាអន្តរជាតិចំពោះកិច្ចព្រមព្រៀងដើម្បីបង្វែរការចំណាយពីរដ្ឋមួយចំនួនទាំងនោះ ទៅអោយក្រុមរដ្ឋដ៏ទូលំទូលាយជាអ្នកចំណាយដោយសារពួកគេក៏ទទួលផលពីព្រៃទឹកភ្លៀងដែរ។

ទោះបីជារដ្ឋអ្នកមានមួយចំនួន (រួមទាំងសហរដ្ឋអាមេរិក) មានព្រៃឈើធំក៏ដោយ ក៏ព្រៃឈើស្រោងធំៗភាគច្រើនស្ថិតនៅក្នុងរដ្ឋក្រីក្រដូចជា ប្រទេសប្រេស៊ីល ឥណ្ឌូនេស៊ី ម៉ាឡេស៊ី និងម៉ាដាហ្គាស្ការ។ រដ្ឋទាំងនេះអាចទទួលបានអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ច ពីការកេងចំណេញពីព្រៃឈើ ដូចជាការកាប់ឈើពាសវាលពាសកាល ការឈូសឆាយព្រៃយកដីធ្វើកសិកម្មនិងការជីកកកាយយករ៉ែជាដើម។ រហូតមកដល់ពេលថ្មីៗនេះ (ហើយនៅតែបន្តខ្លះដែរ) មេដឹកនាំប្រទេសអ្នកមានបានចាប់អារម្មណ៍ខ្លាំងបំផុត ក្នុងការលើកទឹកចិត្តអោយមានកំណើនសេដ្ឋកិច្ចជាអតិបរមានៅក្នុងរដ្ឋក្រីក្រ ទើបពួកគេមានលទ្ធភាពសងបំណុលបរទេស ដោយមិនគិតពីការខូចខាតបរិស្ថាននោះឡើយ។

បច្ចុប្បន្ននេះ ដោយសារប្រទេសអ្នកមានចាប់អារម្មណ៍លើការការពារព្រៃទឹកភ្លៀង ពួកគេកំពុងប្រើប្រាស់ជំនួយអភិវឌ្ឍន៍ជាឥទ្ធិពលដើម្បីជំរុញរដ្ឋក្រីក្រអោយការពារព្រៃឈើរបស់ពួកគេ ជាជាងការកេងចំណេញដោយកាប់ព្រៃឈើទាំងនោះ។ ក្រោមកិច្ចព្រមព្រៀងអន្តរជាតិដែលសម្រេចបាន នៅដើមទសវត្សរ៍ឆ្នាំ

១៩៩០ ប្រទេសអ្នកមានបានរួមចំណែករាប់រយលានដុល្លារជាជំនួយបរទេសសម្រាប់គោលបំណងនេះ។ នៅក្នុងប្រទេសក្រីក្រមួយចំនួនដែលរងអម្រែកបំណុលបរទេសធំៗ អ្នកការពារបរិស្ថាន និងធនាគារិកមកពីរដ្ឋអ្នកមានបានធ្វើការដោះស្រាយបំណុលតាមគំរូដែលហៅថា ការទូទាត់បំណុលដោយធម្មជាតិ ដែលបំណុលត្រូវបានលុបចោលជាថ្នូរនឹងកិច្ចព្រមព្រៀងរបស់រដ្ឋក្នុងការថែរក្សាព្រៃឈើ។ ជាឧទាហរណ៍ នៅក្នុងឆ្នាំ ២០០៦ រដ្ឋាភិបាលសហរដ្ឋអាមេរិកនិងអង្គការក្រៅរដ្ឋាភិបាលបានជួយប្រទេសហ្គាតេម៉ាឡា (Guatemala) លុបចោលបំណុលជាង ២០ លានដុល្លារជាថ្នូរនឹងកម្មវិធីអភិរក្សដែលត្រូវពង្រីកកាន់តែធំ។ ក្នុងឆ្នាំ ២០១៤ ប្រទេសលីបេរីយ៉ា និងប៉េរូបានយល់ព្រមបញ្ចប់ការកាប់បំផ្លាញព្រៃឈើ ជាថ្នូរនឹងការសន្យាផ្តល់ជំនួយបរទេសដ៏សំខាន់មួយ ពីសំណាក់ប្រទេសន័រវេស។ ក្នុងឆ្នាំ ២០០៨ ប្រទេសប្រេស៊ីលបានប្រកាសថា ខ្លួនមានគម្រោងបញ្ចប់ការកាប់បំផ្លាញព្រៃឈើក្នុងរយៈពេលមួយទសវត្សរ៍។ អ្នកការពារបរិស្ថានបានគិតថា ផែនការនេះមានសុទិដ្ឋិនិយមហួសហេតុ ហើយឥឡូវនេះប្រេស៊ីលនិយាយថាខ្លួនសង្ឃឹមថានឹងកាត់បន្ថយការកាប់ព្រៃឈើនៅត្រឹមឆ្នាំ ២០២០។


មហាសមុទ្រ

*មហាសមុទ្រ*ដែលគ្របដណ្តប់ជាង ៧០ ភាគរយនៃផ្ទៃផែនដី (ដូចព្រៃទឹកភ្លៀងដែរ) គឺជាគន្លឹះមួយក្នុងការគ្រប់គ្រងអាកាសធាតុនិងការថែរក្សាជីវចម្រុះ។ មហាសមុទ្រ ដូចជាព្រៃឈើ គឺជាគោលដៅដ៏ទាក់ទាញសម្រាប់ការប្រើប្រាស់សេដ្ឋកិច្ចក្នុងរយៈពេលខ្លី ដែលបណ្តាលអោយខូចខាតដល់បរិស្ថានក្នុងរយៈពេលវែង។ ការប្រើប្រាស់បែបនេះរួមមានការនេសាទហួសកម្រិត ការបោះចោលកាកសំណល់ពុលនិងនុយក្លេអ៊ែរ (និងសំរាមផ្សេងទៀត) និងការដឹកជញ្ជូនប្រេងផ្លូវឆ្ងាយ ដោយមានការហៀរកំពប់កើតឡើងដដែលៗ។ ខុសពីព្រៃស្រោងទាក់ទាញទឹកភ្លៀង មហាសមុទ្រមិនមែនជាកម្មសិទ្ធិរបស់រដ្ឋណាមួយទេ ប៉ុន្តែជាសម្បត្តិសាធារណៈសកលលោកទាំងមូល។ ប្រការនេះធ្វើអោយបញ្ហាផលប្រយោជន៍រួមកាន់តែពិបាក ព្រោះគ្មានអាជ្ញាធរកំពូលសម្រាប់អនុវត្តច្បាប់ឡើយ។ ការថែរក្សាមហាសមុទ្រត្រូវអាស្រ័យលើកិច្ចសហប្រតិបត្តិការរវាងរដ្ឋជាង ១០០ និងតួអង្គមិនមែនរដ្ឋរាប់ពាន់។ ក្រុមអ្នកជិះសេះលែងដៃមានឱកាសច្រើនក្នុងការកេងចំណេញ។ ឧទាហរណ៍ *អួនធំៗ* ដែលជាប្រភេទសំណាញ់មានប្រវែងរាប់សិបម៉ាយល៍ អាចចាប់ឬកៀរយកអ្វីៗគ្រប់យ៉ាងដែលនៅនឹងមុខវា។ វាផ្តល់ផលចំណេញច្រើន ប៉ុន្តែក៏បំផ្លិចបំផ្លាញបរិស្ថានមហាសមុទ្រមិនអោយមាននិរន្តរភាពផងដែរ។ ឥឡូវនេះ រដ្ឋភាគច្រើនបានហាមឃាត់ការប្រើប្រាស់សំណាញ់អួនទាំងនេះ (ក្រោមសម្ពាធពីចលនាការពារបរិស្ថាន)។ ទោះជាយ៉ាងណាក៏ដោយ គ្មានរដ្ឋណាមានសិទ្ធិអំណាចលើ**សមុទ្រជ្រៅ** (high seas) (ផ្ទៃទឹកមិនមែនជាដែនដីរបស់រដ្ឋណាមួយឡើយ) និងបញ្ឈប់ការប្រើប្រាស់អួនទាំងនេះដោយខុសច្បាប់នោះទេ។

ក្រាហ្វិក ១១.៤ ដែនទឹក ក្រោមការគ្រប់គ្រងដោយរដ្ឋ

ការនេសាទហួសហេតុនិងបញ្ហាស្រដៀងគ្នានៃការគ្រប់គ្រង«សមូហភាព»នៃមហាសមុទ្រពិភពលោកត្រូវបានដោះស្រាយដោយការឡោមព័ទ្ធ តំបន់មហាសមុទ្រដ៏សំខាន់បំផុតអោយស្ថិតនៅក្រោមការគ្រប់គ្រងផ្តាច់មុខរបស់រដ្ឋ។ តំបន់ដែលមានស្រមោលព័ទ្ធជុំវិញស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ(EEZ) រយៈចម្ងាយ ២០០ ម៉ាយល៍ ដែលគ្រប់គ្រងដោយរដ្ឋ ក្រោមលក្ខខណ្ឌនៃសន្ធិសញ្ញាUNCLOS ។

ប្រភព៖ ផ្អែកលើ Andrew Boyd, An Atlas of World Affairs, ៩th ed ។ ញូវយ៉ក៖ Routledge ឆ្នាំ ១៩៩២។


150 120 90 60 30 0 30 60 90 120 150 180
60
30
0
30
60
Baltic Straits
Turkish Straits
Dover Straits
Gibraltar Straits
SUEZ CANAL
Hormuz Straits
PANAMA CANAL
Bab el Mandeb Straits
Malacca Straits
Sunda Straits
Magellan Straits
200 mile offshore economic zone

ដំណោះស្រាយមួយដែលរដ្ឋនានាបានបន្តប្រើប្រាស់ ពាក់ព័ន្ធនឹង«ការព័ទ្ធរបង»មហាសមុទ្របន្ថែមទៀត។ ដែនទឹករបស់រដ្ឋត្រូវពង្រីកដល់ផ្ទៃទឹករាប់រយម៉ាយល៍ពីឆ្នេរសមុទ្រ(និងជុំវិញកោះ) ដូច្នេះ អធិបតេយ្យភាពរបស់រដ្ឋបានគ្របដណ្តប់ធនធានជាច្រើនដូចជា ដលផល និងអាងស្តុកប្រេងនិងរ៉ែនៅឈូងសមុទ្រ។ ដំណោះស្រាយនេះត្រូវបានបន្ត នៅក្នុងបរិបទនៃការចរចាពហុភាគីធំជាង លើការគ្រប់គ្រងមហាសមុទ្រ។

អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ (UNCLOS) ដែលត្រូវបានចរចាពីឆ្នាំ ១៩៧៣ ដល់ឆ្នាំ ១៩៨២ គ្រប់គ្រងការប្រើប្រាស់ផ្ទៃមហាសមុទ្រ។ បន្ទាប់ពីការពន្យាពេលជាងមួយទសវត្សរ៍ និងការចរចាឡើងវិញនូវទិដ្ឋភាពមួយចំនួននៃការរុករករ៉ែនៅក្នុងសមុទ្រជ្រៅ សហរដ្ឋអាមេរិកបានចុះហត្ថលេខាលើអនុសញ្ញា UNCLOS ក្នុងឆ្នាំ ១៩៩៤ ប៉ុន្តែ មិនទាន់បានផ្តល់សច្ចាប័នលើអនុសញ្ញានេះនៅឡើយទេ។ អនុសញ្ញា UNCLOS បានបង្កើតច្បាប់ស្តីពីដែនដីទឹក ដោយបែងចែកផ្ទៃទឹក ពីឆ្នេរ ចម្ងាយ ១២ ម៉ាយល៍ (១៩,៣ គីឡូម៉ែត្រ)សម្រាប់ការដឹកជញ្ជូន និងតំបន់សេដ្ឋកិច្ចផ្តាច់មុខ(EEZ) ២០០ ម៉ាយល៍ (៣២១,៨ គីឡូម៉ែត្រ)សម្រាប់សកម្មភាពសេដ្ឋកិច្ច ដូចជាការនេសាទ និងការរុករករ៉ែ។ ដែនកំណត់ ២០០ ម៉ាយល៍ បានទុកជាក់ធនធានមហាសមុទ្រដែលផ្តល់ផលចំណេញសេដ្ឋកិច្ច នៅក្នុងការគ្រប់គ្រងរបស់រដ្ឋ ប្រហែលចំនួនបួនដង់ប (សូមមើលក្រាហ្វិក ១១.៤)។

ការបកស្រាយផ្សេងៗគ្នា បង្កអោយមានជម្លោះអំពីសិទ្ធិសេដ្ឋកិច្ចនៅក្នុងទីតាំងមួយចំនួន។ នៅសមុទ្រចិនខាងត្បូង ប្រទេសចិន ហ្វីលីពីន ម៉ាឡេស៊ី តៃវ៉ាន់ ប្រ៊ុយណេ និងវៀតណាមសុទ្ធតែបានទាមទារកោះតូចៗ និងថ្មប៉ប្រះទឹក។ បណ្តាកោះនិងថ្មប៉ប្រះទឹកស្ថិតនៅជិតតំបន់អាងស្តុកប្រេង ដែលនឹងមានតម្លៃខ្លាំងណាស់សម្រាប់រដ្ឋដែលបានទទួលការទាមទារនេះ។ ក្នុងកំឡុងប្រាំឆ្នាំកន្លងមក ប្រទេសចិនបានប្រើប្រាស់ម៉ាស៊ីនបូមខ្សាច់ចាក់បំពេញដើម្បីពង្រីកថ្មប៉ប្រះទឹក។ ប្រទេសចិនបានទាមទារកោះដែលបង្កើតឡើងដោយមនុស្សថ្មីៗទាំងនេះ ហើយបានប្រើវាជាមូលដ្ឋានយោធាសម្រាប់សមត្ថភាពទ័ពជើងទឹក និងអាកាស។

អនុសញ្ញា UNCLOS ក៏បានបង្កើតគោលការណ៍ទូទៅដែលថា មហាសមុទ្រគឺជាមរតករួមរបស់មនុស្សជាតិ។ យន្តការមួយត្រូវបានបង្កើតឡើង តាមរយៈអាជ្ញាធរបាតសមុទ្រអន្តរជាតិសម្រាប់ការចែករំលែកទ្រព្យសម្បត្តិមួយចំនួនដែលរដ្ឋអ្នកមានអាចទទួលបាន ពីការទាញយករ៉ែនៅលើបាតសមុទ្រ (លើសពី ២០០ ម៉ាយល៍)។

ទ្វីបអង់តាក់ទិក

ដូចមហាសមុទ្រដែរ *ទ្វីបអង់តាក់ទិក*មិនមែនជាកម្មសិទ្ធិរបស់រដ្ឋណាមួយទេ។ ទោះជាយ៉ាងណាក៏ដោយ តម្លៃយុទ្ធសាស្ត្រនិងពាណិជ្ជកម្មរបស់ទ្វីបនេះនៅមានកម្រិត ហើយមិនមានរដ្ឋច្រើនខ្វល់ខ្វាយពីវានោះទេ។ ដូច្នេះ រដ្ឋនានាបានទទួលជោគជ័យក្នុងការឈានដល់កិច្ចព្រមព្រៀងលើទ្វីបអង់តាក់ទិក ដោយសារការចំណាយទាបហើយពាក់ព័ន្ធនឹងតួអង្គតិចតួច។ *សន្ធិសញ្ញាអង់តាក់ទិកឆ្នាំ ១៩៥៩* ដែលជាសន្ធិសញ្ញាពហុភាគីដំបូងបង្អស់ដែលទាក់ទងនឹងបរិស្ថាន ហាមឃាត់សកម្មភាពយោធា ក៏ដូចជាវត្តមានអាវុធនុយក្លេអ៊ែរ ឬការបោះចោលកាកសំណល់នុយក្លេអ៊ែរ។ វាកំណត់ការទាមទារទឹកដីនៅលើទ្វីបនេះសម្រាប់ដំណោះស្រាយនាពេលអនាគត និងបង្កើតរបបមួយដែលរដ្ឋផ្សេងៗធ្វើការស្រាវជ្រាវវិទ្យាសាស្ត្រនៅអង់តាក់ទិក។ សន្ធិសញ្ញានេះត្រូវបានចុះហត្ថលេខាដោយរដ្ឋទាំងអស់ដែលមានផលប្រយោជន៍នៅក្នុងតំបន់ រួមទាំងប្រទេសមហាអំណាចទាំងពីរផងដែរ។ នៅឆ្នាំ ១៩៩១ អង្គការបរិស្ថានGreenpeaceបានបញ្ចុះបញ្ចូលប្រទេសហត្ថលេខីនៃ

សន្ធិសញ្ញាអោយប្រែក្លាយទ្វីបទៅជា «ឧទ្យានពិភពលោក»។ ទ្វីបអង់តាក់ទិកគឺជារឿងជោគជ័យមួយដ៏ធំនៅក្នុងនយោបាយបរិស្ថានអន្តរជាតិ។

១១.២.៤. ការបំពុលបរិស្ថាន

ការបំពុលបរិស្ថានជាទូទៅបង្កើតជាបញ្ហាផលប្រយោជន៍រួម ប៉ុន្តែ មិនតែងតែជាបញ្ហាដែលមានលក្ខណៈជាសកលទេ។ ការបំពុលបរិស្ថានច្រើនតែជាបញ្ហាក្នុងតំបន់ ឬទ្វេភាគី។ ជាមួយនឹងករណីលើកលែងមួយចំនួនដូចជាការបោះចោលកាកសំណល់ទៅក្នុងសមុទ្រ ផលប៉ះពាល់នៃការបំពុលបរិស្ថានស្ថិតក្នុងដែនកំណត់របស់រដ្ឋបង្កនិងរដ្ឋជិតខាងកៀកបំផុត ការបំភាយផ្សែងក្នុងឧស្សាហកម្មរបស់សហរដ្ឋអាមេរិកបណ្តាលអោយមានភ្លៀងអាស៊ីតនៅក្នុងប្រទេសកាណាដា ប៉ុន្តែមិនប៉ះពាល់ដោយផ្ទាល់ដល់រដ្ឋឆ្ងាយៗនោះទេ។ ការបំពុលខ្យល់ដ៏អាក្រក់របស់ប្រទេសចិន បានបណ្តាលអោយជនជាតិចិនជិតកន្លះលាននាក់ត្រូវបាត់បង់ជីវិត ក្នុងមួយឆ្នាំៗ ប៉ុន្តែប៉ះពាល់ជនបរទេសតិចតួចប៉ុណ្ណោះ។ សូម្បីតែនៅពេលដែលការបំពុលឆ្លងកាត់ព្រំដែនរដ្ឋ ជារឿយៗវាមានឥទ្ធិពលខ្លាំងបំផុត នៅត្រឹមជិតប្រភពបង្កបំផុត។ ផលប៉ះពាល់ត្រឹមក្នុងតំបន់បែបនេះធ្វើអោយបញ្ហាផលប្រយោជន៍រួមមិនសូវគួរអោយចាប់អារម្មណ៍ ដោយសាររដ្ឋណាមួយដែលបំពុលមិនងាយជិះលែងដៃបានទេ ហើយមានតួអង្គតិចតួចពាក់ព័ន្ធ។

នៅក្នុងតំបន់មួយចំនួន ជាពិសេសអឺរ៉ុបខាងលិចនិងខាងកើត និងមជ្ឈិមបូព៌ា រដ្ឋនានារស់នៅផ្តុំគ្នាជាក ដងែ្ហមពីបរិយាកាសខ្យល់ដូចគ្នា ប្រើប្រាស់ទឹកទន្លេឬអាងសមុទ្រដូចគ្នា។ ក្នុងស្ថានភាពបែបនេះ ការគ្រប់គ្រងការបំពុលត្រូវតែចរចាជាពហុភាគី។ នៅអឺរ៉ុបក្នុងកំឡុងសង្គ្រាមត្រជាក់ បញ្ហាបំពុលអន្តរជាតិកាន់តែធ្ងន់ធ្ងរទៅៗ ដោយសារអសមត្ថភាពរបស់រដ្ឋអឺរ៉ុបខាងលិចក្នុងការដាក់កម្រិតណាមួយលើរដ្ឋអឺរ៉ុបខាងកើត ដែលមានការបំពុលខ្លាំងក្លា។

កិច្ចព្រមព្រៀងក្នុងតំបន់ជាច្រើនបានព្យាយាមកំណត់កម្រិតនៃ**ភ្លៀងអាស៊ីត** (acid rain) ដែលបង្កឡើងដោយការបំពុលបរិយាកាស។ រដ្ឋអឺរ៉ុបនានា ដែលព្រៃឈើរបស់ខ្លួនត្រូវបានបំផ្លិចបំផ្លាញយ៉ាងខ្លាំង បានយល់ព្រមកម្រិតការបំពុលបរិយាកាសនិងភ្លៀងអាស៊ីត ដើម្បីផលប្រយោជន៍គ្នាទៅវិញទៅមក។ នៅក្នុងឆ្នាំ ១៩៨៨ រដ្ឋចំនួន ២៤ នៅអឺរ៉ុប បានចុះហត្ថលេខាលើសន្ធិសញ្ញាកំណត់ការបំភាយឧស្ម័នអាសូតអុកស៊ីតដល់កម្រិត ១៩៨៨ យ៉ាងយូរត្រឹមឆ្នាំ ១៩៩៥។ បន្ទាប់ពីការចរចារដ៏យូរ សហរដ្ឋអាមេរិក និងកាណាដាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងទ្វេភាគីដើម្បីកំណត់ការបំពុលបែបនេះផងដែរ។ កិច្ចព្រមព្រៀងតំបន់ទាំងនេះបានដំណើរការយ៉ាងល្អ។

រូបថត *កុមារាប៉ាឡេស្ទីនជិះកង់លេងនៅជិតអាងទឹកស្អុយឆ្នាំ ២០១៨*

ទឹកកខ្វក់

ការបំពុលទឹកគឺជាការគំរាមកំហែងជាតិនិងអន្តរជាតិចំពោះសុខភាពនិងសុវត្ថិភាព។ ជាឧទាហរណ៍ ដោយសារកង្វះខាតប្រេងឥន្ធនៈ តំបន់ហ្គាហ្សាមិនអាចរក្សាដំណើរការរោងចក្រប្រព្រឹត្តិកម្មទឹកស្អុយដ៏សំខាន់របស់ខ្លួនបានទេ។ ទឹកស្អុយច្រើនតែត្រូវបានបញ្ចេញចេញពីអាងទឹក ចូលទៅក្នុងមហាសមុទ្រ។ នៅទីនេះ កុមារាប៉ាឡេស្ទីនជិះកង់លេងនៅជិតអាងទឹកស្អុយឆ្នាំ ២០១៨ ។

*ការបំពុលទឹក*ជារឿយៗឆ្លងកាត់ព្រំដែនជាតិនានា ជាពិសេស ដោយសារតែការបំពុលឧស្សាហកម្ម កាកសំណល់របស់មនុស្ស និងជីកសិកម្ម និងថ្នាំសម្លាប់សត្វល្អិត ដែលសុទ្ធសឹងទំនងជាត្រូវបង្ហូរចូលទៅក្នុង

ទន្លេនិងសមុទ្រ។ ជាឧទាហរណ៍ ក្នុងឆ្នាំ ២០០៥ ការកំពប់គីមីដ៏ធំមួយនៅភាគឦសានប្រទេសចិន បានបំពុលទន្លេដែលហូរចូលទៅក្នុងប្រទេសរុស្ស៊ី។ ភ្នាក់ងារក្នុងតំបន់ដែលឈរជើងយូរមកហើយ ដែលគ្រប់គ្រងការដឹកជញ្ជូនតាមដងទន្លេអឺរ៉ុបដែលប្រើប្រាស់ច្រើន ឥឡូវនេះ ក៏ត្រូវដោះស្រាយជាមួយនឹងបញ្ហាបំពុលផងដែរ។ អាងសមុទ្រមេឌីទែរ៉ាណេមានការបំពុលយ៉ាងធ្ងន់ធ្ងរ និងពិបាកក្នុងការគ្រប់គ្រង ដោយសាររដ្ឋជាច្រើនមានព្រំប្រទល់ជាប់សមុទ្រនេះ។ ក្នុងឆ្នាំ ២០១០ ការធ្លាយប្រេងដោយចៃដន្យដ៏ធំបំផុតក្នុងប្រវត្តិសាស្ត្របានកើតឡើងនៅឈូងសមុទ្រមិកស៊ិក។ ការកំពប់នេះបណ្តាលមកពីការផ្ទុះនៅលើអណ្តូងប្រេង។ ការលេចធ្លាយនេះបានចំណាយពេលរាប់ខែដើម្បីទប់ស្កាត់ និងបានគូសបញ្ជាក់ពីគ្រោះថ្នាក់ទាក់ទងនឹងការខួងយកប្រេងក្នុងទឹកជ្រៅ។ ក្រុមហ៊ុនប្រេងអង់គ្លេស «British Petroleum» ដែលជាក្រុមហ៊ុនដែលដំណើរការអណ្តូងប្រេងនោះ បានយល់ព្រមទុកលុយរាប់ប៊ីលានដុល្លារ ដើម្បីសងការខូចខាតដល់អ្នករស់នៅក្នុងរដ្ឋភាគខាងត្បូងមួយចំនួនរបស់សហរដ្ឋអាមេរិកដែលរងផលប៉ះពាល់ដោយការធ្លាយប្រេង។

*ភាកសំណល់ពុល*និង*នុយក្លេអ៊ែរ* គឺជាបញ្ហាពិសេសមួយ ដោយសារតែវាមានគ្រោះថ្នាក់យូរអង្វែង។ ម្តងម្កាល រដ្ឋព្យាយាមដឹកជញ្ជូនកាកសំណល់បែបនេះចេញពីប្រទេសរបស់ខ្លួន។ ទោះជាយ៉ាងណាក៏ដោយ កិច្ចព្រមព្រៀងអន្តរជាតិ ឥឡូវនេះ ហាមឃាត់ការបោះចោលកាកសំណល់ពុលនិងនុយក្លេអ៊ែរទៅក្នុងសមុទ្រ (ជាបញ្ហាផលប្រយោជន៍រួមជាក់លាក់)។ ប៉ុន្តែ កាកសំណល់បែបនេះ ត្រូវបានបញ្ជូនទៅចាក់ចោលក្នុងប្រទេសកំពុងអភិវឌ្ឍន៍ជាថ្នូរនឹងប្រាក់បង់ថ្លៃមួយចំនួន។ ជាឧទាហរណ៍ ផេះធ្ងន់បំពុលពីរដ្ឋ Pennsylvania បានក្លាយជាសម្ភារៈផលិតឥដ្ឋនៅក្នុងប្រទេសហ្គីណេ ហើយកាកសំណល់នុយក្លេអ៊ែររបស់អ៊ីតាលីត្រូវបានដឹកជញ្ជូនទៅប្រទេសនីហ្សេរីយ៉ា។

បទដ្ឋានបានបង្កើតឡើងក្នុងប៉ុន្មានឆ្នាំថ្មីៗនេះប្រឆាំងនឹងការនាំចេញកាកសំណល់ពុល ដែលជាការអនុវត្តដែលត្រូវបានគេមើលឃើញថាជាការកេងប្រវ័ញ្ចលើប្រទេសគោលដៅ។ នៅឆ្នាំ ១៩៨៩ រដ្ឋចំនួន ១០០ បានចុះហត្ថលេខាលើសន្ធិសញ្ញាមួយ ក្រោមការឧបត្ថម្ភរបស់អង្គការសហប្រជាជាតិ ដើម្បីគ្រប់គ្រងការដឹកជញ្ជូនកាកសំណល់ពុលនិងនុយក្លេអ៊ែរ និងទប់ស្កាត់ការដឹកជញ្ជូនដោយសម្ងាត់តាមកិច្ចព្រមព្រៀងដោយពុករលួយណាមួយ។ ប្រទេសចំនួន ៤០ ទៀត នៅក្នុងទ្វីបអាហ្វ្រិក មិនបានចុះហត្ថលេខាលើសន្ធិសញ្ញានេះទេ ប៉ុន្តែបានអំពាវនាវអោយបញ្ឈប់ទាំងស្រុងនូវការដឹកជញ្ជូនកាកសំណល់ពុលទៅកាន់ទ្វីបអាហ្វ្រិក។ ទោះជាយ៉ាងណាក៏ដោយ ក្នុងឆ្នាំ ២០០៦ ក្រុមហ៊ុនពហុជាតិមួយ ដែលមានមូលដ្ឋាននៅក្នុងប្រទេសសាំងហ្គាពួរបានព្យាយាមបោះចោលកាកសំណល់ពុលពីកប៉ាល់ដឹកប្រេងនៅប្រទេសហូឡង់។ ក្រោយពេលបានដឹងរឿងនេះ ជនជាតិហុល្លង់បានតម្លើងថ្លៃបោះចោលកាកសំណល់ កប៉ាល់នោះបានបកត្រលប់ក្រោយវិញ ដើម្បីស្វែងរកទីតាំងថ្មីចាក់ចោល។ ប្រាំមួយសប្តាហ៍ក្រោយមក កប៉ាល់នោះបានយកកាកសំណល់ពុលទៅចាក់ចោល ក្នុងទីក្រុងអាប៊ីដចាន (Abidjan) ប្រទេស កូតឌីវ័រ (Ivory Coast) ជាកន្លែងដែលក្រុមហ៊ុនក្នុងស្រុកមួយបានបោះចោលវានៅទីតាំងជុំវិញទីក្រុង។ អ្នកស្រុករាប់ពាន់នាក់បានឈឺ ហើយមនុស្ស ៨ នាក់បានស្លាប់។ ក្នុងឆ្នាំ ២០០៧ ក្រុមហ៊ុនបានយល់ព្រមបង់ប្រាក់សំណង ២០០ លានដុល្លារដើម្បីដោះស្រាយការប្តឹងទាមទារ។

នៅឆ្នាំ ១៩៨៦ ការរលាយនៅរោងចក្រថាមពលនុយក្លេអ៊ែរសូវៀត នៅក្រុងឆេណូប៊ីល (Chernobyl) ក្នុងប្រទេសអ៊ុយក្រែនបានបង្កើតវិទ្យុសកម្មនៅលើអាកាស ដែលរាលដាលពាសពេញទ្វីបអឺរ៉ុប តាំងពីប្រទេសអ៊ីតាលីរហូតដល់ស៊ុយអែត។ ឧបទ្ទវហេតុនេះបានបង្ហាញពីទិដ្ឋភាពថ្មី ដែលថា ការសម្រេចចិត្តផ្នែកសេដ្ឋកិច្ច

និងបច្ចេកទេសដែលបានធ្វើឡើងនៅក្នុងរដ្ឋមួយ អាចមានផលវិបាកធ្ងន់ធ្ងរដល់បរិស្ថានសម្រាប់ប្រទេសដទៃទៀត។ មេដឹកនាំសូវៀតបានធ្វើអោយបញ្ហាកាន់តែធ្ងន់ធ្ងរ ដោយការខកខានមិនបានជូនដំណឹងដល់រដ្ឋជិតខាងភ្លាមៗអំពីគ្រោះថ្នាក់នេះ។

លើបញ្ហាផ្សេងៗនៃការបំពុលទឹកនិងខ្យល់ ទាំងសកម្មភាពរដ្ឋឯកតោភាគី និងកិច្ចព្រមព្រៀងអន្តរជាតិជាញឹកញាប់ អាចធ្វើទៅបាននិងមានប្រសិទ្ធភាព។ ក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ថ្មីៗនេះ គុណភាពទឹកទន្លេបានប្រសើរឡើងនៅក្នុងតំបន់ឧស្សាហកម្មភាគច្រើន។ សេដ្ឋកិច្ចទីផ្សារបានចាប់ផ្តើមដោះស្រាយជាមួយនឹងការបំពុល ដែលចាត់ទុកវាជាតម្លៃផលិតកម្មបន្ថែមទៀត ដែលគួរតែទូទាត់ពីអ្នកបំពុលជាជាងទាមទារពីសង្គមជាតិ។ រដ្ឋាភិបាលមួយចំនួនបានចាប់ផ្តើមបែងចែក «សិទ្ធិបំពុល» ដែលក្រុមហ៊ុនអាចទិញ និងលក់ដូរនៅលើទីផ្សារសេរី។

នៅក្នុងអតីតប្លុកសូវៀត ដំណើរការនៃឧស្សាហូបនីយកម្មតាមសេដ្ឋកិច្ចផែនការអស់រយៈពេលច្រើនទសវត្សរ៍ បានបង្កបញ្ហាបរិស្ថានកាន់តែធ្ងន់ធ្ងរ។ ជាមួយនឹងការបំផ្លិចបំផ្លាញបរិស្ថានដ៏គួរអោយភ្ញាក់ផ្អើល និងផលប៉ះពាល់សុខភាពមនុស្ស អតីតសាធារណរដ្ឋសូវៀតដែលមានសេដ្ឋកិច្ចជាប់គាំងត្រូវតែចរចាអំពី ការកំណត់ការបំពុល និងជួសជុលការខូចខាត។ ជាឧទាហរណ៍ សមុទ្រអារ៉ាល់ (Aral Sea) ដែលត្រូវបានបំពុលយ៉ាងធ្ងន់ធ្ងរ ដែលពីមុនមាននៅក្នុងរដ្ឋតែមួយ នោះគឺ សហភាពសូវៀត ឥឡូវនេះ ជាសម្បត្តិរួមរបស់រដ្ឋពីរ គឺកាហ្សាក់ស្តាន និងអ៊ូសបេគីស្តាន។ ធ្លាប់តែជាសមុទ្រទឹកជ្រៅធំជាងគេលំដាប់ទីបួននៅលើពិភពលោក ឥឡូវនេះ វាបានរួមតូចជាងពាក់កណ្តាល ជលផលដ៏ធំធេងរបស់វាត្រូវបំផ្លាញ បន្ទាប់ពីគម្រោងធារាសាស្ត្រដ៏ធំក្នុងសម័យសូវៀតដើម្បីដាំកប្បាសនៅវាលខ្សាច់ បានបង្វែរដៃទន្លេរបស់សមុទ្រអារ៉ាល់ និងបំពុលពួកវាដោយថ្នាំសម្លាប់សត្វល្អិត។ អតីតក្រុងនេសាទបានចាប់ផ្តើមសង្កេតឃើញថាខ្លួនឯងស្ថិតនៅឆ្ងាយពីច្រាំងសមុទ្រ ក្នុងចម្ងាយច្រើនម៉ាយល៍។ បន្ទាប់ពីមេដឹកនាំនយោបាយក្នុងស្រុក និងអន្តរជាតិបរាជ័យក្នុងការអនុវត្តផែនការដោះស្រាយបញ្ហានេះ ប្រជាជនក្នុងស្រុកបានទទួលរងនូវផលប៉ះពាល់សុខភាពយ៉ាងទូលំទូលាយ ពីគ្រោះមហន្តរាយនេះ។

១១.៣. ធនធានធម្មជាតិ

១១.៣ ចូរពិពណ៌នាស្ថានភាពចំនួនបី ដែលតម្រូវការធនធានធម្មជាតិអាចបង្កជាជម្លោះអន្តរជាតិ។

បរិស្ថានធម្មជាតិមិនត្រឹមតែជាប្រព័ន្ធអេកូឡូស៊ីដ៏សាំញ៉ាំដែលទាមទារការការពារប៉ុណ្ណោះទេ ប៉ុន្តែក៏ជាឃ្លាំងធនធានធម្មជាតិសំបូរបែបផងដែរ។ ដោយសារតែការទាញយកធនធានផ្តល់ទ្រព្យសម្បត្តិមហាសាលដល់រដ្ឋនានា ធនធានទាំងនេះតែងតែបញ្ចេះជម្លោះអន្តរជាតិ។ ទោះយ៉ាងណាក៏ដោយ ដោយសារតែពួកគេភាគច្រើនមានទីតាំងស្ថិតនៅក្នុងរដ្ឋនីមួយៗ ពួកគេមិនបង្កជាបញ្ហាផលប្រយោជន៍រួមទេ។ ផ្ទុយទៅវិញ រដ្ឋនានាចរចាគ្នាលើធនធានសំខាន់ៗទាំងនេះ។

ទិដ្ឋភាពបីនៃធនធានធម្មជាតិកំណត់តួនាទីរបស់ពួកគេ នៅក្នុងជម្លោះអន្តរជាតិ។ ទីមួយ សេដ្ឋកិច្ចឧស្សាហកម្ម (ជួនកាលសូម្បីតែវិស័យកសិកម្ម) ត្រូវការពួកគេជាចាំបាច់សម្រាប់ប្រតិបត្តិការ។ ទីពីរ ប្រភពរបស់ពួកគេ (កំណប់ធនធានរ៉ែ ទន្លេ សមុទ្រ និងអ្វីៗផ្សេងទៀត)ត្រូវបានផ្សារភ្ជាប់ជាមួយនឹងទឹកដីជាក់លាក់ណាមួយដែលរដ្ឋទាំងឡាយអាចដណ្តើមគ្នាគ្រប់គ្រង។ ទីបី ធនធានធម្មជាតិហាក់ត្រូវបានពង្រាយឬបង្កប់តាមល្បាយមិនស្មើគ្នា ដោយមានការផ្គត់ផ្គង់ច្រើនសន្ធឹកសន្ធាប់នៅរដ្ឋមួយ មានតែបន្តិចនៅរដ្ឋផ្សឹង ឬគ្មាន

ទាល់តែសោះនៅក្នុងរដ្ឋមួយចំនួនទៀត។ ទិដ្ឋភាពទាំងនេះមានន័យថា ពាណិជ្ជកម្មធនធានធម្មជាតិទទួលបានផលចំណេញច្រើន។ ទ្រព្យសម្បត្តិបន្ថែមជាច្រើនត្រូវបានបង្កើតឡើងដោយការជួញដូរបែបនេះ។ ពួកគេក៏មានន័យផងដែរថា ការធ្វើពាណិជ្ជកម្មលើធនធានមានលក្ខណៈនយោបាយខ្លាំងណាស់ដែរដោយបង្កើតភាពមិនល្អឥតខ្ចោះនៃទីផ្សារ ដូចជា សិទ្ធិផ្តាច់មុខ បក្ខពួកនិយមផ្តាច់មុខ និងការគ្រប់គ្រងឬសារ៉េតម្លៃជួនកាល ដោយក្រុមការតែល (សូមមើល មេរៀនទី ៨)។

១១.៣.១. ប្រភពថាមពលពិភពលោក

ក្នុងចំណោមធនធានធម្មជាតិផ្សេងៗដែលរដ្ឋទាំងឡាយត្រូវការ ធនធានថាមពល (ឥន្ធនៈ) គឺជាធនធានសំខាន់ជាងគេ។ ឥន្ធនៈសម្រាប់ពាណិជ្ជកម្ម ដែលផ្តល់ថាមពលដល់សេដ្ឋកិច្ចឧស្សាហកម្មលើពិភពលោកគឺប្រេង (ប្រហែល ៤០ ភាគរយនៃការប្រើប្រាស់ថាមពលពិភពលោក) ធ្យូងថ្ម(៣០ ភាគរយ) ឧស្ម័នធម្មជាតិ (២៥ ភាគរយ) និងវារីអគ្គិសនីនិងថាមពលនុយក្លេអ៊ែរ(៥ ភាគរយ)។ ឥន្ធនៈហ្វូស៊ីល (ធ្យូងថ្ម ប្រេង ឧស្ម័ន) មានចំនួន ៩៥ ភាគរយនៃការប្រើប្រាស់ថាមពលពិភពលោក។ ថាមពលមួយចំនួនដែលប្រើប្រាស់ជាអគ្គិសនីបានមកពីទំនប់វារីអគ្គិសនីឬរោងចក្រថាមពលនុយក្លេអ៊ែរ ប៉ុន្តែភាគច្រើនវាបានមកពីការដុតឥន្ធនៈហ្វូស៊ីលនៅក្នុងរោងចក្រផលិតអគ្គិសនី។

តារាង ១១.១ ការប្រើប្រាស់ថាមពលក្នុងមនុស្សម្នាក់ និងពាណិជ្ជកម្មថាមពលសុទ្ធ ឆ្នាំ ២០១៥

	ការប្រើប្រាស់ក្នុងមនុស្សម្នាក់ (លាន BTU)	ការនាំចេញថាមពលសុទ្ធសរុប[ក] (quadrillion BTU)
អាមេរិកខាងជើង	២៨៥	-៣
អឺរ៉ុប	១៣៥	-៣៧
ជប៉ុន/ប៉ាស៊ីហ្វិក	១៨០	-៤០
រុស្ស៊ី/ភោគទ្រព្យរួមនៃរដ្ឋឯករាជ្យ	១៥៥	+៣១
ចិន	៨០	-១២
មជ្ឈឹមបូព៌ា	១៤០	+៤៧
អាមេរិកខាងត្បូង	៦០	+៣
អាស៊ីទក្សិណ	១៨	-៦
អាហ្វ្រិក	១៦	+១៣
ពិភពលោកទាំងមូល	៧៥	

ក. ការនាំចេញសរុបសំដៅលើទំហំផលិតកម្មដកចំនួនប្រើប្រាស់។ ការនាំចេញសរុបទូទាំងពិភពលោកមិនស្មើនឹងការនាំចូលសរុបទេ ដោយសារហេតុផលបច្ចេកទេស។

ប្រភពៈ គណនាពីក្រសួងថាមពលសហរដ្ឋអាមេរិក។ រដ្ឋបាលព័ត៌មានថាមពល។

សូមមើលបន្ថែម http://www.ela.doe.gov/iea

សាកស្រមៃមើលគំនរធ្យូងថ្មដែលមានទម្ងន់ ៦៥ ផោន។ ថាមពលដែលបញ្ចេញដោយការដុតធ្យូងថ្មយ៉ាងច្រើននេះ មានកម្រិតស្មើនឹងបរិមាណថាមពលដែលជនជាតិអាមេរិកខាងជើងប្រើប្រាស់ក្នុងមនុស្សម្នាក់

ជារៀងរាល់ថ្ងៃ។ ជាការពិតណាស់ អ្នកមានទ្រព្យសម្បត្តិច្រើនជាង ប្រើប្រាស់ថាមពល ក្នុងមនុស្សម្នាក់ៗ ច្រើនជាងអ្នកក្រីក្រ ប៉ុន្តែ ៦៥ ផោនគឺជាបរិមាណមធ្យម។ គំនរធ្យូងថ្មរបស់អាមេរិកខាងជើងនឹងធំជាងគំនរធ្យូងថ្មរបស់មនុស្សម្នាក់ៗនៅប្រទេសចិន ៤ ដង និង ២០ ដងនៃជនជាតិអាហ្វ្រិក។

តារាង ១១.១ បង្ហាញពីការប្រើប្រាស់ថាមពលក្នុងមនុស្សម្នាក់នៅក្នុងតំបន់ពិភពលោកទាំងប្រាំបួន។ តំបន់ឧស្សាហកម្មទាំងបួននៅអឌ្ឍគោលភាគខាងជើងប្រើប្រាស់ថាមពល ក្នុងមនុស្សម្នាក់ៗ ច្រើនជាងតំបន់អឌ្ឍគោលភាគខាងត្បូង។ ដោយសារតែអាស៊ីខាងត្បូងនិងអាហ្វ្រិកមានឧស្សាហកម្មតិចតួច អាមេរិកខាងជើងប្រើប្រាស់ ១៥ ដង ច្រើនជាងក្នុងមនុស្សម្នាក់ៗនៃតំបន់ទាំងពីរនោះ។ ក្នុងចំណោមប្រទេសឧស្សាហកម្មមានភាពខុសគ្នាបើនិយាយអំពីប្រសិទ្ធភាពនៃការប្រើប្រាស់ថាមពល (ផលិតផលក្នុងស្រុកសរុប [GDP] ដែលផលិតក្នុងមួយឯកតានៃថាមពលដែលត្រូវប្រើប្រាស់)។ ប្រសិទ្ធភាពតិចបំផុតគឺអតីតសាធារណរដ្ឋសូវៀត អាមេរិកខាងជើងក៏គ្មានប្រសិទ្ធភាពខ្លាំងណាស់ដែរ។ អឺរ៉ុបនិងជប៉ុនជាប្រទេសដែលប្រើប្រាស់ប្រភពថាមពលយ៉ាងមានប្រសិទ្ធិភាពខ្លាំងជាងគេ។

ដូច្នេះ ពាណិជ្ជកម្មអន្តរជាតិលើថាមពលដើរតួនាទីយ៉ាងសំខាន់ក្នុងសេដ្ឋកិច្ចពិភពលោក។ ដូចដែលតារាង ១១.១ បង្ហាញ តំបន់នៃឧស្សាហូបនីយកម្មលោកខាងលិច សុទ្ធតែជាអ្នកនាំចូលថាមពលសុទ្ធដ៏ធំ។ មជ្ឈិមបូព៌ា អាហ្វ្រិក និងរុស្ស៊ី គឺជាអ្នកនាំចេញថាមពល។ ទោះបីជាគ្រប់ទម្រង់នៃថាមពលត្រូវបានជួញដូរជាអន្តរជាតិក៏ដោយ ប៉ុន្តែ អ្វីដែលសំខាន់បំផុត គឺប្រេង ដែលត្រូវចំណាយទាបបំផុត ដើម្បីដឹកជញ្ជូនក្នុងចម្ងាយឆ្ងាយ។ ប្រទេសរុស្ស៊ីទទួលបានប្រាក់ចំណូលជារូបិយប័ណ្ណខ្លាំងដ៏សំខាន់ ពីការនាំចេញប្រេង។ ប្រទេសវេណេហ្ស៊ុយអេឡានិងមិកស៊ិក(នៅអាមេរិកឡាទីន) និងនីហ្សេរីយ៉ានិងអង់ហ្គោឡា (នៅអាហ្វ្រិក) ក៏ជាប្រទេសនាំចេញប្រេងដ៏សំខាន់ផងដែរ។ ប៉ុន្តែ រហូតមកដល់ពេលនេះ ប្រភពនៃការនាំចេញប្រេងដ៏ធំបំផុតស្ថិតនៅតំបន់មជ្ឈិមបូព៌ា ជាពិសេសបណ្តាប្រទេសជុំវិញឈូងសមុទ្រពែក្ស (អារ៉ាប៊ីសាអូឌីត គុយវ៉ែត អ៊ីរ៉ាក់ អ៊ីរ៉ង់ និងប្រទេសតូចៗនៃប្រទេសអារ៉ាប់រួម កាតា បារ៉ែន និងអូម៉ង់)។ អារ៉ាប៊ីសាអូឌីតគឺជាប្រទេសនាំចេញប្រេងធំជាងគេ ហើយមានស្តុកប្រេងច្រើនជាងគេ (សូមមើលតារាង ៨.១ ក្នុងមេរៀនទី ៨)។ នយោបាយថាមពលពិភពលោកវិលវល់ជុំវិញប្រេងនៅមជ្ឈិមបូព៌ា ដែលត្រូវដឹកជញ្ជូនទៅកាន់អឺរ៉ុបខាងលិច ចិន ជប៉ុន និងអាមេរិកខាងជើង។

សារៈសំខាន់នៃប្រេងនៅក្នុងសេដ្ឋកិច្ចឧស្សាហកម្ម អាចជួយពន្យល់ពីសារៈសំខាន់ផ្នែកនយោបាយនៃមជ្ឈិមបូព៌ានៅក្នុងនយោបាយពិភពលោក។ ថាមពលមិនត្រឹមតែជាវិស័យសេដ្ឋកិច្ចដ៏សំខាន់មួយប៉ុណ្ណោះទេ (ដែលសកម្មភាពឧស្សាហកម្មទាំងអស់ត្រូវអាស្រ័យលើវា) ប៉ុន្តែ វាក៏ជាវិស័យដ៏រសើបបំផុតផ្នែកនយោបាយផងដែរ ដោយសារតែការពឹងផ្អែករបស់បស្ចិមប្រទេសលើថាមពល ដែលនាំចូលពីមជ្ឈិមបូព៌ា និងតំបន់ផ្សេងៗទៀតនៃអឌ្ឍគោលខាងត្បូង។

ដើម្បីទទួលបានការផ្គត់ផ្គង់ប្រេងដែលមកពីមជ្ឈិមបូព៌ាដោយសុវត្ថិភាព ចក្រភពអង់គ្លេសនិងបណ្តាប្រទេសអឺរ៉ុបផ្សេងទៀតបានធ្វើអាណានិគមលើតំបន់នេះនៅដើមសតវត្សរ៍ទី ២០ ដោយបានបែងចែកទឹកដីទាំងអស់ទៅជារបបអាណាព្យាបាល ដោយប្រទេសមហាអំណាចអឺរ៉ុបទុកស្តេចក្នុងស្រុកអោយសោយរាជ្យនៅលើបល្ល័ង្ករបស់ពួកគេដដែល។ សហរដ្ឋអាមេរិកមិនបានទាមទារទឹកដីអាណានិគម ឬអាណាព្យាបាលទេ ប៉ុន្តែ ក្រុមហ៊ុនសាជីវកម្មពហុជាតិរបស់សហរដ្ឋអាមេរិកបានចូលរួមយ៉ាងសស្រាក់សស្រាំ នៅក្នុងការអភិវឌ្ឍន៍

ធនធានប្រេងនៅក្នុងតំបន់ ពីទសវត្សរ៍ឆ្នាំ ១៩២០ ដល់ឆ្នាំ ១៩៦០ ហើយជាញឹកញាប់មានអំណាចដ៏ខ្លាំងក្លាជាង។ ក្រុមហ៊ុនប្រេងរបស់សហរដ្ឋអាមេរិក និងអឺរ៉ុបទាំងនេះបានរក្សាតម្លៃដែលត្រូវបង់ទៅអោយរដ្ឋក្នុងស្រុកទាប ហើយទុកប្រាក់ចំណេញផ្គាល់របស់ពួកគេខ្ពស់ ប៉ុន្តែអ្នកគ្រប់គ្រងឬមេដឹកនាំក្នុងស្រុកពឹងផ្អែកលើជំនាញ និងការវិនិយោគដើមទុនរបស់ក្រុមហ៊ុនទាំងនេះ។

ក្រោយសង្គ្រាមលោកលើកទី ២ អង់គ្លេសបានបោះបង់ការទាមទារទឹកដីអាណានិគមនៅមជ្ឈិមបូព៌ា ប៉ុន្តែ ក្រុមហ៊ុនប្រេងបស្ចឹមលោកនៅតែបន្តផលិតប្រេងថោកនៅទីនោះ សម្រាប់ការប្រើប្រាស់របស់លោកខាងលិច។ បន្ទាប់មកនៅឆ្នាំ ១៩៧៣ ក្នុងអំឡុងពេលសង្គ្រាមអារ៉ាប់-អ៊ីស្រាអែល រដ្ឋអារ៉ាប់ដែលផលិតប្រេងក្នុងតំបន់ បានសម្រេចចិត្តដាក់ទណ្ឌកម្មសហរដ្ឋអាមេរិកសម្រាប់ការគាំទ្រអ៊ីស្រាអែល។ ពួកគេបានកាត់បន្ថយការនាំចេញប្រេងរបស់ពួកគេទៅកាន់សហរដ្ឋអាមេរិក និងកាត់បន្ថយការនាំចេញទាំងមូលរបស់ពួកគេ។ ការខាននការផ្គត់ផ្គង់នេះបានបណ្តាលអោយតម្លៃប្រេងលើពិភពលោកហក់ឡើងថ្លៃ។ អង្គការនៃប្រទេសនាំចេញប្រេង(OPEC) បានដឹងពីសក្តានុពលអំណាចរបស់ខ្លួន និងឆន្ទៈរបស់ពិភពលោកដែលសុខចិត្តចំណាយថ្លៃខ្ពស់សម្រាប់ប្រេង។ វិបត្តិប្រេងឆ្នាំ១៩៧៣នេះបានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើសេដ្ឋកិច្ចពិភពលោក និងលើនយោបាយពិភពលោក។ រូបិយប័ណ្ណខ្លាំងក្នុងចំនួនដ៏ច្រើន ត្រូវបានប្រមូលផ្តុំនៅក្នុងរតនាគារនៃបណ្តាប្រទេសនាំចេញប្រេងនៅមជ្ឈិមបូព៌ា ដែលក្រោយមក បានយកសាច់ប្រាក់ទាំងនោះទៅបណ្តាក់ទុន នៅជុំវិញពិភពលោក (ទាំងនេះត្រូវបានគេហៅថា «petrodollars» ដុល្លារសាំង)។ អតិផរណាខ្ពស់បានញាំញីសេដ្ឋកិច្ចសហរដ្ឋអាមេរិក និងអឺរ៉ុបអស់ជាច្រើនឆ្នាំក្រោយមក។ អស្ថិរភាពសេដ្ឋកិច្ច និងអារម្មណ៍អស់សង្ឃឹមរបស់សហរដ្ឋអាមេរិក បន្ថែមពីលើភាពតានតឹងដ៏កំពូលនៃសង្គ្រាមវៀតណាម ហាក់ដូចជាបង្ហាញពីការធ្លាក់ចុះនៃអំណាចអាមេរិក និងប្រហែលជាការរះឡើងនៃអឌ្ឍគោលខាងត្បូង។

ក្រាហ្វិក ១១.៥ ការបែងចែកសមុទ្រកាសព្យែន

សមុទ្រកាសព្យែន គឺដែនទឹកក្នុងទ្វីបដ៏ធំបំផុតលើពិភពលោក។ វាអាចត្រូវបានកំណត់ នៅក្រោមច្បាប់អន្តរជាតិ ថាជាបឹងឬសមុទ្រ។ បឹងមួយមានតំបន់រួមគ្នានៅកណ្តាល (ពណ៌បៃតងនៅក្នុងរូបខាងឆ្វេង) ដែលអាចធ្វើអាជីវកម្មបានលុះត្រាតែប្រទេសនានាយល់ព្រមលើលក្ខខណ្ឌ។ វាក៏មានតំបន់ឆ្នេរក្រោមការគ្រប់គ្រងផ្គាល់របស់ប្រទេសនីមួយៗផងដែរ។ នៅក្នុងសមុទ្រតិចជាងរយៈចម្ងាយ៤០០ម៉ាយល៍ តំបន់សេដ្ឋកិច្ចផ្តាច់មុខ(EEZs) ២០០ ម៉ាយល៍ របស់ប្រទេសជាប់ព្រំដែន បានបំបែកសមុទ្រទាំងមូល (រូបខាងស្តាំ)។ ប្រសិនបើតំបន់ទាំងមូលត្រូវបានបំបែកដូចនៅក្នុងផែនទីនៅខាងស្តាំ វិស័យអាចត្រូវបានកំណត់ដោយបន្ទាត់មធ្យម (បន្ទាត់ដាច់ៗ) ឬ ដោយការបែងចែកជាប្រាំផ្នែក ស្មើៗគ្នា (បន្ទាត់ចំនុចៗ) ដែលផ្តល់អោយអ៊ីរ៉ង់នូវផ្នែកធំជាងគេ។ ក្នុងឆ្នាំ ២០១០ ជាមួយនឹងការអភិវឌ្ឍប្រេងសំខាន់ៗដែលកំពុងដំណើរការនៅក្នុងតំបន់ឆ្នេរសមុទ្រនៃប្រទេសទាំង ៥ កិច្ចប្រជុំកំពូលបានយល់ព្រមផ្តល់អោយតំបន់នីមួយៗចម្ងាយ ២៥ ម៉ាយល៍។ ក្នុងឆ្នាំ ២០១២ រុស្ស៊ីបានធ្វើសមយុទ្ធយោធារួមគ្នាជាមួយកាហ្សាក់ស្តាន ដើម្បីអនុវត្តការការពារទីតាំងប្រេងពីការវាយប្រហាររបស់អ៊ីរ៉ង់។ ទោះជាយ៉ាងនេះក្តី ជម្លោះនេះត្រូវបានដោះស្រាយយ៉ាងទូលំទូលាយ មិនមែនតាមរយៈគោលការណ៍គ្រប់គ្រងទេ ប៉ុន្តែតាមរយៈគោលការណ៍បដិការ។ នៅឆ្នាំ ២០១៨ ប្រទេសទាំងប្រាំជាប់ព្រំដែនគ្នា ទីបំផុត បានឈានដល់ដំណោះស្រាយមួយ ដោយបានចុះហត្ថលេខាលើសន្ធិសញ្ញាដើម្បី

ចាត់ទុកដែនទឹក ជាសមុទ្រផងនិងបឹងផង។ កិច្ចព្រមព្រៀងនេះចាត់ទុកផ្នែទឹកជាតំបន់អន្តរជាតិ និងបាត សមុទ្រជាតំបន់ដែនដី។







នៅឆ្នាំ ១៩៧៩ បដិវត្តន៍នៅអ៊ីរ៉ង់បាននាំអោយមានវិបត្តិគួរអោយភ្ញាក់ផ្អើលជាលើកទីពីរ។ ប៉ុន្តែតម្លៃប្រេងកាន់តែខ្ពស់នាំទៅដល់ការពង្រីកផលិតកម្មប្រេងនៅក្នុងទីតាំងថ្មី នៅខាងក្រៅអង្គការ OPEC ដូចជា នៅសមុទ្រខាងជើង (ចក្រភពអង់គ្លេស និងន័រវេស) អាឡាស្កា អង់ហ្គោឡា រុស្ស៊ី និងកន្លែងផ្សេងទៀត។ នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៨០ តំបន់មជ្ឈិមបូព៌ាបានបាត់បង់ចំណែកទីផ្សារពាណិជ្ជកម្មប្រេងពិភពលោក យ៉ាងឆាប់រហ័ស។ ទន្ទឹមនឹងនេះ រដ្ឋសេដ្ឋកិច្ចឧស្សាហកម្មបានរៀន *ប្រើប្រាស់ថាមពលអោយមានប្រសិទ្ធិភាពខ្ពស់*។ ជាមួយនឹងការផ្គត់ផ្គង់កើនឡើងនិងតម្រូវការធ្លាក់ចុះ តម្លៃប្រេងបានធ្លាក់ចុះនៅចុងទសវត្សរ៍ឆ្នាំ ១៩៨០ ដល់កម្រិតទាបជាប្រវត្តិសាស្ត្រ តិចជាង $២០ ក្នុងមួយបារ៉ែល។

នៅចុងទស្សវត្សរ៍ឆ្នាំ ១៩៩០ តំបន់សមុទ្រកាសព្យែនត្រូវបានហៅថាជាប្រភពប្រេងថ្មី ដែលភាគច្រើនមិនទាន់បានរុករកនៅឡើយ (សូមមើលក្រាហ្វិក ១១.៥)។ ទោះជាយ៉ាងណាក៏ដោយ ប្រេងត្រូវតែដឹកជញ្ជូនតាមផ្លូវគោកតាមបំពង់ប្រេងដើម្បីនាំទៅដល់ទីផ្សារពិភពលោក (សមុទ្រកាសព្យែន គឺជាសមុទ្រក្នុងទ្វីប)។ ប៉ុន្តែ បំពង់បង្ហូរប្រេងដ៏សំខាន់ពីប្រទេស អាស៊ែបៃហ្សង់ (Azerbaijan) ដែលផលិតប្រេងទៅកាន់សមុទ្រខ្មៅ (ជាកន្លែងដែលកប៉ាល់ដឹកប្រេងអាចផ្ទុកបាន) បានធ្វើដំណើរឆ្លងកាត់ប្រទេសឆេចស្ន៊ៀ (Chechnya)ដែលត្រូវហែកហួរដោយសង្គ្រាមនៅភាគខាងត្បូងនៃប្រទេសរុស្ស៊ី។ បន្ទាប់មក រុស្ស៊ីបានសាងសង់ផ្លូវវាងជុំវិញប្រទេសឆេចស្ន៊ៀ ដែលផ្ទុកប្រេងកាសព្យែនដ៏ច្រើន និងកំពុងកើនឡើងសម្រាប់ការនាំចេញ តាមរយៈសមុទ្រខ្មៅ។ ប្រទេសមហាអំណាចបស្ចឹមលោក បានស្វែងរកផ្លូវបំពង់បង្ហូរប្រេងផ្សេងទៀតដែលមិនឆ្លងកាត់ប្រទេសរុស្ស៊ី ខណៈពេលដែលប្រទេសទួរគីបានស្វែងរកការគ្រប់គ្រងចំណែកទីផ្សារធំជាងមុន និងកាត់បន្ថយការខូចខាតបរិស្ថានចំពោះផ្លូវទឹក បូស្ព័រ (Bosporus) (តាមរយៈនាវាដឹកប្រេងរុស្ស៊ីត្រូវធ្វើដំណើរ)។ បន្ទាប់ពីការចរចាជាយូរមកហើយ។ក្នុងឆ្នាំ ២០០២-២០០៤ រដ្ឋ និងក្រុមហ៊ុនប្រេងបានសាងសង់បំពង់បង្ហូរប្រេងដែល

មានសមត្ថភាពធំដោយចំណាយប្រាក់រាប់ពាន់លានដុល្លារកាត់តាមប្រទេសអាសៀបៃហ្សង់ និងហ្សកហ្ស៊ី ទៅផ្នែរសមុទ្រមេឌីទែរ៉ាណេរបស់ទួរគី។

ជម្លោះហិង្សាធ្វើអោយផ្លូវបំពង់បង្ហូរប្រេង កាន់តែមានភាពស្មុគស្មាញខ្លាំង។ ប្រទេសទាំងបីនៅលើគន្លងបំពង់បង្ហូរប្រេងថ្មី មានសង្គ្រាមរាំងដល់នឹងគ្នា នៅក្នុងទសវត្សរ៍កន្លងមក។ បំពង់បង្ហូរប្រេងជាច្រើនដែលមានស្រាប់និងត្រូវបានស្នើឡើងសម្រាប់ប្រេងសមុទ្រកាសព្យែន មិនមានភាពងាយស្រួលនោះទេ។ នៅទូទាំងសមុទ្រកាសព្យែន ប្រទេសតួកមេនីស្ថានចង់នាំចេញឧស្ម័នធម្មជាតិទៅកាន់ប្រទេសប៉ាគីស្ថាន និងពីទីនោះទៅកាន់អាស៊ី ប៉ុន្តែបំពង់បង្ហូរប្រេងនឹងត្រូវឆ្លងកាត់ប្រទេសអាហ្វហ្គានីស្ថានដែលត្រូវហែកហួរដោយសង្គ្រាម។ ទន្ទឹមនឹងនេះ ក្នុងឆ្នាំ ២០០៣ បំពង់បង្ហូរប្រេងថ្មីក្នុងតម្លៃ ៤ ប៊ីលានដុល្លារបានចាប់ផ្តើមដឹកប្រេងពីប្រទេសឆាដ ឆ្លងកាត់តាមប្រទេសកាមេរូន សម្រាប់ការនាំចេញ ដោយសន្យាថានឹងជួយប្រទេសទាំងពីរកាត់បន្ថយភាពក្រីក្រ ប៉ុន្តែ នៅពេលដែលពួកឧទ្ធាមដែលមានមូលដ្ឋាន នៅប្រទេសស៊ូដង់បានវាយប្រហារនៅប្រទេសឆាដ លុយប្រេងត្រូវបានបង្វែរសម្រាប់គោលដៅយោធា។ ទោះបីជាព្រំដែននិងភូមិសាស្ត្រនយោបាយអាចមានសារៈសំខាន់កាន់តែតិចទៅៗ នៅក្នុងទំនាក់ទំនងនិងធុរកិច្ចក៏ដោយ ក៏វានៅតែមានសារៈសំខាន់ខ្លាំងនៅក្នុងប្រតិបត្តិការសេដ្ឋកិច្ចអន្តរជាតិ ដូចជាបំពង់បង្ហូរប្រេង។

តម្លៃប្រេងបានបន្តឡើងខ្ពស់ បន្ទាប់ពីឆ្នាំ ២០០០ ដែលទីបំផុតបានឡើងដល់ ១៤០ ដុល្លារ ក្នុងមួយបារ៉ែល ក្នុងឆ្នាំ ២០០៨ និងបានជំរុញអោយតម្លៃឧស្ម័នរបស់សហរដ្ឋអាមេរិកឡើងដល់តម្លៃជាង ៤ ដុល្លារក្នុងមួយហ្គាឡុង(៣,៧៨លីត្រ)។ តម្លៃប្រេងខ្ពស់ទាំងនេះមានអត្ថប្រយោជន៍សំខាន់ពីរ។ ទីមួយ ការដុតប្រេងឥន្ធនៈរួមចំណែកដល់ការឡើងកំដៅផែនដី ហើយតម្លៃខ្ពស់បានធ្វើអោយមានផលចំណេញក្នុងការដុតប្រេងតិច និងការប្រើប្រាស់ថាមពលដោយប្រសិទ្ធភាពខ្ពស់។ ទីពីរ តម្លៃប្រេងខ្ពស់បង្កើនប្រាក់ចំណូលការនាំចេញរបស់ប្រទេសផលិតប្រេង។ ប្រទេសនានា ដូចជា វេណេហ្ស៊ុយអេឡា និងម៉ិកស៊ិក ពឹងផ្អែកលើប្រាក់ចំណូលពីប្រេងនៅក្នុងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ពួកគេ និងដើម្បីសងបំណុលបរទេស។ ប្រទេសទាំងនេះបានបន្ធូរបន្ថយបញ្ហាបំណុលរបស់ពួកគេ ដោយសារតម្លៃឡើងថ្លៃ ដែលជាផ្នែកមួយយ៉ាងសំខាន់ក្នុងការស្តារសេដ្ឋកិច្ចរបស់រុស្ស៊ីផងដែរ។ ទោះយ៉ាងណាក៏ដោយ ប្រទេសនាំចេញប្រេងអាចមានផៀលល្អច្រើនពេកហើយ។ ថវិកាដែលធ្លាក់ចូលក្នុងកណ្តាប់ដៃមួយចំនួនតូច យ៉ាងងាយស្រួល បានធ្វើអោយជនផ្តាច់ការគ្រប់គ្រង ហើយលទ្ធិជ្រុលនិយមអាចរីកដុះដាលនៅក្នុងបណ្តារដ្ឋដូចជាប្រទេសអ៊ីរ៉ង់ អាប៉ាប៊ីសាអូឌីត និងវ៉េណេស៊ុយអេឡា។

វិបត្តិសេដ្ឋកិច្ចសកលលោកក្នុងឆ្នាំ ២០០៨-២០០៩ ទីបំផុត បានជំរុញអោយតម្លៃប្រេងធ្លាក់ចុះ ហើយចន្លោះឆ្នាំ ២០១៥ និង ២០១៨ តម្លៃប្រេងនៅមានកម្រិតទាបគួរសម។ តម្លៃប្រេងទាបគឺជាលទ្ធផលនៃផលិតកម្មខ្ពស់ក្នុងចំណោមប្រទេសសមាជិកអង្គការOPEC (ជាពិសេសអាប៉ាប៊ីសាអូឌីត) និងការកើនឡើងនៃផលិតកម្មប្រេងនៅសហរដ្ឋអាមេរិក ដែលជាប្រទេសផលិតប្រេងធំជាងគេបំផុតនៅលើពិភពលោក ក្នុងឆ្នាំ ២០១៧។ ប្រទេសនាំប្រេងចេញនិងរដ្ឋាភិបាលដែលទើបមានបានថ្មីៗរបស់ពួកគេភ្លាមៗបានភ្ញាក់ខ្លួនថាពួកគេខ្សត់ខ្សោយសាច់ប្រាក់ ដែលរួមចំណែកដល់អស្ថិរភាពសេដ្ឋកិច្ចនៅរុស្ស៊ី និងអ៊ីរ៉ង់។

១១.៣.២. សារធាតុរ៉ែ

ដើម្បីកសាងហេដ្ឋារចនាសម្ព័ន្ធ និងទំនិញឧស្សាហកម្មផ្សេងទៀតដែលបង្កើតទ្រព្យសម្បត្តិនៅក្នុងសេដ្ឋកិច្ចជាតិ រដ្ឋទាំងឡាយត្រូវការវត្ថុធាតុដើមជាទៃទៀតក្រៅពីលើថាមពល។ វត្ថុធាតុដើមទាំងនេះរួមមានលោហធាតុ សារធាតុរ៉ែនានា និងវត្ថុធាតុពាក់ព័ន្ធ ដែលត្រូវបានស្រង់ចេញ តាមរយៈការជីកយករ៉ែ។ សេដ្ឋកិច្ចនយោបាយនៃសារធាតុរ៉ែ ដូចជារ៉ែដែក ទង់ដែង ផ្លាទីនជាដើម ខុសពីសេដ្ឋកិច្ចនយោបាយនៃថាមពលពិភពលោក។ តម្លៃពាណិជ្ជកម្មអន្តរជាតិលើប្រេងមានទំហំធំជាងតម្លៃរ៉ែណាមួយ ច្រើនដង។ ជាងនេះទៅទៀត ការផ្គត់ផ្គង់រ៉ែមិនប្រមូលផ្តុំខ្លាំងតែនៅក្នុងតំបន់មួយនៃពិភពលោកនោះទេ។ ប្រទេសឧស្សាហកម្មក៏បានកាត់បន្ថយភាពងាយរងគ្រោះរបស់ពួកគេ តាមរយៈការស្តុកទុករ៉ែជាយុទ្ធសាស្ត្រ។

ធាតុដ៏សំខាន់បំផុតសម្រាប់សេដ្ឋកិច្ចឧស្សាហកម្ម គឺជារ៉ែដែលត្រូវប្រើសម្រាប់ការផលិតឧបករណ៍ឧស្សាហកម្ម។ ជាប្រពៃណីទៅហើយ ជាតិដែកមានសារៈសំខាន់បំផុត វាត្រូវបានប្រើដើម្បីផលិតដែកថែប។ អ្នកផលិតដែកនាំមុខគេ គឺអតីតសហភាពសូវៀត ជប៉ុន សហរដ្ឋអាមេរិក ចិន និងអាឡឺម៉ង់ បន្ទាប់មកគឺប្រទេសប្រេស៊ីល អ៊ីតាលី កូរ៉េខាងត្បូង បារាំង និងអង់គ្លេស។ ដូច្នេះ ប្រទេសឧស្សាហកម្មធំៗផលិតដែកថែបដោយខ្លួនឯងផ្ទាល់ (ប្រទេសអាឡឺម៉ង់និងជប៉ុនជាអ្នកនាំចេញនាំមុខគេនៅទូទាំងពិភពលោក)។ ដើម្បីរក្សាស្ថេរភាពផ្គត់ផ្គង់ក្នុងការផលិតដែកថែប សហរដ្ឋអាមេរិកនិងប្រទេសជាទៃបានប្រើប្រាស់គោលនយោបាយពាណិជ្ជកម្មដើម្បីការពារឧស្សាហកម្មដែកថែបក្នុងស្រុក (ដូចជាពន្ធដែកថែបរបស់សហរដ្ឋអាមេរិក) សូមមើលមេរៀនទី៨)។ ប្រទេសឧស្សាហកម្មមួយចំនួន ជាពិសេសប្រទេសជប៉ុន ត្រូវពឹងផ្អែកយ៉ាងខ្លាំងលើការនាំចូលរ៉ែដែកសម្រាប់ឧស្សាហកម្មដែករបស់ពួកគេ។ រ៉ែដែកមិនប្រមូលផ្តុំនៅក្នុងទីតាំងតែមួយទេ ប៉ុន្តែត្រូវបាននាំចេញពីប្រទេសកំពុងអភិវឌ្ឍន៍និងប្រទេសឧស្សាហកម្មនៅជុំវិញពិភពលោក។

សម្រាប់សារធាតុរ៉ែឧស្សាហកម្មសំខាន់ៗផ្សេងទៀត ដូចជា ទង់ដែង នីកែល និងស័ង្កសី គំរូនៃការផ្គត់ផ្គង់និងពាណិជ្ជកម្មមានលក្ខណៈពង្រាយជាងធនធានប្រេង ហើយបណ្តាប្រទេសឧស្សាហូបនីយកម្មមានលទ្ធភាពស្ថេរភាពផ្គត់ផ្គង់។ សូម្បីតែនៅពេលដែលរដ្ឋក្រីក្រគឺជាអ្នកផ្គត់ផ្គង់ដ៏សំខាន់ ដូចជាសំណប៉ាហាំង និងសារធាតុបុកស៊ីតក៏ដោយ ក៏ពួកគេមិនបានទទួលអំណាចដូចអង្គការ OPEC ដែរ។ មានការតែលដែលជាក្រុមអ្នកផលិតក្នុងករណីខ្លះ(ទង់ដែង) ករណីខ្លះទៀតជាការតែលដែលសមាជិកជាក្រុមអ្នកផលិត-អ្នកប្រើប្រាស់ (សំណប៉ាហាំង) និងការតែលដែលក្រុមអ្នកផលិត ឬក្រុមអ្នកប្រើប្រាស់ ជាច់ដោយឡែកពីគ្នា នៅក្នុងករណីផ្សេងទៀត(បុកស៊ីត)។ នាពេលបច្ចុប្បន្ននេះ ប្រទេសចិនស្ទើរតែមានសិទ្ធិផ្តាច់មុខទាំងស្រុងលើការផ្គត់ផ្គង់សារធាតុរ៉ែដ៏កម្ររបស់ពិភពលោក (ក្នុងបរិមាណតិចតួច) រហូតដល់ការផលិតកម្មអេឡិចត្រូនិច។ ប្រទេសចិនបានកាត់បន្ថយការនាំចេញដើម្បីបង្កើនតម្លៃរ៉ែទាំងនេះ។ ទោះយ៉ាងណាក៏ដោយ ក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយនេះ ប្រទេសដូចជាវៀតណាមបានចាប់ផ្តើមផលិតធាតុទាំងនេះបានមួយចំនួនដែរ ដើម្បីប្រជែងនឹងការក្តោបក្តាប់របស់ចិននៅលើទីផ្សារ។

ផលិតផលកសិកម្មមួយចំនួនបានបង្កើតការតែលដែលជាក្រុមអ្នកផលិត ដូចជាសហភាពនៃប្រទេសនាំចេញផ្លែចេក (UBEC) និងក្រុមប្រឹក្សាគ្រាប់ធញ្ញជាតិអាហ្វ្រិក។ ក៏ដូចជារ៉ែដែរ ដំណាំនាំចេញមួយចំនួនមានប្រភពមកពីប្រទេសមួយចំនួនតែប៉ុណ្ណោះ។ ផលិតផលទាំងនេះរួមមានស្ករ (គុយបា) កាកាវ (កូតឌីវ័រ ហ្គាណា នីហ្សេរីយ៉ា) ស្លឹកតែ (ឥណ្ឌា ស្រីលង្កា ចិន) និងកាហ្វេ(ប្រេស៊ីល និងកូឡុំប៊ី)។ ទោះបីជាមានការ

ប្រមូលផ្តុំក៏ដោយ ក៏ក្រុមអ្នកផលិតមិនទទួលបានជោគជ័យខ្លាំងក្នុងការជំរុញតម្លៃផលិតផលទាំងនេះ ដែលមានសារៈសំខាន់តិចជាងថាមពល។

១១.៣.៣. ធនធានទឹក

បន្ថែមពីលើថាមពលនិងសារធាតុរ៉ែ រដ្ឋក៏ត្រូវការទឹកជាចាំបាច់ណាស់ដែរ។ តម្រូវការនេះកើនឡើងនៅពេលដែលសង្គមមានឧស្សាហូបនីយកម្មកាន់តែច្រើន ព្រោះវាត្រូវបង្កើនវិស័យកសិកម្ម និងនៅពេលដែលចំនួនប្រជាជនកើនឡើង។ ការប្រើប្រាស់ទឹកនៅលើពិភពលោក បានកើនឡើង ៣៥ ដង បើធៀបនឹងប៉ុន្មានសតវត្សរ៍មុននេះ ហើយបានកើនឡើងពីរដងលឿនជាងចំនួនប្រជាជននៅសតវត្សរ៍ទី ២០។ ទោះជាយ៉ាងណាក៏ដោយ ការផ្គត់ផ្គង់ទឹកមិនផ្លាស់ប្តូរទេ ហើយកំពុងមានកម្រិតថយចុះនៅកន្លែងជាច្រើន។ មួយភាគប្រាំនៃចំនួនប្រជាជនលើពិភពលោកខ្វះទឹកស្អាតប្រើប្រាស់ ហើយប្រទេសចំនួន ៨០ រងគ្រោះដោយការខ្វះខាតទឹក។ ប្រភពផ្គត់ផ្គង់ទឹក រួមមានទន្លេនិងទឹកក្រោមដី ជាញឹកញាប់ឆ្លងកាត់ព្រំដែនអន្តរជាតិ ដូចនេះ ហើយប្រភពទឹកកាន់តែក្លាយជាប្រភពនៃជម្លោះអន្តរជាតិច្រើនឡើងៗ។ ពេលខ្លះ នៅពេលដែលរដ្ឋច្រើន ប្រើប្រាស់ទឹកក្រោមដីរួមគ្នា ជម្លោះទាំងនេះគឺជាបញ្ហាផលប្រយោជន៍រួម។

បញ្ហាទឹកមានសារៈសំខាន់ ជាពិសេសនៅមជ្ឈិមបូព៌ា។ ជាឧទាហរណ៍ ទន្លេអឺប្រាត (Euphrates) ហូរចេញពីប្រទេសទួរគីឆ្លងកាត់ប្រទេសស៊ីរី បន្តទៅកាន់ប្រទេសអ៊ីរ៉ាក់ មុនពេលទៅដល់ឈូងសមុទ្រពែក្ស។ អ៊ីរ៉ាក់ជំទាស់នឹងការបង្វែរទឹករបស់ស៊ីរីពីទន្លេនេះ ហើយទាំងប្រទេសអ៊ីរ៉ាក់និងស៊ីរីជំទាស់នឹងការបង្វែរទឹករបស់ទួរគី។

ទន្លេយ័រដាន់(Jordan)មានប្រភពចេញពីប្រទេសស៊ីរីនិងលីបង់ ហើយហូរកាត់ប្រទេសអ៊ីស្រាអែលទៅប្រទេសហ្សកដានី។ នៅទសវត្សរ៍ឆ្នាំ ១៩៥០ អ៊ីស្រាអែលបានចាប់ផ្តើមសាងសង់ប្រឡាយមួយដើម្បីយកទឹកពីទន្លេយ័រដាន់ដើម្បី«ធ្វើអោយវាលខ្សាច់រីកលូតលាស់»។ ហ្សកដានី និងប្រទេសជិតខាងអារ៉ាប់របស់ខ្លួនបានដាក់ពាក្យទៅកាន់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ប៉ុន្តែ វាបានបរាជ័យក្នុងកិច្ចខិតខំប្រឹងប្រែងក្នុងការសម្រុះសម្រួលជម្លោះ ហើយរដ្ឋនីមួយៗបានបន្តដំណើរទៅមុខ ជាមួយនឹងផែនការគ្រប់គ្រងទឹករៀងៗខ្លួន (ទោះជាយ៉ាងនេះក្តី អ៊ីស្រាអែល និងហ្សកដានីបានយល់ព្រមនឹងការបែងចែកទឹកដែលបានស្នើឡើងដោយអង្គការសហប្រជាជាតិ)។ នៅឆ្នាំ ១៩៦៤ ប្រទេសស៊ីរីនិងលីបង់បានព្យាយាមសាងសង់ទំនប់ និងបង្វែរទឹក មុនពេលវាហូរធ្លាក់ទៅដល់ប្រទេសអ៊ីស្រាអែល ដែលធ្វើអោយប្រព័ន្ធទឹកថ្មីរបស់អ៊ីស្រាអែលក្លាយជាអាសារបង់។ ការវាយប្រហារតាមអាកាស និងកាំភ្លើងធំរបស់អ៊ីស្រាអែលលើការដ្ឋានសំណង់ទំនប់បានបង្ខំអោយស៊ីរីបោះបង់ចោលគម្រោងបង្វែរផ្លូវទឹករបស់ខ្លួន ហើយការដណ្តើមកាន់កាប់តំបន់ Golan Heights ឆ្នាំ ១៩៦៧ របស់អ៊ីស្រាអែល បានរារាំងប្រទេសស៊ីរីពីការបន្តសកម្មភាពបែបនេះ។ ដូច្នេះហើយ គោលការណ៍គ្រប់គ្រងចូលរួមចំណែកក្នុងការដោះស្រាយជម្លោះលើធនធានធម្មជាតិ។

ប្រធានបទរួមមួយបានលេចឡើងនៅក្នុងជម្លោះដណ្តើមឥន្ធនៈ សារធាតុរ៉ែ ផលិតផលកសិកម្ម និងដែនទឹក។ ពួកវាត្រូវបានផលិតនៅក្នុងទីតាំងកំណត់ណាមួយ ប៉ុន្តែត្រូវបានជួញដូរទៅកន្លែងឆ្ងាយ។ ការគ្រប់គ្រងទីតាំងទាំងនេះ ផ្តល់អោយរដ្ឋនានានូវស្វ័យភាពផ្គត់ផ្គង់កាន់តែច្រើន (ជាទីពេញនិយមរបស់អ្នកគាំពារនិយម) និងទំនិញសម្រាប់ទីផ្សារដែលបង្កើតទ្រព្យសម្បត្តិ (ជាទីពេញនិយមរបស់សេរីនិយម)។

ជាការពិតណាស់ ធនធានទាំងនេះក៏អាចទាក់ទងដោយផ្ទាល់ ទៅនឹងសន្តិសុខអន្តរជាតិផងដែរ។ អ្នកប្រាជ្ញទំនាក់ទំនងអន្តរជាតិបានពង្រីកការសិក្សាស្រាវជ្រាវរបស់ពួកគេអំពីនយោបាយបរិស្ថាន ដើម្បីសិក្សាជាប្រព័ន្ធអំពីទំនាក់ទំនងនៃកិច្ចការយោធានិងសន្តិសុខទៅនឹងបរិស្ថាន។ នៅចុងម្ខាងនៃទំនាក់ទំនងនេះគឺតួនាទីនៃបរិស្ថានដែលជាប្រភពនៃជម្លោះអន្តរជាតិ។ យើងបានឃើញពីរបៀបដែលការសឹករិចរិលនៃបរិស្ថានអាចនាំអោយមានបញ្ហាផលប្រយោជន៍រួមក្នុងចំណោមរដ្ឋមួយចំនួនធំ និងរបៀបដែលការប្រកួតប្រជែងគ្នាដណ្តើមទឹកដីនិងធនធាននានា អាចបង្កើតជម្លោះរវាងក្រុមរដ្ឋមួយចំនួនតូច។

រូបថត ប្រជាជនអាហ្វ្រិកខាងត្បូងនៅជិត ក្រុង ខេបថោន តម្រង់ជួរទទួលទឹក

មាសារ

នៅពេលដែលកំណើនប្រជាជននិងការអភិវឌ្ឍន៍សេដ្ឋកិច្ចបង្កើនតម្រូវការទឹក ហើយនៅពេលដែលការប្រែប្រួលអាកាសធាតុបង្កអោយមានការប្រែប្រួលនៃគំរូទឹកភ្លៀង ទឹកបានក្លាយជាធនធានដ៏មានតម្លៃថែមទៀត។ ឥឡូវនេះ មានការព្រួយបារម្ភថា តំបន់ដែលមានប្រជាជនខ្ពស់មួយចំនួនអាចទទួលរងការខ្វះខាតទឹករបើប្រាស់ដែលនាំអោយមានវិបត្តិមនុស្សធម៌ និងនយោបាយ។ នៅទីនេះ ប្រជាជនអាហ្វ្រិកខាងត្បូងនៅជិតក្រុង ខេបថោន តម្រង់ជួរទទួលទឹករបើប្រាស់ ឆ្នាំ ២០១៨ ។

ដោយសារបម្រែបម្រួលអាកាសធាតុនាំអោយមានការផ្លាស់ប្តូរអាកាសធាតុ និងលំនាំទឹកភ្លៀង តំបន់ខ្លះបានរកឃើញថាពួកគេមានទឹកច្រើនពន់ពេកក្នុងទម្រង់ជាគ្រោះទឹកជំនន់ ខណៈតំបន់ខ្លះទៀតកំពុងជួបប្រទះនឹងការខ្វះខាតថ្មីក្នុងទម្រង់ជាគ្រោះរាំងស្ងួត។ ក្នុងឆ្នាំ ២០១៧ ទីក្រុង ខេបថោន (Cape Town) ក្នុងប្រទេសអាហ្វ្រិកខាងត្បូងបានប្រកាសថា ខ្លួននឹងអស់ទឹកនៅនិទាឃរដូវឆ្នាំ ២០១៨។ ជាការឆ្លើយតបរដ្ឋាភិបាលបានដាក់កម្រិតតឹងរ៉ឹងលើការប្រើប្រាស់ទឹក ដោយកាត់បន្ថយការប្រើប្រាស់ប្រចាំថ្ងៃពាក់កណ្តាល។ នេះបានរុញច្រាន «ថ្ងៃសូន្យ» (ជាថ្ងៃដែលទឹកនឹងរីងស្ងួតអស់) រំកិលទៅមុខជាច្រើនខែ។ ប៉ុន្តែលុះត្រាតែមានប្រភពទឹកថ្មីត្រូវបានរកឃើញ ឬទឹកភ្លៀងកើនឡើងនោះ ក្រុងCape Town នឹងប្រឈមមុខនឹងអនាគតមិនច្បាស់លាស់ ជាមួយនឹងទឹកកាន់តែតិច។

សកម្មភាពក្នុងវិស័យសន្តិសុខអន្តរជាតិក៏បង្កផលប៉ះពាល់ដល់បរិស្ថានផងដែរ។ សកម្មភាពយោធាជាពិសេសសង្គ្រាម បានរួមចំណែកយ៉ាងសំខាន់ដល់ការសឹករិចរិលបរិស្ថាន លើសនិងហួសពីការសឹករិចរិលដែលបណ្តាលមកពីសកម្មភាពសេដ្ឋកិច្ច ដូចជាការជីកយករ៉ែ និងការផលិតជាដើម។ ជាឧទាហរណ៍ ក្នុងអំឡុងសង្គ្រាមឈូងសមុទ្រឆ្នាំ ១៩៩១ កងកម្លាំងអ៊ីរ៉ាក់បានធ្វើអោយកំពប់ប្រេងគុយវ៉ែតយ៉ាងច្រើនចូលទៅក្នុងឈូងសមុទ្រពែរ្ស ហើយបន្ទាប់មក មុនពេលដកថយពីគុយវ៉ែត បានបំផ្ទុះអណ្តូងប្រេងគុយវ៉ែតរាប់រយកន្លែង ដែលទុកអោយពួកគេឆេះដោយមិនអាចគ្រប់គ្រងបាន និងគ្របដណ្តប់អ៊ីរ៉ាក់ និងអ៊ីរ៉ង់ជាមួយនឹងផ្សែងអ័ព្ទខ្មៅក្រាស់។

១១.៤. ចំនួនប្រជាជន

១១.៤ ចូរពន្យល់ថាតើអ្វីជាអន្តរកាលប្រជាសាស្ត្រ និងមូលហេតុដែលរដ្ឋខ្លះងាយនឹងរងគ្រោះពីកំណើនប្រជាជនយ៉ាងគំហុក។

នាពេលបច្ចុប្បន្ននេះ ចំនួនប្រជាជនពិភពលោកបានឈានដល់កម្រិតខ្ពស់បំផុតដែលមិនធ្លាប់មានពីមុនមក ខណៈពេលដែលវាបន្តកើនឡើងជារៀងរាល់ថ្ងៃ។ ចំនួនប្រជាជនពិភពលោក បានកើនឡើងដល់ចំនួន ៨ ៣ន់


លាននាក់ នៅត្រឹមចុងឆ្នាំ ២០២២ ដោយជាមធ្យមកើនឡើង ៨០ លាននាក់ ជារៀងរាល់ឆ្នាំ។ ការព្យាករណ៍ចំនួនប្រជាជននាពេលអនាគតមានភាពងាយស្រួល ក្នុងទិដ្ឋភាពមួយចំនួន។ ដោយរារាំងសង្គ្រាមនុយក្លេអ៊ែរ ឬគ្រោះមហន្តរាយបរិស្ថាន កុមារាកុមារីសព្វថ្ងៃនេះនឹងធំធាត់ឡើង ហើយនឹង មានកូនចៅផ្ទាល់ខ្លួន។ សម្រាប់រយៈពេលពី ២០ ទៅ ៣០ ឆ្នាំខាងមុខនេះ កំណើនប្រជាជនពិភពលោកនឹងត្រូវបានជំរុញ ដោយចំនួនកុមារដ៏ច្រើនសន្ធឹកសន្ធាប់នៅក្នុងចំនួនប្រជាជន នៅក្នុងអឌ្ឍគោលខាងត្បូង នាពេលបច្ចុប្បន្ននេះ ជាជាងដោយមេកានិច។ ចំនួនប្រជាជនពិភពលោកដែលបានព្យាករណ៍សម្រាប់ឆ្នាំ ២០៣០ នឹងមានពី ៨ ទៅ ៩ ពាន់លាននាក់ ហើយមិនមាននរណាម្នាក់អាចធ្វើការផ្លាស់ប្តូរការព្យាករណ៍នោះបានទេ។

ក្នុងចំណោមកំណើនចំនួនប្រជាជនក្នុងអំឡុងពេលនោះ ៩៦ ភាគរយនឹងស្ថិតនៅក្នុងអឌ្ឍគោលខាងត្បូង។ បច្ចុប្បន្ននេះ កំណើនប្រជាជនពាក់កណ្តាលពិភពលោកបានកើតឡើងនៅក្នុងប្រទេសត្រឹមតែប្រាំមួយប៉ុណ្ណោះ គឺ ឥណ្ឌា ចិន ប៉ាគីស្ថាន នីហ្សេរីយ៉ា បង់ក្លាដែស និងឥណ្ឌូនេស៊ី។ ក្នុងចំណោមប្រទេសក្រីក្របំផុតលើពិភពលោក ចំនួនប្រជាជនត្រូវបានគេរំពឹងថានឹងកើនឡើងបីដង ក្នុងរយៈពេល ៥០ ឆ្នាំខាងមុខ ខណៈប្រទេសអ្នកមានជាច្រើននឹងជួបប្រទះការធ្លាក់ចុះចំនួនប្រជាជន នៅក្នុងរយៈពេលដូចគ្នា។

ការព្យាករណ៍ចំនួនប្រជាជានលើសពី ២៥ ឆ្នាំមានលក្ខណៈពិបាកណាស់។ នៅពេលកុមារសព្វថ្ងៃធំធាត់ឡើង ចំនួនកូនដែលពួកគេបង្កើតនឹងត្រូវរងផលប៉ះពាល់ដោយប្រាក់ចំណូលរបស់ពួកគេ (ដោយសារតែអន្តរកាលប្រជាសាស្ត្រ ដែលត្រូវបានពិភាក្សានៅក្នុងផ្នែកបន្ទាប់)។ ថាតើប្រទេសកំពុងអភិវឌ្ឍន៍ប្រមូលផ្តុំទ្រព្យសម្បត្តិបានកម្រិតណា (ប្រធានបទដែលនឹងត្រូវលើកឡើងនៅក្នុងមេរៀនទី ១៣) ចំនួនប្រជាជនរបស់ពួកគេនឹងកើនឡើងក្នុងល្បឿនយឺតជាងនេះ។ កត្តាទីពីរដែលជះឥទ្ធិពលលើអត្រាកំណើនប្រជាជន គឺជាគោលនយោបាយរបស់រដ្ឋាភិបាលទាក់ទងនឹងសិទ្ធិស្ត្រី និងការគ្រប់គ្រងឫពន្យារកំណើត។

ក្រាហ្វិក ១១.៦ និន្នាការ និងការព្យាករណ៍ចំនួនប្រជាជនពិភពលោក

ប្រភព៖ ការិយាល័យប្រជាជនអង្គការសហប្រជាជាតិ។



ដោយសារកត្តាមិនប្រាកដប្រជាទាំងពីរនេះ ការព្យាករណ៍លើសពីរយៈពេលពីរបីទសវត្សរ៍មានកម្រិតមិនច្បាស់លាស់ខ្លះដែរ (សូមមើលក្រាហ្វិក ១១.៦)។ នៅត្រឹមឆ្នាំ ២០៥០ ចំនួនប្រជាជនពិភពលោកអាច

មានរហូតដល់ ៩ ពាន់លាននាក់ ជាមួយនឹងកម្រិតចុងក្រោយ ប្រហែល ១០ ពាន់លាន ក្នុងរយៈពេល ១០០ ឆ្នាំខាងមុខ។ ទិន្នន័យថ្មីក្នុងឆ្នាំ ២០០២ បានបង្ហាញថា ឋានៈស្ត្រីខ្ពស់ និងអក្ខរកម្មកំពុងកាត់បន្ថយកំណើនប្រជាជនច្រើនជាងការរំពឹងទុក នៅក្នុងប្រទេសក្រីក្រធំៗ។ សកម្មភាពរបស់រដ្ឋ និង អង្គការអន្តរជាតិបាលឥឡូវនេះ នឹងកំណត់ចំនួនប្រជាជននៅលើភពផែនដី ក្នុងរយៈពេល ២០០ ឆ្នាំខាងមុខ។

កាលពី ២០០ ឆ្នាំមុន អ្នកនិពន្ធជនជាតិអង់គ្លេស ថូម៉ាស ម៉ាលធូស (Thomas Malthus) បានព្រមានថា ចំនួនប្រជាជនទំនងជាកើនឡើងលឿនជាងការផ្គត់ផ្គង់ស្បៀងអាហារ ហើយបានបន្តព្យាករណ៍ថា កំណើនប្រជាជននឹងត្រូវបានកម្រិតដោយខ្លួនឯង តាមរយៈគ្រោះទុរ្ភិក្ស និងជំងឺដង្កាត់នានា។ សព្វថ្ងៃនេះ អ្នកជំនាញនិងមន្ត្រី ដែលព្រមានប្រឆាំងនឹងចំនួនប្រជាជនលើសពិភពលោក ជួនកាល ត្រូវបានគេហៅថា *ម៉ាល់ធូសៀន*(Malthusian)។ អ្នកវិះគន់លើទស្សនៈនេះចង្អុលបង្ហាញថា កន្លងមក បច្ចេកវិទ្យាបានរក្សាល្បឿនត្រដមត្រសងជាមួយនឹងចំនួនប្រជាជន ដែលបានអនុញ្ញាតអោយស្បៀងអាហារ និងធនធានផ្សេងទៀតត្រូវបានទាញយកពីបរិស្ថានកាន់តែច្រើន ទោះបីជាមានចំនួនប្រជាជននៅតែបន្តការកើនឡើងខ្លាំងប៉ុណ្ណាក៏ដោយ។

១១.៤.១. អន្តរកាលប្រជាសាស្ត្រ

កំណើនប្រជាជនកើតឡើងពីផលដកវាងអត្រាកំណើតឬអត្រាជាតិ (ក្នុងមនុស្ស១០០០នាក់) និងអត្រាមរណភាព។ នៅក្នុងសង្គមកសិកម្ម(បុរេឧស្សាហកម្ម) ទាំងអត្រាកំណើត និងអត្រាមរណភាពមានកម្រិតខ្ពស់។ ដូច្នេះ កំណើនចំនួនប្រជាជនមានភាពយឺតយ៉ាវខ្លាំង រហូតពេលខ្លះត្រូវថយចុះ នៅពេលដែលអត្រាមរណភាពកើនលើសអត្រាកំណើត (ឧទាហរណ៍ ក្នុងអំឡុងពេលមានគ្រោះទុរ្ភិក្ស ឬជំងឺប៉េស្ត)។

ដំណើរការនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច (ការធ្វើឧស្សាហូបនីយកម្ម និងការប្រមូលផ្តុំទ្រព្យសម្បត្តិនៅលើមូលដ្ឋានមនុស្សម្នាក់ៗ) នាំមកនូវការផ្លាស់ប្តូរអត្រាកំណើត និងអត្រាមរណភាព ដែលធ្វើតាមនិន្នាការសកលហៅថា ការផ្លាស់ប្តូរ ឬ **អន្តរកាលប្រជាសាស្ត្រ** (សូមមើលក្រាហ្វិក ១១.៧)។ ទីមួយ អត្រាមរណភាពធ្លាក់ចុះដោយសារការផ្គត់ផ្គង់ស្បៀងកើនឡើងនិងការទទួលបានការថែទាំសុខភាពកើនឡើងដែរ។ ក្រោយមក អត្រាកំណើតបានធ្លាក់ចុះ នៅពេលដែលមនុស្សទទួលបានការអប់រំ កាន់តែមានសុវត្ថិភាព និងកាន់តែមានទីក្រុងរីកចម្រើនខ្លាំង ហើយនៅពេលដែលឋានៈរបស់ស្ត្រីក្នុងសង្គមកើនឡើង។ នៅចុងបញ្ចប់នៃការផ្លាស់ប្តូរនេះ ក៏ដូចជានៅដើមដំបូងដែរ អត្រាកំណើតនិងអត្រាមរណភាពមានកម្រិតប្រហាក់ប្រហែលគ្នា ម្ល៉ោះហើយកំណើនប្រជាជនមានកម្រិត។ ប៉ុន្តែក្នុងអំឡុងពេលផ្លាស់ប្តូរ នៅពេលដែលអត្រាមរណភាពបានធ្លាក់ចុះកាន់តែច្រើនជាងអត្រាកំណើត ចំនួនប្រជាជនកើនឡើងយ៉ាងឆាប់រហ័ស។

ហេតុផលមួយដែលអ្នកក្រីក្រមានទំនោរចង់បានកូនច្រើននោះ ដោយហេតុថា នៅក្រោមភាពក្រីក្រធ្ងន់ធ្ងរ ការអោចរស់រានមានជីវិតរបស់ទារកឬកុមារមិនត្រូវបានធានានោះទេ។ ជំងឺ កង្វះអាហារូបត្ថម្ភ ឬអំពើហិង្សាអាចឆាបឆក់យកជីវិតកុមារជាច្រើន បានគ្រប់ពេលដោយទុកអោយឪពុកម្តាយគ្មាននរណាមើលថែទាំពួកគេនៅពេលពួកគេចាស់ជរា។ ការមានកូនច្រើនអាចជួយអោយប្រាកដថាមានកូនខ្លះអាចនៅរស់។


ដោយសាររដ្ឋមួយធ្វើអោយមានអន្តរកាលប្រជាសាស្ត្រ រចនាសម្ព័ន្ធនៃចំនួនប្រជាជនរបស់វាផ្លាស់ប្តូរយ៉ាងខ្លាំង។ នៅដំណាក់កាលដំបូងនិងកំឡុងចំណុចកណ្តាលនៃដំណើរការនេះ ភាគច្រើននៃចំនួនប្រជាជនមានវ័យនៅក្មេងនៅឡើយ។ គ្រួសារមានកូនច្រើន ហើយមនុស្សធំមិនមានក្តីរំពឹងទុកថាមានអាយុវែងឡើយ។

ដោយសារតែកុមារជាបន្ទុកគ្រួសារ មិនទាន់មានផលិតភាពសេដ្ឋកិច្ចខ្លាំង កុមារមួយចំនួនធំនៅក្នុងប្រទេសក្រីក្រហាក់មានទំនោរប្រមូលទ្រព្យសម្បត្តិយឺតខ្លាំង។ ប៉ុន្តែ នៅចុងបញ្ចប់នៃអន្តរកាលប្រជាសាស្ត្រ ដោយសារតែមនុស្សធំរស់នៅបានយូរហើយគ្រួសារនីមួយៗមានកូនតិចជាងមុន នោះអាយុជាមធ្យមនៃចំនួនប្រជាជនទាំងអស់មានវ័យកាន់តែចាស់។ នៅទីបំផុត មួយភាគធំនៃចំនួនប្រជាជនគឺជាមនុស្សចាស់ឬជរា ដែលជាចំនួនប្រជាជនអសកម្មដែលជាប្រភេទបន្ទុកគ្រួសារមួយផ្សេងទៀត ដែលសេដ្ឋកិច្ចជាតិត្រូវតែជួយគាំទ្រ។

ក្រាហ្វិក ១១.៧ អន្តរកាលប្រជាសាស្ត្រ

នៅពេលដែលប្រាក់ចំណូលកើនឡើង ដំបូងអត្រាមរណភាពយ៉ាងចុះ ហើយក្រោយមក អត្រាកំណើតក៏ធ្លាក់ចុះ។ គម្លាតរវាងអត្រាទាំងពីរគឺជាអត្រាកំណើនប្រជាជន។ ដើមដំបូងនៃអន្តរកាលប្រជាសាស្ត្រ ចំនួនប្រជាជនភាគច្រើនជាកុមារ; ក្រោយមក វាមានមនុស្សចាស់មួយភាគធំ។

ប្រភព៖ អង្គការសហប្រជាជាតិ។



ប្រទេសឧស្សាហកម្មបានបញ្ចប់ដំណើរការអន្តរកាលប្រជាសាស្ត្រ ហើយឥឡូវនេះបាននឹងកំពុងអោយមានកំណើនប្រជាជនយឺត។ ប្រទេសរុស្សី អឺរ៉ុប និងជប៉ុន មានចំនួនប្រជាជនថយចុះ។ ប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើនកំពុងស្ថិតនៅក្នុងកំឡុងអន្តរកាលប្រជាសាស្ត្រ ហើយមានកំណើនប្រជាជនយ៉ាងគំហុក។

ល្បែងទ្វេគ្រោះនៃអន្តរកាលប្រជាសាស្ត្រមានស្ថានភាពបែបនេះ៖ កំណើនប្រជាជនយ៉ាងឆាប់រហ័ស និងចំនួនប្រជាជនដែលមានកុមារច្រើន គឺជាកម្លាំងដ៏មានឥទ្ធិពល ដែលកាត់បន្ថយប្រាក់ចំណូលសម្រាប់មនុស្សម្នាក់ៗ វិធីសាស្ត្របន្ថយកំណើនប្រជាជនដ៏ល្អបំផុត គឺត្រូវបង្កើនប្រាក់ចំណូលសម្រាប់មនុស្សម្នាក់ៗ។ ដូច្នេះហើយ កំណើនប្រជាជនរួមចំណែកដល់វដ្តដ៏ឃោរឃៅនៅក្នុងរដ្ឋក្រីក្រជាច្រើន។ នៅពេលដែលចំនួនប្រជាជនកើនឡើងក្នុងល្បឿនប្រហែលគ្នានឹងកំណើនទ្រព្យសម្បត្តិសរុប មនុស្សកម្រិតមធ្យម មិនមានភាពប្រសើរជាងមុនឡើយ។ សូម្បីតែនៅពេលដែលសេដ្ឋកិច្ចលូតលាស់លឿនជាងចំនួនប្រជាជន ដូច្នេះប្រាក់ចំណូល*ជាមធ្យម*កើនឡើង *ចំនួន*សរុបនៃប្រជាជនក្រីក្រអាចកើនឡើងដែរ។

អន្តរកាលប្រជាសាស្ត្រមាននិន្នាការពង្រីកគំលាតវិសមភាពទ្រព្យសម្បត្តិជាអន្តរជាតិ។ រដ្ឋដែលអាចចាត់ចែងបង្កើនប្រាក់ចំណូលបន្តិច រំកិលខ្លួនចូលទៅក្នុងជណ្តើរឡើងជារង្វង់ នៅពេលកំណើនប្រជាជនយឺតកម្រិតប្រាក់ចំណូលសម្រាប់មនុស្សម្នាក់ៗកើនឡើងកាន់តែច្រើន ដែលធ្វើអោយកំណើនប្រជាជនកាន់តែយឺត ហើយវដ្តចេះតែបន្តទៀត។ ទន្ទឹមនឹងនេះ រដ្ឋដែលមិនបង្កើនប្រាក់ចំណូល មានកំណើនប្រជាជនដែលមិនមានការថមថយ ប្រាក់ចំណូលសម្រាប់មនុស្សម្នាក់ៗនៅមានកម្រិតទាប ដែលជំរុញកំណើនប្រជាជនកាន់តែច្រើន ដែលរំកិលខ្លួនរដ្ឋនោះចូលទៅក្នុងជណ្តើរចុះជារង្វង់វិញ។

នៅទូទាំងសកលលោក លក្ខណៈខុសគ្នានេះរួមចំណែកដល់គម្លាតនៃទ្រព្យសម្បត្តិរវាងអឌ្ឍគោលខាងជើងនិងខាងត្បូង(សូមមើលមេរៀនទី ១២)។ នៅក្នុងអឌ្ឍគោលខាងត្បូង ភាពខុសគ្នាកាន់តែជ្រាលជ្រៅផងដែរ នៅពេលប្រទេសមួយចំនួនអាចចាត់ចែងទប់ល្បឿនកំណើនប្រជាជននិងបង្កើនប្រាក់ចំណូល ខណៈពេលរដ្ឋផ្សេងទៀតមិនអាចធ្វើដូច្នេះបាន។ សូម្បីតែនៅក្នុងប្រទេសតែមួយ អន្តរកាលប្រជាសាស្ត្រធ្វើអោយមានភាពមិនស្មើគ្នាកាន់តែខ្លាំង។ បណ្តាទីក្រុង វណ្ណៈអ្នកមាន ក្រុមជាតិសាសន៍អ្នកមាន និងខេត្តអ្នកមានហាក់មានអត្រាកំណើតទាប បើប្រៀបធៀបទៅនឹងទីជនបទនិងវណ្ណៈក្រីក្រ ក្រុមជាតិសាសន៍ក្រីក្រ និងខេត្តក្រីក្រជាង។ នៅក្នុងប្រទេសមួយចំនួនដូចជា បារាំង អ៊ីស្រាអែល និងសហរដ្ឋអាមេរិក ក្រុមជាតិសាសន៍ដែលមានទ្រព្យសម្បត្តិច្រើនជាងគេ មានកំណើនប្រជាជនយឺតជាងក្រុមជនជាតិភាគតិចក្រីក្រដទៃទៀត។

ក្នុងប៉ុន្មានទសវត្សរ៍ថ្មីៗនេះ អឌ្ឍគោលខាងត្បូងហាក់ដូចជាត្រូវបានបំបែកជាពីរក្រុមរដ្ឋ។ ក្រុមទីមួយរួមទាំងចិននិងឥណ្ឌា បានចូលដល់ដំណាក់កាលនៃអន្តរកាលប្រជាសាស្ត្រ ដែលត្រូវបានសម្គាល់ដោយការថយចុះអត្រាកំណើត នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៧០។ ប៉ុន្តែនៅក្នុងរដ្ឋក្រីក្រ ជិត ៧០ ប្រទេសផ្សេងទៀត អត្រាមរណភាពបានបន្តធ្លាក់ចុះលឿនជាងអត្រាកំណើត ដែលនាំទៅដល់កំណើនប្រជាជនកាន់តែលឿន។ និន្នាការនៃចំនួនប្រជាជនទាំងនេះបានរួមចំណែកដល់ភាពមិនស្មើគ្នាឬគំលាត នៅក្នុងអឌ្ឍគោលខាងត្បូង ដែលបានលេចឡើងក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ ជាពិសេសរវាងទ្វីបអាហ្វ្រិក និងអាស៊ី។

១១.៤.២. គោលនយោបាយប្រជាជន

គោលនយោបាយដែលរដ្ឋាភិបាលប្រកាន់យក (មិនមែនត្រឹមតែសេដ្ឋកិច្ចនិងលក្ខខណ្ឌប្រជាសាស្ត្រប៉ុណ្ណោះទេ) ជះឥទ្ធិពលលើអត្រាកំណើត។ ក្នុងចំណោមគោលនយោបាយសំខាន់បំផុត គឺការគ្រប់គ្រងអត្រាកំណើត(ការពន្យារកំណើត)។ គោលនយោបាយនានារបស់រដ្ឋមានលក្ខណៈខុសប្លែកគ្នាយ៉ាងទូលំទូលាយ។

នៅឯចុងម្ខាង ប្រទេសចិនប្រើប្រាស់ការគ្រប់គ្រងដ៏រឹងមាំរបស់រដ្ឋាភិបាលរបស់ខ្លួន ដើម្បីព្យាយាមអនុវត្តការកំណត់កូនម្នាក់ក្នុងមួយគ្រួសារ(ប្តីមួយប្រពន្ធមួយ)។ ការផាកពិន័យសម្រាប់អ្នកមានកូនទីពីរ រួមមានការគិតថ្លៃសេវាដែលធ្លាប់តែមិនគិតថ្លៃសម្រាប់កូនទីមួយ។ ប្រទេសចិនបានចាប់ផ្តើមលើកទឹកចិត្តគ្រួសារដែលមានទ្រព្យសម្បត្តិ និងមានការអប់រំកាន់តែច្រើន អោយមានកូនពីរនាក់ ហើយឥឡូវនេះនៅក្នុងទីក្រុងមួយចំនួនរបស់ចិនដូចជាទីក្រុងសៀងហៃ ប្តីប្រពន្ធត្រូវបានអនុញ្ញាតអោយមានគ្រួសារដែលមានកូនពីរនាក់។ លើសពីកូនពីរនាក់ ការផាកពិន័យកាន់តែធ្ងន់ធ្ងរ។ ការពន្យារកំណើត និងការរំលូតកូន មិនត្រូវតម្រូវអោយបង់ថ្លៃឡើយ។ គោលនយោបាយរបស់ប្រទេសចិនបានកាត់បន្ថយអត្រាកំណើនគួរអោយកត់សម្គាល់ នៅក្នុងទីក្រុង ប៉ុន្តែតិចជាងនេះនៅក្នុងទីជនបទ ដែលប្រជាជនភាគច្រើនរស់នៅទីនោះ។ ទោះយ៉ាងណាក៏ដោយក្នុងរយៈពេលមួយទសវត្សរ៍(ទសវត្សរ៍ឆ្នាំ ១៩៧០) អត្រាបង្កកំណើតរបស់ប្រទេសចិនត្រូវធ្លាក់ចុះ ពីកុមារ ៦

នាក់ ក្នុងស្ត្រីម្នាក់ មកនៅត្រឹម ២,៥ នាក់ ដែលជាការផ្លាស់ប្តូរយ៉ាងខ្លាំងសម្បើម។ នៅឆ្នាំ ២០១៥ អត្រាបង្កបង្កើតកំណើតមាន នៅត្រឹម ១,៦ នាក់។

រូបថត *ឪពុកម្តាយជនជាតិចិនសប្បាយរីករាយដែលអាចមានកូនពីរនាក់*

ត្រឹមតែពីរនាក់មិនច្រើនទេ

ដោយសារតែអន្តរកាលប្រជាសាស្ត្រ ការគ្រប់គ្រងកំណើនប្រជាជនជួយដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងបញ្ហាសមកវិញ។ ប្រទេសផ្សេងៗប្រើប្រាស់គោលនយោបាយ ប្រជាជនយ៉ាងទូលំទូលាយរហូតដល់ទីបញ្ចប់មួយនេះ គ្មានអ្វីតឹងរ៉ឹងជាងគោលនយោបាយអោយ«មានកូនតែមួយ»របស់ប្រទេសចិនសម្រាប់គូស្វាមីភរិយានៅទីក្រុងនោះទេ។ ប៉ុន្តែដោយសារតែក្តីបារម្ភអំពីចំនួនប្រជាជនវ័យចំណាស់របស់ខ្លួន ប្រទេសចិនបានចាប់ផ្តើមបង្ហាញពីភាពបត់បែនក្នុងគោលនយោបាយអោយ«មានកូនតែមួយ»របស់ខ្លួនក្នុងឆ្នាំ២០១៣ ដោយអនុញ្ញាតឱ្យគូស្វាមីភរិយាមានរហូតដល់កូនពីរនាក់។ ទោះបីជាមានការផ្លាស់ប្តូរនេះក៏ដោយ វាត្រូវបានគេប៉ាន់ប្រមាណថា គ្រួសារចិនតិចជាង ២០ ភាគរយ បានដាក់ពាក្យសុំមានកូនទីពីរ។ នៅទីនេះ ឪពុកម្តាយជនជាតិចិនរីករាយនឹងគ្រួសារដែលមានកូនពីរនាក់ក្នុងឆ្នាំ ២០១៦។

ប៉ុន្តែ គោលនយោបាយចិនខាងលើនេះក៏មានគុណវិបត្តិខ្លះដែរ។ វាកម្រិតសេរីភាពបុគ្គលដោយបំពេញតាមចិត្តគ្រប់គ្រងរបស់រដ្ឋាភិបាល។ ការរំលូតកូនដោយបង្ខំឬបន្លំ ត្រូវបានរាយការណ៍ថាកើតមានឡើង។ នៅក្នុងសង្គមចិនបុរាណ (ដូចនៅក្នុងប្រទេសមួយចំនួនទៀត) កូនប្រុសត្រូវបានគេអោយតម្លៃខ្លាំងជាងកូនស្រី។ គូស្វាមីភរិយាដែលមានកូនស្រីអាចបន្តព្យាយាម រហូតដល់ពួកគេមានកូនប្រុស។ ក្នុងករណីខ្លះ កសិករចិន តាមសេចក្តីរាយការណ៍ បានសម្លាប់កូនស្រីដែលទើបនឹងកើត ដើម្បីឲ្យពួកគេអាចព្យាយាមរកកូនប្រុស។ ការសូកប៉ាន់ ឬបង់ការផាកពិន័យ បានក្លាយជាផ្លូវទូទៅ កាន់តែច្រើនជុំវិញគោលនយោបាយកូនតែមួយ ក្នុងទសវត្សរ៍ឆ្នាំ ១៩៩០។ ជាញឹកញាប់បំផុត ឪពុកម្តាយនៅក្នុងប្រទេសចិន (និងកន្លែងមួយចំនួនដូចជានៅក្នុងប្រទេសឥណ្ឌា) កំពុងប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន (ការស្កែនអ៊ុលត្រាសោន) ដើម្បីកំណត់អត្តសញ្ញាណភេទរបស់ទារករបស់ពួកគេ ហើយរំលូតកូនប្រសិនបើវាជាស្ត្រី។ ជំរឿនឆ្នាំ ២០០០ របស់ប្រទេសចិនបានបង្ហាញពីភាគរយនៃកំណើតជាស្ត្រីនៅ ០.៨៥ ក្នុងចំណោមក្មេងប្រុសម្នាក់ ជាជាងអត្រាធៀបធម្មតា កម្រិត ០.៩៥ ដែលភាពខុសគ្នាអាចស្មើនឹងក្មេងស្រី «បាត់ខ្លួន» មួយលាននាក់ ក្នុងមួយឆ្នាំ។ នៅតាមទីជនបទ អតុល្យភាពភេទកុមារ មានកម្រិតខ្ពស់ជាងពីរដងក្នុងទីក្រុង ដែលឈានដល់ក្មេងប្រុស ១៤០ នាក់ក្នុងចំនួនក្មេងស្រី ១០០ នាក់ នៅក្នុងតំបន់មួយចំនួនដែលគោលនយោបាយ មានកូនតែមួយត្រូវបានអនុវត្តយ៉ាងតឹងរ៉ឹង។ ប៉ុន្មានឆ្នាំចុងក្រោយនេះ នារីវ័យក្មេងរាប់រយពាន់នាក់ នៅប្រទេសជិតខាង ដូចជាប្រទេសវៀតណាម ត្រូវបានចាប់ពង្រត់និងបញ្ជូនទៅចិន និងលក់ធ្វើជាកូនក្រមុំ។

ដើម្បីឆ្លើយតបទៅនឹងអតុល្យភាពយេនឌ័របែបនេះ និងចំពោះក្តីបារម្ភនៃចំនួនប្រជាជនដែលមានវ័យចំណាស់ រដ្ឋាភិបាលចិនក្នុងឆ្នាំ ២០១៣ បានចាប់ផ្តើមបន្ធូរបន្ថយគោលនយោបាយ«កូនតែមួយក្នុងមួយគ្រួសារ»។ អ្នករស់នៅក្នុងទីក្រុងដែលមានធនធានគ្រប់គ្រាន់អាចស្នើសុំមានកូនទីពីរ។ ភ្លាមៗនោះ គូស្វាមីភរិយាមួយចំនួនបានឆ្លៀតយកប្រយោជន៍ពីគោលនយោបាយដោយមានកូនទីពីរ។ ទោះជាយ៉ាងណាក៏ដោយ ការសិក្សាជាច្រើនបានប៉ាន់ប្រមាណថា មានតែ ១២ ទៅ ១៨ ភាគរយនៃគ្រួសារដែលមានសិទ្ធិ បានដាក់ពាក្យសុំមានកូនទីពីរ។ ក្នុងករណីខ្លះ ក្រុមគ្រួសារបានស្តីបន្ទោសការចំណាយថ្លៃខ្ពស់នៃការរស់នៅក្នុងទីក្រុងធំៗ

របស់ប្រទេសចិន ខណៈខ្លះទៀតនិយាយថា ពួកគេកំពុងបង្អង់មិនចង់បានកូនទៀត តាមចិត្តប្រថ្នារបស់កូនច្បងដែលចង់រក្សាភាពជាកូនទោលក្នុងគ្រួសារ។ រដ្ឋាភិបាលចិនបានសម្តែងការខកចិត្ត ដែលមិនមានគូស្វាមីភរិយាច្រើនខិតខំទាញយកប្រយោជន៍ពីឱកាសថ្មីនេះ។

គោលនយោបាយរបស់ប្រទេសឥណ្ឌា មិនសូវមានលក្ខណៈតឹងរឹងខ្លាំងពេកទេ ប៉ុន្តែមានឥទ្ធិពលយឺតជាង។ អត្រាកំណើតបានធ្លាក់ចុះ ពីប្រហែលកូន ៦ នាក់ក្នុងស្ត្រីម្នាក់ៗ មកនៅត្រឹមប្រហែល ៤,៧ នាក់ក្នុងទសវត្សរ៍ឆ្នាំ ១៩៧០ មកត្រឹម ២,៥ នាក់ ក្នុងឆ្នាំ ២០១៥ និង ២,៤ នាក់ ក្នុងឆ្នាំ ២០១៨។ រដ្ឋាភិបាលរបស់ប្រទេសឥណ្ឌា ដែលបានប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងដំណើរការពន្យារកំណើត បានព្យាយាមបង្កើតព័ត៌មាន និងមធ្យោបាយផ្សេងៗ ដែលអាចប្រើបានយ៉ាងទូលំទូលាយ ប៉ុន្តែក្នុងនាមជាប្រទេសប្រកាន់លទ្ធិប្រជាធិបតេយ្យ វាមិនមានការគ្រប់គ្រងដោយរដ្ឋាភិបាលលើសង្គមខ្លាំងក្លាដូចប្រទេសចិនទេ។ បណ្តាប្រទេសដែលមានប្រាក់ចំណូលខ្ពស់ជាងឥណ្ឌាឬចិន អាចទទួលបានជោគជ័យយ៉ាងងាយស្រួលជាង។ កម្មវិធីផែនការគ្រួសារដ៏រឹងមាំ ប៉ុន្តែមិនមានការបង្ខិតបង្ខំរបស់ប្រទេសម៉ិកស៊ិក ដែលបានអនុម័តក្នុងឆ្នាំ ១៩៧៤ បានកាត់បន្ថយអត្រាកំណើត បានពាក់កណ្តាល តែក្នុងកំឡុងពេលជាង ១៥ ឆ្នាំ មកនៅត្រឹម ២,៧ នាក់ ក្នុងចំណោមស្ត្រីម្នាក់ (និងមកត្រឹមកម្រិតក្រោម ២,២ នាក់ គិតត្រឹមឆ្នាំ ២០១៨)។

នៅឯចុងម្ខាងទៀត ពីប្រទេសចិន គឺជារដ្ឋាភិបាលដែលលើកទឹកចិត្តឬបង្ខំអោយបង្កើតកូន និងហាមប្រាម ឬដាក់កម្រិតលើលទ្ធភាពនៃការពន្យារកំណើត។ គោលនយោបាយបែបនេះត្រូវបានគេហៅថា **អ្នកកំណើតនិយម** (pronatalist [probirth])។ ជាប្រពៃណី រដ្ឋាភិបាលជាច្រើនបានអនុវត្តគោលនយោបាយបែបនេះ ដោយសារតែចំនួនប្រជាជនត្រូវបានគេមើលឃើញថាជាធាតុនៃអំណាចរបស់ជាតិ។ ទាកកាន់តែច្រើននៅថ្ងៃនេះមានន័យថាទាហានកាន់តែច្រើននៅពេលក្រោយ។

សព្វថ្ងៃនេះ មានតែរដ្ឋាភិបាលមួយចំនួនប៉ុណ្ណោះដែលមានគោលនយោបាយជ្រុលនិយម ប៉ុន្តែមនុស្សជាច្រើនមិនបានធ្វើការពន្យារកំណើត ឬការអប់រំផ្លូវភេទសម្រាប់ស្ត្រីក្រីក្រនោះទេ។ នៅក្នុងរដ្ឋបែបនេះខ្លះចំនួនប្រជាជនមិនត្រូវបានចាត់ទុកថាជាបញ្ហានោះទេ (ហើយថែមទាំងអាចត្រូវបានគេមើលឃើញថាជាទ្រព្យសម្បត្តិផងដែរ) នៅក្នុងរដ្ឋផ្សេងទៀត រដ្ឋាភិបាលគ្រាន់តែមិនអាចមានលទ្ធភាពទទួលបានវិធានការណ៍ប្រកបដោយប្រសិទ្ធភាព ដើម្បីបន្ថយអត្រាកំណើត។ យោងតាមមូលនិធិអង្គការសហប្រជាជាតិសម្រាប់ប្រជាជន (UNFPA) ស្ត្រីចំនួន ២០០ លាននាក់ មិនមានលទ្ធភាពក្នុងការពន្យារកំណើត ប្រកបដោយប្រសិទ្ធភាពនោះទេ។

អត្រាកំណើតត្រូវទទួលរងឥទ្ធិពលយ៉ាងខ្លាំងដោយឋានៈរបស់ស្ត្រីនៅក្នុងសង្គម។ ក្នុងវប្បធម៌ដែលជាប្រពៃណីមើលឃើញស្ត្រីមានតម្លៃសម្រាប់តែបង្កើតកូន មានការដាក់ទណ្ឌកម្មធ្ងន់ធ្ងរចំពោះស្ត្រីដែលឈប់ឬមិនព្រមធ្វើដូច្នេះ។ ស្ត្រីជាច្រើនមិនប្រើវិធីពន្យារកំណើតទេ ដោយសារតែប្តីរបស់ពួកគេ នឹងមិនអនុញ្ញាតអោយពួកគេធ្វើ។ ស្វាមីទាំងនេះប្រហែលជាគិតថា ការមានកូនច្រើនគឺជាកស្តុតាងនៃភាពជាបុរសខ្លាំងរបស់ពួកគេ។ ទោះជាយ៉ាងណាក៏ដោយ នៅពេលដែលស្ថានភាពឋានៈរបស់ស្ត្រីមានភាពប្រសើរឡើង ហើយពួកគេអាចធ្វើការក្នុងមុខរបរផ្សេងៗ មានទ្រព្យសម្បត្តិផ្ទាល់ខ្លួន និងមានសិទ្ធិបោះឆ្នោត ស្ត្រីទទួលបានអំណាចក៏ដូចជាការអប់រំនិងប្រាក់ដែលត្រូវការជាចាំបាច់ ដើម្បីកំណត់ទំហំនៃគ្រួសាររបស់ពួកគេ។ បើ យោងតាមអង្គការ UNFPA ការលើកតម្កើងឋានៈស្ត្រី គឺជាមធ្យោបាយដ៏សំខាន់បំផុតមួយក្នុងការគ្រប់គ្រងកំណើន

ប្រជាជនពិភពលោក។ គោលនយោបាយរបស់រដ្ឋាភិបាលអំពីហានៈស្ត្រីមានការប្រែប្រួលពីរដ្ឋមួយ ទៅរដ្ឋមួយទៀត។ កម្មវិធីនិងទីភ្នាក់ងារអន្តរជាតិ ដូចជា គណៈកម្មការអង្គការសហប្រជាជាតិស្តីពីហានៈស្ត្រី កំពុងធ្វើការដើម្បីដោះស្រាយបញ្ហានេះ ជាលក្ខណៈសកល។

១១.៤.៣. ជំងឺឆ្លាត់

កំណើនប្រជាជនត្រូវបានកំណត់ដោយអត្រាមរណៈក៏ដូចជាអត្រាកំណើត។ មនុស្សស្លាប់ដោយសារមូលហេតុផ្សេងៗគ្នា នៅអាយុផ្សេងៗគ្នា។ នៅក្នុងប្រទេសក្រីក្រ ប្រជាជនមានទំនោរស្លាប់ក្នុងវ័យក្មេងជាង ជារឿយៗដោយសារជំងឺឆ្លង។ នៅក្នុងប្រទេសអ្នកមាន ប្រជាជនរស់បានយូរជាង និងស្លាប់ដោយសារជំងឺមហារីក និងជំងឺបេះដូងញឹកញាប់ជាង។ សមាមាត្រនៃទារកដែលស្លាប់ក្នុងឆ្នាំដំបូងរបស់ពួកគេ គឺជា**អត្រាមរណៈទារក** (infant mortality rate)។ អត្រានេះគឺជាសូចនាករដ៏ល្អសម្រាប់សុខភាពទូទៅ ព្រោះវាឆ្លុះបញ្ចាំងពីការទទួលបានអាហារូបត្ថម្ភ ទឹកស្អាត ទីជម្រក និងការថែទាំសុខភាពរបស់ប្រជាជន។ អត្រាមរណៈទារក មានកម្រិត ៤ ភាគរយ នៅទូទាំងពិភពលោក៖ ១ ភាគរយឬតិចជាងនេះ នៅក្នុងប្រទេសអ្នកមាន ប៉ុន្តែច្រើនជាង ១០ ភាគរយ នៅក្នុងប្រទេសក្រីក្របំផុត ឬរហូតខ្ពស់ជាងនេះក៏មានដែរ នៅក្នុងតំបន់ក្នុងស្រុកដែលមានភាពក្រីក្រខ្លាំងបំផុត (ជាពិសេសនៅក្នុងទ្វីបអាហ្វ្រិក និងក្នុងតំបន់សង្គ្រាមនាពេលថ្មីៗនេះ)។

ទោះបីជាអត្រាមរណៈមានកម្រិតខុសគ្នាខ្លាំង ពីរដ្ឋមួយទៅរដ្ឋមួយទៀត ឬតំបន់ទៅតំបន់មួយទៀតក៏ដោយ និន្នាការទាំងមូលហាក់មានស្ថេរភាព ពីមួយទសវត្សរ៍ទៅមួយទសវត្សរ៍ទៀត។ សង្គ្រាមរាំងជល់ គ្រោះរាំងស្ងួត ជំងឺរាតត្បាត និងគ្រោះមហន្តរាយមានឥទ្ធិពលក្នុងតំបន់ ប៉ុន្តែស្ទើរតែមិនមានបញ្ហាជាសកលទេ។ នៅក្នុងប្រទេសក្រីក្របំផុត ដែលទើបតែចាប់ផ្តើមអន្តរកាលប្រជាសាស្ត្រ អត្រាមរណៈបានធ្លាក់ចុះពី ៣០នាក់ក្នុងចំណោមមួយពាន់នាក់ ក្នុងឆ្នាំ ១៩៥០ មកតិចជាង ១៥ នាក់ ចាប់តាំងពីឆ្នាំ ១៩៩០ និងមកត្រឹម ៨ នាក់ក្នុងចំណោមមនុស្សមួយពាន់នាក់ ចាប់តាំងពីឆ្នាំ ២០១៤។ នៅក្នុងប្រទេសឧស្សាហកម្ម អត្រាមរណៈបានធ្លាក់ចុះ ប្រហែលតិចជាង ១០ នាក់ ក្នុងចំណោមមនុស្សមួយពាន់នាក់ នៅឆ្នាំ ១៩៦០ ហើយឥឡូវនេះមានអត្រាប្រហែល ៧ នាក់ នៅបស្ចឹមលោក។ និន្នាការមានស្ថេរភាពក្នុងអត្រាមរណៈទាំងនេះមានន័យថា អត្រាមរណៈមិនមែនជាមធ្យោបាយដែលរដ្ឋាភិបាលឬទីភ្នាក់ងារអន្តរជាតិអាចជះឥទ្ធិពលលើកំណើនប្រជាជននោះទេ ភាពក្រីក្រកាន់តែអាក្រក់អាចបណ្តាលអោយមានគ្រោះទុរ្ភិក្សនិងកំណើនអត្រាមរណៈ ប៉ុន្តែ នេះមិនមែនជាវិធីជាក់ស្តែងដើម្បីគ្រប់គ្រងកំណើនប្រជាជននោះទេ។ វាអាចនឹងមានន័យថាជាការបកក្រោយ តាមរយៈអន្តរកាលប្រជាសាស្ត្រ ដែលនឹងលុបបំបាត់ឱកាសនៃការបន្ទាបអត្រាកំណើត។ ទោះបីសង្គ្រាមសម្លាប់ជីវិតមនុស្សច្រើនមែន វាក៏មិនអាចសម្លាប់មនុស្សច្រើនរហូតដល់អាចកាត់បន្ថយកំណើនប្រជាជនដែរ។ ជារួមតំបន់ភាគច្រើននៅលើពិភពលោកស្ថិតនៅក្នុងកំឡុង ឬនៅផ្នែកខាងចុង នៃអន្តរកាល នៅក្នុងអត្រា*មរណៈ* សំណួរសំខាន់ត្រូវសួរថា តើអត្រាកំណើតត្រូវការពេលវេលាយូរប៉ុណ្ណាដើម្បីបញ្ចប់អន្តរកាល?

ទោះជាយ៉ាងណាក៏ដោយ កត្តាមរណៈបីយ៉ាងៈ មេរោគHIV/ជំងឺអេដស៍ ជំងឺឆ្លងផ្សេងទៀត និងការជក់បារីសមនឹងទទួលបានការយកចិត្តទុកដាក់ជាពិសេស ព្រោះវាទាមទារការចំណាយខ្ពស់ណាស់ ទោះបីជាវាមិនប៉ះពាល់ដល់និន្នាការចំនួនប្រជាជនពិភពលោកច្រើនក៏ដោយ។ នៅក្នុងករណីទាំងនេះ សកម្មភាពដែលបានធ្វើឡើងក្នុងរយៈពេលខ្លីផ្តល់ផលវិបាកជាអន្តរជាតិក្នុងរយៈពេលវែង ហើយជាថ្មីម្តងទៀត មានករណីនៃការចំណាយរយៈពេលខ្លី និងអត្ថប្រយោជន៍ក្នុងរយៈពេលវែង។

មេរោគHIV/ជំងឺអេដស៍

នៅក្នុងការរីករាលដាលនៃជំងឺអេដស៍ទូទាំងពិភពលោក ភាពជោគជ័យឬបរាជ័យរបស់រដ្ឋមួយ ក្នុងការទប់ស្កាត់ការរីករាលដាលនៃមេរោគHIV (វីរុសកំទេចប្រព័ន្ធស៊ាំនឹងជំងឺរបស់សរីរាង្គមនុស្ស) ជះឥទ្ធិពលដល់ការឆ្លងរាលដាលនៅក្នុងរដ្ឋផ្សេងទៀតផងដែរ។ មានការពន្យាពេល ពី ៥ ទៅ ១០ ឆ្នាំ បន្ទាប់ពីការឆ្លងមេរោគ មុនពេលរោគសញ្ញាលេចចេញឡើង ហើយក្នុងអំឡុងពេលនេះ បុគ្គលដែលមានមេរោគអាចឆ្លងទៅអ្នកដទៃទៀតបាន (តាមរយៈការរួមភេទឬការផ្ទេរឬប៉ះពាល់ឈាម)។ ជំងឺអេដស៍រីករាលដាលដាលក្នុណៈអន្តរជាតិ តាមរយៈអាជីវកម្ម ទេសចរណ៍ ការធ្វើចំណាកស្រុក និងប្រតិបត្តិការយោធា ដោយឆ្លុះបញ្ចាំងពីការពឹងអាស្រ័យគ្នាទៅវិញទៅមករបស់រដ្ឋទាំងឡាយ។

នៅត្រឹមឆ្នាំ ២០១៧ ការរាតត្បាតមេរោគHIV/ជំងឺអេដស៍បានសម្លាប់មនុស្សជាង ៣៥ លាននាក់រួចហើយ ហើយប្រហែលជាមានមនុស្សប្រហែល ៣៦-៣៧ លាននាក់ទៀត បានឆ្លងមេរោគនេះ ទោះបីជាពួកគេភាគច្រើនមិនបានដឹងខ្លួនក៏ដោយ។ ពីរភាគបីនៃពួកគេរស់នៅក្នុងទ្វីបអាហ្វ្រិក និងពាក់កណ្តាលទៀតនៅអាស៊ីខាងត្បូង (សូមមើលតារាង ១១.២)។ ជំងឺរាតត្បាតនេះបានធ្វើអោយកុមារកំព្រាចំនួន ១៦ លាននាក់នៅទូទាំងពិភពលោក (ជាង ៧៥ ភាគរយ នៅអាហ្វ្រិក)។ ជារៀងរាល់ឆ្នាំ មនុស្សប្រហែល ១,៨ លាននាក់បានឆ្លងមេរោគHIVថ្មី ហើយ ចំនួន ១ លាននាក់បានស្លាប់ដោយសារជំងឺអេដស៍ រួមទាំងកុមារជិត ១ សែននាក់ផងដែរ។

តារាងទី ១១.២ ចំនួនប្រជាជន និងជំងឺអេដស៍ តាមតំបន់ពិភពលោក ឆ្នាំ ២០១៦

តំបន់[ក]	ចំនួនប្រជាជន (គិតជាលាននាក់)	អត្រាកំណើនចំនួនប្រជាជន ១៩៩២- ២០១៦	ការឆ្លងមេរោគ HIV (គិតជាលាននាក់)
ពិភពលោក	៧៦០០	១,៣%	៣៧
អឌ្ឍគោលខាងជើង	១៤៥០	០,៨	៤
អឌ្ឍគោលខាងត្បូង	៦១៥០	២,៧	៣៣
ក្នុងនោះ:			
ចិន	១៤៥០	០,៨	១
មជ្ឈឹមបូព៌ា	៥០០	១,៨	០,២
អាមេរិកខាងត្បូង	៦៦០	១,៤	២
អាស៊ីទក្សិណ	២៥០០	១,៨	៤
អាហ្វ្រិក(អនុតំបន់សាហារា)	១០៥០	២,៧	២៥

ក. តំបន់មិនត្រូវគ្នានឹងតំបន់ដែលបានប្រើកន្លែងផ្សេងក្នុងសៀវភៅនេះទេ។

ប្រភព: គណនាពីសូចនាករអភិវឌ្ឍន៍ពិភពលោក។ ធនាគារពិភពលោកឆ្នាំ ២០១៧ ទិន្នន័យអង្គការ UNAIDS ២០១៧. UNAIDS.

នៅទ្វីបអាហ្វ្រិក ដែលជាតំបន់ក្រីក្របំផុតនៅលើពិភពលោករួចទៅហើយ ជំងឺអេដស៍បានលេចចេញជាកម្លាំងដ៏មានឥទ្ធិពលមួយ ដែលជំរុញអោយតំបន់នេះត្រឡប់ទៅរកភាពក្រីក្រកាន់តែជ្រៅ។ ប្រហែល ៥ ភាគរយនៃមនុស្សពេញវ័យនៅទីនោះឆ្លងមេរោគHIV ក្នុងចំណោមនោះច្រើនជាងពាក់កណ្តាលជាស្ត្រីភេទ។ នៅក្នុងបណ្តាប្រទេសអាហ្វ្រិកដែលរងផលប៉ះពាល់ខ្លាំងបំផុត នៅអាហ្វ្រិកខាងត្បូង មនុស្សពេញវ័យម្នាក់ក្នុងចំណោមប្រាំមួយនាក់មានផ្ទុកមេរោគHIV (ម្នាក់ក្នុងចំណោមបួននាក់សម្រាប់ប្រទេសបូតស្វាណា ដែលជាករណីដ៏អាក្រក់បំផុត)។ ការឆ្លងមេរោគនេះក៏រីករាលដាលស្រួចស្រាលនៅក្នុងជួរកងទ័ពអាហ្វ្រិក ដោយមានផលប៉ះពាល់ផ្ទាល់ដល់សន្តិសុខអន្តរជាតិ។ នៅប្រទេសអង់ហ្គោឡា ការឆ្លងរីករាលដាលបានចាប់ផ្តើមខ្លាំងបន្ទាប់ពីការ*បញ្ចប់*នៃសង្គ្រាមស៊ីវិលដ៏យូរអង្វែង ដែលបានបើកព្រំដែននិងបង្កើនចរាចរណ៍ជាមួយរដ្ឋជិតខាងដែលមានអត្រាឆ្លងមេរោគHIVខ្ពស់។ នៅពេលដែលអត្រាឆ្លងក្នុងប្រទេសនេះចាប់ផ្តើមកើនឡើង មន្ត្រីយោធាបានផ្តួចផ្តើមគំនិតបង្កើតកម្មវិធីអប់រំ និងការធ្វើតេស្តមេរោគHIVយ៉ាងទូលំទូលាយ នៅក្នុងជួរកងទ័ព។ ផ្ទុយពីរដ្ឋអាហ្វ្រិកផ្សេងទៀត ដែលមានអត្រាឆ្លងមេរោគខ្ពស់ក្នុងជួរយោធា កម្មវិធីសស្រាក់សស្រាំរបស់អង់ហ្គោឡាបានរក្សាអត្រាឆ្លងមេរោគទាបក្នុងចំណោមប្រជាជនទូទៅ ពោលគឺទាបជាង ១០ ភាគរយ។

នៅអាមេរិកខាងជើង និងតំបន់ឧស្សាហូបនីយកម្មផ្សេងទៀត ការព្យាបាលដោយថ្នាំថ្មី (ដែលទប់ស្កាត់មិនអោយមេរោគកើនឡើងក្នុងរយៈពេលជាច្រើនឆ្នាំ) បានកាត់បន្ថយអត្រាស្លាប់ ដោយសារជំងឺអេដស៍យ៉ាងខ្លាំង ដែលចាប់ផ្តើមនៅចុងទសវត្សរ៍ឆ្នាំ ១៩៩០។ ប៉ុន្តែ ការព្យាបាលទាំងនេះមានតម្លៃថ្លៃពេក មិនអាចជួយអ្វីបានច្រើនដល់បណ្តាប្រទេសនៅអាហ្វ្រិកនិងតំបន់ក្រីក្រផ្សេងទៀត។ ប្រទេសឥណ្ឌា និងប្រេស៊ីលបានចាប់ផ្តើមនាំចេញថ្នាំប្រភេទនេះ ដែលមានតំលៃថោកៗ ដោយរំលោភលើសិទ្ធិប៉ាតង់របស់ក្រុមហ៊ុនឱសថបស្ចឹមលោក។ រដ្ឋាភិបាលសហរដ្ឋអាមេរិកបានគំរាមដាក់ទណ្ឌកម្មអាហ្វ្រិកខាងត្បូង និងប្រទេសដទៃទៀតប្រសិនបើពួកគេអនុញ្ញាតអោយនាំចូលថ្នាំទាំងនេះ ដោយមិនផ្តល់សំណងដល់សាជីវកម្មអាមេរិកដែលជាអ្នកកាន់ប៉ាតង់។ អាមេរិកបានដាក់ពាក្យប្តឹងប្រេស៊ីល ទៅកាន់អង្គការWTO។ ជាការឆ្លើយតប សកម្មជនជំងឺអេដស៍ បានធ្វើបាតុកម្មខ្លាំងៗ និងប្រមូលមតិសាធារណៈ ដើម្បីផ្លាស់ប្តូរគោលនយោបាយទាំងនេះ។

សហរដ្ឋអាមេរិកបានដកពាក្យបណ្តឹងរបស់ខ្លួនប្រឆាំងនឹងប្រេស៊ីល ក្នុងឆ្នាំ ២០០១។ ទន្ទឹមនឹងនោះក្រុមហ៊ុនឱសថបានចាប់ផ្តើមផ្តល់តម្លៃទាបដល់ប្រទេសក្រីក្រ ប៉ុន្តែ ការផ្តល់ថ្នាំដល់ប្រជាជនក្រីក្ររាប់លាននាក់ នៅតែមានភាពយឺតយ៉ាវ គួរអោយឈឺចុកចាប់ណាស់។ នៅឆ្នាំ ២០០៤ ទីបំផុត សហគមន៍អន្តរជាតិបានផ្តួចផ្តើមការផ្តល់ថ្នាំប្រឆាំងមេរោគ ក្នុងទ្រង់ទ្រាយធំ ដល់អ្នកជំងឺអេដស៍ នៅក្នុងប្រទេសក្រីក្រ។ ឥឡូវនេះមានការរីកចម្រើនយ៉ាងខ្លាំងក្នុងការចែកចាយថ្នាំទាំងនេះ។ ក្នុងរយៈពេលប្រាំបីឆ្នាំកន្លងមកនេះ ចំនួនអ្នកទទួលការព្យាបាលបានកើនឡើងយ៉ាងខ្លាំង ដោយពេលនេះ អង្គការសហប្រជាជាតិសម្រាប់ជំងឺអេដស៍ (UNAIDS) បានប៉ាន់ប្រមាណថា មនុស្សជិត ២០ លាននាក់បានប្រើប្រាស់ថ្នាំទាំងនេះ។

ការបង្កើនលទ្ធភាពទទួលបានថ្នាំ និងការថែទាំផ្សេងទៀត ត្រូវបានសម្របសម្រួលដោយកំណើនគួរអោយកត់សម្គាល់នៃមូលនិធិដែលមានស្រាប់ដើម្បីព្យាបាលជំងឺ។ ក្នុងឆ្នាំ ២០០១ ក្នុងអំឡុងពេលសម័យប្រជុំពិសេសរបស់អង្គការសហប្រជាជាតិស្តីពីជំងឺអេដស៍ លោក កូហ្វី អាណាន់ បានស្នើសុំថវិកាពិភពលោក ពី ៧ ពាន់លានដុល្លារ ទៅ ១០ ប៊ីលានដុល្លារ ក្នុងមួយឆ្នាំ ដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ (កំណើនមូលនិធិចំនួនប្រាំដង)។ រដ្ឋមហាសេដ្ឋកិច្ចG៨ បានឆ្លើយតបជាមួយនឹងការសន្យាផ្តល់មូលនិធិជាង ១ ប៊ីលានដុល្លារ

«គួរឱ្យសរសើរ» ប៉ុន្តែ «មិនគ្រប់គ្រាន់ទេ» នៅក្នុងទស្សនៈរបស់អាណាន់។ នៅក្នុងឆ្នាំ ២០០៣ លោក ប្រធានាធិបតី ប៊ូស បានសន្យាផ្តល់ប្រាក់ចំនួន ១៥ ប៊ីលានដុល្លារ ក្នុងរយៈពេល ៥ ឆ្នាំ ដើម្បីជួយបន្តយការ ឆ្លងជំងឺអេដស៍ នៅអាហ្វ្រិក។ កម្មវិធីនោះត្រូវបានពង្រីកយ៉ាងខ្លាំង ចាប់តាំងពីពេលនោះមក។ ចាប់តាំងពីឆ្នាំ ២០០៣ សហរដ្ឋអាមេរិកបានផ្តល់ប្រាក់ជិត ២០ ប៊ីលានដុល្លារ ដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍។ រវាងឆ្នាំ ២០០៩ និង ២០១៤ រដ្ឋាភិបាលសហរដ្ឋអាមេរិកបានសន្យាផ្តល់ប្រាក់ចំនួន ៤៨ ប៊ីលានដុល្លារដើម្បីប្រយុទ្ធ ប្រឆាំងនឹងជំងឺអេដស៍ ជំងឺរបេង និងជំងឺគ្រុនចាញ់។ ក្នុងឆ្នាំ ២០០៦ ប្រទេសចំនួនប្រាំ រួមមាន បារាំង អង់គ្លេស នរវេស ប្រេស៊ីល និងឈីលី បានយល់ព្រមរៃអង្គាសប្រាក់ ៣០០ លានដុល្លារក្នុងមួយឆ្នាំ ដើម្បី ទិញថ្នាំសម្រាប់កុមារដែលមានជំងឺអេដស៍ របេង និងគ្រុនចាញ់។ មូលនិធិភាគច្រើន នឹងបានមកពីការបង់ពន្ធ សំបុត្រយន្តហោះ (ជាធម្មតា ៥ ដុល្លារ សម្រាប់សំបុត្រធម្មតា និង ៥០ ដុល្លារ សម្រាប់សំបុត្រពិសេស)។ ខណៈពេលដែលអ្នកសង្កេតការណ៍បានសាទរចំពោះកិច្ចខិតខំប្រឹងប្រែងដែលបានកើនឡើងទាំងនេះ ការងារ ជាច្រើនទៀតនៅតែមាន រួមទាំងការថែទាំកុមារប្រមាណ ១២ លាននាក់ ដែលត្រូវកំព្រាដោយជំងឺអេដស៍នៅ អនុតំបន់សាហារ៉ាអាហ្វ្រិក។

រូបថត កុមារទទួលបានថ្នាំដើម្បីព្យាបាលជំងឺអេដស៍ និងជំងឺរបេង នៅប្រទេសណាមីប៊ី

អ្នកសង្គ្រោះជីវិត

ជំងឺអេដស៍បានសម្លាប់មនុស្សប្រហែល ៣៥ លាននាក់ ហើយកំពុងរីករាលដាលយ៉ាងឆាប់រហ័សនៅ ក្នុងតំបន់អាស៊ីទក្សិណនិងប្រទេសចិន។ កិច្ចខិតខំប្រឹងប្រែងទូទាំងពិភពលោកដើម្បីទប់ស្កាត់ការឆ្លងនៃជំងឺ អេដស៍ ដែលសម្របសម្រួលដោយអង្គការសុខភាពពិភពលោក (WHO) បង្ហាញពីរបៀបដែលបញ្ហាកម្រិត ពិភពលោក ដូចជាជំងឺអេដស៍កំពុងធ្វើអោយអង្គការអន្តរជាតិ ដូចជា WHO កាន់តែមានសារៈសំខាន់ ខ្លាំងឡើង។ បច្ចុប្បន្ននេះ កិច្ចខិតខំប្រឹងប្រែងអន្តរជាតិផ្តោតលើការព្យាយាមទទួលបានថ្នាំប្រឆាំងមេរោគដល់ មនុស្ស ជាង ៣៦ លាននាក់ នៅលើពិភពលោក។ មនុស្សរាប់ម៉ឺននាក់ដែលមិនមានលទ្ធភាពទិញថ្នាំ និងមិន មានកម្មវិធីគាំទ្រដោយឥតគិតថ្លៃ កំពុងតែស្លាប់ដោយសារជំងឺអេដស៍។ នៅទីនេះ កុមារទទួលបានថ្នាំដើម្បី ព្យាបាលជំងឺអេដស៍ និងជំងឺរបេង នៅប្រទេសណាមីប៊ី ឆ្នាំ ២០១៦។

ក្នុងទិដ្ឋភាពខ្លះ ជំងឺអេដស៍បានធ្វើអោយគម្លាតរវាងអឡគោលខាងជើងនិងខាងត្បូងកាន់តែកែងធំ។ សម័យប្រជុំរបស់អង្គការសហប្រជាជាតិឆ្នាំ ២០០១ ក៏បានបង្ហាញពីភាពខុសគ្នាយ៉ាងខ្លាំងរវាងរដ្ឋបស្ចឹម លោកដែលគ្រប់គ្រងបែបអាណាចក្រនិងបណ្តារដ្ឋឥស្លាមមួយចំនួន ដែលជំទាស់ដាច់ខាតនឹងការលើកឡើង អំពីប្រធានបទណាមួយស្តីអំពីមនុស្សស្រលាញ់ភេទដូចគ្នា។ ចំណុចនេះត្រូវបានគូសបញ្ជាក់នៅពេលដែល ប្រធានាធិបតីអ៊ីរ៉ង់នៅពេលនោះ ដែលបានអះអាងនៅក្នុងសុន្ទរកថា ឆ្នាំ ២០០៧ នៅសាកលវិទ្យាល័យ កូឡុំប៊ីថា មិនមានមនុស្សស្រឡាញ់ភេទដូចគ្នានៅក្នុងប្រទេសអ៊ីរ៉ង់ទេ។ អាជ្ញាធរកាតូលិកទូទាំងពិភពលោក បានជំទាស់នឹងកម្មវិធី ដែលលើកទឹកចិត្តអោយប្រើស្រោមអនាម័យ។ ដូចដែលឧទាហរណ៍ទាំងនេះបាន បង្ហាញ វិធានការបង្ការដែលមានប្រសិទ្ធភាពបំផុតមួយចំនួន (ការអប់រំជាសាធារណៈ ការផ្សព្វផ្សាយទៅកាន់ ក្រុមដែលមានហានិភ័យ ការចែកចាយស្រោមអនាម័យ ចែកម្ភូលដោយឥតគិតថ្លៃដល់អ្នកប្រើប្រាស់គ្រឿង ញៀន) គឺជាបញ្ហាវប្បធម៌ និងនយោបាយដ៏រសើប។

រដ្ឋត្រូវតែសហការគ្នា ប្រសិនបើពួកគេចង់គ្រប់គ្រងការរីករាលដាលនៃជំងឺមួយនេះ។ កិច្ចខិតខំប្រឹងប្រែងអន្តរជាតិទាំងនេះត្រូវបានសម្របសម្រួលជាចម្បង ដោយអង្គការសុខភាពពិភពលោក(WHO) និងផ្តល់មូលនិធិជាចម្បងដោយប្រទេសឧស្សាហកម្ម។ ប៉ុន្តែ ថវិការបស់អង្គការសុខភាពពិភពលោកទាំងមូលមានទំហំស្មើនឹងថវិកាមន្ទីរពេទ្យខ្នាតមធ្យមនៅអឡាស្កាតែប៉ុណ្ណោះ។ អង្គការសុខភាពពិភពលោកពឹងផ្អែកលើរដ្ឋាភិបាលជាតិនីមួយៗ ដើម្បីផ្តល់ព័ត៌មាន និងអនុវត្តគោលនយោបាយ ហើយរដ្ឋាភិបាលបានអនុវត្តយឺតក្នុងការឆ្លើយតប។ រដ្ឋាភិបាលមួយចំនួនបានក្លែងបន្លំស្ថិតិ ដើម្បីរាយការណ៍ចំនួនករណីតិចតួច (ក្រែងលោទេសចរត់ចេញឬមិនមកលេងប្រទេសខ្លួន) ហើយរដ្ឋាភិបាលជាច្រើនមានការស្ទាក់ស្ទើរក្នុងការអត់អោនចំពោះឬឧបត្ថម្ភការអប់រំផ្លូវភេទ និងការចែកចាយស្រោមអនាម័យ ដោយសារការហាមឃាត់ខាងសាសនា ឬវប្បធម៌។

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ មេរោគអេដស៍បានរីករាលដាលយ៉ាងឆាប់រហ័ស នៅក្នុងតំបន់អាស៊ីខាងត្បូង ប្រទេសចិន និងរុស្ស៊ី/អឺរ៉ុបខាងកើត ដែលពេស្យាចារ និងការប្រើប្រាស់គ្រឿងញៀនកំពុងកើនឡើង។ ប្រទេសថៃមានភាពងាយរងគ្រោះជាពិសេស ដោយសារតែឧស្សាហកម្មពេស្យាចារីកស្គុះស្គាយ ការបើកចំហរចំពោះជម្រើសភេទ និងឧស្សាហកម្មទេសចរណ៍ដ៏ធំរបស់ខ្លួន។ វាជាប្រទេសមួយក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍន៍ដំបូងគេ ដែលបង្កើតកម្មវិធីប្រឆាំងជំងឺអេដស៍ប្រកបដោយប្រសិទ្ធភាព ដែលផ្តោតលើការអប់រំសាធារណៈ ហើយវាបានកាត់បន្ថយអត្រាឆ្លងមេរោគយ៉ាងខ្លាំងនៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០។

នៅក្នុងប្រទេសចិន រដ្ឋាភិបាលមានសកម្មភាពយឺតយ៉ាវ ហើយការមាក់ងាយនៅតែរារាំងការកំណត់អត្តសញ្ញាណ ឬការព្យាបាលប្រកបដោយប្រសិទ្ធភាពនៃចំនួនប្រជាជន ដែលមានផ្ទុកមេរោគHIVដែលកំពុងកើនឡើងយ៉ាងឆាប់រហ័ស។ អាជីវកម្មបូមឈាមលក់អសីលធម៌ ជាពិសេសនៅតំបន់ជនបទមួយ បានបង្កអោយមានការឆ្លងមេរោគHIVយ៉ាងច្រើន។ នៅតាមជនបទនៃប្រទេសចិន ការអនុវត្តផ្នែកវេជ្ជសាស្ត្រពឹងផ្អែកខ្លាំងលើការចាក់ថ្នាំ ជារឿយៗដោយប្រើម្ជុលដែលមិនត្រូវបានសម្លាប់មេរោគ នៅពេលដែលទម្រង់នៃការព្យាបាលផ្សេងទៀតនឹងមានប្រសិទ្ធភាព។ ជាលទ្ធផល ៦០ ភាគរយនៃប្រជាជនចិនមានជំងឺរលាកថ្លើមប្រភេទ B ធៀបនឹង ១ ភាគរយនៅសហរដ្ឋអាមេរិក និងប្រទេសជប៉ុន ដែលជាសញ្ញាគ្រោះថ្នាក់សម្រាប់ការរីករាលដាលនៃមេរោគអេដស៍នាពេលអនាគតនៅក្នុងប្រទេសចិន។ ប្រទេសចិនមានអ្នកឆ្លងប្រមាណ ១ លាននាក់ ក្នុងឆ្នាំ២០១៨ ទោះបីជាចំនួននេះពិបាកនឹងបញ្ជាក់ក៏ដោយ។

ជំងឺអេដស៍បង្ហាញពីទំនាក់ទំនងឆ្លងដែន ដែលធ្វើអោយព្រំដែនអន្តរជាតិ មិនសូវមានអត្ថន័យដូចកាលពីអតីតកាល។ កិច្ចសហប្រតិបត្តិការអន្តរជាតិប្រកបដោយប្រសិទ្ធភាពអាចជួយសង្គ្រោះជីវិតមនុស្សរាប់លាននាក់ និងលើកកម្ពស់យ៉ាងសំខាន់នូវលទ្ធភាពសម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច នៅក្នុងប្រទេសក្រីក្របំផុតក្នុងទសវត្សរ៍ខាងមុខ។ ប៉ុន្តែជាថ្មីម្តងទៀត បញ្ហាផលប្រយោជន៍រួមកើតមានឡើង ពាក់ព័ន្ធនឹងការបែងចែកការចំណាយនិងផលចំណេញ។ ប្រាក់មួយដុល្លារដែលចំណាយដោយអង្គការWHOមានឥទ្ធិពលដូចគ្នាដោយមិនគិតថាប្រទេសណាជាអ្នកបរិច្ចាគវាឡើយ។

ជំងឺឆ្លងផ្សេងៗទៀត

ជំងឺអេដស៍មិនមែនជាការព្រួយបារម្ភតែមួយគត់នោះទេ។ ជំងឺរបេង ជំងឺគ្រុនចាញ់ ជំងឺរលាកថ្លើមគ្រុនឈាមនិងជំងឺអាសន្នរោគបានកើតមានឡើងវិញ ឬឆ្លងរីករាលដាល ក្នុងប៉ុន្មានទសវត្សរ៍ថ្មីៗនេះ ដែល

ជារឿយៗបម្លែងទៅជាទម្រង់ធន់នឹងថ្នាំ។ ឥឡូវនេះ ជំងឺរបេងបានសម្លាប់មនុស្ស ១,៧ លាននាក់ក្នុងមួយឆ្នាំ (បន្ថែមលើអ្នកជំងឺអេដស៍ដែលឆ្លងជំងឺរបេងផងដែរ)។ ជំងឺគ្រុនចាញ់បានធ្វើអោយមនុស្សរាប់រយលាននាក់ឈឺ និងសម្លាប់មនុស្សជាងមួយលាននាក់ ក្នុងមួយឆ្នាំ ក្នុងនោះអ្នកជំងឺស្ទើរតែទាំងអស់ស្ថិតក្នុងទ្វីបអាហ្វ្រិក។ យុទ្ធនាការថ្មីបានចែកចាយមុងរាប់លាន នៅទ្វីបអាហ្វ្រិក ដើម្បីកាត់បន្ថយជំងឺគ្រុនចាញ់ ដែលជាវិធានការណ៍មានប្រសិទ្ធភាព សមនឹងតម្លៃ។ វ៉ាក់សាំងថ្មីដែលត្រូវបានអនុម័តអោយប្រើប្រាស់យ៉ាងទូលំទូលាយ ក្នុងឆ្នាំ ២០១៥ អាចកាត់បន្ថយករណីជំងឺគ្រុនចាញ់ប្រហែលពាក់កណ្តាល។ កម្មវិធីចាក់វ៉ាក់សាំងបានកាត់បន្ថយអត្រាកើតជំងឺគ្រុនស្វិតដៃជើងនិងជំងឺកញ្ជ្រឹល ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ។ យុទ្ធនាការចាក់ថ្នាំបង្ការជំងឺកញ្ជ្រឹលបច្ចុប្បន្ននេះ បានឈានដល់ ៨៥ ភាគរយនៃទារក នៅទូទាំងពិភពលោក ដោយកាត់បន្ថយការស្លាប់ ៨០ ភាគរយចាប់តាំងពីឆ្នាំ ២០០០។ គួរអោយស្តាយ ការចាក់វ៉ាក់សាំងជំងឺស្វិតដៃជើង នៅក្នុងប្រទេសប៉ាគីស្ថានត្រូវបានកាត់បន្ថយក្នុងឆ្នាំ ២០១២ បន្ទាប់ពីពួកសកម្មប្រយុទ្ធតាលីបង់បានបាញ់សម្លាប់បុគ្គលិកសុខាភិបាលដោយអះអាងថា វ៉ាក់សាំងនេះគឺជាផែនការរបស់លោកខាងលិចក្នុងការក្រៀវកុមារមូស្លីមទាំងឡាយ។

រូបថត សិស្សសាលានៅប្រទេសរុស្ស៊ីពាក់ម៉ាស់ដើម្បីការពារការឆ្លងជំងឺផ្តាសាយ

ការការពារជំងឺរាតត្បាត

ជាមួយនឹងមនុស្សរាប់លាននាក់ដែលឆ្លងកាត់ព្រំដែនជុំវិញពិភពលោកជារៀងរាល់ឆ្នាំ គេតែងតែមានការព្រួយបារម្ភអំពីការផ្ទុះឡើងដោយឯកោនៃជំងឺឆ្លងអាចរីករាលដាលយ៉ាងឆាប់រហ័ស។ ក្នុងឆ្នាំ ២០១៧ សហរដ្ឋអាមេរិកបានទទួលរងនូវជំងឺគ្រុនផ្តាសាយដ៏អាក្រក់បំផុតមួយ ក្នុងប្រវត្តិសាស្ត្រថ្មីៗនេះ ជាមួយនឹងចំនួនអ្នកស្លាប់ ប្រមាណ ៤០០០ នាក់ ក្នុងមួយសប្តាហ៍។ ប្រទេសផ្សេងទៀតដូចជា កាណាដា រុស្ស៊ី និងចិនក៏ជួបប្រទះនឹងជំងឺផ្តាសាយធម្មតាដែរ។ នៅទីនេះ សិស្សសាលានៅប្រទេសរុស្ស៊ីពាក់ម៉ាស់ដើម្បីការពារការឆ្លងជំងឺផ្តាសាយ ២០១៨។

ក្នុងឆ្នាំ ២០១៤ ពិភពលោកបានដោះស្រាយវិបត្តិជំងឺដ៏សំខាន់មួយនៅអាហ្វ្រិកខាងលិច។ មេរោគអេបូឡា (Ebola) បានរីករាលដាលនៅក្នុងប្រទេសហ្គីណេ លីបេរីយ៉ា និងសៀរ៉ាឡេអូន។ គេប៉ាន់ប្រមាណថាមនុស្សជិត ១០០០០ នាក់បានស្លាប់ ដោយសារជំងឺនេះ។ ការព្រួយបារម្ភបានរីករាលដាលពាសពេញពិភពលោក ដែលជាករណីឆ្លងបានចាប់ផ្តើមលេចឡើង នៅខាងក្រៅទ្វីបអាហ្វ្រិក រួមទាំងសហរដ្ឋអាមេរិក និងអេស្ប៉ាញ។ ប្រទេសនានាបានអនុម័តការតឹងតែងការធ្វើដំណើរ និងគោលនយោបាយធ្វើចត្តាឡីស័កសម្រាប់អ្នកដែលសង្ស័យថាមានមេរោគនេះ។ ជំនួយរាប់ពាន់លានដុល្លារត្រូវបានផ្តល់ទៅអោយរដ្ឋអាហ្វ្រិកខាងលិចទាំងនេះ ដើម្បីបញ្ឈប់មេរោគនិងកែលម្អការថែទាំសុខភាពសម្រាប់អ្នកជំងឺ។ ប៉ុន្តែ វាជាឧទាហរណ៍មួយទៀតនៃរបៀបដែល នៅក្នុងពិភពអន្តរកម្មនិងសកលភាវូបនីយកម្ម ជំងឺអាចរីករាលដាលយ៉ាងឆាប់រហ័សលើតំបន់ធំទូលាយ រហូតឆ្លងកាត់មហាសមុទ្រទៀតផង។

ជាប្រវត្តិសាស្ត្រ កង្វះជាតិអ៊ីយ៉ូតបានទទួលការយកចិត្តទុកដាក់តិចតួច ទោះបីជាវាប៉ះពាល់ដល់មនុស្សរហូតដល់ ២ ពាន់លាននាក់ នៅទូទាំងពិភពលោកក៏ដោយ។ សូម្បីតែកង្វះកម្រិតមធ្យមនៅក្នុងទារកអាចបន្ថយភាពវៃឆ្លាត ពី ១០ ទៅ ១៥ ពិន្ទុIQ ហើយការខ្វះខាតធ្ងន់ធ្ងរអាចរារាំងការលូតលាស់ និងបង្កអោយមានជំងឺវិកលចរិត និងពកក (ក្រពេញទីរ៉ូអ៊ីតរីកធំ)។ ដោយចំណាយប្រហែល ៥ សេនសម្រាប់មនុស្សម្នាក់ក្នុងមួយឆ្នាំ ជាតិអ៊ីយ៉ូតអាចត្រូវបានបន្ថែមទៅក្នុងអំបិល និងការពារកង្វះខាតអ៊ីយ៉ូតទាំងស្រុង ប៉ុន្តែ ប្រទេស

ជាច្រើននៅអឌ្ឍគោលខាងត្បូងនិងអតីតប្លុកសូវៀតនៅតែមិនបានធ្វើដូច្នេះទៀត។ យុទ្ធនាការអន្តរជាតិមួយបានបង្កើនការប្រើប្រាស់អំបិលអ៊ីយ៉ូដ ពី ២៥ ភាគរយនៃគ្រួសារនៅទូទាំងពិភពលោកក្នុងឆ្នាំ ១៩៩០ ដល់ ៦៦ ភាគរយក្នុងឆ្នាំ ២០០៦។

ជំងឺរាតត្បាតក្នុងចំនោមសត្វមានផលប៉ះពាល់ធំធេងផងដែរ។ បច្ចុប្បន្ននេះ អ្នកវិទ្យាសាស្ត្របារម្ភថាជំងឺគ្រុនផ្តាសាយបក្សីអាចបម្លែងធាតុ និងរីករាលដាលពីមនុស្សទៅមនុស្ស ដែលបង្កអោយមានជំងឺរាតត្បាតសកលដែលអាចសម្លាប់មនុស្សរាប់លាននាក់។ ក្នុងចន្លោះឆ្នាំ ២០០៩-២០១០ ជំងឺគ្រុនផ្តាសាយជ្រូកបានរីករាលដាលយ៉ាងឆាប់រហ័សនៅជុំវិញពិភពលោក ដែលនាំអោយប្រទេសផ្សេងៗដាក់កម្រិតលើការធ្វើដំណើរទៅកាន់ប្រទេសម៉ិកស៊ិក (ជាកន្លែងដែលជំងឺផ្តាសាយផ្ទុះឡើង)។ ជំងឺផ្តាសាយជ្រូកប្រភេទនេះ (H1N1) ត្រូវបានរកឃើញនៅក្នុងប្រទេសជាច្រើន ដែលភាគច្រើនបានអនុវត្តគោលនយោបាយចត្តាឡីស័កសម្រាប់អ្នកជំងឺទាំងឡាយ។

ការជក់បារី

នៅទូទាំងពិភពលោក មនុស្សជាង ១ ពាន់លាននាក់ជក់បារី ដោយប្រហែល ៥/៦ ក្នុងចំណោមពួកគេរស់នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ហើយមនុស្ស ៥ លាននាក់ក្នុងមួយឆ្នាំបានស្លាប់ដោយសារជំងឺពាក់ព័ន្ធនឹងថ្នាំជក់។ បណ្តារដ្ឋដែលបរាជ័យក្នុងការទប់ស្កាត់ការរីករាលដាលនៃការញៀនជាតិនីកូទីនប្រឈមមុខនឹងការចំណាយខ្ពស់នាពេលអនាគតក្នុងការថែទាំសុខភាព ពោលគឺការចំណាយដែលទើបតែចាប់ផ្តើមមកដល់ នៅក្នុងប្រទេសក្រីក្រជាច្រើន។ ការចំណាយត្រូវបានកំណត់នៅត្រឹមរង្វង់រដ្ឋខ្លួនឯង។ ប្រជាពលរដ្ឋ និងសេដ្ឋកិច្ចរបស់ខ្លួនត្រូវបង់ថ្លៃចំណាយ។ ទោះជាយ៉ាងណាក៏ដោយ ការដួញដូរថ្នាំជក់ធ្វើអោយការជក់បារីក្លាយជាបញ្ហាអន្តរជាតិ។ យុទ្ធនាការទីផ្សាររបស់ក្រុមហ៊ុនថ្នាំជក់ ដែលផ្តោតលើស្ត្រីនៅអឌ្ឍគោលខាងត្បូង អាចបង្កើនចំនួនអ្នកជក់បារីនៅក្នុងក្រុមនោះ នេះបើយោងតាមអង្គការសុខភាពពិភពលោក។ ភាពខុសគ្នារវាងយេនឌ័ក្នុងការជក់បារីនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ មានលក្ខណៈគួរអោយចាប់អារម្មណ៍ៈ ប្រហែល ៤ ភាគរយនៃស្ត្រីជក់បារីរស់នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើន ចំណែកឯចំនួនដែលត្រូវគ្នាសម្រាប់បុរស មានរហូតដល់ ៦០ ភាគរយ (នៅក្នុងប្រទេសចិន)។ ផ្ទុយទៅវិញ នៅសហរដ្ឋអាមេរិក បុរសប្រហែល ២០ ភាគរយជក់បារី ធៀបស្ត្រីដែលមានត្រឹមតែ ១៥ ភាគរយ។

ក្នុងឆ្នាំ ២០០១ ក្រុមហ៊ុនថ្នាំជក់ដែលមានការគាំទ្រពីសហរដ្ឋអាមេរិកមួយចំនួនបានព្យាយាមធ្វើអោយខ្សោយសន្ធិសញ្ញាដែលបានស្នើឡើងថ្មីមួយ គឺ អនុសញ្ញាក្របខ័ណ្ឌស្តីពីការគ្រប់គ្រងថ្នាំជក់ ប៉ុន្តែនៅឆ្នាំ ២០០៣ សហរដ្ឋអាមេរិកបានទម្លាក់ការជំទាស់របស់ខ្លួន ហើយបណ្តារដ្ឋជាសមាជិករបស់អង្គការសុខភាពពិភពលោកបានអនុម័តសន្ធិសញ្ញា ដែលបានចូលជាធរមានក្នុងឆ្នាំ ២០០៥។ រដ្ឋសមាជិកប្តេជ្ញាហាមឃាត់ការផ្សព្វផ្សាយពាណិជ្ជកម្មថ្នាំជក់ និងត្រូវបានលើកទឹកចិត្តអោយដំឡើងពន្ធលើថ្នាំជក់ ៥ ភាគរយក្នុងមួយឆ្នាំលើសពីអត្រាអតិផរណា។ សហរដ្ឋអាមេរិកតែមួយគត់ ក្នុងចំណោមប្រទេសមហាអំណាចធំៗក្នុងពិភពលោកនៅតែមិនបានផ្តល់សច្ចាប័នលើសន្ធិសញ្ញានេះ គិតត្រឹមឆ្នាំ ២០១៨។

បញ្ហាចំនួនប្រជាជន ជួនកាល ត្រូវបានគេប្រៀបធៀបនិងបង្ហាញយ៉ាងសាមញ្ញថា មនុស្សច្រើនពេកញ៉ាំអាហារនិងប្រើប្រាស់ធនធានធម្មជាតិតិចតួចស្តួចស្តើង។ ទោះជាយ៉ាងណាក៏ដោយ គំនិតដែលថាចំនួនប្រជាជនលើស គឺជាមូលហេតុនៃគ្រោះទុរភិក្សនៅក្នុងពិភពលោកបច្ចុប្បន្ន គឺពិតជាមិនត្រឹមត្រូវនោះទេ។ ភាព

ក្រីក្រ និងនយោបាយ ច្រើនជាងចំនួនប្រជាជន គឺជាមូលហេតុនៃកង្វះអាហារូបត្ថម្ភ និងភាពអត់ឃ្លានសព្វថ្ងៃនេះ (សូមមើលគ្រោះទុរភិក្សពិភពលោកនៅក្នុងមេរៀនទី ២)។ ពិតជាមានអាហារ ទឹក ប្រេង ដី និងអ្វីៗផ្សេងទៀតគ្រប់គ្រាន់ គ្រាន់តែធនធានទាំងនេះមិនត្រូវបានចែកចាយដោយល្អាយស្មើសាច់។

ការចែកចាយមិនស្មើគ្នានេះ ពាក់ព័ន្ធដោយផ្ទាល់ទៅនឹងគម្លាតរវាងអឌ្ឍគោលខាងជើងនិងខាងត្បូង។ ភាពតានតឹងក្នុងបរិស្ថាននិងធនធានធម្មជាតិមានវិសាលភាពជាសកល ប៉ុន្តែនៅអឌ្ឍគោលខាងជើង ពួកវាកើតឡើងពីឧស្សាហូបនីយកម្ម(កំណើនផ.ស.ស.សម្រាប់មនុស្សម្នាក់ៗ) ចំណែកនៅអឌ្ឍគោលខាងត្បូង ពួកគេត្រូវរងផលប៉ះពាល់ដោយការកើនឡើងនៃចំនួនប្រជាជន។ ភាពខុសគ្នាទាំងនេះ នៅក្នុងផលប៉ះពាល់បរិស្ថាន គឺមិនមែនជាភាពខុសគ្នារវាងអឌ្ឍគោលខាងជើងនិងខាងត្បូងតែមួយគត់នោះទេ។ មេរៀនពីរបន្ទាប់នឹងបង្វែរការយកចិត្តទុកដាក់ចំពោះការបែងចែកឬគម្លាតរវាងអឌ្ឍគោលខាងជើងនិងខាងត្បូង។

សេចក្តីសង្ខេប

១. បញ្ហាបរិស្ថានគឺជាឧទាហរណ៍នៃការពឹងពាក់គ្នាទៅវិញទៅមកជាអន្តរជាតិ ហើយជារឿយៗបង្កើតបញ្ហាផលប្រយោជន៍រួមសម្រាប់រដ្ឋពាក់ព័ន្ធ។ តួអង្គមួយចំនួនធំដែលពាក់ព័ន្ធនឹងបញ្ហាបរិស្ថានពិភពលោក ធ្វើអោយពួកគេកាន់តែពិបាកដោះស្រាយ។

២. ដើម្បីដោះស្រាយបញ្ហាផលប្រយោជន៍រួមបែបនេះ រដ្ឋទាំងឡាយបានប្រើប្រាស់របបអន្តរជាតិ និងអង្គការអន្តររដ្ឋាភិបាល ហើយក្នុងករណីខ្លះបានពង្រីកអធិបតេយ្យភាពរបស់រដ្ឋ (ជាពិសេសលើដែនទឹក) ដើម្បីធ្វើអោយការគ្រប់គ្រងមានលក្ខណៈជាតិ ជាជាងបញ្ហាអន្តរជាតិ។

៣. កិច្ចខិតខំប្រឹងប្រែងអន្តរជាតិ ដើម្បីដោះស្រាយបញ្ហាបរិស្ថានមានគោលបំណងនាំមកនូវការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយចីរភាព។

៤. ការឡើងកំដៅផែនដីកើតឡើងដោយសារការដុតឥន្ធនៈហ្វូស៊ីល ដែលជាមូលដ្ឋាននៃសេដ្ឋកិច្ចប្រទេសឧស្សាហកម្មសព្វថ្ងៃនេះ។ រដ្ឋឧស្សាហូបនីយកម្មមានទំនួលខុសត្រូវច្រើនចំពោះបញ្ហា នេះ ជាងប្រទេសកំពុងអភិវឌ្ឍន៍ ប៉ុន្តែប្រទេសដូចជាចិន និងឥណ្ឌាក៏រួមចំណែកដល់បញ្ហានេះដែរ។ ដំណោះស្រាយពិបាកសម្រេចបាន ដោយសារការចំណាយមានច្រើន ហើយគ្រោះថ្នាក់ស្ថិតនៅឆ្ងាយនិងមិនច្បាស់លាស់។

៥. ការខូចខាតដល់ស្រទាប់អូហ្សូនរបស់ផែនដី បណ្តាលមកពីការប្រើប្រាស់សារធាតុគីមីដាក់លាក់ ដែលឥឡូវនេះត្រូវបានលុបចោលជាដំណាក់កាល។ ក្រោមកិច្ចព្រមព្រៀងអន្តរជាតិ។ មិនដូចការឡើងកំដៅផែនដីទេ ការចំណាយលើដំណោះស្រាយបញ្ហានេះមានតម្លៃទាបជាងច្រើន ហើយបញ្ហាក៏ត្រូវបានយល់កាន់តែច្បាស់ផងដែរ។

៦. ប្រភេទសត្វជាច្រើនត្រូវបានគំរាមកំហែងជាមួយនឹងការផុតពូជ ដោយសារតែការបាត់បង់ទីជម្រក ដូចជាព្រៃទឹកភ្លៀង។ សន្ធិសញ្ញាអន្តរជាតិស្តីពីជីវចម្រុះ និងកិច្ចព្រមព្រៀងស្តីពីព្រៃឈើមានគោលបំណងកាត់បន្ថយការបំផ្លិចបំផ្លាញនៃប្រព័ន្ធអេកូឡូស៊ីក្នុងស្រុក ជាមួយនឹងការចំណាយចែករម្លែកគ្នាក្នុងចំណោមរដ្ឋនានា។

៧. អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ(UNCLOS) បង្កើតរបបមហាសមុទ្រ ដែលដាក់ជលផលពាណិជ្ជកម្មនិងប្រេងនៅឈូងសមុទ្រភាគច្រើន អោយនៅក្រោមការគ្រប់គ្រងរបស់រដ្ឋ ជាដែនទឹក។

៨. ការបំពុល រួមទាំងភ្លៀងអាស៊ីត ការបំពុលទឹកនិងខ្យល់ និងកាកសំណល់ពុលនិងនុយក្លេអ៊ែរ ហាក់មានលក្ខណៈក្នុងស្រុកទេសជាងលក្ខណៈសកល ហើយត្រូវបានដោះស្រាយជាចម្បង តាមរយៈវិធានការណ៍ឯកតោភាគី ទ្វេភាគី និងតំបន់ ជាជាងវិធានការណ៍សកលលោកទាំងមូល។

៩. រដ្ឋបស្ចឹមលោកភាគច្រើននាំចូលធនធានថាមពល ភាគច្រើនជាប្រេង ចំណែកតំបន់ពិភពលោកផ្សេងទៀតនាំចេញធនធានទាំងនោះ។ តម្លៃប្រេងបានកើនឡើងយ៉ាងខ្លាំង នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៧០ ប៉ុន្តែបានធ្លាក់ចុះនៅក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ នៅពេលដែលសេដ្ឋកិច្ចពិភពលោកបានកែសម្រួលដោយការកើនឡើងនៃការផ្គត់ផ្គង់និងការកាត់បន្ថយតម្រូវការប្រេង។ តម្លៃបានកើនឡើងម្តងទៀតនៅកំឡុងឆ្នាំ ១៩៩១ និងចន្លោះឆ្នាំ ២០០៧-២០០៨ មុនពេលដួលរលំនៅឆ្នាំ ២០០៨។ ការប្រែប្រួលបែបនេះធ្វើអោយប៉ះពាល់ដល់ស្ថិរភាពសេដ្ឋកិច្ចពិភពលោក។

១០. ប្រភពប្រេងដ៏សំខាន់បំផុតដែលត្រូវបានជួញដូរទូទាំងពិភពលោក ស្ថិតនៅតំបន់ឈូងសមុទ្រពែក្ស នៃមជ្ឈិមបូព៌ា។ អាស្រ័យហេតុនេះ តំបន់នេះបានក្លាយជាចំណុចស្នូលនៃជម្លោះនយោបាយអន្តរជាតិជាយូរមកហើយ។

១១. ចំនួនប្រជាជនពិភពលោក គិតត្រឹមឆ្នាំ ២០១៨ នេះ មានរហូតដល់ទៅ ៨ ពាន់លាននាក់ នៅទីបំផុតអាចនឹងមានចំនួនប្រហែល ១០ ពាន់លាននាក់។ ស្ទើរតែចំនួនទាំងអស់នៃកំណើននេះ នឹងមកនៅអឌ្ឍគោលខាងត្បូង។

១២. នាពេលអនាគតដ៏ឃ្លេ កំណើនប្រជាជនពិភពលោកនឹងត្រូវបានជំរុញយ៉ាងខ្លាំងដោយអន្តរកាលប្រជាសាស្ត្រ។ អត្រាមរណៈបានធ្លាក់ចុះនៅទូទាំងពិភពលោក ប៉ុន្តែអត្រាកំណើតនឹងធ្លាក់ចុះតាមចំនួនសមាមាត្រ នៅពេលដែលប្រាក់ចំណូលសម្រាប់មនុស្សម្នាក់ៗកើនឡើង។ សេដ្ឋកិច្ចនៃរដ្ឋក្រីក្រមានការអភិវឌ្ឍន៍កាន់តែលឿន ប្រជាជនរបស់ពួកគេកាន់តែឆាប់ថយចុះ។

១៣. គោលនយោបាយរបស់រដ្ឋាភិបាលអាចកាត់បន្ថយអត្រាកំណើតបានខ្លះ តាមកម្រិតនៃប្រាក់ចំណូលសម្រាប់មនុស្សម្នាក់ៗ។ គោលនយោបាយដែលមានប្រសិទ្ធភាព គឺជាគោលនយោបាយដែលធ្វើអោយប្រសើរឡើងនូវលទ្ធភាពទទួលបានការគ្រប់គ្រងកំណើត និងលើកកម្ពស់ឋានៈរបស់ស្ត្រីនៅក្នុងសង្គម។ គោលនយោបាយដាក់ស្តែងមានភាពខុសប្លែកគ្នាចាប់ពីច្បាប់ដ៏តឹងរឹងបំផុតរបស់ប្រទេសចិន ស្តីពីការមានកូនត្រឹមតែមួយ រហូតដល់រដ្ឋាភិបាលជម្រុញកំណើតនិយម ដែលលើកទឹកចិត្តអោយមានអត្រាកំណើតជាអតិបរមា និងដាក់ការគ្រប់គ្រងកំណើតអោយនៅក្រៅច្បាប់។

១៤. ការរាតត្បាតមេរោគHIV/ជំងឺអេដស៍ជាសកល បង្កើតការចំណាយដ៏ធំសម្រាប់រដ្ឋក្រីក្រជាច្រើន។ បច្ចុប្បន្ននេះ មនុស្សជាង ៣៥ លាននាក់បានឆ្លងមេរោគHIV ហើយ ៣០ លាននាក់ទៀតបានស្លាប់។ ភាគច្រើនស្ថិតនៅក្នុងទ្វីបអាហ្វ្រិក ប៉ុន្តែការឆ្លងថ្មីកំពុងកើនឡើងយ៉ាងឆាប់រហ័សនៅអាស៊ី និងរុស្ស៊ី។

ពាក្យគន្លឹះ

១. **សោកនាដ្យកម្មសាធារណៈ** (tragedy of the commons) គឺជាគ្រោះមហន្តរាយរួមដែលកើតឡើង នៅពេលដែលសម្បត្តិបរិស្ថានរួម (ដូចជាជលផលពិភពលោក) ត្រូវបានបំផ្លាញ ឬធ្លាក់ចុះបរិមាណដោយសាររដ្ឋទាំងឡាយបរាជ័យក្នុងការសហការប្រកបដោយប្រសិទ្ធភាព។ ដំណោះស្រាយមួយគឺត្រូវ«ហ៊ុំព័ទ្ធ»រួម (បំបែកវាទៅជាសម្បត្តិផ្ទាល់ខ្លួន); របបអន្តរជាតិក៏អាចជាដំណោះស្រាយ(ដោយផ្នែក)។

២. **ការហ៊ុំព័ទ្ធ** (enclosure) គឺជាការបំបែកតំបន់រួមឬដីសាធារនៈទៅជាចំណែកឬសម្បត្តិឯកជន ដែលអាចធ្វើអោយម្ចាស់កម្មសិទ្ធិខិតខំគ្រប់គ្រងធនធានប្រកបដោយការទទួលខុសត្រូវ។

៣. **កំណើនកម្តៅសកល** (global warming) គឺជា ការឡើងសីតុណ្ហភាពពិភពលោកជាមធ្យមយឺតៗបន្តិចម្តងៗ និងរយៈពេលវែង ដែលបណ្តាលមកពីការបំភាយឧស្ម័នផ្ទះកញ្ចក់ ដែលភាយចេញពីការដុតឥន្ធនៈហ្វូស៊ីល ប្រេង ធ្យូងថ្ម និងឧស្ម័នធម្មជាតិ។ សូមមើល *ឧស្ម័នផ្ទះកញ្ចក់* ផងដែរ។

៤. **កម្មវិធីបរិស្ថានអង្គការសហប្រជាជាតិ** (UNEP) គឺជាកម្មវិធីដែលតាមដានស្ថានភាពបរិស្ថាន និងក្នុងចំណោមសកម្មភាពផ្សេងទៀត ធ្វើការជាមួយអង្គការឧតុនិយមពិភពលោក ដើម្បីវាស់ស្ទង់ការប្រែប្រួលអាកាសធាតុពិភពលោក។

៥. **ឧស្ម័នផ្ទះកញ្ចក់** (greenhouse gases) សំដៅលើឧស្ម័នកាបូនឌីអុកស៊ីត និងឧស្ម័នផ្សេងទៀត ដែលនៅពេលដែលប្រមូលផ្តុំនៅក្នុងបរិយាកាសធ្វើសកម្មភាពដូចកញ្ចក់នៅក្នុងផ្ទះកញ្ចក់ ដោយផ្តុំកថាមពលនិងនាំដល់ការឡើងកំដៅផែនដី។

៦. **ពិធីសារក្យូតូ** (Kyoto Protocol) គឺជាសន្ធិសញ្ញាអន្តរជាតិសំខាន់ស្តីពីការឡើងកំដៅផែនដី ដែលបានចូលជាធរមានក្នុងឆ្នាំ ២០០៥ និងកំណត់អាណត្តិកាត់បន្ថយការបញ្ចេញកាបូន។ ស្ទើរតែគ្រប់ប្រទេសធំៗលើពិភពលោក លើកលែងតែសហរដ្ឋអាមេរិក គឺជាប្រទេសចុះហត្ថលេខី។

៧. កិច្ចព្រមព្រៀងអាកាសធាតុទីក្រុងប៉ារីស គឺជាកិច្ចព្រមព្រៀងអន្តរជាតិសំខាន់ស្តីពីការឡើងកំដៅផែនដី ត្រូវបានចុះហត្ថលេខាក្នុងឆ្នាំ ២០១៥ ដែលអំពាវនាវអោយរក្សាការកើនឡើងសីតុណ្ហភាពពិភពលោកក្នុងសតវត្សរ៍នេះអោយនៅខាងក្រោម ២ អង្សារសេ លើសពីកម្រិតមុនសម័យឧស្សាហកម្ម។ ប្រទេសស្ទើរតែទាំងអស់ក្នុងពិភពលោកបានចូលរួម។

៨. **ស្រទាប់អូហ្សូន** (ozone layer) គឺជាស្រទាប់មួយនៃបរិយាកាសដែលទប់ស្កាត់កាំរស្មីអ៊ុលត្រាវីយូឡេដ៏គ្រោះថ្នាក់ពីព្រះអាទិត្យ។ សារធាតុគីមីមួយចំនួន ដែលប្រើក្នុងសេដ្ឋកិច្ចឧស្សាហកម្មបានភាយទៅបំផ្លាញស្រទាប់អូហ្សូន។

៩. **ពិធីសារម៉ុងត្រេអាល់** (Montreal Protocol) គឺជា(១៩៨៧) កិច្ចព្រមព្រៀងស្តីពីការការពារស្រទាប់អូហ្សូនដែលរដ្ឋនានាបានសន្យាថា នឹងកាត់បន្ថយហើយបន្ទាប់មកនឹងលុបបំបាត់ការប្រើប្រាស់សារធាតុក្លរ៉ូហ្គុយរ៉ូកាបូន (CFCs)។ វាជាសន្ធិសញ្ញាបរិស្ថានដែលជោគជ័យបំផុតរហូតមកដល់បច្ចុប្បន្ន។

១០. **ជីវៈចម្រុះ** (biodiversity) គឺជាភាពចម្រុះខ្លាំងនៃប្រភេទវុក្ខជាតិនិងសត្វដែលបង្កើតបានជាប្រព័ន្ធអេកូឡូស៊ីរបស់ផែនដី (សកល តំបន់ និងក្នុងស្រុក)

១១. **គណៈកម្មការឆ្លាមអន្តរជាតិ** (International Whaling Commission) គឺជាអង្គការអន្តររដ្ឋាភិបាលដែលកំណត់កូតាសម្រាប់ការនេសាទប្រភេទត្រីបាឡែនមួយចំនួន។ ការចូលរួមរបស់រដ្ឋមានលក្ខណៈស្ម័គ្រចិត្ត។

១២. **សមុទ្រជ្រៅ** (high seas) គឺជាផ្នែកនៃមហាសមុទ្រដែលត្រូវចាត់ទុកថាជាទឹកដីរួម មិនស្ថិតក្រោមយុត្តាធិការរបស់រដ្ឋណាមួយផ្តាច់មុខឡើយ។ សូមមើល *ដែនទឹក* ផងដែរ។

១៣. **សន្និសីទអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ** (UNCLoS) គឺជាសន្ធិសញ្ញាពិភពលោក(១៩៨២) គ្រប់គ្រងការប្រើប្រាស់មហាសមុទ្រ។ សន្ធិសញ្ញាUNCLOS បានបង្កើតច្បាប់ស្តីពីដែនទឹក និងតំបន់សេដ្ឋកិច្ចផ្តាច់មុខ ២០០ ម៉ាយល៍ (EEZ)។ សូមមើល *ដែនទឹក* ផងដែរ។

១៤. **ភ្លៀងអាស៊ីត** (acid rain) គឺជាទឹកភ្លៀងដែលបណ្តាលមកពីការបំពុលខ្យល់ ដែលអាចបំផ្លិចបំផ្លាញដើមឈើ ហើយជារឿយៗឆ្លងកាត់ព្រំដែនជាតិនានា។

១៥. **ឆេណូប៊ីល** (Chernobyl) គឺជាទីក្រុងមួយក្នុងប្រទេសអ៊ុយក្រែន ដែលជាកន្លែងនៃការដួលរលំរលាយនៅឆ្នាំ ១៩៨៦ នៅរោងចក្រថាមពលនុយក្លេអ៊ែរសូវៀត។

១៦. **អន្តរកាលប្រជាសាស្ត្រ** (demographic transition) គឺជានិន្នាធ្លាក់ចុះអត្រាមរណៈ ដែលអមដោយការធ្លាក់ចុះអត្រាជាតិ ហើយជាទូទៅអមជាមួយឧស្សាហូបនីយកម្មនិងការអភិវឌ្ឍសេដ្ឋកិច្ច។

១៧. **កំណើតនិយម**(pronatalist)គឺជាពិពណ៌នាអំពីគោលនយោបាយរបស់រដ្ឋាភិបាលដែលលើកទឹកចិត្តឬបង្ខំអោយបង្កើតកូន និងហាមប្រាមឬកម្រិតលទ្ធភាពទទួលបានមធ្យោបាយពន្យារកំណើត។

១៨. **អត្រាមរណទារក** (infant mortality rate) គឺជា សមាមាត្រនៃទារកដែលស្លាប់ក្នុងឆ្នាំដំបូងនៃជីវិតរបស់ពួកគេ។

សំណួរអនុវត្តន៍

១. ដោយសារបញ្ហាផលប្រយោជន៍រួមក្នុងការគ្រប់គ្រងបញ្ហាបរិស្ថាន (កាន់តែស្មុគស្មាញដោយមានការចូលរួមពីសំណាក់តួអង្គច្រើន) តើមានអង្គការឬកិច្ចព្រមព្រៀងអន្តរជាតិថ្មីអ្វីខ្លះ អាចឬគួរត្រូវបានបង្កើតឡើងនៅឆ្នាំក្រោយៗដើម្បីជួយដោះស្រាយបញ្ហានេះ? តើមានវិធីកាត់បន្ថយចំនួនតួអង្គដែលចូលរួមក្នុងការគ្រប់គ្រងបញ្ហាសកល ដូចជាកកំណើនកម្តៅសកលដែរឬទេ? តើសំណើរបស់អ្នកអាចនឹងមានបញ្ហាអ្វីខ្លះ?

២. កិច្ចព្រមព្រៀងអន្តរជាតិដែលមានប្រសិទ្ធិភាពមួយចំនួនតូច ត្រូវបានសម្រេចឡើង ដើម្បីដោះស្រាយបញ្ហានៃកំណើនកម្តៅសកល។ ដោយសារមានការលំបាកមួយចំនួន ពាក់ព័ន្ធនឹងការគ្រប់គ្រងបញ្ហានេះ តើអ្នកអាចរិះគិតរកដំណោះស្រាយលក្ខណៈអន្តរជាតិដោយការច្នៃប្រឌិតថ្មីអ្វីខ្លះ? តើអ្វីខ្លះទៅជាចំណុចខ្លាំងនិងចំណុចខ្សោយនៃដំណោះស្រាយរបស់អ្នក ទាំងក្នុងរយៈពេលខ្លី និងរយៈពេលវែង?

៣. តើកំណត់ត្រាសហគមន៍អន្តរជាតិស្តីពីការគ្រប់គ្រងបរិស្ថានឆ្លុះបញ្ចាំងពីទស្សនៈរបស់អ្នកគាំពារនិយម ឬ សេរីនិយម ឬ ទាំងពីរ? តើវាឆ្លុះបញ្ចាំងយ៉ាងដូចម្តេចសខ្លះ?

៤. អ្នកនយោបាយខ្លះអំពាវនាវអោយបណ្តាប្រទេសឧស្សាហកម្មបស្ចឹមលោក រួមទាំងសហរដ្ឋអាមេរិក ត្រូវមានធនធានថាមពលគ្រប់គ្រាន់ ដើម្បីកាត់បន្ថយការពឹងអាស្រ័យលើការនាំចូលប្រេងពីមជ្ឈឹមបូព៌ា។ បើយោងតាមទិដ្ឋភាពប្រើប្រាស់ថាមពលពិភពលោកទាំងមូល ក៏ដូចជាសេដ្ឋកិច្ចពាណិជ្ជកម្មអន្តរជាតិ តើសំណើបែបនេះមានគុណសម្បត្តិនិងគុណវិបត្តិអ្វីខ្លះ?

៥. រដ្ឋក្រីក្រមួយចំនួនហាក់ដូចជាជាប់គាំងពាក់ក្នុងអន្តរកាលប្រជាសាស្ត្រ៖ អត្រាមរណៈបានធ្លាក់ចុះ អត្រាកំណើតនៅតែខ្ពស់ ហើយប្រាក់ចំណូលសម្រាប់មនុស្សម្នាក់ៗមិនមានការកើនឡើងទេ។ តើអ្នកគិតថារដ្ឋទាំងនេះ (ទោះមានឬគ្មានជំនួយពីបរទេស) អាចដកខ្លួនចេញពីការជាប់គាំង និងបញ្ចប់ការអន្តរកាលប្រជាសាស្ត្រដោយរបៀបណា?

ការស្វែងរកផលប្រយោជន៍រួម

កំណើនកម្តៅសកល

រូបថត សេចក្តីប្រកាសអំពីកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីអាកាសធាតុឆ្នាំ ២០១៥។

ផលប្រយោជន៍រួម៖ ការពង្រឹងកិច្ចព្រមព្រៀងអាកាសធាតុ

សារៈតារ

ការទប់ស្កាត់កំណើនកម្តៅសកលគឺជាផលប្រយោជន៍រួមដែលប៉ះពាល់ដល់ពិភពលោកទាំងមូល ប៉ុន្តែកើតឡើងដោយសារសកម្មភាពរបស់រដ្ឋនីមួយៗក្នុងពិភពលោក។ អ្នកដែលទទួលរងផលប៉ះពាល់ច្រើនបំផុតនឹងជាអ្នកដែលសូវបានធ្វើសកម្មភាព ដែលបង្កផលប៉ះពាល់ខ្លាំងឡើយ។ គ្រោះមហន្តរាយអាកាសធាតុដូចជាខ្យល់ព្យុះដ៏មហន្តរាយនៅឆ្នាំ ២០១៧ នៅកោះព័រតូរីកូ និងភាគខាងត្បូងនៃទឹកដីសហរដ្ឋអាមេរិកនឹងក្លាយជារឿងធម្មតា ប្រសិនបើពិភពលោកមិនដោះស្រាយបញ្ហាប្រកបដោយប្រសិទ្ធភាព។

ទោះជាយ៉ាងណាក៏ដោយ ការចំណាយលើសកម្មភាពអនុវត្តដែលត្រូវការគឺខ្ពស់ ហើយរឿងម្យ៉ាងមួយទៀតរដ្ឋខ្លះស្ទាក់ស្ទើរក្នុងការបង់ប្រាក់ឱ្យពួកគេ។ រដ្ឋាភិបាលមានទំនោរផ្តោតលើលទ្ធផលរយៈពេលខ្លី។ ដូច្នេះសហគមន៍អន្តរជាតិមានការលំបាកយ៉ាងខ្លាំងក្នុងការដោះស្រាយបញ្ហាធ្ងន់ធ្ងរនៃការឡើងកំដៅផែនដី។ តួអង្គសំខាន់ៗដូចជាសហរដ្ឋអាមេរិក ដែលមិនបានផ្តល់សច្ចាប័នលើពិធីសារក្យូតូ ហើយទោះបីជាប្រទេសនេះបានជួយរចនាកិច្ចព្រមព្រៀងប៉ារីសក៏ដោយ វាបានប្រកាសពីការដកខ្លួនចេញពីកិច្ចព្រមព្រៀងនៅឆ្នាំ ២០១៧ ។

បញ្ហាប្រឈម

នៅចុងឆ្នាំ ២០១៥ រដ្ឋនានាក្នុងពិភពលោកបានប្រមូលផ្តុំគ្នានៅទីក្រុងប៉ារីស ដើម្បីចរចាលើសន្ធិសញ្ញាថ្មីមួយស្តីពីកំណើនកម្តៅសកល ដើម្បីអនុវត្តតាមពិធីសារទីក្រុងក្យូតូ។ ឯកសារដែលសម្រេចបានត្រូវបានចាត់ទុកថាជាកិច្ចព្រមព្រៀងសំខាន់ ដែលព្យាយាមដោះស្រាយការប្រែប្រួលអាកាសធាតុ ដោយអនុញ្ញាតអោយរដ្ឋកំណត់គោលដៅរៀងៗខ្លួន និងអនុម័តវិធីសាស្ត្រផ្ទាល់ខ្លួនសម្រាប់ការបន្ធូរបន្ថយការកើនឡើងនៃការបញ្ចេញកាបូនឌីអុកស៊ីត។ កិច្ចព្រមព្រៀងនេះរួមបញ្ចូលទាំងមាត្រាដែលតម្រូវអោយរដ្ឋអ្នកមានដើម្បីជួយរដ្ឋក្រីក្រដើម្បីសម្រេចបាននូវគោលដៅកាត់បន្ថយការបំភាយឧស្ម័នរបស់ពួកគេ។ ទោះជាយ៉ាងណាក៏ដោយ ការរៀបចំទាំងអស់នោះមិនមានមាត្រាចែងច្បាស់អំពីការពង្រឹងការអនុវត្តន៍ដ៏រឹងមាំនោះទេ រដ្ឋត្រូវទុកអោយតាមដានការវិឌ្ឍន៍របស់ពួកគេដោយខ្លួនឯង ហើយមិនត្រូវប្រឈមមុខនឹងការដាក់ទណ្ឌកម្មពីរដ្ឋផ្សេងទៀត ប្រសិនបើពួកគេបរាជ័យក្នុងការបំពេញគោលដៅរបស់ពួកគេ។

ដំណោះស្រាយ

អស់រយៈពេលជាច្រើនឆ្នាំ ការផ្តោតអារម្មណ៍របស់ពិភពលោកគឺត្រូវធ្វើយ៉ាងណាដើម្បីសម្រេចបាននូវកិច្ចព្រមព្រៀងស្តីពីអាកាសធាតុ។ ក៏ប៉ុន្តែ នៅពេលនេះការយកចិត្តទុកដាក់ទាំងអស់ផ្តោតទៅលើការពង្រឹងការអនុវត្ត។ កិច្ចព្រមព្រៀងទីក្រុងប៉ារីសមិនជាប់កាតព្វកិច្ចផ្លូវច្បាប់នោះទេ ដោយបណ្តាប្រទេសជាភាគីហត្ថលេខីត្រូវតែត្រួតពិនិត្យអនុលោមតាមកិច្ចព្រមព្រៀងនេះ ដោយខ្លួនឯង ទាំងការអនុវត្តរបស់ខ្លួន(និងរដ្ឋដទៃទៀត)។ គោលការណ៍ពីរនឹងក្លាយជាគន្លឹះដោះស្រាយ។ ទីមួយ គោលការណ៍បដិការនឹងគន្លឹះដ៏សំខាន់៖ ការថយចុះនៃការប្រើប្រាស់ឥន្ធនៈហ្វូស៊ីលរបស់រដ្ឋមួយអាចជំរុញអោយរដ្ឋផ្សេងទៀតគោរពតាម។ តាមរបៀបនេះ រដ្ឋអាចត្រូវបានជានាថា រដ្ឋផ្សេងទៀតកំពុងទទួលបន្ទុកចំណាយលើការកាត់បន្ថយការបំភាយឧស្ម័នផងដែរ។ ទីពីរ គោលការណ៍អត្តសញ្ញាណនឹងមានសារៈសំខាន់៖ ដោយសារកង្វះសន្ធិសញ្ញាផ្លូវច្បាប់ រដ្ឋទាំងនោះដែលមិនអនុវត្តតាមការប្តេជ្ញាចិត្តរបស់ពួកគេ មិនអាចត្រូវបានដាក់ទណ្ឌកម្មបានទេ លើកលែងតែការបន្ទុះបង្អាប់និងការថ្កោលទោសជាសាធារណៈ ដោយសង្ឃឹមថាអត្តសញ្ញាណដ៏ល្អរបស់រដ្ឋនោះនឹងត្រូវខូចខាត។ ប្រសិនបើចំនួនប្រទេសច្រើនល្មមអនុវត្តតាម រដ្ឋដែលមានឈ្មោះឬអត្តសញ្ញាណជាអ្នកជិះសេះលែងដៃត្រូវរងភាពអាម៉ាស់ក្នុងនាមជាអ្នកបំពុល។

សន្ធិសញ្ញាអាកាសធាតុថ្មីនៅតែប្រឈមមុខនឹងបញ្ហាសកម្មភាពរួមដ៏ធំធេង។ ថាតើកិច្ចព្រមព្រៀងនាពេលអនាគតនឹងកើតចេញពីដំណោះស្រាយតាមគោលការណ៍បដិការ ឬ គ្រប់គ្រង ឬ អត្តសញ្ញាណមិនទាន់ត្រូវបានដឹងច្បាស់ឡើយ។ ប៉ុន្តែដោយសារតែពាក់ព័ន្ធនឹងផលប្រយោជន៍ច្រើន វាទំនងជាគោលការណ៍ទាំងបីនឹងមានភាពពាក់ព័ន្ធក្នុងការស្វែងរកដំណោះស្រាយ។

មតិសាធារណៈ និងចំណាត់ចំនងអន្តរជាតិ

បម្រែបម្រួលអាកាសធាតុ

បញ្ហាបម្រែបម្រួលអាកាសធាតុ និងការគំរាមកំហែងរបស់វាចំពោះបរិស្ថានធម្មជាតិរបស់យើងបានក្លាយជាបញ្ហានយោបាយដ៏សំខាន់នៅក្នុងប្រទេសជាច្រើនជុំវិញពិភពលោក។ គោលនយោបាយដើម្បីដោះស្រាយការគំរាមកំហែងនៃការឡើងកំដៅផែនដីត្រូវបានពិភាក្សា តស៊ូមតិ និងអនុម័ត នៅកម្រិតអន្តរជាតិ ថ្នាក់ជាតិ ថ្នាក់តំបន់ និងមូលដ្ឋានតាមភូមិឃុំ។ បន្ថែមពីនេះ គោលនយោបាយទាំងនេះក៏អាចមានភាពចម្រូងចម្រាសផងដែរ។

ដូចដែលបានពិភាក្សានៅក្នុងមេរៀននេះ ភាពចម្រូងចម្រាសខ្លាំងនៃគោលនយោបាយកាត់បន្ថយកំណើនកម្តៅពាក់ព័ន្ធនឹងទឹកប្រាក់ត្រូវចំណាយ ហើយនរណាជាអ្នកចំណាយលើគោលនយបាយទាំងនោះ។ លើសពីនេះ មានភាពខុសប្លែកគ្នាក្នុងចំណោមបុគ្គលនីមួយៗក្នុងប្រទេសនានា ទំហំធ្ងន់ធ្ងរនៃការគំរាមកំហែងផងដែរ។ បុគ្គលមួយចំនួនមើលឃើញថា ការគំរាមកំហែងដោយបម្រែបម្រួលអាកាសធាតុមានសភាពធ្ងន់ធ្ងរដូច្នេះហើយ ជំរុញតវ៉ានិងជម្រុញអោយមានការផ្លាស់ប្តូរគោលនយោបាយភ្លាមៗ ដើម្បីកាត់បន្ថយការគំរាមកំហែងនេះ។ អ្នកខ្លះទៀតមើលឃើញថាការប្រែប្រួលអាកាសធាតុមិនមែនជាការគំរាមកំហែងខ្លាំងពេកទេ។


នៅឆ្នាំ ២០១៧ ការស្ទង់មតិស្តីពីឥរិយាបថសកលរបស់ មជ្ឈមណ្ឌលស្រាវជ្រាវ Pew បានសាកសួរបុគ្គលក្នុងប្រទេសចំនួន ៣៨ អំពីការយល់ឃើញរបស់ពួកគេចំពោះការគំរាមកំហែងនៃការឡើងកំដៅផែនដី។ ក្រាហ្វិក ១១.២ បង្ហាញពីលទ្ធផលនៃការស្ទាបស្ទង់មតិនេះ។ នៅក្នុងរដ្ឋភាគច្រើន ជាងពាក់កណ្តាលនៃចំនួន

ប្រជាជនមើលឃើញថា ការប្រែប្រួលអាកាសធាតុជាការគំរាមកំហែងដ៏សំខាន់ (ជាមធ្យមនៅប្រទេសទាំងអស់ មានចំនួន ៦១ ភាគរយ)។ ការត្រួតពិនិត្យមើលទស្សនៈរបស់អ្នកនៅក្នុងប្រទេសនីមួយៗយ៉ាងល្អិតល្អន់ផ្តល់នូវនិន្នាការគួរអោយចាប់អារម្មណ៍ ទោះបីជាគំរូនីមួយៗមានករណីលើកលែងក៏ដោយ។ ជាឧទាហរណ៍ ភាគរយកាន់តែច្រើននៃប្រជាជនរស់នៅក្នុងប្រទេសដែលមានឆ្នេរសមុទ្រយ៉ាងវែងអន្លាយ ដែលអាចរងគ្រោះខ្លាំងបំផុតពីផលវិបាកនៃកំណើនកម្តៅសកល មានការព្រួយបារម្ភអំពីការប្រែប្រួលនៃអាកាសធាតុ។ ចំនួនជាង ៧៥ ភាគរយនៃប្រជាជនក្នុងប្រទេសឈីលី ក្រិក ប៉េរូ កូរ៉េខាងត្បូង និង ប្រទេសអេស្ប៉ាញ ជឿថាការប្រែប្រួលអាកាសធាតុគឺជាការគំរាមកំហែងដ៏ធំមួយ។ ទោះយ៉ាងណា មានករណីលើកលែងចំពោះនិន្នាការនេះមាន៖ ចំនួនតិចតួចនៃប្រជាជនអ៊ីស្រាអែលនិងជនជាតិឥណ្ឌា ដែលរស់នៅក្នុងរដ្ឋទាំងពីរដែលអាចរងការខូចខាតយ៉ាងខ្លាំងពីការកើនឡើងកម្រិតទឹកសមុទ្រ មានអារម្មណ៍ថា ការឡើងកំដៅផែនដី គឺជាការគំរាមកំហែង។

ក្រាហ្វិក ១១.២ ការប្រែប្រួលអាកាសធាតុគឺជាការគំរាមកំហែងដ៏សំខាន់

ប្រភព៖ មជ្ឈមណ្ឌលស្រាវជ្រាវ Pew

ភាគរយយល់ស្របថាការប្រែប្រួលអាកាសធាតុគឺជាការគំរាមកំហែងដ៏ធំមួយ



ប្រជាជននៅក្នុងរដ្ឋមជ្ឈិមបូព៌ា ជាទូទៅ ហាក់បីដូចជាមិនសូវខ្វល់ខ្វាយអំពីការឡើងកំដៅផែនដី។ ប្រទេសអ៊ីស្រាអែល ហ្សកដានី ទុយនេស៊ី និងទួរគី ស្ថិតនៅលំដាប់ ៣ក់កណ្តាលខាងក្រោមនៃចំនួនដែលព្រួយបារម្ភអំពីការប្រែប្រួលអាកាសធាតុ។ យ៉ាងណាក៏ដោយ ក្តីបារម្ភនៅប្រទេសលីបង់ (រដ្ឋឆ្នេរសមុទ្រមួយ) ឡើងដល់កម្រិតជិត ៦០ ភាគរយនៃប្រជាជន។ ទ្រព្យសម្បត្តិហាក់ដូចជាមានទំនាក់ទំនងជាមួយនឹងការព្រួយបារម្ភអំពីការប្រែប្រួលអាកាសធាតុ។ រដ្ឋដែលមានផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់កម្រិតទាបហាក់ដូចជាមានភាគរយទាបនៃអ្នកស្រុកដែលពាក់ព័ន្ធ៖ ហ្គាណា ឥណ្ឌា ហ្សកដានី នីហ្សេរីយ៉ា និងទុយនីស៊ី សុទ្ធតែស្ថិតនៅលំដាប់ឆ្ពោះទៅពាក់កណ្តាលខាងក្រោមនៃបញ្ជី។ យ៉ាងណាក៏ដោយ ប្រជាជនកេនយ៉ា និងតង់ហ្សានី ជាប់ចំណាត់ថ្នាក់ជាប្រទេសមួយចំនួនដែលព្រួយបារម្ភជាងគេ។

ជាការពិតណាស់ ទោះបីជាចំនួនប្រជាជនច្រើនយល់ស្របថា ការប្រែប្រួលអាកាសធាតុគឺជាការគំរាមកំហែងក៏ដោយ ក៏មិនមានការធានាថា ប្រទេសណាមួយនឹងចាត់វិធានការណ៍ជាក់ច្បាស់ដែរ។ នេះអាចដោយសាររដ្ឋាភិបាលមិនប្រកាន់លទ្ធិប្រជាធិបតេយ្យ ហើយមិនឆ្លើយតបតាមការបារម្ភរបស់មតិសាធារណៈ។ ឬអាចដោយសារក្រុមផលប្រយោជន៍ ដែលជំរុញគោលនយោបាយឆ្ពោះទៅទិសដៅណាមួយ អាចមានឥទ្ធិពលលើគោលនយោបាយរបស់រដ្ឋាភិបាល។ ជាឧទាហរណ៍ ការស្ទង់មតិបានរកឃើញថា ខណៈពេលដែលប្រជាជនអាមេរិកចំនួន ៥៦ ភាគរយមើលឃើញថា ការប្រែប្រួលអាកាសធាតុគឺជាការគំរាមកំហែងដ៏ធំក្នុងឆ្នាំដដែលដែលរដ្ឋបាលប្រធានាធិបតីត្រាំ បានដកសហរដ្ឋអាមេរិកចេញពីកិច្ចព្រមព្រៀងទីក្រុងប៉ារីស។

និន្នាការចម្រុះទាំងនេះបង្ហាញពីភាពស្មុគស្មាញនៃបញ្ហាបម្រែបម្រួលអាកាសធាតុ និងមូលហេតុដែលកិច្ចព្រមព្រៀងអន្តរជាតិមិនងាយនឹងសម្រេចបាន។ ហើយកាន់តែពិបាកបង្កើតសម្ព័ន្ធនៃបណ្តារដ្ឋទាក់ទងនឹងបញ្ហានេះ។ ស្ថានភាពនៃកិច្ចការនេះ រួមជាមួយនឹងការចំណាយលើការប្រយុទ្ធប្រឆាំងនឹងឧស្ម័នផ្ទះកញ្ចក់បាននាំអោយមានភាពយឺតយ៉ាវក្នុងដំណើរការ នៅក្នុងកម្រិតអន្តរជាតិ។

ឧស្សន:ទិស័យគោលនយោបាយ

នាយករដ្ឋមន្ត្រីអៀរឡង់ លោក លីអូ វ៉ារ៉ាដការ (Leo Varadkar)

រូបថត នាយករដ្ឋមន្ត្រី លីអូ

បញ្ហា តើអ្នកថ្លឹងថ្លែងតុល្យភាពរវាងកង្វល់បរិស្ថាននិងសេដ្ឋកិច្ចយ៉ាងដូចម្តេច?

សារតារ

ចូរស្រមៃថាអ្នកគឺជាប្រធានាធិបតីនៃប្រទេសអៀរឡង់។ សារពាង្គកាយកែប្រែហ្សែន(GMOs) មានភាពចម្រូងចម្រាសយ៉ាងខ្លាំងនៅទ្វីបអឺរ៉ុប រួមទាំងនៅក្នុងប្រទេសរបស់អ្នកផងដែរ។ ជាឧទាហរណ៍ ក្នុងឆ្នាំ ១៩៩៧ ប្រទេសអៀរឡង់បានយល់ព្រមដោយស្ងាត់ស្ងៀរក្នុងការអនុញ្ញាតអោយសាជីវកម្មពហុជាតិសកល «MNC Monsanto» ដាំប្រភេទធាយថារវ៉ែម beets នៅជិតទីក្រុងដាប្លីន (Dublin) ។ បន្ទាប់ពីការព្យាយាមផ្លូវច្បាប់ជាច្រើនលើកក្នុងការបញ្ឈប់ការដាំដុះដំណាំនេះទាំងបរាជ័យ សកម្មជនបានបំផ្លាញដំណាំនៅក្នុងចម្ការមុនពេលប្រមូលផល។

ប្រទេសរបស់អ្នកបានគាំទ្រយ៉ាងស្ងៀមស្ងាត់ដល់ក្រុមហ៊ុនជីវបច្ចេកវិទ្យាអៀរឡង់ជាច្រើន ក្នុងពេលកន្លងមក ជាមួយនឹងការបណ្តាក់ទុនរួមគ្នាក្នុងការស្រាវជ្រាវ។ ប្រការនេះបានបង្កើតភាពជឿនលឿនជាច្រើនដែលផ្តល់អោយអៀរឡង់នូវអត្ថប្រយោជន៍នាំមុខដ៏សំខាន់ នៅក្នុងវិស័យនេះ ជាងបណ្តារដ្ឋអឺរ៉ុបផ្សេងទៀត។

សាជីវកម្មពហុជាតិជាច្រើនទទួលបានអត្ថប្រយោជន៍ពីការស្រាវជ្រាវនេះ ដោយនាំមកនូវការវិនិយោគ និងប្រាក់ចំណូលពន្ធអោយអ្នកអ្នក។

ការពិចារណាក្នុងស្រុក

ជាអកុសល គោលការណ៍«វិជ្ជមានតែប្រុងប្រយ័ត្នខ្ពស់»បែបនេះ មិនជាទីពេញនិយមក្នុងចំណោមសាធារណជនទេ។ អ្នកខ្លះបារម្ភថា កេរ្តិ៍ឈ្មោះរបស់ប្រទេសអៀរឡង់ដែលល្បីល្បាញជា «កោះបៃតង» នឹងរងការខូចខាត ដែលអាចគំរាមកំហែងដល់វិស័យទេសចរណ៍ ដែលជាប្រភពចំណូលដ៏សំខាន់សម្រាប់ប្រទេសរបស់អ្នក។ អ្នកផ្សេងទៀតចូលរួមបន្ទរតាមការប្រឆាំងជាមួយអឺរ៉ុបចំពោះGMOs ដោយផ្អែកលើការព្រួយបារម្ភខ្លាំងអំពីផលប៉ះពាល់បរិស្ថាន ដោយសារផលិតផលទាំងនេះ។

នៅនិទាឃរដូវក្នុងឆ្នាំ ២០០៤ សហភាពអឺរ៉ុបបានអនុម័តការបញ្ចប់ការហាមឃាត់ការលក់ផលិតផលGMO(ដោយប្រទេសរបស់អ្នកបោះឆ្នោតមតិភាគច្រើន) ម្យ៉ាងតាមការគំរាមកំហែងពីសហរដ្ឋអាមេរិកអោយអនុវត្តសេចក្តីសម្រេចរបស់អង្គការWTOដែលបានរកឃើញការហាមឃាត់ផលិតផលGMO មានលក្ខណៈខុសច្បាប់។ សហរដ្ឋអាមេរិកគឺជាដៃគូពាណិជ្ជកម្មដ៏ធំបំផុតតែមួយគត់របស់អ្នក ប៉ុន្តែបណ្តារដ្ឋដទៃទៀតនៅក្នុងសហភាពអឺរ៉ុប នៅពេលរួមបញ្ចូលគ្នា បង្កើតបានជាទីផ្សារនាំចេញដ៏សំខាន់បំផុតរបស់អ្នក។ នៅឆ្នាំ ២០១៥ សភាអឺរ៉ុបបានច្រានចោលច្បាប់ដែលនឹងអនុញ្ញាតអោយរដ្ឋសមាជិកហាមឃាត់GMOs។ ហើយខណៈពេលដែលមានការគាំទ្រខ្លាំងជាសាធារណៈចំពោះច្បាប់នោះ នៅក្នុងប្រទេសអៀរឡង់ អង្គការធំៗមួយចំនួន ដូចជាសមាគមកសិករអៀរឡង់ បានប្រឆាំងនឹងការហាមឃាត់នេះ។

សេណារីយ៉ូ

ចូរស្រមៃថា បើយោងទៅតាមច្បាប់របស់សហភាពអឺរ៉ុបថ្មីៗនេះ ក្រុមផលប្រយោជន៍ជាក់សម្តែងលើគណបក្សរបស់អ្នកអោយហាមឃាត់ GMOs នៅក្នុងប្រទេសអៀរឡង់។ ក្រុមទាំងនេះគម្រាមថានឹងគាំទ្រគណបក្សប្រឆាំង នៅក្នុងការបោះឆ្នោតបន្ទាប់ ប្រសិនបើអ្នកបដិសេធ។

ដំណាំGMOអាចផ្តល់អត្ថប្រយោជន៍សេដ្ឋកិច្ចដល់ប្រទេសរបស់អ្នក។ ដោយទទួលបានគុណសម្បត្តិធៀបផ្នែកបច្ចេកវិទ្យារបស់អ្នកនៅក្នុងវិស័យនេះ សេដ្ឋកិច្ចរបស់អ្នកទទួលបានផលចំណេញពីការពង្រីកការប្រើប្រាស់GMO តាមរយៈការកើនឡើងនៃទិន្នផលកសិកម្ម និងការកើនឡើងសកម្មភាពអាជីវកម្ម ពីសាជីវកម្មពហុជាតិ។ សហរដ្ឋអាមេរិកមិនមានបទប្បញ្ញត្តិទាក់ទងនឹងការនាំចូលផលិតផល GMO ហើយនឹងបើក ចំហសម្រាប់ការនាំចេញដំណាំទាំងនេះ។

GMOs ក៏អាចនាំមកនូវហានិភ័យជាយថាហេតុផងដែរ។ អ្នកជំនាញផ្នែកបរិស្ថានមួយចំនួនព្រមានថា GMOs អាចមានឥទ្ធិពលអវិជ្ជមានលើផ្នែកបរិស្ថាន សត្វព្រៃ និងសុខភាពមនុស្ស។ ដៃគូសហភាពអឺរ៉ុប របស់អ្នកជាច្រើននឹងជៀសវាងមិនប្រើផលិតផលGMOរបស់អ្នក ដោយប្តូរយកទីផ្សារនាំចេញដ៏ធំសម្រាប់ទំនិញទាំងនេះ។ សម្រាប់នៅក្នុងស្រុកវិញ ការពង្រីកការផលិត GMOs នឹងបង្កភាពចម្រូងចម្រាស។

ចូរជ្រើសរើសគោលការណ៍របស់អ្នក

តើអ្នកនឹងបន្តធ្វើការដោយស្ងៀមស្ងាត់ ដោយជម្រុញលើកទឹកចិត្តដល់ការរីកចំរើននៃដំណាំ GMOដែរឬទេ? តើអ្នកនឹងចាត់វិធានការណ៍ហាមឃាត់ជាឯកតោភាគីលើការផលិត GMOs ដោយសារតែសម្ពាធពីក្រុមផលប្រយោជន៍អោយគោរពកង្វល់បរិស្ថានរយៈពេលវែង ដែលបង្កឡើងដោយផលិតផលទាំងនេះដែរឬ

ទេ? តើអ្នកនឹងធ្វើការជាមួយសាជីវកម្មពហុជាតិ ដើម្បីប្រើប្រាស់គុណសម្បត្តិធៀបរបស់អ្នកដើម្បីចំណេញសេដ្ឋកិច្ចដែរឬទេ? តើអ្នកធ្វើថ្លឹងថ្លែងតុល្យភាពនៃភាពរីកចម្រើនផ្នែកសេដ្ឋកិច្ចជាមួយនឹងការព្រួយបារម្ភអំពីបរិស្ថានយ៉ាងដូចម្តេច?



តោះ! សាកល្បងពិភាក្សាអំពីបញ្ហាជាក់ស្តែង

ការបញ្ឈប់កំណើនកម្តៅសកល៖ តើនរណាគួរបង់ថ្លៃចំណាយ?

ទិដ្ឋភាពទូទៅ

កិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីអាកាសធាតុ គឺជាកិច្ចខិតខំប្រឹងប្រែងថ្មីៗបំផុតដើម្បីគ្រប់គ្រងការបំពុលទាំងឡាយដែលនាំទៅដល់ការឡើងកំដៅផែនដីឬកំណើនកម្តៅផែនដី។ កិច្ចប្រឹងប្រែងមុន ពិធីសារទីក្រុងក្យូតូ បានប្រើយន្តការទីផ្សារ ដើម្បីបែងចែកកម្រិតលើបរិមាណនៃការបំភាយឧស្ម័នចេញពីប្រទេសផ្សេងៗ។ ប៉ុន្តែមានតែប្រទេសអភិវឌ្ឍន៍ប៉ុណ្ណោះដែលត្រូវបានតម្រូវអោយបំពេញតាមគោលដៅ ក្រោមពិធីសារទីក្រុងក្យូតូ។ សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ មិនមានការដាក់កម្រិតចំពោះការបំភាយឧស្ម័នរបស់ពួកគេទេ។

ដើម្បីឆ្ពោះទៅមុខបន្តទៀត ក្នុងការចរចានៅទីក្រុងប៉ារីស រដ្ឋនានាបានយល់ព្រមទម្លាក់ការតឹងបន្តឹងជាប់កាតព្វកិច្ចសម្រាប់ប្រទេសទាំងអស់។ នេះអនុញ្ញាតអោយប្រទេសនានាមានភាពបត់បែនអំពីរបៀបដែលពួកគេកំណត់គោលដៅកាត់បន្ថយការបំភាយឧស្ម័ន ក៏ដូចជាភាពបត់បែនក្នុងរបៀបដែលគោលដៅទាំងនោះត្រូវបានសម្រេច។ ជាលក្ខណៈនយោបាយ ភាពបត់បែនបែបនេះត្រូវការជាចាំបាច់ ដើម្បីអោយរដ្ឋនានាចុះហត្ថលេខាលើកិច្ចព្រមព្រៀងអាកាធាតុទីក្រុងប៉ារីស។ រដ្ឋអភិវឌ្ឍន៍បានបន្តទាមទារអោយរដ្ឋកំពុងអភិវឌ្ឍន៍ (ជាពិសេសប្រទេសចិននិងឥណ្ឌា) ដើរតួនាទីយ៉ាងសកម្មក្នុងការទប់ស្កាត់ការឡើងកំដៅផែនដី ខណៈដែលប្រទេសកំពុងអភិវឌ្ឍន៍បាននិងបន្តទាមទារធនធាន (លុយ និងបច្ចេកវិទ្យា) ដើម្បីទូទាត់ការចំណាយលើការធ្វើដូច្នេះ។

កិច្ចព្រមព្រៀងទីក្រុងប៉ារីសរួមបញ្ចូលទាំងមាត្រាដែលផ្តល់មូលនិធិរហូតដល់ ១០០ ប៊ីលានដុល្លារក្នុងមួយឆ្នាំដល់ប្រទេសកំពុងអភិវឌ្ឍន៍ដើម្បីសម្របខ្លួនផ្នែកសេដ្ឋកិច្ចនិងកាត់បន្ថយកំណើនកម្តៅសកល។ ការសន្យាទាំងនោះត្រូវតែសម្រេចបាននៅត្រឹមឆ្នាំ ២០២០ ហើយដំណើរការរហូតដល់ឆ្នាំ ២០២៥។ តើប្រទេស

កំពុងអភិវឌ្ឍន៍ ដូចជាចិនគួរតែត្រូវបានស្នើសុំអោយចូលរួមចំណែកក្នុងការបញ្ឈប់កំណើនកម្តៅសកលដែរ ឬទេ? តើនរណាខ្លះគួរត្រូវបានតម្រូវអោយចូលរួមចំណែកក្នុងការផ្តល់ប្រយោជន៍សាធារណៈបែបនេះ?

អំណះអំណាង ១

ប្រទេសកំពុងអភិវឌ្ឍន៍គួរតែបង់ចំណែករបស់ពួកគេដើម្បីបញ្ឈប់ការឡើងកំដៅផែនដី។

ប្រទេសកំពុងអភិវឌ្ឍន៍ ក៏បានរួមចំណែកដល់ការឡើងកំដៅផែនដីដែរ ដូច្នេះ ពួកគេគួរតែជួយរ៉ាប់រងការចំណាយដែរ។

ប្រទេសកំពុងអភិវឌ្ឍន៍នានាបានរួមចំណែកបំភាយកាបូនយកឌីអុកស៊ីតយ៉ាងច្រើន ដល់បរិយាកាសសកល។ ពួកគេមិនគួរត្រូវបានអនុញ្ញាតអោយជិះលែងដៃ លើកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋអ្នកមានដែលចង់ពន្យឺតល្បឿនកំណើនកម្តៅសកលនោះទេ។

បច្ចេកវិទ្យានឹងធ្វើអោយការចំណាយទាបក្នុងរយៈពេលវែង។

ខណៈពេលដែលការចំណាយដើម្បីបន្តយការឡើងកំដៅផែនដី នឹងមានកម្រិតតម្លៃខ្ពស់នៅពេលដំបូងៗ នៅពេលយូរៗទៅ បច្ចេកវិទ្យានឹងជួយអោយរដ្ឋរក្សាការចំណាយទាបក្នុងពេលដែលកាត់បន្តយការបំភាយឧស្ម័ន។ ដូច្នេះ គេមិនគួរព្រួយបារម្ភខ្លាំងពេកទេថា ការចំណាយលើការផ្លាស់ប្តូរគោលនយោបាយនៅក្នុងរដ្ឋកំពុងអភិវឌ្ឍន៍នឹងមានតម្លៃច្រើនលើសលប់។

ប្រទេសកំពុងអភិវឌ្ឍន៍អាចទទួលបានអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចពីកិច្ចព្រមព្រៀងអាកាសធាតុ។

ដូចពិធីសារទីក្រុងក្យូតូដែរ កិច្ចព្រមព្រៀងទីក្រុងប៉ារីសមានយន្តការផ្អែកលើទីផ្សារស្រដៀងគ្នា ដែលអាចផ្តល់ផលប្រយោជន៍ដល់ប្រទេសកំពុងអភិវឌ្ឍន៍ជាលក្ខណៈសេដ្ឋកិច្ច។ ប្រសិនបើប្រទេសទាំងនេះអាចកាត់បន្តយការបំភាយឧស្ម័នតាមគោលដៅរបស់ពួកគេ ឬអាចបានលើសគោលដៅ ពួកគេអាចបង្វិលកម្រិតនៃការបំពុល ដែលត្រូវបានអនុញ្ញាតតែ«មិនបានប្រើប្រាស់»របស់ពួកគេ ដើម្បីប្រមូលមកវិញនូវការចំណាយមួយចំនួនសម្រាប់អនុវត្តកិច្ចព្រមព្រៀង។

អំណះអំណាង ២

មានតែប្រទេសអភិវឌ្ឍន៍ទេដែលគួរចំណាយដើម្បីបញ្ឈប់ការឡើងកំដៅផែនដី

ការចំណាយចេញពីប្រទេសកំពុងអភិវឌ្ឍនឹងធ្វើអោយខូចខាតដល់ការអភិវឌ្ឍ។

ការចំណាយលើការកាត់បន្តយកំណើនកម្តៅសកលនឹងមានទំហំធំធេង។ ការទាមទារអោយប្រទេសកំពុងអភិវឌ្ឍចំណាយសូម្បីត្រឹមតែបន្តិច នឹងនាំអោយមានការលំបាកផ្នែកសេដ្ឋកិច្ចដែលនឹងធ្វើអោយខូចដល់ដំណើរការណ៍នៃការអភិវឌ្ឍន៍បន្ថែមទៀត ដែលវាអាចបង្កើនការបំភាយឧស្ម័ន ដោយសារដូចនេះនឹងមិនមានប្រាក់សម្រាប់វិនិយោគលើបច្ចេកវិទ្យាអោយកាន់តែប្រសើរ ឬអភិវឌ្ឍឧស្សាហកម្មស្អាតទេ។

ប្រទេសអភិវឌ្ឍន៍ត្រូវបានគេអនុញ្ញាតឱ្យមានការបំពុលដើម្បីការអភិវឌ្ឍរបស់ខ្លួន។

អស់រយៈពេលជាច្រើនឆ្នាំមកហើយ ដែលប្រទេសអភិវឌ្ឍន៍បានយកចិត្តទុកដាក់តិចតួចបំផុតចំពោះបរិស្ថាននៅពេលដែលពួកគេកំពុងបានធ្វើការសាងសង់ឧស្សាហកម្ម សម្រេចបាននូវកំណើនសេដ្ឋកិច្ច និងទទួលបានជោគជ័យ។ ឥឡូវនេះ ដោយសារតែប្រទេសឥណ្ឌានិងចិនកំពុងទទួលបានជោគជ័យផ្នែកសេដ្ឋកិច្ច រដ្ឋលោកខាងលិចគិតថាជាការគម្រាមកំហែង ហើយចង់ដាក់កម្រិតលើរបៀបដែលរដ្ឋផ្សេងទៀតអាចអភិវឌ្ឍ

និងលើរបៀបដែលពួកគេចាត់ចែងបរិស្ថាន។ រដ្ឋដែលមិនមែនជារដ្ឋបស្ចិមប្រទេស គួរតែត្រូវបានអនុញ្ញាតដូចគ្នា ទៅតាមគន្លងអភិវឌ្ឍន៍ដូចរដ្ឋលោកខាងលិចដែរ។


មែនទែនទៅ វាជាការបំពុលដោយប្រទេសអភិវឌ្ឍន៍។

ទោះបីជាប្រទេសកំពុងអភិវឌ្ឍន៍បានរួមចំណែកក្នុងការបំពុលខ្លះក៏ដោយ ការបញ្ចេញឧស្ម័នទាំងនេះភាគច្រើនបានមកពីឧស្សាហកម្មដែលត្រូវបានដឹកជញ្ជូនពីរដ្ឋអភិវឌ្ឍន៍។ រដ្ឋលោកខាងលិចមិនចង់អោយឧស្សាហកម្មបំពុលទាំងនេះស្ថិតនៅក្នុងប្រទេសរបស់ពួកគេទេ ដូច្នេះ ពួកគេបានបញ្ជូនកាកសំណល់របស់ពួកគេទៅក្រៅប្រទេស ហើយឥឡូវនេះទាមទារអោយប្រទេសម្ចាស់ផ្ទះបង់ប្រាក់សម្រាប់ការសម្អាត។

សំណួរ

- តើប្រទេសអភិវឌ្ឍន៍គួរត្រូវបានចាប់អោយបំពេញកាតព្វកិច្ចដោយកិច្ចព្រមព្រៀងទីក្រុងប៉ារីស និងត្រូវចេញថ្លៃចំណាយកាត់បន្ថយការបំភាយឧស្ម័ននៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដែរឬទេ? តើតម្រូវការនេះធ្វើអោយកិច្ចព្រមព្រៀងទីក្រុងប៉ារីសទំនងជាមានជោគជ័យ(ឧ. ការបន្ថយសីតុណ្ហភាព)ច្រើនឬតិចជាងមុន?
- តើអ្នកជឿថា បញ្ហាបរិស្ថានដូចជាការឡើងកំដៅផែនដីនឹងពិបាកដោះស្រាយច្រើនឬតិចជាងមុនក្នុងអំឡុងពេលនៃការកើនឡើងនៃចលនាប្រឆាំងសកលភាវូបនីយកម្មនេះ? ហេតុអ្វី?
- តើអ្នកគិតថាដំណោះស្រាយបច្ចេកវិទ្យានឹងត្រូវបានបង្កើតឡើងដើម្បីជួយដោះស្រាយបញ្ហាកំណើនកម្តៅសកលដែរឬទេ? ឬការផ្លាស់ប្តូរទម្លាប់ជាមូលដ្ឋានដែលបុគ្គលនីមួយៗប្រើប្រាស់ថាមពលជាវិធីសាស្ត្រល្អប្រសើរជាង ដើម្បីកាត់បន្ថយបញ្ហាកំណើនកម្តៅសកល?

ក្រាហ្វិក៖ ងាយរងគ្រោះបំផុត ប៉ុន្តែទទួលខុសត្រូវតិចបំផុតចំពោះការប្រែប្រួលអាកាសធាតុ



សម្គាល់៖ ប្រទេសក្រីក្រដែលបានរួមចំណែកតិចតួចបំផុតចំពោះការប្រែប្រួលអាកាសធាតុ ប៉ុន្តែស្ថិតក្នុងចំណោមប្រទេសដែលងាយរងគ្រោះបំផុតចំពោះផលប៉ះពាល់របស់វា នាពេលបច្ចុប្បន្ននេះ កំពុងស្វែងរកការប្តេជ្ញាចិត្តផ្នែកហិរញ្ញវត្ថុបន្ថែមទៀតពីប្រទេសអ្នកមាន ដែលភាគច្រើនបានរីកចម្រើនសេដ្ឋកិច្ចរបស់ពួកគេដោយការដុតឥន្ធនៈហ្វូស៊ីល។

និស្សិតអាចសាកល្បងអានឯកសារខាងក្រោមបន្ថែមទៀត ដើម្បីជាគ្រឹះក្នុងការឆ្លើយសំណួរទាំងអស់ខាងលើ ៖

- Klein, Daniel, Maria Pia Carazo, Meinhard Doelle, Jane Bulmer, and Andrew Higham, eds. The Paris Agreement on Climate Change: Analysis and Commentary. Oxford, 2017.
- Nordhaus, William D. The Climate Casino: Risk, Uncertainty, and Economics for a Warming World. Yale, 2015.
- Vogler, John. Climate Change in World Politics. Palgrave, 2016.
- Zedillo, Ernesto. Global Warming: Looking Beyond Kyoto. Brookings, 2008.

ឯកសារគួរអានបន្ថែម

- Barkin, J. Samuel, and Elizabeth R. DeSombre. Saving Global Fisheries: Reducing Fishing Capacity to Promote Sustainability. MIT, 2013.
- Blewit, John. Understanding Sustainable Development. 3rd ed. Routledge, 2018.
- DeSombre, Elizabeth R. The Global Environment and World Politics: International Relations for the 21st Century. 2nd ed. Continuum, 2007.
- Hudson, Valerie M., and Andrea M. Den Boer. Bare Branches: The Security Implications of Asia's Surplus Male Population. MIT, 2004.
- Kahl, Colin H. States, Scarcity, and Civil Strife in the Developing World. Princeton, 2006.
- Sachs, Jeffrey. The Age of Sustainable Development. Columbia, 2015.
- Young, Oran R. On Environmental Governance: Sustainability, Efficiency, and Equity. Paradigm, 2013.

មេរៀនទី ១២ ៖ គម្លាតរវាងអឌ្ឍគោលខាងជើង-ត្បូង

រូបថត ជនភៀសខ្លួនអាហ្វ្រិកឡើងជិះកប៉ាល់ អ៊ីតាលី ឆ្នាំ ២០១៥។

វត្ថុបំណងមេរៀន

១២.១ ចូរកំណត់តម្រូវការជាមូលដ្ឋានរបស់មនុស្ស អោយបានយ៉ាងហោចណាស់ចំនួន ៤ ហើយឆ្លើយថា តើតំបន់នៅអឌ្ឍគោលខាងត្បូងណាមួយបាននឹងកំពុងបំពេញបាននូវតម្រូវការទាំងនោះ។

១២.២ ចូរផ្តល់ឧទាហរណ៍អំពីរដ្ឋនានាដែលទ្រឹស្តីនៃប្រព័ន្ធពិភពលោកចាត់ទុកថាជារដ្ឋស្នូល(core) រដ្ឋជាយក្រុង(semi-periphery) និងរដ្ឋជនបទ(periphery)។

១២.៣ ចូរប្រៀបធៀបផលប៉ះពាល់នៃរបបអាណានិគមនិយមអោយបានបីផ្សេងគ្នា ហើយពន្យល់ពីមូលហេតុដែលផលប៉ះពាល់ទាំងនេះនាំអោយមានបញ្ហាអភិវឌ្ឍសេដ្ឋកិច្ចនៅអឌ្ឍគោលខាងត្បូង។

១២.១. ស្ថានភាពនៃអឌ្ឍគោលខាងត្បូង

១២.១ ចូរកំណត់តម្រូវការជាមូលដ្ឋានរបស់មនុស្ស អោយបានយ៉ាងហោចណាស់ចំនួន ៤ ហើយឆ្លើយថា តើតំបន់នៅអឌ្ឍគោលខាងត្បូងណាមួយបាននឹងកំពុងបំពេញបាននូវតម្រូវការទាំងនោះ។

មេរៀននេះក៏ដូចជាមេរៀនបន្តបន្ទាប់ពាក់ព័ន្ធនឹងតំបន់ក្រីក្រនានាលើពិភពលោក នោះគឺ អឌ្ឍគោលខាងត្បូង ដែលមនុស្សភាគច្រើនរស់នៅ។ រដ្ឋនៅក្នុងតំបន់ទាំងនេះត្រូវបានហៅតាមឈ្មោះផ្សេងៗគ្នា និងត្រូវបានគេស្គាល់ថាជា៖ ប្រទេសតតិយលោក ឬ**ប្រទេសដែលមិនសូវមានការអភិវឌ្ឍន៍** (LDCs) *ឬប្រទេសមិនទាន់អភិវឌ្ឍន៍* (UDCs) ឬ**ប្រទេសកំពុងអភិវឌ្ឍន៍**។ ដោយឡែក មេរៀននេះនឹងពិភាក្សាអំពីគម្លាតនៃទ្រព្យសម្បត្តិរវាងតំបន់ឧស្សាហូបនីយកម្ម (នៅអឌ្ឍគោលខាងជើង) និងតំបន់ដទៃទៀត (អឌ្ឍគោលភាគខាងត្បូង)។ វាអភិវឌ្ឍទ្រឹស្តីចក្រពត្តិនិយម ដែលត្រូវបានបង្ហាញនៅក្នុងមេរៀនទី ៣ ដែលព្យាយាមពន្យល់ពីគម្លាតនេះទាក់ទងនឹងការធ្វើអាណានិគមជាប្រវត្តិសាស្ត្រនៅអឌ្ឍគោលខាងត្បូង តាមរយៈប្រទេសនានានៅខាងជើង។ មេរៀនទី ១៣ ពិភាក្សាអំពីទិដ្ឋភាពអន្តរជាតិនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅអឌ្ឍគោលខាងត្បូង។

អ្នកប្រាជ្ញទំនាក់ទំនងអន្តរជាតិ (IR) មិនយល់ស្របលើមូលហេតុឬផលប៉ះពាល់នៃភាពក្រីក្រនៅក្នុងអឌ្ឍគោលខាងត្បូង ហើយក៏មិនយល់ស្របគ្នាលើដំណោះស្រាយ (ប្រសិនបើមាន) ចំពោះបញ្ហានោះទេ។ ដូច្នេះហើយ ពួកគេក៏មិនយល់ស្របអំពីលក្ខណៈនៃទំនាក់ទំនងរវាងរដ្ឋអ្នកមាន និងរដ្ឋក្រីក្រដែរ (ទំនាក់ទំនងអឌ្ឍគោលខាងជើងនិងខាងត្បូង)។ យ៉ាងណាក៏ដោយ គ្រប់គ្នាយល់ស្របថា ប្រទេសនានានៅអឌ្ឍគោលខាងត្បូងភាគច្រើនជាប្រទេសក្រីក្រ ហើយខ្លះទៀតជាប្រទេសក្រីក្រខ្លាំង។

សរុបមក មនុស្សប្រហែល ១ ពាន់លាននាក់រស់នៅក្នុងភាពក្រីក្រខ្លាំង ដោយគ្មានលទ្ធភាពទទួលបានអាហារូបត្ថម្ភជាមូលដ្ឋាន ឬការថែទាំសុខភាពទូទៅ។ ពួកគេភាគច្រើនប្រមូលផ្តុំរស់នៅក្នុងទ្វីបអាហ្វ្រិក ដែលដោយសារតែកម្រិតប្រាក់ចំណូលបានធ្លាក់ចុះ អស់រយៈពេលជាច្រើនទសវត្សរ៍មកហើយ។ កាលពីពីរទសវត្សរ៍មុន ចំនួនប្រជាជនប្រមូលផ្តុំខ្លាំង នៅអាស៊ីខាងត្បូង ប៉ុន្តែកំណើនសេដ្ឋកិច្ចនៅទីនោះបានកាត់បន្ថយយ៉ាងខ្លាំងនូវចំនួនអ្នករស់នៅក្នុងភាពក្រីក្រខ្លាំង។ ទោះយ៉ាងណាក៏ដោយ ប្រាក់ចំណូលជាមធ្យមសម្រាប់មនុស្សម្នាក់នៅអាស៊ីខាងត្បូង ដែលជាផ្ទះសម្បែងសម្រាប់មនុស្ស ២ ពាន់លាននាក់ បានត្រឹមតែ ៦០០០

ដុល្លារ ក្នុងមួយឆ្នាំ ហើយនៅអាហ្វ្រិកវិញមានចំណូលត្រឹមតែ ៣៧០០ ដុល្លារប៉ុណ្ណោះ (តួលេខទាំងនេះត្រូវបានកែសម្រួលសម្រាប់តម្លៃចំណាយទាបសម្រាប់ការរស់នៅក្នុងតំបន់ទាំងនេះ បើប្រៀបធៀបទៅនឹងអ្នកមានជាង)។ មនុស្សរាប់ពាន់លាននាក់បានកំពុងងើបចេញពីបន្ទាត់នៃភាពក្រីក្រ ប៉ុន្តែដោយសារតែកំណើននៃការកើនឡើងនៃចំនួនប្រជាជនកាន់តែច្រើន ដែលជាហេតុនាំដោយមានចំនួនប្រជាជនក្រីក្រមានចំនួនកើនឡើង ដែលធ្វើអោយវានៅតែមានភាពប្រហាក់ប្រហែលគ្នា។

ចំណុចសំខាន់គឺថារៀងរាល់ដប់វិនាទី នៅកន្លែងណាមួយក្នុងពិភពលោក មានកុមារម្នាក់បានស្លាប់ដោយសារកង្វះអាហារូបត្ថម្ភ ពោលគឺមិនញ៉ាំអាហារគ្រប់គ្រាន់ ឬមិនបានញ៉ាំអាហារត្រឹមត្រូវដើម្បីទប់ទល់នឹងជំងឺផ្សេងៗ។ តួលេខនៃការស្លាប់របស់កុមារនោះគឺមានជាង ៣ លានក្នុងមួយឆ្នាំ។ ពិភពលោកបានផលិតអាហារគ្រប់គ្រាន់ដើម្បីចិញ្ចឹមកុមារទាំងនេះហើយប្រាក់ចំណូលគ្រប់គ្រាន់ដើម្បីចិញ្ចឹមពួកគេ ប៉ុន្តែគ្រួសារ ឬរដ្ឋរបស់ពួកគេមិនមានប្រាក់ចំណូលគ្រប់គ្រាន់ទេដើម្បីទទួលបានរបបអាហារទាំងនោះ។ ទីបំផុត ពួកគេបានស្លាប់ដោយសារភាពក្រីក្រ។ ទន្ទឹមនឹងនេះដែរ ក្នុងរយៈពេល ១០ វិនាទីនោះ ពិភពលោកចំណាយប្រាក់ជាង ៥០ ម៉ឺនដុល្លារ លើកម្លាំងយោធា ដែលមួយភាគក្នុងទំហំទឹកប្រាក់នេះ អាចជួយសង្គ្រោះជីវិតកុមារ និងអ្វីៗជាច្រើនទៀត។ ដូចគ្នាដែរ ប្រជាពលរដ្ឋខ្វះខាតទឹក ទីជម្រក ការថែទាំសុខភាព និងតម្រូវការផ្សេងៗទៀត ដោយសារពួកគេមិនមានលទ្ធភាពទិញ។ ភាពក្រីក្រដែលកំពុងរីករាលដាលទៅលើក្រុមមនុស្ស ដែលមិនមានលទ្ធភាពទិញសម្ភារៈចាំបាច់ ដែលជាឧទាហរណ៍នៃភាពអត់ឃ្លាន ដែលបង្កឡើងដោយសង្គ្រាម ឬគ្រោះរាំងស្ងួត ប៉ុន្តែវាប៉ះពាល់ដល់មនុស្សជាច្រើនទៀត។


អង្គការសហប្រជាជាតិក្នុងឆ្នាំ ២០០០ បានអនុម័តគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (MDG) ដែលកំណត់គោលដៅសម្រាប់វិធានការតម្រូវការជាមូលដ្ឋាន ដែលត្រូវសម្រេចបាននៅឆ្នាំ ២០១៥ និងវាស់វែងប្រឆាំងនឹងទិន្នន័យ ឆ្នាំ ១៩៩០។ គោលដៅទីមួយ ក្នុងចំណោមគោលដៅទាំងប្រាំបី គឺកាត់បន្ថយពាក់កណ្តាលនៃសមាមាត្រនៃចំនួនប្រជាជនពិភពលោក ដែលរស់នៅក្នុង "ភាពក្រីក្រខ្លាំង" ដែលកំណត់ថាជាប្រាក់ចំណូលតិចជាង $១.២៥ ក្នុងមួយថ្ងៃ។គោលដៅនេះ ត្រូវបានសម្រេចបានមុនកាលកំណត់ក្នុងឆ្នាំ ២០១០ បើទោះបីជាទ្វីបអាហ្វ្រិកដើរយឺតជាងអាស៊ីក្នុងការកាត់បន្ថយភាពក្រីក្រ។ ចាប់តាំងពីឆ្នាំ ១៩៩០ មក មនុស្ស ២ ពាន់លាននាក់បានទទួលបានទឹកស្អាតដែលប្រសើរឡើង ប៉ុន្តែជិត ១ ពាន់លាននាក់នៅតែស្រែកឃ្លាននៅជុំវិញតំបន់ពិភពលោក។

តំបន់ទាំងប្រាំនៃអឡ្ឌគោលខាងត្បូងនៃពិភពលោកមានភាពខុសគ្នា មិនត្រឹមតែលើការកាត់បន្ថយភាពក្រីក្រប៉ុណ្ណោះទេ ថែមទាំងលើកម្រិតប្រាក់ចំណូល និងកំណើនផងដែរ។ ដូចដែលក្រាហ្វិក ១២.១ បានបង្ហាញតំបន់ដែលមានកំណើនលឿនបំផុត ប្រទេសចិននិងអាស៊ីខាងត្បូង មិនមែនជាតំបន់ដែលមានចំណូលខ្ពស់បំផុត ឬជាតំបន់ដែលមានចំណូលទាបបំផុតនោះទេ។ នៅមជ្ឈិមបូព៌ាមានការអភិវឌ្ឍន៍ដូចប្រទេសចិនដែរ ទាក់ទងនឹងផលិតផលក្នុងស្រុកសរុប(GDP) ក្នុងមនុស្សម្នាក់ ប៉ុន្តែ វាបាននឹងកំពុងកើនឡើងត្រឹមតែពាក់កណ្តាលអត្រាប៉ុណ្ណោះជីវភាព។ មេរៀនទី ១៣ នឹងស្វែងយល់ពីហេតុផលនៃភាពខុសគ្នាទាំងនេះ នៅក្នុងកំណើនសេដ្ឋកិច្ច ប៉ុន្តែនៅទីនេះ យើងកត់សម្គាល់យ៉ាងសាមញ្ញថា តំបន់នានាលើពិភពលោកប្រែប្រួលទាំងប្រាក់ចំណូល និងកំណើន ដោយវិមាត្រទាំងពីរផ្សេងៗគ្នា។

អ្នកជំនាញមិនយល់ស្របអំពីចំនួននៃភាពក្រីក្រ និងវិសមភាពបានថយចុះនោះទេ។ អ្នកខ្លះអះអាងថា ភាពក្រីក្រត្រូវបានកាត់បន្ថយត្រឹមពាក់កណ្តាលតាមរយៈកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស ហើយការបែងចែកប្រាក់ចំណូលជាសកល ដែលកំពុងផ្លាស់ប្តូរពីការមានអ្នកមាននិងអ្នកក្រយ៉ាងខ្លាំង ទៅជាការចែកចាយខ្សែកោង ជាមួយនឹងចំនួនប្រជាជនដ៏ច្រើននៅកម្រិតចំណូលមធ្យមដែលជាវណ្ណៈកណ្តាលរបស់ពិភពលោកដែលកំពុងមានភាពរីកចម្រើន។ ធនាគារពិភពលោកពិពណ៌នាអំពីវឌ្ឍនភាពយឺតយ៉ាវនេះ។ រវាងឆ្នាំ ១៩៩០ និងនៅក្នុងឆ្នាំ ២០១៣ ប្រាក់ចំណូលក្នុងមនុស្សម្នាក់ៗ (បានកែតម្រូវសម្រាប់អតិផរណា) នៅក្នុងអឌ្ឍគោលខាងត្បូងទាំងមូលបានកើនឡើងពីប្រហែល $៣,០០០ ទៅប្រហែល $៨,០០០ (តួលេខបង្ហាញក្នុង ២០១៥ ដុល្លារ)។ នៅក្នុងអឌ្ឍគោលខាងជើង ប្រាក់ចំណូលកើនឡើងពីប្រហែល ២០,០០០ ដុល្លារទៅប្រហែល ៤០,០០០ ដុល្លារ។ តើនេះបង្ហាញពីការបិទបញ្ចប់គម្លាតដ៏យឺតយ៉ាវ ដែលដោយសារសមាមាត្របានធ្លាក់ចុះពីប្រហែល ៦.៧ ទៅ ៥.០ ដែលជាលទ្ធផលនៃអត្រាកំណើនខ្ពស់នៅភាគខាងត្បូង? ឬតើវាបង្ហាញពីការពង្រីកគម្លាតរវាងមនុស្សម្នាក់រស់នៅក្នុងអឌ្ឍគោលខាងជើង និងមនុស្សម្នាក់ទៀតរស់នៅអឌ្ឍគោលខាងត្បូង ព្រោះបើនិយាយជាជាច់ខាត វាបានកើនឡើងពី ១៧,០០០ ដុល្លារដល់ជាង ៣២,០០០ ដុល្លារ? ដែលទាំងអស់នេះសុទ្ធជាភាពជាក់ស្តែង។

ក្រាហ្វិក ១២.១ កម្រិតប្រាក់ចំណូល និងអត្រាកំណើនតាមតំបន់ពិភពលោក

ប្រភព៖ ផ្អែកលើទិន្នន័យរបស់ធនាគារពិភពលោក។



ចំណាំ៖ សម្រាប់ពិភពលោកខាងជើងទាំងមូល ផ.ស.ស. សម្រាប់មនុស្សម្នាក់ៗ គឺ $៤០០០០

១២.១.១. តម្រូវការមូលដ្ឋានរបស់មនុស្ស

ប្រទេសមួយចំនួននៅអឌ្ឍគោលខាងត្បូងមានការរីកចម្រើនយ៉ាងឆាប់រហ័សក្នុងការបង្កើនប្រាក់ចំណូល ប៉ុន្តែប្រទេសខ្លះទៀតត្រូវបានជាប់នៅក្នុងវដ្តនៃភាពក្រីក្រ។ រហូតដល់ប្រាក់ចំណូលកើនឡើង ប្រជាជននឹងមិនឆ្លង

ផុតការផ្លាស់ប្តូរប្រជាសាស្ត្របានទេ (សូមមើលមេរៀនទី ១១) កំណើនប្រជាជននឹង នៅតែមានកម្រិតខ្ពស់ និងប្រាក់ចំណូលទាប។

ដើម្បីជាក់កំណើនសេដ្ឋកិច្ចនៅលើមូលដ្ឋានរឹងមាំមួយ សង្គមត្រូវតែបំពេញតម្រូវការជាមូលដ្ឋានរបស់មនុស្សភាគច្រើននៃចំនួនប្រជាជន។ មនុស្សត្រូវការអាហារ ទីជម្រក និងរបស់ចាំបាច់ផ្សេងទៀត ក្នុងជីវិតប្រចាំថ្ងៃដើម្បីមានអារម្មណ៍ថាមានសុវត្ថិភាព។ ដរាបណាប្រជាជននៅអឌ្ឍគោលខាងត្បូងស្តីបន្ទោសចក្រពត្តិនិយមចំពោះការខ្វះខាតតម្រូវការជាមូលដ្ឋាន ភាពក្រីក្រខ្លាំងនឹងជំរុញអោយមានបដិវត្តន៍ តេរេកម្ម និងមនោសញ្ចេតនាប្រឆាំងលោកខាងលិច។

រូបថត ស្ត្រីឥណ្ឌាពិនិត្យសុខភាពមុនពេលសម្រាល

ការជំរុញទារក

មនុស្សជិតមួយពាន់លាននាក់ នៅទូទាំងអឌ្ឍគោលខាងត្បូង ដែលភាគច្រើនរស់នៅទ្វីបអាហ្វ្រិក និងអាស៊ីទក្សិណ រស់នៅក្នុងភាពក្រីក្រធ្ងន់ធ្ងរ ខ្វះទឹកស្អាត ផ្ទះសម្បែង អាហារ និងសមត្ថភាពក្នុងការអាន។ គ្រោះធម្មជាតិ គ្រោះរាំងស្ងួត និងសង្គ្រាមអាចជម្លៀសកសិកររចេញពីដីរបស់ពួកគេ ហើយធ្វើអោយបញ្ហាកាន់តែធ្ងន់ធ្ងរឡើង។ ប៉ុន្តែ ការជឿនលឿនប្រកបដោយនិរន្តរភាពក្នុងការថែទាំសុខភាព ដូចជាការពិនិត្យមុនពេលសម្រាលដែលផ្តល់អោយស្ត្រីទាំងនេះ នៅក្នុងប្រទេសឥណ្ឌាក្នុងឆ្នាំ ២០១៣ កំពុងនាំមកនូវភាពប្រសើរឡើងយ៉ាងខ្លាំង។

កុមារគឺជាចំណុចសំខាន់ក្នុងការបំពេញតម្រូវការមូលដ្ឋានរបស់ប្រជាជន។ ជាពិសេសនោះគឺជាការអប់រំដែលអនុញ្ញាតអោយមនុស្សជំនាន់ថ្មីបំពេញតម្រូវការមូលដ្ឋានផ្សេងទៀត ហើយឈានទៅឆ្លងកាត់ការផ្លាស់ប្តូរប្រជាសាស្ត្រ។ អក្ខរកម្ម (ដែលអង្គការទទួលបន្ទុកការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌របស់អង្គការសហប្រជាជាតិ ហៅកាត់ថា «យូណេស្កូ» បានកំណត់ថាជា សមត្ថភាពអាន និងសរសេរប្រយោគសាមញ្ញ) គឺជាធាតុផ្សំសំខាន់នៃការអប់រំ។ អ្នកដែលចេះអាននិងចេះសរសេរអាចទទួលបានព័ត៌មានច្រើនអំពីការធ្វើកសិកម្ម ការថែទាំសុខភាព ការពន្យារកំណើតជាដើម។ ប្រទេសក្រីក្រមួយចំនួនបានបង្កើនអត្រាអក្ខរកម្មយ៉ាងច្រើន ខណៈប្រទេសផ្សេងទៀតមានភាពយឺតយ៉ាវ។


ក៏មានកម្រិតខុសគ្នាខ្លាំងនៅក្នុងការចុះឈ្មោះចូលរៀនផងដែរ។ ការចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សាក្នុងឆ្នាំ ២០១៦ មានច្រើនជាង ៩០ ភាគរយភាគច្រើនក្នុងតំបន់ទាំងមូល ទោះបីជាមានត្រឹមតែ ៧០ ភាគរយសម្រាប់ទ្វីបអាហ្វ្រិកក៏ដោយ។ ការអប់រំកំរិតមធ្យមសិក្សា អនុវិទ្យាល័យនិងវិទ្យាល័យ គឺជាបញ្ហាមួយផ្សេងទៀត។ នៅអឌ្ឍគោលខាងជើង ប្រហែល ៩០ ភាគរយនៃកុមារកម្រិតមធ្យម សិក្សាបានចុះឈ្មោះចូលរៀន ប៉ុន្តែនៅភាគខាងលិចនៃសកលលោក ចំនួនទាំងនោះមានចំនួនតិចជាងគួរអោយកត់សម្គាល់។ សម្រាប់នៅផ្នែកមហាវិទ្យាល័យមានតែផ្នែកតូចមួយនៃចំនួនប្រជាជនប៉ុណ្ណោះដែលបានទទួលការអប់រំនេះ។

យោងតាមអង្គការយូនីសេហ្វ នៅតំបន់ភាគខាងត្បូង ក្នុងឆ្នាំ ២០១៣ កុមារម្នាក់ក្នុងចំណោម ៤ នាក់បានទទួលរងពីបញ្ហាកង្វះអាហារូបត្ថម្ភ ម្នាក់ក្នុងចំណោម ៧ នាក់ខ្វះលទ្ធភាពទទួលបានការថែទាំសុខភាព ហើយម្នាក់ក្នុងចំណោម ៧ នាក់មិនមានទឹកពិសាសុវត្ថិភាព។ ការរាតត្បាតនៃជំងឺអេដស៍កំពុងរីករាលដាលមិនឈប់ឈរដែលបានធ្វើឡើងក្នុងរយៈពេលជាច្រើនទសវត្សរ៍ក្នុងការកាត់បន្ថយការស្លាប់របស់កុមារ និងការបង្កើនការអប់រំ។

ក្រាហ្វិក១២.២បង្ហាញពីការប្រែប្រួលនៅទូទាំងតំបន់ នៅក្នុងសូចនាករសំខាន់ៗចំនួនពីរនៃសុខុមាលភាពរបស់កុមារនៅដំណាក់កាលផ្សេងៗគ្នា៖ ការចាក់ថ្នាំបង្ការ និងការចុះឈ្មោះចូលរៀននៅអនុវិទ្យាល័យ។ ក្នុងករណីទាំងពីរនេះ ការសម្រេចបាននូវតម្រូវការជាមូលដ្ឋានទាំងនេះសម្រាប់កុមារ ប្រហែលទាក់ទងទៅនឹងកម្រិតប្រាក់ចំណូលរបស់តំបន់នីមួយៗ។

ក្រាហ្វិក ១២.២ សូចនាករតម្រូវការមូលដ្ឋានតាមតំបន់ ឆ្នាំ ២០១៦

ប្រភព៖ ផ្អែកលើទិន្នន័យរបស់ធនាគារពិភពលោក។



បង្គោលឆ្វេង៖ អត្រាចាក់ថ្នាំបង្ការជំងឺកញ្ជ្រឹល *បង្គោលស្តាំ៖* អត្រាចុះឈ្មោះចូលរៀននៅអនុវិទ្យាល័យ

ការថែទាំសុខភាពប្រកបដោយប្រសិទ្ធភាព នៅក្នុងប្រទេសក្រីក្រ មិនមានតម្លៃថ្លៃនោះទេ នៅក្នុងតម្លៃមួយដែលតិចជាង ៥ ដុល្លារក្នុងមនុស្សម្នាក់ ក្នុងមួយឆ្នាំសម្រាប់ការថែទាំបឋម។ ជាឧទាហរណ៍ អង្គការយូនីសេហ្វបានផ្សព្វផ្សាយនូវវិធីសាស្ត្រចំនួនបួនដែលមានតម្លៃទាប ដែលបានចូលរួមក្នុងការជួយសង្គ្រោះទៅដល់ជីវិតកុមាររាប់លាននាក់ក្នុងមួយឆ្នាំៗ។ វិធីសាស្ត្រទីមួយគឺការត្រួតពិនិត្យកំណើនប្រជាជន។ អ្នកជំនាញប៉ាន់ប្រមាណថាការគាំទ្រលើទំងន់របស់កុមារ និងការផ្តល់ដំបូន្មានទៅលើការអបរំអាចការពារបានពាក់កណ្តាលនៃករណីទាំងអស់នៃកង្វះអាហារូបត្ថម្ភ។ វិធីសាស្ត្រទីពីរគឺការព្យាបាលដោយប្រើជាតិទឹកតាមមាត់ (ORT) ដែលបញ្ឈប់ការរាគចំពោះកុមារមុនពេលទុកឲ្យពួកគេស្លាប់ដោយសារការខះជាតិទឹក។ គ្រឿងបរិក្ខារដែលផលិតបាន ៣០០ កញ្ចប់ក្នុងមួយថ្ងៃនៃដំណោះស្រាយអំបិលស្ករសាមញ្ញក្នុងតម្លៃ ១,៥ សេនក្នុងមួយកញ្ចប់ត្រូវបានផលិតនៅប្រទេសហ្គាតេម៉ាឡាក្នុងតម្លៃត្រឹមតែ ៥៥០ ដុល្លារប៉ុណ្ណោះ។ ការស្លាប់របស់កុមារដោយជំងឺរាគត្រូវបានកាត់បន្ថយពាក់កណ្តាលក្នុងមួយឆ្នាំ។ វិធីសាស្ត្រទីបីគឺការចាក់ថ្នាំបង្ការប្រឆាំងនឹងជំងឺទូទៅចំនួនប្រាំមួយមុខគឺ៖ កញ្ជ្រឹល ជំងឺស្វិតដៃជើង ជំងឺរបេង តេតាណូស ក្អកមាន់ និងរោគខាន់ស្លាក់។ ក្នុងប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ ចំនួនកុមារដែលទទួលបានថ្នាំបង្ការនៅក្នុងប្រទេសក្រីក្របានកើនឡើងពី ៥ ភាគរយដល់ជាង ៥០ ភាគរយ។ នៅឆ្នាំ ២០១៣ ចំនួនកុមារដែលបានចាក់វ៉ាក់សាំងយ៉ាងហោចណាស់ម្តងប្រឆាំងនឹងជំងឺកញ្ជ្រឹលបានកើនឡើងដល់ ៨៥ ភាគរយ។ វិធីសាស្ត្រទីបួនគឺការលើកកម្ពស់ការបំបៅកូន

ដោយទឹកដោះម្តាយជាជាងការបំបៅកូនដោយទឹកដោះគោ (ពេលខ្លះគឺដោយសារការអូសទាញ តាមរយៈទីផ្សារសម័យទំនើបនិយម)។

ចាប់តាំងពីឆ្នាំ ១៩៩០ ទោះបីជាមានបញ្ហាដ៏គួរអោយភ័យខ្លាចនៃបញ្ហាសង្គ្រាម និងការរីករាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍ក៏ដោយ ក៏សុខភាពសាធារណៈនៅក្នុងពិភពលោកភាគខាងត្បូងបានចុះកំណត់នៅក្នុងអត្ថប្រយោជន៍សំខាន់ៗមួយចំនួន។ ការស្លាប់របស់ទារកដោយគេតាណូសត្រូវបានកាត់បន្ថយចំនួនពាក់កណ្តាល ហើយការទទួលបានទឹកសុវត្ថិភាពត្រូវបានពង្រីកដល់មនុស្សមួយពាន់លាននាក់ទៀត។ ជំងឺស្វិតដៃជើងស្ទើរតែត្រូវបានលុបបំបាត់ ប៉ុន្តែភាពធន់នឹងការចាក់ថ្នាំបង្ការនៅក្នុងផ្នែកខ្លះនៃប្រទេសនីហ្សេរីយ៉ា អនុញ្ញាតអោយជំងឺនេះចាប់ផ្តើមរីករាលដាលម្តងទៀត ដោយប្រទេសចំនួនបី ដែលមានចំនួនប្រជាជនជាជនជាតិដើមភាគតិចនៅឆ្នាំ ២០១៦ (ពី ប៉ាគីស្តាន អាហ្វហ្គានីស្តាន និងនីហ្សេរីយ៉ា ហើយមេរោគនេះបានធ្វើដំណើរពីប៉ាគីស្តាន ទៅអេហ្ស៊ីបក្នុងឆ្នាំ២០១៣)។ នៅក្នុងប្រទេសអាហ្វ្រិកចំនួនប្រាំបីក្នុងឆ្នាំ ២០០៦ បន្ទាប់ពីការសោកល្បងជោគជ័យ នៅក្នុងប្រទេសមួយចំនួនទៀត អាជ្ញាធរបានរួមបញ្ចូលគ្នានូវការចែកចាយមុងព្យាបាលដោយថ្នាំសម្លាប់សត្វល្អិតសម្រាប់ជំងឺគ្រុនចាញ់ជាមួយនឹងថ្នាំបង្ការជំងឺកញ្ជ្រឹល និងជំងឺស្វិតដៃជើង ថ្នាំកម្ចាត់ដង្កូវស៊ី ថ្នាំគ្រាប់វីតាមីន A និងសម្ភារៈអប់រំ ដែលជាវិធីសាស្ត្ររួមបញ្ចូលគ្នា ដែលបង្ហាញថាមានប្រសិទ្ធភាព។ នៅឆ្នាំ ២០១៤ ការស្លាប់របស់កុមារអាយុក្រោម ៥ ឆ្នាំនៅទូទាំងពិភពលោកបានឈានដល់កម្រិតទាបបំផុតគឺទាបជាង ៧ លាននាក់ ដោយបានធ្លាក់ចុះពាក់កណ្តាលចាប់តាំងពីឆ្នាំ ១៩៩០។ ការស្លាប់ដោយជំងឺកញ្ជ្រឹលបានធ្លាក់ចុះបីភាគបួនក្នុងរយៈពេលត្រឹមតែដប់ឆ្នាំប៉ុណ្ណោះ គឺឆ្នាំ ២០០០-២០១០ ដែលជាជោគជ័យដ៏ធំធេងមួយ។

ទោះយ៉ាងណាក៏ដោយ ភាពមិនស្មើគ្នាក្នុងការទទួលបានការថែទាំសុខភាពនៅជុំវិញពិភពលោកបានកំពុងកើតមានឡើង។ ប្រមាណ ៧៥ ភាគរយនៃប្រជាជនទូទាំងពិភពលោកដែលរស់នៅក្នុងអឌ្ឍគោលខាងត្បូងមានប្រហែល ៣០ ភាគរយនៃគ្រូពេទ្យ និងគិលានុបដ្ឋាយិការបស់ពិភពលោក។ នៅក្នុងការស្រាវជ្រាវផ្នែកវេជ្ជសាស្ត្រមានចំនួនតិចជាង ៥ ភាគរយនៃការចំណាយសម្រាប់សុខភាពនៅក្នុងពិភពលោក ផ្តោតទៅលើបញ្ហាសុខភាពផ្ទាល់នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ បើយោងតាមអង្គការសុខភាពពិភពលោក (WHO)។ ឃាតករធំបំផុតគឺជំងឺអេដស៍ ដែលការឆ្លងមេរោគផ្លូវដង្ហើមស្រួចស្រាវដូចជា រាគ របេង គ្រុនចាញ់ និងជំងឺរលាកថ្លើមស្ថិតនៅកំរិតបន្ទាប់។ មនុស្សជាង ៦០០ លាននាក់បានឆ្លងជំងឺត្រូពិច ពី ៤០០ ទៅ ៥០០ លាននាក់ដោយជំងឺគ្រុនចាញ់។ ប៉ុន្តែដោយសារតែមនុស្សដែលមានជំងឺបែបនេះគឺជាប្រជាជនក្រីក្រ ម្យ៉ាងទៀត មិនមានទីផ្សារធំគ្រប់គ្រាន់សម្រាប់ឲ្យក្រុមហ៊ុនឱសថ (ដែលជាសាជីវកម្មពហុជាតិ[MNCs]) នៅក្នុងពិភពឧស្សាហកម្មដើម្បីវិនិយោគលើឱសថសម្រាប់ពួកគេ។ ហើយនៅពេលដែលប្រទេសក្រីក្រត្រូវការថ្នាំដែលត្រូវបានអភិវឌ្ឍសម្រាប់ទីផ្សារអ្នកមាន ថ្នាំអាចមានតម្លៃថ្លៃគួរសម ដូចជាថ្នាំអេដស៍ដែលបានពិភាក្សាក្នុងមេរៀនទី ១១។ ទោះបីជាយ៉ាងនេះក្តី កិច្ចប្រឹងប្រែងដោយអង្គការWHO ក៏ដូចជាអង្គការក្រៅរដ្ឋាភិបាលផ្សេងៗ បានកាត់បន្ថយអត្រាមរណៈពីជំងឺគ្រុនចាញ់ ប្រហែល ២៩ ភាគរយ ចាប់តាំងពីឆ្នាំ ២០១០។

សុវត្ថិភាពទឹក គឺជាធាតុសំខាន់មួយទៀតក្នុងការបំពេញតម្រូវការជាមូលដ្ឋានរបស់មនុស្ស។ នៅតាមទីជនបទជាច្រើន ប្រជាជនត្រូវដើររាប់ម៉ាយល៍ក្នុងមួយថ្ងៃ ដើម្បីដងទឹក សូមចាំថាការទទួលបានទឹកមិនមែនមានន័យថាមានទឹកនៅគ្រប់ផ្ទះនោះទេ ប៉ុន្តែជាអណ្តូងទឹកស្អាត ឬ ទឹកចេញពីក្បាលរ៉ូប៊ីណេសម្រាប់ភូមិមួយ។

ក្នុងឆ្នាំ ១៩៩០-២០១០ ចំនួនប្រជាជនដែលមិនមានលទ្ធភាពប្រើប្រាស់ទឹកបានធ្លាក់ចុះពាក់កណ្តាល ដោយសម្រេចបានគោលដៅMDG អោយបានឆាប់ប៉ុន្តែមនុស្សម្នាក់ក្នុងចំណោមប្រាំមួយនាក់នៅទូទាំងពិភពលោកនៅតែខ្វះទឹកស្អាតផឹកប្រកបដោយសុវត្ថិភាព។ ហើយមនុស្សជាច្រើន ក្នុងចំណោមអ្នកដែលមានទឹកស្អាតមានសុវត្ថិភាព ខ្វះកន្លែងអនាម័យ (ដូចជាលូ និងបង្គន់អនាម័យ)។ ប្រជាជនប្រហែល ២,៥ ពាន់លាននាក់ដែលមួយភាគបីនៃចំនួនប្រជាជនពិភពលោកមិនមានសិទ្ធិចូលប្រើប្រាសដើម្បីអនាម័យ។ ជាលទ្ធផល ការរាតត្បាតបានកើតឡើងដដែលៗ និងជំងឺរាគដែលបានរាលដាលបង្កអោយកុមាររាប់លាននាក់ស្លាប់ក្នុងមួយឆ្នាំ។ តំបន់ជនបទទទួលផលអាក្រក់ជាងនៅតំបន់ទីក្រុង។ អនាម័យមិនល្អនៅក្នុងប្រទេសហៃទីបានអនុញ្ញាតអោយមានការរីករាលដាលនៃជំងឺអាសន្នរោគ (បង្ហាញដោយហួសចិត្ត ដោយការទៅសួរសុខទុក្ខអ្នករក្សាសន្តិភាពនេប៉ាល់ដែលត្រូវបានបញ្ជូនទៅជួយប្រទេសហៃទី) បានសម្លាប់មនុស្សរាប់ពាន់នាក់ក្នុងឆ្នាំ ២០១០-២០១៣។ ទោះបីជាមានការវិវឌ្ឍយ៉ាងធំធេងក៏ដោយ ដែលពិភពលោកបានធ្វើអោយប្រសើរឡើងនូវទឹក និងអនាម័យ ជាមួយនឹងការកើនឡើងចំនួនប្រជាជន នៅតែមានមនុស្សប្រហែល ១ ពាន់លាននាក់ កំពុងខ្វះទឹកសុវត្ថិភាព និងជាង ២ ពាន់លាននាក់មិនមានអនាម័យគ្រប់គ្រាន់។

ទីជម្រកគឺជាតម្រូវការមូលដ្ឋានដ៏សំខាន់មួយទៀត។ ក្នុងចំណោមមនុស្ស ៧ ពាន់លាននាក់នៅលើពិភពលោក ប្រហែល ១ នាក់ក្នុងចំណោម ៦ នាក់រស់នៅក្នុងផ្ទះដែលមិនមានស្តង់ដារ ឬគ្មានផ្ទះសម្បែង។ សម្រាប់សូចនាកមួយទៅសូចនាករ យើងរកឃើញថាមនុស្សប្រហែលមួយពាន់លាននាក់ គ្មានអ្វីសោះបន្សល់ទុក។ សូចនាករផ្សេងគ្នាមិនត្រូវគ្នាឥតខ្ចោះនោះទេ ប៉ុន្តែជាមូលដ្ឋាន រាប់ពាន់លាននៃមនុស្សជាតិភាគច្រើនរស់នៅក្នុងតំបន់ជនបទ ស្ថិតក្នុងភាពក្រីក្រ និងអស់សង្ឃឹម។ កត្តាសំខាន់បំផុតដែលធ្វើអោយមនុស្សទាំងនេះស្ថិតក្នុងភាពក្រីក្រអស់សង្ឃឹម ហាក់ដូចជាសង្គ្រាមស៊ីវិល អំពើពុករលួយ «បណ្តាសាធនធាន» (សូមមើលមេរៀនទី ១៣) និងទីតាំងបិទជិត គ្មានលទ្ធភាពធ្វើពាណិជ្ជកម្ម។


តាមទ្រឹស្តី ការផ្តល់តម្រូវការមូលដ្ឋានគួរតែផ្តល់អោយប្រជាជនក្រីក្រនូវក្តីសង្ឃឹមនៃវឌ្ឍនភាព ហើយគួរតែជានាបាននូវស្ថិរភាពនយោបាយ។ ទោះយ៉ាងណាក៏ដោយ នោះមិនមែនតែងតែជាលទ្ធផលនោះទេ។ នៅប្រទេសស្រីលង្កា រដ្ឋាភិបាលដែលមានគំនិតជឿនលឿនបានអនុវត្តយុទ្ធសាស្ត្រតម្រូវការជាមូលដ្ឋានដ៏ជោគជ័យបំផុតមួយរបស់ពិភពលោក ដោយដោះស្រាយបញ្ហាអាហារូបត្ថម្ភ ការថែទាំសុខភាព និងអក្ខរកម្ម។ គោលនយោបាយនេះបានបង្ហាញថា សូម្បីតែប្រទេសក្រីក្រខ្លាំងក៏អាចបំពេញតម្រូវការមូលដ្ឋាននៅកម្រិតទាបនៃប្រាក់ចំណូលសម្រាប់មនុស្សម្នាក់ផងដែរ។ បន្ទាប់មកទៀត សង្គ្រាមស៊ីវិលនៃក្រុមជនជាតិភាគតិចក៏បានផ្ទុះឡើង។ សង្គ្រាមកាន់តែមានភាពយោរយៅកាន់តែខ្លាំង (ជាមួយនឹងក្រុមពិឃាដ និងការសងសឹកដោយមិនរើសអើងលើជនស៊ីវិល) រហូតដល់វាបានបំផ្លាញវឌ្ឍនភាពដែលស្រីលង្កាបានកសាង។

សង្គ្រាមនៅអឡឺគោលខាងត្បូង (ទាំងអន្តរជាតិ និងសង្គ្រាមស៊ីវិល) គឺជាឧបសគ្គឈានមុខគេក្នុងការផ្តល់តម្រូវការមូលដ្ឋាន។ សង្គ្រាមបង្កអោយមានការខូចខាតច្រើនដល់សង្គម ច្រើនជាងការស្លាប់និងរបួសផ្ទាល់ដែលវាធ្វើអោយប៉ះពាល់ទៅទៀត។ នៅក្នុងតំបន់សង្គ្រាម ហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចដូចជាការដឹកជញ្ជូនត្រូវបានរំខាន ក៏ដូចជាសេវាកម្មរបស់រដ្ឋាភិបាលដូចជាការថែទាំសុខភាព និងការអប់រំជាដើម។ សង្គ្រាមកាត់បន្ថយទំនុកចិត្តយ៉ាងខ្លាំងលើស្ថិរភាពសេដ្ឋកិច្ច និងនយោបាយ ដែលការវិនិយោគ និងពាណិជ្ជកម្មត្រូវពឹងផ្អែក។


ក្រាហ្វិក ១២.៣ អត្រានៃការទទួលបានទឹក និងអាហារ ឆ្នាំ ២០១៥

ប្រភព៖ ផ្អែកលើអង្គការសុខភាពពិភពលោក។

សមាសភាពប្រជាជនប្រើប្រាស់ប្រភពទឹកស្អាតជាងមុនសម្រាប់ទទួលទាន



អត្រាប្រេវ៉ាឡង់នៃកង្វះអាហារូបត្ថម្ភក្នុងចំណោមប្រជាជន



ក្រាហ្វិក ១២.៣ បង្ហាញពីអត្រានៃការទទួលបានទឹកប្រើប្រាស់ និងអាហារបរិភោគប្រកបដោយសុវត្ថិភាព។ ទំនោរជុំវិញពិភពលោកស្រដៀងនឹងផែនទីនៃសង្គ្រាមដែលកំពុងដំណើរការ (សូមមើលមេរៀនទី ៥)។ ប្រសិនបើពិតជាមានទំនាក់ទំនងរវាងសង្គ្រាមនាពេលថ្មីៗនេះ ឬបច្ចុប្បន្ន និងការខ្វះខាតនៃតម្រូវការមូលដ្ឋាន (ហើយផ្ទុយមកវិញ មានទំនាក់ទំនងជាមួយនឹងកម្រិតប្រាក់ចំណូល) តើអ្វីបណ្តាលអោយអ្វី? តើការមានសង្គ្រាមធ្វើអោយសង្គមមួយក្រីក្រ និងរារាំងវាមិនអោយបំពេញតម្រូវការមូលដ្ឋានរបស់ប្រជាជនទេ? ឬមួយភាពក្រីក្រដោយមានតម្រូវការមូលដ្ឋានមិនបានបំពេញ បានធ្វើអោយសង្គមកាន់តែមានសង្គ្រាម?

ប្រហែលជាទាំងពីរជាការពិត។ សង្គ្រាមជារឿយៗជាផ្នែកនៃវង្វង់ដ៏កាចសាហាវមួយសម្រាប់រដ្ឋនានាដែលមិនអាចដើបចេញពីភាពក្រីក្របាន។

ភាពផុយស្រួយនៃជីវិតនៅក្នុងប្រទេសក្រីក្រត្រូវបានបង្ហាញយ៉ាងច្បាស់ផងដែរ នៅក្នុងឆ្នាំ ២០១០ នៅពេលដែលការរញ្ជួយដីដ៏ធំមួយបានបំផ្លិចបំផ្លាញប្រទេសហៃទី ដែលជាប្រទេសក្រីក្របំផុត នៅក្នុងបស្ចឹមលោក ដែលមានផលិតផលក្នុងស្រុកសរុបប្រចាំឆ្នាំ ចំនួន ១៣០០ ដុល្លារ ក្នុងមនុស្សម្នាក់។ ដោយសារតែការសាងសង់មិនល្អ អគារជាច្រើនបានដួលរលំ ហើយដោយសារតែសុខភាព និងអនាម័យមិនល្អ អ្នករស់រានមានជីវិតប្រឈមនឹងស្ថានភាពអស់សង្ឃឹមខ្លាំង។ មនុស្សជាង ១០០.០០០ នាក់បានស្លាប់ និងរាប់លាននាក់ គ្មានផ្ទះសម្បែង។ ប្រជាជនហៃទីអាចតែសង្ឃឹមថា ជំនួយអន្តរជាតិនឹងជួយពួកគេកសាងឡើងវិញពីបាទដៃទទេ។

រូបថត ថ្នាក់គណិតវិទ្យា នៅក្រុងកណ្តាហារ ប្រទេសអាហ្វហ្គានីស្ថានក្នុងឆ្នាំ

ប្រមាណវិធីគណិតវិទ្យា

កុមារទទួលបានការយកចិត្តទុកដាក់ជាពិសេស នៅក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីផ្តល់នូវតម្រូវការជាមូលដ្ឋានរបស់មនុស្សនៅក្នុងអឌ្ឍគោលខាងត្បូង។ ការអប់រំមានសារៈសំខាន់ខ្លាំងសម្រាប់ទាំងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងអន្តរកាលប្រជាសាស្ត្រ។ កុមារីនៅទូទាំងពិភពលោកទទួលបានការអប់រំតិចជាងកុមារ ហើយនៅក្នុងប្រទេសអាហ្វហ្គានីស្ថាន ក្រោមការដឹកនាំរបស់ពួកតាលីបង់ ពួកគេទាំងអស់គ្នាត្រូវបានហាមឃាត់មិនអោយចូលសាលារៀន។ ថ្នាក់គណិតវិទ្យានេះ នៅក្រុងកណ្តាហារ (Kandahar) ប្រទេសអាហ្វហ្គានីស្ថានក្នុងឆ្នាំ ២០០២ ក្រោយដួលរលំរបបតាលីបង់។

១២.១.២. គ្រោះទុរភិក្សនៅលើពិភពលោក

ក្នុងចំណោមតម្រូវការជាមូលដ្ឋានទាំងអស់របស់មនុស្សនៅភាគខាងត្បូង ចំណុចសំខាន់បំផុតគឺចំនីអាហារ។ កង្វះអាហារូបត្ថម្ភ (ឬកង្វះសារធាតុចិញ្ចឹម) សំដៅទៅលើកង្វះអាហារដែលត្រូវការ រួមទាំងតម្រូវការប្រូតេអ៊ីន និងវីតាមីន។ ពាក្យថា *ការស្រេកឃ្លាន* (hunger) សំដៅយ៉ាងទូលំទូលាយទៅលើកង្វះអាហារូបត្ថម្ភខ្លះ ឬកង្វះអាហារូបត្ថម្ភទាំងស្រុង (ឬកង្វះកាឡូរី)។ ការស្រេកឃ្លាន ជាធម្មតា មិនសម្លាប់មនុស្សតាមរយៈការស្រេកឃ្លានទាំងស្រុងនោះទេ ប៉ុន្តែវាធ្វើអោយពួកគេចុះខ្សោយ ហើយទុកអោយពួកគេងាយនឹងឆ្លងជំងឺ ដែលជាធម្មតាវាមិនបណ្តាលអោយមនុស្សស្លាប់យ៉ាងងាយនោះទេ។

ប្រជាជនប្រហែល ៨០០ លាននាក់ (ភាគច្រើននៅក្នុងអឌ្ឍគោលខាងត្បូង) ត្រូវបានគេដឹងថាខ្វះអាហារូបត្ថម្ភរ៉ាំរ៉ៃ (សូមមើលតារាង ១២.១)។ ការរួមចំណែកដ៏មានសក្តានុពលរបស់ពួកគេ ក្នុងការប្រមូលផ្តុំសេដ្ឋកិច្ចមិនបានពេញលេញនោះទេ ពីព្រោះពួកគេមិនអាចធ្វើបាន សូម្បីតែការងារនោះជាការងារស្រាលៗក៏ដោយ។ ជាងនេះទៅទៀត ពួកគេគឺជាប្រភពសក្តានុពលនៃអស្ថិរភាពនយោបាយ រួមទាំងអស្ថិរភាពអន្តរជាតិផងដែរ ដរាបណាពួកគេនៅតែស្រេកឃ្លាន។ ការកត់ត្រាតម្លៃម្ហូបអាហារក្នុងឆ្នាំ ២០១១ បានធ្វើអោយបញ្ហាកាន់តែធ្ងន់ធ្ងរ។ នៅក្នុងកិច្ចប្រជុំកំពូលស្បៀងអាហារពិភពលោក ក្នុងឆ្នាំ ១៩៩៦ មេដឹកនាំពិភពលោកបានអនុម័តគោលដៅមួយ ដើម្បីកាត់បន្ថយការស្រេកឃ្លាន អោយអស់ពាក់កណ្តាល នៅត្រឹមឆ្នាំ ២០១៥។ ពិភពលោកបានខិតជិតដល់ការសម្រេចបាននូវគោលដៅនេះ ប៉ុន្តែវាមិនបានសំរេចទាំងស្រុងនោះទេ។ ជាសមាមាត្រនៃចំនួនប្រជាជនដែលកំពុងកើនឡើង អត្រានៃភាពអត់ឃ្លានបានធ្លាក់ចុះពី ១៩ ទៅ ១១

ភាគរយ ពីឆ្នាំ ១៩៩១ ដល់ឆ្នាំ ២០១៤។ នៅក្នុងឆ្នាំ ២០១៥ មេដឹកនាំពិភពលោកបានសន្យាថានឹងកំណត់គោលដៅអភិវឌ្ឍន៍នៃការបញ្ចប់ភាពអត់ឃ្លាន និងភាពក្រីក្រខ្លាំងនៅឆ្នាំ ២០៣០។

តារាង ១២.១ កង្វះអាហារូបត្ថម្ភសកល

ប្រជាជនដែលខ្វះអាហារូបត្ថម្ភរ៉ាំរ៉ៃតាមតំបន់ គ. ឆ្នាំ ២០១៦

តំបន់	ចំនួន (លាននាក់)	ភាគរយនៃប្រជាជន	១៥ ឆ្នាំមុន
អាស៊ីទក្សិណ	២៧០	១៥%	១៩%
អាស៊ីអាគ្នេយ៍	៦៥	១០%	២២%
ចិន	១៣៥	១០%	១៦%
អាហ្វ្រិក	២០៥	២១%	២៥%
អាមេរិកខាងត្បូង	៤០	៦%	១១%
មជ្ឈឹមបូព៌ា	៤០	៩%	៩%
ពិភពរដ្ឋកំពុងអភិវឌ្ឍ	៧៥៥	១៣%	១៨%

ប្រភព៖ ផ្អែកលើអង្គការស្បៀងអាហារនិងកសិកម្មនៃអង្គការសហប្រជាជាតិ *កម្រិតវិសមភាពស្បៀងអាហារនៅលើពិភពលោក* ឆ្នាំ ២០១៧។

ប្រទេសចិនបានរីកចម្រើនយ៉ាងខ្លាំងក្នុងការកាត់បន្ថយកង្វះអាហារូបត្ថម្ភរបស់កុមារ ដោយបានកាត់បន្ថយចំនួនទាំងនេះមកត្រឹមពាក់កណ្តាលចាប់តាំងពីឆ្នាំ ១៩៩០។ ប៉ុន្តែ ការវិវឌ្ឍន៍នៅអាស៊ីខាងត្បូងមានភាពយឺតយ៉ាវខ្លាំង ហើយអាហ្វ្រិកមិនដំណើរការទៅមុខនោះទេ។ មួយភាគបួននៃកុមារនៅលើពិភពលោកដែលមានអាយុក្រោម ៥ ឆ្នាំ និងជិតពាក់កណ្តាលនៃកុមារនៅក្នុងប្រទេសឥណ្ឌា មានទម្ងន់មិនគ្រប់នោះទេ។ នៅឆ្នាំ ២០១៤ កង្វះអាហារូបត្ថម្ភក្នុងចំណោមកុមារឥណ្ឌាបានធ្លាក់ចុះ ប៉ុន្តែមិនមែនសម្រាប់ជនក្រីក្របំផុត ២០ ភាគរយនោះទេ។

ជាប្រពៃណី សហគមន៍ជនបទបានដាំដុះអាហារផ្ទាល់ខ្លួនរបស់ពួកគេ ពោលគឺការធ្វើកសិកម្មដើម្បីចិញ្ចឹមជីវិត។ ការគ្រប់គ្រងអាណានិគមនិយមបានបង្កាក់ដល់គំរូទាំងនេះ ហើយការរំខានបានបន្តនៅក្នុងសម័យក្រោយអាណានិគម។ បន្ទាប់មកទៀត រដ្ឋនៅអឡឺគោលខាងត្បូង បានចាប់ផ្តើមផ្លាស់ប្តូរពីការចិញ្ចឹមជីវិតផ្អែកលើកសិកម្មទៅជាកសិកម្មសម្រាប់ពាណិជ្ជកម្មវិញ។ ដីតូចៗត្រូវបានបញ្ចូលទៅក្នុងចំការធំៗ ដែលជារឿយៗស្ថិតនៅក្រោមការគ្រប់គ្រងរបស់ម្ចាស់ផ្ទះដែលមានទ្រព្យសម្បត្តិ។ តាមរយៈការប្រមូលផ្តុំដើមទុន និងការតំរង់ទិសសេដ្ឋកិច្ចឆ្ពោះទៅរកទីផ្សារពិភពលោក ដំណើរការនេះសម ស្របជាមួយនឹងទីផ្សារនៃសេដ្ឋកិច្ចសេរី។ យ៉ាងណាក៏ដោយ វាបានធ្វើឲ្យកសិករប្រកបរបរចិញ្ចឹមជីវិតចេញពីដីស្រែរបស់ពួកគេ។ ជាលទ្ធផលស្រដៀងគ្នា សង្គ្រាមបានធ្វើឲ្យកសិករផ្លាស់ទីកាន់តែលឿន។

កសិកម្មពាណិជ្ជកម្មពឹងផ្អែកលើគ្រឿងម៉ាស៊ីន ឥន្ធនៈពាណិជ្ជកម្ម និងជីសិប្បនិម្មិត និងថ្នាំសម្លាប់សត្វល្អិត ដែលត្រូវតែទិញដោយសាច់ប្រាក់ ហើយជារឿយៗ ត្រូវមានការតែនាំចូលពីខាងក្រៅ។ ដើម្បីចំណាយលើការផ្គត់ផ្គង់ទាំងនេះ កសិដ្ឋានធំៗបានដាំដំណាំដែលអាចលក់បានប្រាក់ ដែលជាទំនិញកសិកម្មដែលផលិតសម្រាប់នាំចេញទៅកាន់ទីផ្សារពិភពលោក។ ដំណាំបែបនេះ ជាធម្មតា ផ្តល់អាហារូបត្ថម្ភតិចតួចដល់កសិករក្នុងស្រុក ដូចជា កាហ្វេ តែ និងអំពៅជាដើម។ នៅពេលដែលចម្ការត្រូវបានសាងសង់ ឬពង្រីក កសិករចិញ្ចឹម

ជីវិតនឹងបញ្ចប់ការងារលើចំការដោយប្រាក់ឈ្នួលទាបបំផុត ឬធ្វើចំណាកស្រុកទៅទីក្រុងដើម្បីស្វែងរកការងារធ្វើ។ ជារឿយៗ ពួកគេជាជនក្រីក្រ និងអត់ឃ្លាន។ គួរអោយអស់សំណើចណាស់ តម្លៃស្បៀងមានតម្លៃខ្ពស់បានបង្កើនប្រាក់ចំណូលដល់កសិករនៅតាមជនបទ ប៉ុន្តែមនុស្សជាច្រើនមិនមានលទ្ធភាពទិញអាហារ។

គ្រោះធម្មជាតិអាចជាកត្តាធ្វើឲ្យកង្វះស្បៀងអាហារកាន់តែធ្ងន់ធ្ងរ។ ការគំរាមកំហែងនៃការខ្វះខាតស្បៀងអាហារដ៏ធំបានគំរាមកំហែងប៉ាគីស្តាន បន្ទាប់ពីត្រូវបានបំផ្លិចបំផ្លាញដោយទឹកជំនន់ នៅរដូវក្តៅឆ្នាំ ២០១០។ យោងតាមអង្គការស្បៀងអាហារនិងកសិកម្មរបស់អង្គការសហប្រជាជាតិ ដំណាំប្រមាណជិត ២ លានហិចតា ត្រូវបានបាត់បង់នៅក្នុងទឹកជំនន់ប៉ាគីស្តាន ដែលធ្វើអោយស្បៀងអាហារខ្វះខាតសម្រាប់មនុស្ស និងសត្វកសិដ្ឋាន។ រដ្ឋជាអង្គការអន្តរជាតិ (IGOs) និងអង្គការមិនមែនរដ្ឋាភិបាល (NGOs) បានប្រញាប់ប្រញាល់ក្នុងការផ្តល់ស្បៀងអាហារទៅកាន់ប្រទេសប៉ាគីស្តាន បន្ទាប់ពីទឹកជំនន់ ដោយសង្ឃឹមថានឹងអាចជៀសផុតពីគ្រោះមហន្តរាយមនុស្សធម៌ដ៏ធំមួយ។

ជំនួយអាហារអន្តរជាតិទាំងអស់ មានពេលខ្លះអាចរួមចំណែកដល់បញ្ហាទាំងនេះផងដែរ។ ជំនួយផ្នែកកសិកម្មអាចអនុគ្រោះដល់កសិកម្មពាណិជ្ជកម្ម។ ហើយប្រសិនបើទីភ្នាក់ងារអន្តរជាតិផ្តល់ជំនួយអាហារច្រើនលើសលុបលើតំបន់ដែលជន់លិច នោះតម្លៃនៃម្ហូបអាហារនៅលើទីផ្សារក្នុងស្រុកនឹងធ្លាក់ចុះ ដែលអាចនឹងបង្ខំសូម្បីតែកសិករក្នុងស្រុកកាន់តែច្រើនចេញពីការធ្វើអាជីវកម្មនិងបង្កើនតែទៅលើការពឹងផ្អែកលើអំណោយពីរដ្ឋាភិបាល ឬសហគមន៍អន្តរជាតិ។ ម្យ៉ាងវិញទៀត ប្រជាពលរដ្ឋដែលជួបគ្រោះរាំងស្ងួត ឬទុរ្ភិក្ស ជារឿយៗត្រូវធ្វើដំណើរទៅកាន់កន្លែងផ្តល់អាហារ ដើម្បីទទួលអាហារ ដោយផ្អាកការងារនៅលើដីរបស់ខ្លួន។

១២.១.៣. ប្រជាជនជនបទ និងទីក្រុង

ការផ្លាស់ទីលំនៅរបស់កសិករ ពីការធ្វើកសិកម្មចិញ្ចឹមជីវិតបានរួមចំណែកដល់ការផ្លាស់ប្តូរចំនួនប្រជាជនដ៏ធំដែលជាធម្មតាអមជាមួយនឹងការផ្លាស់ប្តូរប្រជាសាស្ត្រ។ មនុស្សកាន់តែច្រើនឡើង ៗ ផ្លាស់ទីទៅទីក្រុង ចេញពីទីជនបទ ដែលហៅថា**នគរូបនីយកម្ម**(urbanization)។ វាមានការលំបាកក្នុងការវាស់ស្ទង់ពិតប្រាកដ ថាមិនមាននិយមន័យជាស្តង់ដារណាមួយ ដែលទីក្រុងត្រូវបានចាត់ទុកថាជាទីក្រុងនោះទេ។ ប៉ុន្តែ រដ្ឋដាប្រទេសឧស្សាហកម្មបានរាយការណ៍ថា ប្រហែល ៧០ ទៅ ៩០ ភាគរយនៃប្រជាជនរបស់ពួកគេរស់នៅ នៅក្នុងទីក្រុង។ ផ្ទុយទៅវិញ ប្រទេសចិនប្រែក្លាយជាទីក្រុង ប្រហែល៥០ ភាគរយក្នុងឆ្នាំ ២០១៣ ខណៈដែលរដ្ឋភាគច្រើននៅអាស៊ី និងអាហ្វ្រិក មានចន្លោះពី ៣០ ទៅ ៤០ ភាគរយប៉ុណ្ណោះ។ រដ្ឋមជ្ឈិមបូព៌ាវិញ ភាគច្រើនមានទីក្រុងច្រើនជាង ៥០ ភាគរយ ហើយរដ្ឋនៅអាមេរិកខាងត្បូងមានទីក្រុងពី ៧០ ទៅ ៨៥ ភាគរយ។

នគរូបនីយកម្មមិនបណ្តាលមកពីកំណើនប្រជាជនក្នុងទីក្រុងខ្ពស់ជាងនៅជនបទទេ។ តាមការពិតសច្ចៈភាពផ្ទុយពីនេះ។ នៅតាមទីក្រុង ប្រជាជនជាទូទៅទទួលបានការអប់រំកាន់តែប្រសើរឡើង ហើយប្រាក់ចំណូលកាន់តែខ្ពស់។ ពួកគេមានចំនួនច្រើនជាងនៅក្នុងការផ្លាស់ប្តូរប្រជាសាស្ត្រ ហើយមានអត្រាកំណើតទាបជាងប្រជាជននៅជនបទ។ ផ្ទុយទៅវិញ ការកើនឡើងនៃចំនួនប្រជាជននៅទីក្រុងបានបណ្តាលមកពីមនុស្សផ្លាស់ទៅទីក្រុង ពីទីជនបទ។ ពួកគេធ្វើដូច្នេះ ដោយសារតែកម្រិតប្រាក់ចំណូលកាន់តែខ្ពស់នៅក្នុងទីក្រុង (ឱកាសសេដ្ឋកិច្ច) និងក្តីសង្ឃឹមនៃឱកាសកាន់តែច្រើនសម្រាប់ជីវិតដ៏គួរអោយរីករាយ។ ពួកគេក៏បានផ្លាស់ទីផងដែរ ដោយសារកំណើនប្រជាជននៅជនបទរបទទំលំទូលាយលើផ្នែកអាហារ ទឹក ដីបង្កបង្កើនផល និងធនធានផ្សេងទៀត។

នៅក្នុងទីក្រុងជាច្រើន លំហូរនៃប្រជាជនដ៏ច្រើនហាក់ដូចជាមិនអាចឆ្លើយតបនឹងការស្នាក់នៅបានទេ ជាមួយនឹងការងារ លំនៅដ្ឋាន និងសេវាកម្ម។ នៅតាមតំបន់អនាធិបតេយ្យ តំរូវការជាមូលដ្ឋានរបស់មនុស្សច្រើនតែមិនអាចបំពេញបាន។ រដ្ឋជាច្រើនបានពិចារណាលើគោលនយោបាយដើម្បីបំបែកការកាន់កាប់ដីធ្លីដ៏ធំ និងចែកចាយដីឡើងវិញដល់កសិករក្រីក្រសម្រាប់ប្រើប្រាស់ក្នុងការធ្វើកសិកម្មចិញ្ចឹមជីវិត ពោលគឺកំណែទម្រង់ដីធ្លី។ គូប្រជែងសំខាន់នៃកំណែទម្រង់ដីធ្លី គឺជាម្ចាស់ដីធំៗ ដែលជារឿយៗ កាន់អំណាចនយោបាយរឹងមាំ ដោយសារតែទ្រព្យសម្បត្តិ និងទំនាក់ទំនងអន្តរជាតិរបស់ពួកគេជាមួយនឹងទីផ្សារ MNCs និងប្រភពរូបិយប័ណ្ណខ្លាំងផ្សេងទៀត។

១២.១.៤. ស្ត្រីក្នុងការអភិវឌ្ឍន៍

ការអភិវឌ្ឍសេដ្ឋកិច្ចក្នុងប្រទេសក្រីក្រមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធនឹងស្ថានភាពស្ត្រីក្នុងសង្គមទាំងនោះ។ នេះជារបៀបវារៈក់ថ្មីៗ អស់ជាច្រើនទស្សវត្សមកហើយដែលភាគច្រើនគេបានផ្តោតទៅលើបុរសដែលត្រូវបានសន្មតថាជាអ្នកបង្កើតដើមទុនដ៏សំខាន់សម្រាប់ការរស់នៅ។ រដ្ឋាភិបាល និងរបាយការណ៍អន្តរជាតិបានផ្តោតលើការងារដែលអនុវត្តដោយអ្នករកប្រាក់ឈ្នួលថាជាបុរស។ ផ្ទុយទៅវិញ ការងាររបស់ស្ត្រី ជារឿយៗមិនត្រូវបានគិតជាទឹកប្រាក់ និងមិនបង្ហាញនៅក្នុងស្ថិតិហិរញ្ញវត្ថុនោះទេ។ ក៏ប៉ុន្តែស្ត្រីនៅក្នុងពិភពលោកភាគច្រើនធ្វើការងារខ្លាំងជាងបុរស ហើយបានរួមចំណែកកាន់តែច្រើនដល់សុខុមាលភាពសេដ្ឋកិច្ចនៃគ្រួសារ និងនៅក្នុងសហគមន៍របស់ពួកគេ។ ស្ត្រីគឺជាគន្លឹះនៃកិច្ចខិតខំប្រឹងប្រែងដើម្បីកែលម្អអប់រំកូនជាច្រើន និងកាត់បន្ថយនូវអត្រាកំណើតទៀតផង។ នៅក្នុងផ្នែកអាហារូបត្ថម្ភ ការអប់រំ ការថែទាំសុខភាព និងទីជំរក ស្ត្រីគឺជាចំណុចសំខាន់ក្នុងការផ្តល់នូវតម្រូវការជាមូលដ្ឋានរបស់ប្រជាជនក្នុងប្រទេសក្រីក្រ។

ប៉ុន្តែ ស្ត្រីមានឋានៈនៅក្នុងសង្គមទាបជាងបុរស នៅក្នុងបណ្តាប្រទេសនៅអឌ្ឍគោលខាងត្បូង (មានច្រើនជាងសូម្បីតែនៅអឌ្ឍគោលខាងជើង)។ ជាឧទាហរណ៍ នៅពេលដែលអាហារខ្វះខាត ឬមានតិចតួចបុរសនិងក្មេងប្រុសតែងតែបានបរិភោគមុនគេ ដោយស្ត្រីនិងកុមារីញ៉ាំអ្វីដែលនៅសេសសល់។

ការរើសអើងប្រឆាំងនឹងក្មេងស្រីរីករាលដាលនៅក្នុងការអប់រំ និងអក្ខរកម្ម។ នៅទូទាំងពិភពលោកពីរភាគបីនៃមនុស្សពេញវ័យ មានប្រមាណ ៧៧៥ លាននាក់ដែលមិនចេះអាន ឬសរសេរគឺជាស្ត្រី។ នៅទូទាំងអឌ្ឍគោលខាងត្បូង មានតែនៅអាមេរិកឡាទីនទេ ដែលអត្រាអក្ខរកម្មរបស់ស្ត្រី ខិតជិតស្មើនឹងបុរស។ នៅក្នុងប្រទេសប៉ាគីស្តាន ក្មេងប្រុសបីភាគបួន ប៉ុន្តែមានចំនួនតិចជាងពាក់កណ្តាលក្មេងស្រីទទួលបានការអប់រំនៅកំរិតបឋមសិក្សា។ នៅទូទាំងអាស៊ី អាហ្វ្រិក និងមជ្ឈិមបូព៌ា (ប៉ុន្តែមិនមែននៅអាមេរិកឡាទីនទេ) មានក្មេងប្រុសកាន់តែច្រើនទទួលបានការអប់រំ ជាពិសេស នៅកម្រិតមធ្យមសិក្សា ទោះជាយ៉ាងណាក៏ដោយ គម្លាតនេះបានរួមតូចគួរអោយកត់សម្គាល់ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ។ នៅកម្រិតសាកលវិទ្យាល័យ មានតែប្រមាណ ៣០ ភាគរយនៃសិស្សនៅក្នុងប្រទេសចិន និងនៅមជ្ឈិមបូព៌ាប៉ុណ្ណោះជាស្ត្រី និងច្រើនជាង ២០ ភាគរយនៅអាស៊ីខាងត្បូង និងអាហ្វ្រិក (ប៉ុន្តែក្នុងនោះ ៤៥ ភាគរយនៅអាមេរិកឡាទីន)។ របបតាលីបង់នៅប្រទេសអាហ្វហ្គានីស្តាន(១៩៩៦-២០០១) បានចាត់វិធានការយ៉ាងខ្លាំងប្រឆាំងនឹងការអប់រំរបស់ស្ត្រី ដោយហាមឃាត់ក្មេងស្រីទាំងអស់មិនអោយទៅសាលារៀន និងស្ត្រីទាំងអស់ពីការងារដែលទទួលបានប្រាក់ខែ។

រដ្ឋនិងទីភ្នាក់ងារអន្តរជាតិបានចាប់ផ្តើមយកចិត្តទុកដាក់ក្នុងការបញ្ចប់ការរើសអើងក្នុងការសិក្សា និងធានាអោយបានសិទ្ធិរបស់ស្ត្រីក្នុងការទទួលបានការថែទាំសុខភាព និងការពន្យារកំណើត ការអប់រំម្តាយអំពី

ការសម្រាលកូន និងសុខភាពកុមារ ហើយជាទូទៅការលើកកម្ពស់ឋានៈរបស់ស្ត្រីនៅក្នុងសង្គម(បានអនុញ្ញាតអោយពួកគេមានសំឡេងកាន់តែច្រើនក្នុងការសម្រេចចិត្ត)។ ជាឧទាហរណ៍ ទីភ្នាក់ងារអន្តរជាតិជួយដល់ស្ត្រីក្នុងការរៀបចំអាជីវកម្មខ្នាតតូច កសិដ្ឋាន និងសកម្មភាពផលិតប្រាក់ចំណូលផ្សេងទៀត។ យូនីសេហ្វបានជួយដល់ស្ត្រីដើម្បីទទួលបានប្រាក់កម្ចីពីធនាគារក្នុងលក្ខខណ្ឌអំណោយផល ដើម្បីចាប់ផ្តើមអាជីវកម្មខ្នាតតូចនៅអេហ្ស៊ីប និងប៉ាគីស្ថាន ព្រមទាំងកសិដ្ឋានសហករណ៍ក្នុងប្រទេសឥណ្ឌូនេស៊ី។ ស្ត្រីជាច្រើនបានរៀបចំជាក្រុមសហករណ៍នៅទូទាំងអឌ្ឍគោលខាងត្បូង ហើយជាញឹកញាប់នៅតាមតំបន់ជនបទ ដើម្បីបង្កើតប្រាក់ចំណូលតាមរយៈការតម្បាញ និងការផលិតសម្លៀកបំពាក់ និងវាយនភណ្ឌផ្សេងៗ ដែលមានការលក់ដូរតាមហាងលក់រាយ ឬកសិកម្ម ជាដើម។ នៅតំបន់អនាធិបតេយ្យក្នុងទីក្រុង អាឌីស អាបាបា (Addis Ababa) នៃប្រទេសអេត្យូពី ស្ត្រីជាមេគ្រួសារដែលគ្មានដីសម្រាប់ធ្វើកសិកម្មចិញ្ចឹមជីវិតត្រូវបានបង្ខំអោយដើរសុំទាន និងអំពើពេស្យាចារ។ ស្ត្រីដែលចូលរួមនៅក្នុងគម្រោងអភិវឌ្ឍន៍ទីក្រុងដែលរួមបញ្ចូលវិធីសាស្ត្ររួមគ្នា បានរៀបចំអាជីវកម្មដែលបង្កើតប្រាក់ចំណូលនៅក្នុងផ្នែកនានាដូចជា ការកែច្នៃម្ហូបអាហារ ការតម្បាញក្រណាត់ និងផលិតកម្មកាត់ដេរ។ អាជីវកម្មដែលអាចរកបានប្រាក់ចំណេញទាំងនេះទទួលបានប្រាក់ចំណូលសម្រាប់ស្ត្រី និងបានជួយឧបត្ថម្ភធនទៅលើសេវាសុខភាព និងអនាម័យនៅក្នុងតំបន់អនាធិបតេយ្យ។

រូបថត ស្ត្រីនីហ្សេរីយ៉ាណែនាំអំពីគម្រោងសហគ្រិនភាព

អំណាចស្ត្រី

ស្ថានភាពរបស់ស្ត្រីនៅក្នុងបណ្តាប្រទេសនៅអឌ្ឍគោលខាងត្បូងប៉ះពាល់ដល់ការរំពឹងទុករបស់ពួកគេសម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច។ ស្ត្រីគឺជាបុគ្គលស្នូលនៃសេដ្ឋកិច្ចជនបទ យុទ្ធសាស្ត្រចំនួនប្រជាជន និងការផ្តល់តម្រូវការជាមូលដ្ឋានរបស់មនុស្ស រួមទាំងការអប់រំផងដែរ។ នៅទីនេះ ស្ត្រីនៅប្រទេសនីហ្សេរីយ៉ា ផ្តល់នូវដំណើរទេសចរណ៍ណែនាំអំពីគម្រោងសហគ្រិនភាពក្នុងសួនទីក្រុងរបស់ពួកគេ ឆ្នាំ ២០១៨។

១២.១.៥. ការធ្វើចំណាកស្រុក និងជនភៀសខ្លួន

ដំណើរការទាំងនេះគ្រាន់តែគួសបញ្ជាក់ (កង្វះតម្រូវការមូលដ្ឋាន ការដកហូតដីធ្លី ការបណ្តេញចេញពីទីលំនៅ និងនគរូបនីយកម្ម) បានឈានទៅដល់បញ្ហានយោបាយដ៏ធំបំផុតមួយដែលប៉ះពាល់ដល់ទំនាក់ទំនងអឌ្ឍគោលខាងជើងនិងខាងត្បូង៖ ការធ្វើចំណាកស្រុកពីរដ្ឋក្រីក្រទៅរដ្ឋអ្នកមាន។ មនុស្សរាប់លាននាក់មកពីអឌ្ឍគោលខាងត្បូងបានឆ្លងកាត់ព្រំដែនអន្តរជាតិ ជាញឹកញាប់ ដោយខុសច្បាប់ដើម្បីទៅដល់អឌ្ឍគោលខាងជើង។

អ្នកដែលផ្លាស់ទីទៅប្រទេសថ្មីមួយទៀត ក្នុងគោលបំណងស្វែងរកឱកាសសេដ្ឋកិច្ចល្អប្រសើរជាងមុន បរិយាកាសវិជ្ជាជីវៈនិងជីវិតរស់នៅអោយកាន់តែប្រសើរ ឬការចូលទៅកៀកជិតនឹងគ្រួសារ វប្បធម៌ ឬសាសនារបស់គេផ្សេងដែលប្រសើរជាងនេះ គឺជាការធ្វើចំណាកស្រុក (ការធ្វើចំណាកស្រុកចេញពីរដ្ឋចាស់ និងការធ្វើអន្តោប្រវេសន៍ចូលទៅកាន់រដ្ឋថ្មី)។ ការធ្វើចំណាកស្រុកបែបនេះត្រូវបានចាត់ទុកថាជាការស្ម័គ្រចិត្ត។ រដ្ឋកំណើតមិនស្ថិតនៅក្រោមកាតព្វកិច្ចណាមួយ ក្នុងការអនុញ្ញាតអោយមនុស្សបែបនេះចាកចេញទេ ហើយសំខាន់ជាងនេះទៅទៀត គ្មានរដ្ឋណាមួយត្រូវមានកាតព្វកិច្ចទទួលជនចំណាកស្រុកនោះទេ។ ដូចគ្នានឹងបញ្ហាពាណិជ្ជកម្មណាមួយដែរ ការធ្វើចំណាកស្រុកបានបង្កើតគំរូដ៏ស្មុគស្មាញថានរណាជាអ្នកឈ្នះនិងនរណាជាអ្នកចាញ់។ ជនអន្តោប្រវេសន៍តែងតែផ្តល់កម្លាំងពលកម្មថោក ដែលផ្តល់អត្ថប្រយោជន៍ដល់

សេដ្ឋកិច្ចប្រទេសម្ចាស់ផ្ទះទាំងមូល ប៉ុន្តែ ពួកគេក៏ត្រូវប្រកួតប្រជែងដណ្តើមការងារជាមួយពលរដ្ឋ(ក្រីក្រ)នៃប្រទេសម្ចាស់ផ្ទះផងដែរ។

រដ្ឋជាប្រទេសឧស្សាហូបនីយកម្ម ភាគច្រើនព្យាយាមកំណត់ការធ្វើអន្តោប្រវេសន៍ពី អឌ្ឍគោលខាងត្បូង។ ទោះបីជាមានក្រុមឆ្មាំព្រំដែននិងរបងព្រំដែនក៏ដោយ ក៏មនុស្សជាច្រើនធ្វើចំណាកស្រុកដោយខុសច្បាប់។ នៅសហរដ្ឋអាមេរិក ជនអន្តោប្រវេសន៍បែបនេះបានមកពីជុំវិញពិភពលោក ប៉ុន្តែភាគច្រើនមកពីប្រទេសជិតខាង ដូចជាម៉ិកស៊ិក អាមេរិកកណ្តាល និងតំបន់ការាបៀន។ នៅអឺរ៉ុបខាងលិច ពួកគេភាគច្រើនមកពីអាហ្វ្រិកខាងជើង ទួរគី និងស៊ីរី។ មេដឹកនាំអឺរ៉ុបខាងលិចមួយចំនួនព្រួយបារម្ភថា ការបន្ធូរបន្ថយការគ្រប់គ្រងព្រំដែន ក្រោមដំណើរការសមាហរណកម្ម (សូមមើលមេរៀនទី ១០) នឹងធ្វើអោយមានការលំបាកក្នុងការទប់ស្កាត់ជនអន្តោប្រវេសន៍ខុសច្បាប់។ ជាការពិតណាស់ អារម្មណ៍ភ័យខ្លាចចំពោះអន្តោប្រវេសន៍ គឺជាហេតុផលមួយដែលធ្វើអោយអ្នកបោះឆ្នោតនៅក្នុងប្រទេសស្វីស បានធ្វើការបដិសេធសមាជិកភាពចូលក្នុងសហភាពអឺរ៉ុប។ ក្នុងឆ្នាំ ២០០៤-២០០៦ មានប្រជាជនចំណាកស្រុក និងជនភៀសខ្លួនរាប់ម៉ឺននាក់ មកពីអនុតំបន់សាហារ៉ាអាហ្វ្រិកបានមកដល់ប្រទេសម៉ារ៉ុក ហើយបានឡើងលើរបងលួសស្តាន់ដើម្បីចូលទៅក្នុងដែនដីតូចពីររបស់អេស្ប៉ាញ នៅទីនោះ។ នៅពេលដែលនៅពួកគេស្ថិតនៅលើទឹកដីអេស្ប៉ាញ ពួកគេមិនអាចត្រូវបានគេបញ្ជូនទៅប្រទេសដើមកំណើតវិញទេ ប្រសិនបើពួកគេអាចលាក់បាំងមិនអោយអាជ្ញាធរមូលដ្ឋានសម្គាល់សញ្ជាតិរបស់ពួកគេ។ ការកើនឡើងនៃជនអន្តោប្រវេសន៍ដែលព្យាយាមចូលទៅដល់តំបន់ជុំវិញក្នុងប្រទេសម៉ារ៉ុកបានធ្វើតាមកិច្ចខិតខំប្រឹងប្រែងរបស់អេស្ប៉ាញ ដើម្បីរារាំងលំហូរជនចំណាកស្រុកឆ្លងកាត់តាមទូកពីអាហ្វ្រិកខាងជើងទៅអេស្ប៉ាញផ្ទាល់ នៅជិតច្រកសមុទ្រហ្គីប្រាលតា (Gibraltar)។ ផ្ទុយទៅវិញ នៅពេលដែលប្រទេសអេស្ប៉ាញបានបង្ក្រាបលើច្រកឆ្លងកាត់ នៅតំបន់ដែនកោះរបស់ម៉ារ៉ុក ជនជាតិអាហ្វ្រិកបានចេញទូកនិងក្បូនដើម្បីទៅដល់កោះកាណារី(Canary)ដែលជាកម្មសិទ្ធិរបស់អេស្ប៉ាញ នៅអាត្លង់ទិកដោយចេញពីប្រទេសម៉ារ៉ុក(សូមមើលឧទាហរណ៍បន្ថែមស្តីពី ការស្វែងរកផលប្រយោជន៍រួម)។

ច្បាប់អន្តរជាតិ និងទំនៀមទម្លាប់អន្តរជាតិបែងចែកជនចំណាកស្រុកខុសពី**ជនភៀសខ្លួន** ដែលសំដៅលើមនុស្សដែលភៀសខ្លួនដើម្បីស្វែងរកកន្លែងជ្រកកោនចេញពីសង្គ្រាម គ្រោះធម្មជាតិ ឬការបៀតបៀននយោបាយ។ (ការភៀសខ្លួនចេញពីអំពើរើសអើងពុំរ៉ៃអាចជាឬមិនអាចជាហេតុផលគ្រប់គ្រាន់សម្រាប់ឋានៈជាជនភៀសខ្លួន។) បទដ្ឋានអន្តរជាតិតម្រូវអោយប្រទេសនានាទទួលយកជនភៀសខ្លួនដែលមកដល់ព្រំដែនរបស់ពួកគេ។ ជនភៀសខ្លួនចេញពីសង្គ្រាម ឬគ្រោះមហន្តរាយធម្មជាតិ ជាទូទៅ ត្រូវបាននាំអោយស្នាក់នៅក្នុងជំរុំជនភៀសខ្លួនជាបណ្តោះអាសន្ន រហូតដល់ពួកគេអាចត្រឡប់ទៅប្រទេសកំណើតវិញ (ទោះបីជាការស្នាក់នៅរបស់ពួកគេអាចអូសបន្លាយជាច្រើនឆ្នាំក៏ដោយ)។ ជនភៀសខ្លួនពីការបៀតបៀននយោបាយអាចត្រូវបានផ្តល់សិទ្ធិជ្រកកោនអោយស្នាក់នៅក្នុងរដ្ឋថ្មី។ ការទទួលយកជនភៀសខ្លួន (និងសំណួរថាតើរដ្ឋមួយណាដែលត្រូវទទួលបន្ទុកចំណាយ) គឺជាដំណោះស្រាយបញ្ហាផលប្រយោជន៍រួម។

បញ្ហានេះបានឈានដល់ចំណុចក្តៅនៅក្នុងឆ្នាំ ២០១៥ នៅពេលដែលជនភៀសខ្លួនរាប់ម៉ឺននាក់មកពីប្រទេសទុយនីស៊ី និងលីប៊ីបានហូរចូលទៅក្នុងប្រទេសអ៊ីតាលី ដែលពួកគេអាចឆ្លងកាត់ ដោយសេរីទៅកាន់បណ្តាប្រទេសនៅអឺរ៉ុបក្បែរៗនោះ។ ជនចំណាកស្រុករាប់ពាន់នាក់បានស្លាប់បាត់បងជីវិតនៅក្នុងទូកដែលពួកគេបានភៀសខ្លួនឆ្លងសមុទ្រមេឌីទែរ៉ាណេ ខណៈដែលជនភៀសខ្លួនរាប់រយនាក់ផ្សេងទៀតត្រូវរងទុក្ខ

បុកម្ជិញក្រោមកណ្តាប់ដៃអ្នករត់ពន្ធមនុស្ស ដែលជារឿយៗទុកពួកគេ និងបោះបង់ចោល (ឬអាក្រក់ជាងនេះក៏មាន)ជាជនអន្តោប្រវេសន៍ខុសច្បាប់។ បណ្តារដ្ឋនៅអឺរ៉ុបកណ្តាលដូចជាហុងគ្រីក៏បានប្រឈមមុខនឹងរលកនៃជនភៀសខ្លួន ដែលភៀសខ្លួនចេញពីជម្លោះនៅតំបន់មជ្ឈិមបូព៌ា ខណៈដែលមេដឹកនាំសហភាពអឺរ៉ុបបានជជែកវែកញែកយ៉ាងក្តៀវក្តាអំពីរបៀបដោះស្រាយលំហូរជនចំណាកស្រុកចូលទៅក្នុងទ្វីបអឺរ៉ុប។

ចំនួនជនភៀសខ្លួនអន្តរជាតិនៅលើពិភពលោកមានចំនួនជាង ១៥ លាននាក់ ក្នុងឆ្នាំ ២០១៤។ ប្រហែល ៣០ លាននាក់ផ្សេងទៀត ត្រូវបានផ្លាស់ទីឬបណ្តេញចេញពីទីលំនៅ ពីកន្លែងមួយទៅកន្លែងមួយទៀតនៅក្នុងប្រទេសរបស់ពួកគេ។ បីភាគបួននៃជាជនភៀសខ្លួននៅក្នុងផ្ទៃប្រទេសបែបនេះ (IDPs) រស់នៅក្នុងប្រទេសកូឡុំប៊ី កុងហ្គោ សូម៉ាលី ស៊ូដង់ អ៊ីរ៉ាក់ អាហ្វហ្គានីស្ថាន និងស៊ីរី។ ជនភៀសខ្លួនប៉ាឡេស្ទីន ៥ លាននាក់បន្ថែមទៀត ស្ថិតនៅក្រោមការទទួលខុសត្រូវផ្តាល់របស់ *ទីភ្នាក់ងារជំនួយនិងការងាររបស់អង្គការសហប្រជាជាតិ* (UNRWA)។ ជនភៀសខ្លួន និងជនចំណាកស្រុកភាគច្រើនត្រូវបានផ្លាស់ទីលំនៅដោយសង្គ្រាម (សូមមើលតារាង ១២.២) ដូចជាក្នុងពេលថ្មីៗនេះ ជាការភៀសខ្លួនដោយសង្គ្រាមស៊ីវិល នៅក្នុងប្រទេសស៊ីរី ដែលនៅឆ្នាំ ២០១៥ បានបង្កើតជនភៀសខ្លួនចំនួន ៣ លាននាក់នៅក្នុងប្រទេសទួរគី នៅលីបង់ អ៊ីរ៉ាក់ និងហ្សកដានី និង ៦,៥ លាននាក់ ផ្លាស់ទីឬបណ្តេញចេញពីទីលំនៅនៅក្នុងផ្ទៃប្រទេសខ្លួន ដែលគ្រប់គ្នាជាទូទៅសុទ្ធតែបានគេចចេញពីអំពើហិង្សា និងជាពិសេសគេចចេញពីអំពើហិង្សាផ្លូវភេទ។

តារាង ១២.២ ចំនួនប្រជាជនភៀសខ្លួនឆ្នាំ ២០១៧

តំបន់	លាននាក់	ប្រមូលផ្តុំនៅក្នុងប្រទេស
មជ្ឈឹមបូព៌ា	២២	អ៊ីរ៉ាក់ ស៊ីរី អ៊ីរង់ ទួរគី
អាស៊ី	៨	អាហ្វហ្គានីស្ថាន ប៉ាគីស្ថាន ភូមា
ប៉ាឡេស្ទីនក្រោមទីភ្នាក់ងារ UNRWA	៥	ប៉ាឡេស្ទីន ហ្សកដានី លីបង់
អាហ្វ្រិក	២១	នីហ្សេរីយ៉ា សូម៉ាលី អ៊ុយហ្គាន់ដា ស៊ូដង់ សា.កុងហ្គោ
អាមេរិកខាងត្បូង	៩	កូឡុំប៊ី សហរដ្ឋអាមេរិក
អឺរ៉ុប	៧	អាឡឺម៉ង់ អ៊ុយក្រែន
ពិភពលោកសរុប	៧២	

ប្រភព៖ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន(UNHCR)។ ត្រូវរួមបញ្ចូលក្នុងនេះគឺ ជនភៀសខ្លួន អ្នកស្វែងរកសិទ្ធិជ្រកកោន ជនភៀសខ្លួនដែលវិលត្រឡប់មកវិញ និងជនភៀសខ្លួនផ្ទៃក្នុងប្រទេស។

ឥទ្ធិពលនយោបាយរបស់ជនភៀសខ្លួនត្រូវបានគូសបញ្ជាក់ម្តងហើយម្តងទៀត។ បញ្ហាជនភៀសខ្លួនដែលមាននិន្នាការនយោបាយខ្លាំងបំផុត អស់រយៈពេលជាច្រើនទសវត្សរ៍មកហើយ គឺជនជាតិប៉ាឡេស្ទីនដែលផ្លាស់ទីលំនៅ ក្នុងសង្គ្រាមអារ៉ាប់-អ៊ីស្រាអែលឆ្នាំ ១៩៤៨ និង ១៩៦៧ (និងកូន ។ និងចៅ។រៀបស់ពួកគេ)។ ពួកគេរស់នៅក្នុង«ជំរុំ»ដែលបានក្លាយជាសង្កាត់អស់រយៈពេលវែង ដែលភាគច្រើននៅហ្សកដានី លីបង់ និងនៅក្នុងទឹកដីប៉ាឡេស្ទីននៃតំបន់ហ្គាហ្សា (Gaza) និងវ៉ែសបែង (West Bank)។ ផ្ទុយមកវិញ ភាពក្រីក្ររបស់ជនភៀសខ្លួន បានជំរុញអោយមានចលនានយោបាយជ្រុលនិយម ក្នុងចំណោមប្រជាជនក្នុងស្រុក។ សំណួរអំពីសិទ្ធិរបស់ជនភៀសខ្លួនប៉ាឡេស្ទីនក្នុងការវិលត្រឡប់ទៅកាន់កន្លែងដែលពេលនេះ នៅក្នុង

ប្រទេសអ៊ីស្រាអែល បានរារាំងរាល់ការប៉ុនប៉ងក្នុងដំណោះស្រាយសន្តិភាពដ៏ទូលំទូលាយ អស់រយៈពេលជាច្រើនឆ្នាំមកហើយ។

វាមិនតែងតែងាយស្រួលក្នុងការបែងចែកជនភៀសខ្លួន ដែលភៀសខ្លួនចេញពីសង្គ្រាមឬការបៀតបៀននយោបាយ ពីជនចំណាកស្រុកដែលស្វែងរកឱកាសសេដ្ឋកិច្ចល្អប្រសើរនោះទេ។ ជនអន្តោប្រវេសន៍ខុសច្បាប់អាចអះអាងថា ពួកគេជាជនភៀសខ្លួន ដើម្បីទទួលបានការអនុញ្ញាតអោយស្នាក់នៅ នៅពេលដែលពួកគេកំពុងស្វែងរកឱកាសសេដ្ឋកិច្ចកាន់តែប្រសើរជាងមុន។ ក្នុងប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ បញ្ហានេះបានក្លាយជាបញ្ហាធំមួយនៅទូទាំងប្រទេសក្នុងអឌ្ឍគោលខាងជើង។ នៅប្រទេសអាឡឺម៉ង់ បារាំង អូទ្រីស និងកន្លែងផ្សេងទៀត ការអាក់អន់ចិត្តនិងមិនសប្បាយចិត្តចំពោះជនអន្តោប្រវេសន៍បរទេស បានជំរុញអោយមានការកើនឡើងនៃលទ្ធិជាតិនិយម-ស្តាំនិយម នៅក្នុងនយោបាយក្នុងស្រុក។

រូបថត

កំពុងផ្លាស់ទី

ជនភៀសខ្លួនគឺជាលទ្ធផលនៃជម្លោះអន្តរជាតិ និងជាប្រភពនៃជម្លោះ។ បន្ថែមពីលើអ្នកដែលរត់គេចពីសង្គ្រាមនិងការគាបសង្កត់និងអ្នកស្វែងរកឱកាសសេដ្ឋកិច្ចប្រសើរ មនុស្សរាប់រយពាន់នាក់ក្នុងមួយឆ្នាំៗឆ្លងព្រំដែនជាទាសករផ្លូវភេទនិងពលកម្ម។ ជនភៀសខ្លួនទាំងនេះកំពុងចាកចេញពីប្រទេសហុងគ្រី ដែលទំនងជាភ្ជាប់ទៅនឹងប្រទេសអាល្លឺម៉ង់ ឬ អូទ្រីស នៅក្នុងឆ្នាំ ២០១៥។ ហុងគ្រីបានក្លាយជាប្រទេសឆ្លងកាត់ដ៏សំខាន់សម្រាប់អ្នកដែលភៀសខ្លួនចេញពីប្រទេសស៊ីរី។


ប្រាក់បញ្ជើរទៅស្រុក

ទិដ្ឋភាពដ៏សំខាន់មួយនៃការធ្វើចំណាកស្រុកចេញនិងការធ្វើអន្តោប្រវេសន៍ចូល គឺប្រាក់បញ្ជើរទៅស្រុកកំណើត (ប្រាក់ដែលបានផ្ញើទៅអ្នកផ្ទះដោយជនចំណាកស្រុក ទៅកាន់សាច់ញាតិនៅក្នុងប្រទេសដើមកំណើតរបស់ពួកគេ)។ វាគឺជាប្រភពចំណូលដ៏សំខាន់សម្រាប់ប្រទេសក្រីក្រជាច្រើន។ ប្រាក់បញ្ជើរទៅស្រុកកំណើតមានសារៈសំខាន់សម្រាប់រដ្ឋ នៅក្នុងតំបន់ជាច្រើននៃពិភពលោក។ ក្នុងឆ្នាំ ២០១៤ ការផ្ញើរឬផ្ញើរប្រាក់នៅទូទាំងពិភពលោក មានប្រមាណជិត ៦០០ ពាន់លានដុល្លារ បន្ទាប់មកកើនឡើងដល់បីដង ក្នុងទសវត្សរ៍ថ្មីៗនេះ និងមានទំហំធំជាងជំនួយបរទេស ចំនួន ៣ ដង នេះបើយោងតាមទិន្នន័យធនាគារពិភពលោក (ដែលកត់សម្គាល់ថាតួលេខជាក់ស្តែងពិតអាចមានកម្រិតខ្ពស់ជាងនេះ)។

ប្រាក់បញ្ជើរទៅស្រុកកំណើតកំពុងក្លាយជាផ្នែកសំខាន់ កាន់តែខ្លាំងឡើងៗ នៃសេដ្ឋកិច្ចពិភពលោក (សូមមើលក្រាហ្វិក ១២.៥)។ មិនដូចការវិនិយោគផ្ទាល់ពីបរទេស (FDI) នោះទេ ប្រាក់បញ្ជើរទៅស្រុកមិនត្រូវបានផ្ញើរ រវាងក្រុមហ៊ុនឬបុគ្គលដែលមានទ្រព្យសម្បត្តិនោះទេ ប៉ុន្តែ ជាធម្មតា វាគឺជាការផ្ញើរប្រាក់រវាងសមាជិកគ្រួសារ។ ដូច្នេះ ការផ្ញើរប្រាក់មិនអាចកាត់ពីសេដ្ឋកិច្ចអ្នកទទួលបានទេ។ វាក៏មិនមែនជាប្រាក់ដែលត្រូវបានផ្តល់ដោយរដ្ឋាភិបាលនោះដែរ ដូច្នេះ វាមិនស្ថិតនៅក្នុងអំពើពុករលួយ ឬការចាយវាយខ្ជះខ្ជាយរបស់រដ្ឋាភិបាលឡើយ។ ម្យ៉ាងវិញទៀត ខុសពីជំនួយបរទេស ប្រាក់បញ្ជើរទៅស្រុកមិនស្ថិតក្រោមលក្ខខណ្ឌពីម្ចាស់ជំនួយទេ។ វាត្រូវបានផ្តល់អោយដោយសេរី ពីគ្រួសារមួយទៅគ្រួសារមួយ។ លក្ខណៈនៃការផ្ញើរប្រាក់ទាំងនេះ (ក៏ដូចជាទំហំធំឡើងៗរបស់វា) ធ្វើអោយវាមានសារៈសំខាន់ ប៉ុន្តែក៏ពិបាកក្នុងការសិក្សាផងដែរ។

ក្រាហ្វិក ១២.៥ លំហូរសេកលនៃប្រាក់បញ្ជើរទៅស្រុក ឆ្នាំ ១៩៧០-២០១៦

ប្រភព៖ ការគណនារបស់ធនាគារពិភពលោក។



ប្រាក់បញ្ញើរទៅស្រុកបានជួយដល់រដ្ឋនានានៅអឌ្ឍគោលខាងត្បូង។ វាបានផ្តល់ជាប្រាក់ចំណូលដល់គ្រួសារដែលមានជីវភាពក្រីក្រ។ វាបានជួយរដ្ឋក្រីក្រមួយចំនួន ដូចជា ប្រទេសហ្វីលីពីន និងបង់ក្លាដែស ធ្វើអោយប្រសើរឡើងនូវចំណាត់ថ្នាក់នៃការវិនិយោគរបស់ពួកគេ និងលក់មូលបត្របំណុល ដោយទាក់ទាញការវិនិយោគផ្ទាល់ពីបរទេសកាន់តែច្រើន។ ទោះជាយ៉ាងណាក៏ដោយ កម្រិតឬទំហំនៃប្រាក់បញ្ញើរទៅស្រុក ងាយរងប៉ះពាល់ខ្លាំងពីការធ្លាក់ចុះសេដ្ឋកិច្ច នៅក្នុងប្រទេសអ្នកមាន។ ប្រាក់បញ្ញើរទៅស្រុកក៏បន្តវដ្តនៃការពឹងអាស្រ័យរបស់រដ្ឋក្រីក្រលើប្រទេសអ្នកមាន។ ប្រសិនបើប្រទេសអ្នកមានបិទព្រំដែនរបស់ពួកគេ ឬបណ្តេញប្រជាជនចំណាកស្រុក វានឹងបង្កើតការលំបាកសម្រាប់គ្រួសារនីមួយ។ ក៏ដូចជាសេដ្ឋកិច្ចនៃប្រទេសកំពុងអភិវឌ្ឍន៍។

ការជួញដូរ

បន្ថែមពីលើការធ្វើចំណាកស្រុកនិងចំនួនជនភៀសខ្លួន កំណើនចំនួនមនុស្ស (ដែលត្រូវប៉ាន់ប្រមាណថាមានប្រហែល ៧០០០០០ នាក់ ក្នុងមួយឆ្នាំ។) ត្រូវបានគេជួញដូរឆ្លងកាត់ព្រំដែនអន្តរជាតិប្រឆាំងនឹងឆន្ទៈរបស់ពួកគេ។ ពួកគេរួមបញ្ចូលទាំងទាសកររួវភេទ និងទាសករការងារ ដោយប្រភេទនីមួយៗរួមមានស្ត្រីនិងបុរស មនុស្សពេញវ័យនិងកុមារ។ ប្រហែលជា ២០០០០ នៃមនុស្សទាំងនេះ ត្រូវបានជួញដូរទៅរស់នៅក្នុងសហរដ្ឋអាមេរិកជារៀងរាល់ឆ្នាំ។ ក្នុងឆ្នាំ ២០១៤ ក្រសួងការបរទេសសហរដ្ឋអាមេរិកបានចុះបញ្ជីប្រទេសចំនួន ២៣ ដែលខិតខំប្រឹងប្រែងមិនបានគ្រប់គ្រាន់ ក្នុងការបញ្ឈប់ការជួញដូរមនុស្ស រួមទាំងរដ្ឋជាមិត្ត ដូចជា គុយវ៉ែត ម៉ាឡេស៊ី ថៃ និងអារ៉ាប៊ីសាអូឌីត។

ជាទូទៅ ការធ្វើចំណាកស្រុកគ្រប់រូបភាព ពីអឌ្ឍគោលខាងត្បូងទៅអឌ្ឍគោលខាងជើង បានបង្កើតបញ្ហាសម្រាប់រដ្ឋឧស្សាហូបនីយកម្ម ដែលវាហាក់បីដូចជា អាចដោះស្រាយបាន ដោយគ្រាន់តែដោះស្រាយបញ្ហារបស់អឌ្ឍគោលខាងត្បូងប៉ុណ្ណោះ។

១២.២. ទ្រឹស្តីប្រមូលទ្រព្យសម្បត្តិ

១២.២ ចូរផ្តល់ឧទាហរណ៍អំពីរដ្ឋនានាដែលទ្រឹស្តីនៃប្រព័ន្ធពិភពលោកចាត់ទុកថាជារដ្ឋស្នូល(core) រដ្ឋជាយក្រុង(semi-periphery) និងរដ្ឋជនបទ(periphery)។

តើយើងអាចធ្វើការពន្យល់ពីគម្លាតដ៏ធំ រវាងកម្រិតប្រាក់ចំណូលក្នុងតំបន់ឧស្សាហ៍កម្មនៅពិភពលោក និងនៅក្នុងអឌ្ឍគោលខាងត្បូងដោយរបៀបណា? តើគម្លាតបែបនោះប៉ះពាល់អ្វីខ្លះដល់នយោបាយអន្តរជាតិ? មានវិធីសាស្ត្រផ្សេងៗគ្នាជាច្រើន ដើម្បីឆ្លើយតបនឹងសំណួរទាំងនេះ យើងនឹងផ្តោតលើទ្រឹស្តីពីរផ្ទុយគ្នាអំពីការប្រមូលទ្រព្យសម្បត្តិ ដោយផ្អែកលើទស្សនៈសេរីនិយម និងទស្សនៈបដិវត្តន៍។

១២.២.១. ការប្រមូលផ្តុំសេដ្ឋកិច្ច

ការសម្លឹងមើលបញ្ហាពីទស្សនៈមូលធននិយមត្រូវផ្អែកលើសេដ្ឋកិច្ចសេរីនិយម ដែលសង្កត់ធ្ងន់លើប្រសិទ្ធភាពរួមគ្នា ក្នុងការបង្កើន*កំណើនសេដ្ឋកិច្ច*ជាអតិបរមា។ ទិដ្ឋភាពនេះមើលឃើញថា អឌ្ឍគោលខាងត្បូងដើរតាមក្រោយអឌ្ឍគោលខាងជើងដែលមានឧស្សាហ៍កម្មខ្លាំងក្លា។ ការបង្កើតទ្រព្យសម្បត្តិបន្ថែមទៀតនៅអឌ្ឍគោលខាងជើងគឺជារឿងល្អមួយ ក៏ដូចជាការបង្កើតទ្រព្យសម្បត្តិនៅអឌ្ឍគោលខាងត្បូងដែរ ពោលគឺអ្នកទាំងពីរមិនមានជម្លោះទេ។

ទស្សនៈផ្សេងមួយទៀត ពីទស្សនៈនៃសង្គមនិយម ទាក់ទងនឹងការបែងចែកទ្រព្យសម្បត្តិ ដូចជាការបង្កើតទ្រព្យសម្បត្តិជាច់ខាត។ វាជាការបង្ហាញអោយឃើញពីការបែងចែករវាងអឌ្ឍគោលខាងជើង-ខាងត្បូង ហាក់ដូចជាល្បែងផលបូកស្មើសូន្យ ដែលការបង្កើតទ្រព្យសម្បត្តិនៅអឌ្ឍគោលខាងជើងជាញឹកញាប់បំផុតកើតឡើងបាន ដោយសារការខាតបង់របស់អឌ្ឍគោលខាងត្បូង។ វាផ្តល់តួនាទីកាន់តែច្រើនអោយវិស័យនយោបាយ(រដ្ឋ)ក្នុងការបែងចែកទ្រព្យសម្បត្តិ និងការគ្រប់គ្រងសេដ្ឋកិច្ច ជាជាងមូលធននិយម។ ដូច្នេះសង្គមនិយមមានភាពស្របគ្នានឹងលទ្ធិគាំពារនិយម(mercantilism)ក្នុងទិដ្ឋភាពមួយចំនួន។ ប៉ុន្តែ អ្នកសង្គមនិយមមើលឃើញថា ផ្នែកសេដ្ឋកិច្ចជាតួអង្គសំខាន់ជាងរដ្ឋក្នុងការចរចានយោបាយជុំវិញការបែងចែកទ្រព្យសម្បត្តិរបស់ពិភពលោក។ ដូចច្នេះហើយ លទ្ធិគាំពារនិយមបានលើកកម្ពស់គំនិតនៃការប្រមូលផ្តុំទ្រព្យសម្បត្តិ(ជាធាតុនៃអំណាច) ចំណែកសង្គមនិយមលើកកម្ពស់ការបែងចែកទ្រព្យសម្បត្តិកាន់តែទូលំទូលាយ។

រូបថត វាយនភណ្ឌបង់ក្លាដែសកំពុងរៀបចំនាំចេញក្នុងឆ្នាំ ២០១៤

បច្ចេកវិទ្យាទាប

ផលិតកម្មនៅអឌ្ឍគោលខាងត្បូងប្រើប្រាស់ដើមទុនតិចតួច និងកម្លាំងពលកម្មច្រើន (ប្រាក់ឈ្នួលកម្រិតទាប) ដែលឆ្លុះបញ្ចាំងពីដំណាក់កាលដំបូងនៃឧស្សាហូបនីយកម្ម។ ដើម្បីអភិវឌ្ឍសេដ្ឋកិច្ច ប្រទេសក្រីក្រត្រូវបង្កើតមូលធនដែលទ្រទ្រង់ដោយខ្លួនឯង។ កសិកម្ម ថាមពល និងវាយនភណ្ឌ គឺជាផលិតផលនាំចេញបុរាណពីពិភពលោកខាងត្បូង៖ វាត្រូវការដើមទុនតិច និងប្រើកម្លាំងពលកម្មច្រើន។ នៅក្នុងប្រទេសបង់ក្លាដែស វាយនភណ្ឌបែបនេះដែលត្រូវបានរៀបចំសម្រាប់ការនាំចេញក្នុងឆ្នាំ ២០១៤ គឺជាប្រភពចំណូលដ៏សំខាន់នៃការនាំចេញ។

សម្រាប់សង្គមនិយម ការដោះដូរជាអន្តរជាតិត្រូវបានរួមតូច ដោយការកេងប្រវ័ញ្ចកម្លាំងពលកម្មដែលមានតម្លៃថោកនិងធនធានក្នុងតម្លៃទាបរបស់ពួកមូលធននិយម ដោយពួកគេបានប្រើប្រាស់រដ្ឋនានាដើម្បីជួយបង្កើតលក្ខខណ្ឌនយោបាយអំណោយផលសម្រាប់ការកេងប្រវ័ញ្ចនេះ។ (សង្គមនិយមខ្លះផ្តោតលើកម្មករនៅក្នុងប្រទេសក្រីក្រ ខ្លះទៀតផ្តោតលើកម្មកររនៅក្នុងប្រទេសឧស្សាហូបនីយកម្មរុងរឿង និងខ្លះទៀតផ្តោតលើប្រទេសទាំងពីរ។) ដូច្នេះហើយ ខណៈពេលដែលអ្នកគាំពារនិយមមើលឃើញផលប្រយោជន៍នយោបាយ (របស់រដ្ឋ) ថាជាការជំរុញគោលនយោបាយសេដ្ឋកិច្ច អ្នកសង្គមនិយមមើលឃើញផលប្រយោជន៍សេដ្ឋកិច្ច (របស់ពួកមូលធននិយមនិងរបស់កម្មករ) ថាជាការជំរុញគោលនយោបាយ។ នៅអាមេរិកឡាទីន ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ រដ្ឋជាច្រើនបានជ្រើសរើសប្រធានាធិបតីឆ្វេងនិយម ដែលបានប្តេជ្ញាចិត្តក្នុងការផ្លាស់ប្តូរមាគ៌ាឆ្ងាយពីមូលធននិយមទីផ្សារសេរី ដោយឆ្ពោះទៅរកទស្សនៈវិជ្ជាសង្គមនិយម ជាមួយនឹងឧស្សាហកម្មរបស់រដ្ឋកាន់តែច្រើន។ ប្រទេសទាំងនេះរួមមាន វេណេហ្ស៊ុយអេឡា បូលីវី អេក្វាឌ័រ និងនីការ៉ាហ្គា។

គោលការណ៍មូលធននិយមនិងសង្គមនិយមមានភាពមិនស៊ីគ្នា នៅក្នុងភាសានិងការសន្មត់អំពីបញ្ហានៃភាពក្រីក្រនិងផលប៉ះពាល់ជាអន្តរជាតិរបស់វា។ មេរៀននេះមានទំនោរទៅកាន់គោលការណ៍សង្គមនិយមដោយផ្តោតលើប្រវត្តិសាស្ត្រពីអតីតកាលនៃចក្រពត្តិនិយម ដែលជាបុព្វហេតុដ៏ចម្បងនៃការបែងចែករវាងអឌ្ឍគោលខាងជើងនិងខាងត្បូង និងផ្តោតលើយុទ្ធសាស្ត្របដិវត្តន៍ និងការបែងចែកទ្រព្យសម្បត្តិដ៏សម្បើមឡើងវិញសម្រាប់ជាដំណោះស្រាយបញ្ហាបែងចែក។ ផ្ទុយទៅវិញ មេរៀនទី ១៣ យើងនឹងបានស្វែងយល់ពីគោលការណ៍មូលធននិយមសម្រាប់ដោះស្រាយបញ្ហាដូចគ្នា។

តាមពិត គ្មានរដ្ឋណាជាអ្នកមូលធននិយមសុទ្ធសាធនោះទេ។ រដ្ឋស្ទើរតែទាំងអស់មានទម្រង់សេដ្ឋកិច្ចចម្រុះ ដែលរួមមានទាំងកម្មសិទ្ធិឯកជននិងរដ្ឋ។ នៅក្នុងប្រទេសមូលធននិយមភាគច្រើន តួអង្គរដ្ឋាភិបាលបានធ្វើអោយមានតុល្យភាពផ្នែកខាងអមនុស្សធម៌នៃមូលធននិយម ដោយបែងចែកទ្រព្យសម្បត្តិមួយចំនួនឡើងវិញ។ រដ្ឋដែលមានសុខភាពសេដ្ឋកិច្ចល្អ ផ្តល់សុខុមាលភាព ការអប់រំ អត្ថប្រយោជន៍សុខភាពមួយចំនួនសុខុមាលភាពសម្រាប់ជនក្រីក្រជាដើម។ នៅក្នុងវិបត្តិហិរញ្ញវត្ថុ ឆ្នាំ ២០០៨-២០០៩ ប្រទេសដែលមានសេដ្ឋកិច្ចមូលធននិយមធំជាងគេមួយចំនួន រួមទាំងសហរដ្ឋអាមេរិក និងចក្រភពអង់គ្លេស បានរកឃើញថាពួកគេចំណាយប្រាក់ដើម្បីទិញចំណែករបស់ក្រុមហ៊ុនឯកជន ដូចជាក្រុមហ៊ុនធានាវ៉ាប់រង ក្រុមហ៊ុនផលិតរថយន្ត និងធនាគារ ដើម្បីកុំអោយអាជីវកម្មទាំងនេះដើរទៅរកភាពក្សីយធន។

ការអភិវឌ្ឍន៍សេដ្ឋកិច្ចគឺផ្អែកលើ*ការប្រមូលមូលធន* (capital accumulation) ដែលជាការបង្កើតអចលនទ្រព្យ(ដើមទុន) ដូចជាអគារ ផ្លូវថ្នល់ និងរោងចក្រ។ ដើម្បីធ្វើអោយជីវភាពប្រជាពលរដ្ឋ និងដើមទុនកើនឡើង ពួកគេត្រូវបង្កើតអតិរេកសេដ្ឋកិច្ច ដោយប្រើដើមទុនដើម្បីផលិតដើមទុនបន្ថែម។ កត្តានេះត្រូវបានអនុវត្តដោយការវិនិយោគប្រាក់ នៅក្នុងក្រុមមូលធនដែលជាអ្នកផលិត ជាជាងការប្រើប្រាស់វាសម្រាប់ការប្រើប្រាស់។ អតិរេកសេដ្ឋកិច្ចកាន់តែច្រើនធនធានកាន់តែច្រើន អាចរកបានសម្រាប់ការវិនិយោគលើសពីកម្រិតអប្បបរមានៃការប្រើប្រាស់ដែលត្រូវការដើម្បីទ្រទ្រង់ជីវិតមនុស្ស។

បដិវត្តន៍ឧស្សាហកម្មជាច្រើនសតវត្សមុនបានពន្លឿនដំណើរការនៃការប្រមូលផ្តុំពិភពលោកយ៉ាងខ្លាំងដោយទាញយកថាមពលដ៏ច្រើនពីឥន្ធនៈហ្វូស៊ីល។ ប៉ុន្តែឧស្សាហូបនីយកម្មបង្កើយអោយមានគម្លាត

យ៉ាងខ្លាំងពីតំបន់ពិភពលោកមួយទៅតំបន់មួយទៀត។ រដ្ឋនៅអឌ្ឍគោលខាងជើងប្រមូលបានផលប្រយោជន៍និងដើមទុនបានយ៉ាងសម្បើម។ ទោះបីជាអឌ្ឍគោលខាងត្បូងបង្កើតនូវទ្រព្យសម្បត្តិច្រើន និងមានច្រកនៃការប្រមូលផ្តុំជាច្រើនក៏ដោយ នៅក្នុងតំបន់ភាគច្រើន វានៅតែជាសេដ្ឋកិច្ចបុរេឧស្សាហកម្ម ដូចជាមូលហេតុដែលអឌ្ឍគោលខាងជើងប្រើប្រាស់ថាមពលពាណិជ្ជកម្មក្នុងមនុស្សម្នាក់ៗ ប្រហែលដប់ដងច្រើនជាងប្រជាជននៅអឌ្ឍគោលខាងត្បូង (សូមមើលតារាង ១១.១)។

បច្ចេកវិទ្យាព័ត៌មាននាពេលបច្ចុប្បន្ននេះកំពុងធ្វើអោយហេដ្ឋារចនាសម្ព័ន្ធ ហាក់មិនសូវសំខាន់នៅក្នុងប្រទេសដែលមានសេដ្ឋកិច្ចជឿនលឿន។ ប្រទេសនានានៅក្នុងអឌ្ឍគោលខាងត្បូងប្រហែលជាត្រូវឆ្លងកាត់ដំណាក់កាលលំបាកសម្រាប់ឧស្សាហូបនីយកម្ម ដូចដែលប្រទេសនៅអឌ្ឍគោលភាគខាងជើងធ្លាប់បានធ្វើ ឬប្រហែលជាពួកគេអាចអភិវឌ្ឍសេដ្ឋកិច្ចតាមគន្លងផ្សេងៗគ្នា ដោយចាប់ផ្តើមប្រើបច្ចេកវិទ្យាថ្មី។ បញ្ហាគឺថា ដូចជាហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្មភាគច្រើន មានទីតាំងនៅអឌ្ឍគោលភាគខាងជើង ហេដ្ឋារចនាសម្ព័ន្ធព័ត៌មានរបស់ពិភពលោកក៏ដូចគ្នាដែរ (សូមមើលមេរៀនទី ១០)។ ខណៈពេលដែលនិស្សិត នៅក្នុងប្រទេសឧស្សាហូបនីយកម្មមួយជំនាន់ ដំណើរការលើការប្រើប្រាស់អ៊ីនធឺរណែតប្រទេសក្រីក្រនៅតែតស៊ូដើម្បីពង្រីកអក្ខរកម្មដល់ប្រជាជននៅតាមទីជនបទ នៅឡើយ។

១២.២.២. ប្រព័ន្ធពិភពលោក

អ្នកប្រាជ្ញទំនាក់ទំនងអន្តរជាតិមួយចំនួន មើលឃើញប្រព័ន្ធសកលនៃការបែងចែកតំបន់នានាថាជា **ប្រព័ន្ធពិភពលោក** (world-system) ឬ *សេដ្ឋកិច្ចពិភពលោកបែបមូលធននិយម* (capitalist world economy)។ ទស្សនៈនេះមានទំនោរតាមម៉ាក្សស៊ីសនិយម (ផ្តោតលើវណ្ណៈសេដ្ឋកិច្ច សូមមើលមេរៀនទី ៣) ហើយពឹងផ្អែកលើកម្រិតវិភាគសកល។ នៅក្នុងប្រព័ន្ធពិភពលោក ការបែងចែកថ្នាក់ឬវណ្ណៈរដ្ឋត្រូវបានធ្វើឡើងតាមតំបន់នីមួយៗ។ តំបន់នៅអឌ្ឍគោលខាងត្បូងភាគច្រើនទាញយកវត្ថុធាតុដើម (រួមទាំងកសិកម្ម) ដែលជាការងារដែលប្រើប្រាស់កម្លាំងពលកម្មច្រើន និងដើមទុនតិចតួចបំផុត ហើយផ្តល់ប្រាក់ឈ្នួលទាប។ តំបន់ឧស្សាហកម្មភាគច្រើនជាអ្នកផលិតទំនិញ ដែលការងារដែលប្រើដើមទុនកាន់តែច្រើន ហើយត្រូវការកម្លាំងពលកម្ម*ជំនាញ*កាន់តែច្រើន និងផ្តល់ប្រាក់ឈ្នួលខ្ពស់ដល់កម្មករ។ តំបន់ផលិតទំនិញឧស្សាហកម្មត្រូវបានគេហៅថាជាតំបន់*ស្នូល* (ឬ*មជ្ឈមណ្ឌលកណ្តាល*) នៃប្រព័ន្ធពិភពលោក។ តំបន់ទាញយកវត្ថុធាតុដើមត្រូវបានគេហៅថាជាតំបន់បរិវេណឬ*តំបន់ជនបទ*។

កំរិតនៃបញ្ហាសំខាន់បំផុតនាពេលបច្ចុប្បន្ននេះ តាមទស្សនៈនេះគឺថារវាងស្នូល និងទំហំនៃប្រព័ន្ធពិភពលោក។ តំបន់ស្នូលនៃពិភពលោកប្រើថាមពល (បានមកពីទ្រព្យសម្បត្តិរបស់វា) ដើម្បីប្រមូលផ្តុំអតិរេកពីតំបន់ជាយក្រុង ដូចដែលវាបានធ្វើប្រហែល ៥០០ ឆ្នាំមកហើយ។ ជម្លោះរវាងប្រទេសមហាអំណាច រួមទាំងសង្គ្រាមលោកទាំងពីរ និងសង្គ្រាមត្រជាក់ ជាមូលដ្ឋានមកពីការប្រកួតប្រជែងក្នុងចំណោមរដ្ឋស្នូល ជុំវិញសិទ្ធិក្នុងការកេងប្រវ័ញ្ចនៅក្នុងរដ្ឋជនបទ។

រដ្ឋស្នូលនិងរដ្ឋជនបទមិនត្រូវបានកំណត់ច្បាស់លាស់ទេ។ នៅរដ្ឋជនបទ ក៏មានមជ្ឈមណ្ឌល និងបរិវេណឬជនបទផងដែរ (ឧទាហរណ៍ ទីក្រុង Rio de Janeiro បើប្រៀបធៀបនឹងព្រៃអាម៉ាហ្សូន) ដោយសារវាមានតំបន់ស្នូល (ដូចជាទីក្រុងញូវយ៉ក ធៀបនឹងតំបន់ដីសណ្តដ Mississippi)។ រចនាសម្ព័ន្ធសកលលោក

ទាំងមូលគឺជាផ្នែកមួយនៃឋានានុក្រមត្រួតស៊ីគ្នា។ ការប្រមូលផ្តុំដើមទុន និងទំហំប្រាក់ឈ្នួលនីមួយៗបង្កើតបានជាការវិវត្តន៍ជាបន្តបន្ទាប់ ជាជាងការបែងចែកយ៉ាងស៊ីជម្រៅជាពីរប្រភេទផ្សេងគ្នា។

នៅក្នុងទ្រឹស្តីប្រព័ន្ធពិភពលោក *តំបន់ជាយក្រុង*(semi-pheripheryគឺជាតំបន់ដែល មានការផលិតឧស្សាហកម្មផង និងការប្រមូលផ្តុំដើមទុនផង ប៉ុន្តែ តាមធម្មតា វាមិនមានវិសាលភាពស្មើនឹងតំបន់ជឿនលឿនបំផុតនៅក្នុងរដ្ឋស្នូលនោះទេ។ អឺរ៉ុបខាងកើត និងរុស្ស៊ីត្រូវបានចាត់ទុកជាទូទៅថាជាតំបន់ជាយក្រុងក៏ដូចជាប្រទេសឧស្សាហកម្មថ្មីថ្មោងមួយចំនួន ដូចជាកោះតៃវ៉ាន់ និងសិង្ហបុរី។ តំបន់ជាយក្រុងដើរតួនាទីជាប្រភេទទ្រនាប់នយោបាយបណ្តោះអាសន្ន រវាងរដ្ឋស្នូល និងរដ្ឋជនបទ ពីព្រោះថារដ្ឋក្រីក្រនានាអាចមានបំណងប្រាថ្នាចង់ចូលរួមក្នុងតំបន់ជាយក្រុង ជំនួសអោយការប្រាថ្នាចង់បះបោរប្រឆាំងនឹងការត្រួតត្រាដោយតំបន់ស្នូល។

យូរៗទៅ សមាជិកភាពនៅក្នុងតំបន់ស្នូល ជាយក្រុង និងជនបទបានផ្លាស់ប្តូរខ្លះៗ ប៉ុន្តែប្រព័ន្ធសកលនៃទំនាក់ទំនងរវាងវណ្ណៈនីមួយៗនៅតែមាន។ តំបន់នៅឆ្ងាយហួសដែលអឺរ៉ុបទៅមិនដល់ ដូចជាផ្នែកខាងក្នុងនៃអាមេរិកឡាទីន ត្រូវបានរួមបញ្ចូលជាតំបន់ជនបទ។ តំបន់ក្នុងទីជនបទអាចក្លាយជាតំបន់ជាយក្រុងឬរហូតក្លាយជាតំបន់ស្នូល ដូចអាមេរិកខាងជើងបានធ្វើរួចហើយ។ ហើយរដ្ឋស្នូលអាចធ្លាក់ខ្លួនចូលទៅក្នុងតំបន់ជាយក្រុងវិញ ប្រសិនបើពួកគេមិនសូវបានប្រមូលផ្តុំទ្រព្យសម្បត្តិ ដូចដែលអេស្ប៉ាញបានធ្វើនៅចុងសតវត្សរ៍ទីដប់ប្រាំមួយ ដល់ដើមសតវត្សរ៍ទីដប់ប្រាំពីរ។ ដោយសារទ្រឹស្តីប្រព័ន្ធពិភពលោកផ្តល់អោយតែគំនិតទូទៅប៉ុណ្ណោះ ប៉ុន្តែមិននិយមន័យច្បាស់លាស់អំពីអ្វីដែលបង្កើតបានជារដ្ឋស្នូល រដ្ឋជាយក្រុង និងរដ្ឋជនបទ វាពិបាកក្នុងការនិយាយអោយច្បាស់ថារដ្ឋណាស្ថិតក្នុងតំបន់ណាអោយពិតប្រាកដ។

គំរូជាក់ស្តែងនៃពាណិជ្ជកម្មពិភពលោក បានគាំទ្រទ្រឹស្តីប្រព័ន្ធពិភពលោក ក្នុងកម្រិតមួយចំនួន។ ប្រទេសបស្ចឹមលោកដែលមានឧស្សាហូបនីយកម្មរីកចម្រើនសាកសមក្លាយជារដ្ឋស្នូល ដោយមានការនាំចេញច្រើនជាងការនាំចូល ដូចជាគ្រឿងម៉ាស៊ីន សារធាតុគីមី និងទំនិញផលិតធ្ងន់ស្រដៀងគ្នា។ នៅទសវត្សរ៍ឆ្នាំ ១៩៩០ តំបន់ផ្សេងទៀតភាគច្រើនបាននាំចូលច្រើនជាងការនាំចេញទំនិញបែបនេះ។ ប៉ុន្តែនៅក្នុងទសវត្សរ៍ឆ្នាំ ២០០០ ប្រទេសចិន(និងប្រទេសអាស៊ីផ្សេងទៀត) ក៏បានក្លាយជាអ្នកនាំចេញសរុបនៃទំនិញផលិតធ្ងន់ផងដែរ។ អាស៊ីក៏នៅមានទីផ្សារពិសេសក្នុងការនាំចេញផលិតកម្មស្រាល រួមទាំងផលិតកម្មវាយនភ័ណ្ឌផងដែរ។ គំរូបែបនេះសាកសមនឹងស្ថិតក្នុងប្រភេទរដ្ឋជាយក្រុង។ ប្រទេសឧស្សាហូបនីយកម្មបស្ចឹមលោកនាំចូលនូវទំនិញឧស្សាហកម្មទាំងនេះ។ ការផ្លាស់ប្តូរទីតាំងផលិតទំនិញឧស្សាហកម្មនាំចេញពីប្រទេសឧស្សាហកម្មទៅអាស៊ីបានឆ្លុះបញ្ចាំងពីសកលភាវូបនីយកម្ម។

ការនាំចូលថាមពលសរុបដោយប្រទេសឧស្សាហូបនីយកម្មបស្ចឹមលោក គឺជាប្រភេទពាណិជ្ជកម្មដ៏សំខាន់និងដ៏ធំសម្បើម ហើយក៏ជាការចង្អុលបង្ហាញមួយទៀតនៃសកលភាវូបនីយកម្ម។ ប្រទេសនៅអាស៊ីនៅពេលនេះក៏បាននាំចូលថាមពលផងដែរ។ ប្រទេសមជ្ឈិមបូព៌ាមានឯកទេសក្នុងការនាំចេញប្រេង ហើយរុស្ស៊ី អាមេរិកឡាទីន និងអាហ្វ្រិកសុទ្ធតែនាំចេញថាមពល ដោយតុល្យភាពផងដែរ។ នេះគឺជាតួនាទីទាញយកវត្ថុធាតុដើម ដែលជាតួនាទីទូទៅរបស់រដ្ឋជនបទ។ អាមេរិកឡាទីនមានការនាំចេញសរុប នៅក្នុងវិស័យម្ហូបអាហារ ផលិតផលកសិកម្ម និងសារធាតុរ៉ែ ក៏ជាតួនាទីទូទៅរបស់រដ្ឋជនបទផងដែរ។ ទោះយ៉ាងណាក៏ដោយ

គំរូនៃឯកទេសនៃតំបន់ទាំងនេះត្រូវតែសង្កេតមើលតាមទស្សនៈរួម។ គ្រប់តំបន់ទាំងអស់នាំចូលនិងនាំចេញគ្រប់ប្រភេទទំនិញទាំងអស់នេះ។

តំបន់ជាយក្រុង ដែលនាំចេញផលិតផលឧស្សាហកម្ម គឺជាតំបន់(ប្រទេសចិននិងអាស៊ីខាងត្បូង) ដែលបាននឹងកំពុងរីកចម្រើនយ៉ាងឆាប់រហ័ស ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ (សូមមើលក្រាហ្វិក ១២.១)។ តំបន់ទាំងបីដែលជាប់ពាក់ព័ន្ធជាមួយសេដ្ឋកិច្ចពិភពលោកដែលត្រូវធ្វើ សកលភាវូបនីយកម្ម ជាចម្បង ជាអ្នកនាំចេញនូវវត្ថុធាតុដើម (អាហ្វ្រិក មជ្ឈិមបូព៌ា និងអាមេរិកឡាទីន) កំពុងរីកចម្រើនយឺតជាង។

ការដែលមានធនធានធម្មជាតិដែលអាចនាំចេញបាន ទំនងជាអាចល្អប្រសើរសម្រាប់សេដ្ឋកិច្ចមួយប៉ុន្តែ តាមពិតទៅ បញ្ហានៃកំណើនសេដ្ឋកិច្ចដោយផ្អែកលើការនាំចេញធនធានត្រូវបានគេហៅថាជា**បណ្តាសាធនធាន**(resource curse)។ សូម្បីតែនៅក្នុងប្រទេសដែលមានប្រាក់ចំណូលមធ្យម ដូចជាប្រទេសឈីលីជាដើម ការកើនឡើងបួនដងនៃតម្លៃទំនិញនាំចេញដ៏សំខាន់របស់ខ្លួន គឺទង់ដែង ក្នុងឆ្នាំ ២០០៣-២០០៦ គឺជាពរជ័យចម្រុះ។ សម្រាប់ក្រុមអ្នកតវ៉ាដែលបានទាមទារអោយមានការចំណាយរាប់ពាន់លានដុល្លារ សម្រាប់សេវាសង្គមសម្រាប់ជនក្រីក្រ ប៉ុន្តែប្រធានាធិបតី (ទោះបីគាត់ជាអ្នកសង្គមនិយម) បានព្រមានប្រឆាំងនឹងការចំណាយជាអ្វីដែលអាចប្រែក្លាយគ្រោះមហន្តរាយបណ្តោះអាសន្ន។ ទន្ទឹមនឹងនេះ ប្រាក់ចំណូលនាំចេញខ្ពស់បានពង្រឹងរូបិយប័ណ្ណរបស់ប្រទេសឈីលី (ឡើងថ្លៃ) ដែលធ្វើអោយវាកាន់តែពិបាកសម្រាប់ឧស្សាហកម្មផ្សេងទៀត ក្នុងការនាំចេញផលិតផលរបស់ពួកគេ។ បន្ទាប់មក នៅចុងឆ្នាំ ២០០៨ វិបត្តិសេដ្ឋកិច្ចសកលបានបណ្តាលអោយមានការធ្លាក់ចុះនៃតម្លៃទង់ដែង វាបានបណ្តាលអោយមានការកាត់បន្ថយប្រាក់ចំណូលរបស់ប្រទេសឈីលីយ៉ាងខ្លាំង។

១២.៣. ចក្រភព័ត្តិនិយម

១២.៣ ចូរប្រៀបធៀបផលប៉ះពាល់នៃរបបអាណានិគមនិយមអោយបានបីផ្សេងគ្នា ហើយពន្យល់ពីមូលហេតុដែលផលប៉ះពាល់ទាំងនេះនាំអោយមានបញ្ហាអភិវឌ្ឍសេដ្ឋកិច្ចនៅអឌ្ឍគោលខាងត្បូង។

ទាំងភាពមិនស្មើគ្នានៃទ្រព្យសម្បត្តិ រវាងអឌ្ឍគោលខាងជើងនិងខាងត្បូង និងទាំងឯកទេសនាំចេញក្នុងតំបន់មានប្រវត្តិជាយូរអង្វែងណាស់មកហើយ។ នៅក្នុងមេរៀនទី ៣ យើងបានពិភាក្សាអំពីទ្រឹស្តីម៉ាក្សស៊ីសនិយមនៃចក្រពត្តិនិយម ដែលផ្តល់ការពន្យល់ជាក់លាក់មួយអំពីរបៀបដែលធ្វើអោយមានគម្លាតអឌ្ឍគោលខាងជើងនិងខាងត្បូង។ នៅទីនេះ យើងពិនិត្យមើលពីរបៀបដែលចក្រពត្តិនិយមបានជះឥទ្ធិពលដល់អឌ្ឍគោលខាងត្បូង ក្នុងរយៈពេលជាច្រើនសតវត្សរ៍មកហើយ និងរបៀបដែលឥទ្ធិពលរបស់វានៅតែមានមនោគមន៍នៅជុំវិញពិភពលោក។ ចក្រពត្តិនិយម ជាពិសេស នៅសតវត្សរ៍ទីដប់ប្រាំមួយ ដល់ពាក់កណ្តាលសតវត្សរ៍ទី ២០ បានរៀបចំរចនាសម្ព័ន្ធពិភពលោកជុំវិញគោលការណ៍គ្រប់គ្រងបានយ៉ាងរលូន ដោយមានចៅហ្វាយនាយនិងទាសករ អ្នកគ្រប់គ្រងនិងអ្នកត្រូវគេគ្រប់គ្រង ជាមួយនឹងប្រជាជន ដីធ្លី ពលកម្ម និងទ្រព្យសម្បត្តិរបស់ពួកគេ។ ទន្ទឹមនឹងនេះដែរ ចក្រពត្តិនិយមអាស្រ័យទៅលើគោលការណ៍អត្តសញ្ញាណ ដើម្បីបង្រួបបង្រួមអឌ្ឍគោលខាងជើងជុំវិញអត្តសញ្ញាណជាតិសាសន៍រួមមួយ ដែលកំណត់ថាមនុស្សមិនមានស្បែកស ជាប្រភេទមនុស្សក្រៅក្រុម។ (ទោះបីជាបញ្ហាអត្តសញ្ញាណសព្វថ្ងៃនេះមានភាពស្មុគស្មាញជាងក៏ដោយ ការរើសអើងជាតិសាសន៍នៅតែប៉ះពាល់ដល់ទំនាក់ទំនងអឌ្ឍគោលខាងជើងនិងខាងត្បូង។)

១២.៣.១. អរិយធម៌ពិភពលោក

ប្រព័ន្ធអន្តរជាតិនាពេលបច្ចុប្បន្នគឺជាផលិតផលនៃអរិយធម៌ជាក់លាក់មួយ នោះគឺអរិយធម៌បស្ចឹមលោក ដែលផ្តោតលើអឺរ៉ុប។ ប្រព័ន្ធអន្តរជាតិ ដូចដែលយើងដឹងរួចហើយថា បានអភិវឌ្ឍក្នុងចំណោមរដ្ឋអឺរ៉ុបពីជាង ៣០០ ទៅ ៥០០ ឆ្នាំមុន ហើយដែលត្រូវបានសាយភាយទៅកាន់ពិភពលោកទាំងមូល ហើយនៅក្នុងសតវត្សរ៍ចុងក្រោយនេះបានបញ្ចូលទឹកដីស្ទើរតែទាំងអស់នៃពិភពលោកទៅជារដ្ឋអធិបតេយ្យ។ មានអរិយធម៌ជាច្រើនផ្សេងៗទៀត ដែលមាននៅក្នុងតំបន់ពិភពលោក អស់ជាច្រើនសតវត្សរ៍មុនពេលដែលជនជាតិអឺរ៉ុបបានមកដល់។ ប្រពៃណីវប្បធម៌ទាំងនេះបន្តមានឥទ្ធិពលលើ ទំនាក់ទំនងអន្តរជាតិ ជាពិសេសនៅពេលដែលរចនាបថ និងការរំពឹងទុកនៃវប្បធម៌ទាំងនេះ ចូលមកក្នុងអន្តរកម្មអន្តរជាតិ (សូមមើលក្រាហ្វិក ១២.៦)។

វប្បធម៌ជនជាតិដើមភាគតិចនៅអាមេរិកខាងជើងត្រូវបានបំផ្លាញចោល ឬត្រូវរុញច្រានដោយអ្នកតាំងទីលំនៅភាគច្រើននៅតំបន់អឺរ៉ុប។ ប្រជាជនអាមេរិកខាងជើង នាពេលបច្ចុប្បន្ននេះ មានចំនួនច្រើនលើសលប់មានប្រភពចេញមកពីជនអន្តោប្រវេសន៍។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងប្រទេសភាគច្រើននៃពិភពលោក (ជាពិសេសនៅទ្វីបអាហ្វ្រិក និងអាស៊ី) ចក្រភពអឺរ៉ុបប្រើយុទ្ធសាស្ត្ររួមបញ្ចូលជាជាងការរុញច្រានប្រជាជនជនជាតិដើមភាគតិចអោយនៅមួយឡែក។ ប្រជាជនសព្វថ្ងៃនេះ ភាគច្រើនជាជនជាតិដើមភាគតិច មិនមែនជាជនអន្តោប្រវេសន៍នោះទេ។ ដូច្នេះ ប្រជាជនទាំងនេះត្រូវបានចាក់ឫសយ៉ាងរឹងមាំ នៅក្នុងប្រពៃណីវប្បធម៌និងប្រវត្តិសាស្ត្ររបស់ពួកគេ ជាងជនជាតិអាមេរិកភាគច្រើន។

អរិយធម៌អឺរ៉ុបបានវិឌ្ឍន៍ចេញពីឫសគល់នៅសមុទ្រមេឌីទែរ៉ាណេខាងកើត (អេហ្ស៊ីប មេសូប៉ូតាមៀ [អ៊ីរ៉ាក់]និងជាពិសេសក្រិក)។ អ្វីដែលមានសារៈសំខាន់ពិសេសសម្រាប់ទំនាក់ទំនងអន្តរជាតិ គឺសម័យបុរាណនៃរដ្ឋ-បុរីក្រិក ប្រហែល ៤០០ ឆ្នាំមុនគ.ស. ដែលបានលើកឧទាហរណ៍ពីមូលដ្ឋានគ្រឹះមួយចំនួន។ សម្រាប់គោលការណ៍នៃនយោបាយអំណាចអន្តររដ្ឋ (ដោយឆ្លុះបញ្ចាំងនៅក្នុងកំណត់ត្រាប្រវត្តិសាស្ត្របុរាណរបស់លោកស៊ូស៊ីឌីឌីស អំពី សង្គ្រាមប៉េឡូប៉ូនេស៊ី ផ្ទុះឡើងរវាងបុរីអាថែននិងបុរីស្ប៉ាតា)។ នៅពេលនោះ រដ្ឋបុរីនានាមានទំនាក់ទំនងពាណិជ្ជកម្មនិងសង្គ្រាមជាមួយគ្នាជាញឹកញាប់ នៅក្នុងផ្នែកដ៏ធំទូលាយនៃពិភពលោក ចាប់ពីសមុទ្រមេឌីទែរ៉ាណេ តាមរយៈឥណ្ឌា រហូតដល់អាស៊ីបូព៌ា។ ភាគច្រើននៃតំបន់នេះបានស្ថិតនៅក្រោមឥទ្ធិពលចក្រភពក្រិក ជាមួយនឹងការសញ្ជ័យពង្រីកទឹកដីទូលំទូលាយរបស់ អាឡិចហ្សង់ឌ្រមហារាជ (ប្រហែល ៣០០ មុនគ.ស.) បន្ទាប់មក ស្ថិតនៅក្រោមចក្រភពរ៉ូម (ប្រហែល ១ គ.ស.) ហើយបន្ទាប់មក នៅក្រោមចក្រភពអារ៉ាប់ (ប្រហែលឆ្នាំ ៦០០ គ.ស.)។

ក្រាហ្វិក ១២.៦ អរិយធម៌ពិភពលោក

ប្រភព៖ Barraclough, Geoffrey, ed. កាលប្បវត្តិនៃប្រវត្តិសាស្ត្រពិភពលោក។ Hammond, ១៩៧៨. Mozaffari, Mehdi, ed. សកលភាវូបនីយកម្ម និងអរិយធម៌។ Routledge, ២០០២. Abu-Lughod, Janet, មុនពេលអនុត្តរភោពអឺរ៉ុប៖ ប្រព័ន្ធពិភពលោក គ.ស. ១២៥០–១៣៥០។ Oxford, ១៩៨៩. Hodgson, Marshall G. S. ការបណ្តាក់ទុកនៃសាសនាឥស្លាម៖ មនសិការ និងប្រវត្តិសាស្ត្រនៅក្នុងអរិយធម៌ពិភពលោក។ ទីក្រុងឈីកាហ្គោ ឆ្នាំ ១៩៧៤។ Bozeman, Adda ។ នយោបាយ និងវប្បធម៌ក្នុងប្រវត្តិសាស្ត្រអន្តរជាតិ។ ព្រីនស្តុន ឆ្នាំ ១៩៦០។

ប្រទេសចិននៅតែជាអរិយធម៌ឯកោដាច់ដោយឡែកពីគេ ក្នុងអំឡុងទាំងអស់នេះ។ នៅក្នុងសម័យ «សាមកុក» ដំណាលពេលជាមួយនឹងរដ្ឋ-បុរីក្រិក រដ្ឋទំនើប(រៀបចំជាអង្គភាពនយោបាយផ្អែកលើដែនដី)

ដំបូង បានប្រើសង្គ្រាមជាឧបករណ៍នៃនយោបាយអំណាច។ ទាំងអស់នេះត្រូវបានពិពណ៌នានៅក្នុងស្នាដៃបុរាណ «សិល្បៈសង្គ្រាម» ដោយស៊ុនអ៊ូ។ នៅប្រហែលឆ្នាំ៨០០ គ.ស. នៅពេលដែលទ្វីបអឺរ៉ុបស្ថិតនៅក្នុង «យុគងងឹត» និងអរិយធម៌អារ៉ាប់នៅក្នុង «យុគមាស» ប្រទេសចិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់រាជវង្សថាង ដែលជាអរិយធម៌រុងរឿងយ៉ាងខ្លាំង ដែលឯករាជ្យពីឥទ្ធិពលរបស់លោកខាងលិច។ ប្រទេសជប៉ុនដែលទទួលឥទ្ធិពលយ៉ាងខ្លាំងពីអារ្យធម៌ចិនបានលូតលាស់ចេញជាផ្លែផ្កា នៅលើទឹកដីរបស់ខ្លួន នៅក្នុងប៉ុន្មានសតវត្សរ៍ ដែលនាំទៅដល់សម័យសូហ្គុន (Shoguns) (ប្រហែលឆ្នាំ ១២០០ គ.ស.)។ ប្រទេសជប៉ុនបានផ្តាច់ខ្លួនចេញពីឥទ្ធិពលលោកខាងលិចក្រោមរជ្ជកាលសូហ្គុន តូគុហ្គាវ៉ា (Tokugawa) អស់ជាច្រើនសតវត្សរ៍មកហើយ ដែលបានបញ្ចប់បន្ទាប់ពីឆ្នាំ ១៨៥០ នៅពេលដែលការស្តារប្រទេសឡើងវិញក្នុងសម័យពន្លឺ មីអ៊ីយិ (Meiji)បានចាប់ផ្តើមឧស្សាហូបនីយកម្ម និងពាណិជ្ជកម្មអន្តរជាតិរបស់ជប៉ុន។ អាមេរិកឡាទីនក៏មានអរិយធម៌រីកចំរើនដែរ (ជនជាតិម៉ាយ៉ានដែលមានវត្តមាននៅចន្លោះពី ១០០ គ.ស. ទៅ ៩០០ គ.ស. និងអាស្តែក (Aztecs) និងអាំងកាស៍ (Incas) នៅចន្លោះឆ្នាំ ១២០០ គ.ស.) ដែល ឯករាជ្យមិនពាក់ព័ន្ធនឹងឥទ្ធិពលលោកខាងលិច រហូតដល់ពួកគេត្រូវបានសញ្ជ័យ ដោយប្រទេសអេស្ប៉ាញនៅប្រហែលឆ្នាំ ១៥០០។ នៅទ្វីបអាហ្វ្រិកវិញ អាណាចក្រដ៏អស្ចារ្យបានរីកចម្រើន បន្ទាប់ពីឆ្នាំ ១០០០ គ.ស. (នៅដើមឆ្នាំ ៦០០ នៅប្រទេសហ្គាណា) ហើយត្រូវបានអភិវឌ្ឍយ៉ាងខ្លាំងនៅពេលដែលឈ្មួញទាសករអឺរ៉ុបបានមកដល់ ប្រហែលឆ្នាំ ១៥០០។

ចក្រភពរបស់អារ៉ាប់ ប្រហែលឆ្នាំ ៦០០ គ.ស. ទៅ ១២០០ គ.ស. បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងទំនាក់ទំនងអន្តរជាតិនៃតំបន់មជ្ឈិមបូព៌ា។ តំបន់នេះ ស្ទើរតែទាំងអស់ ធ្លាប់បានរួបរួមគ្នា ក្នុងចក្រភពនេះ ដែលបានដើបឡើងនិងបានផ្សព្វផ្សាយសាសនាឥស្លាម។ ការលុកលុយរបស់អឺរ៉ុប (បូជនីយកិច្ច) ត្រូវវាយព្រួចច្រានចេញវិញ។ នៅសតវត្សរ៍ទីដប់ប្រាំមួយ ដល់ សតវត្សរ៍ទីដប់ប្រាំបួន ភាគខាងកើតនៃសមុទ្រមេឌីទែរ៉ាណេបានស្ថិតនៅក្រោមចក្រភពអូតូម៉ង់ ដែលមានមូលដ្ឋាននៅទួរគី ដែលផ្តល់ស្ថេរភាពដែលទាក់ទងទៅវប្បធម៌ក្នុងតំបន់ ប្រសិនបើពួកគេថ្វាយសួយសារអាករ។ ប្រវត្តិសាស្ត្រនៃចក្រភពនេះបានបន្តមានឥទ្ធិពលលើតំបន់ក្នុងសតវត្សរ៍ទី២០។ ឧទាហរណ៍ Pan-Arabism (ឬជាតិនិយមអារ៉ាប់ទាំងមូល) ជាពិសេសខ្លាំងក្លានៅទសវត្សរ៍ឆ្នាំ ១៩៥០ និង ១៩៦០ បានមើលឃើញថា តំបន់នេះជាប្រទេសរួមមួយ ងាចមានសក្តានុពលម្តងទៀត ជាមួយនឹងសាសនា ភាសា និងអត្តសញ្ញាណរួមតែមួយ។ លោក សាដាម ហ៊ូសេន របស់ប្រទេសអ៊ីរ៉ាក់ក្នុងកំឡុងសង្គ្រាមឈូងសមុទ្រ បានប្រដូចខ្លួនគាត់ទៅនឹងមេដឹកនាំដែលបានបណ្តេញកងទ័ពបូជនីយកិច្ចកាលពីមួយពាន់ឆ្នាំមុន។ កម្លាំងនៃក្រុមជ្រុលនិយមអ៊ីស្លាម នៅទូទាំងតំបន់ នាពេលបច្ចុប្បន្ននេះ ក៏ដូចជាអារម្មណ៍ដែលភ្ជាប់ទៅនឹងជម្លោះអារ៉ាប់-អ៊ីស្រាអែល ឆ្លុះបញ្ចាំងពីសារៈសំខាន់បន្តនៃចក្រភពអារ៉ាប់។

អឺរ៉ុបខ្លួនឯងបានចាប់ផ្តើមការកើនឡើងលើការគ្រប់គ្រងពិភពលោក នៅកំឡុងឆ្នាំ ១៥០០ បន្ទាប់ពីមានបុនសម័យ(Renaissance) (នៅពេលដែលអរិយធម៌ក្រិកនិងរ៉ូម៉ាំងបុរាណត្រូវបានប្រទះឃើញឡើងវិញ)។ រដ្ឋ-បុរីរបស់អ៊ីតាលី នាសម័យនោះ ក៏បានរកឃើញឡើងវិញនូវច្បាប់នៃនយោបាយអំណាចអន្តរជាតិដូចដែលបានពិពណ៌នា ដោយទីប្រឹក្សារបស់ព្រះអង្គម្ចាស់បុនសម័យ ឈ្មោះ នីកូឡូ ម៉ាគីយ៉ាវែលី (Niccolò Machiavelli)។ អង្គភាពសក្តិភូមិបានចាប់ផ្តើមរួមបញ្ចូលគ្នាទៅជាប្រជាជាតិដោយផ្អែកលើទឹកដីធំៗ ក្រោមការគ្រប់គ្រងមេដឹកនាំផ្តាច់ការតែមួយ (ព្រះអង្គម្ចាស់ឬព្រះរាជា)។ បដិវត្តន៍យោធាក្នុងសម័យកាលនោះបាន

បង្កើតប្រព័ន្ធកងទ័ពទំនើបដំបូងគេ។ ស្តេចអឺរ៉ុបបានដាក់កាណុងនៅលើកប៉ាល់ ហើយចាប់ផ្តើមចេញដំណើរ «រុករក»ពិភពលោក។ បដិវត្តន៍ឧស្សាហកម្មបានពន្លឿនល្បឿនអភិវឌ្ឍន៍នៃប្រព័ន្ធអន្តរជាតិ ចក្រពត្តិនិយម ពាណិជ្ជកម្មនិងសង្គ្រាម បន្ទាប់ពីឆ្នាំ ១៧៥០ គ.ស.។ ទីបំផុត អឺរ៉ុបធ្វើការសញ្ជ័យលើពិភពលោកបាននាំមកនូវអរិយធម៌ពិភពលោករួមមួយ ទោះបីជាមានការប្រែប្រួលផ្សេងៗគ្នាបន្តិចក្នុងតំបន់និងវប្បធម៌រងក៏ដោយ។


ក្រាហ្វិក ១២.៧ ប្រវត្តិសាស្ត្រនៃចក្រពត្តិនិយម, ១៥០០–២០០០



ក្រាហ្វិក ១២.៨ ការសញ្ជ័យពិភពលោក

អតីតទឹកដីអាណានិគមនៃរដ្ឋអឺរ៉ុប

ប្រភព៖ កែសម្រួលពី Andrew Boyd, អាត្លាសនៃកិច្ចការពិភពលោក។ ទី ៩ ed ។ NY: Routledge, ១៩៩២, ទំ។ ៩១. សម្គាល់៖ B(អង់គ្លេស) G(អាឡឺម៉ង់) N(ហុល្លង់) Belg(បែលហ្ស៊ីក) I(អ៊ីតាលី) P(ព័រទុយហ្គាល់) F(បារាំង) J(ជប៉ុន) S(អេស្ប៉ាញ)



១២.៣.២. ប្រវត្តិសាស្ត្រនៃចក្រពត្តិនិយម ១៥00-២000

ចក្រពត្តិនិយមអឺរ៉ុបបានចាប់ផ្តើមឡើងនៅក្នុងសតវត្សទីដប់ប្រាំ ជាមួយនឹងការអភិវឌ្ឍសំពៅធំៗសម្រាប់ធ្វើនាវាចរណ៍ នៅក្នុងសមុទ្រសែនឆ្ងាយ ដែលក្នុងនោះនាវិកត្រឹមមួយចំនួនតូចអាចដឹកជញ្ជូនទំនិញច្រើន នៅក្នុងរយៈចម្ងាយឆ្ងាយៗបាន។ ប្រទេសព័រទុយហ្គាល់បានត្រួសត្រាយផ្លូវមុនគេ នៅក្នុងការរុករក ហួសពីទ្វីបអឺរ៉ុប។ មិនយូរប៉ុន្មាន ប្រទេសអេស្ប៉ាញ បារាំង និងអង់គ្លេសបានធ្វើតាមក្នុងការស្វែងរុករកនេះ។ ជាមួយនឹងបច្ចេកវិជ្ជាយោធាដ៏ខ្ពង់ខ្ពស់និងទំនើប ជនអឺរ៉ុបបានដណ្តើមការគ្រប់គ្រងទីក្រុងនៅតាមមាត់សមុទ្រ និងបានគ្រប់គ្រងកំពង់ផែសម្រាប់ផ្គត់ផ្គង់ស្បៀងនិងទំនិញ នៅតាមបណ្តោយផ្លូវពាណិជ្ជកម្មសំខាន់ៗ។ បន្តិចម្តងៗ ការគ្រប់គ្រងនេះបានពង្រីកចូលទៅក្នុងដែនដីជ្រៅៗ ឆ្ងាយពីតំបន់ឆ្នេរ ដំបូងគេនៅអាមេរិកខាងត្បូង បន្ទាប់មកនៅអាមេរិកខាងជើង ហើយក្រោយមកទៀត នៅទូទាំងអាស៊ីនិងអាហ្វ្រិក (សូមមើលក្រាហ្វិក ១២.៧) ខាងលើ។

នៅសតវត្សទីដប់ប្រាំមួយ អេស្ប៉ាញ និងព័រទុយហ្គាល់ មានទឹកដីយ៉ាងទូលំទូលាយនៅក្នុងតំបន់នៃអាមេរិកកណ្តាល និងប្រេស៊ីលដែលបានគ្របគ្រងរៀងៗខ្លួន។ អង់គ្លេស និងបារាំងបានដាក់អាណានិគមនៅលើអាមេរិកខាងជើង និងសមុទ្រការ៉ាបៀន។ ពួកចក្រពត្តិនិយមបានទិញទាសកររនៅអាហ្វ្រិក ហើយបញ្ជូនពួកគេទៅមុកស៊ិក និងប្រេស៊ីល ជាកន្លែងដែលពួកគេធ្វើការក្នុងវិស័យកសិកម្មត្រូពិក និងក្នុងការជីកយករ៉ែប្រាក់ និងមាស។ ទ្រព្យសម្បត្តិដែលផលិតបានត្រូវបាននាំចេញទៅកាន់ទ្វីបអឺរ៉ុប ដែលស្តេចបានប្រើវាដើម្បីទិញកងទ័ព និងកសាងរដ្ឋ។

អាណាចក្រទាំងនោះបានបំផ្លិចបំផ្លាញប្រជាជននិងវប្បធម៌ជនជាតិដើមម្ចាស់ស្រុក ដែលបណ្តាលអោយមានការរងទុក្ខយ៉ាងក្រៀមក្រំ។ យូរៗទៅ សេដ្ឋកិច្ចនៃអាណានិគមបានអភិវឌ្ឍជាមួយនឹងការបង្កើតហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូននិងទំនាក់ទំនងជាមូលដ្ឋានរោងចក្រជាដើម។ ប៉ុន្តែ សេដ្ឋកិច្ច ទាំងនេះជារឿយៗត្រូវបានបង្កើតទៅតាមតម្រូវការរបស់ម្ចាស់អាណានិគម មិនមែនប្រជាជនម្ចាស់ស្រុកទេ។

ការរំសាយរបបអាណានិគម(decolonization) បានចាប់ផ្តើមជាមួយនឹងពួកអាណានិគមអង់គ្លេសនៅសហរដ្ឋអាមេរិក ដែលបានប្រកាសឯករាជ្យនៅឆ្នាំ ១៧៧៦។ ភាគច្រើននៃអាមេរិកឡាទីនបានទទួលឯករាជ្យពីរបីទសវត្សរ៍ក្រោយមក។ ជាការពិតណាស់ រដ្ឋថ្មីៗនៅអាមេរិកខាងជើង និងអាមេរិកឡាទីន នៅតែគ្រប់គ្រងដោយកូនចៅរបស់ជនជាតិអឺរ៉ុប ដែលបង្កជាគុណវិបត្តិអោយជនជាតិដើមអាមេរិកាំង និងទាសករអាហ្វ្រិក។

អឺរ៉ុបនៅតែទទួលបានទឹកដីអាណានិគមថ្មី រហូតដល់ចុងសតវត្សទីដប់ប្រាំបួន ដោយឈានដល់ការដណ្តើមយកអាណានិគម នៅទ្វីបអាហ្វ្រិក ក្នុងទសវត្សរ៍ឆ្នាំ ១៨៩០ (ដែលបណ្តាលអោយមានការបែងចែកទឹកដីតាមអំពើចិត្ត ខណៈពេលដែលកងទ័ពអឺរ៉ុបជាគូប្រកួតប្រជែងនឹងគ្នា បានប្រញាប់ប្រញាល់ចូលទឹកដីជ្រៅឆ្ងាយពីឆ្នេរ ពីគ្រប់ទិសទី)។ ប្រទេសឥណ្ឌាបានក្លាយជាអាណានិគមដ៏ធំ និងសំខាន់បំផុតរបស់ចក្រភពអង់គ្លេស នៅសតវត្សរ៍ទីដប់ប្រាំបួន។ អ្នកមកដាក់អាណានិគមក្រោយៗដូចជាអាឡឺម៉ង់និងអ៊ីតាលីមានការខកចិត្តក្នុងការស្វែងរកទឹកដីដ៏គួរអោយទាក់ទាញមួយចំនួន ដែលនៅសេសសល់ក្នុងពិភពលោក នៅពេលដែលពួកគេព្យាយាមកសាងចក្រភពក្រៅប្រទេសនៅចុងសតវត្សរ៍ទីដប់ប្រាំបួន។ ទីបំផុត មានតែតំបន់មិនមែនជាអឺរ៉ុបមួយចំនួនក្នុងពិភពលោក ដែលបានរក្សាឯករាជ្យភាពរបស់ពួកគេ៖ ប្រទេសជប៉ុន ភាគច្រើននៃ

ប្រទេសចិន អ៊ីរ៉ង់ ទួរគី និងតំបន់មួយចំនួនផ្សេងទៀត។ ជប៉ុនបានចាប់ផ្តើមកសាងចក្រភពរបស់ខ្លួនដូចនឹងសហរដ្ឋអាមេរិកដែរ នៅចុងសតវត្សរ៍ទី១៩។ ប្រទេសចិនកាន់តែទន់ខ្សោយ ហើយតំបន់ឆ្នេររបស់ខ្លួនបានធ្លាក់នៅក្រោមការគ្រប់គ្រង ប្រសិនបើមិនមែនជាការគ្រប់គ្រងជាផ្លូវការ ពីប្រទេសមហាអំណាចអឺរ៉ុប។ អឺរ៉ុបបានធ្វើអាណានិគមលើទឹកដីភាគច្រើននៃពិភពលោក ក្នុងកំឡុងពេលណាមួយ មុនឬក្រោយ (សូមមើលក្រាហ្វិក ១២.៨)។

នៅសតវត្សទី ២០ តំបន់ពិភពលោក ដែលពីមុនត្រូវគ្រប់គ្រង ដោយអឺរ៉ុបបានទទួលឯករាជ្យដោយមានរដ្ឋអធិបតេយ្យភាពផ្ទាល់ខ្លួនរបស់ពួកគេចូលរួមក្នុងប្រព័ន្ធអន្តរជាតិ។ ឯករាជ្យបានមកដល់មុននៅទ្វីបអាមេរិក (ប្រហែលឆ្នាំ ១៨០០រ)។ នៅអាមេរិកឡាទីន កំឡុងពេលយ៉ាងយូរនៃសតវត្សរ៍ទីដប់ប្រាំបួនត្រូវញុំញីដោយសង្គ្រាម ការផ្លាស់ប្តូរព្រំដែន ការលេចឡើងនិងការដួលរលំនៃរបបផ្តាច់ការនិងសាធារណរដ្ឋ បញ្ហាបំណុលបរទេសដ៏រ៉ាំរ៉ៃ បដិវត្តន៍និងការលុកលុយផ្នែកយោធាម្តងហើយម្តងទៀត ដោយមហាអំណាចអឺរ៉ុបនិងសហរដ្ឋអាមេរិក ដើម្បីយកបំណុលមកវិញ។

នៅក្នុងរលកនៃការបញ្ចប់របបអាណានិគម បន្ទាប់ពីសង្គ្រាមលោកលើកទី ២ វាមិនមែនជាកូនចៅអាណានិគមក្នុងស្រុក(ដូចនៅអាមេរិក) ប៉ុន្តែជាជនជាតិម្ចាស់ស្រុក នៅអាស៊ី និងអាហ្វ្រិក ដែលបានតស៊ូទាមទារឯករាជ្យ។ ការបញ្ចប់របបអាណានិគម បានបន្តរហូតដល់ពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៩៧០ រហូតដល់ស្ទើរតែគ្មានអាណានិគមអឺរ៉ុបដែលនៅសេសសល់។ រដ្ឋឯករាជ្យថ្មីភាគច្រើនបានប្រឈមមុខនឹងបញ្ហាប្រឈមនិងការលំបាកយ៉ាងខ្លាំង នៅក្នុងសម័យក្រោយអាណានិគម ដោយសារប្រវត្តិអាណានិគមរបស់ពួកគេ។

១២.៣.៣. ឥទ្ធិពលនៃអាណានិគមនិយម

សម្រាប់រដ្ឋភាគច្រើននៅអឌ្ឍគោលខាងត្បូង ប្រវត្តិសាស្ត្រធ្លាប់នៅក្រោមអាណានិគមរបស់អឺរ៉ុប គឺជាចំណុចសំខាន់នៃអត្តសញ្ញាណជាតិ គោលនយោបាយការបរទេស និងជាទីតាំងនៅក្នុងពិភពលោក។ សម្រាប់រដ្ឋទាំងនេះ (និងជាពិសេសសម្រាប់អ្នករស់នៅក្នុងរដ្ឋទាំងនេះដែលពេញចិត្តទស្សនៈសង្គមនិយម) ទំនាក់ទំនងអន្តរជាតិរៀវរៅជុំវិញទំនាក់ទំនងអំណាចមិនស៊ីមេទ្រី ជាមួយនឹងរដ្ឋមានឧស្សាហកម្មរីកចម្រើន។ (ជាធម្មតាទស្សនៈមូលធននិយមហាក់មិនសូវយកចិត្តទុកដាក់និងមិនសូវអោយតម្លៃចំពោះប្រវត្តិសាស្ត្រ ហើយផ្តោតលើបញ្ហាបច្ចុប្បន្ននៅអឌ្ឍគោលខាងត្បូង ដូចជាសេដ្ឋកិច្ចមិនមានតុល្យភាព កម្លាំងពលកម្មគ្មានជំនាញ និងរដ្ឋាភិបាលពុករលួយ។)

ការស្ថិតនៅក្រោមរបបអាណានិគមបានដុះឥទ្ធិពលសោកសៅខ្លាំងក្លាទៅលើប្រជាជន និងវប្បធម៌។ ជនបរទេសវាយលុកលើទឹកដីរបស់ខ្លួនដោយបង្ខំ ហើយចូលមកត្រួតត្រា។ ពួកគេបង្កើតរដ្ឋាភិបាលថ្មីរបស់ពួកគេដោយយកជនជាតិរបស់គេមកធ្វើការផ្ទាល់។ ជនជាតិម្ចាស់ស្រុកត្រូវបង្ខំអោយនិយាយភាសាអ្នកធ្វើអាណានិគម ទទួលយកទំនៀមទម្លាប់និងវប្បធម៌របស់ពួកគេ និងទទួលបានការអប់រំនៅសាលាដែលត្រូវដំណើរការ ក្រោមការណែនាំរបស់ពួកគេ។ ជនជាតិម្ចាស់ស្រុកត្រូវគេប្រាប់ថា ពួកគេគឺជាជាតិសាសន៍ទាបជាងជនបរទេស។

ជនជាតិអឺរ៉ុបស្បែកស នៅក្នុងដែនដីអាណានិគមក្នុងប្រទេសតតិយលោកដូចជានៅទ្វីបអាហ្វ្រិក និងអាស៊ីមានចំនួនតិចជាងប្រជាជនដើមដែលជាម្ចាស់ស្រុក ប៉ុន្តែ បានរក្សាអំណាចដោយការរួមបញ្ចូលគ្នានៃ

កម្លាំងនិង(សំខាន់ជាងនេះ)លក្ខខណ្ឌផ្លូវចិត្ត។ ក្រោយជំនាន់អាណានិគមនិយមអ្នកស្រុកដើមភាគច្រើនបានឃើញការត្រួតត្រាថាជារឿងធម្មតា ឬជឿថាគ្មានអ្វីអាចធ្វើបានអំពីវាទេ។ ជនជាតិស្បែកសជាញឹកញាប់រស់នៅក្នុងពិភពខ្ពង់ខ្ពស់ដែលបែងចែកចេញពីជីវិតរបស់អ្នកស្រុកក្រីក្រ។

អាណានិគមនិយមក៏មានផលប៉ះពាល់សេដ្ឋកិច្ចជាលក្ខណៈអវិជ្ជមានផងដែរ។ សារធាតុរ៉ែដែលអាចយកបានយ៉ាងងាយស្រួលបំផុតត្រូវបានជីកកកាយ និងដឹកជញ្ជូនទៅទីឆ្ងាយ។ ដីស្រែល្អបំផុតត្រូវបានយកទៅដាំដំណាំនាំចេញ ជាជាងដំណាំចិញ្ចឹមជីវិត ហើយជួនកាល ពេលទទួលបានទិន្នផលច្រើនជាងតម្រូវការ និងត្រូវបានបំផ្លាញចោល។ ហេដ្ឋារចនាសម្ព័ន្ធដែលត្រូវបានសាងសង់ ដើម្បីតែបម្រើគោលបំណងនៃចក្រពត្តិនិយម ជាជាងចំនួនប្រជាជនក្នុងស្រុក ជាឧទាហរណ៍ ផ្លូវដែកដែលធ្វើដំណើរត្រង់ពីតំបន់រុករករ៉ែទៅកំពង់ផែ។ ការអប់រំ និងជំនាញដែលត្រូវការដើម្បីដំណើរការសេដ្ឋកិច្ចត្រូវបានកំណត់យ៉ាងទូលំទូលាយចំពោះជនជាតិស្បែកស។

ទោះជាយ៉ាងនេះក្តី ឥទ្ធិពលសេដ្ឋកិច្ចមិនមែនអវិជ្ជមានទាំងអស់នោះទេ។ អាណានិគមនិយមតែងតែជំរុញការប្រមូលផ្តុំសេដ្ឋកិច្ចនៅក្នុងស្រុក (ទោះបីជាត្រូវបានគ្រប់គ្រងដោយជនជាតិស្បែកស)។ ទីក្រុងនានាបានកើតឡើងនិងរីកលូតលាស់ខ្លាំង។ អណ្តូងរ៉ែត្រូវបានជីកដើម្បីប្រើប្រាស់និងបង្កើតជាកសិដ្ឋាន។ វាស្ថិតនៅក្នុងចំណាប់អារម្មណ៍របស់រដ្ឋបាលអាណានិគមក្នុងការជំរុញវដ្តនៃការប្រមូលផ្តុំមូលធនក្នុងស្រុក។ សម្រាប់ហេដ្ឋារចនាសម្ព័ន្ធដែលភាគច្រើន ដែលមានសព្វថ្ងៃនេះ នៅក្នុងប្រទេសតតិយលោក ភាគច្រើនត្រូវបានបង្កើតឡើងដោយពួកអាណានិគម។ ក្នុងករណីខ្លះ (ទោះបីជាមិនមែនទាំងអស់)ការជាក់អាណានិគមរួមបញ្ចូលគ្នានូវសហគមន៍ដែលខ្វែងគំនិតគ្នាទៅជាអង្គភាពនយោបាយដ៏ស្អិតរមួតជាមួយនឹងសាសនា ភាសា និងវប្បធម៌ទូទៅ ដូច្នេះបង្កើតឱកាសកាន់តែច្រើនសម្រាប់ការប្រមូលផ្តុំសេដ្ឋកិច្ច។ ក្នុងករណីខ្លះ វប្បធម៌នយោបាយក្នុងស្រុកដែលជំនួសដោយអាណានិគមនិយម គឺជាការគៀបសង្កត់លើប្រជាជនភាគច្រើន។

ទីណាមានអាណានិគម ទីនោះមានចលនាប្រឆាំងអាណានិគម។ ចលនាឯករាជ្យនៅទូទាំងទ្វីបអាហ្វ្រិក និងអាស៊ីទទួលបានសន្ទុះខ្លាំងក្នុងអំឡុងពេល និងក្រោយសង្គ្រាមលោកលើកទី ២ នៅពេលដែលប្រទេសមហាអំណាចអឺរ៉ុបចុះខ្សោយ។ ឆ្លងកាត់ទសវត្សរ៍ឆ្នាំ ១៩៦០ រលកនៃចលនាឯករាជ្យដ៏ជោគជ័យបានបក់បោកពីប្រទេសមួយទៅប្រទេសមួយ នៅពេលដែលប្រជាជនឈប់ទទួលយកចក្រពត្តិនិយមដូចធម្មតា ឬជៀសមិនរួច។ ក្នុងរយៈពេលពីរបីទសវត្សរ៍ រដ្ឋស្ទើរតែទាំងអស់នៃទ្វីបអាហ្វ្រិកបានផ្តួលរំលំការដឹកនាំរបស់ជនជាតិស្បែកស (សូមមើលក្រាហ្វិក ១២.៩)។

ទោះបីជាប្រទេសតតិយលោកជាច្រើនបានទទួលឯករាជ្យក្នុងពេលជាមួយគ្នាក៏ដោយ ក៏វិធីសាស្ត្រដែលពួកគេបានប្រើប្រាស់មានការប្រែប្រួល។ នៅក្នុងប្រទេសឥណ្ឌា ដែលជាអាណានិគមដ៏សំខាន់បំផុតនៃចក្រភពដ៏ធំបំផុត (ចក្រភពអង់គ្លេស) គន្ធីបានដឹកនាំចលនាមួយ ដោយផ្អែកលើការតស៊ូអហិង្សាចំពោះការគ្រប់គ្រងរបស់អង់គ្លេស (សូមមើលមេរៀនទី ៣)។ ទោះយ៉ាងណាក៏ដោយ អំពើអហិង្សាបានត្រូវបោះបង់នៅក្នុងសង្គ្រាមស៊ីវិលហិណ្ឌូ-មូស្លីមជាបន្តបន្ទាប់ ដែលបានបំបែកឥណ្ឌាជាពីររដ្ឋ ប្រទេសឥណ្ឌាភាគច្រើនជាមួយហិណ្ឌូ និងប្រទេសប៉ាគីស្ថាន (រួមទាំងប្រទេសបង់ក្លាដែស) ដែលភាគច្រើនជាជនមូស្លីម។


អាណានិគមខ្លះ ជាឧទាហរណ៍ប្រទេសអាល់ហ្សេរីនិងវៀតណាមបានទទួលឯករាជ្យតាមរយៈសង្គ្រាមដើម្បីបណ្តេញចៅហ្វាយនាយអឺរ៉ុបរបស់ពួកគេមិនអោយត្រលប់មកដឹកនាំបន្តទៀត។ រីឯប្រទេសផ្សេងទៀត

បានទទួលវាដោយសន្តិវិធី ដោយការចរចាផ្ទៃរអំណាចជាមួយជនជាតិអឺរ៉ុបដែលធុញទ្រាន់។ នៅប្រទេសអាល់ហ្សេរី បារាំងបានបោះបង់ចោលអាណានិគមរបស់ខ្លួនទាំងស្រុង ដោយការទាមទារនៅឆ្នាំ ១៩៦២ តែបន្ទាប់ពីបានប្រយុទ្ធនឹងសង្គ្រាមទ័ពព្រៃដ៏ជូរចត់។ ចលនារំដោះអាណានិគមមួយចំនួនបានប្រយុទ្ធជាមួយនឹងសង្គ្រាមទ័ពព្រៃ ដោយផ្អែកលើមនោគមវិជ្ជាកុម្មុយនិស្ត។ ជាឧទាហរណ៍ ពួកវៀតមិញបានកម្ចាត់ពួកអ្នកកាន់កាប់ស្រុកទេសជាជនជាតិបារាំង នៅឆ្នាំ ១៩៥៤ ហើយបានបង្កើតការគ្រប់គ្រងកុម្មុយនិស្ត៍របស់វៀតណាមនៅគ្រប់ទិសទីនៅឆ្នាំ ១៩៧៥។ សហភាពសូវៀតបានគាំទ្រចលនាបែបនេះជាច្រើន ហើយសហរដ្ឋអាមេរិកបានប្រឆាំងនឹងពួកគេ។ ប៉ុន្តែ ក្នុងករណីភាគច្រើន ការអំពាវនាវនៃចលនារំដោះគឺជាប្រធានបទទូទៅនៃការប្រឆាំងអាណានិគមនិយម ជាជាងមនោគមវិជ្ជាកុម្មុយនិស្ត។

ក្រាហ្វិក ១២.៩ តំបន់នៃការគ្រប់គ្រងជនជាតិភាគតិចសនៅអាហ្វ្រិក ឆ្នាំ ១៩៥២-១៩៩៤

អាណានិគមជាផ្លូវការត្រូវបានបំផ្លិចបំផ្លាញអស់រយៈពេល៤០ឆ្នាំ។ ទោះជាយ៉ាងណាក៏ដោយ ការពឹងផ្អែកក្រោយអាណានិគមនៅតែបន្តកើតមាននៅក្នុងអតីតកាលអាណានិគមជាច្រើន។

ប្រភព៖ កែសម្រួលពី Andrew Boyd, អាត្លាសនៃកិច្ចការពិភពលោក។ ទី ៩ ed ។ Routledge, ១៩៩២, ទំ។ ៩១.



នៅទូទាំងវិធីសាស្ត្រ និងមនោគមវិជ្ជាផ្សេងៗនៃចលនារំដោះនៅភាគខាងត្បូង លក្ខណៈពិសេសមួយគឺការពឹងផ្អែកលើជាតិនិយមសម្រាប់ការគាំទ្រដ៏ពេញនិយមខ្លាំង។ ជាតិនិយមគ្រាន់តែជាគំនិតមួយ ដែលចលនាទាំងនេះបាននាំយកពីអឺរ៉ុប ហើយប្រើដើម្បីធ្វើអោយខូចការគ្រប់គ្រងរបស់អឺរ៉ុប។ កត្តាផ្សេងទៀតរួមមានប្រជាធិបតេយ្យនិងសេរីភាពវឌ្ឍនភាព និងលទ្ធិម៉ាក្សនិយម។ មេដឹកនាំនៃចលនារំដោះជារឿយៗបានទៅសិក្សានៅសាកលវិទ្យាល័យអឺរ៉ុប។ នៅក្រោមការគ្រប់គ្រងរបស់អឺរ៉ុប រដ្ឋជាច្រើនក៏បានធ្វើការអភិវឌ្ឍជាច្រើនទៅលើហេដ្ឋារចនាសម្ព័ន្ធ ស្ថាប័នអប់រំ និងសាសនា ការថែទាំសុខភាព និងកងកម្លាំងយោធា ដោយផ្អែកលើគំរូអឺរ៉ុប។ ការសញ្ជ័យរបស់អឺរ៉ុបលើអឡាគោលខាងត្បូង ម្លោះហើយបានរួមចំណែកឧបករណ៍ដើម្បីលុបចោលការសញ្ជ័យរបស់ពួកគេ។

១២.៣.៤. ទ្រឹស្តីពឹងអាស្រ័យក្រោយអាណានិគម

ប្រសិនបើចក្រពត្តិនិយមប្រមូលផ្តុំទ្រព្យសម្បត្តិនៅក្នុងរដ្ឋស្នូលរបស់ខ្លួន និងបង្ហូរអតិរេកសេដ្ឋកិច្ចចេញពីតំបន់រដ្ឋជនបទ នោះគេអាចរំពឹងបានថា ការប្រមូលផ្តុំនៅអឡាគោលខាងត្បូងនឹងកកើតឡើងវិញ នៅពេលដែលអាណានិគមនិយមត្រូវបានផ្តួលរំលំ។ ជាទូទៅ នេះមិនមែនជាករណីជាក់ស្តែងដែលបានកើតឡើងនោះទេ។ រដ្ឋមួយចំនួនដូចជាសិង្ហបុរីបានប្រមូលមូលធនដោយជោគជ័យចាប់តាំងពីទទួលបានឯករាជ្យ។ ប៉ុន្តែ ប្រទេស

ផ្សេងទៀត រួមទាំងរដ្ឋអាហ្វ្រិកជាច្រើន ហាក់ដូចជាបានដើរថយក្រោយ ដោយមានដើមទុនថ្មីតិចតួចដើម្បីជំនួសហេដ្ឋារចនាសម្ព័ន្ធអាណានិគមចាស់ដែលមានស្រាប់។ អតីតអាណានិគមភាគច្រើនកំពុងធ្វើអោយមានការរីកចម្រើនយឺតយាវក្នុងការប្រមូលផ្តុំទ្រព្យសម្បត្តិ ឯករាជ្យភាពនយោបាយមិនមែនជាការព្យាបាលសម្រាប់ប្រទេសក្រីក្រទាំងអស់នោះទេ។

ហេតុផលមួយដែលបង្កបញ្ហាទាំងនេះ គឺថា នៅក្រោមអាណានិគមនិយម ការបណ្តុះបណ្តាល និងបទពិសោធន៍ដែលត្រូវការដើម្បីគ្រប់គ្រងសេដ្ឋកិច្ចត្រូវបានកំណត់ទុក ដែលជាញឹកញាប់ សម្រាប់តែជនជាតិអឺរ៉ុបស្បែកស ដែលបន្សល់ទុកគម្លាតដ៏ធំមួយនៅក្នុងជំនាញបច្ចេកទេស និងរដ្ឋបាលបន្ទាប់ពីទទួលបានឯករាជ្យ។


បញ្ហាមួយទៀតដែលត្រូវប្រឈមមុខដោយរដ្ឋឯករាជ្យថ្មីគឺថាក្នុងនាមជាទឹកដីអាណានិគម សេដ្ឋកិច្ចរបស់ពួកគេត្រូវបានអភិវឌ្ឍយ៉ាងតូចចង្អៀត ដើម្បីបម្រើសេចក្តីត្រូវការរបស់មាតុប្រទេសអឺរ៉ុប។ សេដ្ឋកិច្ចទាំងនេះភាគច្រើនត្រូវពឹងផ្អែកលើការនាំចេញផលិតផលមួយឬពីរតែប៉ុណ្ណោះ។ សម្រាប់ការនាំចេញ ប្រទេសហ្សំប៊ីពឹងលើរ៉ែទង់ដែង សម្រាប់អែលសាល់វ៉ាឌ័រពឹងលើការនាំចេញកាហ្វេ សម្រាប់បូតស្វាណាពឹងលើនាំចេញពេជ្រជាដើម។ បែបនេះហើយដែលធ្វើអោយសេដ្ឋកិច្ចនាំចេញតូចចង្អៀត ហាក់ដូចជាសាកសមបំផុតក្នុងការប្រើប្រាស់គុណសម្បត្តិធៀបរបស់រដ្ឋ ដើម្បីតែឯកទេសក្នុងវិស័យណាមួយនៃសេដ្ឋកិច្ចពិភពលោក។ ប៉ុន្តែ វាទុកអោយរដ្ឋនានាងាយរងគ្រោះដោយសារការប្រែប្រួលតម្លៃនៅលើទីផ្សារពិភពលោក (សូមមើល**បណ្តាសាធនជាន** នៅក្នុងមេរៀនទី ១៣)។ របបពាណិជ្ជកម្មសេរីបែបសេរីនិយម ដែលមានមូលដ្ឋាននៅជុំវិញអង្គការពាណិជ្ជកម្មពិភពលោក(WTO) បានកែតម្រូវតែផ្នែកខ្លះសម្រាប់ទីតាំងចរចាដ៏ប្រសើររបស់កូរ៉េខាងជើងនៅក្នុងពាណិជ្ជកម្មអឌ្ឍគោលខាងជើង-ខាងត្បូង។ ហើយអង្គការ WTO បានអនុញ្ញាតអោយកសិកម្ម (នាំចេញដោយរដ្ឋជនបទ) នៅតែត្រូវបានការពារ នៅក្នុងរដ្ឋស្ទួល ខណៈពេលដែលការលើកកម្ពស់សេរីភាវូបនីយកម្មនៃពាណិជ្ជកម្មនៅក្នុងទំនិញឧស្សាហកម្មដែលនាំចេញដោយរដ្ឋស្ទួល (សូមមើលមេរៀនទី ៨)។

វាមិនងាយស្រួលទេក្នុងការរៀបចំរចនាសម្ព័ន្ធសេដ្ឋកិច្ចឡើងវិញ ដែលនៅឆ្ងាយពីការនាំចេញទំនិញមួយចំនួន។ មេដឹកនាំរដ្ឋក៏មិនចង់ធ្វើដូច្នេះដែរ ពីព្រោះមេដឹកនាំទទួលបានផលប្រយោជន៍ពីការនាំចូល ដែលអាចទិញបានដោយប្រើប្រាស់រូបិយប័ណ្ណខ្លាំង (រួមទាំងអាវុធ)។ ក្នុងករណីណាក៏ដោយ ចម្ការកាហ្វេ និងអណ្តូងរ៉ែទង់ដែងត្រូវការពេលវេលា និងដើមទុនច្រើនដើម្បីផលិត ហើយពួកវាតំណាងអោយការប្រមូលផ្តុំដើមទុន ពួកគេមិនអាចគ្រាន់តែត្រូវបោះបង់ចោលនោះទេ។ លើសពីនេះ ជំនាញនិងការបណ្តុះបណ្តាលរបស់អ្នករស់នៅក្នុងស្រុក ទំនងជាត្រូវបានប្រមូលផ្តុំ នៅក្នុងឧស្សាហកម្មដែលមានស្រាប់។ ហេដ្ឋារចនាសម្ព័ន្ធដូចជាផ្លូវដែក ភាគច្រើនទំនងជាត្រូវបានបង្កើតឡើងដើម្បីបម្រើសេដ្ឋកិច្ចនាំចេញ។ ជាឧទាហរណ៍ នៅក្នុងប្រទេសអង់ហ្គោឡា និងណាមីប៊ី ផ្លូវដែកសំខាន់ៗដែលសាងសង់ក្នុងសម័យអាណានិគម ចេញពីតំបន់រុករករ៉ែឬចម្ការទៅកាន់កំពង់ផែតែប៉ុណ្ណោះ (សូមមើលក្រាហ្វិក ១២.១០)។

រដ្ឋឯករាជ្យថ្មីបានទទួលមរតកព្រំដែន ដែលត្រូវបានគូសនៅក្នុងរដ្ឋធានីអឺរ៉ុប ដោយមន្ត្រីជាជនជាតិបរទេសដោយសម្លឹងមើលតែលើផែនទី។ ជាលទ្ធផល ជាពិសេស នៅទ្វីបអាហ្វ្រិក ការប្រជែងផ្ទៃក្នុងនៃក្រុមជនជាតិភាគតិច និងតំបន់នានាបានធ្វើអោយរដ្ឋថ្មីមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តផែនការសេដ្ឋកិច្ចដែលស៊ីសង្វាក់គ្នា។ ក្នុងករណីមួយចំនួន ជម្លោះជាតិសាសន៍ នៅក្នុងអតីតអាណានិគមនាំអោយមានសង្គ្រាមស៊ីវិល ដែលបានបញ្ឈប់ឬបង្វែរការប្រមូលដើមទុនមកវិញ។

ក្រាហ្វិក ១២.១០ ព្រំដែន ផ្លូវដែក និងធនធាននៅអង់ហ្គោឡា និងណាមីប៊ី

ទោះបីជាប្រទេសអង់ហ្គោឡា និងណាមីប៊ីទទួលបានឯករាជ្យក៏ដោយ ក៏សម័យអាណានិគមបានធ្វើអោយព្រំដែន និងហេដ្ឋារចនាសម្ព័ន្ធនៅក្នុងតំបន់។



ទីបំផុត រដ្ឋាភិបាលនៃរដ្ឋក្រោយសម័យអាណានិគមជាច្រើនមិនដំណើរការប្រកបដោយប្រសិទ្ធភាពទេ ដែលបង្កើតជាឧបសគ្គមួយទៀតដល់ការប្រមូលផ្តុំទ្រព្យសម្បត្តិ។ ក្នុងករណីខ្លះ អំពើពុករលួយកាន់តែអាក្រក់ទៅៗបន្ទាប់ពីឯករាជ្យ (សូមមើលផ្នែក **អំពើពុករលួយ** នៅក្នុងមេរៀនទី ១៣)។ ក្នុងករណីផ្សេងទៀត រដ្ឋាភិបាលព្យាយាមដាក់ការគ្រប់គ្រងពីថ្នាក់កណ្តាលនិងធ្វើផែនការលើសេដ្ឋកិច្ចជាតិរបស់ពួកគេ ដោយផ្អែកលើជាតិនិយម គាំពារនិយម ឬសង្គមនិយម។

សរុបមក ការរំដោះចេញពីការគ្រប់គ្រងអាណានិគមមិនបានផ្លាស់ប្តូរការពិតផ្នែកសេដ្ឋកិច្ចនោះទេ។ ដៃគូពាណិជ្ជកម្មសំខាន់ៗនៃប្រទេសឯករាជ្យថ្មី ជាធម្មតាគឺជាអតីតចៅហ្វាយនាយអាណានិគមរបស់ពួកគេ។ ផលិតផលសំខាន់ៗជាធម្មតាត្រូវបានបង្កើតឡើងក្រោមអាណានិគមនិយម។អង្គភាពរដ្ឋបាល និងព្រំដែនទឹក

ត្រូវបានបង្កើតឡើងដោយជនជាតិអឺរ៉ុប។ រដ្ឋបានបន្តកាន់កាប់ទីតាំងបរិក្ខារដូចគ្នាក្នុងប្រព័ន្ធពិភពលោកបន្ទាប់ពីឯករាជ្យដូចមុន។ ហើយក្នុងករណីខ្លះ វាបានបន្តពឹងផ្អែកលើអតីតអាណានិគមរបស់ខ្លួនសម្រាប់សន្តិសុខ។

សម្រាប់ហេតុផលទាំងនេះដែលកើតមាននៅអំឡុងពេលបន្ទាប់ពីឯករាជ្យ ជួនកាល ត្រូវបានគេហៅថា នវអាណានិគម ឬអាណានិគមបែបថ្មី (neocolonialism) ដែលជាការបន្ត ការកេងប្រវ័ញ្ចអាណានិគមដោយគ្មានការគ្រប់គ្រងនយោបាយជាផ្លូវការ។ គំនិតនេះក៏គ្របដណ្តប់លើទំនាក់ទំនងនៃអឌ្ឍគោលខាងត្បូងជាមួយនឹងសហរដ្ឋអាមេរិកផងដែរ (ដោយមានករណីលើកលែងមួយចំនួន) ដែលមិនមែនជាអាណានិគមជាផ្លូវការនោះទេ។ ហើយវាគ្របដណ្តប់លើទំនាក់ទំនងអន្តរជាតិរវាងអឌ្ឍគោលខាងជើងនិងខាងត្បូងនៃរដ្ឋអាមេរិកឡាទីន ដែលឯករាជ្យអស់រយៈពេលជិតពីរសតវត្សមកហើយ។

ការពឹងអាស្រ័យ

អ្នកប្រាជ្ញទំនាក់ទំនងអន្តរជាតិបែបម៉ាក្សស៊ីសនិយម បានបង្កើតទ្រឹស្តីពឹងអាស្រ័យ ដើម្បីពន្យល់កង្វះការប្រមូលផ្តុំទ្រព្យសម្បត្តិនៅក្នុងបណ្តាប្រទេសតតិយលោក។ អ្នកប្រាជ្ញទាំងនេះបានកំណត់និយមន័យការពឹងអាស្រ័យថាជាស្ថានភាពមួយដែលការប្រមូលផ្តុំមូលធនមិនអាចទ្រទ្រង់ខ្លួនវា នៅផ្ទៃក្នុងរបស់ខ្លួនបានទេ។ ប្រទេសដែលពឹងអាស្រ័យលើគេ ត្រូវតែខ្ចីដើមទុនដើម្បីផលិតទំនិញ។ ការទូទាត់បំណុលរបស់វាបន្ទាប់មកកាត់បន្ថយការប្រមូលផ្តុះអតិរេក។ (ការពឹងអាស្រ័យ គឺជាទម្រង់នៃការពឹងពាក់គ្នាទៅវិញទៅមកជាអន្តរជាតិ តំបន់អ្នកមានត្រូវការផ្តល់ប្រាក់កម្ចីរបស់ពួកគេ ខណៈពេលតំបន់អ្នកក្រក៏ត្រូវការខ្ចីប្រាក់ផងដែរ] ប៉ុន្តែ វាគឺជាការពឹងផ្អែកគ្នាទៅវិញទៅមក ជាមួយនឹងអតុល្យភាពអំណាចខ្លាំង។)

អ្នកទ្រឹស្តីពឹងអាស្រ័យនិយមមិនផ្តោតលើរចនាសម្ព័ន្ធទាំងមូលនៃប្រព័ន្ធពិភពលោក (រដ្ឋស្នូល និងរដ្ឋជនបទ) ប៉ុន្តែ ត្រូវផ្តោតលើរបៀបដែលទំនាក់ទំនងវណ្ណៈផ្ទៃក្នុងរបស់រដ្ឋជនបទដំណើរការ។ ការអភិវឌ្ឍន៍ (ឬកង្វះនៃការអភិវឌ្ឍន៍) របស់បណ្តារដ្ឋតតិយលោក ត្រូវអាស្រ័យលើលក្ខខណ្ឌក្នុងស្រុក និងប្រវត្តិសាស្ត្ររបស់វា ទោះបីជាវាត្រូវបានប៉ះពាល់ដោយលក្ខខណ្ឌសកល ដូចគ្នានឹងប្រទេសផ្សេងទៀតដែលមានទីតាំងនៅតំបន់ជនបទក៏ដោយ។

លក្ខណៈដ៏សំខាន់ជាប្រវត្តិសាស្ត្រនៃការពឹងអាស្រ័យគឺ**សេដ្ឋកិច្ចបិទជិត** (enclave economy) ដែលក្នុងនោះ ទុនបរទេសត្រូវបានវិនិយោគនៅក្នុងប្រទេសតតិយលោក ដើម្បីទាញយកវត្ថុធាតុដើមជាក់លាក់ណាមួយ នៅទីកន្លែងណាមួយ ជាធម្មតាអាចជា អណ្តូងរ៉ែ អណ្តូងប្រេង ឬដីចម្ការ។ នៅទីនេះ វដ្តនៃការប្រមូលផ្តុំដើមទុនត្រូវបានចាប់ផ្តើមដោយដើមទុនបរទេស ត្រូវបានជំរុញដោយធនធានក្នុងស្រុក និងបញ្ចប់ ដោយខ្លួនវាផ្ទាល់ ជាមួយនឹងការលក់ផលិតផល នៅលើទីផ្សារបរទេស។ ការរៀបចំបែបនេះធ្វើអោយសេដ្ឋកិច្ចរបស់ប្រទេសភាគច្រើនគ្មានការប៉ះពាល់ លើកលែងតែការផ្តល់ការងារដល់កម្មករក្នុងស្រុកមួយចំនួន នៅក្នុងរដ្ឋបិទជិតនោះ និងផ្តល់ពន្ធដល់រដ្ឋ (ឬដាក់ហោប៉ៅរបស់មន្ត្រីរដ្ឋមួយចំនួន)។ យូរៗទៅ វាធ្វើអោយធនធានធម្មជាតិរបស់រដ្ឋបាត់បង់។

ខេត្តកាប៊ីនដា (Cabinda) ក្នុងប្រទេសអង់ហ្គោឡា ដែលមានទីតាំងនៅលើឆ្នេរសមុទ្រ ដាច់ចេញពីតំបន់ដទៃទៀតនៃប្រទេស គឺជាឧទាហរណ៍ល្អមួយនៃសេដ្ឋកិច្ចបិទជិត។ ក្រុមហ៊ុនប្រេងឆេវ៉ុន (Chevron) បូមប្រេងពីអណ្តូងធំមួយ នៅឈូងសមុទ្រ ដោយប្រាក់ទៅអោយមន្ត្រីរដ្ឋាភិបាលអង់ហ្គោឡា ដែលចំណាយអាវុធ និងដាក់ហោប៉ៅប្រាក់យ៉ាងច្រើនក្នុងអំពើពុករលួយដ៏គួរឲ្យកត់សម្គាល់។ ប្រជាជននៃទីក្រុងប៊ីនដា

ក្រៅពីចំនួនតិចតួចដែលធ្វើការអោយក្រុមហ៊ុន ឆេវ៉ុន រស់នៅក្នុងភាពក្រីក្រ ជាមួយនឹងហេដ្ឋារចនាសម្ព័ន្ធដែលដួលរលំ សេវារដ្ឋាភិបាលតិចតួច ការងារតិចតួច និងការលួចបន្លំដោយទាហានដែលមិនមានប្រាក់ខែ។ ទោះជាយ៉ាងណាក៏ដោយ នៅខាងក្នុងបរិវេណក្រុមហ៊ុន ឆេវ៉ុន កម្មករអាមេរិកបើកបរលើផ្លូវក្រាលកៅស៊ូ ញុាំម្ហូបអាហារអាមេរិក និងរីករាយជាមួយទីលានវាយកូនហ្គោល ១៨ រន្ធ។ ពួកគេចំណាយពេល ២៨ ថ្ងៃនៅទីនោះ ធ្វើការ ១២ ម៉ោង បន្ទាប់មកហោះហើរត្រឡប់ទៅសហរដ្ឋអាមេរិកវិញ សម្រាប់ពេលសម្រាក ២៨ ថ្ងៃ។ ធ្វើដំណើរចម្ងាយ ១២ ម៉ាយល៍ ទៅអាកាសយានដ្ឋានដោយឧទ្ធម្ភាគចក្រ ជនជាតិអាមេរិកកម្រនឹងចាកចេញពីបរិវេណដែលមានរបងដែលក្រុមហ៊ុន ឆេវ៉ុន ត្រូវបានគេរាយការណ៍ថា បានឡោមព័ទ្ធដោយគ្រាប់មីន។

គំរូប្រវត្តិសាស្ត្រផ្សេងគ្នា គឺផលិតកម្មដែលគ្រប់គ្រងដោយជាតិ ដែលក្នុងនោះវណ្ណៈមូលធននិយមក្នុងស្រុកគ្រប់គ្រងវដ្តនៃការប្រមូលផ្តុំទ្រព្យសម្បត្តិ ដោយផ្អែកលើការផលិតផលិតផលនាំចេញ។ ទំនោរវិលជុំនេះនៅតែពឹងផ្អែកលើទីផ្សារបរទេស ប៉ុន្តែប្រាក់ចំណេញកើនឡើងដល់មូលដ្ឋានមូលធននិយម បង្កើតក្រុមអ្នកមានអំណាចមួយក្រុមតូចក្នុងប្រទេស។ វណ្ណៈនេះ ដែលរួមមានពួកគហិបតីក្នុងស្រុក មានទំនោរធ្វើតវិយោបថស្របតាមផលប្រយោជន៍នៃប្រទេសឧស្សាហូបនីយកម្មសម្បូរបែប (អាស្រ័យលើទីផ្សារដែលវណ្ណៈនេះត្រូវពឹងអាស្រ័យ)។ ពួកគេមិនមែនជាអ្នកស្នេហាជាតិទេ ប៉ុន្តែ ផលប្រយោជន៍របស់ពួកគេមានទំនោរទៅរកពួកមូលធននិយមបរទេស។ ជាឧទាហរណ៍ ពួកគេចង់រក្សាប្រាក់ឈ្នួលក្នុងស្រុកអោយទាបតាមដែលអាចធ្វើបាន ហើយផលិតទំនិញថោកសម្រាប់អ្នកប្រើប្រាស់ នៅក្នុងប្រទេសអ្នកមាន។ ពួកមូលធននិយមក្នុងស្រុកចងសម្ព័ន្ធភាពជាមួយអាជ្ញាធរនយោបាយ អនុវត្តប្រព័ន្ធគ្រប់គ្រងដែលនៅទីបំផុតបម្រើអោយពួកមូលធននិយមបរទេសនេះ គឺជាទម្រង់នៃការពឹងអាស្រ័យមួយទៀត។

បន្ទាប់ពីសង្គ្រាមលោកលើកទី ២ ទម្រង់ទី ៣ នៃការពឹងអាស្រ័យបានក្លាយជារឿងធម្មតា នោះគឺការជ្រៀតចូលនៃសេដ្ឋកិច្ចជាតិដោយសាជីវកម្មពហុជាតិ។ នៅទីនេះ ដើមទុនត្រូវបានផ្តល់ជូនខាងក្រៅ (ដូចនឹងតំបន់សេដ្ឋកិច្ចបិទជិតដែរ) ប៉ុន្តែការផលិតគឺសម្រាប់ទីផ្សារក្នុងស្រុក។ ជាឧទាហរណ៍ រោងចក្រ General Motors(GM)នៅប្រទេសប្រេស៊ីលផលិតរថយន្តភាគច្រើនសម្រាប់តែលក់នៅក្នុងប្រទេសប្រេស៊ីល។ ដើម្បីបង្កើតទីផ្សារក្នុងស្រុកសម្រាប់ទំនិញផលិតបែបនេះ ប្រាក់ចំណូលត្រូវតែប្រមូលផ្តុំអោយបានគ្រប់គ្រាន់ ដើម្បីបង្កើតវណ្ណៈកណ្តាលដែលអាចទិញទំនិញប្រណិតបែបនេះបាន។ នេះធ្វើអោយមានភាពមិនស្មើគ្នានៃប្រាក់ចំណូលនៅក្នុងប្រទេស (ប្រជាជនភាគច្រើននៅតែក្រីក្រ)។ វដ្តនៃការប្រមូលផ្តុំទ្រព្យសម្បត្តិអាស្រ័យលើកម្លាំងពលកម្មក្នុងស្រុក និងទីផ្សារក្នុងស្រុក ប៉ុន្តែដោយសារ សាជីវកម្មពហុជាតិផ្តល់ដើមទុនបរទេស ពួកគេយកអតិរេកភាគច្រើនជាប្រាក់ចំណេញ។

យោងតាមទ្រឹស្តីពឹងអាស្រ័យ សរសេរស្តម្ភនៃកងកម្លាំងក្នុងផ្ទៃប្រទេសមួយកំណត់ថាតើក្រុមចម្រុះមួយណាបង្កើតក្នុងចំណោមរដ្ឋ ក្រុមយោធា ម្ចាស់ដីធំៗ ពួកមូលធននិយមក្នុងស្រុក ពួកមូលធននិយមបរទេស (MNCs) រដ្ឋាភិបាលបរទេស និងវណ្ណៈកណ្តាល ដូចជាអ្នកជំនាញ និងកម្មករឧស្សាហកម្មជំនាញ។ ម៉្យាងទៀត កសិករ កម្មករ និងពេលខ្លះសិស្សានុសិស្ស និងក្រុមជំនុំព្រះវិហារបង្កើតសម្ព័ន្ធភាព ដើម្បីធ្វើការបែងចែកប្រាក់ចំណូល សិទ្ធិមនុស្ស និងនយោបាយស្មើគ្នា និងការគ្រប់គ្រងសេដ្ឋកិច្ចក្នុងតំបន់។ សម្ព័ន្ធភាពវណ្ណៈទាំងនេះនិងទំនាក់ទំនងសង្គមជាលទ្ធផល មិនត្រូវបានកំណត់ដោយច្បាប់ទូទៅណាមួយទេ ប៉ុន្តែដោយ

លក្ខខណ្ឌជាក់ស្តែង និងការអភិវឌ្ឍន៍ប្រវត្តិសាស្ត្រនៅក្នុងប្រទេសនីមួយៗ។ ដូចទ្រឹស្តីម៉ាក្សនិយមផ្សេងទៀត ទ្រឹស្តីពឹងអាស្រ័យយកចិត្តទុកដាក់ជាពិសេសចំពោះការតស៊ូវណ្ណៈ ដែលជាប្រភពនៃការផ្លាស់ប្តូរសង្គម។

មនុស្សមួយចំនួនគិតថា នៅក្រោមលក្ខខណ្ឌនៃការពឹងអាស្រ័យ ការអភិវឌ្ឍន៍សេដ្ឋកិច្ច ស្ទើរតែមិនអាចទៅរួចទេ។ អ្នកផ្សេងទៀតគិតថា ការអភិវឌ្ឍន៍អាចធ្វើទៅបាន ក្រោមការពឹងអាស្រ័យ ទោះបីជាមានការលំបាកមួយចំនួនក៏ដោយ។ យើងនឹងត្រលប់ពិនិត្យមើលលទ្ធភាពទាំងនេះឡើងវិញ នៅក្នុងមេរៀនទី ១៣។

រូបថត រោងចក្ររបស់ក្រុមហ៊ុនតៃវ៉ាន់ ផលិតខោខូវប៊យលក់នៅសហរដ្ឋអាមេរិក។

ធ្វើការនៅក្នុងទីបិទជិត

សាជីវកម្មពហុជាតិ(MNCs) នឹងសាងសង់រោងចក្រនៅបរទេស ដើម្បីផលិតទំនិញជាមួយនឹងជាតុចូលថោក (សម្ភារៈ ឬកម្លាំងពលកម្ម) បន្ទាប់មកបញ្ជូនផលិតផលសម្រេចទៅកាន់ទីផ្សារធំជាងដើម្បីលក់ ដែលជាការប្រែប្រួលទំនើបនៃសេដ្ឋកិច្ចតំបន់។ នៅទីនេះ ស្ត្រីម្នាក់ធ្វើការដេរខោខូវប៊យក្នុងតំបន់ពាណិជ្ជកម្មសេរីក្នុងប្រទេសនីការ៉ាហ្គា ឆ្នាំ ២០០១។ រោងចក្រនេះគ្រប់គ្រងដោយក្រុមហ៊ុនតៃវ៉ាន់ ហើយខោខូវប៊យត្រូវបានចងសម្រាប់លក់នៅសហរដ្ឋអាមេរិក។

១២.៣.៥. ចលនាបដិវត្តន៍

ភាពក្រីក្រនិងកង្វះលទ្ធភាពទទួលបានតម្រូវការជាមូលដ្ឋានរបស់មនុស្ស គឺជាបុព្វហេតុជាចម្បងនៃបដិវត្តន៍ ជាពិសេសនៅពេលដែលប្រជាជនក្រីក្រឃើញអ្នកដទៃមានជីវភាពប្រសើរជាងខ្លួន។ ចលនាបដិវត្តន៍ភាគច្រើនជម្រុញឧត្តមគតិសមភាព ដូចជាការបែងចែកទ្រព្យសម្បត្តិនិងអំណាចស្មើៗគ្នា។

ក្នុងកំឡុងពេលសង្គ្រាមត្រជាក់ ចលនាបដិវត្តបុរាណគឺជាការបះបោរបែបកុម្មុយនិស្តដែលភាគច្រើនមានមូលដ្ឋានចេញពីជនបទ។ ជាធម្មតា «ចក្រពត្តិនិយមសហរដ្ឋអាមេរិក» ឬ វត្តមានបរទេសបែបនេះ ត្រូវបានចាត់ទុកជាមិត្តរបស់រដ្ឋ និងជាសត្រូវនៃបដិវត្តន៍។ ពេលខ្លះរដ្ឋាភិបាលសហរដ្ឋអាមេរិកបានផ្តល់ជំនួយជាយោធាដោយផ្ទាល់ដល់រដ្ឋាភិបាល ដែលកំពុងប្រឈមមុខនឹងចលនាបដិវត្តន៍បែបនេះ។ ទីប្រឹក្សាយោធាសហរដ្ឋអាមេរិក ហើយសូម្បីតែទាហានប្រយុទ្ធក៏ត្រូវបានបញ្ជូនទៅជួយទម្លាក់បដិវត្តន៍ និងការពារកុំអោយកុម្មុយនិស្តឡើងកាន់អំណាច នៅក្នុងប្រទេសមួយចំនួន។ សម្រាប់សហភាពសូវៀតវិញ ជាញឹកញាប់តែងតែធ្វើការបំពាក់អាវុធ និងជួយបណ្តុះបណ្តាលដល់ក្រុមបដិវត្តន៍។ ដូច្នេះហើយ នយោបាយក្នុងស្រុកនៃប្រទេសក្រីក្របានជាប់ពាក់ព័ន្ធជាមួយនយោបាយប្រទេសមហាអំណាច ក្នុងបរិបទនៃគម្លាតអឌ្ឍគោលខាងជើងនិងអឌ្ឍគោលខាងត្បូង។ តាមការពិត សម្រាប់រដ្ឋាភិបាល និងក្រុមបដិវត្តន៍ទាំងនេះ ភាគច្រើនមានទំនាក់ទំនងតិចតួចណាស់ជាមួយពួកកុម្មុយនិស្តសកល ពួកមូលធននិយមសកល ឬជាមួយក្រុមចក្រពត្តិនិយម។ ពួកគេតស៊ូដណ្តើមអំណាចក្នុងតំបន់ ជួនកាលរវាងអ្នកមាននិងអ្នកក្រ ជួនកាលរវាងក្រុមជាតិសាសន៍ដែលជាគូប្រជែងនឹងគ្នា ដែលទាក់ទាញប្រទេសមហាអំណាចអោយមកពាក់ព័ន្ធជាមួយ។

នៅដើមទសវត្សរ៍ឆ្នាំ ១៩៩០ បដិវត្តន៍កុម្មុយនិស្តទាំងនេះហាក់ដូចជាបានស្តែងចេញដោយខ្លួនឯង នៅកន្លែងខ្លះក៏បានជោគជ័យ និង នៅកន្លែងផ្សេងទៀតក៏បរាជ័យ និងឈានដល់ការជាប់គាំងនយោបាយនៅក្នុងប្រទេសមួយចំនួនផងដែរ។ ការបញ្ចប់នៃសង្គ្រាមត្រជាក់បានដកការគាំទ្ររបស់ក្រុមប្រទេសមហាអំណាចចេញពីភាគីទាំងសងខាង និងការដួលរលំនៃសហភាពសូវៀត និងការអនុវត្តកំណែទម្រង់សេដ្ឋកិច្ចដែលផ្តោតលើមូលធននិយមនៅក្នុងប្រទេសចិនបានកាត់បន្ថយការឃោសនាមនោគមវិជ្ជាបដិវត្តកុម្មុយនិស្ត។ ទោះជា

យ៉ាងនេះក្តី ចលនាបដិវត្តម៉ាក្សនិយមជារច្រើននៅបន្តអូសបន្លាយ រួមទាំងនៅប្រទេសកូឡុំប៊ី ប៉េរូ និងឥណ្ឌា។ នៅប្រទេសនេប៉ាល់ ពួកឧទ្ទាមម៉ៅនិយមបានវាយប្រយុទ្ធ អស់រយៈពេលមួយទសវត្សរ៍ហូតដល់មានកិច្ចព្រមព្រៀងសន្តិភាពឆ្នាំ ២០០៦ បន្ទាប់មកបានឈ្នះការបោះឆ្នោត និងក្លាយជាគណបក្សគ្រប់គ្រងប្រទេស។

នៅក្នុងគោលនយោបាយការបរទេស រដ្ឋាភិបាលបដិវត្តន៍តែងតែចាប់ផ្តើមរៀបចំផែនការទំនាក់ទំនងខុសគ្នាយ៉ាងខ្លាំងជាមួយប្រទេសជិតខាងនិងប្រទេសមហាអំណាច។ គំរូនៃសម្ព័ន្ធភាពអន្តរជាតិ ជារឿយៗផ្លាស់ប្តូរបន្ទាប់ពីបដិវត្តន៍ ដូចជានៅពេលដែលប្រទេសណាមួយនៅក្រោមឥទ្ធពលសង្គ្រាមត្រជាក់នៃប្រទេសមហាអំណាចមួយបានផ្លាស់ប្តូរទៅការគ្រប់គ្រងមួយទៀតបន្ទាប់ពីការផ្លាស់ប្តូររដ្ឋាភិបាល។ ប៉ុន្តែ ជាធម្មតា រដ្ឋាភិបាលថ្មីដឹងច្បាស់ថា នៅពេលដែលខ្លួនកាន់អំណាច វាមានផលប្រយោជន៍ដូចគ្នាទៅនឹងរដ្ឋដទៃទៀតក្នុងការលើកកម្ពស់អធិបតេយ្យភាពជាតិ និងបូរណភាពទឹកដី។ ច្បាប់នៃប្រព័ន្ធអន្តរជាតិ នៅពេលនេះ មានដំណើរការសម្រាប់អ្នកបដិវត្តជំនួសអោយការប្រឆាំងនឹងពួកគេ នៅពេលដែលពួកគេគ្រប់គ្រងរដ្ឋមួយ។ រដ្ឋរបស់ពួកគេក៏មានទីតាំងភូមិសាស្ត្រដូចពីមុនដែរ គឺមានលក្ខណៈប្រវត្តិសាស្ត្រដូចគ្នា។ ជម្លោះជាមួយប្រទេសជិតខាងនិងទំនាក់ទំនងជនជាតិដូចគ្នា។ ដូច្នេះ វាមិនមែនជារឿងចម្លែកទេ ក្នុងរយៈពេលកន្លងមក ក្នុងការស្វែងរកគោលនយោបាយការបរទេសស្រដៀងគ្នា ដែលចេញមកពីរដ្ឋាភិបាលបដិវត្តន៍ ដូចពីជំនាន់មុនរបស់ខ្លួន។ ទោះបីជាបដិវត្តន៍បង្កើតការផ្លាស់ប្តូរយៈពេលខ្លីក្នុងគោលនយោបាយការបរទេសក៏ដោយ ក្នុងរយៈពេលវែង ច្បាប់នៃទំនាក់ទំនងអន្តរជាតិមានទំនោរទៅរកជ័យជំនះលើបញ្ហាប្រឈមបដិវត្តន៍។

រូបថត លោក នេលសុន ម៉ាន់ដេឡា ក្នុងពិធីហែក្បួននៃសមាជជាតិអាហ្វ្រិក ១៩៩២

ជោគជ័យជំកម្រ

អតីតប្រធានាធិបតីអាហ្វ្រិកខាងត្បូង លោក នេលសុន ម៉ាន់ដេឡា (Nelson Mandela) (នៅទីនេះបានបង្ហាញនៅក្នុងការហែក្បួននៃសមាជជាតិអាហ្វ្រិកនៅ បូប៉ាតុង (Boipatong) ១៩៩២) បានទទួលជោគជ័យមិនធម្មតាក្នុងការធ្វើការផ្លាស់ប្តូរដ៏លំបាក ពីជនបដិវត្តន៍ទៅជាមេដឹកនាំរដ្ឋ ហើយបន្ទាប់មកបានចាកចេញពីតំណែងដោយសន្តិវិធី។ គាត់មានគុណសម្បត្តិក្នុងការឡើងកាន់អំណាចដោយអហិង្សា (គួរសម) រីករាយនឹងការគោរពពិភពលោកយ៉ាងខ្លាំង និងដឹកនាំប្រទេសដែលមានវិបុលភាព (ទោះបីជាមានវិសមភាពច្រើនក៏ដោយ) នៅក្នុងទ្វីបក្រីក្រខ្លាំងមួយ។

សរុបមក ទំនាក់ទំនងអឡឺគោលខាងជើងនិងអឡឺគោលខាងត្បូងបង្ហាញពីការលំបាកក្នុងការញែកសេដ្ឋកិច្ចនយោបាយអន្តរជាតិ(IPE)ចេញពីសន្តិសុខអន្តរជាតិ(IS)។ ទំនាក់ទំនងនយោបាយដើមដំបូងដែលបង្កប់នៅក្នុងចក្រពត្តិនិយមអឺរ៉ុប បាននាំអោយមានលក្ខខណ្ឌសេដ្ឋកិច្ចនៅអឡឺគោលខាងត្បូង ដូចជាកំណើនប្រជាជនខ្ពស់ នគរូបនីយកម្ម និងការប្រមូលផ្តុំទ្រព្យសម្បត្តិ ដែលនាំទៅដល់ចលនានយោបាយដើម្បីឯករាជ្យ ហើយក្រោយមកមានបដិវត្តន៍។ ទិដ្ឋភាពផ្សេងៗនៃគម្លាតអឡឺគោលខាងជើងនិងខាងត្បូង ដែលត្រូវបានពិចារណាក្នុងមេរៀននេះ រួមទាំង ការស្រេកឃ្លាន ជនភៀសខ្លួន និងរចនាសម្ព័ន្ធនៃការនាំចេញទំនិញសុទ្ធតែមានទាំងទិដ្ឋភាពសេដ្ឋកិច្ច និងនយោបាយ-យោធា។

ជនម៉ាក្សនិយមសង្កត់ធ្ងន់ថា សច្ចៈភាពសេដ្ឋកិច្ចនៃការប្រមូលផ្តុំទ្រព្យសម្បត្តិ ឬកង្វះនៃការប្រមូលផ្តុំបង្កប់នៅក្រោមការតស៊ូនយោបាយទាំងអស់ ដែលទាក់ទងនឹងទំនាក់ទំនងអឡឺគោលខាងជើងនិងអឡឺគោលខាងត្បូង។ ប៉ុន្តែ យុទ្ធសាស្ត្ររបស់ជនម៉ាក្សនិយម រាប់ចាប់ពីបដិវត្តន៍ប្រដាប់ដោយអាវុធ ដល់ការពឹងអាស្រ័យ

លើខ្លួនឯង រហូតដល់កម្មសិទ្ធិរបស់រដ្ឋ មិនបានជោគជ័យក្នុងការផ្លាស់ប្តូរសច្ចៈភាពទាំងនោះឡើយ។ ដូច្នេះ មេរៀនទី ១៣ ពិនិត្យយ៉ាងស៊ីជម្រៅអំពីសំណួរថា តើសេដ្ឋកិច្ចនៅអឡឡាគោលខាងត្បូងអាចបង្កើតដំណើរការប្រមូលផ្តុំទ្រព្យសម្បត្តិដោយរបៀបណា និងតួនាទីអ្វីដែលអឡឡាគោលខាងជើងអាចដើរតួ ក្នុងដំណើរការនោះ។

សេចក្តីសន្និដ្ឋាន

១. ប្រជាជនពិភពលោកភាគច្រើនរស់នៅក្នុងភាពក្រីក្រនៅអឡឡាគោលខាងត្បូង។ ប្រហែល ១ ពាន់លាននាក់រស់នៅក្នុងភាពក្រីក្រខ្លាំង ដោយមិនមានអាហារបរិភោគ ទឹកគ្រប់គ្រាន់ និងតម្រូវការផ្សេងៗទៀត។

២. ការប្រមូលផ្តុំទ្រព្យសម្បត្តិ (រួមទាំងអន្តរកាលប្រជាសាស្ត្រ ដែលបានពិភាក្សានៅក្នុងមេរៀនទី ១១) ត្រូវអាស្រ័យទៅលើការបំពេញតម្រូវការជាមូលដ្ឋានរបស់មនុស្ស ដូចជា លទ្ធភាពទទួលបានអាហារបរិភោគ ទឹកស្អាត ការអប់រំ ទីជម្រក និងការថែទាំសុខភាព។ ប្រទេសតតិយលោកបានទទួលជោគជ័យចម្រុះក្នុងការបំពេញតម្រូវការមូលដ្ឋានរបស់ប្រជាជនពួកគេ។

៣. ការស្រែកឃ្លាន និងកង្វះអាហារូបត្ថម្ភកំពុងរីករាលដាលនៅអឡឡាគោលខាងត្បូង។ មូលហេតុសំខាន់បំផុតគឺការបណ្តេញកសិករធ្វើកសិកម្មចិញ្ចឹមជីវិតចេញពីដីស្រែចម្ការរបស់ពួកគេ ដោយសារតែសង្គ្រាម សម្ពាធប្រជាជន និងការបំប្លែងដីកសិកម្មទៅជាចម្ការដាំដុះដំណាំនាំចេញ ដើម្បីរកប្រាក់កម្រៃ។

៤. នគរូបនីយកម្មកំពុងកើនឡើងពាសពេញអឡឡាគោលខាងត្បូង ដោយសារមនុស្សកាន់តែច្រើនផ្លាស់ទីពីទីជនបទទៅកាន់ទីក្រុង។ តំបន់អនាធិបតេយ្យដ៏ធំបានរីកធំធាត់នៅក្នុងទីក្រុង នៅពេលដែលប្រជាជនក្រីក្របានមកដល់ ហើយមិនអាចស្វែងរកការងារធ្វើបាន។

៥. តួនាទីស្នូលរបស់ស្ត្រី នៅក្នុងដំណើរការនៃការប្រមូលផ្តុំទ្រព្យសម្បត្តិ បានចាប់ផ្តើមត្រូវបានទទួលស្គាល់។ ទីភ្នាក់ងារអន្តរជាតិដែលមានមូលដ្ឋាននៅភាគខាងជើងបានចាប់ផ្តើមយកការរួមចំណែករបស់ស្ត្រីទៅក្នុងគណនីក្នុងការវិភាគការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅភាគខាងត្បូង។

៦. ភាពក្រីក្រនៅអឡឡាគោលខាងត្បូងបាននាំអោយជនចំណាកស្រុកមួយចំនួនធំ ខំស្វែងរកជីវិតប្រសើរជាងនៅអឡឡាគោលខាងជើង។ នេះបានបង្កើតឲ្យមានជម្លោះនយោបាយអន្តរជាតិ។ សង្គ្រាមនិងការគាបសង្កត់នៅអឡឡាគោលខាងត្បូង បានបង្កើតអោយមានស្ថានភាពជនភៀសខ្លួនរាប់លាននាក់ ខំស្វែងរកទីជម្រកសុវត្ថិភាព។ នៅក្រោមច្បាប់ និងបទដ្ឋានអន្តរជាតិ រដ្ឋជាទូទៅត្រូវបានគេសន្មត់ថាត្រូវទទួលយកជនភៀសខ្លួន ប៉ុន្តែមិនចាំបាច់ទទួលយកជនចំណាកស្រុកទេ។

៧. សង្គ្រាមគឺជាឧបសគ្គដ៏សំខាន់ក្នុងការបំពេញតម្រូវការមូលដ្ឋាន និងការប្រមូលផ្តុំទ្រព្យសម្បត្តិ ជាទូទៅនៅក្នុងប្រទេសក្រីក្រ។ សង្គ្រាមស្ទើរតែទាំងអស់ក្នុងរយៈពេល ៥០ ឆ្នាំចុងក្រោយនេះ ត្រូវបានប្រយុទ្ធគ្នានៅអឡឡាគោលខាងត្បូង។

៨. ការផ្លាស់ប្តូរពីភាពក្រីក្រទៅសុខុមាលភាពទាមទារការប្រមូលដើមទុន។ ពួកមូលធននិយមនិងពួកសង្គមនិយម មានទស្សនៈផ្សេងគ្នាលើដំណើរការនេះ។ ពួកមូលធននិយមសង្កត់ធ្ងន់លើកំណើនជារួមជាមួយនឹងការប្រមូលផ្តុំទ្រព្យសម្បត្តិយ៉ាងច្រើន ចំណែកពួកសង្គមនិយមសង្កត់ធ្ងន់លើការបែងចែកទ្រព្យសម្បត្តិដោយយុត្តិធម៌។

៩. រដ្ឋភាគច្រើនមានសេដ្ឋកិច្ចចម្រុះ ជាមួយនឹងកម្មសិទ្ធិឯកជនលើដើមទុន ខ្លះនិងកម្មសិទ្ធិរបស់រដ្ឋខ្លះដែរ។ ទោះយ៉ាងណាក៏ដោយ កម្មសិទ្ធិរបស់រដ្ឋមិនទទួលបានដោគដ័យយ៉ាងខ្លាំងក្នុងការប្រមូលទ្រព្យសម្បត្តិទេ។ អាស្រ័យហេតុនេះ រដ្ឋជាច្រើនបាននឹងកំពុងលក់សហគ្រាសរដ្ឋ(ឯកជនការូបនីយកម្ម) ជាពិសេសនៅក្នុងប្រទេសរុស្ស៊ីនិងអឺរ៉ុបខាងកើត។

១០. ចាប់តាំងពីសម័យលេនីនមក ពួកម៉ាក្សនិយមជាច្រើនបានចាត់ទុកភាពក្រីក្រនៅអឌ្ឍគោលខាងត្បូងថាជាការប្រមូលផ្តុំទ្រព្យសម្បត្តិនៅអឌ្ឍគោលខាងជើង។ បើយោងតាមទ្រឹស្តីនេះ ពួកមូលធននិយមនៅអឌ្ឍគោលខាងជើងកេងប្រវ័ញ្ចសេដ្ឋកិច្ចនៅអឌ្ឍគោលខាងត្បូង ហើយប្រើប្រាស់ទ្រព្យសម្បត្តិដែលបានបង្កើតដើម្បីទិញទឹកចិត្តកម្មករនៅភាគខាងជើង។ ដូច្នេះបដិវត្តន៍កើតឡើងនៅអឌ្ឍគោលខាងត្បូង ហើយនៅទីបំផុត ត្រូវបង្វែរប្រឆាំងនឹងអឌ្ឍគោលខាងជើង។

១១. អ្នកប្រាជ្ញទំនាក់ទំនងអន្តរជាតិ នៅក្នុងចង្កោមទស្សនៈប្រព័ន្ធពិភពលោកអះអាងថា អឌ្ឍគោលខាងជើងគឺជាតំបន់ស្នូល ដែលមានឯកទេសក្នុងការផលិតទំនិញ ហើយអឌ្ឍគោលខាងត្បូងគឺជាតំបន់ជនបទដែលមានឯកទេសក្នុងការទាញយកវត្ថុធាតុដើម តាមរយៈកសិកម្មនិងការជីកយករ៉ែ។ នៅចន្លោះតំបន់ទាំងពីរនេះ គឺជាតំបន់រដ្ឋជាយក្រុង ជាមួយនឹងការផលិតឧស្សាហកម្មធុនស្រាល។

១២. អរិយធម៌ពិភពលោកដទៃត្រូវបានសញ្ជ័យដោយជនជាតិអឺរ៉ុប ក្នុងរយៈពេលជាច្រើនសតវត្សរ៍ ហើយត្រូវបានស្រូបចូលយ៉ាងខ្លាំងក្លាទៅក្នុងប្រព័ន្ធអន្តរជាតិសកលរួមមួយ ដែលដំបូងឡើយបានផ្តោតលើទ្វីបអឺរ៉ុប។ គម្លាតអឌ្ឍគោលខាងជើងនិងខាងត្បូង នាពេលបច្ចុប្បន្ននេះ មានឫសគល់របស់វាចាប់តាំងពីការធ្វើអាណានិគមពីអតីតកាលលើតំបន់នានាក្នុងអឌ្ឍគោលខាងត្បូងដោយពួកអឺរ៉ុប។ ការធ្វើអាណានិគមនេះបានកើតឡើងនៅពេលវេលាផ្សេងៗគ្នា នៅក្នុងផ្នែកផ្សេងៗនៃពិភពលោក ក៏ដូចជាការរំសាយរបបអាណានិគមផងដែរ។

១៣. ដោយសារឥទ្ធិពលអវិជ្ជមានខ្លាំងនៃអាណានិគមនិយម មកលើប្រជាជនក្នុងស្រុក ចលនាប្រឆាំងអាណានិគមបានកើតមានឡើង ៣សពេញអឌ្ឍគោលខាងត្បូង ក្នុងពេលវេលាផ្សេងៗគ្នា និងប្រើប្រាស់វិធីសាស្ត្រផ្សេងៗ។ ទាំងនេះបានឈានដល់ដំណាក់កាលនៃចលនាឯករាជ្យដ៏ដោគដ័យមួយ បន្ទាប់ពីសង្គ្រាមលោកលើកទី ២ នៅអាស៊ី និងអាហ្វ្រិក។ (រដ្ឋអាមេរិកឡាទីនបានទទួលឯករាជ្យមុនយ៉ាងយូរ។)

១៤. បន្ទាប់ពីទទួលបានឯករាជ្យ រដ្ឋតតិយលោកត្រូវបានបន្សល់ទុកនូវកេរដំណែលនៃអាណានិគមនិយម រួមទាំងហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចជាមូលដ្ឋានរបស់ពួកគេ ដែលធ្វើអោយការប្រមូលផ្តុំទ្រព្យសម្បត្តិមានការលំបាកតាមមធ្យោបាយមួយចំនួន។ បញ្ហាទាំងនេះនៅតែបន្តកើតឡើង នៅក្នុងប្រទេសជាច្រើន។

១៥. នៅពេលដែលចលនាបដិវត្តន៍បានដោគដ័យក្នុងការដណ្តើមកាន់កាប់អំណាច ពួកគេតែងតែផ្លាស់ប្តូរគោលនយោបាយការបរទេសរបស់រដ្ឋពួកគេ។ ទោះជាយ៉ាងណាក៏ដោយ យូរ ៗ ទៅ ផលប្រយោជន៍ជាតិនិងយុទ្ធសាស្ត្រចាស់ៗ ហាក់បានលេចឡើងម្តងទៀត។ បន្ទាប់ពីកាន់អំណាចជាច្រើនទស្សវត្សរ៍មក ជន

បដិវត្ត ជាធម្មតា បានក្លាយជាអ្នកអភិរក្សនិយម ហើយជាពិសេស មកគាំទ្របទដ្ឋាន និងច្បាប់នៃប្រព័ន្ធអន្តរជាតិ (ដែលអំណោយផលដល់ពួកគេក្នុងនាមជាមេដឹកនាំរដ្ឋ)។

ពាក្យគន្លឹះ

១. ប្រទេសអភិវឌ្ឍន៍តិចតួច (less-developed countries- LDCs) គឺជាតំបន់ក្រីក្របំផុតរបស់ពិភពលោកអឌ្ឍគោលខាងត្បូង ដែលជាកន្លែងដែលមនុស្សភាគច្រើនរស់នៅ។ ក៏ត្រូវហៅថាជា *ប្រទេសមិនអភិវឌ្ឍន៍* ឬ*ប្រទេសកំពុងអភិវឌ្ឍន៍*ផងដែរ។

២. ប្រទេសកំពុងអភិវឌ្ឍន៍ (developing countries) គឺជារដ្ឋនៅអឌ្ឍគោលខាងត្បូង ដែលជាតំបន់ក្រីក្របំផុតនៅលើពិភពលោក។ ក៏ត្រូវហៅផងដែរថាជា *ប្រទេសតតិយលោក ប្រទេសមិនសូវអភិវឌ្ឍន៍* និង *ប្រទេសមិនទាន់អភិវឌ្ឍ*។

៣. គោលដៅអភិវឌ្ឍន៍ប្រកបដោយចេរភាព (SDG) គឺជាគោលដៅរបស់អង្គការសហប្រជាជាតិសម្រាប់វិធានការតម្រូវការជាមូលដ្ឋាន ដូចជាការកាត់បន្ថយភាពក្រីក្រ និងការស្រេកឃ្លាន ដែលបានអនុម័តក្នុងឆ្នាំ ២០០០។

៤. តម្រូវការមូលដ្ឋានរបស់មនុស្ស (basic human needs) គឺជា តម្រូវការជាមូលដ្ឋានរបស់មនុស្សដើម្បីទទួលបានអាហារបរិភោគគ្រប់គ្រាន់ ទឹកស្អាត ទីជម្រក ការថែទាំសុខភាព អនាម័យ និងការអប់រំ។ ការបំពេញតម្រូវការបែបនេះអាចត្រូវបានគេគិតថាជាកត្តាចាំបាច់ខាងសីលធម៌ និងទម្រង់នៃការវិនិយោគនៅក្នុង «មូលធនមនុស្ស» ចាំបាច់សម្រាប់កំណើនសេដ្ឋកិច្ច។

៥. កង្វះអាហារូបត្ថម្ភ (malnutrition) គឺជាកង្វះអាហារដែលត្រូវការ រួមទាំងប្រូតេអ៊ីន និងវីតាមីន។ កុមារប្រហែល ៣ លាននាក់បានស្លាប់ជារៀងរាល់ឆ្នាំ ដោយសារមូលហេតុទាក់ទងនឹងកង្វះអាហារូបត្ថម្ភ។

៦. កសិកម្មចិញ្ចឹមជីវិត (subsistence farming) គឺជាសហគមន៍ជនបទដាំដំណាំជាចម្បងសម្រាប់ការប្រើប្រាស់ឬបរិភោគផ្ទាល់ខ្លួន ជាជាងលក់នៅតាមទីផ្សារក្នុងស្រុកឬពិភពលោក។

៧. ដំណាំសាច់ប្រាក់ (cash crops) គឺជាទំនិញកសិកម្មឧស្សាហកម្មសម្រាប់នាំចេញទៅកាន់ទីផ្សារពិភពលោក។

៨. នគរូបនីយកម្ម(urbanization) គឺជាការផ្លាស់ប្តូរចំនួនប្រជាជនពីទីជនបទទៅកាន់ទីក្រុង ដែលជាធម្មតារួមជាមួយនឹងការអភិវឌ្ឍសេដ្ឋកិច្ច និងត្រូវបានកើនឡើង ដោយការផ្លាស់ទីលំនៅរបស់កសិករពីការប្រកបរបរកសិកម្មចិញ្ចឹមជីវិត។

៩. កំណែទំរង់ដីធ្លី (land reform) គឺជា គោលនយោបាយកំណែទម្រង់ដីធ្លី ដែលមានគោលបំណងបំបែកការកាន់កាប់ដីធំៗនិងចែកចាយដីឡើងវិញដល់កសិករក្រីក្រសម្រាប់ប្រើប្រាស់ក្នុងកសិកម្មចិញ្ចឹមជីវិត។

១០. អន្តោប្រវេសន៍(migration) គឺជាចលនាបម្លាស់ទីរវាងរដ្ឋនានា ជាធម្មតា ការធ្វើចំណាកស្រុកចេញពីរដ្ឋចាស់ និងធ្វើអន្តោប្រវេសន៍ចូលទៅរដ្ឋថ្មី។

១១. ជនភៀសខ្លួន (refugees) គឺជាប្រជាជនដែលភៀសខ្លួនចេញពីប្រទេសរបស់ពួកគេ ដើម្បីស្វែងរកកន្លែងជ្រកកោនដោយគេចចេញពីសង្គ្រាម គ្រោះធម្មជាតិ ឬការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយ។ ច្បាប់អន្តរជាតិបែងចែកពួកគេចេញពីជនចំណាកស្រុក។

១២. ប្រាក់បញ្ជើរទៅស្រុក (remittances) គឺជាទឹកប្រាក់ផ្ញើត្រលប់ទៅផ្ទះ ដោយពលករចំណាកស្រុកទៅបុគ្គល(ជាធម្មតាសាច់ញាតិ) នៅក្នុងប្រទេសកំណើតរបស់ពួកគេ។

១៣. អតិរេកសេដ្ឋកិច្ច (economic surplus) គឺជា អតិរេកដែលបង្កើតឡើងដោយការវិនិយោគប្រាក់នៅក្នុងដើមទុនផលិតកម្ម ជាជាងប្រើប្រាស់វាសម្រាប់ការប្រើប្រាស់តែម្តង។

១៤. ប្រព័ន្ធពិភពលោក (world-system) គឺជាទិដ្ឋភាពនៃពិភពលោក ទាក់ទងនឹងការបែងចែកវណ្ណៈក្នុងតំបន់ដែលមានប្រទេសឧស្សាហូបនីយកម្មជារដ្ឋស្នូល ប្រទេសក្រីក្របំផុតជារដ្ឋជនបទ និងតំបន់ផ្សេងទៀត (ឧទាហរណ៍ បណ្តាប្រទេសឧស្សាហកម្មថ្មីៗថ្មោងមួយចំនួន) ជាតំបន់ជាយក្រុង។

១៥. បណ្តាសារធនធាន (resource curse) គឺជាការលំបាកដែលប្រឈមដោយប្រទេសកំពុងអភិវឌ្ឍន៍ និងសំបូរទៅដោយធនធានធម្មជាតិ រួមទាំងការពឹងផ្អែកលើការនាំចេញទំនិញមួយឬច្រើន ដែលមានតម្លៃប្រែប្រួលខ្លាំង ក៏ដូចការញុាំញីដោយអំពើពុករលួយនិងវិសមភាពសង្គម។

១៦. ចក្រព័ត្តិនិយម(imperialism)គឺជាការពង្រីកដែនដីអាណានិគមដោយការធ្វើសង្គ្រាម ឬមធ្យោបាយផ្សេងទៀត។ ទ្រឹស្តីចក្រពត្តិនិយមរបស់លេនីនបានអះអាងថា មូលធននិយមអឺរ៉ុបកំពុងវិនិយោគលើដែនដីអាណានិគម ដែលពួកគេអាចទទួលបានប្រាក់ចំណេញយ៉ាងច្រើន ហើយបន្ទាប់មកប្រើប្រាស់ប្រាក់ចំណេញមួយចំណែកដើម្បីទិញទឹកចិត្តវណ្ណៈកម្មករនៅមាតុប្រទេស។

១៧. អាណានិគមបែបថ្មីឬនវអាណានិគម(neocolonialism) គឺជាការបន្តធ្វើអាជីវកម្មបែបអាណានិគមក្នុងអតីតដែនដីអាណានិគម ដោយគ្មានការគ្រប់គ្រងនយោបាយផ្លូវការ។

១៨. ទ្រឹស្តីពឹងអាស្រ័យនិយម (dependency theory) គឺជាទ្រឹស្តីម៉ាក្សនិយម ដែលពន្យល់ពីការខ្វះខាតនៃការប្រមូលមូលធន នៅក្នុងប្រទេសតតិយលោកដែលជាលទ្ធផលនៃអន្តរកម្មរវាងទំនាក់ទំនងវណ្ណៈក្នុងស្រុកនិងកម្លាំងនៃមូលធនបរទេស។ សូមមើលផងដែរ *សេដ្ឋកិច្ចបិទជិត* ឬ *សេដ្ឋកិច្ចហ៊ុំព័ទ្ធ* ផងដែរ។

១៩. សេដ្ឋកិច្ចហ៊ុំព័ទ្ធឬបិទជិត(enclave economy) គឺជាទម្រង់នៃការពឹងអាស្រ័យដ៏សំខាន់ជាលក្ខណៈប្រវត្តិសាស្ត្រ ដែលដើមទុនបរទេសត្រូវបានវិនិយោគនៅក្នុងប្រទេសតតិយលោក ដើម្បីទាញយកវត្ថុធាតុដើមជាក់លាក់ណាមួយ នៅកន្លែងណាមួយ ជាធម្មតាអណ្តូងរ៉ែ អណ្តូងប្រេង ឬដីស្រែចម្ការ។ សូមមើល *ទ្រឹស្តីភាពអាស្រ័យ* ផងដែរ។

សំណួរអនុវត្តន៍

១. តើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាមេរិកខាងជើង (NAFTA) ដែលបានពិភាក្សានៅក្នុងមេរៀនទី ៨ ឆ្លុះបញ្ចាំងពីស្ថានភាពទូទៅនៃទំនាក់ទំនងអឌ្ឍគោលខាងជើងនឹងខាងត្បូង ដូចដែលបានពិពណ៌នានៅក្នុង

មេរៀននេះ ដោយរបៀបណា? តើមូលធននិយមនិងសង្គមនិយមមានទស្សនៈ ចំពោះកិច្ចព្រមព្រៀងនេះ យ៉ាងដូចម្តេច? ចូរផ្តោតទ្រឹស្តីនៃការប្រមូលទ្រព្យសម្បត្តិ។

២. តំបន់សេដ្ឋកិច្ចពិភពលោក ដូចដែលបានពិពណ៌នាដោយអ្នកទ្រឹស្តីប្រព័ន្ធពិភពលោក ចាត់ទុកអឌ្ឍគោលខាងជើងជាតំបន់ស្នូល និងអឌ្ឍគោលខាងត្បូងជាតំបន់ជនបទ។ តើអ្នកអាចគិតឃើញករណីលើកលែងចំពោះរូបមន្តនេះបានទេ? តើការលើកលែងបែបនេះអាចប៉ះពាល់ដល់គំនិតទូទៅដែលត្រូវបានអនុវត្តចំពោះទំនាក់ទំនងអឌ្ឍគោលខាងជើងនិងខាងត្បូងយ៉ាងដូចម្តេច? ចូរបញ្ជាក់លម្អិតអំពីមូលហេតុដែលការលើកលែងមិនសមនឹងទ្រឹស្តីប្រព័ន្ធពិភពលោក។

៣. នៅអាមេរិកខាងជើងនិងខាងត្បូង ឯករាជ្យភាពពីអាណានិគមនិយមត្រូវទាមទារបាន ដោយកូនចៅនៃអាណានិគមខ្លួនឯង។ នៅអាស៊ីនិងអាហ្វ្រិក វាត្រូវបានទាមទារបាន ដោយប្រជាជនម្ចាស់ស្រុក ដែលមានប្រវត្តិផ្ទាល់ខ្លួនជាយូរលង់ណាស់មកហើយ។ តើអ្នកគិតថាទិដ្ឋភាពនេះជះឥទ្ធិពលយ៉ាងដូចម្តេច ទៅលើប្រវត្តិសាស្ត្រប្រទេសជាតិណាមួយឬច្រើន ក្រោយសម័យអាណានិគម ពីក្រុមនីមួយៗ?

៤. ឧបមាថាអ្នកបានរស់នៅក្នុងតំបន់ក្រីក្រខ្លាំងមួយ នៅអឌ្ឍគោលខាងត្បូង ហើយមិនមានប្រាក់ឬការងារអ្វីទេ ប៉ុន្តែ អ្នកនៅតែមានចំណេះដឹងទាំងអស់ ដែលអ្នកមានស្រាប់ហើយ។ តើអ្នកនឹងប្រើយុទ្ធសាស្ត្រអ្វីខ្លះសម្រាប់ការរស់រាននិងសុខុមាលភាពផ្ទាល់ខ្លួន? តើយុទ្ធសាស្ត្រអ្វីដែលអ្នកអាចបដិសេធបាន ថាមិនអាចធ្វើទៅរួច? តើអ្នកនឹងទទួលយកឬបដិសេធគំនិតបដិវត្តដែរឬទេ? ហេតុអ្វី?

៥. បច្ចុប្បន្ននេះ ប្រាក់ចំណូលរបស់មនុស្សម្នាក់ នៅអឌ្ឍគោលខាងជើង មានកំរិតខ្ពស់ជាង មនុស្សម្នាក់ៗ នៅអឌ្ឍគោលខាងត្បូង ចំនួន ៥ ដង។ ប្រសិនបើអ្នកអាចបែងចែកចំណូលរបស់ពិភពលោក ដោយមន្តអាគមដើម្បីអោយមនុស្សគ្រប់គ្នាមានប្រាក់ចំណូលស្មើគ្នា (១០០០០ ដុល្លារសម្រាប់មនុស្សម្នាក់ក្នុងមួយឆ្នាំ) តើអ្នកនឹងធ្វើវា ដែរឬទេ? តើការផ្លាស់ប្តូរបែបនេះនឹងជះឥទ្ធិពលអ្វីខ្លះដល់អឌ្ឍគោលខាងជើងនិងខាងត្បូង?

ការស្វែងរកផលប្រយោជន៍រួម

របបជនកៀសខ្លួន

ផលប្រយោជន៍រួម៖សុខុមាលភាពរបស់ជនកៀសខ្លួន

សារតារ

សង្គ្រាមនិងគ្រោះមហន្តរាយតែងតែធ្វើអោយមនុស្សរាប់លាននាក់ផ្លាស់ទីលំនៅ ចេញពីផ្ទះសម្បែងរបស់ពួកគេ ខណៈដែលពួកគេត្រូវស្វែងរកសុវត្ថិភាព និងការរស់រានមានជីវិតដោយការកៀសខ្លួន។ មិនជាញឹកញាប់នោះទេ ដែលពួកគេមានវត្តមាននៅព្រំដែនអន្តរជាតិមួយ ដែលស្វែងរកការឆ្លងកាត់និងស្វែងរកកន្លែងជ្រកកោននៅរដ្ឋមួយទៀត។ រដ្ឋដែលអនុញ្ញាតអោយពួកគេក្នុងការធ្វើដូច្នេះ នឹងប្រឈមនឹងការចំណាយដ៏ច្រើនសន្ធឹកសន្ធាប់។ ពិភពលោកទាំងមូលត្រូវបានត្រូវបានសង្គ្រោះ ដោយការជួយជនកៀសខ្លួន ពីព្រោះថាការធ្វើដូច្នេះបានរារាំងអស្ថិរភាពនយោបាយនិងសេដ្ឋកិច្ច(ក៏ដូចជាហានិភ័យសុខភាពសាធារណៈ) ដល់ប្រជាជនដែលអស់សង្ឃឹមមិនអាចគ្រប់គ្រងស្ថានភាពបាន។ ដូច្នេះ ការមើលថែជនកៀសខ្លួន គឺជាដំណោះស្រាយបញ្ហាផលប្រយោជន៍រួមសម្រាប់រដ្ឋនានាក្នុងពិភពលោក។

បញ្ហាប្រឈម

ក្នុងឆ្នាំ ២០១៧ ពិភពលោកមានជនភៀសខ្លួនប្រហែល ១៨ លាននាក់ (និង ៤០ លាននាក់ផ្សេងទៀតបានផ្លាស់ទីលំនៅ ប៉ុន្តែនៅតែរស់នៅក្នុងប្រទេសរបស់ពួកគេ)។ ៨០ ភាគរយគឺជាប្រជាជននៅអឡឹគោលខាងត្បូង។ ជាមួយនឹងសង្គ្រាមដែលភាគច្រើនកើតឡើងនៅក្នុងតំបន់ក្រីក្រនៃពិភពលោក ប្រទេសជិតខាងដែលរំពឹងថានឹងស្រូបយកជនភៀសខ្លួន តែងតែខ្វះធនធានសម្រាប់ផ្គត់ផ្គង់ពួកគេ។ ដូច្នេះហើយ រដ្ឋខ្លះបង្ហាញភាពប្រឆើយកន្តើយ និងបង្វែរជនភៀសខ្លួនចេញពីព្រំដែន។

ដំណោះស្រាយ

គោលការណ៍អត្តសញ្ញាណអាចដើរតួនាទីមួយ ដូចជានៅពេលដែលជនភៀសខ្លួនគឺជាជនជាតិភាគតិចដែលត្រូវបានគេធ្វើទុក្ខបុកម្នេញ ដែលឆ្លងកាត់ព្រំដែនចូលទៅក្នុងប្រទេសដែលក្រុមជនជាតិភាគតិចរបស់ពួកគេភាគច្រើន។ បន្ទាប់មក ប្រទេសម្ចាស់ផ្ទះកំណត់អត្តសញ្ញាណជាមួយពួកគេ ហើយកាន់តែមានធន្ធ:ក្នុងការផ្តល់សម្រាប់ពួកគេ។ ទោះជាយ៉ាងណាក៏ដោយ វិធីសាស្ត្រសំខាន់គឺគោលការណ៍បដិការ មិនរំពឹងថាប្រទេសនានានឹងទទួលយកជនភៀសខ្លួន ដោយគ្រាន់តែចេញពីចិត្តរបស់ពួកគេប៉ុណ្ណោះទេ ប៉ុន្តែក៏មិនគំរាមកំហែងពួកគេ ឬបង្ខំពួកគេអោយធ្វើដូច្នេះដែរ។

របបជនភៀសខ្លួនរបស់ពិភពលោក គឺជាសំណុំនៃច្បាប់ដែលមានមូលដ្ឋានលើគោលការណ៍បដិការ ហើយដែលរដ្ឋនានាក្នុងពិភពលោកបានយល់ព្រមជាមួយគ្នា។ រដ្ឋទាំងអស់ត្រូវអនុវត្តតាមច្បាប់ដូចគ្នា ដែលតម្រូវអោយពួកគេទទួលយកជនភៀសខ្លួនពីសង្គ្រាម។ ដើម្បីជួយដល់ប្រទេសម្ចាស់ផ្ទះ សហគមន៍អន្តរជាតិមានអង្គការអន្តរជាតិមួយ គឺឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន(UNHCR) ដើម្បីជួយមើលថែទាំដល់ជនភៀសខ្លួន។ ការផ្តល់មូលនិធិរបស់ UNHCR គឺជាបញ្ហាផលប្រយោជន៍រួម ហើយទីភ្នាក់ងារនេះច្រើនតែខ្វះការផ្គត់ផ្គង់ដែលត្រូវការជាចាំបាច់នៅពេលដែលទំនិញមិនត្រូវបានផ្តល់អោយ។

មតិសាធារណៈ និងទំនាក់ទំនងអន្តរជាតិ

សីលធម៌ និងសុខភាព

ការទទួលបានវិធីពន្យារកំណើតមួយចំនួន ជារឿយៗ ត្រូវបានកំណត់ថាជាកត្តាគន្លឹះជួយដល់សុខភាពស្ត្រី។ ការសិក្សាជាបន្តបន្ទាប់បានបង្ហាញថា ការទទួលបានវិធីសាស្ត្រពន្យារកំណើតមានសារៈសំខាន់ណាស់ចំពោះសុខភាពស្ត្រី និងកុមារ។ ការប្រើប្រាស់ថ្នាំពន្យារកំណើតត្រូវបានរកឃើញដើម្បីទប់ស្កាត់ការស្លាប់របស់មាតារាប់រយពាន់នាក់ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ ការទុកពេលអោយបានច្រើនរវាងកម្លាតនៃកុមារអាចកាត់បន្ថយអត្រាមរណភាពរបស់កុមារអាយុក្រោម ៥ ឆ្នាំបានប្រមាណ២៥%។

យ៉ាងណាក៏ដោយ ជំនឿសាសនា បទដ្ឋានវប្បធម៌ និងសក្តានុពលនៃគ្រួសារមានឥទ្ធិពលយ៉ាងខ្លាំងទៅលើអាកប្បកិរិយាឆ្ពោះទៅរកការគ្រប់គ្រងការបង្កកំណើត។ ដូច្នេះ បុគ្គលគ្រប់រូបអាចមានទស្សន:ខុសគ្នាខ្លាំងចំពោះសីលធម៌នៃការពន្យារកំណើត។ នេះអាចជាការពិតសូម្បីតែនៅក្នុងគ្រួសារក៏ដោយ៖ នៅក្នុងការសិក្សាដ៏ល្បីល្បាញមួយ បានពន្យល់ពីការពន្យារកំណើតត្រូវបានផ្តល់ជូនស្ត្រីមួយចំនួន នៅចំពោះមុខស្វាមីរបស់ពួកគេ ខណៈដែលអ្នកផ្សេងទៀតវាត្រូវបានផ្តល់ជូនជាលក្ខណៈឯកជន។ ប៉ុន្មានខែក្រោយមក អ្នកដែលត្រូវបានផ្តល់ជូនជាឯកជន គឺទំនងជា តិចជាង ៥០ ភាគរយនៃការមានផ្ទៃពោះដែលមិនចង់បាន។


យ៉ាងណាមិញ ការបំរែបំរួលនៃមតិមាននៅទូទាំងប្រទេសបានលេចឡើង នៅពេលសំណួរចោតសួរថា តើការប្រើប្រាស់ការពន្យារកំណើតជាការរៀបចំផែនការគ្រួសារដែលមានសីលធម៌ឬអត់នោះ។ ការស្វង់មតិ

មួយក្នុងឆ្នាំ ២០១៣ ដែលធ្វើឡើងនៅក្នុងប្រទេសចំនួន ៣៩ បានសួរថា តើការប្រើប្រាស់ថ្នាំពន្យារកំណើតអាចទទួលយកបាន ដោយសីលធម៌ ឬមិនអាចទទួលយកបាន ផ្អែកលើស្ថានភាពសីលធម៌ ឬមិនមែនជាបញ្ហាសីលធម៌ទាល់តែសោះ។ លទ្ធផលត្រូវបានបង្ហាញក្នុងក្រាហ្វិក ១២.៤ ។

ក្រាហ្វិក ១២.៤ ទិដ្ឋភាពសកលនៃការប្រើប្រាស់ថ្នាំពន្យារកំណើត

ប្រភព៖ មជ្ឈមណ្ឌលស្រាវជ្រាវ Pew

ការប្រើប្រាស់ថ្នាំពន្យារកំណើតមានលក្ខណៈ...



ត្រូវសីលធម៌ ខុសសីលធម៌ មិនមែនជាបញ្ហាសីលធម៌ តាមស្ថានភាពសីលធម៌

សម្រាប់អ្នកឆ្លើយតបនៅក្នុងប្រទេសភាគច្រើន ការឆ្លើយតបទូទៅបំផុតគឺថាការប្រើប្រាស់ថ្នាំពន្យារកំណើត អាចត្រូវទទួលយកបានតាមសីលធម៌។ ជាការពិតណាស់ សម្រាប់ប្រទេសភាគច្រើននៃអាមេរិកខាងជើងនិងអឺរ៉ុប ប្រជាជនភាគច្រើនបានឆ្លើយតបថា ការពន្យារកំណើតគឺអាចទទួលយកបានដោយសីលធម៌ ឬមិនមែនជាបញ្ហាសីលធម៌ទាល់តែសោះ។ ទោះយ៉ាងណាក៏ដោយ ក៏មានការប្រែប្រួលសម្រាប់មតិកាន់តែច្រើនដែរនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ នៅក្នុងប្រទេសចំនួនពីរ អ្នកឆ្លើយសំណួរភាគច្រើនយល់ថា ការពន្យារកំណើតមិនអាចទទួលយកបាន៖ ប្រទេសប៉ាគីស្ថាន និងនីហ្សេរីយ៉ា។ នៅក្នុងរដ្ឋកំពុងអភិវឌ្ឍន៍ផ្សេងទៀត ការមិនយល់ព្រមលើការប្រើប្រាស់ថ្នាំពន្យារកំណើត មានកម្រិតខ្ពស់គួរសម៖ ឧទាហរណ៍រួមមានប្រទេសហ្គាណា ទុយនេស៊ី និងអ៊ូហ្គង់ដា។ នៅប្រទេសលីបង់ មានមនុស្សតិចណាស់រកឃើញការពន្យារកំណើតដែលអាចទទួលយកបានតាមសីលធម៌ ប៉ុន្តែមនុស្សតិចណាស់យល់ថា វាមិនអាចទទួលយកបានតាមសីលធម៌។ ការឆ្លើយតបរបស់មនុស្សជាច្រើន នៅក្នុងប្រទេសនោះធ្លាក់ចូលទៅក្នុងប្រភេទពីរផ្សេងទៀតនៃស្ថានភាពសីលធម៌ ឬមិនមែនជាបញ្ហាសីលធម៌។

ប្រសិនបើការធ្វើផែនការគ្រួសារមានសារៈសំខាន់ចំពោះសុខភាពស្ត្រីនិងកុមារដែលធ្វើអោយកត្តាទាំងពីរនេះមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច ការជូនដំណឹងនិងអប់រំសាធារណៈជនអំពីប្រធានបទនេះ នឹងប្រាកដណាស់វានឹងមានភាពរសើបចំពោះបទដ្ឋានសាសនា និងវប្បធម៌ផ្សេងៗគ្នា។ វិធីសាស្ត្ររៀបចំ

ផែនការគ្រួសារនៅលើបង់ត្រូវតែខុសពីប្រទេសប៉ាគីស្ថាន។ អាស្រ័យហេតុនេះ ឥទ្ធិពលនៃមតិលើប្រធានបទនេះ ពិតជាមានសារៈសំខាន់ខ្លាំងណាស់ តាមទស្សនៈគោលនយោបាយសាធារណៈ។

ទស្សនៈវិស័យគោលនយោបាយ

ប្រធានាធិបតីនៃប្រទេសបុតស្វាណា លោក ម៉ុកវីតស្គី ម៉ាស៊ីស៊ី (Mokgweetski Masisi)

រូបថត ប្រធានាធិបតី ម៉ាស៊ីស៊ី

បញ្ហា តើអ្នកប្រឈមមុខនឹងវិបត្តិមនុស្សធម៌ក្នុងតំបន់ដោយរបៀបណា ដោយមិនបាត់បង់សុខុមាលភាពរបស់ប្រជាជនខ្លួនឯង?

សាវតារ

ស្រមៃថាអ្នកគឺជាប្រធានាធិបតីនៃប្រទេសបូតស្វាណា។ ប្រទេសជិតខាងរបស់អ្នកនៅភាគខាងកើតគឺប្រទេសហ្ស៊ីមបាវ៉េ បានឆ្លងកាត់វិបត្តិនយោបាយ សេដ្ឋកិច្ច និងសង្គមជាច្រើនឆ្នាំ។ យ៉ាងណាក៏ដោយ ថ្មីៗនេះ រដ្ឋប្រហារយោធាបានដណ្តើមអំណាចផ្តាច់ការយូរមកហើយរបស់ប្រទេសហ្ស៊ីមបាវ៉ េ គឺ លោក រ៉ូប៊ឺត មូហ្គាបេ (Robert Mugabe)។ នេះបាននាំមកនូវក្តីសង្ឃឹមថា ប្រទេសហ្ស៊ីមបាវ៉េនឹងមានស្ថិរភាពនយោបាយកាន់តែខ្លាំង។ យ៉ាងណាមិញ រដ្ឋាភិបាលថ្មីរបស់ប្រទេសហ្ស៊ីមបាវ៉េកំពុងជួបការលំបាកខ្លាំងផ្នែកសេដ្ឋកិច្ច។ មានវិបត្តិកង្វះស្បៀងអាហារដែលអាចកើតមានដោយសារលក្ខខណ្ឌគ្រោះរាំងស្ងួត នៅតាមក្នុងផ្នែកខ្លះនៃប្រទេស។ សេដ្ឋកិច្ច ហ្ស៊ីមបាវ៉ េ ក៏មានបញ្ហាផងដែរ ជាមួយនឹងអត្រាអតិផរណាលើសពី ២០០ លានភាគរយ។ កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលថ្មីដើម្បីទាក់ទាញប្រាក់ចូលមកប្រទេសបានទទួលជោគជ័យយ៉ាងតិចតួច។ ទីបំផុត ហ្ស៊ីមបាវ៉ េ បានជួបប្រទះនឹងការផ្ទុះឡើងនៃជំងឺអាសន្នរោគជាច្រើន ដែលបានសម្លាប់មនុស្សរាប់ពាន់នាក់។ អ្វីដែលធ្វើអោយបញ្ហាកាន់តែអាក្រក់ គឺ វេជ្ជបណ្ឌិតនៅប្រទេសហ្ស៊ីមបាវ៉េបានធ្វើកូដកម្ម ដោយយកប្រព័ន្ធថែទាំសុខភាពដែលផុយស្រួយអាចត្រូវដួលរលំទាំងស្រុង។

ការពិចារណាក្នុងស្រុក

ស្ថានភាពនយោបាយ និងសេដ្ឋកិច្ចនៅក្នុងប្រទេសរបស់អ្នក មានលក្ខណៈខុសគ្នាខ្លាំងណាស់។ ក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ ប្រទេសរបស់អ្នកបានចាកចេញពីភាពក្រីក្របំផុតមួយ នៅទ្វីបអាហ្វ្រិក ទៅជាប្រទេសមួយដែលមានផលិតផលក្នុងស្រុកសរុប ប្រមាណ ១៦០០០ ដុល្លារសម្រាប់មនុស្សម្នាក់ៗ។ ស្ថានភាពសេដ្ឋកិច្ចនៃប្រទេសរបស់អ្នកមានភាពរឹងមាំ ហើយស្ថានភាពនយោបាយមានស្ថិរភាព។ ទ្រព្យសម្បត្តិថ្មីនេះបានអនុញ្ញាតអោយអ្នកដាក់កម្មវិធីដ៏ទូលំទូលាយមួយ ដើម្បីដោះស្រាយអត្រាខ្ពស់នៃការឆ្លងមេរោគHIV/ជំងឺអេដស៍ (មនុស្សពេញវ័យម្នាក់ក្នុងចំណោមបីនាក់) នៅក្នុងប្រទេសរបស់អ្នក និងចាប់ផ្តើមកាត់បន្ថយអត្រាគ្មានការងារធ្វើខ្ពស់ (៤០ ភាគរយដោយការប៉ាន់ស្មានមួយចំនួន)។

សេណារីយ៉ូ

ឥឡូវស្រមៃថា របបយោធាថ្មីនៅហ្ស៊ីមបាវ៉ េ ចាប់ផ្តើមរងនូវអស្ថិរភាព។ មិនអាចកែប្រែផ្នែកសេដ្ឋកិច្ចបានទេ ក្រុមប្រឆាំងបានចាប់ផ្តើមតវ៉ាប្រឆាំងនឹងរដ្ឋាភិបាលយោធា។ ក្រុមយោធាបានឆ្លើយតបដោយការបង្ក្រាបយ៉ាងឃោរឃៅ ដែលកាន់តែកើនឡើងទៅជាជម្លោះស៊ីវិលដ៏ហិង្សារវាងយោធា និងជាមួយក្រុមគណបក្សប្រឆាំង។ គណបក្សប្រឆាំងបានរត់ទៅប្រទេសរបស់អ្នកដើម្បីសុំសិទ្ធិជ្រកកោន ហើយបានបង្កើតវិបត្តិចំណាកស្រុក។

ខណៈពេលដែលស្ថានភាពនយោបាយ និងសេដ្ឋកិច្ចរបស់អ្នកមានលក្ខណៈប្រសើរជាង នៅក្នុងប្រទេសហ្ស៊ីមបាវ៉េ វានឹងមិនប្រាកដទេថា អ្នកនឹងអាចផ្តល់ជំនួយ ឬជម្រកសម្រាប់ប្រជាជនហ្ស៊ីមបាវ៉េរាប់ម៉ឺននាក់នោះទេ ដែលបានរត់ភៀសខ្លួនទៅប្រទេសរបស់អ្នក។ ជាពិសេស ប្រព័ន្ធថែទាំសុខភាពរបស់អ្នក ដែលកំពុងតែតានតឹងដោយការរីករាលដាលនៃជំងឺអេដស៍ នឹងត្រូវបានបង់ពន្ធយ៉ាងលឿន ដោយជនភៀសខ្លួនដែលចូលមក ពីប្រទេសហ្ស៊ីមបាវ៉េ។ ហើយខណៈពេលដែលសាធារណៈជនរបស់អ្នក ខ្លះមានការអត់ឱនខ្លះចំពោះជនភៀសខ្លួនដែលមានកំណត់ ពួកគេនឹងប្រឆាំងនឹងការផ្តល់កន្លែងស្នាក់នៅដល់ប្រជាជនហ្ស៊ីមបាវ៉េទាំងអស់ដែលចង់បានជំនួយ។ នៅទីបំផុត វាក៏មានឱកាសផងដែរ ដែលប្រសិនបើអ្នកត្រូវបានគេមើលឃើញថាកំពុងការពារគូប្រជែងនៃយោធាហ្ស៊ីមបាវ៉េ អ្នកអាចនឹងត្រូវបានទាញចូលទៅក្នុងជម្លោះជាមួយនឹងប្រទេសជិតខាងរបស់អ្នក។

ជ្រើសរើសគោលនយោបាយរបស់អ្នក

តើអ្នកនឹងធ្វើអ្វីជាមួយជនភៀសខ្លួន? តើអ្នកនឹងបង្ខំពួកគេអោយត្រឡប់ទៅប្រទេសហ្ស៊ីមបាវ៉េវិញដែរឬទេ? នេះជាការប្រឆាំងនឹងច្បាប់ជនភៀសខ្លួនអន្តរជាតិ ហើយអាចបន្ថែមដល់អស្ថិរភាពនៃប្រទេសហ្ស៊ីមបាវ៉េ។ តើអ្នកអនុញ្ញាតអោយជនភៀសខ្លួនស្នាក់នៅ បូតស្វាណា ដែរឬទេ? នេះអាចនាំអោយមានការអាក់អន់ចិត្តចំពោះផ្នែកនៃប្រជាជនផ្ទាល់ខ្លួនរបស់អ្នក ប្រសិនបើជនភៀសខ្លួនទទួលយកការងារ បង្ហូរការផ្គត់ផ្គង់ស្បៀងអាហារ ឬបន្ទុកប្រព័ន្ធថែទាំសុខភាពរបស់អ្នក។ វាក៏ប្រថុយនឹងជម្លោះបើកចំហជាមួយប្រទេសជិតខាងរបស់អ្នកផងដែរ។ តើអ្នកប្តឹងថ្លែងតុល្យភាពតម្រូវការមនុស្សធម៌ជាមួយនឹងការព្រួយបារម្ភចំពោះសុខុមាលភាពផ្លូវកាយនិងសេដ្ឋកិច្ចរបស់ប្រជាជន ដោយរបៀបណា?

តោះ! សាកល្បងពិភាក្សាអំពីបញ្ហាជាក់ស្តែង

កំណែទម្រង់អន្តោប្រវេសន៍៖

តើគួរតែផ្តល់ឲ្យជនអន្តោប្រវេសន៍ខុសច្បាប់នៅក្នុងសហរដ្ឋអាមេរិកមានផ្លូវទៅកាន់ភាពជាពលរដ្ឋស្របច្បាប់ដែរឬទេ?


ទិដ្ឋភាពទូទៅ

លំហូរចលនាប្រជាជនឆ្លងកាត់ព្រំដែន គឺជាកត្តាសំខាន់មួយបញ្ហាដែលលាយឡំនយោបាយក្នុងស្រុកនិងទំនាក់ទំនងអន្តរជាតិ។ ទោះបីជាការជជែកដេញដោលគ្នាភាគច្រើនទាក់ទងនឹងផលប៉ះពាល់របស់ជនអន្តោប្រវេសន៍(និងជនចំណាកស្រុក)ទៅលើសេដ្ឋកិច្ចនៃរដ្ឋម្ចាស់ប្រទេសក៏ដោយកត្តាអន្តរជាតិជាច្រើនដែលបង្ហាញពីការលើកទឹកចិត្តរបស់បុគ្គលម្នាក់ៗ ក្នុងការធ្វើចំណាកស្រុក រួមទាំងលក្ខខណ្ឌសេដ្ឋកិច្ចពិភពលោក លក្ខខណ្ឌនយោបាយនៅក្នុងរដ្ឋជិតខាង និងស្ថានភាពនៃជម្លោះយោធាផ្ទៃក្នុង និងរវាងរដ្ឋ។

ស្ទើរតែគ្រប់ប្រទេសក្នុងពិភពលោកបានចូលរួមជជែកដេញដោលជុំវិញបញ្ហាអន្តោប្រវេសន៍។ នៅមួយផ្នែក បញ្ហាទាំងនេះនៅតែមានភាពស្រពិចស្រពិល ព្រោះវាបានរួមបញ្ចូលគ្នានូវធាតុសំខាន់ៗនៃសេដ្ឋកិច្ច(តើជនអន្តោប្រវេសន៍នឹងទម្លាក់ប្រាក់ឈ្នួលឬដណ្តើមយកការងារទេ?) ជាមួយនឹងធាតុផ្សំនៃអត្តសញ្ញាណជាតិ (ថាតើយើងជាអ្វីក្នុងហានៈជាប្រទេសមួយ ហើយតើយើងនឹងទៅជានរណានៅថ្ងៃអនាគត?)។ គោលនយោបាយអន្តោប្រវេសន៍ត្រូវតែមានតុល្យភាពក្នុងការយោគយល់សម្រាប់អ្នកដែលនៅក្រៅប្រទេស ជាមួយនឹងការទទួលខុសត្រូវសម្រាប់អ្នកដែលនៅទីនេះរួចហើយ។ ទោះបីជាមានការជជែកពិភាក្សាគ្នាអំពីជនភៀស

ខ្លួនសង្គ្រាមនៅក្នុងអាហ្វ្រិកអំពីជនអន្តោប្រវេសន៍សេដ្ឋកិច្ចនៅអឺរ៉ុប ឬជនរងគ្រោះនៃគ្រោះមហន្តរាយធម្មជាតិនៅអាមេរិកឡាទីន គោលការណ៍នយោបាយអន្តោប្រវេសន៍តែងតែជាបញ្ហានៃការជជែកពិភាក្សាគ្នា យ៉ាងខ្លាំងក្លាបំផុត។

ក្រាហ្វិកអំពីជនអន្តោប្រវេសន៍នៅសហរដ្ឋអាមេរិក លេខ និងភាគរយ ១៩០០-២០២១
បូកនឹងការព្យាករណ៍របស់ការិយាល័យជំរឿនដល់ឆ្នាំ ២០៦០



សម្គាល់៖ ឆ្នាំ *ការិយាល័យជំរឿន*

ប្រភព៖ Decennial Census សម្រាប់ឆ្នាំ ១៩០០ ដល់ឆ្នាំ ២០០០ ការស្ទង់មតិសហគមន៍អាមេរិកឆ្នាំ ២០១០ និងខែវិច្ឆិកា ឆ្នាំ ២០២១ ការស្ទង់មតិប្រជាជនបច្ចុប្បន្ន (CPS) សម្រាប់ឆ្នាំ ២០២១។ CPS មិនរួមបញ្ចូលស្ថាប័ន។ សម្រាប់ឆ្នាំ ២០៣០ ដល់ឆ្នាំ ២០៦០ សូមមើលការព្យាករណ៍ជំរឿនដល់ឆ្នាំ ២០៦០។

ការជជែកវែកញែកអំពីអន្តោប្រវេសន៍នៅសហរដ្ឋអាមេរិក ក៏មិនមែនជាករណីលើកលែងដែលមិនត្រូវបានលើកមកពិភាក្សានោះទេ។ សំណួរនៃគោលនយោបាយអន្តោប្រវេសន៍បានក្លាយជាមតិមួយ ក្នុងចំណោមគំនិតដែលបែងចែកយ៉ាងខ្លាំងនៅក្នុងសហរដ្ឋអាមេរិក ដែលជាមតិដែលឆ្លងកាត់មនោគមវិជ្ជាប្រពៃណី និងបន្ទាត់របត់គណបក្សនយោបាយ។ ភាពចម្រូងចម្រាសដែលជាពិសេស គឺជាគំនិតនៃការផ្តល់មធ្យោបាយសម្រាប់ក្រុមជនអន្តោប្រវេសន៍ នៅក្នុងពេលបច្ចុប្បន្ន នៅក្នុងសហរដ្ឋអាមេរិក ដោយខុសច្បាប់ដើម្បីរកមធ្យោបាយដើម្បីអោយពួកគេក្លាយជាពលរដ្ឋ និងផ្តល់ឱ្យពួកគេនូវសិទ្ធិបោះឆ្នោត ការអប់រំ និងកម្មវិធីសង្គម។ តើគួរដែរឬទេដែលរដ្ឋាភិបាលអាមេរិកផ្តល់មធ្យោបាយសម្រាប់ជនអន្តោប្រវេសន៍ខុសច្បាប់ទាំងនេះ ដើម្បីក្លាយជាពលរដ្ឋជនជាតិអាមេរិក?

អំណះអំណាង ១

រដ្ឋាភិបាលសហរដ្ឋអាមេរិកគួរតែផ្តល់ផ្លូវសម្រាប់ភាពជាពលរដ្ឋសម្រាប់ជនអន្តោប្រវេសន៍ខុសច្បាប់។

ការធ្វើអោយស្របច្បាប់ចំពោះជនអន្តោប្រវេសន៍ខុសច្បាប់ នឹងនាំអោយមានការកើនឡើងនៃប្រាក់ចំណូលពន្ធសម្រាប់រដ្ឋាភិបាល។

ដោយសារតែជនអន្តោប្រវេសន៍ខុសច្បាប់ជារឿយៗមិនបង់ពន្ធលើប្រាក់ចំណូល ពួកគេគឺជាប្រភពចំណូលពន្ធដ៏ធំ ដែលមិនអាចប្រើប្រាស់បាន។ ជនអន្តោប្រវេសន៍ទាំងនេះភាគច្រើនប្រើប្រាស់សេវាសង្គមដូចជាការអប់រំ ដូច្នេះហើយការអនុញ្ញាតអោយពួកគេទទួលបានសញ្ជាតិនឹងអនុញ្ញាតអោយពួកគេ «បង់ប្រាក់» សម្រាប់សេវាកម្មទាំងនេះតាមរយៈពន្ធ។

ការផ្ទេរប្រាក់នឹងជួយដល់ការអភិវឌ្ឍន៍នៅក្នុងប្រទេសកំណើតរបស់ជនអន្តោប្រវេសន៍។

កម្មករដែលរកបានប្រាក់កំរៃនៅក្នុងសហរដ្ឋអាមេរិកច្រើនតែបញ្ជូន និងផ្ញើប្រាក់ចំណែកសំខាន់ៗត្រឡប់ទៅប្រទេសកំណើតរបស់វិញ។ ប្រាក់នេះជួយធ្វើអោយប្រទេសដើមមានស្ថិរភាពសេដ្ឋកិច្ច ផ្តល់ឱកាសសម្រាប់សមាជិកគ្រួសារ និងលើកកម្ពស់គុណភាពជីវិតរបស់ពួកគេ។

ជនអន្តោប្រវេសន៍ខុសច្បាប់ គឺចាំបាច់សម្រាប់កម្លាំងការងាររបស់សហរដ្ឋអាមេរិក។

អវត្តមានរបស់ជនអន្តោប្រវេសន៍ ធ្វើឲ្យចំនួនប្រជាជននៅសហរដ្ឋអាមេរិកកំពុងធ្លាក់ចុះ។ ប្រសិនបើគ្មានវត្តមានរបស់ប្រជាជនអន្តោប្រវេសន៍ដែលកំពុងធ្វើការទាំងនេះ (ស្របច្បាប់ និងខុសច្បាប់) ឧស្សាហកម្មមួយចំនួន (ជាពិសេស កសិកម្ម និងសំណង់) នឹងជួបប្រទះនឹងការខ្វះខាតកម្លាំងពលកម្ម ដែលនាំអោយប្រាក់ឈ្នួលមានតម្លៃកើនឡើងសម្រាប់ជនជាតិអាមេរិកទាំងអស់។

អំណះអំណាង ២

រដ្ឋាភិបាលសហរដ្ឋអាមេរិកមិនគួរផ្តល់ផ្លូវទៅកាន់ពលរដ្ឋសម្រាប់ជនអន្តោប្រវេសន៍ខុសច្បាប់នោះទេ។

ការផ្តល់សញ្ជាតិជាការលើកទឹកចិត្តដល់អាកប្បកិរិយាខុសច្បាប់។ មានផ្លូវសម្រាប់ការទទួលបានភាពជាសញ្ជាតិស្របច្បាប់ ដែលត្រូវបានទទួលលដោយជនជាតិអាមេរិករាប់លាននាក់។ វានឹងជារឿងអយុត្តិធម៌ក្នុងការដែលផ្តល់ការលើកទឹកចិត្តជូនពលរដ្ឋដែលចូលក្នុងប្រទេសដោយខុសច្បាប់បន្ទាប់ពីជនជាតិអាមេរិកជាច្រើនត្រូវឆ្លងកាត់ដំណើរការដ៏លំបាកជាយូរមកហើយដើម្បីទទួលបានសិទ្ធិរបស់ពួកគេ។

ជនអន្តោប្រវេសន៍ខុសច្បាប់ ប្រជែងគ្នារកការងារធ្វើ ក្នុងគ្រាលំបាកសេដ្ឋកិច្ច។

ក្នុងអំឡុងពេលសេដ្ឋកិច្ចធ្លាក់ចុះ ការបញ្ឈប់ការងារកើនឡើង ហើយការងារកាន់តែពិបាករក។ ជនអន្តោប្រវេសន៍ខុសច្បាប់ប្រកួតប្រជែងសម្រាប់ការងារខ្វះខាតទាំងនេះ។ ការប្រកួតប្រជែងនេះគឺធ្វើឱ្យខូចខាតជាពិសេសដល់ជនជាតិអាមេរិក ដែលមានហានៈសេដ្ឋកិច្ចសង្គមទាប ដែលត្រូវបានគំរាមកំហែងតាមវិធីផ្សេងទៀតដោយការធ្លាក់ចុះសេដ្ឋកិច្ច។

ការកើនឡើងនៃអន្តោប្រវេសន៍ដែលបណ្តាលមកពីគោលនយោបាយនឹងបង្កើតហានិភ័យសុវត្ថិភាព។

ប្រសិនបើផ្លូវទៅកាន់ភាពជាពលរដ្ឋដំរុញអោយមានការកើនឡើងនៃអន្តោប្រវេសន៍ នាពេលអនាគតវានឹងពិបាកក្នុងការរក្សាសុវត្ថិភាពព្រំដែនសហរដ្ឋអាមេរិក ដែលនាំអោយមានគ្រោះថ្នាក់ដល់សន្តិសុខ។ នៅក្នុងយុគសម័យនៃអំពើភេរវកម្មសកលនេះ កត្តាណាមួយដែលបង្កើនចំនួនមនុស្សដ៏ច្រើន ដែលឆ្លងកាត់ព្រំដែនរដ្ឋអាចគំរាមកំហែងដល់សន្តិសុខរបស់រដ្ឋមួយ។

សំណួរ

- តើអ្នកគិតថារដ្ឋាភិបាលសហរដ្ឋអាមេរិកគួរតែផ្តល់មធ្យោបាយសម្រាប់ជនអន្តោប្រវេសន៍ខុសច្បាប់ដើម្បីទទួលបានសញ្ជាតិស្របច្បាប់របស់ពួកគេទេ? តើមានអំណះអំណាងផ្សេងទៀតដែលអ្នកយល់ឃើញក្នុងការជជែកដេញដោលនេះដែរឬទេ?

• គិតអំពីកិច្ចព្រមព្រៀងNAFTA និងរដ្ឋជាសមាជិកសហភាពអឺរ៉ុប តើហេតុអ្វីបានជាអ្នកគិតថា សហភាពអឺរ៉ុបមានឆន្ទៈក្នុងការបើកព្រំដែនដោយគ្នាទៅវិញទៅមក? តើអ្នកជឿថា សហភាពអឺរ៉ុបនឹងឈានទៅបិទព្រំដែននាពេលអនាគត? តើកិច្ចព្រមព្រៀងNAFTA នឹងកាន់តែបើកចំហ នាពេលអនាគតទេ?

• តើអ្នកមានអារម្មណ៍ថា ទឡ្លីករណ៍នៅក្នុងការជជែកដេញដោលនេះត្រូវបានជះឥទ្ធិពល ដោយកត្តាអន្តរជាតិដូចជាស្ថានភាពសេដ្ឋកិច្ចពិភពលោកយ៉ាងដូចម្តេច? តើកត្តាទាំងនេះប៉ះពាល់ដល់ការជជែកដេញដោលស្រដៀងគ្នាទាក់ទងនឹងសិទ្ធិជនអន្តោប្រវេសន៍ នៅក្នុងប្រទេសផ្សេងទៀតដែរឬទេ?

និស្សិតអាចសាកល្បងអានឯកសារខាងក្រោមបន្ថែមទៀត ដើម្បីជាគ្រឹះក្នុងការឆ្លើយសំណួរទាំងអស់ខាងលើ ៖

- Givens, Terri E., Gary P. Freeman, and David L. Leal, eds. Immigration Policy and Security: U.S., European, and Commonwealth Perspectives. Routledge, 2008.
- Guskin, Jane, and David L. Wilson. The Politics of Immi- gration: Questions and Answers. 2nd ed. Monthly Review, 2017.
- Hollifield, James F., Philip L. Martin, and Pia Orrenius, eds. Controlling Immigration: A Global Perspective. 3rd ed. Stanford, 2014.
- Vecchio, Francesco. Asylum Seeking and the Global City. Routledge, 2016.

អាជីពក្នុងចំណាត់ថ្នាក់ចំនេះអន្តរជាតិ៖ អង្គការមិនមែនរដ្ឋាភិបាល (NGOs)

សង្ខេប

ការងារនៅក្នុងអង្គការក្រៅរដ្ឋាភិបាលផ្តល់បទពិសោធន៍ផ្ទាល់ខ្លួន សម្រាប់អ្នកដែលមានឆន្ទៈធ្វើការយ៉ាងលំបាកក្នុងបុព្វហេតុមួយ ប៉ុន្តែ ពួកគេទទួលបានប្រាក់កម្រៃទាប និងពិបាកក្នុងការទទួលបាន។

អត្ថប្រយោជន៍និងការចំណាយ

មានអង្គការក្រៅរដ្ឋាភិបាលជិត ៤០០០០ ហើយចំនួននោះកើនឡើងជារៀងរាល់ថ្ងៃ។ បុគ្គលរាប់ពាន់នាក់ចាប់អារម្មណ៍ធ្វើការនៅក្នុងអង្គការទាំងនេះ។ ទោះបីជាអង្គការមិនមែនរដ្ឋាភិបាលទាំងអស់មានភាពខុសប្លែកគ្នាក៏ដោយ ប៉ុន្តែមនុស្សជាច្រើនបំពេញមុខងារជាច្រើន៖ ធ្វើការនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ទាក់ទងនឹងបញ្ហាផ្សេងៗ ការផ្សព្វផ្សាយជាសាធារណៈក្នុងប្រទេស និងក្រៅប្រទេស បញ្ចុះបញ្ចូលរដ្ឋាភិបាលដោយផ្លាស់ប្តូរគោលនយោបាយរបស់ពួកគេ រៀបចំគម្រោងដើម្បីដោះស្រាយបញ្ហា និងព្យាយាមស្វែងរកមូលនិធិសម្រាប់ការអនុវត្តរបស់ពួកគេ។

ការធ្វើការបម្រើអង្គការក្រៅរដ្ឋាភិបាលមានអត្ថប្រយោជន៍ជាច្រើន។ បុគ្គលិកតែងតែឃើញនោក្នុងចំណោមមនុស្សផ្សេងដែលខ្វល់ខ្វាយអំពីបញ្ហាដូចគ្នា៖ ការកែលម្អបរិស្ថាន ការការពារសិទ្ធិមនុស្ស ការជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ច ឬការលើកកម្ពស់ការថែទាំសុខភាពកាន់តែប្រសើរឡើង។ ស្មារតីនៃភាពស្និទ្ធស្នាលអាចជាការរីករាយ និងផ្តល់រង្វាន់។

ខណៈពេលដែលការធ្វើការដោយអង្គការក្រៅរដ្ឋាភិបាលអាចទទួលបានរង្វាន់យ៉ាងខ្លាំងផ្ទាល់ខ្លួន វាកម្រទទួលបានរង្វាន់ផ្នែកហិរញ្ញវត្ថុណាស់។ អង្គការក្រៅរដ្ឋាភិបាលភាគច្រើនគឺជាប្រតិបត្តិការមិនរកប្រាក់ចំណេញដែលផ្តល់ប្រាក់ឈ្នួលដល់បុគ្គលិកតិចតួចក្នុងរយៈពេលច្រើនម៉ោង។ ជាងនេះទៅទៀត អង្គការមិនមែនរដ្ឋាភិបាលតូចៗជាច្រើនបានចូលរួមក្នុងការតស៊ូឥតឈប់ឈរ សម្រាប់ការផ្តល់មូលនិធិពីរដ្ឋាភិបាលស្ថាប័នស្រាវជ្រាវ មូលនិធិឯកជន ឬបុគ្គល។ ដំណើរការនៃការរៃអង្គាសប្រាក់អាចចំណាយពេលច្រើន។

ទោះបីជាមានអង្គការក្រៅរដ្ឋាភិបាលមួយចំនួនធំផ្តល់ប្រាក់ខែតិច និងតម្រូវអោយធ្វើការច្រើនម៉ោង ក៏ដោយ ការទទួលបានការងារមួយនៅក្នុងអង្គការក្រៅរដ្ឋាភិបាលអាចជាការពិបាក។ គន្លឹះមួយគឺត្រូវមាន គម្រោងលម្អិត។ ចូរព្យាយាមបង្រួមចំណាប់អារម្មណ៍របស់អ្នកទាក់ទងនឹងផ្នែកសំខាន់ៗ (ឧទាហរណ៍ សិទ្ធិមនុស្ស បរិស្ថាន) និង/ឬ តំបន់ភូមិសាស្ត្រ។ ចូរគិតផងដែរថា តើអ្នកចង់ធ្វើការនៅក្នុងប្រទេសរបស់អ្នក ឬនៅបរទេស។ មុខតំណែងនៅបរទេសអាចទទួលបានរង្វាន់ច្រើនជាង ប៉ុន្តែ មានការផ្គត់ផ្គង់ការងារទាប និងតម្រូវការខ្ពស់ជាង។

ជំនាញត្រូវដុសខាត់

អង្គការក្រៅរដ្ឋាភិបាលកំពុងស្វែងរកអ្នកផ្តួចផ្តើមដោយខ្លួនឯង។ អង្គការភាគច្រើនមានពេលតិចនិងធនធានតិចតួចសម្រាប់ការបណ្តុះបណ្តាល។ ជំនាញការិយាល័យជាមូលដ្ឋាន (ឧទាហរណ៍ ជំនាញកុំព្យូទ័រ Microsoft Word, Excel ឬ Powerpoint) ត្រូវការជាចាំបាច់ ប៉ុន្តែ បុគ្គលិកក៏ត្រូវបំពេញការកិច្ចជាច្រើនជារៀងរាល់ថ្ងៃផងដែរ។ អ្វីទាំងអស់និងអ្វីគ្រប់យ៉ាងត្រូវស្ថិតនៅក្នុងការពិពណ៌នាការងាររបស់អ្នក។ ជំនាញសរសេរនិងទំនាក់ទំនងគឺជាគន្លឹះ ជាពិសេស នៅពេលដែលការរៃអង្គាសប្រាក់ គឺជាផ្នែកមួយនៃការងារនោះ។ ជំនាញភាសាបរទេសក៏មានសារៈសំខាន់ផងដែរ ព្រោះអង្គការក្រៅរដ្ឋាភិបាលជាច្រើនរក្សា ឬធ្វើការជាមួយការិយាល័យនៅបរទេស។

ជាញឹកញយ អង្គការក្រៅរដ្ឋាភិបាលស្នើអោយបុគ្គលិកដែលមានសក្តានុពលងោយធ្វើការស្ម័គ្រចិត្តមួយរយៈពេលដែលពួកគេបណ្តុះបណ្តាលមុនពេលត្រូវបានជួល។ កាន់តែខ្លាំងឡើង ក្រុមហ៊ុនខ្លះត្រូវបង់ថ្លៃដើម្បីដាក់បុគ្គលិកខ្លួនអោយធ្វើក្នុងអង្គការក្រៅរដ្ឋាភិបាល ឬឱកាសស្ម័គ្រចិត្ត ។ ដោយការបង់ប្រាក់ទៅធ្វើការអ្នកអាចទទួលបានរយៈពេលសាកល្បងមួយ ដើម្បីអភិវឌ្ឍជំនាញរបស់អ្នក និងស្គាល់ខ្លួនអ្នក ជាមួយនឹងប្រតិបត្តិការនេះ ហើយទទួលបានប្រសិទ្ធភាពមុនពេលចាប់ផ្តើមបើកប្រាក់ខែ។

ជាចុងក្រោយ នៅក្នុងទីក្រុងដែលអង្គការក្រៅរដ្ឋាភិបាលប្រមូលផ្តុំគ្នា (ឧទាហរណ៍ វ៉ាស៊ីនតោនឌីស៊ី) បណ្តាញផ្ទាល់ខ្លួនដើរតួនាទីយ៉ាងសំខាន់ក្នុងការស្វែងរកឱកាសល្អ។ ជារឿយៗ បុគ្គលិកផ្លាស់ទីពីអង្គការមួយទៅស្ថាប័នមួយទៀត។ អាស្រ័យហេតុនេះ មនុស្សជាច្រើនស្ម័គ្រចិត្ត ឬទទួលយកការងារជាមួយអង្គការក្រៅរដ្ឋាភិបាលដែលមិនស្ថិតនៅក្នុងការងារជាទីចាប់អារម្មណ៍ភ្លាមៗរបស់ពួកគេ ដើម្បីទទួលបានបទពិសោធន៍និងទំនាក់ទំនងល្អ ដែលអាចជួយដល់ការឈានទៅមុខនៃអាជីពនាពេលអនាគត។

រូបថត អង្គការកាកបាទក្រហមហ្សកហ្ស៊ី

ធនធានបន្ថែម

1. King, Richard M. *From Making a Profit to Making a Difference: How to Launch Your New Career in Nonprofits*. Planning/ Communications, 2000.
2. Weiss, David. Careers in International Development and Humanitarian Assistance NGOs. In *Careers in International Affairs*. 9th ed. Georgetown School of Foreign Service, 2014.
3. http://www.ngo.org/links/index.htm
4. http://www.idealist.org
5. http://www.wango.org/resources.aspx?section=ngodir

ឯកសារគួរអានបន្ថែម

- Collier, Paul. *The Bottom Billion: Why the Poorest Countries Are Failing and What Can Be Done About It.* Oxford, 2007. Food and Agriculture Organization. *The State of Food Security and Nutrition in the World: 2017.*

- FAO, 2018. http://www. fao.org/state-of-food-security-nutrition/en/. Hulme, David. *Global Poverty: How Global Governance Is Failing the Poor.* Routledge, 2010.
- Kevane, Michael. *Women and Development in Africa: How Gender Works.* 2nd ed. Lynne Rienner Publishers, 2014.
- Martin, Susan F. *International Migration: Evolving Trends from the Early Twentieth Century to the Present.* Cambridge, 2014.
- UN Development Program. *Human Development Report 2016.* UNDP, 2016. http://hdr.undp.org/en/2016-report.
- UNCHR. *The Global Report: 2016.* UNHCR, 2017. http:// www.unhcr.org/en-us/the-global-report.html.
- U.S. Department of State. *Trafficking in Persons Report 2017.* U.S. Department of State, 2017.
- Wallerstein, Immanuel. *World Systems Analysis: An Introduction.* Duke, 2004.
- World Health Organization. *Health 2015: From MDGs to SDGs.* WHO, 2016.

មេរៀនទី ១៣ ៖ ការអភិវឌ្ឍអន្តរជាតិ

រូបថត ផ្ទះចិនមួយនៅកណ្តាលផ្លូវ ដែលម្ចាស់មិនព្រមលក់ ទីក្រុងសៀងហៃ ឆ្នាំ២០១៧។

វត្ថុបំណងមេរៀន

១៣.១ ចូរប្រៀបធៀបបទពិសោធន៍ដូចគ្នានិងខុសគ្នារបស់ប្រទេសចិននិងឥណ្ឌា ក្នុងការសម្រេចបាននូវការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិរៀងៗខ្លួន។

១៣.២ ចូរកំណត់និងវាយតម្លៃយុទ្ធសាស្ត្រពីរផ្សេងគ្នា ដែលប្រទេសកំពុងអភិវឌ្ឍន៍ប្រើប្រាស់ក្នុងកិច្ចប្រឹងប្រែងដើម្បីសម្រេចបាននូវកំណើនសេដ្ឋកិច្ច។

១៣.៣ ចូរបង្ហាញពីមធ្យោបាយដែលធ្វើអោយបំណុលជាតិដ៏ច្រើនអាចជាកត្តារារាំងដំណើរការនៃការអភិវឌ្ឍសេដ្ឋកិច្ចសម្រាប់បណ្តាប្រទេសនៅអឌ្ឍគោលខាងត្បូង។

១៣.៤ ចូររៀបរាប់ពីហេតុផលចំនួនបី ដែលប្រទេសនានាអាចផ្តល់ជំនួយបរទេសដល់ទៅបណ្តាប្រទេសនៅអឌ្ឍគោលខាងត្បូង។

១៣.១. បទពិសោធន៍

១៣.១ ចូរប្រៀបធៀបបទពិសោធន៍ដូចគ្នានិងខុសគ្នារបស់ប្រទេសចិននិងឥណ្ឌា ក្នុងការសម្រេចបាននូវការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិរៀងៗខ្លួន។


មេរៀនទី ១២ បានពិភាក្សាអំពីស្ថានភាព នៅក្នុងអឌ្ឍគោលខាងត្បូង និងដំណើរដែលវាមានស្ថានភាពដូចសព្វថ្ងៃ។ មេរៀននេះនឹងចោទជាសំណួរថាតើត្រូវធ្វើអ្វីខ្លះដើម្បីអភិវឌ្ឍតំបន់មួយនេះ។ **ការអភិវឌ្ឍន៍សេដ្ឋកិច្ច** (economic development) សំដៅលើដំណើរការចម្រុះនៃការប្រមូលមូលធន ការបង្កើនប្រាក់ចំណូលសម្រាប់ប្រជាជនម្នាក់ៗ (ជាមួយនឹងអត្រាបង្កកំណើតធ្លាក់ចុះ) ការបង្កើនជំនាញក្នុងចំណោមប្រជាជន ការទទួលយកនូវស្នីលបច្ចេកវិទ្យាថ្មី និងការផ្លាស់ប្តូរសង្គមនិងសេដ្ឋកិច្ចពាក់ព័ន្ធផ្សេងទៀត។ ទិដ្ឋភាពសំខាន់បំផុតមួយ គឺជាការប្រមូលផ្តុំដើមទុន (ជាមួយនឹងសក្តានុពលបង្កើតទ្រព្យសម្បត្តិជាបន្តបន្ទាប់)។ គំនិតនៃការអភិវឌ្ឍន៍មានទិដ្ឋភាពទស្សនវិស័យមួយ ដែលមិនអាចត្រូវរាស់ស្ទង់បាន ពោលគឺជាលក្ខណៈវិនិច្ឆ័យថា តើគំរូនៃការបង្កើតនិងការបែងចែកទ្រព្យសម្បត្តិណាមួយ ដែលពិតជាល្អសម្រាប់រដ្ឋនិងប្រជាជនពលរដ្ឋនោះ។ ប៉ុន្តែការរាស់ស្ទង់កម្រិតការអភិវឌ្ឍន៍សេដ្ឋកិច្ចដ៏សាមញ្ញមួយ គឺផលិតផលក្នុងស្រុកសរុប សម្រាប់មនុស្សម្នាក់ៗ (GDP) ដែលសំដៅលើទំហំសកម្មភាពសេដ្ឋកិច្ចក្នុងមនុស្សម្នាក់ៗ។ រង្វាស់នេះ គឺជាអ័ក្សដេកក្នុងក្រាហ្វិក ១២.១ ហើយការផ្លាស់ប្តូររង្វាស់នេះស្ថិតនៅលើអ័ក្សឈរ។

តាមរយៈរង្វាស់រង្វាល់នេះ យើងអាចតាមដានភាពជោគជ័យ និងការបរាជ័យនៃអឌ្ឍគោលខាងត្បូងទាំងមូល ហើយសំខាន់ជាងនេះទៅទៀត អាចកំណត់កម្រិតជោគជ័យនៅក្នុងតំបន់និងប្រទេសទាំងអស់ក្នុងអឌ្ឍគោលខាងត្បូង។ ចំណុចចុងក្រោយនេះពិតជាមានសារៈសំខាន់ខ្លាំងណាស់ ព្រោះវាផ្តុំកនូវគ្រាប់ពូជ និងជាគន្លឹះនៃមេរៀនល្អ ក៏ដូចជាយុទ្ធសាស្ត្រដែលអាចកសាងពីភាពជោគជ័យរបស់អឌ្ឍគោលខាងត្បូង នាពេលអនាគត។ តំបន់ភាគច្រើន ក្នុងអឌ្ឍគោលខាងត្បូងបានធ្វើអោយមានការរីក ចម្រើនលើការអភិវឌ្ឍន៍សេដ្ឋកិច្ចតាំងពីទសវត្សរ៍ឆ្នាំ ១៩៧០ ប៉ុន្តែ ផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់ៗ បានថយចុះ នៅទសវត្សរ៍ឆ្នាំ

១៩៨០ នៅអាមេរិកឡាទីន អាហ្វ្រិក និងមជ្ឈិមបូព៌ា ដោយមានតែប្រទេសចិនប៉ុណ្ណោះ ដែលរីកចម្រើនខ្លាំង។ នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ កំណើនសេដ្ឋកិច្ចពិតប្រាកដបានត្រលប់មកវិញនៅទូទាំងអឌ្ឍគោលខាងត្បូង ដោយមានកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំ ប្រហែល ៥-៦ ភាគរយ សម្រាប់អឌ្ឍគោលខាងត្បូងទាំងមូល ហើយថែមទាំងមានកម្រិតខ្ពស់ជាងប្រទេសចិនទៅទៀត បើធៀបនឹង ២-៣ ភាគរយ នៅក្នុងអឌ្ឍគោលខាងជើង។ ប្រទេសចិនឈរនៅក្នុងចំណោមតំបន់អឌ្ឍគោលខាងត្បូង ដោយបានធ្វើដំណើរយ៉ាងឆាប់រហ័ស ឆ្ពោះទៅរកការអភិវឌ្ឍសេដ្ឋកិច្ច។

ក្រាហ្វិក ១៣.១ កំណើន ផ.ស.ស.ពិតប្រាកដនៃប្រទេសមួយចំនួន ឆ្នាំ ២០១៦

ប្រភព៖ ទិន្នន័យធនាគារពិភពលោក។




ក្នុងសតវត្សរ៍ទី ២១ កំណើនសេដ្ឋកិច្ចបានឡើងលឿន នៅអឌ្ឍគោលខាងត្បូង ហើយឥឡូវនេះល្បឿនវាបានវាំដាច់អឌ្ឍគោលខាងជើង (សូមមើលក្រាហ្វិក ១៣.១)។ ទោះយ៉ាងណាក៏ដោយ អត្រាកំណើន

នេះមិនស្មើគ្នានោះទេ។ នៅអាស៊ីខាងត្បូង (អត្រាកំណើន ៦-៧ ភាគរយក្នុងមួយឆ្នាំៗ) បានចូលរួមជាមួយប្រទេសចិន(៨-៩ ភាគរយ ក្នុងមួយឆ្នាំៗ) ក្នុងការសម្រេចបាននូវកំណើនយ៉ាងឆាប់រហ័ស។ ដោយសារតែប្រទេសចិននិងអាស៊ីខាងត្បូងរួមគ្នាមានចំនួនប្រជាជនភាគច្រើន នៅក្នុងអឡូរគោលខាងត្បូង ហើយដែលនាំអោយការអភិវឌ្ឍទាំងអស់នេះ មានសារៈសំខាន់ខ្លាំងណាស់។

កំណើនសេដ្ឋកិច្ចថ្មីនេះបានបង្ហាញថាលទ្ធភាពក្នុងការងើបចេញពីភាពក្រីក្រទៅឆ្ពោះទៅរកវឌ្ឍនភាពរុងរឿងគួរសម អាចធ្វើទៅបាន។ ប្រទេសកូរ៉េខាងត្បូងសម្រេចបានមុនគេ ហើយតាមពីក្រោយដោយប្រទេសចិន ហើយឥណ្ឌាហាក់ដូចជាចាប់ផ្តើមដើរនៅលើខ្សែកោងដូចគ្នាដែរ (សូមមើលក្រាហ្វិក ១៣.២)។ បើយោងតាមធនាគារពិភពលោក នៅក្នុងទ្វីបអាហ្វ្រិក សេដ្ឋកិច្ចបានកើនឡើង ៤ ភាគរយ ជារៀងរាល់ឆ្នាំ គិតចាប់តាំងពីឆ្នាំ ២០១១ ដល់ឆ្នាំ ២០១៣ (នាំមុខដោយ តែមិនកំណត់ត្រឹមប្រទេសនាំចេញប្រេងនិងរ៉ែ)។ ខណៈពេលដែលវិបត្តិសេដ្ឋកិច្ចសកលឆ្នាំ ២០០៨-២០០៩ បានគំរាមកំហែងដល់ប្រទេសកំពុងអភិវឌ្ឍន៍ ភាគច្រើននៃរដ្ឋនៅក្នុងអឡូរគោលខាងត្បូងបានងើបឡើងវិញយ៉ាងឆាប់រហ័ស ជាងសមភាគីជារដ្ឋអ្នកមាននៅក្នុងអឡូរគោលខាងជើង ដែលជានិន្នាការគួរអោយកត់សម្គាល់មួយ។

ក្រាហ្វិក ១៣.២ ផ.ស.សសម្រាប់មនុស្សម្នាក់ នៅកូរ៉េខាងត្បូង ចិន ឥណ្ឌា និងហ្គាណា
ឆ្នាំ ១៩៥០-២០១៦
ប្រភព៖ ផ្អែកលើទិន្នន័យរបស់ធនាគារពិភពលោក។



សព្វថ្ងៃនេះ ការយកចិត្តទុកដាក់ជាច្រើនត្រូវបានគេផ្តោតទៅលើក្រុមប្រទេសមួយ ដែលត្រូវស្គាល់ថាជា «BRICS» (ប្រេស៊ីល រុស្ស៊ី ឥណ្ឌា ចិន និងអាហ្វ្រិកខាងត្បូង)។ រដ្ឋនីមួយៗមានទំហំសេដ្ឋកិច្ចធំ និងចំនួន

ប្រជាជនច្រើន ដែលមានភាពខុសប្លែកគ្នាខាងផ្នែកសេដ្ឋកិច្ចសំខាន់ៗរវាងរដ្ឋនីមួយៗ។ វាត្រូវបានចាត់ទុកជាក្រុមប្រទេសសំខាន់ៗដែលមានសំឡេងខ្លាំងនិងមានឥទ្ធិពលដល់រដ្ឋកំពុងអភិវឌ្ឍន៍ ជារឿយៗ ជាមួយនឹងសំឡេងដ៏រឹងមាំនៅក្នុងការចរចាជាមួយរដ្ឋដែលមានទ្រព្យសម្បត្តិនៅអាមេរិកខាងជើង និងអឺរ៉ុប។

១៣.១.១. ប្រទេសឧស្សាហកម្មថ្មីៗ

មុនពេលប្រទេសចិនហក់រីកចម្រើន រដ្ឋក្រីក្រមួយចំនួន ដែលត្រូវគេហៅថា **ប្រទេសឧស្សាហកម្មថ្មីៗ** (NICs) ប្រទេសនេះសម្រេចបាននូវការប្រមូលផ្តុំដើមទុន ដែលអាចទ្រទ្រង់ដោយខ្លួនឯងបាន ជាមួយនឹងកំណើនសេដ្ឋកិច្ចដ៏គួរអោយចាប់អារម្មណ៍។ រដ្ឋជាយក្រុងទាំងនេះ ដែលនាំចេញទំនិញឧស្សាហកម្មធុនស្រាល បានប្រកាសពីកំណើនសេដ្ឋកិច្ចដ៏រឹងមាំ នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ និងនៅដើមទសវត្សរ៍ឆ្នាំ ១៩៩០ (សូមមើលប្រព័ន្ធពិភពលោក ក្នុងមេរៀនទី ១២)។ ពួកគេត្រូវទទួលរងការធ្លាក់ចុះសេដ្ឋកិច្ច នៅក្នុងវិបត្តិហិរញ្ញវត្ថុអាស៊ីឆ្នាំ ១៩៩៧ ដោយសារតែកំណើនមានល្បឿនលឿនពេក ជាមួយនឹងប្រាក់កម្ចីស្រួលៗពេក និងការវិនិយោគប្រថុយប្រថាន និងកិច្ចព្រមព្រៀងពុករលួយ។ ប៉ុន្តែ ប្រទេសឧស្សាហកម្មថ្មីៗបានចាប់ផ្តើមទទួលបានកំណើនសេដ្ឋកិច្ចឡើងវិញយ៉ាងឆាប់រហ័ស ហើយបានអភិវឌ្ឍបន្ថែមទៀត និងលឿនជាងភាគច្រើននៅបណ្តាប្រទេសនៅអឌ្ឍគោលខាងត្បូង។

រូបថត បង្ហាញភាពរីកចម្រើនរបស់ខ្លា សិង្ហបុរី

ខ្លាឬសិង្ហ

សិង្ហបុរីគឺជាខ្លាមួយក្នុងចំណោមខ្លាទាំងបួន (រួមជាមួយក្រុងហុងកុង កោះតៃវ៉ាន់ និងកូរ៉េខាងត្បូង)។ សូម្បីតែបន្ទាប់ពីការបរាជ័យនៃវិបត្តិហិរញ្ញវត្ថុឆ្នាំ ១៩៩៧ ក៏ដោយ ក៏កំណើនរបស់ពួកគេបានធ្វើអោយពួកគេរីកចម្រើនតាមស្តង់ដារនៃអឌ្ឍគោលខាងត្បូង។ ប្រទេសផ្សេងទៀតកំពុងព្យាយាមធ្វើត្រាប់តាមគំរូជោគជ័យរបស់ NICs ទាំងនេះ។ ប៉ុន្តែ គ្មានមេរៀនសាមញ្ញតែមួយដែលអាចអនុវត្តបានចំពោះរដ្ឋផ្សេងទៀតដែលផុសចេញពី NICs នោះទេ។

ប្រទេសឧស្សាហកម្មថ្មីៗទទួលបានជោគជ័យបំផុត គឺ «ខ្លាទាំងបួន» ឬ «នាគទាំងបួន» នៃអាស៊ីបូព៌ាមានដូចជា៖ ប្រទេសកូរ៉េខាងត្បូង តៃវ៉ាន់ ទីក្រុងហុងកុង និងប្រទេសសិង្ហបុរី។ ដែលរដ្ឋនីមួយៗបានទទួលជោគជ័យក្នុងការអភិវឌ្ឍន៍លើគ្រប់វិស័យនិងឧស្សាហកម្ម ជាពិសេស គឺជាដៃគូប្រកួតប្រជែង នៅលើទីផ្សារពិភពលោក។ សម្រាប់វិស័យទាំងអស់នេះ ក៏ដូចជាវិស័យឧស្សាហកម្មអាចបង្កើតអោយមានការប្រមូលដើមទុនអោយបានច្រើនគ្រប់គ្រាន់នៅក្នុងប្រទេសនីមួយៗ ដើម្បីពង្រីកខ្លួនជាប្រទេសឧស្សាហកម្មថ្មី(NICs) ឬជាប្រទេសតតិយលោក ដែលសម្រេចបាននូវការប្រមូលផ្តុំដើមទុនដោយនិរន្តរភាពដោយខ្លួនឯងដោយគួរចាប់អារម្មណ៍ និងផ្តោតទៅលើកំណើនសេដ្ឋកិច្ច។ អ្នកប្រាជ្ញមួយចំនួនមិនប្រាកដថាតើប្រទេសឧស្សាហកម្មថ្មីគ្រាន់តែជាក្រុមប្រទេសដែលមានសំណាង ដែលបានផ្លាស់ប្តូរហាន:រដ្ឋជនបទទៅរដ្ឋជាយក្រុងនៃប្រព័ន្ធពិភពលោក (សូមមើលមេរៀនទី ១២) ឬថាតើភាពជោគជ័យរបស់ពួកគេអាចចម្លងជាគម្រូនៅទូទាំងអឌ្ឍគោលខាងត្បូងឬយ៉ាងណា។

ប្រទេសកូរ៉េខាងត្បូងដែលមានធនធានរ៉ែដែក និងធ្យូងថ្ម បានបង្កើតឧស្សាហកម្មដែក និងរថយន្តដែលមានការប្រកួតប្រជែង ដែលត្រូវនាំចេញទៅទូទាំងពិភពលោក បង្កើតអតិរេកពាណិជ្ជកម្ម (សូមមើលមេរៀនទី ៨)។ សម្រាប់កោះតៃវ៉ាន់ក៏បានប្រើប្រាស់គោលនយោបាយឧស្សាហ៍កម្មរបស់រដ្ឋដ៏រឹងមាំ ដែល មាន

ឯកទេសក្នុងផ្នែកឧស្សាហកម្មអេឡិចត្រូនិក និងកុំព្យូទ័រ និងក្នុងការផលិតពន្លឺផ្សេងទៀត។ សម្រាប់ ទីក្រុងហុងកុង ដែលបង្វែរចូលក្រោមការគ្រប់គ្រងដោយប្រទេសចិនតាំងពីឆ្នាំ ១៩៩៧ ក៏មានអេឡិចត្រូនិកមានការប្រកួតប្រជែងកម្រិតពិភពលោក និងឧស្សាហកម្មធុនស្រាលផ្សេងទៀតផងដែរ ប៉ុន្តែ ភាពខ្លាំងបំផុតរបស់ទីក្រុងហុង ស្ថិតក្នុងវិស័យធនាគារនិងពាណិជ្ជកម្ម។ ប្រទេសសិង្ហបុរី គឺជាទីក្រុងពាណិជ្ជកម្ម ដែលមាន ទីតាំងល្អ នៅចុងឧបទ្វីបម៉ាឡេស៊ី ដែលអំណោយផលដល់នាវាចរណ៍តាមផ្លូវសមុទ្រ ទៅសមុទ្រចិនខាងត្បូង មហាសមុទ្រឥណ្ឌា និងអូស្ត្រាលី។

ដោយសារហេតុផលផ្សេងៗ រដ្ឋនីមួយៗក្នុងចំណោមនេះមានស្ថានភាពនយោបាយខុសប្លែកគ្នានៅក្នុងប្រព័ន្ធអន្តរជាតិ។ ប្រទេសកូរ៉េខាងត្បូង និងកោះតៃវ៉ាន់ គឺជាចំណុចក្តៅនៃជម្លោះអន្តរជាតិដែលបានកើតឡើងនៅក្រោមឆ័ត្រថែរក្សាសន្តិសុខដោយសហរដ្ឋអាមេរិក ក្នុងអំឡុងសង្គ្រាមត្រជាក់។ រដ្ឋទាំងពីរត្រូវបានពង្រីកយោធា រដ្ឋផ្តាច់ការមិនអត់អោនអោយមតិប្រឆាំងដែលទាំងពីរនេះបានក្លាយជារដ្ឋប្រជាធិបតេយ្យ។ ការចំណាយជាច្រើនសន្ធឹកសន្ធាប់របស់សហរដ្ឋអាមេរិក នៅអាស៊ីបូព៌ា ក្នុងអំឡុងសង្គ្រាមត្រជាក់ បានផ្តល់ផលប្រយោជន៍អោយដល់ប្រទេសកូរ៉េខាងត្បូង និងកោះតៃវ៉ាន់មានការអភិវឌ្ឍន៍លឿន។ នៅក្នុងករណីទាំងនេះទោះបីជានៅមានជម្លោះយោធា វាក៏មិនបានរារាំងដល់ការអភិវឌ្ឍន៍នោះទេ។

ទីក្រុងហុងកុងនិងប្រទេសសិង្ហបុរី ក៏មានប្រវត្តិនយោបាយខុសគ្នាដែរ។ ទីក្រុងទាំងពីរធ្លាប់ស្ថិតក្រោមអាណានិគមអង់គ្លេស។ ពួកគេមានលក្ខណៈជារដ្ឋបុរី ច្រើនជាងលក្ខណៈជាប្រជាជាតិ ហើយទីក្រុងរបស់ពួកគេគឺជាទីក្រុងកំពង់ផែពាណិជ្ជកម្មនិងមជ្ឈមណ្ឌលហិរញ្ញវត្ថុ។ ទោះបីជាមិនមានលក្ខណៈគាបសង្កត់ ឬពង្រឹងវិស័យយោធាដូចប្រទេសកូរ៉េខាងត្បូងនិងតៃវ៉ាន់នៅក្នុងកំឡុងសម័យសង្គ្រាមត្រជាក់ក៏ដោយ ក៏ទីក្រុងហុងកុងនិងប្រទេសសិង្ហបុរីមិនមែនជាប្រទេសប្រជាធិបតេយ្យដែរ។ ទីក្រុងហុងកុងត្រូវបានគ្រប់គ្រងដោយអភិបាលជនជាតិអង់គ្លេស (ហើយចាប់តាំងពីឆ្នាំ ១៩៩៧ ដោយរដ្ឋាភិបាលនៅទីក្រុងប៉េកាំង) និងសិង្ហបុរីដោយអភិបាលអង់គ្លេសលេចធ្លោខ្លាំង។

១៣.១.២. បទពិសោធន៍ប្រទេសចិន

ប្រសិនបើនៅមានមន្ទិលសង្ស័យថា ជោគជ័យរបស់ប្រទេសឧស្សាហកម្មថ្មីៗ អាចត្រូវបានចម្លងជាគំរូនៅទីកន្លែងផ្សេងទៀតនិងក្នុងទ្រង់ទ្រាយធំជាងនេះ ប្រទេសចិនគឺជាអ្នកបញ្ចប់ការសង្ស័យទាំងនោះ។ ប្រទេសចិនមានប្រជាជនជាង ១,៤ ពាន់លាននាក់ ហើយទំហំដ៏ធំនេះបានធ្វើអោយកិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសចិនក្នុងការបង្កើតការប្រមូលផ្តុំទ្រព្យ ដែលអាចទ្រទ្រង់ខ្លួនឯងបាន សមនឹងទទួលបានការសិក្សារៀនសូត្រតាម។ យ៉ាងណាមិញ ប្រទេសចិនមានសេដ្ឋកិច្ចលូតលាស់លឿនបំផុតលើពិភពលោក ក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះដែរ។

នៅចន្លោះសម័យជ័យជម្នះកុម្មុយនិស្តឆ្នាំ ១៩៤៩ និងបដិវត្តន៍វប្បធម៌ចុងទសវត្សរ៍ឆ្នាំ ១៩៦០ នៅក្នុងសម័យគ្រប់គ្រងដោយលោកប្រធាន ម៉ៅ សេទុង គោលនយោបាយសេដ្ឋកិច្ចរបស់ចិនបានសង្កត់ធ្ងន់ទៅលើភាពគ្រប់គ្រាន់ជាតិនិងមនោគមវិជ្ជាកុម្មុយនិស្ត។ រដ្ឋបានគ្រប់គ្រងសកម្មភាពសេដ្ឋកិច្ចទាំងអស់តាមរយៈការធ្វើផែនការកណ្តាលនិងកម្មសិទ្ធិរបស់រដ្ឋ។ គោលនយោបាយ «ចានបាយដែក» បានធានាតម្រូវការអាហារជាមូលដ្ឋានសម្រាប់ប្រជាជនចិនទាំងអស់ (យ៉ាងហោចណាស់នៅក្នុងទ្រឹស្តី)។

ក្រោយពេល លោក ម៉ៅ សេទុង បានស្លាប់នៅឆ្នាំ ១៩៧៦ ប្រទេសចិនក្រោមការដឹកនាំរបស់ តេង ស៊ាវពីង បានបង្កើតកំណែទម្រង់សេដ្ឋកិច្ច និងបានប្រែក្លាយខេត្តដែលជាប់ឆ្នេរសមុទ្រភាគខាងត្បូងរបស់ខ្លួន ទៅជា*តំបន់សេដ្ឋកិច្ចសេរី* បើកចំហទទួលរាល់ការវិនិយោគបរទេស និងដំណើរការលើគោលការណ៍មូលធននិយម។ កសិករចាប់ផ្តើមធ្វើស្រែចំការរបស់ពួកគេ ជំនួសអោយកសិដ្ឋានសមូហភាព ហើយក្លាយជាអ្នកមាន (តាមស្តង់ដារបស់ប្រទេសចិន) ប្រសិនបើពួកគេធ្វើបានល្អ។ សហគ្រិនបានចាប់ផ្តើមបង្កើតជាក្រុមហ៊ុន ហើយបានជួលកម្មករ និងចាប់ផ្តើមបង្កើតបានប្រាក់ចំណេញ។ ការវិនិយោគបរទេសបានជន់ជោរចូលទៅក្នុងប្រទេសចិនភាគខាងត្បូង ដោយទាញយកអត្ថប្រយោជន៍ពីទីតាំងរបស់ខ្លួន តាមរយៈកម្លាំងពលកម្មថោកៗ និងស្ថិរភាពនយោបាយដែលបានប្រាស្រ័យទាក់ទងគ្នា។ តំបន់ជាច្រើនផ្សេងទៀតនៃប្រទេសចិនបានបើកជាបណ្តើរៗចំពោះគោលការណ៍មូលធននិយមផងដែរ។ រដ្ឋតម្រូវអោយមានឧស្សាហកម្មកាន់តែច្រើន ដើម្បីបង្វែរប្រាក់ចំណេញ និងផ្តល់គំនិតផ្តួចផ្តើមបន្ថែមទៀតដល់អ្នកគ្រប់គ្រង ដើម្បីដំណើរការក្រុមហ៊ុនផ្ទាល់ខ្លួនរបស់ពួកគេ និងចំណាយប្រាក់ចំណេញតាមដែលពួកគេយល់ឃើញ។ កំណើនសេដ្ឋកិច្ចទទួលបានការកែចម្រើនយ៉ាងធាប់រហ័ស ចាប់តាំងពីគោលនយោបាយទាំងនេះត្រូវបានបង្កើតឡើង។ ដូច្នេះស្តង់ដារនៃការរស់នៅរបស់ប្រជាជនចិនបានកើនឡើងយ៉ាងខ្លាំង និងធាប់រហ័ស។

រូបថត អ្នកប្រើប្រាស់ចិនចូលរួមកម្មវិធីតាំងពិពណ៌រថយន្តនៅទីក្រុងប៉េកាំងក្នុងឆ្នាំ ២០១៧

វប្បធម៌រថយន្ត

កំណើនសេដ្ឋកិច្ចយ៉ាងធាប់រហ័សរបស់ប្រទេសចិនបានបង្កើនប្រាក់ចំណូលយ៉ាងច្រើន ជាពិសេសសម្រាប់វណ្ណៈមធ្យមដែលកំពុងកើនឡើង។ ជោគជ័យទាំងនេះបានសម្រេចឡើង ក្រោយការបើកចំហរបស់ប្រទេសចិនចំពោះសេដ្ឋកិច្ចពិភពលោក និងការអនុម័តកំណែទម្រង់ដែលផ្តោតលើទីផ្សារ។ ប្រទេសចិនក៏កំពុងព្យាយាមអភិវឌ្ឍទីផ្សារក្នុងស្រុករបស់ខ្លួន និងបង្កើនការចំណាយរបស់អ្នកប្រើប្រាស់ ជាជាងការពឹងផ្អែកខ្លាំងលើការនាំចេញក្នុងការជម្រុញកំណើនប្រេ។ នៅទីនេះ អ្នកប្រើប្រាស់ចិនចូលរួមកម្មវិធីតាំងពិពណ៌រថយន្តនៅទីក្រុងប៉េកាំងក្នុងឆ្នាំ ២០១៧ ដោយសង្ឃឹមថានឹងទទួលបាននូវការចាប់អារម្មណ៍កាន់តែខ្លាំងឡើងរបស់ប្រទេសចិនជាមួយនឹងទំនិញប្រើប្រាស់ដ៏ធំបំផុតនោះគឺ រថយន្ត។

ទោះជាយ៉ាងណាក៏ដោយ ប្រទេសចិនក៏បានបង្កើតឡើងវិញនូវចរិកលក្ខណៈពិសេសមួយចំនួននៃរបបមូលធននិយម ដែលបដិវត្តន៍របស់ម៉ៅបានផ្តួលរំលំ។ គម្លាតខុសគ្នារវាងវណ្ណៈនីមួយៗបានលេចឡើងវិញ ដោយមានសហគ្រិនស្តុកស្តម្ភបើកឡាននាំចូលយ៉ាងប្រណិត ខណៈពេលដែលកម្មករនិងប្រជាជនក្រីក្រដឹងខ្លួនថាចាប់ផ្តើមគ្មានការងារធ្វើ។ ឧស្សាហកម្មដែលគ្រប់គ្រងដោយរដ្ឋ ដែលមិនរកប្រាក់ចំណេញ បានបញ្ឈប់កម្មករចំនួន ១០ លាននាក់ នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ ដែលចំនួននេះចេះតែមានកាន់តែច្រើនជារៀងរាល់ឆ្នាំ។ នៅតាមទីជនបទ តំបន់ដែលឆ្លងកាត់ដោយការអភិវឌ្ឍន៍នៅតែមានកសិករចិនក្រីក្រ ចំនួន ២០០ លាននាក់។ បញ្ហាសង្គមដូចជាពេស្យាចារបានវិលមកវិញ ដូចជាកើតមានបញ្ហាសេដ្ឋកិច្ចដូចជាអតិផរណា (ចាប់តាំងពីត្រូវបានគ្រប់គ្រងបានភាគច្រើន)។ ការខកចិត្តបំផុតសម្រាប់ជនជាតិចិនទូទៅ គឺអំពើពុករលួយផ្លូវការគ្រប់រូបភាព ដែលរីករាលដាល អមជាមួយបរិយាកាសសម្បូរបែប។

ការអាក់អន់ចិត្តខ្លាំងចំពោះបញ្ហា ដូចជាអតិផរណា និងអំពើពុករលួយបាននាំអោយកម្មករ ក្នុងវិស័យឧស្សាហកម្ម និងសូម្បីតែមន្ត្រីរដ្ឋាភិបាលចូលរួមជាមួយនិស្សិត ក្នុងការតវ៉ាប្រឆាំងរដ្ឋាភិបាល នៅទីលានធាន

អានមេន នៃទីក្រុងប៉េកាំង ក្នុងឆ្នាំ ១៩៨៩។ អាជ្ញាធរបានប្រើយោធាដើម្បីបង្ក្រាបការតវ៉ាដោយហិង្សាដោយបានសម្លាប់មនុស្សរាប់រយនាក់ និងជាសញ្ញាណនៃការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាល ក្នុងការរក្សាការគ្រប់គ្រងនយោបាយតឹងរឹង ខណៈពេលដែលកំណែទម្រង់សេដ្ឋកិច្ចដំណើរការ។ មេដឹកនាំគណបក្សបានអះអាងម្តងហើយម្តងទៀតអំពីគោលនយោបាយនេះ ដោយរួមបញ្ចូលកំណែទម្រង់សេដ្ឋកិច្ច ជាមួយនឹងប្រពៃណីនយោបាយ ហើយមានអារម្មណ៍ថាត្រូវបានបញ្ជាក់ដោយការអនុវត្តសេដ្ឋកិច្ចជាបន្តបន្ទាប់។ ប្រទេសចិននៅពេលនោះទប់ទល់នឹងវិបត្តិហិរញ្ញវត្ថុអាស៊ីឆ្នាំ ១៩៩៧ ទោះបីជាមានបញ្ហារីករាលដាលជាមួយនឹងប្រាក់កម្ចីធនាគារមិនល្អ ឧស្សាហកម្មរដ្ឋដែលបាត់បង់លុយជាច្រើន និងរួមផ្សំនឹងអំពើពុករលួយផងដែរ ។

ការវិនិយោគបរទេសដោយសាជីវកម្មពហុជាតិ(MNCs) បានជំរុញកំណើនយ៉ាងឆាប់រហ័សក្នុងការនាំចេញរបស់ប្រទេសចិន បានកើនឡើងរហូតដល់ប្រមាណ ២៥០ ប៊ីលានដុល្លារ ក្នុងឆ្នាំ ២០០០ និងជាង ២.១ ប៊ីលានដុល្លារ ក្នុងឆ្នាំ ២០១៧។ ប្រទេសចិនបានក្លាយជាអ្នកនាំចេញធំបំផុតនៅលើពិភពលោក ក្នុងឆ្នាំ ២០១០។ ក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខនេះ ប្រទេសនេះបានត្រៀមខ្លួនរួចជាស្រេចក្នុងការចូលរួមជាមួយសហរដ្ឋអាមេរិក ខណៈប្រទេសជប៉ុននិងប្រទេសអាឡឺម៉ង់ជាប្រទេសនាំចេញរថយន្តធំៗ។ សមាជិកភាពរបស់អង្គការពាណិជ្ជកម្មពិភពលោក(WTO)របស់ប្រទេសចិនបានផ្តើមចាប់តាំងពីឆ្នាំ ២០០១ កំពុងពន្លឿននិន្នាការទាំងនេះ នៅពេលបន្តទៅមុខទៀត។

ក្នុងឆ្នាំ ២០១២ មេដឹកនាំចិនជំនាន់ថ្មីបានចូលកាន់តំណែង ដែលដឹកនាំដោយលោកប្រធានាធិបតី ស៊ី ជិនពីង (Xi Jinping)។ ប្រទេសចិនបានរក្សាកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័សរបស់ខ្លួន (ជាទូទៅ ១០ ភាគរយជារៀងរាល់ឆ្នាំ) ពីមួយឆ្នាំទៅមួយឆ្នាំ សូម្បីតែបន្ទាប់ពីការធ្លាក់ចុះសេដ្ឋកិច្ចពិភពលោកឆ្នាំ ២០០៨ បានធ្វើអោយប៉ះពាល់ដល់ការនាំចេញរបស់ចិន ដោយមានជំនួយពីការចំណាយលើហេដ្ឋារចនាសម្ព័ន្ធរបស់រដ្ឋាភិបាលដ៏ច្រើនសម្បើម។ ប៉ុន្តែ កំណើនវិសមភាពនិងអំពើពុករលួយដែលរីករាលដាលបានគំរាមកំហែងដល់ភាពស្របច្បាប់របស់បក្សកុម្មុយនិស្តមួយនេះ។ ការលាតត្រដាងដោយកាសែត New York Times ក្នុងឆ្នាំ ២០១២ បានបង្ហាញថា សមាជិកគ្រួសារនៃអតីតនាយករដ្ឋមន្ត្រីរបស់ប្រទេសចិន បានប្រមូលទ្រព្យសម្បត្តិឯកជនចំនួនប្រមាណ ៣ ប៊ីលានដុល្លារ ខណៈពេលលោកកាន់អំណាច។ ជាការឆ្លើយតប ប្រទេសចិនបានបិទគេហទំព័រកាសែត New York Times នៅក្នុងផ្ទៃប្រទេស។ ទោះបីជាមានការខិតខំទប់ស្កាត់ការបញ្ចេញមតិនយោបាយក៏ដោយ ក៏ប្រជាពលរដ្ឋចិន ជាច្រើនបានសម្តែងនូវទស្សនៈរបស់ពួកគេ មិនត្រឹមតែនៅក្នុងរូបភាពជាកូដកម្មនិងបាតុកម្មប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងបានបង្ហាញនៅលើគេហទំព័រ microblogging ដ៏ពេញនិយមរបស់ប្រទេសចិនផងដែរ ដែលប្រហែលគ្នានឹង Twitter របស់អាមេរិក។ នៅតាមភូមិជនបទ កសិករបានតវ៉ាដោយចំហចំពោះការរឹបអូសយកដី ការយកពន្ធ ការបំពុល និងអំពើពុករលួយរបស់មន្ត្រីថ្នាក់មូលដ្ឋាន។ លោកប្រធានាធិបតី ស៊ី បានប្រកាសថានឹងធ្វើការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយជាអាទិភាពបំផុត ខណៈដែលលោកបន្តបង្អាក់ការតវ៉ានិងសំណេរដែលកំណត់គោលដៅចំមន្ត្រីគណបក្សដែលចូលរួមក្នុងការប្រព្រឹត្តអំពើពុករលួយ។

ជាមួយនឹងការភ្ជាប់អ៊ីនធឺរណែតរបស់ប្រទេសចិន ឥឡូវនេះ សេដ្ឋកិច្ចមានស្ថានភាពល្អប្រសើរខ្លាំង ប៉ុន្តែ ប្រជាពលរដ្ឋរបស់ចិនក៏អាចគេចចេញពីការតាមដានព័ត៌មានដែលគ្រប់គ្រងដោយរដ្ឋាភិបាល។ អ្នកសង្កេតការណ៍ខ្លះព្រឺងថា ការធ្វើសមាហរណកម្មសេដ្ឋកិច្ចក្នុងយុគសម័យព័ត៌មាននឹងបើកប្រព័ន្ធនយោបាយ

របស់ប្រទេសចិនយ៉ាងទូលំទូលាយ និងនាំទៅរកលទ្ធិប្រជាធិបតេយ្យ ចំណែកអ្នកផ្សេងទៀតបានគិតថា ដរាបណាមេដឹកនាំចិនផ្តល់កំណើនសេដ្ឋកិច្ច ប្រជាជននឹងមានការចាប់អារម្មណ៍តិចតួចក្នុងការទាមទារអោយមានការផ្លាស់ប្តូរនយោបាយ។ ជាការពិតណាស់ នៅក្នុងឆ្នាំ ២០១៨ បក្សកុម្មុយនិស្តចិនបានលុបចោលការកំណត់អាណត្តិសម្រាប់តំណែងប្រធានាធិបតី ដែលមានន័យថា លោក ស៊ី ជិនពីង អាចបន្តធ្វើជាប្រធានាធិបតីបានយូរជាងនេះ ឬរហូតមួយជីវិត។ នេះអាចអនុញ្ញាតអោយគាត់បង្រួបបង្រួមអំណាច និងកំណត់បន្ថែមទៀតនូវសេរីភាវូបនីយកម្មនយោបាយនាពេលអនាគត។

ភាពជោគជ័យផ្នែកសេដ្ឋកិច្ចរបស់ប្រទេសចិន បានផ្តល់អោយវានូវកិត្យានុភាពបន្ថែមទៀត នៅក្នុងប្រព័ន្ធអន្តរជាតិ និងទស្សនវិស័យជាសកលបន្ថែមទៀតលើទំនាក់ទំនងអន្តរជាតិ ឆ្ងាយហួសពីព្រំដែនរបស់ប្រទេសចិន។ ក្នុងឆ្នាំ២០០៧ ប្រទេសចិនបានប្រកាសផ្តល់ប្រាក់កម្ចីចំនួន ៣ ប៊ីលានដុល្លារដល់អាហ្វ្រិក ដែលប្រទេសចិនបានសង្កត់ធ្ងន់ថានឹង «មិនអនុវត្តលក្ខខណ្ឌនយោបាយ» (មិនដូចប្រាក់កម្ចីលោកខាងលិច ដែលជារឿយៗទាមទារគោលនយោបាយ ដូចជាការគោរពសិទ្ធិមនុស្ស ឬការប្រយុទ្ធប្រឆាំង និងអំពើពុករលួយ)។ ប៉ុន្មានខែបន្ទាប់ ប្រទេសចិនបានរៀបចំកិច្ចប្រជុំមួយសម្រាប់មេដឹកនាំអាហ្វ្រិកចំនួន ៤៨។ ក្នុងឆ្នាំ ២០១៣ ប្រធានាធិបតីលោកស៊ីបានធ្វើទស្សនកិច្ច នៅទ្វីបអាហ្វ្រិក ហើយបានសន្យាថានឹងបន្តជំនួយផ្នែកសេដ្ឋកិច្ច។ លោកក៏បានចូលរួមកិច្ចប្រជុំ BRICS ដែលមេដឹកនាំមកពីប្រទេសនីមួយៗបានសន្យាថានឹងសហការជាមួយរដ្ឋអាហ្វ្រិកក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច។ ក្នុងឆ្នាំ ២០១៣ នេះផងដែរ ប្រទេសចិនបានប្រកាសពីការបង្កើតធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី (AIIB) ដែលជាកំណែស្រដៀងគ្នានឹងធនាគារអភិវឌ្ឍន៍អាស៊ី និងធនាគារពិភពលោក។ មនុស្សជាច្រើនយល់ឃើញថា ការផ្លាស់ប្តូរនេះជាមធ្យោបាយសម្រាប់ប្រទេសចិនដើម្បីបង្កើត«ធនាគារពិភពលោក»ថ្មីមួយ ដែលខ្លួនជាអ្នកគ្រប់គ្រង។ រហូតមកដល់ពេលនេះ មានប្រទេសចំនួន ៦១ បានចូលរួមជាមួយ AIIB ។ សហរដ្ឋអាមេរិកមិនបានធ្វើដូច្នេះទេ ហើយបានរិះគន់សម្ព័ន្ធមិត្តដែលបានចូលរួមជាមួយធនាគារ (ដូចជាចក្រភពអង់គ្លេស) ។ AIIB បានចាប់ផ្តើមផ្តល់ប្រាក់កម្ចីដើម្បីអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅអាស៊ី ហើយដើមទុនរបស់វា មានរហូត ១០០ ប៊ីលានដុល្លារ ប្រហែលពាក់កណ្តាលនៃធនាគារពិភពលោក។

បន្ថែមពីនេះ ប្រទេសចិនក៏ជាសមាជិកសំខាន់នៃក្រុមប្រទេស ២០ (G២០) ដែរ។ ក្នុងឆ្នាំ ២០០៩ សេដ្ឋកិច្ចលោកខាងលិចដ៏ធំបានប្រកាសថា G២០ នឹងជំនួសក្រុមប្រទេស G៨ ជាស្ថាប័នអន្តរជាតិដ៏សំខាន់ដើម្បីដោះស្រាយជាមួយនឹងសំណួរនៃការសម្របសម្រួលសេដ្ឋកិច្ច ដោយបានបើកផ្លូវដ៏មានសក្តានុពលថ្មីនៃឥទ្ធិពលសម្រាប់ប្រទេសចិន។ ប្រទេសចិនក៏មានទំនាក់ទំនងសេដ្ឋកិច្ចជិតស្និទ្ធជាមួយនឹងប្រទេសអាស៊ីផ្សេងទៀតផងដែរ (សូមមើលក្រាហ្វិក ១៣.៣)។ ការកើនឡើងនូវដំហរក្នុងកិច្ចការអន្តរជាតិរបស់ចិនត្រូវបានជម្រុញដោយការធ្វើជាម្ចាស់ផ្ទះនៃការប្រកួតកីឡាអូឡាំពិកឆ្នាំ ២០០៨ ដែលជាជោគជ័យយ៉ាងសម្បើម។

អព្ភូតហេតុសេដ្ឋកិច្ចរបស់ប្រទេសចិនបានប៉ះទង្គិចខ្លាំង នៅក្នុងវិបត្តិសេដ្ឋកិច្ចឆ្នាំ ២០០៨-២០០៩។ ការវិនិយោគរបស់ចិននៅសហរដ្ឋអាមេរិក ដែលធ្វើអោយមានអតិរេកពាណិជ្ជកម្មដែលចិនបានប្រមូលផ្តុំក្នុងរយៈពេលប៉ុន្មានឆ្នាំមកនេះ បានបាត់បង់ផលចំណេញយ៉ាងច្រើន នៅក្នុងវិបត្តិហិរញ្ញវត្ថុ។ មេដឹកនាំចិនបានប្រកាសពីកញ្ចប់ជំរុញសេដ្ឋកិច្ចដ៏សំខាន់មួយ ក្នុងគោលបំណងជំរុញការចាយវាយទិញទំនិញ ប្រើប្រាស់ក្នុងស្រុកនៅក្នុងប្រទេសចិន ប៉ុន្តែ បញ្ហានេះបានប្រឈមមុខនឹងបញ្ហាក្នុងរយៈពេលខ្លី រួមទាំងបញ្ហាវប្បធម៌ក្នុង

ការធ្វើអោយប្រជាជនដែលធ្លាប់មានប្រវត្តិក្រីក្រ ត្រូវចាយវាយប្រាក់ជាជាងការសន្សំប្រាក់និងបញ្ហាសេដ្ឋកិច្ច នៃការតំរង់ទិសសេដ្ឋកិច្ចជម្រុញដោយការនាំចេញឡើងវិញ ដើម្បីផលិតទីផ្សារក្នុងស្រុក។ ទោះបីជាមានគ្រោះថ្នាក់និងហានិភ័យ ក៏សេដ្ឋកិច្ចប្រទេសចិនបានឈានទៅមុខរួចផុតពីវិបត្តិសេដ្ឋកិច្ច។ ជាឧទាហរណ៍ ការនាំចេញរបស់ចិនបានត្រលប់ទៅកម្រិតមុនវិបត្តិសេដ្ឋកិច្ចវិញយ៉ាងឆាប់រហ័ស បន្ទាប់ពីការធ្លាក់ចុះក្នុងឆ្នាំ ២០០៩ ហើយបានបន្តកើនឡើង។

ក្រាហ្វិក ១៣.៣ ការសម្លឹងមើលរបស់ប្រទេសចិនទៅលើប្រទេសជិតខាងរបស់ខ្លួន។

កំណើនជាបន្តរបស់ប្រទេសចិន គឺជាគំរូឈានមុខគេនៃភាពជោគជ័យនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅក្នុងពិភពលោកខាងត្បូង។ មាគ៌ាអនាគតរបស់ប្រទេសចិននឹងជះឥទ្ធិពលលើអាស៊ីទាំងអស់។



សេដ្ឋកិច្ចរបស់ប្រទេសចិនទំនងជាមានផលប៉ះពាល់ជាលើកទីពីរ ក្នុងសហស្សវត្សរ៍ថ្មី។ ពេញមួយឆ្នាំ ២០១៥ ទីផ្សារភាគហ៊ុនរបស់ប្រទេសចិនបានធ្លាក់ចុះយ៉ាងខ្លាំង ដែលនាំអោយមនុស្សជាច្រើនចោទសួរអំពីស្ថិរភាពសេដ្ឋកិច្ចរបស់ប្រទេសចិន។ ប្រទេសចិនក៏បានធ្វើការទម្លាក់តម្លៃរូបិយប័ណ្ណគួរអោយភ្ញាក់ផ្អើលចំនួនពីរដង ក្នុងការកាត់បន្ថយអត្រាការប្រាក់ផ្លូវការនិងបង្កើនការចំណាយសាធារណៈដើម្បីទប់ទល់អ្វីដែលអាចជា

វិបត្តិសេដ្ឋកិច្ចនាពេលខាងមុខ។ សកម្មភាពទាំងនេះហាក់ដូចជាទទួលបានជោគជ័យ បើទោះបីជាអត្រាកំណើនរបស់ប្រទេសចិនបានធ្លាក់ចុះក្នុងទសវត្សរ៍កន្លងមកក៏ដោយ ក៏វានៅតែខ្ពស់បើធៀបទៅនឹងប្រទេសកំពុងអភិវឌ្ឍន៍ផ្សេងទៀត ដែលមានលើសពី ៦ ភាគរយ។ ហើយខណៈពេលដែលទិដ្ឋភាពសេដ្ឋកិច្ចជាច្រើនរបស់ប្រទេសចិននៅតែរឹងមាំ ភាពអាក់រអួលនៃឆ្នាំ ២០១៥ បាននាំអោយអ្នកជំនាញមួយចំនួនចោទសួរថាតើរយៈពេលប៉ុន្មានឆ្នាំដែលប្រទេសចិនអាចបន្តអត្រាកំណើនសេដ្ឋកិច្ចខ្ពស់របស់ខ្លួន។

សញ្ញាមួយបង្កជាបញ្ហានាពេលខាងមុខសម្រាប់ប្រទេសចិន អាចជាការកើនឡើងនៃមនោសញ្ចេតនាជាតិនិយមនិងប្រឆាំងសកលភាវូបនីយកម្ម នៅទូទាំងពិភពលោក។ ដូចដែលមនុស្សជាច្រើនតែងតែបន្ទោសសហរដ្ឋអាមេរិកចំពោះការផ្សព្វផ្សាយវប្បធម៌របស់ខ្លួនតាមរយៈសកលភាវូបនីយកម្ម មនុស្សជាច្រើននៅជុំវិញពិភពលោកជាពិសេសប្រទេសលោកខាងលិច បានទម្លាក់កំហុសសេចក្តីវេទនាសេដ្ឋកិច្ចរបស់ពួកគេទៅលើប្រទេសចិន។ ដោយសារអតិរេកពាណិជ្ជកម្មធំរបស់ចិន វាក្លាយជាគោលដៅងាយស្រួលសម្រាប់អ្នកដែលមិនសប្បាយចិត្តជាមួយនឹងពាណិជ្ជកម្មក្រោមរបបសកលភាវូបនីយកម្ម។ នៅឆ្នាំ ២០១៧-២០១៨ ប្រធានាធិបតីសហរដ្ឋអាមេរិក លោក ដូណាល់ ត្រាំ បានចាប់ផ្តើមដាក់ពន្ធលើការនាំចូលពីប្រទេសចិន ដែលបង្កអោយមានសក្តានុពលជាសកល។ ប្រតិកម្មប្រឆាំងនឹងពាណិជ្ជកម្មចិនអាចធ្វើអោយគំរូសេដ្ឋកិច្ចប្រទេសចិនប្រឈមនឹងហានិភ័យ ទោះបីជាវាក៏នឹងធ្វើអោយប៉ះពាល់ដល់អ្នកប្រើប្រាស់នៅក្នុងប្រទេស ដែលទិញទំនិញរបស់ចិនយកមកប្រើប្រាស់ក៏ដោយ។

អស់រយៈពេលជាច្រើនឆ្នាំមកហើយ វាហាក់ដូចជាថាចំនួនប្រជាជនដ៏ច្រើនរបស់ប្រទេសចិន នឹងអាចផ្តត់ផ្តង់កម្លាំងពលកម្មថោកៗ គ្មានដែនកំណត់ ដល់អ្នកវិនិយោគបរទេស ដែលផលិតទំនិញនៅក្នុងប្រទេសចិន។ ទោះយ៉ាងណាក៏ដោយ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ កំណើនសេដ្ឋកិច្ចរបស់ប្រទេសចិនបានចាប់ផ្តើមធ្វើអោយកម្លាំងពលកម្មកកស្ទះហើយជំរុញអោយប្រាក់ឈ្នួលកើនឡើង។ ភាពចលាចលផ្នែកការងារបានក្លាយទៅជារឿងធម្មតា នៅទូទាំងប្រទេសចិន ខណៈកម្មករទាមទារដំឡើងប្រាក់ខែនិងលក្ខខណ្ឌការងារអោយកាន់តែប្រសើរ។ សាជីវកម្មពហុជាតិ(MNCs)បានចាប់ផ្តើមផ្លាស់ប្តូរទីតាំងផលិតកម្មធុនស្រាលមួយចំនួនទៅកាន់ប្រទេសអាស៊ីផ្សេងទៀតដែលមានកម្លាំងពលកម្មថោកជាង ដូចជាវៀតណាមជាដើម។

វាមិនច្បាស់ទេថាតើមេរៀនអ្វីដែលជោគជ័យខាងផ្នែកសេដ្ឋកិច្ចរបស់ប្រទេសចិន ក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ មានសម្រាប់អឡឺគោលខាងត្បូង។ វាច្បាស់ណាស់ថា ការផ្លាស់ប្តូរដ៏លើវិថីវែងឆ្ងាយពីការធ្វើសេដ្ឋកិច្ចផែនការ និងឆ្ពោះទៅរកភាពជាម្ចាស់ឯកជនរបស់ប្រទេសចិន ច្បាស់ណាស់ជាកត្តាសំខាន់នៃជោគជ័យរបស់ខ្លួន ប៉ុន្តែរដ្ឋនៅតែបន្តដើរតួនាទីយ៉ាងសំខាន់ ក្នុងការត្រួតពិនិត្យសេដ្ឋកិច្ច (រហូតច្រើនជាងនៅក្នុងប្រទេសឧស្សាហកម្មថ្មី)។ ប្រធានបទទាំងនេះកំពុងត្រូវបានពិភាក្សាយ៉ាងផុសផុលនៅពេលដែលប្រទេសចិនស្វែងរកយុគសម័យថ្មីក្នុងការបង្កើនភាពរុងរឿងនិងក្តីរំពឹងទុក ស្វែងរកវិថីផ្ទាល់ខ្លួននៅក្នុងសេដ្ឋកិច្ចពិភពលោកដែលមានភាពច្របូកច្របល់ថ្មី និងខណៈដែលរដ្ឋក្រីក្រផ្សេងទៀតមើលទៅបទពិសោធន៍របស់ប្រទេសចិនជាគំរូ។

១៣.១.៣. ការចើបឡើងរបស់ឥណ្ឌា

ប្រទេសឥណ្ឌា ក៏ដូចជាប្រទេសចិនដែរ សាកសមនឹងទទួលបានការយកចិត្តទុកដាក់ជាពិសេស ដោយសារតែទំហំរបស់វានិងកំណើនដ៏រឹងមាំ នាពេលថ្មីៗនេះ។ ពីឆ្នាំ ១៩៩៦ ដល់ឆ្នាំ ២០១៣ អត្រាកំណើនជាមធ្យម

ប្រចាំឆ្នាំរបស់ប្រទេសឥណ្ឌា លើសពី ៥ ភាគរយ។ ទស្សវត្សរ៍នៃភាពជោគជ័យរបស់ប្រទេសឥណ្ឌានៅតែមិនអាចប្រៀបធៀបទៅនឹងរយៈពេលជិត ៣ ទសវត្សរ៍របស់ប្រទេសចិន និង ផ.ស.ស.របស់ឥណ្ឌាសម្រាប់មនុស្សម្នាក់ៗនៅតែមិនច្រើនជាងពាក់កណ្តាលនៃប្រទេសចិន។ ប៉ុន្តែ ភាពជោគជ័យរបស់ឥណ្ឌាបានចាប់ផ្តើមវាឆ្ពោះទៅរកអ្វីដែលអាចក្លាយជាការរីកធំឡើងស្រដៀងទៅការកើនឡើងរបស់ប្រទេសចិនចេញពីភាពក្រីក្រ នៅក្នុងប៉ុន្មានឆ្នាំខាងមុខនេះ។

រូបថត ពេទ្យជំនាញខាងវិទ្យុសកម្មនៅទីក្រុង Bangalore ពិភាក្សាអំពីលទ្ធផលស្កែនតាមទូរស័ព្ទ
រងចាំបម្រើអតិថិជន

ប្រទេសឥណ្ឌាបានរីកចម្រើនយ៉ាងឆាប់រហ័សក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ដោយប្រើប្រាស់កម្លាំងពលកម្មក្នុងចំណោមប្រជាជនដែលនិយាយភាសាអង់គ្លេសបានច្រើន និងការអប់រំល្អ ដើម្បីបង្កើតប្រាក់ចំណូលពីការនាំចេញនៅក្នុងវិស័យសេវាកម្ម ពោលគឺក្រុមហ៊ុនកម្មវិធី មជ្ឈមណ្ឌលហៅទូរសព្ទបម្រើអតិថិជនអាមេរិក និងសេវាកម្មវិជ្ជាជីវៈក្នុងផ្នែកដូចជា គណនេយ្យ ស្ថាបត្យកម្ម វិស្វកម្ម និងថ្នាំ។ គ្រូពេទ្យជំនាញខាងវិទ្យុសកម្មនៅទីក្រុង Bangalore រដ្ឋជានីបច្ចេកវិទ្យារបស់ប្រទេសឥណ្ឌា អានរូបថតស្កែនរាងកាយពីមន្ទីរពេទ្យសហរដ្ឋអាមេរិកដែលបានផ្ញើតាមអ៊ីនធឺណិត ហើយពិភាក្សាអំពីលទ្ធផលតាមទូរស័ព្ទជាមួយវេជ្ជបណ្ឌិតរបស់អ្នកជំងឺនៅទីក្រុង Connecticut ឆ្នាំ ២០០៤។

អស់រយៈពេលជាច្រើនទសវត្សរ៍មកហើយ សេដ្ឋកិច្ចរបស់ប្រទេសឥណ្ឌាពឹងផ្អែកលើសង្គមនិយមនិងការគ្រប់គ្រងដោយរដ្ឋទៅលើឧស្សាហកម្មធំៗ ប៉ុន្តែពឹងផ្អែកលើមូលធននិយមឯកជន ក្នុងវិស័យកសិកម្ម និងទំនិញប្រើប្រាស់ប្រចាំថ្ងៃ។ រដ្ឋឧបត្ថម្ភធនលើទំនិញជាមូលដ្ឋាន និងផ្តល់ការព្យាបាលពិសេសដល់កសិករ។ មិនដូចប្រទេសចិនទេ ឥណ្ឌាមានរដ្ឋាភិបាលប្រជាធិបតេយ្យ ប៉ុន្តែ ជាប្រទេសដែលមានចលនាទាមទារស្វ័យភាព និងជម្លោះជាតិសាសន៍ជាច្រើន។ រដ្ឋាភិបាលឥណ្ឌាបានរងគ្រោះពីអំពើពុករលួយ បើទោះបីជាមានភាពប្រសើរឡើងក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ។

ឧស្សាហកម្មដែលគ្រប់គ្រងដោយរដ្ឋរបស់ឥណ្ឌា ក៏ដូចជាបណ្តាប្រទេសផ្សេងទៀតមិនបានផ្តល់ផលចំណេញច្រើនទេនោះ។ ជាឧទាហរណ៍ជាក់ស្តែង ១២ ឆ្នាំបន្ទាប់ពីរោងចក្រជីមួយត្រូវបានសាងសង់ វាបានប្រើប្រាស់កម្មករ ចំនួន ៣០០០ នាក់ ប៉ុន្តែមិនបានផលិតជីបន្តិចឡើយ។ ទស្សនវិជ្ជាសង្គមនិយមរបស់ឥណ្ឌានិងភាពក្រីក្ររីករាលដាលបានកំណត់កំណើននៃវណ្ណៈកណ្តាល ដើម្បីលើកទឹកចិត្តដល់ ការប្រមូលផ្តុំមូលធននិងចំណូលរដ្ឋ៖ តិចជាង ១ ភាគរយនៃចំនួនប្រជាជន មិនបានបង់ពន្ធលើប្រាក់ ចំណូលណាមួយនោះទេ។ ជាងនេះទៅទៀត ការិយាធិបតេយ្យនៅក្នុងប្រទេសឥណ្ឌាបានបង្អាក់ការវិនិយោគពីបរទេស។ នៅទសវត្សរ៍ឆ្នាំ ១៩៩០ ប្រទេសចិនបានទទួលការវិនិយោគបរទេសជាច្រើនដង ដែលប្រទេសឥណ្ឌាបានធ្វើ។ ការដួលរលំនៃសហភាពសូវៀតឆ្នាំ ១៩៩១ ដែលជាដៃគូពាណិជ្ជកម្មដ៏សំខាន់របស់ឥណ្ឌា បានធ្វើដោយប្រទេសឥណ្ឌាធ្លាក់ចូលទៅក្នុងវិបត្តិសេដ្ឋកិច្ចដ៏ធ្ងន់ធ្ងរដែលស្ទើរតែបណ្តាលអោយប្រទេសនេះក្ស័យធន មិនសងបំណុលអន្តរជាតិរបស់ខ្លួន។ ឥណ្ឌាបានស្វែងរកជំនួយពីមូលនិធិរូបិយវត្ថុអន្តរជាតិ(IMF) និងធនាគារពិភពលោក ហើយបានប្តេជ្ញាខ្លួនចំពោះកំណែទម្រង់សេដ្ឋកិច្ចដ៏ទូលំទូលាយ ដូចជាការកាត់បន្ថយរបបការិយាធិបតេយ្យ និងការលក់ឧស្សាហកម្មដែលខាតបង់ប្រាក់(សូមមើលលក្ខណ្ឌមូលនិធិIMF)។ ទោះបីជាកំណែទម្រង់ត្រូវបានគេអនុវត្តដោយមិនបានល្អឥតខ្ចោះ ប្រទេសឥណ្ឌាមានកំណើនសេដ្ឋកិច្ចដ៏រឹងមាំនៅចុងទសវត្សរ៍ឆ្នាំ ១៩៩០។ កំណើន

សេដ្ឋកិច្ចនាពេលថ្មីៗនេះ បានកើតឡើង បើទោះបីជាមានអំពើពុករលួយ និងការិយាធិបតេយ្យ នៅក្នុងរដ្ឋាភិបាលរបស់ប្រទេសឥណ្ឌាក៏ដោយ ក៏ប្រជាជនឥណ្ឌានិយាយលេងសើចថា សេដ្ឋកិច្ចកើនឡើងនៅពេលយប់ ខណៈពេលដែលរដ្ឋាភិបាលកំពុងដេកលក់។

នៅក្នុងយុគសម័យសកលភាវូបនីយកម្ម ទីផ្សារពិសេសរបស់ប្រទេសឥណ្ឌានៅក្នុងសេដ្ឋកិច្ចសកលស្ថិតក្នុងវិស័យសេវាកម្មនិងព័ត៌មានវិទ្យា។ ទោះបីជាវិស័យសេវាកម្មមានចំនួនតិចជាង ៣០ ភាគរយ នៃកម្លាំងពលកម្មរបស់ប្រទេសឥណ្ឌា (ភាគច្រើននៅតែស្ថិតក្នុងវិស័យកសិកម្ម) វារួមចំណែកជិត៦០ ភាគរយនៃផលិតផលក្នុងស្រុកសរុប។ ខណៈពេលដែលកូរ៉េខាងត្បូងមានឯកទេសក្នុងការនាំចេញទំនិញឧស្សាហកម្មធុនធ្ងន់ និងប្រទេសចិនក្នុងការនាំចេញទំនិញឧស្សាហកម្មធុនស្រាល ឥណ្ឌាមានជំនាញក្នុងការនាំចេញផលិតផលព័ត៌មាន ដូចជាកម្មវិធីsoftwares និងសេវាកម្មហៅទូរស័ព្ទ (call center)។ ប្រទេសនីមួយៗបានប្រើប្រាស់កម្លាំងពលកម្មរបស់ខ្លួន ដើម្បីបន្ថែមតម្លៃដល់ផលិតផលដែលត្រូវបាននាំចេញទូទាំងពិភពលោក ជាពិសេសទៅកាន់ទីផ្សារអាមេរិកដ៏ធំ។ ក្នុងករណីប្រទេសឥណ្ឌា កម្លាំងពលកម្មទទួលបានការអប់រំល្អ និងអាចនិយាយភាសាអង់គ្លេស។ ប្រទេសឥណ្ឌាក៏ប្រើប្រាស់ទីតាំងរបស់ខ្លួន ដើម្បីទទួលបានអត្ថប្រយោជន៍ដោយធ្វើការក្នុងស្រុកខ្លួនពេលថ្ងៃ តែស្ថិតក្នុងអំឡុងពេលយប់នៅអាមេរិកខាងជើង។ ក្រុមហ៊ុនសូហ្វវែរអាចប្រគល់គម្រោងប្រចាំថ្ងៃ សម្រាប់វេនការងារយប់ ពេញមួយយប់ទៅឥណ្ឌា ហើយមន្ទីរពេទ្យអាមេរិកអាចផ្ញើកំណត់ត្រាវេជ្ជសាស្ត្រសម្រាប់ការចម្លងពេញមួយយប់ដែរ។ សាជីវកម្មពហុជាតិប្រើប្រាស់យ៉ាងទូលំទូលាយនូវកម្លាំងពលកម្មរបស់ប្រទេសឥណ្ឌា ដើម្បីឆ្លើយការហៅទូរស័ព្ទពីជុំវិញពិភពលោក ដូចជាការហៅជំនួយផ្នែកបច្ចេកទេសសម្រាប់ផលិតផលរបស់ក្រុមហ៊ុន។

ភាពជោគជ័យ ឬបរាជ័យ នាពេលអនាគតរបស់ឥណ្ឌានឹងឆ្លើយតបយ៉ាងខ្លាំង លើទ្រឹស្តីប្រកួតប្រជែងនានាអំពីការអភិវឌ្ឍន៍សេដ្ឋកិច្ច។ ជាពិសេស ប្រទេសចិនបានទទួលជោគជ័យ ក្រោមប្រព័ន្ធនយោបាយមជ្ឈការដ៏តឹងរ៉ឹង ចំណែកឥណ្ឌាមានប្រជាធិបតេយ្យសេរី។ ប្រសិនបើឥណ្ឌាមិនអាចរក្សាកំណើនប្រកបដោយនិរន្តរភាព ពេលនោះប្រហែលជារដ្ឋាភិបាលផ្តាច់ការអាចជួយរអភិវឌ្ឍន៍ជំនួស ម្លោះហើយលទ្ធិប្រជាធិបតេយ្យទំនងគួរតែរង់ចាំរហូតដល់ដំណាក់កាលក្រោយ (យើងនឹងពិភាក្សាក្នុងរយៈពេលខ្លីខាងមុខ)។ យ៉ាងណាមិញ ប្រសិនបើឥណ្ឌាបន្តទទួលបានជោគជ័យ នោះច្បាស់ណាស់រដ្ឋាភិបាលផ្តាច់ការមិនមែនជាលក្ខខណ្ឌនិងជាជម្រើសអាទិភាពឡើយ។


ក្រាហ្វិក ១៣.៤ ប្រៀបធៀបវឌ្ឍនភាពរបស់ប្រទេសចិន និងឥណ្ឌាលើសូចនាករសំខាន់ៗចំនួនពីរ អត្រាមរណៈទារក (ជាវិធានការដ៏ល្អទូទៅវាស់ស្ទង់សុខភាពសាធារណៈ) និងអត្រាបង្កកំណើត។ ក្នុងករណីទាំងពីរនេះ ប្រទេសចិនអាចធ្វើអោយប្រសើរឡើងយ៉ាងខ្លាំងយ៉ាងឆាប់រហ័ស ដោយសារតែរដ្ឋាភិបាលផ្តាច់ការរបស់ខ្លួនដែលការគ្រប់គ្រង(តាមទ្រឹស្តី)បានពង្រីកដល់គ្រប់ភូមិនិងគ្រប់បន្ទប់គេង។ នៅទសវត្សរ៍ឆ្នាំ ១៩៥០ ប្រទេសចិនបានបញ្ជាអោយមានយុទ្ធនាការទ្រង់ទ្រាយធំ ដែលប្រជាពលរដ្ឋបានកំចាត់សត្វល្អិត និងរៀបចំកន្លែងអនាម័យ។ ជាលទ្ធផល នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ អត្រានៃការរីករាលដាលនជំងឺ នៅប្រទេសចិនដូចជាជំងឺអាសន្នរោគ និងប៉េស្តបានធ្លាក់ចុះ ហើយអត្រាមរណភាពទារកក៏ដូចគ្នាដែរ។ ក្នុងទសវត្សរ៍ឆ្នាំ ១៩៧០ ជាមួយនឹងគោលនយោបាយតឹងរ៉ឹងអោយមានកូនតែមួយ ប្រទេសចិនបានបង្ខំអោយអត្រាបង្កកំណើតធ្លាក់ចុះ។ ស្ត្រីដែលជំទាស់អាចត្រូវបានក្រៀវដោយបង្ខំ។ ដូច្នេះប្រទេសចិនពឹងផ្អែកលើគោលការណ៍

ត្រួតត្រា ដើម្បីបង្ខំបុគ្គលអោយធ្វើសកម្មភាពដែលជាផលប្រយោជន៍របស់សង្គម។ ភាពជោគជ័យរបស់វាក្នុងការធ្វើអោយប្រសើរឡើងនូវសុខភាពសាធារណៈ និងការចាយចុះអត្រាបង្កកំណើតបានផ្តល់នូវមូលដ្ឋានគ្រឹះសម្រាប់ភាពជោគជ័យផ្នែកសេដ្ឋកិច្ចជាបន្តបន្ទាប់របស់ប្រទេសចិន ទោះបីជាជាក់ស្តែងត្រូវប៉ះពាល់ដល់សេរីភាពរបស់បុគ្គលគ្រប់រូបក្តី។

ក្រាហ្វិក ១៣.៤ ការប្រៀបធៀបការអភិវឌ្ឍន៍របស់ប្រទេសចិន និងឥណ្ឌា

ប្រភព៖ ផ្អែកលើទិន្នន័យរបស់ធនាគារពិភពលោក។

អត្រាមរណៈទារក (ក្នុង១០០០នាក់) **អត្រាបង្កកំណើត (ចំនួនទារកក្នុងស្ត្រីម្នាក់)**



**អ្ឌគោលខាងជើងក្រោមកម្រិតនេះ *កម្រិតនៃការជំនួស ចំនួនប្រជាជនដែលមានស្ថិរភាព*

ផ្ទុយទៅវិញ ប្រទេសឥណ្ឌាបានពឹងផ្អែកលើគោលការណ៍អត្តសញ្ញាណកាន់តែច្រើន ដោយធ្វើអោយមនុស្សផ្លាស់ប្តូរចំណង់ចំណូលចិត្តរបស់ពួកគេ និង*ចង់*មានកូនចំនួនតិចជាងមុន និងជួយកែលម្អសុខភាពសាធារណៈ។ ប្រសិនបើគ្មានរបបផ្តាច់ការដើម្បីបង្ខំអោយអនុលោមតាមទេ វឌ្ឍនភាពរបស់ឥណ្ឌាច្បាស់ជាកាន់តែយឺត។

ទោះយ៉ាងណាក៏ដោយ យូរៗទៅឥណ្ឌាកំពុងឆ្ពោះទៅរកលទ្ធផលដូចប្រទេសចិន ទោះបីយឺតជាងប៉ុន្មានទសវត្សរ៍ក៏ដោយ ហើយធ្វើដូច្នេះបានដោយមិនបោះបង់អត្តសញ្ញាណជាតិរបស់ខ្លួនក្នុងនាមជាប្រទេសប្រជាធិបតេយ្យ។


១៣.១.៤. បទពិសោធន៍ប្រទេសផ្សេងៗ

ប្រទេសកំពុងអភិវឌ្ឍន៍ដ៏ច្រើនទៀតបានបន្តយុទ្ធសាស្ត្រអភិវឌ្ឍន៍ផ្សេងៗ ដោយមានលទ្ធផលចម្រុះ ជោគជ័យខ្លះនិងបរាជ័យខ្លះ។ លទ្ធផលល្អបំផុតបានមកពីអាស៊ី។ ក្រាហ្វិក ១៣.៥ បង្ហាញពីកម្រិតប្រាក់ចំណូល និងអត្រាកំណើននៃប្រទេសធំៗមានចំនួនប្រជាជនច្រើនជាងគេ ចំនួន ១៦ នៅក្នុងគោលខាងត្បូង។ ក្រាហ្វស្រដៀងគ្នាសម្រាប់តំបន់នានាលើពិភពលោក បង្ហាញក្នុងក្រាហ្វិក ១២.១។ ច្បាស់ណាស់ ប្រទេសធំៗនៅអឌ្ឍគោលខាងត្បូង មានភាពខុសប្លែកគ្នាយ៉ាងទូលំទូលាយ ក្នុងកម្រិតប្រាក់ចំណូល។ ប្រទេសដែលមានប្រាក់ចំណូលខ្ពស់បំផុតទាំងប្រាំ (ទួរគី អ៊ីរ៉ង់ ថៃ ម៉ិកស៊ិក និងចិន) មកពីតំបន់ចំនួនបី ក្នុងចំណោមតំបន់តំបន់ទាំងបួន ហើយមានអត្រាកំណើនខុសគ្នាខ្លាំង។ ប្រទេសបីក្នុងចំណោមប្រទេសលូតលាស់លឿនបំផុត (បង់ក្លាដែស ឥណ្ឌា និងអេត្យូពី) នៅកម្រិត ៧-៨ ភាគរយ ស្ថិតនៅកម្រិតទាបបំផុតនៃមាត្រដ្ឋានប្រាក់ចំណូល។ ក្នុងរយៈពេល២៥ឆ្នាំចុងក្រោយនេះ ប្រទេសចិនបានអភិវឌ្ឍលឿនជាងប្រទេសធំៗ ចំនួន ១៥

ផ្សេងទៀតនៅអឌ្ឍគោលខាងត្បូង ហើយជាមួយនឹងអត្រាកំណើនទាំងនេះ ចិននឹងក្លាយទៅជាប្រទេសមួយក្នុងចំណោមប្រទេសដែលមានប្រាក់ចំណូលខ្ពស់បំផុតទាំងប្រាំ ក្នុងក្រុមនេះ ក្នុងពេលឆាប់ៗ។ ច្បាស់ណាស់ ទីតាំងក្នុងតំបន់ធ្វើអោយមានភាពខុសគ្នា។ ជាការពិតដែលថា តំបន់ទាំងប្រាំនៃអឌ្ឍគោលខាងត្បូងអាចត្រូវបានគូសវាសលើតំបន់ជាប់គ្នាតែមួយនៅក្នុងតួលេខនេះបង្ហាញថាតំបន់ទាំងមូលកំពុងផ្លាស់ប្តូរជាមួយគ្នាតាមលំនាំផ្សេងៗគ្នា។

ក្រាហ្វិក ១៣.៥ កម្រិតប្រាក់ចំណូល និងអត្រាកំណើនរបស់ប្រទេសធំបំផុត ឆ្នាំ ២០១៦

ប្រភព៖ ផ្អែកលើទិន្នន័យរបស់ធនាគារពិភពលោក។



សម្រាប់មនុស្សម្នាក់ៗ

ចំណាំ៖ ក្រាហ្វិកបង្ហាញពីប្រទេសកំពុងអភិវឌ្ឍន៍ចំនួន ១៦ ដែលមានប្រជាជនច្រើនបំផុត

នៅអាស៊ី ប្រទេសបីដំបូងដែលព្យាយាមធ្វើតាម NICs រួមមាន ឥណ្ឌូនេស៊ី ម៉ាឡេស៊ី និងថៃ។ សម្រាប់ប្រទេសឥណ្ឌូនេស៊ីវិញ ក៏បានកំណត់គោលដៅនៅឆ្នាំ ១៩៦៩ ដើម្បីក្លាយជា NIC នៅត្រឹមឆ្នាំ ១៩៩៤។ វាបានធ្លាក់ចុះពីគោលដៅនោះ ប៉ុន្តែ បានធ្វើអោយមានការវិវឌ្ឍន៍មួយចំនួនក្នុងការទាក់ទាញការវិនិយោគពីបរទេស។ ជាមួយនឹងប្រជាជនចំនួន ២៥០ លាននាក់ និងផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់ៗប្រហាក់ប្រហែលនឹងប្រទេសឥណ្ឌា ទ្រព្យសម្បត្តិសំខាន់ៗរបស់ប្រទេសឥណ្ឌូនេស៊ីគឺជាកម្លាំងពលកម្មថោក (ប្រាក់ឈ្នួលអប្បបរមា តិចជាង ៥០ សេន ក្នុងមួយម៉ោង) និងធនធានធម្មជាតិដែលអាចនាំចេញបានរួមទាំងប្រេងផងដែរ។ ប៉ុន្តែ ប្រទេសឥណ្ឌូណេស៊ីត្រូវនាំចូលប្រេង តាំងពីឆ្នាំ ២០០៤ ដោយសារការផលិតធ្លាក់ចុះ។ ទីតាំងរបស់ហ្វីលីពីនស្រដៀងនឹងប្រទេសឥណ្ឌូណេស៊ី។ បន្ទាប់ពីបានឆ្លងផុតវិបត្តិឆ្នាំ ១៩៩៧

យ៉ាងរលូន ប្រទេសហ្វីលីពីនបានឈានដល់ខ្សែកោងកំណើន ដែលបច្ចុប្បន្នមានលើសពី ៥ ភាគរយក្នុងមួយឆ្នាំ ដែលជាសញ្ញាវិជ្ជមាន ប៉ុន្តែមិនលឿនគ្រប់គ្រាន់ដើម្បីដោះស្រាយភាពក្រីក្រដែលកំពុងរីករាលដាលនៅក្នុងប្រទេសនោះទេ។

ម៉ាឡេស៊ីក៏បានដាក់ចេញគោលដៅដើម្បីដើរតាមគន្លងខ្លាទាំងបួនយ៉ាងជិតស្និទ្ធ។ ទោះបីជាប្រទេសនេះនាំចេញប្រេងនិងឧស្ម័នក៏ដោយ ម៉ាឡេស៊ីបានផ្តោតលើឧស្សាហកម្មនាំចេញរបស់ខ្លួនយ៉ាងខ្លាំងលើគ្រឿងអេឡិចត្រូនិក។ វាត្រូវបានរងផលប៉ះពាល់យ៉ាងខ្លាំង ដោយសារការវិស័យផ្នែកព័ត៌មាន dot-com នៃឆ្នាំ ២០០១-២០០២ ប៉ុន្តែបានត្រលប់មកវិញនូវកំណើន ៥-៧ ភាគរយក្នុងមួយឆ្នាំ ក្នុងឆ្នាំ ២០០៤-២០០៨។ ជាមួយនឹងប្រាក់ចំណូលសម្រាប់មនុស្សម្នាក់ៗ លើសពី ២០០០០ដុល្លារ ប្រទេសម៉ាឡេស៊ីបានកើនឡើងដោយជោគជ័យដល់កម្រិតចំណូលមធ្យម។

ប្រទេសថៃត្រូវបានណែនាំជាញឹកញាប់ថាជា «ខ្លាទីប្រាំ» ដែលមានសក្តានុពល។ វាបានទទួលការវិនិយោគពីបរទេសដ៏ធំសម្បើម នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ (ភាគច្រើនមកពីប្រទេសជប៉ុន) ហើយបានបង្កើតជាវណ្ណៈកណ្តាលដ៏ធំ។ ប៉ុន្តែ កំណើនរបស់វាបានបិទបាំងបញ្ហាធ្ងន់ធ្ងរ ដែលត្រូវបានបង្ហាញនៅក្នុងវិបត្តិហិរញ្ញវត្ថុឆ្នាំ ១៩៩៧។ ប្រទេសថៃបានស្ទុះងើបឡើងវិញ ហើយបានបង្ហាញពីកំណើនដ៏ខ្លាំង បើទោះបីជាមានបញ្ហាបន្តទៀតក៏ដោយជាមួយនឹងប្រាក់កម្ចីមិនល្អ។ ប៉ុន្តែ រដ្ឋប្រហារឆ្នាំ ២០០៦ និងអស្ថិរភាពនយោបាយបានធ្វើអោយប្រទេសថៃមិនសូវមានភាពទាក់ទាញសម្រាប់ការវិនិយោគពីបរទេសប៉ុន្មានទេ។

ចាប់តាំងពីឆ្នាំ ២០០១ ប្រទេសអាស៊ីអាគ្នេយ៍មួយចំនួនក៏ត្រូវដោះស្រាយបញ្ហាភេរវកម្ម នៅក្នុងព្រំដែនរបស់ពួកគេ ហើយឥណ្ឌូនេស៊ីបានប្រឈមមុខនឹងភាពចលាចលជនជាតិភាគតិច នៅក្នុងកោះជាច្រើន (ទោះបីជាសង្គ្រាមធ្វើអបគមន៍ដ៏សកម្មនៅក្នុងខេត្តអាឆេ បានបញ្ចប់ក៏ដោយ)។ កត្តាទាំងនេះបានរារាំងការអភិវឌ្ឍន៍សេដ្ឋកិច្ចនៃ NICs នៃអាស៊ីអាគ្នេយ៍។

វៀតណាមក៏បានរកឃើញជោគជ័យស្រដៀងនឹងប្រទេសឥណ្ឌាដែរ។ វៀតណាមគឺជារដ្ឋកុម្មុយនិស្ត៍មួយ ដែលបានធ្វើតាមគំរូកំណែទម្រង់ដែលផ្អែកលើប្រទេសចិន។ ដូចប្រទេសចិនដែរ វៀតណាមមានការព្រួយបារម្ភតិចតួចអំពីអំពើភេរវកម្ម ហើយភាគច្រើនមិនរងផលប៉ះពាល់ដោយវិបត្តិសេដ្ឋកិច្ចឆ្នាំ ២០០៨។ កំណើនសេដ្ឋកិច្ចរបស់ប្រទេសវៀតណាមចាប់តាំងពីឆ្នាំ ១៩៩៧ មានកម្រិតមធ្យមប្រហែល ៧ ភាគរយក្នុងមួយឆ្នាំ។ រយៈពេលនៃកំណើនដ៏ឆាប់រហ័សនេះ ធ្វើឡើងបន្ទាប់ពីសេរីភាវូបនីយកម្មនៃសេដ្ឋកិច្ច ដែលត្រូវបានរារាំងដោយសង្គ្រាមបំផ្លិចបំផ្លាញជាច្រើនទសវត្សរ៍ និងការគ្រប់គ្រងមជ្ឈឹមរបស់កុម្មុយនិស្ត៍។ វៀតណាម ដែលជាពិសេសមានការនាំចេញវាយនភណ្ឌបានចូលជាសមាជិក អង្គការWTO ក្នុងឆ្នាំ ២០០៧។ ដូចទៅនឹងប្រទេសចិនដែរ វៀតណាមបានធ្វើការងារបានល្អក្នុងការបំពេញ តម្រូវការជាមូលដ្ឋានរបស់មនុស្ស ទោះមានកម្រិតប្រាក់ចំណូលជាមធ្យមទាបបំផុត និងបានកាត់បន្ថយភាពក្រីក្រខ្លាំង បើទោះបីជានៅជាប្រទេសក្រីក្រក៏ដោយ។

រដ្ឋធំៗនៅអាស៊ី ដូចជា ប្រទេសបង់ក្លាដែស និងប៉ាគីស្តាន កាន់តែជាប់គាំងក្នុងភាពក្រីក្រ ហើយមានការរំពឹងទុកកាន់តែថយចុះសម្រាប់ការប្រមូលផ្តុំដើមទុន នៅក្នុងប៉ុន្មានឆ្នាំខាងមុខនេះ។ ពួកគេប្រឈមមុខនឹងបញ្ហាជាមួយការិយាធិបតេយ្យរបស់រដ្ឋ អំពើពុករលួយ និងអស្ថិរភាពនយោបាយ។ ទោះជាយ៉ាងណាក៏ដោយ នៅចុងបញ្ចប់នៃឆ្នាំ ២០០៨ ប្រទេសបង់ក្លាដែសបានបញ្ចប់ការគ្រប់គ្រងគ្រាអាសន្ន ដោយជោគជ័យ

ជាមួយនឹងការបោះឆ្នោតដោយយុត្តិធម៌ ដែលឃើញមានអ្នកចូលរួមយ៉ាងច្រើន និងនាំមកនូវក្តីសង្ឃឹមថ្មី សម្រាប់ការអភិវឌ្ឍន៍ និងការទប់ស្កាត់អំពើពុករលួយ។ ផ្ទុយទៅវិញ ប្រទេសប៉ាគីស្ថានបានបន្តតស៊ូជាមួយអស្ថិរភាពនៅក្នុងតំបន់ជាប់ព្រំដែនអាហ្វហ្គានីស្ថាន។ ជាមួយនឹងការបន្តជម្លោះនយោបាយក្នុងចំណោមរដ្ឋាភិបាល តុលាការ និងយោធារបស់ខ្លួន ទស្សនវិស័យកំណើនសេដ្ឋកិច្ចរបស់ប៉ាគីស្ថានត្រូវទុកមួយឡែក ដោយផ្តោតលើការស្វែងរកស្ថិរភាពនយោបាយជាមុនសិន។

នៅអាមេរិកឡាទីន ប្រទេសធំៗចាប់ផ្តើមពីកម្រិតប្រាក់ចំណូលខ្ពស់ ប៉ុន្តែអត្រាកំណើនទាបជាងនៅប្រទេសចិននិងអាស៊ីខាងត្បូង។ ប្រទេសប្រេស៊ីល និងម៉ិកស៊ិក ធំជាងគេ។ ប្រទេសប្រេស៊ីលបានកសាងទីផ្សារផ្ទៃក្នុងដ៏ធំមួយ ដោយប្រមូលផ្តុំប្រាក់ចំណូលនៅក្នុងវណ្ណៈកណ្តាល និងថ្នាក់ខ្ពស់ដែលកំពុងកើនឡើង។ ទោះជាយ៉ាងណាក៏ដោយ ទីក្រុងរបស់វានៅតែសម្បូរទៅដោយអនាធិបតេយ្យដ៏ធំ ដែលពោរពេញទៅដោយប្រជាជនក្រីក្រ។ មួយទសវត្សរ៍មុន ការបោះឆ្នោតជ្រើសរើសប្រធានាធិបតីឆ្វេងនិយម លូឡា ដា ស៊ីលវ៉ា (Lula da Silva) បានបង្កើនការភ័យខ្លាចថាការចំណាយលើកម្មវិធីសង្គមនឹងធ្វើអោយខូចដល់ជំហរហិរញ្ញវត្ថុរបស់ប្រទេសប្រេស៊ីល ប៉ុន្តែ ផ្ទុយទៅវិញគាត់បានបន្តយការចំណាយ កាត់បន្តយអតិផរណា និងស្ថិរភាពជំហរហិរញ្ញវត្ថុរបស់ប្រទេសប្រេស៊ីល ដែលបានបង្ហាញថា នៅក្នុងប្រទេសប្រេស៊ីល ក៏ដូចជានៅក្នុងប្រទេសចិន អ្នកសង្គមនិយមអាចបង្កើតមូលធននិយមដ៏ល្អ។ ចាប់តាំងពីឆ្នាំ ២០១២ មក ប្រទេសប្រេស៊ីលបានរីករាយនឹងការរួមបញ្ចូលគ្នាដ៏កម្រនៃកំណើនស្ថិរភាព លទ្ធិប្រជាធិបតេយ្យ និងវិសមភាពដែលធ្លាក់ចុះ (ទោះបីជាកម្រិតនៅតែខ្ពស់ក៏ដោយ) ដោយផ្តល់នូវគំរូអភិវឌ្ឍន៍សម្រាប់អ្នកដទៃដើម្បីធ្វើតាម។ ប្រេស៊ីលធ្វើជាម្ចាស់ផ្ទះរៀបចំការប្រកួតបាល់ទាត់ពិភពលោកឆ្នាំ ២០១៤ ដោយជោគជ័យ ហើយសង្ឃឹមថានឹងមានកីឡាអូឡាំពិកឆ្នាំ ២០១៦ ក៏នឹងបង្កើនកិត្យានុភាពសេដ្ឋកិច្ចនិងនយោបាយផងដែរ។

ដូចប្រទេសប្រេស៊ីល ម៉ិកស៊ិកមានភាពក្រីក្រជ្រាលជ្រៅ និងបំណុលបរទេសដ៏ច្រើន ប៉ុន្តែ មិនដូចប្រេស៊ីលទេ វាមានប្រេងសម្រាប់នាំចេញ។ ម៉ិកស៊ិកក៏មានស្ថិរភាពនយោបាយដែរ ទោះបីជាមានបញ្ហាពុករលួយខ្លាំងគួរសមក៏ដោយ។ ប្រធានាធិបតីកំណែទម្រង់ម្នាក់ត្រូវបានបោះឆ្នោតជ្រើសរើសក្នុងឆ្នាំ២០០០ ទោះបីជាគណបក្សកាន់អំណាចយូរឆ្នាំ បានឡើងកាន់អំណាចឡើងវិញក្នុងឆ្នាំ ២០១២ ក្តី។ ក្នុងរយៈពេលពីរទសវត្សរ៍ ចាប់តាំងពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាមេរិកខាងជើង (NAFTA) ទោះបីជាមានការចលាចលផ្នែកនយោបាយនិងសេដ្ឋកិច្ចម្តងម្កាលក៏ដោយ ក៏ម៉ិកស៊ិកមិនឃើញមានការចុះអន់ថយឬគ្រោះមហន្តរាយឡើយ។ ទោះយ៉ាងណាក៏ដោយ អំពើហិង្សាទាក់ទងនឹងគ្រឿងញៀនបានឆក់យកជីវិតមនុស្ស ៦០០០០ នាក់ចាប់តាំងពីឆ្នាំ ២០០៦ ហើយបានកាត់បន្តយស្ថិរភាពនយោបាយ និងសេដ្ឋកិច្ច។

នៅទ្វីបអាហ្វ្រិក នីហ្សេរីយ៉ាគឺជាប្រទេសធំជាងគេ ហើយជាមួយនឹងប្រេងសម្រាប់នាំចេញ គួរតែជាប្រទេសមួយក្នុងចំណោមប្រទេសក្រីក្រតិច។ ប៉ុន្តែ នៅកម្រិតប្រាក់ចំណូល ៥៤០០ ដុល្លារ ក្នុងមនុស្សម្នាក់ប្រាក់ចំណូលរបស់វា មានកម្រិតទាបណាស់។ អំពើពុករលួយធ្វើអោយប៉ះពាល់ដល់សេដ្ឋកិច្ច។ នីហ្សេរីយ៉ាហាក់ដូចជាទទួលរងនូវ«បណ្តាសាធនធាន»។ ប្រេងបានផ្តល់ ៩៥ ភាគរយនៃប្រាក់ចំណូលពីការនាំចេញ និងផ្តល់ប្រាក់ចំណូល សម្រាប់ថវិការបស់រដ្ឋាភិបាល ចំនួន ២ ភាគ ៣។ បន្ទាប់ពីរបបផ្តាច់ការយោធាជាច្រើនឆ្នាំ ការបោះឆ្នោតត្រូវបានធ្វើឡើង នៅឆ្នាំ ១៩៩៩ ហើយនីហ្សេរីយ៉ាទទួលបានស្ថេរភាពនយោបាយកាន់តែខ្លាំង នៅក្នុងសតវត្សថ្មី ប៉ុន្តែ បទឈប់បាញ់ជាមួយពួកឧទ្ទាមប្រដាប់ដោយអាវុធនៅភាគខាងត្បូង ដែលសម្បូរ

ប្រេងត្រូវបានបន្តដោយការបំផ្ទុះគ្រាប់បែកកេរវែកអ៊ីស្លាមនៅភាគខាងជើង។ ចាប់តាំងពីឆ្នាំ ២០០៩ មក ក្រុមអ៊ីស្លាមជ្រុលនិយមសំខាន់ ដែលគេស្គាល់ថា បូកូហារ៉ាម (Boko Haram) បានសម្លាប់ជនស៊ីវិលរាប់ពាន់នាក់ ម្លោះហើយបានរួមចំណែកដល់អស្ថិរភាពនយោបាយ។ ស្ថានភាពនយោបាយនិងសេដ្ឋកិច្ចរបស់ប្រទេសនីហ្សេរីយ៉ានៅតែផុយស្រួយ។

រូបថត ពាណិជ្ជករនៅក្នុងប្រទេសឥណ្ឌាតវ៉ាប្រឆាំងនឹង FDI និងអ្នកលក់រាយតាមអ៊ីនធឺណិត

សកលភាវូបនីយកម្មរឿងនេះផង

សកលភាវូបនីយកម្មកំពុងបង្កើតបានអ្នកឈ្នះ និងអ្នកចាញ់ ដែលនាំទៅរកការទាមទារជាក់កម្រិតលើទីផ្សារ។ បំណុល វិបត្តិរូបិយប័ណ្ណ លក្ខខណ្ឌរបស់IMF ការវិនិយោគផ្ទាល់ពីបរទេស(FDI) និងការផ្ញើឯកជន ភាវូបនីយកម្មនៃសហគ្រាសរដ្ឋ គឺជាប្រភពនៃភាពចលាចល និងភាពក្រីក្រនៅក្នុងប្រទេសក្រីក្រជាច្រើន។ នៅទីនេះ ពាណិជ្ជករនៅក្នុងប្រទេសឥណ្ឌាតវ៉ាប្រឆាំងនឹង FDI និងអ្នកលក់រាយតាមអ៊ីនធឺណិតដែលពួកគេនិយាយថាកំពុងធ្វើឱ្យអាជីវកម្មក្នុងស្រុកត្រូវបិទនៅឆ្នាំ ២០១៤ ។

កន្លែងផ្សេងទៀតក្នុងទ្វីបអាហ្វ្រិក ប្រទេសអេត្យូពី និងប្រជាធិបតេយ្យកុងហ្គោ កំពុងរីកចម្រើនយ៉ាងឆាប់រហ័ស ប៉ុន្តែចាប់ផ្តើមពីភាពក្រីក្រយ៉ាងខ្លាំង។ ប្រជាធិបតេយ្យកុងហ្គោបានត្រៀមខ្លួនរួចជាស្រេចដើម្បីងើបឡើងវិញពីសង្គ្រាមជាច្រើនទសវត្សរ៍ ប៉ុន្តែ អំពើហិង្សានៅតែបន្តគំរាមកំហែងដល់ការរីកចម្រើន។ អាហ្វ្រិកខាងត្បូងមានប្រាក់ចំណូលខ្ពស់ (១២០០០ ដុល្លារក្នុងមនុស្សម្នាក់ៗ) ប៉ុន្តែវិសមភាពយ៉ាងខ្លាំង និងអត្រាខ្ពស់នៃការឆ្លងមេរោគHIV/ជំងឺអេដស៍។ យ៉ាងណាមិញ ប្រទេសអាហ្វ្រិកមួយចំនួនដូចជា កេនយ៉ា និងម៉ូរីស កំពុងក្លាយជាសេដ្ឋកិច្ចវិស័យព័ត៌មានគំរូ ដែលមានទស្សនវិស័យអនាគតភ្លឺស្វាងដែរ។

នៅមជ្ឈិមបូព៌ា ប្រទេសអ៊ីស្រាអែលបានអភិវឌ្ឍសេដ្ឋកិច្ចតាមរបៀបប្លែកមិនធម្មតា។ វាបានទទួលការបញ្ចូលជានិរន្តរភាពនៃដើមទុនខាងក្រៅ ពីប្រភពជាច្រើន ដូចជា ប្រាក់សំណងរបស់អាឡឺម៉ង់ ជំនួយបរទេសរបស់សហរដ្ឋអាមេរិក និងការរួមចំណែកពីពួកហ្សៃអូនីសនិយម(zionists)នៅបរទេស។ ជំនួយខាងក្រៅនេះមានលក្ខណៈពិសេសចំពោះប្រវត្តិនៃអំពើប្រល័យពូជសាសន៍របស់អាឡឺម៉ង់ ប្រឆាំងនឹងជនជាតិយូដា ក្នុងអំឡុងពេលសង្គ្រាមលោកលើកទី ២ និងការខិតខំប្រឹងប្រែងរបស់ជនជាតិយូដានៅទូទាំងពិភពលោកដើម្បីជួយកសាងរដ្ឋដ្ធីហ្វមួយនៅពេលក្រោយ។ ប្រទេសកំពុងអភិវឌ្ឍតិចតួចណាស់អាចសង្ឃឹមថានឹងទទួលបានជំនួយខាងក្រៅបែបនេះ (ធៀបនឹងទំហំតូចរបស់អ៊ីស្រាអែល)។ ទោះយ៉ាងណាក៏ដោយ ដូចគ្នាទៅនឹង NICs ផ្សេងទៀត អ៊ីស្រាអែលមានកម្លាំងខ្លាំងការចូលរួមរបស់រដ្ឋ នៅក្នុងឧស្សាហកម្មសំខាន់ៗ និងបានឆ្លាក់ចេញនូវទីផ្សារពិសេសមួយចំនួនសម្រាប់ខ្លួនវានៅក្នុងទីផ្សារពិភពលោក (ជាពិសេសនៅក្នុងផ្នែកកាត់ពេជ្រ កម្មវិធីកុំព្យូទ័រ និងបច្ចេកវិទ្យាយោធា)។

ប្រទេសតូចៗដែលមានការនាំចេញប្រេងធំៗ ដូចជាអារ៉ាប៊ីសាអូឌីត គុយវ៉ែត បារ៉ែន និងអារ៉ាប់រួមបានគ្រប់គ្រងសេដ្ឋកិច្ចបានល្អ។ ប៉ុន្តែ ពួកគេស្ថិតនៅក្នុងថ្នាក់ពិសេសមួយ; បទពិសោធន៍របស់ពួកគេមិនមែនជាបទពិសោធន៍ ដែលរដ្ឋផ្សេងទៀតដែលគ្មានប្រេងអាចធ្វើតាមនោះទេ។ ប្រទេសអ៊ីរ៉ង់ចាប់ផ្តើមរីកចម្រើនយ៉ាងរឹងមាំ និងទាក់ទាញការវិនិយោគបរទេស បន្ទាប់ពីសង្គ្រាមអ៊ីរ៉ង់-អ៊ីរ៉ាក់ បានបញ្ចប់ នៅឆ្នាំ ១៩៨៨ សេដ្ឋកិច្ចភាគច្រើនត្រូវបានគ្រប់គ្រងដោយរដ្ឋ។ លើសពីនេះ លទ្ធិអ៊ីស្លាមបង្កើតការប៉ះទង្គិចជាមួយប្រទេសមហាអំណាចលោកខាងលិច និងធ្វើអោយអ្នកវិនិយោគមានការប្រុងប្រយ័ត្នខ្លាំង។ ជម្លោះលើកម្មវិធី

នុយក្លៃអ៊ែររបស់អ៊ីរ៉ង់បាននាំអោយមានរបបដាក់ទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរ ដែលបានធ្វើអោយខូចដល់កំណើនសេដ្ឋកិច្ចរបស់អ៊ីរ៉ង់យ៉ាងខ្លាំង ក្នុងឆ្នាំ ២០១២ និង ២០១៣។ ទោះជាយ៉ាងណាក៏ដោយ ជាមួយនឹងកិច្ចព្រមព្រៀងនុយក្លៃអ៊ែរដែលសម្រេចបានក្នុងឆ្នាំ ២០១៥ ក្រុមហ៊ុនជាច្រើននៅលោកខាងលិចកំពុងអន្ទះសារចង់វិនិយោគនៅក្នុងសេដ្ឋកិច្ចអ៊ីរ៉ង់ ដែលរួមមាន ៨០ អ្នកប្រើប្រាស់រាប់លាននាក់ និងមានទុនបម្រុងប្រេងរហូតដល់ ៣៥ ទ្រីលានដុល្លារ។ ការដកខ្លួនចេញ កិច្ចព្រមព្រៀងនុយក្លៃអ៊ែរ របស់រដ្ឋបាលប្រធានាធិបតី ត្រាំ ក្នុងឆ្នាំ ២០១៨ បានគំរាមកំហែង មិនត្រឹមតែលទ្ធភាពចូលទៅកាន់ទីផ្សាររបស់អ៊ីរ៉ង់ប៉ុណ្ណោះទេ ថែមទាំងសេដ្ឋកិច្ចរបស់អ៊ីរ៉ង់ផងដែរ ដោយទុកឱកាសនាពេលអនាគតមិនច្បាស់លាស់។

ប្រទេសទួរគីបានទទួលជោគជ័យខ្លះក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ខ្លួន ដោយមិនមានប្រាក់ចំណូលពីការលក់ប្រេង។ ដូចកូរ៉េខាងត្បូង និងតៃវ៉ាន់ដែរ ទួរគីជារដ្ឋផ្តាច់ការអស់រយៈពេលជាច្រើនឆ្នាំ ប៉ុន្តែបានអនុញ្ញាតអោយមានសេរីភាវូបនីយកម្មនយោបាយ តាំងពីទសវត្សរ៍ឆ្នាំ ១៩៩០។ វាត្រូវបានអភិវឌ្ឍក្រោមឆ័ត្រសុវត្ថិភាព (ណាតូ) និងបានទទួលជំនួយបរទេសយ៉ាងច្រើនសន្ធឹកសន្ធាប់ ពីសហរដ្ឋអាមេរិក។ ដូចម៉ិកស៊ិក ទួរគីកំពុងព្យាយាមចូលរួមជាមួយប្រទេសជិតខាងដែលរីកចម្រើនជាង ពោលគឺ សហភាពអឺរ៉ុប (EU) (សូមមើលមេរៀនទី ១០)។ សេដ្ឋកិច្ចរបស់ប្រទេសទួរគីបានរងគ្រោះ ក្នុងអំឡុងវិបត្តិហិរញ្ញវត្ថុឆ្នាំ ២០០៨-២០០៩ ប៉ុន្តែ បានត្រលប់មកកំណើនវិងមាំវិញ នៅឆ្នាំ ២០១០។ នៅឆ្នាំ ២០១៤ ភាពតានតឹងក្នុងស្រុក និងជម្លោះជាមួយប្រទេសស៊ីរី ដែលជាប្រទេសជិតខាងរបស់ទួរគី នៅភាគខាងត្បូង បាននាំមកនូវសម្ពាធយ៉ាងសំខាន់លើសេដ្ឋកិច្ចរបស់ខ្លួន។

ប្រទេសអេហ្ស៊ីបស្ថិតក្នុងភាពក្រីក្រ បើទោះបីជាមានជំនួយយ៉ាងច្រើនពីសហរដ្ឋអាមេរិក ចាប់តាំងពីចុងទសវត្សរ៍ឆ្នាំ ១៩៧០ ក៏ដោយ។ រដ្ឋកាន់កាន់ឧស្សាហកម្មភាគច្រើន ប្រតិបត្តិការសេដ្ឋកិច្ចផែនការកណ្តាលកំណត់ពន្ធនាំចូលខ្ពស់ និងផ្តល់ការងារឧបត្ថម្ភ និងតម្លៃឧបត្ថម្ភធន។ កំណែទម្រង់ក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ បាននាំមកនូវកំណើនសេដ្ឋកិច្ច ប៉ុន្តែ បញ្ហាដែលនៅសេសសល់រួមមាន អត្រាអត់ការងារធ្វើខ្ពស់ ឱនភាពពាណិជ្ជកម្ម និងអំពើពុករលួយរីករាលដាល។ បន្ទាប់ពីការផ្តួលរំលំមេដឹកនាំផ្តាច់ការរបស់ខ្លួន ក្នុងឆ្នាំ ២០១១ អេហ្ស៊ីបទន្ទឹងរង់ចាំការចាប់ផ្តើមសេដ្ឋកិច្ចរបស់ខ្លួនឡើងវិញ ដែលត្រូវបានរំខានយ៉ាងធ្ងន់ធ្ងរដោយអស្ថិរភាពនៃបដិវត្តន៍និទាឃរដូវនៅអារ៉ាប់។ ប៉ុន្តែ ចាប់តាំងពីឆ្នាំ ២០១១ មក អេហ្ស៊ីបមិនអាចបង្កើតគំរូនៃកំណើនសេដ្ឋកិច្ចវិងមាំបាននោះទេ។

១៣.២. មេរៀន

១៣.២ ចូរកំណត់និងវាយតម្លៃយុទ្ធសាស្ត្រពីរផ្សេងគ្នា ដែលប្រទេសកំពុងអភិវឌ្ឍន៍ប្រើប្រាស់ក្នុងកិច្ចប្រឹងប្រែងដើម្បីសម្រេចបាននូវកំណើនសេដ្ឋកិច្ច។

ប្រទេសកំពុងអភិវឌ្ឍន៍ធំបំផុតនានាកំពុងដើរតាមយុទ្ធសាស្ត្រផ្សេងៗគ្នា ហើយក៏ផលិតបានលទ្ធផលខុសគ្នាខ្លះផងដែរ។ ប៉ុន្តែ ក៏មានប្រធានបទរួមមួយចំនួនផងដែរ។ ប្រធានបទទាំងនេះទាក់ទងនឹងពាណិជ្ជកម្ម ការប្រមូលផ្តុំដើមទុន និងអំពើពុករលួយ។

១៣.២.១. កំណើនដោយជំនួសការនាំចូល និងកំណើនដោយការនាំចេញ

នៅទូទាំងអឡាស្កាខាងត្បូង រដ្ឋទាំងឡាយកំពុងព្យាយាមប្រើប្រាស់ពាណិជ្ជកម្មអន្តរជាតិជាមូលដ្ឋាននៃការប្រមូលផ្តុំមូលធន។ ដោយសារហេតុផលដែលត្រូវបានពិភាក្សា នៅក្នុងមេរៀនទី ៨ គោលនយោបាយស្វ័យ

ផ្តត់ផ្តង់ ឬអូតារគី(autorky) យ៉ាងច្រើនបានត្រឹមតែជាវិធីសាស្ត្រមួយដែលមិនបានជួយបង្កើតទ្រព្យសម្បត្តិ។ ប៉ុន្តែ តាមរយៈការបង្កើតនិងបង្កើនពាណិជ្ជកម្មអតិរេក រដ្ឋអាចបង្កើនរូបិយប័ណ្ណខ្លាំងនិងកសាងឧស្សាហកម្ម និងហេដ្ឋារចនាសម្ព័ន្ធ។

មធ្យោបាយមួយដើម្បីបង្កើតអតិរេកពាណិជ្ជកម្ម ដែលត្រូវបានប្រើជាញឹកញាប់កាលពីប៉ុន្មានទសវត្សរ៍មុនគឺតាមរយៈ**ការជំនួសការនាំចូល** (import substitution) ដែលសំដៅលើការអភិវឌ្ឍន៍នៃឧស្សាហកម្មក្នុងស្រុកដើម្បីផលិតទំនិញដែលប្រទេសមួយបាននឹងកំពុងនាំចូលដើម្បីប្រើប្រាស់។ ឧស្សាហកម្មទាំងនេះអាចទទួលបានការឧបត្ថម្ភធនពីរដ្ឋ ឬការការពារដោយគោលនយោបាយគាំពារនិយមតាមរយៈការយកពន្ធគយ។ មធ្យោបាយមួយនេះ ទំនងជាគោលនយោបាយដ៏ល្អសម្រាប់កាត់បន្ថយភាពពឹងអាស្រ័យជាពិសេសលើអតីតម្ចាស់អាណានិគម ក្នុងខណៈពេលដែលការបង្ហូរចិនភាពពាណិជ្ជកម្ម ឬការកសាងអតិរេកពាណិជ្ជកម្ម។ ប៉ុន្តែ វាផ្ទុយនឹងពីគោលការណ៍គុណសម្បត្តិធៀប ហើយមិនបានបង្ហាញថាវាមានប្រសិទ្ធភាពក្នុងករណីភាគច្រើន។ អ្នកប្រាជ្ញមួយចំនួនគិតថា ផលិតកម្មជំនួសការនាំចូលគឺជាគោលនយោបាយដ៏មានប្រយោជន៍តែនៅដំណាក់កាលដំបូងនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច បន្ទាប់ពីនោះ វានឹងផលិតលទ្ធផលខុសពីការរំពឹងទុក។ ហើយអ្នកផ្សេងទៀតគិតថា វានឹងមិនមានប្រយោជន៍សោះឡើយ។

រដ្ឋកាន់តែច្រើនឡើងៗបានផ្លាស់ប្តូរទៅប្រើប្រាស់យុទ្ធសាស្ត្រ **កំណើនដោយការនាំចេញ**(export-led growth) ដែលជាយុទ្ធសាស្ត្រប្រើប្រាស់ដោយបណ្តាប្រទេសឧស្សាហកម្មថ្មីៗ(NICs)។ យុទ្ធសាស្ត្រនេះស្វែងរកការអភិវឌ្ឍន៍ឧស្សាហកម្ម ដែលអាចប្រកួតប្រជែងនៅក្នុងទីផ្សារ ជាពិសេសនៅក្នុងសេដ្ឋកិច្ចទីផ្សារពិភពលោក។ ឧស្សាហកម្មទាំងនេះអាចទទួលបានការគាំពារពិសេសដូចជា ជាការឧបត្ថម្ភធន និងការទទួលបានការការពារការប្រកួតប្រជែងក្នុងទីផ្សារក្នុងស្រុក។ ការនាំចេញតាមរយៈឧស្សាហកម្មទាំងនេះបានបង្កើតរូបិយប័ណ្ណខ្លាំង និងបង្កើតជញ្ជីងពាណិជ្ជកម្មដែលមានអំណោយផលដល់ខ្លួន។ បន្ទាប់មក រដ្ឋក៏អាចចំណាយមួយផ្នែកនៃប្រាក់ចំណូលរបស់ខ្លួនលើការនាំចូលទំនិញ ដែលត្រូវបានផលិតក្នុងតម្លៃថោកជាង នៅទីកន្លែងផ្សេងៗទៀត។ យុទ្ធសាស្ត្របែបនេះក៏មានហានិភ័យដែរ ជាពិសេសនៅពេលដែលរដ្ឋមានជំនាញក្នុងការនាំចេញវត្ថុធាតុដើមប្រភេទមួយចំនួនតូចប៉ុណ្ណោះ (សូមមើល ភាពអាស្រ័យក្រោយរបបអាណានិគម នៅក្នុងមេរៀនទី ១២)។ ប្រទេសក្រីក្រជាអ្នកងាយរងគ្រោះខ្លាំងទៅនឹងការប្រែប្រួលតម្លៃភ្លាមៗសម្រាប់ការនាំចេញរបស់ពួកគេ។

ដូច្នេះ រដ្ឋនានាបានងាកទៅសម្លឹងមើលការនាំចេញទំនិញឧស្សាហកម្ម (ជាជាងវត្ថុធាតុដើម)សម្រាប់ជាគន្លឹះនៃកំណើនដោយការនាំចេញ។ ទោះជាយ៉ាងណាក៏ដោយ ក្នុងការស្វែងរកទីផ្សារពិសេសសម្រាប់ផលិតទំនិញឧស្សាហកម្ម ប្រទេសកំពុងអភិវឌ្ឍន៍ត្រូវតែប្រកួតប្រជែងជាមួយប្រទេសឧស្សាហកម្មដែលមានបច្ចេកវិទ្យារីកចម្រើនជាង កម្លាំងពលកម្មមានកម្រិតអប់រំបណ្តុះបណ្តាលខ្ពស់ជាង និងដើមទុនច្រើនជាង។ វាមិនគ្រប់គ្រាន់ទេក្នុងការឧបត្ថម្ភធននិងការពារឧស្សាហកម្មណាមួយ រហូតដល់វាទំហំរបស់រីកធំឡើង។ នៅក្នុងថ្ងៃណាមួយនាពេលអនាគត វាត្រូវតែមានសមត្ថភាពអាចឈរជើងរបស់ខ្លួន នៅក្នុងពិភពប្រកួតប្រជែង ឬបើមិនដូច្នោះទេ វានឹងមិននាំមកនូវអតិរេកពាណិជ្ជកម្មឡើយ។

១៣.២.២. ការប្រមូលផ្តុំដើមទុនសម្រាប់ផលិតកម្ម

ការផលិតទំនិញឧស្សាហកម្មបានលេចចេញជាគន្លឹះសំខាន់ ក្នុងកំណើនសេដ្ឋកិច្ចដែលជម្រុញដោយការនាំចេញនិងឧស្សាហូបនីយកម្មដែលអាចទ្រទ្រង់ដោយខ្លួនឯង (ការផលិតសម្រាប់ផ្គត់ផ្គង់ទីផ្សារស្រុក)។ ដើម្បីធ្វើការវិនិយោគលើវិស័យផលិតកម្មឧស្សាហកម្ម ប្រទេសទាំងនេះត្រូវតែ*ប្រមូលផ្តុំ*នូវអ្វីដែលសេដ្ឋកិច្ចរបស់ពួកគេផលិតផលលើស ឬអតិរេក។ លុយ ដែលបានចំណាយលើការសាងសង់រោងចក្រឧស្សាហកម្មមិនអាចចំណាយអោយលើសការឧបត្ថម្ភថ្លៃអាហារ ឬសាងសង់សាលារៀនកាន់តែប្រសើរឡើងនោះទេ។ ដូច្នេះការប្រមូលផ្តុំដើមទុនសម្រាប់ការផលិត អាចកាត់បន្ថយកម្រិតខុសគ្នានៃប្រាក់ចំណូល។ ហើយដោយសារតែឧស្សាហកម្មផលិតកម្មនៅក្នុងប្រទេសក្រីក្រមិនមានសមត្ថភាពប្រកួតប្រជែងភ្លាមៗ នៅលើទីផ្សារពិភពលោកដូចនេះយុទ្ធសាស្ត្រទូទៅមួយគឺ ដំបូងឡើយគេត្រូវបង្កើតឧស្សាហកម្មផលិតសម្រាប់ការលក់ទៅកាន់ទីផ្សារក្នុងស្រុក (ការពារដោយពន្ធគយ និងការឧបត្ថម្ភធន)។ ប៉ុន្តែ ទីផ្សារទំនិញឧស្សាហកម្មក្នុងស្រុក មិនមែនផ្សំឡើងដោយកសិករក្រីក្រនៅទីជនបទ ឬ យុវជនអត់ការងារធ្វើនៅតំបន់អនាធិបតេយ្យ ក្នុងទីក្រុងនោះទេ។ ផ្ទុយទៅវិញ ទ្រព្យសម្បត្តិត្រូវតែប្រមូលផ្តុំនៅក្នុង*វណ្ណៈកណ្តាលឬមធ្យម* (middle class) ដែលមានប្រាក់ចំណូលដើម្បីទិញទំនិញឧស្សាហកម្ម។ ភាពមិនស្មើគ្នាទាំងនេះអាចបណ្តាលមានក្រុមកុប្បកម្មមហាជននៅតាមដងផ្លូវ ឬក្រុមទ័ពព្រៃដណ្តើមកាន់កាប់តំបន់ជនបទ។

ដើមទុនសម្រាប់ការផលិតអាចបានមកពីការវិនិយោគបរទេស ឬ ប្រាក់កម្ចីពីបរទេសជំនួសវិញ ប៉ុន្តែនេះនឹងកាត់បន្ថយទំហំអតិរេកសម្រាប់រដ្ឋក្នុងរយៈពេលវែង។ វិធីសាស្ត្រមួយទៀតសម្រាប់កាត់បន្ថយតម្រូវការដើមទុន គឺត្រូវចាប់ផ្តើមដំបូងពីឧស្សាហកម្មដែលត្រូវការដើមទុនទាប។ ឧស្សាហកម្មទាំងនេះអាចចាប់ផ្តើមបង្កើតដើមទុន ដែលបន្ទាប់មក អាចត្រូវបានប្រើប្រាស់ដើម្បីផ្លាស់ប្តូរទៅក្នុងប្រភេទផលិតកម្មដែលមានតម្រូវការខាងបច្ចេកវិជ្ជានិងតម្រូវការដើមទុនច្រើនជាងមុន។ ឧស្សាហកម្មសម្រាប់ចាប់ផ្តើមដំបូង ជាទូទៅ ផ្តោតទៅលើឧស្សាហកម្មវាយនភណ្ឌ។ ឧស្សាហកម្មនេះត្រូវការកម្លាំងពលកម្មច្រើន ដោយផ្តល់គុណសម្បត្តិធៀបដល់ប្រទេសដែលមានកម្លាំងពលកម្មថោក ហើយមិនត្រូវការការវិនិយោគដើមទុនច្រើន ដើម្បីចាប់ផ្តើមនោះទេ។ នៅឆ្នាំ ២០០៥ ពន្ធគយទៅលើឧស្សាហកម្មវាយនភ័ណ្ឌត្រូវបានដកចេញទូទាំងពិភពលោក ដូច្នេះ អ្នកនាំចេញទំនិញវាយនភណ្ឌ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ទទួលបានការអនុគ្រោះនាំចូលទៅកាន់ទីផ្សារលោកខាងលិច ប៉ុន្តែក៏បានប្រឈមមុខនឹងការប្រកួតប្រជែងកាន់តែខ្លាំងពីប្រទេសចិន។

វិធីសាស្ត្រដែលពាក់ព័ន្ធទៅនឹងការប្រមូលមូលធន នៅក្នុងប្រទេសក្រីក្រខ្លាំង ដែលកំពុងតែរីកចម្រើននិងមានប្រជាប្រិយភាពខ្លាំង ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ នោះគឺ **មីក្រូក្រេឌីត** (ឬ*កម្ចីខ្នាតតូច*)។ ដោយផ្អែកលើគំរូជោគជ័យក្នុងប្រទេសបង់ក្លាដែស (ធនាគារ Grameen ដែលបានឈ្នះរង្វាន់ណូបែលសន្តិភាពឆ្នាំ ២០០៦ ហើយឥឡូវនេះដំណើរការការិយាល័យសាខា ជាង ២៤០០) មីក្រូក្រេឌីតប្រើប្រាស់ប្រាក់កម្ចីខ្នាតតូច ដល់ប្រជាជនក្រីក្រ ជាពិសេសស្ត្រី ដើម្បីគាំទ្រដល់ស្វ័យភាពសេដ្ឋកិច្ចគ្រួសារ។ អ្នកខ្ចីប្រាក់ត្រូវបានរៀបចំជាក្រុមតូចៗ ហើយទទួលខុសត្រូវចំពោះភាពជោគជ័យរបស់គ្នាទៅវិញទៅមក រួមទាំងការសងប្រាក់កម្ចីត្រលប់មកវិញផងដែរ។ ដោយសារអត្រានៃការសងវិញមានកម្រិតខ្ពស់ ហើយគំនិតនេះបានរីករាលដាលយ៉ាង ឆាប់រហ័សនៅក្នុងតំបន់ជាច្រើន។ នៅក្នុងកម្មវិធីដ៏ពេញនិយមមួយ ស្ត្រីក្នុងភូមិបានប្រើប្រាស់ប្រាក់កម្ចីខ្នាតតូចដើម្បីចាប់ផ្តើមអាជីវកម្មជួលម៉ោងទូរស័ព្ទ។ កសិកររនៅជនបទបានប្រើពេលវេលាតាមទូរស័ព្ទដើម្បីស្វែងយល់

ពីស្ថានភាពទីផ្សារ មុនពេលធ្វើដំណើរដ៏វែងឆ្ងាយដើម្បីលក់ផលិតផលរបស់ពួកគេ។ ដូច្នេះ ការនាំយកបដិវត្តន៍ព័ត៌មានទៅកាន់ភូមិដាច់ស្រយាល បានបង្កើនប្រាក់ចំណូលសម្រាប់កសិករនិងស្ត្រីដូចគ្នា ហើយធនាគារបានទទួលប្រាក់សំណង់របស់ខ្លួនមកវិញ។ ឥឡូវនេះ មីក្រូក្រេឌីត កំពុងត្រូវបានអនុវត្តលើមាត្រដ្ឋានម៉ាក្រូសេដ្ឋកិច្ច។ គ្រួសាររាប់សិបលានបានទទួលប្រាក់កម្ចីពីស្ថាប័នរាប់ពាន់ នៅទូទាំងពិភពលោក។ មីក្រូក្រេឌីតមានដំណើរផ្ទុយពីវិធីសាស្ត្រពង្រាយពីលើចុះក្រោម ដោយវាចាក់ក្រាលដើមទុន នៅខាងក្រោមនៃឋានានុក្រមសេដ្ឋកិច្ច។ កម្ចីប្រាក់ទិញពូជពពែ ឬទូរសព្ទដៃ ចំណាយដុល្លារបានដុល្លារ ប្រសើរជាជាងកម្ចីដើម្បីសាងសង់ទំនប់។

រូបថត ស្ត្រីនៅអាហ្វ្រិក Burkina Faso រៀនអំពីមីក្រូក្រេឌីតនៅក្នុងសិក្ខាសាលា

ការវិនិយោគដើមទុន

ការវិនិយោគបរទេស បំណុលអន្តរជាតិ និងវិសមភាពក្នុងស្រុក អាចជួយប្រមូលផ្តុំដើមទុនចាំបាច់សម្រាប់ផលិតកម្ម។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ មីក្រូក្រេឌីត—ប្រាក់កម្ចីតិចតួចបំផុតដែលធ្វើឡើងដោយផ្ទាល់ដល់ប្រជាជនក្រីក្របំផុត—ផ្តល់មធ្យោបាយប្រើប្រាស់ដើមទុនកាន់តែទូលំទូលាយ។ នៅទីនេះ ស្ត្រីនៅ Burkina Faso រៀនអំពីមីក្រូក្រេឌីតនៅក្នុងសិក្ខាសាលាដែលដឹកនាំដោយអង្គការក្រៅរដ្ឋាភិបាលមួយ ឆ្នាំ ២០១៧។

ពួកមូលធននិយមហាក់មានចំណាងចំណូលចិត្តប្រមូលផ្តុំដើមទុន ជាមធ្យោបាយមួយសម្រាប់ជំរុញការវិនិយោគ ជាជាងចំណាយប្រាក់ទិញទំនិញប្រើប្រាស់ (និងសម្រាប់សម្រេចសេដ្ឋកិច្ចមានទំហំធំធេង និងជំនាញឯកទេស)។ ស្របតាមលទ្ធិសេរីនិយម ពួកមូលធននិយមចូលចិត្តផ្លូវអភិវឌ្ឍន៍ដែលភ្ជាប់ប្រទេសកំពុងអភិវឌ្ឍន៍យ៉ាងជិតស្និទ្ធទៅនឹងសេដ្ឋកិច្ចពិភពលោកនិងពាណិជ្ជកម្មអន្តរជាតិ។ ពួកគេអះអាងថា ទោះបីជាយុទ្ធសាស្ត្រអភិវឌ្ឍន៍បែបនេះ ផ្ទុយពីគោលការណ៍សមធម៌ក៏ដោយ ក៏វាបានបង្កើនប្រសិទ្ធភាពជាអតិបរមាដែរ។ នៅពេលដែលរដ្ឋមួយអាចចាប់ផ្តើមវដ្តនៃការប្រមូលផ្តុំទ្រព្យសម្បត្តិដោយនិរន្តរភាពដោយខ្លួនឯង វានឹងអាចជួយដោះស្រាយភាពក្រីក្រក្នុងចំណោមប្រជាជនយ៉ាងទូលំទូលាយ និងបានប្រសើរជាងមុន។ បើធ្វើបែបនេះឆាប់ពេកនឹងអាចរារាំងដល់កំណើនសេដ្ឋកិច្ច នេះបើផ្អែកតាមទស្សនៈមួយនេះ។ គំនិតដូចគ្នានេះដែរក៏បានអនុវត្តយ៉ាងទូលំទូលាយ ចំពោះការអភិវឌ្ឍន៍របស់ពិភពលោកទាំងមូល។ តាមទស្សនៈមូលធននិយម ការប្រមូលផ្តុំមូលធនត្រូវបានផ្តុំនៅអឌ្ឍគោលខាងជើង។ ការប្រមូលផ្តុំមូលធនមិនស្មើគ្នាបែបនេះបានបង្កើតអោយមានកំណើនសេដ្ឋកិច្ចកាន់តែលឿន ដែលទីបំផុតនឹងនាំមកនូវទ្រព្យធនបន្ថែមទៀតទៅដល់អឌ្ឍគោលខាងត្បូងផងដែរ។ មិនមានវិធីសាស្ត្រជាក់ស្តែងទេនោះក្នុងទស្សនៈបែបនេះ ដើម្បីបំរែបំរួលនូវទ្រព្យធនពីអឌ្ឍគោលខាងជើងទៅ អឌ្ឍគោលខាងត្បូង ដោយមិនធ្វើអោយខូចដល់សេដ្ឋកិច្ចទីផ្សារសេរី ដែលត្រូវទទួលខុសត្រូវចំពោះកំណើនសេដ្ឋកិច្ចពិភពលោក។

ផ្ទុយទៅវិញ ពួកសង្គមនិយមអះអាងថា ការអភិវឌ្ឍន៍សេដ្ឋកិច្ចដ៏មានអត្ថន័យគួរកែលម្អស្ថានភាពជីវភាពរស់នៅរបស់ប្រជាជនទាំងមូលនិងប្រជាជនក្រីក្រ អោយបានឆាប់កាន់តែល្អ។ ដូច្នេះ ពួកសង្គមនិយមមានទំនោរក្នុងការតស៊ូមតិលើការបែងចែកទ្រព្យសម្បត្តិដោយសមធម៌ជាង។ ពួកគេជំទាស់នឹងគំនិតដែលថាសមធម៌កាន់តែប្រែនឹងរារាំងប្រសិទ្ធភាពឬបន្ថយល្បឿនកំណើនសេដ្ឋកិច្ច។ ផ្ទុយទៅវិញ តាមរយៈការបង្កើនប្រាក់ចំណូលក្នុងចំណោមប្រជាជនក្រីក្រ លើយុទ្ធសាស្ត្រផ្អែកលើសមធម៌ និងពន្លឿនការផ្លាស់ប្តូរជីវភាព

ប្រជាសាស្ត្រ និងនាំអោយមានការប្រមូលផ្តុំប្រកបដោយនិរន្តរភាព ក្នុងល្បឿនលឿនជាងមុន។ នៅកម្រិតពិភពលោក ពួកសង្គមនិយមមិនមើលឃើញគម្លាតរវាងអឌ្ឍគោលខាងជើងនិងខាងត្បូងថា មានភាពត្រឹមត្រូវដោយគិតតែពីអត្ថប្រយោជន៍នៃកំណើនពិភពលោកទេ។ ពួកគេពេញចិត្តនឹងសកម្មភាពនយោបាយដើម្បីជម្រុញប្រាក់ចំណូល ពីអឌ្ឍគោលខាងជើងទៅអឌ្ឍគោលខាងត្បូង ដើម្បីជំរុញកំណើនសេដ្ឋកិច្ចនៅ ខាងត្បូង។ ការបែងចែកឡើងវិញបែបនេះ តាមទស្សនៈនេះ នឹងបង្កើតអោយមានកំណើនសេដ្ឋកិច្ចពិភពលោកកាន់តែលឿន មិនមែនយឺតជាងទេ និងកាន់តែមានតុល្យភាព និងស្ថិរភាពជាងមុន។

ទ្រឹស្តីមូលធននិយមដែលថា ការបែងចែកប្រាក់ចំណូលមិនស្មើភាពគ្នាពាក់ព័ន្ធនឹងកំណើនសេដ្ឋកិច្ចខ្ពស់ ត្រូវបានគាំទ្រតាមរយៈភស្តុតាងជាក់ស្តែងតិចតួចប៉ុណ្ណោះ។ រដ្ឋជាច្រើនដែលមានការបែងចែកប្រាក់ចំណូលដោយសមធម៌ជាង មានអត្រាកំណើនខ្ពស់ (រួមទាំងប្រទេសកូរ៉េខាងត្បូង កោះតៃវ៉ាន់ សិង្ហបុរី និងក្រុងហុងកុង)។ ចំណែកឯរដ្ឋជាច្រើនដែលមានការបែងចែកប្រាក់ចំណូលមិនស្មើគ្នាទទួលបានការរីកចម្រើនយឺត មានដូចជា (ប្រទេសម៉ិកស៊ិក អាហ្សង់ទីន និងហ្គាណា)។ ប៉ុន្តែ ក៏មានករណីលើកលែងដែលបណ្តាប្រទេសមានសមធម៌គួរសមដែលរីកចម្រើនយឺតៗ ហើយប្រទេសមិនមានសមធម៌ដែលរីកចម្រើនយ៉ាងឆាប់រហ័ស។ ធនាគារពិភពលោកបានពិនិត្យឡើងវិញនូវភស្តុតាងស្តីពីឥទ្ធិពលនៃវិសមភាពប្រាក់ចំណូលទៅលើកំណើនសេដ្ឋកិច្ច ហើយបានសន្និដ្ឋានថា វិសមភាពនេះរារាំងកំណើន ដោយការខ្ជះខ្ជាយសក្តានុពលរបស់មនុស្សជទៃទៀត។ ម្លោះហើយ ធនាគារពិភពលោកបានផ្តល់អនុសាសន៍អោយពង្រីកលទ្ធភាពទទួលបានការថែទាំសុខភាព ការអប់រំ និងទីផ្សារការងារ ក៏ដូចជាអំណាចនយោបាយ ដល់ប្រជាជនក្រីក្របំផុតនៅក្នុងសង្គមក្នុងអឌ្ឍគោលខាងត្បូង ដើម្បីជំរុញកំណើនសេដ្ឋកិច្ចកាន់តែលឿន។

១៣.២.៣. អំពើពុករលួយ

អំពើពុករលួយគឺជាកត្តាអវិជ្ជមានខ្លាំង ដែលរារាំងការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅក្នុងរដ្ឋជាច្រើន។ អំពើពុករលួយផ្តោតលើរដ្ឋាភិបាល ដែលជាតួអង្គសំខាន់នៅក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច ជាពិសេសនៅក្នុងឆាកអន្តរជាតិ។ តាមរយៈគោលនយោបាយការបរទេស រដ្ឋាភិបាលបានសម្របសម្រួលទំនាក់ទំនងសេដ្ឋកិច្ចជាតិជាមួយនឹងសេដ្ឋកិច្ចពិភពលោក។ វាគ្រប់គ្រងលើលក្ខខណ្ឌដែលសាជីវកម្មពហុជាតិប្រតិបត្តិការនៅក្នុងផ្ទៃប្រទេស។ បន្ថែមពីលើនេះ គេពង្រឹងវិន័យកម្មករ ដោយអំពាវនាវអោយកងកម្លាំង(ប៉ូលីសឬកងទ័ព)ចេញប្រតិបត្តិការ ក្នុងករណីចាំបាច់ ដើម្បីបំបែកកូដកម្ម ឬបង្ក្រាបបដិវត្តន៍។ វាកំណត់អត្រាពន្ធ និងប្រើប្រាស់ឥទ្ធិពលនៃម៉ាក្រូសេដ្ឋកិច្ចផ្សេងទៀត ដើម្បីគ្រប់គ្រងសេដ្ឋកិច្ចជាតិ។ ម្យ៉ាងទៀតនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើន វាមានភាគហ៊ុនដ៏ធំនៅក្នុងឧស្សាហកម្មធំៗ ដែលករណីខ្លះជាអាជីវកម្មផ្តាច់មុខទៅលើមុខទំនិញទៀតផង ។

មន្ត្រីរដ្ឋមួយចំនួនសម្រេចចិត្តថា តើត្រូវអនុញ្ញាតអោយសាជីវកម្មពហុជាតិចូលទៅក្នុងប្រទេសខ្លួន តើសាជីវកម្មពហុជាតិណាមួយទទួលបានសិទ្ធិខ្លួងយកវ៉ែ និងតើត្រូវទាមទារលក្ខខណ្ឌអ្វីខ្លះ(ថ្លៃឈ្នួល ភាគរយនៃទំហំលក់ ។ល។)។ ទាំងអស់នេះគឺជាកិច្ចព្រមព្រៀងដ៏ស្មុគស្មាញ ដែលត្រូវបានសម្រេចឡើងបន្ទាប់ពីការចរចាដ៏យូរ។ អំពើពុករលួយក៏បន្ថែមតួអង្គផ្សេងទៀត ដូចជាមន្ត្រីពុករលួយ ដើម្បីចែករំលែកអត្ថប្រយោជន៍អោយគ្នាទៅវិញទៅមក។ ជាឧទាហរណ៍ ក្រុមហ៊ុនប្រេងបរទេសបង់លុយទិញទឹកចិត្តមន្ត្រីរដ្ឋដើម្បីទទួលបានកិច្ចសន្យាអំណោយផលដល់ខ្លួន ហើយអ្នកទាំងពីរអោចចំណេញដូចគ្នា។ ក្នុងឆ្នាំ ២០០៣ រដ្ឋអាជ្ញាសហរដ្ឋ

អាមេរិកបានចោទប្រកាន់នាយកប្រតិបត្តិក្រុមហ៊ុនប្រេង *អេកសុនម៉ូបាល* (ExxonMobil) ពីបទសូកប្រាក់ចំនួន ៧៨ លានដុល្លារទៅអោយមន្ត្រីជាន់ខ្ពស់ពីររូប នៅក្នុងប្រទេសកាហ្សាក់ស្តាន (ជាមួយនឹងប្រាក់ត្រឡប់មកវិញ ចំនួន ២ លានដុល្លារ សម្រាប់នាយកប្រតិបត្តិ*អេកសុនម៉ូបាល*) ដើម្បីទទួលបានភាគហ៊ុនវិនិយោគរាប់ប៊ីលានដុល្លារ របស់ *អេកសុនម៉ូបាល* នៅក្នុងអណ្តូងប្រេងដ៏ធំ នៅទីនោះ។ បន្ទាប់ពីគេបានរកឃើញថាគាត់បានសារភាពពីបទគេចពន្ធ និងបានទទួលការកាត់ទោសដាក់ពន្ធនាគារ និងត្រូវបង់ពន្ធ លើប្រាក់ចំនួន ២ លានដុល្លារនោះ។

អំពើពុករលួយមិនកើតឡើងត្រឹមតែនៅអឌ្ឍគោលខាងត្បូងនោះទេ។ ប៉ុន្តែ ដោយហេតុផលមួយចំនួន អំពើពុករលួយមានឥទ្ធិពលកាន់តែជ្រៅទៅលើសង្គមនៅក្នុងប្រទេសក្រីក្រ។ ទីមួយ ដោយសារតែមានអតិរេកតិចតួចដើម្បីរក្សាកំណើនសេដ្ឋកិច្ច ដូចនេះការប្រមូលផ្តុំទ្រព្យសម្បត្តិមានភាពផុយស្រួយខ្លាំង។ ភាពខុសគ្នាមួយទៀតគឺថា នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដែលពឹងផ្អែកតែទៅលើការនាំចេញផលិតផលមួយចំនួនតូចប្រាក់ចំណូលចូលមកក្នុងទម្រង់តូចចង្អៀត (ការទូទាត់ជារូបិយប័ណ្ណខ្លាំង) ដែលបើកឱកាសសម្រាប់អំពើពុករលួយ ជាងនៅក្នុងសេដ្ឋកិច្ចចម្រុះ។ នេះគឺជាធាតុសំខាន់ នៅក្នុង«បណ្តាសាធនធាន» (សូមមើល មេរៀនទី ១២)។ ជាងនេះទៅទៀត នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ប្រាក់ចំណូលច្រើនតែមានកម្រិតទាប ដែលធ្វើអោយមន្ត្រីពុករលួយងាយនឹងទទួលយកសំណូក។

អំពើពុករលួយនៅអឌ្ឍគោលខាងត្បូងឆ្លុះបញ្ចាំងពីបញ្ហាផលប្រយោជន៍រួម សម្រាប់បណ្តារដ្ឋ និងសាជីវកម្មពហុជាតិនៅអឌ្ឍគោលខាងជើង៖ ជាលក្ខណៈផ្ទាល់ខ្លួន សាជីវកម្មពហុជាតិនីមួយៗនិងរដ្ឋដើមកំណើតរបស់ពួកគេអាចទទួលបានផលចំណេញ នៅពេលសម្រេចបានកិច្ចព្រមព្រៀងណាមួយ ដោយការសូកប៉ាន់ឯកជន ប៉ុន្តែ ជាលក្ខណៈសមូហភាព ក្រុមសាជីវកម្មពហុជាតិនិងរដ្ឋអឌ្ឍគោលខាងជើងតែងតែខាតបង់ប្រាក់ ដោយត្រូវចំណាយប្រាក់លើអំពើពុករលួយទាំងអស់នេះ។ ដូច្នេះ ដើម្បីជម្រុញទឹកចិត្តទប់ស្កាត់អំពើពុករលួយ លុះត្រាតែរដ្ឋឧស្សាហូបនីយកម្មផ្សេងទៀតធ្វើដូចគ្នាដែរ។ សហរដ្ឋអាមេរិកក្នុងប៉ុន្មានទសវត្សរ៍ថ្មីៗនេះ បានរារាំងក្រុមហ៊ុនអាមេរិកពីការធ្វើកិច្ចព្រមព្រៀងពុករលួយនៅបរទេស ប៉ុន្តែប្រទេសផ្សេងទៀតនៅអឌ្ឍគោលខាងជើងមិនបានធ្វើដូច្នេះទេ រហូតមកដល់ពេលថ្មីៗនេះ។ ប្រទេសអាឡឺម៉ង់ និង កាណាដាបានថែមទាំងបានអនុញ្ញាតអោយក្រុមហ៊ុនរបស់ពួកគេកាត់បន្ថយពន្ធពីប្រាក់សំណូកបរទេសរបស់ពួកគេផង។

តម្លាភាពបានជួយដោះស្រាយបញ្ហាផលប្រយោជន៍រួម។ អង្គការក្រៅរដ្ឋាភិបាលដែលមានមូលដ្ឋាននៅទីក្រុងប៊ែកឡាំង ដែលមានឈ្មោះថា អង្គការតម្លាភាពអន្តរជាតិ (Transperency International) ថាជួយជំរុញអោយមានសកម្មភាពទប់ស្កាត់អំពើពុករលួយ នៅក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មអន្តរជាតិ ប្រកបដោយជោគជ័យ។ ក្រុមហ៊ុនជាច្រើនបានផ្សព្វផ្សាយការស្ទង់មតិប្រចាំឆ្នាំបង្ហាញពីប្រទេសដែលចាត់ទុកថានាយកប្រតិបត្តិអាជីវកម្ម ជាអ្នកប្រព្រឹត្តអំពើពុករលួយច្រើនបំផុត។ ប្រទេសកំពូលទាំងប្រាំ ក្នុងបញ្ជីក្នុងឆ្នាំ ២០១៤ គឺប្រទេសសូម៉ាលី ប្រទេសកូរ៉េខាងជើង ប្រទេសអាហ្វហ្គានីស្តាន ប្រទេសស៊ូដង់ និងប្រទេសស៊ូដង់ខាងត្បូង។ ក្នុងឆ្នាំ ១៩៩៧ រដ្ឋដែលមានឧស្សាហកម្មឈានមុខគេ ចំនួន ២៩ នៅលើពិភពលោក បានយល់ព្រមហាមឃាត់ក្រុមហ៊ុនរបស់ពួកគេ មិនអោយសូកប៉ាន់មន្ត្រីបរទេស។ ហើយគំនិតផ្តួចផ្តើមតម្លាភាពក្នុងវិស័យឧស្សាហកម្មនិស្សារណកម្ម (Extractive Industries) ដែលជាសម្ព័ន្ធភាពរវាងរដ្ឋ អង្គការក្រៅរដ្ឋាភិបាល និងសាជីវកម្មពហុជាតិ ដែលបានផ្តួចផ្តើមដោយចក្រភពអង់គ្លេស ក្នុងឆ្នាំ ២០០២ ប្រយុទ្ធប្រឆាំង

នឹងអំពើពុករលួយ នៅក្នុងវិស័យប្រេង ឧស្ម័ន និងរ៉ែ ដែលងាយរងគ្រោះខ្លាំងជាងគេ នៅទូទាំងពិភពលោក ដោយធ្វើអោយក្រុមហ៊ុននានាបញ្ចេញព័ត៌មានស្តីពីការទូទាត់ ដែលពួកគេធ្វើទៅកាន់ប្រទេសកំពុងអភិវឌ្ឍន៍។

រូបថត អ្នកតាំទ្រសកម្មជនប្រឆាំងអំពើពុករលួយដែលធ្វើកូដកម្មបង្អត់អាហារនៅក្រុងដេលី

ឃុទ្ធនាការបោសសម្អាត

អំពើពុករលួយជាឧបសគ្គដ៏ធំដល់ការអភិវឌ្ឍសេដ្ឋកិច្ចទាំងក្នុងប្រទេសអ្នកមាននិងប្រទេសក្រីក្រ ប៉ុន្តែវាកាន់តែបំផ្លិចបំផ្លាញដល់សេដ្ឋកិច្ច នៅក្នុងអឌ្ឍគោលខាងត្បូង និងដល់អតីតសេដ្ឋកិច្ចកុម្មុយនិស្តសម័យអន្តរកាល។ នៅក្នុងប្រទេសឥណ្ឌា អំពើពុករលួយរីករាលដាលបានរារាំងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសមភាពអស់រយៈពេលជាច្រើនឆ្នាំ។ ក្នុងរូបនេះ អ្នកតាំទ្រសកម្មជនប្រឆាំងអំពើពុករលួយ Anna Hazare ដែលធ្វើកូដកម្មបង្អត់អាហារ នៅក្រុងដេលី កាន់«កូនសោ» សម្រាប់បើកចូលធនាគារស្ងើស ឆ្នាំ ២០១២។

នៅប្រទេស ឆាដ ក្នុងឆ្នាំ ១៩៩៩ សម្ព័ន្ធមួយដឹកនាំដោយក្រុមហ៊ុនប្រេង ExxonMobil និងគាំទ្រដោយប្រាក់កម្ចីរបស់ធនាគារពិភពលោក បានធ្វើកិច្ចព្រមព្រៀងមួយ ដើម្បីសាងសង់បំពង់បង្ហូរប្រេង ដែលមានតម្លៃ ៤ ប៊ីលានដុល្លារ ជាមួយនឹងប្រាក់ចំណូលពីប្រេងត្រូវឆ្លងកាត់គណនីធនាគារ Citibank នៅទីក្រុងឡុងដ៍ ដើម្បីជៀសវាងអំពើពុករលួយ។ ប្រទេសឆាដក៏បានសន្យាថានឹងប្រើប្រាស់ប្រាក់ទឹកប្រាក់ចំនួន ៧២ ភាគរយ ដើម្បីកាត់បន្ថយភាពក្រីក្រ។ ប៉ុន្តែ នៅក្នុងឆ្នាំ ២០០៥ នៅពេលដែលលុយប្រេងបានហូរចូលរដ្ឋាភិបាលរបស់ប្រទេសឆាដ ដែលស្ថិតនៅក្រោមការវាយប្រហារដោយពួកឧទ្ទាមដែលមានមូលដ្ឋាន នៅក្នុងប្រទេសស៊ូដង់បានដកខ្លួនចេញពីកិច្ចព្រមព្រៀងដើម្បីប្រើប្រាស់ប្រាក់សម្រាប់កម្លាំងយោធារបស់ខ្លួន ហើយធនាគារពិភពលោកបានផ្អាកការផ្តល់ប្រាក់កម្ចីរបស់ខ្លួន។

១៣.៣. លំហូរដើមទុនអឌ្ឍគោលខាងជើងនិងត្បូង

១៣.៣ ចូរបង្ហាញពីមធ្យោបាយដែលធ្វើអោយបំណុលជាតិដ៏ច្រើនអាចជាកត្តារារាំងដំណើរការនៃការអភិវឌ្ឍសេដ្ឋកិច្ចសម្រាប់បណ្តាប្រទេសនៅអឌ្ឍគោលខាងត្បូង។

ដើមទុនពីអឌ្ឍគោលខាងជើងផ្លាស់ទីទៅអឌ្ឍគោលខាងត្បូង ហើយអាចជំរុញកំណើនសេដ្ឋកិច្ច នៅទីនោះក្នុងទិដ្ឋភាពជាច្រើនផ្សេងៗគ្នា ដូចជា ការវិនិយោគបរទេស បំណុល និងជំនួយបរទេស។ ផ្នែកដែលនៅសេសសល់ក្នុងមេរៀននេះ ពិភាក្សាអំពីលំហូរដើមទុនក្នុងទិដ្ឋភាពទាំងនេះ ពីអឌ្ឍគោលខាងជើងទៅខាងត្បូង។

១៣.៣.១. ការវិនិយោគបរទេស

ប្រទេសក្រីក្រមានលុយតិចតួចសម្រាប់វិនិយោគទៅលើរោងចក្រថ្មីៗ កសិដ្ឋាន អណ្តូងរ៉ែ ឬក៏ អណ្តូងប្រេង។ ខណៈការវិនិយោគបរទេស ដែលជាការវិនិយោគលើទំនិញដើមទុនដោយជនបរទេស (ភាគច្រើនជាសាជីវកម្មពហុជាតិ) គឺជាមធ្យោបាយមួយសម្រាប់ចាប់ផ្តើមប្រមូលផ្តុំទ្រព្យសម្បត្តិ (សូមមើល ការវិនិយោគផ្ទាល់ពីបរទេស នៅក្នុងមេរៀនទី ៩)។ ការវិនិយោគពីបរទេសមានសារៈសំខាន់ ចំពោះភាពជោគជ័យ របស់ប្រទេសចិននិងប្រទេសកំពុងអភិវឌ្ឍន៍ នៅអាស៊ីផ្សេងទៀត។ សរុបមក លំហូរមូលធនឬដើមទុនឯកជន ទៅកាន់អឌ្ឍគោលខាងត្បូង មានទំហំជាង ៧០០ ប៊ីលានដុល្លារ ក្នុងឆ្នាំ ២០១៤ ដែលមានទំហំធំជាងជំនួយអភិវឌ្ឍន៍ផ្លូវការ ចំនួនបួនដង។

ជនបរទេសដែលបណ្តាក់ទុនក្នុងប្រទេសមួយ បន្ទាប់មកក្លាយជាម្ចាស់ទីតាំងរោងចក្រ វិនិយោគិនហាក់ដូចជាម្ចាស់ដែរ អាចគ្រប់គ្រងសេចក្តីសម្រេចចិត្ត អំពីចំនួនបុគ្គលិកដែលត្រូវជួល ឬថាតើត្រូវពង្រីកឬ

បិទទ្វាររោងចក្រ ត្រូវផលិតផលទំនិញអ្វី និងរបៀបធ្វើទីផ្សារលក់ទំនិញជាដើម។ ដូចគ្នាផងដែរ វិនិយោគិនបរទេសជាធម្មតាអាចយកប្រាក់ចំណេញពីប្រតិបត្តិការនៅក្រៅប្រទេស (ការបង្វិលប្រាក់ចំណេញ)។ ទោះជាយ៉ាងណាក៏ដោយ សម្រាប់រដ្ឋាភិបាលប្រទេសម្ចាស់ផ្ទះអាចទទួលបានផលចំណេញពីទ្រព្យសម្បត្តិបង្កើតថ្មីតាមរយៈការគិតថ្លៃសេវាកម្មនិងថ្លៃពន្ធ ឬដោយការជួលដីឬសិទ្ធិខួងយករ៉ែ (សូមមើល ទំនាក់ទំនងរដ្ឋាភិបាលប្រទេសម្ចាស់ផ្ទះនិងប្រទេសកំណើត ក្នុងមេរៀនទី ៩)។

ដោយសារតែបទពិសោធន៍អាណានិគមកន្លងមក រដ្ឋាភិបាលជាច្រើននៅក្នុងអឌ្ឍគោលខាងត្បូងមានការព្រួយបារម្ភពីការបាត់បង់អំណាចគ្រប់គ្រង ដែលមកជាមួយនឹងការវិនិយោគបរទេសដោយសាជីវកម្មពហុជាតិ។ ជួនកាល វត្តមានរបស់សាជីវកម្មពហុជាតិ ត្រូវបានផ្សារភ្ជាប់ជាមួយនឹងដំណើរការដ៏ឈឺចាប់នៃការប្រមូលផ្តុំដើមទុន និងគម្លាតរវាងវណ្ណៈសង្គមកាន់តែស្រួចស្រាល នៅក្នុងប្រទេសម្ចាស់ផ្ទះ។ ទោះបីជាការភ័យខ្លាចបែបនេះនៅតែមាន វាត្រូវប្តឹងថ្លែងជាមួយនឹងសមត្ថភាពវិនិយោគិនបរទេសក្នុងការបង្ហូរដើមទុនចូល និងបង្កើតអតិរេកបន្ថែមទៀត។ ទសវត្សរ៍ឆ្នាំ ១៩៨០ និងឆ្នាំ ១៩៩០ ដោយសារគំរូសេដ្ឋកិច្ចស្ងួយផ្តត់ផ្តង់ឬកម្មសិទ្ធិរដ្ឋត្រូវបានស្រាយបញ្ជាក់ថាគ្មានបានផល ចំណែកប្រទេសឧស្សាហកម្មថ្មីៗបានទទួលជោគជ័យ រដ្ឋក្រីក្រជាច្រើនបានប្រញាប់ប្រញាល់ទទួលយកការវិនិយោគបរទេស។ ប្រទេសចិនជាប្រទេសជោគជ័យបំផុតមកទល់ពេលនេះ។

រូបថត នាយកប្រតិបត្តិជនជាតិជប៉ុនទស្សនារោងចក្រ Honda នៅក្នុងប្រទេសឥណ្ឌា

វិនិយោគិនបរទេស

ការវិនិយោគបរទេសគឺជាប្រភពដើមទុនដ៏សំខាន់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច នៅក្នុងអឌ្ឍគោលខាងត្បូង។ ទំនាក់ទំនងរបស់វិនិយោគិនបរទេសនិងប្រទេសម្ចាស់ផ្ទះស្ថែងចេញក្នុងវិស័យសេដ្ឋកិច្ច និងវប្បធម៌ នយោបាយ និងអត្តសញ្ញាណ។ នាយកប្រតិបត្តិជនជាតិជប៉ុនទាំងនេះបានទៅទស្សនារោងចក្រ Honda របស់ពួកគេ នៅក្នុងប្រទេសឥណ្ឌា ដែលក្រុមហ៊ុន Honda បានបណ្តាក់ទុនចំនួន ៤០០ លានដុល្លារក្នុងឆ្នាំ ២០០៨ ។

វិធីសាស្ត្រមួយដែលរដ្ឋបានប្រឹងប្រែងធ្វើដើម្បីកុំអោយបាត់បង់ម្ចាស់ការគ្រប់គ្រងខ្លាំងពេក គឺតាមរយៈ *ការបណ្តាក់ទុនរួមគ្នា* (joint venture) ដែលសំដៅលើក្រុមហ៊ុនដែលគ្រប់គ្រងមួយផ្នែកដោយសាជីវកម្មពហុជាតិបរទេសនិងមួយផ្នែកដោយក្រុមហ៊ុនក្នុងស្រុកឬរដ្ឋាភិបាលប្រទេសម្ចាស់ផ្ទះផ្ទាល់។ ជួនកាលភាពជាម្ចាស់ភាគហ៊ុនបរទេស នៅក្នុងការបណ្តាក់ទុនរួមគ្នា ត្រូវបានកំណត់ត្រឹមប៉ុន្មានភាគរយតែប៉ុណ្ណោះ (ជាញឹកញាប់ ៤៩ ភាគរយ) ដើម្បីធានាថាការគ្រប់គ្រង ចុងក្រោយ ស្ថិតនៅជាមួយប្រទេសម្ចាស់ផ្ទះ។ ភាគរយនៃកម្មសិទ្ធិភាគហ៊ុនជាធម្មតាសមាមាត្រទៅនឹងទំហំដើមទុនដែលត្រូវបានវិនិយោគ។ ប្រសិនបើរដ្ឋាភិបាលម្ចាស់ផ្ទះចង់បានការគ្រប់គ្រងកាន់តែច្រើន វាត្រូវតែដាក់ប្រាក់ជាដើមទុនបន្ថែមទៀត។ ការបណ្តាក់ទុនរួមគ្នាដំណើរការបានល្អសម្រាប់សាជីវកម្មពហុជាតិ ពីព្រោះពួកគេជួយធានាកិច្ចសហប្រតិបត្តិការ របស់រដ្ឋាភិបាលប្រទេសម្ចាស់ផ្ទះក្នុងការកាត់បន្ថយភាពលំបាកខាងការិយាធិបតេយ្យ និងធានានូវភាពជោគជ័យ (ដោយផ្តល់អោយរដ្ឋាភិបាលប្រទេសម្ចាស់ផ្ទះនូវផលប្រយោជន៍ផ្ទាល់ នៅក្នុងលទ្ធផលសម្រេចបាន)។

សាជីវកម្មពហុជាតិបណ្តាក់ទុន នៅក្នុងប្រទេសណាមួយដោយសារតែអត្ថប្រយោជន៍មួយចំនួននៃការធ្វើអាជីវកម្ម នៅទីនោះ។ ក្នុងករណីខ្លះ វាអាចដោយសារវត្តមាននៃធនធានធម្មជាតិ ពេលខ្លះដោយសារកម្លាំង

ពលកម្មតម្លៃថោក ពេលខ្លះទីតាំងភូមិសាស្ត្រគឺជាកត្តាមួយសម្រេច។ រដ្ឋមួយចំនួនមាន*សមត្ថភាពស្រូបយក* (absorbtive capacity) (ដែលសមត្ថភាពក្នុងការដាក់ការវិនិយោគសម្រាប់ការប្រើប្រាស់ប្រកបដោយផលិតកម្មខ្ពស់) បានប្រសើរជាងប្រទេសផ្សេងទៀត ដោយសារហេដ្ឋារចនាសម្ព័ន្ធដែលមានការអភិវឌ្ឍន៍ខ្ពស់ និងកម្រិតជំនាញខ្ពស់ក្នុងចំណោមកម្មករ ឬជាអ្នកគ្រប់គ្រងដ៏ពូកែ។ ពួកកេភាគច្រើនជារដ្ឋដែលមានចំណូលមធ្យម ដូច្នេះ ការបង្ហូរការវិនិយោគទៅកាន់រដ្ឋដែលមានសមត្ថភាពស្រូបយកខ្ពស់ ទំនងជាធ្វើអោយមាន ភាពមិនស្មើគ្នា*នៅក្នុង*អឌ្ឍគោលខាងត្បូង។ សាជីវកម្មពហុជាតិក៏ស្វែងរក*បរិយាកាសបទប្បញ្ញត្តិ*អំណោយផលដែលរដ្ឋម្ចាស់ផ្ទះនឹងជួយសម្រួល ជាជាងរារាំងអាជីវកម្មរបស់សាជីវកម្មពហុជាតិ។

ការសម្រេចចិត្តរបស់សាជីវកម្មពហុជាតិអំពីការវិនិយោគបរទេស ក៏អាស្រ័យទៅលើទស្សនៈវិស័យ*ស្ថិរភាពហិរញ្ញវត្ថុ* ជាពិសេសមានអតិផរណាទាប និងអត្រាប្តូរប្រាក់ដែលមានស្ថិរភាព។ ប្រសិនបើករណីរូបិយប័ណ្ណមិនអាចបំប្លែងបានទេ នោះសាជីវកម្មពហុជាតិនឹងមិនអាចយកប្រាក់ចំណេញត្រឡប់ទៅប្រទេសកំណើតរបស់ខ្លួន ឬយកទៅវិនិយោគនៅកន្លែងផ្សេងទៀតបានទេ។ កត្តាដែលមានសារៈសំខាន់ដូចគ្នាផងដែរក្នុងការទាក់ទាញការវិនិយោគ គឺ*នយោបាយស្ថេរភាព*។ ធនាគារនិងសាជីវកម្មពហុជាតិធ្វើការវិភាគហានិភ័យនយោបាយ ដើម្បីវាយតម្លៃហានិភ័យនៃការរំខានផ្នែកនយោបាយនៅក្នុងរដ្ឋដែលពួកគេអាចវិនិយោគ។

លើសពីការពិចារណាផ្នែកហិរញ្ញវត្ថុទាំងនេះ អ្នកវិនិយោគបរទេសដែលផលិតសម្រាប់ទីផ្សារក្នុងស្រុកចង់ដឹងថា តើកំណើនសេដ្ឋកិច្ចរបស់ប្រទេសម្ចាស់ផ្ទះនឹងទ្រទ្រង់តម្រូវការសម្រាប់ទំនិញដែលកំពុងផលិតដែរឬទេ។ ដូចគ្នានេះដែរ មិនថាផលិតសម្រាប់ការប្រើប្រាស់ក្នុងស្រុក ឬការនាំចេញនោះទេ សាជីវកម្មពហុជាតិចង់អោយការផ្គត់ផ្គង់កម្លាំងពលកម្មក្នុងស្រុក (ថាតើកម្លាំងពលកម្មពាក់កណ្តាលជំនាញ ឬគ្រាន់តែមានតម្លៃថោក) មានស្ថេរភាព។ បន្ថែមមកទៀត វិនិយោគិនបរទេសតែងតែស្វែងរកស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ដូចជាធនាគារពិភពលោកនិងមូលនិធិ IMF និងការវិភាគឯកជន ដើម្បីវិនិច្ឆ័យស្ថិរភាពសេដ្ឋកិច្ចរបស់រដ្ឋមួយ មុនពេលវិនិយោគលើវា។

ការផ្ទេរបច្ចេកវិទ្យា (technology transfer) សំដៅលើការទទួលបានបច្ចេកវិទ្យាថ្មីរបស់រដ្ឋក្រីក្រ (រួមមានចំណេះដឹង ជំនាញ វិធីសាស្ត្រ ការរចនា និងឧបករណ៍ឯកទេស)ពីប្រភពបរទេស ដែលជាធម្មតាភ្ជាប់ជាមួយការវិនិយោគផ្ទាល់ពីបរទេស ឬប្រតិបត្តិការអាជីវកម្មស្រដៀងគ្នា។ ការអភិវឌ្ឍន៍ប្រទេសអាចអនុញ្ញាតអោយសាជីវកម្មពហុជាតិផលិតទំនិញមួយចំនួននៅក្នុងប្រទេស ក្រោមលក្ខខណ្ឌអំណោយផល ដោយផ្តល់អោយសាជីវកម្មពហុជាតិចែករំលែកចំណេះដឹងអំពីបច្ចេកវិទ្យា និងការរចនានៅពីក្រោយផលិតផល។ រដ្ឋអាចព្យាយាមយកប្រជាពលរដ្ឋរបស់ខ្លួនចូលទៅក្នុងការគ្រប់គ្រងនិងកម្លាំងការងារប្រកបដោយវិជ្ជាជីវៈនៃរោងចក្រឬកន្លែងតួនាទីនានាដែលបង្កើតឡើងដោយការវិនិយោគពីបរទេស។ មិនត្រឹមតែដើមទុនរូបវន្តអាចកកកុញក្នុងប្រទេសប៉ុណ្ណោះទេ ប៉ុន្តែក៏អាចជាមូលដ្ឋានបច្ចេកវិទ្យាពាក់ព័ន្ធសម្រាប់ការអភិវឌ្ឍន៍បន្ថែមទៀតផងដែរ។ ប៉ុន្តែ សាជីវកម្មពហុជាតិអាចជាស្ទាក់ស្ទើរក្នុងការចែករំលែកបច្ចេកវិទ្យា ដែលជាកម្មសិទ្ធិរបស់ខ្លួន នៅពេលមានដំណើរការផងដែរ។

រដ្ឋក្រីក្រភាគច្រើនស្វែងរកការបង្កើតក្រុមមនុស្សដែលមានចំណេះដឹង និងជំនាញដើម្បីដំណើរ ការសេដ្ឋកិច្ចជាតិ។ មធ្យោបាយមួយដើម្បីធ្វើដូច្នេះ គឺត្រូវបញ្ជូនសិស្សនិសិស្សទៅរដ្ឋឧស្សាហូបនីយកម្ម សម្រាប់ការអប់រំខ្ពស់។ ទោះយ៉ាងណាក៏ដោយវាក៏បានរួមបញ្ចូលហានិភ័យមួយចំនួន។ សិស្សនិស្សិតមួយចំនួន ដែល

រដ្ឋបញ្ជូនៅសិក្សាអាចរីករាយនឹងជីវិតនៅអឌ្ឍគោលខាងជើង ហើយមិនព្រមត្រឡប់មាតុប្រទេសវិញ។ បញ្ហានៃការបាត់បង់កម្មករជំនាញទៅកាន់ប្រទេសអ្នកមានដែលត្រូវបានហៅថា **ការបែកគំនិត** (brain drain) បានរារាំងដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងរដ្ឋដូចជា ប្រទេសឥណ្ឌា ប៉ាគីស្ថាន និងហ្វីលីពីន (ដែលជាកន្លែង ដែលគិលានុបដ្ឋាយិកាច្រើនជាង មុនបានធ្វើចំណាកស្រុកជាគិលានុបដ្ឋាយិកា ដែលបានបញ្ចប់ការសិក្សា នៅឆ្នាំ ២០០០-២០០៤)។

១៣.៣.២. បំណុលអឌ្ឍគោលខាងជើង-ខាងត្បូង

ការខ្ចីប្រាក់គឺជាជម្រើសមួយផ្សេងក្រៅពីការវិនិយោគពីបរទេស ដែលជាមធ្យោបាយសម្រាប់ទទួលបានដើមទុន ដើម្បីឈានទៅបង្កើតវដ្តនៃការប្រមូលផ្តុំទ្រព្យសម្បត្តិសម្រាប់សេដ្ឋកិច្ចជាតិ។ ប្រសិនបើការប្រមូលផ្តុំបានជោគជ័យ វាបង្កើតអតិរេកគ្រប់គ្រាន់ដើម្បីបង្វិលសងប្រាក់កម្ចី ហើយនៅតែរកប្រាក់ចំណេញបាន។ ការខ្ចីប្រាក់មានអត្ថប្រយោជន៍ជាច្រើន។ វានៅរក្សាអំណាចគ្រប់គ្រងនៅក្នុងកណ្តាប់ដៃរបស់រដ្ឋ (ឬអ្នកខ្ចីប្រាក់ក្នុងស្រុកផ្សេងទៀត) និងបង្កការលះបង់ដ៏ឈឺចាប់ដល់ប្រជាពលរដ្ឋក្នុងតំបន់ យ៉ាងហោចណាស់ក្នុងរយៈពេលខ្លី។

យ៉ាងណាមិញ បំណុលក៏មានគុណវិបត្តិច្រើនដែរ។ អ្នកខ្ចីប្រាក់ត្រូវតែសងបំណុល ដោយធ្វើការទូទាត់ការប្រាក់ជាទៀងទាត់ និងសងប្រាក់ដើមតាមលក្ខខណ្ឌនៃប្រាក់កម្ចី។ *ការសងបំណុល* (debt service) គឺជាការបង្ហូរឥតឈប់ឈរចេញពីអតិរេកណាមួយ ដែលត្រូវបានបង្កើតឡើងដោយការវិនិយោគប្រាក់។ ជាមួយនឹងការវិនិយោគផ្ទាល់ពីបរទេស ការបណ្តាក់ទុនដែលខាតបង់គឺជាបញ្ហារបស់សាជីវកម្មពហុជាតិបរទេស។ ជាមួយនឹងបំណុល វាជាបញ្ហារបស់រដ្ឋខ្ចីដែលត្រូវតែរកលុយនៅកន្លែងផ្សេង។ ជាញឹកញយ រដ្ឋកូនបំណុលត្រូវខ្ចីប្រាក់ថ្មីដើម្បីបង្វិលសងប្រាក់កម្ចីចាស់ ដូច្នេះហើយទើបធ្វើអោយមានបំណុលបន្ថែមទៀត។ ការសងប្រាក់បំណុលបានបង្កើតលំហូរហិរញ្ញវត្ថុសរុប ពីអឌ្ឍគោលខាងត្បូងទៅខាងជើង ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ដោយសារអឌ្ឍគោលខាងត្បូងបានបង់ការប្រាក់រាប់ពាន់លានបន្ថែមទៀត ដល់ធនាគារនិងរដ្ឋាភិបាលនៅអឌ្ឍគោលខាងជើងជាងដែលខ្លួនបានទទួលក្នុងការវិនិយោគបរទេសឬជំនួយអភិវឌ្ឍន៍។

ការខកខានក្នុងការទូទាត់សងបំណុលតាមកាលវិភាគកំណត់ ដែលហៅថា **ការក្ស័យធន** (default) ត្រូវបានចាត់ទុកថាជាសកម្មភាពដ៏ធ្ងន់ធ្ងរមួយ ព្រោះវាបំផ្លាញទំនុកចិត្តរបស់អ្នកអោយខ្ចី ហើយនាំអោយមានការកាត់ផ្តាច់ប្រាក់កម្ចីនាពេលអនាគត។ ជាជាងប្រកាសក្ស័យធន អ្នកខ្ចីជាធម្មតាព្យាយាម**ចរចាបំណុល** (debt regotiation)ឡើងវិញ ដែលជាការពិភាក្សាអំពីលក្ខខណ្ឌត្រូវសងប្រាក់កម្ចីវិញ នៅពេលវេលាណាមួយក្នុងចំនួនប៉ុន្មាន។ តាមរយៈការចរចាបំណុលរបស់ពួកគេជាមួយម្ចាស់បំណុល អ្នកខ្ចីស្វែងរកគ្រោងការណ៍ទូទាត់ដែលអាចទទួលយកបានទាំងអស់គ្នា ដើម្បីរក្សាលំហូរសំណងប្រាក់ខ្លះទៅម្ចាស់បំណុល។ ប្រសិនបើអត្រាការប្រាក់បានធ្លាក់ចុះចាប់តាំងពីពេលប្រាក់កម្ចីត្រូវបានដកចេញដំបូង អ្នកខ្ចីអាចធ្វើការរៀបចំហិរញ្ញវត្ថុឡើងវិញ។ អ្នកខ្ចីនិងម្ចាស់បំណុលក៏អាចចរចារដើម្បីរៀបចំរចនាសម្ព័ន្ធបំណុលឡើងវិញ ដោយការផ្លាស់ប្តូរយៈពេលនៃការខ្ចីប្រាក់ (ជាធម្មតា ប្តូរទៅរយៈពេលសម្រាប់សងត្រលប់ទៅវិញ) ឬលក្ខខណ្ឌផ្សេងទៀត។ ម្តងម្កាល ប្រាក់បំណុលពីរដ្ឋទៅរដ្ឋត្រូវបានលុបចោលទាំងស្រុង «ការលុបបំណុល» ដោយសារហេតុផលនយោបាយ ដូចដែលបានកើតឡើងជាមួយប្រាក់បំណុលរបស់សហរដ្ឋអាមេរិក ទៅដល់អេហ្ស៊ីប បន្ទាប់ពីសង្គ្រាមឈូងសមុទ្រ។

បំណុលអឡឺគោលខាងជើងនិងខាងត្បូងរួមបញ្ចូលទំនាក់ទំនងផ្តល់ប្រាក់កម្ចីជាច្រើនប្រភេទ ដែលទាំងអស់នេះត្រូវបានជះឥទ្ធិពលដោយនយោបាយអន្តរជាតិ។ *អ្នកខ្ចីប្រាក់*អាចជាក្រុមហ៊ុនឯកជន ឬធនាគារនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ឬអាចជារដ្ឋាភិបាលផ្ទាល់។ ប្រាក់កម្ចីដល់រដ្ឋាភិបាលជារឿងធម្មតាជាង ពីព្រោះម្ចាស់បំណុលគិតទុកមុនថារដ្ឋាភិបាលទំនងជាមិនសូវប្រកាសក្ស័យធន ដូចអ្នកខ្ចីឯកជននោះទេ។ *ម្ចាស់បំណុល*អាចជាធនាគារឬក្រុមហ៊ុនឯកជន ឬរដ្ឋណាមួយ (ទាំងពីរមានសារៈសំខាន់ដូចគ្នា)។ ជាធម្មតាធនាគារទទួចអោយអ្នកខ្ចីទូទាត់សងបំណុលអោយទាន់ពេលវេលាទៀងទាត់ជាង និងមានដំហររឹងមាំក្នុងការចរចាបំណុលជាងម្ចាស់បំណុលជារដ្ឋ។ កម្ចីប្រាក់របស់រដ្ឋមួយទៅរដ្ឋមួយទៀតត្រូវបានធ្វើឡើងតាមលក្ខខណ្ឌអំណោយផលនិង*ផ្តល់សម្បទាន* (concessionary) ម្លោះហើយអាចជួយឧបត្ថម្ភធនដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅក្នុងរដ្ឋកូនបំណុល។

ការចរចាបំណុលបានក្លាយជាបញ្ហាចាក់ស្រេះយូរឆ្នាំនៅក្នុងអឡឺគោលខាងត្បូង។ ការចរចាបំណុលឡើងវិញបែបនេះ គឺជាស្ថានការណ៍ចរចាអន្តរជាតិដ៏ស្មុគស្មាញ ដូចជាការចរចាពាណិជ្ជកម្មអន្តរជាតិ ឬការគ្រប់គ្រងសព្វាវុធជាដើម។ ប្រសិនបើរដ្ឋាភិបាលកូនបំណុលណាមួយទទួលយកលក្ខខណ្ឌដែលមានបន្ទុកខ្លាំងពេក វាអាចបាត់បង់ប្រជាប្រិយភាពនៅក្នុងប្រទេស។ ប៉ុន្តែប្រសិនបើរដ្ឋកូនបំណុលមិនព្រមផ្តល់អោយគ្រប់គ្រាន់ដើម្បីទទួលបានកិច្ចព្រមព្រៀងពីម្ចាស់បំណុល វាអាចនឹងត្រូវប្រកាសក្ស័យធន ។

សម្រាប់ម្ចាស់បំណុល ការចរចាបំណុលឡើងវិញជាប់ពាក់ព័ន្ធនឹងបញ្ហាផលប្រយោជន៍រួម៖ ពួកគេទាំងអស់ត្រូវយល់ព្រមលើលក្ខខណ្ឌនៃការចរចាឡើងវិញ ប៉ុន្តែរដ្ឋនីមួយៗខ្វល់ខ្វាយតែពីការទទួលបានប្រាក់របស់ខ្លួនមកវិញ។ ដើម្បីដោះស្រាយបញ្ហានេះ រដ្ឋជាម្ចាស់បំណុលជួបប្រជុំគ្នាជាទៀងទាត់ ដូចជា **ក្លឹបប៉ារីស** (Paris Club) និងម្ចាស់បំណុលឯកជនដូចជា**ក្លឹបឡុងដ៍**(London Club) ដើម្បីពិភាក្សានិងសម្រេចលើលក្ខខណ្ឌរបស់ពួកគេ។

តាមរយៈការចរចាឡើងវិញបែបនេះ និងការទូទាត់សងឬលុបបំណុលដោយធនាគារនានា ប្រទេសកំពុងអភិវឌ្ឍន៍អាចបញ្ចៀសការប្រកាសក្ស័យធន។ ទោះជាយ៉ាងណាក៏ដោយ ក្នុងឆ្នាំ ២០០១ ប្រទេសអាហ្សង់ទីនបានប្រកាសក្ស័យធន។ នៅពេលនោះ ស្ថាប័នហិរញ្ញវត្ថុបានសម្រួលចិត្ត និងទទួលស្គាល់ការពិតដែលថាប្រទេសអាហ្សង់ទីនមិនអាចសងបំណុលរបស់ខ្លួនបានទេ។ ជាការពិតណាស់ អាហ្សង់ទីនបានងើបឡើងវិញ ដោយសេដ្ឋកិច្ចរបស់វាបានកើនឡើង ៩ ភាគរយ ក្នុងមួយឆ្នាំ ចាប់តាំងពីឆ្នាំ ២០០១ ហើយនៅឆ្នាំ ២០០៥ បានផ្តល់អោយម្ចាស់បំណុលរបស់ខ្លួននូវកិច្ចព្រមព្រៀងមួយ «យកឬមិនយក» នូវសំណងតិចជាង ៣០ សេន សម្រាប់ប្រាក់បំណុលមួយដុល្លារ។ ភាគច្រើនបានព្រមទទួលយក។ ទោះជាយ៉ាងណាក៏ដោយ ការប្រកាសក្ស័យធន គឺជាទង្វើដ៏ប្រថុយប្រថានខ្លាំងណាស់ ដោយសារតែតម្រូវការជាចាំបាច់នូវការវិនិយោគបរទេសនិងពាណិជ្ជកម្មបរទេសដើម្បីប្រមូលទ្រព្យសម្បត្តិ។ ម្ចាស់បំណុលក៏បានបង្ហាញនូវឆន្ទៈព្រមទទួលយកការខាតបង់ខ្លះ ជាជាងរុញច្រានអោយកូនបំណុលទាល់ច្រកនិងរងហានិភ័យអស្ថិរភាពហិរញ្ញវត្ថុ។ ប៉ុន្តែក្នុងឆ្នាំ ២០០៨ ប្រទេសអេក្វាឌ័របានប្រកាសក្ស័យធនមិនអាចសងបំណុលបរទេស ចំនួន ១០ ប៊ីលានដុល្លារ ដែលប្រធានាធិបតីឆ្វេងនិយមរបស់ខ្លួនហៅថា «អសីលធម៌ និងខុសច្បាប់»។

ក្នុងប៉ុន្មានទស្សវត្សក៏កន្លងមកនេះ បញ្ហាបំណុលទាំងនេះបានហក់ឡើងដល់តំបន់អឡឺគោលខាងជើងខណៈដែលតំបន់ចាយប្រាក់អឺរ៉ូជួបជំពាក់បំណុលដ៏ធ្ងន់របស់រដ្ឋសមាជិកក្រីក្រមួយចំនួនរបស់ខ្លួន ជាពិសេស

ប្រទេសក្រិក ក៏ដូចជាប្រទេសព័រទុយហ្គាល់ អេស្ប៉ាញ និងអៀរឡង់។ នៅក្នុងកិច្ចព្រមព្រៀងថវិកាសង្គ្រោះឆ្នាំ ២០១១ ធនាគារកណ្តាលបំណុលក្រិកត្រូវទទួលយក សំណងត្រឹម ៥០ សេន សម្រាប់ជារៀងរាល់ប្រាក់បំណុលមួយដុល្លារ។ សូម្បីតែអ្នកបោះឆ្នោតជនជាតិក្រិកបានសម្តែងការខឹងសម្បារចំពោះការកាត់បន្ថយការចំណាយថវិកាដែលតម្រូវអោយបំពេញលក្ខខណ្ឌសម្រាប់ជំណាក់កាលនីមួយៗនៃថវិកាសង្គ្រោះ។ នៅក្នុងឆ្នាំ ២០១៤ ដោយធុញទ្រាន់នឹងលក្ខខណ្ឌសម្រាប់ទទួលបានថវិកាសង្គ្រោះទាំងនេះ អ្នកបោះឆ្នោតក្រិកបានជ្រើសរើសគណបក្សថ្មីមួយ ដើម្បីចរចាថវិកាសង្គ្រោះឡើងវិញជាមួយនឹងលក្ខខណ្ឌតិចជាងមុន។

ទោះបីជាមានស្ថិរភាពក៏ដោយ ប្រទេសកំពុងអភិវឌ្ឍន៍នៅមិនទាន់បានដោះស្រាយបញ្ហាបំណុលនៅឡើយ។ ដូចដែលបានបង្ហាញក្នុងតារាង ១៣.១ តំបន់អឌ្ឍគោលខាងត្បូងជំពាក់បំណុលបរទេសជាង ៦ ទ្រីលានដុល្លារ ហើយត្រូវចំណាយជាង ២ ទ្រីលានដុល្លារ ក្នុងមួយឆ្នាំ ដើម្បីសងបំណុល។ ការសងបំណុល (គិតជារូបិយប័ណ្ណខ្លាំង)ស្រូបយកជាងមួយភាគបីនៃរូបិយប័ណ្ណខ្លាំងទាំងមូលដែលបានពីការនាំចេញ នៅអាមេរិកឡាទីន ដែលជាតំបន់ដែលរងផលប៉ះពាល់ខ្លាំងបំផុត។ សម្រាប់អឌ្ឍគោលខាងត្បូងទាំងមូល វាស្រូបយកជាង ៣៥ ភាគរយនៃការនាំចេញ។

តារាង ១៣.១ បំណុលនៅសកលខាងត្បូង ឆ្នាំ ២០១៧

	បំណុលបរទេស		**សំណងបំណុលប្រចាំឆ្នាំ**	
តំបន់	**គិតជាប៊ីលាន $**	**% នៃ ផ.ស.ស.[ក]**	**គិតជាប៊ីលាន $**	**% នៃ ការនាំចេញ**
អាមេរិកឡាទីន	២០០០	៤១	៥១០	៥១
អាស៊ី	២៩០០	១៨	១៥០០	៤៣
អាហ្វ្រិក	៤៨០	៣៤	៩០	៣០
មជ្ឈឹមបូព៌ា	១០០០	៣៩	៣០០	២៩
ស.អឌ្ឍគោលត្បូង	៦៣៨០	៣៣	២៤០០	៣៨

[ក]GDP មិនត្រូវបានគណនាដោយភាពស្មើគ្នានៃអំណាចទិញទេ។

ប្រភព៖ ផ្អែកលើ IMF មូលដ្ឋានទិន្នន័យទស្សនវិស័យសេដ្ឋកិច្ចពិភពលោក ខែតុលា ឆ្នាំ ២០១៧។

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ សកម្មជននិងអង្គការក្រៅរដ្ឋាភិបាលបានអំពាវនាវអោយមានការលើកលែងបំណុលបរទេសយ៉ាងទូលំទូលាយ សម្រាប់ប្រទេសក្រីក្របំផុត ដែលភាគច្រើនស្ថិតនៅក្នុងទ្វីបអាហ្វ្រិក។ អ្នករិះគន់និយាយថា ការលុបចោលបែបនេះគ្រាន់តែដាក់ប្រាក់បន្ថែមទៀតនៅក្នុងកណ្តាប់ដៃរបស់រដ្ឋាភិបាលពុករលួយនិងអសមត្ថភាព។ ប៉ុន្តែ សមាជិកនៃប្រទេសG៧ ក្នុងឆ្នាំ ២០០៥ បានយល់ព្រមលុបបំបាត់បំណុលទាំងអស់ ដែលប្រទេសក្រីក្រចំនួន ៣៧ ជំពាក់ធនាគារពិភពលោកនិងមូលនិធិIMF ដោយកាត់បន្ថយស្ទើរតែពាក់កណ្តាលនៃបំណុលរបស់ប្រទេសក្រីក្របំផុត ដែលត្រូវប៉ាន់ប្រមាណទំហំ២០០ប៊ីលានដុល្លារ។ ទំហំបំណុល ៤០ ប៊ីលានដុល្លារដំបូង ដែលជំពាក់ដោយប្រទេសចំនួន ១៨ បានចាប់ផ្តើមលុបចោលនៅឆ្នាំ ២០០៦។ គិតត្រឹមឆ្នាំ ២០១៧ មូលនិធិIMFបានលើកលែងបំណុលចំនួន ៧៦ ប៊ីលានដុល្លារនៅក្នុងប្រទេសចំនួន ៣៦ ដែលក្រីក្របំផុត។

១៣.៣.៣. លក្ខខណ្ឌរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ

មូលនិធិIMFនិងធនាគារពិភពលោកមានការផ្តត់ផ្តង់ដើមទុនយ៉ាងច្រើន ពីរដ្ឋជាសមាជិករបស់ពួកគេនីមួយៗ (សូមមើលធនាគារពិភពលោក និងមូលនិធិIMF ក្នុងមេរៀនទី ៩)។ ដើមទុននេះដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់មូលនិធិ នៅដំណាក់កាលដំបូងនៃការប្រមូលផ្តុំទ្រព្យសម្បត្តិ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ និង ជួយពួកគេអោយឆ្លងកាត់ការលំបាកវេទនាខ្លាំងក្នុងរយៈពេលខ្លី។ ក្នុងនាមជាអង្គភាពនយោបាយ ជាជាងធនាគារមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) អាចផ្តល់មូលនិធិបានតាមលក្ខខណ្ឌអំណោយផល។

មូលនិធិIMFពិនិត្យលើផែនការនិងគោលនយោបាយសេដ្ឋកិច្ចរបស់ប្រទេសកំពុងអភិវឌ្ឍន៍ ដោយការបង្កកទុកប្រាក់កម្ចីរហូតទាល់តែវាពេញចិត្តថាមានគោលនយោបាយត្រឹមត្រូវគ្រប់គ្រាន់។ បន្ទាប់មក វាផ្តល់ប្រាក់កម្ចី ដើម្បីជួយរដ្ឋតាមរយៈដំណើរការអន្តរកាលនៃការអនុវត្តគោលនយោបាយ ដែលត្រូវបានអនុម័តដោយមូលនិធិIMF។ មូលនិធិIMFក៏បញ្ជូនសញ្ញាសំខាន់ៗទៅកាន់អ្នកផ្តល់ប្រាក់កម្ចីឯកជន និងអ្នកវិនិយោគផងដែរ។ ការអនុម័តផែនការសេដ្ឋកិច្ចរបស់រដ្ឋគឺជា«ការបោះត្រាឯកភាព»ដែលធនាគារកិនិងសាជីវកម្មពហុជាតិប្រើដើម្បីវាយតម្លៃទ្រឹភាពនៃការវិនិយោគនៅក្នុងរដ្ឋនោះ។ ដូច្នេះ មូលនិធិរូបិយវត្ថុអន្តរជាតិ(IMF)មានអំណាចខ្លាំង ដើម្បីជះឥទ្ធិពលលើគោលនយោបាយសេដ្ឋកិច្ចនៃប្រទេសកំពុងអភិវឌ្ឍន៍។

កិច្ចព្រមព្រៀងផ្តល់ប្រាក់កម្ចីផ្តល់ ដោយមូលនិធិIMF នៅក្នុងលក្ខខណ្ឌដែលគោលនយោបាយជាក់លាក់របស់រដ្ឋាភិបាលមួយចំនួនត្រូវបានអនុម័ត ដែលត្រូវបានគេហៅថាជា **កិច្ចព្រមព្រៀងលក្ខខណ្ឌIMF** (Conditionality)។ ការអនុវត្តលក្ខខណ្ឌទាំងនេះ ត្រូវបានគេហៅថា *កម្មវិធីកែតម្រូវរចនាសម្ព័ន្ធ* (structural adjustment program)។ ប្រទេសកំពុងអភិវឌ្ឍន៍រាប់សិបរដ្ឋបានចូលរួមទៅក្នុងកិច្ចព្រមព្រៀងបែបនេះជាមួយមូលនិធិIMF ក្នុងរយៈពេលពីរទសវត្សរ៍កន្លងមកនេះ។ លក្ខខណ្ឌដែលបានទទួចដោយមូលនិធិIMFជាធម្មតា អាចបង្កផលលំបាកតានតឹងខ្លាំងសម្រាប់ពលរដ្ឋ (និងអ្នកនយោបាយជាតិផងដែរ)។ មូលនិធិIMFទាមទារអោយអតិផរណាក្នុងកម្រិតគ្រប់គ្រងបាន ដែលតម្រូវអោយកាត់បន្ថយការចំណាយរបស់រដ្ឋ និងការបិទកុំអោយមានឱនភាពថវិការដ្ឋ។ ជារឿយៗ វិធានការណ៍ទាំងនេះបានជម្រុញអោយមានភាពអត់ការងារធ្វើកាន់តែច្រើន ហើយតម្រូវអោយមានការកាត់បន្ថយឬលុបចោលការឧបត្ថម្ភធនលើស្បៀងអាហារ និងទំនិញចាំបាច់ជាដើម។ ការប្រើប្រាស់រយៈពេលខ្លីត្រូវបានកាត់បន្ថយ ដើម្បីអោយមានដំណើរការនៃការវិនិយោគរយៈពេលវែង។ អតិរេកត្រូវតែផ្តោតទៅលើបំណុលសេវាកម្ម និងវិនិយោគក្នុងការប្រមូលដើមទុនថ្មី។ មូលនិធិIMFចង់បានការធានាថាប្រាក់ដែលផ្តល់អោយប្រទេសណាមួយ នឹងមិនត្រូវបានចំណាយក្នុងគោលបំណងនយោបាយ ប៉ុន្តែសំដៅលើផ្នែកសេដ្ឋកិច្ច ដែលមិនរកប្រាក់ចំណេញ (ដូចជាការឧបត្ថម្ភធនអាហារ)។ វាក៏ចង់មានការធានាថាអតិផរណាមិនធ្វើអោយមានផលរារាំងហើយសេដ្ឋកិច្ចមានស្ថេរភាពគ្រប់គ្រាន់ដើម្បីទាក់ទាញការវិនិយោគ។ លើសពីនេះទៀត មូលនិធិIMF ក៏បានធ្វើកការទាមទារអោយមានវិធានការណ៍ទប់ស្កាត់អំពើពុករលួយផងដែរ។

ដោយសារតែផលប៉ះពាល់ដែលបង្កឡើងដោយកិច្ចព្រមព្រៀងដែលមានលក្ខខណ្ឌ (និងក្នុងកម្រិតខ្លះដោយកិច្ចព្រមព្រៀងចរចាបំណុលឡើងវិញ) កិច្ចព្រមព្រៀងបែបនេះច្រើនតែមានលក្ខណៈនយោបាយដែលមិនជាទីពេញនិយមនៅក្នុងអឌ្ឍគោលខាងត្បូង។ ក្នុងពេលវេលាណាមួយ កិច្ចព្រមព្រៀងលក្ខខណ្ឌ មួយបាននាំអោយពួកកុប្បកម្មដើរតាមផ្លូវទាមទារអោយមានការផ្តល់ការឧបត្ថម្ភធនឡើងវិញ សម្រាប់ស្បៀងអាហារ

ប្រេងសាំង និងទំនិញចាំបាច់ផ្សេងទៀត។ ពេលខ្លះ រដ្ឋាភិបាលបានគាំទ្រពីកិច្ចព្រមព្រៀង ឬបានបំពានការសន្យារបស់ពួកគេក្រោមសម្ពាធបែបនេះ។ ម្តងម្កាល រដ្ឋាភិបាលត្រូវបានផ្តួលរំលំដោយសារកត្តាទាំងអស់នេះផងដែរ។

នៅក្នុងប្រទេសអេហ្ស៊ីប ជាកន្លែងដែលពាក្យដូចគ្នានេះត្រូវបានប្រើសម្រាប់ពាក្យថានំប៉័ង និងសម្រាប់ជីវិត នំប៉័ងមានតម្លៃថោកមានសារៈសំខាន់ចំពោះស្ថិរភាពនយោបាយ យ៉ាងហោចណាស់ក៏តាមទស្សនៈរបស់រដ្ឋាភិបាលដែរ។ ការឧបត្ថម្ភធនប្រចាំឆ្នាំចំនួន ៣,៥ ប៊ីលានដុល្លារ ផ្តល់នូវការផ្តត់ផ្តង់នំប៉័ងក្នុងការចំណាយពិតប្រាកដ មួយភាគបី សម្រាប់ប្រជាជនក្រីក្រក្នុងចំនួនច្រើនក្នុងប្រទេសអេហ្ស៊ីប។ ការចំណាយទាំងនេះបានបង្ខូចទ្រង់ទ្រាយទីផ្សារសេរី ដោយលើកទឹកចិត្តអោយប្រជាជនអេហ្ស៊ីបបរិភោគ (និងខ្ជះខ្ជាយ) នំប៉័ងច្រើនជាងអ្វីផ្សេងដែលជំរុញអោយមានតម្រូវការសម្រាប់នាំចូលស្រូវសាលី និងបង្កឱកាសអោយអំពើពុករលួយរីករាលដាល ដោយបង្វែរមធ្យោឧបត្ថម្ភធន ឬនំប៉័ងទៅទីផ្សារងងឹត។ ប៉ុន្តែ នៅពេលដែលរដ្ឋាភិបាលព្យាយាមដំឡើងថ្លៃនំប៉័ង នៅក្នុងឆ្នាំ១៩៧៧ កុប្បកម្មតាមដងផ្លូវបានបង្ខំអោយបញ្ច្រាសទិសដៅគោលនយោបាយ។ ផ្ទុយទៅវិញ រដ្ឋាភិបាលមានចរិតស្លូតបូតបានផ្លាស់ប្តូរទំហំ និងសមាសភាពនៃនំប៉័ង ហើយនៅឆ្នាំ ១៩៩៦ បានចាប់ផ្តើមលាយម្សៅពោត ដែលមានតំលៃថោកដោយសម្ងាត់ទៅក្នុងម្សៅស្រូវសាលីដែលកិនដោយរដ្ឋ។

រូបថត នំប៉័ងត្រូវបានយកចេញ ពីបន្ទាយយោធាទៅហាងលក់ នៅក្រោមការឃ្លាំមើលពីយោធា

ការពារនំប៉័ង

កិច្ចព្រមព្រៀងលក្ខខណ្ឌIMFតែងតែអំពាវនាវឱ្យកាត់បន្ថយការឧបត្ថម្ភធនសម្រាប់ម្ហូបអាហារ ការដឹកជញ្ជូននិងតម្រូវការមូលដ្ឋានផ្សេងទៀត។ នៅប្រទេសបូលីវី រដ្ឋាភិបាលបានឧបត្ថម្ភធនម្សៅនាំចូលដើម្បីបញ្ចុះតម្លៃនំប៉័ង។ នៅពេលដែលវាបានបញ្ចប់ការឧបត្ថម្ភធនទាំងនោះនៅក្នុងឆ្នាំ ២០១៥ អ្នកជុតនំនៅក្នុងប្រទេសបានបន្តធ្វើកូដកម្មតវ៉ា ដោយមិនបន្សល់ទុកនំប៉័ងនៅក្នុងប្រទេសសោះ។ បន្ទាប់មក រដ្ឋាភិបាលបានបញ្ជាឲ្យយោធាចាប់ផ្តើមធ្វើនំប៉័ងដើម្បីបំពេញតម្រូវការ។ នៅទីនេះ នំប៉័ងត្រូវបានយកចេញនៅក្រោមការឃ្លាំមើលពីយោធា ពីបន្ទាយយោធា ដើម្បីបញ្ជូនទៅហាង។

ជាការពិតណាស់ លក្ខខណ្ឌរបស់ មូលនិធិIMF ទាំងនេះក៏បានបង្ហាញពីភាពមិនពេញនិយមនៅក្នុងប្រទេសអភិវឌ្ឍន៍ដែលត្រូវការជំនួយ ក្នុងអំឡុងវិបត្តិសេដ្ឋកិច្ចឆ្នាំ ២០០៨-២០០៩។ បន្ទាប់ពីទទួលកញ្ចប់សង្គ្រោះចំនួន ៦ ប៊ីលានដុល្លារពីមូលនិធិIMF ប្រទេសអ៊ីស្លង់ត្រូវបានបង្ខំអោយធ្វើកំណែទម្រង់ជាមូលដ្ឋានចំពោះវិស័យធនាគាររបស់ខ្លួន។ ប្រទេសក្រិកដែលបានទទួលប្រាក់ជាង ១៣៣ ប៊ីលានដុល្លារពីមូលនិធិIMF បានយល់ព្រមលុបបំបាត់ថ្ងៃឈប់សម្រាកដែលមានប្រាក់ឈ្នួលជាច្រើន ខណៈដែលកាត់បន្ថយប្រាក់ឈ្នួលរបស់មន្ត្រីសាធារណៈទាំងអស់ចំនួន ៣ ភាគរយ។

១៣.៣.៤. អឌ្ឍគោលខាងត្បូង ក្នុងរបបសេដ្ឋកិច្ចអន្តរជាតិ

ដោយសារតែតម្រូវការដើមទុននិងទ្រព្យសម្បត្តិដែលបង្កើតឡើងដោយពាណិជ្ជកម្មអន្តរជាតិ រដ្ឋាភាគច្រើននៅអឌ្ឍគោលខាងត្បូងមើលឃើញថា ការអភិវឌ្ឍន៍សេដ្ឋកិច្ចនាពេលអនាគតរបស់ពួកគេត្រូវពឹងផ្អែកលើអន្តរទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយសេដ្ឋកិច្ចពិភពលោក មិនមែននៅលើស្វ័យភាពផ្តត់ផ្តង់របស់ជាតិ ឬសហគមន៍សេដ្ឋកិច្ចក្នុងតំបន់នោះទេ។ ដូច្នេះ រដ្ឋក្រីក្រត្រូវអនុវត្តតាមច្បាប់ឬវិធាននានា ដែលបានបង្កប់នៅក្នុងរបបសេដ្ឋកិច្ចអន្តរជាតិ (សូមមើល មេរៀនទី ៨ និងទី ៩)។

ទោះជាយ៉ាងណា របបពាណិជ្ជកម្មរបស់អង្គការWTO ជួនកាល បានធ្វើអោយប៉ះពាល់ដល់រដ្ឋក្រីក្រជាង បើធៀបនឹងទំនាក់ទំនងប្រទេសឧស្សាហកម្ម។ របបពាណិជ្ជកម្មសេរីបានធ្វើអោយរដ្ឋក្រីក្រកាន់តែពិបាកក្នុងការការពារឧស្សាហកម្មក្មេងខ្ចី ដើម្បីបង្កើតការប្រមូលផ្តុំដើមទុនអោយបានគ្រប់គ្រាន់ដោយខ្លួនឯង។ វាក៏បង្ខំអោយមានការប្រកួតប្រជែងជាមួយរដ្ឋនានាដែលមានបច្ចេកវិទ្យាជឿនលឿនជាង។ រដ្ឋក្រីក្រអាចធ្វើការប្រកួតប្រជែងបានតែនៅក្នុងទីផ្សារដែលមានប្រាក់ឈ្នួលទាប និងដើមទុនទាបប៉ុណ្ណោះ ជាពិសេសអ្នកដែលប្រើប្រាស់ធនធានធម្មជាតិដែលខ្វះខាតនៅអឌ្ឍគោលខាងជើង ដូចជាផលិតផលកសិកម្មត្រូពិច ឧស្សាហកម្មនិស្សារណកម្ម (ការជីកយករ៉ែ និងការខួងយករ៉ែ) និងវិស័យវាយនកណ្ដា។

ប៉ុន្តែ ចំពេលដែលវិស័យសេដ្ឋកិច្ចទាំងអស់នោះ នៅរដ្ឋក្រីក្រមានគុណសម្បត្តិធៀបនៅលើទីផ្សារពិភពលោក(ជាពិសេសវិស័យកសិកម្មនិងវាយនកណ្ដា) ត្រូវបានផាត់ចេញពីច្បាប់ពាណិជ្ជកម្មសេរី អស់ពេលជាច្រើនទសវត្សមកហើយ (សូមមើលមេរៀនទី ៨)។ ផ្ទុយទៅវិញ កិច្ចព្រមព្រៀងពាណិជ្ជកម្មពិភពលោកបានផ្តោតលើពាណិជ្ជកម្មសេរីនៃទំនិញឧស្សាហកម្មដែលរដ្ឋនានានៅអឌ្ឍគោលខាងជើងមានគុណសម្បត្តិធៀប។ ជាលទ្ធផល ប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនត្រូវបើកទីផ្សារក្នុងស្រុករបស់ពួកគេទទួលផលិតផលបរទេសដែលឧស្សាហកម្មក្នុងស្រុករបស់ពួកគេ មិនទាន់មានសមត្ថភាពប្រកួតប្រជែងនៅឡើយ ប៉ុន្តែសង្កេតឃើញថាផលិតផលនាំចេញរបស់ពួកគេ ត្រូវចាល់នៅលើទីផ្សារបរទេស។ ការចរចារបស់អង្គការWTO បច្ចុប្បន្ន កំពុងព្យាយាមដោះស្រាយវិសមភាពនេះ ប៉ុន្តែរហូតមកដល់ពេលនេះ មិនទាន់បានជោគជ័យនៅឡើយ។

ការរិះគន់លើអង្គការពាណិជ្ជកម្មពិភពលោកមួយទៀត ផ្តោតលើប្រព័ន្ធជម្លោះពាណិជ្ជកម្ម ដែលក្នុងនោះរដ្ឋនានាអាចដាក់ពាក្យបណ្តឹងអំពីការអនុវត្តពាណិជ្ជកម្មដោយអយុត្តិធម៌។ វិវាទផ្លូវច្បាប់បែបនេះអាចត្រូវចំណាយប្រាក់រាប់លានដុល្លារដើម្បីដោះស្រាយ ដោយត្រូវដួលមេធាវីថ្លៃៗនិងបុគ្គលិកច្រើនសម្បើម នៅឯទីស្នាក់ការអង្គការWTO នៅទីក្រុងហ្សឺណែវ នៃប្រទេសស្វីស។ រដ្ឋតិចណាស់នៅអឌ្ឍគោលខាងត្បូងអាចមានលទ្ធភាពស្វែងរកដំណើរការគាំពារផ្លូវច្បាប់បែបនេះ ដូច្នេះហើយរដ្ឋតិចណាស់ដែលប្រើយន្តការនេះដើម្បីជួយឧស្សាហកម្មរបស់ខ្លួនបំបាត់រនាំងអយុត្តិធម៌ក្នុងការធ្វើពាណិជ្ជកម្ម។ សូមចាំថា ទោះបីជារដ្ឋមួយឈ្នះជម្លោះនៅក្នុងយន្តការWTOក៏ដោយ ក៏ខ្លួនទទួលបានត្រឹមសិទ្ធិក្នុងការដាក់ពន្ធគយលើទំនិញរបស់ប្រទេសដែលបំពានក្នុងបរិមាណស្មើគ្នា។ សម្រាប់រដ្ឋតូចៗ ការសងសឹកនេះអាចបង្កការខូចខាតយ៉ាងច្រើនទៅលើសេដ្ឋកិច្ចរបស់ពួកគេ ក៏ដូចជាសេដ្ឋកិច្ចនៃរដ្ឋដែលបំពាន។

ដើម្បីទូទាត់សងសម្រាប់វិសមភាពទាំងនេះ និងដើម្បីជួយរដ្ឋក្រីក្រប្រើប្រាស់ពាណិជ្ជកម្មដើម្បីជំរុញកំណើនសេដ្ឋកិច្ចរបស់ពួកគេ អង្គការWTOមានប្រព័ន្ធអនុគ្រោះទូទៅ(GSP) (សូមមើលមេរៀនទី ៨)។ វិធានការណ៍ទាំងនេះ និងវិធានការណ៍ផ្សេងទៀត (ដូចជាអនុសញ្ញាឡូម៉េ(Lomé)និងកូតូនូ(Cotonou) ដែលរដ្ឋសមាជិកសហភាពអឺរ៉ុបបានបន្ធូរបន្ថយពន្ធលើទំនិញពីអឌ្ឍគោលខាងត្បូង) គឺជាករណីលើកលែងចំពោះច្បាប់ពាណិជ្ជកម្មទាំងមូល ហើយមានបំណងធានាអោយមានការចូលរួមក្នុងវឌ្ឍនភាពពាណិជ្ជកម្មពិភពលោក ជាជាងរារាំងការអភិវឌ្ឍន៍។ ទោះជាយ៉ាងណាក៏ដោយ អ្នករិះគន់អះអាងថា រដ្ឋក្រីក្រជាអ្នកចាញ់ក្នុងរបបពាណិជ្ជកម្មពិភពលោកទាំងមូល។

បណ្តាប្រទេសនានានៅអឌ្ឍគោលខាងត្បូង បានឆ្លើយតបចំពោះបញ្ហាទាំងនេះ ដោយមធ្យោបាយមួយចំនួន ជាមួយនឹងរបបសេដ្ឋកិច្ចពិភពលោក។ នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៧០ អង្គការនៃប្រទេសនាំចេញ

ប្រេង(OPEC)បានផ្លាស់ប្តូរលក្ខខណ្ឌពាណិជ្ជកម្មប្រេង ដោយនាំយកដើមទុនយ៉ាងច្រើនចូលទៅក្នុងប្រទេសនាំចេញប្រេង។ រដ្ឋមួយចំនួនសង្ឃឹមថា ជោគជ័យបែបនេះអាចកើតឡើងម្តងទៀត សម្រាប់ទំនិញដទៃ ដែលបណ្តាលអោយមានកំណើនយ៉ាងទូលំទូលាយសម្រាប់អឌ្ឍគោលខាងត្បូង ប៉ុន្តែវាមិនបានកើតឡើងទេ។

នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៧០នេះផងដែរ រដ្ឋក្រីក្រនិងរដ្ឋមានប្រាក់ចំណូលមធ្យមជាច្រើនបានព្យាយាមបង្កើតសម្ព័ន្ធនយោបាយទូលំទូលាយមួយ ដើម្បីជំរុញអោយមានការរៀបចំរចនាសម្ព័ន្ធសេដ្ឋកិច្ចពិភពលោកឡើងវិញ ដើម្បីធ្វើអោយប្រតិបត្តិការសេដ្ឋកិច្ចអឌ្ឍគោលខាងជើងនិងខាងត្បូង កាន់តែអំណោយផលដល់អឌ្ឍគោលខាងត្បូង។ កិច្ចប្រជុំកំពូលនៃចលនាមិនចូលបក្សសម្ព័ន្ធ (សូមមើលមេរៀនទី ២) ក្នុងឆ្នាំ ១៩៧៣ ដំបូងបានអំពាវនាវអោយមាន *សណ្តាប់ធ្នាប់សេដ្ឋកិច្ចអន្តរជាតិថ្មី* (NIEO)។ ចំណុចសំខាន់ចំពោះNIEO គឺជាការផ្លាស់ប្តូរនៅក្នុងលក្ខខណ្ឌពាណិជ្ជកម្ម ដើម្បីអនុគ្រោះដល់ទំនិញចម្បងទាក់ទងនឹងទំនិញឧស្សាហកម្ម។ សំណើរបស់NIEO ក៏បានអំពាវនាវអោយមានការលើកកម្ពស់ឧស្សាហូបនីយកម្ម នៅក្នុងអឌ្ឍគោលខាងត្បូង និងសម្រាប់ការបង្កើនជំនួយអភិវឌ្ឍន៍ពីអឌ្ឍគោលខាងជើង។ NIEO មិនដែលក្លាយជាអ្វីលើសពីការស្រែកតវ៉ាសម្រាប់អឌ្ឍគោលខាងត្បូងនោះទេ ម្យ៉ាងដោយសារតែកង្វះអំណាចរបស់អឌ្ឍគោលខាងត្បូង និងម្យ៉ាងទៀតដោយសារតែភាពខុសគ្នានៅក្នុងអឌ្ឍគោលខាងត្បូង បានបង្កើតជាផលប្រយោជន៍ផ្សេងគ្នា ក្នុងចំណោមរដ្ឋទាំងឡាយនៅទីនោះ។

បណ្តាប្រទេសនៅអឌ្ឍគោលខាងត្បូង បន្តស្វះស្វែងរកសំណើដើម្បីរៀបចំរចនាសម្ព័ន្ធពាណិជ្ជកម្មពិភពលោកឡើងវិញ ដើម្បីផ្តល់ផលប្រយោជន៍ដល់អឌ្ឍគោលខាងត្បូង។ កិច្ចខិតខំប្រឹងប្រែងទាំងនេះបច្ចុប្បន្ននេះ ប្រព្រឹត្តិទៅជាចម្បង តាមរយៈ*សន្និសីទអង្គការសហប្រជាជាតិស្តីពីពាណិជ្ជកម្មនិងការអភិវឌ្ឍន៍* (UNCTAD) ដែលប្រជុំជាទៀងទាត់ ប៉ុន្តែខ្វះអំណាចក្នុងការអនុវត្តកំណែទំរង់ដ៏សំខាន់នៅក្នុងទំនាក់ទំនងសេដ្ឋកិច្ចអឌ្ឍគោលខាងជើងនិងខាងត្បូង។ កិច្ចប្រឹងប្រែងលើកកម្ពស់ពាណិជ្ជកម្មរវាងអឌ្ឍគោលខាងត្បូងនឹងខាងត្បូង (ដោយកាត់បន្ថយភាពពឹងអាស្រ័យលើអឌ្ឍគោលខាងជើង) បានបង្ហាញអោយឃើញថាភាគច្រើនមិនអាចអនុវត្តបានឡើយ។ ពេលខ្លះប្រទេសចិនប្រើហេតុផលសាមគ្គីភាពអឌ្ឍគោលខាងត្បូងនឹងខាងត្បូងក្នុងការស្វាគមន៍សម្ព័ន្ធមិត្តថ្មីនៅអាហ្វ្រិក។ ហើយកិច្ចខិតខំប្រឹងប្រែងបន្តជំរុញកិច្ចសហប្រតិបត្តិការនិងសាមគ្គីភាពនៅក្នុងអឌ្ឍគោលខាងត្បូង តាមរយៈក្រុមជាច្រើន ដូចជាចលនាមិនចូលបក្សសម្ព័ន្ធនិងអង្គការសហប្រជាជាតិ។ យ៉ាងណាក៏ដោយ កិច្ចខិតខំប្រឹងប្រែងបែបនេះ បានធ្វើការតិចតួចដើម្បីផ្លាស់ប្តូរភាពពឹងអាស្រ័យរបស់អឌ្ឍគោលខាងត្បូងលើអឌ្ឍគោលខាងជើង។

១៣.៤. ជំនួយបរទេស

១៣.៤ ចូររៀបរាប់ពីហេតុផលចំនួនបី ដែលប្រទេសនានាអាចផ្តល់ជំនួយបរទេសដល់ទៅបណ្តាប្រទេសនៅអឌ្ឍគោលខាងត្បូង។

ជំនួយបរទេស(foreign assistane) (ឬជំនួយអភិវឌ្ឍន៍ក្រៅប្រទេស) គឺជាប្រាក់ឬជំនួយផ្សេងទៀតដែលអាចរកបាន ដើម្បីជួយបណ្តាប្រទេសតតិយលោកបង្កើនល្បឿនអភិវឌ្ឍន៍សេដ្ឋកិច្ច ឬគ្រាន់តែបំពេញតម្រូវការមនុស្សធម៌។ ប្រភេទជំនួយអភិវឌ្ឍន៍ផ្សេងគ្នាមានគោលបំណងផ្សេងគ្នា ដែលជារឿយៗត្រួតស៊ីគ្នា។ ជំនួយខ្លះមានលក្ខណៈជាមនុស្សធម៌ ខ្លះជារឿងនយោបាយ និងខ្លះទៀតមានបំណងបង្កើតអត្ថប្រយោជន៍សេដ្ឋកិច្ច នាពេលអនាគតសម្រាប់អ្នកផ្តល់ជំនួយ។ រដ្ឋឬអង្គការដែលផ្តល់ជំនួយត្រូវបានគេហៅថា *ម្ចាស់ជំនួយ* ចំណែករដ្ឋ

ឬអង្គការដែលទទួលជំនួយ គឺជា*អ្នកទទួល*។ ជំនួយបរទេសបង្កើតឬពង្រីកទំនាក់ទំនងរវាងម្ចាស់ជំនួយ និងអ្នកទទួល ដែលមានលក្ខណៈនយោបាយនិងវប្បធម៌ ក៏ដូចជាសេដ្ឋកិច្ច ក្នុងពេលដំណាលគ្នា។ ជំនួយបរទេសអាចជាទម្រង់មួយនៃអំណាច ដែលម្ចាស់ជំនួយស្វែងរកឥទ្ធិពលលើអ្នកទទួល ឬវាអាចជាទម្រង់នៃភាពពឹងអាស្រ័យគ្នាទៅវិញទៅមក ដែលម្ចាស់ជំនួយ និងអ្នកទទួលបង្កើតការដោះដូរដែលផ្តល់អត្ថប្រយោជន៍ដល់គ្នាទៅវិញទៅមក។ ផ្នែកដែលនៅសល់នៃមេរៀននេះនឹងពិនិត្យលើទំរង់និងប្រភេទនៃជំនួយបរទេស នយោបាយពាក់ព័ន្ធ និងឥទ្ធិពលជាសក្តានុពលនៃជំនួយបរទេស។

១៣.៤.១. ទំរង់ជំនួយបរទេស

ជំនួយបរទេសយ៉ាងច្រើនបានមកពីរដ្ឋាភិបាលនៅអឡឺរ៉ុប។ ក្នុងចំណោមជំនួយបរទេសរបស់រដ្ឋាភិបាលប្រហែល ១៦០ ប៊ីលានដុល្លារ ដែលផ្តល់ក្នុងឆ្នាំ ២០១៦ ស្ទើរតែ ៩០ ភាគរយបានមកពីសមាជិកនៃ**គណៈកម្មាធិការជំនួយអភិវឌ្ឍន៍**(DAC)ដែលរួមមានបណ្តារដ្ឋមកពីអឺរ៉ុបខាងលិច អាមេរិកខាងជើង និងអាស៊ីបូព៌ា។ ប្រទេសអារ៉ាប់ដែលនាំចេញប្រេងជាច្រើនបានផ្តល់ជំនួយអភិវឌ្ឍន៍បរទេសមួយចំនួនដែរ ហើយនៅក្នុងឆ្នាំ ២០០៣ សេដ្ឋកិច្ចអន្តរកាលបានក្លាយជា«អ្នកនាំចេញ»សរុបនៃជំនួយហិរញ្ញវត្ថុ។ បីភាគបួននៃជំនួយរបស់រដ្ឋាភិបាលរបស់ប្រទេសDAC ផ្តល់ដោយផ្ទាល់ទៅរដ្ឋាភិបាលនៅក្នុងអឡឺរ៉ុបខាងត្បូង ក្នុងទំរង់ជា**ជំនួយទ្វេភាគី** (bilateral aid) រវាងរដ្ឋនិងរដ្ឋ។ ជំនួយសេសសល់ពីនេះ បានឆ្លងកាត់អង្គការសហប្រជាជាតិ ឬទីភ្នាក់ងារផ្សេងទៀត ក្នុងទំរង់ជា**ជំនួយពហុភាគី**(multilateral aid)។

បណ្តាប្រទេសDAC បានដាក់គោលដៅខ្លួនឯង ក្នុងការរួមចំណែក ០,៧ ភាគរយនៃផលិតផលជាតិសរុប (GNPs) របស់ពួកគេ នៅក្នុងជំនួយបរទេស។ ប៉ុន្តែ សរុបមក ពួកគេផ្តល់តិចជាងពាក់កណ្តាលនៃចំនួននេះ។ មានតែប្រទេសន័រវេស ស៊ុយអែត ដាណឺម៉ាក ចក្រភពអង់គ្លេស និងលុចសំបួរប៉ុណ្ណោះដែលសម្រេចគោលដៅ។ តាមការពិត ដូចដែលបានបង្ហាញក្នុងក្រាហ្វិក ១៣.៦ ថវិកាជំនួយបានធ្លាក់ចុះយ៉ាងខ្លាំងនៅចុងទសវត្សរ៍ឆ្នាំ ១៩៦០ និងក្នុងទសវត្សរ៍ឆ្នាំ ១៩៩០។ ហើយខណៈពេលដែលពួកគេបានត្រលប់ទៅកម្រិតខ្ពស់វិញក្នុងទសវត្សរ៍ឆ្នាំ ២០០០ ពួកគេទំនងជាមិនកើនឡើង នាពេលអនាគត ដោយសារភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចពិភពលោក។


សហរដ្ឋអាមេរិកបានផ្តល់ភាគរយនៃផលិតផលជាតិសរុបទាបបំផុតមួយ (ប្រហែល ២ភាគ១០ នៃ១ ភាគរយ) ក្នុងចំណោមរដ្ឋចំនួន ៣០ ក្នុងបស្ចឹមលោកឧស្សាហូបនីយកម្ម ដែលបង្កើតជាអង្គការសម្រាប់កិច្ចសហប្រតិបត្តិការនិងអភិវឌ្ឍន៍សេដ្ឋកិច្ច(OECD)។ នៅក្នុងជំនួយសេដ្ឋកិច្ចសរុបដែលបានផ្តល់អោយ (ជាង ៣៤ ប៊ីលានដុល្លារក្នុងឆ្នាំ ២០១៦) សហរដ្ឋអាមេរិកបាននាំមុខអាឡឺម៉ង់ (ដោយផ្តល់ជំនួយប្រហែល ២៥ ប៊ីលានក្នុងមួយឆ្នាំ) និងអង់គ្លេស (ដែលថ្មីៗនេះបានបង្កើនជំនួយបរទេសរហូតដល់ ១៨ ប៊ីលានដុល្លារ)។ ប្រទេសជប៉ុននិងបារាំង បានផ្តល់ ម្នាក់ ១០ ប៊ីលានដុល្លារ។

ប្រទេសចិនបានក្លាយជាតួអង្គសំខាន់មួយនៅក្នុងវិស័យផ្តល់ជំនួយបរទេស ចាប់តាំងពីឆ្នាំ ២០១០។ យោងតាមការប៉ាន់ប្រមាណមួយ ចន្លោះឆ្នាំ ២០០០ និង២០១៤ ប្រទេសចិនបានផ្តល់ជំនួយបរទេសច្រើនដល់ ៣៥០ ប៊ីលានដុល្លារ ប្រហែលសហរដ្ឋអាមេរិក(៣៩០ ប៊ីលានដុល្លារ)។ ជំនួយភាគច្រើនក្នុងចំណោមនេះជាទំរង់ប្រាក់កម្ចី ដោយប្រហែលពាក់កណ្តាលនៃចំនួនជំនួយសរុប បានផ្តល់ដល់ទ្វីបអាហ្វ្រិក។

ប្រភពសំខាន់មួយទៀតនៃជំនួយបរទេស គឺកម្មវិធីរបស់*អង្គការសហប្រជាជាតិ* (UN Program)។ ទីតាំងនៃកម្មវិធីទាំងនេះ នៅក្នុងរចនាសម្ព័ន្ធអង្គការសហប្រជាជាតិត្រូវបានពិពណ៌នារួចហើយ នៅក្នុងមេរៀនទី ៧។ លំហូរទាំងមូលនៃជំនួយតាមរយៈអង្គការសហប្រជាជាតិត្រូវបានសម្របសម្រួលដោយ**កម្មវិធីអភិវឌ្ឍន៍នៃអង្គការសហប្រជាជាតិ**(UNDP) ដែលគ្រប់គ្រងគម្រោងរហូតដល់ចំនួន ៦០០០ ក្នុងពេលតែមួយ នៅជុំវិញពិភពលោក (ដោយផ្តោតជាពិសេសលើជំនួយអភិវឌ្ឍន៍បច្ចេកទេស)។ កម្មវិធីផ្សេងទៀតរបស់អង្គការសហប្រជាជាតិផ្តោតលើការប្រមូលផ្តុំដើមទុន ការផ្ទេរបច្ចេកវិទ្យា និងការអភិវឌ្ឍជំនាញនៃកម្លាំងពលកម្មសម្រាប់ផលិតកម្មឧស្សាហកម្ម។ អង្គការអភិវឌ្ឍន៍ឧស្សាហកម្មរបស់អង្គការសហប្រជាជាតិ(UNIDO) ធ្វើការលើឧស្សាហូបនីយ កម្មវិទ្យាស្ថានអង្គការសហប្រជាជាតិសម្រាប់ការបណ្តុះបណ្តាលនិងស្រាវជ្រាវ(UNITAR) ធ្វើការលើការបណ្តុះបណ្តាលនិងការស្រាវជ្រាវ។ ប៉ុន្តែ កម្មវិធីរបស់អង្គការសហប្រជាជាតិភាគច្រើន ដូចជាអង្គការយូនីសេហ្វ(UNICEF) មូលនិធិប្រជាជនអង្គការសហប្រជាជាតិ (UNFPA) យូណេស្កូ(UNESCO) និងអង្គការសុខភាពពិភពលោក(WHO) ផ្តោតលើការបំពេញតម្រូវការជាមូលដ្ឋានរបស់មនុស្ស។ (សូមមើលឧទាហរណ៍បន្ថែមស្តីពី ការស្វែងរកផលប្រយោជន៍រួម នៅចុងមេរៀន។)

ក្រាហ្វិក ១៣.៦ ជំនួយបរទេស(%នៃប្រាក់ចំណូលរដ្ឋម្ចាស់ជំនួយ) ២០១៦ និង ១៩៦០-២០១៦

ប្រភព៖ ផ្អែកលើស្ថិតិអភិវឌ្ឍន៍អន្តរជាតិ OECD ។



សម្គាល់៖ ភាគរយនៃចំណូលជាតិសរុប ដែលប្រហែលនឹងផ.ស.ស.

កម្មវិធីរបស់អង្គការសហប្រជាជាតិមានគុណសម្បត្តិបីធំៗ ក្នុងការលើកកម្ពស់ការអភិវឌ្ឍន៍សេដ្ឋកិច្ច។ ទីមួយគឺថា រដ្ឋាភិបាលនិងប្រជាពលរដ្ឋមានទំនោរយល់ឃើញថា អ.ស.ប.(UN) គឺជាមិត្តរបស់អឡឺគោលខាងត្បូង មិនមែនជាកងកម្លាំងជនបរទេស មិនមែនជាការគំរាមកំហែងដល់អធិបតេយ្យភាព ហើយក៏មិនមែន

ជាការរំលឹកពីប្រវត្តិអាណានិគមនិយមដ៏ជូរចត់ទេ។ ទីពីរ បុគ្គលិករបស់អង្គការសហប្រជាជាតិអាចទំនងជាធ្វើការសម្រេចចិត្តដ៏សមស្របដោយសារប្រវត្តិរបស់ពួកគេ។ បុគ្គលិករបស់អង្គការសហប្រជាជាតិ ដែលមកពីអឌ្ឍគោលខាងត្បូង ឬដែលធ្លាប់បានធ្វើការនៅក្នុងប្រទេសក្រីក្រផ្សេងទៀត នៅក្នុងតំបន់មួយ អាចមានការប្រយ័ត្នប្រយែងចំពោះភាពរសើបខ្លាំងនៃលក្ខខណ្ឌក្នុងស្រុក និងចំពោះបញ្ហានៃជំនួយអភិវឌ្ឍន៍ ជាងបុគ្គលិកជំនួយមកពីប្រទេសអ្នកមាន។ ទីបី អង្គការសហប្រជាជាតិអាចរៀបចំជំនួយរបស់ខ្លួន ជាលក្ខណៈសកលដោយផ្តល់អាទិភាពដល់គម្រោងនានា និងជៀសវាងការចម្លងដដែល និងការបង្កើតឡើងវិញនូវកង់នៅក្នុងរដ្ឋនីមួយៗ។

គុណវិបត្តិដ៏ធំដែលប្រឈមមុខដោយកម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ គឺថាមូលនិធិរបស់ពួកគេមួយភាគធំត្រូវបានផ្តល់តាមរយៈការរួមវិភាគទានដោយស្ម័គ្រចិត្តដោយរដ្ឋអ្នកមាន។ កម្មវិធីនីមួយៗត្រូវតែស្នើសុំការរួមវិភាគទានដើម្បីបន្តសកម្មភាពរបស់ខ្លួន ដូច្នេះការរួមចំណែកអាចត្រូវបានកាត់ផ្តាច់ភ្លាមៗប្រសិនបើកម្មវិធីធ្វើអោយរដ្ឋាភិបាលម្ចាស់ជំនួយមិនពេញចិត្ត។ ម្យ៉ាងទៀត រដ្ឋាភិបាលដែលសន្យាផ្តល់ជំនួយប្រហែលជាមិនបានធ្វើតាមការសន្យារបស់ខ្លួនទេ។ ជាឧទាហរណ៍ អង្គការសហប្រជាជាតិបានត្អូញត្អែរនៅដើមឆ្នាំ ២០០៥ ថាមានតែ ៥ ភាគរយនៃ ៥០០ លានដុល្លារ ដែលបានសន្យាផ្តល់ដល់ប្រទេសស៊ូដង់ខាងត្បូងដោយសហគមន៍អន្តរជាតិកាលពីប្រាំខែមុន បានធ្លាក់មកដល់ដៃអ្នកទទួល។ គុណវិបត្តិសំខាន់ទីពីរនៃកម្មវិធីរបស់អង្គការសហប្រជាជាតិ គឺកេរ្តិ៍ឈ្មោះរបស់ពួកគេក្នុងប្រតិបត្តិការក្នុងលក្ខណៈការិយាធិបតេយ្យដែលគ្មានប្រសិទ្ធភាព ដោយគ្មានការសហការនិងធនធាន ដែលរដ្ឋាភិបាលនិងសាជីវកម្មពហុជាតិនានា នៅអឌ្ឍគោលខាងជើងព្រងើយកន្តើយ។

<u>រូបថត</u> អ្នកស្ម័គ្រចិត្តរបស់ទីភ្នាក់ងារ Peace Corps របស់សហរដ្ឋអាមេរិក ធ្វើការនៅប៉ាណាម៉ា ជួយគ្នាក្នុងគ្រាលំបាក

រដ្ឋាភិបាលផ្តល់ជំនួយបរទេសប្រហែល ២០ ប៊ីលានដុល្លារក្នុងមួយឆ្នាំ ហើយម្ចាស់ជំនួយឯកជនច្រើនជាង ៥០ ប៊ីលានដុល្លារជាជំនួយបន្ថែម។ នៅលោកខាងលិច សហរដ្ឋអាមេរិកផ្តល់ជំនួយបរទេសតិចបំផុតបើធៀបនឹងភាគរយនៃផលិតផលក្នុងស្រុកសរុបពួកគេ ទោះបីជាមានការកើនឡើងនាពេលថ្មីៗនេះក៏ដោយ។ នៅទីនេះ អ្នកស្ម័គ្រចិត្តរបស់ទីភ្នាក់ងារ Peace Corps របស់សហរដ្ឋអាមេរិក ធ្វើការនៅប៉ាណាម៉ា នៅក្នុងឆ្នាំ ២០០១។

១៣.៤.២. ប្រភេទនៃជំនួយបរទេស

ជំនួយទ្វេភាគីមានទិដ្ឋភាពច្រើនប្រភេទ។ *ជំនួយឥតសំណង*(grants)គឺជាមូលនិធិផ្តល់ដោយឥតគិតថ្លៃតបស្នងដល់រដ្ឋទទួល ជារឿយៗ សម្រាប់ហេតុផលបញ្ជាក់ច្បាស់លាស់។ *កិច្ចសហប្រតិបត្តិការបច្ចេកទេស* (technical cooperation) សំដៅលើការផ្តល់ជំនួយក្នុងទម្រង់ជាអ្នកជំនាញក្នុងគម្រោងមួយចំនួនជាជាងគ្រាន់តែផ្តល់ប្រាក់ឬទំនិញ។ *ឥណទាន*(credits) គឺជាជំនួយដែលអាចត្រូវបានប្រើដើម្បីទិញផលិតផលមួយចំនួនពីរដ្ឋម្ចាស់ជំនួយ។ ជាឧទាហរណ៍ សហរដ្ឋអាមេរិកផ្តល់ឥណទាន ជាទៀងទាត់ ហើយដែលអាចត្រូវបានប្រើដើម្បីទិញគ្រាប់ធញ្ញជាតិរបស់សហរដ្ឋអាមេរិក។ ប្រសិនបើប្រជាជននៅក្នុងប្រទេសទទួលឥណទាន មានទម្លាប់ប្រើប្រាស់ផលិតផលពីរដ្ឋម្ចាស់ជំនួយ ពួកគេទំនងជានឹងទិញផលិតផលទាំងនោះនាពេលអនាគត។

ប្រាក់កម្ចី (loans) គឺជាមូលនិធិដែលត្រូវបានផ្តល់ ដើម្បីជួយក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច ហើយត្រូវតែសងវិញនៅពេលអនាគត ដែលដកចេញពីអតិរេកដែលបង្កើតដោយដំណើរការអភិវឌ្ឍន៍ (ជាញឹកញាប់ វាក៏ត្រូវបានចង់ភ្ជាប់ទៅនឹងលក្ខណៈទិញផលិតផលពីរដ្ឋម្ចាស់ជំនួយ)។ ខុសពីប្រាក់កម្ចីពាណិជ្ជកម្ម ប្រាក់កម្ចីអភិវឌ្ឍន៍ពីរដ្ឋាភិបាលទៅរដ្ឋាភិបាលជារឿយៗត្រូវបានធ្វើឡើងក្នុងលក្ខខណ្ឌសម្បទាន ជាមួយនឹងរយៈពេលត្រូវសងយូរនិងអត្រាការប្រាក់ទាប។ ទោះបីជានៅតែជាកាតព្វកិច្ចសម្រាប់ប្រទេសអ្នកទទួលក៏ដោយ ប្រាក់កម្ចីបែបនេះមានភាពងាយស្រួលក្នុងការសងត្រលប់ទៅវិញ។

ការធានាប្រាក់កម្ចី (loan guarantees) ដែលត្រូវបានប្រើម្តងម្កាល គឺជាការប្តេជ្ញារបស់រដ្ឋម្ចាស់ជំនួយក្នុងការបម្រុងទុកប្រាក់កម្ចីពាណិជ្ជកម្មដល់ប្រទេសអ្នកទទួល។ ប្រសិនបើរដ្ឋជាអ្នកទទួលអាចសងបំណុលបែបនេះបណ្តើរៗ ហើយចុងក្រោយសងវិញទាំងអស់ នោះគ្មានការខាតបង់ចំពោះអ្នកផ្តល់ជំនួយឡើយ។ ប៉ុន្តែ ប្រសិនបើអ្នកទទួលប្រាក់កម្ចីមិនអាចទូទាត់បានទេ ម្ចាស់ជំនួយត្រូវតែចូលខ្លួន និងរ៉ាប់រងបំណុលជំនួស។ ការធានាប្រាក់កម្ចីអនុញ្ញាតអោយរដ្ឋដែលជាអ្នកទទួលអាចខ្ចីប្រាក់ដោយអត្រាការប្រាក់ទាបពីធនាគារពាណិជ្ជ (ព្រោះហានិភ័យចំពោះធនាគារមានកម្រិតទាបជាងច្រើន)។

ជំនួយយោធា (military aid) ជាធម្មតាមិនរួមបញ្ចូលនៅក្នុងជំនួយអភិវឌ្ឍន៍ទេ ប៉ុន្តែ ក្នុងន័យទូលំទូលាយ វាស្ថិតក្នុងចំណោមនោះ។ វាជាលុយដែលហូរពីអឌ្ឍគោលខាងជើងទៅអឌ្ឍគោលខាងត្បូង ពីរដ្ឋាភិបាលមួយទៅរដ្ឋាភិបាលមួយទៀត ហើយវាពិតជាបានបន្ថែមតម្លៃចូលទៅក្នុងសេដ្ឋកិច្ចនៃអឌ្ឍគោលខាងត្បូង។ ប្រសិនបើប្រទេសមួយគ្រោងមានកងទ័ពទំហំជាក់លាក់ជាមួយនឹងអាវុធជាក់លាក់ ការទទួលបានអាវុធទាំងនោះដោយឥតគិតថ្លៃពីរដ្ឋម្ចាស់ជំនួយ នោះរដ្ឋអ្នកទទួលនឹងបង្វែរលុយយកទៅប្រើប្រាស់នៅកន្លែងផ្សេងទៀតនៅក្នុងសេដ្ឋកិច្ច។ ទោះជាយ៉ាងណាក៏ដោយ ក្នុងចំណោមប្រភេទជំនួយអភិវឌ្ឍន៍ទាំងអស់ ជំនួយយោធាជាប្រភេទមានប្រសិទ្ធភាពតិចបំផុត ហើយងាយនឹងត្រូវបានរារាំង ជាជាងជួយអភិវឌ្ឍន៍សេដ្ឋកិច្ច។ វាក៏ត្រូវបានបង្កើតឡើងសម្រាប់សម្ព័ន្ធភាពនយោបាយផ្តាច់មុខ ជាជាងតម្រូវការអភិវឌ្ឍន៍ជាក់ស្តែង។

ទីភ្នាក់ងារសំខាន់ដែលចែកចាយជំនួយសេដ្ឋកិច្ចបរទេសរបស់សហរដ្ឋអាមេរិក (ប៉ុន្តែ មិនមែនជាជំនួយយោធា) គឺជា *ទីភ្នាក់ងារសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ*(USAID) របស់ក្រសួងការបរទេស ដែលធ្វើការជាចម្បងតាមរយៈស្ថានទូតសហរដ្ឋអាមេរិក នៅក្នុងប្រទេសអ្នកទទួលនីមួយៗ។ អ្នកទទួលជំនួយបរទេសសំខាន់ៗរបស់សហរដ្ឋអាមេរិករួមមាន ប្រទេសអ៊ីស្រាអែល អេហ្ស៊ីប និងទួរគី ដែលជាសម្ព័ន្ធមិត្តយុទ្ធសាស្ត្រសំខាន់ៗទាំងអស់ នៅក្នុងមជ្ឈិមបូព៌ាដ៏ផុយស្រួយ។

ទីភ្នាក់ងារ Peace Corps របស់សហរដ្ឋអាមេរិក ផ្តល់ជំនួយជាអ្នកស្ម័គ្រចិត្ត សម្រាប់ជំនួយអភិវឌ្ឍន៍បច្ចេកទេស នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ ពួកគេបំពេញការងារតាមការស្នើសុំ និងក្រោមការដឹកនាំរបស់រដ្ឋម្ចាស់ផ្ទះ ក៏ប៉ុន្តែត្រូវបានផ្តល់ប្រាក់ឧបត្ថម្ភដោយរដ្ឋាភិបាលសហរដ្ឋអាមេរិក។ ផ្តួចផ្តើមដោយប្រធានាធិបតីកេណ្ណឺឌី ក្នុងឆ្នាំ ១៩៦១ ឥឡូវនេះ ទីភ្នាក់ងារ Peace Corps បានបញ្ជូនអ្នកស្ម័គ្រចិត្តជិត ៧០០០ នាក់ទៅកាន់ប្រទេសជិត ៧០ ដែលពួកគេចូលរួមក្នុងគម្រោងដែលជះឥទ្ធិពលដល់មនុស្សប្រហែលមួយលាននាក់។

នៅក្នុងជំនួយបរទេស ម្ចាស់ជំនួយត្រូវតែមានការអនុញ្ញាតពីរដ្ឋាភិបាលអ្នកទទួល ដើម្បីដំណើរការនៅក្នុងប្រទេសខ្លួន។ នេះត្រូវត្រឡប់ទៅលើគោលការណ៍អធិបតេយ្យភាពជាតិ និងប្រវត្តិសាស្ត្រនៃអាណានិគមនិយម។ រដ្ឋាភិបាលជាតិមានសិទ្ធិគ្រប់គ្រងការចែកចាយជំនួយ និងវត្តមានបុគ្គលិកបរទេសនៅលើដីរបស់

ពួកគេ។ ម្តងម្កាល គោលការណ៍នេះត្រូវបានរំលោភបំពាន ដូចជាពេលដែលសហរដ្ឋអាមេរិក និងសម្ព័ន្ធមិត្ត បានធ្វើការផ្តល់ជំនួយដល់ជនជាតិយីដអ៊ីរ៉ាក់ ដោយប្រឆាំងនឹងឆន្ទៈរបស់រដ្ឋាភិបាលអ៊ីរ៉ាក់ បន្ទាប់ពីសង្គ្រាមឈូងសមុទ្រ។ បទដ្ឋានអន្តរជាតិអាចចាប់ផ្តើមផ្លាស់ប្តូរនៅក្នុងបញ្ហានេះ នៅពេលជំនួយមនុស្សធម៌រយៈពេលខ្លី ត្រូវបានគេមើលឃើញថាជាបញ្ហាសិទ្ធិមនុស្ស ដែលមិនគួរស្ថិតនៅក្រោមសិទ្ធិវេតូរបស់រដ្ឋាភិបាល។

ជំនួយឯកជន

ការបរិច្ចាគឯកជនផ្តល់ជំនួយក្នុងចំនួនតិចជាង ទោះបីជាពេលខ្លះមានសារៈសំខាន់ខ្លាំងក៏ដោយ។ ជាឧទាហរណ៍ មូលនិធិគូស្វាមីភរិយា ប៊ីលនិងមេលីនដា ហ្គេត (Bill and Melinda Gates) បានបរិច្ចាគច្រើនជាង ២ ប៊ីលានដុល្លារ ជារៀងរាល់ឆ្នាំ ដល់យុទ្ធនាការសុខភាពពិភពលោក។ ជំនួយឯកជនគឺជាប្រភពជំនួយដ៏សំខាន់សម្រាប់អង្គគោលខាងត្បូង។ នៅឆ្នាំ ២០១៦ យោងតាម OECD ជំនួយឯកជនហូរចេញពីប្រទេស DAC ជិត ១៥០ ប៊ីលានដុល្លារ។ តួលេខនេះមានទំហំធំជាងជំនួយអភិវឌ្ឍន៍ផ្លូវការ ដែលផ្តល់ដោយរដ្ឋាភិបាលរបស់រដ្ឋនានា។

មានប្រភពជំនួយឯកជនជាច្រើន។ បុគ្គលនៅក្នុងរដ្ឋអ្នកមាន អាចផ្តល់អោយជាលក្ខណៈបុគ្គល (ដូចជា លោក Bill Gates ឬ លោក George Soros)។ បុគ្គលម្នាក់ៗអាចផ្តល់ទៅអោយអង្គការសប្បុរសធម៌ដែលផ្ញើប្រាក់ឬអាហារទៅក្រៅប្រទេស ដូចជា កាកបាទក្រហម គ្រូពេទ្យគ្មានព្រំដែន ឬព្រះវិហារក្នុងស្រុករបស់ពួកគេ។ ក្រុមសប្បុរសធម៌ឯកជនមួយ ក្នុងចំណោមក្រុមសប្បុរសធម៌ឯកជនធំៗ គឺ **Oxfam America** (មួយក្នុងចំណោមក្រុមទាំងប្រាំពីរនៅទូទាំងពិភពលោកបានមកពីគណៈកម្មាធិការ Oxford សម្រាប់ជំនួយសង្គ្រោះគ្រោះទុរភិក្ស ដែលបានបង្កើតឡើង ក្នុងឆ្នាំ ១៩៤២ ក្នុងប្រទេសអង់គ្លេស)។

អង្គការ Oxfam បានបង្កើតគំរូប្លែកខុសគេតែមួយគត់នៃជំនួយបរទេស។ ដើមឡើយ វាគឺជាជំនួយដើម្បីជួយសង្គ្រោះជនរងគ្រោះដោយទុរ្ភិក្សរយៈពេលខ្លី ហើយវានៅតែសកម្មក្នុងកិច្ចខិតខំប្រឹងប្រែងនោះ។ អង្គការ Oxfam America បានសង្កេតឃើញថា ក្នុងរយៈពេលវែងជាងនេះ មនុស្សមិនគ្រាន់តែត្រូវការអំណោយជាអាហារប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវការមធ្យោបាយចិញ្ចឹមដោយខ្លួនឯង ដូចជា ដីធ្លី ទឹកប្រើប្រាស់គ្រាប់ពូជ ឧបករណ៍កសិកម្ម និងការបណ្តុះបណ្តាលបច្ចេកទេស។

ទិដ្ឋភាពប្លែកខុសគេនៃគំរូរបស់ Oxfam គឺថាវាពឹងផ្អែកលើសហគមន៍មូលដ្ឋានដើម្បីកំណត់តម្រូវការរបស់ប្រជាជនខ្លួនឯង ហើយអនុវត្តគម្រោងអភិវឌ្ឍន៍ដោយពួកគេផ្ទាល់។ អង្គការOxfam មិនដំណើរការគម្រោងដោយខ្លួនឯងទេ ប៉ុន្តែផ្តល់ជាជំនួយមូលនិធិដល់អង្គការក្នុងស្រុកជាអ្នកដំណើរការគម្រោង។ អង្គការ Oxfam ក៏មិនហៅខ្លួនឯងថាជាអ្នកផ្តល់ជំនួយ ហើយក៏មិនហៅអង្គការក្នុងស្រុកទាំងនោះថាជាអ្នកទទួលដែរ។ ផ្ទុយទៅវិញ វាហៅភាគីទាំងសងខាងថា «ដៃគូគម្រោង» ដោយធ្វើការសហប្រតិបត្តិការជាមួយគ្នាដើម្បីសម្រេចបានគោលដៅរួមមួយ។ នៅក្នុងគំរូនេះ ទឹកប្រាក់ខាងក្រៅតិចតួចនេះអាចបន្តដំណើរឆ្ពោះទៅរកការកសាងការអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងស្រុកប្រកបដោយនិរន្តរភាព។ ជាងនេះទៅទៀត គម្រោងអង្គការជួយអោយអ្នកចូលរួមពង្រឹងអំណាចខ្លួនដោយខ្លួនឯងផ្ទាល់ ដោយរួមគ្នាបំពេញតម្រូវការរបស់ពួកគេផ្ទាល់។

ជាឧទាហរណ៍ អង្គការ Oxfam អាមេរិក បានជួយសហករណ៍ស្ត្រីអេត្យូពី ពង្រីកនិងបង្កើនអត្រាការងារ។ អង្គការ Oxfam មិនបានរចនា ឬរៀបចំគម្រោងនេះទេ តែធ្វើឡើងដោយស្ត្រីនៅទីក្រុង Addis Ababa។ ប៉ុន្តែនៅពេលដែលសិក្ខាសាលារៀនកាត់ដេររបស់ពួកគេទទួលបានផលចំណេញ ហើយបានត្រៀម

ខ្លួនរួចជាស្រេចដើម្បីពង្រីកនិងផ្តល់ការងារដល់ស្ត្រីច្រើនជាងពីរដង អង្គការ Oxfam បានផ្តល់អោយក្រុមនេះនូវជំនួយចំនួន ១៥០០០ ដុល្លារ ដើម្បីសាងសង់អគារថ្មីមួយ។

ទំនាក់ទំនងរវាងអឡឹគោលខាងជើងនិងខាងត្បូង ក្រុមនានាដូចជា អង្គការOxfam និងដៃគូគម្រោងរបស់ពួកគេ ត្រូវបានប្រដូចទៅនឹងអាពាហ៍ពិពាហ៍ដ៏ល្អមួយ ដែលការសម្រេចចិត្តត្រូវបានធ្វើឡើងរួមគ្នា ហើយភាពអាស្រ័យមិនរីកកាន់តែខ្លាំងនោះទេ។ នៅក្នុងគំរូនេះ ការអភិវឌ្ឍន៍សេដ្ឋកិច្ចមិនមែនជាសប្បុរសធម៌ទេ។ វាជាផលប្រយោជន៍របស់ប្រជាជនក្នុងប្រទេសអ្នកមាន ក៏ដូចជាអ្នកក្រ។ ទំនាក់ទំនងពោរពេញដោយការសហការគ្នារវាងអឡឹគោលខាងជើងនិងខាងត្បូង មានសារៈសំខាន់សម្រាប់ពិភពលោក ពោរពេញដោយសន្តិភាពនិងវិបុលភាព។ សូម្បីតែក្នុងន័យសេដ្ឋកិច្ចតូចចង្អៀតក៏ដោយ ក៏ការអភិវឌ្ឍន៍នៅអឡឹគោលខាងត្បូងបង្កើតទីផ្សារថ្មីនិងផលិតផលថ្មី ដែលនឹងធ្វើអោយប្រទេសឧស្សាហកម្មរីកចម្រើនផងដែរ។ នៅក្នុងសេដ្ឋកិច្ចការបង្កើតទ្រព្យសម្បត្តិ គឺជា ល្បែងផលបូកវិជ្ជមាន។

វិធីសាស្ត្ររបស់អង្គការOxfam ស្វែងរកការគិតឡើងវិញនូវជំនួយអភិវឌ្ឍន៍ ដើម្បីផ្តោតលើការអភិវឌ្ឍន៍រយៈពេលវែង តាមរយៈយុទ្ធសាស្ត្រតម្រូវការមូលដ្ឋានពីក្រោមឡើងលើ និងការផ្តល់អំណាចនយោបាយដល់ប្រជាជនក្រីក្រ។ ទស្សនវិជ្ជារបស់ក្រុមនៃ «គោលការណ៍ផ្អែកលើសិទ្ធិក្នុងការអភិវឌ្ឍន៍» បានទាក់ទាញការសរសើរពីអង្គការសិទ្ធិមនុស្ស។ ដោយសារតែការខកចិត្តនឹងការប្រើប្រាស់នយោបាយនៃជំនួយបរទេសនាពេលកន្លងមក អង្គការOxfam បានព្យាយាមកាត់បន្ថយតួនាទីនៅក្នុងគម្រោងរបស់រដ្ឋាភិបាល ទាំងនៅអឡឹគោលខាងជើងនិងអឡឹគោលខាងត្បូង។ ជាឧទាហរណ៍ អង្គការ Oxfam មិនទទួលយកមូលនិធិរបស់រដ្ឋាភិបាល ហើយក៏មិនផ្តល់ជំនួយដល់រដ្ឋាភិបាលផងដែរ។

គោលដៅទូទៅនៃគំរូរបស់អង្គការOxfam សម្រាប់ជំនួយបរទេស ស្របជាមួយនឹងចលនាទូលំទូលាយនៅក្នុងអឡឹគោលខាងត្បូង ឆ្ពោះទៅរក*ការពង្រឹងអំណាច*មូលដ្ឋាន។ កិច្ចខិតខំប្រឹងប្រែងរបស់អង្គការដូចជាដៃគូអង្គការOxfam ត្រូវបានរៀបចំឡើងដោយប្រជាជនក្រីក្រ ដើម្បីទទួលបានអំណាចមួយចំនួន លើស្ថានភាពរបស់ពួកគេ និងបំពេញតម្រូវការជាមូលដ្ឋានរបស់ពួកគេ មិនមែនដោយការដណ្តើមគ្រប់គ្រងរដ្ឋក្នុងបដិវត្តន៍នោះទេ ប៉ុន្តែតាមរយៈមធ្យោបាយដែលមានលក្ខណៈផ្ទាល់ក្នុងស្រុក និងមិនសូវមានអំពើហិង្សា។ គន្លឹះនៃភាពជោគជ័យគឺជាការរៀបចំ និងស្វែងរកព័ត៌មាន ដែលទទួលបានទំនុកចិត្តលើខ្លួនឯង និងការទទួលបានធនធានដែលត្រូវការ ដើម្បីអនុវត្តផែនការសកម្មភាព។

ជាឧទាហរណ៍ នៅក្នុងប្រទេសឥណ្ឌា ក្រុមស្ត្រីក្នុងស្រុកដែលប្រើតែអំណាចនៃការបញ្ចុះបញ្ចូលនិងតក្កវិជ្ជាបានបញ្ចុះបញ្ចូលម្ចាស់ដីមួយចំនួនអោយផ្តល់ដីដល់ពួកគេ សម្រាប់គម្រោងបង្កើតប្រាក់ចំណូលដោយសហករណ៍ ដូចជាការដាំបន្លែ និងការចិញ្ចឹមដង្កូវនាងជាដើម។ នៅកន្លែងផ្សេងទៀត នៅក្នុងប្រទេសឥណ្ឌា ស្ត្រីដែលធ្វើការជាអ្នកប្រមូលឈើ និងអនុផលព្រៃឈើផ្សេងទៀតត្រូវបានរៀបចំឡើងដើម្បីទទួលបានប្រាក់ឈ្នួលអប្បបរមាស្របច្បាប់សម្រាប់កម្មកររព្រៃឈើជាស្ត្រីចំនួន ២៥០ ០០០ ដែលមានទំហំបីដងនៃប្រាក់ឈ្នួលដែលពួកគេបានទទួលពីមុន។ ក្នុងករណីនេះ សកម្មភាពរបស់រដ្ឋាភិបាលគឺជាការចាំបាច់ ប៉ុន្តែសម្ពាធសម្រាប់សកម្មភាពបែបនេះបានមកពីការរៀបចំក្នុងមូលដ្ឋាន។ ក្រុមស្ត្រីបានយកករណីបញ្ហារបស់ពួកគេទៅបង្ហាញសាធារណៈជន និងសារព័ត៌មាន ធ្វើបាតុកម្មតវ៉ា និងទទួលការតាំងពិព័រណ៍សិល្បៈ ទាក់ទងនឹងបុព្វហេតុរបស់ពួកគេ នៅទីរួមខេត្តឆ្ងាយៗ។

ឧទាហរណ៍បែបនេះមិនមានន័យថា រដ្ឋាភិបាលជាតិ និងបរទេសមិនសំខាន់នោះទេ។ ផ្ទុយទៅវិញ គោលនយោបាយរបស់រដ្ឋាភិបាលជះឥទ្ធិពលលើប្រជាជនរាប់លាននាក់ កាន់តែលឿនជាងនិងកាន់តែទូលំទូលាយជាងការខិតខំប្រឹងប្រែងរបស់ថ្នាក់មូលដ្ឋាន។ ជាការពិតណាស់ ការរៀបចំនៅមូលដ្ឋាន ជារឿយៗមានគោលដៅចុងក្រោយគឺការរៀបចំរចនាសម្ព័ន្ធជីវិតនយោបាយនិងសង្គមជាតិឡើងវិញ ដើម្បីធ្វើអោយគោលនយោបាយឆ្លុះបញ្ចាំងពីតម្រូវការរបស់ប្រជាពលរដ្ឋក្រីក្រ។ ប៉ុន្តែ ភាពជោគជ័យនៃការផ្តល់សិទ្ធិអំណាចនៅមូលដ្ឋានបង្ហាញថា សហគមន៍ក្រីក្រអាចច្រើនជាងជនរងគ្រោះនៃភាពក្រីក្រ ដែលកំពង់រង់ចាំការសង្គ្រោះ ឬអ្នកនៅស្ងៀមយ៉ាងអកម្មនៅក្នុងទំនាក់ទំនងអឌ្ឍគោលខាងជើងនិងអឌ្ឍគោលខាងត្បូង។ ហើយអ្នកក្រក៏មិនត្រូវដាក់ក្តីសង្ឃឹមចង់បានការផ្លាស់ប្តូរ នៅក្នុងបដិវត្តន៍ពោរពេញដោយអំពើហិង្សា ដែលមានគោលបំណងផ្តួលរំលំរដ្ឋាភិបាលជាតិ។ ជាញឹកញាប់ បដិវត្តន៍នាំទៅរកទុក្ខធំ ជាងការអភិវឌ្ឍន៍សេដ្ឋកិច្ចដោយស្ថេរភាព។

រូបថត ស្ត្រីៗជួបពិភាក្សាគ្នាអំពីបញ្ហាអាជីវកម្មជាមួយក្រុម Oxfam នៅប្រទេសកេនយ៉ា

ដៃគូក្នុងការអភិវឌ្ឍន៍

គំរូជំនួយបរទេសរបស់អង្គការ Oxfam សង្កត់ធ្ងន់លើការគាំទ្រសម្រាប់ក្រុមដៃគូក្នុងស្រុក ដែលអាចជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ចដោយនិរន្តរភាពដោយខ្លួនឯងនៅកម្រិតមូលដ្ឋាន។ ភាពជាដៃគូរវាងអឌ្ឍគោលខាងជើងនិងអឌ្ឍគោលខាងត្បូង ដែលមានអត្ថប្រយោជន៍ទៅវិញទៅមក គឺជាគោលដៅសកលនៃគម្រោងបែបនេះ។ ស្ត្រីទាំងនេះជួបពិភាក្សាគ្នាអំពីបញ្ហាអាជីវកម្មជាមួយក្រុមដែលពាក់ព័ន្ធអង្គការ Oxfam នៅប្រទេសកេនយ៉ា ឆ្នាំ ២០០៧ ។

គំរូអង្គការOxfam រហូតមកដល់បច្ចុប្បន្ន ត្រូវបានសាកល្បងលើកម្រិតតូចៗប៉ុណ្ណោះ។ ទោះបីជាគំរូនេះអាចមានប្រសិទ្ធភាពនៅក្នុងសហគមន៍មូលដ្ឋាន ដែលវាទៅដល់ក៏ដោយ វាត្រូវតែអនុម័តអោយបានទូលំទូលាយនិងចម្លងគំរូនៅលើខ្នាតធំជាងនេះ ដើម្បីជះឥទ្ធិពលលើទស្សនៈវិស័យអភិវឌ្ឍន៍ទាំងមូល។ ក្នុងករណីជំនួយដល់អ្នករស់រានមានជីវិតពីរលកយក្សសូណាមិ ឆ្នាំ ២០០៤ វិភាគទានចំនួន ១២ លានដុល្លាររបស់អង្គការOxfam ប្រៀបធៀបនឹងចំនួនប្រហែល ៥០ ដងនៃចំនួនដែលបានសន្យាដោយរដ្ឋាភិបាលសហរដ្ឋអាមេរិក។ វានៅតែមិនច្បាស់ទេថាតើគោលការណ៍ដែលគំរូរួមបញ្ចូលពីការពឹងផ្អែកលើអ្នករៀបចំសហគមន៍មូលដ្ឋានរហូតដល់ការជៀសវាងពីការចូលរួមរបស់រដ្ឋាភិបាលនឹងដំណើរការក្នុងទ្រង់ទ្រាយធំដែរឬទេ។ គំរូមួយដែលឆ្លងកាត់រដ្ឋាភិបាលក៏ចៀសវាងប្រាក់ភាគច្រើន ដែលចំណាយសម្រាប់ជំនួយបរទេសនៅទូទាំងពិភពលោក។

អត្ថប្រយោជន៍មួយនៃការផ្តល់ជំនួយឯកជន ដូចអង្គការOxfam គឺភាពបត់បែនដែលវាអាចត្រូវបានផ្តល់អោយ។ អង្គការជំនួយឯកជនក៏អាចមានប្រសិទ្ធភាពជាង (ដោយសារទំហំតូចជាង) និងអាចបង្កើតភាពជាដៃគូជាមួយអ្នកទទួលក្នុងស្រុកបានប្រសើរជាងមុន។ ជាអកុសល កង្វះទំហំរបស់អង្គការជំនួយឯកជននិងនៅក្នុងហានៈផ្លូវការរបស់រដ្ឋាភិបាលក៏អាចជាគុណវិបត្តិផងដែរ។ ពួកគេអាចត្រូវបានហាមឃាត់មិនអោយចូលទៅក្នុងប្រទេសមួយ (ប្រទេសហ្ស៊ីមបាវ៉េបានបណ្តេញអង្គការក្រៅរដ្ឋាភិបាលឯកជនទាំងអស់ ក្នុងឆ្នាំ ២០០៨ ចំណែកប្រទេសហុងគ្រីពិភាក្សាអំពីច្បាប់ហាមឃាត់អង្គការក្រៅរដ្ឋាភិបាលដែលផ្តល់ជំនួយដល់ជនអន្តោប្រវេសន៍ក្នុងឆ្នាំ ២០១៨) ហើយពួកគេអាចមានការលំបាកក្នុងការផ្តល់ជំនួយសង្គ្រោះទ្រង់ទ្រាយធំ

ក្នុងគ្រាមានវិបត្តិ។ ពួកគេក៏អាចលើកកម្ពស់គោលនយោបាយអភិវឌ្ឍន៍ ដែលផ្ទុយនឹងគោលនយោបាយផ្ទាល់របស់រដ្ឋាភិបាល ដោយធ្វើអោយមានជម្លោះជាមួយរដ្ឋាភិបាលម្ចាស់ជំនួយផ្សេងទៀត។

១៣.៤.៣. នយោបាយនៃជំនួយបរទេស

រដ្ឋាភិបាលនិងអង្គការសង្គមស៊ីវិលជាច្រើនកំពុងផ្តល់ជំនួយអភិវឌ្ឍន៍ជាបន្តបន្ទាប់ ក្នុងទម្រង់ជាគម្រោងនៅក្នុងសហគមន៍មូលដ្ឋាននៅអឌ្ឍគោលខាងត្បូង ដែលគ្រប់គ្រងផ្ទាល់ដោយភ្នាក់ងារមកពីអឌ្ឍគោលខាងជើង ដើម្បីជួយបំពេញតម្រូវការជាមូលដ្ឋាន។ កម្មវិធីសប្បុរសធម៌បែបនេះគឺជាមធ្យោបាយមានប្រយោជន៍ ដែលប្រជាជននៅតំបន់អឌ្ឍគោលខាងជើងផ្តល់ជាធនធានដល់ប្រជាជននៅអឌ្ឍគោលខាងត្បូង ប៉ុន្តែពួកគេក៏អាចបង្កើតបញ្ហាដែលមិននឹកស្មានដល់។ ជាឧទាហរណ៍ កម្មវិធីភាគច្រើនមិនបាននិយាយអំពីមូលហេតុនៃភាពក្រីក្រ ដំហរប្រទេសក្រីក្រក្នុងតំបន់សេដ្ឋកិច្ចពិភពលោក ឬលក្ខខណ្ឌនយោបាយក្នុងស្រុក ដូចជាការគ្រប់គ្រងយោធា ឬអំពើពុករលួយជាដើម។ លើសពីនេះ រូបថតរបស់កុមារដែលស្រេកឃ្លានអាចសម្លឹងមើលអ្នកអាន ពីក្នុងទំព័រទស្សនាវដ្តី ខណៈពេលដែលអត្ថបទដែលភ្ជាប់មកជាមួយកត់សម្គាល់ថា ពីរបីសេនក្នុងមួយថ្ងៃអាច «សង្គ្រោះ» កុមារទាំងនោះបាន ហើយវិធីសាស្ត្របែបនេះអាចបង្កើនការយល់ដឹងនៅអឌ្ឍគោលខាងជើងអំពីវិសាលភាពនៃភាពក្រីក្រនៅក្នុងអឌ្ឍគោលខាងត្បូង ប៉ុន្តែ ពួកគេបែរជាត្រូវរងការកេងប្រវ័ញ្ចនិងប្រើប្រាស់ដើម្បីពង្រឹងទស្សនៈរើសអើងនិងការប្រកាន់ពូជសាសន៍ចំពោះមនុស្សនៅក្នុងអឌ្ឍគោលខាងត្បូង។

ជាងនេះទៅទៀត ទោះបីជាមានការលើកទឹកចិត្តសម្រាប់ជំនួយបរទេសដើម្បីជួយដល់អ្នកដែលមិនសូវមានសំណាងក៏ដោយ ក៏រដ្ឋម្ចាស់ជំនួយបានរកឃើញថា ជំនួយបរទេសក៏ជាឧបករណ៍សំខាន់សម្រាប់ជះឥទ្ធិពលលើរដ្ឋទទួលជំនួយផងដែរ។ ដូច្នេះ រដ្ឋម្ចាស់ជំនួយជាច្រើនព្យាយាមប្រើប្រាស់ប្រភេទជំនួយបរទេសមួយចំនួនដើម្បីបង្កើតការផ្លាស់ប្តូរសេដ្ឋកិច្ចនិងនយោបាយ នៅក្នុងប្រទេសទទួលជំនួយ។

ដូចរដ្ឋម្ចាស់ជំនួយស្ទើរតែទាំងអស់ដែរ សហរដ្ឋអាមេរិកប្រើប្រាស់ពាក្យសន្យាផ្តល់ជំនួយបរទេស ឬការគម្រាមកំហែងផ្តាច់ជំនួយ ដែលជាឥទ្ធិពលក្នុងការចរចានយោបាយជាមួយរដ្ឋអ្នកទទួល។ ជាឧទាហរណ៍ នៅពេលដែលប៉ាគីស្ថានបានបន្តកម្មវិធីអាវុធនុយក្លេអ៊ែរ នៅចុងទសវត្សរ៍ឆ្នាំ ១៩៨០ បើទោះបីជាមានការព្រមានពីសហរដ្ឋអាមេរិកក៏ដោយ លំហូរដ៏ធំនៃជំនួយរបស់សហរដ្ឋអាមេរិកត្រូវបានបញ្ចប់។ បន្ទាប់មកនៅពេលដែលប៉ាគីស្ថានបានគាំទ្រសកម្មភាពយោធារបស់សហរដ្ឋអាមេរិក នៅក្នុងប្រទេសអាហ្វហ្គានីស្ថានក្បែរនោះ ក្នុងឆ្នាំ ២០០១ ជំនួយរបស់សហរដ្ឋអាមេរិកត្រូវបានផ្តល់ឡើងវិញ។

ក្នុងឆ្នាំ ២០០៤ សហរដ្ឋអាមេរិកបានចាប់ផ្តើមកម្មវិធី «សាជីវកម្មប្រកួតប្រជែងសហស្សវត្សរ៍» (Millennium Challenge Corporation [MCC]) ដែលបង្កើនជំនួយរបស់សហរដ្ឋអាមេរិក ប៉ុន្តែសម្រាប់តែរដ្ឋាភិបាលដែលមានគោលនយោបាយមួយចំនួន ដូចជានីតិរដ្ឋ ការគ្រប់គ្រងអំពើពុករលួយ ការវិនិយោគក្នុងវិស័យអប់រំនិងការគ្រប់គ្រងសារពើពន្ធត្រឹមត្រូវ។ បន្ទាប់ពីអ្នកទទួលសក្តានុពលដាក់ពាក្យសុំជំនួយក្រុមប្រឹក្សាមួយដែលមានមន្ត្រីរដ្ឋាភិបាលនិងឯកជនពិនិត្យមើលពាក្យស្នើសុំ។ បន្ទាប់មក អ្នកដាក់ពាក្យសុំត្រូវបានពិនិត្យឡើងវិញ សម្រាប់ភាពសមស្របរបស់ពួកគេសម្រាប់ជំនួយ ដោយផ្អែកលើសំណុំនៃលក្ខណៈវិនិច្ឆ័យ ដែលបង្កើតឡើងដោយកម្មវិធីMCC។ តាមរបៀបនេះ សហរដ្ឋអាមេរិកសង្ឃឹមថានឹងកាត់បន្ថយជំនួយដែលបាត់បង់ក្នុងអំពើពុករលួយ និងការខ្ជះខ្ជាយ។

ប្រាកដណាស់ ជំនួយបរទេសក៏ជាដំណើរការនយោបាយក្នុងស្រុកដ៏ស្មុគស្មាញផងដែរ។ ជំនួយពីបរទេសអាចមិនជាទីពេញនិយមក្នុងចំណោមសាធារណៈជនមួយចំនួន ដែលមានអារម្មណ៍ថាប្រាក់ពន្ធរបស់ពួកគេនឹងទៅអោយអ្នកដែលនៅក្រៅប្រទេស ជាជាងអ្នកដែល«នៅក្នុងប្រទេស» (សូមមើលឧទាហរណ៍បន្ថែម មតិសាធារណៈនិងទំនាក់ទំនងអន្តរជាតិ)។ នេះអាចនាំអោយមានការទាមទារអោយផ្តល់តែប្រភេទជំនួយមួយចំនួនប៉ុណ្ណោះ។ ជាឧទាហរណ៍ ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ អ្នកតស៊ូមតិផ្នែកជំនួយនៅសហរដ្ឋអាមេរិកបានប្រយុទ្ធនឹងច្បាប់របស់សហរដ្ឋអាមេរិកដែលតម្រូវអោយអាហារដែលធ្វើទៅចិញ្ចឹមអ្នកស្រែកឃ្លានត្រូវបានដាំដុះនៅក្នុងសហរដ្ឋអាមេរិក និងដឹកជញ្ជូនតាមកប៉ាល់របស់សហរដ្ឋអាមេរិក។ ជំនួសអោយប្រព័ន្ធចែកចាយដ៏សាមញ្ញនេះ ពួកគេបានស្នើអោយប្រើប្រាស់មូលនិធិរបស់សហរដ្ឋអាមេរិក ដើម្បីទិញអាហារក្នុងស្រុកនៅក្នុងទ្វីបអាហ្វ្រិក ដែលនឹងជួយសន្សំប្រាក់បានច្រើន បញ្ជូនជំនួយដល់ប្រជាជនដែលស្រែកឃ្លានលឿនជាងមុនជាច្រើនខែ និងជួយកសិករអាហ្វ្រិក។ ប៉ុន្តែ សំណើនេះត្រូវបានជំទាស់ដោយអ្វីដែលហៅថា *ត្រីកោណដែក* នៃជំនួយស្បៀងអាហាររបស់សហរដ្ឋអាមេរិក ដែលជាក្រុមហ៊ុនធ្វើអាជីវកម្មកសិផលដែលចំណេញពីការលក់ស្បៀងអាហារដល់រដ្ឋាភិបាលក្រុមហ៊ុនដឹកជញ្ជូនរបស់សហរដ្ឋអាមេរិកដែលចំណេញពីការដឹកជញ្ជូនវា និងអង្គការសប្បុរសធម៌របស់សហរដ្ឋអាមេរិក (រួមទាំងអង្គការ CARE និងសេវាជំនួយសង្គ្រោះកាតូលិក[CRS]) ដែលផ្តល់មូលនិធិដល់ប្រភាគនៃថវិការបស់ពួកគេ ដែលមានសុខភាពល្អដោយលក់គ្រាប់ធញ្ញជាតិមួយចំនួននៅអាហ្វ្រិកដែលដឹកជញ្ជូនតាមកប៉ាល់ពីសហរដ្ឋអាមេរិកទៅ។ អង្គការសប្បុរសធម៌ តាមរយៈការក្លាយជាឈ្មួញគ្រាប់ធញ្ញជាតិអន្តរជាតិនិងពន្លិចទីផ្សារក្នុងស្រុកជាមួយនឹងស្បៀងអាហារថោកៗ (ទាំងលក់និងផ្តល់ដោយឥតគិតថ្លៃ) ត្រូវប្រកួតប្រជែងជាមួយកសិករក្នុងស្រុក និងជំរុញអោយតម្លៃក្នុងស្រុកចុះថោក ដែលបណ្តាលអោយប៉ះពាល់ដល់ការងើបសេដ្ឋកិច្ចជាតិឡើងវិញ ក្នុងរយៈពេលវែង។ ប៉ុន្តែ ដោយសារតែអំណាចបញ្ចុះបញ្ចូលរបស់ក្រុមត្រីកោណដែក សភាបានបញ្ឈប់សំណើដើម្បីអនុញ្ញាតអោយទិញស្បៀងអាហារក្នុងស្រុក នៅអាហ្វ្រិក។

ជំនួយបរទេសមួយប្រភេទ ដែលមានចរិតនយោបាយ*តិចតួចបំផុត* គឺជំនួយសង្គ្រោះបន្ទាន់គ្រាមានគ្រោះមហន្តរាយ។ វាជាជំនួយពីបរទេសដែលត្រូវផ្តល់អោយ នៅពេលដែលប្រជាពលរដ្ឋក្រីក្រជួបគ្រោះទុរ្ភិក្ស គ្រោះរាំងស្ងួត ការរញ្ជួយដី គ្រោះទឹកជំនន់ ឬគ្រោះធម្មជាតិផ្សេងៗទៀត។ (សង្គ្រាមក៏ជាគ្រោះមហន្តរាយដែរ ហើយអាចផ្សំជាគ្រោះមហន្តរាយដែលកើតឡើងដោយធម្មជាតិ។) នៅពេលដែលមានគ្រោះមហន្តរាយវាយប្រហាររដ្ឋក្រីក្រ មនុស្សជាច្រើនត្រូវបានទុកចោល ដោយគ្មានមធ្យោបាយចិញ្ចឹមជីវិត ហើយជារឿយៗគ្មានផ្ទះសម្បែងរបស់ពួកគេ។ **ការសង្គ្រោះបន្ទាន់គ្រាមានគ្រោះមហន្តរាយ** (disaster relief) គឺជាការផ្តល់ជំនួយសង្គ្រោះរយៈពេលខ្លី ដល់មនុស្សបែបនេះ ក្នុងទម្រង់ស្បៀងអាហារ ទឹក ទីជម្រក សម្លៀកបំពាក់ និងសម្ភារៈចាំបាច់ផ្សេងៗទៀត។

ការសង្គ្រោះបន្ទាន់គ្រាមានគ្រោះមហន្តរាយមានសារៈសំខាន់ខ្លាំងណាស់ ពីព្រោះគ្រោះមហន្តរាយអាចបំផ្លាញវឌ្ឍនភាពជាច្រើនឆ្នាំ ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងការវាយប្រហារតែម្តង។ ជាទូទៅ សហគមន៍អន្តរជាតិព្យាយាមឆ្លើយតបដោយមានជំនួយគ្រប់គ្រាន់ ដើម្បីអោយមនុស្សរឹងប៉ឹងឡើងវិញ។ ការចំណាយលើជំនួយបែបនេះមានតិចតួច ប៉ុន្តែអត្ថប្រយោជន៍ស្តែងចេញពិតៗ និងលទ្ធផលល្អ។ ការមានប្រព័ន្ធសង្គ្រោះ

គ្រោះមហន្តរាយផ្តល់អោយអង្គគោលខាងត្បូងនូវប្រភេទនៃការធានារ៉ាប់រង ដើម្បីទប់ទល់នឹងការខាតបង់ភ្លាមៗ ដែលអាចធ្វើអោយមានអស្ថិរភាពដល់ការប្រមូលផ្តុំសេដ្ឋកិច្ច។

គ្រោះមហន្តរាយជាទូទៅកើតឡើងយ៉ាងឆាប់រហ័សនិងដោយគ្មានការព្រមានទុកមុនឡើង។ ការឆ្លើយតបអោយបានឆាប់រហ័ស ពិបាកនឹងសម្របសម្រួល។ ការផ្តល់ជំនួយសង្គ្រោះគ្រោះមហន្តរាយអន្តរជាតិកាន់តែមានការរៀបចំបានល្អនិងមានការសម្របសម្រួលកាន់តែប្រសើរឡើង ក្នុងទសវត្សរ៍កន្លងមក ប៉ុន្តែវានៅតែជាដំណើរការដ៏ស្មុគស្មាញ ដែលប្រែប្រួលពីស្ថានភាពមួយទៅស្ថានភាពមួយទៀត។ ការរួមចំណែករបស់រដ្ឋាភិបាល អង្គការសប្បុរសធម៌ឯកជន និងក្រុម និងទីភ្នាក់ងារផ្សេងទៀត ត្រូវបានសម្របសម្រួលតាមរយៈ *ការិយាល័យអង្គការសហប្រជាជាតិនៃអ្នកសម្របសម្រួលជំនួយសង្គ្រោះគ្រោះមហន្តរាយ*(UNDRO) នៅក្នុងទីក្រុងហ្សឺណែវ។ ក្នុងឆ្នាំ ២០០៦ អង្គការសហប្រជាជាតិបានបង្កើតមូលនិធិដែលមានទំហំទឹកប្រាក់ ៥០០ លានដុល្លារដើម្បីអោយវាឆ្លើយតបយ៉ាងឆាប់រហ័សចំពោះគ្រោះមហន្តរាយ ដោយមិនចាំបាច់រង់ចាំការប្រមូលមូលនិធិជាមុន រៀងរាល់ពេលដែលមានគ្រោះមហន្តរាយកើតឡើង។ ជាធម្មតា ការរួមចំណែកជាអន្តរជាតិមានចំនួនមិនលើសពីមួយភាគបីនៃកិច្ចខិតខំប្រឹងប្រែងក្នុងការផ្តល់ជំនួយសង្គ្រោះសរុបនោះទេ ដែលនៅសេសសល់បានមកពីសហគមន៍មូលដ្ឋាន និងរដ្ឋាភិបាលជាតិ នៅក្នុងរដ្ឋដែលរងផលប៉ះពាល់។

ការសង្គ្រោះគ្រោះមហន្តរាយ គឺជាផលប្រយោជន៍រួមមួយ ពីព្រោះរដ្ឋអង្គគោលខាងជើងមិនទទួលបានអត្ថប្រយោជន៍ជាបុគ្គលរៀងៗខ្លួន ដោយការរួមវិភាគទាន ប៉ុន្តែ ពួកគេទទួលបានអត្ថប្រយោជន៍ច្រើនក្នុងរយៈពេលវែង ពីស្ថិរភាពកាន់តែល្អ នៅអង្គគោលខាងត្បូង។ ទោះបីជាមានបញ្ហាផលប្រយោជន៍រួមដែលមានសក្តានុពលជាមួយតួអង្គមួយចំនួនធំក៏ដោយ ការសង្គ្រោះគ្រោះមហន្តរាយជាទូទៅជាឧទាហរណ៍វិជ្ជមាននៃកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីសម្រេចបានការងារ និងជាឧទាហរណ៍នៃការប្រើប្រាស់គោលការណ៍អត្តសញ្ញាណដើម្បីដោះស្រាយបញ្ហាផលប្រយោជន៍រួម។ អាហារដែលផ្តល់ដោយក្រុមប្រឹក្សាពិភពលោកនៃព្រះវិហារអាចត្រូវបានដឹកទៅកាន់កន្លែងកើតហេតុនៅក្នុងយន្តហោះយោធាសហរដ្ឋអាមេរិក ហើយបន្ទាប់មកចែកចាយដោយសម្ព័ន*អន្តរជាតិគណៈកម្មាធិការកាកបាទក្រហម* (ICRC)។ ការបរាជ័យដ៏គួរអោយអាម៉ាស់ក្នុងអតីតកាល (ពីការឆ្លើយតបមិនគ្រប់គ្រាន់ ឬការឆ្លើយតបហួសហេតុ ការព្យាយាមស្នូនគ្នា ឬភ្នាក់ងារដែលធ្វើការក្នុងគោលបំណងឆ្លង) បានក្លាយជារឿងកម្រមាននៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ ហើយនៅក្នុងសតវត្សរ៍ទី ២១ ក្រុមសម្របសម្រួលសកម្មភាពរបស់ពួកគេកាន់តែមានប្រសិទ្ធភាព។

ការរញ្ជួយដីដ៏បំផ្លិចបំផ្លាញនៅប្រទេសហៃទីក្នុងឆ្នាំ ២០១០ បានបង្ហាញពីវឌ្ឍនភាព និងកម្រិតនៃកិច្ចខិតខំប្រឹងប្រែងសង្គ្រោះអន្តរជាតិ។ ក្នុងពេលត្រឹមមួយយប់ មនុស្សរាប់លាននាក់បានបាត់បង់សមាជិកគ្រួសារ ផ្ទះសម្បែង ទ្រព្យសម្បត្តិ ទឹកស្អាត និងជីវភាពរស់នៅ។ ដោយមិនមានដំណើរការរបស់រដ្ឋាភិបាល ឬប្រព័ន្ធថែទាំវេជ្ជសាស្ត្រ កិច្ចខិតខំប្រឹងប្រែងសង្គ្រោះបឋមមានភាពវឹកវរ និងយឺតយាវ ហើយជំនួយអន្តរជាតិមិនត្រូវបានសម្របសម្រួលយ៉ាងរលូនទេ។ ជនរងគ្រោះជាច្រើនបានស្លាប់ ដោយសារយន្តហោះបានគៀបពីលើអាកាសយានដ្ឋានតូច មិនអាចដឹកជញ្ជូនការផ្គត់ផ្គង់បាន។ ទោះយ៉ាងណាក៏ដោយ ប៉ុន្មានថ្ងៃមកនេះកងកម្លាំងយោធាអាមេរិកបានកាន់កាប់អាកាសយានដ្ឋាន ហើយជំនួយអន្តរជាតិយ៉ាងច្រើនបានហូរចូល។ រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលបានសន្យាផ្តល់ប្រាក់រាប់ពាន់លានដុល្លារ ដើម្បីជួយប្រទេសហៃទីស្តារប្រទេសឡើងវិញ ក្រោមការណែនាំរបស់អង្គការសហប្រជាជាតិ។

ទាំងអង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាល បានប្រមូលផ្តុំយ៉ាងឆាប់រហ័សដើម្បីអនុវត្តអ្វីដែលត្រូវបានគេហៅថា «កិច្ចប្រឹងប្រែងសង្គ្រោះដ៏ធំបំផុតក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ»។ កិច្ចខិតខំប្រឹងប្រែងរបស់អង្គការទាំងនេះត្រូវបានសម្របសម្រួល តាមរយៈភ្នាក់ងារផ្តល់ជំនួយជាច្រើន រួមទាំង ICRC អង្គការអន្តរជាតិសម្រាប់ចំណាកស្រុក ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន (UNHCR) និង អង្គការ Oxfam។ ដំបូង វាហាក់ដូចជាថាសហរដ្ឋអាមេរិក នឹងសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងសង្គ្រោះរបស់ខ្លួនដោយផ្ទាល់ ក្រៅពីរង្វង់អង្គការសហប្រជាជាតិ ប៉ុន្តែបន្ទាប់ពីការពិចារណាឡើងវិញ សហរដ្ឋអាមេរិកបានប្រគល់តួនាទីនាំមុខ ក្នុងការផ្តល់ជំនួយដល់អង្គការសហប្រជាជាតិ។ ការសម្របសម្រួលរលូន ចម្រុះដោយរដ្ឋ អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាល ហាក់ដូចជាផ្ទុយទៅនឹងប្រព័ន្ធអន្តរជាតិដ៏អនាធិបតេយ្យ។

ទំនាក់ទំនងរវាងគ្រោះមហន្តរាយ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចមានលក្ខណៈស្មុគស្មាញ ហើយការឆ្លើយតបសមស្របប្រែប្រួល អាស្រ័យតាមទីតាំង ប្រភេទ និងទំហំនៃគ្រោះមហន្តរាយ និងដំណាក់កាលនៃការស្តារឡើងវិញ។ គេត្រូវការធនធានផ្សេងៗគ្នា ក្នុងដំណាក់កាលសង្គ្រោះបន្ទាន់ (ឧទាហរណ៍ ស្បៀងអាហារ និងការផ្គត់ផ្គង់វេជ្ជសាស្ត្រ) ជាងក្នុងដំណាក់កាលសាងសង់ឡើងវិញ (ឧទាហរណ៍ ការជួសជុលលំនៅដ្ឋានដែលធន់នឹងការរញ្ជួយដី)។ ការឆ្លើយតបដែលមានទំហំតូចពេក ឬរយៈពេលខ្លីពេក អាចបរាជ័យក្នុងការបំពេញតម្រូវការសំខាន់ៗ ប៉ុន្តែអ្វីដែលធំពេក ឬយូរពេក អាចគ្របដណ្តប់លើសេដ្ឋកិច្ចក្នុងតំបន់ និងបង្កើតភាពអាស្រ័យលើកម្លាំងខាងក្រៅ (កាត់បន្ថយការលើកទឹកចិត្តអោយជួយខ្លួនឯង)។

បទដ្ឋានអន្តរជាតិកំពុងផ្លាស់ប្តូរ ទាក់ទងនឹងកាតព្វកិច្ចផ្លូវច្បាប់របស់រដ្ឋក្នុងការជួយរដ្ឋដទៃ ក្នុងគ្រាមានគ្រោះធម្មជាតិ និងទទួលយកជំនួយបែបនេះប្រសិនបើចាំបាច់ ។ អ្នកខ្លះថែមទាំងបានស្នើអោយពង្រីកគំនិតនៃការទទួលខុសត្រូវ ក្នុងការការពារដល់តំបន់សង្គ្រោះគ្រោះមហន្តរាយ។ គំនិតនេះមានការពាក់ព័ន្ធជាពិសេសបន្ទាប់ពីព្យុះស៊ីក្លូន Nargis ដែលបានវាយប្រហារប្រទេសភូមា ក្នុងឆ្នាំ ២០០៨។ មនុស្សប្រមាណ ១៣០០០០ នាក់ បានស្លាប់នៅក្នុងគ្រោះធម្មជាតិនោះ ប៉ុន្តែ រដ្ឋាភិបាលដែលគាបសង្កត់របស់ប្រទេសនេះបានពន្យារពេល ឬបដិសេធកិច្ចខិតខំប្រឹងប្រែងរបស់សហគមន៍អន្តរជាតិក្នុងការផ្តល់ជំនួយដល់អ្នកដែលរងផលប៉ះពាល់ដោយព្យុះស៊ីក្លូន។ ខណៈពេលដែលជំនួយបានចូលទៅក្នុងប្រទេសភូមានៅទីបំផុត ពេលវេលាច្រើនសប្តាហ៍ត្រូវបានខ្ជះខ្ជាយ ខណៈដែលរដ្ឋាភិបាលបានបដិសេធជំនួយដែលត្រូវការជាចាំបាច់សម្រាប់ទប់ទល់នឹងព្យុះស៊ីក្លូន។

១៣.៤.៤. ឥទ្ធិពលនៃជំនួយបរទេស

ក៏មានគ្រោះថ្នាក់ក្នុងការផ្តល់ជំនួយពីបរទេស ជាពិសេសនៅក្នុងកម្មវិធីជំនួយរបស់រដ្ឋាភិបាលក្នុងទ្រង់ទ្រាយធំដែលប្រជាជនមកពីអឌ្ឍគោលខាងជើង អាចនឹងផ្តល់ជំនួយមិនសមរម្យសម្រាប់លក្ខខណ្ឌនិងវប្បធម៌ ក្នុងស្រុករបស់ប្រទេសកំពុងអភិវឌ្ឍន៍។ គ្រោះថ្នាក់នេះត្រូវបានបង្ហាញដោយបទពិសោធន៍ នៅប្រទេសកេនយ៉ាក្នុងទសវត្សរ៍ឆ្នាំ ១៩៧០។ អ្នកចិញ្ចឹមសត្វនៅតំបន់បឹង Turkana ក្បែរវាលខ្សាច់សាហារ៉ា ដែលជាកុលសម្ព័ន្ធ Turkana មានភាពក្រីក្រនិងងាយរងគ្រោះនឹងគ្រោះរាំងស្ងួត ជាប្រចាំ។ ម្ចាស់ជំនួយលោកខាងលិច និងរដ្ឋាភិបាលកេនយ៉ាបានសម្រេចចិត្តថា របៀបរស់នៅបែបប្រពៃណីរបស់អ្នកចិញ្ចឹមសត្វមិនមាននិរន្តរភាពបរិស្ថានទេ ហើយគួរតែត្រូវបានជំនួសដោយការនេសាទត្រីទីឡាព្យ៉ា (tilapia) ដ៏សម្បូរបែបនៅក្នុងបឹង Turkana។ សម្រាប់នៅក្នុងប្រទេសនិរវេស ដោយមានបទពិសោធន៍យ៉ាងយូរក្នុងការនេសាទ ត្រូវបានគេស្នើ

សុំអោយបង្រៀនពីរបៀបនេសាទ និងការកសាងទូកទៅកាន់ ជនជាតិTurkana។ ដើម្បីបង្កើតសេដ្ឋកិច្ចក្នុងស្រុកប្រកបដោយនិរន្តរភាព អ្នកប្រឹក្សានំរវេសបានផ្តល់អនុសាសន៍អោយធ្វើទីផ្សារចំណិតសាច់ត្រីក្លាសេទៅកាន់ទីផ្សារប្រទេសកេនយ៉ា និងនៅក្នុងពិភពលោក។ ដូច្នេះហើយ នៅក្នុងឆ្នាំ ១៩៨១ ប្រទេសនំរវេសបានបញ្ចប់ការសាងសង់រោងចក្របង្កកត្រីដ៏ទំនើប តម្លៃ ២ លានដុល្លារ នៅលើមាត់ច្រាំងបឹង Turkana និងផ្លូវ ២០ លានដុល្លារ ដែលតភ្ជាប់រោងចក្រនេះទៅនឹងប្រព័ន្ធនៃការដឹកជញ្ជូនរបស់ប្រទេសកេនយ៉ា។

រូបថត ការផ្តត់ផ្តង់ទឹកខ្ពុរមាត់ដោយមិនគិតថ្លៃ ដោយឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក

ទឹកខ្ពុរមាត់សម្រាប់ប្រទេសម៉ូរីតានី

ពេលខ្លះ ជំនួយបរទេសបានរួមចំណែកជាទំនិញដល់សេដ្ឋកិច្ចប្រទេសតតិយលោក ដោយការយល់ដឹងតិចតួចអំពីតម្រូវការក្នុងស្រុក ឬយុទ្ធសាស្ត្ររយៈពេលវែង។ នៅទីនេះ ការផ្តត់ផ្តង់ដោយមិនគិតថ្លៃ រួមទាំងទឹកខ្ពុរមាត់ត្រូវបានផ្តល់ជូនដោយឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក និងប្រជានក្រុមនៃនាវិកងទ័ពជើងទឹកសហរដ្ឋអាមេរិក ដែលចូលរួមក្នុងគម្រោង Handclasp ឆ្នាំ ១៩៨៩។

មានបញ្ហាតែបីប៉ុណ្ណោះត្រូវបានលើកឡើង។ ទីមួយ ដោយមានសីតុណ្ហភាព ១០០ អង្សាដឺក្រេនៅខាងក្រៅ (ផ្ទុយពីប្រទេសនំរវេសទាំងស្រុង) ការចំណាយលើប្រតិបត្តិការម៉ាស៊ីនបង្កកលើសពីប្រាក់ចំណូលដែលបានមកពីការលក់សាច់ត្រី។ ដូច្នេះ ពីរបីថ្ងៃក្រោយមក ទូរបង្កកត្រូវបានបិទ ហើយកន្លែងនោះបានក្លាយជាឃ្លាំងត្រីងៀតដែលមានតម្លៃថ្លៃជ្រុលហួស។ ទីពីរ វប្បធម៌របស់ជនជាតិ Turkana បានចាត់ទុកការនេសាទជាអាជីពដែលមានឋានៈសង្គមទាបបំផុត ដែលសមរម្យសម្រាប់តែអ្នកដែលគ្មានសមត្ថភាពក្នុងការចិញ្ចឹមត្រី។ ទីបី រៀងរាល់ពីរបីទសវត្សរ៍ម្តង បឹង Turkana កាន់តែរួមតូច ដោយសារគ្រោះរាំងស្ងួតកាត់បន្ថយលំហូរទឹក។ គ្រោះរាំងស្ងួតបែបនេះ ក្នុងចន្លោះឆ្នាំ ១៩៨៤-១៩៨៥ បានលុបបំបាត់ឈូងសមុទ្រដែលទីតាំងប្រតិបត្តិការនេសាទ។ ជនជាតិនំរវេសប្រហែលជាអាចមើលឃើញបញ្ហាទាំងនេះ ប្រសិនបើបានស្រាវជ្រាវបន្ថែម ជាជាងគ្រាន់តែចម្លងអ្វីដែលអាចដំណើរការបានតែនៅក្នុងប្រទេសនំរវេស។ នៅពេលដែលគ្រោះរាំងស្ងួតកើតឡើង អ្នកចិញ្ចឹមហ្វូងសត្វពាហនៈ ចំនួន ២០០០០ នាក់ ត្រូវនៅម្តុំគ្នានៅមាត់បឹងដែលរួមកាន់តែតូច យ៉ាងកកកុញ ចំណែកវាលស្មៅក៏ត្រូវសឹករេចរឹល ដើមឈើត្រូវបានគេកាប់សម្រាប់ធ្វើអុស ហើយសត្វពាហនៈភាគច្រើនបានស្លាប់។ ជំនួសអោយការក្លាយជាមនុស្សគ្រប់គ្រាន់ ប្រជាជន Turkana បានពឹងផ្អែកទាំងស្រុងលើជំនួយពីខាងក្រៅ។

ក្នុងពេលប៉ុន្មានទសវត្សរ៍កន្លងមកនេះ អ្នកប្រាជ្ញជាច្រើនបានធ្វើការស្រាវជ្រាវដើម្បីស្វែងយល់ថាតើជំនួយបរទេសមានប្រសិទ្ធភាពក្នុងការបង្កើតកំណើនសេដ្ឋកិច្ចនិងការកាត់បន្ថយភាពក្រីក្រ នៅក្នុងអឌ្ឍគោលខាងត្បូងដែរឬទេ។ ការជជែកដេញដោលគ្នាយ៉ាងក្តៅគគុក នៅពេលនេះ បានកើតឡើងក្នុងចំណោមអ្នកសិក្សាស្រាវជ្រាវនិងអ្នកបង្កើតគោលនយោបាយអំពីថាតើជំនួយមានប្រសិទ្ធភាពហើយឬយ៉ាងណា ថាតើគួរផ្តល់អោយច្រើនឬតិចជាងមុន។ នៅជ្រុងម្ខាង អ្នកប្រាជ្ញស្នើអោយបង្កើនជំនួយពីបរទេស ដើម្បីកាត់បន្ថយវិសមភាពដែលកំពុងធ្លាក់ចុះរវាងអឌ្ឍគោលខាងជើងនិងអឌ្ឍគោលខាងត្បូង។ ដោយសារអឌ្ឍគោលខាងត្បូងមិនអាចរក្សានិរន្តរភាពនៃការប្រមូលផ្តុំមូលធនបាន ជំនួយពីអឌ្ឍគោលខាងជើងមានភាពចាំបាច់ដើម្បីចាប់ផ្តើមកំណើនសេដ្ឋកិច្ចក្នុងដំណាក់កាលដំបូង។

ទោះជាយ៉ាងណាក៏ដោយ ដោយប្រឆាំងនឹងជំហរនេះ ការសិក្សាស្រាវជ្រាវបានបង្ហាញថា ជំនួយមិនតែងតែជួយប្រទេសក្រីក្រអភិវឌ្ឍសេដ្ឋកិច្ចទេ។ ជាពិសេស លុះត្រាតែប្រទេសជាអ្នកទទួលមានស្ថាប័នរដ្ឋាភិបាលដែលមានការអនុវត្តអភិបាលកិច្ចល្អ បើមិនដូច្នេះទេជំនួយនឹងត្រូវខ្ជះខ្ជាយ ឬធ្លាក់ចូលហោប៉ៅមេដឹកនាំពុករលួយ។ ការស្រាវជ្រាវនេះគឺជាការបំផុសគំនិតសម្រាប់គោលនយោបាយ MCC របស់សហរដ្ឋអាមេរិក ក៏ដូចជាលក្ខខណ្ឌIMF បន្ថែមទៀត។

អ្នកវិះគន់ផ្សេងទៀតអំពីជំនួយ ផ្តល់យោបល់ថា ជាទូទៅ គួរតែកាត់បន្ថយជំនួយ ។ ពួកគេជំទាស់ថាលំហូរនៃជំនួយបានអនុញ្ញាតអោយមេដឹកនាំក្នុងរដ្ឋក្រីក្រជៀសវាងការផ្លាស់ប្តូរគោលនយោបាយ ដ៏លំបាកដែលនឹងត្រួសត្រាយផ្លូវសម្រាប់កំណើនសេដ្ឋកិច្ចក្នុងរយៈពេលវែង។ ពួកគេប្រកែកថា នៅក្នុងប្រទេសមួយចំនួននៅទ្វីបអាហ្វ្រិក ការបញ្ចូលជំនួយបរទេសយ៉ាងច្រើនបន្ទាប់ពីការធ្វើអាណានិគមបានដឹកនាំបង្កើនភាពក្រីក្រ និងការពឹងផ្អែកលើសប្បុរសធម៌ ជាជាងការបង្កើនទ្រព្យសម្បត្តិ និងឯករាជ្យភាពឬស្វ័យភាព។

ប្រឈមមុខនឹងគម្លាតអឌ្ឍគោលខាងជើង-ខាងត្បូង

ការផ្តល់និងការទទួលជំនួយបរទេសគឺជារឿងនយោបាយ ទោះបីជាការលើកទឹកចិត្តក្នុងការផ្តល់វាមិនមែនជារឿងនយោបាយក៏ដោយ។ ប្រហែលជាអ្វីដែលសំខាន់បំផុតនោះគឺថា ប្រជាជននៅអឌ្ឍគោលខាងជើងដឹងអំពីគម្លាតយ៉ាងខ្លាំងរវាងអឌ្ឍគោលខាងជើងនិងខាងត្បូង ហើយព្យាយាមដោះស្រាយបញ្ហានេះ។ ភាពក្រីក្រអាចមើលទៅមានច្រើនលើសលប់ ដែលពលរដ្ឋក្នុងប្រទេសអ្នកមានអាចនឹងព្រងើយកន្តើយដាក់ ហើយគ្រាន់តែព្យាយាមរស់នៅតាមសម្មាជីវៈរបស់ពួកគេតែប៉ុណ្ណោះ។

ប៉ុន្តែ ក្នុងពិភពលោកដែលអាស្រ័យលើគ្នាទៅវិញទៅមក នាពេលបច្ចុប្បន្ននេះ ការធ្វើដូច្នេះពិតជាមិនអាចទៅរួចនោះទេ។ ទំនាក់ទំនងអឌ្ឍគោលខាងជើងនិងអឌ្ឍគោលខាងត្បូងបានក្លាយជាផ្នែកមួយនៃជីវភាពរស់នៅប្រចាំថ្ងៃ។ សេដ្ឋកិច្ចសកលរួមគ្នាបាននាំទៅអឌ្ឍគោលខាងជើងនូវផលិតផលនិងមនុស្សពីអឌ្ឍគោលខាងត្បូង។ បដិវត្តន៍ព័ត៌មានបង្ហាញរូបភាពនៃភាពក្រីក្រនៅលើកញ្ចក់ទូរទស្សន៍នៅក្នុងបន្ទប់គេងដែលមានផាសុកភាព។ ទំនាក់ទំនងសន្តិសុខនិងសេដ្ឋកិច្ចនយោបាយក៏ដូចគ្នាដែរ បានផ្លាស់ប្តូរនៅក្នុងយុគសម័យក្រោយសង្គ្រាមត្រជាក់ ដើម្បីផ្តល់ភាពល្បីល្បាញថ្មីដល់អឌ្ឍគោលខាងត្បូង។

សេចក្តីសន្និដ្ឋាន

១. ការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅអឌ្ឍគោលខាងត្បូងមានកម្រិតមិនស្មើគ្នា។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ប្រទេសក្រីក្រជាច្រើនបានរីកចម្រើនខ្លាំង ជាពិសេសប្រទេសចិន។ កំណើនសេដ្ឋកិច្ចនៅអឌ្ឍគោលខាងត្បូងមានភាពរឹងមាំ បន្ទាប់ពីវិបត្តិសេដ្ឋកិច្ចឆ្នាំ ២០០៨-២០០៩ ប៉ុន្តែថ្មីៗនេះបានធ្លាក់ចុះ។

២. ភ័ស្តុតាងមិនបានគាំទ្រអំណះអំណាងថា កំណើនសេដ្ឋកិច្ចបានមកពីសមភាពផ្នែកក្នុងសម្រាប់ការបែងចែកទ្រព្យសម្បត្តិ ឬ ជាមួយនឹងវិសមភាពផ្នែកក្នុងនោះទេ។

៣. ប្រទេសឧស្សាហកម្មថ្មី(NICs)នៅអាស៊ី (កូរ៉េខាងត្បូង តៃវ៉ាន់ ហុងកុង និងសិង្ហបុរី)បង្ហាញថា គេអាចងើបចេញពីភាពក្រីក្រ ឆ្ពោះទៅរកការប្រមូលផ្តុំសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព។

៤. ប្រទេសចិនបានកត់ត្រាកំណើនសេដ្ឋកិច្ចដ៏រឹងមាំក្នុងរយៈពេល៣០ឆ្នាំចុងក្រោយនៃកំណែទម្រង់សេដ្ឋកិច្ច ដែលផ្តោតលើទីផ្សារ។ ទោះបីនៅជាប្រទេសក្រីក្រ ដោយគិតលើមូលដ្ឋានចំណូលសម្រាប់មនុស្សម្នាក់ៗ ចិនគឺជាប្រទេសជោគជ័យឈានមុខគេ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច លើពិភពលោក។

៥. កំណើនសេដ្ឋកិច្ចដោយការនាំចេញបានក្លាយជាយុទ្ធសាស្ត្រអភិវឌ្ឍន៍ពេញនិយម ជំនួសកំណើនដោយជំនួសការនាំចូល។ នេះឆ្លុះបញ្ចាំងពីបទពិសោធន៍របស់NICs និងប្រទេសចិន ក៏ដូចជា ទ្រឹស្តីនៃគុណសម្បត្តិផៀប។

៦. ទ្រឹស្តីដែលថាក្រោយការធ្វើលទ្ធិប្រជាធិបតេយ្យនឹងមានការពង្រឹងការអភិវឌ្ឍន៍សេដ្ឋកិច្ច មិនត្រូវបានគាំទ្រដោយបទពិសោធន៍ជាក់ស្តែងនៃប្រទេសក្រីក្រនោះទេ។ ប៉ុន្តែទ្រឹស្តីផ្ទុយមួយ ដែលថាគេត្រូវការរដ្ឋាភិបាលផ្តាច់ការជាចាំបាច់ដើម្បីរក្សាការគ្រប់គ្រងខណៈពេលកំពុងប្រមូលផ្តុំដើមទុន សម្រាប់ឧស្សាហូបនីយកម្ម ក៏មិនត្រូវបានគាំទ្រដែរ។

៧. អំពើពុករលួយរបស់រដ្ឋាភិបាលគឺជាឧបសគ្គចម្បងចំពោះការអភិវឌ្ឍន៍នៅទូទាំងអឌ្ឍគោលខាងត្បូង។

៨. ដោយសារកង្វះដើមទុនក្នុងស្រុក នៅក្នុងរដ្ឋក្រីក្រភាគច្រើន ការវិនិយោគបរទេសដោយ MNCs អាចជាមធ្យោបាយជំរុញកំណើនសេដ្ឋកិច្ច។ MNCs ស្វែងរកលក្ខខណ្ឌក្នុងស្រុកអំណោយផល រួមទាំងស្ថិរភាពនយោបាយនិងសេដ្ឋកិច្ច នៅក្នុងការសម្រេចចិត្តថាតើត្រូវវិនិយោគឬអត់។

៩. បំណុលជាតិ ដែលកើតឡើងភាគច្រើនបានមកពីការខ្ចីប្រាក់លើសលុប ក្នុងទសវត្សរ៍ឆ្នាំ ១៩៧០ និងដើមទសវត្សរ៍ឆ្នាំ ១៩៨០ គឺជាបញ្ហាចម្បងមួយ នៅក្នុងអឌ្ឍគោលខាងត្បូង។ តាមរយៈការចរចាឡើងវិញ និងកិច្ចខិតខំប្រឹងប្រែងគ្រប់គ្រងបំណុលផ្សេងទៀត អឌ្ឍគោលខាងជើងនិងខាងត្បូងបានធ្វើអោយស្ថានភាពបំណុលមានភាពប្រសើរឡើងក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ។ ទោះជាយ៉ាងណាក៏ដោយ អឌ្ឍគោលខាងត្បូងនៅតែជំពាក់បំណុលអឌ្ឍគោលខាងជើង ប្រហែល ៦ ទ្រីលានដុល្លារ។

១០. មូលនិធិ IMF បានផ្តល់ប្រាក់កម្ចីដល់រដ្ឋនានានៅអឌ្ឍគោលខាងត្បូង ដោយភ្ជាប់លក្ខខណ្ឌ កំណែទម្រង់សេដ្ឋកិច្ចនិងរដ្ឋាភិបាល។ លក្ខណ្ឌនៃកិច្ចព្រមព្រៀងទាំងនេះ ជារឿយៗ ត្រូវការវិធានការណ៍នយោបាយដែលមិនពេញនិយម ដូចជាការកាត់ប្រាក់ឧបត្ថម្ភស្បៀងអាហារជាដើម។

១១. របបពាណិជ្ជកម្មរបស់អង្គការ WTO ហាក់ធ្វើការប្រឆាំងនឹងអឌ្ឍគោលខាងត្បូង ដោយអនុញ្ញាតអោយប្រទេសអ្នកមានការពារវិស័យដែលអឌ្ឍគោលខាងត្បូងមានគុណសម្បត្តិផៀប ជាពិសេសវិស័យកសិកម្មនិងវាយនភណ្ឌ។ ប្រព័ន្ធអនុគ្រោះទូទៅ(GSP)ព្យាយាមកង្វល់នេះដោយការបន្ថយរបាំងសម្រាប់ការនាំចេញពីអឌ្ឍគោលខាងត្បូង។

១២. ជំនួយបរទេសដែលភាគច្រើនមកពីរដ្ឋាភិបាលនៅអឌ្ឍគោលខាងជើង ដើរតួយ៉ាងសំខាន់ក្នុងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចនៃរដ្ឋក្រីក្រនៅអឌ្ឍគោលខាងត្បូង។

១៣. នៅអឌ្ឍគោលខាងជើង មានតែរដ្ឋមួយចំនួនប៉ុណ្ណោះដែលសម្រេចបាននូវគោលដៅរួមវិភាគទាន ០.៧ ភាគរយនៃ GNPs របស់ពួកគេ សម្រាប់ជាជំនួយបរទេសដល់អឌ្ឍគោលខាងត្បូង។

១៤. ជំនួយបរទេសភាគច្រើនរួមមានជំនួយទ្វេភាគី និងប្រាក់កម្ចីពីរដ្ឋាភិបាលនៅអឌ្ឍគោលខាងជើង ទៅដល់រដ្ឋាភិបាលណាមួយនៅអឌ្ឍគោលខាងត្បូង។ ជំនួយបែបនេះ ជារឿយៗត្រូវបានប្រើប្រាស់សម្រាប់ជាឥទ្ធិពលនយោបាយ និងលើកកម្ពស់ការនាំចេញផលិតផលពីរដ្ឋម្ចាស់ជំនួយ។

15. ម្ចាស់ជំនួយនៅអឌ្ឍគោលខាងជើង ប្រើប្រាស់គំរូជំនួយផ្សេងៗដើម្បីចែកចាយជំនួយដល់ប្រទេសកំពុងអភិវឌ្ឍន៍ ដែលនីមួយៗមានគុណសម្បត្តិ និងគុណវិបត្តិរៀងៗខ្លួន។

ពាក្យគន្លឹះ

១. **ការអភិវឌ្ឍន៍សេដ្ឋកិច្ច** (economic development) គឺជាដំណើរការរួមគ្នានៃការប្រមូលផ្តុំមូលធនកំណើនប្រាក់ចំណូលសម្រាប់មនុស្សម្នាក់ៗ (ជាមួយនឹងការថយចុះនៃអត្រាកំណើត) ការកើនឡើងនៃជំនាញក្នុងចំណោមប្រជាជន ការទទួលយកបច្ចេកវិទ្យាថ្មី និងការផ្លាស់ប្តូរសង្គមនិងសេដ្ឋកិច្ចដែលពាក់ព័ន្ធផ្សេងទៀត។

២. **ប្រទេសឧស្សាហកម្មថ្មី** (newly industrializing countries- NICs) សំដៅលើប្រទេសតតិយលោកដែលសម្រេចបាននូវការប្រមូលផ្តុំដើមទុនដោយនិរន្តរភាពដោយខ្លួនឯង ជាមួយនឹងកំណើនសេដ្ឋកិច្ចដែលគួរអោយចាប់អារម្មណ៍។ ជោគជ័យបំផុតគឺ «ខ្លាបួន» ឬ «នាគបួន»នៃអាស៊ីបូព៌ា៖ កូរ៉េខាងត្បូង តៃវ៉ាន់ ហុងកុង និងសិង្ហបុរី។

៣. **«ខ្លាបួន»ឬ«នាគបួន»** ("four tigers"/"four dragons") គឺជា តំបន់ឧស្សាហកម្មថ្មីដែលជោគជ័យបំផុតនៃអាស៊ីបូព៌ា៖ កូរ៉េខាងត្បូង តៃវ៉ាន់ ហុងកុង និងសិង្ហបុរី។

៤. **កំណើនដោយជំនួសការនាំចូល** (import substitution) គឺជាយុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍ឧស្សាហកម្មក្នុងស្រុក ដែលជារឿយៗ ធ្វើឡើងនៅពីក្រោយគោលនយោបាយគាំពារដើម្បីផលិតទំនិញដែលប្រទេសមួយបាននឹងកំពុងនាំចូល។

៥. **កំណើនដោយការនាំចេញ** (export-led growth) គឺជាយុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ចដែលព្យាយាមអភិវឌ្ឍន៍ឧស្សាហកម្មដែលមានសមត្ថភាពប្រកួតប្រជែងក្នុងទីផ្សារ ជាពិសេស ក្នុងសេដ្ឋកិច្ចទីផ្សារពិភពលោក។

៦. **ឥណទានខ្នាតតូច ឬមីក្រីក្រេឌីត** (microcredit) គឺជា ការប្រើប្រាស់ប្រាក់កម្ចីតិចតួចបំផុតដល់ក្រុមបុគ្គលតូចៗ ជារឿយៗ ជាស្ត្រី ដើម្បីជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ច(គ្រួសារ)។

៧. **ការផ្ទេរបច្ចេកវិទ្យា** (technology transfer) គឺជាការដែលប្រទេសតតិយលោកទទួលបានបច្ចេកវិទ្យា (ចំណេះដឹង ជំនាញ វិធីសាស្ត្រ រចនា ឧបករណ៍ឯកទេស ជាដើម) ពីប្រភពបរទេស ជាធម្មតារួមជាមួយការវិនិយោគបរទេសផ្ទាល់ ឬប្រតិបត្តិការអាជីវកម្មស្រដៀងគ្នា។

៨. **ការបែកគំនិត** (brain drain) គឺជាស្ថានភាពរបស់ប្រទេសក្រីក្រត្រូវបាត់បង់កម្មករជំនាញទៅប្រទេសអ្នកមាន ម្លោះហើយត្រូវបាត់បង់ធនធានមនុស្សកសាងជាតិខ្លួន។

៩. **ការក្ស័យធន** (default) គឺជាបរាជ័យក្នុងការទូទាត់បំណុលតាមកាលវិភាគកំណត់។

១០. **ការចរចារប្រាក់បំណុលឡើងវិញ** (debt renegotiation) គឺជាដំណើរការចរចាលក្ខខណ្ឌសម្រាប់សងប្រាក់កម្ចី ចរចារញឹកញាប់ដោយរដ្ឋាភិបាលកូនបំណុលតតិយលោក ដើម្បីជៀសវាងកុំអោយខកខាន។

១១. **ក្លឹបប៉ារីស** (Paris Club) គឺជាក្រុមនៃរដ្ឋាភិបាលបស្ចឹមលោក ដែលបានផ្តល់ប្រាក់កម្ចីទៅរដ្ឋាភិបាលតតិយលោក ដោយជួបជាទៀងទាត់ដើម្បីដោះស្រាយលក្ខខណ្ឌនៃការចរចាបំណុលឡើងវិញ។

១២. **ក្លឹបឡុងដ៏** (London Club) គឺជា ក្រុមនៃម្ចាស់បំណុលឯកជនដែលបានផ្តល់ប្រាក់កម្ចី ទៅរដ្ឋាភិបាលតតិយលោក ដោយជួបជាទៀងទាត់ដើម្បីដោះស្រាយលក្ខខណ្ឌនៃការចរចាបំណុលឡើងវិញ។

១៣. **លក្ខ័ណ្ឌមូលនិធិIMF** (IMF conditionality) គឺជាកិច្ចព្រមព្រៀងផ្តល់ប្រាក់កម្ចីដោយមូលនិធិ IMF ក្នុងលក្ខខណ្ឌដែលគោលនយោបាយរដ្ឋាភិបាលមួយចំនួនត្រូវបានអនុម័ត។ រដ្ឋតតិយលោករាប់សិបប្រទេសបានចូលរួមក្នុងកិច្ចព្រមព្រៀងបែបនេះជាមួយមូលនិធិIMF ក្នុងរយៈពេលពីរទសវត្សរ៍កន្លងមកនេះ។ សូមមើល *មូលនិធិរូបិយវត្ថុអន្តរជាតិ* (IMF) ផងដែរ។

១៤. **ជំនួយបរទេស** (foreign assistance) គឺជា ប្រាក់កម្ចីឬជំនួយផ្សេងសម្រាប់រដ្ឋតតិយលោក ដើម្បីជួយពួកគេបង្កើនល្បឿននៃការអភិវឌ្ឍន៍សេដ្ឋកិច្ច ឬបំពេញតម្រូវការមនុស្សធម៌។ ជំនួយបរទេសភាគច្រើនត្រូវបានផ្តល់ដោយរដ្ឋាភិបាល ហើយត្រូវបានគេហៅថា ជំនួយអភិវឌ្ឍន៍ជាផ្លូវការ (ODA)។

១៥. **គណៈកម្មការជំនួយអភិវឌ្ឍន៍**(Development Assistance Committee- DAC) គឺជាគណៈកម្មាធិការដែលមានសមាជិក ដូចជារដ្ឋមកពីអឺរ៉ុបខាងលិច អាមេរិកខាងជើងនិងអាស៊ី ផ្តល់ ៩៥ ភាគរយនៃជំនួយអភិវឌ្ឍន៍ផ្លូវការដល់ប្រទេសនានានៅអឌ្ឍគោលខាងត្បូង។

១៦. **ជំនួយទ្វេភាគី** (bilateral aid) គឺជាជំនួយរបស់រដ្ឋាភិបាលដែលផ្តល់ដោយផ្ទាល់ដល់រដ្ឋាភិបាលប្រទេសតតិយលោក ជាជំនួយពីរដ្ឋមួយទៅរដ្ឋមួយទៀត។

១៧. **ជំនួយពហុភាគី** (multilateral aid) គឺជា ជំនួយបរទេសរបស់រដ្ឋាភិបាលពីរដ្ឋមួយចំនួនដែលឆ្លងកាត់ភាគីទីបី ដូចជាអង្គការសហប្រជាជាតិ ឬទីភ្នាក់ងារផ្សេងទៀត។

១៨. **កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ** (UN Development Program- UNDP) គឺជាកម្មវិធីដែលសម្របសម្រួលលំហូរនៃជំនួយអភិវឌ្ឍន៍ពហុភាគី និងគ្រប់គ្រងគម្រោងចំនួន ៦០០០ ក្នុងពេលតែមួយជុំវិញពិភពលោក (ផ្តោតជាពិសេសលើជំនួយអភិវឌ្ឍន៍បច្ចេកទេស)។

១៩. **ទីភ្នាក់ងារ Peace Corps** គឺជាអង្គការមួយត្រូវបានផ្តួចផ្តើមដោយប្រធានាធិបតី ចន កេណ្ណឺឌី ក្នុងឆ្នាំ ១៩៦១ ដែលផ្តល់អ្នកស្ម័គ្រចិត្តសហរដ្ឋអាមេរិកសម្រាប់ជាជំនួយអភិវឌ្ឍន៍ក្នុងផ្នែកបច្ចេកទេសនៅក្នុងប្រទេសតតិយលោក។

២០. **អង្គការអុកស្វាមអាមេរិក** (Oxfam America) គឺជាក្រុមសប្បុរសធម៌ឯកជនដែលធ្វើការជាមួយសហគមន៍ប្រទេសតតិយលោកក្នុងតំបន់ ដើម្បីកំណត់តម្រូវការរបស់ប្រជាជនរបស់ពួកគេ និងអនុវត្តគម្រោងអភិវឌ្ឍន៍។ អង្គការOxfam មិនបានដំណើរការគម្រោងនេះផ្ទាល់ទេ ប៉ុន្តែផ្តល់មូលនិធិដល់អង្គការក្នុងស្រុកដើម្បីអនុវត្តគម្រោង។

២១. **ជំនួយសង្គ្រោះបន្ទាន់គ្រាមានគ្រោះមហន្តរាយ** (disaster relief) គឺជា ការផ្តល់ជំនួយសង្គ្រោះរយៈពេលខ្លីក្នុងទម្រង់ជាអាហារ ទឹក ទីជម្រក សម្លៀកបំពាក់ និងសម្ភារៈចាំបាច់ផ្សេងទៀតដល់ប្រជាជនដែលប្រឈមមុខនឹងគ្រោះមហន្តរាយធម្មជាតិផ្សេងៗ។

សំណួរអនុវត្តន៍

១. តើកំណើនសេដ្ឋកិច្ចរឹងមាំរបស់បណ្តាប្រទេសឧស្សាហកម្មថ្មី(NICs) នៅអាស៊ី និងប្រទេសចិន អាចប៉ះពាល់ដល់សំណើបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ី ស្រដៀងនឹងNAFTA និងEU យ៉ាងដូចម្តេច? តើអ្វីអាចជាផលប្រយោជន៍និងការព្រួយបារម្ភរបស់ជប៉ុន របស់ចិន និង របស់NICs និងរបស់រដ្ឋក្រីក្រក្នុងតំបន់ អំពីសំណើរៀបចំបែបនេះ?

២. ដោគជ័យកន្លងមកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចបានពឹងផ្អែកយ៉ាងខ្លាំងទៅលើការអភិវឌ្ឍមូលដ្ឋានគ្រឹះនៃផលិតកម្មដែលត្រូវការដើមទុនដែលគេខ្វះខាត។ តើអ្នកគិតថាបដិវត្តព័ត៌មាន និងតួនាទីកាន់តែខ្លាំងឡើងនៃសេវាកម្ម នៅក្នុងសេដ្ឋកិច្ចពិភពលោក កំពុងផ្លាស់ប្តូរគំរូនេះដែរឬទេ? តើបទពិសោធន៍របស់ប្រទេសឥណ្ឌាឆ្លុះបញ្ចាំងអ្វីខ្លះអំពីលទ្ធភាពនៃការស្វែងរកទីផ្សារ ពិសេស នៅក្នុងសេដ្ឋកិច្ចពិភពលោក ដែលកំពុងរីកចម្រើននេះ ហើយប្រហែលជាវ៉ាហួសផលិតកម្ម?

៣. ចូរប្រៀបធៀបបញ្ហាបំណុលនៅអឌ្ឍគោលខាងត្បូង ជាមួយបំណុលសហរដ្ឋអាមេរិក ដែលត្រូវបានពិភាក្សាក្នុងមេរៀនទី ៩ ដោយផ្តោតលើទំហំនិងផលវិបាករបស់បំណុលនីមួយៗ។ តើបញ្ហាបំណុលទាំងពីរកើតឡើងដោយបុព្វហេតុស្រដៀងគ្នាឬ? តើបញ្ហាមួយណាដែលអ្នកគិតថាធ្ងន់ធ្ងរជាង? ហេតុអ្វី?

៤. អ្នកប្រាជ្ញខ្លះរិះគន់មូលនិធិ IMF ថាបានជាក់លក្ខខណ្ឌតឹងតែងក្នុងកិច្ចព្រមព្រៀងលក្ខខណ្ឌរបស់ខ្លួនជាមួយរដ្ឋក្រីក្រ។ អ្នកផ្សេងទៀតអបអរសាទរមូលនិធិIMF ដែលទាមទារកំណែទម្រង់ស៊ីជម្រៅមុនពេលផ្តល់ធនធានហិរញ្ញវត្ថុ។ ប្រសិនបើអ្នកជាមេដឹកនាំដែលកំពុងចរចាជាមួយមូលនិធិIMF តើលក្ខខណ្ឌអ្វីខ្លះដែលអ្នកអាចនឹងយល់ព្រម ហើយតើលក្ខខណ្ឌអ្វីខ្លះដែលអ្នកនឹងត្រូវជំទាស់? ហេតុអ្វី?

៥. ប្រសិនបើរដ្ឋនានានៅអាមេរិកខាងជើង អឺរ៉ុបខាងលិច និងអាស៊ីបូព៌ា បានសំរេចគោលដៅក្នុងការផ្តល់ជំនួយបរទេស ដោយចំណាយ ០,៧ ភាគរយនៃ GNP តើវានឹងមានសម្រេចបានផលអ្វីខ្លះ? តើគួរបន្ថែមជំនួយប៉ុន្មានទៀត? តើវាទំនងជាបានទៅដល់អ្នកណាខ្លះ? តើវាអាចជះឥទ្ធិពលអ្វីខ្លះដល់រដ្ឋអ្នកទទួលនិងការអភិវឌ្ឍសេដ្ឋកិច្ចជាទូទៅ?

ការស្វែងរកផលប្រយោជន៍រួម

ជំនួយតាមរយៈអង្គការយូនីសេហ្វ

ផលប្រយោជន៍រួម៖ ប្រាក់ជំនួយជួយដល់កុមារក្រីក្រជុំវិញពិភពលោក

សារតារ

កុមារនៅលើពិភពលោក ចំនួនមនុស្ស ២ ពាន់លាននាក់ដែលមានអាយុក្រោម ១៨ ឆ្នាំ មានតម្រូវការមនុស្សធម៌ជាពិសេស។ ពិភពលោកនាពេលអនាគតត្រូវអាស្រ័យលើពួកគេ ប៉ុន្តែពួកគេស្ថិតក្នុងចំណោមក្រុមមនុស្សដែលងាយរងគ្រោះបំផុតក្នុងសង្គមរបស់ពួកគេ ហើយងាយរងគ្រោះពីការស្លាប់ដោយសារជំងឺនានា។ កុមារភាគច្រើនក្នុងពិភពលោករស់នៅក្នុងអឌ្ឍគោលខាងត្បូង រួមទាំងចំនួនដ៏ច្រើនរស់នៅ ក្នុងភាពក្រីក្រធ្ងន់ធ្ងរ ក្នុងប្រទេសក្រីក្របំផុត។

សហគមន៍អន្តរជាតិបានដោះស្រាយតម្រូវការរបស់កុមារ តាមរយៈទីភ្នាក់ងារនានាសម្រាប់មនុស្សធម៌ សុខភាពសាធារណៈ និងជំនួយអភិវឌ្ឍន៍សេដ្ឋកិច្ច ជាពិសេសតាមរយៈមូលនិធិកុមាររបស់អង្គការសហប្រជាជាតិ (UNICEF)។ មនុស្សជាតិបានទទួលយកអត្ថប្រយោជន៍ទាំងនេះគ្រប់ៗគ្នា ដោយមិនគិតពីថាតើ

នរណាជាអ្នកចូលរួមបរិច្ចាគ ហើយចូលប៉ុន្មាននោះទេ។ យ៉ាងណាក៏ដោយ ប្រសិនបើមានការព្រងើយកន្តើយច្រើនពេក អង្គការយូនីសេហ្វនឹងខ្វះធនធាន ហើយកុមារក្រក្សត់ក៏នឹងខ្វះដែរ។

បញ្ហាប្រឈម

ក្នុងឆ្នាំ ២០១៥ អង្គការសហប្រជាជាតិបានអនុម័តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព(SDG) សម្រាប់ការកាត់បន្ថយភាពក្រីក្រ នៅក្នុងអឌ្ឍគោលខាងត្បូង។ SDGs ជាច្រើនផ្តោតទៅលើកុមារ ហើយអង្គការយូនីសេហ្វគឺជាអ្នកចូលរួមក្នុងដំណើរការស្នូល។ គោលដៅដែលមានមហិច្ឆតាធំនេះ ត្រូវបានគេសន្មត់ថានឹងសម្រេចបាននៅឆ្នាំ ២០៣០ ដោយទុករយៈពេលអោយពិភពលោក ១៥ ឆ្នាំដើម្បីកែលម្អជីវិតរបស់កុមារនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ ហើយខណៈពេលដែល ១៥ ឆ្នាំចុងក្រោយនេះត្រូវបានគេមើលឃើញថាមានការរីកចម្រើនគួរអោយកត់សម្គាល់ គឺការធ្វើអោយប្រសើរឡើងនូវជីវិតរបស់កុមារនោះ នៅមានការងារជាច្រើនទៀតដែលគេត្រូវធ្វើ។ នៅអឌ្ឍគោលខាងត្បូង ប្រហែល ២២ ភាគរយនៃកុមារមានទម្ងន់មិនគ្រប់ពោលគឺធ្លាក់ចុះពី ៣១ ភាគរយ នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ ប៉ុន្តែនៅតែធ្ងាយពីការសម្រេចគោលដៅ SDG ។ នៅក្នុងការចុះឈ្មោះចូលរៀនកម្រិតបឋមសិក្សា អឌ្ឍគោលខាងត្បូងបានកើនឡើងពី ៨២ ទៅ ៩១ ភាគរយ ប៉ុន្តែកុមារជិត ៦០ លាននាក់ នៅតែមិនបានចូលរៀន។

ដំណោះស្រាយ

គោលការណ៍គ្រប់គ្រងមិនបានជួយដល់កុមារក្នុងពិភពលោក ដែលស្ថិតក្នុងឋានានុក្រមទាបបំផុតនៅលើពិភពលោក។ អង្គការយូនីសេហ្វក៏មិនមានអំណាចគ្រប់គ្រាន់ទាក់ទងនឹងករណីកិច្ចនៃកាតព្វកិច្ចចំពោះគ្នាទៅវិញទៅមក និងការត្រួតពិនិត្យការប្តេជ្ញាចិត្តដែលមាននៅក្នុងអង្គការដែលផ្អែកលើគោលការណ៍បដិការដូចជាអង្គការ WTO ជាដើម។ ផ្ទុយទៅវិញ អង្គការយូនីសេហ្វពឹងផ្អែកលើការរួមវិភាគទានដោយស្ម័គ្រចិត្ត ក្នុងនោះ ពីរភាគបីបានពីរដ្ឋាភិបាលនានា និងមួយភាគបីទៀតបានពីមូលនិធិ អង្គការក្រៅរដ្ឋាភិបាល និងបុគ្គលឯកជន។ គោលការណ៍អត្តសញ្ញាណអាចប្រព្រឹត្តិទៅបានល្អក្នុងស្ថានភាពនេះ ពីព្រោះមនុស្សទាំងអស់ក្នុងពិភពលោកធ្លាប់ជាកុមារ ហើយអាចកំណត់អត្តសញ្ញាណខ្លួនជាមួយកុមារបាន។

ដើម្បីបង្ហាញពីអត្តសញ្ញាណនេះ អង្គការយូនីសេហ្វ បានចាប់ផ្តើមយុទ្ធនាការមួយនៅឆ្នាំ ១៩៥០ ដែលហៅថា ជាភាសាអង់គ្លេសថា «Trick or Treat for UNICEF» ដែលអាចមានន័យប្រហាក់ប្រហែលជាភាសាខ្មែរថា «ជំនួយសម្រាប់យូនីសេហ្វ» ។ ខណៈពេលដែលសិស្សសាលាអាមេរិក ដើរគោះទ្វារផ្ទះអ្នកស្រុកដើម្បីសុំស្តរគ្រាប់ (ឬត្រូវបន្លាច) នៅថ្ងៃបុណ្យហាឡូវីន (Halloween) ជារៀងរាល់ឆ្នាំ ពួកគេក៏ឆ្លៀតរៃអង្គាសប្រាក់សម្រាប់វិភាគទានដល់អង្គការយូនីសេហ្វ ក្នុងប្រអប់ក្រដាសកាតុងពណ៌ទឹកក្រូចផងដែរ។ បច្ចុប្បន្នយុទ្ធនាការរៃអង្គាសប្រាក់បានជិត ៥ លានដុល្លារក្នុងមួយឆ្នាំ។ អ្វីដែលសំខាន់ជាងនេះទៅទៀត វាបានពង្រឹងទំនាក់ទំនងអត្តសញ្ញាណរបស់ជនជាតិអាមេរិកជាមួយអង្គការយូនីសេហ្វ ក្នុងរយៈពេលជាច្រើនទស្សវត្សរ៍ ដោយបានជួយកៀងគរវិភាគទានជិត ២០ លានដុល្លារបន្ថែមទៀតពីមូលនិធិ និងជំនួយរបស់សហរដ្ឋអាមេរិកក៏ដូចជា ១៣០ លានដុល្លារពីសភាសហរដ្ឋអាមេរិក។ ម្ចាស់ជំនួយកំពូលទាំងបួនដល់អង្គការយូនីសេហ្វបន្ទាប់ពីសហរដ្ឋអាមេរិក គឺប្រទេសន័រវេស ហូឡង់ ចក្រភពអង់គ្លេស និងស៊ុយអែត ដែលសុទ្ធជាប្រទេសដែលជំនួយមនុស្សធម៌គឺជាធាតុផ្សំដ៏រឹងមាំនៃអត្តសញ្ញាណជាតិរបស់ពួកគេ។

មតិសាធារណៈ និងទំនាក់ទំនងអន្តរជាតិ

នយោបាយជំនួយបរទេស

នៅសហរដ្ឋអាមេរិក ប្រហែលជាគ្មានប្រធានបទនយោបាយការបរទេសណាមួយត្រូវបានជជែកដេញដោលច្រើនជាងប្រធានបទជំនួយបរទេសទេ។ អ្នកតស៊ូមតិអះអាងថា ជំនួយចាំបាច់ដើម្បីផ្តល់ទំនិញជាមូលដ្ឋាន (អាហារ និងទីជម្រក) ដល់ប្រទេសក្រីក្រ និងជាតម្រូវការខាងសីលធម៌នៃគោលនយោបាយការបរទេស។ អ្នកប្រឆាំងបានតបតថា លុយជំនួយជាច្រើនត្រូវបានខ្ជះខ្ជាយដោយរដ្ឋាភិបាលពុករលួយ ហើយថាលុយអាចនឹងត្រូវចំណាយកាន់តែប្រសើរជាង នៅក្នុងរង្វង់ព្រំដែនប្រទេសម្ចាស់ជំនួយ។ តាមពិត ការជជែកវែកញែកអំពីជំនួយនេះ ឆ្លុះបញ្ចាំងនៅក្នុងកម្រិតកើនឡើងនិងការធ្លាក់ចុះនៃជំនួយបរទេស ដែលសហរដ្ឋអាមេរិកបានផ្តល់អោយ ជាបន្តបន្ទាប់ (សូមមើលក្រាហ្វិក ១៣.៦)។ ពេលក្រុមអ្នកតស៊ូមតិគ្រប់គ្រងសភា នាំអោយថវិកា (ជំនួយ)កាន់តែធំ តែត្រូវជំនួសដោយអ្នកប្រឆាំង ដែលនឹងកាត់បន្ថយការចំណាយលើជំនួយ។

ដោយសារតែប្រធានបទនៃជំនួយបរទេសមានភាពចម្រូងចម្រាសខ្លាំង ការស្ទង់មតិជាច្រើនត្រូវបានធ្វើឡើង ដោយសាកសួរសាធារណជនអាមេរិកអំពីទស្សនៈពួកគេចំពោះជំនួយបរទេស។ ក្រាហ្វិក ១៣.៧ បង្ហាញទិន្នន័យនៃការស្ទាបស្ទង់មតិ ដែលសួរអំពីកម្រិតនៃជំនួយបរទេស ចន្លោះឆ្នាំ ១៩៧០ និង ២០១៧។ ការស្ទង់មតិទាំងនេះសួរអ្នកឆ្លើយថាតើកម្រិតជំនួយបរទេសបច្ចុប្បន្នប្រហែលសមល្មម តិចពេក ឬច្រើនពេក។

ពេញមួយទសវត្សរ៍ឆ្នាំ ១៩៧០ និង ១៩៨០ ប្រជាជនអាមេរិកភាគច្រើនជឿជាក់ថាជំនួយបរទេសហាក់ដូចជាមានកម្រិតខ្ពស់ពេក។ ចម្លើយតបទូទៅតិចបំផុត គឺថា សហរដ្ឋអាមេរិកបានផ្តល់ជំនួយតិចតួចពេក។ និន្នាការនេះបានចាប់ផ្តើមផ្លាស់ប្តូរ បន្ទាប់ពីឆ្នាំ ១៩៩០ ទោះបីជាប្តូរយ៉ាងយឺតក៏ដោយ។ អ្នកដែលជឿថា ថវិកាជំនួយបរទេសរបស់អាមេរិកខ្ពស់ពេក បានថយចុះកាន់តែលឿន ខណៈពេលដែលអ្នកដែលជឿថាថវិកាជំនួយសមល្មមហើយ ឬតិចតួចពេក បានកើនឡើង។ ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ អ្នកឆ្លើយតបថាពួកគេជឿថាសហរដ្ឋអាមេរិកផ្តល់ជំនួយបរទេសច្រើនពេកបានឈានដល់កម្រិតទាបថ្មី។ ទោះជាយ៉ាងណាក៏ដោយ ប្រជាជនអាមេរិកស្ទើរតែភាគច្រើនបញ្ចេញមតិបែបនេះ។

តើអ្វីដែលជាកត្តាជម្រុញទស្សនៈអវិជ្ជមានចំពោះកម្រិតជំនួយបរទេស ក្នុងចំណោមមតិសាធារណៈអាមេរិក? ចម្លើយចម្បងគឺជំនឿមិនត្រឹមត្រូវរបស់សាធារណជនអំពីទំហំនៃថវិកាជំនួយបរទេស។ នៅពេលធ្វើការស្ទង់មតិអំពីចំនួនថវិកាសរុបរបស់រដ្ឋាភិបាលត្រូវបានផ្តល់អោយប្រទេសផ្សេងទៀត ក្នុងជំនួយបរទេសចម្លើយជាមធ្យម គឺ ២០ ភាគរយ។ តែតាមការពិត ថវិកាជាតិប្រហែល ១ ភាគរយតែប៉ុណ្ណោះ បានទៅដល់ជំនួយបរទេស។

តើនឹងមានអ្វីកើតឡើង ប្រសិនបើជនជាតិអាមេរិកកាន់តែច្រើនដឹងពីកម្រិតពិតនៃជំនួយបរទេស? នៅក្នុងការស្ទង់មតិសាធារណៈចំនួនពីរ ឆ្នាំ ២០១៦ នៅពេលដែលអ្នកឆ្លើយតបត្រូវបានជូនដំណឹងអំពីតួលេខ ១ ភាគរយ ចំនួនអ្នកដែលឆ្លើយថា«ច្រើនពេក» បានថយចុះមកត្រឹម ២៦ ភាគរយ។ ឬអាចនិយាយម្យ៉ាងទៀតថាប្រហែលពាក់កណ្តាលនៃប្រជាជនដែលជំទាស់នឹងជំនួយបរទេសអាចផ្លាស់ប្តូរគំនិតរបស់ពួកគេប្រសិនបើពួកគេដឹងពីការពិតជុំវិញទំហំនៃថវិកាជំនួយ។


ជាការពិតណាស់ រដ្ឋមន្ត្រីការបរទេសអាមេរិកមួយចំនួន បានកត់សម្គាល់ថា ក្រសួងការបរទេសបានបើកកិច្ចខិតខំប្រឹងប្រែងកាន់តែប្រសើរឡើង ក្នុងការអប់រំសាធារណៈជនអំពីកម្រិតជំនួយបរទេស។ នេះអាច

បង្ហាញពីការធ្លាក់ចុះចំនួនជនជាតិអាមេរិកដែលឆ្លើយតបថា ថវិកា«ច្រើនពេក»ត្រូវបានចំណាយលើជំនួយបរទេស ដែលបង្ហាញក្នុងក្រាហ្វិក ១៣.៧ ។ មិនមានអ្វីត្រូវសង្ស័យឡើយថា កត្តាផ្សេងទៀតក៏អាចដើរតួនាទីបានដែរ ប៉ុន្តែក៏មានការសង្ស័យតិចតួចដែរថា ជំនួយបរទេសនឹងបន្តក្លាយជាការបែងចែកនយោបាយក្នុងគោលនយោបាយការបរទេស។

ក្រាហ្វិក ១៣.៧ ទិដ្ឋភាពលើកម្រិតជំនួយបរទេសនៅសហរដ្ឋអាមេរិកចាប់តាំងពីឆ្នាំ ១៩៧១

ប្រភព៖ មជ្ឈមណ្ឌលស្រាវជ្រាវមតិសាធារណៈ Roper ឆ្នាំ ២០១៧

កម្រិតជំនួយបរទេស...



ខ្សែកោងកណ្តាល៖ សមល្មម *ខ្សែកោងក្រោម៖*តិចពេក *ខ្សែកោងលើ៖*ច្រើនពេក

ឧស្សាន:ឥស័យគោលនយោបាយ

ប្រធានាធិបតីឥណ្ឌូនេស៊ី លោក ចូកូ វីដូដូ (Joko Widodo)

បញ្ហា៖ តើអ្នកថ្លឹងថ្លែងតុល្យភាពរវាងការទាមទាររបស់តួអង្គក្នុងស្រុក និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិដោយរបៀបណា?

សាវតារ

ចូរស្រមៃថាអ្នកគឺជាប្រធានាធិបតីនៃប្រទេសឥណ្ឌូនេស៊ី។ សេដ្ឋកិច្ចរបស់អ្នកបានរងគ្រោះយ៉ាងខ្លាំងនៅក្នុងវិបត្តិហិរញ្ញវត្ថុអាស៊ីឆ្នាំ ១៩៩៧ ប៉ុន្តែចាប់តាំងពីពេលនោះមក អ្នកបានជួបប្រទះនឹងកំណើនសេដ្ឋកិច្ចដ៏រឹងមាំឡើងវិញ រហូតបានឆ្លងផុតវិបត្តិហិរញ្ញវត្ថុសកលឆ្នាំ ២០០៨-២០០៩ ទៀតផង។ កំណើន ផ.ស.ស. ប្រចាំឆ្នាំមានកម្រិតប្រហែល ៥ ភាគរយ ចាប់តាំងពីឆ្នាំ ២០០៣។ ការនាំចេញវត្ថុធាតុដើមរួមផ្សំបានជា ផ្នែកដ៏សំខាន់មួយនៃសេដ្ឋកិច្ចរបស់អ្នក។ នៅក្នុងទិដ្ឋភាពជាទូទៅ អង្គការអន្តរជាតិបានសរសើរភាពជោគជ័យផ្នែកសេដ្ឋកិច្ចរបស់អ្នក ក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ។

យ៉ាងណាក៏ដោយ ផ្នែកមួយនៃសេដ្ឋកិច្ចរបស់អ្នកត្រូវបានរិះគន់យ៉ាងខ្លាំង។ នោះគឺជាកម្រិតនៃការគាំពារនៃសេដ្ឋកិច្ច ដែលមិនត្រឹមតែសម្រាប់ការការពារពាណិជ្ជកម្មប៉ុណ្ណោះទេ ប៉ុន្តែក៏មានបទប្បញ្ញត្តិប្រឆាំង

នឹងការវិនិយោគផ្ទាល់ពីបរទេស(FDI)ផងដែរ។ ឥណ្ឌូនេស៊ីមានបទប្បញ្ញត្តិខ្លាំងបំផុតមួយចំនួនដែលសម្រាប់ការពារក្រុមហ៊ុននៅក្នុងប្រទេសរបស់អ្នក ពីការទទួលយកការវិនិយោគពីក្រៅប្រទេស។ ច្បាប់ជាច្រើនទាំងនេះត្រូវបានបង្កើតឡើងដើម្បីការពារអាជីវកម្មដែលគ្រប់គ្រងដោយគ្រួសារ ដែលមានទំនាក់ទំនងល្អប្រសើរ (រួមទាំងទំនាក់ទំនងជាមួយអតីតប្រធានាធិបតី)។ ច្បាប់បានធានានូវពីការជ្រៀតជ្រែកមកពីខាងក្រៅអោយមានកំរិតតិចតួចបំផុតនៅក្នុងឧស្សាហកម្មទាំងនោះ ខណៈច្បាប់ទាំងនោះបានធានានូវប្រាក់ចំណេញសម្រាប់អ្នកដែលមានអំណាចខាងផ្នែកនយោបាយច្រើនជាង។

មូលនិធិIMF និងក្រុមហ៊ុនវិនិយោគឯកជន បានរិះគន់យ៉ាងខ្លាំងលើការរឹតត្បិតលើ FDI ខាងលើ។ រហូតដល់ឆ្នាំ ២០១៧ ដែលជាក្រុមហ៊ុនវាយតម្លៃសញ្ញាប័ណ្ណដ៏សំខាន់មួយបានបដិសេធមិនដំឡើងចំណាត់ថ្នាក់សញ្ញាប័ណ្ណរបស់អ្នក ម្យ៉ាងដោយសារការរឹតបន្តឹងលើការវិនិយោគបរទេស។ នៅពេលដែលបានបង្កើនការវាយតម្លៃរបស់អ្នក ការវិនិយោគផលប័ត្រ (ផ្សារភាគហ៊ុនឥណ្ឌូនេស៊ី) នឹងកើនឡើងដែរ។

ការពិចារណាក្នុងស្រុក

អ្នកគឺជាប្រធានាធិបតីដ៏មានប្រជាប្រិយភាពមួយរូប ហើយបានទទួលជោគជ័យក្នុងការធ្វើកំណែទម្រង់សេដ្ឋកិច្ចមួយចំនួន សូម្បីតែការដកចេញនូវកម្មវិធីដ៏ពេញនិយម ដូចជាការឧបត្ថម្ភធនប្រេង។ ទោះជាយ៉ាងណាក៏ដោយ មូលដ្ឋាននៃការគាំទ្រគណបក្សរបស់អ្នកបានមកពីក្រុមគ្រួសារ និងក្រុមហ៊ុន ដែលមានទំនាក់ទំនងល្អ ដែលទទួលបានអត្ថប្រយោជន៍ពីការវិនិយោគនិងការការពារពាណិជ្ជកម្ម។ ដូច្នេះ គណៈបក្សរបស់អ្នកគាំទ្រចំពោះការរឹតបន្តឹងការវិនិយោគ។

ការដាក់កំហិតលើការវិនិយោគទាំងនេះក៏មានប្រជាប្រិយភាពគួរសម ក្នុងចំណោមប្រជាជន។ នៅក្នុងក្រសែភ្នែកសាធារណៈច្បាប់រារាំង«ការជ្រៀតជ្រែកពីបរទេស»ជាមួយសេដ្ឋកិច្ចរបស់អ្នក មិនថាជ្រៀតជ្រែកពីអង្គការដូចជាមូលនិធិIMF ឬពីអ្នកវិនិយោគខាងក្រៅនៅក្នុងប្រទេសចិន និងសហរដ្ឋអាមេរិក។ អ្នកនឹងត្រូវឈរឈ្មោះបោះឆ្នោតឡើងវិញ នៅឆ្នាំ ២០១៩ ដូច្នេះ ការទទួលបានការគាំទ្រដ៏ពេញនិយមសម្រាប់អ្នកនិងគណបក្ស នឹងមានសារៈសំខាន់ ជាពិសេសនាពេលអនាគតដ៏ខ្លីខាងមុខនេះ។

សេណារីយ៉ូ


ឥឡូវនេះ ចូរស្រមៃថាសង្គ្រាមពាណិជ្ជកម្មសកលដែលកំពុងកើនឡើង (ដែលបានចាប់ផ្តើមដំបូងរវាងសហរដ្ឋអាមេរិកនិងចិន) បង្កអោយសេដ្ឋកិច្ចអ្នកមានការធ្លាក់ចុះយ៉ាងខ្លាំង។ សេដ្ឋកិច្ចរបស់អ្នកកំពុងជួបការលំបាក ហើយអ្នកចាប់ផ្តើមមានឱនភាពថវិកានិងឱនភាពពាណិជ្ជកម្មសំខាន់ៗ។ អ្នកងាកទៅរកមូលនិធិIMF ដើម្បីកម្ចីសង្គ្រោះបន្ទាន់ ដើម្បីជួយដំនះគ្រាលំបាក។ មូលនិធិ IMF និយាយថា ខ្លួនមានឆន្ទៈក្នុងការជួយប៉ុន្តែថា ជាលក្ខខណ្ឌនៃកម្ចីថ្មីណាមួយ អ្នកត្រូវលុបចោលបទប្បញ្ញត្តិលើការវិនិយោគបរទេស។ ដោយសារពេលនេះប្រទេសរបស់អ្នកកំពុងត្រូវការជើមទុនបរទេស មូលនិធិIMFនឹងទាមទារការផ្លាស់ប្តូរនេះមុនពេលផ្តល់ប្រាក់កម្ចីដ៏សំខាន់។ ហើយដោយសារតែ មូលនិធិIMF តាមដានការប្តេជ្ញាចិត្តរបស់កម្មវិធីអស់រយៈពេលជាច្រើនឆ្នាំបន្ទាប់ពីការផ្តល់ប្រាក់កម្ចី ការផ្លាស់ប្តូរបទប្បញ្ញត្តិណាមួយនឹងត្រូវបន្តដំណើរការក្នុងរយៈពេលជាច្រើនឆ្នាំបន្តទៀត។

ចូរជ្រើសរើសគោលនយោបាយរបស់អ្នក

តើអ្នកនឹងបន្តរបន្តយច្បាប់វិនិយោគរបស់អ្នក ដើម្បីលើកទឹកចិត្ត FDI កាន់តែច្រើនឬយ៉ាងណា? តើអ្នកប្រជុំយប្រថានជាមួយប្រតិកម្មនយោបាយក្នុងស្រុកចំពោះចំណាត់ការនេះ ដែលនឹងធ្វើអោយអ្នកគាំទ្រសំខាន់ៗប្រឆាំងនឹងអ្នកវិញដែរឬទេ? តើអ្នកសង្ឃឹមថា វិបត្តិសេដ្ឋកិច្ចពិភពលោកនឹងបញ្ចប់ក្នុងពេលឆាប់ៗ ហើយសេដ្ឋកិច្ចរបស់អ្នកនឹងប្រសើរឡើង ដោយខ្លួនឯងដែរឬទេ? តើអ្នកជាក់ឥណ្ឌាណេស៊ីអោយឯកោពីលំហូរមូលធនបន្ថែម ដែលអាចជួយបង្កើនកំណើនសេដ្ឋកិច្ចដែរឬទេ?

ក្រាហ្វិកស្តីអំពីជំនួយអភិវឌ្ឍន៍ផ្លូវការសរុប និងជំនួយផ្លូវការទទួលបាន ២០១៩

ជំនួយអភិវឌ្ឍន៍ផ្លូវការសរុប(ODA) រួមមានការផ្តល់ប្រាក់កម្ចីដែលធ្វើឡើងតាមលក្ខខណ្ឌសម្បទាន (ការសងប្រាក់ដើមសរុប) និងជំនួយដោយភ្នាក់ងារផ្លូវការ នៃសមាជិកនៃគណៈកម្មាធិការជំនួយអភិវឌ្ឍន៍ (DAC) ដោយស្ថាប័នពហុភាគី និងដោយប្រទេសមិនមែន DAC ។ (គិតជាដុល្លារអាមេរិក)។



តោះ! សាកល្បងពិភាក្សាអំពីបញ្ហាជាក់ស្តែង

ជំនួយបរទេស៖ ជាដំណោះស្រាយសម្រាប់ការអភិវឌ្ឍន៍ ឬជាប្រភពនៃបញ្ហា?

ទិដ្ឋភាពទូទៅ

ជំនួយបរទេសរាប់ពាន់លានដុល្លារក្នុងមួយឆ្នាំៗ បានហូរចេញពីប្រទេសអភិវឌ្ឍន៍ទៅកាន់ប្រទេសកំពុងអភិវឌ្ឍន៍។ ទោះជាយ៉ាងណាក៏ដោយ ដូចដែលបានពិភាក្សានៅក្នុងមេរៀននេះ បរិមាណនៃជំនួយបរទេសពីគណៈកម្មាធិការជំនួយអភិវឌ្ឍន៍(DAC) មានការប្រែប្រួលយ៉ាងខ្លាំង ពីមួយឆ្នាំទៅមួយឆ្នាំ។ នៅពេលគេវាស់ស្ទង់ជាភាគរយនៃ ផលិតផលក្នុងស្រុករបស់ប្រទេសDAC បរិមាណនៃជំនួយបរទេសបានធ្លាក់ចុះជាលំដាប់ ក្នុងរយៈពេល ៤ ទសវត្សកន្លងមក។ ទោះយ៉ាងណាក៏ដោយ នៅពេលគេវាស់ស្ទង់ដោយចំនួន

ដាច់ខាត ជាប្រាក់ដុល្លារ ចំនួនទឹកប្រាក់បានកើនឡើង។ តើការបរិចាគសម្រាប់ពេលបច្ចុប្បន្នដោយប្រទេស DAC មានលក្ខណៈគ្រប់គ្រាន់ដែរឬទេ?

ជំនួយបរទេសមិនមែនមកពីDAC បានកើនឡើងជាប្រាក់ដុល្លារក្នុងចំនួនដាច់ខាត។ ទីភ្នាក់ងារពហុភាគី(ដូចជាធនាគារវិនិយោគនិងអង្គការសហប្រជាជាតិ) ផ្តល់ជាង ៤០ ប៊ីលានដុល្លារដល់អឌ្ឍគោលខាងត្បូង។ សម្រាប់ក្រុមម្ចាស់ជំនួយឯកជនមកពីប្រទេស DAC នៅពេលនេះ បានផ្តល់ជំនួយជិត ៥០ ប៊ីលានដុល្លារផងដែរសម្រាប់ជួយដល់ជនក្រីក្រ។

ថ្មីៗនេះ ភាពចម្រូងចម្រាសមួយបានកើតឡើងទាក់ទងនឹងសំណួរថា តើត្រូវផ្តល់ជំនួយចំនួនប៉ុន្មាន? អ្នកសេដ្ឋកិច្ច និងឥស្សរជននយោបាយលេចធ្លោមួយចំនួនបានអំពាវនាវអោយមានការបង្កើនជំនួយបរទេសអោយបានច្រើនដែលផ្តល់ដោយប្រទេស DAC ដែលមានទំហំធំជាងការកើនឡើងយ៉ាងច្រើន បន្ទាប់ពីការវាយប្រហារថ្ងៃ១១ កញ្ញា «៩/១១» ។ ទោះជាយ៉ាងនេះក្តី មានអ្នកខ្លះសង្ស័យពីចេតនានៃសកម្មភាពនេះ។ ខណៈពេលដែលអ្នកខ្លះមានមន្ទិលសង្ស័យ មិនចាំបាច់អំពាវនាវអោយមានការបន្តយជំនួយពីបរទេស ពួកគេអះអាងថា ការបង្កើនកម្រិតនៃជំនួយបរទេសនឹងមិនអាចជួយអោយសម្រេចបាននូវគោលដៅចុងក្រោយនៃជំនួយភាគច្រើននោះទេ ដែលជា ការអភិវឌ្ឍសេដ្ឋកិច្ច។ តើប្រទេស DAC គួរតែ បង្កើនថវិកាជំនួយបរទេសរបស់ពួកគេអោយបានច្រើនពិតប្រាកដ? តើការបង្កើនជំនួយបែបនេះនឹងជួយ ឬគ្រាន់ជាឧបសគ្គរារាំងដល់ការអភិវឌ្ឍន៍?

អំណះអំណាង ១

ប្រទេស DAC គួរតែបង្កើនជំនួយបរទេសអោយបានច្រើន

ជំនួយបរទេសអាចជួយដោះស្រាយបញ្ហាសំខាន់ៗ។

តាំងពីវិបត្តិថែទាំសុខភាព ការជួសជុលហេដ្ឋារចនាសម្ព័ន្ធ និងកម្មវិធីអក្ខរកម្ម រហូតដល់ជំនួយស្បៀងអាហារ ជំនួយបរទេសអាចមានសារៈសំខាន់ដើម្បីជួយរដ្ឋក្រីក្រចាប់ផ្តើមដំណើរការអភិវឌ្ឍន៍។ កម្រិតខ្ពស់នៃជំនួយនឹងបង្កើនគុណភាពជីវិតសម្រាប់មនុស្សរាប់លាននាក់ ដែលរស់នៅក្នុងភាពក្រីក្រនៅបរទេស។

ការបង្កើនជំនួយបរទេសនឹងបង្កើនសុចន្នៈ។

នៅពេលដែលសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុបប្រកួតប្រជែងដណ្តើមឥទ្ធិពលជាមួយប្រទេសចិននៅទីតាំងដូចជានៅអាហ្វ្រិក និងអាមេរិកឡាទីន ការបង្កើនជំនួយបរទេសនឹងបង្កើតទំនាក់ទំនងសេដ្ឋកិច្ចនយោបាយ និងសង្គមកាន់តែស្អិតរមួយរវាងប្រទេស DAC និងរដ្ឋអ្នកទទួល ដែលអាចរារាំងប្រទេសចិនពីការទទួលបានសម្ព័ន្ធមិត្តនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។

ជំនួយបរទេសកាន់តែច្រើននឹងបង្កើនសន្តិសុខលោកខាងលិច។

តាមរយៈការផ្តល់ប្រាក់និងធនធានផ្សេងទៀត ដើម្បីធ្វើស្ថិរភាពប្រទេសក្រីក្រ បណ្តាប្រទេស DAC កាត់បន្ថយឱកាសដែលមនុស្សគ្រប់រូបដែលរងផលប៉ះពាល់នៅក្នុងប្រទេសទាំងនោះ នឹងបន្ទោសលោកខាងលិចចំពោះបញ្ហារបស់ពួកគេ។ ការអាក់អន់ចិត្តនេះជារឿយៗនាំអោយមានអាកប្បកិរិយានិងមនោសញ្ចេតនាប្រឆាំងនឹងលោកខាងលិច ក្នុងករណីធ្ងន់ធ្ងរបំផុត ពួកគេអាចនឹងគាំទ្រអំពើភេរវកម្ម។

អំណះអំណាង ២

បណ្តាប្រទេស DAC មិនគួរបង្កើនជំនួយបរទេសគួរច្រើនពេកទេ។

ជំនួយបរទេសមួយចំនួនធំត្រូវបានប្រើប្រាស់យ៉ាងខ្ជះខ្ជាយ ឬត្រូវលួចបន្លំ។

អ្នកសេដ្ឋកិច្ចមួយចំនួនបានប៉ាន់ប្រមាណថា ក្នុងករណីខ្លះ កញ្ចប់ជំនួយពាក់កណ្តាលត្រូវបានលួចដោយមេដឹកនាំពុករលួយ ឬមន្ត្រីរដ្ឋាភិបាល ចំណែកករណីផ្សេងទៀត ជំនួយត្រូវបានខ្ជះខ្ជាយ និងប្រើប្រាស់ខុសគោលដៅ។ ការបង្កើនជំនួយបរទេសនឹងមិនជួយប្រទេសកំពុងអភិវឌ្ឍន៍ទេ។ វាគ្រាន់តែជាការបោះលុយចោលទទេៗ។

លំហូរជំនួយបរទេសដ៏ធំនឹងបង្កើតភាពពឹងអាស្រ័យ ទម្លាប់ពឹងពាក់បរទេសពេក។

ប្រទេសកំពុងអភិវឌ្ឍន៍អាចសុំនឹងការទទួលបានជំនួយយ៉ាងច្រើនសន្ធឹក និងការធ្វេសប្រហែសក្នុងការអភិវឌ្ឍន៍កម្មវិធីផ្ទៃក្នុង ដើម្បីផ្តល់ការអប់រំ ការថែទាំសុខភាព ឬការជួសជុលហេដ្ឋារចនាសម្ព័ន្ធ។ ការពឹងផ្អែកនេះមានគ្រោះថ្នាក់សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ ព្រោះវាទុកអោយពួកគេងាយរងគ្រោះដោយសារ (បម្រែបម្រួល)គោលនយោបាយរបស់ប្រទេសម្ចាស់ជំនួយ។

ជំនួយបរទេសអាចរំលោភលើអធិបតេយ្យភាពរបស់រដ្ឋទទួល។

កម្មវិធីជំនួយភាគច្រើនភ្ជាប់មកជាមួយលក្ខខណ្ឌនានា។ ដូច្នេះ ជាលក្ខខណ្ឌសម្រាប់ការទទួលជំនួយ រដ្ឋកំពុងអភិវឌ្ឍន៍ត្រូវតែសន្យាថានឹងធ្វើការផ្លាស់ប្តូរឬអនុវត្តកិច្ចការជាក់លាក់ណាមួយ។ នេះគឺជាការរំលោភលើអធិបតេយ្យភាពយ៉ាងធ្ងន់ធ្ងរ ព្រោះវាត្រូវបានធ្វើឡើង ក្រោមការជួយដល់រដ្ឋអ្នកទទួល។

សំណួរ

- តើប្រទេស DAC គួរតែបង្កើនថវិកាជំនួយបរទេសរបស់ខ្លួនអោយបានច្រើនដែរឬទេ? តើជំនួយនេះនឹងក្លាយជាឧបសគ្គ ឬជាជំនួយដល់ការអភិវឌ្ឍន៍?
- តើប្រទេស DAC អាចមានលទ្ធភាពក្នុងការបង្កើនជំនួយបរទេសអោយបានច្រើនសមល្មមដែរឬទេ? តើអ្វីរារាំងប្រទេស DAC មិនអោយផ្តល់ជំនួយបរទេសបន្ថែមទៀត?
- អង្គការក្រៅរដ្ឋាភិបាលឯកជន (ព្រះវិហារ មូលនិធិBill & Melinda Gates)ក៏បានផ្តល់ជំនួយយ៉ាងច្រើនសន្ធឹកដើម្បីជួយដល់ប្រទេសកំពុងអភិវឌ្ឍន៍។ តើរដ្ឋ និងក្រុមអង្គការក្រៅរដ្ឋាភិបាលគួរសហការគ្នាយ៉ាងណាដើម្បីពង្រីកកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេក្នុងការផ្តល់ជំនួយបរទេស? តើអ្នកគិតថាអង្គការមិនមែនរដ្ឋាភិបាលឯកជនអាចធ្វើបានប្រសើរជាងក្នុងកិច្ចការខ្លះ ចំណែករដ្ឋនឹងប្រសើរជាងនៅកិច្ចការផ្សេងទៀត?

ក្រាហ្វិកស្តីពី គោលដៅអភិវឌ្ឍប្រកបដោយចីរភាព



គោលដៅទី១៖ បញ្ចប់ភាពក្រីក្រគ្រប់ទម្រង់នៅគ្រប់ទីកន្លែង

គោលដៅទី២៖ បញ្ចប់ភាពអត់ឃ្លាន សម្រេចឲ្យបានសន្តិសុខស្បៀង និងអាហារូបត្ថម្ភប្រសើរជាងមុន និងលើកកម្ពស់ កសិកម្មប្រកបដោយចីរភាព

គោលដៅទី៣៖ ធានាឲ្យមានការរស់នៅប្រកបដោយសុខភាពល្អ និងលើកកម្ពស់សុខុមាលភាព សម្រាប់មនុស្សគ្រប់រូបនៅគ្រប់វ័យ

គោលដៅទី៤៖ ធានាឲ្យបានការអប់រំប្រកបដោយគុណភាពជាបរិយាប័ន្ន និងដោយមានសមធម៌ ព្រមទាំងលើកកម្ពស់ឱកាសរៀនសូត្រពេញមួយជីវិតសម្រាប់មនុស្សគ្រប់រូប

គោលដៅទី៥៖ សម្រេចឲ្យបានសមភាពយេនឌ័រ និងពង្រឹងភាពអង់អាចរបស់ស្ត្រីនិងកុមារីគ្រប់រូប

គោលដៅទី៦៖ ធានាឲ្យមានទឹកស្អាតនិងអនាម័យ និងការគ្រប់គ្រងទឹកនិងអនាម័យប្រកបដោយចីរភាពសម្រាប់មនុស្សគ្រប់រូប

គោលដៅទី៧៖ ធានានូវការទទួលបានថាមពលក្នុងតម្លៃសមរម្យ អាចទុកចិត្តបាន ប្រកបដោយចីរភាព និងទំនើបសម្រាប់មនុស្សគ្រប់រូប

គោលដៅទី៨៖ ជំរុញឲ្យមានកំណើនសេដ្ឋកិច្ចប្រកបដោយបរិយាប័ន្ននិងចីរភាព មានមុខរបរពេញលេញ និងមានផលិតភាពខ្ពស់និងមានការងារសមរម្យសម្រាប់មនុស្សគ្រប់រូប

គោលដៅទី៩៖ កសាងហេដ្ឋារចនាសម្ព័ន្ធ ដែលធននឹងការប្រែប្រួលអាកាសធាតុ លើកកម្ពស់ឧស្សាហូបនីយកម្មប្រកបដោយបរិយាប័ន្ននិងចីរភាព និងលើកស្ទួយនវានុវត្តន៍

គោលដៅទី១០៖ កាត់បន្ថយវិសមភាពនៅក្នុងប្រទេស និងក្នុងចំណោមបណ្តាប្រទេសនានា

គោលដៅទី១១៖ ធ្វើឲ្យទីក្រុងនិងកន្លែងតាំងទីលំនៅថ្មីរបស់មនុស្ស មានលក្ខណៈបរិយាប័ន្ន មានសុវត្ថិភាព មានភាពធននឹងការប្រែប្រួលអាកាសធាតុ និងប្រកបចីរភាព

គោលដៅទី១២៖ ធានាឲ្យមានទម្រង់នៃការប្រើប្រាស់ផលិតផល និងផលិតកម្មប្រកបដោយចីរភាព

គោលដៅទី១៣៖ ចាត់វិធានការជាបន្ទាន់ ដើម្បីប្រយុទ្ធនឹងការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់

គោលដៅទី១៤

អភិរក្សនិងប្រើប្រាស់ប្រកបដោយចីរភាព នូវមហាសាគរ សមុទ្រ និងធនធានសមុទ្រ សម្រាប់ការអភិវឌ្ឍ ប្រកបដោយចីរភាព

គោលដៅទី១៥៖ ការពារ ស្តារ និងជំរុញការប្រើប្រាស់ប្រព័ន្ធអេកូឡូស៊ីលើដីគោកប្រកបដោយចីរភាព គ្រប់គ្រងព្រៃឈើប្រកបដោយចីរភាពប្រយុទ្ធនឹងវិនាភាពដីនិងបញ្ឈប់ ព្រមទាំងបង្វែរទិសនៃការរេចរឹលគុណភាពដី និងបញ្ឈប់ការបាត់បង់ជីវៈចម្រុះ

គោលដៅទី១៦៖ លើកកម្ពស់សង្គមដែលមានសន្តិភាពនិងប្រកបដោយបរិយាប័ន្នសម្រាប់ការអភិវឌ្ឍ ប្រកបដោយចីរភាព ផ្តល់នូវការទទួលបានយុត្តិធម៌ដល់មនុស្សគ្រប់រូប និងកសាងស្ថាប័នដោយប្រសិទ្ធភាព គណនេយ្យភាពប្រកបដោយបរិយាប័ន្ននៅគ្រប់លំដាប់ថ្នាក់

គោលដៅទី១៧៖ ពង្រឹងមធ្យោបាយអនុវត្តនានា និងបង្កើតភាពរស់រវើកនៃភាពជាដៃគូជាសកល សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព

និស្សិតអាចសាកល្បងអានឯកសារខាងក្រោមបន្ថែមទៀត ដើម្បីជាគ្រឹះក្នុងការឆ្លើយសំណួរទាំងអស់ខាងលើ ៖

- Easterly, William. *The White Man's Burden: Why the West's Efforts to Aid the Rest Have Done So Much Ill and So Little Good.* Penguin, 2007.
- Honig, Dan. *Navigation by Judgment: Why and When Top Down Management of Foreign Aid Doesn't Work.* Oxford, 2018.
- Swedlund, Haley J. *The Development Dance: How Donors and Recipients Negotiate the Delivery of Foreign Aid*. Cornell, 2017.
- Whitfield, Lindsay. *The Politics of Aid: African Strategies for Dealing with Donors.* Oxford, 2009.

អាជីពក្នុងទំនាក់ទំនងអន្តរជាតិ៖ ការអប់រំ និងស្រាវជ្រាវ

សង្ខេប

ការងារក្នុងការបង្រៀន និងស្រាវជ្រាវផ្តល់សេរីភាពក្នុងការបន្តរុករកគំនិត និងធ្វើការជាមួយមិត្តរួមការងារ ប៉ុន្តែពួកគេទាមទារអោយមានការចូលរៀនច្រើនឆ្នាំនិងបន្តរៀនថ្មីរហូត។

អត្ថប្រយោជន៍និងការចំណាយ

មនុស្សដើរតាមមាគ៌ាផ្សេងៗគ្នា ឆ្ពោះទៅចំណាប់អារម្មណ៍ក្នុងការបង្រៀននិងស្រាវជ្រាវក្នុងវិស័យIR។ សាស្ត្រាចារ្យឬលោកគ្រូរបស់អ្នកផ្ទាល់ទំនងជាមានរឿងប្លែកៗ អំពីរបៀបដែលគាត់ចាប់អារម្មណ៍លើកិច្ចការអន្តរជាតិ។

អត្ថប្រយោជន៍មួយនៃអាជីពឧត្តមសិក្សានិងការស្រាវជ្រាវ មិនថានៅក្នុងស្ថាប័នដែលផ្តោតលើការបង្រៀន ឬសាកលវិទ្យាល័យស្រាវជ្រាវធំៗនោះទេ គឺសេរីភាពផ្នែកបញ្ញា។ មនុស្សម្នាក់អាចចំណាយលើអាជីពមួយដើម្បីខិតទៅជិតប្រធានបទជាច្រើនដែលគួរអោយចាប់អារម្មណ៍ និងមានការវិវឌ្ឍឥតឈប់ឈរ អាចពាក់ព័ន្ធនឹងការធ្វើដំណើរទៅក្រៅប្រទេសដើម្បីបំពេញការងារ ហើយអាចអោយអ្នកភ្ជាប់ទំនាក់ទំនងជាមួយសហសេវិករាប់រយនាក់ដែលចាប់អារម្មណ៍លើប្រធានបទស្រដៀងគ្នា។

មុខតំណែងស្រាវជ្រាវភាគច្រើន (ឧទាហរណ៍នៅក្នុងក្រុមអ្នកគិតឬវិភាគ) មានភាពខុសប្លែកគ្នាពីរយ៉ាងធំៗ។ ទីមួយ ការងារទាំងនេះច្រើនតែផ្តល់ទិសដៅបន្ថែមទៀតដល់បុគ្គលម្នាក់ ទាក់ទងនឹងការស្រាវជ្រាវដែលត្រូវអនុវត្ត។ ទីពីរ មានការបង្រៀនតិចតួចឬគ្មានពាក់ព័ន្ធទាល់តែសោះ។ ទោះបីជាយ៉ាងណាក៏ដោយ សម្រាប់អ្នកដែលចាប់អារម្មណ៍លើការស្រាវជ្រាវIR ការងារបែបនេះអាចបណ្តាលអោយមានការផ្សព្វផ្សាយកាន់តែទូលំទូលាយនៃការងាររបស់មនុស្សម្នាក់ទៅកាន់ទស្សនិកជនទូលំទូលាយ ដែលជារឿយៗ រួមមានអ្នកបង្កើតគោលនយោបាយ។

ដើម្បីបង្រៀនទំនាក់ទំនងអន្តរជាតិនៅកម្រិតឧត្តមសិក្សា ឬដើម្បីធ្វើការស្រាវជ្រាវសម្រាប់ក្រុមអ្នកគិតឬវិភាគ និងទីភ្នាក់ងាររដ្ឋាភិបាល ជាធម្មតា តម្រូវអោយមានសញ្ញាបត្រកម្រិតខ្ពស់ ស្ទើរតែជាសញ្ញាបត្រអនុបណ្ឌិត ហើយជាញឹកញាប់ថ្នាក់បណ្ឌិត (Ph.D.)។ កម្មវិធីថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ច្រើនតែចំណាយពេលពីមួយទៅពីរឆ្នាំ ខណៈពេលដែលថ្នាក់បណ្ឌិត ជំនាញទំនាក់ទំនងអន្តរជាតិជាធម្មតា ទាមទារយ៉ាងតិចប្រាំឆ្នាំ។ ជារឿយៗ និស្សិតឆ្លៀតពេលសម្រាក នៅចន្លោះការសិក្សាថ្នាក់បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់របស់ពួកគេ ដើម្បីធ្វើដំណើរទៅក្រៅប្រទេស ឬទទួលបានបទពិសោធន៍ការងារ ដើម្បីសម្រួចចំណាប់អារម្មណ៍របស់ពួកគេ។ ជាការពិតណាស់ និស្សិតជាច្រើនមិនដែលត្រលប់មកបន្តការសិក្សារបស់ពួកគេវិញទេ ប្រសិនបើពួកគេ

ស្វែងរកការងារដែលអនុញ្ញាតអោយពួកគេសម្រេចបាននូវគោលដៅផ្ទាល់ខ្លួន និងអាជីពរបស់ពួកគេ។

ជាចុងក្រោយ ក្នុងការបញ្ចប់សញ្ញាបត្រកម្រិតខ្ពស់បំផុត បរិមាណដ៏ច្រើននៃទិសដៅផ្ទាល់ខ្លួនមានភាពចាំបាច់ណាស់។ វគ្គសិក្សាក្នុងថ្នាក់គឺគ្រាន់តែជាផ្នែកមួយនៃកម្មវិធីថ្នាក់អនុបណ្ឌិត ឬបណ្ឌិតតែប៉ុណ្ណោះ និក្ខេបបទក៏ត្រូវបានទាមទារផងដែរ។ ការសរសេរនិក្ខេបបទតម្រូវអោយធ្វើការតាមកាលវិភាគផ្ទាល់ខ្លួនរបស់អ្នក ដោយហេតុនេះធ្វើអោយមានតុល្យភាពជាមួយនឹងភារកិច្ចផ្សេងទៀត (ដូចជាការងារជាគ្រូបង្រៀន ឬជំនួយការស្រាវជ្រាវ) ដែលអាចប្រមូលផ្តុំការងារផ្ទាល់ខ្លួនរបស់អ្នកបានយ៉ាងងាយ។ មនុស្សជាច្រើនដែលបានបញ្ចប់វគ្គសិក្សាសម្រាប់សញ្ញាបត្រខ្ពស់មិនបានបញ្ចប់និក្ខេបបទរបស់ពួកគេ ឬចំណាយពេលច្រើនឆ្នាំដើម្បីបញ្ចប់វាទេ។

ជំនាញត្រូវដុសខាត់

ទោះនរណាម្នាក់ចង់បន្តសញ្ញាបត្រកម្រិតខ្ពស់ ដើម្បីគោលបំណងបង្រៀននៅក្នុងសាកលវិទ្យាល័យ ឬចូលរួមក្នុងការស្រាវជ្រាវអនុវត្តនោះទេ គេត្រូវមានជំនាញសំខាន់ៗដែលត្រូវអភិវឌ្ឍ។

ទីមួយហើយសំខាន់បំផុតគឺការរិះគិតបែបរិះគន់។ អ្នកប្រាជ្ញ និងអ្នកស្រាវជ្រាវត្រូវតែពិចារណាជម្រើសជាច្រើនជាចម្លើយចំពោះសំណួរណាមួយ ខណៈពេលដែលអាចវាយតម្លៃសុពលភាព ឬសារៈសំខាន់នៃជម្រើសទាំងនោះ។ ទីពីរគឺការសរសេរ។ មុនពេល កំឡុងពេល និងក្រោយពេលផលិតនិក្ខេបបទ ការសរសេរគឺជាជំនាញសំខាន់សម្រាប់អ្នកសិក្សាជាន់ខ្ពស់និងអ្នកស្រាវជ្រាវ។ ជាចុងក្រោយ ចូរគិតអំពីការបង្កើតជំនាញអនុវត្តដើម្បីប្រើជាប្រអប់ឧបករណ៍ ខណៈពេលកំពុងវិភាគសំណួរ។ ខ្លឹមសារនៃប្រអប់ឧបករណ៍នេះអាចរួមបញ្ចូលភាសាផ្សេងទៀតដើម្បីជួយសម្រួលដល់ការងារនៅក្រៅប្រទេស។ ពួកគេអាចរួមបញ្ចូលការប្រើប្រាស់ស្ថិតិ និងជំនាញទិន្នន័យ ដើម្បីជួយសម្រួលដល់ការវិភាគបរិមាណ។ ឬពួកគេអាចរួមបញ្ចូលគណិតវិទ្យា ដើម្បីប្រើគំរូទ្រឹស្តីហ្គេម។ មិនថាឧបករណ៍ណាដែលអ្នកសង្កត់ធ្ងន់នោះទេ ជំនាញឯកទេសនឹងជួយអ្នកអោយឆ្លើយសំណួរស្រាវជ្រាវ មិនថាជាផ្នែកមួយនៃសាលា ឬនៅក្នុងស្ថាប័នស្រាវជ្រាវឯកជន ឬរដ្ឋាភិបាលក៏ដោយ។

រូបថត ថ្នាក់រៀនទំនាក់ទំនងអន្តរជាតិ

ធនធានបន្ថែម

1. American Political Science Association. Earning a PhD in Political Science. 4th ed. Washington, DC, 2004.
2. The Chronicle of Higher Education (weekly). Online at chronicle. com/
3. http://www.apsanet.org
4. http://www.apsia.org
5. http://www.isanet.org

ឯកសារគួរអានបន្ថែម

- Acemoglu, Daron, and James Robinson. *Why Nations Fail: The Origins of Power, Prosperity, and Poverty.* Crown Business, 2013.
- Banerjee, Abhijit, and Esther Duflo. *Poor Economics: A Radical Rethinking of the Way to Fight Global Poverty.* PublicAffairs, 2012.
- Carmody, Padraig. *The New Scramble for Africa.* Polity, 2011.
- Chayes, Sarah. *Thieves of State: Why Corruption Threatens Global Security.* Norton, 2015.
- Overholt, William H. *China's Crisis of Success.* Cambridge, 2017.
- Panagariya, Arvind. *India: The Emerging Giant.* Oxford, 2010.

មេរៀនទី ១៤ ៖ អថសាន្តកថា

រូបថត កុមារឡើងលើកំពូលភ្នំដើម្បីចូលរៀននៅសាលា ប្រទេសចិន ឆ្នាំ ២០១៧ ។

នៅទីបំផុត ជម្លោះនិងល្ខោននៃទំនាក់ទំនងអន្តរជាតិ គឺជាបញ្ហារបស់សង្គមមនុស្ស៖ ការតស៊ូដើម្បីអំណាចនិងទ្រព្យសម្បត្តិ កិច្ចប្រឹងប្រែងដើម្បីសហការទោះបីជាមានភាពខុសគ្នា បញ្ហាសង្គមនិងបញ្ហាផលប្រយោជន៍រួម តុល្យភាពរវាងសេរីភាពនិងសណ្តាប់ធ្នាប់ ការដេកវាងអ្នកសកលនិយមនិងអ្នកជាតិនិយម និងការដោះដូរសមធម៌ជាមួយនឹងប្រសិទ្ធភាព និងលទ្ធផលរយៈពេលវែងធៀបនឹងរយៈពេលខ្លី។ ប្រធានបទទាំងនេះមិនអាចគេចផុតពីសង្គមមនុស្សបានទេ រាប់ចាប់ពីក្រុមគួចបំផុត រហូតដល់សហគមន៍ពិភពលោក។ ក្នុងន័យនេះ ប្រធានបទនៃទំនាក់ទំនងអន្តរជាតិគឺជារសជាតិបន្ថែមនៃជីវិតប្រចាំថ្ងៃ ហើយនិងការឆ្លុះបញ្ចាំងពីជម្រើសរបស់មនុស្សម្នាក់ៗ។ ទំនាក់ទំនងអន្តរជាតិ (IR) គឺជាកម្មសិទ្ធិរបស់យើងទាំងអស់គ្នា មិនថាអ្នកនៅអឌ្ឍគោលខាងជើងឬអឌ្ឍគោលខាងត្បូង ស្ត្រីឬបុរស ប្រជាពលរដ្ឋឬអ្នកដឹកនាំឡើយ ដែលរស់នៅជាមួយគ្នានៅលើភពផែនដីនេះ។

សៀវភៅនេះបានបង្ហាញថា នៅក្នុងទំនាក់ទំនងអន្តរជាតិ ច្រើនជាងស្ថានភាពសង្គមផ្សេងទៀត បញ្ហាផលប្រយោជន៍រួមបង្កបញ្ហាប្រឈមយ៉ាងខ្លាំងចំពោះកិច្ចសហប្រតិបត្តិការជោគជ័យ ក្នុងចំណោមតួអង្គឯករាជ្យ(រវាងរដ្ឋនិងរដ្ឋ)មួយចំនួនធំ។ ដោយគ្មានរដ្ឋាភិបាលកណ្តាលដើម្បីអនុវត្តការគ្រប់គ្រងតាមលំដាប់ថ្នាក់ តួអង្គនៅក្នុងទំនាក់ទំនងអន្តរជាតិបានបង្កើតដំណោះស្រាយបីប្រភេទចំពោះបញ្ហាផលប្រយោជន៍រួមដែលជាគោលការណ៍ស្នូលទាំងបីរបស់យើង។ ប្រទេសនានាងាកទៅរកគោលការណ៍គ្រប់គ្រង ជាពិសេសការប្រើកម្លាំងយោធា ដែលភាគច្រើននឹងជាញឹកញាប់ នៅក្នុងកិច្ចការសន្តិសុខអន្តរជាតិ(មេរៀនទី៦)។ គោលការណ៍អត្តសញ្ញាណមានសារៈសំខាន់បំផុត នៅក្នុងដំណើរការសមាហរណកម្មគួរអោយកត់សម្គាល់ (មេរៀនទី ១០)។ ទោះជាយ៉ាងណាក៏ដោយ គោលការណ៍បដិការមានសារៈសំខាន់បំផុតហើយដែលស្ថិតនៅក្រោមសន្ធិសញ្ញាអន្តរជាតិ ច្បាប់ និងអង្គការនានា តាមរយៈអង្គការសហប្រជាជាតិ រហូតដល់អង្គការពាណិជ្ជកម្មពិភពលោក (WTO)។ លក្ខណៈនៃដំណោះស្រាយ ដោយផ្អែកលើគោលការណ៍ចំរុះ គឺមានភាពស្មុគស្មាញក្នុងរយៈពេលយូរ ដើម្បីយល់ព្រមនិងទាមទារអោយមានការត្រួតពិនិត្យការអនុលោមតាមយ៉ាងទូលំទូលាយ។ ប៉ុន្តែដោយត្រូវរួមគ្នាជាឆ្លងមួយ កិច្ចព្រមព្រៀងដែលផ្អែកលើគោលការណ៍បដិការទាំងនេះផ្តល់នូវមូលដ្ឋានសម្រាប់ប្រព័ន្ធអន្តរជាតិ ដែលបានផ្លាស់ប្តូរអស់ជាច្រើនសតវត្សរ៍មកហើយ ពីភាពងាយនឹងរងគ្រោះដោយសង្គ្រាមខ្លាំង ទៅកាន់សន្តិភាពនិងវិបុលភាពកាន់តែរឹងមាំ ទោះបីជាបញ្ហាដ៏ធ្ងន់ធ្ងរជាច្រើនរបស់ពិភពលោកនៅសេសសល់ក៏ដោយ។

ប្រធានបទដ៏សំខាន់មួយនៃសៀវភៅនេះ គឺលក្ខណៈនៃប្រព័ន្ធអន្តរជាតិ ដែលជាសំណុំនៃច្បាប់ និងដែលត្រូវបានអភិវឌ្ឍយ៉ាងល្អ ដោយផ្អែកលើអធិបតេយ្យភាពរបស់រដ្ឋ ទឹកដីនិយម និង «ភាពអនាធិបតេយ្យ» ដែលជាកង្វះនៃរដ្ឋាភិបាលកណ្តាល។ ប៉ុន្តែប្រព័ន្ធអន្តរជាតិកាន់តែស្មុគ្រស្មាញ កាន់តែមានលក្ខណៈពិសេសនិងកាន់តែមានទំនាក់ទំនងគ្នាទៅវិញទៅមក ជាមួយទិដ្ឋភាពផ្សេងទៀតនៃសង្គម។ អធិបតេយ្យភាពរបស់រដ្ឋឥឡូវនេះត្រូវបានជំទាស់ដោយគោលការណ៍នៃការកំណត់ជោគវាសនាដោយខ្លួនឯង។ បទដ្ឋានអន្តរជាតិបានចាប់ផ្តើមកំណត់សិទ្ធិរបស់រដ្ឋាភិបាលក្នុងការគ្រប់គ្រងប្រជាជនដោយបង្ខំ ដែលផ្ទុយពីឆន្ទៈរបស់ខ្លួននិង

រំលោភសិទ្ធិមនុស្ស។ បូរណភាពទឹកដីក៏មានបញ្ហាដែរ ដោយសារព្រំដែនជាតិមិនបញ្ឈប់ព័ត៌មាន ការប្រែប្រួលបរិស្ថាន ឬការប្រើប្រាស់មីស៊ីលទេ។ ព័ត៌មានអនុញ្ញាតអោយតួអង្គរដ្ឋ តួអង្គនៅក្រោមកម្រិតរដ្ឋ និង តួអង្គបរមានុភាព (supranational) ដើម្បីដឹងពីអ្វីដែលកំពុងកើតឡើង នៅគ្រប់ទីកន្លែងក្នុងពិភពលោក និងសម្របសម្រួលសកម្មភាពជាសកល។

ការអភិវឌ្ឍន៍បច្ចេកវិទ្យាគ្រាន់តែជាទិដ្ឋភាពមួយនៃការផ្លាស់ប្តូរយ៉ាងជ្រាលជ្រៅប៉ុន្តែច្រើនសម្បើមខ្លាំងដែលកើតឡើងនៅក្នុងទំនាក់ទំនងអន្តរជាតិ។ តួអង្គថ្មីកំពុងទទួលបានអំណាច គោលការណ៍ដែលមានរយៈពេលយូរកាន់តែមានប្រសិទ្ធភាពតិចជាងមុន។ ហើយបញ្ហាប្រឈមថ្មីកំពុងកើតឡើងសម្រាប់ក្រុមរដ្ឋ និងបុគ្គលដូចគ្នា។ បច្ចេកវិទ្យាកំពុងផ្លាស់ប្តូរឧបករណ៍ប្រើប្រាស់និងតួនាទីរបស់កងកម្លាំងយោធា យ៉ាងខ្លាំងក្លា។ បច្ចេកវិទ្យាបានដើរតួនាទីយ៉ាងសំខាន់ទៅលើភាគីទាំងពីរសង្វាង នៅក្នុងសង្គ្រាមប្រឆាំងការបះបោរ និងសង្គ្រាមសកម្មចំនួន ១៤ ផ្សេងទៀតនៅក្នុងពិភពលោក។

ទម្រង់នៃអានុភាពមិនមែនជាយោធា ជាពិសេសការលើកទឹកចិត្តសម្រាប់សេដ្ឋកិច្ច បានក្លាយជាសមត្ថភាពអំណាចដ៏សំខាន់ជាង។ យុគសម័យក្រោយសង្គ្រាមត្រជាក់ គឺជាសម័យកាលសន្តិភាពណាស់ដែរ ប៉ុន្តែសន្តិភាពនេះហាក់មានភាពផុយស្រួយ។ តើយុគសម័យនេះ (ដូចជាយុគសម័យក្រោយសង្គ្រាមនាពេលកន្លងមក) ដែលរំលងបន្តិចម្តងៗ ចូលទៅក្នុងយុគសម័យបុរេសង្គ្រាមបន្ទាប់ ឬតើវានឹងនាំទៅរក «សន្តិភាពអចិន្ត្រៃយ៍» ដ៏រឹងមាំ និងយូរអង្វែង ដូចដែល កានត៍ (Kant) បានស្រមៃ?

នៅក្នុងសេដ្ឋកិច្ចនយោបាយអន្តរជាតិ (IPE) យើងឃើញនិន្នាការក្នុងពេលដំណាលគ្នាឆ្ពោះទៅរកការធ្វើសមាហរណកម្ម និងការបែកបាក់ទឹកដីក្នុងចំណោមរដ្ឋ។ មនុស្សបន្តនិយាយភាសារបស់ពួកគេ ធ្វើការហោះហើរ ប្រើទង់ជាតិរបស់ពួកគេ និងប្រើប្រាស់រូបិយប័ណ្ណផ្ទាល់ខ្លួនជាមួយនឹងរូបភាព និងនិមិត្តសញ្ញារបស់គេ។ ជាតិនិយមនៅតែជាកម្លាំងដ៏សំខាន់។ ទោះយ៉ាងណាក៏ដោយ ទន្ទឹមនឹងនោះ ខណៈពេលដែលមនុស្សកំណត់បានអត្តសញ្ញាណជាមួយរដ្ឋរបស់ពួកគេ ឥឡូវនេះ ពួកគេក៏មានអត្តសញ្ញាណប្រកួតប្រជែង ដោយផ្អែកលើទំនាក់ទំនងជាតិសាសន៍ ភេទ និង(ក្នុងករណីអឺរ៉ុប)តំបន់។ ក្នុងពាណិជ្ជកម្មអន្តរជាតិ សេដ្ឋកិច្ចសេរីនិយមមានឥទ្ធិពលដោយសារវាមានដំណើរការល្អ។ រដ្ឋបានសិក្សាឃើញថា ដើម្បីរស់បាន ពួកគេត្រូវតែជួយបង្កើតទ្រព្យសម្បត្តិដោយ/ជាមួយសាជីវកម្មពហុជាតិ(MNCs) និងតួអង្គផ្សេងទៀត។

ការបំផ្លាញបរិស្ថានអាចក្លាយជាបញ្ហាឧបសគ្គដ៏ធំបំផុតតែមួយគត់ចំពោះកំណើនសេដ្ឋកិច្ច និងប្រកបដោយនិរន្តរភាពទាំងនៅអឌ្ឍគោលខាងជើងនិងខាងត្បូង។ ដោយសារតែការចំណាយខ្ពស់ តួអង្គមួយចំនួនធំនិងបញ្ហាផលប្រយោជន៍រួម ការចរចាអន្តរជាតិជុំវិញបរិស្ថានមានការពិបាកណាស់។

ទន្ទឹមនឹងនោះ ទំនាក់ទំនងរវាងអឌ្ឍគោលខាងជើង-ខាងត្បូងបានកំពុងឈានទៅដល់ចំណុចស្នូលនៃនយោបាយពិភពលោក។ និន្នាការប្រជាសាស្ត្រ និងសេដ្ឋកិច្ចកំពុងធ្វើអោយមានគម្លាតរវាងអឌ្ឍគោលខាងជើងនិងខាងត្បូង ដោយអឌ្ឍគោលខាងជើងនៅតែបន្តប្រមូលផ្តុំទ្រព្យសម្បត្តិ ច្រើនខណៈដែលអឌ្ឍគោលខាងត្បូងភាគច្រើនមានភាពយឺតយ៉ាវក្នុងការអភិវឌ្ឍ។ នៅទីបំផុត អឌ្ឍគោលជើងនឹងត្រូវខាតបង់ច្រើនចំពោះការមិនដោះស្រាយការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសខាងត្បូង។ ប្រហែលជាតាមរយៈការប្រើប្រាស់កុំព្យូទ័រនិងការច្នៃប្រឌិតបច្ចេកវិទ្យាជីវសាស្ត្រ រដ្ឋក្រីក្រមួយចំនួនអាចអភិវឌ្ឍសេដ្ឋកិច្ចរបស់ពួកគេកាន់តែមានប្រសិទ្ធភាព និងនិរន្តរភាព ជាងអឺរ៉ុបឬអាមេរិកខាងជើង។

នៅពេលនេះ គឺគេមិនអាចដឹងបានទេថានៅពេលអនាគតនឹងទៅជាយ៉ាងណា ប៉ុន្តែនៅពេលវាលាតត្រដាងចេញមក អ្នកអាចធ្វើការប្រៀបធៀបវា (នៅពេលវេលាសែនឆ្ងាយទៀត)ទៅនឹងពិភពលោកដែលអ្នកប្រាថ្នាចង់បាន និងរំពឹងទុក។ ជាឧទាហរណ៍ អ្នកអាចសួរសំណួរដូចតទៅនេះ (សួរខ្លួនឯង ម្តងមួយសំណួរៗ ហេតុអ្វីបានជាអ្នកឆ្លើយតាមរបៀបនោះ សម្រាប់អនាគតដែលអ្នកចង់បាន និងអនាគតដែលអ្នករំពឹងទុក)៖

១. តើអធិបតេយ្យភាពរបស់រដ្ឋនឹងត្រូវបំផ្លាញដោយអាជ្ញាធរបរមានុភាពដែរឬទេ?

២. តើបទដ្ឋានសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យនឹងក្លាយទៅជាបទដ្ឋានសកលដែរឬទេ?

៣. តើអង្គការសហប្រជាជាតិនឹងវិវត្តទៅជារដ្ឋាភិបាលមួយសម្រាប់ពិភពលោកដែរឬទេ?

៤. តើ UN នឹងរៀបចំរចនាសម្ព័ន្ធឡើងវិញទេ?

៥. តើសាលក្រមរបស់តុលាការពិភពលោកនឹងអាចអនុវត្តបានដែរឬទេ?

៦. តើចំនួនរដ្ឋនឹងកើនឡើងដែរឬទេ?

៧. តើប្រទេសចិននឹងក្លាយទៅជាប្រជាធិបតេយ្យដែរឬទេ?

៨. តើបច្ចេកវិទ្យាព័ត៌មាននឹងមានឥទ្ធិពលអ្វីខ្លះលើទំនាក់ទំនងអន្តរជាតិ?

៩. តើអាវុធប្រល័យលោកនឹងរីកដុះដាលដែរឬទេ?

១០. តើអានុភាពយោធានឹងលែងប្រើហើយ ឬនៅបន្តទៀត?

១១. តើការរំសាយអាវុធនឹងកើតឡើងដែរឬទេ?

១២. តើស្ត្រីនឹងចូលរួមពេញលេញនៅក្នុងទំនាក់ទំនងអន្តរជាតិដែរឬទេ? តើមានឥទ្ធិពលអ្វីខ្លះ?

១៣. តើនឹងមានរូបិយប័ណ្ណពិភពលោកតែមួយដែរឬទេ?

១៤. តើនឹងមានរបបពាណិជ្ជកម្មសេរីសកលដែរឬទេ?

១៥. តើជាតិនិយមនឹងរលាយបាត់ ឬបន្តរឹងមាំ?

១៦. តើមនុស្សជាច្រើននឹងបង្កើតអត្តសញ្ញាណសកលរួមគ្នាដែរឬទេ?

១៧. តើវប្បធម៌ពិភពលោកនឹងមានភាពដូចគ្នា ឬពហុនិយមឬចម្រុះជាង?

១៨. តើសហភាពអឺរ៉ុប (EU) ឬអង្គការអន្តរជាតិក្នុងតំបន់ (IOs) សម្រេចបាននូវសហភាពនយោបាយពេញលេញដែរឬទេ?

១៩. តើការបំផ្លិចបំផ្លាញបរិស្ថានពិភពលោកនឹងធ្ងន់ធ្ងរដែរឬទេ? បើអញ្ចឹងឆាប់បំផុត តើពេលណា?

២០. តើបច្ចេកវិទ្យាថ្មីនឹងរារាំងឧបសគ្គបរិស្ថានដែរឬទេ?

២១. តើបញ្ហាសកលនឹងបង្កើតសណ្តាប់ធ្នាប់ពិភពលោកខ្លាំង ឬខ្សោយជាង?

២២. តើកំណើនប្រជាជននឹងធ្លាក់ចុះទេ? បើដូច្នេះ តើពេលណា និងកម្រិតណា?

២៣. តើប្រទេសក្រីក្របំផុតនឹងប្រមូលទ្រព្យសម្បត្តិ? បើអញ្ចឹង តើឆាប់ដល់ណា?

២៤. តើអឌ្ឍគោលខាងជើងនឹងដើរតួនាទីអ្វីក្នុងការអភិវឌ្ឍន៍អឌ្ឍគោលខាងត្បូង?

ជម្រើសដែលអ្នកជ្រើសរើសហើយសកម្មភាពដែលអ្នកធ្វើ នៅទីបំផុតនឹងជះឥទ្ធិពលដល់ពិភពលោកដែលអ្នករស់នៅ។ អ្នកមិនអាចជ្រើសរើសគេចចេញពីការចូលរួមក្នុងទំនាក់ទំនងអន្តរជាតិបានទេ។ អ្នកត្រូវតែពាក់ព័ន្ធ ហើយពីមួយឆ្នាំទៅមួយឆ្នាំ បដិវត្តន៍ព័ត៌មាន និងទិដ្ឋភាពផ្សេងទៀតនៃការពឹងអាស្រ័យគ្នាទៅវិញទៅមក កំពុងទាក់ទាញអ្នកអោយកាន់តែជិតស្និទ្ធជាមួយសកលលោកទាំងមូល។ អ្នកអាចធ្វើតាមវិធីជាច្រើន

ដើម្បីនាំពិភពលោកដែលអ្នករំពឹងទុកអោយស្របតាមពិភពលោកដែលអ្នកប្រាថ្នាចង់ឃើញ។ អ្នកអាចផ្តល់អំណាចដល់ខ្លួនអ្នកដោយស្វែងរកសកម្មភាព និងជម្រើសដែលកំណត់ទីតាំងរបស់អ្នកនៅក្នុងទំនាក់ទំនងអន្តរជាតិ។

ឥឡូវនេះ អ្នកបានបញ្ចប់ការសិក្សាដែលមាននៅក្នុងសៀវភៅនេះហើយ សូមកុំឈប់នៅត្រឹមនេះ។ ចូរបន្តស្វ័យសិក្សាអំពីពិភពលោក ហួសពីព្រំដែននៃប្រទេសកម្ពុជាយើង។ ចូរបន្តគិតអំពីពិភពលោកដែលអាចនឹងលេចចេញជារូបរាង។ ចូរចូលរួមចំណែក នៃការផ្លាស់ប្តូរដែលនឹងបន្តនិរន្តរភាពនៃពិភពលោកនេះ ក្នុងទសវត្សរ៍ខាងមុខ។ វាជាពិភពលោករបស់អ្នក៖ សិក្សាស្វែងយល់អំពីវា ថែរក្សាវា អោយបាននិរន្ត៕

សេចក្តីសង្ខេបសៀវភៅ

សៀវភៅសិក្សាគោលនេះ មានគោលបំណងបង្ហាញមូលដ្ឋានគ្រឹះចំណេះដឹង នៅក្នុងវិស័យទំនាក់ទំនងអន្តរជាតិ (International Relations) ដោយពិភាក្សាយ៉ាងទូលំទូលាយ និងងាយយល់សម្រាប់អ្នកអានសិក្សាទូទៅ៖ ដើម្បីផ្តល់នូវគំរោង ប្រធានបទផ្សេងៗ ចាប់អារម្មណ៍ដោយសហគមន៍ស្រាវជ្រាវផ្សេងៗតាមលំដាប់លំដោយ។ គំរោងសៀវភៅនេះត្រូវបានរៀបចំតាមមែកធាងរបស់មុខវិជ្ជាទំនាក់ទំនងអន្តរជាតិ រួមមាន សន្តិសុខអន្តរជាតិ(IS) និងសេដ្ឋកិច្ចនយោបាយអន្តរជាតិ(IPE)។ មែកធាងទាំងពីរនេះ ទោះបីត្រូវបានបំបែកជាពីរផ្នែកនៅក្នុងសៀវភៅនេះក៏ដោយ ក៏ត្រូវបានដាក់បញ្ចូលតាមមេរៀននីមួយៗ និងត្រួតលើគ្នា(នៅក្នុងមេរៀននេះផង និងមេរៀននោះផង) តាមវិធីជាច្រើន។ គោលការណ៍ស្នូលទូទៅសម្រាប់ដោះស្រាយបញ្ហាផលប្រយោជន៍រួម៖ គោលការណ៍គ្រប់គ្រង គោលការណ៍បដិការ និងគោលការណ៍អត្តសញ្ញាណ បង្រួបបង្រួមអត្ថបទសៀវភៅទាំងមូល ដោយបង្ហាញពីរបៀបដែលគំរូទ្រឹស្តីអនុវត្តលើប្រធានបទនានា ក្នុងសន្តិសុខអន្តរជាតិ និងសេដ្ឋកិច្ចនយោបាយ។

រចនាសម្ព័ន្ធទាំងមូលនៃអត្ថបទក្នុងសៀវភៅនេះ ត្រូវបានរៀបចំតាមប្រធានបទសំខាន់ៗ ផ្នែកទីមួយគឺសន្តិសុខអន្តរជាតិ និងផ្នែកបន្ទាប់បន្ទាប់ទៀត នៅក្នុងសេដ្ឋកិច្ចនយោបាយអន្តរជាតិ។ មេរៀនទី ១ ណែនាំអំពីសញ្ញាណទូទៅនៃការសិក្សាអំពីទំនាក់ទំនងអន្តរជាតិ; ពន្យល់ពីបញ្ហាផលប្រយោជន៍រួម និងគោលការណ៍ស្នូលសំរាប់ដោះស្រាយរួមមាន គោលការណ៍គ្រប់គ្រង គោលការណ៍បដិការ និងគោលការណ៍អត្តសញ្ញាណ; និងផ្តល់នូវបរិបទភូមិសាស្ត្រ និងប្រវត្តិសាស្ត្រសង្ខេបៗសម្រាប់ប្រធានបទនេះ។ ទស្សនវិស័យប្រវត្តិសាស្ត្របញ្ចូលនិន្នាការឬព្រឹត្តិការណ៍ថ្មីៗ ជាពិសេសសកលភាវូបនីយកម្ម នៅក្នុងបរិបទនៃការវិវត្តនៃប្រព័ន្ធអន្តរជាតិក្នុងសតវត្សរ៍ទី ២០ ខណៈពេលដែលការតំរង់ទិសជាសកល ឆ្លុះបញ្ចាំងពីភាពចម្រុះនៃបទពិសោធន៍ទំនាក់ទំនងអន្តរជាតិ សម្រាប់តួអង្គផ្សេងៗគ្នា ជាពិសេស តួអង្គអឡាគោលខាងត្បូង។ មេរៀនទី ២ និងទី ៣ ពន្យល់ពីទ្រឹស្តីសំខាន់ៗ ក្នុងមុខវិជ្ជាទំនាក់ទំនងអន្តរជាតិ ដូចជា ទ្រឹស្តីប្រាកដនិយម ទ្រឹស្តីសេរីនិយម ទ្រឹស្តីសង្គមនានា (ទ្រឹស្តីស្ថាបនានិយម(constructivist), ទ្រឹស្តីក្រោយសម័យទំនើបនិយម (postmodern) និងទ្រឹស្តីម៉ាក្សស៊ីសនិយម (Marxist)) សន្តិភាពវិទ្យា និងទ្រឹស្តីយេនឌ័រ។

មេរៀនទី ៤ ពិភាក្សាអំពីយុទ្ធសាស្ត្របង្កើត និងការអនុវត្តគោលនយោបាយការបរទេស រួមទាំងការពិភាក្សាអំពីស្ថាប័នសំខាន់ៗ ដែលពាក់ព័ន្ធនឹងដំណើរការនោះ។ មេរៀនទី ៥ ចង្អុលបង្ហាញពីប្រភពចម្បងនៃជម្លោះអន្តរជាតិ រួមទាំងជម្លោះជនជាតិភាគតិច ជម្លោះសាសនា ជម្លោះទឹកដី និងជម្លោះសេដ្ឋកិច្ច។ លក្ខខណ្ឌនិងរបៀបដែលជម្លោះបែបនេះនាំទៅរកការប្រើប្រាស់អំពើហិង្សាត្រូវបានពិភាក្សានៅក្នុងមេរៀនទី៦ ស្តីពីកម្លាំងយោធា និងអំពើភេរវកម្ម។ មេរៀនទី ៧ បង្ហាញពីរបៀបដែលអង្គការនិងច្បាប់អន្តរជាតិ ជាពិសេសអង្គការសហប្រជាជាតិ បានវិវត្តទៅជាឥទ្ធិពលដ៏សំខាន់ ក្នុងទំនាក់ទំនងសន្តិសុខ និងរបៀបដែលសិទ្ធិមនុស្សកាន់តែមានសារៈសំខាន់។ ការសិក្សាអំពីអង្គការអន្តរជាតិក៏បានផ្សារភ្ជាប់ ប្រធានបទសន្តិសុខអន្តរជាតិជាមួយនឹងប្រធានបទក្នុងសេដ្ឋកិច្ចនយោបាយអន្តរជាតិ។

មេរៀនបន្តបន្ទាប់ ផ្តោតលើប្រធានបទផ្សេងៗ ដែលរួមផ្សំបង្កើតបានជាការសិក្សាអំពីសេដ្ឋកិច្ចនយោបាយអន្តរជាតិ ដោយចាប់ផ្តើមពីគោលការណ៍មីក្រូសេដ្ឋកិច្ច និងសេដ្ឋកិច្ចជាតិ តាមរយៈពាណិជ្ជកម្ម

និងហិរញ្ញវត្ថុ, សមាហរណកម្មអន្តរជាតិ, បរិស្ថាននិងប្រជាជន, និងទំនាក់ទំនងអឡរគោលខាងជើង-ខាងត្បូង ដោយផ្តោតលើការអភិវឌ្ឍន៍យ៉ាងពិសេស។ មេរៀនទី ៨ ណែនាំអំពីបញ្ហាតិនិងទ្រឹស្តីនៃសេដ្ឋកិច្ចនយោបាយ (បង្ហាញពីរបៀបដែលទ្រឹស្តីនៃសន្តិសុខអន្តរជាតិ ប្រែក្លាយទៅជា បញ្ហាសិក្សាអំពីសេដ្ឋកិច្ចនយោបាយអន្តរជាតិ) និងពិភាក្សាអំពីប្រធានបទសំខាន់បំផុតនៅក្នុងសេដ្ឋកិច្ចនយោបាយអន្តរជាតិ ពោលគឺទំនាក់ទំនងពាណិជ្ជកម្ម។ មេរៀនទី ៩ ពិពណ៌នាអំពីនយោបាយនៃហិរញ្ញវត្ថុសកល និងប្រតិបត្តិការធុរកិច្ចពហុជាតិនៅក្នុងយុគសម័យនៃសកលភាវូបនីយកម្ម។ មេរៀនទី ១០ ស្វែងយល់ពីដំណើរការនៃសមាហរណកម្មអន្តរជាតិ ទូរគមនាគមន៍ និងការផ្លាស់ប្តូរវប្បធម៌ លើមាត្រដ្ឋានតំបន់ (ដូចជា សហភាពអឺរ៉ុប) និងកម្រិតសកល។ មេរៀនទី ១១ បង្ហាញពីរបៀបដែលនយោបាយបរិស្ថាន និងកំណើនប្រជាជន ពង្រីកការចរចាអន្តរជាតិ និងការពឹងអាស្រ័យគ្នាទៅវិញទៅមក ទាំងក្នុងតំបន់ និងសកលលោក។ មេរៀនទី ១២ និយាយអំពីទំនាក់ទំនងអឡរគោលខាងជើង-ខាងត្បូង ដោយមានការយកចិត្តទុកដាក់ជាពិសេសចំពោះភាពក្រីក្រនៅក្នុងអឡរគោលខាងត្បូង។ បន្ទាប់មកទៀត មេរៀនទី ១៣ ពិចារណាជម្រើសនិងបទពិសោធន៍សម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងបរិបទនៃធុរកិច្ចអន្តរជាតិ បំណុលជាតិ និងជំនួយបរទេស។ ចុងក្រោយ មេរៀនទី ១៤ ឆ្លុះបញ្ចាំងលើប្រធានបទសំខាន់របស់សៀវភៅគោលទាំងមូល និងបើកវេទិកាជជែកនិងត្រិះរិះពិចារណាអំពីអនាគត។

ជាងនេះទៅទៀត នៅចុងមេរៀននីមួយៗ ក៏មានបញ្ចូលនូវធាតុនៃគរុកោសល្យបួនសំខាន់ៗផងដែរ៖

ធាតុគរុកោសល្យ

នៅក្នុងមុខវិជ្ជា ដូចជាទំនាក់ទំនងអន្តរជាតិនេះ ដែលក្នុងនោះចំណេះដឹង ត្រូវការការបំពេញបន្ថែមរហូត និងការអភិវឌ្ឍន៍ជាក់ស្តែង អាចយកឈ្នះលើទ្រឹស្តី, ការគិតបែបរិះគន់ ឬការត្រិះរិះពិចារណាគឺជាជំនាញដ៏សំខាន់សម្រាប់និស្សិតមហាវិទ្យាល័យក្នុងការអភិវឌ្ឍន៍។ នៅចំណុចផ្សេងៗ ក្នុងសៀវភៅ ការសន្និដ្ឋានត្រូវបើកចំហទុក ដើម្បីអោយសិស្សនិស្សិតវែកញែកអំពីមាគ៌ារបស់ពួកគេ តាមរយៈបញ្ហាណាមួយ ហើយបន្ថែមលើសំណួរនៃការគិតពិចារណានៅចុងបញ្ចប់នៃមេរៀននីមួយៗ អត្ថបទឧទាហរណ៍ផ្សេងៗអាចជួយដល់ការគិតត្រិះរិះពិចារនាកាន់តែស៊ីជម្រៅ។

ការស្វែងរកដំណោះស្រាយបញ្ហាផលប្រយោជន៍រួម

ប្រអប់អត្ថបទបន្ថែមទាំងនេះ ផ្តោតលើគំនិតគោល សម្រាប់ការរៀបចំគ្រោងមេរៀនក្នុងសៀវភៅ៖ បញ្ហាផលប្រយោជន៍រួម។ ប្រអប់អត្ថបទនីមួយៗពិភាក្សាអំពី ផលប្រយោជន៍រួម និងបញ្ហាដែលរដ្ឋជួបប្រទះក្នុងការប៉ុនប៉ងសម្រេចអោយបាននូវកិច្ចសហប្រតិបត្តិការ ដើម្បីធានាការសម្រេចបាននូវផលប្រយោជន៍នោះ។ នៅក្នុងឧទាហរណ៍នីមួយៗ យើងគូសបញ្ជាក់ពីរបៀប ដែលគោលការណ៍ស្នូលមួយ ឬច្រើន (គោលការណ៍គ្រប់គ្រង បដិកា និងអត្តសញ្ញាណ) ត្រូវបានប្រើប្រាស់ ដោយជោគជ័យ (ឬបរាជ័យ) ក្នុងការផ្តល់ផលប្រយោជន៍ដែលគេចង់បាន។

មតិសាធារណៈ និងទំនាក់ទំនងអន្តរជាតិ

លក្ខណៈពិសេសថ្មីនេះ ពិភាក្សាអំពីស្ថានភាពនៃមតិសាធារណៈលើបញ្ហាសំខាន់ៗក្នុងទំនាក់ទំនងអន្តរជាតិ។ ដោយសារប្រធានបទក្នុងសៀវភៅមួយនេះ រៀបរាប់អំពីការកើនឡើងនៃលទ្ធិប្រជានិយម និងជាតិនិយម វាជាការសំខាន់ណាស់ ដែលត្រូវដឹងថា តើស្ថានភាពនៃមតិសាធារណៈមានអ្វីខ្លះចំពោះបញ្ហាសកលសំខាន់ៗ។ ការកើនឡើងនៃទិន្នន័យស្ទង់មតិសាធារណៈ ដែលអាចជឿទុកចិត្តបានពីជុំវិញពិភពលោក

ផ្តល់អោយយើងនូវឱកាសស្វែងយល់បន្ថែមអំពីរបៀប ដែលសាធារណជនសម្លឹងមើលប្រធានបទក្នុងវិស័យទំនាក់ទំនងអន្តរជាតិ។

ឧស្សន:ទិស័យផ្នែកគោលនយោបាយ

លក្ខណៈពិសេសនេះនៅក្នុងមេរៀននីមួយៗ ដាក់សិស្សនិស្សិតក្នុងស្ថានភាពឧទាហរណ៍ថា ពួកគេគឺជាអ្នកដឹកនាំរដ្ឋដែលត្រូវធ្វើការសម្រេចចិត្តសម្រាប់ជាតិមាតុភូមិ។ លក្ខណៈពិសេសនេះភ្ជាប់ទ្រឹស្តីទំនាក់ទំនងអន្តរជាតិទៅនឹងបញ្ហាគោលនយោបាយខណៈពេលដែលបង្ហាញពីការដោះដូរអ្វីមួយទៅនឹងអ្វីមួយទៀត ជាញឹកញាប់ មានវត្តមាន នៅក្នុងការសម្រេចចិត្តផ្នែកនយោបាយ និងការគូសបញ្ជាក់ពីទំនាក់ទំនងរវាងគោលនយោបាយបរទេស និងគោលនយោបាយក្នុងស្រុក។

តោះ! សាកល្បងពិភាក្សាអំពីបញ្ហាជាក់ស្តែង

ប្រអប់ទាំងនេះ ជួយសិស្សនិស្សិតគិតពិចារណាលើប្រធានបទដ៏ចម្រូងចម្រាស។ ប្រធានបទនៅក្នុងមេរៀននីមួយៗ ត្រូវបានជ្រើសរើស ដើម្បីពង្រីកគោលគំនិតសំខាន់ៗ ដែលបានពិភាក្សានៅក្នុងមេរៀននោះ។ ដូច្នេះ លក្ខណៈពិសេសនេះ ធ្វើអោយកាន់តែស៊ីជម្រៅក្នុងការស្វែងយល់ពីប្រធានបទជាក់លាក់ណាមួយ ខណៈពេលដែលវាអាចជួយពង្រឹងប្រធានបទទូទៅនៅក្នុងមេរៀននីមួយៗ។

អាជីពក្នុងទំនាក់ទំនងអន្តរជាតិ

ជាចុងក្រោយ **អាជីពក្នុងទំនាក់ទំនងអន្តរជាតិ** ជួយសិស្សឱ្យគិតអំពីលទ្ធភាពការងារក្នុងវិស័យនេះ។ លក្ខណៈពិសេស (នៅក្នុងមេរៀនសមស្រប) ត្រូវបានឧទ្ទិសដល់អាជីពនៅក្នុងអង្គការមិនមែនរដ្ឋាភិបាល ច្បាប់អន្តរជាតិ រដ្ឋាភិបាល និងការទូត អាជីវកម្មអន្តរជាតិ និងការបង្រៀន និងការស្រាវជ្រាវ។ វាឆ្លើយតបទៅនឹងសំណួរថា «តើមុខវិជ្ជានេះនឹងជួយខ្ញុំក្នុងការស្វែងរកការងារដោយរបៀបណា?» និងរួមបញ្ចូលសៀវភៅ និងគេហទំព័រវែបសាយ ដើម្បីបន្តបញ្ហានេះបន្ថែមទៀត។

មនុស្សជាច្រើនស្វែងរកព័ត៌មាន - ជាពិសេសគំនិតអរូបី - កាន់តែងាយស្រួលក្នុងការយល់នៅពេលភ្ជាប់ជាមួយរូបភាព។ ដូច្នេះ សៀវភៅនេះប្រើរូបថតពណ៌យ៉ាងទូលំទូលាយ ដើម្បីបង្ហាញពីចំណុចសំខាន់ៗ។ ចំណងជើងរូបថតពង្រឹងប្រធានបទសំខាន់ៗពីផ្នែកនីមួយៗនៃសៀវភៅ ហើយភ្ជាប់វាជាមួយនឹងឈុតដែលបានបង្ហាញ។ រូបថតជាច្រើននៅក្នុងការបោះពុម្ពនេះគឺថ្មីៗនេះ ថតនៅឆ្នាំ ២០១៧ និង ២០១៨។

និស្សិតផ្សេងគ្នាមានវិធីសាស្ត្រនិងទម្លាប់សិក្សាផ្សេងៗគ្នា។ និស្សិតដែលជាអ្នកសិក្សាដែលមើលឃើញគួរតែស្វែងរកមិនត្រឹមតែរូបថតប៉ុណ្ណោះទេ ប៉ុន្តែក៏មានក្រាហ្វិកពណ៌ជាច្រើនដែលមានប្រយោជន៍ជាពិសេស។ ការប្រើប្រាស់ទិន្នន័យបរិមាណក៏ជំរុញអោយមានការគិតប្រកបដោយការរិះគន់ផងដែរ។ ទិន្នន័យជាមូលដ្ឋានបង្ហាញយ៉ាងសាមញ្ញ និងសមរម្យនៅកម្រិតសកល អនុញ្ញាតអោយសិស្សបង្កើតការវិនិច្ឆ័យរបស់ពួកគេ និងវែកញែកតាមរយៈផលប៉ះពាល់នៃគោលនយោបាយ និងទ្រឹស្តីផ្សេងៗ។ សៀវភៅនេះប្រើប្រាស់ទិន្នន័យកម្រិតសកល (បង្ហាញរូបភាពទាំងមូល) បង្រួបបង្រួមលេខដើម្បីរំលេចនូវអ្វីដែលសំខាន់ និងបង្ហាញព័ត៌មានជាក្រាហ្វិក តួលេខ ឬផែនទី តាមកន្លែងដែលសមស្រប។

ទំនាក់ទំនងអន្តរជាតិគឺជាប្រធានបទដ៏ធំមួយ ដែលផ្តល់ទិសដៅជាច្រើនសម្រាប់ការរុករកចំណេះដឹងបន្ថែមទៀត។ ការអានដែលបានណែនាំរាយបញ្ជីប្រភពបន្ថែមសម្រាប់ការអានបន្ថែមលើប្រធានបទផ្សេងៗ។ លើកលែងតែមានការកត់សម្គាល់ផ្សេង ពួកវាមិនមែនជាកំណត់ត្រាប្រភពប្រពៃណីទេ។

ការបោះពុម្ពសៀវភៅទំនាក់ទំនងអន្តរជាតិនេះព្យាយាមរួមមានការកែសម្រួលសំខាន់ៗ នៅទូទាំងដើម្បីរក្សាសៀវភៅបច្ចុប្បន្ន នៅក្នុងពេលវេលានៃការផ្លាស់ប្តូរយ៉ាងទូលំទូលាយនិងភាពមិនច្បាស់លាស់នៅក្នុងប្រព័ន្ធអន្តរជាតិ។ ប្រធានបទដែលឥឡូវនេះត្រូវបានបង្កើតឡើងពេញមួយសៀវភៅគឺការប្រឆាំងកាន់តែខ្លាំងឡើងប្រឆាំងនឹងសកលភាវូបនីយកម្ម និងស្ថាប័នដែលបានគាំទ្រដល់ការរីកចម្រើនរបស់វា។ ប្រតិកម្មនេះបានធ្វើអោយការសម្រេចចិត្តរបស់ចក្រភពអង់គ្លេសចាកចេញពីសហភាពអឺរ៉ុប ការបោះឆ្នោតជ្រើសរើសប្រធានាធិបតីអាមេរិកដែលប្រជែងនឹងសណ្តាប់ធ្នាប់ពិភពលោក និងការកើនឡើងនៃប្រជាជាតិនិយម និងជាតិនិយមជុំវិញពិភពលោក។

លក្ខណៈពិសេសថ្មីដ៏សំខាន់មួយនៅក្នុងការបោះពុម្ពនេះ មតិសាធារណៈ និងទំនាក់ទំនងអន្តរជាតិ ពិភាក្សាអំពីស្ថានភាពនៃមតិសាធារណៈលើបញ្ហាសំខាន់ៗនៃទំនាក់ទំនងអន្តរជាតិ។ លក្ខណៈពិសេសនេះពិនិត្យមើលចំណុចតែមួយក្នុងពេលមួយនៅទូទាំងប្រទេសជាច្រើនដើម្បីប្រៀបធៀបអ្វីដែលសាធារណជនគិតអំពីបញ្ហាជាច្រើន ចាប់ពីការគំរាមកំហែងនៃការវាយប្រហារតាមអ៊ីនធឺណិត រហូតដល់ទំនាក់ទំនងអាជីវកម្មបរទេស។ ដោយសារប្រធានបទនៃការបោះពុម្ពផ្សាយនេះអំពីការកើនឡើងនៃប្រជានិយម និងជាតិនិយមវាជាការសំខាន់ណាស់ ដែលត្រូវដឹងពីស្ថានភាពនៃមតិសាធារណៈលើបញ្ហាសំខាន់ៗមួយចំនួន។ ការកើនឡើងនៃទិន្នន័យស្ទង់មតិសាធារណៈដែលអាចជឿទុកចិត្តបានពីជុំវិញពិភពលោក ផ្តល់អោយយើងនូវឱកាសដើម្បីស្វែងយល់បន្ថែមអំពីនិន្នាការនៃទស្សនៈសាធារណៈលើទំនាក់ទំនងអន្តរជាតិ។ លក្ខណៈពិសេសនីមួយៗវិភាគនិន្នាការនៅក្នុងទិន្នន័យ ដោយប្រើការយល់ដឹងពីសម្ភារៈដែលបានបង្ហាញនៅក្នុងជំពូកនោះ។

លើសពីនេះ យើងបានផ្លាស់ប្តូរមុខងារពេញនិយមក្នុងទំនាក់ទំនងអន្តរជាតិពីឧបសម្ព័ន្ធទៅជាមេរៀនដែលពាក់ព័ន្ធ។ ជាឧទាហរណ៍ លក្ខណៈពិសេសស្តីពីអាជីពក្នុងអាជីវកម្មឥឡូវនេះ មាននៅក្នុងមេរៀនទី ៩ នៅកណ្តាលនៃការពិភាក្សាអំពីអាជីវកម្មពហុជាតិ។ យើងបានបន្ថែមមុខងារថ្មីនៃអាជីព ដោយពិភាក្សាអំពីច្បាប់អន្តរជាតិទៅកាន់មេរៀនទី ៧។ លក្ខណៈពិសេសទាំងនេះត្រូវបានសង្ឃឹមថានឹងផ្តល់អោយនិស្សិតនូវការណែនាំ និងធនធានមួយចំនួនទាក់ទងនឹងការងារក្នុងវិស័យទំនាក់ទំនងអន្តរជាតិ។

នៅក្នុងមេរៀនទាំងអស់ តារាង និងតួលេខត្រូវបានធ្វើបច្ចុប្បន្នភាពជាមួយនឹងទិន្នន័យដែលមានថ្មីៗបំផុត។ នេះរួមបញ្ចូលទាំងទិន្នន័យថ្មីស្តីពីផលិតផលក្នុងស្រុកសរុប(ផ.សស.) កងកម្លាំងយោធា ការធ្វើចំណាកស្រុកនិងជនភៀសខ្លួន បំណុល ការផ្ទេរប្រាក់ ជំនួយបរទេស ការរីករាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍ និងប្រតិបត្តិការរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ដើម្បីដាក់ឈ្មោះមួយចំនួន។

ជាចុងក្រោយ ទំនាក់ទំនងអន្តរជាតិលើកទី១២នេះ កែប្រែកម្មវិធីរូបថតយ៉ាងសំខាន់។ រូបថតថ្មីរាប់សិបសន្លឹក ជាច្រើនពីឆ្នាំ ២០១៧ និង ២០១៨ ទាក់ទាញចំណាប់អារម្មណ៍ដែលមើលឃើញចំពោះព្រឹត្តិការណ៍បច្ចុប្បន្ន ខណៈពេលដែលពង្រឹងគោលគំនិតសំខាន់ៗនៅក្នុងសៀវភៅ។

បញ្ជីឯកសារយោង

Nath, C. (1967). *Khmer Dictionary.* Phnom Penh: Buddhist Institute.

Wilson, A. (2021, October 15). *Avoiding the Global Warming Impact of Insulation*. Retrieved from Building Green: https://www.buildinggreen.com/feature/avoiding-global-warming-impact-insulation

Pevehouse, J. C., & Goldstein, J. S. (2020). *International Relations.* London: Pearson Education.

Booth, K. (2005). *Critical Security Studies and World Politics.* Lynne Rienner Publishers.

Cohen, B. J. (2008). *International Political Economy: An Intellectual History.* New York: Princeton.

Doyle, M. W. (1997). *Ways of War and Peace: Realism, Liberalism, and Socialism.* . Norton.

Drezner, D. W. (2008). *All Politics Is Global.* Princeton.

Gilpin, R. (2001). *Global Political Economy: Understanding the International Economic Order* . Princeton.

Held, D., & McGrew., A. (2007). *Globalization/Anti-Globalization: Beyond the Great Divide.* . Polity.

Raymond, D., & Michael Barnett. (2005). *Power in Global Governance.* Cambridge.

Waltz, K. (1979). *Theory of International Politics.* Addison-Wesley.

Mearsheimer, J. J. (2003). *The Tragedy of Great Power Politics.* Norton.

Goldstein, J. S. (2001). *War and Gender: How Gender Shapes the War System and Vice Versa.* Cambridge.

Keohane, R. O., & Nye., J. S. (2001). *Power and Interdependence.* Pearson.

Beasley, R. K. (2002). *Foreign Policy in Comparative Perspective: Domestic and International Influences on State Behavior.* CQ Press.

Lamy, S. L., & Masker, J. S. (2021). *Introduction to Global Politics.* Oxford: Oxford University Press.

Waltz, K. N. (2001). *Man, the State, and War: A Theoretical Analysis.* Columbia.

Saunders, E. (2014). *Leaders at War: How Presidents Shape Military Interventions.* Cornell.

Feaver, P. D., & Gelpi, C. (2005). *Choosing Your Battles: American Civil-Military Relations and the Use of Force.* Princeton.

Pape, R. (2005). *Dying to Win: The Strategic Logic of Suicide Terrorism.* Random House.

Straus, S. (2015). *Making and Unmaking Nations: War, Leadership, and Genocide in Modern Africa.* Cornell.

Goodheart, M. (2016). *Human Rights: Politics and Practice.* Oxford.

North, D. C., & Thomas, R. P. (1973). *The Rise of the Western World: A New Economic History.* Cambridge.

Aliber, R. Z. (2011). *The New International Money Game.* Palgrave.

Cohen, B. J. (2015). *Currency Power: Understanding Monetary Rivalry.* Princeton.

Ragnedda, M., & Muschert, G. W. (2015). *The Digital Divide: The Internet and Social Inequality in International Perspective.* Routledge.

Dinan, D., Nugent, N., & Paterson., W. E. (2017). *The European Union in Crisis.* Palgrave.

Blewit, J. (2018). *Understanding Sustainable Development.* Routledge .

Kahl, C. H. (2006). *States, Scarcity, and Civil Strife in the Developing World.* Princeton.

Wallerstein, I. (2004). *World Systems Analysis: An Introduction.* Duke.

Martin, S. F. (2014). *International Migration: Evolving Trends from the Early Twentieth Century to the Present.* Cambridge,.

Chayes, S. (2015). *Thieves of State: Why Corruption Threatens Global Security.* Norton.

Overholt, W. H. (2017). *China's Crisis of Success.* Cambridge.

Booth, Ken, ed. Critical Security Studies and World Politics. Rienner, 2005.

Cohen, Benjamin J. International Political Economy: An Intellectual History. Princeton, 2008.

Doyle, Michael W. Ways of War and Peace: Realism, Liberalism, and Socialism. Norton, 1997.

Drezner, Daniel W. All Politics Is Global. Princeton, 2008. Gilpin, Robert. Global Political Economy: Understanding the International Economic Order. Princeton, 2001.
Held, David, and Anthony McGrew. Globalization/Anti- Globalization: Beyond the Great Divide. Polity, 2007.
Neack, Laura. Elusive Security: States First, People Last. Rowman & Littlefield, 2007.
Rodrik, Dani. The Globalization Paradox: Democracy and the Future of the World Economy. Norton, 2012.
Rudra, Nita. Globalization and the Race to the Bottom in Developing Countries: Who Really Gets Hurt? Cambridge, 2008.
Barnett, Michael, and Raymond Duvall, eds. *Power in Global Governance.* Cambridge, 2005.
Brooks, Stephen G., and William Wohlforth. *World Out of Balance: International Relations and the Challenge of American Primacy.* Princeton, 2008.
Johnston, Seth A. *How NATO Adapts: Strategy and Organization in the Atlantic Alliance Since 1950.* Johns Hopkins, 2016.
Kreps, Sarah. *Coalitions of Convenience: United States Military Interventions After the Cold War.* Oxford, 2011.
Kydd, Andrew. *International Relations Theory: The Game Theoretic Approach.* Cambridge, 2015.
Mearsheimer, John J. *The Tragedy of Great Power Politics.* Norton, 2003.
Narang, Vipin. *Nuclear Strategy in the Modern Era: Regional Powers and International Conflict.* Princeton, 2014.
Schelling, Thomas C. *The Strategy of Conflict.* Harvard, 1960.
Walt, Stephen M. *Taming American Power: The Global Response to U.S. Primacy.* Norton, 2005.
Waltz, Kenneth. *Theory of International Politics.* Addison- Wesley, 1979.
Bacevich, Andrew J. *The New American Militarism: How Americans Are Seduced by War.* Oxford, 2005.
Barnett, Michael, and Martha Finnemore. *Rules for the World.* Cornell, 2004.
Elshtain, Jean Bethke. *Women and War.* 2nd ed. Chicago, 1995.
Goldstein, Joshua S. *War and Gender: How Gender Shapes the War System and Vice Versa.* Cambridge, 2001.
Keck, Margaret, and Kathryn Sikkink. *Activists Beyond Borders: Advocacy Networks in International Politics.* Cornell, 1998.
Keohane, Robert O., and Joseph S. Nye. *Power and Interdependence.* 3rd ed. Pearson, 2001.
Mansfield, Edward D., and Jack Snyder. *Electing to Fight: Why Emerging Democracies Go to War.* MIT, 2005.
McDonald, Patrick. *The Invisible Hand of Peace.* Cambridge, 2009.
Runyon, Anne Sisson, and V. Spike Peterson. *Global Gender Issues in the New Millennium.* Routledge, 2013.
Tickner, J. Ann. *Gendering World Politics: Issues and Approaches in the Post–Cold War Era.* Columbia, 2001.
Allison, Graham T., and Philip Zelikow. *Essence of Decision: Explaining the Cuban Missile Crisis.* 2nd ed. Longman, 1999.
Beasley, Ryan K., et al., eds. *Foreign Policy in Comparative Perspective: Domestic and International Influences on State Behavior.* CQ Press, 2002.
Holsti, Ole R. *Public Opinion and American Foreign Policy.* Rev. ed. Michigan, 2004.
Milner, Helen V., and Dustin Tingley. *Sailing the Water's Edge: The Domestic Politics of American Foreign Policy*. Princeton, 2015.
Neustadt, Richard E., and Ernest R. May. *Thinking in Time: The Uses of History for Decision Makers.* Free Press, 1986.
Page, Benjamin I., and Marshall M. Bouton. *The Foreign Policy Disconnect.* Chicago, 2006.
Smith, Tony. *Foreign Attachments: The Power of Ethnic Groups in the Making of American Foreign Policy.* Harvard, 2000.
Horowitz, Donald L. *Ethnic Groups in Conflict.* 2nd ed. California, 2000.
Kalyvas, Stathis N. *The Logic of Violence in Civil War.* Cambridge, 2006.
Saunders, Elizabeth. *Leaders at War: How Presidents Shape Military Interventions*. Cornell, 2014.
Straus, Scott. *Making and Unmaking Nations: War, Leadership, and Genocide in Modern Africa.* Cornell, 2015.
Van Evera, Stephen. *Causes of War: Power and the Roots of Conflict.* Cornell, 1999.
Waltz, Kenneth N. *Man, the State, and War: A Theoretical Analysis.* Columbia, 2001.
Weeks, Jessica L. P. *Dictators at War and Peace.* Cornell, 2014.

Feaver, Peter D., and Christopher Gelpi. *Choosing Your Battles: American Civil-Military Relations and the Use of Force.* Princeton, 2005.
Gat, Azar. *The Causes of War and the Spread of Peace.* Oxford, 2017.
Hoffman, Bruce, and Fernando Reinares, eds. *The Evolution of the Global Terrorist Threat*. Columbia, 2016.
Hoffman, Peter J., and Thomas G. Weiss. *Sword and Salve: Confronting New Wars and Humanitarian Crises.* Rowman & Littlefield, 2006.
Narang, Vipin. *Nuclear Strategy in the Modern Era: Regional Powers and International Conflict.* Princeton, 2014.
Pape, Robert. *Dying to Win: The Strategic Logic of Suicide Terrorism.* Random House, 2005.
Feaver, Peter D., and Christopher Gelpi. *Choosing Your Battles: American Civil-Military Relations and the Use of Force.* Princeton, 2005.
Gat, Azar. *The Causes of War and the Spread of Peace.* Oxford, 2017.
Hoffman, Bruce, and Fernando Reinares, eds. *The Evolution of the Global Terrorist Threat*. Columbia, 2016.
Hoffman, Peter J., and Thomas G. Weiss. *Sword and Salve: Confronting New Wars and Humanitarian Crises.* Rowman & Littlefield, 2006.
Narang, Vipin. *Nuclear Strategy in the Modern Era: Regional Powers and International Conflict.* Princeton, 2014.
Pape, Robert. *Dying to Win: The Strategic Logic of Suicide Terrorism.* Random House, 2005.
Autessere, Severine. *Peaceland: Conflict Resolution and the Everyday Politics of International Intervention.* Cambridge, 2014.
Barnett, Michael N., and Martha Finnemore. *Rules for the World: International Organizations and Global Politics.* Cornell, 2004.
Evans, Gareth. *The Responsibility to Protect: Ending Mass Atrocity Crimes Once and for All.* Brookings, 2008.
Fortna, Virginia Page. *Does Peacekeeping Work? Shaping Belligerents' Choices After Civil War.* Princeton, 2008.
Goodheart, Michael. *Human Rights: Politics and Practice.* 3rd ed. Oxford, 2016.
Keck, Margaret, and Kathryn Sikkink. *Activists Beyond Borders: Advocacy Networks in International Politics.* Cornell, 1998.
Risse, Thomas, Stephen C. Ropp, and Kathryn Sikkink, eds. *The Persistent Power of Human Rights: From Commitment to Compliance.* Cambridge, 2013.
Straus, Scott. *Making and Unmaking Nations: War, Leadership, and Genocide in Modern Africa.* Cornell, 2015.
Walzer, Michael. *Arguing About War.* Yale, 2004.
Weiss, Thomas G. *What's Wrong with the United Nations and How to Fix It.* 3rd ed. Polity, 2016.
Bernstein, William J. *A Splendid Exchange: How Trade Shaped the World.* Grove, 2009.
Blackwill, Robert D., and Jennifer M. Harris. *War by Other Means: Geoeconomics and Statecraft.* Belknap, 2017.
Hufbauer, Gary Clyde, Jeffrey Schott, Kimberly Ann Elliot, and Barbara Oegg. *Economic Sanctions Reconsidered.* Peterson Institute, 2008.
Irwin, Douglas. *Against the Tide: An Intellectual History of Free Trade.* Princeton, 1996.
North, Douglass C., and Robert Paul Thomas. *The Rise of the Western World: A New Economic History.* Cambridge, 1973.
Rivoli, Pietra. *The Travels of a T-Shirt in the Global Economy: An Economist Examines the Markets, Power, and Politics of World Trade.* Wiley, 2014.
Mueller, Sherry Lee, and Mark Overmann. *Working World: Careers in International Education, Exchange, and Develop- ment*. 2nd ed. Georgetown, 2014.
Penrith, Deborah, ed. *The Directory of Jobs and Careers Abroad*. 13th ed. Vacation, 2007.
https://www.myperfectresume.com/how-to/career-resources/ internat/
https://jobs.goabroad.com
http://www.transitionsabroad.com/listings/work/careers/index.shtml
Dinan, Desmond, Neill Nugent, and William E. Paterson. *The European Union in Crisis.* Palgrave, 2017.
Hanson, Elizabeth C. *The Information Revolution in World Politics.* Rowman & Littlefield, 2008.
Moravcsik, Andrew. *The Choice for Europe: Social Purpose and State Power from Messina to Maastricht*. Cornell, 1998.

Pollack, Mark A. *The Engines of Integration: Delegation, Agency, and Agenda Setting in the European Union.* Oxford, 2003.
Ragnedda, Massimo, and Glenn W. Muschert, eds. *The Digital Divide: The Internet and Social Inequality in International Perspective.* Routledge, 2015.
Collier, Paul. *The Bottom Billion: Why the Poorest Countries Are Failing and What Can Be Done About It.* Oxford, 2007. Food and Agriculture Organization. *The State of Food Security and Nutrition in the World: 2017.*
FAO, 2018. http://www. fao.org/state-of-food-security-nutrition/en/. Hulme, David. *Global Poverty: How Global Governance Is Failing the Poor.* Routledge, 2010.
Kevane, Michael. *Women and Development in Africa: How Gender Works.* 2nd ed. Lynne Rienner Publishers, 2014.
Martin, Susan F. *International Migration: Evolving Trends from the Early Twentieth Century to the Present.* Cambridge, 2014.
UN Development Program. *Human Development Report 2016.* UNDP, 2016. http://hdr.undp.org/ en/2016-report.
UNCHR. *The Global Report: 2016.* UNHCR, 2017. http:// www.unhcr.org/en-us/the-global-report.html.
U.S. Department of State. *Trafficking in Persons Report 2017.* U.S. Department of State, 2017.
Wallerstein, Immanuel. *World Systems Analysis: An Introduction.* Duke, 2004.
World Health Organization. *Health 2015: From MDGs to SDGs.* WHO, 2016.